# នៅពេលដែលសង្គ្រាមឈប់ទៅ

## អេលីហ្សាបែត បេិកខ័រ



*ហួត បុប្ផាណា*

ឯកសារបកប្រែទី៥ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា

◆ **អេលីហ្សាបែត បេ៊កខ័រ : នៅពេលដែលសង្គ្រាមរលត់ទៅ** កម្ពុជានិងបដិវត្តន៍ខ្មែរក្រហម

◆ បកប្រែជាភាសាខ្មែរដោយ ទេព ម៉េងឃាន និង សុខា អ៊ីរ៉ែន ◆ ពិនិត្យ និងកែសម្រួលដោយ ឆាំង យុ ◆ ក្រាហ្វិក និង កុំព្យូទ័រការីដោយ គីម សុវណ្ណដានី ◆ រចនាក្រប និង តួសៀវភៅដោយ ឆាំង យុ និង គីម សុវណ្ណដានី ◆ បោះពុម្ពផ្សាយលើកទី១ នៅឆ្នាំ២០០៥ ដោយមជ្ឈមណ្ឌលឯកសារកម្ពុជាសហការជាមួយស្ថានទូតអាមេរិកាំងប្រចាំនៅកម្ពុជា ◆ រក្សាសិទ្ធិ ◆

Translation Series No.5 ◆ Documentation Center of Cambodia

◆ Elizabeth Becker: When the War Was Over, Cambodia and the Khmer Rouge Revolution
◆ Translated by Tep Meng Khean and Sokha Irene ◆ Edited by Youk Chhang ◆ Graphic by Kim Sovanndany ◆ Cover and Book design by Youk Chhang and Kim Sovanndany ◆ Published by Documentation Center of Cambodia and the American Embassy in Phnom Penh ◆ Printed in Cambodia, 2005 ◆ Copyright ◆

មជ្ឈមណ្ឌលឯកសារកម្ពុជា
*Searching for the truth.*
Documentation Center of Cambodia
P.O. Box 1110, Phnom Penh, Cambodia
Tel.: + 855 (23) 211-875
Fax.: + 855 (23) 210-358
Email: dccam@online.com.kh
Homepage: www.dccam.org

DISCLAMER
The views expressed in this paper are solely those of the author.
ទស្សនៈបញ្ចេញនៅក្នុងសៀវភៅនេះ គឺរបស់អ្នកនិពន្ធតែម្នាក់គត់ ។

ISBN-10: 99950-60-00-0
លសខអ-១០: ៩៩៩៥០-៦០-០០-០
ISBN-13: 978-99950-60-00-8
លសខអ-១៣: ៩៧៨-៩៩៩៥០-៦០-០០-៨

Printed in Cambodia

# WHEN THE WAR WAS OVER

◆

## Cambodia and the Khmer Rouge Revolution

◆

*Elizabeth Becker*

PublicAffairs
*New York*

*Copyright © 1986, 1998 by Elizabeth Becker.*
*Published by PublicAffairs™,*
*A Member of the Perseus Books Group.*
*All rights reserved.*
*Printed in the United States of America.*
*No part of this book may be reproduced in any manner whatsoever without written permission except in the case of brief quotations embodied in critical articles and reviews. For information, address PublicAffairs, 250 West 57th Street, Suite 1825, New York, NY 10107.*
*Book design by Jenny Dossin.*
*Excerpts from* On Violence, *copyright © 1969, 1970 by Hannah Arendt, are reprinted by permission of Harcourt Brace Jovanovich, Inc.*
*All of the photographs that appear in the insert were taken by the author with the exception of* The first meeting of Prince Norodom Sihanouk . . . *: F. de la Mure and* U.S. General John Vessey . . . *: Xuan Lam.*

*Library of Congress Cataloging-in-Publication Data*
*Becker, Elizabeth.*
*When the war was over : Cambodia and the Khmer Rouge revolution / Elizabeth Becker.*
*p. cm.*
*Originally published: New York : Simon and Schuster, c1986.*
*Includes bibliographical references (p. 545) and index.*
*ISBN 1-891620-00-2 (pbk.)*
*1. Cambodia—History—20th century. I. Title.*
*DS554.8.B43 1998*
*959.604—dc21 98-37790*
*CIP*

*3 5 7 9 10 8 6 4 2*

# មាតិកា


អារម្ភកថា

ជំពូកទី១ អ្នកដែលដើរតាមពីចម្ងាយ ........ ១
ជំពូកទី២ ភាពចាប់ផ្ដើមនៃប្រទេសកម្ពុជាសម័យទំនើប ........ ៣៣
ជំពូកទី៣ មាគ៌ាឆ្ពោះទៅរកអំពើក្បត់ ........ ៨៧
ជំពូកទី៤ សត្វក្រពើ ស ........ ១៥៣
ជំពូកទី៥ ការបដិវត្តន៍ចុងក្រោយបង្អស់ ........ ២១៧
ជំពូកទី៦ រដ្ឋកាលនៃអំពើហិង្សា ........ ២៧៥
ជំពូកទី៧ "បក្សជាទីគោរព និងជាទីស្នេហា!..." ........ ៣៤៧
ជំពូកទី៨ ខ្លា និងក្រពើ ........ ៣៨៥
ជំពូកទី៩ ទម្លាប់ផ្សេងៗនៃសង្គ្រាម ........ ៤៣៣
ជំពូកទី១០ ទីបញ្ចប់នៃភាពនៅស្ងៀមស្ងាត់ ........ ៤៨៣
ជំពូកទី១១ ការវិលត្រឡប់ទៅទីក្រុងភ្នំពេញម្ដងទៀត ........ ៥៣១
ជំពូកទី១២ សង្គ្រាមក្នុងនាមនៃប្រទេសកម្ពុជា ........ ៥៧១
ជំពូកទី១៣ សន្តិភាពអសារបង់ (ចំណាយកម្លាំងធំធេង ប៉ុន្តែទទួលបានផលតិច) ........ ៥៧៩

អវសានកថា ........ ៦៥៣
កំណត់ចំណាំខ្លីៗ ........ ៦៦១
ឧបសម្ព័ន្ធស្ដីពីឯកសារផ្សេងៗនៅសារមន្ទីរទួលស្លែង (អតីតមន្ទីរស-២១) ........ ៦៩០
កាលប្បវត្តិសង្ខេប ........ ៧០៤
សេចក្ដីថ្លែងអំណរគុណ ........ ៧១១
អំពីអ្នកនិពន្ធ ........ ៧១២

# អារម្ភកថា

នៅពេលល្ងាចមួយក្នុងកំឡុងរដូវភ្លៀង ខ្ញុំនៅឈររង់ចាំឲ្យមេឃស្រឡះល្អក្នុងចន្លោះពេលភ្លៀងកំពុងធ្លាក់យ៉ាងខ្លាំង ។ ពេញមួយសប្តាហ៍មកហើយ ភ្លៀងធ្លាក់ជាញឹកញាប់ដោយធ្វើឲ្យជនបទរបស់កម្ពុជាជោកជាំទៅដោយទឹកសស្វាច ហើយបង្ខំឲ្យកូនទាហាន និងមេបញ្ជាការទាំងឡាយលុបចោលផែនការវាយប្រយុទ្ធរបស់ពួកគេ ។ ក្នុងកំឡុងជាច្រើនថ្ងៃនៃការគ្មានធ្វើសកម្មភាពអ្វីសោះ និងភាពអស់កម្លាំងដោយសារមានរឿងតិចតួចត្រូវរាយការណ៍ ឬសរសេរ ខ្ញុំបានរៀបចំនូវអ្វីដែលលើកកម្លាំងចិត្តខ្ញុំ ជាងគេ គឺខ្ញុំបានធ្វើដំណើរទៅលេងមិត្តភក្តិនានា ហើយខ្ញុំនិយាយបូរបាច់អំពីសង្រ្គាមថែមទៀត ។

នៅពេលដែលភ្លៀងឈប់ធ្លាក់ ខ្ញុំចេញពីសណ្ឋាគារចំណាស់ និងរឹងមាំរបស់ខ្ញុំ ហើយស្រែកហៅអ្នកស៊ីក្លូម្នាក់ ដែលកំពុងផាក់តែម្នាក់ឯងនៅខាងមុខចម្រឹងទ្វារចូល ។ អ្នកផាក់ស៊ីក្លូ និងខ្ញុំដែលសុទ្ធតែគ្របដណ្តប់ដោយកៅស៊ូប្លាស្ទិច និងពាក់ស្បែកជើងផ្ទាត់កៅស៊ូ បាននិយាយត្រូវរ៉ូវគ្នាយ៉ាងស្រួល ពីតម្លៃនៃចម្ងាយផ្លូវដែលត្រូវធ្វើដំណើរទៅផ្ទះមិត្តរបស់ខ្ញុំ ។ ជាមនុស្សនិយាយប្រោកប្រាជ្ញច្រើន គាត់បានសួរខ្ញុំជាសាសន៍អ្វី ក្នុងភាសាបារាំងមួយល្អជាងជនជាតិបារាំងទៅទៀត ។ នៅពេលដែលខ្ញុំឆ្លើយប្រាប់គាត់ថាខ្ញុំជាអ្នកកាសែតអាមេរិកាំងម្នាក់ គាត់បានប្រែនិយាយជាភាសាអង់គ្លេសរដាក់រដុបមួយ ដើម្បីចាប់ផ្តើមក្នុងអ្វីដែលខ្ញុំចាត់ទុកថា ជាការសន្ទនាតាមធម្មតាមួយនៅភ្នំពេញក្នុងសម័យសង្រ្គាម ។ គាត់បាននិយាយប្រាប់ខ្ញុំពីអតីតកាលរបស់គាត់ ហើយរៀបរាប់ប្រាប់ថា គាត់ធ្លាប់សិក្សារៀនសូត្រក្នុងវិទ្យាល័យមួយនៅខេត្តរហូតដល់ពេលដែលសង្រ្គាមហៀរចូលមកដល់ដោយបង្ខំឲ្យគាត់ស្វែងរកទីពំនាក់អាស្រ័យនៅក្នុងរដ្ឋធានីវិញ ។ គាត់គ្មានសមានចិត្តចំពោះក្រុមច្បាំងគ្នាណាមួយឡើយ ហើយមុនអ្វីៗទាំងអស់ គាត់រវល់គិតគូរការពារគ្រួសារ និងធ្វើឲ្យមានម្ហូបអាហារលើតុតែប៉ុណ្ណោះ រហូតដល់សង្រ្គាមត្រូវបញ្ចប់ ដែលអាចឲ្យពួកអ្នកភៀសខ្លួនវិលត្រឡប់ទៅខេត្តរបស់គាត់វិញ ។ គាត់សង្ឃឹមថា គេហដ្ឋាន និងវិទ្យាល័យរបស់គាត់នៅតែឈរជង្រ្គឹងដដែល ដោយមិនខូចខាតអ្វីឡើយ ។

គាត់មានបុកពារហ័សរហួនបែបខ្មែរមួយ ដែលមិនធ្វើឲ្យបារម្ភ ទាំងមិនលើកទឹកចិត្តឲ្យមានមិត្តភាពមួយនៅថ្ងៃខាងមុខដែរ ។ នៅពេលដែលគាត់ផាក់ស៊ីក្លូតាមចន្លោះថ្លុកទឹកជាច្រើន យើងសើចសប្បាយដោយការនិយាយកំប្លែងលេងរបៀបឆ្គួតៗ ឬនិយាយដោយយកចិត្តទុកដាក់ ពីការវាយប្រហារដោយគ្រាប់រ៉ុក្កែត ដែលច្បាស់ជា មកដល់ក្នុងពេលឆាប់ៗ ។ ខ្ញុំបានផ្តល់ប្រាក់កម្រៃក្រៅឲ្យគាត់យ៉ាងច្រើន នេះជាអំពើសប្បុរសធម៌ដ៏កម្រមួយ ក្នុងចំណោមអំពើសប្បុរសធម៌ខាងលុយកាក់ ដែលថវិការបស់ខ្ញុំអនុញ្ញាតឲ្យខ្ញុំធ្វើបាន ហើយយើងបានជម្រាបលាគ្នា ។

នេះគឺរដូវភ្លៀងនៅឆ្នាំ១៩៧៣ ជាឆ្នាំដែលស្លាកស្នាមផ្សេងៗរបស់ប្រទេសបានប្រេះបែកដែលអាច

មើលឃើញយ៉ាងច្បាស់ ហើយដែលមិត្តកម្ពុជាម្នាក់បានដណ្ដឹងសួរខ្លួនឯងជាឯកជនស្ដីពីអ្វីដែលនឹងនៅសេសសល់បន្ទាប់ពីសង្គ្រាម ។ ដោយមានសុទិដ្ឋិនិយមតិចជាងអ្វីដែលគាត់ធ្លាប់មានពីមុនមក អ្នកធាក់ស៊ីក្លូបានផ្ញើទុកនៅផ្ទះមិត្តរបស់ខ្ញុំ -ជាការទូតអាស៊ីម្នាក់- នូវលិខិតមួយដែលផ្ញើទៅឲ្យ «លោកស្រី រាត្រីថ្ងៃពុធ» *(La dame de mercredi soir)* ។ តាមការសរសេរមួយដែលគាត់រៀនចេះនៅក្នុងសាលាបារាំងនានា គាត់ចង់បានថាតើ «លោកស្រីរាត្រីថ្ងៃពុធ» អាចមានចិត្តសប្បុរសជួយរកគេហដ្ឋានប្រសើរជាងមុនមួយ ឲ្យគ្រួសារគាត់នៅបានដែរឬទេ ។ គាត់តែងនៅឈររង់ចាំខ្ញុំ ខាងមុខចម្រឹងទ្វារសណ្ឋាគារជានិច្ច ។

ក្នុងចន្លោះពេលនោះ អ្នកធ្លាក់ស៊ីក្លូទាំងឡាយបានមកប្រមូលផ្ដុំគ្នាតាមទម្លាប់របស់គាត់ នៅខាងមុខសណ្ឋាគារ ហើយអ្នកសុំខ្ញុំធ្វើការ មិនសូវមានរាសនារកបានមុខរបរណាមួយឡើយ ។ គាត់មិនដែលឃើញត្រឡប់ទៅផ្ទះមិត្តខ្ញុំជាអ្នកការទូតវិញសោះ ហើយខ្ញុំក៏លែងជួបគាត់ជារៀងរហូត ។

ប៉ុន្តែ ខ្ញុំយល់ពីមនោសញ្ចេតនារបស់អ្នកនោះដែលបញ្ចេញឲ្យខ្ញុំដឹងជាច្រើនលើកច្រើនសា ៖ នៅខាងមុខហាងកាហ្វេមួយ នៅលើដីបូលរាបស្មើនៃផ្ទះមួយ ក្នុងអណ្ដូងរ៉ែត្បូងកណ្ដៀងនាដងភ្នំភាគខាងលិចប្រទេស ជាមួយប្រជាកសិករដែលកំពុងលក់ផលិតផលរបស់គាត់នៅទីផ្សារ ឬជាមួយពួកទាហានដែលកំពុងយាមការពារឲ្យតែរួចពីដៃ នៅជុំវិញវត្តមួយ បណ្ដាមិត្តកម្ពុជា និងបរទេស ដែលបន្ទរអារម្មណ៍ដោយនិយាយពីផែនការផ្ទាល់ខ្លួនរបស់គាត់សម្រាប់ជីវិតថ្មីមួយ នៅពេលដែលសង្គ្រាមត្រូវចប់នៅពេលខាងមុខ ។ នេះជារឿងដដែលៗ ដែលប្រជាជនទន្ទេញមិនឈប់ ហើយពិតណាស់ មនុស្សឯទៀតៗដែលរស់នៅក្នុងសង្គ្រាមផ្សេងទៀត បានបំបាត់ការភ័យខ្លាចរបស់គាត់ ដោយការសន្ទនាដូចគ្នាស្ដីពីអនាគតមួយដែលគ្មានគ្រាប់បែក គ្មានគ្រាប់កាំភ្លើង និងគ្មានជំរំជនភៀសខ្លួន ។

ប៉ុន្តែមានមនុស្សតិចតួចប៉ុណ្ណោះ ដែលស្គាល់ការស្រងាកចិត្តដ៏ល្វីងជូរចត់ដូចគ្នានឹងប្រជាជនកម្ពុជាដែរនៅពេលដែលសង្គ្រាមរលត់ទៅ ។ តាំងពីថ្ងៃជ័យជម្នះ ពួកកុម្មុយនិស្តដែលពាក់ឈ្មោះខ្មែរក្រហម បានដាក់បង្ខំឲ្យប្រជាជនអនុវត្តតាមនូវបដិវត្តន៍បែបភេរវកម្ម និងវិនាសកម្មមួយ ដែលមិនធ្លាប់ដែលមានពីមុនមកសោះ ។ មាគ៌ាបដិវត្តន៍ធំៗ ត្រូវបានគេស្គាល់ដឹងជាទូទៅ ៖ រដ្ឋធានី និងទីក្រុងឯទៀតៗត្រូវបណ្ដេញប្រជាជនដែលធ្លាប់រស់នៅចេញទាំងអស់ ហើយបញ្ជូនទៅឲ្យធ្វើស្រែ ក្រុមវរជននៃរបបសង្គមចាស់ត្រូវអង្គការស្រាវជ្រាវស្វែងរកចាប់ខ្លួនដាច់អហង្ការ ហើយជាញឹកញយត្រូវសម្លាប់ចោលតែម្ដង ម្ហូបអាហារមានដោយកម្រ, កន្លែងស្នាក់នៅរខេករខាក, ការធ្វើការ ងារដោយគ្មានឈប់សម្រាកមួយដែលដាក់បង្ខំឲ្យប្រជាជនធ្វើប្រៀបដូចជាការដាក់ទណ្ឌកម្មអ៊ីចឹង ។ ប្រជាជនមួយ ដែលដឹកនាំដោយភេរវជន, ប្រទេសមួយដែលផ្ដន្ទាទោសដោយការធ្វើទារុណកម្ម និងការសម្លាប់ បានក្លាយទៅជាទម្លាប់ប្រចាំថ្ងៃមួយ ។

ក្នុងសៀវភៅនេះ ខ្ញុំសាកល្បងសរសេរបង្ហាញប្រវត្តិរបស់ការបដិវត្តនេះ បកស្រាយបំភ្លឺអ្នកណាខ្លះជា

ខ្មែរក្រហម ហេតុអ្វីបានជាពួកគេបេះតម្រូវខ្លួនទាំងស្រុងតាមប្រវត្តិសាស្ត្រនៃប្រទេសផ្ទាល់របស់គេ និងចលនាកុម្មុយនិស្ត ហេតុអ្វីនិងយ៉ាងដូចម្តេចបានជាពួកគេដាក់បង្ខំឲ្យមានរបបមួយដែលបង្ខិនបង្ហោចដូច្នេះនៅប្រទេសកម្ពុជា ហេតុអ្វីបានជាបដិវត្តន៍នេះជំរុញប្រទេសទៅរកការធ្វើសង្គ្រាមជាមួយវៀតណាម និងបណ្តាលឲ្យមានការកាន់កាប់របស់វៀតណាមលើប្រទេសកម្ពុជាទៅវិញ ។ សៀវភៅនេះ គឺជាការសាកល្បងមួយ ដើម្បីរៀបរាប់រឿងរ៉ាវទាំងអស់របស់ពួកខ្មែរក្រហម ហើយខ្ញុំនឹកឃើចាប់ក្រៃលែងចំពោះនាទីស៊ើបរកការពិតខ្លះៗ ដែលមិនអាចរកឃើញ ។

ក៏ប៉ុន្តែខ្ញុំបានទទួលគុណប្រយោជន៍ពីការងាររគ្រួសគ្រាយរបស់អ្នកនិពន្ធឯទៀតៗ ដែលជួយបង្កើតនូវមូលដ្ឋានផ្សេងៗសម្រាប់ការស្រាវជ្រាវមួយបែបនេះ ជាពិសេស *Chanthou Boua, Timothy Carney, Stephen Heder, Ben Kiernan* និង *François Ponchaud* ។ វាពុំមានប្រវត្តិសាស្ត្រទូទៅរបស់ប្រទេសកម្ពុជាសម័យទំនើបទេ ហើយរឹតតែមិនសូវមានទៅទៀតគឺប្រវត្តិសាស្ត្រពួកខ្មែរក្រហម ហើយមួយផ្នែកដ៏សំខាន់នៃសៀវភៅនេះ គឺពឹងផ្អែកជាសំអាងលើការស្រាវជ្រាវតាមសំណៅដើម ។ ខ្ញុំត្រូវប្រើរយៈពេលប្រាំពីរឆ្នាំក្នុងការតែងសរសេរ និងការស្វែងរកការពិត មុនពេលដែលខ្ញុំអាចឆ្លើយតបចំពោះសំណួរសំខាន់ៗ ដែលទាក់ទងនឹងពួកខ្មែរក្រហម និងប្រទេសកម្ពុជា ។

ការផ្តើមធ្វើកិច្ចការចាំបាច់នេះមិនអាចប្រព្រឹត្តទៅបានទេ បើសិនជាវៀតណាមពុំបានលុកលុយ និងកាន់កាប់ប្រទេសកម្ពុជានៅឆ្នាំ១៩៧៩នោះ ។ ក្នុងគោលបំណងលាតត្រដាងអំពើសាហាវយង់ឃ្នង របស់របបខ្មែរក្រហម វៀតណាមបានអនុញ្ញាតឲ្យចូលទៅរកមើលឯកសារប្រាកដជាក់លាក់មួយចំនួន ដែលបន្សល់ទុកដោយពួកខ្មែរក្រហម ។ ឯកសារទាំងនោះត្រូវបានរក្សាទុកក្នុងមន្ទីរឃុំឃាំងទួលស្លែង ឬស-២១ ជាទីសេនាធិការសន្តិបាលរបស់ពួកខ្មែរក្រហម ជាមន្ទីរសម្រាប់ធ្វើទារុណកម្ម និងសម្លាប់អ្នកដែលត្រូវចោទប្រកាន់ថា ក្បត់នឹងរបបបដិវត្តន៍ ដែលសុទ្ធតែមានសារសំខាន់លើសលុបមួយ មិនអាចវាយតម្លៃបាន ។

ការលុកលុយបានបណ្តាលឲ្យប្រជាជនកម្ពុជាយ៉ាងច្រើន រត់ចេញពីប្រទេសរបស់គេ ដែលអាចឲ្យអ្នកកាសែតឯទៀតៗ និងរូបខ្ញុំផ្ទាល់បានជួបធ្វើសម្ភាសន៍ជាមួយអ្នកទាំងនោះយ៉ាងពិស្តារ ។ ខ្ញុំបានជួបនិយាយនឹងអ្នកភៀសខ្លួនមួយចំនួនធំក្នុងឱកាសនៃការដើរមើលតាមជំរំនានានៅប្រទេសថៃនិងម៉ាឡេស៊ី ព្រមទាំងក្នុងឱកាសនៃការសម្ភាសន៍ផ្សេងៗនៅអាមេរិកខាងជើង ។ ខ្ញុំធ្លាប់បានទៅជួបពួកមេដឹកនាំ វៀតណាម កម្ពុជា និងមេដឹកនាំសញ្ជាតិផ្សេងៗទៀតក្នុងអំឡុងនៃការធ្វើដំណើរជាច្រើន -ពីរដងនៅប្រទេសវៀតណាម មួយដងនៅប្រទេសឡាវ ពីរដងនៅប្រទេសកម្ពុជា- បូកបន្ថែមការស្រាវជ្រាវរបស់ខ្ញុំនៅសហរដ្ឋអាមេរិកផង ។

សៀវភៅនេះ បានបង្ហាញឡើងរបៀបជារឿងនិទានមួយ ក្រោមទម្រង់ជាការឆ្លើយជាសាក្សីរបស់មនុស្សទាំងឡាយដែលខ្ញុំបានជួបសម្ភាសន៍ ឬរឿងរ៉ាវដែលខ្ញុំរកឃើញនៅក្នុងសំណុំឯកសារនានា ក្នុងគុកខ្មែរក្រហមជាច្រើនកន្លែង ។ អ្នកដែលបានឃើញបានដឹងបានឮរឿងរ៉ាវទាំងនេះ គឺជាមនុស្សស្ថិតក្នុងគ្រប់ស្រទាប់

សង្គម និងបណ្ដាមជ្ឈដ្ឋានមតិសាធារណៈទាំងអស់ ៖ ធនាគារិកកម្ពុជាសម័យទំនើបម្នាក់ ជាតំណាងជនកម្ពុជា រាប់ពាន់នាក់ ដែលមិនដឹងអ្វី ទាល់តែសោះអំពីពួកខ្មែរក្រហម និងបានទទួលស្វាគមន៍ជ័យជម្នះរបស់ពួកនេះ ទាំងងងឹតងងល់ក្នុងក្ដីសង្ឃឹមថា ជ័យជម្នះនេះ នឹងទាញផ្ដាច់ប្រទេសជាតិឲ្យចាកផុតពីភាពក្រីក្រគោកយ៉ាករបស់ខ្លួន, យុវកសិករកំព្រាម្នាក់ ដែលទៅចូលរួម បម្រើបដិវត្តន៍ក្នុងវ័យជំទង់របស់ខ្លួន បានឡើងឋានៈតួនាទីក្នុងជួរ ហើយត្រូវបានសម្លាប់ព្រោះតែបទឧក្រិដ្ឋផ្សេងៗដែលខ្លួនមិនដែលប្រព្រឹត្តសោះ ស្ត្រីនៅតាមខេត្តពីរនាក់ ដែលម្នាក់ក្លាយជាជនគំរូរបស់បដិវត្តន៍ម្នាក់ទៀត ក្លាយជាជនរងគ្រោះគំរូទៅវិញ ក្នុងទីបំផុត គឺពួកមេដឹកនាំផ្ទាល់ រួមទាំង ប៉ុល ពត និង អៀង សារី ជាដើម ។ ទាំងអស់នេះ គឺជាសំឡេងរបស់ពួកពេជ្ឈឃាដ និងជនរងគ្រោះជាច្រើន ។

គឺក្នុងឋានៈជាសាក្សីដែលបណ្ដាលឲ្យខ្ញុំសម្រេចចិត្តសរសេរសៀវភៅនេះ ។ អាស្រ័យដោយកាលៈទេសៈពិសេស និងផលប្រយោជន៍រយៈពេលវែងមួយសម្រាប់ប្រទេសនេះ ខ្ញុំគឺជាស្ត្រីបស្ចិមប្រទេសម្នាក់គត់ ដែលមើលឃើញប្រទេសកម្ពុជាឆ្លងកាត់គ្រប់ដំណាក់កាលទាំងអស់នៃភាពក្រីក្រគោកយ៉ាក ។ ក្នុងរយៈពេលជិតពីរឆ្នាំ ខ្ញុំធ្លាប់បាន "សរសេរអត្ថបទការពារ" សង្គ្រាមសម្រាប់កាសែតវ៉ាស៊ីនតោនប៉ុស្តិ៍ ។ ក្រោយមក ខ្ញុំបានទៅជាអ្នកកាសែតលោកខាងលិចម្នាក់ក្នុងចំណោមពីរនាក់ដែលត្រូវបានអនុញ្ញាតឲ្យធ្វើដំណើរទៅប្រទេសកម្ពុជា ទោះបីជាពួកខ្មែរក្រហមនៅកំពុងកាន់អំណាចក្ដី ។ នៅទីបញ្ចប់ ថ្ងៃនេះខ្ញុំបានវិលត្រឡប់មកប្រទេសកម្ពុជាវិញ ដែលស្ថិតនៅក្រោមការកាន់កាប់របស់វៀតណាម ដើម្បីបន្តប់ការស្រាវជ្រាវរបស់ខ្ញុំ ។

ប្រវត្តិសាស្ត្ររបស់ពួកខ្មែរក្រហមបានលេចឡើងឲ្យឃើញលក្ខណៈធម្មតាផង និងត្រឡប់ត្រឡិនផង ដូចគ្នានឹងប្រវត្តិនៃការឈានឡើងរបស់លទ្ធិណាហ្ស៊ីនិយម (ជាទ្រឹស្ដីរបស់គណបក្សកម្មករជាតិសង្គមនិយមអាល្លឺម៉ង់ដែលមានហ៊ីត្លែរជាមេដឹកនាំ) នៅប្រទេសអាល្លឺម៉ង់ ឬជោគជ័យរបស់ស្តាលីនក្នុងការធ្វើបដិវត្តន៍រុស្ស៊ីដែរ ។ រឿងប្រវត្តិនេះបានចាក់ឫសយ៉ាងជ្រៅក្នុងប្រវត្តិសាស្ត្ររបស់កម្ពុជា និងពុំមែនក្នុងចក្ខុវិស័យរបស់ប្រជាជននៅប្រទេសកម្ពុជាប្រៀបដូចជា "ឋានសួគ៌មួយដែលវិនាស" នោះទេ ។ មុនសង្គ្រាមឆ្នាំ១៩៧០ ប្រទេសកម្ពុជា ធ្លាប់មានកិត្តិស័ព្ទល្បីល្បាញជាសង្គមមួយដែលសម្បូរទៅដោយសំណង់វប្បធម៌គួរឲ្យចង់រស់នៅ ហើយប្រហែលជាមិនចាប់ភ្ញីកនឹងវិបល្លាសដែលកំពុងរំដើបរំជួលនៅក្នុងបណ្ដាប្រទេសក្បែរខាងខ្លួនផងទេ - សង្គ្រាម និងការធ្វើបដិវត្តន៍នៅទិសខាងកើត គឺប្រទេសវៀតណាម ការរីកលូតលាស់ដែលកំពុងប្រែមុខមាត់ប្រទេសថៃ ទៅជាប្រទេសយោធានិយមនៅទិសខាងលិច ។ ដោយភាពផ្ទុយគ្នា លក្ខណៈមួយផ្នែកយ៉ាងធំ ដែលការពារប្រទេសកម្ពុជា ភាពអនុគ្រោះដល់ប្រជាជនខ្លួនបានបញ្ចេញឲ្យឃើញការទាក់ចិត្តមួយបែបនេះ ដែលគេពិពណ៌នាដោយទូទៅថា ជាកោះសន្តិភាពមួយ ថែមទាំងជាឋានសួគ៌មួយទៀតផង ។

គំនិតចង់ឲ្យប្រទេសជាតិមានវិបុលភាពនេះ ត្រូវបានបន្ទុចបង្អាក់ដោយសង្គ្រាម និងការបដិវត្ត ដែលស្ទើរតែប្រល័យជីវិតប្រជាជនអស់ ។ ប៉ុន្តែពួកអ្នកទ្រឹស្ដីបានរកប្រទេសក្រៅដែលអាចឲ្យគ្រោះថ្នាក់មួយ ដើម្បីពន្យល់

ពីអ្វីដែលមិនអាចពន្យល់បាន - ដោយរបៀបណាបានជាឋានសួគ៌មួយធ្លាក់ទៅក្នុងក្ដីវិនាសតែមួយពព្រិចភ្នែកដូច្នេះ? កំហុសគួរបន្ទោសចំនួនបីដែលគេខស្សៅហ៍លើកយកមកនិយាយជាសំអាងជារឿយៗ គឺមនោគមន៍វិជ្ជា កុម្មុយនិស្ដម៉ៅនិយម នយោបាយសង្គ្រាមរបស់សហរដ្ឋអាមេរិក ជាពិសេស យុទ្ធនាការទម្លាក់គ្រាប់បែករបស់អាមេរិកាំងនៅឆ្នាំ១៩៧៣ ហើយនិងគោលបំណងរបស់ប្រទេសវៀតណាមមកលើប្រទេសកម្ពុជា ដែលមានច្រើនសតវត្សរ៍មកហើយ ។

ទោះជាសហរដ្ឋអាមេរិកនិងប្រទេសវៀតណាម មានចំណែកក្នុងការទទួលខុសត្រូវពិតប្រាកដជាមួយគ្នា ចំពោះទុក្ខវេទនាមួយភាគធំរបស់ប្រទេសកម្ពុជាក៏ដោយ ក៏ការវិភាគថ្មីៗនេះបានរកឃើញថា ប្រជាជនកម្ពុជាត្រូវទទួលរងគ្រោះពីពួកមេដឹកនាំ ពីទម្លាប់ជាប្រពៃណី និងប្រវត្តិសាស្ដ្ររបស់ខ្លួន ។ និមិត្តរូបគួរឲ្យស្រឡាញ់នៃឋានសួគ៌មួយ បានបិទបាំងប្រទេសដោយមនោសញ្ចេតនាក្រអឺតក្រអោងដ៏ជ្រាលជ្រៅមួយ ដែលត្រូវគេប្រមាថការភ័យខ្លាចមួយពីការរលត់រលាយជាតិសាសន៍ ជំនឿយ៉ាងច្បាស់ក្រឡែតមួយចំពោះភាពខ្ពង់ខ្ពស់ជាងគេផ្នែកវប្បធម៌ ថែមទាំងពូជសាសន៍ផង ។ នេះជាប្រទេសមួយដែលធ្លាប់ត្រូវពួកមេដឹកនាំ កាន់អំណាចផ្ដាច់ការ ពួកអ្នកចូលចិត្តខាងបន្តវង្សហេតុ គ្រប់គ្រងតាំងពីយូរមកហើយ ដោយចាត់ទុកអាណា ប្រជារាស្ដ្រ ឬប្រជាពលរដ្ឋរបស់ខ្លួនជាកូនជាចៅ ហើយយល់ឃើញប្រទេសកម្ពុជាជាប្រទេសរងគ្រោះមួយ ក្នុងចំណោមប្រទេសរងគ្រោះធំៗនៃប្រវត្តិសាស្ដ្រ ។ នៅទីបំផុត នេះជាប្រទេសមួយដែលអំពើហិង្សាបានក្លាយជាប្រពៃណីទៅហើយ ។

ចលនាកុម្មុយនិស្ដរបស់កម្ពុជា គឺជាការសម្ដែងចេញនូវកម្លាំងជំរុញចិត្តឲ្យធ្វើអំពើអ្វីដែលជិតាស់ ដែលអស់សង្ឃឹមទាំងនេះដូចការបដិវត្តរបស់រុស្ស៊ីដែលជាស្រមោលនៃដំណែលជាតិមួយដែរ ។ គឺដូច្នេះហើយ ដែលខ្ញុំបង្ហាញជូនក្នុងសៀវភៅនេះ នូវចលនាខ្មែរក្រហមដែលកើតអំពីប្រវត្តិសាស្ដ្រប្រទេសកម្ពុជា និងអនាគត ដែលប្រែប្រួលរបស់ខ្លួន ក្នុងកំឡុងនៃការរំដើបរំជួលយ៉ាងខ្លាំងនៅអាស៊ី នាសតវត្សរ៍ទី២០ ។ នេះជារឿងនិទានគួរឲ្យចុកចាប់មួយ ពីព្រោះការឈានឡើងរបស់ពួកខ្មែរក្រហមពុំមែនជារឿង ដែលជៀសមិនរួចនោះទេ ។ ខ្មែរក្រហមបានឡើងកាន់កាប់អំណាចតាមរយៈការប្រើល្បិចកលផ្សេងៗ ដែលគិតតែប្រយោជន៍ខ្លួនឯងជាហូរហែមួយ និងកំហុសរបស់បណ្ដាមេដឹកនាំកម្ពុជា និងប្រជាជាតិបរទេសនានា សម្រាប់មួយចំណែកធំ គឺប្រទេសវៀតណាម និងសហរដ្ឋអាមេរិក ។

រឿងនិទាននេះក៏ជាការដាស់តឿនមួយដែរ ។ លក្ខណៈមួយក្នុងចំណោមលក្ខណៈគួរឲ្យព្រឺខ្លាចបំផុត របស់ចលនាខ្មែរក្រហម គឺចេតនាដែលដណ្ដប់ជាថ្មីលើការប្រព្រឹត្តខុសគន្លងរបស់ខ្លួន ។ មួយចំណែកធំនៃវិនាសកម្ម ដែលបង្កឡើងដោយការបដិវត្ត គឺធ្វើឡើងក្នុងនាមអនាគតកាល យ៉ាងហោចអំពីទម្រង់ដឹកនាំ ដែលពួកខ្មែរក្រហមមើលឃើញអនាគតល្អក្នុងបណ្ដាប្រទេសផ្សេងៗ ដែលអួតខ្លួនថាជាប្រទេសទំនើបដែរ ។ ក្នុងនាមនៃប្រសិទ្ធភាព (ភាពដែលធ្វើឲ្យសម្រេច) និងផលិតភាព (ភាពអាចឲ្យផល) ខ្មែរក្រហមបានលុបបំបាត់ជីវភាពរស់នៅជាគ្រួសារ

នៅពេលដែលសង្គ្រាមរលត់ទៅ

ជីវភាពឯកជន ចន្លោះនៃសកម្មភាពនៅស្រុកស្រែចម្ការ ហើយបង្កើតជាប្រព័ន្ធជំរំការងារមួយ ក្នុងទូទាំងប្រទេស ។ អ្វីដែលគួរឲ្យខ្លាចខ្លាំងបំផុត ក្នុងចំណោមរឿងភូតកុហករបស់ពួកអ្នកអនាគតនិយម បានសម្រេចជារូបរាងឡើង នៅក្នុងប្រទេសចុងកាត់មាត់ញកមួយនៃតតិយលោក គឺពុំមែនក្នុងប្រទេសដែលមានឧស្សាហកម្មលូតលាស់នោះទេ ។

ការប្រកាន់ស្តិតលទ្ធិ ឬគណបក្សណាមួយហួសពេក បានរលាយបាត់ទៅ មុនពេលពួកខ្មែរក្រហមមិនទាន់ឡើងកាន់អំណាចម្ល៉េះ ដូចជាលទ្ធិហ្វាស៊ីសធ្លាប់អនុវត្តដែរ ដែលបណ្តាលឲ្យមានការសម្លាប់មនុស្សយ៉ាងរង្គាលក្រោមរបបខ្មែរក្រហម ។ គឺពុំមែនជាចៃដន្យទេ ដែលពួកខ្មែរក្រហមជ្រើសរើសគំរូកុម្មុយនិស្តជ្រុលហួសហេតុជាងគេ ហើយដែលខ្លួនខំប្រឹងញាំញីប្រទេសកម្ពុជា ឲ្យទៅជាប្រទេសមានបដិវត្តតែក្នុងមួយយប់ ដើម្បីបង្ហាញពីភាពខ្ពង់ខ្ពស់ប្រសើរលើសគេរបស់ខ្លួន ។ ខ្មែរក្រហមជាអ្នកទទួលមរតកនូវអ្វីៗដែលអាក្រក់បំផុតក្នុងអតីតកាលរបស់ប្រទេសកម្ពុជា ។

ក៏ប៉ុន្តែសៀវភៅនេះមានផ្ទុកនូវកំណត់សម្គាល់ជាទីសង្ឃឹមមួយ ។ ក្នុងចំណោមសាក្សីជាច្រើន ដែលផ្តល់កំណើតដល់រឿងនិទាននេះមានមនុស្សជាច្រើនបានបង្ហាញឲ្យឃើញភាពក្លាហាន និងភាពថ្លៃថ្នូរពិតប្រាកដមួយ ។ ហេតុដូច្នេះ ទោះបីជាពួកមេដឹកនាំរបស់ខ្លួន ទោះបីជាការក្លែងខុសពីសភាពពិត ដែលប្រទេសនានាតុបតែងឲ្យក៏ដោយ ក៏ប្រជាជនកម្ពុជានៅតែជាប្រជាជនមិនអាចបំភ្លេចបានមួយ លម្អទៅដោយវប្បធម៌ ដែលមានភាពជានិមិត្តរូបមួយ ក្រោមទម្រង់ដ៏ល្អឆើតឆាយ និងសោភ័ណភាពគួរឲ្យស្ញប់ស្ញែងបំផុត គឺប្រាសាទអង្គរវត្តដ៏ល្បីល្បាញ ។ សេចក្តីក្លាហានរបស់គាត់បាននាំឲ្យមានរឿងប្រវត្តិគួរឲ្យព្រឺរន្ធត់នេះ ពីអ្វីដែលធ្វើឲ្យស្ញើបរំភើបទៅអ្វីដែលប្រកបដោយទុក្ខភ័យវិញ ។

នៅពេលនេះ ខ្ញុំសូមសម្តែងនូវការដឹងគុណរបស់ខ្ញុំចំពោះពួកអ្នកឯកទេស និងមិត្តភក្តិទាំងឡាយ ដែលបានជួយជ្រោមជ្រែង និងលើកទឹកចិត្តខ្ញុំ នៅពេលដែលខ្ញុំចាប់ផ្តើមសរសេរសៀវភៅនេះ ។ មិត្តភក្តិរបស់ខ្ញុំពុំទទួលខុសត្រូវសេចក្តីសន្និដ្ឋានរបស់ខ្ញុំ ដែលនេះគឺជារបស់ខ្ញុំតែម្នាក់ប៉ុណ្ណោះ ។

អេលីហ្សាបែត បេ៊កខ័រ

ក្រុងវ៉ាស៊ីនតោន ឌី.ស៊ី.

# ជំពូកទី១
## «អ្នកដែលដើរតាមពីចម្ងាយ...»

*ភូមិទាំងឡាយត្រូវដុតឲ្យឆេះខ្ទេចខ្ទី ទីក្រុងនានាទទេស្អាតគ្មានមនុស្សម្នាក់ រស្មីព្រះអាទិត្យពេលព្រឹក បានឃ្លាតចេញពីទេសភាពតាមដងទន្លេ ការភ័យស្លន់ស្លោ បានរួបរឹតអ្នកដែលដើរតាមពីចម្ងាយ ហើយខ្ញុំនឹកភ័យបារម្ភ នៅពេលអានវគ្គអត្ថបទត្រង់នេះនឹងដឹងថា អ្នកទាំងឡាយដែលខ្ញុំធ្លាប់ស្រឡាញ់ត្រូវបានកម្ចាត់អស់ហើយ ដោយពួកអ្នកដែលខ្ញុំធ្លាប់កោតសរសើរ ប៉ុន្តែដែលខ្ញុំមិនធ្លាប់ដែលស្គាល់សោះ ពួកទាហានដែលចូលចិត្តលេងសប្បាយ បានវាយប្រយុទ្ធរហូតដល់បរាជ័យរបស់គេ ហើយខ្ញុំនឹកភ័យបារម្ភថា ភាគច្រើននៃមិត្តភក្តិរបស់ខ្ញុំត្រូវស្លាប់ទាំងអស់[១] ។*

*ចេម ហ្សេនតុន*

*ក្នុងសៀវភៅកំណត់ហេតុ ឆ្នាំ១៩៧៦*

*នេះគឺជារឿងមួយដែលត្រូវខាំមាត់សង្កត់ចិត្តដើម្បីរស់ ហើយមួយទៀតស៊ូទ្រាំសម្រាប់តែស្លាប់ម្យ៉ាងប៉ុណ្ណោះ ។ ខ្ញុំបានសម្រេចចិត្តរង់ចាំពីរឆ្នាំៈ បើសិនពុំមានផ្លាស់ប្តូរពីពេលនេះទៅទេខ្ញុំនឹងធ្វើអត្តឃាដ[២] ។*

*មុី កុម្ពត*

*ខែកក្កដា ឆ្នាំ១៩៧៥ នៅប្រទេសកម្ពុជា*

សង្គ្រាមឥណ្ឌូចិនលើកទី២[៣] (១៩៦០ - ១៩៧៥) គឺជាសង្គ្រាមរបស់ប្រទេសវៀតណាម ។ នៅក្រោមឈ្មោះនេះហើយ ដែលគេស្គាល់ឥណ្ឌូចិន គឺប្រទេសវៀតណាមនេះឯង ដែលគូទំនាស់ទាំងសងខាង ធ្វើការប្រយុទ្ធគ្នាយ៉ាងខ្លាំងក្លា ។ ប្រទេសឡាវហើយក្រោយមកប្រទេសកម្ពុជាត្រូវបានប្រទាញឲ្យធ្លាក់ទៅក្នុងជម្លោះយ៉ាងឆាយ ដោយប្រទេសមួយឬប្រទេសផ្សេងទៀត ។ ពួកកុម្មុយនិស្តវៀតណាម មិនដែលសម្តែងខ្លួនជាប្រទេសយក្សនៅក្បែរបណ្តាប្រទេសជាសម្ព័ន្ធមិត្ររបស់គេសោះឡើយ ហើយថារវាងសម្ព័ន្ធមិត្រនានា ដែលស្មើភាពគ្នាពួកវៀតណាមមានលក្ខណៈស្មើភាពជាងសម្ព័ន្ធមិត្រឯទៀតៗ ។

ក្រោយឆ្នាំ១៩៧៥ ការយកចិត្តទុកដាក់បានផ្តោតយ៉ាងឆាប់រហ័ស និងប្រកបដោយគ្រោះថ្នាក់ពីប្រទេសវៀតណាមកប្រទេសកម្ពុជាវិញ ។ សង្គ្រាមនៅប្រទេសវៀតណាមបានដកថយខ្លួនចេញពីការបាក់ទ័ពរបស់កម្ពុជា ។ ប្រទេសកម្ពុជាបានក្លាយទៅជាប្រទេសនៃភាពក្រីក្រគោកយ៉ាក សេចក្តីស្លាប់ វិនាសកម្ម សេចក្តីអស់សង្ឃឹម ហើយនិងអាថ៌កំបាំង ។ វាហាក់ដូចជាចម្លែកនិងមិនអាចពន្យល់បាន ដែលពួកកុម្មុយនិស្តកម្ពុជាដឹកនាំ

ដោយ ប៉ុល ពត អាចផ្ដើមធ្វើការពិសោធន៍ដ៏បង្ហូរឈាមមួយក្នុងការរៀបចំ សង្គមឡើងវិញ ដែលគោងតែនាំជនរួមជាតិឯង ចំនួនពីរលាននាក់ទៅរកសេចក្ដីស្លាប់យ៉ាងទាន់ហន់[៤] បន្ទាប់ពីសង្គ្រាមមួយដែលបង្ខិនបង្ខោចប្រទេសជាតិស្ទើររលាយសាបសូន្យ ។ ហើយអ្នករងគ្រោះនៃការបដិវត្តន៍នេះ រឹតតែយល់ដឹងតិចជាងអ្នកណាៗទាំងអស់ ។

ម៉ី កុម្ហួត[៥] មានអាយុសាមសិបប្រាំពីរឆ្នាំ នៅពេលដែលសង្គ្រាមរលត់ទៅក្នុងប្រទេសរបស់គាត់ ។ ការវាយប្រយុទ្ធបានចាប់ផ្ដើមនៅឆ្នាំ១៩៧០ ហើយបញ្ចប់ទៅនៅនិទាឃរដូវឆ្នាំ១៩៧៥ ដែលមានរយៈពេលតែប្រាំឆ្នាំប៉ុណ្ណោះ ។ លើកនេះ ពុំមានទាំងស្ថានការណ៍ស្មុគស្មាញដោះស្រាយមិនរួច ទាំងសង្គ្រាមពន្រ្ទេចពន្រ្ទីលធ្វើឡើងដោយពួកបារាំង បន្ទាប់មកដោយពួកអាមេរិកាំងដែលជំរុញការវាយប្រយុទ្ធដ៏យូរនិង វិនាសហិនហោចរបស់គេ ព្រោះតែមិនទទួលស្គាល់ឯករាជ្យមួយរបស់ពួកកុម្មុយនិស្តវៀតណាម ដែលពួកនេះជឿថា ដណ្ដើមបាននៅឆ្នាំ១៩៥៤ទេ ។ ការរអិលធ្លាក់របស់ប្រទេសកម្ពុជាទៅក្នុងគ្រោះអាក្រក់ កម្រោលឃោឃៅនិងលឿនរហ័សដូច្នេះ បានធ្វើឲ្យប្រជាជនកម្ពុជាទាំងអស់ភ្ញាក់ផ្អើលស្រឡាំងកាំង ជាពិសេស មនុស្សប្រុសៗដូចកុម្ហួតជាដើម ។

គឺក្នុងមុខតំណែងប្រកបដោយឯកសិទ្ធិជាទីបំផុតមួយ ដែលគាត់មានមុខនៅពេលកើតមានព្រឹត្តការណ៍ដួលរលំនៃប្រទេសរបស់គាត់ ដោយហេតុថាគាត់ជាមន្ត្រីជាន់ខ្ពស់នៃធនាគារឯកជនមួយ ក្នុងចំណោមធនាគារឯកជនធំៗ សំខាន់ៗនៅក្រុងភ្នំពេញ ។ ជាមនុស្សល្អិតល្អន់ ប្រាជ្ញាវាងវៃ និងនៅលីវហើយបានឈានចូលក្នុងបណ្ដាមជ្ឈដ្ឋាន អ្នកមានទ្រព្យសម្បត្តិ និងអ្នកមានឋានៈខ្ពង់ខ្ពស់របស់រដ្ឋធានី កុម្ហួត បានដើរតួជាតំណាងឲ្យអ្វីៗទាំងអស់ដែលរបបសាធារណរដ្ឋខ្មែរ និងពួកអ្នកឧបត្ថម្ភអាមេរិកាំងរបស់ខ្លួនអះអាងថា ការពារ ។ ប៉ុន្ដែ កុម្ហួត ដែលជាមនុស្សធុញទ្រាន់នឹងសង្គ្រាម និងដែលត្រូវធ្វើឲ្យអស់សង្ឃឹមដោយក្រុមមេដឹកនាំក្រុងភ្នំពេញនោះ គ្មានចង់បានអ្វីទាំងអស់ ក្រៅពីទីបញ្ចប់នៃសង្គ្រាម និងជ័យជម្នះរបស់ខ្មែរក្រហម ដែលគាត់ដឹងថា មិនអាចជៀសរួចឡើយ ។

កុម្ហួត ដឹងតិចតួចណាស់អំពីរឿងរ៉ាវពួកខ្មែរក្រហម ។ ពួកកុម្មុយនិស្តកម្ពុជាពុំធ្លាប់ដែលធ្វើឲ្យគេស្គាល់ខ្លួនតាមរយៈឃោសនាការឃោសនាបែបប៉ិនប្រសប់ធំៗ ដូចសមភាគីវៀតណាមរបស់ពួកគេឡើយ ។ ដោយថ្លឹងពិចារណាជាស្រេច ពួកគេបានទុកប្រវត្តិសាស្ត្រ និងគោលដៅចុងក្រោយរបស់គេក្នុងភាពគ្មានឲ្យអ្នកណាដឹងដោយរៀបចំធ្វើសង្គ្រាមទាំងស្រុងវិញ ។

ប៉ុន្ដែ កុម្ហួត បានត្រូវបង្ខំចិត្តឲ្យផ្ដោតការវិនិច្ឆ័យមួយទៅលើពួកកុម្មុយនិស្តទាំងនេះ ហើយសម្រេចថាគាត់ចង់ឲ្យពួកខ្មែរក្រហមមានជ័យជម្នះ ។ នៅទីបំផុតគាត់បានអះអាងដោយការឆ្លើយបាទមួយ បែបស្ទាក់ស្ទើរ ៖ ពួកខ្មែរក្រហមពុំអាចជាមនុស្សអាក្រក់ហួសហេតុ ដូចពួកមេដឹកនាំក្រុងភ្នំពេញទេ ។ គឺហេតុនេះហើយដែល កុម្ហួត ក្លាយទៅជាអ្នកដើរតាមពីចម្ងាយម្នាក់ក្នុងចំណោម "អ្នកដែលដើរតាមពីចម្ងាយ" ជាច្រើន ។

គាត់បានឈានដល់ការសម្រេចនេះ ពីព្រោះគាត់ទុកចិត្តលើមេៗខ្មែរក្រហមខ្លះ ដែលគេទទួលស្គាល់ ហើយ

បើតាមគាត់គិត ពីព្រោះជនជាតិកម្ពុជាភាគច្រើនបានអបអរសរសើរចំពោះគុណសម្បត្តិនោះដូចគ្នា ។ មេដឹកនាំទាំងឡាយដែលចេញមកពីជួរពួកខ្មែរក្រហមក្នុងរយៈពេលនៃសង្គ្រាម សុទ្ធតែជាបុរស និងស្ត្រី ដែល កុម្ពុត និងយុវជនជំនាន់គាត់កោតសរសើរតាំងពីយូរមកហើយ ។ នៅដើមទសវត្សរ៍១៩៦០ អ្នកទាំងនោះបានធ្វើឲ្យគេស្គាល់ខ្លួននៅក្រុងភ្នំពេញក្នុងឋានៈ ជាបញ្ញវន្ត អ្នកនិពន្ធ អ្នកកាសែត អ្នកនយោបាយ ប្រកបដោយទេពកោសល្យដែលកំពុងប្រយុទ្ធទល់នឹងអំពើពុករលួយ ។ ជំងឺនេះ ហើយដែលទប់យោបាយរបស់កម្ពុជាឲ្យមានកម្រិតមួយដូចនៅសម័យយុគកណ្តាលដែរ ។

កុម្ពុត ខ្លួនឯងស្គាល់តែឥស្សរជនខ្មែរក្រហមម្នាក់គត់ គឺ ខៀវ ប៉ុណ្ណារី ។ ប៉ុណ្ណារី ជាគ្រូបង្រៀនគួរឲ្យគោរពម្នាក់ក្នុងមជ្ឈដ្ឋានឥស្សរជនធំៗ ។ នាងជាស្ត្រីដំបូងគេម្នាក់ក្នុងចំណោមស្ត្រីដំបូងៗ របស់ប្រទេសដែលបង្ហាញឲ្យឃើញគំនិតទាមទារឯករាជ្យ ។ នាងធ្លាប់ធ្វើជាសាស្ត្រាចារ្យរបស់ កុម្ពុត នៅក្នុងអំឡុងនៃការសិក្សាឆ្នាំដំបូងរបស់គាត់ នៅវិទ្យាល័យ ហើយគាត់បានរំពុកពីបញ្ញាឆ្លាតវៃ និងការយល់ដឹងពីលទ្ធិជាតិនិយមខ្មែរដ៏មុតស្រួចរបស់អ្នកគ្រូគាត់ ។ ក៏ប៉ុន្តែ នាងមិនដែលបង្ហាញឲ្យឃើញការស្រឡាញ់ចូលចិត្តលទ្ធិកុម្មុយនិស្តផ្ទាល់ខ្លួនរបស់នាងនៅក្នុងថ្នាក់ ទាំងការជំពាក់ចិត្តនឹងលទ្ធិកុម្មុយនិស្តរបស់ប្តីនាង ដែលក្លាយទៅជាអ្នកល្បីឈ្មោះយ៉ាងអាក្រក់ម្នាក់ក្រោមរហស្សនាម (នាមសម្ងាត់) ថា ប៉ុល ពត សោះឡើយ ។

ខៀវ ប៉ុណ្ណារី និងមេដឹកនាំខ្មែរក្រហមដទៃៗទៀត សុទ្ធតែត្រូវសន្មតថាជាអ្នកកាន់លទ្ធិកុម្មុយនិស្ត ប៉ុន្តែ នៅក្រុងភ្នំពេញ ភាគច្រើនបំផុតនៃវណ្ណៈបញ្ញវន្តបានសន្និដ្ឋានថា ពួកខ្មែរក្រហមសុទ្ធតែមានគំនិតជាតិនិយមជាងកុម្មុយនិស្តនិយម ដូច្នេះមិនសូវផ្តល់គ្រោះថ្នាក់ប៉ុន្មានទេ ។ ប៉ុន្តែ រយៈពេលជាងដប់ឆ្នាំបានកន្លងទៅ តាំងពីពេលដែល កុម្ពុត និងប្រជាពលរដ្ឋនៅក្រុងភ្នំពេញបានឃើញពួកមេដឹកនាំខ្មែរក្រហមជាលើកចុងក្រោយបំផុត ។ ពួកគេចាប់ផ្តើមបាត់ខ្លួនពីរាជធានីនៅក្នុងឱកាសនៃការតាមស្វែងរកនិងកម្ចាត់ចោល ដែលបញ្ចេញឲ្យដឹងនៅឆ្នាំ១៩៦៣ ដោយសម្តេច ព្រះនរោត្តម សីហនុ ។ នៅឆ្នាំ១៩៦៧ ឥស្សរជនឆ្នើមៗរបស់ចលនាកុម្មុយនិស្ត បានរត់ចោលទីក្រុងឆ្ពោះទៅព្រៃភ្នំ និងធ្វើការតស៊ូប្រឆាំងវិញ ។ ឥស្សរជនឆ្នើមៗទាំងនេះ បានបន្សល់ទុកពីក្រោយខ្លួននូវនិមិត្តរូប បែបប្រលោមលោកមួយ ដែលធ្វើឲ្យយុវជនជំនាន់ កុម្ពុត នៅក្រុងភ្នំពេញនឹកមមៃជាប់ ហើយផ្តល់នូវសេចក្តីសង្ឃឹមចំពោះអ្នកដែលនឹងមកកាន់អំណាចនៅពេលដែលសង្គ្រាមនឹងត្រូវបញ្ចប់ ។

កុម្ពុត បានបង្កើតគំនិតរវើរវាយរឹងមាំមួយតែខ្លួនឯងអំពីពួកខ្មែរក្រហម និងគម្រោងការរបស់ពួកគេក្រោយពេលដែលសង្គ្រាមរលត់ទៅ ។ គាត់មិនរវល់យកចិត្តទុកដាក់នឹងការឃោសនា ដែលបង្ហាញឲ្យឃើញថាពួកខ្មែរក្រហមជាមនុស្សកំណាចឡើយ ហើយយល់ឃើញដូចអ្នកដទៃជាច្រើនទៀតក្នុងមជ្ឈដ្ឋានរបស់គាត់ថា អ្នកជាតិនិយមកម្ពុជាទាំងនេះ បានបង្ហាញឲ្យឃើញព្រឹត្តិការណ៍ខ្លះៗ ដែលមានលំនាំដូចគ្នានឹងទម្រង់របស់យូហ្គោស្លាវីដែលកាន់លទ្ធិកុម្មុយនិស្តដែរ ។ កុម្ពុត ពិចារណាថា បើសិនជាពួកខ្មែរក្រហមទទួលជ័យជម្នះ ហើយបង្កើតរដ្ឋាភិ

បាលកុម្មុយនិស្ត ពួកគេនឹងលើកតម្លៃទេពកោសល្យ និងគាំទ្របណ្តាសមាជិកក្រុមអ្នកមានវិជ្ជាជីវៈសេរីដូចជា ខ្ញុំ មិនខាន ។

ពួកខ្មែរក្រហមបានជួយឲ្យសមបំណងដល់ការយល់ច្រឡំបែបនោះ ដោយកាន់កាប់អំណាចពីក្រោយរដ្ឋាភិបាល រួបរួមជាតិមួយដែលតាំងនៅទីក្រុងប៉េកាំងតាំងពីឆ្នាំ១៩៧០មក និងដែលដឹកនាំដោយសម្តេចព្រះនរោត្តម សីហនុ ជាក្សត្រមិនមែនកុម្មុយនិស្តមួយអង្គ ។

អ្វីដែលទំនងជាភាពទន់ខ្សោយមួយសម្រាប់ពួកកុម្មុយនិស្ត គឺការគ្មានលទ្ធភាពប្រកាសជាចំហថា ពួកគេជាអ្នកណា ពីព្រោះសម្តេច ព្រះនរោត្តម សីហនុ បានធ្វើជាប្រមុខដឹកនាំចលនារបស់គេទៅហើយ នេះបង្ហាញឲ្យឃើញយុទ្ធសាស្ត្រ មួយដែលធ្វើបានសម្រេចផលយ៉ាងប៉ិនប្រសប់ ។ ពួកខ្មែរក្រហមបានបញ្ចេញឲ្យឃើញការដោះស្រាយជ្រុលហួសហេតុមួយ ដើម្បីជំនួសរបៀបគ្រប់គ្រងពីមុន ប៉ុន្តែ របៀបជាទម្រង់ថ្មីមួយនៃសកម្មភាពនយោបាយដែលគេស្គាល់ច្បាស់ ។ ដូច្នេះ ប្រជាជនកម្ពុជា បានដើរតាមការណែនាំដំបូងៗរបស់ពួកខ្មែរក្រហមនៅចុងបញ្ចប់នៃសង្គ្រាមគោរពធ្វើតាមបទបញ្ជាតឹងរ៉ឹងរបស់ពួកគេនៅចុងឆ្នាំ១៩៧៥ និងសុខចិត្តចូលរួមក្នុងការរស់នៅកម្រិតគោកយ៉ាកបំផុត ដែលគ្មានអ្នកណាម្នាក់នឹកស្មានដល់ ។

ប៉ុន្តែ វាធ្លាប់មានភ័ស្តុតាងបង្ហាញឲ្យដឹងជាច្រើនរួចមកហើយ ប៉ុន្តែគាត់ធ្វេសប្រហែសនឹងរឿងទាំងនេះ ។ កុម្ហុត ធ្លាប់ឮគេនិយាយពីអំពើសាហាវយង់ឃ្នងរបស់ពួកខ្មែរក្រហមដែរ ប៉ុន្តែគាត់ធ្លាប់ឃើញអំពើសាហាវយង់ឃ្នងដែលកងទ័ពរបស់រដ្ឋាភិបាលក្រុងភ្នំពេញប្រព្រឹត្តទៅវិញ ។ គេដឹងថា ទាហាននៃកងទ័ពរបស់សាធារណរដ្ឋខ្មែរ (កងយោធពលខេមរជាតិ) បានកាត់ក្បាលពួកខ្មែរក្រហមដែលពួកគេចាប់បានជាឈ្លើយសឹក វះពោះឈ្លើយសឹកទាំងនោះដើម្បីស៊ីថ្លើមដែលនៅស្រស់នៅឡើយ ឬឆ្កូតមុខមាត់ កុំឲ្យមើលស្គាល់ ដើម្បីសងសឹក ។ មេបញ្ជាការខ្លះ បានប្រឹងប្រែងរាំងរាទធ្វើទាំងនេះដែលធ្វើឲ្យស្ថិតស្ថេរដោយទំនៀមរបស់កម្ពុជាពីមុនមក ។ ប៉ុន្តែ អំពើសាហាវឃោរឃៅទាំងអស់ ត្រូវបានគេដឹងឮជាហូរហែដើម្បីនឹងឲ្យពួកអ្នកថតរូប និងពួកអ្នកកាសែតបរទេសផ្តល់នូវ សក្ខីភាពនៃអំពើឃោរឃៅទាំងនេះដោយត្រឹមត្រូវ ទោះបីជាក្រោយឆ្នាំ១៩៧៣ សារពត៌មានរបស់អាមេរិកាំង បដិសេធមិនចុះផ្សាយរូបថតផ្សេងៗទៀតនៃភាពគួរឲ្យរន្ធត់ទាំងនេះក៏ដោយ ។ គូសត្រូវទាំងសងខាងបានប្រព្រឹត្ត អំពើអាក្រក់ទៅលើប្រជាជនស៊ីវិល និងកងទ័ពតាមរបៀបតែមួយដូចគ្នា ។ ភាពសាហាវឃោរឃៅហាក់ដូចជាយុទ្ធវិធីមួយ ដែលត្រូវប្រើប្រាស់ដោយកងទ័ពទាំងសងខាង ហើយ កុម្ហុត សន្និដ្ឋានថា វានឹងត្រូវបោះបង់ចោលបន្ទាប់ពីជ័យជម្នះ ។

ជាសំខាន់ កុម្ហុត យល់ឃើញថា វានឹងគ្មានចម្បាំងនៅប្រទេសកម្ពុជាទេ បើគ្មានសង្គ្រាមនៅប្រទេសវៀតណាម ។ បើសិនសង្គ្រាមនៅវៀណាមចប់ សង្គ្រាមនៅកម្ពុជាក៏នឹងចប់ដែរ ហើយសន្តិភាពនឹងត្រូវធ្វើឲ្យមានឡើងវិញដូចដើម ។ ម្យ៉ាងទៀត កុម្ហុត ពិតជាតម្រូវឲ្យជឿទុកចិត្តលើពួកខ្មែរក្រហមហើយ ពីព្រោះគាត់គ្មានឃើញ

អ្នកណាម្នាក់ក្រៅពីនេះដែលធ្វើឲ្យគាត់ជឿជាក់បាន ។ អ្នកដឹកនាំដទៃទៀតទាំងអស់ ដែលមានក្នុងពេលសព្វថ្ងៃនៅប្រទេសកម្ពុជា ឃើញថាសុទ្ធតែគ្មានសមត្ថភាព ។ ការភ្ញាក់ខ្លួននេះ គឺឲ្យសំអាងដោយភាពប្រាកដក្នុងចិត្តថា ប្រទេសមួយដែលធ្លាប់ថ្កុំថ្កើងរុងរឿង បានត្រូវប្រព្រឹត្តបំពានដោយសារពួកមេដឹកនាំអន់គម្រក់ ។ សូមទុកឲ្យប្រជាជន និងប្រទេសជាតិរីកលូតលាស់ដោយគ្មានមនុស្សទាំងនេះ ហើយប្រទេសកម្ពុជានឹងក្លាយទៅជាប្រជាជាតិមួយ ក្នុងចំណោមប្រជាជាតិដែលបរិបូរដោយសុខុមាលភាពនៃភពផែនដី ។ កុម្មុត និងពួកខ្មែរក្រហមបានមានទស្សនៈ នេះដូចគ្នា ប៉ុន្តែមានគំនិតខុសគ្នាទាំងស្រុងពី«ប្រជាជន» និងពួកមេដឹកនាំល្អត្រឹមត្រូវ ។

កុម្មុត បានបង្ហាញឲ្យឃើញភាពគ្មានការវិនិច្ឆ័យមួយ ដូចគ្នានឹងជនកម្ពុជាចេះដឹងដទៃៗទៀតដែរ ។ អាស្រ័យដោយការអប់រំរបស់គេ មនុស្សទាំងនេះទៅជាមានគំនិតគ្មានពិសោធន៍មួយអំពីសង្គ្រាម ការបដិវត្តនិងការពិតទាំងឡាយដែលមាននៅទ្វីបអាស៊ីសម័យទំនើប ។ ពួកគេបានចម្រើនវ័យធំធាត់នៅក្រោមរបបផ្តាច់ការនិងលើកជំនួយរបស់សម្តេច ព្រះនរោត្តម សីហនុ ។ សម្តេចបានឡើងគ្រងរាជ្យបល្ល័ង្កនៅឆ្នាំ១៩៤១ ហើយបានគ្រប់គ្រងដឹកនាំប្រទេសក្នុងឋានៈជាព្រះមហាក្សត្រ ឬមេដឹកនាំជ្រើសតាំងរហូតដល់ឆ្នាំ១៩៧០ ។ ព្រះអង្គបានបង្កើតឲ្យមានភាពជានិមិត្តរូបដែលគួរឲ្យទុកចិត្តជាច្រើន និងរឿងបំភ្លៃខុសពីការពិតដែលហួសសម័យទៅហើយ ដើម្បីការពារប្រជារាស្ត្រ និងប្រទេសរបស់ព្រះអង្គ ឲ្យផុតពីសង្គ្រាមឥណ្ឌូចិន ព្រមទាំងគុណវិបត្តិទាំងឡាយ ដែលអាចលាក់ខ្លួននៅមាត់ទ្វារ “ឋានសួគ៌” គឺប្រទេសកម្ពុជានេះឯង ។ សម្តេច ព្រះនរោត្តម សីហនុ បានទទួលជាមរតកនូវប្រទេសមួយ ដែលជិតដាមទៅដោយមនោសញ្ចេតនាជឿកម្មផលដ៏ជ្រាលជ្រៅមួយ ប្រជារាស្ត្រមួយដែលឃើញពូជសាសន៍ខ្លួនត្រូវគំរាមកំហែងដោយបណ្តាប្រទេសជិតខាងលោភលន់ចង់បានទឹកដី ហើយដែលវប្បធម៌ធ្លាប់ឈានដល់កម្រិតកំពូល មួយកាលពីប៉ុន្មានសតវត្សរ៍មុន ។ ដោយសារប្រវត្តិសាស្ត្រ និងការលម្អៀង ដែលមានពីកំណើតរបស់ខ្លួន ប្រជាជនកម្ពុជាបានបណ្តោយឲ្យសម្តេច ព្រះនរោត្តម សីហនុ “ការពារ” និងចាត់ទុកពួកគេប្រៀបដូចជាកូនចៅ ដែលនៅជ្រកកោនក្នុងប្រទេសក្តៅមួយ ។

គំនិតវិលវល់អំពីឋានសួគ៌ (ឬប្រទេសសប្បាយបំផុត) នេះ ពុំមែនជារឿងចម្លែកទាំងស្រុងទេ ។ ប្រជាជនតូចតាចរបស់កម្ពុជារស់នៅក្នុងប្រទេសប្រកបដោយសោភ័ណភាព និងសម្បូរសប្បាយមួយ ។ ស្ថិតនៅភាគកណ្តាលនៃឧបទ្វីបអាស៊ីអាគ្នេយ៍ ប្រទេសកម្ពុជាបានត្រូវទន្លេមេគង្គដ៏ធំហូរកាត់ចំពាក់កណ្តាល ។ នៅភាគខាងលិចមានជួរភ្នំក្រវាញសណ្តូកខ្លួនខ្ពស់ឡើងត្រដែត ដែលភ្នំតូចៗខ្លះមានត្បូងកណ្តៀង និងត្បូងទទឹមនៅកប់ក្នុងនោះផង ។ ទឹកពណ៌ខៀវថ្លា និងដែលអាចធ្វើនាវាចរណ៍បាននៃឈូងសមុទ្រសៀម បានរួមបង្កជាព្រំដែនភាគខាងត្បូង ។ ទន្លេសាបដែលលាតសន្ធឹងនៅភាគខាងជើងឆៀងខាងលិច និងផ្តល់ទឹកដល់ដៃទន្លេមួយមានឈ្មោះដូចគ្នាដែលហូរចាក់ទៅក្នុងទន្លេមេគង្គ ។ ផ្នែកខាងក្នុងប្រទេស គឺគ្របដណ្តប់ទៅដោយវាលស្រែ ផ្លែឈើ និងបន្លែបង្ការគ្រប់ប្រភេទ ដើមឈើផងទាំងពួងកំពុងដុះលូតលាស់យ៉ាងល្អនៅលើដីសណ្តដ៏សម្បូរជីជាតិ ។ ជួរភ្នំរង និងចម្ការ

កោះស៊ូដ៏ធំល្វឹងល្វើយនានាបាន រួមបង្កើតជាតំបន់ភាគខាងជើង និងខាងកើតដែលមានទន្លេពីរហូរប្រសព្វគ្នាស្ទើរតែចំពាក់កណ្ដាលប្រទេស បង្កើតជាសញ្ញាខ្វែងជើងក្អែកមួយដែលមានរាជធានីភ្នំពេញតាំងនៅ ។

បឹងនិងព្រែកស៊ីងទន្លេតូចធំ បានផ្ដល់នូវមច្ឆាជាតិយ៉ាងសម្បូរបែប ។ ប្រទេសកម្ពុជាបានផ្គត់ផ្គង់ស្រូវអង្ករដោយទៀងទាត់ ចំពោះប្រជាជនរបស់ខ្លួន ច្រើនជាងប្រទេសដទៃទៀតទាំងអស់នៅអាស៊ីភាគអាគ្នេយ៍ ទោះបីជានៅពេលដែលការប្រមូលកាត់មិនបានផលល្អក៏ដោយ ។ ទិដ្ឋភាពមួយផ្នែកធំ នៅតែមានរូបភាពដូចកាលពីច្រើនសតវត្សរ៍មុនដែរ ជាមួយវាលស្រែពណ៌បៃតងស្រងាត់ដែលបាំងទៅដោយម្លប់ដើមឫស្សី និងដើមត្នោតជាច្រើន ។ ប្រជាកសិកររស់នៅក្នុងខ្ទមតូចៗ ឬក្នុងផ្ទះបុរាណធ្វើពីឈើ ដែលសង់ខ្ពស់ផុតពីទឹកជំនន់ក្នុងរដូវវស្សា ។ ដំបូលស្រួចជមទៅលើរបស់វត្តអារាមនានាបានលេចឡើងត្រដែតត្រដឹមពីលើភូមិនានា និងការរស់នៅរបស់កសិករទាំងឡាយ ។

ប្រទេសកម្ពុជាមានអព្ភូតហេតុប្រចាំឆ្នាំរបស់ខ្លួន គឺនៅខែសីហាជារៀងរាល់ឆ្នាំ ទឹកទន្លេសាប បានហូរបញ្ច្រាសមកវិញ –នេះជាបាតុភូតដែលកើតឡើងដោយសារទឹកភ្លៀងហូរចាក់ទៅខ្លាំងនៅរដូវវស្សា និងកម្ពស់ខុសគ្នារវាងទន្លេមេគង្គ និងទន្លេសាបដែលខ្ពស់ជាង ។ ប្រជាជនកម្ពុជា បានប្រារព្ធពិធីបុណ្យអបអរហេតុការណ៍សំខាន់នេះ ដោយបុណ្យអុំទូកមួយយ៉ាងធំ និងមានពិធីបុណ្យជាច្រើនទៀត ដើម្បីកត់សម្គាល់នូវការផ្លាស់ប្ដូរភាគច្រើននៃរដូវកាល ។ សង្គមរបស់កម្ពុជាមានលក្ខណៈបុរាណគួរសមដែរ ទោះបីជាបានលាយបញ្ចូលសាសនា និងវប្បធម៌យ៉ាងជិតស្និទ្ធទៅនឹងភូមិសាស្ត្រនិងបរិស្ថាន (ទីជុំវិញ) ក៏ដោយ ។ បុណ្យទាន សិល្បៈ និងភាគល្អិតល្អន់នៃជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជា មានលក្ខណៈដោយឡែកពីគេបំផុត ។ សង្គមរបស់កម្ពុជា ប្រហែលជាស្ថិតនៅដាច់តែឯងពីពិភពលោកខ្លាំងពេក ហើយពួកបារាំងបានប្រៀបធៀបប្រជាជនកម្ពុជាដែលធ្វើឲ្យជាប់ចិត្តខ្លាំងនឹងដីធ្លីរបស់គេ ទៅនឹងស្រាទំពាំងបាយជូរយ៉ាងឆ្ងាញ់ពិសា ដែលមិនអនុញ្ញាតឲ្យដឹកហួសកម្រិតឡើយ ។

ក៏ប៉ុន្តែ ប្រទេសកម្ពុជាគេចពុំផុតពីតំបន់ដែលគួរឲ្យភ័យព្រួយ នៃធាតុអាកាសមានពីររដូវក្នុងមួយឆ្នាំទេ ។ ជំងឺមុខជារាតត្បាតនៅទីនោះ បើសិនគេមិនប្រយុទ្ធប្រឆាំងនឹងវា ដែលជារឿយៗពុំមានករណីនេះទេ ។ ធាតុអាកាសផ្លាស់វេនខុសពីគ្នាខ្លាំងបំផុត រដូវក្ដៅមួយដែលមានរយៈពេលវែង ប្រហែលមិនចេះផុតផងក៏មិនដឹង ហើយបន្តដោយរដូវវស្សាមួយដែលមានភ្លៀងធ្លាក់យ៉ាងជោកជាំ ។ ព្រៃស្បាត និងសត្វព្រៃ តែងតែគំរាមដណ្ដើមយកដីដាំដុះទៅវិញជានិច្ច ។ ភាពរាំងស្ងួត និងទឹកជំនន់អាចបង្កឲ្យមានការខូចខាតយ៉ាងធំដល់ផលដំណាំផ្សេងៗ ។

និមិត្តរូបនៃជំនឿ ដែលមានអាយុរាប់រយឆ្នាំមកហើយរបស់ប្រជាជនកម្ពុជា ចំពោះទេវរាជាមួយអង្គក្សត្រពាក់កណ្ដាលអាទិទេពមួយអង្គដែលលើកតម្កើងដោយអាទិទេពផ្សេងៗ ហើយដោយកាន់កាប់អំណាចផ្ដាច់ការមួយខាងអាណាចក្រ សម្ដេច ព្រះនរោត្តម សីហនុ បានចាត់ទុកប្រទេសកម្ពុជាដូចឋានសួគ៌ (ប្រទេសសប្បាយ

បំផុត) របស់ព្រះអង្គ ។ ព្រះអង្គបានតម្រូវព្រះកាយទៅតាមករណីយកិច្ចថ្មៃប្រឌិតរដ្ឋមួយ ដើម្បី«ការពារ» ប្រទេសកម្ពុជា បញ្ចៀសឥទ្ធិពលទាំងឡាយរបស់បរទេស ឬភាពទំនើបមិនគួរឲ្យប្រាថ្នា ដែលអាចធ្វើឲ្យមានវិបរិតដល់ជីវភាពរស់នៅមួយភាគធំរបស់អ្នកជនបទ និងអ្នកកាន់ពុទ្ធសាសនានៃព្រះរាជាណាចក្រព្រះអង្គ ។ សម្ដេច ព្រះនរោត្តម សីហនុ បានយកព្រះទ័យទុកដាក់ជាសារវន្តចំពោះឯករាជ្យនៃប្រទេសរបស់ទ្រង់ ពីព្រោះជាមធ្យោបាយចាំបាច់មួយ ដើម្បីរារាំងសង្គ្រាមឥណ្ឌូចិនលើកទីមួយ (១៩៤៦-១៩៥៤) មិនឲ្យកើតមាននៅប្រទេសកម្ពុជា និងកម្ចាត់វាឲ្យបាត់ជារៀងរហូត ។ ក្នុងព្រះរាជតម្រិះរបស់ព្រះអង្គ ឯករាជ្យភាពពុំគ្រាន់តែជាការផ្ដើមឈានចូលសតវត្សរ៍ទី២០ របស់ប្រទេសកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែ ជាការធានាឲ្យប្រទេសជាតិនឹងនៅតែជាប្រទេសសម្បូរសប្បាយមួយនៅអាស៊ី ដែលគ្មានប៉ះពាល់ដោយភាពទំនើបទាន់សម័យមួយដែលអាចធ្វើឲ្យអំណាចរបស់ព្រះអង្គរង្គោះរង្គើ ។

យូរទៅទៀត សម្ដេច ព្រះនរោត្តម សីហនុ មានលក្ខណៈដូចអតីតមហាក្សត្រអឺរ៉ុបមួយអង្គ ជាងមេដឹកនាំប្រទេសតតិយលោកមួយ ដែលកំពុងប៉ងប្រាថ្នាដណ្ដើមយកឋានៈនាទីក្នុងពិភពលោកទំនើបមួយ ។ ព្រះអង្គសព្វព្រះទ័យឲ្យតម្លៃជីវភាពនៅស្រុកស្រែចម្ការ សិល្បៈ មិនយកព្រះទ័យទុកដាក់នឹងពាណិជ្ជកម្ម ឧស្សាហកម្ម និងហិរញ្ញវត្ថុ ។ ក្នុងពេលដែលប្រទេសថៃ ម៉ាឡេស៊ី ក្រោយមកសិង្ហបុរី និងប្រទេសវៀតណាមទាំងពីរ ដែលបំផ្លិចបំផ្លាញ ដោយសារសង្គ្រាម ប្រឹងប្រែងបំពាក់ឲ្យប្រទេសរបស់ខ្លួន មានមូលដ្ឋានឧស្សាហកម្ម សម្ដេចសព្វព្រះទ័យប្រមូលផ្ដុំការប្រឹងប្រែងរបស់ព្រះអង្គមុនអ្វីៗទាំងអស់ទៅលើវិស័យអប់រំ ការកសាងហេដ្ឋារចនាសម្ព័ន្ធមួយមានផ្លូវថ្នល់ និងផ្លូវរទេះភ្លើងជាដើម រួមទាំងកំពង់ផែសមុទ្រមួយផង - ជាគំនិតដែលប្រហែលជាទទួលជាមរតកពីពួកអាណានិគមបារាំងដោយមិនដឹងខ្លួន ។

សម្ដេច ព្រះនរោត្តម សីហនុ មានព្រះរាជតម្រិះថា «ផ្នែកកសិកម្ម ដែលផ្ដល់នូវផលយ៉ាងខ្ពស់មួយនៅពេលដែលសកម្មភាពខាងពាណិជ្ជកម្ម និងសេវាកម្មផ្សេងៗទៀត តិច ឬច្រើន ហាក់ដូចជាអ្វីដែលរស់ដោយសារគេអឺចឹង»[៦] ។ ព្រះអង្គចោលព្រះនេត្ររបៀបឆ្មើងឆ្មៃទៅលើប្រទេសថៃ ដែលកសិករទាំងឡាយបោះបង់ចោលការធ្វើស្រែចម្ការ ដើម្បីទៅធ្វើការនៅក្នុងរោងចក្រថ្មីៗ និងរស់នៅក្នុងបណ្ដាភូមិអ្នកក្រីក្រតាមជាយក្រុង ។ ព្រះអង្គធ្វើឲ្យខូចទឹកចិត្តនូវរាល់គម្រោងការធំៗ ផ្នែកឧស្សាហកម្ម និងការវិនិយោគផ្នែកពាណិជ្ជកម្មរបស់បរទេសដែលអាចនឹងទាក់ទាញប្រជាកសិករខ្មែរឲ្យមកកាន់ទីក្រុងភ្នំពេញ ។ ចំពោះចំណុចនេះ ផែនការរបស់សម្ដេចបានទទួលជោគជ័យ គឺមិនសូវមានអ្នករត់មករស់នៅទីក្រុងនានាច្រើនប៉ុន្មានទេ នៅក្នុងអំឡុងរជ្ជកាលរបស់ព្រះអង្គ ។ ម្យ៉ាងទៀតទីក្រុងភ្នំពេញ នៅតែជាទីក្រុងសំខាន់តែមួយគត់ ជាមួយនឹងពលរដ្ឋប្រហែលដប់ភាគរយនៃប្រជាពលរដ្ឋទូទាំងប្រទេស ។ ប៉ុន្តែ ចាប់តាំងពីដើមទសវត្សរ៍៦០ ក្រុមវរជនរបស់ប្រទេសចាប់ផ្ដើមភ័យព្រួយពីអនាគតរបស់ខ្លួន ។ បងប្អូន និងមិត្តភក្ដិរបស់ កុម្ហត បារម្ភថា ប្រទេសកម្ពុជាកំពុងមានភាពយឺតយ៉ាវ

ខ្លាំង បើនិយាយអំពីផ្នែកសេដ្ឋកិច្ច និងនយោបាយ ។

ប្រជាជនជាងបីភាគបួនរស់នៅស្រុកស្រែចម្ការ ។ ចំពោះកសិករទាំងនេះយល់ថា គុណប្រយោជន៍នៃឯករាជ្យ ត្រូវសម្ដែងចេញឲ្យឃើញដោយការរីកលូតលាស់ផ្នែកសង្គមកិច្ច ការធ្វើឲ្យវិស័យអប់រំល្អប្រសើរជាងមុន ដែលបើតាមព្រះរាជបន្ទូលរបស់សម្ដេច ព្រះនរោត្តម សីហនុ ថា មិនត្រូវបំភ្លេចទ្រង់ទ្រាយសំខាន់នៃលក្ខណៈអ្នកកាន់ពុទ្ធសាសនាជាប្រពៃណីរបស់ប្រជាកសិករឲ្យខុសពីសភាពដើមឡើយ ។ សម្ដេច បានប្រើប្រាស់មួយភាគបីនៃថវិកាជាតិ[៧]សម្រាប់គោលដៅនេះជាសមាមាត្រយ៉ាងសម្បើម នៅពេលដែលគេដឹងថា ភាគច្រើននៃបណ្ដាប្រទេសកំពុងរីកលូតលាស់ ប្រើថវិកាយ៉ាងច្រើនរវាងពីប្រាំទៅដប់ភាគរយនៃប្រភពធនធានរបស់គេប៉ុណ្ណោះ សម្រាប់វិស័យអប់រំ ។ នៅឆ្នាំ១៩៧០ ជាឆ្នាំដែលព្រះអគ្គត្រូវផ្ដួលរំលំសម្ដេច ព្រះនរោត្តម សីហនុ បានយល់ព្រមផ្ដល់ម្ភៃប្រាំភាគរយ នៃថវិកាជាតិថែមទៀតចំពោះវិស័យនេះ ។

កុមារា-កុមារី នៅភូមិនានារបស់កម្ពុជា បានក្លាយទៅជាអ្នកមានចំណេះវិជ្ជាដោយពិតប្រាកដ ។ នៅពេលដែលប្រទេសបានទទួលឯករាជ្យ មានតែកុមារា-កុមារីមួយភាគបីប៉ុណ្ណោះបានចូលសាលារៀននៅឆ្នាំ១៩៥៥ ។ នៅក្នុងរយៈពេលដដែលនេះ ចំនួនកូនសិស្សវិទ្យាល័យបានឡើងពី ៥.០០០ដល់ ១១៨.០០០នាក់ ចំនួនគ្រូបង្រៀនបានឡើងពី៧.០០០ ដល់ ២៨.០០០នាក់ ។ ប៉ុន្តែអ្វីដែលយុវជនទាំងនេះរៀនសូត្រ គឺជារឿងមួយទៀត ។ ជាញឹកញយ ខ្លឹមសារនៃមុខវិជ្ជាសិក្សាទាំងឡាយពុំមានអ្វីធំដុំដែលត្រូវដឹងទេ ជាមួយនឹងគួនាទីអនាគតរបស់គេជាអ្នកធ្វើស្រែនោះ ។ ក្នុងសាលាដាច់ស្រយាលភាគច្រើននៅជនបទ សាស្ត្រាចារ្យទាំងឡាយបានអនុវត្តកម្មវិធីសិក្សាមួយ ដែលចម្លងតាមរបៀបបង្ហាត់បង្រៀនរបស់បារាំងទាំងងងឹតងងល់ ហើយក្នុងការបង្ហាត់បង្រៀនប្រវត្តិសាស្ត្រពិភពលោកគឺមាន លក្ខណៈអឺរ៉ុបជាងអាស៊ី ហើយខាងមុខវិជ្ជាសិល្បៈ និងវប្បធម៌ គឺមានលក្ខណៈបារាំងជាងខ្មែរ ។ សាលារៀនទាំងឡាយដែលតម្រង់ទៅរកវិជ្ជាជីវៈមួយ គឺមានតិចតួចណាស់ ។ នៅឆ្នាំ១៩៦៨ ទូទាំងប្រទេសមាននិស្សិត៧.០០០នាក់ ដែលមានតែ១៣០នាក់ប៉ុណ្ណោះរៀនខាងកសិកម្មសាស្ត្រ ។ ជនជាតិបារាំងម្នាក់ ដែលបង្រៀនមុខវិជ្ជាប្រវត្តិសាស្ត្រក្នុងវិទ្យាល័យរបស់កម្ពុជាមួយ នៅឆ្នាំ១៩៦៩ បានបកស្រាយថា ខ្ញុំរកឃើញភាពមិនច្បាស់លាស់យ៉ាងឆាប់រហ័សថា មុខវិជ្ជាប្រវត្តិសាស្ត្រសាបព្រោះគ្រាប់ពូជក្នុងចិតគំនិតយុវជនទាំងនេះ... ។ សម្រាប់ពួកនេះ ប្រវត្តិសាស្ត្រពិភពលោកគឺជាការប្រយុទ្ធមិនច្បាស់មួយ ដែលគូសត្រូវធំៗទាំងអស់ ចាប់ពីសេហ្សាដល់ណាប៉ូឡេអុង និងបីស្មាក់ បានប្រឈមមុខតទល់គ្នាលើដីស្រែដ៏ធំល្វឹងល្វើយមួយ...»[៨] ។

បែបផែននៃប្រព័ន្ធអប់រំ ដែលធ្វើតាមវប្បធម៌បរទេសមួយទាំងធ្មេចភ្នែកនេះ គឺជាផលបង្កើតឲ្យមានការបែងចែកវណ្ណៈផ្សេងៗ ដោយសំអាងលើគំនិតថា វាមានក្រុមវរជនអ្នកចេះដឹងមួយ ដែលមិនចេះប្រឈមមុខនឹងការលំបាកគ្រប់បែបយ៉ាងក្នុងសង្គមទេ លើកលែងតែធ្វើការ និងបញ្ញាប៉ុណ្ណោះ ។ គំនិតនេះ បែកចេញមកដោយ

ឯកឯងពីគំនិតដែលវាយតម្លៃខ្ពស់ចំពោះខ្លួនឯងមួយទៀតរបស់សម្ដេច ព្រះនរោត្តម សីហនុ ដែលធ្វើឲ្យចាក់ឫស យ៉ាងជ្រៅ ថ្វីបើមិនបញ្ជាក់ក៏ដោយ ហើយតាមរយៈនេះកសិករទាំងឡាយអាចលួមចិត្តនឹង «បេះផ្លែលើដើមឈើ» ទាំងឡាយដើម្បីរស់នៅយ៉ាងស្រួល ។ នេះជាគំនិតគ្មានដឹងពីការងារធ្វើឲ្យបាក់កម្លាំង ដែលតម្រូវឲ្យដីស្រែចម្ការ ត្រូវបញ្ចូលទឹកនៅក្រោមកម្ដៅថ្ងៃយ៉ាងក្ដៅឡើយ ។ សម្រាប់សម្ដេច ព្រះនរោត្តម សីហនុ ទ្រង់ព្រះចិន្ដាថា កសិករនៅជនបទរស់នៅប្រកបដោយសុភមង្គលហើយ ហើយសម្ដេចយកព្រះទ័យទុកដាក់ធ្វើយ៉ាងណាឲ្យ ប្រជាជនកម្ពុជា និងពួកបរទេសទទួលស្គាល់ការពិតនេះ ។

កុម្ពុត តោងតែទៅជាមនុស្ស «អ្នកបេះដឹង» ម្នាក់ក្នុងចំណោមអ្នកបេះដឹងនានា ។ យុវជនទាំងឡាយ បានកំណត់ គោលបំណងទៅរកអនាគតមួយបែបនោះ ដោយចូលរៀននៅតាមវិទ្យាល័យល្បីៗ បន្ទាប់មក សាកលវិទ្យាល័យ ផ្សេងៗនៅបរទេសទៀត ក្នុងគោលបំណងធ្វើជាគ្រូបង្រៀន និងសាស្ត្រាចារ្យ ដែលសម្ដេច ព្រះនរោត្តម សីហនុ ត្រូវការសម្រាប់ «កូនចៅ» ព្រះអង្គជាពលរដ្ឋនៅកម្ពុជា ។ ប្រទេសកំពុងអភិវឌ្ឍន៍ដទៃៗទៀតបានជំរុញ ពួក និស្សិតគេដែលមានទេពកោសល្យ និងមហិច្ឆតាខ្ពស់ឲ្យក្លាយទៅជាគ្រូ ខាងមុខវិជ្ជាវិទ្យាសាស្ត្រ អ្នកបច្ចេកា ធិបតេយ្យ ឬអ្នកបំពេញភារកិច្ចផ្សេងៗ ឲ្យទទួលបានសមត្ថភាពចាំបាច់នានា ដើម្បីជំនួសពួកអ្នកជំនាញការ បរទេស (ពួកបារាំងនៅក្នុងករណីប្រទេសកម្ពុជា) ។ ក្នុងប្រទេសរបស់សម្ដេច ព្រះនរោត្តម សីហនុ ពួកអ្នកបេះ ដឹងទាំងនោះ បានក្លាយជាសាស្ត្រាចារ្យឧត្តមសិក្សា ជាមួយប្រាក់បៀវត្សរ៍យ៉ាងខ្ពស់[៧] ។ មនុស្ស«បេះដឹង» ទាំងនេះជាប្រភពផ្ដល់នូវបុគ្គលិកដល់សាលារៀន និងសកលវិទ្យាល័យថ្មីៗ ការិយាល័យនានារបស់រដ្ឋាភិបាល និងសារពត៌មាន ។ ពួកគេបានបង្កើតសមាគមសាស្ត្រាចារ្យ សមាគមអ្នកនិពន្ធតូចតាចមួយ ហើយបញ្ញវន្ដដទៃៗ ទៀត បង្កើតសហគមន៍ នាដករនាដការី តន្ត្រីករ និងវិចិត្រករមួយ ។

ពួកគេរស់នៅក្នុងទីក្រុងមួយប្រកបដោយសោភ័ណភាព ដែលត្រូវទំនុកបម្រុងយ៉ាងយកចិត្តទុកដាក់ ដោយបង្ហាញឲ្យឃើញពីផែនការផ្សេងៗរបស់សម្ដេច ព្រះនរោត្តម សីហនុ ចំពោះក្រុមវរជនរបស់ព្រះអង្គ ។ គ្មានការគ្រោង គិតអំពីផ្ទះថ្មខ្ពស់ៗសាងសង់ជាប់ៗគ្នាតាមបណ្ដោយមហាវិថីនានានៅក្រុងភ្នំពេញ ទាំងរោងចក្រ ផ្សេងៗ ដែលកំពុងខ្ជាក់ផ្សែងចេញធ្វើឲ្យកខ្វក់ទន្លេមេគង្គ និងទន្លេបាសាក់ផងទេ ។ សម្ដេច ព្រះនរោត្តម សីហនុ ចង់បានអគាររដ្ឋបាលសាធារណៈនានា ដែលនាំឲ្យនឹកឃើញដល់និម្មាបនកម្មនៃខេត្តរបស់បារាំង ។ (ពួកអាណា និគមបារាំងបានសាងសង់ផ្ទុយពីនោះ ដោយហេតុថា ពួកគេបានកសាងព្រះបរមរាជវាំងយ៉ាងធំនៅក្នុងទីក្រុង សារមន្ទីរ និងកំផែងព្រះរាជវាំងក្នុងរចនាប័ទ្មនៃនិម្មាបនកម្មខ្មែរ) ។ រាជធានីនឹងនៅតែជាកំពង់ផែផ្លូវទឹកបែប រ៉ូម៉ង់ទិចមួយ ។

ក្នុងទីក្រុងភ្នំពេញរបស់សម្ដេច ព្រះនរោត្តម សីហនុ សហគមន៍ដទៃៗទៀតបានរ៉ាប់រងបម្រើសេវាផ្សេងៗ ដើម្បីជា ប្រយោជន៍ដល់រាជធានី ។ ពាណិជ្ជកម្មត្រូវបានគ្រប់គ្រងដោយពួកចិន ដែលធ្វើនិរប្រវេសន៍ (ការចេញ

ទៅតាំងនៅប្រទេសដទៃ) មកដល់ថ្មីៗ នៅចុងសតវត្សរ៍ទី១៩ ជាមួយបំណងធ្វើឲ្យមានទ្រព្យសម្បត្តិស្តុកស្តម្ភក្នុងផ្នែកមួយ ដែលសម្តេច ព្រះនរោត្តម សីហនុ វិនិច្ឆ័យថា ក្រុមវរជនរបស់ព្រះអង្គមិនមានចំណូលចិត្ត ។ ពួកចិនបានកាន់កាប់ស្ទើរតែផ្តាច់មុខលើពាណិជ្ជកម្ម សហគ្រាសផ្សេងៗ និងធនាគារឯកជន ។ ពួកបញ្ញវន្តខ្មែរ ដែលចូលចិត្តខាងសេដ្ឋកិច្ច បានត្រូវបញ្ចុះបញ្ចូលឲ្យក្លាយទៅជាមន្ត្រីផ្តល់យោបល់ដល់រាជរដ្ឋាភិបាល និងបន្ទាប់មកផ្តល់ក្របខ័ណ្ឌ (វង្វង់កម្រិតថ្នាក់អ្នករាជការជាន់ខ្ពស់ ជាន់បន្ទាប់ និងជាន់ទាប) ដល់បណ្តាធនាគាររាជរដ្ឋាភិបាលថែមទៀត ។ ព្រះរាជតម្រិះនេះ ពឹងផ្អែកជាសំអាងលើឥរិយាបថ ដែលពួកបារាំងធ្លាប់ប្រកាន់យកជាប្រពៃណីមកហើយ ជាហេតុបណ្តាលឲ្យមាននៅទីបញ្ចប់នូវទីក្រុងមួយ ដែលតាំងឡើងលើការបែងចែកជាតិសាសន៍ពេញទីៈ ពួកចិន សុទ្ធតែជាអ្នករកស៊ីចងការដោយយកការប្រាក់ហួសប្រមាណ និងជាអ្នកជំនួញ ពួកវៀតណាមដែលមកដល់ជាមួយពួកអាណានិគមបារាំងបានបំពេញមុខងារជាឈ្មួញកណ្តាល ឬប្រកបមុខរបរទីបី ប្រជាជនកម្ពុជាជាប្រភពផ្តល់កសិករ មន្ត្រីរាជការ និងបញ្ញវន្ត ពួកបារាំងដែលនៅសល់ក្រោយប្រទេសបានឯករាជ្យសុទ្ធតែជាអ្នកជំនាញការ ម្ចាស់កម្មសិទ្ធិចម្ការកៅស៊ូ ឬធ្វើការក្នុងវិស័យអាហារ័ណ-នីហរ័ណ ។ នៅជំនាន់សម្តេច ព្រះនរោត្តម សីហនុ គេមិនចាំបាច់ចេះ ភាសាខ្មែរនៅពេលធ្វើដំណើរក្នុងទីក្រុងទេ ៈ ចេះភាសាបារាំង វៀតណាម ឬចិន គឺគ្រប់គ្រាន់ហើយ ។

បណ្តាជនជាតិខ្មែរវណ្ណៈមធ្យមនៅក្រុងភ្នំពេញ ដែលរស់នៅធំធាត់ក្នុងទីកន្លែងដែលមានវេទយិតភាពនេះគឺនៅដាច់តែឯង ពីចំណែកធំមួយនៃជីវភាពរស់នៅរបស់រាជធានី ហើយដាច់ឆ្ងាយពីពិភពលោកទៀត ។ កុម្មុត និងប្រជាជនកម្ពុជាជំនាន់គាត់បានទៅជាកូនចៅទម្រើសរបស់សម្តេច ព្រះនរោត្តម សីហនុ ពុំមែនជាពលរដ្ឋឯករាជ្យដែលអាចមានជោគជ័យ ឬបរាជ័យតែម្នាក់ឯងបានឡើយ ។ អំពើពុករលួយទូទៅបានធ្វើឲ្យពួកអ្នកមានបុព្វសិទ្ធិមានជីវភាពស្រួលស្រណុកមួយ ហើយសម្តេច ព្រះនរោត្តម សីហនុ មានការទោរទន់មួយនៅពេល ដែលព្រះអង្គចាត់ចែងការងារក្នុងឋានៈជាមហាក្សត្រមួយអង្គ ។ ព្រះអង្គសព្វព្រះទ័យផ្តល់តំណែង និងបុព្វសិទ្ធិផ្សេងៗ នៅតាមទំនើងព្រះទ័យរបស់ព្រះអង្គ ហើយពុំធ្វើទៅតាមសញ្ញាណសម័យមួយក្នុងការបែងចែកអំណាច ឬរបៀបគ្រប់គ្រងសមតាមវិចារណញ្ញាណក្នុងការផ្តល់រង្វាន់ឡើយ ។ ពួកអ្នកដែលអែបអបរកប្រយោជន៍ ត្រូវបានជួយឲ្យសមតាមបំណងប្រាថ្នា ពួកអ្នកញុះញង់ឲ្យមានវឹកវរត្រូវទទួលទណ្ឌកម្ម ហើយដោយសារប៉ូលិស និងសភាវគតិរបស់សម្តេច ព្រះនរោត្តម សីហនុ ចេះញែកក្រុមមួយឲ្យឃើញខុសគ្នាពីក្រុមមួយទៀត ។

សម្តេច បានបង្កើតសម្រាប់មនុស្សទូទៅ ដូចកុម្មុត ជាដើមនូវសង្គមមួយដែលផ្ទុយគ្នា ថែមទាំងមិនស្របនឹងវិចារណញ្ញាណទៀតផង ។ ព្រះអង្គបានបញ្ជាក់ថា កម្ពុជាជាប្រទេសកាន់លទ្ធិប្រជាធិបតេយ្យមួយ ប៉ុន្តែ គ្រប់គ្រងដោយព្រះមហាក្សត្រទាំងស្រុង ។ កសិករទាំងឡាយបានបោះឆ្នោតឲ្យគណបក្សរបស់ព្រះអង្គ ពីព្រោះព្រះអង្គ ជាទេវរាជា និងជាមេដឹកនាំមួយអង្គដែលចេះធ្វើឲ្យប្រជាជនចូលចិត្ត ។ សង្គមនិយមរបស់សម្តេច

ព្រះនរោត្តម សីហនុ ជារបៀបបកស្រាយទំនើបមួយយ៉ាងនៃរាជាធិបតេយ្យ ដែលជួយទំនុកបម្រុង និងគាំពារអ្នកដទៃជានិច្ច ។ សម្តេច បានប្រើប្រាស់ភាសាមិនពិតមួយនៃលទ្ធិម៉ាក្សស៊ីស ដើម្បីថ្កោលទោស“មូលធននិយម” ក្នុងពេលដែលព្រះអង្គដៀលត្មះភាពទំនើបទាន់សម័យ ដើម្បីតម្កើង“លទ្ធិសង្គមនិយម” ទុកណាជាព្រះអង្គមានគំនិត“អភិជនាធិប-តេយ្យ”ក៏ដោយ ។ អំពីវិស័យនយោបាយការបរទេស ព្រះអង្គមានព្រះរាជបន្ទូលដឹកនាំប្រឆាំងនឹងអាមេរិកាំង ដោយជួយធ្វើឲ្យទំនាក់ទំនង ដ៏ជិតស្និទ្ធជាមួយបណ្តាប្រទេសកុម្មុយនិស្តក្បែរខាងរីកលូតលាស់ ជាជាងជាមួយប្រទេសថៃ“មូលធននិយម” ហើយរួតខ្លួនព្រមជាមួយគ្នាថា ជាអ្នកប្រឆាំងលទ្ធិកុម្មុយនិស្តខ្លាំងជាងគេបំផុតក្នុងពិភពលោក ។

បុគ្គលិកលក្ខណៈរបស់សម្តេច ព្រះនរោត្តម សីហនុ បានគ្របដណ្តប់លើប្រទេសជាតិ បុកកម្ទេច កុម្ពូត និងបណ្តាមិត្តរបស់គាត់ដែលរៀននៅវិទ្យាល័យ នៅពេលដែលពួកគេចេញផុតពីករុណាវ័យ និងចាប់ផ្តើមរៀបចំផែនការផ្សេងៗសម្រាប់អនាគត ។ ប៉ុន្តែ នៅឆ្នាំ១៩៦០ ពួកកុម្មុយនិស្តនៅវៀតណាមខាងត្បូង បានផ្តើមធ្វើសង្គ្រាមជាចំហមួយប្រឆាំងនឹងរដ្ឋាភិបាលក្រុងព្រៃនគរ និងវាយតបចំពោះយុទ្ធនាការប្រឆាំងកុម្មុយនិស្តរបស់របបនេះ ។ សង្គ្រាមឥណ្ឌូចិនលើកទីពីរបានចាប់ផ្តើម ។ ក្នុងប្រទេសកម្ពុជាក្បែរខាង ការប្រយុទ្ធគ្នាបានលុបលើកិត្យានុភាពរបស់សម្តេច ព្រះនរោត្តម សីហនុ យ៉ាងឆាប់រហ័ស ហើយ កុម្ពូត យល់ថា សង្គ្រាមនៅប្រទេសវៀតណាម នឹងកំណត់សម្រេចអនាគតនៃប្រទេសរបស់គាត់ដែរ ។

ប្រទេសកម្ពុជាពុំមែនស្ថិតនៅក្នុងតំបន់កៀនកោះមួយនៃអាស៊ីទេ ប៉ុន្តែ គឺនៅចំកណ្តាលសង្គ្រាមឥណ្ឌូចិនលើកទីពីរ ។ ប្រទេសវៀតណាមខាងត្បូងនៅភាគខាងកើត និងប្រទេសឡាវនៅភាគខាងជើង សុទ្ធតែជាសមរភូមិប្រយុទ្ធ ។ ប្រទេសថៃដែលនៅខាងលិចបានក្លាយទៅជាបង្អែកក្រោយរបស់អាមេរិកាំង ជាមូលដ្ឋានមួយសម្រាប់យន្តហោះប្រដេញប្រតិកម្ម និងជាទីកម្សាន្តសប្បាយមួយសម្រាប់កងទ័ពអាមេរិកាំងដែលឈប់សម្រាក ។ ក្នុងចន្លោះប្រទេសទាំងបីនេះ ប្រទេសកម្ពុជារបៀបជនបទរបស់សម្តេច ព្រះនរោត្តម សីហនុ បានលេចឡើងក្នុងឋានៈជាទឹកដីអព្យាក្រឹតមួយមិនគួរឲ្យជឿ ។

នៅពេលដំបូង សង្គ្រាមហាក់ដូចជាបង្រួបបង្រួមប្រជាជនកម្ពុជាឲ្យមូលតែមួយ ។ កុម្ពូត មើលឃើញភាពខុសគ្នាតិចតួចរវាងជំហររបស់សម្តេច ព្រះនរោត្តម សីហនុ និងជំហររបស់សាស្ត្រាចារ្យទាំងឡាយរបស់គាត់ដែលនិយមឆ្វេងជ្រុលស្តីពីបញ្ហាសង្គ្រាមនៅប្រទេសវៀតណាម ។ ទាំងអស់គ្នាបានប្រឆាំងជំទាស់ នឹងការធ្វើអន្តរាគមន៍របស់អាមេរិកាំង ។ ទាំងអស់គ្នាជាយុទ្ធិកជននៃនយោបាយអព្យាក្រឹតមួយរបស់កម្ពុជា ។ ក្នុងអំឡុងឆ្នាំដំបូងៗនៃជម្លោះ អ្នកទាំងអស់ដូច កុម្ពូត ជាដើមបានកោតសរសើរ និងគាំទ្រនយោបាយការបរទេសរបស់សម្តេច ព្រះនរោត្តម សីហនុ ទុកណាជាពួកគេបន្តការតវ៉ាប្រឆាំងនឹងអំណាចបង្ក្រាប ដែលព្រះអង្គធ្វើមកលើជីវិត

រស់នៅរបស់គេក៏ដោយ ។

នៅពេលដែលសង្គ្រាមផ្ទុះឡើង សម្តេច ព្រះនរោត្តម សីហនុ ត្រូវបានគេស្គាល់ដឹងច្បាស់ក្នុងពិភពលោកទាំងមូល ចំពោះការប្រកាន់អព្យាក្រឹតនិយមយ៉ាងខ្ជាប់ខ្ជួនរបស់ព្រះអង្គ[10] ។ នៅឆ្នាំ១៩៥៥ ព្រះអង្គបានយាងទៅចូលរួមសន្និសីទនៅក្រុងបាន់ឌុង ដោយណែនាំបណ្តាប្រទេសកំពុងអភិវឌ្ឍកុំឲ្យភ្ជាប់ជោគវាសនារបស់ខ្លួន នឹងមហាអំណាចណាមួយ ហើយត្រូវសម្រេចផ្លូវដើរផ្ទាល់របស់ខ្លួនដោយខ្លួនឯង ។ តាមលំនាំជាទូទៅមួយពិភពកុម្មុយនិស្តបានទះដៃអបអរសាទរចំពោះសេចក្តីប្រកាសនេះ ។ សហរដ្ឋអាមេរិកមិនរវល់នឹងអ៊ីទាំងអស់ ។ នៅឆ្នាំបន្ទាប់គឺឆ្នាំ១៩៥៦ សហរដ្ឋអាមេរិកបានសាកល្បងពិសោធន៍អព្យាក្រឹតនិយមរបស់សម្តេច ព្រះនរោត្តម សីហនុ ដោយស្នើឲ្យប្រទេសកម្ពុជា ចូលជាសមាជិកមួយនៃអង្គការសន្ធិសញ្ញាអាស៊ីភាគអាគ្នេយ៍ (ហៅកាត់ សេ.អា.តូ) ជាបក្សសម្ព័ន្ធការពារមួយ ដែលបង្រួបបង្រួមបណ្តាប្រទេសនៅក្រោមបង្គាប់សហរដ្ឋអាមេរិកទាំងអស់ ។ សម្តេចបានបដិសេធ ។ ជាការសងសឹករបបក្រុងព្រៃនគរ បានសម្រេចរាំងខ្ទប់ផ្នែកសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា និងកំណត់ទំនិញផ្សេងៗ ដែលដឹកឡើងតាមទន្លេមេគង្គ រហូតដល់ក្រុងភ្នំពេញដែលនៅពេលនោះជាកំពង់ផែតែមួយគត់របស់ប្រទេស ។

ជាមួយនឹងសង្គ្រាមនៅប្រទេសវៀតណាម ការបង្ខិតបង្ខំថ្មីៗទៀតបានសង្កត់មកលើសម្តេច ព្រះនរោត្តម សីហនុ ក្នុងបំណងឲ្យព្រះអង្គកែប្រែយ៉ាងហោចនូវនយោបាយអព្យាក្រឹតនិយមរបស់ព្រះអង្គ ។ បក្សពួកទាំងសងខាង ប៉ងប្រាថ្នាចង់បានដោយស្ងាត់កំបាំងនូវផ្លូវផ្គត់ផ្គង់ភ័ស្តុភារ -សម្ភារៈសឹកដ៏មានតម្លៃនៅប្រទេសកម្ពុជា ហើយចង់ប្រើប្រាស់ប្រទេសនេះ ដើម្បីតាំងមូលដ្ឋានផ្សេងៗរបស់ខ្លួនផង ។ សហរដ្ឋអាមេរិក ជាអ្នកប្រើការគាបសង្កត់ ដំបូងគេប្រកបដោយភាពម៉ឺងម៉ាត់បំផុត ដោយប្រកាសចំពោះសម្តេច ព្រះនរោត្តម សីហនុ ថាធ្វើខ្លួនជាប្រទេសអព្យាក្រឹត តែបែរជាគាំទ្រពួកកុម្មុយនិស្តទៅវិញ ។ មុនដំបូង សម្តេច ព្រះនរោត្តម សីហនុ ធ្វើតាមការគាបសង្កត់ទាំងនេះ ហើយអះអាងថា ព្រះអង្គត្រូវការពួកគេដើម្បីទទួលបានការធានាដ៏រឹងមាំមួយ ខាងផ្នែកសន្តិសុខពីបណ្តាប្រទេសមិនមែនកុម្មុយនិស្ត ក្បែរខាងរបស់ព្រះអង្គ គឺប្រទេសថៃ និងវៀតណាមខាងត្បូង ។ ប៉ុន្តែពួកអាមេរិកាំងបដិសេធមិនទទួលស្គាល់ ហើយសម្តេច ព្រះនរោត្តម សីហនុ បានត្រូវញុាំងឲ្យជឿថា សហរដ្ឋអាមេរិកជាអ្នកទាញខ្សែពីក្រោយការរួមគំនិតក្បត់មួយ សំដៅផ្តួលរំលំព្រះអង្គកាលពីឆ្នាំមុន គឺឆ្នាំ១៩៥៩ ។ (ព្រះអង្គមានបន្ទូលត្រូវ) ។ ដូច្នេះអព្យាក្រឹតនិយមរបស់មេដឹកនាំកម្ពុជា ក្រោយមកបានត្រូវលាបលនដោយការមិនទុកចិត្តផ្ទាល់ខ្លួនយ៉ាងខ្លាំងមួយ -និងមានបង្ហាញភ័ស្តុតាងផង- ចំពោះពួកអាមេរិកាំង ។

ឆ្នាំ១៩៦៣ បានកំណត់នូវរបត់មួយសម្រាប់ប្រទេសវៀតណាម ប្រទេសកម្ពុជា កុម្ហុត ក្រុមនិយមស្តាំ និងនិយមឆ្វេងរបស់កម្ពុជា ។

ឆ្នាំនេះជាឆ្នាំចុងក្រោយរបស់កុម្ហុតនៅវិទ្យាល័យ ។ មិត្តភក្តិទាំងឡាយរបស់គាត់ និងខ្លួនគាត់នឹងត្រូវធ្វើឲ្យ

អំពល់មុនអ្វីៗទាំងអស់ក្នុងការជ្រើសរើសសាកលវិទ្យាល័យមួយ ដែលពួកគេនឹងត្រូវចូលរៀន ប៉ុន្តែ សង្គ្រាមមិនអនុញ្ញាតឲ្យគេនៅតែជាមនុស្សបរិសុទ្ធបានឡើយ ។ សង្គ្រាមក៏មិនអនុញ្ញាតឲ្យសម្ដេច ព្រះនរោត្តម សីហនុ ធ្វើអ្វីកើតដែរ ដែលចាប់ផ្ដើមភ័យបារម្ភចំពោះរូបព្រះអង្គផ្ទាល់ព្រមទាំងចំពោះប្រទេសកម្ពុជាផង ។ ជាអាទិ៍ ឧត្ដមសេនីយ៍ គីនីម ផុលសេនា នាយករដ្ឋមន្ត្រីអព្យាក្រឹតនិយមឡាវ បានត្រូវសម្លាប់នៅផ្ទះរបស់គាត់ដោយក្រុមមនុស្សនិយមស្ដាំ ដែលបោះបង់រណសិរ្សរួបរួមបង្កើតឡើងនៅឆ្នាំដដែលនោះ ដើម្បីទប់ស្កាត់សង្គ្រាម ។ ផុលសេនា ជាមិត្តម្នាក់របស់សម្ដេច ព្រះនរោត្តម សីហនុ និងមានទស្សនៈមួយដូចសម្ដេចដែរ ។ បើសិនសង្គ្រាមរាលដាលដល់ប្រទេសឡាវ តើប្រទេសកម្ពុជានឹងមានអ្វីកើតឡើង?

មួយខែក្រោយមក គឺនៅខែឧសភា ឆ្នាំ១៩៦៣ បាតុកម្មអហិង្សាមួយរបស់ព្រះសង្ឃពុទ្ធសាសនា ដែលកំពុងប្រព្រឹត្តទៅនៅទីក្រុងវ៉េ វៀតណាមខាងត្បូង ត្រូវបានបង្ក្រាបដោយកងទ័ពនៅទីនោះ ដែលបានបើកការបាញ់ប្រហារទៅលើហ្វូងមនុស្សដោយកាំភ្លើងយន្តជាច្រើនដើម និងបានសម្លាប់មនុស្សប្រាំបួននាក់ ដែលក្នុងនោះមានក្មេងប្រាំពីរនាក់ផង ។ ប្រទេសវៀតណាមខាងត្បូងបានបញ្ចេញឲ្យ ឃើញនូវការប្រើកម្លាំងដោយឯកឯង និងយ៉ាងឃោរឃៅ ។ ព្រះសង្ឃពុទ្ធសាសនាមួយអង្គព្រះជន្ម ៧០ ព្រះវស្សាបានធ្វើអត្តឃាដ ដោយដុតខ្លួនឯងនៅទីក្រុងព្រៃនគរ ។ អ្នកបួសបីនាក់ និងដូនជីម្នាក់ បានសម្លាប់ខ្លួនឯងនៅខែសីហា ដើម្បីតវ៉ាប្រឆាំងនឹងនយោបាយបង្ក្រាបរបស់របប ង៉ោ ឌិញយៀម ។ គ្មានអ្វីមួយអាចធ្វើឲ្យប៉ះពាល់ថែមទៀត ដល់ប្រទេសកាន់ពុទ្ធសាសនាមួយដូចប្រទេសកម្ពុជាបានឡើយ ហើយសម្ដេច ព្រះនរោត្តម សីហនុ បានប្រកាសជាសាធារណៈថា យៀម ជាមនុស្សកាន់សាសនាកាតូលិក-រ៉ូម៉ាំង មានសមានចិត្តតិចតួច ចំពោះព្រះពុទ្ធសាសនាដែលនឹងបន្តកាន់អំណាចមិនលើសពី ពីរ-បីខែឡើយ ។

ក្រុងភ្នំពេញបានត្រូវធ្វើឲ្យភ្ញាក់ភ្លាំងដោយសារសង្គ្រាម ។ ដោយត្រូវធ្វើឲ្យពិរោធខ្លាំង សម្ដេច ព្រះនរោត្តម សីហនុ ប្រកាសថា សហរដ្ឋអាមេរិក និង យៀម សុទ្ធតែជាអ្នកត្រូវទទួលទោស ។ សម្ដេចបានកាត់ផ្ដាច់ទំនាក់ទំនងការទូតជាមួយប្រទេសវៀតណាមខាងត្បូង ហើយបានទាយទុកជាមុនពីជ័យជម្នះមួយរបស់កុម្មុយនិស្ដ ៖ «ជោគវាសនារបស់ប្រទេសវៀតណាម ហាក់ដូចជាត្រូវកំណត់រួចហើយ ។ ជោគវាសនារបស់ប្រទេសខ្ញុំ ប្រហែលជានឹងដូចគ្នាក្នុងពេលមិនប៉ុន្មានទៀត ។ ប៉ុន្តែយ៉ាងហោច យើងមានការលួងចិត្តខ្លះៗដែរ ដែលបានព្រមានពិភពខាងលិចជាញឹកញាយ»[១១] ។

នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ១៩៦៣ ប្រធានាធិបតី យៀម និង ង៉ោឌិញញូ ជាប្អូនបង្កើតរបស់គាត់ ត្រូវបានសម្លាប់ក្នុងក្របខណ្ឌនៃរដ្ឋប្រហារមួយ ដែលមានការយល់ព្រម និងជួយសម្រួលដោយសហរដ្ឋអាមេរិក ។ សម្ដេច ព្រះនរោត្តម សីហនុ ជាឥស្សរជនដំបូងក្នុងចំណោមឥស្សរជនដំបូងៗនៃពិភពលោក ដែលសម្គាល់ឃើញការលូកដៃរបស់ក្រុងវ៉ាស៊ីនតោនក្នុងរដ្ឋប្រហារនេះ ហើយបានថ្កោលទោសសហរដ្ឋអាមេរិកពីការប្រព្រឹត្តអំពើក្បត់ ដែល

ជាបទខុក្រិដ្ឋ និងដែលគិតទុកជាមុនក្នុងឋានៈជាសម្ព័ន្ធមិត្តមួយ ។ ព្រះអង្គ បានប្រានចោលភ្លាមមួយរំពេច នូវជំនួយទាំងអស់របស់អាមេរិកាំង ដែលផ្តល់មកឲ្យប្រទេសកម្ពុជា ។ សម្តេចមានព្រះទ័យចង់ទប់សហរដ្ឋអាមេរិក ឲ្យស្ថិតនៅក្រៅកិច្ចការរបស់កម្ពុជាទាំងស្រុង ដើម្បីបន្ថយលទ្ធភាពនៃការរួមគំនិតក្បត់មួយរបស់អាមេរិកាំង សំដៅផ្តួលរំលំ ឬធ្វើឃាតព្រះអង្គ ។

ចំពោះនយោបាយក្នុងប្រទេសវិញ ការឆ្លើយតបរបស់សម្តេច ព្រះនរោត្តម សីហនុ ចំពោះសង្គ្រាមនៅប្រទេសវៀតណាមមានលក្ខណៈមិនច្បាស់លាស់ដូចគ្នា ។ នៅឆ្នាំ១៩៦៣ ព្រះអង្គបានចាត់ចែងធ្វើការផ្លាស់ប្តូរសំខាន់ៗ ជាច្រើនដែលបង្កឲ្យមានកំហឹង និងការខ្វែងយោបល់គ្នាសម្រាប់ក្រុមនិយមស្តាំ ក៏ដូចក្រុមនិយមឆ្វេង ហើយដែលនៅទីបំផុត ក៏នាំទៅដល់ការដួលរលំសម្រាប់រូបព្រះអង្គ ។

ទោះបីជាព្រះអង្គមានសមានចិត្តចំពោះពួកកុម្មុយនិស្តបរទេសក៏ដោយ ក៏ព្រះប្រមុខរដ្ឋខ្មែរមិនទុកចិត្តក្រុមនិយមឆ្វេងរបស់កម្ពុជាដែរ ។ នៅឆ្នាំ១៩៦៣ ពេលដែលសង្គ្រាមផ្ទុះឡើងនៅក្នុងប្រទេសវៀតណាមក្បែរខាង ព្រះអង្គបានប្រកាន់យកនយោបាយជាសត្រូវយ៉ាងចេញមុខចំពោះក្រុមនិយមឆ្វេង ។ ការបះបោរប្រឆាំងបានចាប់ផ្តើម ដោយការធ្វើកូដកម្មរបស់កូនសិស្សក្នុងខេត្តមួយនៅភាគពាយ័ព្យ បន្ទាប់មក បានរាលដាលមកដល់រាជធានីទៀត ។ ដើមដំបូង ចលនាបាតុកម្មរបស់កូនសិស្ស ធ្វើឡើងដើម្បីតវ៉ាជាសំខាន់ប្រឆាំងនឹងអំពើកម្រោលឃោរឃៅរបស់ប៉ូលិសខេត្តទេ ប៉ុន្តែបន្ទាប់មក វាបានប្រែក្លាយទៅជាការវាយប្រហារទូទៅ ចំពោះរដ្ឋអំណាចទាំងអស់ ជាពិសេស រូបសម្តេច ព្រះនរោត្តម សីហនុ ផ្ទាល់ ។

សម្តេច ព្រះនរោត្តម សីហនុ បានចោទប្រកាន់ក្រុមនិយមឆ្វេងថា ជាអ្នកញុះញង់ឲ្យមានការរំជើបរំជួលនេះ ដែលជាហេតុបង្ខំឲ្យពួកមេដឹកនាំឆ្វេងនិយមចាកចេញពីក្រុងភ្នំពេញ ។ ក្នុងចំណោមនោះ ក៏មានសមាជិកសំខាន់ៗនៃគណៈកម្មាធិការកណ្តាលខ្មែរក្រហម ដែលបានបង្កើតបក្សកុម្មុយនិស្តផ្ទាល់របស់គេជាផ្លូវការ នៅឆ្នាំ១៩៦០ ជាឆ្នាំនៃការចាប់ផ្តើមសង្គ្រាមនៅប្រទេសវៀតណាមដែរ ។ ភាគច្រើននៃពួកខ្មែរក្រហមទាំងនេះ បានស្វែងរកទីលាក់ខ្លួនក្នុងព្រៃស្បាត រត់ចូលព្រៃម៉ាគី និងចាប់ផ្តើមរៀបចំបក្សពួកប្រឆាំងនឹងសម្តេចវិញ ។ ខ្មែរក្រហមខ្លះទៀត បានចេញដំណើរទៅប្រទេសបារាំងជាថ្មី ។ ការចាកចេញរបស់គេ បានធ្វើឲ្យរញ្ជួយញាប់ញ័រយ៉ាងខ្លាំង ដល់សហគមន៍និស្សិត និងបញ្ញវន្តនៅក្រុងភ្នំពេញ ។ កុម្ភួត នឹកឃើញពីការច្របូកច្របល់ដែលស្ថិតមានមួយរយៈក្នុងរាជធានី នៅពេលនោះស្តីពីបញ្ហាសង្គ្រាម និងឥរិយាបថដែលត្រូវប្រកាន់យកចំពោះអ្នកនិយមឆ្វេង ។ សម្តេច ព្រះនរោត្តម សីហនុ អួតខ្លួនឯងថា សង្គមនិយម ប៉ុន្តែ ព្រះអង្គបានទម្លាក់ទោសលើពួកអ្នកទាំងឡាយ ដែលប្រកាសខ្លួនឯងថា ជាអ្នកសង្គមនិយមដែរ ហើយប្រកាសពីការយកចិត្តទុកដាក់របស់ព្រះអង្គ ចំពោះទំនើបភាវូបនីយកម្ម និងការចាត់ចែងឲ្យបានរីកចម្រើននូវផ្នែកសេដ្ឋកិច្ច និងសង្គមរបស់កម្ពុជា ។

បើការវាយប្រហាររបស់សម្តេច ព្រះនរោត្តម សីហនុ ប្រឆាំងនឹងក្រុមនិយមឆ្វេងមានលក្ខណៈត្រង់ៗ

ការប្រឈមមុខ ជាមួយក្រុមនិយមស្តាំពុំមែនជារឿងចាំបាច់ត្រូវធ្វើទេ ដែលចេញមកពីការប៉ុនប៉ងមួយ ដើម្បីកែកុនសេដ្ឋកិច្ចរបស់ប្រទេស បន្ទាប់ពីការបដិសេធជំនួយអាមេរិកាំង ។ កងទ័ពរបស់កម្ពុជារស់ដោយសារជំនួយនេះ ដែលជួយធ្វើឲ្យមានលំនឹងដល់ជញ្ជីងទូទាត់ចំណូល-ចំណាយរបស់ប្រទេសកម្ពុជាផង ។ គ្មានមូលនិធិទាំងនេះ កងទ័ពរបស់កម្ពុជានឹងចុះខ្សោយ នៅពេលដែលកងទ័ពរបស់បណ្តាប្រទេសជិតខាងរីកធំធាត់ ។ ហើយពួកមេៗកងទ័ពរបស់សម្តេច ព្រះនរោត្តម សីហនុ ត្រូវធ្វើឲ្យអស់សង្ឃឹមដែលមិនអាចការពារប្រទេសបាន ក្នុងករណីដែលមានការវាយប្រហារពីប្រទេសវៀតណាម ឬប្រទេសថៃ ។ ដូច្នេះ កងទ័ព គឺជាស្នូល នៃអ្វីដែលប្រហែលជាក្លាយទៅជាចង្កោមអ្នកបះបោរនិយមស្តាំមួយ ប្រឆាំងនឹងសម្តេច ព្រះនរោត្តម សីហនុ និងបង្កឲ្យមានរដ្ឋប្រហារមួយនៅឆ្នាំ១៩៧០ ។

ម្យ៉ាងទៀត សម្តេច បានធ្វើឲ្យគេដឹងឮជាសាធារណៈនូវកម្មវិធីមួយ ដើម្បីពង្រីកជាតូបនីយកម្ម ផ្នែកសេដ្ឋកិច្ច និងដោះស្រាយបញ្ហាផ្សេងៗ ដែលបណ្តាលឡើងដោយការបាត់បង់ជំនួយអាមេរិកាំង ។ ព្រះអង្គបានធ្វើជាតូបនីយកម្មសហគ្រាសជាច្រើន ធនាគារ និងក្រុមហ៊ុនអាហរ័ណ-នីហរ័ណទាំងអស់ ។ ព្រះអង្គបានទប់តម្លៃទំនិញផ្សេងៗ ដើម្បីបំបាត់ការប្រកួតប្រជែងនិងបន្ថយការវិនិយោគរបស់បរទេស ។ នៅពេលដែលប្រទេសថៃកំពុងមានសន្ទុះរីកលូតលាស់ ដោយសារកិច្ចការជំនួញ និងជំនួយរបស់អាមេរិកាំងភ្ជាប់នឹងសង្គ្រាម ប្រទេសកម្ពុជាបែរជាមានអត្រារីកលូតលាស់ទាបមួយប្រមាណប្រាំភាគរយប៉ុណ្ណោះ ។ សម្រាប់សហគមន៍អ្នករកស៊ីតូចតាចរបស់ប្រទេស សម្រាប់ក្រុមវរជន និងវណ្ណៈកណ្តាល នៅក្រុងភ្នំពេញ នេះជាការបន្ទំភ្នែកមួយហើយ គឺពួកគេនេះឯង ដែលដើរតួនាទីជាគន្លឹះមួយក្នុងរដ្ឋប្រហារនៅឆ្នាំ១៩៧០ ។

អ្វីៗហាក់ដូចជាគ្មានន័យទាំងអស់ ។ កុម្ភួត និងមិត្តភក្តិទាំងឡាយរបស់គាត់ ពិតជាពិបាកស្វែងយល់ពីព្រឹត្តិការណ៍ផ្សេងៗណាស់ ។ ឪពុក-ម្តាយ មិត្តភក្តិរបស់ពួកគេ, ពួកអ្នកនយោបាយ និងសម្តេច ព្រះនរោត្តម សីហនុ ផ្ទាល់បាននិយាយនិងមានព្រះបន្ទូលផ្ទុយគ្នាស្តីពីសង្គ្រាម និងអនាគតប្រទេសកម្ពុជា ។ ប្រទេសជាតិត្រូវបែកជាបក្សជាពួក យ៉ាងហោចក៏នៅក្រុងភ្នំពេញដែរ ។ កុម្ភួត យល់ឃើញអនាគតរបស់ខ្លួនត្រូវគំរាមកំហែងមិនត្រឹមតែដោយសារសង្គ្រាមនៅវៀតណាមប៉ុណ្ណោះទេ ប៉ុន្តែ ដោយការជ្រើសរើសមានកំណត់ដែលប្រទេសរបស់សម្តេច ព្រះនរោត្តម សីហនុ ផ្តល់ឲ្យគាត់ ។

នៅឆ្នាំ១៩៦៣ គឺក្នុងកាលៈទេសៈនេះហើយ ដែលកុម្ភួតបានចេញដំណើរទៅសិក្សានៅបរទេស ។ គាត់មានបំណងគេចឲ្យផុតពីការរស់នៅចង្អៀតចង្អល់ និងកាន់តែតានតឹងឡើងៗនៅទីក្រុងភ្នំពេញ ។ គាត់បានសម្រេចចិត្តធ្វើដំណើរទៅឲ្យឆ្ងាយពុំមែននៅប្រទេសបារាំងដូចបណ្តាមិត្តភក្តិភាគច្រើនរបស់គាត់ទេ ប៉ុន្តែទៅប្រទេសកាណាដា ជាទីដែលគាត់បានបន្តការសិក្សាដំបូងនៅសកលវិទ្យាល័យឡាវ៉ាល់ បន្ទាប់មក នៅសកលវិទ្យាល័យម៉ាក់ហ្ស៊ីល ដោយនៅតែបន្តការទាក់ទងគ្នា (តាមសំបុត្រឆ្លើយឆ្លង) ជាមួយគ្រួសារ និងមិត្តភក្តិទាំងឡាយនៅ

ប្រទេសកម្ពុជាដដែល ។ កុម្ពូត ស្ថិតនៅប្រទេសកាណាដា នៅពេលដែលសហរដ្ឋអាមេរិកចាប់ផ្ដើមបញ្ជូនទ័ពយ៉ាងច្រើនមកប្រទេសវៀតណាម នៅឆ្នាំ១៩៦៥ ហើយដែលធ្វើឲ្យគាត់នឹកភ័យខ្លាច ។ ពីប៉័ស្ដិ៍សង្កេតពិនិត្យរបស់គាត់ គាត់បានប្រមាណពីកម្លាំងរបស់អាមេរិក ដែលគាត់មិនធ្លាប់វាយតម្លៃសោះនៅប្រទេសបារាំង ហើយយល់ច្បាស់ពីភាពពុះពោរនៃការប្រឆាំងតទល់នឹងកុម្មុយនិស្តរបស់ពួកអាមេរិកាំង ។ ប៉ុន្តែ ជាជំនួសធ្វើឲ្យគេស្គាល់ខ្លួនក្នុងការជជែកពិភាក្សាស្ដីពីសង្គ្រាម គាត់រកឃើញថា ការចាប់អារម្មណ៍របស់គាត់ចំពោះនយោបាយ បានត្រូវធ្វើឲ្យចុះអន់ថយ ។

នៅប្រទេសកាណាដា កុម្ពូតបានបង្ហាញគំនិតខ្លួនដែរថា គាត់មានបំណងសិក្សាខាងផ្នែកសេដ្ឋកិច្ច ។ គាត់បានស្រាវជ្រាវពីទ្រឹស្ដីផ្សេងៗរបស់លទ្ធិសង្គមនិយម និងមូលធននិយមដោយសម្គាល់ឃើញការជជែកពិភាក្សា (ខាងនយោបាយ) ក្នុងប្រទេសរបស់គាត់នៅតែមានកម្រិតដូចសម័យដើមនៅឡើយ ។ បន្ទាប់មក គាត់យកចិត្តទុកដាក់នៅខាងផ្នែកសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងការគ្រប់គ្រងផ្នែកពាណិជ្ជកម្មវិញ ។ ការរៀនសូត្ររបស់គាត់ត្រូវបានបញ្ចប់ ហើយគាត់បានវិលត្រឡប់មកប្រទេសកម្ពុជាវិញនៅឆ្នាំ១៩៦៨ ។ គាត់ចាកចេញពីប្រទេសកាណាដាក្នុងពេលដែលចលនាប្រឆាំងសង្គ្រាមរបស់អាមេរិកាំងរីករាលដាល ហើយដែលចំនួនទាហានអាមេរិកាំងស្លាប់នៅប្រទេសវៀតណាមកើនឡើង ។ គាត់ចាប់ផ្ដើមជឿជាក់ក្នុងចិត្តថា មធ្យោបាយប្រសើរជាងគេក្នុងការជួយប្រទេសរបស់គាត់ គឺប្រឹងប្រែងបង្កើតសេដ្ឋកិច្ចខ្លាំងមួយ ពុំមែនចូលរួមក្នុងការជជែកពិភាក្សានយោបាយមិនចេះចប់នេះហើយនោះទេ ។

ប៉ុន្តែនៅពេលមកដល់ប្រទេសរបស់គាត់ កុម្ពូតដឹងខ្លួនថា គំនិតថ្មីៗរបស់គាត់ពុំសូវឃើញមានប្រើប្រាស់ក្នុងប្រទេសកម្ពុជារបស់សម្ដេច ព្រះនរោត្តម សីហនុ ទេ ។ នៅឆ្នាំ១៩៦៨ កម្មវិធីជាតូបនីយកម្មរបស់សម្ដេចបានចូលជា ធរមានតាំងពីប្រាំឆ្នាំមកហើយ និងបានធ្វើមនុស្សគ្រប់គ្នាខកចិត្តជាខ្លាំង ។ សម្ដេច ព្រះនរោត្តម សីហនុ បានរឹបយកសហគ្រាសនានាពីពួកអ្នកជំនួញ ហើយប្រគល់ទៅឲ្យពួកអ្នកធ្វើការដែលមានបៀវត្សរ៍ទាប និងគ្មានសមត្ថភាពកាន់កាប់វិញ ។ គាត់បានល្បងបង្កើតរដ្ឋ-អ្នកឧបត្ថម្ភមួយ (Etat-providence) ដោយគ្មានក្រដាសប្រាក់ និងការគាំទ្រនយោបាយចាំបាច់ ។ នៅឆ្នាំ១៩៦៧ គាត់បានរលាស់ចោលមេដឹកនាំនិយមឆ្វេងសំខាន់ៗ បន្ទាប់មកគាត់បែរមកពឹងពាក់ក្រុមនិយមស្ដាំវិញ ដើម្បីឲ្យដឹកនាំអនុវត្តកម្មវិធីសង្គមនិយមរបស់គាត់ ។ គ្មានអ្នកណាម្នាក់ចង់ធ្វើតាមកុម្ពូតទេ នៅពេលដែលគាត់ស្នើបង្កើតសហគ្រាសសេដ្ឋកិច្ចចម្រុះថ្មីៗ ៖ សង្គ្រាមនៅវៀតណាម និងស្ថានការណ៍នយោបាយតឹងតែងទាល់ច្រកនៅកម្ពុជា គឺជាបុព្វហេតុតែមួយគត់ ដែលគួរឲ្យធ្វើការពិនិត្យពិច័យ ។

កុម្ពូតបានឈានជើងចូលក្នុងពិភពធនាគារ-នៅក្រុងភ្នំពេញ ជាពិភពនៃធនាគារដែលត្រូវធ្វើជាតូបនីយកម្ម ។ ដោយមិនអាចប្រឆាំងបាន គាត់ត្រូវអូសទាញឲ្យចូលក្នុងការជជែកពិភាក្សា (ខាងនយោបាយ) ជាថ្មីម្ដងទៀត ហើយក្នុងរយៈពេលពីរឆ្នាំ ដែលមានជាបន្ត ដំណើររស់នៅរបស់គាត់ ក៏ដូចជាដំណើររស់នៅរបស់សមាជិក

ភាគច្រើននៃក្រុមវរជននៅរាជធានីដែរ ដែលជាអ្នកប្រមូលនិងផ្សាយពាក្យចចាមអារ៉ាមផ្សេងៗអំពីសង្គ្រាម ។ សម្ដេច ព្រះនរោត្តម សីហនុ នៅពេលនេះបានមានព្រះបន្ទូលខ្លាំងៗយ៉ាងចេញមុខ ប្រឆាំងនឹងពួកខ្មែរក្រហម ដែលព្រះអង្គចោទថា មានបំណងអូសទាញប្រទេសកម្ពុជាឲ្យធ្លាក់នៅក្នុងសង្គ្រាមនៅប្រទេសវៀតណាម ។

កុម្ហួត និងបណ្ដាមិត្តភក្ដិរបស់គាត់ មិនជឿការចោទប្រកាន់របស់សម្ដេចប្រឆាំងនឹងក្រុមនិយមឆ្វេងទេ ហើយអ្នកខ្លះក្នុងចំណោមនោះ បានចាកចេញពីរាជធានី ដើម្បីទៅរួបរួមនឹងពួកខ្មែរក្រហមរួចទៅហើយ ។ អ្នកខ្លះទៀត ស្ថិតនៅក្នុងរាជធានីដដែល និងរង់ចាំមើលដោយខ្លាចក្រែងថា ការវាយប្រយុទ្ធទាំងអស់អាចទាក់ទាញសហរដ្ឋអាមេរិក ឬវៀតណាមមកកាន់ប្រទេសកម្ពុជា-ឬប្រទេសទាំងពីរផងក៏មិនដឹង ។ កុម្ហួត ជាចំណែកមួយនៃក្រុមចុងក្រោយនេះ ដែលជាក្រុមខាងភាគច្រើន ។ ទោះបីជាគាត់មានកំហឹងនឹងសម្ដេច ព្រះនរោត្តម សីហនុក៏ដោយ ក៏ធនាគារិករូបនេះ បានបន្តអបអរសរសើរពាក្យសន្យារបស់សម្ដេច ដែលនឹងធ្វើឲ្យប្រទេសស្ថិតនៅដោយឡែកពីសង្គ្រាមនៅវៀតណាមដែរ ។

ពាក្យចចាមអារ៉ាមថ្មីៗបានលេចឮសុសសាយក្នុងរាជធានី ។ នៅឆ្នាំ១៩៧០ គេខ្សឹបខ្សៀវថា សម្ដេច ព្រះនរោត្តម សីហនុ បានចងសម្ព័ន្ធភាពជាមួយពួកកុម្មុយនិស្តវៀតណាម ហើយបានអនុញ្ញាតឲ្យពួកនេះតាំង "ទីជម្រក" នៅកម្ពុជា ។ ក្នុងតំបន់ជនបទនានា ពួកខ្មែរក្រហមបានបង្ហាញឲ្យឃើញភាពចេញមុខកាន់តែខ្លាំងឡើងក្នុងការប្រឹងប្រែងរបស់ពួកគេ ដើម្បីបង្កឲ្យមានការបះបោរមួយរបស់កសិករប្រឆាំងនឹងក្រុងភ្នំពេញ ។ ទីក្រុងបានប្រុងប្រៀបខ្លួនចំពោះការប្រឈមមុខតទល់គ្នា ដែលច្បាស់ជាមកដល់ក្នុងពេលឆាប់ៗ ។

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ក្រុមនិយមស្ដាំបានរៀបចំរដ្ឋប្រហារមួយប្រឆាំងនឹងសម្ដេច ព្រះនរោត្តម សីហនុ ។ កុម្ហួត និងបណ្ដាមិត្តភក្ដិរបស់គាត់ មានចិត្តសប្បាយរីករាយជាខ្លាំង ពីព្រោះពួកគេពិនិត្យឃើញព្រឹត្តិការណ៍មួយ ដែលអាចប្រៀបធៀបបាននឹងការបង្កើតរបបសាធារណរដ្ឋនៅប្រទេសបារាំងដែរ ។ មែនហើយពួកមេៗនៃការរួមគំនិតគ្នាធ្វើរដ្ឋប្រហារ បានសន្យាបង្កើតសាធារណរដ្ឋខ្មែរមួយ ដែលនឹងមានលក្ខណៈទាន់សម័យប្រជាធិបតេយ្យ និងអព្យាក្រឹតពិតប្រាកដ ។ ទីក្រុងភ្នំពេញពោរពេញ ទៅដោយការសប្បាយរីករាយជាខ្លាំង ៖ គេនឹងផ្លាស់ជំនួសរបបពុករលួយមួយ ហើយអួតអំពីការបណ្ដោយឲ្យធ្វើអ្វីៗតាមចិត្ត ដោយរដ្ឋាភិបាលស័ក្តិសិទ្ធិស្អាតស្អំ និងទាន់សម័យមួយ ។ ប្រការនេះទំនងជាថ្ងៃថ្នូរណាស់ នៅពេលទៅជាការពិត -សាធារណរដ្ឋមួយដោយឥតមានបដិវត្តន៍ គ្មានការប្រទាញឲ្យធ្លាក់ក្នុងភ្លើងសង្គ្រាមនៅវៀតណាម ។

ការយល់ច្រឡំទាំងនេះ មិនមានថិរវេលារហូតដល់ឆ្នាំចុងឆ្នាំឡើយ ហើយមិនយូរប៉ុន្មាន វាលេចឡើងឲ្យឃើញថា រដ្ឋប្រហារត្រូវបានដឹកនាំជាសារវន្ត ដោយមនុស្សពីរនាក់ គឺព្រះអង្គម្ចាស់ សិរិមតៈ និងឧត្តមសេនីយ លន់ នល់ ។ សិរិមតៈ ជាទាយាទខាងខ្សែ ស៊ីសុវត្ថិ នៃព្រះរាជវង្សានុវង្សខ្មែរ ដែលតាមរយៈម្ខាងនោះ ពួកបារាំងបានប្រគល់រាជបល្ល័ង្កទៅឲ្យសម្ដេច ព្រះនរោត្តម សីហនុ ឡើងគ្រងរាជ្យ នៅឆ្នាំ១៩៤១ទៅវិញ ។ សិរិមតៈ ជាគូ

ប្រដែនរបស់សម្តេច ព្រះនរោត្តម សីហនុ និងផ្ទុយពីព្រះអង្គដោយហេតុថាព្រះអង្គម្ចាស់សព្វព្រះទ័យនឹងពិភព ជនួញ និងសហរដ្ឋអាមេរិក ។ ចំពោះរឿងនេះ ព្រះអង្គម្ចាស់បានចងសម្ព័ន្ធនឹងពួកអាមេរិកាំងដែលប្រជាជនកម្ពុជា មួយចំនួនសន្មតថា ព្រះអង្គម្ចាស់ ប្រហែលបានទទួលការយល់ព្រមពីពួកអាមេរិកាំងដើម្បីធ្វើរដ្ឋប្រហារ និងពាក្យ សន្យាគាំទ្រមួយហើយមើលទៅ ។ សិរិមតៈ ជាតំណាងភាពទំនើបទាន់សម័យ ភាពប៉ិនប្រសប់ ចំណងជាមួយនឹង ជំនួយអាមេរិកាំងនេះ ដែលសម្តេច ព្រះនរោត្តម សីហនុ បានប្រានចោល ។ ព្រះអង្គម្ចាស់ជាតួអង្គមួយ ដែលធ្វើ ឲ្យមនុស្សជាច្រើនដូចជា កុម្ពុត ជាដើម ចូលចិត្តយ៉ាងខ្លាំង ហើយបណ្តាសមាជិកនៃអ្នកមានវិជ្ជាជីវៈសេរី នៅក្រុងភ្នំពេញសម្គាល់ឃើញព្រះអង្គម្ចាស់ថា ជាអ្នកស្រោចស្រង់ប្រទេសជាតិ ។

លន់ នល់ ជាឥស្សរជនម្នាក់ដែលមានមុខយូរមកហើយ ។ ជាមេប៉ូលិសរបស់សម្តេច ព្រះនរោត្តម សីហនុ និងជាមេដឹក នាំកងទ័ពក្នុងរយៈពេលជាច្រើនឆ្នាំ គាត់ត្រូវបានចាត់ទុកជាមនុស្សឥតខ្វោះទីពីររបស់ សិរិមតៈ ។ គឺ លន់ នល់ ដែលញុះកងទ័ពឲ្យប្រឆាំងសម្តេច ព្រះនរោត្តម សីហនុ ។ ជាមនុស្សដែលចេះលំឱនតាមបំណងអ្នកដទៃ គាត់ធ្លាប់បានដឹកនាំគណៈប្រតិភូជាច្រើនលើកទៅក្រុងប៉េកាំង ដើម្បីបង្កើតទំនាក់ទំនងដ៏ជិតស្និទ្ធជាមួយពួក កុម្មុយនិស្តចិន ហើយឥឡូវនេះ បានចេញមុខចាត់ចែងធ្វើការងារសម្រាប់ សិរិមតៈ វិញម្តង ។

កុម្ពុត និងបណ្តាមិត្តភក្តិរបស់គាត់ បានសម្តែងឃើញភាពឆោតល្ងង់បំផុត ព្រោះថារដ្ឋប្រហារបាននាំមកនូវ សង្គ្រាម ពុំមែននាំសន្តិភាពមកឲ្យប្រទេសទេ ។ ម្យ៉ាងវិញទៀត ពុំមែន សិរិមតៈ ទេ ដែលកាន់អំណាច ប៉ុន្តែគឺ លន់ នល់ ទៅវិញដែលក្លាយទៅជាមនុស្សចំបងគេនៃរបបផ្តាច់ការមួយ ។

ពីរ-បីថ្ងៃបន្ទាប់ពីការបង្កើតរបស់ខ្លួន សាធារណរដ្ឋខ្មែរត្រូវបានអូសទាញឲ្យធ្លាក់ទៅក្នុងជម្លោះ ព្រំដែន ដែលបង្កឡើយភ្លាមៗដោយពួកកុម្មុយនិស្តវៀតណាម ។ គាត់បានអំពាវនាវឲ្យកងទ័ពកម្ពុជាទាំងអស់ ដែលមិន ទាន់មានលទ្ធភាពគ្រប់គ្រាន់រួមគ្នាប្រយុទ្ធទល់នឹងសត្រូវ ។ នៅខែឧសភា សហរដ្ឋអាមេរិកបានចូលលុកលុយ ប្រទេសកម្ពុជា ក្នុងគោលបំណងដេញតាមពួកកុម្មុយនិស្តវៀតណាម ។ ប្រជាកសិករបានធ្វើបាតុកម្មក្នុងខេត្ត ជាច្រើនដើម្បីទាមទារឲ្យសម្តេចវិលត្រឡប់មកវិញ ។ នៅទីក្រុងប៉េកាំង សម្តេចបានទទួលយល់ព្រមធ្វើជា មេដឹកនាំរណសិរ្សមួយ ក្នុងគោបំណងវាយប្រយុទ្ធទល់នឹងសាធារណរដ្ឋខ្មែរថ្មី ដែលតាមពិត ព្រះអង្គបម្រើជា ដំបូលបាំងពួកខ្មែរក្រហមសោះ ។

កុម្ពុត ត្រូវការរយៈពេលជាច្រើនខែ ដើម្បីស្វែងយល់ពីភាពឆោតល្ងង់របស់ខ្លួន ។ គាត់បានយល់ព្រម បំពេញបេសកកម្មខ្លីមួយ ដោយធ្វើដំណើរទៅបរទេស ដើម្បីជួយគាំទ្របុព្វហេតុរបស់សាធារណរដ្ឋថ្មី និងបញ្ចប់ ពាក្យចចាមអារ៉ាមផ្សេងៗ ដែលថារដ្ឋប្រហារនោះ ត្រូវបានរៀបចំឡើងដោយពួកមេទាហាន ដែលនៅក្រោម បង្គាប់ពួកអាមេរិកាំង ហើយដែលប្រញាប់ចង់នាំប្រទេសឲ្យធ្លាក់ទៅក្នុងភ្លើងសង្គ្រាមនៅវៀតណាម ។ គេជ្រើស រើសគាត់ ពីព្រោះគាត់ជាខ្មែរម្នាក់ក្នុងចំណោមជនជាតិខ្មែរដ៏កម្រ ដែលចេះនិយាយអង់គ្លេស ។

ពីរ-បីខែក្រោយមក នៅពេលគាត់ត្រឡប់មកវិញ ទើប កុម្ហួត ដឹងខ្លួនពីដំណើរខុះគំនិត និងសេចក្ដីត្រិះរិះទាំងស្រុងរបស់គាត់ ។ លន់ នល់ បានដណ្ដើមអំណាច (ដោយប្រើឧបាយកល) ស្ទើរតែ ទាំងអស់ទៅហើយ ។ ដោយពិត លន់ នល់ បានធ្វើឲ្យបរិយាកាសនៅរដ្ឋធានីផ្លាស់ប្ដូរ ដូចដែលគាត់បានសន្យា ប៉ុន្តែទីក្រុងឥឡូវនេះរឹតតែពុករលួយជាងនៅក្រោមរបបសម្ដេច ព្រះនរោត្តម សីហនុទៅទៀត ហើយអ្វីដែលត្រូវលើកយកមកពិភាក្សា ពុំមែនទំនើបភាវូបនីយកម្មទេ ប៉ុន្តែគឺសង្គ្រាមទៅវិញ ។ លន់ នល់ ស្នើសុំជំនួយយោធាពីសហរដ្ឋអាមេរិក ហើយជាថ្នូរទៅវិញ គាត់ដាក់ជោគវាសនារបស់ប្រទេសកម្ពុជា ក្នុងកណ្ដាប់ដៃពួកអាមេរិកាំង ។

កុម្ហួត ចាប់ផ្ដើមនឹកក្នុងចិត្តថា ពាក្យចចាមអារ៉ាមទាំងអស់សុទ្ធតែមានមូលហេតុ តើសហរដ្ឋអាមេរិក ឃុបឃិតគ្នារៀបចំរដ្ឋប្រហារ តើ សិរិមតៈ ឬ លន់ នល់ ឬទាំងពីរនាក់ត្រូវអាមេរិកផ្ដល់លុយឲ្យមែនឬ ។ មិត្តភក្ដិទាំងអស់របស់គាត់មានយោបល់មួយ គ្មានអ្នកណាម្នាក់មានចម្លើយទេ ។ ដោយដឹងខ្លួនត្រូវគេបំពាន អំណឹះតទៅ គាត់បដិសេធចំណងទាក់ទងផ្លូវការទាំងអស់ជាមួយសាធារណរដ្ឋខ្មែរ ដោយប្រមូលផ្ដុំគំនិតទៅលើអាជីពរបស់គាត់ ហើយខំធ្វើការដើម្បីឡើងបុណ្យសក្តិនៅធនាគារពាណិជកម្មខ្មែរវិញ ។

នៅខាងក្រៅកន្លែងធ្វើការរបស់ កុម្ហួត ទីក្រុងបានប្រែប្រួលប្លែកពីមុន ។ មហាវិថីទាំងឡាយ សុទ្ធតែគុបតែងដោយរបងខ្សែលួសបន្លា ។ ពួកនាយទាហានដែលមានឯកសណ្ឋានកាគីបានចូលពាសពេញហាងកាហ្វេនានា បើកបរឡានហ្សីបយ៉ាងអស់លឿនឆ្លងកាត់រដ្ឋធានី ដោយបន្ហុយដីទ្រលោមពីក្រោយ និងធ្វើឬកពាដូចស្ដេចត្រាញ់សង្គ្រាមតូចតាច ។ នាយទាហានខ្លះក្នុងចំណោមនោះ សុទ្ធតែជាមិត្តភក្ដិរបស់កុម្ហួត ដែលសម្រេចចិត្តប្រកបអាជីពក្នុងវិស័យមួយដែលរកកម្រៃក្រៅបានយ៉ាងច្រើន ហើយដែលកំពុងរីករាលដាលពេញទំហឹងនៅក្នុងកងទ័ព និងរដ្ឋាភិបាលថ្មី ។ គាត់នៅតែទាក់ទងជាមួយអ្នកទាំងនោះ ហើយពេញរយៈពេលនៃសង្គ្រាម គេបានឃើញគាត់ផឹកស្រានៅបានីយដ្ឋានសណ្ឋាគារឡឺភ្នំ (អតីតសណ្ឋាគាររ៉ូយ៉ាល់) ជាមួយនាយទាហានមួយក្រុម ដែលបរិភោគអាហារថ្ងៃត្រង់នៅភោជនីយដ្ឋាន ប៉ារីស (Café de Paris) ជាមួយមន្ត្រីជាន់ខ្ពស់នៃក្រសួងការបរទេស ។

ជាមនុស្សគួរឲ្យស្រឡាញ់ ចូលចិត្តចេញដើរលេងនិងតែងស្លៀកពាក់ស្អាតបាតជានិច្ចនោះ កុម្ហួត គឺជាអ្នកដែលត្រូវគេទទួលស្វាគមន៍ក្នុងការជួបជុំគ្នាប្រភេទនោះ ។ គាត់បានបញ្ចូលខ្លួនទៅក្នុងមជ្ឈដ្ឋាន ដែលមានអំណាចជាច្រើន ទាំងខ្មែរក៏ដូចបរទេស ហើយយកចិត្តទុកដាក់យ៉ាងពេញលេញ ចំពោះជោគវាសនារបស់គាត់ ដើម្បីនិយាយព្រោកប្រាជ្ញគ្នាទៅវិញទៅមក ក្នុងសេចក្ដីសង្ឃឹមស្វែងរកចម្លើយផ្សេងៗ ។ រឿងតែមួយគត់ដែលផ្ដល់លក្ខណៈឲ្យគាត់ខុសពីគេ គឺគាត់កម្របញ្ចេញឲ្យដឹងយោបល់ណាមួយណាស់ ។ គាត់ទុកចិត្តលើមនុស្សតិចតួច ហើយចូលចិត្តឃ្លាំមើលជាង ដោយមិនចូលរួមឡើយ ។

នៅពេលដំបូង សង្គ្រាមមិនសូវធ្វើឲ្យរបៀបរស់នៅរបស់ កុម្ហួត ផ្លាស់ប្ដូរទេ ។ រហូតដល់មានការប្រែប្រួលខ្លាំងនៅឆ្នាំ១៩៧៣ ការប្រយុទ្ធគ្នាបានបង្ហាញឲ្យឃើញលក្ខណៈដែលធ្វើឲ្យភ្ញាក់ផ្អើល ចម្លែក និងគួរឲ្យព្រឺខ្លាច

មួយ ។ នៅខាងក្រៅ ប្រជាជនកម្ពុជាសើចញញឹម ពោលពាក្យចំអន់គ្នាលេងយ៉ាងសប្បាយ ។ អ្វីដែលប្រជាជនចាត់ទុកដូចការជជែកពិភាក្សាខាងនយោបាយ ជាទូទៅច្រើនបែរទៅរកការផ្លាស់ប្តូរសម្តីរអេចរអូចទៅវិញ ។ គ្មានមិត្តភក្តិណាម្នាក់របស់កុម្ពូតយល់ពីអត្ថន័យ និងទំហំនៃជម្លោះឡើយ ៖ ហេតុអ្វីបានជាប្រទេសកម្ពុជា ត្រូវបញ្ចូលទៅក្នុងសង្គ្រាមវៀតណាម ឬក្នុងគោលដៅ របស់ពួកអាមេរិកាំងដែលសុទ្ធតែជាគូសត្រូវពិតប្រាកដ អ៊ីចឹង? ក្នុងពេលដ៏ណាលគ្នាដែល កុម្ពូត អាចយល់ដឹងពីរឿងនេះ មនុស្សទូទៅនៅស្រុកស្រែចម្ការពុំទាន់រងផលប៉ះពាល់ពីសង្គ្រាមនៅឡើយទេ ។ ភាគច្រើនក្នុងចំណោមនោះ នៅតែជឿថាសម្តេច ព្រះនរោត្តម សីហនុ គ្រប់គ្រងលើផ្ទៃប្រទេសពីទីក្រុងភ្នំពេញទៅ ។ ពួកបរទេសសម្គាល់ឃើញក្នុងភាពខ្វះការយល់ដឹងកិច្ចការផ្សេងៗ ឬក្នុងភាពមិនអើពើនូវភ័ស្តុតាងមួយ ដែលមិនមានលក្ខណៈធ្ងន់ធ្ងរ ឬគ្រោះថ្នាក់ ដូចក្នុងប្រទេសវៀតណាមក្បែរខាងឡើយ ។

កុម្ពូត ជឿតាមពាក្យពួកបរទេស-អាមេរិកាំង និងបារាំង-ដែលពិពណ៌នាពីក្រុងភ្នំពេញ និងសង្គ្រាមថាជាកន្លែងដែលកើតមានព្រឹត្តិការណ៍ឥតន័យមួយ ។ ពួកនាយទាហានជាន់ខ្ពស់អាមេរិកាំងបាននិយាយពីទាហានកម្ពុជាថាជា "កូនខ្លា" របស់ពួកគេ ទោះបីជានៅពេលពួកគេចាញ់ការប្រយុទ្ធពីសមរភូមិមួយ ទៅសមរភូមិមួយក៏ដោយ ។ កងទ័ពរបស់កម្ពុជាដែលកំពុងប្រយុទ្ធពាក់ផ្លាកសញ្ញាអក្សររបស់គាត់ "គួរឲ្យចង់សើច" កងយោធពលខេមរជាតិ និងវណ្ណសិរ្សប្រមូលជាតិកម្ពុជា ។ ទាហានរបស់ លន់ នល់ សុទ្ធតែជាមនុស្សរចម្លែកដែលកំពុងចេញទៅវាយប្រយុទ្ធដោយបៀមរូបព្រះ, ខ្សែគាថា ទាហានមួយចំនួនតូចបានបុកទម្លុះទ័ពសត្រូវ បន្ទាប់ពីបានជក់កញ្ឆាមួយខ្សៀ ។ អគ្គបញ្ជាការកងទ័ពរបស់ លន់ នល់ ជាឧត្តមសេនីយតូចតាចម្នាក់ ដើមកំណើតខ្មែរ-ហ្វីលីពីន ឈ្មោះ សូស្តែន ហ្វែរណង់ដេស ធ្លាប់បានស្ថាបនាសម្រាប់ការិយាល័យរបស់គាត់នូវអគារធុនតូចមួយ ដែលធ្វើឲ្យចាប់អារម្មណ៍ពីអំនួតរបស់គាត់ ដោយរៀបចំឲ្យវាលេចឡើងឲ្យឃើញធំជាងគេបំផុត ។ ពាក្យចំអន់ប្រសើរជាងគេសម្រាប់ពួកអាមេរិកាំង គឺឈ្មោះអ្នកនាំពាក្យកងទ័ព អាំ រ៉ុង *(Am Rong: I am wrong:* *ខ្ញុំយល់ខុស)* ។ ពួកបរទេសសុទ្ធតែត្រូវធ្វើឲ្យរំភើបចិត្ត ដោយលក្ខណៈដែលហាក់ដូចជាពាយផាយ ឬក្លែងបន្លំនៅប្រទេសកម្ពុជា ។

កុម្ពូត ហាក់ដូចជាដឹងខ្លួនថា លែងយល់ពីប្រទេសរបស់គាត់ទៀតហើយ ។ គាត់ដឹងថាពួកបរទេសមិនអាចសម្រេចរកឲ្យឃើញច្បាស់ពីការពិតនៅប្រទេសកម្ពុជាបានទេ ប៉ុន្តែ ក៏មិនអាចកំណត់ដោយច្បាស់លាស់អំពីកលល្បិចនៃសង្គ្រាមបានដែរ គឺនេះហើយជារឿងដែលប្រជាជនកម្ពុជាវាយប្រយុទ្ធគ្នា ។ មិត្តភក្តិទាំងឡាយរបស់គាត់ហាក់ដូចជាត្រូវធ្វើឲ្យហេងហាងក្នុងចិត្ត ។ លន់ នល់ មានបុកពាជាអ្នកកាន់អំណាចផ្តាច់ការដែលជឿជំនឿមិនសមហេតុផល ៖ តាមពាក្យណែនាំរបស់បព្វជិតជាគ្រូសំណព្វរបស់គាត់ គាត់បានឲ្យគេបាចរោយ "ខ្សាច់មន្ត" ជុំវិញទីក្រុងដើម្បីបញ្ចៀសឲ្យសត្រូវទៅឆ្ងាយ ។ ម្យ៉ាងទៀត គាត់មានអាកប្បកិរិយារើសអើងជាតិសាសន៍ដែលអាចផ្តល់គ្រោះថែមទៀត ដោយជឿជាក់ពីភាពខ្ពស់លើសគេនៃប្រជាជនខ្មែរលើពួកវៀតណាម ។ កុម្ពូត មិនអាច

គោរពមនុស្សម្នាក់បែបនោះទេ ហើយរឹតតែមិនបណ្តោយឲ្យគាត់ដឹកនាំថែមទៀត ហើយបណ្តាមិត្តភក្តិគាត់មួយចំនួនក៏មាននិន្នាការដូចគាត់ដែរ ។

ចាប់ពីឆ្នាំ១៩៧១ ពួកអ្នកដែលមានបុព្វសិទ្ធិនៅទីក្រុងភ្នំពេញបានចាប់ផ្តើមចាកចេញពីប្រទេស ។ គ្រូពេទ្យ បញ្ញវន្តនិងពួកអ្នកប្រកបវិជ្ជាជីវៈសេរី បានភៀសខ្លួនទៅជ្រកនៅប្រទេសបារាំង ពួកដែលស្ថិតនៅទីនោះរួចមក ហើយបានស្ថិតនៅបន្តទៅទៀត ។ ចំណែក កុម្ហួត មិនដែលគិតចង់ចាកចេញពីប្រទេសសោះឡើយ ។ គាត់បញ្ជាក់ប្រាប់មិត្តភក្តិទាំងឡាយរបស់គាត់ថា "នេះជាប្រទេសខ្ញុំ ខ្ញុំនឹងរង់ចាំទីបញ្ចប់នៃសង្គ្រាម" ។

លន់ នល់ បានព្យួរសេរីភាពក្នុងការសម្តែងមតិដូចដែលសម្តេច ព្រះនរោត្តម សីហនុ ធ្លាប់ធ្វើដែរ ។ កុម្ហួត ធ្លាប់ដឹងរឿងនេះពីមុនមកហើយ ប៉ុន្តែ ក្នុងពេលជាមួយគ្នានោះ គាត់មិននឹកស្មានថាអំពើពុករលួយបានកើតមានជាទូទៅឡើយ ។ ក្នុងពេលប្រទេសមានសង្គ្រាម កងទ័ពបានក្លាយទៅជាកន្លែងរកលុយបានច្រើនជាងគេរបស់សង្គម -អ្នកដែលមានលទ្ធភាពលួចលុយរាប់លានដុល្លារពីជំនួយរបស់អាមេរិកាំង- និងជាកន្លែងដែលប្រព្រឹត្តបទឧក្រិដ្ឋខ្លាំងជាងគេបំផុត ។ ពួកឧត្តមសេនីយ បាននាំមុខដំណើររស់នៅបែបអនាចារមួយយ៉ាងចេញមុខ ផឹកស្រាកូញាក់លាយសូដាមុនពេលថ្ងៃត្រង់ ទម្លាប់កសាងគេហដ្ឋានធ្វើពីស៊ីម៉ង់ត៍ធំៗ នាំចូលរថយន្តទំនើបៗ បើកគណនេយ្យនៅធនាគារប្រទេសស្វីស ជាមួយលុយដែលលួចបានពីសហរដ្ឋអាមេរិក និងពីកងទ័ពផ្ទាល់របស់ពួកគេ ។

ក្នុងឋានៈគាត់ជាធនាគារិក និងជាអ្នកដែលមនុស្សទូទៅទុកចិត្តលើគាត់ កុម្ហួត បានត្រឹមតែដឹងច្រើនពីរឿងអាស្រូវទាំងនេះប៉ុណ្ណោះ ។ រឿងអាស្រូវខ្លះក្នុងចំណោមរឿងអាស្រូវជាច្រើនត្រូវបានបផ្សាញ និងបរិហារយ៉ាងវែងក្នុងសារពត៌មានអន្តរជាតិ ប៉ុន្តែគ្មានលទ្ធផលជាដុំកំភួនទេ ។ មធ្យោបាយកិបកេងលុយរបស់ពួកយោធាមានគ្រប់រូបភាព ។ ឧទាហរណ៍ដូចជា ពួកនាយទាហានបានដាក់ឈ្មោះទាហានខ្មោចជាច្រើន ក្នុងបញ្ជីបើកប្រាក់ខែ ។ ពួកគេបញ្ចេញសម្ភារៈសឹករបស់ពួកទាហានខ្លួនទៅលក់នៅផ្សារងងឹត លក់ទៅឲ្យពួកខ្មែរក្រហមនូវគ្រាប់រំសេវដែលសហរដ្ឋអាមេរិកផ្តល់ឲ្យ យកលុយសម្រាប់ផ្គត់ផ្គង់ភស្តុភារ ដាក់ហោប៉ៅខ្លួនឯង ហើយទុកឲ្យកូនទាហានស៊ីអត់ស៊ីឃ្លាន ។

ធនធានសម្រាប់ការរស់នៅរបស់កុម្ហួត គឺពឹងផ្អែកលើជំនួយសប្បុរសធម៌របស់អាមេរិកាំងទាំងស្រុង ។ ធនាគាររបស់គាត់ ក៏ដូចជាធនាគារដទៃទៀតទាំងអស់ដែរ បានបំពេញផលកម្រៃតាមរយៈកម្មវិធីប្រាក់ជំនួយមួយរបស់អាមេរិកាំង ដែលផ្គត់ផ្គង់ជារូបិយប័ណ្ណសុទ្ធសម្រាប់ការនាំចូលរបស់កម្ពុជា ។ នៅពេលដែលកុម្ហួតរួបរួមគ្នាជាមួយនឹងធនាគានិក និងអ្នកជំនាញខាងហិរញ្ញវត្ថុផ្សេងៗឯទៀតៗ ដើម្បីតវ៉ាប្រឆាំងនឹងនយោបាយអតិផរណា (ការបញ្ចេញចាយហួយប្រមាណ នូវធនប័ត្រជាហេតុបណ្តាលឲ្យតម្លៃទំនិញឡើងទូទៅ) របស់ លន់ នល់ គាត់បានកត់ត្រាក្នុងចិត្តថា ម្តេចបានជាក្រុមរបស់គាត់មានឥទ្ធិពលតិចតួចម្ល៉េះ ។ នៅពេលដែលជនផ្តាច់ការត្រូវ

ការលុយដើម្បីទូទាត់ទឹកប្រាក់ដែលគេគៃបំបាត់ គាត់បានត្រឹមតែបង្កើនតម្លៃលុយខ្មែរដែលដាក់ឲ្យចរាចរមួយទ្វេជាពីរប៉ុណ្ណោះ ដោយគ្មានប្រាប់ឲ្យដឹងជាមុនឡើយ ។ ធនាគារនានាបានតវ៉ាប្រឆាំង ប៉ុន្តែ លន់ នល់ និងពួកអាមេរិកាំងពុំយកចិត្តទុកដាក់នឹងរឿងនេះបន្តិចសោះឡើយ ។

ធនាគារទាំងឡាយ បានតបទៅវិញដោយល្បងហាមឃាត់គ្រឿងសម្ភារៈប្រណីតៗ ដែលនាំចូលដោយ លន់ នល់ និងពួកអ្នកសមគំនិត ។ ពួកនាយទាហានរបស់ជនផ្តាច់ការបានសងទៅវិញភ្លាមៗដែរ ដោយបើកធនាគារផ្ទាល់ខ្លួនដែលទ្រទ្រង់ដោយ «មូលនិធិកងទ័ពដែលមិនតម្រូវឲ្យប្រើប្រាស់» ហើយបាននាំចូលរថយន្តទំនើបៗ និងម៉ាស៊ីនត្រជាក់ដោយខ្លួនឯងជាមួយធនប័ត្រនៃធនាគារផ្ទាល់ខ្លួនរបស់គេ ។ ការប្រព្រឹត្តខុសគន្លងនេះពុំត្រឹមតែប៉ះពាល់ដល់វិជ្ជាជីវៈរបស់កុម្ហូតទេ ប៉ុន្តែវាធ្វើឲ្យជ្រាបសព្វពេញទីក្រុង និងចំណែកនៃប្រទេស ដែលនៅគ្រប់គ្រងដោយ លន់ នល់ នៅឡើយ ។

ភាគកាន់តែធ្ងន់ធ្ងរនៃស្ថានការណ៍ប្រទេស បានកើនឡើងបន្តិចម្តងៗ ហើយមកដល់ឆ្នាំ១៩៧៣ ទើបសង្គ្រាមចាប់ផ្តើមប៉ះពាល់ដល់ដល់ការរស់នៅរបស់ប្រជាជនម្នាក់ៗ ទាំងអ្នកនៅទីក្រុងក៏ដូចជានៅជនបទ ខណៈដែលសហរដ្ឋអាមេរិកផ្តើមយុទ្ធនាការទម្លាក់គ្រាប់បែកយ៉ាងសម្បើមរបស់គេ ហើយពួកខ្មែរក្រហមចាប់ផ្តើមក្នុងពេលដំណាលគ្នានូវដំណើរពីរឆ្នាំរបស់ខ្លួនឆ្ពោះទៅរកជ័យជម្នះផ្តាច់ព្រ័ត្រដែរ ។

ក្នុងអំឡុងនៃការទម្លាក់គ្រាប់បែកប្រាំពីរខែ ដោយគ្មានឈប់ឈររបស់អាមេរិកាំង ប្រជាជនកម្ពុជាជាងមួយលានប្រាំសែននាក់បានភៀសខ្លួនមកកាន់ក្រុងភ្នំពេញ ដែលធ្វើឲ្យប្រជាជនក្នុងក្រុងកើនឡើងទ្វេ[១២] ។ សរុបទៅសហរដ្ឋអាមេរិកបានទម្លាក់គ្រាប់បែកមកលើជនបទប្រទេសកម្ពុជាចំនួន ២៥៧.៨៦៥តោន ច្រើនជាងពាក់កណ្តាលនៃបរិមាណគ្រាប់បែក ដែលបានទម្លាក់ទៅលើប្រទេសជប៉ុនក្នុងអំឡុងសង្គ្រាមលោកលើកទី២ ។ លទ្ធផលបានមានឡើងជាបន្តបន្ទាប់គ្នា និងបង្កឲ្យមានការខូចខាតយ៉ាងសម្បើម ។ ប្រជាជនលែងអាចធ្វើស្រែចម្ការ និងនេសាទ ប្រកបដោយសន្តិសុខទៀតហើយ ហើយវាគ្រោះថ្នាក់ខ្លាំងណាស់ក្នុងការធ្វើដំណើរតាមផ្លូវជាតិនានា ។ ហេតុការណ៍សាមញ្ញៗទាំងនេះ បង្ហាញឲ្យឃើញពីទុក្ខលំបាកវេទនាសម្រាប់ប្រជាជនស្ទើរតែទាំងអស់ ។ ផ្ទៃដីស្រែបានធ្លាក់ចុះពីបីលានហិកតា នៅពេលចាប់ផ្តើមសង្គ្រាមមកនៅត្រឹមជាងប្រាំសែនហិកតាប៉ុណ្ណោះនៅពេលបញ្ចប់យុទ្ធនាការទម្លាក់គ្រាប់បែក ។ នៅក្នុងប្រទេសមានការខ្វះខាតស្បៀងអាហារយ៉ាងខ្លាំង ហើយក្នុងទីក្រុងនានា របស់ប្រើប្រាស់ល្អៗកម្រមានឃើញណាស់ ពីព្រោះវាគ្រោះថ្នាក់ខ្លាំងណាស់ ដែលឈ្មួញដឹករបស់ទាំងនេះមកតាមផ្លូវទឹក ឬផ្លូវថ្នល់ និងមានតម្លៃហួសហេតុ បើដឹករបស់ទាំងនេះមកតាមយន្តហោះ ។

កុម្ហូត បានសម្លឹងមើលទីក្រុងរបស់គាត់ ដែលប្រែក្លាយទៅជាមជ្ឈដ្ឋានច្របូកច្របល់ដោយខ្លួនឯង ។ សម្រាប់ជាលើកដំបូងក្នុងប្រវត្តិសាស្រ្តនៃសម័យពួកអ្នកសុំទានបានលេចមុខនៅតាមផ្លូវនានាក្នុងទីក្រុង ។ ដើមឈើទាំងឡាយ ដែលដុះអមតាមមហាវិថីនានាក្នុងសង្កាត់ដែលមានធនាគាររបស់ កុម្ហូត តាំងនៅ ត្រូវគេបក

សម្បុកចេញ ដើម្បីយកទៅប្រើប្រាស់ធ្វើជាខសដុត ។ សំណង់អនាធិបតេយ្យបានរីកលូតលាស់នៅគ្រប់កន្លែង ។ កុម្ពុត និងមិត្តភក្តិទាំងឡាយរបស់គាត់ បានផ្តល់ទីជម្រកឲ្យបងប្អូនដែលមកពីឆ្ងាយៗស្នាក់នៅ ។

ម្ហូបអាហារ បានចោទជាបញ្ហាមួយរឹតតែធ្ងន់ធ្ងរជាងកន្លែងស្នាក់នៅទៅទៀត ហើយការហូបអាហារ មិនគ្រប់គ្រាន់បានចាប់ផ្តើមរាលដាលក្នុងជំរំជនភៀសខ្លួននានា ។ ភាពក្រីក្រគឺមានជាទូទៅ ។ លន់ នល់ បានប្រកាន់នយោបាយមួយដែលដូចជាទទួលស្គាល់បរាជ័យរបស់គាត់ដែរ ៖ ដោយដោះសាពីការផ្លាស់ប្តូរយុទ្ធសាស្ត្រមួយ សមាជិកទាំងឡាយរបស់រដ្ឋាភិបាលបានប្រកាសថា ពួកគេខ្នះខ្នែងគ្រប់គ្រងពុំមែនតែដែនដីទេ ប៉ុន្តែ ប្រជាជនរបស់ខ្លួនដែរ ហើយថាសហរដ្ឋអាមេរិកនឹងផ្តល់ជំនួយចាំបាច់ដើម្បីចិញ្ចឹមអ្នកទាំងនេះ ។ កងទ័ពរបស់ លន់ នល់ រួមមានពួកនាយទាហានដែលកាត់តែពុករលួយខ្លាំងឡើងៗ ឬគ្មានសមត្ថភាព និងកូនទាហានដែលផ្គត់ផ្គង់អាហារឲ្យមិនគ្រប់គ្រាន់ ប្រមូលសុទ្ធតែបរាជ័យ ហើយសមត្ថភាពរបស់ពួកអាមេរិកាំងក្នុងការផ្គត់ផ្គង់រដ្ឋធានី បានត្រូវធ្វើឲ្យអន្តរាយ ។ ពួកខ្មែរក្រហមបានដណ្តើមយកការត្រួតត្រាទន្លេមេគង្គ ។ នៅឆ្នាំ១៩៧៤ ពួកខ្មែរក្រហមបានបិទខ្ទប់ផ្លូវជាតិទាំងអស់ ហើយនៅទីបំផុត យន្តហោះបានទៅជាមធ្យោបាយតែមួយគត់ ក្នុងការផ្គត់ផ្គង់អង្ករ និងគ្រឿងសម្ភារៈសឹកឲ្យរដ្ឋធានី ។ ក្រុងភ្នំពេញគ្រាន់តែជាកោះសិប្បនិម្មិតមួយប៉ុណ្ណោះ ដែលភ្ជាប់ដោយខ្សែសង្គ្រោះមិនស្ថិតស្ថេរមួយចម្ងាយរាប់ពាន់គីឡូម៉ែត្រទៅនឹងរដ្ឋាភិបាលអាមេរិកាំងមួយ ដែលធ្វើឲ្យរង្គោះរង្គើដោយជំហៀវផ្ទាល់របស់ខ្លួន ដែលបញ្ចេញឲ្យឃើញតាមរយៈរឿងអាស្រូវ វ៉ាថឹហ្គេត ។

ក្នុងរដ្ឋធានី អង្ករបានក្លាយទៅជាការខ្វល់ខ្វាយអំពល់មួយ ឥទ្ធិពលនៃសង្គ្រាមបានធ្លាក់ទៅជារឿងបន្ទាប់បន្សំវិញ ។ ការស្វែងរកអង្ករនិងលុយកាក់ដើម្បីទិញវា គឺជាកង្វល់ធំបំផុតមិនគ្រាន់តែសម្រាប់ប្រជាជនស៊ីវិលទេ ប៉ុន្តែសម្រាប់ពលទាហាន ។ សហរដ្ឋអាមេរិកបានប្រគល់ការចែកចាយស្បៀងអាហារឲ្យរដ្ឋាភិបាល លន់ នល់ មើលខុសត្រូវតែបែរជាលោភលន់បំផ្លើសចំនួនអង្ករដែលគេដឹងឮគ្រប់គ្នាទៅវិញ ។ មនុស្សទាំងនេះ បានលក់អង្ករតិចជាងពាក់កណ្តាលនៃចំនួនស្តុកឲ្យកូនទាហានក្នុងតម្លៃទាបមួយ ឲ្យប្រាក់ជំនួយ និងលក់អង្ករ ដែលនៅសល់ក្នុងតម្លៃហួសប្រមាណមួយសម្រាប់ហោប៉ៅផ្ទាល់របស់ខ្លួន ។ ការខ្វះខាតម្ហូបអាហារបានកើតឡើងព្រមគ្នា នឹងអតិផរណា មួយ ដែលឡើងលឿនដូចព្រួញ ៖ ក្នុងរវាងមួយឆ្នាំ ប្រាក់រៀលបានឡើងពី២៨០ដល់ ១៦០០ រៀលសម្រាប់មួយដុល្លារ បើដូរតាមអត្រាផ្លូវការ[១៣] ។ ផលិតផលដែលប្រជាជនត្រូវការជាចាំបាច់បំផុត លែងអាចលូកដៃទិញបានហើយសម្រាប់ប្រជាជនវណ្ណៈកណ្តាល និងរឹតតែមិនអាចទៀតសម្រាប់ទាហានក្រីក្រ ដែលកើនចំនួនកាន់តែច្រើនឡើងៗ នៅទីក្រុង ។

ប៉ុន្តែមិនដូច្នោះ វណ្ណៈកណ្តាលទាំងនេះ និងពួកអ្នកមានបុព្វសិទ្ធិដូច កុម្ពុត ជាដើម បានទទួលស្គាល់របប លន់ នល់ ដោយស្ម័គ្រចិត្ត ។ ពួកគេបានសម្តែងឲ្យឃើញការអាក់អន់ស្រពន់ចិត្តយ៉ាងខ្លាំង ប៉ុន្តែគ្មានចង់ដឹងអ្វីក្រៅតែពីទីបញ្ចប់នៃសង្គ្រាមឡើយ ។ ពួកគេត្រូវធ្វើឲ្យរំភើបចិត្តដោយការគ្រាំទ្រទាំងស្រុង ដែលសហរដ្ឋអាមេរិកយល់ព្រម

ផ្ដល់ឲ្យ លន់ នល់ ហើយអ្វីៗដែលជាអាជ្ញាបញ្ញានៃសង្គ្រាម បានត្រឹមតែទុកឲ្យគាត់នូវដែនដីបន្តិចបន្តួចប៉ុណ្ណោះ សម្រាប់ដឹកនាំការប្រយុទ្ធឲ្យមានជោគជ័យ ។ នៅខែមីនាឆ្នាំ១៩៧៣ លន់ នល់ បានផ្អាកសេរីភាពចុងក្រោយបំផុតរបស់បុគ្គលម្នាក់ៗ (សេរីភាពក្នុងការសម្ដែងមតិ ជំនឿ និងការប្រជុំ សេរីភាពក្នុងការបោះពុម្ពផ្សាយ) ដែលធានាដោយរដ្ឋធម្មនុញ្ញ ។ លន់ នល់ ថែមទាំងបំបិទសិទ្ធិដែលមានលក្ខណៈជាជនទាក់ទងនឹងលំនៅឋាន និងសំបុត្រឆ្លើយឆ្លង ក្នុងគោលដៅសម្រួលដល់ការចាប់ខ្លួនដល់ផ្ទះដោយមិនចាំបាច់មានដីកា ការត្រួតពិនិត្យសំបុត្រឆ្លើយឆ្លង ការឃ្លាំមើលការធ្វើដំណើរទាំងអស់ ។ ការអនុញ្ញាតឲ្យចាកចេញពីប្រទេសនាំបណ្ដាលឲ្យមានប្រាក់ទឹកតែ រាប់ពាន់ដុល្លារជាចាំបាច់ ។

ប៉ុន្ដែនៅឆ្នាំ១៩៧៥ កុម្ពុត អាចទាញហេតុសំអាងតែទិដ្ឋភាពទីក្រុងភ្នំពេញមួយប៉ុណ្ណោះ ដោយនៅរក្សាលក្ខណៈស្អាតបរិសុទ្ធមួយចំនួនតូច ។ ដូច្នេះ គាត់មិនព្រួយបារម្ភខ្លាំងឡើយ នៅពេលដែលពួកខ្មែរក្រហមដំណើរការវាយលុកផ្ដាច់ព្រ័ត្ររបស់គេនៅថ្ងៃចូលឆ្នាំសាកល (ថ្ងៃទី១ ខែមករា) និងចាប់ផ្ដើមធ្វើឲ្យកងទ័ពមួយ ដែលអាមេរិកាំង សន្មតការពារត្រូវបរាជ័យជាបន្តបន្ទាប់ ។ គាត់ជឿទាំងខុសថា គាត់មិនអាចមានជោគវាសនាអាក្រក់ជាងរបបសាធារណរដ្ឋខ្មែរទេ ។ ប្លែកអំពីពួកអ្នកមានបុព្វសិទ្ធិនៅវៀតណាមខាងត្បូង ដែលមើលឃើញក្នុងបរាជ័យ ច្បាស់ជាមកដល់ក្នុងពេលឆាប់ៗនូវសញ្ញាមួយឲ្យចាកចេញពីប្រទេសនោះ កុម្ពុត ពុំមានបំណងចាកចេញពីប្រទេសកម្ពុជាទេ ហើយភាគច្រើននៃមិត្តភក្តិរបស់គាត់ក៏អឺចឹងដែរ ។ ពួកគេអះអាងថា ថ្ងៃបន្ទាប់ៗនឹងល្អប្រសើរជាងមុន ។

ថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៥ កុម្ពុត និងប្រជាជនទាំងអស់នៅក្រុងភ្នំពេញយល់ថា សង្គ្រាមចប់ហើយ ។ នៅថ្ងៃនោះ ពួកខ្មែរក្រហមបានដណ្ដើមទីប្រជុំជនអ្នកលឿងជាកំពង់ផែផ្លូវទឹក និងជាខ្សែក្រវាត់ការពារភាគខាងត្បូងភ្នំពេញ ។ អ្នកលឿងជាសមរភូមិក្ដៅមួយក្នុងចំណោមសមរភូមិក្ដៅជាច្រើន ដែលគួរឲ្យខ្លាចរន្ធត់បំផុតនៃសង្គ្រាម គឺការទម្លាក់គ្រាប់បែកប្រទ្បាំទៅលើមូលដ្ឋានអ្នកលឿងដោយយន្ដហោះបេ-៥២ អាមេរិកាំងមួយគ្រឿង បានបណ្ដាលឲ្យមនុស្សស្លាប់១៣៧នាក់ និងរបួស២៦៨នាក់ ។ តាំងពីនោះមក ឈ្មោះអ្នកលឿងគឺជារូបភាពនៃការខូចមុខមាត់និងភាពជូរចត់ ដែលសង្គ្រាមនេះបង្កើតឡើង រួមទាំងបែបផែនមិនគួរមាន ដែលពួកអាមេរិកាំងប្រព្រឹត្តមកលើសម្ព័ន្ធមិត្រទាំងឡាយរបស់គេផង ។

ការដួលរលំអ្នកលឿង បានញុាំងឲ្យសហគមន៍បរទេសជឿថា ដល់ពេលដែលត្រូវចាកចេញហើយ ។ ភ្លាមៗ ស្ថានទូតនានាបានបិទទ្វារមុនកំណត់ពេល ហើយពួកអាមេរិកាំងបានជម្លៀសបុគ្គលិកតូចតាចរបស់គេយ៉ាងឆាប់រហ័សបំផុតតាមដែលអាចធ្វើទៅបាន ។ កូនអ្នកមានលុយកម្ពុជាខ្លះ ជាពិសេស ពួកអ្នកដែលមានឪពុកម្ដាយ បងប្អូននៅបរទេស បានចាកចេញពីប្រទេសព្រមគ្នា ។ នៅថ្ងៃទី១២ ខែមេសា បណ្ដាសមាជិកចុង

ក្រោយនៃស្ថានទូតសហរដ្ឋអាមេរិកបានចាកចេញដែរ ។ ដោយផ្ទុយនឹងអ្វី ដែលមានឡើងនៅវៀតណាមខាងត្បូង ប្រជាជនកម្ពុជាមិនសម្រុកដូចមនុស្សឆ្កួតទៅក្នុងស្ថានទូត ដើម្បីដណ្ដើងរកកន្លែងអង្គុយមួយ នៅក្នុងឧទ្ធម្ភាគចក្ររបស់អាមេរិកាំងជាច្រើនគ្រឿងឡើយ ។

នៅថ្ងៃទី១៦ ខែមេសា គឺបួនថ្ងៃបន្ទាប់ពីការចាកចេញរបស់ពួកអាមេរិកាំង ពួកខ្មែរក្រហមបានដណ្ដើមកាន់កាប់អាកាសយានដ្ឋានរបស់ទីក្រុង ។ កុម្ភួត បានទៅកាន់ការិយាល័យធ្វើការតាមពេលម៉ោងដូចសព្វដង ប៉ុន្តែនៅពេលនោះគាត់បានយកថង់មួយដែលដាក់ប្រាសដុះធ្មេញ ខោអាវពីបង្ក្រាម៉ាទៅជាមួយផង ។ ដោយពិតនៅពេលយប់ គាត់សម្រាកនៅធនាគារ លើក្ដារឿមួយក្បែរបន្ទប់ដាក់ទូដែក ។ ព្រឹត្តិការណ៍ដំបូងដែលគាត់មើលឃើញពេលបើកភ្នែកឡើងនៅពេលព្រឹកថ្ងៃបន្ទាប់ គឺសហការីម្នាក់កំពុងលាកម្រាលពូកមួយនៅផ្លូវចូល ។ «តើអ្នកឯងធ្វើអីហ្នឹង?» កុម្ភួត សួរទាំងមិនទាន់ភ្ញាក់ដឹងខ្លួន ស្រួលបួល «ខ្ញុំរៀបចំលើកទង់ជ័យស» មិត្តរបស់គាត់ឆ្លើយតបវិញ ។

ដំបូង កុម្ភួត មិនយល់អ្វីទាល់តែសោះ ។ គាត់គ្មានបំណងបញ្ចេញឲ្យឃើញសេចក្ដីត្រេកអរ ស្ទើរលោតទេ គាត់ដឹងខ្លួនថា គាត់ជាមនុស្សអព្យាក្រឹត ។ គាត់ចេញមកឈរលើខឿនដណ្ដើររបស់ធនាគារ ដោយសម្លឹងមើលនៅគ្រប់ទិសទី ។ គ្រឹះស្ថាននេះស្ថិតផ្លូវត្រឡែងកែងដ៏ល្បីមួយក្នុងចំណោមផ្លូវត្រឡែងកែងល្បីៗរបស់ទីក្រុង ដែលវិថីមួយមកពីអាកាសយានដ្ឋានខ្វែងនិងមហាវិថីព្រះមុនីវង្ស ជាផ្លូវសំខាន់របស់រដ្ឋធានី ដែលសណ្ដូកខ្លួនពីជើងទៅត្បូង ។ ជាថ្មីទៀត គាត់លែងកត់សម្គាល់អ្វីទាំងអស់ ក្រៅតែពីទង់ជ័យសៗ ដែលលើកតុបតែងឲ្យតែបានៗ នៅគ្រឹះស្ថានផ្សេងៗទៀត ។

នៅពេលត្រឡប់ចូលមកក្នុងការិយាល័យគាត់វិញ គាត់ឃើញយុទ្ធជនវ័យក្មេងស្លៀកពាក់ខ្មៅម្នាក់ នៅក្នុងនោះ ដែលស្នើឲ្យគាត់នាំទៅជួបរដ្ឋមន្ត្រីជាអ្នកទទួលខុសត្រូវកន្លែងនេះ ។ «ខ្ញុំឆ្លើយតបទៅយុទ្ធជននោះថា អ្នកឯងប្រឡូកកន្លែងហើយ កុម្ភួត និយាយ ។ ពុំមានរដ្ឋមន្ត្រីទេ ហើយទីនេះក៏ពុំមែនគ្រឹះស្ថានរបស់រដ្ឋាភិបាលដែរ នេះជាធនាគារមួយ ។ គាត់ក៏ចេញទៅវិញភ្លាម» ។

ខ្មែរក្រហមរូបនេះ ដែលកុម្ភួតជួបជាលើកដំបូង ប្រហែលជាពុំមែនយុវយុទ្ធជនធម្មតាម្នាក់ដែលវង្វេងផ្លូវទេ ។ កុម្ភួត អង្គុយហើយចាប់ផ្ដើមធ្វើការបន្តទៀត ។ ប្រហែលនៅម៉ោង១០ព្រឹក សម្ដេចព្រះសង្ឃរាជ បានមានសង្ឃដីកាតាមវិទ្យុ នូវសេចក្ដីអំពាវនាវមួយឲ្យរក្សាភាពស្ងប់ស្ងៀមៈ «សង្គ្រាមចប់ហើយ យើងទាំងអស់គ្នា សុទ្ធតែជាបងប្អូន ។ សូមស្ថិតនៅស្ងៀមស្ងាត់នៅតាមផ្ទះរៀងខ្លួន[១៤]» ។

បន្តិចក្រោយមក ឧត្ដមសេនីយ៍ម្នាក់នៃកងទ័ពរដ្ឋាភិបាលដែលចាញ់បានធ្វើសេចក្ដីប្រកាសតាមវិទ្យុមួយដូចគ្នា ហើយបានចេញបញ្ជាឲ្យបញ្ឈប់ការប្រយុទ្ធទាំងអស់ ព្រោះថា «ការចរចាគ្នាកំពុងតែប្រព្រឹត្តទៅ» ។

ប្រហែលនៅវេលាថ្ងៃត្រង់ កុម្ភួត បានចាកចេញពីការិយាល័យរបស់គាត់ដើម្បីទៅបរិភោគអាហារថ្ងៃ

ត្រង់ជាមួយបងប្អូនជីដូនមួយគាត់ឈ្មោះ អ៊ិន ញ៉ិល នៅផ្លូវម្ខាងទៀត ដែលគាត់ធ្វើការនៅក្រុមហ៊ុនរាជាយស្ម័យយានកម្ពុជាក្នុងឋានៈជានាយក ។ ពួកកងទ័ពខ្មែរក្រហមស្លៀកពាក់ខ្មៅ ឥឡូវនេះ បានដើរឡើងតាមមហាវិថីព្រះមុនីវង្សជាក្រុមតូចៗ ។ នៅកន្លែងអាហារដ្ឋានរាជាយស្ម័យយាន កុម្ហួត និងបងប្អូនជីដូនមួយគាត់ នាំគ្នានិយាយពីទីបញ្ចប់នៃសង្គ្រាម ហើយសាកសួរអំពីតួនាទីដែលសម្តេច ព្រះនរោត្តម សីហនុ នឹងត្រូវសម្តែងនៅក្នុងរដ្ឋាភិបាលថ្មី ។ ពីរម៉ោងក្រោយមក នៅពេលដែលកុម្ហួតត្រឡប់ទៅការិយាល័យគាត់វិញ គាត់ឃើញបេសកជនមានអំណាចម្នាក់របស់ពួកខ្មែរក្រហមស្ថិតនៅទីនោះជាស្រេច ។

«តាមការមើលឃើញជាក់ស្តែង នេះជាបញ្ញវន្តម្នាក់, កុម្ហួត បញ្ជាក់ ។ គាត់នោះបានស្នើសុំជួបប្រធានធនាគារដែលត្រឡប់ទៅផ្ទះគាត់វិញបាត់ទៅហើយ ។ បន្ទាប់មក បេសកជននោះប្រកាសថា គាត់ចង់ដកហូតប្រាក់កាស និងអ្វីៗទាំងអស់ដែលមានតម្លៃ ព្រមទាំងមាស ។ល ។ ខ្ញុំគោងតែពន្យល់ប្រាប់គាត់ថា ធនាគារឯកជនទាំងឡាយមិនរក្សាទុកមាសទេ គឺទុកតែធនប័ត្រប៉ុណ្ណោះ ។ គាត់នោះបានសងសម្តីមកវិញថា ពួកអាមេរិកាំងមានគម្រោងទម្លាក់ គ្រាប់បែកលើក្រុងភ្នំពេញ ហើយថា គាត់បានទទួលបញ្ជាឲ្យនាំយកអ្វីៗទាំងអស់ ដែលមានតម្លៃទៅជាមួយ» ។

ការគំរាមពីការវាយប្រហាររបស់អាមេរិកាំងនេះ ពុំធ្វើឲ្យកុម្ហួតជ្រួលប្រាលឡើយ ។ គាត់មិនជឿពីរឿងនេះទេ ហើយគាត់បានអះអាងនឹងបេសកជនខ្មែរក្រហមវិញថា កុំឲ្យព្រួយបារម្ភអី ៈ គាត់ស្គាល់ពួកអាមេរិកាំងច្បាស់ ពួកគេនឹងមិនប្រព្រឹត្តរឿងអ៊ីចឹងៗ នៅពេលដែលគេចាញ់ឥឡូវនេះទេ ។ «ខ្ញុំបាននិយាយជាមួយគាត់ ខ្ញុំបានធ្វើឲ្យគាត់ស្ងប់អារម្មណ៍ដោយងាយ កុម្ហួត រៀបរាប់ ។ ខ្ញុំជាមនុស្សចុះចំណោមនឹងអ្នកដទៃជានិច្ច ហើយខ្ញុំដូចជាមានមនោសញ្ចេតនានឹងគាត់ណាស់ ។ ខ្ញុំថែមទាំងបញ្ជាក់ប្រាប់គាត់ដើម្បីលេងសើចថា បន្ទប់ដាក់លុយរបស់យើងគឺមាំខ្លាំងណាស់អាចទប់ទល់នឹងគ្រាប់បែកច្រើនគ្រាប់ របស់យន្តហោះបេ-៥២បាន ។ ប៉ុន្តែ កម្មាភិបាលខ្មែរ នៅតែស្នើឲ្យខ្ញុំហៅប្រធានធនាគារមកជួបដដែល» ។

កុម្ហួត បានទូរស័ព្ទទៅប្រធានរបស់គាត់ដែលយល់ព្រមមកជួបភ្លាមនៅធនាគារ ។ ប៉ុន្តែ វត្តមានរបស់បុគ្គលិកពីរនាក់ទៀត គឺជាអ្នកចាំបាច់ខានមិនបាន ម្នាក់ជាអគ្គត្រួតពិនិត្យនិងម្នាក់ទៀតជាហិរញ្ញឹក ដើម្បីបើកទ្វារទូដែក ។ កុម្ហួត សុខចិត្តធ្វើដំណើរតាមរថយន្តទៅរកអ្នកទាំងពីរដល់ផ្ទះ ហើយនាំមកកាន់ធនាគារវិញ ។ នៅតាមផ្លូវគាត់សង្កេតមើលទិដ្ឋភាពផ្សេងៗ ដែលគាត់បានប្រមាណទុកជាមុន ។ ពួកខ្មែរក្រហមបានដកហូតអាវុធពីប្រជាជនទាំងអស់ ៈ ទន្ទឹមនឹងពេលសង្គ្រាមជិតបញ្ចប់ ពលរដ្ឋស៊ីវិល បានចាប់ផ្តើមមានអាវុធខ្លីដើម្បីការពារខ្លួន ។ គាត់ឃើញគំនរអាវុធជាច្រើននៅតាមជ្រុងផ្លូវនានា ប៉ុន្តែគាត់ជាប់រវល់នឹងបេសកម្មរបស់គាត់ខ្លាំងមែនទែនរហូតទាល់តែគាត់មិនបានសម្គាល់ពីការសប្បាយរីករាយ របស់ប្រជាជនសាមញ្ញឡើយ ។ នៅពេលដែលមន្ត្រីធនាគារសំខាន់ៗទាំងបីជួបជុំគ្នាហើយ គេក៏ចាត់ចែងបើកទ្វារទូដែក ហើយ កុម្ហួត បានត្រួតពិនិត្យពីលើការរាប់ធន

ប័ត្រ ដែលមានប្រហែលជាមួយលានដុល្លារគិតជាលុយខ្មែរ ។ គាត់រៀបចំបង្កាន់ដៃទទួលមួយដែលមានចុះហត្ថលេខាដោយត្រឹមត្រូវ ហើយប្រគល់កូនសោទូដែកទៅឲ្យខ្មែរក្រហមរូបនោះ ។ ពេលរាត្រីបានឈានចូលមកដល់ គាត់បានធ្វើការងារនេះជិតដល់ម៉ោង៧យប់ ហើយបេសកជនខ្មែរក្រហមបានស្នើឲ្យ កុម្ហត យកលុយដាក់ក្នុងទូដែកវិញ ។

ទោះជាគាត់ប្រើពេលមួយចំណែកធំ នៅពេលរសៀលដើម្បីរាប់ធនប័ត្រក្នុងបរិយាកាសស្ងប់ស្ងៀមនៅធនាគារក៏ដោយ ក៏កុម្ហត ដឹងថា បរិយាកាសរបស់ទីក្រុងប្រែប្រួលដែរ ។ គាត់ឮសំឡេងបាញ់កាំភ្លើង តែពីសតែពាស និងការបាញ់រះដោយកាំភ្លើងយន្ត ។ បុគ្គលិកម្នាក់ បានខ្សឹបប្រាប់គាត់ថា ពួកខ្មែរក្រហមបានបញ្ជាឲ្យប្រជាជនចាកចេញពីទីក្រុង ។ ប៉ុន្តែ វិទ្យុពុំមានផ្សព្វផ្សាយបទបញ្ជាឲ្យធ្វើការជម្លៀសចេញទេ ។ កុម្ហត ត្រូវធ្វើឲ្យទាល់គំនិតមិនដឹងគិតបែបណា ហើយឥឡូវនេះ ដែលគាត់បញ្ចប់កិច្ចការរបស់គាត់រួចហើយ គាត់ដឹងខ្លួនថា ការខឹងមួម៉ៅបានរាលដាលពេញខ្លួនប្រាណគាត់ ។

កម្មាភិបាលខ្មែរក្រហមរូបនោះបានសុំឲ្យកុម្ហត និងអ្នកទទួលខុសត្រូវឯទៀតៗរបស់ធនាគារស្ថិតនៅទីនេះសិនដើម្បីជួយស្រាវជ្រាវ ជ្រើសរើសឯកសារផ្សេងៗ ។ «ខ្ញុំសើចញឹមៗហើយឆ្លើយតបថា ៖ ទេ! អរគុណហើយ ខ្ញុំចង់ចេញពីទីនេះ កុម្ហត រៀបរាប់ប្រាប់ ។ នៅពេលនោះពួកគេបានស្នើជូនដំណើរខ្ញុំ ត្រឡប់ទៅវិញតាមរថយន្តមួយក្នុងចំណោមរថយន្តជាច្រើនគ្រឿងរបស់ពួកគេ ក្នុងគោលបំណងឲ្យខ្ញុំឆ្លងកាត់របាំងហាមឃាត់នានា ដោយគ្មានបញ្ហា ប៉ុន្តែខ្ញុំបានច្រានចោលការស្នើរបស់គេ ។ ខ្ញុំជម្រាបលាប្រធាន និងបណ្តាសហការីរបស់ខ្ញុំ ។ ជំនួសឲ្យការត្រឡប់ទៅផ្ទះ ខ្ញុំបែរជាសម្រេចចិត្តធ្វើដំណើរទៅសណ្ឋាគារឡឺភ្នំវិញ ព្រោះខ្ញុំត្រូវការផឹកមួយកែវសិន» ។

កុម្ហត បានចេញដើរក្នុងពេលយប់ ហើយគំនិតរបស់គាត់បានចាប់ផ្តើមវិលវល់មិនប្រាកដប្រជា ។ នៅចំពោះមុខគាត់ គាត់ឃើញទីក្រុងមួយដែលត្រូវរាតត្បាត ភ័យព្រួយ និងទទេស្អាត ។ គាត់ត្រូវការពេលមួយរយៈដើម្បីត្រួតត្រាការជ្រួលច្របល់ក្នុងចិត្តរបស់គាត់ឡើងវិញ ។ ក្នុងទីក្រុងគ្មានសល់មនុស្សម្នាក់សោះ! ។

ក្នុងពេលដែលកុម្ហត កំពុងធ្វើការនៅធនាគារ ពួកខ្មែរក្រហមបានផ្តើមជម្លៀសចេញពីទីក្រុងភ្នំពេញ ដោយចាប់ផ្តើមពីមន្ទីរពេទ្យនានាទៅ ។ ពួកអ្នករបួស អ្នកពិការ ដើរអូសខ្លួនដោយលំបាកតាមដែលពួកគេអាចធ្វើបាន ។ អ្នករបួសមួយចំនួនដេកស្តូកស្តឹងនៅលើគ្រែនៅឡើយ ដែលមានបងប្អូនម្នាក់ រុញពីក្រោយដោយកាន់ដប្លោកសេរ៉ូមផង ។ ឪពុកម្នាក់ដែលស្ពាយកូនស្រីគាត់ដាក់ក្នុងកម្រាលពូកមួយ ចងជុំវិញករបស់គាត់កំពុងយំអណ្តឺតអណ្តក ។ មនុស្សជិតពីរម៉ឺនត្រូវបានបណ្តេញចេញពីមន្ទីរពេទ្យនានា នៅពេលរសៀលថ្ងៃនោះ ។

បន្ទាប់ពីបានដេញមនុស្សចេញពីមន្ទីរពេទ្យអស់ហើយ កងទ័ពកុម្មុយនិស្តជាក្រុមតូចៗ ដែល កុម្ហត ធ្លាប់ឃើញដើរចូលក្រុងភ្នំពេញ បានបំបែកគ្នាទៅកាន់សង្កាត់ផ្សេងៗក្នុងក្រុងភ្នំពេញ ។ យុទ្ធជនខ្លះបញ្ជាចរាចរណ៍នៅតាមផ្លូវក្រឡែងកែង យុទ្ធជនខ្លះទៀតដើរពីផ្ទះមួយទៅផ្ទះមួយដើម្បីបញ្ជាឲ្យប្រជាជនចាកចេញភ្លាមៗ ។ ពួកគេ

អះអាងដោយគួរសមថា ៖ «ពួកអាមេរិកាំងនឹងមកទម្លាក់គ្រាប់បែកលើក្រុងភ្នំពេញ ។ សូមចេញដំណើរជាបន្ទាន់ មិនបាច់យកអីទៅជាមួយច្រើនទេ បន្តិចទៀតបងប្អូននឹងត្រឡប់មកវិញហើយ» ។

ពួកអ្នកដែលប្រកែកតវ៉ា សុទ្ធតែត្រូវបញ្ជាឲ្យទៅតាមទិសដៅកំណត់ដោយការបាញ់កាំភ្លើងបង្ហើល អ្នកទាំងឡាយណាដែលរឹងរូសសុទ្ធតែត្រូវកម្ទេចចោល ។ កុម្ភួតធ្លាប់បានឮសំឡេងគ្រាប់កាំភ្លើង ដែលកងទ័ពខ្មែរក្រហមបាញ់ក្នុងរយៈពេលនៃការឈ្លោះប្រកែកគ្នាបន្តិចបន្តួចទាំងនេះ ។ នៅពេលនេះគាត់គ្មានឃើញអ្វីក្រៅតែពីសំណល់ដែលនៅសល់ក្រោយការវិនាសប៉ុណ្ណោះ ។ អគ្គិភ័យបានឆេះជះពន្លឺរន្ទាលឡើងនៅឯជើងមេឃ ។ ដូចប្រជាពលរដ្ឋទាំងអស់នៅក្រុងភ្នំពេញដែរ កុម្ភួត មិនសូវដេកពួនទេ ក្នុងរយៈពេលពីរសប្តាហ៍ចុងក្រោយក្រោមភ្លៀងគ្រាប់កាំភ្លើងធំនៃការវាយលុកផ្តាច់ព្រ័ត្ររបស់ខ្មែរក្រហម ។ ការអស់កម្លាំងរបស់គាត់បានរលាយបាត់ភ្លាម នៅពេលដែលគាត់ខំប្រឹងទទួលយកទស្សនីយភាពដែលគាត់ឃើញ ក្រោមកែវភ្នែករបស់គាត់ គឺទីក្រុងភ្នំពេញស្ងាត់ជ្រងំដូចវាលរហោឋាន ។

គាត់ដើរឡើងតាមវិថីព្រះមុនីវង្សសំដៅទៅកាន់សណ្ឋាគារ ហើយសំណួរផ្សេងៗកំពុងកកូរកកាយក្នុងខួរក្បាល របស់គាត់ ។ គាត់នឹកក្នុងចិត្តថា គាត់នឹងទទួលបានចម្លើយនៅសណ្ឋាគារឡឺភ្នំ ។ កាលពីប៉ុន្មានថ្ងៃមុនកន្លែងនេះត្រូវបានប្រកាសថាជាតំបន់អព្យាក្រឹតសម្រាប់ជនបរទេសទាំងអស់ ។ ពួកអ្នកទាំងនោះ នឹងរៀបរាប់ប្រាប់គាត់ពីអ្វីដែលកើតមានឡើង ។ នៅពេលដែលគាត់មកដល់ផ្លូវក្រាលក្រួសល្អិតៗរបស់សណ្ឋាគារ គាត់រត់ទាំងស្ពុងអារម្មណ៍រិះតែប៉ះអ្នកដែលស្គាល់រាប់អានគ្នាយូរមកហើយ គឺវិស្វករម្នាក់ ធ្វើការនៅក្រសួងប្រៃសណីយ៍ទូរគមនាគមន៍ដែលធ្លាប់ទៅសិក្សានៅសហរដ្ឋអាមេរិក ។

កុម្ភួត ឈប់ងឹក់ពេលកំពុងរត់ ។ «ខ្ញុំអាចសន្និដ្ឋានបានតាមរយៈទឹកមុខរបស់គាត់ ។ គាត់ហាក់ដូចជាត្រូវធ្វើឲ្យខូលចិត្តណាស់ ។ គាត់ប្រាប់ដំណឹងខ្ញុំថា ពួកបរទេសបានចេញដំណើរទៅកាន់ស្ថានទូតរបស់បារាំងអស់ហើយ ។ បន្ទាប់មក គាត់បញ្ជាក់ប្រាប់ខ្ញុំថា គាត់បានប្រគល់កូនតែមួយគត់របស់គាត់ឲ្យពួកបរទេសមើលខុសត្រូវ ហើយដើម្បីឲ្យវារួចផុតពីគ្រោះថ្នាក់! ។ ខ្ញុំមិនចង់ជឿគាត់ពីរឿងនេះទេ ប៉ុន្តែគាត់បដិសេធមិនឆ្លើយនឹងសំណួរផ្សេងៗទៀតឡើយ ។ គាត់ពោលថា គាត់មិនចង់និយាយប្រាប់ខ្ញុំទេ ហើយថាគាត់មិនដឹងថាអ្នកណាមួយ ដែលគាត់ទុកចិត្ត ។ បន្ទាប់មកគាត់ដើរចេញពីខ្ញុំទៅបាត់» ។

ពួកបរទេសគឺជាមនុស្សចុងក្រោយដែលពួកខ្មែរក្រហមត្រូវគិតគូរ ។ បន្ទាប់ពីបានធ្វើការជម្លៀសប្រជា-ជនកម្ពុជាចេញពីរដ្ឋធានីឲ្យទៅកាន់ទីដៅផ្សេងៗរួចហើយ ពួកគេបានបញ្ជាតាមប្រដាប់បំពងសំឡេង (មេក្រូ) ឲ្យអតិថិជនទាំងអស់នៅតាមសណ្ឋាគារចាកចេញ ៖ គ្រឹះស្ថាននេះពុំមែនជាតំបន់ដែលត្រូវបានការពារមួយទេ ។ ដូច្នេះពួកបរទេសត្រូវទៅកាន់ស្ថានទូតរបស់បារាំងទាំងអស់ ។ ប៉ុន្តែប្រជាជនកម្ពុជា ដែលឈ្លាសវៃជាងគេ ដូចជាវិស្វករដែលកុម្ភួតធ្លាប់បានជួប ដឹងថាស្ថានទូតបារាំងពុំអាចការពារជនជាតិខ្មែរបានឡើយ ។

បើសិនជាគាត់បណ្ដោយខ្លួនទៅតាមទិដ្ឋភាពនេះ កុម្ភតច្បាស់ជាស្រែកដោយការភ័យខ្លាច ។ មួយផ្នែកនៃការតស៊ូយកឈ្នះខ្លួនឯងនេះបានធ្វើឲ្យគាត់ដកដង្ហើមដោយពិបាក ៖ «នេះជាលើកចុងក្រោយហើយដែលខ្ញុំត្រាច់ចរតាមផ្លូវនានានៅក្នុងទីក្រុងរបស់ខ្ញុំ» ។ បន្ទាប់មកគាត់មានស្មារតីឡើងវិញ ។ «គឺមិនអាចមានអ្វីចឹងទេ ។ ខ្ញុំត្រូវតែទុកសិទ្ធិនៃការមិនទុកចិត្តឲ្យគាត់ចុះ ។ យើងនឹងមកវិញទាំងអស់គ្នា» ។ គាត់បែរត្រឡប់ក្រោយ ហើយចាប់ផ្ដើមស្វែងរកអ៊ិនញ៉ិលជាបងប្អូនជីដូនមួយរបស់គាត់ ។ គាត់មិនអាចពុះពារនឹងព្រឹត្តិការណ៍អាក្រក់នេះតែម្នាក់ឯងទេ ។ គាត់បានជួបអ៊ិនញ៉ិល ដោយចៃដន្យនៅចម្ងាយជាងមួយរយម៉ែត្រ ហើយអ្នកទាំងពីរបានចេញដំណើរជាមួយគ្នាតាមរថយន្តទៅកាន់សង្កាត់ជាយក្រុងឈ្មោះទួលគោក ជាកន្លែងដែលបងប្អូនជីដូនមួយគាត់មានខ្ទមតូចមួយឆ្ងាយពីផ្លូវថ្នល់ ។

ពួកគេនៅលាក់ខ្លួនទីនោះជាមួយគ្រួសាររបស់ញ៉ិល ហើយនិយាយគ្នារអ៊ុះៗដោយស្ងប់ស្ងៀម ។ ពួកគេចង់ភ្លេចពួកខ្មែរក្រហមទៅហើយ ។ «មិនត្រូវបណ្ដោយខ្លួនឲ្យធ្លាក់ទៅក្នុងការធ្វេសប្រហែសទេ កុម្ភត និយាយ ។ យើងត្រូវតែសង្ឃឹម ។ ខ្ញុំមិនអាចជឿដោយបោះបង់កូនរបស់ខ្ញុំនៅថ្ងៃមួយបន្ទាប់ពីការមកដល់របស់ពួកខ្មែរក្រហមទេ ។ ខ្ញុំមិនចង់លើកតម្លៃពួកខ្មែរក្រហមហួសហេតុពេកឡើយ ខ្ញុំចង់ធ្វើខ្លួនជាអ្នកប្រកបដោយវិចារណញ្ញាណម្នាក់» ។

បន្ទាប់ពីរយៈពេលបីថ្ងៃ កន្លែងលាក់ខ្លួនរបស់គាត់ត្រូវបានរកឃើញនៅក្នុងអំឡុងនៃការឆែកឆេរ រុករើយ៉ាងដាក់លាក់មួយនៅក្នុងរដ្ឋធានី ។ យុទ្ធជនម្នាក់បានបង្ហាញខ្លួននៅមាត់ទ្វារផ្ទះគាត់ ហើយនិយាយ ដោយគួរសមថា ៖ «បងប្អូន សមមិត្តសូមអញ្ជើញចាកចេញពីផ្ទះ ។ ពួកចក្រពត្តិនឹងមកទម្លាក់គ្រាប់បែកលើទីក្រុងយើងមិនខាន ។ ពីរ-បីថ្ងៃទៀតបងប្អូនអាចត្រឡប់មកវិញហើយ» ។

នៅពេលនេះ កុម្ភត សុខចិត្តជឿពីរឿងទម្លាក់គ្រាប់បែកនេះ ។ បងប្អូនជីដូនមួយគាត់ និងរូបគាត់បានចេញដំណើរជាមួយគ្រួសាររបស់គាត់ដោយបោះបង់ចោលទ្រព្យសម្បត្តិទាំងអស់ និងគោរពតាមបញ្ជាដែលខ្មែរក្រហមកំណត់ឲ្យ ។ ពួកគេបានចាកចេញពីទីក្រុងភ្នំពេញតាមផ្លូវជាតិលេខ៥ ដែលនាំឆ្ពោះទៅទិសខាងជើង ដោយហេតុថាពួកខ្មែរក្រហមបញ្ជាក់ប្រាប់ឲ្យត្រឡប់ទៅភូមិកំណើតវិញ គឺភូមិរបស់ឪពុកម្ដាយ ឬជីដូនជីតារបស់ខ្លួនរស់នៅ ។ ក្រុងភ្នំពេញជា «ភូមិកំណើត»របស់ កុម្ភត ដូច្នេះគាត់បានសម្រេចទៅតាមអ៊ិនញ៉ិលរហូតដល់ភូមិរបស់គាត់ដែលជាភូមិធំមួយនៅក្នុងខេត្តកំពង់ចាម ។ តែក្នុងរយៈពេលប៉ុន្មានម៉ោងប៉ុណ្ណោះ ពួកគេបានទៅទាន់ហ្វូងប្រជាជនយ៉ាងច្រើន ដែលត្រូវបណ្ដេញពីទីក្រុងភ្នំពេញដែរ នៅពេលដែល កុម្ភត កំពុងរាប់ធនប័ត្រនៅក្នុងធនាគារ ។

ពួកគេដើរមាត់ច្រកចេញពីទីក្រុង សមុទ្រមនុស្សនៅឈរកកកុញពេញលើផ្លូវដ៏តូចដែលត្រូវនាំឆ្ពោះទៅជនបទដោយកង់ទ័ពស្លៀកពាក់ខ្មៅជាច្រើននាក់ ។ កុម្ភត នឹកគិតទៅដល់មនុស្សមួយហ្វូងដែល នៅជាប់ក្នុងស្ពាដ

មួយគ្មានច្រកចេញ ។ ពួកអ្នកមានៗដែលនៅសល់ក្រដាសប្រាក់នៅឡើយ បានទិញម្ហូបអាហារពីអ្នកលក់ដូរដែលតាំងនៅតាមចិញ្ចើមផ្លូវ ដោយលក់ក្នុងតម្លៃថ្លៃហួសហេតុ ៖ អង្ករកន្លះគីឡូក្រាម ថ្លៃមួយរយដុល្លារគិតជាលុយខ្មែរ ត្រីដែលស្ងួតបានពីប្រឡាយទឹកមួយថ្លៃហាសិបដុល្លារ ។ ពួកអ្នកក្រីក្រ ដែលគ្មានអ្វីសោះបានផាកចេញមិនទិញអ្វីទាំងអស់ ។ អ្នកជំងឺខ្លះស្លាប់ឈាមត្រដរខ្យល់នៅលើចិញ្ចើមថ្នល់ ។ គ្មានអ្នកណាម្នាក់ឈប់ដើម្បីជួយអ្នកដែលគេមិនស្គាល់ឡើយ ។ គ្មានអ្នកណាម្នាក់នឹកគិតប្រឆាំងនឹងពួកខ្មែរក្រហម និងបញ្ឈប់ការចាកចេញទាំងហ្វូងៗដែលគួរឲ្យរន្ធត់នេះផងទេ ។ សម្រាប់រឿងនេះគេគោងតែកម្ចាត់ចេញនូវសកម្មភាពមិនសមហេតុសមផលទាំងអស់នៅពេលដែលពួកគេបន្តដើរក្នុងជំហានធ្ងន់ពាប់មួយ ។ រៀងរាល់ថ្ងៃ នៅម៉ោង៨ល្ងាចគេប្រាប់ឲ្យគាត់ដេក ហើយពួកគេអស់សង្ឃឹមជាខ្លាំងពីម្នាក់ទៅម្នាក់ ។ គេដាស់អ្នកទាំងនោះឲ្យភ្ញាក់នៅមុនពេលព្រឹក ដើម្បីចេញដំណើរទៅមុខទៀត ។ ពួកគេដើរផ្តុំគ្នា ទៅតាមមជ្ឈដ្ឋានសង្គមរបស់គេ ៖ កុម្ពួត និងបងប្អូនជីដូនមួយគាត់ ដើរជាមួយជនជាតិខ្មែរបេះដឹងដទៃៗ ទៀរបស់ទីក្រុង ពួកម្ចាស់ហាងទំនិញដើរទៅមុខជាមួយម្ចាស់ហាងទំនិញដូចគ្នា ពួកអ្នកសុំទានជាមួយពួក អ្នកសុំទាន ។ កុម្ពួត បានដើរដូច្នេះក្នុងរយៈពេលដប់ថ្ងៃ រហូតដល់ហ្វូងមនុស្សដែលមានរាប់ពាន់នាក់ទៅដល់ស្ពានមួយឆ្លងកាត់ទន្លេសាប ។ នៅកន្លែងនោះ កុម្ពួត និងបងប្អូនជីដូនមួយគាត់បានដើរសំដៅទៅទិសខាងកើតនិងភូមិកំណើតរបស់ញ៉ិលវិញ ។

គាត់ឈប់សម្រាកនៅព្រែកក្តាមជាទីប្រជុំជនតូចមួយនៅត្រើយម្ខាងនៃទន្លេ ដែលនៅពេលនេះ ត្រូវមនុស្សបីម៉ឺននាក់ចូលនៅពាសពេញដោយរង់ចាំធ្វើដំណើរបន្តទៀត ឆ្ពោះទៅកាន់ភូមិកំណើតរបស់គេ ។ នៅព្រែកក្តាមមានម្ហូបអាហារនិងមានកម្មាភិបាលខ្មែរកំពុងរង់ចាំត្រួតពិនិត្យមនុស្សទូទៅ ។ អ៊ិន ញ៉ិល ត្រូវបានហៅឲ្យចុះឈ្មោះមុនគេ ។ កុម្ពួត ធ្លាប់ឮគេនិយាយថា ពួកកុម្មុយនិស្តស្រាលជ្រើសមនុស្សម្នាដោយស្នើឲ្យសរសេរ“ប្រវត្តិរូប” របស់ខ្លួន ជាពិសេសអំពីការងារដែលពួកគេធ្លាប់ធ្វើ ក្រោមរបប លន់ នល់ ។ “នៅពេលដែលពួកខ្មែរក្រហមសូមឲ្យបងប្អូនជីដូនមួយខ្ញុំសរសេរជីវប្រវត្តិរបស់គាត់ ខ្ញុំបានសុំសរសេរដូចគ្នាដែរ កុម្ពួត រៀបរាប់ ។ យើងឮប្រជាជនខ្លះនិយាយថា គេនាំមនុស្សទៅរៀនសូត្រ ដែលយើងបកស្រាយថាជា “ការលាងខួរក្បាល” ។ យើងប្រាថ្នាស្ថិតនៅរួមជាមួយគ្នា ដើម្បីគាំពារគ្នាទៅវិញទៅមក ហើយត្រូវខ្មែរក្រហមបើកឲ្យទៅទាំងពីរនាក់” ។

បងប្អូនជីដូនមួយសាច់ឆ្ងាយម្នាក់ ដែលជាអតីតមន្ត្រីគយនៅអាកាសយានដ្ឋានពោចិនតុង បានបញ្ចេញបំណងរួមដំណើរជាមួយយើងដែរ ហើយយើងទាំងបីនាក់បានទៅបង្ហាញខ្លួនរួមគ្នានៅមុខពួកខ្មែរក្រហម ។ “បន្ទាប់ពីបានផ្តល់ព័ត៌មានទាំងអស់ស្តីពីរូបយើងដែលពួកគេចង់បានហើយ យើងប្រកាសថាយើងចង់ចេញដំណើរទៅជាមួយគ្នា ។ ពួកគេនាំញ៉ិលនិងមន្ត្រីគយចេញទៅ ប៉ុន្តែបានអះអាងថា ពួកគេពុំត្រូវការប្រវត្តិរូបរបស់ខ្ញុំទេ ។ អ្នកទទួលខុសត្រូវម្នាក់បញ្ជាក់ប្រាប់ខ្ញុំថា “នៅពេលណាគេត្រូវការប្រវត្តិរូបនោះ គេនឹងសួររកពីសមមិត្តហើយ ។ ខ្ញុំស្ថិតនៅតែម្នាក់ឯងគត់” ។

ដោយឃើញបងប្អូនជីដូនមួយគាត់ដើរទៅឆ្ងាយ ក្រោមការអមការពាររបស់ពួកខ្មែរក្រហមប្រដាប់អាវុធ កុម្ពុត មានអាការៈភ័យស្លន់ស្លោជាខ្លាំង ។ តាំងពីថ្ងៃទី១៧ ខែមេសា ញ៉ិលធ្លាប់ជាអ្នករួមដំណើរជាមួយគាត់ គ្រប់ដំហាន ។ ការជជែកគ្នាលេងរបស់គាត់បានការពាររូបគាត់ដូចជាខែលមួយពីទស្សនីយភាពគួរឲ្យព្រឺខ្លាចទាំងឡាយ ដែលកំពុងកើតមានបន្តគ្នាជុំវិញគាត់ ។ ក្នុងរយៈពេលដប់ពីរថ្ងៃអ្នកទាំងពីរបានដើរពីភ្នំពេញទៅព្រែកក្តាមដោយមិនសូវខ្វាយខ្វល់នឹងពួកអ្នកក្រីក្រនិងអ្នកអត់ឃ្លាន អ្នកត្រដរខ្យល់ជិតស្លាប់អ្នកបាត់ខ្លួនឡើយ ព្រោះយើងជជែកគ្នាតែពីមូលហេតុនៃការជម្លៀស ពីតួនាទីដែលសម្តេច ព្រះនរោត្តម សីហនុ នឹងកាន់កាប់នៅក្នុងរបបថ្មី ពីកាលបរិច្ឆេទនៃការត្រឡប់ទៅក្រុងភ្នំពេញ ពីការរួមចំណែកដែលយើងអាចផ្តល់ដល់ការបដិវត្តន៍ប៉ុណ្ណោះ ។ ពួកគេធ្លាប់រក្សាឲ្យស្ថិតស្ថេរយ៉ាងយូរតាមដែលអាចធ្វើទៅបាន នូវជីវិតប្រកបដោយឯកសិទ្ធិ ដែលគ្មានភាពប្រាកដរបស់គេ ។ ឥឡូវនេះគឺភាពស្ងាត់ជ្រងំ កុម្ពុត ស្ថិតនៅតែម្នាក់ឯងពោរពេញទៅដោយការភ័យរន្ធត់ ។

គាត់ត្រឡប់មករកគ្រួសាររបស់ញ៉ិលវិញ – ប្រពន្ធរបស់ញ៉ិល កូនៗរបស់គាត់ និងបងប្អូនជីដូនមួយ ពីរ–បីនាក់ទៀត– ហើយបាត់បង់សេចក្តីសង្ឃឹមជាបន្ទាន់ ។ ក្រុមគ្រួសារដែលនៅសល់ប្រាំមួយនាក់ បានទទួលបញ្ជាឲ្យឡើងជិះក្នុងឡានកាមីញ៉ុងមួយគ្រឿង ផ្ទុកមនុស្សពេញណែនទៅហើយ ដែលបានដាក់គ្រួសារនេះចុះនៅឯនាយឆ្ងាយជាងដប់ប្រាំគីឡូម៉ែត្រក្នុងវាលស្រែស្ងាត់ជ្រងំមួយ ។ ពេលនោះភ្លៀងក៏បង្អុរចុះមក ។ ដោយគ្មានអាហារមួយគ្រាប់ក្នុងពោះ ពួកគេបានសម្រាកក្នុងយប់នោះដោយដេកត្រសុលទល់ខ្នងគ្នា ។ ស្អែកឡើងពួកគេបានត្រូវនាំទៅកាន់ភូមិជិតខាងមួយជាទីដែលគេផ្តល់កន្លែងឲ្យរស់នៅក្រោមខ្ទមមួយសង់ពីគល់ឬស្សីបុកដាំក្នុងដីផ្ទាល់ ដែលជាធម្មតាកន្លែងនេះជាទីជម្រករបស់សត្វប៉ុណ្ណោះ ។ «យើងរស់នៅដូចជាសត្វជ្រូកដោយបរិភោគសំណល់ម្ហូបអាហារដែលគេបោះមកឲ្យយើង ។ ខ្ញុំដឹងខ្លួនថា យើងទាំងអស់គ្នាស្ថិតក្រោមការកាន់កាប់របស់បដិវត្តន៍ដែលយើងពុំបានជួយបដិវត្តន៍» ។

ពួកគេបានដើរឆ្លងកាត់ខេត្តដោយល្បឿនយឺតៗ ពីកន្លែងឈប់ដ៏កម្សត់មួយទៅកន្លែងមួយទៀត រហូតដល់ភូមិកំណើតរបស់គាត់នៅជិតស្ទឹងចក្ការលើ ដែលជាតំបន់ដីស្រែដ៏មានជីជាតិនៅក្បែរចក្ការកោះស៊ូ ។ នៅពេលនេះជាថ្ងៃ១៦ ខែឧសភា គឺជិតមួយខែបានកន្លងទៅចាប់តាំងពីជ័យជម្នះរបស់ខ្មែរក្រហម ។ វានឹងពុំមានការវិលត្រឡប់ទៅក្រុងភ្នំពេញ និងទៅរកជីវភាពរស់នៅដែលកុម្ពុតធ្លាប់បានស្គាល់ឡើយ ។ ក្រុមគ្រួសារពុំត្រូវបានអនុញ្ញាតឲ្យទៅជួបជុំគ្នាវិញទេ ប៉ុន្តែត្រូវបញ្ជូនឲ្យទៅរស់នៅក្នុង «សហករណ៍» ធំមួយ ដែលប្រមូលផ្តុំ មួយពាន់ប្រាំរយគ្រួសារស្ថិតក្រោមការត្រួតត្រារបស់ខ្មែរក្រហមបីនាក់ ។ កុម្ពុត ត្រូវចាត់តាំងឲ្យធ្វើការក្នុងកងផលិតមួយជាមួយមនុស្សពេញវ័យដប់ពីរនាក់ទៀត ហើយបានទទួលរបបស្បៀងអាហារប្រចាំខែជាលើកដំបូង ដែលកំណត់ឲ្យគ្រួសារគាត់ ៖ អង្ករដប់ប្រាំគីឡូសម្រាប់ពលករម្នាក់ៗ ដែលធ្វើការពេញម៉ោង ប្រាំពីរគីឡូកន្លះ សម្រាប់អ្នកដែលធ្វើការពាក់កណ្តាលពេល ចំណែកក្មេងៗ គ្មានបានទទួលអ្វីសោះ ដោយគេសន្មតថាត្រូវផ្តល់ឲ្យមនុស្ស

ពេញវ័យហើយ ។ គឺមានតែប៉ុណ្ណឹង គ្មានត្រី គ្មានបន្លែ គ្មានប្រេងឆា គ្មានសាច់ទេ កុម្ហត បានត្រូវធ្វើឲ្យព្រួយបារម្ភពីរឿងនេះថែមទៀត ។

«ខ្ញុំដឹងខ្លួនថា យើងទាំងអស់គ្នាលះបង់អស់ហើយ ។ ការវិភាគទាំងអស់ដែលយើងធ្លាប់និយាយក្នុងរយៈពេលនៃសង្គ្រាម ទស្សនៈទាំងអស់របស់យើងអំពីអ្វីដែលប្រទេសកម្ពុជានឹងទៅជាយ៉ាងណា សុទ្ធតែខុសយ៉ាងខ្លាំង រហូតទាល់តែខ្ញុំលែងមើលឃើញនូវអ្វីដែលកើតមានពិតប្រាកដ ។ នៅទីបំផុត ខ្ញុំយល់ច្បាស់នូវអ្វីដែលកើតមានចំពោះអ្នកទាំងឡាយដែលខ្មែរក្រហមជ្រើសរើសឲ្យទៅ «រៀនសូត្រ» ហើយពួកគេត្រូវសម្លាប់ចោលទាំងអស់ ។ ក្នុងចំណោមយើង អ្នកដែលពួកកុម្មុយនិស្តមិនសម្លាប់គឺទុកសម្រាប់ធ្វើការដូចសត្វធាតុ» ។

តមកទៀត គេស្នើឲ្យមនុស្សទាំងអស់សរសេរប្រវត្តិរបស់ខ្លួនឬសូត្រឲ្យគេសរសេរតាម ។ នៅខែឧសភា និងមិថុនា កុម្ហត បានប្រើពេលវេលាទាំងអស់របស់គាត់ដើម្បីរៀនធ្វើស្រែ ស្វែងរកអ្វីដែលអាចបរិភោគបាននៅក្នុងព្រៃ ។ ជាមួយគ្រួសាររបស់ ញ៉ិល គាត់ដើររើសខ្យង បេះបន្លែព្រៃ ស្លឹកចេក ដើម្បីស្ល ធ្វើ «បបរប្រួង» (បបរគ្រឿងមួយប្រភេទមានបង់បន្លែលាយផង) ។ នៅដើមដំបូង ពួកគេពុំមានចានឆ្នាំងសោះឡើយ គឺមានតែឧបករណ៍ធ្វើស្រែ (រន្ទ័ល រនាស់) ប៉ុណ្ណោះ ។ ពួកគេមានតែសម្លៀកបំពាក់នៅជាប់នឹងខ្លួន ដែលពួកគេស្លៀកពាក់នៅពេលដែលចាកចេញពីទីក្រុងភ្នំពេញមក ។ ពួកខ្មែរក្រហមប្រាប់ថា ការសាកល្បងអ្វីៗឲ្យដឹងពិបាក-ស្រណុកទាំងនេះគឺជាការចាំបាច់ ដើម្បី «ធ្វើបដិវត្តន៍ឈានទៅរកការខត្តម្ភខ្លួនដោយខ្លួនឯង» ។

ប៉ុន្តែ នៅខែកក្កដា មនុស្សជាច្រើនបានចាប់ផ្តើមបាត់ខ្លួននៅពេលយប់ ។ គេនាំអ្នកទាំងនោះ ទៅម្តងមួយៗ អតីតទាហាន ឬឪពុកម្តាយរបស់អតីតទាហានទាំងនោះ អតីតមន្ត្រីរដ្ឋការ អតីតសមាជិករដ្ឋាភិបាលរបស់ លន់ នល់ អតីតបញ្ញវន្ត ។ កុម្ហត ត្រូវគេទុកឲ្យរស់នៅតទៅទៀត ។ «ខ្ញុំបានសរសេរសម្រាប់ពួកខ្មែរក្រហមនូវប្រវត្តិរូបពិស្តារមួយ ពីព្រោះក្នុងសហករណ៍មានបញ្ញវន្តផ្សេងៗ ទៀតយ៉ាងច្រើនដែលធ្លាប់ស្គាល់ខ្ញុំ កាលនៅក្រុងភ្នំពេញ ។ ប៉ុន្តែពួកខ្មែរក្រហមមិនដឹងអ្វីធំដុំពីធនាគារទេ ។ ចំពោះខ្មែរក្រហមទាំងនោះយល់ថា គ្រូបង្រៀនជាបញ្ញវន្ត ប៉ុន្តែ មិនមែនធនាគារិកទេ ។ សម្រាប់ពួកគេយល់ថា ធនាគារគ្រាន់តែជាកន្លែងមួយគេរក្សាទុកលុយ ហើយពួកគេប្រហែលជាចាត់ទុកខ្ញុំជាស្មៀនស្មេរសាមញ្ញម្នាក់ប៉ុណ្ណោះ ដែលឆ្លាតប្រសប់ ប៉ុន្តែពុំមានប្រាជ្ញាប៉ិនប្រសប់ណាទេ» ។

នៅសហករណ៍ យប់ៗមានសភាពស្ងាត់ជ្រងំ គឺមានតែពួកកម្មាភិបាលខ្មែរក្រហមប៉ុណ្ណោះ ដែលហ៊ានដើរពីកន្លែងមួយទៅកន្លែងមួយ ។ គេស្តាប់ឮជាញឹកញាយនូវសំឡេងជើងមនុស្សដើរខុសពីធម្មតា សំឡេងក្អួរៗរបស់អ្នកណាម្នាក់ដែលគេនាំយកទៅ ។ កុម្ហត នៅនឹកឃើញថា យប់មួយសំឡេងមនុស្សដើរមានលាន់ឮក្បែរខ្ទមរបស់គាត់ដែលធ្វើឲ្យគាត់សន្និដ្ឋានថា គេមកនាំរូបគាត់ទៅទេដឹង ។ ខ្ញុំនឹកក្នុងចិត្តថា «នេះជារឿងមួយ ដែលត្រូវខាំមាត់សង្កត់ចិត្តដើម្បីរស់ ហើយមួយទៀតស៊ូទ្រាំរស់សម្រាប់តែស្លាប់ម្យ៉ាងប៉ុណ្ណោះ ។ ខ្ញុំបានសម្រេចចិត្តរង់ចាំពីរឆ្នាំ បើសិនពុំមានប្រែប្រួលពីពេលនេះទៅទេ ខ្ញុំនឹងធ្វើអត្តឃាដ» ។

# ជំពូកទី២
# ភាពចាប់ផ្តើមនៃប្រទេសកម្ពុជាសម័យទំនើប

ចំពេលដែល កុម្មុត គ្រោងគិតពីផែនការសម្លាប់ខ្លួន នៅខែមិថុនា ឆ្នាំ១៩៧៥ ប៉ុល ពត ដែលជាអ្នកទទួលខុសត្រូវធំបំផុតលើទុក្ខវេទនារបស់ធនាគារិក បានថ្លែងសុន្ទរកថាដ៏សំខាន់មួយក្នុងទីក្រុងភ្នំពេញ ដែលស្ងាត់ជ្រងំស្ទើរតែដូចវាលរហោឋាន ។ ដោយនិយាយក្នុងឋានៈគាត់ជាប្រធានគណៈកម្មាធិការយោធានៃបក្សកុម្មុយនិស្តកម្ពុជា គាត់បានថ្លែងនូវប្រភេទសុន្ទរកថាគួរឲ្យធុញទ្រាន់មួយ នៅមុខកងទ័ពចំនួន៣.០០០នាក់ ដែលមកជួបជុំគ្នាក្នុងរដ្ឋធានី ដើម្បីតំណាងឲ្យបណ្តាអង្គភាពទ័ពធំៗរបស់បក្សកុម្មុយនិស្តកម្ពុជា ។ សុន្ទរកថានេះ រួមមានការបកស្រាយរបស់បក្ស អំពីប្រវត្តិសាស្ត្រ ដែលទើបមានថ្មីៗនេះ ។ ក្នុងនោះ គាត់ក៏បានបកស្រាយ ពីការដែលបក្សកងទ័ព និងពួកមេដឹកនាំរបស់បក្ស បានតម្រូវខ្លួនទៅតាមប្រវត្តិសាស្ត្ររបស់កម្ពុជា និងពិភពកុម្មុយនិស្តដោយរបៀបយ៉ាងណាផង ។

គាត់បានគូសបញ្ជាក់ពីអំពើក្បត់ ដែលជំនាន់យុវជនកម្ពុជាមួយពោរពេញទៅដោយក្តីសង្ឃឹមវាយតម្លៃថាពួកគេជាអ្នកទទួលរងគ្រោះ ។ ឥឡូវនេះពួកគេសុទ្ធតែជាម្ចាស់កាន់កាប់ប្រទេសជាតិទាំងមូល ។ សម្តីទាំងឡាយរបស់ ប៉ុល ពត គឺការឃោសនាដោយគ្មានអៀនខ្មាស គ្មានប្រវត្តិសាស្ត្រ ប៉ុន្តែ ពាក្យសម្តីនេះបានឆ្លុះបញ្ចាំងឲ្យឃើញយ៉ាងពិតប្រាកដនូវរឿងរ៉ាវដ៏អស្ចារ្យផ្សេងៗ និងប្រវត្តិទាំងឡាយ ដែលពួកកុម្មុយនិស្តកម្ពុជាទាំងនេះបង្កើតឲ្យមានឡើង ដើម្បីបន្តអត្ថិភាពពីបណ្តាឆ្នាំដ៏ខ្មៅអាប់អួ និងដែលស្ទើរតែបំផ្លាញឲ្យសាបសូន្យទៅហើយ ។

ប៉ុល ពត បាននិយាយថា «ក្នុងទូទាំងពិភពលោក តាំងតែពីមានសង្គ្រាមបដិវត្តន៍ មកហើយតាំងតែពីចក្រពត្តិអាមេរិកាំង វាកកើតមកមិនទាន់ដែលមានប្រជាជាតិណាមួយ កងទ័ពណាមួយ អាចមានសមត្ថភាពដេញកម្ចាត់ចក្រពត្តិអាមេរិកដល់ទីបំផុត ហើយដណ្តើមបានជោគជ័យមួយទាំងស្រុងបាននោះឡើយ ។ គ្មានមនុស្សណាម្នាក់ផ្សេងទៀត ក៏ពុំអាចធ្វើដូច្នេះបានដែរ... កងទ័ពរបស់យើងបានបំពេញបេសកកម្មនេះ ប្រកបដោយជោគជ័យមួយ ដែលមានពីមុនមកសោះក្នុងពិភពលោកទាំងមូល ។ បើនិយាយតាមភាសាធម្មតាក្នុងរឿងនេះគេជឿថានេះជាស្នាដៃ របស់ព្រះអាទិទេព ពីព្រោះកិច្ចការនេះមានលក្ខណៈធំលើសលប់ក្រៃលែង មនុស្សសាមញ្ញពុំអាចធ្វើឲ្យសម្រេចបានឡើយ»[១] ។

ពួកអ្នកដែលកំពុងស្តាប់សុន្ទរកថានេះ សុទ្ធតែស្លៀកពាក់ខោអាវហែករយ៉ីរយ៉ៃគ្រប់ប្រភេទ អ្នកខ្លះមានរូបកាយស្គាំងស្គម ដោយសារការបរិភោគអាហារអត្តខាត់ក្នុងសម័យសង្គ្រាមដោយសារជំងឺ និងមុខរបួសផ្សេងៗ ។ តួនាទីជាអ្នកចម្បាំងប្រចាំសតវត្សរ៍ ដែលខាំក្រាញនៀល លើសំណល់មហិច្ឆតារបស់ចក្រពត្តិអាមេរិកាំងមុនគេបំផុត ហាក់ដូចជាជ័យជម្នះនេះ មិនធួនល្មមនឹងចិត្តរបស់គេសោះ ប៉ុន្តែ ប៉ុល ពត បានប្រកាស

ប្រាប់ថា លក្ខណៈសុភាពរាបសាររបស់គេ ត្រូវបានបន្ថែមទៅលើភាពថ្លៃថ្នូរ លើ«ភាពបរិសុទ្ធ» នៃជ័យជម្នះរបស់គេថែមទៀត ។

ប៉ុល ពត បានបន្តថា ក្នុងអំឡុងជាងពីរពាន់ឆ្នាំ នៃប្រវត្តិសាស្ត្ររបស់យើងតាំងពីមុនមក យើងពុំដែលបានរំដោះប្រទេសយើង ហើយដណ្តើមបានឯករាជ្យទាំងស្រុងមួយដូចពេលនេះ ។ នេះគឺជាជ័យជម្នះមួយ «មិនដែលមានពីមុនមកសោះក្នុងប្រវត្តិសាស្ត្រកងទ័ពនៃប្រទេសយើង» និងពិភពលោកទាំងមូល ។ មានតែប្រជាជាតិកម្ពុជា ប្រជាជនកម្ពុជា កងទ័ពបដិវត្តកម្ពុជា និងបក្សកុម្មុយនិស្តកម្ពុជាមួយប៉ុណ្ណោះ ដែលបានសម្រេចរំដោះប្រទេសខ្លួន និងប្រជាជនខ្លួនបានទាំងស្រុង ដាច់ខាត និងស្អាតបរិសុទ្ធយ៉ាងនេះ ។

ប៉ុល ពត បានរៀបរាប់បញ្ចូលក្នុងសុន្ទរកថានេះថា «ជ័យជម្នះដ៏បរិសុទ្ធ» និង«ម្ចាស់ការ» បានធ្វើឲ្យប្រទេសកម្ពុជាទៅជាប្រជាជាតិកុម្មុយនិស្ត ប្រសើរខ្ពង់ខ្ពស់ជាងគេក្នុងពិភពលោកលើប្រទេសចិន និងលើប្រទេសវៀតណាម ដែលជាសម្ព័ន្ធមិត្តរបស់ខ្លួនទៅទៀត ។ ពួកកុម្មុយនិស្តកម្ពុជា ពុំអាចក្លាយទៅជាអ្នកមានជ័យជម្នះបានទេបើសិនជាគ្មានជំនួយរបស់ចិននិងវៀតណាមនោះ ប៉ុន្តែ ប៉ុល ពត ត្រូវតែប្រកាន់យកភាសាមួយផ្សេងពីនេះ ។

ជ័យជម្នះរបស់ប្រជាជនកម្ពុជាលើពួកអាមេរិកាំង ក៏ពុំអាចទៅជាជម្នះដ៏ល្បីល្បាញក្នុងប្រវត្តិសាស្ត្របានដែរ បើសិនជាគ្មានពួកវៀតណាមប្រយុទ្ធតស៊ូជាមួយសហរដ្ឋអាមេរិកដោយប្រាកដប្រជា អស់រយៈពេល ដ៏ យូរអង្វែងនោះទេ ។ ក្នុងសុន្ទរកថារបស់ខ្លួន ប៉ុល ពត បានលើកយកបណ្តាថ្ងៃខែដ៏សែនអាក្រក់ ចំនួន៨ខែ ក្រោមការទម្លាក់គ្រាប់បែកអាមេរិកាំងក្នុងឆ្នាំ១៩៧៣ មកធ្វើជាទឡ្ហីករណ៍ ដើម្បីសំអាងការអួតក្អេងក្អាងពីបក្ស របស់ខ្លួនថាជាអ្នកឈ្នះសហរដ្ឋអាមេរិក មុនគេបង្អស់ ។ គាត់បាននិយាយបន្តថា «ក្រោយការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពនៅខែមករាឆ្នាំ១៩៧៣ ចក្រពត្តិអាមេរិកាំង ដែលកាលពីមុនត្រូវវាយប្រយុទ្ធលើសមរភូមិ ៣ ផ្សេងគ្នា វៀតណាម ឡាវ កម្ពុជានោះ ចាប់ពីពេលនេះទៅអាចប្រមូលផ្តុំកម្លាំងរបស់ខ្លួន មកវាយលើសមរភូមិប្រយុទ្ធតែមួយ នៅកម្ពុជាវិញ ។ ប្រជាជនក្នុងពិភពលោកជឿថា យើងនឹងត្រូវគេ «កិនកម្ទេច»... ។ គីស្ស៊ីងហ្គ័របានព្រមានថា «ក្រោយកិច្ចព្រមព្រៀងក្រុងប៉ារីស បើសិនជាកម្ពុជានៅតែបន្តច្រានចោលការសម្រុះសម្រួលនិងការចរចា យន្តហោះ ៣-៥២ នឹងត្រូវបញ្ជូនទៅកម្ទេចប្រជាជនទាំងនោះ ក្នុងរយៈពេល ៧២ម៉ោង»... ។

ពីការភូតកុហកទាំងនេះហើយ ដែលពួកខ្មែរក្រហមបានលើកឡើងពីអ្វីដែលសំខាន់នឹងគ្រោះថ្នាក់ជាគេបំផុតនោះ គឺអំនួតក្អេងក្អាង របៀបលាក់ពុតនេះ ដែលបានវាយឈ្នះ«ចក្រពត្តិនិយមអាមេរិកាំង» ដោយម្ចាស់ការតែម្នាក់ឯងគត់ ។ ក្នុងរយៈពេលពីរឆ្នាំនៃការប្រយុទ្ធគ្នា ពួកកុម្មុយនិស្តខ្មែរបានវាយឈ្នះរដ្ឋមួយ ស្ថិតក្រោមចំណុះសហរដ្ឋអាមេរិក គឺសាធារណរដ្ឋខ្មែររបស់ លន់ នល់ ប៉ុន្តែ ពិតណាស់ គឺពុំមែនវាយឈ្នះកងទ័ពអាមេរិកាំងនោះទេ ព្រោះកងទ័ពនេះបានវាយប្រយុទ្ធនៅកម្ពុជាមិនដល់ ៣ខែផង ។ ក្រោយដែលសភាអាមេរិកាំងបានដាក់កំណត់ឲ្យ

បញ្ចប់ការទម្លាក់គ្រាប់បែកនៅកម្ពុជាត្រឹមថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៣ ពួកខ្មែរទាំង ២ក្រុមបានបន្តការវាយប្រយុទ្ធគ្នាតែឯង ហើយគូប្រយុទ្ធទាំងសងខាងគិតថា ពួកគេត្រូវអតីតសម្ព័ន្ធមិត្តរបស់ខ្លួនបោះបង់ចោលស្រេចទៅហើយ ។

សង្គ្រាមបានត្រូវធ្វើប្រែប្រួល - ហើយប្រែក្លាយកាន់តែឃោរឃៅគួរឲ្យរន្ធត់ថែមទៀត ។ បន្ទាប់ពីរយៈកាលបីឆ្នាំ ក្នុងការប្រយុទ្ធទល់នឹងគូសត្រូវមួយ ដែលមានតែក្នុងការសន្មតគូប្រយុទ្ធទាំងសងខាងបានងើបចេញមកកណ្ដាលវាល ហើយដឹងខ្លួនថាពួកគេបានវាយប្រយុទ្ធប្រឆាំងតែបងប្អូនឯង គឺពុំមែនប្រឆាំងនឹងពួកវៀតណាមខាងជើងដូចដែល លន់ នល់ បានអះអាងនោះទេ ហើយក៏ពុំមែនប្រឆាំងនឹងកងទ័ពអាមេរិកាំងដូចដែល ប៉ុល ពត បញ្ជាក់អះអាងនោះដែរ ។ ប៉ុន្តែ គឺពួកគេប្រឆាំងតែជាមួយជនរួមជាតិកម្ពុជាដូចគ្នាប៉ុណ្ណោះ ។ កំហឹងរបស់គេបានផ្ទុះឡើង ទៅជាអំពើសាហាវឃោរឃៅបំផុត ដែលគេពុំធ្លាប់ដែលឃើញសោះលើសមរភូមិប្រយុទ្ធមួយក្នុងប្រទេសឥណ្ឌូចិនដទៃៗទៀត ដែលកំពុងធ្វើសង្គ្រាម ។

ប៉ុល ពត ត្រូវតែលុបចោលអនុស្សាវរីយ៍នេះចេញយ៉ាងហោចណាស់ក៏ក្នុងប្រវត្តិសាស្ត្រកងទ័ពដែរ ។ ក្នុងសុន្ទរកថារបស់គាត់នៅខែកក្កដា គាត់បានសង្កត់បញ្ជាក់អំពីព្រឹត្តិការណ៍ផ្សេងៗនាថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៧៥ ជាថ្ងៃដែលបុគ្គលិកចុងក្រោយរបស់ស្ថានទូតអាមេរិកាំង ត្រូវជម្លៀសចេញពីទីក្រុងភ្នំពេញថា “ចក្រពត្តិអាមេរិកបានបញ្ជូនឧទ្ធម្ភាគចក្រចំនួន៥០គ្រឿងដើម្បីជម្លៀសមនុស្សរបស់ខ្លួន... ដែលជារឿងមួយបង្ហាញឲ្យពិភពលោកឃើញច្បាស់ថា ប្រទេសកម្ពុជាដ៏តូចព្រមជាមួយនឹងប្រជាជន ដ៏តិចមួយបានសម្ដែងឲ្យឃើញនូវសេចក្ដីក្លាហានយ៉ាងអស្ចារ្យ ហើយអាចវាយឲ្យចក្រពត្តិអាមេរិកាំង រត់ភៀសខ្លួនចេញពីកម្ពុជាយ៉ាងអាម៉ាស់បំផុត...” ។

ដោយអួតក្អេងក្អាងថា ប្រជាជនកម្ពុជាបានឈ្នះសង្គ្រាមតែម្នាក់ឯងគត់ព្រោះ ប្រជាជន បានលត់ដំខ្លួនទៅជា“កងទ័ពបដិវត្តមួយដែលឯករាជ និងស្វ័យត ដោយគ្មានការគាំទ្រពីបរទេស”នោះ ប៉ុល ពត បានបង្កើតឲ្យមានមូលដ្ឋាន អំពីបទពិសោធន៍ “ខ្លួនឧបត្ថម្ភខ្លួន” ដ៏វិនាសហិនហោច ខ្លោចផ្សា ដែលប្រជាជនត្រូវតែដើរតាមជាស្រេច ។

គោលគំនិត នៃការបដិវត្តន៍មួយនេះ ដែល“បរិសុទ្ធ ម្ចាស់ការ” គឺជាកម្លាំងជំរុញខាងក្រោយទុក្ខវេទនាដែលសង្គ្រប់មកលើ កុម្មុត និងប្រជាជនកម្ពុជាប្រាំមួយលាននាក់ ។ ភ្លាមៗ គេត្រូវការឲ្យគាត់ប្រែក្លាយខ្លួនទៅជាកសិករ កម្មករ ឬកងទ័ពដូចៗគ្នា ។ មុខរបរផ្សេងៗ ដែលឥតប្រយោជន៍បានត្រូវលុបបំបាត់ចោលតាំងពីថ្ងៃដំបូងនៃការបដិវត្តន៍ម្ល៉េះ ។ ពាណិជ្ជកម្ម សហគ្រាសឯកជន បានរលាយបាត់បង់ គេបិទផ្សារ ហាងលក់ទំនិញភោជនីយដ្ឋាន ហើយគេបំបាត់ប្រាក់កាសលែងឲ្យមានចាយថែមទៀត ។ មនុស្សម្នាក់ៗ បានទទួលរបបហូបចុកសម្រាប់តែការងារដែលខ្លួនបានធ្វើប៉ុណ្ណោះ ។ បដិវត្តបានអួតក្អេងក្អាងបំពេញតាមសេចក្ដីត្រូវការទាំងអស់របស់ប្រជាជនឲ្យបានគ្រប់គ្រាន់ ។

រដ្ឋបានទាមទារធ្វើជាម្ចាស់កម្មសិទ្ធិលើទ្រព្យសម្បត្តិទាំងអស់ និងការត្រួតពិនិត្យរាល់ សកម្មភាពទាំងអស់របស់ប្រជាជនកម្ពុជាទៀត ។ សេរីភាពរបស់បុគ្គលម្នាក់ៗ ត្រូវបានហាមឃាត់ក្នុងប្រទេសស្ទើរតែលែងមានច្បាប់អ្វីទាំងអស់ ។ ប្រជាជនគឺស្ថិតនៅក្នុងកណ្តាប់ដៃក្រុមមេដឹកនាំរបស់ខ្លួន ដែលជាអ្នកសម្រេចអំពីបរិមាណស្បៀងដែលត្រូវហូប ការផ្តត់ផ្គង់ថ្នាំសម្រាប់ព្យាបាល ទណ្ឌកម្មផ្សេងៗដែលអនុវត្តលើអ្នកមានទោស ។

ការរស់នៅរបស់ប្រជាជនស្ថិតនៅត្រង់ការធ្វើការតែម៉្យាងគត់ ។ សាលារៀនត្រូវបិទទាំងអស់ សាសនាត្រូវហាមឃាត់ ។ លែងមានបញ្ញាកម្សាន្តសប្បាយ ការសម្រាកលំហែទៀតហើយ ។ ការធ្វើដំណើរ ការអាន ការសរសេរត្រូវហាមឃាត់ទាំងស្រុងចំពោះប្រជាជនទាំងអស់ វៀរលែងតែអ្នកមានបុព្វសិទ្ធិមួយចំនួនតូចប៉ុណ្ណោះ ។

ពួកមេដឹកនាំកុម្មុយនិស្តកម្ពុជា មិនទុកចិត្តពួកបរទេសយ៉ាងខ្លាំង រហូតទាល់តែពួកគេឯកោប្រទេសពីពិភពលោក ដើម្បីបង្កើតបដិវត្តន៍ផ្ទាល់ក្នុងប្រទេសរបស់ខ្លួន ។ សេចក្តីត្រូវការធ្វើឲ្យល្បីឈ្មោះជាជនកុម្មុយនិស្តប្រសើរលើសគេក្នុងពិភពលោក ក្នុងប្រវត្តិសាស្ត្ររបស់កម្ពុជានេះ គឺចេញមកអំពីលក្ខណៈពិសេសដោយឡែកនៃអតីតកាលរបស់កម្ពុជា និងដំណើរបត់បែននៃការបដិវត្តន៍កុម្មុយនិស្តនៅអាស៊ីនេះឯង ។ ប្រជាជនកម្ពុជាយល់ឃើញថា ខ្លួនត្រូវមិត្តភក្តិទាំងឡាយប្រានទម្លាក់ទៅក្នុងជ្រោះជ្រៅ ហើយដែលសម្តែងខ្លួនឡើងជាសត្រូវទៅវិញ ។ ប្រជាជនទាំងនេះដឹងថា ខ្លួនត្រូវគំរាមកំហែងជាប់ជានិច្ច រហូតទាល់តែតម្រូវឲ្យពួកគេចាប់ផ្តើមបង្ហាញឲ្យឃើញថាពួកគេក៏ជាចំណែកមួយនៃពូជសាសន៍ និងប្រជាជាតិប្រសើរលើសគេទាំងឡាយដែរ ដើម្បីនឹងសង្គ្រោះខ្លួនឲ្យរួចផុតពីការបំផ្លាញឲ្យសាបសូន្យ ។

ការលើកនិយាយអតីតកាលឡើងវិញនេះ អាចជួយបំភ្លឺឲ្យដឹងពីចរិតនិយមប្រើអំពើជ្រុលហួសហេតុ ព្រមទាំងគំនិតមិនសមហេតុផលផ្សេងៗការជឿសប់ ការភ័យខ្លាចនិងព្រឹត្តិការណ៍ទាំងឡាយ ដែលនៅទីបំផុត -ប៉ុន្តែពុំមែនចៀសមិនរួចនោះទេ- បាននាំទៅដល់ការបដិវត្តន៍ដ៏គួរឲ្យខ្លោចផ្សារបស់ពួកខ្មែរក្រហមនេះឯង ។

អតីតរាជាណាចក្រអង្គរ ដែលថ្កុំថ្កើងរុងរឿងពីសតវត្សរ៍ទី៩ដល់ទី១៤ បានចម្លងមកឲ្យបណ្តាមេដឹកនាំងរបស់កម្ពុជា នូវផ្នត់គំនិត «ទេវរាជា» (ស្តេចជាតំណាងព្រះអាទិទេព) ភាពក្រអឺតក្រទម ឬមោទនភាពផ្នែកវប្បធម៌របស់ប្រទេស និងគំនិតពិសេសដោយឡែកមួយនៃពិភពលោក ដែលដក់ជាប់ក្នុងចិត្តរបស់អ្នកបានកាន់អំណាចតាំងពីនោះរហូតមកដល់សព្វថ្ងៃនេះ ។ ទំនៀមទម្លាប់ទាំងឡាយរបស់រាជាណាចក្រនេះបានផ្តល់ជាគំរូមួយ ពុំត្រឹមតែ ទេវរាជា សម័យទំនើប គឺស្តេច ព្រះនរោត្តម សីហនុ ប៉ុណ្ណោះទេ ប៉ុន្តែ ក៏ផ្តល់ជាគំរូចំពោះអ្នកទាំងឡាយដែលប្រជែងអំណាចជាមួយនឹងព្រះអង្គ ។

ការធ្លាក់ចុះអាប់ឱនរបស់រាជាណាចក្រអង្គរ ការបែកបាក់ក្នុងផ្ទៃរាជវង្សានុវង្ស ដែលជាហេតុធ្វើឲ្យងាយស្រួលការច្បាំងដណ្តើមយកប្រទេសកម្ពុជា និងការត្រួតត្រារយៈពេលកៅសិបឆ្នាំរបស់អាណានិគមបារាំង បាន

បន្ថែមភាពល្បីល្បាញរបស់ខ្មែរទៅលើមរតកនោះទៀត ។ ក្នុងទីបំផុត នៅពេលដែលប្រទេសកម្ពុជាសម្រេចដណ្ដើមបានឯករាជ្យរបស់ខ្លួននៅសតវត្សរ៍ទី២០ នោះ សេចក្ដីថ្លៃថ្នូររបស់ប្រជាជាតិខ្លួន បានត្រូវធ្វើឲ្យខូចខាតយ៉ាងធ្ងន់ធ្ងរ ។ ប្រទេសជិតខាងទាំងពីរមាន សៀម និងវៀតណាម បានកាត់យកទឹកដីខ្លះរបស់ខ្លួន ដោយមានការជួយជ្រោមជ្រែងស្ទើរតែទាំងស្រុងពីស្ដេចខ្មែរមួយអង្គជានិច្ច ហើយពួកបារាំងក៏ធ្លាប់ប្រកាសថា ប្រជាជនកម្ពុជាមិនចេះរស់នៅឲ្យចុះសម្រុងតាមសម័យទំនើបឡើយ ។ នៅពេលដែលអ្នកដឹកនាំណាម្នាក់ ងើបឡើងប្រឆាំងនឹងពួកបារាំងដូចជា នៅក្នុងអំឡុងសង្គ្រាមលោកលើកទីពីរជាដើម អ្នកនោះតែត្រូវសម្លាប់ចោលដោយជនរួមជាតិឯងផងដោយជនបរទេសម្នាក់ ។

របបរាជាធិបតេយ្យ និងព្រះពុទ្ធសាសនា បានស្ថិតស្ថេរគង់វង្សក្នុងសភាពរំដើបរំជួលរាប់សតវត្សរ៍មកហើយ ។ ប៉ុន្តែ ក្រោយទទួលបានឯករាជ្យ ការខិតខំរបស់សម្ដេច ព្រះនរោត្តម សីហនុ ដើម្បីឯកោប្រទេសរាជាធិបតេយ្យ និងវប្បធម៌ខ្មែរឲ្យដាច់ពីភាពទំនើប និងផលវិបាកផ្សេងៗនៃសង្គ្រាមនៅវៀតណាម បានជួយបង្កលក្ខណៈឲ្យពួកខ្មែរក្រហមចាប់កំណើតឡើង បន្ទាប់មក បានធ្វើឲ្យបដិវត្តន៍របស់គេលេចធ្លោឡើងទៀត ។

អ្វីៗដែលជាគ្រឿងពិសោធប្រវត្តិសាស្ត្រ[៧] របស់កម្ពុជាអត្តសញ្ញាណនៃប្រទេសគឺប្រាង្គប្រាសាទអង្គរវត្តនេះឯង ។ វិមានធ្វើ ពីថ្មដ៏ស្កឹមស្កៃនេះ គឺសម្រាប់ប្រជាជនកម្ពុជាសម័យនេះដូចវិមានប៉ាតេណុង *(Parténon)* សម្រាប់ប្រជាជនក្រិចសព្វថ្ងៃដែរជាស្នាដៃស្ថាបត្យកម្ម និងជាការរំឭកអនុស្សាវរីយ៍មួយឡើងវិញថា កាលពីដើមប្រទេសកម្ពុជាគឺជារដ្ឋដំបូងបំផុត ដែលមានវប្បធម៌សម្បូរបែបជាងគេនៅក្នុងតំបន់នេះ ។

ជនជាតិខ្មែរដែលបង្កើតរាជាណាចក្រអង្គរ សុទ្ធតែជាមនុស្សដែលមានមហិច្ឆតា គ្មានព្រំដែនមួយប្រកបដោយគំនិតរឹងមាំមួយខាងវប្បធម៌ ។ ពួកគេមានទំនោរពីធម្មជាតិមួយ ក្នុងការគ្រាប់តាម និងផ្សំតម្រូវតាមគំនិតផ្សេងៗទាំងខាងសាសនា ក៏ដូចការប្រតិបត្តិ ។ អ្នកទាំងនោះក៏ជាសិល្បករដែរ ។ គេមានវិញ្ញាណរស់រវើកណាស់អំពីសោភ័ណភាព និងភាពសមសង្ហា តុល្យភាព និងសមាមាត្រ (ភាពស៊ីគ្នារវាងទំហំ) ត្រឹមត្រូវណាស់ ក្នុងប្រព័ន្ធធារាសាស្ត្រ ក៏ដូចក្នុងសិល្បៈខាងការឆ្លាក់ដ៏ប្រណីតរបស់ពួកគេដែរ ។

សមិទ្ធិធំៗក្នុងវិស័យនិម្មាបនកម្ម (សិល្បៈខាងការសាងសង់ ឬគុបតែង) និងសំណង់ធារាសាស្ត្រ សុទ្ធតែជាមូលដ្ឋាននៃកេរ្តិ៍ឈ្មោះដ៏គួរឲ្យស្ញប់ស្ញែងរបស់ក្រុងអង្គរ ។ ក្នុងផ្នែកទាំងពីរនោះ ពួកខ្មែរបានស្រង់គំនិតផ្សេងៗពីវប្បធម៌ដទៃៗទៀត ហើយកែប្រែធ្វើឲ្យវាកាន់តែល្អឡើង ។ នៅសតវត្សរ៍ទី១៦ ពួកគេបានទទួលជាមរតកនូវចំណេះដាន់ដំបូងអំពីរបៀបប្រើប្រាស់ទឹករបស់បណ្ដាប្រជាជនដែលធ្លាប់រស់នៅមុនពួកគេ ក្នុងជ្រលងទន្លេមេគង្គក្រោម ហើយដែលចេះបង្ហូរទឹក ចេញពីវាលភក់ល្បប់នៅដែនដីសណ្ដ ចេះគ្រប់គ្រងទឹកជំនន់នៅរដូវភ្លៀង និងរក្សាទឹកទុកសម្រាប់បញ្ចូលស្រែនៅរដូវប្រាំង ។ ដូចគ្នាដែរ រចនាប័ទ្មនៃនិម្មាបនកម្មនៅអង្គរមានទម្រង់ដូចប្រាសាទនៅ

ព្រះរាជាណាចក្រចាម្ប៉ា ដែលជារដ្ឋប្រជែងមួយស្ថិតនៅទិសខាងកើតក្រុងអង្គរដែរ ។ ពួកខ្មែរបានគ្រាប់តាមពួកចាមអំពីរូបរាងសណ្ឋាន និងបច្ចេកទេសខាងការឆ្លាក់រូបចម្លាក់ឈើ ដែលពួកគេយកមកអនុវត្តលើថ្មភក់វិញ ។

ក៏ប៉ុន្តែ គឺប្រទេសឥណ្ឌា ដែលបាននាំមកនូវការរួមវិភាគទានមួយភាគយ៉ាងធំដល់ការធ្វើឲ្យក្រុងអង្គរមានអារ្យធម៌ ។ វប្បធម៌របស់ឥណ្ឌា -សាសនា ទស្សនវិជ្ជា គំនិតខាងនយោបាយ និងភាសារបស់ខ្លួន- បានផ្តល់ឲ្យជនជាតិខ្មែរនូវក្របខ័ណ្ឌជំនាញមួយចំនួនយ៉ាងធំ ដែលពួកគេកំពុងត្រូវការដើម្បីកសាងរាជាណាចក្រពិតប្រាកដមួយ ។ ចាប់តាំងពីសតវត្សរ៍ទី២ ក្រោយគ្រិស្តសករាជ ពួកព្រាហ្មណ៍ឥណ្ឌាបានធ្វើដំណើរខ្វាត់ខ្វែងនៅក្នុងតំបន់នេះ ពីប្រទេសភូមា មកកម្ពុជា និងប្រទេសចាម្ប៉ា ។ ជនជាតិឥណ្ឌាទាំងនេះដែលជាបុព្វជិត ឬឈ្មួញបាននាំមកនូវវប្បធម៌ថ្មីមួយក្នុងឋានៈជាបេសកជនជំនួញ ឬសាសនា ពុំមែនជាទ័ពស្រួចនៃកងទ័ពច្បាំងដណ្តើមទឹកដីមួយឡើយ ។ ប្រទេសឥណ្ឌាពុំដែលត្រួតត្រាតំបន់នេះទាល់តែសោះ ប៉ុន្តែ វប្បធម៌របស់ខ្លួនបានធ្វើឲ្យជ្រួតជ្រាបក្នុងសង្គមនានានៅអាស៊ីអាគ្នេយ៍ រួចទៅហើយតាមរយៈការផ្លាស់ប្តូរទំនិញទៅវិញទៅមកដោយសន្តិវិធីទាំងនេះ ។

ជនជាតិខ្មែរក៏ស្ថិតនៅក្នុងចំណោមអ្នកយកលំនាំតាមវប្បធម៌ថ្មីរបស់ឥណ្ឌាដ៏ប៉ិនប្រសប់ទាំងឡាយដែរ ។ វិទ្យាសាស្ត្រស្តីពីច្បាប់ក្បួននៃភពផែនដី (លោកធាតុវិទ្យា) ការយល់ដឹងអំពីព្រហ្មញ្ញសាសនា បានលេចរូបរាងឡើងឲ្យខ្លួនឃើញដូចការពង្រីកលោកទស្សនៈផ្ទាល់របស់ខ្លួនដែរ គឺពុំមែនជាទស្សនៈប្រកួតប្រជែងមួយទេ ហើយការលាយបញ្ចូលអរិយធម៌ទាំងពីរនេះបានបញ្ចេញឲ្យឃើញផលសម្បូរបែបបំផុត ។ រាជាណាចក្រអង្គរ ដែលមានឋិរវេលាប្រាំមួយរយឆ្នាំ ហើយដែលមានឈ្មោះល្បីខ្ទរខ្ទារទៅគ្រប់ទិសទីមួយបែបនេះ ក៏ដោយសារតែស្ថាប័នទាំងឡាយរបស់ខ្លួនស្ថិត នៅក្នុងលក្ខណៈរឹងមាំដដែល ថ្វីបើមានការប្រែប្រួលខ្លះៗ ឬត្រូវធ្វើឲ្យប៉ះពាល់ដល់ទីជម្រៅក៏ដោយ រហូតមកដល់ការបដិវត្តន៍របស់ខ្មែរក្រហមទៀត ។

នៅពេលដែលពួកព្រាហ្មណ៍ឥណ្ឌាមកដល់ ប្រទេសកម្ពុជាជាប្រទេស ដែលដឹកនាំដោយមេកុលសម្ព័ន្ធជាច្រើន ដែលសុទ្ធតែចាត់ទុកខ្លួនឯងជាព្រះអាទិទេពតាំងពីពេលនោះម្ល៉េះ ។ ជាអ្នកដែលជឿថា មានព្រលឹង ឬកម្លាំងចិត្តដឹកនាំលោក (ឧបមាដូចជាភ្លៀង ផ្គរ ខ្យល់ ឬគ្រោះធំៗ ដែលត្រូវធ្លាក់មកលើមនុស្សជាតិហាក់ដូចជាបេះគិតគូរ បេះក្តៅក្រហាយ ឬចង់ផ្តន្ទាសម្លាប់ដូចជាមនុស្សយើងដែរ) ជនជាតិខ្មែរបានព្រមទទួលយកសាសនាហិណ្ឌូនេះរួមទាំងសញ្ញាណ ទេវរាជា មួយផង ដោយពុំបោះបង់គំនិតដែលជឿថា មានព្រលឹង កម្លាំងចិត្តដឹកនាំលោករបស់ខ្លួនឡើយ ហើយដែលស្ថិតស្ថេររហូតមកដល់សព្វថ្ងៃនេះទៀត ។ ទេវរាជាបានក្លាយទៅជាមេដឹកនាំតែម្នាក់គត់លើស្តេចត្រាញ់នៃកុលសម្ព័ន្ធទាំងឡាយ ដែលមានឫទ្ធានុភាពខ្ពស់លើអ្វីៗទាំងអស់ ។ នៅកាលក្រោយមក បណ្តាស្តេចនៅអង្គរបានសម្រេចធ្វើឲ្យគេគោរពបូជាខ្លួន ដូចជាបណ្តាស្តេចនៃអាទិទេពដូច្នោះដែរ ។ បណ្តាស្តេចទាំងនេះបានទទួលនាទីក្នុងចំណោមស្តេច កាន់អំណាចផ្តាច់ការទាំងឡាយ នៃសម័យកាលរបស់ខ្លួនជាមេដឹកនាំកំពូល ខាងផ្នែកនយោបាយ សីលធម៌ ទំនៀមទម្លាប់ និងសាសនានៃអាណាប្រជារាស្ត្ររបស់ខ្លួន ។ ប្រវត្តិវិទូដ៏ឆ្នើម

ម្នាក់ គឺលោក ហ្វ៊ុកសឺដេស បានសរសេរថា "គេអាចអះអាងដោយមិនខ្លាចខុសថា គឺព្រះមហាក្សត្រនេះហើយ ដែលជាអាទិទេពធំនៃប្រទេសកម្ពុជាបុរាណ"[៣] ។

ទេវរាជាផ្ដាច់ការនេះ ជាអ្នកបង្កើតដោយផ្ទាល់នូវរបៀបគ្រប់គ្រងរដ្ឋមួយ ដែលប្រមូលផ្ដុំអំណាចមកកាន់ ក្នុងកណ្ដាប់ដៃខ្លួនទាំងអស់ ដែលបម្រើជាមូលដ្ឋានក្នុងការរៀបចំទឹកដី និងភាពសម្បូររុងរឿងនៃរាជាណាចក្ររបស់ ខ្លួន ។ នៅសម័យរុងរឿងកំពូលរបស់ខ្លួននាសតវត្សរ៍ទី១៤ អង្គរ គឺជារាជាណាចក្រមួយ ដែលមានអានុភាពខ្លាំង បំផុតនៅជ្រោយឥណ្ឌូចិន ។ រាជាណាចក្រនេះ លាតសន្ធឹងទៅទិសខាងកើតរហូតដល់សមុទ្រចិនភាគខាងត្បូង ដោយរាប់បញ្ចូលទាំងភាគខាងត្បូងវៀតណាម និងដីសណ្ដទន្លេមេគង្គផង ។ នៅភាគខាងលិចមានរួមបញ្ចូលពីភាគ ខាងត្បូងប្រទេសឡាវ រហូតដល់រាជធានីហ្លួងប្រាបាង និងឡើងរហូតទៅដល់ប្រទេសចិនទៀត ។ នៅភាគខាងលិច មានរួមបញ្ចូល ប្រទេសថៃ និងមួយផ្នែកប្រទេសភូមា ហើយនៅភាគនិរតីរហូតដល់ជ្រោយសមុទ្រ ក្រា ដែលភ្ជាប់ ប្រទេសថៃ ទៅប្រទេសម៉ាឡេស៊ី ។

ព្រះមហាក្សត្រមិនសូវឃ្លាតខ្លួនពីករណីយកិច្ចរបស់ព្រះអង្គជាអ្នកធ្វើសញ្ញ័យជា ទេវរាជា គោរពបូជា ចំពោះសាសនា និងជាអ្នក គ្រប់គ្រងកិច្ចការសាធារណៈឡើយ ។ ភាពថ្កុំថ្កើងរុងរឿងរបស់ព្រះរាជាណាចក្រ ផ្អែក លើការងារធំៗដែលដឹកនាំ ដោយព្រះមហាក្សត្រ ជាពិសេសបណ្ដាញអាងស្ដុកទឹក ទំនប់ទឹក និងភ្លឺស្រែ ដែលមាន បច្ច័យដល់បដិវត្តន៍ខាង នយោបាយសម្រាប់ជំនាន់របស់ព្រះអង្គ ។ រឿងសំខាន់បំផុតគឺ ព្រះអង្គត្រូវធ្វើជាម្ចាស់ លើបញ្ហាទឹកឲ្យបាន ។ ធាតុអាកាសដែលមានភាពផ្ទុយគ្នានឹងខ្យល់រដូវ ដោយឆ្លាស់គ្នារវាងទឹកជំនន់លិចលង់ និង ភាពរាំងស្ងួត គោងតែជំនះពុះពារដោយការធ្វើអាងស្ដុកទឹកធំៗ ដើម្បីអនុញ្ញាតឲ្យក្រុងអង្គររីកលូតលាស់ ។ ព្រះ មហាក្សត្រទាំងឡាយបានផ្ដើមស្ថាបនាប្រព័ន្ធធារាសាស្ត្រ ជាលក្ខណៈជាតិមួយនៅចុងសតវត្សរ៍ទី៩ ហើយនៅ សតវត្សរ៍ទី១៤ ប្រព័ន្ធធារាសាស្ត្រនេះ នឹងអនុញ្ញាតឲ្យប្រជាជនធ្វើស្រែ បានជិតប្រាំពីរលានហិកតា ។

ការបញ្ចូលទឹកក្នុងស្រែបានកើនឡើងមិនត្រឹមតែផ្ទៃដីធ្វើស្រែប៉ុណ្ណោះទេ ប៉ុន្ដែចំនួន នៃផលដំណាំប្រចាំឆ្នាំ ដែលកើនពីមួយដល់ពីរដងរហូតដល់បីដងផងក្នុងមួយឆ្នាំ ។ ចំនួនលើសពីកំណត់នៃផលស្រូវ គឺជាប្រភពធនធាន ដ៏ស្ដុកស្ដម្ភរបស់ក្រុងអង្គរ ។

ប្រព័ន្ធធារាសាស្ត្របានផ្ដល់ជាគមនាគមន៍តាមផ្លូវទឹកថែមទៀត ។ ប្រឡាយនានាដែលភ្ជាប់ទៅផ្នែក ផ្សេងៗនៃព្រះរាជាណាចក្រ បានរ៉ាប់រងធ្វើឲ្យមានការទាក់ទងគ្នាជាហូរហែ និងជួយសម្រួលដល់ការដឹកជញ្ជូន ផ្សេងៗ ៈ ទូកទាំងឡាយដែលផ្ទុកស្រូវពេញៗ ឬដឹកថ្ម សម្រាប់កសាងប្រាសាទ, កប៉ាល់ដឹកកងទ័ពទៅប្រយុទ្ធ, ទូកតូចៗបាននាំយកទំនិញមកលក់ក្នុងរាជធានីដ៏រុងរឿង ។ មុនបង្អស់ អង្គរ គឺជាព្រះរាជាណាចក្រទឹកមួយ ។

ក្រុងអង្គរក៏ជាសង្គមមួយដែលធ្វើឲ្យជ្រួតជ្រាបទៅដោយជំនឿចំពោះទេវរាជា ដែលតាមការពន្យល់របស់ ព្រះមហាក្សត្រទាំងឡាយថា វាចាំបាច់ដល់ការស្ថាបនាវិមានតម្កល់សពធំស្កឹមស្កៃជាច្រើន ដែលយើងធ្លាប់ស្គាល់

មកហើយ ។ ក្នុងក្បួនលោកធាតុវិទ្យានៃសាសនា ដែលពួកខ្មែរទទួលដំណែលពីប្រទេសឥណ្ឌាថា ចំណុចកណ្ដាលនៃភពផែនដីគឺភ្នំមេរុ ដែលអាទិទេពទាំងឡាយស្នាក់នៅ ។ អង្គរជារាជធានីនៃព្រះរាជាណាចក្រត្រូវបានកសាងឡើង ជាពិភពបង្រួញមួយនៃភពផែនដី ។ ប្រាសាទអង្គរវត្ត ជាតំណាងភ្នំមេរុក្នុងរឿងទេវកថាដែលជាចំណុចកណ្ដាលនៃភពផែនដី និងជាទីសំណាក់នៃអាទិទេពទាំងឡាយ ។ តាមកាព្យនិទានសំស្រ្កឹតមួយថា គឺជា«បុរីមួយដែលព័ទ្ធជុំវិញដោយកំពែងធំៗមហិមាហាក់ដូចជាភ្នំជាច្រើន ដែលព័ទ្ធពិភពលោកដ៏ធំល្វឹងល្វើយ ។ នៅពេលនោះ ដោយសម្ពឹងគយគន់ ទីទួលរាបស្មើពណ៌មាស និងប្រាក់ ប្រជាជនមិនត្រូវការចង់មើលអ្វីក្រៅពីកំពូលភ្នំមេរុឡើយ[៤]» ។

ព្រះវិហារនានារបស់ខ្មែរ ត្រូវបានកសាងឡើងតាមគម្រោងប្លង់គួរឲ្យស្ញែង ដើម្បីបង្ហាញឲ្យឃើញពីអានុភាពដ៏អស្ចារ្យមួយដោយនៅរក្សាតាមកម្រិតរបស់មនុស្សដដែល ។ លទ្ធផលគឺ បូជនីយដ្ឋានជាច្រើន «ដែលមិនអាចប្រៀបផ្ទឹមបានតាមចំនួន, ទំហំ និងភាពល្អឥតខ្ចោះរបស់វា[៥]» ។ អង្គរវត្ត ជាប្រាសាទតំណាងលទ្ធិសាសនាធំជាងគេបំផុតក្នុងពិភពលោក ។ បើបណ្ដាញប្រព័ន្ធធារាសាស្រ្តបង្ហាញឲ្យឃើពីគំនិតបញ្ចូល របៀបថ្មីខាងបច្ចេកទេសរបស់ជនជាតិខ្មែរ ប្រាង្គប្រាសាទនានាបង្ហាញឲ្យឃើញពីទេពកោសល្យផ្នែកសោភ័ណភាព ។ សំណង់ផ្សេងៗ បរិបូណ៌ទៅដោយភាពចុងចើ្កងរុងរឿងខាងនិម្មាបនកម្មរហូតដល់បដិមាករចម្លែកខុសគេ -រូបអាទិទេព និងរូបយក្សទាញព្រ័ត្របន្ដគ្នាជាជួរយ៉ាងវែង រូបចម្លាក់សត្វនាគវ័ណ្ឌខ្លួនជាប់គ្នា រូបសត្វដំរីបែងភាគជាក្បាលបី និងរូបអប្សរាដ៏ល្អឆើតឆាយជាច្រើន ។

ប៉ុន្ដែ ប្រភពនៃភាពសម្បូររុងរឿង -ប្រព័ន្ធធារាសាស្រ្ត- និងប្រភពនៃការបញ្ចុះបញ្ចូលឲ្យជឿ -ស្ដេចជាអាទិទេពមានអានុភាពខ្ពស់លើអ្វីៗទាំងអស់- ក៏ជាមូលហេតុនៃការដួលរលំរបស់ព្រះរាជាណាចក្រដែរ ។ ព្រះរាជាដែលស្នងរាជ្យបន្ដបន្ទាប់គ្នា បានតម្រូវឲ្យកសាងប្រាសាទកាន់តែធំ និងកាន់តែច្រើនដោយគ្មានឈប់ឈរ ដើម្បីលើកសរសើរលក្ខណៈជាអាទិទេពរបស់ព្រះអង្គ ដោយហេតុនេះបានធ្វើឲ្យថាមពល និងភាពចម្រើនលូតលាស់របស់ប្រទេសចុះខ្សោយ ។ ប្រព័ន្ធធារាសាស្រ្ត ដែលហាក់ដូចជាផ្ដល់គុណប្រយោជន៍ខ្លាំងបានប៉ះយ៉ាងស្រាល និងព្រំដែននៃទឹកជំនន់ ហើយចាប់ផ្ដើមហូរច្រោះដី ។ ការណ៍ដែលសំខាន់បំផុត គឺប្រឡាយទឹកទាំងឡាយសុទ្ធតែងាយនឹងខូចវិនាសណាស់បើមានការវាយប្រហារពីសត្រូវមួយ ។

ភូមិសាស្រ្តប្រទេសរបៀបនេះ ក៏ធ្វើឲ្យការធ្លាក់អាប់ឱនរបស់រាជាណាចក្រអង្គរកាន់តែឆាប់មកដល់ដែរ ។ ដោយមានផ្នែកកណ្ដាលជាវាលរាបនៅភាគពាយ័ព្យប្រទេស ព្រះរាជាណាចក្រមានមួយចំណែកធំបានត្រូវការផ្ដាច់ពីការធ្វើពាណិជ្ជកម្មថ្មីៗដ៏រីកលូតលាស់ជាមួយប្រទេសចិន ។ ម្យ៉ាងទៀតនៅទិសខាងលិច និងខាងកើតបណ្ដារដ្ឋថ្មីៗចេះតែរីកធំធាត់ឡើង ដែលក្រោយមកបានប្រជែងគ្នាដណ្ដើម ភ្ជាប់រាជាណាចក្រខ្មែរទាំងមូលជារណបរបស់ខ្លួន ។ ក្នុងអំឡុងប្រាំមួយសតវត្សរ៍ជាបន្ទាប់មក ប្រទេសសៀម ហើយក្រោយមកប្រទេសវៀតណាម

(ដែលមានវាំងស្តេចតាំងនៅទីក្រុងវេ៉) បានវាយឈ្នះខ្មែរជារឿងៗ ហើយដណ្តើមយកដោយកម្លាំងទ័ពនូវទឹកដីមួយផ្នែករបស់ខ្លួន ។

ប្រទេសជាតិត្រូវរងគ្រោះពីព្រះរាជវង្សានុវង្ស ដូចគ្នានឹងបញ្ហាភូមិសាស្ត្រនយោបាយដែរ (គឺការសិក្សាពីផលផ្សេងៗ ដែលស្ថិតមានរវាងរដ្ឋនានាព្រមជាមួយនឹងនយោបាយរបស់ប្រទេសខ្លួន ។ លក្ខណៈក្រោយនេះហើយ ដែលកំណត់ឲ្យប្រទេសនោះសម្រេចធ្វើអ្វីមួយទៅលើប្រទេសដទៃទៀត ភូមិសាស្ត្រនយោបាយនេះបានរីកលូតលាស់ ជាពិសេសនៅប្រទេសអាល្លឺម៉ង់ -កំណត់របស់អ្នកប្រែសម្រួល) ពីព្រោះការឈ្លោះគ្នាពីរឿងស្នងរាជ្យចេះតែកើនឡើងបើគិត ទៅតាមលក្ខណៈបញ្ច្រាសគ្នានៃវិសាលភាពរបស់ប្រទេស ។ ព្រះមហាក្សត្រជាច្រើន (ជួនកាលមានមហាក្សត្រីផង) បានទទូចសុំជំនួយពីប្រទេសសៀម ឬវៀតណាម ដើម្បីកម្ចាត់គូប្រជែងមួយទៀត ដែលទាមទារចង់បានរាជបល្ល័ង្កដែរ ។ ជាកិច្ចតបស្នងសងគុណទៅវិញ ស្តេចទាំងនោះ បានលះបង់សិទ្ធិត្រួតត្រាទឹកដីខ្មែរមួយចំណែកទៅឲ្យអ្នកដែលបានជួយខ្លួននោះទៅ ។

រាជធានីត្រូវបានផ្ទេរពីអង្គរមកតាំងនៅខេត្តដុង្គ ដែលស្ថិតនៅចំកណ្តាលប្រទេសវិញ បន្ទាប់មកក្នុងសតវត្សរ៍ទី១៩ បានផ្ទេរមកភ្នំពេញទៀត ។ នៅពេលនោះ អង្គរគ្រាន់តែជាអនុស្សាវរីយ៍សែនឆ្ងាយលន្លង់លន្លោចមួយប៉ុណ្ណោះ ហើយប្រាង្គប្រាសាទមួយចំនួនធំ ត្រូវគេបោះបង់ចោលនៅកណ្តាលព្រៃស្បាតយ៉ាងជ្រៅ ។ ប្រជាជនកម្ពុជាចូលចិត្តចៀសឆ្ងាញពីប្រាសាទ ដែលកំពុងរលំបាក់បែកទាំងនោះដោយការ ភ័យខ្លាចព្រលឹងព្រាយបិសាចដែលសណ្ឋិតនៅក្នុងនោះ ។ ប្រទេសកម្ពុជាបានក្លាយទៅជាប្រជាជាតិ មួយកាន់សាសនាព្រះពុទ្ធ ដែលព្រះសង្ឃទាំងឡាយលែងកោតញញើតបណ្តាអតីតអាទិទេពហិណ្ឌូនៅអង្គរទៀតហើយ ។ អតីតប្រាសាទខ្លះនៅអង្គរត្រូវគេប្រែក្លាយទៅជាវត្តព្រះពុទ្ធសាសនាវិញ ប៉ុន្តែ អតីតកាលក៏ត្រូវរលាយបាត់បង់ជាមួយ គឺនៅសល់តែប្រពៃណីទាំងឡាយនៅសម័យអង្គរ ដូចជាទេវរាជា រាជាណាចក្រសម្បូរទឹក និងជំនឿសិប់អំពីភាពខ្ពង់ខ្ពស់ប្រសើរលើសគេនៃវប្បធម៌របស់កម្ពុជាដែលក្លាយខុសពីសភាពដើមប៉ុណ្ណោះ ។

ប្រវត្តិសាស្ត្រប្រទេសកម្ពុជាសម័យទំនើប ចាប់ផ្តើមឡើងនៅក្នុងរជ្ជកាលស្តេចនរោត្តម ជាព្រះអយ្យកោរបស់សម្តេច ព្រះនរោត្តម សីហនុ ។ នៅពេលដែលស្តេចនរោត្តមត្រូវបានជ្រើសរើសឲ្យធ្វើជាព្រះមហាក្សត្រក្នុងឆ្នាំ១៨៦០ ប្រទេសកម្ពុជាគ្រាន់តែជាស្រមោលនៃរាជាណាចក្រ ដែលធ្លាប់មានអត្ថិភាពនៅសម័យអង្គរប៉ុណ្ណោះ ។ ប្រទេសវៀតណាមបានដណ្តើមយកភាគខាងក្រោមនៃដីសណ្តទន្លេមេគង្គ (បច្ចុប្បន្នភាគខាងត្បូងវៀតណាម) ហើយថ្មីៗនេះបានសាកល្បងធ្វើអាណានិគមមកលើប្រទេសកម្ពុជាដោយខ្លួនឯងទៀត ។ ការបះបោរមួយរបស់ប្រជាជនកម្ពុជា និងការប្រើកលខបាយផ្សេងៗរបស់សៀមបានបង្ខំឲ្យពួកវៀតណាមដកថយទៅវិញ ។ សៀម និងវៀតណាម បានទាមទារសិទ្ធិគ្រប់គ្រងមួយមកលើប្រទេសកម្ពុជា ហើយសម្តេច ព្រះនរោត្តម

សីហនុ មានការលំបាកនឹងបំពេញចិត្តប្រទេសជិតខាងខ្លួនទាំងពីរ ដោយមិនឲ្យបាត់ប្រទេសព្រះអង្គណាស់ ។ ការធ្លាក់ឱនថយផ្នែកវប្បធម៌ និងសេដ្ឋកិច្ច បានប្រទាញប្រទេសជាតិទៅរកសភាពចុះដុនដាប ហើយប្រជាជនកម្ពុជាបានដណ្តឹងសួរដោយស្មោះត្រង់ថា តើប្រទេសរបស់គេត្រូវជំរុញទៅរកការរលាយសាបសូន្យមែនឬ?

គឺក្នុងចន្លោះប្រហោងនេះហើយ ដែលពួកបារាំងបានសម្រុកចូលមកកាន់ទីនេះយ៉ាងច្រើន ក្នុងការប្រណាំងប្រជែងមួយរវាងប្រជាជាតិអឺរ៉ុបនានា ដើម្បីដណ្តើមយកភាពសម្បូរដោយធនធាននៅអាស៊ី ។ ពួកបារាំង បានសំគាល់ឃើញថា ទន្លេមេគង្គគឺជាផ្លូវទឹកមួយ នាំទៅដល់ប្រទេសចិនបានតាមទិសខាងត្បូង ហើយយល់ឃើញថាដោយធ្វើអាណានិគមលើបណ្តាប្រទេសដែលមានទន្លេនេះហូរកាត់ ពួកគេនឹងជម្រុលដំណើរ រហូតដល់អាណាចក្រកណ្តាល (ប្រទេសចិន) ថែមទៀត ហើយនឹងធ្វើឲ្យកក្រើករញ្ជួយដល់ទីតាំងទាំងឡាយរបស់ពួកអង់គ្លេស ដែលមាននៅប្រទេសចិននោះទៀតផង ។ ប៉ុន្តែ មន្ត្រីជាន់ខ្ពស់ ដែលនៅអមស្តេចសៀមបានទប់ទល់នឹងពួកបារាំងដោយមធ្យោបាយផ្សេងៗយ៉ាងប៉ិនប្រសប់ សំដៅទៅរកពួកអង់គ្លេសវិញ ៖ ប្រទេសសៀម នៅរក្សាបានឯករាជ្យរបស់ខ្លួន ជាថ្នូរនឹងការចង់បានរបស់ខ្លួនមកលើប្រទេសកម្ពុជា ក៏ប៉ុន្តែ ព្រមជាមួយនោះបានចំណេញទឹកដីមួយចំនួនរបស់ ឡាវ និងកម្ពុជា ដែលយល់ព្រមផ្តល់ឲ្យដោយពួកអាណានិគមបារាំង ។

ប្រទេសបារាំងបានញ៉ាំងឲ្យស្តេចនរោត្តមជឿថា គេមានបំណងត្រឹមតែរៀបចំប្រទេសរបស់ព្រះអង្គជាអាណាព្យាបាលមួយប៉ុណ្ណោះ និងធ្វើឲ្យទៅជារដ្ឋទ្រនាប់មួយ រវាងអាណានិគមវៀតណាម ដែលបារាំងវិនិច្ឆ័យថាសំខាន់ជាងគេ និងប្រទេសសៀម ដែលត្រូវចាត់ទុកនៅពេលនោះថា ជាចំណែកមួយស្ថិតក្នុងវង្វង់ឥទ្ធិពលរបស់អង់គ្លេស ។ សម្តេច ព្រះនរោត្តម សីហនុ បានឡាយព្រះហស្តលេខាលើសន្ធិសញ្ញាផ្សេងជាមួយ ប្រទេសបារាំងក្នុងឆ្នាំ១៨៦៣ និង១៨៦៤ ដើម្បីការពាររាជបល្ល័ង្ករបស់ព្រះអង្គពីបំណងប្រាថ្នាជាបន្តបន្ទាប់មួយរបស់ក្សត្រទាមទាររាជបល្ល័ង្កជាច្រើន ព្រមទាំងប្រទេសវៀតណាម និងសៀមផង ។ បន្ទាប់មកក្នុងមធ្យោបាយដើម្បីឈានទៅដល់គោលដៅចុងក្រោយមួយ ព្រះអង្គបានសាកល្បងបោកបញ្ឆោតពួកបារាំង ដោយចរចាចុះសន្ធិសញ្ញាសម្ងាត់ ជាមួយប្រទេសសៀមតែព្រះអង្គត្រូវបរាជ័យ ។

ពួកបារាំង បានប្រកាសប្រាប់ស្តេចនរោត្តម ដែលនឹងបន្តដឹកនាំប្រទេសរបស់ព្រះអង្គថា ប្រទេសបារាំងនឹងណែនាំឲ្យព្រះអង្គធ្វើតាមតែរឿងនយោបាយការបរទេសរបស់កម្ពុជាប៉ុណ្ណោះ ។ ដរាបណាពួកបារាំងគិតថាខ្លួនអាចឡើងទៅដល់ប្រទេសចិនបានតាមទន្លេមេគង្គ ដរាបនោះ ប្រទេសកម្ពុជាលែងសូវមានសារសំខាន់ចំពោះពួកគេទៀតហើយ ហើយស្តេចនរោត្តមនៅតែជាស្តេច ដែលគ្រប់គ្រងប្រទេសដោយអំណាចផ្តាច់ការបែបពាក់កណ្តាលអាទិទេពក្នុងប្រពៃណីដ៏ទូលំទូលាយរបស់ខ្មែរដដែល ។

ស្តេចនរោត្តម សព្វព្រះទ័យនឹងមុខងារនេះយ៉ាងប្រាកដ ។ អ្នកនៅជំនាន់នោះម្នាក់បានសរសើរព្រះអង្គនៅឆ្នាំ១៨៨៨ថា “ព្រះអង្គមានការយល់ដឹងខ្ពស់មួយអំពីនយោបាយនៅអាស៊ី មានទស្សនៈក្រអឺតមួយ អំពីភាព

ថ្ងៃថ្នូរនៃពូជសាសន៍របស់ព្រះអង្គ ។ គេអាចនិយាយដោយគ្មានភ័ន្តច្រឡំថា ព្រះអង្គជាជនជាតិខ្មែរដំបូងបង្អស់នៃរាជាណាចក្ររបស់ព្រះអង្គ លើកលែងតែព្រះអង្គម្នាក់គត់[៦] » ។ ស្ដេចនរោត្ដមផ្ដេកផ្ដួលនឹងសេចក្ដីក្រេវក្រោធរបស់ព្រះអង្គដោយគ្មានរឹតត្បិតឡើយ ។ ព្រះអង្គបានបញ្ជាឲ្យគេវាយតប់មន្ត្រីទាំងឡាយ ដែលលំបាកប្រដៅ និងសម្លាប់ស្រីៗ ដែលមិនស្មោះត្រង់នៅក្នុងវាំងចោល ។ ហើយរាស្ត្រប្រជា របស់ព្រះអង្គ ដែលពុំគិតពីការប្រព្រឹត្តរបស់ព្រះអង្គ បានខ្ទិសខ្វួនចំពោះព្រះអង្គនូវការគោរពមួយ ដែលមិនអាចមានអ្វីមកធ្វើឲ្យរង្គោះរង្គើបាន ។ ព្រះមហាក្សត្រគឺប្រទេសជាតិ យ៉ាងហោចប្រហែលជានរោត្តមទ្រង់យល់ដូច្នេះ ។ អ្នករដ្ឋការបារាំងជាន់ខ្ពស់ម្នាក់បានកត់សម្គាល់ឃើញថា «ការជំពាក់ចិត្តរបស់ប្រជាជនកម្ពុជាចំពោះបណ្ដាមហាក្សត្ររបស់គាត់ ដែលគ្រងរាជ្យសម្បត្តិពីឪពុកដល់កូន គឺមានលក្ខណៈជ្រាលជ្រៅនិងស្មោះត្រង់អស់ពីពោះពីពុង ។ តាំងពីយូរយារណាស់មកហើយ ប្រជាជាតិទាំងមូលមានទម្លាប់នឹងគំនិតមួយថា មិនត្រូវធ្វើឲ្យអត្តិភាពផ្ទាល់របស់ខ្លួនឃ្លាតឆ្ងាយពីព្រះរាជវង្សានុវង្សឡើយ ។ ព្រះរាជាគឺជាការចាប់កំណើតរបស់ព្រះអាទិទេព ជាបុគ្គលដែលមានលក្ខណៈគួរឲ្យគោរពបូជា និងខ្ពង់ខ្ពស់ជាងគេបំផុតរបស់ប្រជាជាតិ»[៧] ។

ក្នុងពេលដំណាលគ្នា ស្ដេចនរោត្ដមត្រូវតែស្វែងរកការគាំទ្រពីវណ្ណៈអភិជន និងការទទួលស្គាល់ តាមផ្លូវច្បាប់ពីប្រជាជន ដើម្បីឲ្យខ្លួនត្រូវចាត់ទុកថា ជាព្រះមហាក្សត្រពេញលក្ខណៈ ។ ព្រះអនុជទាំងពីររបស់ព្រះអង្គ គឺព្រះអង្គម្ចាស់ស៊ីសុវត្ថិ និងស៊ីវត្ថា (ឪពុកតែមួយម្ដាយទីទៃ) បានទាមទារដណ្ដើមរាជបល្ល័ង្ក ហើយជម្លោះឡើងស្នងរាជ្យសម្បត្តិបានកើតមានឡើងឥតឈប់ឈរ ៖ ស៊ីសុវត្ថិ បានសាកល្បងទម្លាក់នរោត្ដមពីរាជបល្ល័ង្ក ដោយទទួលបានការឲ្យដៃរបស់ពួកបារាំង ចំណែក ស៊ីវត្ថា ក៏ចង់ដណ្ដើមរាជ្យសម្បត្តិដែរដោយបំពាក់អាវុធឲ្យបណ្ដាកុលសម្ព័ន្ធភ្នំ និងញុះញង់ពួកនេះឲ្យធ្វើការបះបោរប្រឆាំង ។

នៅពេលដែលពួកបារាំងដឹងថា ទន្លេមេគង្គនឹងពុំអនុញ្ញាតឲ្យគេធ្វើដំណើរទៅប្រទេសចិន តាមផ្លូវទឹកបាននោះ ពួកគេត្រូវតែស្វែងរកអត្ថប្រយោជន៍ផ្សេងទៀត ដែលមាននៅប្រទេសកម្ពុជាវិញ ។ បែបបទនៃការតាំងអាណានិគមបានបំផ្លាញទំនាក់ទំនងផ្សេងៗ ដែលធ្លាប់បណ្ដោយឲ្យស្ដេចនរោត្ដមគង់លើរាជបល្ល័ង្ករបស់ព្រះអង្គមួយរយៈខ្លី ។ ជាដំបូងពួកបារាំងបាន យកការប្រមូលពន្ធដារពីអាភៀន និងសុរាមកកាន់ក្នុងដៃ ។ ស្ដេចនរោត្ដមបានឲ្យសេចក្ដីយល់ព្រម ពីព្រោះប្រទេសបារាំងបានបញ្ជាក់ថា ប្រាក់ដែលប្រមូលបាននេះ នឹងយកទៅប្រើប្រាស់សម្រាប់ ទូទាត់ចំណាយក្នុងកិច្ចការពារប្រទេសកម្ពុជា ។ បន្ទាប់មកនៅឆ្នាំ១៨៨៤ ពួកបារាំងបានទាមទារសិទ្ធត្រួតពិនិត្យលើ ពន្ធគយរបស់ប្រទេសថែមទៀត ដែលផ្ដល់ប្រាក់ចំណូលយ៉ាងសន្ធឹកសន្ធាប់ ។ លើកនេះសម្ដេច ព្រះនរោត្ដម សីហនុ បានបដិសេធ ។តាមព្រះរាជតម្រិះរបស់ព្រះអង្គ ៖ «គេនឹងគិតថា ព្រះមហាក្សត្រច្បាស់ជាបាត់បង់អំណាចទាំងអស់លើប្រជារាស្ត្ររបស់ព្រះអង្គមិនខាន» ។

ដោយមានកំហឹងយ៉ាងខ្លាំង ពួកបារាំងបានសម្រេចចិត្តឈប់ធ្វើលេងៗជាមួយស្ដេចកាន់អំណាចផ្ដាច់ការ

ប៉ែកបូព៌ាប្រទេសនេះ ហើយបានតាក់តែងសន្ធិសញ្ញាថ្មីមួយទៀត ដោយរៀបចំការគ្រប់គ្រងរបស់គេ លើកិច្ចការរដ្ឋបាល តុលាការ ហិរញ្ញវត្ថុ និងពាណិជ្ជកម្ម របស់ប្រទេសកម្ពុជា ដែលសឹងតែកាត់បន្ថយទៅជារដ្ឋអាណានិគមមួយទៅហើយ ។ ដើម្បីបន្ថែមលើការប្រមាថនេះ អគ្គទេសាភិបាលបារាំង បានបង្ខំឲ្យ នរោត្តម ចុះហត្ថលេខាលើសិទ្ធិសញ្ញាថ្មីនេះ ដោយប្រើកម្លាំងទ័ពសម្រុកចូលដល់ក្រឡាបន្ទំផ្ទាល់របស់ព្រះអង្គ (១៧.៧.១៨៨៤) ហើយបានបង្គាប់បញ្ជាឲ្យព្រះអង្គឡាយព្រះហស្ថលេខានៅក្រោមការគំរាមកំហែងពីអាវុធរបស់ខ្លួន ។

ការផ្តើនបំបាក់មុខនេះ បានប៉ះពាល់ដល់ភាពថ្លៃថ្នូររបស់ជាតិ ។ ក្រោមការដឹកនាំរបស់រាជវង្សានុវង្សប្រជាជាតិទាំងមូលបានងើបបះបោរប្រឆាំងនឹងពួកបារាំង ។ ការបះបោរដែលគេឲ្យឈ្មោះថា កុប្បកម្ម ឆ្នាំ ១៨៨៥ ឬចលនាការពារព្រះមហាក្សត្រ បានរីករាលដាលពាសពេញផ្ទៃប្រទេស និងអូសបន្លាយក្នុងរយៈពេលពីរឆ្នាំ ។ កសិករទាំងឡាយ បានចាប់កាន់អាវុធតទល់នឹងពួកអាណានិគមក្នុងនាមនៃរាជាធិបតេយ្យ បើទោះជាមិនមែនស្តេចនរោត្តមក៏ដោយ ។ ជាញឹកញយ កសិករទាំងនោះ តែងត្រូវបានសមាជិកមួយអង្គនៃរាជវង្សានុវង្ស ឬសមាជិក មួយរូបនៃក្រុមគ្រួសារអ្នកមានបុណ្យសក្តិធំៗ នៅក្រុងភ្នំពេញដឹកនាំធ្វើការប្រយុទ្ធ ។ ព្រះអង្គម្ចាស់ ស៊ីវត្ថា ដែលជាគូប្រជែងនឹងស្តេចនរោត្តម គឺជាអ្នកដឹកនាំប្រយុទ្ធសំខាន់ជាងគេ ។ ដោយហេតុនេះព្រះអង្គបានបង្កើតឲ្យមានព្រមគ្នានូវការទំនុកបម្រុងមួយ ចំពោះស្តេចនរោត្តម ពីព្រោះព្រះអង្គធ្វើឲ្យពួកបារាំងខ្លាច និងការគំរាមមួយ ពីព្រោះព្រះអង្គតាំងខ្លួនជាក្សត្រទាមទាររាជបល្ល័ង្កពេញច្បាប់ ។

ពួកមេដឹកនាំនៃការបះបោរ បានប្រយុទ្ធតស៊ូដើម្បីរារាំងបារាំងមិនឲ្យកាន់កាប់ព្រះរាជវាំងរបស់គេបាន ប៉ុន្តែ សម្រាប់ប្រជាកសិករដែលដើរតាមពួកមេៗទាំងនោះវិញ អ្វីដែលគេអាចខាតបង់ គឺមានទំហំធំធេងណាស់ ។ បើសិនជាពួកបារាំងពង្រឹងអំណាចរបស់គេកាន់តែរឹងមាំឡើង ប្រការនេះ នឹងមានន័យថា ពន្ធអាករផ្សេងៗ នឹងកើនកាន់តែខ្ពស់ ហើយការនាំចូលនូវកម្មសិទ្ធិឯកជនមកកម្ពុជាច្បាស់ជាបញ្ចប់របៀបគ្រប់គ្រងបែបសក្តិភូមិ ប៉ុន្តែ វាបាននាំមកនូវអត្ថប្រយោជន៍មួយចំនួន ដោយអនុញ្ញាតឲ្យព្រះរាជាឲ្យមានដីធ្លីខ្លះៗ ។ តាមពិត ពួកបារាំងមានបំណងតម្រូវឲ្យមានរបៀបគ្រប់គ្រង«សមតាមវិចារណញ្ញាណ»មួយ ដែលតាមរយៈនេះ ដីធ្លីនឹងត្រូវក្លាយទៅជាកម្មសិទ្ធិឯកជន សម្រាប់ជាលើកដំបូងបំផុត និងជាកម្មសិទ្ធិរបស់ពួកបារាំង ពួកអន្តោប្រវេសន៍វៀតណាមដែលមកពីកូសាំងស៊ីន ពួកចិនកាត់ខ្មែរ ដែលលោភលន់ទ្រព្យសម្បត្តិ និងពួកអភិជនខ្មែរ ដែលនឹងធ្វើឲ្យកសិករទាំងនោះ ក្លាយទៅជាកម្មករក្រោមកិច្ចសន្យាវិញ ។ ជាមួយនឹងប្រព័ន្ធគ្រប់គ្រងរបស់ព្រះរាជាកសិករទាំងឡាយ មានសិទ្ធទទួលផលពីដីធ្លី ដែលពួកគេបានដាំដុះក្នុងរយៈពេលមួយយូរអង្វែងដែរ ។

ស្តេចនរោត្តម បានទុកដាក់ព្រះកាយឆ្ងាយពីការប្រឡូកគ្នានេះ ដោយព្រះអង្គនៅចាំសង្កេតមើល និងរង់ចាំបរាជ័យដ៏ទាន់ហន់របស់ពួកបារាំងទៅវិញ តែរឿងនេះ មិនដែលកើតមានឡើងម្តងណាឡើយ ។ នៅទីបំផុតនាខែសីហា ឆ្នាំ១៨៨៦ ព្រះអង្គបានសម្រេចព្រះទ័យធ្វើអ្វីមួយដើម្បីប្រឆាំងពីក្រោយខ្នងស៊ីវត្ថា ដែលកាន់តែមាន

ប្រជាប្រិយភាពខ្លាំងឡើងៗ ហើយ ដែលអាចនឹងទៅជាអ្នកទាមទាររាជបល្ល័ង្កមួយអង្គ ។ ប៉ុន្តែ ក្នុងសេចក្ដីទៀងត្រង់របស់ព្រះអង្គស្ដេចនរោត្ដម ប្រហែលជាជឿថា ពួបារាំងនឹងដឹងគុណពីការធ្វើអន្តរាគមន៍របស់ព្រះអង្គ ហើយនឹងនឹកឃើញអំពីសេចក្ដីត្រូវការចាំបាច់ដែលពុំអាចអត់ទ្រាំបានជាច្រើនរបស់ពួកគេមិនខាន ។

ព្រះមហាក្សត្របានធ្វើសេចក្ដីប្រកាសមួយ ដែលតាមរយៈនោះថា ពួកបារាំងបានថ្វាយអំណាចមួយផ្នែកធំមកឲ្យព្រះអង្គវិញ ដែលនេះជាការបំផ្លើសជ្រុលហួសហេតុមួយ បន្ទាប់មកព្រះអង្គបានយាងដោយផ្ទាល់ព្រះអង្គទៅកាន់ខេត្តនានាជាមួយនឹងកងរក្សាព្រះអង្គ ដើម្បីបញ្ចុះបញ្ចូលឲ្យប្រជារាស្ត្រដាក់អាវុធ និងបញ្ចប់ការបះបោរប្រឆាំង ។ ចំពោះរឿងនេះ វាមានការបំភាន់ គឺពួកបារាំងបំភាន់ស្ដេចនរោត្ដម ដោយធ្វើឲ្យព្រះអង្គជឿទុកចិត្តនូវអ្វីៗដែលព្រះអង្គចង់ជឿ ហើយរូបព្រះអង្គផ្ទាល់ ក៏បំភាន់ប្រជារាស្ត្រដែរ ដោយទទួលអះអាងនឹងប្រជាជនពីរឿងផ្សេងៗ ទោះបីជាព្រះអង្គលែងអាចធ្វើបានតាមពាក្យសន្យាក៏ដោយ ។

ប្រជាជនកម្ពុជាបានជឿព្រះមហាក្សត្ររបស់គេ ដោយសំអាងទៅលើព្រះបន្ទូលយ៉ាងម៉ឺងម៉ាត់ ។ ក្នុងរយៈពេលហាសិបឆ្នាំដែលមានជាបន្ទាប់មកទៀត ក៏នៅមានការតវ៉ាប្រឆាំងដាច់ពីគ្នាជាច្រើនថ្វីបើវាមានលក្ខណៈស្លុះស្លា ប្រឆាំងនឹងទិដ្ឋភាពកម្រោលឃោរឃៅបំផុតនៃការតាំងជាអាណានិគមរបស់បារាំងក៏ដោយ ក៏វាពុំមានការងើបបះបោរជាលក្ខណៈជាតិដែរ ។ ព្រះមហាក្សត្រត្រូវបារាំងទិញទឹកចិត្តបាន ។ ជាថ្នូរនឹងសិទ្ធិកាន់កាប់រាជបល្ល័ង្ករបស់ព្រះអង្គ ស្ដេចនរោត្ដម បានអនុញ្ញាតឲ្យប្រទេសបារាំងគ្រប់គ្រងដឹកនាំអាណាព្យាបាលរបស់ខ្លួនខ្លះៗដូចដែលប្រទេសបារាំងត្រូវរ៉ូវជាមួយព្រះអង្គ ។

វគ្គត្រង់នេះគឺជាហេតុសញ្ញាមួយនៃទំនាក់ទំនងទាំងឡាយរបស់ប្រទេសកម្ពុជាជាមួយពិភពលោកខាងក្រៅក្នុងជំនាន់គ្នានោះ ។ មហាអំណាចបរទេសមួយ (ក្នុងកាលៈទេសៈនេះ គឺប្រទេសបារាំង) បានជួយការពារប្រទេសឲ្យផុតពីកណ្ដាប់ដៃរដ្ឋដ៏មានគ្រោះថ្នាក់ ២ គឺវៀតណាម និងសៀម បន្ទាប់មក ក៏ក្បត់នឹងប្រទេសកម្ពុជា ដោយទាមទា ការត្រួតត្រាលើប្រទេសជាតិទាំងមូល ។ ប្រជាជនបានស៊ូមិនព្រមចុះចូល ប៉ុន្តែ បានត្រូវបង្អាក់ ដោយមេដឹកនាំម្នាក់ ដែលធ្លាប់ចុះញ៉មចំពោះមុខកម្លាំងរបស់បរទេស ។ ហើយដោយរឿងនេះអាចនឹងកើតមានឡើងវិញ នៅពេលក្រោយមកទៀត ព្រះរាជាអង្គនេះបានធ្វើអ្វីៗគ្រប់បែបយ៉ាង ដើម្បីនឹងឲ្យអ្នកទាំងឡាយដែលប្រឹងប្រែងរំដោះប្រទេសជាតិ ខ្វាតចេញពីឆាកនយោបាយទាំងអស់ និងពុំអាចធ្វើខ្លួន ជាគូប្រជែងរបស់ព្រះអង្គបានឡើយ ។ ប្រទេសកម្ពុជាបានងើបចេញពីបញ្ហាអស់នេះទាំងទ្រុឌទ្រោមជាមួយនឹងចំនួនមេដឹកនាំរបស់ខ្លួន ចេះតែថយតិចទៅៗក្រោមការត្រួតត្រាមួយរបស់បរទេស ដែលមានកម្លាំងខ្លាំងជាង ។

ពួកបារាំងបានយល់ដឹងមេរៀន នៃការបះបោរប្រឆាំងប្រកបដោយការឈ្លេងយល់មួយ ដែលនាំឲ្យអាម៉ាស់ ។ ពួកគេបានរក្សាទុកស្ដេចឲ្យនៅគ្រងរាជ្យដដែល បង្រួបបង្រួមបង្កើតក្រុមប្រឹក្សាមន្ត្រីក្នុងស្រុកមួយ ដើម្បីបិទបាំងការត្រួតត្រាប្រទេសទាំងស្រុងរបស់គេ ។ ការបះបោរប្រឆាំងជាច្រើនបានជួយ សង្គ្រោះរបបរាជា

ធិបតេយ្យឲ្យផុតពីគ្រោះថ្នាក់ ពួកបារាំងដឹងខ្លួនថាពួកគេ ខ្លួនពុំអាចយកប្រៀបលើស្តេចកាន់អំណាចផ្តាច់ការនៅប៉ែកបូព៌ាប្រទេស និងពួកមន្ត្រីដែលនៅអមព្រះអង្គបានឡើយ ។ ប្រហែលជាការបះបោរទាំងនោះ បានជួយសង្គ្រោះ ប្រទេសកម្ពុជាក្នុងឋានៈជាប្រជាជាតិមួយដូចគេដូចឯង ពីព្រោះជនជាតិបារាំងខ្លះដែលជាអ្នកប្រកាន់បក្សពួកចង់ឲ្យភ្ជាប់ប្រទេសកម្ពុជាទៅនឹងកូសាំងស៊ីន ជាភាគខាងត្បូងប្រទេសវៀតណាម -ភាគខាងជើងមានឈ្មោះថា តុងកឹង ហើយភាគកណ្តាលគេហៅថាអាណ្ណាម ។

ការប្រគល់អំណាចពិតប្រាកដបានដល់កំណត់ពេលប្រគល់ឲ្យពួកបារាំងទាំងអស់ អ្វីដែលប្រជាកសិករធ្លាប់ភ័យខ្លាចពន្ធអាករផ្សេងៗត្រូវបានបង្កើនប្រាក់កាសត្រូវគេបញ្ជូនទៅក្រុងហាណូយ ព្រៃនគរឬក្រុងប៉ារីស ។ ប្រទេសកម្ពុជាបានផ្គត់ផ្គង់ហិបប្រាក់របស់ប្រទេសបារាំង និងវៀតណាម ប៉ុន្តែ ពុំបានទទួលអ្វីជាថ្នូរមកវិញទេ ។ ពួកអន្តោប្រវេសន៍វៀតណាមយ៉ាងច្រើន បានធ្វើស្រែចម្ការលើដីធ្លីប្រទេសកម្ពុជា នេសាទក្នុងដែនទឹករបស់ខ្លួន និងជួយធ្វើការពួកបារាំងឲ្យគ្រប់គ្រងប្រទេសទៀត ។

ពួកបារាំងធ្លាប់វិនិច្ឆ័យថា ពួកវៀតណាមជាជាតិសាសន៍មួយដែលប៉ិនប្រសប់នៅពេលអនាគត ហើយជាតិសាសន៍ខ្មែរជាប្រជាជនមួយ ដែលខ្ជិលច្រអូស ដែលត្រូវតុលាការផ្តន្ទាទោសដោយបានប្រព្រឹត្តល្មើស ហើយថា ព្រះពុទ្ធសាសនា និងបណ្តាព្រះមហាក្សត្រ ដែលមានទ្រព្យសម្បត្តិហូរហៀរ បានដឹកនាំប្រទេសជាតិទៅដល់ភាពធ្លាក់ចុះអាប់ឱន ។ ពួកវៀតណាមបានទទួលយកភាពទំនើបដោយស្មោះស្ម័គ្រ ហើយហាក់ដូចជាបង្កើតឧបសគ្គដោយជំនឿណាមួយដែលតឹងរ៉ឹង ដែលហួសហេតុឡើយ ៖ លទ្ធិតាវនិយម ធ្វើឲ្យមនុស្សចាប់អារម្មណ៍ពីទ្រឹស្តីមួយ ដែលបដិសេធអាទិទេព ប្រៀបធៀបនឹងទស្សនៈដែលពួកបារាំងធ្លាប់វាយតម្លៃថា ព្រះពុទ្ធសាសនាចម្លែក និងផ្តាច់ពិភពលោកនេះពីប្រជាជនកម្ពុជា ។ ពួកអភិបាលបារាំងនៅកូសាំងស៊ីនពុំដែលលះបង់ចោលទាំងស្រុងនូវបំណងខ្ជាប់ខ្លួនរបស់គេ ដើម្បីភ្ជាប់ប្រទេសកម្ពុជាទៅនឹងវៀតណាមភាគខាងត្បូងឡើយ ជាមហិច្ចតាដែលវៀតណាមបានចិញ្ចឹមទុកក្នុងចិត្តខ្លួនឯងដែរ ។

ស្តេចនរោត្តម គោងតែសម្របខ្លួនទៅតាមស្ថានភាពប្រទេសជាតិ ដែលជារដ្ឋអាណាព្យាបាល ។ ក្រៅពីមជ្ឈដ្ឋានព្រះរាជបរិពារជាន់ខ្ពស់មានប្រជាជនតិចតួចប៉ុណ្ណោះ ដែលដឹងខ្លួនថា ពួកបារាំងបានដាក់នឹមត្រួតត្រាទាំងស្រុងមួយមកលើប្រទេសរបស់គាត់ ។ ព្រះអង្គ បានបាត់បង់កិត្តិយសមួយផ្នែកធំ និងប្រាក់ចំណូល ជាពន្ធអាករផ្សេងៗ ដែលចាំបាច់សម្រាប់ទ្រទ្រង់សន្ធាក់ នៃការរស់នៅរបស់ព្រះអង្គជាព្រះមហាក្សត្រ ។ ជាមនុស្សដែលមានចិត្តដូចអណ្តាតភ្លើង ព្រះអង្គបានរិះរកមធ្យោបាយ ដើម្បីបង្កើនប្រាក់ដាក់ក្នុងឃ្លាំងព្រះរាជទ្រព្យវិញ ដោយផ្តេកផ្តួលទៅក្នុងអំពើពុករលួយ ដោយលក់ដូរមុខតំណែង និងឯកសិទ្ធិផ្សេងៗម្តងម្កាលតាម ដែលព្រះអង្គអាចធ្វើបាន ។ ព្រះអង្គបានសោយទិវង្គតនៅដើមសតវត្សរ៍ទី២០ ជាព្រះមហាក្សត្រដែលត្រូវធ្វើឲ្យខូចព្រះទ័យ ដោយនិរទេសព្រះកាយដោយចិត្តឯង ទៅគង់ប្រថាប់នៅក្នុងព្រះរាជដំណាក់ផ្ទាល់របស់ព្រះអង្គ ។

ដោយផ្ទុយនឹងមតិទូទៅ ក្នុងលំដាប់ដែលអំណាចពិតៗរបស់ព្រះអង្គត្រូវកាត់បន្ថយ ព្រះរាជាបានបង្កើនកិត្យានុភាពរបស់ព្រះអង្គក្នុងចំណោមប្រជាជនឡើងវិញ ។ នៅពេលដែលជីវភាពប្រចាំថ្ងៃផ្ដល់ឲ្យគេនូវតឹកតាងថា ប្រទេសជាតិបានក្លាយទៅជាអាណានិគមមួយរបស់ប្រទេសបារាំង ប្រជាជនកម្ពុជាដែលមានជំនឿមួយយ៉ាងមុតមាំ បានបែរមករកព្រះរាជារបស់ខ្លួនវិញ ដែលជានិមិត្តរូប និងជាចន្ទល់មួយរបស់ប្រទេសជាតិ ។ និមិត្តរូបរបស់ប្រទេសកម្ពុជានេះ បានផ្ដើមឃ្លាតចេញពីអំណាចដឹកនាំប្រទេសកាន់តែខ្លាំងឡើងៗ ប៉ុន្តែ ប្រជាជនកម្ពុជានៅតែគោរពនិមិត្តរូបនេះ ពុំមែនគោរពអំណាចទេ ជាទម្លាប់ដែលរក្សាការយល់ប្រទូំទាំងឡាយឲ្យនៅស្ថិតស្ថេរហូតមក ហើយធ្វើឲ្យការបះបោរប្រឆាំងទាំងឡាយ មិនបានសម្រេចជោគជ័យទៀតផង ។ ចំពោះអ្នកទាំងឡាយដែលឡើងសោយរាជ្យបន្តពីស្ដេចនរោត្តម បានទទួលនូវមរតកផ្ទុយគ្នាមួយ ពីសេចក្ដីស្មោះត្រង់ប្លែកពីធម្មតារបស់ហ្វូងប្រជាជន ដែលប្រមូលផ្ដុំនូវការស្អប់ខ្ពើមមួយយ៉ាងខ្លាំងដូចវណ្ណៈក្រុមបញ្ញវន្ត ដែលដឹងថា ព្រះមហាក្សត្របានប្រព្រឹត្តបំពានអាណត្តិដ៏ពិសិដ្ឋ និងប្រទេសរបស់ព្រះអង្គ ។

ក៏ប៉ុន្តែ អាណានិគមកិច្ចរបស់បារាំង ក៏មានលក្ខណៈខ្លះដែលផ្ដល់គុណប្រយោជន៍ដល់ប្រទេសកម្ពុជាដែរ ដោយអាណានិគមកិច្ចនេះ បានជួយការពារប្រទេសពីការឈ្លានពានមួយរបស់បណ្ដាប្រទេសជិតខាងខ្លួនទាំងពីរ ។ ប្រជាកសិករខ្មែរលែងភៀសខ្លួនទៅប្រទេសថៃ ដើម្បីគេចចេញពីសង្គ្រាមផ្សេងៗ ដូចដែលពួកគេធ្លាប់បានធ្វើកាលពីសតវត្សរ៍ទី១៩នោះទៀតហើយ ហើយក៏លែងត្រូវចាប់នាំយកទៅ ដោយកងទ័ពសៀមដែលធ្វើប្រតិបត្តិការចូលលុកលុយប្រទេសដែរ ។ អ្នកទាំងនោះបានរស់នៅលើដីធ្លីរបស់គាត់ ហើយចាប់ផ្ដើមធ្វើស្រែលើដីទំនេរដែលគេបោះបង់ចោលពីពេលមុន ឡើងវិញដោយហេតុនេះបានធ្វើឲ្យផលិតផលស្រូវឡើងមួយកម្រិត ។ ចំនួនប្រជាជនបានកើនឡើងមួយជាបីក្រោមការត្រួតត្រារបស់បារាំង ដែលចេះបង្កឲ្យមានភាពសុខសាន្តថ្មីមួយ ខាងនយោបាយ និងត្រូវបង្អាក់ឱកាសនៃការបះបោរប្រឆាំងនឹងបារាំងតែប៉ុណ្ណោះ ហើយដែលកម្រនឹងកើតឡើងផង ។

ប៉ុន្តែ អ្វីដែលគេនាំមកច្រើនជាងគេ ប្រហែលជាវត្តមានរបស់បារាំងនោះហើយ គឺកិច្ចប្រឹងប្រែងផ្សេងៗរបស់ពួកអ្នកស្រាវជ្រាវមួយចំនួនតូច ដើម្បីធ្វើឲ្យគេស្គាល់ពីប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា ។ ការងាររបស់ពួកនេះ បាននាំទៅដល់មោទនភាពមួយរបស់ខ្មែរ ដែលរកឃើញឡើងវិញនៅក្នុងមរតករបស់ប្រទេសជាតិ និងផ្ដល់នូវគ្រឹះដល់មនោគមវិជ្ជារបស់ខ្មែរ ក្នុងសេចក្ដីប្រាថ្នាស្វែងរកភាពទំនើបតាមអាការៈដែលសម្ដែងចេញនៃប្រជាជាតិខ្មែរឯករាជ្យមួយ ។

គេមានការពិបាកស្រមៃឃើញប្រទេសកម្ពុជាជំនាន់នោះ ដោយគ្មានប្រាង្គប្រាសាទអង្គរដ៏បវរ ដែលជានិមិត្តរូបនៃវប្បធម៌របស់ខ្មែរទេ ។ រូបប្រាសាទអង្គរវត្ត បានត្រូវគេយកទៅលម្អនៅលើទង់ជាតិទាំងឡាយរបស់

ប្រទេសកម្ពុជាឯករាជ្យ ។ ក៏ប៉ុន្តែ មុនការមកដល់នៃពួកបុរាណវត្ថុវិទ្យា និងពួកប្រវត្តិវិទូបារាំង ប្រាសាទទាំងនោះគឺគ្រាន់តែជាសំណល់បាក់បែក ដែលគេបោះបោលដ៏កណ្តោចកណ្តែងនៅក្នុងព្រៃស្មសាន នាទិសពាយ័ព្យប្រទេសតាំងពី៣០០ឆ្នាំមុនប៉ុណ្ណោះ ។ ពួកបារាំងទាំងនេះ បានសម្រេចជោគជ័យ ធ្វើឲ្យការភ័យខ្លាចខ្មោចព្រាយអារក្សអ្នកតារបស់ប្រជាជនកម្ពុជា រលាយបាត់បង់អស់មួយចំនួនធំ ហើយនៅសតវត្សរ៍ទី១៩ គេបានចាប់ផ្តើមធ្វើការជួសជុលប្រាសាទឡើងវិញ ទន្ទឹមនឹងការមើលអក្សរបុរាណនៃអតីតកាលរបស់កម្ពុជា ដែលកប់នៅក្នុងដីទៀតផង ។ នៅពេលដែលអ្នកទាំងនេះ ត្រូវបញ្ចប់កិច្ចការរបស់ពួកគេ ក្នុងអំឡុងទសវត្សរ៍១៩៦០ ពួកបារាំងបានបង្ហាញភ័ស្តុតាងឲ្យឃើញថា ជនជាតិខ្មែរមានឋានៈតួនាទីដូចពួកសិល្បកររ៉ូម៉ាំង និងក្រិកដែរ ក្នុងចំណោមពួកសិល្បករ និងពួកអ្នកកែប្រែឲ្យមានរបៀបថ្មី ដែលគ្មានគូប្រដូចនាសម័យបុរាណ ។

ស្នាដៃរបស់អ្នកស្រាវទាំងនេះបានមានឡើងដំណាលគ្នា នឹងការជជែកពិភាក្សាខាងនយោបាយនៅប្រទេសបារាំងដែរ ស្តីពីឥរិយាបថ ដែលពួកអាណានិគមបារាំងត្រូវប្រកាន់យកចំពោះវប្បធម៌ផ្សេងៗ របស់អ្នកស្រុកចំពោះដែនដីដែលវាយបានរបស់គេ ។ បញ្ហាដែលត្រូវដឹងគឺថា ឬមួយប្រទេសបារាំងត្រូវបង្ខិតបង្ខំឲ្យប្រជាជនដែលគេតាំងអាណានិគម លាយបញ្ចូលវប្បធម៌របស់ខ្លួនជាមួយវប្បធម៌បារាំង ហើយប្រែក្លាយទៅជាអាណិកជននៃមហាសហគមន៍ក្នុងតំបន់ (មានប្រទេសខ្មែរ វៀតណាម និងឡាវ) ឬមួយក៏អនុញ្ញាតឲ្យវប្បធម៌ក្នុងស្រុកនៅគង់វង្សអែបនឹងវប្បធម៌បារាំងដែរ ទោះជាយ៉ាងណាក៏ដោយ ក៏បញ្ហាអស់នេះមានតែវរជនក្នុងស្រុកប៉ុណ្ណោះ ដែលមានសមត្ថភាពលាយបញ្ចូលវប្បធម៌ទាំងពីរបាន ។ សំណើចុងក្រោយនេះបានទទួលជោគជ័យ នៅក្នុងកិច្ចពិភាក្សានោះ សម្រាប់ហេតុផលផ្សេងៗខាងអនុវត្តដក៏ដូចខាងនយោបាយ ។

ការធ្វើឲ្យប្រជាជនដែលកើតក្នុងស្រុកប្រែក្លាយទៅជាពលរដ្ឋ ចេះនិយាយ និងធ្វើបុកពាដូចពលរដ្ឋខ្លួននោះនឹងនាំឲ្យខាតបង់ច្រើនហួសប្រមាណ ។ ម្យ៉ាងវិញទៀត នយោបាយនេះ នឹងបង្កឲ្យមានរឿងរ៉ាវជាច្រើនជាមួយពលរដ្ឋម្ចាស់ស្រុក ដែលកំពុងប្រយុទ្ធនឹងប្រទេសបារាំងដោយត្រឹមត្រូវ ពីព្រោះការតាំងជាអាណានិគមបានឲ្យប្រផ្នូលពីទីបញ្ចប់នៃវប្បធម៌ និងទំហំប្រទេសជាតិខ្លួនបានមកដល់ហើយ ។ ពួកអ្នកស្រាវជ្រាវបារាំង ដែលខំប្រឹងប្រែងកែលម្អការយល់ដឹងរបស់បារាំង ចំពោះពិភពនៅបូព៌ាទិសឲ្យល្អប្រសើរជាងមុននោះ គឺសុទ្ធតែជាអ្នកកាន់ទង់នាំមុខអ្នកនយោបាយនានា ដែលមានបំណងការពារវប្បធម៌ទាំងឡាយក្នុងស្រុកអាយទាំងនេះ ។ ពួកអ្នកស្រាវជ្រាវទាំងនោះ បានផ្តល់ទឡ្ហីករណ៍ថ្មីមួយ ដែលឲ្យប្រយោជន៍ដល់ការរក្សាប្រទេសកម្ពុជា ជាប្រទេស ដោយឡែក និងជួយធ្វើឲ្យពួកអ្នកត្រួតត្រាបារាំងនៅក្រុងព្រៃនគរ ដែលនៅបន្តប្រើកលល្បិចផ្សេងៗ ដើម្បីបញ្ចូលកម្ពុជាទៅក្នុងកូសាំងស៊ីននោះមិនបានសម្រេចជោគជ័យទៀតផង ។

លទ្ធផលនៃកិច្ចការទាំងនោះ បានសម្រេចជោគជ័យជាងការពិភាក្សាខាងនយោបាយ ដែលប្រព្រឹត្តឡើងជាបន្តបន្ទាប់នោះទៅទៀត ។ អស់រយៈពេលជិតមួយសតវត្សរ៍ ក្នុងការងារដ៏នឿយលំបាក ពួកបុរាណវត្ថុវិទូ

ពួកប្រវត្តិវិទូ និងពួកអ្នកប្រាជ្ញខាងភាសារបស់បារាំង បានប្រោះព្រំឲ្យប្រវត្តិសាស្ត្រកម្ពុជា និងព្រលឹងជាតិខ្មែរ មានជីវិតជាថ្មីឡើងវិញ ។ នៅជុំវិញអង្គរពួកបារាំងបានជួសជុលប្រាសាទចំនួន ចិតសិបពីរ ឡើងវិញ ដែលក្នុងនោះមានប្រាសាទអង្គរវត្តផង ។ កិច្ចការទាំងនេះ បានរួមបន្ថែជាផ្នែកសំខាន់មួយក្នុងការស្រាវជ្រាវប្រវត្តិសាស្ត្រ ដោយហេតុថា សំណង់ទាំងនោះបានផ្ដល់នូវតម្លៃដ៏លើសលុបមួយ ដើម្បីបកស្រាយពីប្រភពនៃអំណាចរបស់ក្រុងអង្គរ, ការយល់ដឹងពីខ្លួនឯង និងមូលដ្ឋាន នៃគំណរាជ្យព្រះមហាក្សត្រតាមពូជពង្សព្រះរាជវង្សរបស់ខ្លួន ។ គឺក្នុងរយៈពេលនៃការជួសជុលប្រាសាទឡើងវិញ ដែលពួកអ្នកបុរាណវត្ថុវិទូបារាំង បានចេញផ្សាយសៀវភៅស្ដីពីអាងទឹក, ទំនប់ទឹក និងថ្នល់ ជាទំនប់នៃអតីតប្រព័ន្ធបញ្ចេញបញ្ចូលទឹកក្នុងស្រែ ។ មួយចំណែកធំនៃអ្វីដែលគេដឹងសព្វថ្ងៃនេះពីអតីតកាលប្រទេសកម្ពុជា រកឃើញដោយពួកអ្នកស្រាវជ្រាវបារាំងទាំងនេះ ។

ស្នាដៃរបស់អ្នកទាំងនោះ បានមានលទ្ធផលជាថ្នាំលើកកម្លាំងមួយមកលើជនជាតិខ្មែរ ដែលសេចក្ដីថ្លៃថ្នូរធ្លាប់ត្រូវជាន់ឈ្លីដោយប្រទេសសៀម វៀតណាម និងពួករដ្ឋបាលបារាំង ជារឿយៗ ។ ប្រជាជនកម្ពុជានៃសតវត្សរ៍ទី១៩ ធ្លាប់មានអតីតកាលមួយ ដែលពួកគេអាចវាយឫកក្រអឺតថា ខ្លួនគ្រាន់បើជាងគេ ។ ដោយការរកឃើញដែលមានន័យជាប្រវត្តិសាស្ត្រនេះ ពួកបារាំងបានផ្ដល់កម្លាំងចិត្តដល់ស្ថាប័ននានា របស់ខ្មែរ ដែលកំពុងចុះដុនដាបនូវថាមពលមួយថ្មីឡើងវិញ ដោយបានបង្កើតឲ្យមានសាលាពុទ្ធិកៈជាច្រើនសមស្របទៅតាមប្រពៃណីព្រះពុទ្ធសាសនា និងរាជាធិបតេយ្យថែមទៀត ។

មានតែមនុស្សប្រុសនិងស្រីមួយចំនួនតូចប៉ុណ្ណោះ ដែលទទួលខុសត្រូវមួយចំណែកធំក្នុងកិច្ចការទាំងនេះ ។ ក្នុងចំណោមនោះ គឺមានស្រីដ៏ឆ្នើមម្នាក់ឈ្មោះ ស៊ុយហ្សាន កាប៉ីឡេស[៨] *(Suzanne Karpelès)* ដែលជាអ្នកជួយធ្វើឲ្យព្រះពុទ្ធសាសនារីកលូតលាស់ឡើងវិញក្នុងសភាពស្ងប់ស្ងាត់មួយ មុននឹងជួយទ្រទ្រង់ចលនាទាមទារឯករាជ្យរបស់កម្ពុជា នៅពេលក្រោយមកទៀត ។ នាងជាបុគ្គលិកធ្វើការនៅសាលាបារាំង ចុងបូព៌ាប្រទេស នៅទីក្រុងហាណូយ ដែលនៅពេលនោះជាមជ្ឈមណ្ឌលសិក្សាពីភាសា និងអារ្យធម៌ បូព៌ាប្រទេសដ៏សំខាន់បំផុតក្នុងពិភពលោក ។ កាប៉ីឡេស បានធ្វើដំណើរមកកាន់ទីក្រុងភ្នំពេញ ដើម្បីរៀបចំបង្កើតរាជ្យបណ្ណាល័យឲ្យទៅជាកន្លែងមួយ សម្រាប់ទុកដាក់ឯសារផ្សេងៗ និងសាស្ត្រាស្លឹករឹត ដែលមិនអាចជំនួសបានខាងសាសនា ដែលនាងប្រមូលបានយ៉ាងច្រើន ដើម្បីការពារថែទាំ ក៏ដូចដើម្បីធ្វើឲ្យព្រះសង្ឃខ្មែរទាំងឡាយយល់ដឹងនូវអត្ថបទទាំងនោះ ដែលគ្មានអ្នកណាម្នាក់យកចិត្តទុកដាក់អស់រយៈពេលជាយូរមកហើយ ។

បេសកកម្មរបស់នាង ស្ថិតនៅលើការអប់រំព្រះសង្ឃជាថ្មី ក្នុងជំនឿសាសនាជាប្រពៃណីរបស់ខ្លួន និងកម្ចាត់ចោលទម្លាប់ជឿខ្មោចព្រាយ អ្នកតា បានមួយចំណែកធំ ដែលធ្លាប់«ធ្វើឲ្យខូច»តម្លៃព្រះពុទ្ធសាសនាថេរវាទ -ហីនយាន- នៅឥណ្ឌូចិន ។ រាជ្យបណ្ណាល័យបានបង្កើតវិទ្យាស្ថានពុទ្ធសាសនបណ្ឌិតនៅឆ្នាំ១៩៣០ ជាមជ្ឈមណ្ឌលតែមួយគត់របស់កម្ពុជា ដែលបានទាក់ទាញនិស្សិតជាច្រើនពីរដ្ឋអាណានិគមដទៃទៀត នៅឥណ្ឌូចិន

ជាពិសេសជនជាតិភាគតិចខ្មែរ ដែលកំពុងរស់នៅកូសាំងស៊ីន ។ (អ្នកកាន់ពុទ្ធសាសនាវៀតណាម ដែលមានភាគតិចនៅក្នុងប្រទេសខ្មែរ គឺប្រតិបត្តិព្រះពុទ្ធសាសនាមហាយាន) ។

ប្រជាជនកម្ពុជនៅភាគខាងត្បូងវៀតណាមទាំងនោះ គឺពួកខ្មែរក្រោម ក៏មានរួមបញ្ចូលក្នុងគម្រោងការដ៏ទូលំទូលាយរបស់កាប៉ីឡេសដែរ សម្រាប់ជួយធ្វើឲ្យវប្បធម៌ ភាពថ្លៃថ្នូរ និងការស្វែងរកឧត្តមគតិរបស់កម្ពុជាមានជីវិតជាថ្មីឡើងវិញ ។ នាងបានសិក្សាពីជនជាតិភាគតិចខ្មែរ នៅភាគខាងត្បូងវៀតណាមទាំងនោះ ហើយបានលើកទឹកចិត្តឲ្យប្រជាជន កម្ពុជានឹកឃើញថា កាលពីដើម ដីសណ្តទន្លេមេគង្គទាំងមូល គឺជាកម្មសិទ្ធរបស់ខ្លួន ។ (តាមពិត ផ្នែកខាងក្រោមដីសណ្តនេះ ត្រូវកម្ពុជាកាន់កាប់មួយរយៈពេលខ្លីប៉ុណ្ណោះ គឺប្រហែលមួយសតវត្សរ៍ ។ កាលពីមុនទីនោះ ជាប្រទេសរបស់ជនជាតិចាម ដែលជាភាគីប្រជែងមួយក្នុងចំណោមភាគីប្រជែងទាំងឡាយរបស់ខ្មែរ) ។ ក្រោយមក ជនអន្តោប្រវេសន៍ខ្មែរក្រោមទាំងនោះ បានក្លាយទៅជាអ្នកជាតិនិយម ដែលមានចិត្តមោះមុតបំផុត និងជាទាហានថ្មី ដែលពួកសេ.អ៊ី.អា. ក៏ដូចរបបសាធារណរដ្ឋខ្មែររបស់ លន់ នល់ ចូលចិត្តជ្រើសរើសជាងគេ ។

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ បានប្រែក្លាយយ៉ាងឆាប់រហ័សទៅជាសំបុកសម្រាប់ការធ្វើសកម្មភាពថ្មីមួយរបស់បញ្ញវន្ត ក្នុងសម័យកាលដ៏សំខាន់ចន្លោះសង្គ្រាម ។ ពួកបារាំងមិនបង្កើតប្រព័ន្ធសាលារៀនសម្រាប់ប្រជាជនជាគ្រហស្ថនៅប្រទេសកម្ពុជាទេ ប៉ុន្តែ គ្រាន់តែកែប្រែការសិក្សាដែលបង្រៀនដោយព្រះសង្ឃនៅតាមសាលាវត្តនានា របស់អ្នកស្រុកប៉ុណ្ណោះ ។ ដោយហេតុនេះយុវជនខ្មែរមួយភាគធំ សុទ្ធតែបានទទួលការបង្ហាត់បង្រៀនដោយព្រះសង្ឃទាំងឡាយ ដែលទទួលខុសត្រូវការបង្រៀនកម្រិតខ្ពស់របស់ប្រទេស -ដែលពិជាខ្ពស់ជាងនៅប្រទេសវៀតណាម- ហើយវិទ្យាស្ថានបានលេចឡើងជាកន្លែងបញ្ចប់ខ្ពស់បំផុត នៃការអប់រំផ្នែកពុទ្ធសាសនានៅប្រទេសកម្ពុជា ។ វិទ្យាស្ថានបានពន្យល់ឲ្យបោលគំនិត ធ្វើដំណើរទៅប្រទេសថៃ ដើម្បីរៀនបញ្ចប់មុខវិជ្ជារបស់ខ្លួនខាងផ្នែកសាសនា ៖ នៅក្រុងបាងកក ប្រជាជនកម្ពុជាទាំងនោះ មិនគ្រាន់តែបានរៀនសូត្រជាមួយ ព្រះសង្ឃថៃដោយងាយប៉ុណ្ណោះទេ ប៉ុន្តែ ក៏បានរៀនពីគំនិតប្រឆាំងបារាំង ដែលផ្តល់នូវគ្រោះថ្នាក់ ។

ពួកបារាំងបានពង្រីកវិស័យវប្បធម៌ផ្សេងៗថែមទៀត ជាពិសេស ខាងវិស័យសិល្បៈ ។ ពួកនេះ បានរៀបចំក្រុមរបាំព្រះរាជទ្រព្យឡើងវិញ ស្ថាបនាសារមន្ទីរផ្សេងៗ និងកសាងសាលាជាច្រើន ដែលនៅទីនោះគេបានបង្រៀនពីសិល្បៈរបស់ខ្មែរដល់យុវជនស្រករក្រោយៗទៀត ។ នៅឆ្នាំ១៩២០ លោកហ្សរ័ ក្រូសលីយេ (Georges Groslier) បានបង្កើតសាលាសិល្បៈរបស់កម្ពុជា ដើម្បីលុបបំបាត់និន្នាការផ្សេងៗ ដែលបន្តឡើងដោយនយោបាយសេដ្ឋកិច្ចអាណានិគម ។ ការយកពន្ធដារយ៉ាងធ្ងន់ធ្ងរលើផលិតផលក្នុងស្រុក និងការនាំចូលទំនិញបស្ចិមប្រទេស ដែលមានតម្លៃថោកៗ បានធ្វើឲ្យទីផ្សារលក់វត្ថុសិល្បៈខ្មែរស្រុតចុះ ។ ព្រះសង្ឃដែលពីដើមធ្លាប់ជួយជ្រោមជ្រែងបណ្តាសិប្បករក្នុងស្រុក លែងហ៊ានផ្តល់ទុនជួយសិល្បករណ្ឌប្រទេសទៀតហើយ ហើយទិញ

*ផ្កាក្រដាស និងទំនិញបស្ចិមប្រទេសសម្រាប់ដាក់លើអាសនៈតាមវត្តវិញ សាលារបស់ ក្រូលីយេ បានធ្វើឲ្យទម្លាប់ជាប្រពៃណីរបស់សិប្បករ ដែលរកស៊ីតែម្នាក់ៗឯងនោះមានជីវិតជាថ្មី ហើយបានការពារវិចិត្រកម្មការឆ្លាក់លើគ្រឿងប្រាក់ និងស្នាដៃរបស់ជាងចម្លាក់ទៀតផង ។*

*ការគ្រប់គ្រងរបស់អាណានិគម គ្មានបានធ្វើអ្វីជាដុំកំភួន ដើម្បីជួយជំរុញសេដ្ឋកិច្ចខ្មែរឲ្យមានសន្ទុះជាថ្មី ហើយស្ទើរតែគ្មានការប៉ុនប៉ងនវូបនីយកម្មណាមួយសោះឡើយ ។ ក្នុងឥណ្ឌូចិន ដែលជាអាណានិគមរបស់បារាំង ការពង្រីកវិស័យសេដ្ឋកិច្ចបានប្រមូលផ្ដុំ ជាពិសេស លើវិស័យកសិកម្ម និងការរុករកអណ្ដូងរ៉ែ ជាពិសេសនៅវៀតណាមខាងត្បូង ។ នៅប្រទេសកម្ពុជា ពួកបារាំង បានរៀបចំធ្វើដំណាំចម្ការធំៗភាគច្រើន គឺកៅស៊ូ ប៉ុន្តែក៏មានកាហ្វេ និងដំណាំសម្រាប់នាំចេញផ្សេងៗទៀតដែរ ។ ពួកបារាំង បានជួយឲ្យលូតលាស់ដោយមិនចំពោះដល់ផ្នែកតែមួយគត់ខាងវិស័យសេដ្ឋកិច្ច គឺពួកចិនរកស៊ីយកការប្រាក់ហួសប្រមាណ ដោយតម្រូវឲ្យសងផលដំណាំមកវិញយ៉ាងធ្ងន់ ។ កសិករទាំងឡាយ បានប្រឆាំងតបតដោយផ្ដើមបង្ហាញឲ្យឃើញការមិនសូវបង្កបង្កើនផលិតផលស្រូវរបស់គាត់ទេ ។ សារពើពន្ធដ៏ធ្ងន់ធ្ងរ និងបំណុលផ្សេងៗចំពោះពួកអ្នកចងការប្រាក់ បានធ្វើឲ្យប្រជាកសិករធ្លាក់ទៅក្នុងជីវភាពក្រីក្រមួយថ្មី ដែលជារឿយៗឃើញថា មានភាពដូចនរក ។*

*ចំពោះពួកអ្នកត្រួតត្រាបារាំងយល់ថា ប្រតិកម្មនេះ បានបញ្ជាក់បន្ថែមចំពោះសម្ដីដែលគេខស្វាហ៍និយាយថា ប្រជាជនកម្ពុជាជាមនុស្សខ្ជិលច្រអូសនោះ រឹតតែច្បាស់ឡើងថែមទៀត ។ ស្ត្រីប្រវត្តិវិទូអាមេរិកាំងម្នាក់ឈ្មោះ វៀហ្សីនីញ៉ា ថុមសុន (Virginia Thompson) ដែលធ្លាប់មកធ្វើទស្សនកិច្ចនៅឥណ្ឌូចិន បានអធិប្បាយរៀបរាប់ពីអាកប្បកិរិយារបស់ពួកបារាំងចំពោះប្រជាជនម្ចាស់ស្រុក ក្នុងអត្ថបទមួយនាឆ្នាំ១៩៣៧ថា "ភាពផ្ទុយគ្នា បានធ្វើឲ្យគេចាប់អារម្មណ៍យ៉ាងខ្លាំង រវាងអតីតកាលដែលមានឈ្មោះដ៏ល្បីល្បាញមួយ និងបច្ចុប្បន្នកាលដែលមិនចេះកើតទុក្ខ និងសប្បាយរីករាយមួយ និងអនាគតកាល ដែលនាំឲ្យវិនាសហិនហោចមួយ...។ ជនជាតិបារាំងជាច្រើនគិតថា ពួកគេស្ទើរតែគ្មានសង្ឃឹមថា អាចកែកុនពូជសាសន៍មួយ ដែលរកកលតែវិនាសទៅហើយនោះណាស់ ដោយប្រជាជនទាំងនេះគ្មានប្រឹងប្រែងធ្វើអ្វីមួយដើម្បីជួយខ្លួនឯងទាល់តែសោះ ។ ជនជាតិខ្មែរទាំងនេះ នឹងពុំអាចធ្វើឲ្យបានស្មើនឹងបុព្វបុរសរបស់ខ្លួនជាដរាប បើនិយាយអំពីសិល្បៈ នយោបាយ ឬផ្នត់គំនិត ។ អនាគតសេដ្ឋកិច្ចរបស់គេមានលក្ខណៈរកទុកចិត្តមិនបានឡើយ ។ ពួកនេះ សុទ្ធតែត្រូវទោសឲ្យរលាយសាបសូន្យនៅចំពោះមុខពួកអន្តោប្រវេសន៍វៀតណាម..."[៧] ។*

*ប្រជាជនកម្ពុជាទាំងអស់ដូចសម្ដេច ព្រះនរោត្តម សីហនុ និង ប៉ុល ពត ដែរ បានចម្រើនវ័យធំធាត់ជាមួយនឹងការផ្ដន្ទានេះពីសំណាក់ពួកអ្នករំលោភបៀតបៀនជាបរទេស ។ ពួកបារាំងបាននាំយកកម្មករវៀតណាមក្រោមកិច្ចសន្យាមកធ្វើការនៅចម្ការកៅស៊ូនានារបស់កម្ពុជា ជាជាងទុកចិត្តជាតិខ្មែរ "ដែលខ្ជិលច្រអូស" ។ ពួកបារាំងពុំបានជួយជំរុញការអប់រំតាមសម័យទំនើបផងទេ ៖ ប្រទេសកម្ពុជាពុំមានវិទ្យាល័យបារាំងនៅឡើយ*

មុនឆ្នាំ១៩៣៥ ហើយភាគច្រើននៃកូនសិស្សវិទ្យាល័យ សុទ្ធតែវៀតណាម និងបារាំង ។ ពួកកូនចៅរបស់វរជនកម្ពុជា ដូចជាសម្ដេច ព្រះនរោត្ដម សីហនុ ជាព្រះនត្តាព្រះមហាក្សត្រនរោត្តមជាដើម ត្រូវគេបញ្ជូនឲ្យទៅរៀននៅវិទ្យាល័យនានារបស់បារាំងនៅប្រទេសវៀតណាមឯណោះ ។

ចំណែកនៅកម្ពុជា ពួកបារាំង ពុំបានបង្កើតរដ្ឋបាលទូលំទូលាយជាមួយមន្ត្រីក្នុងស្រុកដូចនៅវៀតណាមទេ ហើយជនជាតិវៀតណាម នៅតែបន្តទទួលបន្ទុកធ្វើកិច្ចការរដ្ឋបាលផ្សេងៗនៅក្រុងភ្នំពេញដដែល ។ ក្នុងប្រទេសពុំមានវរជនថ្មី ដែលបានទទួលគុណប្រយោជន៍ពីការអប់រំទំនើបមួយសម្រាប់ប្រឆាំង នឹងពួកបារាំងដែរ ហើយដោយក្រុមមន្ត្រីអមព្រះរាជា ទ្រទ្រង់ការត្រួតត្រារបស់បរទេសយ៉ាងមាំទាំ ប្រទេសកម្ពុជានៅតែ ជាអាណានិគមមួយដែលងាយដឹកដដែល ។ នៅទីបំផុតសមាគមអ្នកកាន់ពុទ្ធសាសនា ជាស្ថាប័នរបស់កម្ពុជាតែមួយគត់ដែលមានឥទ្ធិពលខ្លាំងគួរសមបានចាប់ផ្ដើមគាំទ្រដល់មនោសញ្ចេតនាប្រឆាំងបារាំង និងដើម្បីបន្ថែមហេតុនឹងព្រះមហាក្សត្រថែមទៀត ។ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យរបស់ កាប៉ីឡេស បានក្លាយទៅជាសំបុកប្រឆាំងអាណានិគមមុនគេបង្អស់នៅក្រុងភ្នំពេញ ។

ព្រះសង្ឃទាំងឡាយ មានលក្ខណសម្បត្តិយ៉ាងគ្រប់គ្រាន់ដើម្បីនាំប្រទេសកម្ពុជាឈានទៅកាន់សម័យនយោបាយទំនើបមួយ ។ ក្រោមការជួយទំនុកបម្រុងរបស់បារាំងដូចនាង កាប៉ីឡេស ជាដើម ព្រះសង្ឃទាំងនោះបានពួតដៃជួយគ្នាក្នុងចំណោមប្រជាជនកម្ពុជាដ៏កម្រទាំងឡាយ ដែលប្រៀនប្រដៅឲ្យដឹងពីទស្សនៈផ្សេងៗនៃពិភពលោកទំនើប ។ រឿងដែលសំខាន់ គឺពួកគេបានទទួលចំណេះដឹងទាំងនេះ ដោយមិនធ្វើឲ្យខូចខាតដល់អត្តសញ្ញាណជាតិខ្មែររបស់គេឡើយ ។ បណ្ដាសមាជិកភាគច្រើននៃវរជនតូចតាចរបស់កម្ពុជា មានការយល់ដឹងយ៉ាងប្រសើរមួយអំពីទម្លាប់របស់បារាំង ប៉ុន្តែ បានធ្វើឲ្យខូចកេរ្ដិ៍ឈ្មោះប្រទេសជាតិ ដោយសារតែការព្រមទទួលនឹមអាណានិគមរបស់គេ ។

នេះជាលើកទីពីរហើយ ដែលព្រះសង្ឃទាំងនោះបានសម្ដែងតួជាភ្នាក់ងារធ្វើឲ្យមានការផ្លាស់ប្ដូរនៅកម្ពុជា ។ ប្រាំពីររយឆ្នាំមុន ក្នុងរយៈពេលនៃការធ្លាក់អាប់ឱនរបស់រាជាណាចក្រអង្គរ បុព្វាធិការី (អ្នកកាន់តំណែងមុន) របស់គេធ្លាប់បានទេសនាផ្សព្វផ្សាយពីសាសនាថ្មី គឺព្រះពុទ្ធសាសនាថេរវាទចំពោះប្រជាជនកម្ពុជាចាស់ទុំទាំឡាយ ដើម្បីញុំាងឲ្យដូរសាសនាចេញ ។ ភាពស្មុគស្មាញផ្នែកនយោបាយ ចរិយាធម៌ និងសីលធម៌ របស់រាជាណាចក្រនៅពេលនោះបានចោទឡើង ហើយប្រជាជនកម្ពុជាទាំងមូលបានប្ដូរចិត្តគំនិតមកជឿលើសាសនាថ្មីវិញ ដោយនាំមកនូវភាពសុខសាន្តក្នុងសង្គមជាតិ មួយដោយរលាស់ចោលការប្រណាំងប្រជែង ស្វែងរកផលប្រយោជន៍ខាងសម្ភារ និងអំណាចចេញអស់ពីខ្លួន ។ គ្រងចីពរពណ៌លឿងយ៉ាងសាមញ្ញ ព្រះសង្ឃថ្មីទាំងនោះយល់ថា ព្រះអង្គជាអ្នកទទួលខុសត្រូវលើអ្វីៗទាំងអស់ មិនមែនមានតែបណ្ដាសមាជិកនៃវណ្ណៈអភិជននោះទេ ។

នៅទីបំផុត ព្រះសង្ឃបានសម្រេចធ្វើខ្លួនឲ្យគេគោរពបូជាដូចទេវរាជាដែរ ដែលបានដូរព្រះទ័យមកជឿលើព្រះពុទ្ធសាសនាថេរវាទដូចគ្នា ហើយបានក្លាយទៅជាអ្នកការពារសាសនាទៀតផង ។

នៅសតវត្សរ៍ទី២០ ព្រះសង្ឃទាំងអស់បានប្រើប្រាស់ផលនៃអំណាចប្លែកពីធម្មតាមួយ ថ្វីបើសភាពក្រៅមើលទៅ ដូចជាអ្នកដាក់ព្រះកាយក៏ដោយ ។ នៅពេលព្រឹកព្រហាម ព្រះសង្ឃទាំងឡាយបាននិមន្តទៅកាន់ផ្ទះរបស់អ្នកភូមិ ព្រះកេសឱនចុះ និងយកបាត្រទទួលចង្ហាន់ពីអ្នកស្រុក ។ ព្រះអង្គបាននិមន្តទៅបង្ហាត់បង្រៀនក្មេងៗ ចិញ្ចឹមពួកក្មេងកំព្រា ចងក្រងក្បួនច្បាប់ ចរិយាធម៌ និងច្បាប់សង្គម ប្រៀនប្រដៅអំពីឥរិយាបថ ដែលត្រូវប្រតិបត្តិក្នុងទិដ្ឋភាពផ្សេងៗ ដែលមានប្រចាំថ្ងៃ ឬដែលចាំបាច់ក្នុងជីវភាពរស់នៅរបស់ភូមិស្រុក ។ ជាថ្នូរមកវិញ កសិករទាំងឡាយបាននាំគ្នាកសាងវត្តអារាម ព្រះវិហារ កុដិ សាលាឆាន់ និងធ្វើតាមការទូន្មានប្រៀបប្រដៅរបស់ព្រះសង្ឃទាំងនោះផង ។ ព្រះសង្ឃទាំងឡាយ ធ្លាប់ប្រមូលបានពីសហគមន៍ជាតិខ្លួននូវស្ថានភាពខាងផ្លូវចិត្តជាឯកច្ឆ័ន្ទមួយចៀសផុតពីឆន្ទៈរបស់ស្ដេច ដែលធ្វើអ្វីៗដោយគ្មានគិតពិចារណាវែងឆ្ងាយឡើយ ។

នៅទីបំផុតព្រះសង្ឃពុទ្ធសាសនាជាជនកម្ពុជាតែមួយគត់ ដែលមានឥទ្ធិពលអាចបង្កហេតុជាមួយពួកបារាំងនិងព្រះរាជាបាន ។ ខុសប្លែកពីប្រទេសវៀតណាម និងប្រទេសដទៃទៀត ដែលកាន់ទំនៀមទម្លាប់ចិន ប្រទេសកម្ពុជាពុំទាន់មានវណ្ណៈមន្ត្រីដ៏មានអំណាចខ្លាំងមួយ ដូចមន្ត្រីស្រុកចិនជាន់ដើមនៅឡើយទេ ប៉ុន្តែ គឺមានតែវណ្ណៈអប្បជនាធិបតេយ្យប៉ុណ្ណោះ (ជារបៀបគ្រប់គ្រងដែលស្ថិតនៅក្នុងកណ្ដាប់ដៃមនុស្សពី៤ទៅ១០នាក់) ដែលទទួលរ៉ាប់រងការដឹកនាំប្រទេសជាតិ ហើយដែលភ័ព្វសំណាងរបស់គេត្រូវពឹងផ្អែកលើព្រះមហាក្សត្រមួយភាគយ៉ាងធំ ។ ព្រះសង្ឃទាំងឡាយត្រូវបានទទួលស្គាល់ថា ជាក្រុមស្វ័យតមួយ ដែលកំពុងការពារតម្លៃផ្សេងៗ និងវប្បធម៌របស់ប្រទេសជាតិ ។ ហើយនៅ ពេលដែលសន្តរបុគ្គលទាំងនេះចាប់ផ្ដើមចោទប្រកាន់ចំពោះការត្រួតត្រារបស់បារាំង ការចោទសួរទាំង ឡាយរបស់ព្រះអង្គ បានបង្កឲ្យមានការភ្ញាក់រលឹកយ៉ាងជ្រាលជ្រៅមួយរបស់ប្រជាជននៅទូទាំងប្រទេស ។

ព្រះសង្ឃមួយចំនួន បានប្រឆាំងតវ៉ានឹងពួកបារាំងតាំងពីដំបូងដៃ ។ មុនការងើបបះបោរនៅឆ្នាំ១៨៨៥ ព្រះសង្ឃពីរអង្គបាននិមន្តទៅទេសនាប្រឆាំងនឹងពួកអាណានិគម នៅតាមភូមិនានារបស់កម្ពុជារួចទៅហើយ ដោយអំពាវនាវឲ្យប្រជាកសិករងើបបះបោរប្រឆាំងឡើង ដើម្បីរំឭកអនុស្សាវរីយ៍នៃភាពថ្កុំថ្កើងរុងរឿងកាលពីអតីតកាល ។ សេចក្ដីរាយការណ៍មួយរបស់បារាំងនៅសម័យនោះបានឲ្យដឹងថា “អ្នកដើរទេសពីរនាក់នេះស្ថិតក្នុងចំណោមតំណាងរបស់ព្រះជាច្រើននាក់ ដែលស្រមើស្រមៃចង់ស្ដាបនាព្រះរាជាណាចក្រកម្ពុជាឡើងវិញក្នុងភាពរុងរឿងរបស់ខ្លួនកន្លងមក[១០] ដោយនិយាយអួតខ្លួនថាជាអ្នកមានអំណាចអធិធម្មជាតិមួយ” ។ ព្រះសង្ឃដទៃទៀតដែលប្រឆាំងបារាំងក៏បានដើរតាម ។ ព្រះសង្ឃទាំងនេះបានឈានដល់គោលដៅបង្កើតកងទ័ពមួយមានមនុស្សប្រាំពាន់នាក់ សុទ្ធតែប្រជាកសិករទាំងអស់ ប៉ុន្តែ ត្រូវវាយឲ្យបរាជ័យដោយព្រះរាជវង្សានុវង្ស

ច្រើនជាងដោយពួកបារាំង ។ នៅឆ្នាំ១៨៦៧ ព្រះសង្ឃមួយអង្គចុងក្រោយ ដែលជាមេបះបោរដែរនោះ បានត្រូវពួកបារាំងចាប់ខ្លួន ហើយកាត់យកក្បាលដាក់លើក្តារឆ្នួនមួយនាំយកមកក្រុងភ្នំពេញ ដើម្បីតាំងបង្ហាញឲ្យប្រជាជនមើល ។

ព្រះសង្ឃទាំងឡាយបាននៅសម្ងំស្ងៀម ប៉ុន្តែ មិនដែលយល់ព្រមផ្តល់ការគាំទ្រទាំងស្រុងរបស់ព្រះអង្គចំពោះពួកបារាំងសោះឡើយ ។ ព្រះសង្ឃទាំងនោះយល់ឃើញថា អាណានិគមនិយម បានបំផ្លិចបំផ្លាញប្រទេសកម្ពុជាដល់ឫសគល់ជាជាងជួយការពារប្រទេសនេះ ពីព្រោះពួកបារាំងអះអាងដូច្នេះ ។ អ្នកនាំព្រះសង្ឃបះបោរ បានទទួលដឹកមុខចលនាតវ៉ាមួយប្រឆាំងនឹងការជ្រើសរើស ប្រជាជនកម្ពុជាឲ្យចូលធ្វើទាហានដើម្បីទៅជួយច្បាំងពួកបារាំងក្នុងពេលមានសង្គ្រាមលោកលើកទី១ ហើយបានហែកប័ណ្ណប្រកាសជ្រើសរើសទ័ពនៅតាមផ្លូវនានាក្នុងទីក្រុងភ្នំពេញចោលទាំងអស់ ។ នៅពេលដែល ស៊ុយហ្សាន កាប៉ឺឡេស បង្កើតវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យរបស់ខ្លួន គឺពួកប្រឆាំងទាំងនេះហើយ ដែលនាងបានជួយផ្តល់ជាមូលដ្ឋានប្រតិបត្តិការមួយ ហើយវិទ្យាស្ថានបានទទួលស្វាគមន៍យុទ្ធិកជនប្រឆាំងអាណានិគមដំបូងរបស់កម្ពុជានៃសម័យទំនើបនេះ ។

សឺង ង៉ុកថាញ់ កើតនៅប្រទេសកម្ពុជា និងចម្រើនវ័យធំធាត់នៅវៀតណាមភាគខាងត្បូងក្នុងដែនដីសណ្តទន្លេមេគង្គ ដែលកាលពីដើមជាកម្មសិទ្ធិរបស់រាជាណាចក្រអង្គរ ។ ប្រជាជនកម្ពុជានៅតំបន់នេះ គេហៅខ្មែរក្រោម បានរួមគ្នាជាជនជាតិភាគតិចមួយពោរពេញទៅដោយគំនិតជាតិនិយម យ៉ាងខ្លាំងក្លា ដែលរស់នៅដោយឡែកពីមាតុប្រទេសរបស់ខ្លួន និងកំពុងរស់នៅក្រោមការគ្រប់គ្រងរបស់បរទេស ។ ពីក្នុងចំណោមពួកអ្នកទាំងនោះហើយ ដែលផុសឡើងនូវមនុស្ស ដ៏មានឈ្មោះល្បីល្បាញមួយចំនួនធំ និងអ្នកប្រយុទ្ធសំខាន់ៗជាច្រើនដើម្បីឯករាជ្យ ។

ព្រឹត្តិការណ៍ ដែលគួរឲ្យកត់សម្គាល់គឺ ថាញ់ បានចាប់ផ្តើមការសិក្សារបស់គាត់នៅក្នុងសាលាវត្តនានា ដែលបង្រៀនភាសាខ្មែរ នៅកូសាំងស៊ីន ។ តមកទៀត គាត់បានផ្លាស់ទៅរៀនក្នុងប្រព័ន្ធសិក្សា របស់បារាំង សម្រាប់ផ្នែកមធ្យមសិក្សារបស់គាត់ បន្ទាប់មកបានធ្វើដំណើរទៅបន្តការសិក្សាវិជ្ជាជាន់ខ្ពស់នៅប្រទេសបារាំងទៀត ដោយបានរៀននៅមហាវិទ្យាល័យនីតិសាស្ត្រមួយឆ្នាំផង ។ ជាពលរដ្ឋនៃអាណានិគមមួយរបស់បារាំង គឺកូសាំងស៊ីន ដែលពុំមែនជារដ្ឋក្នុងអាណាព្យាបាល ថាញ់ បានទទួលការអប់រំមួយខុសពីធម្មតាបន្តិចសម្រាប់ជនកម្ពុជាម្នាក់នៅជំនាន់នោះ ។ គាត់បានវិលត្រឡប់មក កូសាំងស៊ីន វិញ ហើយទីបំផុតបានសម្រេចមកតាំងលំនៅនៅក្រុងភ្នំពេញជាទីដែលគាត់បានចូលធ្វើការ នៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ក្រោយការបង្កើតគ្រឹះស្ថាននេះបន្តិច ។ ដោយសារចំណេះដឹងរបស់គាត់ គាត់បានក្លាយទៅជាលេខាធិការរបស់វិទ្យាស្ថាននេះ ហើយនៅឆ្នាំ១៩៣៦ គាត់បានរួបរួមជាមួយ ប៉ាច ឈឿន ក្នុងការបង្កើតកាសែតភាសាខ្មែរជាលើកដំបូងបំផុតរបស់ប្រទេសមានឈ្មោះថា “នគរវត្ត” ។ តាមរយៈឈ្មោះនេះ និងកាសែតនេះ ថាញ់ បានលាតត្រដាងពីវត្តុបំណងចង់បានឯករាជ្យរបស់ប្រជាជនខ្មែរ ចង់លើកតម្កើងវប្បធម៌របស់ជាតិឡើងវិញ និងរក្សាការពារប្រជាជាតិផង ។

គាត់ជឿជាក់ក្នុងចិត្តថា ពួកបារាំងប្រាថ្នាក្តោបក្តាប់ប្រទេសរបស់គាត់ក្នុងស្ថានភាពមួយ ដែលដើរមិនទាន់សម័យ និងដែលពឹងផ្អែកតែទៅលើគេ ដើម្បីប្រគល់ទៅឲ្យពួកវៀតណាមនៅទីបំផុត ។

កាសែតបានអំពាវនាវឲ្យប្រជាជនប្រកាន់អាកប្បកិរិយាមួយដែលលំអៀងទៅរកការបះបោរ ប៉ុន្តែ បានបិទបាំងការអំពាវនាវនេះដោយសម្គាល់ការទាក់ទងគ្នាតាមរបៀបសរសេរអត្ថបទមួយជាភាពសាសនា ។ ថាញ់រួមនឹងព្រះសង្ឃទាំងឡាយ បានផ្តើមចោទប្រកាន់ប្រាកដប្រជាចំពោះអាណានិគមនិយមជាលើកដំបូង នៅក្រុងភ្នំពេញ ។ បារាំងបានតបមកគាត់វិញដោយការត្រួតពិនិត្យកាសែត និងការដាក់ឲ្យស្ថិតនៅក្រោមការឃ្លាំមើលទៀត ។ ដោយដឹងខ្លួនថា ព្រះពុទ្ធសាសនា ដែលគេយកមកប្រើខាងផ្លូវនយោបាយ បានក្លាយទៅបញ្ហាពិបាកមួយនៅប្រទេសភូមានោះ ពួកបារាំងបានរួសរាន់រឹតត្បិតសកម្មភាពទាំងឡាយរបស់ចលនាព្រះសង្ឃជាតិនិយមដែលកំពុងចាប់កំណើតនៅកម្ពុជាដែរ ។

នៅឆ្នាំ១៩៤១ កងទ័ពព្រះចៅអធិរាជជប៉ុនបានចូលមកដល់ក្រុងភ្នំពេញ ហើយបានប្រកាសពីការផុតរលត់នៃភាពចំណុះគេរបស់អាស៊ីពីមហាអំណាចអឺរ៉ុបនានា ។ ការចូលកាន់កាប់របស់ ជប៉ុន គឺជាធាតុផ្សំ ដែលផ្តល់សំទុះរបស់ខ្លួនដល់ចលនាទាមទារឯករាជ្យរបស់កម្ពុជា ។

ប្រទេសបារាំងបានចុះចាញ់នៅចំពោះមុខប្រទេសអាល្លឺម៉ង់ ដែលជាសម្ព័ន្ធមិត្តប្រទេសជប៉ុន ក្នុងបក្សសម្ព័ន្ធហ្វាស៊ីសតាំងពីពេលនោះម្ល៉េះ ។ ពួកអាល្លឺម៉ង់បានបន្តាប់បញ្ជាឲ្យរបបនៅក្រុងវីឈី *(VICHY)* របស់បារាំងដែលសុខចិត្តឱនក្បាលចូលដៃជាមួយសត្រូវ [របបក្រុងវីឈីជារដ្ឋាភិបាលសាធារណរដ្ឋបារាំង ដឹកនាំដោយសេនាប្រមុខប៉េតាំង *(PÉTAIN)* ហើយដែលបានតាំងស្នាក់ការនៅក្រុងវីឈី ជំនាន់អាល្លឺម៉ង់ចូលឈ្លានពានកាន់កាប់ប្រទេសក្នុងសម័យសង្គ្រាមលោកលើកទី២ ពីឆ្នាំ១៩៤១ ដល់ឆ្នាំ១៩៤៥ -កំណត់អ្នកប្រែសម្រួល] បន្តាប់ពួកមន្ត្រីគ្រប់គ្រងអាណានិគមទាំងអស់នៅឥណ្ឌូចិន ធ្វើសហប្រតិបត្តិការជាមួយពួកជប៉ុន ។ ប្រការនេះ គឺបកស្រាយឲ្យដឹងថា ពុំមានការប្រយុទ្ធគ្នាក្នុងនាមនៃប្រទេសកម្ពុជាទេ ៖ ពួកអាណានិគមបារាំងទទួលយល់ព្រមសហការជាមួយពួកជប៉ុនដោយរីករាយដរាបផលប្រយោជន៍ផ្សេងៗជារបស់ខ្លួន នឹងត្រូវបានការពារដោយពិតប្រាកដ ។ អ្វីដែលមិនសូវទៅមករកគ្នា គឺអ្នកដែលធ្លាប់មានសមានចិត្តចំពោះចលនាតស៊ូរបស់បារាំង ដែលកំពុងប្រយុទ្ធប្រឆាំងនឹងពួកណាហ្ស៊ី ។

ប្រទេសកម្ពុជា បានធ្វើឲ្យគេសម្គាល់ខ្លួនដោយប្រគល់ខ្លួនផ្តល់ គូលីកំណែន និងពួកអ្នកស្រុក ដែលគេបានចាត់តាំងឡើងក្នុងគោលបំណង "ធ្វើសហប្រតិបត្តិការ" ទៅឲ្យពួកជប៉ុន ។ នេះជាប្រទេសអាណានិគមតែមួយគត់ក្នុងតំបន់ដែលពុំមានចលនាទាមទារឯករាជ្យដូចគេ ហើយពួកបារាំងនៃរដ្ឋាភិបាលក្រុងវីឈី ជាពួកបស្ចិមប្រទេសតែមួយគត់ ដែលមិនប្រឆាំងតបនឹងពួកជប៉ុន ។ ពួកហូល្លង់ ពួកអង់គ្លេស និងពួកអាមេរិកាំង បានវាយប្រហារបក្សសម្ព័ន្ធនេះ ហើយនៅទីបំផុត បានសម្រេចបញ្ចុះបញ្ចូលពួកអ្នកតស៊ូភាគច្រើននៃចលនាទាមទារឯករាជ្យទាំងអស់

មកចូលរួមជាមួយពួកគេ ដើម្បីវាយប្រយុទ្ធនឹងប្រទេសជប៉ុន ។

ដោយពុំមានខ្វាចញញើតអំពើបះបោរណាមួយ នៅប្រទេសកម្ពុជា កងទ័ពព្រះចៅអធិរាជជប៉ុនគ្រាន់តែបង្កើតទីសេនាធិការតូចមួយ នៅក្រុងភ្នំពេញក្បែរមន្ទីរប្រៃសណីយ៍ប៉ុណ្ណោះ ហើយប្រគល់ភារកិច្ចឲ្យពួករាជការរដ្ឋបាលបារាំងបន្តដឹកនាំអាណានិគមតទៅទៀត ។ ចក្រភពជប៉ុន បានប្រើកងកម្លាំងទាំងអស់របស់ខ្លួន ដើម្បីពង្រីក និងពង្រឹង "មណ្ឌលវិបុលភាព" របស់ខ្លួននៅក្នុងភាគខាងកើតអាស៊ី ។ សម្រាប់បច្ចុប្បន្នកាល ឥណ្ឌូចិនបានបំពេញមុខងារជាមូលដ្ឋានមួយបម្រើឲ្យជប៉ុន ដែលកងទ័ពរបស់ខ្លួនអាចនឹងវាយប្រហារទៅលើប្រទេសដទៃទៀតនៅអាស៊ីអាគ្នេយ៍ ។

មួយឆ្នាំក្រោយមកនៅខែឧសភា ឆ្នាំ១៩៤២ ពួកជប៉ុនបានវាយដណ្ដើមបានដែនដីមួយភាគធំ ដែលពួកគេធ្លាប់ប៉ងចង់បានគឺឥណ្ឌូចិន ហុងកុង សិង្ហបុរី ម៉ាឡេស៊ី ឥណ្ឌូនេស៊ី ភូមា និងហ្វីលីពីន ។

នៅពេលដែលប្រទេសជប៉ុនជាប់រវល់នឹងសង្គ្រាមទាំងនោះ ប្រទេសថៃក៏រិះរកឱកាសដែលអនុគ្រោះមួយដើម្បីឆ្លៀតទាញយកគុណប្រយោជន៍ពីភាពទន់ខ្សោយដែលទើបមានថ្មីៗរបស់ពួកអាណានិគមបារាំង នៅកម្ពុជាដែលបន្ថយមកត្រឹមតួនាទីជាអ្នកការពារប៉ុណ្ណោះ ។ ប្រទេសថៃបានវាយលុកភាគពាយ័ព្យប្រទេសកម្ពុជានៅឆ្នាំ ១៩៤១ បន្ទាប់មក បានធ្វើការសម្រុះសម្រួលមួយជាមួយអាជ្ញាធរយោធាជប៉ុនទៀត ។ ដោយទូទាត់សន្តិភាពជាមួយប្រទេសថៃ ពួកជប៉ុនបានបង្ខំឲ្យពួកបារាំងប្រគល់អាណាខេត្តបាត់ដំបង និងស៊ីសុផុន រួមជាមួយផ្នែកខ្លះនៃខេត្តសៀមរាបទៅឲ្យពួកថៃ ។ តែមួយភ្លែតសោះ ប្រទេសកម្ពុជាបានបាត់បង់ទឹកដីរបស់ខ្លួន មួយភាគបី និងមនុស្សជិតកន្លះលាននាក់ ។

ប្រជាជនកម្ពុជាឈឺចាប់ចំពោះការបាត់បង់នេះ ហាក់ដូចជាគេកាត់អវៈយវៈណាមួយចេញពីរាងកាយដូច្នោះដែរ ។ ការកាន់កាប់របស់ពួកថៃនៅភាគពាយ័ព្យប្រទេស បានបណ្ដាលឲ្យមានប្រតិកម្មពីរ ដែលជួយកំណត់រយៈកាលនៃសង្គ្រាមដែរ ៖ កំហឹង និងភាពអាម៉ាស់ បានបង្ខំឲ្យការសោយទិវង្គតរបស់ស្ដេច ដែលកំពុងសោយរាជ្យ គឺព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស រឹតតែឆាប់មកដល់ ។ ដោយធ្វើរំលងពីលើក្បាលរជ្ជទាយាទ (អ្នកដែលត្រូវសោយរាជ្យបន្តពីស្ដេចមុន) ដែលគេបានសន្មតរួចមកហើយនោះ ពួកបារាំងបានប្រគល់រាជបល្ល័ង្កទៅឲ្យស្ដេចក្មេងមួយអង្គវិញគឺ សម្ដេច ព្រះនរោត្តម សីហនុ ព្រះជន្ម ១៨ព្រះវស្សា ជាព្រះរាជនត្តារបស់ស្ដេចនរោត្តមវិញ ។ នៅជំនាន់នោះ សម្ដេច ព្រះនរោត្តម សីហនុ ហាក់ដូចជាគ្រាន់តែជាសិស្សវិទ្យាល័យមិនចេះកើតទុក្ខម្នាក់ ដែលចូលចិត្តស្រឡាញ់សត្វសេះ ការរ៉េម និងខ្សែភាពយន្ត ប៉ុណ្ណោះ ហើយជាមនុស្សដែលគេចង់ឆ្លាក់ទៅជាអ្វី ក៏បានដែរ ។ ប៉ុន្ដែ ព្រះអង្គត្រូវតែធ្វើខ្លួនឲ្យក្លាយទៅជាទេវរាជាសម័យទំនើបមួយអង្គ ដែលទាំងប្រទេសបារាំងទាំងមហាអំណាចបរទេសដទៃណាមួយទៀត អាចថែទាំការរួបរួមជាមួយព្រះអង្គ ដើម្បីក្លាយជាម្ចាស់កម្មសិទ្ធិឡើយ ។

ម្យ៉ាងទៀត ការបាត់បង់ទឹកដីមួយភាគបី បាននាំឲ្យមានការរួបរួមជាលើកដំបូង រវាងបណ្ដាព្រះសង្ឃជាតិ

និយម និងពួកវរជន ដែលមានការចេះដឹងជ្រៅជ្រះ ថ្វីដ្បិតតែវាមានលក្ខណៈបណ្ដោះអាសន្នក៏ដោយ ។ ការរួបរួមនេះ ប្រហែលជាបម្រើជាថ្នាលបណ្ដុះបណ្ដាលអ្នកជាតិនិយមផ្សេងៗ ដែលនឹងធ្វើការដើម្បី សម្ដេច ព្រះនរោត្តម សីហនុ ឬប្រឆាំងនឹងព្រះអង្គវិញក៏មិនដឹង ជាពិសេស គឺយុវបុរស ប៉ុល ពត និងអនាគតមេដឹកនាំខ្មែរក្រហមដទៃទៀតជាច្រើន ។

ពួកបារាំងមិនបានបំពេញការទទួលខុសត្រូវយ៉ាងសំខាន់របស់គេ ដើម្បីការពារប្រទេសកម្ពុជាពីប្រទេសជិតខាងខ្លួនសោះឡើយ ។ វរជនក្នុងស្រុកលះបង់ចោលការយល់ប្រឡំរបស់ខ្លួននៅពេលដែល សឺង ង៉ុកថាញ់ នៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិតបង្កើតឲ្យមាននូវការព្រមព្រៀងខាងផ្នែកនយោបាយមួយ រវាងព្រះសង្ឃថ្នាក់ក្រោមទាំងឡាយ និងវរជនក្នុងស្រុក ។ គាត់ជា ឥស្សរជនគ្មានគូប្រដូចម្នាក់ អាស្រ័យការទុកចិត្តពីព្រះសង្ឃស្នេហាជាតិទាំងពួង ដែលធ្លាប់មានទំនាក់ទំនងជាមួយអ្នកមានបុណ្យសក្ដិធំៗ ចូលចិត្តនិយាយភាសាបារាំង នៅក្រុងភ្នំពេញជាធម្មតា ។ ដូច្នេះព្រះសង្ឃទាំងនោះ សុទ្ធតែជាអ្នកយកចិត្តទុកដាក់យ៉ាងខ្លាំងនឹងប្រពៃណីរបស់ខ្លួន ហើយបើព្រះអង្គមាន ពុទ្ធដីកាជាភាសាបរទេសមួយ គឺភាសាថៃ ។ អ្នកទាំងនោះបានជ្រើសរើសសមាជិក និងយុទ្ធិកជនរបស់គេពីក្នុងស្រទាប់ប្រជាជនក្រីក្រនៃសង្គម និងពួកនិស្សិតដែលពួកគេទទួលយកក្នុងរាជធានី ជាទូទៅច្រើនចេញមកពីសាលាបច្ចេកទេសនានា ។

ថាញ់ បានឈានចូលក្នុងស្រទាប់ជាន់ខ្ពស់តាមរយៈសមាគម អតីតសិស្សសាលាស៊ីសុវត្ថិ ។ នៅទីបំផុតពួកបារាំងបានសម្រេចចិត្តបង្កើតវិទ្យាល័យបារាំងមួយនៅភ្នំពេញ មុនសង្គ្រាមលោកលើកទីពីរបន្តិច គេដាក់ឈ្មោះសាលានោះថា សាលាស៊ីសុវត្ថិ ជាឈ្មោះនៃខ្សែស្រឡាយមួយ ក្នុងចំណោមខ្សែស្រឡាយរបស់ ព្រះរាជវង្សានុវង្សខ្មែរ ។ ពួកអតីតសិស្សសាលានេះ បានបង្កើតសមាគមមួយសម្រាប់រកការងារធ្វើក្នុងរដ្ឋបាលអាណានិគម ហើយបានស្នើឲ្យ សឺង ង៉ុកថាញ់ ធ្វើជាទីប្រឹក្សាគតិយុត្តិរបស់គេ ។ ហើយគឺរូបគាត់នេះឯង ដែលជួយធ្វើឲ្យសមាគមនេះប្រែក្លាយទៅជាក្រុមអ្នកជាតិនិយមមួយវិញ ។

ពួកអតីតសិស្សសាលាស៊ីសុវត្ថិ បានទៅជាសមាគមតែមួយគត់របស់វណ្ណៈជាន់ខ្ពស់ ដែលទាមទារឲ្យមានទំនើបភាវូបនីយកម្មប្រទេសជាតិ និងទម្រង់ឯករាជ្យប្រាកដមួយសម្រាប់ប្រទេសកម្ពុជា ។ គ្មានគោលដៅណាមួយក្នុងចំណោមគោលដៅទាំងនេះ ដែលមិនទាក់ទងនឹងបំណងប្រាថ្នារបស់ព្រះសង្ឃស្នេហាជាតិ ដែលចង់រៀបចំប្រទេសកម្ពុជាទៅជារបបរាជាធិបតេយ្យឯករាជ្យមួយ ហើយទុកឲ្យប្រពៃណីទាំងឡាយរបស់ខ្មែររីកត្រកុំត្រកាលដូចដើមឡើងវិញឡើយ ។ ប៉ុន្តែ ក្រោមការកាន់កាប់របស់ជប៉ុន បន្ទាប់ពីការបាត់បង់ទឹកដីនៅភាគពាយ័ព្យ ថាញ់ អាចចាត់វិធានការប្រមូលក្រុមទាំងពីរនេះ ដោយសារតែក្រុមណាក៏ដូចក្រុមណា គឺចង់ឲ្យប្រទេសមានឯករាជ្យដូចគ្នា ។

សមាគមអតីតសិស្សសាលាស៊ីសុវត្ថិ បានចាប់ផ្ដើមផ្ដល់លុយកាក់ចំពោះព្រះសង្ឃទាំងឡាយ សម្រាប់ការ

និមន្តរបស់ព្រះអង្គទៅតាមស្រុកស្រែចម្ការដើម្បីទេសនាប្រឆាំងនឹងអាណានិគមបារាំង ។ សមាគមនេះបានជួយផ្ដល់ឲ្យព្រះសង្ឃនូវទឹកប្រាក់យ៉ាងច្រើន ដែលព្រះអង្គកំពុងត្រូវការជាខ្លាំងនិងធម្មានុរូបថ្មីមួយ ។ ចលនាព្រមគ្នានេះ បានរួមបង្កជាការគំរាមកំហែងដ៏មានអានុភាពមួយសម្រាប់ពួកបារាំង និងសម្រាប់របបរាជាធិបតេយ្យខ្មែរដោយមិនចំពោះ ក្នុងពេលដែលព្រះមហាក្សត្រជួយគាំទ្រពួកអាណានិគម ។ ព្រះសង្ឃទាំងឡាយ ដែលប្រកាន់ប្រពៃណីខ្ជាប់ខ្ជួន និងពួកអ្នកមានឯកសិទ្ធិទំនើប ដែលនិយមភាសា និងនយោបាយរបស់បារាំង បានទទួលលទ្ធផលភ្លាមមួយរំពេច ប៉ុន្តែ ដោយចំនួនវរជនមានតិច សមាគមបានផ្អែកលើព្រះសង្ឃឲ្យក្លាយទៅជានិមិត្តរូបនៃការបះបោរ និងយកស្បង់ចីពររបស់ព្រះអង្គធ្វើជានិមិត្តរូបនៃការប្រយុទ្ធប្រឆាំងនឹងលទ្ធិអាណានិគមនិយម ។

ពួកអ្នកកាន់អំណាចអាណានិគមបានប្រឆាំងតបវិញដោយមិនបង្អង់យូរឡើយ ។ ពួកមន្ត្រីបារាំងនៃរដ្ឋាភិបាលក្រុងវីឈី ដែលត្រូវធ្វើក្ដៅក្រហាយដោយការអំពាវនាវឲ្យប្រជាជនធ្វើការបះបោរប្រឆាំង កាន់តែចេញមុខខ្លាំងឡើងៗ បានសម្រេចបិទកាសែតនគរវត្តមិនឲ្យចេញផ្សាយ ហើយប៉ុន្មានខែក្រោយមកទៀត គឺនៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៤២ ពួកបារាំងបានចាប់ខ្លួនមេដឹកនាំព្រះសង្ឃមួយអង្គគឺអាចារ្យ ហែម ចៀវ ដែលធ្លាប់អំពាវនាវឲ្យទាហានកម្ពុជារត់ចេញពីជួរកងទ័ពអាណានិគម ។ ព្រះអង្គជាសាស្ត្រាចារ្យម្នាក់នៅសាលាបាលីជាន់ខ្ពស់ ជាអ្នកស្ទាត់ជំនាញក្នុងការបកប្រែក្បួនច្បាប់ផ្នែកសាសនា ដោយអំពាវនាវឲ្យប្រជាជនងើបបះបោរឡើង ។ ព្រះអង្គបានទេសនាពីធម៌អហិង្សា ប៉ុន្តែ ដោយលំនាំដាច់ឡែក ពីព្រោះព្រះអង្គយល់ថា កងទ័ព និងប៉ូលិសបារាំងបានរួមបង្កជាឧបសគ្គគួរឲ្យព្រឺខ្លាច ចំពោះការតស៊ូដើម្បីឯករាជ្យ ។ ក្នុងចំណោមភស្តុតាងនៃពិរុទ្ធភាពដែលគេប្រមូលបានប្រឆាំងនឹងព្រះអង្គ និងព្រះសង្ឃដទៃទៀតគេចោទប្រកាន់ថា ព្រះអង្គបានបកប្រែឯកសារផ្សេងៗ ដែលលម្អៀងទៅរកការបះបោរពីភាសាថៃ ។ ប៉ុន្តែ ដោយចាប់ព្រះអង្គដាក់គុក ពួកបារាំង បានធ្វើឲ្យស្ថានការណ៍កាន់តែធ្ងន់ធ្ងរថែមទៀតប៉ុណ្ណោះ ពីព្រោះលោក ហែម ចៀវ មិនត្រឹមតែទទួលបានការគោរពរាប់អានពីពួកបញ្ញវន្តចំពោះស្នាដៃទាំងឡាយរបស់ព្រះអង្គនៅសាលាប៉ុណ្ណោះទេ ប៉ុន្តែ ក៏ទទួលបានការគោរពបូជាពីប្រជាកសិករ ។

ប៉ូលិសបារាំងបានយក ហែម ចៀវ និងព្រះសង្ឃមួយអង្គទៀត ព្រះនាម នួន ឌួង ទៅដាក់គុក ដោយគ្មានអើពើនឹងវិន័យរបស់សាសនា ដែលតម្រូវឲ្យព្រះសង្ឃទាំងនេះចូលទៅបង្ហាញខ្លួននៅចំពោះមុខក្រុមជំនុំសង្ឃរបស់ ព្រះអង្គផ្ទាល់ជាមុនសិន (សង្ឃកម្ម) ដើម្បីលាចាកសិក្ខាបទមុននឹងប្រគល់ទៅឲ្យអាជ្ញាធរស៊ីវិល -ជាការប្រតិបត្តិដែលសម្រាប់ការពារលក្ខណៈដ៏ពិសិដ្ឋរបស់សាសនា ។ ហេតុនេះ ពួកបារាំងពុំត្រឹមតែចាប់មេដឹកនាំដ៏មានប្រជាប្រិយម្នាក់ដាក់គុកប៉ុណ្ណោះទេ ប៉ុន្តែ បានប្រមាថដល់សាសនាថែមទៀត ។ ជាការសងសឹកតបវិញ បណ្ដាអ្នកប្រឆាំងដទៃទៀត បានអំពាវនាវឲ្យធ្វើបាតុកម្មប្រឆាំងបារាំងជាលើកដំបូងបំផុតនៃប្រវត្តិសាស្ត្រទីក្រុងភ្នំពេញ ។

បាតុកម្មនេះ គឺជាគំនិតមួយរបស់ សឺង ង៉ុកថាញ់[១១] ។ នៅពេលដែលកាសែតនគរវត្តត្រូវហាមមិនឲ្យចេញ

ផ្សាយ ថាញ់ បានវិនិច្ឆ័យថា ដល់ពេលវេលាដែលត្រូវសាកល្បងធ្វើរដ្ឋប្រហារមួយអែបជប៉ុន និងប្រកាសប្រទេសកម្ពុជា ឯករាជ្យពីប្រទេសបារាំងហើយ ។ ក្រោយពីការចាប់ ហៀម ចៀវ ថាញ់ បានគេចខ្លួនទៅនៅផ្ទះស័ក្តិបីជប៉ុនម្នាក់ ហើយបានទទួលនូវការយល់ព្រមពីអាជ្ញាធរជប៉ុនយ៉ាងឆាប់រហ័សចំពោះការរៀបចំធ្វើបាតុកម្មនេះ ។ ថាញ់ បានជូនដំណឹងជាមុនចំពោះពួកជប៉ុនអំពីការទាមទារផ្សេងៗ ដែលគាត់នឹងដាក់ជូនពួកបារាំងពិនិត្យនៅពេលខាងមុខ គឺការដោះលែងអ្នកទោសនយោបាយទាំងអស់ ការរៀបចំស្ថាប័នសាធារណៈនានារបស់ប្រទេសឡើងវិញ ការសហការផ្នែកសេដ្ឋកិច្ចដ៏ជិតស្និទ្ធជាមួយពួកជប៉ុន ដើម្បីជួយទ្រទ្រង់ដល់ការប្រឹងប្រែងធ្វើសង្រ្គាមរបស់គេ និងការតាក់តែងរដ្ឋធម្មនុញ្ញមួយដែលកំណត់ប្រទេសកម្ពុជាជា «រាជាធិបតេយ្យជាតិសង្គមនិយមមួយ» ។

នៅថ្ងៃទី២០ ខែកក្កដា មនុស្សជិត ពីរពាន់នាក់ បានឆ្លើយតាមការអំពាវនាវរបស់ថាញ់ ហើយបានមកជួបជុំគ្នានៅខាងក្រោយព្រះបរមរាជវាំង វេលាម៉ោង៩ព្រឹក ដើម្បីដើរដង្ហែជាក្បួនមួយដែលនាំពួកគេទៅដល់មុខការិយាល័យធ្វើការរបស់រ៉េស៊ីដង់ជាន់ខ្ពស់បារាំង ស្ថិតនៅក្បែរវត្តភ្នំ ។ បាតុករទាំងអស់បានត្រូវធ្វើឲ្យរំជួលក្នុងចិត្តជាខ្លាំង ដោយពុទ្ធដីការបស់លោក ហែម ចៀវ ដែលទល់នឹងពួកប៉ូលិសបារាំងក្នុងពេលចាប់ព្រះអង្គថា «លោក! នៅទីនេះ លោកឯងអាចធ្វើអ្វីៗបានតាមតែចិត្តលោកឯងចង់ ព្រោះលោកឯងជាចៅហ្វាយនាយ ។ លោកឯងអាចយកជីវិតខ្ញុំបាន ប៉ុន្តែ ព្រលឹងរបស់ខ្ញុំនឹងបន្តស្ថិតនៅជារៀងរហូត»[១៧] ។

នៅពេលដែលពួកបាតុករទៅដល់មុខគ្រឹះស្ថាននោះ គេបានប្រកាសថា មានតែប្រតិភូមួយចំនួនតូចប៉ុណ្ណោះដែលនឹងត្រូវអនុញ្ញាតឲ្យចូលខាងក្នុង ដើម្បីបង្ហាញជូនការទាមទារផ្សេងៗរបស់ខ្លួន ។ ហ្វូងមនុស្សដែលក្នុងចំណោះនោះ មានព្រះសង្ឃជិតប្រាំរយអង្គ បានប្រឆាំងតវ៉ា ។ ប៉ូលិសបារាំង បានស្ទុះសំដៅទៅរកបាតុករដែលគ្មានអាវុធ ហើយវាយសំពងក្បាលពួកនោះដោយព្រនង់នៅក្រោមក្រសែភ្នែកពួកប៉ូលិសជប៉ុន ដែលស្ថិតនៅដោយឡែកធ្វើមិនដឹង ។ ពួកអ្នកប្រឆាំងតវ៉ាបានរត់គេចខ្លួនដែលក្នុងចំណោមនោះ មានមួយចំនួនធំ មិនបានវិលត្រឡប់ចូលមករាជធានីវិញជារៀងរហូត ។ តែក្នុងរយៈប៉ុន្មានថ្ងៃប៉ុណ្ណោះ ពួកអ្នកប្រឆាំងជិតពីររយនាក់បានត្រូវបារាំងចាប់ខ្លួន ប៉ុន្តែ ពុំមានរូប សឺង ង៉ុកថាញ់ ទេ ។

ដោយត្រូវលាក់ដោយពួកជប៉ុន សឺង ង៉ុកថាញ់ បានស្ថិតនៅភ្នំពេញនៅឡើយ គាត់បានផ្ញើសំបុត្រជាហូរហែ ទៅទីសេនាធិការជប៉ុននៅទីក្រុងព្រៃនគរ ដោយអង្វរករសុំឲ្យពួកជប៉ុនបញ្ជូនកងទ័ពមួយមកភ្នំពេញ ដើម្បីវាយផ្តួលរំលំពួកបារាំង និងជួយបំពេញការទាមទារផ្សេងៗរបស់គាត់ ។ នៅដំណាច់ឆ្នាំ ដោយដឹងថា សំណើសុំរបស់ខ្លួននឹងមិនត្រូវធ្វើឲ្យសម្រេច គាត់បានធ្វើដំណើរឆ្លងចូលទៅប្រទេសថៃ ហើយនៅខែមករា គាត់បានចាកចេញពីក្រុងបាងកក ឆ្ពោះទៅកាន់ទីក្រុងតូក្យូទៀត ជាទីដែលគាត់បានស្ថិតនៅទីនោះបីឆ្នាំ ។ គាត់បានទទួលការបណ្តុះបណ្តាលមួយ ហើយបានទទួលឋានន្តរស័ក្តិជាអនុសេនីយ៍ឯក ក្នុងកងទ័ពព្រះចៅអធិរាជ ។ នៅប្រទេសជប៉ុន

ថាញ់ បានយល់ព្រមយ៉ាងឆាយអំពីហេតុផលពន្យារការធ្វើរដ្ឋប្រហារមួយ ដែលគាត់បានផ្ញើសំបុត្រមកឲ្យជនរួមជាតិគាត់ ដែលស្ថិតនៅក្នុងប្រទេសកម្ពុជាថា «យើងត្រូវតែរង់ចាំ ។ មានតែជ័យជម្នះទាំងស្រុងរបស់ជប៉ុននៅអាស៊ីប៉ុណ្ណោះ ដែលនឹងអាចដោះស្រាយបញ្ហាទាំងអស់នៅប្រជាជនអាស៊ី ដែលក្នុងនោះភ័ព្វវាសនារបស់ប្រទេសកម្ពុជាយើងត្រូវតែភ្ជាប់ជាមួយដែរ»[១៣] ។

ប្រជាជនកម្ពុជាច្រើន ដែលត្រូវចាប់ខ្លួនដោយពួកបារាំង បានទទួលរងទុក្ខវេទនាមួយយ៉ាងខ្លោចផ្សា ។ ពួកមេដឹកនាំមួយចំនួន ត្រូវបានបញ្ជូនទៅទីក្រុងព្រៃនគរដើម្បីកាត់ទោសឲ្យជាប់គុកនៅកោះពូឡូកុងដ័រ (POULO CONDOR) ខ្មែរហៅកោះត្រឡាច ។ បីឆ្នាំក្រោយមក ហែម ចៀវ បានទទួលអនិច្ចកម្មនៅទីនោះ ហើយព្រះអង្គបានថ្លែងប្រកាសមុនពេលរលត់ជីវិតថា «ខ្ញុំស្លាប់ដោយរីករាយ បើសិនជាខ្ញុំដឹងប្រាកដក្នុងចិត្តថា ប្រទេសរបស់ខ្ញុំនឹងត្រូវដោះលែងពីនឹមអាណានិគមបរទេសនោះ ។ ខ្ញុំសូមបន់ស្រន់ដើម្បីសេរីភាព»[១៤] ។

ពួកអ្នកដែលនៅរស់មានជីវិត ហើយដែលបានវិលត្រឡប់មកកម្ពុជាវិញបានរៀបរាប់ពីរបៀប ដែលពួកគេបានទាក់ទងចងមិត្តភាពជាមួយពួកអ្នកទោសវៀតណាម ដែលបានសាកល្បងអូសទាញពួកខ្លួនឲ្យចូលរួមក្នុងចលនារបស់គេ គឺបក្សកុម្មុយនិស្តឥណ្ឌូចិននិង «វាយកម្ចាត់» ពួកបារាំង ។ អ្នកដទៃទៀតដែលរត់គេចខ្លួនរួចក្នុងអំឡុងបាតុកម្មខែកក្កដា នៅទីបំផុតក៏សម្រេចចិត្តយល់ព្រមតាមសំណើនេះ ។ អាចារ្យ មៀន សាស្ត្រាចារ្យភាសាបាលីនៅវត្តមួយនាក្រុងភ្នំពេញបានភៀសខ្លួនទៅកាន់ខេត្តកំពង់ចាម បន្ទាប់មក រត់ទៅប្រទេសវៀតណាមទៀត ដែលនៅទីនោះ គាត់បានទៅជាជនជាតិកម្ពុជាលើកដំបូង ដែលបានសុំចូលបក្សកុម្មុយនិស្តឥណ្ឌូចិនក្រោមរហស្សនាមថា សឺង ង៉ុកមិញ ។

សម្ព័ន្ធភាពបណ្តោះអាសន្នរវាងព្រះសង្ឃ និងបានរលំរលាយ ។ ដោយ ថាញ់ នៅប្រទេសជប៉ុន ចៀវជាប់គុកនៅវៀតណាម និងដោយព្រះសង្ឃដទៃទៀតភ័យខ្លាចមិនហ៊ានវិលចូលមកក្រុងភ្នំពេញវិញ នៅក្នុងរាជធានី ពុំមានឥស្សរជនណាម្នាក់ផ្តើមចលនាប្រឆាំងនឹងពួកអាណានិគមបារាំងឡើយ ។ ក្រុមវរជន និងព្រះសង្ឃទាំងឡាយ បានផ្អាកទំនាក់ទំនងផ្សេងៗរបស់ខ្លួន ហើយបានដើរទៅតាមទិសដៅតែរៀងខ្លួន ។ សម្រេចសម្រួលទៅពួកអភិជន នៃសមាគមអតីតសិស្សសាលាស៊ីសុវត្ថិ បានក្លាយទៅជាមេដឹកនាំប្រទេសកម្ពុជាឯករាជ្យក្រោមរជ្ជកាលរបស់សម្តេច ព្រះនរោត្តម សីហនុ នៅពេលដែលព្រះសង្ឃសំខាន់ៗងាកទៅចូលជាមួយពួកកុម្មុយនិស្តវិញ ។

ព្រះសង្ឃ ដែលជ្រើសយកឈ្មោះ សឺង ង៉ុកមិញ ជាឈ្មោះដែលគេហៅជាការចំអក គឺជាការផ្សំគ្នារវាងឈ្មោះ សឺង ង៉ុកថាញ់ និង ហូ ជីមិញ គ្រាន់តែជាព្រះសង្ឃដំបូងក្នុងចំណោមព្រះសង្ឃជាងដប់ថ្វាយអង្គ ដែលចាកចេញពីក្រុងភ្នំពេញ និងស្វែងរកការជួយឧបត្ថម្ភពីពួកវៀតណាមក្នុងគោលបំណងបង្កើតចលនាមួយដើម្បីទាមទារឯករាជ្យប៉ុណ្ណោះ ។

នៅឆ្នាំ១៩៤២ តាមព្រំដែនទាំងពីររបស់កម្ពុជា ពួកបរទេសមានបំណងអុជអាលការបះបោរនៅក្រុង

ភ្នំពេញឲ្យផ្ទុះឡើង ។ នៅទិសខាងកើតពួកកុម្មុយនិស្តវៀតណាម បានសាកល្បងជ្រើសរើសប្រជាជនកម្ពុជាតាំងពីច្រើនឆ្នាំមកហើយ ដោយមិនសូវបានទទួលជោគជ័យឡើយ ។ នៅឆ្នាំ១៩៣០ ហូ ជីមិញ បានបង្កើតបក្សកុម្មុយនិស្តឥណ្ឌូចិនតាមការណែនាំពីអង្គការកូមិនទែន នៅក្រុងមូស្គូ ដែលចាត់តាំងឲ្យគាត់បង្កើតបក្សមួយ ដើម្បីប្រមូលបណ្តាចលនាកុម្មុយនិស្តនៅកម្ពុជា ឡាវ និងវៀតណាម ឲ្យចូលគ្នាតែមួយ ។ ប៉ុន្តែ នៅកម្ពុជាពុំមានចលនាកុម្មុយនិស្តទេ ហើយបក្សកុម្មុយនិស្តឥណ្ឌូចិនបានសម្រេចជ្រើសរើសសមាជិករបស់ខ្លួន តែក្នុងចំណោមពួកគូលីវៀតណាម ដែលកំពុងធ្វើការក្នុងចម្ការកៅស៊ូនានា នៅភាគខាងកើតប្រទេសកម្ពុជាប៉ុណ្ណោះ ។ ផ្ទុយទៅវិញបន្ទាប់ពីការគាបសង្កត់ ដែលពួកបារាំងធ្វើមកលើព្រះសង្ឃនៅទីបំផុត បក្សកុម្មុយនិស្តឥណ្ឌូចិនចាប់ផ្តើមបញ្ចូលប្រជាជនកម្ពុជាជាសមាជិក ។

នៅទិសខាងលិច តាមព្រំដែនថៃ ស្ថានភាពមានលក្ខណៈខុសពីគ្នាទាំងស្រុង ដោយហេតុថា ពួកថៃជួយគាំទ្រចលនាជាតិនិយមមិនមែនកុម្មុយនិស្តមួយ ដែលដាក់ឈ្មោះថា ខ្មែរឥស្សរៈបង្កើតឡើងដោយជនកម្ពុជាជាច្រើននាក់ដែលភៀសខ្លួនទៅរស់នៅទីក្រុងបាងកក ។ ចលនានេះបានចាប់ផ្តើមទទួលជំនួយមួយពីពួកថៃ នៅឆ្នាំ១៩៤០ ប៉ុន្តែ ចលនានេះខ្វះរចនាសម្ព័ន្ធដឹកនាំ និងការឯកភាពក្នុងទិសដៅផ្សេងៗរបស់បក្សកុម្មុយនិស្តឥណ្ឌូចិនឡើយ ។ ខ្មែរឥស្សរៈជាចលនាមួយ ដែលមានរចនាសម្ព័ន្ធរាយដឹកនាំដោយបានប្រកាន់នយោបាយមួយក្នុងការតស៊ូដោយអាវុធប្រឆាំងនឹងអាណានិគមនិយមបារាំង ប៉ុន្តែ គ្មានកម្មវិធីនយោបាយ ធ្វើឲ្យមានឯកភាពតែមួយទេ ។

ចលនាខ្មែរឥស្សរៈ រីកលូតលាស់ឆាប់រហ័សជាងបក្សកុម្មុយនិស្តឥណ្ឌូចិន ប៉ុន្តែ មិនអត្ថិមានស្ថិរភាពយូរឡើយ ។ ម្យ៉ាងទៀត សមាជិកជាច្រើនរបស់ខ្លួនបានរួមសហការជាមួយពួកជប៉ុន ក្នុងផ្ទៃសម្ព័ន្ធភាពមួយដើម្បីប្រឆាំងនឹងពួកបារាំង ដែលមុនដំបូងនៅមិនទាន់ចេញមុខនៅឡើយ ។ ជាពិសេសទៅទៀត អ្នកទាំងនោះ ពឹងផ្អែកលើរដ្ឋាភិបាលថៃទាំងស្រុង ដែលផ្តល់ទីជ្រកកោនមួយដល់ពួកគេផុតពីវង្វង់ប្រតិបត្តិការរបស់ប៉ូលិសបារាំង ព្រមទាំងជួយផ្តល់អាវុធ និងគ្រាប់រំសេវ ស្បៀងអាហារចាំបាច់ជាច្រើនដើម្បីដឹកនាំចាត់ចែងការបះបោរមួយផង ។

ចលនាកុម្មុយនិស្ត ដែលបំពាក់អាវុធដោយពួកវៀតណាម និងខ្មែរឥស្សរៈ ដែលជួយទ្រទ្រង់ដោយពួកថៃ ទើបនឹងចាប់កំណើតដំណាលគ្នាក្នុងពេលដែលកើតមានបាតុកម្មនៅក្រុងភ្នំពេញ ។ ម្នាងៗបានរាយទ័ពនៅតាមតំបន់ព្រំដែនតែរៀងខ្លួន ។ បានចុះបញ្ជីយកមនុស្សចំណូលថ្មីបានជាច្រើននាក់ ក្រោយពីមានចលាចលនៅឆ្នាំ១៩៤២ ។ ពួកអ្នក ជាតិនិយមមួយចំនួនធំ ដែលរត់ភៀសខ្លួនចេញពីភ្នំពេញ នៅទីបំផុត ក៏សម្រេចចិត្តទៅចូលរួមជាមួយពួកឥស្សរៈនៅភាគខាងលិចកម្ពុជា អ្នកខ្លះទៀតរត់ទៅទិសខាងកើត សុំចូលបក្សកុម្មុយនិស្តឥណ្ឌូចិន ហើយមួយចំនួន ផ្សេងទៀតបានចូលទៅខាងពួកជប៉ុន ។

នៅឆ្នាំ១៩៤៣ បន្ទាប់ពីត្រូវរងការវាយបកក្នុងមហាសមុទ្រប៉ាស៊ីហ្វិក ពួកជប៉ុនបានផ្លាស់ប្តូរយុទ្ធសាស្ត្ររបស់ខ្លួន គឺពួកគេបានបញ្ចប់កិច្ចសហប្រតិបត្តិការជាមួយអតីតរដ្ឋាភិបាលអាណានិគមជាច្រើន ហើយ

បានបង្កើតឲ្យមានរបប អាយ៉ង "ឯករាជ្យ" នៅប្រទេសភូមា សិង្ហបុរី និងនៅកោះហ្សាវ៉ា (ឥណ្ឌូនេស៊ី) ។

ប្រជាជននៅប្រទេសទាំងនោះ មិនគាំទ្ររបបអន្តោគ្រាមទាំងនេះទេ ហើយការប្រយុទ្ធតស៊ូយ៉ាងសកម្មតទល់នឹងពួកជប៉ុនបានកើតមាននៅប្រទេសភូមា ឥណ្ឌូនេស៊ី និងម៉ាឡេស៊ី ជាបន្តទៅទៀត ដោយមានជំនួយពីទ័ពសម្ព័ន្ធមិត្ត (អាមេរិកាំង អង់គ្លេស) ផង ។ និយាយដោយខ្លី ពួកជប៉ុនពុំអាចសម្រេចធ្វើឲ្យប្រជាជនទាំងនោះ ផ្លាស់ប្តូរចិត្តបានឡើយ ហើយដោយដឹងខ្លួនពីបរាជ័យនេះ ទើបពួកគេសម្រេចចិត្ត មិនរៀបចំបង្កើតរបបអាយ៉ងរបៀបដូចនោះនៅឥណ្ឌូចិនទេ ព្រោះ រដ្ឋអាណានិគមទាំងអស់របស់បារាំង រួមបង្កជាប្រភពផ្គត់ផ្គង់ដ៏សំខាន់បំផុតសម្រាប់ការប្រើងប្រែងធ្វើសង្គ្រាមរបស់ជប៉ុន ។

ទាល់តែមកដល់និទាឃរដូវឆ្នាំ១៩៤៥ ក្នុងស្ថានភាពដ៏អស់សង្ឃឹមមួយ ទើបពួកជប៉ុនប្រថុយប្រថានធ្វើឲ្យឥណ្ឌូចិនបាត់បង់ស្ថិរភាព ។ នៅពេលនោះ ពួកឥស្សរៈនៅខាងលិច និងពួកកុម្មុយនិស្តនៅខាងកើត បានពង្រឹងកម្លាំងរបស់ខ្លួនកាន់តែរឹងមាំឡើង ហើយបានបង្កើតកងទ័ពផ្ទាល់របស់គេទៀតផង ។ ពួកអ្នកជាតិនិយមបានបង្កបង្កើតចលនាដែលមានអានុភាពបំផុត ប៉ុន្តែ មេៗរបស់ពួកគេ បានសម្តែងឲ្យឃើញភាពទោរទន់ទប់មិនឈ្នះក្នុងរឿងចង់បានប្រាក់កាស និងអំណាចតាំងពីពេលនេះទៅហើយ ។ ពួកកុម្មុយនិស្ត ជាអ្នកគោរពវិន័យត្រឹមត្រូវជាងគេ និងស្ថិតនៅក្រោមអំណាចពួកវៀតណាមទាំងស្រុង ។ ប៉ុន្តែ បើសិនចលនាទាំងពីរនេះ មិនបង្ហាញឲ្យឃើញការគំរាមកំហែងពិតប្រាកដមួយចំពោះរដ្ឋាភិបាលបារាំង ក៏ពួកគេបានបង្ហាញឲ្យពួកជប៉ុនដឹងថា នៅប្រទេសកម្ពុជាមានចលនាជាតិនិយមមួយ ដែលមានសមត្ថភាពអាចផ្តើមធ្វើការប្រយុទ្ធមួយប្រឆាំងនឹងពួកបារាំងដែរ ហើយប្រហែលជាចុះចូលនឹងប្រទេសជប៉ុនទៀតផង ។

ថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៤៥ ពួកជប៉ុនបានផ្តើមធ្វើពលប្រហារមួយ ដោយបានចាប់ខ្លួនទាហាន និងប៉ូលិសបារាំងជាច្រើន ព្រមទាំងទាហានក្នុងស្រុកផង ហើយនៅទីបំផុត ក៏សម្រេចចាប់ប្រជាជនស៊ីវិលបារាំងទាំងដាក់ឃុំឃាំង ។ បួនថ្ងៃក្រោយមក សម្តេចព្រះឧបយុវរាជ ព្រះនរោត្តម សីហនុ បានប្រកាសរំលាយសន្ធិសញ្ញាឆ្នាំ១៨៦៣ និង១៨៨៤ ដែលឡាយព្រះហស្តលេខាដោយព្រះអយ្យកោព្រះអង្គ ហើយប្រកាសពីទីបញ្ចប់អាណាព្យាបាល របស់បារាំងផង ។ ប៉ុន្មានសប្តាហ៍ក្រោយមកក្នុងសាររបស់ព្រះអង្គ ដែលថ្លែងនៅពេលចូលឆ្នាំខ្មែរ សម្តេច ព្រះនរោត្តម សីហនុ បានមានបន្ទូលថា "នេះជាឆ្នាំ ដែលចក្រភពនៃព្រះអាទិត្យរះបានរំដោះប្រជាជននៅនានា អាស៊ី ហើយបានផ្តល់ចំពោះប្រជាជនខ្មែរបច្ចុប្បន្ននេះ នូវឯករាជ្យ មួយមិនអាចវាយតម្លៃបាន"[១៥] ។

មិនយូរប៉ុន្មាន ពួកជប៉ុនបានបង្ហាញឲ្យឃើញថា ពាក្យសន្យាការពារប្រទេស កម្ពុជារបស់គេជាពាក្យឥតខ្លឹមសារ ដូចគ្នានឹងពាក្យសន្យារបស់មហាអំណាចបរទេសដទៃទៀត ដែលបាននិយាយពីមុនដែរ ។ ប្រទេសជប៉ុនបានចាប់ផ្តើមធ្វើការប្លន់ដណ្តើមទ្រព្យសម្បត្តិរបស់ប្រទេសជាតិ ប្រមូលយកស្រូវអង្កររាប់ពាន់តោនទៅចិញ្ចឹមកងទ័ពរបស់ខ្លួន និងរើសជនកម្ពុជា ប្រាំពីរពាន់នាក់ឲ្យចូលធ្វើកងទ័ពជាបន្ទាន់ ។ ការចាប់ពួករដ្ឋបាល និងពួកអ្នក

បច្ចេកទេសបារាំងទាំងអស់ដាក់គុក បានជ្រមុចសេដ្ឋកិច្ចជាតិទៅក្នុងភាពចុះដុនដាប ។ ក្រោមការបង្ខិតបង្ខំសម្ដេចព្រះនរោត្តម សីហនុ បានយល់ព្រមផ្ដល់សិទ្ធិឲ្យពួកជប៉ុនប្រើប្រាស់ប្រជាកសិករខ្មែរ ក្នុងការស្ថាបនាផ្លូវថ្នល់ជាច្រើនកន្លែង ។ គេបានបង្រៀនភាសាជប៉ុននៅតាមសាលានានាក្នុងរាជធានីដែរ ។ ក្រោមលេសថា រំដោះប្រទេសពីបារាំង ពួកជប៉ុនបានដាក់ឲ្យមានការកាន់កាប់មួយ និងរដ្ឋបាលយោធាមួយដោយផ្ទាល់នៅប្រទេសកម្ពុជាថែមទៀត ។

ត្រូវជំរុញចិត្តឲ្យហ៊ានដោយគំរូរបស់ជប៉ុន ពួកថៃបានរឹតបន្ដឹងអំណាចរបស់គេលើដែនដីភាគពាយ័ព្យប្រទេស ដែលពួកគេដណ្ដើមយកដោយកម្លាំងនៅឆ្នាំ១៩៤១ នោះឡើងវិញដែរ ។ ពួកថៃបានប្រមូលពន្ធដារក្នុងបណ្ដាខេត្តកម្ពុជា ដែលពួកគេ ត្រួតត្រា ហើយបានបង្ខំឲ្យប្រជាជនទាំងនោះនិយាយភាសាថៃថែមទៀត ។ ភាពអាក់អន់ស្រពន់ចិត្ត បានរាលដាលពេញផ្ទៃប្រទេសហើយ គឺក្នុងសម័យនេះហើយ ដែលការយកចិត្តទុកដាក់ចំពោះអព្យាក្រឹតនិយម បានចាក់ឫសប្រាកដមែនទែន ដែលប្រទេសកម្ពុជានឹងបង្ហាញឲ្យឃើញក្នុងទសវត្សរ៍ដែលមានជាបន្តបន្ទាប់មកទៀត ។

នៅមានសល់ចំណុចមួយ ដែលគេត្រូវជជែកពិភាក្សាគ្នា តើអ្នកណាសមនឹងកាន់កាប់អំណាចមួយ នៅក្រុងភ្នំពេញ? ពួកជប៉ុនបានហៅ សឺង ង៉ុកថាញ់ ពីទីក្រុងតូក្យូត្រឡប់មកវិញ ហើយបានតែងតាំងគាត់ជារដ្ឋមន្ត្រីការបរទេសនៃប្រទេសកម្ពុជាមួយដែល "ឯករាជ្យ" ។ ដោយចាត់ទុកខ្លួនឯងជាមនុស្សថ្លៃថ្នូរ សក្ដិសមនឹងដឹកនាំប្រទេស ថាញ់ បានចាប់ផ្ដើមប្រឆាំងយុវព្រះមហាក្សត្រសម្ដេច ព្រះនរោត្តម សីហនុភ្លាម ។ អតីតភាពរបស់គាត់ជាអតីតយុទ្ធិកជន ជាតិនិយម បានធ្វើឲ្យគាត់ទៅជាគូប្រជែងប្រាកដប្រជាមួយចំពោះព្រះរាជា ហើយ ថាញ់ហាក់ដូចជាគ្មានខ្វល់ ព្រួយពីសេចក្ដីអៀនខ្មាស ដែលគាត់អាចមានក្នុងរឿង ដែលគាត់ដឹកនាំរបបអាយ៉ងមួយនៅចំពោះភ្នែកប្រជាជន ក៏ដូចក្នុងចិត្តគំនិតរបស់គាត់ផ្ទាល់ផងទេ ។ គាត់គិតឃើញជាស្រេចពី ទីបញ្ចប់នៃសង្គ្រាមដែលកាន់តែខិតជិតមកដល់ជាងប្រទេសកម្ពុជា ឬប្រទេសជប៉ុនធ្លាប់នឹកស្មានទៅទៀត ។

ថ្ងៃទី៩ ខែសីហា ឆ្នាំ១៩៤៥ ជាថ្ងៃដែលសហរដ្ឋអាមេរិកទម្លាក់គ្រាប់បែកបរមាណូមួយគ្រាប់ទៀតលើទីក្រុងណាហ្គាសាគី ដែលបញ្ជាក់ពីបរាជ័យជាស្ថាពររបស់ប្រទេសជប៉ុន មិត្តភក្ដិទាំងឡាយរបស់ ថាញ់ បានរៀបចំធ្វើរដ្ឋប្រហារមួយនៅភ្នំពេញ ហើយបានតែងតាំងគាត់ជារដ្ឋមន្ត្រីទី១ ។ នៅទីបញ្ចប់នៃសង្គ្រាម ពួកអ្នកទាំងនោះមានបំណងថាប្រទេសកម្ពុជាត្រូវមានមេដឹកនាំជាតិនិយមម្នាក់ ប្រកបដោយភាពប្រាកដក្នុងចិត្តរឹងមាំម្នាក់ ពុំមែនយុវក្សត្រសហការនិយមមួយអង្គ ដែលបង្ហាញថា សមត្ថភាពរបស់ព្រះអង្គ អាចធ្វើការដោយគ្មានរើសមុខសម្រាប់ព្រះចៅអធិរាជបារាំង ឬជប៉ុន ។

ថាញ់ ត្រូវបានលើកឲ្យធ្វើជារដ្ឋមន្ត្រីទី១ ដើម្បីរារាំងប្រទេសបារាំងមិនឲ្យត្រឡប់មកកម្ពុជាម្ដងទៀត ។ លោក ដឺហ្គោល និងពួកបារាំងសេរី ធ្លាប់បានប្រកាសឲ្យដឹងពីបំណងរបស់គេដើម្បីប្រមូលយកអាណានិគមរបស់

បារាំងទាំងប៉ុន្មានមកវិញ ។ ដោយស្វែងរកមធ្យោបាយទាំងអស់សង្ឃឹម ដើម្បីរាំងស្កាត់ផ្លូវពួកអតីតអ្នកគាំង អាណានិគម ថាញ់ បានប្រឹងប្រែងបង្កើតឲ្យមានការរួមកម្លាំងមួយជាមួយចលនាវៀតមិញរបស់ ហូ ជីមិញ ជាចលនាតែមួយគត់របស់វៀតណាម ដែលប្រឆាំងនឹងការវិលត្រឡប់មកវិញនៃរបបអាណានិគម ហើយដែល ថាញ់ គិតឃើញថា ជាចលនា មានកម្លាំងគ្រប់គ្រាន់សម្រាប់វាយប្រហារពួកបារាំង ។

ប៉ុន្តែ រដ្ឋមន្ត្រីការពារប្រទេសរបស់ ថាញ់ ផ្ទាល់ ដែល សម្តេច ព្រះនរោត្តម សីហនុ ធ្លាប់លើកទឹកចិត្តជាសម្ងាត់នោះ បានរត់គេចខ្លួនទៅក្រុងព្រៃនគរ ហើយបានប្រាប់ឲ្យពួកបារាំងដឹងពីផែនការផ្សេងៗរបស់ សឺង ង៉ុកថាញ់ ទៀតផង ។ ក្នុងនាមព្រះរាជា លោករដ្ឋមន្ត្រីបានសុំឲ្យពួកបារាំងត្រឡប់ចូលមកក្រុងភ្នំពេញវិញជាបន្ទាន់ ហើយជួយទប់ស្កាត់សម្ព័ន្ធភាពមួយ ដែល ថាញ់ ធ្វើជាមួយវៀតណាមនោះផងដែលតាម លោកយល់សម្ព័ន្ធភាពនេះ នឹងនាំទៅរកការកាន់កាប់ប្រទេសកម្ពុជាដោយប្រទេសវៀតណាមជាមិនខាន ពុំមែននាំទៅរកឯករាជ្យនោះទេ ។

នៅថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៤៥ កងឯកភាពទ័ពអង់គ្លេស បារាំង និងឥណ្ឌា បានរុលចូលក្នុងរាជធានី ។ ថាញ់ ត្រូវចាប់ខ្លួនព្រោះតែអំពើក្បត់របស់គាត់ ។ សម្តេច ព្រះនរោត្តម សីហនុ ដែលជាអ្នកបានបញ្ចប់អាណាព្យាបាលរបស់បារាំង ហើយដែលតាមការពិតជាអ្នកនៅជាប់ទោសពីរឿងក្បត់នឹងប្រទេសបារាំងនៅឡើយនោះ បានសុខព្រះទ័យយល់ព្រមឲ្យពួកបារាំងបន្តការត្រួតត្រាប្រទេសកម្ពុជាជាថ្មីឡើងវិញ ។ ព្រះអង្គបានស្វែងរកសេចក្តីអនុគ្រោះពីពួកបារាំង ដើម្បីបានស្ថិតនៅលើរាជបល្ល័ង្កដដែល ។ ក្រោយមក ព្រះអង្គបានខ្នះខ្នែងបង្ហាញភស្តុតាងពីទង្វើទាំងឡាយរបស់ព្រះអង្គថា «យើងសុទ្ធតែជាអ្នកក្រីក្រតោខ្លាំងណាស់ ដើម្បីជួយផ្គត់ផ្គង់សេចក្តីត្រូវការផ្សេងៗរបស់យើង ឬការពារប្រទេសយើង... យើងជាប្រជាជាតិតូចមួយ មានប្រជាជនបីលាននាក់ ស្ថិតនៅចន្លោះ ប្រជាជនវៀតណាម ម្ភៃលាននាក់ និងប្រជាជនសៀម ដប់ពីរលាននាក់)» ។

ដោយការប្រើល្បិចកលទាំងនេះ សម្តេច ព្រះនរោត្តម សីហនុ បានបង្ហាញឲ្យឃើញនូវចរិតពិតប្រាកដរបស់ព្រះអង្គ ។ ក្នុងអំឡុងបណ្តាឆ្នាំដំបូងៗនៃរជ្ជកាលរបស់ព្រះអង្គ ទ្រង់បានបណ្តោយឲ្យរដ្ឋាភិបាលអាណានិគមបារាំងដឹកនាំដោយគ្មានសម្តែងការអាក់អន់ស្រពន់ព្រះទ័យជាសាធារណៈឡើយ ។ ការយល់ព្រមដោយគ្មានរីងរូសរបស់ព្រះអង្គចំពោះពលប្រហាររបស់ជប៉ុននៅឆ្នាំ១៩៤៥ គឺជារឿងដែលគេអាចដឹងមុនដូចតែគ្នា ។ ភាពប៉ិនប្រសប់ប្រើកល្បិចរបស់ព្រះអង្គ នៅពុំទាន់បញ្ចេញឲ្យឃើញទេមុនការបញ្ចប់នៃសង្គ្រាម ក្នុងពេលដែលអំណាចរបស ់ព្រះអង្គជាកម្មវត្ថុនៃការពិភាក្សាខាងនយោបាយនោះ ។ កាលណោះ សម្តេចបានសម្តែងឲ្យឃើញថា ព្រះអង្គអាចដោះដៃចេញពីគូប្រជែងទាំងឡាយរបស់ទ្រង់ ជាពិសេស សឺង ង៉ុកថាញ់ ។ និយាយដោយខ្លី ព្រះអង្គត្រៀមបម្រុងប្រគល់ប្រទេសកម្ពុជា ទៅឲ្យពួកបារាំងជាស្រេចឲ្យតែព្រះអង្គបាននៅធ្វើជាស្តេចដដែល ។

សម្តេច ព្រះនរោត្តម សីហនុ នៅកាន់កាប់រាជបល្ល័ង្ករបស់ព្រះអង្គ ហើយពួកបារាំងបានយល់ព្រមផ្តល់លក្ខន្តិកៈប្រទេសកម្ពុជាជា«រដ្ឋស្វយ័តក្នុងផ្ទៃសហភាពបារាំង» ។ សម្តេច ព្រះនរោត្តម សីហនុ បានបោះបង់ការ

តស៊ូដើម្បីទាមទារឯករាជ្យ ក្នុងគោលបំណងរក្សាមកុដរាជ្យរបស់ព្រះអង្គ ហើយព្រះអង្គបានចំអកឲ្យ ថាញ់ ក្នុងឱកាសនោះភ្លាម ។ រឿងទាំងអស់នេះ គ្មានរឿងណាមួយគេចផុតពីក្រសែភ្នែកពួកយុវជននៅរាជធានីឡើយ ដែលទើបនឹងចូលរួមក្នុងវគ្គទីមួយនៃប្រវត្តិសាស្ត្រសម័យទំនើបរបស់កម្ពុជា ហើយដែលរៀបចំខ្លួនកាន់កាប់តួនាទីសំខាន់បំផុតក្នុងភាគរឿងជាបន្តទៅទៀត ។

## ជំនាន់យុវជន ដែលពោរពេញដោយភាពគួរឱ្យសង្ឃឹម

នៅពេលដែល សម្តេច ព្រះនរោត្តម សីហនុ ឃុបឃិតឲ្យមានការវិលត្រឡប់របស់ពួកបារាំងមកកម្ពុជាវិញ ជាសម្ងាត់ ហូ ជីមិញ និងវៀតមិញបានរៀបបម្រុងផែនការផ្សេងៗដើម្បីរារាំងប្រទេសបារាំងមិនឲ្យតាំងអាណានិគមលើប្រទេសវៀតណាមជាថ្មីឡើយ ។ ក្នុងអំឡុងសង្គ្រាមលោកលើកទី២ ពួកវៀតមិញបានបរិហារពួកជប៉ុនជាសាធារណៈ ហើយបានរួមសហការជាមួយពួកសម្ព័ន្ធមិត្តប្រឆាំងពួកហ្វាស៊ីស ជាពិសេសដោយប្រមូលពត៌មានផ្សេងៗ និងផ្តល់នូវការគាំទ្រមួយផ្នែកដឹកជញ្ជូនភស្តុភារឲ្យពួកអាមេរិកាំងផង ។ នៅទីបញ្ចប់នៃសង្គ្រាម ហូ ជីមិញ បានលេចឡើងជាបិតាឯករាជ្យដោយឥតប្រកែកបានរបស់ប្រជាជនវៀតណាម ហើយនៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៤៥ នាទីក្រុងហាណូយ គាត់បានប្រកាសឯករាជ្យរបស់វៀតណាម នៅទីលាន បាឌិញ យ៉ាងឱឡារិក ។ ព្រះចៅអធិរាជបាវដាយ របស់វៀតណាម បានអបអរសាទរសើរសេចក្តីប្រកាសនេះជាបន្ទាន់ ។

ប៉ុន្តែ ដប់មួយថ្ងៃក្រោយមក ពួកបារាំងបានវិលត្រឡប់មកក្រុងព្រៃនគរវិញ ដោយសារការធ្វើអន្តរាគមន៍របស់កងទ័ពអង់គ្លេស ។ ដោយជ្លុយនឹងពាក្យសន្យាផ្តល់ ឯករាជ្យឲ្យរដ្ឋអាណានិគមនានាបន្ទាប់ពីសង្គ្រាមក៏ដោយ ក៏ពួកសម្ព័ន្ធមិត្តនៅតែអនុញ្ញាតឲ្យប្រទេសបារាំងយកឥណ្ឌូចិន មកធ្វើជា កម្មសិទ្ធិដដែល ។ បន្តិចក្រោយមកសង្គ្រាមបានផ្ទុះឡើងហើយបានរាលដាលដល់ភាគខាងជើងនៅឆ្នាំ១៩៤៦ ។ ពួកបារាំងបានសម្រេចចិត្តបំបាត់ ហូ ជីមិញ ចេញពីជោគជ័យរបស់ គាត់ និងរាំងខ្ទប់មិនឲ្យប្រជាប្រិយភាពរបស់គាត់សាយភាយមកភាគខាងត្បូងជាទី ដែលពួកវៀត មិញកំពុងប្រកួតប្រជែងជាមួយនឹងបណ្តាចលនាអ្នកជាតិនិយមផ្សេងៗទៀត ។ នេះគឺជាសង្គ្រាមឥណ្ឌូចិនលើកទី១ ដែលមានថិរវេលារហូតដល់ឆ្នាំ១៩៥៤ ។

នៅទីបំផុត សង្គ្រាមនេះបានរាលដាលមកដល់ប្រទេសកម្ពុជា ប៉ុន្តែ នៅពេលដែលសង្គ្រាមផ្ទុះឡើងពុំមានឥស្សរជនជាតិនិយមណាម្នាក់ ធ្វើការប្រមូលផ្តុំប្រជាជនកម្ពុជាប្រឆាំងនឹងសម្តេច ព្រះនរោត្តម សីហនុ និងនយោបាយចុះញ៉មរបស់ព្រះអង្គឡើយ ។ ព្រះសង្ឃ ហែម ចៀវ ត្រូវសុគតក្នុងពន្ធនាគារ ថាញ់ ត្រូវពួកបារាំងចាប់ដាក់គុកតាមការស្នើសុំរបស់សម្តេច ព្រះនរោត្តម សីហនុ ។ ចលនាអ្នកជាតិនិយមដ៏តូចត្រូវបំបែកខ្លួនជាបីក្រុមដាច់ដោយឡែកពីគ្នា ។ ភាគច្រើននៃពួកអ្នកប្រឆាំងជាព្រះសង្ឃ ដែលធ្លាប់ធ្វើនយោបាយជាមួយ ហែម ចៀវ បានរត់គេចខ្លួនទៅរស់នៅតាមជនបទ ហើយនៅទីបំផុតមានមួយចំនួនធំក្នុងចំណោមនោះ បានសម្រេចចិត្ត

ទៅរួមសហការជាមួយពួកកុម្មុយនិស្តវៀតណាម ដោយប្រមូលគ្នាជាបក្សតែមួយ និងវាយប្រយុទ្ធក្នុងជួរពួកវៀតណាមចាប់ពីមូលដ្ឋាននានា ដែលតាំងនៅក្នុងភាគអាគ្នេយ៍ប្រទេសកម្ពុជា ។ បណ្ដាក្រុមឥស្សរៈមិនមែនកុម្មុយនិស្ត ដែលប្រមូលផ្ដុំនៅខាងម្ខាងទៀតនៃប្រទេសក្នុងខេត្តនានាភាគពាយ័ព្យបានអះអាងប្រុងប្រៀបខ្លួនតស៊ូនឹងសម្ដេច ព្រះនរោត្តម សីហនុ និងពួកបារាំង ជាស្រេច ប៉ុន្តែ ជាមួយនឹងជំនួយរបស់ពួកថៃ។ ពួកអតីតសិស្សសាលាស៊ីសុវត្ថិ ជាក្រុមអ្នកជាតិនិយមតែមួយគត់ ដែលស្ថិតនៅក្នុងរាជធានី បានបង្កើតគណបក្សនយោបាយមួយដើម្បីតទល់នឹងសម្ដេច ព្រះនរោត្តម សីហនុ និងពួកបារាំងតាមមធ្យោបាយសន្តិវិធី ។

នេះជារយៈពេលច្របូកច្របល់មួយ ដែលក្នុងរយៈពេលនោះពួកបារាំង និងពួកកម្ពុជា លែងដឹងថាអ្នកណាមួយ ដែលពួកគេត្រូវវាយប្រហារហើយ ។ ក្រុមឥស្សរៈនានា មិនសូវមានរចនាសម្ព័ន្ធល្អត្រឹមត្រូវទេ ដោយមានទស្សនៈរួមតែមួយ គឺបំណងវាយយកឈ្នះពួកបារាំងតែប៉ុណ្ណោះ ។ ពួកកុម្មុយនិស្តក៏ចង់វាយពួកបារាំងដូចពួកឥស្សរៈដែរ ប៉ុន្តែ បន្ទាប់មកគឺធ្វើបដិវត្តន៍បន្តទៀត ហើយពួកនេះក៏មានចេតនាបញ្ចុះបញ្ចូលពួកឥស្សរៈឲ្យមកចូលរួមជាមួយពួកខ្លួនដែរ ។ ពួកអ្នកជាតិនិយមនៅភ្នំពេញមានយោបល់ថា ត្រូវប្រឆាំងនឹងពួកបារាំងដាច់ដោយឡែក ពីព្រោះពួកគេបដិសេធការតស៊ូដោយអាវុធ ហើយអួតសរសើរពីការផ្លាស់ប្តូរសង្គមតាមនយោបាយនិយមផ្លូវកណ្ដាលវិញ ។

បើគិតឲ្យសព្វៗទៅ ពួកខ្មែរក្រហមនឹងស្រង់យកពួកមេដឹកនាំ និងសមាជិករបស់គេពីក្នុងក្រុមទាំងបីនេះ ប៉ុន្តែ ពុំមែននៅមុនការបញ្ចប់ទៅនៃសង្គ្រាមឥណ្ឌូចិនលើកទី១ នៅឆ្នាំ១៩៥៤ទេ គឺបន្ទាប់ពីចលនានីមួយៗ ផ្ដើមបែកបាក់គ្នារីតតែខ្លាំងឡើងៗ ។ ពួកមេដឹកនាំខ្មែរក្រហមខ្លះក្នុងចំណោមពួកមេដឹកនាំខ្មែរក្រហមដែលល្បីឈ្មោះយ៉ាងអាក្រក់មានប្រភពមកពីក្រុងភ្នំពេញ និងពីសមាគមអតីតសិស្សសាលាស៊ីសុវត្ថិ ជាពិសេសអ្នកនយោបាយប្រុស និងស្រី មួយចំនួនធំ ដែលបានដឹកនាំរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យនេះឯង ។ ដើម្បីយល់ដឹងពួកពួកខ្មែរក្រហមពីលក្ខណៈស្មុគស្មាញ និងពីភាពមិនចុះសម្រុងគ្នារបស់ពួកនេះ គេត្រូវតែផ្ដោតគំនិតមួយទៅលើអ្វីដែលកើតមាននៅក្រុងភ្នំពេញ បន្ទាប់ពីសង្គ្រាមលោកលើកទីពីរផុតរលត់ទៅ ។

ពួកអតីតសិស្សសាលាស៊ីសុវត្ថិ បានជ្រើសរើសសមាជិករបស់ខ្លួនជាសំខាន់ពីក្នុងចំណោមសិស្សវិទ្យាល័យនេះទាំងអស់ ដែលជាគ្រឹះស្ថានមធ្យមសិក្សាមួយសម្រាប់តែកូនចៅវរជនក្នុងស្រុករៀនសូត្រប៉ុណ្ណោះ ប៉ុន្តែក៏មានកូនសិស្សនៅសាលាបច្ចេកទេស និងវិជ្ជាជីវៈ មកចូលរួមក្នុងចលនានេះដែរ ។ ក្នុងចំណោមសិស្សសាលាក្រោយនេះ មានយុវជនម្នាក់ដែលនៅពេលនោះ ហាក់ដូចជាអ្នកដែលព្រួយបារម្ភនឹងរត់ចេញឲ្យផុតពីអន្ទប់នៃប្រព័ន្ធអប់រំរបស់កម្ពុជាប៉ុណ្ណោះ ។ សាឡុត ស ដែលបន្ទាប់មក បានប្រកាន់យករហស្សនាមថា ប៉ុល ពត ធ្លាប់បានរៀនសូត្រក្នុងអនុវិទ្យាល័យមួយនៅខេត្ត ក្នុងពេលដែលពួកជប៉ុនចូលមកដល់ទីក្រុងភ្នំពេញ ។ ជាកូនប្រុសរបស់អ្នកមានផ្ទះសម្បែង ដីធ្លីម្នាក់នៅភាគខាងជើងខេត្តកំពង់ធំ ស ត្រូវបានរាប់ចូលក្នុងគ្រួសារមួយ ដែលមានជីវភាព

ធូរធារគ្រាន់បើ ប៉ុន្តែពុំមែនជាចំណែកមួយនៃវរជនចេះដឹង ដែលរស់នៅទីក្រុងឡើយ ។ តាមការអះអាងផ្ទាល់ខ្លួនរបស់គាត់ថា[១៦] គាត់បានរៀនសូត្រប្រាំមួយឆ្នាំក្នុងសាលាវត្តមួយនៅក្រុងភ្នំពេញ បន្ទាប់មក គាត់បានប្រឡងធ្លាក់វិញ្ញាបនបត្របឋមសិក្សា នៅពេលមានអាយុដប់មួយឆ្នាំហើយបានតម្រូវឲ្យគាត់វិលត្រឡប់ទៅរស់នៅក្នុងវង្សត្រកូលវិញ ។

ក្នុងអំឡុងដប់ឆ្នាំដែលមានជាបន្ទាប់មកទៀត ការសិក្សាទាំងអស់របស់គាត់បានបង្ហាញឲ្យឃើញនូវការប្រឹងប្រែងដូចគ្នា និងមិនបានជោគជ័យដដែល ។ ស បានរៀនសូត្រស្ទើរតែពេញបណ្ដាឆ្នាំនៃការត្រួតត្រារបស់ជប៉ុន ក្នុងគ្រឹះស្ថានមធ្យមសិក្សាមួយនៅខេត្តកំពង់ចាម ដែលមានរបៀបរបបដូចសាលាបារាំងដែរ ព្រោះថាគាត់ពុំដែលបានសម្រេចចូលរៀនក្នុងវិទ្យាល័យពិតប្រាកដមួយឡើយ ។ នៅឆ្នាំ១៩៤៨ ក្នុងអាយុដប់ប្រាំបួនឆ្នាំគាត់បានចាកចេញពីអនុវិទ្យាល័យនេះ ដើម្បីធ្វើដំណើរទៅក្រុងភ្នំពេញ ដែលគាត់បានចូលរៀនក្នុងសាលាបច្ចេកទេសមួយ ។ គាត់បានរៀនខាងមុខជំនាញជាងឈើ ក្រោមការមើលខុសត្រូវរបស់បងប្រុសគាត់ និងជាអ្នកទំនុកបម្រុងគាត់ គឺ ឡុត ស្វួង ដែលជាបុគ្គលិកតូចតាចផ្នែកក្រសួងពិធីការនៅព្រះបរមរាជវាំង ។ ជាច្រើនឆ្នាំក្រោយមក បងប្រុស គាត់បាននិយាយឲ្យដឹងថា នៅជំនាន់នេះ ស ជាយុវបុរសម្នាក់ ដែលគួរឲ្យចូលចិត្តសាមញ្ញ ខស្សរាប់ព្យាយាមមធ្យ័ត នឹងធឹង ហើយមិនយកចិត្តទុកដាក់រឿងនយោបាយឡើយ ។

ប៉ុន្តែ ដំណើរជីវិតរបស់ ស គឺធ្វើទៅតាមគេឲ្យយោបល់ប៉ុណ្ណោះ ជាជាងកុំឲ្យគេថា គាត់ជាបុរសម្នាក់ដែលបានសម្រេចដើរតួដោយឆាប់រហ័សក្នុងជោគវាសនារបស់ប្រទេសគាត់នូវតួនាទីមួយ ដែលមានអំណាចជាងកសិដ្ឋានរបស់ឪពុកគាត់ទៅទៀត ។ ទោះជាមានការចាញ់ប្រៀបយ៉ាងសម្បើម ដែលបង្កឡើងដោយសារដើមកំណើតរបស់គាត់ជាអ្នកធ្លាប់រស់នៅស្រុកស្រែចម្ការ និងសមត្ថភាពផ្សេងៗ របស់គាត់មិនសូវប្រាកដប្រជាក៏ដោយ ក៏ ស ប្រឹងប្រែងធ្វើការដោយមានះក្នុងគ្រឹះស្ថាននានា ដែលបានផ្ដល់កន្លែងមួយសម្រាប់រូបគាត់ ។ ដើមកំណើតរបស់គាត់ទាំងនេះ ប្រហែលជាតម្រង់គាត់ទៅរកក្រុមនៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ប៉ុន្តែកាលនោះនៅភ្នំពេញគាត់បាន ធ្វើសកម្មភាពក្រវែលៗជុំវិញសមាគមអតីតសិស្សសាលាស៊ីសុវត្ថិ ហើយនៅទីបំផុតក៏ក្លាយទៅជាសមាជិកនៃចលនានេះ ដែលតទៅមុខទៀតគាត់ត្រូវតែយកប្រៀបពីលើព្រះសង្ឃទាំងឡាយទៀត ។

ស បានចូលរៀនសាលាបច្ចេកទេសនៅក្រុងភ្នំពេញ ក្នុងសម័យកាល ដែលមានភាពសុខសាន្តផ្នែកនយោបាយ ហើយការផ្លាស់ប្ដូរមួយ ។ បញ្ហាទាំងអស់ដែលនឹងដែលគ្របដណ្ដប់លើប្រវត្តិសាស្ត្ររបស់កម្ពុជាក្នុងអំឡុងសាមសិបឆ្នាំបន្តបន្ទាប់មកទៀត បានចោទឡើងជាលើកដំបូងបំផុត ដោយមនុស្សមួយចំនួនធំ ដែលនឹងកំណត់សម្រេចក្រោយមកនូវចម្លើយផ្សេងៗ ។

ការជជែកពិភាក្សាខាងនយោបាយ បានចាប់ផ្ដើមភ្លាមក្រោយសង្គ្រាមលោកលើកទី២ នៅពេលដែលពួកបារាំងបានអនុញ្ញាតឲ្យប្រជាជនកម្ពុជា បង្កើតគណបក្សនយោបាយផ្សេងៗ និងចូលរួមក្នុងការបោះឆ្នោតជ្រើស

រើសសភាសម្រាប់ «ពិគ្រោះ» មួយ ។ ធ្វើដូច្នេះ ប្រទេសបារាំងប្រាថ្នាបញ្ចប់ការទាមទារផ្សេងៗ ដើម្បីឯករាជ្យ និងលុបបំបាត់ការបះបោរប្រដាប់អាវុធ ដែលកំពុងរីកធំឡើងៗ នៅតាមជនបទ ដោយមិនលះបង់ចោលអំណាចរបស់ខ្លួនមួយចំណែកណាឡើយ ។ គណបក្សបីត្រូវបានបង្កើតឡើង ដែលសុទ្ធតែដឹកនាំដោយព្រះអង្គម្ចាស់មួយអង្គ - នេះជាភស្តុតាងបញ្ជាក់ថា ប្រជាជនកម្ពុជានៅតែជាប់ជំពាក់ចិត្ត នឹងប្រពៃណីសក្តិភូមិនិងព្រះមហាក្សត្រជានិច្ច ។

ព្រះអង្គម្ចាស់យុត្តិវង្សបានបង្កើតគណបក្សប្រជាធិបតេយ្យនិយមផ្លូវកណ្តាល ដែលប្រមូលផ្តុំសុទ្ធតែពួកអតីតយុទ្ធិកជនរបស់ សឺង ង៉ុកថាញ់ បណ្តាសមាជិកនៃសមាគមអតីតសិស្សសាលាស៊ីសុវត្ថិ និងប្រជាជនកម្ពុជាដែលប្រកបដោយចិត្តគំនិតប្រជាធិបតេយ្យ និងគំនិតសង្គមនិយមថែមទៀត ។ គឺគណបក្សនេះហើយ ដែលទាក់ទាញបានកូនសិស្សអនុវិទ្យាល័យនានាដូចជា ស ជាដើម និងកូនសិស្សវិទ្យាល័យស៊ីសុវត្ថិ ដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភ ។ នៅក្នុងការបោះឆ្នោតខែកញ្ញា ឆ្នាំ១៩៤៦ គណបក្សប្រជាធិបតេយ្យបានទទួលជោគជ័យភ្លូកទឹកភ្លូកដីមួយ ហើយបានបង្កើតគណៈរដ្ឋមន្ត្រីជាលើកដំបូងបង្អស់ សម្រាប់ដឹកនាំប្រទេសជាតិ ។

ពួកប្រជាធិបតេយ្យបានខំប្រឹងទាញអត្ថប្រយោជន៍ទាំងឡាយ ដែលអាចមានពីស្ថានភាពរបស់ខ្លួន ដែលជាអ្នកមានប្រៀបជាងគេនៅក្នុងសភាសម្រាប់ «ពិគ្រោះ» ។ រដ្ឋាភិបាលបានចាប់ផ្តើមកែទម្រង់បណ្តាស្ថាប័នសម្រាប់ ព្រះមហាក្សត្រដែលចាស់ហួសសម័យទៅហើយ ហើយបានបង្កើតរចនាសម្ព័ន្ធផ្សេងៗ សម្រាប់ប្រទេសកម្ពុជាទំនើបមួយ ។ រដ្ឋាភិបាលបានធ្វើឲ្យគេយល់យ៉ាងច្បាស់ថា ខ្លួននឹងសម្រេចធ្វើការងារដោយមិនចំណុះអ្នកណាឡើយ ។ ប៉ុន្តែ ជាជាងបង្កឲ្យមានសង្គ្រាមមួយ រដ្ឋាភិបាលបានធ្វើសេចក្តីអំពាវនាវអែបខាងពួកបារាំងក្នុងគំនិតគិតថា ប្រទេសបារាំងនឹងពុំអាចស្ថិតនៅប្រទេសកម្ពុជាជារៀងរហូតទេ ដរាបណាសង្គ្រាមកំពុងរីករាលយ៉ាងខ្លាំងនៅប្រទេសវៀតណាមនោះ ។ ពួកប្រជាធិបតេយ្យ បានផ្សាយនូវជម្រើសរវាងលទ្ធភាពពីរដែលខ្លួនត្រូវបង្ហាញចំពោះប្រទេសបារាំងថា ឬមួយសុខចិត្តផ្តល់ឯករាជ្យមកឲ្យពួកខ្លួនគឺ ពួកបញ្ញវន្ត ពួកវរជនកម្ពុជា ឬនៅទីបំផុតត្រូវបង្ខំចិត្តផ្តល់ឯករាជ្យទៅឲ្យពួកបះបោរ ដែលកំពុងប្រយុទ្ធតស៊ូក្នុងព្រៃភ្នំ បន្ទាប់ពីការធ្វើសង្គ្រាមបង្ហូរឈាមមួយ ។ នៅឆ្នាំ១៩៤៧ លោក សឺន សាន រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុបានធ្វើខ្លួនជាអ្នកពាំនាំសេចក្តីអំពាវនាវដ៏គួរសមនេះទៅឲ្យប្រទេសបារាំង ៖ «យើងស្នើសុំ ឲ្យអស់លោកយល់ពីបំណងប្រាថ្នាដ៏ជ្រាលជ្រៅរបស់យើងអំពីរឿងឯករាជ្យនេះ ហើយជួយយើងឲ្យបានសម្រេចតាមសំណូមពរនេះផង...»[១៧] ។

គណបក្សប្រជាធិបតេយ្យ ក៏បានអំពាវនាវទៅកាន់ក្រុមឥស្សរៈនានា ឲ្យបោះបង់ចោលការតស៊ូ ដោយអាវុធរបស់គេប្រឆាំងនឹងប្រទេសបារាំង និងជួយកែប្រែស្ថានភាពប្រទេសជាតិ តាមមធ្យោបាយស្របច្បាប់វិញ ។ ពួកប្រជាធិបតេយ្យនៅតែទៅមុខដរាបទុកណាជាមេកោយរបស់ខ្លួន គឺអ្នកអង្គម្ចាស់ យុត្តិវង្ស សោយទិវង្គតនៅឆ្នាំ១៩៤៧ ក្នុងជន្មាយុសាមសិបបួនឆ្នាំក៏ដោយ ។ តាមការឲ្យយោបល់របស់សម្តេច ព្រះនរោត្តម សីហនុ

ពួកបារាំងបានដាក់ជំនួស យុត្តិវង្ស ដោយព្រះអង្គម្ចាស់មួយអង្គទៀត ដែលជាមនុស្សអភិរក្សនិយម ដូចព្រះមហាក្សត្រដែរ ហើយដែលមិនទទួលដឹងនូវអ្វីៗដែលគណបក្សប្រជាធិបតេយ្យបានធ្វើមួយភាគធំកន្លងមក ។ មេដឹកនាំថ្មីនេះបានយកពួករដ្ឋមន្ត្រីអភិរក្សនិយមថ្មីៗ ជាច្រើននាក់មកដាក់ជុំវិញខ្លួន ហើយបានកែប្រែសភាសម្រាប់«ពិគ្រោះ» ទៅជាសភា«ប្រថាប់ត្រា»វិញ ។

ប៉ុន្តែគណបក្សប្រជាធិបតេយ្យនៅមានឥទ្ធិពលមួយយ៉ាងខ្លាំងលើប្រទេសជាតិ ហើយស្ថិតស្ថេរយូរអង្វែងជាងរយៈពេលនៃការកាន់កាប់អំណាចយ៉ាងខ្លីរបស់ខ្លួននោះទៅទៀត ។ ប៉ុន្មានឆ្នាំ ក្រោយមកសម្ដេច ព្រះនរោត្តម សីហនុ បានយកសម្ដី និងគំនិតផ្សេងៗរបស់ពួកប្រជាធិបតេយ្យមកប្រើឡើងវិញ ដើម្បីដោះព្រះកាយចេញពីពួកបារាំង ហើយបានបញ្ចេញឲ្យគេដឹងថាខ្លួនជាព្រះបិតាឯករាជ្យជាតិរបស់ប្រទេស ។ម្យ៉ាងវិញទៀត គណបក្សប្រជាធិបតេយ្យបានបំផុសទឹកចិត្តយុវជនរដ្ឋធានីឲ្យកម្រើកសកម្មភាពឡើង ។ គម្រោងរដ្ឋធម្មនុញ្ញ និងសេចក្ដីថ្លែងការណ៍របស់ខ្លួនស្ដីពីរដ្ឋាភិបាលទាន់សម័យមួយ សម្រាប់ប្រទេសកម្ពុជានោះ បានមានឥទ្ធិពលយ៉ាងសម្បើមមួយទៅលើពួកយុវជនទាំងនោះ ។ ពួកកូនសិស្សនៅសាលាស៊ីសុវត្ថិ បានផ្លាស់ប្ដូរចិត្តមកជឿទស្សនៈផ្សេងៗរបស់គណបក្សប្រជាធិបតេយ្យវិញ ដែលធ្លាប់ស្វះស្វែងឲ្យមានការចូលរួមរបស់ពួកអ្នកទាំងនោះ ដើម្បីបង្កើនថាមពលឧត្ដមគតិនិយមដើមកំណើតសង្គមរបស់គេពីព្រោះគណបក្សប្រជាធិបតេយ្យដឹងថា មនុស្សពេញវ័យទាំងនេះនឹងទៅជាប្រភពនៃបណ្ដាមេដឹកនាំសម្រាប់ជំនាន់បន្ទាប់ ជាជំនាន់ដែលពោរពេញទៅដោយភាពគួរឲ្យសង្ឃឹមច្រើន ដែលនឹងធ្វើឲ្យប្រទេសកម្ពុជាឯករាជមិនចំណុះគេ ។

ដោយពិតមានយុវមេដឹកនាំជាច្រើនបានជម្រុលខ្លួនមកខាងមុខឆាកនយោបាយ ។ ចាប់តាំងពីឆ្នាំ១៩៤៦ ពួកនិស្សិតបានមកបង្កើតក្រុមមួយហៅថា ក្រុមរំដោះប្រទេសកម្ពុជាពីអាណានិគមនិយមបារាំង ដែលដឹកនាំដោយយុវបុរសម្នាក់ឈ្មោះ អៀង សារី[១៨] ។ គាត់ជាមនុស្សប្រឡើសបើសគ្មានសុជីវធម៌ម្នាក់នៅសាលាស៊ីសុវត្ថិ ។ គាត់មានដើមកំណើតនៅកម្ពុជាក្រោមក្នុងភាគខាងត្បូងប្រទេសវៀតណាម សារី និយាយខ្មែរប៉ែឡាំមានសំនៀងជាវៀតណាម ហើយពុំមែនស្ថិតនៅក្នុងចំណោមពួកអ្នកហ៊ឺហាដូចពួកអ្នករៀនសូត្រជាមួយគាត់ទេ ប៉ុន្តែ គាត់ខំប្រឹងប្រែង ធ្វើការយ៉ាងស្វិតស្វាញដើម្បីឲ្យបានក្លាយទៅជាប្រជាជនកម្ពុជាដូចគេឯងដែរ ។ គាត់បានផ្លាស់ឈ្មោះគីមត្រាង ទៅជា អៀង សារី វិញ ព្រោះវាមានសំនៀងជាខ្មែរច្រើនជាង ហើយបានក្លែងបន្លំសំបុត្រជាតិកំណើតមួយ ដើម្បីធ្វើឲ្យគាត់មានអាយុតិច ងាយស្រួលក្នុងការផ្ទេរការសិក្សាពីសាលាមួយនៅភាគខាងត្បូងរបស់វៀតណាម មករៀនក្នុងគ្រឹះស្ថានសិក្សានៅក្នុងខេត្តមួយនៅប្រទេសកម្ពុជា ។ នៅទីនោះ គាត់បានបញ្ចេញឲ្យឃើញសមត្ថភាពរបស់គាត់យ៉ាងច្រើន ហើយមិនយូរប៉ុន្មាន ក៏បានចូលរៀននៅសាលាស៊ីសុវត្ថិ ដោយមានអាហាររូបករណ៍មួយផង ។ ជាសិស្សពូកែគណិតវិទ្យាបំផុត គាត់បានប្រឡងជាប់មធ្យមសិក្សាបត្រទីមួយរបស់គាត់ ជាមួយពិន្ទុល្អប្រសើរណាស់ ។ បន្ទាប់មក គាត់បានប្រកាន់យកស្ថានភាពក្នុងផ្លូវនយោបាយភ្លាម ។

ជាមនុស្សអង់អាចស្វាហាប់ ប្រាជ្ញាវាងវៃ និងចុះចំណោម សារី បានត្រូវធ្វើឲ្យចាប់ចិត្តដោយនយោបាយរបស់គណបក្សប្រជាធិបតេយ្យហើយ ពុំមែនមានតែគាត់ម្នាក់ឯងទេ ។ អ៊ុំ ស៊ីម ដែលក្រោយមកបានក្លាយទៅជាឯកអគ្គរដ្ឋទូតរបស់ លន់ នល់ ប្រចាំសហរដ្ឋអាមេរិក និង កេង វ៉ាន់សាក់ អនាគតអ្នកដឹកនាំសំខាន់បំផុតរបស់គណបក្សប្រជាធិបតេយ្យ បានចូលរួមជាមួយ អៀង សារី និងអ្នកដទៃទៀតក្នុងការជជែកពិភាក្សាគ្នាជាញឹកញាប់ដែរ ដោយបានធ្វើឲ្យវិទ្យាល័យនេះ មានសកម្មភាពអូរអរជានិច្ច ។ វិទ្យាល័យព្រះស៊ីសុវត្ថិ គឺជាមជ្ឈមណ្ឌលល្អឥតខ្ចោះសម្រាប់អនាគតមេដឹកនាំទាំងអម្បាលម៉ាននេះ ។ គ្រឹះស្ថាននេះស្ថិតនៅកណ្តាលទីក្រុងក្រោមស្រមោលវត្តភ្នំចំពីក្រោយសារមន្ទីរជាតិ ច្បាស់ណាស់នេះជាសាលាសម្រាប់កូនៗមន្ត្រីក្នុងស្រុករៀនសូត្រ ជាកន្លែងដែលផុសចេញនូវការតវ៉ាប្រឆាំង ក្នុងចំណោមប្រជាជាតិនានា ដែលស្ថិតនៅក្រោមនឹមអាណានិគមបរទេស ។

បាតុកម្មជាហូរហែមួយនៅវិទ្យាល័យនេះ បានចេញពីច្រកចង្អៀតមកលើទីលាននយោបាយព្រមជាមួយការអំពាវនាវមួយឲ្យមានកូដកម្មទូទាំងប្រទេស ដើម្បីជួយគាំទ្រការទាមទារឯករាជ្យផ្ទាល់របស់គណបក្សប្រជាធិបតេយ្យ - ការទាមទារ ដែលច្រានចោលដោយសម្តេច ព្រះនរោត្តម សីហនុ ។ នេះគឺជាបាតុកម្មរបស់ពួកនិស្សិតដែលកើតមានជាលើកដំបូងបំផុតក្នុងប្រវត្តិសាស្ត្រនៃទីក្រុងភ្នំពេញ ។

កូដកម្ម ដែលដឹកនាំដោយ អៀង សារី ហាក់ដូចជាពុំសូវមានអត្ថន័យធំដុំប៉ុន្មានទេនៅសម័យនោះ ប៉ុន្តែវាបានដោយ៉ាងជ្រៅក្នុងចិត្តរបស់យុវមេដឹកនាំរូបនេះ ដែលដឹងថាខ្លួនបានក្លាយទៅជាស្នូល ស្ថិតនៅចំកណ្តាលឆាកនយោបាយរបស់ជាតិស្រេចទៅហើយ ។ សម្តេច ព្រះនរោត្តម សីហនុ បានបរិហារចលនានេះជាសាធារណៈ ហើយបានថ្លែងប្រកាសថា ពួកសិស្សវិទ្យាល័យគួរធ្វើអ្វីៗឲ្យបានប្រសើរជាងនេះ ដើម្បីជួយទ្រទ្រង់កិច្ចរបាននានារបស់ព្រះអង្គជាមួយពួកបារាំងវិញ ។ ក្នុងពេលជាមួយគ្នានោះ សម្តេចបានធ្វើឲ្យគេយល់យ៉ាងច្បាស់ថា ព្រះអង្គគ្មានបំណងចែករំលែកអំណាចជាមួយរដ្ឋសភាទេ ហើយរឹតតែអត់ថែមទៀតបន្ទាប់ពីមរណភាពរបស់ទ្រង់យុត្តិវង្ស ។ ហេតុនេះការយកស្វ័យភាពនយោបាយ ដែលព្រះអង្គយកមកប្រើប្រាស់ជានិមិត្តរូបនេះ បានបង្ហាញឲ្យឃើញថា គ្មានបានប្រយោជន៍អ្វីទាំងអស់ ។

ដោយត្រូវធ្វើឲ្យស្រងាកចិត្ត និស្សិតជាច្រើនបានចាប់ផ្តើមលើកនិយាយពីពួកអ្នកតស៊ូវៀតមិញ ដែលតាមពុគេអះអាងថា បានប្រយុទ្ធតស៊ូដើម្បីឯករាជ្យនៅប្រទេសវៀតណាមដែរ ។ ត្រូវធ្វើឲ្យខកចិត្តដោយសារឧបសគ្គផ្សេងៗខាងនយោបាយ ដែលកំពុងកើតឡើងនៅភ្នំពេញ សារី បានស្នើសុំទៅរៀននៅក្រុងប៉ារីសដោយបានទទួលអាហារូបករណ៍សិក្សាមួយផង ។ អាហារូបករណ៍ទាំងនេះ កម្រអ្នកណាបានទទួលណាស់ ព្រោះម្ធ្យាបាយដែលគ្រប់គ្រងតាមរយៈការិយាល័យនិស្សិតកម្ពុជាទើបតែចាប់ផ្តើមនៅឆ្នាំ១៩៤៧ ជាមួយនឹងអាហារូបករណ៍សាមសិបមួយប៉ុណ្ណោះ ។ វាទំនងជាអាចថា សារី បានស្នើឲ្យអ្នកមានបុណ្យសក្តិ ដែលគាត់ធ្លាប់ស្គាល់តាមរយៈគណបក្សប្រជាធិបតេយ្យជួយធ្វើអន្តរាគមន៍ដើម្បីធានាឲ្យរូបគាត់បានទទួលកន្លែងរៀនមួយក្នុងសកលវិទ្យាល័យ

របស់បារាំង ។ នៅឆ្នាំ១៩៥០ គាត់បានធ្វើដំណើរ ទៅក្រុងព្រៃនគរដើម្បីឡើងជិះកប៉ាល់ហោះ ឆ្ពោះទៅប្រទេសបារាំង ។ គាត់បានបែកចេញពីពិភពដ៏តូចនៃអ្នកនយោបាយជានិស្សិតនៅភ្នំពេញ ដើម្បីជីវភាពនៅតាមមហាវិថីនានានៅក្រុងប៉ារីសវិញ ដែលគាត់នឹងចងមិត្តភាពជាមួយកម្ពុជាម្នាក់ទៀត ។

សាឡុត ស បានទៅដល់ប្រទេសបារាំងកាលពីមួយឆ្នាំមុន ។ ដោយគិតទៅដល់លទ្ធផលនៃការសិក្សាដ៏ព្យាយាមរបស់គាត់ ស ក៏ទំនងជាបានទទួលអាហារូបករណ៍តាមរយៈទំនាក់ទំនងដូចគ្នានឹង សារី ដែរ នេះជាទំនៀមទម្លាប់មួយនៅក្រុងភ្នំពេញទៅហើយ ។ ការដែលពួកនិស្សិតធ្វើដំណើរទៅប្រទេសបារាំងដើម្បីបន្តការសិក្សាវិជ្ជាជាន់ខ្ពស់នៅទីនោះបានរួមបញ្ចូល ស ទៅក្នុងប្រភេទពួកអ្នកត្រួសត្រាយដែរ ។ ពិតហើយការសិក្សានៅសកលវិទ្យាល័យ គឺជាឯកសិទ្ធិមួយ ដែលក្នុងនោះ ប្រជាជនកម្ពុជាសាមញ្ញទើបតែបានឈោងដល់ក្នុងពេលថ្មីៗនេះប៉ុណ្ណោះ ហើយមានយុវជនត្រកូលអភិជនតិចតួច ធ្លាប់បានទៅធ្វើការសិក្សារបស់គេនៅទីក្រុងប៉ារីស ។ កាលពីមុនប្រជាជនកម្ពុជាបានទៅរៀននៅសកលវិទ្យាល័យបារាំង នាទីក្រុងហាណូយឯណោះ ព្រោះនៅភ្នំពេញគ្មានសាលារៀនរបៀបនេះទេ ។ ប៉ុន្តែ ការកាន់កាប់ត្រួតត្រារបស់ជប៉ុន ហើយបន្ទាប់មកសង្គ្រាមនៅវៀតណាមបានធ្វើឲ្យទីក្រុងហាណូយទៅជាទីក្រុងមួយលែងសូវមានសុវត្ថិភាព ហើយប្រហែលជានៅចុងទសវត្សរ៍១៩៤០ ជនកម្ពុជាមួយចំនួនតូចបានចាប់ផ្ដើមរួមជាមួយបណ្ដាយុវជននៃរដ្ឋ អាណានិគមផ្សេងៗទៀត ដែលពុះពារធ្វើដំណើរដ៏វែងឆ្ងាយ និងដ៏លំបាករហូតទៅដល់ក្រុងប៉ារីស ដើម្បីទទួលបានសញ្ញាបត្រ និងរៀនធ្វើនយោបាយ ។ ការរកឃើញផ្លូវទៅក្រុងប៉ារីសដោយគ្មានជំពាក់ជំពាក់វិននឹងវរជនណា បានបណ្ដាលឲ្យ ស និង សារី មានអារម្មណ៍ថា ខ្លួនត្រូវបានគេជ្រើសរើសជាអ្នកឈានមុខគេ ក្នុងបណ្ដាអ្នក«ដែលមានសមត្ថភាព និងចំណេះវិជ្ជាខ្ពង់ខ្ពស់»ទាំងឡាយ -នេះជាឥរិយាបថ ដែលអ្នកទាំងពីរ មិនដែលបោះបង់ចោលម្ដងណាសោះឡើយ ។

ផលអាក្រក់ផ្សេងៗ ដែលកើតមាននៅក្នុងការបញ្ជូនពួកនិស្សិត ពិបាកប្រដៅ និងប្រកបដោយមហិច្ឆតាហួសហេតុ ទៅរៀននៅប្រទេសមួយ ដែលភាគច្រើននៃពួកកម្មករបោះឆ្នោតឲ្យគណបក្សកុម្មុយនិស្តនោះ បានក្លាយ ទៅជារឿងគួរឲ្យមន្ទិលសង្ស័យតាំងពីដំបូងទីម្ល៉េះ ។ នៅពេលដែល សាឡុត ស ទៅដល់ទីក្រុងប៉ារីស មាននិស្សិតខ្មែរជាច្រើនបានសាកល្បងចង់ដឹងលទ្ធិម៉ាក្សសិស្សរួចស្រេចទៅហើយ ហើយថែមទាំងបង្កើតនូវអ្វីដែលនឹងក្លាយទៅជាក្លឹបម៉ាក្សលេនីនរបស់កម្ពុជានៅក្រុងប៉ារីសទៀតផង ។ ពីក្នុងចំណោមក្រុមនេះមានលេចចេញបុគ្គលិកលក្ខណៈរបស់និស្សិតម្នាក់ឈ្មោះ ជួន មុំ ដែលបានទៅដល់ប្រទេសបារាំងកាលពីឆ្នាំ១៩៤៦ ។ គាត់ជាមនុស្សដែលគួរឲ្យស្រឡាញ់ចូលចិត្ត និងជាអ្នកទទួលមរតកនៃគ្រួសារអភិជនមួយ ក្នុងចំណោមគ្រួសារអភិជនទាំងឡាយនៅកម្ពុជា ។ ជាមនុស្សប៉ិនប្រសប់ ស្អាតសង្ហា ដោយមានបុកពាជាអ្នកចូលចិត្តសប្បាយ ដែលអាចបំបាត់កង្វល់ផ្សេងៗរបស់ជនជាតិកម្ពុជាម្នាក់ ដែលទើបទៅដល់ទីក្រុងប៉ារីសថ្មីៗ ។ គាត់នឹងក្លាយទៅជាជនជាតិខ្មែរដំបូងបង្អស់ ដែលបានទទួលសញ្ញាបត្រពីសាលាពហុបច្ចេកទេសក្រុងប៉ារីស ។

នៅសម័យនេះក៏ដូចពេញរយៈពេលនៃប្រវត្តិដ៏ច្របូកច្របល់របស់ពួកខ្មែរក្រហមដែរ ម៉ុំ និងប្អូនប្រុសទាំងបីរបស់គាត់ បានផ្ដល់ឲ្យចលនាកុម្មុយនិស្តកម្ពុជា នូវភាពថ្លៃថ្នូរ និងលក្ខណៈដែលធ្វើឲ្យគេគោរពកោតខ្លាច ។ តែខ្លួនគាត់ម្នាក់ ឈ្មោះរបស់វង្សត្រកូល ជួន បានបណ្ដាលឲ្យមានលទ្ធផលនេះ ។ គ្រួសាររបស់គាត់បានឈានឡើងដល់ស្ថានភាពមួយលើសគេលើសឯងក្នុងអំឡុងសតវត្សរ៍ទី១៩ នៅពេលដែលពួកបារាំង តម្រូវឲ្យសម្ដេច ព្រះនរោត្តម សីហនុ ទទួលយល់ព្រមធ្វើការតែងតាំងមន្ត្រីរាជការម្នាក់[១៩] ឈ្មោះ ជួន ឲ្យកាន់មុខតំណែងជាលោក "វាំង" (រដ្ឋមន្ត្រីអមព្រះរាជវាំង) នេះជាមុខងារមួយ ដែលត្រូវកាន់តកូនតចៅ មានឋានៈស្មើនឹងរដ្ឋមន្ត្រីទី១ដែរ ហើយតួនាទីនេះក៏អនុញ្ញាតឲ្យ ជួន មានមូលដ្ឋានមួយយ៉ាងរឹងមាំ និងផ្ដល់ទៅឲ្យកូនចៅគាត់ថែមទៀត ។ គាត់ចេះទាញយកផលប្រយោជន៍អំពីមុខងាររបស់គាត់ណាស់ ហើយក្នុងទម្លាប់នៃអំពើពុករលួយរបស់ពួកមន្ត្រីអមព្រះរាជាខ្មែរគាត់ក៏បានក្លាយទៅជាអ្នកមានសម្បត្តិយ៉ាងស្ដុកស្ដម្ភម្នាក់ ប៉ុន្តែ ប្រការនេះប្រហែលជាធ្វើឲ្យគាត់បាត់បង់ការស្រលាញ់រាប់អានពីសំណាក់សម្ដេច ព្រះនរោត្តម សីហនុ ដែរ ។ គាត់បានបង្កើតឲ្យមានរវាងអ្នកទាំងពីរ គឺគាត់និងសម្ដេច ព្រះនរោត្តម សីហនុ នូវការប្រណាំងប្រជែងមួយ ដែលមូលហេតុផ្សេងៗបានកប់បាត់នៅក្នុងសភាពស្មុគស្មាញនៃការនិយាយដើមអាក្រក់ពីពួកស្ដេចទាំងនេះរបស់ពួកគេ ដោយហេតុនេះទើបបានជាកូនរបស់លោកវាំង ត្រូវគេផាត់ចោលមិនរាប់រកដោយបណ្ដាស្ដេច ដែលអ្នកស្នងរាជបន្តពីស្ដេច នរោត្តម មកទៀត ។

ការប្រណាំងប្រជែងនេះនេះស្ថិតនៅបន្តរហូតមក ។ ប៉ុន្តែ ចៅៗរបស់លោកវាំង គឺកូនប្រុសរបស់ត្រកូលជួន បានទៅជាចំណែកមួយនៃក្រុមយុវបុរស ដែលមានឯកសិទ្ធិបំផុតនៅក្នុងក្រុងភ្នំពេញ ហើយមិនបណ្ដោយខ្លួនឲ្យសម្ដេច ព្រះនរោត្តម សីហនុ សម្គុតបរាជ័យបានឡើយ ។ ថ្វីបើពួកគេអាចពេញចិត្តនឹងជីវភាពមួយ ដែលសម្បូរទៅដោយភាពទំនេរ ការអង្អែលថ្នាក់ថ្នមពីហ្វូងអ្នកបម្រើក្នុងភូមិគ្រឹះមួយក្នុងបណ្ដាភូមិគ្រឹះជាច្រើនរបស់ខ្លួននៅភ្នំពេញ និងស្រួលស្រណុកយ៉ាងណាក៏ដោយ ក៏យុវបុរសទាំងនេះបានជ្រើសរើសផ្លូវមួយខុសៗគ្នា ។ ក្រោមការកាន់កាប់របស់ជប៉ុន អ្នកទាំងនេះធ្លាប់បានចូលរួមនឹងក្រុមអ្នកជាតិនិយមដោយចេញមុខ -ដំបូងជាមួយពួកយុទ្ធិកជនរបស់ សឺង ង៉ុកថាញ់ ក្រោយមកជាមួយគណបក្សប្រជាធិបតេយ្យ ។

ស្ថានភាពសង្គមរបស់ពួកគេបានផ្ដល់នូវកម្លាំងសក្ដិសិទ្ធិមួយសម្រាប់ប្រឆាំងជំទាស់នឹងសម្ដេច ព្រះនរោត្តម សីហនុ ឬអ្នកណាម្នាក់ផ្សេងទៀតទោះជាអ្នកណាក៏ដោយ ។ កូនម្នាក់ក្នុងចំណោមកូនៗរបស់គ្រួសារត្រកូលជួនមានសេចក្ដីក្លាហានអស្ចារ្យ ដោយហ៊ានទិតៀនសម្ដេច ព្រះនរោត្តម សីហនុ ចំពោះការប្រព្រឹត្តមិនសមទំនងរបស់ព្រះអង្គ ដែលបង្អាប់បង្អោនកិត្តិយសប្រទេសកម្ពុជា ក្នុងឱកាសនៃព្រះរាជដំណើរមួយទៅកាន់ក្រុងប៉ារីស កាលពីឆ្នាំ១៩៤៦ ។ សម្ដេច ព្រះនរោត្តម សីហនុ បានសម្រេចព្រះទ័យចាត់ទុកក្រុមគ្រួសារ ជួន ថាជាក្រុមមនុស្សដែលយកចិត្តទុកដាក់សងសឹក ដើម្បីលុបលាងកិត្តិយសឲ្យបង ឬប្អូនស្រី របស់គេ គឺពុំមែនជាអ្នកនយោបាយត្រឹមត្រូវ ដូចអ្នកនយោបាយឯទៀតៗ ដែលចង់ដឹកនាំប្រទេសកម្ពុជាឆ្ពោះទៅរកប្រព័ន្ធនយោបាយមួយប្លែកពី

នេះ ។ ព្រះអង្គបានប្រកាសដោយត្រង់ថា "គ្រួសារដួន ដ៏មានអំណាច មិនដែលអត់ឱនឲ្យខ្ញុំទាល់តែសោះ ព្រោះខ្ញុំបដិសេធមិនព្រមរៀបការជាមួយកូនស្រីគាត់"[៧០] ។

ទោះជាដូចម្ដេចក្ដី មូលហេតុដែលជំរុញឲ្យពួកគេធ្វើអ្វីមួយបានលេចជារូបរាងឡើង ក្រុមគ្រួសារដួន នឹងបង្អិលជោគវាសនារបស់កម្ពុជាស្របទៅតាមគំនិតរបស់ខ្លួនដោយទឹកចិត្តមោះមុតបំផុត នៅពេលដែលពួកគេបានចងសម្ព័ន្ធភាពជាមួយយុវជនទាំងឡាយមាន សាឡុត ស និង អៀង សារី ជាដើម ហើយបានរួមបង្កើតជាមួយអ្នកទាំងនេះនូវក្លឹបម៉ាក្សលេនីនទៀតផង ។ សាឡុត ស បានចុះឈ្មោះចូលរៀននៅសាលាបារាំងផ្នែកវិទ្យុអគ្គិសនី ចំណែក អៀង សារី បានត្រៀមរៀបចំប្រឡងយកមធ្យមសិក្សាកកម្រិត២របស់ខ្លួនដែរ ។

បរិយាកាសនយោបាយនៅពេលនោះ[៧១] កំពុងពុះកញ្ជ្រោលយ៉ាងខ្លាំង ហើយពួកបញ្ញវន្តបារាំងបានតាក់តែងឡើងនូវមូលបទផ្សេងៗដែលមានលក្ខណៈលេចធ្លោជាងគេសម្រាប់សម័យក្រោយសង្គ្រាម នៅឆ្នាំ១៩៤៩ ដល់ ឆ្នាំ១៩៥០ នៅពេលដែលយុវជនកម្ពុជាទាំងពីរចាប់ផ្ដើមការសិក្សារបស់គេ គណបក្សកុម្មុយនិស្តបារាំងតែងតែប្រឈមមុខនឹងការលេចឮដំណឹងផ្សេងៗដែលថា ប្រជាជនសូវៀតរាប់ពាន់នាក់ ត្រូវគេចាប់ឃុំឃាំងក្នុងជំរំនានារបស់ស្តាលីនដែរ ។ ជំនឿទុកចិត្តចំពោះការសាកល្បងរបស់សូវៀត បានត្រូវបំផ្លាញដូចគ្នាដោយសារការវាយប្រហារយ៉ាងធ្ងន់ធ្ងររបស់ស្តាលីនប្រឆាំងនឹង ទីតូ និងនយោបាយមិនចំណុះគេរបស់ប្រទេសយូហ្គោស្លាវី ។

ប៉ុន្តែ ភាពស្រងាកចិត្តចំពោះនយោបាយរបស់សូវៀត ត្រូវបានជំនួសមកវិញដោយរលកនៃចលនាប្រឆាំងនិន្នាការអាមេរិកាំងនិយម ដែលមានថិរវេលាពេញរយៈពេលសង្គ្រាមនៅប្រទេសវៀតណាម ។ សង្គ្រាមនៅកូរ៉េ ឆ្នាំ១៩៥១ ផែនការម៉ាស្ហាល ក្នុងការស្ដាបនាអឺរ៉ុបឡើងវិញ និងភាពផ្ដាច់មុខខាងថាមពលបរមាណូរបស់អាមេរិកាំង បូកបញ្ចូលទៅបានធ្វើឲ្យសហរដ្ឋអាមេរិកលេចឡើងជាការគំរាមកំហែងមួយ ចំពោះពួកបារាំងនិយមឆ្វេងជាច្រើននាក់ ។ អ្នកខ្លះមើលឃើញក្នុងផែនការ ម៉ាស្ហាល នូវការប៉ុនប៉ងមួយដើម្បីដាក់ប្រទេសបារាំងឲ្យស្ថិតនៅក្រោមអំណាចនយោបាយ និងវប្បធម៌របស់ពួកអាមេរិកាំង ។ អ្នកខ្លះទៀត បានសំអាងលើ "ចលនាស្វែងរកសន្តិភាព" ថ្មីរបស់សូវៀត ជាចលនាការពារសន្តិភាព ដែលកើតឡើងត្រូវកាលៈទេសៈ សម្រាប់ទាហានអាមេរិកាំងដែលកំពុងប្រយុទ្ធនៅប្រទេសកូរ៉េ និងគ្រាប់បែកអាមេរិកាំង ដែលកំពុងគំរាមកំហែងសន្តិភាពនៅអឺរ៉ុប ក្រោយសម័យសង្គ្រាមលោក ។ នៅពេលដែលលោក ហ្សង់ប៉ូល សាត្រ *(Jeam-Paul Sartre)* ធ្វើការផ្លាស់ប្ដូរជំហរគួរឲ្យចាប់អារម្មណ៍មួយនៅឆ្នាំ១៩៥២ ដើម្បីគាំទ្រសហភាពសូវៀត គាត់បានផ្ដើមបង្កើតចលនាមួយដែលមានវិសាលភាពយ៉ាងធំធេង ។

នេះគឺជាបរិយាកាសកំពុងធ្វើឲ្យឈ្លក់វង្វេងមួយចំពោះពួកយុវជនកម្ពុជា ដែលសន្យាដណ្ដើមយកឯករាជ្យជូនប្រទេសរបស់គេ ។ នៅពេលទៅដល់ទីក្រុងប៉ារីស ពួកគេនៅតែជឿជាក់លើរបៀបគ្រប់គ្រងតាមលទ្ធិប្រជាធិបតេយ្យមួយថែមទៀត ប៉ុន្តែ បានចាត់ទុកខ្លួនឯងជាអ្នកបដិវត្តន៍ ពីព្រោះពួកគេបានដាក់ឲ្យពិនិត្យនូវបញ្ហាតួនាទី

របស់ព្រះរាជាមួយអង្គក្នុងប្រទេសកម្ពុជាមួយដែលឯករាជ្យ ។ ការប្រែប្រួលរបស់គេពីអ្នកប្រជាធិបតេយ្យដ៏ពុះពោរទៅជាអ្នកម៉ាក្សស៊ីសនិយម ត្រូវបានជួយសម្រួលដោយកុម្មុយនិស្តបារាំង ដោយហេតុថា បើតាមសម្ដីអៀង សារី គឺលោក ម៉ូរីសថូរ៉េ (MAURICE THOREZ) ផ្ទាល់ ដែលជាអគ្គលេខាបក្សកុម្មុយនិស្តបារាំងតាំងពីច្រើនឆ្នាំមកហើយ បានផ្ដល់ឲ្យពួកកម្ពុជានូវការជួយជ្រោមជ្រែងរបស់គាត់ដើម្បីរៀបចំបង្កើតក្លឹបមួយ សម្រាប់សិក្សាពីលទ្ធិកុម្មុយនិស្ត[២២] ។

ក្លឹបនេះ បានកត់សម្គាល់នូវដំណាក់កាលសំខាន់មួយក្នុងប្រវត្តិសាស្ត្រ រហូតមកទល់ពេលនោះ ដែលកំណត់នូវបរាជ័យផ្សេងៗរបស់ពួកនិយមឆ្វេងកម្ពុជា ។ កាលពីមុន សម្រាប់និស្សិត ម្នាក់នៅក្រុងភ្នំពេញផ្លូវដ៏ប្រសើរឆ្ពោះទៅរកលទ្ធិកុម្មុយនិស្តត្រូវឆ្លងកាត់តាមរយៈព្រៃភ្នំ ហើយចេញពីទីនេះឈានទៅរកពួកយុវជនវៀតមិញដែលកំពុងប្រយុទ្ធតស៊ូតាមតំបន់ព្រំដែនភាគខាងកើតថែមទៀត ។ នៅក្រុងភ្នំពេញ សកម្មភាពរបស់កុម្មុយនិស្ត ពុំបានប្រព្រឹត្តទៅជាប់លាប់រហូតទេ ហើយក៏ពុំសូវមានឥស្សរជនកុម្មុយនិស្តសម្រាប់ជួយតម្រង់ផ្លូវស្ថិតនៅក្នុងរាជធានីដែរ ។ ក្នុងប្រទេសរបស់គេ យុវបុរសទាំងពីរត្រូវតែលះបង់ចោលមជ្ឈដ្ឋាននិស្សិត ហើយសុខចិត្តទទួលយកអាណាព្យាបាលវៀតណាមនៅក្នុងតំបន់ទ័ពព្រៃមួយ ដើម្បីអាចសិក្សាពីលទ្ធិកុម្មុយនិស្ត នេះជាផ្លូវដ៏តូចចង្អៀត ដែលមានតែនិស្សិតនៅភ្នំពេញតិចតួចប៉ុណ្ណោះ បានសម្រេចចិត្តពុះពារតស៊ូនៅជំនាន់នោះ ។

នៅទីក្រុងប៉ារីស ស និង សារី បានធ្វើការហាត់រៀនជាមួយនឹងគ្រូទាំងឡាយ ដែលជាអ្នករៀបចំក្នុងទីក្រុងមួយ ដែលមានវណ្ណៈកម្មករមួយ និងពួកបញ្ញវន្ត ដែលជាខ្លួនទៅក្នុងវណ្ណកម្មអក្សរសិល្ប៍ម៉ាក្សស៊ីស និងគណបក្សកុម្មុយនិស្តមួយ ដែលកំពុងទាមទារប្រាក់បៀវត្សរ៍ខ្ពស់ជាងមុនសម្រាប់ពួកកម្មករ ហើយចូលរួមក្នុងការបោះឆ្នោត ។ គណបក្សកុម្មុយនិស្តបារាំងធ្លាប់បានប្រកាន់មាគ៌ា “សន្តិវិធី” ឆ្ពោះទៅរកលទ្ធិសង្គមនិយមតាមរយៈការបោះឆ្នោត គឺពុំមែនការតស៊ូដោយអាវុធទេ –ជាជំហរដែលនឹងដូចជំហរគ្រាដំបូងរបស់ពួកខ្មែរក្រហមដែរ ។ អ្វីដែលមានសារសំខាន់ជាទីបំផុតមួយគឺ ពួកគ្រូបង្ហាត់បង្រៀនលទ្ធិកុម្មុយនិស្តដល់ពួកយុវជនកម្ពុជាទាំងនេះជាក្រុមតែមួយគត់ក្នុងឋានៈជាបក្ស ដែលប្រឆាំងជំទាស់នឹងសង្គ្រាម ដែលពួកបារាំងនាំមុខធ្វើនៅឥណ្ឌូចិន ។

អៀង សារី និង សាឡុត ស បានក្លាយទៅជាមិត្តភក្តិនឹងគ្នាយ៉ាងជិតស្និទ្ធបំផុត និងបានចងសម្ព័ន្ធមិត្រដោយឡែកជាមួយ ជួន ប្រសិទ្ធិ ទៀត ដែលជាអ្នកមិនសូវបានរៀនសូត្រប៉ុន្មានទេ ក្នុងចំណោមបងប្អូនប្រុសទាំង ៨នាក់ ។ សារី ដែលជាមនុស្សចូលចុះក្នុងជំនុំចំណោមមិត្តភក្តិជាងគេ គឺជាយុវបុរសម្នាក់មានទឹកមុខស្រស់ស្រាយដែលងាយក្នុងការសើច និងជាជនប្រកបដោយឆន្ទៈម្នាក់ ដែលលម្អៀងទៅខាងការសម្រេចចិត្តភ្លាមៗ ហើយឆាប់រំភើបញាប់ញ័រ ដែលរោលរាលដូចអណ្ដាតភ្លើង ។ សាឡុត ស ជាមនុស្ស មឹះៗមិនសូវចេះនិយាយស្ដីប្រកបដោយលក្ខណៈផ្សេងៗ ជាអ្នកគិតគូរវែងឆ្ងាយ និងមានបុគ្គលិកលក្ខណៈស្អាតបរិសុទ្ធជាងគេ ។ គាត់មានសេចក្ដីប្រាកដក្នុងចិត្តមួយយ៉ាងស្ងប់ស្ងៀម ដែលនាំឲ្យគេចូលចិត្តធ្វើតាមគាត់គ្រប់គ្នា ។ មិត្តរបស់គាត់ឈ្មោះប្រសិទ្ធិ

ដែល ចេះនិយាយបារាំងស្ទាត់ហើយនោះ គឺជាមនុស្សម្នាក់ច្រើនមួម៉ៅ ឆាប់ខឹង និងឆាប់ទុកចិត្តគេ ប៉ុន្តែចូលចិត្តធ្វើឲ្យគេបាក់មុខដែរ ដោយសារតែស្ថានភាពរបស់គាត់ជាកូនពៅនៃគ្រួសារ ដ៏ខ្ពង់ខ្ពស់មួយ គាត់ពុំមែនជាគូប្រជែងម្នាក់សម្រាប់ ស និង សារី ទេ ។

ពួកអ្នកទាំងនោះបានរស់ជុំគ្នានៅផ្ទះលេខ២៨ ផ្លូវសាំងអស់ ជ្រេ ដេអារ៍ (Saint-André-des-Arts) សន្តាត់ឡាតាំង ក្នុងល្វែងបន្ទប់នៃអគារមួយ ដែល អៀង សារី, មុំ, ប្រសិទ្ធិ និង ទិក សាគុន ព្រមទាំងនិស្សិតខ្មែរក្រហមផ្សេងៗទៀត បានរស់នៅក្នុងសម័យកាលខុសៗគ្នា ។ មិនយូរប៉ុន្មាន មានយុវនារីម្នាក់ បានចូលមករស់នៅជាមួយដែរ នាងជាស្ត្រីម្នាក់ដែលមានរូបសម្រស់ជាខ្មែរ និងមានឆន្ទៈរឹងប៉ឹងឈ្មោះ ខៀវ ធីរិទ្ធិ[៣៣] ជាកូនស្រីរបស់ចៅក្រមគួរឲ្យគោរពម្នាក់ ។ ជាមនុស្សមានចរិតមិនចំណុះអ្នកណា នាងបានទៅជានារីម្នាក់ក្នុងចំណោមនារីដំបូងៗ ដែលបានរៀនសូត្រនៅសាលាស៊ីសុវត្ថិ ហើយបានទទួលពិន្ទុផ្នែកភាសាបារាំងល្អប្រសើរជាងគេ ។ នាងបានទាក់ទាញការយកចិត្តទុកដាក់ពីយុវជនមួយចំនួនដែរ ប៉ុន្តែ តាមការភ្ញាក់ផ្អើលពីបណ្ដាមិត្តរួមថ្នាក់របស់នាង គេថានាងបានបាក់ចិត្តស្រឡាញ់ អៀង សារី ទៅហើយ ។ បើអ្នកដទៃទៀតវាយតម្លៃនាងខ្ពង់ខ្ពស់ជាង អៀង សារី ដោយស្ថានភាពក្នុងសង្គមសមត្ថភាពខាងចំណេះវិជ្ជា និងរូបសម្ផស្សនោះ ធីរិទ្ធ បានរក្សាទុកអនុស្សាវរីយ៍មួយផ្សេងទៅវិញ ៖ ចំពោះ អៀង សារី នាងមើលឃើញថា គេដែលកើតមកសម្រាប់តែធ្វើជាមេដឹកនាំ ជាមនុស្សដែលស្គាល់តម្លៃបុគ្គលិកលក្ខណៈរបស់ខ្លួន ហើយដែលយល់ឃើញថា ទស្សនៈរបស់ខ្លួនសុទ្ធតែល្អទាំងអស់ ដ្បិតអី នាងក៏ជាប់ចិត្តជាខ្លាំងនឹងបុព្វហេតុជាតិនិយមដូចជារូបគាត់ដែរ ។ តាមពិតនាងបានជ្រើសរើសរៀននៅសាលាស័របោន (Sorbonne) ដើម្បីប្រឡងយកសញ្ញាប័ត្រមួយផ្នែកអក្សរសាស្ត្រអង់គ្លេស តាមនាងនិយាយគឺដើម្បីប្រឆាំងនឹងអាណានិគមនិយមបារាំង ។ គឺហេតុដូច្នេះហើយ បានជានាងធ្វើដំណើរថ្កាត់ទៅជួប អៀង សារី នៅទីក្រុងប៉ារីសនោះ ដែលជាមួយគាត់នេះនាងបានភ្ជាប់ពាក្យលើកជំនូនតាំងពីមុនការចេញដំណើររបស់នាងទៅស្រុកបារាំងម៉្លេះ ។

អាពាហ៍ពិពាហ៍ ដែល ធីរិទ្ធ បានរៀបចំនៅពេលដែលទៅដល់រដ្ឋធានីបារាំង បានទៅជាតួយ៉ាងមួយ នៅសម័យ នោះ ជាការគ្រាប់ធ្វើតាមរបៀបចំអកមួយចំពោះវណ្ណៈគហបតីក្រុងភ្នំពេញជាន់ចាស់ និងអ្នកនយោបាយរបស់និស្សិតមុនពេលដែលនាងមិនទាន់ក្លាយទៅជាអ្នកបដិវត្តន៍ ។ គូស្វាមីភរិយាទាំងពីរ បានជួលបន្ទប់ធំមួយ ហើយបានអញ្ជើញមនុស្សទាំងឡាយណា ដែលគេធ្លាប់ស្គាល់មកចូលរួមក្នុងពិធីនេះ ។ ដូច្នេះការទទួលធ្វើបដិសណ្ឋារកិច្ចភ្ញៀវ បានប្រមូលផ្ដុំអ្នកតំណាងរបស់កម្ពុជាប្រចាំទីក្រុងប៉ារីស (ដែលប្រពន្ធរបស់គាត់គឺជាមិត្តភក្តិជិតស្និទ្ធរបស់ ធីរិទ្ធ) និស្សិតកម្ពុជាទាំងអស់ បណ្ដាមិត្តភក្តិម៉ាក្សស៊ីសនិយមរបស់ សារី ពួកនិស្សិតនៃបណ្ដាប្រទេសអាណានិគមដូចជា វៀតណាម ទុយណេហ្ស៊ី អាល់ហ្សេរី និងម៉ារ៉ុក ជាដើម ។ គេបានសុំឲ្យម្នាក់ៗបង់វិភាគទានមួយចំនួន ពីររយហ្វ្រង់ សម្រាប់ពិធីនេះ ហើយអ្នកចូលរួមស្ទើរតែទាំងអស់ បានបំពេញតាមសំណូមពរ ។ ធីរិទ្ធ បានបញ្ចុះបញ្ចូល ប្រសិទ្ធិ ឲ្យរៀបចំធ្វើភត្តាហារ ព្រោះគាត់មានទេពកោសល្យខាងវិជ្ជាធ្វើម្ហូបអាហារ ។

នេះគឺជាបរិយាកាសចុងក្រោយប្រកបដោយសុភមង្គលបំផុត ដែល ធីរិទ្ធ នៅតែនឹកឃើញពីជំនាន់នោះជានិច្ច ព្រោះមិត្តភក្តិកម្ពុជាទាំងអស់របស់ នាងអាចជួបជុំគ្នា ដោយគ្មានឈ្លោះដណ្តើមយកឈ្នះគ្នាឡើយ ។ នាងបាននិយាយថា “នៅពេលនោះពុំមានការបែកបាក់គ្នារវាងជនជាតិកម្ពុជាទេ ។ យើងទាំងអស់រួបរួមគ្នាល្អណាស់” ។

អាពាហ៍ពិពាហ៍នេះ គឺជាមានផលប្រយោជន៍មួយលើសពីនោះទៅទៀត ពីព្រោះវាពុំត្រឹមតែផ្សំផ្គុំយុទ្ធិកជននយោបាយក្បាលរឹងពីរនាក់ប៉ុណ្ណោះទេ ប៉ុន្តែ វាក៏បានបង្រួបបង្រួមបងស្រីរបស់ ធីរិទ្ធ ឈ្មោះ ខៀវ ប៉ុណ្ណារី ជាមួយ សាឡុត ស ដែលជាមិត្តរបស់ សារី ដែរ ។ ប៉ុណ្ណារី បានធ្វើដំណើរ ទៅកាន់ក្រុងប៉ារីសជាមួយប្អូនស្រីរបស់នាង ក្នុងគោលបំណងក្លាយជាសាស្ត្រាចារ្យម្នាក់ ។ នាងជានិស្សិតស្រីម្នាក់ ដែលធ្វើការអ្វីមួយដោយ ល្អិតល្អន់ណាស់ នាងមានរាងរៅសង្ហាជាងរូបសម្ផស្ស ហើយមានប្រាជ្ញាស្មារតីក្លៀវក្លាផង ។ នាងបានជួប សាឡុត ស ក្នុងសម័យប្រជុំផ្សេងៗរបស់ក្លឹបម៉ាក្សស៊ីស ដោយ ធីរិទ្ធ ជាអ្នកបញ្ចុះបញ្ចូលឲ្យនាងចូលរួមជាមួយគេឯង ។ គ្មានអ្វីមួយបង្ហាញថា នេះជាសេចក្តីស្នេហាដ៏ធំធេងរវាង សាឡុត ស និងប៉ុណ្ណារី ទេ ហើយអាពាហ៍ពិពាហ៍របស់គេ គឺជាអាពាហ៍ពិពាហ៍មួយ ដែលធ្វើឡើងដោយគិតតែពីប្រយោជន៍ផ្ទាល់ខ្លួន គ្មានគិតពីសេចក្តីស្នេហាឡើយ ។ ដោយញ៉ាំងឲ្យគេជឿជាក់អំពីចរិតប្រាកដប្រជា នៃការស្រលាញ់ចូលចិត្តខាងនយោបាយរបស់ខ្លួន សារី និង ស ក៏ដូចពួកអ្នកបដិវត្តន៍មុននិងក្រោយពួកគេដែរ មានបំណងរៀបការតែជាមួយអ្នកណាដែលខ្លួនទុកចិត្ត ហើយដែលពុំមានហេតុផលណាមួយក្បត់នឹងពួកគេប៉ុណ្ណោះ ។ ឥឡូវនេះយុវអ្នកប្រយុទ្ធតស៊ូទាំងពីរ បានរួបរួមគ្នាដោយចំណងគ្រួសារ ជាងដោយចំណងនយោបាយ ។

នយោបាយនេះ បានត្រូវដាស់ឲ្យកម្រើកឡើងនៅក្នុងបរិយាកាសនៃទីក្រុងបារីស ។ យុវបុរសទាំងពីរជាសមាជិកបក្សកុម្មុយនិស្តបារាំង ប៉ុន្តែ អ្នកទាំងពីរបានបង្ហាញឲ្យឃើញរួចមកហើយនូវទស្សនៈមួយ ដែលគេមិនអាចស្មានទុកជាមុន ទាក់ទងនឹងបញ្ហាពិសេសៗ ដែលកំពុងកើតមាននៅប្រទេសកម្ពុជា ។ នៅឆ្នាំ១៩៥០ ចំពេលដែលការវាយប្រហារយ៉ាងខ្លាំងរបស់ ស្តាលីន ប្រឆាំងនឹងលោកសេនាប្រមុខ ទីតូ និងបក្សកុម្មុយនិស្តបារាំង ស បានធ្វើដំណើរទៅកាន់ប្រទេសយូហ្គោស្លាវី ។ គាត់បានរស់នៅទីនោះតែមួយខែប៉ុណ្ណោះ ក្នុងឋានៈជានិស្សិតស្ម័គ្រចិត្ត ក្នុងកងពលការងារមួយ ដែលកំពុងស្ថាបនាផ្លូវជាតិពីហ្សាក្រេបទៅក្រុង បែល ហ្ក្រាដ (Zagreb-Belgrade) ។ គាត់បានសម្តែងឲ្យឃើញ សមានចិត្តរបស់គាត់ចំពោះប្រទេសកុម្មុយនិស្តដ៏តូចមួយ ដែលប៉ុនប៉ងកំណត់មាគ៌ាមួយដាច់ឡែក បើទោះបីជាមានការទិតៀនជាច្រើនពីបណ្តាប្រទេសកុម្មុយនិស្តជិតខាង ដែលមានអំណាចខ្លាំងជាងខ្លួនក៏ដោយ ។ ដោយសភាវគតិពួកនិស្សិតកម្ពុជាបានយល់ច្បាស់ពីស្ថានភាពនេះ ។

(ម្ភៃប្រាំពីរឆ្នាំក្រោយមក នៅពេលដែលគាត់ត្រូវគេស្គាល់ក្រោមឈ្មោះថា ប៉ុល ពត នោះ ស នឹងធ្វើឲ្យអនុស្សាវរីយ៍នៃការស្នាក់អាស្រ័យមួយខែនេះ ផុសឡើងជាថ្មី ដោយគាត់បានអញ្ជើញជនជាតិយូហ្គោស្លាវី ក្នុងចំណោមជនជាតិអឺរ៉ុបដំបូងគេបំផុតមកធ្វើទស្សនកិច្ច ដោយអនុញ្ញាតឲ្យពួកនោះ ថតជាខ្សែភាពយន្តនូវបទពិ

សោធន៍នៃការធ្វើបដិវត្តន៍របស់គាត់ ហើយបានផ្ដល់ប្រវត្តិរូបនយោបាយរបស់គាត់ជាលើកដំបូងទៀតផង) ។

អ្នកនិយមឆ្វេងបារាំងខ្លះ ក៏មិនយល់ស្របចំពោះការចោទប្រកាន់ផ្សេងៗអំពី"គំនិតជាតិនិយមនៃគហបតីតូចតាច" និង "គំនិតប្រឆាំងសូវៀតនិយម" ដែលប្រើប្រឆាំងនឹង ទីតូ ដែរ ពីព្រោះគាត់មិនព្រមទទួលស្គាល់ថា "គំនិតប្រឆាំងសូវៀតនិយម" គោងតែជារបស់សូវៀត ទើបត្រូវនៅពេលដែលវាជាជោគវាសនារបស់ប្រទេសយូហ្គោស្លាវី ។ បញ្ញវន្តបារាំងជាច្រើននាក់ ធ្លាប់បានធ្វើដំណើរបូជនីយយេសចរណ៍ទៅកាន់ប្រទេសយូហ្គោស្លាវី ហើយនៅពេលត្រឡប់មកវិញ ពួកនេះបានថ្លែងសរសើរ ទីតូ ដែលជាអ្នកកសាងលទ្ធិសង្គមនិយម "ជាមួយនឹងសេចក្ដីក្លាហានមួយ និងគំនិតស្មារតីពេញលក្ខណៈមួយ ដែលប្រហែលមានតែមួយនៅក្នុងពិភពលោក[២៤] ។ សម្ដីសរសើរទាំងនេះ បានទៅជាការលើកទឹកចិត្តមួយសម្រាប់ សាឡុត ស ដែរ ដែលបានចោទប្រកាន់ដោយចេញមុខ និងដាប់មិនដាច់ជាមួយមិត្តភក្ដិរបស់គាត់ចំពោះការប្រមាថរបស់ សូវៀតចំពោះរូប ទីតូ ។ សាមសិបឆ្នាំក្រោយមក ធីរិទ្ធ បានរំឭកឡើងវិញថា "យើងមានការខ្វែងយោបល់គ្នា[ជាមួយបក្សកុម្មុយនិស្ដបារាំង] តែអំពីបញ្ហាអធិបតេយ្យដែលមានកំណត់" ប៉ុណ្ណោះ ដោយយោងតាមទ្រឹស្ដីសូវៀត ដែលថា អធិបតេយ្យ របស់ប្រជាជាតិមួយ គឺត្រូវកម្រិតកំណត់ដោយការវិនិច្ឆ័យផ្សេងៗ ទៅលើអ្វីដែលត្រឹមត្រូវសម្រាប់សហគមន៍កុម្មុយនិស្ដជាទូទៅដោយអនុលោមទៅតាមលក្ខណៈវិនិច្ឆ័យរបស់សហភាពសូវៀត ដែលជាអ្នកអភិបាលចលនាកុម្មុយនិស្ដអន្តរជាតិ ។

នៅដើមទសវត្សរ៍១៩៥០ នេះគ្រាន់តែជាចំណុចតូចតាចមួយសម្រាប់ពួកនិស្សិតឥណ្ឌូចិននៅក្រុងប៉ារីស ដែលទៅរួបរួមគ្នាក្នុងជួរអ្នកបដិវត្ដម៉ាក្សលេនីនប៉ុណ្ណោះ ។ ពួកនិស្សិតកម្ពុជា បានធ្វើការងារដោយសហការយ៉ាងជិតស្និទ្ធនិងដោយគ្មានគំនិតលាក់លៀមបន្តិចសោះឡើយជាមួយពួកនិស្សិតវៀតណាម ។ ការតស៊ូរួមរបស់គេប្រឆាំងនឹងអាណានិគមបារាំង បានជ្រើសរើសនយោបាយ ដែលពួកគេធ្លាប់ប្រតិបត្តិរួចមកហើយ បានជួយបិទបាំងការវិវាទផ្សេងៗរបស់ពួកគេ ។ ធីរិទ្ធ បានវាយតម្លៃពីជនជាតិវៀតណាមជាច្រើន ក្នុងចំណោមសម្ព័ន្ធមិត្តដ៏ជិតស្និទ្ធក្នុងរបស់ក្រុម ហើយនាងបានរំឭកពីបញ្ញវន្តម្នាក់ឈ្មោះ ង្វៀន ខាក់វៀន ថាជាមិត្តផ្ទាល់ខ្លួនម្នាក់របស់នាង ។ "គាត់តែងមកអគាររបស់យើង[នៅផ្លូវសាំងអត់ជ្រេដេអាវ៍]ជាញឹកញាប់ ហើយបានប្រឡែងលេងជាមួយនឹងទារកជាកូនរបស់យើង ...យើងមានការទាក់ទងគ្នាល្អណាស់ គឺទំនាក់ទំនងជាមិត្តភាពជាមួយគាត់ និងជនជាតិវៀតណាមដទៃទៀតនៅក្រុងប៉ារីស" ។

និយាយដោយពិត នៅពេលនោះជនជាតិកម្ពុជាម៉ាក្សស៊ីសនិយម ត្រូវបានចាត់ទុកដោយបណ្ដានិស្សិតខ្មែរដទៃទៀតថា ជាអ្នកជិតស្និទ្ធនឹងពួកវៀតណាមខ្លាំងពេក ។ អ្នកខ្លះបានចោទសួរពីរបៀបបែបណាដែលអ្នកម៉ាក្សស៊ីសនិយមអាចអួតខ្លួនថា ជាពួកអ្នកជាតិនិយមដ៏ខ្លាំងក្លា និងធ្វើសហការព្រមគ្នា ជាមួយនឹងពួកវៀតណាមដែលជាសត្រូវសួពូជ ។

ប៉ុន្ដែ ពួកម៉ាក្សស៊ីសនិយមកម្ពុជា មិនគិតភាពអមិត្តជាប្រវត្តិសាស្ត្រទេ ហើយចូលចិត្តធ្វើតាមរបៀបវារៈ

ដែលរៀបចំឡើងដោយបក្សកុម្មុយនិស្តបារាំង គឺលទ្ធិ ស្តាលីន និយមការប្រឆាំងនឹងការនិយមធ្វើអ្វីៗតាមលក្ខណៈអាមេរិកាំង និងការប្រឆាំងលទ្ធិអាណានិគមនិយម ។ នៅពេលនោះ គណបក្សកុម្មុយនិស្តបារាំង បានយកតម្រាប់តាមដំណែលចុងក្រោយនៃលទ្ធិស្តាលីននិយមដែរ ។ ពួកកុម្មុយនិស្តបានកាត់ទោសវីរបុរសពីរនាក់របស់បក្សចំពោះបទឧក្រិដ្ឋផ្សេងៗ ផ្នែកនយោបាយនៅក្នុងឱកាសនៃការកម្ចាត់ជនប្រឆាំងតូចមួយ សំដៅបង្ហាញឲ្យស្តាលីនឃើញថា ខ្លួនក៏កម្ចាត់មនុស្សមិនល្អចេញពីជួររបស់គេដែរ ។ ការកាត់ទោសអង់ដ្រេម៉ារទី *(André* Marty) និងស្ហាល ទីយ៉ុង *(Charles Tillon)* ជាអតីតយុទ្ធជនពីររូប ក្នុងសង្គ្រាមនៅប្រទេសអេស្ប៉ាញនៅឆ្នាំ១៩៥២ បានទៅជាការគ្រាប់ធ្វើតាមការកាត់ទោសផ្សេងៗរបស់ពួកស្តាលីននិយម បានទាក់ទាញការយកចិត្តទុកដាក់យ៉ាងខ្លាំង ដែលរៀបចំឡើងក្នុងប្រទេសនានានៅអឺរ៉ុបខាងកើត ។ ដោយភ័ព្វល្អ គណបក្សកុម្មុយនិស្តបារាំង ពុំបានចិញ្ចឹមចិត្តសម្លាប់ អ្នកទាំងឡាយណាដែលត្រូវគេប្រកាសជាពិរុទ្ធជនទេ គឺគ្រាន់តែបណ្តេញអ្នកនោះចេញពីបក្សប៉ុណ្ណោះ ។ ប៉ុន្តែ ឥទ្ធិពលនៃលទ្ធិស្តាលីននិយមដែលនៅមានលក្ខណៈបរិសុទ្ធនេះ មកលើជនជាតិកម្ពុជាបានលេចចេញរូបរាងឡើងក្នុងរយៈពេលជាច្រើនឆ្នាំក្រោយមកទៀត នៅពេលដែលការកម្ចាត់ជនប្រឆាំងរបស់សាឡុត ស បានឆ្លុះបញ្ចាំងឲ្យឃើញលក្ខណៈពិសេស ដែលបន្សល់ទុកដោយអ្នកស្តាលីននិយមកាលពីអតីតកាល ។

ការប្រឆាំងលទ្ធិអាណានិគមនិយម គឺជាមូលហេតុសំខាន់នៃការទាក់ទាញចិត្ត ដែលគណបក្សកុម្មុយនិស្តបារាំងសាកល្បងមកលើជនជាតិកម្ពុជាទាំងនោះ ។ រឿងនេះ ពុំអាចរបូតផុតពីយុវជនវៀតណាមម្នាក់គឺ ហូ ជីមិញទេ ដែលធ្លាប់បានជួយនិយាយបញ្ចុះបញ្ចូលពួកកុម្មុយនិស្តបារាំងប្រកាន់ជំហរនេះ ។ គឺការប្រឆាំងនឹងលក្ខណៈអាមេរិកាំងនិយមនេះហើយ ដែលជារឿងថ្មីសម្រាប់ជនកម្ពុជាទាំងនោះ និងជះឥទ្ធិពលទៅលើនយោបាយរបស់ស យ៉ាងជាក់ច្បាស់ ។ សាធារណមតិដ៏ទូលំទូលាយមួយរបស់បារាំងភ័យខ្លាច “ទ្វីបអឺរ៉ុបមួយ ដែលគេធ្វើឲ្យមានលក្ខណៈជាអាមេរិកាំង” ដោយគំរាមកំហែងដល់វប្បធម៌ នយោបាយ សន្តិសុខរបស់បារាំង ដោយឡែកឯករាជ្យរបស់ប្រជាជាតិបារាំង ។ ក្រុមនិយមឆ្វេងរបស់បារាំងបានប្រុងស្មៀតប្រឆាំងនឹងការបំពាក់អាវុធជាថ្មីមួយរបស់បស្ចិមប្រទេសក្រោមការដឹកនាំរបស់សហរដ្ឋអាមេរិក ដែលក្រុមនិយមឆ្វេងចាត់ទុកថា ជាគំនិតផ្តួចផ្តើមរបស់អ្នកចូលចិត្តដោះស្រាយអ្វីមួយដោយចម្បាំង ប្រហែលជាមានជាប់ទាក់ទងទៅនឹងផែនការវាយប្រហារមួយរបស់អាមេរិកាំងដោយអាវុធនុយក្លេអ៊ែរ ដើម្បីការពារខ្លួនជាមុនប្រឆាំងនឹងសហភាពសូវៀតទៀតផងក៏មិនដឹង ។ ក្រុមនិយមឆ្វេងនេះ ហ៊ានរហូតដល់ទៅនិយាយថា ពួកទាហានបារាំងនឹងក្លាយទៅជា“អ្នកស៊ីឈ្នួលច្បាំង”ឲ្យអង្គការសន្ធិសញ្ញា អាត្លង់ទិកខាងជើង“អូតង់” ថែមទៀត ។ ក្រុមនិយមឆ្វេងបារាំងបានប្រែក្លាយយុទ្ធនាការឃោសនារបស់ខ្លួនប្រឆាំង នឹងសហរដ្ឋអាមេរិក ទៅជា“ការប្រយុទ្ធដើម្បីឯករាជ្យជាតិ”វិញ ។ រឿងហ្នឹងហើយ គឺជាការគិតបម្រុងរបស់ជនកម្ពុជា និងប្រជាជននៅក្រោមអាណានិគមដទៃទៀត ដែលកំពុងរៀបចំខ្លួនវាយប្រយុទ្ធនឹងអាណានិគមនិយមបារាំង នៅពេលដែលពួកគេវិលត្រឡប់ទៅប្រទេសរៀងៗខ្លួនវិញ ។

ក្រុមនិយមឆ្វេងរបស់បារាំងប្រមូលយកសម្ពុះចិត្តទាំងអស់របស់ចលនា ។ សម្រាប់ខ្លួន សង្គ្រាមនៅកូរ៉េជាអំពើឈ្លានពានមួយរបស់អាមេរិកាំងយ៉ាងច្បាស់ ។ វិចិត្រករ ប៉ាប្លូ ពីកាស្សូ បានគូរគំនូរមួយផ្ទាំងស្ដីពីការសម្លាប់រង្គាលនៅកូរ៉េ ។ នៅនិទាឃរដូវឆ្នាំ១៩៥២ លោក អង់ជ្រេស៊ីល បានសរសេរចុះក្នុងកាសែត អ៊ុយម៉ានីទេ នូវអត្ថបទជាហូរហែរមួយ ដោយចោទប្រកាន់សហរដ្ឋអាមេរិកដឹកនាំធ្វើសង្គ្រាមជីវសាស្ត្រមួយ ប្រឆាំងនឹងប្រជាជនកូរ៉េ ហើយត្រូវតែបញ្ឈប់[២៥] ។ ជាច្រើនឆ្នាំកន្លងផុតទៅ នៅប្រទេសបារាំងពីខែកញ្ញា ឆ្នាំ១៩៤៩ ដល់ខែធ្នូ ឆ្នាំ១៩៥២ គឺជាការស្នាក់អាស្រ័យដ៏យូរដែលមានតែម្ដងគត់របស់ សាឡុត ស នៅក្រៅប្រទេសកម្ពុជា -ក្រោយមកគាត់នឹងធ្វើដំណើរផ្សេងៗទៀតតែម្នាក់ឯង- និងទស្សនកិច្ចខ្លីៗនៅប្រទេសចិន វៀតណាមខាងជើង និងកូរ៉េខាងជើង ។ ការស្នាក់អាស្រ័យនៅប្រទេសបារាំងបានចារឹកក្នុងខ្លួនរបស់ ស នូវផ្នត់គំនិតមួយ ដែលមិនងាយផ្លាស់ប្ដូរតាមរបៀបឆាប់រំភើបចិត្តណាមួយសោះឡើយ ។ លោក ហ្សង់ ប៉ូល សាត្រ (Jean Paul Sartre) អាចផ្លាស់ប្ដូរទស្សនៈចំពោះពួកសូវៀតក្នុងឆ្នាំ១៩៥៦ ដោយសារការបង្ក្រាបនៅប្រទេសហុងគ្រី (Hongrie) នៅពេលនោះ ស បានប្រយុទ្ធតស៊ូដើម្បីទ្រទ្រង់ចលនាកុម្មុយនិស្តរបស់កម្ពុជាឲ្យនៅមានជីវិតតទៅទៀត ហើយមិនសូវខ្វាយខ្វល់នឹងបញ្ហាភូមិសាស្ត្រនយោបាយ ដែលធ្លាប់អូសទាញគាត់ឲ្យធ្លាក់ចូលក្នុងការបដិវត្តឡើយ ។

ក្នុងអំឡុងស្នាក់នៅជាច្រើនឆ្នាំនៅទីក្រុងប៉ារីស ស បានចាប់ផ្ដើមបោះជំហានដ៏សំខាន់ឆ្ពោះទៅរកការចាត់ចែង ដឹកនាំចលនាកុម្មុយនិស្តកម្ពុជាមុនគេ ។ គាត់បានជ្រៀតចូលក្នុងមជ្ឈដ្ឋានវរជននិយមឆ្វេងរបស់ប្រទេសគាត់ -ជារឿងងាយបំផុតនៅបរទេសជាងនៅប្រទេសគាត់- ហើយបានទទួលមុខងារមួយជាអ្នកជំនាញខាងយុទ្ធសាស្ត្រ) ថែមទាំងជាអនាគតមេដឹកនាំទៀតផង ។ គាត់ក៏បានបញ្ចេញសមត្ថភាពឲ្យបណ្ដាសមាជិកនៃគណបក្សប្រជាធិបតេយ្យនៅទីក្រុងប៉ារីស និងទីក្រុងភ្នំពេញបានស្គាល់ ។ គាត់បានផ្ដល់អត្ថបទផ្សេងៗទៅចុះផ្សាយក្នុងទស្សនាវដ្ដីជាភាសាខ្មែរមួយ ឈ្មោះនិស្សិតកម្ពុជាដែលកំពុងបរិហារសម្ដេច ព្រះនរោត្តម សីហនុ និងនយោបាយរបស់ព្រះអង្គ[២៦] ។ ក្នុងគោលបំណងកុំឲ្យបាត់បង់អាហារូបករណ៍របស់គេ ពួកយុវបញ្ញវន្តទាំងនេះ បានប្រើប្រាស់រហស្សនាមជាច្រើនដូចជា "ខ្មែរសេរី" "ពលករខ្មែរ" ហើយចំពោះ សាឡុត ស គាត់ដាក់ថា "ខ្មែរដើម" ។

រហស្សនាមនេះ បានបង្ហាញឲ្យឃើញនូវគំនិតជាតិនិយមខ្លាំងក្លាបំផុតរបស់ សាឡុត ស និងចរិតដែលវាយតម្លៃខ្ពស់ចំពោះខ្លួនឯងប្លែកពីធម្មតារបស់គាត់ផង ។ គឺជាឈ្មោះអ្នកនិពន្ធម្នាក់ ដែលចាត់ទុកខ្លួនឯងក្នុងឋានៈជាមេដឹកនាំសំខាន់បំផុត ។ "ខ្មែរដើម" បានតែងសរសេរសម្រាប់ទស្សនាវដ្ដីនិស្សិតកម្ពុជានូវអត្ថបទបរិយាមួយ ដែលបង្ហាញឲ្យគេដឹងថែមទៀតថា រូប សាឡុត ស ដែលលេចចេញមកជាមនុស្សអន់គម្រក់នោះ បានក្លាយខ្លួនទៅជាអ្នកនយោបាយ និងជាអ្នកមនោគមវិជ្ជាដ៏ប៉ិនប្រសប់ម្នាក់ ។ ការប្រឡងយកសញ្ញាប័ត្រផ្នែកវិទ្យុអគ្គិសនីរបស់គាត់ មិនដែលបានសម្រេចលទ្ធផលល្អឡើយ ប៉ុន្តែគាត់បានទៅអ្នកគ្រូគេខាងទ្រឹស្ដីកុម្មុយនិស្ត ហើយដែលគាត់បានយកមកអនុវត្តយ៉ាងចម្លែកនៅប្រទេសរបស់គាត់ផ្ទាល់ ។

អត្ថបទដែលមានចំណងជើងថា «រាជាធិបតេយ្យ ឬប្រជាធិបតេយ្យ» ត្រូវបានបោះពុម្ពផ្សាយ នៅឆ្នាំ ១៩៥២ ។ ដាបឋមគាត់បានធ្វើឲ្យគេចាប់អារម្មណ៍ថា ជាអត្ថបទផ្ចិតចម្ងងមួយដែលផ្ទុកទៅដោយគំនិត ជាគំរូផ្សេងៗរបស់ពួកកុម្មុយនិស្តបារាំងនៅសម័យនោះ ។ ប៉ុន្តែ ស បានបង្ហាញឲ្យឃើញពីល្បិចដ៏ឆ្លាតវាងវៃរបស់គាត់ក្នុងការជ្រើសរើសទីដៅ ដែលគាត់ត្រូវបាញ់ដែរ គឺសម្ដេច ព្រះនរោត្តម សីហនុ និងរាជាធិបតេយ្យពុំមែនអាណានិគមបារាំងទេ ព្រោះថាអត្ថបទ និងសេចក្ដីថ្លែងការណ៍ផ្សេងៗទៀត ច្រើនតែបរិហារជាញឹកញាប់ទៅលើអាណានិគមនិយមបារាំង និងចក្រពត្តិនិយមអាមេរិកាំងទៅហើយ ។ សាឡុត ស មានសេចក្ដីវាងវៃធ្វើឲ្យគេជឿថា សម្ដេច ព្រះនរោត្តម សីហនុ និងរាជាធិបតេយ្យខ្មែរជាឧបសគ្គរំខានដល់ពួកនិយមឆ្វេងទាំងឡាយ ដែលប្រយុទ្ធតស៊ូក្នុងព្រៃភ្នំ ឬដែលស្រុះចិត្តគ្នាធ្វើអ្វីមួយដោយរលាក់នៅទីក្រុងប៉ារីស ។

ជាដំបូង អត្ថបទបានថ្កោលទោសរបបរាជាធិបតេយ្យថា ជាមិត្តរបស់អាណានិគមនិយមបារាំង ជាសត្រូវរបស់ប្រជាជន និងព្រះពុទ្ធសាសនានៅកម្ពុជា ។ បន្ទាប់មក ស បានបង្ហាញពីលទ្ធិប្រជាធិបតេយ្យក្នុងក្របខ័ណ្ឌកុម្មុយនិស្តមួយថា ជាគំនិតថ្មីដែលនឹងនាំមកផ្ដល់ឲ្យប្រទេសជាតិនូវរដ្ឋាភិបាលទាន់សម័យ និងប្រកបដោយមនុស្សធម៌មួយ ។ ក្នុងពេលជាមួយគ្នានោះ គាត់ខំប្រឹងពន្យល់វែកញែកយ៉ាងជាក់លក់ថា គំនិតថ្មីនេះនឹងបើកផ្លូវទៅរកទំនៀមទម្លាប់ផ្សេងៗកាលពីបុរាណ ដើម្បីភ្ជាប់សម័យទំនើបទៅអតីតកាលឡើងវិញ ។ «របបប្រជាធិបតេយ្យបានលើកម្ពស់ថែមទៀតនូវពាក្យប្រៀនប្រដៅទាំងឡាយរបស់ព្រះពុទ្ធ ពីព្រោះព្រះពុទ្ធជាអម្ចាស់របស់យើងជាមនុស្សដំបូងបំផុត ដែលបានចង្អុលបង្ហាញ [ពីលទ្ធិប្រជាធិបតេយ្យ] ។ ដូច្នេះ មានតែរបបប្រជាធិបតេយ្យមួយប៉ុណ្ណោះ ដែលនឹងអាចស្រោចស្រង់តម្លៃដ៏ជ្រាលជ្រៅរបស់ព្រះពុទ្ធសាសនា» ។

ស ស្គាល់ទឹកចិត្តអ្នកអានរបស់គេច្បាស់ណាស់ គាត់ដឹងថា ប្រទេសរបស់គាត់ពុំមានប្រពៃណីកាន់លទ្ធិប្រជាធិបតេយ្យទេ ហើយគាត់ត្រូវតែបង្កើតអ្វីមួយដើម្បីជំនួសរាជាធិបតេយ្យវិញ ។ ដោយហេតុនេះ គាត់ធ្វើហាក់ដូចជាជឿថា មានតែសាសនាប៉ុណ្ណោះ អាចបំពេញកន្លែងប្រហោងនេះបាន ។ គាត់ដឹងដែរថា វណ្ណៈគហបតី នឹងចាប់មានសេចក្ដីភ័យខ្លាច បើសិនជាពួកនិយមឆ្វេងអួតអំពីការលុបបំបាត់រាជាធិបតេយ្យ និងព្រះពុទ្ធសាសនា ដែលជាដើមហេតុនៃសេចក្ដីរាយការណ៍មិនល្អិត ដែលគាត់បានលាតត្រដាងឲ្យឃើញរវាងលទ្ធិកុម្មុយនិស្ត និងព្រះពុទ្ធសាសនា ។ ដោយប្រមូលផ្តុំការតម្រង់បាញ់របស់គាត់ទៅលើសម្ដេច ព្រះនរោត្តម សីហនុ គាត់បានសរសេរថា យុទ្ធសាស្ត្ររបស់ព្រះមហាក្សត្រស្ថិត នៅត្រង់ធ្វើឲ្យសង្គ្រាមរបស់ពួកបារាំងប្រឆាំងនឹងពួកអ្នកតស៊ូដើម្បីឯករាជ្យអូសបន្លាយក្នុងរយៈពេលពីរឆ្នាំទៀត បន្ទាប់ពីនោះ ព្រះអង្គនឹងទាមទារឯករាជ្យនេះពីពួកបារាំង ហើយព្រះអង្គនឹងអួតក្អេងក្អាងថា ជាអ្នកបាននាំយកសេរីភាពមកផ្ដល់ឲ្យប្រទេសជាតិរបស់ព្រះអង្គ ។

ការវិភាគរបស់គាត់ គឺពិតជាត្រឹមត្រូវមែន ។ ស បាននិយាយទុកជាមុនថា កម្មវិធីមួយបែបនោះនឹងពុំផ្ដល់ឲ្យកម្ពុជានូវឯករាជ្យពិតប្រាកដមួយឡើយ ហើយនឹងបើកឱកាសឲ្យសម្ដេច ព្រះនរោត្តម សីហនុ «ខ្ទប់មាត់ប្រជាជន

ចាប់ចង និងកម្ចាត់អ្នកទាំងឡាយណាដែលប្រឆាំងជំទាស់នឹងនយោបាយរបស់ព្រះអង្គតែប៉ុណ្ណោះ ។ បន្ទាប់មក ព្រះអង្គរិះរកល្បិចធ្វើការរំលាយគណបក្សផ្សេងៗ ដែលប្រឆាំងនឹងផលប្រយោជន៍រាជបល្ល័ង្កចោលទាំងអស់ ដ្បិតអីគណបក្សនយោបាយទាំងនោះមិនព្រមនៅស្ងៀមឡើយ ។ នៅទីបំផុតនយោបាយរបស់ព្រះមហាក្សត្រ គឺបង្កឲ្យមានសង្គ្រាមស៊ីវិលមួយ ដែលនឹងដុតកម្ទេចអ្វីៗទាំងអស់ រួមទាំងវត្តអារាមផង ។ ព្រះសង្ឃ ប្រជាជន បុគ្គលិករាជការទាំងឡាយ នឹងស្គាល់នូវការឈឺចាប់ខ្លោចផ្សាដោយការព្រាត់ប្រាសគ្រួសារ ។ អ្នកទាំងនោះនឹង ឃើញឪពុកម្ដាយ ប្រពន្ធ និងកូនចៅរបស់គេ ត្រូវកិនកម្ទេចដោយហ្វូងរថក្រោះ ផលដំណាំផ្សេងៗ នឹងត្រូវ បំផ្លាញចោល» ។

តាមគាត់សរសេរក្នុងអត្ថបទរបស់គាត់ថា លទ្ធិប្រជាធិបតេយ្យ ដែល ស ចង់បានសម្រាប់ប្រទេសកម្ពុជា នឹងអាចប្រៀបធៀបបាននឹងបណ្ដាលទ្ធិប្រជាធិបតេយ្យ ដែលកើតចេញពីការបដិវត្តរបស់បារាំង នៅឆ្នាំ១៧៨៩ ការបដិវត្តរុស្ស៊ីនៅឆ្នាំ១៩១៧ ដែលដឹកនាំដោយលេនីន និងស្តាលីន ការបដិវត្ត ចិនរបស់បណ្ឌិត ស៊ុន យ៉ាតសេន -និងការបដិវត្តទាំងអស់ ដែលបានលុបបំបាត់រាជាធិបតេយ្យចោល ។សម្ដេច ព្រះនរោត្តម សីហនុ និងរាជា ធិបតេយ្យត្រូវតែរលត់រលាយ ។

សាឡុត ស បានចាកចេញពីប្រទេសបារាំងនៅឆ្នាំ១៩៥៣ ក្រោយពេលដែលរដ្ឋាភិបាលកម្ពុជា បានផ្អាក អាហារូបករណ៍របស់គាត់ ព្រោះតែធ្វើឲ្យមានការរំដើបរំជួលខាងនយោបាយ និងការមិនបានជោគជ័យក្នុងការ ប្រឡងយកសញ្ញាប័ត្រផ្នែកវិទ្យុអគ្គិសនីរបស់គាត់ចំនួនបីលើក ។ (តាមគេនិយាយថា ស ច្រើនចំណាយពេលវេលា ជាច្រើនដើម្បីអានកំណាព្យបារាំង ជាងរៀនសូត្រតាមសៀវភៅបច្ចេកទេសផ្សេងៗ) ។ គាត់បានសម្រេចចិត្ត វិលមកកម្ពុជាវិញ ដើម្បីវាយប្រយុទ្ធប្រឆាំងនឹងបារាំង ជាជាងនៅបន្តការសិក្សារៀនសូត្រលទ្ធិកុម្មុយនិស្តរបស់ គាត់ នៅទីក្រុងប៉ារីស ។ ប៉ុណ្ណារី គូដណ្ដឹងរបស់គាត់ក៏បាត់បង់អាហារូបករណ៍ដូចជាគាត់ដែរ ចំពោះការធ្វើ សកម្មភាពនយោបាយរបស់នាង ហើយអ្នកទាំងពីរបានរៀបការយកគ្នាជាប្ដីប្រពន្ធរួចស្រេចទៅហើយ មុននឹង ត្រឡប់មកក្រុងភ្នំពេញវិញ ។

អៀង សារី និងប្រពន្ធរបស់គាត់បន្តស្ថិតនៅក្នុងអគារតាមផ្លូវ សាំងអង់ជ្រេ ដេអារ៍ ដដែល និងចិញ្ចឹមជីវិត ដោយសារប្រាក់កាសដែលម្ដាយ ធីរិទ្ធ ផ្ញើទៅឲ្យ ដែលអនុញ្ញាតឲ្យកូនស្រីគាត់រៀនបញ្ចប់យកសញ្ញាប័ត្រអក្សរ សាស្ត្រអង់គ្លេសរបស់នាងនៅសាលាស័របោន ។ ចំណែក សារី វិញ ក៏បោះបង់ការសិក្សាទាំងអស់របស់គាត់ ដើម្បីបដិវត្តន៍ដែរ ។ ជាមួយ ជួន មុំ គាត់បានទៅចូលរួមក្នុងមហោស្រពយុវជនកុម្មុយនិស្តជាច្រើន ដែលរៀបចំ នៅទ្វីបអឺរ៉ុប និងបានជ្រើសរើសនៅទីក្រុងប៉ារីសនូវជនកម្ពុជាដទៃទៀត ឲ្យចូលជាសមាជិកក្លឹបម៉ាក្សលេនីនរបស់ គាត់ ។ មុំ ដែលធ្វើព្រងើយកន្តើយនឹងការគាបសង្កត់របស់ក្រុងភ្នំពេញ បានតាំងលំនៅដ្ឋានជាស្ថាពរនៅក្រុង ប៉ារីស និងរៀបការជាមួយស្រីបារាំងម្នាក់ ហើយបានក្លាយទៅជានិមិត្តរូប មួយប្រៀបដូចជាឪពុកសម្រាប់ពួក

និស្សិតកម្ពុជាកាន់តែច្រើនឡើងៗ ដែលសុំចូលជាសមាជិកក្លឹបនេះ ហើយតមកទៀត អ្នកទាំងនេះសុទ្ធតែក្លាយទៅជាពួកមេដឹកនាំខ្មែរក្រហម គឺ ខៀវ សំផន, សុន សេន និង ហ៊ូ យន់ ។

អត្ថបទផ្សេងៗ ដែលបន្សល់ទុកដោយនិស្សិតពីរនាក់ក្នុងចំណោមនិស្សិតទាំងនោះ គឺ ខៀវ សំផន និង ហ៊ូ យន់ បានឆ្លុះបញ្ចាំងឲ្យឃើញនូវភាពល្អិតល្អន់មួយនៃនយោបាយរបស់ក្រុមឆ្វេងនិយមកម្ពុជា ក្នុងអំឡុងសម័យកាលទីពីរនេះ នៅប្រទេសបារាំង ។ អ្នកទាំងពីរបានសរសេរក្នុងនាមនៃសកលវិទ្យាល័យនូវនិក្ខេបបទថ្នាក់បណ្ឌិតមួយម្នាក់ ដោយចង្អុលបង្ហាញរចនាសម្ព័ន្ធផ្សេងៗផ្នែកសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា និងស្នើឲ្យពិនិត្យនូវសេចក្តីសម្រេចធ្វើការផ្លាស់ប្តូរ ដែលនឹងធ្វើឲ្យប្រទេសជាតិបានទំនើបទាន់សម័យ ដោយផ្តើមចេញពីការបែងចែកប្រកបដោយសមធម៌មួយនូវភោគទ្រព្យទាំងឡាយ និងការពង្រឹងឯករាជ្យមួយរបស់ប្រទេសឲ្យកាន់តែរឹងមាំឡើង ។

ថ្វីបើមានការប៉ុនប៉ងផ្សេងៗ ដែលមាននៅពេលខាងមុខ ដើម្បីរៀបចំការងារទាំងឡាយរបស់ ខៀវ សំផន ឲ្យបានសម្រេចជោគជ័យ ជាពិសេសសេចក្តីព្រាងអំពីការបដិវត្តឆ្នាំ១៩៧៥ ក៏ដោយ ក៏និក្ខេបបទទាំងនេះ មានលក្ខណៈ ប្លែកពីគេដោយសាររបៀបនិយាយបែបសាមញ្ញ និងនិយមផ្លូវកណ្តាលរបស់អ្នកទាំងពីរ ។ (និក្ខេបបទទាំងនេះនឹងក្លាយទៅជាគំរូនៃការសាកល្បងកសាងសង្គមនិយម ដែលសម្តេច ព្រះនរោត្តម សីហនុ ប៉ុនប៉ងធ្វើតាមក្នុងកំឡុងទសវត្សរ៍១៩៦០) ។ មនុស្សទាំងពីរនាក់នេះ បានប្រឹងប្រែងរៀបចំតារាងប្រាកដនិយមមួយ អំពីសេដ្ឋកិច្ចរបស់ប្រទេសដែលគ្មានអ្នកស្រាវជ្រាវកម្ពុជាណាម្នាក់ផ្សេងទៀតធ្លាប់បានធ្វើដូច្នេះឡើយ ។ សេចក្តីសម្រេចផ្សេងៗ ដែលពួកគេអួតអាងដើម្បីឲ្យគេយកទៅប្រើតាម ហាក់ដូចជាបម្រើផលប្រយោជន៍ផ្សេងៗរបស់វណ្ណៈកាន់អំណាច ជាងមនោសញ្ចេតនារបស់អ្នកតស៊ូក្នុងព្រៃ ដែលកំពុងមានកអានភាពទៅវិញ ។

ហ៊ូ យន់ បានសរសេរអំពីប្រជាកសិករកម្ពុជានិងគម្រោងការផ្សេងៗរបស់ខ្លួនក្នុងការធ្វើទំនើបភាវូបនីយកម្មនៅឆ្នាំ១៩៥៥ ។ ក្នុងនោះគាត់បានការពារថា ប្រទេសកម្ពុជាពុំមែនធ្វើឲ្យលំបាក វេទនាដោយសារវណ្ណៈម្ចាស់ដីធំមួយ ដែលកំពុងសង្កត់កប្រជាជនកសិករតាមរយៈការជួលប្រវាស់ដីដូចជីវភាព ក្នុងជនបទមួយចំនួនធំនៅអាស៊ីនោះទេ ប៉ុន្តែ ប្រទេសកម្ពុជាត្រូវប្រឈរមុខនឹងបញ្ហាជាច្រើនផ្សេងៗទៀតជារបស់ខ្សែជាប់ដោយឡែក ។ ប្រជាកសិករកម្ពុជា ស្ទើតែទាំងអស់សុទ្ធតែមានដីធ្លី ប៉ុន្តែ ជាអំពកដីតូចៗពេក ដែលពួកគេពុំអាចទាញយកផលបានគ្រប់គ្រាន់ មកចិញ្ចឹមជីវិតឡើយ ។ ដូច្នេះពួកគេត្រូវវិណ្ណកដូចជាប់ច្រវាក់ដោយសារការជំពាក់បំណុលរបស់គេ ដូចជាពន្ធអាករផ្សេងៗ ដែលអនុមតិឲ្យប្រើដោយពួកបារាំង គឺវាធ្ងន់ធ្ងរខ្លាំងណាស់ ។ តម្លៃដែលពួកឈ្មួញបង់ទៅឲ្យប្រជាកសិករសម្រាប់ផលិតផលទាំងឡាយ គឺទាបជាងតម្លៃផលិតផលនៅទីផ្សារទៅទៀត ។ ប្រជាកសិករពុំអាចកែប្រែផលដំណាំឲ្យបានកើនលើសពីមុនឡើយ ដោយគ្មានប្រាក់កាសទិញជីឬសម្ភារទំនើបៗ ។ ដើម្បីបំពេញសេចក្តីត្រូវការយ៉ាងត្រដាបត្រដួសទម្រាំទៅដល់ចុងឆ្នាំក្រោយ ប្រជាកសិករត្រូវតែទៅខ្ចីលុយកាក់ពីអ្នករកស៊ីចងការ ដែលយកការប្រាក់ហួសកំណត់ បន្ទាប់មកខ្ចីជាថ្មីទៀតដើម្បីសងបំណុលលើកមុន ។ ហ៊ូ យន់ បានសរសេរ

ថា «សម្រាប់អ្វីក៏ដោយ គឺប្រជាកសិករត្រូវការប្រាក់ជាចាំបាច់ - សងបំណុលចាស់ បង់ពន្ធដារ ទិញគ្រាប់ពូជ ជួលដី ជួលឧបករណ៍ផលិត ជួលសត្វពាហនៈ ...គាត់តែងតែទៅរកអ្នកឲ្យខ្ចីជានិច្ច» ។

ការបែងចែកដីជាចំណែកតូចៗនៅតាមជនបទនានា និងការជំពាក់បំណុលរបស់កសិករគឺជាហេតុនាំឲ្យគេបកស្រាយថា ហេតុអ្វីបានជាប្រទេសកម្ពុជាមានទិន្នផលស្រូវក្នុងមួយហិកតាទាបខ្លាំងជាងគេម៉្លេះ ក្នុងចំណោមទិន្នផលស្រូវដែលទាបជាងគេនៅក្នុងតំបន់នេះ ។ ក្រោមការគ្រប់គ្រងរបស់អាណានិគមបារាំង រដ្ឋាភិបាលពុំបានផ្តើមគំនិតធ្វើការងារធំៗ ដែលប្រជាកសិករត្រូវការនោះឡើយ ជាពិសេស ប្រព័ន្ធធារាសាស្ត្រ ដែលសំខាន់បំផុតសម្រាប់វិស័យកសិកម្មរបស់កម្ពុជា ។ ប្រជាកសិករនៅតែលិចលង់ក្នុងបំណុល ផ្សេងៗតទៅទៀត ហើយគោងតែ«យក»សមាជិកខ្លះនៃគ្រួសាររបស់គេ ទៅធ្វើជាខ្ញុំកញ្ចះដាច់ថ្លៃរបស់ម្ចាស់បំណុល និងលក់ដីធ្លីមួយចំណែករបស់គេហើយ ខ្ចីលុយការប្រាក់កាន់តែច្រើនឡើងៗថែមទៀត ។ ហ៊ូ យន់ យល់ឃើញថាប្រជាជននៅតាមជនបទ របស់ប្រទេសកម្ពុជា ប៉ែតសិបភាគរយ ជាកសិករក្រ ដែលមានដីតែមួយហិកតាប៉ុណ្ណោះក្នុងមួយគ្រួសារ មានឧបករណ៍ផលិតតិចតួចហើយតម្រូវឲ្យជួលដី ជួលឧបករណ៍ និងជួលសត្វពាហនៈគេជារឿយៗ ដោយគ្មានចំណូលអ្វីដើម្បីកាត់ផ្តាច់ដំណើរវិលចុះវិល ឡើងនៃទុរគត៌ភាពនេះទាល់តែសោះ ។

និស្សិតបានទាមទាឲ្យមានការធ្វើអន្តរាគមន៍មួយពីរដ្ឋាភិបាល ។ ដើម្បីអនុញ្ញាតឲ្យប្រជាកសិករក្លាយទៅជាអ្នកសងបំណុលគេបាន រដ្ឋាភិបាលត្រូវតែផ្តល់ឲ្យគាត់នូវ «របៀបគ្រប់គ្រងឥណទានមួយ ដែលមានលក្ខណៈប្រជាជនពិតៗ ក្នុងផលប្រយោជន៍របស់ហ្វូងប្រជាកសិករ ដែលជាប្រភពថាមពលតែមួយគត់ នៃភាពសម្បូររុងរឿងរបស់ប្រទេស» ។ ដោយរំដោះខ្លួនរួចពីការគិតមមៃរឿងជំពាក់បំណុលគេ ប្រជាកសិករ នឹងចាប់ផ្តើមកែលម្អការផលិតឲ្យកាន់តែប្រសើរជាងមុនមិនខាន ។ ហ៊ូ យន់ បានសរសេរថា ជាពិសេស បើសិនជារដ្ឋាភិបាល ជួយផ្គត់ផ្គង់គ្រឿងឧបករណ៍ និងធ្វើឲ្យតំបន់ជនបទនានាទំនើបទាន់សម័យឡើងហើយ ប្រឹងប្រែងរៀបចំរចនាសម្ព័ន្ធការងារប្រកបដោយវិចារណញ្ញាណមួយ ក្នុងក្របខ័ណ្ឌនៃផែនការសរុបមួយក្នុងការផលិត ។

និក្ខេបបទរបស់ ខៀវ សំផន មានចំណងជើងថា សេដ្ឋកិច្ចរបស់កម្ពុជា និងបញ្ហាទំនើបភាវូបនីយកម្ម បានត្រូវបញ្ចប់បួនឆ្នាំក្រោយមកទៀត គឺក្នុងឆ្នាំ១៩៥៩ ។ គេអាចពិនិត្យមើលនិក្ខេបបទនេះថាជាយោបល់រួមមួយ អំពីផលិតផលជាតិរបស់កម្ពុជា ដោយឆ្លុះបញ្ចាំងឲ្យឃើញនូវគំនិតផ្សេងៗរបស់ ហ៊ូ យន់ ដែរ ។ ម្យ៉ាងទៀត និក្ខេបបទរបស់ ហ៊ូ យន់ក៏មានបង្ហាញប្រាប់ក្នុងជំពូកឯកសារពិគ្រោះដ៏ខ្លីរបស់ ខៀវ សំផន ដែរ ដែលគម្រោងការទំនើបភា-វូបនីយកម្ម និងឧស្សាហូបនីយកម្មប្រទេសជាតិហាក់ដូចជាផ្អែកលើការសិក្សាវិភាគរបស់ ហ៊ូ យន់ ទាំងអស់ ។

ខៀវ សំផន បានសរសេរដោយភាពប្រាកដក្នុងចិត្តថា «ប្រទេសកម្ពុជាអាចធ្វើឲ្យមានលក្ខណៈជាប្រទេសឧស្សាហកម្មបាន ពីព្រោះវាគ្មានវដ្តចក្រ (ដំណើរវិលវល់មិនចេះចប់) នៃភាពក្រីក្រគោកយ៉ាក ដែលអាចបំបាត់បានដោយការប្រឹងប្រែងរបស់មនុស្សដែលមានសម្បជញ្ញៈ» ។ តាមរយៈការវិភាគដ៏សាំញ៉ាំមួយអំពីសមត្ថភាព

ផ្នែកខស្សរាហកម្មរបស់ប្រទេស គាត់បានពន្យល់វែកញែកយ៉ាងដាក់លាក់ពីលក្ខណៈ សមហេតុសមផលនៃនិក្ខេបបទដែលមានពីមុនរបស់ ហ៊ូ យន់ ដោយផ្ដើមចេញពីស្ថានភាពមួយប្លែកពីគ្នា ដែលតាមរយៈនោះថា ការលុបបំបាត់ប្រាក់បំណុលរបស់កសិករគឺជាគន្លឹះនៃការចាប់ភពជាថ្មីរបស់ប្រទេសកម្ពុជា ។ ខៀវ សំផន បានបញ្ចូលទំនើបភាវូបនីយកម្មវិស័យកសិកម្មក្នុងគម្រោងការអភិវឌ្ឍន៍ផ្នែកខស្សរាហកម្មរបស់គាត់ ។ គាត់បានប្រកាសដោយម៉ឺងម៉ាត់ថា គេមិនត្រូវបណ្ដោយឲ្យផលប្រយោជន៍ផ្សេងៗរបស់រដ្ឋាភិបាល និងសហគ្រាសបរទេសនានាបង្ខំឲ្យយើងធ្វើតាមបែបបទដែលត្រូវតែធ្វើទំនើបកម្មប្រទេសកម្ពុជាឡើយ ។ តាមការពិត នេះគឺជាការចោទប្រកាន់មុនការវេលាមួយ ចំពោះបណ្ដាក្រុមហ៊ុនពហុជាតិ និងឥទ្ធិពលរបស់ក្រុមហ៊ុនទាំងនេះ មកលើប្រទេសតតិយលោកនានា ។ សំផន ពុំបានអួតអំពីទីបញ្ចប់នៃការវិនិយោគរបស់ពួកបរទេសទេ គឺណែនាំតែអំពីការត្រួតពិនិត្យដ៏ទូលំទូលាយមួយលើការផ្លាស់ប្ដូរទំនិញ និងពាណិជ្ជកម្មរបស់កម្ពុជាប៉ុណ្ណោះ ។ គាត់បានទាមទារឲ្យរដ្ឋធ្វើពាណិជ្ជកម្មផ្ដាច់មុខលើគ្រឿងបរិភោគសំខាន់ៗ ការត្រួតពិនិត្យប្រព័ន្ធហិរញ្ញប្បទាន និងសារព័ន្ធនៃតម្លៃ ទៀត ។ គោលដៅរបស់គាត់គឺការប្រមូលផ្ដុំនិងការធ្វើម្ចាស់លើប្រាក់មូលធនថ្មីមួយ ដែលនឹងត្រូវយកទៅដាក់ជាដើមទុនរកស៊ីក្នុងកម្មវិធីផ្សេងៗដើម្បីធ្វើទំនើបភាវូបនីយកម្មប្រទេសកម្ពុជា ពុំមែនយកទៅដាក់ធនាគារបរទេសផ្សេងៗឡើយ ។ ប្រការនេះនឹងជួយធ្វើបំពេញស្ស័យភាពរបស់ជាតិនិងនាំមកនូវអត្រានៃមុខរបរបង្កើនផលកើនកាន់តែខ្ពស់ ហើយនឹងធានាការធ្វើឲ្យរឹតតែប្រសើរឡើងនូវកម្រិតជីវភាពរបស់ប្រជាជនទាំងអស់ –នេះជាបណ្ដាគោលដៅ ដែលក្នុងនោះគាត់មើលឃើញយ៉ាងច្បាស់ពីសេចក្ដីត្រូវការជាធម្មតារបស់ប្រទេសជាតិ ។

ម្យ៉ាងវិញទៀត សំផន បានសុំឲ្យមានការត្រួតពិនិត្យយ៉ាងតឹងរ៉ឹងមួយរបស់រដ្ឋទៅលើខស្សរាហូបនីយកម្មការទាក់ទងផ្សេងៗរបស់បរទេសនិងការកែទម្រង់រចនាសម្ព័ន្ធសេដ្ឋកិច្ច ។ ហេតុការណ៍សំខាន់ គឺអ្នកដែលវាយតម្លៃសំណើផ្សេងៗរបស់គាត់ក៏ដូចជាសំណើទាំងឡាយរបស់ ហ៊ូ យន់ គឺជាអ្នកដែលមានភាពប្រាកដក្នុងចិត្តដូចគ្នាថា ប្រទេសជាតិនិងស្គាល់នូវភាពសម្បូររុងរឿងជាមិនខាន បើសិនជាប្រជាកសិករអាចបង្កបង្កើនផលលើដីធ្លីរបស់គេ ដោយមានវណ្ណៈគហបតីកម្ពុជាភាគច្រើនក៏យល់ស្របតាមគំនិតនេះដែរ ។ គោលការណ៍ទាំងឡាយ ដែលបែកចេញពីសំណើទាំងនោះ សុទ្ធតែជាគោលការណ៍ ដែលមាននៅក្នុងការងារធំៗរបស់ សំផនៈ អ្វីដែលជាឧបសគ្គសម្រាប់ប្រជាកសិករកម្ពុជា គឺទម្លាប់អាក្រក់នៃការធ្វើការងារ ដែលធ្វើឲ្យឋិតឋេរដោយអ្នករំខានផ្សេងទៀតនេះ គឺអ្នកគ្រប់គ្រងរដ្ឋមិនល្អ ។ ធនាគារិក ម៉ី កម្ពូត ធ្លាប់អបអរសរសើរការវិភាគនេះហើយសម្ដេច ព្រះនរោត្ដម សីហនុ ក៏យល់ស្របដែរ ។ ប៉ុន្តែគ្មានបញ្ញវន្តណាម្នាក់ក្នុងចំណោមបញ្ញវន្តទាំងនេះ ដឹងនូវអ្វីដែលប្រជាកសិករផ្ទាល់គិតឃើញ ហើយប្រឆាំងតបតចំពោះវិធីទាំងនេះបែបណាទេ ។

ការងារ និងគំនិតផ្ដួចផ្ដើមទាំងឡាយរបស់បណ្ដាយុវជនកម្ពុជាម៉ាក្សនិយម បានទាក់ទាញការយកចិត្តទុកដាក់ជាច្រើន ហើយពួកបញ្ញវន្តបារាំងសំខាន់ៗបានចាត់ពួកគេចូលក្នុងចំណោមអ្នកត្រិះរិះកម្រិតខ្ពស់ ដែលមាន

គំនិតភ្លឺស្វាង និងដែលបញ្ចូលរបៀបថ្មីប្រសើរលើសគេលើសឯងរបស់ប្រទេសកម្ពុជា ។ មិនយូរប៉ុន្មាន គេបាននិយាយពីជំនាន់ យុវជនជាទីសង្ឃឹមនេះ ។ ក្នុងការនិពន្ធល្បងមួយនៅឆ្នាំ១៩៦១ អំពីលិទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ដែលសរសេរសម្រាប់មជ្ឈមណ្ឌលសិក្សាពីទំនាក់ទំនងអន្តរជាតិ មានឈ្មោះមនុស្សបីនាក់នៅក្នុងគន្ថនិទ្ទេសនៃសៀវភៅជាច្រើន ដែលសរសេរដោយពួកកម្ពុជា គឺ ខៀវ សំផន, ហ៊ូ យន់ និង ជួន ជឿន (កូនម្នាក់ក្នុងចំណោមកូនទាំង៨របស់ត្រកូលជួន) អ្នកទាំងនេះសុទ្ធតែជាអនាគតមេដឹកនាំខ្មែរក្រហម ។

កេរ្តិ៍ឈ្មោះដ៏ល្បីល្បាញរបស់គេ បានធ្វើឲ្យសម្ដេច ព្រះនរោត្ដម សីហនុ ព្រួយបារម្ភ ដែលបានដាក់ឲ្យមានវិធានការថ្មីៗជាច្រើន ដើម្បីរារាំងកុំឲ្យពួកនិស្សិតកម្ពុជាដទៃទៀត«ឆ្លងមេរោគ»ពីលទ្ធិកុម្មុយនិស្ដនៅទីក្រុងប៉ារីស ដោយបានចាត់ឲ្យមនុស្សនិយមឆ្វេងខ្លាំងៗ ទៅរៀននៅក្នុងសកលវិទ្យាល័យបារាំងតាមខេត្តវិញ ។ ប៉ុន្ដែ អ្វីដែលទាក់ទាញចិត្តរបស់ក្រុមឆ្វេងនិយមស្ថិតនៅមានដដែល ។

ពួកយុវអ្នកស្រាវជ្រាវ ដែលពោរពេញទៅដោយការប្ដេជ្ញាចិត្តទាំងនោះ បានចាត់ទុកខ្លួនឯងជាអ្នកនិយមលទ្ធិម៉ាក្សស៊ីសទាំងសាច់ទាំងឈាម ពុំមែនជានិស្សិតធម្មតានោះទេ ហើយបានផ្ដើមចូលប្រឡូកក្នុងឆាកនយោបាយទាំងអស់គ្នា នៅពេលដែលគេវិលត្រឡប់មកកម្ពុជាវិញ ។ ពួកគេបានចាប់ផ្ដើមអនុវត្តភ្លាមនូវការផ្លាស់ប្ដូរទ្រង់ទ្រាយប្រទេសរបស់ខ្លួន នូវអ្វីដែលពួកគេធ្លាប់បានរៀនចេះដឹងក្នុងសកលវិទ្យាល័យនានារបស់បារាំង និងក្នុងផ្ទៃបក្សកុម្មុយនិស្ដបារាំងដែលនិយមស្ដាលីន ។

ក្នុងរយៈពេលនៃអភិក្រមនេះ ពួកគេផ្ទាល់ ក៏ត្រូវផ្លាស់ប្ដូរចរិតលក្ខណៈរបស់ខ្លួនដែរ ដែលជាញឹកញាប់ហៀប តែនឹងក្លាយទៅជាមនុស្ស ដែលគេស្ទើរតែទៅហើយ ។ ពួកគេបានត្រូវធ្វើឲ្យស្របទៅតាមស្ថានភាពលត់ដំខ្លួន និងធ្វើឲ្យឈឺចាប់ខ្លាំងដោយសារសង្គ្រាមដែលពួកបារាំងនាំមុខធ្វើ ដើម្បីឲ្យបានស្ថិតនៅឥណ្ឌូចិនតទៅទៀត ដោយសារសង្គ្រាមដែលសម្ដេច ព្រះនរោត្ដម សីហនុ ដឹកនាំធ្វើ ដើម្បីបំបាត់លទ្ធិកុម្មុយនិស្ដរបស់កម្ពុជា ដោយសារជម្លោះដែល ខ្វះសេចក្ដីស្មោះត្រង់រវាងពួកកុម្មុយនិស្ដអាស៊ី និងដោយសារសង្គ្រាមដ៏គួរឲ្យខ្ពើមរអើមរបស់ពួកអាមេរិកាំង នៅឥណ្ឌូចិន ។

ខ្មែរក្រហមដំបូងបង្អស់ក្នុងចំណោមខ្មែរក្រហម ដែលចាកចេញពីទីក្រុងប៉ារីស ដើម្បីត្រឡប់មកប្រទេសកម្ពុជាវិញគឺ សាឡុត ស ។ គាត់បានមកដល់កម្ពុជានៅខែមករា ឆ្នាំ១៩៥៣ ហើយបានក្លាយទៅជាជនកុម្មុយនិស្ដកម្ពុជាដំបូងម្នាក់ ក្នុងចំណោមជនកុម្មុយនិស្ដកម្ពុជាដំបូងៗ ដែលបណ្ដុះបណ្ដាលដោយពួកបារាំងឲ្យទៅរួបរួមជាមួយវៀតមិញ ក្នុងរណសិរ្សសង្គ្រាមដណ្ដើមឯករាជ្យ ប្រឆាំងនឹងប្រទេសបារាំង ។

# ជំពូកទី៣
# មាគ៌ាឆ្ពោះទៅរកអំពើក្បត់

តាំងពីកុមារភាព ប្រជាជនកម្ពុជាទាំងអស់បានត្រូវធ្វើឲ្យជ្រួតជ្រាបវប្បធម៌របស់ខ្លួនតាមរយៈរឿងនិទានប្រជាប្រិយខ្មែរ រឿងប្រវត្តិផ្សេងៗ ដែលពោរពេញទៅដោយការកំប្លែងសួគមួយរបៀបអនាចារ ហើយជាញឹកញាប់ គឺការកំប្លែងលេងស្តីពីភាពឥតន័យរបស់ជីវិតមនុស្សក្នុងវាលវដ្តសង្សារ ដែលមានទំនោរមួយដុះទៅខាងសេចក្តីសប្បាយក្នុងកាមតណ្ហានិងអំពើអបាយមុខផ្សេងៗ ។ តួអង្គដែលមាននៅក្នុងរឿងព្រេងទាំងនេះ ច្រើនតែជាពពួកមន្ត្រីរបស់ព្រះរាជាដ៏មានឫទ្ធានុភាពខ្លាំងបំផុត សត្វក្រពើល្ងង់ខ្លៅ សត្វទន្សាយដែលឆ្លាតវាងវៃ និងប្រជាជនកម្ពុជាសាមញ្ញធម្មតា ដែលបណ្តែតបណ្តោយឲ្យតណ្ហាដ៏ពុះកញ្ជ្រោលរបស់ខ្លួនដាន់ឈ្លីលើ វិចារណញ្ញាណដ៏ល្អត្រឹមត្រូវ ។ ទាំងនេះសុទ្ធតែជារឿងព្រេង រឿងភរ វែងមិនចេះចប់ ដែលសាច់រឿងទាំងនោះច្រើនត្រួតជាន់គ្នាពីមួយទៅមួយប្រកបដោយលក្ខណៈឆោតល្ងង់ខ្លៅស្តីពីជីវភាពនៅស្រុកស្រែចម្ការ ដែលឆ្លុះបញ្ចាំងឲ្យឃើញនូវជីវភាពមួយ ដែលគ្រប់គ្រងដោយកម្លាំងធម្មជាតិ និងជំនឿលើផលកម្មវាសនាទាក់ទងនឹងសាសនាព្រះពុទ្ធ ។ ជីវភាពរស់នៅ ដែលរឿងព្រេងទាំងនោះរ៉ាយរ៉ាប់ច្រើនមានការបញ្ចប់មួយកំបុតកំបុតធ្លុញ ។ តាមសភាពខាងក្រៅរឿងទាំងនោះ ពុំមានដំបូន្មានទេ ហើយជួនកាលហាក់ដូចជាគ្មានអត្ថប្រយោជន៍ផង ។ រឿងនិទានទាំងនោះ ច្រើនបង្ហាញឲ្យឃើញថា ការរស់នៅ គឺពោរពេញទៅដោយហេតុការណ៍ដែលមិនបានគិតទុកជាមុនថា អំពើហិង្សាជាចំណែកមួយនៃការពិសោធន៍ ហើយដែលគេត្រូវតែប្រឹងប្រែងស្វែងរកផ្លូវមួយ នាំឆ្ពោះទៅរកជីវិតរស់នៅដ៏ប្រសើរជាងមុនក្នុងការចាប់ភពរបស់ខ្លួននៅជាតិខាងមុខទៀត ។ នេះជារឿងមួយ ដែលមានចំណងជើងថា មាយាស្ត្រី[១] :

កាលពីព្រេងនាយ មានបុរសម្នាក់មានប្រពន្ធតែពុំមានកូនទេ ដល់យូរៗទៅ ប្រពន្ធនោះមានសហាយនាំមកដេកក្នុងផ្ទះតែសព្វថ្ងៃ ។

ថ្ងៃមួយ ប្តីទៅជីកដំឡូងក្នុងព្រៃ ដល់ថ្ងៃក្តៅក៏ចូលទៅជ្រកនៅខ្ទមអ្នកតាមួយ ។ ប្រពន្ធយកតង្វាយទៅបន់អ្នកតាឲ្យធ្វើប្តីខ្លួនឲ្យងាប់ ឆ្នាលនឹងយកសហាយធ្វើជាប្តី ។ ប្តីឃើញប្រពន្ធដើរដំដៅមកខ្ទមអ្នកតាកើតចិត្តនឹកឆល់ក៏ចូលទៅពួនក្រោយខ្នងរូបអ្នកតាចាំមើលប្រពន្ធ ។

ប្រពន្ធអុជទៀនធូបរួចហើយ និយាយបន់ស្រន់ថា :

- ខ្ញុំមិនចង់យកប្តីខ្ញុំទេ ខ្ញុំយកប្តីទៀត សូមអ្នកតាកាច់ប្តីខ្ញុំឲ្យស្លាប់ទៅ ខ្ញុំនឹងថ្វាយជ្រូកមួយ ។

ប្តីឮដូចនោះ ក៏ឆ្លើយឡើងពីក្រោយខ្នងអ្នកតាថា :

- អើ បើនាងមានសហាយ ហើយចង់ឲ្យអញកាច់ប្តីឲ្យងាប់នោះ ងាយទេវិលទៅផ្ទះវិញ ត្រូវរកមាន់ក្រាបទាំងមេទាំងពងមួយសម្បុក សោរឲ្យវាស៊ីទៅស្លាប់ហើយ ។

មេនោះក៏ប្រញាប់វិលមកផ្ទះវិញដោយត្រេកអរ រកទិញបានមេមាន់ក្រាបមួយសម្បុកសោរទុកឲ្យប្តីស៊ី ។ លុះដល់ព្រលប់ប្តីមកពីដីកដំឡូងក៏សួរថា ៖

គេហ៍អើយ បានអីស៊ីបាយ?

មេនោះឆ្លើយ

◆ ចាំ មានមាន់ក្រាបមួយសម្បុកស្ងោរទុកឲ្យអ្នក

ប្តីស្រដីបន្ថែមថា ៖

◆ រៀបបាយមកស៊ី ។

ប្រពន្ធក៏លើកបាយទាំងមាន់ក្រាបមកឲ្យប្តី ។ ប្តីស៊ីអស់មាន់ក្រាបមួយសម្បុកក៏ធ្វើជាឈឺដេកថ្ងូរហ៊ឺៗ ។ មេនោះអរណាស់មិនស្មានថា ប្តីអ្នកតាធ្វើមែន ក៏បើកទ្វារនាំសហាយមកដេកជាមួយ ។ ប្តីក្រោកឡើងអង្គុយ ។ ប្រុសសហាយឃើញដូចនោះស្ទុះរត់មិនទាន់ក៏ចូលទៅពួនក្នុងពាងធំមួយ ។ ប្តីឃើញ តែធ្វើជាមិនឃើញមិនឮ ហើយស្រែកប្រាប់ប្រពន្ធថា ៖

◆ អញរងាណាស់ ដាំទឹកឲ្យក្ដៅងូតបន្តិចឆ្អាលនឹងស្លាប់ ។

នាងនោះឮថាប្តីចង់ស្លាប់អរណាស់ ដ្បិតត្រូវនឹងពាក្យដែលទៅបន់អ្នកតាមែន ។ លុះប្រពន្ធដាំទឹកពុះហើយ ប្តីបង្គាប់ថា ៖

◆ ដងទឹកត្រជាក់បានមួយក្អមមក យកមកលាយនឹងទឹកក្ដៅ ប្រពន្ធក៏កណ្តៀតក្អមចេញទៅដងទឹក ។ ប្តីឃើញប្រពន្ធចេញទៅបាត់ ក៏ក្រោកឡើងដើរទៅលើកទឹកពុះមួយថ្លាងស្រោចទៅលើសហាយនៅក្នុងពាងនោះស្លាប់ទៅ ហើយចូលទៅដេកវិញធ្វើជាឈឺថ្ងូរហ៊ឺៗដូចមុន ។

នាងនោះវិលពីដងទឹកមកវិញ មើលទៅឃើញសហាយត្រូវទឹកក្ដៅរួញសរសៃដកកចេញពីពាងមក ក៏ធ្វើសញ្ញាឲ្យលិបក្នុងពាងវិញ តែសហាយនេះមិនព្រមធ្វើតាមសោះ ក៏លូកដៃទៅចាប់ជ្រមុជត្រូវស្លឹកត្រចៀករលេះជ្រុះទាំងសក់ ទើបដឹងថាប្តីស្រោចទឹកក្ដៅសម្លាប់សហាយទៅហើយ នាងពុំស្តីយកគ្របពាងមកគ្រប ហើយយកទឹកមកឲ្យប្តីងូត ឯប្តីក៏មិនស្តីអ្វី ទឹកក៏មិនងូតហើយក៏ដេកទៅ ។

លុះព្រឹកឡើង មេនោះពុំដឹងគិតធ្វើដូចម្តេចនឹងយកខ្មោចឲ្យផុតពីផ្ទះ ក៏នឹកឃើញ “ក្នុងស្រុកមានចោរបួននាក់ តែងដើរលួចអ្នកផងរៀងរាល់យប់ ដូចនេះអញបោកពួកនេះម្តង” ។

គិតហើយ នាងនោះក៏ដើរខ្ចីសំពត់ហូល អាវព្រៃ យកមកហាលជុំវិញផ្ទះ ។ ឯពួកចោរឃើញហើយ គិតថា

◆ យើ! មេនេះមានណាស់តើ យើសយប់នេះយើងទៅលួចវាឲ្យបាន ។

នាងនោះក៏ហាលសំពត់ហូលអាវព្រៃនោះ លុះដល់ពេលល្ងាចទើបយកទៅជូនគេវិញ ហើយយកខ្សែចងរឹតពាងខ្មោចយ៉ាងជាប់ ។

ឯចោរបួននាក់ លុះដល់យប់ក៏បបួលគ្នាទៅលួច ចូលទៅរករបស់ទាំងនោះពុំឃើញ ឃើញតែពាងមួយចង មាត់ជាប់ ក៏នាំគ្នាសែងយកពាងទៅដល់ព្រៃឆ្ងាយក៏ស្រាយលូកមើល ។

អាមួយលូកដៃទៅត្រូវសក់ដកដៃចេញ ហើយស្រែក

◆ វ៉ឺយសូត្រ ។

អាមួយលូកដៃទៅត្រូវស្លឹកត្រចៀក ត្រូវភ្នែក ច្រមុះ តាំងស្រែក

◆ វ៉ឺយខ្មោច ។

អាមួយទៀតមិនជឿ ក៏លូកដៃទៀតត្រូវដើមទ្រូង ផើបពោលបញ្ឆោក់

◆ ខ្មោចមែនវ៉ឺយ ខ្មោចមែន ។

ចោរទាំងបួននាក់ក៏ស្ទុះរត់ចោលពាង ហើយនឹកខឹងនឹងមេនោះខ្លាំងណាស់ គុំឃ្លាំចាំមើលនឹងចាប់វាវាយឲ្យ រាងចាលម្ដង ។

ជួនថ្ងៃមួយ មេនោះចុះទៅកំពង់រកទិញអីវ៉ាន់ ដ្បិតមានសំពៅទើបមកដល់ពីស្រុកក្រៅ ។ មេនោះដើរដល់ ពាក់កណ្ដាលផ្លូវ ក៏ជួបនឹងចោរបួននាក់នោះ ។ ពួកចោរឃើញហើយក៏នាំគ្នាព្រួតចាប់ដើម្បីវាយតែមេនោះពោល ថា ៖

ណ្ហើយអ្នក បើអ្នកវាយខ្ញុំក៏ឥតប្រយោជន៍ដែរ ដ្បិតខ្ញុំទៅទារប្រាក់ពីនាយសំពៅ ដូចនេះអ្នកទៅជាមួយខ្ញុំ ទៅ កាលណាទារប្រាក់បាន យើងនឹងចែកគ្នាចាយ ។

ចោរទាំងបួននាក់ ឮថាទៅទារប្រាក់ក៏ពេញចិត្តបបួលគ្នាទៅ ។ មេនោះផ្ដាំចោរទាំង៤នាក់ថា ៖

◆ អស់អ្នកឈរចាំខ្ញុំនៅលើច្រាំងចុះ បើកាលណាឃើញខ្ញុំបោយដៃអ្នកចុះទៅចុះបានប្រាក់ហើយ ។

ថាហើយ វាក៏ចុះទៅក្នុងសំពៅ និយាយលក់ចោរទាំងបួននាក់ឲ្យនាយសំពៅ ។ នាយសំពៅក៏យល់ព្រម ហើយប្រគល់ប្រាក់បួនណែនកន្លះទៅឲ្យមេនោះ ។ មេនោះចេញមកក្រៅក៏បក់ដៃហៅចោរ ។ ពួកចោរស្មានថា វាហៅឲ្យទៅយកប្រាក់ក៏នាំគ្នាចុះទៅ ។ ដល់ហើយនាយសំពៅបានប្រើបម្រើឲ្យចាប់ពួកនេះដាក់ច្រវាក់នៅបាត សំពៅ ។

មេនោះបានប្រាក់ហើយវិលត្រឡប់មកផ្ទះវិញ ។ ដល់ពាក់កណ្ដាលផ្លូវជួនជាយប់ក៏ឡើងដេកលើ ដើមឈើ មួយប្របមាត់ផ្លូវ ។

ឯចោរទាំងបួននាក់នាំគ្នាកាច់ច្រវាក់រត់ចេញពីសំពៅទាំងយប់ ។ ជួនជាយប់យូរណាស់ ក៏នាំគ្នាឡើងទៅ ដេកលើដើមឈើធំ ដែលមេនោះដេកដែរ ។ ចោរបីនាក់ឡើងទៅដេកលើមែកដោយខ្លួន ។ ចោរម្នាក់ទៀតឡើង ទៅក៏ជួបមេនោះនៅលើចុងឈើ ។ អាចោរនោះថា អើហ៎ឯងហើយម្ដងនេះ ហ៎ឯងរត់ចុះបើរួច ។

មេនោះលើកប្រាក់បង្ហាញហើយ ឱន ខ្សឹបថា ៖

◆ ណ្ហើយអ្នកកុំមាត់ឲ្យអ្នកទាំងបីដឹង យើងត្រូវយកគ្នាជាប្តីប្រពន្ធយកប្រាក់នេះទៅរកស៊ីប្រសើរជាង អ្នកកុំធ្វើបាបខ្ញុំ ។

អាចោរពុទ្ធដូចនោះ ក៏មិនស្តី ហើយក៏ចូលទៅជិតលូកដៃឱបប្រកៀកមេនោះរួចនិយាយថា អូនឯងហៅប្រាជ្ញធំបញ្ឆោតបងពីរដងហើយ ឥឡូវបងបាននាងជាប្រពន្ធ គឺដោយសារសំណាងយើង ។

មេនោះស្រដីថា ៖

◆ ក្រែងអ្នកស្រឡាញ់ខ្ញុំមិនស្មោះចំណែកខ្ញុំស្រឡាញ់អ្នកស្មោះចិត្តមួយហើយ ។ អានោះថា បងស្រឡាញ់ស្មោះហើយ ឲ្យបងស្បថប្តូឲ្យបងធ្វើអ្វីក៏ធ្វើដែរ ។ មេនោះនិយាយបញ្ឆោក់ ៖

◆ បើស្រឡាញ់ចិត្តមួយនឹងគ្នា មានតែលិទ្ធអណ្តាតគ្នា ។

នាងនោះលៀនអណ្តាតហើយឱនទៅរកអាចោរ ។ អាចោរលិទ្ធអណ្តាតនាងនោះ ហើយលានអណ្តាតវាឲ្យនាងនោះលិទ្ធវិញ ។ នាងនោះខាំអណ្តាតអាចោរនោះដាច់អស់មួយកំណាត់ ហើយប្រានទម្លាក់ពីលើចុងឈើធ្លាក់ដល់ដីស្រែកពុទ្ធតែឡូល១ ចោរបីនាក់គិតស្មានថា នាយសំពៅចោមចាប់ក៏លោតពីមែកឈើរត់ទៅហើយស្រែកហៅគ្នា ៖

◆ វ៉ុយគ្នាយើងរត់ នាយសំពៅដេញហើយ ។

អាចោរដាច់អណ្តាតនោះ ស្រែកហៅគ្នាវាឲ្យចាប់នាងនោះនៅលើចុងឈើ ប៉ុន្តែ វានិយាយមិនច្បាស់ពុទ្ធតែឡូល១ គ្នាវាគិតស្មានតែគេដេញចាប់ក៏ប្រឹងរត់យកតែព្រះអាយុសរៀង១ខ្លួន ។

មេនោះចុះពីលើចុងឈើយកប្រាក់ទៅផ្ទះ ទៅរកស៊ីជាមួយប្តីសុខសប្បាយតទៅ ។

រឿងនិទានប្រជាប្រិយ ដែលប្រកបដោយល្បិចកលនេះ ត្រូវរាប់ចូលក្នុងប្រភេទទូទៅដូចគ្នានឹងរឿងព្រេងរបស់បងប្អូនប្រុសឈ្មោះ គ្រ៊ីម (Grimm) ទាំងពីរនាក់ដែរ [និរុត្តិវិទូ និងជាអ្នកនិពន្ធអាល្លឺម៉ង់ (១៧៨៥ - ១៨៦៣) ជាអ្នកបង្កើតនិរុត្តិវិទ្យាភាសាអាល្លឺម៉ង់ កើតនៅ ហាណូ (Hanau) រដ្ឋហេស (Hess) អាល្លឺម៉ង់ខាងលិច ។ គាត់បានរួមជាមួយប្អូនប្រុសរបស់គាត់ឈ្មោះ វីលហែម (Wilhelm) កើតនៅហាណូ (១៧៨៦ - ១៨៥៩) សរសេររឿងប្រជាប្រិយអាល្លឺម៉ង់ជាច្រើន -កំណត់របស់អ្នកបកប្រែ] ។ ប៉ុន្តែ លក្ខណៈនៃអំពើហិង្សា ដែលមានដំណាលក្នុងរឿងនោះ និងហេតុការណ៍ដែលសភាពឃោរឃៅនៅតែគ្មានអ្នកណាផ្តន្ទាទោស បានផ្តល់ឋានៈឲ្យគាត់ដាច់ដោយឡែក ។ វាពុំមានដំបូន្មាន ឬសីលធម៌ទេ គឺមានតែការវែកញែកពន្យល់ថា ការប្រព្រឹត្តអំពើឃោឃៅចំពោះអ្នកដទៃបណ្តាលឲ្យមានអំពើឃោរឃៅរឹតតែខ្លាំងឡើងថែមទៀត ។

ប្រាកដណាស់ វប្បធម៌មួយដែលបង្កើតរឿងនិទានបែបនោះ ពុំមែនជារឿងល្អគួរឲ្យចូលចិត្តជានិច្ច ជាងកេរ្តិ៍ឈ្មោះរបស់ខ្លួនដែលត្រូវការនោះទេ ។ រឿងភរទាំងនោះ ជាភ័ស្តុតាងមួយនៃអំពើឃោរឃៅ សឹងតែមិនអាចពន្យល់បាន ដែលកញ្ជ្រោលបោកបាចនៅ ប្រទេសកម្ពុជាក្នុងរយៈពេលសង្គ្រាម និងការបដិវត្តន៍របស់ខ្មែរ ។ នេះ

ជាអំពើឃោរឃៅមួយ ដែលជាលក្ខណៈ មួយនៃសេចក្ដីអង់អាចរបស់ជាតិយ៉ាងហោចណាស់ តាំងពីសម័យអង្គរមកម្ល៉េះ ។

ប្រជាកសិករនៃរាជាណាចក្រអង្គរធ្លាប់ បានរស់នៅក្រោមម្លប់នៃព្រះមហាក្សត្រគ្មានទសពិធ រាជធម៌ទាំងឡាយ ដែលតម្រូវឲ្យបង់ពន្ធដារ និងឲ្យបំពេញការងាររលំបាកលំបិនគ្មានផលកម្រៃដើម្បីស្ថាបនា ប្រាសាទសម្រាប់បូជាព្រះអាទិទេព និងអំណួតរបស់ព្រះរាជា ។ ប្រជាជនក្រីក្ររស់នៅគ្មានអ៊ីបន្តិចបន្តួចសោះក្នុងខ្លួន វណ្ណៈអភិជន តូចតាចស្គាល់តែភាពសម្បូរហូរហៀរ ហើយភាពខុសគ្នារវាងវណ្ណៈទាំងពីរបានលេចឡើងយ៉ាងច្បាស់ក្រឡែត ។ ប្រជាកសិករដែលប្រឹងធ្វើការយ៉ាង ហួសប្រមាណក្រោមកម្ដៅព្រះអាទិត្យ ដែលក្ដៅស្ទើរឆេះសុទ្ធតែជាពួកដែលគេឲ្យឈ្មោះថា «មនុស្ស មាឌធំស្បែកខ្មៅ» ចំណែកឯពួកអ្នកមានទ្រព្យសម្បត្តិ ដែលទំនេរគ្មានធ្វើការអ្វីហើយដែលកំពុងចំរើនរស់យ៉ាង ស្រួលក្នុងគេហដ្ឋានដ៏ធំស្កឹមស្កៃរបស់ខ្លួនមានឈ្មោះជា «មនុស្សស្បែកសភ្លឺដូចថ្មើមថ្ម» ទៅវិញ ទោះបីជាវណ្ណៈ ទាំងពីរមានពូជសាសន៍តែមួយក៏ដោយ ។ ក្រុមវរជន ដាក់ឈ្មោះរបស់ខ្លួនសុទ្ធតែភាសាសំស្ក្រឹតហើយវែងៗ ទៀត រីឯប្រជាជនកម្ពុជានិងអ្នករស់នៅតាមព្រៃភ្នំ ដែលត្រូវគេយកទៅធ្វើជាខ្ញុំកញ្ជះនោះ ពុំមានទាំងឈ្មោះថែមទៀត ហើយត្រូវគេសម្គាល់ដោយហៅ «អាឆ្កែ» ឬជា«អាសំអុយ» ។

របៀបចាត់ចែងខាងតុលាការច្រើនតែធ្វើផ្ទុយនឹងច្បាប់រដ្ឋ ដូចស្ថាប័នដទៃៗ ទៀតរបស់ព្រះរាជាដែរ ហើយក្រុមមនុស្សដែលកាន់អំណាចចូលចិត្តទោរទន់ទៅរកកំហឹងណាស់ ។ ប្រជាជនកម្ពុជាសាមញ្ញ ច្រើនមានកាន់អាវុធមួយក្នុងដៃជានិច្ច ម៉្លោះហើយជម្លោះកំប៉ិកកំប៉ុកទាំងឡាយអាចនាំគេទៅរកការប្រយុទ្ធ ស៊ីសាច់ហុតឈាមគ្នាទាល់តែបាន ។ ការនិយមជឿខ្មោចព្រាយអារក្សអ្នកតា និងជំនឿថា មានព្រលឹងឬកម្លាំងធម្មជាតិដឹកនាំលោកនោះ មិនដែលបំផ្លាញសាសនាផ្សេងៗរបស់ប្រទេសដែលរីកលូតលាស់ឡើងនូវការប្រតិបត្តិមន្តអាគមអូមអាមសម័យដើមដែលត្រូវការអំពើឃោឃៅជាជំនួយ ។ ការកាត់អវៈយវៈខ្លះចេញពីរាងកាយ -ប្រដាប់បន្តពូជ ឬក្បាល -ត្រូវបានចាត់ទុកថា ផ្ដល់ឫទ្ធិអំណាចដល់អ្នកដែលធ្វើទុក្ខទោសពួកគេ ។ បណ្ដាព្រះរាជា ដែលជាគូប្រជែងត្រូវគេកាត់ក្បាលដៃ- ជើងហើយគេចាត់ធ្វើពិធីកប់សាកសពតាមប្រពៃណីសាសនារបស់ជនជាតិខ្មែរក្រីក្រគោកយ៉ាក មុននឹងចាប់ផ្ដើមការស្ថាបនាតាមគម្រោងការធំមួយ ដើម្បីធានាជោគជ័យដល់សំណង់នោះ ។ គេក៏ប្រើមធ្យោបាយរបៀបដូចគ្នានេះដែរ សម្រាប់គូប្រជែងទាំងឡាយដែលចង់ដណ្ដើមរាជបល្ល័ង្ក ។ អ្នកកត់ត្រាសាវតារម្នាក់នៅសម័យអង្គរបានប្រាប់ឲ្យដឹងថា «នៅថ្ងៃដែលព្រះរាជាអង្គថ្មីត្រូវប្រកាសឡើងសោយរាជ្យ ព្រះអនុជរបស់ព្រះអង្គ សុទ្ធតែត្រូវគេកាត់យកអវៈយវៈមួយចេញ ខ្លះត្រូវគេកាត់ម្រាមដៃមួយ ខ្លះទៀតត្រូវគេកាត់ច្រមុះ»[៣] ។

ទាំងអស់នេះជាពាក្យសម្ដីរបស់ ជូ តាកាន់ ជាជនជាតិចិន ដែលបានមកទស្សនារាជាណាចក្រនេះ នៅដំណាច់សតវត្សរ៍ទី១៣ ។ គាត់បានដំណាលថា មនុស្សទាំងឡាយ ដែលត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋធ្ងន់ធ្ងរ

បានត្រូវគេយកទៅកប់ទាំងរស់ក្នុងរណ្តៅជាច្រើន ដែលគេជីកនៅខាងមុខមាត់ផ្លូវចូលទិសខាងលិចរាជធានី ។ គេបានដាក់ទោសចំពោះអំពើឧក្រិដ្ឋតូចតាចផ្សេងៗ ដោយកាត់ម្រាមដៃ ចង្កូលដៃ ឬដៃទាំងមូលមួយ ហើយបើតាមអ្នកដំណើរជាតិចិននេះថា ជនជាតិខ្មែរមានចិត្តគំនិតចម្លែកខុសពីធម្មតាស្ដីពីលក្ខណៈប្រកបដោយគ្រោះថ្នាក់នៃបទល្មើសមួយ ។ គាត់បញ្ចេញគំនិតថា «អំពើអបាយមុខ និងល្បែងស៊ីសងពុំមានហាមឃាត់ទេ»[៤] ប៉ុន្តែ ស្វាមីម្នាក់ អាចធ្វើទារុណកម្មសហាយរបស់ប្រពន្ធខ្លួនដែលផិតក្បត់បាន ដោយកៀបជើងសហាយនោះនឹងដង្កាប់មួយរហូតទាល់តែអ្នកនោះសុខចិត្តប្រគល់ទ្រព្យសម្បត្តិទាំងអស់របស់ខ្លួនជាជំងឺចិត្ត ។

មួយសតវត្សរ៍ក្រោយការចុះដុនដាបរបស់ចក្រភពអង្គរ ក៏អំពើឃោរឃៅនេះគ្មានថមថយចុះដែរ ។ ឯសេចក្ដីអង់អាចរបស់ប្រជាជនកម្ពុជាទើបនឹងបន្ថែមគំនិតទុទិដ្ឋិនិយមមួយ និងគំនិតជឿកម្មវាសនាយ៉ាងជ្រាលជ្រៅមួយដែលគេអាចសម្គាល់តែម្យ៉ាងគត់ចំពោះការសំណេះសំណាលរបស់គេពីព្រះពុទ្ធសាសនា ។ នៅពេលដែលបណ្ដាលរដ្ឋជិតខាងមាន វៀតណាម និងសៀម ពង្រីកអំណាច និងចំណាប់ស្រុកឃ្លានរបស់គេមកលើទឹកដីខ្មែរ ប្រជាជនកម្ពុជាបានត្រូវញាំងឲ្យជឿថា ពូជសាសន៍និងវប្បធម៌របស់ខ្លួន មុខនឹងត្រូវរលាយសាបសូន្យមិនខាន ។ ហើយវប្បធម៌របស់គេបានបញ្ចេញឲ្យឃើញចម្លើយអាចធ្វើបានពីរចំពោះការគំរាមកំហែងមួយបែបនោះ ៖ ឬមួយព្រមទទួលយកការគំរាមកំហែងនេះ ពីព្រោះវាជារឿងមិនអាចចៀសរួច ឬមួយប្រើប្រាស់មធ្យោបាយទាំងអស់ដោយគ្មានការលើកលែងទោះជាត្រូវប្រើអំពើឃោរឃៅក៏ដោយ ដើម្បីប្រយុទ្ធទល់នឹងការគំរាមកំហែងនោះ ។

ការដាក់បណ្ដាសាដោយឡែកមួយ ហាក់ដូជាសង្កត់ថែមលើប្រជាជនខ្មែររងទុក្ខវេទនា គឺប្រភពទាំងឡាយនៃអំពើឃោឃៅរបស់គេ មិនដែលរីងស្ងួតសោះឡើយ ។ ប្រភពទាំងនេះសំងំនៅក្រោមអនិស្សរភាពមួយ ដែលរីកកាន់តែធំឡើងៗ ចំពោះការប្រើមន្តអាគម និងការជឿលើខ្មោចព្រាយបិសាចដោយគ្រាន់តែមានអ៊ីបិទបាំងប៉ុណ្ណោះ ។ ក្នុងរយៈពេលសង្គ្រាមពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ ដំណើររឿងមានតគ្នាហូរហែដែលមានប្រជាប្រិយភាពបំផុត បានរៀបរាប់ឲ្យដឹងពីឧប្បត្តិហេតុជាប្រវត្តិសាស្ត្រ ទាំងឡាយដែលបណ្ដាព្រះរាជាសម័យអង្គរកាត់ក្បាលសត្រូវនានារបស់ព្រះអង្គ និងប្រតិបត្តិវិជ្ជាមន្តអាគមគាថា ។ ក្នុងអំឡុងពេលនៃសង្គ្រាមនេះភាពទន់ភ្លន់ដ៏ល្បីល្បាញរបស់ខ្មែរ ជាសញ្ញាបង្ហាញឲ្យឃើញការអត់ឱនមួយ តិចជាងភាពអ្នករងអំពើរបស់គេដោយមិនតបតវិញ ។ លោកខាងក្រៅកំពុងក្លាយទៅជាលោកដែលគេមិនអាចត្រួតត្រាបាន ប្រជាជនកម្ពុជាបានលាក់ខ្លួននៅក្នុងលោកខាងក្នុង ដែលជឿលើកម្លាំងធម្មជាតិដឹកនាំលោក ដែលពោរពេញដោយព្រលឹងខ្មោចព្រាយ អារក្សអ្នកតា ។ ព្រះរាជាណាចក្រមួយ ដែលគេមិនស្គាល់ ជាទីដែលសោភ័ណ និងខ្សែគាថានាំមកនូវការជួយលួងលោមចិត្តធ្វើឲ្យរសាយទុក្ខប្រឈមនឹងគ្រោះអាសន្នចម្លែកៗមិនអាចយល់បាន ។ ប៉ុន្តែ នៅពេលតថភាពនៃនយោបាយអន្តរជាតិ និងតថភាពនៃសង្គ្រាមលេចឡើងជាថ្មី ការប្រឆាំងតបតទៅវិញមានសភាពឃោរឃៅហួសប្រមាណ ។ នៅពេលដែលក្រុមអ្នកបដិវត្តន៍របស់ ប៉ុល ពត ចូលដល់រដ្ឋធានី ប្រជាពលរដ្ឋទាំងអស់នៅក្រុងភ្នំពេញសំគាល់

ឃើញ ពួកអស់នោះស្លៀកពាក់«ខ្មៅ»ខ្លាំងណាស់ ហើយគឺមនុស្ស «ស្លៀកពាក់ខ្មៅ» ទាំងនេះហើយ ដែលសម្រេចចិត្តចាត់ទុកប្រជាពលរដ្ឋ «ស្បែកសដូចថ្លើមថ្មី» រស់នៅទីក្រុងជាជនរងគ្រោះ គឺជនដែលគេត្រូវតែសម្លាប់ ដើម្បីលុបលាងកំហឹងតាមអំពើកំណាចឃោរឃៅរបស់គេ ដែលគេបានចិញ្ចឹមក្នុងចិត្តតាំងពីយូរយាណាស់មកហើយ ។

នៅពេលដែលវៀតមិញផ្តើមសង្គ្រាមនៅឆ្នាំ១៩៤៦ ដើម្បីរារាំងកុំឲ្យប្រទេសបារាំងធ្វើអាណានិគមជាថ្មីម្តងទៀត មកលើប្រទេសវៀតណាមនោះ ប្រជាជនកម្ពុជាបានវាយប្រយុទ្ធប្រឆាំងពួកបារាំងរួចមកហើយ នៅក្នុងប្រទេសផ្ទាល់របស់ខ្លួន ។ ទីតាំងដ៏រឹងមាំរបស់គេជាច្រើនមានស្ថិតនៅក្នុងប៉ែកខាងលិចប្រទេស ដែលនៅទីនោះពួកខ្មែរឥស្សរៈមិនមែនកុម្មុយនិស្តបានបោះជំរំរបស់ខ្លួន ដោយមានប្រទេសថៃជាមូលដ្ឋានបង្អែកផង ។ នៅជំនាន់នេះ ប្រជាជនថៃ គឺស្ថិតនៅក្រោមរបបសេរីនិយមប្រឆាំងអាណានិគមនិយមរបស់លោក ព្រីឌី ផាណុំយ៉ុង (Pridi Phanomyong) ។ ត្រូវជំរុញដោយបំណងដ៏ជ្រាលជ្រៅមួយ ដើម្បីដេញកម្ចាត់បណ្តាលអាណានិគមអឺរ៉ុប ចេញពីអាស៊ីភាគអាគ្នេយ៍ ព្រីឌី បានធ្វើឲ្យក្រុងបាងកកទៅជាជម្រកដ៏សុខសាន្តមួយ សម្រាប់ពួកអ្នកប្រយុទ្ធ ដើម្បីឯករាជ្យភាពនៃបណ្តាប្រទេសឡាវ ភូមា វៀតណាម ឥណ្ឌូនេស៊ី និងកម្ពុជា ។

នេះគឺជាមូលដ្ឋានសំខាន់ស្មើអាយុជីវិតសម្រាប់ពួកអ្នកជាតិនិយមឥស្សរៈ ដោយហេតុថាពីប្រទេសថៃទៅពួកគេអាចវាយពួកបារាំងពីក្រោយខ្នង បើសិនជាពួកវៀតមិញបន្តវាយប្រយុទ្ធនៅភាគខាងកើតនោះ ។ នៅក្រុងបាងកក ពួកឥស្សរៈបានសម្របសម្រួលសកម្មភាពផ្សេងៗរបស់ពួកគេជាមួយចលនាឯករាជផ្សេងៗទៀត ដើម្បីទិញស្បៀង អាវុធ និងផ្លាស់ប្តូរពត៌មានទៅវិញទៅមក ។ រាជធានីរបស់ថៃបានក្លាយទៅជាទីក្រុងរឹតតែទាក់ទាញចិត្តថែមទៀត នៅឆ្នាំ១៩៤៦ ពេលដែល ព្រីឌី ត្រូវបង្ខិតបង្ខំឲ្យប្រគល់ទៅប្រទេសកម្ពុជាវិញ នូវបណ្តាខេត្តទាំងឡាយនៅភាគពាយ័ព្យ ក្រោមការគាបសង្កត់របស់ពួកបារាំង និងសហគមន៍អន្តរជាតិៈ នេះគឺជាតម្លៃដែលប្រទេសថៃឡង់ដ៏ ត្រូវតែបង់ដើម្បីបានចូលអង្គការសហប្រជាជាតិ ។ ដូច្នេះជនជាតិថៃ លែងស្តែងឡើងជាអ្នកធ្វើអាណានិគមកិច្ចទៀតហើយតាមការមើលឃើញរបស់ប្រជាជនកម្ពុជា ។

ប៉ុន្តែ នៅខែវិច្ឆិកា ឆ្នាំ១៩៤៧ រដ្ឋប្រហារយោធាមួយរបស់ក្រុមនិយមស្តាំបានផ្តួលរំលំ ព្រីឌី ហើយបង្ខំឲ្យបណ្តាចលនាឯករាជរបស់កម្ពុជាត្រឡប់មកប្រទេសរបស់ខ្លួនវិញ ។ ដំណើរភាន់ប្រែនេះ បានធ្វើឲ្យលក្ខណៈតស៊ូរបស់ប្រជាជនកម្ពុជាដើម្បីឯករាជ្យ និងសង្គ្រាមឥណ្ឌូចិនលើកទី២ ដែលត្រូវបន្តធ្វើតទៅទៀតនោះប្រែប្រួលផងដែរ ។ ដោយគ្មានការគាំទ្ររបស់ថៃ ខ្មែរឥស្សរៈនៅមានប្រភពផ្តល់ជំនួយតែមួយគត់គឺ វៀតមិញកុម្មុយនិស្ត ។ ទាំងសហរដ្ឋអាមេរិក ទាំងប្រទេសអង់គ្លេសគ្មានចង់គាំទ្រពួកឥស្សរៈទេ ។ ពួកឥស្សរៈមួយចំនួនធំក្នុងចំណោមនោះ បានបដិសេធមិនព្រមសហការជាមួយពួកកុម្មុយនិស្តទេ ដោយទៅចូលរួមក្នុងរណសិរ្សរួបរួមមួយប្រឆាំងនឹងពួកបារាំងវិញ ជាហេតុបណ្តាលឲ្យមានការកាត់ផ្តាច់ជាស្ថាពរមួយរវាងបណ្តាចលនាកុម្មុយនិស្តឯករាជ និងមិន

មែនកុម្មុយនិស្តនៅប្រទេសកម្ពុជា ។

ក្នុងពេលដំបូងៗ ពួកកុម្មុយនិស្តវៀតណាមបានសាកល្បងបង្កើតរណសិរ្សឯកភាពមួយ ដោយប្រមូលផ្តុំឡើងវិញនូវក្រុមខ្មែរឥស្សរៈ និងចលនាកុម្មុយនិស្តខ្មែរ ដែលមានកំណើតក្រោមការត្រួតត្រារបស់វៀតណាម ។ ក្នុងពេលដែលមានរដ្ឋប្រហាររបស់ក្រុមនិយមស្តាំថៃ ពួកវៀតណាមបានចាប់ផ្តើមបណ្តុះបណ្តាលជនជាតិកម្ពុជាជាច្រើន ដើម្បីរៀបចំឲ្យទៅជាកម្មាភិបាលសម្រាប់ចលនាកុម្មុនិស្តខ្មែរមួយក្នុងផ្ទៃនៃចលនាកុម្មុយនិស្តឥណ្ឌូចិន ។ កាលបើពួកកុម្មុយនិស្តកម្ពុជាទាំងនេះត្រូវបានបំពាក់បំប៉ន និងរៀបចំរួចហើយពួកគេនឹងបង្កើតរណសិរ្សដ៏ទូលំទូលាយមួយជារបស់ខ្មែរ ដើម្បីវាយប្រយុទ្ធប្រឆាំងនឹងពួកបារាំង ។

ប៉ុន្តែស្ថានការណ៍នៅប្រទេសវៀតណាម បានបង្ខំឲ្យពួកកុម្មុយនិស្តកម្ពុជាបញ្ចេញឲ្យឃើញសកម្មភាពមួយដោយឆាប់រហ័ស ។ នៅឆ្នាំ១៩៤៥ ហូ ជីមិញ បានសម្រេចថា បក្សត្រូវតែផ្តើមធ្វើសកម្មភាពដោយលួចលាក់ ។ បក្សកុម្មុយនិស្តឥណ្ឌូចិនត្រូវបានរំលាយចោលជាផ្លូវការ ដើម្បីធ្វើឲ្យគេចាប់អារម្មណ៍ថា នេះគឺជារណសិរ្សឯកភាពរបស់វៀតមិញមិនមែនពួកកុម្មុយនិស្តទេ ដែលដឹកនាំធ្វើសង្គ្រាមតស៊ូទល់នឹងពួកបារាំងនោះ ។

ដើម្បីពង្រឹងនិមិត្តជាតិនិយមរូបរបស់ចលនា ពួកវៀតណាមបានសម្រេចថា ប្រទេសនីមួយៗក្នុងចំណោមប្រទេសឥណ្ឌូចិនទាំងបី នឹងមានបក្សផ្ទាល់របស់ខ្លួនហើយថាប្រទេសទាំងនោះ នឹងមិនត្រូវប្រមូលឡើងវិញក្នុងផ្ទៃនៃអង្គការតំបន់មួយឡើយ ។ ពួកកុម្មុយនិស្ត ឡាវ និងខ្មែរនឹងមានអង្គការចាត់តាំងផ្ទាល់របស់គេ ហើយដូច្នេះពួកគេអាចនឹងពង្រីកផលប្រយោជន៍របស់គេក្នុងប្រទេសរៀងៗខ្លួន ព្រោះនៅមិនទាន់មានបក្សពិតប្រាកដមួយ ។

ចំពោះគោលបំណងនេះ ពួកកុម្មុយនិស្តកម្ពុជាបានរៀបចំធ្វើមហាសន្និបាតតំណាងទូទាំងប្រទេសលើកទី១ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៥០ ក្នុងព្រៃភ្នំភាគនិរតីប្រទេសកម្ពុជាដោយមានតំណាងជាងពីររយនាក់ ចូលរួម ដែលក្នុងនោះមានព្រះសង្ឃប្រហែលមួយរយអង្គផង ។ គេគោងតែនិយាយដែរថា នៅពេលនោះបក្សកុម្មុយ និស្តឥណ្ឌូចិនមានសមាជិកកម្ពុជាតែសែសិបនាក់ប៉ុណ្ណោះ គឺជាចំនួនតិចតួចណាស់សម្រាប់បង្កើតបក្សមួយដាច់ ផ្សេក ។ ពួកគេបានបង្កើតរណសិរ្សឯកភាពឥស្សរៈ ឬហៅ មគ្គៈឥស្សរៈជាជំនួសវិញ ដែលដឹកនាំដោយអតីតព្រះសង្ឃមួយអង្គព្រះនាម សឺង ង៉ុកមិញ ដែលធ្លាប់ចូលរួមក្នុងបក្សកុម្មុយនិស្តឥណ្ឌូចិន លួចលាក់កាលពីឆ្នាំ ១៩៤៦ ។ ពួកកុម្មុយនិស្តប្រើប្រាស់ពាក្យ ឥស្សរៈក្នុងសេចក្តីសង្ឃឹមបង្រួបបង្រួមក្រោមអំណាចបក្សពួកគេនូវក្រុមទាំងអស់របស់ចលនានេះ ។

ដោយពិត បើសិនជាពួកគេសម្រេចជោគជ័យប្រមូលផ្តុំក្រុមឥស្សរៈមួយចំនួន តូចដែលមិនសូវស៊ីខ្សែគ្នា ក្នុងផ្ទៃរណសិរ្សឯកភាពឥស្សរៈមែននោះ គឺដូចជាពួកគេបង្កើតឲ្យមានភាពមិនច្បាស់លាស់ទូទៅមួយ ដោយហេតុពាក្យឥស្សរៈវាមានន័យថា មិនមែនកុម្មុយនិស្តស្រេចទៅហើយ ។ ម្យ៉ាងទៀតអតីតព្រះសង្ឃ ដែលគាំទ្រនឹងលទ្ធិកុម្មុយនិស្តនោះ បានជ្រើសរើសរហស្សនាមមួយគ្រាប់តាមឈ្មោះមេដឹកនាំជាតិនិយមមិនមែនកុម្មុយនិស្ត សឺង

ងុំកថាញ់ ដែរ ដោយបានថ្លឹងពិចារណាមុនជាស្រេច ។ ភាពមិនច្បាស់រឹតតែកើនឡើងថែមទៀត ។ ដូចដែលជនបដិវត្តម្នាក់ បានប្រកាសឲ្យដឹងពីរឿងនេះនៅដើមដំបូងនៃសង្គ្រាមថា «គេលំបាកនឹងដឹងថា អ្នកណាជាពួកឥស្សរៈពិតប្រាកដ គឺអ្នកបដិវត្តត្រឹមត្រូវបរិសុទ្ធ ហើយអ្នកណាខ្លះជាពួកមនុស្សខូច ជាពួកចោរប្លន់»[៥] ។

នៅឆ្នាំ១៩៥១ ព្រឹត្តិការណ៍ផ្សេងៗបានប្រែក្លាយទៅជាកាន់តែច្របូកច្របល់ឡើងៗសម្រាប់ពួកកុម្មុយនិស្តទាំងអស់ ក្រោយពីការបង្កើតរណសិរ្សឯកភាពឥស្សរៈ ។ នៅឆ្នាំនោះពួកវៀតណាមបានរៀបចំបង្កើតឡើងវិញ នូវបក្សរបស់ខ្លួនជាផ្លូវការក្រោមឈ្មោះថា បក្សពលកវៀតណាមបន្ទាប់ពីធ្វើសកម្មភាពលួចលាក់ប្រាំឆ្នាំ ។ នៅប្រទេសកម្ពុជា បក្សនៅតែរក្សាទុកឈ្មោះចាស់គឺ បក្សកុម្មុយនិស្តឥណ្ឌូចិនដដែល ដូចគ្នានឹងការចាត់ចែងរៀបចំជាអង្គការបក្សមូលដ្ឋាននិងសាខាបក្សចម្រុះខ្មែរ-វៀតណាម ក្រោមការត្រួតត្រារបស់ពួកវៀតណាម និងនៅតែស្ថិតក្នុងសភាពលួចលាក់ថែមទៀត ។

នៅឆ្នាំដដែលនេះ ពួកកុម្មុយនិស្តកម្ពុជា បានសម្រេចចិត្តបង្កើតបក្សផ្ទាល់របស់គេជាលើកដំបូង និងបានប្រកាសពីការបង្កើតបក្សប្រជាជនបដិវត្តខ្មែរជាសាធារណៈផង ។ ពួកកុម្មុយនិស្តវៀតណាមបានតាក់តែងលក្ខន្តិកៈផ្សេងៗសម្រាប់បក្សប្រជាជនបដិវត្តខ្មែរ និងគម្រោងកម្មវិធីនយោបាយមួយ ដែលពួកវៀតណាមបានបញ្ជូនទៅឲ្យកម្ពុជាដើម្បីធ្វើការបកប្រែជាភាសាខ្មែរ និងឲ្យសេចក្តីយល់ព្រម ។ ពួកវៀតណាមបានវិនិច្ឆ័យថា «បក្សប្រជាជាជនបដិវត្តខ្មែរ ពុំមែនជាបក្សឈានមុខរបស់វណ្ណៈកម្មករទេ (ជាការបញ្ជាក់លក្ខណៈគំរូនៃបក្សកុម្មុយនិស្តមួយ) ប៉ុន្តែជាបក្សឈានមុខរបស់ប្រជាជាតិដែលប្រមូលសមាសភាពអ្នកស្នេហាជាតិ និងអ្នកចម្រើននិយមទាំងអស់នៃប្រជាជន»[៦] ។

របនាសម្ព័ន្ធមួយបែបនោះ អាចក្លាយទៅជាបក្សកុម្មុយនិស្តពិតប្រាកដមួយបាន លុះណាតែបន្ទាប់ពីបានចាត់វិធានការផ្សេងៗទៀត ជាពិសេសការបើកមហាសន្និបាតស្ថាបនិកមួយ ដោយប្រកាសពីការរៀបចំបក្សម៉ាក្សលេនីនមួយ ហើយក្រោយមកទៀតគឺការសរសេរប្រវត្តិសាស្ត្ររបស់បក្សមួយផង ។ ប៉ុន្តែ ពួកកុម្មុយនិស្តកម្ពុជាពុំអាចចាត់វិធានការទាំងនេះ មុនរយៈពេល៩ឆ្នាំឡើយ ដែលក្នុងរយៈកាលនោះ បក្សប្រជាជនបដិវត្តខ្មែរ ពុំដែលអនុវត្តបានតាមលក្ខន្តិកៈ នៃបក្សកុម្មុយនិស្តកម្ពុជាឯករាជសោះឡើយ ទាំងតាមទ្រឹស្តី ទាំងការប្រតិបត្តិតាមលទ្ធិកុម្មុយនិស្ត ។ ម្យ៉ាងទៀត បន្ទាប់ពីឆ្នាំ១៩៥១ ពួកកុម្មុយនិស្តខ្មែរត្រូវបានបញ្ចូលទៅក្នុងបក្សកុម្មុយនិស្តឥណ្ឌូចិនលួចលាក់វិញ ព្រោះថា ការនៅរួមក្នុងបក្សប្រជាជនបដិវត្តខ្មែរពុំបានធ្វើឲ្យអ្នកទាំងនោះ ទៅជាសមាជិកនៃបក្សមែនទែនមួយឡើយ ។ ស្ថានការណ៍ស្រពេចស្រពិលនេះបានសាបព្រោះមិនត្រឹមតែភាពមិនច្បាស់ក្នុងចិត្តគំនិត របស់ពួកកុម្មុយនិស្តកម្ពុជានៅជំនាន់នោះប៉ុណ្ណោះទេ ប៉ុន្តែ ក្រោយមករឿងនេះបានបណ្តាលឲ្យមានការជជែកតទល់គ្នាយ៉ាងពុះកញ្ជ្រោល នៅពេលដែលពួកខ្មែរឈ្លោះទាស់ទែងគ្នា ពីរឿងដើមកំណើតនៃបក្សកុម្មុយនិស្តរបស់ ។ តើបក្សនេះ កើតចេញពីបក្សកុម្មុយនិស្តឥណ្ឌូចិនដោយផ្ទាល់នៅឆ្នាំ១៩៥១ ហើយដែលស្ថិតនៅ

ក្រោមបង្គាប់ពួកវៀតណាមមែនឬ? ឬមួយបក្សនេះត្រូវបានបង្កើតឡើងពិតប្រាកដនៅឆ្នាំ១៩៦០ ដោយពួកកម្ពុជា ដែលពឹងផ្អែកយ៉ាងតិចតួចបំផុតលើប្រទេសវៀតណាម? ។

សង្គ្រាមប្រឆាំងនឹងពួកបារាំង គឺត្រូវគ្រប់សង្កត់នៅភាគពាយ័ព្យត្រូវដោយក្រុមឥស្សរៈមិនមែនកុម្មុយនិស្តផ្សេងៗ ដែលនាំមុខការប្រយុទ្ធតស៊ូមួយផ្នែកយ៉ាងធំនៃប្រទេស ។ ពួកគេបានសម្របសម្រួលសកម្មភាពរបស់គេជាញឹកញយជាមួយរណសិរ្សឯកភាពឥស្សរៈ ដែលត្រួតត្រាដោយពួកកុម្មុយនិស្ត ជារឿងបន្ថែមឲ្យរឹតតែមានការភាន់ច្រឡំថែមទៀត ។ ពួកឥស្សរៈខ្លះជាពួកចោរប្លន់ធម្មតា អ្នកខ្លះទៀតជាអ្នកប្រយុទ្ធតស៊ូដ៏មោះមុតដើម្បីឯករាជ្យភាព ។ នេះគឺជាវាសនារបស់ប្រទេសកម្ពុជា ដែលគ្មានមេដឹកនាំណាមួយមានសមត្ថភាពប្រមូលផ្តុំចលនាទាំងអស់នេះ ដោយពួកឥស្សរៈមិនមែនពួកកុម្មុយនិស្ត គ្មានជឿទុកចិត្តពួកកុម្មុយនិស្តខ្មែរ ដែលស្ថិតនៅក្រោមចំណុះពួកវៀតណាមឡើយ ។

ដោយពួកបារាំងធ្វើសង្គ្រាមក្នុងឥណ្ឌូចិនទាំងមូលនោះ វាជាការត្រឹមត្រូវណាស់ ដែលពួកអ្នកប្រយុទ្ធតស៊ូដើម្បីសេរីភាពរបស់ប្រជាជនវៀតណាម កម្ពុជា និងឡាវរួបរួមគ្នាវាយតបទៅវិញ ។ ហើយតើមានសាស្ត្រាចារ្យប្រសើរជាងគេណាខ្លះអាចមានប្រៀបលើបណ្តាមិត្តរួមអាវុធរបស់ ហូ ជីមិញ ដែលការបដិវត្តន៍ ខែសីហា ឆ្នាំ១៩៤៥ បានបង្ហិនបង្ហោចប្រទេសវៀតណាមទាំងមូល ហើយដែលបានឈ្នះពីជ័យជម្នះមួយ នៅជ័យជម្នះមួយ? ប៉ុន្តែពួកវៀតណាមបានដឹកនាំ និងបញ្ចុះបញ្ចូលពួកកម្ពុជាឲ្យធ្វើតាមលើសពីសាស្ត្រាចារ្យទាំងនោះ ទៅទៀតថា តើនៅពេលណា ឬរបៀបយ៉ាងដូចម្តេច ដើម្បីបង្កើតអង្គការចាត់តាំង និងធ្វើការវាយប្រយុទ្ធរបស់ពួកគេ ។ បន្តនៅសង្គ្រាមនៅកម្ពុជា និងឡាវ គោងតែលៃទៅតាមជយ័ជម្នះនៅវៀតណាមដែរ ។ ភាពខ្លាំងលើសលប់ជាងគេរបស់វៀតណាមមានលក្ខណៈជាក់ច្បាស់ណាស់ ហើយបង្ហាញឲ្យឃើញដោយផ្នែកនូវអ្នកប្រយុទ្ធតស៊ូមួយចំនួនតូចនៃបណ្តាកងឯកភាពទ័ពឥស្សរៈនិយមកុម្មុយនិស្ត និងវៀតមិញផង ។ យ៉ាងច្រើនបំផុត មានតែប្រជាជនកម្ពុជា ៥៧០០នាក់ប៉ុណ្ណោះ ដែលប្រយុទ្ធតស៊ូជាមួយពួកកុម្មុយនិស្ត ប្រឆាំងនឹងពួកបារាំង[៧] ។

សរុបទៅកងកម្លាំងឥស្សរៈទាំងអស់មានចំនួនប្រមាណដប់ពាន់ថ្វាយនាក់ ប៉ុន្តែ ពុំមែនប្រមូលផ្តុំគ្នាជាអង្គការតែមួយទេ ។ មេដឹកនាំឥស្សរៈខ្លះ នឹកព្រួយបារម្ភដោយឥតលាក់លៀមអំពីភាពនៅក្រោមអំណាចពួកកុម្មុយនិស្តវៀតណាម និងផលវិបាកផ្សេងៗរបស់ខ្លួនចំពោះអនាគតទៀតផង ។ មេដឹកនាំជាព្រះសង្ឃអភិរក្សនិយមម្នាក់បានបញ្ចេញឲ្យគេដឹងនូវការព្រមាននេះថា «យើងមិនត្រូវបណ្តោយឲ្យពួកវៀតមិញ ឈ្លានពានប្រទេសយើងទេ ទោះបីជាពួកនោះជាអ្នកស្នេហាជាតិក្នុងប្រទេសផ្ទាល់របស់គេក៏ដោយ»[៨] ។ វាមានការវាយប្រយុទ្ធដាច់ឡែកជាច្រើនរបស់ពួកឥស្សរៈប្រឆាំងនឹងវៀតមិញដែរ ហើយពួកកុម្មុយនិស្តខ្លះត្រូវបានគេសម្លាប់ ។ ប៉ុន្តែ ពួកវៀតមិញជាមួយ អ្នកប្រយុទ្ធ ៣.០០០នាក់ យ៉ាងហោច គឺជាក្រុមដែលខ្លាំងបំផុត ពិតមែនបណ្តុះបណ្តាលក៏ដោយ ។ ម្យ៉ាងទៀត វៀតមិញបានផ្ទេរបញ្ជាការដ្ឋានយោធារបស់ខ្លួនពីប្រទេសវៀតណាមមកភាគ

អាគ្នេយ៍ប្រទេសកម្ពុជាវិញ ដើម្បីគេចឲ្យផុតពីកណ្ដាប់ដៃពួកបារាំង ។ ពួកកុម្មុយនិស្តកម្ពុជារឹតតែមិនទុកចិត្តថែមទៀត ។ អ្នកតំណាងមួយរូប ដែលបានទៅចូលរួមសន្និសីទចាត់តាំងបង្កើតរណសិរ្សឯកភាពឥស្សរៈបានរំឭកថា ខ្លួនបានបន្ទុំក្រុមខ្មែរបោះឆ្នោតប្រឆាំងនឹងបំណងបង្កើតសហព័ន្ធកុម្មុយនិស្តឥណ្ឌូចិនមួយ ដែលស្ថិតនៅក្រោមការត្រួតត្រារបស់វៀតណាម ។

វៀតមិញផ្ទាល់ ពុំបោះបង់គំនិតសហព័ន្ធនេះចោលឡើយ ហើយបានប្រកាស ក្នុងឯកសារមួយរបស់បក្សនៅចុងឆ្នាំ១៩៥១ ថា “បក្សវៀតណាមនៅរក្សាសិទ្ធិត្រួតពិនិត្យពីលើសកម្មភាពផ្សេងៗ របស់បណ្ដាបក្សជាបងប្អូននៅកម្ពុជានិងនៅឡាវតទៅទៀត... ប៉ុន្តែ តទៅមុខទៀតបើសិនជាលក្ខខណ្ឌផ្សេងៗអនុគ្រោះ បក្សបដិវត្តន៍ទាំងបីនៅប្រទេសវៀតណាម ឡាវ និងកម្ពុជា អាចនឹងរួបរួមគ្នាដើម្បីបង្កើតជាបក្សតែមួយបាន គឺបក្សសហព័ន្ធវៀតណាម-ខ្មែរ-ឡាវ”[៩] ។ ក៏ប៉ុន្តែ ពួកឡាវបានបង្កើតបក្សមួយដាច់ដោយឡែកនៅឆ្នាំ១៩៥៥ ហើយពួកកម្ពុជាមិនអាចបើកមហាសន្និបាតបង្កើតបក្សរបស់ខ្លួន នៅមុនឆ្នាំ១៩៦០បានទេ ។ នៅរយៈកាលនោះ បណ្ដាបក្សជា “បងប្អូន” បានផ្លាស់ប្តូរយ៉ាងច្រើន នៅពេលពិនិត្យមើលសំណើមួយបែបនោះ ។

នៅពេលដែល សាឡុត ស ត្រឡប់មកពីប្រទេសបារាំងវិញក្នុងឆ្នាំ១៩៥៣ គឺគាត់គ្រាន់តែជានិស្សិតម្នាក់ដែលធ្លាប់បណ្ដុះបណ្ដាលនៅបរទេសប៉ុណ្ណោះ ដោយបានទៅរួបរួមជាមួយប្រជាជនកម្ពុជារាប់ពាន់នាក់ ដែលកំពុងប្រយុទ្ធដើម្បីឯករាជ្យជាតិ ។ គាត់បានក្លាយទៅជាសមាជិករបស់កងទ័ពកុម្មុយនិស្ត ប៉ុន្តែ មានទទួលឋានៈនាទីមួយក្រោមបង្គាប់គេនៅឡើយ ព្រោះថា ចលនានេះ មានមេដឹកនាំដែលមានការចាត់តាំងយ៉ាងត្រឹមត្រូវស្រេចទៅហើយ ក្រោមការត្រួតត្រារបស់វៀតមិញ ។ ពួកកុម្មុយនិស្តបានវាយប្រយុទ្ធប្រកៀកស្មាគ្នាជាមួយកម្លាំងជាតិនិយមឥស្សរៈជាញឹកញយ ហើយបានបង្កើតរណសិរ្សមួយរួចមកហើយ ក្នុងសេចក្ដីសង្ឃឹមថានឹងយកពួកឥស្សរៈទាំងនោះ មកដាក់ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់គេ ។

រឿងនេះពុំដែលបានសម្រេចឡើងសោះ ។ គ្មានចលនាណាមួយបញ្ចេញពីរជួររបស់ខ្លួននូវមេដឹកនាំម្នាក់ដែលគេទទួលស្គាល់ជាបិតាឯករាជ្យរបស់ប្រទេសឡើយ ។ នៅឆ្នាំ១៩៥៣ ការវាយប្រយុទ្ធដើម្បីសេរីភាពគឺនៅតែដឹកនាំដោយឥស្សរជនទាំងឡាយ ដែលប្រយុទ្ធតស៊ូដាច់ៗពីគ្នានៅឡើយ នៅតែបែងចែករវាងឥស្សរៈ និងពួកអ្នកបដិវត្ត នៅតែបែងចែកភូមិសាស្ត្រគ្នា និងនៅតែមិនសូវបានទទួលការគាំទ្រពីពួកយុទ្ធិកជន នៅភ្នំពេញ ថែមទៀត ។ មួយឆ្នាំក្រោយមក នៅពេលដែលសង្គ្រាមត្រូវចប់ ដោយសារសន្និសីទក្រុងហ្សឺណែវ នៅឆ្នាំ១៩៥៤ ចលនាទាំងអស់នៅតែបែកបាក់គ្នាជានិច្ច ។ ដោយកាន់កាប់កន្លែងទំនេរ សម្ដេច ព្រះនរោត្តម សីហនុ បានចរចាបញ្ហាឯករាជ្យជាមួយពួកបារាំង ហើយបានឲ្យគេសារខ្លួនឯងជាបិតាឯករាជ្យជាតិ ។ ព្រះអង្គបានទទួលជ័យជម្នះលើពួកកុម្មុយនិស្ត ហើយបានធ្វើឲ្យពួកឥស្សរៈភាគច្រើនពេញចិត្តគាំទ្របុព្វហេតុរបស់ទ្រង់ទៀតផង ។

ក្នុងកំឡុងពេលដប់ឆ្នាំដែលមានបន្ត បន្ទាប់ពីការវិលត្រឡប់របស់គាត់ពីទីក្រុងប៉ារីសមកវិញ សាឡុត ស និងពួកកុម្មុយនិស្ត កម្ពុជាដទៃទៀត នៅទីបំផុត បានបង្កើតបក្សមួយនៅភ្នំពេញ ហើយបានបញ្ចូលក្នុងបក្សនូវអ្នកប្រយុទ្ធតស៊ូសេសសល់ទាំងអស់ ដែលស្ថិតនៅតាមជនបទនានា ។ ពួកគេបានតាំងឲ្យ ប៉ុល ពត ធ្វើជាមេដឹកនាំផ្ទាល់របស់គេ ដោយមិនសូវមានការជួយឧបត្ថម្ភពីពួកវៀតណាមឡើយ ។ ដោយបានបង្កើតបក្សនេះ ដែលមានលក្ខណៈជាតិដ៏ទូលំទូលាយ ពួកកុម្មុយនិស្តបានបំពេញនូវលក្ខខ័ណ្ឌដែលគេត្រូវធ្វើជាដំបូងដោយខានមិនបានមុននឹងឈមមុខតតាំងនឹងរបបរបស់សម្តេច ព្រះនរោត្តម សីហនុ ហើយក្រោយមកជាមួយរបប លន់ នល់ ទៀត ។

ការស្គាល់ដឹងពីរបៀបដែលកិច្ចការនេះត្រូវបានធ្វើឲ្យសម្រេចឡើង គឺមានសារសំខាន់ណាស់ ដើម្បីស្វែងយល់ពីបែបផែន ដែលពួកខ្មែរក្រហមដឹកនាំគ្រប់គ្រងប្រទេសនៅពេលណាមួយដែលបានកាន់អំណាច ។ មួយផ្នែកធំនៃប្រវត្តិសាស្ត្រនេះ គឺជាប្រវត្តិដែលគេមិនសូវស្គាល់ និងពិបាកយល់ ៖ ពួកកុម្មុយនិស្តរបស់កម្ពុជាបានរង់ចាំដល់ឆ្នាំ១៩៦៧ ទើបចាប់ផ្តើមការតស៊ូដោយអាវុធក្នុងប្រទេសរបស់ខ្លួនហើយ ទាល់តែមកដល់ឆ្នាំ១៩៧០ ទើបពួកគេចូលប្រឡូកក្នុងសង្គ្រាមឥណ្ឌូចិនដែរ ។ ពួកគេបានរស់នៅមួយភាគធំបំផុតក្នុងសភាពលួចលាក់ កាលពីបណ្តាឆ្នាំមុនៗ ដោយបង្កើតបក្សរបស់គេជាសម្ងាត់ ដោយបង្កើតឲ្យមានការនៅក្នុងឱវាទ (ខាងនយោបាយ) វាងគ្នាឯង និងជាមួយសម្ព័ន្ធមិត្តកុម្មុយនិស្តរបស់គេគឺប្រទេសចិន និងវៀតណាម ដោយធ្វើប្រតិកម្មតបតចំពោះល្បិចកលនិងដំណើរបត់បែនផ្សេងៗនៃសង្គ្រាម ដែលកំពុងកញ្ច្រោលវក់វីនៅជុំវិញពួកគេ ។

ពួកខ្មែរក្រហមបាត់ចាត់ទុករយៈកាលនេះថា ជាភាពបន្តគ្នាមួយនៃអំពើក្បត់ដូចគ្នានឹងពួកអ្នកទាំងឡាយដែលពួកគេធ្លាប់ជឿទុកចិត្ត ក៏ដូចពួកអ្នកទាំងឡាយដែលពួកគេធ្លាប់ស្តាប់បង្គាប់ដែរ ។ ពួកគេយល់ឃើញថា ត្រូវពួកកុម្មុយនិស្តបរទេសខ្លះរារាំងជាឧបសគ្គ នឹងត្រូវមិនឲ្យតម្លៃដោយជនរួមជាតិឯង ជាពិសេស សម្តេច ព្រះនរោត្តម សីហនុ ដែលប៉ុនប៉ងកម្ទេចពួកគេចោលតាមរយៈប៉ូលិសរបស់ព្រះអង្គ ។ ទីបំផុត នៅពេលដែលពួកគេដណ្តើមអំណាចបាន ដោយកម្លាំងពួកខ្មែរក្រហមបានចាប់ផ្តើមបង្ហាញសក្តិភាពឲ្យក្រុមម្ខាង និងក្រុមមួយទៀត ព្រមទាំងខ្លួនឯងផ្ទាល់ផងឃើញថា ពួកគេសមនឹងទទួលបដិសណ្ឋារកិច្ចប្រសើរជាងគេមួយ ។ បើទុកជាមានការវិនិច្ឆ័យពីអ្នកដទៃទៀតក៏ដោយ ក៏ពួកគេចាប់ផ្តើមបង្ហាញឲ្យឃើញថា ពួកគេគឺជាពួកកុម្មុយនិស្តប្រសើរលើសគេនៅអាស៊ីនេះ ។

បណ្តាឆ្នាំទាំងនេះដែលមហាជនមិនសូវដឹង ហាក់ដូចជារូបភាពមួយឆ្លុះបញ្ចាំងឲ្យឃើញប្រវត្តិសាស្ត្ររបស់ប្រទេសជាតិដែរ បក្សកុម្មុយនិស្តកម្ពុជាដ៏តូច ដែលគេមិនឲ្យតម្លៃក្នុងប្រទេសកម្ពុជាដ៏តូចដែលគេមើលងាយនឹងរកឃើញកន្លែងប្រកបដោយកិត្តិនាមមួយ ក្នុងប្រវត្តិសាស្ត្រនៃការបដិវត្តន៍ ។

ពេលដែលគាត់មកដល់ក្រុងភ្នំពេញ សាឡុត ស គឺជាសមាជិកម្នាក់របស់កុម្មុយនិស្តបារាំង ហើយពុំមានចំណងទាក់ទងជាមួយបក្សរបស់កម្ពុជាណាមួយឡើយ លើកលែងតែគណបក្សប្រជាធិបតេយ្យ ដែលកំពុងស្ថិតក្នុងសភាពចុះដុនដាបយ៉ាងខ្លាំង ។ ភ្លាមនោះ គាត់បានស្វែងរកខ្សែរយៈទាក់ទងជាមួយចលនាឥស្សរៈកុម្មុយនិស្ត

ក្នុងគោលបំណងចូលរួមធ្វើការវាយប្រយុទ្ធផ្សេងៗ ។ គឺក្នុងបណ្ដាខែចុងក្រោយនៃសង្គ្រាម ហើយយុវនិស្សិតនេះគ្មានមានគំនិតអ្វីក្រៅតែគិតថា គាត់នឹងបម្រើបុព្វហេតុបដិវត្តន៍ ក្នុងរយៈពេលមួយយ៉ាងខ្លីប៉ុណ្ណោះ ។

ស បានដឹងរឿងរ៉ាវរបស់ចលនាតស៊ូកម្ពុជាតិចតួចណាស់ ក្នុងរយៈកាលនៃការស្នាក់អាស្រយ័នៅក្រុងប៉ារីសរបស់គាត់ ថ្វីបើមានការរួមប្រជុំខ្លះ ដែលគេធ្វើដោយលួចលាក់ក៏ដោយ ។ គាត់បែរជាមានភាពងាយស្រួលបំផុតក្នុងការទទួលពត៌មានពីការបដិវត្តរបស់ ហូ ជីមិញ នៅប្រទេសវៀតណាម និងពីជ័យជម្នះរបស់ ម៉ៅ សេទុងនៅប្រទេសចិនទៅវិញ ។ អនាគត ប៉ុល ពត បានចុះពីនាវាជាន់ទឹកដីក្រុងប៉ារីស គឺបន្ទាប់ពី ម៉ៅ បានទទួលជោគជ័យយ៉ាងធំ ហើយនៅពេលដែលគាត់ចេញដំណើរពីទីក្រុងប៉ារីសត្រឡប់មកវិញ បដិវត្តន៍របស់ចិនបានដុតបញ្ឆេះទ្រឹស្ដីដ៏ងប់ងុលរបស់ក្រុមនិយមឆ្វេងបារាំងឲ្យឆេះឆួលឡើងដែរ ។ បណ្ដាអ្នកនិពន្ធនិយមលទ្ធិកុម្មុយនិស្ដបាននាំយកពីប្រទេសចិននូវសេចក្ដីរាយការណ៍ធ្វើឲ្យមានអភិមានះដំបូងៗ គឺពួកកសិករដែលជាអ្នកដឹកនាំប្រទេស វិចារណញ្ញាណត្រូវបានជំនួសការបង្ខិតបង្ខំឆ្លងតាមរយៈ ការជជែកពិភាក្សាគ្នា ទិតៀន និងស្វ័យទិតៀន ។ល ។ ការបដិវត្តរបស់ចិនបាននាំមកនូវភាពធូរស្រាលមួយ ដែលមកដល់ត្រូវកាលៈទេសៈបន្ទាប់ពីអ្វីៗដែលធ្វើឲ្យរជួលចិត្តដូចរឿងប្រលោមលោករបស់បដិវត្តន៍រុស្ស៊ី ដែលប្រើអំណាចផ្ដាច់ការ និងដែលគិតថា ខ្លួនជាអ្នកធ្វើបដិវត្តន៍មុនគេនៅលើពិភពលោកនេះ ។

ពេលមកដល់ ប្រទេសវិញ សាឡុត ស បានទៅរស់នៅជាមួយបងប្រុសរបស់គាត់ឈ្មោះ ឡុត សួង ហើយ ស បាននិយាយប្រាប់បងគាត់ពីកម្មសិក្សារបស់ខ្លួនក្នុងកងពលស្ថាបនាមួយរបស់យូហ្គោស្លាវី ព្រមទាំងសម័យប្រជុំសម្ងាត់មួយរបស់ ពួកអ្នកតស៊ូកម្ពុជានៅប្រទេសអេស្ប៉ាញទៀតផង ។ ស បាននិយាយសរសើរសហភាពសូវៀតមិនដាច់ពីមាត់ ដែលធ្វើឲ្យបងបង្អស់របស់គាត់ងឿងឆ្ងល់ក្នុងចិត្តជាខ្លាំង ។ ពេលដែល ស រស់នៅជាមួយគាត់នៅក្រុងភ្នំពេញ ហើយទៅរៀនសូត្រនៅអនុវិទ្យាល័យបច្ចេកទេសនោះ ស បានចំណាយពេលស្ទើរតែទាំងស្រុងទៅលើការ សិក្សារបស់ខ្លួន –ទោះជាយ៉ាងណាក៏ដោយ ក៏ សួង ជឿជាក់លើដែរ ។ ជាច្រើនឆ្នាំក្រោយមក សួង បាននិយាយថា «វាពុំចេះដើរញែ៉ស្រី ហើយពុំចេះផឹកស្រាទេ ។ វាខំប្រឹងរៀនសូត្រណាស់... គឺជាក្មេងប្រុសដ៏ល្អម្នាក់»[១០] ។

កាលនៅក្រុងភ្នំពេញស មិនសូវបានប្រើពេលវេលា ដែលគាត់អាចមានទាំងប៉ុន្មានឡើយ ពេលដែលស្ថានការណ៍ប្រទេសមានសភាពគួរឲ្យអស់សង្ឃឹម ដូចគ្នានឹងស្ថានភាព ដែលគាត់បានទាយទុកកាលពីឆ្នាំមុនក្នុងអត្ថបទមួយ ដែលមានចុះហត្ថលេខា «ខ្មែរដើម» នោះដែរ ។ មួយខែក្រោយការវិលត្រឡប់របស់គាត់មកដល់រាជធានីគាត់ដឹងថា សម្ដេច ព្រះនរោត្ដម សីហនុ បានចេញដំណើរទៅកាន់ប្រទេសបារាំងក្នុងគោលបំណងចាប់ផ្ដើមធ្វើកិច្ចចរចាផ្សេងៗ ស្ដីពីឯករាជ្យរបស់ប្រទេស ។ វាមានភាពអាសន្នដែលចាប់ផ្ដើមមានគេដឹងឮសុសសាយ ។ គណបក្សប្រជាធិបតេយ្យបានបង្ហាញឲ្យឃើញថា ខ្លួនគ្មានសមត្ថភាពបញ្ឈប់ព្រះមហាក្សត្រក្នុងគោលបំណងរាំងរាមិនឲ្យ

សម្តេច ព្រះនរោត្តម សីហនុ ប្រកាសខ្លួនជាបិតាឯករាជ្យបានឡើយ បើទុកជា ស និងអ្នកផ្សេងៗទៀតប៉ុនប៉ងដឹកនាំពួកប្រជាធិបតេយ្យឲ្យប្រកាន់ជំហរដ៏អង់អាចមួយ និងនិយមឆ្វេងក៏ដោយ ។

គឺ «កន្លែងទំនេរ» នេះហើយដែល សាឡុត ស ធ្លាប់ព្រួយបារម្ភខ្លាំងមែនទែន ។ ពួកឥស្សរៈមិនមែនកុម្មុយនិស្តធ្លាប់និយាយថា និងដេញកម្ចាត់ពួកអាណានិគមនិយមបារាំងចេញពីប្រទេស ។ រណសិរ្សឥស្សរៈ ដែលត្រួតត្រាដោយពួកវៀតណាម ក៏ចង់វាយបណ្តេញពួកបារាំងព្រមទាំងចក្រពត្តិនិយមអាមេរិកាំង ចេញពីប្រទេសដែរ ហើយរៀបចំ «ប្រជាធិបតេយ្យប្រជាមានិត» របស់កម្ពុជាវិញ ។ ក្នុងការឃោសនាមួយផ្នែកធំរបស់ខ្លួន រណសិរ្សនេះ បានទុកបញ្ហាស្តេចមួយអន្លើ ហើយចូលចិត្តនិយាយពីឯកភាពរបស់ពួកអ្នកប្រយុទ្ធតស៊ូជាតិវៀតណាម កម្ពុជា និងឡាវ និងការបង្កើតសហព័ន្ធមួយរវាងប្រជាជាតិទាំងបីជាង ។ ក្នុងប្រវត្តិសាស្ត្រតំបន់ វាពុំដែលមានលទ្ធិភាពគ្រប់គ្រងជាសហព័ន្ធប្រភេទនេះទេ ហើយពិតណាស់ពុំមែនសហព័ន្ធ ដែលអំណាចត្រូវបានបែងចែកស្មើៗគ្នានោះឡើយ ។ រណសិរ្សបានទិតៀន សម្តេច ព្រះនរោត្តម សីហនុ ចំពោះប្រព័ន្ធនយោបាយសក្តិភូមិរបស់ព្រះអង្គ និងភាពពឹងផ្អែកពាក់របស់ព្រះអង្គចំពោះពួកបារាំង ប៉ុន្តែ ពុំមែនដោយរបៀបល្អិតល្អន់ និងដាច់អហង្ការដូចដែល ស ចង់បាននោះទេ ។

យុវបុរស ស មានគំនិតគិតអំពីការបដិវត្តន៍របស់ចិននិងរបស់វៀតណាមដែរ នៅពេលដែលគាត់ធ្វើការទាក់ទងជាមួយពួកកុម្មុយនិស្តនៅភាគខាងកើតប្រទេសកម្ពុជានោះ ។ បងប្រុសរបស់គាត់ម្នាក់ទៀតក្នុងចំណោមបងប្អូនប្រុសរបស់គាត់ សាឡុត ឆាយ បានទទួលរ៉ាប់រង ណែនាំឲ្យគេស្គាល់ ហើយ ស បានប្តូរប័ណ្ណបក្សកុម្មុយនិស្តបារាំង របស់គាត់ដោយប្តូរយកប័ណ្ណបក្សកុម្មុយនិស្តឥណ្ឌូចិន ដែលធ្វើសកម្មភាពលួចលាក់វិញ ក្នុងសាខាមួយរួមមានជនជាតិកម្ពុជាដប់នាក់ និងវៀតណាមដប់នាក់ ។

ការពើបប្រទះជាលើកដំបូងជាមួយនឹងនយោបាយបដិវត្តន៍ គឺមានសភាពគ្រោតគ្រាតណាស់ ពីព្រោះគាត់ត្រូវគេដាក់ឲ្យធ្វើការនៅក្នុងកងផលិតមួយ ហើយគេបានប្រគល់ឲ្យគាត់ទទួលខុសត្រូវកនូវអ្វី ដែលគាត់ចាត់ទុកថាប្រៀបដូចជាការងាររបស់កម្មករដូច្នេះដែរ ។ ប្អូនថ្លៃរបស់គាត់គឺ ខៀវ ធីរិទ្ធ ប្រពន្ធ អៀង សារី បាននិយាយរៀបរាប់ថា ស នឹកឈឺចិត្តជាខ្លាំង ដែលគាត់ត្រូវគេចាត់ទុកដូចជាកសិករសាមញ្ញម្នាក់ ព្រោះថា មេៗរបស់គាត់សុទ្ធតែជាតិវៀតណាម និងពុំមែនជនជាតិកម្ពុជាដូចគាត់ទេ ។ នាងបាននិយាយថា «នេះជាការសាកល្បងមួយដែលធ្វើឲ្យគាត់នឿយលំបាកយ៉ាងខ្លាំង ។ ពួកវៀតមិញបានដាក់និស្សិតក្រុងប៉ារីស ទាំងអស់ឲ្យធ្វើការដោយឡែកតែឯង ដោយឲ្យទទួលបន្ទុកចិញ្ចឹមមាន់ទា លាងសម្អាតបង្គន់ ។ សាឡុត ស មានករណីកិច្ចសែងអាចម៍ទៅចាក់ចោលជំនួសពួកវៀតណាម គេមិនប្រគល់កិច្ចការនយោបាយឲ្យគាត់ធ្វើទេ»[១១] ។ សេចក្តីថ្លែងការណ៍មួយរបស់កម្ពុជាប្រជាធិបតេយ្យនៅឆ្នាំ១៩៨០ បាននិយាយរំពុករឿងរ៉ាវកាលពីជំនាន់នោះថា «បញ្ញវន្តស្នេហាជាតិដែលត្រឡប់មកពីប្រទេសបារាំង និងប្រទេសដទៃទៀតត្រូវគេទុកឲ្យនៅកៀនជញ្ជាំង ។ ពួកគេមិនត្រឹមតែមិនបាន

ទទួលនូវការអប់រំ ដែលអាចឲ្យគេក្លាយទៅជាកម្មាភិបាលនិងជាអ្នកដឹកនាំប៉ុណ្ណោះទេ តែនូវត្រូវបានទទួលភារកិច្ច ដែលគ្មានទាក់ទងទៅនឹងជំនាញរបស់គេបន្តិចបន្តួចសោះ កិច្ចការទាំងនេះគឺដាំស្លដឹកជញ្ជូនជីដាក់ដំណាំ ។ល។» ។

ពួកវៀតណាមមានការនឹកឃើញខុសគ្នាមួយ ហើយបើតាមពួកគេថា ស បានរៀនពី «ចលនាមហាជននៅតាមមូលដ្ឋាន និងរៀបចំគណៈកម្មាធិការឥស្សរៈផ្សេងៗក្នុងកម្រិតថ្នាក់ភូមិ»[១២] ។

ពួកកម្ពុជា ដែលមិនបានរៀនសូត្រនៅក្រុងប៉ារីស ដែលមិនធ្លាប់បានចាត់ទុកខ្លួនឯងជាមេដឹកនាំ នៃការបដិវត្តន៍មួយរបស់កម្ពុជាដែលឯករាជ្យដាច់ពីគេ បានសម្តែងឲ្យឃើញថាពួកគេមិនសូវខ្វល់ព្រួយនឹងអំណាចគ្រប់សង្កត់របស់វៀតណាមប៉ុន្មានឡើយ ។ សម័យនោះ វ៉ន វ៉េត យុវនិស្សិត ដែលជាមេរៀបចំបាតុកម្មនៅខេត្តកាលពីឆ្នាំ១៩៥២ បានក្លាយទៅជាសមាជិករណសិរ្សឯកភាពឥស្សរៈកុម្មុយនិស្ត ។ គាត់នឹងក្លាយទៅជាមេដឹកនាំខ្មែរក្រហមម្នាក់ដូច ស ដែរ ។ ជាច្រើនឆ្នាំក្រោយមក វ៉េត បានសរសេរថា គាត់មានសេចក្តីរីករាយនឹងធ្វើការជាមួយពួកវៀតណាមយ៉ាងខ្លាំង «ខ្ញុំសប្បាយចិត្ត ខ្ញុំជឿជាក់លើការឃោសនារបស់គេ ដែលតាមរយៈនោះថា ពួកគេមកនេះដើម្បីជួយយើង ។ ពួកវៀតណាមបានកាន់កាប់តំណែងសំខាន់ៗនៅគ្រប់កន្លែង ។ យើងដែលជាខ្មែរយើងគ្រាន់តែចូលរួមជួយឧបត្ថម្ភពួកគេប៉ុណ្ណោះ ។ ប្រការទាំងអស់នេះ ពុំបានធ្វើឲ្យខ្ញុំព្រួយបារម្ភឡើយពីព្រោះ ពួកគេនិយាយតែពីស្មារតីអន្តរជាតិនិយម ពីមនសិការការងាររវាងខ្មែរ-វៀតណាម ហើយខ្ញុំក៏យល់ឃើញដូចពាក្យសម្តី ដែលប្រកបដោយសុភនិច្ឆ័យរបស់ពួកគេដែរ»[១៣] ។

តាមភាពទំនងជាគួរឲ្យជឿជាក់ថា ក្នុងចំណោមពួកកម្ពុជាទាំងអស់ ពួកវៀតណាមបានទំនុកបម្រុង សាឡុត ស មិនជាប្រសើរ ហើយក៏មិនជាអន់ប៉ុន្មានដែរថ្វីបើពួកកម្ពុជាដទៃៗទៀតបានក្លាយទៅជាមនុស្សស្មោះត្រង់បំផុតចំពោះវៀតមិញ តាមរយៈបទពិសោធន៍ខាងសង្គ្រាមរបស់គេក៏ដោយ ព្រោះថានៅពេលនោះវាគ្មានអ្នកណាផ្សេងទៀត ក្រៅពីពួកវៀតណាមជួយពួកគេឡើយ ។ ហើយសារសំខាន់នៃបញ្ហាផ្សេងៗ ដែលមានចរិតជាតិនិយមចំពោះអ្នកដែលត្រូវមកកាន់ចង្កូតចលនាកុម្មុយនិស្តកម្ពុជាជាថ្មីទៀតនោះ ហាក់ដូចជាមានស្តួចស្តើងណាស់បើប្រៀបធៀបទៅនឹងបញ្ហាពិបាកដោះស្រាយ ដែលសម្តេច ព្រះនរោត្តម សីហនុ បានចោទឲ្យមានឡើង ។ នៅពេលដែល សាឡុត ស ប្រយុទ្ធតស៊ូក្នុងព្រៃភ្នំ សម្តេចក៏បានចាប់ផ្តើមធ្វើចលនាមួយ ដែលទ្រង់ហៅថា «ព្រះរាជបូជនីយកិច្ច ទាមទារឯករាជ្យ» ដែរ ហើយដែលផ្តាច់ដើងពួកកុម្មុយនិស្តថែមទៀត ។

នៅឆ្នាំ១៩៥៣ សម្តេច ព្រះនរោត្តម សីហនុ បានប្រកាសប្រើប្រាស់ច្បាប់អាជ្ញាសឹកដោយសំអាងលើការកើនឡើងនៃសង្គ្រាមរឹតតែខ្លាំង និងបញ្ចប់ការសាកពិសោធន៍ជាមួយរដ្ឋសភាជាតិដែលហាក់ ដូចជាចងដៃចងជើងគូប្រជែងទាំងឡាយរបស់ព្រះអង្គដែរ ជាពិសេស ក្នុងផ្នែកគណបក្សប្រជាធិបតេយ្យ ។ បន្ទាប់មក ព្រះអង្គបានចាប់ផ្តើមព្រះរាជដំណើរ មួយព័ទ្ធជុំវិញពិភពលោកដោយបានទទួលផលប្រយោជន៍ពីការធ្វើសន្និសីទកាសែតដ៏គគ្រឹកគគ្រេងមួយ ដើម្បីបញ្ចុះបញ្ចូលឲ្យពួកបារាំងប្រគល់អំណាចថ្វាយព្រះអង្គ ក្នុងគោលបំណងបញ្ចៀសមិនឲ្យពួក

កុម្មុយនិស្តដណ្តើមយកប្រទេសកម្ពុជាដោយកម្លាំង ។ សម្តេចបានទាញហេតុផលថា ព្រះអង្គនឹងស្ថាបនាកម្ពុជាមួយឯករាជ្យអព្យាក្រឹត ដោយហាមមិនឲ្យកងទ័ពទាំងអស់ប្រើប្រាស់ទឹកដីរបស់កម្ពុជាឡើយ ។

សម្តេច ព្រះនរោត្តម សីហនុ បានបញ្ជាក់អះអាងថា បើប្រទេសកម្ពុជាដណ្តើមបានឯករាជ្យ "ដោយសន្តិវិធី" ពួកខ្មាំងកុម្មុយនិស្តលែងមានលេសសម្រាប់បន្តការវាយប្រយុទ្ធរបស់ខ្លួននៅក្នុងប្រទេសតទៅទៀតហើយ ហើយព្រះអង្គបានសង្កត់បញ្ជាក់ថា បើសិនជាព្រះអង្គបានដឹកនាំគ្រប់គ្រងកម្ពុជាមួយឯករាជ្យព្រះអង្គនឹងបដិសេធមិនវាយប្រយុទ្ធ ឬដើម្បីប្រឆាំងនឹងពួកវៀតមិញឡើយ ។ នេះជាគំនិតដ៏សំខាន់សម្រាប់ពួកបារាំងដែលកំពុងប្រឈមមុខនឹងបរាជ័យផ្នែកយោធាមួយ នៅប្រទេសវៀតណាម ។

សម្តេចបានវិលត្រឡប់មកពីព្រះរាជដំណើរពន្ធ័ជុំវិញពិភពលោករបស់ព្រះអង្គវិញហើយបានចេញដំណើរទៅ "កន្លែងនិរទេស" ក្នុងខេត្តបាត់ដំបងភាគពាយ័ព្យប្រទេសកម្ពុជា ។ ព្រះអង្គមានទាហាន និងប៉ូលិសជិត បីពាន់នាក់ នៅជាប់ជាមួយ ដែលបង្កើតបានទៅជាការបង្ហាញកម្លាំងមួយគួរឲ្យចាប់អារម្មណ៍ក្រៃលែង ។ នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ក្រុងប៉ារីសបានយល់ព្រមផ្តល់ឯករាជ្យឲ្យព្រះអង្គ ។ ដោយត្រូវទ្រុឌទ្រោមដោយសារសង្គ្រាមនៅប្រទេសវៀតណាម និងនៅតែព្រួយបារម្ភអំពីការបាត់បង់ប្រទេសកម្ពុជា ប្រទេសបារាំងបានផ្ទេរអំណាចសំខាន់ៗរបស់ខ្លួនមកឲ្យសម្តេច ព្រះនរោត្តម សីហនុ ។ ដែលបានប្រកាសដោយផ្ទាល់ព្រះអង្គឯងថា ជាបិតាឯករាជ្យកម្ពុជា ។

បន្ទាន់ភ្លាមនោះ ក្នុងចលនាឥស្សរៈកើតមានការរត់ចោលជួរយ៉ាងសម្បើម ។ ពួកអ្នកតស៊ូមិនមែនកុម្មុយនិស្តភាគច្រើនបានទទួលស្គាល់លក្ខណៈស្របច្បាប់នៃឯករាជ្យរបស់សម្តេច ព្រះនរោត្តម សីហនុ ។ ពួកកុម្មុយនិស្តខ្លះ បានដាក់អាវុធចុះដើម្បីវិលត្រឡប់ទៅផ្ទះសម្បែងរបស់ខ្លួនវិញ ប៉ុន្តែអ្នកដទៃទៀត ដែលមានចំនួនយ៉ាងច្រើននោះយល់ថា ការប្រឹងប្រែងទាំងប៉ុន្មានរបស់ខ្លួន គឺហាក់ដូចជាជួយក្រាលផ្លូវសម្រាប់សម្តេច ព្រះនរោត្តម សីហនុទៅវិញ ហើយបានថ្កោលទោសដោយកំហឹងចំពោះ"ឯរាជ្យរបៀបចំអក" នេះទៀតផង ។

ពួកវៀតមិញ បានទទួលជោគជ័យរបស់ខ្លួនយ៉ាងសម្បើមនៅដៀនបៀនភូ ដែលបានបង្ខំឲ្យពួកបារាំងព្រមធ្វើកិច្ចចរចាជាមួយ ។ នៅចុងខែមីនា ឆ្នាំ១៩៥៤ គឺពីរខែមុនសន្និសីទចាប់បើកធ្វើនៅទីក្រុងហ្សឺណែវនាខែឧសភា កងទ័ពចម្រុះឥស្សរៈរួមនឹងពួកវៀតមិញបានចាកចេញពីប្រទេសវៀតណាម ជ្រៀតចូលក្នុងភាគពាយព្យប្រទេសកម្ពុជា ដើម្បីវាយប្រហារ "ស្តេចអាយ៉ង" ដែលឥឡូវនេះត្រូវចោទប្រកាន់ថា ជាអ្នកនៅក្រោមអាណាព្យាបាលរបស់សហរដ្ឋអាមេរិក ។ ដោយការវាយឆ្មក់មិនឲ្យដឹងខ្លួនមុនរបស់កងទ័ពទាំងនោះ សម្តេចព្រះនរោត្តម សីហនុ បានដឹកនាំការវាយបកជាប់រហូតមួយដោយផ្ទាល់ព្រះអង្គ ។ ការប្រយុទ្ធតទល់គ្នានេះដែលប្រហែលជាគ្មានសារសំខាន់អ្វីសោះនោះ បានអនុញ្ញាតឲ្យសម្តេចថ្លែងប្រកាសនៅក្រុងហ្សឺណែវថា ពួកកុម្មុយនិស្តខ្មែរពុំអាចទាមទារឲ្យមានមូលដ្ឋានប្រមូលផ្តុំទ័ពមួយនៅកម្ពុជាបានឡើយ ។ ព្រះអង្គយល់ច្បាស់ណាស់

ពីរឿងនេះ ពួកឥស្សរៈកុម្មុយនិស្តបានធ្វើតាមយុទ្ធសាស្ត្ររបស់វៀតមិញ ដោយសុខចិត្តផ្ដល់អាទិភាពចំពោះជ័យជម្នះនៅប្រទេសវៀតណាម ហើយមិនយកចិត្តទុកដាក់ការពារទីតាំងផ្សេងៗរបស់ពួកគេក្នុងប្រទេសផ្ទាល់របស់ខ្លួនផងទេ ។

រឿងរ៉ាវអាក្រក់ដែលនិយាយទុកជាមុនដោយ សាឡុត ស បានក្លាយទៅជាការពិត ។ ជាច្រើនឆ្នាំក្រោយមក នៅក្នុងផ្ទៃចលនាកុម្មុយនិស្តរបស់កម្ពុជា គាត់បានជជែកតវ៉ាប្រឆាំងនឹងភាពស្ថិតនៅក្រោមចំណុះគេទាំងស្រុងនៃការបដិវត្តន៍របស់ខ្មែរ តាមគោលដៅទូលំទូលាយបំផុតរបស់ការបដិវត្តន៍វៀតណាម ។ នៅពេលដែលពួកកុម្មុយនិស្តខ្មែរទៅដល់ក្រុងហ្សឺណែវ ពួកគេបានរកឃើញចំណុចខ្វះដែល«ស្ដេចអាយ៉ង» ធ្លាប់បានប្រើកលឧបាយយ៉ាងប៉ិនប្រសប់ ។

សន្និសីទក្រុងហ្សឺណែវ ត្រូវបានកោះប្រជុំឡើងដើម្បីដាក់កាលកំណត់ពេលមួយ ចំពោះការប្រយុទ្ធនៅប្រទេសកូរ៉េ និងនៅឥណ្ឌូចិន ។ សង្គ្រាមនៅកូរ៉េត្រូវគេដាក់បញ្ចូលក្នុងរបៀបវារៈដំបូង ចំណែករឿងសង្គ្រាមនៅឥណ្ឌូចិន ត្រូវគេយកមកដោះស្រាយនៅខែឧសភា ឆ្នាំ១៩៥៤ ។ ប្រទេសដែលចូលរួមក្នុងសន្និសីទមានបារាំង អង់គ្លេស សហរដ្ឋអាមេរិក សហភាពសូវៀត ចិន និងប្រទេសឥណ្ឌូចិនទាំងបីគឺ វៀតណាម ឡាវ និងកម្ពុជា ។ បើសង្គ្រាមនៅវៀតណាម បណ្ដាលឲ្យមានការខ្វល់គំនិតខ្លាំងជាងគេ បញ្ហាប្រទេសកម្ពុជា ស្ដែងឲ្យឃើញរឹតតែលំបាកជាងការដែលបណ្ដាប្រទេសកម្មុយនិស្តនានា ធ្លាប់គិតទុកជាមុនទៅទៀត ។

កាលពីឆ្នាំមុន ប្រទេសបារាំងបានយល់ព្រមផ្ដល់ឲ្យប្រទេសកម្ពុជា នូវអំណាចស្វយ័តសំខាន់ៗជាច្រើនដែលកម្ពុជាអាចមានសិទ្ធិគ្រប់គ្រងខ្លួនឯងតាមផ្លូវច្បាប់ ហើយសន្និសីទក្រុងហ្សឺណែវជាអ្នកបំពេញបន្ថែមអំពីដំណើរប្រព្រឹត្តទៅនៃការអនុវត្តសិទ្ធិអំណាចនេះតទៅទៀត ដោយហេតុថា ប្រទេសត្រូវបានគេទទួលស្គាល់ក្នុងឋានៈជាប្រជាជាតិមួយឯករាជ្យរួចហើយ ។ ក្នុងសន្និសីទនេះ ពួកកុម្មុយនិស្តខ្មែរពុំបានចូលរួមដូចសមភាគីវៀតណាម និងឡាវ ដែលជាដៃគូរបស់ខ្លួនឡើយ ។ នៅក្រោយពេលសន្និសីទចប់ ពួកកុម្មុយនិស្តកម្ពុជាបានបាត់បង់អ្វីៗទាំងអស់ ។

ពួកគេពុំមានមូលដ្ឋានសម្រាប់ផ្ទុំទ័ពនៅក្នុងប្រទេសខ្លួនឡើយ ពួកគេបាត់បង់សិទ្ធិកាន់អាវុធ ឬចូលរួមក្នុងគណៈកម្មាធិការ ដែលរៀបចំឡើងដើម្បីពិនិត្យមើលរបៀបអនុវត្តន៍កិច្ចព្រមព្រៀងដែលមានពួកគេ ដែលជាអ្នកប្រយុទ្ធចុងក្រោយនៃចលនាដែលនឹងត្រូវរាយការណ៍ដែរ ។ ពួកកុម្មុយនិស្តឡាវ ត្រូវបានយល់ព្រមឲ្យមានខេត្តពីរនៅជាប់ព្រំប្រទល់ជាមួយប្រទេសវៀតណាម ព្រមទាំងសិទ្ធិគ្រប់បែបយ៉ាង ដែលគេបដិសេធមិនផ្ដល់ឲ្យពួកកុម្មុយនិស្តខ្មែរ ។ ប៉ុន្តែ ពួកកុម្មុយនិស្តវៀតណាមបានខាតបង់លើតុចរចានូវទឹកដីមួយផ្នែកធំដែលពួកគេវាយដណ្ដើមបាន ហើយបានសុខចិត្តយល់ព្រមឲ្យមានការបែងចែក«ជាបណ្ដោះអាសន្ន»មួយ នូវប្រទេសរបស់គេផង ។ ក្នុងចំណោមពួកអ្នកដឹកនាំឥណ្ឌូចិនទាំងអស់ មានតែសម្ដេច ព្រះនរោត្តម សីហនុ ទេ ដែលជាអ្នកឈ្នះច្រើនជាងគេ

ទុកណាជា ព្រះអង្គស្ទើរតែគ្មានបានធ្វើអ្វីសោះ ដើម្បីរារាំងប្រយុទ្ធទល់នឹងអាណានិគមនិយមបារាំងក៏ដោយ ។

សម្រាប់ពួកកុម្មុយនិស្តខ្មែរ ការខាតបង់ដីធំនៅសន្និសីទក្រុងហ្សឺណែវត្រូវបានចារឹកក្នុងដំពូកនៃអំពើក្បត់ជាបន្តបន្ទាប់មួយចំពោះសម្ព័ន្ធមិត្តតូចតាចទាំងឡាយ ។ សហភាពសូវៀតបានពន្យុះពួកកូរ៉េឲ្យលោតចូលក្នុងសង្គ្រាម ដើម្បីដេញកម្ចាត់សហរដ្ឋអាមេរិកពីប្រទេសកូរ៉េ បន្ទាប់មកបានស្នើសុំឲ្យប្រទេសចិនជួយស្រោចស្រង់ស្ថានការណ៍នេះផង ដោយបង់តម្លៃជីវិតប្រជាជនចិនយ៉ាងច្រើនសន្ធឹកសន្ធាប់ ជាពិសេស គឺជីវិតរបស់កូនប្រុសម៉ៅ សេទុង ។ ដោយក្លាយទៅជារដ្ឋ «ឈ្លានពានគេ» ប្រទេសចិនបានបាត់បង់ភ័ព្វសំណាងទាំងអស់ក្នុងការចូលជាសមាជិកអង្គការសហប្រជាជាតិ ។ ដោយត្រូវធ្វើឲ្យចុះទន់ខ្សោយ និងត្រូវគំរាមគំហែងដោយការហ៊ុំព័ទ្ធខាងយោធាពីសហរដ្ឋអាមេរិក ពួកចិនបានធ្វើទៅតាមការទទូចសុំទាំងបន្ទិរបស់ពួកសូវៀត ដោយប្តេជ្ញាចិត្តទទួលស្គាល់ការបែងចែកប្រទេសកូរ៉េជាពីរ ។ ពួកចិនបានសម្រេចចិត្តធ្វើតាម ហើយក្នុងដំណាក់កាលទីពីរបានជួយធ្វើឲ្យជញ្ជីងថ្លឹងទៅម្ខាង ជាគុណប្រយោជន៍ដល់ការបែងចែកប្រទេសវៀតណាមមួយទៀត ដើម្បីរារាំងការតាំងមូលដ្ឋានទ័ពរបស់អាមេរិកនៅតាមព្រំដែនចិន-វៀតណាម ។

ម៉្យាងទៀតពួកវៀតណាម ដែលត្រូវគាបសង្កត់យ៉ាងខ្លាំងដោយពួកចិន និងយ៉ាងតិចៗដោយពួកសូវៀតក៏ត្រូវប្រឈមមុខទល់នឹងការគំរាមកំហែងចូលធ្វើអន្តរាគមន៍របស់អាមេរិកាំងនៅឥណ្ឌូចិន ។ នេះជាការគំរាមកំហែងគួរឲ្យព្រឺខ្លាចបំផុតជាមួយនឹងទីបញ្ចប់នៃសង្គ្រាមនៅកូរ៉េ ដោយបើកឲ្យកងទ័ពអាមេរិកាំង ដែលកំពុងជាប់ដៃប្រយុទ្ធនៅទីនោះរួចផុតពីចំណងដែរ ហេតុនេះវៀតណាមបានសុខចិត្តយល់ព្រមប្រគល់ភាគខាងត្បូងប្រទេសវៀតណាម និងប្រទេសកម្ពុជាជាថ្នូរនឹងប្រទេសវៀតណាមខាងជើង និងមួយផ្នែកនៃប្រទេសឡាវ ដែលមានព្រំប្រទល់ជាប់នឹងប្រទេសខ្លួន ។ ដូច្នេះពួកកុម្មុយនិស្តកម្ពុជាត្រូវតែលះបង់អ្វីៗគ្រប់បែបយ៉ាងទាំងអស់ ដោយគ្មានបានទទួលអ្វីជាថ្នូរមកវិញឡើយ ។ ម៉្យាងវិញទៀត ក្រោយសន្និសីទហ្សឺណែវ សេចក្តីអំពាវនាវផ្សេងៗ របស់ពួកកុម្មុយនិស្តអំពី«អន្តរជាតិនិយមវណ្ណៈអធន» មានអត្ថន័យតិចតួចណាស់សម្រាប់ពួកមេដឹកនាំខ្មែរក្រហម ។

ដោយពួកកុម្មុយនិស្តខ្មែរគ្មានបានទទួលអ្វីសោះនោះ ទាំងពួករុស្ស៊ី ទាំងពួកចិន ទាំងពួកវៀតណាម ក៏ពុំទាន់ប្រថុយប្រថានជួយពួកគេដែរ ។ ដូច្នេះពួកខ្មែរត្រូវធ្វើការជ្រើសរើសរវាងការសាកល្បងត្រដររស់នៅក្នុងប្រទេសកម្ពុជា ឬសុខចិត្តធ្វើតាមសំណើរបស់វៀតណាម ដោយនិរទេសខ្លួនទៅកាន់ប្រទេសវៀតណាមខាងជើងសិន ដើម្បីរង់ចាំសង្គ្រាមរំដោះជាតិមួយផ្សេងទៀត ដែលជួយគាំទ្រដោយពួកវៀតណាម ។ សន្និសីទក្នុងហ្សឺណែវបានអះអាងបន្ថែមឲ្យពួកកម្ពុជាដឹងនូវបទពិសោធន៍ផ្សេងៗដែលមានពីមុនជាមួយ ពួកបារាំង ពួកថៃ និងពួកជប៉ុនដែលគេធ្លាប់បានបង្ហាញឲ្យឃើញរួចមកហើយ គឺពួកគេពុំអាចទុកចិត្តពួកបរទេសទៀតទេ ។ មនោសញ្ចេតនាស្អប់ជនបរទេស ដែលធ្វើឲ្យឈឺចាប់ខ្លាំងឡើង ហើយដែលពួកគេធ្វើឲ្យរីកធំក្រោយមកទៀត គឺពុំមែនគ្មានមូលហេតុនោះទេ ។

សហភាពសូវៀតបានចាកចេញពីក្រុងហ្សឺណែវជាមួយកេរ្តិ៍ឈ្មោះយ៉ាងប្រសើរមួយលើឆាកនយោបាយអន្តរជាតិ និងការទាក់ទងជាមួយប្រទេសបារាំងល្អប្រសើរជាងមុន ។ ពួកចិន និងពួកវៀតណាម បានទទួលនូវការផុតរលត់ (ជាបណ្តោះអាសន្ន) នៃសង្គ្រាម ប៉ុន្តែពួកកម្ពុជាក៏ពុំបានទទួលអ្វីដូចតែគ្នា គ្រាន់តែគេបានព្រមព្រៀងគ្នាធានាថា នឹងពុំមានមូលដ្ឋានកងទ័ពអាមេរិកាំងណាមួយត្រូវបាន តាំងនៅប្រទេសកម្ពុជាប៉ុណ្ណោះ ។ ការគ្មានមូលដ្ឋានទ័ពណាមួយត្រូវបានបង្កើតក្រោមរបបសម្តេច ព្រះនរោត្តម សីហនុ គឺពីព្រោះសហរដ្ឋអាមេរិកប្រមាថសម្តេចពុំមែន ដោយការសន្យាដែលធ្វើនៅក្រុងហ្សឺណែវទេ ។

ដោយពុំពេញចិត្តនឹងលទ្ធផលទាំងឡាយរបស់សន្និសីទហ្សឺណែវ និងដោយខ្លាចបារម្ភទទួលរងបរាជ័យផ្សេងៗទៀត ពួកកុម្មុយនិស្តវៀតណាមបានប្រកាន់យកការសម្រេចចិត្តមួយ ដែលតែងតែធ្វើឲ្យពួកគេខ្វល់ចិត្តក្នុងរយៈពេលបីទសវត្សរ៍ជាបន្តបន្ទាប់មកទៀត ។ ក្នុងគោលបំណងគាំពារសម្តេច ព្រះនរោត្តម សីហនុ ផងចលនាកុម្មុយនិស្តរបស់កម្ពុជាផង និងធ្វើឲ្យចលនានេះយកតាមគំរូរបស់គេ ពួកវៀតណាមបានបែងចែកចលនានេះដូចតទៅ ៖ សឺង ង៉ុកមិញ មេដឹកនាំសំខាន់ជាងគេនិងយុទ្ធជនខ្មែរប្រហែលមួយពាន់នាក់ ត្រូវនិរទេសខ្លួនទៅវៀតណាមខាងជើង មានភាគច្រើនបានបន្លំខ្លួនជាមួយកងទ័ពវៀតមិញមុនចាកចេញពីប្រទេសកម្ពុជា ទៅតាមសខសំខាន់ៗនៃកិច្ចព្រមព្រៀងក្រុងហ្សឺណែវ ។ ពួកកម្ពុជាខ្លះក្នុងចំណោមពួកកម្ពុជាទាំងនេះ បានទទួលបញ្ជាឲ្យចាកចេញពីប្រទេសកម្ពុជាពីមេបញ្ជាការខ្មែរឥស្សរៈ ឬវៀតមិញរបស់គេ ហើយអ្នកខ្លះទៀតបានចាកចេញដោយស្ម័គ្រចិត្ត ។ អៀង លីម យុទ្ធជនវ័យក្មេងម្នាក់ ក្នុងចំណោមយុទ្ធជនក្មេងៗទាំងនេះ នៅចាំបានថា[១៨] ពួកវៀតណាមបានសួរគាត់ថា តើអ្នកឯងចង់ធ្វើដំណើរទៅវៀតណាមខាងជើង ដើម្បី«ហាត់រៀនវិជ្ជាយោធា» របស់ខ្លួនទេ ។ គាត់បានយល់ព្រមតាមការស្នើដោយគ្មានគិតពីពេលវេលា ដែលត្រូវទៅរៀនសូត្រនៅទីនោះមានរយៈពេលប៉ុន្មានផងទេ ។

ពួកកម្ពុជាទាំងនោះបានស្លៀកឯកសណ្ឋានជាទាហានវៀតណាម បន្ទាប់មក ត្រូវគេរំលែកចូលជាមួយកងឯកភាពទ័ពផ្សេងៗរបស់ក្រុងហាណូយ ។ ក្នុងវៀតណាមដប់នាក់មានខ្មែរម្នាក់ឈរតម្រង់ជួរលើកំពង់ផែមួយនៅភាគខាងត្បូងវៀតណាម ដើម្បីឲ្យគណៈកម្មាធិការអន្តរជាតិខាងបទត្រួតត្រា ដែលបង្កើតឡើងដោយសន្និសីទហ្សឺណែវធ្វើការត្រួតពិនិត្យ ។ លីមបាននិយាយរៀបរាប់ថា គេបានបង្គាប់បញ្ជាពួកកម្ពុជាទាំងនោះថា មិនត្រូវនិយាយពាក្យអ្វីទាំងអស់ បើសិនមានគេមកសួរថា តើពួកអ្នកឯងចេញដំណើរទៅភាគខាងជើងដោយចិត្តឯងមែនឬ? អ្នកទាំងអស់បានរក្សាភាពស្ងៀមស្ងាត់ ហើយពួកខ្មែរទាំងនោះបានឡើងជិះលើនាវាប៉ូឡូញមួយគ្រឿងដែលដឹកយកពួកគេឆ្ពោះទៅវៀតណាមខាងជើង ។ គេបានសន្យាចំពោះលីមថា គាត់នឹងបានវិលត្រឡប់មកប្រទេសវិញពីរឆ្នាំក្រោយយ៉ាងយូរ ។ ប៉ុន្តែ គាត់ត្រូវរស់នៅវៀតណាមខាងជើងរហូតដល់ទៅដប់ប្រាំមួយឆ្នាំឯណោះ ។ គាត់បានរៀនភាសាវៀតណាម និងបន្តរៀនសូត្រវិជ្ជាបច្ចេកទេសមួយ ហើយត្រូវគេដាក់បញ្ចូលទៅ

ក្នុងកងទ័ពរបស់វៀតណាមខាងជើង ដែលនៅទីនោះគាត់បានទៅជាគ្រូបង្ហាត់បង្រៀនទាហានជ្រើសរើសថ្មី បន្ទាប់មក ត្រូវគេចាត់តាំងឲ្យទៅធ្វើការនៅសាលាយោធាសឺនតៃ ។ ហេតុនេះ សមាជិកជាងពាក់កណ្ដាលនៃចលនាកុម្មុយនិស្តកម្ពុជា ដែលមិនរឹងប៉ឹងត្រូវគេដាក់ពង្រាយពាសពេញប្រទេសវៀតណាមខាងជើង ដោយមិនអាចបង្កើតកងទ័ពបដិវត្តន៍ផ្ទាល់របស់គេ និងមិនអាចជួយឧបត្ថម្ភបណ្ដាសមមិត្តរួមអាវុធរបស់គេ ដែលស្ថិតនៅក្នុងប្រទេសកម្ពុជាឡើយ ។

ក្នុងចំណោមអ្នកដែលស្ថិតនៅក្នុងប្រទេស គឺមាន សាឡុត ស ដែរ ។ គាត់ប្រហែលជាទទួលបានសេចក្ដីរាប់អានពីពួកវៀតណាមហើយមើលទៅ ដោយហេតុថាគាត់ស្ថិតនៅក្នុងចំណែកពួកខ្មែរម្ភៃនាក់ ដែលត្រូវបានសម្រាំងសម្រាប់កិច្ចការនយោបាយដោយលួចលាក់មួយនៅក្នុងប្រទេស ។ នៅឆ្នាំ១៩៥៤ ពេលដែលសង្គ្រាមផុតរលត់ទៅ បានលបចូលមកក្រុងភ្នំពេញជាសម្ងាត់ ដោយក្លែងជាអង្គរក្សនាយទាហានវៀតណាមម្នាក់[១៥] ។ ប៉ុន្តែ ទាំងរូបគាត់ ទាំងពួកកុម្មុយនិស្តដទៃទៀត ដែលស្ថិតនៅក្នុងប្រទេសកម្ពុជា ពុំត្រូវបានទទួលការផ្គត់ផ្គង់គ្រឿងអាវុធ (លុយកាក់) សម្រាប់ការពារខ្លួនទល់នឹងសម្ដេច ព្រះនរោត្តម សីហនុ ឡើយ ។ ការបែកបាក់គ្នានៃចលនាកុម្មុយនិស្តនៅឆ្នាំ១៩៥៥ ដោយមនុស្សមួយពាន់នាក់ នៅក្នុងប្រទេសកម្ពុជា និងមួយពាន់នាក់នៅវៀតណាមខាងជើង បានបង្កើតឲ្យមានការខ្វែងគំនិតខាងផ្នែកនយោបាយមួយយ៉ាងជ្រាលជ្រៅ ដែលបានផ្ទុះឡើងព្រមជាមួយអំពើសាហាវយង់ឃ្នង ម្ភៃឆ្នាំក្រោយមកទៀត ។

ភាគច្រើននៃប្រជាជនកម្ពុជាជឿថា សង្គ្រាមចប់ហើយ ។ ប្រទេសកម្ពុជាជាប្រទេសឯករាជ្យ កងទ័ពបរទេសទាំងអស់ -កងទ័ពអាណានិគមបារាំងនិងវៀតមិញ- បានយល់ព្រមសុខចិត្តចាកចេញពីប្រទេស តាមកិច្ចព្រមព្រៀងនៃសន្និសីទក្រុងហ្សឺណែវ ។ ការបោះឆ្នោតដោយសេរីប្រហែលជាប្រព្រឹត្តទៅនៅឆ្នាំ១៩៥៥ ។ តាមការណែនាំរបស់ក្រុងហាណូយ ពួកកុម្មុយនិស្តកម្ពុជាបានប្រមូលផ្ដុំគ្នាឡើងវិញនៅទីក្រុងភ្នំពេញ ដើម្បីកំណត់ទិសដៅនយោបាយមួយ ដែលប្លែកពីមុនទាំងស្រុងសម្រាប់ចលនារបស់គេ ។

ក្រុងភ្នំពេញជាទឹកដីថ្មីមួយ (ដែលនៅស្អាតបរិសុទ្ធមិនទាន់មានអ្នកណាចូលធ្វើសកម្មភាព) សម្រាប់ពួកកុម្មុយនិស្តភាគច្រើន ។ កន្លងមកពួកនេះ ពុំធ្លាប់ដែលមានមូលដ្ឋាននៅក្នុងរាជធានីទេ ហើយភាគច្រើនជាអ្នកមិនធ្លាប់ដែលស្គាល់ទីក្រុងទាល់តែសោះ ។ តាមពិតនៅក្នុងប្រទេសមានតែជនកុម្មុយនិស្តខ្មែរប្រាកដចំនួនហាសិបប្រាំនាក់ប៉ុណ្ណោះ សែសិបជាមាជិកបក្សកុម្មុយនិស្តឥណ្ឌូចិន, ដប់នាក់មកពីបក្សកុម្មុយនិស្តបារាំង ហើយបី ឬបួននាក់មកពីបក្សថៃ[១៦] ។ មេដឹកនាំនយោបាយរបស់គេគឺ សឺង ង៉ុកមិញ បានតាំងទីស្នាក់អាស្រ័យនៅទីក្រុងហាណូយ ដែលនៅទីនោះគាត់បានក្លាយទៅជាប្រភេទនិមិត្តរូបក្បាលនាវាមួយ ។ ស៊ីវ ហេង មនុស្សលេខពីរ និងជាមេបញ្ជាការកងទ័ពឥស្សរៈកុម្មុយនិស្តបានទទួលការចាត់ចែងដឹកនាំចលនា និងទទួលការខុសត្រូវតាមជនបទ ។ ទូ សាមុត

មនុស្សលេខបីទទួលបន្ទុកការផ្សាយឃោសនា កសាងបក្សក្នុងរាជធានីនិងទីរួមខេត្តផ្សេងៗ ។ អ្នកទាំងពីរនេះដឹកនាំគ្រប់គ្រងជនជាតិខ្មែរជាង មួយពាន់នាក់ដែលគេអាចចាត់ទុកជាអ្នកដើរតាម ឬគាំទ្រចលនាប៉ុណ្ណោះ ។ នេះគឺជាក្រុមកម្រិតតូចមួយ ដែលអាចនឹងត្រូវវាយប្រហារបំផុត ។

ក្នុងរាជធានី ពួកកុម្មុយនិស្តបានប្រកាន់យកយុទ្ធសាស្ត្រតស៊ូមួយ លើរណសិរ្សបើដូចគ្នានឹងយុទ្ធសាស្ត្ររបស់សមមិត្តគេនៅទីក្រុងព្រៃនគរដែរ ដែលទន់ខ្សោយដូចគ្នានៅក្នុងទីក្រុងនេះ ។ នេះជាការគិតគូរមួយអំពីនយោបាយផ្លូវផ្ទឹត និងការរៀបចំអង្គការសហជីពនានា ។ ពួកកុម្មុយនិស្តបានបង្កើតបក្សនយោបាយ ដោយមានច្បាប់អនុញ្ញាតត្រឹមត្រូវគឺក្រុមប្រជាជន ដើម្បីចូលរួមការបោះឆ្នោតឆ្នាំ១៩៥៥ ។ ពួកបញ្ញវន្ត និងពួកអ្នកនយោបាយនិយមឆ្វេង ដែលគេស្គាល់ថា ជាមនុស្សរបស់ចលនានេះបានរួមដៃគ្នាធ្វើសកម្មភាពជាមួយក្រុមប្រជាជនដោយចេញមុខ ។ អ្នកឯទៀតៗដូចជា សាឡុត ស ជាដើម បានក្លាយទៅជាគ្រូបង្រៀន អ្នកនិពន្ធ អ្នកកាសែត ក្នុងគោលបំណងបិទបាំងការចូលរួមក្នុងបក្ស និងភារកិច្ចរបស់គាត់ ដែលស្ថិតនៅត្រង់ការជ្រើសរើសសមាជិកថ្មីៗទៀត និងបង្កើតក្រុមតស៊ូនយោបាយផ្សេងៗក្នុងចំណោមពួកនិស្សិត ពួកកម្មករ និងពួកបញ្ញវន្តនៅក្រុងភ្នំពេញ ។ ក្រុមទីបី ដែលមានចិត្តនឹងលទ្ធិកុម្មុយនិស្ត បានទទួលបញ្ជាឲ្យបំពេញបេសកកម្មធ្វើការក្នុងផ្ទៃរបបសម្តេច ព្រះនរោត្តម សីហនុ ដោយផ្ទាល់ ។

គេលែងនិយាយពីសង្គ្រាមទៀតហើយ ។ ពួកកុម្មុយនិស្តកម្ពុជា និងពួកអ្នកមានសមានចិត្តរបស់គេមានតែសេចក្តីសង្ឃឹមមួយប៉ុណ្ណោះចាប់ផ្តើមបង្កើតចលនាមួយ ដែលនឹងទាញយកផលប្រយោជន៍ពីការបោះឆ្នោតឆ្នាំ១៩៥៥ ហើយនិងទទួលបានសមាជិកថ្មីៗថែមទៀត តាមរយៈកិច្ចប្រឹងប្រែងរៀបចំរចនាសម្ព័ន្ធទាំងឡាយរបស់ពួកគេ ។ តាមកិច្ចព្រមព្រៀងនៃសន្និសីទក្រុងហ្សឺណែវពួកគេពុំមានទាំងសិទ្ធកាន់អាវុធ ទាំងការធ្វើសកម្មភាពវិទ្ធង្សនាឡើយ ។ ម្យ៉ាងទៀត ពួកគេក៏ពុំអាចគ្រោងគិតការប្រឈមមុខដោយអាវុធមួយចំពោះសម្តេច ព្រះនរោត្តម សីហនុ ដែលជាអ្នកគ្រប់គ្រងលើកងទ័ព និងប៉ូលិសដែរ ។

បញ្ហាមួយទៀត ដែលមានលក្ខណៈទូទៅបានទៅជាបញ្ហាធ្វើឲ្យអំពល់មួយដែរចំពោះពួកកុម្មុយនិស្ត ដើម្បីអ្វីទៅដែលពួកគេត្រូវវាយប្រហារតែគ្នាឯង? ពុំមែនដើម្បីឯករាជ្យទាំងក៏ពុំមែនដើម្បីលិទ្ធិប្រជាធិបតេយ្យដែរ ព្រោះពួកបារាំងលែងធ្វើជាចៅហ្វាយនាយទៅហើយ ហើយការបោះឆ្នោតក៏កាន់តែខិតជិតមកដល់ ។ ដូច្នេះពួកគេត្រូវកំណត់កម្មវិធីនយោបាយមួយស្តីពីទំនើបភាវូបនីយកម្ម លទ្ធិសង្គមនិយម អព្យាក្រឹតភាព និងការប្រឆាំងលក្ខណៈអាមេរិកាំងនិយមវិញប្រសើរជាង- ជាកម្មវិធីនយោបាយ ដែលសម្តេច ព្រះនរោត្តម សីហនុបានយកទៅធ្វើជារបស់ព្រះអង្គយ៉ាងរហ័ស ។

ព្រឹត្តិការណ៍ ដែលពួកកុម្មុយនិស្តបានរួចផុតពីគ្រោះថ្នាក់នៅជំនាន់នេះពិតជាមានរឿងរ៉ាវមួយចំនួនតូចមានហេតុភេទយ៉ាងអស្ចារ្យ ។ ពួកអ្នកតស៊ូប្រុសនិងស្រីមួយចំនួន ដែលមិនសូវដាច់ខាតធ្លាប់បដសេធមិនប្រឈម

មុខទល់នឹងសម្ដេច ព្រះនរោត្តម សីហនុ ដែលសម្ដែងឲ្យឃើញជាអ្នកនយោបាយដ៏ប៉ិនប្រសប់ម្នាក់ និងជាសត្រូវគ្មានមេត្តាម្នាក់របស់ក្រុមនិយមឆ្វេង ។ ភ្នំពេញជាទីក្រុងរបស់ព្រះអង្គ ហើយព្រះអង្គស្គាល់គូសត្រូវទាំងឡាយរបស់ទ្រង់ច្បាស់លាស់ណាស់ ។ អតីតគណបក្សប្រជាធិបតេយ្យបានត្រូវកម្រើកឡើងវិញ ដោយការបញ្ចូលឥស្សរជនថ្មីៗជាច្រើន ជាពិសេស ជួន មុំ ដែលជាបងប្អូនប្រុសត្រកូលជួនម្នាក់ធ្លាប់រៀននៅក្រុងប៉ារីស ។ គណបក្សនេះ ធ្លាប់បានទទួលជ័យជម្នះទាំងស្រុងមួយនៅឆ្នាំ១៩៤៦ សម្រាប់ការបោះឆ្នោតតែមួងគត់ ដែលមិនដែលរៀបចំសោះ នៅក្នុងប្រទេស ហើយបើសិនណាជាត្រូវបង្រួបបង្រួមកម្លាំងទាំងអស់របស់ខ្លួនជាមួយនឹងគណបក្សថ្មី ដែលនិយមឆ្វេង គឺក្រុមប្រជាជនសម្រាប់ការបោះឆ្នោតឆ្នាំ១៩៥៥ នោះ សម្ដេច នឹងត្រូវប្រឈមមុខនឹងការគំរាមកំហែងដ៏គួរឲ្យព្រឺខ្លាចមួយ ។ ហេតុនេះហើយ បានជាសម្ដេច ព្រះនរោត្តម សីហនុ សម្រេចព្រះទ័យចុះចេញពីរាជបល្ល័ង្ក ដើម្បីប្រគល់ទៅឲ្យព្រះបិតាព្រះអង្គសោយរាជ្យវិញ ។ ដោយក្លាយទៅជាព្រះអង្គម្ចាស់នរោត្តម សីហនុ ព្រះអង្គអាចមានសេរីភាពចូលរួមក្នុងការបោះឆ្នោតបាន ។ នេះជាទង្វើមួយដែលព្រះអង្គធ្វើបានសម្រេចល្អយ៉ាងប៉ិនប្រសប់ ។

សម្ដេចបានបង្កើតគណបក្សផ្ទាល់របស់ព្រះអង្គ គឺសង្គមរាស្ត្រនិយម ហើយដោយប្រើប្រាស់គ្រឿងជន្ទាញឲ្យជាប់ចិត្តយ៉ាងច្រើន សម្ដីរបស់ព្រះអង្គ និងដោយបង្កើនពាក្យសន្យាជួយគាំពារព្រះអង្គបានបញ្ចុះបញ្ចូលអ្នកនយោបាយនិយមស្ដាំ និងនិយមកណ្ដាលភាគច្រើនឲ្យរំលាយគណបក្សតូចៗរបស់គេចោល ហើយចូលមករួមជាមួយគណបក្សសង្គមវិញ ។ ដូច្នេះមានតែក្រុមនិយមឆ្វេង និងក្រុមនិយមស្ដាំ ដែលនៅគាំទ្រ សឺង ង៉ុកថាញ់ ប៉ុណ្ណោះ ស្ថិតនៅលើឆាកប្រយុទ្ធសម្រាប់តតាំងនឹងសម្ដេច ។ សម្ដេច ព្រះនរោត្តម សីហនុ គ្មានត្រៀមបម្រុងចែករំលែកអំណាចជាមួយក្រុមណាទេ ហើយជាពិសេសជាមួយក្រុមនានា ដែលកំពុងទាមទារថា ធ្លាប់បានប្រយុទ្ធតស៊ូក្នុងរយៈពេលយ៉ាងយូរ និងយ៉ាងស៊ិតស្វាញដើម្បីឯករាជ្យដែរនោះ ។ ក្រុមប្រឆាំងបានសំអាងថា គឺសន្និសីទក្រុងហ្សឺណែវទេ ដែលសម្រេចផ្ដល់ឯករាជ្យឲ្យកម្ពុជា ពុំមែនការចរចារបស់សម្ដេច ព្រះនរោត្តម សីហនុជាមួយពួកបារាំងឡើយ ។ ក្រុមប្រឆាំងបានធ្វើយុទ្ធនាការប្រឆាំង និងជំនួយរបស់អាមេរិកាំង ដែលសម្ដេចព្រះនរោត្តម សីហនុ បានយល់ព្រម នៅឆ្នាំ១៩៥៥ ហើយបានប្រឆាំងនឹងការគំរាមកំហែង ដែលសហរដ្ឋអាមេរិករៀបចំឡើងនៅក្នុងប្រទេសវៀតណាមក្បែរខាងទៀត ។

ជាបឋម សម្ដេចដែលស្ថិតនៅជាព្រះប្រមុខរដ្ឋ បានសាកល្បងរាំងរាក្រុមប្រជាជនមិនឲ្យចូលរួមក្នុងការបោះឆ្នោតទេ ហើយព្រះអង្គអនុញ្ញាតឲ្យក្រុមនេះចូលរួមបានក៏ដោយសារតែមាន“ការជំរុញយ៉ាងខ្លាំងក្លា”ពីសំណាក់ជនជាតិឥណ្ឌាជាប្រធានគណៈកម្មាធិការអន្តរជាតិខាងបទឈ្លប់ត្រួតត្រា ដែលរៀបចំឡើងស្របតាមកិច្ចព្រមព្រៀងក្រុងហ្សឺណែវនោះដែរ ។ ដោយចាញ់ត្រង់ចំណុចនេះ ព្រះអង្គបានលើកយកការបោះឆ្នោតទៅធ្វើនៅខែកញ្ញាវិញ ហើយបានផ្ដុកផ្ដាក់ឲ្យកងទ័ពធ្វើទុក្ខបុកម្នេញគូប្រជែងទាំងអស់របស់ព្រះអង្គទៀតផង ។ ក្នុងរយៈពេល

នៃការឃោសនាបោះឆ្នោត សមាជិកក្រុមប្រជាជនម្នាក់បានត្រូវគេចាប់ខ្លួន និងយកទៅដាក់គុកជាមួយនឹងបេក្ខជនបីនាក់របស់ពួកគេ ។ យ៉ាងហោចណាស់មានមនុស្សពីរនាក់ ត្រូវបានគេសម្លាប់នៅក្នុងតំបន់ជនបទ ។ គណបក្សប្រជាធិបតេយ្យក៏ត្រូវសម្តេចកំណត់ជាគោលដៅវាយប្រហារដូចគ្នា ៖ បេក្ខជនម្នាក់ត្រូវគេចាប់ដាក់គុក មេដឹកនាំម្នាក់បានរងរបួស ដោយគ្រាប់កាំភ្លើងដែលបាញ់ដោយពួកប៉ូលិស ។ ជួន មុំ បានចាកចេញពីប្រទេស ហើយភៀសខ្លួនទៅនៅប្រទេសបារាំងវិញ ដែលគាត់បានរស់នៅទីនោះអស់រយៈពេល១៦ឆ្នាំជាបន្តមកទៀត ។ គណបក្សសង្គមរបស់សម្តេច ព្រះនរោត្តម សីហនុ បានប្រមូលយកកៅអីទាំងអស់នៅក្នុងរដ្ឋសភាដែលមួយផ្នែកនៃជោគជ័យនេះ គឺបានមកដោយសារប៉ូលិស ប៉ុន្តែ ជាពិសេសក៏ដោយសារប្រជាប្រិយភាពរបស់សម្តេចដែរ ។ អ្វីដែលក្រុមប្រជាជនធ្វើបានសម្រេចផលល្អនោះ គឺការបង្ហាញឲ្យពួកប៉ូលិសដឹងនូវឈ្មោះមនុស្សនិយមឆ្វេងទាំងអស់ ដែលព្រោះខ្លួនបានលាតត្រដាងជាសាធារណៈក្នុងរយៈពេលនៃការឃោសនាបោះឆ្នោតនេះឯង ។

នៅក្រោយពេលចប់ទឹកទីមួយនេះ សម្តេច ព្រះនរោត្តម សីហនុ គ្មានបានបង្ហាញឲ្យឃើញអាធ្យាស្រ័យបន្តិចសោះក្នុងជ័យជម្នះនេះ ។ ព្រះអង្គបានតបទៅវិញយ៉ាងសាហាវចំពោះពួកកុម្មុយនិស្តក្នុងគោលបំណងកុំឲ្យពួកនេះ អាចសម្តែងនូវតួនាទីណាមួយក្នុងប្រទេសរបស់ព្រះអង្គ ។ ប្រការនេះពុំត្រឹមតែការពារអំណាចផ្តាច់ការរបស់ព្រះអង្គប៉ុណ្ណោះទេ ប៉ុន្តែ ដោយព្រះអង្គខ្លាចក្រែងថា ពួកកុម្មុយនិស្តទាំងនេះ ដែលស្ថិតនៅក្រោមបង្គាប់ពួកកុម្មុយនិស្តវៀតណាម បង្កើតជាស្ពានមួយសម្រាប់ការវាតទឹកដីរបស់វៀតណាម នៅពេលអនាគត ។ ម្យ៉ាងទៀត ភ័ព្វសំណាងរបស់សម្តេចមានជាប់រហូត ស៊ីវ ហេង ដែលជាអ្នកគ្រប់គ្រងលើពួកកុម្មុយនិស្តខ្មែរទាំងអស់ បានចូលមកជួបនឹងសម្តេចជាសម្ងាត់ ហើយបានយល់ព្រមធ្វើជាភ្នាក់ងារឲ្យព្រះអង្គទៀតផង ។ ក្រោយមក ហេង បានបកស្រាយឲ្យដឹងថា ការដែលគាត់បោះបង់ចោលបក្សពួក ពីព្រោះគាត់គ្មានឃើញផលប្រយោជន៍ណាមួយ ដើម្បីបន្តការវាយប្រយុទ្ធទាល់តែសោះ ក្រោយគេលដែលឯករាជ្យត្រូវដណ្តើមបានហើយនោះ ។ ក្នុងអំឡុងបណ្តាឆ្នាំចុងក្រោយរបស់គាត់ក្នុងតំណែងជាអគ្គលេខាធិការចលនាតស៊ូ ហេង បានផ្តល់ពត៌មានយ៉ាងច្រើន ស្តីពីពួកកុម្មុយនិស្តនៅតាមជនបទ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់ផ្ទាល់ និងពត៌មានផ្សេងៗទៀត ដែលអនុញ្ញាតឲ្យ លន់ នល់ ជាមេទ័ពរបស់សម្តេច ព្រះនរោត្តម សីហនុ កម្ចាត់ក្រុមអ្នកតស៊ូនយោបាយជាសម្ងាត់អស់ជាច្រើនក្នុងទូទាំងប្រទេស ។ នៅពេលដែល ហេង បោះបង់បក្សហើយសុំចុះចូលជាចំហជាមួយសម្តេច ព្រះនរោត្តម សីហនុ នៅឆ្នាំ ១៩៥៩ ពួកកម្មាភិបាល កុម្មុយនិស្តប្រហែលកៅសិបភាគរយនៅជនបទបានត្រូវគេកម្ទេច ។ អ្នកខ្លះត្រូវសម្លាប់ដោយប៉ូលិសរបស់សម្តេច ព្រះនរោត្តម សីហនុ អ្នកខ្លះទៀតត្រូវចាត់ទុកថា បាត់ខ្លួន ឬស្លាប់ ហើយមានអ្នកខ្លះទៀត ដោយភ័យខ្លាចគ្រោះថ្នាក់ដល់ជីវិតរបស់ខ្លួន បាននាំគ្នារត់គេចទៅលាក់ខ្លួន ពួនអាត្មានៅទីកន្លែងផ្សេងៗ ។

ដូច្នេះមូលដ្ឋានរបស់ពួកកុម្មុយនិស្តនៅជនបទ បានដួលរលំក្រោមការវាយសំពងរបស់សម្តេច ។ វានៅសល់តែក្រុម ដែលនៅឆ្ងាយដាច់ពីគេមួយចំនួនរបស់ប្រជាកសិករ ដែលស្មោះត្រង់នឹងបុព្វហេតុកុម្មុយនិស្ត

ប៉ុណ្ណោះ ប៉ុន្តែ គ្មានរចនាសម្ព័ន្ធសម្រាប់រៀបចំពួកនោះឲ្យមានដំណើរឡើងវិញទេ ហើយក៏ពុំសូវបានបង្កើនចំនួនសមាជិករបស់គេថែមទៀតដែរ ។ សង្គ្រាមចិត្តសាស្ត្ររបស់សម្តេច ព្រះនរោត្តម សីហនុ បានធ្វើឲ្យសេចក្តីភ័យខ្លាចកើនឡើង ដែលគ្របដណ្តប់ជាប់នៅតាមជនបទនានា ។ ព្រះអង្គមិនដែលប្រកាសសង្គ្រាមដោយចេញមុខជាមួយពួកកុម្មុយនិស្ត មិនដែលបញ្ចេញឲ្យដឹងពីការបោះបង់ចោលបក្សពួក និងការបោសសម្អាតពួកនោះម្តងណាទាល់តែសោះ ប៉ុន្តែ បែរជាវាយប្រហារពួកកុម្មុយនិស្តដោយស្ងាត់ៗទៅវិញ ។ កងទ័ពនិងប៉ូលិសរបស់ព្រះអង្គបានសម្លាប់ពួកកុម្មុយនិស្តយ៉ាងច្រើន ដោយព្រះអង្គគ្មានទទួលធ្វើដឹងឮ និងដោយគ្មាន ដែលបញ្ជូនពួកនោះទៅឲ្យតុលាការកាត់ទោសឡើយ គឺវាពិតប្រាកដជាអ៊ីចឹងមែន ។ សម្តេច ព្រះនរោត្តម សីហនុ បានសម្របព្រះកាយទៅតាមដំណើររឿង ដើម្បីចាត់ការដោយប្រយោល ជាមួយនឹងសកម្មភាពប្រឆាំងកុម្មុយនិស្តផ្ទាល់របស់ព្រះអង្គ និងដើម្បីជៀសវាងបង្ក ជារូបភាពគ្មានត្រាប្រណីមួយឲ្យគេឃើញផង ។ បំណុលឈាមចេះតែកើនខ្ពស់ឡើងៗ ប៉ុន្តែ វាស្ថិតនៅក្នុងសភាពស្ងៀមស្ងាត់នៅឡើយ ។ អំពើហិង្សាក្លាយទៅជាមធ្យោបាយសម្ងាត់ (ដើម្បីសម្រេចគោលដៅរបស់ខ្លួន) នៅពេលដែលសម្តេច ព្រះនរោត្តម សីហនុ ចាប់ផ្តើមដឹកនាំ ប្រទេសជាតិក្នុងឋានៈជាព្រះមហាក្សត្រកំពូល ដែលត្រូវបានជ្រើសតាំងឡើងតាមលិទ្ធិប្រជាធិបតេយ្យពិតៗ ។

ឥឡូវនេះចលនាកុម្មុយនិស្តត្រូវតែធ្វើឲ្យបានសម្រេចផលល្អនៅក្រុងភ្នំពេញ ឬត្រូវទទួលរងការចុះដុនដាប ។ គឺក្នុងទីក្រុងនេះហើយ ដែល សាឡុត ស ឈានឡើងជាអ្នកមានឋានៈខ្ពស់ជាងបណ្តាសមមិត្តរបស់ខ្លួននោះ ។ ភារកិច្ចចាំបាច់ដំបូងមួយក្នុងចំណោមភារកិច្ចចាំបាច់ដំបូងៗរបស់គាត់ គឺរ៉ាប់រងធ្វើឲ្យមានការរួបរួមរវាងក្រុមប្រជាជន និងគណបក្សប្រជាធិបតេយ្យក្នុងរយៈពេលនៃការបោះឆ្នោតឆ្នាំ១៩៥៥ ។ គេនៅនឹកឃើញថា គាត់ធ្លាប់បានចូលរួមការតាក់តែងលក្ខន្តិកៈ របស់ក្រុមប្រជាជនដែរដោយឆ្លៀតប្រើប្រាស់ទេពកោសល្យមួយ ដែលគាត់នៅទីក្រុងប៉ារីស ។ ស បានផ្លាស់ប្តូរចិត្តគំនិតតាំងតែពីសម័យ ដែលគាត់បានរៀននៅអនុវិទ្យាល័យបច្ចេកទេសក្រុងភ្នំពេញម្ល៉េះ ហើយឥឡូវនេះគាត់បានបង្ហាញឲ្យឃើញសេចក្តីអង់អាច និងភាពងាយស្រួលជាអ្នកបម្រើប្រយោជន៍រាស្ត្រវ័យក្មេងម្នាក់ ។ គាត់ទើបនឹងរៀបការជាមួយ ខៀវ ប៉ុណ្ណារី ជាបញ្ញវន្ត ស្រីម្នាក់ ដែលគេគោរពរាប់អានក្នុងមជ្ឈដ្ឋានគហបតីថែមទៀត ។

ក្រុមប្រជាជនបានស៊ូទ្រាំខាំមាត់ចំពោះបរាជ័យរបស់ខ្លួនក្នុងការបោះឆ្នោត ។ ពួកកុម្មុយនិស្តបានប្រមូលផ្តុំកិច្ចប្រឹងប្រែងទាំងអស់ទៅលើកាសែតផ្សេងៗរបស់ពួកគេ ដែលផ្ទុយនឹងច្បាប់ ហើយដឹងថា អត្ថរសនៃអត្ថបទរបស់គេបានទាក់ទាញទឹកចិត្តយុវជនយ៉ាងច្រើន ។ ពួកមេដឹកនាំនៃគណបក្សសង្គមរបស់សម្តេច ព្រះនរោត្តម សីហនុ គឺភាគច្រើនជាពួកអភិរក្សនិយមជាន់ចាស់ ហើយពួកកុម្មុយនិស្តដឹងថា បើសិនជាសម្តេចមិន “បន្លំសន្លឹកឆ្នោត” និងធ្វើទុក្ខបុកម្នេញបេក្ខជនរបស់ខ្លួន ពួកគេអាចនឹងមានកៅអីខ្លះ នៅក្នុងរដ្ឋសភាថ្មីនេះមិនខាន ។ សម្តេច ព្រះនរោត្តម សីហនុ ក៏ដឹងខ្លួនពីរឿងនេះដែរ ហើយបានប្រញាប់ប្រញាល់ផ្តើមយកកម្មវិធីនយោបាយ

និងឥទ្ធិពលទាក់ទាញចិត្តរបស់ក្រុមឆ្វេងនិយមទៀតផង ។

ព្រះអង្គ បានផ្ដើមធ្វើការឃោសនាយ៉ាងប៉ិនប្រសប់មួយ ដើម្បីឯកោពួកកុម្មុយនិស្តនៅក្នុងរាជធានី និងទាក់ទាញបានបណ្ដាសម្ព័ន្ធមិត្តរបស់ពួកគេនៅលើឆាកអន្តរជាតិមកខាងព្រះអង្គវិញ ។ ដើម្បីធ្វើកិច្ចការនេះ ព្រះអង្គបានពឹងផ្អែកលើមធ្យោបាយពីមុនៗមក[១៩] ចង់ដឹងថា តើពួកមនុស្សនិយមឆ្វេងទាំងនោះជាអ្នកស្នេហាជាតិ ឬជា “មិត្តរបស់ពួកវៀតមិញ” ។ បន្ទាប់មក ព្រះអង្គបានធ្វើឲ្យមហាអំណាចកុម្មុយនិស្តបរទេសទន់ចិត្ត ដោយព្រះអង្គស្នើទទួលស្គាល់ និងភ្ជាប់ចំណងទាក់ទងមិត្តភាពជាមួយប្រទេសទាំងនោះ ដោយអនុលោមទៅតាមនយោបាយអព្យាក្រឹតរបស់ព្រះអង្គផង ។ ហេតុនេះហើយបានជាព្រះអង្គបដិសេធមិនចូលរួមក្នុងអង្គការសន្ធិសញ្ញាអាស៊ីអាគ្នេយ៍ហៅ សេអាតូ ដែលមានពួកអាមេរិកាំងត្រួតត្រាពីលើឡើយ ហើយព្រះអង្គបានចងភ្ជាប់ប្រទេសទៅនឹងគោលការណ៍បញ្ចសីលា (គោលការណ៍សន្តិសហវិជ្ជមានទាំង៥) ដែលប្រកាសឡើងដោយសន្និសីទនៃបណ្ដាប្រទេសអាស៊ី អាហ្វ្រិកនាទីក្រុងបាន់ឌុង (ប្រទេសឥណ្ឌូនេស៊ី) នាឆ្នាំ១៩៥៥វិញ ដែលទ្រង់ក៏ជាមេដឹកនាំម្នាក់ក្នុងចំណោមមេដឹកនាំទាំងឡាយដែលគេទទួលស្គាល់ ។ [បញ្ចសីលា ១) ការគោរពអធិបតេយ្យភាព និងបូរណភាពទឹកដីទៅវិញទៅមក ២) ការមិនជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងរបស់ប្រទេសដទៃ ៣) ការមិនឈ្លានពានគ្នា ៤) ការធ្វើឲ្យមានសមភាព និងផលប្រយោជន៍ទៅវិញទៅមក និង ៥) ការរួមរស់ដោយសន្តិវិធី- កំណត់របស់អ្នកបកប្រែប្រួល] ។

ជាឯកជនក្រុមឆ្វេងនិយមនៅរាជធានីបានអួតក្អេងក្អាងថា បានជួយតម្រង់ផ្លូវសម្ដេច ព្រះនរោត្តម សីហនុ ទៅរកជំហរអព្យាក្រឹតនិយមមួយ ប៉ុន្តែ នៅពេលដែលក្រុមនេះថ្លែងសរសើរសម្ដេចជាសាធារណៈនោះ ព្រះអង្គបែរជាច្រានចោលការបញ្ចើចបញ្ចើរបស់ពួកគេទៅវិញ ។ តាមរយៈបទវិចារណកថាជាច្រើន ដែលចុះផ្សាយក្នុងកាសែតនានារបស់សម្ដេចបានចោទសួរដោយចង់ដឹងថា[២០] តើការអបអរសរសើររបស់ក្រុមប្រជាជនចំពោះនយោបាយអព្យាក្រឹតរបស់ព្រះអង្គមានជាប់ទាក់ទងទៅនឹង“ការទ្រទ្រង់របស់បរទេស” ដែលកំពុងស្ថិតនៅពីក្រោយគណបក្សនោះដែរទេ? ។ ហើយនៅពេលដែលសម្ដេច ព្រះនរោត្តម សីហនុ អបអរនឹងការសរសើររបស់បណ្ដាប្រទេសកុម្មុយនិស្តនោះ សម្ដេចក៏ធ្វើឲ្យអ្នកស្ដាប់ទាំងអស់របស់ព្រះអង្គមើលឃើញនូវភាព ខុសគ្នាវវាង “សុច្ឆន្ទៈ”នៃប្រជាជាតិនានា ដូចជាប្រទេសចិនឬ សហភាពសូវៀតជាដើមនិងអំពើវៀចក្បត់នៃពួកកុម្មុយនិស្តកម្ពុជា ។

ការបដិសេធមិនចូលរួមក្នុងអង្គការសេអាតូរបស់ព្រះអង្គ ត្រូវបានទូទាត់មកវិញដោយការថ្លែងសរសើរពីប្រទេសវៀតណាមខាងជើងនិងដោយការសម្រេចចិត្តរបស់ប្រទេសចិន ដែលយល់ព្រមផ្ដល់ជំនួយរបស់ខ្លួនជាលើកដំបូងមកឲ្យប្រទេសកម្ពុជានៅឆ្នាំ១៩៥៦ ។ សហរដ្ឋអាមេរិក បានបញ្ចេញប្រតិកម្មយ៉ាងខ្លាំង ។ បណ្ដាសម្ព័ន្ធមិត្តរបស់អាមេរិក វៀតណាមខាងត្បូងនិងថៃ -បានដាក់ទណ្ឌកម្មប្រទេសកម្ពុជាដោយការរាំងខ្ទប់ខាងផ្នែក

សេដ្ឋកិច្ច ជាបណ្ដោះអាសន្ន ដែលជាការព្រមានប្រឆាំងនឹងការពង្រឹងជំហរអព្យាក្រឹតនិយមរបស់ព្រះអង្គរឹតតែខ្លាំងឡើងៗ ។ ប៉ុន្តែ សម្ដេចបដិសេធមិនព្រមបណ្ដោយឲ្យប្រទេសរបស់ព្រះអង្គសម្ដែងតួនាទីមួយក្នុងសង្គ្រាមឥណ្ឌូចិនមួយទៀតឡើយ ទោះជាតូចតាចក៏ដោយ ។

សម្ដេច ព្រះនរោត្ដម សីហនុ បានរៀបចំចាត់ចែងធ្វើការបោះឆ្នោតដើម្បីរក្សាអំណាចឲ្យគង់វង្សដោយផ្ទុយនឹង ង្វៀ ឌិញយៀម (ប្រធានាធិបតីវៀតណាមខាងត្បូង) ដែលមិនព្រមឲ្យមានការបោះឆ្នោតទាំងអស់ ក្រោយកិច្ចព្រមព្រៀងឆ្នាំ១៩៥៤ ពីព្រោះគាត់ប្រាកដក្នុងចិត្តថា ហូ ជីមិញ នឹងឈ្នះក្នុងការបោះឆ្នោតនោះជាមិនខាន ។ ពួកវៀតណាមខាងជើង ជាមួយនឹងការយល់ព្រមតាមរបស់ប្រទេសចិនផងបានចាត់ទុកជំហរអព្យាក្រឹតនិយមរបស់សម្ដេច ព្រះនរោត្ដម សីហនុ ថា ជាមធ្យោបាយធ្វើឲ្យសម្រេចកិច្ចការសំខាន់ សម្រាប់បុព្វហេតុព្រះអង្គ ។ អព្យាក្រឹតភាពរបស់កម្ពុជា បានជួយសម្រាលកន្ទល់មហាអំណាចកុម្មុយនិស្តនានានៅអាស៊ី ដែលព្រួយបារម្ភចំពោះការកើនឡើងនៃវត្តមានយោធាអាមេរិកាំងនៅក្នុងតំបន់នេះ ប៉ុន្តែក៏បានជួយធ្វើឲ្យពួកកុម្មុយនិស្តកម្ពុជាធ្លាក់ទៅក្នុងការបំភ្លេចចោល ដែលប្រការនេះជាគោលដៅរបស់សម្ដេច ព្រះនរោត្ដម សីហនុ ដែរ ។

សម្ដេចគឺជាមនុស្សសំខាន់ម្នាក់ ដែលធ្វើឲ្យគេព្រួយបារម្ភដោយព្រះអង្គធ្លាប់សហការដោយស្ម័គ្រព្រះទ័យជាមួយនឹងរបបក្រុងវីឈី ពួកហ្វាស៊ីសជប៉ុន បន្ទាប់មក ជាមួយពួកអាណានិគមបារាំងជាថ្មីម្ដងទៀត ។ ឥឡូវនេះព្រះអង្គបានបង្ហាញលេចឡើង ជាមេដឹកនាំជាតិនិយមនៃប្រទេសតតិយលោកថែមទៀត ពីព្រោះនេះជាមធ្យោបាយដើម្បីស្រោចស្រង់អំណាច និងប្រទេសរបស់ព្រះអង្គ ។ អតីតអ្នករួមសហការនឹងសត្រូវនៅពេលនេះ ត្រូវបានប្រជាជនស្រែកអបអរសាទរក្នុងមាតុភូមិរបស់ព្រះអង្គ និងក្នុងពិភពលោកក្នុងឋានៈជានិមិត្តរូបនៃឯករាជ្យរបស់ប្រទេសកម្ពុជាសម័យទំនើប ។

ក្នុងភូមិភាគអាស៊ីទាំងមូល បុគ្គល ឬក្រុមដែលមានកិត្តិយសមួយបែបនោះ -ពួកកុម្មុយនិស្តនៅវៀតណាម គណបក្សសមាជនៅប្រទេសឥណ្ឌា ឬរបបរាជាធិបតេយ្យរបស់ថៃ ដែលធ្លាប់រារាំងការធ្វើអាណានិគមរបស់ពួកអឺរ៉ុប- បានទទួលអត្ថប្រយោជន៍ពីលក្ខណៈត្រឹមត្រូវតាមច្បាប់មួយ គ្របបាំងពីលើអំពើបាបកម្មទាំងឡាយ ដែលពួកគេធ្លាប់បានប្រព្រឹត្ត ។ ក្នុងទ្វីបអាស៊ីក្រោយសង្គ្រាម ឯករាជ្យបានទៅជាបញ្ហាសំខាន់បំផុត ហើយរារាំង «អ្នករំដោះ» ប្រទេសទៀត ក្នុងការរត់ប្រណាំងឆ្ពោះទៅរកគ្រោះកំណាចដ៏ធំបណ្ដាលឲ្យហិនហោចជាក់ជាប្រាកដ ។

ពួកកុម្មុយនិស្តកម្ពុជាយល់ឃើញថា គេបានលួចការបដិវត្តមួយ របស់ខ្លួននៅពេលដែលបណ្ដាសមមិត្តវៀតណាមរបស់គេ ដែលរៀនសូត្រជាមួយគ្នានៅក្រុងប៉ារីស ដូចជា ង្វៀង ខាក់វៀន ជាដើម វិលត្រឡប់មកក្រុងហាណូយវិញ និងចូលរួមក្នុងការ «តស៊ូរំដោះជាតិ» ជាមួយ ហូ ជីមិញ ពួកកម្ពុជាក៏ចាកចេញពីទីក្រុងប៉ារីសមកមាតុភូមិវិញដែរ ។ តាមពាក្យសម្ដីផ្ទាល់របស់គេថា វាជា «ភាពចម្លែក» មួយផ្នែកនយោបាយគឺ ប្រទេសកម្ពុជាឯករាជ្យមួយត្រូវគ្រប់គ្រងដឹកនាំដោយ ស្ដេចអាទិទេពមួយអង្គ ដែលត្រូវជ្រើសតាំងឡើង «តាមលិទ្ធិប្រជា

ធិបតេយ្យ» ។ អ្វីដែលអាក្រក់ជាទីបំផុតនោះ គឺស្ដេចអាទិទេពអង្គនេះបានអួតខ្លួនជាអ្នកសង្គមនិយម ហើយមានចំណងមិត្តភាពជាមួយរដ្ឋកុម្មុយនិស្ដជាច្រើននៅអាស៊ីទៀត ។

នៅខណៈនេះ សម្ដេច ព្រះនរោត្ដម សីហនុ ដឹងយ៉ាងប្រាកដពីមធ្យោបាយដើម្បីទាញយកផលប្រយោជន៍បែបណាពីឧត្ដមភាពរបស់ខ្លួន ។ ពួកអាមេរិកាំង និងពួកបារាំងបានយល់ព្រមផ្ដល់មកឲ្យព្រះអង្គនូវជំនួយខាងយោធា និងសេដ្ឋកិច្ច ដែលព្រះអង្គត្រូវការជាចាំបាច់ ហើយប្រទេសជាតិបានស្គាល់នូវភាពសម្បូរសប្បាយមួយកម្រិតតូចដែរ ។ សម្ដេចយកព្រះទ័យទុកដាក់ការពារជំហរជាស្ដេចអាទិទេពតែមួយរបស់ព្រះអង្គយ៉ាងហ្មត់ហែងក្នុងចំណោមប្រជាកសិករទាំងឡាយ ព្រះអង្គបានជ្រើសរើសពួកអ្នកនយោបាយនៅទីក្រុងដើម្បីឲ្យឈរឈ្មោះជាបេក្ខជនតំណាងរាស្ដ្រក្នុងទីជនបទផ្សេងៗ ហើយបញ្ជាក់ថា អ្នកទាំងនោះនឹងមិនក្លាយទៅជាអ្នកដឹកនាំជាប់រហូតទេ ។ តាមរយៈការទាក់ទងជាសាធារណៈផ្សេងៗ ព្រះអង្គបានញុំាងឲ្យប្រជាជនកម្ពុជាមួយភាគធំ និងពិភពលោកជឿថា ប្រទេសកម្ពុជាបានក្លាយទៅជាឋានសួគ៌អាព្យាក្រឹតនិយមល្អស្អាតមួយ ។

ក្នុងសភាពរំដើបរំជួលនៅដើមដំបូងនៃឯករាជ្យ សម្ដេច ព្រះនរោត្ដម សីហនុ ហើយរាជាធិបតេយ្យនៅតែជាគ្រឹះមួយក្នុងចំណោមគ្រឹះទាំងឡាយរបស់ប្រទេសជាតិដដែល និងមានដាក់ក្នុងច្បាប់រដ្ឋធម្មនុញ្ញថែមទៀត ។ ព្រះបរមរាជវាំង នៅតែជាមជ្ឈមណ្ឌលរបស់សង្គមជាតិ ប៉ុន្ដែ គឺសម្ដេច ព្រះនរោត្ដម សីហនុ និងមហេសីរបស់ព្រះអង្គព្រះនាម ម៉ូនិក សម្ដេច ព្រះនរោត្ដម សីហនុ ជាអ្នកមានឋានៈដ៏ឧត្ដុង្គឧត្ដមជាងគេ គឺពុំមែនព្រះមហាក្សត្រ និងមហាក្សត្រិយានីជាព្រះបិតាមាតារបស់សម្ដេច ព្រះនរោត្ដម សីហនុ ទេ ។ម្យ៉ាងទៀតសម្ដេចបានផ្ដល់ប្រាក់ឧបត្ថម្ភដោយចិត្តសប្បុរសដល់និមិត្តរូបរបស់រាជបល្ល័ង្កដែរ ក្រុមរបាំព្រះរាជទ្រព្យ ព្រះរាជវាំង និងព្រះរាជបរិពារ រាជសារមន្ទីរ ការធ្វើអន្ដរាគមន៍ក្នុងរឿងផ្សេងៗនៅគ្រប់កន្លែង របស់ព្រះរាជា បានធ្វើឲ្យព្រះអង្គដឹងថាមានឥទ្ធិពលខ្លាំងណាស់ ។ សម្ដេច ព្រះនរោត្ដម សីហនុ មានមុខតំណែងមួយដែលនឹងធ្វើឲ្យបំណងរបស់ស្ដេចសោយរាជ្យមុនៗព្រះអង្គផុសឡើងភ្លាមមួយរំពេច គឺក្ដោបក្ដាប់អំណាចមួយទាំងស្រុងលើប្រទេស ដោយគ្មានការជួយគាំពារពីមហាអំណាចបរទេសមួយ ដែលចូលចិត្តត្រួតត្រាលើគេឡើយ ។

គំនិតបដិវត្តន៍របស់ពួកកុម្មុយនិស្ដ ត្រូវបានសាកល្បងយ៉ាងតឹងតែងបំផុតកំឡុងសម័យកាលនេះ ដូចដែលប្រវត្តិសាស្ដ្របក្សបានបញ្ជាក់ឲ្យឃើញជាភ័ស្ដុតាងនៅពេលក្រោយមកទៀតដែរ ។ មុននឹងថា មេដឹកនាំផ្ទាល់របស់គេចូលដៃចូលជើងជាមួយនឹងសម្ដេច ព្រះនរោត្ដម សីហនុ ជាសម្ងាត់នោះ ពួកកុម្មុយនិស្ដក្មេងៗនៅទីក្រុងមានការលំបាកយ៉ាងខ្លាំងក្នុងការកំណត់កម្មវិធី និងការពារសន្តិសុខមេកោយរបស់គេផង ។ ពួកគេបានប្រកាន់យកយុទ្ធសាស្ដ្រធម្មតាមួយគឺ«រណសិរ្សរួបរួម» ដែលក្រុងហាណូយជាអ្នកណែនាំឲ្យធ្វើដើម្បីជណ្ដើមយកអ្នកមានសមានចិត្តថ្មីៗទៀត តាមរយៈយុទ្ធនាការឃោសនានយោបាយដ៏ទូលំទូលាយមួយរបស់ក្រុមនិយមឆ្វេងដែលនឹងធ្វើឲ្យសម្ដេច ព្រះនរោត្ដម សីហនុ ទោទន់មករកក្រុមនិយមឆ្វេងវិញ ។ ប៉ុន្ដែ សម្ដេចបានដឹងពីសមត្ថភាព និង

ចំណាប់ចំណូលចិត្តរបស់ពួកគហបតីក្នុងរាជធានីច្បាស់លាស់ ។ ព្រះអង្គបានរាំងរាមិនឲ្យក្រុមនិយមឆ្វេង ដែលគេស្គាល់ជាសាធារណៈ បង្រៀននៅក្នុងសាលានានារបស់រដ្ឋ ដែលជាបេះដូងរបស់ប្រទេសកម្ពុជាទំនើបឡើយ ។

សម្តេច ព្រះនរោត្តម សីហនុ ក៏ដឹងដែរថា តែមួយគត់ ដែលក្នុងនោះក្រុមនិយមឆ្វេងអាចជ្រើសរើសសមាជិកថ្មីថែមទៀតបាន គឺមជ្ឈដ្ឋានយុវជនដែលមានឧត្តមគតិរបស់ប្រទេសជាតិ ។ ដូចនេះហើយបានជាព្រះអង្គខ្ទប់ផ្លូវមិនឲ្យក្រុមនិយមឆ្វេងចូលបង្រៀនក្នុងសាលារបស់រដ្ឋ ដោយទ្រង់ប្រឹងប្រែងបំផ្លាញឥទ្ធិពលរបស់ពួកនេះនៅបរទេសទៀតផង ។ ព្រះអង្គបានបន្តការលុបចោលអាហារូបករណ៍របស់រដ្ឋាភិបាលដែលផ្តល់ឲ្យនិស្សិតរៀននៅបរទេសសម្រាប់ហេតុផលខាងនយោបាយ ហើយក្នុងសុន្ទរកថាមួយពេលសម្ពោធនិវេសនដ្ឋានថ្មីមួយសម្រាប់និស្សិតខ្មែរនៅទីក្រុងប៉ារីស ព្រះអង្គបានព្រមានពួកនិស្សិតឲ្យប្រុងប្រយ័ត្ន ប្រឆាំងនឹង«ការឃោសនា និងមនោគមវិជ្ជាបរទេស» ដែលជាមេនាំអាទិបក្ករឿង ជាពិសេសលទ្ធិកុម្មុយនិស្តរបស់បស្ចិមប្រទេស ។ ព្រះអង្គបានក្រើនរំឭកថា ករណីកិច្ចរបស់ខ្លួនជាអ្នកចេះដឹងជ្រៅជ្រះ គឺត្រូវ«គោរពឧត្តមគតិជាតិ»[២១] របស់ប្រជាជនកម្ពុជា ជំនឿសាសនា និងព្រះមហាក្សត្រជាបាវចនាបីរបស់រដ្ឋធម្មនុញ្ញប្រទេស និងអំណាចរបស់សម្តេច ព្រះនរោត្តម សីហនុ ។

បើទុកជាទ្រង់បានអនុញ្ញាតឲ្យមានសេរីភាពមួយខាងការបោះពុម្ពផ្សាយ ដែលមានតែរូបភាពក្រៅក៏ដោយ ក៏ព្រះអង្គបានបម្រុងទុកនូវសិទ្ធិដាក់ទណ្ឌកម្មពួកអ្នកនិពន្ធអត្ថបទផ្សេងៗ ដែលព្រះអង្គវិនិច្ឆ័យថា ជាអត្ថបទដែលបំបះបំបោរប្រឆាំងនឹងរដ្ឋអំណាច ។ អ្នកកាសែតដំបូងម្នាក់ក្នុងចំណោមអ្នកកាសែតដំបូងៗ ដែលត្រូវចាប់ខ្លួន គឺបងប្រុសរបស់ សាឡុត ស ដោយគ្រាន់តែជាប់គុកមួយរយៈពេលយ៉ាងខ្លីប៉ុណ្ណោះសម្រាប់អត្ថបទមួយដែលក្នុងនោះគាត់បានសរសេរថា ហេតុអ្វីបានជាសម្តេច ព្រះនរោត្តម សីហនុយល់ព្រមទទួលជំនួយយោធារបស់អាមេរិកាំង ។ (ពួកយុវជនកុម្មុយនិស្តច្បាស់ជាដឹងថា កងកម្លាំងប៉ូលិសរបស់សម្តេចនឹងប្រើប្រាស់រឿងនេះដើម្បីធ្វើទុក្ខបុកម្នេញពួកនិយមឆ្វេងដទៃទៀត ដែលនៅដាច់ពីគេជាមិនខាន) ។

ប៉ុន្តែ សាខាកុម្មុយនិស្តនៅរាជធានីបានបន្ត«ការតស៊ូនយោបាយ» របស់ខ្លួនតទៅទៀតហើយបានបើកវិទ្យាល័យឯកជនរបស់ខ្លួនផ្ទាល់ឈ្មោះ កម្ពុជបុត្រ ដោយមាន សាឡុត ស ហើយក្រោយមក អៀង សារី ជាមិត្តរបស់គាត់បង្រៀននៅទីនោះផង ។ ពួកនិស្សិតបានត្រូវទាក់ទាញចិត្តដោយក្រុមឆ្វេងនិយមទាំងពីរ ហើយពួកកម្មករទាំងឡាយក៏ត្រូវដឹកនាំឲ្យស្តាប់សុន្ទរកថារបស់ពួកគេដែរ ។ ម្យ៉ាងទៀត ក្នុងរយៈពេលដែលស្ថានការណ៍ធ្លាក់នៅក្នុងសភាពអាប់អួជាខ្លាំងនោះ ពួកមេដឹកនាំក្មេងៗនៃចលនា បានពង្រីកទេពកោសល្យ ជាអ្នកចាត់ចែងរៀបចំអង្គការនិងវិទ្យាសាស្ត្រមួយក្នុងការធ្វើឲ្យចលនាស្ថិតនៅគង់វង្ស ដែលលេចឡើងសំខាន់ស្មើអាយុជីវិតតទៅមុខទៀត ។ ពីឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៥៩ ពួកគេបានប្រឹងប្រែងរៀបចំកម្មករ នៅតាមរោងចក្រមួយចំនួនតូចក្រុងភ្នំពេញ ដោយដឹងប្រាកដថា នយោបាយសេដ្ឋកិច្ចរបស់សម្តេច ព្រះនរោត្តម សីហនុ មានគោលដៅរាំងខ្ទប់

ការបង្កើតវណ្ណៈអធនមួយក្នុងទីក្រុងទំនើប ដែលអាចបណ្តាលឲ្យមានការជ្រួលច្របល់ផ្សេងៗ ។ ក្នុងវិស័យនេះ ពួកគេបានទទួលជោគជ័យខ្លះៗជាបណ្តោះអាសន្ន ។ នៅឆ្នាំ១៩៥៦ ពួកកម្មករនៅក្រុមហ៊ុនអគ្គិសនី និងទឹករបស់ទីក្រុងព្រមទាំងអ្នកធ្វើការនៅរោងចក្របារីមួយរបស់ក្រុមហ៊ុនអាមេរិកាំង-អង់គ្លេស បានគំរាមធ្វើកូដកម្មទាមទារប្រាក់បំណាច់ឲ្យបានប្រសើរជាងមុន និងការការពារនិយោជក ពេលមានគ្រោះថ្នាក់ក្នុងពេលបំពេញការងារផង[២២] ។ សម្តេច ព្រះនរោត្តម សីហនុ នឹកសង្ស័យពួកកុម្មុយនិស្តថា ជាអ្នកស្ថិតនៅពីក្រោយកូដកម្មនេះ ហើយបានបញ្ជាឲ្យគេវាយបំបែកក្រុមបាតុករថែមទៀត ។

តាមអ្នកនាំពាក្យម្នាក់ក្នុងចំណោមអ្នកនាំពាក្យរបស់ព្រះអង្គ ទ្រង់បានប្រកាសថា “ប្រទេសកម្ពុជា មិនធ្លាប់ដែលមានកូដកម្មទាល់តែសោះ បច្ចុប្បន្នរដ្ឋាភិបាលគ្មានបំណងអនុញ្ញាតឲ្យធ្វើកូដកម្មរបៀបនេះទេ”[២៣] ។ ដូច្នេះការប៉ះទង្គិចផ្នែកសង្គមកិច្ចលើកដំបូងនៅប្រទេសកម្ពុជាដែលឯករាជ្យ បានបញ្ចប់ទៅដោយការដកថយមួយរបស់ពួកកម្មករ ក្រោយពេលដែលរដ្ឋាភិបាលមិនទទួលស្គាល់សិទ្ធធ្វើកូដកម្មរបស់ពួកនោះ ។

ពួកកុម្មុយនិស្តបានទទួលជោគជ័យយ៉ាងច្រើនជាមួយពួកកម្មកររទេះភ្លើង ដែលដឹកនាំដោយ កែវ មាស ជាមេដឹកនាំសម្ងាត់ និងឆ្លាតវាងវៃម្នាក់របស់គណៈកម្មាធិការបក្សទីក្រុងភ្នំពេញ ។ មាស ដែលគេស្គាល់ថាជាសមាជិករបស់ក្រុមប្រជាជននោះ គឺជាបេក្ខជនតែមួយគត់របស់ក្រុមនេះក្នុងការបោះឆ្នោតសម្រាប់រដ្ឋសភាជាតិនៅឆ្នាំ១៩៥៨ ។ តាមទម្លាប់របស់សម្តេច ព្រះនរោត្តម សីហនុ បានឲ្យគេបញ្ឆោកសន្លឹកឆ្នោតបន្ថែមទៅក្នុងហិបឆ្នោត ហើយ កែវ មាស ត្រូវតែចាញ់ ។ ដោយក្លាយទៅជាមនុស្សដែលអាចត្រូវរងគ្រោះថ្នាក់ គាត់បានរត់ភៀសខ្លួន ទៅវៀតណាមខាងជើងក្រោយនោះបន្តិច ដើម្បីគេចពីការចាប់ខ្លួនមួយដែលប្រាកដជាមានដោយធ្វើឲ្យចលនានេះ បាត់បង់មេដឹកនាំដែលមានបទពិសោធន៍ដ៏កម្រម្នាក់ ។ ដោយពិត មាស ធ្លាប់បានប្រយុទ្ធតស៊ូក្នុងកំឡុងសង្គ្រាមឥណ្ឌូចិនលើកទីមួយ ហើយបានបង្កឲ្យមានទំនាក់ទំនងផ្សេងៗដ៏ល្អប្រសើរនៅក្នុងរាជធានី ។ ម្ភៃឆ្នាំ ក្រោយមក គាត់បានវិលត្រឡប់មកវិញដោយបានត្រឹមតែកាន់តំណែងមួយ ដែលមិនសូវសំខាន់ប៉ុណ្ណោះ ។ អ្នកស្នងកន្លែងគាត់ ជាមេដឹកនាំពួកកុម្មុយនិស្តនៅទីក្រុង និងជាអ្នកទទួលខុសត្រូវធ្វើការទាក់ទងជាមួយជនបទគឺ សាឡុត ស និង អៀង សារី ដែលវិលត្រឡប់មកភ្នំពេញវិញកាលពីឆ្នាំមុន គឺឆ្នាំ១៩៥៧ ហើយចាប់ពីថ្ងៃនេះទៅអ្នកទាំងពីរបានកាន់កាប់ទីតាំងមួយ ដែលអនុញ្ញាតឲ្យពួកគេប្រើឥទ្ធិពលរបស់គេទៅលើក្រុមនិយមឆ្វេងទាំងអស់នៅក្រុងភ្នំពេញ ។

ទូ សាមុត អ្នកទទួលខុសត្រូវលើសកម្មភាពទាំងអស់របស់ពួកកុម្មុយនិស្តក្នុងទីក្រុងទាំងធំទាំងតូច មិនសូវបានស្ថិតនៅក្នុងរាជធានីប៉ុន្មានទេ ។ គាត់រស់នៅតាមជនបទក្បែរព្រំដែនវៀតណាមជាមួយ ស៊ីវ ហេង ភ្នាក់ងារសម្ងាត់របស់សម្តេច ព្រះនរោត្តម សីហនុ ដែលនៅទទួលមើលខុសត្រូវតំបន់ជនបទនានានៅឡើយ ។ ភាពញែកឃ្លាតពីគ្នាមានកាន់តែជ្រៅទៅរវាងពួកកុម្មុយនិស្តនៅទីក្រុង និងចលនាកុម្មុយនិស្តដែលកំពុងរកកលដួលរលំទាំង

ស្រុងនៅជនបទ ។ យុទ្ធសាស្ត្ររបស់ក្រុមប្រជាជនត្រូវបរាជ័យ ពួកកុម្មុយនិស្តនៅទីក្រុងភ្នំពេញ ក៏បន្ថយដែនប្រតិបត្តិការរបស់គេដែរៈ របៀបប្រើរូបភាពគណបក្សនយោបាយស្របច្បាប់ ដើម្បីជះឥទ្ធិពលទៅលើប្រជាជននៅក្នុងប្រទេសជាតិឃើញថា មានគ្រោះថ្នាក់ខ្លាំងណាស់ ។ ក្រោយឆ្នាំ១៩៥៨ ពួកគេបានរៀបចំធ្វើសកម្មភាពតាមរយៈចលនា និងកាសែតគ្មានច្បាប់អនុញ្ញាតទាំងឡាយរបស់គេវិញ ហើយចាប់ផ្តើមជ្រៀតចូលក្នុងរដ្ឋាភិបាលយ៉ាងស្ងាត់ៗ ។

ដោយជឿទុកចិត្តកាន់តែខ្លាំងឡើងៗ សម្តេច ព្រះនរោត្តម សីហនុ លែងព្រួយបារម្ភពីផលវិបាកផ្សេងៗដែលកើតឡើងពីការធ្វើទុក្ខបុកម្នេញ ទៅលើពួកកុម្មុយនិស្តក្រៅផ្លូវច្បាប់របស់ព្រះអង្គ និងមិត្តភាពដែលទើបនឹងចាប់កំណើតរបស់ព្រះអង្គជាមួយបណ្តាមហាអំណាចកុម្មុយនិស្តបរទេសទៀតហើយ ។ អំពីចំណុចក្រោយនេះ ព្រះអង្គមានការជ្រើសរើសមិនច្រើនទេ ។ យៀម បានសម្តែងខ្លួនឡើងជាសត្រូវម្នាក់ ហើយបានបង្កឧប្បត្តិហេតុតូចៗជាច្រើននៅតាមព្រំដែន ដែលតាមការយល់ឃើញរបស់សម្តេច ព្រះនរោត្តម សីហនុ ថា នេះជាផ្នែកមួយនៃផែនការរបស់អាមេរិកាំង ដើម្បីអូសទាញប្រទេសកម្ពុជាឲ្យធ្លាក់ទៅក្នុងបរិយាកាសសង្គ្រាម ដែលករជារូបរាងឡើងនៅវៀតណាមខាងត្បូង ។ សម្តេចបានពង្រឹងជំហរប្រឆាំងចក្រពត្តិរបស់ព្រះអង្គហើយ បានដៀលត្មេះការប៉ុនប៉ងទាំងឡាយរបស់សហរដ្ឋអាមេរិក ដើម្បីត្រួតត្រាពិភពលោកថែមទៀត ដោយទ្រង់នៅតែបន្តទទួលជំនួយអាមេរិកាំងដដែល ដើម្បីទូទាត់ចំណាយសម្រាប់កងទ័ព និងធ្វើឲ្យសេដ្ឋកិច្ចរបស់ព្រះមានតុល្យភាព ។

គឺស្ថានភាពដ៏លំបាកស្មុគស្មាញនេះហើយ ដែលលើកតម្លៃព្រះប្រមុខរដ្ឋរបស់កម្ពុជាឲ្យមានកេរ្តិ៍ឈ្មោះល្បីល្បាញជាអន្តរជាតិ ដូចតួអង្គ ដុន គីឆុត *(don-quicchottesque)* និងជាស្តេច "ដែលឆាប់ញោចជាងគេ" បានដាក់សម្មតិនាមព្រះអង្គថា "ស្តេចដើរលើខ្សែពួរ" មានន័យថា ជាមនុស្សរេរា (ម្តងងាកទៅណេះម្តងងាកទៅណោះ) ។ កេរ្តិ៍ឈ្មោះដ៏ល្បីល្បាញនេះ បានធ្វើឲ្យពួកកុម្មុយនិស្តខ្មែរបាត់បង់លទ្ធភាពទិតៀនសម្តេច ព្រះនរោត្តម សីហនុជាសាធារណៈ ។ ពួកកុម្មុយនិស្តក៏ជាអ្នកដើរលើខ្សែពួរដូចគ្នា ។ តើគេចាត់ទុកមនុស្សម្នាក់ ដែលយល់ព្រមទទួលស្គាល់សាធារណរដ្ឋប្រជាមានិតចិនតាមផ្លូវច្បាប់ និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មមួយជាមួយប្រទេសវៀតណាមខាងជើងថា ជាអ្នកចក្រពត្តិនិយមបានដែរឬទេ? ពួកកុម្មុយនិស្តបានអះអាងនៅពេលក្រោយមកទៀតថា គឺពួកគេជាអ្នកជំរុញឲ្យសម្តេច ព្រះនរោត្តម សីហនុ ប្រកាន់យកជំហរទាំងនេះ ប៉ុន្តែវាពុំសូវមានភស្តុតាងសម្រាប់បញ្ជាក់ដល់ការពោលអាងនេះទេ ។

នៅសម័យនោះ យុទ្ធិកជនពីររូបក្នុងចំណោមយុទ្ធិកជនជាច្រើន ដែលមានទេពកោសល្យរបស់បក្សកុម្មុយនិស្តបានចូលរួមក្នុងរដ្ឋាភិបាលរបស់សម្តេច ព្រះនរោត្តម សីហនុ គឺ ហ៊ូ យន់ ដែលជាអ្នកសរសេរនិក្ខេបបទនៅឆ្នាំ១៩៥៥ ស្តីពីប្រជាកសិករខ្មែរ និង ហូ នឹម ដែលក្រោយមកបានសរសេរនិក្ខេបបទថ្នាក់បណ្ឌិតមួយ ដោយទាញហេតុផលជាសំអាងស្តីពីជីវភាពរស់នៅរបស់ប្រជាកសិករកម្ពុជា ។ អ្នកទាំងពីរបានក្លាយទៅជាសមាជិ

គណបក្សរបស់សម្ដេច ហើយបានផ្ដល់ព័ត៌មានផ្សេងៗស្ដីពីរបបនេះទៅឲ្យពួកកុម្មុយនិស្ដផង ។ ប៉ុន្តែ អ្នកទាំងពីរក៏បានក្លាយទៅជាមនុស្សដែលក្រុមនិយមស្ដាំចាំតែទម្លាក់កំហុសគ្រប់បែបយ៉ាងទៅលើដែរ -ជាមុខតំណែងដែលសម្ដេច ព្រះនរោត្តម សីហនុ ទុកព្រះទ័យផ្ដល់ឲ្យ ប្រហែលជាទ្រង់ចង់បោកបញ្ឆោតផងក៏មិនដឹង)- ហើយពីរឆ្នាំក្រោយមកអ្នកទាំងពីរ បានត្រូវខ្ទាតចេញពីរដ្ឋាភិបាល ក្នុងក្របខ័ណ្ឌនៃយុទ្ធនាការលើកដំបូងរបស់សម្ដេច ព្រះនរោត្តម សីហនុ ប្រឆាំងនឹងក្រុមនិយមឆ្វេងជាសាធារណៈ ។

សង្គ្រាមស្ងាត់ស្ងៀមរវាងសម្ដេច និងពួកកុម្មុយនិស្ដបានឈានចូលក្នុងដំណាក់មួយថ្មីដែលប្រកបដោយគ្រោះថ្នាក់ជាងពេលមុនទៅទៀត ។ សំឡេងគ្រាប់កាំភ្លើង ដែលកំណត់នូវការចាប់ផ្ដើមសង្គ្រាមនេះ បានត្រូវប៉ូលិសបាញ់ទៅលើនិពន្ធនាយកកាសែតកុម្មុយនិស្ដមួយឈ្មោះប្រជាជន នៅថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៥៩ ។ បុគ្គលនេះ ស្លាប់ពីរថ្ងៃក្រោយមកទៀត ។ សម្ដេច ព្រះនរោត្តម សីហនុ បានថ្លែងផ្ដន្ទាទោសឃាតកម្មនេះជាផ្លូវការ ប៉ុន្តែរដ្ឋមន្ត្រីស្រួងឃោសនាការរបស់ព្រះអង្គគឺ ឡុង បូរ៉េត បានឆ្លៀតយកឱកាសនេះ ដើម្បីទិតៀនកាសែតនិយមឆ្វេងមួយទៀត ដោយមិនបញ្ចេញឈ្មោះថា បាន«ប្រើប្រាស់»ឃាតកម្មនេះ ដើម្បីស្រោចការសង្ស័យផ្សេងៗមកលើរដ្ឋាភិបាល ។ តាមការពិត «អ្វីដែលសមហេតុសមផលជាងគេ» ក្នុងរឿងនេះ គឺថាឧត្តមសេនីយ៍ លន់ នល់ អ្នកទទួលខុសត្រូវលើកងទ័ព និងប៉ូលិសបានបញ្ជាឲ្យគេធ្វើការបាញ់សម្លាប់នេះក្រោយពេលដែលសម្ដេច ព្រះនរោត្តម សីហនុ មានព្រះបន្ទូលប្រាប់គាត់ថា កាសែតនេះបង្កឲ្យមានការលំបាកច្រើនណាស់ ដូចដែលស្ថានទូតអាមេរិកាំងប្រចាំក្រុងវ៉ាស៊ីនតោនដឹងរឿងនេះក្នុងរបាយការណ៍សម្ងាត់មួយនៅជំនាន់នោះដែរ[២៤] ។

យុទ្ធនាការធ្វើឃាតដោយចេតនា និងការបង្ក្រាប ដែលបានសម្លាប់រង្គាលពួកកុម្មុយនិស្ដនៅជនបទនៅពេលនេះ បានសង្គ្រប់មកលើពួកកុម្មុយនិស្ដនៅទីក្រុងដែរ ។ ប៉ុន្តែនៅភ្នំពេញ សង្គ្រាមនេះអាចប្រព្រឹត្តទៅបានតែក្នុងសភាពលួចលាក់ប៉ុណ្ណោះ ព្រោះគូប្រឆាំងទាំងអស់សុទ្ធតែស្គាល់មុខគ្នាច្បាស់ល្អណាស់ ។ ក្នុងរាជធានីពួកកុម្មុយនិស្ដអាចសង្ឃឹមលើក្រុមបញ្ញវន្តដែលមានវិជ្ជាជីវៈសេរី និងវណ្ណៈគហបតី ដែលកំពុងមានការរីកចម្រើនឡើងដើម្បីល្បងការពារសេរីភាពផ្សេងៗ និងថ្កោលទោសដល់អំពើឃោរឃៅគ្មានពិចារណាទាំងនោះ ។

មេដឹកនាំកុម្មុយនិស្ដ ដែលធ្វើការអំពាវនាវអំពីរឿងនេះ ដោយសំនួនវោហារដ៏ថ្លៃថ្នូរមួយចំពោះ ការយកចិត្តទុកដាក់នឹង«ល្បែងលេងដោយស្មោះត្រង់»នេះ គឺ ខៀវ សំផន ដែលទើបនឹងត្រឡប់មកពីក្រុងប៉ារីសក្នុងពេលថ្មីៗ និងជានិពន្ធនាយកកាសែតថ្មីមួយជាភាសាបារាំង គឺកាសែតអ្នកសង្កេតការណ៍ ជាកាសែតដែល ឡុង បូរ៉េត បានទិតៀនដោយមិនបញ្ចេញឈ្មោះនោះឯង ។ ភ្លាមនោះ សំផន បានញុាំងឲ្យក្រុមវរជននិយមភាសាបារាំងនៅទីក្រុង ជាពិសេសពួកនិស្សិតលុះក្នុងឥទ្ធិពលរបស់ខ្លួន ។ គាត់បានសរសេរអត្ថបទតាមទម្រង់ជាអ្នកកាសែតទាន់សម័យមួយ[២៥] ស្ដីពីព្រឹត្តិការណ៍ផ្សេងៗ ដែលកាសែតដទៃទៀតមិនដែលរវីរវល់ ដោយគេមានឯកទេសសរសេរតែអត្ថបទបញ្ចើចបញ្ចើសម្ដេច ព្រះនរោត្តម សីហនុ តែម្យ៉ាងប៉ុណ្ណោះ ។ សំផន បាននាំមុខធ្វើការអង្កេតទៅលើ

ផ្នែកមួយ បែបសង្គមសាស្ត្រស្តីពីតំបន់ដែលគេបិទបាំងនៅក្នុងរាជធានី ដោយលាតត្រដាងឲ្យឃើញពីទុគ៌ភាពរបស់ពួកអ្នកអត់ការងារធ្វើ ពួកអ្នកញៀនស្រា ពួកអ្នកធ្វើការមានវ័យក្មេងៗ «ដែលមានមុខដូចមនុស្សចាស់ និងបាត់បង់អស់នូវភាពសប្បាយរីករាយក្នុងវ័យយុវភាពរបស់ខ្លួន» ។

នៅពេលដែលនិពន្ធនាយកកាសែតប្រជាជន ត្រូវគេលួចសម្លាប់ សំផន បានសរសេរវិចារណកថាមួយ ដោយបង្ហាញឲ្យឃើញពីមាគ៌ាដឹកនាំរបស់បក្ស ដែលនៅបន្តភ្ជាប់ទស្សនៈរបស់ខ្លួនអំពីលទ្ធិប្រជាធិបតេយ្យទំនើបមួយ ទៅនឹងព្រះពុទ្ធសាសនាជាផ្លូវការតទៅទៀត ។ «ហេតុការណ៍ដែលនិពន្ធនាយកកាសែតមួយ ដែលបង្កើតឡើងស្របតាមផ្លូវច្បាប់ ដោយមានការអនុញ្ញាតរបស់រដ្ឋាភិបាលអាចត្រូវគេ វាយទាត់ធាក់តាមផ្លូវថ្នល់ដូចសត្វឆ្កែមួយនោះ គឺជាឧទាហរណ៍មួយនៃអាកប្បកិរិយាព្រៃផ្សៃ ដែលពុំធ្លាប់មានពីមុនមកសោះ នៅក្នុងប្រទេសកាន់ព្រះពុទ្ធសាសនាមួយដូចប្រទេសយើងនេះ»[២៦] ។

ប៉ុន្តែ អត្ថបទនេះពុំមានធ្វើការវាយប្រហារណាមួយប្រឆាំងនឹងសម្តេច ព្រះនរោត្តម សីហនុ ទេ ពីព្រោះប្រការនេះនឹងអាចនាំយក សំផន និងកាសែតរបស់គាត់ទៅតុលាការបាន ហើយថែមទាំងត្រូវជាប់គុកទៀតផង ។ សម្តេចបានសន្និដ្ឋានថា សំផន ជាអ្នកកាន់លទ្ធិកុម្មុយនិស្ត ហើយមានបន្ទូលពីរូបគាត់ព្រមទាំងបណ្តាសមមិត្ត ដែលមានគំនិតដូចគាត់ដែរនោះថា «ល្បិចកលរបស់គាត់ដូចធ្លាប់មានមកហើយនោះ ស្ថិតនៅត្រង់ថា «បើសិនអ្នកអត់ទោសឲ្យខ្ញុំ ពីរឿងនេះ ប្រៀបដូចជាអ្នកឱបថើបថ្ពាល់ខ្ញុំ ដោយធាក់ចំឆ្អឹងស្មងជើងខ្ញុំទៅវិញ...[២៧]» ។

កាសែតអ្នកសង្កេតការណ៍ ពុំត្រឹមតែត្រូវផ្តល់លុយកាក់ដោយពួកកុម្មុយនិស្តប៉ុណ្ណោះទេ តែគឺជាកាសែតរបស់ពួកកុម្មុយនិស្ត ដែលត្រឡប់មកពីប្រទេសបារាំង ដែលសម្តែងឲ្យឃើញជាអ្នកមានសមត្ថភាពធ្វើឲ្យ ប្រជាជនតាមដានអានច្រើនជាងគេនៅក្រុងភ្នំពេញ ។ អៀង ធីរិទ្ធ[២៨] ប្រពន្ធ អៀង សារី បានបង់ប្រាក់មួយភាគធំក្នុងការចំណាយផ្សេងៗសម្រាប់ដំណើរប្រព្រឹត្តទៅនៃកាសែត ដោយដកពីប្រាក់បៀវត្សរ៍របស់នាងជាគ្រូបង្រៀន ដែលកាន់មុខងារពីរ ។ នាងបាននិយាយរៀបរាប់ថា នៅសម័យនោះប្រពន្ធៗរបស់មេដឹកនាំកុម្មុយនិស្តមានករណីយកិច្ចធ្វើការជាច្រើនម៉ោងដើម្បីចិញ្ចឹមគ្រួសារផង និងទ្រទ្រង់បក្សផង នៅពេលដែលប្តីៗរបស់នាងចំណាយពេលវេលាបំពេញភារកិច្ចផ្សេងៗ ក្នុងការប្រយុទ្ធតស៊ូដើម្បីជោគជ័យនៃគណបក្សមួយ ដែលភាគច្រើនត្រូវគេបណ្តេញចេញពីការងារ ដែលផ្តល់ប្រាក់កម្រៃយ៉ាងច្រើន ។

នាងបាននិយាយថា «ខ្ញុំបានបញ្ឈប់សកម្មភាព ផ្សេងៗរបស់ខ្ញុំខាងនយោបាយ ដើម្បីអាចបង្រៀននៅក្នុងសាលាសាធារណៈមួយ ដែលបងស្រីរបស់ខ្ញុំ (ប្រពន្ធ ប៉ុល ពត) និងខ្ញុំសុទ្ធតែជាសាស្ត្រាចារ្យនៅវិទ្យាល័យ ។ ដោយហេតុថា គេត្រូវរៀបចំជីវភាពរស់នៅឲ្យបានប្រសើរជាងមុន ខ្ញុំត្រូវតែមានការងារមួយធ្វើ» ។

នេះជាសម័យដែលសម្តេច ព្រះនរោត្តម សីហនុ បង្កើនចំនួនសាលាសាធារណៈយ៉ាងច្រើនហើយមានគ្រូបង្រៀន ដែលមានសមត្ថភាពដូច ធីរិទ្ធ និងប៉ុណ្ណារី តិចតួចណាស់ ។ បរិញ្ញាប័ត្រខាងភាសាអង់គ្លេស ដែលនាងទទួល

ពីសាលា សរ័បោន បានផ្តល់នូវអត្ថប្រយោជន៍ជាពិសេសសម្រាប់ធីរិទ្ធ ដោយនាយកវិទ្យាល័យរបស់នាង បានស្នើនាងឲ្យកាន់មុខងារពីរ ។ នាងទទួលយល់ព្រមភ្លាមៈបក្សត្រូវការលុយកាក់នេះ ។

នៅពេលដែលសម្តេច ព្រះនរោត្តម សីហនុ ប៉ុនប៉ងស្រឡាញ់រាប់អានធីរិទ្ធ -និងប្តីរបស់នាងប្រហែលតាមរយៈរូបនាង- ដោយប្រគល់មុខតំណែងមួយ នៅក្នុងរដ្ឋាភិបាល នាងបានបដិសេធតាមបញ្ជារបស់បក្ស ។ គេសង្ស័យលើរូបនាងថា នាងនឹងរកប្រាក់បានយ៉ាងច្រើនសម្រាប់ទ្រទ្រង់កាសែត និងសកម្មភាពផ្សេងៗទៀត ។ “ដោយខ្ញុំអាចបង្រៀន ម៉ោងបន្ថែមបានច្រើនម៉ោង តាមដែលចិត្តខ្ញុំចង់ (នៅវិទ្យាល័យ) ខ្ញុំរកបានប្រាក់ក្រាស់ក្រែលណាស់ ល្មមគ្រប់គ្រាន់សម្រាប់សង់វីឡាមួយឬទិញរថយន្តមួយបាន ប៉ុន្តែ ខ្ញុំមិនធ្វើអ្វីទាំងអស់” ។

ក្នុងពេលដំបូងៗ ពួកកុម្មុយនិស្តបានស្នើសុំលុយកាក់ពីពួកសូវៀត ។ ធីរិទ្ធបានរៀបរាប់ថា “យើងបានទទូចសុំខ្ចីប្រាក់ចំនួនដប់ពាន់រៀលប៉ុណ្ណោះ ពីឯកអគ្គរដ្ឋទូតសូវៀតប្រចាំក្រុងភ្នំពេញ ប៉ុន្តែ គាត់បានបដិសេធ” ។ នៅឆ្នាំ១៩៥៩ពួកកុម្មុយនិស្តកម្ពុជាពុំទាន់មានការទាក់ទងជាមួយពួកចិនទេ ហើយពួកកុម្មុយនិស្តនៅរាជធានីមានអារម្មណ៍ថា បណ្តាសមមិត្តនៃបក្សជាបងប្អូនបានបោះបង់ពួកគេចោលជាថ្មីម្តងទៀតហើយ ។

គឺនៅក្នុងកំឡុងឆ្នាំដដែលនោះហើយ ដែល ស៊ីវ ហេង មេដឹកនាំរបស់គេបានសុំចុះចូលជាមួយសម្តេច ព្រះនរោត្តម សីហនុ ជាសាធារណៈ ជាអំពើក្បត់ដែលពួកគេមិនដែលគិតទុកជាមុនសោះ ។ កាលពីមុន បញ្ហាផ្សេងៗរបស់ពួកកុម្មុយនិស្តនៅតំបន់ជនបទ ហាក់ដូចជាជាប់ទាក់ទងទៅនឹងប្រជាប្រិយភាពរបស់សម្តេច ព្រះនរោត្តម សីហនុ និងប៉ូលិសរបស់ព្រះអង្គជាសំខាន់ ។ កសិករទាំងឡាយមើលឃើញព្រះអង្គពុំត្រឹមតែជាទេវរាជាមួយអង្គប៉ុណ្ណោះទេ ប៉ុន្តែ ជាអ្នកស្នេហាជាតិមាតុភូមិដំបូងរបស់ប្រទេស ហើយប៉ូលិសរបស់ព្រះអង្គក៏ធ្វើអ្វីៗបានសម្រេចលទ្ធផលល្អដែរ ។ ការបោះបង់ចោលបក្សពួករបស់ ស៊ីវ ហេង ជាអ្នកទទួលខុសត្រូវតំបន់ជនបទ បានធ្វើឲ្យកើតមានការមិនទុកចិត្តគ្នាផ្សេងៗទៀតនៅក្នុងជួររបស់ចលនា ដែលកំពុងទន់ខ្សោយស្រាប់ ។

ពួកកុម្មុយនិស្តនៅតាមតំបន់ជនបទនានា បានត្រូវគេចាប់ខ្លួន និងយកទៅដាក់គុកជារឿយៗ បើទុកជាពួកគេបានយល់ព្រមនឹងយុទ្ធសាស្ត្រមួយក្នុងការតស៊ូនយោបាយប្រឆាំងទល់នឹងសម្តេច ព្រះនរោត្តម សីហនុ ដោយមិនប្រើអាវុធ និងគោរពច្បាប់ភូមិបាលក៏ដោយ ។ ប៉ុន្តែ តាមការឲ្យដឹងរបស់បក្សថា យុទ្ធិកជនរបស់ខ្លួនក្នុងតំបន់ជនបទចំនួនកៅសិបភាគរយ បានត្រូវវង់គ្រោះដោយសារប៉ូលិស ដោយការភ័យខ្លាចប៉ូលិស ឬដោយការព្រួយបារម្ភទូទៅ ។ នៅពេលជិតឈានចូលដល់ឆ្នាំថ្មី ពួកកុម្មុយនិស្តកម្ពុជាស្ថិតក្នុងសភាពរិះតែរលត់រលាយទៅហើយនៅក្នុងជនបទនានា ហើយវង្វង់ប្រតិបត្តិការរបស់គេនៅក្នុងទីក្រុងនានាក៏កាន់តែរួញតូច ។ សម្តេច ព្រះនរោត្តម សីហនុ ជាសម្ព័ន្ធមិត្តដ៏មានតម្លៃម្នាក់របស់ពួកកុម្មុយនិស្តវៀតណាម និងចិន ជាអ្នកគាបសង្កត់ពួកកុម្មុយនិស្តដ៏ប៉ិនប្រសប់ម្នាក់ នៅក្នុងប្រទេសផ្ទាល់របស់ព្រះអង្គ ។ នៅឆ្នាំ១៩៦០ពួកកុម្មុយនិស្តកម្ពុជា បានប្រមូលផ្តុំកិច្ចប្រឹងប្រែងរបស់គេសំដៅ បើកធ្វើមហាសន្និបាតបក្សមួយ ជាគោលដៅមួយដែលពួកគេបានកំណត់កាលពីពេលមុន

នេះ ហើយមានទទួលដំណឹងបន្ទាន់មួយថា ចលនារបស់គេហាក់ដូចជារអិលធ្លាក់ទៅក្នុងការបំភ្លេចខាងនយោបាយទៅហើយ ។ មហាសន្និបាតនេះ មានករណីកិច្ចប្រមូលបណ្ដាអ្នកតំណាងតំបន់ជនបទ និងទីក្រុងនានាឡើងវិញក្នុងគោលបំណងបង្រួបបង្រួមផ្នែក ដែលមិនសូវស៊ីខ្សែគ្នាឡើងវិញ និងបង្កើតបក្សម៉ាកលេនីន ពិតប្រាកដមួយសម្រាប់ប្រទេសកម្ពុជាផង ។

នេះពុំមែនជាបាតុភូតមួយដាច់ឡែកពីគេនោះទេ ។ វាជាការនិយាយឡើងវិញនូវសេចក្ដីសម្រេចចិត្តផ្សេងៗ កាលពីមុនរបស់ពួកកុម្មុយនិស្តវៀតណាម ដែលវាទំនងជាលទ្ធផល ដែលសន្និបាតនេះបានសម្រេចដែរ ។ ក្នុងសម័យប្រជុំជាច្រើនលើករបស់គណៈកម្មាធិការមជ្ឈិមបក្សពលករវៀតណាម ដែលបើកធ្វើនៅខែមករា និងខែឧសភា ឆ្នាំ១៩៥៩ ក្រុងហាណូយ បានសម្រេចអនុញ្ញាតឲ្យពួកកុម្មុយនិស្ត នៅភាគខាងត្បូងវៀតណាមផ្លាស់ប្ដូរពីការតស៊ូនយោបាយទៅការតស៊ូដោយអាវុធប្រឆាំងនឹងរបបរបស់ ង៉ូ ឌិញយៀម វិញ ។ ពួកកុម្មុយនិស្តភាគខាងជើងបានយល់ព្រមចំពោះការប្រើប្រាស់ «ហិង្សាបដិវត្ត ដើម្បីទល់នឹងហិង្សាប្រឆាំងបដិវត្តន៍»[១៤] របស់យៀម ដែលប្រព្រឹត្តទៅលើប្រជាជននៅភាគខាងត្បូង និង«ការពឹងផ្អែកការតស៊ូដោយអាវុធរួមផ្សំនឹងការតស៊ូនយោបាយ»ទៀត ។ ពួកវៀតណាមខាងជើង បានចាប់ផ្ដើមត្រួសត្រាយធ្វើផ្លូវលំ ហូជីមិញ ដែលបាញ់ឆ្ពោះមកភាគខាងត្បូង ហើយបញ្ជូនគ្រឿងសម្ភារបរិក្ខារនិងមនុស្សយ៉ាងច្រើនមកជាមួយផង ។

នៅប្រទេសឡាវ សេចក្ដីសម្រេចដូចគ្នាមួយត្រូវបានប្រកាន់យក ហើយចលនាប៉ាថេតឡាវ ដែលដឹកនាំដោយពួកកុម្មុយនិស្តឡាវបានផ្ដើមប្រឡូកក្នុងការតស៊ូប្រដាប់អាវុធជាចំហ ហើយបានបោះបង់ចោលការតស៊ូផ្នែកនយោបាយសុទ្ធសាធក្នុងផ្ទៃរដ្ឋាភិបាលចម្រុះមួយ ដែលហៀបនឹងរលំទៅហើយ ។ ក្នុងឱកាសមហាសន្និបាតលើកទី១ ពួកឡាវបានបង្កើតបក្សផ្ទាល់របស់គេ គឺបក្សប្រជាជនបដិវត្តន៍ឡាវ ហើយត្រូវបានប្រកាសជាសាធារណៈនៅថ្ងៃទី២២ ខែមីនា ឆ្នាំ១៩៥៥ ។ នៅឆ្នាំ១៩៦០ កងទ័ពនិងមូលដ្ឋាននានារបស់ខ្លួនក្នុងខេត្តពីរដែលជាប់ព្រំដែននឹងវៀតណាមខាងជើង ហើយដែលធានាដោយកិច្ចព្រមព្រៀងក្រុងហ្សឺណែវ បានរួមវិភាគទានយ៉ាងសំខាន់ដល់កិច្ចការពារផ្លូវលំ ហូជីមិញ ព្រមទាំងជួយដល់ការធ្វើឲ្យសម្រេចនូវគោលដៅផ្សេងៗរបស់ពួកកុម្មុយនិស្តឡាវខ្លួនឯងផង គឺយកឈ្នះពួកអាមេរិកាំងក្នុងប្រទេសផ្ទាល់ ។ ពួកកុម្មុយនិស្តកម្ពុជាមិនទាន់មានជំហរអួតអំពីការតស៊ូប្រឆាំងនឹងសម្ដេច ព្រះនរោត្តម សីហនុ ដោយអាវុធទេ ។ ជាបឋម ពួកគេត្រូវតែបង្កើតបក្សមួយជាមួយនឹងសំណល់ដែលនៅមានជាដំណែលរបស់ចលនាខ្លួនសិន ។

ការបង្កើនល្បឿនដំណើរបន្តគ្នានៃសកម្មភាពបដិវត្តន៍នៅវៀតណាមខាងត្បូង ឡាវ និងកម្ពុជា គឺពិតជាដឹកនាំដោយក្រុងហាណូយយ៉ាងប្រាកដ ។ ពួកវៀតណាមខាងជើងនឹកសង្ឃឹមទទួលជ័យជម្នះទាំងស្រុង ក្នុងប្រទេសវៀតណាមទាំងមូលមុនរយៈពេល១០ឆ្នាំយ៉ាងយូរ ។ នេះជាគោលដៅដែលតាមពួកគេថា ទាមទារឲ្យមានយុទ្ធសាស្ត្រមួយក្នុងកម្រិតឥណ្ឌូចិនទាំងមូល ។ ប៉ុន្តែ ឋានៈនាទីរបស់ប្រទេសកម្ពុជាក្នុងផែនការទាំងនេះឃើញថា

ជាបញ្ហាអចិន្ត្រៃយ៍មួយសម្រាប់ក្រុងហាណូយ ។

ក្នុងអំឡុងពេលនេះ សម្តេច ព្រះនរោត្តម សីហនុ បានគិតបម្រុងរៀបចំគម្រោងផែនការផ្សេងៗយ៉ាងមោះមុត ដើម្បីពង្រឹងអំណាចរបស់ខ្លួន និងចាត់ការដោះស្រាយបញ្ហាពួកកុម្មុយនិស្តក្នុងប្រទេសផ្ទាល់របស់ព្រះអង្គ ។ ព្រះមហាក្សត្រ ដែលជាព្រះបិតារបស់ព្រះអង្គបានសោយទិវង្គតនៅឆ្នាំ១៩៦០ ហើយអំណើះតទៅ សម្តេច ព្រះនរោត្តម សីហនុ ប្រាថ្នាដឹកនាំប្រទេសជាតិ ក្នុងឋានៈជាព្រះប្រមុខរដ្ឋម្នាក់វិញ ។ ដើម្បីរៀបចំរឿងនេះ តាមការយល់ឃើញរបស់ព្រះអង្គ គឺតោងតែបង្ក្រាបក្រុមនិយមឆ្វេងឲ្យស្ងាត់ស្ងៀមសិន ។ នៅពេលនោះ ការចេញផ្សាយរបស់កាសែត អ្នកសង្កេតការណ៍រួមជាមួយកាសែតភាសាខ្មែរនិយមឆ្វេងបីទៀត គឺកាសែតប្រជាជន មិត្តភាព និងឯកភាព បានកើនឡើងដល់ដប់ពាន់ច្បាប់ ។ សម្តេច ព្រះនរោត្តម សីហនុ បានចាប់ផ្តើមធ្វើយុទ្ធនាការមួយប្រឆាំងនឹងពួកអ្នកកាសែតរបស់គេ ដែលមានប្រជាប្រិយភាពបំផុត ។ ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៦០ ក្រុមប៉ូលិសបានចាប់ ខៀវ សំផន វាយតប់ទាំងកណ្តាលថ្ងៃ ។ មនុស្សដប់នាក់ បានបញ្ឈប់គាត់ ទាញគាត់ទម្លាក់ពីលើកង់ ហើយបានវាយដំគាត់ទាល់តែទ្រមខ្លួន ។ បន្ទាប់មក ពួកគេបានថតរូបគាត់ ហើយបានចែកផ្សាយរូបថតទាំងនោះក្នុងក្រុងភ្នំពេញទាំងមូល ។

សំផន និងពួកកាសែតដទៃទៀត បានត្រូវគេចាប់ខ្លួនជាសម្ងាត់ កាសែតរបស់ពួកគេត្រូវបិទទ្វារ សមាជិកជាបុគ្គលិកកាសែតត្រូវគេចាប់យកទៅញាត់គុក ឬសួរចម្លើយ ។ សម្តេច ព្រះនរោត្តម សីហនុ បានអះអាងជាឯកជនថា ព្រះអង្គបានបំផ្លាញគម្រោងការធ្វើរដ្ឋប្រហារមួយរបស់ពួកកុម្មុយនិស្ត ដែលជាការអះអាងគ្មានមូលដ្ឋានច្បាស់លាស់សោះ ។ សម្តេចចង់ដណ្តើមយកក្រុមនិយមឆ្វេងពីមូលដ្ឋានរបស់ខ្លួន ដែលមានក្នុងវណ្ណៈបញ្ញវន្តយ៉ាងជាក់ច្បាស់ ប៉ុន្តែ គេមិនដឹងថាហេតុអ្វីបានជាព្រះអង្គយល់ឃើញថា ត្រូវពឹងលើការប្រើកម្លាំងបាយបែបហ្នឹងឡើយ ។ សំផន បានស្ថិតនៅក្នុងគុកអស់រយៈពេល២ខែ ដោយគ្មានការចោទប្រកាន់ពីបទល្មើសអ្វីមួយឡើយ ។ គាត់ត្រូវគេ ដោះលែងមកវិញនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៦០ ដោយគ្មានការបញ្ជាក់បំភ្លឺណាមួយដែរ ។ មួយសប្តាហ៍ក្រោយមក មហាសន្និបាតលើកដំបូងរបស់ពួកកុម្មុយនិស្តកម្ពុជា បានចាប់ផ្តើមបើធ្វើនៅក្នុងទូរថភ្លើងទំនេរជាច្រើន ដែលចតនៅក្នុងឃ្លាំងធំនៃស្ថានីយអយស្ម័យយានក្រុងភ្នំពេញ ។

## ចលនាខ្មែរក្រហម

ពួកកុម្មុយនិស្ត ដែលរួមប្រជុំក្នុងទូរថភ្លើងទាំងនេះនៅខែកញ្ញា ឆ្នាំ១៩៦០ ប្រហែលជាវិនិច្ឆ័យពីស្ថានភាពរបស់គេដែលស្ទើរតែអស់សង្ឃឹមទៅហើយមើលទៅ ប៉ុន្តែ ពួកគេបានរៀបចំបង្កើតជាក្រុមយ៉ាងរឹងមាំមួយ ទោះបីជាយុទ្ធិកជនរបស់ខ្លួនបានចុះថយក្នុងកំឡុងប្រាំឆ្នាំ នៃការធ្វើសកម្មភាពកសាងអង្គការបក្ស នៅក្នុងរាជធានីពីឆ្នាំ១៩៥៥ដល់ឆ្នាំ១៩៦០ក៏ដោយ ។ ពួកគេមានគ្រោងឆ្អឹងជាបក្សកុម្មុយនិស្តមួយ ហើយក្រោយមក កងទ័ព

មួយ ។ ការយល់ស្របដែលឲ្យប្រយោជន៍បំផុត ដែលពួកគេទៅរក គឺក្នុងចំណោមពួកនិស្សិតទាក់ទងនឹងឋានៈគេជាគ្រូបង្រៀន ឬអ្នកនិពន្ធដែលនេះជាចំណុចចេញដំណើរតែមួយដូចគ្នា សម្រាប់ចលនាកុម្មុយនិស្តទាំងអស់ ក្នុងពិភពលោកទាំងមូល ។ ពួកគេបានបង្រៀនក្នុងសាលាសាធារណៈ និងឯកជនជាច្រើន នឹងបោះពុម្ពផ្សាយកាសែតផ្ទាល់របស់គេ ហើយក្នុងសារមួយដែលពាំនាំការជឿជាក់ក្នុងចិត្ត បានអំពាវនាវឲ្យយុវជនកម្ពុជាកម្ចាត់របៀបរបបសក្តិភូមិ ដែលធ្វើឲ្យបរិយាកាសនៅភ្នំពេញអាប់អួ និងប្រយុទ្ធ តស៊ូដើម្បីលទ្ធិប្រជាធិបតេយ្យទំនើប និងម៉ឺងម៉ាត់មួយ ។

យុវជនម្នាក់ក្នុងចំណោមយុវជន ដែលធ្វើតាមការអំពាវនាវនេះ គឺក្មេងកំព្រាម្នាក់រស់នៅខេត្តឈ្មោះប៉ុល ពត[៣០] ។ គាត់ជាតំណាងនៃតួយ៉ាងគំរូសម្រាប់និស្សិតកុម្មុយនិស្តជាច្រើនដែលមកពង្រីកជួរចលនាខ្មែរក្រហមដែលទើបចាត់កំណើតនោះឲ្យរីកធំឡើង ហើយបន្ទាប់មកបានធ្វើឲ្យគាត់ប្រែក្លាយពីមនុស្សល្អទៅអាក្រក់វិញដោយសារសង្គ្រាម និងការបដិវត្តន៍ ។ ផាត បានក្លាយខ្លួនជានាយទាហាន អ្នកធ្វើការក្នុងការិយាល័យ បន្ទាប់មកជាពេជ្ឈឃាត ហើយនៅទីបំផុតជាអ្នករងគ្រោះម្តង ។ នៅពេលដែលពួកកុម្មុយនិស្តបង្កើតបក្សរបស់គេ នៅឆ្នាំ ១៩៦០ ផាត់ នៅពុំទាន់ដឹងថាជនកុម្មុយនិស្តម្នាក់ត្រូវធ្វើយ៉ាងម៉េចផងទេ ។

កើតនៅឆ្នាំ១៩៣៨ ជាកូនពៅរបស់គ្រួសារមួយ ដែលមានកូន៧នាក់ រស់នៅក្នុងកសិដ្ឋានមួយ នៅខេត្តតាកែវ ។ ឪពុកម្តាយរបស់គាត់បានទទួលមរណភាពនៅពេលដែល ផាត មានវ័យនៅក្មេងនៅឡើយ គាត់ត្រូវបានចិញ្ចឹមបីបាច់ដោយបងស្រីនិងបងប្រុសច្បងរបស់គាត់ ។ អ្នកទាំងពីរបានបញ្ជូនគាត់ ទៅរៀនសូត្រក្នុងសាលាជាច្រើនរបស់ខេត្តរហូតដល់អាយុ១៦ឆ្នាំ បន្ទាប់មកគាត់បានចាប់ផ្តើមសិក្សាវិជ្ជាផ្នែកព្រះពុទ្ធសាសនានៅក្នុងវត្តមួយ ។ នេះគឺជាទំនៀមទម្លាប់មួយសម្រាប់ក្មេងប្រុសៗ នៅតាមជនបទដែលត្រូវឆ្លងកាត់ការរៀនសូត្រមួយរយៈពេលនៅតាមវត្តនានា ដោយគ្មានបំណងប្រែក្លាយខ្លួនជាបព្វជិតឡើយ ។

នៅក្នុងវត្តផាតជាកូនសិស្សដ៏ល្អម្នាក់ យល់ជាក់អំពីធម៌អាថ៌ព្រះពុទ្ធសាសនា ព្រះវិន័យដោយចេះចាំរត់មាត់មួយភាគធំ ហើយបានទម្លាប់ខ្លួនទៅនឹងវត្តប្រណិប័តយ៉ាងតឹងរ៉ឹងក្នុងការរៀនសូត្រនេះផង ។ ក្នុងរយៈមួយឆ្នាំគាត់ទទួលសញ្ញាប័ត្រមួយជាលើកដំបូង ហើយនៅឆ្នាំ១៩៥៥ក្នុងអាយុ១៧ឆ្នាំ គាត់ធ្វើដំណើរមកកាន់ក្រុងភ្នំពេញដើម្បីត្រៀមរៀនសូត្រប្រឡងយកសញ្ញាប័ត្របន្ទាប់ទៀតក្នុងវត្តមួយនៅរាជធានី ។ គាត់បានទៅរស់នៅជាមួយបងប្រុសច្បងរបស់គាត់ ដែលធ្វើទាហានឆ័ត្រយោងក្នុងកងទ័ពរបស់សម្តេច ព្រះនរោត្តម សីហនុ ។

ទោះណាជាគាត់បន្តធ្វើខ្លួនជាសិស្សដ៏ប្រសើរម្នាក់ក្នុងវត្តថ្មីនេះក៏ដោយ ក៏យុវបុរស ផាត ត្រូវធ្វើឲ្យល្អក់កករចិត្ត ដោយសាភាពប៉ះទង្គិចជាលើកដំបូងជាមួយនឹងសកម្មភាពគគ្រឹកគគ្រេងនៃទីក្រុងឆ្ងាយពីស្រុកស្រែចម្ការនិងភូមិស្រុកដែលគាត់ធ្លាប់រស់នៅ ។ គាត់បានចាប់ផ្តើមរៀនសូត្រចំណេះវិជ្ជាទូទៅបន្តទៀត ហើយគាត់បានចុះឈ្មោះចូលរៀនក្នុងវិទ្យាល័យឯកជនមួយឈ្មោះកម្ពុជបុត្រ ។ នៅសាលានោះ ការរៀនយកចំណេះវិជ្ជា

ដូចជាមិនសូវតឹងរ៉ឹងប៉ុន្មានដូចគ្រឹះស្ថានសិក្សាសាធារណៈឡើយ ការរៀនសូត្រទៀតសោតក៏មានកម្រិតមួយទាបជាងដែរ ។ វិទ្យាល័យនេះជាជម្រកមួយរបស់បណ្ដាយុវជនកុម្មុយនិស្តជាច្រើននាក់ ជាកន្លែងដែល ផាត មិនធ្លាប់ដែលដឹងសោះ ។

ជីវិតរបស់គាត់បានផ្លាស់ប្ដូរភ្លាមមួយរំពេច ដ្បិតអីទាំងវត្តទាំងបន្ទាយទាហានឆត្រយោងពុំបានផ្ដល់ឲ្យគាត់មានមិត្តភក្តិច្រើនដូចគេឡើយ ។ ទីក្រុង ដែលមានប្រជាជនសាមសិបម៉ឺននាក់[៣១] មានសភាពហាក់ដូចជាកន្លែងមួយធំណាស់ចំពោះចក្ខុគាត់ ហើយរបៀបរបបរស់នៅនៅទីនេះ ជួនកាលមានសភាពរំលោភបំពានលើគ្នាថែមទៀត ។ ប៉ុន្តែ ក្នុងសាលាថ្មីរបស់គាត់ៗ រកបានមិត្តភក្តិយ៉ាងច្រើនជាងពួកអ្នកទីក្រុង ដែលមានចិត្តគំនិតស្អាតស្អំល្អ ជាពិសេស ពួកម៉ាកដ៏ជិតស្និទ្ធម្នាក់ដែលអញ្ជើញគាត់ទៅលេងផ្ទះរបស់គេជារឿយៗ ។ មិត្តរួមថ្នាក់នេះ គឺកូនប្រុសរបស់លោក ណុប បូផាន់ ជាជនកុម្មុយនិស្តលាក់មុខម្នាក់ ដែលប៉ូលិសរបស់សម្ដេច ព្រះនរោត្ដម សីហនុ បានលួចសម្លាប់បីឆ្នាំក្រោយមកទៀត ។ ផាត បានរក្សាទុកអនុស្សាវរីយ៍ដ៏រំភើបចិត្តមួយអំពីការជួបជុំគ្នាជាច្រើន នៅផ្ទះរបស់ បូផាន់ ជាពិសេសការកម្សាន្តល្បែងវាយសីរបៀបប៉ាកលើយរៀងរាល់ល្ងាចជាមួយយុវជនក្មេងៗ ដែលសុទ្ធតែជាអ្នកកាសែតរបស់ "ក្រុមប្រជាជន" ទាំងអស់ ។ ផាត មានអារម្មណ៍ថា ខ្លួនបានរកឃើញគ្រួសារថ្មីមួយដែលគោរពគាត់ ដោយ "សេចក្ដីរាប់អាន" "មិត្តភាព" ហើយក្រោយមកមិនដល់មួយឆ្នាំផង គាត់បានចូលធ្វើការនៅអគ្គភាពកាសែតមួយឈ្មោះ ប្រជាជន ។

ដំបូងគាត់ ដើរលក់កាសែតគ្រប់ច្រកល្ហកក្នុងទីក្រុង បន្ទាប់មកទៀត គាត់សរសេរកំណាព្យចុះក្នុងកាសែត ។ ដោយត្រូវពង្រីកមិត្តភក្តិ គាត់តែងបានធ្វើដំណើរទៅទីស្នាក់ការកាសែតខ្មែរកុម្មុយនិស្តពីរផ្សេងទៀតជារឿយៗ ។

នៅពេលដែល ខៀវ សំផន បង្កើតកាសែត "អ្នកសង្កេតការណ៍" គាត់បានចូលទៅធ្វើការនៅទីនោះដែរ ហើយនៅក្នុងយប់មួយ គាត់បានគេចខ្លួនចេញពីផ្ទះបងប្រុសរបស់គាត់ដោយគ្មានវិលត្រឡប់ទៅវិញជារៀងរហូត ។ ចាប់ពីពេលនេះទៅ គាត់បានសម្រេចចិត្តចំណាយពេលវេលាទាំងអស់របស់ខ្លួន បូជាចំពោះមិត្តភក្តិ "ចម្រើនជឿនលឿន" និងកាសែតនានារបស់ពួកគេថែមទៀត ។ ផាត មិនដែលនឹកសង្ស័យថា ពួកនោះជាពួកកុម្មុយនិស្តនិយមឡើយ ហើយក៏មិនដឹងថាមានចលនាកុម្មុយនិស្តតូចមួយក្នុងប្រទេសរបស់ខ្លួនដែរ ។ ក្នុងសង្គមដែលមានការបែងចែកវណ្ណៈបុណ្យស័ក្តិយ៉ាងខ្លាំងនៃទីក្រុងភ្នំពេញ ពេលដែលដើមកំណើត សញ្ញាប័ត្រ ការស្រឡាញ់រាប់អានរបស់ស្ដេច ជាចំណុចសំខាន់សម្រាប់ផ្លាស់ប្ដូរស្ថានភាពសង្គមរបស់គេ និងចូលរួមយ៉ាងសកម្មខាងនយោបាយនោះ ផាត បានរកឃើញផ្លូវជាថ្មីទៀតក្នុងចំណោមមនុស្សទាំងឡាយ ដ៏អង់អាចស្វាហាប់ដែលចូលចិត្តព្រួយបារម្ភ ជួយស្រោចស្រង់ប្រជាជនជាងការប្រើល្បិចកលសម្ងាត់ដាក់គ្នាដើម្បីធ្វើឲ្យខ្លួនមានមុខតំណែងខ្ពស់មួយ ។

ផាត បានរស់នៅក្នុងការិយាល័យរបស់កាសែត "អ្នកសង្កេតការណ៍" ដោយពេលយប់គាត់ដេកនៅទីនោះ

ហើយធ្វើការងារជាមួយ ខៀវ សំផន នៅពេលថ្ងៃ ។ បណ្តាខែដំបូងៗ បានប្រព្រឹត្តទៅដោយគ្មានឧប្បត្តិហេតុឡើយ បន្ទាប់មក នៅឆ្នាំ១៩៦០ សហការីជាច្រើននៃកាសែតកុម្មុយនិស្តនិយមទាំងឡាយ បានត្រូវប៉ូលិសចាប់ខ្លួន និងយកទៅដាក់គុក ។ ជាត នៅឈរទាំងអស់សង្ឃឹមក្រោយចម្រឹងដែករបស់គុក នៅពេលដែលបក្សត្រូវបានបង្កើតឡើង គឺគាត់នៅជាប់ក្នុងគុកនៅឡើយ ។

វត្តមានរបស់ ជាត ក្នុងផ្ទៃចលនាគឺជាតឹកតាង ដែលពួកកុម្មុយនិស្តកម្ពុជាអាចបន្ថែមកម្លាំង និងជ្រើសរើសយុទ្ធជនសម្រាប់បក្សរបស់គេ ដែលកំពុងចាត់ចែងបង្កើតឡើងនោះ ។ មេដឹកនាំទាំងឡាយរបស់បក្សមានការពិចារណាក្នុងគំនិតយ៉ាងប្រាកដរួចជាស្រេច នៅពេលដែលពួកគេបានរួមប្រជុំគ្នាជាសម្ងាត់អស់រយៈពេលបីថ្ងៃ សម្រាប់រៀបចំមហាសន្និបាតបង្កើតបក្ស[៣២] ។ អ្នកតំណាងម្ភៃមួយរូប នៃចលនាមួយ ដែលបែកខ្ញែក និងដែលនៅដាច់ដោយឡែកពីគ្នា បានអនុម័តលក្ខន្តិកៈបក្ស និងជ្រើសតាំងគណៈកម្មាធិការកណ្តាលមួយ ដែលមានគ្នាបីនាក់ដឹកនាំ ។ ទូ សាមុត ត្រូវបានចាត់តាំងជាអគ្គលេខា ។ គាត់ជាសមាជិកតែម្នាក់គត់ នៃត្រីជនាភិបាលរបស់ចលនាកុម្មុយនិស្តកម្ពុជា សង្គ្រាមឥណ្ឌូចិនលើកទី១ ដែលបានមកចូលរួមក្នុងការប្រជុំនេះ ព្រោះ សឺង ង៉ុកមិញ ស្ថិតនៅឯទីក្រុងហាណូយឯណោះ នៅទីនោះ ពួកវៀតណាមនៅតែបន្តផ្តល់ឋានៈគាត់ជាមេដឹកនាំពួកកុម្មុយនិស្តកម្ពុជាដដែល ហើយ ស៊ីវ ហេង ក៏បោះបង់បក្ខពួកចោលដែរ ។ នួន ជា ដែលនៅដើមដំបូងត្រូវបានជ្រើសរើសដោយបក្សថៃក្នុងពេលដែលគាត់ទៅរៀនសូត្រនៅក្រុងបាងកកនោះបានត្រូវគេជ្រើសតាំងជាមនុស្សទី២ សាឡុត ស ជាមនុស្សទី៣ ហើយមិត្តរបស់គាត់គឺ អៀង សារី ជាមនុស្សទី៥ ។

នៅពេលនេះពួកកុម្មុយនិស្ត ដែលត្រឡប់មកពីប្រទេសបារាំង បានទៅជាចំណែកមួយ ដែលចូលមកបំពេញក្នុងគណៈកម្មាធិការបក្សទីក្រុងទាំងអស់ ។ ក្នុងអំឡុងប្រាំបួនឆ្នាំកន្លងទៅ ចាប់តាំងពីពេលដែលពួកកុម្មុយនិស្តកម្ពុជាបានរួមប្រជុំគ្នាដើម្បីជ្រើសរើសគណៈដឹកនាំបក្សប្រជាជនបដិវត្តន៍ខ្មែរ ចលនានេះបានឈប់ធ្វើតាមគំរូដែលមានលំនាំតែមួយដូចអតីតបក្សកុម្មុយនិស្តឥណ្ឌូចិនទៀតហើយ ។ មូលដ្ឋានបផ្អែកចាស់ៗរបស់បក្សកុម្មុយនិស្តឥណ្ឌូចិននៅតាមជនបទ ក៏លែងមានធ្វើសកម្មភាព ហើយចុះខ្សោយយ៉ាងខ្លាំង ដោយសារការវាយប្រហាររបស់សម្តេច ព្រះនរោត្តម សីហនុ និងការបោះបង់ចោលបក្ខពួករបស់ ស៊ីវ ហេង ក្នុងពេលដែលសាខាបក្សនៅក្រុងភ្នំពេញ ដែលរហូតមកដល់ពេលនេះ នៅទន់ខ្សោយនៅឡើយនោះ បានចំណេញសមាជិកថ្មីៗទៀតជាច្រើនដូចជា ជាត ជាដើម ហើយសាខានេះបានក្លាយទៅជាមជ្ឈមណ្ឌលនៃលទ្ធិកុម្មុយនិស្តក្នុងប្រទេស ។ តាមការពិតលក្ខណៈខុសគ្នារវាងសមាជិកនានាដែលចេញមកពីបក្សកុម្មុយនិស្តបារាំង ថៃ ឬវៀតណាម បានរលាយបាត់បង់ ។ ឥឡូវនេះអ្នកទាំងនោះសុទ្ធតែជាជនកុម្មុយនិស្តកម្ពុជាទាំងអស់ ហើយសកម្មភាពមួយភាគធំក្នុងរាជធានីបានត្រូវដឹកនាំដោយ សាឡុត ស និង អៀង សារី ។ ការងារពាក់កណ្តាលលួចលាក់របស់ពួកគេ ដែលផ្ទុយនឹងសកម្ម

ភាពស្របច្បាប់នោះ បានទទួលលទ្ធផលខ្លះៗដែរ ដោយគេដឹងឮគ្រប់ៗគ្នាថា ជាសកម្មភាពរបស់ពួកឃុទ្ទិកជននៃក្រុមប្រជាជន ។

មហាសន្និបាតបក្សបានដាក់ឈ្មោះឲ្យចលនារបស់គេថា បក្សពលករកម្ពុជា ដែលនៅឆ្នាំ១៩៦៦ បានប្រែទៅជាបក្សកុម្មុយនិស្តកម្ពុជាវិញ ។ ដោយតម្រូវទៅតាមច្បាប់ទម្លាប់ មហាសន្និបាតបានតាក់តែង និងអនុម័តអំពីភារកិច្ច និងទិសដៅរបស់ជនកុម្មុយនិស្តស្ដីពីស្ថានភាពនយោបាយនិងសេដ្ឋកិច្ចរបស់ប្រទេសជាតិ ។ មហាសន្និបាតក៏បានដៅបញ្ជាក់ពីមូលហេតុដែលពួកគេគិតថា ប្រទេសកម្ពុជាត្រូវការការបដិវត្តន៍មួយ ហើយយ៉ាងដូម្ដេចបានជាពួកគេមានបំណងធ្វើបដិវត្តន៍នេះ ។ ការវិភាគនេះមានលក្ខណៈដូចបន្ទាត់នយោបាយរបស់ក្រុងហាណូយទាំងស្រុងស្ដីពីស្ថានការណ៍នៅក្នុងឥណ្ឌូចិនទាំងមូល ពេលដែលបន្ទាត់នយោបាយនេះនៅពុំទាន់បានអនុវត្តន៍ជាក់ស្ដែងនៅកម្ពុជានៅឡើយ ។ ពួកខ្មែរពុំមានបញ្ចេញឲ្យឃើញសញ្ញាទោមនស្សណាមួយ ចំពោះប្រទេសវៀតណាម ក្នុងបណ្ដាឯកសារដំបូងរបស់បក្សទេ ។

ពួកខ្មែរយល់ឃើញដូចក្រុងហាណូយដែរថា អាមេរិកជាសត្រូវចម្បងគេថា សហរដ្ឋអាមេរិក បានមកជំនួសប្រទេសបារាំងតាំងពីមានកិច្ចព្រមព្រៀងក្រុងហ្សឺណែវម៉្លេះ ។ ពួកគេបានបញ្ជាក់អះអាងដូចគ្នាថា ប្រទេសរបស់គេជាប្រទេស «ស្ថិតនៅក្រោមចំណុះចក្រពត្តិនិយមទូទៅ» ហើយពិសេសបំផុត គឺ«ចក្រពត្តិនិយមអាមេរិកាំង» ។

ពួកកុម្មុយនិស្តកម្ពុជា បានទទួលស្គាល់ក្នុងពេលជាមួយនឹងអ្នកសង្កេតការណ៍ម្នាក់ ដែលគេមិនប្រាប់ឲ្យដឹងមុនថា ប្រទេសរបស់គេអាចលេចឡើងជាប្រជាជាតិឯករាជ្យ និងអព្យាក្រឹតមួយ ។ ប៉ុន្តែ អ្វីដែលសំខាន់គឺផ្ទុយពីនោះទាំងអស់ ។ «តាមការពិត សេដ្ឋកិច្ចជាតិ បានត្រូវចក្រពត្តិត្រួតត្រាទាំងស្រុង ផ្នែកវប្បធម៌ក៏ដូច្នោះដែរ ។ ចំណែកព្រលឹងរបស់សង្គមនិងរបៀបរបបរស់នៅសុទ្ធតែស្ថិតនៅក្រោមអំណាចរបស់ពួកចក្រពត្តិ ជាពិសេស គឺក្រោមមជ្ឈដ្ឋានពួកមេដឹកនាំប្រទេស» ។

ជាដាច់ពិនិត្យពិច័យការទាក់ទាញចិត្ត និងភាពនៅក្រោមចំណុះ របស់មន្ត្រីក្នុងស្រុកចំពោះ បស្ចិមប្រទេស មហាសន្និបាតបក្សគ្រាន់តែជំរុញសញ្ញាណឯករាជ្យភាព រហូតដល់កម្រិតប៉ុណ្ណោះ ជាទម្លាប់ដែលពួកកុម្មុយនិស្តខ្មែរមិនដែលបោះបង់ចោលសោះឡើយ ។ ហើយជាដាច់ត្រូវការចង់ដឹងដោយប្រាកដនិយមថាតើរយៈពេលប៉ុន្មាន ដែលសម្ដេច ព្រះនរោត្តម សីហនុ នឹងនៅលេងលើល្បែងដើរលើខ្សែពួរជាមួយ នឹងនយោបាយអព្យាក្រឹតរបស់ព្រះអង្គ នៅពេលដែលសង្គ្រាមនៅវៀតណាមកាន់តែរីកធំឡើងៗនោះ ពួកគេបានសម្របខ្លួនទៅតាមកាលៈទេសៈនេះ ហើយបានចាត់ទុកសម្ដេចថា ជាស្ដេចគ្មានឆន្ទៈ –ជាការផ្ដល់គុណសម្បត្តិមួយ ដែលផ្ទុយនឹងវិចារណញ្ញាណ ។

ប៉ុន្តែ ប្រជាជនកម្ពុជាដឹងថាសង្គ្រាមបានរាលដាលរីតតែខ្លាំងឡើង ។ ពីរសប្ដាហ៍មុនមហាសន្និបាត ខែកញ្ញា

ឆ្នាំ១៩៦០ ពួកវៀតណាមខាងជើងបានប្រកាសឲ្យដឹងជាផ្លូវការនូវការសម្រេចចិត្តរបស់គេ ដើម្បី «វាយប្រយុទ្ធរំដោះភាគខាងត្បូងចេញពីការត្រួតត្រារបស់ពួកចក្រពត្តិអាមេរិកាំង និងខ្ញុំកញ្ជះរបស់ពួកវា[៣៣]» ។ បីខែក្រោយមករណសិរ្សរំដោះជាតិវៀតណាមខាងត្បូង បានត្រូវបង្កើតឡើងក្នុងគោលដៅនេះ ។ ទន្ទឹមនឹងនោះពួកកម្ពុជាបានរៀបចំតាក់តែងកម្មវិធីមួយដែរ ដើម្បីបញ្ចូលខ្លួនទៅក្នុងការប្រយុទ្ធ«យកស្លាប់រស់»នេះ ។

សេចក្តីស្មោះត្រង់របស់ពួកខ្មែរចំពោះការប្រតិបត្តិតាមតែទ្រឹស្តីរបស់វៀតណាម និងចិន បានរកឃើញផលប្រយោជន៍ដ៏ប្រសើរមួយ នៅពេលដែលពួកគេនិយាយរិះគន់សត្រូវបន្ទាប់ គឺពួកសក្តិភូមិម្ចាស់ដីធំៗ ។ ដោយហេតុថា ប៉ែតសិបប្រាំភាគរយនៃប្រជាជនកម្ពុជាជាកសិករ ដូច្នេះកសិករទាំងនេះប្រហែលជាគោលដៅដ៏សំខាន់ ក្នុងការប្រើងប្រែងជ្រើសរើសមកធ្វើជាកម្លាំងរបស់ខ្លួន ។ ពួកកុម្មុយនិស្តបានព្រមានថា សត្រូវយ៉ាងធំបំផុតរបស់កសិករ គឺពួកអ្នកចងការប្រាក់ដោយយកការហួសកំណត់នេះឯង ។

បញ្ញវន្តកុម្មុយនិស្តពីររូបក្នុងចំណោមបញ្ញវន្តកុម្មុយនិស្តសំខាន់ៗគឺ ហ៊ូ យន់ និង ហ៊ូ នឹម នឹងបោះពុម្ពផ្សាយតែរៀងខ្លួន នៅឆ្នាំ១៩៦៤ និង១៩៦៥ នូវការធ្វើអង្កេតផ្សេងៗស្តីពីស្ថានភាពរស់នៅរបស់ប្រជាកសិករ ដោយពន្យល់វែកញែកយ៉ាងជាក់លាក់ថា ប្រព័ន្ធគ្រប់គ្រងកម្មសិទ្ធិដីធ្លី កម្មវិធីផ្សេងៗផ្នែកសេដ្ឋកិច្ចរបស់សម្តេចព្រះនរោត្តម សីហនុ និងពួកអ្នកមានលុយឲ្យគេខ្ចីបានធ្វើឲ្យស្ថានភាពរស់នៅរបស់កសិករជាច្រើន កាន់តែដុនដាបឡើងៗតាំងតែពីប្រទេសទទួលបានឯករាជ្យម្ល៉េះ ។

នៅទីបញ្ចប់ បក្សត្រូវតែជ្រើសរើស«មាគ៌ា»របស់ខ្លួន និងពាក្យស្លោកផ្សេងៗ ដែលសង្ខេបនូវគោលដៅនិងរបៀបដឹកនាំរបស់ខ្លួន ។ បក្សបានជ្រើសរើសយកទិសស្លោកក្នុងនាមនៃ «ឯករាជ្យ អធិបតេយ្យជាតិ ខ្លួនឧបត្ថម្ភខ្លួន (មាគ៌ាម្ចាស់ការ) និង«ហិង្សាបដិវត្តន៍» ។ មាគ៌ានេះមានលាយឡំទៅដោយឥទ្ធិពលរបស់វៀតណាមនិងឥទ្ធិពលចិន ដែលធ្វើឲ្យពុះពោរដោយពួកវៀតណាម ។ មាគ៌ាប្រើហិង្សា ឬភេរវនិយមបដិវត្តន៍ (ដែលប្រព្រឹត្តឡើងដោយក្រុមអ្នកបដិវត្តន៍) ប្រឆាំងនឹងរដ្ឋអំណាចជាមាគ៌ាដែលពួកកុម្មុយនិស្តបានប្រកាន់យកនៅភាគខាងត្បូងវៀតណាម ដើម្បីទប់ទល់នឹងអំពើឃោរឃៅរបស់ប៉ូលិសប្រធានាធិបតី យៀម ។ ដោយប្រៀបធៀបនឹងការវាយប្រហារសម្តេច ព្រះនរោត្តម សីហនុ ប្រឆាំងនឹងពួកកុម្មុយនិស្ត ខ្មែរហាក់ដូចជាមានការថ្លឹងថ្លែងជាង ប៉ុន្តែស្ទើរតែមានប្រសិទ្ធភាពដូចគ្នាដែរ ។

«ហិង្សាបដិវត្តន៍»ពុំទាន់បានអនុវត្តន៍ភ្លាមៗទេ ។ ពួកកម្ពុជាដឹងថា ការជ្រើសរើសយកការតស៊ូនយោបាយដោយគ្មានអាវុធ ធ្លាប់ផ្តល់នូវគ្រោះថ្នាក់ចំពោះពួកគេយ៉ាងខ្លាំងនៅជនបទ ពេលដែលពួកគេមានបំណងជ្រើសរើសកសិកររាប់ពាន់នាក់ឲ្យចូលធ្វើទ័ពនៅពេលឥឡូវនេះ ។ ប៉ុន្តែ ពួកគេនៅប្រដាប់ដោយគ្រឿងអាវុធយ៉ាងខ្សត់ខ្សោយបំផុត ដែលពួកគេត្រូវការពេលវេលាមួយឆ្នាំទៀត គ្មានអ្វីក្រៅពីការប្រមូលផ្តុំអាវុធឲ្យបានគ្រប់គ្រាន់ដើម្បីបង្កើតជាសម្ងាត់នូវកងស្ម័យត្រាណតូចៗ ដែលទទួលបន្ទុកការពារពួកមេដឹកនាំរបស់គេសិន ។ កងឯកភាព

ទាំងនេះមានតែការបិត និងដំបងខ្ចីៗប៉ុណ្ណោះ ។ នៅទីបំផុត សម្តេច ព្រះនរោត្តម សីហនុ ដឹងថារឿងនេះលេចចេញពីផ្ទៃក្នុងក្រុមនិយមឆ្វេងតែទ្រង់នៅតែសព្វព្រះទ័យពង្រឹងប៉ូលិស របស់ព្រះអង្គឲ្យធ្វើការត្រួតត្រាកាន់តែខ្លាំងឡើងថែមទៀត ។

ការបើកមហាសន្និបាតមួយ និងប្រកាសនូវការបង្កើតបក្សម៉ាក្សលេនីនមួយ ដែលឯករាជ្យ គឺមានគ្រោះថ្នាក់ផង និងមានសារសំខាន់ផង សម្រាប់ពួកកុម្មុយនិស្តកម្ពុជា ។ បើសិនការផ្តួចផ្តើមគំនិតនេះ មានការយល់ព្រមពីក្រុងហាណូយទៀតនោះ វានឹងជំរុញឲ្យមានការបែកបាក់គ្នាក្នុងផ្ទៃចលនាកុម្មុយនិស្តកម្ពុជា រឹតតែជ្រាលជ្រៅថែមទៀត ។ ពួកកុម្មុយនិស្តកម្ពុជាប្រហែលមួយពាន់នាក់ស្ថិតនៅវៀតណាមខាងជើង ដើម្បីទទួលការបណ្តុះបណ្តាលលទ្ធិកុម្មុយនិស្តនៅទីនោះ ជាពិសេស សឺង ង៉ុកមិញ ដែលក្រុងហាណូយនៅតែចាត់ទុក ជាមេដឹកនាំរបស់ពួកកុម្មុយនិស្តកម្ពុជាដដែល ។ ដូច្នេះឥឡូវនេះ វាមានក្រុមដ៏មានសក្តានុពលពីរ ដែលប្រឆាំងប្រជែងគ្នាគឺក្រុមខាងក្រុងហាណូយ ដែលស្ថិតនៅក្រោមអាណាព្យាបាលផ្ទាល់របស់វៀតណាម និងក្រុមមួយទៀតនៅកម្ពុជាដែលទើបនឹងបង្កបង្កើតជាបក្ស ដែលឯករាជ្យមិនចំណុះអ្នកណា ។

ការបែកបាក់នេះ បានលេចឡើងឲ្យឃើញចំពោះតែពួកមេៗនៃក្រុមទាំងពីរប៉ុណ្ណោះ ។ ចំពោះអ្នកចំណូលថ្មីដូច ផាត ជាដើមបានដឹងត្រឹមតែថាមាន“ចលនាចម្រើនជឿនលឿន”មួយគត់ ដែលដឹកនាំដោយពួកបញ្ញវន្តនៅភ្នំពេញ ។ ហើយគឺសេចក្តីស្មោះត្រង់ប្តូរផ្តាច់របស់មនុស្សទាំងប្រុសទាំងស្រីដូចរូប ផាត ជាដើមនោះហើយ ដែលនឹងកំណត់សម្រេចពីបញ្ហានៃចលនាទាំងពីរក្រុមនេះថា ក្រុមណានឹងទទួលកិត្តិយសជាអ្នកឈ្នះគេនោះ ។

ផាត ត្រូវបានដោះលែង[៣៨] ឲ្យមានសេរីភាព នៅមុនដំណាច់ឆ្នាំ១៩៦០ ជាមួយនឹងពួកបុគ្គលិករបស់កាសែតជាច្រើននាក់ទៀត ។ គាត់រកបានការងារធ្វើនៅក្នុងកន្លែងសង់ផ្ទះថ្មមួយ ប៉ុន្តែ ដោយខ្លាចក្រែងប៉ូលិសសម្ងាត់រកចាប់ខ្លួនជាថ្មី គាត់បានទៅរស់លាក់ខ្លួនជាមួយព្រះសង្ឃមួយអង្គក្នុងវត្តមួយនៅភ្នំពេញ ។ ដូចក្នុងកំឡុងសង្គ្រាមឥណ្ឌូចិនលើកទី១ ព្រះសង្ឃទាំងឡាយតែងបានផ្តល់ទីជម្រកឲ្យពួកអ្នកដែលរត់គេចខ្លួនជានិច្ច ហើយការពារពួកនេះដោយលាក់មិនឲ្យប៉ូលិសដឹងទៀតផង ។ ដោយលាក់ខ្លួនជាមួយព្រះសង្ឃ ពុទ្ធសាសនា ផាត បានចាប់ផ្តើមសរសេរនិងតែងនិពន្ធអត្ថបទឡើងវិញ ដោយសរសេរបែបអ្នក“ចម្រើននិយម” ក្នុងការវិភាគពីរឿងប្រជាប្រិយខ្មែរមួយ ព្រមទាំងវិភាគប្រលោមលោកសម័យមួយឈ្មោះ “កុលាបប៉ៃលិន”របស់លោក ញ៉ុក ថែម ផង ។ បណ្តាមិត្តភក្តិរបស់គាត់ដែលធ្វើការក្នុងកាសែត បានជួយផ្តល់ប្រាក់កាស បន្ទាប់មក បានជួលផ្ទះមួយឲ្យគាត់នៅទៀត ជាទីដែលគាត់មានករណីយកិច្ចបន្តនូវអ្វីជាការឃោសនាមួយ ដែលឥឡូវនេះ គាត់បានយល់ពីរឿងនោះហើយ ។

នៅពេលដែលសម្តេច ព្រះនរោត្តម សីហនុ អនុញ្ញាតឲ្យកាសែតប្រជាជនចេញផ្សាយឡើងវិញនៅឆ្នាំ ១៩៦១ ផាត បានលេចមុខជាថ្មី ហើយបានសរសេរអត្ថបទផ្សេងៗសម្រាប់កាសែតនេះ ។ ប៉ុន្តែ ការត្រឡប់មក

វិញនេះ មានរយៈពេលខ្លីបំផុត ពីព្រោះកាសែតត្រូវបិទទ្វារ ក្រោយពីបានចេញផ្សាយតែមួយលេខប៉ុណ្ណោះ ហើយផាតត្រូវទទួលបញ្ជាឲ្យធ្វើសកម្មភាពលួចលាក់ដូចពីមុនវិញ ។ គាត់បានគោរពធ្វើតាមដោយបញ្ចូលខ្លួនទៅក្នុងពិភពមិត្តភក្តិ ចម្រើនជឿនលឿនទាំងឡាយរបស់គាត់ជាស្ថាពរ ។ ក្នុងពេលដែលគាត់លាក់ខ្លួនក្នុង“ជម្រក” ទីពីរនេះ មានមនុស្សម្នាក់ក្នុងចំណោមពួកអ្នកនៅទីនោះបានសួរគាត់ថា តើអ្នកចង់ក្លាយខ្លួនជាជនកុម្មុយនិស្តទេ ។ ផាត នៅតែនឹកឃើញពីការសន្ទនានោះច្បាស់ល្អណាស់ ៈ “គាត់បានសួរខ្ញុំថា សមមិត្តពេញចិត្តនឹងចូលបក្សមែនឬ? នៅជំនាន់នោះ ខ្ញុំនៅពុំទាន់ដឹងថាមានបក្សមួយនៅឡើយទេ ។ គាត់បានពន្យល់ប្រាប់ខ្ញុំអ៊ីទៅ ដែលគេហៅថាបក្ស ហើយបានស្នើខ្ញុំឲ្យសុំចូលបក្សនេះ” ។

ផាតបានសរសេរប្រវត្តិរូបសង្ខេបរបស់គាត់ដូចដែលច្បាប់ទម្លាប់តម្រូវ ហើយត្រូវបានទទួលយល់ព្រមជាបេក្ខជនត្រៀម ។ “ក្នុងជម្រក”ទី៣ ក្រោយមន្ទីពេទ្យព្រះសង្ឃចាស់នៅក្រុងភ្នំពេញ គាត់បានក្លាយទៅជាសមាជិកបក្សកុម្មុយនិស្តកម្ពុជា នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៦២ ។ ពិធីបញ្ចូលបក្សមានរយៈពេលយ៉ាងខ្លី គាត់បានត្រូវខទ្វេសនាម ដោយពួកអ្នកបំពាក់បំប៉នរបស់គាត់ក្នុងបក្ស និងធ្វើការប្តេជ្ញាចិត្តតែប៉ុណ្ណោះ ។

បន្ទាប់មកគាត់បានទៅរៀនសូត្រនៅសាលាមួយរបស់បក្ស ដែលតាមសំដីរបស់គាត់ថា នៅទីនោះគាត់បានក្លាយខ្លួនទៅជាសាវ័កម្នាក់ (អ្នកកាន់តាមទ្រឹស្តី) របស់បក្សកុម្មុយនិស្តកម្ពុជា ។ ពាក្យសាវ័ក តាមន័យសាសនាបានលាតត្រដាងយ៉ាងជាក់លាក់ពីជីវិតរបស់គាត់ក្នុងបក្សនិងជំនឿស៊ប់ ការប្តូរផ្តាច់ ដែលបក្សបានបញ្ចុះបញ្ចូលគាត់ឲ្យចង់ធ្វើ ។ ផាត បានផ្ទេរទៅឲ្យបក្សវិញនូវភក្តីភាព ការគោរពលក្ខការណ៍ និងអាជ្ញា ដែលគេធ្លាប់បានបណ្តុះក្នុងខួរក្បាលគាត់កាលនៅរៀនឯវត្ត ។ នៅសាលា គាត់បានទាក់ទងស្គាល់អនាគតមេដឹកនាំរបស់ខ្លួនដែរដោយហេតុថា សាឡុត ស បានទៅបង្រៀនឯកសារមួយចំនួននៅទីនោះ ។ ផាតជាកូនសិស្សដ៏ល្អម្នាក់នៅក្នុងថ្នាក់របស់ ស និងក្នុងភាគច្រើននៃថ្នាក់ផ្សេងទៀត ។ គាត់បានបញ្ចប់ការសិក្សារបស់គាត់ ហើយគេបានបង្រៀនឲ្យគាត់ចេះបំពេញការងារជាអ្នកប្រយុទ្ធ ដើម្បីជោគជ័យនៃគណបក្សផង ។

យុវបុរសផាត ជាចំណែកមួយនៃជំនាន់សមាជិកថ្មីៗរបស់បក្ស ដែលបានសុំចូលជាសមាជិកក្នុងបណ្តាឆ្នាំដែលមានបន្តពីមហាសន្និបាតបក្សឆ្នាំ១៩៦០ ។ មួងនេះពួកគេមានបក្សរបស់ខ្លួនផ្ទាល់ ដោយហេតុនេះពួកកម្ពុជាបានបង្កើនការជ្រើសរើសសមាជិករបស់ខ្លួនរឹតតែច្រើនឡើងថែមទៀត ។ សម័យកាលដែលគេមិនដឹងថា តើបក្សណាមួយ ដែលជនកុម្មុយនិស្តខ្មែរម្នាក់ត្រូវតែចូលនោះ បានចប់នៅត្រឹមនេះ ។ ពួកកុម្មុយនិស្តមិនត្រឹមតែខំបង្កើនចំនួនសមាជិករបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែ បានបណ្តុះបណ្តាលពួកអ្នកជ្រើសរើសថ្មីយ៉ាងសកម្ម ទាំងនៅសាលាដែលផាត ធ្លាប់រៀនសូត្រក៏ដូចតាមទីកន្លែងឯទៀតៗដែរ ។

ការសង្កត់បញ្ជាក់អំពីការពង្រឹងបក្សឲ្យរឹតតែរឹងមាំឡើង បានសម្តែងឲ្យឃើញលក្ខណៈសំខាន់យ៉ាងខ្លាំង ។ ក្រោយការសុំចូលបក្សរបស់ ផាត បន្តិច លទ្ធភាពផ្សេងៗក្នុងការជ្រើសរើសសមាជិកថ្មីបានថយចុះយ៉ាងច្រើន

នៅក្នុងរាជធានី ។ ព្រឹត្តិការណ៍ផ្សេងៗ ដែលកើតមានដោយចៃដន្យនៅប្រទេសកម្ពុជា និងនៅបរទេស បានចាប់ផ្តើមធ្វើឲ្យយុទ្ធសាស្ត្ររបស់សម្តេច ព្រះនរោត្តម សីហនុ រលំដួល ហើយដោយហេតុនេះ ក៏ធ្វើឲ្យយុទ្ធសាស្ត្ររបស់ពួកកុម្មុយនិស្តប្រែប្រួល ។ នៅដើមឆ្នាំនោះ ក្រុមប៉ូលិសបានចាប់សមាជិក«ក្រុមប្រជាជន»នៅក្នុងខេត្តកំពង់ចាមចំនួនដប់បួននាក់ និងចាប់យកបានឯកសារជាច្រើន បង្ហាញយ៉ាងច្បាស់ប្រាកដពីល្បិចកលក្នុងការចាត់ចែងការងាររបស់ពួកកុម្មុយនិស្តកម្ពុជា ។ នៅខែកុម្ភៈ សម្តេច ព្រះនរោត្តម សីហនុ បានបញ្ជាឲ្យធ្វើយុទ្ធនាការមួយប្រឆាំងនឹងពួកនិយមឆ្វេងក្នុងផ្ទៃគណបក្សរបស់ព្រះអង្គផ្ទាល់ គឺគណបក្សសង្គមរាស្ត្រនិយម ។ បន្ទាប់មកព្រះអង្គបានប្តូរព្រះរាជហឫទ័យភ្លាម ហើយមិនយូរប៉ុន្មានក្រោយមក ព្រះអង្គបានជ្រើសរើសដោយផ្ទាល់ព្រះអង្គនូវបេក្ខជនក្នុងការបោះឆ្នោតនីតិបញ្ញត្តិ ដែលជាបញ្ញវន្តនិយមឆ្វេងដ៏ឆ្នើមបំផុតនៅរាជធានីចំនួនបីរូប គឺ ខៀវ សំផន, ហ៊ូ យន់ និង ហ៊ូ នឹម ដោយជ្រកក្រោមផ្លាកគណបក្សសង្គមរាស្ត្រនិយម ។

ក្រោយមក សម្តេច ព្រះនរោត្តម សីហនុ បានតែងតាំង សំផន ជារដ្ឋលេខាធិការទទួលបន្ទុកពាណិជ្ជកម្ម ហើយ ហ៊ូ យន់ ជារដ្ឋលេខាធិការក្រសួងផែនការ ដោយប្រគល់ទៅឲ្យមនុស្សពីរនាក់ ដែលគេសង្ស័យថា ជាជនកុម្មុយនិស្តនោះ នូវការទទួលខុសត្រូវខាងផ្នែកសេដ្ឋកិច្ច ដែលលំបាកដោះស្រាយជាទីបំផុត ។ ការដឹកនាំរឿងដ៏អស្ចារ្យនេះ គឺជាព្រះរាជតម្រិះរបស់សម្តេច ព្រះនរោត្តម សីហនុ សុទ្ធសាធ ។ មួយចំណែក គឺព្រះអង្គប៉ុនប៉ងប្រមូលមនុស្សពីរនាក់ ក្នុងចំណោមពួកនិយមឆ្វេង ដែលដើរផ្លូវខុសមកចូលរួមជាមួយព្រះអង្គវិញ មួយចំណែកទៀត គឺព្រះអង្គចង់ប្រើប្រាស់អ្នកសេដ្ឋវិទូ ដែលមានសមត្ថភាពទាំងនេះដើម្បីនាំយកប្រទេសរបស់ព្រះអង្គឲ្យចេញផុតពីបញ្ហាលំបាកផ្សេងៗ ដែលមានតាំងពីយូរមកហើយៗក៏ប្រហែលជាដើម្បីធ្វើឲ្យបណ្តាប្រទេសកុម្មុយនិស្ត ដែលកំពុងផ្តល់ជំនួយរបស់គេមកឲ្យប្រទេសកម្ពុជា ដឹងពីសេចក្តីត្រូវការរបស់ខ្លួន ។ បើសិនជាអ្នកទាំងពីរបង្ហាញឲ្យឃើញថា ខ្លួនរ៉ាប់រងកិច្ចការនេះមិនបាន សម្តេចនឹងអាចធ្វើឲ្យអ្នកទាំងពីរទៅជាមនុស្សដែលគេចាំតែទម្លាក់កំហុសទៅលើគ្រប់បែបយ៉ាង និងគ្រប់ពេលវេលា ដោយព្រះអង្គអាចចោទប្រកាន់អ្នកទាំងពីរថាពុំអាចដោះស្រាយបញ្ហាផ្សេងៗ ដែលគេបានប្រគល់ឲ្យខ្លួនធ្វើ ។

ក្នុងសុន្ទរកថារបស់ព្រះអង្គ ក្នុងពេលប្រកាសតែងតាំងគណៈរដ្ឋមន្ត្រីថ្មីនៅខែតុលា ឆ្នាំ១៩៦២ សម្តេច ព្រះនរោត្តម សីហនុ បានលើកឡើងពីទិសដៅធំៗនៃយុទ្ធសាស្ត្រសេដ្ឋកិច្ចមួយដូចគ្នានឹងទិសដៅដែល សំផន បានលើកឡើងក្នុងនិក្ខេបបទបណ្ឌិតរបស់គាត់ដែរ ។ សម្តេចព្រះប្រមុខរដ្ឋ បានសម្រេចព្រះទ័យធ្វើការសាកល្បងតាមសំណើផ្សេងៗរបស់ក្រុមនិយមឆ្វេង ដោយបានធ្វើការបញ្ជាក់បំភ្លឺដំណាលគ្នាថា ព្រះអង្គនឹងមិនអត់ឱននូវការប្រឆាំងជំទាស់ណាមួយរបស់ក្រុមនិយមឆ្វេងឡើយ ។ ហេតុនេះហើយបានជាព្រះអង្គផ្តន្ទាទោសសមាជិក «ក្រុមប្រជាជន» ដប់បួនរូបឲ្យជាប់គុកជារៀងរហូត ព្រោះតែ«ការធ្វើឲ្យប៉ះពាល់ដល់ឯករាជ្យរបស់ប្រទេស» ។ វិធានការនេះ បានញ៉ាំងឲ្យពួកកុម្មុយនិស្តជឿថា ពួកគេត្រូវតែរំលាយចោលលក្ខណៈស្របច្បាប់ចំហរបស់គេ

គឺគណបក្សប្រជាជននេះឯង ។ មានតែបញ្ញវន្តពីររូបប៉ុណ្ណោះក្នុងរដ្ឋាភិបាលរបស់សម្តេច ព្រះនរោត្តម សីហនុ ហើយ ហ៊ូ នឹម ដែលត្រូវបាន បោះឆ្នោតឲ្យចូលក្នុងរដ្ឋសភា ពុំបានធ្វើសកម្មភាពដោយលួចលាក់ទេ ។

ក្នុងល្បែងដ៏តឹងតែងនេះ ដែលកំពុងតែប្រព្រឹត្តទៅក្នុងលក្ខណៈស្ងាត់ៗគឺ ខៀវ សំផន ដែលជាអ្នកមានបន្ទុកអាថ៌កំបាំងច្រើនជាង សម្តេច ព្រះនរោត្តម សីហនុ ។ សម្តេចបានអនុវត្តនូវល្បិចកលដ៏ល្អិតល្អន់របស់ព្រះអង្គ ដើម្បីបំបាក់ពួកប្រឆាំងមិនឲ្យធ្វើសកម្មភាពកើត តាមរយៈការប្រឹងធ្វើឲ្យគេចូលចិត្តព្រះអង្គដោយអំនួតក្អេងក្អាង និងការធ្វើឲ្យបណ្តាតស្សរៈជននិយមឆ្វេង ដែលមានគេគោរពរាប់អានច្រើន មកចុះចូលនឹងព្រះអង្គ ។ អ្វីដែលធ្វើឲ្យគេលំបាកយល់ គឺថាហេតុអ្វីបានជា ខៀវ សំផន ដែលជាអ្នកបង្កើតគំនិតដោះស្រាយស្តីពីភាពទន់ខ្សោយនៃសេដ្ឋកិច្ចកម្ពុជា បែរជាសម្របគំនិតទាំងឡាយរបស់ខ្លួនធ្វើការដោះស្រាយបញ្ហាផ្សេងៗរបស់សម្តេច ព្រះនរោត្តម សីហនុ ក្នុងពេលដែលព្រះអង្គខំប្រឹងផ្តួលរំលំរដ្ឋាភិបាលនោះទៅវិញ? សំផន ជាមនុស្សដែលចំណាន និងដែលមានគុណធម៌ម្នាក់ ដែលទម្លាប់ធ្វើករណីយកិច្ចមួយ ដោយបដិសេធ«ជំនូន» ទាំងអស់ព្រោះវាអាចនឹងនាំឲ្យល្បីឈ្មោះជាអ្នកស៊ីសំណូកម្នាក់ ។ ក្នុងពេលជាមួយគ្នានោះ គាត់ហាក់ដូចជាមនុស្សទៀងត្រង់ គ្មានល្បិចកល ហើយប្រហែលជាត្រៀមខ្លួនចាំតែធ្វើតាមអ្នកណាម្នាក់ទោះជាអ្នកណាក៏ដោយ ដែលបានកាន់កាប់អំណាច ហើយដែលនិយាយថា នឹងជួយជ្រោមជ្រែងឲ្យគំនិតទាំងឡាយរបស់ត្រូវបានគេយកទៅអនុវត្តនោះ ។

ទោះជាយ៉ាងណាក៏ដោយ សំផន ជឿថាភារកិច្ចរបស់គាត់ជាភាកិច្ច ដែលជួយទ្រទ្រង់រដ្ឋាភិបាលយ៉ាងពិតប្រាកដ ។ គាត់បានចាប់ផ្តើមធ្វើយុទ្ធនាការប្រឆាំងនឹងការផ្តល់សាច់ប្រាក់បំពេញឲ្យការចំណាយសាធារណៈផ្សេងៗរបស់រដ្ឋ ដោយសារការចំណាយមានច្រើនជាងចំណូលហើយបានប្រកាសថា ប្រការនេះនឹងនាំឲ្យមានអតិផរណាកាន់តែធ្ងន់ធ្ងរឡើង ផ្ទុយទៅវិញគាត់បានអួតអាងពីការធ្វើវិនិយោគទុនរបស់រដ្ឋាភិបាលក្នុងបណ្តាសហគ្រាសផលិតកម្មវិញ ។ ក្នុងសំណើដ៏ល្អិតល្អន់មួយ គាត់បានណែនាំឲ្យអនុវត្តនូវនយោបាយរឹតត្បិតមួយគួបផ្សំនឹងការបង្កើនពន្ធលើផលិតផលប្រណីតៗ និងការកែទម្រង់ផ្សេងៗ ដើម្បីកាត់បន្ថយផលផ្សេងៗរបស់នយោបាយនេះទៅលើប្រជាជនស្រទាប់ក្រោមនៃសង្គមជាតិ ។ មួយផ្នែកនៃពួកអ្នករកស៊ីបានប្រឆាំងជំទាស់នឹងគាត់ រដ្ឋាភិបាលក៏ត្រូវបែកបាក់ចេញពីគ្នា ។ ក៏ប៉ុន្តែ ការកែទម្រង់ជាច្រើនបានចូលជាធរមានជាស្រេចទៅហើយ ហើយនៅឆ្នាំបន្ទាប់ក្រុមនិយមស្តាំបានប្រើកលឧបាយផ្សេងៗ ក្នុងគោលបំណងឲ្យមានការលុបកម្មវិធីរបស់សំផន ចោល ។

នៅពេលដែល សំផន បង្ហាញស្នាដៃឲ្យគេឃើញថា គាត់អាចធ្វើការដើម្បីជាប្រយោជន៍ដល់ សម្តេច ព្រះនរោត្តម សីហនុ និងដាក់ចេញនូវសំណើជាច្រើន ដែលធនាគារពិភពលោក នឹងយកទៅពិនិត្យពិចារណាដោយប្រុងប្រយ័ត្ននោះ ពួកកុម្មុយនិស្តក៏រងទទួលគ្រោះអាក្រក់មួយយ៉ាងធ្ងន់ធ្ងរដែរ ។ ទូសាមុត មេដឹកនាំបក្សបានបាត់ខ្លួនយ៉ាងអាថ៌កំបាំងបំផុត ទំនងជាត្រូវគេលួចចាប់ពង្រត់យកទៅហើយសម្លាប់ចោល ។ គាត់ទើបនឹងត្រឡប់ពីការ

ធ្វើដំណើរជាសម្ងាត់មួយទៅក្រុងហាណូយ នៅដើមឆ្នាំ១៩៦៣ ហើយបក្សខ្វាចរអែងថា គាត់ត្រូវគេយកទៅធ្វើជាកម្មវត្ថុមួយសម្រាប់ស៊ើបសួររកទីតាំងរបស់បក្សដោយពួកប៉ូលិសរបស់សម្តេច ព្រះនរោត្តម សីហនុ ។ គេបានបើកធ្វើមហាសន្និបាតវិសាមញ្ញមួយដើម្បីជ្រើសរើសមេដឹកនាំថ្មីម្នាក់ ហើយការជ្រើសរើសនេះ បានធ្លាក់ទៅលើ សាឡុត ស ។ អៀង សារី ក៏បានឡើងឋានៈចូលក្នុងឋានានុក្រមគណៈដឹកនាំបក្ស ជាមួយមិត្តភក្តិរបស់គាត់ដែរ ព្រោះថា គាត់បានក្លាយទៅជាមនុស្សទីពីររបស់បក្ស ។ សាឡុត ស បានអនុវត្តដោយស្មោះស្ម័គ្រ និងដោយជោគជ័យនូវផែនការប្រយុទ្ធក្នុងទីក្រុង ដែលអូតអាងដោយពួកវៀតណាម នៅឆ្នាំ១៩៥៨ហើយ តាមទិដ្ឋភាពខាងក្រៅទាំងអស់គាត់ហាក់ដូចជាស្មោះត្រង់នឹងពួកវៀតណាមដែរ ព្រោះផែនការនេះគាត់ធ្លាប់បានដឹងត្រួសៗនៅក្នុងរយៈពេលចុងក្រោយនៃសង្គ្រាមតស៊ូក្នុងព្រៃភ្នំ ។ ខុសប្លែកអំពី នួន ជា មេដឹកនាំសំខាន់ជាងគេ បន្ទាប់ពី ទូ សាមុត និងអ្នកដែលគេជឿថា ទទួលតំណែងបន្តពីគាត់ គឺ សាឡុត ស បានយល់ព្រមដោយសេចក្តីរីករាយខ្លាំងនូវការទទួលខុសត្រូវរបស់គាត់ ។ "ខ្មែរដើម" បានបង្ហាញឲ្យឃើញនូវមហិច្ឆតាមួយខ្លាំងក្លាជាទីបំផុត ។ និស្សិតដ៏ខស្សោយព្យាយាមម្នាក់បានក្លាយទៅជាអ្នកនយោបាយមធ្យ័ត និងប៉ិនប្រសប់ខាងការដឹកនាំម្នាក់យ៉ាងប្រសើរ ។ គាត់បានបញ្ចេញឲ្យឃើញសេចក្តីអង់អាចមួយពោរពេញទៅដោយស្មារតីរឹងប៉ឹង គ្មានតក់ស្លុតក្នុងកណ្តាលការរំដើបរំជួលផ្សេងៗ ដែលចេះតែរីកធំឡើងៗ ហើយបានរៀបប្រកបដោយទេពកោសល្យគ្រប់ ទិដ្ឋភាពទាំងអស់ដល់ចលនាសម្រាប់បំផ្លាញមួយ ។ ស ចេះដឹងជាពិសេសពីវិទ្យាសាស្ត្រខាងរឿងលាក់អាថ៌កំបាំង ឬការសម្ងាត់ហើយចេះរៀបចំដំឡើងបេសកកម្មផ្សេងៗឲ្យគេបំពេញថែមទៀត ។

ផាត បានត្រូវគេយកចេញពី"ទីជម្រក" ដែលគាត់រស់នៅក្នុងរយៈពេលដ៏វែងនិងដ៏ធុញទ្រាន់របស់គាត់ ក្រោយពេលដែល សាឡុត ស បានក្លាយទៅជាមេដឹកនាំបក្សបន្តិច ។ មិត្តភក្តិជាច្រើនបានទៅសាកសួរសុខទុក្ខគាត់ជារឿយៗ ដើម្បីលើកទឹកចិត្តហើយបានសន្យានឹងចាត់តាំងឲ្យកាន់មុខតំណែងសំខាន់មួយ ពេលដែលឱកាសមកដល់ ។ នៅទីបំផុត យប់មួយគេបានបញ្ជាឲ្យគាត់ចេញដំណើរភ្លាមទៅកាន់វត្តមួយនៅក្រុងភ្នំពេញ ហើយឲ្យរង់ចាំរថយន្តមួយ ដែលមានពាក់ផ្លាកលេខសម្គាល់ប្លែកពីគេនៅទីនោះ ។

រថយន្តបានបើកមកដល់ ផាត ក៏បើកទ្វារហើយឱនចូលទៅអង្គុយលើពូកឡានខាងក្រោយ ។ សាឡុត ស ជាអ្នកកាន់ចង្កូត ។ អគ្គលេខាបក្សចាប់បញ្ឆេះម៉ាស៊ីនជាថ្មីហើយបើកបរនៅក្នុងទីក្រុង ។ គាត់បានសួរដេញដោលផាត ដោយទទូចថា តើមិត្តប្រាកដជាចង់ចូលរួមក្នុងការតស៊ូនៅតំបន់ជនបទមែនឬ? នៅពេលដែល សាឡុត ស ប្រាកដក្នុងចិត្តពីសម្តីស្មោះត្រង់របស់យុវបុរសនេះហើយ គាត់ក៏បញ្ឈប់រថយន្តក្បែរកីឡដ្ឋានរបស់ក្រុង ជាទីដែល អៀង សារី នៅរង់ចាំអ្នកទាំងពីរត្រង់កន្លែងនោះ ។

គឺ សារី ដែលជាអ្នកគិតគូរពីការចេញដំណើររបស់ ផាត តទៅទៀត ។ ផាតបាននិយាយថា គាត់ (សាឡុត ស) បាន "ធ្វើឲ្យជីវិតរបស់ខ្ញុំកាន់តែរឹងប៉ឹងជាងមុន" ។ សារី បានធ្វើការណែនាំដល់ផាតជាច្រើន សម្រាប់ដំណាក់

កាលនៃការធ្វើដំណើរជាបន្ទាប់ទៀត ៖ ពេលព្រឹកនិរសារជាតិវៀតណាមម្នាក់នឹងមកយកមិត្តឯងចេញពីទីក្រុង ហើយនាំយកទៅកាន់ព្រៃភ្នំ ។ នៅសម័យនោះពួកកុម្មុយនិស្តវៀតណាម និងកម្ពុជានៅធ្វើការរួមគ្នានៅឡើយ ។ ផាតបានទៅតាមនិរសារវៀតណាមដោយដើរឆ្លងកាត់ប្រទេសកម្ពុជា ចូលទៅកាន់ប្រទេសវៀតណាម ដែលនៅទីនោះគាត់ត្រូវគេដាក់ឲ្យនៅធ្វើការកន្លែងវិទ្យុផ្សាយសំឡេងជាភាសាខ្មែរ ។ ដូច្នេះ គាត់បានស្ថិតនៅខាងក្រៅប្រទេស សម្រាប់សភាពការណ៍បត់បែននៅពេលខាងមុខឆាប់ៗក្នុងប្រវត្តិសាស្ត្របក្ស ។

នៅឆ្នាំ១៩៦៣ សម្តេច ព្រះនរោត្តម សីហនុ បានត្រូវធ្វើឲ្យខូលព្រះទ័យដោយសារសង្គ្រាមនៅវៀតណាមខាងត្បូងនៃវត្តមាន និងការបន្ថែមកម្លាំង កងទ័ពអាមេរិកាំងក្នុងតំបន់នេះ ។ បន្ទាប់ភ្លាមៗនោះ ការបះបោររបស់ពួកសិស្សវិទ្យាល័យបានផ្ទុះឡើងនៅដើមឆ្នាំ ក្នុងទីក្រុងមួយរបស់កម្ពុជាឈ្មោះសៀមរាប ដោយគេមិនបានប្រមាណជាមុនសោះឡើយ ។ នេះជាបាតុកម្មដំបូងៗ ប្រភេទដូចនេះនៅប្រទេសកម្ពុជា ។ ចលាចលដែលបង្កឡើងដោយការ រំលោភបំពានរបស់មន្ត្រីខេត្តភាពឃោរឃៅរបស់ប៉ូលិស និងអំពើពុករលួយបានក្លាយទៅការបរិហារប្រឆាំងនឹងសម្តេច ព្រះនរោត្តម សីហនុ ផ្ទាល់ ។ ពួកសិស្សវិទ្យាល័យបានដុតរូបថតរបស់សម្តេចចោល ហើយក្នុងការប្រឡូកគ្នា ដែលកើតមានជាបន្តមកទៀតមានកូនសិស្សជាច្រើននាក់ក្នុងចំណោមនោះ និងប៉ូលិសម្នាក់បានត្រូវស្លាប់ ។ នៅក្រុងភ្នំពេញ និងនៅទីក្រុងផ្សេងៗទៀត ពួកសិស្សវិទ្យាល័យ បានអំពាវនាវឲ្យធ្វើកូដកម្មសាមគ្គីមួយ ដើម្បីសម្តែងការគោរពដល់បណ្តាមិត្តរបស់គេ ដែលស្លាប់នៅសៀមរាប ។ សម្តេច ព្រះនរោត្តម សីហនុ បានតបទៅវិញដោយទាមទារឲ្យមានការលាលែងរបស់រដ្ឋាភិបាលទាំងមូល ។ នេះគឺជារបត់មួយ ព្រោះពុំមែនតែលើកនេះទេ ដែលពួកនិស្សិតមានទម្លាប់ផ្តេសផ្តាសធ្វើតាមនិស្សិតសកលវិទ្យាល័យ ប៉ុន្តែសិស្សខាងផ្នែកមធ្យមសិក្សាក៏យល់ឃើញថា សម្តេច ព្រះនរោត្តម សីហនុ និងរបបរបស់ព្រះអង្គ ជារបបដែលផ្អែកតែទៅលើអំពើចិត្តរបស់មនុស្សតែម្នាក់ ។ សម្តេចបានបាត់បង់ការទ្រាំទ្រ ពីសំណាក់ពួកសិស្សវិទ្យាល័យក្នុងប្រទេសទាំងមូលថែមទៀត ។

ពួកកុម្មុយនិស្តក៏រងទទួលផលអាក្រក់ដោយមិនដឹងខ្លួនដែរ ។ តាមទ្រឹស្តី ពួកគេធ្លាប់បានផ្លាស់ប្តូរយុទ្ធសាស្ត្រដោយបោះបង់ចោលវណ្ណៈគហបតី ពោលគឺ ពួកនិស្សិត និងកូនសិស្ស ហើយយកវណ្ណៈកសិករវិញ ។ ពួកគេ បានចងភ្ជាប់សេចក្តីសង្ឃឹមរបស់ខ្លួនទៅនឹងការតស៊ូប្រឆាំងអាមេរិកក្នុងកម្រិតឥណ្ឌូចិនទាំងមូល ហើយលែងគិតចំពោះអ្វីដែលកើតមាននៅប្រទេសកម្ពុជាទៀតហើយ ។ ក្នុងឱកាសនេះ ពួកគេភ័យបារម្ភពីការមិនឲ្យតម្លៃសក្តានុពលបដិវត្តន៍ក្នុងប្រទេសផ្ទាល់របស់គេ ហើយសង្ស័យចលនានិស្សិតថា ត្រូវបានរៀបចំឡើងដោយពួកអ្នកនយោបាយនិយមស្តាំ ប្រឆាំងនឹងសម្តេច ព្រះនរោត្តម សីហនុ ពីព្រោះព្រះអង្គជាអ្នកប្រឆាំងអាមេរិកាំង និងដែលគេសន្មតថាជាអ្នកជិតស្និទ្ធនឹងពួកកុម្មុយនិស្តដែរ ។ ពួកកុម្មុយនិស្តកម្ពុជាមិនសូវមានការជ្រើសរើសទេ ៖ ឬមួយពួកគេត្រូវធ្វើឲ្យគេស្គាល់ខ្លួនក្នុងការធ្វើសកម្មភាពផ្សេងៗ ឬមួយពួកគេត្រូវបោះបង់មុខងាររបស់គេជាកងឈានមុខ ។

តាមការពិត វាហាក់ដូចជាបាតុកម្មទាំងឡាយដែលប្រព្រឹត្តទៅឯង១ ពុំមានត្រូវបានរៀបចំឡើង ដោយក្រុមនិយមស្តាំ ឬក្រុមនិយមឆ្វេងឡើយ ។ ប៉ុន្តែ សម្តេច ព្រះនរោត្តម សីហនុ បានចោទប្រកាន់ពួកបញ្ញវន្តកុម្មុយនិស្តថា ជាអ្នកទទួលខុសត្រូវលើកូដកម្មទាំងនេះ ហើយក្រោយនោះបន្តិច ព្រះអង្គបានប្រកាសនៅមហាវិទ្យាល័យភូមិន្ទវេជសាស្ត្រក្នុងឱកាសនៃការផ្តល់សញ្ញាបត្រដល់និស្សិតជំនាន់ទី១ថា «យើងដឹងថានិស្សិតជាច្រើន ធ្លាប់ជាអ្នករងគ្រោះពីការឃោសនានយោបាយនៅបរទេស ដោយបំភ្លេចពីហេតុផលផ្សេង១ ដែលពួកគេត្រូវបានបញ្ជូនឲ្យទៅរៀននៅប្រទេសបារាំង ហើយគ្មានគិតអ្វីក្រៅតែពីធ្វើឲ្យមានភាពច្របូកច្របល់នៅក្នុងប្រទេសផ្ទាល់របស់គេប៉ុណ្ណោះ តើពួកគេក្រពុលមុខលែងស្គាល់ខុសត្រូវ ឬពួកគេបំភ្លេច[៣៥]» ។

សម្តេចបានចោទប្រកាន់ជាពិសេស ហើយទាំងខុសទៅលើជនកុម្មុយនិស្តលាក់មុខម្នាក់ឈ្មោះ សុន សេន ជាមិត្តរបស់ សាឡុត ស កាលនៅទីក្រុងប៉ារីស និងធ្វើជានាយកវិទ្យាស្ថានគរុកោសល្យមួយនៅភ្នំពេញ ។ មេដឹកនាំម្នាក់ទៀត ដែលត្រូវចោទប្រកាន់ជាអ្នកទទួលខុសត្រូវអំពើបះបោរនៅសៀមរាបដែរ គឺលោក កេង វ៉ាន់សាក់ ជាសមាជិកអតីតគណបក្សប្រជាធិបតេយ្យ ។ សេនបានបដិសេធមុខនាទីទាំងអស់របស់គាត់ក្នុងការរំដើបរំជួលរបស់សិស្សវិទ្យាល័យទាំងនោះ ប៉ុន្តែសម្តេច ព្រះនរោត្តម សីហនុ បានសម្រេចព្រះទ័យប្រើប្រាស់វិបត្តិនេះ ដើម្បីធ្វើឲ្យមានការប្រឈមមុខមួយ ដោយដាក់ឲ្យក្រុមនិយមឆ្វេងជល់នឹងព្រះអង្គផ្ទាល់ ព្រមទាំងគណបក្សសង្គមរបស់ព្រះអង្គទៀត ។

សម្តេចបានទាមទារថា បើសិនជាវិបត្តិនេះកកើតឡើងដោយសារតែមតិសាធារណៈចូលចិត្តក្រុមនិយមឆ្វេងជាពួកសង្គមនោះ ព្រះអង្គបានឲ្យយោបល់ថា ក្រុមនិយមឆ្វេងគួរតែបង្កើតគណៈរដ្ឋមន្ត្រីរបស់ខ្លួនផ្ទាល់ ។ ព្រះអង្គបានរៀបចំបញ្ជីមួយ ដែលមានឈ្មោះមនុស្សសាមសិបបួននាក់ ដែលតាមព្រះអង្គថាពួកនេះត្រូវតែរួមចំណែកក្នុងរដ្ឋាភិបាលមួយបែបនោះ ។ ប៉ុន្តែតាមពិត បញ្ជីនេះប្រមូលផ្តុំសុទ្ធតែឈ្មោះគូសត្រូវនិយមឆ្វេង និងនិយមស្តាំរបស់សម្តេចទាំងអស់ ។ បញ្ជីនេះ រួមមានឈ្មោះបណ្តាសមាជិកគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្ត ដែលធ្វើសកម្មភាពលួចលាក់ជាច្រើនរូប ជាពិសេស សាឡុត ស និង អៀង សារី ។ បញ្ជីឈ្មោះនេះ និងការហៅឲ្យសាកល្បងបង្កើតរដ្ឋាភិបាលមួយ បានកើតមានឡើងដោយចៃដន្យក្រោយពេលដែល ទូ សាមុត ត្រូវបាត់ខ្លួន ហើយដែលប្រហែលជាត្រូវគេសម្លាប់ចោលផងក៏មិនដឹង ហើយពួកកុម្មុយនិស្តមើលឃើញ ក្នុងការប្រឈមមុខនេះនូវការឲ្យតម្រុយជាមុនមួយ អំពីការចាប់ខ្លួន និងការសម្លាប់ពួកគេនោះឯង ។ ពួកគេជឿថា សម្តេច ព្រះនរោត្តម សីហនុ និង ប៉ូលិសរបស់ព្រះអង្គបានស្រាវជ្រាវរកឃើញឈ្មោះពួកមេដឹកនាំបក្ស និងប្រុងប្រៀបកម្ចាត់ពួកគេចោលដូច ដែលពួកនោះបានកម្ចាត់ ទូ សាមុត ដែរ ។

សាឡុត ស និងបក្ស បានសម្រេចថា សម័យកាលដែលពួកកុម្មុយនិស្ត អាចរៀបចំចលនាឲ្យមានទម្រង់ត្រឹមត្រូវ ដោយគ្មានគ្រោះថ្នាក់ នៅក្នុងរាជធានីនោះគឺលែងមានទៀតហើយ ។ សមាជិកគណៈកម្មាធិការមជ្ឈិម

ចំនួនកៅសិបភាគរយ បានចាកចេញពីភ្នំពេញដោយស្ងាត់កំបាំង ហើយរលាយបាត់នៅក្នុងព្រៃភ្នំទិសខាងកើត ដើម្បីបង្កើតក្រុមអ្នកតស៊ូមួយនៅទីនោះ ។ មុនដំបូង ពួកគេបានតម្រង់ឆ្ពោះទៅកាន់ព្រំដែនជាប់ជាមួយប្រទេសវៀតណាម ដែលនៅទីនោះការទាក់ទងគ្នាផ្សេងៗ និងការធ្វើសហប្រតិបត្តិការជាមួយពួកវៀតណាមនឹងមានភាពងាយស្រួលច្រើនជាង ។ ដាត ត្រូវបានគេបញ្ជូនទៅភាគខាងកើតប្រទេសកម្ពុជាដូចគេដែរ ជាមួយនឹងពួកកុម្មុយនិស្តខ្មែរក្រោមមួយក្រុម ហើយបានទទួលបន្ទុកធ្វើការ ឃោសនាតាមភូមិនានា ។ នៅពេលនោះហើយដែលគាត់ចាប់ផ្តើមធ្វើការងារសម្រាប់គណៈកម្មាធិការមជ្ឈិម ។

យុវជនក្មេងៗរាប់រយនាក់ដូចជារូបគាត់ដែរ បានធ្វើឲ្យជួររបស់បក្សដែលមានចំនួនតិចតួចនោះរីកកាន់តែធំឡើងៗ នៅពេលដែលគាត់បានបោះទីតាំងនៅជនបទ ។ មានមនុស្សជាច្រើនត្រូវបានជ្រើសរើសឲ្យចូលបក្សដោយបងប្អូនដែលមានវ័យចាស់ជាង ដោយបងប្អូនជីដូនមួយឬឪពុកមា ដែលកោតសរសើរពួកនោះជាយូរមកហើយអ្នកខ្លះទៀតបានសុំចូលបក្សដោយមានការឈឺចាប់ចំពោះការជិះជាន់របស់សម្តេច ព្រះនរោត្តម សីហនុ និង លន់ នល់ ។ គឺក្នុងព្រៃម៉ាគីនោះហើយ ដែលគេបានសាកល្បងឲ្យយុវជននិងយុវនារីមួយចំនួនតូច ហាត់ប្រយុទ្ធគ្នាក្នុងរយៈពេលខ្លីៗ ហើយបានពង្រឹងស្មារតីឲ្យរឹតតែស្វាហាប់ឡើងទៀត ដោយការរៀនដើរក្នុងពេលយប់តាមផ្លូវលំនានា ដោយការប្រើងប្រែងផ្សេងៗដើម្បីធ្វើឲ្យខូចគម្រោងការរបស់ប៉ូលិស ដើម្បីលត់ដំខ្លួនស៊ូទ្រាំទប់ទល់នឹងចំណង់ទាំងឡាយរបស់កាយ និងចិត្ត ហើយនិងរៀនពីរបៀប“ចលនាប្រជាកសិករ”ទៀតផង ។

ក្នុងទីតាំងជួរមុខថ្មីនៅជនបទរបស់គាត់ សាឡុត ស ចាប់ផ្តើមដឹងពីការនៅដាច់ឆ្ងាយពីគេនៃចលនារបស់គាត់ទាំងខាងក្នុងក៏ដូចខាងក្រៅប្រទេស ។ ការជាប់ដៃប្រយុទ្ធរបស់អាមេរិកាំង ដែលចេះតែរីកធំឡើងៗ នៅវៀតណាមខាងត្បូង បានបង្វិលនូវការយកចិត្តទុកដាក់ទាំងអស់ពីខាងក្រៅ ហើយពួកសម្ព័ន្ធមិត្តកុម្មុយនិស្តរបស់ស បានចាត់ទុកថា ការជួយជ្រោមជ្រែងរបស់សម្តេច ព្រះនរោត្តម សីហនុ គឺមានសារសំខាន់ខ្លាំងណាស់ ។ នៅខែឧសភា ឆ្នាំ១៩៦៣ មេដឹកនាំចិនឈ្មោះ លីវ ចាវជី បានធ្វើដំណើរមកកាន់ប្រទេសកម្ពុជាដើម្បីគាំទ្រមិត្តរបស់គាត់ គឺ សម្តេច ព្រះនរោត្តម សីហនុ ហើយបានសង្កត់បញ្ជាក់ពីចំណងមិត្តភាពផ្សេងៗ ដែលកំពុងបង្រួបបង្រួមប្រទេសទាំងពីររបស់គេថែមទៀត ។ ទន្ទឹមនឹងនោះ ក្រុងហាណូយបានទទួលស្គាល់សិទ្ធិផ្សេងៗរបស់ប្រទេសកម្ពុជា នៅលើកោះទាំងឡាយក្នុងឈូងសមុទ្រសៀម ដែលទាមទារដោយប្រទេសវៀតណាមខាងត្បូង ។ ប្រទេសកុម្មុយនិស្តអាស៊ីទាំងពីរបានយកចិត្តយកថ្លើម សម្តេច ព្រះនរោត្តម សីហនុ ដើម្បីរារាំងមិនឲ្យពួកអាមេរិកាំងពង្រីកសង្គ្រាមចូលមកប្រទេសកម្ពុជាទៀត ។

ការប៉ះទង្គិចរវាងក្រុមនិយមឆ្វេងកម្ពុជា និងសម្តេច ព្រះនរោត្តម សីហនុ បានប្រព្រឹត្តទៅក្នុងពេលដែលវិបត្តិចុងក្រោយមួយបានធ្វើឲ្យរង្គោះរង្គើដល់របបរបស់យៀមនៅវៀតណាមខាងត្បូង ។ ហើយបណ្តារដ្ឋសង្គមនិយម ដែលមានវៀតណាមខាងជើង និងចិនកាន់តែមានអំពល់ថែមទៀត ក្នុងការថែរក្សាចំណងមិត្តភាពជាមួយ

សម្តេច ព្រះនរោត្តម សីហនុ ជាជាងជួយគាំទ្រពួកកុម្មុយនិស្ត ដែលកំពុងបង្កហេតុនឹងរបបរបស់ព្រះអង្គ ។ នៅក្រោយពេលដែល សាឡុត ស និង អៀង សារី និងមេដឹកនាំឯទៀតៗ ភៀសខ្លួនទៅជនបទ បណ្តាព្រះសង្ឃ ពុទ្ធសាសនានៅវៀតណាមខាងត្បូង ក៏បាននាំគ្នាធ្វើបាតុកម្មដែរ ហើយក្រោយបន្តិចពេលដែលពួកកុម្មុយនិស្តរៀបចំទីតាំងរបស់ខ្លួននៅតាមជនបទ ជិតព្រំដែនរបស់វៀតណាម យៀម បានត្រូវគេសម្លាប់នៅក្រុងព្រៃនគរដែរ ។

សម្តេច ព្រះនរោត្តម សីហនុ បានកាត់ផ្តាច់មិនទទួលគ្រប់កម្មវិធីជំនួយរបស់អាមេរិកាំងភ្លាមមួយរំពេច ហើយបានអំពាវនាវសុំជំនួយផ្នែកយោធាពីប្រទេសចិន និងប្រទេសកុម្មុយនិស្តផ្សេងៗទៀតដើម្បីជំនួសជំនួយរបស់សហរដ្ឋអាមេរិក ដែលពេលនោះគេយល់ឃើញវាមានគ្រោះថ្នាក់ខ្លាំងណាស់ ។ មិនយូរប៉ុន្មាន គ្រឿងសព្វាវុធរបស់ចិន ឆេកូស្លូវ៉ាគី បានមកដល់ប្រទេសកម្ពុជា ប៉ុន្តែ គឺសម្រាប់សម្តេច ព្រះនរោត្តម សីហនុ ពុំមែនសម្រាប់ពួកកុម្មុយនិស្តទេ ។ នៅដំណាក់កាលនេះ សាឡុត ស និងសមមិត្តទាំងអស់របស់គាត់ពិនិត្យឃើញថា គេមិនព្រមផ្តល់ជំនួយយោធាមកឲ្យខ្លួនទេ ហើយត្រូវជំរុញឲ្យផ្អាកនូវគម្រោងការបដិវត្តន៍ទាំងអស់ ទោះបីជាគេមើលឃើញជាក់ស្តែងថា សម្តេច ព្រះនរោត្តម សីហនុ មានព្រះរាជបំណងខំប្រឹងទាញប្រទេសរបស់ព្រះអង្គចេញពីពួក «ខ្មែរក្រហម» ក៏ដោយក្នុងពេលដែលសម្តេចឲ្យឈ្មោះថា ពួកកុម្មុយនិស្តកម្ពុជា ។ បើគិតឲ្យសព្វទៅទាំង សាឡុត ស និងបក្សរបស់គាត់បានស្ថិតនៅដោយឡែកពីសង្គ្រាមឥណ្ឌូចិនលើកទី២នេះ ។ ហើយពួកគេនឹកបារម្ភថា បណ្តាសម្ព័ន្ធមិត្តចិន និងវៀតណាមរបស់គេ បានក្បត់នឹងបុព្វហេតុកុម្មុយនិស្តនៅកម្ពុជា ដោយបោះបង់ការបដិវត្តន៍កម្ពុជាចោល ដើម្បីជួយស្រោចស្រង់ពួកវៀតណាម ។

ក្នុងពេលជាមួយគ្នា បក្សប្រឆាំងដែលនិយមស្តាំ បានពង្រឹងកម្លាំងរបស់ខ្លួនស្របទៅតាមវិធានការនីមួយៗ ដែលសម្តេច ព្រះនរោត្តម សីហនុ ប្រកាន់យក ដើម្បីទ្រទ្រង់ជំហរអព្យាក្រឹតនិយមរបស់ព្រះអង្គរឹតតែរឹងមាំឡើងទៀត ។ ដោយឲ្យរង្វាន់សម្តេច ព្រះនរោត្តម សីហនុចំពោះអព្យាក្រឹតភាពរបស់ព្រះអង្គ ពួកកុម្មុយនិស្តចិន និងវៀតណាម បានជួយជ្រោមជ្រែងព្រះអង្គដោយគ្មានដឹងថា រឿងនេះក៏បានបំផ្លាញរបបរបស់ព្រះអង្គនៅកម្ពុជាផងទេ ។ ក្រុមនិយមស្តាំសម្គាល់ឃើញថា សម្តេចជាមិត្តមួយរបស់ប្រទេសកុម្មុយនិស្តនានា ហើយដោយគ្មានក្រុមនិយមឆ្វេងមួយ ដែលអាចធ្វើឲ្យមានការយល់ចិត្តគ្នាបាននៅក្រុងភ្នំពេញនោះ សម្តេចព្រះប្រមុខរដ្ឋមិនអាចកម្ចាត់ក្រុមនិយមស្តាំបានឡើយ ។ នេះគឺជាអ្វីដែលបណ្តាលឲ្យមានការវិនាសរបស់ព្រះអង្គ ។

ក្នុងរយៈពេលពាឆ្នាំនៅជនបទ ការផ្តួចផ្តើមគំនិតទាំងឡាយរបស់ពួកកុម្មុយនិស្ត និងការប៉ុនប៉ងផ្សេងៗរបស់ ដើម្បីចាត់ចែងរៀបចំពួកសិករបានមានឥទ្ធិពលបន្តិចបន្តួចទៅលើជីវភាពនយោបាយនៅក្រុងភ្នំពេញ ។ អ្វីដែលជាភាពសំខាន់ គឺអវត្តមានរបស់គេក្នុងពេលដែលសម្តេច ព្រះនរោត្តម សីហនុ ប្រថុយធ្វើសកម្មភាពចុងក្រោយនៃ«បទពិសោធន៍សង្គមនិយម»របស់ព្រះអង្គ ។

សម្ដេចបានបាត់បង់ដៃគូរបស់ព្រះអង្គ ។ ក្រុមនិយមស្ដាំបានបង្ខិតបង្ខំឲ្យ ខៀវ សំផន និងហ៊ូ យន់ លាលែងពីរដ្ឋាភិបាលនៅពាក់កណ្ដាលឆ្នាំ១៩៦៣ ។ ជនកុម្មុយនិស្ដលាក់មុខទាំងពីរនាក់នេះបានស្ថិតនៅភ្នំពេញ និងរក្សាកៅអីរបស់គេនៅរដ្ឋសភាជាតិក៏ដូច ហ៊ូ នឹម ជនកុម្មុយនិស្ដទីបី ដែលទទួលបន្ទុកឃ្លាំមើលរដ្ឋាភិបាលដែរ ។ នឹមបានបាត់បង់មុខតំណែងរបស់គាត់ជានិពន្ធនាយករងកាសែតផ្លូវការមួយរបស់គណបក្សសង្គម ហើយមនុស្សទាំងបីនាក់នេះ ដែលគេទុកជាគ្រឿងពិសោធន៍នោះពិនិត្យឃើញថា សម្ដេច ព្រះនរោត្តម សីហនុ បានបែរទៅរកពួកអភិរក្សនិយម ដែលចាប់ផ្ដើមលេចឡើង ដើម្បីជួយស្ថាបនា«លទ្ធិសង្គមនិយមរបៀបខ្មែរ»របស់ព្រះអង្គ ។

សម្ដេចបានខាំក្រាញនឹងនយោបាយមួយ ដែលក្រុមនិយមស្ដាំជៀលគ្នះ គឺជាតូបនីយកម្ម វិស័យសំខាន់ៗផ្នែកសេដ្ឋកិច្ច ការជួយឧបត្ថម្ភសហគ្រាសផ្សេងៗរបស់ជាតិ ប្រឈមនឹងការប្រកួតប្រជែងរបស់បរទេស ការការពារអព្យាក្រឹតភាព ការលុបបំបាត់ជំនួយអាមេរិកាំង ការទទួលខុសត្រូវរបស់រដ្ឋ ចំពោះប្រជាជនទាំងអស់ខាងវិស័យអប់រំនិងសុខាភិបាល ។ ពួកមនុស្សខាងក្រុមនិយមឆ្វេង ដែលធ្លាប់ជួយបង្កើតបរិយាកាសយោគយល់មួយ ចំពោះវិធានការទាំងនេះ បច្ចុប្បន្នសុទ្ធតែត្រូវបង្ខំឲ្យស្ងាត់ស្ងៀម លែងនិយាយអ្វីបានទាំងអស់ ឬត្រូវបាត់ខ្លួនតែម្ដង ហើយក្រុមនិយមស្ដាំបានខំប្រឹងធ្វើឲ្យរបប សម្ដេច ព្រះនរោត្តម សីហនុ វិនាសបន្តិចម្ដងៗដែរ ។

នៅពេលដែលពួកកុម្មុយនិស្ដរំឭកពីសម័យកាលនេះឡើងវិញ ក្នុងប្រវត្តិសាស្ត្រសង្ខេបមួយរបស់បក្សគេ ពួកគេបានអួតខ្លួនថា បានរុញសម្ដេច ព្រះនរោត្តម សីហនុ ឲ្យធ្លាក់ក្នុងស្ថានភាពទាល់ច្រកមួយ ដើម្បីធ្វើឲ្យលេចចេញនូវ«ភាពមិនចុះសម្រុងគ្នាផ្សេងៗ» ដែលអាចមាននៅពេលនោះ ។ ពួកគេអះអាងថា បានបញ្ចេញ«ចលនាតស៊ូរបស់ជាតិ»ឲ្យគេដឹងព្រុគ្រប់គ្នា ដែលបង្ខិតបង្ខំឲ្យសម្ដេច ព្រះនរោត្តម សីហនុ «បដិសេធជំនួយដ៏មានពិសពុលរបស់ពួកចក្រពត្តិអាមេរិកាំងក្នុងឆ្នាំ១៩៦៣ និងកាត់ផ្ដាច់ចំណងទាក់ទងខាងផ្លូវទូតជាមួយពួកនោះទៀតផង»[៣៦] ។ តាមការពិត នៅពេលនោះ ពួកកុម្មុយនិស្ដកម្ពុជា បានចាប់ផ្ដើមដកខ្លួនកាន់តែច្រើនឡើងៗ ចេញពីឆាកនយោបាយនៅក្រុងភ្នំពេញ ដើម្បីរង់ចាំឲ្យរបាំងបាំងផ្លូវដួលរលំ និងដើម្បីរៀបចំមូលដ្ឋានមួយក្នុងចំណោមកសិករទាំងឡាយដែលពួកអ្នកសម្ដែងតួទាំងប៉ុន្មានក្នុងរឿងនេះ បានបំភ្លេចចោល ។

ក្នុងពេលដែលរឿងនេះកើតមានក្នុងរយៈពេលនៃប្រវត្តិសាស្ត្រទាំងមូលរបស់កម្ពុជា ព្រឹត្តិការណ៍ផ្សេងៗនៅក្រៅប្រទេស ក៏នាំបណ្ដាលឲ្យមានការវិនាសហិនហោចនៅខាងក្នុងប្រទេសដែរ ។ ដោយមិនព្រមទទួលជំនួយរបស់សហរដ្ឋអាមេរិក ដើម្បីបង្ការការធ្វើអន្តរាគមន៍មួយរបស់អាមេរិកាំង សម្ដេច ព្រះនរោត្តម សីហនុក៏បាត់បង់សាច់ប្រាក់ដែលធ្លាប់ជួយទប់ទល់ថវិការបស់ព្រះអង្គ ក្នុងរយៈពេលជាច្រើនឆ្នាំមកហើយ ។ ដើម្បីទូទាត់ការខាតបង់នេះ ព្រះអង្គបានកាត់បន្ថយប្រាក់ឥណទានផ្សេងៗ សម្រាប់កងទ័ពដែលនាំឲ្យមានការអាក់អន់ស្រពន់ចិត្តពីសំណាក់កងទ័ពរឹតតែខ្លាំងឡើង ។ ក្រុមនិយមស្ដាំបានតបតវិញ ដោយធ្វើឲ្យគេយល់ព្រមធ្វើតាមកម្មវិធីមួយក្នុងការបញ្ចុះតម្លៃទិញស្រូវពីប្រជាកសិករ ។ រដ្ឋាភិបាលអាចនឹងបន្តលក់ស្រូវទៅបរទេសតទៅទៀត ក្នុងតម្លៃខ្ពស់

ដដែល ហើយអាចបង្កើនប្រាក់ចំណេញយ៉ាងច្រើន ទៅក្នុងហិបប្រាក់របស់រដ្ឋថែមទៀត ។ ដោយពិត រដ្ឋាភិបាលបានបញ្ចេញប្រាក់យ៉ាងច្រើនក្នុងនាមនៃប្រតិបត្តិការនេះ ប៉ុន្តែ ដោយផ្អែកលើការមិនសប្បាយចិត្តខ្លាំងមួយរបស់កសិករ ។ មិនយូរប៉ុន្មាន ពួកអ្នកទទួលជួលដីបានបញ្ចេញប្រតិកម្មទៅតាមរបៀបជាប្រពៃណី ដោយរក្សាទុកផលដំណាំផ្សេងៗរបស់ពួកគេ ហើយក្នុងចំណោមនោះមានអ្នកខ្លះបានបដិសេធលែងដាំស្រូវតទៅទៀត ដែលគេដាំសម្រាប់តែចិញ្ចឹមគ្រួសាររបស់គេប៉ុណ្ណោះ ។

នៅឆ្នាំ១៩៦៦ ជាឆ្នាំដែលមានការបោះឆ្នោតនីតិបញ្ញត្តិ សម្តេច ព្រះនរោត្តម សីហនុ ស្ទើរតែត្រូវបង្អាក់មិនឲ្យធ្វើអ្វីកើតដោយសត្រូវទាំងឡាយនៅក្នុង និងក្រៅប្រទេស ដែលកំពុងប្រយុទ្ធប្រឆាំងនឹងព្រះអង្គ ។ កាលពីឆ្នាំមុន ព្រះអង្គធ្លាប់បានទទួលរៀបចំធ្វើសន្និសីទប្រជាជនឥណ្ឌូចិនមួយនៅភ្នំពេញ ដោយបានអញ្ជើញរណសិរ្សរំដោះវៀតណាមខាងត្បូង រដ្ឋាភិបាលវៀតណាមខាងជើង និងប៉ាថេតឡាវកុម្មុយនិស្តក្នុងឋានៈជាអ្នកចូលរួមតែម្នាក់ឯង ។ ក្រុមនិយមស្តាំ ពុំសប្បាយរីករាយនឹងរឿងនេះឡើយ ។ សម្តេចបានសម្រេចព្រះទ័យមិនឈមមុខតតាំងដោយចេញមុខទេ ហើយបានប្រកាសជាលើកដំបូងថា ព្រះអង្គនឹងលែងចាត់តាំងបេក្ខជនដូវការរបស់គណបក្សសង្គម ក្នុងការបោះឆ្នោតទៀតហើយ ។

ជាលើកទីមួយហើយក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជាឯករាជ្យ ដែលអ្នកណាៗ ក៏អាចឈរឈ្មោះឲ្យគេបោះឆ្នោតចូលក្នុងរដ្ឋសភាដែរ ។ នេះជាការបោះឆ្នោតដែលមានតម្លៃបំផុត ដែលប្រទេសជាតិមិនធ្លាប់បានជួបប្រទះសោះពីមុនមក ៈ បេក្ខជនអភិរក្សនិយមដែលមានលុយច្រើន បានដើរទិញសន្លឹកឆ្នោត ហើយបានទទួលជ័យជម្នះយ៉ាងលើសលប់មួយក្នុងមណ្ឌលបោះឆ្នោតភាគច្រើន លើកលែងតែមណ្ឌលមួយចំនួនចេញ ដែលជនកុម្មុយនិស្តបីនាក់បានជាប់ឆ្នោតចូលក្នុងរដ្ឋសភាដដែល គឺ ខៀវ សំផន, ហ៊ូយ យន់ និង ហ៊ូ នឹម ដែលត្រូវជាប់ឆ្នោតដោយងាយស្រួលក្នុងមណ្ឌលជនបទរបស់គាត់ បើទុកជាមានការតាមធ្វើទុក្ខបុកម្នេញរបស់ប៉ូលិសក៏ដោយ ។

រដ្ឋសភាថ្មីរបស់ក្រុមនិយមស្តាំបានតែងតាំង លន់ នល់ ឲ្យកាន់តំណែងជារដ្ឋមន្ត្រីទី១ និងផ្តល់ឲ្យព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ ដែលជាគូប្រជែងរបស់សម្តេច ព្រះនរោត្តម សីហនុ នូវឋានៈជាមនុស្សទី២របស់រដ្ឋាភិបាល ។ លន់ នល់ នៅរក្សាកេរ្តិ៍ឈ្មោះមួយជាមេបញ្ជាការកងទ័ពប្រកបដោយគ្រោះថ្នាក់ម្នាក់ ប៉ុន្តែ នៅមានសេចក្តីស្មោះត្រង់ចំពោះសម្តេច ព្រះនរោត្តម សីហនុ ។ ក៏ប៉ុន្តែ សិរិមតៈ ដែលត្រូវចាត់ទុកជាមនុស្សជិតស្និទ្ធនឹងពួកអាមេរិកាំងបំផុតនោះ ហាក់ដូចជាមានលក្ខណៈគំរាមកំហែងមួយយ៉ាងពិតប្រាកដចំពោះ សម្តេច ព្រះនរោត្តម សីហនុ ទៅវិញ ។

សម្តេចនៅតែជាព្រះប្រមុខរដ្ឋ ប៉ុន្តែ ព្រះអង្គត្រូវប្រជែងក្នុងការរត់ប្រណាំងមួយ បញ្ច្រាសនឹងទ្រនិចនាឡិកាដើរ ។ ព្រះអង្គបានរៀបចំបង្កើតខុទ្ទកាល័យខ្មោចមួយ ដែលមានសុទ្ធតែពួកអ្នកនយោបាយស្មោះត្រង់ ហើយបានចាប់ផ្តើមពង្រឹងថែមទៀតនូវអ្វីដែលទ្រង់បានប្រកាន់យក សម្រាប់ជាមធ្យោបាយអាចសម្រេច

លទ្ធផលច្រើនប្រការរបស់ព្រះអង្គ គឺមិត្តភាពរបស់ព្រះអង្គជាមួយពួកកុម្មុយនិស្តវៀតណាម ។ ដោយទោរទន់តាមការគាបសង្កត់របស់ក្រុងហាណូយ ព្រះអង្គបានយល់ព្រមផ្តល់សិទ្ធិឲ្យពួកវៀតណាមឆ្លងកាត់ប្រទេសរហូតដល់ក្រុងព្រះសម្តេច ព្រះនរោត្តម សីហនុ ជាកំពង់ផែសមុទ្រ ដែលព្រះអង្គបានឲ្យគេស្ថាបនានៅលើមាត់ឈូងសមុទ្រសៀម ដើម្បីរារាំងពួកអាមេរិកាំង មិនឲ្យរាំងខ្ទប់ប្រទេសកម្ពុជា ដោយការធ្វើអន្តរាគមន៍របស់ប្រទេសវៀតណាមខាងត្បូង ដែលត្រួតត្រាទន្លេមេគង្គ និងកំពង់ផែភ្នំពេញបានឡើយ ។ ពួកកុម្មុយនិស្តវៀតណាមត្រូវបានអនុញ្ញាតឲ្យនាវាផ្ទុយ អាវុធរបស់គេចូលចតនៅក្រុងព្រះសម្តេច ព្រះនរោត្តម សីហនុ បន្ទាប់មកអាវុធទាំងនោះ ត្រូវបានដឹកតាមឡានកាំមីញ៉ុងជាច្រើន រហូតដល់ភាគខាងកើតប្រទេសកម្ពុជាទៀត ។ នៅឆ្នាំ១៩៦៧ ពួកវៀតណាមខាងជើងបានរៀបចំរួចជាស្រេច នូវការវាយលុកពេលបុណ្យចូលឆ្នាំចិន-យួននៅឆ្នាំបន្ទាប់ គឺឆ្នាំ១៩៦៨ ។ បើសិនជា“ការបះបោរ”ដែលសន្យា បានសម្រេចជោគជ័យ សម្តេច ព្រះនរោត្តម សីហនុ ក៏លែងបារម្ភពីការធ្វើអន្តរាគមន៍របស់អាមេរិកាំងដែរ ។ សង្គ្រាមនឹងចប់ទៅក្នុងនាមនៃជ័យជម្នះមួយរបស់កុម្មុយនិស្ត ។

សម្តេចបានចាត់តាំងឲ្យ លន់ នល់ អគ្គមេបញ្ជាការទ័ពរបស់ព្រះអង្គជាអ្នកត្រួតពិនិត្យលើការដឹកជញ្ជូនគ្រឿងសព្វាវុធទាំងនោះពីទីក្រុងព្រះសម្តេច ព្រះនរោត្តម សីហនុ ទៅវៀតណាមខាងត្បូង ។ លន់ នល់ បានកាត់យកមុននូវអាវុធមួយចំនួនធំដោយមានការយល់ព្រមពីពួកវៀតណាមខាងជើងផង ជាតម្លៃនៃកិច្ចធ្វើសហប្រតិបត្តិការរបស់គាត់ ។ តាមភាពទំនងជាពិត ពួកវៀតណាមបានផ្តល់ឲ្យនូវបរិមាណអាវុធច្រើនជាងអាវុធ ដែលគាត់បានទទួលពីប្រទេសចិនទៅទៀត ។ ជាឯកជន លន់ នល់ បានសម្តែងឲ្យដឹងពីការភ័យខ្លាចរបស់គាត់ថា ពួកកុម្មុយនិស្តវៀតណាមមាន គោលបំណងចូលលុកលុយប្រទេសកម្ពុជា កាលបើពួកគេទទួលបានជ័យជម្នះនៅភាគខាងត្បូង ដូច្នេះគាត់គិតតែ ធ្វើយ៉ាងណាឲ្យកងទ័ពរបស់គាត់មានអាវុធយុទ្ធភណ្ឌគ្រប់គ្រាន់សិន ក្នុងព្រឹត្តិការណ៍ដែលអាចកើតមានដោយថាហេតុនេះ ។

គណៈរដ្ឋមន្ត្រីរបស់ លន់ នល់ បានរិះរកស្នៀតគ្រប់បែបយ៉ាង ជាមួយនឹងការអនុវត្តន៍ដើម្បីធ្វើឲ្យកម្មវិធីនយោបាយក្នុងប្រទេសរបស់សម្តេច ព្រះនរោត្តម សីហនុ ទៅជារបស់ដែលគេមិនត្រូវការ ។ កាលពីឆ្នាំមុន បរិមាណស្រូវនាំចេញជិតពីរភាគបី បានរបូតផុតពីការបង់ពន្ធដ៏ធ្ងន់ធ្ងររបស់រដ្ឋាភិបាល តាមរយៈការលក់ដូរមិនស្របច្បាប់ជាច្រើន មួយផ្នែកធំ គឺលក់ទៅឲ្យពួកកុម្មុយនិស្តវៀតណាម ។ លន់ នល់ បានដឹងរឿងនេះយ៉ាងច្បាស់ ពីព្រោះ ប៉ូលិសរបស់គាត់បានផ្តល់ពត៌មានពីការលក់ដូរទាំងនេះ ។ គាត់បានខិតខំរាំងខ្ទប់បញ្ហានេះ មិនត្រឹមតែដើម្បីធ្វើឲ្យសាច់ប្រាក់ហូរចូលថវិកាជាតិប៉ុណ្ណោះទេ ប៉ុន្តែ ក៏ដើម្បីបន្ទូរចំណងផ្សេងៗរបស់កម្ពុជាជាមួយពួកកុម្មុយនិស្តវៀតណាម ។

បន្ទាប់មក រដ្ឋាភិបាលបានកែប្រែរបៀបគ្រប់គ្រងក្នុងការប្រមូលស្រូវ ៖ ប្រជាកសិករដែលរក្សាទុកផលស្រូវមួយចំណែករបស់គាត់ នឹងត្រូវបង្ខិតបង្ខំឲ្យលក់ស្រូវជូនរដ្ឋាភិបាលតាមតម្លៃផ្លូវការមួយ ក្រោមការគំរាម

កំហែងដោយចុងអាវុធ ដែលនៅតែថោកដដែល[៣៧] ។ ដើម្បីធ្វើឲ្យប្រាកដប្រជាក្នុងការអនុវត្តបទកញ្ចក់គាត់ លន់ នល់ បានផ្លាស់ប្តូរមន្ត្រីរដ្ឋការខេត្តទាំង ប៉ុន្មាន ដែលតែងតាំងដោយ សម្តេច ព្រះនរោត្តម សីហនុ ចេញទាំងអស់ ដោយដាក់មនុស្សផ្ទាល់របស់គាត់ជំនួសវិញ ។

មេបញ្ជាការទ័ពរូបនេះ មិនបានបង្ការទុកជាមុនចំពោះប្រតិកម្មខ្លាំងក្លាប្រឆាំងនឹងរបៀបគ្រប់គ្រងថ្មីក្នុង "ការប្រមូលស្រូវ" នេះទាល់តែសោះ ។ ខេត្តបាត់ដំបង ដែលនៅពេលនោះជាជង្រុកស្រូវរបស់ប្រទេស បានក្លាយទៅជាគោលដៅសំខាន់បំផុតក្នុងយុទ្ធនាការប្រមូលស្រូវនេះ ។ លន់ នល់ ធ្លាប់ធ្វើជាអភិបាលខេត្តនេះ កាលពីសម័យសង្គ្រាម ឥណ្ឌូចិនលើកទី១ ហើយគាត់ស្គាល់ប្រវត្តិរបស់ខេត្តនិងដឹងនូវអ្វីៗ ដែលក្រុមនិយមឆ្វេង និងពួកអ្នកជាតិនិយមធ្លាប់ ធ្វើសកម្មភាពនៅទីនេះច្បាស់ណាស់ ។ លន់ នល់ បានបង្គាប់បញ្ជាឲ្យទាហានរបស់គាត់ យកចិត្តទុកដាក់ឲ្យប្រជាកសិករនៅខេត្តបាត់ដំបង លក់ស្រូវជូនរដ្ឋាភិបាល ហើយមិនមែនលក់ឲ្យពួកកុម្មុយនិស្តវៀតណាមទេ ។ ពួកអ្នកមានស្រូវបានរឹងទទឹង មិនធ្វើតាមឡើយ ព្រោះពួកវៀតណាមបានឲ្យថ្លៃស្រូវលើសពីតម្លៃរដ្ឋកំណត់ពីរដង ។ ភ្លាមៗនោះ នៅក្នុងខេត្តមានលេចចេញសៀវភៅស្តើងៗជាច្រើន ដែលធ្វើឲ្យគេចាប់អារម្មណ៍ថា ពួកកុម្មុយនិស្តជាអ្នកតាក់តែងឡើង ។ សៀវភៅស្តើងទាំងនោះ បានអុជអាលឲ្យប្រជាកសិករបះបោរប្រឆាំងនឹងពួកទាហានរបស់ លន់ នល់ ហើយប្រជាកសិករខ្លះ បានអំពាវនាវឲ្យផ្តួលរំលំរបបនេះថែមទៀត ។

បញ្ហាជាក់ស្តែងនៃកម្មវិធីរបស់ពួកកុម្មុយនិស្តនៅឆ្នាំ១៩៦០ គឺការគ្មានសមត្ថភាពរបស់គេក្នុងការរិះរកមធ្យោបាយផ្សេងៗ ដែលសំខាន់ស្មើអាយុជីវិតដើម្បីកេណ្ឌប្រមូលកសិករទាំងនេះ ។ ក្នុងភាគច្រើននៃតំបន់ផ្សេងៗ ការលំបាករបស់ប្រជាកសិករ ទាមទារឲ្យមានកែទម្រង់ដោយការបដិវត្តន៍មួយ ដូចដែលពួកបញ្ញវន្ត ខៀវ សំផន, ហ៊ូ យន់ និងហ៊ូ នឹម ធ្លាប់បានពន្យល់វែកញែកក្នុងស្នាដៃស្រាវជ្រាវគាត់ដូច្នោះដែរ ។ ហើយសម្តេច ព្រះនរោត្តម សីហនុ បានសាកល្បងអនុវត្តន៍ការកែទម្រង់ទាំងនេះ ដោយបង្កើតប្រពន្ធ័សហករណ៍មួយរបស់រដ្ឋាភិបាលដែលរ៉ាប់រងផ្តល់ឥណទានមួយឲ្យប្រជាកសិករខ្ចី ដោយយកការប្រាក់ថោកៗ ។ ប៉ុន្តែ ដូចការផ្តើមគំនិតសង្គមនិយមផ្សេងៗទៀតរបស់សម្តេចដែរ សហករណ៍នេះបានធ្លាក់ទៅក្នុងកណ្តាប់ដៃពួកការិយាធិបតេយ្យដែលគ្មានសមត្ថភាព និងដែលពុករលួយទៅវិញហើយវាក៏ក្លាយទៅជាបរាជ័យមួយ ។

ការជ្រើសរើសយកខេត្តបាត់ដំបង សម្រាប់យុទ្ធនាការដ៏សំខាន់ក្នុងការប្រមូលស្រូវនោះ បានកើតមានឡើងដោយពួកកុម្មុយនិស្តមិនបានដឹងខ្លួនជាមុនឡើយ ។ នេះជាខេត្តតែមួយគត់ ដែលភាគច្រើនជាងគេនៃប្រជាកសិករខ្មែរ មិនសម្របខ្លួនទៅតាមកលៈទេសៈ ហើយដែលកសិករទាំងឡាយស្ថិតនៅក្រោមអំណាចនៃម្ចាស់កម្មសិទ្ធិដីធ្លីធំៗ ។ ក្រោយសង្គ្រាមលោកលើកទី២ ការកាន់កាប់ម្តងម្កាល របស់ថៃបានត្រូវបញ្ចប់ ហើយខេត្តបាត់ដំបងបានត្រូវបង្កឲ្យមានប្រជាជនឡើងវិញ ដោយពួកអ្នកចំណូលថ្មី គឺពួកអ្នកដែលបានទិញដីស្រែចម្ការដ៏ធំល្វឹងល្វើយ ហើយដែលបានទាញយកផលកម្រៃពីដីទាំងនោះដោយជួលប្រវាស់ឲ្យប្រជាជននៅទីនោះ

ដែលត្រូវប្រគល់ភោគផលរបស់ខ្លួនចំនួនពាក់កណ្ដាលមកឲ្យម្ចាស់ដីទុកជា«ការប្រាក់» ឬ «ឈ្នួលដី» ។ ពួកអ្នកចំណូលថ្មីទាំងនេះ សុទ្ធតែពួកខ្មែរក្រោម ដែលរត់គេចពីសង្គ្រាមនៅវៀតណាមខាងត្បូង ហើយបានមកតាំងទីលំនៅក្នុងខេត្តនេះចំនួនរាប់ពាន់នាក់ ហើយដែលពួកគេត្រូវធ្វើការប្រកួតប្រជែង ជាមួយនឹងកសិករនៅមូលដ្ឋាននោះខាងដីធ្លី និងការងារ ។ ហេតុដូច្នេះហើយបានជាមានការឈ្លោះប្រកែកគ្នារវាងប្រជាជនដែលរស់នៅនៅតំបន់នោះជារឿយៗ ។

តាមការពិត បក្សរបស់ សាឡុត ស និង នួន ជា ពុំមែនជាអ្នកតាក់តែងប្រភេទសៀវភៅស្ដើងៗមួយឈុតដំបូងនោះទេ សៀវភៅនេះ គឺតែងសរសេរដោយអង្គការកុម្មុយនិស្តនៅមូលដ្ឋាននោះ ដែលរួមមានសមាសភាពជាអតីតអ្នកប្រយុទ្ធក្នុងសម័យសង្គ្រាមឥណ្ឌូចិនលើកទី១ ស្ទើរតែទាំងអស់ ដែលបន្សល់ទុកឲ្យនៅនឹងកន្លែង ដើម្បីទ្រទ្រង់ចលនា មានជីវិតតទៅទៀត ។ សាឡុត ស បានទូន្មានឲ្យមានការប្រុងប្រយ័ត្ន ប៉ុន្ដែ ពួកកុម្មុយនិស្ត និងប្រជាកសិករមូលដ្ឋាននោះ មិនជឿពីប្រសិទ្ធិភាពនៃការអត់ធ្មត់ឡើយ ។ ពួកគេ បានសម្រេចធ្វើសកម្មភាពយ៉ាងឃោរឃៅព្រមគ្នាតែម្ដង ។

រដ្ឋាភិបាលបានបញ្ជូនកងទ័ពយ៉ាងច្រើន ដើម្បីទៅប្រមូលស្រូវអង្ករ បណ្ដាលឲ្យកើតមានឧប្បត្តិហេតុតូចៗដែលកើតឡើងឯងៗជាច្រើន ហើយកងទ័ពខ្លះបានត្រូវគេវាយប្រហារ ។ នៅក្រុងភ្នំពេញ ខៀវ សំផន បានក្ដាប់ជាប់បញ្ហានេះ ហើយបានរៀបចំបាតុកម្មមួយ ដេម្បីបង្ខិតបង្ខំឲ្យរដ្ឋាភិបាល លន់ នល់ បញ្ចប់ការប្រមូលស្រូវនិងលាលែងពីមុខតំណែង ដោយសារកំហុសដែលគាត់បានប្រព្រឹត្ត ។ នេះជាគំនិតផ្ដើមដ៏ក្លាហានអស្ចារ្យមួយហើយ សំផន ក៏ត្រៀមទទួលការសងសឹកវិញដែរ ។ ផ្ទុយទៅវិញ ការសងសឹកនេះបានលេចចេញពីប្រភពមួយដ៏គួរឲ្យភ្ញាក់ផ្អើលមួយ គឺ សម្ដេច ព្រះនរោត្ដម សីហនុ បានទម្លាក់ទោសទៅលើ ខៀវ សំផន រួមទាំង ហ៊ូ យន់ និង ហ៊ូ នឹម ផង ដោយចោទប្រកាន់ថា ជាអ្នកស្ថិតពីក្រោយខ្នងការច្របូកច្របល់ផ្សេងៗនៅខេត្តបាត់ដំបង ។

នៅសម័យមួយ ការរិះគន់ជាសាធារណៈរបស់សម្ដេច ធ្លាប់បាន បង្ខំឲ្យអ្នកទាំងបីសុំលាលែងពីមុខតំណែងម្ដងរួចមកហើយ ។ លើកនេះពួកគេបានសម្រេចចិត្តនៅស្ងៀមមិនធ្វើអ្វីទាំងអស់ ដើម្បីសាកល្បងចង់ដឹងពីហេតុដែលនាំឲ្យប្រជាជនជឿសម្ដេច ព្រះនរោត្ដម សីហនុ ហើយពួកគេបានឈ្នះសម្ដេចមែន ។ ពួកគេនៅរក្សាកៅអីក្នុងរដ្ឋសភាជាតិដដែល ក្នុងពេលដែលដំណាងរាស្ដ្រពីរនាក់ទៀត ដែលទទួលខុសត្រូវក្នុងការគ្រប់គ្រងខេត្តដោយផ្ទាល់ ត្រូវបានបណ្ដេញចេញពីរដ្ឋសភា ។ មូលដ្ឋានអំណាចដែលទ្រេតទ្រោតរកកល់នឹងរលំដួលរបស់សម្ដេចព្រះនរោត្ដម សីហនុ ធ្លាប់ត្រូវបានបរិហារព្រមៗគ្នាដោយក្រុមនិយមស្ដាំ និងក្រុមនិយមឆ្វេង បន្ទាប់ពីសម្ដេចធ្វើឲ្យភ្ញាក់ស្មៀតតែម្ដងគត់ ។ ម្យ៉ាងទៀត ដោយវាយប្រហារទាំងឆ្គងទៅលើក្រុមនិយមឆ្វេង សម្ដេច ព្រះនរោត្ដម សីហនុ បានរាំងរាមិនឲ្យក្រុមនេះជួយព្រះអង្គឲ្យស្ថិតនៅក្នុងអំណាចឡើយ ។ ហើយការត្អូញត្អែរផ្សេងៗរបស់ព្រះអង្គ ដែលមានក្រោយមកទៀត បានឲ្យសញ្ញាថា គ្មានបានការអ្វីទាំងអស់ដោយសារក្រុមនិយមឆ្វេងបង្កឲ្យ

ព្រះអង្គបរាជ័យ ។

ការផ្ទុះរឿងពិតប្រាកដ បានកើតមានឡើងយ៉ាងឆាប់រហ័ស ។ ក្នុងពេលព្រលឹមអរុណថ្ងៃទី២ ខែមេសា ឆ្នាំ ១៩៦៧ ទាហានពីរនាក់ ដែលកំពុងចាត់ចែងប្រមូលស្រូវបានត្រូវគេលួចសម្លាប់នៅសំឡូតក្នុងខេត្តបាត់ដំបង ។ ពួកអ្នកភូមិដែលចូលរួម ក្នុងប្រតិបត្តិការនេះ បានដណ្ដើមយកអាវុធពីទាហានដែលស្លាប់ដោយសេចក្ដីក្លាហានយ៉ាងមោះមុត ហើយបានវិលត្រឡប់មកកន្លែងដដែលវិញ នៅពេលរសៀលជាមួយអាវុធបន្ថែម និងបដាជាច្រើនដែលសរសេរថ្កោលទោសរដ្ឋាភិបាល លន់ នល់ និងចក្រពត្តិនិយមអាមេរិកាំង ។ ពួកគេបានត្រូវប្រជាកសិករជាច្រើនទៀតមកចូលរួមជាមួយទៀត ហើយនៅពេលដែលមនុស្សប្រហែល ២០០នាក់ ជួបជុំគ្នា ពួកគេបានដើរតម្រង់ទៅកាន់មណ្ឌលនីតិកម្ម ឬរដ្ឋបាលជនបទមួយ ហើយវាយកម្ទេចបំផ្លាញទីនោះរាបដល់ដី ។ ដោយគ្មានអ្វីដែលធ្វើឲ្យព្រួយបារម្ភ ពួកគេបានបន្តធ្វើបាតុកម្មតទៅទៀត ដោយធ្វើការវាយលុកបន្ទាយកងរក្សាខេត្តទៀតផង ។

មួយពីរឆ្នាំក្រោយ ការដើរចូលក្រុងហាណូយប្រកបដោយជោគជ័យរបស់ ហូ ជីមិញ និងការថ្លែងប្រកាសពីជ័យជម្នះនៃការបដិវត្តន៍ខែសីហារបស់វៀតមិញ ការបះបោរប្រឆាំងដោយអាវុធរបស់ពួកកុម្មុយនិស្តបានចាប់ផ្ដើមនៅប្រទេសកម្ពុជាដែរ ។

ដំណឹងនៃព្រឹត្តិការណ៍ផ្សេងៗនៅសំឡូត បានលាន់ឮទៅដល់ សាឡុត ស ដែលរស់នៅភាគខាងកើតកម្ពុជាក្បែរព្រំដែនវៀតណាម ជាទីដែលគណៈកម្មាធិការមជ្ឈិមបក្សបានបោះទីតាំងធ្វើការនៅទីនោះ ។ ជាថ្មីម្ដងទៀតពួកកុម្មុយនិស្តបាន បញ្ជាក់ថា ពួកគេបានវាយតម្លៃខុសអំពីសក្ដានុពលបដិវត្តន៍របស់កម្ពុជា ប៉ុន្តែ ម្ដងនេះបក្សមានអត្ថិភាព ហើយលើកនេះពួកមេដឹកនាំរបស់ខ្លួនក៏ប្រុងប្រៀបឆ្លងទៅដំណាក់កាលបន្ទាប់ជាស្រេចដែរ គឺការតស៊ូដោយអាវុធប្រឆាំងនឹងសម្ដេច ព្រះនរោត្តម សីហនុ ។

នៅក្រុងភ្នំពេញ សមាជិករបស់បក្សបីនាក់ ដែលរស់នៅក្នុងរាជធានីនោះអាចពើបប្រទះគ្រោះថ្នាក់យ៉ាងធំ ។ ថ្ងៃទី២២ ខែមេសា សម្ដេច ព្រះនរោត្តម សីហនុ បានចោទប្រកាន់ ខៀវ សំផន, ហ៊ូ យន់ និង ហ៊ូ នឹម ជាសាធារណៈថា បានញុះញង់ឲ្យកើតអំពើបះបោរនៅសំឡូត ហើយបានគំរាមដាក់អ្នកទាំងបីឲ្យតុលាការសឹកជំនុំជម្រះទោសទៀតផង ។ ពីរថ្ងៃក្រោយមក ខៀវ សំផន និង ហ៊ូ យន់ បានចាកចេញពីរាជធានីដោយបន្ទំលាក់ខ្លួនក្នុងទេះគោរបស់ ប្រជាកសិករក្នុងសភាពអ៊ូអរទ្រហឹងអ៊ឹងអាប់នាពេលថ្ងៃរៀបអស្ដង្គត ។ ហ៊ូ នឹម បានរស់នៅក្នុងក្រុងភ្នំពេញរហូតដល់ខែកញ្ញា ដើម្បីឃ្លាំមើលរដ្ឋាភិបាល បន្ទាប់មក បក្សវិនិច្ឆ័យថា រូបគាត់ក៏ត្រូវមានគ្រោះថ្នាក់ដូចគ្នា ហើយគាត់ក៏គេចខ្លួនរត់ចូលព្រៃដោយស្ងាត់កំបាំងដែរ ។

ក្រោយមក លន់ នល់ បានអះអាងថា មនុស្សទាំង៣នាក់នេះត្រូវបានគេសម្លាប់ចោលទាំងអស់ ។ នៅពេលដែលលេចមុខឡើងវិញក្នុងឋានៈជាមេដឹកនាំខ្មែរក្រហម គេបានហៅអ្នកទាំងនោះថា "បិសាចទាំងបី" ។ ពួកគេបាន

ដើរតួនាទីមួយក្នុងរឿងទេវកថារបស់កម្ពុជាសម័យទំនើប ។

បក្សតោងតែកេណ្ឌប្រមូលកម្លាំងរបស់ខ្លួនដោយឆាប់រហ័សបំផុត ។ ផាត ជាចំណែកមួយនៃក្រុមដំបូង ដែលជាអ្នកផ្ទេរទីបញ្ជាការក្រុមកុម្មុយនិស្តពីតំបន់ខាងកើត ដែលអាចត្រូវគេវាយប្រហារទៅតំបន់ព្រៃភ្នំពិបាកចូលដល់នៅភាគឦសានវិញ ។ ក្នុងឋានៈជាកងការពារ ផាត បានបំពេញមុខងារជានិរសារវាងទីបញ្ជាការដ្ឋាន និងក្រុងភ្នំពេញថែមទៀត ។ នៅខែកក្កដា គាត់បានអមការពារ សាឡុត ស នៅក្នុងខេត្តរតនគិរី ហើយគឺពីព្រៃភ្នំក្រំថ្មទាំងនេះហើយ ដែលពួកកុម្មុយនិស្តផ្តើមការបដិវត្តន៍មួយ ដោយគ្មានជួយគាំទ្រពីបណ្តាសម្ព័ន្ធមិត្តបរទេសណាមួយសោះ ហើយមានការគាំទ្រមួយយ៉ាងខ្សោយបំផុតនៅពេលដំបូងៗក្នុងចំណោមកសិករទាំងឡាយ ដែលពួកគេប្រាថ្នារំដោះមុនគេ ។

ការស្ថិតនៅក្នុងវាលទំនាប គឺប្រថុយប្រថានឲ្យសម្តេច ព្រះនរោត្តម សីហនុ ងាយស្រួលចាប់ខ្លួនបំផុត ។ ប្រាកដហើយ សម្តេចបានសម្រេចព្រះទ័យផ្តន្ទាទោសកសិករទាំងឡាយដែលបះបោរប្រឆាំងនឹងព្រះអង្គ ។ នយោបាយមិនសម្របសម្រួលរបស់ព្រះអង្គ បានរុញច្រានសម្តេចទៅរកចំណុចមួយ ដែលគ្មានវិលត្រឡប់ក្រោយបាន ។ ដោយអនុញ្ញាតឲ្យពួកវៀតណាមខាងជើងប្រើប្រាស់កំពង់ផែក្រុងព្រះសម្តេច ព្រះនរោត្តម សីហនុពេញចិត្តនោះ សម្តេចបានកាត់ថ្លៃក្បាលពួកកុម្មុយនិស្ត និងពួកអ្នកបះបោរកម្ពុជាទាំងអស់ ហើយសន្យាផ្តល់រង្វាន់យ៉ាងច្រើនជាថ្នូរនឹងភូមិបះបោរនីមួយៗ ដែលត្រូវកម្ទេចទៅជាផេះផង់ទៀតផង[២៨] ។ ព្រះអង្គបានបញ្ជាឲ្យកងទ័ពជើងគោក និងជើងអាកាស ពន្វ័ដេញតាម ពួកអ្នកបះបោរ និងវាយប្រហារតំបន់ជនបទទាំងអស់ ដែលគេចាត់ទុកថា លំអៀងទៅរកការបះបោរ ។

យន្តហោះ ដែលផ្តល់ឲ្យដោយពួកចិនជាច្រើនគ្រឿង ត្រូវបានយកទៅប្រើប្រាស់សម្រាប់ទម្លាក់គ្រាប់បែកលើភូមិនានា ដែលគេសង្ស័យជាភូមិបះបោរ ។ កាំភ្លើងរបស់ចិន ដែលប្រគល់ឲ្យ លន់ នល់ ដោយពួកវៀតណាមជាថ្នូរនឹងសិទ្ធិឆ្លងកាត់តាមក្រុងព្រះសម្តេច ព្រះនរោត្តម សីហនុ នៅពេលនេះបានត្រូវគេយកទៅប្រើដើម្បីវាយប្រហារពួកកុម្មុយនិស្តវិញ ដែលពួកវៀតណាមដដែលនេះ ធ្លាប់បានជ្រើសរើសកាលពីម្ភៃឆ្នាំមុន ដើម្បីធ្វើបដិវត្តន៍នៅប្រទេសកម្ពុជា ។ គេបានដោតក្បាល“សត្រូវ” លើបង្គោលជាច្រើន ។ សង្គ្រាមប្រឆាំងនឹងលទ្ធិកុម្មុយនិស្តកម្ពុជានឹងធ្វើឲ្យសម្តេច ព្រះនរោត្តម សីហនុជាប់រវល់រហូតមកដល់ថ្ងៃ ដែលរដ្ឋាភិបាលរបស់ព្រះអង្គត្រូវបានផ្តួលរំលំ បីឆ្នាំក្រោយមក ដោយរដ្ឋប្រហារមួយរបស់ក្រុមនិយមស្តាំ ។

សាឡុត ស និងបក្សរបស់គាត់បានសម្រេចចិត្តថា ពួកគេពុំមានការជ្រើសរើសណាផ្សេងទៀត ក្រៅពីរៀបចំខ្លួនធ្វើសង្គ្រាមឡើយ បើសិនជាពួកគេចង់បន្តធ្វើខ្លួនឲ្យមានឈ្មោះជាអ្នកបដិវត្តន៍ ។ បើមិនដូច្នោះទេអ្នកដទៃៗទៀតដូចជាមនុស្សខាងក្រុមនិយមស្តាំដែលកំពុងគាំទ្រ សឺង ង៉ុកថាញ់ ជាដើម ហើយដែលឥឡូវនេះបានទទួលប្រាក់កាសពីសេ.អ៊ី.អា. នឹងចូលកាន់កាប់កន្លែងចំហ ឬកន្លែងទំនេរ ហើយនឹងបំពាក់អាវុធឲ្យប្រជាកសិករ

មិនខាន ។ អាស្រ័យហេតុនេះ ពួកកុម្មុយនិស្តបានសម្រេចចិត្តបញ្ចេញនូវសេចក្តីអំពាវនាវមួយ ឲ្យធ្វើការតស៊ូដោយអាវុធបើទុកជាបណ្តាសម្ព័ន្ធមិត្តរបស់គេទូន្មានឲ្យមានការចេះប្រមាណ កុំប្រព្រឹត្តជ្រុលហួសហេតុក៏ដោយ ។ ហើយ ស បានដឹងដោយជាក់លាក់ថា បក្សរបស់គាត់គោងតែប្រយុទ្ធតស៊ូតែឯកឯងប៉ុណ្ណោះ ។ ពីរឆ្នាំមុន គឺនៅឆ្នាំ១៩៦៥ ស ធ្លាប់បានធ្វើដំណើរជាសម្ងាត់មួយទៅក្រុងហាណូយ និងប៉េកាំងដើម្បីស្ទាបស្ទង់ទឹកចិត្តបណ្តាសម្ព័ន្ធមិត្តរបស់គាត់ និងបង្ហាញខ្លួនគាត់ឲ្យគេស្គាល់ក្នុងឋានៈជាអគ្គលេខាបក្សកុម្មុយនិស្តកម្ពុជាផង ។ គាត់បានត្រូវអមដំណើរដោយ អៀង សារី រួមជាមួយ អៀង ធីរិទ្ធ ផង ហើយតាមភស្តុតាង ជាច្រើនថា ពួកគេត្រូវបានទទួលធ្វើបដិសណ្ឋារកិច្ចយ៉ាងរាក់ទាក់ក្នុងរដ្ឋធានីទាំងពីរនេះ ។ ប៉ុន្តែ វត្តមានរបស់គាត់ត្រូវបានគេរក្សាទុកជាសម្ងាត់ ហើយគេបាននិយាយណែនាំឲ្យគាត់រង់ចាំពេលវេលាសមស្របសិន ដើម្បីផ្តើមការបដិវត្តន៍របស់គាត់គឺពេលវេលាដែលវានឹងមិនធ្វើឲ្យមានគ្រោះថ្នាក់ដល់បដិវត្តន៍របស់វៀតណាមផង និងឡាវផង ។ ក្នុងពេលជាមួយគ្នានោះ ប្រទេសវៀតណាមនិងចិនបានប្រឹងប្រែងស្វែងរកការគាំពារផ្សេងៗពី សម្តេច ព្រះនរោត្តម សីហនុ ។ សហភាពសូវៀតក៏ពុំអាចឲ្យគេចាត់ទុកថាជាអ្នកគាំពារដ៏មានសក្តានុពលមួយបានដែរ ដោយសារខ្លួនធ្វើឲ្យខូចទឹកចិត្តការធ្វើបដិវត្តន៍ដោយអាវុធ ព្រោះសម័យនោះជាសម័យនៃ «ការរួមរស់ដោយសន្តិសហវិជ្ជមាន» កំពុងមានឥទ្ធិពលខ្លាំងក្លាបំផុត ។ តាមសម្តីរបស់ អៀង ធីរិទ្ធ[៣៩] បានឲ្យដឹងថា អត្ថប្រយោជន៍សំខាន់បំផុតនៃការធ្វើដំណើរនេះ គឺផ្តល់ពត៌មានឲ្យក្រុងប៉េកាំងដឹងថា បក្សមួយរបស់កម្ពុជា ដែលឯករាជ្យបានកើតឡើងហើយ ហើយពុំមែនជាសាខាខ្មែរមួយរបស់បក្សកុម្មុយនិស្តឥណ្ឌូចិននោះទេ ។

វាទំនងជាអាចថា ព្រឹត្តិការណ៍ផ្សេងៗនៅប្រទេសចិនក្នុងឆ្នាំ១៩៦៧ បានដើរតួនាទីមួយក្នុងការសម្រេចចិត្តរបស់ពួកកុម្មុយនិស្ត ដើម្បីប្រកាសសង្គ្រាមដោយចេញមុខប្រឆាំងនឹងសម្តេច ព្រះនរោត្តម សីហនុ ។ នៅខែសីហា ឆ្នាំ១៩៦៧ ពួកឆ្មាំក្រហមនៃការបដិវត្តន៍វប្បធម៌បានដណ្តើមកាន់កាប់ទីស្តីការរដ្ឋមន្ត្រីក្រសួងការបរទេស ហើយបានប្រកាន់យកពាក្យស្លោកថា «ការបដិវត្តន៍គិត និយាយ ធ្វើត្រូវជានិច្ច» ដើម្បីដឹកនាំនយោបាយបរទេសរបស់ចិន ។ ប្រវត្តិវិទូម្នាក់វាយតម្លៃថា« ដោយស្ងាត់កំបាំង ពួកកុម្មុយនិស្តកម្ពុជាប្រហែលជាត្រូវជួយគាំទ្រ និងលើកទឹកចិត្តដោយពួកអ្នកទាំងឡាយ ដែលនៅពេលនោះជាអ្នកកាច់ចង្កូតនយោបាយការបរទេសរបស់ប្រទេសចិន[៤០] ។

បើសិនជាមានករណីនេះមែន ការគាំទ្រនេះក៏មានរយៈពេលខ្លីដែរព្រោះថាក្រោយពីបានដណ្តើមកាន់កាប់នយោបាយបរទេសរបស់ប្រទេសគាត់ឡើងវិញ ជូអេនឡាយ បានផ្តល់នូវការទ្រាំទ្ររបស់ក្រុងប៉េកាំងពេញធឹងចំពោះសម្តេច ព្រះនរោត្តម សីហនុ ជាថ្មី ។ ជូអេនឡាយ បានបំបាត់ឧបសគ្គផ្សេងៗ ដែលបង្កឡើងដោយពួកឆ្មាំក្រហមក្នុងទំនាក់ទំនងទាំងឡាយជាមួយសម្តេច ព្រះនរោត្តម សីហនុ បន្ទាប់មកគាត់បានបង្ហាញឲ្យឃើញពីសុឆន្ទៈរបស់ប្រទេសចិន ដោយចាប់ផ្តើមផ្តល់ជំនួយយោធាមកឲ្យសម្តេចថែមទៀត ។ ហើយនៅខែមករា ឆ្នាំ១៩៦៨

គ្រឿងអាវុធមួយចំនួនថ្មីទៀត ដែលចេញពីទីក្រុងប៉េកាំងបានមកដល់ប្រទេសកម្ពុជាមានយន្តហោះប្រតិកម្ម យន្តហោះទម្លាក់គ្រាប់បែកយន្តហោះសម្រាប់ដឹកជញ្ជូនទ័ព កាំភ្លើងធំធុនធ្ងន់ និងធុនស្រាល កាំភ្លើងវែង និងគ្រាប់រំសេវ ។

ឥឡូវនេះ ពួកខ្មែរក្រហមគោងតែរៀបចំយុទ្ធសាស្ត្រមួយ ដើម្បីដឹកនាំធ្វើសង្គ្រាមនិងទ្រឹស្តីមួយដើម្បីឲ្យសំអាងគាំទ្រសង្គ្រាមនេះ ។ បន្ទាប់ពីការបះបោរនៅសំឡូត បក្សបានសន្មតជាមុនថា ប្រជាកសិករនឹងបន្តប្រយុទ្ធប្រឆាំងនឹងការប្រមូលស្រូវរបស់រដ្ឋាភិបាលតទៅទៀតហើយថា ការបះបោរនេះត្រូវមាន ឬមិនចំបាច់មាន បក្សកុម្មុយនិស្តសម្រាប់ដឹកនាំទេ ។ បក្សនិយាយថា ប្រជាកសិករ«ប្រៀបបីដូចជាចំបើងក្រៀមស្ងួត... នៅក្នុងស្រែដែលរង់ចាំតែកម្ទេចភ្លើងតូចមួយសម្រាប់ធ្វើឲ្យឆេះឡើងប៉ុណ្ណោះ»[៤១] ។

ដោយឃ្លាតកាន់តែឆ្ងាយទៅៗពីរាជធានី ពីវាលទំនាបភាគខាងកើត ទៅរស់នៅព្រៃភ្នំឆ្ងាយដាច់ស្រយាលនៃភាគឦសាន សាឡុត ស និងគណៈកម្មាធិការមជ្ឈិមបក្សបានចាកចោលមិនត្រឹមតែវប្បធម៌ និងសង្គម ដែលធ្លាប់ជាប្រភពផ្តល់គំនិតបដិវត្តន៍របស់គេប៉ុណ្ណោះទេ ប៉ុន្តែ ក៏ចាកចោលគំនិតផ្ទាល់របស់គេមួយចំនួនធំដែរ ។ ក្នុងភាពរស់នៅដាច់ឆ្ងាយពីគេឯងទាំងរូបកាយ និងទាំងនយោបាយរបស់គេ ពួកខ្មែរក្រហមបានផ្លាស់ជំនួសសញ្ញាណចាស់ៗ ដែលពួកគេធ្លាប់ទទួលអំពីពួកកុម្មុយនិស្តដទៃៗទៀត ដោយប្រកាន់យកនយោបាយថ្មីមួយ ដែលច្រឡំបល់មិនច្បាស់លាស់ហើយមួយផ្នែកធំ គឺធ្វើទៅតាមសភាពជាក់ស្តែងនៃកាលៈទេសៈប៉ុណ្ណោះ ។ ភាពមិនច្បាស់លាស់បានក្លាយទៅជាកាន់តែជាក់ច្បាស់ឡើង នៅពេលដែលពួកគេត្រូវប្រឆាំងតបតនឹងស្ថានការណ៍មួយ ដែលកំពុងវិវត្តទៅយ៉ាងលឿនស្ទេវ ។ ចំពោះពួកគេត្រូវតែបោះបង់គំនិតចាស់គំរិលចោលទាំងអស់ គឺ«កុម្មុយនិស្តនិយមអន្តរជាតិ» ដែលពុំធ្លាប់ជួយអ្វីដល់គេបន្តិចណាសោះ ក្នុងពេលដែលពួកគេត្រូវការពួកសម្ព័ន្ធមិត្តរបស់គេឲ្យជួយនោះ ដោយហេតុថា អាទិភាព ដែលគេបានព្រមព្រៀងគ្នាចំពោះជម្លោះទូទាំងឥណ្ឌូចិន ជាពិសេស ចំពោះសង្គ្រាមនៅវៀតណាមនោះ បានធ្វើឲ្យការតស៊ូរបស់ពួកគេចុះខ្សោយក្នុងប្រទេសផ្ទាល់របស់ខ្លួនដែរ ។

ហើយពួកកុម្មុយនិស្តកម្ពុជា ស្ទើរតែគ្មានទ្រឹស្តីអ្វីដើម្បីជំនួយគំនិតចាស់ៗទាំងនេះឡើយ ។ ការដោះស្រាយរបស់គេស្ថិតនៅត្រង់ការលើកតម្កើងស្ថានភាពគោកយ៉ាកខ្វះមុខខ្វះក្រោយ រៀបចំគុណធម៌ ដែលជាភាពចំបាច់ខានមិនបាន ជ្រោងឡើងនូវ "ភាពបរិសុទ្ធ" សេចក្តីស្មោះត្រង់ដាច់ខាតក្នុងបរិយាកាសមួយ ដែលពួកគេវិនិច្ឆ័យថាមានពោរពេញទៅដោយពួកក្បត់ ពួកមិត្តភក្តិ ដែលអាចក្បត់នឹងចលនារបស់គេ ។ ដូច្នេះក្នុងភាពឯកោរបស់គេសាឡុត ស និងបក្សបានសង្កត់ធ្ងន់ទៅលើភាពថ្លៃថ្នូរ នៃការតស៊ូ ជាមួយនឹងប្រភពធនធានស្តួចស្តើង និងភាពបរិសុទ្ធនៃមាគ៌ា«ឯករាជ្យម្ចាស់ការ» ។ ចំពោះ ស ការធ្វើខ្លួនឲ្យបរិសុទ្ធ បានទៅជាការគិតមមៃមួយ ដែលធ្លាយចេញទៅជាអំពើសាហាវយង់ឃ្នងផ្សេងៗទៀត នៅពេលដែលទស្សនៈចង្អៀតចង្អល់របស់ការបដិវត្តន៍ ដែលគេរៀបចំអស់រយៈពេលយ៉ាងយូរនៅក្នុងព្រៃភ្នំ ត្រូវបានពង្រីកឲ្យរាលដាលទៅលើប្រជាជាតិទាំងមូលនោះ ។

ព្រៃស្បាតដ៏អាថ៌កំបាំងរបស់ខេត្តរតនគិរី សមស្របនឹងចិត្តគំនិតបែបនោះជាខ្លាំង ។ ស្ថានភាពដី ស្ទើរតែមិនអាចឲ្យគេធ្វើអ្វីកើត ព្រៃក្រាស់ឃ្មឹកចង្អៀតណែន ដែលរាតត្បាតទៅដោយជំងឺគ្រុនចាញ់បានធ្វើឲ្យប្រជាជននៅវាលទំនាបខ្លាចរអាយ៉ាងខ្លាំង ហើយត្រូវពួកខ្មែរអ្នកទីក្រុងចាត់ទុកថា ជាកន្លែងដែលមានអន្តរាយយ៉ាងសម្បើម ។ ជីវភាពក្នុងព្រៃភ្នំទាំងនេះ មិនសូវមានការផ្លាស់ប្តូរប៉ុន្មានទេតាំងពីពេលដែលអ្នកធម្មជាតិវិទ្យា ដ៏ល្បីល្បាញរបស់បារាំងឈ្មោះ ហង់រី មូហូត (Henri Mouhot) បានរុករក ស្រាវជ្រាវតំបន់នេះជាលើកដំបូង កាលពីមួយសតវត្សរ៍មុន ។ ក្នុងសៀវភៅដែលមានចុះព្រឹត្តិការណ៍ផ្សេងៗរបស់គាត់[៤២] មូហូត បានសរសេររៀបរាប់ពីលក្ខណៈសម័យដើម ដែលប្រហែលជាមានមុនប្រវត្តិ សាស្ត្រទៅទៀត ព្រៃស្មសាន ដែលរុករានដោយ សត្វដំរី ក្របីព្រៃ រមាស ខ្លាធំ ខ្យាដំរី ពស់ និងសត្វមូស គ្រប់ប្រភេទ ។ បើទុកជាពួកកុម្មុយនិស្តកម្ពុជាមួយចំនួន ធ្លាប់រងការលំបាកវេទនាក្នុងកុមារភាពនៅជនបទក៏ដោយ ក៏ពួកគេពុំដែលត្រៀមខ្លួនទៅរស់នៅក្នុងព្រៃភ្នំទាំងនេះ ដូចគ្នានឹងពួកបារាំងដែរ ។ ប៉ុន្តែ ដូចអ្នកធម្មជាតិវិទ្យានោះដែរ ពួកគេយល់ឃើញថាស្ថានភាពដ៏គួរឲ្យខ្លាចទាំងនេះ ច្រើនតែបានតបស្នងមកវិញ ដោយការទទួលរាក់ទាក់គួរសមរបស់ប្រជាជននៃកុលសម្ព័ន្ធផ្សេងៗ ដែលរស់នៅទីនោះ ។ ពីក្នុងចំណោមខ្មែរលើឬ អ្នកស្រុកភ្នំទាំងនេះ មូហូត បានសរសើរអំពីន័យនៃសមភាព និងសាមគ្គីភាព ដែលគ្របដណ្តប់លើសហគមន៍តូចៗទាំងនោះ ។

សាឡុត ស បានរកឃើញ "មនុស្សព្រៃដ៏ថ្លៃថ្នូរ" ទាំងនេះក្នុងប្រវត្តិសាស្ត្ររបស់កម្ពុជាជាថ្មី ដែលបានចូលរួមក្នុងការបះបោរប្រឆាំងរបស់គាត់ដោយងាយស្រួល ដូចពួកគេធ្លាប់បានធ្វើតាមអ្នកបះបោរជាតិខ្មែរឯទៀតៗ និងទាហានជាច្រើនដែលរត់មកជ្រកក្នុងព្រៃភ្នំទាំងនេះ[៤៣] ។ ក្នុងរយៈដែលមានជម្លោះរវាងស្តេច និងស្តេច នៅសម័យអង្គរ ពួកខ្មែរលើបានកាន់ជើងខាងស្តេចទាំងឡាយ ដែលធ្លាក់បុណ្យក្នុងសេចក្តីសង្ឃឹម បញ្ចប់នូវការវាយឆ្មក់ របស់ពួកខ្មែរវាលទំនាប ដើម្បីយកពួកគេទៅធ្វើជាទាសករ ។ ជាឧទាហរណ៍ នៅពេលដែលព្រះអង្គម្ចាស់ ស៊ីវត្ថា ផ្តើមការងើបបះបោររបស់ព្រះអង្គប្រឆាំងនឹងពួកបារាំង និងស្តេចនរោត្តម ជាព្រះអយ្យកោរបស់សម្តេច ព្រះនរោត្តម សីហនុ សតវត្សរ៍ទី១៩ ព្រះអង្គបានជ្រើស រើសពួកខ្មែរលើទាំងនេះ ហើយឲ្យចូលធ្វើទ័ពខាងព្រះអង្គ ។

ចំពោះ ស និងបក្ស, ព្រៃភ្នំ និងអ្នកស្រុក ដែលរស់នៅទីនោះ បានបង្ហាញឲ្យឃើញបញ្ហាញផ្ទាល់ខ្លួនផ្សេងៗរបស់ពួកគេជាថ្មី ហើយ ស បានចុះជាប់ជាមួយពួកនោះក្នុងការប្រយុទ្ធប្រឆាំងនឹងសត្រូវរួម ។ ម្យ៉ាងទៀត ភាពក្រីក្រគោកយ៉ាករបស់ពួកអ្នកស្រុកទាំងនោះបានធ្វើឲ្យទស្សនៈផ្ទាល់របស់ ស កម្រើកឡើងក្នុងឋានៈជាមេដឹកនាំចលនារំដោះជាតិមួយ ។ ក្រោយមកគាត់បានសរសេរថា ពួកអ្នកស្រុកភ្នំទាំងនោះរស់នៅដូច "សត្វធាតុ"[៤៤] ក្រោមរបបកេងប្រវ័ញ្ចមួយ ប្រកបដោយភាពអំណាចឃោរឃៅជាទីបំផុត ហើយពួកអ្នកទាំងនោះគ្មានដែលស្គាល់អ្វីក្រៅពីការអាម៉ាស់មុខ និងការប្រមាថមាក់ងាយឡើយ ។ ក្នុងព្រៃភ្នំទាំងនេះ ពុំមាន "ធាតុ" អ្វីដែលមាន

ន័យមិនច្បាស់លាស់ដូចនៅតំបន់វាលទំនាប ដែលគេនៅតែគោរពបូជាសម្តេច ព្រះនរោត្តម សីហនុ ឡើយ ។ សាឡុត ស ធ្វើដំណើរទៅព្រៃភ្នំស្វែងរកលាក់ខ្លួន ហើយនៅទីបំផុតគាត់ក៏សម្រេចអូសទាញបានពួកអ្នកស្រុកទាំងនោះ ដែលត្រូវការឲ្យមានការបដិវត្តន៍មួយដូចគ្នា ។ ប្រាំបីឆ្នាំក្រោយមក នៅពេលដែលកងទ័ពរបស់គាត់បានទទួលជ័យជម្នះ មានសាក្សីជាច្រើនបានកត់សម្គាល់ឃើញនូវសមាមាត្រដ៏ខ្ពស់នៃកងទ័ពសម្បុរខ្មៅស្រគាំ វាយប្រយុទ្ធក្នុងជួរទ័ពរបស់គាត់ដែរ ។ ក្រោយមកទៀត សម្តេច ព្រះនរោត្តម សីហនុ បានធ្វើឲ្យ "មនុស្សព្រៃ" ទាំងនោះទៅជាអ្នកទទួលខុសត្រូវលើអំពើឃោរឃៅផ្សេងៗរបស់បក្សកុម្មុយនិស្តកម្ពុជា ដែលនេះជាករណីបុរេនិច្ឆ័យរបស់ស្តេចចំពោះរាស្ត្រសាមញ្ញទាំងឡាយ ជាប្រពៃណីទៅហើយ ដែលខ្លួនឯងក៏ក្លាយទៅជាអ្នករងគ្រោះពីអំពើឃោរឃៅរបស់ពួកកុម្មុយនិស្តដែរ គឺពុំមែនអ្នកប្រព្រឹត្តទេ នៅពេលដែលពួកខ្មែរក្រហមទម្លាក់ទោសបន្ទាប់មកទៀត ទៅលើជនជាតិភាគតិច ។

ប៉ុន្តែ នៅឆ្នាំ១៩៦៧ ពួកកុម្មុយនិស្តបានពឹងផ្អែកលើសុច្ឆន្ទៈរបស់អ្នកស្រុកភ្នំទាំងនោះ ហើយសម្រាប់លើកនេះ សម្ព័ន្ធមិត្ត (អ្នកស្រុកភ្នំ) ទាំងនេះ បានឆ្លើយតបមកវិញដោយទឹកចិត្តជ្រះថ្លាថា មិនដែលមានចិត្តក្បត់នឹងពួកកុម្មុយនិស្តសោះឡើយ ហើយបានជួយនាំផ្លូវពួកនេះដើរកាត់ព្រៃព្រឹក្សា ព្រមទាំងការពារពួកនេះពីការវាយប្រហារពីកងទ័ពសម្តេច ព្រះនរោត្តម សីហនុ ទៀតផង ។ ដាត បានជួយរៀបចំតាំងទីបញ្ជាការកុម្មុយនិស្ត ហើយត្រូវបានគេ តែងតាំងជាអនុប្រធានទទួលបន្ទុកផ្នែក "អក្សរសម្ងាត់" និងម៉ាស៊ីនសម្រាប់បោះពុម្ពឯកសារ ។ យុវនិស្សិតនេះដែលជាអ្នកចំណូលថ្មី បានប្រែក្លាយខ្លួនទៅជាមនុស្សម៉ាស៊ីនម្នាក់ និងជាអ្នកឃោសនាខានមិនបានសម្រាប់បក្ស ។ ដោយគ្មានរួញរា ដាត បានភ្ជាប់ជីវិតរបស់ខ្លួនទៅនឹងចលនាបន្តិចម្តងៗ ហើយនៅពេលដែលបក្សតម្រូវឲ្យមានសេចក្តីស្មោះត្រង់ដាច់ខាតមួយ គាត់បានយល់ព្រមធ្វើតាមទាំងគ្មានពិចារណា ដូចគាត់ធ្លាប់បានប្រតិបត្តិកាលគាត់នៅវត្តដូច្នេះដែរ ។

ដាត ធ្វើការនៅទីបញ្ជាការនៃគណៈកម្មាធិការមជ្ឈិម បក្សកុម្មុយនិស្តពួកកុម្មុយនិស្ត នៅតំបន់វាលទំនាបត្រូវប្រឈមមុខបំពេញកិច្ចការចាំបាច់ទាំងលំបាក ដើម្បីបង្កើតកងទ័ពមួយ និងស្វែងរកអាវុធមកបំពាក់ឲ្យយុទ្ធជនរបស់ខ្លួន ។ បក្សបានរៀបចំពួកអ្នកជ្រើសរើសថ្មីរបស់ខ្លួននៅ "មូលដ្ឋានបផ្អែកទាំងឡាយ[៤៥]" តាមតំបន់ដាច់ស្រយាលនានា ដែលគេយល់ថា មានសន្តិសុខគ្រប់គ្រាន់ ហើយដែលប្រជាជនមិនសហការជាមួយកងទ័ពរដ្ឋាភិបាល បើទោះជាពួកប្រជាជនទាំងនោះគ្មានសមានចិត្តជាមួយពួកគេក៏ដោយ ។ ក្រៅពីមូលដ្ឋានបផ្អែកទាំងនេះមាន "មូលដ្ឋានទ័ពព្រៃ" ជាច្រើនទៀត ។ ពួកកុម្មុយនិស្តបានដាក់កម្លាំងប្រយុទ្ធ ស៊ើរភ្លើងទាំងនេះ ឲ្យនៅប្រចាំការក្បែរៗទីក្រុងនានា ដើម្បីប្រើជាមូលដ្ឋានសម្រាប់ប្រតិបត្តិការ ប៉ុន្តែ រាងឆ្ងាយបន្តិចដែរដើម្បីងាយស្រួលក្នុងការដកថយ ។ នៅទីបំផុត ពួកគេបានកំណត់តំបន់ដ៏ធំល្វឹងល្វើយរបស់ប្រទេសថា ជា "តំបន់ធ្វើសង្រ្គាមឆ្នក់" គឺដែនដីទាំងឡាយ ដែលពួកខ្មាំងត្រូវឈមមុខតតាំងនឹងទាហានរបស់រដ្ឋាភិបាលជាចំហ ។

តំបន់ខ្លះក្នុងចំណោមតំបន់ទាំងនេះ បានត្រូវកាត់ផ្ដាច់ពីទីបញ្ជាការរបស់បក្ស ហើយគណកម្មាធិការមជ្ឈិមបក្សដែលសន្និដ្ឋានថា បានត្រួតត្រាលើសង្គ្រាមនេះមួយកម្រិតតូច គ្មានឹកគិតពីលទ្ធផល នៃការវាយប្រយុទ្ធ ឬ "ការបះបោរ"ខ្លះៗ និងចំនួនទាហានដែលគេទាក់ទាញបានទាំងចំណុចខ្វាំងរបស់ខ្លួន ក្នុងចំណោមប្រជាកសិករសោះឡើយដូច ដែលពួកកុម្មុយនិស្តបានទទួលស្គាល់រឿងនេះ ក្រោយមកថា "គ្មានតំបន់ណាមួយអាចទៅជួយតំបន់មួយទៀតដោយផ្ទាល់បានទេ ព្រោះថាតំបន់ទាំងអស់នោះស្ថិតនៅឆ្ងាយពីគ្នាខ្វាំងណាស់ ។ អគ្គការសម្រាប់ចាត់ចែងដឹកនាំរបស់យើងក៏ត្រូវរំលែកទៅគ្រប់កន្លែង ៈ អគ្គការខ្លះស្ថិតនៅក្នុងភូមិភាគពាយ័ព្យ ក្នុងភូមិភាគនិរតី, ភូមិភាគបូព៌ា, ភូមិភាគឦសាន និងនៅក្រុងភ្នំពេញ ដូច្នេះគឺស្ថិតនៅក្នុងទីកន្លែងផ្សេងៗ ដាច់ស្រយាលពីគ្នាពីកន្លែងមួយទៅកន្លែងមួយទៀត ។ ការទាក់ទងទាំងអស់ត្រូវប្រើរយៈពេលមួយខែ ពីព្រោះគេគោងតែធ្វើដំណើរដោយជើង ដោយជិះលើខ្នងដំរី ហើយជាងនេះទៅទៀត គេគោងតែជៀសវាងពីសត្រូវ ដែលកាត់ផ្ដាច់ផ្លូវឆ្លងកាត់របស់យើងជានិច្ចកាលនោះផង ។ ក្នុងរយៈមួយខែ ស្ថានការណ៍មានការប្រែប្រួលយ៉ាងច្រើន ។ របាយការណ៍ស្ដីពីស្ថានការណ៍ប្រចាំខែ មុននឹងទៅដល់ទីតាំងរបស់គណៈកម្មាធិការមជ្ឈិមបក្ស ដែលស្ថិតនៅរតនគិរីនោះ គឺវាលែងសមស្របនឹងស្ថានការណ៍ថ្មីទៀតហើយ ។ តំបន់នីមួយៗត្រូវតែគិតគូរដោះស្រាយជីវភាពដោយខ្លួនឯង ហើយត្រូវអនុវត្តមាគ៌ានយោបាយរបស់បក្សដោយត្រឹមត្រូវថែមទៀត ។

នៅខែមករា ឆ្នាំ១៩៦៨ ពួកកុម្មុយនិស្តបានដំណើរការនូវអ្វីដែលពួកគេពិពណ៌នាខ្លួនឯងថា ជាការវាយលុកលើកដំបូងរបស់ខ្លួន ។ ការវាយលុកនេះមានកម្រិតតូច ហើយ"ជោគជ័យ"របស់វាក៏មានយ៉ាងស្តួចស្តើងដែរ គឺដណ្តើមយកអាវុធសត្រូវបានពីបួនទៅដប់ដើមនៅខែមករា, បួន ឬប្រាំដើមទៀតនៅខែមីនា ។ នៅទីបញ្ចប់នៃ "ការវាយលុករដូវប្រាំង" ជាលើកដំបូងរបស់ការបដិវត្តខ្មែរក្រហមនេះ ពួកកុម្មុយនិស្តនៅរតនគិរីបានបម្រុងទុកកាំភ្លើងដប់ដើម សម្រាប់ការពារ សាឡុត ស និងគណៈកម្មាធិការមជ្ឈិមបក្ស ។

ពួកប៉ូលិសបានរកឃើញទីកន្លែង ដែលពួកកុម្មុយនិស្តបានតាំងមូលដ្ឋាន ហើយសម្តេច ព្រះនរោត្តម សីហនុ បានសម្រេចព្រះទ័យយាងទៅខេត្តរតនគិរីដោយផ្ទាល់ព្រះអង្គ ដើម្បីលើកទឹកចិត្តដល់ការវាយបកទៅវិញ ជាមួយនឹងអាវុធយុទ្ធភ័ណ្ឌ ដែលទើបមកដល់ពីទីក្រុងប៉េកាំងក្នុងពេលថ្មីៗ ។ ព្រះអង្គបានបង្គាប់ឲ្យកងទ័ពរដ្ឋាភិបាលសំដែងឲ្យឃើញ"ភាពឥតប្រណី" ដើម្បីកម្ទេចការងើបបះបោរនេះ ។ ម្យ៉ាងទៀត សម្តេចបានប្រកាសពីការទទួលខុសត្រូវជាសាធារណៈ ចំពោះការផ្ដល់បទបញ្ជាឲ្យសម្លាប់អ្នកបះបោរទាំងអស់ដោយមិនចាំបាច់គិតគូរច្រើន ។ សម្តេចបានប្រកាសដូច្នេះថា "ខ្ញុំព្រះអង្គនឹងរ៉ាប់រងទទួលទទួលខុសត្រូវក្នុងរឿងនេះ ហើយនឹងឲ្យតុលាការប្រជាជនវិនិច្ឆ័យខ្ញុំព្រះអង្គចុះ"[៤៧] ។

ដោយពិត កងទ័ពរបស់ លន់ នល់ បានលបចូលទៅដល់មាត់ច្រកទីបញ្ជាការខ្មែរក្រហម ហើយវិះតែចាប់បាន សាឡុត ស ទៅហើយ ប៉ុន្តែ កម្មាភិបាលនៅមន្ទីរចាត់ការបក្សបានគេចខ្លួនផុតទាំងអស់[៤៨] ។ ជាត

ដែលនឹកឃើញពីការប្រយុទ្ធគ្នានាពេលនោះ ព្រោះគាត់ធ្លាប់បានសិក្សានៅ "សាលាហ៊ីកហ៊ឺន វិជ្ជាយោធា"ដំបូង ដែលរៀបចំឡើងដោយ ស ហើយគាត់ធ្លាប់បានទៅបង្រៀននៅទីនោះផង ។ "បងទី១ [គឺលេខសម្ងាត់របស់ សាឡុត ស] ទើបនឹងបានខទ្វេសនាមពីកម្មវិធីសិក្សា ស្រាប់តែកងទ័ពរបស់ លន់ នល់ លេចចេញឡើង ហើយបាន ដណ្តើមយកកាំភ្លើងពីពួកនិរសារ ដែលទទួលបន្ទុកការពារមេដឹកនាំម្នាក់ទៀត ។ សាលាត្រូវបិទទ្វារជា បណ្តោះអាសន្ន ហើយកងឈ្លបត្រូវបានបញ្ជូនទៅកាន់ទីលានប្រយុទ្ធ"[៤៩] ។

កាលនោះ បងទី១ បានចាត់តាំងឲ្យ ផាត បំពេញបេសកកម្មមួយថ្មីទៀត គឺ "ធ្វើដំណើរទៅភូមិនានា ដែល ស្ថិតនៅប៉ែកខាងលើ ជម្លៀសមនុស្សចេញពីតំបន់នោះ ហើយនាំចូលទៅក្នុងព្រៃដើម្បីវាយប្រហារសត្រូវ នៅប៉ុស្តិ៍យោធាមួយក្បែរនោះ" ។ ផាត បានបន្ថែមថា "បន្ទាប់មក បងទី១ បានពឹងខ្ញុំឲ្យជូនដំណើរ សុន សេន ទៅវ៉ឹនសៃ ដើម្បីវាយប្រហារសត្រូវ" ហើយខ្ញុំស្ថិតនៅទីនោះរហូតដល់មានការផ្តួលរំលំសម្តេច ព្រះនរោត្តម សីហនុ ។ ការវាយបកទៅវិញរបស់ សាឡុត ស ប្រឆាំងនឹង លន់ នល់ បានសម្រេចជោគជ័យ បងទី១ និងសមាជិក គណៈកម្មាធិការមជ្ឈិមបក្សសេសសល់ទាំងអស់បានចាកចេញទៅកាន់កន្លែងមួយទៀត ដែលមានសន្តិសុខ គ្រប់គ្រាន់ ។

ដោយត្រូវធ្វើឲ្យឡប់ស្មារតី សម្តេច ព្រះនរោត្តម សីហនុ បានប្រកាសថា កងទ័ពរបស់ព្រះអង្គប្រហែល សម្លាប់ពួកអ្នកបះបោរអស់ហើយ ។ "ពួកវា (ពួកកុម្មុយនិស្ត) បានផ្តល់កាំភ្លើងការ៉ាប៊ីនទៅឲ្យពួកខ្មែរលើ ហើយ បង្គាប់បញ្ជាឲ្យបាញ់មកលើកងទ័ពជាតិ...។ ដោយពុំអាចបណ្តោយឲ្យមានរឿងដូច្នេះ ខ្ញុំបានចាត់វិធានការយ៉ាង តឹងរ៉ឹងបំផុត ដោយចេញអាជ្ញាឲ្យធ្វើការកម្ចាត់ឲ្យសូន្យអ្នកស្រុកភ្នំចំនួនមួយរយប៉ែតសិបនាក់ និងការចាប់ខ្លួន មេដឹកមុខ សាមសិបនាក់ទៀត ដែលបន្ទាប់ត្រូវយកទៅបាញ់ចោលទាំងអស់ ។ ខ្ញុំមិនខ្វាចចុះនរកទេ ខ្ញុំនឹងដាក់ជូន បណ្តាឯកសារត្រឹមត្រូវឥតល្អៀងជូនយមរាជដោយផ្ទាល់ថែមទៀត"[៥០] ។

នៅទីបញ្ចប់ សម្តេច ព្រះនរោត្តម សីហនុ បានបង្កើតឋាននរកផ្ទាល់របស់ព្រះអង្គ ដោយផ្អែកគឺដោយសារ តែការចាត់ការ ដាក់ទោស ដែលបណ្តាលឲ្យពួកអ្នកភូមិស្លូតត្រង់ស្លាប់ច្រើនជាងពួកកុម្មុយនិស្តពិតប្រាកដទៅទៀត កាលនោះ នៅមានចំនួនតិចនៅឡើយ ។ ម្យ៉ាងទៀត ភាគច្រើនក្នុងចំណោមពួកនោះបានវាយប្រយុទ្ធទាំង "ដៃទទេ" ដោយគ្មានអាវុធមួយដើមសោះ ហើយបានចំណាយពេលវេលាយ៉ាងច្រើនដើម្បីស្វែងរកស្បៀង អាហារ ក៏ដូចជ្រើសរើសសមាជិកថ្មីៗទៀតដែរ ។ នៅពេលដែលពួកគេវាយប្រហារប៉ុស្តិ៍ជួរមុខតូចៗរបស់ រដ្ឋាភិបាល គោលដៅសំខាន់របស់គេ គឺឆក់ដណ្តើមយកអាវុធប៉ុណ្ណោះ ពុំមែនដណ្តើមយកដែនដីមួយ ដែល គ្រប់គ្រងដោយរដ្ឋាភិបាលឡើយ ។

ប៉ុន្តែ មិនដូច្នោះនៅឆ្នាំ១៩៦៨ សម្តេច ព្រះនរោត្តម សីហនុ បានថ្លែងប្រកាសថា ប្រទេសកម្ពុជាបានត្រូវ ជ្រមុជទៅក្នុង "សង្គ្រាមទូទៅមួយ...។ សង្គ្រាមស៊ីវិលបានលាតសន្ធឹងក្នុងរវាងប៉ុន្មានថ្ងៃនេះទៅដល់ខេត្តផ្សេង

ទៀត ដូចជា កំពង់ស្ពឺ គិរីរម្យ ចំបក់ និងកំពត[៥១] (ច្រើនជាងគេនៅខេត្តបាត់ដំបង) រហូតដល់តំបន់ដែលនៅរាយប៉ាយពាសពេញប្រទេស ។ ព្រះអង្គបានរៀបចំ“បាតុកម្មជាច្រើន ប្រឆាំងនឹងពួកខ្មែរក្រហម និងខ្មែរសេរី ជាបក្សពួកនិយមស្ដាំរបស់ សឺង ង៉ុកថាញ់ ។ ហើយការទាក់ទងគ្នារបស់កងទ័ពព្រះអង្គ ដែលទុកឲ្យពួកកុម្មុយនិស្ដមានកម្លាំងទ័ពមួយខ្លាំងជាងខ្លួនឯងនោះ ត្រូវបានវាយតម្លៃក្រោយមកក្នុងការទាក់ទងដោយខ្សែករបស់ពួកគេ ។

ការប្រកាសពត៌មានជាផ្លូវការរបស់សម្ដេច ព្រះនរោត្ដម សីហនុ បានលើកឡើងជាឧទាហរណ៍នូវការលួចប្លន់អាវុធ ហាសិបដើម ដោយពួកខុទ្ទាមបះបោរក្នុងរយៈតែមួយថ្ងៃប៉ុណ្ណោះក្នុងទូទាំងប្រទេស ។ ដូចគ្នានេះដែរ ក្រុងភ្នំពេញបានវាយតម្លៃថា ពួកអ្នកភូមិចំនួនដប់ពាន់នាក់ បានដើរតាមពួកខ្មែរក្រហមចូលទៅនៅក្នុងព្រៃ ។ រឿងពិតទំនងជាស្ថិតនៅចន្លោះការពោលអាងផ្សេងៗរបស់សម្ដេច ព្រះនរោត្ដម សីហនុ និងការពោលអាងរបស់ពួកកុម្មុយនិស្ដនោះហើយ ។

នៅពេលដែលសម្ដេច ព្រះនរោត្ដម សីហនុ តទល់ជាមួយក្រុមនិយមឆ្វេងមិនព្រមរាថយនោះ ក្រុមនិយមស្ដាំក្នុងរដ្ឋាភិបាល ក៏ត្រៀមខ្លួនធ្វើឲ្យព្រះអង្គវិនាសអន្ដរាយដែរ ។ ក្រុមនិយមស្ដាំបានញុះញង់ឲ្យសម្ដេចចោទប្រកាន់ពួកវៀតណាមថា បានជួយគាំទ្រពួកខ្មែរក្រហម ហើយព្រះអង្គបានចាប់ផ្ដើមចោទសួរជាសាធារណៈថា បណ្ដាមិត្តវៀតណាម និងចិនរបស់ព្រះអង្គ បានគាំទ្រពួកកុម្មុយនិស្ដកម្ពុជាក្នុងពេលថ្មីៗនេះមែនឬ? បើទុកជារឿងនេះ បង្ហាញឲ្យឃើញផ្ទុយស្រឡះនឹងការពិតក៏ដោយ ។ សេចក្ដីភ័យខ្លាចខ្លាំងបំផុតរបស់ក្រុងហាណូយ ហៀបនឹងក្លាយទៅជារឿងពិត ៖ សម្ដេច ព្រះនរោត្ដម សីហនុ បានស្ទាបស្ទង់ស្ថានការណ៍ជាមុន ដើម្បីចង់ដឹងថា តើពួកវៀតណាមខាងជើង អាចក្លាយទៅជាអ្នកដែលចាំតែរងកំហុសចំពោះបញ្ហាផ្សេងៗខាងក្នុងប្រទេសរបស់ព្រះអង្គមែនទេ? ។ ព្រះអង្គ បានស្នើឲ្យគណៈកម្មាធិការត្រួតពិនិត្យអន្ដរជាតិ ស៊ើបអង្កេតពីការពោលអះអាងផ្សេងៗដែលថា ពួកកុម្មុយនិស្ដវៀតណាមបានរំលោភបូរណភាពដែនដីរបស់កម្ពុជា (ជារឿងដែលព្រះអង្គបានដឹងយ៉ាងពិតប្រាកដរួចមកហើយ) ។

ប៉ុន្ដែ សេចក្ដីភ័យខ្លាចរបស់សម្ដេច ព្រះនរោត្ដម សីហនុ បានក្លាយទៅជារឿងពិតដូចគ្នា ។ មិនដល់បីឆ្នាំផងពួកខ្មែរក្រហម បានបង្កើតកងទ័ពមួយមានយុទ្ធជនជាងប្រាំពាន់នាក់ – ជាទ័ពដែលហាត់ហ្វឹកហ្វឺនមិនទាន់បានល្អ និងប្រដាប់ដោយអាវុធមិនទាន់គ្រប់គ្រាន់ គឺជារឿងពិត ។ ទោះជាកងទ័ពនេះ ហាក់ដូចជាមានលក្ខណៈទន់ខ្សោយជាងកងទ័ពរបស់ប្រទេសវៀតណាមក៏ដោយ ក៏កងទ័ពនេះបានបង្កជាការគំរាមកំហែងមួយចំពោះកងទ័ពរដ្ឋាភិបាលដែលមានចំនួនមិនលើសពី សាមសិបប្រាំពាន់នាក់ហើយ ដែលពឹងផ្អែកលើជំនួយរបស់ប្រទេស កុម្មុយនិស្ដខាងក្រៅទាំងស្រុងសម្រាប់បំពាក់អាវុធឲ្យកងទ័ពរបស់ខ្លួន ។ នេះគឺជាស្ថានភាពមួយដែលធ្វើឲ្យ លន់ នល់ ព្រួយបារម្ភដូចគ្នា ។

អំណឹះតទៅ លន់ នល់ បានកាន់តំណែងជារដ្ឋមន្ត្រីទីមួយផង និងជារដ្ឋមន្ត្រីការពារប្រទេសផង ។ រដ្ឋាភិបាល

របស់គាត់បានស្មុគស្មាញចិត្តសហរដ្ឋអាមេរិកជាសម្ងាត់ ក្នុងគោលបំណងកែលម្អទំនាក់ទំនងផ្សេងៗ រវាងប្រទេសទាំងពីរឲ្យបានប្រសើរឡើងវិញ ។ សម្ដេច ព្រះនរោត្តម សីហនុ បានយល់ព្រមស្នើសុំចូលជាសមាជិកស្ថាប័នផណាទានបី ដែលស្ថិតនៅក្រោមអំណាចរបស់ពួកអាមេរិកាំង គឺធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី និងមូលនិធិរូបិយវត្ថុអន្តរជាតិ ដើម្បីធ្វើឲ្យពួកនិយមស្តាំដែលជាគូប្រជែងនឹងព្រះអង្គបានស្ងប់ចិត្ត និងនាំយកប្រទេសកម្ពុជាចេញពីភាពចុះដុនដាបផ្នែកសេដ្ឋកិច្ចផង ។ ប៉ុន្តែ ព្រះអង្គលែងដឹកនាំប្រទេសដែលគេសន្មតថា ព្រះអង្គជាអ្នកគ្រប់គ្រងទៀតហើយ នៅឆ្នាំបន្ទាប់ គឺឆ្នាំ១៩៦៩ នយោបាយបរទេសរបស់ព្រះអង្គបានលិចលង់ទៅក្នុងភាពប្របូកប្របល់ និងត្រឡប់ត្រឡិនខ្លាំងមែនទែន ។ នៅខែមីនា សហរដ្ឋអាមេរិកបានធ្វើយុទ្ធការទម្លាក់គ្រាប់បែកជាសម្ងាត់ លើកងទ័ពកុម្មុយនិស្តវៀតណាម ដែលបោះទីតាំងនៅប្រទេសកម្ពុជា ។ សម្ដេច ព្រះនរោត្តម សីហនុ បានត្អូញត្អែរពីរឿងនេះជាសាធារណៈ ហើយបានថ្លែងនូវការប្ដេជ្ញាចិត្តបាញ់ទម្លាក់យន្តហោះអាមេរិកាំងឲ្យបានច្រើនតាមដែលអាចធ្វើបាន ។ ប៉ុន្តែ ប៉ុន្មានខែក្រោយមក ព្រះអង្គបានភ្ជាប់ទំនាក់ទំនង ដែលបានផ្អាកជាយូរមកហើយជាមួយនឹងសហរដ្ឋអាមេរិកឡើងវិញ ក្រោយពេលដែលអាមេរិកបានទទួលស្គាល់ព្រំដែនបច្ចុប្បន្នរបស់ប្រទេសកម្ពុជា ។

ក្នុងពេលជាមួយគ្នានោះ ព្រះអង្គក៏ទទួលស្គាល់រដ្ឋាភិបាលបដិវត្តបណ្ដោះអាសន្នរបស់ពួកកុម្មុយនិស្តវៀតណាមខាងត្បូងជាផ្លូវការដែរសម្រាប់មូលហេតុផ្សេងៗដូចគ្នាបេះបិទ ព្រោះរដ្ឋាភិបាលបដិវត្តបណ្ដោះអាសន្នបានសន្យាដោយលាយលក្ខណ៍អក្សរថា កងទ័ពវៀតណាមទាំងអស់នឹងចាកចេញពីប្រទេសកម្ពុជា កាលបើសន្តិភាពត្រូវបានរៀបចំឲ្យមានឡើងនៅប្រទេសវៀតណាម ដែលនេះជាការទទួលសារភាពជាសាធារណៈ ដែលធ្វើឱ្យរន្ធត់ឡើងអំពីវត្តមាននៃកងទ័ពកុម្មុយនិស្តវៀតណាមនៅប្រទេសកម្ពុជា ។ ដូច្នេះ សម្ដេច ព្រះនរោត្តម សីហនុ បានទទួលស្គាល់រដ្ឋាភិបាលមួយ ដែលមានកងទ័ពជាច្រើនកាន់កាប់មួយផ្នែកធំនៃទឹកដីរបស់ព្រះអង្គ និងរដ្ឋាភិបាលមួយទៀត ដែលកំពុងទម្លាក់គ្រាប់បែកលើទឹកដីដដែលនេះ ។ នេះលែងជានយោបាយបរទេសមួយ «ដែលមានសមតា» ទៀតហើយ ។ នេះជាភាពអស់សង្ឃឹម ហើយគ្មានអ្នកណាម្នាក់យល់ដឹងពីរឿងនេះប្រសើរជាង លន់ នល់ ទេ ដែលនៅខែសីហា ឆ្នាំ១៩៦៩ គាត់បានរៀបចំបង្កើតគណៈរដ្ឋមន្ត្រីថ្មីមួយដោយដាក់ឲ្យស្ថិតនៅក្រោមការត្រួតត្រារបស់គាត់ទាំងស្រុង ។ គាត់បានលុបក្រឹត្យច្បាប់ចុងក្រោយនៃកម្មវិធីជាតូបនីយកម្មរបស់ខៀវ សំផន ចោលទាំងអស់ ហើយបានបង្កើនសង្គ្រាមប្រឆាំងនឹងពួកកុម្មុយនិស្តកម្ពុជាកាន់តែខ្លាំងក្លាឡើង ដោយទម្លាក់ទោសព្រមគ្នាទៅលើ «ទីជម្រក» ទាំងឡាយរបស់ពួកវៀតណាមថែមទៀត ។

ក្រុងប៉េកាំង និងក្រុងហាណូយ ព្រួយបារម្ភពីបញ្ហានេះដូចគ្នា ។ នៅឆ្នាំ១៩៦៩ សាឡុត ស និងសម្ដេច ព្រះនរោត្តម សីហនុ បានធ្វើដំណើរទៅវៀតណាមខាងជើងព្រមគ្នា គឺសម្ដេចទៅចូលរួមពិធីបុណ្យបញ្ចុះសពប្រធាន ហូ ជីមិញ ។ ពួកវៀតណាមខាងជើងបានប្រឹងប្រែងស្មុគស្មាញពីបំណងផ្សេងៗរបស់សម្ដេច ព្រះនរោត្តម

សីហនុ ព្រមទាំងបំណងរបស់ពួកខ្មែរក្រហមផង ក្នុងគោលបំណងរៀបចំខ្លួនជាមុនសម្រាប់ការប្រែប្រួលនយោបាយមួយ ។

ទន្ទឹមនឹងនោះ លន់ នល់ បានចងសម្ព័ន្ធភាពដាច់ដោយឡែកជាច្រើន ហើយនៅខែកញ្ញា ឆ្នាំ១៩៦៩ គាត់បានចាប់ផ្ដើមធ្វើកិច្ចចរចាជាមួយ សឺង ង៉ុកថាញ់ ដែលជាអ្នកប្រយុទ្ធទាមទារឯករាជ្យមុនគេបំផុត ។ ក្នុងរយៈពេលម្ភៃប្រាំឆ្នាំកន្លងទៅ តាំងពីពេលដែលគាត់បញ្ចេញសមត្ថភាពឲ្យគេស្គាល់ក្នុងកម្រិតជាតិ ថាញ់ បានឆ្លងកាត់ពីជីហរនិយមកណ្ដាលមករកជីហរនិយមស្ដាំវិញ ប៉ុន្តែ គាត់មិនដែលប្ដូរទស្សនៈចំពោះសម្ដេច ព្រះនរោត្តម សីហនុ ដែលគាត់មិនចូលចិត្តម្ដងណាឡើយ ។ ក្នុងកំឡុងសង្គ្រាមឥណ្ឌូចិនលើកទី១ ថាញ់ ធ្លាប់បានប្រយុទ្ធតទល់នឹងសម្ដេចក្នុងជួរពួកអ្នកមិនមែននិយមលទ្ធិកុម្មុយនិស្តរួចម្ដងមកហើយ ។ បន្ទាប់ពីប្រទេសបានឯករាជ្យ គាត់នៅតែធ្វើការទាក់ទងជាមួយយុទ្ធិកជនរបស់គាត់នៅក្នុងរាជធានីដដែល ប៉ុន្តែគាត់បានតាំងទីលំនៅក្នុងស្រុកកំណើតរបស់គាត់នៅវៀតណាមខាងត្បូង ជាទីដែលគាត់បានជ្រើសរើសពួកខ្មែរក្រោមឲ្យចូលធ្វើទាហានយ៉ាងច្រើន ដើម្បីវាយប្រយុទ្ធប្រឆាំងនឹងពួកកុម្មុយនិស្តវៀតណាមផង និងសម្ដេច ព្រះនរោត្តម សីហនុ ផង ។ ដោយមានពួក សេ.អ៊ី.អា. អាមេរិកាំង ជួយជ្រោមជ្រែងក្នុងការខិតខំប្រឹងប្រែងទាំងនេះ គាត់បានក្លាយទៅជាគូប្រជែងស្ដាំនិយមដ៏រឹងមាំជាងគេរបស់សម្ដេច ។ ដោយគិតទុកជាមុនស្រេច ថាញ់ បានយល់ព្រមសហការជាមួយ លន់ នល់ ហើយបន្ទាប់ពីការសម្រេចកិច្ចព្រមព្រៀងមួយ ក្រុមនិយមស្ដាំបានរង់ចាំឲ្យសម្ដេចចាកចេញពីប្រទេសនៅនិទាឃរដូវខាងមុខ ដើម្បីរៀបចំធ្វើរដ្ឋប្រហារមួយ ។

រដ្ឋប្រហារនេះ បានទទួលគុណប្រយោជន៍ពីការយល់ព្រម និងការគាំទ្រដោយផ្ទាល់របស់ពួកអាមេរិកាំង ។ ទំនាក់ទំនងផ្សេងៗរបស់ សឺង ង៉ុកថាញ់ ជាមួយនឹងពួកសេ.អ៊ី.អា. មិត្តភាពរបៀបដឹងគុណរបស់ព្រះអង្គ សិរិមតៈ ជាមួយពួកអ្នកទទួលខុសត្រូវអាមេរិកាំង និងគោលដៅផ្សេងៗដែលត្រូវវាយប្រហារនៅថ្ងៃដំបូងនៃការធ្វើបាតុកម្ម គឺស្ថានទូតកុម្មុយនិស្តវៀតណាមខាងជើង និងរដ្ឋាភិបាលបដិវត្តបណ្ដោះអាសន្នវៀតណាមខាងត្បូង បាននាំឲ្យប្រជាជនកម្ពុជា ក៏ដូចជាពួកបរទេសជឿថា ក្រុងវ៉ាស៊ីនតោន ជាអ្នកស្ថិតនៅពីក្រោយខ្នងពួកអ្នកឃុបឃិតធ្វើរដ្ឋប្រហារទាំងនោះ ។

រដ្ឋប្រហារបានបញ្ចប់នូវល្បែង ដែលពួកកុម្មុយនិស្តចិន និងវៀតណាមបានលេងតាំងតែពីម្ភៃប្រាំមួយឆ្នាំមុន ហើយនៅពេលនេះ ប្រទេសទាំងពីរបានសម្រេចចិត្តបង្រួបបង្រួម សម្ដេច ព្រះនរោត្តម សីហនុ ជាមួយពួកខ្មែរក្រហមវិញ ។ សាឡុត ស និងសម្ដេច បានស្ថិតនៅក្រុងប៉េកាំងជាមួយគ្នា បន្ទាប់ពីកើតព្រឹត្តិការណ៍នេះបន្តិច ហើយទោះបីជាអ្នក ទាំងពីរមិនដែលជួបមុខគ្នាសោះក៏ដោយ ក៏ពួកគេបានយល់ព្រមសហការដែរ ៖ សម្ដេច ព្រះនរោត្តម សីហនុ នឹងក្លាយទៅជាមេដឹកនាំមានតែឈ្មោះរបស់ខ្មែរក្រហម សាឡុត ស ទើបជាមេដឹកនាំពិតប្រាកដរបស់ចលនានេះ ។ ពួកកុម្មុយនិស្តកម្ពុជាលែងមានហេតុផលវាយប្រហារស្ដេចមួយអង្គ ដែលជាប់ចិត្ត

នឹងបុព្វហេតុសង្គមនិយមតទៅទៀតហើយ ។ កាលពីពេលមុន ការគាំទ្ររបស់វៀតណាម មានកំណត់ត្រឹមតែអនុញ្ញាតឲ្យពួកកុម្មុយនិស្តខ្មែរប្រើប្រាស់«ទីជម្រកទាំងឡាយ»របស់ខ្លួន ដែលមាននៅប្រទេសកម្ពុជា ដើម្បីគេចឲ្យផុតពីកងទ័ពរបស់ លន់ នល់ ប៉ុណ្ណោះ ។ នៅពេលនេះ ពួកគេអាចទុកចិត្តទៅលើការជួយទ្រទ្រង់ពីសំណាក់ពួកវៀតណាមទាំងស្រុង ដែលកងទ័ពកុម្មុយនិស្តវៀតណាមគេបានប្រុងប្រៀបចូលប្រឡូកក្នុងការប្រយុទ្ធប្រឆាំងនឹង លន់ នល់ ជាស្រេចហើយដែរ ។

ក៏ប៉ុន្តែ វាពុំមានការផ្លាស់ប្តូរណាមួយក្នុងទស្សនៈបដិវត្តរបស់ពួកខ្មែរក្រហម ដែលនៅតែបន្តសំអាងលើ «ភាពស្អាតបរិសុទ្ធ» «ស្វ័យភាព» ការមិនទុកចិត្តចំពោះពួកបរទេស ជាពិសេស ពួកកុម្មុយនិស្តចិន និងវៀតណាមដដែល ។ បណ្តាមេដឹកនាំបក្សនៅតែជឿជាក់ក្នុងចិត្តថា គេត្រូវតែជ្រើសរើសរវាងអ្វីៗទាំងអស់ ដើម្បីជួយសង្គ្រោះប្រទេសរបស់ខ្លួនឲ្យរួចផុតពីគ្រោះថ្នាក់ «ដែលកិត្តិយស និងភាពថ្លៃថ្នូរធ្លាប់ត្រូវគេបន្អាប់បង្អោនមាក់ងាយ ហើយដែលធ្លាប់កេងប្រវ័ញ្ច សង្កត់សង្កិន មើលងាយមើលថោកអស់រយៈពេលជាច្រើនសតវត្សរ៍មកហើយ»[៥២] ។

ជាឯកជន ពួកគេនៅតែចាត់ទុកសម្តេច ព្រះនរោត្តម សីហនុ, សហរដ្ឋអាមេរិក និងពួកវៀតណាមថាជាអ្នកទទួលខុសត្រូវធំបំផុតចំពោះស្ថានភាពគោកយ៉ាករបស់គេ និងស្ថានភាពប្រទេសកម្ពុជាថែមទៀត ។ ប៉ុន្តែមិនដូច្នោះ ពួកគេបែរជាសម្រេចចិត្តធ្វើសម្ព័ន្ធភាពជាមួយសត្រូវពីរ ក្នុងចំណោមសត្រូវទាំងបីរបស់គេទៅវិញ ។ មានតែពួកចិនប៉ុណ្ណោះ ដែលអាចសម្រុះសម្រួលឲ្យមានឯកភាពមួយដែលគួរឲ្យគោរព ដោយទាមទារឲ្យមានការចាត់វិធានការដ៏ឈ្លាសវៃ និងសម្ងាត់ជាច្រើន ។ សម្រាប់មូលហេតុផ្នែកមនោគមវិជ្ជា និងប្រវត្តិសាស្ត្រដ៏សែនស្មុគស្មាញពិបាកយល់ ដែលពួកខ្មែរក្រហមបានជ្រើសរើសយកពួកកុម្មុយនិស្តចិន ដែលមានបដិវត្តខ្លាំងជាង និងនៅឆ្ងាយដាច់ស្រយាលជាងគេ មកធ្វើជាអ្នកគាំពាររបស់ខ្លួន ។ សម្ព័ន្ធភាពដ៏ស្អាត«បរិសុទ្ធ»នេះ បានស្ថិតស្ថេររហូតមកដល់ទីបញ្ចប់នៃសង្គ្រាម បន្ទាប់បានបែកបាក់ទៅវិញ នៅពេលដែលពួកកុម្មុយនិស្តកម្ពុជាបានភ្ជាប់ខ្លួនគេទៅនឹងគោលការណ៍ទាំងឡាយ ស្តីពីស្វ័យភាពហិង្សាបដិវត្ត រដ្ឋាភិបាលលួចលាក់ និងគំនិតប្រហោងក្លួងនៃភាពបរិសុទ្ធរបស់គេ ។

បន្ទាប់ពីរដ្ឋប្រហាររបស់ លន់ នល់ ។ ផាត ត្រូវបានគេដំឡើងឋានៈជាស្នងការនយោបាយកងអនុសេនាធំមួយរបស់ខ្មែរក្រហម ដែលកំពុងវាយប្រយុទ្ធក្នុងខេត្តរតនាគិរី ។ គាត់បានបញ្ចេញសមត្ថភាពឲ្យឃើញសក្តិសមនឹងភារកិច្ចរបស់គាត់មែន ហើយក៏បានក្លាយទៅលេខាបក្សតំបន់មួយទាំងមូល ។ ប៉ុន្តែ ផាត អ្នកចំណូលថ្មីដ៏ស្មោះត្រង់បានមើលឃើញថា ក្រោយពេលចប់សង្គ្រាម ខ្លួនគាត់ផ្ទាល់ក៏ដូចអ្នកដែលធ្លាប់តែធ្វើតាមការណែនាំគ្រប់បែបយ៉ាងរបស់បក្សដែរ ត្រូវតែបង្ហាញឲ្យឃើញភាពបរិសុទ្ធរបស់ខ្លួនជាថ្មីម្តងទៀត ។

# ជំពូកទី៤
# សត្វក្រពើ ស

ក្នុងបណ្តាថ្ងៃដំបូងៗនៃខែមីនា ឆ្នាំ១៩៧០ ពាក្យចចាមអារ៉ាមលេចពសុសសាយក្នុងក្រុងភ្នំពេញថា គេបានឃើញក្រពើសមួយផុសនៅក្បែររាជធានី ។ រឿងនេះបានលាន់ឮគ្រប់ទិសទីយ៉ាងឆាប់រហ័សបំផុត ព្រោះថា ក្រពើស ជានិមិត្តរូបមួយក្នុងចំណោមនិមិត្តរូបដ៏មានមហិទ្ធិឫទ្ធិ និងជាទីពេញនិយមបំផុតនៃជាតិខាងមុខរបស់ខ្មែរ ។ សត្វនេះបានមានមុខនៅពេលប្រទេសកម្ពុជាចាប់កំណើត ហើយបន្ទាប់មក បានទទួលរងបន្ទុកត្រួតពិនិត្យមើលចរន្តទឹកទន្លេមេគង្គទៀត ។ ក្នុងរឿងព្រេងនិទានសត្វក្រពើ ស ជាអ្នកកំណត់អព្ភូតហេតុប្រចាំឆ្នាំដែលធ្វើឲ្យទឹកទន្លេហូរច្រាសទិសក៏មាន ។ សត្វនេះបង្ហាញខ្លួនតែនៅពេលណាដែលប្រជាជនកម្ពុជាបានមកដល់ផ្លូវ ត្រឡែងកែងមួយ  ពេលជួបប្រទះនឹងស្ថានការណ៍សំខាន់ៗប៉ុណ្ណោះ ។

ជាច្រើនថ្ងៃតមកទៀត ចំនួនមនុស្សដែលឮគេនិយាយពីសត្វក្រពើផុសបានកើនចំនួនកាន់តែច្រើន ៖ អ្នកដែលបំផុសពាក្យចចាមអារ៉ាមទាំងនេះ បានរៀបចំធ្វើឲ្យមានការផ្លាស់ប្តូរមួយរួចជាស្រេច ។ ហើយក្នុងចំហាយក្តៅនាពេលរសៀលថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០[1] ប្រធានរដ្ឋសភាជាតិកម្ពុជា បានថ្លែងតាមវិទ្យុរដ្ឋាភិបាលនូវសេចក្តីជូនដំណឹងខ្លីមួយដែលមានខ្លឹមសារថា សភាទាំងពីរបានសម្រេច «ដកសេចក្តីទុកចិត្តរបស់គេពីសម្តេច ព្រះនរោត្តម  សីហនុ  ជាឯកច្ឆ័ន្ទក្នុងឋានៈព្រះអង្គជាព្រះប្រមុខរដ្ឋ» ។

តាមរបៀបវិនិច្ឆ័យពីទម្រង់គ្រប់គ្រងរដ្ឋ នេះជារដ្ឋប្រហារមួយដែលទម្លាក់តែមេដឹកនាំប្រទេសម្នាក់ប៉ុណ្ណោះ មានតែសម្តេច ព្រះនរោត្តម សីហនុ មួយអង្គដែលត្រូវផ្តួលរំលំរដ្ឋាភិបាលទាំងមូលនៅកាន់អំណាចដដែល ។ តាមការពិត នេះជាភាពចាប់ផ្តើមនូវការផុតរលត់មួយចំណែកធំនៃអ្វីដែលប្រទេសកម្ពុជាធ្លាប់ជួបប្រទះមិនត្រឹមតែចាប់តាំងពីបានឯករាជ្យប៉ុណ្ណោះទេ ប៉ុន្តែ គឺមានតាំងពីច្រើនសតវត្សរ៍មកហើយ ។ របបរាជាធិបតេយ្យមួយ ក្នុងចំណោមរបបរាជាធិបតេយ្យនានានៃពិភពលោក ដែលមានតាំងតែពីយូរយារមកហើយ បានត្រូវលុបបំបាត់ចោល ។ ដើម្បីជំនួសរបបនេះ ពួកអ្នកដឹកនាំថ្មី បានសន្យាកសាងរបបសាធារណរដ្ឋមួយ ប៉ុន្តែ ជំនួសការប្រកាន់ពាក្យសម្តីរបស់គេ ពួកនេះបែរជាសម្រុកតម្រង់ទៅរកសង្គ្រាមដោយគ្មានងាកក្រោយទៅវិញ ។

ចាប់តាំងពីច្រើនឆ្នាំមកហើយ ឥទ្ធិពលនិងប្រជាប្រិយភាពរបស់សម្តេច ព្រះនរោត្តម សីហនុ បានថយចុះខ្សោយទៅៗ ។ សម្តេចគ្មានសមត្ថភាពញែកបញ្ហាផ្ទៃក្នុងរបស់ប្រទេសកម្ពុជា ចេញពីការប្រយុទ្ធដែលកំពុងកញ្ជ្រោលបោកបាចនៅតាមព្រំដែនឡើយ ។ ព្រះអង្គក៏ពុំដឹងស្វែងរកជំហរកណ្តាលមួយ ដើម្បីរារាំងក្រុមនិយមស្តាំ ឬក្រុយមនិយមឆ្វេង មិនឲ្យត្រួសត្រាយផ្លូវថ្មីមួយទៅរកសង្គ្រាមដែរ ។ ផ្ទុយទៅវិញ នយោបាយរបស់

ព្រះអង្គ ប្រហែលជាបានរុញច្រានឲ្យសត្រូវទាំងឡាយរបស់ព្រះអង្គប្រកាន់យកជំហរផ្សេងៗ ខ្លាំងហួសប្រមាណ ផងក៏មិនដឹង ។

នៅឆ្នាំ១៩៦៩ សម្ដេច ព្រះនរោត្តម សីហនុ បានគ្រប់គ្រងដឹកនាំប្រទេសកម្ពុជាដោយប្រយោល គឺមិនផ្ទាល់ព្រះអង្គទេ ។ នៅឆ្នាំ១៩៦៣ ព្រះអង្គជាព្រះប្រមុខរដ្ឋមានអំណាចសឹងតែដូចស្ដេចដែរ ជាមុខតំណែង ដែលព្រះអង្គបង្កើតឡើងសម្រាប់ព្រះអង្គឯង ពេលដែលព្រះបិតារបស់ព្រះអង្គចូលទិវង្គត ។ រីឯរដ្ឋាភិបាល គឺដឹកនាំដោយ លន់ នល់ ជានាយករដ្ឋមន្ត្រី និងអភិបាលមដោយព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ និងពួកនិយមស្ដាំ ឬនិយមកណ្ដាលដទៃទៀត ដែលប្រឆាំងនឹងសម្ដេច ព្រះនរោត្តម សីហនុ ។

រដ្ឋសភាជាតិក៏ប្រឆាំងនឹងសម្ដេចដូចខាងកងទ័ពដែរ ។ មានតែក្រសួងប៉ូលិសដែលដឹកនាំដោយ អ៊ុំ ម៉ាណូរិន ដែលជាញាតិសន្តាននឹងសម្ដេច ព្រះនរោត្តម សីហនុ ប៉ុណ្ណោះដែលនៅស្មោះត្រង់នឹងព្រះប្រមុខរដ្ឋ ។ សម្ដេច ព្រះនរោត្តម សីហនុ ត្រូវប្រឈមមុខនឹងការក្រែងរអែងទៅថ្ងៃមុខ ដែលអាចក្លាយខ្លួនទៅជាប្រភេទបុគ្គលម្នាក់ ដែលមានតែឈ្មោះ ប៉ុន្តែគ្មានអ្វីទាំងអស់ ។ គ្រប់ផ្នែកទាំងអស់នៃរដ្ឋាភិបាល បានធ្វើប្រាស់នឹងកម្មវិធីទាំងឡាយ របស់ព្រះអង្គទាំងអស់ ។ គ្រប់ៗគ្នាបានបង្ហាញឲ្យឃើញការខឹងមួម៉ៅក្នុងចិត្តចំពោះព្រះអង្គផ្ទាល់ ។

នៅនិទាឃរដូវឆ្នាំ១៩៧០ សម្ដេច ព្រះនរោត្តម សីហនុ បានយាងទៅធ្វើវិស្សមកាលនៅប្រទេសបារាំង ដែលនៅទីនោះ ព្រះអង្គមានបំណងសម្រាកលំហែកាយ មុននឹងយាងទៅកាន់សហភាពសូវៀត និងប្រទេសចិន ។ ជាមួយនឹងការយល់ព្រមរបស់សម្ដេច ប្រទេសកម្ពុជាបានធ្វើឲ្យមានការទាក់ទងគ្នានឹងសហរដ្ឋអាមេរិកឡើងវិញ ហើយ សម្ដេច ព្រះនរោត្តម សីហនុ បានធានាអះអាងចំពោះបណ្ដាប្រទេសជាមហាអំណាចកុម្មុយនិស្ដថា ប្រទេសរបស់ព្រះអង្គគ្មានគោលបំណងផ្លាស់ប្ដូរនយោបាយ“អព្យាក្រឹតនិយម”របស់ព្រះអង្គ ចំពោះសង្គ្រាម នៅប្រទេសវៀតណាមទេ ។

នេះគឺជាវិស្សមកាលដំបូងក្នុងចំណោមវិស្សមកាលជាច្រើន ដែលព្រះអង្គបានប្រកាន់យកតាំងពីបីឆ្នាំមក ហើយ ហើយព្រះអង្គបានប្រគល់រដ្ឋាភិបាលទៅឲ្យពួកមនុស្សដែលព្រះអង្គធ្លាប់គាំទ្រកាលពីឆ្នាំ១៩៦៩ នៅពេល ឲ្យបង្កើតរដ្ឋាភិបាលសង្គ្រោះជាតិមួយដែលមាន លន់ នល់ និងសិរិមតៈ ជាអ្នកដឹកនាំ ។ នៅថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧០ គឺបន្ទាប់ពីការចេញដំណើររបស់ព្រះប្រមុខរដ្ឋបន្តិច កងទ័ពរបស់កម្ពុជាបានរៀបចំបាតុកម្មប្រឆាំង វៀតកុង នៅក្នុងខេត្តស្វាយរៀងដែលមានព្រំប្រទល់ជាប់ប្រទេសវៀតណាម ។ បីថ្ងៃក្រោយមក ចលនាបាតុកម្ម នេះ បានឆ្លងរាលដាលមកដល់រាជធានី ហើយលើកនេះ គោលដៅរបស់គេ គឺវាយប្រហារស្ថានទូតក្រុងហាណូយ និងស្ថានទូតរបស់រដ្ឋាភិបាលបដិវត្តបណ្ដោះអាសន្នវៀតណាមខាងត្បូង ។

ដោយឧបាយកលមួយដែលបានរៀបចំបម្រុងយ៉ាងល្អនោះ រដ្ឋសភាជាតិបានឆ្លៀតទាញយកគុណ ប្រយោជន៍ពីបាតុកម្មទាំងនេះ សម្រាប់រិះគន់យោបាយរបស់សម្ដេច ព្រះនរោត្តម សីហនុ ដែលអនុគ្រោះចំពោះ

ពួកកុម្មុយនិស្តវៀតណាម ហើយបានអនុម័តក្រឹត្យមួយដោយសម្រេចឲ្យបន្ថែមចំនួនកងទ័ព ដប់ពាន់នាក់ ថែមទៀត ។ សារទូរលេខមួយដែលប្រាប់ពីដំណឹងនេះ ត្រូវបានគេបញ្ជូនទៅឲ្យសម្ដេចនៅថ្ងៃទី១២ ខែមីនា ។ នៅថ្ងៃដដែលនោះ រដ្ឋាភិបាលកម្ពុជាបានសម្ដែងនូវការសុំទោស ចំពោះស្ថានទូតទាំងពីររបស់វៀតណាម រួមមានទាំងឱសានវាទមួយ ដែលតម្រូវឲ្យកងទ័ពវៀតណាមទាំងអស់ចាកចេញពីប្រទេសកម្ពុជាឲ្យបានមុន ថ្ងៃទី១៥ ខែមីនា គឺ២ថ្ងៃក្រោយមកទៀត ។

រដ្ឋាភិបាលទើបនឹងធ្វើឲ្យផ្ទាំនយោបាយចុងក្រោយរបស់សម្ដេចព្រះប្រមុខរដ្ឋ បើុងបែកទៅជាបំណែកតូចៗ ។ ក្នុងទូរលេខមួយដែលផ្ញើមកឲ្យព្រះមាតារបស់ព្រះអង្គ គឺព្រះមហាក្សត្រិយានី កុសុមៈ នរោត្តម បានទូលឲ្យដឹងថា ព្រះអង្គនឹងយាងមកកាន់ប្រទេសវិញក្នុងរវាងប៉ុន្មានថ្ងៃទៀតនេះ គឺថ្ងៃទី១៨ ខែមីនា ហើយនឹងដាក់ឲ្យប្រជាជនធ្វើការជ្រើសរើសរវាងនយោបាយអព្យាក្រឹតរបស់ព្រះអង្គ និងនយោបាយរំលោភបំពានរបស់ លន់ នល់ និងសិរិមតៈ ។ មហាក្សត្រិយានី បានទទួលទូរលេខនៅថ្ងៃសុក្រ ទី១៣ ខែមីនា ប៉ុន្តែរវាងតែបីថ្ងៃប៉ុណ្ណោះ បុត្ររបស់ព្រះអង្គ បានផ្លាស់ប្ដូរព្រះទ័យទៅវិញ ពីព្រោះវាជាទម្លាប់របស់ព្រះអង្គទៅហើយ ហើយបានវាយទូរលេខតបមកវិញថា ព្រះអង្គនឹងពន្យារការវិលត្រឡប់របស់ព្រះអង្គទៅថ្ងៃទី២៨ ខែមីនា វិញ ដើម្បីអាចយាងទៅកាន់មូស្គូ និងក្រុងប៉េកាំងទៀត ។

នៅពេលនោះ ព្រះមហាក្សត្រិយានី បានកោះហៅ លន់ នល់ និងសិរិមតៈ ដែលជព្រះភាគិនេយ្យ (ក្មួយ) របស់ព្រះអង្គឲ្យ ចូលមកគាល់ដើម្បីសុំឲ្យអ្នកទាំងពីរបញ្ឈប់បាតុកម្មទាំងអស់ និងសុំឲ្យធ្វើតាមនយោបាយរបស់សម្ដេច ព្រះនរោត្តម សីហនុ ឡើងវិញ ។ ព្រះអង្គក៏បានសរសេរសំបុត្រមួយទៅឲ្យលោក ចេង ហេង ប្រធានរដ្ឋសភាជាតិ ដើម្បីគំរាមរំលាយរដ្ឋសភាគាត់ចោល បើសិនជាគាត់មិនបញ្ឈប់ប្រកាសផ្សព្វផ្សាយសេចក្ដីថ្លែងការណ៍ប្រឆាំងវៀតណាមទេនោះ ។ ព្រះមាតារបស់សម្ដេច ដែលពុំមានអំណាចផ្លូវការណាមួយបានធ្វើសកម្មភាព ហាក់ដូចជាតំណាងកូនប្រុសរបស់ព្រះអង្គដែរ ។ រដ្ឋាភិបាល និងសភា បានស្នើបញ្ជូនគណៈប្រតិភូមួយ ទៅក្រុងប៉ារីស ក្នុងគោលបំណងពិភាក្សាជាមួយសម្ដេច ព្រះនរោត្តម សីហនុ និងរិះរកការសម្របសម្រួលមួយ ។ សំណើនេះបានត្រូវបដិសេធ ៖ ព្រះមហាក្សត្រិយានី និង លន់ នល់ បានបញ្ជូនគណៈប្រតិភូមួយតែរៀងខ្លួន ដោយមាននាំយកឯកសារផ្សេងៗ ដែលបង្ហាញឲ្យឃើញដឹងពីចេតនាផ្សេងៗរបស់ពួកវៀតណាមខាងជើងទៅជាមួយផង ប៉ុន្តែ សម្ដេច ព្រះនរោត្តម សីហនុ គ្មានបំណងទទួលជួបគណៈប្រតិភូនេះឡើយ ។

នៅយប់ថ្ងៃដដែលនោះ ដោយមានឬគ្មានសេចក្ដីយល់ព្រមរបស់សម្ដេច ពួកប៉ូលិសបានប៉ុនប៉ងធ្វើរដ្ឋប្រហារមួយប្រឆាំងនឹង លន់ នល់ ។ អ៊ុំ ម៉ាណូរិន ដែលជារដ្ឋមន្ត្រីក្រសួងសន្តិសុខជាតិ បានត្រូវបង្ខំឲ្យលាលែងពីតំណែងនៅថ្ងៃបន្ទាប់ ប៉ុន្តែប្រហែលជាត្រូវចោទពីបទប្រព្រឹត្តអំពើពុករលួយទៅវិញ គឺពុំមែនពីបទប៉ុនប៉ងធ្វើរដ្ឋប្រហារ ដែលមិនបានសម្រេចនោះទេ ។

មូលហេតុនៃការចោទប្រកាន់នេះ និងការមិនព្រមនិយាយពីរឿងរដ្ឋប្រហារមិនបានសម្រេចតាមវិទ្យុជាតិ បានលេចឡើងយ៉ាងច្បាស់នៅថ្ងៃបន្ទាប់ គឺថ្ងៃទី១៨ ខែមីនា ក្រុមនិយមស្ដាំបានរៀបចំរដ្ឋប្រហារមួយប្រឆាំងនឹងសម្ដេច ព្រះនរោត្តម សីហនុ ដែលការដឹកនាំរបស់ព្រះអង្គកាលពីសប្ដាហ៍មុន បានផ្ដល់ជាអត្ថប្រយោជន៍ឲ្យគូប្រជែងទាំងឡាយរបស់ព្រះអង្គដោយគ្មានដឹងខ្លួន ។ លន់ នល់ និងពួកយុទ្ធិកជន របស់គាត់បានបញ្ជាក់អះអាងថា ដើមដំបូង នាយករដ្ឋមន្ត្រីចង់ឲ្យមានការផ្លាស់ប្ដូរនយោបាយមួយចំពោះពួកកុម្មុយនិស្តវៀតណាមតែប៉ុណ្ណោះ គឺពុំមែនផ្ដួលរំលំ សម្ដេច ព្រះនរោត្តម សីហនុ ទេ ប៉ុន្តែថា រដ្ឋប្រហារដែលមិនបានសម្រេច និងអាកប្បកិរិយារំលោភបំពានរបស់សម្ដេច បានញុាំងឲ្យ លន់ នល់ ចងភ្ជាប់ជោគជតារបស់គាត់ទៅនឹងគូប្រជែងរបស់សម្ដេច ព្រះនរោត្តម សីហនុ ម្នាក់ទៀត ដែលព្រះអង្គប្រកាសឲ្យដឹងឮរួចមកហើយគឺ សិរិមតៈ ។

ដោយពិត រដ្ឋប្រហារនេះទំនងជាស្នាដៃរបស់ សិរិមតៈ និងពួកអាមេរិកាំងដែលជាអ្នកគាំពារគាត់ ។ នៅក្រុងភ្នំពេញ គេសន្និដ្ឋានថា សិរិមតៈ បានទទួលជំនួយមួយខាងផ្នែកនយោបាយ និងហិរញ្ញវត្ថុពីក្រុម សេ.អ៊ី. អា ។ រដ្ឋប្រហារបានប្រព្រឹត្តទៅក្នុងរបៀបរៀបរយ និងគ្មានការបង្ហូរឈាមឡើយ ។ កងទ័ពបានត្រូវគេដាក់ឲ្យស្ថិតនៅក្នុងសភាពប្រុងជើងការ រថក្រោះជាច្រើនបានត្រូវគេដាក់ឡោមព័ទ្ធជុំវិញគ្រឹះស្ថាននានារបស់រដ្ឋាភិបាល ប៉ុន្តែពួកយោធាបានជៀសវាងមិនធ្វើការបង្ហាញកម្លាំងទាំងអស់ ដែលគ្មានប្រយោជន៍ឡើយ ហើយ លន់ នល់ បានសង្កត់បញ្ជាក់ជាសាធារណៈនូវការរក្សាព្រះពុទ្ធសាសនាក្នុងការរៀបចំសង្គមថ្មីនេះទៀត ។ គ្មានការវាតត្បាតបំផ្លាញព្រះបរមរាជវាំងនិងការប្រយុទ្ធគ្នាតាមផ្លូវឡើយ ។ ការទាក់ទងគ្នាជាមួយប្រទេសក្រៅ បានត្រូវកាត់ផ្ដាច់ក្នុងរយៈពេលម្ភៃបួនម៉ោង ហើយអាកាសយានដ្ឋានអន្តរជាតិពោធិចិនតុងនៅតែបិទមិនឲ្យយន្តហោះចុះចតអស់រយៈពីរ-បីថ្ងៃ ។ បណ្ដាមន្ត្រីជាន់ខ្ពស់មួយក្ដាប់តូច ត្រូវគេដាក់ឲ្យស្ថិតនៅតែក្នុងផ្ទះ ដោយមានការឃ្លាំមើលថែមទៀត រួមទាំងសមាជិករាជវង្សានុវង្សជាច្រើនអង្គផង ជាពិសេស ព្រះមហាក្សត្រិយានី កុសុមៈ ដែលនៅសោយសោកតែមួយអង្គឯងក្នុងព្រះរាជដំណាក់របស់ព្រះអង្គ ចំពោះការរំលំដួលរបបរាជាធិបតេយ្យនេះ ។

តាមវិថីនានាក្នុងក្រុងភ្នំពេញ គេលែងនិយាយពីសត្រូវក្រពើសទៀតហើយ ។

សាធារណរដ្ឋថ្មី ត្រូវបានដឹកនាំដោយមនុស្សបីនាក់គឺ លន់ នល់, សិរិមតៈ និង ចេង ហេង ប្រធានរដ្ឋសភាជាតិ ។ តុលាការកំពូលរបស់កម្ពុជាបានកាត់ទោស សម្ដេច ព្រះនរោត្តម សីហនុ (ដែលគ្មានបង្ហាញខ្លួននៅមុខតុលាការ) ហើយបានប្រកាសឲ្យដឹងថា នរោត្តម ព្រះអង្គមានទោសពីបទក្បត់ជាតិដោយរួមគំនិតជាមួយបរទេស ជាពិសេសចំពោះការដែលព្រះអង្គយល់ បានយល់ព្រម«ដោយខុសច្បាប់» ឲ្យកងទ័ពកុម្មុយនិស្តវៀតណាមមានសិទ្ធិកាន់កាប់ទឹកដីរបស់កម្ពុជាសិទ្ធិប្រើប្រាស់កំពង់ផែក្រុងព្រះសម្ដេច ព្រះនរោត្តម សីហនុ និងតាំងមូលដ្ឋានទ័ពយ៉ាងច្រើននៅក្នុងប្រទេសខ្មែរ ។ តុលាការកំពូលយល់ឃើញថា សម្ដេចបានរំលោភបំពានលើនយោបាយអព្យាក្រឹតរបស់ព្រះអង្គផ្ទាល់ ដែលគំរាមកំហែងដល់បូរណភាពដែនដី និងឯករាជ្យភាពរបស់ប្រទេស

កម្ពុជាទៀត ។ គ្មានជនណាម្នាក់លើកយកមកនិយាយពីតួនាទីដ៏សកម្មរបស់ លន់ នល់ ដែលបានចុះកិច្ចព្រមព្រៀងផ្សេងៗជាមួយពួកវៀតណាមសោះឡើយ ហើយសម្តេច ព្រះនរោត្តម សីហនុ បានត្រូវតុលាការកាត់ទោសប្រហារជីវិតបង់ ។

តាំងពីដើមទី សាធារណរដ្ឋថ្មីបានដាក់ភាពត្រឹមត្រូវពេញច្បាប់របស់ខ្លួន លើការសន្យារំដោះប្រទេសពីការគំរាមកំហែងរបស់ពួកកុម្មុយនិស្តវៀតណាម ។ ក្នុងឋានៈគាត់ជាអគ្គបញ្ជាការកងទ័ព លន់ នល់ បានក្លាយទៅជាឥស្សរជនដែលមានបន្ទុកធ្វើតាមការសន្យានេះ ។ ក្នុងក្របខ័ណ្ឌនៃការរៀបចំរដ្ឋប្រហារ លន់ នល់ ក្នុងឋានៈគាត់ជានាយករដ្ឋមន្ត្រី បានតម្រូវឲ្យពួកកុម្មុយនិស្តវៀតណាមខាងជើង និងខាងត្បូង ដកកងទ័ពចេញពីទឹកដីខ្មែរឲ្យអស់ក្នុងរវាង សែសិបប្រាំបីម៉ោង ។ នេះគឺជាការតម្រូវមួយដែលគ្មានន័យទាល់តែសោះ ព្រោះថា ខ្លួនគាត់ផ្ទាល់ធ្លាប់បានជួយជ្រោមជ្រែងពួកកុម្មុយនិស្តវៀតណាម ក្នុងការជួយផ្គត់ផ្គង់ស្បៀងអាហារ គ្រាប់រំសេវទៅឲ្យមូលដ្ឋាននានារបស់ពួកនោះ ដែលតាំងនៅក្នុងទឹកដីខ្មែរដែរ ។

ក្រោយរដ្ឋប្រហារ ពួកអ្នកការទូតវៀតណាមដែលប្រចាំការនៅក្រុងភ្នំពេញបានប្រកាសឲ្យដឹងថា ពួកគេនៅតែចាត់ទុក សម្តេច ព្រះនរោត្តម សីហនុ ជាមេដឹកនាំត្រឹមត្រូវតាមច្បាប់របស់រដ្ឋមួយដែលធ្លាប់ផ្តល់សិទ្ធិឲ្យគេតាំង «ទីជម្រក» ក្នុងតំបន់ព្រំដែនរបស់កម្ពុជាដដែល ។ ឧប្បត្តិហេតុជាច្រើនបានផ្ទុះឡើងភ្លាមៗរវាងកងទ័ពរបស់កម្ពុជា និងកងទ័ពកុម្មុយនិស្តវៀតណាមក្នុងតំបន់ទាំងនោះ ។ ប្រាំបួនថ្ងៃបន្ទាប់ពីរដ្ឋប្រហារ ពួកវៀតណាមបានបិទស្ថានទូត និងវិលត្រឡប់ទៅកាន់មាតុប្រទេសរបស់គេវិញ ។

ចំណែកខាងពួកចិន បានបញ្ចេញការប្រឹងប្រែងជាលើកចុងក្រោយមួយ ដើម្បីរិះរកធ្វើសហប្រតិបត្តិការជាមួយ លន់ នល់ ដោយលៃលកឲ្យមានសម្ព័ន្ធភាពមួយរវាង សម្តេច ព្រះនរោត្តម សីហនុ និងខ្មែរក្រហមផង ។ ក្រុងប៉េកាំង បានបញ្ជូនបេសកជនជាច្រើនមកកាន់ក្រុងភ្នំពេញ ដោយស្នើធ្វើការទទួលស្គាល់រដ្ឋាភិបាលថ្មីមានដាក់លក្ខខណ្ឌបី ៖ សិទ្ធិសម្រាប់ពួកចិន ដើម្បីបន្តផ្គត់ផ្គង់ពួកកុម្មុយនិស្តវៀតណាមដោយឆ្លងកាត់តាមដីខ្មែរ ការអនុញ្ញាតឲ្យពួកកុម្មុយនិស្តវៀតណាមរក្សាទុកមូលដ្ឋាននានារបស់គេក្នុងទឹកដីកម្ពុជាតទៅទៀត និងការជួយគាំទ្រពួកកុម្មុយនិស្តវៀតណាម តាមរយៈសេចក្តីថ្លែងការណ៍ផ្សេងៗរបស់រដ្ឋាភិបាលកម្ពុជា ។

ម្យ៉ាងទៀត នៅកាលបរិច្ឆេទដែលឃឹតក្រមកដល់នេះ ពួកចិនបានចាត់ចែង«ពន្យារ» ការបដិវត្តរបស់កម្ពុជាថែមទៀត ដើម្បីជួយការបដិវត្តរបស់វៀតណាម និងរក្សាទុករណសិរ្សចិន-វៀតណាមមួយ សម្រាប់តតាំងនឹងសហរដ្ឋអាមេរិក ។ ពួកចិនប្រុងប្រៀបក្បត់នឹងពួកកុម្មុយនិស្តកម្ពុជាជាស្រេច ដើម្បីធ្វើឲ្យពួកអាមេរិកាំងបរាជ័យជាស្ថាពរ នៅប្រទេសវៀតណាម ។ ប៉ុន្តែ ការទាមទារទាំងប៉ុន្មានរបស់ចិន បានត្រូវក្រុងភ្នំពេញបដិសេធចោលទាំងអស់ ។

ការវាយប្រយុទ្ធគ្នាជាច្រើនបានផ្ទុះឡើងភ្លាមមួយរំពេចក្នុង «ទីជម្រក» ទាំងឡាយរបស់វៀតណាម ។

កងទ័ពរបស់ លន់ នល់ បានផ្ដើមវាយប្រហារក្នុងការសាកល្បងជានិមិត្តរូបមួយ ដើម្បីដេញកម្ចាត់ពួកវៀតណាម ក្នុងសេចក្ដីសង្ឃឹមឥតបានការថា ពួកនោះនឹងដកថយទៅវិញ ដោយមិនប្រយុទ្ធតបតឡើយ ។ ប៉ុន្តែ គេកំពុងស្ថិតនៅក្នុងឆ្នាំ១៩៧០ ហើយផ្លូវលំ ហូ ជីមិញ កាន់តែមានប្រយោជន៍ខ្លាំងឡើងៗ សម្រាប់ពួកវៀតណាម ដែលមានកងឯកភាពជាច្រើនប្រុងនឹងវាយបកមកវិញជាស្រេច ។ ប្រហែលជាដោយការជួយទាក់ទងរបស់សហរដ្ឋអាមេរិកនោះហើយ លន់ នល់ បានហៅពួកវៀតណាមខាងត្បូងឲ្យមកជួយ ហើយនៅចុងខែមីនា កងទ័ព រ៉េងហ្សេ (Rangers) របស់វៀតណាមខាងត្បូងបីកងវរសេនាតូច បានមកចូលរួមជាមួយកងទ័ពរបស់កម្ពុជា ដើម្បីធ្វើការវាយលុក «ទីជម្រក» មួយរបស់ពួកវៀតកុងចម្ងាយបីគីឡូម៉ែត្រ ខាងក្នុងទឹកដីខ្មែរ ។ នៅខែមេសា ពួកកុម្មុយនិស្តវៀតណាមបានចាប់ដំណើរការវាយប្រហារ ដាច់ដោយឡែកគ្នាជាច្រើនប្រឆាំងនឹងកងទ័ពរបស់ លន់ នល់ ដែលនៅឆ្ងាយៗពីព្រំដែនគឺក្នុងភាគខាងត្បូង និងភាគឦសានប្រទេស នៅក្បែរទីក្រុងភ្នំពេញថែមទៀត ។

ក្រុងហាណូយបានប្រកាសថា កម្ពុជាលែងជាប្រទេសអព្យាក្រឹតទៀតហើយ ដោយសំអាងជាភ័ស្តុតាងអំពីកិច្ចព្រមព្រៀងដែលបានសម្រេចធ្វើឡើងរវាង លន់ នល់ និងប្រទេសវៀតណាមខាងត្បូង ។ ប្រទេសកម្ពុជា បានចូលប្រឡូកក្នុងសង្គ្រាមនេះយ៉ាងសកម្ម ហើយពួកវៀតណាមខាងជើងយល់ឃើញថា ខ្លួនមានសិទ្ធិពេញលេញក្នុងការវាយប្រហារតបទៅវិញ ។ ពួកគេបានចាប់ផ្ដើមធ្វើការវាយសម្រុកទៅលើកងទ័ពរបស់ លន់ នល់ ដែលស្ថិតនៅរាយប៉ាយដាច់ៗពីគ្នា ហើយកងទ័ពវៀតណាមចំនួន មួយរយហាសិបនាក់ បានវាយកាន់កាប់ទីប្រជុំជនស្អាងស្រុកកោះធំ ខេត្តកណ្ដាល ក្នុងរយៈពេលបីថ្ងៃ ។ នៅចុងខែមេសា ពួកចិនបានកោះប្រជុំ «សន្និសីទកំពូលមួយរបស់ប្រជាជនឥណ្ឌូចិន « នៅទីក្រុងកង់តុង ដើម្បីបង្រួបបង្រួម សម្ដេច ព្រះនរោត្ដម សីហនុ ពួកអ្នកតំណាងខ្មែរក្រហម ពួកកុម្មុយនិស្តវៀតណាម និងឡាវ ឲ្យមូលត្រកូលគ្នា ។ អ្នកចូលរួមសន្និសីទទាំងអស់បានប្រកាសថា ចាប់ពីពេលនេះទៅ ពួកវៀតណាម គឺជា«សម្ព័ន្ធមិត្ត»របស់មេដឹកនាំស្របច្បាប់របស់ប្រទេសកម្ពុជា គឺសម្ដេច ព្រះនរោត្ដម សីហនុ ។

នៅពេលដែលពួកចិនបង្កើតឲ្យមានសម្ព័ន្ធភាពផ្សេងៗ និងរៀបចំធ្វើសន្និសីទកំពូលរបស់ប្រជាជនឥណ្ឌូចិន សហភាពសូវៀត ត្រូវគេផាត់ចោលឲ្យនៅដាច់ដោយឡែកតែឯង ។ ក្នុងពេលដែលពួកចិនទាមទារតួនាទីជាអ្នកសម្រុះសម្រួលសំខាន់បំផុត ដើម្បីជាគុណប្រយោជន៍ដល់ការបដិវត្តនៅឥណ្ឌូចិននោះ ពួកសូវៀតបែរជាប្រកាន់យកយុទ្ធសាស្ត្រមួយខុសប្លែកពីគ្នាទាំងស្រុង ។ អ៊ីចឹងហើយ បានជាពួកគេមិនព្រមផ្ដាច់ការទាក់ទងជាមួយ លន់ នល់ ហើយនៅរក្សាទុកស្ថានទូតរបស់ខ្លួននៅភ្នំពេញ ពេញរយៈនៃសង្គ្រាមទៀត ។ ពួកខ្មែរក្រហមបានបកស្រាយពីឥរិយាបថនេះថា ជាការយល់ព្រមរបស់សូវៀតអំពីយុទ្ធសាស្ត្រមួយរបស់វៀតណាម នៅឥណ្ឌូចិនដែលមិនចុះសម្រុងនឹងពួកគេ ។

នៅខែមីនា ឆ្នាំ១៩៧០ លន់ នល់ បានស្នើឲ្យអង្គការសហប្រជាជាតិកំណត់ថា ពួកកុម្មុយនិស្តវៀតណាមជា

អ្នកឈ្លានពានប្រទេសកម្ពុជា ប៉ុន្តែ អគ្គការសហប្រជាជាតិបានឆ្លើយតបមកវិញថា ការប្តឹងផ្តល់ពីរឿងនេះ គឺត្រូវបញ្ជូនទៅឲ្យគណៈកម្មាធិការដែលបង្កើតដោយសន្និសីទក្រុងហ្សឺណែវឆ្នាំ១៩៥៤ ទើបត្រឹមត្រូវជាង ។ មធ្យោបាយដោះកុនតាមផ្លូវច្បាប់នេះ បានបង្ហាញឲ្យឃើញនូវភាពទាល់ច្រកមួយ ។ កាលពីឆ្នាំមុន គឺឆ្នាំ១៩៦៩ សម្តេច ព្រះនរោត្តម សីហនុ បានបញ្ចប់អាណត្តិគណៈកម្មាធិការនេះ លែងឲ្យមាននៅកម្ពុជាតទៅទៀត គឺពីរខែបន្ទាប់ពីបានចុះកិច្ចព្រមព្រៀងអនុញ្ញាតឲ្យពួកវៀតកុងតាំងមូលដ្ឋានជាច្រើននៅក្នុងទឹកដីខ្មែរ[៧] ។

បន្ទាប់ពីបានទទូចសុំអគ្គការអន្តរជាតិនានាអស់រយៈពេលពីរសប្តាហ៍រួចមក លន់ នល់ បានធ្វើការអំពាវនាវជាសាធារណៈឲ្យប្រទេសទាំងអស់ជួយកម្ចាត់ «លទ្ធិកុម្មុយនិស្តវៀតណាម» ផង ។ នៅថ្ងៃទី៣០ ខែមេសា រដ្ឋាភិបាលអាមេរិកាំង និងវៀតណាមខាងត្បូងបានឆ្លើយតបនឹងការអំពាវនាវនេះ ដោយចាប់ផ្តើមធ្វើការវាយលុកក្នុងទ្រង់ទ្រាយយ៉ាងធំមួយ ប្រឆាំងនឹង«ទីជម្រក»នានា របស់ពួកកុម្មុយនិស្តវៀតណាម នៅភាគខាងកើតប្រទេសកម្ពុជា ដោយគ្មានប្រាប់ឲ្យ លន់ នល់ បានឹងពត៌មានជាមុនឡើយ ។ មិនដល់ពីរខែផង ពួកមេដឹកនាំក្រុងភ្នំពេញ បានជ្រមុជខ្លួនរបៀបគ្មានពិសោធន៍ និងរបៀបផ្សងព្រេងទៅក្នុងសង្គ្រាមឥណ្ឌូចិនលើកទី២នឹងគេដែរ ។ គឺដោយរបៀបគ្មានដឹងខ្យល់នេះហើយ ដែលពួកគេត្រូវជាប់ដៃក្នុងសង្គ្រាម ហើយត្រូវចាញ់សង្គ្រាមតទល់នឹងពួកខ្មែរក្រហមនោះ ។

នៅដំណាក់កាលនេះ លន់ នល់ បានយកប្រៀបលើពួកមេគំនិតធ្វើរដ្ឋប្រហារមុនគេ ហើយបានដណ្តើមយកប្រភពអំណាចផ្សេងៗក្នុងរដ្ឋធានីមកកាន់ក្នុងដៃទាំងអស់ ។ សិរិមតៈ ដែលពេលដំបូងផ្តោតសេក្តីសង្ឃឹមលើពួកអាមេរិកាំង ហើយដែលបានទទួលកាគាំទ្រពីពួកគហបតីនៅក្រុងភ្នំពេញបង្ហាញឲ្យឃើញថាគ្មានសមត្ថភាពនឹងបញ្ឈប់ លន់ នល់ មិនឲ្យធ្វើដូច្នោះបានឡើយ ។ ជាមនុស្សក្រអឺតក្រអោង រូបរាងសង្ហា និងល្អិតល្អន់ជាងសម្តេចស៊ីហនុ ជាបងប្អូនជីដូនមួយរបស់គាត់ដែលមានរូបរាងធាត់ក្រអាញ និងទាបទ្រនាប់ សិរិមតៈ បានបញ្ចុះបញ្ចូលពួកអាមេរិកាំងថា គាត់អាចធ្វើទំនើបកម្មប្រទេសកម្ពុជាបានជាមួយនឹងជំនួយរបស់អាមេរិក និងធ្វើឲ្យប្រទេសងាកទៅរកសហរដ្ឋអាមេរិកវិញ ។ បើវិនិច្ឆ័យពីទង្វើទាំងឡាយរបស់គាត់ដែលមានក្រោយៗមកទៀត គេអាចសន្និដ្ឋានថា ជាថ្នូរនឹងសហប្រតិបត្តិការរបស់ប្រទេសកម្ពុជា សិរិមតៈ សង្ឃឹមថាសហរដ្ឋអាមេរិកនឹងការពារប្រទេសគាត់ពីការគំរាមកំហែងរបស់ពួកវៀតណាម គឺពុំមែនប្រទាញប្រទេសគាត់ឲ្យធ្លាក់ទៅក្នុងសង្គ្រាមមួយដែលមានទំហំយ៉ាងធំឡើយ ។ តាមក្បួនច្បាប់នយោបាយ សិរិមតៈ បានសម្តែងឲ្យគេឃើញថា គាត់ជាមនុស្សដែលនិយមនិយាយតែការពិត ជានយោបាយដែលគ្មានការពិសោធន៍ ពុំត្រឹមតែក្នុងទំនាក់ទំនងផ្សេងៗរបស់គាត់ជាមួយសហរដ្ឋអាមេរិកប៉ុណ្ណោះទេ ប៉ុន្តែ ចំណុចសំខាន់ ពីព្រោះ គាត់បានវាយតម្លៃគុណសម្បត្តិ លន់ នល់ ទាបជាងគុណសម្បត្តិពិតប្រាកដខ្លាំងពេក ។

ខុសប្លែកអំពី សិរិមតៈ លន់ នល់ ហាក់ដូចជាគិតបារម្ភតែពីការឈមមុខតតាំងដោយមោះមុតនឹងពួក

វៀតណាមខាងជើងប៉ុណ្ណោះ ដែលគាត់បានចោទប្រកាន់ពីអំពើថោកទាបគ្រប់បែបយ៉ាងរបស់ប្រទេសវៀតណាម ដែលបានធ្វើឲ្យប្រទេសកម្ពុជាទទួលរងគ្រោះក្នុងកំឡុងជាច្រើនសតវត្សរ៍មកហើយ ។ គាត់ជាមនុស្សបុរាណម្នាក់ក្នុងចំណោមសមាជិកដឹកនាំប្រទេសទាំងបី រូបនិងជាប្រភពដើមនៃពាក្យចចាមអារ៉ាមផ្សេងៗ ពីរឿងសត្វក្រពើ ស ដែលលាន់ឮមុនពេលមានរដ្ឋប្រហារ និងមនុស្សមានបន្ទប់អាថ៌កំបាំងមួយ ក្នុងពិភពអ្នកនយោបាយនៅក្រុងភ្នំពេញ ។ ជាមនុស្សមានចរិតមួយជាអ្នកកសិករពីកំណើត និងមានទេពកោសល្យបន្តិចបន្តួច គាត់បានឡើងបុណ្យសក្តិដោយសារតែគាត់ជាមនុស្សសំណព្វ បម្រើសម្តេច ព្រះនរោត្តម សីហនុ យ៉ាងស្មោះត្រង់ប៉ុណ្ណោះ ។ សម្តេចបានវាយតម្លៃ លន់ នល់ ចំពោះចរិតមិនចេះអត់ឱន និងការរវៀសរវៃរបស់គាត់ក្នុងការបំពេញកិច្ចការថោកទាបមួយ ក្នុងឋានៈគាត់ជាមេក្រសួងប៉ូលិស និងធ្វើអ្វីៗដោយគ្មានចេះថ្លូវត្អូញត្អែរ និងចេះលាក់ការសម្ងាត់មួយ ដែលមិន ទៀងទាត់ ។ ម្យ៉ាងទៀត សម្តេច ព្រះនរោត្តម សីហនុ បានចាត់ទុក លន់ នល់ ជាមនុស្សម្នាក់ ដែលមានប្រាជ្ញារអន់បំផុត មិនអាចក្លាយខ្លួនទៅជាអ្នកគំរាមកំហែងមួយចំពោះព្រះអង្គឡើយ ជាទស្សនៈដែលពួកអ្នកសមគំនិតគ្នាក្នុងការរៀបចំធ្វើរដ្ឋប្រហារយល់ឃើញដូច្នេះដែរ ។ ក្រុមអ្នកហែហមគាត់ប្រហែលជាឲ្យគាត់ខុសដូចគ្នា ។

ក្នុងវិស័យនេះ និងវិស័យផ្សេងៗទៀតជាច្រើន លន់ នល់ មានលក្ខណៈដូចគ្នាយ៉ាងច្រើនជាមួយនឹងមនុស្សដែលនឹងបន្តឲ្យមានការវិនាសរបស់គាត់នៅពេលក្រោយមកទៀតគឺ សាឡុត ស ។ ក្នុងយុវភាពរបស់គាត់ គាត់បានសម្តែងឲ្យឃើញថាជាអ្នកធ្វើការងាររច្រើន និងប្រកបដោយមហិច្ឆតាថែមទៀត ។ កើតនៅឆ្នាំ១៩១៣ លន់ នល់ មានមោទនភាពអំពីដើមកំណើតជាខ្មែររបស់គេយ៉ាងជ្រុលហួសហេតុ ហើយបើ សាឡុត ស ជ្រើសរើសឈ្មោះ «ខ្មែរដើម» ជាឈ្មោះនិពន្ធរបស់គាត់ លន់ នល់ បានលើកទឹកចិត្តឲ្យពួកទាហានរបស់គាត់ហៅគាត់ថា «ប៉ាប៉ាខ្មៅ»[៣] ដែរ ដោយសារតែពណ៌ស្បែកសម្បុរខ្មៅគរបស់គាត់ ដែលជាលក្ខណៈសម្គាល់ពូជសាសន៍ខ្មែរ យ៉ាងពិតប្រាកដ ។

លន់ នល់ បានឡើងឋានៈតាមលំដាប់លំដោយបុណ្យសក្តិក្នុងឋានានុក្រមកងទ័ព ប៉ុន្តែ បានដឹកនាំជីវភាពនយោបាយមួយយ៉ាងប្រសើរដែរ ។ គាត់បានបង្កើតគណបក្សនយោបាយមួយ ដើម្បីចូលរួមក្នុងការបោះឆ្នោតជាតិ ជាលើកដំបូងនៅឆ្នាំ១៩៤៦ ហើយដាក់ឈ្មោះថា គណបក្សខេមរបុនក្ការ (La Rénovation Khmer) ដើម្បីសម្តែងឲ្យឃើញសេចក្តីសង្ឃឹមថា ប្រពៃណីទាំងឡាយរបស់ប្រទេសជាតិអាចត្រូវគេយកមកអនុវត្តជាជាងកែទម្រង់លក្ខណៈដើមរបស់វា ។ គាត់ត្រូវសម្តេច ព្រះនរោត្តម សីហនុ ចាត់តាំងឲ្យទៅវាយប្រហារពួកខ្មាំងឥស្សរៈ និងពួក វៀតមិញនៅភាពពាយ័ព្យប្រទេស ក្នុងរយៈពេលនៃសង្គ្រាមឥណ្ឌូចិនលើកទី១ ។ នៅក្នុងការបោះឆ្នោតឆ្នាំ១៩៥៥ លន់ នល់ បានរំលាយបញ្ចូលគណបក្សនយោបាយដ៏តូចរបស់គាត់ជាមួយនឹងគណបក្សសង្គមរបស់សម្តេច ព្រះនរោត្តម សីហនុ ។

ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៥០ និង១៩៦០ មានប្រជាជនកម្ពុជាតិចតួចប៉ុណ្ណោះ ដែលមានមហិច្ឆិតា គិត

ចង់ប្រកបអាជីពយោធាមួយ ។ លន់ នល់ ត្រូវបានតែងតាំងជានាយអគ្គសេនាធិការកងទ័ពកម្ពុជា នៅឆ្នាំ១៩៥៥ ហើយគាត់បានប្រើប្រាស់មុខតំណែងនេះ ធ្វើជាឈ្នាន់មួយ ឆ្ពោះទៅរកអំណាចទៀត ។ កាលណោះ កងទ័ពមួយភាគធំត្រូវបានជ្រើសរើសពីក្នុងចំណោមប្រជាកសិករ ពុំមែនពីក្នុងចំណោមវណ្ណៈអ្នកចេះដឹងឡើយ ។ លន់ នល់ អាចការពារឥរិយាបថជាកសិករជាមួយនឹងមនុស្សរបស់គាត់ទាំងនេះ និងរារាំងមិនឲ្យអ្នកនយោបាយផ្សេងៗ ទៀតដណ្ដើមយកកន្លែងរបស់គាត់បាន ។ ម្យ៉ាងទៀត គេរកបានប្រាក់តិចតួចណាស់នៅក្នុងកងទ័ព ជាពិសេសក្រោយពេលដែលសម្ដេច ព្រះនរោត្តម សីហនុ បានដាក់កំណត់មួយពីរឿងជំនួយរបស់អាមេរិកាំង ហើយ លន់ នល់ ដោយមានការគាំទ្រពីសម្ដេចផង បានកាន់កាប់បញ្ជីបុគ្គលិកកងទ័ពទាំងមូលក្នុងការតម្លើងឋានន្តរ សក្តិ ។ ពិតហើយ មុនរដ្ឋប្រហារកងទ័ពជាកម្មសិទ្ធិរបស់ លន នល់ ពុំមែនរបស់សម្ដេច ព្រះនរោត្តម សីហនុ ទេ ។

សម្ដេចព្រះប្រមុខរដ្ឋ បានជួយធ្វើឲ្យអាជីពរបស់ លន់ នល់ រីកចម្រើនលើសគេលើសឯង ជាថ្នូរនឹងសេចក្ដីស្មោះត្រង់ខាងនយោបាយ ក៏ដូចសមត្ថភាពខាងខាងយោធារបស់គាត់ដែរ ដែលនេះជារឿងនឹងទៅជារឿងជាក់ស្ដែងបន្ទាប់ពីរដ្ឋប្រហារ ។ ពួកទាហានដើងចាស់ដែលមានវិជ្ជាជីវៈត្រឹមត្រូវបានត្អូញត្អែរជាញឹកញាប់ពីការខ្វះសមត្ថភាពរបស់មេកោយខ្លួន ប៉ុន្តែ សម្ដេច ព្រះនរោត្តម សីហនុ ពុំយកព្រះកាណ៌ស្ដាប់តាមពាក្យអ្នកទាំងនោះឡើយ ។ ប៉ុន្តែ បើសម្ដេចសព្វព្រះទ័យឲ្យតម្លៃសមត្ថភាពផ្សេងៗខាងផ្នែកនយោបាយរបស់ លន់ នល់ ក៏ដោយ ក៏ព្រះអង្គប្រមាណខុសដោយផ្នែកនូវសមត្ថភាពផ្សេងៗរបស់គាត់ដែរ ពីព្រោះមហិច្ឆតារបស់ឧត្ដមសេនីយ៍នេះមានប្រភពដើម ដែលគេមិនសូវស្គាល់ ឬមិនអាចយល់បាន ។

លន់ នល់ ពុំលាក់កំបាំងគំនិតរបស់គាត់ដែលចង់ធ្វើឲ្យពូជសាសន៍ វប្បធម៌ និងព្រះពុទ្ធសាសនាខ្មែរស្អាតបរិសុទ្ធ ប្រាសចាកពីការបំពុលរបស់បរទេស ដែលតាមគាត់ថាបានបំផ្លាញថាមពលរបស់ប្រទេសជាតិ ស៊ីរូងអត្តសញ្ញាណ និងទឹកដីរបស់ខ្លួនឡើយ[៤] ។ ក្នុងមជ្ឈដ្ឋានវរជនដែលចេះដឹង គេបានចាត់ទុកគំនិតរបស់ លន់ នល់ ជាគំនិតចម្លែកមួយគួរឲ្យឆ្ងល់ ប្រហែលជាគំនិតដែលនាំរំខានដល់គេឯងទៀតផង ប៉ុន្តែ ពិតណាស់ពុំមែនជារឿងលេងសើចទេ ។ គឺជាមនុស្សអភិរក្សនិយមជ្រុលម្នាក់ដែលគោរពជឿសាសនាហួសហេតុពេក ដោយផ្ដេកផ្ដួលទៅក្នុងមន្តអាគមគាថា និងជាអ្នកកាន់ព្រះពុទ្ធសាសនា មានពាក់សេន ខ្សែចង្កេះជាប់នឹងខ្លួន ដែលចាស់ទុំនៅភូមិរបស់គាត់បំពាក់ឲ្យក្នុងពេលដែលគាត់ជាយុវជននៅឡើយ ។ គាត់បានយកពួកហោរា និងពួកសន្ដរបុគ្គលមកដាក់ជុំវិញខ្លួនគាត់ ប៉ុន្តែ គាត់ប្រាកដក្នុងចិត្តថា មន្តអាគម ត្រូវតែរៀបចំនៅទីស្ងាត់កំបាំង ដើម្បីការពារឫទ្ធិអំណាចរបស់វា គាត់មិនដែលសម្ដែងឲ្យគេឃើញពីការប្រតិបត្តិរបស់គាត់ឡើយ ។ សម្ដេច ព្រះនរោត្តម សីហនុ អាចធ្មេចព្រះនេត្រធ្វើជាមិនដឹងមិនឮ រហូតដល់ទីបញ្ចប់អំពីគំនិតប្រឆាំងនឹងការជឿនលឿនរបស់នាយអគ្គសេនាធិការព្រះអង្គ ។

បីខែមុនមានរដ្ឋប្រហារ លន់ នល់ បានបង្កើតវិទ្យាស្ថានខ្មែរមន ដើម្បីផ្សព្វផ្សាយទស្សនៈទាំងឡាយរបស់

គាត់ ។ សម្តេចដែលអើពើនឹងរឿងនេះ បានសម្រេចអនុញ្ញាតឲ្យគាត់រៀបចំមជ្ឈមណ្ឌលគួរឲ្យសង្ស័យនេះក្នុងផ្ទះធំ និងចំណាស់មួយ និងជារបស់ជនជាតិបារាំងនៅក្នុងរាជធានី ។ នៅទីនោះ លន់ នល់ សង្ឃឹមថា នឹងជួយធ្វើឲ្យបណ្តាសញ្ញាណប្លែកខុសគេរបស់គាត់ខាងផ្នែកចិរយាធម៌ និងមរតកជាប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា មានរូបរាងជាថ្មីឡើងវិញ ។ ប៉ុន្តែ ការយកចិត្តទុកដាក់របស់គាត់ មានលក្ខណៈទូលំទូលាយជាងអ្វីដែលសម្តេច ព្រះនរោត្តម សីហនុ ឬអ្នកនយោបាយសម័យទំនើបដទៃទៀតធ្លាប់បានគិតទៅទៀត ។ គាត់ធ្លាប់ដឹកនាំកងទ័ពជាច្រើនទសវត្សរ៍មកហើយ ហើយគាត់អាចដឹងពីឥទ្ធិពលនៃគំនិតផ្សេងៗរបស់គាត់ដែលមានទៅលើមនុស្សសាមញ្ញជាច្រើន ដែលជាសមាសភាពនៃកងទ័ពរបស់កម្ពុជាច្បាស់លាស់ណាស់ ។

ក្នុងវិស័យនេះក៏ដូចវិស័យដទៃទៀត លន់ នល់ បានប្រើប្រាស់រូបភាពមោទនភាពជាតិដូច សាឡុត ស ជាគូប្រជែងផ្នែកមនោគមវិជ្ជារបស់គាត់ដែរ ។ ប៉ុន្តែ នៅពេលដែល សាឡុត ស ងាកទៅរកអ្វីដែលគាត់វិនិច្ឆ័យថា ជាដំណោះស្រាយមួយទាន់សម័យ គឺការបដិវត្តកុម្មុយនិស្តនោះ លន់ នល់ បែរជាមើលឃើញការស្រោចស្រង់ប្រទេសជាតិក្នុងកាលកន្លងទៅហើយ នៅក្នុងការបញ្ជាក់ការអះអាងពីមរតករបស់ព្រះពុទ្ធសាសនាទៅវិញ ។ ប្រទេសកម្ពុជាបានលេចឡើងជាដែនដីដែលឲ្យផលមួយសម្រាប់គំនិតទាំងពីរនេះ ដែលកំពុងលើកតម្កើងពូជ-សាសន៍ និងប្រជាជាតិខ្មែរដែលត្រូវគេប្រមាថមាក់ងាយ ។ ជាច្រើនសតវត្សរ៍នៃបរាជ័យ និងភាពអាម៉ាស់មុខតាំងពីសម័យអង្គរ អាកប្បកិរិយាវាយឫកធំរបស់ពួកបារាំងចំពោះប្រជាជនកម្ពុជា “ដែលខ្ជិលច្រអូស” ដោយផ្ទុយគ្នាស្រឡះនឹងពួកវៀតណាម “ដែលស្រឡាញ់ការងារ” និងការខ្លាចរអែងថា ពួកវៀតណាម “ដែលស្រឡាញ់ការងារ” ទាំងនោះដណ្តើមយកប្រទេសកម្ពុជាដោយប្រើកម្លាំង បានបន្សល់ទុកនូវលក្ខណៈពិសេសរបស់គាត់រហូតមក ។

នៅពេលដែលប្រទេសជាតិចាប់ផ្តើមចុះទន់ខ្សោយ និងទ្រេតទ្រោតរកកលដួល អ្នកទាំងពីរនាក់នេះដែលជាតំណាងគំនិតជ្រុលហួសហេតុ និងដែលផ្ទុយគ្នា និងនយោបាយជាបន្តបន្ទាប់នោះ បានតម្រង់ឆ្ពោះទៅរកគោលដៅតែមួយក្នុងការផ្លាស់ទ្រង់ទ្រាយប្រទេសកម្ពុជា ទៅជារដ្ឋហ្វាស៊ីសមួយ តាមន័យប្រាកដប្រជារបស់ពាក្យ[៥] គឺថារបបមួយដែលលើកតម្កើងប្រជាជាតិ និងពូជសាសន៍របស់ខ្លួន ដែលអួតអំពីរដ្ឋាភិបាលអត្តាធិបតេយ្យ ដែលប្រមូលផ្តុំអំណាចមកតែមួយកន្លែង ដោយមានមេដឹកនាំប្រើអំណាចផ្តាច់ការម្នាក់ដឹកនាំដែលដាក់ឲ្យមានបទបញ្ញត្តិដ៏តឹងរ៉ឹងមួយខាងផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ច និងសង្កត់សង្កិនទៅលើគណបក្សប្រឆាំង ។ អ្នកទាំងពីរបានជួយជំរុញទ្រឹស្តីបន្ទាប់បន្សំនៃលទ្ធិហ្វាស៊ីស ក៏ដូចការប្រកាន់ពូជសាសន៍ និងការស្អប់ខ្ពើមជនបរទេស ។

ប៉ុន្តែ បញ្ហាទាំងអស់នេះបានលេចឡើងឲ្យឃើញនៅក្នុងរយៈពេលនៃសង្គ្រាមឆ្នាំ១៩៧០ - ១៩៧៥ ។ គ្មានក្រុមណាមួយទទួលស្គាល់ដោយចេញមុខថា ការប្រព្រឹត្តិរបស់ខ្លួនដែលកាន់តែសាហាវឡើងៗនោះ មានការប្រកាន់ពូជសាសន៍ជាគ្រឹះឡើយ ។ សម្ព័ន្ធមិត្តអាមេរិកាំងរបស់ លន់ នល់ បានត្រូវធ្វើឲ្យខូលខ្វាយចិត្ត ដោយសារ

“ភាសាស្ដាប់មិនបាន” របស់គាត់ ដែលជាអ្នកកាន់ព្រះពុទ្ធសាសនាម្នាក់ ប៉ុន្តែ ពួកនោះពុំសូវជាជឿប៉ុន្មានទេ លើកលែងតែអ្នកទទួលខុសត្រូវនយោបាយម្នាក់ឈ្មោះ វីល្លីយ៉ាំ ហាប៊ីន ប៉ុណ្ណោះ ។ នៅឆ្នាំ១៩៧២ គាត់បានបញ្ជូនទូរលេខសម្ងាត់មួយទៅក្រុងវ៉ាស៊ីនតោន ដែលមានចំណងជើងថា ទស្សនៈទាក់ទងទៅនឹងសាវតារធម្មជាតិរបស់មនុស្សស្ដីពី លន់ នល់ ដោយបានអធិប្បាយរៀបរាប់ពីឥទ្ធិពលដែល លន់ នល់ ធ្លាប់មានលើប្រជាជនខ្មែរ និងបានទាយទុកជាមុនអំពីបញ្ហាផ្សេងៗ ដែលឥទ្ធិពលទាំងនោះនឹងបង្កើតឲ្យមានឡើង ប្រកបដោយលក្ខណៈត្រឹមត្រូវទៀតផង ៖

“លន់ នល់ ជាមនុស្សដែលយកតាមយោបល់គេ (ដោយឥតពិចារណា) មុននឹងក្លាយទៅជាមនោសញ្ចេតនាមួយ គឺមនោសញ្ចេតនាដ៏ជ្រាលជ្រៅ ដែលគិតមមៃពីភាពអន់ថយជាងគេរបស់ប្រជាជនខ្មែរ ចំពោះពួកវៀតណាមនៅក្បែរខាងពួកគេ និងចំពោះវណ្ណៈអ្នកជំនួញជាតិចិន ដែលតាមរឿងទេវកថាបានបំភ្លឺឲ្យដឹងថា ជនជាតិខ្មែរជាអ្នកមានពូជពង្សតពីពួកអ្នកកសាងប្រាសាទស្ដេចជំនាន់ដើម ។ ដោយបំបាត់មន្តអាគមអូមអាមរបស់ខ្លួនចោល ពួកគេអាចនឹងបូកបន្ថែមមនោសញ្ចេតនានៃមោទនភាពជាតិមួយទៅនឹងន័យដ៏ជ្រាលជ្រៅទាក់ទងនឹងអត្តសញ្ញាណជាតិសាសន៍មួយក្នុងចិត្តរបស់ប្រជាជនយ៉ាងច្រើននេះ នៅពេលដែលត្រូវច្រោសចោលក្នុង“តំបន់ស្វយ័ត”ណាមួយ របៀបជនជាតិរុស្ស៊ី [ជាការនិយាយបញ្ចិតបញ្ចៀងទៅរកអ្វីដែលពួករុស្ស៊ីបានប្រព្រឹត្តទៅលើរដ្ឋអេស្តូនី] ក្នុងផ្ទៃនៃចក្រភពមួយរបស់វៀតណាម ហើយដែលទន់ខ្សោយយ៉ាងខ្លាំង ដើម្បីធ្វើឲ្យគេស្គាល់ខ្លួនក្នុងការធ្វើសញ្ជ័យមួយនៅបរទេស[៦] ។

ហារប៊ីន ពុំបានដឹងថា ជនកម្ពុជាម្នាក់ដែលស្ថិតនៅក្រុមម្ខាងទៀត ដែលប្រឈមមុខគ្នាក្នុងសង្គ្រាមស៊ីវិលមួយដែលកំពុងតែរីកធំឡើងនោះជា លន់ នល់ ម្នាក់ដែលគ្មានចាំបាច់ប្រើមន្តអាគមគាថាឡើយ ។ សាឡុត ស ចង់ឲ្យប្រទេសកម្ពុជាមានឋានៈនាទីពេញច្បាប់របស់ខ្លួន ដែលជាអ្នកទទួលមរតកពីរាជាណាចក្រអង្គរ មានសភាពរុងរឿងដូចដើមឡើងវិញ និងធ្វើឲ្យប្រទេសជាតិបានស្អាតបរិសុទ្ធចាកផុតពីឥទ្ធិពលរបស់បរទេសទាំងស្រុងដូចគ្នា ។ លន់ នល់ និង សាឡុត ស សុទ្ធតែជាលទ្ធផលនៃប្រវត្តិសាស្ត្រថ្មីៗរបស់ប្រទេសទាំងពីរនាក់ ប៉ុន្តែ ក្នុងពាក់កណ្ដាលទីពីរ នៃសតវត្សរ៍ទី២០ប៉ុណ្ណោះ ។ លទ្ធិកុម្មុយនិស្ដបានបញ្ចេញឲ្យឃើញរបាំងមួយបិទបាំងនយោបាយហ្វាស៊ីស ប្រសើរជាងពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ ។ សាឡុត ស បានតុបតែងគំនិតផ្សេងៗ របស់គាត់ដោយវាក្យស័ព្ទម៉ាក្សលេនីនប្លែកៗ មកធ្វើជាឡប់ខ្មែ ជាពិសេស គឺទស្សនៈក្នុងការរំដោះជាតិ ។ ដូចបណ្ដាមិត្ត
៨ របស់គាត់នៅប្រទេសចិន និងវៀតណាម សាឡុត ស នេះបេះរៀបសម្រួលទ្រឹស្ដី“ទំនើប និងដែលមានលក្ខណៈវិទ្យាសាស្ត្រ” របស់លទ្ធិម៉ាក្សលេនីន ដើម្បីផ្ដល់នូវវិញ្ញត្តិធម្មានុរូបមួយចំពោះឥរិយាបថប្រកាន់ជាតិសាសន៍ដែលមានជាប់តាំងពីយូរមកហើយ និងសម្អប់ខាងវប្បធម៌ ។ សង្គ្រាមក្នុង“ការរំដោះជាតិ”ជាច្រើន បានចាប់ផ្ដើម

មុនដំបូងគឺ ប្រឆាំងនឹងពួកមហាអំណាចអាណានិគមអឺរ៉ុប ហើយបន្តប្រឆាំងនឹងសត្រូវស្នូលពូជខ្សែរខាងទៀត ។

វិបាកផ្សេងៗមានសភាពនាំឲ្យវិនាសហិនហោចយ៉ាងខ្លាំងចំពោះប្រទេសកម្ពុជា ។ ក្នុងរយៈពេលនៃការធ្វើសង្គ្រាមរបស់គេ សាឡុត ស និង លន់ នល់ បានចោទប្រកាន់គ្នាទៅវិញទៅមកថា ជាអាយ៉ងស៊ីឈ្នួលឲ្យមហាអំណាចបរទេសមួយ ហើយអ្នកទាំងពីរបានផ្តើមចលនាបំបាត់ជាតិសាសន៍បរទេសយ៉ាងសាហាវ ដើម្បីបង្ហាញឲ្យឃើញភាព "បរិសុទ្ធ" របស់គេ ។ ស ស្គាល់ចិត្តពួកអ្នកស្តាប់របស់គាត់ គ្រាន់បើជាង លន់ នល់ ហើយដឹងថា ប្រជាកសិករជាមនុស្សមានវេទយិតភាពជាងវណ្ណៈគហបតី ចំពោះសេចក្តីអំពាវនាវឲ្យជួយការពារ និងធ្វើឲ្យឈាមព្រមទាំងទឹកដីបានស្អាតបរិសុទ្ធ ។ ម្យ៉ាងទៀត បណ្តាសម្ព័ន្ធមិត្តរបស់គាត់ គឺប្រទេសចិន និងវៀតណាម ក៏ប្រយ័ត្នប្រយែងលាក់បាំងនូវការវិវាទផ្សេងៗ និងការមិនទុកចិត្តរបស់ពួកគេ រហូតដល់ពេលដែល ស ទទួលបានជ័យជម្នះថែមទៀត ។ ស បានបង្ហាញឲ្យឃើញនៅពេលនេះថា ការទស្សន៍ទាយផ្នែកទី២របស់ ហារប៊ីនពិតជាត្រឹមត្រូវ មែនៈ ប្រជាជនកម្ពុជា ជាប្រជាជនទន់ខ្សោយ ខ្លាំងណាស់ដើម្បីធ្វើឲ្យគេស្គាល់ខ្លួនក្នុងសង្គ្រាមមួយនៅប្រទេស ។ ក៏ប៉ុន្តែការពុករលួយរបស់វៀតណាម មានលក្ខណៈផ្ទុយនឹងគំនិតរបស់អាមេរិកាំងដែលតាមរយៈនោះថា ប្រជាជនខ្មែរមានចំនួនច្រើនហួសពេក នៅពេលត្រូវលេបត្របាក់ដោយចក្រភពវៀតណាមមួយ ។

លន់ នល់ បានចាប់ញាត់បំពេញកងទ័ពរបស់គាត់នូវមនុស្សដែលមានលក្ខណៈដូចរូបគាត់ដែរ ជាពួកមនុស្សដែលគ្មានទាំងការបណ្តុះបណ្តាលខាងវិជ្ជាជីវៈយោធា គ្មានទាំងដើមកំណើតប្រាកដប្រជាដែលត្រូវតែមានជាចាំបាច់ សម្រាប់ធ្វើជាផ្លូវរបស់គេក្នុងចំណោមប្រជានជនស៊ីវិលទាំងឡាយ ហើយដែលជាមនុស្សដែលប្តូជាខ្លួនទាំងស្រុងចំពោះគាត់ ។

ប៉ុន្មានថ្ងៃក្រោយរដ្ឋប្រហារ លន់ នល់ បានទទួលកាន់មុខងារជាអ្នកដឹកនាំធ្វើចម្បាំង ហើយមិនដំអក់បង្ហាញឲ្យឃើញពីភាពខ្វះខាតប្រាជ្ញាឈ្លាសវៃផ្នែកយុទ្ធសាស្ត្ររបស់គាត់ឡើយ ។ គាត់គិតតែធ្វើយ៉ាងណាឲ្យសង្គ្រាមនេះទៅជាបូជនីយកិច្ចប្រឆាំងនឹងពួកទមិឡជាតិវៀតណាម និងការប្តេជ្ញារបស់គាត់ក្នុងការធ្វើឲ្យកិត្តិស័ព្ទប្រទេសកម្ពុជា និងព្រះពុទ្ធសាសនាមានសភាពដូចដើមឡើងវិញប៉ុណ្ណោះ ។ ក្នុងបណ្តាខែដំបូងៗនៃការប្រយុទ្ធគ្នាបានបណ្តាលឲ្យមានមហន្តរាយយ៉ាងខ្លាំង[៧] ហើយកងទ័ពរបស់ក្រុងភ្នំពេញ បានត្រូវវិនាស ឬបោះបង់ទៅឲ្យពួកវៀតណាមនូវការត្រួតត្រារបស់ខ្លួនជាងពាក់កណ្តាលប្រទេស ។ ភូមិភាគខាងកើត និងឦសាន បានធ្លាក់ក្នុងកណ្តាប់ដៃវៀតណាមយ៉ាងឆាប់រហ័ស ៈ ឈ្នួល ជប់ (តំបន់ចម្ការកៅស៊ូ ដែលបក្សកុម្មុយនិស្តឥណ្ឌូចិនរបស់វៀតណាមធ្លាប់បានជ្រើសរើសសមាជិកដំបូងៗរបស់ខ្លួននៅកម្ពុជា) ក្រែក ស្ទឹងត្រែង រួមទាំងខេត្តមណ្ឌលគិរី និងរតនគិរី ដែលជាទីបញ្ជាការរបស់បក្សកុម្មុយនិស្តកម្ពុជារបស់ សាឡុត ស ផង ។ នៅពេលចូលដល់ខែសីហា កងទ័ពវៀតណាមខាងជើងបានបង្ខំឲ្យកងទ័ពរបស់សាធារណរដ្ឋខ្មែរ បោះបង់ទឹកដីមួយផ្នែកយ៉ាងសំខាន់នៅភាពខាងលិចប្រទេសគឺ ចាប់ពីខេត្តបាត់ដំបង រហូតដល់ឈូងសមុទ្រសៀម រួមទាំងតំបន់ដែលស្ថិតនៅចន្លោះខេត្តកំពង់ស្ពឺ

និងកំពង់ផែផ្លូវទឹករបស់ខេត្តកំពតទៀតផង ។

អំណឹះតទៅ កងទ័ពរបស់ក្រុងហាណូយ ជាកងទ័ពមួយប្រសើរជាងគេនៅអាស៊ីអាគ្នេយ៍ ចំណែកកងទ័ពក្រុងភ្នំពេញមានមុខមាត់ក្នុងចំណោមកងទ័ពដែលអន់ជាងគេបំផុត ។ ហើយ លន់ នល់ បានដឹកនាំការទទួលខុសត្រូវក្នុងការចាត់វិធានការខ្លាំងមួយ ក្នុងពេលមានរដ្ឋប្រហារ កងទ័ពរបស់គាត់មានចំនួនសាមសិបប្រាំពាន់នាក់ ដែលបំពាក់អាវុធឲ្យមិនគ្រប់គ្រាន់ ។ ក្នុងរយៈពេលពីរខែ គាត់បានបន្ថែមចំនួននេះ ឡើងមួយជាបី ដោយគ្មានសម្ភារបរិក្ខារសឹកថ្មី និងគ្មានការហាត់ហ្វឹកហ្វឺន ក្បួនយុទ្ធសាស្ត្រឲ្យបានប្រាកដប្រជាសម្រាប់ការប្រយុទ្ធឡើយ ។ តាមបញ្ជារបស់ លន់ នល់ មនុស្សទាំងនេះត្រូវបានបញ្ជូនទៅរកការសម្លាប់រង្គាលមួយដោយជៀសមិនផុត ។ នាយទាហានម្នាក់ក្នុងចំណោមនាយទាហានរបស់គាត់គឺ សាក់ ស៊ុតសាខន បានវាយតម្លៃ នៅពេលក្រោយមក ចំពោះការពង្រីកគ្មានការទទួលខុសត្រូវនេះថា «ជាមហិច្ឆិតាចម្លែកខុសគេ ដែលកែប្រែធ្វើឲ្យកងទ័ពនេះ ក្លាយទៅជាកងទ័ពដ៏អស្ចារ្យមួយក្នុងរយៈពេលដ៏ខ្លីតាមរូបភាពកងទ័ពអាមេរិកាំង ដោយគ្មានយកចិត្តទុកដាក់ពីគោលការណ៍ជាសារវន្ត ក្នុងការដាក់ពង្រាយទ័ព និងធ្វើប្រតិបត្តិឡើយ» ។

មហិច្ឆតាបង្កើតកងទ័ពមួយតែក្នុងរវាងម្ភៃបួនម៉ោង បានលេចឡើងព្រមគ្នានឹងចំណង់ចង់បង្ហាញឲ្យឃើញថា ប្រទេសកម្ពុជាមានសមត្ថភាពបណ្តុះកងទ័ពវៀតណាមយ៉ាងរហ័សដូចគ្នា ។ ហើយ លន់ នល់ បានសុំឲ្យសហរដ្ឋអាមេរិកបំពាក់អាវុធឲ្យកងទ័ពរបស់គាត់តែក្នុងមួយថ្ងៃប៉ុណ្ណោះ ។ នៅខណៈនេះ ពួកអាមេរិកាំងបានបដិសេធ ហើយ លន់ នល់ បានបង្កើត «កងទ័ពម្ភៃបួនម៉ោង» របស់គាត់ ដោយព្រមទទួលយកទាហានជ្រើសរើសថ្មីទាំងអស់ ដោយគ្មានគិតពីសមត្ថភាពរបស់ពួកនោះឡើយ ហើយអនុញ្ញាតឲ្យការតំលើងឋានន្តរសក្តិលឿនរហ័សហួសហេតុ ដែលវាក្លាយទៅជានីតិក្រមទម្លាប់ទៅហើយ នៅក្នុងកំឡុងពេលនៃសង្គ្រាមនោះ ។ វានៅមានការអនុវត្តជាច្រើន ដែលរឹតតែធ្វើឲ្យគេភ័ន្តភាំងស្រឡាំងកាំងថែមទៀត គឺការចាប់បញ្ចូលក្មេងៗឲ្យធ្វើទ័ព បញ្ជីបើកប្រាក់ខែពោរពេញទៅដោយឈ្មោះ «ទាហានខ្មោច» សម្រាប់យកទៅសងគុណពួកនាយ ទាហានដែលឡើងបុណ្យសក្តិយ៉ាងឆាប់រហ័ស និងដែលពុករលួយ ហើយ លន់ នល់ បានបណ្តោយឲ្យមានទម្រង់នៃអំពើពុករលួយផ្សេងៗទៀត ក្នុងកម្រិតមួយយ៉ាងធំដែលបាននាំទៅដល់ការធ្លាក់ទឹកចិត្តមួយ ក្នុងចំណោមកងទ័ពទាំងមូល ។

ដោយមិនព្រមទទួលស្គាល់បញ្ហាទាំងនេះ លន់ នល់ បែរជាចូលចិត្តប្រឹងខ្នះខ្នែងផ្តល់ទៅឲ្យកងទ័ពរបស់គាត់នូវគ្រឿងការពារខាងផ្នែកវេទមន្តជាង ដែលតាមរូបគាត់ គាត់ជឿក្នុងចិត្តថា វានឹងឲ្យកងទ័ពទាំងនោះទៅរកជ័យជម្នះជាមិនខាន ។ នៅឆ្នាំ១៩៧០ គាត់បានចេញក្រឹត្យមួយបង្កើត «អង្គការសង្គ្រាមវប្បធម៌មួយ ដោយប្រើប្រាស់វេទមន្តបុរាណខ្មែរ-មន ស្ថិតនៅក្នុងការិយាល័យកំណែនកងទ័ព ។ អង្គការនេះ ត្រូវគេដាក់ ឈ្មោះថា គណៈកម្មាធិការសម្របសម្រួលសកម្មភាពទាំងឡាយរបស់បណ្តាមិត្តភក្តិខ្មែរ-មន និង វប្បធម៌ខ្មែរ-មនម៉ាឡាយូ-ប៉ូលីណេស៊ី ។ ជាបឋម អង្គការនេះ បានយកចិត្តទុកដាក់ធ្វើការបោះពុម្ពផ្សាយសៀវភៅមួយ ស្តីពីការ

*ប្រតិបត្តិផ្សេងៗសម្រាប់ប្រាប់ឲ្យទាហានទាំងអស់ធ្វើតាមគឺ «បញ្ចុះវត្ថុសក្តិសិទ្ធិក្នុងស្បែក ដើម្បីអនុញ្ញាតឲ្យព្រះពុទ្ធជាម្ចាស់ចូលសណ្ឋិតក្នុងខ្លួនប្រាណ និងនាំយកមហិទ្ធិឫទ្ធិរបស់ព្រះអង្គមកផ្តល់ឲ្យខ្លួនយើងផង... កាត់ដេរសម្លៀកបំពាក់ដោយការចារអក្សរយ័ន្ត ដែលផ្តល់នូវថាមពលដល់អ្នកណាដែលបានពាក់ខោអាវទាំងនោះ... បន្តឲ្យមានការភ័ន្តច្រឡំអំពីចំនួនទ័ព ដើម្បីបន្លាចសត្រូវ..»[៨] ។*

*កងទ័ពដែលមួយភាគធំជាសមាសភាពប្រជាកសិករនោះ ចូលចិត្តធ្វើតាមការប្រតិបត្តិទាំងនេះណាស់ ដោយមានឬដោយគ្មានការបង្គាប់បញ្ជា ។ ពួកទាហានច្រើនមានពាក់កន្សែងយ័ន្ត បៀមលុយសេនបញ្ចៀសគ្រោះ ពាក់បន្ទោងរូបព្រះពុទ្ធ ពាក់គាថានៅករបស់ខ្លួន និងពាក់ខ្សែចង្កេះ សាក់រូបវត្ថុសក្តិសិទ្ធិលើរាងកាយ មុននឹងចេញទៅច្បាំងជាមួយសត្រូវ ។ ពួកអ្នកដែលធ្វើតាមការណែនាំនេះដោយវៀសវៃជាងគេ គឺពួកខ្មែរក្រោម ដែលមានដើមកំណើតនៅវៀតណាមភាគខាងត្បូង ហើយដែលចូលធ្វើទាហានក្នុងកងទ័ពរបស់ លន់ នល់ យ៉ាងច្រើននៅឆ្នាំ ១៩៧០ ដោយចាកចេញពីកងទ័ពវៀតណាមខាងត្បូង ឬអាមេរិកាំងជាមួយការអនុញ្ញាតឲ្យវិលមកការពារមាតុភូមិរបស់គេវិញ ។*

*ចំពោះក្រុមវរជននៅភ្នំពេញ យល់ឃើញច្បាស់ថា គំនិតមិនសមហេតុផលរបស់ លន់ នល់ ស្តីពីសង្គ្រាមខុសប្លែកពីគំនិតរបស់ពួកគេ និងខុសពីគំនិតរបស់ពួកអាមេរិកាំង ដែល លន់ នល់ ចង់ឲ្យជួយបង់ថ្លៃក្នុងចម្បាំងនេះផង ។ ឥឡូវនេះ លន់ នល់ ជឿថា ខ្លួនគាត់មានឧបនិស្ស័យមួយដែលញាណដឹងមុនដូចព្រះ ដូច្នេះហើយបានជាគាត់ចាត់ទុកបទបញ្ជាផ្សេងៗរបស់គាត់ជាចំណាររបស់ព្រះ ដែលប្រកបដោយគតិបណ្ឌិតមួយមិនអាចប្រកែកបានដោយទាញចេញពីក្បួនវេទមន្តទាំងឡាយ និងធម៌អាថ៌របស់ព្រះពុទ្ធជាម្ចាស់ ។ គាត់បានចាត់ទុកខ្លួនឯងថាជាអ្នកដឹកនាំធ្វើសង្គ្រាមមួយដែលប្រកាសដោយព្រះពុទ្ធអង្គផ្ទាល់ ដើម្បីការគង់វង្សនៃព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា ប្រឆាំងនឹងពួកទមិឡឥតសាសនាជាបរទេស ។*

*ពួកនិស្សិត ពួកហត្ថពលករ ពួកនិយោជិតប្រាក់ខែតិច និងពួកប្រជាកសិករដែលស្រោកស្រាំចូលចុះឈ្មោះក្នុងការិយាល័យជ្រើសរើសទ័ពជាច្រើនកន្លែងនៅក្រុងភ្នំពេញក្នុងកំឡុងឆ្នាំដំបូងនេះ ពុំមានគិតពីការប្រព្រឹត្តខុសគន្លងដែលមានលក្ខណៈដេរខុសគេរបស់ លន់ នល់ ទាល់តែសោះ ។ ពួកគេ ប្រជ្រៀតគ្នាឡើងជិះរថយន្តធំៗយ៉ាងពពាក់ពពូនជាមួយវ៉ាលិសរបស់គេ ដោយប្រកូកប្រកាសបបួលសាកថ្មីដៃគ្នា ចំពោះពួកវៀតណាមឈ្លានពាន ហើយត្រូវបានបញ្ជូនទៅកាន់សមរភូមិភ្លាមមួយរំពេច ។ តាមសម្តី សាក់ ស៊ុតសាខន ជាមេបញ្ជាការកងទ័ពម្នាក់ក្នុងចំណោមមេបញ្ជាការទាំងឡាយថា បន្ទាប់ពីការហាត់ហ្វឹកហ្វឺនវិជ្ជាយោធាត្រួសៗក្នុងជំរំហ្វឹកហ្វឺនជាច្រើនកន្លែងរួចហើយ ហើយដោយមានការមន្តអាគមពី លន់ នល់ ផង ពួកគេបានត្រូវពួកសត្រូវ «វាយឲ្យខ្ចាត់ខ្ចាយ រត់រប៉ាត់រប៉ាយ ឬត្រូវបំផ្លាញខ្ទេចខ្ទីទាំងអស់» ក្នុងកំឡុងបណ្តាខែដំបូងៗនៃសង្គ្រាម ។*

*បណ្តានាយទាហានរបស់ លន់ នល់ បានចាញ់ក្នុងការប្រយុទ្ធសំខាន់ៗជាច្រើន ដោយតែអន្តរាគមន៍ មិន*

ព្រមផ្ទាស់ប្តូររបស់មេកោយគេ គឺលន់ នល់ នេះឯង ។ គាត់បានកែប្រែផែនការប្រយុទ្ធទៅតាមការទស្សន៍ទាយរបស់ហោរាផ្ទាល់ខ្លួនរបស់គាត់ហើយ គាត់បានរៀបចំការប្រយុទ្ធរបស់កងទ័ពឡើងវិញ ក្នុងគោលបំណងដណ្តើមយកស្នាដៃគួរទុកឲ្យកូនចៅជាន់ក្រោយជាជាងដណ្តើមយកទីតាំងរបស់សត្រូវ ដែលធ្វើឲ្យយឺតដល់ការវាយបកមួយ ដើម្បីធ្វើឲ្យប្រាកដបណ្តាមនុស្សដែលពាក់អាវយ័ន្ត អាចបញ្ចៀសគ្រាប់កាំភ្លើងរបស់សត្រូវមែន ។

នាយអគ្គសេនាធិការរបស់កម្ពុជារូបនេះ ពុំមែនកំណត់សង្គ្រាមសាសនារបស់គាត់នៅលើសមរភូមិទេ ៖ តែប៉ុន្មានថ្ងៃប៉ុណ្ណោះ បន្ទាប់ពីរដ្ឋប្រហារ សុន្ទរកថាទាំងឡាយរបស់ លន់ នល់ ប្រឆាំងនឹងពួកវៀតណាមខាងជើង បានប្រែក្លាយទៅជាយុទ្ធនាការប្រឆាំងនឹងប្រជាជនវៀតណាមទាំងអស់[៩] ហើយនៅក្នុងចំណោមនោះ មានកន្លះលាននាក់ កំពុងរស់នៅកម្ពុជាក្នុងឆ្នាំ១៩៧០ ។ ភាគច្រើន បានមកតាំងទីលំនៅនៅប្រទេសកម្ពុជាក្រោមកិច្ចគាំពាររបស់ពួកអាណានិគមបារាំង ហើយប្រកបមុខរបរជានិយោជិត អ្នករកស៊ី ឬកម្មករជំនាញនៅក្រុងភ្នំពេញ ។ តាមធម្មតា ពួកនេះក៏ជាអ្នកប្រឆាំងកុម្មុយនិស្តដូចរបបថ្មីរបស់ លន់ នល់ ដែរ ប៉ុន្តែ ដោយគួរឲ្យសោកស្តាយពួកគេត្រូវរាប់ចូលក្នុងជាតិសាសន៍តែមួយដូចពួកវៀតកុង ។ ដូច្នេះពួកគេបានធ្លាក់ទៅក្នុងប្រភេទជា «ពួកសត្រូវសួពូជ» សម្រាប់ លន់ នល់ ដូចគ្នា ។

ក្រោយរដ្ឋប្រហារបន្តិច ការសរសេរពាក្យគ្រោតគ្រាតជាច្រើនបានលេចឡើងនៅលើកញ្ចក់ហាងលក់ទំនិញនានារបស់ជនជាតិវៀតណាម ដែលធ្វើឲ្យមានការមិនទុកចិតលើកម្មសិទ្ធិរបស់គេថែមទៀតផង ។ ការនិយាយមិនសមហេតុផលទាំងឡាយ បានបណ្តាលឲ្យមានការមិនរាប់រកមួយ ចំពោះគ្រឹះស្ថានទាំងឡាយរបស់ជនជាតិវៀតណាម តាំងពីភោជនីយដ្ឋានរហូតដល់យានដ្ឋានជួសជុលរថយន្ត ។

នៅដើមខែមេសា ឆ្នាំ៩៧០ លន់ នល់ បានបន្តាប់បញ្ជាឲ្យដៃដើងរបស់គាត់រៀបចំបង្កើតជំរំឃុំទុកជាច្រើនសម្រាប់ដាក់ប្រជាជនវៀតណាមទាំងអស់ ។ កងទ័ពបានចាប់ខ្លួនជនជាតិវៀតណាមជាច្រើន ហើយបានបង្ខាំងទុកពួកនោះក្នុងអគារធំៗដែលគេបោះបង់ចោល ។ ស្ត្រីកម្ពុជាម្នាក់បាននិយាយរំឭកពីជំរំដ៏គួរឲ្យខ្លាចមួយក្នុងបណ្តាជំរំដ៏គួរឲ្យព្រឺខ្លាចនៅក្បែរផ្ទះនាងថា «ពួកទាហានបានប្រមូលយករបស់របរចេញពីផ្ទះគ្មានមនុស្សនៅមួយ ស្ថិតនៅក្បែរវត្ត ហើយចាក់សោទុកពួកវៀតណាមនៅក្នុងផ្ទះនោះ ។ ពួកនេះគ្មានសម្ភារអ្វីជាប់នឹងខ្លួនទាំងអស់ ពួកគេដេកក្នុងអង្រឹងហើយនៅអង្គុយស្ងៀមពេញៗមួយថ្ងៃ ដោយគ្មានធ្វើអ្វីសោះនៅក្នុងជំរំ... លន់ នល់ មិនចូលចិត្តពួកនេះឡើយ[១០]» ។

យុទ្ធនាការនេះបានប្រែក្លាយទៅជាការសម្លាប់រង្គាលពូជសាសន៍បរទេសមួយ ។ រដ្ឋាភិបាលទទួលស្គាល់ថាបានចាប់ខ្លួនជនជាតិវៀតណាមប្រហែលសាមសិបពាន់នាក់ ហើយដាក់គុកមនុស្សប្រាំពីរពាន់នាក់ ក្នុងចំនួនទាំងអស់នោះដែរគេសង្ស័យថា ចូលដៃជាមួយសត្រូវ ។ ក៏ប៉ុន្តែ រដ្ឋាភិបាល ពុំបានទទួលស្គាល់ពីការសម្លាប់រង្គាលភាគច្រើន ដែលដំណឹងថ្មីៗបានព្មមកដល់ក្រុងភ្នំពេញឡើយ ។ នៅថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៧០ ក្នុងទីប្រជុំជន

ប្រសូត្រ (ខេត្តស្វាយរៀង) ប្រជាពលរដ្ឋវៀតណាម ប៉ែតសិបប្រាំបួននាក់ ត្រូវបានសម្លាប់ភ្លាមៗដោយពួកទាហានរបស់ លន់ នល់ ។ ពាក្យចចាមអារ៉ាមផ្សេងៗដែលគ្មានការអះអាងបន្ថែម បានឲ្យដឹងពីការកាប់សម្លាប់របៀបដូចគ្នា នៅក្នុងភាគផ្សេងៗទៀតរបស់ប្រទេស ។ ពីរសប្តាហ៍ក្រោយមក កងទ័ពបានទម្លាក់ទោសទៅលើសហគមន៍វៀតណាមមួយ ក្នុងចំណោមសហគមន៍សំខាន់ៗរបស់វៀតណាមដែលមួយភាគធំ ជាអ្នកកាន់សាសនាកាតូលិក តាំងនៅជ្រោយចង្វាទល់មុខរដ្ឋធានីផ្ទាល់ ។

ពួកទាហានបានឡើងទៅទាំងកណ្តាលអធ្រាត្រ ហើយបាននាំយកហត្ថពលករវៀតណាមប្រហែល ប្រាំរយនាក់ ទៅជាមួយផង ដោយចាប់ចងដៃពួកគេបត់មកក្រោយខ្នង ហើយនាំឡើងជិះលើទូកជាច្រើនគ្រឿង រួចសម្លាប់ពួកនោះរហូតដល់អ្នកចុងក្រោយ ហើយទម្លាក់ខ្មោចទាំងនោះទៅក្នុងទឹកទន្លេ ។ ក្នុងរយៈពេលជាច្រើនថ្ងៃ សាកសពដែលហើមប៉ោម បានអណ្តែតឡើងមកលើផ្ទៃទឹក ។ នេះជាការព្រមានមួយដ៏គួរឲ្យព្រឺខ្លាចចំពោះប្រជាជនវៀតណាមទាំងឡាយដែលកំពុងរស់នៅប្រទេសកម្ពុជា ។

សារពត៌មានអន្តរជាតិ បានរាយការណ៍ភាគច្រើននូវការសម្លាប់រង្គាលទាំងនេះ ជាពិសេស ការសម្លាប់រង្គាលមួយផ្សេងទៀតដែលកងទ័ពបានប្រព្រឹត្តនៅខេត្តតាកែវ ។ ពិភពលោកទាំងមូល កើតក្តីក្តៅក្រហាយនឹងរឿងនេះ ហើយស្ថានទូតអាមេរិកាំងបានធ្វើលិខិតតវ៉ាទៅ លន់ នល់ ថា អំពើទាំងអម្បាលម៉ាននេះ នឹងធ្វើឲ្យសម្ព័ន្ធភាពដ៏ផុយស្រួយជាមួយនឹងរដ្ឋាភិបាលវៀតណាមខាងត្បូង ដែលដឹកនាំដោយប្រធានាធិបតី ង្វៀន វ៉ាន់ធីវ អន្តរាយបាក់បែកជាមិនខាន ។ អ្នករងគ្រោះក្នុងការកាប់សម្លាប់ទាំងនោះ គឺមានអំណោយផលសម្រាប់ ធីវ ពុំមែនសម្រាប់ពួកកុម្មុយនិស្តទេ ហើយគឺពួកទាហានរបស់ ធីវ ដែលបានវាយប្រហារពួកវៀតណាមខាងជើងនៅតាមព្រំដែនរបស់កម្ពុជា ។

ក្រុងភ្នំពេញ និងក្រុងព្រៃនគរ បានចាប់ផ្តើមស្ទឹបខ្មោសគ្នាទៅវិញទៅមកជាហូរហែមួយ[១១] ។ កងទ័ពរបស់ ធីវ បានធ្វើ ឲ្យការមកជួយរបស់ខ្លួននេះ នេះទៅជាការឆក់ប្លន់ នៅពេលធ្វើដំណើរឆ្ពោះមកក្រុងភ្នំពេញទៅវិញ ហើយក្នុងបណ្តឹងផ្លូវការមួយ ប្រជាជនកម្ពុជាបានប្រកាសឲ្យដឹងថា កងទ័ពវៀតណាមខាងត្បូងបានលួចយកគ្រឿងបន្លាស់រថយន្ត សម្បកកង់ ម៉ាស៊ីនដេរ និងស្រូវ មានតម្លៃស្មើនឹង មួយម៉ឺនដុល្លារសហរដ្ឋអាមេរិក នៅពេលឆ្លងកាត់ខេត្តកំពង់ចាម ។ ក្នុងទីបំផុត នៅពេលដែលកងទ័ព ទាំងនេះមកដល់រដ្ឋធានីនៅខែកញ្ញា ការប្រយុទ្ធគ្នាជាច្រើន បានផ្ទុះឡើងរវាងទាហានកម្ពុជា និងវៀតណាម ។

ក្នុងលិខិតទូរលេខមួយក្នុងចំណោមទូរលេខជាច្រើនរបស់ពួកគេដែលផ្ញើទៅឲ្យក្រុងវ៉ាស៊ីនតោន ពួកអ្នកទទួលខុសត្រូវ នៃស្ថានទូតអាមេរិកាំងប្រចាំក្រុងភ្នំពេញ បានរៀបរាប់ពីការប្រយុទ្ធតាំងមួយរវាងប៉ូលិសខ្មែរ និងទាហានម៉ារីនវៀតណាមខាងត្បូង ដែលបណ្តាលឲ្យមានមនុស្សម្នាក់ត្រូវស្លាប់ និងរបួសដប់ពីរនាក់ ។ សេចក្តីរាយការណ៍បន្ថែមថា ឧប្បត្តិហេតុដែលកកើតឡើងនេះ “បានធ្វើឲ្យទំនាក់ទំនងផ្សេងៗរវាងរដ្ឋាភិបាលវៀតណាម

និងរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ ដែលកន្លងមកមានការពិបាករួចទៅហើយនោះ កាន់តែតានតឹងឡើងថែមទៀត[១៧]» ។ ពួកនាយទាហានកម្ពុជាដែលគេបញ្ជូនទៅវៀតណាមខាងត្បូង ដើម្បីហ្វឹកហ្វឺនក្បួនយុទ្ធសាស្ត្រ បាននិយាយរៀបរាប់នៅពេលត្រឡប់មកវិញថា នៅទីនោះមានការប្រព្រឹត្តិមិនល្អជាច្រើន ដែលមានពួកគេជាកម្មវត្ថុ ។ ការប្រឆាំងគ្នាប្រែទៅជាមានកាន់តែច្រើនឡើងៗ រហូតទាល់តែជនជាតិអាមេរិកាំងប្រឆាំងសង្គ្រាមមួយក្រុម និយាយទុកជាមុនថា បើសិនជាពុំមានជ័យជម្នះរបស់កុម្មុយនិស្តទេ ពួកវៀតណាមក្រុងព្រៃនគរនឹងវាតត្បាតកាន់កាប់ប្រទេសកម្ពុជា ដោយប្រើកម្លាំងទ័ពមិនខាន ។

ប្រជាជនវៀតណាមនៅប្រទេសកម្ពុជា ពុំមែនជាគោលដៅតែមួយរបស់ លន់ នល់ ដែលរករឿងចំពោះអាណិកជនចិនដូចគ្នា ។ ក្នុងសារពត៌មានក្នុងស្រុកទាំងអស់ គាត់បានធ្វើយុទ្ធនាការប្រឆាំងនឹងពួកអ្នកជំនួញចិនដែលលោភលន់ឥតខ្មាស់ ព្រោះតែកូនៗរបស់គាត់មិនចូលធ្វើកងទ័ព ដែលចាំតែឆ្លៀតយកផលប្រយោជន៍ពីសង្គ្រាម និងដំឡើងថ្លៃទំនិញ ហើយដែលសេចក្តីស្មោះត្រង់ចំពោះប្រទេសកម្ពុជា មានលក្ខណៈម្យ៉ាងគួរឲ្យសង្ស័យផង ។ សារពត៌មានមួយដែលស្និទ្ធនឹងរដ្ឋាភិបាលបានសរសេរថា ពួកជនជាតិចិននៅក្រុងភ្នំពេញអាចនឹងទទួលរងនូវជោគវាសនាមួយដូចពួកចិននៅប្រទេសឥណ្ឌូនេស៊ីដែរ ដែលត្រូវកងទ័ព សម្លាប់រង្គាលក្នុងរយៈពេលនៃការបះបោរមួយនៅឆ្នាំ១៩៦៥ ។

ប៉ុន្តែ នៅទីបំផុត ក្រុមវរជនចេះដឹងរបស់ប្រទេស បាននឹកពិភាល់ពីលក្ខណៈធំធេងនៃសង្គ្រាមសាសនាដែលដឹកនាំដោយ លន់ នល់ ។ បណ្តាសមាជិករដ្ឋាភិបាលរបស់គាត់ ពុំមានចំណែកទាំងក្នុងការសម្លាប់រង្គាលជាតិសាសន៍មួយ ទាំងការតវ៉ាដោយសកម្មប្រឆាំងនឹងគាត់ដែរ ។ ក្នុងការជជែកពិភាក្សាលើរដ្ឋធម្មនុញ្ញរបស់សាធារណរដ្ឋថ្មី ពួកគេបានសាកល្បងលុបចោលសញ្ញាណ «ពូជសាសន៍សុទ្ធ» ចេញពីច្បាប់នេះ ។ ក្នុងសេចក្តីព្រាងដំបូង លន់ នល់ បានផ្តើមប្រយោគរបស់គាត់ដោយពាក្យថា «យើងពូជសាសន៍ខ្មែរ ដែលជាបច្ចាញាតិខ្មែរ-មន[១៣]» ជាការនិយាយយោងពីប្រភេទជាតិសាសន៍មួយស្ទើរតែដូចគ្នាបើគិតពីសាវតារកម្មជាតិនៃមនុស្ស ។ លន់ នល់ ក៏មាននិយាយពី «សម័យអង្គរ» ដែលជាសម័យអារ្យធម៌កំពូលរបស់ខ្មែរដែរ ។ ប្រតិភូជាច្រើនក្នុងសភាមានសេចក្តីព្រួយបារម្ភជាខ្លាំង ព្រោះអីមានប្រជាជនកម្ពុជាតិចណាស់ ដែល «សុទ្ធគ្មានលាយឈាមសាសន៍ដទៃ» តាមន័យដែល លន់ នល់ ចង់ដាក់បញ្ចូលទៅក្នុងអត្ថបទរដ្ឋធម្មនុញ្ញរបស់គាត់នោះ ។ បើសិនជាប្រជាជនកម្ពុជាទាំងអស់ត្រូវរាប់បញ្ចូលក្នុងពូជសាសន៍តែមួយ គឺមានប្រជាជនយ៉ាងច្រើនដែលមានដើមកំណើតជាកូនកាត់ ។ ក្រៅពីមានជីដូនជីតាជាចិន និងវៀតនាម ជនជាតិខ្មែរអាចមានឪពុកម្តាយក្នុងក្រុមផ្សេងគ្នាជាច្រើនដូចជាជាតិ ព័រទុយហ្គាល់ ឥណ្ឌា ឥណ្ឌូនេស៊ីជាដើម ។ អ្នកតំណាងម្នាក់បានឡើងធ្វើបទអន្តរាគមន៍ដើម្បីប្រកាសថា រដ្ឋធម្មនុញ្ញមួយបែបនោះនឹងត្រូវគេបកស្រាយនៅក្នុងន័យប្រកាន់ពូជសាសន៍មួយ ។ គាត់បានបន្ថែមថា ហើយការប្រកាន់ពូជសាសន៍ «គឺជាប្រភពនៃគុណវិបត្តិជាច្រើនដែលក្នុងនោះមានសង្គ្រាមជាដើម» ។

ការប្រើប្រាស់ពាក្យពេចន៍ខ្មែរ-មន និងការនិយាយយោងដល់សម័យអង្គរ អាចប្រើជាមូលហេតុសម្រាប់សង្គ្រាមច្បាំងដណ្ដើមទឹកដី ហើយសមាជិកនៃក្រុមវរជនបានដណ្ដឹងសួរនៅពេលនេះថាតើ លន់ នល់ មានគិតធ្វើឲ្យអតីតចក្រភពខ្មែរមានលក្ខណៈដូចដើមវិញ និងច្បាំងយកបណ្ដាខេត្តដែលបាត់បង់នៅភាគខាងត្បូងវៀតណាម នៅថៃ និងនៅឡាវមកវិញដែរទេ ។ ហេតុនេះហើយ បានជាពួកគេប្រញាប់ប្រញាល់លុបចោលសង្កត់អត្ថបទដែលចោទឲ្យមានបញ្ហាចេញពីច្បាប់រដ្ឋធម្មនុញ្ញទាំងអស់ ។

ការភ័យបារម្ភទាំងប៉ុន្មានរបស់ពួកគេ បានបង្ហាញភ័ស្តុតាងឲ្យឃើញពិតជាត្រឹមត្រូវមែន ។ លន់ នល់ ក៏ស្ថិតនៅក្នុងចំណោមជនកម្ពុជាទាំងនេះដែលអាចសម្រេចហៅរកកងទ័ពនៅខាងត្បូងវៀតណាមឲ្យមកជួយ គឺកម្ពុជាក្រោម ឬភាគខាងក្រោមប្រទេសកម្ពុជា ។ ក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ក្នុងឋានៈជាមេបញ្ជាការទ័ពរបស់សម្ដេចព្រះនរោត្តម សីហនុ ។ លន់ នល់ បានជំរុញឲ្យពួកខ្មែរកម្ពុជាក្រោមប្រយុទ្ធតស៊ូព្រមៗគ្នា និងពួកវៀតណាមខាងជើងផង ពួកវៀតណាមខាងត្បូងផង ទល់នឹងពួកកុម្មុយនិស្ដ ក៏ដូចពួកមិនមែនកុម្មុយនិស្ដផង ដើម្បីបុព្វហេតុមហានគរខ្មែរ ។ ព្រឹត្តបត្រដំបូង វិទ្យាស្ថានខ្មែរ-មនរបស់ លន់ នល់ បានបោះពុម្ពផ្សាយផែនទីអតីតចក្រភពខ្មែរនាសម័យកាលដ៏រុងរឿងរបស់ខ្លួនចុះក្នុងនោះដែរ ។

បន្ទាប់មកទៀត លន់ នល់ បានពង្រីកគំនិតជាច្រើនរបស់គាត់ក្នុងសៀវភៅស្ដើងមួយ ដែលមានចំណងជើងថា “នវខេមរនិយម (*Néo-Khmérisme*) ក្នុងការបកប្រែផ្លូវការជាភាសាបារាំងរបស់គាត់ ។ បោះពុម្ពផ្សាយដោយរដ្ឋាភិបាលក្រុងភ្នំពេញ ទុកដូចជាសេចក្ដីថ្លែងការណ៍របស់ លន់ នល់ (ដើម្បីពន្យល់ពីផ្លូវដើរតាំងពីដើមមក និងរបៀបត្រូវដើរទៅថ្ងៃមុខទៀត) ស្នាដៃនេះគឺជាការបកស្រាយសើៗអំពីប្រវត្តិសាស្ត្រខ្មែរ សំដៅលើកតម្កើងប្រទេសកម្ពុជា និងពូជសាសន៍ខ្មែរឡើងវិញ ដោយបណ្ដាលឲ្យខូចប្រយោជន៍ប្រទេសជិតខាងរបស់ខ្លួន ។ ក្នុងវគ្គមួយ លន់ នល់ បានពន្យល់ពីការដួលរលំរបស់រាជាណាចក្រអង្គរថា : “នៅសម័យកាលថ្កុំថ្កើងរុងរឿងរបស់ខ្លួនប្រទេសយើងបានទទួលសម្មតិនាមថា “បេនឡាសម្បូរភោគទ្រព្យ” ហើយប្រជាជនយើងធ្លាប់រស់នៅក្នុងជីវភាពមួយប្រកបដោយភាពស្រណុកសុខស្រួល និងសប្បាយរីករាយ ។ ការរស់នៅពោរពេញដោយសេចក្ដីរីករាយនេះបានធ្វើឲ្យខ្មែរភ្លេចគិតពីការគំរាមកំហែងនៃសង្គ្រាម ហើយប្រជាជនខ្មែរ បន្ទាប់ពីស្គាល់នូវសម័យកាលដ៏រុងរឿងនិងសុខសន្តិភាពមួយរយៈមក បានរងទទួលនូវការឈ្លានពានមួយ ពីសំណាក់ពួកសៀមនៅសតវត្សរ៍ទី១៤ ។ នៅឆ្នាំ១៤៣២ ខ្មែរបានដូររាជធានីរបស់ខ្លួនពីអង្គរមកខដុង្គវិញ ។ នៅសតវត្សរ៍ទី១៧ និងទី១៨ ការវាយប្រហារផ្ទួនៗគ្នារបស់ពួកអាណ្ណាម (វៀតណាម) និងពួកសៀម (ថៃ) បានធ្វើឲ្យកើតមានចលាចលក្នុងផ្ទៃប្រទេស ហើយប្រជាជនយើង ក្រោយពីធ្លាប់មានជោគជ័យ និងអានុភាព បានឈានចូលទៅក្នុងសករាជនៃការទាស់ទែងគ្នាជាច្រើន ព្រោះថា នៅពេលនេះ លទ្ធិអាណានិគមនិយមអឺរ៉ុប បានលេចស្រមោលឡើងនៅឯប្រទេសម្ខាងជាស្រេច ។ ពួកអង់គ្លេសនៅម្ខាង ហើយពួកបារាំងនៅម្ខាងទៀត បានចាប់ផ្ដើមបែងចែកជ្រោយឥណ្ឌូចិន បន្ទាប់មក

ទ្វីបអាស៊ីទាំងមូលបានធ្លាក់ទៅក្រោម «ការត្រួតត្រារបស់ពួកស្បែកស»[១៨] ដោយសារពួកគេមានគ្រឿងសព្វាវុធមួយទាន់សម័យបំផុត ។

លន់ នល់ ឬ«ប៉ាប៉ាខ្មៅ» បានអធិប្បាយជាបន្តមកទៀតអំពីស្ថានការណ៍បច្ចុប្បន្ន និងសត្រូវក្នុងបច្ចុប្បន្នកាល គឺពួកវៀតណាមខាងជើង និងពួកវៀតកុង ជាអ្នកតពូជពីជនជាតិអាណ្ណាម ធ្លាប់បានច្បាំងដណ្តើមយកទឹកដីកម្ពុជាក្រោម ។ គាត់បានសរសេរថា ពួកនេះមានគោលបំណង «កម្ទេចបំផ្លាញរចនាសម្ព័ន្ធសង្គមសេដ្ឋកិច្ចយើង និងអារ្យធម៌យើង ពួកនេះមិនត្រឹមតែចង់យកប្រទេសយើងដាក់ជាខ្ញុំកញ្ជះគេប៉ុណ្ណោះទេ ប៉ុន្តែ ក៏ចង់ផ្លាស់ប្តូររបៀបរស់នៅរបស់យើង កែរបៀបគិតពិចារណារបស់យើង និងលុបបំបាត់ជំនឿខាងសាសនារបស់យើងទៀត» ។

លន់ នល់ បានបន្ថែមថា ជនជាតិខ្មែរត្រូវ «ផ្តើមប្រឡូកក្នុងការប្រយុទ្ធតស៊ូដើម្បីការរស់នៅ និងអត្តិភាពរបស់មាតុភូមិខ្លួន» ឈមនឹង«សត្រូវមួយដែលគេមិនអាចធ្វើឲ្យបន្ទន់ ដែលឃោរឃៅ និងកម្រោលឃោឃៅបំផុតនៃប្រវត្តិសាស្ត្រ» ។ ប៉ុន្តែ គាត់ជឿទុកចិត្តលើពួកអ្នកច្បាំងដ៏មានវិន័យរបស់គាត់ ទាំងស្រុងដែលច្បាស់ជាវាយឈ្នះពួកវៀតណាមមិនខាន ។ «ក្នុងកំឡុងពេលប្រាំសតវត្សរ៍ ប្រជាជនយើងរស់នៅស្គាល់តែភាពក្រីក្រតោកយ៉ាក និងវិបត្តិភ័យប៉ុណ្ណោះ ប៉ុន្តែ បើទោះជាមានដំណើរប្រែត្រឡប់ (ពីអាក្រក់ទៅល្អ ពីល្អទៅអាក្រក់) ទាំងនេះក៏ដោយ -ទឹកដីត្រូវគេកាន់កាប់, ប្រជាជនត្រូវគេត្រួតត្រា- ក៏ប្រជាជនខ្មែរតែងតែងើបឡើង និងដណ្តើមយកសេរីភាពរបស់គេបានមកវិញជានិច្ច ដោយសារតែការប្តេជ្ញាចិត្ត និងសេចក្តីក្លាហាន ដែលបំបាក់មិនបានរបស់គេ ។ ដើម្បីនឹងអាចឲ្យយើងធ្វើឲ្យភាពរុងរឿងជាប្រវត្តិសាស្ត្រ ដែលអនុញ្ញាតឲ្យប្រទេសយើងមានឋានៈជា «កោះសន្តិភាព» និងជា «បេនឡាសម្បូរភោគទ្រព្យ» មានសភាពដូចដើមឡើងវិញនោះ ចាំបាច់ត្រូវតែជំនាន់យើងរចនាដោយដៃរបស់ខ្លួននូវរដ្ឋខ្មែរថ្មីមួយ ដែលមានផលហូរហៀរ ឯករាជ្យ និងសុខសន្តិភាព» ។

មិនយូរប៉ុន្មាន បណ្តាស្រទាប់អ្នកចេះដឹងនៅក្រុងភ្នំពេញ បានដឹងខ្លួនថា ត្រូវជាប់គុកក្នុងអន្ទាក់សង្គ្រាមសាសនារបស់ លន់ នល់ ។ ម៉ី កុម្ភត បានចាប់ផ្តើមនឹកឃើញ សម្តេច ព្រះនរោត្តម សីហនុ ដែលជាអ្នកបានលើកទឹកចិត្តឲ្យប្រជាជនបំភ្លេចគំនិតជាតិនិយមចង្អៀតចង្អល់ និងឲ្យរស់នៅដោយសន្តិភាពជាមួយបណ្តាប្រទេសជិតខាងរបស់ខ្លួន ។ អ្នកខ្លះក្នុងចំណោមនោះដែលត្រេកអរចំពោះការផ្តួលរំលំសម្តេច ហើយដែលងាកទៅចូលរួមខាងក្រុមសាធារណរដ្ឋថ្មីបានដឹងខ្លួនថា ពួកគេសុទ្ធតែត្រូវគេបំភាន់ ព្រោះ លន់ នល់ គ្មានបំណងបើកឱកាសឲ្យប្រទេសកម្ពុជាប្រែក្លាយទៅជាប្រទេសកាន់លទ្ធិប្រជាធិបតេយ្យមួយសោះ ។ តាមការពិត ប្រទេសជាតិបានក្លាយទៅជារដ្ឋយោធាមួយរបស់អ្នកកាន់ព្រះពុទ្ធសាសនាម្នាក់ ។ ផ្ទាំងប៉ាន់ណូស្តីពីសង្គ្រាម ដែលមានប្រជាប្រិយភាពជាងគេ ត្រូវបានជ្រើសរើសយកក្នុងក្របខ័ណ្ឌនៃការប្រឡងប្រណាំងមួយ ឧបត្ថម្ភឡើងដោយស្ថានទូតអាមេរិកាំង ដែលមានគូររូបតួអង្គជាច្រើនក្នុងរឿងរាមកេរ្តិ៍បុរាណ ដែលគេបានច្នៃឲ្យមានលក្ខណៈតាមសម័យថ្មី

គឺរូបពួកព្រាយបិសាចពាក់មួកដួន ប្រថាប់រូបផ្កាយក្រហមរបស់កងទ័ពកុម្មុយនិស្តវៀតណាមពួកនេះ ពុំមែនជិះលើសត្វផ្សេងៗ ដូចមានក្នុងរឿងព្រេងនោះទេ ប៉ុន្តែគឺជិះនៅលើរថក្រោះជាច្រើនគ្រឿង ហើយកាន់កាំភ្លើងកាវ៉ាប៊ីនមួយដើម ជាជំនួសដាវវិញ ។ ប៉ុន្តែ ពួកព្រាយបិសាចទាំងអស់នោះ ហាក់ដូចជាគ្មានឫទ្ធិអំណាចអ្វីទាំងអស់នៅចំពោះព្រះភ័ក្ត្រដ៏ស្ងប់ស្ងាត់របស់ព្រះពុទ្ធជាអម្ចាស់ ដែលគង់ព្រះភ្នែននៅលើផ្កាឈូកមួយមានពន្លឺឆព្វណ្ណរង្សី លឿង លឿងទុំ បៃតង និងខៀវ ចាំងរស្មីផ្លេកៗព័ទ្ធជុំវិញព្រះកេស ហើយពន្លឺនោះបានដុតរោល ឬរុញច្រានពួកព្រាយបិសាចវៀតណាមទាំងនោះ ទម្លាក់ទៅក្នុងសមុទ្រងងឹតខ្មៅ ។ នៅក្បែរជើងបល្ល័ង្ករបស់ព្រះអង្គ សត្វក្រពើសមួយបានដេកសន្ធឹងខ្លួនចាំការពារនៅប្របនឹងនោះដែរ ។

នៅតាមជនបទ រូបផ្ទាំងប៉ាន់ណូនេះ បានត្រូវប្រជាជនយកទៅប្រើប្រាស់ដាក់តាំងនៅលើអាសនៈសម្រាប់ធ្វើសក្ការៈបូជាដែរ ។ លន់ នល់ បានជឿទាំងខុសថា គាត់នឹងធ្វើឲ្យប្រជាកសិករ ចូលរួមជាមួយបុព្វហេតុរបស់គាត់ ដោយបានប្រកាសតាមធម្មតាថា ព្រះអាទិទេព ឬព្រះពុទ្ធជាម្ចាស់ស្ថិតនៅក្បែរពួកគេជានិច្ច និងបញ្ជាក់ថា ពួកសត្រូវគឺពួកវៀតណាមអត់សាសនា ។ គាត់មិនព្រមជឿថា គូសត្រូវពិតប្រាកដរបស់គាត់ គឺចលនាកុម្មុយនិស្តកម្ពុជាមួយ ដែលធ្លាប់ចាត់តាំងដឹកនាំប្រជាកសិករឲ្យងើបបះបោរប្រឆាំង បន្ទាប់ពីខ្លួនគាត់ផ្ទាល់ជាអ្នកត្រួតពិនិត្យពីលើយុទ្ធនាការបង្រ្កាបក្នុងការប្រមូលស្រូវទេ ។

លន់ នល់ បានបង្កើតសង្គ្រាមសាសនារបស់ខ្លួន តាមគំនិតមិនសមហេតុសមផលមួយចំនួនធំ ហើយការកំហុសមួយក្នុងចំណោមកំហុសធ្ងន់ធ្ងរជាងគេរបស់គាត់ គឺគាត់ជឿថា ពាក្យសន្យារបស់អាមេរិកាំងក្នុងការប្រើងប្រែងធ្វើសង្គ្រាម ជាមូលប្បទានប័ត្រមួយសន្លឹក ដែលឥតទាន់មានសរសេរអ្វី ។

ពួកអាមេរិកាំងមិនដែលផ្តល់នូវការគាំទ្រគាត់ជាសាធារណៈសម្រាប់រយៈពេលវែង ហើយក៏មិនដែលយល់ព្រមអំពីគោលដៅផ្សេងៗសោះឡើយ ។ រីឆាដ៍ និចសុន (Richard Nixon) ប្រធានាធិបតីសហរដ្ឋអាមេរិកបានរៀបចំជាមួយ ហង់រី គីស៊ីងហ្គ័រ (Henri Kissinger) ទីប្រឹក្សាសន្តិសុខជាតិរបស់គាត់ បន្ទាប់ពីការបោះឆ្នោតឆ្នាំ១៩៦៨ នូវផែនការមួយសំដៅទុកកងទ័ពអាស៊ីវាយប្រយុទ្ធគ្នាតែឯងចុះ ។ វានឹងមានការដកថយកងទ័ពរបស់សហរដ្ឋអាមេរិកចេញទៅមាតុប្រទេសវិញ ប៉ុន្តែ គ្មានលុយកាក់របស់អាមេរិកផ្តល់មកជួយទេ ។ សហរដ្ឋអាមេរិកនឹងបន្តជួយគាំទ្រកិច្ចប្រឹងប្រែងធ្វើសង្គ្រាមរបស់បណ្តាសម្ព័ន្ធមិត្តរបស់គេតទៅទៀត រហូតទាល់តែគោលដៅផ្សេងៗរបស់ក្រុងវ៉ាស៊ីនតោន បានសម្រេច ជាសំខាន់ គឺការដោះលែងឈ្លើយសង្គ្រាមអាមេរិកាំង និងការដកថយទាំងស្រុងនូវកងទ័ពអាមេរិកាំងទាំងអស់ ប្រកបដោយការខូចខាតមួយយ៉ាងតិចបំផុត ។ ការពង្រីកសង្គ្រាមចូលក្នុងប្រទេសកម្ពុជាជាមួយនឹងការទម្លាក់គ្រាប់បែកជាសម្ងាត់នៅឆ្នាំ១៩៦៩ និង“ការលុកលុយ” នៅឆ្នាំ១៩៧០ ក៏មានទាក់ទងជាមួយនឹងផែនការនេះដែរ ។ កងទ័ពរបស់កម្ពុជា នឹងបញ្ឈប់កងទ័ពកុម្មុយនិស្តវៀតណាម មិនឲ្យធ្វើសកម្មភាពកើតក្នុងរយៈពេលនៃការដកថយរបស់កងទ័ពអាមេរិកាំង ។ យុទ្ធសាស្ត្ររបស់សហរដ្ឋអាមេរិក គឺជួយ

គ្នាស្រឡះនឹងយុទ្ធសាស្ត្ររបស់ពួកវៀតណាមខាងជើង ដែលត្រៀមធ្វើសង្គ្រាមជាច្រើនឆ្នាំទល់នឹងកងទ័ពរបស់ លន់ នល់ ដើម្បីផ្តល់ឱកាសឲ្យពួកកុម្មុយនិស្តកម្ពុជាបង្កើត និងហ្វឹកហ្វឺនកងទ័ពផ្ទាល់របស់ពួកគេ ។

និចសុន និង គីស៊ីងហ្គ័រ ពុំមានបំណងដឹកនាំធ្វើសង្គ្រាមមួយដល់ "ទីផ្តាច់ព្រ័ត្រ" ប្រឆាំងនឹងលទ្ធិកុម្មុយនិស្ត នៅអាស៊ីទេ ទោះបីជាសហរដ្ឋអាមេរិកមិនប្រកាសពីសម្ព័ន្ធមិត្តថ្មីរបស់គេ គឺក្រុងភ្នំពេញក៏ដោយ ។ បេសកជនជាច្រើនមាន អាឡិចហ្សង់ដ័រ ហេក (Alexander Haig) អនុប្រធានាធិបតី ស្ពីរ៉ូ អាកញូ (Spiro Agnew) និង ឃីសស៊ីងហ្គ័រផ្ទាល់ បានត្រូវចាត់មកពីទីក្រុងវ៉ាស៊ីនតោន ដើម្បីផ្តល់ពត៌មានប្រាប់ លន់ នល់ ថាសហរដ្ឋអាមេរិកនៅជួយគាំទ្រអស់ពីចិត្តពីថ្លើម ចំពោះការប្រយុទ្ធប្រឆាំងនឹងពួកកុម្មុយនិស្តវៀតណាម លន់ នល់ មិនព្រមពិនិត្យមើលអ្វីៗទាំងអស់ ដែលបង្ហាញឲ្យឃើញផ្ទុយពីរឿងនេះទេ គឺការនៅខ្វះកិច្ចព្រមព្រៀងទាំងឡាយជាផ្លូវការដែលដៅបញ្ជាក់ដោយច្បាស់លាស់នូវការគាំទ្រនេះ ឥរិយាបថរបស់សភាសហរដ្ឋអាមេរិក ដែលបានកាត់បន្ថយលទ្ធភាពផ្សេងៗដើម្បីរៀបចំធ្វើសង្គ្រាមភ្លាមៗ បន្ទាប់ពីការលុកលុយរបស់ទាហានអាមេរិកាំងនៅប្រទេសកម្ពុជាក្នុងខែឧសភា ឆ្នាំ១៩៧០[១៥] ដោយបញ្ញាតិឲ្យមានបុគ្គលិកចំនួន ពីររយនាក់យ៉ាងច្រើនបំផុត អាចធ្វើការងារសម្រាប់រដ្ឋាភិបាលអាមេរិកាំងនៅប្រទេសកម្ពុជា ហើយកំណត់មុខនាទីរបស់កងទ័ពអាមេរិកាំងនៅប្រទេសនេះយ៉ាងតឹងរ៉ឹងបំផុត ។ តាមការពិត សភាអាមេរិកប្រាថ្នាថា សង្គ្រាមនៅប្រទេសកម្ពុជាត្រូវធ្វើឲ្យចប់មុនដែលត្រូវចាប់ផ្តើម ។

វាមានបន្តមកនូវរបៀបប្រើល្បិចកល និងការបញ្ឆោតមួយ រវាងប្រធានាធិបតីអាមេរិកាំង និងសភា មួយចំណែកហើយមួយចំណែកទៀត រវាងប្រធានាធិបតីដដែលនេះ និងសម្ព័ន្ធមិត្ត លន់ នល់ របស់គាត់ ។ ពួកអ្នកតំណាងអាមេរិកាំងប្រចាំនៅប្រទេសកម្ពុជា ត្រូវបានចាត់ទុកជាអ្នកកាន់អំណាចផ្តាច់ការដែរ ពីព្រោះក្រុងភ្នំពេញពឹងផ្អែកលើជំនួយរបស់អាមេរិកាំង ។ ប៉ុន្តែ នៅទីក្រុងវ៉ាស៊ីនតោន រដ្ឋាភិបាល និចសុន បានលាក់មិនឲ្យគេដឹងពីតម្លៃ និងទំហំនៃកិច្ចសន្យារបស់អាមេរិកាំងឡើយ ដោយសាបព្រោះដោយចេតនានូវភាពមិនច្បាស់លាស់ស្តីពីលក្ខណៈ និងភាពធ្ងន់ធ្ងរនៃសង្គ្រាម រហូតដល់គោលដៅទាំងឡាយរបស់ខ្លួន ត្រូវបានសម្រេចនៅវៀតណាមសិន ។ ជំនួយទាំងអស់ដែលអាចប្រើប្រាស់បាន ត្រូវគេបញ្ជូនជាបឋមទៅឲ្យកងទ័ព ដែលស្រួលបិទបាំងបំផុត ហើយដែលផលប្រយោជន៍ផ្សេងៗរបស់អាមេរិកាំងមាននៅទីនោះផង ។ សហរដ្ឋអាមេរិក ពុំដែលផ្តល់ជំនួយមនុស្សធម៌ណាមួយសម្រាប់ប្រទេសកម្ពុជាទេមុនឆ្នាំ១៩៧២ ថ្វីបើនៅពេលនោះមានការខ្វះខាតយ៉ាងខ្លាំង សម្រាប់ជួយពួកអ្នកភៀសខ្លួនដែលមានចំនួនកាន់តែច្រើនឡើងៗ អ្នករបួសក្នុងមន្ទីរពេទ្យនានាដែលផ្ទុកមនុស្សហួសហេតុ និងសម្រាប់មនុស្សកំពុងរងគ្រោះដោយការអត់ឃ្លានរាប់សិបពាន់នាក់ទៀត ពីព្រោះ ស្រែចម្ការទាំងឡាយបានត្រូវធ្វើឲ្យទៅជាសមរភូមិអស់ទៅហើយ ។

កន្លប់ចម្បងបំផុតរបស់រដ្ឋាភិបាលនិចសុន ស្ថិតនៅត្រង់ការរិះរកមធ្យោបាយដើម្បីដកខ្លួនថយពីប្រទេសវៀតណាម ដោយមានទំនងជាមិនឲ្យបង់ខាតអ្វីសោះឡើយ ។ នៅក្រុងវ៉ាស៊ីនតោន គេបានទទួលសេចក្តីរាយ

ការណ៍ផ្សេងៗទាំងមិនសប្បាយចិត្តស្ដីពីលក្ខណៈស្មុគស្មាញនៃសង្គ្រាម ការខ្វះសមត្ថភាព អំពើពុករលួយ និងសេចក្ដីសង្ឃឹមមិនសមហេតុផលរបស់ លន់ នល់ ហើយគេគ្មានយកចិត្តទុកដាក់ពីរឿងណាមួយឡើយ ។ វីល្លីយ៉ាំ ហារប៊ឺន អ្នកនិពន្ធការស្រាវជ្រាវអំពី លន់ នល់ ដែលចោទប្រកាន់ពីតួនាទីរបស់សហរដ្ឋអាមេរិកនៅប្រទេសកម្ពុជា ត្រូវបានដកចេញពីមុខតំណែងរបស់គាត់ទាំងអស់នៅស្ថានទូតក្រុងភ្នំពេញ ។ អ្វីដែលក្រុងវ៉ាស៊ីនតោនចង់ដឹងជាងគេគឺថា លន់ នល់ មានកងទ័ពក្នុងដៃ និងប្ដេជ្ញាចិត្តវាយប្រហារពួកកុម្មុយនិស្តដែរឬទេ ។

ដោយហេតុនេះ ការប្រើងប្រែងធ្វើសង្គ្រាមរបស់អាមេរិកាំងនៅកម្ពុជា បានផ្ដល់គុណប្រយោជន៍ដល់គូសត្រូវជារឿយៗ ហើយយុទ្ធនាការទម្លាក់គ្រាប់បែកជាច្រើន បានផ្ដល់ជាឧទាហរណ៍ពេញលេញមួយក្នុងរឿងនេះ ។ ការទម្លាក់គ្រាប់បែកដំបូងៗដែលធ្វើសម្ងាត់ និងខុសច្បាប់នៅឆ្នាំ១៩៦៩ គឺមានគោលដៅកម្ទេច "ជម្រក" ទាំងឡាយរបស់វៀតកុង និងកាត់បន្ថយការគាបសង្កត់ផ្សេងៗទៅលើកងទ័ពរបស់អាមេរិកាំង និងវៀតណាមខាងត្បូង នៅប្រទេសវៀតណាមខាងត្បូង[១៦] ។ នៅពេលដែលសហរដ្ឋអាមេរិកជំរុញការទម្លាក់គ្រាប់បែកដូចគ្នានេះ នៅតាមតំបន់ព្រំដែន បន្ទាប់ពីរដ្ឋប្រហារឆ្នាំ១៩៧០ គឺមានគោលដៅជួយកងទ័ព លន់ នល់ ឲ្យវាយប្រហារពួកវៀតណាម ប៉ុន្តែ ពួកគេបានទទួលលទ្ធផលផ្ទុយគ្នាទៅវិញ ។

ដើម្បីជៀសវាងពីការទម្លាក់គ្រាប់បែកទាំងនេះ កងទ័ពពួកកុម្មុយនិស្តវៀតណាមបានជ្រៀតចូលយ៉ាងជ្រៅមកក្នុងទឹកដីខ្មែរ ដែលបង្កជាការគំរាមកំហែងធ្ងន់ធ្ងរមួយដល់កងទ័ពក្រុងភ្នំពេញថែមទៀត ។ មុនរដ្ឋប្រហារ ពួកវៀតណាមធ្លាប់សម្ដែងឲ្យឃើញនូវការគោរពខ្លះៗដែរចំពោះ "អព្យាក្រឹត" របស់សម្ដេច ព្រះនរោត្តម សីហនុ ដោយមិនពង្រាតទីចេញឆ្ងាយពី "ជម្រក" នៅតាមតំបន់ពំដែន ដែលកំណត់ដោយកិច្ចព្រមព្រៀងរួមមួយឡើយ ។ ដោយ លន់ នល់ ឡើងកាន់អំណាច ពួកគេលែងមានហេតុផលណាមួយត្រូវគោរពព្រំប្រទល់គោក និងអព្យាក្រឹតភាពទៀតហើយ ។ ទោះណាជាមានបញ្ហាបូរណភាពទឹកដី ដែលលើកឡើងដោយសម្ព័ន្ធមិត្តខ្មែរក្រហមរបស់ពួកគេក៏ដោយ ក៏ពួកវៀតណាមខាងជើង បានពង្រាយទ័ពពាសពេញប្រទេសកម្ពុជា ដោយដឹកនាំការប្រយុទ្ធក្នុងរយៈពេលពីរឆ្នាំដំបូងនៃសង្គ្រាមប្រឆាំងនឹង លន់ នល់ ដែរ ហើយបានវាយដណ្ដើមកាន់កាប់ទឹកដីមួយផ្នែកយ៉ាងធំរបស់កម្ពុជា ។

ម្យ៉ាងវិញទៀត ប្រជាជនយ៉ាងច្រើនបានភៀសខ្លួនចេញពីតំបន់នានា ដែលយន្តហោះអាមេរិកាំង បានកំណត់ជាគោលដៅសម្រាប់ទម្លាក់គ្រាប់បែក ។ ប្រជាជនទាំងនេះបានបោះបង់វិសាលភាពដ៏ធំធេងនៃបណ្ដាខេត្តនៅភាគខាងកើតប្រទេស ដែលពួកកុម្មុយនិស្តវៀតណាមចូលកាន់កាប់យ៉ាងស្រួលបំផុត ហើយត្រូវកងទ័ពខ្មែរក្រហមដែលទើបនឹងចាប់កំណើត ប្រើប្រាស់ទុកជាមូលដ្ឋានបង្អែកទៀតផង ។ ពួកនាយទាហានរបស់ លន់ នល់ ផ្ទាល់ បានត្អូញត្អែរពីផលវិបាក ដែលនាំមកនូវវិនាសហិនហោចដោយសារការទម្លាក់គ្រាប់បែកទាំងនេះដែរ ប៉ុន្តែមេកោយរបស់គេមិនយកត្រចៀកស្ដាប់ឡើយ[១៧] ។

លន់ នល់ បានអនុវត្តផែនការសង្គ្រាមរបស់គាត់ ដោយគ្មានយុទ្ធសាស្ត្រពិតប្រាកដឡើយ ។ មានតែពួកអាមេរិកាំងប៉ុណ្ណោះ ដែលជួយឲ្យយោបល់គាត់មួងម្កាលក្នុងការគិតគ្រោងផែនការផ្នែកយោធា ដែលប្រសើរជាងមុន ។ គាត់នៅតែមានះជឿលើមន្តអាគមអូមអាម ហើយមិនព្រមស្តាប់បណ្តាមេបញ្ជាការរបស់គាត់ឡើយ ដោយសូត្រហៅតេជបារមី និងអានុភាពរបស់គាត់តែប៉ុណ្ណោះ នៅពេលណាដែលគាត់ជួបប្រទះនឹងខបសគ្គណាមួយ ។ នៅពេលដែលគេដាក់អ្វីឲ្យគាត់ពិនិត្យ គាត់តែងតែបួងសួងដល់"ក្បួន"បញ្ជាន់រូបជានិច្ច ។ នៅពេលដែលពួកអ្នកនយោបាយឯទៀតធ្វើអន្តរាគមន៍ គាត់ចាប់ផ្តើមជ្រៀតជ្រែកអំណាចខាងស៊ីវិល (ដោយប្រើកម្លាំង ឬខបាយកល) ថែមទៀត ។ មិនដល់ពីរឆ្នាំផង គាត់បានបំផ្លាញអស់នូវសមត្ថភាពផ្សេងៗរបស់កងទ័ពគាត់ផ្ទាល់ ហើយក្នុងចន្លោះពេលនោះ គាត់បានស្រវាក្តាប់ការគ្រប់គ្រងរដ្ឋាភិបាលទាំងស្រុង ។

គ្រោះមហន្តរាយធ្ងន់ធ្ងរ បានចាប់ផ្តើមនៅឆ្នាំ១៩៧០ នៅពេលដែលគាត់ចេញបញ្ជាឲ្យកងទ័ពដំណើរការវាយលុកយ៉ាងធំជាលើកដំបូងនៅក្នុងសង្គ្រាម ។ ពួកវៀតណាមខាងជើង បានវាយដណ្តើមកាន់កាប់ទឹកដីកម្ពុជាជាងពាក់កណ្តាលរួចស្រេចទៅហើយ ហើយ លន់ នល់ បានផ្តល់បទបញ្ជាឲ្យនាយទាហានទាំងឡាយរបស់គាត់រៀបចំយុទ្ធសាស្ត្រមួយក្នុងការវាយយកតំបន់នានាដែលបាត់បង់មកវិញ ជាពិសេស នៅភាគខាងកើតប្រទេស ។ គាត់បានផ្តោតការជ្រើសរើសរបស់គាត់ សំដៅធ្វើយុទ្ធនាការមួយវាយបើកផ្លូវជាតិមួយ ដែលភ្ជាប់ពីរដ្ឋធានីទៅទីប្រជុំជនស្គន់ ។ កងទ័ពបានចាប់ផ្តើមធ្វើចលនាទៅមុខ ការវាយប្រយុទ្ធប្រឆាំងនឹងពួកវៀតណាមខាងជើងមានច្រកចេញមួយមិនប្រាកដឡើយ ហើយ លន់ នល់ ក៏ពុំបានធ្វើឲ្យគោលដៅរបស់គាត់ ក្នុងការច្បាំងដណ្តើមយកភាគខាងកើតប្រទេសមានវឌ្ឍនភាពឡើយ ។

ប៉ុន្តែគាត់បានប្រកាន់ចិត្តថា ការវាយលុកនេះដែលដាក់ឈ្មោះថា ចេនឡាទី១ គឺជាជោគជ័យមួយ ។ គេបានប្រារព្ធធ្វើបុណ្យជ័យជម្នះ គេស្រែកអបអរសាទរ លន់ នល់ ដែលជាមេបញ្ជាការនៃប្រតិបត្តិការសឹកនេះ ។ ក្រុងភ្នំពេញបានបណ្តោលខ្លួនឲ្យលង់លក់ក្នុងការយល់ច្រឡំថា ពួកវៀតណាមបានត្រូវវាយឲ្យបរាជ័យហើយ ។ នៅដើមឆ្នាំថ្មី កងទាហានពិសេស (តាមភាសាវៀតណាមគេហៅពួកដាតកុង) ចំនួនប្រមាណមួយរយថ្វាយនាក់ បានវាយប្រហារចូលអាកាសយានដ្ឋានពោធិចិនតុងនៅថ្ងៃទី២១ ខែមករា ឆ្នាំ១៩៧១ ហើយបានកម្ទេចយន្តហោះភាគច្រើនដែលគេដាក់ក្នុងរោងបង្ហាទាំងឡាយ (រោងសម្រាប់ទុកយន្តហោះ) ជាពិសេស យន្តហោះប្រដេញប្រតិកម្មធុនមិក-១៩ អស់ជាច្រើនគ្រឿង ។ ជ័យជម្នះនៃប្រតិបត្តិការសឹកចេនឡាទី១ បានផុសឡើងឲ្យឃើញសម្រាប់ទីក្រុងមួយ ដែលត្រូវធ្វើឲ្យមានភាពស្រឡាំងកាំងទៅវិញ ។ នៅទីក្រុងនេះ និងនៅទីឯទៀតៗ គេចាប់ផ្តើមចង់ដឹងពីការចេញដំណើររបស់ លន់ នល់ ពីប្រទេស ។

ភ័ព្វវាសនាបានកើតឡើងក្នុងពេលចន្លោះនោះ ។ នៅថ្ងៃទី៩ ខែកុម្ភៈ លន់ នល់ បានរងនូវការឈឺស្ដឹកមួយចំហៀងខ្លួន ហើយគេបានសាកសួរគ្នាថា តើគាត់អាចរស់រានមានជីវិតជាមួយការបាត់បង់សមត្ថភាពខាងផ្លូវកាយ

និងផ្លូវចិត្តបានដែរឬទេ? គាត់បានចាកចេញពីប្រទេស ហើយត្រូវគេដឹកយកទៅកាន់មន្ទីរពេទ្យអាមេរិកាំងមួយនៅទីក្រុងហូណូលូលូ (Honolulu) កោះហាវ៉ៃ (Hawaï) ។ សិរិមតៈ បានឡើងកាន់ចង្កូតដឹកនាំប្រទេសជាបណ្ដោះអាសន្ន ។ បន្ទាប់ពីការចេញដំណើររបស់ លន់ នល់ មានលេចចេញពាក្យចចាមអារ៉ាមស្ដីពីរដ្ឋប្រហារយោធាបានលាន់ឮសុសសាយគ្រប់ទិសទី ហើយពួកអាមេរិកាំងទំនងជាបង្ហាញឲ្យឃើញការប្រុងប្រៀបខ្លួនជាស្រេចដើម្បីពិភាក្សាអំពីការផ្លាស់ប្ដូរមួយ ទាំងក្បាលម៉ាស៊ីនដឹកនាំរដ្ឋាភិបាល ក៏ដូចការរៀបចំនៅសមរភូមិប្រយុទ្ធ ។

តាមប្រហែល នេះជាការជ្រើសរើសរវាងពួកនាយទាហានទាន់សម័យ និងអ្នកនយោបាយទំនើបមានដូចជា សិរិមតៈ ជាដើម ។ បន្ទាប់មក លន់ នល់ បានវិលត្រឡប់មកវិញនៅពាក់កណ្ដាលខែមេសា ដោយមានជំងឺស្លាប់មួយចំហៀងខ្លួន ប៉ុន្តែ ពុំមានខូចខាតប្រាជ្ញាស្មារតីឡើយ ។ មនុស្សគ្រប់គ្នា រួមទាំងអាមេរិកផង បានសន្និដ្ឋានថា គាត់នឹងប្រគល់អំណាចដែលមានពិតៗទៅឲ្យ សិរិមតៈ ហើយនឹងកាន់កាប់មុខងារពិធីការមួយក្នុងឋានៈជាប្រមុខរដ្ឋម្នាក់ ។ លោក អេម៉ូរី ស្វាំង (Emory Swank) ជាឯកអគ្គរដ្ឋទូត អាមេរិកាំងបានបញ្ចេញគំនិតប្រាប់ក្រុងវ៉ាស៊ីនតោនថា «ជាក់ស្ដែងគាត់ត្រូវធ្វើឲ្យចាញ់ប្រៀបច្រើនណាស់ សម្រាប់ប្រឈមនឹងអ្វីដែលគេត្រូវការពីនាយករដ្ឋមន្ត្រីម្នាក់[១៨] បើនិយាយអំពីប្រាជ្ញាស្មារតី និងការរំជួលចិត្ត ។

មនុស្សទាំងអស់បានច្រឡំ ៈ លន់ នល់ មានលក្ខណៈបេ្តជ្ញាចិត្តជាងពេលណាៗទាំងអស់ ដើម្បីដឹកនាំធ្វើសង្គ្រាមសាសនារបស់គាត់ ។ ជាបន្ទាន់ភ្លាមនោះ គាត់បានយកកងទ័ពមកកាន់ក្នុងដៃឡើងវិញ ហើយបានថ្លែងប្រកាសប្រាប់ពួកនាយទាហានរបស់គាត់ ដែលត្រូវធ្វើឲ្យងឿងឆ្ងល់ស្រឡាំងកាំងថា ពួកអស់លោកនឹងត្រូវរៀបចំធ្វើប្រតិបត្តិសឹកមួយឈ្មោះ ចេនឡាទី២ ដើម្បីសងសឹកចំពោះការវាយប្រហារបំបាក់មុខមកលើអាកាសយានដ្ឋាន ។ នាយទាហានម្នាក់ក្នុងចំណោមនោះ បាននិយាយរៀបរាប់ថា លន់ នល់ បានវាយតម្លៃពីពេលវេលាដើម្បី «ដាក់ទណ្ឌកម្មសត្រូវឲ្យសមនឹងកំហុស[១៩]» មកដល់ហើយ ។ លើកនេះ ជនកាន់អំណាចផ្ដាច់ការមានបំណងវាយបើកផ្លូវមួយដែលនាំឆ្ពោះទៅភាគខាងជើង គឺផ្លូវជាតិលេខ៦ ដើម្បីតភ្ជាប់ក្រុងភ្នំពេញទៅខេត្តកំពង់ធំ ជាធានីខេត្តស្ថិតនៅតំបន់សម្បូរស្រូវមួយ ហើយដែលក្រុងភ្នំពេញចាប់ផ្ដើមត្រូវការជាចាំបាច់ ។

សេនាធិការកងទ័ពបានប្រឆាំងជំទាស់យ៉ាងម៉ឺងម៉ាត់ ។ ពួកនាយទាហានបានឆ្លៀតឱកាស ក្នុងពេលដែល លន់ នល់ អវត្តមានប៉ុន្មានខែនេះ ដើម្បីជួសជុលការខូចខាតកាលពីឆ្នាំមុន ដោយខិតខំលើកទឹកចិត្តពលទាហានរបស់ខ្លួន និងពង្រឹងរចនាសម្ព័ន្ធកងទ័ពឲ្យរឹងតែរឹងមាំឡើងថែមទៀត ។ កិច្ចការរបស់គេ កំពុងរៀបចំចាប់ផ្ដើម ពួកគេបានឆ្លើយប្រាប់ លន់ នល់ ថា កងទ័ពនៅទន់ខ្សោយខ្លាំងណាស់បន្ទាប់ពីប្រតិបត្តិការសឹក ចេនឡាទី១ ។ កងទ័ពរបស់ពួកគេ នៅតែពុំបានទទួលការហ្វឹកហ្វឺនក្បួនយោធាចាំបាច់ដដែល ដើម្បីប្រឈមមុខនឹងកងទ័ពវៀតណាមខាងជើងដែលប្រកបដោយអាវុធយុទ្ធភ័ណ្ឌសម្បូរបែបជាង និងថ្មីកក្កុងការធ្វើចម្បាំងផង ។

បន្ទាប់មក ពួកនាយទាហានទាំងអស់បានចោទប្រកាន់ពីផែនការប្រយុទ្ធរបស់ លន់ នល់ ដែលមិនអាច

ការពារទ័ព ដូចដែលគាត់ធ្លាប់យល់ដដែល ។ លន់ នល់ ចង់ដាក់ពង្រាយទាហានរបស់គាត់តាមបណ្ដោយផ្លូវ ដោយគ្មានការទ្រទ្រង់ពីផ្នែកដឹកជញ្ជូនគ្រឿងសម្ភារសម្រាប់ផ្គត់ផ្គង់កងទ័ពឲ្យបានគ្រប់គ្រាន់ទាន់ពេល និងគ្មានផែនការផ្លាស់ប្ដូរកម្លាំង ដើម្បីវាយតបតទៅនឹងការការពារដែលពួកវៀតណាម នឹងប្រកាន់យកដោយដាក់ស្ដែងឡើយ គឺបំបែក និងកាត់ខ្សែទ័ពដ៏វែង និងដ៏ស្ដួចស្ដើងឲ្យដាច់ដាកង់ៗ ។ លន់ នល់ មិនព្រមស្ដាប់ការស្ដីបន្ទោសរបស់ពួកនាយទាហានគាត់សោះឡើយ ។ ហើយពួកនាយទាហានទាំងនេះជឿជាក់ថា ពួកអាមេរិកាំងនឹងរក្សាទុកគាត់ឲ្យនៅ កាន់អំណាចដដែល ហើយចាត់ទុកការគិតបម្រុងធ្វើរដ្ឋប្រហារ ឬធ្វើអ្វីផ្សេងទៀត នឹងត្រូវចោទប្រកាន់ថា ជាអំពើមួយប្រហាក់ប្រហែលនឹងអំពើក្បត់ដែរ ជាតវិយាបថឲ្យ«បាត់បង់ស្ថេរភាព»មួយ ដែលនឹងធ្វើឲ្យទៅឲ្យពួកកុម្មុយនិស្តឆ្លៀតទាញយកគុណប្រយោជន៍ប៉ុណ្ណោះ ។

លន់ នល់ បានឈ្នះក្នុងរឿងនេះ ព្រោះប្រតិបត្តិសឹកចេនឡាទី២ ត្រូវដាក់ឲ្យដំណើរការនៅចុងខែសីហា ឆ្នាំ ១៩៧១ ។ ការប្រយុទ្ធគ្នាបានបន្តក្នុងរយៈពេលជាងបីខែ ហើយបានបញ្ចប់នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧១ ជាមួយនឹងការវិនាសអន្តរាយ នៃខ្សែទ័ពដែលគេដាក់ពង្រាយតាមបណ្ដោយផ្លូវ ។ កងទ័ពដែលមានចំនួនប្រហែលហាសិបពាន់នាក់ បានត្រូវវៀតណាមកម្ចាត់ស្ទើរតែរលាយសូន្យ ក្នុងឋានៈជាអង្គទ័ពដែលមានការរៀបចំត្រឹមត្រូវ ។ កងទ័ពថ្មើរជើងឆ្នើមៗរបស់គាត់បានរលាយបាត់រូបរាង ។ ទ័ព៣០០០នាក់ ស្មើនឹងដប់កងវរសេនាតូចបានត្រូវសម្លាប់ ។ គ្រឿងសម្ភារបរិក្ខារសឹកសម្រាប់ទាហាន ម្ភៃកងវរសេនាតូច ជាពិសេសរថយន្តពាសដែក និងឡានកាមីញ៉ុង ដែលមានតម្លៃថ្លៃៗជាច្រើនគ្រឿង បានត្រូវបំផ្លាញខ្ទេចខ្ទី ។ នេះគឺជាគ្រោះមហន្តរាយមួយ ដែលបណ្ដាលឲ្យកងទ័ពទាំងមូលបាក់ស្មារតីជារៀងរហូត ។ ក្រោយមក មានកងពលធំ ឬកងពលតូចខ្លះបានដឹកនាំធ្វើការប្រយុទ្ធមួយប្រកបដោយវីរភាព ។ ឧត្ដមសេនីយ៍ទាំងឡាយ នឹងផ្ដើមធ្វើការវាយប្រហារជួយគាំទ្រជាច្រើន ហើយការពារទីតាំងនានារបស់ពួកគេយ៉ាងក្លាហានបំផុត ប៉ុន្តែ កងទ័ពទាំងមូលរបស់គាត់មិនដែលនឹកឃើញប្រតិបត្តិការសឹកចេនឡាទី២ ទាល់តែសោះ ។

ថ្វីបើគាត់ទទួលបរាជ័យ ក៏លន់ នល់ នៅរក្សាអំណាចរបស់គាត់លើកងទ័ពដដែល ។ ដោយត្រូវប្រឈមមុខនឹងបរាជ័យផ្សេងៗទៀត ពួកអាមេរិកាំងរឹតតែបង្ហាញឲ្យឃើញពីការសប្បាយចិត្តគ្រោងគិតពីការការផ្លាស់ប្ដូរមេដឹកនាំខ្លាំងឡើងៗ ។ ជាមួយនឹងកងទ័ពរបស់គាត់ និងការគាំទ្ររបស់សហរដ្ឋអាមេរិក លន់ នល់ បានវាយបកនឹងពួកអ្នកនយោបាយដែលមិនជឿថាគាត់មានសមត្ថភាពធ្វើកើត ។ បីខែបន្ទាប់ប្រតិបត្តិការសឹកចេនឡាទី២ គាត់បានដណ្ដើមកាន់មុខងារផ្សេងៗជាប្រមុខរដ្ឋ ដោយចិត្តឯងផ្អាករដ្ឋធម្មនុញ្ញ និងបញ្ជាឲ្យរំលាយរដ្ឋសភាជាតិចោលទៀត ។

ចេង ហេង ប្រមុខរដ្ឋមានតែឋានៈ បានសុំលាឈប់កាលពី បីថ្ងៃមុន ព្រោះគាត់អះអាងថា គាត់«លែងអាចប្រឈមមុខនឹងស្ថានការណ៍នយោបាយមួយ ដែលកាន់តែមានសភាពកាន់តែធ្ងន់ធ្ងរឡើងៗទៀតហើយ» ។

សិរិមតៈ ជាមនុស្សពិបាកកម្ចាត់ចេញបំផុត ប៉ុន្តែ នៅខែមិថុនា ឆ្នាំ១៩៧២ គាត់បានចាកចេញពីជួរពួកយុទ្ធិកជន ដែលមានតែឈ្មោះរបស់ លន់ នល់ ហើយបានបង្កើតគណបក្សថ្មីមួយ គឺគណបក្សសាធារណរដ្ឋនិយម ។ ក្រុមប្រឆាំងបានបែកខ្ញែកគ្នា ៖ គេគ្មានមធ្យោបាយផ្តួលរំលំមនុស្សម្នាក់ ដែលអាចអាងលើសេចក្តីស្មោះត្រង់របស់ពួកអាមេរិកាំងដែលជាអ្នកផ្តល់ប្រាក់កាសសម្រាប់ធ្វើសង្គ្រាម និងសេដ្ឋកិច្ចរបស់កម្ពុជា និងលើសេចក្តីស្មោះត្រង់របស់កងទ័ពដែលកំពុងប្រយុទ្ធនឹងសត្រូវឡើយ ។

ដោយជឿប្រាកដពីជ័យជម្នះមួយ លន់ នល់ បានចេញបញ្ជាឲ្យរៀបចំធ្វើការបោះឆ្នោត ។ ប៉ុន្តែ គាត់វិះតែត្រូវបាក់មុខទៅហើយដោយចាញ់អ្នកសេរីនិយមម្នាក់ឈ្មោះ អ៊ិន តាំ ដែលជាអ្នកបានទទួលជោគជ័យនៅក្រុងភ្នំពេញ ហើយប្រហែលជាអាចឈ្នះនៅតាមជនបទទៀតផង បើសិនជា លន់ នល់ មិនបានចាត់ឲ្យកងទ័ពទៅប្រមូល និងរាប់សន្លឹកឆ្នោតទេនោះ ។ ដោយទើសចិត្តចំពោះការបន្លំសន្លឹកឆ្នោតយ៉ាងជាក់ច្បាស់នេះ និងដោយទទួលបញ្ជាពីទីក្រុងវ៉ាស៊ីនតោនឲ្យរក្សាទុករដ្ឋាភិបាលឲ្យនៅទាំងមូលដដែល ឯកអគ្គរដ្ឋទូតអាមេរិកាំង បានចំណាយពេលវេលាពេញចុងឆ្នាំនោះ ក្នុងការបញ្ចុះបញ្ចូល អ៊ិន តាំ ជាសម្ងាត់ដោយស្នើឲ្យគាត់ព្រមចូលរួម ក្នុងរដ្ឋាភិបាល "ដែលត្រូវជ្រើសតាំងឡើង" ដើម្បីផ្តល់ឲ្យសាធារណរដ្ឋមានឯកភាពតែ "សម្បកក្រៅ" មួយ ។

អ៊ិន តាំ បានបដិសេធ ហើយបានអះអាងពីហេតុផលផ្សេងៗរបស់គាត់ប្រាប់ឯកអគ្គរដ្ឋទូតអាមេរិកាំង[២០] ថា ៖ លន់ នល់ ជាជនផ្តាច់ការពុករលួយម្នាក់ ជាមេទាហានគ្មានសមត្ថភាពម្នាក់ និងជាមនុស្សដែលគាត់ (អ៊ិន តាំ) គ្មានលទ្ធភាពធ្វើការជាមួយបានឡើយ កាលបើ លន់ នល់ យកពួក "អ្នកឱកាសនិយម" ដែលចូលចិត្តប្រព្រឹត្តអាក្រក់ៗ មកដាក់ជុំវិញខ្លួនគាត់ច្រើនពេក ។ ការវិនិច្ឆ័យនេះ ជាការវិនិច្ឆ័យមួយដោយត្រង់ៗគ្មានលាក់ និងថ្លៃថ្នូរបំផុតក្នុងចំណោមការវិនិច្ឆ័យជាច្រើន ដែលពួកអាមេរិកាំងក៏យល់ស្របពីរឿង លន់ នល់ ដូចគ្នាដែរ ប៉ុន្តែ គ្មានធ្វើអ្វីកើតទាំងអស់ ។ ក្រុងវ៉ាស៊ីនតោន ជិតបានសម្រេចកិច្ចព្រមព្រៀងសន្តិភាពមួយជាមួយពួកកុម្មុយនិស្តវៀតណាមណាស់ទៅហើយ ក្រែងមានសំណាងមួយដោះខ្លួនចេញពីឥណ្ឌូចិន ។

"សាធារណរដ្ឋខ្មែរ" មានសភាពដូចមនុស្សស្លាប់ កងទ័ពត្រូវវិនាសអន្តរាយ ។ ប៉ុន្តែ និចសុន បែរជាអន្ទះអន្ទែងចុះហត្ថលេខាលើសន្ធិសញ្ញាសន្តិភាពមួយ ដែលនឹងធ្វើឲ្យគាត់ដកខ្លួនចេញពីការទទួលខុសត្រូវ យកឈ្នះសង្គ្រាមឥណ្ឌូចិនលើកទី២ទាំងអស់ ។

គឺនៅខណៈនេះហើយ ដែល សាឡុត ស និងពួកខ្មែរក្រហមបានរៀបចំខ្លួនដឹកនាំធ្វើប្រតិបត្តិការលើសមរភូមិប្រយុទ្ធនៅតំបន់ខាងកើតវិញម្តង" ។

នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៧០ ជាថ្ងៃនៃការវាយលុកយ៉ាងធំដំបូងរបស់ពួកវៀតណាមខាងជើងនៅប្រទេសកម្ពុជា រហូតមកដល់ពាក់កណ្តាលឆ្នាំ១៩៧២ កងទ័ពដ៏តូចដែលគ្មានបទពិសោធន៍របស់ លន់ នល់ គោងតែប្រឈមមុខតតាំងនឹងកងទ័ពពូកែលើសគេនៅអាស៊ីអាគ្នេយ៍ គឺពួកវៀតណាមខាងជើង ។ ប៉ុន្តែ សម្តេច

ព្រះនរោត្តម សីហនុ បានអះអាងមិនថា គឺកងទ័ពរបស់ព្រះអង្គទេដែលបានធ្វើឲ្យកងទ័ពក្រុងភ្នំពេញទទួលបរាជ័យនោះ ។ ហេតុនេះ ពួកទាហានរបស់ លន់ នល់ បានដុះចិត្តស្អប់ខ្ពើម សម្តេច ព្រះនរោត្តម សីហនុ និងពាក្យភរភូតរបស់ព្រះអង្គ ដូចគ្នានឹងពួកខ្មែរក្រហមស្អប់ព្រះអង្គដែរ ។

ពួកកុម្មុយនិស្តកម្ពុជាបានឆ្លៀតទាញយកផលប្រយោជន៍ក្នុងរយៈពេលបីឆ្នាំ ដែលក្នុងកំឡុងពេលនេះពួកវៀតណាមខាងជើងបានចូលជួយប្រយុទ្ធនៅក្នុងការប្រយុទ្ធផ្សេងៗ ដើម្បីធ្វើឲ្យចំនួនកងទ័ពរបស់ពួកកុម្មុយនិស្តកម្ពុជាកើនពីដប់ប្រាំនៅសែសិបពាន់នាក់[២១] ។ ពួកកុម្មុយនិស្តកម្ពុជាបានរៀបចំកងទ័ពតាមរបៀបរបបត្រឹមត្រូវមួយ ដោយតម្លើងឋានន្តរសក្តិឲ្យនាយទាហានទាំងឡាយទៅតាមគុណសម្បត្តិរបស់គេ និងដោយរៀបចំឲ្យមនុស្សទាំងនោះបន្តការហាត់ហ្វឹកហ្វឺនមួយយ៉ាងពេញទំហឹងថែមទៀត ។ ជំនួយសំខាន់បំផុតដែលពួកវៀតណាមផ្តល់ទៅឲ្យពួកកុម្មុយនិស្តខ្មែរ គឺពេលវេលា ហើយពួកគេបានធ្វើឲ្យវាប្រើបានយូរថែមទៀត ។ ប្រដាប់ដោយអាវុធមិនល្អ ពួកគេបានពឹងផ្អែកលើអាវុធអាមេរិកាំង ដែលដណ្តើមបានពីសត្រូវ ក៏ដូចអាវុធដែលពួកចិន ឬពួកវៀតណាមបញ្ជូនមកឲ្យពួកគេដែរ ។ ប្លែកគ្នាអំពី លន់ នល់ ដែលទទួលបានជំនួយអាមេរិកាំងចំនួន ជាងមួយកោដិប្រាំមួយរយលានដុល្លារ ក្នុងរយៈពេលនៃសង្គ្រាម ឬខុសប្លែកពីពួកវៀតណាមខាងជើង ដែលសហភាពសូវៀតនិងប្រទេសចិនផ្តល់ឲ្យក្នុងមួយឆ្នាំស្មើនឹងទឹកប្រាក់មួយកោដិ[២២]ដុល្លានោះ ពួកខ្មែរក្រហម ត្រូវតែផ្គត់ផ្គង់ជីវភាពរបស់ខ្លួនខ្លះៗ ដោយប្រភពធនធានរបស់ពួកគេផ្ទាល់ ។

ពួកកុម្មុយនិស្តខ្មែរបានទិញថ្នាំពេទ្យ ប្រេងឥន្ធនៈ និងផលិតផលផ្សេងៗទៀតពីពួកនាយទាហាន ពុករលួយ និងពួកឈ្មួញដែលនៅខាងប៉ែក លន់ នល់ ដោយឲ្យបង់តម្លៃជាប្រាក់ដុល្លារដែលពួកគេរកបានពីការលក់កៅស៊ូតាមកិច្ចព្រមព្រៀងមួយស្មើរតែជួរការដែរជាមួយនឹងរដ្ឋាភិបាលក្រុងភ្នំពេញ ។ ដោយពិត ពួកខ្មែរក្រហមបានដណ្តើមកាន់កាប់ចម្ការកៅស៊ូទាំងអស់តាំងតែពីពេលចាប់ផ្តើមសង្គ្រាមម្ល៉េះ[២៣] ។ ពួកអតីតម្ចាស់កម្មសិទ្ធិនិងពួកអ្នកគ្រប់គ្រងបារាំង បានធ្វើកិច្ចចរចាជាមួយ លន់ នល់ និងពួកខុទ្ទាមខ្មែរក្រហមដើម្បីធ្វើកិច្ចសន្យាមួយដែលតាមរយៈនេះ ជ័រកៅស៊ូត្រូវ«លក់»មកឲ្យក្រុងភ្នំពេញ ជាកន្លែងសម្រាប់កែច្នៃមុននឹងយកទៅលក់នៅទីផ្សារអន្តរជាតិ ដោយបាក់ចំណេញទាំងអស់ត្រូវបែងចែកគ្នា ដោយឥតល្អៀងរវាងក្រុមដែលច្បាំងគ្នាទាំងពីរ ។ ក្នុងរដ្ឋធានី ពួកបារាំងបានស្ថាបនារោងចក្រកែច្នៃថ្មីៗជាច្រើនកន្លែងដែលពួកគេបានឲ្យដំណើរការពេញៗម្ភៃបួនម៉ោងក្នុងមួយថ្ងៃ ។ ក្នុងកំឡុងពេលសង្គ្រាម ជ័រកៅស៊ូគឺជាប្រភពផ្តល់រូបិយប័ណ្ណតែមួយគត់របស់ប្រទេសកម្ពុជា ។ ក្នុងរយៈពេលពីរឆ្នាំចុងក្រោយ នៅពេលដែលក្រុងភ្នំពេញ ត្រូវនាំចូលនូវអ្វីៗសឹងតែទាំងអស់នោះ ជ័រកៅស៊ូបានផ្តល់ចំណូលយ៉ាងហោច ក្នុងមួយឆ្នាំក៏ដប់លានដុល្លាដែរ[២៤] ។ ដូច្នេះរដ្ឋាភិបាល លន់ នល់ ត្រូវបង់ទៅឲ្យពួកខ្មែរនូវទឹកប្រាក់មួយចំនួនដែលពួកកុម្មុយនិស្តត្រូវយកទៅបង់តម្លៃទំនិញឲ្យពួកឈ្មួញ និងឲ្យវង្វាន់ពួកនាយទាហានដែលលោភលន់ទ្រព្យសម្បត្តិដែលរកអាវុធមកផ្តល់ឲ្យគេថែមទៀត ។

ថ្វីបើតួនាទីសំខាន់ត្រូវសម្តែងដោយពួកកងទ័ពវៀតណាមខាងជើងក៏ដោយ ក៏ពួកខ្មែរក្រហមសរសើរខ្លួនឯងពីស្វ័យភាពពេញលេញពី«ឯករាជ្យ និងអធិបតេយ្យ» របស់គេដែរ ។ ជាឯកជន ពួកខ្មែរក្រហមយល់ឃើញថា ពួកកុម្មុយនិស្តវៀតណាមបានវាយប្រយុទ្ធសម្រាប់តែផលប្រយោជន៍ផ្ទាល់របស់ពួកគេប៉ុណ្ណោះ គឺការពារ «ទីជម្រក»ទាំងឡាយ នៅប្រទេសកម្ពុជា ការពារច្រកផ្លូវមួយដើម្បីធានាដល់ការដឹកជញ្ជូនស្បៀងអាហារ និងគ្រឿងសម្ភារចាំបាច់ឲ្យកងទ័ពរបស់ពួកគេសម្រាប់ធ្វើការប្រយុទ្ធនៅវៀតណាមខាងត្បូង ។ ជាសម្ងាត់ សាឡុត ស ក៏រួមចំណែកក្នុងការព្រួយបារម្ភអំពីមហិច្ឆតារបស់ពួកវៀតណាមក្នុងតំបន់នេះ ដូច លន់ នល់ ដែរ ប៉ុន្តែ សាឡុត ស គិតថា ត្រូវទុកឲ្យពួកវៀតណាមនៅយូរបន្តិចទៀតសិន ដើម្បីបានពង្រឹងកងទ័ពផ្ទាល់របស់គាត់ បន្ទាប់មកទើបបណ្តេញពួកនេះចេញ ។ នៅក្នុងរយៈពេលនៃការជួបចរចាជាមួយសម្តេច ព្រះនរោត្តម សីហនុ នាទីក្រុងប៉េកាំង មេដឹកនាំខ្មែរក្រហមបានជួបពិភាក្សាជាមួយ ផាំ វ៉ាន់ដុង ដែរ ហើយបានជំទាស់នឹងសំណើមួយរបស់វៀតណាម ដែលសុំឲ្យរំលាយបញ្ចូលអំណាចបញ្ជាការ និងកងឯកភាពប្រយុទ្ធវៀតណាម-ខ្មែរ[២៥] ចូលគ្នាទាំងអស់ ។ ស បានអះអាងថា គាត់បានបដិសេធសំណើរបស់ក្រុងហាណូយក្នុងការបញ្ជូនទីប្រឹក្សាបច្ចេកទេស និងនយោបាយមកជួយរៀបចំ«តំបន់រំដោះ»ទាំងឡាយ នៅប្រទេសកម្ពុជា ប៉ុន្តែ សាក្សីដែលបានឃើញផ្ទាល់ភ្នែកជាច្រើននាក់ បានរាយការណ៍ឲ្យដឹងថា ពួកវៀតណាមមានធ្វើជាមេគេខ្លះ នៅតំបន់ដ៏ធំល្វឹងល្វើយរបស់ប្រទេសក្នុងបណ្តាខែដំបូងៗនៃសង្គ្រាម[២៦] ។

ស្ថានភាពបែបនេះមិនតម្រូវឲ្យគេពន្យារពេលយូរតទៅទៀតឡើយ ។ នៅឆ្នាំ១៩៧១ ពួកខ្មែរក្រហមយល់ថា ខ្លួនមានកម្លាំងគ្រប់គ្រាន់ហើយដើម្បីដំណើរការនូវកម្មវិធី «វិសុទ្ធកម្ម» ផ្ទាល់របស់គេ ហើយដូច លន់ នល់ ដែរ ជាដំបូងពួកគេបានរករឿងអាណិកជនវៀតណាមកំពុងរស់នៅតាមតំបន់នានា ដែលពួកគេគ្រប់គ្រងនៅភាគខាងកើតប្រទេសកម្ពុជា[២៧] ។ ដោយយកលេសពីការរួមគំនិតក្បត់មួយរបស់វៀតណាម ដែលជារឿងមិនសូវច្បាស់លាស់ ពួកខ្មែរក្រហមបានដកហូតអាវុធពីប្រជាជនស៊ីវិលវៀតណាមទាំងអស់ ។ អ្នកខ្លះត្រូវចាប់ខ្លួន ខ្លះទៀតត្រូវសម្លាប់ចោល ហើយមានជាច្រើននាក់បានបោះបង់ផ្ទះ កសិដ្ឋាន ឬភូមិនេសាទរបស់គេ ដើម្បីរត់គេចទៅនៅប្រទេសវៀតណាមវិញ ។ រឿងទាំងនោះបានប្រព្រឹត្តទៅដោយស្ងាត់កំបាំងបំផុត ។ នៅក្នុងប្រទេស ពុំមានអ្នកតំណាងកាសែតអន្តរជាតិប្រចាំនៅនឹងកន្លែងទេ ហើយទោះជាយ៉ាងណាក៏ដោយ បើក្រុងហាណូយដឹង ក៏គ្មានសេចក្តីថ្លែងការណ៍ជាសាធារណៈដែរ ។

តមកទៀត ពួកខ្មែរក្រហមបានយកចិត្តទុកដាក់នឹងពួកកុម្មុយនិស្តខ្មែររាប់រយនាក់ ដែលវិលត្រឡប់ពីវៀតណាមខាងជើងមកវិញ ក្រោយពីការនិរទេសខ្លួនរយៈពេលដប់ប្រាំឆ្នាំ ដើម្បីចូលរួមធ្វើបដិវត្តន៍ក្នុងឆ្នាំ១៩៧០ ។ បក្សរបស់ ស គ្មានទុកចិត្ត «សមមិត្ត» ទាំងអស់នោះទេ ហើយពួកគេបានចាត់ទុកជាសម្ងាត់ថា «ពួកក្បាលយួនខ្លួនខ្មែរ» ។ ប៉ុន្តែ ពួកនេះត្រូវបានបញ្ជូនឲ្យមកប្រទេសកម្ពុជាវិញ ដើម្បីបង្រួបបង្រួមចលនា ដែលបែក

បាក់គ្នាឡើងវិញ ។ នៅពេលមកដល់ ពួកគេត្រូវបានទទួលស្វាគមន៍នៅភាគគ្នាសានដោយ អៀង សារី ដែលមើលខុសត្រូវដោយខ្លួនឯងក្នុងចាត់តាំងឲ្យកាន់មុខតំណែងផ្សេងៗ ក្រោមបង្គាប់គេទាំងអស់ ។ ពួកកុម្មុយនិស្តទាំងនេះដែលគេស្គាល់ក្រោមឈ្មោះថា "ពួកមាតុភូមិនិវត្ត" នោះបានត្រូវ សឹង ង៉ុកមិញ និយាយដាស់តឿនដោយផ្ទាល់នៅទីក្រុងហាណូយថា ពួកគេនឹងជួបប្រទះស្ថានភាពស្មុគស្មាញលំបាកដោះស្រាយជាមិនខាន ។ ជនម្នាក់ក្នុងចំណោមអ្នកដែលគេបញ្ជូនមកមាតុភូមិទាំងនេះ នៅនឹកឃើញថា "សឹង ង៉ុកមិញ ធ្លាប់បញ្ជាក់ប្រាប់ថា ជនរួមជាតិដែលកំពុងវិលត្រឡប់ទៅប្រទេសកម្ពុជាវិញ នឹងពើបប្រទះការលំបាកស្មុគស្មាញផ្សេងៗ ព្រោះតែភាពមិនចុះសម្រុងគ្នារវាងពួកអ្នកនៅក្នុងប្រទេស និងពួកអ្នកធ្លាប់សិក្សានៅបរទេស... សឹង ង៉ុកមិញ បានផ្ដែផ្ដាំថា នៅពេលទៅដល់ប្រទេសវិញ សូមកុំឲ្យពួកយើងទាមទារអ្វីឲ្យសោះ... គឺសូមឲ្យយើងពេញចិត្តនឹងភារកិច្ចទាំងឡាយដែលគេប្រគល់ឲ្យ[២៨] យើងបំពេញ" ។

សាឡុត ស បានបញ្ចេញឲ្យឃើញជាថ្មី ដែលអាចប្រើប្រាស់បណ្ដាសត្រូវរបស់គាត់ក្នុងការបម្រើផលប្រយោជន៍គាត់មុននឹងកម្ចាត់ពួកនោះឲ្យសាបសូន្យ ។ ពួកមាតុភូមិនិវត្តដែលពួកវៀតណាមធ្លាប់បណ្ដុះបណ្ដាលខាងផ្នែកយោធាផ្សេងៗពីគ្នានោះ បានត្រូវផ្ទុកផ្ដាក់ឲ្យជួយបង្កើតកងទ័ពខ្មែរក្រហម ។ បើទុកណាជាគាត់បដិសេធការបង្កើតកងឯកភាពចម្រុះវៀតណាម-ខ្មែរ ប្រហែលពីព្រោះថា ក្នុងកំឡុងពេលសង្គ្រាមឥណ្ឌូចិនលើកទី១ គឺមានសុទ្ធតែពួកវៀតណាមដែលជាអ្នកដឹកនាំបញ្ជាកងឯកភាពបែបនោះក៏ដោយ ក៏ ស បានត្រៀម បម្រុងឆ្លៀតទាញយកប្រយោជន៍ពីពួកខ្មែរទាំងនេះ ដែលបណ្ដុះបណ្ដាលដោយក្រុងហាណូយដែរ ។ មានពួកមាតុភូមិនិវត្តតិចតួចណាស់ ដែលគេអនុញ្ញាតឲ្យកាន់តំណែងសំខាន់ៗ តែពួកគេត្រូវធ្លាក់ពីមុខតំណែងនេះជាបន្តបន្ទាប់ ។ ភាគច្រើនដឹងខ្លួនឯងថា រស់នៅឯកោគ្មានអ្នកណារាប់រក តាមការពិត ទោះជាករណីនេះ ជាករណីមួយសម្រាប់ជនកុម្មុយនិស្តជាទូទៅក៏ដោយ ។ ជនមាតុភូមិនិវត្តដដែលនេះ បាននិយាយទៀតថា "ការទាក់ទងផ្សេងៗរវាងថ្នាក់លើ និងថ្នាក់ក្រោម គឺប្រៀបដូចរវាងមេឃ និងដី ។ សមមិត្តម្នាក់ស្គាល់តែអ្នកណាមួយដែលមានការទាក់ទងនឹងគេប៉ុណ្ណោះ ។ គ្មានរឿងត្រូវធ្វើចេះធ្វើដឹង អំពីស្ថានភាពដែលខ្លួន បានជួបប្រទះឡើយ ទោះជារឿងនោះជារឿងអ្វីក៏ដោយ[២៩]" ។

ក្នុងចំណោមអ្នកធ្វើមាតុភូមិនិវត្តន៍មានម្នាក់ឈ្មោះ អៀង លីម[៣០] ជាយុវជនកម្ពុជាស្និទ្ធកុម្មុយនិស្តម្នាក់ដែលបានចាកចេញពីប្រទេសខ្លួននៅឆ្នាំ១៩៥៥ តាមការរៀបចំរបស់ពួកវៀតណាម ដោយក្លែងខ្លួនជាពលទាហានវៀតណាម ដើម្បីជៀសវាងពីលក្ខខ័ណ្ឌកំណត់ ដែលបង្កើតឡើងដោយគណៈកម្មាធិការអន្តរជាតិខាងបទគ្រួតត្រាតាមកិច្ចព្រមព្រៀងក្រុងហ្សឺណែវ នៅពេលឡើងជិះកប៉ាល់ប៉ូឡូញមួយគ្រឿង ធ្វើដំណើរឆ្ពោះទៅវៀតណាមខាងជើង ។ នៅឆ្នាំ១៩៧០ គាត់បានវិលត្រឡប់មកកម្ពុជាវិញ នៅពេលសង្គ្រាមចាប់ផ្ដើមដំបូង

ដោយទុកប្រពន្ធជាតិវៀតណាមរបស់គាត់នៅភាគខាងជើងវៀតណាម ។ សឺង ង៉ុកមិញ ដែលគាត់ជឿថា ជាមេដឹកនាំបក្សកុម្មុយនិស្តរបស់កម្ពុជា បានណែនាំឲ្យគាត់គោរពធ្វើតាមបទបញ្ជាផ្សេងៗរបស់បក្ស កាលបើគាត់ឆ្លងចូលទៅក្នុងប្រទេសកម្ពុជាហើយ ។ លីម និងក្រុមរបស់គាត់បានធ្វើដំណើរមកកាន់ប្រទេសវិញដោយចុះតាមផ្លូវលំ ហូ ជីមិញ ក្នុងរយៈពេលនៃការធ្វើដំណើរមួយដ៏សែនលំបាក និងប្រកបដោយគ្រោះថ្នាក់មួយចំនួនបីខែ ។

នៅប្រទេសកម្ពុជា គាត់បានជួបប្រទះនឹងអរិភាពមួយ ដែលបង្កឡើងដោយការបែងចែកបក្សជាពីរពួកក្នុងកំឡុងពេលដប់ប្រាំឆ្នាំ និងភាពជាសត្រូវមួយដែលរីកកាន់តែធំឡើងរវាងពួកខ្មែរក្រហម និងពួកវៀតណាម ។ ពេកមកដល់ប្រទេសនៅខែកញ្ញា គាត់បានត្រូវគេចាត់តាំង ពីរ-បីខែក្រោយមកឲ្យធ្វើជាមេដឹកនាំកង ឯកភាពមួយ ដែលមានពួកខ្មែរក្រហម សាមសិបនាក់ ។ គាត់បានបង្ហាត់ក្បួនយុទ្ធសាស្ត្រឲ្យកូនទាហានទាំងនេះ និងបានចូលរួមក្នុងការប្រយុទ្ធជាច្រើនលើក ជាពិសេសនៅក្នុងខេត្តកំពង់ធំ ។ គាត់ឃើញកងទ័ពខ្មែរក្រហម និងវៀតណាមចូលប្រយុទ្ធ កត់ចំណាំពីភាពអន់គម្រក់របស់កងទ័ពក្រុងភ្នំពេញ និងយល់ពីមារ៉ាធំៗរបស់បដិវត្តន៍ ហើយសន្និដ្ឋានថា ខ្លួនគាត់ផ្ទាល់ និងអ្នកធ្វើមាតុភូមិនិវត្តន៍ឯទៀតៗ សុទ្ធតែបានធ្លាក់ទៅក្នុងស្ថានភាពពិបាកដោះខ្លួនដូចៗគ្នា ។

លីម បាននិយាយថា គាត់មានសេចក្តីភ័យខ្លាចពួកវៀតណាមខាងជើងដែលខំប្រឹងត្រួតត្រាពួកកម្ពុជាដូចពួកគេត្រួតត្រាពួកកុម្មុយនិស្តឡាវដែរ ដោយចាត់ទុកជាអ្នកបដិវត្តប្រភេទថ្មី ។ តាំងពីឆ្នាំ១៩៧០ លីម បានដឹងដោយខ្លួនឯងថា ទំនាក់ទំនងផ្សេងៗរវាងពួកកុម្មុយនិស្តខ្មែរ និងវៀតណាមពុំ«ល្អប្រសើរ»ទេ ។ គាត់ពុំបានវាយតម្លៃអំពីទំនាក់ទំនងផ្សេងៗរវាងពួកកុម្មុយនិស្ត និងប្រជាជនកម្ពុជាយូរទៅទៀតឡើយ ហើយគាត់សន្និដ្ឋានថាពួកខ្មែរក្រហមអាចយកឈ្នះសង្គ្រាមបាន ប៉ុន្តែ ពុំមានការរួបរួមរបស់ប្រជាជនទេ ។ ថ្ងៃមួយ គាត់ត្រូវតែរារាំងពួកខ្មែរក្រហមដោយផ្ទាល់ខ្លួនឯង មិនឲ្យសម្លាប់ប្រជាជនស៊ីវិល នៅបារាយណ៍ក្នុងខេត្តកំពង់ធំ ជាកន្លែងដែលគេបានសម្លាប់កសិករអស់ជាច្រើននាក់ ព្រោះតែប្រព្រឹត្តបទល្មើសកំប៉ិកកំប៉ុក ។

លីម បានដឹងយ៉ាងឆាប់រហ័សថា សម្តេច ព្រះនរោត្តម សីហនុ ក៏ពួកខ្មែរក្រហមមិនសូវចូលចិត្តដែរ ព្រោះពួកនេះ ពាក់រូបសញ្ញារបស់ព្រះអង្គតែនៅពេលណាដែលគេបញ្ជូនឲ្យទៅបំពេញក្នុងជួរទ័ពវៀតណាមខាងជើងប៉ុណ្ណោះ ។ ក្នុងចំណោមគ្នាគាត់ (ខ្មែរក្រហម) ពួកគេនិយាយដើមសម្តេចដោយភាពល្វីងជូរចត់បំផុត ។

បន្តិចម្តងៗ លីម បាត់បង់សេចក្តីសង្ឃឹមទាំងស្រុងអំពីការបដិវត្តមួយរបស់ខ្មែរ ។ គាត់ធ្លាប់បានរស់នៅវៀតណាមខាងជើងចំនួន ដប់ប្រាំមួយឆ្នាំ រង់ចាំធ្វើការប្រយុទ្ធដើម្បី«រំដោះ»មាតុភូមិរបស់ខ្លួន ហើយនៅទីបំផុតគាត់រកឃើញថា សង្គ្រាមនៅប្រទេសកម្ពុជាផ្តល់អត្ថប្រយោជន៍» ជាសំខាន់ដល់ប្រទេសវៀតណាមខាងជើង គឺពុំមែនដល់ការបដិវត្តខ្មែរ ដែលគាត់ធ្លាប់ឮគេនិយាយជាញឹកញាប់នោះទេ» គឺនៅឆ្នាំ១៩៧១ ក្រោយការមកដល់របស់គាត់មួយឆ្នាំ ។ គាត់បានដំណាលថា ជាមួយកងឯកភាពរបស់គាត់ គាត់បានចូលប្រយុទ្ធនៅភាគខាងជើងខេត្តកំពង់ធំ ហើយត្រូវកងឯកភាពវៀតណាមខាងជើងមួយ ដកថយ រត់ចោល ដោយគ្មានប្រាប់ឲ្យគ្នាគាត់ដឹង

ជាមុនឡើយ ។

ដោយពុំអាចរស់នៅក្នុងសភាពបោកបញ្ឆោត និងការស្រងាកចិត្ត លីម បានរត់មកសុំចុះចូលខាងពួក លន់ នល់ ប្រាំថ្ងៃបន្ទាប់ពីការប្រយុទ្ធនេះ ។ គាត់បានត្រូវសាកសួរដោយនាយទាហានស៊ើបការណ៍នៃស្ថានទូតអាមេរិកាំង ដែលធ្វើឲ្យគេរំជួលចិត្តចំពោះការភ័យខ្លាចរបស់គាត់ គឺការភ័យខ្លាចនឹងអំពើឃោរឃៅរបស់ពួកខ្មែរក្រហម ឬកពាក្រអឺតក្រអោង និងមហិច្ឆតារបស់ពួកវៀតណាម ចំនួនអ្នករងគ្រោះដែលនឹងត្រូវគេបំភ្លេចចោល បន្ទាប់ពីសង្គ្រាមដ៏ប្រឫកប្របល់នេះ ដែលបណ្តាសម្ព័ន្ធមិត្តសុទ្ធតែជាសត្រូវ និងជាសត្រូវរបស់ពួកសម្ព័ន្ធមិត្ត ។ គាត់គ្មានយល់ច្រឡំសោះរវាងកងទ័ពរបស់ លន់ នល់ ដែលកូនទាហានបង្ហាញឲ្យឃើញភាពកំសាក ហើយពួកនាយទាហានសុទ្ធតែមានសមត្ថភាពអន់គម្រក់ ។ ក្នុងការដំណាលរឿងដែល លីម វាយតម្លៃពីសង្គ្រាមគឺពុំមានតួអង្គជាវីរជនទេ ។

នៅពេលដែលពួកកុម្មុយនិស្តកម្ពុជាទទួលដឹកនាំទាំងស្រុង ក្នុងការហើយទៅធ្វើសង្គ្រាម ពេលដែលពួកវៀតណាមដកថយទៅកាន់តំបន់ព្រំដែន និងត្រឡប់ទៅធ្វើសង្គ្រាមផ្ទាល់របស់ខ្លួននៅឆ្នាំ១៩៧៣វិញនោះ ពួកអ្នកធ្វើមាតុភូមិនិវត្តបានត្រូវគេតាមដានយ៉ាងស្អិត ហើយនៅឆ្នាំ១៩៧៥ ភាគច្រើនក្នុងចំណោមអ្នកទាំងនោះបានត្រូវគេសម្លាប់រង្គាល ។

ការកាប់សម្លាប់បំបាត់ពូជសាសន៍ ប្រឆាំងនឹងអាណិកជនវៀតណាម និង«ពួកក្បាលយួនខ្លួនខ្មែរ» គឺអាងលើទ្រឹស្តីនយោបាយមួយ ដូចគ្នានឹងទ្រឹស្តីនយោបាយដែលនាំឲ្យមានការសម្លាប់បំបាត់ពូជសាសន៍របស់ លន់ នល់ ដែរ ។ សាឡុត ស និងពួកខ្មែរក្រហម បានផ្តើមនិយាយដូចគ្នាក្នុងនាមនៃពូជសាសន៍ និងប្រជាជាតិខ្មែរ ប៉ុន្តែពួកខ្មែរក្រហមបាននិយាយទៅកាន់ហ្វូងអ្នកស្តាប់មួយដែលងាយចាប់អារម្មណ៍ជាងគេ គឺប្រជាកសិករនេះឯង ។ ក្នុងរយៈពេលបីឆ្នាំដំបូង ពួកគេបានសម្តែងឲ្យឃើញលក្ខណៈនិយមផ្លូវកណ្តាល ក្នុងសេចក្តីថ្លែងការណ៍ផ្សេងៗរបស់គេប្រហែលដោយសារឥទ្ធិពលគ្របសង្កត់ក្នុងរយៈពេលដ៏យូរ របស់កងទ័ពវៀតណាមខាងជើង និងពីព្រោះពួកគេចង់ឆ្លៀតទាញយកប្រយោជន៍អំពីសំណល់ប្រជាប្រិយភាពរបស់សម្តេច ព្រះនរោត្តម សីហនុ ដើម្បីជ្រើសរើសពួក កសិករមុនៗដែលធ្លាប់ស្មោះត្រង់នឹង ទេវរាជា អង្គនេះ ឲ្យចូលធ្វើទ័ពរបស់គេហើយមើលទៅ ។ ពួកខ្មែរក្រហមបានរួមផ្សំការអំពាវនាវអំពីមោទនភាពជាតិ និងសេចក្តីបញ្ញត្តិរបស់កុម្មុយនិស្ត ដើម្បីធ្វើឲ្យមានយុត្តិធម៌ខាង សេដ្ឋកិច្ច និងនយោបាយដ៏ទូលំទូលាយមួយ ។ គឺជាលើកដំបូងហើយក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជាដែលគេត្រូវការប្រជាជននៅជនបទឲ្យសម្តែងតួនាទីដ៏សំខាន់មួយក្នុងការផ្លាស់ប្តូរនៃសង្គម ហើយលទ្ធផល គឺទទួលបានខ្លាំងមែនទែន ។

ការលាយបញ្ចូលបញ្ញវន្ត និងកសិករនេះ បង្ហាញឲ្យឃើញថាជាការលាយរបស់ពីរយ៉ាងដែលនាំឲ្យផ្ទុះ[៣១] ។ ពួកបញ្ញវន្ត ខ្មែរក្រហមធ្វើជាប្រកាន់អាកប្បកិរិយាក្រអឺតក្រទមថា ពួកគេជាមេដឹកនាំកម្ពុជាដំបូង ដែលជំពាក់ចិត្ត

ខ្លាំង នឹងបុព្វហេតុរបស់ប្រជាកសិករ ព្រោះ៩០ភាគរយនៃប្រជាជនទាំងនេះ រស់នៅយ៉ាងកម្សត់កម្របំផុត នៅពេលដែលពិភពលោកចាត់ទុកប្រទេសកម្ពុជាជាឋានសួគ៌មួយ» នេះបើតាមសម្ដីរបស់ ជួន ប្រសិទ្ធិ ។ ជាបឋម ពួកមេៗទាំងនោះប្រហែលជាមានការបន្លាញដើមហេតុដែលគិតឃើញតែប្រយោជន៍ឯង ប៉ុន្តែ ក្នុងលំដាប់ដែលសង្គ្រាមរីករាលដាល ដែលពលិកម្មផ្សេងៗកើនច្រើនឡើង ពួកបញ្ញវន្ត និងពួកកសិករ បានរកឃើញជាមួយនឹងភាពរន្ធត់ថា ពួកគេបានចិញ្ចឹមនូវការស្អប់ខ្ពើមពិបាកដោះស្រាយមួយតែរៀងៗខ្លួន ។

ការមិនទុកចិត្តដែលមានតាំងពីមុនមករបស់ប្រជាកសិករចំពោះទីក្រុង អ្នកប្រមូលពន្ធដារ និងពួកបញ្ញវន្ត បានរួមផ្សំទ្រឹស្ដីផ្សេងៗរបស់ខ្មែរក្រហម តាមប្រព័ន្ធសេដ្ឋកិច្ចអន្តរជាតិ ហើយអានុភាពបំផ្លិចបំផ្លាញរបស់វាមកលើពាណិជ្ជកម្មក្នុងស្រុក ការលោភលន់របស់ចក្រពត្តិនិយម និងតួនាទីដែលទីក្រុង បណ្ដាបុគ្គលិករដ្ឋការ បណ្ដាវណ្ណៈកណ្ដាល និងពួកបញ្ញវន្តខំបំពេញជាផ្នូរនឹងជំនួយរបស់ពួកចក្រពត្តិ និងសហគ្រាសពាណិជ្ជកម្មនានាឲ្យគាបសង្កត់ប្រជាកសិករ ។ ពួកខ្មែរក្រហម និងកសិករ បានចុះសម្រុងគ្នាដោយងាយស្រួលបើគុណសម្បត្តិខ្ពង់ខ្ពស់នៃសកម្មភាពស្ដីពីការយល់ដឹងដែលបានមកពីសៀវភៅ ឬការយល់ដឹងរបស់ហត្ថពលករ ដែលកំពុងធ្វើការយ៉ាងលំបាកលើពួកឈ្មួញវៃឆ្លាត និងពួកនិយោជិតដែលពេញទៅដោយជីវភាពស្រួលស្រណុក ។ ត្រូវលើកទឹកចិត្តដោយការអំពាវនាវរបស់ សាឡុត ស ក្នុងការរៀបចំធ្វើឲ្យភាពខ្ពង់ខ្ពស់របស់ប្រជាជាតិខ្មែររីកត្រកុំត្រកាលឡើងវិញ កសិករទាំងនេះបានរួមបង្កើតជាមូលដ្ឋានមនុស្សដែលផុសចេញមកពីខាងក្នុងចិត្តរបស់ការបដិវត្តន៍ និងលទ្ធិផ្ដល់ការដែលភាពខ្ពង់ខ្ពស់ជាអ្នកបណ្ដាលឲ្យមានឡើង ។

កសិករទាំងឡាយគ្រាន់តែនយោបាយសើៗប៉ុណ្ណោះ ។ ពួកគេធ្លាប់ជា «មនុស្សនៅក្នុងការជួយឧបត្ថម្ភ» របស់សម្ដេច ព្រះនរោត្តម សីហនុ ដែលជាអ្នកស្រាល់ជ្រើសអ្នកតំណាងរបស់ពួកគេ និងឃ្លាំមើលមិនឲ្យពួកនេះមានទំនាក់ទំនងណាមួយជាមួយអ្នកទាំងនោះឡើយ ។ សម្ដេចបានដកយកប្រាក់ពីថវិការបស់ប្រជាជាតិ ដើម្បីផ្គត់ផ្គង់ការចាត់ចែងផ្នែកសង្គហសង្គ្រោះរបស់ព្រះអង្គផ្ទាល់ និងសម្រាប់យាងទៅធ្វើទស្សនកិច្ចក្នុងរយៈពេលខ្លីៗតាមទីជនបទ ហើយនៅក្នុងឱកាសនោះ ព្រះអង្គបានចែកចាយសម្ភារបរិក្ខារផ្សេងៗ ឬកសាងមន្ទីរគិលានដ្ឋានជាច្រើនកន្លែង ។ សិករទាំងឡាយជាអ្នកបង់ពន្ធដារ ធ្វើស្រែ ឬចូលបម្រើក្នុងកងទ័ព ។ បើសិនពួកគេទទួលបានមុខតំណែងមួយក្នុងរដ្ឋបាលការរៀនសូត្រខ្ពស់ និងឈានឡើងដល់វណ្ណៈកណ្ដាលបាន គឺបន្ទាប់ពីគេលុបបំបាត់ចរិតកសិកររបស់ខ្លួនចោលតែប៉ុណ្ណោះ ។ ដោយចាក់ទាញការជួយគាំទ្ររបស់ប្រជាកសិករ ដោយរៀបចំឲ្យមានការបោះឆ្នោតជ្រើសរើសប្រធានភូមិនានានៅតាមបណ្ដាតំបន់ ដែលពួកគេត្រួតត្រា និងដោយសន្យាធ្វើតាមកម្មវិធីផ្នែកកសិកម្មរបស់ ហ៊ូ យន់ ពួកកុម្មុយនិស្តបានប្រើសាកនូវកម្លាំងទាញស្រូបមួយទៅលើប្រជាកសិករ ។

នេះជាសម័យអន្តរកាល ដែលក្នុងរយៈពេលនេះពួកកុម្មុយនិស្តកម្ពុជាបានបណ្ដោយឲ្យកងទ័ពវៀតណាមខាងជើងវាយប្រយុទ្ធនឹងកងទ័ព លន់ នល់ សិន ហើយប្រមូលផ្ដុំកិច្ចប្រឹងប្រែងទាំងអស់របស់គេជាមួយប្រជា

កសិករវិញ ។ នៅខែកក្កដា ឆ្នាំ១៩៧១ ពួកគេបានប្រារព្ធបើកមហាសន្និបាតមួយដែលក្នុងឱកាសនោះ ពួកគេបានសម្រេចចិត្តឆ្លងទៅដំណាក់កាលបន្ទាប់ទៀត នៅពេលដែលពួកគេនឹងត្រូវជំនួសពួកវៀតណាមនៅលើសមរភូមិ ។ នៅពេលដែលពួកគេចាប់ផ្តើមធ្វើការវាយប្រយុទ្ធ ស្ថានភាពរបស់គេនៅពេលនោះ គឺមានសភាពផ្ទុយគ្នាស្រឡះ ពីស្ថានភាពឆ្នាំ១៩៦៧ ។ នៅឆ្នាំ១៩៦៧ កម្លាំងសំខាន់ៗរបស់ពួកគេស្ថិតនៅក្នុងរាជធានី ហើយនៅជនបទគឺមានតែក្រុមតស៊ូតូចៗ ដែលមានពិតប្រាកដ ឬដែលមិនទាន់ចេញជាក់ស្តែង និងពួកអ្នកដែលមានសមានចិត្តនឹងកុម្មុយនិស្តប៉ុណ្ណោះ ។ នៅឆ្នាំ១៩៧១ ជនបទបានក្លាយទៅជាមូលដ្ឋានបង្អែកទីក្រុងជាដែនដីមួយដែលពួកគេកាន់តែពិបាកទាក់ទងខ្លាំងឡើងៗ ។

នៅមុនពេលរដ្ឋប្រហារ វ៉ន វ៉េត ដែលទទួលបន្ទុកការងារកសាងបក្សនៅក្រុងភ្នំពេញ បានបាត់បង់យុទ្ធិកជនរបស់គាត់ចំនួនពាក់កណ្តាលក្នុងការវាយប្រហារជាហូរហែមួយ ដែលផ្តើមឡើងដោយ សម្តេច ព្រះនរោត្តម សីហនុ ។ នៅចុង ទសវត្សរ៍ឆ្នាំ១៩៦០ មានការបាញ់កាំភ្លើងតគ្នាទៅវិញទៅមកតាមផ្លូវថ្នល់ក្នុងក្រុងភ្នំពេញ នៅពេលដែលពួក កុម្មុយនិស្ត ខំប្រឹងរត់គេចពីពួកប៉ូលិសរបស់សម្តេច ។ ខៀវ ប៉ុណ្ណារី ប្រពន្ធរបស់ សាឡុត សរ៖ តែត្រូវគេ ចាប់ខ្លួនបាន ។

ឥឡូវនេះ នៅតាមជនបទ ពួកខ្មែរក្រហមបានប្រុងប្រៀបខ្លួនអនុវត្តគោល “នយោបាយកុម្មុយនិស្តនៃសង្គ្រាម” (ជានយោបាយដែលតម្រូវឲ្យរដ្ឋធ្វើជាតួបនីយកម្មសហគ្រាសឯកជននានា ប្រមូលយកចំណែកលើសនៃស្បៀងរបស់កសិករ គ្រប់គ្រងការបែងចែកស្បៀង និងគ្រឿងឧបភោគ-បរិភោគ បង្កើនកាតព្វកិច្ចពលកម្មសម្រាប់មនុស្សគ្រប់រូប បំបាត់វណ្ណៈឲ្យអស់ពីសង្គម) របស់ពួកបុកឆេវិចរុស្ស៊ី ជាស្រេចដោយដាក់បង្ខំការត្រួតត្រារបស់គេលើប្រជាកសិករទាំងឡាយ និងដោយប្រើកម្លាំងទ័ព ដើម្បីដេញកម្ចាត់ពួកវៀតណាមពីកម្ពុជា ។ មុននឹងផ្តើមសង្គ្រាមរបស់ខ្លួន ពួកគេបានចាប់ពង្រឹងការគាំទ្រពីប្រជាកសិករសិន ដោយឲ្យពួកនេះកាន់មុខតំណែងសំខាន់ៗនៅតាមជនបទ ។ បន្ទាប់ពីមហាសន្និបាតឆ្នាំ១៩៧១ គណៈកម្មាធិការមជ្ឈិមបក្សបានបញ្ជូនមតិណែនាំថ្មីៗទៅគ្រប់ភូមិភាគទាំងអស់ ប៉ុន្តែ កាលៈទេសៈ និងទស្សនៈរបស់បណ្តាមេដឹកនាំនៅតាមមូលដ្ឋានមានលក្ខណៈខុសប្លែកពីគ្នាយ៉ាងច្រើនពីតំបន់មួយទៅតំបន់មួយ ហើយលទ្ធផលក៏មានមិនស្មើគ្នាដែរ ។ ក្នុងតំបន់ខ្លះ ពួកខ្មែរក្រហមបានបង្កើតក្រុមសាមគ្គីជាច្រើន ដើម្បីដាក់ជារួមនូវកម្លាំងធ្វើការ និងប្រភពធនធានរបស់ប្រជាកសិករ ក្នុងតំបន់ខ្លះទៀត គេបណ្តោយឲ្យប្រជាកសិករទៅធ្វើស្រែចម្ការទាំងក្រុមៗ ដូចដែលពួកគេធ្លាប់បានធ្វើតាំងតែពីច្រើនសតវត្សរ៍មកហើយ ។ ប៉ុន្តែ ទិដ្ឋភាពសំខាន់ៗនៃដំណាក់កាល “រណសិរ្ស” (ការប្រមូលកម្លាំង) លើកដំបូងនេះ គឺត្រូវធ្វើឲ្យញ៉ាំងប្រជាកសិករជឿជាក់ថា ពួកអ្នកបះបោរជាតំណាងលទ្ធិជាតិនិយមរបស់កម្ពុជា ដោយពិតប្រាកដ ។

រណសិរ្សនេះ បានបោកបញ្ឆោតស្ទើរតែគ្រប់ភាគីទាំងអស់ដែលចូលប្រឡូកក្នុងសង្គ្រាមនេះ ។ សាឡុត ស

បានបញ្ចប់ការរួបរួមធ្វើសង្គ្រាមរបស់បក្សពន្ធគាត់ប្រកបដោយភាពប្រាកដនិយមមួយ ដោយបង្កើតបន្ទប់តាំងរូបថតមួយ ដែលបន្ទុចទ្រង់ទ្រាយ និងបំផ្លើសពីកម្លាំងដែលប្រឈមមុខនឹង លន់ នល់ ។ ស មិនចង់ត្រឡប់មកនៅក្រោមប្រដាប់បញ្ចាំងពន្លឺ ឬភ្លើងហ្វារវិញឡើយ ហើយពេញចិត្តនឹងរង់ចាំចាប់កំហុសមួយរបស់គូប្រជែងទាំងឡាយរបស់គាត់ ហើយប្រើប្រាស់បណ្តាសត្រូវថ្មីៗរបស់គាត់ទុកដូចជាសម្ព័ន្ធមិត្តនៅឱកាសនេះ ។

ស្រទាប់ដំបូងនៃសេចក្តីពិពណ៌នាសម្រាប់បំភ័ន្តនេះ គឺតួនាទីរបស់សម្តេចជាមេដឹកនាំរណសិរ្ស ។ សេចក្តីថ្លែងការណ៍ដែលព្រះអង្គមានបន្ទូលនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ ដើម្បីប្រកាសបង្កើតរណសិរ្សរួបរួមជាតិកម្ពុជាមានជាអាទិ៍ថា «ទាហានរបស់យើងបានទទួលបញ្ជាឲ្យឈប់ការពារព្រំដែន និងទឹកដីរបស់ប្រទេស ដើម្បីប្រឆាំងនឹងជនរួមជាតិឯងវិញ និងបាញ់សម្លាប់ដោយគ្មានអាណិតអាសូរចំពោះអ្នកទាំងឡាយ ដែលហ៊ានបញ្ចេញការប្រឆាំងជំទាស់ទោះជាតាមពាក្យសម្តីក៏ដោយ ចំពោះរដ្ឋាភិបាលជាអ្នកកាន់លទ្ធិហ្វាស៊ីសថ្មីដែលបំពេញមុខងារឲ្យចក្រពត្តិនិយមអាមេរិកាំង ...ខ្ញុំសូមអំពាវនាវចំពោះជនរួមជាតិទាំងអស់ដែលជាកូនចៅរបស់ខ្ញុំ ទាំងកងទ័ព និងស៊ីវិល ដែលពុំអាចទ្រាំទ្រ នូវការសង្កត់សង្កិនដ៏អយុត្តិធម៌ពីសំណាក់ពួកក្បត់ ហើយដែលមានសេចក្តីក្លាហាន និងស្មារតីស្នេហាជាតិ សូមរត់ចូលមករួបរួមធ្វើសង្គ្រាមឆ្មក់នៅក្នុងព្រៃប្រឆាំងនឹងពួកសត្រូវរបស់យើង»[៣២] ។

ដោយសង្គ្រាមនេះ ត្រូវបង្កើតភាពថ្លៃថ្នូរជាតិរបស់ប្រទេសកម្ពុជាឡើងវិញ សម្តេច ព្រះនរោត្តម សីហនុ ពុំមានបញ្ជិតបញ្ចៀងណាមួយចំពោះកងទ័ពវៀតណាម ដែលទទួលបានចំណែកច្រើនជាងគេទាំងអស់ក្នុងការប្រយុទ្ធឡើយ ។ ព្រះអង្គមិនទទួលសារភាពថា «រណសិរ្ស» គឺស្ថិតនៅក្នុងកណ្តាប់ដៃពួកកុម្មុយនិស្តទាំងស្រុងថែមទៀត ។ សម្តេច ព្រះនរោត្តម សីហនុ សព្វព្រះទ័យប្រកាន់អាកប្បកិរិយាជាប្រធានរណសិរ្ស និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាជាង ដោយរិះគន់ដៃគូទាំងឡាយរបស់ព្រះអង្គនៅក្នុងរណសិរ្សជារឿយៗ ដើម្បីធ្វើខ្លួនឲ្យគេទុកចិត្ត ប៉ុន្តែ បែរជាជំទាស់មិនព្រមជឿពីលក្ខណៈជាមូលដ្ឋានដែលជាគ្រឹះនៃ«សង្គ្រាមរំដោះជាតិ»នេះឡើយ ។ គេមិនដែលដឹងសោះនូវអ្វីដែល សម្តេច ព្រះនរោត្តម សីហនុ មានព្រះរាជបំណងដោយពិតប្រាកដ ព្រោះព្រះអង្គ គង់នៅតែក្នុងមហាព្រះរាជដំណាក់របស់ព្រះអង្គនៅទីក្រុងប៉េកាំងឆ្ងាយពីការច្បាំងគ្នា និងរឿងពិតទាំងអស់ ។ ប៉ុន្តែ នៅពេលដែលសម្តេចធ្វើសេចក្តីថ្លែង ការណ៍ពីរដ្ឋធានីរបស់ចិន អ្នកជំនាញការបរទេសជាច្រើនបានចាត់ទុកសេចក្តីថ្លែងការណ៍នោះថា ជាបន្ទាត់នយោបាយពិតប្រាកដរបស់រណសិរ្ស ។ រហូតមកដល់ទីបញ្ចប់នៃសង្គ្រាម មហាអំណាចបស្ចិមប្រទេសនានាជឿ ថា សម្តេច ព្រះនរោត្តម សីហនុ ជាមនុស្សមានឥទ្ធិពលគួរសមសម្រាប់កាន់កូនសោក្នុងការរិះរកដំណោះស្រាយមួយ ដោយការចរចារមិនខាន ។

បណ្តាអ្នកដែលកាន់អំណាចពិតប្រាកដ ពុំមានឈ្មោះនៅក្នុងបញ្ជីសមាជផ្លូវការរបស់រណសិរ្សរួបរួមជាតិកម្ពុជា ឬរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាឡើយ[៣៣] ។ សាឡុត ស និង នួន ជា មេដឹកនាំដ៏សំខាន់ពីររូប នៃបក្សកុម្មុយនិស្ត បានបង្ហាញរូបរាងតែក្នុងឋានៈជាសមាជិកអគ្គបញ្ជាការដ្ឋានកងទ័ពប៉ុណ្ណោះ ។ ស ក្នុងឋានៈជា

អនុប្រធានទី១ ទទួលបន្ទុក ដឹកនាំកងទ័ពប្រយុទ្ធ នួន ជា ក្នុងឋានៈជាអនុប្រធានទី២ ទទួលខុសត្រូវខាងផ្នែកនយោបាយកងទ័ព ។ សុន សេន ជាអ្នកជិតស្និទ្ធនឹង ស ក្នុងផ្ទៃក្រុមនិស្សិតក្រុងប៉ារីស ត្រូវបានតែងតាំងជានាយអគ្គសេនាធិការ ។ បក្សដែលនៅតែស្ថិតក្នុងសភាព សម្ងាត់ជាទីបំផុតនោះ បានទទួលអ្វីៗទាំងអស់ ដែលគេប៉ងប្រាថ្នា គឺអំណាចបញ្ជាការកងទ័ពក្រៅពីនោះ គឺនៅតែការផាត់ពណ៌លាបម្សៅប៉ុណ្ណោះ ។

ជាការពិត នេះជាការផាត់ពណ៌លាបម្សៅហួសប្រមាណមួយ ដែលធ្វើឲ្យគេជឿស្ទុង ។ អៀង សារី ពុំមានតំណែងណាជាផ្លូវការទេ ទាំងក្នុងរណសិរ្សទាំងក្នុងរាជរដ្ឋាភិបាល ប៉ុន្តែ ត្រូវបានតែងតាំង ជាបេសកជនពិសេសទទួល រ៉ាប់រងធ្វើការទាក់ទងរវាងសមរភូមិនៅកម្ពុជា និង«ប្រធាន»រណសិរ្សនៅប៉េកាំង ។ តាមការពិត គាត់ជាអ្នកទទួលបន្ទុកបង្ខំឲ្យសម្តេច ព្រះនរោត្តម សីហនុ គោរពនឹងការណែនាំ និងឃ្លាំមើល មិនឲ្យបន្ទុបតាំងរូបថតត្រូវគេបំផ្លាញឲ្យសាបសូន្យទេ នេះជាការទទួលខុសត្រូវផ្សេងៗ ដែលនាំគាត់ឲ្យធ្វើដំណើរទៅក្រុងហាណូយដែរ ។

បងប្អូនត្រកូលជួនបីនាក់ជាមួយនឹងការវាយបុកសំញែងរបៀបជាមនុស្សថ្លៃថ្នូរ, ដើមកំណើតគ្រួសារ និងបែបបទរបៀបអឺរ៉ុបរបស់ពួកគេ ត្រូវចាត់ឲ្យធ្វើអ្នកនាំពាក្យរបស់រណសិរ្ស និងរាជរដ្ឋាភិបាល ។ ប្រសិទ្ធិ ជាមនុស្សទីបីរបស់រណសិរ្សរួបរួមជាតិកម្ពុជា និងកាន់កាប់តំណែងរដ្ឋមន្ត្រីមួយក្នុងផ្ទៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ។ បងប្រុសរបស់គាត់ឈ្មោះ ម៉ុំ ដែលជាបញ្ញវន្តបានកាន់កាប់ឋានៈខ្ពស់មួយក្នុងរណសិរ្ស និងជារដ្ឋមន្ត្រីទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់រដ្ឋាភិបាល ។ អ្នកទាំងបី បានធ្វើឲ្យការព្រួយបារម្ភផ្សេងៗរបស់រណសិរ្ស ធូរស្រាកនៅពេលពួកគេធ្វើដំណើរទៅទ្វីបអឺរ៉ុប ហើយបានប្រកាសប្រាប់ពួកបស្ចិមប្រទេស ក៏ដូចបណ្តាមេដឹកនាំប្រទេសតតិយលោកថា ពួកគេជាអ្នកដែលតំណាងឲ្យចលនារបស់សម្តេច ព្រះនរោត្តម សីហនុ ។ នេះជាការដោះស្រាយទំនើប និងដែលមានប្រយោជន៍មួយ សម្រាប់ជំនួសរបបពុករលួយ ឱនថយ និងប្រតិកិរិយារបស់ លន់ នល់ ។

ប៉ុន្តែ អ្វីដែលមានទំនងជាធ្វើឲ្យគេជឿខ្លាំងបំផុតសម្រាប់ប្រជាជនកម្ពុជានៅក្នុងប្រទេស ឬនៅក្រៅប្រទេស គឺមុខតំណែងដ៏សំខាន់ដែលកាន់កាប់ដោយ «បិសាចទាំងបី» នោះហើយមើលទៅ ។ ខៀវ សំផន, ហ៊ូ យន់ និង ហ៊ូ នឹម –ជាមនុស្សនិយមឆ្វេងគួរឲ្យចូលចិត្តទាំងបី ដែលធ្លាប់បម្រើរបបសម្តេច ព្រះនរោត្តម សីហនុ មុននឹងត្រូវប្រកាសថា ស្លាប់ដោយសម្តេច- បានត្រូវប្រោះឲ្យរស់ឡើងវិញ ដើម្បីដឹកនាំរណសិរ្ស និងរាជរដ្ឋាភិបាលនៅពីក្រោយសម្តេច ព្រះនរោត្តម សីហនុ ដោយមានការកោតសរសើរហួសហេតុ ។ ការលេចមុខចេញជាថ្មីបន្ទាប់ពីត្រូវលាក់ខ្លួនក្នុងរយៈពេលជាច្រើនឆ្នាំ វីរបុរសទាំងបី ដូចក្នុងរឿងប្រលោមលោក គឺជាតំណាងរដ្ឋាភិបាលមួយ ដែលប្រកបដោយគុណធម៌ ទាន់សម័យ និងប្រជាធិបតេយ្យ ។ បណ្តាសមាជិកនៃរដ្ឋាភិបាល លន់ នល់ ព្រមទាំងស្ថានទូតអាមេរិកាំងនៅក្រុងភ្នំពេញ បានប្រកាសឲ្យដឹងថា មនុស្សទាំងបីនាក់នេះ បានស្លាប់អស់ហើយ ហើយថា បិសាចថ្មីទាំងនេះ ជាមនុស្សដែលគេយកមកបន្លំបោកប្រាស់ប៉ុណ្ណោះ ។

ការបន្លំរបស់រណសិរ្ស បញ្ចេញឲ្យឃើញលក្ខណៈប្រសប់ខ្លាំងណាស់ ។ ពួកខ្មែរក្រហមតោងតែរំងាប់

ទឹកចិត្តពួកយុទ្ធិកជនរបស់គេ ដែលក្តៅក្រហាយនឹងអ្វីដែលសម្តេច ព្រះនរោត្តម សីហនុ ត្រូវគេផ្តល់ឋានៈឲ្យធ្វើជាមេដឹកនាំសង្គ្រាមរបស់គេ ទោះបីជាដាក់យកតែនាមក៏ដោយ ។ ពួកមេដឹកនាំបក្សបាននិយាយប្រាប់បណ្តាកម្មាភិបាលខ្មែរក្រហមថា សម្តេចជាមនុស្ស ដែលគេប្រើប្រាស់ទុក ដូចជា "ក្របីមួយក្បាលជិះឆ្លងភក់"[៣៨] ប៉ុណ្ណោះ ។ ដូច្នេះជនដ៏ល្បីល្បាញជាងគេរបស់ប្រទេស បានត្រូវគេយកទៅទីមរទេះបក្ស ទេវរាជាអង្គនេះបានទទួលការវាយសំពងដោយគ្មានរបស់ពួកកុម្មុយនិស្ត ។

អធិការមួយរូបនៅក្រុងភ្នំពេញ បានខំស្វែងទៅរួបរួមនឹងពួកខ្មែរក្រហមក្នុងកំឡុងសម័យកាល "រណសិរ្ស" នេះ ដោយសម្រេចធ្វើដំណើរទៅកាន់ប៉ែកម្ខាងទៀត និងបានសម្គាល់ឃើញលក្ខណៈពិតប្រាកដរបស់ពួកកុម្មុយនិស្តទាំងនោះ ហើយបានធ្វើសេចក្តីរាយការណ៍ដ៏ល្អិតល្អន់ដែលមានតែមួយគត់ស្តីពីដំណើរប្រែប្រួលបន្តបន្ទាប់របស់ការបដិវត្តនេះ[៣៥] ។ អធិការរូបនេះឈ្មោះ អ៊ិត សារិន គាត់បានចាកចេញពីខាងក្រុម លន់ នល់ នៅឆ្នាំ ១៩៧២ ដោយការធុញថប់ ដើម្បី "រត់ចូលព្រៃ" និងស្វែងរកពួកអ្នកស្នេហាជាតិពិតប្រាកដ ។ បន្ទាប់ពីរស់នៅជាមួយរណសិរ្សប្រាំបួនខែ គាត់បានវិលត្រឡប់មកក្រុងភ្នំពេញវិញ ផ្ទុកពេញទៅដោយគំនិតប្រឆាំងនឹងលទ្ធិកុម្មុយនិស្តមួយយ៉ាងខ្លាំងក្លា ហើយនៅឆ្នាំ១៩៧៣ គាត់បានបោះពុម្ពផ្សាយសៀវភៅមួយមានចំណងជើងថា "ស្រណោះព្រលឹងខ្មែរ" ដែលក្នុងសៀវភៅនេះគាត់មានបំណង "បញ្ឈាក់បំភ្លឺពីបញ្ហាផ្សេងៗរបស់ខ្មែរ និងចង្អុលបង្ហាញពីគ្រោះថ្នាក់កុម្មុយនិស្តក្នុងប្រទេស" ផង ។

នេះជាជោគជ័យមួយរបស់គាត់ផ្ទាល់ ។ ក្នុងក្រុងភ្នំពេញទាំងមូល គេអាចមើលស្គាល់សៀវភៅនេះដោយស្រួលតាមរយៈក្របរបស់វា ដែលមានគូររូបផែនទីប្រទេសកម្ពុជាមួយរបៀបជារូបបេះដូងបែកជាពីរដោយទន្លេមេគង្គហូរកាត់ពីលើមកក្រោម ។ ពួកអ្នកធាក់ស៊ីក្លូ និងពួកអ្នកនយោបាយ បានអាននូវការលាតត្រដាងឲ្យដឹងរឿងសម្ងាត់ទាំងនេះ ហើយដឹងថា ពួកកុម្មុយនិស្តកម្ពុជាកំពុងរៀបចំធ្វើការបដិវត្តមួយ ពួកវៀតណាមខាងជើងបានវាយប្រយុទ្ធដើម្បីត្រួសត្រាយផ្លូវឲ្យខ្មែរក្រហម ប៉ុន្តែ ពួកកុម្មុយនិស្តកម្ពុជាទាំងនេះ មិនសូវស្រុះចិត្តគ្នាប្រឆាំងនឹងក្រុងហាណូយប៉ុន្មានឡើយ ។ ដោយនិយាយពីកម្លាំងរបស់ពួកខ្មែរក្រហម សារិន បានព្រមាន លន់ នល់ ថា ត្រូវទាក់ទងនិយាយជាមួយនឹងសត្រូវដ៏គួរឲ្យព្រឺខ្លាចមួយ ហើយថា ក្រុងភ្នំពេញគោងតែផ្លាស់ប្តូររបៀបដឹកនាំរបស់ខ្លួន ដើម្បីយកឈ្នះលើសត្រូវនេះ ។

អ្នកកាន់អំណាចផ្តាច់ការ បានហាមមិនឲ្យសៀវភៅនេះចេញលក់ ហើយបញ្ជាឲ្យចាប់អ្នកនិពន្ធដាក់គុក ព្រោះរបបគាត់ចង់បន្តការវាយប្រយុទ្ធប្រឆាំងនឹងពួកបិសាចបរទេសតទៅទៀត ។ បណ្តាសមាជិកនៃក្រុម សេ.អ៊ី.អា. ដែលប្រចាំការនៅស្ថានទូតអាមេរិកាំងក្រុងភ្នំពេញ មិនជឿពីសេចក្តីសុចរិតរបស់ អ៊ិត សារិន ឡើយ ហើយសន្និដ្ឋានថា សៀវភៅរបស់គាត់ជាសៀវភៅ "ឃោសនាដោយស្ងប់ស្ងៀម" មួយដែលលើកតម្កើងហួសហេតុជំនួសពួកខ្មែរក្រហម ។ និយាយដោយពិត សៀវភៅ "ស្រណោះព្រលឹងខ្មែរ" ក៏គ្មានទាក់ទងនឹង

គោលដៅឃោសនាផ្សេងៗរបស់ពួកសេ.អ៊ី.អា.ដែរ ។

មនុស្សទាំងអស់សុទ្ធតែភាន់ច្រឡំ ។ ក្នុងសៀវភៅនេះ ប្រកបទៅដោយពត៌មានដ៏មានតម្លៃជាច្រើនស្តីពីពួកខ្មែរក្រហម បញ្ហាផ្សេងៗរបស់ពួកគេជាមួយពួកវៀតណាម និងគំនិតបដិវត្តរបស់ពួកនេះផង ។ ជីវភាពរស់នៅក្នុងតំបន់ខ្មែរក្រហមកាន់កាប់ ដែលរៀបរាប់ដោយ អ៊ិត សារិន គឺមានសភាពពិបាកយ៉ាប់យ៉ឺន តឹងរ៉ឹងម៉ឺងម៉ាត់ ប៉ុន្តែគ្មានអ្វីធ្វើឲ្យទាស់ចិត្តទេ ។ អធិការរូបនេះ បានដឹងយ៉ាងឆាប់រហ័សថា អង្គការរណសិរ្ស គឺស្ថិតនៅក្រោមអំណាចរបស់ពួកកុម្មុយនិស្តខ្មែរ "ដែលមានលក្ខណៈឥតមេត្តា និងចចេសមានះពីកំណើត" ដោយដាក់បង្ខំឲ្យធ្វើតាមឆន្ទៈខ្លួននូវ"វិន័យដែកថែបមួយ" ដោយនៅថែរក្សាការដឹកនាំដ៏ "សាមញ្ញ និងសុភាពរាបសា"មួយ ចំពោះប្រជាកសិករដដែល ។ សារិន សរសេរថា ពួកកុម្មុយនិស្ត "ធ្វើការជាមួយប្រជាជន... ដើម្បីបម្រើប្រជាជន និងជួយពួកកសិករឲ្យស្តាបនាភ្លឺស្រែ ទំបន់ទឹក អាងស្តុកទឹក និងផ្ទះសម្បែង ។ ពួកគេយល់យ៉ាងច្បាស់ និងចេះទាញយកប្រយោជន៍ពីការមិនសប្បាយចិត្តដ៏ជ្រាលជ្រៅរបស់ប្រជាកសិករ ចំពោះអំពើពុករលួយ ភាពក្រអឺតក្រទម អំពើឃោរឃៅ និងការខ្វះសមត្ថភាពរបស់រដ្ឋាភិបាលក្រុងភ្នំពេញ ។ "សកម្មភាពខាងចិត្តសាស្ត្រទាំងអស់នេះ បានទទួលជោគជ័យមួយខ្លាំងមែនទែន ហើយមុតផ្ទុះទឹកចិត្ត ប្រជាជនជ្រាលជ្រៅជាងការបង្រៀនទ្រឹស្តីទៅទៀត ។ កសិករនៅបណ្តាតំបន់បង្អែក ដែលគ្មានដឹងអ្វីទាំងអស់អំពីការបដិវត្តសង្គមនិយមនោះ បានចាប់ផ្តើមចូលចិត្ត និងគាំទ្រ"អង្គការ"វិញយ៉ាងឆាប់រហ័ស ដោយសារមនោសញ្ចេតនាស្មោះត្រង់ និងភាពរាក់ទាក់ ដែលអង្គការបានបង្ហាញឲ្យឃើញកន្លងមក" ។

បក្សកុម្មុយនិស្តរបស់កម្ពុជាបានឲ្យឈ្មោះខ្លួនឯងថា"អង្គការ" តាមទម្លាប់ជាប្រពៃណីដែលបក្សកុម្មុយនិស្តឥណ្ឌូចិន និងពួកកុម្មុយនិស្តវៀតណាមខាងត្បូងបង្កើតឡើង និងប្រើពាក្យ "អង្គការ"នេះ ដើម្បីទាក់ទាញប្រជាកសិករឲ្យជឿតាមនយោបាយរបស់ពួកគេ ដោយមិនបញ្ចេញឲ្យដឹងថា ពួកគេជាពួកកុម្មុយនិស្តឡើយ ។ សារិន បានបន្ថែមថា បុគ្គលម្នាក់ៗត្រូវតែប្រតិបត្តិធ្វើតាមអង្គការទាំងស្រុង ដែលប្រកបដោយអំណាចខ្ពស់លើសអ្វីៗទាំងអស់ សឹងដូចអ្នកមានជំនឿស៊ប់ទៅក្នុងសាសនា ៖ ពាក្យសម្តីរបស់អង្គការមានអានុភាពជាច្បាប់ ហើយគ្រប់ការប៉ុនប៉ងទាំងអស់ ដើម្បីបំពានលើអង្គការសុទ្ធតែត្រូវរកឃើញជានិច្ច ។ អ្នកនិពន្ធរូបនេះ បានបញ្ចប់សៀវភៅរបស់គាត់ដោយឃ្លាគំរូមួយ ដែលនឹងក្លាយទៅជាឃ្លា ត្រូវគេចូលចិត្តប្រើប្រាស់បន្ទាប់ពីជ័យជម្នះរបស់ខ្មែរក្រហម គឺ"អង្គការមានភ្នែកដូចភ្នែកម្នាស់ ហើយមិនដែលភ័ន្តច្រឡំម្តងណាឡើយ" ។

គឺលក្ខណៈតឹងរ៉ឹងក្នុងការត្រួតត្រាទាំងស្រុងនេះហើយ ដែលធ្វើឲ្យ សារិន ព្រឺខ្លាច ។ គ្រប់បញ្ហា ការភ្លាំងភ្លាត់ខុសទាំងអស់ គេត្រូវទម្លាក់ទោសទៅលើបុគ្គលម្នាក់ៗ ហើយមិនដែលទម្លាក់ទៅលើអង្គការ ឬនយោបាយរបស់ខ្លួនសោះឡើយ ។ សម័យប្រជុំទិតៀននិងស្វ័យទិតៀន តាមរបៀបកុម្មុយនិស្ត ក៏ពុំដែលហ៊ានថ្កោលទោសច្បាប់ទម្លាប់ វិន័យរបស់អង្គការដែរ ប៉ុន្តែមានតែកសិករក្រីក្របុ៉ណ្ណោះ ដែលអាចដើរតាមច្បាប់ទម្លាប់របស់

អង្គការបាន ។ ប៉ុន្តែ សារិន មិនបាននិយាយអំពីការមិនសប្បាយចិត្តជាចំហមួយ ក្នុងចំណោមប្រជាកសិករឡើយ លើកលែងតែចាស់ព្រឹទ្ធាចារ្យមួយចំនួនតូចប៉ុណ្ណោះ ដែលដឹងថា សម្តេច ព្រះនរោត្តម សីហនុ ពុំមែនជាមេដឹកនាំពិតប្រាកដរបស់រណសិរ្សទេ ។ ចាស់ៗទាំងនោះ ធ្លាប់បាននិយាយប្រាប់គាត់ថា "ប្រជាជនគ្រប់គ្នាសុទ្ធតែរង់ចាំ ឯកោ ពួកគេត្រូវការភាពកក់ក្តៅរបស់សម្តេច ដើម្បីបន្តជីវិតរស់យូរតទៅទៀត" ។

សារិន បានផ្តល់ការចាប់អារម្មណ៍ផ្ទាល់ខ្លួនថា ប្រជាកសិករបានឲ្យតម្លៃ ជាទូទៅមួយអំពីអត្ថប្រយោជន៍ផ្សេងៗខាងផ្នែកសម្ភារៈ ក្នុងការរស់នៅជាមួយពួកខ្មែរក្រហម ។ កសិករទាំងនេះលែងត្រូវគេចាត់ទុកដូចជាកូនឈ្នួលទៀតហើយ ។ ម្នាក់ៗទោះជាមានឋានៈកម្រិតណាក៏ដោយត្រូវបំពេញការងាររហត្ថកម្ម បរិភោគអាហារអត្តខាត់ ស្លៀកពាក់ខោអាវ និង ធ្វើការក្នុងរយៈពេលជាច្រើនម៉ោងដូចៗគ្នា ។ ក្រៅពីទិសដៅនយោបាយក្នុងការប្រែក្លាយប្រជាជន និងពួកកម្មាភិបាលឲ្យទៅវណ្ណៈអធននៅជនបទ ច្បាប់ទម្លាប់ផ្សេងៗរបស់អង្គការ ក៏មានទិសដៅរៀបចំអ្នកទាំងនោះទៅរកអ្វីដែលពួកគេបានរៀបចំជាស្រេចហើយដែរ ។ សារិន ធ្លាប់បានឮគេនិយាយពីកម្មាភិបាលម្នាក់ ដែលប្រញាប់ប្រញាល់ទៅមើល កសិករឈឺម្នាក់ទាំងកណ្តាលអធ្រាត្រ កំពុងមានព្យុះភ្លៀង ដើម្បីថែទាំព្យាបាល និងលួងលោមឲ្យរសាយទុក្ខ ។ គាត់បានកត់សម្គាល់ដូចគ្នាពីភាពគ្មានអំពើពុករលួយ ការតាមពិនិត្យមើលក្រឹត្យវិន័យផ្សេងៗយ៉ាងតឹងរ៉ឹង ដែលហាមប្រាមមិនឲ្យមានការលួច ការរំលោភលើរូបកាយនារី ការផឹកស្រា និងការប្រព្រឹត្តល្បែងស៊ីសង ។

សៀវភៅរបស់អធិការរូបនេះ បានបង្ហាញឲ្យដឹងនូវភស្តុតាងផ្សេងៗ ស្តីពីអ្នកណាមួយដែលនឹងត្រូវតាមសង្កេត ។ សារិន មិនត្រឹមតែប្រាប់ឲ្យដឹងពីតួនាទីរបស់បក្សកុម្មុយនិស្តកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែ បានប្រាប់ទាំងបណ្តាពួកមេដឹកនាំរបស់បក្សទៀតផង គឺ សាឡុត ស, អៀង សារី, សុន សេន និង ខៀវ សំផន ។ គាត់បានលាតត្រដាងឲ្យដឹងទៀតថា សម្តេច ព្រះនរោត្តម សីហនុ គ្មានឥទ្ធិពលបន្តិចណាសោះនៅក្នុងចលនានោះ ហើយថា ពួកកុម្មុយនិស្តកម្ពុជា បានកាត់ផ្តាច់ខ្សែរយៈទាក់ទងជាមួយពួកកុម្មុយនិស្តវៀតណាម ដែលពួកគេលែងសូវចូលចិត្តទៀតហើយ ។ សារិន បានដកស្រង់មករៀបជាសំអាងនូវពាក្យសម្តី ដែល ហ៊ូ យន់ បានថ្លែងក្នុងឱកាសនៃសម័យប្រជុំមួយ ហើយក្រោយមកក្នុងការការសន្ទនាគ្នាមួយថា ៖ "ទំនាក់ទំនងផ្សេងៗរវាងពួកកុម្មុយនិស្តកម្ពុជា និងវៀតណាម ត្រូវបាន "កែលម្អ" ជាសារវន្តប្រសើរជាងពីមុន ពីព្រោះពួកខ្មែរក្រហមបានដោះខ្លួនផុតពីឥទ្ធិពលរបស់ពួកវៀតណាមខាងជើង និងពួកវៀតកុងហើយ ។ នៅពេលនេះ ពួកកុម្មុយនិស្តខ្មែរមានលក្ខណៈ "ឯករាជ្យ និងស្វយ័ត" មិនចំណុះអ្នកណាទាំងអស់ ។ ម្យ៉ាងទៀត "អង្គការ" មានផែនការជាច្រើនដើម្បីគិតគូរដោះស្រាយជាមួយពួកវៀតណាមក្នុងករណីដែលពួកគេបង្កឲ្យមានបញ្ហាជាថ្មី" ។

ដោយហេតុតែសេចក្តីបញ្ជាក់ពីបញ្ហាផ្សេងៗរវាងពួកកុម្មុយនិស្តវៀតណាម និងពួកកុម្មុយនិស្តខ្មែរនេះហើយ ទើបពួកអ្នកសង្កេតការណ៍បរទេសរហូតដល់មតិអ្នកនយោបាយជាច្រើន បានធ្វើឲ្យតម្លៃសៀវភៅនេះ

ធ្លាក់ចុះ ។ អ្នកទាំងនោះគិតថា ប៉ែកខាងពួកកុម្មុយនិស្ត ជាបក្សនយោបាយរឹងមាំតែមួយដុំ ដែលគ្មានអ្នកណាចូលចុះ ។ សម្តេច ព្រះនរោត្តម សីហនុ ទោះបីជាស្ថិតនៅក្រៅវង់កាន់តែឆ្ងាយទៅៗក៏ដោយ ក៏នៅតែធ្វើឲ្យពួកអ្នកកាសែត និងពួកអ្នកការទូតជាប់ជំពាក់ចិត្តនឹងព្រះអង្គដែរ ។ ប្រការនេះ បានធ្វើឲ្យមានប្រយោជន៍ដល់ពួកកុម្មុយនិស្តកម្ពុជា ដែលទុកឲ្យសម្តេចថែទាំការប្រោសប្រណីពីអន្តរជាតិសិនចុះ ក្នុងរយៈពេលដែលពួកគេរៀបចំដំណាក់កាលទីពីរ ក្នុងការយកសង្គ្រាមមកកាន់ដៃ ។ កិច្ចចរចារវាងអាមេរិកាំង-វៀតណាម ដែលនឹងនាំទៅដល់កិច្ចព្រមព្រៀងក្រុងប៉ារីសនៅថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៧៣ កំពុងតែប្រព្រឹត្តទៅមុខជាហូរហែ ។ ពួកខ្មែរក្រហម បានបដិសេធមិនចូលរួមក្នុងការជជែកពិភាក្សាទាំងអស់ស្តីពីការឈប់បាញ់គ្នា ហើយពួកគេដឹងថា បន្ទាប់ពីការសម្រេចកិច្ចព្រមព្រៀងមួយ ពួកគេស្ទើរតែនឹងត្រូវចាកចេញតែខ្លួនឯង ។ ពួកគេបានសម្រេចរង់ចាំពេលវេលាយកដល់ ដើម្បីបោះពុម្ពផ្សាយប្រវត្តិសាស្ត្របក្សជាផ្លូវការលើកដំបូងរបស់ខ្លួន ។

ការបោះពុម្ពផ្សាយប្រវត្តិសាស្ត្រមួយរបស់បក្ស[៣៦] ជាព្រឹត្តិការណ៍ប្លែកពីធម្មតាមួយសម្រាប់ចលនាកុម្មុយនិស្តទាំងអស់ ។ ប្រវត្តិសាស្ត្រនេះ មានតម្លៃស្មើគ្នានឹងក្បួនហោរារបស់ លន់ នល់ ដែរ ៈ ប្រវត្តិនេះបានបញ្ជាក់អះអាងពីស្មារតីធ្វើម្ចាស់អនាគត ដោយចង្អុលបង្ហាញឲ្យឃើញនូវការយល់ដឹងពេញលេញមួយអំពីអតីតកាល និងរៀបចំការគ្រប់គ្រងត្រឹមត្រូវតាមសីលធម៌ ដែលមានករណីយកិច្ចនឹងដឹកនាំបញ្ជាចលនា ។ ជាធម្មតាបក្សមួយត្រូវសរសេរប្រវត្តិសាស្ត្ររបស់ខ្លួន នៅពេលដែលគេដើរមកដល់ផ្លូវក្រឡែងកែងមួយ ពេលដែលគេប្រុងប្រៀបខ្លួនពេលមានស្ថានការណ៍ថ្មីមួយ ដែលត្រូវការឲ្យមាននយោបាយមួយផ្សេងទៀតជាចាំបាច់ ឬនៅពេលដែលពួកមេដឹកនាំរបស់ខ្លួនវាយតម្លៃថា ពួកគេត្រូវបញ្ចប់ការទាស់ទែងខ្វែងគំនិតរួចរាល់អស់ហើយ ហើយរៀបចំមាគ៌ាតែមួយ ដែលកកើតឡើងដោយការរំលាយបញ្ចូលគ្នាពីក្រោយមេដឹកនាំមួយ ឬក្បួនទ្រឹស្តីតែមួយ ។ ម៉ៅ សេទុង ស្តាលីន ទីតូ សុទ្ធតែបោះពុម្ពផ្សាយប្រវត្តិសាស្ត្របក្សគ្រប់គ្នា -ឬសេចក្តីសម្រេចចិត្តអំពីប្រវត្តិសាស្ត្របក្ស- នៅចំកាលៈទេសៈសំខាន់ៗ ដែលពួកគេត្រូវអះអាងពីជំហរជាមេដឹកនាំរបស់គេ ហើយប្រុងប្រៀបនាំមុខកងទ័ពរបស់ខ្លួនឆ្ពោះទៅដំណាក់កាលថ្មីៗទៀត ។

ក្នុងពាក់កណ្តាលទី២នៃឆ្នាំ១៩៧២ សាឡុត ស និងពួកកុម្មុយនិស្តកម្ពុជា ហៀបនឹងផ្តើមធ្វើបដិវត្តន៍ដោយអាវុធស្រេចទៅហើយ ។ ទោះជាយ៉ាងណាក៏ដោយ ក៏ប្រវត្តិសាស្ត្រដែលពួកគេសរសេរ បានរួមបង្កជាការសម្របសម្រួលគ្នាជាបណ្តោះអាសន្នមួយស្តីពីបញ្ហាដ៏ចម្រូងចម្រាស់នៃតួនាទី របស់ពួកកុម្មុយនិស្តវៀតណាមដែរ ។ ប្រវត្តិនេះធ្វើឲ្យគេជឿថា ជាការព្រមានតែមួយគត់ នៅពេលដែលការបោសសម្អាត ចាប់ផ្តើមធ្វើក្នុងផ្ទៃបក្ស ប្រហែលជាដើម្បីធ្វើសម្រេចភាពស្រុះស្រួលគ្នានេះហើយ ។ ក្នុងការបកស្រាយប្រវត្តិសាស្ត្ររបស់កម្ពុជានេះ ពួកកុម្មុយនិស្តបានអួតខ្លួនថា បានជំរុញឲ្យសម្តេច ព្រះនរោត្តម សីហនុ ឈរលើជំហរអព្យាក្រឹតប្រឆាំងអាមេរិកាំងរបស់ព្រះអង្គ ។ លទ្ធផលនៃយុទ្ធសាស្ត្រ សាំញ៉ាំលំបាកយល់របស់គេមានគោលបំណងប្រើការគាប

សន្តត់ផ្សេងៗក្នុងផ្ទៃរដ្ឋាភិបាល ដោយចាត់ចែងរៀបចំវណ្ណៈបញ្ញវន្ត និងពួកកម្មករឲ្យមានសកម្មភាពឡើងនៅក្នុងរយៈពេលនៃការលាក់ខ្លួនពួនអាត្មានៅក្រុងភ្នំពេញ ។ ដោយគ្មាននិយាយពីលទ្ធផលនេះ ពួកគេបានប្រៀបធៀបខ្លួនទៅនឹងពួកកុម្មុយនិស្តវៀតណាមខាងត្បូង ដែលពុំបានសម្រេចបង្កើតឲ្យមានរឿងហេតុដូចគ្នាជាមួយ ង៉ូ ឌិញ យៀម ឡើយ ។ ដូច្នេះរយៈពេលដប់ឆ្នាំ ដែលមានមុនការឡើងកាន់អំណាចរបស់ សាឡុត ស ត្រូវបានវិនិច្ឆ័យថាជារយៈពេលមានការវិនាសអន្តរាយយ៉ាងខ្លាំង ហើយពួកកុម្មុយនិស្តមិនបង្អែបង្អង់និយាយពិតួនាទីរបស់ ស៊ីវ ហេង និងអំពើក្បត់របស់គាត់ឡើយ ។

បន្ទាប់ពីពេលដែល ស ក្តាប់ជាប់ព្រឹត្តិការណ៍ទាំងអស់ក្នុងកណ្តាប់ដៃ ប្រវត្តិសាស្ត្របក្ស បានក្លាយទៅជាប្រវត្តិសាស្ត្រមានលក្ខណៈសុទិដ្ឋិនិយមយ៉ាងដាច់ខាត ។ បក្សកុម្មុយនិស្តកម្ពុជាមានសេចក្តីក្រអឺតក្រអោងជាពិសេស ដែលបានសម្រេចចិតផ្តើមការបដិវត្តពិតប្រាកដមួយនៅឆ្នាំ១៩៦៧ ហើយបញ្ជាក់អះអាងថារឿងនេះ បានធ្វើឲ្យបក្សមានស្ថានភាពមួយយ៉ាងប្រសើរមួយ ដើម្បីឆ្លៀតទាញយកផលប្រយោជន៍ពីរដ្ឋប្រហារនៅឆ្នាំ១៩៧០ ។ ការសម្រេចចិត្តនេះត្រូវបានប្រកាន់យកផ្ទុយនឹងការឲ្យយោបល់របស់សម្ព័ន្ធមិត្តចិន និងវៀតណាម ប៉ុន្តែ អត្ថបទប្រវត្តិសាស្ត្រពុំមាននិយាយពីរឿងនេះមួយម៉ាត់សោះ ។ នៅខណៈនេះ បក្សត្រូវការរណសិរ្សរួបរួម មួយនៅក្នុងផ្ទៃអង្គការផ្ទាល់ និងបណ្តាសម្ព័ន្ធមិត្តរបស់ខ្លួន ។

ឯកសារបានបញ្ចេញតមកទៀតនូវ «មេរៀនរិះគន់គេ»ជាច្រើន ដែល អ៊ិត សារិន ដកស្រង់យកមកចុះផ្សាយក្នុងសៀវភៅរបស់គាត់ឡើងវិញមួយចំនួនធំហើយ ដែលគាត់ចាត់ទុកដូចជាពាក្យស្លោកឃោសនា ឬគោលការណ៍ផ្សេងៗរបស់ពួកកុម្មុយនិស្តដែរ ។ ឧទាហរណ៍ដូចជាបក្សនិយាយថា បើប្រជាកសិករត្រូវគេជិះជាន់សង្កត់សង្កិនដោយគ្មានប្រណីនោះ ពួកគេពុំអាចទៅជា«វណ្ណៈកម្មករ» មួយបានទេ ហើយនៅតែមានចរិតពឹងផ្អែកតែទៅកសិកម្មមួយមុខដដែល ។ ឱសថសម្រាប់កែរោគនេះ ស្ថិតនៅត្រង់ការបញ្ចូលធាតុវណ្ណៈកម្មករមួយទៅក្នុងខួរក្បាលរបស់គេក្នុងកម្រិតជា«អតិបរមា» និងស្មារតីវណ្ណៈកម្មករមួយ ទៅតាមមនោគមវិជ្ជាម៉ាក្សលេនីន ។ ត្រង់ចំណុចនេះ សារិន បានកត់ចំណាំនូវពាក្យស្លោកណែនាំមួយថា «ត្រូវរៀនសូត្រពីប្រជាជនដើម្បីធ្វើខ្លួនឲ្យដូចប្រជាជន» ប៉ុន្តែ «មិនត្រូវបណ្តោយឲ្យប្រជាជនដឹកច្រមុះបានតាមចិត្តទេ» ។

ការវិភាគអំពីវណ្ណៈ ប្រភពដើមវណ្ណៈ ទាមទារឲ្យមានធាតុវណ្ណៈពិតប្រាកដមួយ បានធ្វើឲ្យប្រជាជនកម្ពុជាក្លាយខ្វល់ដូចបណ្តាជនកុម្មុយនិស្តភាគច្រើនដទៃទៀត ដែលកំពុងសាកល្បង «បណ្តុះ» លើទ្វីបអាស៊ីនិយមនូវទ្រឹស្តីនយោបាយមួយ ដែលទាញចេញពីទ្វីបអឺរ៉ុប មានខស្សរាហកម្មលូតលាស់ ។ បក្សព្រួយបារម្ភចំពោះពួកបញ្ញវន្តនិងពួកគហបតីតូចតាចនៅក្នុងផ្ទៃចលនារបស់ខ្លួន ដែលនៅតែរក្សា «វណ្ណៈភាពដើមរបស់ពួកគេ» ដដែល ។ ហើយបក្សបានអះអាងបញ្ជាក់ពីគោលដៅរបស់ខ្លួន ដែលមានសមាជិកភាគច្រើនស្ថិតក្នុងវណ្ណៈកម្មការ ។ តមកទៀត បក្សបានសាកល្បងធ្វើឲ្យសម្រេចគោលដៅនេះ ហើយបានពើបប្រទះនឹង «លក្ខណៈ» ដោយឡែក

របស់ប្រជាកសិករ ដែលពុំអាចទទួលចិត្តគំនិតមួយរបៀប "កម្មករ" ក្នុងរយៈពេលដ៏ខ្លីបានឡើយ ហើយក៏ពើបប្រទះនឹងលក្ខណៈដោយឡែករបស់ប្រជាគហបតីតូចតាច ដែលពុំអាចអនុវត្តតាមដូចតែពួកកសិករដែរ នៅពេលដែលគេបង្កាប់បញ្ជាឲ្យធ្វើតាមគោលដៅនេះ ។

ប្រជាជនកម្ពុជា បានប្រកាន់យកសញ្ញាណលេនីននិយម ដែលតាមរយៈនេះ អ្នកណាក៏ដោយ នៅទីណាក៏ដោយ ក៏អាចប្រែក្លាយខ្លួនទៅជាអធនិកម្នាក់ក្នុងការបដិវត្តវណ្ណៈអធនមួយបានដែរ ដោយទទួល ការអប់រំមួយដែលសមស្របនឹងលទ្ធិនោះ ។ ពួកគេទទួលឱវាទនេះ ដោយឥតល្អៀងដូចពួកគេទទួលឱវាទពីទ្រឹស្ដីកុម្មុយនិស្ដដែរ ។ ការបដិវត្តន៍អាចធ្វើឡើងនៅគ្រប់ប្រទេសទាំងអស់មិនប្រកាន់ថា ប្រទេសណាមួយឡើយឲ្យតែការបដិវត្តនោះត្រូវដឹកនាំយ៉ាងត្រឹមត្រូវដោយបក្សមួយ ក្រៅពីនេះ គឺជាភារកិច្ចខាងការអប់រំរៀនសូត្រ ។ ហើយការអប់រំរៀននោះ គឺរៀនក្បួនទ្រឹស្ដីរបស់បក្ស ។

ក្នុងប្រវត្តិសាស្ត្រនេះ គេបាននិយាយណែនាំឲ្យកម្មាភិបាលទាំងឡាយជួយធ្វើឲ្យក្បួនទ្រឹស្ដីមនោគមវិជ្ជាប្រែក្លាយទៅជាថាមពលដ៏ "មុតស្រួច" មួយ ដែលនឹងផ្ដល់ឲ្យគេនូវភាពក្លៀវក្លាក្នុងការប្រយុទ្ធតទល់នឹងខ្មាំងសត្រូវ រហូតដល់ទទួលបានជ័យជម្នះចុងក្រោយបំផុត ។ ដើម្បីឈានដល់គោលដៅនេះ និងដើម្បីយកជោគជ័យលើចក្រពត្តិនិយមអាមេរិកាំង ដែលមាន លន់ នល់ ជាខ្ញុំបម្រើបក្សត្រូវតែបង្កើតឲ្យបាន "ឯកភាពផ្ទៃក្នុងដាច់ខាត" ។ ក្នុងរឿងនេះ គេមិនត្រូវឲ្យមានការវែងគំនិតគ្នាក្នុងជួររបស់ខ្លួនទេ ហើយបក្សបានធ្វើការព្រមានយ៉ាងធ្ងន់ដល់បញ្ញវន្តទាំងឡាយ ដែលនឹងអាចសាកល្បងពិនិត្យមើលទ្រឹស្ដីផ្សេងៗ ដែលមានបង្ហាញក្នុងសៀវភៅផ្សេងៗទៀត ។ នេះគ្រាន់តែជាគំនិត "ប្រហោងក្លួង" ប៉ុណ្ណោះ គឺពុំមានបង្ហាញឲ្យឃើញភ័ស្ដុតាងដោយការពិសោធន៍របស់កម្ពុជាទេ ហើយដែលអាចបង្កឲ្យមានទំនាស់ជាមួយនឹងសកម្មភាពផ្សេងៗ ដែលបក្សរៀបចំរួចហើយផង ។ ប្រវត្តិសាស្ត្របក្ស បានដណ្ដើមកន្លែងស្នាដៃរបស់ជនកុម្មុយនិស្ដផ្សេងទៀតទាំងអស់ ។ ការនិយមភាពល្ងិតល្ងង់ និងការប្រឆាំងបញ្ញានិយម បានស្ថិតមានមួយរយៈក្នុងចំណោមពួកខ្មែរក្រហមជាជាងក្នុងភាគច្រើន នៃសង្គ្រាមបដិវត្តផ្សេងៗទៀតរបស់ពួកកុម្មុយនិស្ដ ។

ជំពូកសំខាន់ បានសរសេររាយការណ៍ពីជំនួយ ក៏ដូចគំរូរបស់ពួកកុម្មុយនិស្ដបរទេសនានា ដែលបង្ហាញឲ្យឃើញទិដ្ឋភាពពីរផ្ទុយគ្នា គឺពុំមែនបណ្ដាឲ្យមានគំនុំជាចំហនោះទេ ។ ក្រៅពីជំនួយ ពួកកុម្មុយនិស្ដកម្ពុជាបានទទួល "លទ្ធផលផ្សេងៗយ៉ាងអាក្រក់" ដោយធ្វើតាមគំរូ និងការណែនាំរបស់បណ្ដាមិត្តបរទេស ។ ចំពោះថ្ងៃខែកំណើតបក្ស ពួកខ្មែរក្រហមបានយល់ស្របតាមការសម្រុះសម្រួលគ្នាមួយ ដែលហាក់ដូចជាធ្វើឲ្យមានការពេញចិត្តព្រមគ្នា ទាំងចំពោះពួកយុទ្ធិកជនដែលមានចំណងទាក់ទងដ៏ជិតស្និទ្ធជាមួយវៀតណាមផង ទាំងពួកអ្នកដែលមិនជឿទុកចិត្តវៀតណាមផង ។ ពួកគេបានជ្រើសរើសយកថ្ងៃទី៣០ ខែកញ្ញា ជាថ្ងៃបើកមហាសន្និបាតទី១របស់បក្ស (នៅឆ្នាំ១៩៦០) ប៉ុន្តែ គឺដាក់ឆ្នាំ១៩៥១វិញ នៅពេលដែលពួកកម្ពុជាបង្កើតអង្គការមួយដោយឡែកក្នុងបក្ស

កុម្មុយនិស្តឥណ្ឌូចិនរបស់វៀតណាម ។ គេស្រុះស្រួលគ្នាកំណត់ថ្ងៃកំណើតបក្សដោយដាក់ថា ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៥១ (ពុំមែនថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៦០ទេ) ។

កែវ មាស[៣៧] បក្ខជនដើងចាស់ ដែលចូលជាសមាជិកបក្សកុម្មុយនិស្តឥណ្ឌូចិន ត្រូវបានតែងតាំងឲ្យធ្វើជាប្រធានគណៈកម្មាធិការមួយ ដែលទទួលបន្ទុកតាក់តែងប្រវត្តិសាស្ត្របក្ស ហើយបានបោះពុម្ពផ្សាយនៅឆ្នាំ១៩៧២ ។ គាត់បានបញ្ជាក់បំភ្លឺថា ការដាក់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៥១ គឺជាការស្រុះស្រួលគ្នាមួយ សំដៅបង្រួបបង្រួមបណ្តាសមមិត្តឆ្នាំ១៩៥១ ដែលជិតស្និទ្ធនឹងពួកវៀតណាម ជាមួយនឹងពួកឆ្នាំ១៩៦០ ដែលមិនទុកចិត្តចំពោះក្រុងហាណូយដូចគ្នា ។ ប៉ុន្តែ គាត់បានបន្ថែមថា ពីឆ្នាំ១៩៥១ ដល់ឆ្នាំ១៩៦០ នៅពុំទាន់មានបក្សពុំមានមហាសន្និបាត ដើម្បីចាត់តាំងបង្កើតគណៈកម្មាធិការកណ្តាលពិតប្រាកដមួយ ដើម្បីអនុម័តលក្ខន្តិកៈបក្ស និងមាគ៌ានយោបាយជាយុទ្ធសាស្ត្រ និងយុទ្ធវិធីនៅឡើយទេ ។

ក្នុងទីបំផុត ការសម្របសម្រួលនេះ ពុំធ្វើឲ្យមនុស្សណាម្នាក់ពេញចិត្តឡើយ ។ ប្រវត្តិសាស្ត្របក្ស ឆ្នាំ១៩៧២ បានដឹកនាំឲ្យបក្សធ្វើការកាត់ផ្តាច់ចំណងមិត្តភាពយ៉ាងគំហុកមួយ ជាមួយនឹងពួកវៀតណាមភ្លាមៗបន្ទាប់ពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពនៅក្រុងប៉ារីសរួចមក ហើយបណ្តាមេដឹកនាំបក្ស មិនចង់ធ្វើឲ្យបណ្តាសមមិត្ត ដែលជាប់ចិត្តខ្លាំងនឹងពួកវៀតណាមភ័យខ្លាចឡើយ ។ ម្យ៉ាងទៀត ពាក្យសម្តីដែលគេប្រើប្រាស់សម្រាប់និយាយពីពួកសមមិត្តទាំងនោះ សុទ្ធតែជាពាក្យសម្តីសម្រាប់ផ្សះផ្សាគ្នា ពុំមែនជាសម្តីគំរាមកំហែងទេ ពីព្រោះបក្សត្រៀមខ្លួនកាត់ផ្តាច់ចំណងទាក់ទងជាមួយពួកនិយមសម្តេច ព្រះនរោត្តម សីហនុ ដែលគេស្គាល់ក្រោម ឈ្មោះថា ខ្មែររំដោះ ឬខ្មែរអ្នកជាតិនិយម និងជាមួយ“កម្លាំងទីបី ដែលកំពុងបំបែកកម្លាំងនយោបាយផ្សេងៗនៅប្រទេសកម្ពុជាទៅជាបី ឬបួនក្រុមនោះដែរ ។

បើសិនជានៅមានការមិនទុកចិត្តមួយ ចំពោះការទាមទារសិទ្ធហួសហេតុរបស់បក្ស ដើម្បីប្រើអំណាចផ្តាច់ការមួយ ប្រវត្តិសាស្ត្របក្សបានធ្វើឲ្យរលាយអស់នូវការសង្ស័យនេះ ដោយសម្រេចតាមការសុំឲ្យរដ្ឋអំណាចជាន់ខ្ពស់ និងបក្សនេះ មានអំណាចខ្លាំងជាងចំនួនសរុបនៃក្រុមមនុស្សដែលរួមបង្កើតជាបក្សនេះ ។ “យើងត្រូវតែស្រឡាញ់ គោរពបូជាបក្ស និងបម្រើបក្សដោយស្មោះត្រង់ឥតលក្ខខណ្ឌហើយ ដែលត្រូវធ្វើជាដំបូង ដើម្បីតបស្នងសងគុណចំពោះការខិតខំប្រឹងប្រែងទាំងឡាយ ដែលបក្សបានបំពាក់បំប៉នយើង ...គ្មានអ្វីប្រសើរថ្លៃថ្លា និងប្រកបដោយកិត្តិយសជាងការចូលរួមក្នុងជួររបស់បក្សឡើយ...” ។

មុនពេលដែលប្រវត្តិនេះត្រូវចែកផ្សព្វផ្សាយក្នុងបក្សបន្តិច សៀវភៅស្តើងៗជាច្រើនត្រូវបានគេបោះពុម្ពផ្សាយ ក្នុងនាមរណសិរ្សរួបរួមជាតិនៅទីក្រុងប៉េកាំង ដោយមានរូបថតគណៈដឹកនាំខ្មែរក្រហម ដែលតាំងនៅក្នុងប្រទេសកម្ពុជាទៀតផង[៣៨] ។ ការចេញផ្សាយសៀវភៅស្តើងទាំងនេះ គឺមានគោលបំណងឆ្លើយតបទៅនឹង“ពាក្យមួលបង្កាច់ដ៏ថោកទាប និងគួរឲ្យស្អប់ខ្ពើមរបស់ម៉ាស៊ីនឃោសនារបស់ចក្រពត្តិអាមេរិកាំង” ដោយការពារ

ថាចលនាតស៊ូមិនទទួលស្គាល់ សម្ដេច ព្រះនរោត្ដម សីហនុ ជាមេដឹកនាំឡើយ ។ ដោយខុសពីទិសចំពោះសម្ដេច រូបថតចំនួនសាមសិបប្រាំពីរទំព័របានបង្ហាញឲ្យពិភពលោកឃើញមុខមនុស្សជាច្រើន ដែលគេមិនធ្លាប់ស្គាល់សោះនៃឋានានុក្រមកុម្មុយនិស្ដរបស់កម្ពុជា ។ នៅទំព័រដំបូង និងត្រង់កន្លែងកិត្តិយស គឺរូបថត«បិសាចទាំងបី» -ខៀវ សំផន, ហ៊ូ យន់ និង ហ៊ូ នឹម- ដែលបង្ហាញខ្លួនឡើងជាអ្នកមានសមត្ថភាពនៃរឿងប្រវត្តិរបស់គាត់មែន ៖ ជាមនុស្សស្អាតសង្ហា ត្រឹមត្រូវ ថ្លៃថ្នូរ ដែលឃ្លាតខ្លួនចេញពីជួរទាហានកសិករ ដូចពួកបញ្ញវន្ត និងបណ្ដាមេដឹកនាំដែលជឿជាក់លើខ្លួនឯងដែរ ។ គេបានពិពណ៌នាពីអ្នកទាំងបីថា ជាមនុស្សសំខាន់នៃសម័យកាលប្រែប្រួលមួយដែលកំពុងរស់នៅក្នុងព្រៃភ្នំក្រាំថ្ម ដើរកាត់វាលល្បប់ចែករំលែកម្ហូបអាហារដ៏អត្តខាត់ជាមួយគ្នា ចូលរួមសម័យប្រជុំផ្សេងៗ ដោយដេកសម្រាលក្នុងអង្រឹងមួយ ប្រកបដោយបុកពាជឿទុកចិត្តលើខ្លួនឯងជានិច្ច ។

ដោយធ្វើតាមបន្ទប់តាំងរូបថតពួកមេដឹកនាំពិតប្រាកដរបស់បក្ស គេមិនដែលបញ្ចេញឲ្យឃើញដូចពេលនេះឡើយ ។ រូបថតទីមួយ បង្ហាញឲ្យឃើញរូប សាឡុត ស អង្គុយក្បែរ នួន ជា ខាងមុខព្រៃឫស្សីមួយ ដៃដាក់ខ្វែងគ្នាដោយប្រអូសលើជង្គង់ ។ រស្មីព្រះអាទិត្យបានបាចសាចពន្លឺពុះជ្រែកតាមចន្លោះមែកឈើ ហាក់ដូចជាប្រដាប់បញ្ចាំងពន្លឺមួយជះមកលើថ្ពាល់កំពុងទាំងពីរ លើសក់ក្បាលរបស់ ស ដែលធ្វើឲ្យគាត់មានលក្ខណៈមួយ ដែលមិនចេះព្យាបាទអ្នកណា របៀបដូចអ្នកស្រែល្ងីល្ងើម្នាក់ដូច្នោះ ។ ឥរិយាបថរបស់គាត់ ដូចក្នុងរូបថតពីរផ្សេងទៀតដែលថតជាក្រុមដែរ ពេលដែលគាត់បង្ហាញរូបរាជក្បែរ អៀង សារី ម្នាក់ មើលសឹងតែមិនស្គាល់ ព្រោះគាត់ស្គមខ្លាំងពេក និង កុយ ធួន ប្រកបដោយទឹកមុខដែលឲ្យប្រផ្នូលអាក្រក់ម្នាក់ ហើយជាថ្មី ស ឈរ ថតក្បែរ នួន ជាម្ដងទៀត ។ អ្នកទាំងអស់នេះ សុទ្ធតែជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្សដ៏មានឥទ្ធិពលបំផុត ថ្វីបើចំណងជើងរូបថតមិននិយាយឲ្យដឹងហេតុការណ៍នេះក៏ដោយ ហើយបានផ្ដល់ឲ្យដឹងតែមុខងាររបស់ពួកគេនៅ ក្នុងផ្ទៃរណសិរ្សរួបរួមជាតិប៉ុណ្ណោះ ។

ពួកគេបានបង្ហាញ «ឋានៈ» របស់គេតាមរយៈសម្លៀកបំពាក់ និងបរិបទ ដែលពួកគេបានជ្រើសរើសសម្រាប់ការថតរូបទាំងនេះ ។ ពុំមានតុបតែងខ្លួនដោយសម្លៀកបំពាក់ពណ៌ខ្មៅ ទៅតាមទម្លាប់ទាំងពុំមានក្រមាក្រឡាដុំការរ៉ូបង់ជុំវិញកដូច «ពួកបិសាចទាំងបី» ឡើយ ។ ពួកគេពាក់អាវសឺមីដៃខ្លីមួយ និងស្លៀកខោកាគី កាត់ដេរគ្មានសមមួយ ដែលធ្វើឲ្យគេយល់ពីការរស់នៅដ៏ពិបាកតឹងតែងមួយក្នុងព្រៃភ្នំ ។ ពួកគេបានឈរថតនៅខាងមុខព្រៃមួយ ដែលគេស្គាល់ភ្លាមថា កន្លែងនេះជាទីតាំងពិតប្រាកដរបស់ពួកអ្នកពួនព្រៃដើម្បីតស៊ូ ។ គេពុំឃើញពួកនោះពាក់ មួកយោធាទេ ដោយស៊ូទ្រាំនឿយលំបាកក្នុងវាលល្បប់ ឬសើចសប្បាយជាមួយនឹងសមមិត្តជាយុទ្ធជនរបស់ពួកគេ ដូច«បិសាចទាំងបី»ដែរ ។ ពួកមេដឹកនាំពិតប្រាកដ ច្រើនមានលក្ខណៈរស់នៅតែឯកឯង ។ ពួកគេមានទឹកមុខស្រងូតស្រងាត់ និងអស់កម្លាំង ម៉ឺងម៉ាត់ ទោះបីជានៅពេលដែលគេអាចធ្វើឲ្យម្នាក់ៗ បញ្ចេញស្នាមញញឹមមួយក៏ដោយ ក៏ពួកគេនៅតែម៉ឺងម៉ាត់ដដែល ។ ក្នុងចំណោមអ្នកទាំងអស់ សាឡុត ស មានលក្ខណៈមិនសូវឲ្យគេ

កត់សម្គាល់ប៉ុន្មានទេ ឥរិយាបថឈរថតរបស់គាត់ ក៏មិនសូវបញ្ចេញរាងឲ្យគេឃើញប៉ុន្មានដែរ ។ នៅពីមុខកែវម៉ាស៊ីនថត គាត់ច្រើនតែលាក់មុខ ។

រូបថតស្ត្រី ដែលមានតែមួយក្នុងសៀវភៅស្តើង គឺរូបថតប្រពន្ធរបស់ អៀង សារី និង សាឡុត ស ឈ្មោះ ខៀវ ធីរិទ្ធ និងបងស្រីរបស់នាងឈ្មោះ ខៀវ ប៉ុណ្ណារី ។ ធីរិទ្ធ ត្រូវបានបង្ហាញឲ្យដឹងថា នាងជាភរិយារបស់ អៀង សារី ប៉ុន្តែ គេមិនបានរៀបរាប់បញ្ចូលពីចំណងទាក់ទងផ្សេងៗ ដែលបានបង្រួបបង្រួម ប៉ុណ្ណារី ជាប្រពន្ធរបស់ ស ទេ ។ ទោះជា ប៉ុណ្ណារី មានអាយុលើស ធីរិទ្ធ តែប្រាំបួនឆ្នាំក៏ដោយ ក៏នាងហាក់ដូចជាម្តាយរបស់ ធីរិទ្ធ អ៊ីចឹង ។ សក់ក្បាលរបស់នាងមានសម្បុរល្បាយអាចម៍ខ្វាគួរឲ្យឆ្ងល់ មុខរបស់នាងស្គមតូចមានសភាពដូចមុខខ្មោច ។ នៅពេលដែល ធីរិទ្ធ សម្លឹងមើលចំកែវម៉ាស៊ីនថត ប៉ុណ្ណារី បែរជាសម្លឹងទៅចំណុចមួយក្នុងទីដ៏ឆ្ងាយទៅវិញ ដៃទាំងពីរសំយ៉ុងចុះតាមបណ្តោយខ្លួនរបស់នាងយ៉ាងប៉ក់ល្ហើយ ។ ការឈរឲ្យគេថតពុំបានបិទបាំងលក្ខណៈរបស់នាងឡើយ ៖ ប៉ុណ្ណារី បានក្លាយទៅជាមនុស្សឡប់ស្មារតី ក្នុងការបម្រើបដិវត្តន៍របស់ប្តីនាង ។

តមកទៀត គេឃើញរូប សុន សេន កំពុងឱនពិនិត្យមើលផែនទី និងរបាយការណ៍ផ្សេងៗ នៅទីសេនាធិការកងទ័ព ។ នេះជាការបញ្ជាក់អះអាងថា គាត់ជាប្រមុខកងទ័ពដែលបក្សបានជ្រើសរើសដោយខ្លួនឯង ។ សម្រាប់ពួកអ្នកសង្កេតការណ៍ ដែលឆ្លាតវៃដឹងថា បណ្តាសមាជិកនៃក្រុមក្រុងប៉ារីស បានលេចមុខឡើងក្នុងឋានៈជាមេដឹកនាំរបស់ការបដិវត្ត ដោយអះអាងបញ្ជាក់ពីការក្តោបក្តាប់ស្ថាប័នសំខាន់បំផុតមួយក្នុងចំណោមស្ថាប័នសំខាន់ទាំងអស់របស់ខ្លួន គឺស្ថាប័នកងទ័ព ។ កងទ័ពជាអង្គភាពចម្រុះមួយ ដែលបង្រួបបង្រួមប្រជាកសិករដែលឃ្លាតចាកស្រុកកំណើត និងពួកបញ្ញវន្ត ដែលបានបោះបង់ចោលអាជីពរបស់គេ ។ គឺក្នុងកងទ័ពនេះហើយ ដែលពួកកសិករនិងពួកអ្នកភៀសខ្លួនពីទីក្រុង ចាប់ទទួលការអប់រំផ្នែកនយោបាយ ដែលពួកគេត្រូវបញ្ចុះបញ្ចូលឲ្យមានជំនឿលើទ្រឹស្តីកុម្មុយនិស្តថែមទៀត ។ ពួកយុវជន ដែលគួរឲ្យសង្ស័យច្រើន សុទ្ធតែត្រូវដឹកនាំទៅរកមុខតំណែងទទួលខុសត្រូវផ្សេងៗក្នុងកងទ័ព គឺពុំមែនរក្សាទុកនៅសមរភូមិក្រោយសម្រាប់បំពេញភារកិច្ច ដែលគ្មានគ្រោះថ្នាក់នោះទេ ។ ការបញ្ចេញស្នាដៃរបស់ខ្លួននៅពេលប្រយុទ្ធ គឺជារបៀបមួយក៏ដូចរបៀបដទៃទៀតដែរ ដើម្បីបញ្ចេញឲ្យគេឃើញសម្រាប់ជនបដិវត្តម្នាក់ ។

យុវជនទាំងឡាយ ត្រូវតែធ្វើខ្លួនជាសមាសភាពដ៏មោះមុតមួយរបស់ការបដិវត្ត ហើយការបដិវត្តគោងតែពឹងផ្អែកជាសំអាងលើកងទ័ព ។ យោធនិយម គឺជាក្បួនទ្រឹស្តីរបស់លទ្ធិម៉ាក្សលេនីន ។ ដូចក្នុងប្រទេសវៀតណាមជិតខាង ពួកកម្ពុជាបានរកឃើញក្នុងពេលមានសង្គ្រាមថា វាជាការប្រសើរបំផុត ដែលត្រូវជ្រើសរើសសមាជិកថ្មីៗទៀតនៅក្នុងកងទ័ព បន្ទាប់មក ក្នុងចំណោមប្រជាជនស៊ីវិល ។ ក្នុងកងទ័ព យុវជនទាំងនេះអាចនឹងជម្រុះវណ្ណៈភាពដើមរបស់ពួកគេជាកសិករ ឬជាគហបតីតូចតាច ហើយទាមទារឲ្យគេរាប់ចូលក្នុងវណ្ណៈអធនវិញ នៅពេលដែលពួកគេនឹងវាយប្រយុទ្ធបានខ្លាំងក្លា នៅសមរភូមិនានារួចមក ។

សង្គ្រាមនៅប្រទេសកម្ពុជាបានឆ្លងចូលទៅដំណាក់កាលថ្មីមួយទៀត ជាមួយនឹងកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស ដែលចុះហត្ថលេខានៅថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៧៣ ដោយសហរដ្ឋអាមេរិក និងវៀតណាមខាងជើង ។ កិច្ចចរចានោះ មានថិរវេលាបួនឆ្នាំ គឺពេញអាណត្តិទី១របស់ប្រធានាធិបតី និចសុន ដែលបានត្រឹមតែផ្តល់អត្ថប្រយោជន៍ចំពោះក្រុងវ៉ាស៊ីនតោន និងក្រុងហាណូយប៉ុណ្ណោះ ។ ពួកអាមេរិកាំង បានទទួលនូវទីបញ្ចប់នៃការជាប់ដៃប្រយុទ្ធរបស់គេក្នុងសង្គ្រាម និងការធ្វើឲ្យមានសេរីភាពដល់ពួកទាហានអាមេរិកាំង ដែលគេឃុំឃាំងទុកជាឈ្លើយសង្គ្រាម ។ ពួកវៀតណាមខាងជើង បានតម្រូវឲ្យកងទ័ពសហរដ្ឋអាមេរិកដកថយចេញពីវៀតណាមខាងត្បូង និងការបញ្ឈប់ការទម្លាក់គ្រាប់បែកលើវៀតណាមខាងជើង ដោយមិនបានដកទ័ពរបស់ពួកគេចេញពីវៀតណាមខាងត្បូង ដែលបទឈប់បាញ់គ្នាមួយបានត្រូវប្រកាសឡើងផងទេ ។

ទោះយ៉ាងណាក៏ដោយ ក៏ លន់ នល់ បានស្នើឲ្យគូសត្រូវរបស់គាត់ពិនិត្យមើលបទឈប់បាញ់គ្នាមួយជាមួយគាត់ដែរ ។ ប៉ុន្តែពួកខ្មែរក្រហម បានបដិសេធមិនចូលរួមក្នុងកិច្ចចរចាទាំងនេះទេ ដោយមានគំនិតថា ការផ្អាកឈប់ច្បាំងគ្នាមួយនៅប្រទេសកម្ពុជា នឹងធ្វើឲ្យពួកគេបាត់បង់ប្រៀបឈ្នះសំខាន់បំផុតផ្នែកយុទ្ធសាស្ត្រមិនខាន គឺភាពស្ទើរតែឯកោរបស់ទីក្រុងភ្នំពេញ ដែលត្រូវកាត់ផ្តាច់ដោយផ្នែកពីដែនដីផ្សេងទៀត ដែលកាន់កាប់ដោយរបបសាធារណរដ្ឋខ្មែរ និងពីប្រភពផ្គត់ផ្គង់ទាំងឡាយនៅប្រទេសវៀតណាមខាងត្បូង និងថៃ[៣៩] ។ សហរដ្ឋអាមេរិកបានយល់ព្រមដាក់កាលកំណត់មួយ ក្នុងការទម្លាក់គ្រាប់បែកនៅប្រទេសឡាវដែរ កាលបើកិច្ចព្រមព្រៀងឈប់បាញ់គ្នាមួយនឹងត្រូវចុះហត្ថលេខា នៅក្នុងប្រទេសនេះនៅខែកុម្ភៈ ឆ្នាំ១៩៧៣ គឺមួយខែក្រោយមក ។

ផលវិបាកផ្សេងៗសម្រាប់ប្រទេសកម្ពុជាបានកើតមានឡើងភ្លាមៗយ៉ាងសម្បើម ហើយធ្លាក់សង្គ្រប់មកលើប្រទេសជាតិដោយគ្មានដឹងខ្លួនជាមុនឡើយ ។ ដោយស្ថិតនៅខាងក្រៅកិច្ចចរចាទាំងអស់ ពួកខ្មែរក្រហមបានធ្វើឲ្យប្រទេសរបស់គេ ក្លាយទៅជាចំណុចកណ្តាលថ្មីមួយដោយអចេតនា ក្នុងសង្គ្រាមឥណ្ឌូចិនលើកទីពីរ កិច្ចព្រមព្រៀងទាំងឡាយ បាននាំទៅដល់ការដកថយកងទ័ពកុម្មុយនិស្តវៀតណាមមួយភាគធំ ចេញពីកម្ពុជាយ៉ាងឆាប់រហ័ស ។ កងទ័ពទាំងនេះ បានត្រឡប់ទៅប្រទេសវៀតណាមវិញ ឬនៅប្រមូលផ្តុំតាមបណ្តោយព្រំដែនរួម ដោយទុកសមរភូមិប្រយុទ្ធឲ្យពួកសម្ព័ន្ធមិត្តខ្មែររបស់ពួកគេម្តង ។ ដោយចៃដន្យ ឬដោយចេតនា ក្រោយនោះបន្តិចគ្រឿងសព្វាវុធផ្សេងៗ ដែលទុកសម្រាប់ឲ្យកងទ័ពរបស់ សាឡុត ស បានត្រូវគេធ្វើឲ្យយឺតយ៉ាវ ឬមិនដែលមកដល់ទាល់តែសោះ ។ នៅទីបំផុត សង្គ្រាមនៅប្រទេសកម្ពុជា បានធ្វើឲ្យកងទ័ពរបស់កម្ពុជាទាំងអស់វាយប្រយុទ្ធតែជាមួយគ្នាឯង ហើយកម្រិតនៃសង្គ្រាមនេះ ប្រើវិធីកាន់តែខ្លាំងឡើងដែរ ។

សារសំខាន់ទីពីរនៃកិច្ចព្រមព្រៀងនេះ គឺការហាមឃាត់រាល់ការចូលពាក់ព័ន្ធផ្នែកយោធារបស់អាមេរិកាំងនៅប្រទេសវៀតណាម និងឡាវ ។ ប្រទេសកម្ពុជា បានក្លាយទៅជាកន្លែងប្រតិបត្តិការតែមួយគត់សម្រាប់យន្តហោះប្រតិកម្មទម្លាក់គ្រាប់បែករបស់អាមេរិកាំង ហើយនៅខែកុម្ភៈ ឆ្នាំ១៩៧៣ ភ្លៀងគ្រាប់បែកជាច្រើន

គោន បានចាប់ផ្ដើមធ្លាក់ពីយន្តហោះបេ-៥២ ។ ពួកវៀតណាមខាងជើង ធ្លាប់បានប្រាប់ឲ្យពួកកុម្មុយនិស្តកម្ពុជា ប្រុងប្រៀបការពារខ្លួនតទល់នឹងភាពដែលអាចកើតឡើងដោយថាហេតុនេះដែរ ប៉ុន្តែពួកខ្មែរក្រហមបានវិនិច្ឆ័យថា កិច្ចព្រមព្រៀងនេះ ជាអំពើក្បត់មួយរបស់បណ្ដាប្រទេសជិតខាង និងសម្ព័ន្ធមិត្តរបស់ពួកគេថែមទៀត ។ ប៉ុន្តែ ជាសាធារណៈ ពួកខ្មែរក្រហមបានរក្សាការស្ងៀមស្ងាត់ មិននិយាយអ្វីទាំងអស់ ។ នៅលើសមរភូមិ ពួកគេបានធ្វើការរៀបចំឲ្យស្រេចនូវផែនការសាមញ្ញ និងដ៏ម៉ឺងម៉ាត់មួយ ដើម្បីការពារខ្លួនទល់នឹងការទម្លាក់គ្រាប់បែក និងអំពើ "ក្បត់ថ្មី" មួយរបស់ពួកវៀតណាម គឺផែនការមួយតម្រូវឲ្យដាក់ខ្លួននៅតែឯកឯង និងពង្រឹងស្ថានភាពវាយប្រយុទ្ធការពារអាយុជីវិតខ្លួន និងធ្វើពលិកម្មចាំបាច់គ្រប់បែបថែមទៀត ។

ពួកខ្មែរក្រហមបានប្រមូលផ្ដុំប្រជាជនទាំងអស់នៅតំបន់របស់ខ្លួន បង្កើតជាសហករណ៍ដែលមានបទបញ្ញត្តិយ៉ាងតឹងរ៉ឹង ជាប្រភេទ "បន្ទាយការពារ" ជាទីដែលគេបង្ខាំងមនុស្ស ផលដំណាំ និងគ្រឿងសម្ភារសព្វបែបយ៉ាងទុកសម្រាប់តែឲ្យបក្ស និងបដិវត្ត ប្រើប្រាស់ប៉ុណ្ណោះ[៤០] ។ គ្មានអ្នកណាម្នាក់អាក្រក់អាចចូល ឬចេញពីសហករណ៍ទាំងនេះ ដោយគ្មានការអនុញ្ញាតពីបក្សបានឡើយ ។ ភូមិទាំងឡាយបានក្លាយទៅជា "បន្ទាយតូចៗ" នៅជនបទ ដែលត្រូវបានគ្រប់គ្រងតាមច្បាប់អាជ្ញាសឹក ។ អ្វីៗទាំងអស់ដែលផលិតបានដោយសហករណ៍ ត្រូវបានប្រើប្រាស់សម្រាប់ការបដិវត្តខ្មែរ ។ គ្មានអ្នកណាម្នាក់ ហើយជាពិសេស គឺពួកវៀតណាមមានសិទ្ធិទិញផលិតផលរបស់កម្ពុជាឡើយ ការទាក់ទងជាមួយពិភពខាងក្រៅ ក៏លែងមានសេរីភាពក្នុងការបោះពុម្ពផ្សាយ និងការដើរហើរត្រូវបានហាមឃាត់ ។ ក្រដាសប្រាក់ត្រូវបានបំបាត់ចោលក្នុងបំណងធ្វើឲ្យការជួញដូរមិនស្របច្បាប់ផ្សេងៗលែងបានប្រយោជន៍ ។ របៀបគ្រប់គ្រងតាមបែបភេរវកម្មមួយ ត្រូវបានបង្កើតឡើង ។

សាឡុត ស បានរៀបរាប់ពីទិសដៅជាយុទ្ធសាស្ត្រ ឆ្លងតាមរយៈសហករណ៍ទាំងនេះថា "*កាលពីដើម ពួកអ្នកមានផ្ទះសម្បែងដីធ្លី និងពួកឈ្មួញ បានប្រមូលទិញស្រូវទាំងអស់ដើម្បីលក់ទៅឲ្យបនលន់នល់ និងពួកវៀតណាម ។ ស្រទាប់អ្នកក្រីក្រនៃប្រជាជនយើង ខ្វះខាតស្រូវអង្ករហូបយ៉ាងខ្លាំង ។ ...កងទ័ពបដិវត្តដែលវាយប្រយុទ្ធនៅសមរភូមិក៏ខ្វះអង្ករហូបដែរ ហើយត្រូវបង្ខំចិត្តហូបបបរគ្រប់តែពេលបាយ... ។ គឺសម្រាប់មូលហេតុនេះហើយ បានជាគណៈកម្មាធិការមជ្ឈិមបក្សយើង សម្រេចបង្កើតសហករណ៍នៅក្នុងតំបន់រំដោះទាំងមូល នៅឆ្នាំ១៩៧៣ ទោះជាសហករណ៍ទាំងនោះមានកម្រិតទាប ឬកម្រិតខ្ពស់ក៏ដោយ*[៤១]" ។

ការបង្កើតសហករណ៍ បានក្លាយទៅជាវគ្គមួយនៃសង្គ្រាម ដែលតាមរយៈនេះ ពួកខ្មែរក្រហមបានបញ្ចប់បញ្ហាកងទ័ព សេដ្ឋកិច្ច និងសង្គមកិច្ច បានសម្រេចព្រមគ្នា ។ ដោយកាន់កាប់អំណាចស្ទើរតែផ្ដាច់ការមួយ ពួកគេអាចរៀបចំពេលម៉ោងធ្វើការត្រូវគ្នានឹងការទម្លាក់គ្រាប់បែករបស់ពួកអាមេរិកាំង ។ ដួន ប្រសិទ្ធិ បានបកស្រាយថា "របៀបចាត់ចែងនេះ ជួយធ្វើឲ្យប្រជាជនយើងចេះរៀបចំការបង្កបង្កើនផលបានដោយស្រួល ។ បើគេទម្លាក់គ្រាប់បែកនៅពេលថ្ងៃ ពួកគាត់ធ្វើការនៅពេលយប់ ហើយធ្វើឆ្លាស់គ្នាទៅវិញទៅមក នៅពេលណា

ដែលការទម្លាក់គ្រាប់បែកប្រែប្រួល» ។ ឥឡូវនេះ ពួកកុម្មុយនិស្តវៀតណាមត្រូវបានចាត់ទុកជាពួកអ្នកនាំវិវាទថែមទាំងជាសត្រូវទៀតផង ។ ច្បាប់វិន័យដ៏តឹងរ៉ឹងរបស់សហករណ៍ បានរាំងរាមិនឲ្យមានការទាក់ទងទាំងអស់ជាមួយពួកវៀតណាម ជាការហាមឃាត់ដែលក៏ត្រូវអនុវត្តដោយឯងៗជាមួយទាហាន លន់ នល់ ដែរ ។

សេចក្ដីសម្រេចបង្កើតសហករណ៍ បានរំសាប់សេចក្ដីភ័យព្រួយរបស់ប្រជាកសិករដែលព្រឺខ្លាចថា គេច្បាស់ជាបញ្ចូលមនុស្សពេញកម្លាំង ព្រមទាំងយុវជននារីមួយចំនួនធំឲ្យចូលបម្រើកងទ័ពទាំងអស់ ដែលនឹងធ្វើឲ្យភូមិមិនអាចផលិតអ្វីៗចិញ្ចឹមជីវិតបានឡើយ ។ ដោយមានសហករណ៍ទាំងនេះ ពួកខ្មែរក្រហមបានសន្យាថា គ្មានអ្នកណាម្នាក់ត្រូវអត់បាយឡើយ ទាំងយុវស្វាមីដែលគេបញ្ជូនទៅសមរភូមិ ទាំងឪពុកម្ដាយ ទាំងប្រពន្ធទាំងកូនៗរបស់ខ្លួនដែលស្ថិតនៅផ្ទះសម្បែង ។ ស្បៀងអាហារដែលគេត្រៀមទុកទាំងអស់ត្រូវបានបែងចែកគ្នាខ្លះៗ ដោយត្រឹមត្រូវជានិច្ច ។ របស់អស់នេះមានមិនគ្រប់គ្រាន់មែន ប៉ុន្តែ ពួកខ្មែរក្រហមវាយតម្លៃថា ប្រជាជនអាចធ្វើពលិកម្ម ជាចាំបាច់ដើម្បីបានឈ្នះ «សង្គ្រាមស្រូវ» ដែលគេនាំមុខធ្វើស្របគ្នានឹងប្រតិបត្តិការខាងយោធាដែរ ។ ជ័យជម្នះនឹងធ្លាក់មកលើក្រុមណា ដែលចេះផ្គត់ផ្គង់ប្រជាជន និងកងទ័ពរបស់ខ្លួនជាមិនខាន ។

មូលហេតុជំរុញទៅរកការសងសឹក បានចូលមកឡូកឡំក្នុងរឿងនេះ ។ សម្រាប់ពួកខ្មែរក្រហម យល់ថា ដោយបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្រុងប៉ារីស ពួកវៀតណាមខាងជើង បានបើកឱកាសឲ្យពួកអាមេរិកាំងបញ្ជូនយន្តហោះយ៉ាងច្រើនមកទម្លាក់គ្រាប់បែកនៅប្រទេសកម្ពុជា ។ ឥឡូវនេះ ពួកវៀតណាមប្រហែលជាទទួលរងផលវិបាកផ្សេងៗពីរឿងនោះដូចគ្នា គឺកងទ័ពរបស់ក្រុងហាណូយ លែងអាចធ្វើដំណើរទៅមកដោយសេរីនៅកម្ពុជាទៀតហើយ ទាំងក៏មិនអាចចិញ្ចឹមកងទ័ពរបស់ខ្លួនដោយស្រូវអង្ករបស់កម្ពុជាទៀតដែរ ។ ប្រសិទ្ធិ រៀបរាប់ ពួកវៀតណាមជាអ្នកបង្កឲ្យមានបញ្ហាសំខាន់នៅ [ឆ្នាំ១៩៧៣] ដែលយើងបណ្ដោយឲ្យគេនិយាយមិនត្រឹមត្រូវ (ដើម្បីឲ្យអ្នកដទៃចាប់អារម្មណ៍) ។ ពួកគេចង់ទិញអង្ករពីយើង នៅពេលនោះ យើងបំបាត់មិនឲ្យចាយលុយក្លាម ។ ដូច្នេះ បើប្រជាជនមិនត្រូវការលុយកាក់ បើពួកគាត់រស់នៅក្នុងសហករណ៍មួយ ដែលអ្វីៗត្រូវបានផ្គត់ផ្គង់ដោយរដ្ឋនោះ ច្បាស់ជាពួកគាត់មិនលក់ស្រូវអង្ករឲ្យពួកវៀតណាមឡើយ[៤២] » ។

សង្គ្រាម ដែលគ្មានប្រកាសរវាងពួកកុម្មុយនិស្តខ្មែរ និងពួកវៀតណាមបានចាប់ផ្ដើមហើយ ។ ជាច្រើនឆ្នាំក្រោយមក ឡេ ឌឹកថូ មេដឹកនាំម្នាក់ក្នុងចំណោមមេដឹកនាំវៀតណាមខាងជើង បានទទួលស្គាល់នូវផលវិបាកផ្សេងៗ ដែលនាំមកនូវការវិនាសអន្តរាយដោយសារការផ្លាស់ប្ដូរយុទ្ធសាស្ត្ររបស់ខ្មែរក្រហមថា «បន្ទាប់ពីឆ្នាំ ១៩៧៣ កងទ័ពរបស់វៀតណាមបានពើបប្រទះនឹងឧបសគ្គយ៉ាងច្រើន ដែលពួកកុម្មុយនិស្តកម្ពុជាបានបង្កើតឡើងក្នុងការធ្វើដំណើរដោយសេរី និងការទិញដូរគ្រឿងឧបភោគបរិភោគរបស់យើង[៤៣] » ។

ថ្វីបើ ប្រសិទ្ធិ បានអះអាងក្រោយមកទៀតថា នៅឆ្នាំ១៩៧៣ ពួកវៀតណាមបានរួមបង្កឲ្យមានបញ្ហាសំខាន់នេះឡើងក៏ដោយ ក៏គឺដើម្បីប្រឆាំងនឹងសាធារណរដ្ឋខ្មែរ ក៏ដូចពួកកុម្មុយនិស្តកម្ពុជាដែលកំពុងធ្វើសង្គ្រាម

ដែរ ។ ដើម្បីយល់ដឹងពីរបៀបណាដែលពួកខ្មែរក្រហមត្រូវជំនួសពួកវៀតណាមទាំងស្រុងនៅលើសមរភូមិ និងវាយឈ្នះក្រុងភ្នំពេញតែរវាងជាងពីរឆ្នាំនេះ គេគោងតែពិនិត្យមើលផ្នែកខាងក្នុងសហករណ៍ទាំងនោះទើបបានដឹង ។ គឺពុំមែនជាសហគមន៍កសិកម្មសង្គម ដែលអធិប្បាយដោយ ហ៊ូ យន់ នោះទេ ប៉ុន្តែ គឺពិតជាជំរំយោធា ដែលនឹងក្លាយទៅជាគំរូរបស់ «សង្គមថ្មី» ។

ពួកខ្មែរក្រហមបានបំបែកភូមិភាគនានារបស់ពួកគេស្ថិតនៅដាច់ដោយឡែក ដោយបង្កើតជា «ដែនដីចន្លោះ» (ដែនដីនៅចន្លោះទ័ព៣២) ជាច្រើនកន្លែងដែលមានទំហំទទឹងជាច្រើនគីឡូម៉ែត្រ ។ ប្រជាកសិករដែលរស់នៅក្នុងតំបន់ទ្រនាប់ទាំងនេះ ត្រូវបានកៀរយកទៅដូចសត្វធាតុរហូតទៅដល់សហករណ៍នានា ដែលស្ថិតនៅកណ្តាលដែនដីខ្មែរក្រហម ឬក្នុងតំបន់រហោឋានផ្សេងៗ ជាទីដែលពួកគេត្រូវចាប់ផ្តើមបំពេញកិច្ចការពីលេខសូន្យទៅ ដោយរៀបចំកាប់គាស់រានព្រៃ និងភ្ជួរដីក្នុងស្ថានភាពខ្វះមុខខ្វះក្រោយ ដោយបានទទួលជំនួយសម្ភារយ៉ាងតិចតួចបំផុតពីសំណាក់ពួកកុម្មុយនិស្ត ។ តំបន់ទ្រនាប់ទាំងនេះ មានពង្រាយអន្ទាក់ជាច្រើន និងមានកងល្បាតដើរយាមកាមទាំងយប់ទាំងថ្ងៃ ។

ការឃ្លាំមើលយ៉ាងតឹងរ៉ឹងនៅតាម «ព្រំប្រទល់» ដែនដីទាំងនេះ បានប្រព្រឹត្តទៅព្រមគ្នានឹងការត្រួតត្រាសហករណ៍នានាយ៉ាងណែនមួយដូចគ្នា ។ មិនយូរប៉ុន្មាន មនុស្សជាច្រើនបានចាប់ផ្តើម «បាត់ខ្លួន» ។ គេមិនដែលឃើញពួកអ្នកដែលគេដេញតាមទៅទាន់ពេលកំពុងឆ្លងកាត់ព្រំប្រទល់តាមទិសមួយ ឬទិសផ្សេងទៀត ដោយគ្មានសំបុត្រអនុញ្ញាតពីរដ្ឋអំណាច បានវិលត្រឡប់មកវិញសោះឡើយ ។ ពីទីក្រុងប៉េកាំង សម្តេច ព្រះនរោត្តម សីហនុ បានមានព្រះបន្ទូលថា ព្រះអង្គមិនអាចធានាការពារគ្រប់ជនបរទេសទាំងអស់ទោះ ជាជនបរទេសណាក៏ដោយ ដែលធ្វើដំណើរទៅ «ប៉ែកម្ខាងទៀត» ។ ការសាយភាពជាលើកដំបូងនូវសេចក្តីភ័យខ្លាច មិនអាចពិពណ៌នាបានមួយ បានរាលដាលពេញ «តំបន់រំដោះ» នានា ។ ដំណាក់កាលនៃរបៀបរៀបចំយឺតៗ និងដែលគិតគូរផលប្រយោជន៍មិនប្រាកដរបស់ប្រជាជនបានត្រូវបញ្ចប់ ។ ខេនណេត គ្វីន *(Kenneth Quinn)* មន្ត្រីអាមេរិកាំងផ្នែកការងារទូតដែលជាអ្នកបានសាកសួរពួកអ្នកភៀសខ្លួន ដែលរត់ចេញពីតំបន់ទាំងនេះ បានសរសេរថា «អ្នកទាំងឡាយ ដែលបានរួចផុតពីគ្រោះថ្នាក់ក្នុងការធ្វើដំណើរដំបូងៗ [ដើម្បីបង្កើតតំបន់ទ្រនាប់នានា] បានរៀបរាប់ថា មានមនុស្សជាច្រើនត្រូវស្លាប់ក្នុងពេលធ្វើដំណើរ ហើយថាពួកដែលនៅរស់ពេលដែលទៅដល់ [តំបន់រហោឋានទាំងនោះ] ត្រូវធ្វើការដូចពួកអ្នកជាប់ទោសឧក្រិដ្ឋ ដែលត្រូវបង្ខំឲ្យធ្វើការជាទម្ងន់[៤៤]» ។

គ្វីន បានបំពេញមុខងារនៅវៀតណាមខាងត្បូង ក្នុងខេត្តកង់ថឺ ក្បែរព្រំដែនកម្ពុជា ដោយមានបេសកកម្មតាមដានព្រឹត្តិការណ៍ផ្សេងៗផ្នែកនយោបាយនៅប្រទេសវៀតណាមផង ។ នៅដើមឆ្នាំ១៩៧៣ គាត់បានត្រូវធ្វើឆ្ងល់សង្ស័យដោយការប្រែប្រួលភ្លាមៗ ដែលធ្វើឲ្យប៉ះពាល់ដល់ផ្សារងងឹត និងការរត់ពន្ធនៅក្នុងតំបន់នេះ ។ មិនយូរប៉ុន្មាន គាត់បានតាមដានពិនិត្យមើលបញ្ហានេះដោយខ្លួនឯង ។ ដោយពុំបានទទួលការបំភ្លឺរឿងអាថ៌កំបាំង

នេះ ពីខាងប្រភពព័ត៌មានរបស់វៀតណាម គ្វីន បានទៅសួរដេញដោលរឿងនេះពីពួកអ្នកភៀសខ្លួនកម្ពុជាម្តង ។ លទ្ធផលនៃការងារនេះ ដែលផ្អែកលើការសន្ទនាផ្សេងៗ ដែលសម្រេចធ្វើពីខែមីនា ឆ្នាំ១៩៧៣ ដល់ខែមករា ឆ្នាំ១៩៧៤ បានទៅជាឯកសារសម្ងាត់មួយរបស់ក្រសួងការបរទេសអាមេរិកាំង មានសាមសិបប្រាំពីរទំព័រ និងមានចំណងជើងថា កម្មវិធីរបស់ខ្មែរក្រហមដើម្បីបង្កើតសង្គមកុម្មុយនិស្តមួយក្នុងភាគខាងត្បូងប្រទេសកម្ពុជា ។

ការសិក្សាស្រាវជ្រាវរបស់ គ្វីន ស្តីពីសហករណ៍អាចឲ្យគេយល់ឆ្ងះថា ជាសេចក្តីព្រាងមួយអំពីប្រព័ន្ធគ្រប់គ្រង ដែលពួកខ្មែរក្រហមប្រកាន់យកជាស្រេច កាលបើពួកគេឈានទៅដល់អំណាច ។ ការផ្លាស់ប្តូរប្រជាជនពីកន្លែងមួយទៅកន្លែងមួយ ជាសញ្ញាឲ្យដឹងមុនពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ។ ការបិទព្រំដែនទាំងអស់ ការនៅដាច់ឆ្ងាយពីគេដែលធ្វើដោយចិត្តឯង បានត្រូវគេពង្រីកឲ្យរាលដាលតមកទៀត រហូតដល់កម្រិតជាតិ ។ «ពួកអ្នកបាត់ខ្លួន» ការរឹតត្បិតយ៉ាងតឹងតែងបំផុតក្នុងការរស់នៅរបស់ប្រជាជនជារៀងរាល់ថ្ងៃ បានធ្វើឲ្យប្រជាជនហាក់ដូចជាដឹងខ្លួនមុនពីអំពើគួរឲ្យខ្លាច និងការបោសសម្អាតផ្សេងៗ ដែលជាលក្ខណៈសម្គាល់មួយរបស់របបខ្មែរក្រហម ។ រឿងនិទានទាំងឡាយពីពួកអ្នកភៀសខ្លួនរបស់ គ្វីន ក៏ឲ្យដំណឹងមុនពីការសង្កត់សង្កិនទៅលើជនជាតិភាគតិចនានា និងអំពើប្រទូសរ៉ាយដ៏សាហាវចំពោះ ពួកកុម្មុយនិស្តវៀតណាមដែលនឹងមកដល់ខាងមុខផងដែរ ។

ប៉ុន្តែក្នុងអត្ថបទរបស់គាត់ គ្វីន បានទទួលស្គាល់ថា មិនយល់ពីមូលហេតុនៃបញ្ហា ដែលគាត់បានស្រាវជ្រាវរកឃើញអំពីរបៀបរស់នៅរវាងពួកកុម្មុយនិស្តកម្ពុជា និងវៀតណាមឡើយ ៖

«ដោយគិតទៅដល់ចំណងមិត្តភាពតាំងពីយូរយារមកហើយ ដែលបានបង្រួបបង្រួមក្រុងហាណូយ និងបក្សកុម្មុយនិស្តខ្មែរនោះ គេសង្ឃឹមថានឹងមានសហប្រតិបត្តិការដ៏ជិតស្និទ្ធមួយ... ។ ប៉ុន្តែមិនដូច្នោះ ពួកខ្មែរក្រហមនៅខេត្តកណ្តាល... ។ ព្រមទាំងខ្មែរក្រហមនៅខេត្តកំពត និងខេត្តតាកែវ បានធ្វើកិច្ចប្រឹងប្រែងស៊ីគ្រលុំគ្នា ដើម្បីដេញកម្ចាត់ពួកវៀតកុង និងកងទ័ពវៀតណាមខាងជើងឲ្យទៅភាគខាងត្បូងវៀតណាមវិញ... ។ វាអាចមានប្រាកដណាស់ថា ទំនាក់ទំនងផ្សេងៗ របស់ពួកខ្មែរក្រហមជាមួយក្រុងហាណូយ បានធ្លាក់ចុះយ៉ាងខ្លាំងក្នុងរយៈប៉ុន្មានឆ្នាំចុងក្រោយថ្មីនេះ ដោយសារតែការគាំទ្រតាមពាក្យសម្តីរបស់វៀតណាមចំពោះសម្តេច ព្រះនរោត្តម សីហនុ ក្នុងតំបន់នានា ដែលពួកវៀតណាមកាន់កាប់ និង, ឬដោយសារការប៉ុនប៉ងមួយរបស់ក្រុងហាណូយ ដើម្បីត្រួតត្រាលើបក្សកុម្មុយនិស្តកម្ពុជា ។ មូលហេតុមួយទៀតដែលអាចមានដែរ គឺថា ពួកខ្មែរក្រហមនៅតំបន់ព្រំដែនដំបូងមានសុទ្ធតែប្រជាជនធម្មតា ហើយតមកទៀត គឺពួកកុម្មុយនិស្ត ពោលគឺការមិនចូលចិត្តរបស់ (ដោយមិនដឹងមកពីហេតុអ្វី) ចំពោះពួកវៀតណាមបានមានប្រៀបលើ ភាពជាដៃគូផ្អែកមនោគមនវិជ្ជា ដែលពួកគេអាចមានចំពោះ [កុម្មុយនិស្តវៀតណាម]...» ។

ប៉ុន្តែ នៅឆ្នាំ១៩៧៣ រដ្ឋាភិបាលអាមេរិកាំងនៅវ៉ាស៊ីនតោន ពុំបានយកចិត្តទុកដាក់នឹងការស្រាវជ្រាវ

របស់ គៀន ទេ ហើយវាក៏មិនសូវមានឥទ្ធិពលទៅលើស្ថានទូតរបស់សហរដ្ឋអាមេរិកប្រចាំនៅក្រុងភ្នំពេញដែរ ។ គៀន ពុំមែនជាអ្នកឯកទេសម្នាក់ខាងបញ្ហាកម្ពុជាទេ ហើយការវិភាគរបស់គាត់ត្រូវគេចាត់ទុកថា ជាអំពើជ្រៀតជ្រែកមួយទៅក្នុងរឿងគេ ។ ដូច អ៊ិត សារិន ដែរ គៀន ក៏សង្ស័យចំពោះសម្ភតិកម្មរបស់ក្រុងវ៉ាស៊ីនតោនដែរ ដែលតាមរយៈរឿងនេះថា ពួកកុម្មុយនិស្តបានបង្កើតជាបក្សនយោបាយយ៉ាងរឹងមាំមួយ ថ្វីបើប្រហែលជាមានការឈ្លោះទាស់ទែងគ្នាខ្លះៗក៏ដោយ ។ ពួកអ្នកដែលសម្រេចអំពីនយោបាយប្រទេស មានប្រវត្តិរឿង "សម្លាប់មនុស្ស" គ្រប់គ្រាន់ ដែលច្រើនតែលេចឡើងឲ្យឃើញថា ជារឿងខុះមូលដ្ឋានពិតប្រាកដ ។

ការស្រាវជ្រាវរបស់ គៀន បានបំភ្លឺបន្ថែម និងបន្តសៀវភៅរបស់ អ៊ិត សារិន ឲ្យរឹតតែច្បាស់ឡើងថែមទៀត ទោះបីជាគាត់ សរសេរចង្អុលអំពីតំបន់មួយផ្សេងទៀតរបស់ប្រទេសក៏ដោយ ។ ពួកអ្នកភៀសខ្លួនមួយភាគធំដែល គៀន បានសាកសួរ គឺច្រើនចេញមកពីភាគខាងត្បូង និងខាងកើតប្រទេសកម្ពុជា ក្នុងពេលដែល សារិន ធ្វើដំណើរទៅភាគពាយ័ព្យ និងភាគកណ្តាលប្រទេស ។ តាមទស្សនៈរបស់ គៀន យល់ឃើញថា ស្ថានការណ៍ផ្លាស់ប្តូរតែបន្តិចបន្តួចប៉ុណ្ណោះ ក្រោមរបៀបចាត់ចែងជាហករណ៍ ៖ មនុស្សជាច្រើនត្រូវគេរៀបចំឲ្យធ្វើការជុំវិញភូមិនានាដែលមាននៅសព្វថ្ងៃ ជំនួសមនុស្សភាគច្រើនដែលរស់នៅលើផ្ទះរបស់គេ និងធ្វើស្រែចម្ការលើដីដែលៗ ។ បញ្ហាកម្មសិទ្ធិដីធ្លីត្រូវបានដៀសវាងរួចតាំងពីដំបូងមក ប៉ុន្តែអ្វីៗទាំងអស់មាន ដី ផ្ទះ សាលារៀន មន្ទីរពេទ្យ វត្តអារាម ត្រូវស្ថិតនៅក្រោមការត្រួតត្រារបស់គណៈសហករណ៍ ដែលជា "ឧបករណ៍មួយ" របស់បក្ស ដូចកងទ័ពដែរ ។

តាម គៀន សិក្សាថាការត្រួតត្រានេះមានគោលដៅ "រៀបចំរចនាសម្ព័ន្ធសង្គមខ្មែរជាថ្មី" តាមរយៈការអប់រំនយោបាយខ្លាំងក្លាមួយឲ្យដល់យុវជនទាំងឡាយ និង "ការទិតៀនមួយទៅតាមគោលការណ៍អំពីពូជពង្សគ្រួសារ" ដែលជាធាតុសំខាន់មួយក្នុងចំណោមធាតុសំខាន់ៗរបស់សង្គមកម្ពុជាដែលនិយមប្រពៃណី ។ គៀន កត់សម្គាល់ថា "ការកែទម្រង់ផ្នែកសង្គម -វប្បធម៌ធំដុំជាងគេ ដែលពួកខ្មែរក្រហមធ្លាប់ប៉ុនប៉ង គឺប្រហែលជាការវាយប្រហារប្រឆាំងនឹងសាសនាជាទូទៅ និងព្រះវិហារព្រះពុទ្ធសាសនាថេរវាទជាពិសេស" ។

ក្រុមសាមគ្គីជាច្រើនដែលមានម្ភៃគ្រួសារក្នុងមួយក្រុម ឬលើសពីនេះ ត្រូវបានរៀបចំឲ្យទៅជា "កងផលិតមួយ" ដើម្បីធ្វើស្រែចម្ការ ។ គណៈកម្មការមួយដែលមានមនុស្សបីនាក់ត្រូវបានយល់ព្រមដោយបក្សឲ្យដឹកនាំសហគមន៍ និងការចែកផលដែលធ្វើបាន ៖ ចំណែកមួយៗត្រូវបែងចែកដោយឡែកៗពីគ្នាសម្រាប់ពួកអ្នកធ្វើការ សម្រាប់ជម្រករបស់រដ្ឋ និងសម្រាប់សមរភូមិ ។ ក្រដាសប្រាក់ និងទីផ្សារបានត្រូវលុបបំបាត់មិនឲ្យមាន ហើយដាក់ជំនួសវិញ ដោយអគារលក់ទំនិញរបស់រដ្ឋជាទី ដែលផលិតផលផ្សេងៗត្រូវបានដោះដូរជាមួយប្រជាជន ។ អគារលក់ដូរទាំងនេះ ត្រូវបានរដ្ឋផ្គត់ផ្គង់ឲ្យនូវសាច់ក្រណាត់ ប្រេងកាត និងប្រដាប់ប្រើប្រាស់ផ្សេងៗ ... ។ល ។ តាមរបៀបគ្រប់គ្រងផ្តាច់មុខមួយខាងការនាំចេញនាំចូល ។ ភ្នាក់ងារខាងទិញដូរជាច្រើននាក់របស់បក្សជាអ្នកលក់ដូរ និងចែកចាយផលិតផលគ្រប់មុខ តាំងពីស្រូវ បន្លែ ថ្នាំព្យាបាល និងកៅស៊ូ ។ នេះជាកន្លែងដែលធ្វើឲ្យ

ពាណិជ្ជកម្ម ពីប្រទេសមួយទៅប្រទេសមួយទៀតត្រូវរលាយបាត់បង់ ដែលជំរុញឲ្យ គ្លីន ផ្ដើមធ្វើការស្រាវជ្រាវរបស់គាត់នេះ ។

គឺរបៀបនេះហើយ ដែលពួកខ្មែរក្រហមបានឈ្នះ "សង្គ្រាមស្រូវ" ។ សហករណ៍ទាំងអស់របស់ពួកគេ បានត្រួតត្រាលើផលិតផលស្រូវ និងគ្រឿងបរិភោគទាំងអស់ ដែលគេទុកប្រើការ ។ រដ្ឋ ឬអង្គការ ខំប្រឹងប្រែងចែកចាយរបស់របរទាំងនោះដោយត្រឹមត្រូវបំផុត នៅពេលដែលកាលៈទេសៈហុចឲ្យ ។ ការចាប់អារម្មណ៍ជាទូទៅ គឺថាប្រជាជនទាំងអស់ជាប់រវល់ខ្លាំងក្នុងសង្គ្រាម ដោយគ្មានលើកលែងអ្នកណាម្នាក់ ។ របៀបគ្រប់គ្រងនេះ មានភាពផ្ទុយគ្នាស្រឡះពីជីវភាពនៅក្រុងភ្នំពេញ ដែលការលោភលន់ទ្រព្យសម្បត្តិ និងអំពើពុករលួយបានបង្កឲ្យក្រុមអ្នកអ្នកភៀសខ្លួនដែលអត់ឃ្លាន កំពុងរស់នៅក្បែរៗពួកអ្នកមានឯកសិទ្ធិ ដែលដុះក្បាលពោះ និងមានទ្រព្យសម្បត្តិច្រើន ព្រមទាំងវណ្ណៈគហបតីតូចតាចមួយ ដែលរស់នៅយ៉ាងលំបាកលំបិន ហើយខំប្រឹងស៊ូទ្រាំរស់នៅ ដែលធ្វើហាក់ដូចជាថា វាគ្មានអ្វីជាធ្ងន់ធ្ងរឡើយ ហើយបន្តការយកចិត្តទុកដាក់ធ្វើជំនួញរបស់ខ្លួនតទៅទៀត ដោយគ្មាននិយាយពី"សង្គ្រាម" សោះឡើយ ។

ការដឹកនាំផ្ទុយគ្នាស្ដីពីការផ្គត់ផ្គង់ស្បៀងឲ្យដល់ប្រជាជនខ្លួនទាំងនេះ គឺចេញមកអំពីយុទ្ធសាស្ត្រខាងយោធា ដែលប្រកាន់យកដោយភាគីនីមួយៗ និងឆ្លុះបញ្ចាំងឲ្យឃើញនយោបាយសម្ព័ន្ធមិត្តរបស់ពួកគេទៀតផង ។ កងទ័ពរបស់ លន់ នល់ ពឹងផ្អែកទាំងស្រុងលើសហរដ្ឋអាមេរិក ទាំងស្បៀងអាហារ ក៏ដូចគ្រឿងសព្វាវុធ ហើយពុំមានជោគជ័យការពារប្រជាកសិករ ដែលកំពុងធ្វើស្រែចម្ការឡើយ ។ សាធារណរដ្ឋខ្មែរបានអះអាងប្រយុទ្ធដើម្បីដណ្ដើមប្រជាជន ពុំមែនដណ្ដើមដីទេ ហើយស្រែចម្ការទាំងឡាយត្រូវបានបោះបង់ចោលទាំងអស់ ។ នៅឆ្នាំ១៩៧៤ មានតែភូមិភាគ ពាយ័ព្យមួយប៉ុណ្ណោះ ដែលផលិតស្រូវបានបរិមាណយ៉ាងសម្បើម ក្នុងតំបន់ដែលត្រួតត្រាដោយកងទ័ពរបស់ លន់ នល់ ហើយស្រូវនេះត្រូវបានលក់ចេញទៅទីផ្សារងងឹតនៅប្រទេសថៃ ឬលក់ឲ្យពួកខ្មែរក្រហម ឬអ្នកណាម្នាក់ ដែលហ៊ានឲ្យថ្លៃខ្ពស់ជាងគេ ។

នយោបាយរបស់ក្រុងភ្នំពេញចំពោះប្រជាជនស៊ីវិល និយាយដោយខ្លី គឺស្ថិតនៅត្រង់ការមិនយកចិត្តទុកដាក់មួយដែលផ្ទុយពីច្បាប់ធម្មជាតិ ។ រដ្ឋធានីបានប្រែក្លាយទៅជាទីក្រុងគោកយ៉ាកមួយ ដែលពួកនាយទាហាន និងដៃដើងរបស់ពួកគេ "ដកហូត" ទ្រព្យសម្បត្តិពួកអ្នកភៀសសឹកអស់រលីងពីខ្លួននៅតាមរបាំងនានា ដែលគេដាក់នៅតាមមាត់ច្រកចូលមកក្នុងទីក្រុងនេះ ។ ពួកនោះ បានរឹបអូសយកនូវរបស់របរទាំងអស់ដែលមានតម្លៃ ទិញស្រីដែលមានវ័យក្មេងៗ -ជាជាងទិញស្ត្រីក្រមុំព្រហ្មចារីយ៍- ដើម្បីផ្គត់ផ្គង់ទៅឲ្យផ្ទះបនរបស់ពួកគេ ។ ចាប់ពីឆ្នាំ ១៩៧២ ការខ្វះខាតអង្ករ បានបង្កឲ្យ មានការបះបោរជាច្រើនពីសំណាក់ប្រជាជន ហើយស្ថានការណ៍នៅឆ្នាំ ១៩៧៣ បានធ្វើឲ្យគេអស់សង្ឃឹមខ្លាំងមែនទែន រហូតទាល់តែស្ថានទូតអាមេរិកាំងត្រូវបញ្ជូនទូរលេខទៅក្រុងវ៉ាស៊ីនតោនជារៀងរាល់សប្ដាហ៍ ដើម្បីប្រាប់ពីស្តុកអង្ករដែលបម្រុងទុកប្រើការក្នុងទីក្រុង ។

ជាមួយនឹងការកើនឡើងនៃសង្គ្រាម ដែលកើតមានបន្ទាប់ពីកិច្ចព្រមព្រៀងក្រុងប៉ារីសទីក្រុងភ្នំពេញ បានប្រែក្លាយទៅជាទីក្រុងមួយសម្រាប់ជនភៀសខ្លួនមួយយ៉ាងឆាប់រហ័ស ។ នៅឆ្នាំ១៩៧៤ សហរដ្ឋអាមេរិកបានប្រគល់ដោគវាសនារបស់ពួកអ្នកគ្មានទីជម្រកទៅឲ្យអង្គការមនុស្សធម៌ឯកជននានា ទទួលមើលខុសត្រូវដែលត្រូវទិញសម្ភារគ្រប់បែបយ៉ាងសម្រាប់ប្រជាជនមួយ ដែលចេះតែកើនឡើងគ្មានឈប់ឈរ ។ ថ្វីបើខ្លួនមានចិត្តស៊ូទ្រាំយ៉ាងណាក៏ដោយ ក៏បណ្តាសមាជិកនៃអង្គការទាំងនេះទ្រាំទ្រនឹងភារកិច្ចនោះពុំរួចដែរ ដោយសារតែទំហំកិច្ចការនេះមានសភាពធំធេងពេក ។ កងទ័ពរបស់ លន់ នល់ បានច្បាំងចាញ់ក្នុងការប្រយុទ្ធជាច្រើនកន្លែង ហើយពួកអាមេរិកាំង ក៏គ្មានសមត្ថភាពនាំចូលស្បៀងអាហារឲ្យបានគ្រប់គ្រាន់សម្រាប់ពួកអ្នកភៀសខ្លួនដែរ ។ ការផ្គត់ផ្គង់អាហារមិនគ្រប់គ្រាន់បានកើតមានរឿយៗ នៅក្នុងចំណោមក្មេងៗ ។

ប្រជាជនកម្ពុជាបានហូរចូលមកក្នុងរដ្ឋធានីដូចបាក់ទំនប់[៤៥] ។ គេគោងតែជ្រើសរើសរវាងគំនិតផ្ទុយគ្នាពីរៈ ប្រថុយស្លាប់ដោយការអត់បាយ ដោយរត់ភៀសខ្លួនទៅនៅតំបន់របស់សាធារណរដ្ឋខ្មែរ ឬលក់សម្បជញ្ញៈរបស់ខ្លួនទៅឲ្យអង្គការ ជាថ្នូរនឹងការធានាឲ្យបានទទួលរបស់របរខ្លះសម្រាប់បរិភោគ ។ រត់គេចចេញពីរបបសមូហភាវូបនីយកម្មដោយបង្ខំនៅជនបទ បានត្រឹមតែឲ្យកូនៗអាចត្រូវស្លាប់ដោយអត់បាយនៅក្រុងភ្នំពេញប៉ុណ្ណោះ ។

សង្គម និងវប្បធម៌ខ្មែរ បានត្រូវធ្វើឲ្យដល់នូវបរាជ័យទាំងក្នុងបណ្តាសហករណ៍ថ្មី ក៏ដូចក្នុងតំបន់កាន់កាប់របស់ លន់ នល់ ដែរ ។ ក៏ប៉ុន្តែភាពចាំបាច់នៃសង្គ្រាមអាចបញ្ជាក់ឲ្យដឹងថា ប្រព័ន្ធគ្រប់គ្រងដែលមានលក្ខណៈរួមនេះត្រឹមត្រូវ ។ អ្វីៗទាំងអស់ដែលសម្គាល់នូវលក្ខណៈនៃជីវភាពរស់នៅប្រចាំថ្ងៃរបស់កម្ពុជា បានរលាយបាត់បង់ក្រោមការបង្ខំឲ្យប្រើប្រាស់ពេលវេលាទាំងអស់របស់ខ្លួន ដើម្បីបង្កបង្កើនផលឲ្យបានគ្រប់គ្រាន់សម្រាប់ចិញ្ចឹមជីវិតវិញ ។ ដោយគ្មានផ្សារផ្សា គ្មានបុណ្យទាន គ្មានការកំសាន្តសប្បាយ មនុស្សម្នាលែងបានជួបមុខមិត្តភក្តិរបស់ខ្លួន លែងបានចែករំលែកម្ហូបអាហារគ្នា ពួកក្មេងជំទង់ៗត្រូវគេបំបែកចេញពីឪពុកម្តាយរបស់វា គ្រួសារញាតិសន្តានក៏ស្លាប់វិនាសអន្តរាយដូចគ្នា ។ ពួកអ្នកភៀសខ្លួនដែលសាកសួរដោយ គ្មីន ហាក់ដូចជាមនុស្សឯកោឃ្លាតឆ្ងាយពីមិត្តភក្តិ និងឪពុកម្តាយរបស់ពួកគេ ដែលត្រូវកាត់ផ្តាច់ទាំងស្រុងពីពិភពខាងក្រៅ ។

សាសនាក៏ត្រូវគេគាបសង្កត់ គ្រប់ពិធីបុណ្យផ្នែកសង្គម និងផ្នែកសាសនា ត្រូវហាមឃាត់មិនឲ្យមាន ។ គេចំអកឲ្យព្រះពុទ្ធសាសនា ដោយគេបង្ហាញថាជាសាសនាប្រឆាំងនឹងការជឿនលឿន និងមានចរិតសក្តិភូមិ ។ ការរៀបអាពាហ៍ពិពាហ៍ស្ទើរតែត្រូវហាមឃាត់ទាំងស្រុង ដើម្បីនឹងអាចឲ្យបក្សរើសពួកយុវជនចូលបម្រើក្នុងកងទ័ពបានដោយងាយស្រួល ។ ការសប្បាយរីករាយបានក្លាយទៅជារឿងដែលត្រូវគេសង្ស័យ ការទាក់ទងគ្នាខាងផ្លូវស្នេហាត្រូវគេផ្តន្ទាទោសយ៉ាងធ្ងន់ធ្ងរបំផុត ដូចការលេងល្បែងស៊ីសងដែរ ។ សម្លៀកបំពាក់ដែលដេញរស្មីផ្ទេកៗ គ្រឿងអលង្ការផ្សេងៗ គឺលំនាំដែលមាន«លក្ខណៈប្លែកពីគេ» ទាក់ទងនឹងសម្លៀកបំពាក់ត្រូវបានហាម

យាត់ដូចដែល គ្មីន សរសេរ ។ ច្បាប់ទម្លាប់ទាំងនេះ បានប៉ះពាល់ជាពិសេសដល់ជនជាតិភាគតិចចាមកាន់សាសនាអ៊ីស្លាមដែរ ព្រោះអាវផាយ គ្រឿងអលង្ការ ការតុបតែងសក់របស់ពួកស្ត្រីចាម គឺជាផ្នែកមួយដ៏សំខាន់របស់សាសនា និងអត្តសញ្ញាណនៃជាតិសាសន៍របស់ពួកគេ ។ ព្រឹត្តិការណ៍ផ្សេងៗដែលកើតមានមកជាក្រោយទៀត នឹងបង្ហាញឲ្យឃើញថា នេះពុំមែនជាការដឹកនាំ ដែលកើតមានដោយចៃដន្យនេះទេ ៖ បណ្ដាជនជាតិភាគតិចទាំងអស់ -ចិន ចាម ឬវៀតណាម- នឹងត្រូវរងការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ នៅពេលណាដែលពួកខ្មែរក្រហមបញ្ចេញឲ្យឃើញពីគំនិតជាតិនិយមរបស់គេប្រកបដោយអនុភាពបំផុត ។

ហើយតមកទៀត វាក៏មានអំពើគួរឲ្យខ្លាច ។ ពួកអ្នកភៀសខ្លួនបានរៀបរាប់ប្រាប់ គ្មីន ថា ពួកគេខ្លាចនឹងនិយាយស្ដី ឬប្រព្រឹត្តអំពើឆ្គាំឆ្គងមួយណាស់ ដោយខ្លាចប្រឈមមុខនឹងសេចក្ដីស្លាប់ ។ នៅទីនេះពុំមានច្បាប់ប្រាកដប្រជា ដែលតុលាការ និងពួកចៅក្រមជាអ្នកមើលខុសត្រូវលើការអនុវត្តទេ មានតែការផ្ដន្ទាទោសភ្លាមៗប៉ុណ្ណោះ គ្មានអ្វីលើសពីហ្នឹងទៀតទេ ហើយក៏គេមិនទទួលស្គាល់នូវការមិនព្រមចំណុះ ឬការតវ៉ាប្រឆាំងដែរ ។ បណ្ដាសមាជិករបស់បក្ស ក៏ជៀសមិនរួចពីច្បាប់ទាំងនោះដូចគ្នា ។ បើសិនជាកម្មាភិបាលទាំងឡាយត្រូវយោបល់គ្នាពីការផ្លាស់ប្ដូរប្រជាជនពីកន្លែងមួយទៅកន្លែងមួយទៀត គេនឹងនាំពួកអ្នកទាំងនោះយកទៅ ហើយគេសម្លាប់ចោល ។ គ្មានអ្នកណាម្នាក់អាចដឹងពីរឿងដែលអាចនាំបណ្ដាលឲ្យបក្សមានកំហឹងនោះទេ ហើយក៏គ្មានដឹងពីទណ្ឌកម្មបែបណាដែលខ្លួនត្រូវរងទទួលដែរ ។ ភាពពិតជាក់លាក់តែមួយគត់ គឺសេចក្ដីស្លាប់នឹងទៅជារឿងសម្ងាត់បំផុត ។

អ៊ីចឹងហើយ បានជាពួកខ្មែរក្រហមមិនដែលទទួលស្គាល់ពីការចាប់មនុស្សយកទៅ និងការកាប់សម្លាប់ទាល់តែសោះ ហើយកម្មាភិបាលទាំងនោះអះអាងមិនបានដឹងពីជោគវាសនារបស់មនុស្សជាច្រើននាក់ ដែលគេចាប់យកទៅទាំងកណ្ដាលអធ្រាត្រ ហើយដែលបាត់ខ្លួនលែងឃើញរហូតទេ ។ ក្នុងបរិយាកាសដ៏វន្ធត់ញាប់ញ័រនេះ ប្រជាជនក៏មិនដឹងថា អ្នកណាមួយដែលមានអំណាច បង្គាប់បញ្ជាឲ្យធ្វើប្រតិបត្តិមួយបែបនេះដែរ ហេតុអ្វីបានជាមនុស្សទាំងនោះត្រូវគេកាត់ទោសប្រហារជីវិត? គេបានបណ្ដេញឪពុកម្ដាយជនរងគ្រោះជាច្រើនឲ្យថយទៅវិញទាំងកំរោល នៅពេលដែលពួកគាត់ទៅស៊ើបសួរពីវាសនាអ្នកបាត់ខ្លួន ហើយមនុស្សគ្រប់គ្នាបានដឹងដោយឆាប់រហ័សថា គេមិនត្រូវសួរនាំពីរឿងផ្សេងឡើយ ។ ការភ័យខ្លាចបានរាលដាលពាសពេញសហករណ៍មួយចំនួនធំ ។ ពាក្យចចាមអារ៉ាមផ្សេងៗបានលេចឮសុះសាយថា អ្នកដែលបាត់ខ្លួនទាំងប៉ុន្មាន ត្រូវគេសម្លាប់ចោលទាំងអស់ មួយចំនួនទៀត ត្រូវគេបញ្ជូនទៅឃុំឃាំងនៅក្នុងគុកមួយ ដែលនៅទីបំផុតក៏ត្រូវ ស្លាប់ដោយការបរិភោគមិនគ្រប់គ្រាន់ ឬដោយជំងឺគ្រុនចាញ់ដែរ ប៉ុន្តែ គ្មានអ្នកណាម្នាក់ដឹងដោយជាក់លាក់ថា ពួកអ្នកទាំងនោះមានស្ថានភាព ឬវាសនាបែបណាឡើយ ។

នេះពុំមែនជារបៀបសង្សឹកជាចំហមួយប្រឆាំងនឹងមនុស្សទាំងឡាយ ដែលចូលដៃដើងជាមួយសត្រូវទេ

ហើយគ្មានស្តែងឲ្យឃើញលក្ខណៈណាមួយដូចព្រឹត្តិការណ៍ ដែលកើតមានកន្លងមកនៅប្រទេសបារាំងសម័យធ្វើសង្គ្រាមរំដោះជាតិនៅឆ្នាំ១៩៤០ ដែលមានលោក ដឺហ្គោល ជាមេដឹកនាំដែរ ។ នេះក៏ពុំមែនជាហេតុការណ៍ដែលគេអាចប្រៀបធៀបនឹង «ការគ្រប់គ្រងដោយប្រើអំពើឃោរឃៅ» របស់ការបដិវត្តកុម្មុយនិស្តដទៃៗទៀត ដែលលើកទឹកចិត្តឲ្យប្រជាកសិករសម្លាប់វង្គាលពួកអភិជន «ប្រឆាំងបដិវត្ត» ក៏ទេដែរ ហើយដែល ម៉ៅ សេទុង បាននិយាយនៅក្នុងរបាយការណ៍ខេត្ត ហ៊ូណាន់ (Hunan) របស់គាត់នៅឆ្នាំ១៩២៧ ថា «នៅពេលដែលជនផ្តាច់ការក្នុងស្រុក និងពួកអភិជន ដែលចូលចិត្តប្រើអំពើអាក្រក់រឿងដល់កំពូលនៃអំណាចរបស់គេ ពួកគេច្បាស់ជាសម្លាប់ប្រជាកសិករដោយគ្មានពព្រិចភ្នែកបន្តិចសោះ... ។ តើត្រូវទប់ប្រជាកសិករទាំងនោះមិនឲ្យងើបបះបោរ និងសម្លាប់ពួកអភិជនម្នាក់ ឬពីរនាក់ ហើយតាំងឲ្យមានឡើងនូវ«រជ្ជកាលប្រើអំពើភេរវកម្ម»កម្រិតទាបមួយ ដោយកម្ចាត់ពួកអ្នកប្រឆាំងបដិវត្តទាំងអស់ចេញដោយរបៀបណា[៤៦]? ក្នុងរយៈពេលនៃការធ្វើសង្គ្រាមបដិវត្តនៅប្រទេសចិន និងនៅវៀតណាម ការប្រហារជីវិតពួកអ្នកនយោបាយច្រើនធ្វើឡើងជាចំហ ពួកអ្នកជាប់ចោទត្រូវបង្ខំឲ្យបង្ហាញខ្លួននៅចំពោះមុខកសិករជាច្រើន ហើយត្រូវសារភាពពីអំពើឧក្រិដ្ឋរបស់ខ្លួនផង ។ អំពើភេរវកម្មរបស់ពួកខ្មែរក្រហមមានទម្រង់មួយផ្សេងពីនេះទៀតហើយ ពិតណាស់ គេមិនងាយរកឃើញទម្រង់នៃការអនុវត្តនេះក្នុងឯកសារផ្លូវការណាមួយឡើយ ។

អ្នកទទួលខុសត្រូវខ្មែរក្រហមគ្រប់លំដាប់ថ្នាក់ទាំងអស់ និងក្នុងទូទាំងប្រទេសបានរួមចំណែកដោយផ្ទាល់ក្នុងការប្រព្រឹត្តអំពើឃោរឃៅ ដែលគេបានដាក់ប្រើក្នុងរយៈពេលនៃសង្គ្រាម ។ ដូចដែល សាឡុត ស និងបណ្តាសមមិត្តរបស់គាត់ បានថ្លែងប្រកាសនៅពេលក្រោយមកទៀតថា បដិវត្តរបស់គេជា«ស្នាដៃរបស់អាទិទេព... ដែលធ្វើឲ្យស្ញប់ស្ញែងយ៉ាងខ្លាំងសម្រាប់មនុស្សសាមញ្ញទូទៅ ដែលប្រកបដោយលក្ខណៈបរិសុទ្ធជាងគេ មិនធ្លាប់ដែលមានសោះក្នុងប្រវត្តិសាស្ត្រជាង២០០០ឆ្នាំ[៤៧]» របស់ប្រទេស ។ គ្មានសត្រូវ ឬគូប្រឆាំងណាមួយរបស់បដិវត្ត អាចរាំងស្ទះដំណើររបស់វាបានឡើយ ។ បក្សនឹងធានារ៉ាប់រងធ្វើឲ្យពូជសាសន៍ខ្មែរស្ថិតស្ថេរចីរកាលតទៅ» ។

ពួកខ្មែរបានឈានទៅដល់ចំណុចចុងបំផុតនៃភាពសមហេតុសមផលរបស់គេ ។ ដោយធ្លាប់តែរស់នៅឯកោពីគេឯង និងត្រូវគេក្បត់បំពានក្នុងរយៈពេលជាច្រើនឆ្នាំ ពួកខ្មែរត្រូវគេធ្វើឲ្យទ័លប្រាជ្ញា បន្ទាប់ក៏ក្លាយទៅជាមនុស្សដែលដក់ដោយកំហឹង និងការតូចចិត្តយ៉ាងខ្លាំង ។ ភាពកំណាចឃោរឃៅ ដែលបង្កប់នៅក្នុងទស្សនៈបរិសុទ្ធភាព -ជនកុម្មុយនិស្តបរិសុទ្ធ ជនជាតិកម្ពុជាបរិសុទ្ធ- បានមកជំនួសទស្សនៈនេះ ។ ការស្រោចស្រង់ពូជសាសន៍ «កិត្តិយស និងភាពថ្លៃថ្នូររបស់ជាតិ» ការរៀបចំធ្វើការត្រួតត្រាលើ «ទឹកដីនិងពូជសាសន៍» ឡើងវិញ បានក្លាយទៅជាបុព្វបទរបស់ការបដិវត្តដែលគេដឹងឮគ្រប់គ្នា ។ សាឡុត ស បានក្លាយខ្លួនឲ្យទៅជា លន់ នល់ ដែលជាមនុស្សមានគំនិតបំផ្លិចបំផ្លាញមិនអន់ជាងគ្នាឡើយ ។

ពួកខ្មែរក្រហមខ្លួនឯងបានទទួលស្គាល់ថាឆ្នាំ១៩៧៣ គឺជាឆ្នាំទីដំបូង ដែល "ពួកគេបានវាយប្រយុទ្ធតែម្នាក់ឯងគត់នៅលើសមរភូមិកម្ពុជា[៩៨]" ដោយបដិសេធអំពីករណីខ្លះ ដែលពួកវៀតណាមខាងជើងបានជួយច្បាំងពួកគេនៅសមរភូមិផង ។ ពួកគេបានអនុវត្តតាមយុទ្ធសាស្ត្ររបស់ពួកកុម្មុយនិស្តវៀតណាម ដោយបានបោះទីតាំងនៅក្បែរកងទ័ពរបស់ លន់ នល់ តាមដែលអាចធ្វើបាន ក្នុងកំឡុងពេលមានការទម្លាក់គ្រាប់បែកដ៏ខ្លាំងក្លារបស់អាមេរិកាំង ដើម្បីជៀសពីការដែលយកពួកគេធ្វើជាទីដៅវាយប្រហារ ។ នៅពេលកំពុងមានការទម្លាក់គ្រាប់បែកឡើងដល់កម្រិតខ្លាំងបំផុតនេះ ពួកគេបានចាប់ផ្ដើមធ្វើការវាយលុកទៅលើក្រុងភ្នំពេញជាបីមុខព្រួញ ហើយបានវាយប្រយុទ្ធហាក់បីដូចជាពួកមនុស្សដែលគ្មានវិញ្ញាណ ប៉ុន្តែ ដោយដឹងពត៌មានថា សភា និងមតិសាធារណជននៅសហរដ្ឋអាមេរិក បានទាមទារឲ្យមានការបញ្ចប់ការទម្លាក់គ្រាប់បែកទាំងអស់ ។

ពួកខ្មែរក្រហមបានវាយប្រហារពីទិសខាងត្បូង ដោយបានគំរាមកំហែងដល់ខ្សែការពារសំខាន់ៗ នៅតាមផ្លូវជាតិលេខ១ ដែលតភ្ជាប់ពីទីក្រុងភ្នំពេញទៅក្រុងព្រៃនគរ ។ មានតែការធ្វើអន្តរាគមន៍ដ៏សន្ធឹកសន្ធាប់របស់កងយន្តហោះបេ-៥២ប៉ុណ្ណោះ ដែលបានជួយស្រោចស្រង់កងទ័ពរបស់សាធារណរដ្ឋខ្មែរ ។ នៅខែមេសា ឆ្នាំ១៩៧៣ កុម្មុយនិស្តបានចូលមកកៀករដ្ឋធានី ដែលគេអាចបាញ់កាំភ្លើងត្បាល់ចូលទៅដល់ទីក្រុងបាន ហើយបានបង្កឲ្យមានការចាកចេញរបស់ជនបរទេសដ៏ធំជាលើកដំបូង ។ ក្នុងទីក្រុងភ្នំពេញ ទឹក និងអគ្គិសនី ត្រូវបានគេចាប់ផ្ដើមចែកចាយតាមកម្រិត ។ ការវាយប្រហាររបស់ពួកខ្មែរក្រហមតាមទន្លេមេគង្គ និងក្បួន កប៉ាល់ ដែលកំពុងនាំស្បៀងមកផ្គត់ផ្គង់ទីក្រុងភ្នំពេញ បានបង្ហាញឲ្យឃើញថាបានទទួលផលសក្ដិសិទ្ធិណាស់ ។ រដ្ឋធានីត្រូវស្ថិតក្នុងការហ៊ុមព័ទ្ធ ហើយបើទោះជាមានសេចក្ដីប្រកាសប្រកបដោយគំនិតសុទិដ្ឋិនិយមរបស់ស្ថានទូតអាមេរិកាំងក៏ដោយ ក៏ទីក្រុងលែងបានស្គាល់ស្ថានភាពប្រក្រតីមួយដូចកាលពីមុនទៀតដែរ ។

នៅខែឧសភា និងខែមិថុនា កងទ័ពរបស់ សាឡុត ស បានបន្តធ្វើការវាយលុករបស់គេទៅមុខទៀត ដំបូងគឺវាយតាមបណ្ដោយផ្លូវជាតិលេខ៥ នៅទិសខាងជើង បន្ទាប់មក គឺវាយទីក្រុងភ្នំពេញនៅខែកក្កដា ។ នៅទិសខាងកើត ពាយ័ព្យ និងទិសខាងជើង ពួកគេវាយសំពងទៅលើខ្សែការពារទាំងរបស់របស់សាធារណរដ្ឋខ្មែរយ៉ាងខ្លាំង ហើយមានតែការទម្លាក់គ្រាប់បែករបស់អាមេរិកាំងប៉ុណ្ណោះ ដែលរារាំងមិនឲ្យពួកខ្មែរក្រហមទម្លុះចូលទៅបាន ។ បង្គួចផ្ទះនានានៅទីក្រុងឡើងញ័ររញ្ជួយទៅតាមសំឡេងរណ្ដំយ៉ាងខ្លាំងហើយវែង ដោយសារតែគ្រាប់បែកដែលយន្តហោះបេ-៥២ ទម្លាក់នៅក្បែរៗទីនោះ ។ ការឡោមព័ទ្ធរបស់ខ្មែរក្រហមបានរលាធូរខ្សោក ។ មិនយូរប៉ុន្មានក្រោយមក សភារបស់អាមេរិកបានដាក់កាលបរិច្ឆេទកំណត់មួយក្នុងការបញ្ចប់ ការវាយប្រហារតាមផ្លូវអាកាសទាំងអស់របស់អាមេរិកាំងនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៣ ។ សាធារណរដ្ឋខ្មែរស្ថិតនៅក្នុងភាពទទេស្អាតគ្មានអ្វីទាំងអស់ ដែលអាចត្រូវរងគ្រោះថ្នាក់ដល់វិនាស ព្រោះដឹងខ្លួនថាត្រូវវាយប្រយុទ្ធនឹងកងទ័ពមួយ សុទ្ធតែជាជនរួមជាតិឯង ដែលជំរុញដោយការប្ដេជ្ញាចិត្តមួយមានសភាពស្ទើរតែដូចមនុស្ស លែងដឹងខុសត្រូវទាំង

អស់ ។

ជាច្រើនខែក្រោមការទម្លាក់គ្រាប់បែករបស់ពួកអាមេរិកាំង បានធ្វើឲ្យពួកខ្មែរក្រហមទទួលរងផលវិបាកយ៉ាងធ្ងន់ធ្ងរប្រហែលខាងផ្លូវចិត្តច្រើនជាងខាងផ្លូវកាយ ។ ក្នុងកំឡុងពេលនេះ ពួកគេបានប្រកាសថា ជំងឺគ្រុនចាញ់បានធ្វើឲ្យកងទ័ពរបស់ខ្លួនស្លាប់អន្តរាយច្រើនជាងការទម្លាក់គ្រាប់បែកទៅទៀត ប៉ុន្តែ ពួកអ្នកទាំងនេះ បានដឹកនាំធ្វើការប្រយុទ្ធដំបូងគេ ដែលធ្វើឲ្យគេមានមុខមានមាត់ក្នុងចំណោមវីរជននៃការបដិវត្តនៅតណ្ហូចិន ។ តាមការមើលឃើញផ្ទាល់ ពួកគេបានក្លាយទៅជាអ្នករងគ្រោះសំខាន់បំផុតរបស់ចក្រពត្តិនិយម និយមអាមេរិកាំង ។ ពួកគេបានបញ្ជាក់ប្រាប់ពួកចិនថា គ្មានកងទ័ពបដិវត្តណាមួយទទួលរងការខូចខាតច្រើនជាងកងទ័ពរបស់គេឡើយ ក្នុងរយៈពេលនៃយុទ្ធនាការទម្លាក់គ្រាប់បែករបស់អាមេរិកាំង ។ នេះជាសម្ដីពោលអាង ដែលពួកគេនិយាយឡើងវិញ នៅចំពោះមុខពួកវៀតណាមខាងជើង ដែលធ្លាប់ត្រូវគេទម្លាក់គ្រាប់បែកក្នុងរយៈពេលជាច្រើនឆ្នាំដូចខ្លួនដែរ ។ ឡេ ឌឹកថូ បានសងសម្ដីយ៉ាងសោះកក្រោះទៅវិញថា «ចំនួនគ្រាប់បែករបស់អាមេរិកាំង ដែលទម្លាក់នៅប្រទេសឡាវ និងវៀតណាមខាងជើង គឺពិតជាមានចំនួនច្រើនជាងគ្រាប់បែកដែលអាមេរិកាំងទម្លាក់នៅប្រទេសកម្ពុជាទៅទៀត[៤៩]» ។

ប៉ុន្តែ ចិត្តសាស្ត្ររបស់ពួកខ្មែរក្រហម បានសំអាងតាំងពីយូរមកហើយលើគំនិតមួយដែលថា គ្មានបក្សកុម្មុយនិស្តណា មួយទទួលរងការខូចខាតដូចបក្សរបស់ខ្លួនឡើយ ជាគំនិតដែលស្របនឹងទស្សនៈមួយថា គ្មានប្រទេសណាមួយ ត្រូវគេបំបាក់មុខដូចប្រទេសកម្ពុជាឡើយពេញកំឡុងពេលជាច្រើនសតវត្សរ៍កន្លងមក ។ ការរួចផុតគ្រោះថ្នាក់ពីការទម្លាក់គ្រាប់បែកទាំងនេះ គឺជាការបញ្ជាក់ឲ្យឃើញយ៉ាងជាក់ច្បាស់ណាស់ នូវការប្ដេជ្ញាចិត្តផុតវិស័យមនុស្សរបស់គេ ។ គ្មានប្រទេសណាមួយ បក្សណាមួយ និងពួកវៀតណាម អាចពោលអាងផ្ទុយពីនេះឡើយ ។ អៀង ធិរិទ្ធ បានបញ្ជាក់យ៉ាងម៉ឺងម៉ាត់ថា «ប្រទេសរបស់យើងពិតជារងការខូតខាត ដោយសារសហរដ្ឋអាមេរិកច្រើនជាងប្រទេសវៀតណាម... ពិតណាស់ ប្រទេសយើងត្រូវរងការបំផ្លិចបំផ្លាញ ច្រើនជាងប្រទេសវៀតណាម ដោយសារការទម្លាក់គ្រាប់បែកចំនួនពីររយថ្ងៃ និងពីររយយប់ ជាប់រហូតគ្មានដាច់ ។ វាជាការពុំពិតទេ ដែលថាប្រទេសវៀតណាមរងការខូចខាតពីការទម្លាក់គ្រាប់បែករបស់អាមេរិកាំង លើសហ្នឹងទៀតនោះ ។ ពួកវៀតណាមពុំមានរងការទម្លាក់គ្រាប់បែក ពីររយថ្ងៃ ពីររយយប់ ដូចយើងទេគឺគ្មាន[៥០]» ។

និន្នាការប្រឆាំងរបស់អាមេរិក បានគាំទ្ររឿងនេះក្នុងចិត្តរបស់ពួកគេដូចគាំទ្រការសម្លាប់រង្គាល ដែលបង្កឡើងដោយទម្ងន់គ្រាប់បែកចំនួន ៥៣៩១២៩តោន ដែលអាមេរិកាំងទម្លាក់នៅប្រទេសកម្ពុជាដែរ ។ របៀបដែលប្រកាន់យកដោយពួកអាមេរិកាំង ដើម្បីជ្រើសរើសទីដៅសម្រាប់ធ្វើការទម្លាក់គ្រាប់បែករបស់គេគឺ គ្មានដឹងខុសត្រូវអ្វីទាំងអស់ ៖ ផែនទីភូមិសាស្ត្ររបស់គេច្រើនតែមិនត្រឹមត្រូវ ដែលជាហេតុធ្វើឲ្យយន្តហោះជាច្រើន

ទម្លាក់គ្រាប់បែកមិនចំ«ទិសដៅ» ។ តាមការពិត គោលដៅវាយប្រហារទាំងឡាយ សុទ្ធតែកំណត់ដោយអគ្គបញ្ជាការដ្ឋានកងទ័ពសាធារណរដ្ឋខ្មែរ របៀបមិនច្បាស់លាស់បន្តិចណាសោះ ព្រោះគេចូលចិត្តប្រើប្រាស់ការវាយប្រហារតាមផ្លូវអាកាស ជាជាងឲ្យកងទ័ពថ្មើរជើងរបស់គេចូលវាយប្រយុទ្ធដោយផ្ទាល់ ។ ពត៌មានផ្សេងៗស្តីពីចលនាទ័ពរបស់ពួកខ្មែរក្រហម ដែលពួកគេមានច្រើនតែជាពត៌មានខុសពីការពិត ។ ភូមិដែលមានប្រជាជនស៊ីវិលស្លូតត្រង់រស់នៅជាច្រើនកន្លែង សុទ្ធតែត្រូវគេបាញ់កម្ទេចបំផ្លាញចោល ហើយដំណើរនៃការភ័ន្តច្រឡំដ៏គួរឲ្យខ្លោចផ្សារដែលមានជាហូរហែមកទៀតនោះ គឺត្រូវបញ្ចប់ត្រឹមការ ទម្លាក់គ្រាប់បែកលើមូលដ្ឋានទ័ពរបស់រដ្ឋាភិបាលនៅអ្នកលឿង ស្ថិតនៅតាមមាត់ទន្លេមេគង្គ ។ នេះជាការភ័ន្តច្រឡំមួយ ដែលធ្វើឲ្យប្រជាជនស្លូតត្រង់ស្លាប់យ៉ាងច្រើន ដោយអ្នកទាំងនោះ គ្មានបានដឹងខ្លួនជាមុនទេ «រឿងនេះបានក្លាយទៅជានិមិត្តរូបនៃភាពល្ងីល្ងើមួយ» របស់អាមេរិកាំងប្រឈមនឹងភាពស្មុគស្មាញ នៃសង្គ្រាមឥណ្ឌូចិនជាលើកទីពីរនេះ ។

បន្ទាប់ពីការបញ្ចប់ការទម្លាក់គ្រាប់បែក រដ្ឋាភិបាលរបស់ និចសុន ក៏ត្រូវជាប់គុន ដោយការនិយាយភាសាពីរត្រូតគ្នា ដែលលោកបានធ្វើជាមួយ លន់ នល់ ផង និងជាមួយសភាអាមេរិកាំងផង ។ សមាជិកសភាអាមេរិកមិនដែលអនុម័តយល់ព្រមសោះ រឿងអ្វីក៏ដោយដែលមានលក្ខណៈដូចកិច្ចសន្យាមួយរបស់សហរដ្ឋអាមេរិក ដើម្បីគាំទ្ររបបក្រុងភ្នំពេញម្តងណាសោះឡើយ ។ ព្រឹត្តិការណ៍អាក្រក់ជាច្រើន ដែលទ្រាំទ្រ ដោយ លន់ នល់ អំពើពុករលួយនៃរបបរបស់គាត់បានជំរុញឲ្យបណ្តាឲ្យសមាជិកសភាអាមេរិកគិតឃើញថា ជនផ្តាច់ការរូបនេះ (គឺ លន់ នល់) មិនសមនឹងទទួលនូវការគាំទ្រមួយបែបនេះពីយើងឡើយ ។ នៅទីបំផុត ការធ្លាយចេញនូវរឿងអាថ៌កំបាំងទាំងឡាយបានបង្ហាញឲ្យដឹងថា ស្ថានទូតរបស់សហរដ្ឋអាមេរិកនៅទីក្រុងភ្នំពេញជាអ្នកចាត់ចែងផ្ទាល់ក្នុងការទម្លាក់គ្រាប់បែកនៅក្នុងប្រទេសកម្ពុជាជាសម្ងាត់ ហើយបំផ្លាញដល់បង្អែកដែលរដ្ឋាភិបាល និចសុន ធ្លាប់បានទទួលពីសភាថែមទៀត ។ នេះជារដូវកាលដែលកើតមាន «រឿងអាស្រូវ វ៉ឺរជឺហ្គេត» [ជារឿងចារកម្មនយោបាយដែលកើតមានឡើងនៅអគារ វ៉ឺរជឺហ្គេត ជាគ្រឹះស្ថានច្រើនជាន់មួយស្ថិតនៅទីក្រុងវ៉ាស៊ីនតោន ដែលគណបក្សប្រជាធិបតេយ្យប្រើប្រាស់ នៅក្នុងពេលឃោសនាបោះឆ្នោតជ្រើសរើសប្រធានាធិបតីនៅឆ្នាំ១៩៧២ ។ ការស៊ើបអង្កេតរបស់កាសែតវ៉ាស៊ីនតោនប៉ុស្ដិ៍ បាននាំឲ្យមានការចោទប្រកាន់ទីប្រឹក្សារបស់ប្រធានាធិបតី និចសុន ចំនួនប្រាំនាក់ ហើយរឿងអាស្រូវនេះបានបង្ខំឲ្យ និចសុន លាលែងពីតំណែងនៅក្នុងឆ្នាំ១៩៧៤] ហើយការក្តៅក្រហាយ ដែលបង្កឡើងដោយការទម្លាក់គ្រាប់បែកទាំងនោះ បានរលាយចូលគ្នាតែមួយរបស់ចលនាជាតិ ដើម្បីដេញ និចសុន ឲ្យខ្ទាតចេញពីតំណែង ។

សេចក្តីអំពាវនាវជាច្រើនរបស់រាជរដ្ឋាភិបាល មិនឲ្យបោះបង់សម្ព័ន្ធមិត្តមួយហាក់ដូចជា «ចាក់ទឹកលើក្បាលទា» គឺបណ្តាសមាជិកសភា ធ្វើមិនដឹងមិនឮអ្វីទាំងអស់ ។ សហរដ្ឋអាមេរិក ដែលជាអ្នកចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពនៅទីក្រុងប៉ារីសបានសម្មត់ថា ត្រូវដកខ្លួនថយចេញពីឥណ្ឌូចិនហើយ ។ សត្រូវ គឺពួកខ្មែរ

ក្រហមបានលាក់ខ្លួនពីក្រោយ សម្តេច ព្រះនរោត្តម សីហនុ ដែលសមាជិកព្រឹទ្ធសភា និងតំណាងរាស្ត្រអាមេរិកាំងជាច្រើន នៅតែមានសេចក្តីរាប់អានចំពោះព្រះអង្គនៅឡើយ ។ រដ្ឋាភិបាលអាមេរិកាំង បានខំប្រឹងពន្យល់ឲ្យសភាជឿ ដោយបានបញ្ជូនឯកអគ្គរដ្ឋទូតថ្មីម្នាក់ទៀត ទៅទីក្រុងភ្នំពេញនៅនិទិឃរដូវ ឆ្នាំ១៩៧៤ ។ ហ្សនហ្គុនធើដៀន (John Gunther Dean) បានបង្ហាញឲ្យឃើញថា គាត់ជាមនុស្សមានសមត្ថភាព និងស្វាហាប់ ប៉ុន្តែ គាត់មកដល់ដោយយឺតពេលណាស់ទៅហើយ ។ នៅលើសមរភូមិ គឺពួកកុម្មុយនិស្តទេដែលមានជោគជ័យ ហើយនៅសហរដ្ឋអាមេរិកវិញ យុទ្ធនាការដើម្បីធ្វើការកាត់បន្ថយ ឬការផ្អាកជំនួយមកឲ្យ លន់ នល់ បានទទួលការគាំទ្រមួយយ៉ាងសម្បើម ទាំងក្នុងមតិសាធារណជនក៏ដូចនៅសភាដែរ ។

នៅក្រុងភ្នំពេញ អារម្មណ៍របស់កងទ័ព និងពួកអ្នកនយោបាយ បានប្រែទៅជាមួរម៉ៅក្តៅក្រហាយគ្រប់គ្នាពីព្រោះពួកគេវិនិច្ឆ័យក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីសថា ជាការចាប់ផ្តើមនូវទីបញ្ចប់នៃផលប្រយោជន៍របស់អាមេរិកាំងនូវឥណ្ឌូចិន ។ កងទ័ពមានលក្ខណៈត្រូវធ្វើឲ្យភ័យ និងបាក់ទឹកចិត្ត ។ គេលែងអាចលាក់បិទបាំងបរាជ័យនៃរបៀបចាត់ចែងនយោបាយសម្រាប់រ៉ាប់រងកិច្ចការពារប្រទេសទៀតហើយ ។ តាមការនិយាយរៀបរាប់របស់មេបញ្ជាការទ័ពម្នាក់ក្នុងចំណោមមេបញ្ជាការទ័ពរបស់ទីក្រុងភ្នំពេញថា ៖ ការខ្វះខាតស្បៀងអាហារ ការបែងចែកអង្ករមិនស្មើភាពគ្នា និងភាពក្រីក្រគោកយ៉ាកដែលចេះតែរីកធំឡើងៗ ដោយមិននិយាយពីបរាជ័យនៅសមរភូមិផងនោះសុទ្ធតែជា«អានុភាពសណ្តំ»មួយ[៥១] លើពួកមេបញ្ជាការទ័ពមួយចំនួនធំ ។

ម្យ៉ាងទៀត ក្នុងប្រទេសក៏នៅមានសត្រូវ គឺពួកខ្មែរក្រហមដែលមានចិត្តមោះមុតអង់អាចក្លាហានក្នុងការប្រយុទ្ធ និងប្រជាជនកម្ពុជាដែលមិនទាក់ទងនឹងរបៀបធ្វើការដូចសព្វដង ។ នៅពេលដែលស្ថានទូតអាមេរិក ធ្វើអន្តរាគមន៍ ដើម្បីបង្ខំឲ្យក្រុងភ្នំពេញបន្ទាយពេលម៉ោងធ្វើការរហូតដល់ថ្ងៃរសៀល[៥២] ពួកខ្មែរក្រហមបានធ្វើការទាំងយប់ទាំងថ្ងៃ ។ ពួកបុគ្គលិកសិក្សា និងពួកនិស្សិតបាននាំគ្នាធ្វើបាតុកម្មនៅក្នុងរដ្ឋធានី ពួកកម្មករបានចាប់ផ្តើមធ្វើកូដកម្មដើម្បីសុំដំឡើងប្រាក់ខែ ពួកទាហានបានដើរឆក់ប្លន់តាមទីផ្សារនានា ក្នុងពេលដែលពួកខ្មែរក្រហម ស្ថិតនៅកៀកនឹងខ្លួន ដែលហាក់ដូចជាធានាបាននូវឯកភាព និងសេចក្តីស្មោះត្រង់យ៉ាងដាច់ខាតពីសំណាក់កងទ័ពទាំងអស់របស់ពួកគេ ។ ក្នុងរយៈពេលនៃការធ្វើការប្រយុទ្ធដំបូងៗ នៅឆ្នាំ១៩៧៣ កងទ័ពរបស់ លន់ នល់ បានត្រូវធ្វើឲ្យភ័ន្តភាំងស្រឡាំងកាំង ដោយសារការខូចខាតធ្ងន់ធ្ងរ ដែលពួកកុម្មុយនិស្តត្រៀមទទួលនៅលើសមរភូមិ ។ កងទ័ពកុម្មុយនិស្តប្រមាណជាមួយរយថ្វាយនាក់បានស្លាប់នៅក្នុងការប្រយុទ្ធទាំងនេះ ហើយកងកងទ័ពរបស់សាធារណរដ្ឋខ្មែរ មានស្លាប់តែជាងដប់នាក់ប៉ុណ្ណោះ ។

ឥឡូវនេះ ពួកខ្មែរក្រហមបានចាប់ផ្តើមសម្តែងជាអ្នកប្រដាប់ដោយគ្រឿងចាំបាច់សម្រាប់ការពារខ្លួនដែលគេមិនអាចវាយឈ្នះបាន ដូចរឿងនិទានចំពោះក្រសែភ្នែកគួសត្រូវក្រុងភ្នំពេញរបស់ពួកគេ ។ បើពួកកុម្មុយនិស្តបន្តរុលមកមុខក្រោមភ្លៀងគ្រាប់បែកមួយរបស់អាមេរិកាំងនោះ តើមានអ្នកណាមួយអាចបញ្ឈប់

ពួកគេបាន? ពួកនាយទាហានខ្លះរបស់ លន់ នល់ ត្រូវញ៉ាំងឲ្យជឿថា ពួកខ្មែរក្រហម បានប្រើប្រាស់ថ្នាំញៀនច្រើនហួសកំណត់ ដើម្បីធ្វើឲ្យមានសេចក្ដីក្លាហាន ។ នាយទាហានខ្លះទៀតប្រាកដក្នុងចិត្តថា ពួកកុម្មុយនិស្តមានប្រើអំពើអាបធ្មប់ ដែលធ្វើឲ្យខ្លួនគេមានឫទ្ធិអំណាចមួយផុតវិស័យមនុស្ស ។ រឿងនេះ ពុំមែនជារឿងចៃដន្យមួយទេ បើពួកទាហានរបស់សាធារណរដ្ឋខ្មែរចាប់ផ្ដើមដក់កញ្ឆាយ៉ាងច្រើន ឬស្លៀកពាក់អាវយន្ត មុននឹងចេញទៅច្បាំងដែរនោះ ។ បើសិនជាពួកទាហាន លន់ នល់ អាចមើលឃើញនូវអ្វីៗ ដែលមាននៅខាងក្រោយខ្សែការពាររបស់គូសត្រូវខ្លួននោះ ពួកគេច្បាស់ជាបាត់បង់ការយល់ច្រឡំទាំងអស់ ស្ដីពីការធ្វើអន្តរាគមន៍មួយនៃអានុភាពអាថ៌កំបាំងជាមិនខាន ហើយមុខជាមើលឃើញអ្នកដែលពួកគេកំពុងវាយប្រយុទ្ធតទល់នោះជាមនុស្សពិតៗ ថ្វីបើមានចរិកកាចសាហាវក៏ដោយ ។

ពួកខ្មែរក្រហមបានវាយតម្លៃពីការប្រយុទ្ធផ្សេងៗ ដូចពួកគេវាយតម្លៃចំពោះបញ្ហាផ្សេងៗទៀតដែរ ៖ ការសម្រេចចិត្តឈានឲ្យដល់គោលដៅ ទោះជាត្រូវបង់ខាតប៉ុន្មានក៏ដោយការរៀបចំយុទ្ធសាស្ត្រតឹងរឹងបំផុត ការមិនរួញរានឹងលះបង់ជីវិតមនុស្ស ។ បើមើលពីក្រៅ ពួកខ្មែរក្រហមហាក់ដូចជាបញ្ចេញសមត្ថភាពឲ្យឃើញពីការបញ្ចូលរបៀបថ្មីដែរ ជោគជ័យខ្លះក្នុងចំណោមជោគជ័យដ៏អស្ចារ្យរបស់ពួកគេ ច្រើនតែបានទទួល នៅក្នុងកំឡុងធ្វើប្រតិបត្តិការពេលយប់ ប៉ុន្តែ តាមសម្ដីនិយាយរបស់ ហែម សាមិន ជាជនមាតុភូមិនិវត្ត ដែលបែកចេញពីបក្សពួកម្នាក់ ដែលក្រោយមកបានភៀសខ្លួនត្រឡប់ទៅប្រទេសវៀតណាមវិញ បានឲ្យដឹងថា បើដឹងថាមើលផ្ទៃក្នុងវិញ គិតត្រឹមថ្នាក់មេបញ្ជាការរងចុះមកក្រោម គឺវិធីប្រយុទ្ធរបស់ពួកគេលេចចេញឲ្យឃើញលក្ខណៈ «សាហាវព្រៃផ្សៃណាស់» ។

សាមិន បាននិយាយថា «គេបានប្រាប់ឲ្យយើងវាយប្រយុទ្ធលឿនរហ័ស ទោះជាត្រូវបាត់បង់ជីវិតមនុស្សប៉ុន្មានក៏ដោយ កាលបើយើងមានប្រៀបជាងសត្រូវ ដោយមិនឲ្យយើងគិតគូរពីចំនួនមនុស្សស្លាប់ឡើយ ពីព្រោះថា រឿងនេះវាមិនសំខាន់ទេ[៥៣]» ។ បើសិនជាការវាយប្រយុទ្ធត្រូវទទួលបរាជ័យ មេបញ្ជាការ ដែលបញ្ជាកងឯកភាពនោះមុខជាត្រូវគេ «កម្ទេចចោល» ភ្លាម ហើយត្រូវជំនួសដោយមេបញ្ជាការរងម្នាក់ ដែលគេវិនិច្ឆ័យថាមានសេចក្ដីស្មោះត្រង់ចំពោះបក្ស ដែលជាអ្នកប្រមូលទ័ពឡើងវិញ ហើយចេញបញ្ជាឲ្យធ្វើការវាយលុកជាថ្មី ។ ពួកយុទ្ធជនដែលយកចិត្តទុកដាក់នឹង សាឡុត ស ជាងគេក៏ទទួលស្គាល់ថា ពួកគេបានវាយប្រយុទ្ធដោយរបៀបធ្វើឲ្យគូសត្រូវភ័ន្តភាំងស្រឡាំងកាំងដែរ ។ វ៉ុន ខ្មែរក្រហមម្នាក់ ដែលគេជ្រើសរើសពីក្នុងចំណោមប្រជាកសិករ បានផ្ដល់នូវចម្លើយជាសាក្សីនេះថា ៖ «ក្នុងរយៈពេលសង្គ្រាម គេបានកំណត់ឲ្យបរិភោគបាយអង្ករសម្រួបពីរដងក្នុងមួយថ្ងៃ ប៉ុន្តែជាញឹកញយ គេគ្មានបានបរិភោគអ្វីទាំងអស់ ហើយគ្មានថ្ងៃណាបានឈប់សម្រាកឡើយ ។ ពេញរយៈពេលនៃការទម្លាក់គ្រាប់បែក យើងទាំងអស់ត្រូវតែបោះទីតាំងកៀកបំផុតនឹងទាហានពួក លន់ នល់ តាមដែលអាចធ្វើបាន ដើម្បីយកពួកនោះធ្វើជារបាំងការពារពីការទម្លាក់គ្រាប់បែក ។ ពួកអាមេរិកាំងពុំអាចធ្វើអ្វី

យើងបានទេ ប៉ុន្តែ ពួកទាហាន លន់ នល់ អាចវាយប្រហារមកលើយើងបាន ។ មានយុទ្ធជនជាច្រើនក្នុងចំណោមពួកយើងបានត្រូវគេសម្លាប់ ពីព្រោះពួកមេបញ្ជាការយើងគិតថា មធ្យោបាយតែមួយ ដើម្បីដណ្តើមជ័យជម្នះ គឺត្រូវវាយប្រហារដោយគ្មានឈប់ឈរ ហើយរុលទៅមុខ ទោះបីជាមានការបាត់បង់អន្តរាយ និងការខ្វះខាតស្បៀងយ៉ាងណាក៏ដោយ» ។

សហករណ៍ទាំងឡាយបង្កើតបានផ្តល់ជាខ្សែរយៈផ្គត់ផ្គង់ភ័ស្តុភារមួយយ៉ាងលើសលុប ។ ទោះបីជាមានគ្រាប់បែកយ៉ាងច្រើនរបស់អាមេរិកាំង ហើយក្រោយមក មានការឆ្លក់វាយប្រហារពីសំណាក់យន្តហោះទម្លាក់គ្រាប់បែក និងការបាញ់រះពីសំណាក់ហ្វូងយន្តហោះតេ-២៨ របស់ លន់ នល់ ក៏ដោយ ក៏ការផលិតស្រូវបានកើនឡើងយ៉ាងច្រើន ពីឆ្នាំ១៩៧៣ ដល់ឆ្នាំ១៩៧៥ ដែរ ។ ការខ្វះការទាក់ទងគ្នារវាងបញ្ជាការដ្ឋានជាន់ខ្ពស់ខ្មែរក្រហម និងយុទ្ធជនរបស់គេ ត្រូវបានជំនួសមកវិញ ដោយខ្សែបណ្តាញសហករណ៍នេះឯង ។

នៅដំណាច់ឆ្នាំ១៩៧៣ ពួកខ្មែរក្រហម ដែលដោកជាំដោយជំនឿទុកចិត្តដ៏ហួសហេតុមួយ បានចេញបញ្ជា[៥៤] ឲ្យធ្វើការវាយលុកជាទូទៅមួយ ដើម្បីធ្វើឲ្យកងទ័ពរបស់សាធារណរដ្ឋខ្មែរចុះទន់ខ្សោយ មុននឹងបើកការវាយលុកផ្តាច់ព្រ័ត្រនៅរដូវប្រាំងឆ្នាំ១៩៧៤ ។ ជាដំបូង ពួកគេបានវាយប្រហារទៅលើទីក្រុងកំពង់ចាម ដែលស្ថិតនៅត្រើយខាងលិចទន្លេមេគង្គនៅសរទរដូវឆ្នាំ១៩៧៣ ប៉ុន្តែ បានត្រូវកងទ័ពរបស់សាធារណរដ្ឋខ្មែរវាយរុញឲ្យថយមកក្រោយវិញ ក្រោយពីការវាយប្រយុទ្ធគ្នាដ៏គួរឲ្យព្រឺខ្លាចជាច្រើនសប្តាហ៍ ។

នៅដើមឆ្នាំ១៩៧៤ ពួកខ្មែរក្រហមបានវាយប្រហារទីក្រុងភ្នំពេញ ។ នៅខែមករា ពួកគេបានវាយរុលចូលកៀករដ្ឋធានី ដែលល្មមឲ្យគេបាញ់កាំភ្លើង១០៥មម ចំនួន៣២០គ្រាប់ ទៅលើតំបន់ជាយក្រុងខាងត្បូងបណ្តាលឲ្យមានមនុស្សស្លាប់៩៥នាក់ និងរបួស១៩២នាក់ ។ ស្ថានទូតអាមេរិកាំង បានបញ្ជូនដំណឹងនេះទៅក្រុងវ៉ាស៊ីនតោន ហើយបានបន្ថែមថា ការវាយប្រហារនេះ «ដែលពួកកុម្មុយនិស្តអាចធ្វើបានដូច្នេះ គឺដោយសារតែការប្រឆាំងតបតយឺតយ៉ាវ និងភាពឥតសណ្តាប់ធ្នាប់របស់កងទ័ព លន់ នល់ ចំពោះការវាយយ៉ាងសម្បើមមួយរបស់សត្រូវក្នុងភាគខាងត្បូងរដ្ឋធានី»[៥៥] ។

តែក្នុងប៉ុន្មានថ្ងៃប៉ុណ្ណោះ ពួកកុម្មុយនិស្តបានបាញ់គ្រាប់ផ្លោងស្រោចមកលើទីក្រុងដូចភ្លៀងម្តងទៀត ដោយបានបំផ្លាញលំនៅដ្ឋានអស់ចំនួនដប់ពាន់ខ្នង និងធ្វើឲ្យមានអ្នករងគ្រោះជាច្រើននាក់ ។ សារពត៌មានអន្តរជាតិ បានពិពណ៌នាពីការបំផ្លិចបំផ្លាញដ៏សម្បើមអស្ចារ្យ និងការបាត់បង់អាយុជីវិតមនុស្ស ដែលបង្កឡើងដោយការបាញ់ផ្គត់នេះដែរ ហើយពួកខ្មែរក្រហមបានឆ្លើយតបពីក្រុងប៉េកាំងមកថា ការទម្លាក់គ្រាប់បែកទាំងប៉ុន្មានរបស់អាមេរិកាំងបានធ្វើឲ្យកើតមាន «អំពើគួរឲ្យខ្លាច» និងបង្កឡើងនូវ «អំពើឧក្រិដ្ឋក្នុងបំណងបំផ្លាញសង្គមមួយ»ក្នុងពេលដែលពួកយើងកំណត់ទីដៅវាយប្រហារតែទៅលើមូលដ្ឋានយោធា ឬនិវេសនដ្ឋានរបស់ «ពួកក្បត់ជាតិ» ប៉ុណ្ណោះ ។ម្យ៉ាងទៀត ពួកខ្មែរក្រហមបានបន្ថែមថា ពួកគេក៏បានប្រាប់ប្រជាជនឲ្យដឹងជាមុនថា យកល្អ

ត្រូវចាកចេញឲ្យផុតពីទីក្រុងដែរ ។

កងទ័ពរបស់ លន់ នល់ បានប្រមូលផ្ដុំគ្នាឡើងវិញនៅខែកុម្ភៈ ហើយបានវាយរុញច្រានពួកកុម្មុយនិស្ដផុតពីបរិវេណខ្សែក្រវាត់ការពាររបស់ក្រុងភ្នំពេញ ប៉ុន្ដែ កងទ័ពទាំងនេះនៅបន្ដការវាយប្រយុទ្ធ ហើយសម្រេចបានលទ្ធផល ក្នុងការដឹកជញ្ជូនតាមដងទន្លេមេគង្គរហូតមកដល់ដំណាច់ឆ្នាំនោះទៀត[៥៦] ។ ក្នុងកំឡុងការជាប់ដៃប្រយុទ្ធដ៏សំខាន់មួយនៅខាងលិចរដ្ឋធានី ពួកខ្មែរក្រហមបានបាត់បង់ជីវិតអស់៣៨០នាក់ ចំណែកខាងកងទ័ពរដ្ឋាភិបាលមានស្លាប់តែ៣៥នាក់ប៉ុណ្ណោះ ប៉ុន្ដែ ពួកកុម្មុយនិស្ដនៅតែបន្ដការវាយប្រយុទ្ធរបស់ខ្លួនតទៅទៀត ។ នៅខែវិច្ឆិកា ពួកគេបានចេញបញ្ជាឲ្យធ្វើការវាយលុករដ្ឋធានីម្ដងទៀត លើកនេះគឺនៅភាគត្បូងសាន ។ ការវាយលុកនេះ បានធ្វើឲ្យពួកកុម្មុយនិស្ដស្លាប់អស់ ៥៥៨នាក់ កងទ័ពសាធារណរដ្ឋខ្មែរស្លាប់១៦នាក់ ។ នៅដំណាច់ឆ្នាំ១៩៧៤ របប លន់ នល់ ជឿជាក់ថា បានពង្រឹងទីតាំងការពារសំខាន់ៗរបស់ខ្លួនរួចជាស្រេចអស់ហើយ ហើយប្រុងប្រៀបខ្លួនធ្វើការវាយបកមួយនារដូវប្រាំងខាងមុខទៀត ។ នៅក្រុងភ្នំពេញ ពួកមេដឹកនាំទាំងឡាយបានយកចិត្ដទុកដាក់ការពារជ័យជម្នះថ្មីៗដោយគ្មានដកថយ ដើម្បីពិនិត្យមើលទីតាំងរបស់គេដែលសត្រូវអាចវាយយកវិញបាន ។ ទីក្រុងត្រូវឡោមព័ទ្ធជុំជិត ទន្លេមេគង្គបានធ្លាក់ទៅក្នុងកណ្ដាប់ដៃខ្មែរក្រហមស្ទើរតែទាំងស្រុង ។ នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ១៩៧៤ ពួកកុម្មុយនិស្ដបានផ្សព្វផ្សាយតាមវិទ្យុលួចលាក់របស់ខ្លួននូវពាក្យព្រមាននេះថា "បើសិនជាផ្លូវទឹកទន្លេមេគង្គភាគខាងក្រោមត្រូវយើងខ្ទប់ជាប់ បន លន់ នល់ នឹងត្រូវស្លាប់ដូចគេប្របាច់កមិនខាន..." ។

ក្នុងពេលជាមួយគ្នានោះ ស្ថានទូតអាមេរិកាំងបានពិនិត្យមើលដោយល្អិតល្អន់អំពីការផ្ដួចផ្ដើមគំនិតរកសន្ដិភាពដោយថាហេតុតាមការស្នើរបស់ប្រទេសឥណ្ឌូនេស៊ី និងប្រទេសថៃ ។ វាហួសពេលទៅហើយ ។ ទូរលេខដែលបញ្ជូនទៅក្រុងវ៉ាស៊ីនតោន នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៥ បង្ហាញឲ្យជាទូលេខដឹងរឿងនេះយ៉ាងច្បាស់ ៖

"កងទ័ពរបស់កុម្មុយនិស្ដខ្មែរ បានធ្វើការរុលចូលមកមុខយ៉ាងគឃ្លើន ដោយផ្ដើមការវាយលុកធំៗជុំវិញទីក្រុងភ្នំពេញនៅដើមឆ្នាំថ្មីនេះ (ឆ្នាំ១៩៧៥) ។ នៅទិសពាយ័ព្យ កងពលធំលេខ៧របស់ លន់ នល់ បានត្រូវកងទ័ពខ្មែរក្រហម ធ្វើឲ្យខូចខាតយ៉ាងធ្ងន់ធ្ងរ ហើយបានដកទៅរកទីតាំងមួយចំនួនទៀត ដែលស្ថិតនៅទិសត្បូងសានរដ្ឋធានី និងត្រើយខាងស្ដាំទន្លេមេគង្គ ដែលចេញពីទីនេះទៅ ពួកអ្នកបាញ់កាំភ្លើងធំរបស់ពួកកុម្មុយនិស្ដបានបាញ់ផ្លោងគ្រាប់រ៉ុក្កែតទំហំ ១០៥មម ជាងសែសិបគ្រាប់ មកលើកណ្ដាលទីក្រុង ។ តំបន់ដទៃទៀត ដែលនៅតាមបរិវេណខ្សែការពារទីក្រុង ត្រូវខាងយើងកាន់កាប់យ៉ាងរឹងមាំ ថ្វីបើពួកកុម្មុយនិស្ដបានផ្លោងគ្រាប់កាំភ្លើងត្បាល់៨១មម គ្រាប់រ៉ុក្កែត និងគ្រាប់១០៥មម ធ្លាក់មកក្បែរៗអាកាសយានដ្ឋានពោធិចិនតុងក៏ដោយ ។ដំណើររុលមកមុខរបស់ពួកកុម្មុយនិស្ដកាន់តែមានសភាពធ្ងន់ធ្ងរថែមទៀតនៅតាមបណ្ដោយទន្លេមេគង្គ ជាទីដែលពួកនោះបានបញ្ឈប់

ចលនាកងពលតូចមួយរបស់រដ្ឋាភិបាលមិនឲ្យធ្វើសកម្មភាពកើត ដើម្បីកាត់ផ្តាច់ផ្លូវជាតិលេខ១ ហើយវាយទៅរកវាយទីតាំងនានា នៅផ្នែកខាងក្រោមទន្លេមេគង្គទៀត[៥៧] » ។

ពួកខ្មែរក្រហមបានចាត់ចែងធ្វើការប្រយុទ្ធទៅតាមក្បួនយុទ្ធសាស្រ្ត ដោយមិនដែលគិតគូរពីខាងក្រោយសោះឡើយ ។ ទន្លេមេគង្គត្រូវគេពង្រាយមីនពោសពេញ ហើយក្លាយទៅជាផ្លូវទឹកមួយ ដែលមិនអាចធ្វើចរាចរបាន ។ រៀងរាល់ថ្ងៃចំណតអាកាសយាន ត្រូវទទួលរងគ្រាប់កាំភ្លើងធំពីសាមសិបទៅសែសិបគ្រាប់ ។ នៅភាគខាងត្បូង កងទ័ពកុម្មុយនិស្តបានរុលមកមុខ ហើយនៅថ្ងៃទី១ ខែមេសា បានវាយកាន់កាប់ទីប្រជុំជនអ្នកលឿង ។ នៅថ្ងៃដដែលនោះ លន់ នល់ ត្រូវបង្ខំឲ្យចាកចេញពីប្រទេស ដោយពួកនាយទាហាន និងពួកមេដឹកនាំនយោបាយផ្ទាល់របស់គាត់ដែលសង្ឃឹមថា កាយវិការមួយបែបនេះ នឹងជួយជំរុញឲ្យមានកិច្ចចរចាសន្តិភាពជាមិនខាន ។

ថ្ងៃទី១២ ខែមេសា បុគ្គលិកស្ថានទូត និងឯកអគ្គរដ្ឋទូតរបស់សហរដ្ឋអាមេរិក បាននាំគ្នាចាកចេញពីទីក្រុងភ្នំពេញ ។ ថ្ងៃទី១៥ ខែមេសា នៅតាខ្មៅ ដែលជាទីតាំងការពារចុងក្រោយត្រូវរលំដួល ។ ក្នុងរដ្ឋធានី បរិយាកាសមានលក្ខណៈស្ងប់ស្ងាត់បជាពលរដ្ឋ ទាំងអស់នឹកព្រួយបារម្ភក្នុងចិត្ត ប៉ុន្តែ នៅមានសេចក្តីអត់ធ្មត់ ហើយពុំមានសភាពជ្រួលច្របល់ដូចនៅទីក្រុងព្រៃនគរទេ ពុំមានហ្វូងមនុស្សដែលប៉ុនប៉ងបុកទម្លាយរបងដែកស្ថានទូតអាមេរិកាំង ដើម្បីប្រយិតប្រយោង ឡើងជិះឧទ្ធម្ភាគចក្រ និងចាកចេញពីប្រទេសដែរ ។ ការភ័យខ្លាចដែលបញ្ចេញឲ្យប្រជាជនដឹងដោយ លន់ នល់ ពីរឿងពួកវៀតណាមដណ្តើមយកប្រទេសកម្ពុជាដោយកម្លាំងនោះ បានលេចឡើងឲ្យឃើញគ្មានមូលដ្ឋានសោះ ព្រោះអ្នកលុកលុយសុទ្ធតែជាជនជាតិកម្ពុជាដូច ។

នៅថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥ សាធារណរដ្ឋខ្មែរ បានវាយទូរលេខទៅសម្តេច ព្រះនរោត្តម សីហនុ ដែលគង់ប្រថាប់នៅក្រុងប៉េកាំង ដោយធ្វើសំណើមួយឲ្យមានបទឈប់បាញ់គ្នាជាបន្ទាន់ និងសូមថ្វាយអំណាចទៅព្រះអង្គវិញ ។

នៅព្រឹកថ្ងៃបន្ទាប់ សម្តេច ព្រះនរោត្តម សីហនុ បានឆ្លើយតបមកវិញដោយការបដិសេធដាច់អហង្ការ-មួយ ។ (ម្យ៉ាងទៀត ព្រះអង្គក៏គ្មានលទ្ធភាពទទួលយកដង្វាយអំណាចនេះដែរ បើទុកជាព្រះអង្គចង់បានក៏ដោយ) ។

នៅម៉ោង៨ៈ៣០នាទី ថ្ងៃដដែលនោះ[៥៨] ពួកមេដឹកនាំសាធារណរដ្ឋ បាននាំគ្នាទៅប្រមូលផ្តុំនៅកីឡដ្ឋានអូឡាំពិច ដើម្បីរង់ចាំឧទ្ធម្ភាគចក្រជាច្រើនគ្រឿង ដែលនឹងត្រូវមកដឹកយកពួកគេភ្លោះទៅភាគខាងជើងប្រទេស ប្រហែលពួកគេនឹកគិតថា នឹងរៀបចំបង្កើតរដ្ឋាភិបាលនិរទេសមួយនៅទីនោះ ។ ការប៉ងប្រាថ្នានេះ បានបញ្ចប់ទៅប្រកបដោយសោកនាដកម្មដូចគ្នា ។ ភាគច្រើននៃឧទ្ធម្ភាគចក្រភាគមានបញ្ហាខូចម៉ាស៊ីន ហើយមានតែមួយចំនួនតូចប៉ុណ្ណោះ ដែលអាចហោះឡើងបាន ។ កងទ័ពរបស់ខ្មែរក្រហមខាងភូមិភាគឧត្តរ និងបូព៌ា បានសម្រុកចូលទីក្រុងនៅពេលព្រឹកព្រហាម ។ រដ្ឋមន្រ្តីទី១ ឡុង បូរ៉េត មេដឹកនាំម្នាក់ក្នុងចំណោមមេដឹកនាំជាច្រើន ដែលរត់គេចសខ្លួនពុំរួចត្រូវពួកកម្មាភិបាលរបស់ ខៀវ សំផន ចាប់ខ្លួនបាន ។ (ដប់ប្រាំមួយឆ្នាំមុន ឡុង បូរ៉េត ដែលជារដ្ឋមន្រ្តី

ក្រសួងឃោសនាការរបស់សម្ដេច ព្រះនរោត្ដម សីហនុ ធ្លាប់បានទិតៀន ខៀវ សំផន និងកាសែតរបស់គាត់យ៉ាងខ្លាំង) ។ តាមគេគិតស្មានទង្វើដំបូងមួយក្នុងចំណោមទង្វើដំបូងៗរបស់ពួកកុម្មុយនិស្ដ ដែលចូលមកដល់ក្នុងទីក្រុង គឺការកាត់ក្បាល ឡុង បូរ៉េត នៅលើវាលស្មៅមណ្ឌលកីឡដ្ឋានឯកជន (ខាងលិចវត្តភ្នំ) នេះឯង ។

សាឡុត ស បានវាយឈ្នះ លន់ នល់ ។ បន្ទាប់ពីបានក្លាយជាមេដឹកនាំប្រទេសកម្ពុជាបដិវត្ត ស បានប្រកាន់យករហស្សនាម ប៉ុល ពត របស់គាត់ជាផ្លូវការ ។

# ជំពូកទី៥
# ការបដិវត្តន៍ចុងក្រោយបង្អស់

*យើងត្រូវតែផ្តល់គុណសម្បត្តិ ចំពោះមហាជ័យជម្នះអស្ចារ្យណាស់របស់យើងនៅលើឆាកអន្តរជាតិ ព្រោះថា ពីមុនមកមិនដែលមានព្រឹត្តិការណ៍ ដូចនេះនៅក្នុងប្រវត្តិសាស្ត្រសង្គ្រាមបដិវត្តន៍នៃពិភពលោកសោះឡើយ... ។ ការទទួលបានមហាជ័យជម្នះដូច្នេះក្នុងរយៈស្មើរតែមិនដល់ប្រាំឆ្នាំផង គឺលឿនរហ័សខ្លាំងណាស់ ។ ដូច្នេះបក្សបានបញ្ជាឲ្យខំប្រឹងប្រែងកសាងជាតិដោយចាប់ផ្តើមជាបន្ទាន់ ដើម្បីធ្វើឲ្យសម្រេចជោគជ័យតាមល្បឿនមហាលោតផ្លោះ ក្នុងគោលបំណងឲ្យប្រទេសរបស់យើងក្លាយទៅជារដ្ឋចម្រើនរុងរឿងមួយប្រកបទៅដោយកសិកម្ម និងឧស្សាហកម្មទំនើបមួយ និងធ្វើឲ្យជីវភាពរស់នៅរបស់ប្រជាជនយើងកាន់តែប្រសើរជាងមុន ដោយឆាប់រហ័ស[១] ។*

*ប៉ុល ពត សុន្ទរកថារំឭកថ្ងៃជ័យជម្នះ, ខែកក្កដា ឆ្នាំ១៩៧៥*

*ការសាកល្បងទាំងអស់ ហាក់ដូចជាឧបការណ៍មួយនៃការប្រព្រឹត្តផ្តេសផ្តាសយ៉ាងសម្បើមមិនគួរឲ្យជឿមួយ ដែលក្នុងនោះគោលការណ៍នៃភាពសមហេតុសមផល និងគោលការណ៍ទាំងអស់ផ្នែកសេដ្ឋកិច្ចបានត្រូវធ្វើឲ្យក្រឡាប់ចាក់ ។ គឺហាក់ដូចជាប្រជាជាតិទាំងមូលមួយត្រូវបោះបង់ចោល ហើយកម្ទេចគេហដ្ឋាន និងផ្ទះខ្ទមរបស់ខ្លួន...ដើម្បីទៅរស់នៅក្នុងបណ្តាអគារផ្សេងៗ ដែលស្ថិតក្នុងការស្រមៃ ដោយមានអាវុធ និងអីវ៉ែអីវ៉ាន់ជាច្រើនផង ។ ប្រទេស ត្រូវបានដឹកនាំដោយបង្ខំក្នុងការអនុវត្តនូវគម្រោងហួសពីការពិតនេះ ដែលត្រូវរុញនឹងជន្ទញនិងវាយនឹងរំពាត់ខ្សែតី ដោយមនុស្សសាមញ្ញ, ធម្មតារមទម្យបង្គួរម្នាក់ ដែលចិត្តគំនិតបានប្រែទៅជាគិតមមៃភ្លាមមួយរំពេច ដោយទស្សនៈរវើរវាយ ពាក់កណ្តាលការពិត ពាក់កណ្តាលមមើមមាយមួយ, ជាមនុស្សម្នាក់ ទទួលតួនាទីជាចៅក្រមផង និងជាស្តាបត្យករកំពូលផង ដែលជាតួនាទីព្រះចៅហ្វារ៉ាអុងសម័យទំនើបម្នាក់[២] ។*

*ប្រវត្តិវិទូ អ៊ីសាក់ ដាច់ឈ័រ អំពីបដិវត្តន៍ទីពីររបស់*
*ហ្សូហ្សេហ្វ ស្តាលីន នៅសហភាពនៃសាធារណរដ្ឋ*
*សង្គមនិយមសូវៀត នាចុងទសវត្សរ៍១៩២០*

*ឥឡូវនេះ ពួកមេដឹកនាំចិនសុទ្ធតែតឿនបង្ខំ ។ ពួកគេចង់បានលទ្ធផលឆាប់រហ័ស ។ ពួកគេសង្ឃឹមធ្វើឲ្យមានឡើងវិញក្នុងរវាងបី ឬបួនឆ្នាំ -ប្រាំឆ្នាំយ៉ាងច្រើន- ដើម្បីធានាធ្វើឧស្សាហូបនីយកម្ម និងការរីក*

*លូតលាស់ផ្នែកសេដ្ឋកិច្ចដែលមានលក្ខណៈឃើតយ៉ាវពីរ-បីទសវត្សរ៍មកហើយ ។ ហើយពួកគេមានបំណងឈានទៅដល់គោលដៅនេះ ដោយបង្ខំឲ្យប្រជាជនធ្វើការកាន់តែខ្លាំងឡើងៗ ដោយចាប់ផ្ដើមធ្វើការអភិវឌ្ឍដំណាលគ្នា ខាងផ្នែកឧស្សាហកម្ម និងកសិកម្ម-និយាយឲ្យខ្លីគឺ តាមរយៈដំណើរមហាលោតផ្លោះទៅមុខ[៣] ។*

*សាស្ត្រាចារ្យ វិទ្យា ប្រសាក ឌុត*
*អំពីនយោបាយមហាលោតផ្លោះរបស់ប្រទេសចិននៅចុងទសវត្សរ៍១៩៥០*

នៅពេលនេះ ប្រជាជនកម្ពុជាបានស្ថិតនៅក្នុងកណ្ដាប់ដៃពួកខ្មែរក្រហម ដែលចាប់ផ្ដើមធ្វើបដិវត្តន៍ ចុងក្រោយបំផុតដោយពិតប្រាកដ ។ ពួកគេបានរៀបចំកម្មវិធីផ្លាស់ប្តូរមួយ ដោយបញ្ញត្តិថា ត្រូវអនុវត្តតាមកម្មវិធីនេះឲ្យបានយ៉ាង "ដាច់ខាត" "ពេញលេញ" និង"ឆាប់រហ័សបំផុត" ។ គ្រាន់តែមួយភ្លែតសោះ កម្មសិទ្ធិឯកជនបានត្រូវលុបបំបាត់ចោល ប្រជាជននៅតាមទីក្រុងធំតូច ត្រូវបញ្ជូនឲ្យទៅរស់នៅតាមជនបទនានា ។ អ្វីៗទាំងអស់ដែលផលិតបានក្នុងប្រទេស ក្នុងស្រែចម្ការ ឬក្នុងរោងចក្រផ្សេងៗត្រូវរដ្ឋប្រមូលយកមកកាន់កាប់ ។ ការធ្វើដំណើររបស់ប្រជាជនត្រូវដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់រដ្ឋ ប្រទេសជាតិបាន ត្រូវបានកាត់ផ្ដាច់ពីពិភពខាងក្រៅ ។ ចាប់ពីពេលនេះតទៅ គឺមានតែវណ្ណៈអ្នកបដិវត្ត ៖ កម្មករ កសិករ កងទ័ព និងកម្មាភិបាលទទួលខាងផ្នែកនយោបាយប៉ុណ្ណោះ ហើយប្រភពអំណាចក៏មានតែមួយគត់ដែរ គឺបក្សកុម្មុយនិស្តកម្ពុជា ហៅម្យ៉ាងទៀតថា "អង្គការ" ។

ពួកខ្មែរក្រហម បានផ្ដល់ពត៌មានអំពីវិធីសាស្ត្រ និងមហិច្ឆតារបស់ពួកគេឲ្យពិភពលោកដឹង យ៉ាងតិចតួចបំផុតតាមដែលអាចធ្វើទៅបាន ។ ការនៅស្ងៀមមិននិយាយរបស់គេ គឺជារឿងអាថ៌កំបាំង ដែលពុំអាចយល់បានថែមទាំងគួរឲ្យព្រឺខ្លាចទៀតផង ។ ភ័ស្តុតាងដំបូងៗស្តីពីជីវភាពរស់នៅក្រោមការក្តោបក្តាប់របស់គេ បានលេចចេញពីប្រជាជនកម្ពុជាជាច្រើន ដែលសម្រេចរត់ភៀសខ្លួនទៅប្រទេសថៃ ។ អ្នកទាំងនោះបានរំលើកបើកកកាយរបបនេះថា ជារបបចម្លែកមួយគួរឲ្យខ្លាចខ្លាំងណាស់ ។ ពួកអ្នកភៀសខ្លួនបាននិយាយឲ្យដឹងថា គេបានសម្លាប់មនុស្សដែលមានពាក់វ៉ែនតា ពីព្រោះពួកខ្មែរក្រហមជឿថា មានតែពួកបញ្ញវន្តប៉ុណ្ណោះ ដែលពាក់វ៉ែនតា គេបង្ខំឲ្យយុវនារីស្អាតៗរៀបការជាមួយនឹងអតីតយុទ្ធជនពិការ គ្រឿងល្បែងសម្រាប់ក្មេងលេង ក៏ត្រូវគេហាមឃាត់ដែរ គេលែងឃើញមានខ្លែងក្រដាសអណ្តែតក្នុងលំហអាកាសទៀតហើយ ទាំងសត្វឆ្កែក៏គ្មានឃើញរត់តាមផ្លូវដែរ ពីព្រោះប្រជាជនដែលស្រេកឃ្លាន បានសម្លាប់វាដើម្បីយកសាច់ទៅបរិភោគអស់ទៅហើយ ។

នេះជាការនិយាយពន្លើសខ្លះៗ ប៉ុន្តែ ដោយសំអាងលើការពិតមួយគួរឲ្យព្រឺខ្លាចជាខ្លាំង ដែលពិកបាកនិយាយពន្យល់ឲ្យគេជឿដូចរឿងប្រឌិតខ្លីៗដែរ ។ រឿង "វ៉ែនតា" បានឆ្លុះបញ្ចាំងឲ្យឃើញពីរបៀប ដែលពួក

ខ្មែរក្រហមកំណត់ទីដៅវាយប្រហារទៅលើពួកបញ្ញវន្ត ដោយចាត់ទុកថា ជាមនុស្សអាចផ្ដល់គ្រោះថ្នាក់ ហើយគេបានសម្លាប់មនុស្សអស់ជាច្រើនពាន់នាក់ ពីព្រោះតែអ្នកទាំងនោះបានរៀនសូត្រចេះដឹងជ្រៅជ្រះប៉ុណ្ណោះ ។ ប្រវត្តិរបស់យុវនារីស្អាតៗ ដែលរៀបការនឹងយុទ្ធជនពិការ អាចបកស្រាយឲ្យឃើញការត្រួតត្រាទាំងស្រុងរបស់អង្គការទៅលើការរៀបអាពាហ៍ពិពាហ៍ ការហាមមិនឲ្យមានការទាក់ទងខាងផ្លូវភេទ និងស្នេហាលួចលាក់គ្មានរៀបការ ដោយមានការសម្លាប់អ្នកប្រព្រឹត្តល្មើសចោលជាញឹកញយទៀតផង ។ ប្រដាប់សម្រាប់ក្មេងលេង និងខ្លែងក្រដាស បានឆ្លុះបញ្ចាំងដោយត្រឹមត្រូវពីស្ថានភាពរបស់យុវជនកម្ពុជាទាំងឡាយ ដែលបាត់បង់អស់នូវយុវភាពរបស់ខ្លួន ហើយត្រូវមានករណីកិច្ចធ្វើការងារដូចជា មនុស្សពេញវ័យដែរ ។ គេមិនបណ្ដោយឲ្យមានពេលទំនេរ មិនឲ្យលេងសើចសប្បាយ និងលេងកីឡាឡើយ ហើយចំពោះអ្នកទាំងនេះ គេអនុញ្ញាតឲ្យមានពេលវេលាយ៉ាងតិចតួចបំផុតសម្រាប់ការរៀនសូត្រត្រឹមតែថ្នាក់ទី៣ប៉ុណ្ណោះ ។ នៅទីបញ្ចប់ ការបាត់សត្វឆ្កែអស់ពីភូមិមានភាពជានិមិត្តរូបនៃការបាត់បង់ម្ហូបអាហារសម្រាប់មនុស្សមួយចំនួនធំ ។

ប្រជាជនកម្ពុជាខ្លះ ដែលរួចរាល់ជីវិតពីរបបខ្មែរក្រហមជឿជាក់ថែមទៀតថា វាច្បាស់ជាលែងមានវ៉ែនតា ប្រដាប់ក្មេងលេង និងសត្វឆ្កែក្នុងប្រទេសកម្ពុជារបស់ ប៉ុល ពត ទៀតហើយ - ប្រហែលជាផ្អែកលើការពិសោធន៍ផ្ទាល់របស់គាត់ហើយមើលទៅ ។ វាទំនងគួរឲ្យជឿដែរ ដែលការនិយាយពន្លើសទាំងនេះ បានក្លាយទៅជាប្រភេទនិយាយបញ្ឆោតខ្លីៗគួរឲ្យទទួលយកបានស្ដីពីភាពនាំឲ្យព្រឺរន្ធត់ ដោយឡែក ដែលពួកអ្នករួចផុតពីគ្រោះថ្នាក់ប្រហែលជាមិនចង់និយាយប្រាប់ ។

ដោយផ្អែកលើភស្តុតាងមុនៗជាច្រើន ដែលដូចសុទ្ធសាធនឹងបណ្ដាភស្តុតាងពីមុនរបស់សម្ដេច ព្រះនរោត្តម សីហនុ និង លន់ នល់ ពួកខ្មែរក្រហមជឿថា ករណីយកិច្ចទីមួយរបស់គេ គឺការពារប្រទេស ទោះជាត្រូវខូចខាតប៉ុន្មានក៏ដោយ និងបញ្ចៀសមិនឲ្យមហាអំណាចបរទេសទាំងអស់ ឈ្លានពានដែនដីរបស់ប្រទេសកម្ពុជាបានឡើយ ។ ពួកគេមានបំណងបញ្ឈប់ការពង្រេចពង្រីលឯករាជ្យភាព និងអធិបតេយ្យរបស់ប្រទេសជាតិ ការពារពូជពង្ស និងវប្បធម៌ របស់ខ្មែរ ។ ពួកគេបាននិយាយរឿងនេះឡើងវិញជាញឹកញាប់ ហើយរឿងនោះ មុនដំបូងហាក់ដូចជារឿងគួរឲ្យអស់សំណើចណាស់ ។ សម្ដេច ព្រះនរោត្តម សីហនុ និង លន់ នល់ ក៏ធ្លាប់នឹកព្រួយបារម្ភនឹងរឿងការពារប្រទេសកម្ពុជាដែរ នៅពេលដែលពួកអាមេរិកាំង និងពួកវៀតណាមកំពុងជាប់ដៃច្បាំងគ្នានោះ ។ ក្នុងពេលដែលសង្គ្រាមឥណ្ឌូចិនផុតរលត់ ពួកខ្មែរក្រហមហាក់ដូចជាគ្មានភ័យព្រួយពីរឿងអ្វីទាំងអស់ ។ បណ្ដាសម្ព័ន្ធមិត្ត វៀតណាម និងឡាវ របស់ពួកគេ សុទ្ធតែបានឈ្នះសង្គ្រាមរៀងៗខ្លួន ។ ប្រទេសថៃ ដែលកាលពីដើមធ្លាប់ធ្វើឲ្យគេព្រួយបារម្ភ មានបំណងបង្កើតទំនាក់ទំនងល្អជាមួយកម្ពុជា បើទុកជាមានភស្តុតាងផ្ទួនៗ ស្ដីពីអំពើឃោរឃៅជាច្រើន ដែលពួកខ្មែរក្រហមបានប្រព្រឹត្តនៅក្នុងប្រទេសផ្ទាល់របស់គេក៏ដោយ ។

ប៉ុន្តែ ពួកខ្មែរក្រហមនៅតែរក្សាអនុស្សាវរីយ៍សំខាន់ជាងគេមួយនៃ ក្នុងបញ្ហាផ្សេងៗរបស់ពួកគេជាមួយ

នឹងពួកកុម្មុយនិស្តវៀតណាម និងការឲ្យយោបល់ម្តងហើយម្តងទៀតរបស់ក្រុងហាណូយ ក្នុងនាមនៃសហព័ន្ធឥណ្ឌូចិនមួយដែលយកទម្រង់តាមបែបសូវៀតជានិច្ច ។ ពួកមេដឹកនាំ "អង្គការ" បានចាប់ផ្តើមធ្វើបដិវត្តន៍មួយដែលនឹងផ្តល់នូវអ្វីៗដែលពួកគេចាត់ទុកជាការការពារមួយ ដែលគ្មានអ្នកណាអាចជ្រៀតចូលបានប្រឆាំងនឹងការគាបសង្កត់គ្រប់បែបយ៉ាងរបស់បរទេស ហើយដែលនឹងធ្វើឲ្យបានសម្រេចនូវគោលដៅទី២របស់ខ្លួនព្រមគ្នាទៀត ៖ កសាង និងធ្វើឲ្យប្រទេសកម្ពុជាទំនើបទាន់សម័យ លើកកម្ពស់កម្រិតជីវភាពប្រជាជន និងបញ្ចប់ភាពក្រីក្រគោកយ៉ាក ។ នេះគឺជាគោលបំណង ដែលការបដិវត្តទាំងអស់របស់ពួកកុម្មុយនិស្ត តែងតែប្រកាសឲ្យដឹងគ្រប់គ្នា ។

ការដោះស្រាយបញ្ហានេះ ស្ថិតនៅត្រង់កាត់ផ្តាច់ប្រទេសជាតិពីពិភពខាងក្រៅទាំងស្រុង បង្កើតប្រទេសខ្លួនឧបត្ថម្ភមួយ ដោយគ្មានត្រូវការឲ្យមានការធ្វើពាណិជ្ជកម្ម និងការទាក់ទងជាមួយបរទេសឡើយ ។ ប្រទេសកម្ពុជារបស់ពួកខ្មែរក្រហម ដែលផ្តាច់ខ្លួនចេញពីពួកបរទេសមិនគួរឲ្យប្រាថ្នា ដែលការពារឥទ្ធិពលបរទេស នឹងក្លាយទៅជាបន្ទាយដ៏រឹងមាំមួយមិនអាចមានអ្នកណាវាយលុកបានឡើយ ។ នយោបាយខ្លួនឧបត្ថម្ភខ្លួន និងការពារប្រទេសដោយខ្លួនឯង បានក្លាយទៅជាគោលដៅតែមួយដូចគ្នា ។ គ្រឿងសម្រាប់ការពារអ្នកប្រើអំណាចផ្តាច់ការដែលរៀបចំឡើងដោយសម្តេច ព្រះនរោត្តម សីហនុ បានក្លាយទៅជាកន្លែងការពារយ៉ាងមាំទាំមួយ ដែលពង្រឹងដោយពួកអាមេរិកាំង ដើម្បីជួយទ្រទ្រង់ លន់ នល់ ថែមទៀត ហើយឥឡូវនេះ ភាពនៅដាច់ឡែកតែឯងគ្មានទាក់ទងជាមួយអ្នកណានឹងត្រូវបញ្ចប់ដោយពួកខ្មែរក្រហម ហើយប្រទេសជាតិនឹងត្រូវធ្វើឲ្យទៅជា«គុកឥតជញ្ជាំង»វិញ ។

ទម្លាប់ជាប្រពៃណីរបស់ពួកកុម្មុយនិស្ត គឺយល់ស្របជាមួយនឹងគោលដៅនេះ ហើយវាមានទម្លាប់ជាប្រពៃណីមួយចំនួនដែលធ្លាប់មានពីមុនទាក់ទងនឹងបដិវត្តខ្មែរក្រហមដែរ ។ ឧទាហរណ៍ដូចជា ពួក បុល សេវិច បានសម្រេចរក្សាទុកច្បាប់អាជ្ញាសឹកបន្ទាប់ពីជ័យជម្នះរបស់គេ ក្នុងសេចក្តីសង្ឃឹមស្វែងរក«ផ្លូវកាត់មួយ» ដែលនាំឆ្ពោះទៅលទ្ធិសង្គមនិយម ។ ក្នុងរយៈពេលនៃបដិវត្តន៍ទីពីរ ស្តាលីន បានតម្រូវឲ្យប្រជាជនរុស្ស៊ីធ្វើពលិកម្មយ៉ាងសម្បើម រួមទាំងជីវិតផ្ទាល់ខ្លួនផង ក្នុងគោលបំណងធ្វើឲ្យសហភាពសូវៀតអាចធ្វើឧស្សាហូបនីយកម្មតែក្នុងរវាងពីរ-បីឆ្នាំប៉ុណ្ណោះ ។ សាមសិបឆ្នាំក្រោយមក នយោបាយមហាលោតផ្លោះរបស់ចិន បានចាប់ផ្តើមឡើងតាមមាគ៌ាដដែលនេះ ក្នុងគោលបំណងធ្វើទំនើបកម្មវិស័យឧស្សាហកម្ម និងកសិកម្មរបស់ចិនឲ្យបានសម្រេចក្នុងរយៈពេលយ៉ាងខ្លីបំផុត ។ ការពិសោធន៍ទាំងពីរនេះ បានបណ្តាលឲ្យមានមនុស្សស្លាប់ឥតប្រយោជន៍ច្រើនរាប់មិនអស់ បណ្តាលឲ្យមានស្ថានភាពអត់ឃ្លាននៅក្នុងតំបន់ជនបទជាច្រើន និងមានចលនាផ្លាស់ប្តូរប្រជាជន ទាំងបង្ខំពីកន្លែងមួយទៅកន្លែងមួយ ការរឹបអូសទ្រព្យសម្បត្តិឯកជន និងការរៀបចំរបបភេរវកម្មថ្មីមួយពីសំណាក់រដ្ឋទៀត ។

ត្រូវជំរុញមួយផ្នែកដោយការភ័យព្រួយរបស់ប្រជាជនកម្ពុជា ក្រែងបាត់បង់ប្រទេសជាតិ និងវិនាសពូជសាសន៍ខ្លួនពួកខ្មែរក្រហមបានប្រកាន់យកទម្រង់ជ្រុលហួសហេតុនៃមនោគមន៍វិជ្ជាកុម្មុយនិស្ត និងនយោបាយ

មួយ ដែលស្តែងឡើងជាសញ្ញាឲ្យកើតមានការបារម្ភដោយផ្ទាល់មួយ ចំពោះរបៀបរបបរស់នៅជាប្រពៃណីរបស់ប្រទេសកម្ពុជា ។ នៅពេលដែលគេឲ្យប្រជាជនចាកចេញពីក្រុងភ្នំពេញនៅថ្ងៃ បន្ទាប់ពីជ័យជម្នះ ប្រជាជនកម្ពុជាមួយចំនួនធំ បាននឹកគិតទៅដល់ពាក្យទំនាយដែលថា ប្រជាជាតិខ្មែរនឹងត្រូវរលត់រលាយពីភពផែនដីមិនខាន ។

នៅពេលដែលពួកខ្មែរក្រហមដណ្តើមបានជ័យជម្នះ[៤] អៀង សារី កំពុងស្ថិតនៅទីក្រុងហាណូយឯណោះ ។ គាត់មានអត្ថប្រយោជន៍ផ្ទាល់ខ្លួនក្នុងការប្រកាសប្រាប់ពួកវៀតណាមថា ពួកកុម្មុយនិស្តកម្ពុជា បានដណ្តើមកាន់កាប់ទីក្រុងភ្នំពេញ មុនកងទ័ពវៀតណាមខាងជើង មិនទាន់វាយយកបានទីក្រុងព្រៃនគរទៅទៀត ។ មួយសប្តាហ៍ក្រោយមក គាត់បានវិលត្រឡប់មកប្រទេសវិញតាមយន្តហោះមួយគ្រឿង ដែលបន្ទាបខ្លួនរត់នៅលើផ្លូវក្រហែងក្រហូងនៃចំណតអាកាសយានដ្ឋានពោធិចិនតុង ។ ក្នុងរថយន្តដែលដឹកគាត់ឆ្ពោះមកកាន់រដ្ឋធានី គាត់មើលឃើញទីកន្លែងជាច្រើន ដែលគាត់ធ្លាប់ស្គាល់កាលពីមុន ប៉ុន្តែ ឥឡូវនេះ បែរជាដេរដាសទៅដោយកាកសំណល់បាក់បែកនៃសង្គ្រាមទៅវិញ ហើយទុកជាយ៉ាងដូចម្តេចក៏ដោយ ក៏គាត់បានថតទុករូបភាពមួយ ដែលខុសពីសភាពដើម នៅក្នុងខួរក្បាលរបស់គាត់ដែរ ។ សារី ធ្លាប់ចាកចេញពីទីក្រុងទាំងតក្កហលកាលពីដប់ពីរឆ្នាំមុន ហើយតាំងពីពេលដែលគាត់រត់ចូលព្រៃ គាត់បានខិតខំជម្រុះវប្បធម៌ដែលទទួលបាននៅក្រុងភ្នំពេញ ចេញពីជីវភាពផ្ទាល់របស់គាត់ ដូចបក្ស«ដាត់»ទីក្រុងចេញពីការបដិវត្តនៅទីបំផុតដែរ ។ សង្គ្រាមដែលពួកខ្មែរក្រហមជាប់ដៃប្រយុទ្ធ គឺដឹកនាំប្រឆាំងនឹងទីក្រុង បានក្លាយទៅជាការប្រជុយចាញ់ឈ្នះមួយ តិចជាងជាឧបសគ្គមួយ ។ នៅពេលនេះ ក្នុងចំហាយក្តៅនាចុងខែមេសា សម្រាប់ សារី ទីក្រុងភ្នំពេញមានសភាពដូចកន្លែង ផ្ទុកសម្រាមមួយអ៊ីចឹង ។

ធូលី ភាពក្រខ្វក់ សត្វមូស កំពុងហើរពីលើគំនរកម្ទេចកម្ទីនៃសង្គមមួយ ។ ក្នុងទីក្រុងគ្មានឃើញស្រមោលមនុស្សណាម្នាក់ គ្មានសភាពអ៊ូអរដូចពីដើមឡើយ ។ ប្រជាជនបានចាកចេញពីទីក្រុងទាំងអស់ ដោយត្រូវបណ្តេញចេញនៅក្រោយពេលបាយថ្ងៃត្រង់បន្តិចនៅថ្ងៃជ័យជម្នះនោះ ។ កងទ័ពខ្មែរក្រហមបានលេចចេញភ្លាមៗមិនដឹងមកពីណាក្នុងពេលដែលប្រជាជនកំពុងរៀបចំរបស់របរ និងនាំយកទៅជាមួយខ្លួនបានតែទ្រព្យសម្បត្តិបន្តិចបន្តួចប៉ុណ្ណោះ... គឺមាស គ្រឿងអលង្ការ និងសម្ភារផ្សេងៗ ដែលពួកអ្នកមានៗអាចទុកចិត្ត ។ គេដេរលាក់វត្ថុមានតម្លៃទាំងនេះក្នុងទ្រនាប់អាវខាងក្នុង ក្នុងហោប៉ៅសម្ងាត់ គេចៀរបញ្ចូលទៅក្នុងទ្រនាប់ស្បែកជើងនូវសន្លឹកក្រដាសខ្លះ ដែលមានសរសេរអាសយដ្ឋានមួយ កំណត់រឿងមួយដែលគេចង់រំឭកឡើងវិញ នៅពេលក្រោយទៀត ។ អ្វីដែលនៅសល់ ត្រូវបោះបង់ចោលទាំងអស់ ។ គេហដ្ឋាននានានៅល្អស្អាតមិនទាន់មាននរណាប៉ះពាល់ ៈ ទូសំអាងមានពោរពេញទៅដោយសារុង និងសម្លៀកបំពាក់នារី ដែលនៅរៀបជាជួរយ៉ាងស្អាតមានស្បែកជើងសង្រែក និងស្បែកជើងល្អរបស់ប្រទេសអឺរ៉ុប នៅលើហ៊ឹងមានរូបព្រះពុទ្ធ ជើងដោតធូប និងកម្រងផ្កាក្រដាស

ចម្រុះពណ៌ ។ នៅលើតុមានតាំងរូបថតរៀបអាពាហ៍ពិពាហ៍ រូបថតឪពុកម្តាយ ជីដូនជីតា ក្នុងថតតុមានសំបុត្រកំណើត លិខិតស្នាមជំនួញ ក្រែឈើ ទូរាវចាន កន្ទេល និងអ្វីៗទាំងអស់ស្ថិតនៅតាមកន្លែងដើមរបស់វាដដែល ។

សារី បានអួតថា គាត់នឹកគិតដល់រឿងមួយផ្សេង គាត់និយាយថា “ទីក្រុងមានសភាពស្ងប់ស្ងាត់មែនទែន ហើយក្រខ្វក់ខ្លាំងណាស់ ។ ខ្ញុំឃើញតែកម្ទេចកម្ទីបាក់បែក ។ គ្មានប្រជាជនណាម្នាក់ស្ថិតនៅសោះ ព្រោះកងទ័ពបានបណ្តេញប្រជាជនចេញពីទីក្រុងអស់ទៅហើយ ។ ខ្ញុំនឹកឃើញថា ធនាគារជាតិត្រូវគេបំផ្លាញខ្ទេចខ្ទីរួចទៅហើយ...” ។

ប៉ុល ពត បាននៅរង់ចាំបួនថ្ងៃរបស់គាត់ ។ មេនិយមកុម្មុយនិស្តថ្មីរបស់ប្រទេសកម្ពុជា បានទៅដល់មុនមួយថ្ងៃ គឺថ្ងៃ២៣ ខែមេសា ដោយគ្មានក្បួនដង្ហែដំណើរ គ្មានក្រុមភ្លេងត្រែកងទ័ពទទួលស្វាគមន៍ គ្មានប្រារព្ធពិធីអ្វីមួយ ដើម្បីឲ្យគេដឹងឮជាសាធារណៈថា គឺគាត់នេះហើយ, អតីត សាឡុត ស ជាប្រមុខបក្សកុម្មុយនិស្តកម្ពុជាដ៏ជាញជ័យ និងកងកងទ័ពរបស់គាត់ ។ ដូចចោររកស៊ីពេលយប់ម្នាក់ ដែលរត់គេចពន្លឺថ្ងៃ ប៉ុល ពត បានសម្រេចចិត្តលាក់អត្តសញ្ញាណ និងបក្សរបស់គាត់ជាសម្ងាត់ ហើយពេលបានទទួលជ័យជម្នះ ក៏គាត់នៅតែលាក់ដែរ ។

ដោយរបៀបម្យ៉ាងៗ ដែលមានទម្រង់ក្រោសម្តេច ព្រះនរោត្តម សីហនុ ត្រូវបានផ្តល់កិត្តិយសឲ្យដឹកនាំប្រទេសកម្ពុជាថ្មី ក្នុងឋានៈព្រះអង្គជាប្រធានរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ។ ប៉ុល ពត នៅរង់ចាំមួយឆ្នាំ មុននឹងប្រកាសឲ្យដឹងពីការបាត់តាំងរដ្ឋាភិបាលថ្មីមួយ (ដោយមានខ្លួនគាត់ផ្ទាល់ជានាយករដ្ឋមន្ត្រី) ប៉ុន្តែ នៅពេលនោះគាត់នៅតែមិនព្រមទទួលស្គាល់ថា ប្រទេសកម្ពុជាត្រូវបានដឹកនាំដោយបក្សកុម្មុយនិស្តមួយ ឬថា ជនមានឈ្មោះ ប៉ុល ពត ជាអតីត សាឡុត ស ឡើយ ។

មិនខុសគ្នានឹងមនុស្ស ដែលលាក់ខ្លួនពីក្រោយ សម្តេច ព្រះនរោត្តម សីហនុ ដែរ បក្សបានបិទបាំងខ្លួនក្រោមការហៅរបៀបមានន័យមិនច្បាស់លាស់ថា “អង្គការ” ។ ពីរឆ្នាំបានកន្លងផុតទៅ មុនបក្សកុម្មុយនិស្តកម្ពុជាបង្ហាញខ្លួនឲ្យគេស្គាល់ជាសាធារណៈ –“ការបង្ហាញមុនដំបូង” ប្លែកពីគេក្នុងប្រវត្តិសាស្រ្តរបស់ពួកកុម្មុយនិស្ត ។ គ្មានបក្សកុម្មុយនិស្តណាមួយផ្សេងទៀតរក្សាភាពលាក់មុខនៅពេលសង្គ្រាម បន្ទាប់ពីបានទទួលជ័យជម្នះហើយទេ ប៉ុន្តែ គេគួរតែនិយាយថា គ្មានបក្សកុម្មុយនិស្តណាមួយផ្សេងទៀត គិតខ្វាយខ្វល់ចំពោះចំណុចនេះ ដោយសារការគំរាមកំហែងរបស់សត្រូវ និងភាពចាំបាច់ក្នុងការការពារខ្លួនជាមុន ហើយរុំព័ទ្ធការសម្ងាត់យ៉ាងធំជុំវិញខ្លួន ។

ក្នុងថ្ងៃដំបូងៗ ការសម្ងាត់នេះ បានបម្រើឲ្យគោលបំណងផ្សេងៗរបស់បក្ស ។ “អង្គការ” បានរៀសរវៃបញ្ចៀសការងើបបះបោរមួយ ៖ ពួកទាហាននៃកងទ័ពដែលចាញ់ ត្រូវបានដកហូតយកអាវុធភ្លាមៗ ពួកនាយទាហានជាន់ខ្ពស់របស់ លន់ នល់ ត្រូវគេប្រើល្បិចកលបញ្ឆោះបញ្ចូលឲ្យមកបង្ហាញខ្លួននៅមុខរដ្ឋអំណាចថ្មី ហើយក៏ត្រូវគេសម្លាប់ចោលភ្លាមគ្មានបង្អង់ ។ “ការសម្ងាត់” នេះក៏ជួយបិទបាំងការភ័យព្រួយរបស់បក្ស ដែលមិនយកសមាជិកថ្មីទៀត បញ្ចូលក្នុងជួររបស់ខ្លួនឲ្យបានគ្រប់គ្រាន់ ដើម្បីត្រួតត្រាប្រជាជនឡើយ ។

អ៊ីចឹងហើយបានជាមានកងទ័ព និងកម្មាភិបាលកុម្មុយនិស្តតែបន្តិចបន្តួចប៉ុណ្ណោះ សម្រាប់គ្រប់គ្រងប្រជាជន ទោះជាយ៉ាងណាក៏ដោយ ក៏វាមិនគ្រប់គ្រាន់ដើម្បីដឹកនាំប្រទេសកម្ពុជា ដោយពេញមុខនៅខែមេសា ឆ្នាំ១៩៧៥ដែរ ។ កងទ័ពមានចំនួន ៦៨.០០០នាក់ បក្សមានសមាជិក ១៤.០០០នាក់[១៥] ។ «ការណ៍សម្ងាត់» ដែលកំពុងរុំព័ទ្ធជុំវិញ អង្គការបានជួយពង្រឹងរូបភាពអំណាចខ្ពស់លើអ្វីទាំងអស់របស់ខ្លួន និងផ្តល់ឱកាសឲ្យពួកមេដឹកនាំទាំងនោះ មានពេលត្រិះរិះពិចារណាពីដំណាក់កាលធ្វើបដិវត្តជាបន្ទាប់ទៀត រួមទាំងបែបកាន់កាប់អំណាចផង ។ នៅក្នុងផ្ទៃបក្ស ទំនាក់ទំនងផ្សេងៗ ត្រូវបានបន្ថយដល់កម្រិតអប្បបរមាក្នុងបំណងមិនឲ្យម្នាក់ៗដឹងរឿងរ៉ាវពីគ្នាច្រើនពេក ។ អត្តសញ្ញាណពិតប្រាកដរបស់កម្មាភិបាលទាំងឡាយច្រើនតែត្រូវបិទបាំងជារឿយៗដោយរហស្សនាមផ្សេងៗ ។ ប្រជាជនកម្ពុជាដែលនៅក្រៅបក្ស ឬកងទ័ព ត្រូវស្ថិតនៅក្នុងភាពងងឹតសូន្យសុង គ្មានដឹងអ្វីទាំងអស់ ជាពិសេស គឺពួកអ្នក ដែលត្រូវបង្ខំឲ្យចាកចេញពីទីក្រុងភ្នំពេញ ។

ប្រជាជនជាអតីតអ្នកទីក្រុង បានស្គាល់ត្រឹមតែឈ្មោះអង្គការប៉ុណ្ណោះ ជាអង្គការក៏មានអំណាច និងប៉ិនប្រសប់បំផុតដើម្បីញ៉ាំងឲ្យអ្នកទាំងនេះបោះបង់ផ្ទះសម្បែងរបស់គេចោលហើយ បន្ទាប់មក បញ្ជូនឲ្យទៅរស់នៅក្នុងជម្រករខេករខាកនៅតាមជនបទនានា ។ ពួកខ្មែរក្រហម បានចាត់ទុកការជម្លៀសប្រជាជនចេញពីរដ្ឋធានីថាជាផែនការដ៏មោះមុត និងគ្មានអាណិតអាសូរមួយរបស់អង្គការដ៏មានអំណាច តែតាមពិត នេះជាទង្វើដែលបង្ហាញឲ្យឃើញសេចក្តីអស់សង្ឃឹមរបស់បក្សមួយ ដែលមានសមាជិកតិចពេក ហើយដែលមានការភ័យខ្លាចជ្រុលហួសហេតុ ។ ហើយទីក្រុង គឺស្ថិតនៅចំកណ្តាលការភ័យខ្លាចទាំងនេះ ។

ក្នុងកំឡុងពេលសង្គ្រាម ពួកកុម្មុយនិស្តពុំបានសម្រេចផលទាក់ទាញប្រជាពលរដ្ឋក្រុងភ្នំពេញឲ្យគាំទ្របុព្វហេតុបដិវត្តន៍របស់គេឡើយ ។ ប៉ូលិសរបស់ លន់ នល់ ដែលដឹងមុនបានកម្ទេចភ្នាក់ងារផ្សេងៗរបស់បក្ស ហើយភាគច្រើននៃពួកអ្នកទីក្រុងនៅមិនទាន់ទុកចិត្ត ដើម្បីចូលរួមធ្វើការដោយសកម្មជាមួយពួកអ្នកបះបោរទាំងនេះ នៅឡើយទេ ។ ដោយហេតុនេះ បានជាពួកខ្មែរក្រហមមិនដែលមមៃគិតពីសេចក្តីសង្ឃឹមមិនសមហេតុផលអំពីលទ្ធភាពធ្វើឲ្យមានការងើបបះបោររបស់ប្រជាជនក្នុងទីក្រុងនានាសោះឡើយ ហើយក៏មិនដែលបញ្ចូលបញ្ហានេះ ក្នុងយុទ្ធសាស្ត្ររបស់គេ ដូចពួកវៀតណាមធ្លាប់បានអនុវត្តក្នុងការវាយលុកពេលបុណ្យចូលឆ្នាំចិន-យួន ឆ្នាំ១៩៦៨ ដែលមិនបានសម្រេចជោគជ័យដែរ ។ ផ្ទុយទៅវិញ ពួកកុម្មុយនិស្តកម្ពុជា បានចាត់ទុកទីក្រុងជាគោលដៅវាយប្រហារមួយ ហើយចាត់ទុកប្រជាពលរដ្ឋទីក្រុងទាំងនោះថា ជាអ្នកភៀសខ្លួន ដែលរត់គេចចេញពីបដិវត្តន៍យ៉ាងកំសាក ។ ដោយក្រអឺតក្រទមនឹងជ័យជម្នះ ពួកគេបានតបតទៅវិញជាបន្តបន្ទាប់ភ្លាមៗ ហើយមិនជួសជុលរៀបចំទីក្រុង ដែលពួកគេធ្លាប់ប្រមាថមាក់ងាយផងទេ ។ យូរទៅមុខទៀត ពួកគេក៏មិនយកចិត្តទុកដាក់ចំពោះពួកអ្នកដែលគេប្រើកម្លាំងបង្ខំឲ្យចាកចេញពីរដ្ឋធានីដែរ ។ គេមិនអាចទុកចិត្តលើប្រជាពលរដ្ឋទីក្រុងភ្នំពេញឡើយ ។ ការដោះស្រាយតែមួយគត់ គឺបណ្តេញពួកនេះចេញពីផ្ទះសម្បែងរបស់គេ ហើយរៀបចំឲ្យប្រែក្លាយ

ទៅជាកសិករទាំងអស់ ។

ការជម្លៀសប្រជាជនចេញពីទីក្រុងនានា ជាជំហានដំបូងឆ្ពោះទៅរកបដិវត្តន៍ខ្លួនទុកដាក់ខ្លួនឯង និងឯករាជ្យពេញលេញ ។ ប្រជាជនត្រូវគេនាំទៅដាក់នៅតាមជនបទ គឺពុំមែនជនបទ ដែលមានជីវភាពរស់នៅដូចពីដើមនោះទេ ប៉ុន្តែ គឺជាសហករណ៍ថ្មីៗ ដែលគេបង្កើតឡើងក្នុងរយៈពេលសង្គ្រាម ដើម្បីជំនួសសង្គមចាស់ ។ បក្សបានកាត់ផ្តាច់ពួកអ្នកទីក្រុងចេញពីកម្មសិទ្ធិ និងវប្បធម៌របស់គេយ៉ាងឆាប់រហ័ស ។ ម្នាក់ៗត្រូវតែធ្វើការយ៉ាងពេញទំហឹង ដើម្បីស្តារប្រទេសកម្ពុជាឡើងវិញ បន្ទាប់មក ធ្វើឲ្យទំនើបទាន់សម័យទៀត លើកលែងតែករណីសំខាន់ៗខ្លះចេញ ព្រោះថា ជំនួយបរទេសត្រូវហាមឃាត់មិនឲ្យមានឡើយ ។

ក្នុងពេលជាមួយគ្នានោះ ពួកខ្មែរក្រហមបានដកខ្លួនចេញពីសហគមន៍អន្តរជាតិដោយចេតនា តាមការពិតនៅក្នុងសតវត្សរ៍ទី២០នេះ ដូចជាមានពួកអ្នកបដិវត្តតិចណាស់ ដែលធ្វើដូច្នេះមុនពួកគេនោះ ។ ពួកគេថែមទាំងកាត់ផ្តាច់ការទាក់ទងជាអន្តរជាតិរបស់ខ្លួនខាងផ្នែកទូរស័ព្ទ និងទូរលេខទៀត ។ លើកលែងតែការហោះហើររបស់យន្តហោះខ្លះៗ ដែលមកពីក្រុងប៉េកាំង និងក្រុងហាណូយប៉ុណ្ណោះ ទំនាក់ទំនងជាប្រក្រតីតាមផ្លូវអាកាសក៏ត្រូវកាត់ផ្តាច់ដែរ ។ ព្រំដែនត្រូវបិទមិនឲ្យចេញចូល និងមានរាយមីនពាសពេញ ហើយតាមឆ្នេរសមុទ្រត្រូវបានឃ្លាំមើលដោយនាវាល្បាតជាច្រើនគ្រឿង ។ ជនណាក៏ដោយ ដែលចូល ឬចេញពីប្រទេសដោយគ្មានការអនុញ្ញាតនឹងត្រូវផ្តន្ទាទោសដល់ស្លាប់ ។ (ប៉ុន្តែ នៅចុងឆ្នាំនោះ ទំនាក់ទំនងខាងទូរលេខត្រូវបានរៀបចំឡើងវិញជាមួយប្រទេសកុម្មុយនិស្តមួយចំនួនតូច) ។ ជនបរទេសទាំងអស់ត្រូវបណ្តេញចេញ ពួកអ្នកដែលរត់ទៅជ្រកនៅស្ថានទូតបារាំងត្រូវខ្មែរក្រហមដឹកតាមក្បួនរថយន្តកាមីញ៉ុងទៅកាន់ប្រទេសថៃ ក្នុងសប្តាហ៍ទីមួយនៃខែឧសភា ។ ក្នុងរយៈពេលជាច្រើនខែ គ្មានស្ថានទូតបរទេសណាមួយធ្វើឲ្យខ្មែរក្រហមទុកចិត្តឡើយ ហើយពួកអ្នកការទូតដ៏កម្រជាច្រើនដែលនៅទីបំផុតត្រឡប់មកកាន់មុខតំណែងនៅក្រុងភ្នំពេញវិញ ត្រូវបានកម្រិតព្រំដែន ក្នុងការធ្វើដំណើររបស់ពួកគេរហូតទាល់តែអ្នកទាំងនោះមានអារម្មណ៍ថា ខ្លួនត្រូវកំណត់ឲ្យនៅតែក្នុងនិវេសនដ្ឋានហើយមើលទៅ ។

នៅខាងក្នុងប្រទេស ប្រជាជនកម្ពុជាបានស្គាល់នូវភាពរស់នៅតែឯកឯងមួយ យ៉ាងតឹងរ៉ឹងបំផុត ។ នេះជាអំពើតបតទៅនឹងភាពរស់នៅដាច់ឆ្ងាយពីគេ និងការអត់ឃ្លាន ដែលពួកខ្មែរក្រហមធ្លាប់ស៊ូទ្រាំលំបាកវេទនា ក្នុងកំឡុងនៃបណ្តាឆ្នាំដែលគួរឲ្យភ័យខ្លាចរបស់ពួកគេ ។ ការបដិវត្តបានចាប់ចេញដំណើរតាំងពីថ្ងៃជ័យជម្នះទៅ ។ ប្រហែលដោយមិនដឹងខ្លួនផងក៏មិនដឹង ពួកកុម្មុយនិស្តបានទាញប្រទេសកម្ពុជាពីសតវត្សរ៍ទី១៩មកកន្លែងដើមវិញ ក្នុងគោលបំណងបង្កើតសង្គមកុម្មុយនិស្តមួយ និងធ្វើឲ្យប្រទេសមានឧស្សាហកម្មក្នុងរយៈពេលតិចជាង ដប់ឆ្នាំយ៉ាងយូរ ។ គេនឹងត្រូវការឲ្យប្រជាជនប្រឹងប្រែងធ្វើការយ៉ាងហួសកម្រិតមួយ ។ ប្រជាជននឹងលែងឲ្យមានពេលទំនេរសម្រាប់ធ្វើកិច្ចការផ្សេងទៀត ក្រៅពីធ្វើការងារសម្រាប់អង្គការទៀតហើយ ។ ក្នុងរយៈមួយឆ្នាំ ប្រជាជនកម្ពុជាបានត្រូវអង្គការដាក់ពង្រាយពាសពេញ ផ្ទៃប្រទេសតាមសហករណ៍ពាក់កណ្តាលស្វយ័តនានា ដែលគេបាន

ចាប់ផ្ដើមបង្កើតនៅឆ្នាំ១៩៧៣ ។ ប្រជាជនអស់នោះ ដេកសម្រាកក្នុងជម្រកផ្សេងៗ របៀបបន្ទាយទាហានបរិ-ភោគក្នុងផ្ទះបាយរួម ត្រូវឃ្លាតចេញពីកូនតូចៗរបស់គាត់ និងធ្វើតែការងារប៉ុណ្ណោះ ។ ក្រៅពីនេះ ត្រូវហាមឃាត់មិនឲ្យមានទាំងអស់ ៖ ទីផ្សារ ប្រាក់កាស សាលារៀន សៀវភៅអាន សាសនា ការសូត្រធម៌ ពេលម៉ោងទំនេរសម្រាប់ជជែកគ្នាលេង និងសើចសប្បាយ ការលេងតូរ្យតន្ត្រី ។ល ។ ពួកគេត្រូវធ្វើការរៀងរាល់ថ្ងៃ លើកលែងតែថ្ងៃដ៏កម្រខ្លះ ដែលគេប្រើប្រាស់សម្រាប់ធ្វើការប្រជុំ «រៀនសូត្រនយោបាយ» ។ ការងារបានចាប់ផ្ដើមប្រហែលនៅម៉ោង ៦ព្រឹក ហើយអាចមានថិរវេលារហូតដល់ម៉ោង ៨ ឬ១០យប់ ។ ដូចបរិមាណម្ហូបអាហារ និងលក្ខណៈនៃជម្រករស់នៅដែរ កិច្ចការត្រូវធ្វើក្នុងមួយថ្ងៃ បានស្គាល់នូវការប្រែប្រួលយ៉ាងសម្បើម ។ ប៉ុន្តែ ក្នុងរយៈពេលនៃឆ្នាំដំបូងនេះ រង្វាន់រួមសម្រាប់ពួកអ្នកទីក្រុងនេះគឺជាការហត់នឿយមួយ លាយឡំទៅដោយការភ័យខ្លាច ។

តាំងពីដំបូងដៃម្ល៉េះ ពួកខ្មែរក្រហមបានគ្រប់គ្រងប្រទេសដោយការប្រើអំពើឃោរឃៅ ។ ក្នុងកំឡុងសប្ដាហ៍ដំបូងៗ ពួកគេបានកម្ទេច «សត្រូវរបស់បដិវត្ត» សំខាន់ៗបំផុត គឺអតីតអ្នកទទួលខុសត្រូវជាន់ខ្ពស់ខាងប៉ូលិស និងកងទ័ពក្រោមរបប លន់ នល់ បណ្ដាសមាជិកជាវរជននយោបាយ និងការិយាល័យធិបតេយ្យនៃសង្គមចាស់ ។ ប្រជាជនមួយចំនួន ដែលប្រកបវិជ្ជាជីវៈសេរី ដូចជា វិស្វករ ឬគ្រូពេទ្យ ត្រូវបានសម្លាប់ចោលក្នុងរយៈពេលនៃការបោសសម្អាតលើកដំបូងនេះដែរ ពីព្រោះខ្មែរក្រហមបានចាត់បញ្ចូលពួកអ្នកទាំងនោះទៅក្នុងប្រភេទមនុស្សប្រឆាំងបដិវត្ត ដែលផ្ដល់នូវគ្រោះថ្នាក់ខ្លាំងជាង ។ ការកាប់សម្លាប់ដំបូងៗទាំងនេះ រួមផ្សំនឹងការជម្លៀសប្រជាជន ល្មមអាចធ្វើឲ្យពួកអ្នកទីក្រុងមានសេចក្ដីភ័យរន្ធត់ និងការពិភាល់ក្នុងចិត្តដែលឥតសង្ឃឹមយ៉ាងគ្រប់គ្រាន់ ។ ក្នុងចំណោមនោះ មានមនុស្សជាច្រើនបានបែកពីគ្រួសារ និងមិត្តភក្តិរបស់គេ ដែលនៅក្រោមអំណាចនៃពួកមនុស្សដែលគេមិនធ្លាប់ស្គាល់ ហើយស្ទើរតែមិនដឹងរកអ្វីមកចិញ្ចឹមជីវិតឡើយ ។ ម្នាក់ៗពឹងផ្អែកទៅលើរដ្ឋអំណាច ដើម្បីជួយបំពេញសេចក្ដីត្រូវការទាំងអស់របស់ខ្លួន ៖ ស្បៀងអាហារ សម្លៀកបំពាក់ ថ្នាំពេទ្យ ប្រដាប់ប្រដាប្រើប្រាស់ ។ គ្មានបុគ្គលណាម្នាក់អាចហ៊ានជជែកវែកញែកពីបទបញ្ជាមួយ ឬតវ៉ាប្រឆាំងសម្រាប់ការពារជោគវាសនារបស់ខ្លួនឡើយ -អ្នកណាមួយហ៊ានប្រថុយមុខជាបាត់ខ្លួនមិនខាន ។

ដូច្នេះប្រទេសកម្ពុជាបានក្លាយទៅជាជំរំពលកម្មដ៏ធំធេងមួយ ដែលផ្ទះសម្បែង និងកន្លែងបានទៅជាភាគដីតូចមួយ ដែលគេមិនអាចដើរចេញទៅណារួច ។ តាមការសម្រេចជាផ្លូវការពីថ្នាក់ដឹកនាំជាន់ខ្ពស់ ពលរដ្ឋទាំងអស់បានក្លាយទៅជាកសិករ កម្មករ ឬកងទ័ពក្នុង«កម្ពុជាប្រជាធិបតេយ្យ»ថ្មី ។ គេសន្យាផ្ដល់ឲ្យតែសិទ្ធិមួយគត់ គឺសិទ្ធិធ្វើការងារ ។ ប្រជាកសិករ និងពួកកម្មករបានជួយកសាងឲ្យរដ្ឋថ្មី មានមូលដ្ឋានឧស្សាហកម្មមួយ និងជួយបង្កើនផលិតផលកសិកម្មទៀត ហើយកងទ័ពជាអ្នកការពារប្រទេសជាតិ ។ សម្រាប់ពេលនេះ មានការពើបប្រយុទ្ធគ្នាបន្តិចបន្តួចជាមួយនឹងពួកវៀតណាម ដែលមានបំណងកែប្រែព្រំដែន «ទូទៅ» និងបើកធ្វើការចរចាពីបញ្ហាទឹកដីថែមទៀត ។ ឧប្បត្តិហេតុ ដែលមានលក្ខណៈជាមហន្តរាយក្នុងរឿងនា វាជំនួញអាមេរិកាំងឈ្មោះ ម៉ាយ៉ាហ្គេ

បានរាំងរាពួកកម្ពុជាមិនឲ្យបន្តហេតុជាមួយពួកវៀតណាមតាំងពីដើមដំបូងនៃការបដិវត្តម្ល៉េះ ។ ពួកខ្មែរបាន "ដាក់លេខថយក្រោយ" ហើយយល់ព្រមទាំងហ្មត់ហ្មងនូវការពន្យារកិច្ចពិភាក្សាមួយ រហូតដល់ពួកគេនឹកស្មានថា ពួកចក្រពត្តិអាមេរិកបានហោះយន្តហោះរបស់ពួកគេមកទម្លាក់គ្រាប់បែកម្តងទៀត ។ ក្នុងរយៈពីរឆ្នាំដំបូង ពួកខ្មែរមានការព្រួយបារម្ភពីសណ្តាប់ធ្នាប់អន្តរជាតិតិចតួចដែរ ក្រៅពីការភ័យខ្លាចរបស់គេអំពីការវាយប្រហាររបស់អាមេរិកាំងជាថ្មី ។ នៅខណៈនេះ ប្រទេសវៀតណាមហាក់ដូចជាគំរាមកំហែងតិចជាងសហរដ្ឋអាមេរិក ។

ប្រវត្តិសាស្ត្ររបស់កម្ពុជាប្រជាធិបតេយ្យ គឺជាឈុតរឿងបន្តគ្នាមួយ ដែលអន្ទន់ដោយរឿងសោកនាដកម្មជាច្រើន ហើយមិនដែលបង្កជាភាពទាំងមូលឡើយ ។ សាក្សីនីមួយៗមានលក្ខណៈត្រូវរឹតត្បិតដោយគំនិតសុញនៃបទពិសោធន៍របស់ខ្លួន ក្នុងរយៈពេលនៃការធ្វើបដិវត្តន៍, ដោយការដឹងខ្លួនពីពិរុទ្ធភាព ភាពច្របូកច្របល់ដែលរឹតរួតប្រជាជនកម្ពុជាទាំងអស់ ដែលមានជីវិតរស់នៅក្នុងសម័យនេះ ។ ក្រុមអ្នកចេះដឹងរបស់បក្សរស់នៅក្នុងមជ្ឈដ្ឋានមួយ ដែលមានគំនិតដោយឡែករបស់គេ ។ ពួកអ្នកបដិវត្តន៍ជាកសិករ បានរស់នៅទៅតាមបែបមួយផ្សេងជាមួយនឹងគំនិតមួយផ្សេងអំពីលទ្ធផលទាំងឡាយរបស់ការបដិវត្ត ។ ពួកគហបតីតូចតាច ដែលត្រូវបញ្ជូនទៅរស់នៅតាមជនបទបានស្គាល់នូវការរស់នៅមួយគោកយ៉ាកយ៉ាំងខ្លាំង ។ ពួកអ្នកការទូត និងពួកភ្ញៀវបរទេសដែលមិនសូវមាន បានវិនិច្ឆ័យកម្ពុជាប្រជាធិបតេយ្យមួយដោយឡែកពីគេ ពួកអ្នកត្រួតត្រាមណ្ឌលកាប់សម្លាប់មនុស្សជាច្រើនកន្លែងបានដឹងរឿងនេះខុសពីអ្នកឯទៀត ។ ម្នាក់ៗមានបំណែកមួយសម្រាប់ផ្គុំរូបកាន់យកមក ប៉ុន្តែ បញ្ហាតែមួយបានធ្វើអ្នកទាំងនេះវិលក្បាលគ្រប់ៗគ្នា ៈ អ្នកណាជាអ្នកទទួលខុសត្រូវ? អ្នកណាអាចនឹងបញ្ចៀសគ្រោះថ្នាក់បាន? ហេតុអ្វីបានជាគ្មានការងើបះបោររបស់ប្រជាជន?

មនុស្ស គ្រាន់បើជាងគេសម្រាប់ផ្តល់ចម្លើយមួយគឺ អ្នកកាន់អំណាចផ្តាច់ការម្នាក់ក្នុងចំណោមអ្នកកាន់អំណាចផ្តាច់ការដ៏អាថ៌កំបាំងបំផុតនៃប្រវត្តិសាស្ត្រ ។ ប៉ុល ពត បានថ្លែងសុន្ទរកថា តែបន្តិចបន្តួចប៉ុណ្ណោះ ហើយបានយល់ព្រមជួបធ្វើសម្ភាសន៍យូរៗម្តង ក្នុងរយៈពេលដែលគាត់កាន់អំណាច ។ ភាគច្រើន ពួកអ្នករួមគំនិតរបស់គាត់ សម្តែងឲ្យឃើញនូវការស្ទាក់ស្ទើរមិនចង់ជជែកពិភាក្សានូវអ្វីដែលកើតមានក្នុងកំឡុងនៃការគ្រប់គ្រងរបស់កម្ពុជាប្រជាធិបតេយ្យដែរ -ហេតុអ្វី?

ទោះបីជាមានការចាញ់ប្រៀបគេទាំងអស់នេះក៏ដោយ ក៏ពួកគេអាចពិពណ៌នាតែរឿងសំខាន់ៗនៃការបដិវត្តន៍ចុងក្រោយបំផុតមួយ ដោយចាប់ផ្តើមពីទីក្រុងដែរ ។

ប៉ុល ពត និងចំណែកអាថ៌កំបាំងបំផុតរបស់បក្ស -គណៈលេខានៃគណៈកម្មាធិការមជ្ឈិមបក្ស- គឺជាស្នូលអង្គការទាំងស្រុង ។ តាមការពិត ក្នុងភាសាដោយឡែករបស់បក្ស គេហៅអង្គការកំពូលនេះត្រឹមតែពាក្យថា មជ្ឈិមប៉ុណ្ណោះ ។ ភារកិច្ចទីមួយសម្រាប់ ប៉ុល ពត គឺត្រូវពង្រឹងអំណាចកណ្តាលឲ្យរឹតតែរឹងមាំ ដើម្បីបង្រួបបង្រួម

ប្រទេស ។ ភូមិភាគនានា ដែលបង្កើតដើម្បីធ្វើសង្គ្រាមបានក្លាយទៅជាភូមិភាគឯករាជ្យហួសហេតុ ដូច្នេះគេត្រូវតែប្រមូលរួបរួមយុទ្ធជនទាំងអស់ជាកងទ័ពជាតិតែមួយ ដោយដាក់ឲ្យស្ថិតនៅក្រោមការដឹកនាំដោយរបស់បក្ស ។ ប្រធានភូមិភាគនានា ព្រមទាំងលេខាបក្សតំបន់ តោងតែចុះចូលនៅក្រោម ការត្រួតត្រាមួយដោយផ្ទាល់ពីមជ្ឈិមច្រើនជាងពីអតីតកាលទៅទៀត ។

ក្នុងរយៈពេលនៃការដើរពិនិត្យទីក្រុងជាលើកដំបូងរបស់គាត់ ប៉ុល ពត និង អៀង សារី បានរកឃើញថារបស់ទ្រព្យដែលប្រមូលបានពីសត្រូវ មិនសូវជាធំដុំដូចដែលពួកគេធ្លាប់នឹកស្មានឡើយ, នេះបើតាមការនិយាយឲ្យដឹងរបស់ អៀង សារី ។ ពួកគេធ្លាប់ស្មានរកឃើញក្នុងទីក្រុងនូវកន្លែងលាក់ទុកសម្ភារយោធាដ៏សម្បើមមួយ ។ អ្នកទាំងពីរតោងតែវែកផ្លូវដើរមួយ តាមគំនរបាក់បែកជាច្រើន ហើយ សារី បានរៀបរាប់ថា គាត់ទៅជាស្រឡាំងកាំងដោយសារតែអ្វីៗបានរលាយបាត់អស់ពីក្រុងភ្នំពេញ ។ ដោយគោរពធ្វើតាមបទបញ្ជាផ្សេងៗ ពួកយុទ្ធជនបានចាប់ផ្ដើម ធ្វើការបំផ្លិចបំផ្លាញមួយតាមរបៀបជាក្បួន ។ ពួកគេបានប្រមូលរថយន្ត ម៉ាស៊ីនត្រជាក់ ទូទឹកកកដាក់គរត្រួតពីលើគ្នា ។ គំនរម៉ាស៊ីនផ្សេងៗដែលប្រែះស៊ីនៅនឹងកន្លែង ម៉ាស៊ីនខ្លះទៀតបានត្រូវដោះយកគ្រឿងចេញអស់ ខ្លះទៀតត្រូវគេលើកបោះទៅក្នុងភ្លើង ដែលគេដុតសម្ដែងសេចក្ដីសប្បាយរីករាយ ។ បន្ទាញមុខហាងលក់ទំនិញនានា ត្រូវបានកែប្រែឲ្យទៅជាកន្លែងសម្រាប់ស្តុកវត្ថុផ្សេងៗ ក្នុងគោលបំណងទុកប្រើប្រាស់នៅពេលក្រោយទៀត ៈ គេដាក់តុទូក្នុងផ្ទះទីមួយ កៅអីក្នុងផ្ទះទីពីរ បន្ទប់ប៊ុយរ៉ូធ្វើការ និងទូសម្រាប់ដាក់ឯកសារក្នុងផ្ទះទីបី ។ នៅពេលណាដែលប្រទេសកម្ពុជាចាប់ផ្ដើមរៀបចំមហាលោតផ្លោះរបស់ខ្លួន គេនឹងបពោញរបស់ទាំងនោះយកទៅប្រើប្រាស់ គេនឹងចែករបស់ស្តុកទាំងអស់ ដែលជារបស់ដែលខ្មែរក្រហមប៉ងប្រាថ្នា តែរកមិនបាន ។ គេដុតបំផ្លាញសៀវភៅ ដើម្បីលាងសំអាតប្រទេសពីនិន្នាការបញ្ញានិយមប្រឆាំងបដិវត្តរបស់ខ្លួន ។ បណ្ណាល័យខ្លះត្រូវខ្មែរក្រហមរើកកូរកកាយបំផ្លាញខ្ទេចខ្ទី ខ្លះទៀតត្រូវបិទចោល ។

ភាគច្រើននៃអគាររបស់រដ្ឋាភិបាលដូចជាព្រះបរមរាជវាំង និងរាជសារមន្ទីរ ព្រមទាំងអគារច្រើនជាន់មួយចំនួនបានក្លាយទៅជាកន្លែងធ្វើការ និងកន្លែងស្នាក់នៅរបស់របបបដិវត្តន៍ ។ កម្មាភិបាល និងកងទ័ពច្រើនរាប់រយនាក់ ត្រូវបានបញ្ជូនទៅធ្វើការនៅក្រុងភ្នំពេញដើម្បីបោសសម្អាតសង្កាត់តូចមួយ ដែលនឹងត្រូវជ្រើសរើសធ្វើជារដ្ឋធានីថ្មី ។ ផ្លូវថ្នល់, ចិញ្ចើមថ្នល់ និងអគារមួយចំនួន បានប្រែជាមានភាពស្អាតឥតខ្ចោះមួយ ។ របបនេះ បានស្រាវជ្រាវរកពួកវិស្វករ ដែលធ្លាប់ដឹងពីបណ្ដាញចរន្តអគ្គិសនីក្នុងទីក្រុង ហើយចាត់តាំងឲ្យជួសជុលអគ្គិសនីឡើងវិញក្នុងសង្កាត់ ដែលពួកមេដឹកនាំបដិវត្តន៍រស់នៅជាជាងសម្លាប់ ឬបញ្ជូនពួកនេះឲ្យទៅធ្វើស្រែចម្ការ ។

អ្វីដែលនៅសល់ពីនោះ ត្រូវគេទុកចោល ឬវាយកម្ទេច ។ ផ្សារធំថ្មី ដែលអំណឹះតទៅគេលែងប្រើត្រូវគេដាក់ដាំចេកពាសពេញ ។ សួនច្បារទាំងឡាយ ដែលលាតសន្ធឹងពីមុខគ្រឹះស្ថានធំៗ ដែលគ្មានមនុស្សនៅ ក៏ត្រូវកែប្រែឲ្យទៅជាសួនបន្លែដែរ ។ ផ្ទះមួយចំនួនត្រូវគេរុះកម្ទេច ដើម្បីយកឈើទៅប្រើការផ្សេងទៀត ។ ប៉ុន្តែ នៅពេល

ដែលពួកមេដឹកនាំវាយតម្លៃពីរបស់ស្តុកក្នុងក្រុង ពួកគេយល់ឃើញមិនសូវសំខាន់ដូចដែលប៉ាន់ស្មានពីមុនឡើយ ។

ដើមឡើយ សហរដ្ឋអាមេរិកបានផ្តល់មកឲ្យក្រុងភ្នំពេញនូវជំនួយមួយ ដែលមានសារសំខាន់តិចតួចណាស់ បើប្រៀបធៀបទៅនឹងជំនួយ ដែលសហរដ្ឋអាមេរិកបានជះទៅឲ្យក្រុងព្រៃនគរដោយចិត្តសប្បុរសនោះ ។ ម្យ៉ាងទៀត ការវាយលុកផ្តាច់ព្រ័ត្ររបស់ខ្មែរក្រហម ដែលមានសភាពកំរោលឃោរឃៅបំផុត បានធ្វើឲ្យរដ្ឋធានីទទួលរងនូវការខូចខាតយ៉ាងខ្លាំង ។ ការរាំងខ្ទប់ទន្លេមេគង្គ មិនឲ្យធ្វើចរាចរកើតក្នុងរយៈពេលជិតបីឆ្នាំ និងការវាយប្រហារក្នុងពេលថ្មីៗប្រឆាំងនឹងអាកាសយានដ្ឋានពោធិចិនតុង បានធ្វើឲ្យគ្រឿងសម្ភារទាំងឡាយ ដែលគេទុកបម្រុងរីងខ្សោះអស់ពីទីក្រុង ។ ការទម្លាក់គ្រាប់បែកផ្សេងៗ ក៏ធ្វើឲ្យខូចខាតដល់ជំនួយសំខាន់ៗ និងធ្វើឲ្យភោគសម្បត្តិដ៏មានតម្លៃវិនាសហិនហោចអស់ដែរ ។ មន្ទីរពេទ្យនានា ដែលមានសភាពមិនល្អស្រាប់ ពុំមានស្តុកថ្នាំណាមួយសោះ ។ ពួកខ្មែរក្រហមធ្លាប់បានបិទបាំងការឃោសនារបស់គេ ជាដាំងនិយាយពីរដ្ឋធានី ដែលកំពុងជួបការអត់ឃ្លានជាខ្លាំង ពីរបបដែលកំពុងតែរលំដួល ពីភាពកខ្វក់ និងភាពទ្រុឌទ្រោម ប៉ុន្តែ ពួកខ្មែរក្រហមផ្ទាល់បានត្រូវធ្វើឲ្យស្រឡាំងកាំងនឹងភាពដុនដាបរបស់ទីក្រុងនេះដែរ, តាមសម្តីរបស់ អៀង សារី និយាយ ។

ក្រុងភ្នំពេញ បានបញ្ចេញឲ្យឃើញភាពផ្ទុយគ្នាគួរឲ្យឆ្ងល់មួយ បើប្រៀបធៀបនឹងស្ថានភាពនៅទីក្រុងព្រៃនគរ[៦] នៅពេលដែលពួកវៀតណាមខាងជើងចូលទៅដល់ទីនោះនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៥ ។ ពួកវៀតណាមបានប្រទះឃើញទីក្រុងមួយ ពោរពេញទៅដោយរបស់របរសម្បូរហូរហៀរ មូលដ្ឋានឧស្សាហកម្មមួយ ដែលនៅល្អស្អាតទាំងអស់ ស្តុកសម្ភារយោធាយ៉ាងច្រើន ដែលធ្វើឲ្យប្រទេសវៀតណាមទៅជាប្រទេសនាំមុខគេក្នុងចំណោមប្រទេសនានានៅអាស៊ី ខាងផ្នែកសឹកសង្គ្រាម ហើយនៅសល់ស្បៀងអាហារ សម្រាប់ចិញ្ចឹមប្រជាជនទីក្រុងទាំងមូលបានជិត ប្រាំមួយខែទៀត ។ ចំពោះប្រជាជនទីក្រុងព្រៃនគរចំនួន បួនលាននាក់ គេត្រូវការស្បៀងតែចំនួន ១៣៥.០០០តោនបន្ថែមទៀតប៉ុណ្ណោះ សម្រាប់បរិភោគរហូតទៅដល់ដាច់ឆ្នាំ ។ បន្ទាប់ពីការវាយលុកក្នុងឱកាសបុណ្យចូលឆ្នាំយួនឆ្នាំ១៩៦៨មក ក្រុងព្រៃនគរពុំដែលស្គាល់ការវាយប្រហារគ្នាទាល់តែសោះ ៖ ការប្រយុទ្ធផ្សេងៗបានកើតមាននៅទីឆ្ងាយៗ តាមស្រុកស្រែចម្ការ ហើយពួកអាមេរិកាំងអាចផ្គត់ផ្គង់ស្បៀងឲ្យទីក្រុងបានយ៉ាងទៀងទាត់ ។

ចំណែកពួកខ្មែរក្រហម បានទទួលមរតកពីទីក្រុងភ្នំពេញមួយនូវបរិមាណស្បៀងសម្រាប់ជួយផ្គត់ផ្គង់ប្រជាជន ពីរលាននាក់របស់ខ្លួនមិនដល់១អាទិត្យផង ហើយក៏គ្មានរបស់របរដែលគេប្រមូលបានពីសត្រូវ អាចប្រៀបធៀបនឹងទីក្រុងព្រៃនគរដែរ[៧] ។ ការជួយឧបត្ថម្ភរបស់អាមេរិកាំងចំពោះរបប លន់ នល់ មានចំនួនសរុប ១,៦កោដិដុល្លារ ដែលក្នុងនោះមានជាង១កោដិជាជំនួយផ្នែកយោធា ជាទឹកប្រាក់មួយស្តួចស្តើងបំផុត បើប្រៀបធៀបទៅនឹងទឹកប្រាក់ចំនួន ១៥៩,៤២កោដិដុល្លារ ដែលអាមេរិកបានចំណាយសម្រាប់ធ្វើសង្គ្រាមនៅវៀតណាមនោះ ។ ហើយជំនួយនេះទៀតសោត គឺមានតែគ្រឿងបរិក្ខារចាំបាច់ប៉ុណ្ណោះ ពុំមានយន្តហោះប្រដេញ

ប្រតិកម្ម និងរថក្រោះទេ គឺមានតែយន្តហោះតេ-២៨ប្រើកង្ហារ ខ្ទម្ភាគចក្រមួយចំនួនដែលគេប្រើខូចខាតខ្លះទៅហើយ និងរថពាសដែកសម្រាប់ដឹកទ័ព ពុំមានកាំភ្លើងធំបាញ់បានឆ្ងាយដូចជាកាណុង១៥៥មមឡើយ ។ សហរដ្ឋអាមេរិកពុំដែលបានជួយឲ្យ លន់ នល់ កសាងរោងចក្រមួយ ជម្រកសម្រាប់ទ័ព ឬអគ្គសេនាធិការទំនើបមួយ ទាល់តែសោះ ។ ជំនួសរបស់របរដែលទទួលបានពីសត្រូវ ពួកខ្មែរក្រហមបានជួបប្រទះតែដីវាលទទេស្អាតទៅវិញ[៨] ។ ប្រព័ន្ធគមនាគមន៍ផ្សេងៗបានត្រូវធ្វើឲ្យខូចខាតពី៦០ ទៅ៨០ភាគរយ ឬត្រូវបំផ្លាញខ្ទេចខ្ទីទាំងស្រុង ផ្លូវដែកត្រូវការរៀបចំជួសជុលជាចាំបាច់ ផ្លូវជាតិនិងផ្លូវបន្ទាប់បន្សំមានរណ្តៅក្រហេងក្រហូងយ៉ាងច្រើន ដែលប្រើការមិនកើតជាច្រើនគីឡូម៉ែត្រ ។ ដីដែលអាចភ្ជួររាស់បានចំនួនពាក់កណ្តាល ត្រូវគេទុកចោលទំនេរ ឬខូចខាតដោយការទម្លាក់គ្រាប់បែក និងការប្រយុទ្ធផ្សេងៗ ។ ភាគច្រើននៃសហគ្រាសតូចតាចរបស់ប្រទេសត្រូវខ្វះវត្ថុធាតុដើម ហើយពុំមានស្បៀងអាហារ ថ្នាំពេទ្យ ឬគ្រឿងបន្លាស់ឡើយ ។

ប្រជាជនទាំងអស់សុទ្ធតែមានស្ថានភាពយ៉ាងអាក្រក់ ។ មនុស្សជាច្រើនត្រូវទ្រុឌទ្រោមទាំងកម្លាំងកាយ និងកម្លាំងចិត្ត បន្ទាប់ពីការឡោមព័ទ្ធទីក្រុង ។ ក្នុងចំនួនប្រជាជន ៣.៣៨៩.០០០នាក់ មានមនុស្សឃ្លាតចេញពីស្រុកកំណើតរបស់ខ្លួនពាក់កណ្តាល ។ តាមពត៌មានពីរដ្ឋាភិបាលថា សង្គ្រាមបានធ្វើឲ្យខាង លន់ នល់ ស្លាប់អស់កន្លះលាននាក់ និងប្រាំមួយពាន់នាក់នៅក្នុងតំបន់ផ្សេងៗរបស់ពួកខ្មែរក្រហម ព្រមទាំងមនុស្សពិការ និងមនុស្សខូចទឹកចិត្តរាប់រយពាន់នាក់ទៀត ។

បក្សបានសម្រេចចិត្តមិនព្រមទទួលយកជំនួយថ្នាំពេទ្យ និងស្បៀងអាហារ ដែលស្នើផ្តល់ដោយអង្គការអន្តរជាតិនានាឡើយ ហើយដែលជំនួយនេះអាចជួយសង្គ្រោះមនុស្សបានមួយចំនួនក្នុងចំណោមអ្នករងគ្រោះទាំងនេះ ។ បក្សមិនព្រមទទួលយកជំនួយនេះ ដោយប្រកាសថា វាមិនចាំបាច់ ។ តាមការពិត ប្រទេសជាតិត្រូវការស្បៀងអាហារ និងថ្នាំពេទ្យដោយអស់សង្ឃឹមជាខ្លាំង ប៉ុន្តែពួកខ្មែរក្រហមនៅតែប្រកាន់ខ្ជាប់គំនិត "ឯករាជ្យម្ចាស់ការ" (ខ្លួនទុកដាក់ខ្លួន) យ៉ាងចចេស ហើយជឿប្រាកដក្នុងចិត្តថា សំណើទាំងនេះគ្រាន់តែ ជាមធ្យោបាយប្រើល្បិចកលរបស់មហាអំណាចបរទេសមួយចំនួន ដើម្បីដឹកនាំឲ្យស្របទៅតាមគោលបំណងខ្លួន និងធ្វើវិទ្ធង្សនា ទៅលើប្រទេសនានា មានប្រទេសកម្ពុជាជាដើម ។ ចំពោះពួកខ្មែរក្រហមនៅមានអស្មិមានះមួយក្នុងចិត្តគំនិតរបស់គេថែមទៀត ៖ ពួកគេបាននិយាយម្តងហើយម្តងទៀតថា ពួកគេពុំចង់ក្លាយខ្លួនទៅជា "ស្មូមយាចក" ហើយសុខចិត្តទទួលសេចក្តីអនុគ្រោះរបស់ បរទេសដោយមិនគិតដល់ប្រជាជនកម្ពុជាមួយចំនួន ដែលធ្វើពលិកម្មដើម្បីភាពខ្ពង់ខ្ពស់របស់ខ្មែរក្រហមឡើយ ។

បក្សសម្រេចមិនរៀបចំជួសជុលការខូចខាតមួយភាគយ៉ាងធំ ដែលប៉ះពាល់ទៅលើទីក្រុង និងប្រទេសជាតិ ព្រោះការជួសជុលនេះ ត្រូវមានលុយ និងគ្រឿងសម្ភារៈជាចាំបាច់ ដែលពួកខ្មែរក្រហមគ្មានអ្វីទាំងអស់ ។ ម្យ៉ាងទៀត ពួកមេដឹកនាំក្រុងភ្នំពេញសម្គាល់ឃើញថា ការបំផ្លិចបំផ្លាញខ្លះក្នុងចំណោមការបំផ្លិចបំផ្លាញទាំងអស់

នេះ ក៏ផ្តល់អត្ថប្រយោជន៍សម្រាប់គេដែរ គឺវាមិនសូវមានការប្រថុយប្រថានក្នុងការលួចរត់ ឬការងើបបះបោរឡើយ បើសិនជាទូរស័ព្ទផ្ទាល់ទាំងឡាយត្រូវ គេជីកកាប់គាស់ជាកង់ៗ បើសិនជាគ្មានឡានធំៗដឹកមនុស្ស និងរថយន្តតូចនោះ ។ ដោយគ្មានទូរស័ព្ទ គ្មានទូរលេខ និងគ្មានការឆ្លើយឆ្លងគ្នាតាមសំបុត្រ មធ្យោបាយទាក់ទងគ្នាទាំងអស់ នឹងត្រូវគេរៀបចំជាថ្មីឡើងវិញ លុះណាតែក្រុងភ្នំពេញត្រួតត្រាគ្រប់មធ្យោបាយទាក់ទងក្នុងផ្ទៃប្រទេសទាំងអស់សិន ។

ភារកិច្ចមួយក្នុងចំណោមភារកិច្ចដំបូងៗរបស់ពួកកុម្មុយនិស្ត ស្ថិតនៅត្រង់ការរៀបចំឲ្យដំណើរការឡើងវិញ នូវសិទ្ធិផ្តាច់មុខខាងផ្នែកផ្សាយពត៌មាន និងមធ្យោបាយទាក់ទងគ្នាផ្សេងៗ ។ គណៈកម្មាធិការមជ្ឈិមជាអ្នកក្តោបក្តាប់ការកម្រិតកំណត់អំពីបរិមាណស្តុករបស់របរផ្សេងៗ និងការបែងចែករបស់ទ្រព្យទាំងអស់ ។ គេបានរៀបចំផែនការផ្សេងៗដោយគ្រោងទុកជាមុននូវកន្លែង ដែលត្រូវធ្វើការចែកចាយជាច្រើនក្នុងបណ្តាភូមិភាគ តំបន់ និងស្រុក ប៉ុន្តែ គឺស្ថិតនៅក្រោមការត្រួតពិនិត្យពីមជ្ឈិមតែមួយគត់ ។ សម្រាប់ការទទួលពត៌មានផ្សេងៗ និងការបញ្ជូនបទបញ្ជា ឬសារលិខិត ក៏ប្រព្រឹត្តទៅរបៀបដូចគ្នានេះដែរ ដោយហេតុថា ក្រុងភ្នំពេញបានយកចិត្តទុកដាក់ឲ្យបណ្តាភូមិភាគ ទីបញ្ជាការយោធា និងឋបនភ័ណ្ឌពិសេសៗទាក់ទងផ្ទាល់មករដ្ឋធានីដោយត្រង់តែម្តង គឺពុំមែនពីមួយទៅមួយ តាមរបៀបពីដើមនោះទេ ។ តំបន់នីមួយៗត្រូវទទួលបទបញ្ជាផ្ទាល់ពីមជ្ឈិមដោយមិនចាំបាច់មានអ្នកកណ្តាល ហើយពួកខ្មែរក្រហម បានដឹកនាំគ្រប់គ្រងប្រទេសតាមរបៀបនេះ រហូតដល់ទីបញ្ចប់នៃរបបរបស់ខ្លួន ។

នេះគឺជារបៀបគ្រប់គ្រងមួយ ដែលនាំមកនូវការខ្ជះខ្ជាយពេលវេលា និងការសម្បូរពាក្យឥតប្រយោជន៍ ដែលប្រហែលជាបំពេញតាមបំណងពួកមេដឹកនាំទាំងឡាយ ក្នុងការត្រួតត្រាដោយផ្ទាល់លើប្រទេសជាតិទាំងមូលមែន ប៉ុន្តែ របៀបនេះមិនសូវប្រមូលសេដ្ឋកិច្ចប្រទេសឲ្យមូលតែមួយឡើយ ។ ឧទាហរណ៍ [៧] កំពង់ផែសមុទ្រតែមួយគត់របស់កម្ពុជានៅឈូងសមុទ្រសៀម គឺកំពង់សោម បានទទួលបទបញ្ជាផ្សេងៗពីភ្នំពេញ ហើយស្ទើរតែគ្មានការទាក់ទងណាមួយជាមួយពួកអាជ្ញាធរតំបន់ ដែលនៅមូលដ្ឋាននាវាចរ រាម ក្បែរនោះឡើយ ។ បើសិនជាកម្មករកំពង់ផែកំពង់សោមត្រូវការឡានកាមីញ៉ុងបន្ថែមដើម្បីផ្ទុកទំនិញ ដែលរើចេញពីនាវាចិន ពួកអ្នកកាន់កាប់កំពង់ផែ ត្រូវបញ្ជូនពាក្យសុំមួយមកក្រុងភ្នំពេញ ដែលតទៅទៀត ត្រូវបញ្ជាទៅមូលដ្ឋានរាម ឲ្យបញ្ជូនឡានទៅខាងកំពង់ផែ ។

ពួកអ្នកដែលដឹកនាំការផ្លាស់ប្តូរទាំងនេះ និងការកសាងប្រទេសឡើងវិញ គឺ ប៉ុល ពត និងការិយាល័យនយោបាយរបស់បក្ស ។ អតីត សាឡុត ស បានមកតាំងលំនៅក្នុងរដ្ឋធានីភ្លាមៗនោះដែរ ។ គាត់មានគេហដ្ឋានជាច្រើនកន្លែងដែលសុទ្ធតែលាក់ការណ៍ទាំងអស់ ហើយគាត់មិនដែលដេកក្នុងផ្ទះមួយពីយប់ជាប់គ្នាទេ ។ តាំងតែពីដើមដំបូងនៃការបដិវត្តម្ល៉េះ គាត់តែងតែព្រឺខ្លាចការប៉ុនប៉ងលបធ្វើឃាដជានិច្ច ។ ខៀវ ប៉ុណ្ណារី ប្រពន្ធរបស់គាត់

ស្ទើរតែក្លាយទៅជាមនុស្សឆ្កួតទៅហើយ នៅពេលដែលកងទ័ពរបស់ប្តីនាងដណ្តើមបានជ័យជម្នះ ហើយត្រូវគេដាក់ឲ្យស្ថិតនៅក្រោមការព្យាបាលដោយខ្មែរក្រហមក្នុងផ្ទះមួយនៅទីក្រុង ។ អៀង ធីរិទ្ធ ប្អូនស្រីរបស់នាង និងជាប្រពន្ធ អៀង សារី បានក្លាយទៅជា "ស្ត្រីទីមួយ" របស់ការបដិវត្ត ។

អៀង ធីរិទ្ធ សារី និងកូនៗរបស់គាត់ សុទ្ធតែជាមនុស្ស ដែលមានស្ថានភាពប្រសើរជាងគេរបស់របបនេះ[១០] ។ ជាស្ត្រីដំបូង ដែលបានកាន់កាប់មុខតំណែងមួយក្នុងរដ្ឋាភិបាល នាងក៏ក្លាយទៅជារដ្ឋមន្ត្រីការបរទេសដែរ ។ ក្នុងពេលដែលបក្សចាប់បំបែកគ្រួសារនីមួយៗឲ្យទៅរស់នៅតាមជនបទ ធីរិទ្ធ បានសម្របសម្រួលកិច្ចការខ្លះដើម្បីឲ្យកូនរបស់នាងទាំងបួន ដែលនាងធ្លាប់បែកឃ្លាតក្នុងរយៈពេលដប់ឆ្នាំនោះ បានមករស់នៅក្បែររូបនាង និងក្រេបជញ្ជក់ឯកសិទ្ធិផ្សេងៗនៃក្រុមវរជនថ្មី ។ គ្រួសារទីមួយរបស់ប្រទេសបានបង្កើតរបៀបរស់នៅមួយជាមេដឹកនាំនៃការបដិវត្ត ដែលមានគ្រួសារនាងជាអ្នកផ្តល់គំរូយ៉ាងសុក្រឹតមួយ ។ កូនៗរបស់នាង ដែលមានសមត្ថភាពមិនប្រាកដ បានទទួលមុខតំណែងផ្សេងៗ ដែលគេកម្ររកបាន ។ កូនស្រីច្បងបានធ្វើជាគ្រូពេទ្យ បើទុកជានាងពុំដែលទទួលការបណ្តុះបណ្តាលវិជ្ជាពេទ្យ ដែលត្រូវតែមានជាចាំបាច់ក៏ដោយ កូនស្រីពីរនាក់ទៀត បានប្រកបវិជ្ជាជីវៈជាឱសថការី គឺម្នាក់ធ្វើការនៅកន្លែងស្រាវជ្រាវឱសថមួយ ដែលស្ថិតនៅជាយក្រុងម្នាក់ទៀតនៅធ្វើការក្នុងមន្ទីរពិសោធន៍មួយនៅភ្នំពេញ ដែលផលិតថ្នាំវ៉ាក់សាំង ។ ចំណែកកូនប្រុសធ្វើជាអ្នកបើកយន្តហោះនៅអាកាសយានដ្ឋានពោធិចិនតុង ។ កូនៗផ្សេងទៀតរបស់ឥស្សរជនជាន់ខ្ពស់ បានស្នាក់អាស្រ័យនៅក្នុងកន្លែងដេករួមពិសេសៗ ដែលនៅទីនោះ ពួកគេត្រូវបានថែទាំងទំនុកបម្រុងដោយខ្មែរ និងទទួលការមកសួរសុខទុក្ខពីសំណាក់ឪពុកម្តាយរបស់ពួកគេយ៉ាងទៀតទាត់ ។

មើលពីក្រៅទៅបែបផែននៃការរស់នៅក្នុងក្រុងភ្នំពេញថ្មី ហាក់ដូចជាបែបផែននៃការរស់នៅក្នុងសហករណ៍ទាំងឡាយ ដែលគេរៀបចំនៅតាមជនបទនានាដែរ ។ កងទ័ព កម្មាភិបាល និងកម្មកររាប់ពាន់នាក់ បានមកតាំងទីលំនៅជាថ្មីក្នុងរដ្ឋធានី ដោយស្នាក់អាស្រ័យក្នុងកន្លែងដេករួមនានា និងហូបបាយក្នុងផ្ទះបាយរួមមួយ ប៉ុន្តែគេហដ្ឋានសម្រាប់ស្នាក់នៅទំនើបៗផ្ទះនៅមាំទាំចាស់ៗ ដែលត្រូវបានផ្គត់ផ្គង់ភ្លើងអគ្គិសនី ទឹកស្អាត មុង និងម៉ាស៊ីនត្រជាក់សម្រាប់តែផ្ទះខ្លះប៉ុណ្ណោះ មិនអាចប្រៀបធៀបនឹងរោងដំបូលមួយចំហៀង អង្រឹង និងដីធ្លីផ្ទះសម្បែងរបស់សហករណ៍ជាច្រើននៅជនបទឡើយ ។

ធីរិទ្ធ និង សារី បានបញ្ជាក់ថា ពួកគេពេញចិត្តនឹងបែបបទរស់នៅរបៀបសហករណ៍នេះណាស់ ប៉ុន្តែ ពួកគេនៅមានក្រុមអ្នកបែហហមក្នុងគ្រួសារជាច្រើននាក់ អ្នកបម្រើស្ត្រីសម្រាប់ធ្វើកិច្ចការក្នុងផ្ទះ និងរៀបចំបាយទឹក អ្នកបើកឡាន កងការពារ និងអង្គរក្សមួយចំនួន ។ សម្លៀកបំពាក់របស់ សារី គឺវាស់វែងកាត់ដេរនៅប្រទេសចិន ហើយ ធីរិទ្ធ អាចជ្រើសរើសសាច់ក្រណាត់សម្រាប់សំពត់ និងសម្លៀកបំពាក់ធ្វើការរបស់នាងតាមចិត្តចង់ ។ សម្លៀកបំពាក់ជាប្រពៃណីពណ៌ខ្មៅ ដែលកាត់ដេរឲ្យតែបានៗក្នុងបណ្តាឆ្នាំនៃការរស់នៅក្នុងព្រៃភ្នំ គឺជាកម្មសិទ្ធ

របស់អតីតកាល យ៉ាងហោចណាស់ក៏សម្រាប់ពួកអ្នកទាំងនោះដែរ ។ សាប៊ូដុំ សាប៊ូកក់សក់ ផលិតផលនាំចូលទាំងអស់ ដែលហាមមិនឲ្យជនរួមជាតិគេមួយភាគធំប្រើប្រាស់ ត្រូវបានតម្កល់ទុកដោយឡែក កាលបើរបស់ទាំងនេះនៅមានសល់ក្នុងទីក្រុង ។ អ្នកទាំងពីរបានទទួលទានបាយក្នុងផ្ទះ "រួម" មួយ ដែលគ្រួសារគាត់បានចូលរួមជាមួយនឹងពួកមេដឹកនាំដទៃទៀត ហើយនៅទីនោះ ពួកគេបានទទួលនូវការផ្គត់ផ្គង់ម្ហូបអាហារប្រសើរជាងគេ ដែលប្រទេសជាតិអាចផ្តល់ឲ្យ ។ ប៉ុន្តែ ធីរិទ្ធ បានចាត់ទុកខ្លួនឯងជាអ្នកមានគុណសម្បត្តិគ្រប់គ្រាន់ ដើម្បីវិនិច្ឆ័យពីប្រសិទ្ធភាពនៃរបៀបរស់នៅជារួម ដែលនាងអួតខ្លួនថា បានរួមចំណែកជាមួយនឹងប្រជាជនដែរ ។

"វាជាការងាយស្រួលណាស់សម្រាប់ពួកកម្មករ ដោយពួកគេពុំចាំបាច់ដណ្តាំស្លឡើយ ។ ពួកគេទៅធ្វើការ ត្រឡប់មកវិញរួចចាំបរិភោគស្រាប់... ។ ប្រជាជនក្រីក្រមានគេចាំបម្រើជាស្រេច នេះជាប្រការដែលគេពុំដែលធ្វើឲ្យសម្រេចសោះតាំងពីមុនមក ។ កាលពីដើម ស្ត្រីៗត្រូវទៅធ្វើការ ត្រឡប់មកផ្ទះវិញ ដោយទិញត្រី និងអង្ករ រួចដណ្តាំស្ល ហើយត្រូវចំណាយពេលមើលកូនចៅទៀត គឺយ៉ាប់សម្បើមណាស់" ។

អ្វីដែល "យ៉ាប់សម្បើមណាស់" សម្រាប់ធីរិទ្ធនេះ គឺប្រហែលបានរួមបង្កើតនូវសេចក្តីរីករាយក្នុងការរស់នៅរបស់ស្ត្រី និងបុរសដទៃទៀតដែលមានភាគច្រើនបំផុតហើយមើលទៅ ៖ ចិញ្ចឹមកូន ធ្វើកិច្ចការក្នុងផ្ទះ រៀបចំធ្វើបាយទឹកនៅផ្ទះរបស់គេ ដែលជាចង្វាក់ការងារប្រចាំថ្ងៃរបស់ខ្មែរ ។ ក៏ប៉ុន្តែ ធីរិទ្ធ បានឆ្នៃបង្កើតឲ្យមានជីវភាពទំនើបថ្មីមួយសម្រាប់ស្ត្រី និងគ្រួសារទាំងអស់នៅប្រទេសកម្ពុជា ។ នៅទីបំផុត នាងបានក្លាយទៅជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ចតែមួយគត់របស់របបនេះ ។ នាងបានចូលរួមជួយរៀបចំសម្រាប់ជនរួមជាតិនាងនូវជីវភាពលំបាកលំបិនមួយដូច ដែលនាងធ្លាប់បានទ្រាំទ្រក្នុងរយៈពេលធ្វើសកម្មភាពសម្ងាត់ និងការធ្វើសង្គ្រាមជាច្រើនឆ្នាំ ប្រហែលដោយគ្មានដឹងខ្លួនទេមើលទៅ ៖ គ្រួសារត្រូវព្រាត់ប្រាសគ្នា របបអាហារខ្វះខាតខ្សោយ ការខ្វះការថែទាំព្យាបាល ស្ថានភាពផ្នែកសុខភាពដ៏គួរឲ្យព្រឺខ្លាច ការធ្វើសង្គ្រាមរាប់អាទិត្យ រាប់ខែ រាប់ឆ្នាំ ដែលគួរឲ្យធុញទ្រាន់ដោយគ្មាន ដែលគេចរួចពីការងារ ការភ័យខ្លាច និងការហត់នឿយសោះឡើយ ។

ប៉ុន្តែ ពួកមេដឹកនាំខ្មែរក្រហម បានបង្ហាញឲ្យឃើញនូវការចេះប្រមាណជាទូទៅមួយ ក្នុងការនិយមប្រើរបស់ប្រណីត ដែលពួកគេអាចមានសេរីភាពប្រើប្រាស់តាម ។ គឺជាក្រុមប្រកាន់គោលការណ៍តឹងរ៉ឹងបំផុតមួយ ដែលគេកម្រឃើញពួកនោះផឹកស្រាណាស់ បើទុកជាមានរៀបចំពិធីជប់លៀងភ្ញៀវរបស់ពួកគេក៏ដោយ ។ (គេនិយាយថា ក្នុងគ្រួសារ ក៏ពួកនេះមិនដែលផឹកស្រាដែរ) ។ ក្នុងចំណោមនោះ មានអ្នកចេះជក់បារីតិចណាស់ ។ អ្នកទាំងនោះមានទម្លាប់និយាយស្តីដោយសំឡេងតិចៗ ប្លែកពីធម្មតា ក្នុងការពិភាក្សាផ្សេងៗ ដែលគេស្ទើរតែមិនអាចស្តាប់ឮបាន ។ ពួកគេហាក់ដូចជាវាយឫកក្រអឺតនឹងសមត្ថភាពរក្សាលក្ខណៈខាងក្រៅស្ងប់ស្ងាត់ ក្នុងការនិយាយ ការដើរ ការធ្វើកាយវិការយឺតៗ និងបែបរិះគិតល្អិតល្អន់ ។ ពួកគេច្រើនសើចញឹមៗ ប៉ុន្តែ កម្រសើចក្អាកក្អាយណាស់ ពួកគេសំអិតសំអាងខ្លួនយ៉ាងស្អាតបាត និងយ៉ាងផ្ចិតផ្ចង់ជានិច្ច តាមដែលពេលវេលាអនុញ្ញាត ។

ភាពស្អាតបាតសម្រាប់ពួកគេ ទំនងជាមានលក្ខណៈនាំរំខានដូចគ្នានឹងសេចក្តីត្រូវការភាពស្ងប់ស្ងាត់ និងភាពរៀបរយដែរ ។ ការបដិវត្ត "សម័យទំនើប" បានធ្វើឡើងដោយគ្មានហ្វូងមហាជនខៀវខ្វារ ដែលសម្តែងទឹកចិត្តលោតស្រែកសប្បាយរីករាយ ហើយកំពុងធ្វើការឆាវឆាវយ៉ាងមមាញឹក និងលំបាក ដែលចូលមកតាំងទីលំនៅនៅក្នុងរដ្ឋធានីកាលពីពេលកន្លងមកមិនយូរប៉ុន្មាន ។

ជីវភាព "ស្ងប់ស្ងៀម" នេះ ដែលពួកគេបានបង្កើតនៅភ្នំពេញ ជារបៀបបកស្រាយបំផ្លើសមួយនូវគំរូសហករណ៍ ដែលពួកគេធ្លាប់ធ្វើជាអ្នកត្រួសត្រាយផ្លូវក្នុងរយៈពេលនៃសង្គ្រាម ។ គឺពួកគេទាំងនេះហើយ ដែលបំបិទមិនឲ្យមានស្នេហាខុសប្រពៃណីក្រោមការធ្វើទុក្ខទោសរហូតដល់ស្លាប់ ដែលយល់ឃើញការផាត់មុខលាបម្សៅ និងសម្លៀកបំពាក់ឆើតឆាយរបស់ស្ត្រី ជាសញ្ញាសម្គាល់មួយនៃភាពអន់ថយរបស់បស្ចិមប្រទេស ។ គឺពួកគេទាំងនេះដែរ ដែលវិនិច្ឆ័យស្ទើរតែដូចអ្នកទោសនូវការសម្តែងសេចក្តីត្រេកអរ ឬសុភមង្គល ។ នៅភ្នំពេញពួកគេបានសម្តែងឲ្យឃើញគំរូនៃការរស់នៅយ៉ាងតឹងរ៉ឹងបំផុត ដែលពួកគេមានបំណងដាក់បង្ខំឲ្យសង្គមមួយអនុវត្តតាមវប្បធម៌សម្បូរបែបរបស់គេ ភាពត្រឹមត្រូវ ភាពស្អាត របៀបរៀបរយ សេចក្តីស្មោះត្រង់ និងការស្តាប់បង្គាប់ដាច់ខាត ការទាត់ចោលការរំភើបញាប់ញ័រផ្សេងៗ ដែលអាចប្រទាញចិត្តឲ្យចុះចាញ់ ។

ដោយវាយដណ្តើមក្រុងភ្នំពេញបាន បច្ចុប្បន្ន មជ្ឈិមបានត្រៀមខ្លួនគ្រប់គ្រងដឹកនាំប្រទេសជាតិទាំងមូលជាស្រេច ។

មេដឹកនាំថ្មីទាំងអស់បានមកស្នាក់អាស្រ័យនៅក្នុងទីក្រុង ៈ ប៉ុល ពត អគ្គលេខាបក្ស នួន ជា អគ្គលេខាបក្សរង អៀង សារី, សុន សេន និង កុយ ធួន ប្រធានអតីតភូមិភាគឧត្តរ ព្រមទាំង ខៀវ សំផន ផង ដែលសុទ្ធតែជាសមាជិកគណៈកម្មាធិការមជ្ឈិម និង វ៉ន វេត លេខាបក្សភូមិភាគពិសេសភ្នំពេញ ។ ភារកិច្ចរបស់គេ ដែលជាអាទិភាព គឺត្រូវបង្កើតកងទ័ពតែមួយ ការគ្រប់គ្រងជាតិតែមួយ ទីតាំងសម្រាប់ធ្វើការ និងសាលានយោបាយមួយរបស់បក្សក្នុងរដ្ឋធានី ។ គេត្រូវតែប្រមូលផ្តុំភូមិភាគ ដែលឯករាជ្យនានា ដើម្បីរៀបចំឲ្យទៅជារចនាសម្ព័ន្ធតែមួយគត់ សម្រាប់សម្របសម្រួលសកម្មភាពទាំងអស់ ខាងផ្នែកនយោបាយ កសិកម្ម និងឧស្សាហកម្ម ក្នុងគោលបំណងធ្វើឲ្យប្រទេសជាតិអាចអនុវត្តដំណើរ "មហាលោតផ្លោះ" របស់ខ្លួនដោយខ្លួនឯងក្នុងយុគសម័យទំនើបនេះ ។

ក្នុងចំណោមស្ថាប័នទាំងអស់នេះ កងទ័ពគឺជាស្ថាប័ន ដែលមានសារសំខាន់ជាងគេ ។ ការបដិវត្តធ្លាប់បានបង្កើតឡើងដោយសារកងទ័ព ការបដិវត្តដំណាក់កាលទីពីរ ត្រូវតែមានការគាំទ្រពីពួកនេះ ។ ប៉ុន្តែ កងទ័ពរបស់កម្ពុជាប្រជាធិបតេយ្យ តាមពិតរួមមានអង្គភាពទ័ពចំនួនប្រាំមួយផ្សេងពីគ្នា ដែលជារបស់ភូមិភាគ ឧត្តរ ឦសាន បូព៌ា និរតី ពាយ័ព្យ និងភូមិភាគពិសេស ។ ដោយភាពចាំបាច់ និងអនុលោមតាមអាណត្តិបដិវត្តន៍នៃរបៀបគ្រប់គ្រងសហករណ៍នោះ មេដឹកនាំភូមិភាគ -លេខាបក្សត្រូវបានតែងតាំងដោយគណៈលេខាមជ្ឈិម- ជាអ្នក

ទទួលខុសត្រូវលើកងទ័ព បក្ស និងប្រជាជនស៊ីវិលនៅតំបន់របស់គេ ។ អ្នកទាំងនេះ ទទួលបញ្ជាផ្សេងៗពីគណៈកម្មាធិការមជ្ឈិម ដែលមានពួកគេជាសមាជិកដែរ ប៉ុន្តែ ត្រូវរិះរកមធ្យោបាយដោយខ្លួនឯង ដើម្បីអនុវត្តគោលមាគ៌ាធំៗទាំងនេះ និងមានសិទ្ធិអំណាចយ៉ាងសម្បើមមួយ ដើម្បីសម្រេចឈានឲ្យដល់គោលដៅទាំងឡាយទៅតាមបែបផែនដែលត្រូវនឹងគំនិតរបស់គេ ។

ភូមិភាគទាំងនេះ ជាដំណែលពីសម័យកាលដ៏រុងរឿងរបស់វៀតណាមក្នុងសង្គ្រាមឥណ្ឌូចិនលើកទីមួយ ។ ដោយឆ្លងកាត់ព្រំប្រទល់ខេត្តពីមុនៗ ដែលជាព្រំប្រទល់កំណត់ឡើងតាមគំរូផ្នែកភូមិសាស្ត្រ ដែលពួកវៀតណាមធ្លាប់បានប្រើប្រាស់ សម្រាប់ការរៀបចំផ្នែកយោធារបស់គេក្នុងក្របខ័ណ្ឌនៃព្រំដែនរបស់អាណានិគមបារាំង ។ ក្នុងប្រវត្តិសាស្ត្រលើកដំបូងរបស់បក្ស ដែលចេញផ្សាយនៅឆ្នាំ១៩៧៣ ពួកកុម្មុយនិស្តកម្ពុជា បានសម្តែងឲ្យដឹងនូវការមិនសប្បាយចិត្តចំពោះបញ្ហា «អាកប្បកិរិយារបៀបម្ចាស់ទឹកម្ចាស់ដីមួយកន្លែង» ដែលរបៀបគ្រប់គ្រងភូមិភាគទាំងឡាយបង្កឲ្យមានឡើង ។ សហករណ៍ដែលពួកគេចាប់ផ្តើមបង្កើតនៅជំនាន់នោះ បែរជាមានផលមួយបញ្ច្រាសមកលើខ្លួនវិញ ហើយពង្រឹងឲ្យរឹតតែខ្លាំងឡើង សូវកុំឲ្យសហករណ៍ទាំងនេះ ធ្វើឲ្យចុះខ្សោយអំណាចរបស់លេខាបក្សភូមិភាគនានា ។

បន្ទាប់ពីឆ្នាំ១៩៧៣ លេខាបក្សភូមិភាគនានា បានប្រែក្លាយទៅជាមេដឹកនាំផ្តាច់ការ ដែលគ្រប់គ្រងប្រជាជនដោយច្បាប់អាជ្ញាសឹក ។ ពួកនេះបានរក្សាទុកដដែលនូវរបៀបគ្រប់គ្រង ដែលបំបែកភូមិភាគទៅជាតំបន់ ស្រុក និងសង្កាត់ ប៉ុន្តែការបង្កើតឲ្យមានសហករណ៍ បានលុបចោលទម្រង់នៃការបែងចែកការទទួលខុសត្រូវនេះ ។ សហករណ៍បានបណ្តាលឲ្យមានការលុបបំបាត់ទីផ្សារ និងប្រាក់កាស ព្រមទាំងបានក្តោបក្តាប់ពេញដៃនូវបញ្ហាផ្សេងៗ ដែលទាក់ទងទៅនឹងជីវភាពរស់នៅរបស់ប្រជាជនថែមទៀត ៖ តើបរិមាណស្បៀងប៉ុន្មានដែលត្រូវបែងចែក ហើយចែកទៅខាងណា? តើអ្នកណាខ្លះ ដែលត្រូវបញ្ចូលទៅក្នុងកងទ័ព តើក្មេងប្រភេទណាដែលត្រូវចាត់តាំងឲ្យទៅធ្វើកងចល័ត តើអ្នកណាខ្លះ ដែលបញ្ចេញឲ្យឃើញសញ្ញានៃការមិនស្មោះត្រង់ចំពោះបដិវត្តន៍ តើអ្នកណាខ្លះដែលត្រូវរស់នៅក្នុងផ្ទះគំរូ ។ល ។ សហករណ៍បានរំលាយប្រព័ន្ធសិក្សាអប់រំ និងហាមមិនឲ្យមានសាសនា ដោយកម្ចាត់ចោលការអំពាវនាវផ្សេងៗ ដែលអាចសម្តែងឲ្យឃើញនូវអំណាចដាក់លាក់មួយ ។

ដោយហេតុនេះ អំណាចពិតប្រាកដត្រូវផ្អែកលើអ្នកគាំទ្រចំនួនពីរ ៖ សមាជិកគណៈដឹកនាំសហករណ៍ទាំងបីរូប និងលេខាបក្សភូមិភាគ ។ លេខាបក្សភូមិភាគនេះ ជាប្រភពដើមក្នុងការផ្គត់ផ្គង់ភ័ស្តុភារសម្រាប់ប្រជាជនស៊ីវិល ក៏ដូចសម្រាប់កងទ័ព ជាសំឡេងបញ្ជា និងកាត់សេចក្តី ។ កម្រិតមុខងារដែលនៅចន្លោះរវាងមេដឹកនាំភូមិភាគ និងប្រធានសហករណ៍មិនសូវមានសារសំខាន់ប៉ុន្មានទេ ហើយក៏ពុំមានដើរតួនាទីណាមួយ សម្រាប់បក្ស និងកងទ័ព ដែលគេប្រមូលផ្តុំឲ្យមានតែមួយក្នុងប្រព័ន្ធចែកជាពួកជាក្រុមនេះ ដូចនៅសម័យសង្គ្រាមដែរ ។ ការបំបែកទ្រឹស្តី ស្តីពីបដិវត្តន៍របស់អ្នកជនបទ និងលក្ខណៈពិសេសនៃសង្គ្រាមនៅប្រទេសកម្ពុជា បាននាំឲ្យមាន

អត្ថិភាពមិនត្រឹមតែបក្សមួយទេ ប៉ុន្តែ មានប្រាំមួយបក្សពុំមែនមានតែកងទ័ពមួយទេ គឺមានដល់ទៅប្រាំមួយ និងមានលេខាបក្សប្រាំមួយ ម្ចាស់ទឹកម្ចាស់ដីប្រាំមួយ ដែលធ្លាប់បានគ្រប់គ្រងលើទឹកដីជារបស់គេផ្ទាល់ ។

ពួកខ្មែរក្រហមពុំដែលមានធានីសម្រាប់ធ្វើការប្រឆាំងដោយចេញមុខទល់នឹងរដ្ឋអំណាចទេ –ពុំមានរូងភ្នំសាមនឿ ដូចពួកប៉ាថេតឡាវ ពុំមានខេត្តហ៊ូណាន់ ដូច ម៉ៅ សេទុង ហើយប្រាកដណាស់ ពុំមានទីក្រុងដូចទីក្រុងហាណូយរបស់វៀតណាមខាងជើងឡើយ ។ សម្ដេច ព្រះនរោត្ដម សីហនុ ដែលមានភាពជានិមិត្តរូបនៃភាពទទេស្អាត ស្ថិតមាននៅក្នុងប្រទេសកំពុងដឹកនាំពេញឋានៈក្នុងទីក្រុងប៉េកាំង ដែលនៅឆ្ងាយដាច់ស្រយាលឯណោះ ។ គណៈកម្មាធិការកណ្ដាលរបស់ពួកកុម្មុយនិស្តកម្ពុជាមានទីតាំងរបស់ខ្លួននៅភូមិភាគឧត្ដរ ។ ក្នុងកំឡុងឆ្នាំចុងក្រោយនៃសង្គ្រាម ពួកខ្មែរក្រហមបានបញ្ជាក់អះអាងថា ខ្លួនបានបង្កើតធានីមួយនៅក្នុងព្រៃភ្នំ ប៉ុន្តែ ការនិយាយសំអាងនេះ គឺសម្រាប់ប្រើប្រាស់ជាសំខាន់នៅខាងក្រៅប្រទេសប៉ុណ្ណោះ ។ គ្មានជនបរទេសណាម្នាក់ធ្លាប់បានធ្វើដំណើរទៅដល់ទីនោះម្ដងឡើយ ហើយទោះជាយ៉ាងណាក៏ដោយ ក៏វាមិនអាច និយាយថា កន្លែងនោះជាធានីមួយបានដែរ ព្រោះថា កន្លែងដែលដាក់ចេញការសម្រេចចិត្តផ្សេងៗមាននៅរាយតែពាសក្នុងភូមិភាគជាច្រើន ។

បីខែក្រោយជ័យជម្នះ គឺនៅខែកក្កដា ឆ្នាំ១៩៧៥ ប៉ុល ពត បានកោះអញ្ជើញបណ្ដាអ្នកដឹកនាំភូមិភាគ និងបណ្ដាអ្នកតំណាងនៃកងទ័ពនីមួយៗមកកាន់ទីក្រុងភ្នំពេញ ដើម្បីបង្កើតកងទ័ពជាតិដំបូងរបស់ពួកកុម្មុយនិស្តជាផ្លូវការ ។ នៅចំពោះមុខពួកអ្នកទាំងនោះ គាត់បានថ្លែងសុន្ទរកថាដ៏សំខាន់ស្ដីពីជ័យជម្នះក្នុងពេលថ្មីៗ និងបានធ្វើអត្ថាធិប្បាយយ៉ាងលម្អិតអំពីការបេះអត់ធ្មត់ស៊ូទ្រាំលំបាកវេទនា ដែលរួមបង្កជាមូលដ្ឋានក្នុងការធ្វើសង្គ្រាម ហើយដែលជំរុញប្រទេសឲ្យឆ្ពោះទៅរកបដិវត្តទីពីរទៀត... ។ ប៉ុល ពត ដែលជាមនុស្សប្រុងប្រយ័ត្នជាប់ជានិច្ចនោះ បានស្នើឲ្យអ្នកមកចូលរួមម្នាក់ៗ ដែលប្រមូលផ្ដុំគ្នាក្នុងសាលធំមួយទុកអាវុធរបស់ខ្លួននៅកន្លែងសម្រាប់ផ្ញើអាវុធសិន ។ នៅពេលនោះក្នុងចំណោមអ្នកមកប្រជុំទាំងអស់ មានភាគច្រើនបានឃើញជាលើកដំបូងបង្អស់នូវបុគ្គលដែលធ្លាប់ធ្វើជាមេកោយដ៏អាថ៌កំបាំងរបស់គេ ហើយឥឡូវនេះជាអ្នកអំពាវនាវឲ្យពួកគេបោះបង់ចោល«គំនិតនិយមភូមិភាគ»របស់ខ្លួន ដើម្បីប្រែក្លាយទៅជាមេទ័ព ដែលស្ដាប់បញ្ជាកម្ពុជាប្រជាធិបតេយ្យរបស់ខ្លួនវិញ ។

គឺក្នុងសន្ទថានេះហើយ ដែល ប៉ុល ពត ពោលអះអាងថា ក្នុងប្រវត្តិសាស្ត្រគ្មានបដិវត្តកុម្មុយនិស្តណាមួយផ្សេងទៀត បានទទួលជ័យជម្នះជាស្ថាពរមួយលើសហរដ្ឋអាមេរិកទេ ហើយក្នុងប្រវត្តិសាស្ត្រពីរពាន់ឆ្នាំរបស់ខ្លួនគ្មានពេលណាមួយដែលប្រទេសកម្ពុជាត្រូវបានរំដោះពិតប្រាកដដូចជាពេលនេះឡើយ ។ គាត់បាននិយាយទៅកាន់ទីប្រជុំអ្នកស្ដាប់របស់គាត់ ក្នុងឋានៈជាអ្នកបដិវត្តម្នាក់ ដែលនិយមការកែទម្រង់សង្គមដល់ទីជម្រៅ និងជាមេដឹកនាំនយោបាយ ដ៏មានអំណាចខ្លាំងបំផុត ។ ដោយគាត់ជាប្រធានគណៈកម្មាធិការមជ្ឈិមបក្សស្រាប់ គាត់អាចក្ដាប់ការត្រួតត្រាលើរចនាសម្ព័ន្ធផ្សេងៗរបស់កងទ័ពបានយ៉ាងងាយស្រួល ។ ប៉ុន្តែក្នុងឋានៈគាត់ជាមេដឹកនាំ គាត់ត្រូវតែសម្ដែងឲ្យឃើញនូវសិទ្ធិអំណាចរបស់គាត់ និងពន្យល់ណែនាំពីករណីកិច្ចដ៏ពិសិដ្ឋដែលកងទ័ព ត្រូវបំពេញ

ឲ្យបានសម្រេចនៅដំណាក់កាលជាបន្ទាប់ទៀត ។ គាត់បាននិយាយថា «យើងបានធ្វើសង្គ្រាម ហើយយើងបានទទួលជ័យជម្នះក្នុងរយៈពេលដ៏ខ្លីបំផុត... ដូច្នេះ យើងត្រូវតែកសាងប្រទេសឲ្យបានឆាប់រហ័សដូចគ្នា[១១]» ។

ប៉ុល ពត បានប្រគល់គុណូបការៈទាំងអស់របស់បដិវត្តទៅឲ្យកងទ័ពរបស់បក្សកុម្មុយនិស្តកម្ពុជា ដែលមានរូបគាត់ជាមេដឹកនាំក្នុងកំឡុងពេលធ្វើសង្គ្រាម និងបន្ទាប់ពីសង្គ្រាម ។ បណ្ដាលេខាបក្សភូមិភាគ និងអ្នកកាន់អំណាចដទៃទៀត បានស្ដាប់គាត់និយាយ និងយល់ស្របតាមទស្សនៈយល់ឃើញរបស់គាត់ស្ដីពីព្រឹត្តិការណ៍ផ្សេងៗ ហើយបានសុខចិត្តប្រគល់កងទ័ពទាំងអស់ទៅឲ្យមជ្ឈិមតាមការស្នើរបស់គាត់ ។ លទ្ធផលនៃការរៀបចំជាថ្មីនេះ[១២] គឺការបង្កើតកងទ័ពមួយរបស់គណៈកម្មាធិការមជ្ឈិម ដែលស្រូបអស់ពីរភាគបីនៃចំនួនទាហាន ដែលបោះទីតាំងនៅក្រុងភ្នំពេញ ។ មួយភាគបីទៀត ត្រូវដាក់ឲ្យស្ថិតនៅក្រោមការត្រួតត្រាមានតែឈ្មោះ របស់មជ្ឈិម ប៉ុន្តែ កងទ័ពទាំងអស់ គឺស្ថិតនៅប្រចាំការក្នុងភូមិភាគដើមរបស់គេដដែល ។

បន្ទាប់មក មជ្ឈិមបានកំណត់ព្រំប្រទល់ភូមិភាគនានាជាថ្មី ដែលជាប្រការបន្ថយសិទ្ធិអំណាច បណ្ដាលេខាបក្ស ភូមិភាគទាំងនោះថែមទៀត ។ មិនយូរប៉ុន្មានក្រោយមក អតីតភូមិភាគឧត្តរត្រូវគេរំលាយ ហើយរំលែកមួយផ្នែកទៅឲ្យភូមិភាគកណ្ដាលដែលទើបបង្កើតថ្មី និងភូមិភាគបូព៌ាចាស់ ។ ភូមិភាគពាយ័ព្យត្រូវបែងចែកជាងពីរផ្នែក ៖ មួយផ្នែកបញ្ចូលទៅក្នុងភូមិភាគបស្ចិម និងនិរតី ។ កងទ័ពក៏ដូចជាភូមិភាគដែរ ត្រូវគេសើរើរៀបចំជាថ្មីតាមទិសដៅផ្សេងៗ ដែលមជ្ឈិមវិនិច្ឆ័យថា មានសារសំខាន់ចាំបាច់បំផុត ដើម្បីផ្ដល់សន្ទុះដល់ការកសាង និងការពារប្រទេសឡើងវិញ ។

ប៉ុល ពត និងមជ្ឈិម បានកត់សម្គាល់ដោយសេចក្ដីពេញចិត្តថា បណ្ដាមេដឹកនាំភូមិភាគស្រឡាញ់ចូលចិត្តជាខ្លាំងចំពោះបដិវត្ត ហើយបានប្រតិបត្តិតាមមតិណែនាំផ្សេងៗរបស់មជ្ឈិមទៀតផង ។ ម្យ៉ាងទៀត អ្នកទាំងនោះមានហេតុផល គិតឃើញផ្ទុយពីនេះតែបន្តិចបន្តួចប៉ុណ្ណោះ ។ នៅខណៈនេះ ប៉ុល ពត បានតាំងខ្លួនជាមេដឹកនាំដ៏ភ្លឺស្វាងម្នាក់ ។ គាត់ធ្លាប់ជំរុញសម្ដេច ព្រះនរោត្ដម សីហនុ ដែលជាអ្នកពូកែប្រើល្បិចកលឲ្យធ្វើសកម្មភាពផ្សេងៗស្របទៅតាមគោលបំណងរបស់ខ្លួន ហើយបានទាញយកគុណប្រយោជន៍ពីគ្រប់លទ្ធភាពទាំងអស់ ដែលហុចឲ្យតាមរយៈការ ផ្តួលរំលំសម្ដេច ដោយគ្មានបោះបង់ឯករាជ្យរបស់កម្ពុជាទៅឲ្យពួកវៀតណាម ឬចិន ឡើយ ។ គឺអគ្គលេខាបក្សនេះហើយ ដែលបានលើកជ្រោងបក្សចេញពីស្ថានភាពមិនសូវមានគេស្គាល់នៅឆ្នាំ១៩៦៣ ទៅដល់អំណាចផ្ដាច់ការមួយក្នុងរវាងប្រមាណជាដប់ពីរឆ្នាំប៉ុណ្ណោះ ។ ប្រហែលនៅទីបញ្ចប់នៃសង្គ្រាម នៅពេលដែលបក្សអាចរៀបចំដើងព្រួលធ្វើការវាយលុកផ្ដាច់ព្រ័ត្រ និងការជម្លៀសប្រជាជនចេញពីរដ្ឋធានី កងទ័ពរបស់ភូមិភាគទាំងអស់ បានរួមធ្វើសហប្រតិបត្តិការនឹងគ្នាយ៉ាងជិតស្និទ្ធ ។ ពួកគេបានបែងចែកទីក្រុងជាសង្កាត់ៗ ដូចគេកាត់ចែកនំក្រែមដែរ ហើយជម្លៀសប្រជាជនចេញពីតំបន់ផ្សេងៗដែលជាចំណែករបស់ភូមិភាគគេបានរំដោះ ។ ក្នុងការរៀបចំជម្លៀសនេះ ពុំមានការខ្វែងគំនិតគ្នាណាមួយទេ ។ យុទ្ធជនទាំងនេះ ប្រហែលជាត្រូវធ្វើឲ្យឡប់គំនិត

ដោយលក្ខណៈជាគោលដៅនៃការជម្លៀសនេះ តើការជម្លៀសនេះមានលក្ខណៈជាស្ថាពរ ឬជាបណ្តោះអាសន្ន? ប៉ុន្តែ ពួកគេបានធ្វើតាមបទបញ្ជាទាំងអស់ ដោយបណ្តេញអ្នកជំងឺឲ្យចេញពីមន្ទីរពេទ្យនានា ដោយសម្លាប់ពួកអ្នកដែលរឹងទទឹង ដោយកម្ចាត់ពួកទាហាន និងបុគ្គលិករដ្ឋការរបស់ លន់ នល់ យ៉ាងច្រើន ។

ប៉ុន្តែ ដោយប្រកាន់ថា ភូមិភាគនានាជាកម្លាំងឯកភាព ប៉ុល ពត និងបក្សបានប្រឌិតភាពតានតឹងប្រកបដោយគ្រោះថ្នាក់មួយ ដែលបំផ្លាញដល់ឫសគល់នៃកម្លាំងឯកភាព ដែលពួកគេបានស្រាវជ្រាវរកដោយហ្មត់ចត់ ។ មជ្ឈិម មានបំណងថា សហករណ៍ទាំងអស់ត្រូវមានគំនិតរួមមួយចំពោះកម្មវិធីកសាងប្រទេសឡើងវិញរបស់ពួកគេ ប៉ុន្តែ តើត្រូវដាក់សហករណ៍ ទាំងនោះឲ្យស្ថិតនៅក្រោមអំណាចបញ្ជាការរបស់ភូមិភាគ ឬមជ្ឈិម? បើសិនជាស្ថានភាពប្រែប្រួលពីភូមិភាគមួយទៅភូមិភាគមួយ តើគេត្រូវអនុវត្តបទបញ្ជាផ្សេងៗដោយឥតល្អៀង ឬតម្រូវបទបញ្ជាទាំងនោះទៅតាមសភាពជាក់ស្តែងដូចក្នុងរយៈពេលសង្គ្រាម? តើអ្នកណាទទួលខុសត្រូវក្នុងការធ្វើផែនការបរាជ័យ -ភូមិភាគ សហករណ៍ ឬមជ្ឈិម? បណ្តាលេខាបក្សភូមិភាគ មានកិត្យានុភាពមួយយ៉ាងធំមួយក្នុងដែនដីរបស់គេផ្ទាល់ ក្នុងពេលដែលសមាជិកភាគច្រើនរបស់បក្ស និងមជ្ឈិមគ្រាន់តែជា “ហ្វូងមនុស្ស” មានអំណាចតែសម្បកក្រៅប៉ុណ្ណោះ ។ តើគណៈដឹកនាំភូមិភាគនីមួយៗ នឹងត្រូវប្រើជាគ្រឿងទប់ និងជាកន្លែងបណ្តាក់រវាង មជ្ឈិម និងសហករណ៍នានា? តើអ្នកទាំងនោះនឹងប្រែក្លាយទៅជាអ្នកបង្កើតឲ្យមានបញ្ហាលំបាកស្មុគស្មាញ ឬជាអ្នកជួយធ្វើការដោះស្រាយបញ្ហាក្នុងការស្វែងរករបស់ការបដិវត្តចុងក្រោយបំផុតនេះ?

ចម្លើយដែលនាំមកក្នុងកំឡុងពេលបីឆ្នាំ ដែលមានជាបន្តមកទៀត គឺសំអាងដោយផ្អែកលើប្រវត្តរៀងខ្លួនរបស់ភូមិភាគនានា និងបុគ្គលិកលក្ខណៈរបស់មេដឹកនាំរបស់ភូមិភាគទាំងនោះ ។ លេខាធិបក្សភូមិភាគទាំងអស់ពុំមែនជាមនុស្សចេញពីក្រុមតែមួយ ដូចក្រុមមេដឹកនាំជាន់ខ្ពស់របស់បក្សនោះទេ ។ ក្នុងចំណោមលេខាទាំងនោះ ពុំមានអ្នកណាម្នាក់បានទទួលការរៀនសូត្រជ្រៅជ្រះដូច ប៉ុល ពត, អៀង សារី និង សុន សេន ហើយក៏មិនដែលធ្វើដំណើរទៅបរទេស ក្រៅពីប្រទេសវៀតណាម និងថៃឡើយ ។ ពួកគេបានរួមបង្កជាខ្សែកាត់ទទឹងមួយដែលបែងចែកភូមិភាគ និងចលនានយោបាយជាច្រើន ដែលធ្លាប់ជួយទ្រទ្រង់បក្សកុម្មុយនិស្តកម្ពុជា ។ សមត្ថភាពរបស់លេខាបក្សទាំងនោះ សុទ្ធតែមានលក្ខណៈខុសប្លែកពីគ្នា អំណាចរបស់គេគឺអាស្រ័យទៅតាមសារសំខាន់នៃភូមិភាគ ដែលពួកគេគ្រប់គ្រងដឹកនាំ និងរយៈពេលនៃការធ្វើសកម្មភាពបម្រើបដិវត្តរបស់ពួកគេដែរ ។ ភ្លាមៗបន្ទាប់ពីសម័យសង្គ្រាម មេដឹកនាំភូមិភាគពាយ័ព្យ និងបូព៌ា បានត្រូវគេដំឡើងឋានៈខ្ពស់ជាងលេខាបក្សភូមិភាគឯទៀតៗ ប៉ុន្តែក្រោយមក គឺភូមិភាគនិរតីពុំមែនភូមិភាគពាយ័ព្យទេ ដែលនឹងក្លាយទៅជាភូមិភាគសំខាន់ ហើយនឹងដើរតួនាទីជាភូមិភាគស្នូលជាមួយនឹងភូមិភាគពាយ័ព្យ ។

ក្នុងសម័យសង្គ្រាម ភូមិភាគនិរតីជាភូមិភាគធំល្វឹងល្វើយ និងក្រខ្សត់ជាងគេ[១៣] ។ ភូមិភាគនេះ លាតសន្ធឹងពីវាលទំនាបភាគកណ្តាលនៃខេត្តកណ្តាល និងកំពង់ស្ពឺទៅដល់ឈូងសមុទ្រសៀម ពីព្រំដែនភាគខាងកើតជាប់នឹង

ប្រទេសវៀតណាមរហូតដល់ទៅដល់ខេត្តកោះកុងភាគខាងលិចនៅជាប់មាត់សមុទ្រ ។ នៅជំនាន់នោះ មួយភាគធំនៃតំបន់នេះបានស្គាល់នូវភាពក្រីក្រមួយជាប់ជាប្រចាំ ហើយកសិករទាំងឡាយនៅភាគនិរតីសុទ្ធតែជាអ្នកជំពាក់បំណុលគេច្រើនលើសលុប ។ ដូច្នោះពួកគេស្ថិតក្នុងចំណោមមនុស្សចំណូលថ្មីដំបូងគេនិងស្មោះត្រង់បំផុតរបស់ចលនាកុម្មុយនិស្ត និងដែលបានផ្តល់នូវការជួយជ្រោមជ្រែងយ៉ាងសម្បើមមួយក្នុងការធ្វើសង្គ្រាម ។ ភូមិភាគនិរតី បានដាក់ទ័ពឲ្យប្រយុទ្ធ និងផលិតស្រូវបានយ៉ាងច្រើនសម្រាប់បុព្វហេតុបដិវត្តន៍ជាងភូមិភាគដទៃទៀតទាំងអស់ ។

កងទ័ពរបស់ភូមិភាគនិរតីជាកងទ័ពមួយក្លាហានមោះមុត ក្នុងចំណោមកងទ័ព ដែលមានទឹកចិត្តអង់អាចជាងគេក្នុងការប្រយុទ្ធនានា ហើយបានទទួលរងបរាជ័យខ្លះៗក្នុងចំណោមបរាជ័យដ៏អាក្រក់បំផុត នៅរយៈពេលធ្វើសង្គ្រាម - ជាពិសេសក្នុងរយៈពេលនៃការវាយប្រហារអត្តឃាដទៅលើក្រុងភ្នំពេញ ក្នុងឆ្នាំ១៩៧៣ ចំពេលដែលការវាយលុកតាមផ្លូវអាកាសខ្លាំងក្លាបំផុតរបស់សហរដ្ឋអាមេរិក ។ នៅឆ្នាំ១៩៧៥ ភូមិភាគនេះបានបាត់បង់កងទ័ព និងភាពល្បីល្បាញរបស់ខ្លួនបន្តិចបន្តួចដែរ ប៉ុន្តែ នៅតែបង្ហាញឲ្យឃើញនូវភាពមោះមុតក្នុងការកែប្រែភូមិនានារបស់ខ្លួន ធ្វើឲ្យក្លាយជាសហករណ៍ទាំងអស់ ដែលខ្លួនធ្លាប់បានបញ្ចេញឲ្យឃើញនៅលើសមរភូមិឡើយ ហើយគ្រាន់តែមានប្រៀបជាងភូមិភាគបូព៌ាក្នុងការរៀបចំរបៀបគ្រប់គ្រងមួយបែបនោះប៉ុណ្ណោះ ។ ម្យ៉ាងទៀត ក្នុងរយៈពេលសង្គ្រាម ភូមិភាគនិរតី បានដណ្តើមយកសម្រាប់ខ្លួនឯងនូវកេរ្តិ៍ឈ្មោះបណ្តុះបណ្តាលកម្មាភិបាលជាច្រើន ដែលលេចមុខជាបណ្តាមេដឹកនាំដ៏មានសក្តានុពលសម្រាប់មជ្ឈិម ។ តាម៉ុក[១៨] ដែលជាមេដឹកនាំភូមិភាគនេះនៅចុងបញ្ចប់នៃសង្គ្រាម បានប្រមូលផ្តុំចំណុចខ្លាំង និងចំណុចខ្សោយរបស់ដែនដីគាត់មកដាក់លើខ្លួនគាត់ទាំងអស់ ។

រហស្សនាមរបស់គាត់គឺ ម៉ុក ប៉ុន្តែ ជាទូទៅគេច្រើនហៅរបៀបគួរសមដោយមានបន្ថែមពាក្យ "តា" ពីមុខទៀត ។ គាត់កើតក្នុងគ្រួសារកសិករមានមួយនៅភាគនិរតី ហើយបានចូលបួសរៀនក្នុងវត្តព្រះពុទ្ធសាសនាមួយក្នុងខេត្តតាកែវជាទីដែលគាត់បានទទួលការសិក្សាយ៉ាងជ្រៅជ្រះមួយខាងភាសាបាលី ។ បន្ទាប់មក គាត់បានលាចាកសិក្ខាបទ ដើម្បីចាប់ផ្តើមរកស៊ីលក់ឈើជាមួយគ្រួសារវិញ ហើយនៅពេលដែលសង្គ្រាមលោកលើកទីពីរផ្ទុះឡើង គាត់បានសុំចូលរួមក្នុងចលនាតស៊ូប្រឆាំងនឹងបារាំង មុនដំបូង ជាមួយពួកខ្មែរឥស្សរៈ បន្ទាប់មក ជាមួយពួកកុម្មុយនិស្តវៀតណាម និងកុម្មុយនិស្តខ្មែរ ។ គាត់បានស្ថិតនៅកម្ពុជាដដែល បន្ទាប់ពីសន្និសីទក្រុងហ្សឺណែវបរាជ័យ ហើយគាត់បានបន្តរៀបចំជនបទនៅភាគនិរតីចាប់ពីទសវត្សរ៍១៩៥០ ដល់១៩៦០ ។គឺជាបក្ខជនដើមចាស់ពិតប្រាកដម្នាក់របស់ការបដិវត្តន៍ ដែលធ្លាប់បានចូលរួមគ្រប់ដំណាក់កាលកាលតស៊ូទាំងអស់របស់គាត់ ។

តាមបណ្តាសមមិត្តរួមជំនាន់ជាមួយគាត់បានឲ្យដឹងថា គាត់បានរួចពីគ្រោះថ្នាក់ និងអំពើក្បត់ផ្សេងៗក៏ដោយសារស្នាដៃវិសេសក្នុងសង្គ្រាមរបស់គាត់ដែរ ។ មេដឹកនាំខ្មែរក្រហមម្នាក់បានលើកតម្កើងគាត់ជាប្រភេទ

ស្តេចណាប៉ូឡេអុងតូចម្នាក់ ៖ ជាមនុស្សដែលវាយឫកក្រអឺតក្រអោងអួតក្អេងក្អាង និងចិត្តស្រាល ឆាប់ខឹងច្រឡោត ហើយដែលចេះស្ទាបនាមូលដ្ឋាននៃអំណាចផ្ទាល់របស់គាត់បាន ។ គាត់គឺជាមនុស្សដែលគ្មានចេះអាណិតអាសូរម្នាក់ដែរ ៖ ប្រហែលជានៅចុងបញ្ចប់នៃសង្គ្រាម គាត់បានឲ្យគេធ្វើឃាដគូប្រជែងយ៉ាងសំខាន់របស់គាត់ពីរនាក់ ដើម្បីគាត់បានក្លាយជាលេខាបក្សភូមិភាគ ។

តាមការគោរពរាប់អានជាច្រើន គេយល់ឃើញថា តាម៉ុក ជាមនុស្សមាន "ឫកពាគ្គង" ជាងបណ្តាលេខាបក្សភូមិភាគនានា ជាមនុស្សដែលមិនសូវចេះគិតគូរទៅណាឆ្ងាយក្រៅពីសេចក្តីត្រូវការផ្ទាល់របស់គាត់ និងភូមិភាគគាត់ឡើយ ។ គាត់បានការពារយ៉ាងចចេសនូវការជ្រៀតជ្រែកគ្រប់បែបយ៉ាងពីមជ្ឈិម ឬពីភូមិភាគដទៃទៀតមកលើដែនដីរបស់គាត់ ដែលធ្វើឲ្យមនុស្សជាច្រើនអាក់អន់ចិត្តជាខ្លាំង ។ គាត់ជាសមាជិកថ្មីម្នាក់ក្នុងចំណោមសមាជិកថ្មីៗបំផុតរបស់គណៈលេខាមជ្ឈិមបក្ស ហើយតាំងពីដើមដំបូង គាត់បានដាក់ខ្លួននៅក្រោមជម្ទោះ និងការឃុបឃិតគ្នាបម្រុងបំផ្លាញអ្នកណាម្នាក់ ដែលរីករាលដាលធំឡើងៗ នៅពេលដែលមជ្ឈិមចាប់ផ្តើមសង្ស័យអំពីសេចក្តីស្មោះត្រង់របស់មេដឹកនាំភូមិភាគខ្លះៗ ។ ទោះបីជាភូមិភាគរបស់គាត់ជាភូមិភាគមានឥទ្ធិពល មានសក្តានុពលខាងសេដ្ឋកិច្ចយោធាខ្លាំក៏ដោយ ក៏គាត់មានកម្រិតនយោបាយមួយទាបដែរ ហើយមជ្ឈិមបានវិនិច្ឆ័យពីរូបគាត់ថា ពុំមែនជាមនុស្សដែលឲ្យកើតមានការបារម្ភម្នាក់ ពុំមែនជាបញ្ហាមួយ ដែលទាមទារឲ្យមានការយកចិត្តទុកដាក់របស់ខ្លួនជាបន្ទាន់នោះទេ ទាំងក៏ពុំមែនជាឥស្សរជនសំខាន់ ដែលស័ក្តសមនឹងផ្តល់រង្វាន់មានតម្លៃមួយដែរ ។

ភូមិភាគបូព៌ាជាភូមិភាគទីពីរ បើគិតទៅតាមទំហំផ្ទៃដី និងត្រូវដឹកនាំដោយ សោ ភឹម ដែលនៅឆ្នាំ១៩៧៥ ជាអ្នកកាន់មុខតំណែងមួយកៀកបំផុតនឹងក្បាលម៉ាស៊ីនដឹកនាំប្រទេស ។ ដែនដីរបស់គាត់លាតសន្ធឹងចាប់ពីខាងកើតទន្លេមេគង្គ ដែលរួមមានទាំងអស់ ឬដោយផ្នែកបណ្តាខេត្តជាយុទ្ធសាស្ត្រផ្សេងៗ ដូចជា ព្រៃវែង ស្វាយរៀង កំពង់ចាម និងក្រចេះ ។ គឺភូមិភាគនេះហើយ ដែលពួកកុម្មុយនិស្តវៀតណាមបានតាំង"ទីជម្រក"យ៉ាងច្រើន ហើយដែលសហរដ្ឋអាមេរិកបានខំប្រឹងកម្ទេចបំផ្លាញទាំងអស់សង្ស៊ឹម គឺនៅទីនេះដែរ ដែលគេឃើញមានចម្ការកៅស៊ូរាប់ម៉ឺនហិកតា ដែលផ្តល់កម្រៃយ៉ាងក្រាស់ក្រែល និងជាតំបន់ផលិតស្រូវដ៏សំខាន់បំផុត ។ ប៉ុន្តែ ជាពិសេសភូមិភាគបូព៌ាក៏ជាចំណុចដែលធ្វើឲ្យទំនាក់ទំនងខ្មែរ-វៀតណាមឆាបឆេះឡើង ។

ភូមិភាគបូព៌ាមានព្រំប្រទល់ជាប់នឹង "ដែនដីកម្ពុជាក្រោម" ភាគខាងត្បូងវៀតណាម ដែលជាកម្មសិទ្ធិរបស់រាជាណាចក្រខ្មែរក្នុងរយៈពេលមួយយ៉ាងខ្លី ។ ភូមិភាគនិរតីក៏មានព្រំប្រទល់មួយជាប់ជាមួយដែនដីកម្ពុជាក្រោមដែរ ប៉ុន្តែ ភូមិភាគនេះស្ថិតនៅខាងលិចទន្លេមេគង្គ ជាតំបន់ដែលមិនសូវរងការសៅហ្មងដោយការធ្វើអន្តោប្រវេសន៍ជាប្រពៃណីរបស់ជនជាតិវៀតណាមប៉ុន្មានឡើយ ។ ភាគខាងកើតទន្លេមេគង្គ ដែលស្ថិតនៅក្នុងភូមិភាគបូព៌ា គឺជាចំណុចសំខាន់ក្នុងការទាក់ទងរវាងវៀតណាម-កម្ពុជារវាងពួកកុម្មុយនិស្ត និងមិនមែនកុម្មុយនិស្តក្នុងគោលដៅផ្សេងៗខាងផ្នែកយោធា នយោបាយ ឬពាណិជ្ជកម្ម ។ គឺជាអាណាខែត្រព្រំដែន ដែលមានជម្លោះ ទាស់

ទែងគ្នា និងដែលរំដើបរំជួលខ្លាំងជាងគេ ។ តាំងពីជំនាន់ដែលសម្តេច ព្រះនរោត្តម សីហនុ ជំរុញឲ្យពួកកុម្មុយនិស្តវៀតណាម ទទួលស្គាល់ព្រំដែនបច្ចុប្បន្នជាថ្នូរនឹងសហប្រតិបត្តិការរបស់ព្រះអង្គ ដើម្បីទ្រទ្រង់សង្គ្រាមរបស់គេ តំបន់នេះ បានត្រូវចាត់ទុកជាដែនដីមួយដែលពួកវៀតណាមនឹងចូលមកតាំងទីលំនៅមិនខាន បើសិនជាពួកគេមានឱកាស ។

សោ ភឹម[១៥] ត្រូវបានគេស្គាល់ច្រើនចំពោះរបៀបដោះស្រាយដ៏ប៉ិនប្រសប់របស់គាត់ ជាមួយពួកវៀតណាម ដោយមិនប្រគល់បូរណភាពទឹកដីកម្ពុជាឡើយ ។ គាត់ជាអ្នកបដិវត្តជើងចាស់ម្នាក់នៅជំនាន់សង្គ្រាមឥណ្ឌូចិនលើកទីមួយ ដូច ម៉ុក ដែរ ប៉ុន្តែ ភាពដូចគ្នាមានត្រឹមតែប៉ុណ្ណឹង ។ ភឹម បេះសម្តែងចេញនូវការគ្មានអាណិតអាសូររបស់គាត់ ប៉ុន្តែពុំមែនដូច ម៉ុក ទេ ហើយគាត់ជាមនុស្សមានលក្ខណៈឈ្លាសវៃជាងលេខាបក្សភូមិភាគនិរតីដែលជាមនុស្ស "មានបុកពាន្លង" ថែមទៀត ។ គាត់ត្រូវបានកោតសរសើរយ៉ាងខ្លាំងក្នុងបក្ស ហើយត្រូវបានចាត់ទុក ជាអ្នកកាន់វិន័យម៉ឺងម៉ាត់ជាងគេ ។ បន្ទាប់ពីសន្និសីទហ្សឺណែវ គាត់បានសម្រេចចិត្តធ្វើដំណើរទៅប្រទេសវៀតណាមខាងជើង ប៉ុន្តែគាត់បានត្រឡប់មកវិញក្រោយពីរស់នៅក្នុងភាគខាងជើងពីរ-បីខែ ដើម្បីរៀបចំចាត់ចែងក្រុមអ្នកបដិវត្តក្នុងភូមិភាគបូព៌ាឲ្យមានសកម្មភាពឡើង ។

គាត់ធ្លាប់បានទទួលជោគជ័យយ៉ាងគ្រប់គ្រាន់ក្នុងអំឡុងទសវត្សរ៍១៩៥០ នៅពេលត្រូវបានជ្រើសរើសជាសមាជិកគណៈកម្មាធិការមជ្ឈិមក្នុងឱកាសមហាសន្និបាតឆ្នាំ១៩៦០ ។ នាសម័យប្រជុំមួយនៅឆ្នាំ១៩៦៣ នៅពេលដែល ប៉ុល ពត ត្រូវបានជ្រើសតាំងជាអគ្គលេខាបក្ស ភឹម ក៏បានឈានឡើងចូលក្នុង គណៈលេខាមជ្ឈិមដូច ប៉ុល ពត ដែរ ។ កាលនោះ ភឹម បានក្លាយជាមេអណ្តើកដ៏សំខាន់ម្នាក់ក្នុងការទាក់ទងផ្សេងៗ ជាមួយពួកវៀតណាម ។ មួយភាគធំនៃសកម្មភាពផ្សេងៗក្នុងការបណ្តុះបណ្តាលបក្ខជន កងទ័ព និងទំនាក់ទំនងទាំងឡាយរវាងពួកកុម្មុយនិស្តនៃប្រទេសទាំងពីរបានត្រូវសម្របសម្រួល តាមរយៈភឹមនិងតំបន់របស់គាត់ទាំងអស់ ។ ភូមិភាគបូព៌ាបានក្លាយទៅជា "ប្រកទ្វារ" របស់ចលនាទាំងពីរ ហើយនៅឆ្នាំ១៩៦៩ នៅពេលដែលសម្តេច ព្រះនរោត្តម សីហនុ ផ្តើមការវាយលុករបស់ព្រះអង្គជាទូទៅប្រឆាំងនឹងពួកកុម្មុយនិស្តកម្ពុជានោះ ភឹម បានរត់ភៀសខ្លួនទៅនៅឯប្រទេសវៀតណាមឯណោះ ។ គាត់បានត្រឡប់មកកម្ពុជាវិញ បន្ទាប់ពីរដ្ឋប្រហារឆ្នាំ១៩៧០ ។ ក្នុងសម័យសង្គ្រាមភូមិភាគរបស់គាត់ជាភូមិភាគដំបូងគេ ដែលស្ថិតនៅក្រោមការត្រួតត្រាទាំងមូលរបស់ពួកកុម្មុយនិស្តកម្ពុជា ដោយមានការជួយឧបត្ថម្ភរបស់ពួកវៀតណាមផង ។

ប៉ុន្តែ ភឹម ជាមនុស្សដែលអាចបែរក្បាលប្រឆាំងនឹងសម្ព័ន្ធមិត្តចាស់របស់គាត់ បានទាំងស្រុង ។ ជាអ្នកទទួលមើលខុសត្រូវលើពួកកម្ពុជា ដែលកំពុងវិលត្រឡប់ចូលមាតុប្រទេសវិញ ក្រោយពីការនិរទេសខ្លួនដ៏យូរមួយនៅវៀតណាមខាងជើង គាត់បានបញ្ចេញឲ្យឃើញសមានចិត្តតិចតួចណាស់ តាំងពីការចេញដំណើរមក ហើយបានយល់ព្រមឲ្យអ្នកទាំងនោះកាន់តំណែងផ្សេងៗ ក្រោមបង្គាប់គេទាំងអស់ ។ នៅទីបំផុត ក្នុងចំណោមនោះ

មានភាគច្រើនបានត្រូវគាត់ចាប់ឃុំឃាំងក្នុង «ជំរំអប់រំកែប្រែជាថ្មី» ដែលតាមការពិតជាកន្លែងដែលពួកគេត្រូវបានសម្លាប់ចោលក្រោយពីការជាប់ឃុំមួយរយៈមក ។ គេបានរួមបញ្ចូល ភីម ជា«ស្លាបម្ខាង» របស់បក្ស ដែលយល់ឃើញថា ប្រទេសវៀតណាមអាចជាសម្ព័ន្ធមិត្តដ៏ថ្លៃថ្លាមួយក្នុងរយៈពេលធ្វើសង្គ្រាម ប៉ុន្តែ មិនត្រូវចូលជ្រៀតជ្រែកក្នុងការដឹកនាំរបស់បដិវត្តកម្ពុជាទេ ហើយជាពិសេសមិនត្រូវជ្រៀតតាមរយៈ «កម្លាំងទីប្រាំ» ដែលជាពួកខ្មែរទើបនឹងវិលត្រឡប់មកពីក្រុងហាណូយឡើយ ។

ហែម សាមិន ជាអ្នកមាតុភូមិនិវត្តន៍ម្នាក់ក្នុងបណ្តាអ្នកមាតុភូមិនិវត្តន៍ជាតិខ្មែរដ៏កម្រជាច្រើន ដែលបានរស់រាន «ពួកមេដឹកនាំរបស់ភូមិភាគបូព៌ា បានសង្កត់បញ្ឈាក់ម្តងហើយម្តងទៀតថា ពួកគេពេញចិត្តណាស់ដែលបាន ដឹកនាំធ្វើការប្រយុទ្ធតស៊ូក្នុងប្រទេស... បានស្គាល់នូវការអត់ឃ្លាន និងការខ្វះខាតសព្វបែបយ៉ាងរួមសុខរួមទុក្ខជាមួយប្រជាជន នៅពេលដែលយើងទាំងអស់គ្នារត់គេចខ្លួនទៅរស់នៅក្នុងប្រទេសមួយផ្សេងទៀតក៏ដោយ[១៦]» «នេះគ្រាន់តែជាសម្តីចំអក ជាការប្រមាថត្រង់ៗប៉ុណ្ណោះ -ការចាប់ថ្នាក់ប្រឆាំងនឹងពួក«ក្បាលយួនខ្លួនខ្មែរ»ទាំងនេះ... យើងពុំអាចនិយាយតបតបានទេ ដ្បិតអីយើងដឹងថា បើយើងឆ្លើយតបតទៅវិញចម្លើយរបស់យើង ក៏ដូចខ្លួនពួកយើងផ្ទាល់ដែរ និងមានជីវិតខ្វីមិនខាន...។ ពួកគេអាចកម្ទេចពួកយើងបានគ្រប់ពេលវេលា មិនថាពេលថ្ងៃ ឬក៏ពេលយប់ឡើយ» ។

សោ ភីម ជាអ្នកពិនិត្យត្រួតត្រាលើការកាប់សម្លាប់មិនត្រឹមតែពួកមាតុភូមិនិវត្តន៍ប៉ុណ្ណោះទេ ប៉ុន្តែលើពួកជនជាតិភាគតិចកាន់សាសនាអ៊ីស្លាមក្នុងភូមិភាគរបស់គាត់ដែរ ព្រោះថា ភូមិភាគនេះ បានផ្តល់ទីជម្រកឲ្យជនជាតិចាមរស់នៅយ៉ាងច្រើន ដែលពុំដែលដាក់បញ្ចូលប្រពៃណីរបស់ខ្លួនក្នុងសង្គមរបស់កម្ពុជាម្តងណាសោះឡើយ ហើយក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏នៅតែអ៊ីចឹងដដែល ។ ការកម្ទាត់របស់គាត់លើជនជាតិចាម ដែលស្ទើរតែរលាយអស់ទាំងស្រុងនោះ គឺជាវគ្គរឿងមួយក្នុងចំណោមវគ្គរឿងដែលគួរឲ្យព្រួយបារម្ភរបស់ការបដិវត្ត ។ សាមិន អះអាងថា «សោ ភីម ជាមនុស្សមានលក្ខណៈកាចសាហាវដែលមាននិស្ស័យខាងស្អប់ឈ្នានីសគេឯង ។ បើសិនជាយុទ្ធជនម្នាក់ធ្វើមិនឲ្យគាត់ទុកចិត្តទេ គាត់គ្មានរួញរានឹងបាញ់សម្លាប់អ្នកនោះចោលឡើយ» ។

គេបានដំណាលថា ភីម បានសម្លាប់អ្នកបើកឡាន និងគ្រូពេទ្យផ្ទាល់របស់គាត់ចោល ក្រោយពេលចប់សង្គ្រាមបន្តិច ពីព្រោះអ្នកទាំងពីរបាន«ប្រព្រឹត្តអំពើខុសឆ្គង» ផ្សេងៗ ។

ដោយគាត់បានទទួលទំនុកទុកចិត្តពីបក្ស ហើយដោយគាត់ជាអ្នកដឹកនាំភូមិភាគសំខាន់មួយក្នុងបណ្តា ភូមិភាគសំខាន់ៗបំផុតនោះ សោ ភីម បានប្រកាន់ជំហរឯករាជ្យមួយស្តីពីបញ្ហាមួយចំនួនធំក្នុងរយៈពេលសង្គ្រាម ។ ជាពិសេស គាត់បានរៀបចំប្រព័ន្ធគ្រប់គ្រងបែបផ្តល់ «រង្វាន់» មួយ ដោយអនុញ្ញាតឲ្យប្រជាកសិកររក្សាទុកផលមួយភាគធំ ដែលផលិតបានធំ ជាគោលការណ៍ដែលគាត់ចង់ទុកឲ្យមានដដែលក្នុងពេលដែលបានសន្តិភាពហើយ ។ គាត់ជាមេទ័ពដ៏អង់អាចក្លៀវក្លា និងម៉ឺងម៉ាត់ម្នាក់ ដែលគេចាត់ចូលក្នុងចំណោមអ្នក ដែលកាន់វិន័យត្រឹមត្រូវជាង

គេបំផុតរបស់ប្រទេសជាតិ ។ គាត់បានឲ្យកងទ័ពទាំងអស់របស់គាត់ស្លៀកពាក់ឯកសណ្ឋាន ពណ៌ប្រផេះ ដើម្បីធ្វើឲ្យខុសប្លែកពីពួកខ្មែរក្រហមផ្សេងទៀត ដែលស្លៀកពាក់ខោអាវពណ៌ខ្មៅជាប្រពៃណី ។ (ពួកនាយទាហាន បានដាក់សម្មិតនាមឲ្យកងទ័ពភូមិភាគបូព៌ាថា "ពួកត្មាតប្រផេះ" ហើយហៅពួកខ្មែរក្រហមដទៃទៀតថា "ពួកក្អែកខ្មៅ") ។ កងទ័ពរបស់ភូមិភាគបូព៌ាមានចរិតកាចឃោរឃៅមែន ប៉ុន្តែ គេមិនសូវនិយាយពីរឿងកាប់សម្លាប់ ជ្រុលហួសហេតុ ឬការចាប់ចងដែលធ្វើដោយអំណាចចិត្តផងទេ ថ្វីបើជនជាតិភាគតិចជាច្រើន និងពួកខ្មាំងសត្រូវពិតប្រាកដ ឬគ្រាន់តែសន្មត់ ត្រូវបានគេកម្ទេចចោលអស់សន្ទឹកសន្ធាប់ក៏ដោយ ។ សោ ភឹម កងទ័ព និងសហករណ៍ទាំងអស់របស់គាត់ បានលេចឡើងជាគំរូគួរឲ្យពេញចិត្តរបស់ខ្មែរក្រហម នៅចុងបញ្ចប់សង្គ្រាម ។

ហើយ ភឹម ត្រូវបានផ្តល់រង្វាន់លើកទឹកចិត្ត ដោយគេអនុញ្ញាតឲ្យគាត់រក្សាទុកកងពលធំពីរ ក្នុងចំនួនកងពលធំទាំងបីរបស់គាត់ក្នុងភូមិភាគបូព៌ា ហើយប្រគល់តែមួយកងពលធំប៉ុណ្ណោះទៅឲ្យមជ្ឈិម ។ គាត់ក៏ត្រូវបានតែងតាំងជាអនុប្រធានគណៈប្រធានរដ្ឋ នៅពេលដែលរដ្ឋាភិបាលត្រូវគេបង្កើតនៅឆ្នាំ១៩៧៦ ។ តាមការពិតគាត់បានទទួលចំណែកគុណប្រយោជន៍របស់គាត់ បន្ទាប់ពីការកម្ចាត់លេខាបក្សភូមិភាគម្នាក់ ដែលជាគូប្រជែងរួចមក ។ ភឹម ជាមនុស្សជិតស្និទ្ធនឹងក្រុមមនុស្សដ៏អាថ៌កំបាំងបំផុតរបស់បក្ស ជាងបណ្តាលេខាបក្សភូមិភាគឯទៀតៗ ហើយ ប៉ុល ពត ទុកចិត្តលើគាត់សម្រាប់អូសទាញភូមិភាគផ្សេងទៀតក្នុងកិច្ចប្រឹងប្រែងស្តាបនាប្រទេសឡើងវិញ និងការពារប្រទេសទល់នឹងពួកវៀតណាម ដែលស្ថិតនៅម្ខាងទៀតជាប់ព្រំដែនជាមួយភូមិភាគបូព៌ា ។

លេខាបក្សភូមិភាគមួយនាក់ទៀត ដែលមានកិត្យានុភាពដូច ភឹម ដែរ គឺ ញឹម រស់ ជាអ្នកទទួលខុសត្រូវលើភូមិភាគពាយ័ព្យ ។ ជាកូនប្រុសរបស់គ្រួសារកសិករក្រ គាត់ធ្លាប់បានធ្វើការវាយប្រយុទ្ធក្នុងកំឡុងសង្គ្រាមឥណ្ឌូចិនលើកទីមួយដែរ ។ គាត់បានទៅរួបរួមជាមួយពួកខ្មែរឥស្សរៈ បន្ទាប់មកបានក្លាយខ្លួនជាជនកុម្មុយនិស្តដោយបានរស់នៅជាមួយពួកឥស្សរៈឯករាជទាំងឡាយ ដែលបានធ្វើឲ្យភូមិភាគពាយ័ព្យក្លាយទៅជាមូលដ្ឋានរបស់គេផង ។ គាត់បានរៀបចំចាត់ចែង និងដឹកនាំភូមិភាគនេះក្នុងសម័យកាលដ៏គួរឲ្យភ័យបារម្ភជាច្រើនឆ្នាំ ។ សម្រាប់ពួកកុម្មុយនិស្តយល់ថា តំបន់ពាយ័ព្យ បានស្តែងឡើងឲ្យឃើញជាតំបន់លំបាកគ្រប់គ្រង -ដែលមិនអាចគិតទុកជាមុនបាន និងប្រែប្រួលមិនទៀងទាត់- ប៉ុន្តែមានសារសំខាន់ក្នុងផែនការអភិវឌ្ឍន៍ទាំងមូល ដោយហេតុថា ដីស្រែទាំងអស់សម្បូរដីជាតិណាស់ ។

ភូមិភាគនេះ ពួកកុម្មុយនិស្តមិនធ្លាប់ដែលយកធ្វើជាមូលដ្ឋានបង្អែកមួយសោះឡើយ ប៉ុន្តែ គឺដោយសារប្រជាកសិករនៅសំឡូតនៃភូមិភាគពាយ័ព្យ ងើបបះបោរប្រឆាំងសម្តេច ព្រះនរោត្តម សីហនុ និង លន់ នល់ នៅឆ្នាំ១៩៦៧នោះ ហើយ ដែលជំរុញឲ្យពួកកុម្មុយនិស្តដំណើរការតស៊ូដោយអាវុធក្នុងកម្រិតខ្លាំងមួយ[១៧] ។ ប៉ុន្តែប្រជាជនទូទាំងតំបន់ពុំបានដើរតាមចលនាដែលខ្លួនបង្កឡើងទេ ហើយពេញរយៈពេលនៃសង្គ្រាមស៊ីវិល ភូមិភាគពាយ័ព្យហើយ ដោយឡែកខេត្តបាត់ដំបង នៅតែស្មោះត្រង់យ៉ាងប្តូរផ្តាច់នឹងរបបសាធារណរដ្ឋខ្មែរជានិច្ច ។

នៅឆ្នាំ១៩៧៥ ពួកខ្មែរក្រហមនៅតែពុំទាន់សម្រេចជោគជ័យរៀបចំបង្កើតប្រព័ន្ធសហករណ៍ដ៏រឹងមាំមួយ ឬកងទ័ពដ៏ខ្លាំងពូកែ មួយក្នុងភូមិភាគនេះនៅឡើយ ។ ញឹម រស់ យុទ្ធជនដើងចាស់ ដែលគួរឲ្យគោរពកោតខ្លាចម្នាក់ត្រូវបានតែងតាំងជាអនុប្រធានទី២នៃគណៈប្រធានរដ្ឋក្រោម សោ ភឹម មួយថ្នាក់ ។ ទោះជាជោគជ័យដែលទទួលបានក្នុងរយៈពេលសង្គ្រាមមានស្តួចស្តើងយ៉ាងណាក៏ដោយ ក៏ភូមិភាគរបស់ ញឹម រស់ ត្រូវបានចាត់ទុកជាតំបន់ដ៏មានសក្តានុពលរបស់កម្ពុជាបន្ទាប់ពីសម័យសង្គ្រាមដែរ ។ មុនការបដិវត្ត តំបន់នេះជាជង្រុកស្រូវរបស់ប្រទេស ហើយគេវាយតម្លៃថា នៅពេលដែលបក្សពង្រីកកម្លាំងប្រជាជនរបស់ខ្លួនថែមទៀត តំបន់នេះនឹងសម្រេចបានលទ្ធផលល្អប្រសើរ ជាងភូមិភាគដទៃទៀតជាមិនខាន ។ សេចក្តីសង្ឃឹមយ៉ាងមុតមាំទាំងនេះហើយ ដែលប្រហែលជានាំមកនូវការវិនាសរបស់ ញឹម រស់ នៅពេលក្រោយមក ។

ក្នុងរយៈពេលសង្គ្រាម លេខាបក្សភូមិភាគពិសេស នៅជុំវិញក្រុងភ្នំពេញ គឺ វ៉ន វ៉េត ដែលត្រូវបាត់បង់មុខតំណែងរបស់គាត់ភ្លាមបន្ទាប់ពីជ័យជម្នះ នៅពេលដែលគណៈកម្មាធិការមជ្ឈិមក្តោបក្តាប់ការទទួលខុសត្រូវលើរដ្ឋធានី ។ នៅសម័យសង្គ្រាមឥណ្ឌូចិនលើកទីមួយ វ៉ន វ៉េត ជានិស្សិតរៀននៅភ្នំពេញ ហើយបានរត់ចូលព្រៃធ្វើការតស៊ូ មួយឆ្នាំមុនទីបញ្ចប់នៃការច្បាំងគ្នា ។ បន្ទាប់មក គាត់បានវិលត្រឡប់មករាជធានីវិញ ហើយនៅទីបំផុតគាត់បានទទួលតំណែងជាលេខាគណៈកម្មាធិការបក្សទីក្រុងភ្នំពេញ ដែល ប៉ុល ពត ជាអ្នកបង្កើតឡើង ។ នៅឆ្នាំ១៩៦៣ គាត់បានឡើងឋានៈចូលក្នុងគណៈកម្មាធិការមជ្ឈិម ហើយចាប់ពីពេលនោះមក គាត់បានទៅជាមនុស្សសំខាន់ម្នាក់ក្នុងចំណោមក្រុម មេដឹកនាំជាន់ខ្ពស់មួយក្រុមតូច ។ វ៉ន វ៉េត បានចំណាយពេលវេលាទៅក្នុងការប្រយុទ្ធយ៉ាងអង់អាចក្លាហានមួយ ប៉ុន្តែ ឥតបានការ ដើម្បីការពារខ្សែបណ្តាញកុម្មុយនិស្តមួយក្នុងទីក្រុងក្រោយឆ្នាំ១៩៦៩ នៅពេលដែលសម្តេច ព្រះនរោត្តម សីហនុ និង លន់ នល់ ដេញតាមចាប់ភ្នាក់ងាររបស់ខ្លួន និងបានសម្លាប់ពួកនោះ កណ្តាលផ្លូវអស់មួយចំនួនធំ ។ ក្នុងអំឡុងសង្គ្រាម គាត់បានធ្វើឲ្យបក្សមានសេចក្តីពេញចិត្តជាខ្លាំង ហើយគេត្រូវការឲ្យគាត់ស្ថិតនៅក្នុងធានីបន្តទៀត ដើម្បីដឹកនាំកិច្ចប្រឹងប្រែងក្នុងការស្តារប្រទេសជាតិឡើងវិញ ហើយនៅទីបំផុត គាត់បានទទួលបន្ទុកមើលខុសត្រូវខាងផ្នែកឧស្សាហកម្ម និងផ្នែកសេដ្ឋកិច្ចមួយភាគធំរបស់ប្រទេស ។

លេខាបក្សភូមិភាគសំខាន់ៗដទៃទៀតក្នុងរយៈពេលសង្គ្រាមគឺ កុយ ធួន មេដឹកនាំភូមិភាគឧត្តរ ដែលគណៈកម្មាធិការមជ្ឈិមធ្លាប់មានទីស្នាក់ការរបស់ខ្លួននៅទីនោះ ។ ជាអតីតគ្រូបង្រៀននៅខេត្តកំពង់ចាមភាគខាងកើតកម្ពុជា គាត់ជាបញ្ញវន្តបេះដឹងខ្ពស់ជាងគេក្នុងចំណោមលេខាបក្សភូមិភាគទាំងអស់ ។ គឺមុខចម្អឹង រោមចិញ្ចើញអង្កាញ់នេះហើយ ដែលគេប្រទះឃើញក្នុងសៀវភៅស្តើងឆ្នាំ១៩៧២ ដែលបង្ហាញរូប ប៉ុល ពត – កាលនោះត្រូវគេស្គាល់ក្រោមឈ្មោះថា សាឡុត ស– និង នួន ជា ឲ្យពិភពលោកបានស្គាល់ ។ ប្រហែលដោយសារតែគាត់ស្ថិតនៅក្រោមការសង្កេតពិនិត្យយ៉ាងយកចិត្តទុកដាក់ជារឿយៗ ពីសំណាក់មេដឹកនាំជាន់ខ្ពស់របស់បក្ស និងដោយ

ភូមិភាគរបស់គាត់អាចត្រូវតាមពិនិត្យ ដោយល្អិតល្អន់ជាងភូមិភាគផ្សេងៗទៀត កុយ ធួន បានក្លាយទៅជាមេដឹកនាំភូមិភាគដំបូងបង្អស់ ដែលគេជ្រើសរើសទុកជាមុនក្នុងឋានៈជាសត្រូវ ។

ដែនដីរបស់គាត់ បានត្រូវបែងចែករវាងភូមិភាគឧត្តរថ្មីមួយ និងភូមិភាគកណ្ដាលមួយ ។ កុយ ធួន ត្រូវបានហៅមកក្រុងភ្នំពេញវិញ ហើយចាត់តាំងឲ្យទទួលបន្ទុកក្រសួងសេដ្ឋកិច្ចជាតិ ដែលជាភារកិច្ចលំបាកស្មុគស្មាញបំផុតមួយ ក្នុងសភាពជ្រួលច្របល់គួរឲ្យព្រឺខ្លាច ក្រោយពេលដែលពួកខ្មែរក្រហមដណ្ដើមអំណាចបាន ហើយចាប់ផ្ដើមត្រូវការពីប្រជាជននូវអ្វីៗដែលគាត់ពុំអាចធ្វើបាន ។

ហ្នឹងហើយ ជាមេដឹកនាំភូមិភាគសំខាន់ៗ នៅពេលដែលប្រទេសជាតិត្រៀមផ្ដើមធ្វើការបដិវត្តដំណាក់កាលទីពីរ ។ បណ្ដាលេខាបក្សភូមិភាគដទៃទៀត -កែ ពក នៃភូមិភាគកណ្ដាល ម៉ែន សាន នៃភូមិភាគឦសានក្រោយមក កង ចាប កាន់ភូមិភាគឧត្តរថ្មី និង ជូ ជេត កាន់ភូមិភាគថ្មី គឺបស្ចិម- បានសម្ដែងតួនាទីគាំទ្រផ្សេងៗក្នុងការតស៊ូដណ្ដើមអំណាច ដែលប្រព្រឹត្តទៅក្នុងបណ្ដាខែ និងបណ្ដាឆ្នាំជាបន្តបន្ទាប់មកទៀត ។

ក្រោមមេដឹកនាំទាំងនេះ មានខ្មែរក្រហមផ្ទាល់រៀងៗខ្លួន ជាពួកបុរស និងនារី ដែលមួយភាគធំ មានដើមកំណើតជាកសិករ និងមានបទពិសោធន៍ប្លែកៗពីគ្នា ។ អ្នកខ្លះមានឫសគល់ចេញពីចលនាទាមទារឯករាជ្យ ដែលធ្វើសកម្មភាពនៅក្រោមការកាន់កាប់របស់ជប៉ុនម្ល៉េះ ។ រចនាសម្ព័ន្ធរបស់បក្សគឺ កងទ័ព និងអតីតយុទ្ធជននៃសង្គ្រាមឆ្នាំ១៩៧០-១៩៧៥ ។ គេបានប្រគល់ទៅឲ្យអ្នកទាំងនោះនូវមុខតំណែងផ្សេងៗជាគណៈដឹកនាំក្នុងសហករណ៍រោងចក្រ ហើយអ្នកទាំងនេះបានរួមបង្កជាសមាជិកភាគច្រើនបំផុតរបស់បក្ស ។ ដូចនៅប្រទេសវៀតណាមដែរ បក្សចូលចិត្តជ្រើសរើសសមាជិករបស់ខ្លួនពីក្នុងកងទ័ព ហើយនៅក្បាលម៉ាស៊ីនបក្សគឺត្រូវដឹកនាំដោយបញ្ញវន្ត និងកសិករ ដែលធ្លាប់បញ្ចេញសមត្ថភាពរបស់គេនៅក្នុងការប្រយុទ្ធផ្សេងៗ ។ អ្នកទាំងអស់នេះមិនជឿពីសេចក្ដីស្មោះត្រង់របស់ពួកគហបតីតូចតាចឡើយ ហើយក៏មិនទុកចិត្តសតិអារម្មណ៍ឃ្លេងឃ្លោងរបស់ពួកគេដែរ ។

ពួកខ្មែរក្រហមបានចាប់ផ្ដើមការបដិវត្តទី២របស់ខ្លួន នៅថ្ងៃដែលពួកគេដណ្ដើមបានជ័យជម្នះ ។ ជំហានដំបូងនៃយុទ្ធសាស្ត្ររបស់គេ គឺដំណាក់កាលប្រើ «នយោបាយកុម្មុយនិស្តនៃសង្គ្រាម» បានបន្តស្ថិតមានរហូតដល់ពេលដែលពួកគេរៀបចំកម្មវិធីមួយជាផ្លូវការ សម្រាប់មហាសន្និបាតលើកទី៨របស់បក្សដែលគ្រោងធ្វើនៅខែមករា ឆ្នាំ១៩៧៦ ។

ជាមួយការជម្លៀស និងការផ្លាស់ប្ដូរទីលំនៅដោយបង្ខំឲ្យប្រជាជនទៅរស់នៅតាមជនបទ ពួកខ្មែរក្រហមបែរជាអនុវត្តនៅពេលប្រទេសមានសន្តិភាពនូវនយោបាយរបស់គេ ដែលប្រើក្នុងសម័យសង្គ្រាមទៅវិញ ។ អ្វីដែលត្រូវរៀបចំក្នុងឆ្នាំដំបូង គឺគេធ្លាប់បានសាកពិសោធន៍តាមតំបន់នានា តាំងពីការប្រកាសបង្កើតសហករណ៍

ម្ល៉ះ ។ គេនៅរក្សាពាក្យទាំងឡាយ និងចិត្តគំនិតមួយដូចនៅសម័យសង្គ្រាមដែរ ។ បន្ទាប់ពីជ័យជម្នះ គឺពុំមានការឈប់អែអង់ឡើយ ៈ គេរង់ចាំពីប្រជាជនថាគាត់ច្បាស់ជាធ្វើការរឹតតែខ្លាំងឡើងថែមទៀត ហើយថាគេមុខជាឈ្នះលើ«សត្រូវទាំងឡាយ» ។ ជាពួកចារបុរស ដែលគេមិនបញ្ចេញឈ្មោះ ហើយដែលកំពុងធ្វើការដើម្បីជាប្រយោជន៍ដល់ពួកភ្នាក់ងារបរទេស ឬមនុស្សផងទាំងពួង ដែលបញ្ចេញឲ្យឃើញលក្ខណៈផ្សេងៗ អាចបំផ្លាញដល់គ្រឹះបដិវត្តបាននោះគឺការជាប់ជំពាក់នឹងផលប្រយោជន៍គ្រួសារ ប្រយោជន៍ស្ងួនតួ ចំណង់ចង់មានកម្មសិទ្ធិឯកជន ។ លក្ខណៈទាំងនេះ សុទ្ធតែជា «សត្រូវវណ្ណៈ» ។ បក្សនឹងបែងចែករឿងនេះឲ្យដាច់ពីគ្នាក្នុងដំណាក់កាលបន្ទាប់ ដោយប្រកាសធ្វើ«សង្គ្រាមវណ្ណៈជាទូទៅ» និងចាត់តាំងឲ្យក្រុមសន្តិសុខស្រាវជ្រាវរកពួកភ្នាក់ងារកា.ហ្សេ.បេ. សូវៀត សេ.អ៊ី.អា. អាមេរិកាំង ហើយក្រោយមក គឺពួកភ្នាក់ងារវៀតណាមទៀត ។

ភាសាបដិវត្ត ដែលគេទម្លាប់ប្រើក្នុងរយៈពេលធ្វើសង្គ្រាម ត្រូវបានដាក់បង្ខំឲ្យប្រជាជន ប្រើប្រាស់ក្នុងពេលមានសន្តិភាពដែរ ។ ឋានៈគ្រាន់តែជាកិត្តិយសដែលមានលក្ខសាំញ៉ាំ ដែលជាប្រពៃណីសម្រាប់សម្គាល់សមាជិករបស់គ្រួសារនីមួយៗត្រូវគេលុបបំបាត់ចោល ។ អំណើះតទៅ មនុស្សទាំងអស់លែងមានឋានៈអ្វីក្រៅតែជាសមមិត្ត មា ឬម្តាយមីង ជាពុក ឬម៉ែ ប៉ុណ្ណោះ ។ ពាក្យសម្តីរបៀបកងទ័ពបានត្រូវប្រើជំនួសភាសាប្រើក្នុងគ្រួសារ ហើយពាក្យដែលកាលពីមុនមានន័យថា«ធ្វើការ» ឥឡូវនេះ ត្រូវថា«ប្រយុទ្ធ»វិញ ។ ប្រជាជនកម្ពុជាលែងនិយាយថា ដាំស្រូវហើយ គឺពួកគេថា «ប្រយុទ្ធដើម្បីដាំស្រូវ ឬភ្ជួរដី» ពួកគេក៏និយាយថា «ប្រយុទ្ធ» ដើម្បីចាប់ត្រីដែរ ។ ពួកគេលែងនិយាយថា លើកទំនប់ទឹកទៀតហើយ គឺគេថា «វាយសម្រុក» ដើម្បីកសាងទំនប់ទឹកទាំងនោះ ។ ដំណាំហូបផ្លែ ដូចជា ចេក អំពៅ ដំឡូង ព្រលិត ដែលគេដាំសម្រាប់បន្ថែមលើរបបម្ហូបអាហារបានក្លាយទៅជាដំណាំយុទ្ធសាស្ត្រទាំងអស់ ដោយសារតែដំណាំទាំងនោះដុះលូតលាស់ដោយងាយ ហើយចិញ្ចឹមកងទ័ពទៀតផង ។ នៅទីបញ្ចប់ និងជាពិសេស គឺពួកខ្មែរក្រហមបានដឹកនាំធ្វើការ«ប្រយុទ្ធ»ប្រឆាំងនឹងសតិអារម្មណ៍ឃ្លេងឃ្លោងរបស់ពួកគេទៀត ។

ពួកកុម្មុយនិស្តបានធ្វើឲ្យសមតាមវិចារណញ្ញាណនូវយុទ្ធវិធីនេះ ដែលបង្ហាញឲ្យឃើញសេចក្តីបំព្រួញមួយពោរពេញទៅដោយគំនិតឆ្នៃ ប្រឌិតឆ្ពោះទៅកាន់លទ្ធិសង្គមនិយម ។ ក្នុងទស្សនាវដ្តី«ទង់បដិវត្ត» លេខដំបូងរបស់គេ ដែលចេញផ្សាយនៅក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ជាថ្ងៃនៃជ័យជម្នះពួកគេមានការពេញចិត្តយ៉ាងខ្លាំងដែលបានរៀបចំផែនការមួយដោយកម្ចាត់អស់លទ្ធិ មូលធននិយមតែមួយភ្លែតប៉ុណ្ណោះ ។ ពួកមេដឹកនាំបក្សបានអះអាងថា ដោយបញ្ជូនប្រជាជនឲ្យទៅរស់នៅក្នុងសហករណ៍ និងជនបទនានា ពួកគេបានកសាងលទ្ធិសង្គមនិយម និងបោសសម្អាតលទ្ធិមូលធននិយមនៅប្រទេសកម្ពុជាចេញទាំងអស់ ។ ការពោលអាងរបស់គេ គឺថាកម្មសិទ្ធិឯកជននេះហើយ ដែលបង្ក ជាមូលដ្ឋានរបស់សង្គមអ្នកមានមូលធន ដោយបណ្តេញមនុស្សដែលមានទ្រព្យសម្បត្តិផ្ទាល់ខ្លួនច្រើនចេញពីទីក្រុងភ្នំពេញទាំងអស់ គឺពួកគេបានកម្ចាត់កម្មសិទ្ធិឯកជនព្រមគ្នានឹងលទ្ធិ

មូលធននិយមដែរ ។ ដោយគ្មានកម្មសិទ្ធិឯកជន ប្រទេសកម្ពុជាលែងអាចត្រូវចាត់ទុកជាសង្គមមូលធនមួយទៀតហើយ ។ អត្ថបទទស្សនាវដ្តីបានបញ្ជាក់ថា «បើសិនជាយើងទុកឲ្យមនុស្សរស់នៅក្នុងក្រុងភ្នំពេញ នោះកម្មសិទ្ធិឯកជននឹងមានអំណាចមួយយ៉ាងខ្លាំង... ។ យើងធ្លាប់ជាអ្នកខ្លាំងពូកែ និងមានអំណាចបំផុតក្នុងពេលដែលយើងស្ថិតនៅឯជនបទ ។ នៅភ្នំពេញ យើងនឹងក្លាយទៅជាអាយ៉ងរបស់ពួកអ្នកមានទ្រព្យសម្បត្តិឯកជនមិនខាន ប៉ុន្តែ យើងពុំបានទុកឲ្យប្រជាជនស្ថិតនៅក្រុងភ្នំពេញទេ ដូច្នេះកម្មសិទ្ធិឯកជនក៏លែងមានអំណាចតទៅទៀតដែរ[១៨]» ។

ក្នុងទស្សនាវដ្តី «ទង់បដិវត្ត» លេខបន្ទាប់ បក្សបានពង្រីកការពោលអាងរបស់ខ្លួនថា «លក្ខណៈពិសេសដោយឡែករបស់កម្មសិទ្ធិឯកជនជាលក្ខណៈពិសេសរបស់វណ្ណៈនាយទុន ។ លក្ខណៈទាំងនេះបង្កបានជា «ខ្លឹម» ដែលជាផ្នែកសំខាន់បំផុតនៃសកម្មភាពផ្សេងៗរបស់វណ្ណៈនាយទុន[១៩]» ។ លក្ខណៈទាំងនេះរួមមានសួនតួនិយម អស្មិមានះ អំនួត ការជំពាក់ចិត្តនឹងផលប្រយោជន៍គ្រួសារ បក្សពួកនិយម ចាត់ចែងនិយម ការិយាធិបតេយ្យនិយម និងអាជ្ញានិយម ។ ពួកខ្មែរក្រហមជឿជាក់ខ្លួនឯងថា ដោយលុបបំបាត់កម្មសិទ្ធិឯកជន ពួកគេនឹងកម្ចាត់ការប្រព្រឹត្តទាំងនេះឲ្យអស់ពីសង្គមបាន ។ ការឆ្លើយតបនឹងបញ្ហាផ្សេងៗផ្នែកសីលធម៌ នយោបាយ សេដ្ឋកិច្ច ឬវណ្ណៈដូចដែលពួកគេជឿជាក់ គឺត្រូវដាក់ជាកម្មសិទ្ធរដ្ឋទាំងអស់ ។ ក្នុងរវាងមួយឆ្នាំ ពួកខ្មែរក្រហមបានធ្វើរដ្ឋូបនីយកម្មទ្រព្យសម្បត្តិទាំងអស់របស់ប្រទេស- ជាអំពើមួយដែលពុំមានរដ្ឋាភិបាល កុម្មុយនិស្តណាមួយផ្សេងទៀត ធ្លាប់សាកល្បងធ្វើដូច្នេះឡើយ ។

ហ្នឹងហើយ ជារបៀបគិតទៅម៉្យាងដោយឡែក ដែលលាក់ខ្លួនពីក្រោយការពោលអាងដ៏ក្រអឺតក្រទម ពោរពេញដោយអំនួតថា តាំងពីមុនមក មិនដែលមានប្រទេសណាមួយរំដោះជាតិបានទាំងស្រុង ដូចប្រទេសកម្ពុជារបស់ពួកខ្មែរក្រហមទាល់តែសោះ ហើយក៏មិនដែលមានប្រទេសណាមួយផ្សេងទៀត កសាងលទ្ធិសង្គមនិយមបានឆាប់រហ័សដូច្នេះដែរ ។ ប៉ុន្តែ វាគ្មានអ្វីថ្មី ឬវៃឆ្លាតបន្តិចសោះ ក្នុងការបញ្ចប់ច្បាប់អាជ្ញាសឹក ដែលសម្រេចដោយពួកកុម្មុយនិស្តក្នុងផ្លូវកាត់ឆ្ពោះទៅរកសមភាពនិយមនេះ ដែលធ្វើឲ្យបុគ្គលម្នាក់ៗទៅជាសមាជិកមួយរូបរបស់សហករណ៍មួយ ដែលដឹកនាំដោយរដ្ឋ និងលុបបំបាត់ភាពខុសគ្នាផ្នែកសេដ្ឋកិច្ច ។ ពួកបុលឆេវិចរុស្ស៊ីក៏ធ្លាប់ប្រកាន់យកយុទ្ធសាស្ត្រមួយរបៀបដូចគ្នាដែរគឺ «នយោបាយកុម្មុយនិស្តនៃសង្គ្រាម» បន្ទាប់ពីដណ្តើមអំណាចបានរួចមក ។ ពួកនេះធ្លាប់បានសាកល្បងលុបបំបាត់ភាព ខុសគ្នារបស់វណ្ណៈ ដោយការធ្វើជាតូបនីយកម្មភ្លាមជាបន្ទាន់មួយ ។ ការវិនិច្ឆ័យរបស់លោក អ៊ីហ្សាអាក់ ដឺតឈ័រ (Isaac Deutscher) ស្តីពីសម័យកាលដ៏ខ្លីនៃការបដិវត្តរបស់រុស្ស៊ីនេះ ថាមានលំនាំដូចគ្នាបេះបិទនឹងលក្ខណៈ នៅកម្ពុជាប្រជាធិបតេយ្យរបស់ខ្មែរក្រហមដែរៈ

«នយោបាយកុម្មុយនិស្តនៃសង្គ្រាម ជាការគ្រោប់ធ្វើតាមនាំឲ្យមានអន្តរាយមួយនូវទស្សនៈ ម៉ាក្សស៊ីសនិយមអំពីសង្គមអនាគត ។ សង្គមនេះត្រូវតែពឹងផ្អែកលើធនធានបង្កើតផលទាំងឡាយ ដែលត្រូវធ្វើឲ្យលូតលាស់

ក្នុងកម្រិតខ្ពស់មួយ និងចាត់ចែងរៀបចំឲ្យបានត្រឹមត្រូវព្រមទាំងផ្នែកលើភាពសម្បូរហូរហៀរមួយផ្នែកភោគទ្រព្យ និងសេវាកម្មផង... ដើម្បីលុបបំបាត់វិសមភាពខាងសេដ្ឋកិច្ច ដោយធ្វើឲ្យកម្រិតជីវភាពរស់នៅស្មើគ្នាតាំងពីថ្នាក់លើមក ។ នយោបាយកុម្មុយនិស្តនៃសង្គ្រាមចាប់កំណើតឡើងបញ្ច្រាសនឹងការធ្វើឲ្យសង្គមបែកខ្ញែក បង្កឡើងដោយការអត់ឃ្លានសម្បើមមួយពុំដែលមានពីមុនមកសោះ... ។ គេខំប្រឹងលុបបំបាត់វិសមភាពពិតមែន ប៉ុន្តែ គេអនុវត្តដោយប្រើអំណាចបង្ខិតបង្ខំ ដើម្បីធ្វើឲ្យជីវភាពរស់នៅស្មើគ្នាពីថ្នាក់ក្រោមទៅវិញ និងធ្វើឲ្យភាពក្រីក្រតោកយ៉ាកមានជាទូទៅ...[២០]» ។

ពួកសូវៀតបានបោះបង់ចោល «នយោបាយកុម្មុយនិស្តនៃសង្គ្រាម» របស់គេយ៉ាងឆាប់រហ័ស ដើម្បីប្រកាន់យក «នយោបាយសេដ្ឋកិច្ចថ្មី»មួយ ដែលមានលក្ខណៈសមស្របជាង ។

ពួកខ្មែរក្រហម មានទ្រឹស្តីមិនសូវជឿនលឿនមួយនៅខាងក្រោយប្រព័ន្ធសហករណ៍របស់គេ ដែលប្រែទៅជា«ជំរំពលកម្ម»ទាំងអស់ ។ ដូចសម្តេច ព្រះនរោត្តម សីហនុ ដែរ បណ្តាមេដឹកនាំកុម្មុយនិស្តជឿថា ជនបទខ្មែរគឺជាប្រភពសំបូរទៅដោយធនធានមួយ ដែលមិនទាន់មានគេធ្វើអាជីវកម្ម ព្រោះពួកគេបានធ្វើតាមក្បួនដើមជាច្រើនរបស់ព្រះអង្គ ។ ប៉ុន្តែ ជាជាងវាយតម្លៃប្រជាកសិករថាជាមនុស្ស«ខ្ជិលច្រអូស» ដូចពួកបារាំង ឬ«កូនចៅ» ដូចសម្តេច ព្រះនរោត្តម សីហនុ ធ្លាប់ហៅ ពួកខ្មែរក្រហមយល់ឃើញតាមធម្មតាថា កសិករទាំងនោះមិនដឹងផលប្រយោជន៍ផ្ទាល់របស់គេស្ថិតនៅទីណាតែប៉ុណ្ណោះ ។ ប្រជាកសិករនឹងធ្វើការរឹតតែខ្លាំងឡើងថែមទៀត បើសិនជាពួកគេក្លាយទៅជាភាគីពាក់ព័ន្ធដោយផ្ទាល់ នៃអនាគតរបស់គេតាមរយៈ«ប្រព័ន្ធសង្គមនិយម»មួយ ដែលគ្មានកម្មសិទ្ធិដីធ្លីផ្ទះសម្បែង គ្មានអ្នកយកការប្រាក់ហួសកំណត់ គ្មានកម្មសិទ្ធិឯកជន គ្មានទ្រព្យសម្បត្តិផ្ទាល់ខ្លួនម្នាក់ៗ ជាមួយនឹងទស្សនវិស័យក្នុងការកសាងប្រទេសកម្ពុជាទាន់សម័យ និងថ្កុំថ្កើងរុងរឿងមួយ ។ ដោយជម្រុះចោលនូវសតិអារម្មណ៍ដែលនាំឲ្យឃ្លាតចេញពីគោលដៅ ដូចជាសាសនា ឬការជាប់ជំពាក់នឹងផលប្រយោជន៍គ្រួសារ កសិករទាំងនោះអាចនឹងលះបង់ពេលវេលាទាំងអស់របស់ខ្លួនទៅធ្វើការនៅតាមវាលស្រែចម្ការ និងតាមរោងចក្រ ដោយមិនចាំបាច់ទៅទិញត្រី បន្លែបង្ការ មិនចាំបាច់ធ្វើកិច្ចការក្នុងផ្ទះ ដាំស្ល និងព្រួយបារម្ភពីបញ្ហាចិញ្ចឹមកូនចៅឡើយ ។ ប្រទេសជាតិនឹងស្គាល់នូវអព្ភូតហេតុផ្នែកសេដ្ឋកិច្ចមួយដ៏អស្ចារ្យ ។ ការរុះរើរៀបចំរចនាសម្ព័ន្ធជាថ្មីយ៉ាងម៉ឺងម៉ាត់ និងការធ្វើឲ្យសង្គមបាន«ទំនើ»នេះ និងធ្វើឲ្យសក្តានុពល ដែលកប់ក្នុងប្រជាជនចេញមកក្រៅបានទាំងអស់នេះ គ្រាន់តែជាកិច្ចការរៀបចំចាត់ចែង និងតម្រង់ទិសដៅប៉ុណ្ណោះ ។

ពួកខ្មែរយល់ឃើញថាខ្លួនជាអ្នកឈានមុខគេខាងទំនើបនិយម ហើយគ្រោងធ្វើឲ្យបានសម្រេចតែក្នុងរវាងពីរ-បីឆ្នាំប៉ុណ្ណោះ នូវការផ្លាស់ប្តូរផ្សេងៗ ដែលបណ្តាសង្គមបស្ចិមប្រទេសធ្លាប់បានស្គាល់ក្នុងរយៈពេលជាច្រើនសតវត្សរ៍មកហើយនូវការបដិវត្តន៍ខាងវិស័យឧស្សាហកម្ម ៈ ការលុបបំបាត់មិនឲ្យមានសាសនា ការចាត់ចែងផ្នែកផលិតកម្មឲ្យបានរីកចម្រើនដោយឲ្យអស់សោហ៊ុយតិចបំផុត ការប្រែក្លាយប្រជាជនជនបទមួយ ដែលមាន

គំនិតសក្តិភូមិឲ្យទៅជាហត្ថពលករ ប្រកបដោយគុណសម្បត្តិគ្រប់គ្រាន់ និងមានការរៀបចំត្រឹមត្រូវ ហើយនៅទីបំផុត ការធ្វើឧស្សាហូបនីយកម្មមួយ ដែលត្រូវពង្រីកថែមទៀតជាជាងបំផ្លាញភាពសម្បូរខាងផ្នែកកសិកម្មរបស់កម្ពុជា ។ ពួកខ្មែរក្រហម មានជំនឿទុកចិត្តមួយបែបនេះចំពោះប្រភពធនធានផ្សេងៗរបស់ជនបទ ដែលពួកគេគិតឃើញថា ជនបទនេះនឹងជួយទ្រទ្រង់ប្រទេសក្នុងរយៈពេលនៃរដូវកាលបន្តបង្កើនផល ដោយល្បងឲ្យដឹងថា ពួកគេបានរៀបចំប្រុងប្រៀបសម្រាប់ការបដិវត្តដំណាក់កាលទីពីរ រួចស្រេចហើយ ។

តាមផែនការនេះ កម្ពុជាប្រជាធិបតេយ្យនឹងក្លាយទៅជាប្រទេសទំនើបទាន់សម័យ និងរុងរឿងមួយនៅឆ្នាំ ១៩៩០ ជាមិនខាន ហើយគេត្រូវសម្រេចស្នាដៃនេះឲ្យបានក្នុងសភាពឯកោមួយទាំងស្រុង ផុតពីការផ្លាស់ប្តូរនៃសេដ្ឋកិច្ចពិភពលោក និងការគំរាមកំហែងនៃការឈ្លានពានមួយរបស់បរទេស ។ ដោយត្រូវបដិវត្តរបស់ខ្លួនទំនុកបម្រុងយ៉ាង នៅពេលនោះប្រទេសកម្ពុជានឹងលេចឡើង ក្នុងឋានៈជាអព្ភូតហេតុគួរឲ្យភ្ញាក់ផ្អើល នៅសតវត្សរ៍ទី ២០ នេះ ។

នៅពេលដែលបក្សអនុម័តកម្មវិធីនេះជាផ្លូវការនៅខែមករា ឆ្នាំ១៩៧៦ បក្សបានដាក់មនុស្ស ដែលគួរទុកចិត្តឲ្យទទួលការងារគ្រប់គ្រងដឹកនាំខាងផ្នែកឧស្សាហកម្ម និងកសិកម្ម ។ កម្មាភិបាលទាំងនោះ បានរៀបចំកម្មវិធីសមូហភាវូបនីយកម្មទូទាំងប្រទេសតាមផែនការរបស់បក្ស ៖ ផ្ទះបាយរួម របៀបរៀបចំបង្កើតកងការងារ ដើម្បីបញ្ជូនមនុស្សឲ្យទៅចូលរួមធ្វើកិច្ចការធំៗ និងដោះស្រាយបញ្ហាទឹកក្នុងទូទាំងប្រទេស ។ គេសង្ឃឹមថា ប្រជាជនកម្ពុជានឹងកសាងទំនប់ទឹកធំតូច ប្រឡាយទឹក ភ្លឺស្រែយ៉ាងគ្រប់គ្រាន់ដោយបាតដៃទទេ ដើម្បីស្រោចស្រពផ្ទៃដីស្រែប្រហែលប្រាំរយពាន់ហិកតា តែក្នុងមួយឆ្នាំប៉ុណ្ណោះ ។ រោងចក្រថ្មីៗ រោងចក្រធ្វើស៊ីម៉ង់ត៍ រោងចក្រចម្រាញ់ប្រេងកាត ត្រូវបានគេគ្រោងទុកជាមុនដែរ ហើយគេត្រូវបង្កើតពូជស្រូវថ្មីៗទៀត ដែលអាចធន់ទ្រាំនឹងជំងឺបាន ។ តាមគេអះអាងថា យ៉ាងហោចគេគោងតែបង្កើនចំនួនប្រជាជនទ្វេមួយជាពីរ ដើម្បីឲ្យមានហត្ថពលករ រឹតតែច្រើន ។

ប៉ុល ពត បានបំភ្លឺថា គោលដៅរបស់យើងគឺ «ធ្វើឲ្យកម្ពុជា ដែលជាប្រទេសកសិកម្មអន់ថយទៅជាប្រទេសប្រកបដោយមូលដ្ឋានឧស្សាហកម្មមួយក្នុងរយៈពេលជាកំណត់មួយពីដប់ប្រាំ ទៅម្ភៃឆ្នាំ ។ គោលដៅនេះ សំដៅបង្កើតលក្ខខ័ណ្ឌផ្សេងៗសម្រាប់ប្រទេសឧស្សាហកម្មមួយ ដោយបំពាក់ឲ្យកម្ពុជានូវឧស្សាហកម្មធុនស្រាលមួយ រោងចក្រធ្វើម្ហូបអាហារមួយ រោងចក្ររំលាយលោហធាតុមួយ រោងចក្រធ្វើគ្រឿងយន្តមួយ រោងចក្រអគិសនីមួយ រោងចក្រចម្រាញ់ប្រេងកាតមួយ និងរោងចក្រគីមីមួយ[២១] » ។

គាត់បានបកស្រាយពីរបៀប ដែលបក្សបានគ្រោងធ្វើឲ្យប្រទេស "អន់ថយ" នេះ សម្រេចឈានដល់គោលដៅទាំងឡាយដ៏គួរឲ្យស្រឡាំងកាំងនាពេលខាងមុខ ដោយគ្មានជំនួយបរទេស ៖ "ដើម្បីធ្វើឲ្យសម្រេចគោលដៅនេះ... យើងត្រូវស្តាបនារោងសិប្បកម្មឲ្យបានច្រើន នៅតាមភូមិភាគ តំបន់ ស្រុក និងសហករណ៍នានា ។

យើងបានចាត់ការធ្វើយ៉ាងណាឲ្យទាល់តែរោងសិប្បកម្មទាំងនោះ ក្លាយទៅជារោងចក្របន្តិចម្តងៗក្នុងពេលអនាគត ។ ដូច្នេះយើងទាំងអស់គ្នា ត្រូវខិតខំពង្រីកវិស័យសិប្បកម្ម និងឧស្សាហកម្មឲ្យបានគ្រប់ទីកន្លែងនៅទូទាំងប្រទេស[២២] » ។

« តើយើងទៅរកដើមទុនពីទីណាមក ដើម្បីកសាងឧស្សាហកម្មរបស់យើង? ដើមទុនរបស់យើង បានមកជាសំខាន់ពីការធ្វើការងាររបស់ប្រជាជនយើង ។ តាមរយៈការងាររបស់គាត់ ប្រជាជនយើងនឹងធ្វើឲ្យផលិតផលកសិកម្មរីកលូតលាស់... ។ យើងនៅមានប្រភពទុនយ៉ាងសំខាន់មួយទៀត គឺយើងពុំមានផ្តល់ប្រាក់ឈ្នួលឲ្យពួកអ្នកទាំងនោះឡើយ ។ ការគ្មានផ្តល់ប្រាក់ឈ្នួល គឺជាប្រភពនៃការសន្សំដើមទុនមួយយ៉ាងធំដោយខ្លួនឯងផ្ទាល់[៣៣] » ។

តាមបែបផែននៃការគ្រប់គ្រងដ៏ជ្រុលហួសហេតុរបស់គេ ពួកខ្មែរក្រហមបានគ្រាប់ធ្វើតាមឡើងវិញ នូវបទពិសោធន៍ផ្សេងៗ ដែលផ្តើមអនុវត្តដោយ ស្តាលីន និង ម៉ៅ សេទុង ក្នុងប្រទេសរៀងៗខ្លួន នៅថ្ងៃបន្ទាប់ នៃការបដិវត្ត ។ ពួកគេបានធ្វើតាមគំនិតពួកកុម្មុយនិស្តវៀតណាមមួយចំនួនធំដែរ ទោះបីជាអំនួតរបស់ពួកគេសឲ្យឃើញយ៉ាងច្បាស់ថា ពួកគេមានបំណងបង្កើតគំនិតថ្មីៗក៏ដោយ ។ ប៉ុល ពត បានទទួលស្គាល់តែមួយដងគត់ថា គំនិតរបស់ ម៉ៅ សេទុង គឺជាប្រភពផ្តល់យោបល់មួយសម្រាប់រូបគាត់ ។

ស្តាលីន បានផ្តើមការបដិវត្តទីពីរ និងកម្មវិធីរបស់គាត់ ជាបន្ទាន់សម្រាប់វិស័យកសិកម្ម និងឧស្សាហកម្ម ជាមួយនឹងការអំពាវនាវជាលើកដំបូងរបស់សូវៀត ចំពោះអ្នកជាតិនិយមរុស្ស៊ីដែលកំពុងបំផ្លាញ ប្រពៃណីម៉ាក្សស៊ីស ដែលមានរួចមកហើយ ហើយបើកផ្លូវទៅរកសង្គ្រាម និងការបដិវត្តនៅពេលខាងមុខ ដែលនឹងត្រូវដឹកនាំធ្វើក្នុងនាមនៃការរំដោះជាតិ ។ « នៅពេលដែល ស្តាលីន បង្ហាញកម្មវិធីរបស់គាត់ចំពោះប្រជាជន ដែលទាមទារឲ្យមានការប្រឹងប្រែង និងការលះបង់ គាត់អាចបកស្រាយបំភ្លឺត្រឹមតែពាក្យពេចន៍ថា នេះជាភាពចាំបាច់ខាងសេដ្ឋកិច្ចដែលយើងត្រូវតែធ្វើជាបន្ទាន់ប៉ុណ្ណោះ ។ ជាលើកដំបូងហើយ ដែលគាត់បានអំពាវនាវជាចំហចំពោះនិន្នាការជាតិនិយម និងសង្គមនិយមរបស់ប្រជាជនជាមួយគ្នា[២៤] » ។

នៅឆ្នាំ១៩៣១ ស្តាលីន បានថ្លែងប្រកាសក្នុងសុន្ទរកថាមួយថា « ប្រទេសរុស្ស៊ីធ្លាប់ត្រូវគេវាយប្រហារគ្មានឈប់ឈរ ពីព្រោះខ្លួនជាប្រទេសអន់ថយ ។ ត្រូវវាយប្រហារដោយពួកខាន់ម៉ុងហ្គោល ពួកប៊ី ទួរគី ពួកស្តេចត្រាញ់សក្តិភូមិនៅប្រទេសស៊ុយអែដ ពួកប៉ង់នៅប្រទេសប៉ូឡូញ និងលីទុយអានី ពួកមូលធនអង់គ្លេស-បារាំង ពួកអភិជនជប៉ុន -ប្រទេសរុស្ស៊ី ត្រូវគេវាយសម្រុកពីគ្រប់ទិសទី ពីព្រោះខ្លួនជាប្រទេសអន់ថយ គឺអន់ថយទាំងវិស័យយោធា វប្បធម៌ នយោបាយ ឧស្សាហកម្ម កសិកម្ម... ។ យើងនៅមានភាពយឺតយ៉ាវជាងបណ្តាប្រទេសឧស្សាហកម្មនានាពីហាសិបឆ្នាំទៅមួយរយឆ្នាំ ដូច្នេះយើងត្រូវបំពេញភាពយឺតយ៉ាវនេះឲ្យបានក្នុងរយៈពេលដប់ឆ្នាំ ។ ឬមួយយើងត្រូវធ្វើកិច្ចការនោះឲ្យបានសម្រេចជោគជ័យ ឬមួយពួកគេនឹងកម្ទេចពួកយើង[២៥] » ។

ស្តាលីន បានចាត់ទុកកម្មវិធីរបស់គាត់ថាជា « ការវាយសម្រុករបស់សង្គមនិយមទៅលើរណសិរ្សទាំង

អស់» ជា«សង្គ្រាមគ្មានប្រណីមេត្តា» ជា«នយោបាយរបស់វណ្ណៈ ដែលគ្មានមេត្តា[២៦]» ហើយគាត់បានបង្កើតកងពលករសម្រាប់បំពេញបេសកកម្មនៅទីកន្លែងដែលប្រកបដោយគ្រោះថ្នាក់ខ្លាំងជាច្រើនកងពល ។ ផែនការរបស់គាត់ក៏តម្រូវឲ្យមានការផ្លាស់ប្តូរទីលំនៅទាំងបន្ទុំរបស់ប្រជាជន ។ អាស្រ័យដោយអំណាចនៃការសម្រេចចិត្តតែមួយប៉ុណ្ណោះ ប្រជាកសិករចំនួនមួយលាននាក់ និងគ្រួសាររបស់គេ បានបាត់បង់ដីធ្លី និងទ្រព្យសម្បត្តិទាំងអស់ ។ មនុស្សរាប់រយពាន់នាក់ ត្រូវគេបណ្តេញចេញពីទីក្រុងធំៗ ហើយបញ្ជូនឲ្យទៅធ្វើការនៅតាមជនបទ នៅការដ្ឋានសាងសង់រោងចក្រ ឬនៅកសិដ្ឋានផ្សេងៗ ។

ការបដិវត្តខាងឧស្សាហកម្មរបស់ស្តាលីន បានទទួលនូវលទ្ធផលមួយ ដែលនាំមកនូវមហន្តរាយយ៉ាងធំ គឺទុរភិក្ស ការរៀបចំបង្កើតអង្គការនានារបស់រដ្ឋសម្រាប់គាបសង្កត់ប្រជាជន ។ គ្រោះអត់ឃ្លាន គឺជាផលវិបាកនៃរបៀបចាត់ចែងមិនល្អរបស់ប្រទេស និងការបដិសេធរបស់កសិករមិនព្រមបង្កបង្កើនផល ក្រោមរបបគ្រប់គ្រងថ្មីៗ ហើយគឺគ្រោះអត់ឃ្លាននេះឯង ដែលជំរុញឲ្យ ស្តាលីន បោះបង់ចោលការសាកពិសោធន៍ជ្រុលហួសហេតុរបស់គាត់នោះ ។ ការប្រើអំពើឃោរឃៅគាបសង្កត់ ជាការឆ្លើយតបចំពោះការលួចសម្លាប់មេដឹកនាំម្នាក់ គឺចេញមកបរាជ័យផ្សេងៗ ដែលខ្លួនបានទទួលរង ព្រមទាំងការប៉ុនប៉ងកម្ចាត់ចោលនូវជនទាំងឡាយ ដែលគេចាត់ទុកជាឧបសគ្គដល់ជោគជ័យនៃគម្រោងការរបស់គេនៅក្នុងមហាជន និងក្នុងឋានានុក្រមបក្ស ។

ម៉ៅ សេទុង បានដាក់ប្រើនយោបាយ «មហាលោតផ្លោះ» របស់គាត់សាមសិបឆ្នាំក្រោយមកទៀត ហើយពិតណាស់ពួកកម្ពុជាបានយកបទពិសោធន៍របស់ចិននេះមកធ្វើជាគំរូដោយគ្មានខុសត្រង់ណាបន្តិចសោះ ។ ពួកចិនជឿដូចពួកខ្មែរដែរថា បើសិនជាប្រជាជនខិតខំធ្វើការពេញទំហឹង បើសិនជាគេរៀបចំប្រជាជនទៅជាសហគមន៍ធំៗ ដោយរ៉ាប់រងក្នុងការបំពេញសេចក្តីត្រូវការផ្សេងៗឲ្យអ្នកទាំងនោះបានគ្រប់គ្រាន់ ប្រទេសជាតិនឹងអាចជំរុញវិស័យឧស្សាហកម្ម និងកសិកម្មទៅដល់កម្រិតទាន់សម័យមួយ ដោយនាំមកវិញនូវការរីកលូតលាស់ជាច្រើនទសវត្សរ៍ មកធ្វើត្រឹមតែពីរ–បីឆ្នាំប៉ុណ្ណោះ ។ ពួកចិនជឿថា សំខាន់បំផុត គឺការចាត់ចែងរៀបចំ និងការតម្រង់ផ្លូវត្រូវដើរឡើងវិញ ដែលកំណត់ដោយរដ្ឋអំណាច ពុំមែនលទ្ធផលនៃការផ្លាស់ប្តូរខាងវិទ្យាសាស្ត្រ និងការធ្វើផែនការដ៏សាំញ៉ាំមួយឡើយ ។ តាមការមើលឃើញរបស់ពួកគេថា ការពិនិត្យពិច័យខាងបច្ចេកវិជ្ជា វាបានត្រឹមតែជាឧបសគ្គប៉ុណ្ណោះ ។

ប្រវត្តិវិទូម្នាក់បានអធិប្បាយរៀបរាប់ពីស្ថានភាពស្មុគស្មាញ និងច្របូកច្របល់ ដែលបង្កឡើងដោយនយោបាយមហាលោតផ្លោះរបស់ចិនថា ៖ «នៅឆ្នាំ១៩៦៨ មនុស្សជាងមួយរយលាននាក់ បានត្រូវគេកេណ្ឌឲ្យទៅស្ថាបនាទំនប់ទឹក អាងស្តុកទឹក និងប្រព័ន្ធធារាសាស្ត្រផ្សេងៗ ។ ភាគច្រើននៃការងារទាំងនោះ ជាគម្រោងការតូចតាច ដែលគេបានអនុម័តទាំងតក្កហល ដោយគ្មានការពិនិតសិក្សាឲ្យបានត្រឹមត្រូវជាមុន ព្រមទាំងគ្មានផែនការសម្រាប់អនុវត្តឲ្យសមស្របតាមសភាពជាក់ស្តែងផងទេ ។ ក្នុងរយៈសម័យកាលនេះ មធ្យោបាយធម្មតាក្នុងការ

ស្ថាបនាបានត្រូវគេកែប្រែ ដើម្បីចំពេញពេលវេលាដូចគ្នានឹងការស្ថាបនាសំណង់ធំៗ ។ មធ្យោបាយការពារសន្តិសុខដែលគេយល់ថា ជា«ការប្រតិបត្តខុសឆ្គង» ត្រូវបានបោះបង់ចោល[២៧] » ។

គេបានលួចក្លែងបន្ទំស្ថិតិផ្សេងៗ ដើម្បីបង្ហាញឲ្យឃើញថា បទពិសោធន៍នេះទទួលបានជោគជ័យមែន ។ ពួកមេដឹកនាំក្រុងប៉េកាំងបានជឿទៅលើតួលេខបំភាន់ទាំងនេះ ហើយបានតម្រូវឲ្យមានការបង្កើនមួយខាងផ្នែកផលិតផល និងការដំឡើងភាគរយមួយខាងផ្នែកកសិកម្ម ។ ក្នុងទូទាំងប្រទេស គេបានស្ថាបនាឡរំលាយដែកនៅតាមទីធ្លាក្រោយផ្ទះប្រជាជន ដើម្បីផលិតដែកថែប គឺជាតម្រុញនាំមុខមួយនៃ «រោងសិប្បកម្ម» របស់ ប៉ុល ពត សម្រាប់ផលិតប្រដាប់ប្រដាប្រើប្រាស់ និងសម្ភារបរិក្ខារចាំបាច់ផ្សេងៗ ។ តំបន់ដីធំល្វឹងល្វើយនៅតាមជនបទត្រូវគេកាប់ដើមឈើខ្ទេចខ្ទី ដើម្បីយកទៅធ្វើអុសដុតសម្រាប់ឡស្លដែកជាន់ដើមនេះ ។ ផលិតផលដែលធ្វើនៅក្នុងរោងចក្ររបស់ចិនក៏ត្រូវបាត់បង់គុណភាពរបស់ខ្លួន ។ នយោបាយមហាលោតផ្លោះ ត្រូវចប់យ៉ាងរហ័សនៅពេលដែលស្រមោល នៃគ្រោះអត់ឃ្លានបានគ្របដណ្តប់មកលើប្រជាជន ហើយដែលពួកមេដឹកនាំគោងតែវាយតម្លៃពី«ជោគជ័យ»របស់ពួកគេឡើងវិញ ។

ដំណើរប្រែក្រឡាស់ខាងផ្នែកសេដ្ឋកិច្ចទាំងអស់នេះ បានធ្វើឲ្យប្រជាជនចិនខូចទឹកចិត្តមិនអន់ជាងការធ្វើរៀបចំជាសហគមន៍ឡើយ ។ បើទុកជាប្រជាជនចិនរស់នៅជួបជុំគ្នាក៏ដោយ ក៏ប្តី និងប្រពន្ធកម្របានជួបមុខគ្នាណាស់ ពីព្រោះអ្នកទាំងពីរទៅធ្វើការវេនរម្ទងៗរាប់ម៉ោង ។ ម្យ៉ាងទៀត ពួកគេក៏មិនសូវបានជួបមុខកូនៗរបស់ខ្លួនដែលរស់នៅកន្លែងសម្រាប់ថែទាំក្មេង ឬនៅសាលារៀនពេញៗមួយថ្ងៃនោះដែរ ។ ការកាត់ផ្តាច់ចំណងទាក់ទងគ្រួសារ គឺជាទុក្ខវេទនាមួយក្នុងចំណោមទុក្ខវេទនា ដែលលំបាកទ្រាំទ្រជាងគេបំផុត ។

នៅប្រទេសចិន ការសម្លាប់មនុស្សបានប្រព្រឹត្តឡើងក្រោយពីការធ្វើអ្វីមួយមិនបានសម្រេចជោគជ័យដូចគ្នា ។ គេមិនដឹងពីចំនួនអ្នករងគ្រោះថាមានប៉ុន្មានទេ ប៉ុន្តែ ប្រជាជនចិនច្រើនឥតគណនាបានត្រូវគេសម្លាប់ចាប់ដាក់គុក បញ្ជូនទៅដាក់ក្នុងជំរំពលកម្មផ្សេងៗ ។ តាមប្រវត្តិវិទូម្នាក់បានឲ្យដឹងថា «សន្តិសុខផ្ទាល់របស់បុគ្គលម្នាក់ៗត្រូវគំរាមកំហែងជាប់ជាប្រចាំ គេត្រូវស្ថិតនៅក្រោមបរិយាកាសអសន្តិសុខដ៏គ្មានតឹងមួយ និងការគាបសង្កត់មួយ[២៨] » ។

ទាំងហ្នឹងហើយ ជាមេបន្តពូជពីរ ដែលជាអ្នកផ្តល់កំណើតដល់គោលដៅនៃការបដិវត្តចុងក្រោយបំផុតរបស់ពួកខ្មែរក្រហម ។ លក្ខណៈផ្សេងៗទៀត ត្រូវបានចម្លងធ្វើតាមពួកវៀតណាម ឬដកស្រង់ចេញពីប្រភពមួយរបស់ចិនតាមរយៈពួកវៀតណាម ជាពិសេសដូចជារបៀបនិយាយ ឬសរសេរ ការរៀបចំផ្នែកការិយាធិបតេយ្យ និងគំនិតផ្សេងៗមានគំនិតខាងការអប់រំកែប្រែថ្មីជាដើម ។ បដិវត្តន៍វប្បធម៌ដែលបង្ហិនប្រទេសចិន នៅពាក់កណ្តាលទសវត្សរ៍១៩៦០ បានធ្វើឲ្យពួកខ្មែរក្រហមផុសគំនិត ដោយផ្អែកនូវការស្អប់ខ្ពើមរបស់គេចំពោះនិន្នាការនិយមបញ្ញាជាធំ និងការថ្កោលទោសរបស់គេចំពោះ «វប្បធម៌វណ្ណៈគហបតី» ។ ហេតុការណ៍ដែលគួរឲ្យ

កត់សម្គាល់ គឺពួកកុម្មុយនិស្តខ្មែរ បានវិនិច្ឆ័យដោយពេញចិត្តចំពោះការបដិវត្តរបស់កូរ៉េខាងជើង ដែលបង្ហាញឲ្យឃើញលក្ខណៈសម្គាល់ដោយការនិយមប្រើអំណាចផ្តាច់ការមួយដែលលំបាកតម្រូវចិត្ត និងទស្សនៈខ្លួនទបត្ថម្ភខ្លួនដូចគ្នាមួយ ដែលជំរុញទៅរកការផប់ផល់តែនឹងទ្រឹស្តី ឬលទ្ធិមួយយ៉ាងហួសហេតុ ដោយលែងគិតពិចារណាអ្វីទាំងអស់ ។

ក្នុងប្រវត្តិសាស្ត្ររបស់កម្ពុជា វាមានទម្លាប់ធ្លាប់មានពីមុនមកជាច្រើនដែលទម្លាប់ខ្លះ មានលក្ខណៈខ្លះសាហាវឃោរឃៅ និងគួរឲ្យព្រឺខ្លាចដូចរបបខ្មែរក្រហមបានប្រព្រឹត្តដែរ[២៩] ។ គេអាចរាប់បញ្ចូល ស្តាលីន, ម៉ៅ និងព្រះរាជាមួយអង្គ នៅសតវត្សរ៍ទី១៣ គឺជ័យវរ្ម័នទី៧ ក្នុងប្រភេទតែមួយ ដែលយ៉ាងហោចអ្នកទាំងនេះគឺជាអ្នកឲ្យគម្រុយម្នាក់ខាងផ្នែកចិត្តគំនិតដល់បណ្តាមេដឹកនាំកុម្មុយនិស្តទាំងនេះ ។

សិលាចារឹកបុរាណមួយបានរៀបរាប់ថា នៅពេលដែលការស្ថាបនាអង្គរធំ -រាជធានីថ្មីរបស់ជ័យវរ្ម័នទី៧- សាងសង់បានពាក់កណ្តាលហើយនោះ ព្រះអង្គបានប្រើប្រាស់ក្នុងគម្រោងនេះនូវកម្មករចំនួន៣០៦.៣៧២ នាក់ ដោយឲ្យស្នាក់នៅក្នុងភូមិចំនួន ១៣.៥០០ ដែលគេបានកសាងឡើង ដើម្បីឲ្យសម្រេចគោលដៅនេះ ។ ក្នុងផ្នែកផ្សេងៗទៀតរបស់ព្រះរាជាណាចក្រ កងការងារជាច្រើនក្រុម បានកសាងផ្លូវថ្នល់ថ្មីៗ ព្រះវិហារ និងកន្លែងទីសក្ការៈតូចៗ និងមន្ទីរពេទ្យថ្មីជាងមួយរយកន្លែង ។ កម្មវិធីក្នុងការសាងសង់របស់ព្រះអង្គ ជាកម្មវិធី«គ្មានសមស្របសេះដោយភាពធំសម្បើមនៃសំណង់ ដោយការរហន់កសាង និងការមិនយកចិត្តទុកដាក់ ជាមួយនឹងបញ្ហាទាំងនេះហើយ ដែលព្រះអង្គត្រូវធ្វើឲ្យសម្រេចពិតប្រាកដ[៣០]» ។

ប្រវត្តិវិទូ ហ្សក សឺដេស (Georges Coedès) ដែលជាអ្នកស្រាវជ្រាវខាងប្រវត្តិសាស្ត្រខ្មែរបានសរសេរថា ជ័យវរ័ន្មទី៧ ជា«ព្រះរាជាឆ្គួតនឹងយសសក្តិមួយអង្គ ដែលលក្ខណៈខ្លះខ្លាយយ៉ាងច្រើនហួសហេតុរបស់ព្រះអង្គ គឺជាបុព្វហេតុមួយក្នុងចំណោមបុព្វហេតុជាច្រើននៃការធ្លាក់ចុះអាប់ឱនរបស់ប្រទេសរបស់ព្រះអង្គ ។ គេគោងតែនឹកក្នុងចិត្តពីកងទ័ពជាងជាច្រើននាក់ ដែលកំពុងខំប្រឹងធ្វើការយ៉ាងហួសកម្លាំងលើជម្រាលភ្នំ ក្រុមអ្នកលីសែងកំពុងអូសដុំថ្មធំៗ ពួកជាងកំបោរកំពុងរៀបចំដុំដុំថ្មទាំងនោះ ជាងចម្លាក់ និងជាងរចនាកំពុងផ្ចិតផ្ចង់ការងាររៀងៗខ្លួន ។ មនុស្សដូច ហ្វូងស្រមោចទាំងនេះ ពុំមែនផុសគំនិតមកធ្វើការងារ ដោយសារមានជំនឿរួមមួយនោះទេ… ប៉ុន្តែ គឺត្រូវគេកេណ្ឌឲ្យមកធ្វើការដោយជ្រើសរើសយកតែអ្នកដែលមានអាយុត្រូវធ្វើទាហាន ដើម្បីស្ថាបនាវិមានធំៗខទ្ទិសដល់កិត្តិនាមដ៏ល្បីល្បាញនៃព្រះមហាក្សត្ររបស់ពួកគេ[៣១]» ។

ប្រាំពីរសតវត្សរ៍ក្រោយមក ពួកខ្មែរក្រហមបានបង្កើតទស្សនីយភាពរស់រវើកដដែលនេះឡើងវិញ ដោយឲ្យប្រជាជនទាំងអស់ធ្វើការដូចពួកទាសករក្រោមអំណាចរបស់អង្គការ ដើម្បីកសាងសំណង់ទំនើបទាន់សម័យសម្រាប់មេដឹកនាំរបស់ពួកគេ ។ ក្រោមការគ្រប់គ្រងរបស់ពួកខ្មែរក្រហម ពួកកម្មករនឹងរស់នៅជាថ្មី ក្នុង«ជំរំ

ពលកម្ម»ជាច្រើន ហើយនឹងទទួលរបបអាហារប្រចាំថ្ងៃយ៉ាងអត្តខាត់បំផុត ។ ពួកគេនឹងត្រូវបង្ខំឲ្យកសាងប្រព័ន្ធភ្លឺស្រែមួយ ដែលពិបាកយល់សំដៅជុំវិញប្រទេសកម្ពុជា ឲ្យឆ្ពោះទៅរកអនាគតដ៏រុងរឿងមួយ ដោយយកតម្រាប់តាមរបៀបដឹកនាំធ្វើពីអតីតកាលទាំងអស់ ។ ដោយគ្មានអត្ថន័យជាការពេបជ្រាយណាមួយ ពួកខ្មែរក្រហមខំប្រឹងបង្ហាញឲ្យឃើញដោយចេតនាថា របបរបស់គេជាអ្នកទទួលមរតកដោយផ្ទាល់ពីសម័យអង្គរមក ដូចដែលការផ្សាយរបស់វិទ្យុរបស់របបនេះបានថ្លែងឲ្យដឹងពីរឿងនេះដែរថា ៖

«ដោយសិក្សាស្រាវជ្រាវពីអារ្យធម៌ សិល្ប ស្ថាបត្យកម្ម របស់កម្ពុជា យើងទាំងអស់គ្នាដឹងថា ប្រជាជនកម្ពុជាមានទឹកចិត្តតស៊ូក្នុងការងារជានិច្ច ជាពលករដែលមានសមត្ថភាពច្នៃប្រឌិតខ្ពស់ និងប៉ិនប្រសប់... ។ ដោយសម្លឹងមើលប្រាសាទអង្គរ អង្គរធំ និងប្រាសាទ ដែលនៅព័ទ្ធជុំវិញទីនោះ យើងទាំងអស់បានត្រូវធ្វើឲ្យភ្លឹកភ្លាំងនឹងហេតុការណ៍ដែលមានពិតថា តំបន់ទាំងអស់នេះជាទីក្រុងមួយយ៉ាងធំកាត់ខ្វាត់ខ្វែងទៅដោយផ្លូវថ្នល់ត្រង់ភ្លឹងៗ និងប្រឡាយទឹកយ៉ាងច្រើនស្ថិតក្នុងក្របខ័ណ្ឌនៃរបៀបចាត់ចែងដ៏អស្ចារ្យមួយ... ដែលកសាងឡើងគ្មានទាស់ត្រង់ណាបន្តិចសោះ ហើយបានធ្វើឲ្យសម្រេចឡើងប្រកបដោយភាពជាក់លាក់ និងការយកចិត្តទុកដាក់យ៉ាងមុតមាំបំផុត... ។ ប៉ុន្តែ ប្រជាជាតិ និងប្រជាជនកម្ពុជាយើង ដែលធ្លាប់ត្រូវបំបាក់ក្រោមអំណាចនៃការឈ្លានពានជារឿយៗរបស់ពួកចក្រពត្តិ និងអាណានិគមចាស់ និងថ្មី អារ្យធម៌នេះ ...ត្រូវរលត់រលាយបាត់សូន្យ... ។ សព្វថ្ងៃនេះ លើមូលដ្ឋាននៃប្រពៃណីទាំងឡាយរបស់យើង យើងបានលាយបញ្ចូលទំនៀមទម្លាប់ថ្មី ជាមួយនឹងវិទ្យាសាស្ត្រ... ដោយរួមផ្សំទម្លាប់ជាប្រពៃណីផ្សេងៗរបស់ប្រទេសយើងជាមួយវិទ្យាសាស្ត្រទំនើប ។ ប្រជាជនយើងកំពុងតែកសាងកម្ពុជាថ្មីមួយ[៣២]» ។

ប៉ុន្តែ ពួកខ្មែរក្រហមពុំបានអនុវត្តពិតប្រាកដនូវ «វិទ្យាសាស្ត្រទំនើប» ក្នុងការងារស្តារប្រទេសជាតិដ៏ធំសម្បើមរបស់ពួកគេផងទេ ។ សម្រាប់ពួកគេ លទ្ធិកុម្មុយនិស្ត និងនយោបាយ គឺជាវិទ្យាសាស្ត្រ ដែលបង្ហាញផ្លូវឆ្ពោះទៅរកការអភិវឌ្ឍ ។ ពួកគេសុទ្ធតែជាសាវ័ករបស់ ស្តាលីន និងម៉ៅ ដែលយល់ឃើញថា បណ្តាប្រទេសអន់ថយ អាចក្លាយទៅជារដ្ឋទំនើបមួយយ៉ាងឆាប់រហ័ស ដោយបង្ខំឲ្យប្រជាជនប្រឹងប្រែងធ្វើការហួសកម្លាំងលើកន្លែងការដ្ឋានធំៗ ។ ដូច ស្តាលីន ហើយជាពិសេសដូច ម៉ៅ ដែរ ពួកខ្មែរក្រហមយល់ឃើញថា មនុស្សដែលពួកគេទុកចិត្ត គឺត្រូវមានឥរិយាបថនយោបាយត្រឹមត្រូវ មានជីវភាពរវណ្ណៈច្បាស់លាស់ និងមាគ៌ាត្រឹមត្រូវចំពោះបក្ស ។ ពួកសេដ្ឋវិទូ ពួកវិស្វករ គ្មានបានប្រយោជន៍អ្វីទាំងអស់នៅក្នុងគម្រោងការផ្សេងៗរបស់ពួកគេ ហើយនៅទីបំផុតពួកខ្មែរក្រហម បានប្រើប្រាស់បច្ចេកទេសផ្សេងៗ អន់ជាងបច្ចេកទេសដែលពួកអ្នកកសាងអង្គរវត្តធ្លាប់ប្រើនៅសតវត្សរ៍ទី១២នោះទៅទៀត ពីព្រោះពួកគេមិនព្រមហៅរកវិស្វករដែលមានធាតុវណ្ណៈគហបតីឲ្យមកជួយឡើយ ។

ពួកកុម្មុយនិស្តកម្ពុជា បានបង្កើតឲ្យមានជាថ្មីនូវកំហុសមួយចំនួនធំ ដែលប្រព្រឹត្តដោយបណ្ដាព្រះរាជាសម័យអង្គរ ពួកកុម្មុយនិស្តរុស្ស៊ី និងចិន ។ អ្វីដែលមានលក្ខណៈខុសប្លែកពីអ្នកទាំងអស់នេះ គឺឆន្ទៈរបស់គេក្នុងការជំរុញនយោបាយទាំងមូលរហូតដល់កម្រិតកំណត់របស់វា និងហួសពីនេះទៅទៀត ដោយទាមទារការធ្វើពលីកម្មជាអតិបរមាពីប្រជាជន ពីខ្លួនឯងផ្ទាល់និងពីប្រទេសជាតិរហូតដល់ការដួលរលំ ។ ជ័យវរ្ម័នទី៧ ធ្លាប់បានប្រព្រឹត្តអំពើដូចគ្នានេះលើប្រទេសកម្ពុជាដែរ ។ លូវីស៍ ហ្វ៊ីណូត (Louis Finot) ប្រវត្តិវិទូ បារាំងម្នាក់ទៀតបានអធិប្បាយរៀបរាប់នូវអ្វី ដែលបានកើតឡើងនៅពេលដែលរាជាណាចក្រអង្គរត្រូវ រងការលុកលុយពីរាជាណាចក្រសៀមដ៏ខ្លាំង និងដ៏លោភលន់ក្នុងសតវត្សទី១៣ថា ៖

"គ្មានអ្វីបញ្ជាក់ឲ្យដឹងថា ប្រជាជនទាំងនេះ[ខ្មែរ] បានប្រយុទ្ធតស៊ូចំពោះការឈ្លានពានដោយអង់អាចក្លាហានឡើយ ។ ពួកគេប្រហែលជាទទួលស្វាគមន៍អ្នកឈ្លានពានទាំងនោះ ដូចជាការមកដោះឲ្យផុតអំពីទុក្ខទោសដែរ ។ បើសិនគេវិនិច្ឆ័យថា ពួកគេបានត្រូវបង្ខិតបង្ខំឲ្យធ្វើជាហត្ថពលករដើម្បីស្ថាបនាប្រាសាទដ៏ធំស្កឹមស្កៃទាំងនេះ ដែលទំហំរបស់វានៅតែធ្វើឲ្យគេងឿងឆ្ងល់រហូតមកដល់បច្ចុប្បន្ន... យើងអាចត្រឹមតែភ្ញាក់ផ្អើលថា ក្រោយរបបនេះជាច្រើនសតវត្សមកទៀត ប្រជាជនដ៏ខ្សត់ខ្សោយព្យាយាមនេះ ត្រូវបានគេសម្លាប់រង្គាល និងធ្វើឲ្យហិន-ហោច ខ្សោះរីងរៃដូច្នេះឡើយ ។ ពិតណាស់ ប្រជាជនមិនបានការពារបណ្ដាអាទិទេពលោភលន់ ទាំងអ្នកចាំយាមមើលពួកទាសករទាំងអ្នកប្រមូលពន្ធដារទាំងនេះដោយទឹកចិត្តក្លៀវក្លាឡើយ[៣៣]" ។

ប៉ុល ពត និងបក្សកុម្មុយនិស្តកម្ពុជា ប្រហែលជាល្បងដើរតួនាទីជំនួសបណ្ដាទេវរាជា ដែលធ្លាប់ដឹកនាំប្រទេសក្នុងរយៈពេលរាប់សតវត្សរ៍ជាព្រះមហាក្សត្រកាន់អំណាចផ្ដាច់ការ និងច្បាប់សម្រាប់អាទិទេពដោយមិនដឹងខ្លួនទេមើលទៅ ។ តាមលំដាប់ប្រវត្តិសាស្ត្រខ្មែរ និងបទពិសោធន៍ដ៏ខ្លីរបស់សាធារណរដ្ឋខ្មែរ ដែលពុករលួយ និងប្រជាធិបតេយ្យក្លែងក្លាយរបស់សម្ដេច ព្រះនរោត្តម សីហនុ មិនសូវមានសារសំខាន់ប៉ុន្មានឡើយ ។ ប្រជាជនកម្ពុជាពុំបានរើបម្រះចេញពីដំណែលវប្បធម៌ ដែលធ្វើឲ្យខ្លួនព្រមទទួលស្គាល់បណ្ដាមេដឹកនាំដ៏មានអំណាចដូចអាទិទេពសោះឡើយ ហើយក៏ពុំបានរៀបចំឲ្យមានការដោះស្រាយសម្រាប់ផ្លាស់ប្ដូរជាថ្មីដែរ ។

ព្រមជាមួយគ្នានោះ ជនជាតិខ្មែរបានគាំទ្រស្ថាប័នសំខាន់ពីរនៃវប្បធម៌ជាប្រពៃណីរបស់ខ្មែរថែមទៀត គឺរាជាធិបតេយ្យផ្ទាល់ និងព្រះពុទ្ធសាសនា ដែលធ្វើឲ្យបារម្ភដូចគ្នាដល់អំណាចផ្ដាច់ការ ដែលប៉ងប្រាថ្នាដោយពួកកុម្មុយនិស្ត ។ ដូច្នេះពួកនេះត្រូវតែវាយកម្ទេចគ្រឹះសង្គមទាំងពីរនេះតាមគ្រប់មធ្យោបាយ ហើយបំពេញកន្លែងចំហនេះដោយ "វប្បធម៌បដិវត្ត" ជារបស់គេផ្ទាល់វិញ ។

"មាគ៌ា" ឬវាក្យស័ព្ទនយោបាយ ដែលពួកខ្មែរក្រហមជ្រើសរើសសម្រាប់សរុបមហិច្ឆិតាផ្សេងៗ របស់ពួកគេ បានឆ្លុះបញ្ចាំងឲ្យឃើញពីការសម្រេចចិត្តប្រកបដោយអព្ភូតញាណរបស់គេក្នុងការដើរតួជាព្រះរាជា ប្រើអំណាចផ្ដាច់ការបន្តទៀត ។ ពួកគេបានប្រកាន់យក មាគ៌ាមួយក្នុងនាមនៃអធិបតេយ្យ ឯករាជ្យ ខ្លួនឧបត្ថម្ភខ្លួន និង

ហិង្សាបដិវត្ត» ។ ពួកគេធ្លាប់ទទួលដំណែលពីពួកកុម្មុយនិស្តវៀតណាម និងចិន ប៉ុន្តែ យកវាមកសម្តែងជារបៀបខ្មែរវិញ ។ សម្រាប់ពួកគេយល់ថា អធិបតេយ្យ មានន័យថា អំណាចរដ្ឋជាអំណាចធំបំផុត ជាអំណាចផ្តាច់ការឯករាជ្យ និងខ្លួនខបត្តម្ភផាច់ខាត ដែលជួយពង្រឹងគ្នាទៅវិញទៅមកឲ្យរឹតតែខ្លាំង និង«ហិង្សាបដិវត្ត» គឺជាមធ្យោបាយដើម្បីឈានឲ្យដល់គោលដៅ ទាំងអស់នោះ ។ «ហិង្សាបដិវត្ត» មានន័យថា ក្នុងដំណាក់កាលផ្សេងៗនៃការ «តស៊ូវណ្ណៈ» អំពើឃោរឃៅ និងការកាប់សម្លាប់មានលក្ខណៈចាំបាច់ខានមិនបាន ដើម្បីកម្ចាត់«សត្រូវវណ្ណៈ» ។ អំពីឃោរឃៅមានលក្ខណៈមួយជាអំពើស្របច្បាប់ ។

ស្របគ្នានោះ ពួកកុម្មុយនិស្តបានប្រឹងប្រែងផ្លាស់ជំនួសគ្រឹះរបស់សង្គមមួយទៀតគឺព្រះពុទ្ធសាសនា ។ សាសនានេះ បានចាក់ឫសយ៉ាងជ្រៅក្នុងវប្បធម៌របស់កម្ពុជា រហូតទាល់តែពុំអាចនិយាយថា គឺពុំមែនជាស្ថាប័នមួយដាច់ដោយឡែកទេ ប៉ុន្តែ វាជាបែបផែនមួយនៃរបៀបរបបរស់នៅរបស់ខ្មែរ ។ សាសនា បានធ្វើឲ្យប្រជាជនជ្រួតជ្រាបតាមរយៈ ភាសា ទម្លាប់ក្នុងការបរិភោគ របាំ សិល្បៈ និងការប្រព្រឹត្តរបស់ជនានុជនក្នុងទិដ្ឋភាពភាគច្រើននៃការរស់នៅប្រចាំថ្ងៃ ។ ប្រជាជនកម្ពុជាពុំមែនសុទ្ធតែជាអ្នកកាន់ព្រះពុទ្ធសាសនា «ត្រឹមត្រូវ» តាមន័យពិតប្រាកដរបស់ពាក្យនេះ ។ ជាអ្នកជឿខ្មោចព្រាយអ្នកតាខ្លាំងជាទីបំផុត ពួកនេះបានគោរពបូជាព្រលឹងអារក្សអ្នកតាមុនគេបំផុតដូចនឹងគោរពព្រះពុទ្ធជាម្ចាស់ដែរ ហើយក្នុងចំណោមអ្នកទាំងនេះ មានអ្នកខ្លះមិនទាំងស្គាល់គោលការណ៍តម្រូវឲ្យប្រតិបត្តិ ដែលជាជំនឿចំពោះសាសនាថែមទៅទៀត ។ គេពិបាកនិយាយថា អ្នកណាខ្លះ ជាអ្នកកាន់ព្រះពុទ្ធសាសនា និងអ្នកណាខ្លះ ដែលមិនកាន់ពុទ្ធសាសនាក្នុងវប្បធម៌របស់ខ្មែរនោះណាស់ ។ ភាគច្រើននៃប្រជាជនកម្ពុជា សុទ្ធតែចាត់ទុកខ្លួនឯងថាជាអ្នកកាន់ពុទ្ធសាសនា ទោះជាបាន ឬមិនបានប្រតិបត្តិតាមបញ្ញត្តិសាសនាក៏ដោយ ។ បើជាប្រជាជនកម្ពុជា គឺជាអ្នកកាន់ព្រះពុទ្ធសាសនាហើយ ។

ពួកខ្មែរក្រហមពុំមែនជាមនុស្សដោយឡែកពីប្រជាជនឯទៀតទេ ។ ភាគច្រើនបំផុតក្នុងបំណោមនោះធ្លាប់ត្រូវអប់រំឲ្យបួសជាព្រះសង្ឃ មានភាគច្រើនធ្លាប់យកព្រះសង្ឃធ្វើជាគ្រូបាធ្យាយក្នុងការសិក្សារបស់គេ ហើយមានមួយចំនួនដែលមានឥទ្ធិពល បានឡើងឋានន្តរៈចូលមកក្រុមគណៈដឹកនាំសង្ឃថែមទៀត ។ ប្រភពនៃការបេះអត់ធ្មត់ដំបងរបស់គេ គឺព្រះពុទ្ធសាសនា –ថ្វីបើគាត់យល់ខ្លះក៏ដោយ– ហើយគោលការណ៍ទាំងឡាយរបស់សាសនានេះ សុទ្ធតែមានទាក់ទងទៅនឹងការរស់នៅរបស់ពួកគេដែរ ៖ សេចក្តីទុក្ខជាមរតករបស់មនុស្សជាតិ គោលដៅនៃការជឿសាសនា គឺបំបែកវដ្តចក្រនៃសេចក្តីទុក្ខនេះ ។ ការប្រឆាំងនឹងទ្រឹស្តីថា គ្មានអ្វីអាចស្ថិតនៅក្រៅរូបធាតុ ហើយការផ្តាច់ខ្លួនចេញពីលោកិយនេះ គឺចេញមកពីជំនឿលើសាសនានេះឯង គេត្រូវប្រកាន់ឥរិយាបថអហិង្សាមួយ ព្រោះថាមានសេចក្តីទុក្ខច្រើនណាស់នៅក្នុងលោកពុំមែនព្រោះថា មានហេតុផលផ្សេងៗ ដែលធ្វើឲ្យខ្លួនសង្រឹម ឬធ្វើឲ្យខ្លួនសប្បាយរីករាយក្នុងជីវិតផ្ទាល់ខ្លួននោះទេ ។

ព្រះសង្ឃទាំងឡាយ ដែលផ្តល់នូវការអប់រំប្រៀបប្រដៅដល់ពួកខ្មែរក្រហម និងប្រជាជនកម្ពុជាដទៃទៀត

បានប្រតិបត្តិតាមតបធម៌ (ធម៌សម្រាប់ប្រព្រឹត្តដើម្បីដុតបំផ្លាញគ្រឿងសៅហ្មងចិត្ត) របស់គេជាទូទៅ ។ អ្នកទាំងនេះ ជាអ្នកនិយមបរិភោគបន្លែ តមហូបសាច់ ជាអ្នកនៅលីវ មិនប្រព្រឹត្តអំពើឃោរឃៅ លះបង់ខ្លួនក្នុងជីវភាពក្រីក្រមួយ ។ ពួកគេបានបង្ហាញឲ្យឃើញការសន្តោសប្រណីមួយយ៉ាងធំ- មានទស្សនៈ ដែលជឿអ៊ីមួយសិប់ និងច្បាប់បញ្ញត្តិតឹងរ៉ឹងបន្តិចបន្តួចប៉ុណ្ណោះ ក្នុងសាសនារបស់ព្រះពុទ្ធ បុគ្គលម្នាក់ៗត្រូវជ្រើសរើសតាមបរិយត្តិនូវ "ធម៌" ឬ"មគ្គៈ" របស់ខ្លួន ។ ព្រះពុទ្ធសាសនាបានរីកលូតលាស់ក្នុងប្រទេសជាច្រើន ដូចប្រទេសកម្ពុជាជាដើម ជាទីដែលពួកមេដឹកនាំដ៏មានប្ញទ្ធិអំណាចដូចអាទិទេព បានផ្តល់នូវការគាំទ្ររបស់គេចំពោះសាសនា ដែលធ្វើខ្លួនជា "សាសនូបត្ថម្ភ" ដ៏ជាទីសក្ការៈម្នាក់ជាជំនួសវិញ ។ ទោះជានៅពេលដែលអ្នកកាន់ពុទ្ធសាសនាងើបបះបោរប្រឆាំងនឹងពួកអាណានិគមបារាំងក៏ដោយ ក៏ធ្វើឡើងក្នុងនាមព្រះមហាក្សត្រដ៏ទៀងចំពោះសាសនា និងស្ថានភាពរបស់ប្រទេសកម្ពុជានាពេលនោះដែរ ។

មនោគមវិជ្ជារបស់ខ្មែរក្រហម ហាក់ដូចជាពុំលុះក្នុងឥទ្ធិពលព្រះពុទ្ធសាសនាទេ ហើយរួមបង្កជាប្រតិកម្មខ្លាំងក្លាមួយទល់នឹងទ្រឹស្តីដែលថា គ្មានអ្វីអាចស្ថិតនៅក្រៅរូបធាតុ និងធម៌អហិង្សារបស់សាសនាទៀតផង ។ ប៉ុន្តែការអនុវត្តលទ្ធិកុម្មុយនិស្តនៅប្រទេសកម្ពុជាបានត្រូវធ្វើឲ្យប៉ះពាល់ ដោយសារការអប់រំផ្នែកពុទ្ធសាសនារបស់ពួកខ្មែរក្រហម ហើយលក្ខណៈនៃជីវភាពជាបព្វជិត ប្រហែលជាបំភ្លឺឲ្យឃើញពីការប្រកាន់យកគោលការណ៍ខ្លាំងពេករបស់ពួកខ្មែរក្រហមនោះហើយមើលទៅ ។ ជីវប្រវត្តិផ្លូវការរបស់ ប៉ុល ពត បានបញ្ចប់ដោយឃ្លាចម្លែកមួយថា គាត់ចូលចិត្តរស់នៅក្នុង "សភាពស្ងប់ស្ងាត់" ដែលនេះជាសញ្ញាដ៏ជ្រាលជ្រៅរបស់ព្រះពុទ្ធ[៣៨] ។ម្យ៉ាងទៀត ភាសារបស់ព្រះពុទ្ធបានជ្រាបចូលក្នុងបក្ស ឧទាហរណ៍ដូចជា ការប្រើពាក្យ "សាវ័ក" សម្រាប់កត់សម្គាល់បុគ្គលមួយរូបដែលកំពុងហាត់ពត់លត់ដំ ដើម្បីប្រែក្លាយខ្លួនទៅជាសមាជិករបស់បក្ស ឬឃ្លាប្រយោគផ្សេងៗ ដែលប្រើប្រាស់សម្រាប់និយាយទៅកាន់បក្សក្នុងវគ្គស៊ុយទិតៀនថា "បក្សជាទីគោរព និងជាទីស្នេហាបណ្តាសមមិត្តបងជាមេដឹកនាំបក្ស" ជាដើម ។

ក្នុងទីបំផុត ព្រះពុទ្ធសាសនាគឺជាសាសនាប្រតិកិរិយាមួយ ។ ពួកអ្នកកាន់សាសនានេះ មិនត្រឹមតែកាន់ដើម្បីជៀសវាងពីសេចក្តីទុក្ខប៉ុណ្ណោះទេ ប៉ុន្តែ ក៏ជឿលើពុទ្ធទំនាយ ដែលថាក្រោយសម័យព្រះពុទ្ធជាម្ចាស់សាសនានឹងធ្លាក់ចុះអន់ថយរហូតដល់ភ្លើងឆេះកល្ប ជាយុគអន្ធការ ដែលអំពើអាក្រក់នឹងឈ្នះលើអំពើល្អ ឬ"បាបធម៌ និងមានជ័យជម្នះលើកុសលធម៌" ។

នៅពេលដែលពួកខ្មែរក្រហមលុបបំបាត់ព្រះពុទ្ធសាសនានៅដើមដំបូងនៃការបដិវត្តរបស់គេ គឺជាផ្នែកធំមួយនៃវប្បធម៌របស់កម្ពុជា ដែលពួកគេបានបំផ្លាញចោល ។ អំណឹះតទៅ វប្បធម៌ គឺការងារ គ្មានអ្វីផ្សេងក្រៅពីនេះឡើយ ។ អ្នកការទូតចិនម្នាក់ ដែលបំពេញមុខងារក្នុងកម្ពុជាប្រជាធិបតេយ្យរបស់ ប៉ុល ពត បានប្រកាសឲ្យដឹងថា "ខ្ញុំជាជនកុម្មុយនិស្តអស់មួយភាគធំនៃជីវិតរបស់ខ្ញុំ ។ ខ្ញុំមានទម្លាប់នឹងការអត់ឃ្លាន និងការខ្វះខាតសព្វបែប

យ៉ាងរួចទៅហើយ ។ ប៉ុន្តែ ខ្ញុំពុំបានរៀបចំខ្លួនជាមុនចំពោះជីវភាពរស់នៅមួយនៅក្រុងភ្នំពេញទេ... ។ មនុស្សទាំងអស់ គ្មានធ្វើអ្វីក្រៅពីធ្វើការងារឡើយ ក្រៅពីនេះគឺគ្មានអ្វីទាំងអស់[៣៥] ...» ។

ប៉ុន្តែ ការហាមឃាត់មិនឲ្យប្រជាជនប្រតិបត្តិសាសនា មិនអាចបំបាត់ព្រះពុទ្ធសាសនាបានឡើយ ។ សម្រាប់ប្រជាជនកម្ពុជាជាច្រើន ព្រះពុទ្ធសាសនាបានបង្ហាញឲ្យឃើញបរិការណ៍ (ការណ៍ទាំងឡាយដែលកើតមុន និងក្រោយព្រឹត្តិការណ៍មួយ) ដែលអាចឲ្យគេយល់ថា ហេតុអ្វីបានជាជីវិតរបស់គេ ត្រូវធ្វើឲ្យប្រែដោយជនរួមជាតិឯងដូច្នេះ ។ ម្យ៉ាងទៀត លន់ នល់ ប្រហែលជាក្រាល ដោយក្រើនរំឭកជារឿយៗពុទ្ធទំនាយ ដែលឲ្យប្រផ្នូលថា ពួកអ្នកជឿសាសនានឹងត្រូវគំរាមកំហែងដោយពួកអ្នកមិនជឿសាសនាជាសាសន៍បរទេស គឺពួកទមិឡ ។ លន់ នល់ បានអំពាវនាវឲ្យ ប្រជាជនប្រុងប្រយ័ត្នប្រឆាំងទប់ទល់នឹងការមកដល់នៃ «យុគអន្ធការ» បើសិនជាពួកកុម្មុយនិស្តឈ្នះសង្គ្រាមនោះ ។

គេមានឧទាហរណ៍ដោយឡែកៗពីគ្នា ប៉ុន្តែ ប្រជាកសិករយ៉ាងច្រើន ដែលគ្មានការចេះដឹង និងពួកអ្នកទីក្រុង ដែលចេះដឹងបានងាកទៅរកច្បាប់ប្រពៃណី និងធម៌អាថ៌របស់សាសនា ដើម្បីបកស្រាយពីការភាន់ប្រែ ប្រឡាក់ទៅដោយឈាមរបស់ការបដិវត្តខ្មែរក្រហមនេះ ។ ពិន យ៉ាថៃ ជាវិស្វករនៅក្រុងភ្នំពេញ បាននិយាយរំឭកក្នុងសៀវភៅរបស់គាត់ពី «ពាក្យទំនាយប្រាកដប្រជាមួយ ដែលទាយទុកជាមុនអំពីយុគសម័យអពមង្គលមួយសម្រាប់ប្រទេសកម្ពុជា... ។ ផ្ទះសម្បែងនឹងគ្មានមនុស្សនៅផ្លូវនឹងគ្មានមនុស្សដើរ ពួកល្ងង់ខ្លៅនិងពួកស្រទាប់បាតនឹងដកហូតអំណាចពីពួកអ្នកកាន់តំណែងផ្សេងៗក្នុងប្រទេស ។ ពួកអ្នកមានចំណេះវិជ្ជានឹងត្រូវថ្កោលទោសឲ្យធ្លាក់កាន់តែទាបជាងពួកអ្នកល្ងង់ខ្លៅទៅទៀត ។ វានឹងទៅជាយុគសម័យមួយដែលគ្មានសាសនា គ្មានព្រះពុទ្ធសាសនា ។ ពួកទមិឡ... នឹងឡើងកាន់កាប់អំណាចផ្តាច់ការ ហើយធ្វើទុក្ខបុកម្នេញព្រះសង្ឃថែមទៀត ។ មានតែពួកអ្នកធ្វើកធ្វើថ្លង់ប៉ុណ្ណោះ ដែលអាចរួចផុតពីគ្រោះថ្នាក់បានក្នុងអំឡុងសម័យអពមង្គលនេះ ។ ដោយធ្វើក ធ្វើថ្លង់ ខ្ញុំ (យ៉ាថៃ) បានរកឃើញមធ្យោបាយធ្វើខ្លួនឲ្យរួចពីសេចក្តីស្លាប់បាន[៣៦] » ។

យ៉ាថៃ ពុំមែនជាមនុស្សចេះធ្វើដូច្នេះតែម្នាក់ឯងនោះទេ ៖ ដោយសភាវគតិ ប្រជាជនកម្ពុជាមួយចំនួនធំបានក្លាយទៅជាមនុស្សចេះធ្វើកធ្វើថ្លង់ដែរ ។ ភាគច្រើននៃប្រជាជនកម្ពុជា ពុំសូវនឹកឃើញពុទ្ធទំនាយដូច យ៉ាថៃ ទេ ព្រោះអ្នកទាំងនោះ បានត្រាំត្រែងក្នុងសេចក្តីភ័យបារម្ភពីសម័យភ្លើងឆេះកល្ប (ទីបញ្ចប់នៃពិភពលោក) ពីជ័យជម្នះនៃអំពីអាក្រក់ទៅលើអំពើល្អទៅហើយ ។ នៅពេលដែលគេបញ្ជាអ្នកទាំងនោះដូចសត្វធាតុឲ្យចេញពីទីក្រុង ហើយក្រោយមក ទៅនៅតាមជនបទ ហើយនៅពេលដែលពួកគេមើលឃើញបណ្តាមិត្តភក្តិ និងឪពុកម្តាយរបស់គេ ដើរតម្រង់ទៅរកសេចក្តីស្លាប់ជាក់ប្រាកដមួយ ទើបមានមនុស្សជាច្រើនក្នុងចំណោមនោះ នឹកស្រមៃទៅដល់ភាពដូចគ្នានេះក្នុងរឿងព្រះពុទ្ធ និងរឿងអ្នកបង្កើតសាសនាប្រឆាំងនឹងសាសនា ព្រះយេស៊ូគ្រិស្ត ។

ពាក្យទំនាយដែលរំឭកឡើងដោយ យ៉ាថៃ បានបង្ហាញឲ្យឃើញនូវភាពដូចគ្នា មួយដ៏ចម្លែក និងគួរឲ្យព្រួយ

បារម្ភជាមួយនឹងរបបខ្មែរក្រហម ។ ពាក្យទំនាយបានប្រាប់ឲ្យដឹង ពីការមកដល់នៃយុគសម័យ «អន្ធការ» ដែលស្របនឹងពាក្យ «កលិយុគ» ដែរ ។ តាមគេនិយាយថាទីបញ្ចប់នៃសម័យ «កលិយុគ» នឹងមានលក្ខណៈកត់សម្គាល់ដោយ «ការច្របូកច្របល់នៃវណ្ណៈផ្សេងៗ ការកម្ទេចចោលក្បួនច្បាប់ដែលគេបានបង្កើតរួចហើយ ការបញ្ឈប់មិនឲ្យមានពិធីបុណ្យផ្នែកសាសនាទាំងអស់ និងការត្រួតត្រារបស់បណ្ដាស្ដេចបរទេសដែលសាហាវឃោរឃៅ[៣៧]» ។ តាមការគន់គូរជាក់លាក់ថា សម័យកលិយុគនេះ នឹងត្រូវចប់ប្រហែលនៅទីបញ្ចប់នៃសង្គ្រាមលោកលើកទីពីរ ។

វាមានមូលហេតុច្បាស់លាស់មួយចំនួនដែលក្នុងនោះប្រជាជនកម្ពុជា ពុំបានងើបបះបោរប្រឆាំងនឹងពួកខ្មែរក្រហមទេ ប៉ុន្តែលក្ខណៈជាអ្នកសន្សំផលបុណ្យ ដែលពួកគេសុខចិត្តទ្រាំទ្រនឹងផលកម្មរបស់គេនោះ អាចបកស្រាយដោយផ្នែក បណ្ដាលមកពីជំនឿជាទូទៅមួយដែលថា ពិភពលោកបានធ្វើដំណើរមកដល់ទីបញ្ចប់របស់ខ្លួនហើយ ។

ក្នុងរយៈពេលនៃការបដិវត្តដំណាក់កាលទីមួយ គឺសម័យប្រើ «នយោបាយកុម្មុយនិស្តនៃសង្គ្រាម» ពួកមេដឹកនាំ បានយកចិត្តទុកដាក់កម្ចាត់ពួកសត្រូវដែលមិនទាន់ចេញជាក់ស្ដែង មិនអន់ជាងកសាងសេដ្ឋកិច្ចថ្មីមួយឡើយ ។ កម្ពុជាប្រជាធិបតេយ្យបានកែតម្រូវចង្វាក់ការងារផ្ទាល់ដោយខ្សែករបស់ខ្លួន ដែលស្ថិតនៅត្រង់ជំរុញការបដិវត្តទៅមុខមួយជំហាន បន្ទាប់មក ស្វែងរកពួកខ្មាំងសត្រូវ នៅដំណាក់កាលនៃការបដិវត្តនេះផង ។ ក្នុងកំឡុងដំណាក់កាលទីមួយនេះ ពួកខ្មែរក្រហមបានគិតគូរជាបឋមចំពោះគូសត្រូវរបស់ពួកគេ នៅសម័យសង្គ្រាម គឺបណ្ដាមេដឹកនាំ និងនាយទាហានធំរបស់របប លន់ នល់ ។ ពួកគេក៏ព្រួយបារម្ភនឹងសត្រូវបរទេសដែលអាចគំរាមកំហែងដល់ឯករាជ្យភាព និងអធិបតេយ្យភាពរបស់កម្ពុជា ។ ក្រោយមក នៅពេលដែលការបដិវត្តឆ្លងចូលទៅដំណាក់កាលផ្សេងៗទៀត ពួកគេបានត្រូវធ្វើឲ្យខ្វល់ចិត្តដោយ «សត្រូវវណ្ណៈ» ដែលបង្កប់ខ្លួនក្នុងប្រជាជនម្ដង ។ ក្នុងលំដាប់ដែលការបដិវត្តមិនបានសម្រេចជោគជ័យ ពួកគេពិនិត្យឃើញសត្រូវទាំងនោះ មានសេរីភាពកាន់តែខ្លាំងឡើងៗដែរ ។ ការធ្វើមិនបានសម្រេច ជោគជ័យទាំងឡាយបណ្ដាលឲ្យមានអ្នកដែលគេទម្លាក់កំហុសលើជាច្រើនៈ មេដឹកនាំទាំងឡាយបានប្រឌិតបក្សពួកប្រឆាំងផ្សេងៗនៅក្នុងផ្ទៃបក្ស បន្ទាប់មក កម្ចាត់អ្នកទាំងនោះ ចោលទាំងអស់តាមរយៈការបោសសម្អាតជាហូរហែនូវអ្នកទាំងឡាយណា ដែលពួកគេអះអាងថា ជាមនុស្សស្ថិតនៅក្នុងក្រុមប្រឆាំងទាំងនេះ ហើយដោយហេតុនេះ គឺសុទ្ធតែជាអ្នកទទួលខុសត្រូវលើបរាជ័យរបស់ការបដិវត្ត ។

ក្នុងជំហានដំបូង ពួកកុម្មុយនិស្តបានចាប់ផ្ដើមសម្លាប់ពួកអ្នកកាន់អំណាចតាមលំដាប់លំដោយ បុណ្យសក្ដិនៃរបបចាស់ដែលពួកគេបានវាយឈ្នះ ។ ដោយជឿជាក់ថា មនុស្សទាំងនោះនឹងក្លាយទៅជាសត្រូវគ្រោះថ្នាក់ដល់របបផ្ទាល់របស់គេនោះ ពួកគេបានចាប់ផ្ដើមសម្លាប់ចោលនៅថ្ងៃជ័យជម្នះ ។ គ្រាន់តែពួកគេវាយដណ្ដើមកាន់កាប់ទីក្រុងភ្នំពេញភ្លាម ពួកខ្មែរក្រហមបាននិយាយផ្សាយតាមវិទ្យុ ដោយសំឡេងមុតៗនូវសេចក្ដីអំពាវនាវមួយ

ដោយដាក់កំហិតឲ្យក្រុមនាយទាហានធំៗ មន្ត្រីជាន់ខ្ពស់ទាំងអស់ ចូលទៅបង្ហាញខ្លួននៅទីស្តីការរដ្ឋមន្ត្រីក្រសួងឃោសនាការដាច់ខាត -គ្មានការលើកលែងណាមួយ គ្មានអវត្តមានណាមួយ ត្រូវគេអត់ឱនឲ្យឡើយ[៣៨] ។ ហើយដោយគ្មានសង្ស័យទៅលើអ្វីដែលនៅរង់ចាំពួកគេ នាយទាហានធំៗ និងមន្ត្រីជាន់ខ្ពស់ភាគច្រើន បានចូលខ្លួនទៅតាមការអំពាវនាវនេះ ។

ពួកនាយទាហានធំៗ ត្រូវបានគេបញ្ជូនទៅកាន់សណ្ឋាគារមនោរម្យ ដោយគេបានស្នើសុំឲ្យពួកនេះសរសេរ "ជីវប្រវត្តិ"របស់គេ ជាការស្នើរសុំឲ្យសរសេរជាលាយលក្ខណ៍អក្សរ ដែលជាទម្លាប់មួយក្នុងបណ្តាប្រទេសកុម្មុយនិស្តភាគច្រើន នៅពេលដែលជនសង្ស័យម្នាក់ត្រូវគេនាំយកទៅដាក់គុក ។ មេទាហានជាន់ខ្ពស់ទាំងអស់ បានសរសេរពីប្រវត្តិនៃជីវិតផ្ទាល់របស់គេ ហើយការធ្វើដូច្នេះប្រៀបដូចជាបង្ហាញភស្តុតាងពីលក្ខណៈសម្បត្តិរបស់គេជា "ពួកក្បត់" នៅចំពោះមុខពួកកុម្មុយនិស្តដូច្នោះដែរ ។ គេបាននាំយកពួកនោះចេញទៅ ហើយសម្លាប់ចោលគ្មានសល់ម្នាក់ ។ ក្នុងចំណោមនោះ មានភាគច្រើនត្រូវគេសម្លាប់ នៅក្នុងស្តាតអូឡាំពិកជាកីឡាដ្ឋានយ៉ាងធំមួយដែលកសាងឡើងដោយសម្តេច ព្រះនរោត្តម សីហនុ ។

គេបានរាយការណ៍ឲ្យដឹងថា ឥស្សរជននយោបាយជាន់ខ្ពស់បំផុតជាច្រើន ត្រូវគេធ្វើឃាដនៅក្នុងមណ្ឌលកីឡាដ្ឋានមួយ "គឺក្លឹបសម្រាប់ពួកវរជនដែលស្ថាបនាឡើងដោយពួកបារាំង ស្ថិតនៅក្បែរវត្តភ្នំ" ដោយកាត់ក្បាលនៅលើតារាងវាយតិន្នីស[៣៩] ។ លន់ នល់ ពុំមានស្ថិតនៅក្នុងចំណោមពួកមេដឹកនាំទាំងនោះទេ ពីព្រោះគាត់បានចាកចេញពីក្រុងភ្នំពេញតាំងពីមុនពេលបរាជ័យម្ល៉េះ ដោយបន្ទន់ខ្លួនទៅតាមការគាបសង្កត់របស់ពួកអាមេរិកាំង និងកាណាដា ។ ពួកអាមេរិកាំង និងសមាជិករដ្ឋាភិបាលភាគច្រើនដែលស្ថិតនៅក្នុងប្រទេសនឹកសង្ឃឹមថា បើសិនជាលន់ នល់ ចាកចេញពីប្រទេស វានឹងមានលទ្ធភាពមួយ ក្នុងការចរចាបញ្ចប់សង្គ្រាមជាមួយពួកខ្មែរក្រហម និងការបង្កើតរដ្ឋាភិបាលចម្រុះមួយ ។ លន់ នល់ បានទទួលលុយ ១ លានដុល្លារសម្រាប់ទុកឲ្យគេមានសេរីភាពពេញលេញក្នុងការដឹកនាំប្រទេស ។

ប៉ុន្តែ ការស្រមើស្រមៃអំពីរដ្ឋាភិបាលចម្រុះជាមួយពួកខ្មែរក្រហម បានរលត់រលាយមុនពេលបរាជ័យទៅទៀត ។ ពីទីក្រុងប៉េកាំង សម្តេច ព្រះនរោត្តម សីហនុ បានថ្លែងប្រកាសថា ពុំមានការសម្រេចធ្វើកិច្ចចរចាគ្នាទេ ។ ហើយពួកខ្មែរក្រហមបានបោះពុម្ពផ្សាយនូវបញ្ជីឈ្មោះ "មនុស្សក្បត់កំពូលៗ" មួយគឺជាពួកមេដឹកនាំរដ្ឋាភិបាល ដែលត្រូវសម្លាប់មុនគេ ។ ប៉ុន្តែ ភាគច្រើននៃឥស្សរជនទាំងនោះ បានបដិសេធមិនព្រមចាកចេញទៅជាមួយពួកអាមេរិកាំងទេ នៅពេលដែលពួកនេះជម្លៀសបុគ្គលិករបស់គេចេញពីទីក្រុងភ្នំពេញ នៅថ្ងៃទី១២ ខែមេសា នោះ ។ ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ មេនាំអាទិម្នាក់ក្នុងចំណោមមេនាំអាទិជាច្រើន ទៀតនៃរដ្ឋប្រហាររបស់ លន់ នល់ ហើយដែលខ្មែរក្រហមឲ្យដំណឹងមុនថានឹងយកទៅចងបង្គោលបាញ់សម្លាប់ ចោលបានផ្ញើទៅឲ្យលោក ហ្សុន ហ្គុនថឺ ឌៀន ឯកអគ្គរដ្ឋទូតអាមេរិកាំងនូវសារលិខិតមួយ ដោយបកស្រាយបំភ្លឺពីមូលហេតុ

ដែលព្រះអង្គពុំអាចបោះបង់ចោលប្រទេសជាតិរបស់ខ្លួន «គ្មានពេលណាមួយដែលខ្ញុំជឿថា លោកនឹងបោះបង់ប្រជាជនមួយ ដែលបានជ្រើសរើសយកសេរីភាពដូចនៅពេលនេះឡើយ ។ លោកមិនអាចការពារប្រទេសខ្ញុំបាន ហើយខ្ញុំពុំអាចធ្វើអ្វីកើតទាំងអស់ ។ ខ្ញុំបានប្រព្រឹត្តកំហុសតែមួយគត់ គឺការជឿទៅលើពួកអស់លោក [សហរដ្ឋអាមេរិក] ខ្លាំងពេក[៤០] » ។

នេះជាចម្លើយសារភាពចុងក្រោយរបស់ សិរិមតៈ ។ កំហឹងរបស់គាត់ គឺសំដៅប្រឆាំងនឹងពួកអាមេរិកាំង ជាពួកដែលគាត់ទុកចិត្តដើម្បីការពារប្រទេសកម្ពុជា ពុំមែនសំដៅប្រឆាំងនឹងជនរួមជាតិឯង «ខ្មែរក្រហម» ដែលប្រុងនឹងសម្លាប់គាត់នោះទេ ។ គេបាននាំយក សិរិមតៈ ពីស្ថានទូតបារាំង ជាកន្លែងដែលគាត់បានស្វះស្វែងរកទីលាក់ខ្លួន ជាមួយសហគមន៍បរទេស ។ លន់ ណុន ប្អូនរបស់ លន់ នល់ ក៏ត្រូវគេសម្លាប់ ។ ជាមនុស្សដែលរបស់មេដ្ឋាច់ការ គាត់នៅតែមានសេចក្តីសង្ឃឹមខុសជានិច្ចថា គាត់អាចនឹងបញ្ចុះបញ្ចូលពួកខ្មែរក្រហមឲ្យមករួមរស់ជាមួយរបបខ្លួនបាន ។

ពួកមេដឹកនាំច្រើននាក់ផ្សេងទៀត ត្រូវបានចាប់ខ្លួនតាមរបាំងយាំងផ្លូវនានា ដែលពួកកុម្មុយនិស្តបានបង្កើតឡើងនៅតាមផ្លូវជាមាត់ច្រកចេញពីរដ្ឋធានី ។ ដោយនៅតែពុំដឹងពីមូលហេតុនៃការសុំឲ្យសរសេរ «ជីវប្រវត្តិ»ទាំងនេះ ពួកគេបានលាតត្រដាងប្រាប់ពួកខ្មែរក្រហមខ្ទេចខ្ទីថា ពួកគេជាអ្នកណា ហើយធ្វើការអ្វីខ្លះឲ្យរដ្ឋាភិបាល លន់ នល់ ។ មនុស្សជាច្រើន ដូចជាឪពុកម្តាយរបស់ ម៉ី កុម្ពត ជាដើមជឿថា ពួកគេលែងសូវបារម្ភនឹងកម្មសិក្សា«រៀនសូត្រ»ជាថ្មី ក្រោមទម្រង់ ឬបែបផែនផ្សេងទៀត ទើបគេអនុញ្ញាតឲ្យវិលត្រឡប់ទៅរួមរស់ជាមួយគ្រួសារ និងធ្វើការដើម្បីស្តារប្រទេសឡើងវិញទៀតហើយ ។ ពួកអ្នកដែលនៅមិនទុកចិត្ត ហើយដែលលាក់អត្តសញ្ញាណពិតប្រាកដរបស់ខ្លួន បានត្រូវអ្នកដទៃទៀតដែលធ្លាប់ស្គាល់ បាននិយាយអាថ៌កំបាំងរបស់ពួកគេប្រាប់ពួកកុម្មុយនិស្តជារឿយៗ ។ ដូច្នេះហើយបានជានាយទាហាន និងអ្នករដ្ឋការជាន់ខ្ពស់រាប់ពាន់នាក់ ត្រូវបានសម្លាប់រង្គាលក្នុងសប្តាហ៍ដំបូងៗ បន្ទាប់ពី«ការរំដោះ»រួចមក ។

ដែនដីផ្សេងមួយគត់ដែលច្បាំងចាញ់ក្រោយគេរបស់សាធារណរដ្ឋខ្មែរ គឺស្ថិតនៅក្នុងខេត្តបាត់ដំបង ភាគពាយ័ព្យប្រទេស ។ នៅទីនោះ កងទ័ពរបស់ លន់ នល់ បានធ្វើការវាយប្រយុទ្ធជាលើកចុងក្រោយមួយ ហើយទូទាត់មកវិញ ដោយការសម្លាប់ពួកនាយទាហានទាំងអស់ ដោយគ្មានការវិនិច្ឆ័យទោសជាមុនឡើយ ។ ថ្ងៃទី១៩ ខែមេសា ពួកខ្មែរក្រហមបានបញ្ជាឲ្យមេទាហានទាំងនោះ ចូលមកបង្ហាញខ្លួនក្នុងរវាងមួយម៉ោង នៅត្រង់ទីកន្លែងមួយដែលគេកំណត់ជាស្រេច ។ គេបានស្នើឲ្យអ្នកទាំងនោះ បញ្ជាក់បំភ្លឺឲ្យបានល្អិតល្អន់ថា តើពួកគេមានមុខងារជាអ្វីខ្លះ បន្ទាប់មក គេឲ្យប្រមូលផ្តុំជាថ្មី ម្តងនេះត្រូវស្លៀកពាក់ឯកសណ្ឋានធំជាមួយនឹងគ្រឿងឥស្សរិយយសរបស់ពួកគេទាំងអស់ ។ គេបានធ្វើឲ្យពួកនោះជឿថា ពួកគេនឹងត្រូវធ្វើដំណើរទៅក្រុងភ្នំពេញដើម្បី ទទួលស្វាគមន៍សម្តេចព្រះនរោត្តម សីហនុ ដែលវិលត្រឡប់ពីទីក្រុងប៉េកាំងមកវិញ ។

ពួកនាយទាហានទាំងនោះបានគោរពធ្វើតាម ហើយបាននាំគ្នាប្រជ្រៀតឡើងជិះពេញលើឡានកាមីញ៉ុងចំនួនប្រាំមួយគ្រឿង ។ រថយន្តទាំងអស់បានចេញដំណើរសំដៅមកក្រុងភ្នំពេញ ដែលនាំមុខដោយឡានហ្សីបមួយគ្រឿង និងឡានឡង់រ៉ូវែរមួយគ្រឿង ផ្ទុកពេញទៅដោយយុទ្ធជនខ្មែរក្រហម ហើយមានឡានមួយគ្រឿងទៀតដែលមានកងទ័ពជិះពេញដែរនោះ បើកតាមពីក្រោយ ។ នៅត្រង់ផ្លូវបែកជាបួនមួយ មិនឆ្ងាយប៉ុន្មានពីក្រុងបាត់ដំបង ក្បួនរថយន្តបានបើកចេញពីផ្លូវជាតិ ហើយក៏ឈប់នៅស្ងៀមទ្រឹង ។ ពួកនាយទាហាន បានទទួលបញ្ជាឲ្យចុះពីរថយន្តដើម្បីពត់ដៃជើងឲ្យបាត់ចុកស្រពន់ ។ គ្រាន់តែចុះមកដល់ដីភ្លាម រថយន្តទាំងនោះបានបើកចេញទៅវិញអស់ ហើយកងទ័ពខ្មែរក្រហមបានលេចឆ្មោចេញពីព្រៃក្បែរៗនោះភ្លាមដែរ ។ ក្នុងរយៈពេលដប់ប្រាំនាទីពួកនាយទាហានដែលគេដកហូតអាវុធអស់ហើយ បានឈរសម្លឹងមើលពេជ្ឈឃាតរបស់ខ្លួនគ្មានព្រិចភ្នែកឡើយ ។ បន្ទាប់ មក ពួកខ្មែរក្រហមក៏ចាប់ផ្ដុះអាវុធ សម្លាប់ពួកនាយទាហានទាំងអស់លើកលែងតែបួននាក់ប៉ុណ្ណោះដែលរួចរស់ជីវិត ។

មិនយូរប៉ុន្មានក្រោយមក ក្នុងថ្ងៃដដែលនោះ ពួកនាយទាហានរងជាច្រើននាក់ទៀតនៅបាត់ដំបង បាននាំគ្នាឡើងជិះលើឡានកាមីញ៉ុងប្រមាណជាដប់គ្រឿង ដើម្បីធ្វើដំណើរទៅកាន់ជំរំមួយស្ថិតនៅជិតទីក្រុងដែរ ដោយគេនិយាយប្រាប់ពួកអ្នកទាំងនោះថា ពួកគេនឹងត្រូវអប់រំកែប្រែជាថ្មី ដើម្បីប្រែក្លាយខ្លួនទៅជាអ្នកបដិវត្ត ។ តាមពិតគេបានឲ្យពួកនេះចុះពីរថយន្តនៅខាងភាគជើងទីក្រុង ហើយគេបានសម្លាប់ចោលនៅលើផ្លូវនោះ ។ ក្នុងវេលារសៀល ក្រោយពេលដែលការកាប់សម្លាប់ដ៏ធំនៅក្រុងភ្នំពេញ និងបាត់ដំបងចប់សព្វគ្រប់អស់ហើយ ប៉ុល ពតបានធ្វើដំណើរត្រឡប់ចូលមករដ្ឋធានីវិញ ។

ការសម្លាប់រង្គាលទាំងនេះ មានផ្លាកសញ្ញាជារបស់ខ្មែរក្រហម ៖ ពុំមានតុលាការ ពុំមានការកាត់ទោសជាសាធារណៈ ពុំមានក្រុមប្រឹក្សាតុលាការប្រជាជនឡើយ ។ អ្នករងគ្រោះទាំងអស់ត្រូវគេនាំទៅរកសេចក្ដីស្លាប់ដោយការភូតកុហក ហើយត្រូវសម្លាប់ដោយស្ងាត់ៗ ។ ពួកខ្មែរក្រហមមិនចង់ធ្វើការសម្លាប់មនុស្សជាសាធារណៈទេ ។ ពួកគេលាក់បិះបាំងការសម្លាប់រង្គាលទាំងនេះមិនឲ្យប្រជាជនដឹងឡើយ ហើយបដិសេធរឿងទាំងអស់នោះជានិច្ចកាលណាមានគេសាកសួរខ្លួនពីបញ្ហានេះ ។ ដំណើរវិលទៅមុខរបស់ការបដិវត្ត ការបង្ក្រាបអំពើប្រឆាំងបដិវត្តន៍ គឺធ្វើឲ្យកើតមានមនុស្សស្លាប់តែហោងយ៉ាងឃោរឃៅ និងស្ងាត់កំបាំងរបៀបនេះគ្រប់ទីកន្លែង ។

បើសិនជាពួកខ្មែរក្រហម រៀបចំផែនការប្រឈមមុខគ្នានេះជាមួយនឹងពួកសត្រូវរបស់គេ នៅសម័យសង្គ្រាម ពួកគេក៏ត្រូវធ្វើឲ្យភ្ញាក់ផ្អើលដោយការលេចចេញនូវខ្មាំងសត្រូវបរទេសភ្លាមៗនោះដែរ ។ ពួកវៀតណាមដែលជាសម្ព័ន្ធមិត្តដ៏គួរឲ្យខ្លាចរបស់ខ្លួន បានបង្ខំឲ្យពួកកម្ពុជាទទួលរងមុនគេ នូវអ្វីដែលប្រហែលជាការប្រឈមមុខទល់គ្នាដ៏មុឺងម៉ាត់មួយជាមួយបរទេស ក្នុងកំឡុងខែដំបូងនៃការកាន់អំណាចរបស់ពួកខ្មែរក្រហមដោយមិនអែអង់

យូរឡើយ ។

ក្រអឺតក្រអោងនឹងជ័យជម្នះ ពួកវៀតណាមបានកំណត់ចាកចេញពី«ទីជម្រក»នានា ដែលពួកគេធ្លាប់បានប្រើប្រាស់សម្រាប់វាយប្រហារពួកអាមេរិកាំង និងកងទ័ពវៀតណាមខាងត្បូងជាស្រេច ។ ប៉ុន្តែ ពួកកុម្មុយនិស្តវៀតណាម នៅអែអង់មិនប្រញាប់ដកថយពីទឹកដីកម្ពុជាឡើយ ជាពិសេសនៅបណ្តាតំបន់ដាច់ស្រយាលនៃខេត្តរតនគិរី និងមណ្ឌលគិរី ។ ពួកខ្មែរបានផ្ញើពាក្យបណ្តឹងផ្លូវការមួយទៅឲ្យក្រុងហាណូយ ដោយស្នើឲ្យកងកម្លាំងវៀតណាមទាំងអស់ចាកចេញពីទឹកដីកម្ពុជា ។ ពួកគេបានទទួលការឆ្លើយតបមកវិញជាសេចក្តីថ្លែងការណ៍មួយ ដែលក្នុងនោះថា មួយចំណែកនៃទឹកដីនេះគឺជារបស់វៀតណាម ដូច្នេះកងទ័ពវៀតណាមស្ថិតនៅក្នុងទឹកដីរបស់ប្រទេសគេទេ ។ ការប៉ះទង្គិចគ្នាស្រាលៗបានផ្ទុះឡើងនៅតាមព្រំដែននៃប្រទេសទាំងពីរ ហើយបណ្តាលឲ្យមានការប្រឈមមុខគ្នាជាលើកដំបូងរវាង មជ្ឈិម និងសោ ភឹម លេខាបក្សភូមិភាគបូព៌ាថែមទៀត ។ ប៉ុល ពត និងបក្ស បានស្តីបន្ទោស ភឹម ដែលរហន់វាយប្រយុទ្ធជាមួយនឹងពួកវៀតណាមពេក ហើយទូន្មានគាត់ឲ្យអត់ធ្មត់ទប់ចិត្តកុំអាលប្រព្រឹត្តអ្វីជ្រុលហួស ។

ការវាយប្រយុទ្ធគ្នាជាច្រើន បានរាលដាលពីភាគខាងជើងបំផុតមកព្រំដែនភាគខាងត្បូង និងរហូតដល់កោះទាំងឡាយក្នុងឈូងសមុទ្រសៀម ដែលពួកវៀតណាមបានទាមទារថាជារបស់ខ្លួនថែមទៀត ។ ពួកកម្ពុជាបានចោទសួរពួកវៀតណាមថា ហេតុអ្វីបានជាមិនគោរពកិច្ចព្រមព្រៀង ដែលពួកគេធ្លាប់បានសម្រេចចុះហត្ថលេខាជាមួយនឹងសម្តេច ព្រះនរោត្តម សីហនុ កាលពីឆ្នាំ១៩៦៧ ហើយដែលទទួលស្គាល់ព្រំប្រទល់បច្ចុប្បន្នរវាងប្រទេសវៀតណាម និងកម្ពុជា ។ ទោះជាពួកបារាំងគូសបន្ទាត់ព្រំដែនទាំងនេះ ដែលផ្តល់ចំណេញដល់ពួកវៀតណាមក៏ដោយ ក៏សម្តេច ព្រះនរោត្តម សីហនុ ធ្លាប់ប្រើប្រាស់ខ្សែបន្ទាត់នេះក្នុងកិច្ចចរចាផ្សេងៗ ដើម្បីបង្ហាញភ័ស្តុតាងតែម្យ៉ាងប៉ុណ្ណោះថា ពួកវៀតណាមលែងមានសិទ្ធិទាមទារយកទឹកដីផ្សេងទៀតហើយ ។

ពួកវៀតណាមទើបនឹងឈ្នះសង្គ្រាមរបស់គេថ្មីៗ នៅពេលដែលពួកគេប្រកាសប្រាប់ពួកមេដឹកនាំក្រុងភ្នំពេញជាសាធារណៈថា គេគួរតែបើកធ្វើកិច្ចចរចាស្តីពីបញ្ហាព្រំដែនជាថ្មីម្តងទៀត[៤១] ។ រឿងដែលត្រូវជជែកគ្នាខ្លាំងបំផុតនោះ គឺខ្សែបន្ទាត់ព្រំដែន «ប្រេវីយេ» ដែលពួកបារាំងបានគូសជាព្រំដែនសមុទ្ររវាងប្រទេសទាំងពីរ ប៉ុន្តែកាលនោះ ពួកបារាំងបានគូសឡើងគ្រាន់តែជាការកំណត់ព្រំដែនរដ្ឋបាលអាណានិគមប៉ុណ្ណោះ ពុំមែនជាព្រំដែនអន្តរជាតិពិតប្រាកដមួយឡើយ ។ ពួកកម្ពុជាបានបញ្ចេញប្រតិកម្មតបទៅវិញ ដោយបានបញ្ជូននាវាល្បាតជាច្រើនគ្រឿងទៅកាន់តំបន់កោះទាំងឡាយ ដែលក្នុងនោះមានកោះ ពូឡូវៃ មួយ បានក្លាយទៅជាចំណុចសំខាន់នៃការវិវាទគ្នានេះ ។

នៅដើមខែឧសភា ពួកខ្មែរក្រហម នឹកព្រួយបារម្ភយ៉ាងខ្លាំង ចំពោះគោលបំណងផ្សេងៗរបស់ពួកវៀតណាម មកលើទឹកដីដ៏ពិសិដ្ឋរបស់ខ្មែរ រហូតធ្វើឲ្យពួកគេចាប់ផ្តើមឆែកឆេរនាវាបរទេសទាំងអស់ ដែលបើក

ឆ្លងកាត់ក្នុងតំបន់នេះ[៤៧] ។ ពួកគេបានធ្វើរបៀបនេះ ទៅលើនាវារបស់ប្រទេសប៉ាណាម៉ាមួយគ្រឿង ហើយបីថ្ងៃក្រោយមក គេបានបាញ់កាំភ្លើងទៅលើនាវាមួយគ្រឿងរបស់ប្រទេសស៊ុយអែដ ដែលកំពុងឆ្លងកាត់នៅជិតៗកោះពូឡូវៃទៀត ។ បន្ទាប់មក នៅព្រឹកថ្ងៃទី១២ ខែឧសភា ពួកគេបានបញ្ចុះកងទ័ពមួយក្រុមតូចឲ្យឡើងទៅនៅលើកោះនោះ ហើយបានបញ្ជាក់អះអាងពីសិទ្ធិពេញច្បាប់របស់គេលើកោះពូឡូវៃទៀតផង ។

ប៉ុន្មានម៉ោងក្រោយមក មាននាវាដឹកជញ្ជូនអាមេរិកាំងមួយគ្រឿងឈ្មោះ ម៉ៃយ៉ាហ្គេ បានបើកចូលទៅកៀកកោះពូឡូវៃមែនទែនរហូតដល់ទ័ពជើងទឹកខ្មែរក្រហម ដែលទទួលបទបញ្ជាឲ្យនៅរក្សាការពារទល់នឹងការឈ្លានពានរបស់បរទេស បានព័ទ្ធស្ទាក់ចាប់នាវានេះបាន ។ ប្រតិបត្តិការនេះ ត្រូវបានដឹកនាំធ្វើដោយនាវាល្បាតជាច្រើនគ្រឿងរបស់ភូមិភាគនិរតី ដោយគ្មានបានធ្វើការទាក់ទងផ្ទាល់ជាមួយក្រុងភ្នំពេញឡើយ ។

ក្រុងវ៉ាស៊ីនតោន បានដឹងពីការស្ទាក់ចាប់នាវានេះមុនក្រុងភ្នំពេញទៅទៀត ហើយបានប្រកាសថា នេះជាឧប្បត្តិហេតុអន្តរជាតិដ៏ធ្ងន់ធ្ងរមួយ ។ តែប៉ុន្មានសប្តាហ៍កន្លងផុតទៅប៉ុណ្ណោះ តាំងពីបរាជ័យជាប្រវត្តិសាស្ត្ររបស់ទីក្រុងព្រៃនគរ និងក្រុងភ្នំពេញដែលធ្វើឲ្យសហរដ្ឋអាមេរិករន្ធត់ក្នុងចិត្ត និងអាម៉ាស់មុខយ៉ាងខ្លាំង ។ ហង់រី គីស៊ីងហ្គ័រ ដែលប្រធានាធិបតីថ្មី ហ្សេរ៉ាល់ ហ្វដ ទុកឲ្យនៅធ្វើជារដ្ឋមន្ត្រីការបរទេស បានកែប្រែធ្វើឲ្យរឿងចាប់នាវានេះ ទៅជាការប្រឈមមុខខាងសង្គ្រាមត្រជាក់វិញ ។ គាត់បានថ្លែងប្រកាសថា «វាមានកម្រិតព្រំដែនដែលសហរដ្ឋអាមេរិកពុំអាចបណ្តោយគេលោតរំលងពីលើបាន» ហើយវិបត្តិនេះ ត្រូវបានបង្ហាញជាផ្លូវការថាជាបញ្ហា «ធ្ងន់ធ្ងរជាងគេបំផុត» ដែលប្រធានាធិបតី ហ្វដ ត្រូវប្រឈមមុខដោះស្រាយ ។

សេតវិមាន បានទាមទារជាសាធារណៈឲ្យមានការដោះលែងនាវានេះជាបន្ទាន់ ។ រដ្ឋាភិបាលអាមេរិកាំងបានបញ្ជូនសារលិខិតជាច្រើនទៅឲ្យពួកខ្មែរក្រហម តាមរយៈប្រទេសចិន ដោយតម្រូវឲ្យដោះលែងនាវាមកវិញក្នុងរវាងម្ភៃបួនម៉ោង ហើយគំរាមធ្វើការសងសឹកវិញ បើសិនជាខ្លួនពុំបានទទួលសេចក្តីពេញចិត្តក្នុងរឿងនេះ ។ ពួកចិនបានបញ្ជូនសារលិខិតទាំងនោះត្រឡប់មកវិញ ដោយមានភ្ជាប់សេចក្តីមួយថា ពួកគេពុំមានមធ្យោបាយភ្ជាប់ការទាក់ទងនឹងពួកមេដឹកនាំកម្ពុជាសោះឡើយ ។ កាលណោះ ក្រុងប៉េកាំង ប្រហែលជាមានការទាក់ទងជាមួយក្រុងភ្នំពេញតែតាមទូរស័ព្ទ ឬតេឡិចប៉ុណ្ណោះ ប៉ុន្តែវាពុំប្រាដជាអឺចឹងទេ ។ នៅខែឧសភានោះ ពុំទាន់មានរដ្ឋាភិបាលពិតប្រាកដមួយនៅទីក្រុងភ្នំពេញទេ ហើយក៏ពុំទាន់មានគណៈបេសកកម្មទូតណាមួយតាំងនៅទីនោះដែរ ហើយជាពិសេសនៅពុំទាន់មានបណ្តាញទូរគមនាគមន៍ណាមួយ ដោយផ្ទាល់ និងឆាប់រហ័សរវាងក្រុងភ្នំពេញ និងពិភពលោកខាងក្រៅផង ។

នៅពេលដែលឱសានវាទផុតកំណត់ដោយខ្លួនពុំបានទទួលចម្លើយតបមកវិញ សេតវិមាន បានចេញបញ្ជាឲ្យធ្វើការសងសឹកខាងយោធា ហើយយន្តហោះអាមេរិកាំងជាច្រើនគ្រឿង បានត្រូវបញ្ជូនឲ្យទៅទម្លាក់គ្រាប់បែកនៅលើតំបន់នោះ ។ នាវាឈ្លបយកការណ៍មួយចំនួនរបស់អាមេរិកាំង ក៏បើកសំដៅឆ្ពោះទៅឈូងសមុទ្រសៀម

ដែរ ។ ក្រោយពេលដែលផ្នែកយកការណ៍ស៊ើបដឹងថា ក្រុមនាវិកនាវាម៉ៃយ៉ាហ្គេទាំងអស់ ត្រូវគេផ្ទេរចេញទៅដាក់នៅលើដីគោកហើយនោះ យន្តហោះអាមេរិកាំងក៏ចាប់ទម្លាក់គ្រាប់បែកទៅលើកោះតាងភ្លាម ។ ក្នុងពេលជាមួយគ្នានោះ សហរដ្ឋអាមេរិកបានស្នើលោក ខឹត វ៉ាល់ដែម អគ្គលេខាធិការអង្គការសហប្រជាជាតិជួយដឹងឮពីរឿងនេះដែរ ។ លោក វ៉ាល់ដែម រាវែកចិត្ត បន្ទាប់មក បានប្រកាសថា អង្គការសហប្រជាជាតិ ក៏គ្មានមធ្យោបាយភ្ជាប់ទំនាក់ទំនងជាមួយពួកកម្ពុជារបៀបដូចតែគ្នា ។

ក្នុងពេលនោះ ពួកមេដឹកនាំក្រុងភ្នំពេញបានបញ្ជាក់ថា ពួកគេបានដឹងពីការស្ទាក់ចាប់នាវានេះ ដោយសារតែការផ្សាយរបស់វិទ្យុ «សំឡេងសហរដ្ឋអាមេរិក[៤៣]» ប៉ុណ្ណោះ ។ បក្សបានចេញបទបញ្ជាភ្លាម ទៅឲ្យពួកអាជ្ញាធរកំពង់ផែកំពង់សោមចាប់ផ្ដើមការទាក់ទងជាមួយកងទ័ពនៅកោះពូឡូវៃ និងឲ្យកោះហៅមេបញ្ជាការរបស់គេ មកកាន់ទីក្រុងភ្នំពេញជាបន្ទាន់ ។

អៀង សារី បានរ៉ាយរ៉ាប់ថា «មេបញ្ជាការនោះបានមកដល់ភ្នំពេញ នៅម៉ោងពីរសៀលថ្ងៃដដែល ។ គាត់បានផ្ដល់ព័ត៌មានប្រាប់ពីហេតុការណ៍នេះ ហើយប្រមាណជាម៉ោងប្រាំល្ងាច យើងបានឲ្យគាត់វិលត្រឡប់ទៅវិញជាមួយបញ្ជាឲ្យដោះលែងនាវាម៉ៃយ៉ាហ្គេទៅឲ្យសហរដ្ឋអាមេរិកវិញភ្លាមកុំបង្អង់» ។

ស្អែកឡើងថ្ងៃទី១៤ ខែឧសភា វេលាព្រឹក រដ្ឋមន្ត្រីក្រសួងឃោសនាការ ហ៊ូ នឹម បានប្រកាសជាសាធារណៈតាមវិទ្យុរដ្ឋាភិបាលថា នាវានេះនឹងត្រូវដោះលែងទៅវិញ ។ (នៅខណៈនេះ មានតែ ខៀវ សំផន និង ហ៊ូ នឹម ប៉ុណ្ណោះ ដែលកាន់កាប់តំណែងជាផ្លូវការក្នុងរដ្ឋាភិបាលមួយ ដែលមានតែឈ្មោះនៅឡើយ ហើយដែលដឹកនាំដោយសម្ដេច ព្រះនរោត្តម សីហនុ ។ គឺក្នុងនាមពួកខ្មែរក្រហមនេះហើយ ដែលបានចេញបទបញ្ជាមួយសមស្របតាមកាលៈទេសៈនោះ បើគេគិតពីស្ថានភាពប្រទេសក្នុងអំឡុងសប្ដាហ៍ដំបូងៗបន្ទាប់ពីសង្គ្រាមផុតរលត់ទៅ ហើយពិសេស ជាងនេះទៅទៀត គឺការភ័យខ្លាចក្រែងពួកអាមេរិកាំងត្រឡប់មកទម្លាក់គ្រាប់បែកលើរដ្ឋធានីវិញ ។ ជាក់ច្បាស់ណាស់ ពួកកុម្មុយនិស្តកម្ពុជាពុំចង់ឲ្យមានការប្រឈមមុខមួយ ជាមួយសហរដ្ឋអាមេរិកទេ នៅចំពេលដែលពួកគេខំប្រឹងដេញកម្ចាត់ពួកវៀតណាមចេញពីកោះពូឡូវៃ ។

ចម្លើយរបស់ ហ៊ូ នឹម ផ្ដើមឡើងពុំបានលឿនរហ័សទាន់សភាពការណ៍សម្រាប់សហរដ្ឋអាមេរិកសោះ ។ សាមសិបនាទីក្រោយការប្រកាសព័ត៌មានផ្សាយតាមវិទ្យុខ្មែរក្រហម កងកុម្មង់ដូម៉ារីនអាមេរិកាំងមួយក្រុមបានវាយឡើងគោកនៅកោះតាង ហើយសេតវិមានបានបកស្រាយថា ក្រុងភ្នំពេញនិយាយមិនបានច្បាស់លាស់សោះថា គេនឹងដោះលែងក្រុមនាវាវិញព្រមជាមួយនឹងនាវាផងទេ ។ ពួក«ម៉ារីន» បានបះទង្គិចនឹងករទប់ទល់មួយយ៉ាងខ្លាំងក្លាពីសំណាក់ពួកខ្មែរក្រហម ដែលបានពង្រឹងស្ថានភាពការពារនៅលើកោះនោះរួចមុនជាស្រេច ក្នុងបំណងត្រៀមទុកឲ្យហើយចំពោះការវាយលុកមួយរបស់វៀតណាម ។

ក្នុងរយៈពេលដែលពួកទាហានម៉ារីនអាមេរិកាំង វាយប្រយុទ្ធគ្នានៅកោះតាង ពួកអាជ្ញាធរខ្មែរ បានដោះ

លែងក្រុមនាវិក និងនាវាម៉ៃយ៉ាហ្គេ ដោយគ្មានឧប្បត្តិហេតុអ្វីឡើយ ។ ប៉ុន្តែ សហរដ្ឋអាមេរិកបានបញ្ជូនយន្តហោះឲ្យទៅធ្វើការវាយឆ្មក់តាមផ្លូវអាកាសជាលើកចុងក្រោយមួយនៅលើដីគោកទៀត ហើយធ្វើឲ្យតំបន់កំពង់ផែកំពង់សោមរងការខូចខាតជាទម្ងន់ - ចំណតរថភ្លើង រោងចក្រចម្រាញ់ប្រេងកាត អាកាសយានដ្ឋាន ព្រមទាំងផ្លូវសម្រាប់យន្តហោះចុះឡើង រោងបន្ទាធំៗសម្រាប់ដាក់យន្តហោះ និងយន្តហោះជាច្រើនគ្រឿងរបស់មូលដ្ឋាននាវាចរវាម ដែលស្ថិតនៅក្បែរនោះផង ។ តាមដឹង ការវាយប្រហារតាមអាកាសនេះ មានគោលដៅ "ការពារ" កងទ័ពម៉ារីនអាមេរិកាំងដែលខំប្រឹងចាកចេញដោយគ្នាច្រើនពីកោះតាង ដែលនៅតំបន់ឆ្ងាយ ប៉ុន្តែ ដូចមេដឹកនាំអាមេរិកាំង បានប្រកាសរឿងនេះប្រាប់ទស្សនាវដ្ដីមួយនៅពេលនោះថា ៖ «វានឹងពុំក្លាយទៅជា រឿងអាក្រក់ទេ បើសិនជាម្ចាងទៀតមិនធ្វើមួយជ្រុលហួស ហើយខំប្រឹងឆ្លៀតទាញគុណប្រយោជន៍ដែលយើងស្ថិតនៅលើដីដើម្បីព័ទ្ធចាប់យើងទាំងរស់ ។ ប្រការនេះ នឹងផ្ដល់ឱកាសឲ្យយើងវាយប្រហារគេដោយមិនឲ្យដឹងខ្លួនមុន - ដោយសំពងយ៉ាងខ្លាំង[៤៤]» ។

នៅពេលដែលការប្រយុទ្ធគ្នាផុតរលត់ទៅ ទាហានអាមេរិកាំងសាមសិបប្រាំនាក់ បានត្រូវស្លាប់ព្រោះតែទៅជួយសង្គ្រោះក្រុមនាវិកនាវាម៉ៃយ៉ាហ្គេចំនួនសាមសិបប្រាំបួននាក់ ហើយភាគច្រើននៃទាហានម៉ារីនទាំងនេះ គឺត្រូវស្លាប់ក្រោយ ពីមានការដោះលែងពួកកម្មករនាវាថែមទៅទៀត ។ អ្នករងគ្រោះទាំងនោះ ត្រូវបានគេចុះបញ្ជីថា ជាការខូចខាត ចុងក្រោយបង្អស់របស់សហរដ្ឋអាមេរិក នៅក្នុងសង្គ្រាមនៅឥណ្ឌូចិន[៤៥] ។

ក្រុងវ៉ាស៊ីនតោន បានលើកសរសើរពីជោគជ័យនេះយ៉ាងគគ្រឹកគគ្រេង ។ ប៉ុន្តែ ឯកអគ្គរដ្ឋទូតអាមេរិកាំងប្រចាំក្រុងបាងកក បានវាយតម្លៃវិបត្តិនេះក្រោមលក្ខណៈមួយខុសគ្នាយ៉ាងខ្លាំង ។ «មេបញ្ជាការទ័ពតាមមូលដ្ឋានជាច្រើនរបស់កម្ពុជា ប្រហែលជាមានស្វ័យភាពដ៏ធំធេងមួយ ហើយបានប្រើសិទ្ធិអំណាចរបស់គេស្រេចតែក្បាលចិត្ត ជួនកាលធ្វើឲ្យមានឧបសគ្គដល់រដ្ឋអំណាចមជ្ឈិមទៀតផង[៤៦]» ។ នេះជាទូរលេខសម្ងាត់មួយ ដែលសំអាងដោយផ្អែកៗទៅលើឧប្បត្តិហេតុនាវាម៉ៃយ៉ាហ្គេនេះ ។

ជ័យនឹងអំនួតក្អេងក្អាងរបស់ពួកគេ គឺពុំមែនពួកអាមេរិកាំងទេ ដែលចេញពីស្ថានភាពប្រឈមមុខគ្នា ជាអ្នកឈ្នះនោះ ប៉ុន្តែគឺពួកវៀតណាមទៅវិញសោះ ។ ពួកអាមេរិកាំងបានបំផ្លាញផ្នែកអាកាសចររបស់កម្ពុជាអស់មួយផ្នែកធំហើយបានធ្វើឲ្យកងម៉ារីនរបស់កម្ពុជាខូចខាតជាទម្ងន់ ។ អាស្រ័យហេតុនេះ ពួកខ្មែរក្រហមគោងតែផ្អាកផែនការវាយប្រយុទ្ធរបស់គេទាំងអស់ជាមួយពួកវៀតណាម និងជម្លោះផ្សេងៗទៀតក្នុងការដណ្ដើមយកកោះដែលស្ថិតនៅឯនាយសមុទ្រសិន ។ នៅខែមិថុនា ពួកគេបានយល់ព្រមតាមសំណើរបស់ពួកវៀតណាម ស្ដីពីការផ្លាស់ប្ដូរទស្សនកិច្ចមួយទៅវិញទៅមករវាងពួកមេដឹកនាំនៃប្រទេសទាំងពីរ ។ ពួកកម្ពុជាបានធ្វើការសុំទោសរបស់ពួកគេ ចំពោះ«ឧប្បត្តិហេតុ»ទាំងនោះ ដោយប្រកាសថា ពួកមេបញ្ជាការប្រចាំមូលដ្ឋានទាំងនោះ មានកម្រិតយល់ដឹងខាងផ្នែកភូមិសាស្ត្រតិចតួចណាស់ ។ ពួកវៀតណាមបានយកកោះពូឡូវៃ ធ្វើជាកម្មសិទ្ធិរបស់ខ្លួនឡើងវិញ ។

ផលវិបាកមួយទៀតដែលសំខាន់ដូចគ្នា គឺប្រហែលជានិមិត្តរូបរបស់សហរដ្ឋអាមេរិក ដែលនៅតែដក់ជាប់ក្នុងចិត្តគំនិតរបស់ពួកខ្មែរក្រហមហើយមើលទៅ ។ ជាថ្មីម្តងទៀត ពួកអាមេរិកាំងបានទម្លាក់គ្រាប់បែកទៅលើប្រទេសរបស់គេដោយគ្មានមូលហេតុសោះ ក្រោយពេលដែលពួកគេសន្យាដោះលែងនាវាដែលខ្លួនស្កាត់ចាប់បានរួចហើយក៏ដោយ ។ ឧប្បត្តិហេតុនាវាម៉ៃយ៉ាហ្គេបានបន្ថែមទៅលើការប្រកាន់ក្នុងចិត្តរបស់ពួកគេឲ្យកាន់តែច្បាស់ថា ចក្រពត្តិនិយមអាមេរិកាំងប្រហែលជាសេចក្តីកង្វល់ចម្បងរបស់គេ ហើយភាពប្រទូសរ៉ាយចំពោះប្រទេសវៀតណាម បានលាប់ឡើងវិញមួយភ្លែត ។ ពួកខ្មែរ និងពួកវៀតណាម បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសហប្រតិបត្តិសេដ្ឋកិច្ចមួយនៅខែសីហា ក្នុងឱកាសទស្សនកិច្ចមួយរបស់មេដឹកនាំវៀតណាម ឡេ យន់ នៅទីក្រុងភ្នំពេញ ។

ពីខែឧសភា ឆ្នាំ១៩៧៥ មកនិទាឃរដូវឆ្នាំ១៩៧៧ ពួកខ្មែរក្រហមជឿថា សហរដ្ឋអាមេរិកបានខំប្រឹងល្បងបំផ្លាញការបដិវត្តរបស់គេ ដោយប្រើប្រាស់ភ្នាក់ងារសេ.អ៊ី.អា.ជាច្រើននាក់ ។ ក្រុងភ្នំពេញនៅតែចាត់ទុកសហរដ្ឋអាមេរិក ជាសត្រូវធំបំផុតដែលមានគ្រោះថ្នាក់ជាងគេ ហើយបើប្រៀបធៀបគ្នាទៅ ប្រទេសវៀតណាមគ្រាន់តែបង្កការគំរាមកំហែងបន្តិចបន្តួចប៉ុណ្ណោះ ។

ពួកខ្មែរក្រហម បានសម្រេចចិត្តមិនចូលរួមក្នុងបក្សសម្ព័ន្ធណាមួយឡើយ ទាំងក្នុងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ហៅអាស៊ាន ដែលទ្រទ្រង់ដោយលោកខាងលិច ទាំងមិនចុះសន្ធិសញ្ញាមិត្តភាពមួយជាមួយប្រទេសវៀតណាមថែមទៀត ។ ក្រុងភ្នំពេញអាចធ្វើពាណិជ្ជកម្មជាមួយក្រុងហាណូយបាន ប៉ុន្តែ ជាផ្លូវការ ប្រទេសវៀតណាមនៅតែជាមិត្តមួយដដែលដែលជាមួយនឹងប្រទេសនេះ កម្ពុជានៅមានរឿងទាស់ទែងគ្នាជាច្រើននៅឡើយ ។ ចំណែកសហរដ្ឋអាមេរិកគឺជាសត្រូវចក្រពត្តិធំបំផុត ។

ក្រោយឧប្បត្តិហេតុនាវាម៉ៃយ៉ាហ្គេ ពួកខ្មែរក្រហមបានចាប់ផ្តើមកិច្ចប្រឹងប្រែងរបស់គេឡើងវិញ ដើម្បីរៀបចំពង្រឹងសជីហរ និងការបដិវត្តន៍របស់គេ ។ កងទ័ពជាតិមួយត្រូវបានបង្កើតឡើង ភូមិភាគនានាបានទទួលការកំណត់ព្រំដែនជាថ្មីបន្ទាប់ពីសម័យសង្គ្រាម ហើយក្រុងភ្នំពេញក៏រៀបចំបង្កើតឲ្យមានមន្ទីរ ក្រសួងនានារបស់រដ្ឋដែរ ទីស្តីការរដ្ឋមន្ត្រី បណ្តាអគ្គការបក្ស ហើយនិងសហគ្រាសពាណិជ្ជកម្មនិងឧស្សាហកម្ម ។ តាមការវាយតម្លៃរបស់ពួកកុម្មុយនិស្តថា វាដូចជាឆាប់រហ័សពេកក្នុងការដាក់ជំនួសសម្តេច ព្រះនរោត្តម សីហនុ ដោយ ប៉ុល ពត នោះ ប៉ុន្តែ មានឥស្សរជនខ្លះនៃរដ្ឋាភិបាល បានប្រគល់តំណែងទៅឲ្យបណ្តាមេដឹកនាំរបស់បក្សនៅខែសីហារួចទៅហើយ ។ អៀង សារី ត្រូវបានតែងតាំងជារដ្ឋមន្ត្រីក្រសួងការបរទេស ជំនួសកន្លែង សារិន ឆាក ដែលជាអ្នកឯកទេសដ៏ឆ្នើមជាងគេរបស់កម្ពុជាខាងទំនាក់ទំនងខ្មែរ-វៀតណាម ។ គាត់ជាមនុស្សដែលនៅតែមិនទុកចិត្តក្រុងហាណូយជាង អៀង សារី ផ្ទាល់ដែលជាខ្មែរក្រោមនោះទៅទៀត ។ សុន សេន សមាជិកនៃក្រុមក្រុងប៉ារីសម្នាក់ទៀត ដែលនៅអែបជាប់ ប៉ុល ពត នោះ បានក្លាយទៅរដ្ឋមន្ត្រីក្រសួងការពារប្រទេស ។ សារី និង សុន សេន

ដែលជាសមាជិកគណៈលេខាមជ្ឈិមបក្សបានកាន់កាប់តំណែងសំខាន់ទាំងពីរនេះតាំងពីមុនរដ្ឋាភិបាល ដែលមានលក្ខណៈគ្រាន់តែបញ្ឆោត ត្រូវបានប្រកាសរំលាយជាផ្លូវការម្ល៉េះ ដើម្បីបង្ហាញប្រាប់ពិភពលោកនូវមុខមាត់ពិតប្រាកដរបស់កម្ពុជាប្រជាធិបតេយ្យបដិវត្ត ។

សារី បានយកពួកអតីតក្រុមក្រុងប៉ារីស មកបំពេញក្រសួងរបស់គាត់ ហើយយក ដួន ប្រសិទ្ធិ ដែលជាមិត្តជិតស្និទ្ធជាងគេរបស់គាត់កាលនៅរៀនប្រទេសបារាំង មកធ្វើជាឧបការី ។ បណ្តាបញ្ញវន្តដទៃទៀត ដូចជា ឱក សាគុណ និង គាត ឈន់ ជាដើម បានរកឃើញទីពំនឹងមួយ និងកិច្ចគាំពារដ៏ជាក់លាក់មួយក្នុងក្រសួងនេះ នៅពេលដែលបក្សចាប់ផ្តើមធ្វើការបោសសម្អាតពួកបញ្ញវន្តរបស់ខ្លួន ។ អ្នកឯទៀតដែលមានចំនួនយ៉ាងច្រើនបំផុតពុំបានទទួលភ័ព្វវាសនាដូចនេះទេ ។ ភ្នាក់ងារទូតជាច្រើនដែលធ្វើការដើម្បីផលប្រយោជន៍សម្រាប់ខ្មែរក្រហមក្នុងពេលសង្គ្រាមនោះ ក៏ពុំបានទទួលមុខតំណែងអ្វីដែរបន្ទាប់ពីឆ្នាំ១៩៧៥ ហើយបានត្រូវគេបញ្ជូនទៅដាក់នៅក្នុងជំរំពលកម្មពិសេសៗ មិនឆ្ងាយពីទីក្រុងប៉ុន្មានឡើយ ។ នៅទីនោះ ពួកគេបានជួបនឹងបញ្ញវន្តជាច្រើនដែលធ្លាប់ជួយគាំទ្រពួកខ្មែរក្រហមនៅបរទេសជាថ្មីម្តងទៀត ហើយដែលសុទ្ធតែត្រឡប់មកកម្ពុជាវិញ ដើម្បីជួយការបដិវត្ត ។ ក្នុងឋានៈជាបញ្ញវន្ត ពួកគេមុខជាទទួលរងសេចក្តីស្លាប់ក្នុងជំរំពិសេសទាំងនេះមិនខាន ។ ប៉ុន្តែ ការរស់នៅដោយលំបាកវេទនាដូចការរស់នៅក្នុងជំរំទាំងនេះ ឃើញថា មិនអាចមានគ្រោះថ្នាក់ជាងកន្លែងឯទៀតៗ ក្នុងប្រទេសកម្ពុជានៅកំឡុងការបដិវត្តទីពីរ ដែលពួកគេត្រូវដើរតាមឡើយ ។

សារី បានត្រៀមខ្លួនកាន់មុខងារផ្សេងៗដែលគាត់កាន់កាប់នៅពេលនេះ តាំងពីយូរយារមកហើយ ។ គាត់ធ្លាប់បានរៀបចំគោលការណ៍ខ្មែរក្រហម ស្តីពីការងារបរទេស និងលទ្ធិកុម្មុយនិស្តអន្តរជាតិតាំងពីជំនាន់គាត់នៅទីក្រុងប៉ារីសម្ល៉េះ ដែលនៅក្នុងពេលនោះគាត់ធ្លាប់បានទៅចូលរួមជាបន្តបន្ទាប់ក្នុងមហាស្រពយុវជនកុម្មុយនិស្តជាច្រើនលើក ដែលគេរៀបចំឡើងនៅអឺរ៉ុប និងបានជួបពួកអ្នកតំណាងកុម្មុយនិស្តនៃប្រទេសធំៗព្រមទាំងបានស្តាប់គោលគំនិតអំពីការបដិវត្តជាតិ និងពិភពលោករបស់គេផង ។ បន្ទាប់មក គាត់បានវិលត្រឡប់មកប្រទេសវិញ ហើយបានរួមចំណែកជួយដល់ការបដិវត្តកម្ពុជាជាមួយបងថ្លៃរបស់គាត់ គឺ ប៉ុល ពត ដោយបង្រៀនឲ្យដឹងវិធីសាស្ត្រផ្សេងៗ និងចរិតមនុស្សរបស់បក្ស ដោយយល់ព្រមទទួលភារកិច្ចផ្សេងៗដែលបងថ្លៃគាត់ប្រគល់ឲ្យ ៖ តាំងពីការពង្រីកពង្រឹងបក្សនៅភ្នំពេញ នៅដើមទសវត្សរ៍១៩៦០ រហូតដល់ការងារទំនាក់ទំនងជាមួយនឹងប្រទេសវៀតណាម និងចិន ។ ក្នុងសម័យសង្គ្រាម សារី បានចំណាយពេលវេលាដ៏សំខាន់របស់គាត់ដោយចេញមុខទាក់ទងជាមួយនឹងសម្ព័ន្ធមិត្តបរទេសនានា ដោយធ្វើដំណើរចុះឡើងទៅក្រុងប៉េកាំង ឬក្រុងហាណូយ រ៉ាប់រង“ការទាក់ទងគ្នា” ជាមួយសម្តេច ព្រះនរោត្តម សីហនុ និងប្រុងប្រយ័ត្នមិនឲ្យសម្តេចធ្វើអ្វីរំលងព្រំដែនដែលគេបានកំណត់ឲ្យទ្រង់ធ្វើនោះផង ។

ក្នុងឱកាសនេះ គាត់នឹងថ្លែងការណ៍ទៅកាន់អង្គការសហប្រជាជាតិ និងពិភពលោកក្នុងឋានៈជារដ្ឋមន្ត្រី

ក្រសួងការបរទេសរបស់កម្ពុជាប្រជាធិបតេយ្យ ។ គាត់ជាតំណាងនៃការស្អប់ខ្ពើមជនបរទេសរបស់ប្រទេសកម្ពុជា ដោយច្រានចោលសំណើសុំផ្តល់ជំនួយមកឲ្យកម្ពុជាទាំងអស់ និងអះអាងបញ្ជាក់ពីការមិនចូលបក្សសម្ព័ន្ធណាមួយរបស់ប្រទេសគាត់ទាំងស្រុង ។ សារី គឺជាមនុស្សតែម្នាក់គត់ ដែល ប៉ុល ពត ជឿទុកចិត្តសម្រាប់ឲ្យនិយាយប្រាប់ពិភព លោកពីមុខមាត់ពិតប្រាកដរបស់កម្ពុជាបដិវត្ត ។ គេបាននិយាយថា គាត់ក៏ជាមនុស្សតែម្នាក់គត់ដែរ ដែលហ៊ាន និយាយឲ្យ ប៉ុល ពត ដឹងនូវរឿងមិនជាទីពេញចិត្ត ដែលគាត់ប្រមូលបានក្នុងរយៈពេលនៃបេសកកម្មមួយក្នុង ចំណោមបេសកកម្មជាច្រើនលើកនៅឯបរទេស ។ សារី តែងតែធ្វើដំណើរជាមួយ ប្រសិទ្ធិ ដែលបម្រើគាត់ជា ជំនួយការ និងជាអ្នកបកប្រែភាសា ដែលភារកិច្ចនេះ ប្រសិទ្ធិបានបំពេញសម្រាប់ ប៉ុល ពត នៅកម្ពុជា ។ អតីត សាឡុត ស កម្រទទួលជួបជនបរទេសម្នាក់ដោយគ្មាន សារី និង ប្រសិទ្ធិ នៅអមក្បែរគាត់ឡើយ ។ នៅពេលដែលបញ្ហាអន្តរជាតិកាន់តែមានសារសំខាន់ខ្លាំងឡើងៗក្នុងបណ្តាឆ្នាំជាបន្តបន្ទាប់មកទៀត សារី ត្រូវបានចាត់តាំងឲ្យទទួលបន្ទុករៀបចំ និងអនុវត្តផែនការមួយ ក្នុងគោលបំណងជួយស្រោចស្រង់ប្រទេសជាតិ ។

សុន សេន រដ្ឋមន្ត្រីការពារប្រទេស ក៏ជាមនុស្សម្នាក់ដែលបានត្រៀមខ្លួនទទួលមុខតំណែងនេះ ដូចជា សារី តាំងពីយូរយារមកហើយដែរ បើទុកជាការរៀនសូត្ររបស់គាត់ខាងវិស័យនេះមិនសូវជាបានដុំកំភួនក៏ដោយ ។ គាត់ជាគរុកោសល្យវិទូពេញលក្ខណៈ ដោយបានទទួលបរិញ្ញាប័ត្រផ្នែកទស្សនវិជ្ជា មួយនៅសាលាស័រប៊ោន ក្រុងប៉ារីស ។ គាត់បានវិលត្រឡប់មកភ្នំពេញវិញនៅឆ្នាំ១៩៥៥ ដើម្បីបង្រៀនសិស្ស និងដឹកនាំការបដិវត្ត ។ សុន សេន ធ្លាប់ត្រូវបានតែងតាំងឲ្យធ្វើការនៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ និងវិទ្យាល័យស៊ីសុវត្ថិ មុននឹងក្លាយជានាយកផ្នែកស្រាវជ្រាវនៅវិទ្យាស្ថានជាតិគរុកោសល្យ ។ ក្នុងកំឡុងពេលនៃការកាន់កាប់មុខតំណែងនេះហើយ ដែលមានផ្ទុះឡើងនូវបាតុកម្មរបស់ពួកនិស្សិតក្នុងឆ្នាំ១៩៦៣ ហើយដែលសម្តេច ព្រះនរោត្តម សីហនុ បានចាត់ទុកគាត់ជាអ្នក ទទួលខុសត្រូវក្នុងរឿងនេះ ។ ដោយគួរឲ្យស្តាយ សេន បានប្រកាសក្រោយមកថា គាត់មិនអាចបញ្ចេញអំនួត ថា គាត់បានកេណ្ឌនិស្សិតទាំងនោះឲ្យធ្វើបាតុកម្មឡើយ ក៏ប៉ុន្តែ សម្តេច ព្រះនរោត្តម សីហនុ ពុំបានចុះឈ្មោះគាត់ក្នុងបញ្ជីឈ្មោះ មនុស្សចំនួន សាមសិបប្អូននាក់ដែរ ហើយ សេន បានចាកចេញ ពីទីក្រុងជាមួយនឹងជនកុម្មុយនិស្តជាច្រើននាក់ ផ្សេងទៀតទៅ ។

មនុស្សមាឌតូចស្តើង ពាក់វ៉ែនតាស បានត្រូវគេប្រគល់ភារកិច្ចឲ្យទទួលខុសត្រូវខាងផ្នែកកងទ័ព ។ សេចក្តីស្មោះត្រង់ដែលគាត់បង្ហាញឲ្យឃើញតាំងពីនៅក្រុងប៉ារីស ប្រហែលបង្កជាមូលដ្ឋាននៃការទុកចិត្តឲ្យគាត់កាន់មុខតំណែងសំខាន់ជាងគេនេះហើយ ។ សេន បានចាប់ផ្តើមបំពេញមុខងារថ្មីរបស់គាត់ក្នុងឋានៈជាអ្នកដែលមានវិជ្ជាជ្រៅជ្រះ ហើយដែលបានសិក្សាយ៉ាងស៊ីជម្រៅអំពីសង្គ្រាមទាំងឡាយ ដែលគាត់វិនិច្ឆ័យថា មានលក្ខណៈសមស្របជាងគេ ដូចជាសង្គ្រាមរបស់ព្រះចៅអធិរាជ ណាប៉ូឡេុង ជាដើម ជាពិសេសការឡោមព័ទ្ធទីក្រុងមូស្គូ

និងសង្គ្រាមរបស់ចក្រភពអូទ្រីស-ហុងគ្រី[៤៧] ។ គាត់ចង់ដឹងណាស់ ពីរបៀបដែលពួករុស្ស៊ីវាយបំបាក់ពួកចក្រពត្តិបារាំង ពីរបៀបដែលចក្រភពអូទ្រីស ត្រូវគេធ្វើឲ្យវិនាសបន្តិចម្តងៗ ។ គាត់គ្មានបានធ្វើការសិក្សាណាមួយអំពីសង្គ្រាមទ័ពព្រៃ ឬសង្គ្រាមរបស់ប្រជាជនអាស៊ីទេ ហើយ សេន គឺជាតួយ៉ាងគំរូដែលទទួលរងឥទ្ធិពលពីប្រព័ន្ធអប់រំរបស់បារាំងតែមួយ ។ ប៉ុន្តែមិនដូច្នោះ ក្នុងរយៈពេលនៃការប្រយុទ្ធតស៊ូជាងដប់ឆ្នាំនៅក្នុងព្រៃ គាត់បានដឹកនាំធ្វើសង្គ្រាមឈ្លបមួយប្រកបដោយជោគជ័យគួរឲ្យភ្ញាក់ផ្អើល ។ ក្នុងកំឡុងនៃការប្រយុទ្ធគ្នាចំនួនប្រាំឆ្នាំ មានការធ្វើប្រតិបត្តិការសឹកតាមបែបធម្មតាតិចតួចណាស់ ។ ជ័យជម្នះទាំងអស់ជាលទ្ធផលបានមកពីការសង្គ្រាមទ័ពព្រៃមួយផ្នែកធំ ហើយគេបានប្រគល់ទៅឲ្យ សេន នូវគុណសម្បត្តិដ៏សំខាន់ចំពោះការវាយលុកផ្តាច់ព្រ័ត្រនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដែលធ្វើឲ្យគេស្រឡាំងកាំងគ្រប់គ្នា ។

ដូច្នេះ ការតែងតាំងគាត់ជារដ្ឋមន្ត្រីការពារប្រទេស គឺពិតជាសមហេតុសមផល បើទុកជាលេខាបក្សភូមិភាគខ្លះធ្លាប់មានបទពិសោធន៍មួយខាងផ្នែកកងទ័ពយូរជាងគាត់ក៏ដោយ ។ ប៉ុន្តែ ជាមួយនឹង សេន ប៉ុល ពត ពុំញញើតនឹងផ្ញើសេចក្តីទុកចិត្តទៅលើរូបគាត់ឡើយ ។ ក្នុងបណ្តាឆ្នាំជាបន្តបន្ទាប់មកទៀត ការយល់ដឹងរបស់ សេន បានលេចឡើងឲ្យឃើញហាក់ដូចជាមានកម្រិតព្រំដែន ។ គាត់ចេះដឹងពីបញ្ហាកងទ័ពរបស់កម្ពុជាយ៉ាងច្បាស់ គាត់ធ្លាប់បានសិក្សាស្រាវជ្រាវពីសង្គ្រាមផ្សេងៗរបស់ពួកអឺរ៉ុប ប៉ុន្តែ គាត់ពុំមែនជាអ្នកឯកទេសខាងបញ្ហាកងទ័ពវៀតណាមឡើយ ។

សមាជិកនៃរដ្ឋាភិបាលរណសិរ្សសម័យសង្គ្រាមមួយភាគបានស្ថិតនៅទីក្រុងប៉េកាំងជាមួយសម្តេច ព្រះនរោត្តម សីហនុ នៅឡើយ ដែលគេប្រើជាមេដឹកនាំមានតែឈ្មោះ ប៉ុន្តែអត់អំណាចដដែល បើទុកជាព្រះអង្គសារភាពថា ពុំដែលបានដឹងពីព្រឹត្តិការណ៍ដែលកើតមាននៅកម្ពុជាយ៉ាងណាក៏ដោយ ។ ប៉ុន្តែ បក្សបានរៀបចំធ្វើការបដិវត្តដំណាក់កាលទីពីររួចជាស្រេច គឺការផ្លាស់ប្តូរមេដឹកនាំទាំងស្រុងមួយក្នុងបណ្តាខែជាបន្តបន្ទាប់មកទៀត[៤៨] ។ ក្រុងភ្នំពេញត្រូវបានគេរៀបចំបោសសម្អាត កម្មាភិបាលថ្មីៗបានចូលមកតាំងលំនៅនៅទីស្តីការរដ្ឋមន្ត្រីនានា បានទទួលបុគ្គលិកឲ្យចូលធ្វើការ ។ ពួកខ្មែរក្រហមដែលធ្វើឲ្យខ្វល់ចិត្តពីរឿងរបាយការណ៍នោះ បានប្រឌិតសេចក្តីរាយការណ៍ និងឯកសារយ៉ាងសន្ធឹកសន្ធាប់ ដោយខ្វះលក្ខណៈត្រឹមត្រូវទាំងអស់ ។

បើទុកជាកម្មាភិបាលមួយចំនួនធំដែលគេចាត់តាំងឲ្យធ្វើជាប្រធានសហករណ៍នានា និងប្រធានគណៈកម្មការគ្រប់គ្រងសហគ្រាសផ្សេងៗ សុទ្ធតែអ្នកមិនចេះអក្សរក៏ដោយ ក៏គេស្នើសុំឲ្យផ្តល់របាយការណ៍ស្តីពីស្ថិតិសព្វសារពើ ឈ្មោះ និងអាយុរបស់សមាជិកសហករណ៍ ចំនួនអ្នកស្លាប់ និងអ្នកកើត ចំនួនផលិតផល បញ្ជីសារពើភ័ណ្ឌអំពីស្តុកសម្ភារប្រើប្រាស់សព្វបែបយ៉ាង តាំងពីខ្មៅដៃរហូតដល់ ចប ប៉ែល ។ នៅទីបំផុត សហករណ៍នានាត្រូវតែបញ្ជូនរបាយការណ៍មួយរៀងរាល់១០ថ្ងៃម្តង ទៅឲ្យរដ្ឋាភិបាលកណ្តាលនៅភ្នំពេញ ។ របាយការណ៍ទាំងនោះ សុទ្ធតែបំភ្លៃខុសពីការពិត ដើម្បីធ្វើឲ្យវា "ស៊ី" ទៅនឹងការគ្រោងទុកជាមុនរបស់មជ្ឈិម រួចហើយគេរៀប

ទុកដាក់ជាឯកសារទៀត ។ ដោយបានទទួលពត៌មានពីរបាយការណ៍ទាំងនោះ ដែលសុទ្ធតែខុសពីការពិត មជ្ឈិមបានស្នើឲ្យសហករណ៍ទាំងអស់បង្កើននូវកិច្ចប្រឹងប្រែងមួយថែមទៀត ។ រឿងរ៉ាវត្រូវបែកខ្ញែកខ្ចាយ ព្រោះវាច្បាស់ជាកើតឡើងដោយជៀសមិនផុត នៅពេលណាដែលការខ្វះខាត និងការធ្វើមិនបានសម្រេចជោគជ័យទាំងឡាយក្លាយទៅពិតជាក់ស្តែង ។ មជ្ឈិមបានផ្អែកលើក្រដាសរាយការណ៍គ្មានតម្លៃទាំងអស់នេះ ដើម្បីទាញសេចក្តីសន្និដ្ឋានថា ច្បាស់ជាមានអំពើក្បត់តែមួយមុខប៉ុណ្ណោះ ។ ការប្រមូលផលមួយបានស្រូវចំនួន១០០តោន ដែលស្ថិតក្នុងការស្រមើស្រមៃនោះ បានក្លាយទៅជាបទឧក្រិដ្ឋមួយអាចមានទោសដល់អស់ជីវិត ។

ក្នុងខែកក្កដា ឆ្នាំ១៩៧៥ បក្សបានរៀបចំទីស្នាក់ការរបស់ខ្លួននៅភ្នំពេញ ហើយអគ្គលេខាវង នួន ជា ត្រូវបាត់ឲ្យទទួលបន្ទុកមើលខុសត្រូវលើបណ្តាអង្គការបក្ស រួមទាំងសាលាអប់រំផ្នែកនយោបាយថ្មីរបស់គាត់ និងសម្ព័ន្ធយុវជនផង ។ ជា ដែលនៅតែជាមនុស្សលេខ២ បន្ទាប់ពី ប៉ុល ពត នោះ ពុំមែនជាមនុស្សដែលចេញមកពីក្រុមក្រុងប៉ារីសទេ ។ ជាអ្នកមានដើមកំណើតនៅបាត់ដំបង គាត់បានទៅបន្តការសិក្សាឯប្រទេសថៃ ក្នុងវិទ្យាល័យមួយ រួចហើយបានរៀននៅសាកលវិទ្យាល័យមួយក្នុងក្រុងបាងកកទៀត ។ ជាដំបូង គាត់បានសុំចូលបក្សថៃ មុននឹងក្លាយខ្លួនទៅជាសមាជិកបក្សកុម្មុយនិស្តឥណ្ឌូចិនរបស់វៀតណាម ។ ចំពោះឋានៈនេះ គាត់គឺជាយុទ្ធជនដើងចាស់ម្នាក់ ក្នុងចំណោមយុទ្ធជនដើងចាស់ជាច្រើន របស់ចលនាកុម្មុយនិស្តកម្ពុជា ហើយ ប៉ុល ពត មានសេចក្តីទុកចិត្តទៅលើគាត់ ដោយប្រគល់ឲ្យទទួលខុសត្រូវក្នុងការរៀបចំកសាងបក្ស ដែលជាភារកិច្ចលំបាក និងសំខាន់ស្មើអាយុជីវិតរបស់កម្ពុជាប្រជាធិបតេយ្យ ។ អតីត សាឡុត ស បានបែងចែកតំណែងរដ្ឋមន្ត្រីផ្សេងៗទៅបណ្តាមិត្តភក្តិក្រុងប៉ារីសរបស់គាត់ ប៉ុន្តែ មុខតំណែងក្នុងផ្ទៃបក្សដែលសំខាន់បំផុតនោះ នៅតែស្ថិតក្នុងកណ្តាប់ដៃពួកកុម្មុយនិស្តដែលចេញមកពីប្រភពផ្សេងដដែល ។

ក្នុងពេលដែលការបដិវត្តក្រោយសម័យសង្គ្រាមចេះតែបន្តទៅមុខ នួន ជា ប្រហែលជាមេដឹកនាំតែម្នាក់គត់ ដែលពុំត្រូវរងគ្រោះដោយរលកនៃការបោសសម្អាតផ្សេងៗ ។ ពួកមេដឹកនាំដែលធ្លាប់រៀនសូត្រនៅក្រុងប៉ារីស បានស្ថិតនៅក្នុងចំណោមមនុស្សដំបូងដែលត្រូវដកហូតពីមុខតំណែង ឬត្រូវបាត់ខ្លួន នៅក្នុងការរើរុះរៀបចំគណៈរដ្ឋមន្ត្រីជាច្រើនលើក ។ ក្នុងបញ្ជីឈ្មោះអ្នកដែលត្រូវដំឡើងឋានៈថ្មី គេពិនិត្យឃើញមានបាត់ឈ្មោះ ហ៊ូ យន់ ជាបិសាចម្នាក់ក្នុងចំណោម "បិសាចទាំងបី" ដែលកេរ្តិ៍ឈ្មោះល្បីល្បាញរបស់គាត់ ធ្លាប់ផ្តល់ឲ្យពួកខ្មែរក្រហមនូវលក្ខណៈគោរពកោតខ្លាចយ៉ាងខ្លាំងពីសំណាក់ប្រជាជនក្នុងរយៈពេលមានសង្គ្រាម ។ ហ៊ូ យន់ បាន "បាត់មុខ" មិនដឹងទៅណា ។ ក្រោយមកពួកខ្មែរក្រហមបានអះអាងថា គាត់បានស្លាប់ក្នុងកំឡុងពេលធ្វើការវាយលុកផ្តាច់ព្រ័ត្រលើក្រុងភ្នំពេញ ប៉ុន្តែ គេបានសន្និដ្ឋានជាទូទៅថា គាត់ត្រូវបណ្តាមិត្តភក្តិរបស់គាត់ធ្វើឃាតទៅហើយ ។ ហ៊ូ យន់ ជាមនុស្សមានឈ្មោះល្បីល្បាញ ព្រោះតែចិត្តគំនិតមិនចំណុះអ្នកណារបស់គាត់ ។ ជាអ្នកជំនាញការខាងបញ្ហាដែលទាក់ទងនឹងវិស័យកសិកម្មដ៏ឆ្នើមរបស់កម្ពុជា គាត់បានអួតអាងអំពីទស្សនៈនយោបាយនិយម

ផ្លូវកណ្ដាលរបស់គាត់ ដែលគ្មានជាប់ទាក់ទងនឹងបណ្ដាផែនការរបស់អ្នកបដិវត្តនិយមឆ្វេងជ្រុល ដែលរៀបចំឡើងសម្រាប់ប្រទេសកម្ពុជាឡើយ ។ គាត់បានចំណាយពេលវេលាយ៉ាងច្រើនដើម្បីបង្ហាញអត្ថន័យនៃនយោបាយកសិកម្មមួយដែលសមស្របតាមសុភនិច្ឆ័យ កុំឲ្យវាក្លាយទៅជាឧបសគ្គរារាំងដល់ប្រព័ន្ធសហករណ៍ ដែលជាឧបករណ៍ជិះជាន់ប្រជាជនរបស់បក្ស ។ ការកម្ចាត់រូបគាត់ គឺជាប្រផ្នូលនៃការបោសសម្អាតផ្សេងៗទៅលើពួកអ្នកដែលបែកបក្សពួកនៅក្នុងផ្ទៃបក្សជាច្រើននាក់ទៀតមិនខាន ។

ហ៊ូ នឹម បិសាចម្នាក់ទៀតនៃ "បិសាចទាំងបី" បាននៅកាន់មុខតំណែងជារដ្ឋមន្ត្រីក្រសួងឃោសនាការ ដែលមានតែឈ្មោះ ប៉ុន្តែឥតអំណាចដដែល ។ គាត់ក៏អ៊ីចឹងដែរ គឺជាមនុស្សដែលមានឥទ្ធិពលបន្តិចបន្តួច ហើយមិនដែលបានជាប់ឈ្មោះចូលក្នុងគណៈកម្មាធិការមជ្ឈិមបក្សទាល់តែសោះ ។ គាត់បានទទួលកិច្ចគាំពារខ្លះៗពីសំណាក់ពួកចិន ហើយត្រូវបានអនុញ្ញាតឲ្យបំពេញភារកិច្ចមួយចំនួនតូច ដែលគ្រាន់តែជាទម្រង់ (ម៉ាៗយកតែសឹង) សុទ្ធសាធ ប៉ុន្តែ គាត់នៅតែស្ថិតនៅក្រោមការតាមដានយ៉ាងស្អិត ពីសំណាក់ក្រុមអ្នកធ្វើការជាមួយគ្នាដែលមិនទុកចិត្តគាត់ជានិច្ច ។

អ្នកដែលមានឈ្មោះល្បីល្បាញជាងគេក្នុងចំណោម "បិសាចទាំងបី" គឺមានតែ ខៀវ សំផន ម្នាក់ប៉ុណ្ណោះ ដែលនៅបន្តការឈានឡើងឋានៈរបស់គាត់ជាដរាប ។ ដោយធ្វើការងារជាមួយពួកខ្មែរក្រហម ដូចដែលគាត់ធ្លាប់បានធ្វើជាមួយនឹងសម្ដេច ព្រះនរោត្ដម សីហនុ ដែរនោះ គាត់បានបំពេញភារកិច្ចគ្រប់បែបយ៉ាង ដែលគេប្រគល់ឲ្យគាត់ធ្វើយ៉ាងពេញសមត្ថភាព ប្រហែលជាគាត់យល់ព្រមធ្វើតាមយុទ្ធសាស្ត្ររបស់បក្ស និងសុខចិត្តទទួលយកនូវផលវិបាកផ្សេងៗទៀតផង ។ គាត់ធ្លាប់ជារដ្ឋមន្ត្រីដ៏ពូកែម្នាក់ដើម្បីជាប្រយោជន៍ដល់សម្ដេច ព្រះនរោត្ដម សីហនុ ហើយគាត់ ក៏ធ្វើដូច្នេះក្នុងឋានៈជាប្រធានរដ្ឋដែលមានតែឈ្មោះប៉ុន្តែអត់អំណាចសម្រាប់ ប៉ុល ពត ដែរ ។

នៅពេលដែលបក្សរៀបចំស្ថានភាពផ្សេងៗ និងកម្មវិធីរបស់ខ្លួននៅក្រុងភ្នំពេញ កងទ័ព និងសមាជិកសហករណ៍នានាក្នុងសម័យសង្គ្រាម បានរៀបចំដាក់មនុស្សជិតបីលាននាក់ឲ្យទៅរស់នៅតាមជនបទ ។ នៅខែខសភា មនុស្សទាំងនេះបានទទួលលំនៅមួយត្រូវពេលនឹងរដូវបង្កបង្កើនផល ។ ការរៀបចំកន្លែងតាំងទីលំនៅថ្មីខ្លះមានសភាពចង្អៀតណែន និងខ្វះមុខខ្វះក្រោយបីដូចជាជំរំអ្នកភៀសខ្លួនមួយដែរ កន្លែងខ្លះទៀត សឹងតែមានលក្ខណៈជាភូមិគំរូទៅហើយ ។ ក្នុងកន្លែងខ្លះ "ពួកអ្នកថ្មី" ដែលត្រូវបណ្ដេញចេញពីតំបន់នានារបស់ លន់ នល់ បានត្រូវទទួលឲ្យស្នាក់អាស្រ័យយ៉ាងរាក់ទាក់ពីសំណាក់ "ពួកអ្នកចាស់" ដែលធ្លាប់រស់នៅក្នុងតំបន់ផ្សេងៗរបស់ពួកខ្មែរក្រហមក្នុងរយៈពេលមានសង្គ្រាម ។ ក្នុងតំបន់ខ្លះទៀត គេព្រមទទួលឲ្យ"ពួកអ្នកថ្មី" រស់នៅទាំងសោះអង្គើយ ហើយផ្ដល់ស្បៀងអាហារឲ្យយ៉ាងតិចតួចបំផុត ។ ក្នុងតំបន់មួយចំនួនតូច ពួកអតីតទាហានរបស់ លន់ នល់ ត្រូវគេដាក់ឲ្យរស់នៅភូមិជាច្រើនដាច់ដោយឡែកពីគេឯង ហើយក្នុងតំបន់ផ្សេងទៀត គេសម្លាប់ពួកនោះ ចោលភ្លាមៗ ។ នៅគ្រប់ទីកន្លែង "ពួកអ្នកចាស់" បានត្រូវខ្វាយខ្វល់ចិត្តដោយសារផែនការដាក់បញ្ចូលពួកអ្នកទីក្រុងមក

រស់នៅក្នុងសហករណ៍របស់ភូមិខ្លួន ។

ពួកមេដឹកនាំនៅមជ្ឈិម បានពឹងផ្អែកទៅលើសហករណ៍ទាំងឡាយខ្លាំងហួសហេតុ ។ ប្រហែលជាពួកគេត្រូវសហករណ៍ទាំងនោះញ៉ាំងឲ្យជឿថា ការជម្លៀសប្រជាជនចេញពីទីក្រុងនានា នឹងមានដំណើរប្រព្រឹត្តទៅដោយគ្មានបញ្ហាឡើយ តាមរបាយការណ៍ផ្សេងៗដែលបណ្ដាប្រធានសហករណ៍ទាំងនោះផ្ញើមកឲ្យមជ្ឈិមក្នុងរយៈពេលសង្គ្រាមដែលនិយាយបំផ្លើសហួសហេតុ អំពីប្រភពធនធាន និងលក្ខណៈខាងផ្នែកសុខាភិបាលនៃតំបន់របស់គេ ព្រោះខ្លាចក្រែង "អង្គការ" អាក់អន់ចិត្ត ។

ចាប់ពីខែមីនា ឆ្នាំ១៩៧៥ បន្ទាប់ពីការអនុម័តគម្រោងផែនការជម្លៀស និងការផ្ទេរប្រជាជនពីកន្លែងមួយទៅកន្លែងមួយក្នុងឱកាសមហាសន្និបាតរណសិរ្សរួបរួមជាតិលើកទីពីរ ដែលប្រារព្ធធ្វើនៅខែកុម្ភៈក្នុងប្រទេសកម្ពុជានោះ គេបានស្នើឲ្យ "ពួកអ្នកចាស់" ប្រុងប្រៀបខ្លួនទទួលនូវការមកដល់របស់ "ពួកអ្នកថ្មី" រួចជាស្រេច ។ គេនៅខ្វះពេលវេលាជាច្រើន ដើម្បីរៀបចំផែនការផ្សេងៗក្នុងការជម្លៀសប្រជាជន ដោយមិនគិតពីការរិះរកមធ្យោបាយដើម្បីចិញ្ចឹម និងរៀបចំលំនៅជាថ្មីឲ្យមនុស្សរាប់លាននាក់ផងទេ ។ គ្មានអ្នកណាមួយដឹងថា មានប្រជាជនប៉ុន្មាននាក់ដែលប្រកាសថាខ្លួនជាអ្នកមានកំណើតនៅ ខេត្តកំពង់ចាម ខេត្តបាត់ដំបង ឬខេត្តតាកែវឡើយ ។ កងទ័ពប្រចាំភូមិភាគត្រូវបានចាត់តាំងឲ្យជួយដឹងជញ្ជូន "ពួកអ្នកថ្មី" ទាំងបន្ទុំមកដាក់ក្នុងភូមិកំណើតរបស់គេ ឬដាក់ក្នុងភូមិភាគផ្ទាល់របស់កងទ័ពទាំងនោះចំពោះប្រជាជនណាដែលមិនមានកំណើតនៅជនបទ ។ កងទ័ពក៏មាន ករណីយកិច្ចធានាសន្តិសុខ និងកម្ទេចចោលនូវប្រជាជនកម្ពុជាទាំងឡាយណាដែលគេប្រកាសថា ជាសត្រូវក្នុងសម័យសង្គ្រាម ដោយបំបែក ពួកនោះចេញពីពួកអ្នកដទៃទៀត ហើយសម្លាប់ចោលនៅតាមផ្លូវ ឬក្នុងសហករណ៍ផ្សេងៗ ។

មានតែប្រភេទបោកបញ្ឆោតយ៉ាងប៉ិនប្រសប់តែម៉្យាងប៉ុណ្ណោះ ដែលបិទបាំងការព្រួយបារម្ភផ្ទាល់ពីអនាធិបតេយ្យដែលបក្សព្រឺខ្លាចណាស់ ។ មានតែកងទ័ពភូមិភាគប៉ុណ្ណោះ ដែលបញ្ចៀសមិនឲ្យការបដិវត្តន៍ត្រូវរលាយសាបសូន្យ -ជាសក្ខីភាពនៃការស្មោះត្រង់ដែលភូមិភាគទាំងអស់បានបញ្ចេញឲ្យឃើញនៅពេលចាប់ផ្ដើមធ្វើបដិវត្តដំបូងចំពោះ "អង្គការ" ។ ក្នុងឋានៈជាអ្នកបម្រើដ៏មានភក្ដី កងទ័ពបានត្រួតពិនិត្យពីលើដំណាក់កាលផ្សេងៗក្នុងការជម្លៀស និងការសម្លាប់ "ពួកសត្រូវ" អស់ជាច្រើនពាន់នាក់ ។

រំាដល់ពេលដែល "ពួកអ្នកចាស់" បង្រៀន "ពួកអ្នកថ្មី" ឲ្យដឹងពីភាពពិបាកទ្រាំទ្រ និងច្បាប់វិន័យរបស់ប្រទេសកម្ពុជាបដិវត្តហើយ ។ មាន "ពួកអ្នកចាស់" ខ្វះ ប្រហែលជាខកចិត្ត និងស្រឡាំងកាំង ដោយបានដឹងពីផែនការផ្សេងៗ ក្នុងការផ្ទេរប្រជាជនពីកន្លែងមួយទៅកន្លែងមួយទៀត ។ រឿងនេះមានន័យថា ច្បាស់ជាពុំមានការប្រែប្រួលទេ ។ ជាធម្មតាវិធានការណ៍ដ៏តឹងតែងជាច្រើននៅសម័យសង្គ្រាម ត្រូវបានបន្ធូរបន្ថយថែមទាំងត្រូវបោះបង់ចោលទៀតផង ក្នុងពេលប្រទេសមានសន្តិភាព ។ បើទុកជាទីបញ្ចប់នៃសង្គ្រាមពុំបាននាំមកនូវការរីកចម្រើនខាងស្បៀងអាហារបន្តិចសោះក៏ដោយ ក៏យ៉ាងហោចណាស់វាធ្វើឲ្យមានសេចក្តីសង្ឃឹមក្នុងការស្វែងរក

ក្រុមគ្រួសារដែលព្រាត់ប្រាស់គ្នា ការធ្វើបុណ្យទាន ការវិលត្រឡប់ទៅរកជីវភាពដ៏សុខសាន្ត ដូចពេលដែលមានសន្តិភាពដែរ ។ ជំនួសរឿងនេះ គេបានប្រកាសប្រាប់«ពួកអ្នកចាស់»ឲ្យដឹងថា ពួកគេត្រូវទទួលបន្ទុកចិញ្ចឹមពួកសមាជិកថ្មីៗក្នុងសហករណ៍របស់ខ្លួនជាបន្ថែមទៀត ។ ដូច្នេះពួកគេត្រូវបែងចែកស្បៀងបម្រុងទុកដ៏ស្តួចស្តើងរបស់ខ្លួនទៅឲ្យពួកមនុស្សដែលគេមិនធ្លាប់ស្គាល់ រកទីកន្លែងសម្រាប់ឲ្យពួកនោះដេកពួន និងបង្រៀនឲ្យចេះធ្វើស្រែចម្ការផង ។ នេះហើយជារង្វាន់ដ៏តិចតួចមួយចំពោះពួកអ្នកទាំងឡាយណាដែលបានប្រយុទ្ធតស៊ូ និងដែលបានលះបង់ជីវិតដើម្បីខ្មែរក្រហមនោះ ។

បក្សបានស្រុះស្រួលនឹង«ពួកអ្នកចាស់» ដោយអនុញ្ញាតឲ្យពួកនេះបង្កើតក្នុងសហករណ៍ផ្សេងៗនូវប្រព័ន្ធដឹកនាំមួយដែលមិនត្រូវតាមក្បួនទ្រឹស្តី ដោយយល់ព្រមឲ្យពួកអ្នកថ្មីនូវស្ថានភាពមួយទាបជាងមានសិទ្ធិ និងមានស្បៀងអាហារតិចតួច ហើយមានការងារធ្វើច្រើនជាង ។ បន្ទាប់ពីការជម្លៀសនៅពេលដំបូង បក្សក៏បានអនុញ្ញាតឲ្យពួកគេផ្លាស់ប្តូរអ្នកថ្មីមួយចំនួនធំចេញពីកន្លែងមួយទៅកន្លែងមួយទៀតដែរ នៅពេលដែល«ពួកអ្នកចាស់» ត្អូញត្អែរពីរឿងសហករណ៍មានប្រជាជនច្រើនលើសលុបពេក ។ បណ្តាលេខាបក្សភូមិភាគខ្លាំងៗដូចជា សោ ភឹម និង តាម៉ុក ជាដើម បានអនុវត្តយ៉ាងម៉ឺងម៉ាត់នូវនយោបាយនៃការផ្ទេរផ្ទួរប្រជាជននេះ ព្រោះវាត្រូវនឹងចិត្តរបស់គាត់ស្រាប់ ហើយមិនយូរប៉ុន្មាន គេឃើញមានភាពខុសគ្នាតាមជនបទរបស់កម្ពុជា បន្ទាប់ពីសង្គ្រាមច្រើនជាងក្នុងរយៈពេលមានសង្គ្រាមទៅទៀត ។ ពួកអ្នកថ្មីមួយចំនួនធំ បានដើរចប្រច់ពាសពេញផ្ទៃប្រទេស ក្នុងការស្វែងរកសហករណ៍មួយ ដើម្បីសុំឲ្យសហករណ៍ទទួលយកពួកគេឲ្យចូលទៅរស់នៅផង អ្នកខ្លះទៀតត្រូវធ្វើដំណើរទៅមុខទៀត នៅពេលដែលសហករណ៍នានាវិនិច្ឆ័យថា ជាពួកមនុស្សដែលគេមិនត្រូវការ ។

ក្នុងរយៈពេលនៃការចាកចេញដំណើរទាំងគ្រួៗនេះ បក្សក៏បានបណ្តេញសមាជិករបស់ខ្លួនខ្លះៗ ដែលធ្លាប់ទទួលស្គាល់ឲ្យចូលបម្រើការនៅសម័យសង្គ្រាមដែរ ប៉ុន្តែឥឡូវនេះត្រូវបានចាត់ទុកជាអ្នកមិនចេះសម្របខ្លួនតាមសង្គមដែលខ្លួនរស់នៅ ដោយហេតុថា ប្រភពកំណើតរបស់ពួកនេះជា «វណ្ណៈគហបតី» ។ ដើម្បីរៀបចំធ្វើការចម្រាញ់នេះ បក្សបានបិទទ្វារមិនជ្រើសរើសសមាជិកថ្មីៗទៀតឡើយ ។ ព្រមពេលជាមួយគ្នានោះ កងទ័ពដែលគេទើបនឹងបញ្ចូលជាកងទ័ពជាតិតែមួយក្នុងពេលថ្មីៗ ក៏ត្រូវគេជម្រុះយុទ្ធជន និងមេបញ្ជាការណាដែលមានប្រភពដើមមិនល្អចេញពីជួរដែរ ។ នៅពេលដែលបក្សប្រារព្ធបើកមហាសន្និបាតលើកទីបីរបស់ខ្លួន នៅខែមករា គោលនយោបាយធំៗពីរ នឹងត្រូវប្រុងប្រៀបវាយប្រហារជាស្រេច នៅដំណាក់កាលបដិវត្តទីពីរ ជាស្រេច គឺការតស៊ូវណ្ណៈជាទូទៅ ។

ដំណាក់កាលទី១ នៃការបដិវត្តគឺការអនុវត្ត «នយោបាយកុម្មុយនិស្តនៃសង្គ្រាម» បានមកដល់ចំណុចហៀបនឹងបញ្ចប់ទៅហើយ[៥០] ។ នៅក្រុងភ្នំពេញ គេបានរៀបចំប្រព័ន្ធសន្តិសុខជាតិមួយ ដែលអំណឹះតទៅនឹងត្រូវទទួលភារកិច្ចសម្រេចកំណត់មុខសញ្ញាសត្រូវវណ្ណៈ ឬភ្នាក់ងារធ្វើការឲ្យបរទេស ហើយត្រូវស្រាវជ្រាវរកឲ្យឃើញ

ដើម្បីកម្ទេចចោលឲ្យអស់ ។ កងទ័ពត្រូវបានគេប្រកាសឲ្យដឹងនៅខែវិច្ឆិកាថា ខ្លួនធ្លាប់បានបំពេញមុខងារសន្តិសុខ ហើយឥឡូវនេះ អាចប្រើប្រាស់ពេលវេលាទាំងអស់ជាថ្មីក្នុងករណីកិច្ចផ្សេងៗដែលសំខាន់បំផុតបន្ថែមទៀត ៖ ការពារព្រំដែន និងចូលរួមក្នុងការស្ដារប្រទេសជាតិឡើងវិញ ។

# ជំពូកទី៦
# រជ្ជកាលនៃអំពើហិង្សា

*ប្រសិទ្ធភាពរបស់អំពើភេរវកម្ម ពឹងផ្អែកស្ទើរតែទាំងស្រុង ទៅនឹងកម្រិតនៃការធ្វើឲ្យសង្គមបាក់បែកចេញពីគ្នា -ជាពាក្យមួយមានលក្ខណៈខ្វះវាយហួសហេតុ និងសាមញ្ញពេក ចំពោះអំពើភេរវកម្ម ដែលមាននៅក្នុងនោះ ។ របបផែនទាំងអស់នៃការប្រឆាំងជិតាស់ ដែលចាត់ចែងរៀបចំឲ្យមានដំណើរឡើងប្រហែលជារលាយបាត់មុនដែលរំដោះខ្លួនពីអំពើភេរវកម្ម ដោយមធ្យោបាយគ្រប់បែបយ៉ាង ។*

*ហាណា អារិន*

*បងតប់ប្រមល់ជាខ្លាំង ដែលធ្វើឲ្យបងនៅមិនសុខសោះ ។ បងព្រឺខ្លាចអ្វីៗទាំងអស់ ដែលបងឃើញនៅជុំវិញខ្លួនបង ។ ការមើលឃើញរបស់បង ត្រឡប់ត្រឡិនអស់ហើយ ។ ប៉ុន្តែបងនឹងទ្រាំទ្រសង្កត់ចិត្ត ដើម្បីអាចជួបមុខអូនម្តងទៀត អូនសម្លាញ់ ។ ក្នុងវាលវដ្តសង្សារនេះ អូនមានបាបកម្ម ហើយយើងទាំងពីរនាក់មានដូចគ្នា ។ [....] បងគោងតែ និយាយលាអូនត្រឹមនេះចុះ ពីព្រោះបងហូរទឹកភ្នែកច្រើនណាស់[១] ។*

*សំបុត្ររបស់សមមិត្ត ដែត កម្មាភិបាលខ្មែរក្រហម*

*ផ្ញើទៅឲ្យប្រពន្ធគាត់ បុប្ផាណា*

*ខែកុម្ភៈ ឆ្នាំ១៩៧៦*

នៅនិទាឃរដូវឆ្នាំ១៩៧៥ សម្តេច ព្រះនរោត្តម សីហនុ បានចាកចេញពីនិវេសនដ្ឋានដ៏ល្អឆើតឆាយរបស់ព្រះអង្គនាទីក្រុងប៉េកាំងដើម្បីវិលត្រឡប់មកកាន់ប្រទេសកម្ពុជាបដិវត្តវិញ ។ ផ្លូវដែលត្រូវយាងធ្វើដំណើរមកមានលក្ខណៈបត់បែនក្រវិចក្រវក់ និងគួរឲ្យញញើត ។ សម្តេច ព្រះនរោត្តម សីហនុ បានឈប់សំចតមួយរយៈខ្លីនៅក្រុងភ្នំពេញ ដើម្បីប្រារព្ធធ្វើពិធីបូជាសពព្រះមាតារបស់ព្រះអង្គ គឺព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈ បន្ទាប់មក ព្រះអង្គបានចេញដំណើរទៅក្រៅប្រទេសភ្លាម ដើម្បីបំពេញបេសកកម្មការទូត ជាប្រយោជន៍ដល់ពួកខ្មែរក្រហម ។

ព្រះអង្គបានឡើងយន្តហោះឆ្ពោះទៅទីក្រុងញូវយ៉ក ជាទីដែលទ្រង់ត្រូវចូលរួមប្រជុំមហាសន្និបាតរបស់អង្គការសហប្រជាជាតិ តាមពីក្រោយ អៀង សារី ដែលបានទៅដល់មុនព្រះអង្គក្នុងឋានៈជារដ្ឋមន្ត្រីការបរទេសថ្មីរបស់កម្ពុជា ។ សម្តេច ព្រះនរោត្តម សីហនុ បានដឹកនាំឲ្យសមតាមតួនាទីរបស់ព្រះអង្គយ៉ាងជំនាញ ដោយព្រះអង្គមានបន្ទូលទៅតាមសម្តីភូតកុហក ដែល សារី បានថ្លែងនៅអង្គការសហប្រជាជាតិនោះឡើងវិញ ហាក់ដូចជាទ្រង់

បានដឹងហេតុនោះពិតប្រាកដណាស់អ៊ីចឹង ៖ ការជម្លៀសប្រជាជនមានដំណើរប្រព្រឹត្តទៅ «ដោយគ្មានការបង្ហូរឈាម» ចម្លើយជាសាក្សីរបស់ពួកអ្នកភៀសខ្លួនអំពីការកាប់សម្លាប់អតីតនាយទាហានទាំងក្រុមៗ សុទ្ធតែគ្មានមូលដ្ឋានទាំងអស់ ការបដិវត្តឈរលើដីហរ «ខ្លួនទុកដាក់ខ្លួន» ហើយមិនត្រូវការជំនួយបរទេសឡើយ ។

បេសកកម្មរបស់ព្រះអង្គបានបំពេញចប់សព្វគ្រប់ សម្ដេច ព្រះនរោត្តម សីហនុ បានយាងចាកចេញពីទីក្រុងញូវយ៉ក ហើយបានប្រកាសឲ្យដឹងជាសាធារណៈថា ព្រះអង្គនឹងយាងទៅបំពេញទស្សនកិច្ចនៅប្រទេសដប់មួយទៀត ដូចជា អាល់បានី សូម៉ាលី សាធារណរដ្ឋ អារ៉ាប់យេម៉េន ជាដើមមុននឹងវិលត្រឡប់មកកាន់ប្រទេសកម្ពុជាវិញ ។ ជនជាតិកម្ពុជាដែលធ្លាប់បម្រើព្រះអង្គ ជាសហការីនៅក្រុងប៉េកាំង ក្នុងរយៈពេលនៃការនិរទេសខ្លួនជាច្រើនឆ្នាំមកហើយនោះ បានសម្រេចចិត្តបោះបង់មុខតំណែងចោលទាំងអស់ ។ ជាឯកជន សម្ដេចធ្លាប់មានបន្ទូលប្រាប់ឲ្យពួកនោះឲ្យដឹងពីគ្រោះថ្នាក់ផ្សេងៗ ដែលពួកគេអាចនឹងជួបប្រទះដែរ ហើយអ្នកទាំងនេះបានស្វែងទៅជ្រកកោននៅប្រទេសបារាំងវិញ ។ នៅក្រុងប៉ារីស ជនជាតិកម្ពុជាទាំងនេះ បាននិយាយបដិសេធនូវសេចក្ដីថ្លែងការណ៍ទាំងអស់របស់សម្ដេច ព្រះនរោត្តម សីហនុ ស្ដីពីពួកខ្មែរក្រហមដែលព្រះអង្គបានថ្លែងនៅអង្គការសហប្រជាជាតិ ។ ពួកគេបានអះអាងបញ្ជាក់ថា ពួកអ្នកបដិវត្តថ្មីបានបោះបង់ចោល នូវកម្មវិធីសេរីនិយមដែលធ្លាប់បានសន្យាកាលពីសម័យសង្គ្រាម ព្រោះពួកគេបារម្ភថា សក្ខីភាពផ្សេងៗដែលលើកឡើងដោយពួកអ្នកភៀសខ្លួនសុទ្ធតែជារឿងពិត ដូច្នេះហើយ បានជាពួកគេភ័យខ្លាចនឹងវិលត្រឡប់មកក្រុងភ្នំពេញវិញណាស់ ។

សម្ដេចសីហនុពុំបានឆ្លើយតបទៅពួកអ្នកទាំងនោះវិញទេ ហើយបានបន្តដំណើររបស់ព្រះអង្គតទៅទៀត ។ ប៉ុន្តែ ដំណឹងស្ដីពីការសម្រេចព្រះទ័យរបស់ព្រះអង្គវិលមកមាតុប្រទេសវិញ មានឥទ្ធិពលជះទៅលើពួកកម្ពុជាដទៃទៀត ដែលកំពុងស្នាក់នៅឯបរទេសដែរ ហើយពួកនេះបាននិយាយថា បើសម្ដេចអាចវិលត្រឡប់ទៅកម្ពុជា បានពួកគេក៏អាចទៅវិញបានដូចគ្នា[២] ។ ពួកបញ្ញវន្ត និងពួកយុទ្ធិកជន (អ្នកដែលប្រយុទ្ធដើម្បីជោគជ័យនៃឧត្តមគតិមួយ) រាប់រយនាក់ និងពួកនាយទាហានដែលទទួលការបណ្ដុះបណ្ដាល នៅសហរដ្ឋអាមេរិកជាច្រើននាក់ទៀត បានយល់ស្របតាមការបកស្រាយ ប្រកបដោយន័យនយោបាយជឿនលឿននិយមរបស់ការបដិវត្ត ដែលលើកឡើងដោយសម្ដេច ព្រះនរោត្តម សីហនុ នោះ បាននាំគ្នាវិលត្រឡប់មកប្រទេសជាតិរបស់គេវិញ – ដើម្បីទទួលរងក្នុងករណីជាច្រើននូវជោគវាសនាដ៏គួរឲ្យព្រឺខ្លាចបំផុតមួយ ៖ ការចាប់ឃុំឃាំង ការធ្វើទារុណកម្ម និងសេចក្ដីស្លាប់ ។

ការបដិវត្តពុំនៅរង់ចាំសម្ដេចទេ ។ មុនពេលព្រះអង្គសម្រេចព្រះទ័យវិលត្រឡប់ចូលមកប្រទេសវិញ រដ្ឋាភិបាលនៃរណសិរ្សរួបរួមជាតិ ដែលមានព្រះអង្គជាមេដឹកនាំតាមការសន្មតិនោះ បានរួមប្រជុំនៅក្រុងភ្នំពេញជាលើកចុងក្រោយបង្អស់នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៧៥ ហើយបានអនុម័តរដ្ឋធម្មនុញ្ញថ្មីមួយ ដោយធ្វើឲ្យទៅជាផ្លូវការនូវអ្វីៗដែលបានក្លាយទៅជាច្បាប់របស់ប្រទេសតាំងពីថ្ងៃទី១៧ ខែមសា ម្ល៉េះ[៣] ។ នេះជាមហាសន្និបាតលើកទីបី និងជាលើកចុងក្រោយបំផុត ។ រដ្ឋធម្មនុញ្ញដែលមហាសន្និបាតបានអនុម័ត បានលុបបំបាត់របបរាជាធិប

តេយ្យ និងសាសនា «ប្រតិកិរិយា» ។ នៅពេលនេះ សម្ដេច ព្រះនរោត្តម សីហនុ ជារាស្ត្រសាមញ្ញម្នាក់ ហើយជំនឿចំពោះសាសនា និងសេចក្ដីស្មោះត្រង់ចំពោះបុព្វបុរសទាំងឡាយ និងប្រទេសជាតិរបស់ព្រះអង្គ ត្រូវបានហាមឃាត់ ។ សម្ដេច នឹងពុំមានកាន់មុខតំណែងណាមួយនៅក្នុងរដ្ឋាភិបាលថ្មីទេ ។

ទ្រព្យសម្បត្តិត្រូវគេប្រមូល «ដាក់រួម» ទាំងអស់គឺស្រែចម្ការ រោងចក្រ លំនៅដ្ឋាន មន្ទីរក្រសួងនានា ជនយានតូចៗសម្រាប់នេសាទ សម្ភារប្រើប្រាស់ និងរថយន្តបានក្លាយទៅជាកម្មសិទ្ធិរបស់រដ្ឋ ។ ប្រជាពលរដ្ឋគ្រប់រូបត្រូវបែងចែកជាបីប្រភេទ -កម្មករ កសិករ និងកងទ័ព- លើកលែងតែមនុស្សមួយចំនួនចេញ ។ តាមច្បាប់រដ្ឋធម្មនុញ្ញ អ្វីៗទាំងអស់ដែលប្រជាជនត្រូវធ្វើ គឺធ្វើការងារ និងការពារប្រទេស ។ បញ្ហាស្ដីពីប្រព័ន្ធតុលាការ បានត្រូវអង្គការចាត់ការលុបបំបាត់ចោលយ៉ាងឆាប់រហ័ស គឺមានតែតុលាការប្រជាជនដែលពុំមានបញ្ជាក់លក្ខណៈឲ្យបានច្បាស់លាស់ប៉ុណ្ណោះ ហើយអត្ថបទរដ្ឋធម្មនុញ្ញ បានធ្វើសេចក្ដីព្រមានត្រង់ៗទាំងកំរោលថា «ជនណាម្នាក់ដែលធ្វើសកម្មភាពប្រឆាំងរដ្ឋប្រជាមានិត អាចត្រូវផ្ដន្ទាទោសយ៉ាងធ្ងន់ធ្ងរជាទីបំផុត» ។

រដ្ឋាភិបាលត្រូវបានបង្ហាញឡើងជាមនុស្សមួយក្រុមដែលធ្វើការរួមជាសមូហភាព ។ គណៈប្រធានរដ្ឋមួយដឹកនាំដោយប្រធានម្នាក់ ហើយមានអនុប្រធានទីមួយម្នាក់ និងអនុប្រធានទីពីរម្នាក់ ដោយយកតាមរបៀបគ្រប់គ្រងសហករណ៍ដែលមានមនុស្សបីនាក់ ជាអ្នកមើលខុសត្រូវ ។ ជំពូកដាច់ដោយឡែកមួយ ត្រូវគេទុកសម្រាប់និយាយពីសមាសភាពនៃកងទ័ពបដិវត្តរបស់កម្ពុជា ម្យ៉ាងទៀត រដ្ឋធម្មនុញ្ញក៏បានអះអាងពីសមភាពខាងភេទ ហាមឃាត់មិនឲ្យមានប្រពន្ធច្រើន និងប្ដីច្រើនដែរ ។ ប៉ុន្តែ ជាពិសេសរដ្ឋធម្មនុញ្ញនេះ និយាយពីរឿងការងារ និងការបង្កបង្កើនផលច្រើនជាងគេ ។ សញ្ញាជាតិរបស់ប្រទេស គឺមានប្រព័ន្ធភ្លឺស្រែ និងប្រឡាយទឹកជានិមិត្តរូបនៃកសិកម្មជឿនលឿន មានរោងចក្រជានិមិត្តរូបនៃឧស្សាហកម្ម មានកម្រងកួរស្រូវជាស្នែងក្របីព័ទ្ធពីក្រៅ ។ ការបង្កបង្កើនផល ត្រូវបានកំណត់យ៉ាងច្បាស់លាស់ថា កំពុងបានរួមចំណែក ក្នុងភារកិច្ចការពារប្រទេសកម្ពុជា និងប្រែក្លាយឲ្យទៅជាប្រទេសដ៏សម្បូររុងរឿងមួយ ។ ការផ្គត់ផ្គង់ស្បៀង ឲ្យពលករម្នាក់ៗគឺត្រូវបានធានាយ៉ាងគ្រប់គ្រាន់ ហាមមិនឲ្យមានភាពទំនេរគ្មានការងារធ្វើក្នុងប្រទេស ដែលប្រសិទ្ធិនាមថ្មីថា កម្ពុជាប្រជាធិបតេយ្យឡើយ គឺរដ្ឋធម្មនុញ្ញបាននិយាយដូច្នេះ ។

ពុំមានការសរសេរចូលអំពី «សិទ្ធិសេរីភាព» ណាមួយក្នុងរដ្ឋធម្មនុញ្ញនេះឡើយ ។ «បណ្ដា ពលករ កម្មករ និងកសិករ គឺជាម្ចាស់រោងចក្រ ម្ចាស់លើការងាររបស់គេ និងម្ចាស់លើមធ្យោបាយផលិតកម្មទាំងអស់» ប៉ុន្តែសិទ្ធិតែមួយគត់របស់ពួកគេ គឺសិទ្ធិបំពេញការងារ ។

អត្ថបទរដ្ឋធម្មនុញ្ញ បានរៀបរាប់ពីនយោបាយបរទេសរបស់ប្រទេស ដែលប្រកាន់ខ្ជាប់នយោបាយឯករាជ្យ សន្តិភាព មិនចូលបក្សសម្ព័ន្ធ និងអព្យាក្រឹត ហើយបានប្រាប់ឲ្យពិភពលោកដឹងថា កម្ពុជាប្រជាធិបតេយ្យប្រឆាំងជំទាស់រាល់អំពើវិទ្ធង្សនា និងអំពើឈ្លានពានគ្រប់ប្រភេទពីខាងក្រៅទោះជាខាងផ្នែកយោធាក្ដី នយោបាយ

ក្តី វប្បធម៌ក្តី សង្គមកិច្ចក្តី ខាងការទូត ឬមនុស្សធម៌តាមការអួតអាងរបស់បរទេសក្តី ប៉ុន្តែ បានបញ្ជាក់អះអាងថា ខ្លួនមាន«សុឆន្ទៈដ៏ពេញលេញ» និង«បានសម្រេចចិត្តដោយម៉ឺងម៉ាត់ ដើម្បីរក្សាចំណងទាក់ទងដ៏ជិតស្និទ្ធ និងជាមិត្តភាពជាមួយបណ្តាប្រទេសដែលមានព្រំដែនជាប់នឹងខ្លួន ព្រមទាំងជាមួយបណ្តាប្រទេសជិតឆ្ងាយទាំងអស់ ក្នុងពិភពលោក ដោយឈរលើមូលដ្ឋាននៃការគោរពអធិបតេយ្យភាព និងបូរណភាពទឹកដីទៅវិញទៅមកដោយត្រឹមត្រូវ» ។

រដ្ឋធម្មនុញ្ញពុំបានផ្តល់លក្ខណៈសម្បត្តិរដ្ឋាភិបាលថាជារដ្ឋាភិបាលសង្គមនិយមទេ ហើយក៏មិនថា ជារដ្ឋាភិបាលកុម្មុយនិស្តដែរ ។ ត្រង់ចំណុចនេះ ក៏ដូចចំណុចជាច្រើនឯទៀត រដ្ឋធម្មនុញ្ញនេះមានលក្ខណៈ សាមញ្ញ ងាយស្រួលយល់ជាទីបំផុត ហើយវាសមស្របទៅនឹងប្រព័ន្ធគ្រប់គ្រងដែលពួកខ្មែរក្រហមធ្លាប់បានអនុវត្តមកហើយដែរ ។ បទភ្លេងជាតិដែលមានចំណងជើងថា «១៧ មេសា មហាជោគជ័យ» បង្ហាញឲ្យឃើញនូវគំនិតមួយដែលប្រសើរថ្លៃថ្លាជាងគេនៃលក្ខណៈរបស់របបថ្មីនេះជាស្រេច ៖

- *ឈាមក្រហមច្រាលស្រោចស្រពក្រុងវាលកម្ពុជាមាតុភូមិ*
  *ឈាមកម្មករកសិករដ៏ឧត្តម*
  *ឈាមយុទ្ធជន យុទ្ធនារីបដិវត្ត ៗ*
  *ឈាមប្រែក្លាយជាកំហឹងខ្លាំងក្លាតស៊ូមោះមុត*
  *១៧ មេសា ក្រោមទង់បដិវត្ត*
  *ឈាមរំដោះផុតពីភាពខ្ញុំគេ ។*
- *ជយោ! ជយោ ១៧ មេសាជោគជ័យ*
  *មហាអស្ចារ្យ មានន័យធំធេងលើសម័យអង្គរ*
  *យើងរួបរួមគ្នា កសាងកម្ពុជានិងសង្គមថ្មីបវរ*
  *ប្រជាធិបតេយ្យ សមភាព និងយុត្តិធម៌*
  *តាមមាគ៌ាម្ចាស់ការឯករាជ្យ រឹងមាំ*
- *ប្តេជ្ញាដាច់ខាតការពារមាតុភូមិ*
  *ទឹកដីឧត្តមបដិវត្តដ៏រុងរឿង*
  *ជយោ ជយោ ជយោ*
  *កម្ពុជាថ្មី ប្រជាធិបតេយ្យសម្បូរថ្កុំថ្កើង*
  *ប្តេជ្ញាជ្រោងគ្រវីទង់បដិវត្តក្រហមខ្ពស់ឡើង*
  *សាងមាតុភូមិយើងឲ្យចម្រើនលោតផ្លោះ*
  *មហារុងរឿងមហាអស្ចារ្យ ។*

នៅទីបំផុត សម្តេច ព្រះនរោត្តម សីហនុ បានសម្រេចព្រះទ័យវិលមកប្រទេសវិញនៅដំណាច់ខែធ្នូ ហើយនៅថ្ងៃទី៣ ខែមករា ឆ្នាំ១៩៧៦ ព្រះអង្គបានប្រកាសឲ្យប្រើរដ្ឋធម្មនុញ្ញថ្មី ។ ដោយច្បាប់នោះតម្រូវឲ្យមាន "សភាតំណាង ប្រជាជន"មួយ គេក៏រៀបចំធ្វើការបោះឆ្នោតនៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៦ ក្នុងទូទាំងប្រទេស ដើម្បីជ្រើស រើសសមាជិកសភា ដែលបន្ទាប់មកបានរួមប្រជុំអស់រយៈពេលពីរថ្ងៃក្នុងខែមេសា ឆ្នាំដដែលនោះ ។ សភាបានទទួលយល់ព្រមនូវការសុំលាលែងរបស់រដ្ឋាភិបាលសម័យរណសិរ្ស ហើយបានយល់ព្រមតាមពាក្យសុំដកខ្លួនពីកិច្ចការសាធារណៈរបស់សម្តេច ព្រះនរោត្តម សីហនុ ទៀតផង ។ ភ្លាមៗនោះ រដ្ឋាភិបាលថ្មីមួយត្រូវបានបង្កើតឡើង ដោយមាន ប៉ុល ពត ជាមេដឹកនាំ ។ ជាមនុស្សដែលពិភពលោកខាងក្រៅមិនធ្លាប់ដែលស្គាល់សោះ រហស្សនាមនេះ ត្រូវបានប្រើប្រាស់សម្រាប់លាក់អត្តសញ្ញាណរបស់ សាឡុត ស ។

សម្តេចនរោត្តម សីហនុ ដែលក្លាយទៅជាមនុស្សគ្មានបានការសម្រាប់របបថ្មី ត្រូវបានគេបំបែកចេញឆ្ងាយ និងដាក់ឲ្យស្ថិតនៅតែក្នុងព្រះរាជដំណាក់ នាព្រះបរមរាជវាំងដោយមានការតាមដានថែមទៀត ។

សម័យរណសិរ្សរួបរួមត្រូវចប់ត្រឹមនេះ ។ គេលែងបញ្ចូលសមាជិកពីគ្រប់ស្រទាប់វណ្ណៈ នៃសង្គមចាស់មកក្នុងរបបបដិវត្តន៍ថ្មីទៀតហើយ ។ អង្គការក៏លែងយកចិត្តយកថ្លើមព្រះសង្ឃ បញ្ញវន្ត ឬបណ្តាសមាជិកនៃព្រះវង្សានុវង្សទៀតដែរ ដែលកិត្តិនាមរបស់អ្នកទាំងនោះបានជួយបង្កើនកិត្យានុភាព និងការគោរពរាប់អានជាគុណប្រយោជន៍ដល់បុព្វហេតុរបស់គេហើយ ដែលការខំប្រឹងប្រែងរបស់អ្នកទាំងនោះមានតម្លៃខ្លាំងណាស់នៅកាលៈទេសៈសំខាន់ៗនៃការបដិវត្ត ។ ពួកអ្នកការទូតនៃបណ្តាប្រទេសកុម្មុយនិស្តដទៃទៀត ជាពិសេស ខាងបូកសូវៀតមានការស្ងើតចិត្តជាខ្លាំង ដោយសេចក្តីប្រកាសពីការ "ចូលរ៉ែត្រែត"របស់សម្តេច ព្រះនរោត្តម សីហនុ និងការបញ្ចប់យុទ្ធសាស្ត្រនៃរណសិរ្សរួបរួម ក៏ដូចប្រជាជាតិនានា មិនមែនកុម្មុយនិស្តដែរ ។ ពួកគេអាចដឹងថា វានឹងមានគ្រោះថ្នាក់ប៉ុនណា ដែលគេធ្វើផ្តុយនឹងការពិត ដោយការកម្ចាត់មនុស្សមួយចំនួនដែលប្រជាជនធ្លាប់គោរពស្រឡាញ់ និងស្ងើចសរសើរឆាប់រហ័សពេក និងដែលមិនអាចដកវិញបាននោះ ។ ប៉ុន្តែ ពួកខ្មែរក្រហមបានផាកចេញពីការទិតៀនជាសាធារណៈទាំងអស់ ។

ពួកខ្មែរក្រហមបានការពារជាមុនដែលទុកឲ្យមានស្លាកស្នាមក្នុងប្រវត្តិសាស្ត្រ ដោយធ្វើឲ្យរង្គោះរង្គើការប្រកាន់តាមទ្រឹស្តីរបស់កុម្មុយនិស្តរួមទាំងបុកពានយោបាយ ដែលធ្លាប់មានរួចមកហើយផង ។ គ្មានប្រទេសសង្គមនិយមណាមួយផ្សេងទៀត ហ៊ានសាកល្បងធ្វើសមូហភាវូបនីយកម្មមួយលើកម្មសិទ្ធិឯកជនជាទូទៅដូច្នេះទេ ហើយជាពិសេស បន្ទាប់ពីទទួលបានជ័យជម្នះមិនដល់មួយឆ្នាំផងនោះ ។ តាមទ្រឹស្តីគេត្រូវគ្រោងរៀបចំការបដិវត្តជាដំណាក់ៗដោយប្រុងប្រយ័ត្ន ដើម្បីរៀបចំឲ្យប្រជាជនផ្លាស់ជំនួស របៀបរបបរស់នៅចាស់ជាលំដាប់ដោយរបៀបរស់នៅថ្មីមួយរបស់កុម្មុយនិស្ត ។ ពួកខ្មែរក្រហមចាប់ផ្តើមបដិវត្តន៍របស់គេដោយដំណាក់កាលមួយដែលបណ្តាប្រទេសកុម្មុយនិស្តភាគច្រើនចាត់ទុកថា ជាគោលដៅជ្រុលហួសហេតុមួយ ហើយប្រាកដណាស់

ពុំមែនជាចំណុចចេញដំណើរមួយទេ ។

ពួកកុម្មុយនិស្តកម្ពុជា បានយកបទពិសោធន៍ផ្នែកសេដ្ឋកិច្ចដែលមានលក្ខណៈឆ្កេងបំផុតនៃប្រវត្តិសាស្ត្ររបស់កុម្មុយនិស្ត -ការបដិវត្តខស្សាហកម្មក្នុងរវាងម្ភៃប្អូនម៉ោងរបស់ស្តាលីន និង ម៉ៅ សេទុង- មកអនុវត្តជាសង្វាក់ធម្មតារបស់ការបដិវត្តគេ ។ ហើយពួកគេបានដឹកនាំការភាន់ប្រែទាំងនេះ តាមរយៈ«អង្គការ»ដ៏អាថ៌កំបាំង ដោយហេតុថា ពួកគេនៅតែលាក់បក្សពីក្រោយជញ្ជាំងសម្ងាត់មួយជានិច្ច ។ ដោយអនុះអន្ទែងហួសហេតុ ដើម្បីសាកល្បងទាញយកការគាំទ្រពីប្រជាជនទាំងឥតអៀនខ្មាស ពួកគេបានក្លាយទៅជាអ្នកកាន់អំណាចផ្តាច់ការ និងគ្រប់គ្រងដឹកនាំប្រទេសដោយប្រើអំពើភេរវកម្ម ។ សារាចរណែនាំនីមួយៗ ដែលពួកគេផ្សព្វផ្សាយឲ្យដឹងជាសាធារណៈ តែងអមទៅដោយរលកនៃការកម្ទេច និងការបោសសម្អាតមួយថ្មីទៀតមិនដែលខាន ដើម្បីការស្តាប់បង្គាប់ពីសំណាក់ប្រជាជនកម្ពុជាទាំងមូល ។

អៀង សារី បានអះអាងថា មជ្ឈិមមិនដែលនឹកស្មានថា បានត្រួតត្រាប្រទេសដោយពិតប្រាកដដូច្នេះទាល់តែសោះ ហើយបក្សអាចវាយតម្លៃថា ខ្លួនត្រូវគំរាមកំហែងជាហូរហែរមិនចេះចប់ពីសំណាក់ពួកសត្រូវដែលកំពុងសាកល្បងដណ្តើមអំណាចគេ[៥] ។ មុនដំបូង បក្សបានចោទប្រកាន់ទៅលើពួកមន្ត្រីនៃសង្គមចាស់ ហើយបានសម្លាប់ពួកនេះចោលអស់មួយចំនួនធំ ។ បន្ទាប់មក បក្សបានផ្សាយចេញនូវរបៀបបកស្រាយអំពីបដិវត្តន៍សង្គមនិយមរបស់ខ្លួន ហើយនៅពេលដែលស្ថានការណ៍របូតផុតពីដៃរបស់ខ្លួន បក្សបានចាប់ផ្តើមសង្ស័យទៅលើលេខាបក្សភូមិភាគខ្លះៗ ហើយបានឲ្យគេសម្លាប់ចោលអស់ជាច្រើននាក់ ។ ដោយដឹងខ្លួនថា ត្រូវហ៊ុំព័ទ្ធជុំវិញសុទ្ធតែសត្រូវ បក្សបានអនុវត្តន៍«សង្គ្រាមវណ្ណៈ» ក្នុងការស្រាវជ្រាវរក«ពួកខ្មាំងសត្រូវ»ទាំងអស់សង្ស័យមួយហើយបានកម្ចាត់កសិករ និងសមមិត្តទាំងឡាយរបស់គេ ពីព្រោះអ្នកទាំងនោះពុំមានប្រភពកំណើតជាវណ្ណៈដែលក្រីក្របំផុត ឬពីព្រោះពួកនោះ បានចងសម្ព័ន្ធមេត្រីជាមួយសត្រូវវណ្ណៈមួយដែលមានះចង់បំផ្លាញការបដិវត្តតែគេមិនបានបញ្ជាក់លក្ខណៈឲ្យបានច្បាស់លាស់ផងទេ ។ មជ្ឈិមមានមន្ទិលសង្ស័យទៅលើសហរដ្ឋអាមេរិក សហភាពសូវៀត និងវៀតណាមថាមានបង្កប់ភ្នាក់ងារជាច្រើននាក់ នៅក្នុងផ្ទៃបក្សកុម្មុយនិស្តកម្ពុជា ។ ការបោសសម្អាតទាំងឡាយ បានបន្តដោយការបោសសម្អាតជាច្រើនទៀត ប៉ុន្តែ «សត្រូវ»កាន់តែមិនអាចចាប់បាន និងមានគ្រោះថ្នាក់ខ្លាំងឡើងៗ ក្នុងចិត្តគំនិតរបស់បក្ស ។

ពួកខ្មែរក្រហមបានធ្លាយឲ្យដឹងថា អំណាចពុំមែនស្ថិតនៅ«ចុងកាណុងកាំភ្លើង» ទេ ។ អាវុធរបស់ពួកគេ ធ្លាប់បានវាយផ្តួលរំលំរបបចាស់ ប៉ុន្តែសម្រេចសម្រួចទៅ អាវុធទាំងនោះបង្ហាញឲ្យឃើញថា ពុំមានសមត្ថភាពបង្កើតមូលដ្ឋានអំណាចថ្មីមួយឡើយ ។ ចំពោះរឿងនេះ គេត្រូវតែធ្វើឲ្យមានការគាំទ្រនិងការយោគយល់គ្នាដ៏ជាក់លាក់មួយពីប្រជាជន ដែលពួកកុម្មុយនិស្តកម្ពុជាមិនដែលស្វះស្វែងរកនិងមិនដែលទទួលបានទាល់តែសោះ ។ ដោយខ្វះការគាំទ្រនេះ ពួកគេបានគ្រប់គ្រងដឹកនាំប្រទេសដោយការប្រើអំពើឃោរឃៅ និងភេរវកម្ម ។

*ហាន់ណាស់ អារ៉េនត៍ (Hannah Arendt) អ្នកឯកទេសខាងបញ្ហាបដិវត្ត បានធ្វើការសង្កេតនេះជាច្រើនឆ្នាំមុន ពួកខ្មែរក្រហមមិនទាន់សាកល្បងនូវការបដិវត្តចុងក្រោយបំផុតរបស់គេម្ល៉េះ ៖ «ប្រើអំពើហិង្សាឆ្ពោះទៅរកអំណាចអាចផ្តល់នូវជ័យជម្នះមែន ប៉ុន្តែ តម្លៃដែលត្រូវបង់ គឺមានកម្រិតខ្ពស់ណាស់... នៅទីបំផុតរឿងនេះច្បាស់ជានាំទៅដល់ការបំផ្លាញអំណាចទាំងអស់[៦]» ។*

*លោកស្រី អារ៉េនត៍ បានពិពណ៌នាពីរបបប្រើអំពើហិង្សាទាំងស្រុងមួយនឹងប្រព្រឹត្តទៅតាមរបៀបណា ហើយហេតុអ្វីបានជាវាបង្កឲ្យមានបរាជ័យផ្ទាល់ ដែលជាមហន្តរាយដល់ខ្លួនឯងទៅវិញ ។ មុនដំបូង របបដែលប្រើអំពើហិង្សាត្រូវតែកម្ទេចបក្សពួកប្រឆាំងទាំងអស់ ។ គេត្រូវ«បំបែកប្រជាជនឲ្យរស់នៅដាច់ពីគ្នា[៧]» ជាប្រយោគស្រាលផុតចំពោះអំពើគួរឲ្យរន្ធត់ដែលមានបង្កប់ក្នុងនោះ ។ មនុស្សទាំងអស់បានត្រូវគេបំបែកឲ្យទៅរស់នៅឆ្ងាយពីគ្នា ខ្វះការទាក់ទង និងភាពជិតស្និទ្ធ ជាលទ្ធផលដែលពួកខ្មែរក្រហមនឹងទទួលបាន ជាមួយនឹងការផ្លាស់ប្តូរប្រជាជនពីកន្លែងមួយទៅកន្លែងមួយ និងប្រព័ន្ធគ្រប់គ្រងលើសហករណ៍នានា ។ បន្ទាប់មក គេត្រូវការរៀបចំតាមដានប្រជាជនជាចាំបាច់ដោយពួកឈ្លប និងពួកអ្នកឲ្យការណ៍ ដែលមាននៅគ្រប់ទីកន្លែង ។ ពួកខ្មែរក្រហមបានបង្កើតប្រព័ន្ធឈ្លបយកការណ៍មួយ តាមរយៈភ្នាក់ងារសន្តិសុខរបស់ខ្លួន និងពួកឈ្លបនៅក្នុងសហករណ៍នានា ។ គេញុះញង់ឲ្យក្មេងៗរាយការណ៍ពីឪពុកម្តាយរបស់វាឲ្យមិត្តក្បត់នឹងមិត្ត ដើម្បីសង្គ្រោះអាត្មាខ្លួនឲ្យផុតពីសេចក្តីស្លាប់ប៉ុណ្ណោះ ។*

*លោកស្រី អារ៉េនត៍ បាននិយាយថា លទ្ធផល គឺជារបបមួយដែលគេពុំអាចជឿទុកចិត្ត ចំពោះអ្នកណាម្នាក់ឡើយ ជារបបដែលអនុវត្តន៍អ្វីៗក្នុងគោលបំណងបំផ្លាញសង្គមជាតិដោយចេតនា និងប្រើមធ្យោបាយពន្យារសម្រាប់ដោះខ្លួនមិនទទួលខុសត្រូវថែមទៀត ។ ក្នុងបរិបទមួយបែបនោះ ការរីកចម្រើនផ្នែកសេដ្ឋកិច្ចត្រូវលប់ចោល ពីព្រោះអំពើហិង្សា បានបង្កឲ្យមានភាពអសកម្មក្នុងសង្គម ជាតិទាំងមូល ។ ការប្រើខ្ជះខ្ជាយនូវជីវិតមនុស្ស និងផលិតផល គឺជាផ្លែផ្កាដែលមានពីកំណើតនៃអំពើភេរវកម្ម ។ នៅទីបំផុតរបបបានបំផ្លាញខ្លួនដោយខ្លួនឯង ពីព្រោះគេខំស្រាវជ្រាវរកពួកសត្រូវដែលពុំអាចស្គាល់បាននៅផ្ទៃក្នុងរបស់ខ្លួនផ្ទាល់កាន់តែខ្លាំងឡើងៗ ដែលលួចការរីកលូតលាស់ និងអំណាចរបស់គេ ។ បើគិតឲ្យសព្វៗទៅ ការធ្វើនេះ គឺប្រឆាំងតែខ្លួនឯងប៉ុណ្ណោះ ។*

*ហើយលោកស្រី អារ៉េនត៍ បានសន្និដ្ឋានថា «របបប្រើអំពើភេរវកម្ម ពុំមែនសំដៅប្រឆាំងតែពួកសត្រូវរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែក៏ប្រឆាំងនឹងបណ្តាសមមិត្តនិងយុទ្ធិកជនរបស់ខ្លួន ព្រោះថារបបនេះមានសេចក្តីភ័យខ្លាចអំណាចទាំងអស់ទាំងអំណាចរបស់បណ្តាមិត្តរបស់ខ្លួនផង ។ គេឈានឡើងទៅដល់ចំណុចខ្ពស់បំផុតនៃការប្រើអំពើភេរវកម្ម នៅពេលណាដែលក្រុមសន្តិសុខរដ្ឋ ចាប់ផ្តើមធ្វើឲ្យកុមារាកុមារីជាកូនចៅរបស់ខ្លួនផ្ទាល់ត្រូវវិនាសអន្តរាយ នៅពេលណាដែលពេជ្ឈឃាតពីម្សិលក្លាយទៅជាអ្នករងគ្រោះនៅថ្ងៃស្អែក[៨]» ។*

*លោកស្រី អារ៉េនត៍ បានសរសេរសៀវភៅផ្នែកទ្រឹស្តីមួយនេះ មុនពេលពួកខ្មែរក្រហមមិនទាន់បានក្តោប*

ក្តាប់ប្រទេសកម្ពុជាទៅទៀត ។ គាត់បាននិយាយទុកជាមុនស្រេចពីផលវិបាកផ្សេងៗនៃរបបមួយ ដែលកំពុងរុញច្រានការបដិវត្តទៅមុខដោយប្រើអំពើភេរវកម្មទៅដល់ចំណុចខ្លាំងបំផុតរបស់វា គឺភាពច្របូកច្របល់ខាងផ្នែកសេដ្ឋកិច្ចការកម្ចាត់ជនប្រឆាំង បរាជ័យនិងសេចក្តីស្លាប់ ។ គាត់ក៏បានបញ្ជាក់អំពីវិធីដែលរបបមួយបែបនោះត្រូវតែអនុវត្តអំពើភេរវកម្មនេះដែរ ៖ «ការបំបែកមនុស្សក្នុងសង្គមទាំងមូល» ។

ដោយផ្អែកលើគំនិតស្តីពីការបំបែកមនុស្សក្នុងសង្គមនេះហើយ ដែលគេបានយល់ដឹងកាន់តែប្រសើរជាងមុនពីអានុភាពរបស់ការបដិវត្តន៍មកលើប្រជាជនកម្ពុជា ។ ដំណើរបន្តគ្នានៃការបំបែកមនុស្សជាផ្នែកៗ ការធ្វើឲ្យសង្គមនៅឯកោពីគេ សឲ្យឃើញនិងបង្ហាញយ៉ាងច្បាស់ព្រមៗគ្នានូវជំងឺមួយ ដែលស្វែងរកយ៉ាងខ្លាំងដោយការបដិវត្តរបស់កម្ពុជាអស់រយៈការយូរមកហើយ មុនពួកកងទ័ពកុម្មុយនិស្តមិនទាន់ដណ្តើមបានជ័យជម្នះនៅឆ្នាំ ១៩៧៥ម្ល៉េះ ។ ក្នុងរយៈពេលនៃបណ្តាឆ្នាំដ៏អាប់អួទាំងនោះ ពួកខ្មែរក្រហមបានធ្វើឲ្យរីកធំនូវការគិតមមៃមួយអំពីក្បត់ដែលក្លាយទៅជាការគិតមមៃ សឹងតែខ្លាំងជាងការខ្វាយខ្វល់របស់គេចំពោះកិត្តិយសដែលបាត់បង់របស់ប្រទេសកម្ពុជាទៅទៀត ។ ប្រការនេះហើយដែលកំណត់ការជ្រើស រើសរបស់គេនូវមនោគមកុម្មុយនិស្តមួយដែលជំរុញទៅរកការប្រើកម្លាំងយ៉ាងជ្រុលហួសហេតុ និងបែបផែន«សម្ងាត់»មួយនៃការបដិវត្ត ។

ដោយកសាងបក្សនិងការបដិវត្តរបស់គេ ដោយគ្មានការគាំទ្រយ៉ាងសកម្ម និងការស្មគ្រ័យល់ព្រមពីសំណាក់ពិភពកុម្មុយនិស្ត ហើយមិនសូវមានគាំទ្រពីប្រជាជនកម្ពុជាទៀតនោះ ពួកខ្មែរក្រហមដឹងថាមិនត្រូវជឿទុកចិត្តលើអ្នកណាទាំងអស់ ។ អ្វីៗគ្រប់បែបយ៉ាងសុទ្ធតែរឿងសម្ងាត់ ។ ភាពនៅដាច់តែឯកឯង បានក្លាយទៅជាអ្វីដែលអាចឲ្យសម្រេចលទ្ធផលច្រើនប្រការ ដោយហេតុថា វាធ្វើឲ្យលេចចេញមនោសញ្ចេតនាអាថ៌កំបាំង ដែលកប់នៅក្នុងជម្រៅចិត្តមនុស្សមកខាងក្រៅ ហើយផ្តល់ឲ្យបក្សនូវរូបភាពធំហួសខ្នាតមួយ ដែលធ្វើឲ្យអំណាចផ្ទាល់របស់ខ្លួនចេះតែរីកធំឡើងៗ ។ ការសម្ងាត់ ការមិនជឿទុកចិត្ត និងការនៅដាច់តែឯកឯង បានក្លាយទៅជា«បែបផែនអនុវត្តន៍»របស់ពួកខ្មែរក្រហម ហើយបណ្តាលឲ្យកើតទ្រឹស្តីផ្សេងៗសម្រាប់ការប្រយុទ្ធរបស់ពួកគេ ដែលត្រូវនាំមុខ និងសម្រាប់សង្គមល្អឥតខ្ចោះមួយ ដែលមានជាបន្តមក ។ ពួកគេសម្គាល់ឃើញ «ពួកសត្រូវ»មាននៅគ្រប់កន្លែង ហើយគេជឿជាក់ថា មានតែវិធានការខ្លាំងៗបំផុតប៉ុណ្ណោះ ដែលនឹងអនុញ្ញាតឲ្យគេកម្ទេច និងយកឈ្នះលើពួកនេះបាន ។ គឺហេតុដូច្នេះហើយ បានជាសហករណ៍ទាំងឡាយរបស់ពួកគេក្នុងសម័យសង្គ្រាម ត្រូវតែប្រែឲ្យទៅជា«គុកឥតជញ្ជាំងទាំងអស់» ហើយកងទ័ពរបស់ពួកគេបានទទួលបញ្ជាឲ្យវាយប្រយុទ្ធរហូតស្លាប់ខ្លួន ដូចពួកកាមីកាហ្សេ (Kamikazés) ។ [កាមីកាហ្សេ គឺអាកាសយានិកជប៉ុនដែលសម្លាប់ខ្លួនឯង ដោយបើកយន្តហោះមានផ្ទុកគ្រាប់បែកពេញហោះសំដៅទៅបុកនាវាបច្ចាមិត្តក្នុងសង្គ្រាមលោកលើកទី២ -កំណត់របស់អ្នកបកប្រែ] ។

ជាមួយនឹងជ័យជម្នះ ការប្រុងប្រយ័ត្នរបស់គេរឹតតែត្រូវបង្កើនកាន់តែខ្លាំង ជាជាងត្រូវបន្ធូរបន្ថយ ។ ថ្វីបើពួកគេបានលើកសរសើរទឹកចិត្តប្រជាជនជាញឹកញាប់ ក្នុងសេចក្តីថ្លែងការណ៍ផ្សេងៗរបស់ពួកគេយ៉ាងណា

ក៏ដោយ ក៏ពួកគេមិនដែលទុកចិត្ត "អ្នកទាំងនោះ" សោះឡើយ ។ ដោយត្រូវប្រឈមមុខនឹងមនុស្សទាំងឡាយ ពួកខ្មែរក្រហមគ្មានមើលឃើញអ្វីក្រៅតែសត្រូវប៉ុណ្ណោះ ។ តាមការមើលឃើញរបស់ពួកគេ របបសង្គមចាស់គឺជាសម្បកមួយរបស់សត្រូវ ដែលគេត្រូវតែកម្ទេចចោល ។ ការទាក់ទងគ្នារវាងមនុស្ស និងមនុស្ស មានលក្ខណៈគួរឲ្យសង្ស័យទាំងអស់ ។ ពួកគេមិនទទួលស្គាល់សញ្ញាណនៃជីវិតឯកជន សិទ្ធិផ្សេងៗ និងមនោសញ្ចេតនារបស់មនុស្សម្នាក់ៗ ។ មនុស្សទាំងអស់ពុំមានចិត្តស្មោះត្រង់ចំពោះការបដិវត្តទេ គឺមានតែវណ្ណៈផ្សេងៗប៉ុណ្ណោះ ៈ វណ្ណៈកសិករ, វណ្ណៈកម្មករ និងកងទ័ព ។

ការរស់នៅជាគ្រួសារប្រហែលជារលាយបាត់បង់ បើសិនជាគេចង់រស់រានមានជីវិត ពីព្រោះថារដ្ឋត្រូវដណ្ដើមយកអំណាចគ្រួសារមកកាន់កាប់ ។ ទំនាក់ទំនងរវាងគ្រួសារ និងគ្រួសារ មានសភាពខ្លាំងក្លាបំផុត ហើយដែលគួរឲ្យព្រឺខ្លាចបំផុតនៃសង្គមចាស់ ។ នៅជនបទ គ្រួសារកសិករទាំងឡាយធ្លាប់ក្ដោបក្ដាប់អំណាចសម្រេចចិត្តមួយ ស្ដីពីបញ្ហាសំខាន់ៗដែលឥឡូវនេះ បដិវត្តន៍មានបំណងរក្សាទុកសម្រាប់ខ្លួនឯងវិញ ៈ តើដំណាំអ្វីដែលត្រូវជ្រើសរើស, តើផ្ទៃដីប៉ុន្មានដែលត្រូវប្រើប្រាស់, នៅពេលណាដែលត្រូវយកផលដំណាំទៅលក់នៅលើទីផ្សារ, អ្នកណាខ្លះដែលនឹងត្រូវទៅធ្វើស្រែ, អ្នកណាខ្លះដែលនឹងត្រូវធ្វើការនៅផ្ទះ ។

ក្នុងរបៀបវិនិច្ឆ័យជាទូទៅមួយ អត្តសញ្ញាណរបស់មនុស្សទូទៅ មានលក្ខណៈដែលគួរឲ្យសង្ស័យដូចគ្នា ។ បណ្ដាជនជាតិភាគតិចដែលកាន់សាសនា និងដែលមានវប្បធម៌ផ្ទាល់ ត្រូវតែបោះបង់ចោលលក្ខណៈពិសេសដោយឡែករបស់ពួកគេ ហើយត្រូវតែរំលាយខ្លួនក្នុងសហគមន៍ខ្មែរដូចគេដូចឯង ។ សមាជិកនៃក្រុមគ្រួសាររបស់ពួកគេ គោងតែក្លាយខ្លួនទៅជាប្រជាជនកម្ពុជាថ្មី ឬត្រូវប្រឈមមុខនឹងសេចក្ដីស្លាប់ ។ មនុស្សគ្រប់គ្នាត្រូវមានលក្ខណៈដូចគ្នា មនុស្សទាំងអស់ត្រូវស្មោះត្រង់ចំពោះរដ្ឋតែប៉ុណ្ណោះ ។ កសិករទាំងឡាយ ត្រូវបានបង្ខំឲ្យបោះបង់ចោលទំនៀមទម្លាប់ជាប្រពៃណី លក្ខណៈពិសេសនៃ ភូមិ-ស្រុក ខេត្តរបស់ពួកគេ ដើម្បីប្រកាន់យករបៀបរបបរស់នៅជាសហករណ៍វិញ ដែលប្រហែលជាមានលក្ខណៈដូចគ្នាតែមួយក្នុងទូទាំងប្រទេស ។ រាល់ការទាក់ទងផ្សេងៗក្រៅពីការទាក់ទងរវាងមនុស្សម្នាក់ៗនិងរដ្ឋ ត្រូវបានបញ្ឈប់ហើយថែមទាំងបំបិទមិនឲ្យមានទៀតផង ។

ការវាយប្រហារប្រឆាំងនឹងសង្គមជាតិឯងនេះ ត្រូវបាននាំមុខធ្វើឡើងក្នុងនាមនៃការធ្វើឲ្យបដិវត្តន៍ស្អាតបរិសុទ្ធ ដើម្បីការពារបណ្ដាកម្មាភិបាលកុម្មុយនិស្តពីធាតុមិនល្អផ្សេងៗ ដែលជាមេរោគចម្លងនៃ សង្គមចាស់ ឬសត្រូវវណ្ណៈ ។ ប៉ុន្តែ ការកំណត់អំពើលក្ខណៈសត្រូវបានប្រែប្រួលជារឿយៗ នៅពេលដែលបក្សពុំបានសម្រេចឈានដល់គោលដៅពង្រឹងអំណាចផ្ទាល់របស់ខ្លួន និងធ្វើឲ្យសេដ្ឋកិច្ចទទួលបានជោគជ័យដ៏អស្ចារ្យដូចដែលខ្លួនចង់បាន ។ ការផ្លាស់ប្ដូរមួយក្នុងនយោបាយរបស់បក្ស ការកែប្រែមួយក្នុងទ្រឹស្ដីបដិវត្តន៍ បានបង្កើតឲ្យមានប្រភេទសត្រូវថ្មីៗទៀតជាច្រើន ។ ការភ័យខ្លាចអំពីសត្រូវវណ្ណៈ ត្រូវបានជំនួសដោយការភ័យខ្លាចសមាសភាពសត្រូវផ្សេងៗ ដែលជ្រៀតចូលក្នុងផ្ទៃបក្សវិញម្ដង ។ បើគិតឲ្យសព្វៗទៅ គ្មានអ្នកណាម្នាក់រួចផុតពីការតាមឃ្លាំមើល

ឡើយ ព្រោះថា បក្សលែងឃើញអ្នកណាមួយដែលអាចឲ្យទុកចិត្តទៀតហើយឡើយ ។ "អង្គការ" កំពុងស្ថិតនៅលើផ្លូវនៃការបំផ្លាញខ្លួនឯងទាំងស្រុងមួយ និងការបំបែកសង្គមទាំងមូលមួយខ្ទេចខ្ទី ។

នេះគឺជាប្រវត្តិរបស់ជនរងគ្រោះមួយចំនួនតូច ក្នុងការស្វែងរកភាពបរិសុទ្ធរបស់បដិវត្តន៍ ។

## ប្រវត្តិប្លែកពីធម្មតារបស់ សមមិត្ត រ៉េត ការបំផ្លាញជីវភាពរស់នៅជាគ្រួសារ

ហួត លីស៊ីថា និង ហួត បុប្ផាណា ជាបងប្អូនជីដូនមួយឆ្ងាយ ដែលបានកើត និងធំធាត់ពេញវ័យនៅទីរួមស្រុកបារាយណ៍មានប្រជាជនរស់នៅ ម្ភៃពាន់នាក់ និងជាផ្លូវត្រឡែងកែងដ៏សំខាន់របស់ខេត្តកំពង់ធំ ។ ក្នុងឆ្នាំ១៩៦៥ ពេលចេញពីតរុណវ័យ លី និងបុប្ផាណា បានក្លាយទៅជាគូដណ្តឹងនឹងគ្នា ហើយលីបានចាកចេញទៅរៀនសូត្រក្នុងវត្តមួយស្របតាមប្រពៃណីរបស់ខ្មែរ ។ ក្នុងរយៈពេលប្រាំឆ្នាំ គាត់បានវិលត្រឡប់មកបារាយណ៍វិញ ហើយបានរស់នៅជាមួយបុប្ផាណា ដោយបានត្រៀមខ្លួនប្រឡងយកសញ្ញាបត្រមធ្យមសិក្សាមួយ ។

នៅឆ្នាំ១៩៧០ ពេលដែលសង្គ្រាមផ្ទុះឡើង ទីរួមស្រុកបាយរាយណ៍បានក្លាយទៅជាសមរភូមិមួយយ៉ាងធំក្នុងចំណោមសមរភូមិធំៗដែលកើតមានមុនគេបង្អស់[១០] ។ ការធ្វើប្រតិបត្តិការពីរលើករបស់ លន់ នល់ គឺចេនឡាទី១ និងប្រតិបត្តិការចេនឡាទី២ មានគោលដៅកាន់កាប់ការត្រួតត្រាតំបន់ត្រីកោណ ដ៏ធំល្វឹងល្វើយមួយនៅទិសខាងជើងក្រុងភ្នំពេញ រួមមានទាំងស្រុកបារាយណ៍ផងដែលរួមបង្កជាចំណុចកណ្តាលរបស់ប្រទេស ។ នៅឆ្នាំ១៩៧០ ក្នុងកំឡុងនៃការធ្វើប្រតិបត្តិការសឹកចេនឡាទី១ ពួកវៀតណាមខាងជើងបានវាយកាន់កាប់ស្រុកបារាយណ៍នេះ ។ មួយឆ្នាំក្រោយមក ក្នុងប្រត្តិបត្តិការសឹកចេនឡាទី២ កងទ័ពរបស់ លន់ នល់ បានវាយដណ្តើមយកវិញ ប៉ុន្តែនៅខែតុលា ទីរួមស្រុកនេះមានធ្លាក់ក្នុងកណ្តាប់ដៃរបស់ពួកវៀតណាមជាថ្មីម្តងទៀត ដោយវាយប្រយុទ្ធរួមគ្នាជាមួយពួកកម្ពុជា ។ បារាយណ៍ស្ថិតនៅខាងប៉ែកពួកកុម្មុយនិស្តពេញថិរវេលានៃសង្គ្រាម ។ នៅឆ្នាំ១៩៧៣ នៅពេលដែលពួកខ្មែរក្រហមរៀបចំបង្កើតរដ្ឋអំណាចរបស់គេត្រួតត្រាលើតំបន់នេះ គឺពួកគេបានប្រព្រឹត្តអំពើឃោរឃៅខ្លះៗក្នុងចំណោមអំពើឃោរឃៅដំបូងៗរបស់ខ្លួន ប្រឆាំងនឹងប្រជាជនស៊ីវិល ដែលរស់នៅជិតៗតំបន់បារាយណ៍នេះ ។

បន្ទាប់ពីឆ្នាំ១៩៧០ លី និងបុប្ផាណា បានភៀសខ្លួនចេញពីផ្ទះដូចប្រជាជនខ្មែរភាគច្រើនឯទៀតដែរ ។ ប៉ុន្តែ អ្នកទាំងពីរពុំបានភៀសខ្លួនទៅជាមួយគ្នាទេ ៈ លី បានរត់ទៅរស់នៅក្នុងវត្តមួយនៅខេត្តកំពង់ចាម ដែលមានព្រំដែនជាប់គ្នា- នេះជាជម្រើសសែលមនុស្សពេញវ័យមួយចំនួនធំដទៃទៀត ដែលមានអាយុត្រូវចូលធ្វើកងទ័ព ហើយដែលមិនចង់ច្បាំងឲ្យពួកខាងណាមួយ ។ បុប្ផាណា បាននាំម្តាយមេម៉ាយ និងប្អូនស្រីពីរនាក់ មករស់នៅក្រុង

ភ្នំពេញដើម្បីរកការងារធ្វើ និងរកលំនៅស្ថានមួយ ។ បុប្ផាណា មានផ្ទៃពោះទៅហើយ ប៉ុន្តែក្នុងឋានៈនាងជាកូនស្រីច្បងដែលបានទទួលការរៀនសូត្រចេះដឹងខ្ពស់គួរសម នាងបានសម្រេចចិត្តថា ត្រូវជួយផ្គត់ផ្គង់សេចក្ដីត្រូវការផ្សេងៗរបស់គ្រួសារនាង ។ នាងប្រសូត្របានកូនប្រុសម្នាក់ ដែលនាងបានប្រគល់ឲ្យប្អូនស្រីម្នាក់ក្នុងចំណោមប្អូនស្រីទាំង២ជួយមើលថែទាំ នៅពេលណាដែលនាងចេញទៅរកការងារធ្វើម្ដងៗ ។

ក្នុងរយៈពេលមួយឆ្នាំ នាងបានពឹងគេឲ្យជួយរកការងារឲ្យនាងធ្វើ ប៉ុន្តែ ក្នុងទីក្រុងមានស្ត្រីរបៀបនាងច្រើនឥណគណនា ។ នៅកន្លែងក្រុមហ៊ុនអាកាសចរណ៍កម្ពុជា គេមិនទទួលយកនាងឲ្យធ្វើជាអ្នកបម្រើភ្ញៀវក្នុងយន្តហោះទេ ព្រោះនាងមានរូបរាងស្គមពេក ។ នៅក្នុងធនាគារមួយ គេបានឆ្លើយប្រាប់នាងថា នាងត្រូវតែមានសញ្ញាប័ត្រជាន់ខ្ពស់មួយដើម្បីក្លាយជាបុគ្គលិកនៅទីនេះ ។ គ្រួសារនាងត្រូវរើជញ្ជូនអីវ៉ាន់ទៅនៅក្នុងផ្ទះតូចជាងមុនមួយវិញ ព្រោះឈ្នួលជួលថោកជាង ហើយ បុប្ផាណា បានលក់របស់របរផ្ទាល់របស់នាងអស់មួយចំនួនធំ ដើម្បីបង់ថ្លៃឈ្នួលផ្ទះ និងទិញម្ហូបអាហារ ។ នៅដើមឆ្នាំ១៩៧៣ នាងស្ទើរតែអស់សង្ឃឹមទៅហើយ នៅពេលដែលលោកស្រី ហ្គាតាណា អិនឌ័រ (Gaetana Anders) ជាភរិយាលោក ថូម៉ាស់ អិនឌ័រ (Thomas Enders) ភារធារីស្ថានទូតអាមេរិកាំងប្រចាំក្រុងភ្នំពេញបានបើកមជ្ឈមណ្ឌលទទួលជនភៀសខ្លួនមួយ ដើម្បីជួយសម្រាលទុក្ខស្ត្រីមេម៉ាយនៅក្នុងរដ្ឋធានី ។ គេឲ្យឈ្មោះមជ្ឈមណ្ឌលនេះថា គ្រឹះស្ថានមេអំបៅ[11] ពីព្រោះ«មេអំបៅ» ជារហស្សនាមកាលពីក្មេងរបស់លោកស្រី អិនឌ័រ ដែលមានដើមកំណើតជាអ៊ីតាលី ។ ប៉ុន្តែ ពាក្យនេះក៏សំគាល់ ស្រីលក់ខ្លួន ស្រីពេស្យា ដែលមាននៅក្រុងភ្នំពេញដែរ ហើយក្នុងពេលបើកដំបូង មានស្ត្រីមួយចំនួនតូចប៉ុណ្ណោះ ដែលបានទទួលអត្ថប្រយោជន៍ពីការជួយឧបត្ថម្ភ និងការបណ្ដុះបណ្ដាលវិជ្ជាជីវៈរបស់មជ្ឈមណ្ឌលនេះ ។

បុប្ផាណា គ្មានអ្វីមួយអាចរារាំងនាងបានឡើយ ។ រៀងរាល់ថ្ងៃពុធ នាងតែងទៅបង្ហាញខ្លួន ក្នុងឋានៈជាស្ត្រីមេម៉ាយម្នាក់ជានិច្ច ដើម្បីឈរបន្តកន្ទុយគ្នាចាំទទួលអង្ករ ត្រី ទឹកដោះគោ មុង សាប៊ូ ស្ករស គឺរបៀបនេះហើយដែលនាងអាចផ្គត់ផ្គង់ជីវភាពគ្រួសារនាងបានដោយងាយស្រួលនោះ ។ នាងបានទៅរៀនកាត់ដេរដោយមិនចាំបាច់ បង់ប្រាក់នៅទីនោះយ៉ាងទៀតទាត់ ហើយបានទទួលសញ្ញាបត្រមួយទៀតផង ។ បុគ្គលិកស្ត្រីកម្ពុជាម្នាក់ក្នុងចំណោមបុគ្គលិកស្រីឯទៀតៗ ដែលធ្វើការនៅមជ្ឈមណ្ឌលនោះ បានកត់សម្គាល់ទៅលើរូបនាងពីយូរមកហើយ ហើយបានសួរនាងថា តើនាងពេញចិត្តធ្វើកិច្ចការដូចគ្នានេះ និងបែងចែកជំនួយសង្គ្រោះដល់ពួកអ្នកភៀសខ្លួនដែលកំពុងហូរហៀរចូលមកក្រុងភ្នំពេញយ៉ាងសន្ធឹកសន្ធាប់ដែរទេ ។ ការទម្លាក់គ្រាប់បែកជាច្រើនដែលរៀបចំផែនការដោយលោក ថូម៉ាស អិនឌ័រ បានបង្កឲ្យមានហ្វូងអ្នកភៀសខ្លួន ដែលត្រូវការជំនួយរបស់អង្គការមនុស្សធម៌នានា ដូចជាអង្គការរបស់ហ្គាតាណាឌ័រនេះជាដើម ហូរចូលមកក្រុងភ្នំពេញហូរហែមិនចេះចប់ នេះជាការចំអកនៃសង្គ្រាមមួយដ៏គួរឲ្យចុកចាប់ ។

ដោយបានក្លាយទៅជាបុគ្គលិករបស់អង្គការនេះ បុប្ផាណា បានចាប់រៀនភាសាអង់គ្លេសយ៉ាងខ្ជាប់ខ្ជួន ។

ជាសហការីដ៏ប្រសើរ នាងតែងតែទៅធ្វើការនៅទីស្នាក់ការរបស់អង្គការនេះ ដែលស្ថិតនៅក្បែរមាត់ទន្លេបាសាក់ដោយទៀតទាត់ ។ ជីវភាពគ្រួសាររបស់នាង កាន់តែបានប្រសើរជាងមុនដែរ ។

នៅខែខសភាឆ្នាំ១៩៧៤ លី បានត្រឡប់មកភ្នំពេញម្តងទៀត ដើម្បីសិក្សានៅវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ ជាមជ្ឈមណ្ឌលដ៏ល្បីល្បាញដែលកសាងឡើងដោយពួកបារាំង កាលពីប៉ុន្មានទសវត្សរ៍មុន ។ បច្ចុប្បន្ន មជ្ឈមណ្ឌលនេះជាទីជម្រកសម្រាប់យុវជនក្មេងៗដែលគេចពីសង្គ្រាមមួយដែលកាន់តែឃោរឃៅខ្លាំងឡើងៗ ។ លី បានធ្វើការទាក់ទងជាមួយ បុប្ផាណា ហើយអ្នកទាំងពីរក៏បានជួបមុខគ្នា ។ ប៉ុន្តែ លី បានក្លាយទៅជាព្រះសង្ឃមួយអង្គ ដែលគ្រងចីពរពណ៌លឿងមានបុកពា ស្ងប់ស្ងាត់ជាអ្នកតំណាងសាសនាព្រះពុទ្ធម្នាក់ទៅហើយ បុប្ផាណា ក៏ផ្លាស់ប្តូរចរិកលក្ខណៈជាស្ត្រីខ្មែរម្នាក់ ដែលមាននឹងធឹងទៅជាស្ត្រីម្នាក់ដែលមានបុកពាបែបបស្ចិមប្រទេសវិញ ។ ភាពអៀនប្រៀនជាស្ត្រីរស់នៅតាមខេត្តរបស់នាង បានរលាយបាត់អស់ ។ នាងបានកាត់សក់វែងធ្លាក់មកដល់ចង្កេះរបស់នាងចោល ហើយបានប្រកាន់យករបៀប សម្លឹងមើលត្រង់ៗ និងជាស្ត្រីដែលផ្ចិតផ្ចង់ក្នុងការងារម្នាក់ ។ រូបថតជាច្រើនរបស់នាង បានបង្ហាញឲ្យឃើញថា នាងជាស្ត្រីម្នាក់ដែលមានរូបសម្ផស្សយ៉ាងស្អាត ។ អ្នកទាំងពីរបានជួបមុខគ្នាប្រហែលជាពីរ-បីខែក្រោយមកទៀតដែរ បន្ទាប់មក លី បានបាត់ខ្លួនពីទីក្រុងដោយគ្មាននិយាយលានាងមួយម៉ាត់ឡើយ ។

ក្នុងកំឡុងប៉ុន្មានខែចុងក្រោយនៃសង្គ្រាម បុប្ផាណា ប្រឹងធ្វើការគ្មានឈប់ឈរដើម្បីអង្គការមនុស្សធម៌នេះ ដោយចែកអំណោយសង្គ្រោះ និងចូលរួមគ្រប់ការប្រជុំជាមួយជនបរទេសមួយចំនួនតូច ដែលសុខចិត្តស្ថិតនៅក្នុងក្រុងភ្នំពេញដើម្បីជួយពួកអ្នកភៀសខ្លួន ។ នៅខែមករាឆ្នាំ១៩៧៥ នាងត្រូវបានតែងតាំងជាលេខាធិការរបស់អង្គការនេះ ។ នៅខែមេសា ពួកអាមេរិកាំងបានចាកចេញពីរដ្ឋធានី ហើយប៉ុន្មានថ្ងៃក្រោយមក ពួកខ្មែរ-ក្រហមបានចូលមកដល់ទីក្រុងក្នុងនាមជាអ្នកឈ្នះសង្គ្រាម ។

ក្នុងសភាពច្របូកច្របល់នៃការជម្លៀសប្រជាជន បុប្ផាណា ត្រូវបែកឃ្លាតពីគ្រួសាររបស់នាង ដែលប្រហែលជានាងមិនបានជួបគ្នាម្តងទៀតជារៀងរហូត ។ ដោយធ្វើតាមបទបញ្ជារបស់ខ្មែរក្រហមឲ្យត្រឡប់ទៅកាន់ភូមិកំណើតរបស់ខ្លួនវិញ នាងក៏ធ្វើដំណើរត្រឡប់មកខេត្តកំពង់ធំវិញ ជាមួយប្រជាជនយ៉ាងច្រើន ។ ស្រុកបារាយណ៍របស់នាងបានប្រែក្លាយទៅជាកន្លែងការពារមាំទាំមួយរបស់ពួកកុម្មុយនិស្តទៅហើយ ។ ពួកខ្មែរក្រហមធ្លាប់បានធ្វើជាម្ចាស់នៅទីនេះ ក្នុងរយៈពេលមួយភាគធំនៃសង្គ្រាម ហើយបានរៀបចំបង្កើតប្រព័ន្ធសហករណ៍ដ៏រឹងមាំមួយរួចជាស្រេច ។ ជាមួយនឹងស្បែកភ្លឺថ្លា និងរលោងរបស់នាង និងបុកពាបែបបស្ចិមប្រទេសរបស់នាង បុប្ផាណា បានក្លាយទៅជាគោលដៅមួយនៃការនិយមចូលចិត្តពីអ្នកដទៃច្រើនជាងគេ ។ ជាច្រើនឆ្នាំមកហើយ នាងពុំដែលធ្លាប់បានរត់លូនពីការទម្លាក់គ្រាប់បែក គ្រាប់កាំភ្លើងទេ ពុំដែលធ្វើការនៅក្រោមកម្តៅថ្ងៃដែលក្តៅស្ទើរឆេះ ពុំដែលទ្រាំទ្រនឹងការខ្វះខាតសព្វបែបយ៉ាងដូចប្រជាជនឯទៀតៗឡើយ ។ ឥឡូវនេះ នាងនឹងបានស្គាល់ជោគ

វាសនានេះហើយ ។ ត្រូវកំណត់ចាត់ទុកជាអនុប្រជាជន (មិនទាន់ពេញសិទ្ធិជាប្រជាជន) ពីសំណាក់សហករណ៍ដំបូង នាងពុំបានទទួលរបបម្ហូបអាហារបន្តិចសោះ ហើយនាងត្រូវតែលួចបេះផ្លែឈើស៊ីដើម្បីបំពេញក្រពះ ។ នៅពេលយប់ បណ្តាមិត្តភក្តិចាស់ៗរបស់នាង បានលបលួចយកម្ហូបអាហារបន្តិចបន្តួចមកឲ្យនាងបរិភោគជាសម្ងាត់ ។ នៅពេលថ្ងៃ នាងត្រូវបំពេញកិច្ចការដ៏លំបាកហើយគ្មានបានផល ដែលគេបានចាត់ឲ្យនាងធ្វើ ។ នាងបេះប្រយ័ត្ន លាក់ពីកិច្ចការដែលនាងធ្លាប់បានធ្វើនៅភ្នំពេញ ហើយក៏លែងនិយាយពីរូប លី ដែរ ព្រោះនាងមិនដឹងថាគាត់ស្លាប់ ឬក៏នៅរស់នៅឡើយ ។

ប្រពន្ធរបស់ប្រធានសហករណ៍ ដែលជាអតីតប្រធានភូមិបានចាប់ផ្តើមសង្ស័យលើរូប បុប្ផាណា ពីរឿងខុសសីលធម៌ ។ គាត់បានចោទប្រកាន់ថា នាងធ្លាប់ធ្វើជាស្រីសំផឹងនៅភ្នំពេញក្នុងរយៈពេលសង្គ្រាម ហើយបានដណ្តឹងសួរក្នុងចិត្តថា តើនាងដែលលេងសើចជាមួយពួកកម្មាភិបាលខ្មែរក្រហមក្នុងពេលយប់ដែរឬទេ? បុប្ផាណាមានរាងកាយចុះស្គម ហើយការភ័យខ្លាច ការនឿយហត់ និងការស្រេកឃ្លាន បានធ្វើឲ្យសុខភាពរបស់នាងរីងរៃបន្តិចម្តងៗ ។ បន្ទាប់មក នៅខែកញ្ញា លី បានត្រឡប់មកបារាយណ៍វិញ ដើម្បីសួរសុខទុក្ខម្តាយរបស់គាត់ ហើយការរស់នៅរបស់ បុប្ផាណា ក៏បានប្រសើរជាងមុន ។

លី បានចាកចេញពីវត្តនៅក្រុងភ្នំពេញ ហើយបានក្លាយទៅជាយុទ្ធជនខ្មែរក្រហមម្នាក់ ។ បន្ទាប់ពី បាត់ខ្លួនក្នុងសភាពអាថ៌កំបាំងពីរដ្ឋធានី និងពីជីវិតរបស់ បុប្ផាណា គាត់បានចូលទៅធ្វើកងទ័ពជាមួយ កុយ ធួន ក្នុងភូមិភាគឧត្តរ ។ ស្បង់ចីពរត្រូវជំនួសដោយឯកសណ្ឋានពណ៌ខ្មៅ និងកាំភ្លើងខ្លីមួយដើម ។ គាត់ក៏បានផ្លាស់ ឈ្មោះ ហួត លីស៊ីថា ទៅជាសមមិត្ត ដែត វិញ ។ គាត់បានឡើងសក្តិយសតាមឋានានុក្រមកុម្មុយនិស្តយ៉ាងលំបាក ហើយនៅពេលដែលសង្គ្រាមផុតរលត់ទៅ និងពេលដែលប្រធានភូមិភាគឧត្តរក្លាយទៅជារដ្ឋមន្ត្រីសេដ្ឋកិច្ចរបស់ប្រទេស ដែតបានមកធ្វើការជាអនុប្រធានរបស់កុយធួនដដែល ។ គាត់កំពុងឈប់សម្រាកមួយរយៈខ្លីក្នុងស្រុកកំណើតរបស់គាត់ នៅពេលដែលគាត់រកឃើញ បុប្ផាណា ដែលជាមនុស្សអត់អាហារយូរថ្ងៃមកហើយ ហើយដែលត្រូវគេសង្ស័យថា ជាចារនារីម្នាក់ផង ។

ដោយរំភើបចិត្តជាខ្លាំង នាងបានសរសេរសំបុត្រជាលើកដំបូង ក្នុងចំណោមសំបុត្រជាហូរហែមួយ ដែលគេហាមឃាត់ទៅឲ្យប្តីរបស់នាង ។ នាងដឹងថា នាងបានរំលោភលើវិន័យមួយក្នុងចំណោមវិន័យសំខាន់ៗរបស់បដិវត្តន៍ ហើយនាងដឹងថាការធ្វើរបៀបនេះហាក់ដូចជាជំរុញឲ្យរូប លី និងរូបនាងផ្ទាល់ ធ្លាក់ទៅក្នុងគ្រោះថ្នាក់ដូចគ្នា ។

> «ដោយមនោសញ្ចេតនានឹករឭកចំពោះប្តីសម្លាញ់! ខ្ញុំទើបនឹងបានជួបមុខប្តីសម្លាញ់ជាថ្មីក្រោយពីបែកបាក់គ្នាជាច្រើនឆ្នាំមក ។ ការបដិវត្តរបស់កម្ពុជា បានបោះមួយជំហានទៅមុខហើយ ។ បណ្តាមិត្តភក្តិ បងប្អូនជីដូនមួយទាំងអស់គ្នា បានក្លាយទៅជាប្តីប្រពន្ធ ។ ក្រោយសម័យដែលប្រកបដោយទុក្ខព្រាត់និរាសនាឆ្នាំ១៩៧០ ភាពល្វីងជូរចត់ បានបន្ថែមការចុកចាប់មកលើ

ដួងចិត្តខ្ញុំបន្តិចម្តងៗរហូតដល់ថ្ងៃដែលខ្ញុំដឹងថា ខ្ញុំបានជួបមុខ ដែត ជាថ្មីទាំងរូបកាយនិងចិត្ត ។
ពីប្រពន្ធដ៏អភ័ព្វរបស់បង
បុប្ផាណា ផ្កាស្នេហ៍កម្ម»

ដែត បានប្រកាសថា បុប្ផាណា ដែលនៅតែស្រស់ស្អាតដដែល គឺជាប្រពន្ធដែលគាត់ជឿថា ស្លាប់បាត់បង់ជីវិតជាយូរមកហើយៗ គាត់បានរៀបចំឲ្យនាងរស់នៅក្នុងផ្ទះជាមួយម្តាយ និងជីដូនគាត់ (ឪពុកគាត់បានស្លាប់តាំងពីតាំងពីមុនសង្គ្រាមម្ល៉េះ) ។ ដោយលែងមានគិតគូរពីអ្វីទៀត ដែត បានសម្រេចកសាងជីវិតមួយជាមួយ បុប្ផាណា ជាថ្មី ក្នុងសភាពប្របូកប្រថុលនៃការបដិវត្ត ។ «ពួកអ្នកចាស់» ក្នុងភូមិ មិនអាចតវ៉ាជំទាស់នឹង ដែត ទេ ថែមទាំងត្រូវគាត់បង្ខំមិនឲ្យនិយាយពីរឿងរបស់គ្រួសារគាត់ទៀតផង ព្រោះគាត់ជាកម្មាភិបាលជាន់ខ្ពស់ម្នាក់ ។ ប៉ុន្តែ ពួកអ្នកភូមិមិនជឿសម្តីគាត់ឡើយ ព្រោះថា បុប្ផាណា មិនដែលនិយាយពីរូបគាត់ម្តងណាទាល់តែសោះ ក្នុងរយៈពេលប្រាំខែដែលនាងបានចូលមករស់នៅក្នុងសហករណ៍នេះ ។ ទន្ទឹមនឹងនោះ គ្រួសាររបស់ ដែត ក៏ពុំដែលនិយាយថា យុវនារីនេះជាប្រពន្ធរបស់ ដែត ដែរ ។ ប៉ុន្តែ អ្នកទាំងអស់នោះ កំពុងស្ថិតនៅក្នុងដំណាក់ទីមួយនៃការបដិវត្តនៅឡើយ បក្សក៏ពុំទាន់រៀបចំបើកមហាសន្និបាតរបស់ខ្លួនដែរ ហើយ«ពួកអ្នកចាស់» ក្នុងសហករណ៍ដែលកំពុងបញ្ឈរក់អះអាងពីសិទ្ធិអំណាចរបស់គេលើ«ពួកអ្នកថ្មី» ដែលទើបមកពីភ្នំពេញ សុទ្ធតែគោរពកោតខ្លាច «អង្គការ» យ៉ាងខ្លាំងដើម្បីប្រឆាំងជំទាស់នឹងកម្មាភិបាលម្នាក់ក្នុងចំណោមកម្មាភិបាលទាំងឡាយរបស់អង្គការ ។ ដូច្នេះ បុប្ផាណា ត្រូវបានអនុញ្ញាតឲ្យរស់នៅជាមួយគ្រួសាររបស់ ដែត ក្នុងឋានៈជាភរិយាកម្មាភិបាលម្នាក់ ។

បុប្ផាណា និង ដែត បានសរសេរសំបុត្រឆ្លើយឆ្លងគ្នារបៀបជាសង្សារមួយគូ ដែលត្រូវរាំងរាដោយទំនាយ គឺពុំមែនសរសេររបៀបអ្នកប្រវត្តិវិទូទេ ។ ពួកគេសរសេរជាភាសាខ្មែរដូចគ្នា ។ ដែត និង បុប្ផាណា បានឆ្លងកាត់ចំណែកដែលនៅសេសសល់នៃជីវិតដ៏ខ្លីរបស់គេ ដោយប្រព្រឹត្តបំពានវិន័យរបស់អង្គការ ដែលនៅលើនោះពួកខ្មែរក្រហមបានបង្ហាញខ្លួនឡើងជាមនុស្សដែលឆាប់ប្រកាន់ខឹងជាទីបំផុត ។ អ្នកទាំងពីរបានស៊ុមគ្រលុំគ្នាជាសម្ងាត់ក្នុងការរួមរស់ជាប្តីប្រពន្ធឡើងវិញ តាមរយៈសំបុត្រជាច្រើន ដែលលាតត្រដាងឲ្យគេដឹងរឿងអាថ៌កំបាំងផ្សេងៗរបស់គេខ្ទេចខ្ទី ដោយសរសេរក្នុងពេលយប់ និងផ្ញើទៅឲ្យគ្នាដោយលួចលាក់តាមមិត្តភក្តិផ្សេងៗ ។ សំបុត្រទាំងនេះ បានបង្កជាសេចក្តីរាយការណ៍ដ៏សំខាន់មួយដែលកម្រមានណាស់ ក្នុងកំឡុងខែដំបូងៗនៃការបដិវត្ត ជាការសាកល្បងគ្មានបានប្រយោជន៍របស់បុរសម្នាក់ និងស្ត្រីម្នាក់ ដើម្បីរស់នៅក្នុងឋានៈជាប្តីប្រពន្ធនឹងគ្នា មុននឹងស្គាល់ការវង្គន្ទាទោសចំពោះ «បទឧក្រិដ្ឋទាំងឡាយ»របស់ពួកគេ ។ ដែត ជាកម្មាភិបាលដ៏សំខាន់ម្នាក់របស់ខ្មែរក្រហម បុប្ផាណា ជាលេខាធិការិនីម្នាក់មានបុកពារបែបបស្ចឹមប្រទេសរបស់អង្គការមនុស្សធម៌មួយ នៅពេលដែលជីវិតរបស់គេក្លាយទៅជាការសាកល្បងជាហូរហែមួយដោយគ្មានទីបញ្ចប់ ពួកគេបានបែរទៅរកវប្បធម៌សម័យព្រេងនាយ ដើម្បីរិះរកគំរូចរិយាធម៌មួយសម្រាប់មាគ៌ាជីវិតទៅវិញ ។ ពួកគេបានជួបគ្នារបៀប ព្រះរាម និងនាងសីតា

ជាតួអង្គក្នុងរឿងរាមកេរ្តិ៍ ដែលជាប្រវត្តិដ៏គួរឲ្យខ្លោចផ្សា ដែលបានបណ្តុះអារម្មណ៍ក្នុងខួរក្បាលមនុស្សរាប់ជំនាន់ ស្តីពីករណីយកិច្ច និងស្នេហានៅចំពោះមុខផលកម្មដ៏អាក្រក់[១៧] ។

ក្នុងរឿងរាមកេរ្តិ៍ នាងសីតា ត្រូវក្រុងរាពណ៍កំណាចចាប់ពង្រាត់យកទៅ បន្ទាប់មក បានត្រូវជួយសង្គ្រោះដោយស្វាមីរបស់នាង គឺព្រះរាម ហើយបានល្បងពីភាពបរិសុទ្ធរបស់នាងដែលត្រូវព្រះអង្គសង្ស័យ ។ នាងជាមនុស្សដែលហាក់ដូចជាត្រូវគេបំបរបង់ចោល ហើយនៅទីបញ្ចប់នាងត្រូវមានករណីកិច្ចធ្វើវិញ្ញាសាដើរកាត់ភ្លើងដើម្បីបង្ហាញឲ្យឃើញពីភាពបរិសុទ្ធរបស់នាង ។ នាងបានដើរកាត់អណ្តាត ភ្លើងដោយគ្មានឆេះរលាកខ្លួនឡើយ ប៉ុន្តែ នាងបានសុំឲ្យព្រះធរណីស្រូបយកនាងទៅចុះ ព្រោះព្រះនាងបានទទួលរងនូវការប្រមាថយ៉ាងអាម៉ាស់ជ្រុលពេកហើយ ។ បុប្ផាណា និងស្រីជំទង់កម្ពុជាឯទៀតៗ បានស្តាប់ឮនូវប្រវត្តិស្នេហាបរិសុទ្ធ និងប្តូរផ្តាច់របស់នាងសីតា ចំពោះ ព្រះរាម នេះដែរ ហើយក្នុងអំឡុងពេលនៃការបដិវត្តនេះ បុប្ផាណា បាននឹកគិតទៅដល់ទុក្ខវេទនារបស់នាង សីតា គ្មានឈប់ឈរឡើយ ។

ដែតបានទុកប្រពន្ធរបស់ខ្លួននៅផ្ទះម្តាយរបស់គាត់ ហើយវិលត្រឡប់មកទីស្នាក់ការបណ្តោះអាសន្ន នៃទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចវិញ ដោយរង់ចាំការរៀបចំការិយាល័យធ្វើការជាសម្រេចនៅក្រុងភ្នំពេញ ។ គាត់បានសន្យាថា នឹងយកនាងទៅនៅក្រុងភ្នំពេញដែរ កាលណាគេប្រគល់លំនៅស្ថានមួយឲ្យគាត់ ហើយបានណែនាំឲ្យនាងខស្សរាប់និយាយរំឭកថា គេទាំង២បានរៀបការជាប្តីប្រពន្ធតាំងពីឆ្នាំ១៩៧០ម៉្លេះ ។ គាត់បានប្រាប់នាងឲ្យដឹងជាមុនក្នុងសំបុត្រមួយថា «បើពុំដូច្នេះទេ អង្គការ និងមិនព្រមអនុញ្ញាតឲ្យស្ត្រីអ្នកជម្លៀសម្នាក់ រៀបការជាមួយកម្មាភិបាលរបស់បក្សឡើយ» ។

សំបុត្រដែល បុប្ផាណា ផ្ញើទៅឲ្យគាត់នៅស្នាក់ការបណ្តោះអាសន្ន មានលក្ខណៈជាមនុស្សនៅមានសុទិដ្ឋិនិយមជានិច្ច ។ ភាគខាងលើនៃសំបុត្រ នាងបានសរសេរដោយក្លាហានហួសប្រមាណជាភាសាអង់គ្លេស ដោយបញ្ចេញឲ្យឃើញសក្តិភាពនៃការសិក្សារៀនសូត្ររបស់នាងថា ៖

*«ប្តីសម្លាញ់! អូនទើបនឹងបានទទួលសំបុត្រព្រមទាំងរបស់របរដែលបងបានផ្ញើមកឲ្យអូននៅពេលរសៀលនេះប្រកបដោយសេចក្តីសប្បាយរីករាយយ៉ាងខ្លាំង ។ ស្នេហារបស់អូន! សូមបងកុំបារម្ភពីរឿងអូនអី ឥឡូវនេះអូនសុខសប្បាយជាទេ ប៉ុន្តែ បាត់តែបង មិនឃើញមករកអូនសោះ»* ។ បន្ទាប់មក នាងបន្តសេចក្តីសំបុត្រជាភាសា និងអក្សរខ្មែរថា ៖

*«អូនបានធ្វើនូវអ្វីៗទាំង អស់ ដែលបងបានណែនាំអូន ដោយអូនត្រូវក្រោកពីយប់ដើម្បីរៀបចំបាយទឹកសម្រាប់ជូនម៉ែ បោកគក់ខោ អាវរបស់យាយ ប្អូនប្រុស ប្អូនស្រី និងដណ្តាំស្លគ្រប់ពេលវេលា ។ សព្វថ្ងៃអូនឈប់ដើរទៅធ្វើការទៀតហើយ ។ ថ្ងៃស្អែកម៉ែបានទៅសុំគេឲ្យអូននៅធ្វើការជាមួយនិងស្ត្រីឯទៀតៗនៅក្នុងភូមិ... ។ ប្តីសម្លាញ់! សូមបងអភ័យទោស ចាំស្តាប់អូននិយាយពីរឿងដែលបងបានស្នើអូនកាលពីថ្ងៃមុន គឺអូនពុំមាន*

ឱកាសសរសេរសំបុត្រនៅពេលថ្ងៃបានទេ ហើយអូនក៏គ្មានប្រេងចាក់ចង្កៀងសម្រាប់សរសេរសំបុត្រនៅពេលយប់ដែរ ។ តើបងនៅភ្នំពេញសុខសប្បាយជាទេ? ប្រហែលប៉ុន្មានថ្ងៃ ប៉ុន្មានខែទៀត ទើបបងមករកអូន!» ។

អំណឹះតទៅ បុប្ផាណា បានរស់នៅប្រកបដោយឯកសិទ្ធដូច«ពួកអ្នកចាស់» និងប្រពន្ធៗរបស់ថ្នាក់ដឹកនាំសហករណ៍ដែរ ។ នាងមានម្ហូបអាហារគ្រប់គ្រាន់សម្រាប់បរិភោគ មានសម្លៀកបំពាក់ច្រើនបន្លាស់ និងមានក្របខ័ណ្ឌជាគ្រូសារកម្មាភិបាលម្នាក់ ។ នាងខិតខំធ្វើការយ៉ាងស្វិតស្វាញ ប៉ុន្តែ នេះលែងជាពេលម៉ោងដែលគេអត់ទ្រាំមិនបានដូចមុនទៀត ហើយនៅពេលដែលនាងត្រូវក្រោកមុនពេលព្រឹកព្រលឹម ដើម្បីស្រោចច្បារបន្លែរបស់សហករណ៍ «ប្រាំដងក្នុងពេលព្រឹក» រួចហើយបំពេញភារកិច្ចជាធម្មតារបស់នាង ទើបត្រឡប់ទៅស្រោចបន្លែរបស់នាងម្តងទៀត «ប្រាំដងក្នុងពេលល្ងាច» ។

«ពួកអ្នកចាស់» នៅតែសង្ស័យរូបនាងជានិច្ច ។ នាងបាននិយាយប្រាប់ ដែត ជាសម្ងាត់ក្នុងសំបុត្រមួយដែលមានមកក្រោយទៀតថា «បណ្តាមិត្តភក្តិរបស់អូនបាននិយាយថា មាននារីច្រើននាក់ណាស់ ដែលច្រណែននឹងអូន ។ នារីទាំងនោះធ្លាប់រស់នៅជាមួយបដិវត្តន៍តាំងពីប្រាំឆ្នាំមកហើយ ហើយគ្មាននារីណាម្នាក់មានប្តីដែលមានឋានៈខ្ពស់ដូចបងឡើយ តើគេត្រូវធ្វើយ៉ាងដូចម្តេចដើម្បីបានឡើងឋានៈខ្ពស់ដូច្នេះ? » ។

ផ្កាយជីវិតរបស់ ដែត បានរះកាន់តែខ្ពស់ថែមទៀត ។ មិនយូរប៉ុន្មាន ក្រោយពេលដែល បុប្ផាណា សរសេរសំបុត្រទីពីររបស់នាងទៅឲ្យប្តីនៅដើមឆ្នាំ១៩៧៦ ដែត និងក្រសួងរបស់គាត់ត្រូវបានផ្ទេរមកតាំងនៅទីក្រុងភ្នំពេញវិញ ។ ប៉ុន្តែ មុននឹងចាកចេញទៅ ដែត បានធ្វើដំណើរទៅបារាយណ៍ដើម្បីជួប បុប្ផាណា សិន ហើយនៅពេលដែលគាត់ចូលកាន់មុខតំណែងនាងក៏មានផ្ទៃពោះដែរ ។ កូនទីមួយរបស់នាងត្រូវបាត់បង់ជីវិតក្នុងភាពច្របូកច្របល់នៃសង្គ្រាមទៅហើយ ឥឡូវនេះ ពួកគេប្រហែលជាអាចចិញ្ចឹមកូនរបស់ខ្លួនដោយខ្លួនឯងបាន ។ អង្គការបានប្រកាសថា ប្រជាជនត្រូវតែបង្កើតកូនឲ្យកើនទ្វេមួយជាពីរ ដើម្បីឲ្យមានហត្ថពលករកាន់តែច្រើន សម្រាប់ស្តារប្រទេសឡើងវិញ ។

ប៉ុន្តែ ការស្រមើស្រមៃរបស់ ដែត បានត្រូវធ្វើឲ្យរលាយបាត់បង់ពេលដែលគាត់មកតាំងលំនៅនៅក្រុងភ្នំពេញម៉្លេះ ។ តែពីរឆ្នាំសោះ ទីក្រុងដែលគាត់ធ្លាប់ស្គាល់កាលពីគាត់នៅជាព្រះសង្ឃ រៀនសូត្រនៅទីនេះ បានក្លាយទៅជាទីក្រុងមួយដែលលែងមានអ្វីៗទាំងអស់ ។ គេហដ្ឋានធំៗ និងអគារដែលមានច្រើនជាន់ត្រូវបានគេកែប្រែឲ្យទៅជាកន្លែងដេករួម ដែលពួកបុរស និងនារី ត្រូវរស់នៅដោយឡែកពីគ្នា ។ ជាទូទៅ ខាងក្នុងគ្រឹះស្ថានទាំងនោះ មានផ្ទះបាយរួមមួយដែលគេត្រូវទៅហូបបាយនៅទីនោះគ្រប់តែពេល ។ ជីវភាពរស់នៅជាគ្រួសារ គឺពិបាកណាស់យ៉ាងហោចណាស់ក៏សម្រាប់ ដែត និងកម្មាភិបាលផ្សេងៗទៀត ដែលមានឋានៈស្មើនឹងគាត់ដែរ ។

ការរស់នៅរបស់គាត់ ត្រូវបានគ្រាប់តាមគំរូនៃភាពជាប់ឃុំទាំងស្រុង ដូចពួកអ្នកធ្វើការឯទៀតៗក្នុងរដ្ឋធានីដែរ ។ គាត់បានរស់នៅក្នុងលំនៅស្ថានមួយជាមួយបុរសជាច្រើនផ្សេងទៀត ដែលត្រូវក្រោកពីព្រលឹម

ហូបបាយដើរទៅធ្វើការដូចៗគ្នា ។ អ្នកទាំងអស់នោះបានត្រឡប់មកកន្លែងវិញ ដើម្បីហូបបាយ គ្រប់តែពេល និង ដេកពួនក្នុងផ្ទះដេករួមមួយ ។ ដើម្បីបំពេញពេលវេលាទំនេរ ពួកនោះគ្មានធ្វើអ្វីក្រៅតែពីដាំបន្លែបន្ការ និងដាំស្រូវ លើផ្ទៃដីដែលមានក្នុងទីក្រុង ត្រង់នេះបន្តិចត្រង់នោះបន្តិច និងដីដែលនៅជុំវិញកន្លែងធ្វើការនោះឡើយ ។ ភាពគ្មាន ស្រីៗដែលគេពិបាកទ្រាំទ្រក្នុងសម័យសង្គ្រាម បានបន្តរហូតមកដល់ជីវភាពរស់នៅដូចអ្នកជាប់គុកនេះទៀត ។ គេបានសន្យាអនុញ្ញាតច្បាប់ឲ្យពួកបុរសៗ ទៅសួរសុខទុក្ខគ្រួសាររបស់ខ្លួនដែរ ដោយបានព្រមានថា ពួកគេនឹងពុំ បានស្គាល់ជីវភាពរស់នៅជួបជុំគ្រួសារឡើងវិញក្នុងពេលដ៏ខ្លីនេះទេ ហើយក៏ពុំមានកន្លែងណាមួយសម្រាប់ បុប្ផាណា ដែរ ។

ហេតុការណ៍មានសភាពកាន់តែធ្ងន់ធ្ងរឡើងៗដែលនាំឲ្យដែតចាប់ផ្តើមពិភាល់ចំពោះខ្លួនឯងផ្ទាល់ ។ មជ្ឈិម បានចោទប្រកាន់ កុយ ធួន ជាមេកោយរបស់គាត់ ហើយគាត់បានដណ្តឹងសួរខ្លួនឯងថា តើការធ្វើមិនបានសម្រេច ជោគជ័យរបស់ក្រសួងសេដ្ឋកិច្ច វាជាលទ្ធផលនៃអំពើក្បត់មួយមែនឬ? ពុំនោះទេ តើត្រូវបកស្រាយពីការប្រួត កាត់លើកដំបូងនៅខែធ្នូ ដែលធ្វើឲ្យស្រងាកចិត្ត និងតួលេខមិនល្អរបស់សហករណ៍នានា ក្នុងវិស័យផ្សេងៗទៅ ដោយរបៀបណា? ។ ការធ្វើឲ្យផ្នែកឧស្សាហកម្ម និងសិប្បកម្មមានសំទុះថ្មី, ការសម្របសម្រួលផ្នែកសេដ្ឋកិច្ច មានសភាពយឺតយ៉ាវ ។ នៅដើមឆ្នាំ១៩៧៦ កុយ ធួន ត្រូវបានចាប់ខ្លួន សាកសួរចម្លើយរួចដោះលែងឲ្យមាន សេរីភាពឡើងវិញ ប៉ុន្តែ មិនទាន់ឲ្យរួចទោសទេ ។ តាមពិត មជ្ឈិម និងផ្នែកសន្តិសុខ ត្រូវការពេលវេលាដើម្បី រៀបចំការចោទប្រកាន់ទៅលើរូបគាត់ ។ ប៉ុន្តែ គាត់ជាគោលដៅនៃការវាយប្រហារមួយងាយស្រួលជាទីបំផុត ពីព្រោះ កុយ ធួន លែងគ្រប់គ្រងដឹកនាំភូមិភាគ និងលែងមានកងទ័ពនៅក្រោមបញ្ជាការរបស់គាត់ទៀតហើយ ។ ម្យ៉ាងទៀត អតីតដែនដីឧត្តររបស់គាត់ ធ្លាប់តែទន់ខ្សោយស្រាប់ផង បើប្រៀបធៀបទៅនឹងបណ្តាភូមិភាគ ផ្សេងៗទៀត ដែលស្មោះត្រង់នឹងចលនាកុម្មុយនិស្តកម្ពុជាខ្លាំងជាងគេ ដូចជាភូមិភាគបូព៌ា និងនិរតីជាដើម ។ ក្នុងនាមនៃការសម្លាប់បង្ហើយនូវបណ្តាមនុស្ស ដែលមានវណ្ណៈភាពដើមជាគហបតីតូចតាចដូច កុយ ធួន អតីត គ្រូបង្រៀនជាអាទិ៍នោះ គឺ មជ្ឈិម ទើបនឹងចាប់បញ្ចេះសង្គ្រាមវណ្ណៈ ក្នុងទូទាំងប្រទេសហើយ ។

កត្តាប្លែកៗទាំងនេះ ជាសញ្ញានាំមកនូវការខ្វាយខ្វល់ចិត្តយ៉ាងខ្លាំងសម្រាប់សហការីទាំងឡាយរបស់ កុយ ធួន ជាពិសេស សមមិត្ត ដែត ដែលបានឡើងបុណ្យស័ក្តិក្រោមការជួយទំនុកបម្រុងរបស់ កុយ ធួន ។ ម្យ៉ាងទៀត ដែត បានលាក់អតីតភាពរបស់គាត់មិនឲ្យបក្សដឹងឡើយ ហើយបក្សក៏គ្មានបានដឹងពីការសិក្សារៀនសូត្រ និង ការរៀបអាពាហ៍ពិពាហ៍របស់គាត់ជាមួយ បុប្ផាណា ដែរ ។ មុនឆ្នាំ១៩៧៦ នៅពេលដែល“អង្គការ”ធ្វើសង្គ្រាម និងរៀបចំផែនការផ្លាស់ប្តូរទីលំនៅប្រជាជនពីកន្លែងមួយទៅកន្លែងមួយ និងដាក់ឲ្យប្រជាជនទាំងនោះ រស់នៅក្នុង សហករណ៍នានា អង្គការពុំសូវមានពេលពិនិត្យពិច័យឲ្យល្អិតល្អន់ពី “សមាសភាពវណ្ណៈ” ក្នុងជួរកងទ័ពរបស់ខ្លួនទេ ទាំងពុំបានគិតពីសម្ព័ន្ធភាពផ្សេងៗរបស់សមាជិកខ្លួន ជាមួយនឹងរបបដែលចាញ់សង្គ្រាមដែរ ។ ឥឡូវនេះ មាន

សារាចរណែនាំជាច្រើនបានស្នើឲ្យស៊ើបអង្កេត លើបណ្ដាសមាជិកក្នុងបក្សនិងកងទ័ព ជាពិសេស បណ្ដាសមាជិកនៃអតីតភូមិភាគខាងត្បូងដែលអាចមានជាប់ទាក់ទងនឹង កុយ ធួន ផ្ទាល់ ។

ក្រោយការមកដល់ក្រុងភ្នំពេញបន្តិច ដែត បានសរសេរសំបុត្រមួយទៅឲ្យប្រពន្ធរបស់គាត់ ដែលមានជិតដាមទៅដោយការអស់សង្ឃឹមមួយយ៉ាងក្រៀមក្រំ ។ គាត់ចាប់ផ្ដើមដឹងខ្លួនថា មានចំណងមួយកំពុងរួបរឹតខ្លួនគាត់យ៉ាងតឹង គាត់ដណ្ដឹងសួរខ្លួនឯងថា តើការបដិវត្តបានត្រៀមបម្រុងអ្វីខ្លះសម្រាប់រូបគាត់ និងបុប្ផាណា?

*«ដោយទុក្ខក្រៀមក្រំជាខ្លាំងចំពោះភរិយាជាទីស្រឡាញ់ដែលរងទុក្ខវេទនា!»*

*«ប្រពន្ធសម្លាញ់! ហេតុអ្វីបានជាអូនរងទុក្ខវេទនាដូចបងដែរ? (បុប្ផាណា បានសរសេរសំបុត្រទៅប្រាប់ដែតថា នាងមានជំងឺ) ។ បងក៏អ៊ីចឹងដែរ បងចាប់ផ្ដើមចុកចាប់ក្នុងចិត្តណាស់ ។ បងមានការតប់ប្រមល់ជាខ្លាំង ទ្រូងបងឡើងក្ដៅងំ ។ បងមានសេចក្ដីភ័យខ្លាច អ្វីៗទាំងអស់ដែលបងមើលឃើញជុំវិញខ្លួនបង ។ ការសម្លឹងមើលរបស់បងត្រឡប់ត្រឡិនអស់ហើយ ។ ប៉ុន្តែ បងនឹងទ្រាំទ្រការចុកចាប់នេះ ដើម្បីអាចបានជួបមុខអូនម្ដងទៀត ។ ក្នុងដំណើរវិលវល់នៃការចាប់កំណើតក្នុងជាតិនេះ អូនមានបាបកម្ម បងក៏មានបាបកម្ម គឺយើងមានដូចគ្នា ។ ម៉ែមានជំងឺគ្រុនផ្ដាសាយមួយយ៉ាងខ្លាំង ហើយបងដឹងថា គាត់មានក្ដីកង្វល់ចំពោះរូបបង គាត់ព្រួយចិត្តនឹងយើងទាំងពីរណាស់... ។ បងនឹកដល់អូនជានិច្ច បងឈឺចាប់យ៉ាងខ្លាំង ។ ពេលនេះបងសុំលាអូនត្រឹមនេះសិន ព្រោះបងយំហូរចេញទឹកភ្នែកច្រើនណាស់ ។*

*ពីប្ដីដ៏កម្សត់របស់អូនដែលរងទុក្ខវេទនា !*

*ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៦*

ការសិក្សាផ្នែកពុទ្ធសាសនាអស់ជាច្រើនឆ្នាំរបស់ ដែត បានធ្វើឲ្យគាត់មើលឃើញអំពីការបដិវត្ត ។ ព្រះពុទ្ធបានប្រៀនប្រដៅថា ជីវិតគឺជាភាពបន្តគ្នានៃសេចក្ដីទុក្ខដែលវិលវល់ចុះឡើងមិនចេះចប់ ។ ដូចប្រជាជនកម្ពុជាឯទៀតដែរ ដែត បានរិះរកនូវបែបទផ្សេងៗក្នុងវប្បធម៌ផ្នែកសាសនារបស់ខ្លួននូវគំរូផ្សេងៗ ដែលអាចជួយឲ្យគាត់ប្រឈមមុខនឹងភាពគួរឲ្យរន្ធត់ដែលចេះតែរីកធំឡើងៗនៃការបដិវត្ត ។ ក្នុងសេចក្ដីឆ្លើយតបរបស់នាង បុប្ផាណា បានចាប់ផ្ដើមដាក់ឈ្មោះខ្លួនឯងថា សីតា ហើយបានចុះហត្ថលេខា សីតា ដែត គឺ សីតា របស់ ដែត ។

បុប្ផាណា បានក្លាយទៅជាស្ត្រីដែលអាចត្រូវរងគ្រោះថ្នាក់ថែមទៀតជាមួយនឹងការវិវត្តនៃស្ថានការណ៍ប្រទេសនៅឆ្នាំ១៩៧៦ ។ ការប្រួតកាត់នៅខែធ្នូ ឆ្នាំ១៩៧៥ បានធ្វើឲ្យមជ្ឈិមខកចិត្តយ៉ាងខ្លាំង ។ ពួកមេដឹកនាំធំៗបានសម្រេចចិត្តថា ការដោះស្រាយរឿងនេះ ស្ថិតនៅត្រង់ការដកហូតកម្មាភិបាលមិនល្អ ដែលទទួលខុសត្រូវលើបញ្ហានេះចេញពីមុខតំណែងទាំងអស់ ហើយបានបញ្ជាឲ្យពង្រីកកងការងារជាច្រើនទៀត កាត់បន្ថយព្រមទាំងលុបបំបាត់ជីវភាពគ្រួសារទាំងស្រុងដើម្បីបង្កើនល្បឿនបដិវត្តន៍ ។ អំណើះតទៅ ប្រជាជនទាំងអស់ត្រូវតែហូប

បាយនៅផ្ទះបាយរួម ដូច្នេះ បុប្ផាណា លែងអាចធ្វើបាយទឹកសម្រាប់ជីដូនរបស់ ដែត និងបោកគក់ខោអាវសម្រាប់គ្រួសារទៀតហើយ ។ នាងខំប្រឹងធ្វើការយ៉ាងហួសប្រមាណឆ្ងាយពីផ្ទះសម្បែងក្នុងកងការងាររមួយដោយគ្មានការជួយគាំពារដែល ដែត និងគ្រួសាររបស់នាងអាចផ្តល់មកឲ្យនាងឡើយ ។ នៅពេលដែលគេប្រកាសពីការបង្កើតរដ្ឋាភិបាលថ្មី រដ្ឋធម្មនុញ្ញថ្មី និងការដាក់ សម្តេច ព្រះនរោត្តម សីហនុ ឲ្យនៅដាច់តែឯង បុប្ផាណាក៏ស្ថិតនៅក្រោម ការឃ្លាំមើលជាប់ជាប្រចាំ ហើយត្រូវសហករណ៍សង្ស័យលើនាងថែមទៀត ។ "ពួកអ្នកចាស់" នៅរង់ចាំជាមួយ នឹងការជឿជាក់ថា ការកែទម្រង់នឹងធ្លាក់មកដល់ជាថ្មីទៀត ។

ក្នុងសំបុត្រដ៏វែងអន្លាយ និងគួរឲ្យពិបាកចិត្តមួយ ដែលនាងដាក់ឈ្មោះខ្លួនឯងថា សីតា នោះ បុប្ផាណាបានទទួលស្គាល់ថា នាងមានបញ្ហាជាច្រើននៅឯសហករណ៍ ។ ប៉ុន្តែ ឈ្មោះដែលនាងសន្មតដាក់ឲ្យខ្លួនឯងនេះ មានន័យថា នាងនឹងទ្រាំទ្រទុក្ខលំបាកវេទនាគ្រប់បែបយ៉ាង ដូច នាងសីតា ក្នុងរឿងរាមកេរ្តិ៍ដែរ ។ ជាដំបូង នាងបានសាកសួរសុខទុក្ខរបស់ ដែត នាងព្រួយបារម្ភពីរឿងដែលគេដកហូតកាំភ្លើងខ្លីរបស់គាត់ជាសញ្ញាថា គាត់កំពុងស្ថិតក្នុងគ្រោះថ្នាក់ បន្ទាប់មក នាងបាននិយាយរៀបរាប់ត្រឡប់ត្រឡិន ដែលគ្មានទាក់ទងគ្នាសោះ ពីការនិយាយដើមជាច្រើន ដែលមានរូបនាងជាកម្មវត្ថុ ។ "មិត្តភក្តិទាំងឡាយរបស់បងបាននិយាយប្រាប់ សីតា ថា "សីតា នាងពុំមែនជា សីតា របស់ ដែត ទេ" ។ (ពួកគេមិនជឿថា អ្នកទាំង២ បានរៀបការរួចមកហើយទេ) ។ ប៉ុន្តែ នៅពេលដែល សីតា ឃើញ បងក្លាយទៅជាកម្មាភិបាល ក៏គោរពបងជាប់... (គួសត្រូវម្នាក់) បានអះអាងថា សីតា ធ្លាប់ធ្វើជាស្រីសំផឹងនៅក្រុងភ្នំពេញ គឺមកពីរឿងនេះហើយ ដែលនាងបង្កើតឲ្យមានភាពចលាចលពេញបារាយណ៍ ។ ប្រពន្ធរបស់ប្រធានសហករណ៍ក៏និយាយដែរថា សីតា ជាស្រីខូចម្នាក់ ដែលលួចប្រព្រឹត្តស្នេហាជាមួយពួកកម្មាភិបាលដើម្បីលាភសក្ការៈ ឱ!ប្តីសម្លាញ់ ពាក្យមួលបង្កាច់ទាំងនេះ ធ្វើឲ្យ សីតា ឈឺចុកចាប់ពន់ពេកណាស់ ពួកគេលបតាមដាន សីតា ពេលដែលអូនទៅដួតទឹកក៏ពួកគេតាមយកការណ៍ដែរ ។ អូនមានអារម្មណ៍ថា ហាក់ដូចជាមនុស្សមានទោសអស់ជីវិតអីចឹង ។ នៅពេលដែលអូនងើបពីឈឺ គេបានបញ្ជូនអូនទៅលើកភ្លឺមួយជាមួយប្រជាជនឯទៀតៗភ្លាម ថែមទាំងគេទិតៀនអូនថែមទៀត ។ មិត្តភក្តិទាំង ឡាយបាននិយាយប្រាប់អូនថា ពួកគេនឹងមិនឲ្យអូននៅរក្សាស្បែកដ៏ភ្លឺថ្លាដូច្នេះទៀតទេ ។ អូនត្រូវតែធ្វើឲ្យស្បែកឡើងស្រគាំដូចគេដូចឯង ។

បុប្ផាណា មានសភាពធ្លាក់ចុះខ្សោយខាងផ្លូវចិត្ត និងផ្លូវកាយយ៉ាងខ្លាំង ហើយបានអង្វរកឲ្យ ដែត ជួយស្រោចស្រង់នាងផង ។

"ប្តីសម្លាញ់! អូនសូមអង្វរ សូមនិយាយប្រាប់សីតាឲ្យត្រង់មកថា តើហេតុអ្វីបានជាមិនឃើញមានអ្នកណាមកយកអូនចេញពីទីនេះសោះ ។ ម៉ែបាននិយាយប្រាប់អូនថា នឹងមានមនុស្សម្នាក់មកយកអូនទៅ ប៉ុន្តែ សីតា នៅរង់ចាំ ចាំបាត់ៗ... ។ ក្នុងការគប់ប្រមល់ចិត្តរបស់អូន សីតា នឹកដល់បងជានិច្ច ។ អូនអាចរត់គៀសខ្លួនជាសម្ងាត់ ប៉ុន្តែ អូននឹងមិនធ្វើដូច្នេះឡើយ (នាងនឹងមិនរត់ទៅកាន់ព្រំដែនថៃទេ) ។ សីតា ចង់ជួបបង ...តើប្រវត្តិនេះ

នឹងបញ្ចប់ទៅដោយរបៀបណា? ប្តីសម្លាញ់! សីតា អស់សង្ឃឹមខ្លាំងណាស់ សីតា ចង់ជួបនឹងប្តីសម្លាញ់...» ។

នាងបាននិយាយជាលើកដំបូងពីសេចក្តីស្លាប់ដែលអាចកើតមាន របស់នាងហើយបានសច្ចាថា នឹងសងសឹកទៀត ។ «បើសិនជាសីតាស្លាប់ អូនសូមអង្វរបង!សូមបងកុំភ្លេចយកសំពត់រាត្រីរបស់អូនមកស្លៀកពាក់ឲ្យអូនផង ដើម្បីអូនអាចសងសឹកនៅភពខ្មោច ។ ទោះបីខ្ញុំក្លាយទៅជាខ្មោចម្នាក់ ក៏គំនុំសងសឹករបស់អូននៅតែឆេះក្តៅងំក្នុងដើមទ្រូងរបស់ សីតា ដែរ ធ្វើឲ្យអូននៅមិនសុខឡើយ...» ។

ដោយលាក់កំហឹងរបស់នាងមិនឲ្យគេដឹង បុប្ផាណា បានប្រឹងប្រែងគោរពពេលម៉ោងធ្វើការដែលកាន់តែយ៉ាប់យ៉ឺនឡើងៗរបស់សហករណ៍នាង ដើម្បីជៀសវាងការកត់សម្គាល់ពីអ្នកដទៃ និងការលំបាកចិត្តផ្សេងៗ ។ នៅដើមឆ្នាំ១៩៧៦ គេបានបញ្ជូននាងឲ្យទៅជីកប្រឡាយទឹកជាមួយកងការងារមួយក្រុម ។ ដើម្បីស្រោចស្រពផ្ទៃដីស្រែចំនួនមួយលានប្រាំសែនហិកតា ប្រជាជនទាំងអស់ត្រូវស្ថាបនាទំនប់ទឹក ប្រឡាយទឹកយ៉ាងច្រើនជាមួយនឹងគ្រឿងឧបករណ៍យ៉ាងតិចតួចបំផុត និងដោយគ្មានការឲ្យយោបល់ពីអ្នកបច្ចេកទេសផងទេ ។ ចំណុចសំខាន់នៃការស្ថាបនាបានប្រព្រឹត្តទៅនៅកំឡុងរដូវប្រាំ គឺនៅរវាងរដូវច្រូតកាត់ និងរដូវបង្កបង្កើនផល ។ បុប្ផាណា បានក្លាយទៅជាស្រមោចមួយក្នុងហ្វូងស្រមោចជាច្រើនដែលនៅមីរដេរដាសលើដី ជានារីម្នាក់ក្នុងចំណោមនារីទាំងឡាយដែលកំពុងលើកដុំថ្ម និងជញ្ជូនទៅដាក់កន្លែងមួយដែលនឹងត្រូវស្ថាបនាទំនប់ទឹក ។

ប៉ុន្តែ បុប្ផាណា ជាស្រីដែលមានសុខភាពទន់ខ្សោយស្រាប់ និងមានផ្ទៃពោះផងនោះ បានរលំដួលនៅលើការដ្ឋាន ហើយគេក៏ដឹកនាងយកមកផ្ទះវិញ ។ បន្ទាប់ពីការឈប់សម្រាកពីរ-បីថ្ងៃ នាងក៏វិលត្រឡប់ទៅធ្វើការវិញ ។ ម្ហូបអាហារចាប់ផ្តើមខ្វះខាត ហើយពុំមែនមានតែនាងម្នាក់ទេ ដែលធ្លាក់ខ្លួនឈឺដោយការហត់នឿយ ការស្រេកឃ្លាន និងការអស់សង្ឃឹម ។ ក្រោយពីបានស្តាប់សម្តេច ព្រះនរោត្តម សីហនុ មានព្រះបន្ទូលតាមវិទ្យុថាព្រះអង្គនឹងដកព្រះកាយចេញពីកិច្ចការសាធារណៈមក មានប្រជាជនកម្ពុជាយ៉ាងច្រើន បានបាត់បង់ក្តីសង្ឃឹមអស់ហើយ បានប្រថុយប្តូរជីវិតដើម្បីលួចរត់ចេញពីប្រទេស ។ «ពួកអ្នកថ្មី»មួយចំនួនតូច នៅសហករណ៍របស់បុប្ផាណា បានសម្រេចរត់គេចខ្លួនដោយជោគជ័យនៅខែឧសភា ។ ប្រធានសហករណ៍ បានទម្លាក់ការទទួលខុសត្រូវអំពីរឿងនេះមកលើរូបនាង ហើយសម្រាប់ជាលើកដំបូងបង្អស់ ដែលនាងមានបំណងធ្វើអត្តឃាដមែនទែន ។ ប៉ុន្តែ នាងបានផ្លាស់ប្តូរគំនិតនេះចោលវិញ ។

នាងបានធ្លាក់ខ្លួនឈឺជាថ្មី ហើយត្រូវគេនាំយកទៅដេកសម្រាកក្នុងមន្ទីរពេទ្យមួយ ដែលកម្មាភិបាលពេទ្យជាច្រើននៅទីនោះធ្លាប់មានការបណ្តុះបណ្តាលខាងវិជ្ជាពេទ្យដ៏សំគិះមួយ ប៉ុន្តែ ពួកខ្មែរក្រហមបានចាត់ពួកនេះ ឲ្យទទួលរ៉ាប់រងដឹកនាំវិស័យសុខាភិបាលបដិវត្តន៍របស់គេ ។ ដោយមិនទុកចិត្តពួកគិលានុបដ្ឋាក និងគ្រូពេទ្យនៃរបបចាស់ ដែលមានការបណ្តុះបណ្តាលត្រឹមត្រូវ ពួកកុម្មុយនិស្តបានសម្លាប់អ្នកទាំងនោះចោលអស់មួយភាគធំ ដែលបានប្រាប់ពីមុខវិជ្ជាជីវៈរបស់ខ្លួនត្រង់ៗ ។ ពួកកុម្មុយនិស្តបានជ្រើសរើសបុគ្គលិក ពេទ្យរបស់គេដោយឈរលើ

លក្ខណៈវិនិច្ឆ័យខាងនយោបាយខ្លាំងជាងវិជ្ជាជីវៈ ឧទាហរណ៍ ពួកគេបានជ្រើសរើសកូនៗរបស់បណ្ដាមេដឹកនាំបក្ស (ដូចជាកូនស្រីពីរនាក់របស់ អៀង សារី ជាដើម) កូនចៅរបស់ពួកស្រទាប់បាតនៃសង្គម ឬអ្នកដែលស្ថិតនៅក្នុងចលនាយុវជនបដិវត្តន៍ ដើម្បីឲ្យទៅទទួលការហាត់រៀនវិជ្ជាពេទ្យជាន់ដំបូងមួយ ក្នុងអ្វីដែលពួកខ្មែរក្រហមចាត់ទុកដូចជាការប្រតិបត្តិតាមក្បួនពេទ្យដែលជាគ្រឹះដ៏សំខាន់ ។ តាមយោបល់របស់អ្នកទាំងនោះ ពួកគេបានប្រើប្រាស់រុក្ខជាតិផ្សេងៗសម្រាប់ផ្សំធ្វើឱសថ ប៉ុន្តែ ការយល់ដឹងរបស់ពួកគេក្នុងវិស័យនេះ ជាទូទៅ ច្រើនតែផ្អែកលើប្រពៃណី ឬលើជំនឿផ្ដេសផ្ដាសទៅវិញ ។ ពួកអ្នកថ្មីកខាងវិជ្ជាពេទ្យរបស់ខ្មែរក្រហម ដែលតាំងខ្លួនជាអ្នកចេះវេជ្ជសាស្ត្រសម័យនោះ ជាទូទៅសុទ្ធតែជាគ្រូពេទ្យបោកប្រាស់ ដែលច្រើនតែធ្វើឲ្យអ្នកជំងឺរិតតែឈឺខ្លាំងឡើងច្រើនជាងធ្វើឲ្យបានជាសះស្បើយ ។

នៅពេលដែលនាងទៅដល់មន្ទីរពេទ្យ គេបានចាក់ថ្នាំឲ្យនាងត្រង់ត្រគាកជាច្រើនម្ជុល ។ កន្លែងចាក់ថ្នាំនោះឡើងហើមប៉ោង ក្លាយទៅជាអាប់សែក្ដៅធំ ហើយ បុប្ផាណា បានរងនូវការរលូតកូនថែមទៀត ។ នាងបានចេញពីមន្ទីពេទ្យវិលមកបារាយណ៍វិញ ដើម្បីសម្រាកឲ្យមានសុខភាពស្រួលបួល និងរង់ចាំជួប ដែត ។

នាងបានសរសេរសំបុត្រមួយទៅឲ្យ ដែត ដែលក្នុងនោះនាងបាននិយាយពីការព្យាបាលរោគនៅមន្ទីពេទ្យពីជំងឺគ្រុនញាក់របស់នាង ពីត្រគាកដែលអាប់សែដោយសារចាក់ថ្នាំមិនត្រឹមត្រូវ ហើយបានបញ្ជាក់ប្រាប់ថានាងត្រូវចាប់ផ្ដើមធ្វើការឡើងវិញហើយ ក្រោយពីការវិលត្រឡប់មកផ្ទះបានពីរថ្ងៃ ។ “អូនបានចាប់ផ្ដើមធ្វើការវិញហើយ ប៉ុន្តែ អូនដូចជាគ្មានកម្លាំងកំហែងសោះ អូនហេវហត់យ៉ាងខ្លាំង ។ ថ្នាំពេទ្យទាំងនោះ ធ្វើឲ្យអូនឡើងញ័រសព្វសាច់ ហើយក្នុងទ្រូងអូនក្ដៅក្រហល់ក្រហាយ ។ តាមស្មានមើលទៅ គ្រឿងក្នុងរបស់អូនវាឆេះក្ដៅខ្លោចអស់ហើយពុំដឹង ។ ប្ដីសម្លាញ់! តើបងអាចផ្ញើថ្នាំ ដូចជាថ្នាំ តេត្រាស៊ីគ្លីន ស្ករសមួយគីឡូក្រាម មកឲ្យប្រពន្ធរបស់បងខ្លះបានទេ? ឬត្រូវរង់ចាំថ្ងៃណាដែលការងារលែងត្រូវការរូបអូន?” ។

ដែត អស់សង្ឃឹមជាខ្លាំងពេលអានមកដល់ត្រង់វគ្គដែល បុប្ផាណា ប្រាប់ឲ្យដឹងពីថ្ងៃមរណភាពរបស់នាង “ពេលដែលការងារលែងត្រូវការអូន” ។ គាត់បានសរសេរសំបុត្រមួយដោយមានចារពាក្យថា “ប្រញាប់” លើខ្នងសំបុត្រ ហើយផ្ញើទៅឲ្យនាងតាមនិរសារម្នាក់ ដើម្បីប្រាប់នាងឲ្យសាកល្បងបញ្ចុះបញ្ចូលប្រធានសហករណ៍សុំច្បាប់ធ្វើដំណើរមកជួបគាត់នៅភ្នំពេញ ។ នេះជាសេចក្ដីស្នើការមិនសមទំនងមួយ ដែលបានប្រែក្រឡាស់មកប្រឆាំងនឹងអ្នកទាំងពីរវិញ ។ ប្រធានសហករណ៍មិនត្រឹមតែមិនយល់ព្រមតាមពាក្យសុំរបស់ បុប្ផាណា ប៉ុណ្ណោះទេ គាត់ថែមទាំងចាប់ផ្ដើមការស៊ើបអង្កេតមួយអំពីរូបនាងទៀត និងស្នើឲ្យសន្តិសុខភូមិជួយតាមដានរូបនាងផង ។

ដោយនឹកព្រួយបារម្ភ ដែត បានម្រេចជោគជ័យក្នុងការរិះរកសំណុំលិខិតចាំបាច់ផ្សេងៗសម្រាប់ ធ្វើដំណើរទៅដោយខ្លួនឯង ហើយបានទៅដល់បារាយណ៍នៅខែមិថុនា ។ គាត់បានបង្ខំប្រធានសហករណ៍ អនុញ្ញាតឲ្យគាត់នាំយក បុប្ផាណា មកភ្នំពេញ ប៉ុន្តែ ដោយគាត់គ្មានលិខិតអនុញ្ញាតធ្វើដំណើរសម្រាប់រូបនាង ពាក្យស្នើសុំរបស់

គាត់បានត្រូវគេបដិសេធ ។ ដែត បានប្រាប់ប្រពន្ធឲ្យឈប់ប្រើប្រាស់ថ្នាំដែលបញ្ញត្តិដោយ«ពួកវេជ្ជបណ្ឌិត» ខ្មែរក្រហមនោះទៅ ហើយបានសន្យាថា ពេលត្រឡប់ទៅភ្នំពេញគាត់នឹងប្រឹងប្រែងធ្វើឲ្យបានលិខិតត្រឹមត្រូវតាមច្បាប់ ដើម្បីនាំយកនាងទៅរស់នៅឯរាជធានីឲ្យទាល់តែបាន ។ តាមពិត គាត់បានពឹងពាក់កម្មាភិបាលម្នាក់ ដែលអាចចេញលិខិតស្នាមបែបនោះ ហើយបញ្ចុះបញ្ចូលឲ្យកម្មាភិបាលនោះ ចេញច្បាប់អនុញ្ញាតសម្រាប់ បុប្ផាណា បានមករួមរស់ជួបជុំគ្នាជាមួយគាត់នៅក្រុងភ្នំពេញ ។

ប៉ុន្តែ មុនពេលដែលគាត់អាចចាកចេញពីភ្នំពេញ ដើម្បីធ្វើដំណើរទៅរក បុប្ផាណា ការបដិវត្តបានដើរមុនគាត់មួយជំហាន ។ ក្រុមសន្តិសុខបានទទួលបទបញ្ជាឲ្យស្វែងរកភ័ស្តុតាងផ្សេងៗ ដែលក្រសួងពាណិជ្ជកម្មដឹកនាំដោយ កុយ ធួន មេកោយរបស់ ដែត ជាជម្រកមួយរបស់ពួកវិច្ឆេទករ ។ ធួន បានក្លាយទៅជាគោលដៅវាយប្រហារនៅក្នុងការបោសសម្អាតផ្នែកនយោបាយយ៉ាងធំ របស់បក្សជាលើកដំបូងបំផុត សម្រាប់មូលហេតុ២ ៖ គាត់ជាអតីតលេខាបក្សភូមិភាគឧត្តរ និងបច្ចុប្បន្នជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។ បក្សបានកម្ទេចកម្មាភិបាលរបស់ភូមិភាគនេះអស់យ៉ាងច្រើន ដែលជាប់ចោទថាបានក្បត់នឹងប្រទេសជាតិ ។ ចំណែកខាងរឿងរបស់ក្រសួង គាត់ត្រូវគេចោទថា ជាអ្នកទទួលខុសត្រូវចំពោះការគ្មានសមត្ថភាពធ្វើឲ្យសេដ្ឋកិច្ចជាតិដែលគ្រោងទុកជាមុន ដោយបក្សសម្រេចបានជោគជ័យ ។ ដូច្នេះ កុយ ធួន សម្រាប់ប្រើជាមនុស្សដែលគេចាំទម្លាក់កំហុសទៅលើគ្រប់បែបយ៉ាងចំពោះបញ្ហាចុះដុនដាបផ្នែកសេដ្ឋកិច្ច ព្រមទាំងចំពោះពួកអ្នកដែលគេសន្មតថា បានប្រព្រឹត្ត «អំពើក្បត់»ក្នុងអតីតភូមិភាគរបស់គាត់ផង ។

សន្តិបាលក៏បានទទួលបញ្ជាឲ្យឆែកឆេរនៅកន្លែងដេករួមរបស់ ដែត ដែរ ពីព្រោះ មានកម្មាភិបាលម្នាក់ដែលនៅទីនោះជាជនសង្ស័យម្នាក់ ក្នុងចំណោមជនជាប់សង្ស័យសំខាន់ៗនៃការស៊ើបអង្កេតពីរឿង កុយ ធួន នេះ ។ ពួកសន្តិបាលគ្មានរកឃើញវត្ថុអ្វីមួយសម្រាប់ចោទប្រកាន់ជននោះឡើយ ប៉ុន្តែ នៅពេលដែលរៀបចាកចេញពីទីនោះ ពួកគេបានប្រទះឃើញកន្លែងសម្ងាត់មួយដ៏គួរឲ្យសង្ឃឹម នៅកៀនជញ្ជាំងដែល ដែត ដេក ។ ក្នុងចំណោមវត្ថុប្រើប្រាស់ផ្ទាល់ខ្លួនរបស់ ដែត គេបានរកឃើញសំបុត្រស្នេហាចំនួនប្រាំច្បាប់ រូបថត បុប្ផាណា បីសន្លឹក និងលិខិតស្នាមដែលគេអនុញ្ញាតច្បាប់ឲ្យ ដែត ធ្វើដំណើរទៅភូមិភាគឧត្តរ និងនាំយក បុប្ផាណា មករស់នៅភ្នំពេញ ។

ដែត ត្រូវចាប់ខ្លួនក្រោមការចោទប្រកាន់ពីបទធ្វើចារកម្មឲ្យ កុយ ធួន ហើយសន្តិសុខក៏ចេញបញ្ជាឲ្យចាប់ខ្លួន បុប្ផាណា ដែរ ។ ពួកមេដឹកនាំសហករណ៍របស់នាង បានបញ្ចេញសេចក្តីរីករាយមួយ នៅពេលប្រគល់រូបនាងទៅឲ្យពួកឈ្លបភូមិ ។ នាងត្រូវគេដឹកយកមករដ្ឋធានីភ្នំពេញ ហើយនាំទៅដាក់មន្ទីរឃុំឃាំងទួលស្លែងនៅថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៦ ។ នៅពេលដែលប្រធានសន្តិសុខអានសំបុត្រទាំងអស់ រួចហើយក៏មានគំនិតមួយថា ត្រូវសើរើរឿងដើមទាំងប៉ុន្មាន ដែលនាងបានប្រព្រឹត្តពីអតីតកាលកន្លងមក ហើយថា គឺរូបនាងនេះហើយ ដែលជាអ្នកជាប់សង្ស័យសំខាន់ជាងគេ ពុំមែន ដែត ទេ ។ គេបានចោទប្រកាន់នាង ធ្វើការដើម្បីជាប្រយោជន៍ដល់សេ.អ៊ី.អា.

ដូច កុយ ធួន ដែរ ។ ត្រូវចោទថា ជាអ្នកចាញ់បោកប្រពន្ធរបស់ខ្លួន ដែត ត្រូវបានសម្លាប់ចោល ហើយសំណុំរឿងរបស់គាត់ក៏បាត់បង់រកមិនឃើញដែរ ។

បុប្ផាណា ទំនងជាត្រូវគេចងភ្ជាប់នឹងគ្រែមួយ ដោយមានដាក់ខ្នោះជង់នៅក្នុងបន្ទប់តូចមួយ[១៣] ។ នាងបានឆ្លងកាត់យប់ដំបូងរបស់នាង ដោយគ្មានដឹងពីមូលហេតុដែលគេនាំយកនាងមកដាក់ក្នុងឋាននរកនេះ ពីទោសទណ្ឌកម្មអ្វីខ្លះ ដែលគេត្រៀមបម្រុងសម្រាប់ចោទប្រកាន់រូបនាងឡើយ ។ ចាប់ពីពេលថ្ងៃនេះទៅ នាងនឹងលែងនិយាយពីរូបនាងក្រោមឈ្មោះថា សីតា ដែត ទៀតហើយ គឺមានតែឈ្មោះ បុប្ផាណា ប៉ុណ្ណោះ ។ ហើយនាងត្រូវទទួលរង«ការសាកល្បងដើរកាត់ភ្លើង»ជាលើកចុងក្រោយនេះ (ដូចនាងសីតា ដើរកាត់ភ្លើងដើម្បីបញ្ជាក់ពីភក្ដីភាពរបស់នាងចំពោះព្រះរាមដែរ) ក្រោមការធ្វើទារុណកម្មចំនួយប្រាំខែគ្មានស្រាកស្រាន្ត មុនព្រះធរណីស្រូបយករូបនាងនៅទីបញ្ចប់ ។

ពុំមានមធ្យោបាយដោះកុនសម្រាប់ បុប្ផាណា ទេ ៖ ពិតណាស់ នាងជាប្រភេទមនុស្សដែលបក្សចង់កម្ទេចចោលក្នុងរលកនៃការសម្លាប់មនុស្សជាលើកដំបូងនេះ ។ នៅឆ្នាំ១៩៧៦ ពួកមេដឹកនាំខ្មែរក្រហមនៅតែខ្វាយខ្វល់ពីការបំផ្លាញរបបសង្គមចាស់ឲ្យសាបសូន្យនៅឡើយ ជាពិសេស អ្នកទាំងឡាយណាដែលធ្លាប់កាន់មុខតំណែងខ្ពស់ៗ ។ ដោយ បុប្ផាណា ធ្លាប់ធ្វើការឲ្យអង្គការមនុស្សធម៌មួយ និងរួមចំណែកជាមួយរដ្ឋាភិបាល លន់ នល់ ក្នុងការជួយពួកអ្នកភៀសខ្លួននោះ នាងត្រូវគេចាត់ចូលក្នុងប្រភេទអ្នករដ្ឋការសង្គមចាស់ដែរ ។ ដោយសារតែ ដែត នាងត្រូវគេចោទប្រកាន់ថា បានបង្ខូចកម្មាភិបាលម្នាក់ក្នុងចំណោមកម្មាភិបាលជាច្រើនរបស់បដិវត្តន៍ -ជាអំពើឧក្រិដ្ឋកម្មមួយដែលរបបខ្មែរក្រហមព្រឺខ្លាចជាងគេបំផុត ។

អ្វីៗទាំងអស់ដែលនាងបានប្រព្រឹត្ត សុទ្ធតែប្រឆាំងបដិវត្តន៍ ។ ឌុច មេគុកទួលស្លែង និងជាប្រធានសន្តិសុខយល់ឃើញថា បទឧក្រិដ្ឋផ្នែកនយោបាយរបស់នាង ពិតជាមានយ៉ាងជាក់ស្ដែង ព្រោះនាងធ្លាប់ធ្វើការឲ្យអង្គការមនុស្សធម៌មួយ ដែលផ្ដល់លុយកាក់ និងដឹកនាំដោយបណ្ឌិតភរិយាអ្នកការទូតអាមេរិកាំង និងអឺរ៉ុប ដែលជារបាំងតូចមួយសម្រាប់ការធ្វើប្រតិបត្តិការរបស់សេ.អ៊ី.អា. ។ ដោយ បុប្ផាណា មានឋានៈខ្ពស់ក្នុងអង្គការមនុស្សធម៌នេះ នាងប្រហែលជាមានមុខងារជាប្រធានខ្សែបណ្ដាញដ៏សំខាន់មួយរបស់សេ.អ៊ី.អា.ហើយមើលទៅ ។ ឌុច បានផ្ដល់មតិណែនាំឲ្យកូនចៅរបស់ខ្លួន ដឹកនាំការសួរចម្លើយធ្វើយ៉ាងណាឲ្យទាល់តែលេចចេញរឿងពិតជាក់ស្ដែងនេះ ។ ជាអ្នករៀនចេះដឹងម្នាក់ បុប្ផាណា បានសរសេរសំបុត្រស្នេហាជាច្រើនដែលគេហាមឃាត់ទៅឲ្យមនុស្សម្នាក់ ដែលពុំអាចក្លាយទៅជាប្ដីរបស់នាងបាន- ឌុច ក៏ជឿជាក់ពីរឿងនេះដែរ ។ នាងបានប្រើរូបសម្រស់ស្អុយកខ្វក់របស់នាង ដើម្បីទាក់ទាញចិត្ត ដែត និងបំផ្លាញបដិវត្តតាមរយៈ ដែត ។ រឿងនេះអាចបញ្ជាក់ឲ្យឃើញភ័ស្តុតាងដោយងាយ តាមរយៈសំបុត្រជាច្រើន ដែលក្នុងនោះ នាងបានត្អូញត្អែរជៀលការបដិវត្ត បានប្រកាសពីការស៊ូស្លាប់របស់នាងចំពោះ ដែត ជាជាងស្លាប់ដើម្បីអង្គការ ហើយបានសច្ចាប្រណិធានធ្វើការសងសឹកថែមទៀត ។ ឌុច

កម្របានទទួលភ័ស្តុតាងជាក់ស្តែងរបៀបដូចនេះណាស់ ។

ប៉ុន្តែ ទោះជាមានរឿងហេតុយ៉ាងណាក៏ដោយ ក៏បុប្ផាណា មិនព្រមបណ្តោយឲ្យគេកាច់បំបាក់នាងដែរ ។ នាងបានចុះហត្ថលេខាលើចម្លើយសារភាពទាំងអស់របស់នាងដោយដាក់ឈ្មោះថា សីតា ដែត ដើម្បីបង្ហាញឲ្យឃើញពីទឹកចិត្តភក្តីចំពោះអ្នកដែលនាងបានស្មោះស្ម័គ្រមេត្រី ។ ការធ្វើទារុណកម្មលើរូបនាង មានថិរវេលាជាច្រើនខែ ។ បន្ទាប់ពីការឆ្លើយឲ្យការណ៍របស់នាង គេបានស្នើឲ្យនាងសរសេរហើយសរសេរទៀត នូវជីវប្រវត្តិរបស់នាង រហូតទាល់តែនាងព្រមទទួលសារភាពពីអំពើឧក្រិដ្ឋផ្សេងៗ ដែលអាចយកធ្វើជាភ័ស្តុតាង សម្រាប់សម្លាប់រូបនាងចោល ។ នាងត្រូវសរសេរចម្លើយសារភាពដោយខ្លួនឯង ត្រូវកែប្រែខ្លឹមសារខ្លះ បើសិនជា ឌុច មិនទាន់វិនិច្ឆ័យថា ចម្លើយសារភាពទាំងនេះល្មមជាទីពេញចិត្តរបស់គាត់ ។ ប្រព័ន្ធគ្រប់គ្រងរបៀបនេះ បានទទួលដំណែលមួយភាគធំពីបណ្តាប្រទេសកុម្មុយនិស្តផ្សេងៗទៀត ជាពិសេស ប្រទេសវៀតណាម ។ ប៉ូលិសសម្ងាត់របស់ក្រុងហាណូយ បានចាប់ខ្លួនពួកអ្នកដែលត្រូវគេសង្ស័យ ដោយគ្មានការចោទប្រកាន់ពីបទអ្វីមួយជារឿយៗ ហើយយកអ្នកទាំងនោះ ទៅដាក់គុកបង្ខំឲ្យសរសេរជីវប្រវត្តិ បន្ទាប់មក បង្ខំឲ្យសារភាពពី "បទឧក្រិដ្ឋ"របស់គេប្រឆាំងនឹងរដ្ឋទៀត ។ គេធ្វើឲ្យមនុស្សទទួលរងនូវការសាកសួរចម្លើយមិនចេះចប់ គេបញ្ចុះបញ្ចូលឲ្យអ្នកទាំងនោះរួមបញ្ចូលទាំងមិត្តភក្តិ និងឪពុកម្តាយរបស់ពួកគេថែមទៀត ។ ប៉ុន្តែ នៅវៀតណាម -ដូចនៅប្រទេសចិន និងអតីតសហភាពសូវៀត- ការធ្វើទារុណកម្ម ដែលចូលចិត្តធ្វើឲ្យអ្នកទោស ឈឺចាប់ ពុំមែនជាចំណែកមួយក្នុងការសួរចម្លើយឡើយ ហើយការឃុំឃាំងមនុស្សពុំមែននាំទៅរកការប្រហារជីវិតដោយស្វ័យប្រវត្តិដែរ ។

បុប្ផាណា ដែលក្លាយទៅជា សីតា ដែត ត្រូវតែថ្កោលទោសប្តីរបស់នាង និងមនុស្សជាង១០នាក់ផ្សេងទៀត បូកនឹងរូបនាងម្នាក់ផង ។ នាងតោងតែសារភាពថា នាងធ្លាប់ធ្វើការជា ភ្នាក់ងារម្នាក់របស់សេ.អ៊ី.អា. ដែលដឹកនាំខ្សែបណ្តាញចារកិច្ចមួយក្រុម តាមរយៈប្តីរបស់នាង ហើយថាខ្សែបណ្តាញនេះ មានភារៈទទួលខុសត្រូវធ្វើឲ្យស្ទាក់ដំណើរក្នុងការដឹកជញ្ជូនសន្ទូងស្រូវក្នុងរដូវដកស្ទូងនៅដើមឆ្នាំ១៩៧៦ ។ វាជារឿងចម្លែកដូចគ្នាដែលថាការរួមគំនិតក្បត់មួយបែបនេះអាចលេចឡើងឲ្យឃើញ អ្នករងគ្រោះទាំងអស់ ប្រហែលជាទទួលស្គាល់ថាខ្លួនជាអ្នកទទួលខុសត្រូវបញ្ហាផ្សេងៗ ដែលមានពិតប្រាកដរបស់របបនេះ ។ តមកទៀត ឌុច អាចនាំយក"សេចក្តីសារភាព"ទាំងនេះ ទៅគណៈលេខាមជ្ឈិមបក្ស ហើយបង្ហាញភ័ស្តុតាងថា ពួកសមាសភាពសម្រាប់ធ្វើវិទ្ធង្សនាបានធ្វើឲ្យស្ទាក់ដំណើរក្នុងការដឹកជញ្ជូនសន្ទូងស្រូវដោយចេតនាមែន ។ ដូច្នេះ បរាជ័យពុំមែនធ្លាក់ទៅលើបក្ស ឬផែនការរបស់ខ្លួនទេ គឺត្រូវតែធ្លាក់ទៅលើក្រុមជនប្រឆាំងបដិវត្តន៍ និងពួកសត្រូវបរទេសឯណោះសោះ ។ ឧទាហរណ៍ដូចជា វាមានសារសំខាន់តិចតួចណាស់ដែលថា បុប្ផាណា ដឹងពីការប្រព្រឹត្តទៅនៃការដឹកជញ្ជូនរបស់កម្ពុជាប្រជាធិបតេយ្យ ទាំងកាលបរិច្ឆេទដែលគេត្រូវការដឹកជញ្ជូនសន្ទូងឲ្យទាន់ពេលវេលា សម្រាប់រដូវដាំដុះដំបូងផង ។ ការអានសំណុំលិខិតផ្សេងៗរបស់មន្ទីរឃុំឃាំងទួលស្លែង បណ្តាលឲ្យគេមានគំនិតថា កាលណាអំពើ

ឧក្រិដ្ឋមាន លក្ខណៈផ្ទុយនឹងវិចារណញ្ញាណកាន់តែខ្លាំង ហាក់ដូចជាកាន់តែជាក់ស្ដែងចំពោះគណៈលេខាមជ្ឈិមបក្សកាលនោះដែរ ។

ឌុច បានផ្ញើកំណត់ខ្លីមួយទៅឲ្យអ្នកទទួលបន្ទុកសួរចម្លើយ បុប្ផាណា ថា “វាសំខាន់ណាស់ ដែលត្រូវធ្វើឲ្យនាងទទួលស្គាល់ថា ប្ដីរបស់នាងពិតជាកម្លាំងមួយរបស់សេ.អ៊ី.អា.មែន” ។ នាងបានយល់ព្រមសរសេរជីវប្រវត្តិរបស់ ដែត ប៉ុន្តែ មិនប្រកាសថា គាត់ជាភ្នាក់ងារម្នាក់របស់អាមេរិកាំងទេ ។ ឌុច បានចារនៅគែមខាងលើកំណត់ហេតុសួរចម្លើយថា “ហេតុអ្វីបានជានាងមិនព្រមឆ្លើយថា ប្ដីរបស់នាងជាភ្នាក់ងារសេ.អ៊ី.អា.?” ខាងក្រោមបន្តិច ឌុច បានឆ្លើយនឹងសំណួរខ្លួនឯងនេះ ដោយការកត់ត្រាមួយផ្សេងទៀតថា “សូមកុំភ្លេច (ការភ្លេចនិយាយពីការចូលរួមរបស់ ដែត ជាមួយសេ.អ៊ី.អា.) ទាំងអស់នេះ សុទ្ធតែជាល្បិចកលដោះសាររបស់ស្រីនេះ ដើម្បីបង្វែងដានយើងប៉ុណ្ណោះ” ។

ច្រើនខែបានកន្លងផុតទៅ ។ ជីវប្រវត្តិដំបូងរបស់ បុប្ផាណា ដែលនាងសរសេរនៅខែតុលា បង្ហាញឲ្យឃើញនូវភាពដូចគ្នាតិចតួចណាស់ជាមួយនឹងចម្លើយសារភាពដែលគេទទួលបានទាំងលំបាក ដោយការធ្វើទារុណកម្មទៅលើរូបនាងនៅខែមករា ។ សញ្ញាតែមួយគត់ដែលមិនផ្លាស់ប្ដូរ គឺហត្ថលេខារបស់នាង - សីតា ដែត ។ ពីពេលនេះតទៅ នាងមានរូបកាយនិងចិត្តប្រេះស្រាំអស់ទៅហើយ ព្រោះតែនាងបានសារភាពពីអំពើក្បត់មួយដែលស្ថិតនៅតែក្នុងការស្រមៃតាមសេចក្ដីត្រូវការរបស់ ឌុច ។ នាងបានប្រកាសថា នាងត្រូវបានជ្រើសរើសឲ្យចូលធ្វើការ ដោយភរិយាលោកឯកអគ្គរដ្ឋទូតអាមេរិកាំង ចុងក្រោយបង្អស់ គឺលោក ហ្សន ហ្គុនធឺ ឌៀន ។ ក្នុងចំណោមបេសកកម្មសម្ងាត់ផ្សេងៗ នាងត្រូវបានចាត់តាំងឲ្យចែកចាយស្បៀងអាហារដល់ពួកអ្នកភៀសខ្លួន ក្នុងរយៈពេលសង្គ្រាម ដើម្បីធ្វើឲ្យអ្នកទាំងនោះស្រឡាញ់ចូលចិត្តចក្រពត្តិអាមេរិកាំងជាងសូវៀត ។ នៅឆ្នាំ១៩៧៥ គេបានបញ្ជាឲ្យនាងបំផ្លាញសន្ទូងស្រូវ និងសម្ភារដឹកជញ្ជូន នៅពេលណាដែលបដិវត្តមានជ័យជម្នះ ។ “ខ្សែបណ្ដាញសេ.អ៊ី.អា.” របស់នាងមានសញ្ញាសម្គាល់ជារូបគំនូរ បេះដូងមួយ ។ នៅស្ថានទូតអាមេរិកាំង នាងត្រូវបានគេទទួលឲ្យចូលអង្គការសេ.អ៊ី.អា. ក្នុងពិធីមួយដែលនាងបានសច្ចាប្រណិធានគោរពវិន័យ និងបទបញ្ញត្តិផ្សេងៗរបស់ក្រុមនេះ និងស្បថស្បែថា នឹងអារបំពង់ក បើសិនជានាងក្បត់ ។ ការនិយាយផ្ដេសផ្ដាសទាំងនេះ វាត្រូវនឹងការអនុវត្តរបស់បក្សកុម្មុយនិស្តកម្ពុជាច្រើនជាងការនឹកឃើញរបស់ សីតា ដែត ទៅទៀត ។

គេប្រាប់ឲ្យនាងសរសេរថា នាងមិនបានស្រលាញ់ ដែត ទេ នាងគ្រាន់តែធ្វើជាស្រលាញ់ក្នុងបំណងក្លាយជាប្រពន្ធកម្មាភិបាលម្នាក់ និងបានមករស់នៅក្នុងក្រុងភ្នំពេញជាមួយគ្នាប៉ុណ្ណោះ ដែលនៅទីនោះ នាងអាចរៀបចំផែនការបំផ្លាញការដឹកជញ្ជូនសន្ទូងស្រូវបានងាយស្រួលបំផុត ។ គេបានធ្វើទារុណកម្មនាង ដើម្បីឲ្យនាងប្រកាសថា នាងមិនដែលបានរៀបការជាមួយ ដែត ទេ នេះគឺជាការភូតកុហកមួយដែរ ។ ឌុច បានកត់ត្រាលើសំណុំលិខិតថា សេចក្ដីប្រកាសនេះបង្ហាញឲ្យឃើញថា បុប្ផាណា គ្រាន់តែជាស្រីសំផឹងម្នាក់ប៉ុណ្ណោះ ហើយដាក់ឈ្មោះឲ្យនាងជា

ភាសាខ្មែរធម្មតា ដែលមានន័យស្រដៀងគ្នាថា «សត្រូវក៏ជាមិត្ត ឬ ខ្មាំងជាអ្នកដែលមិនរអើម» ។ គេពិបាកនឹងនិយាយថា តើ បុប្ផាណា ត្រូវគេធ្វើទារុណកម្មដោយរបៀបណានោះណាស់ ។ អ្នកជាប់គុកទាំងអស់ ទាំងបុរស ស្ត្រី និងកូនក្មេង ត្រូវគេវាយនឹងរំពាត់ ឆក់ខ្សែភ្លើង និងចាប់ក្បាលជ្រមុជទៅក្នុងទឹក ប៉ុន្តែ តាមគេនិយាយក៏មានការធ្វើទារុណកម្ម ពិសេស ដោយឡែកសម្រាប់ពួកស្រីៗដែរ ៖ ចៀរកាត់ដោះ យោនី ត្រូវគេដុតរោលដោយភ្លើងចន្លុះ យកពស់ មានពិសឲ្យវារលើខ្លួនប្រាណ[១៤] ។ បើសិនជាស្រីៗទាំងនោះជាម្តាយ គេបានបង្ខំឲ្យនៅឈរមើលកូនៗខ្លួនឯង ដែលត្រូវគេវាយធ្វើបាបអស់រយៈពេលយ៉ាងយូរ ។

ដោយ ឌុច នៅដំអែដំអក់ចាំឲ្យ បុប្ផាណា រៀបរាប់ពីអាពាហ៍ពិពាហ៍ខុសសីលធម៌នោះ នាងប្រហែលត្រូវគេ ដាក់ឲ្យស្ថិតនៅក្រោមការធ្វើទារុណកម្មតាមរបៀបនេះហើយ ។ ដោយបេជ្ញាធ្វើឲ្យភាពរុងរឿងរបស់ប្រទេស ជាតិកើតមានភ្លាមៗ ពួកខ្មែរក្រហមបានប្រកាន់យកអាកប្បកិរិយាមួយ ដូចមនុស្សកើតរោគខួរក្បាល ដែលលែង ស្រឡាញ់ ឬជាប់ចិត្តនឹងអ្វីៗទាំងអស់ចំពោះផ្លូវភេទ និងការបង្កើតកូន ។ ម្យ៉ាង ពួកគេគិតថា គេត្រូវតែរឹតត្បិត ការទាក់ទងគ្នាខាងផ្លូវភេទនេះ ពីព្រោះវាធ្វើឲ្យខាតពេលវេលាច្រើនណាស់ និងនាំឲ្យមនុស្សបោះបង់ពីភារកិច្ច ការងារដែលត្រូវបំពេញទៀតផង –ការធ្វើឲ្យប្រទេសមានលក្ខណៈឧស្សាហកម្មឆាប់រហ័ស ការលើកតម្កើងជាតិ មាតុភូមិ ។ ម្យ៉ាងទៀត ពួកគេយល់ឃើញថា គេត្រូវការចំនួនប្រជាជនកម្ពុជាច្រើនថែមទៀត ដើម្បីបម្រើឲ្យការ អនុវត្តកម្មវិធីនេះ ។ ដំណោះស្រាយចំពោះបញ្ហានេះ ពុំមែនរឿងភេទ ឬរឿងស្នេហាទេ ប៉ុន្តែ គឺសិទ្ធិទៅសួរ សុខទុក្ខគ្រួសារដោយទៀងទាត់ ដែលគេអនុញ្ញាតឲ្យប្តីទៅជួបប្រពន្ធនិងប្រពន្ធទៅជួបប្តី ។

តាមពិត ពួកខ្មែរក្រហមបានក្លាយទៅជាអ្នកបង្ក្រាបវិស័យភេទនេះ ខ្លាំងណាស់ដែលការសប្បាយនឹងធ្វើឲ្យ អ្នកដទៃឈឺចាប់ខ្លះៗ បានប៉ះពាល់ដល់ជីវភាពរស់នៅមួយភាគធំក្នុងសហករណ៍ផង ។ អាយុត្រូវរៀបការ ត្រូវ បានលើកដល់ម្ភៃពីរឆ្នាំសម្រាប់បុរស និងម្ភៃឆ្នាំសម្រាប់នារី –ជាបញ្ញត្តិដែលមានប្រើប្រាស់ដំបូងតែក្នុងជួរ កងទ័ពប៉ុណ្ណោះ ។ ក្នុងសហករណ៍ និងភូមិភាគជាច្រើន ទំនាក់ទំនងខាងផ្លូវស្នេហាមុនពេលរៀបអាពាហ៍ពិពាហ៍ អាចទទួលរងនូវការផ្តន្ទាទោសសដល់ប្រហារជីវិត ។ ពួកយុវជនត្រូវរស់នៅដោយឡែកពីពួកយុវនារី ។ គេសង្ឃឹម លើពួកនេះថា នឹងខិតខំធ្វើការ រៀនហាត់ពត់លត់ដំ ដើម្បីបញ្ចេញឲ្យឃើញការធ្វើពលិកម្មទាំងស្រុងមួយចំពោះ «អង្គការ» និងបំភ្លេចចោលភេទមួយទៀត ។ ដូចដែលបានប្រមាណទុកជាមុន អត្រាកំណើតទារកបានធ្លាក់ចុះ យ៉ាងសម្បើម ។ ស្ត្រីភាគច្រើនលែងមានរដូវ មួយផ្នែកគឺបណ្តាលមកពីការបរិភោគអាហារមិនគ្រប់គ្រាន់ មួយ ផ្នែកទៀត គឺបណ្តាលមកពីដំណើរប៉ះទង្គិចខាងផ្លូវចិត្ត[១៥] ។

ជាទូទៅ ពួកខ្មែរក្រហមដឹងខ្លួនថាត្រូវធ្វើឲ្យបារម្ភដោយលក្ខណៈគ្រប់បែបយ៉ាងនៃសេចក្តីស្រឡាញ់ ឬការ ជំពាក់ចិត្ត ៖ រវាងប្តីនិងប្រពន្ធ ឪពុកនិងកូន មិត្តភក្តិនិងសហសេវិក (អ្នកមានមុខការដូចគ្នា) ។ មនុស្សទាំងអស់ គោងតែជម្រុះជីវិតឯកជនរបស់ខ្លួនចោល ដូចដែលលោកស្រី ហាន់ណាស់ អារេនត៍ បាននិយាយទុកជាមុនដែរ ។

ដោយបានសរសេរឆ្លើយឆ្លងគ្នាតាមសំបុត្រ ដែត និងបុប្ផាណាមិនអាចរស់នៅតែម្ដងឯង, ដាច់ពីគេ និងគ្មានអ្វីទាំងអស់ដូច្នេះទេ ។ រឿងនេះប្រហែលជាបទឧក្រិដ្ឋមួយយ៉ាងធំរបស់នាងនៅមុខក្រសែភ្នែករបស់ ឌុច ហើយ ។

រយៈពេលនៃការស្ថិតនៅមន្ទីរឃុំឃាំងទួលស្លែងរបស់ បុប្ផាណា មានសភាពយូរខុសពីធម្មតា ។ នាងបានបញ្ចប់ជីវប្រវត្តិរបស់នាង ខែមករា ដោយកត់សម្គាល់នេះថា ៖ «ក្រោយពីការទទួលសារភាពនូវអំពើក្បត់ទាំងនេះរួចហើយ តើជីវិតរបស់នាងអាចនៅមានសារសំខាន់អ្វីទៀតទេ?» ហើយនាងនៅតែចុះហត្ថលេខា ឈ្មោះ សីតា ដែត ដូចមុនៗជានិច្ច ។ គេទុកឲ្យនាងនៅរងការឈឺចាប់ចំនួនពីរខែទៀត ។

គេបានស្នើឲ្យ បុប្ផាណា បំពេញបន្ថែមក្នុងចម្លើយសារភាពនូវបណ្ដាឈ្មោះមិត្តភក្តិ សហសេវិក និងបងប្អូនរបស់នាង ដែលជាសមាជិក «ខ្សែបណ្ដាញសេ.អ៊ី.អា.» របស់នាង ។ នេះជាលក្ខណៈគួរឲ្យព្រឺខ្លាចដោយឡែកមួយនៃការធ្វើទារុណកម្ម ៖ ជនរងគ្រោះទាំងអស់ត្រូវបានបង្ខិតបង្ខំឲ្យរាយការណ៍ពីបងប្អូនរបស់ពួកគេ ហើយជាញឹកញាប់ច្រើនតែត្រូវស្លាប់ដោយដឹងក្នុងចិត្តថា «ចម្លើយសារភាព»របស់ពួកគេ ដែលទទួលបានក្រោមការធ្វើទារុណកម្មបាននឹងនាំឲ្យមានការចាប់ចង និងសេចក្ដីស្លាប់សម្រាប់ជនទាំងឡាយ ដែលខ្លួនធ្លាប់ស្រឡាញ់រាប់អានទៀតផង ។ មិត្តភាពជាលក្ខណៈដែលនាំឲ្យមានគ្រោះថ្នាក់ ៖ ក្នុងកំឡុងឆ្នាំដំបូងៗរបស់របបនេះ ការប្ដឹងបរិហាររបស់ពួកអ្នកទោសបីនាក់ ល្មមគ្រប់គ្រាន់ឲ្យគេចាប់ជនដែលត្រូវសង្ស័យម្នាក់បាន[១៦] ហើយមានមនុស្សតិចតួចណាស់ ដែលបានរួចខ្លួនចេញមកវិញ ក្នុងចំណោមអ្នកដែលគេនាំយកទៅដាក់គុកនៅទួលស្លែងនោះ ។

បុប្ផាណា ដ៏កម្សត់ដែលមានសម្រស់ស៊ិតស្រពោន បានឆ្លងកាត់មួយភាគធំក្នុងជីវិតម្ភៃប្រាំឆ្នាំរបស់នាងក្នុងបន្ទប់ឥដ្ឋតូចមួយ រង់ចាំតែសេចក្ដីស្លាប់មកនាំយកនាងទៅប៉ុណ្ណោះ ។ សំឡេងស្រែករបស់ជនរងគ្រោះឯទៀតៗ ប្រហែលជាធ្វើឲ្យនាងឈឺចាប់ដូចមុខរបួសរបស់នាងផ្ទាល់ដែរ ។ ក្នុងរយៈពេលប្រាំខែ ដែលនាងជាប់គុកនៅទួលស្លែង យ៉ាងហោចណាស់មានមនុស្ស ២៦១នាក់ត្រូវបានយកទៅសម្លាប់ ហើយមានអ្នកដទៃទៀតច្រើនរាប់ពុំអស់ ត្រូវគេធ្វើទារុណកម្មនៅក្នុងអតីតសាលានេះ ។ សរុបទៅ គេបានបង្ខំឲ្យនាងសរសេរ ឬនិយាយឲ្យគេសរសេរតាមនូវចម្លើយសារភាពជីវប្រវត្តិ និងសេចក្ដីប្រកាសផ្សេងៗ ច្រើនជាងអ្នករងគ្រោះឯទៀតៗ ដែលគេបានរកឃើញសំណៅនៅក្នុងឯកសារផ្សេងៗដែលមាននៅមន្ទីរឃុំឃាំងទួលស្លែង ។ បណ្ដាមេដឹកនាំជាន់ខ្ពស់ដែលត្រូវបញ្ជូនទៅដាក់នៅទីនោះ នៅពេលក្រោយមក ក៏ត្រូវគេបង្ខំឲ្យសរសេរចម្លើយសារភាពច្រើន ដូចជានាងដែរ ។ បុប្ផាណា ប្រហែលជាដឹងខ្លួនថា វាសនារបស់នាងមានលក្ខណៈដាច់ឡែកពីគេ ហើយទុក្ខលំបាកវេទនាខាងផ្លូវចិត្តយ៉ាងយូររបស់នាង ក៏មានលក្ខណៈខ្លាំងហួសប្រមាណជាងគេដែរ ។

នាងប្រហែលជាឆ្ងល់សួរខ្លួនឯងថា ហេតុអ្វីបានជាវាសនារបស់នាង កម្មផលរបស់នាង បម្រុងទុកការឈឺចាប់ សម្រាប់នាងច្រើនយ៉ាងដូច្នេះ? ប៉ុន្តែ ក្នុងរយៈពេលនៃការបដិវត្តន៍របស់ខ្មែរក្រហមវាជារឿងដែលគេមិនអាចជៀសផុតឡើយ ។ បុប្ផាណា ត្រូវនាំយកទៅដោយរលកដំបូង ដែលបក្សដឹកនាំសំដៅប្រឆាំងនឹងរបបសង្គម

ចាស់ ពួកមេដឹកនាំ និងបណ្ដាឥស្សរជនគួរឲ្យគោរពរបស់រដ្ឋាភិបាលដែលចាញ់សង្គ្រាម ។ នាងប្រហែលជាត្រូវចាប់ខ្លួន ព្រោះតែរឿងដែលកើតមានដោយមិនដឹងខ្លួនជាហូរហែរមួយ ប៉ុន្តែ វាទំនងជាមានតិចតួចណាស់ដែលថា នារីផ្សេងទៀតបានពុះពារតស៊ូជាមួយនឹងភាពស៊ិតស្វាញមួយបែបនោះ ដើម្បីរស់នៅជាមួយប្ដីរបស់ខ្លួន អាចនៅរស់រានមានជីវិតក្រោមរបបខ្មែរក្រហមណាស់ ។

ពួកឆ្មាំគុកនៅទួលស្លែង បានទុកចោលខ្មោចនៅក្នុងបន្ទប់ជាច្រើន ដាក់ច្រវាក់ភ្ជាប់នឹងគ្រែដែកមួយ រហូតដល់ថ្ងៃខែដែលគេបានគ្រោងទុកជាមុន ទើបយកទៅកប់ ។ ពេលនោះ មនុស្សមួយក្រុមរបស់ពន្ធនាគារ បានយកខ្មោចទាំងនោះចេញផុតពីទីក្រុង ។ ឌុច ច្រើនតែជ្រើសរើសថ្ងៃខែដែលមានភាពជានិមិត្តរូប ដើម្បីធ្វើការកប់ខ្មោចទាំងនេះ ដូចថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៧ ជាដើម ជាខួបលើកទី៧នៃការធ្វើរដ្ឋប្រហាររបស់ លន់ នល់ ប្រឆាំងនឹងសម្ដេច ព្រះនរោត្តម សីហនុ ។ នៅថ្ងៃនេះ មានមនុស្សប្រមាណជាងដប់នាក់ត្រូវបានប្រកាសជាផ្លូវការថា ស្លាប់ដើម្បីនឹងឲ្យ ឌុច អាចបំពេញរណ្ដៅមួយ ជារបៀបប្រារព្ធពិធីបុណ្យខួបនោះ ។ វាលំបាកនឹងជឿថា បុប្ផាណា នៅរស់ជីវិតនៅឡើយ នៅថ្ងៃដែល ឌុច ចារថា យុវនារីម្នាក់ដែលគេស្គាល់ក្រោមឈ្មោះថា សីតា ដែត ទើបនឹងត្រូវកម្ទេចជាផ្លូវការ ។

## ដំណើររបស់បងប្អូនប្រុសស្រី នៃគ្រួសារត្រកូល ម៉ៃ
## ការបំផ្លាញជីវភាពគ្រួសារ

ប្រជាជនកម្ពុជាយ៉ាងច្រើន ប្រហែលអាចទ្រាំទ្រនឹងការគំរាមកំហែងមកលើអាយុជីវិតរបស់ខ្លួន ប្រហែលមិនសូវលំបាកដូចជាការវាយប្រហាររបស់ការបដិវត្តន៍មកលើឪពុកម្ដាយរបស់ខ្លួនឡើយ ។ តាមលក្ខណៈវិនិច្ឆ័យរបស់ជនជាតិអាស៊ី ជនជាតិខ្មែរជាមនុស្សដែលជាប់ជំពាក់ចិត្តនឹងគ្រួសារខ្លាំងជាទីបំផុត ។ ប្រាកដណាស់ ការជំពាក់ចិត្តនេះ ជាធាតុផ្សំបង្កជាការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរចំពោះ "អង្គការ" ហើយមតិណែនាំស្ទើរតែទាំងអស់របស់ពួកកុម្មុយនិស្ត បានតម្រង់ទៅរកការរំលាយគ្រួសារចោល តាមមធ្យោបាយគ្រប់បែបយ៉ាង ។ ជំងឺ ការបរិភោគអាហារមិនគ្រប់គ្រាន់ ឬពួថៅរបស់ពេជ្ឈឃាត បានសម្លាប់យ៉ាងរង្គាលគ្រួសារទាំងឡាយ មុនបដិវត្តមិនទាន់បង្កើតកម្មវិធីដោយឡែកតាមប្រភេទ ដើម្បីបំផ្លាញទម្លាប់ជាប្រពៃណីរបស់គ្រួសារកម្ពុជាទៅទៀត ។

វិធានការមួយក្នុងចំណោមវិធានការដំបូងៗ ស្ថិតនៅត្រង់លុបបំបាត់ការប្រើប្រាស់ឈ្មោះរបស់គ្រួសារ ។ ពេញកំឡុងការបដិវត្តន៍ ប្រជាជនកម្ពុជាទាំងអស់បានប្រើប្រាស់ឈ្មោះតែមួយប៉ុណ្ណោះ ជាទូទៅ ច្រើនបំព្រួញបកតិនាមជាគោត្រនាម បណ្ដាសមាជិករបស់បក្ស ក៏ប្រឌិតឈ្មោះដោយខ្លួនឯងតែមួយម៉ាត់ដែរ ជាទូទៅច្រើនតែឯកព្យាង្គទៀត ដូចជា កម្មាភិបាល ហួត លីស៊ីថា ទៅជា ស.ម ដែត ជាដើម ។ ក៏ប៉ុន្តែ អតីតធនាគារិក ម៉ី

កុម្មុតគ្រាន់តែបំព្រួញបកតិនាម (ឈ្មោះកំណើត) របស់គាត់ឲ្យខ្លីដោយហៅត្រឹម ដូត ប៉ុណ្ណោះ ។

ការលុបបំបាត់គ្រួសារ ដែលជាកោសិកាសំខាន់របស់សង្គម បានបង្កឲ្យមានវិធានការសំខាន់មួយផ្សេងទៀត ។ ក្រៅពីការរៀបចំប្រជាជនជាបីប្រភេទស្របតាមច្បាប់រដ្ឋធម្មនុញ្ញ -កម្មករ កសិករ និងកងទ័ព- ពួកខ្មែរក្រហមបានរៀបចំឲ្យមានប្រភេទ សិប្បនិម្មិតផ្សេងៗទៀត ដោយបង្កើតជាប្រព័ន្ធវណ្ណៈថ្មីមួយ គ្មានស្របតាមទ្រឹស្តីសោះ ដែលលៃតាមគ្រួសារដោយនិយាយថាជាគ្រួសារមិនពិត ។ ប្រភេទទាំងនេះ ត្រូវកំណត់អត្តសញ្ញាណនិងឥរិយាបថច្បាស់លាស់ជាថ្មី ត្រូវជម្រុះចោលការជំពាក់ចិត្តនឹងគ្រួសារ ជំនួសដោយការស្មោះត្រង់ចំពោះបដិវត្តន៍វិញ ឬយ៉ាងហោច ពួកខ្មែរក្រហមនឹងសង្ឃឹមដូច្នេះ ។

ការបែងចែកដំបូងដែលគេដាក់ឲ្យអនុវត្តបានញែក "ពួកអ្នកចាស់" ដោយឡែកពី "ពួកអ្នកថ្មី" ។ "ពួកអ្នកចាស់" គឺពួកអ្នកដែលធ្លាប់រស់នៅតំបន់រំដោះរបស់ខ្មែរក្រហមក្នុងពេលមានសង្គ្រាម និងជាអ្នកដែលធ្លាប់រួមចំណែកជួយដល់ការបដិវត្តន៍ ។ គេហៅពួកនេះថា "ពួកមូលដ្ឋាន" យោលទៅតាមការរស់នៅរបស់អ្នកទាំងនេះក្នុងមូលដ្ឋាននានានៅសម័យសង្គ្រាម និងយោលទៅតាមវណ្ណៈដើមរបស់ពួកគេផង ៖ ភាពចូលរួមរបស់គេនឹងវណ្ណៈកម្មករ និងកសិករ គឺក្នុងនាមអ្នកទាំងនេះហើយដែលពួកកុម្មុយនិស្តរៀបចំធ្វើបដិវត្តនោះ ។ "ពួកអ្នកថ្មី" គឺអ្នកទាំងឡាយដែលធ្លាប់រស់នៅខាងប៉ែកម្ខាងទៀតក្នុងរយៈពេលសង្គ្រាម ហើយសម្រាប់ពួកនេះ យល់ថាបដិវត្តន៍ និងគំនិតរវើរវាយរបស់ខ្មែរក្រហមសុទ្ធតែជារបស់ថ្មីទាំងស្រុង ។ ជារឿយៗ គេច្រើនសម្គាល់អ្នកទាំងពីរនេះ ដោយសារខែថ្ងៃដែលគេបានដាក់ឲ្យ គឺ"ពួកអ្នកចាស់" គេហៅ"ពួក១៨មីនា"ជាថ្ងៃលន់លល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ ។ "ពួកអ្នកថ្មី" គេហៅ"ពួក១៧មេសា" ជាថ្ងៃដែលពួកខ្មែរក្រហមទទួលជ័យជម្នះ ។

លក្ខណៈកត់សម្គាល់នេះ ដែលមានប្រជាប្រិយនៅពេលដំបូងៗ ត្រូវបានបញ្ចូលទៅក្នុងភាសាគំរូរបស់បក្ស ។ ហើយ"ពួកអ្នកចាស់" បានសម្រេចចិត្តពុះពារមួយជំហានទៅមុខទៀត ។ ពួកគេដឹងខ្លួនថាត្រូវធ្វើឲ្យបារម្ភនិងទ្រាំទ្រមិនបានដោយដឹងច្បាស់ថា "ពួកអ្នកថ្មី"ចូលមកកុះករក្នុងតំបន់ទាំងឡាយរបស់ពួកគេ នៅទីបញ្ចប់នៃសង្គ្រាមមិនខាន ។ បក្សបានប្រគល់ភារកិច្ចឲ្យទទួលខុសត្រូវរឹតតែច្រើនជាងមុន ដែលពួកគេមិនចង់បានទាល់តែសោះ ព្រោះគ្មានផ្តល់ឲ្យគេនូវមធ្យោបាយចាំបាច់ ទាំងក៏មិនឲ្យរង្វាន់សម្រាប់ភារកិច្ចថ្មីៗរបស់ពួកគេផង ។ "ពួកអ្នកចាស់" សម្រេចចិត្តសម្តែងឲ្យឃើញនូវ "ចិត្តបុណ្យ" តែម្យ៉ាងប៉ុណ្ណោះ ដោយស្រុះស្រួលផ្តល់ឲ្យ"ពួកអ្នកថ្មី" នូវកន្លែងសមល្មមសម្រាប់ដេកពួន ម្ហូបអាហារបន្តិច ដើម្បីគ្រាន់នឹងឲ្យរស់សិន ។ ប្រធានសហករណ៍មួយនៅភូមិភាគនិរតីបាននិយាយថា "នៅពេលដែលពួកទាំងនោះទើបមកពីភ្នំពេញ គឺពួកគេគ្មានយកអ្វីមកជាប់នឹងខ្លួនទាំងអស់ ពួកគេគ្មានចេះធ្វើអ្វីទេ យើងតោងតែបង្រៀនពួកគេឲ្យចេះស្ទូង និងច្រូតស្រូវទៀត យើងជាអ្នកផ្គត់ផ្គង់ឲ្យពួកគេគ្រប់បែបយ៉ាង ។ នៅឆ្នាំដំបូង ពួកនេះគ្មានចេះធ្វើអ្វីឲ្យបានត្រឹមត្រូវសោះ[១៧]" ។

នៅឆ្នាំ១៩៧៥ មិនទាន់មានមតិណែនាំថ្មីៗដែលមានលក្ខណៈពិសេសតាមប្រភេទទេ ។ បក្សសង្ឃឹមលើ

«ពួកអ្នកចាស់» ដើម្បីជួយស្រោចស្រង់ស្ថានការណ៍ ហើយផលិតមានផលលើសមួយជាធម្មតានៅចុងឆ្នាំ ។ «ពួកអ្នកចាស់» បានឆ្លៀតទាញយកគុណប្រយោជន៍ពីរដ្ឋាភិបាលនេះតាមការយល់ព្រម ដើម្បីបង្កើតឋានានុក្រមថ្មីមួយនៅសហករណ៍ ដោយដាក់ឲ្យពួកគេធ្វើជាប្រធានដឹកនាំ ដោយការពារនូវឯកសិទ្ធិផ្សេងៗរបស់ពួកគេ (ព្រមទាំងទ្រព្យសម្បត្តិផង) ហើយចាត់ទុក«ពួកអ្នកថ្មី»នៅថ្នាក់ក្រោមបំផុត ។

ដោយបន្ថែមភារកិច្ចឲ្យសហករណ៍ចាត់ចែងបញ្ចូលមនុស្សចូលបក្ស ពួកអ្នកចាស់បានទទួលសិទ្ធិក្នុងការសម្រេច ពួកណាមួយដែលនឹងអាចក្លាយទៅជាសមាជិកសហករណ៍[១៨] ។ ដូចគ្នាដែរពួកគេបានបង្កើតប្រភេទផ្សេងៗដោយចម្លងតាមប្រភេទផ្សេងៗរបស់បក្ស ដើម្បីបែងចែកពួកអ្នកថ្មី ដែលទើបមកដល់ ។ នៅថ្នាក់ក្រោមបង្អស់ គឺមានប្រភេទមនុស្ស«បញ្ញើ» ។ ភាគច្រើននៃ «ពួកអ្នកថ្មី» បានទទួលកម្រិតនេះឯង ដែលមានន័យថា គេត្រូវតែសម្របខ្លួនទទួលយក ដោយខិតខំបញ្ចេញសមត្ថភាព និងខំប្រឹងប្រែងធ្វើការឲ្យពេញទំហឹងថែមទៀត ហើយហូបបន្តិចបន្តួច ។

បន្ទាប់មកទៀត គឺប្រភេទ «សមាជិកត្រៀម» ។ មាន«ពួកអ្នកថ្មី»តិចតួចណាស់ ដែលឈានឡើងភ្លាមៗដល់កម្រិតនេះ ដែលអនុញ្ញាតឲ្យគេមានសិទ្ធិចូលរួមក្នុងការចាត់ចែងកិច្ចការខ្លះ នៅក្បាលម៉ាស៊ីនដឹកនាំសហ-ករណ៍ និងទទួលបាននូវឧបករណ៍ប្រើប្រាស់ល្អៗ ព្រមទាំងម្ហូបអាហារកាន់តែច្រើនជាងមុន ។ គេព្រមសម្រួលដោយងាយបំផុត ចំពោះរឿងដែលកើតមានពីការមិនទុកចិត្ត បើសិនជាពួកគេធ្វើមិនបានសម្រេចក្នុងកិច្ចការរបស់ខ្លួន ពួកអតីតអ្នកធាក់ស៊ីក្លូ ប្រជាកសិករក្រីក្រគោកយ៉ាក ដែលភៀសខ្លួនទៅនៅភ្នំពេញកាលពីសម័យសង្គ្រាម និងពួកអ្នកក្រីក្រ នៅទីក្រុងនានា មានភ័ព្វសំណាងត្រូវបានគេអនុញ្ញាតឲ្យចូលក្នុងប្រភេទ «សមាជិកត្រៀម» នេះច្រើនជាងគេ ។

ប្រភេទខ្ពស់ជាងគេ គឺប្រភេទសមាជិកពេញសិទ្ធិ ដែល«ពួកអ្នកចាស់»រង់ចាំឱកាសយូរមកហើយ ពីព្រោះប្រភេទនេះផ្តល់ឲ្យគេមានសិទ្ធិបែងចែកស្បៀងអាហារ សម្ភារប្រើប្រាស់ ទីជម្រក សម្លៀកបំពាក់ និងឧបករណ៍ផ្សេងៗទៀត ។ មានតែពួកអ្នកពេញសិទ្ធិប៉ុណ្ណោះ ដែលជាអ្នកកំណត់នយោបាយរបស់សហករណ៍ បែងចែកភារកិច្ចឲ្យសមាជិកបំពេញ ផ្តល់ការណែនាំក្នុងការទទួលមនុស្សឲ្យចូលបក្ស ចូលកងទ័ព និងដើម្បីទទួលបានការងារផ្សេងៗ ដែលមានឯកសិទ្ធ ។ ពួកគេក៏ជាអ្នកចាត់តាំងកុមារាកុមារី ពួកអ្នកនៅលីវ ទាំងបុរស និងនារី ដើម្បីបញ្ជូនទៅធ្វើការក្នុងកងការងារដែរ ។ នៅទីបំផុតពួកគេជាអ្នកកាត់សេចក្តី ឬធ្វើជំនួសគេ ។ ពួកមេដឹកនាំសហករណ៍តែងស្តាប់សម្តីនិយាយរបស់ពួកគេ នៅពេលដែលគេរាយការណ៍ពីបុកពាប្រតិកិរិយាពីការភាពប៉ក់ល្មើយក្នុងការងារ និងទម្លាប់អាក្រក់ផ្សេងៗទៀត ដែលគេសម្គាល់ឃើញបែបនេះ ឬបែបនោះ ។ ពួកអ្នកពេញសិទ្ធិជាអ្នកចាំតាមដាន ជាចៅក្រម និងជាទីប្រឹក្សាតុលាការ ។ ពួកគេជាអ្នកទទួលខុសត្រូវខាងបញ្ហាសន្តិសុខថែមទៀត ហើយសេចក្តីរាយការណ៍ទាំងអំបាលម៉ានរបស់ពួកគេ ដែលឲ្យការណ៍ពីការប្រព្រឹត្តមិនស្មោះត្រង់របស់អ្នកណា

ម្នាក់ អាចនាំទៅរកការចាប់ខ្លួនដាក់គុក និងសេចក្ដីស្លាប់បាន ។

តាមពួកខ្មែរក្រហមថា បុប្ផាណា បានទាក់ទាញចិត្តពួកមេដឹកនាំសហករណ៍របស់នាងដោយផ្នែកៗ ពីព្រោះការឈានឡើងភ្លាមៗរបស់នាងទៅដល់កម្រិតជាប្រពន្ធកម្មាភិបាល និងជាកូនប្រសាស្រីនៃគ្រួសារ "ពួកអ្នកចាស់" មួយនោះ បានអនុញ្ញាតឲ្យនាងលោតផ្លោះពីលើប្រភេទ បែងចែកទាំងអស់ និងមានឯកសិទ្ធិផ្សេងៗជាសមាជិកពេញសិទ្ធិម្នាក់ទាំងស្រុង ដែលនាងមិនសក្តិសមនឹងទទួលបានដូច្នេះសោះ ។

មុនទៅដល់សហករណ៍មួយ មុនអាចស្នើសុំចូលជាសមាជិកសហករណ៍នោះ "ពួកអ្នកថ្មី" បានត្រូវសម្រិតសម្រាំងជ្រើសដោយកងទ័ព និងពួកសន្តិសុខខ្មែរក្រហមដែលដាក់ទីតាំងប្រចាំការនៅតាមផ្លូវរួចជាស្រេច ។ ពួកខ្មែរក្រហមទាំងនេះ បានធ្វើការសម្រាំងមួយដោយឈរលើមូលដ្ឋានលក្ខណៈវិនិច្ឆ័យផ្សេងៗទៀត ដែលកំណត់ដោយច្បាស់លាស់នៅខែមេសា ឆ្នាំ១៩៧៥ ។ ពួកគេបានស្រាវជ្រាវរកសត្រូវវណ្ណៈពិតប្រាកដរបស់ការបដិវត្តន៍ គឺ "សត្រូវយុទ្ធសាស្ត្រទាំងបី [១៩]" ដែលអាចបង្កការគំរាមកំហែងជាបន្តបន្ទាប់ ចំពោះការបដិវត្តន៍ខ្លាំងជាងគេ ៖ ពួកចក្រពត្តិ ពួកសក្តិភូមិ និងនាយទុនកុំប្រាដ័រ ។ ប្រភេទសត្រូវទាំងនេះ និងការប្រើប្រាស់ពាក្យ "យុទ្ធសាស្ត្រ" សុទ្ធតែទទួលដំណែលពីពួកកុម្មុយនិស្តចិន ប៉ុន្តែ ពួកកម្ពុជាបានកំណត់អត្ថន័យមួយទន់ភ្លន់ជាង និងមិនសូវច្បាស់លាស់ជាង "គ្រូដើម" ទៅទៀត ។

"ចក្រពត្តិនិយម" គឺអ្វីៗទាំងអស់ដែលគេចាត់ទុកថាជាតិដទៃ អាណិកជនវៀតណាម ជួនកាលចិន ចាមកាន់សាសនាអ៊ីស្លាម និងជាតិសាសន៍បរទេស ដ៏កម្រមានដទៃទៀត ដែលកុនខ្លួនក្នុងបដិវត្ត -ជាទូទៅ ច្រើនតែអ្នកមានឈាមជ័រជាតណ្ហា ។ ភាសាបរទេស ដូចជា បារាំង អង់គ្លេស វៀតណាម និងចិន ត្រូវហាមឃាត់ ។ សាសនាផ្សេងៗ សម្លៀកបំពាក់បរទេស គឺអ្វីៗទាំងអស់ដែលមានលក្ខណៈជាវប្បធម៌បរទេស រួមទាំងសៀវភៅជាភាសាអង់គ្លេស ឬបារាំង ក៏ត្រូវហាមមិនឲ្យមានដែរ ព្រោះគេវិនិច្ឆ័យថាជារបស់ "ពួកចក្រពត្តិ" ។

ពួក "សក្តិភូមិ" គឺពួកអ្នកដែលមានឥទ្ធិពល និអ្នកទាំងឡាយដែលកាន់អំណាចនៃរបបសង្គមចាស់ -របស់ដែលមិនអាចចាប់យកបាននេះហើយ ដែលពួកកុម្មុយនិស្តខំស្រាវជ្រាវទាំងអស់សង្ឃឹមនោះ ។ ព្រះសង្ឃ បញ្ញវន្តបុគ្គលិករដ្ឋការ ជាពិសេស ពួកអភិជនត្រូវគេចាត់ទុកថា សុទ្ធតែត្រូវចាត់ទុកជាពួកសក្តិភូមិ ។ គឺក្នុងនាមនៃការរំលំរបបសក្តិភូមិ ដែលពួកខ្មែរក្រហមបានវាយកម្ទេចគ្រឹះពីររបស់សង្គមកម្ពុជា គឺរាជាធិបតេយ្យ និងព្រះសង្ឃតំណាងសាសនាព្រះពុទ្ធ ។

"សត្រូវយុទ្ធសាស្ត្រ" ទីបី និងចុងក្រោយបង្អស់ ដែលគេត្រូវកម្ទេចចោលដែរនោះ គឺពួកនាយទុនកុំប្រាដ័រដែលមានទ្រព្យសម្បត្តិច្រើន និងកាន់កាប់លើភោគទ្រព្យទាំងអស់របស់ប្រទេស ។ ចំពោះប្រជាជនកម្ពុជាយល់ថាប្រភេទនេះមានសមាសភាពមួយភាគធំជាអាណិកជនចិន -វាមានមូលហេតុមួយក្នុងចំណោមមូលហេតុផ្សេងៗដែលពួកចិនទាំងនេះ ពុំត្រូវបានគេចាត់ទុកថា "ពួកចក្រពត្តិ" ជានិច្ចនោះ ។ សម្អប់យ៉ាងជ្រៅរបស់ជនជាតិខ្មែរ

ចំពោះពួកអ្នកកេងប្រវ័ញ្ចជាតិចិន បានកម្រើករំពើកឡើងក្នុងរយៈពេលក្រោយសង្គ្រាមនេះឯង ។ ជនជាតិចិនជាច្រើន បានត្រូវសម្លាប់យ៉ាងរង្គាលភ្លាមៗ អ្នកដទៃទៀត ដែលគេចរួចពីការចម្រាញ់លើកដំបូង នៅពេលចេញពីទីក្រុងភ្នំពេញ បានស្ថិតនៅក្រោមការគំរាមសម្លាប់ជាប់ជាប្រចាំដែរ ពីព្រោះពួកគេជាចំណែកមួយនៃពូជសាសន៍ភាគតិចមួយ ឬវណ្ណៈនាយទុនកុំប្រាដ័រ ។ មានតែការចងសម្ព័ន្ធភាពដ៏ជិតស្និទ្ធជាមួយក្រុងប៉េកាំងម្យ៉ាងប៉ុណ្ណោះ ដែលមិនធ្វើឲ្យពួកចិនវិនាសពីការកម្ទាត់ចោលទាំងស្រុងមួយ ដូចការកម្ទាត់ព្រះសង្ឃ ឬពួកចាមកាន់សាសនាអ៊ីស្លាម ។

បក្សបានបញ្ជាឲ្យកងទ័ព សន្តិសុខ និង«ពួកមូលដ្ឋាន» វាយកម្ទេច«សត្រូវយុទ្ធសាស្ត្រទាំងបី»ឲ្យរាបដល់ដី ។ ជាថ្នូរមកវិញ «ពួកមូលដ្ឋាន» ទំនងជាស្នើឲ្យបក្សយល់ព្រមពីប្រភេទសត្រូវទាំងបីនេះ ដើម្បីស្រួលកត់សម្គាល់សមាជិកទាំងឡាយនៅតាមសហករណ៍ ។

ក្នុងចិត្តពួកមេដឹកនាំយល់ឃើញថា ប្រភេទ និងវណ្ណៈទាំងនេះជំរុញទៅរកគោលដៅតែមួយ គឺរារាំងមនុស្សទាំងអស់មិនឲ្យកំណត់វណ្ណៈខ្លួនក្រៅពីវណ្ណៈកសិករឡើយ ។ តាមទស្សនៈពួកគេយល់ថា ប្រទេសកម្ពុជាត្រូវតែបំពេញភាពឃើតយ៉ាវរបស់ខ្លួនឲ្យលើសប្រជាជាតិដទៃទៀត ដោយផលិតកសិផលឲ្យបានច្រើនលើសលុប និងបង្កើនផលិតផលខស្បៀងអាហារម្ហូបអាហារម្ឆ្យកាន់តែច្រើនថែមទៀត ។ ដូច្នេះ គេត្រូវការតែពួកម្មករ និងកសិករប៉ុណ្ណោះ ហើយពាក្យស្លោកដែលពួកខ្មែរក្រហមត្រូវចិត្តជាងគេ គឺ«គ្មានការងារអ្វីប្រសើរថ្លៃថ្លាជាងការដាំស្រូវឡើយ» ។

ថ្វីត្បិតតែសារសំខាន់ដែលគេផ្ដល់ទៅលើគោលការណ៍ផ្សេងៗ និងការបែងចែកប្រភេទប្រជាជនទាំងនោះក៏ដោយ ក៏ឆ្នាំដំបូងនោះមានសភាពច្របូកច្របល់ពិតប្រាកដមែន ។ «ពួកអ្នកថ្មី» បានផ្ដើមធ្វើបដិវត្តន៍ដូចជាអ្នកដើរផ្សងព្រេងក្នុងវាលរហោឋាន ដែលផ្លូវត្រូវដើរនិងជោគវាសនារបស់គេ តែងប្រែប្រួលទៅតាមសតិអារម្មណ៍របស់ប្រជាជនតាមតំបន់ដែលពួកគេត្រូវចូលទៅរស់នៅដែរ ។ អ្នកខ្លះ រកបានទីកន្លែងមួយសម្រាប់ខ្លួនភ្លាមៗ អ្នកខ្លះទៀតត្រូវគេបញ្ជូនឲ្យទៅនៅព្រៃរបោះកណ្ដាលទ្រូងព្រៃ ។ នៅពេលដំបូង អ្នកខ្លះត្រូវបាត់បង់មិត្តភក្តិ និងឪពុកម្ដាយដែលស្លាប់ដោយគ្រាប់កាំភ្លើងរបស់ពួកពេជ្ឈឃាត ឬស្លាប់ក្នុងរយៈពេលនៃការជម្លៀសចេញពីផ្ទះសម្បែង ។ អ្នកខ្លះទៀត យកបានមកតាមខ្លួននូវអង្ករ និងមាសប្រាក់បន្តិចបន្តួចដែលធ្វើឲ្យគេរស់នៅបានដោយងាយស្រួលក្នុងបណ្ដាខែដំបូងៗ ។ អ្នកខ្លះត្រូវគេទទួលឲ្យស្នាក់នៅទាំងសោះអង្គើយ ត្រូវគេធ្វើទារុណកម្មចំពោះកំហុសទាំងឡាយ ដែលគេបានធ្វើខុសក្នុងការហាត់រៀនធ្វើស្រែចម្ការ អ្នកខ្លះទៀត ត្រូវបានទទួលស្វាគមន៍យ៉ាងប្រសើរ ពីព្រោះពួកគេចេះព្យាបាលអ្នកជំងឺ ឬចេះកាន់បញ្ជីកត់ត្រាផ្សេងៗ ។

ប៉ុន្តែនៅទីបំផុត ការរស់នៅរបស់មនុស្សទាំងអស់បាននាំទៅរកភាពតឹងតែងដូចៗគ្នា ។ ក្នុងគ្រាដំបូង គ្រួសារ គឺជា«គ្រឿងលួងចិត្ត» តែមួយគត់របស់ពួកអ្នកថ្មី ។ បក្សមិនដែលឃាត់ឃាំងពីការរស់នៅជួបជុំគ្រួសារឡើយ ហើយក្នុងរយៈពេលនៃឆ្នាំងដំបូង ក៏បដិវត្តន៍អនុញ្ញាតឲ្យមនុស្សដែលជាកោសិកាគ្រួសារ រស់នៅជុំគ្នា

បន្តមកទៀតដែរ ។ ប៉ុន្តែ នៅឆ្នាំបន្ទាប់ មតិណែនាំថ្មីបានដាក់ចេញដើម្បីបំបែកគ្រឹះគ្រួសារនេះចោល ដែលជាគ្រឹះមានអំណាចជាងគ្រឹះណាៗទាំងអស់ ។ បទបញ្ជាឲ្យហូបបាយរួមជំនួសការហូបបាយតាមគ្រួសារ បទបញ្ជាឲ្យបញ្ជូនក្មេងជំទង់ទៅរស់នៅកន្លែងដេករួមផ្សេងដោយឡែកពីពួកក្មេងស្រីៗ និងកំណត់ឲ្យគ្រួសារនីមួយៗមាននៅតែឪពុកម្ដាយ និងក្មេងៗដែលមានអាយុតិចជាងប្រាំមួយឆ្នាំប៉ុណ្ណោះ ។ ដោយមិនទុកឲ្យមានចំណងទាក់ទងក្នុងគ្រួសារតទៅទៀត គេក៏ឆ្លៀតទាញយកផលប្រយោជន៍បានពីរឿងនេះដែរ ។ គេញុះញង់ឲ្យក្មេងៗយកការណ៍ពីឪពុកម្ដាយឯង ។ នៅពេលដែលអ្នកណាម្នាក់ត្រូវកាត់ទោសប្រហារជីវិត គេច្រើនតែចាប់ និងសម្លាប់សមាជិកគ្រួសារនោះទាំងមូល ។

នេះជាប្រវត្តិគ្រួសារកម្ពុជាមួយ ដែលត្រូវនិរាសព្រាត់ប្រាស់ ក្នុងកំឡុងភាគរឿងមួយនៃបណ្ដាភាគច្រើនដ៏ក្រៀមក្រំខ្លោចផ្សាបំផុតរបស់ការបដិវត្តន៍ -ការជម្លៀសលើកទីពីរ និងការបោសសម្អាតរបស់ភូមិភាគពាយ័ព្យ- ហើយអ្នកដែលនៅមានជីវិតរស់តមកទៀត មានមិនសូវច្រើនមែន ប៉ុន្តែ ជាអ្នកប្រកបដោយការប្ដេជ្ញាចិត្តមួយខ្ពស់បំផុត ។

ពីខែកញ្ញាដល់ខែវិច្ឆិកា ឆ្នាំ១៩៧៥ មជ្ឈិមបានចេញបញ្ជាថា ប្រជាជនកម្ពុជារាប់ពាន់ម៉ឺននាក់ ដែលបណ្ដេញចេញពីក្រុងភ្នំពេញកាលពីពេលជម្លៀសនៅខែមេសា ត្រូវផ្លាស់ទីកន្លែងរស់នៅម្ដងទៀត លើកនេះគឺចេញពីភូមិភាគនិរតីទៅតំបន់ផ្សេងទៀត ជាពិសេសទៅភូមិភាគពាយ័ព្យ ។ តាម៉ុក លេខាបក្សភាគនរតីបានត្អូញត្អែរថា ភូមិភាគរបស់គាត់មានប្រជាជនច្រើនហួសចំណុះ ហើយគណៈមជ្ឈិមបក្សបានគិតបម្រុងផែនការដែលមានគោលបំណងច្រើននៅពេលតែមួយ សម្រាប់ភូមិភាគពាយ័ព្យដែរ ។

មជ្ឈិមប្រាថ្នាបង្កើតភាពរុងរឿងនៃរាជាណាចក្រអង្គរនៅក្នុងភូមិភាគនេះឡើងវិញ ។ រូបប្រាសាទអង្គរវត្ត ត្រូវបានតុបតែងលំអលើទង់ជាតិថ្មីរបស់ប្រទេស ហើយរាជាណាចក្រសម្បូរទឹកជាន់មុន បានក្លាយទៅជាគំរូមួយសម្រាប់សេដ្ឋកិច្ចថ្មីរបស់«បដិវត្តន៍»ដែរ ។ មជ្ឈិម បានបង្គាប់បញ្ជាឲ្យស្ដាបនាទំនប់ទឹកធំៗសម្រាប់ស្រោចស្រពផ្ទៃដីភូមិភាគ និងបង្កើនផលស្រូវមួយទ្វេជាពីរនៅភូមិភាគពាយ័ព្យនេះ ជាពិសេសតំបន់វាលទំនាបរបស់ខេត្តបាត់ដំបង ។ ប៉ុន្តែ មាន«ពួកអ្នកថ្មី»បន្តិចបន្តួចប៉ុណ្ណោះ ដែលត្រូវគេបញ្ជូនទៅតំបន់នេះ ដែលជាភូមិភាគមួយទន់ខ្សោយជាងគេក្នុងចំណោមភូមិភាគទន់ខ្សោយនានារបស់បក្សក្នុងរយៈពេលនៃសង្គ្រាម ។ តំបន់នេះមានហត្ថពលករតិចណាស់សម្រាប់ធ្វើស្រែចម្ការ ឬកាប់គាស់រានដីថ្មី ហើយមិនសូវមានគំនិតផ្ដើមកសាងទំនប់ទឹកធំៗថែមទៀត ។ ដូច្នេះការជម្លៀសប្រជាជននៅលើកទីពីរនេះ ប្រហែលជាផ្ដល់នូវការពេញចិត្តព្រមគ្នាចំពោះបណ្ដាមេដឹកនាំភូមិភាគនិរតីផង និងពាយ័ព្យផង ។

ការចាកចេញទាំងហ្វូងទាំងហ្វាយនៅលើកទីពីរនេះ មានសភាពរៀបចំមិនបានល្អដូចជាលើកទីមួយដែរ ។ មនុស្សរាប់រយនាក់បានស្លាប់នៅតាមផ្លូវ ។ ជាថ្មីម្ដងទៀត ពួកខ្មែរក្រហមបានលាក់មិនឲ្យប្រជាជនដឹងពីគោលដៅ

ពិតប្រាកដនៃការធ្វើដំណើរនេះឡើយ ។ ពួកកម្មាភិបាលខ្មែរក្រហមបាននិយាយប្រាប់«ពួកអ្នកថ្មី»ថា ពួកគេត្រូវត្រឡប់ទៅនៅរដ្ឋធានី ឬត្រូវបញ្ជូនទៅភាគខាងជើងដើម្បីជួយច្រូតស្រូវសហករណ៍សិន ហើយបន្ទាប់មក ពួកគេអាចនឹងវិលចូលក្រុងភ្នំពេញវិញ ។ ដូច្នេះ«ពួកអ្នកថ្មី» ក៏សុខចិត្តលះបង់ផ្លែផ្កានៃការងាររបស់គេចោលក្នុងភូមិភាគនិរតី ហើយស្ម័គ្រចិត្តចាកចេញទៅភាគខាងជើង ដែលជាកន្លែងខ្វះខាតស្បៀងអាហារ និងទីជម្រកតិចតួច ។

ក្នុងខេត្តតាកែវ ភាគខាងកើតភូមិភាគនិរតី ស្ត្រីជួយថែទាំអ្នកជំងឺម្នាក់ អាយុម្ភៃពីរឆ្នាំ ឈ្មោះ ម៉ៃ ស៊ីសូផា បានស្ម័គ្រចិត្តជាមួយប្តី និងកូនៗរបស់នាងធ្វើដំណើរទៅបាត់ដំបងដែរក្នុងក្របខ័ណ្ឌនៃការជម្លៀសលើកទីពីរនេះ ។ នាងជាសមជិកគ្រួសារមួយ[២៦] មានបងប្អូនប្រុស-ស្រីចំនួនប្រាំបួននាក់ គឺមនុស្សពេញវ័យប្រាំមួយនាក់ និងក្មេងៗបីនាក់ ។ ម្តាយនាងមិនដែលឃើញវិលមកវិញសោះបន្ទាប់ពីការធ្វើដំណើរមួយទៅបរទេស មុនការបញ្ចប់ទៅនៃសង្គ្រាម ។ ឪពុករបស់នាងបានត្រូវពួកខ្មែរក្រហមសម្លាប់នៅខែមិថុនា ។ គាត់ជាគ្រូពេទ្យនៅភ្នំពេញ និងធ្លាប់ចាត់ចែងរៀបចំការចេញដំណើររបស់គ្រួសារគាត់នៅពេលមានការជម្លៀសលើកទីមួយ ។ គ្រួសារម៉ៃ បានដើរអស់រយៈពេលពីរខែ មុននឹងបានតាំងលំនៅក្នុងសហករណ៍មួយរបស់ខេត្តតាកែវ ។ ដប់ថ្ងៃក្រោយដែលពួកគេត្រូវបានទទួលយល់ព្រមឲ្យរស់នៅក្នុងភូមិនេះ មានមនុស្សបួននាក់បានមកបង្ហាញខ្លួននៅផ្ទះរបស់គេ ហើយស្នើយកឪពុកគេទៅបាត់ ។

ស៊ីសូផា បានដំណាលថា «ពួកយើងធ្លាប់និយាយប្រាប់គេថា យើងទាំងអស់គ្នាជាអ្នកក្រីក្រទេ ប៉ុន្តែខ្ញុំយល់ថាឈ្លួលស្រីរបស់យើងច្បាស់ជានិយាយពីគ្រួសារយើងប្រាប់គេមិនខាន ។ អ្នកទាំងបួននាក់នោះ បានប្រាប់យើងថា គេនាំឪពុករបស់យើងទៅមណ្ឌលអប់រំកែប្រែមួយ និងធ្វើការនៅក្នុងព្រៃតែពីរ ឬបីថ្ងៃប៉ុណ្ណោះ» ។

ឪពុកបាននិយាយប្រាបកូនៗថា កុំប្រឆាំងជំទាស់នឹងគេ ហើយបានចាកចេញទៅដោយមានជនប្រដាប់អាវុធអមទៅជាមួយផង ។ ប្រហែលមួយខែក្រោយមក មិត្តម្នាក់បានមកប្រាប់ពួកគេថា ឪពុកអ្នកឯងត្រូវគេធ្វើទារុណកម្មរហូតដល់ស្លាប់ទៅហើយ ។

ដោយបានយកមកជាមួយខ្លួននូវអង្ករ ស្ករស មាស និងសាច់ក្រណាត់ល្អៗពេលចាកចេញពី ភ្នំពេញ គ្រួសារម៉ៃ បានរស់នៅបន្តមកទៀតដោយការដោះស្រាយស្បៀងអាហាររបៀបផ្សារងងឹតនៅក្នុងភូមិនេះ ។ សហករណ៍ហាក់ដូចជាអនុគ្រោះចំពោះពួកគេដែរ ។ ជួនកាល គេប្រគល់កិច្ចការដ៏នឿយលំបាកមួយឲ្យធ្វើនៅឯស្រែ ជួនកាលពេលវេលាច្រើនថ្ងៃបានកន្លងផុតទៅ ដោយគេគ្មានផ្តល់បទបញ្ជាមួយឲ្យធ្វើឡើយ ។ ពួកគេត្រូវដាក់ឲ្យរស់នៅដាច់ឡែកពី «ពួកមូលដ្ឋាន» ដោយមិនដែលត្រូវបញ្ចូលឲ្យទៅរស់ក្នុងភូមិ ឬរចនាសម្ព័ន្ធផ្សេងៗរបស់សហករណ៍សោះឡើយ ។ ពួកកម្មាភិបាល និងកងទ័ពខ្មែរក្រហម ក៏រស់នៅក្រៅភូមិដូចពួកគេដែរ ប៉ុន្តែ ពួកនោះរស់នៅក្នុងផ្ទះល្អៗ ដោយមានម្ហូបអាហារ និងថ្នាំពេទ្យសម្បូរហូរហៀរ ។

នៅពេលដែលសហករណ៍បើកធ្វើការប្រជុំធំមួយ ដើម្បីសាកសួររកពួកអ្នកស្ម័គ្រចិត្តទៅរស់នៅភូមិភាគ

ពាយ័ព្យ គឺគេទុកចិត្តទៅលើ "ពួកអ្នកថ្មី" យ៉ាងច្បាស់សម្រាប់ឲ្យលើកដៃ ។ សមាជិកពេញវ័យរបស់គ្រួសារម៉ៃ រួមមានយុវកញ្ញាវិទ្យាល័យម្នាក់អាយុដប់ប្រាំឆ្នាំ កូនក្មោះពីរនាក់អាយុដប់ប្រាំពីរឆ្នាំ ដែលរៀនសូត្រចប់មធ្យមសិក្សា និស្សិតពេទ្យម្នាក់អាយុដប់ប្រាំបួនឆ្នាំ ស៊ីសូផា និងប្ដីរបស់នាង ព្រមទាំងស្រីម្នាក់ទៀតអាយុម្ភៃប្រាំមួយឆ្នាំ និងប្ដីរបស់នាង ។ ក្នុងនោះមានថែមកូនប្រាំមួយនាក់ទៀត ។ នៅជំនាន់នោះ ភាពមិនច្បាស់ក្នុងចិត្តរបស់មនុស្សម្នាក់ៗ គឺមានលក្ខណៈដូចគ្នា ។ ពួកគេបានចាកចេញពីសម័យប្រជុំជាមួយនឹងអារម្មណ៍ខុសៗគ្នា ស្ដីពីការធ្វើដំណើរដែលមាននៅពេលខាងមុខ ។ ស៊ីសូផា គិតថា ពួកខ្មែរក្រហមនឹងដឹកយកពួកគេទៅភ្នំពេញ ក្នុងពេលភ្លាមនេះ បុប្ផា កូនក្មោះម្នាក់ក្នុងចំណោមកូនក្មោះទាំងពីរជឿជាក់ថា មុនដំបូងពួកគេនឹងទៅកាន់ខេត្តបាត់ដំបងក្នុងភូមិភាគពាយ័ព្យសិន ហើយបន្ទាប់ពីជួយប្រូតកាត់រូច ពួកគេនឹងបានវិលត្រឡប់មកផ្ទះរបស់ខ្លួននៅរដ្ឋធានីមិនខាន ។ នៅពេលយប់ពួកគេបាននាំគ្នារៀបចំអីវ៉ាន់ហើយក្រោកតាំងពីព្រលឹមស្រាងៗ អន្ទះអន្ទែងចង់ចាកចេញពីភូមិភាគនិរតីភ្លាមៗ ។ ឡានកាមីញ៉ុងប្រមាណជាម្ភៃគ្រឿងបានមកដល់ ពួកកងទ័ពបានដកហូតបង្ហូចខោអាវពីអ្នកទាំងនោះដែលពួកគេស្ពាយជាប់នឹងខ្លួន បន្ទាប់មកទើបអនុញ្ញាតឲ្យឡើងជិះឡាន ប្រជ្រៀតគ្នាឡើងណែនតាន់ ដូចគេដាក់ជ្រូកនាំយកទៅលក់ឯទីផ្សារដែរ ។ ក៏ប៉ុន្តែ គ្រួសារម៉ៃ ពុំមានបាត់បង់សេចក្ដីក្លាហានឡើយ ។ ផ្ទៃមេឃ មានសភាពស្រឡះល្អណាស់ គឺជារដូវក្ដៅហួតហែង ហើយការធ្វើដំណើរនេះនឹងនាំយកពួកគេទៅហួសឆ្ងាយពីឋាននរកទៅទៀត ។

រថយន្តទាំងនោះបានបើកមកដល់ភ្នំពេញនៅពេលរសៀល ។ គ្រួសារម៉ៃ បានមើលឃើញទីក្រុងកំណើតរបស់គេម្ដងទៀតជាលើកដំបូងបង្អស់ តាំងពីពេលដែលការភាន់ប្រែរបស់ការបដិវត្តន៍ចាប់ផ្ដើមម្ល៉េះ ។ ប៉ុន្តែ ឥឡូវនេះ ឃើញមានកងទ័ព និងកម្មាភិបាលស្លៀកពាក់ខោអាវពណ៌ខ្មៅ រស់នៅពាសពេញ ។ ពួកគេនាំគ្នាសម្លឹងមើលកីឡាដ្ឋានអូឡាំពិចពីចម្ងាយ បន្ទាប់មក រថយន្តបានបង្កើនល្បឿនចាកចេញពីទីក្រុង សំដៅទៅទិសខាងជើងតែម្ដង ។ អ្នកទាំងឡាយដែលធ្លាប់ជឿថា ពួកគេច្បាស់ជាបានត្រឡប់ចូលភ្នំពេញវិញនោះ បានចាប់ផ្ដើមព្រួយបារម្ភក្នុងចិត្ត ។ ស៊ីសូផា បានរៀបរាប់ថា "មនុស្សនៅលើឡានទាំងអស់បានសាកសួរគ្នាពីបញ្ហាផ្សេងៗ តើគេនាំយកពួកយើងទៅណា? គេយកយើងទៅសម្លាប់ចោលឬ? ខ្ញុំគ្មានដឹងរឿងអ៊ីទាំងអស់ ហើយខ្ញុំសម្រេចក្នុងចិត្តថារឿងនេះវាគ្មានអ៊ីជាសំខាន់ឡើយ ។ ប្អូនប្រុសខ្ញុំឈ្មោះ សូម៉េត នៅស្ងៀមគ្មាននិយាយស្ដីមួយម៉ាត់ ។ មិនយូរប៉ុន្មាន អ្នកទាំងនោះក៏នៅស្ងៀមស្ងាត់លែងមាត់ក ព្រោះវាគ្មានអ៊ីសម្រាប់និយាយ" ។

គេពុំមែនយកអ្នកទាំងនោះទៅសម្លាប់ចោលទេ ។ បន្ទាប់ពីការធ្វើដំណើរអស់រយៈមួយថ្ងៃកន្លះ ដោយគ្មានឈប់សម្រាកដើម្បីឲ្យពត់ដៃពត់ជើង គេបានឲ្យពួកនោះចុះនៅត្រង់ផ្លូវបែកជាប្អូនមួយនាខេត្តពោធិសាត់ ។ នៅថ្ងៃបន្ទាប់ គេឲ្យពួកនោះដើរហូតដល់ឃ្លាំងទុកសម្ភារៈអយស្ម័យយានខេតពោធិសាត់ ជាទីដែលពួកគេបានជួបនឹងពួកអ្នកជម្លៀសរាប់ពាន់នាក់ផ្សេងទៀត ដែលកំពុងបោះជំរំបណ្ដោះអាសន្ននៅពាសពេញទីនោះ ។ អ្នកនៅទីនេះ

សុទ្ធតែ «ពួកអ្នកថ្មី» ហើយត្រូវបានគេដោះស្រាយដូចពួកអ្នកមកដល់មុនដែរ ។ អាចម៍មនុស្សមាននៅរាយតែពីសតែពាស និងមានសត្វមូសច្រើនឥតគណនា ។ ពុំមានអ្វីគ្រាន់បើសម្រាប់ហូបទេ ហើយក៏គ្មានកន្លែងសម្រាប់ទម្រេតខ្លួនដែរ ពុំមានទឹកផឹកឲ្យគ្រប់គ្រាន់ ដោយមិនទាន់គិតដល់ទឹកសម្រាប់មុជផង ។

ក្នុងអន្តប្រជុំនៅសហករណ៍ គេគ្មាននិយាយប្រាប់ពីមូលហេតុដែលគេស្នើឲ្យអ្នកទាំងនោះធ្វើដំណើរទៅកាន់ភូមិភាគពាយ័ព្យទេ ។ គេក៏មិនដឹងថា មជ្ឈិមមានគោលដៅដ៏ធំធេងក្នុងការផ្ទេរ «ពួកអ្នកថ្មី» រាប់ពាន់នាក់ឲ្យទៅរស់នៅតាមដីវាលដែលមិនសូវមានមនុស្សរបស់ភូមិភាគពាយ័ព្យដែរ ។ ពួកគេនៅស្គាល់បក្សតែក្រោមឈ្មោះ «អង្គការ»ប៉ុណ្ណោះ ហើយគ្មានយល់ពីមហិច្ឆតាដ៏សម្បើមហួសហេតុរបស់បក្សបន្តិចសោះឡើយ ។ តាមការយកចិត្តទុកដាក់ជាច្រើន ការធ្វើដំណើរលើកទីពីរ នេះមានសភាពលំបាកខ្លាំងជាងកាលពីពេលជម្លៀសចេញពីទីក្រុងភ្នំពេញទៅទៀត ។ តាំងពីនោះមក រយៈពេលជាច្រើនខែកន្លងទៅ «ពួកអ្នកថ្មី» បានចុះថមថយកម្លាំង ហើយមានទឹកចិត្តទ្រាំទ្រនឹងភាពខកបំណងផ្សេងៗទៀតហើយ ។

«ពួកអ្នកថ្មី» បានដើរមកដល់ឃ្លាំងផ្ទុកសម្ភាររថភ្លើងខេត្តពោធិសាត់ជាហូរហែ ។ ពួកខ្មែរក្រហម បានរៀបចំអ្នកបម្រើការងារស្បៀងមួយក្រុមសម្រាប់ចែកចាយរបបចុងអង្ករៀងរាល់បីថ្ងៃម្តង ។ សាកសពមនុស្សមាននៅរាយតែពាសក្នុងជំរំ ក្លិនអាសោចនៃអាចម៍មនុស្ស និសត្វពាហណៈ បានធ្វើឲ្យអ្នកនៅទីនោះទ្រាំទ្រសឹងពុំបាន ។ ទីបំផុត រយៈប្រាំបីថ្ងៃក្រោយមក រទេះភ្លើងបានមកដល់ ។ មុនដំបូងរថភ្លើង បានបើកទៅឈប់នៅជិតឃ្លាំងផ្ទុកសម្ភារ ដើម្បីដាក់សត្វពាហណៈចុះ បន្ទាប់មក ទើបបើកមកឈប់នៅពីមុខពួកអ្នកជម្លៀស ដែលត្រូវឡើងជិះដាន់កគ្នាជំនួសកន្លែងសត្វទាំងនោះ ។ គ្រួសារនីមួយៗបានទទួលលេខសម្គាល់មួយ ហើយពួកអ្នកទទួលខុសត្រូវ ដែលកំពុងឈរពីមុខទូរថភ្លើងនានា បានហៅឈ្មោះពួកអ្នកជម្លៀសឲ្យឡើងរថភ្លើងម្តងមួយៗ ។ កាលបើដល់វេនរបស់ខ្លួន គ្រួសារម៉ៃបានដើរតម្រង់ទៅរកទូរថភ្លើងមួយ ។ គ្រួសារនាងបានឡើងជិះជិតអស់គ្នាទៅហើយ ស្រាប់តែអ្នកទទួលខុសត្រូវទូនោះប្រកាសថា ទូនេះពេញណែនអស់ហើយ ដោយរារាំងបងស្រីច្បង ប្តី និងកូនៗរបស់គាត់មិនឲ្យឡើងជិះឡើយ ហើយបញ្ជាឲ្យពួកគេរង់ចាំរថភ្លើងក្រោយទៀត ។ គ្មានការអង្វរករណាមួយ អាចញ៉ាំងឲ្យអ្នកទទួលខុសត្រូវទាំងអស់នោះ អនុញ្ញាតឲ្យពួកគេបានទៅជួបជុំគ្រួសារដែលនៅលើរថភ្លើងនោះឡើយ ។ រថភ្លើងបានបញ្ឆេះម៉ាស៊ីនចេញដំណើរ បងស្រីច្បងបានលើកដៃជាសញ្ញាលាបងប្អូនរបស់គាត់ ដែលរូបនាងត្រូវព្រាត់ប្រាសជារៀងរហូត ។

ការដឹកជញ្ជូនពីចុងម្ខាងប្រទេសទៅចុងម្ខាងទៀត បានក្លាយទៅជាលក្ខណៈសម្គាល់មួយប្លែកពីគេ ក្នុងចំណោមលក្ខណៈសម្គាល់ទាំងឡាយរបស់ការបដិវត្តន៍ ។ ពួកខ្មែរក្រហមបានប្រើប្រាស់ការជម្លៀស មនុស្សទាំងហ្វូងៗដើម្បីបញ្ជូនហត្ថពលករទៅកន្លែងឆ្ងាយៗដែលខ្វះខាតកម្លាំងមនុស្សធ្វើការ ។ ពួកមេដឹកនាំបានចាត់ទុក «ពួកអ្នកថ្មី» ជាវណ្ណៈទាសករ ដែលគេអាចដឹកនាំស្រេចតែចិត្ត ដែលចាំបាច់ចំពោះសង្គមនានា ដែលកំពុងជោះ

ជំហានចូលទៅក្នុងដំណាក់កាលទីមួយនៃទំនើបកម្មរបស់គេ ។ ការផ្លាស់ប្រជាជនពីកន្លែងមួយទៅកន្លែងមួយ ក៏ត្រូវបានប្រើប្រាស់ក្នុងក្របខ័ណ្ឌនៃការបោសសម្អាតមនុស្ស ដើម្បីជម្រុះចោលពួកអ្នកដែលគេគិតថា ជាអ្នកផ្តល់នូវគ្រោះថ្នាក់មួយក្នុងតំបន់កំណើតរបស់គេ ។ ការជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ ត្រូវបានរៀបចំឡើងសម្រាប់ហេតុផលម្យ៉ាងៗនោះឯង ។

ក្នុងរទេះភ្លើងឆ្ពោះទៅខេត្តបាត់ដំបង គ្រួសារម៉ៃ បានអារម្មណ៍ហាក់ដូចជាកូនកំព្រា ។ ពួកគេគ្មានដឹងថាម្តាយរបស់ខ្លួនស្ថិតនៅទីណាឡើយ ឪពុករបស់ខ្លួនត្រូវគេយកទៅសម្លាប់ចោល ហើយបងស្រីច្បងនិងប្តីរបស់គាត់ដែលពួកគេចាត់ទុកជាឪពុកម្តាយនោះ ក៏នៅជាប់ឯពោធិសាត់ទៅទៀត ។ ប៉ុន្តែ ពួកគេប្តេជ្ញាចិត្តមិនចុះញ៉មឡើយ ។ ស៊ីសូផា និយាយថា «យើងទាំងអស់បានសន្យាគ្នាទៅវិញទៅមកថា នឹងធ្វើអ្វីៗគ្រប់បែបយ៉ាង ដើម្បីឲ្យបានរស់ជីវិត ក្នុងគោលបំណងជួយគ្នាទៅវិញទៅមក និងអាចវិលត្រឡប់ចូលក្រុងភ្នំពេញវិញទាំងអស់គ្នា» ។

ថេភ្លើងបានឈប់សំចតនៅខេត្តបាត់ដំបង ពួកអ្នកជម្លៀសបានឡើងជិះរទេះគោជាច្រើនសម្រាប់ភាគដែលនៅសល់នៃដំណើររបស់ខ្លួនទៀត ។ គ្រួសារម៉ៃ បានត្រូវគេនាំយកទៅដាក់នៅតំបន់៥០ ជាតំបន់មួយ ដែលមានស្ថានភាពអាក្រក់បំផុតក្នុងចំណោមតំបន់នានារបស់ភូមិភាគពាយ័ព្យ ។ នៅទីនោះ សម្រាប់ពួកអ្នកថ្មី គឺគ្មានអ្វីបន្តិចសោះសម្រាប់ហូប ហើយត្រូវសង់ទីជម្រកដោយខ្លួនឯងទៀត ។ គ្រួសារម៉ៃ បានកាត់សក់ខ្លីទាំងអស់គ្នាក្នុងរបៀបតវ៉ាមិនចេញស្តីមួយដែលកើតឡើងឯងៗ ហើយបានរិះរកមធ្យោបាយមួយដើម្បីចេញឲ្យផុតពីស្ថានភាពនេះ ។

ក្រោយមកមិនយូរប៉ុន្មាន នៅពេលដែលកម្មាភិបាលម្នាក់សួរថា នៅទីនោះមានជនជាតិវៀតណាមក្នុងចំណោមពួកអ្នកដែលទើបនឹងមកដល់នេះឬទេ? បុប្ផា កូនក្មេងម្នាក់ក្នុងចំណោមកូនក្មេងទាំង៧ បានឆ្លើយថា មានគ្រួសារខ្ញុំមានដើមកំណើតនៅវៀតណាម ។ ម្តាយរបស់នាងដែលមានដើមកំណើតនៅកម្ពុជាក្រោម បានបង្រៀនភាសាវៀតណាមដល់កូនៗទាំងអស់ ។ គ្រួសារម៉ៃ បានក្លែងបន្លំជាជាតិវៀតណាម ហើយបានទទួលបញ្ជាឲ្យធ្វើដំណើរទៅវត្តមួយដែលនៅជិតនោះ ។ ដូចភូមិភាគដទៃៗទៀត ភូមិភាគពាយ័ព្យក៏បានទទួលបញ្ជាឲ្យបណ្តេញក្រុមអាណិកជនវៀតណាមទៅកាន់ប្រទេសដើមរបស់ពួកគេវិញដែរ ឬសម្លាប់ពួកនោះចោលក៏បាន ។

ពោរពេញដោយក្តីសង្ឃឹម គ្រួសារនេះបានចាកចេញម្តងទៀតដោយជំហានយឺតៗឆ្ពោះទៅរកចំណុចចេញដំណើរមួយថ្មីទៀត ប៉ុន្តែ ពួកគេបានទៅដល់ទីនោះដោយយឺតពេលបន្តិច ៖ ក្បួនរថយន្តដែលដឹកជញ្ជូនពួកវៀតណាម បានចាកចេញពីវត្តបាត់ទៅហើយ ។ ពួកកម្មាភិបាលខ្មែរក្រហម បានបញ្ជាឲ្យគ្រួសារម៉ៃវិលត្រឡប់មកកន្លែងដើមវិញ ។ ពួកគេធ្វើហាក់ដូចជាត្រឡប់មកសហករណ៍ ប៉ុន្តែ កាលបើផុតពីភ្នែកពួកនោះ គ្រួសារម៉ៃ ក៏ធ្វើចលនាឆ្ពោះទៅទិសមួយផ្សេង ហើយអង្វររកសុំឲ្យភូមិមួយទទួលឲ្យពួកគេរស់នៅជាមួយផង ។ ស៊ីសូផា បានឲ្យដឹងថា «នៅតំបន់៥០ ខ្មែរក្រហមបានសម្លាប់មនុស្សចោលអស់ច្រើនណាស់ ពួកនោះបង្ខំឲ្យពួកយើងធ្វើការ

ប្រៀបដូចយើងជាអ្នកទោសឧក្រិដ្ឋ ដោយគ្មានឲ្យអ៊ីហូបបន្តិចសោះ ។ យើងទាំងអស់គ្នា ក៏ធ្វើដំណើរទៅ រាមគន់ (Réam Khun) ទៅ» ។

សហករណ៍ថ្មីនេះ បានអនុវត្តតាមបទបញ្ជាផ្សេងៗរបស់មជ្ឈិមដែលឲ្យបំបែកមនុស្សក្នុងគ្រួសារ និង កម្ទេចសមាសភាព«ប្រតិកិរិយា»ចោលដែរ ។ ប៉ុន្តែ គ្រួសារម៉ៃ បានញ៉ាំងឲ្យពួករដ្ឋអំណាចជឿថា ពួកគេសុទ្ធតែ មានដើមកំណើតជាអ្នកក្រ ហើយក៏បានរួចផុតពីការតាមដានរបស់ពួកសន្តិសុខ ។

គេបានបំបែកគ្រួសារនាងឲ្យទៅរស់នៅក្នុងកន្លែងដេករួម និងលំនៅដ្ឋានផ្សេងៗពីគ្នា ។ ស៊ីសូផា និងប្តីរបស់ នាង បានស្នើសុំទុកកូនពៅម្នាក់អាយុបួនឆ្នាំ រស់នៅជាមួយពួកគេ ប៉ុន្តែ កូនប្រុសពីរនាក់ទៀត ដែលមានអាយុ ប្រាំមួយ និងប្រាំបួនឆ្នាំ ត្រូវបានបញ្ជូនទៅរស់នៅផ្ទះមួយសម្រាប់ដាក់ក្មេងៗ ហើយអ្នកទាំងពីរលែងបានឃើញ ពួកវាត្រឡប់មកវិញជារៀងរហូត ។ ក្រោយមកគ្រួសារនាងបានដឹងថា ពួកវាបានស្លាប់ដោយបរិភោគអាហារ មិនគ្រប់គ្រាន់ ។ សូម៉េត អាយុដប់ប្រាំបួនឆ្នាំ ត្រូវគេបញ្ជូនទៅដាក់ក្នុងផ្ទះមួយសម្រាប់យុវជន កូនក្មេងទាំងពីរ ដាក់ក្នុងកន្លែងដេករួមមួយសម្រាប់យុវនារី ហើយប្អូនស្រីពៅឈ្មោះ ឱភា អាយុដប់ប្រាំឆ្នាំ នៅក្នុងកងចល័ត យុវ ជនដែលត្រូវបានទទួលការបណ្តុះបណ្តាលជាគិលានុបដ្ឋាយិកា មុននឹងបញ្ជូនទៅទីកន្លែងផ្សេងៗទៀតក្នុងតំបន់ ។ ពេញរយៈពេលនៃដំណាក់កាលដំបូងនេះ បងប្អូនប្រុសស្រីរបស់គ្រួសារម៉ៃ អាចទាក់ទងគ្នាតាមរយៈសំបុត្រ ដោយមានកម្មាភិបាលម្នាក់ជាអ្នកជួយ ព្រោះគាត់ខស្សរាប់ធ្វើដំណើរពីសហករណ៍មួយទៅសហករណ៍មួយ ។

គ្រួសារម៉ៃ បានរួចផុតពីរលកនៃការសម្លាប់លើកដំបូង ដែលបង្គាប់បញ្ជាដោយមជ្ឈិម ដើម្បីសម្រួច «ការតស៊ូវណ្ណៈ» ជាសញ្ញាណនៃលទ្ធិម៉ាក្សលេនីន ដែលពួកខ្មែរក្រហមយកមកសម្តែងតាមគ្មានខុសបន្តិចសោះ ។ បណ្តាលេខាបក្សភូមិភាគ និងប្រធានសហករណ៍ មានគោលការណ៍ផ្ទាល់របស់គេក្នុងការបញ្ជាក់លក្ខណៈវណ្ណៈ ផ្សេងៗរបស់ប្រជាជនកម្ពុជា ទោះបីជាមានបញ្ជីដែលគេរៀបចំឡើងកាលពីខែមេសា ឆ្នាំ១៩៧៥ ត្រូវបែក ចាយក្នុងទូទាំងប្រទេសរួចហើយក៏ដោយ ។ អ្នកខ្លះដែលទុកតម្លៃការងារជាធំមិនបានយកប្រភពកំណើតរបស់ មនុស្សម្នាក់ៗមកគិតទេ ទោះណាជាអ្នកនោះបានគោរព ធ្វើតាមបទបញ្ជាផ្សេងៗច្រើនយ៉ាងណាក៏ដោយ ។ អ្នក ខ្លះទៀត ជាពិសេស ក្នុងតំបន់ដែលគេមិនទាន់បានរៀបចំឲ្យរឹងមាំនាភូមិភាគពាយ័ព្យ បានប្រើងប្រែងស្រាវជ្រាវ រកជនទាំងឡាយណាដែល «មាននិន្នាការពាក់ព័ន្ធនឹងវណ្ណៈមិនល្អ» ប្រកបដោយភាពងប់ងល់ជ្រុលហួសហេតុ ។

ការកំណត់ន័យពាក្យ «ពាក់ព័ន្ធនឹងវណ្ណៈមិនល្អ» បានបើកដៃឲ្យគេអាចធ្វើអ្វីៗបានគ្រប់បែបយ៉ាង ។ គេអាចមានឈ្មោះជាប់ពាក់ព័ន្ធនឹងវណ្ណៈមិនល្អមួយតាមប្រភពកំណើតរបស់ខ្លួន ឬដោយការចងសម្ព័ន្ធភាពរវាង ត្រកូលមួយនិងត្រកូលមួយ ។ បើសិនគេកើតក្នុងគ្រួសារគហបតីមួយ គេច្បាស់ជារងនូវការប្រហារជីវិតជាមិន ខាន ។ បើសិនគេមានបងប្រុសម្នាក់ធ្វើនាយទាហានក្នុងកងទ័ព លន់ នល់ គេអាចទៅជាមនុស្សដែលគួរឲ្យសង្ស័យ បើសិនគេមានបងស្រីម្នាក់បានរៀបការជាមួយនាយទាហានម្នាក់របស់កងទ័ព លន់ នល់ គេអាចទៅជាអ្នកមាន

ទោសដោយសារការចងសម្ព័ន្ធភាពនេះ ។ បើនិយាយតាមរបៀបម្យ៉ាងទៀតថា នៅពេលដែលប្រធានសហករណ៍មួយ ឬប្រធានសន្តិសុខចង់កម្ចាត់គ្រួសារណាមួយចោល ពួកនេះតែរិះរកភស្តុតាងមួយដែលមាននៅក្នុងគោលការណ៍ថ្មីៗនៃ«ការតស៊ូវណ្ណៈ» និង «ការជាប់ពាក់ព័ន្ធនឹងវណ្ណៈ»នេះឯង ។ នៅក្នុងភូមិភាគពាយ័ព្យ ដែលពួកកម្មាភិបាលទន់ខ្សោយ ភ័យខ្លាចនិងពេលដែលមជ្ឈិមតម្រូវធ្វើឲ្យសេដ្ឋកិច្ចរីកចម្រើនលោតផ្លោះ អត្រានៃការសម្លាប់មនុស្ស បានកើនឡើងសម្បើមក្រៃលែងនៅតំបន់មួយចំនួនតូច ។ ស៊ីសូផា បានវាយតម្លៃថា ចំនួនសមាជិកសហករណ៍ របស់នាងចំនួនពាក់កណ្តាល បានស្លាប់នៅឆ្នាំ១៩៧៦ ដោយត្រូវសម្លាប់ ឬស្លាប់ដោយជំងឺផ្សេងៗ ។

អៀង សារី ផ្ទាល់ដែលជារដ្ឋមន្ត្រីការបរទេស និងជា«បងទី២»របស់បក្ស បានបញ្ជាក់បន្ថែមពីលើការវាយតម្លៃរបស់ ស៊ីសូផា ថា «យើងបានរកឃើញក្នុងបរិការណ៍មួយ (កាលៈទេសៈដែលនៅ ជុំវិញព្រឹត្តិការណ៍មួយ) វណ្ណៈផ្តាច់ការអធន និងការតស៊ូវណ្ណៈ...។ ការច្របូកច្របល់យ៉ាងមួយបានស្ថិតមាននៅមួយរយៈនៅឆ្នាំ ១៩៧៦ ។ ប្រជាជនដែលធ្លាប់រស់នៅមូលដ្ឋានតាំងពីយូរយារមកហើយ ក៏ត្រូវគេចោទថាជាពួកភ្នាក់ងារធ្វើការឲ្យបរទេសដែរ[២១]» ។ តាម អៀង សារី យល់គឺ សោ ភឹម ក្នុងភូមិភាគបូព៌ា និង រស់ ញឹម ក្នុងភូមិភាគពាយ័ព្យនេះហើយ ដែលជាអ្នកបានផ្តើមគំនិតក្នុងការបែងចែកប្រភេទប្រជាជនមុនគេ ។ ប៉ុន្តែ អ្នកទទួលខុសត្រូវ គឺផ្នែកសន្តិសុខ កងឈ្លប ដែលប៉ិនភូតកុហក និងមន្ទីរឃុំឃាំងទួលស្លែង គឺ សុន សេន រដ្ឋមន្ត្រីការពារប្រទេសដែលជាមិត្តរបស់ អៀង សារី តាំងពីជំនាន់ក្រុងប៉ារីស ។ ហើយអំណាចបញ្ជាការទូទៅផ្នែកសន្តិសុខ ក៏ដូចកងទ័ព និងបក្សដែរ គឺស្ថិតក្នុងកណ្តាប់ដៃរបស់ ប៉ុល ពត ផ្ទាល់ ។

គឺ ប៉ុល ពត និងបក្ស រួមទាំងបណ្តាលេខាបក្សភូមិភាគផង ដែលជាអ្នករៀបរៀងមតិណែនាំផ្សេងៗស្តីពីការតស៊ូវណ្ណៈ ។ កសិករមានដែលធ្លាប់ប្រយុទ្ធតស៊ូដើម្បីបដិវត្តន៍តាំងពីដើមដំបូង បានទៅជាកម្មវត្ថុនៃការបោសសម្អាត និងត្រូវយកទៅសម្លាប់ចោល ។ សមាជិកបក្ស យុទ្ធជនខ្មែរក្រហមជាច្រើននាក់ ក៏ត្រូវគេសម្លាប់ដែរ ព្រោះតែវណ្ណៈភាពដើមរបស់ខ្លួនមិនល្អ ។ បណ្តាប្រធានឃុំ ឬពួកឈ្លប អាចធ្វើការសម្លាប់មនុស្សយ៉ាងងាយស្រួលដោយបង្ហាញភស្តុតាងពីការសម្លាប់ទាំងនេះ ដោយសំអាងលើការបង្គាប់បញ្ជា ដ៏ដាក់លាក់របស់បក្សប៉ុណ្ណោះ ។

ក្នុងភូមិភាគពាយ័ព្យ គ្រួសារម៉ៃ បានលាក់ប្រភពកំណើតរបស់ពួកគេដោយជោគជ័យ ។ ពួកគេបានភូតកុហកពីមុខងារឪពុករបស់ខ្លួន ពីកម្រិតចំណេះវិជ្ជា និងពីទ្រព្យសម្បត្តិកាលពីដើមរបស់គាត់ ដែលរកបានមួយភាគធំក្នុងរយៈពេលសង្គ្រាម ។ ទោះជាពួកគេញុាំងឲ្យពួកកម្មាភិបាលទាំងនោះជឿបែបនេះក៏ដោយ ក៏ពួកគេពុំអាចគេចផុតពីស្ថានភាពដ៏សែនលំបាកផ្សេងៗ ដែលគេត្រូវពុះពារជារៀងរាល់ថ្ងៃនៅឆ្នាំ១៩៧៦ដែរ ។ ស្បៀងអាហារកាន់តែខ្វះខាតយ៉ាងខ្លាំង ។ ភូមិភាគពាយ័ព្យធ្លាប់គោរពធ្វើតាមបទបញ្ជាផ្សេងៗរបស់បក្ស ដែលទាមទារឲ្យពង្រីក និងពង្រឹងសហករណ៍នានា រហូតដល់សហករណ៍ទាំងនោះ មានសមាជិកមួយពាន់នាក់ និងកែប្រែកងការ

ងារ ក្រុមធ្វើការតូចៗ ដែលមានលក្ខណៈជាគ្រួសារធ្វើឲ្យក្លាយទៅជាកងផលិតធំៗ ។ ថ្នាក់ដឹកនាំសហករណ៍មានសមាសភាពប្រមាណជាសាមសិបនាក់ ជា"អ្នកមូលដ្ឋាន" និងជាយុទ្ធជនខ្មែរក្រហមដើងចាស់ដែលធ្លាប់ប្រយុទ្ធតស៊ូក្នុងរយៈពេលសង្គ្រាម ។ នៅថ្នាក់នេះ មានភាពខុសគ្នាបន្តិចបន្តួចប៉ុណ្ណោះរវាង បក្ស កងទ័ព និងសន្តិសុខ ៖ ប្រធានសហករណ៍បានកាន់កាប់សិទ្ធអំណាចជាទូទៅមួយ ។ ហើយនៅក្នុងសម័យនៃការបោសសម្អាតការខុះខាត និងពេលម៉ោងធ្វើការងារដ៏លំបាកទ្រាំទ្រនេះ បណ្តាមេដឹកនាំសហករណ៍ទាំងអស់សុទ្ធតែជាអាទិទេព ។ តាមរយៈការសម្រេចចិត្តផ្សេងៗប្រចាំថ្ងៃ ស្តីពីរបបអាហារ ការបែងចែកកិច្ចការឲ្យប្រជាជនធ្វើសេចក្តីរាយការណ៍ពីសន្តិសុខ និងការព្យាបាលជំងឺ ពួកគេសុទ្ធតែជាអ្នកមានសិទ្ធអំណាចឲ្យស្លាប់ ឬរស់ចំពោះបុគ្គលគ្រប់ៗរូប ។

នៅទីបំផុត សមាជិកម្នាក់របស់គ្រួសារម៉ៃ បានប្រព្រឹត្តអំពើខុសឆ្គងមួយ ។ មីលីយ៉ា កូនក្មេងម្នាក់ ក្នុងចំណោមកូនក្មេងទាំងពីរ បានកត់ទុកនូវគំនិតប្រឆាំងបដិវត្តក្នុងសៀវភៅមួយក្បាល ដែល បុប្ផា កូនក្មេងម្នាក់ទៀត ប្រើប្រាស់ក្នុងមុខតំណែងរបស់នាងជាគ្រូបង្រៀននៅសហករណ៍ ។ បុប្ផា ជាអ្នកបង្រៀនក្មេងៗ ដែលមានអាយុត្រូវចូលរៀនចេះអាន និងសរសេរមួយភ្លែតៗ នៅពេលព្រឹកមុនពេលទៅបំពេញការងារប្រចាំថ្ងៃ ។ សៀវភៅនេះ ត្រូវបានគេរកឃើញក្នុងរយៈពេល ព្រោះជាសៀវភៅរបស់នាង ។ នាងអះអាងថា មិនស្គាល់អក្សររបស់ប្អូនស្រីនាងទេ ហើយថានាងមិនបានសរសេរកំណត់ខ្លីៗទាំងនេះទេ នាងក៏ត្រូវគេដោះលែងមកវិញ ។ នៅពេលប្រធានសហករណ៍កោះហៅ មីលីយ៉ា ទៅជួប មីលីយ៉ា បានឆ្លើយទទួលសារភាព ។ ប្រធានសហករណ៍ធ្មេចភ្នែក ហើយបានទូន្មានកុំឲ្យនាងប្រព្រឹត្តរបៀបឆ្កួតៗ ដូច្នេះទៀតទៅថ្ងៃមុខ ព្រោះប្រការនេះអាចបណ្តាលឲ្យមានរឿងរ៉ាវច្រើនណាស់ ។

ប៉ុន្តែ រឿងនេះបានលេចឮសុសសាយប្រជាជនដឹងឮគ្រប់ៗគ្នា ហើយកូនក្មេងទាំងពីរត្រូវឆ្លងកាត់ការវិនិច្ឆ័យទោស ក្នុងឱកាសនៃការប្រជុំនយោបាយធំមួយ ។ បុប្ផា បានដាក់ខ្លួនឲ្យគេទិតៀន និងចាំទទួលទណ្ឌកម្មមុនគេ នាងត្រូវបាត់បង់តំណែងជាគ្រូបង្រៀន ហើយត្រូវបញ្ជូលទៅក្នុងកងការងារមួយ ។ សម្រាប់ មីលីយ៉ា ការប្រជុំទិតៀន និងការកាត់ទោសមានរយៈពេលយ៉ាងខ្លីបំផុត ។ គេបាននាំយកនាងចេញទៅ ដៃទាំងពីរត្រូវគេចងដាក់មកក្រោយខ្នង ហើយគេមិនដែលឃើញនាងត្រឡប់មកវិញសោះ ។ ក្រោយមក គ្រួសារនេះដឹងថាគេបានសម្លាប់ មីលីយ៉ា ដោយការចាក់សុសពេញខ្លួនប្រាណ ។

នៅពេលនោះដែរ ប្តីរបស់ ស៊ីសូផា បានធ្លាក់ខ្លួនឈឺ ។ គាត់ឈឺដោយការបរិភោគអាហារមិនគ្រប់គ្រាន់ដូចសមាជិកគ្រួសារគាត់ដទៃទៀតដែរ ហើយខ្លួនប្រាណគាត់ចាប់ផ្តើមហើមស្គុល ហើយស្លាប់នៅយប់នោះ ។ កូនពៅអាយុប្រាំឆ្នាំ ក៏ត្រូវស្លាប់ដោយសារជំងឺហើមប្រហែលនៅជំនាន់នោះដែរ ។ ដោយក្លាយទៅជាស្រីមេម៉ាយដោយគ្មានក្មេងក្នុងបន្ទុក ស៊ីសូផា ត្រូវគេផ្លាស់ឲ្យទៅនៅក្នុងរោងមួយមានសុទ្ធតែស្រីៗ ។ គ្រួសារម៉ៃ បានមកដល់ភូមិភាគពាយ័ព្យនេះកាលពីប្រាំមួយខែមុន ។ នៅកំឡុងឆ្នាំដំបូង គ្រួសារនាងចំនួនដប់មួយនាក់ បានត្រូវស្លាប់ ឬ

បាត់ខ្លួន ។ ឥឡូវនេះ មាននៅសល់តែប្អូននាក់ប៉ុណ្ណោះ ដែលកំពុងរស់នៅឆ្ងាយៗពីគ្នា គ្មានលទ្ធភាពជួយយកអាសាគ្នាទៅវិញទៅមក ដូចដែលពួកគេបានសន្យានឹងគ្នា នៅក្នុងរទេះភ្លើងដែលបើកឆ្ពោះមកបាត់ដំបងឡើយ ។

ប្រហែលនៅពាក់កណ្តាលឆ្នាំ១៩៧៦ បន្ទាប់ពី ស៊ីសូផា ត្រូវបាត់បង់ប្តីរបស់នាងមក ភូមិភាគពាយ័ព្យបានទទួលធ្វើពិធីបដិសណ្ឋារកិច្ចនូវភ្ញៀវស្រីដ៏ខ្ពង់ខ្ពស់ម្នាក់ គឺ អៀង ធីរិទ្ធ ជារដ្ឋមន្ត្រីថ្មីទទួលបន្ទុកក្រសួងសង្គមកិច្ច ដែលគេបានប្រកាសឲ្យដឹងកាលពីខែមេសា ។ អៀង ធីរិទ្ធ ដែលជាអ្នកទទួលខុសត្រូវខ្ពស់បំផុតក្នុងចំណោមសមាជិកគណៈរដ្ឋមន្ត្រីខាងវិស័យសុខាភិបាល សុខុមាលភាពប្រជាជន បានត្រូវបញ្ជូនទៅកាន់តំបន់នោះ តាមសំណើរបស់ ប៉ុល ពត ដើម្បីស៊ើបអង្កេតអំពីទន្ទឹករណ៍ (ការពាលអាង) ផ្សេងៗ ដែលលើកឡើងពីមានស្ថានភាពខ្វះខាតជាច្រើន ក្នុងវិស័យសុខភាពប្រជាជន ម្ហូបអាហារ និងទីជម្រករបស់ពលករ ។

ធីរិទ្ធ បានរកឃើញភស្តុតាងក្នុង«បញ្ហា»នេះយ៉ាងច្រើន សម្រាប់ធ្វើកិច្ចការរបស់នាងបន្តទៅទៀត ។ នាងបាននិយាយថា «ស្ថានភាពផ្សេងៗនៅទីនោះមានលក្ខណៈខុសប្លែកពីគេជាខ្លាំង ។ ខ្ញុំរកឃើញថា "ពួកកម្មាភិបាល" បានបញ្ជូនប្រជាជនទាំងអស់ឲ្យទៅធ្វើការនៅតាមស្រែ ដែលស្ថិតនៅយ៉ាងឆ្ងាយពីភូមិនានា ។ ប្រជាជនគ្មានទីជម្រកសមរម្យស្នាក់នៅ ពួកគេមានសុខភាពទន់ខ្សោយបំផុត ។ ខ្ញុំធ្លាប់ដឹងថា មតិណែនាំផ្សេងៗរបស់នាយករដ្ឋមន្ត្រី [ប៉ុល ពត] គឺហាមមិនឲ្យបញ្ជូនមនុស្សចាស់ ស្ត្រីមានផ្ទៃពោះ ឬស្ត្រីកំពុងមើលថែទាំទារក ក្មេងតូចៗទៅធ្វើការនៅតាមស្រែឡើយ ។ ប៉ុន្តែ ខ្ញុំឃើញប្រជាជនទាំងអស់ធ្វើការពេញៗស្រែ ក្រោមកម្តៅព្រះអាទិត្យមួយ ដែលក្តៅស្ទើរឆេះ ។ មានមនុស្សច្រើននាក់បានធ្លាក់ខ្លួនឈឺដោយជំងឺរាករូស និងគ្រុនចាញ់[២២]» ។

ធីរិទ្ធ នឹងជួបប្រទះស្ថានភាពគួរឲ្យរន្ធត់ស្រៀបគ្នានេះក្នុងផ្នែកផ្សេងៗទៀតរបស់កម្ពុជាប្រជាធិបតេយ្យដែរ ប៉ុន្តែ បេសកកម្មរបស់នាងស្ថិតនៅត្រង់បង្ហាញឲ្យឃើញបញ្ហាទាំងឡាយរបស់ភូមិភាគពាយ័ព្យប៉ុណ្ណោះ ។ នៅពេលត្រឡប់មកក្រុងភ្នំពេញវិញ នាងបានសរសេររបាយការណ៍មួយ ដែលនាងបានបញ្ចប់ខ្លឹមសារ ដោយបញ្ជាក់អះអាងថា កម្មាភិបាលភូមិភាគពាយ័ព្យបានបំពានលើបទបញ្ជាផ្សេងៗ របស់មជ្ឈិមដោយចេតនា ។ តាមការរៀបរាប់បញ្ចូលក្នុងរបាយការណ៍របស់នាង នាងបានឲ្យដឹងថា ដោយគ្មានយកចិត្តទុកដាក់ដោះស្រាយបញ្ហាទាំងឡាយ ដូចជា ស្ថានភាពការងាររលំបាកហួសហេតុ ស្ថានភាពគ្រួសារនីមួយៗ ស្រីមានផ្ទៃពោះ និងពួកក្មេងជំទង់ៗជាដើម ធីរិទ្ធ បានបញ្ចេញប្រតិកម្មដូចសហសេវិករបស់នាងក្នុងគណៈកម្មាធិការមជ្ឈិមដែរ ហើយចាប់ផ្តើមសង្ស័យភ្លាមពីការធ្វើអន្តរាគមន៍របស់ពួកភ្នាក់ងារសត្រូវ ។

នាងបានអះអាងថា «ភ្នាក់ងារជាច្រើនរូបបានជ្រៀតចូលក្នុងជួររបស់យើងរហូតដល់ថ្នាក់ខ្ពស់បំផុត ។ ពួកនោះ បានសម្តែងឲ្យឃើញជាមនុស្សក្បាលពីរ ដើម្បីធ្វើឲ្យយើងជឿថា ពួកគេដើរតាមមាគ៌ាដឹកនាំរបស់យើងដែរ[២៣]» ។

ការស៊ើបអង្កេតរបស់ ធីរិទ្ធ មានរួមបញ្ចូលនូវការឃុបឃិតគ្នាជាសម្ងាត់មួយដែលរៀបចំឡើងដោយ

បណ្ដាមេដឹកនាំក្រុងភ្នំពេញ ដើម្បីទម្លាក់កំហុសទៅលើពួកកម្មាភិបាលនៅភូមិភាគពាយ័ព្យ ចំពោះបរាជ័យជាបន្តបន្ទាប់មួយរបស់បដិវត្តន៍ ។

មជ្ឈិមប្រមូលបាន «ភស្តុតាង» យ៉ាងច្រើនដោយលាតត្រដាងឲ្យឃើញថា ភូមិភាគនេះធ្លាប់ត្រូវពួកភ្នាក់ងារសត្រូវជ្រៀតចូលក្នុងគោលបំណងបំផ្លាញការបដិវត្តន៍មែន ។ បន្ទាប់មក ពួកមេដឹកនាំមជ្ឈិម បានរៀបចំធ្វើការបោសសម្អាតមួយដើម្បីផ្លាស់កម្មាភិបាលដែលធ្លាក់បុណ្យដោយដាក់បក្ខជនកុម្មុយនិស្ដ ដែលគេយល់ឃើញថាមានចិត្តស្មោះត្រង់នឹងក្រុងភ្នំពេញជំនួសវិញ ។ ធីរិទ្ធ ផ្ទាល់បានធ្វើឲ្យអ្វីៗដែលពិបាកដោះស្រាយទៅជាបញ្ហាត្រួតពិនិត្យមួយរបស់បដិវត្តទៅវិញ ៖ «នៅឆ្នាំ១៩៧៦ យើងមិនទាន់បានក្ដាប់អំណាចពេញលេញនៅឡើយ ។ អំណាច គឺស្ថិតក្នុងកណ្ដាប់ដៃបណ្ដាលេខាបក្សភូមិភាគនានា ។ ទោះជាផ្នែកកងទ័ពក៏មិនទាន់ស្ថិតនៅក្រោមការត្រួតត្រារបស់យើងទាំងស្រុងដែរ[៧៤] » ។

ប៉ុន្តែ ព្រឹត្តិការណ៍អាក្រក់នៅភូមិភាគពាយ័ព្យ ពុំមែនបង្កឡើងដោយពួកភ្នាក់ងារសត្រូវដែលចង់ដណ្ដើមអំណាចពីមជ្ឈិមនោះទេ តែនេះជាការខ្វាចបារម្ភសំខាន់បំផុត ដែលទ្រទ្រង់គម្រោងការចម្លែកខុសគេរបស់ការបដិវត្តនេះឯង ។ ភូមិភាគពាយ័ព្យបានក្លាយទៅជាមណ្ឌលនៃនយោបាយ «មហាលោតផ្លោះ» ជាកន្លែងសាកពិសោធន៍គំនិត ឆ្កួតជ្រុលហួសហេតុរបស់របបថ្មី ដើម្បីអនាគត«សង្គមថ្មី»មួយ ។ ប្រវត្តិរបស់គ្រួសារម៉ៃ បង្ហាញឲ្យឃើញ លទ្ធផលចុងបញ្ចប់ថា នេះជាភូមិភាគមួយដែលគ្រប់គ្រងដឹកនាំដោយអំពើភេរវកម្ម និងជាភូមិភាគមួយ ដែលភាពទាក់ទងគ្នាហូរហែក្នុងសង្គមត្រូវបានបំផ្លាញខ្ទេចខ្ទីទាំងអស់ ។

ដោយរឿងនេះក្លាយទៅជារឿងជាក់ស្ដែងក្នុងភូមិភាគពាយ័ព្យ គោលដៅផ្សេងៗផ្នែកសេដ្ឋកិច្ចដែលគ្មានអ្នកណាធ្វើបានរបស់បដិវត្ត មានលក្ខណៈមិនអាចបំបែកចេញពីនយោបាយសង្គមកិច្ចឥតមេត្តារបស់ខ្លួនឡើយ ។ ក្នុងរយៈពេលនៃការផ្លាស់ប្ដូរប្រជាជនលើកទីពីរនេះ «ពួកអ្នកថ្មី» រាប់ពាន់នាក់ត្រូវបានបញ្ជូនទៅកន្លែងឆ្ងាយៗដូចសត្វធាតុ ដើម្បីបំពេញឲ្យភូមិភាគពាយ័ព្យនូវហត្ថពលករយ៉ាងពពាក់ពពូន ដោយគ្មានយកចិត្តទុកដាក់ពីការខ្វះខាតរបស់គេក្នុងការបណ្ដុះបណ្ដាល និងការខ្វះសមត្ថភាពរបស់ភូមិភាគ ដែលត្រូវផ្ដល់ទីជម្រក និងចិញ្ចឹមបីបាច់អ្នកទាំងនោះផងទេ ។ គ្រួសារជាច្រើនត្រូវគេបំបែកចេញពីគ្នាមិនគ្រាន់តែដើម្បីបំបាត់មនោសញ្ចេតនាជាប់ជំពាក់ចិត្តដ៏ជ្រាលជ្រៅមួយប៉ុណ្ណោះទេ ប៉ុន្តែ គឺដើម្បីធ្វើឲ្យប្រាកដថា មនុស្សពេញកម្លាំងទាំងអស់ ដោយរាប់ចូលទាំងកូនក្មេងអាយុប្រាំពីរឆ្នាំ ឬស្រីចាស់អាយុចិតសិបឆ្នាំផង ត្រូវចូលប្រឡូកយ៉ាងពេញទំហឹងក្នុងការងារដែលបង្ខំឲ្យធ្វើដោយបដិវត្តន៍ ។

ដូច្នេះ មជ្ឈិមបានរៀបចំនៅឆ្នាំ១៩៧៦ នូវគម្រោងការមួយក្នុងចំណោមគម្រោងការផ្នែកសេដ្ឋកិច្ចប្លែកខុសគេរបស់ខ្លួន ដែលត្រូវគ្នានឹងការត្រូវការមិនសមហេតុផលជាច្រើន ចំពោះភូមិភាគពាយ័ព្យ ។ នៅដើមឆ្នាំ ក្នុងឱកាសសន្និបាតមួយរបស់បក្ស បណ្ដាមេដឹកនាំបក្សបានសម្រេចថា ដំណាក់កាលទីមួយនៃការបដិវត្តន៍បាន

បញ្ចប់ហើយ ហើយថាប្រទេសកម្ពុជាអាចឆ្លងទៅដំណាក់កាលបន្ទាប់ទៀត គឺបដិវត្តសង្គមនិយម ។ សហករណ៍ក្នុងទូទាំងប្រទេសត្រូវតែផលិតស្រូវឲ្យបានច្រើនជាអតិបរមា ដើម្បីជួយទ្រទ្រង់ដល់ការជំរុញ ល្បឿនបដិវត្តនេះ ។ នៅរដូវក្ដៅ របបកម្ពុជាប្រជាធិបតេយ្យបានវាយតម្លៃថា ការប្រមូលផលឆ្នាំនេះ គឺគ្រប់គ្រាន់ សម្រាប់សម្រុកទៅមុខទៀត ។ ក្នុងបទសម្ភាសន៍មួយជាមួយភ្នាក់ងារពត៌មានវៀតណាមថ្មី ប៉ុល ពត បានប្រកាសថា ការប្រមូលផលនៅខែធ្នូ ឆ្នាំ១៩៧៥ មានសភាព«ល្អណាស់» វាមានការរីកចម្រើន ថែមទាំងជា«មហាជោគជ័យ»ផង ។ គាត់បានសង្កត់បញ្ជាក់ថា ប្រទេសជាតិបានប្រមូលផ្តុំកិច្ចប្រឹងប្រែងទាំងអស់របស់ខ្លួនទៅលើប្រព័ន្ធធារាសាស្ត្រថ្មីមួយ ដែលអាចស្រោចស្រពផ្ទៃដីចំនួន មួយលានហិកតាកន្លះ ។ ប្រការនេះច្បាស់ជាជួយដោះស្រាយ«បញ្ហាទឹក»បាន រួមទាំងស្បៀងអាហារផង និងបម្រើជាឈ្នាន់សម្រាប់ដំណាក់កាលបន្ទាប់ទៀត គឺឧស្សាហូបនីយកម្ម ។

នៅខែសីហា បណ្ដាមេដឹកនាំបក្សបានពឹងផ្អែកជាសំអាងលើគំនិតសុទ្ធិដ្ឋិនិយមដែលគ្មានមូលដ្ឋាននេះ ដើម្បីដាក់ចេញនូវនៅខែមករា ឆ្នាំ១៩៧៧ ផែនការសេដ្ឋកិច្ចមួយសម្រាប់រយៈបួនឆ្នាំ ។ ដើម្បីទ្រទ្រង់កម្មវិធីនេះ ការវាយតម្លៃរបស់ខ្លួនប្រហែលជាផលិតបានដោយភូមិភាគពាយ័ព្យ បូព៌ា និរតី និងភូមិភាគថ្មី គឺបស្ចិម ។ នៅទីបំផុតមជ្ឈិមបានទទួលស្រូវ ប្រហែលមួយរយហាសិបពាន់តោនប៉ុណ្ណោះ ពីភូមិភាគទាំងនោះ ។ មួយចំណែកត្រូវនាំចេញទៅប្រទេសចិន មួយចំណែកទៀត ទុកសម្រាប់ចិញ្ចឹមពួកបុគ្គលិក និងកម្មករនៅភ្នំពេញ ហើយបរិមាណស្រូវមួយចំនួនធំត្រូវបានប្រគល់ទៅឲ្យខាងកងទ័ព ។

ប៉ុន្តែ មជ្ឈិម ត្រូវការបរិមាណស្រូវច្រើនជាងនេះ សម្រាប់នយោបាយ«មហាលោតផ្លោះ»របស់ខ្លួន ។ បដិវត្តខាងសង្គមកិច្ចរបស់ខ្លួន បានធ្វើឲ្យផែនការផ្នែកសេដ្ឋកិច្ចវិនាសហិនហោចដែរ ថ្វីបើគណៈលេខាមជ្ឈិមបក្សមិនដែលទទួលស្គាល់ការពិតជាក់ស្ដែងនេះសោះក៏ដោយ ។ ដោយការរៀបចំ និងការផ្គត់ផ្គង់អាហារមិនល្អពលករទាំងឡាយ ពុំបានផលិតស្រូវគ្រប់គ្រាន់តាមបំណងរបស់មជ្ឈិមឡើយ ។ ប្រព័ន្ធដឹកជញ្ជូនត្រូវខូចខាតស្រូវដែលគេបម្រុងដឹកយកទៅឲ្យបណ្ដាតំបន់ដែលផលិតស្រូវបានតិច ក៏មិនដែលបានទៅដល់ទីនោះដែរ ហើយបណ្ដាភូមិភាគខ្លះ ក៏ខ្វះសន្ទូងសម្រាប់រដូវខាងមុខថែមទៀត ។ (គឺវិបត្តិនេះហើយ ដែលជំរុញឲ្យពួកកម្មាភិបាលនៅមន្ទីរឃុំឃាំងទួលស្លែងបង្ខំឲ្យ បុប្ផាណា និងអ្នករងគ្រោះផ្សេងទៀត ទទួលសារភាពថា ពួកគេជាអ្នកបំផ្លាញការដឹកជញ្ជូនសន្ទូងស្រូវដោយចេតនា ។ ដូច្នេះ គេអាចទម្លាក់ការទទួលខុសត្រូវផ្សេងៗទៅលើពួកសត្រូវ ពុំមែនមកពីនយោបាយរបស់បក្សទេ) ។

នៅខែកញ្ញានាទីក្រុងតូក្យូ អៀង សារី មិនបាននិយាយរឿងនេះប្រាប់សារពត៌មានទេ គឺនិយាយតែពីការនាំស្រូវដែលសល់ទៅប្រទេសក្រៅ ដោយនាំយករូបិយប័ណ្ណបរទេសល្មមគ្រប់គ្រាន់ ដើម្បីផ្ដើមធ្វើយន្តូបនីយកម្មក្នុងវិស័យកសិកម្ម និងបង្កើតរោងចក្រថ្មីៗសម្រាប់កែច្នៃកសិផល ។ តាមការពិត នៅខែតុលា របបនេះបាន

បង្កើតសហគ្រាសពាណិជ្ជកម្មរបស់ខ្លួនផ្ទាល់នៅទីក្រុងហុងកុង ដោយដាក់ឈ្មោះថា ក្រុមហ៊ុន រ៉េន ហ៊ុង (Ren Fung Co., Ltd)[២៥] ។ ក្រុមហ៊ុននេះត្រូវបានបង្កើតឡើងជាមួយនឹងជំនួយ និងលុយកាក់របស់ប្រទេសចិន ដែលគេត្រូវការជាចាំបាច់សម្រាប់ទូទាត់ឥណទានផ្សេងៗ ជារូបិយប័ណ្ណបរទេស ។ តាមរយៈក្រុមហ៊ុននេះ ប្រទេសកម្ពុជាបានទិញគ្រឿងបន្លាស់ សម្រាប់ជួសជុលប្រព័ន្ធដឹកជញ្ជូន និងគមនាគមន៍ រួមទាំងផលិតផលផ្នែកឱសថផង ដែលមានទឹកប្រាក់ចំនួន ២,៨លានដុល្លារ ប៉ុន្តែ លក់ត្រី និងកៅស៊ូទៅឲ្យគេវិញ បានរូបិយប័ណ្ណតែ ៣៥៧.០០០ដុល្លារប៉ុណ្ណោះ ។ ស្រូវទាំងប៉ុន្មានដែល អៀង សារី បានអះអាងនាំចេញនោះ ពុំមាននៅក្នុងបញ្ជីរបស់ក្រុមហ៊ុនទេ ។

នៅដំណាច់ឆ្នាំ ពួកមេដឹកនាំបក្សបានរួមប្រជុំគ្នា ដើម្បីវាយតម្លៃអំពីលទ្ធផលផ្សេងៗរបស់ប្រទេស ។ ភូមិភាគបូព៌ា បានទទួលពិន្ទុល្អប្រសើរជាងគេចំពោះរបៀបរបបការងារ និងការប្រមូលផលរបស់ខ្លួន -សោ ភឹម នៅតែជាលេខាបក្សភូមិភាគប្រសើរជាងគេដដែល ។ ភូមិភាគនិរតី គ្រប់គ្រងដឹកនាំភូមិភាគខ្លួនបានល្អបង្គួរ ប៉ុន្តែ ភូមិភាគពាយ័ព្យ ត្រូវបានគេកត់សម្គាល់ដោយការធ្វើមិនបានសម្រេចជោគជ័យជាច្រើនរបស់ខ្លួន ។

ក្នុងរបាយការណ៍ដំណាច់ឆ្នាំរបស់ខ្លួន មន្ទីរបក្សបានសរសេរថា ៖ «ក្នុងភូមិភាគខ្លះ ជាពិសេស ភូមិភាគពាយ័ព្យ "សមាមាត្រនៃពួកអ្នកថ្មី" មានកម្រិតមួយយ៉ាងខ្ពស់ ។ ពួកអតីតទាហាន និងបុគ្គលិករដ្ឋការសង្គមចាស់ បានជ្រៀតចូលដោយស្ងាត់ៗកាន់មុខតំណែងទទួលខុសត្រូវផ្សេងៗ ក្នុងសហករណ៍ជាច្រើន ។ ចំពោះមូលហេតុនេះ បក្សគ្មានសមត្ថភាពការពារអំណាចមួយឲ្យបានជិតដល់ឡើយ រហូតមកសព្វថ្ងៃនេះ ។ យុទ្ធជន និងយុវជនបដិវត្តមួយចំនួនធំត្រូវបានស្រោលជ្រើស ដើម្បីដឹកនាំសហករណ៍ទាំងនោះ ក្នុងគោលបំណងរារាំងសត្រូវ (គ្មានបញ្ជាក់លក្ខណៈ) មិនឲ្យដណ្ដើមរដ្ឋអំណាចបាន[២៦] » ។

ភាពស្រងាកចិត្តរបស់បក្សចំពោះភូមិភាគពាយ័ព្យ គឺផ្ដោតជាសំខាន់ទៅលើបញ្ហាដឹកនាំធ្វើការងារ ដូចជាការប្រមូលផលស្រូវបានស្តួចស្តើងជាដើម ប៉ុន្តែ សម្ដែងឲ្យដឹងគំនិតខ្លួនតាមន័យនយោបាយ ។ របាយការណ៍ដំណាច់ឆ្នាំ បានធ្វើឲ្យកាន់តែឃើញច្បាស់អំពីការបដិសេធដោយចេតនារបស់បក្ស ដែលមិនព្រមពិនិត្យមើលហេតុការណ៍ខ្លះៗ និងភាពមិនសមស្រមនៃគំនិតទាំងឡាយរបស់ខ្លួន ។ មជ្ឈិមធ្លាប់ត្រូវការភោគផលយ៉ាងច្រើនពីភូមិភាគនេះ ដោយគ្មានផ្ដល់អ្វីធំដុំជាថ្នូរវិញឡើយ ។ ដោយហេតុនេះ នៅពេលដែលកម្រិតជីវភាពប្រជាជនធ្លាក់ចុះ មជ្ឈិមបានកំណត់ការធ្វើមិនបានសម្រេចជោគជ័យនេះថា បណ្ដាលមកពីការអនុវត្តន៍នយោបាយមួយមិនល្អ ៖ «បណ្ដាសមមិត្តខ្លះទំនងជាជឿថា "ពួកអ្នកថ្មី" សុទ្ធតែជាសត្រូវ ដូច្នេះហើយបានជាមិនយកចិត្តទុកដាក់លើកកម្ពស់សតិអារម្មណ៍នយោបាយពួកនេះ មិនដោះស្រាយបញ្ហាផ្គត់ផ្គង់ស្បៀងអាហារឲ្យពួកអ្នកទាំងនោះថែមទៀត ។ នេះគឺជាការភ័ន្តច្រឡំមួយយ៉ាងធំ ពីព្រោះប្រការនេះនឹងមានន័យថា គេពុំបានទាក់ទាញមនុស្សទាំងនោះ ឲ្យចូលរួមនឹងបុព្វហេតុរបស់បដិវត្តឡើយ...[២៧] » ។

សមមិត្តជាច្រើននៅភូមិភាគពាយ័ព្យ បានត្រូវគេស្ដីបន្ទោសព្រមគ្នាព្រោះតែការស្នើសុំយក "ពួកអ្នកថ្មី"

មកដាក់ក្នុងភូមិភាគរបស់គេច្រើនហួសពេក (ទុកណារឿងនេះជាការសម្រេចរបស់មជ្ឈិមក៏ដោយ) ហើយមិនយកចិត្តទុកដាក់ថែទាំអ្នកទាំងនោះឲ្យបានដិតដល់ទៀត ។ តែថា មជ្ឈិមមិនបានបញ្ជូនស្បៀងអាហារ និងថ្នាំពេទ្យភ្លាមៗ ដើម្បីជួយសម្រាលបន្ទុកប្រជាជនដែលកំពុងរស់នៅក្នុងស្ថានភាពដ៏គួរឲ្យរន្ធត់ផងទេ ប៉ុន្តែ បែរជាបញ្ជាឲ្យធ្វើការបោសសម្អាតមួយជាជំនួសទៅវិញ គឺបណ្តេញកម្មាភិបាលចេញទាំងអស់ -នេះជាការបោសសម្អាតលំដាប់ភូមិភាគជាលើកទីពីរ តាំងពីពេលដែលពួកខ្មែរក្រហមបានក្តាប់អំណាចកាលពីមួយឆ្នាំមុន ។ ក្នុងកំឡុងនៃការបោសសម្អាតលើកទីមួយ មជ្ឈិមបានប្រគល់ភារកិច្ចឲ្យភូមិភាគបូព៌ា ចូលរួមធ្វើការបោសសម្អាតអតីតភូមិភាគឧត្តរ ។ លើកនេះ បានស្នើឲ្យពួកកម្មាភិបាលភូមិភាគនិរតី ជួយបោសសម្អាតភូមិភាគពាយ័ព្យម្តង ។

ការដកហូតមុខងាររបស់ពួកអ្នកធ្វើការ បានចាប់ផ្តើមនៅដើមរដូវភ្លៀង បន្ទាប់ពីភូមិភាគពាយ័ព្យបញ្ចប់ការច្រូតកាត់នៅឆ្នាំ១៩៧៦ ។ ដំបូងលេខាបក្សភូមិភាគបានរួមសហការជាមួយ មជ្ឈិម និងកម្មាភិបាលភូមិភាគនិរតី ដើម្បីតាមដាន និងកម្ចាត់ "អ្នកដែលត្រូវគេសង្ស័យ" ត្រឹមកម្រិតថ្នាក់តំបន់សិន ។ មួយឆ្នាំក្រោយមក នៅពេលដែលការបោសសម្អាតត្រូវបញ្ចប់ កងទ័ពរបស់ភូមិភាគនិរតី បានដកហូតតំណែង ឬសម្លាប់ថ្នាក់ដឹកនាំសំខាន់ៗចំនួនសែសិបនាក់ ក្នុងចំណោមពួកមេដឹកនាំសំខាន់ៗនៃភូមិភាគពាយ័ព្យ ព្រមទាំងប្រធានសហករណ៍នានា យ៉ាងសន្ធឹកសន្ធាប់ផង ។

ពួកកម្មាភិបាលដែលទៅពីភូមិភាគនិរតី បានធ្វើឲ្យភ្ញាក់ផ្អើលយ៉ាងខ្លាំងដោយសារតែអ្វីៗ ដែលពួកគេបានស្រាវជ្រាវឃើញ ។ តំបន់ខ្លះៗក្នុងចំណោមតំបន់ទាំងប្រាំបួន របស់ភូមិភាគពាយ័ព្យខ្វះខាតស្បៀងអាហារខ្លាំងមែនទែន រហូតដល់ពួកមេដឹកនាំទាំងនោះត្រូវអត់ខ្លួនឯងដែរ ។ ជាក់ស្តែង មជ្ឈិមបានទាមទារយកចំណែកស្រូវមួយយ៉ាងសម្បើម ពីភូមិភាគនេះក្នុងរដូវច្រូតកាត់លើកដំបូង ប៉ុន្តែ ដោយខ្លាចក្រែងមានគ្រោះថ្នាក់ ធ្វើឲ្យក្រុងភ្នំពេញខឹងក្តៅក្រហាយ ពួកអ្នកទទួលខុសត្រូវនៅតំបន់ទាំងនោះ បានសរសេរចូលក្នុងរបាយការណ៍របស់ខ្លួនពីការប្រមូលផលស្រូវថា បានយ៉ាងច្រើន ហើយបានផ្តល់ស្រូវទៅឲ្យមជ្ឈិមច្រើនជាងភូមិភាគបូព៌ា ដែលសហករណ៍ជាច្រើនមានការរៀបចំល្អប្រសើរជាងខ្លួនទៅទៀត ។

ភូមិភាគពាយ័ព្យ គឺជាភស្តុតាងត្រដរខ្យល់ក៏ដូចគំនិតប្រើអំណាចរបស់បដិវត្តន៍ដែរ -ជម្លៀសប្រជាជនចេញពីទីក្រុងនានា ដើម្បីប្រែក្លាយអ្នកទាំងនោះឲ្យទៅជាកសិករភ្លាមៗ បានត្រូវទទួលបរាជ័យ ។ តាមចម្លើយសាក្សីខ្លះថា អនុលេខាបក្សរបស់ភូមិភាគពាយ័ព្យ បានធ្វើដំណើរត្រាច់ចរគ្រប់ទីកន្លែងក្នុងតំបន់ ដោយស្តីបន្ទោសឲ្យ "ពួកអ្នកចាស់" ថា បានធ្វើបាប "ពួកអ្នកថ្មី" ព្រោះតែគ្នាជាមនុស្សថ្មីមិនសូវប្រសប់ធ្វើការ ប៉ុន្តែ ទង្វើនេះពុំបានជួយគាត់ឲ្យផុតពីគ្រោះថ្នាក់ឡើយ ។ មានតែលទ្ធផលមួយមុខគត់ ដែលមានសារសំខាន់ ។ បើសិនជាមជ្ឈិម និងលេខាបក្សភូមិភាគដទៃទៀត ពិនិត្យមើលវិបត្តិនៅភូមិភាគពាយ័ព្យឲ្យបានល្អិតល្អន់ ដោយគិតទៅដល់ការពិត និងហេតុការណ៍ផ្សេងៗនោះ ពួកគេប្រហែលជាផ្លាស់ប្តូរទាំងស្រុង នូវទស្សនៈបដិវត្តរបស់គេជាមិនខាន ។ អ្វីដែល

ពិតប្រាកដជាងគេក្នុងរឿងនេះ អនុលេខាបក្សភូមិភាគ គឺជាអ្នករងគ្រោះដំបូងម្នាក់ក្នុងចំណោមអ្នករងគ្រោះដំបូងៗ ក្នុងការបោសសម្អាតនៅភូមិភាគពាយ័ព្យ ។

តាមការពិត ពួកកម្មាភិបាលភូមិភាគនិរតី បានឲ្យកងទ័ពរបស់គេកាន់កាប់តំបន់នេះទាំងមូល ។ ការទៅដល់របស់កងទ័ពថ្មីត្រូវបានគេទទួលរាក់ទាក់នៅក្នុងឃុំជាច្រើន ប្រៀបដូចជាអ្នកដែលជួយរំដោះគេឲ្យផុតពីទុក្ខទោសអឺចឹង ។ ស៊ីសូផា បានដំណាលថា កងទ័ពភូមិភាគនិរតី បានសម្លាប់ពួកមេដឹកនាំសហករណ៍របស់នាងដែលអាក្រក់ៗ ចោលទាំងអស់ ។

នាងនិយាយថា "ពួកភូមិភាគនិរតីមានបំណងជួយយកអាសាពួកយើង ឲ្យមានហូបគ្រប់គ្រាន់ ហើយគេសម្លាប់តែពួកកម្មាភិបាលប៉ុណ្ណោះ គេមិនសម្លាប់អ្នក ១៧មេសា ទេ ។ ពួកគេបានសម្លាប់កម្មាភិបាលប្រហែលពីម្ភៃទៅសាមសិបភាគរយ ក្នុងសភាពស្ងាត់កំបាំងបំផុត ។ ពួកកម្មាភិបាលភូមិភាគនិរតី ទំនងជាមានការអប់រំមួយប្រសើរជាងពួកកម្មាភិបាលភូមិភាគពាយ័ព្យបន្តិច អ្នកខ្លះចេះអាន និងចេះអក្សរខ្មែរ ។ ពួកគេបានឲ្យយើងធ្វើការកាន់តែខ្លាំងថែមទៀត ...ម្ភៃម៉ោងក្នុងមួយថ្ងៃ... ដើម្បីរកទឹកប្រើប្រាស់ដោយជីកយ៉ាងជ្រៅទៅក្នុងដី ។ ប៉ុន្តែយើងបានទទួលផលស្រូវលើកទីពីរច្រើនជាងមុនទៅទៀត ហើយយើងមានអង្ករយ៉ាងច្រើនសម្រាប់បរិភោគ ។

ពួកកម្មាភិបាលរបស់ភូមិភាគនិរតី បានទទួលភារកិច្ចធ្វើយ៉ាងណាឲ្យទាល់តែភូមិភាគពាយ័ព្យស្ទុះងើបឡើងវិញ សក្តិសមនឹងកេរ្តិ៍ឈ្មោះរបស់ខ្លួនពីដើម ដូចដែល ប៉ុល ពត ត្រូវការ ព្រោះវាជាតំបន់ដែលមានសំណង់ទំនប់ទឹកធំៗ និងដីស្រែសម្បូរទៅដោយជីវជាតិយ៉ាងខ្លាំង ។ ក្នុងកំឡុងនៃការបោសសម្អាត គេបានដាក់បន្ទុំឲ្យអនុវត្តនូវការកសាងទំនប់ទឹកថ្មីធំៗក្នុងរយៈពេលមួយយ៉ាងខ្លី ដែលចាំបាច់ត្រូវមានពលករជាច្រើនក្រុម ដោយឲ្យធ្វើការម្ភៃបួនម៉ោងលើម្ភៃបួនម៉ោង ការអារកាត់សេចក្តីឆាប់រហ័ស និងការតស៊ូពុះពារយ៉ាងសម្បើមមួយ ។ គម្រោងការទាំងឡាយ ត្រូវបានត្រូវរៀបចំឡើងដោយបណ្តាកម្មាភិបាល ដែលគ្មានបទពិសោធន៍ផ្នែកវិស្វកម្មបន្តិចសោះ ហើយគ្មានសាកសួរពិគ្រោះនឹងកសិករ ដែលធ្លាប់រស់នៅតំបន់នេះផងទេ ។ ការកសាងទំនប់ទឹក ១មករា បានបង្ហាញឲ្យឃើញឧទាហរណ៍ជាក់ស្តែងមួយ នៃលទ្ធផលដែលនាំឲ្យមាការវិនាសអន្តរាយយ៉ាងធំ[២៨] ។

ទំនប់នេះត្រូវបានកសាងឡើងក្នុងភូមិភាគពាយ័ព្យនៅឆ្នាំ១៩៧៧ ។ មជ្ឈិម បានបង្គាប់ថា ត្រូវធ្វើឲ្យបានសម្រេចនៅចន្លោះរដូវច្រូតកាត់ខែមករា និងរដូវស្ទូងនៅខែឧសភា ។ ទំនប់នេះ ត្រូវស្រោចស្រពផ្ទៃដីចំនួន ២០.០០០ហិកតា ។ ក្នុងការស្ថាបនា ស្ទើរតែគ្មានការផ្គត់ផ្គង់ខាងគ្រឿងយន្តឡើយ គ្មាន ប៊ុលដូហ្សែ សម្រាប់ជីកដី គឺមានតែឡាន ពីរ-បីគ្រឿងប៉ុណ្ណោះសម្រាប់ដឹកដី ។ ឃុំទាំងឡាយដែលនៅជុំវិញទីនោះ គេឯតែ"ផ្តល់"អ្នកធ្វើការជាច្រើនក្រុម គឺមនុស្សរាប់ពាន់នាក់ដែលគ្មានជំនាញអ្វីទាំងអស់ ។ ពួកគេធ្វើការដូចហ្វូងស្រមោច ដោយកាប់គាស់ដីជាមួយនឹងចបកាប់ ចបប៉ែល ប៉ុណ្ណោះ ។ ពួកគេខំប្រឹងប្រែងធ្វើការយ៉ាងហួសកម្លាំងពេញ ម្ភៃបួនម៉ោង ដោតអុជចង្កៀងបំភ្លឺធ្វើនៅពេលយប់ទៀត ប៉ុន្តែ ការស្ថាបនានេះ បានចប់សព្វគ្រប់តាមការកំណត់ ។

ហើយនៅរដូវភ្លៀងឆ្នាំ១៩៧៨ ទំនប់នេះបានស្រុតបាក់រលាយខ្ទេចខ្ទី ។ គេធ្លាប់ស្ថាបនាទំនប់ដោយគ្មានប្រឡាយសម្រាប់បង្ហូរទឹកចេញតែអ៊ីចឹង ព្រោះគេយល់ថា អាចកាត់បន្ថយរយៈពេលស្ថាបនាបានពាក់កណ្ដាល ប៉ុន្តែទំនប់នេះ ច្បាស់ជាបាក់រលំមិនខាន នៅពេលដែលមានភ្លៀងធ្លាក់ខ្លាំង និងទឹកជំនន់ ។

ទំនប់ទឹករបស់កម្ពុជាប្រជាធិបតេយ្យស្ទើរតែទាំងអស់ ត្រូវបានស្ថាបនាឡើងតែរបៀបដូចនេះ ។ ក្រោយមក វិស្វករម្នាក់ ដែលបានទៅពិនិត្យមើលប្រព័ន្ធទំនប់ទឹករបស់ពួកខ្មែរក្រហម បានពិពណ៌នាពីការមិនយកចិត្តទុកដាក់ធ្វើតាមក្បួនខ្នាត ក្នុងកម្មវិធីស្ថាបនាទាំងនោះថា «ដោយគ្មានប្រឡាយសម្រាប់បង្ហូរទឹកចេញ គឺគេគ្មានមធ្យោបាយណាមួយ ទប់ទល់នឹងទឹកបានទេ ហើយវាច្បាស់ជាបណ្ដាលឲ្យមានការបាក់ធ្លាយដាច់ជាមិនខាន ។ នៅពេលដែលទំនប់ទឹកបាក់ធ្លាយ ប្រជាជនដែលរស់នៅកៀកនឹងទំនប់នោះមុខជាត្រូវទឹកជន់លិចលង់ទាំងអស់ ។ សំណង់ធារាសាស្ត្រដែលនៅសេសសល់អាចនៅប្រើប្រាស់បាន ដែលគេមិនចាំបាច់ជួសជុលធំដុំឡើយ បើសិនជាសំណង់ទាំងនោះ ធ្លាប់បានស្ថាបនាឡើងដោយត្រឹមត្រូវនៅពេលចាប់ផ្ដើម[២៩]» ។

ប៉ុន្តែ ការពិចារណាបែបនោះ ពុំមានឃើញនៅក្នុងផែនការ«មហាលោតផ្លោះទៅមុខ»របស់របបនេះទាំងក៏គ្មាននៅក្នុងគោលការណ៍ដែលជាគ្រឹះរបស់ខ្លួនដែរ ៖ សតិអារម្មណ៍នយោបាយរបស់ពលករសំខាន់ជាងសមត្ថភាពបច្ចេកទេស ។ វាជាការចំអកដោយឡែកទាំងស្រុងមួយ ក្នុងហេតុការណ៍ដែលពួកខ្មែរក្រហមស្វែងរកគំនិតរបស់គេខាងវិស័យនេះ ក្នុងសម័យរាជាណាចក្រអង្គរ ។ «បើសិនយើងធ្វើម្ចាស់លើទឹកបាន យើងក៏ជាម្ចាស់លើប្រទេសដែរ ។ បើសិនយើងអាចទប់ទឹកជំនន់បាន... ។ ប្រជាជនយើងនឹងក្លាយជាម្ចាស់ទឹក ជាអ្នកទទួលពីពួកអ្នកកសាងរាជាណាចក្រអង្គរ[៣០]» ។

ទុកណាជាពួកខ្មែរសម័យអង្គរ ធ្វើឲ្យបច្ចេកទេសរីកលូតលាស់ ដោយកសាងប្រព័ន្ធធារាសាស្ត្ររឹតតែវិសេសឡើង សម្រាប់ជំនាន់របស់គេក៏ដោយ ក៏ពួកកុម្មុយនិស្តខ្មែរចាត់ទុកថាជាបច្ចេកទេសបន្ទាប់បន្សំដែរ ។ ពួកគេបានសម្រេចបង្កើតប្រព័ន្ធទាសភាពនៅសម័យនេះជាថ្មី ហើយក្រៅពីនេះ មិនជាប៉ុន្មានទេ ។ វិស្វករបញ្ជាក់ថា «សំណង់ទាំងនេះ មានតម្លៃស្មើសឹងការកសាងប្រាសាទពីរ៉ាមីដនៅប្រទេសអេហ្ស៊ីបដែរ ហើយវាជាព្រឹត្តិការណ៍អាក្រក់មួយដូចគ្នា» ។

វិទ្យុភ្នំពេញបានផ្សព្វផ្សាយពីសមិទ្ធិផលទាំងនេះថា ជាមហាជោគជ័យមួយ ដោយបានរៀបរាប់យ៉ាងល្អិតល្អន់ ពីទំហំ ចំនួនហិកតាដែលត្រូវស្រោចស្រព ពីការបង្កើនទិន្នផលស្រូវ ដែលគេសង្ឃឹមទុក ។ ស៊ីសូផា និងប្រជាជនដទៃទៀតនៅភូមិភាគពាយ័ព្យ ត្រូវបានផ្លាស់ពីការដ្ឋានមួយទៅការដ្ឋានមួយ បន្ទាប់មក ត្រូវគេបញ្ជូនឲ្យទៅធ្វើស្រែតាមទីកន្លែងផ្សេងៗ ។

ពួកកម្មាភិបាលរបស់ភូមិភាគនិរតី បានសម្លាប់ប្រធានសហករណ៍អស់ជាច្រើន ដែលចាំបាច់តម្រូវឲ្យគេជ្រើសរើសមេដឹកនាំសហករណ៍ក្នុងចំណោម «ពួកអ្នកថ្មី» ថែមទៀត ។ គេបានស្នើឲ្យ ស៊ីសូផា កាន់តំណែងជំនួស

អ្នករងគ្រោះម្នាក់ក្នុងចំណោមអ្នករងគ្រោះជាច្រើនដែលត្រូវសម្លាប់ ក្នុងការបោសសម្អាតផ្សេងៗ ។ ដូច«ពួកអ្នកថ្មី» ឯទៀតៗ ស៊ីសូផា នៅតែភ្ជូមិកុហកពីប្រភពកំណើតរបស់ខ្លួនជានិច្ច នៅពេលដែលពួកកម្មាភិបាលភូមិភាគនិរតីមកដល់ទីនេះ ។ នាងបន្លំធ្វើបុកជាអ្នកមិនចេះអក្សរ ផ្លាស់ឈ្មោះទៅជា ម៉ាឡា ជាឈ្មោះរបស់នាងមួយដែលសាមញ្ញបំផុត ។ គេបានសាកពិសោធន៍លើរូបនាង ហើយវិនិច្ឆ័យថា ជាមនុស្សល្មមឲ្យគេទុកចិត្តបាន ដើម្បីតែងតាំងនាងឲ្យធ្វើជាមេដឹកនាំពលករមួយក្រុម ។ មុនដំបូង នាងទទួលខុសត្រូវលើមនុស្សមួយក្រុម ដែលមានគ្នា ដប់នាក់ ។ នាងបាននិយាយថា «ខ្ញុំខំប្រឹងធ្វើការយ៉ាងខ្លាំងក្លា ហើយខ្ញុំក៏ឲ្យអ្នកនៅក្នុងក្រុមធ្វើការ ដូចជាខ្ញុំដែរ ។ ពេលនោះ គេបានប្រគល់មនុស្ស សាមសិបនាក់មកឲ្យខ្ញុំមើលខុសត្រូវ បន្ទាប់មកកៅសិបនាក់ ។ ចាប់ពីពេលនោះមកមានក្មេងជំទង់ពីរនាក់អាយុប្រហែល ដប់ប្រាំឆ្នាំ តែងតាមខ្ញុំជាប់ជានិច្ច ដើម្បីដើរមើលគេធ្វើការនៅវាលស្រែ ។ ពួកគេទាំងពីរសុទ្ធតែមានកាន់អាវុធ» ។

ស៊ីសូផា ពុំមែនជា«អ្នកថ្មី»ម្នាក់ដែលគេហៅឲ្យធ្វើការជំនួស «ពួកអ្នកចាស់» ជាអ្នករងគ្រោះដោយការបោសសម្អាតនោះទេ ។ ប៉ុន្តែ «អ្វីៗដែលផ្អែមល្ហែម» ជាមួយពួកកម្មាភិបាលភូមិភាគនិរតី មានរយៈពេលខ្លីបំផុតពីព្រោះមជ្ឈិមពុំបានបន្ធូយការទាមទាររបស់ខ្លួនឡើយ ។ ដំបូងគឺស្រូវ ៖ មជ្ឈិមបានទាមទារស្រូវមួយចំណែកយ៉ាងធំក្នុងការប្រមូលផលលើកទីពីរនេះ ។ ស៊ីសូផា បានរៀបរាប់ថា «ស្រូវរបស់យើង បានចាប់ផ្ដើមរលស់បាត់អស់ ។ ពួកយើងហូបតែកន្ទក់ និងគល់ចេកប៉ុណ្ណោះ ។ គេបានបំភ្លឺប្រាប់ខ្ញុំថា គេបានបញ្ជូនស្រូវរបស់យើងទៅប្រទេសក្រៅហើយ» ។

បន្ទាប់មក ក្រុងភ្នំពេញបានតម្រូវថា ប្រជាជនគ្រប់រូបត្រូវប្រឹងប្រែងធ្វើការឲ្យរឹតតែខ្លាំងក្លាឡើងថែមទៀត ដើម្បីស្ថាបនាទំនប់ទឹកធំៗ ។ នៅពាក់កណ្ដាលឆ្នាំ១៩៧៧ មតិណែនាំថ្មីមួយ បានបង្គាប់ឲ្យធ្វើការកម្ទេចប្រភេទសត្រូវថ្មីមួយទៀត គឺប្រជាជនកម្ពុជាដែលមានដើមកំណើតជាវៀតណាម ។ ក្នុង ចន្លោះពេលនោះ ស៊ីសូផា ចេះលាក់ដើមកំណើតខ្មែរក្រោមរបស់គ្រួសារនាងទាន់ ។ «ពួកគេចាប់ផ្ដើមកាប់សម្លាប់មនុស្សទាំងឡាយណា ដែលមានឈាមជ័រជាវៀតណាម ព្រមទាំងពួកខ្មែរកម្ពុជាក្រោម ។ នៅពេលដំបូង យើងមិនដឹងដោយសារហេតុអីទេ» ។

«ពួកអ្នកថ្មី» ពុំដឹងពីហេតុផលផ្សេងៗ ដែលបិទបាំងពីក្រោយមតិណែនាំសឹងតែទាំងអស់ ដែលដាក់ចេញដោយមជ្ឈិម ចាប់តាំងពីដើមដំបូងនៃការបដិវត្តន៍នៅខែមេសា ឆ្នាំ១៩៧៥មក ។ ពួកអ្នកថ្មីដែលរួចផុតពីការសម្លាប់ យល់ឃើញថា ការបោសសម្អាតនៅភូមិភាគពាយ័ព្យ បាននាំមកនូវភាពធូរស្រាលខ្លះៗ សម្រាប់ពួកគេដែរ ។ ស៊ីសូផា បានបកស្រាយថា «នៅពេលដែលគេប្រគល់ការទទួលខុសត្រូវមកឲ្យយើងកាន់ គ្មានគ្នាយើងណាម្នាក់ត្រូវគេសម្លាប់ទេ ។ នៅក្នុងស្រែពួកយើងខំធ្វើការយ៉ាងពេញទំហឹងគ្រប់គ្នា ។ មានក្មេងកំលោះម្នាក់ និងក្មេងក្រមុំម្នាក់ បានលួចរត់ ខ្ញុំបានតាមចាប់ពួកគេ និងនាំយកមកវិញ ពួកគេពុំត្រូវបានសម្លាប់ទេ ។ បើសិនជា

*ខ្ញុំពុំចាប់មកវិញ អ្នកទាំងពីរច្បាស់ជាត្រូវឈ្លបភូមិសម្លាប់ចោលមិនខាន» ។*

*ដូច្នេះ «ពួកអ្នកថ្មី» បានឈានមកដល់សេចក្ដីភ័យរន្ធត់ក្នុងចិត្តម្ដងម្កាលដែរ ។ មជ្ឈិម ក៏គ្រាន់តែជឿ -ទាំងខុស- ជាបណ្ដោះអាសន្នថា ៖ ដោយបំផ្លាញសត្រូវចាស់ និងកម្ទេចពួកកម្មាភិបាលភូមិភាគ គេអាចធ្វើឲ្យភូមិភាគពាយ័ព្យទទួលបានជោគជ័យជាក់ជាប្រាកដ ។ ប៉ុន្តែ សមមិត្តនារី ម៉ាឡា ឬស៊ីសូផា បានផ្ដល់ភស្ដុតាងផ្ទុយពីនេះ ។ ដូច«ពួកអ្នកថ្មី»ឯទៀតៗ និង«ពួកអ្នកចាស់»មួយចំនួន ពីថ្ងៃនេះទៅនាងមានតែសេចក្ដីស្អប់ខ្ពើមមួយកាន់តែរីកធំឡើងៗ ចំពោះការបដិវត្តន៍ប៉ុណ្ណោះ ។ ភក្ដីភាពរបស់នាងចំពោះសមាជិកខ្លះនៃគ្រួសារនាង ដែលនៅរស់រានមានជីវិត គឺនៅតែមុឹងម៉ាត់ដដែល ។ តាមការពិត គ្រួសារទាំងមូលមានសារសំខាន់ណាស់សម្រាប់រូបនាង ។ នៅទីបំផុតនាងនៅតែប្រកាន់តាមពាក្យសន្យា ដែលនាងបានសច្ចាជាមួយប្អូនប្រុស និងប្អូនស្រីរបស់នាង នៅពេលដែលសមាជិកសេសសល់នៃគ្រួសារម៉ែ បានភៀសខ្លួនចេញទៅដល់ប្រទេសថៃឡង់ដ៏ដោយសុវត្ថិភាព ។*

## «មនុស្សមុខ ស»
## អ្នកនៅរស់ក្រោយពីការសម្លាប់បំបាត់ពូជសាសន៍

*អ្វីដែលធ្វើឲ្យអស់សង្ឃឹមខ្លាំងជាងគេក្នុងកម្ពុជាប្រជាធិបតេយ្យ គឺពួកអ្នកដែលមើលឃើញពូជសាសន៍ ជំនឿចំពោះសាសនា ឬវប្បធម៌របស់គេ ត្រូវជំរុញទៅរកការបំបាត់ចោលឯង ។ សេចក្ដីមានះរបស់ពួកខ្មែរក្រហម ដើម្បីដាក់បង្ខំឲ្យប្រជាជនទាំងអស់ទទួលយកជីវភាពមួយដែលតឹងរឹង អត្តខាត់ និងដែលឯកោដូចៗគ្នានោះ ច្បាស់ជាមានផលវិបាកជៀសមិនរួចឡើយ នៅក្នុងការតម្រូវថា មនុស្សទាំងអស់ត្រូវតែមានលក្ខណៈដូចគ្នាតែមួយ ជាក់ស្ដែង ពលរដ្ឋម្នាក់ៗត្រូវតែជាជនជាតិខ្មែរពិតប្រាកដម្នាក់ ដូចដែលរដ្ឋធម្មនុញ្ញបានកំណត់យ៉ាងច្បាស់លាស់ ។ បេសកកម្មខ្មែរក្រហម ស្ថិតនៅត្រង់ធ្វើឲ្យភាពរុងរឿង និងសេចក្ដីថ្លៃថ្នូររបស់ប្រទេសកម្ពុជារស់ឡើងវិញ ដោយផ្អែករួមទាំងរក្សាពូជសាសន៍ខ្មែរឲ្យស្ថិតស្ថេរចីរកាលតទៅ ដូចសម្ដី ប៉ុល ពត បានប្រកាសពីបញ្ហានេះដោយខ្លួនឯងផ្ទាល់ ។*

*ក្នុងគោលដៅនេះ ពួកខ្មែរក្រហម បានប្រកាន់យកនយោបាយមួយស្ដីអំពីបរិសុទ្ធភាព និងឧត្ដមភាពខាងពូជសាសន៍ ដែលនាំឲ្យគេនឹកឃើញដល់នយោបាយនៅប្រទេសអាល្លឺម៉ង់សម័យណាហ្ស៊ីដែរ រហូតដល់ការពឹងផ្អែកលើការកាប់សម្លាប់បំបាត់ជាតិសាសន៍ដទៃ ដើម្បីកម្ទេចជនជាតិភាគតិចឲ្យរលាយសាបសូន្យ សំដៅធ្វើឲ្យពូជសាសន៍ខ្លួន «សុទ្ធល្អគ្មានលាយ» ។ ម្យ៉ាងទៀត ទស្សនៈស្ដីពីប្រជាជាតិខ្មែរ«សុទ្ធ» គ្មានលាយ មានលក្ខណៈសម្បើមហួសខ្នាត ផ្ដេសផ្ដាសដូចទស្សនៈដែលរៀបចំឡើងដោយពួកណាហ្ស៊ីដែរ ។ ប្រជាជនកម្ពុជា ជាជាតិសាសន៍មួយដែលលាយចម្រុះពូជសាសន៍ជាច្រើន[៣១] -ជាសំខាន់ពូជសាសន៍ ណេហ្គ្រូអ៊ីដ (negroïde) អូស្ត្រាឡូអ៊ីដ*

*(australoïde)* ម៉ាឡេ *(malaise)* និង ម៉ុងហ្គោឡូអ៊ីដ *(mongoloïde)*- ក្រោយមក ពួកនេះបានត្រូវបន្លាត់ដោយពួកអន្តោប្រវេសន៍ អឺរ៉ុប ចិន និងវៀតណាមថែមទៀត ។ ទស្សនៈអំពីពូជសាសន៍ខ្មែរសុទ្ធគ្មានលាយ គឺសំអាងលើការបំប្លែងការពិត ពុំមែនសម្អាងលើកទិន្នន័យវិទ្យាសាស្ត្រទេ ។

ពួកខ្មែរក្រហម បានលាយបញ្ចូលទស្សនៈខាងពូជសាសន៍ជាមួយនឹងទស្សនៈខាងវប្បធម៌ ជំនឿចំពោះសាសនា ភាសា និងប្រជាជាតិ ដូចដែលពួកណាហ្ស៊ី ធ្លាប់បានអនុវត្តរួចមកហើយដែរ ។ ពួកគេបានសម្រេចដោយបំពានថា បណ្ដាជនជាតិភាគតិចនៅកម្ពុជា -ចិន ចាម ថៃ និងបណ្ដាកុលសម្ព័ន្ធភ្នំ ប្រសិនជាមាន- អាចរួមបង្កជាគ្រោះថ្នាក់មួយចំពោះសេចក្ដីសុខសាន្ត និងការគង់វង្សជីវិតរបស់ប្រជាជាតិខ្មែរ ។ ការឆ្លើយតបរបស់គេចំពោះការគំរាមកំហែងនេះ គឺត្រូវប្រកាសឲ្យប្រើច្បាប់មួយ ដោយហាមមិនឲ្យមានជនជាតិភាគតិចទាំងអស់ : «នៅកម្ពុជាមានការបដិវត្តន៍តែមួយប៉ុណ្ណោះ មានប្រជាជាតិតែមួយ និងភាសាតែមួយ គឺភាសាខ្មែរ ។ អំណឹះតទៅ សញ្ជាតិផ្សេងៗ លែងស្ថិតមាននៅកម្ពុជាទៀតហើយ[៣២] » ។

ច្បាប់នេះត្រូវបានអនុវត្តដោយម៉ឺងម៉ាត់ខ្លះៗ និងដោយប្រើមធ្យោបាយហិង្សាផង ដែលមានភាពខុសៗគ្នាទៅតាមភូមិភាគនានា ។ ក្នុងតំបន់ខ្លះ គេបានចូលរួមមើលការកាប់សម្លាប់ និងកម្ទេចជាតិសាសន៍ដទៃផ្ទាល់ភ្នែក ។ ក្នុងតំបន់ខ្លះទៀត ពួកជនជាតិភាគតិចត្រូវគេអនុញ្ញាតឲ្យរស់នៅក្នុងសហករណ៍នានាបាន លុះណាតែអ្នកទាំងនោះលះបង់ ភាសា សាសនា និងទំនៀមទម្លាប់ របស់គេ ។ ពួកខ្មែរក្រហម បានបង្កើតសំណួររបៀបបណ្ដៅមួយថា តើខ្មែរពិតប្រាកដម្នាក់មានលក្ខណៈដូចម្ដេច? ចំពោះសំណួរនេះ អ្នកទាំងនោះអាចត្រឹមតែឆ្លើយរបៀបបដិសេធប៉ុណ្ណោះ ។ អ្នកណាក៏ដោយដែលពុំមាន«បុគពា»ជាខ្មែរ ពុំមាន«អាកប្បកិរិយា»របៀបជាខ្មែរ និងពុំនិយាយភាសាខ្មែរ គឺជាមនុស្សដែលគេសង្ស័យ ។

នេះគឺជាប្រវត្តិរបស់ជនជាតិភាគតិចចិនម្នាក់ ដែលរួចផុតពីការកាប់សម្លាប់បំបាត់ជាតិសាសន៍ ប្រឆាំងនឹងពូជសាសន៍ដទៃដែលគេមិនត្រូវការ ។

សង្កាត់ផ្សារចាស់ ស្ថិតនៅចំកណ្ដាលបេះដូងទីក្រុងភ្នំពេញ ជាតំបន់ជំនួញមួយដែលមានជនជាតិចិនមួយភាគធំរស់នៅតាំងពីដើមមក ។ ជនជាតិចិនទាំងនោះ បានធ្វើឲ្យប្រជាជនកម្ពុជាស្អប់ខ្ពើមច្រណែន និន្ទា និងខ្លាចញញើតចំពោះការចូលចិត្តធ្វើការងាររបស់ពួកគេ ។ គឺពួកនេះហើយ ដែលធ្លាប់កោរប្រជាកសិករមិនដាក់ទឹកប្រមូលស្រូវស្តុកទុកសម្រាប់តម្លើងថ្លៃ ដោយទាមទារយកអត្រាប្រាក់ចំណេញយ៉ាងខ្ពស់ ដែលធ្វើឲ្យជីវភាពគ្រួសារជាច្រើនធ្លាក់ដុនដាបនៅទីក្រុង ក៏ដូចនៅជនបទដែរ ។ ផ្សារចាស់ គឺជាប្រភេទបុរីមួយដែលត្រូវបានការពារ ដែលនៅដាច់ដោយឡែកពីគេទាំងភាសា និងទំនៀមទម្លាប់រហូតមកដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។

កាលនោះ ហ្វូងទ័ពខ្មែរក្រហម បានសម្រុកចូលស្រ ទប់មិនឈ្នះសំដៅទៅរកពួកចិនទាំងនោះ ជាពិសេសអ្នកជំនួញវ័យក្មេងម្នាក់ឈ្មោះ ហាន់ គាវ[៣៣] អាយុសាមសិបមួយឆ្នាំ ដែលរៀបការរួច និងជាឪពុកទារកម្នាក់ ។

គាត់ធ្លាប់រស់នៅធំធាត់នៅជុំវិញផ្សារចាស់នេះ ក្នុងចំណោមហាងលក់ទំនិញជាច្រើន ដែលតាំងបង្ហាញក្នុងកញ្ចក់របស់ខ្លួននូវដើមរុក្ខជាតិឱសថដាំក្នុងផើងពីកែវ ឬផែនទីប្រាប់ពីតួខ្លួនមនុស្ស ដែលត្រូវចាក់ម្ជុលវិទ្យាសាស្ត្រ និងស្លាក មានសរសេរចិន្តានុលេខចិនថែមទៀត ។ គាត់ទើបនឹងស្គាល់កងទ័ពខ្មែរក្រហមច្បាស់នៅពេលនេះ ដែលមកគោះទ្វារផ្ទះរបស់គាត់ និងបញ្ជាឲ្យគាត់ចាកចេញពីផ្ទះជាបន្ទាន់ ។ តាវ បានសួរទៅវិញដោយនិយាយខ្មែរប៉ែឡាំថា តើចេញទៅទីណា? កងទ័ពនោះឆ្លើយថា «ទៅភូមិកំណើតរបស់អ្នកឯង» ។

ភូមិកំណើតរបស់ តាវ ទីកន្លែងកំណើតរបស់ជីដូនជីតាគាត់ ស្ថិតនៅប្រទេសចិនភាគខាងត្បូងឯណោះ ហើយជនបទរបស់កម្ពុជាជាកន្លែងដែលគាត់មិនធ្លាប់ស្គាល់ទាំងស្រុង ។ ដូច្នេះ គាត់បានធ្វើដំណើរឆ្ពោះទៅភូមិភាគនិរតី ជាតំបន់របស់កងទ័ពនោះ ។ តាវ និងប្រពន្ធគាត់បាននាំយកទៅជាមួយខ្លួន នូវទ្រព្យសម្បត្តិបន្តិចបន្តួចដែរ តាមការទទូចរបស់យុទ្ធជនខ្មែរក្រហមនោះ ប៉ុន្តែអ្នកទាំងពីរ បានលាក់មាសក្នុងសម្លៀកបំពាក់ផ្សេងៗរបស់ពួកគេយ៉ាងប្រយ័ត្នប្រយែង ។ បន្ទាប់មក ពួកគាត់បានចាកចេញពីផ្ទះ ហើយបានដើរទៅចូលក្នុងក្បួនមនុស្សឯទៀតៗ ដែលកំពុងដើរយឺតៗឆ្ពោះទៅទីដៅមួយ ដែលគេមិនទាន់ដឹងនៅឡើយ ។

សេចក្តីសង្ឃឹមរបស់អ្នកទាំងពីរស្ថិតនៅជាប់ជាមួយពួកគេជានិច្ច ។ ភូមិភាគនិរតី ជាភូមិភាគមួយ ក្នុងចំណោមភូមិភាគជាច្រើន ដែលមានការរៀបចំគ្រាន់បើជាងគេ ក្នុងការទទួល«ពួកអ្នកថ្មី»ឲ្យស្នាក់នៅ នៅពេលដំបូងនៃការបដិវត្តន៍ ។ មិនឆ្ងាយប៉ុន្មានពីទីក្រុងភ្នំពេញ តាវ និងគ្រួសារ ត្រូវបានសហករណ៍មួយក្នុងខេត្តកំពង់ស្ពឺទទួលយល់ព្រមឲ្យស្នាក់នៅ ។ ពួកអ្នកកាន់អំណាចនៅទីនោះ បានចាត់បញ្ចូលពួកគេទៅក្នុងប្រភេទ«សមាជិកបញ្ញើ» និងបញ្ជូនឲ្យទៅនៅចុងភូមិជាប់ព្រៃភ្នំ ។ នៅកន្លែងនោះ ពួកអ្នកភូមិបានសង់ទីជម្រក ដែលធ្វើឲ្យតែបានៗជាច្រើន ហើយ តាវ បានរស់នៅក្នុងជម្រកមួយក្នុងរយៈពេលពីរខែ ដើម្បីប្រតិបត្តិតាមប្រភេទមនុស្សដែលគេដាក់ឲ្យរស់នៅឆ្ងាយពីគេឯងទាំងផ្នែកនយោបាយ និងសេដ្ឋកិច្ច ដោយរង់ចាំបញ្ចេញសមត្ថភាពផ្សេងៗរបស់ខ្លួន ។

គាត់ដឹងខ្លួនថាអស់សង្ឃឹមរលីង ។ គ្មានអ្វីមួយដែលធ្វើឲ្យគាត់ស្រឡះក្នុងអារម្មណ៍សោះ ទាំងទេសភាពស្ងប់ស្ងាត់ និងក្រៀមក្រោះ ទាំងចង្វាក់ជីវភាពប្រចាំថ្ងៃនៅជនបទ ព្រោះគាត់ត្រូវក្រោកមុនព្រះអាទិត្យរះ ទៅធ្វើការរហូតទាល់តែព្រះអាទិត្យលិច ។ តាវ ពុំធ្លាប់ដែលរស់នៅដោយគ្មានរបស់របរចាំបាច់សម្រាប់ប្រើប្រាស់ដូច្នេះឡើយ ដូចជា មុង ទឹក សាប៊ូ គ្រែដេក និងពេលបាយទៀងទាត់ ។ គាត់មិនដែលធ្វើការហត្ថកម្ម ហើយខ្លួនប្រាណសម្តើងរបស់គាត់ គ្មានសាច់ដុំដូចកម្មករម្នាក់ឡើយ ។ ប៉ុន្តែ គាត់យល់ថា គាត់ត្រូវតែសម្របខ្លួនឲ្យបានឆាប់រហ័ស និងមិនត្រូវត្អូញត្អែរអ្វីទាំងអស់ ។ គេបានរំឭកប្រាប់គាត់ជារឿយៗថា គាត់ជាចំណែកមួយនៃវណ្ណៈនាយទុន កុំប្រាជ័រ ។

ចំពោះពួកអ្នកបដិវត្តយល់ថា ក្នុងករណីពួកជនជាតិចិន ពូជសាសន៍ និងវណ្ណៈ មានលក្ខណៈមិនអាចរំលាយ

បានឡើយ ។ តាវ បានត្រូវធ្វើឲ្យធ្លាប់ខ្លួននឹងការចំអកបញ្ឈឺចិត្តរើសអើងជាតិសាសន៍ដោយមានការយល់ព្រមខាងនយោបាយរបស់របបថ្មីផង ។ គេបានចាត់ទុកគាត់ជា “មនុស្សល្មោភស៊ី” (ដែលរកតែម្ហូបឆ្ងាញ់) “មនុស្សមុខ ស” នាយទុនចិន ។ គេបាននិយាយច្រំដែលៗប្រាប់គាត់ថា ជោគជតាបានប្រែក្រឡាប់ហើយ អ្នករងគ្រោះពីការយកការប្រាក់ហួសកំណត់របស់សមាគមន៍គាត់ពីថ្ងៃនេះទៅ បានក្លាយទៅជាអ្នកមានឋានៈខ្ពស់បំផុត នៅពេលដែលគាត់ និងពួកចិនដទៃទៀត បានធ្លាក់ដល់កម្រិតក្រោមបំផុត ។ គាត់បាននិយាយរៀបរាប់ថា “ពួកយើងមានសិទ្ធិហូបតែបបររាវកក្លូក យើងជាអ្នកចុងក្រោយគេដែលត្រូវទទួលសម្លៀកបំពាក់ ។ ពួកកម្មាភិបាលបានគំហកឲ្យយើងថា ពួកឯងសុទ្ធតែជាពួកនាយទុនចិន អ្នកឯងពុំចាំបាច់យកខោអាវទេ ។ គេជេរប្រទេចយើង គេចាត់ទុកយើងជា“ពួកមុខស” ។

មនុស្ស“មុខស”ទាំងនេះ ត្រូវតែបង្ហាញភស្តុតាងឲ្យឃើញថា ពួកគេមានបំណងក្លាយខ្លួនទៅជាជនជាតិខ្មែរពិតៗ ហើយលក្ខណៈវិនិច្ឆ័យសំខាន់គឺត្រូវនិយាយតែភាសាខ្មែរប៉ុណ្ណោះ ។ ក្នុងតំបន់ខ្លះ ការនិយាយភាសាចិន ឬការសម្ញែងវប្បធម៌របស់ចិនតាមរូបភាពណាមួយក៏ដោយ ក៏អាចទទួលរងនូវការផ្ដន្ទាទោស ដល់ប្រហារជីវិតដែរ ។ តាមចម្លើយសាក្សីជាច្រើនបានឲ្យដឹងថា មានសមាជិកជនជាតិភាគតិចចិនមួយចំនួន បានប្រថុយប្តូរជីវិតគ្មានខ្លាចស្លាប់ ដោយហ៊ាននិយាយភាសាចិនទៅរកគណៈប្រតិភូ ដែលមកពីទីក្រុងប៉េកាំង ។ ពួកអ្នកជំនាញការនិងពួកទីប្រឹក្សាចិនរាប់រយនាក់ ហើយថែមទាំងរាប់ពាន់នាក់ផង បានធ្វើដំណើរមកប្រទេសកម្ពុជា ប៉ុន្តែ ពួកចិនប៉េកាំងដែលបានជួបប្រាស្រ័យជាមួយអាណិកជនចិននៅកម្ពុជា បានប្រកាន់អាកប្បកិរិយាហាក់ដូចជា ពួកគេគ្មានចំណងទាក់ទងខាងពូជសាសន៍ ឬវប្បធម៌ជាមួយពួកចិននៅកម្ពុជាទាល់តែសោះ ។ នៅពេលដែលពួកចិនកាត់ខ្មែរ ប៉ុនប៉ងនិយាយទៅរក “បងប្អូន” ដែលមកពីប្រទេសចិនថា បដិវត្តកម្ពុជាបានធ្វើទុក្ខបុកម្នេញមកលើពួកខ្លួន ពួកគេបានត្រូវឃាត់ឃាំងដោយពួកកម្មាភិបាលខ្មែរក្រហមជាបន្ទាន់ ហើយបានយកទៅសម្លាប់ចោល ឬត្រូវប្ដឹងឲ្យការណ៍ដោយពួកភ្ញៀវប៉េកាំង ដែលមកធ្វើទស្សនកិច្ចផ្ទាល់ ។

ពួកកុម្មុយនិស្តកម្ពុជា បានធ្វើសកម្មភាពជាចំហរស្ដីពីការព្រួយបារម្ភដ៏ជ្រាលជ្រៅខាងជាតិសាសន៍របស់ប្រទេស ដើម្បីធ្វើឲ្យការភ័យខ្លាចក្លាយទៅជាការស្អប់ខ្ពើមរកទីបំផុតគ្មាន ។ ដូចរដ្ឋាភិបាល លន់ នល់ ដែរ ពួកអ្នកបដិវត្តបានឃ្លាំមើលការសម្លាប់ជនជាតិវៀតណាមយ៉ាងច្រើន ក្នុងរយៈពេលសង្គ្រាម ប៉ុន្តែ ការសម្លាប់រង្គាលរបស់ពួកខ្មែរក្រហមបានប្រព្រឹត្តទៅដោយសម្ងាត់បំផុត ។ បន្ទាប់ពីសង្គ្រាមនយោបាយដដែលនេះ ដែលជួយគាំទ្រដោយគំនិតរបស់ប្រជាជនកម្ពុជាក្នុងការប្រយុទ្ធតស៊ូ“រំដោះជាតិ” បាននាំទៅដល់ការសម្លាប់បំផុតពូជ ដែលធ្វើឲ្យពួកចាមកាន់សាសនាអ៊ីស្លាមភ័យបារម្ភពីការរលាយពូជសាសន៍របស់ខ្លួន និងបង្កឲ្យមានមនុស្សក្នុងសហគមន៍ជនជាតិចិននៅទីក្រុងស្លាប់អស់ជិតពាក់កណ្តាល ។ នយោបាយនេះ ត្រូវបានដាក់ចេញឲ្យអនុវត្តក្នុងទូទាំងប្រទេស ៖ ភូមិភាគបូព៌ា និងនិរតីទទួលខុសត្រូវលើការកាប់សម្លាប់ជនជាតិចាម ភូមិភាគនិរតី និងបស្ចិម

ធ្វើទុក្ខបុកម្នេញលើជនជាតិថៃ ភូមិភាគទាំងអស់ត្រូវយាយីរំខានជនជាតិចិន ។ បញ្ហាបរិសុទ្ធភាពខាងពូជសាសន៍ប្រហែលដើរទន្ទឹមគ្នានឹងភាពខ្ពង់ខ្ពស់លើសគេ ដែលពួកខ្មែរក្រហមវាយតម្លៃថា មានលើពួកកុម្មុយនិស្ត និងប្រទេសដទៃៗទៀត ដូចដែល ប៉ុល ពត បានអះអាងពីរឿងនេះថា ការបដិវត្តត្រូវដឹកនាំធ្វើ «ដោយអនុលោមទៅតាមចរិតពិតប្រាកដរបស់វណ្ណៈកម្មករ ៣៨» និង «ដើម្បីធានាឲ្យពូជសាសន៍ខ្មែរស្ថិតស្ថេរជាស្ថាពរទៅ» ។

មតិណែនាំផ្សេងៗដែលបញ្ជូនទៅគ្រប់ភូមិភាគបានចែងពីខសំខាន់មួយថា ភាសាខ្មែរ ជាភាសាតែមួយគត់របស់កម្ពុជាប្រជាធិបតេយ្យ ថាសញ្ជាតិរបស់ជនជាតិភាគតិច «លែងមានអត្ថិភាព» ទៀតហើយ មានន័យថាសមាជិករបស់ជនជាតិទាំងនោះត្រូវធ្វើការជ្រើសរើសរវាងការរួមបញ្ចូលជាតិសាសន៍ខ្លួន ដែលជួនកាលមានប្រើកម្លាំងផង ដើម្បីចូលក្នុងសហគមន៍ជាតិខ្មែរ និងការប្រហារជីវិតបង់ ។ កម្មាភិបាលខ្មែរក្រហមខ្លះ បានបកស្រាយច្បាប់នេះថា ជាការអនុញ្ញាតឲ្យគេកាប់សម្លាប់ជនជាតិភាគតិចទាំងអស់ ។ (ការសាកល្បងទាំងឡាយរបស់ស្តាលីន ដើម្បីដាក់បន្ទុំឲ្យធ្វើខស្សរាហូបនីយកម្មមួយលឿនរហ័សនៅសហភាពសូវៀតនោះ ក៏ធ្លាប់អនុញ្ញាតឲ្យសម្លាប់បណ្តាជនជាតិភាគតិច យ៉ាងសាហាវរបៀបនេះដែរ) ។

ក្រោមរបបខ្មែរក្រហម ការគិតមមៃតែអំពីបរិសុទ្ធភាពខាងពូជសាសន៍ បាននាំទៅដល់ការលុបបំបាត់ចោលអាពាហ៍ពិពាហ៍ជាមួយជនបរទេសថែមទៀត ។ ក្រៅពីនោះ ទុកណាជាពួកមេដឹកនាំជាន់ខ្ពស់ ក៏ត្រូវបង្ខំចិត្តទុកប្រពន្ធរបស់ពួកគេជាសញ្ជាតិបារាំងនៅឯប្រទេសបារាំងដែរ ។ ស្រីជប៉ុនដែលជាប្រពន្ធជនជាតិខ្មែរម្នាក់បានរួចផុតពីគ្រោះថ្នាក់នេះ ។ ស្វាមី ឬភរិយាជនជាតិបរទេសជាច្រើនទៀត ដែលគេរកឃើញនៅដើមដំបូងនៃការបដិវត្ត ត្រូវបានបណ្តេញចេញពីប្រទេសដំណាលគ្នា នឹងពួកបរទេសដែលរត់ទៅជ្រកនៅស្ថានទូតបារាំងដែរ ។ អាណិកជនវៀតណាម ក៏ត្រូវបណ្តេញចេញដែរ ហើយភាគច្រើនបានត្រឡប់ទៅវៀតណាមខាងត្បូងមុនដំណាចឆ្នាំ១៩៧៥ ។

តាវ បានរួចផុតពីសេចក្តីស្លាប់ ដោយជ្រៀតជ្រកខ្លួនយ៉ាងប្រសប់ក្នុងចន្លោះខបាយកលបញ្ឆោតផ្សេងៗ និងដោយបញ្ចេញសេចក្តីស្វាហាប់មួយប្លែកខុសពីធម្មតា ។ គាត់មិនដែលថ្ងូរត្អូញត្អែរ មិនដែលតបតទៅនឹងការជេរប្រមាថឡើយ ។ បន្ទាប់ពីការរស់នៅឆ្ងាយពីគេពីឯងអស់រយៈពេលពីរខែ គេបានអនុញ្ញាតឲ្យគាត់ចូលមករស់នៅក្នុងភូមិវិញ ជាកន្លែងដែលគាត់រៀនស្គាល់ដឹងពីការរស់នៅរបស់កសិករបដិវត្ត ។

ក្រោកនៅមុនព្រះអាទិត្យរះ តាវបានចេញដំណើរទៅកាន់ស្រែនៅម៉ោងបួនភ្លឺ ដើម្បីធ្វើការជាមួយក្រុមរបស់គាត់ ។ បីម៉ោងក្រោយមក នៅពេលដែលព្រះអាទិត្យចាប់ផ្តើមរះក្រហមព្រាងៗនៅជើងមេឃ អ្នកធ្វើការទាំងអស់ បានទទួលបបរមួយកូនចានជាជំនួសអាហារពេលព្រឹក ។ ពួកគេចាប់ផ្តើមធ្វើការឡើងវិញ និងឈប់សម្រាកយ៉ាងយូរនៅពេលថ្ងៃត្រង់ ហើយវិលត្រឡប់ទៅស្រែវិញនៅម៉ោងបួនល្ងាច ធ្វើការរហូតដល់ម៉ោង៧ ឬ ៨យប់ ។ តាវ មានអារម្មណ៍ថា ខ្លួនគាត់ធាត់ឡើងរួញ ស្បែកសស្លាំងរបស់គាត់ប្រែទៅជាពណ៌ក្រម៉ៅ ។ ប្រពន្ធ

របស់គាត់ក៏ប្រែសភាពដូចជារូបគាត់ដែរ ។ គេបានបញ្ញត្តិពេលម៉ោងធ្វើការមួយឲ្យនាងធ្វើ ដែលនឿយលំបាកស្មើរបាក់ចង្កេះ ក្នុងក្រុមនារីមួយក្រុម ជួនកាលនាងត្រូវភ្ជួររាស់ ជួនកាលគេឲ្យនាងជីកប្រឡាយ ឬដាំបន្លែសម្រាប់សហករណ៍ ។ តាវ និងប្រពន្ធរបស់គាត់ បានជួបមុខគ្នាតែនៅពេលយប់ជ្រៅប៉ុណ្ណោះ ហើយពេលនោះ គេទាំងពីរបានរៀបចំបរិភោគអាហារពេលល្ងាចរួមជាមួយគ្នា -នៅឆ្នាំដំបូង ស្បៀងអាហារត្រូវគេបែងចែកតាមកម្រិតកំណត់ ប៉ុន្តែបណ្ដាសមាជិកក្នុងគ្រួសារមួយ អាចនៅបរិភោគរួមគ្នាបាននៅឡើយ ហើយអាចប៉ះប៉ូវរបបអាហារបន្ថែមទៀត ជាមួយនឹងអ្វីដែលគេអាចរកបាន ។

«ស្បៀងអាហារមានសភាពខ្វះខាតយ៉ាងខ្លាំង យើងបានលួចបេះផ្លែឈើខ្លះៗដូចជាចេក មើមដំឡូងជាដើម ។ ក្នុងចំណោមយើង មានមនុស្សជាច្រើនចាប់កើតជំងឺគ្រុនចាញ់ ពីព្រោះយើងសុទ្ធតែគ្មានមុងដេក ។ កាលនៅភ្នំពេញ គេមិនអនុញ្ញាតឲ្យយើងយកអ្វីមកតាមខ្លួនទេ ប៉ុន្តែ ខ្ញុំបានលាក់ក្នុងខោអាវរបស់ខ្ញុំនូវមាសប្រាក់និងវត្ថុមានតម្លៃជាច្រើន ហើយយើងបានរួចផុតពីសេចក្ដីស្លាប់» ។

តាវ និងគ្រួសាររបស់គាត់បានរស់រានមានជីវិត ដោយសារកំណប់ទ្រព្យសម្ងាត់នេះ ក្នុងរយៈពេលប្រាំបួនខែដំបូង ។ ផ្សារងងឹតបានរីកដុះដាលទូទាំងប្រទេស ថ្វីបើទីផ្សារគ្រប់ប្រភេទត្រូវគេបំបាត់ចោលក៏ដោយ ។ «ពួកអ្នកថ្មី» បានយកមាស សម្លៀកបំពាក់ល្អៗ នាឡិកាដៃ និងវត្ថុមានតម្លៃផ្សេងទៀត ទៅដោះដូរជាមួយមាន់ អង្ករ បន្លែ ឬថ្នាំ អាស្ពីរីន ។ ភូមិរបស់ តាវ បានធ្លាក់ក្នុងកណ្ដាប់ដៃខ្មែរក្រហមតាំងពីឆ្នាំ១៩៧០ ហើយបានរៀបចំជាកងការងារនៅឆ្នាំ១៩៧៣ ។ នៅឆ្នាំ១៩៧៥ ភូមិនេះត្រូវបានវាយតម្លៃថា ជាសហករណ៍មួយដែលមានការរៀបចំរឹងមាំជាងគេក្នុងចំណោមសហករណ៍នានារបស់ភូមិភាគនិរតី ។ ដោយទុកចិត្តលើខ្លួនឯង បណ្ដាមេដឹកនាំសហករណ៍របស់គាត់ បានបញ្ចេញបុកពាឈ្លើយខុសគេមួយមិនសូវខុសពីពួកមេដឹកនាំជាច្រើនដទៃទៀតឡើយ ។ ពួកគេច្រើនមានប្រតិកម្មតឹងរ៉ឹង ប៉ុន្តែ គេអាចប្រមាណដឹងមុនបាន ។ តាវ បានរៀបរាប់ថា «ខ្ញុំខំធ្វើការតាមដែលពួកមេដឹកនាំទាំងនោះនិយាយប្រាប់ខ្ញុំ ។ ពួកគេបានធ្វើបាបខ្ញុំ ចាត់ទុកខ្ញុំជាសត្វតិរច្ឆាន ជាមនុស្សកម្ជិល ប៉ុន្តែខ្ញុំខំធ្វើការ ទៅតាមពួកគេបាននិយាយប្រាប់ខ្ញុំទាំងអស់ ខ្ញុំក៏បានរួចពីគ្រោះថ្នាក់» ។

«ពួកអ្នកថ្មី» ដែលចិញ្ចឹមជីវិតដោយរបបអាហារបន្តិចបន្តួច និងមិនធ្លាប់ធ្វើការងារប្រភេទនេះបានទទួលរងនូវការបរិភោគមិនគ្រប់គ្រាន់ និងជំងឺតម្កាត់ញឹកញាប់ជាង «ពួកអ្នកចាស់» ។ ពួកអ្នកថ្មី ដែលស្ទើរតែមិនហ៊ានចូលសុំថ្នាំពេទ្យ បានត្រូវស្លាប់ដោយជំងឺរាករូស មួល គ្រុនចាញ់ គ្រុនពោះវៀន ។ ជំងឺបានឆ្លងរាលដាលខ្លាំងមែនទែន រហូតទាល់តែពួកខ្មែរក្រហម ធ្វេចភ្នែកបំពាននយោបាយឯករាជ្យម្ចាស់ការដ៏មានតម្លៃរបស់ខ្លួន ដោយបានស្នើសុំថ្នាំ ដេ.ដេ.តេ. ពីអង្គការមនុស្សធម៌អាមេរិកាំងមួយ ដើម្បីយកមកប្រឆាំងនឹងសត្វមូស ដែលជាភ្នាក់ងារចម្លងជំងឺគ្រុនចាញ់ ។ នៅឆ្នាំដដែលនោះ កូនប្រុសរបស់ តាវ បានធ្លាក់ខ្លួនឈឺ ហើយគាត់បានឈប់ធ្វើការមួយព្រឹក ដើម្បីយកមាសទៅដូរជាមួយថ្នាំពេទ្យ ។ ប្រធានសហករណ៍បាននិយាយនឹងគាត់ថា ក្នុងឋានៈអ្នកឯងជា

«នាយទុនសក្តិភូមិ អ្នកឯងពុំមានសិទ្ធិប្រើថ្នាំពេទ្យទេ» ។

រដូវចម្រូតបានមកដល់ តាវ លែងមានពេលគិតព្រួយបារម្ភពីបទល្មើស និងកំហុសរបស់គាត់តទៅទៀតហើយ ។ នៅជំនាន់នោះ «ពួកអ្នកថ្មី» មួយចំនួនធំ បានត្រូវគេផ្ទេរចេញពីភូមិភាគនិរតីទៅភូមិភាគពាយ័ព្យ ហើយសហករណ៍របស់ តាវ ក៏ត្រូវខ្វះកម្លាំងមនុស្សធ្វើការ ។ ប្រពន្ធរបស់គាត់ និងគាត់ខំធ្វើការងាររាល់ថ្ងៃ ដែលមានថិរវេលាកាន់តែវែង ហើយរឹតតែបាត់បង់កូនរបស់ខ្លួនដែលឈឺថែមទៀត ។ តាមធម្មតា កូនរបស់គាត់តែងប្រគល់ទៅឲ្យមនុស្សវ័យចាស់របស់សហករណ៍ជាអ្នកមើលថែទាំក្នុងពេលថ្ងៃ ។ តាវ បាននិយាយថា «ប៉ុន្តែ នៅរដូវចម្រូតលើកដំបូងនេះ ពួកស្ត្រីចំណាស់ៗ ត្រូវតែក្រោកមុនពេលព្រឹកទៅធ្វើការនៅឯស្រែដូចគេឯងដែរ ។ កូនក្មេងជាច្រើនត្រូវគេទុកចោលគ្មានអ្នកណាថែទាំឡើយ ។ នៅទីនេះ ពុំសូវមានមនុស្សសម្រាប់មើលក្មេងៗទេ» ។

ការប្រមូតកាត់លើកនេះទទួលបានផលស្រូវយ៉ាងច្រើនក្នុងតំបន់របស់តាវ ហើយគាត់សង្ឃឹមថា ជីវភាពរស់នៅ នឹងបានធូរស្រាល ។ អ្វីដែលអាក្រក់ជាទីបំផុត -ការជម្លៀស ភាពរអាក់រអួលក្នុងការតាំងលំនៅនៅជនបទ ការរៀនសូត្រតាមជីវភាពកសិករ និងជនកុម្មុយនិស្ត- បានកន្លងផុតអស់ហើយ ។ កិច្ចការចាំបាច់ផ្សេងៗប្រែជាមានសភាពងាយស្រួលច្រើនជាងមុន ។ តាវ និងប្រពន្ធរបស់គាត់ ក៏សម្របខ្លួនទៅតាមនោះដែរ ។

ប៉ុន្តែ នៅពេលដែលបណ្តាសមាជិកគណៈកម្មាធិការមជ្ឈិមបក្ស ប្រារព្ធបើកមហាសន្និបាតរបស់ខ្លួន នៅខែមករា ឆ្នាំ១៩៧៦ ពួកគេបានសម្រេចថា ដំណាក់កាលអនុវត្ត «នយោបាយកុម្មុយនិស្តនៃសង្គ្រាម» ដែលបានដំណើរការចាប់ពីដើមទីមកនោះ បានទទួលជោគជ័យមួយល្មមគ្រប់គ្រាន់ ដើម្បីអនុញ្ញាតឲ្យយើងឆ្លងចូលទៅដំណាក់កាលបដិវត្តបន្ទាប់ទៀត គឺបង្កើនកម្រិតសមូហភាវូបនីយកម្មតាមសហករណ៍នានា «ការផ្លាស់ទ្រង់ទ្រាយសង្គម» ឲ្យកាន់តែស៊ីជម្រៅ ដោយកម្ចាត់សមាសភាព «វណ្ណៈគហបតី» និងដោយតម្រូវឲ្យប្រជាជនធ្វើពលិកម្មច្រើនឡើងថែមទៀត ។ កម្ពុជាប្រជាធិបតេយ្យ ប្រុងប្រៀបឈានចូលក្នុងដំណាក់កាល «បដិវត្តសង្គមនិយម» រួចជាស្រេច ។

បក្សបានបង្កើតរដ្ឋាភិបាលថ្មី តាក់តែងច្បាប់រដ្ឋធម្មនុញ្ញ ហើយបានបញ្ជូនមគ្គុទេសក៍ថ្មីៗទៅឲ្យសហករណ៍នានា ជាមគ្គុទេសក៍ដែលភូមិភាគនិរតីបានអនុវត្តយ៉ាងពេញលេញ និងលឿនរហ័សជាងភូមិភាគផ្សេងៗទៀត ។

ពួកមេដឹកនាំក្រុងភ្នំពេញ បានទាមទារកម្រិតភាគរយមួយយ៉ាងខ្ពស់ ពីការប្រមូលផលស្រូវលើកដំបូង ហើយភូមិភាគនិរតីបានសម្រេចធ្វើតាមសំណូមពរនេះ ។ របបអាហាររបស់ តាវ បានថយចុះជាងមុន ហើយ តាវ បានរៀបរាប់ថា «ពួកខ្មែរក្រហមបាននិយាយប្រាប់យើងថា អង្គការបានបញ្ជូនស្រូវរបស់យើងទៅឲ្យកន្លែងផ្សេងទៀតដែលគេត្រូវការ ហើយគេនឹងបើកមន្ទីរសម្រាប់ដោះដូរទំនិញដើម្បីឲ្យយើងបានទទួលសម្លៀកបំពាក់ និងថ្នាំពេទ្យខ្លះ ។ រឿងនេះគឺពុំពិតទេ ។ យើងនៅតែស្លៀកខោអាវរហែករយ៉ីរយ៉ៃដដែល ហើយពុំមានទាំងថ្នាំពេទ្យលេបផង បើមានវាក៏ពុំមែនសម្រាប់ពួកយើងដែរ» ។

បន្ទាប់មក របបសមូហភាវូបនីយកម្មបានចាប់ផ្ដើម ។ លក្ខណៈ«ស្វនត្តនិយម» ត្រូវបានហាមឃាត់ ។ ម្នាក់ៗត្រូវតែទៅបរិភោគនៅផ្ទះបាយរួម លែងមានការហូបជាគ្រួសារ លែងមានការចែករបបអាហារសម្រាប់គ្រួសារនីមួយៗទៀតហើយ ។ គេក៏ហាមមិនឲ្យដាំបន្លែជាឯកជន មិនឲ្យចិញ្ចឹមសត្វសម្រាប់ខ្លួនឯង ជាពិសេស សត្វជ្រូក ។ ទំហំសហករណ៍ ត្រូវគេបញ្ចូលគ្នាពីរ ឬបី ធ្វើជាសហករណ៍មួយ ក្នុងតំបន់ទាំងមូល ។ ដោយតម្រូវទៅតាមការអនុវត្ត ដូច្នេះ ផ្ទៃដីស្រែក៏ត្រូវបង្កើនឡើងដែរ ។ គម្ពោតព្រៃ និងរណ្ដៅជាច្រើន ដែលជាព្រំដីស្រែចម្ការតាំងពីច្រើនជំនាន់មកហើយ បានត្រូវគេកាប់ឆ្ការ និងចាក់ដីបំពេញ ។ ក្រុមការងារត្រូវគេពង្រីកឲ្យរឹតតែធំឡើង ហើយបណ្ដាសមាជិកនៃក្រុមការងារទាំងនោះ សុទ្ធតែត្រូវបញ្ជូនឲ្យទៅធ្វើស្រែដែលស្ថិតនៅឆ្ងាយៗពីភូមិ ។

គឺនៅខណៈនេះដែរ ដែលក្មេងៗចាប់ពីអាយុប្រាំទៅប្រាំមួយឆ្នាំ ត្រូវបានបំបែកពីគ្រួសាររបស់គេ ហើយយកទៅដាក់ក្នុងកន្លែងដេករួមជាច្រើនកន្លែង គឺផ្ទះមួយសម្រាប់ក្មេងប្រុស ផ្ទះមួយទៀតសម្រាប់ក្មេងស្រី ។ គ្រួសារតាវ ពុំទាន់មានបាត់បង់សមាជិកណាម្នាក់របស់ខ្លួនឡើយ ប៉ុន្តែ វាក៏លែងមានការរស់នៅជួបជុំគ្រួសារដូចមុនទៀតដែរ ។

«ពួកអ្នកមូលដ្ឋាន» ដែលពុំពេញចិត្តទាំងស្រុងនឹងដំណាក់កាលបដិវត្តថ្មីនេះ បានឆ្លៀតយកប្រយោជន៍ពីស្ថានភាពរបស់គេជាសមាជិកពេញសិទ្ធិ ដើម្បីរក្សាបុព្វសិទ្ធិខ្លះៗដែលគេនៅមាន ។ ពួកគេក៏ត្រូវទៅបរិភោគបាយនៅផ្ទះបាយរួមដែរ ប៉ុន្តែ ពួកគេបានត្រៀមទុកម្ហូបអាហារឆ្ងាញ់ៗដោយសម្រាប់ខ្លួនគេ ហើយទុកម្ហូបសេសសល់សម្រាប់ពួកសមាជិកត្រៀម និងមនុស្សដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ខ្លួន ។ តាវ និយាយថា ៖ «បបររបស់យើងនៅតែរាវកក្លក ។ អង្ករមួយកំប៉ុងដាក់បបរក្នុងខ្ទះមួយ សម្រាប់មនុស្សម្ភៃ ឬសាមសិបនាក់ ។ គ្មានសាច់គ្មានបន្លែសម្រាប់យើងទេ មានតែកន្ទក់លាយជាមួយត្រកៀត, គល់ចេក ឬពោត ។ «ពួកអ្នកមូលដ្ឋាន» បរិភោគគ្រាន់បើ ដោយអង្គុយដាច់ដោយឡែកនៅក្នុងផ្ទះបាយរួម ៖ មានសាច់ជ្រូក, បន្លែ, បាយមួយគោម ហើយជួនកាលមានទាំងត្រីថែមទៀត ។

ក្នុងប្រទេសមួយដែលកំពុងស្គាល់នូវការខ្វះខាតសព្វបែបយ៉ាង ការបង្កើតឲ្យមានផ្ទះបាយរួមច្រើនដូច្នេះ មិនត្រឹមតែជាសេចក្ដីសម្រេចមួយ ដែលផ្ទុយនឹងបំណងរបស់ប្រជាជនប៉ុណ្ណោះទេ ប៉ុន្តែ ជាកំហុសមួយ ។ នៅពេលបណ្ដាសមាជិកនៃគ្រួសារមួយបរិភោគបាយជុំគ្នា ឪពុកឬម្ដាយអាចរៀបចំធ្វើម្ហូបអាហារជាមួយនឹងបន្លែដែលដុះឯងៗក្នុងព្រៃ ឬសត្វតូចតាច ដែលគេរកបានក្នុងទីជិតៗនោះ ។ ប៉ុន្តែ នៅពេលដែលមនុស្សរាប់រយនាក់ទៅបរិភោគរួមគ្នា តើគេចែកម្ហូបអាហារទាំងនោះដោយរបៀបណាទៅ? ម្យ៉ាងទៀត ក្នុងសហករណ៍ជាច្រើនគេបានហាមមិនឲ្យរកអ្វីពីនេះពីនោះមកផ្សេងផ្សំបន្ថែមទេ ពីព្រោះគេយល់ថា ប្រការនេះវាធ្វើឲ្យខាតពេលវេលាដ៏មានតម្លៃមួយ ។ ការរកម្ហូបអាហារផ្សេងផ្សំនៅក្នុងព្រៃ ជាទម្លាប់របស់ប្រជាជនកម្ពុជារាប់សតវត្សរ៍មកហើយ ដែលផ្ដល់នូវមធ្យោបាយឲ្យប្រជាកសិកររស់រានជីវិត ក្នុងសម័យកាលដ៏លំបាកៗជាច្រើន និងធ្វើឲ្យជីវភាពបាន

ល្អប្រសើរ នៅពេលប្រទេសមានសុខសន្តិភាពផង ។ ការលុបបំបាត់ចោលទម្លាប់នេះ របស់របបខ្មែរក្រហម សឲ្យឃើញនូវការធ្វើមិនដឹងមិនស្គាល់ទាំងស្រុង ចំពោះជីវភាពរបស់អ្នកជនបទកម្ពុជា ។

មតិណែនាំទាំងឡាយ ដែលបង្គាប់បញ្ជាឲ្យបន្តកម្ចាត់ចោលពីសង្គម នូវសមាសភាពសល់ពីសង្គមចាស់ ដែលគេមិនត្រូវការ បានបង្កឲ្យមានផលប៉ះទង្គិចគ្នាក្នុងពេលភ្លាមៗនោះ ។ ពួកប្រធានៗសហករណ៍ និង«ពួកអ្នកចាស់» បានផ្តើមរករឿង«ពួកអ្នកថ្មី»រឹតតែខ្លាំងឡើងៗ និងចាប់ស៊ើបអង្កេតពីពួកកម្មាភិបាលដែលធ្វើការមុនពួកគេថែមទៀត ។ អ្នករដ្ឋការ និស្សិត គ្រូបង្រៀន យោធា និងអ្នកមានវិជ្ជាជីវៈសេរីរាប់រយនាក់ ដែលរួចផុតពីការកាប់សម្លាប់លើកទីមួយ ក៏គេចមិនផុតពីការកាប់សម្លាប់នៅលើកទីពីរនេះដែរ ។ ក្នុងឆ្នាំ១៩៧៦ ការសម្លាប់រង្គាលថ្មីៗទាំងនេះ ត្រូវបានបញ្ចេញឲ្យឃើញតាមរយៈឯកសារផ្សេងៗនៅមន្ទីរឃុំឃាំងទួលស្លែង ដែលពួកអ្នករងគ្រោះមួយភាគធំត្រូវបាននាំទៅដាក់គុកនៅទីនោះ ដើម្បីសួរចម្លើយ និងសម្លាប់ចោល ។ក្នុងភូមិភាគរបស់ តាវ គឺភូមិភាគនិរតី ពួកសន្តិសុខបានធ្វើបាប និងសម្លាប់អតីតទាហានរបស់ លន់ នល់ (ដែលនៅពេលដំបូងទាហានទាំងនោះ ធ្លាប់បានទទួលការខបត្ថម្ភគាំពារនៅក្នុងភូមិភាគនេះ) និស្សិត សាស្ត្រាចារ្យ និងមេដឹកនាំខ្លះនៃរបបសង្គមចាស់អស់មួយចំនួនធំ[៣៥] ។ ក្នុងភូមិភាគបូព៌ា និងពាយ័ព្យ ពួកសន្តិសុខបានប្រមូលផ្តុំកិច្ចប្រឹងប្រែងរបស់ខ្លួនសំដៅទៅលើអ្នកមានមុខវិជ្ជាជីវៈសេរីទាំងអស់ ។

ក្នុងសហករណ៍របស់ តាវ ដែលគេពង្រីកកាន់តែធំជាងមុន ពួកអ្នកនៅមានជីវិតជាជនជាតិចិន បានក្លាយទៅជាមនុស្សដែលត្រូវគេសង្ស័យជាថ្មី ហើយមនុស្សមួយចំនួនក្នុងចំណោមនោះបានបាត់ខ្លួន មិនដឹងទៅណា ។ តាវ បានធ្វើឲ្យពួកមេដឹកនាំសហករណ៍ស្តីបន្ទោសយ៉ាងខ្លាំង ពីព្រោះគាត់មិនសូវប្រសប់បញ្ជាក្របី ដែលគេប្រើប្រាស់សម្រាប់ការភ្ជួររាស់ ។ មេដឹកនាំទាំងនោះ បាននិយាយថា «ខ្ញុំពុំអាចភ្ជួរគន្លងមួយឲ្យត្រង់ភ្លឹងបានទេ ហើយប្រការនេះ បង្ហាញឲ្យឃើញថា ខ្ញុំជាវណ្ណៈអ្នកជិះជាន់គេ» ។

នៅក្នុងអង្គប្រជុំមួយដែលគេបើកធ្វើបន្ទាប់នោះ តាវ ត្រូវទទួលរងនូវការប្រជុំ «ទិតៀន -ស្វ័យទិតៀន» មួយ ។ ជាទូទៅ សម័យប្រជុំទាំងនោះ គេច្រើនធ្វើនៅពេលយប់ក្នុងអគារកណ្តាលរបស់ភូមិ ដែលគេប្រើសម្រាប់ធ្វើជាផ្ទះបាយរួម ។ នៅទីនោះក្រោមពន្លឺចង្កៀងគោម ឬអំពូលភ្លើងអគ្គីសនីដែលយុត្តិធម៌ត្រូវគេរក ខុសត្រូវ និងបកស្រាយពន្យល់ពីមតិណែនាំផ្សេងៗរបស់មជ្ឈិម ក្នុងកំឡុងសម័យប្រជុំនីមួយៗ ដែលមានថិរវេលាម្តងៗយូរណាស់ ។ ជារឿយៗ មតិណែនាំទាំងនោះ មាននិយាយទាក់ទងពីពេលម៉ោងធ្វើការ និងការបែងចែកភារកិច្ចសម្រាប់រដូវចុះស្ទូង និងច្រូតកាត់ប៉ុណ្ណោះ ។ ចំណែកឯការប្រជុំ«ទិតៀន-ស្វ័យទិតៀន» គឺមានលំនាំស្រដៀងនឹងតុលាការប្រជាជនមួយដែរ ។ ជាទូទៅ ពួកប្រធានសហករណ៍ជាអ្នកទទួលភារៈធ្វើការទិតៀន ដោយទុកឲ្យអ្នកជាប់ចោទធ្វើការស្វ័យទិតៀន ។

នៅសម័យប្រជុំនេះ តាវ ត្រូវគេហៅឲ្យទៅឈរនៅចំពោះមុខអ្នកភូមិទាំងអស់ ចាំស្តាប់«ពួកអ្នកចាស់»

លើកពីកំហុសផ្សេងៗរបស់គាត់ និងធ្វើការស្ដីបន្ទោស ។ លើកនេះ អ្នកទាំងនោះ គ្រាន់តែព្រមានថា កំហុសថ្មីៗទៀត អាចនឹងធ្វើឲ្យគាត់ទទួលទោសទណ្ឌមួយយ៉ាងតឹងរ៉ឹងបំផុត ។

ចាប់តាំងពីថ្ងៃនោះមក តាវ បានទៅជាកម្មវត្ថុនៃការតាមដានយ៉ាងស្អិត ។ គាត់ដឹងខ្លួនថា មានគេតាមយកការណ៍ពីគាត់ជារឿយៗ ហើយគាត់គ្មានស្គាល់ភិនភាគអ្នកឈ្លបយកការណ៍របស់សហករណ៍ គាត់បន្តិចសោះ ។ នៅទីបំផុត គាត់បានធ្វើឲ្យបាក់ផាលនង្គ័លដែលគាត់ភ្ជួរប៉ះនឹងថ្មមួយដុំ ។ នេះជាគ្រោះថ្នាក់មួយ ប៉ុន្តែគេនិយាយថា នេះជាបទឧក្រិដ្ឋទៅវិញ ។ តាវ ត្រូវទៅបង្ហាញមុខនៅសម័យប្រជុំជាបន្ទាន់មួយ ដែលធ្វើឲ្យគាត់មានសេចក្ដីតូចចិត្តយ៉ាងខ្លាំង ។ គាត់បានរៀបរាប់ថា «បើសិនជា កសិករម្នាក់ជាពួកអ្នកចាស់ ធ្វើឲ្យបាក់ផាលនង្គ័លវិញ គេគ្មាននិយាយអ្វីទាំងអស់ ផាលត្រូវគេជួសជុលប្រើជាថ្មី» ។

ប៉ុន្តែ តាវ ជាជនជាតិចិន ហើយ «ពួកអ្នក ចាស់» យល់ឃើញថា ការប្រើអំណាចផ្ដាច់ការដែលពួកគេធ្វើមកលើរូបគាត់ ត្រូវបានបង្ហាញឲ្យឃើញដោយការសង្កត់សង្កិន ដែលសហគមន៍របស់គាត់ធ្លាប់បានប្រព្រឹត្តមកលើពួកគាត់កាលពីដើម ។

នៅឈរចំពោះមុខហ្វូងមនុស្សជាច្រើន គាត់បានស្ដាប់«ពួកអ្នកចាស់»ចោទប្រកាន់ពីបទឧក្រិដ្ឋប្រឆាំងបដិវត្តតមកទៀត អ្នកចោទម្នាក់ក្នុងចំណោមអ្នកចោទរូបគាត់បានបញ្ចប់សេចក្ដីថា «បើសិនជាអ្នករាល់គ្នារក្សាទុកមនុស្សនេះ ក៏គ្មានបានចំណេញអ្វីដែរ បើសិនដករូបគាត់ចេញ ក៏យើងគ្មានខាតបង់អ្វីទាំងអស់ តាមឃ្លាខ្លីដែលគេនិយមប្រើក្នុងពេលនោះគឺ «ទុកក៏មិនចំណេញ ដកចេញក៏មិនខាត» ។

នេះគឺជាឃ្លាប្រយោគដែលមនុស្សគ្រប់រូបព្រឺខ្លាចបំផុត រូបមន្ត «ទុកក៏មិនចំណេញ ដកចេញក៏មិនខាត» ដែលជាប្រផ្នូលនៃសេចក្ដីស្លាប់នេះ បានត្រូវគេប្រើប្រាស់ទូទាំងកម្ពុជាប្រជាធិបតេយ្យ ។ នេះជារូបមន្តមួយរបស់បដិវត្តផ្ទាល់ ហើយដើមដំបូងគេធ្លាប់តែប្រើប្រឆាំងនឹងពួកកុម្មុយនិស្តកម្ពុជា ដែលវិលត្រឡប់ពីវៀតណាមខាងជើងមកមាតុប្រទេសវិញកាលពីឆ្នាំ១៩៧០ប៉ុណ្ណោះ ។

ញាប់ញ័រដោយសេចក្ដីភ័យខ្លាច តាវ បានថ្លែងនូវការសោកស្ដាយពីកំហុសរបស់ខ្លួនយ៉ាងច្រើន ហើយសន្យាថា នឹងលែងធ្វើឲ្យមានកំហុសរបៀបនេះជារៀងរហូត ។ គាត់បន្ទាបខ្លួនចុះ ឱនក្បាលដល់ដី ធ្វើយ៉ាងណាឲ្យគេជឿជាក់ ដើម្បីស្រោចស្រង់ជីវិតខ្លួនគាត់ និងជីវិតប្រពន្ធកូនផង ។

នៅដំណាក់កាលបដិវត្តន៍នេះ ក្នុងសហករណ៍នានា និងក្នុងពន្ធនាគារខ្លះៗ ពួកអ្នកជាប់ចោទ អាចទទួលនូវការលើកលែងទោសរបស់គេបានដោយលំបាក តាមរយៈការថ្លែងសារភាពពីកំហុសរបស់ខ្លួន ដែលបានប្រព្រឹត្តកន្លងមក ។ កាលពីមុន ក្នុងរយៈពេលសង្គ្រាម អ្នកជាប់ចោទអាចត្រូវគេដោះលែង បើសិនជាអ្នកនោះឆ្លើយបដិសេធពីកំហុសដែលដាក់បន្ទុកមកលើខ្លួន ប៉ុន្តែ ករណីបែបនេះ កម្រមានឃើញណាស់ក្នុងប្រទេសកម្ពុជាក្រោយសម័យសង្គ្រាម ។ ក្រោយឆ្នាំ១៩៧៥ បក្សបានជឿដោយគ្មានពិចារណានូវការចោទប្រកាន់ផ្សេងៗ

ដែលលើកឡើងប្រឆាំងនឹងប្រភេទសត្រូវខ្លះ និងវណ្ណៈផ្សេងៗរបស់កម្ពុជា ។ ប្រការនេះ ជាផ្នែកមួយនៃមនោគមវិជ្ជា ដែលបានក្លាយទៅជាមូលដ្ឋានមនោគមវិជ្ជារបស់ការបដិវត្ត ។

ត្រង់ចំណុចនេះ ប្រទេសកម្ពុជាកុម្មុយនិស្តមានលក្ខណៈដូចគំរូរបស់ចិនក៏ដូចគំរូរបស់សូវៀត ។ ស្តាលីនបានរៀបចំធ្វើការកាត់ក្តី ដែលនាំឲ្យគេរិះគន់ជាច្រើនលើក ដើម្បីបង្ហាញភ័ស្តុតាងឲ្យឃើញថា ការកាប់សម្លាប់របស់គាត់ពិតជាត្រឹមត្រូវ ហើយអ្នកចូលរួមទាំងប៉ុន្មានដឹងខ្លួនថា បានចំណាយពេលវេលាទៅក្នុងការសម្តែងរឿងដែលនាំឲ្យអាម៉ាស់មួយ ។ ប៉ុន្តែ ពួកពេជ្ឈឃាតរបស់ ម៉ៅ ជឿជាក់យ៉ាងពិតប្រាកដចំពោះអ្វីៗដែលពួកគេបានប្រព្រឹត្ត ជាពិសេស ពួកឆ្មាំក្រហមដែលបានដឹកនាំធ្វើការបោសសម្អាតជាច្រើន ក្នុងពេលធ្វើបដិវត្តន៍វប្បធម៌ ។

ដូច្នេះ លក្ខណៈនៃការបោសសម្អាតពួកអ្នកមិនល្អចេញរបស់កម្ពុជា បានប្រែប្រួលនៅពេលដែលវាក្លាយទៅជាចំណុចសំខាន់សម្រាប់ មជ្ឈិម ក្នុងការស្វែងរកពួកសត្រូវ ដែលគេអាចធ្វើឲ្យទៅជាអ្នកទទួលខុសត្រូវ ចំពោះការធ្វើមិនបានសម្រេចជោគជ័យរបស់ការបដិវត្ត ។ គេលែងឲ្យមានលទ្ធភាពឆ្លើយបដិសេធភស្តុតាងនៃពិរុទ្ធភាពទៀតហើយ ។ ចម្លើយសារភាព និងការសម្តែងសេចក្តីស្តាយក្រោយ ក៏លែងគ្រប់គ្រាន់ដើម្បីឲ្យគេមិនសម្លាប់ខ្លួនដែរ ។

ទោះបីជាសហគមន៍ចិនដែលធ្លាប់រស់នៅទីក្រុងនានា ត្រូវពួកខ្មែរក្រហមសម្លាប់រង្គាល អស់ប្រហែលជិតពាក់កណ្តាលក៏ដោយ ក៏ តាវ អាចនៅរស់រានមានជីវិត ដោយសារការជម្រុះលក្ខណៈជាចិនរបស់គាត់ចោលទាំងអស់ ។ គាត់លែងនិយាយភាសាដើមរបស់ខ្លួន ទោះបីជានិយាយជាមួយប្រពន្ធគាត់ក៏ដោយ ព្រោះគាត់ខ្លាចឈ្លបណាម្នាក់លួចស្តាប់ពួ ។ នេះជាបែបផែនតែមួយគត់ ដែលធ្វើឲ្យគាត់នៅគង់វង្សជីវិតសម្រាប់“ពួកអ្នកដែលមានធាតុបក្រពត្តិនិយមសក្តិភូមិ ឬពួកនាយទុនកុំប្រាដ័រ” ជាជនជាតិភាគតិច ៖ តាមរយៈការប្រឹងប្រែងសម្របខ្លួនឲ្យបានខ្លាំងក្លាបំផុត ទៅនឹងការរស់នៅរបស់ជនកុម្មុយនិស្តខ្មែរ និងការដាក់ខ្លួនស្តាប់បទបញ្ជាពួកមេដឹកនាំទាំងស្រុង ។

ជនជាតិចិន ពុំមែនជាសហគមន៍តែមួយដែលត្រូវបង្ខំឲ្យរំលាយជាតិសាសន៍ចូលជាមួយខ្មែរ ឬត្រូវរលាយសាបសូន្យនោះទេ ។ ពួកខ្មែរក្រហម បានធ្វើបាបជនជាតិថៃដែលកំពុងរស់នៅក្នុងភូមិភាគនិរតី និងបស្ចិមនៅខេត្តកោះកុង តាមបណ្តោយឈូងសមុទ្រសៀមដែរ[៣៦] ។ ការកម្ចាត់របស់គេ មានសភាពលឿនរហ័សបំផុតដោយមិនឲ្យដឹងខ្លួនជាមុន បណ្តាលឲ្យជនជាតិថៃដែលធ្វើទ័ពក្នុងជួរពួកកុម្មុយនិស្តដែរ មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ។ មួយភាគបីនៃសហគមន៍ថៃនៅខេត្តកោះកុង ត្រូវពួកខ្មែរក្រហមយកទៅសម្លាប់ចោល ។ សមាជិកមួយចំនួនរបស់ខ្លួន ដែលគេចផុតពីកណ្តាប់ដៃពួកពេជ្ឈឃាត បានភៀសខ្លួនទៅជ្រកនៅតាមព្រំដែន ជាប់ជាមួយប្រទេសថៃ ។ ជនជាតិថៃទាំងនេះ ដែលជាអតីតខ្មែរក្រហមដែរនោះ បានទទួលពីកងទ័ពថៃនូវសម្ភារសឹកយ៉ាងច្រើន សម្រាប់ធ្វើការប្រយុទ្ធតស៊ូទល់នឹង ប៉ុល ពត វិញ ។ នៅពេលដំបូង ការឆ្លក់វាយប្រហារប្រឆាំងនឹង “សមមិត្តចាស់” របស់ពួកគេ បានប្រព្រឹត្តទៅដោយគ្មានបានផលឡើយ បើនិយាយពីផ្នែកយោធា ប៉ុន្តែ ប៉ុន្មានឆ្នាំ

ក្រោយមក មនុស្សទាំងអស់នេះ បានក្លាយទៅជាបុគ្គលដែលមានសារសំខាន់បំផុត នៅពេលដែលពួកវៀតណាមស្ទុះស្វែងរកអតីតខ្មែរក្រហម ដើម្បីជំនួសរូប ប៉ុល ពត នោះ ។

នៅភូមិភាគឦសានក្នុងខេត្តរតនគិរីផ្ទាល់ ដែលគណៈកម្មាធិការ មជ្ឈិម ធ្លាប់ភៀសខ្លួនទៅជ្រកនៅទីនោះនាចុងទសវត្សរ៍ឆ្នាំ១៩៦០ និងជាកន្លែងដែល ប៉ុល ពត ចាប់ផ្ដើមមើលឃើញអំពើជិះជាន់មកលើអ្នកស្រុកនៅទីនេះ ក៏កើតមានការវាយប្រហារដោយពេលៗម្ដងម្កាលដែរ ។ ប៉ុន្តែអាស្រ័យដោយកត្តាខ្លះ -ដែលមានការចងភ្ជាប់ឡើងវិញដោយផ្ទាល់របស់គណៈកម្មាធិការមជ្ឈិម និងឥទ្ធិពលដ៏សម្បើម របស់ជនជាតិភាគតិចទាំងនោះ ជាមួយគណៈលេខាភូមិភាគតាំងពីមុនមក- ភូមិភាគឧត្តរ និងឦសាន ពុំបានយកចិត្តទុកដាក់ធ្វើតាមបទបញ្ជាមួយភាគធំរបស់មជ្ឈិម ដែលឲ្យដាក់រួម ឬកម្ទេចសមាសភាព «ចក្រពត្តិនិយម» ឬបណ្ដាជនជាតិភាគតិចទេ ។

គឺពួកចាមកាន់សាសនាអ៊ីស្លាម ដែលការបញ្ញត្តិឲ្យលុបបំបាត់ជនជាតិភាគតិចទាំងអស់នេះចោល បានទទួលលទ្ធផលច្រើនជាងគេ ។ ប្រជាជនដែលមកពីប្រទេសក្រៅនេះ ត្រូវគេផ្ដន្ទាទោសពីរដង ៖ ចំពោះ«ពូជសាសន៍បរទេស» និងជំនឿចំពោះសាសនា«ប្រតិកិរិយា»របស់ខ្លួន ។ ក្នុងរយៈពេលជាច្រើនជំនាន់មកហើយ ពួកនេះបានជៀសផុតពីការស្រូបចូលក្នុងសង្គមជាតិខ្មែរដែលកាន់ព្រះពុទ្ធសាសនា ។ ម្ដងនេះ ពួកកុម្មុយនិស្តមិនបណ្ដោយឲ្យពួកគេមានសិទ្ធិធ្វើការជ្រើសរើសទៀតឡើយ ៖ «ជនជាតិចាមគោងតែផ្លាស់ប្ដូរឈ្មោះ ដោយដាក់ឈ្មោះថ្មី ស្រដៀងនឹងឈ្មោះខ្មែរដែរ ។ លក្ខណៈជាចាម ដូចជា សញ្ជាតិ ភាសា ទំនៀមទម្លាប់ សម្លៀកបំពាក់ សាសនា ជាដើម គឺត្រូវលុបបំបាត់ចោល ។ អ្នកទាំងឡាយណាដែលមិនប្រតិបត្តិតាមបញ្ជានេះ នឹងទទួលរងនូវផលវិបាកមិនខាន[៣៧] » ។

ពួកចិន តែងតែរស់នៅដាច់ដោយឡែកពីគេជានិច្ច[៣៨] ។ គេគិតថា ពួកគេសុទ្ធតែតពូជពីប្រជាពលរដ្ឋនៃនគរចាម្ប៉ា ដែលត្រូវចូលលុកលុយដោយពួកវៀតណាម ។ ពួកនេះ មិនជឿពីការរំលាយបញ្ចូលគ្នាទេ ពួកគេបាននាំគ្នាបង្កើតភូមិ, សាងសង់ផ្ទះជុំវិញវិហារអ៊ីស្លាមមួយ, ប្រតិបត្តិតាមវិន័យតមអាហារផ្ទាល់របស់ពួកគេ, ស្លៀកពាក់ និងទទូរក្រមាលើក្បាលទៅតាមជំនឿចំពោះសាសនារបស់គេ ហើយក្នុងការប្រកបវិជ្ជាជីវៈ ជាអ្នកពូកែបំផុតខាងរបបរនេសាទ និងការដួញដូរសំពត់ហូលជាមួង ។

វប្បធម៌របស់គេ ជាវប្បធម៌សម្បូរបែបមួយ ។ ស្ត្រីៗ បេះក្រងសក់យ៉ាងប្រសប់ជាមួយនឹងខ្សែបូវែង និងកន្ទា ហើយគ្របក្បាលដោយសំពត់ព្រែស្តើងរលើបរលោងធំៗ ។ ចំណែកបុរសៗ ពាក់មួកកាតីបមូលរាក់ ហើយច្រើនទុកពុកមាត់ ។ បព្វជិតទាំងឡាយ ពាក់ឈ្នួតក្បាល ។ ប្រជាជនខ្មែរច្រើនមានបុរេនិច្ច័យមួយ ប្រឆាំងនឹងជនជាតិភាគតិចនេះ ។ ពួកចាមដែលត្រាច់ចរខ្វាត់ខ្វែងទៅជនបទ ដើម្បីលក់សំពត់ឲ្យប្រជាកសិករខ្មែរ ហើយដែលតថ្លៃដោយខ្ជាប់ខ្ជួន ច្រើនមានឈ្មោះជាអ្នកភូតកុហកយ៉ាងប៉ិនប្រសប់ ។ ពហិលក្ខណៈរបស់បណ្ដាស្ត្រីចាម ដែលមកពីប្រទេសក្រៅ បានធ្វើឲ្យនឹកឃើញប្រវត្តិសាស្ត្រស្ដីពីការទោរទន់ទៅកាមមុច្ឆារបស់គេ ។ ដោយភាសា និងអក្សរក្រមរបស់គេសុទ្ធតែជារបស់បរទេស -អារ៉ាប់- គេបានសន្មតថា ជនជាតិចាមមានចំណេះដឹងពិសេស មួយខាង

មន្តអាគម និងការទស្សន៍ទាយពីអនាគតយ៉ាងគាប់ប្រសើរ ។ នៅទីបំផុត ពួកគេសុទ្ធតែមានជំនឿម៉ឺងម៉ាត់ចំពោះសាសនាអ៊ីស្លាម ដែលជឿចំពោះអទិទេពមួយប៉ុណ្ណោះ ។ នេះជាប្រការខុសគ្នាពីព្រះពុទ្ធសាសនាទាំងស្រុង ។

សម្តេច ព្រះនរោត្តម សីហនុ ធ្លាប់បានសាកល្បងបញ្ចូលពួកចាមមកក្នុងសហគមន៍ខ្មែរដែរ ប៉ុន្តែ ទាំងពួកចាម ទាំងប្រជាជនខ្មែរ ពុំស្រុះស្រួលចិត្តចូលជាមួយគ្នាឡើយ ។ ពួកចាមពុំចង់ឲ្យបាត់បង់អត្តសញ្ញាណរបស់គេ ហើយក៏ពុំចង់ប្រព្រឹត្តល្មើសនឹងជំនឿសាសនារបស់គេដែរ ។ ជនជាតិខ្មែរ ជាអ្នករើសអើងជាតិសាសន៍យ៉ាងធ្ងន់ធ្ងរ ព្រោះតែចូលចិត្តដាក់ពួកចាមមិនឲ្យចូលស្និទ្ធស្នាលនឹងខ្លួន ដោយចង់ឲ្យពួកនេះមានស្ថានភាពទាបជាង ។

គឺនៅឆ្នាំ១៩៧០ ពេលចាប់ផ្តើមសង្គ្រាមដំបូង ពួកចាមបង្ហាញឲ្យឃើញសមាចិត្តរបស់គេចំពោះបុព្វហេតុរបស់ខ្មែរក្រហមដែរ ។ ពួកគេនឹកស្មានថា ពួកកុម្មុយនិស្តនឹងបានទទួលជ័យជម្នះ ហើយនឹងបញ្ចប់នយោបាយប្រកាន់ជាតិសាសន៍បន្តិចបន្តួច ដែលពួកអ្នកកាន់អំណាចក្រុងភ្នំពេញ ធ្លាប់បានអនុវត្តអស់រយៈពេលជាយូរមកហើយ ។ ក្រុមច្បាំងគ្នាទាំងសងខាងចូលចិត្តរើសពួកចាមឲ្យចូលធ្វើកងទ័ពរៀងៗខ្លួន ពីព្រោះជនជាតិភាគតិចនេះ ដែលសាសនា របស់គេអនុញ្ញាតឲ្យធ្វើសឹកសង្គ្រាមដែរនោះ ត្រូវបានចាត់ទុកជាយុទ្ធជនដ៏ឆ្នើមលើសគេ ហើយសាហាវជាងគេនៅសមរភូមិប្រទេសកម្ពុជា ។ ភាគច្រើននៃពួកចាម បានទៅចូលរួមជាមួយពួកខ្មែរក្រហម ហើយបានស្ថិតនៅក្នុងជួរពួកនេះនៅឡើយក្នុងឆ្នាំ១៩៧៣ ជាមួយនឹងការបង្កើតឲ្យមានសហករណ៍ជាច្រើន នៅពេលដែលក្រុងភ្នំពេញប្រកាសថា របៀបរបបរបស់ជនជាតិចាម មានលក្ខណៈប្រឆាំងបដិវត្តន៍ ។

ស្ត្រីៗចាមទាំងអស់ត្រូវតែស្លៀកពាក់តាមរបៀបខ្មែរក្រហម កាត់សក់ខ្លីលើកញ្ចឹងក និងស្លៀកពាក់ខោអាវខ្មៅ ។ ពួកអ្នកកាន់ព្រះពុទ្ធសាសនា អាចមានការយល់ទាស់ផ្ទាល់ខ្លួនចំពោះរបៀបស្លៀកពាក់នេះ ប៉ុន្តែក្នុងករណីស្ត្រីៗចាម គឺសាសនារបស់គេ ដែលហាមមិនឲ្យគេកាត់សក់ខ្លី និងបោះបង់សម្លៀកបំពាក់ជាប្រពៃណីរបស់គេបានឡើយ ។ ក្នុងឃុំខ្លះ គេបានបង្ខំឲ្យពួកចាមស៊ីសាច់ជ្រូក ជាសាច់ដែលសាសនាអ៊ីស្លាមហាមឃាត់ គេរារាំងមិនឲ្យពួកចាមនិយាយភាសា និងប្រតិបត្តិសាសនារបស់ខ្លួនថែមទៀត ។ នៅពេលដែលសង្គ្រាមឈានទៅជិតដល់ទីបញ្ចប់ លន់ នល់ បានដឹងរឿងនេះតាមរយៈរបាយការណ៍ផ្សេងៗ របស់ពួកភ្នាក់ងារស៊ើបការណ៍របស់គាត់ថា ពួកខ្មែរក្រហមបានធ្វើទុក្ខបុកម្នេញពួកចាមយ៉ាងខ្លាំង ហើយបានល្បងទាក់ទាញពួកនេះឲ្យចូលមកខាងគាត់វិញ ។ លន់ នល់ បានដំឡើងបុណ្យសក្តិឲ្យពួកនាយទាហានចាមមួយថ្នាក់ ហើយរឹតចំណងទាក់ទងជាមួយបណ្តាប្រទេសកាន់សាសនាអ៊ីស្លាមនៅមជ្ឈិមបូព៌ា ក៏ដូចជានៅអាស៊ីអាគ្នេយ៍ ។ ប៉ុន្តែ វាយឺតពេលណាស់ទៅហើយ ។ សង្គ្រាមត្រូវចប់ ពាក្យចចាមអារ៉ាមដែលនិយាយតៗគ្នា អំពីការរើសអើងជាតិសាសន៍ចំពោះពួកចាម បានក្លាយទៅជាការសម្លាប់បំបាត់ពូជសាសន៍យ៉ាងពិតប្រាកដ ។

បន្ទាប់ពីជ័យជម្នះរបស់កុម្មុយនិស្ត ការវាយប្រហារប្រឆាំងនឹងពួកចាម បានប្រព្រឹត្តទៅយ៉ាងចំហ និងម៉ឺងម៉ាត់បំផុត ។ ពួកមេដឹកនាំខាងសាសនា និងនយោបាយរបស់ជនជាតិភាគតិចចាម ត្រូវគេតាមដាន ស្វែងរកចាប់

ខ្លួន និងសម្លាប់ចោល ។ វិហារអ៊ីស្លាមជាច្រើន ត្រូវគេកម្ទេចចោល ឬប្រមាថកាតទាន ត្រូវគេប្រែក្លាយឲ្យទៅជាជង្រុក ស្រូវ ទ្រុងជ្រូក ឬគុក ដូចវត្តអារាមពុទ្ធសាសនាដែរ ។ គេបានដុតគម្ពីរកូរ៉ាន់ចោល សាលារៀនរបស់ចាមត្រូវបិទទ្វារ ដូចសាលារៀនផ្សេងទៀតនៅទីដទៃដែរ ។

បទបញ្ញត្តិផ្សេងៗដែលប្រជាជនកម្ពុជាម្នាក់ៗត្រូវតែប្រតិបត្តិ តាមបន្ទាប់ពីថ្ងៃជ័យជម្នះ ក៏មានផលវិបាកនាំឲ្យវិនាសអន្តរាយសម្រាប់ជនជាតិចាមកាន់តែខ្លាំងថែមទៀត ដែលត្រូវបង្ខិតបង្ខំឲ្យធ្វើការជ្រើសរើសរវាងជំនឿចំពោះសាសនា អត្តសញ្ញាណរបស់គេ និងជីវិតផ្ទាល់របស់ខ្លួន ។ ពួកគេត្រូវលះបង់ឈ្មោះដើមរបស់ខ្លួន ហើយជ្រើសរើសឈ្មោះថ្មីជាខ្មែរវិញ ។ ដើម្បីបង្ហាញឲ្យគេឃើញបុកពាជាខ្មែរ ពួកគេបានកាត់សក់ និងកោរពុកមាត់ចេញ ស្លៀកពាក់ខោអាវខ្មែរ ដែលជាប្រការបញ្ចប់នូវអត្តសញ្ញាណរបស់គេទាំងអស់ ។ ដើម្បីសាកល្បងនៅលើពួកនោះ គេបានបង្ខំឲ្យហូបសាច់ជ្រូក ក្រោមការគំរាមកំហែងដោយចុងអាវុធ ។ គ្រួសារចាមជាច្រើនត្រូវគេបំបែកបំបាក់ចេញពីគ្នា ដើម្បីបញ្ចៀសកុំឲ្យពួកមនុស្សពេញវ័យចម្លងវប្បធម៌របស់គេទៅឲ្យពួកក្មេងៗដែលត្រូវបញ្ជូនឲ្យទៅរស់នៅជាមួយកូនខ្មែរ ក្នុងកន្លែងដេករួមជាច្រើន ឬក្នុងកងចល័តយុវជន ។

ប៉ុន្តែ ពួកចាមបានបះបោរប្រឆាំង ។ ភូមិចាមជាច្រើនបានចាប់កាន់អាវុធ ហើយបានត្រូវកម្ទេចដោយពួកខ្មែរក្រហម ។ ភូមិជាច្រើនទៀត ដែលតវ៉ាប្រឆាំងដោយមិនចេញមុខ ក៏ត្រូវពួកកម្មាភិបាលខ្មែរក្រហមបំផ្លិចបំផ្លាញរាបដល់ដីដូចគ្នា ។ ពុំមានសហគមន៍ចាមណាមួយ រួចផុតពីគ្រោះថ្នាក់ឡើយ ។ ពួកចាមត្រូវគេបំបែកយកទៅដាក់ភូមិផ្សេងៗ ដែលមានខ្មែរច្រើនលើសលុបជាង ហើយត្រូវបង្ខំឲ្យធ្វើខ្លួនដូចជាខ្មែរថែមទៀត ។

ភាគច្រើននៃភូមិចាមច្រើនស្ថិតនៅតាមមាត់ទន្លេមេគង្គក្នុងភូមិភាគបូព៌ា និងភូមិភាគនិរតី ព្រមទាំងក្នុងអតីតភូមិភាគឧត្តរផង ។ ភូមិខ្លះទៀតក៏មានស្ថិតនៅក្នុងភូមិភាគពិសេសរបស់ភ្នំពេញដែរ ។ ទីប្រមូលផ្តុំមួយ ដែលមានជនជាតិចាមរស់នៅច្រើនជាងគេ គឺស្ថិតនៅក្នុងភូមិភាគបូព៌ា ដែលមាន សោ ភឹម ជាលេខាបក្ស ជាអ្នកល្បីល្បាញ ខាងធ្វើឲ្យពួកកម្មាភិបាលខ្លួនមានវិន័យ និងរារាំងមិនឲ្យមានការបង្ហូរដោយឥតប្រយោជន៍ឡើយ ។ ប៉ុន្តែគាត់បានបង្ហាញឲ្យឃើញលក្ខណៈមិនចេះអាណិតអាសូរបន្តិចសោះ ចំពោះពួកចាមនេះ ។ ដោយភូមិភាគគាត់គោរពធ្វើតាមបទបញ្ជាផ្សេងៗរបស់បក្ស ក្នុងការកាប់សម្លាប់ពួកកុម្មុយនិស្តខ្មែរ ដែលត្រឡប់មកពីវៀតណាមខាងជើងវិញ ក្នុងរយៈពេលសង្គ្រាមនោះ ភូមិភាគបូព៌ា ក៏បានធ្វើតាមបទបញ្ជាឲ្យកម្ចាត់ពូជសាសន៍ចាមដែរ ។

ពួកចាមមានមធ្យោបាយតិចតួចណាស់ ដើម្បីគេចឲ្យផុតពីកណ្តាប់ដៃពួកខ្មែរក្រហម ហើយសុទ្ធតែជាអ្នករីងរូសបំផុត នៅពេលយល់ព្រមឲ្យមានការបំផ្លិចបំផ្លាញវប្បធម៌ និងសាសនារបស់គេ ។ ក្នុងការកាន់អំណាចរបស់កុម្មុយនិស្តមិនដល់បួនឆ្នាំផង សហគមន៍ចាមចំនួនពាក់កណ្តាលបានត្រូវវិនាស- ពុំមែនដោយគ្មានប្រយុទ្ធតស៊ូនោះទេ ។ គេត្រូវកត់សម្គាល់ថា ការបះបោរមួយចំនួនតូច ដែលគេផ្សាយឲ្យដឹងជាសាធារណៈ គឺការបះបោររបស់ពួកជនជាតិភាគតិចនានា ៈ ពួកថៃនៅខេត្តកោះកុង ពួកចាម និងពួកចិន ដែលងើបបះបោរប្រឆាំងនឹងរដ្ឋអំណាចដាច់

ដោយឡែកៗពីគ្នា ហើយដែលរងគ្រោះថ្នាក់ដល់ស្លាប់ ដោយគ្រាន់តែហៅរកពួកទីប្រឹក្សាចិន ដែលមកពីក្រុងប៉េកាំងឲ្យជួយសង្គ្រោះពួកគេប៉ុណ្ណោះ ។

ភាគច្រើននៃប្រជាជនកម្ពុជា ដែលសុទ្ធតែជាខ្មែរពិតៗ បាននិយាយពីការយល់ឃើញ ទាក់ទងនឹងបញ្ហាជាតិសាសន៍ និងវប្បធម៌ ក៏ត្រូវបាត់បង់វប្បធម៌ គ្រួសារ របៀបរបបរស់នៅរបស់គេ ក្នុងរយៈពេលនៃការធ្វើបដិវត្តដូចគ្នា ប៉ុន្តែ គ្មានសេចក្ដីរាយការណ៍ ណាមួយបញ្ជាក់ឲ្យដឹងថា ពួកគេបានងើបបះបោរឡើយ ។ អ្នកខ្លះបានភៀសខ្លួនទៅកាន់ប្រទេសថៃ វៀតណាម អ្នកខ្លះទៀតបានសម្លាប់ខ្លួនឯង ។ ប្រពៃណីរាប់រយឆ្នាំមកហើយ ក្នុងការស្ដាប់បង្គាប់ព្រះរាជាផ្ដាច់ការមួយអង្គ ប្រហែលរារាំងប្រជាជនខ្មែរមិនឲ្យងើបប្រយុទ្ធតស៊ូនឹងពួកខ្មែរក្រហមហើយមើលទៅ ។

ពួកគេពុំមែនជាប្រជាជាតិតែមួយ ដែលត្រូវបាត់បង់លក្ខណៈជាមនុស្សដោយការសង្កត់សង្កិន ព្រោះតែងើបបះបោរប្រឆាំងនោះទេ ។ នៅសតវត្សរ៍ទី២០ បាតុភូតដូចគ្នានេះ ក៏កើតមានឡើងក្នុងបណ្ដាប្រទេស នៅអាស៊ី អឺរ៉ុប អាហ្វ្រិក និងអាមេរិកឡាទីន ដែរ គឺបណ្ដាប្រទេសដែលធ្លាប់ស្គាល់ជំរំប្រមូលផ្ដុំ ទារុណកម្ម ការអត់ឃ្លាន ។ ដោយស្ថិតនៅក្រោមស្ថានភាពផ្សេងៗបែបនោះ មនុស្សទាំងអស់មិនប្រឆាំងតបតដោយ «កំហឹង និងការប្រើកម្លាំង[៣៩]»ឡើយ ហើយការគ្មានប្រតិកម្មតបតជាក់ស្ដែងបែបនោះ គឺជា«សញ្ញានៃការបាត់បង់លក្ខណៈជាមនុស្ស» យ៉ាងច្បាស់ ដែលធ្វើឲ្យប្រជាជាតិមួយគាំងស្ងួកលែងធ្វើអ្វីកើតទាំងអស់ ។ ក្នុងពេលដែលរលកនៃអំពើភេរវកម្មកំពុងរាលដាលពេញផ្ទៃប្រទេសទាំងមូល ប្រជាជនកម្ពុជាគ្រប់រូប កាន់តែប្រកាន់មារយាទខ្លាំងឡើងហាក់ដូចជាប្រជាជន«គ-ថ្លង់» (គឺធ្វើមិនដឹងមិនឮ និងមិននិយាយអ្វីទាំងអស់) ដូចក្នុងពាក្យទំនាយរបស់គេ ដែលបានព្យាករណ៍ទុកជាមុនពីទីបញ្ចប់នៃពិភពលោកពិតប្រាកដមែន ។

## ឆយ ខណ្ណា ឬ កម្ពុជាថ្មី
## ការបំផ្លាញវប្បធម៌នៅជនបទ

គ្មានអ្វីដែលធ្វើឲ្យគេឃើញច្បាស់លាស់ជាគំរូ ជាងការប្រមាថរបស់បដិវត្តន៍ចំពោះប្រពៃណីនៃការរស់នៅនៅជនបទរបស់ប្រជាជនកម្ពុជាភាគច្រើន ជាងការបំផ្លាញសាសនា និងរបៀបរបបរស់នៅ របស់អ្នកកាន់ព្រះពុទ្ធសាសនាដោយរបបគ្រប់គ្រងនេះឡើយ ។

ប៉ុន្តែ ព្រះសង្ឃមួយចំនួនធំសង្ឃឹមចូលរួមចំណែកជាមួយបដិវត្តន៍ដែរ ពុំធ្វើខ្លួនជាអ្នករងគ្រោះទេ ។ ជាពិសេស ដោយសារការលើកទឹកចិត្ត និងការអំពាវនាវរបស់សម្ដេច ព្រះនរោត្តម សីហនុ ដែលថ្លែងពីទីក្រុងប៉េកាំងមក ទើបបានជាពុទ្ធសាសនិកជនយ៉ាងច្រើននៅតាមជនបទស្មគ្រ័ចិត្តទៅរួបរួម ជាមួយនឹងពួកខ្មែរក្រហម

ក្នុងរយៈពេលសង្គ្រាមនៅឆ្នាំដំបូង នៅពេលដែលពួកកុម្មុយនិស្ត ជ្រើសរើសបុគ្គលិកយ៉ាងសកម្មក្នុងចំណោមព្រះសង្ឃ និងទំនុកបម្រុងព្រះអង្គដោយគោរពប្រតិបត្តិយ៉ាងត្រឹមត្រូវ ។ ព្រះសង្ឃជាច្រើនអង្គត្រូវបានតែងតាំងឲ្យកាន់មុខតំណែងផ្សេងៗ គ្រាន់តែជាកិត្តិយសក្នុងផ្ទៃរដ្ឋាភិបាលរណសិរ្ស ហើយត្រូវបានអនុញ្ញាតឲ្យនៅត្រួតត្រាព្រះសង្ឃ ដែលនៅក្រោមឱវាទព្រះអង្គជាបន្តទៅទៀតក្នុងតំបន់ជាច្រើន ក្រោមការកាន់កាប់របស់ខ្មែរក្រហម ។ នៅពេលដែលសាសនាត្រូវហាមឃាត់ក្នុងភាគចុងក្រោយនៃសង្គ្រាម ពួកកុម្មុយនិស្តបានសន្យាថា នេះគ្រាន់តែជាវិធានការបណ្ដោះអាសន្នមួយប៉ុណ្ណោះ ដើម្បីអនុញ្ញាតឲ្យមានការកេណ្ឌប្រជាជនឲ្យចូលធ្វើកងទ័ពពេញលេញមួយ ។

បន្ទាប់ពីជ័យជម្នះ ពួកខ្មែរក្រហមបានចាប់ផ្ដើមទម្លាក់ទោសទៅលើព្រះសង្ឃ វត្តអារាម ព្រះពុទ្ធរូប គម្ពីរក្បួនខ្នាត បណ្ណាល័យ និងសាលាសម្រាប់ព្រះសង្ឃរៀនសូត្រភ្លាមៗតែម្ដង ។ ការបំផ្លិចបំផ្លាញនេះ ស្ទើរតែទាំងស្រុង បានបង្កឲ្យមានផលវិបាកកាន់តែវិនាសហិនហោចថែមទៀតសម្រាប់ប្រទេសកម្ពុជា ដូចការវាយប្រហាររបស់ចិនប្រឆាំងនឹងព្រះពុទ្ធសាសនានៅទីបេតដែរ ។

ពួកកុម្មុយនិស្តបានសម្លាប់សម្ដេចសង្ឃ ហួត តាត ភ្លាមៗគ្មានបង្អង់ បន្ទាប់ពីបានបញ្ចុះបញ្ចូលឲ្យព្រះសង្ឃទាំងឡាយ និមន្តឆ្ពោះទៅរកពេជ្ឈឃាតរបស់ព្រះអង្គ ដោយប្រើល្បិចកលផ្សេងៗមិនខុសពីល្បិចដែលគេធ្លាប់ប្រើប្រាស់ ដើម្បីកម្ទេចអតីតនាយទាហានរបស់របប លន់ នល់ ឡើយ ។ ក្នុងចំនួនព្រះសង្ឃ ពីសែសិប ទៅ ហុកសិបពាន់អង្គ ដែលគេឃើញមាននៅកម្ពុជា គឺមានតែជាង មួយពាន់អង្គប៉ុណ្ណោះ ដែលនៅគង់វង្សព្រះជន្មពីសម័យខ្មែរក្រហម៤០ ។ ព្រះសង្ឃមួយចំនួនត្រូវបានសម្លាប់ចោល មួយចំនួនទៀតត្រូវបាត់ខ្លួន ។

ព្រះសង្ឃទាំងឡាយដែលមិនត្រូវសម្លាប់ បានទទួលបញ្ជាឲ្យលាចាកសិក្ខាបទ និងចូលរួមធ្វើការងារផ្សេងៗក្នុងសហករណ៍ដូចកសិករសាមញ្ញដែរ នេះជាការបង្គាប់បញ្ជាដាច់ខាត ដែលផ្ទុយនឹងវិន័យរបស់សាសនា ។ ព្រះសង្ឃអង្គណាដែលមិនព្រមធ្វើតាមច្បាស់ជា ត្រូវគេនាំយកទៅសម្លាប់ចោល ។ ព្រះសង្ឃជាច្រើនអង្គត្រូវចាប់បង្ខំឲ្យរៀបការប្រពន្ធ ដែលនេះជាប្រការរារាំងមិនឲ្យព្រះសង្ឃទាំងនោះ បួសសាជាថ្មីទៀត ។ ក្នុងតំបន់ខ្លះៗ ពួកកុម្មុយនិស្ត បានអនុញ្ញាតឲ្យព្រះសង្ឃនៅគ្រងស្បង់ចីពរបាន ប៉ុន្តែ ត្រូវមជ្ឈិមបដិសេធមិនឲ្យមានឡើយ ។

ដោយគ្មានព្រះសង្ឃ ប្រជាជនលែងបានគោរពប្រតិបត្តិសាសនាតទៅទៀត ប៉ុន្តែពួកខ្មែរក្រហម នៅតែជម្នះលុបបំបាត់សាសនាចេញពីសតិចងចាំរបស់ប្រជាជន ។ វត្តនៅប្រទេសកម្ពុជាដែលមានចំនួនប្រហែលបីពាន់បានត្រូវគេប្រមាថកាតទាន ឬកម្ទេចចោល និងធ្វើឲ្យប្រែក្លាយទៅជា ក្រោលសេះ ឬជង្រុកស្រូវ ជាគុក ឬជាកន្លែងសម្រាប់សម្លាប់មនុស្ស ។ រូបបដិមាករព្រះពុទ្ធ ត្រូវគេធ្វើឲ្យប្រឡាក់ប្រឡូសមើលលែងស្គាល់គម្ពីរក្បួនខ្នាតខាងសាសនា ត្រូវគេដុតបំផ្លាញ ឬហែកចោល ។

ពួកខ្មែរក្រហម បានធ្វើឲ្យវិនាសនូវចំណុចស្នូលនៃដំណើរស់នៅរបស់ប្រជាជនកម្ពុជា គឺបំផ្លាញវត្តអារាម

ជំនួសដោយផ្ទះបាយរួម និងរោងធំៗនៅតាមឃុំ ដែលអ្វីៗជានិមិត្តរូបនៃជំនឿចំពោះសាសនា ដែលប្រតិបត្តិដោយប្រជាជនកម្ពុជាជិត ប៉ែតសិបភាគរយ ត្រូវរលាយបាត់បង់ ។

ពួកកុម្មុយនិស្តមិនត្រឹមតែបំផ្លាញប្រពៃណីរស់នៅរបស់ប្រទេសជាតិប៉ុណ្ណោះទេ ប៉ុន្តែ បានកម្ទេចអារ្យធម៌ដ៏យូរលង់របស់ខ្លួន ដែលមានរាប់សតវត្សរ៍មកហើយ ។ ការប្រើប្រាស់ឈ្មោះភូមិភាគ ជាជាងប្រើឈ្មោះចាស់របស់ខេត្តផ្សេងៗ ដើម្បីកំណត់ព្រំដែនតំបន់ផ្សេងៗ តាមភូមិសាស្ត្ររបស់ប្រទេសនោះ ជានិមិត្តរូបនៃការរៀបចំ ថ្មីទាំងស្រុង ដែលគេបង្កើតឲ្យមាននៅជនបទ ។ គេបានបង្ខំឲ្យប្រជាជនប្រើប្រាស់ឈ្មោះភូមិភាគនានាដែលគេបានប្រឌិតឡើងដោយយកទិសធំៗទាំងបួនជាគោល និងកំណត់កន្លែងដែលគេរស់នៅជាលេខសម្គាល់តំបន់មួយ ជាជាងដាក់ឈ្មោះមួយទៅវិញ ។

មនុស្សគ្រប់គ្នាលែងអាចប្រកាន់ថា ខ្លួនស្ថិតនៅខេត្តតាកែវ ឬបាត់ដំបងទៀតហើយ ។ ឈ្មោះ និងការកំណត់ព្រំដែនខេត្ត -ខ័ណ្ឌផ្សេងៗ ត្រូវបានបោះបង់ចោល រួមទាំងលក្ខណៈដោយឡែករបស់ខេត្តខ័ណ្ឌនោះផង-ជាមួយនឹងការរៀបចំថ្មីរបស់បដិវត្តន៍ តំបន់ ឬភូមិភាគទាំងអស់ ត្រូវតែមានលក្ខណៈដូចគ្នាតែមួយ ។ ខេត្តតាកែវលែងជាខេត្តមួយដែលល្បីខាងជាងតម្បាញទៀតហើយ ។ ខេត្តកំពង់ចាមបានរលាយអស់នូវសហគមន៍ជាងទងរបស់ខ្លួន ។ ទំនៀមទម្លាប់ជាប្រពៃណីទាំងឡាយត្រូវបានបំផ្លាញតែមួយយប់ប៉ុណ្ណោះ ។

ពួកអ្នកឯកទេសខាងធ្វើម្ហូបអាហារឆ្ងាញ់ៗប្រចាំភូមិភាគ ក៏រលាយបាត់បង់ដែរ ។ កាលពីដើមខេត្តខ្លះត្រូវបានប្រជាជនស្គាល់ដឹងច្បាស់ចំពោះទឹកគ្រឿងរបស់គេ និងបង្អែម ។ នៅមុនកាលបដិវត្ត គឺមុនសង្គ្រាមមិនទាន់រីករាលដាលដល់ ភាគច្រើនបំផុតនៃតំបន់ជនបទ ប្រជាជនកម្ពុជាពេញចិត្តណាស់នឹងពូជស្រូវខុសៗគ្នារបស់គេ ។ ពូជស្រូវរបស់ខេត្តបាត់ដំបងមានរសជាតិមួយ ដែលខុសគ្នាទាំងស្រុងពីស្រូវដែលដាំក្នុងខេត្តតាកែវហើយដែលគេទទួលស្គាល់ជាបន្តបន្ទាប់ ។ លក្ខណៈពិសេសដោយឡែកទាំងនេះ បានរលត់រលាយអស់ ដោយការជម្លៀសប្រជាជនទាំងបង្ខំពីកន្លែងមួយទៅកន្លែងមួយ, ការដឹកជញ្ជូនសន្ទូងដែលអនុវត្តដោយឥតគិតគូរពីពេលវេលា និងបញ្ញត្តិដែលប្រិតប្រៀបថា គ្រប់ឃុំ, តំបន់ និងភូមិភាគទាំងអស់ត្រូវប្រើពូជស្រូវដូចគ្នាទាំងអស់ ។

ពួកកម្ពុជា បានទទួលដំណែលអំពីរបៀបគ្រប់គ្រងភូមិភាគ និងតំបន់នានា ដោយការដាក់លេខសម្គាល់នេះពីពួកកុម្មុយនិស្តវៀតណាម ដែលធ្លាប់បង្កើតឲ្យមាននៅក្នុងរយៈពេលនៃសង្គ្រាមឥណ្ឌូចិនលើកទីមួយ ។ ដោយគ្រប់គ្រងប្រទេសទុកដូចជាទីលានប្រយុទ្ធមួយនោះ គេបានបំបាត់ទំនៀមទម្លាប់ជាប្រពៃណីនៅជនបទចោលទាំងអស់ ដូចជា សិល្បៈ និងសិប្បកម្ម របាំ តូរ្យតន្ត្រី ប្រពៃណីនៃការនិទានរឿងប្រឌិតជាដើម ។

សម្រេចសម្រួលទៅ ដោយកម្ចាត់ចោលមនុស្សជាច្រើន និងស្ថាប័នផ្សេងៗដែលគេយល់ឃើញថា មិនបរិសុទ្ធ សក្តិភូមិ នាយទុន ឬដោយនឹកបារម្ភចំពោះអំណាចរបស់គេរលំរលាយដោយរបៀបម្យ៉ាងៗ ពួកខ្មែរក្រហមបានបំផ្លាញសង្គមកម្ពុជាដល់ឫសគល់ ។ បន្ទាប់ពីការកាប់សម្លាប់បំបាត់ជាតិសាសន៍ដទៃ វានៅសល់តែអ្វី

ដែលបក្សចាត់ទុកថា ជាឧត្តមគតិថ្មីសម្រាប់បដិវត្តន៍កម្ពុជាប៉ុណ្ណោះ គឺមនុស្សជំនាន់មនុស្សថ្មី ។

បក្សតែងតែបែរទៅរកកម្លាំងយុវជនជានិច្ច សម្រាប់ជំនួសមនុស្សដែលពួកគេបានសម្លាប់ចោល ជាអ្នករងគ្រោះពីការបោសសម្អាតផ្សេងៗ ឬការធ្វើឲ្យក្លាយទៅជាទាសភាព ។ តាំងពីភាពចាប់ផ្ដើមនៃប្រវត្តិសាស្ត្ររបស់ខ្លួន បក្សតែងជឿទុកចិត្តលើយុវជនជាដរាប ។ យុវជនទាំងឡាយមានរូប ផាត ជាដើម ដែលរស់នៅឆ្ងាយពីទីក្រុង និងដែលចាប់អារម្មណ៍ទៅលើឧត្តមគតិនិយមរបស់បដិវត្តន៍ បានស្វះស្វែងទៅចូលរួមក្នុងជួររបស់បក្ស ។ ការបដិវត្តភាគច្រើន សុទ្ធតែពឹងផ្អែកលើកម្លាំងយុវជន ហើយក្នុងចំណោមនោះ មានការបដិវត្តមួយចំនួនតូចប៉ុណ្ណោះ ដែលបានអនុវត្តដូចពួកខ្មែរក្រហមក្នុងការបង្កើតរបបថ្មីមួយ ។ ការបោះពុម្ពផ្សាយមួយ ក្នុងចំណោមការបោះពុម្ពផ្សាយដំបូងរបស់បក្ស គឺកាសែតយុវជនបដិវត្ត ដែលប្រឹងប្រែង«អប់រំ, បំពាក់បំប៉ន និងបណ្ដុះសតិអារម្មន៍នយោបាយបដិវត្តមួយដល់យុវជន និងយុវនារីនានា[៤១]» ។ ពួកវ័យជំទង់ទាំងនេះ បានយល់ដឹងការសម្ងាត់របស់បក្សមុនពួកមនុស្សពេញវ័យ ឧទាហរណ៍ ពេលនៅក្នុងចលនាយុវជនបដិវត្ត គេបានប្រាប់ឲ្យដឹងថា «អង្គការ» គឺជាបក្សកុម្មុយនិស្តកម្ពុជា ។ គេបានបើកសម័យប្រជុំជាមួយយុវជនទាំងនេះជាច្រើនលើក ដោយលើកពីបញ្ហាស្មុគស្មាញផ្សេងៗ ដែលមានទាក់ទងនឹងលក្ខណៈ របស់ការបដិវត្តកុម្មុយនិស្តនៅកម្ពុជាមកពិភាក្សា គឺទិសដៅ វិធីសាស្ត្រ និងមនោគមវិជ្ជារបស់បក្ស ។

ក្នុងលេខដំបូងរបស់ខ្លួនដែលចេញផ្សាយនៅខែសីហា ឆ្នាំ១៩៧៣ ទស្សនាវដ្ដីបក្សបានសរសេរថា យុវជនត្រូវធ្វើខ្លួនឲ្យក្លាយទៅជា«កម្លាំងស្នូលរបស់ចលនាបដិវត្ត» ។ បក្ស បានលើកតម្លៃពីគុណូបការៈរបស់យុវជនរាប់រយពាន់នាក់ ដែលស្ថិតនៅក្នុងជួរបដិវត្តន៍នាពេលនោះ -ក្នុងកងទ័ព មន្ទីរក្រសួងនានា សមរភូមិមុខ និងសមរភូមិក្រោយ ។ បក្ស និងកងទ័ព ត្រូវបានជ្រើសរើសពីក្នុងផ្ទៃអង្គការយុវជនបដិវត្តដែលជាអង្គការរណបមួយ ក្នុងចំណោមអង្គការរណបដ៏កម្រមានរបស់បក្ស ។ យុវជនបានក្លាយទៅជា«រចនាសម្ព័ន្ធ» របស់កងទ័ពខ្មែរក្រហម ហើយនៅថ្ងៃជ័យជម្នះ ប្រជាជននៅក្រុងភ្នំពេញ មានអាការៈភ្ញាក់ផ្អើលយ៉ាងខ្លាំង ដោយបានឃើញមុខយុទ្ធជនក្មេងៗយ៉ាងចម្លែក នៅក្នុងជួររបស់អ្នកឈ្នះ ។

យុវជនទាំងនេះ ក៏ធ្លាប់ធ្វើឲ្យកងទ័ព លន់ នល់ ភ្ញាក់ផ្អើលមិនតិចដែរក្នុងរយៈពេលសង្គ្រាម ។ នៅចុងឆ្នាំ ១៩៧៣ កងទ័ពស្រីខ្មែរក្រហមមួយកងវរសេនាតូច ត្រូវបានចាប់ជាឈ្លើយសឹក ហើយត្រូវសាកសួរចម្លើយដោយកងទ័ពរបស់ លន់ នល់ ។ អ្វីដែលធ្វើឲ្យពួកទាហានទទួលបន្ទុកសួរចម្លើយស្រឡាំងកាំង គឺអាកប្បកិរិយារបស់យុទ្ធនារីទាំងនោះ «ភាពមោះមុតរបស់ស្រីក្រមុំទាំងនេះ ដែលមានបុកពាព្រហើន ហ៊ានសម្លឹងមើលមនុស្សប្រុសម្នាក់ ពេញកែវភ្នែករបស់ខ្លួន ហើយដែលគ្មានអង្រួនជើងឡើយ និងមានបុកពារមទម្យមួយជាស្ត្រីខ្មែរត្រឹមត្រូវពិតៗ[៤២]» ។

ស្ត្រីទាំងនោះ សុទ្ធតែជាយុទ្ធនារីដែលបែកចេញពីគ្រួសារ និងភូមិកំណើតរបស់គេតាំងពីអាយុ ដប់ពីរឆ្នាំ

ម្ល៉ះ ហើយមិនដែលវិលត្រឡប់ទៅផ្ទះវិញសោះឡើយ ។ កងទ័ពទាំងនេះ ត្រូវបានបំពាក់បំប៉នសតិអារម្មណ៍ និងបញ្ចូលទ្រឹស្តីដោយបក្ស ។ ប្រជាជនកម្ពុជាភាគច្រើនបានប្រៀបធៀបពួកកម្មាភិបាល និងយុទ្ធជនក្មេងៗទាំងនេះ ទៅនឹងឆ្កែសម្រាប់ការពារម្ចាស់ ដែលគេបានបង្ហាត់បង្រៀនយ៉ាងល្អ ។ សម្តីមួយម៉ាត់របស់ចៅហ្វាយនាយគេ អាចបញ្ជូនពួកគេឲ្យទៅប្រព្រឹត្តអំពើឧក្រិដ្ឋផ្សេងៗទាំងកំរោល ឬស្ទុះរត់តម្រង់ទៅរកកាំភ្លើងយន្តសត្រូវដោយគ្មានរួញរាឡើយ យ៉ាងហោចក៏តាមលក្ខណៈខាងក្រៅដែរ ។ ពួកគេសុទ្ធតែជាកងឈានមុខ (ទ័ពស្រួច) ជាវីរជនវ័យក្មេង ដែលសុខចិត្តលះបង់ថាមពល និងទេពកោសល្យរបស់ខ្លួន ចំពោះមនោគមវិជ្ជា ដែលមានព្រំដែនរបស់ខ្មែរក្រហម ។

បក្សបានណែនាំប្រាប់ពួកគេថា ត្រូវមាន«សតិអារម្មណ៍វណ្ណៈមួយ ទស្សនៈបដិវត្តដាច់ខាត មោទនភាពជាតិ និងទឹកចិត្តស្នេហាជាតិ ត្រូវឈានមុខធ្វើការប្រយុទ្ធមិនស្រាកស្រាន្តមួយប្រឆាំងនឹងសត្រូវ និងធម្មជាតិ «ដើម្បីកសាងខ្លួនដោយខ្លួនឯង» ត្រូវបម្រើប្រជាជាតិ និងប្រជាជនដោយ «វីរភាពបដិវត្តខ្ពស់» និង «ដោយសតិអារម្មណ៍ស្រួចស្រាល់ចំពោះរបបសម្ហូហភាព និងជម្រុះចោលប្រយោជន៍ស្ទួនតួទាំងអស់...» ។

ក្នុងរយៈពេលសង្គ្រាម ពួកយុវជនបានវាយប្រយុទ្ធឥតឈប់ឈរឡើយ ។ យុទ្ធជនម្នាក់បាននិយាយថា «ក្នុងបណ្តាថ្ងៃខ្លះ យើងគ្មានបានហូបអ្វីទាំងអស់... យើងនៅតែវាយលុកជានិច្ច... ទោះជានៅក្នុងកំឡុងពេលមានការទម្លាក់គ្រាប់បែកយ៉ាងខ្លាំងពីសំណាក់ពួកអាមេរិកក៏ដោយ[៤៣]» ។

បន្ទាប់ពីសង្គ្រាម បក្សបានរំសាយយុទ្ធជនក្មេងៗមួយចំនួនធំឲ្យចេញពីកងទ័ព ដើម្បីប្រគល់តំណែងឲ្យធ្វើជាមេដឹកនាំសហករណ៍ រោងចក្រ ចម្ការកៅស៊ូ និងមន្ទីរក្រសួងនានា[៤៤] ។ បទពិសោធន៍ខាងកងទ័ពរបស់ពួកគេមានសារសំខាន់ជាងសមត្ថភាពរបស់រៀមច្បងពួកគេទៅទៀត ។ យុវជនទាំងនោះ បានទទួលរង្វាន់លើកទឹកចិត្តជាថ្នូរមកវិញនូវមុខតំណែងផ្សេងៗ ម្ហូបអាហារមួយ និងលំនៅដ្ឋានមួយយ៉ាងប្រសើរ និងនិមិត្តរូបផ្សេងៗនៃអំណាច ដែលឈានពីម៉ូតូទៅប៊ិច និងកាំភ្លើងខ្លី ។ គេបានផ្តល់គុណសម្បត្តិឲ្យអតីតយុទ្ធជនក្មេងៗទាំងនេះថាជា«ឧបករណ៍នៃអំណាចផ្តាច់ការ ដែលស្មោះត្រង់បំផុត របស់អង្គការបដិវត្តន៍» ។

ពួកវ័យជំទង់ទាំងនេះ ត្រូវបានទទួលការអនុគ្រោះប្រសើរជាងគេ ។ ពួកគេបានរួចផុតពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលតម្រូវដោយពួកចាស់ៗ ។ ក្នុងកម្ពុជាប្រជាធិបតេយ្យ គេអាចរៀបអាពាហ៍ពិពាហ៍បានលុះណាតែមានការយល់ព្រមពី «ពួកអ្នកចាស់» នៅក្នុងសហករណ៍ប៉ុណ្ណោះ បានន័យថា គ្រប់អាពាហ៍ពិពាហ៍ គឺបក្សជាអ្នករៀបចំទុកដាក់ឲ្យ ។ ការប្រកាន់ច្បាប់តឹងរ៉ឹងហួសរបស់របបនេះ បានរារាំងមិនឲ្យគូស្វាមីភរិយាជាច្រើនរស់នៅជួបជុំគ្នាឡើយ ហើយបានអនុញ្ញាតសិទ្ធិឲ្យមករួមដំណេកតែពីរ-បីដងប៉ុណ្ណោះក្នុងមួយខែ ។

ក្នុងលំដាប់ដែលការកាប់សម្លាប់ កើនរឹតតែច្រើនឡើងៗ និងពេលដែលបក្សមិនអបអរវណ្ណៈ និងប្រភេទប្រជាជនថ្មី ពួកវ័យជំទង់ត្រូវ បានត្រូវហៅឲ្យទៅកាន់កាប់មុខងារផ្សេងៗ នៅតាមជនបទ តាមរោងចក្រ និងមន្ទីរ

ក្រសួងនានា ។ ក្មេងជំទង់ម្នាក់ក្នុងចំណោមក្មេងៗទាំងនោះឈ្មោះ ឆយ វណ្ណា[៨៦] ដែលជាមនុស្សសំណព្វរបស់បដិវត្ត បានរស់នៅក្នុងជីវភាពប្រសើរជាងគេមួយ បើប្រៀបធៀបនឹងប្រជាជនកម្ពុជាភាគច្រើនដទៃទៀត ។

វណ្ណា មានអាយុដប់បួនឆ្នាំ នៅពេលដែលពួកខ្មែរក្រហមឈ្នះសង្គ្រាម ។ កាលណោះ ឪពុកម្តាយរបស់នាងមានដីចម្ការចំនួន ពីរហិកតា នៅភាគខាងត្បូងខេត្តកំពង់ចាម ដែលនៅលើដីនោះ គាត់បានដាំថ្នាំជក់ ដំឡូង និងសណ្តែកបាយ ។ គាត់ទាំងពីររកលុយបានយ៉ាងគ្រប់គ្រាន់សម្រាប់ឲ្យ វណ្ណា បានទៅរៀនសូត្រនៅសាលាបឋមសិក្សាមួយ រហូតដល់នាងមានអាយុ១០ឆ្នាំ និងជិតចេះអាន ចេះសរសេរទៅហើយ ។ ក្នុងរយៈពេលមួយភាគធំនៃសង្គ្រាម គ្រួសារនាងបានស្ថិតនៅក្រោមការកាន់កាប់របស់កងទ័ព លន់ នល់ ហើយ វណ្ណា បានឃើញខ្មែរក្រហមម្នាក់ជាលើកដំបូងបំផុត បន្ទាប់ពីការវាយប្រយុទ្ធគ្នាបញ្ចប់ទៅ នៅពេលដែលកងទ័ពរបស់ភូមិភាគបូព៌ាចូលមកត្រួតត្រាដឹកនាំតំបន់នេះ ។

ឪពុកម្តាយរបស់ វណ្ណា ពុំត្រូវគេចាត់ទុកដូចពួកអ្នកទីក្រុង ដែលត្រូវជម្លៀសទេ ៈ ជាកសិករដែលគ្មានឆ្លងកាត់ការអប់រំនយោបាយ គាត់បានត្រូវគេផ្តល់សិទ្ធិផ្សេងៗ ដូចជា "ពួកអ្នកមូលដ្ឋាន" ដែរ ។ វណ្ណា ក៏ពុំដែលជួបប្រទះ "អ្នកថ្មី" ណាម្នាក់ក្នុងកំឡុងឆ្នាំទីមួយ បន្ទាប់ពីសម័យសង្គ្រាមដែរ ។ គ្រួសារនាង ត្រូវគេបញ្ជូនទៅភាគខាងត្បូង ដើម្បីជួយដាំស្រូវក្រុមសាមគ្គីមួយ នៅខែឧសភា ឆ្នាំ១៩៧៥ ។ នាងត្រូវគេដាក់ឲ្យស្ថិតនៅក្រោមការទទួលខុសត្រូវរបស់កសិករបដិវត្តម្នាក់ ដែលធ្វើឲ្យ វណ្ណា កោតស្ញប់ស្ញែងយ៉ាងខ្លាំង ដោយសារទស្សនៈយុត្តិធម៌ និងសមភាពរបស់គាត់ ។ នាងបាននិយាយរៀបរាប់ថា "ពេលម៉ោងធ្វើការ មានលក្ខណៈពិបាកបំពេញណាស់ ស្បៀងអាហារមិនគ្រប់គ្រាន់ ប៉ុន្តែ យើងបរិភោគអាហារដូចៗគ្នាទាំងអស់" ។

ការរស់នៅក្នុងចំណោម "ពួកអ្នកមូលដ្ឋាន" ពុំមែនជារឿងនាំឲ្យធុញទ្រាន់ "ពួកអ្នកថ្មី" បានស្គាល់នោះទេ ។ នៅពេលនាងត្រឡប់មកផ្ទះវិញ គ្រួសាររបស់ វណ្ណា ត្រូវបានអង្គការបញ្ចូលទៅក្នុងសហករណ៍មួយ ហើយត្រូវបាត់បង់ដីកម្មសិទ្ធិផ្ទាល់របស់គាត់ ប៉ុន្តែ គ្រួសារនាងបានសម្របតាមដោយគ្មានថ្ងូរត្អូញត្អែរឡើយ ។ នៅខែកក្កដា ឆ្នាំ១៩៧៦ ការរស់នៅបានផ្លាស់ប្តូរយ៉ាងគំហុក ៈ គេបានបង្កើតផ្ទះបាយរួមមួយ សហករណ៍ និងកងឯកភាពការងារទាំងឡាយ ត្រូវបានគេពង្រីកឲ្យកាន់តែធំ ថ្វីបើមានការតវ៉ាជំទាស់ជាច្រើនលើកក៏ដោយ ។ សមាជិកគ្រួសារនីមួយៗត្រូវគេបំបែកចេញពីគ្នា ។ វណ្ណា ដែលមានអាយុដប់ប្រាំឆ្នាំ និងមានសុខភាពមាំមួន បានត្រូវគេចាត់តាំងឲ្យទៅនៅកងចល័តមួយ ជាមួយយុវនារីដទៃទៀត ដែលមានអាយុស្របាលៗនឹងនាងដែរ ហើយត្រូវគេបញ្ជូនឲ្យទៅធ្វើការនៅផ្នែកផ្សេងទៀតរបស់ខេត្ត ។ នាងបានចាកចេញពីឪពុកម្តាយរបស់នាង ដែលនាងប្រហែលជាលែងបានឃើញមុខគាត់ម្តងទៀត ជារៀងរហូត ។

ជាអ្នកត្រូវកសាងទំនប់ទឹក យុវនារីទាំងនេះ បានសង់ទីជម្រករស់នៅដោយខ្លួនឯងផ្ទាល់ ។ ក្រោយពីបានដាំស្រូវ និងជីកប្រឡាយក្នុងរយៈពេលពីរ-បីខែរួចមក ពួកនេះត្រូវគេផ្លាស់ទីកន្លែងជាថ្មី និងបញ្ជូនឲ្យទៅធ្វើការ

នៅចម្ការកៅស៊ូជប់ ដែលបានក្លាយទៅជាកសិកដ្ឋានមួយរបស់រដ្ឋ ។ របបម្ហូបអាហារប្រចាំថ្ងៃ មានគុណភាពសមល្មម ប៉ុន្តែ ពួកនាងពុំសូវមានពេលបានឈប់សម្រាកទេ ។ នេះជាការរស់នៅរបស់ពួកយុវជនដែលមានឯកសិទ្ធិ ។

នៅពេលដែលយុវនារីទាំងនេះ ចាប់ផ្ដើមចេះបំពេញការងារខាងកៅស៊ូច្បាស់លាស់ហើយ ពួកនាងបានត្រូវគេផ្ទេរទៅកន្លែងថ្មីមួយទៀត គឺរោងចក្រឆ្នៃជ័រកៅស៊ូមួយនៅក្រុងភ្នំពេញ ។ វណ្ណា មានចិត្តសប្បាយរីករាយណាស់ ដែលលែងស្គាល់នូវភាពតឹងតែងនៃ“ក្រុមការងារ”របស់នាង និងជីវិតរបៀបពនេចរឆ្ងាយពីគេរបស់នាងតទៅទៀត ។ នាងជាកូនស្រីរបស់កសិករ ពុំមែនជាកូនរបស់ទាសករទេ ហើយនាងមិនចូលចិត្តធ្វើការងារជា“ក្រុម”ៗរបៀបនេះឡើយ ។ គេបានចាត់ឲ្យនាងទៅធ្វើការនៅក្នុងរោងចក្រមួយ ស្ថិតនៅជាយក្រុងខាងជើងរដ្ឋធានី ដែលស្ថាបនាឡើងដោយក្រុមហ៊ុនចម្រុះរបស់បារាំង ស្ថិតនៅតាមបណ្ដោយមាត់ច្រាំងទន្លេមេគង្គ ដោយមានកំពង់ដែលសម្រាប់រើដាក់ជ័រកៅស៊ូ ដែលមកពីចម្ការកៅស៊ូនានាដោយងាយស្រួល ។ គ្រឿងយន្តទាំងអស់ត្រូវបានគ្រួសារមួយនៅភ្នំពេញ ដែលធ្លាប់ធ្វើការក្នុងរោងចក្រនេះ កាលពីជំនាន់បារាំង ជាអ្នកមើលថែទាំ ។ ពួកអ្នកធ្វើការដទៃទៀត សុទ្ធតែជាពួកយុវជនបដិវត្តរបស់ភូមិភាគបូព៌ា ពីព្រោះកម្មករចាស់ ត្រូវគេសម្លាប់ចោលអស់ទៅហើយ ។

រោងចក្រនេះ បានធ្វើសកម្មភាពពេញម្ភៃបួនម៉ោង ដោយបែងចែកជាបីវេន ក្នុងមួយវេនប្រាំបីម៉ោង ។ ជាទូទៅ យុវនារីទាំងនេះ ទទួលរ៉ាប់រងការងារតែមួយវេនប៉ុណ្ណោះ ក្នុងមួយថ្ងៃ ។ ក្នុងដប់ថ្ងៃម្ដង រោងចក្របានអនុញ្ញាតឲ្យឈប់សម្រាកមួយថ្ងៃ ប៉ុន្តែ ពុំមែនឈប់បំពេញភារកិច្ចបដិវត្តនោះទេ ពួកនាងៗទាំងនោះ ត្រូវដាំបន្លែបន្ការ ឬដាំស្រូវនៅលើដីក្បែរៗទីក្រុង ចូលរួមស្ដាប់សម័យប្រជុំនយោបាយផ្សេងៗ ដែលគួរឲ្យធុញទ្រាន់ របៀបគ្នានឹងការប្រជុំនៅសហករណ៍ទាំងឡាយដែរ ។ វណ្ណា បានរៀបរាប់ថា «គេតឿនបង្ខំឲ្យយើងខំធ្វើការខ្លាំងថែមទៀត គេមិនឲ្យនឹកគិតទៅក្រុមគ្រួសាររបស់យើងគ្រប់តែពេលនោះទេ ហើយមិនត្រូវគេចវេះពីការងារឡើយ ទោះបីជាយើងមានជំងឺបន្តិចបន្តួចក៏ដោយ ។ យើងអាចឈប់សម្រាកមិនធ្វើការងារ លុះត្រាតែពេលណាដែលយើងឈឺធ្ងន់ប៉ុណ្ណោះ» ។

នៅទីនោះ គ្មានអ្វីសម្រាប់កែអផ្សុកឡើយ គ្មានសៀវភៅ គ្មានទាំងការអប់រំពិតប្រាកដ ហើយមិនដែលមានការឈប់សម្រាកទាល់តែសោះ ។ ប៉ុន្តែ វណ្ណា យល់ឃើញថា នាងមានជីវភាពមួយដែលមានឯកសិទ្ធិដែរ ។ នាងជាសមាជិកម្នាក់ក្នុងយុវនារីមួយក្រុម ដែលមានគ្នាសាមសិបនាក់ ស្នាក់អាស្រ័យក្នុងផ្ទះឈើធំទូលាយមួយ នៅចំពីមុខរោងចក្រ ។ យុវនារីទាំងនេះ ធ្វើការ ដេក និងហូបរួមគ្នា ហើយម្ហូបអាហារមានគុណភាពល្អ និងសម្បូរពោរពាស ។ ប្រធានរបស់ពួកនាង ជាបុរសម្នាក់ដែលត្រូវបរិភោគមុនគេ ហើយពេលដែលគាត់ឆ្អែតស្កប់ស្កល់ ទើបពួកយុវនារីទាំងនោះ អាចចូលហូបបាន ។ ម្យ៉ាងវិញទៀត ពួកនាងទាំងនោះ ក៏មានសិទ្ធិផ្ញើ និងទទួលសំបុត្រពីគ្រួសារបានដែរ ។ អ្នកទទួលខុសត្រូវលើកប៉ាល់ទាំងឡាយ ដែលដឹកជញ្ជូនជ័រកៅស៊ូឲ្យរោងចក្រ រួមទាំងអ្នកបើក

ឡានកាមីញ៉ុងផង ជាអ្នកនាំសាររត់សំបុត្រក្រៅផ្លូវការម្នាក់ ដែលត្រូវនាំសំបុត្រស្នាមទៅឲ្យ“ពួកអ្នកមូលដ្ឋាន” និងពួកកុម្មុយនិស្ត ។ ម្យ៉ាងទៀត យុវនារីទាំងនេះ បានទទួលការថែទាំព្យាបាលជំងឺក្នុងមន្ទីរពេទ្យនានារបស់ខ្មែរក្រហមនៅក្រុងភ្នំពេញ ។ យុវនារីខ្លះ បានរៀបការនៅក្នុងកំឡុងដែលមានពិធីរៀបការម្តងៗ ជាច្រើនគូ ប៉ុន្តែ បើសិនជាយុវនារីណាម្នាក់ តវ៉ាដោយម៉ឺងម៉ាត់នោះ នាងអាចរួចផុតពីអាពាហ៍ពិពាហ៍ដែលផ្ទុយនឹងឆន្ទៈរបស់នាងបាន ។ វណ្ណា ពុំដែលនឹកឃើញពីអំពើឃោរឃៅណាមួយ ដែលគេប្រព្រឹត្តមកលើរូបនាង ឬអ្នកណាម្នាក់ក្នុងចំណោមមិត្តភក្តិរបស់នាងឡើយ ។

នាងមិនបោះបង់ការចាប់អារម្មណ៍មួយអំពីជំនាន់នេះ ដែលនឹងធ្វើឲ្យ ប៉ុល ពត សប្បាយរីករាយយ៉ាងខ្លាំង ៖ “ការរស់នៅមានរបៀបរៀបរយល្អ និងសុខសាន្ត” ។

យុវនារីទាំងនេះ សុទ្ធតែជាមនុស្សដែលរស់នៅដាច់ឆ្ងាយពីការបដិវត្ត ពិសេសឆ្ងាយពីមន្ទីរឃុំឃាំងដ៏គួរឲ្យព្រឺខ្លាចនៅទួលស្លែង ពីភាពក្រីក្រតោកយ៉ាក និងការសម្លាប់រង្គាលទាំងឡាយ ដែលគេបានប្រព្រឹត្តនៅក្នុងទីក្រុង ក៏ដូចនៅជនបទដែរ ។ នាងៗទាំងនោះ បានចាកចេញពីភូមិភាគបូព៌ា នៅមុនមានការបោសសម្អាតផ្សេងៗ ហើយការកម្រិតព្រំដែនក្នុងការដើរហើរ ហាក់ដូចជាបង្ការពួកនាងឲ្យរួចផុតពីអំពើកំណាចឃោរឃៅ ដែលកើតមានរៀងរាល់ថ្ងៃក្នុងក្រុងភ្នំពេញ ព្រោះថា ពួកនាងពុំមានសិទ្ធិចេញពីផ្ទះ ឬពីរោងចក្រឡើយ ទោះជាការដើរកំសាន្តជាធម្មតាមួយក្តី ។ នៅពេលដែលគេនាំពួកនាងទាំងនោះទៅស្ទូងស្រូវ ឬដាំបន្លែក្នុងតំបន់ជុំវិញទីក្រុង ពួកនាងត្រូវគេបំបែកចេញទីទៃៗពីគ្នា ។ នេះជា “ការបំបែកបំបាក់សង្គមមនុស្ស” ដ៏ល្អឥតខ្ចោះ ដែលលោកស្រី ហាន់ណាស់ អារេនត៍ ធ្លាប់បានពិពណ៌នា ក្នុងសង្គមមួយដែលគេបង្កើតឡើងលើអំពើភេរវកម្ម ។

ប៉ុន្តែ ស្ថានការណ៍ដ៏គ្រោះថ្នាក់ផ្សេងៗរបស់បដិវត្តន៍ បានជ្រាបចូលសន្សឹមៗមកក្នុងជីវភាពរស់នៅរបស់នាងហើយ ។ វណ្ណា បានទទួលសំបុត្រមួយពីម្តាយរបស់នាងដែលមានជំងឺជាទម្ងន់ ដោយផ្ញើរសុំឲ្យនាងវិលទៅផ្ទះវិញ ។ នាងបានធ្វើពាក្យសុំមួយទៅប្រធានរោងចក្រ ប៉ុន្តែ គេពុំព្រមអនុញ្ញាតច្បាប់ឈប់ឲ្យនាងឡើយ ។ វណ្ណា បានគោរពតាមការសម្រេចនេះ ។ ប៉ុន្មានខែក្រោយមក នាងបានទទួលដំណឹងមរណភាពរបស់ម្តាយនាង ហើយនាងលែងបានទទួលពត៌មានណាមួយពីគ្រួសារនាងទៀតហើយ ។ អំណឹះតទៅ នាងនៅតែម្នាក់ឯងគត់ ដោយរស់ទាំងអស់សង្ឃឹមក្នុងបដិវត្តន៍អាថ៌កំបាំងនេះ ។

នៅឆ្នាំ១៩៧៧ ប្រហែលជាខែកញ្ញា មានយុវនារីម្នាក់ក្នុងចំណោមពួកនាង បានធ្លាក់ខ្លួនឈឺ ហើយត្រូវបាននាំយកទៅកាន់មន្ទីរពេទ្យព្យាបាល ដែលនៅទីនោះ នាងបានឃើញកងទ័ពរបួសជាច្រើននាក់ តាមគេនិយាយប្រាប់នាងថា ត្រូវរបួសក្នុងការប្រយុទ្ធគ្នាជាមួយនឹងកងទ័ពវៀតណាម ។

ប្រហែលជានៅជំនាន់នោះដែរ មានលេចឮពាក្យចចាមអារ៉ាមតៗគ្នា ស្តីពីការជ្រួលច្របល់នៅក្នុងភូមិភាគបូព៌ា បានរាលដាលពេញផ្ទៃរោងចក្រ ៖ កម្មាភិបាលមួយចំនួនតូច ឬទូទាំងភូមិភាគ ត្រូវ មជ្ឈិម ចោទប្រកាន់ពីបទ

ថា បានដឹកនាំគ្រប់គ្រង ដែលនាំឲ្យមានគ្រោះថ្នាក់ដល់ប្រទេសជាតិ ។ មេដឹកនាំភូមិភាគបូព៌ាជាច្រើននាក់ បានប្រព្រឹត្តអំពើក្បត់ ហើយយុវនារីទាំងនោះ ឮគេនិយាយទៀតថា ភូមិភាគនិរតី បានបញ្ជូនកម្មាភិបាលថ្មីៗយ៉ាងច្រើន ទៅជំនួសពួកកម្មាភិបាលភូមិភាគបូព៌ា ដែលប្រែទៅជាមានឈ្មោះថា ជាមនុស្សដែលផ្តល់គ្រោះថ្នាក់ ឬជាមនុស្សក្បត់ជាតិទៅវិញ ។ គេបានកោះធ្វើការប្រជុំ ក្នុងពេលអាសន្នមួយនៅរោងចក្រ ដើម្បីពិភាក្សាគ្នាពីការគំរាមកំហែងរបស់វៀតណាម ប៉ុន្តែ គ្មានអ្នកណាម្នាក់ លើកនិយាយពីការវឹកវរ ដែលកំពុងកើតមាននៅភូមិភាគបូព៌ាឡើយ ។ បញ្ហានេះ បានធ្វើឲ្យពួកយុវនារីទាំងនោះ ខ្វល់ព្រួយក្នុងចិត្ត ដូចគ្នានឹងគ្រោះថ្នាក់ ដែលចេញមកពីពួកវៀតណាមដែរ ពីព្រោះពួកនាងសុទ្ធតែមានដើមកំណើតនៅភូមិភាគបូព៌ាទាំងអស់ ។ តើកម្មាភិបាលទាំងនោះជាអ្នកណាខ្លះទៅ? ជាមិត្តភក្តិ ឬជាឪពុកម្តាយ? ជាមនុស្សនៅក្នុងភូមិរបស់គេ? ហើយក្នុងកាលៈទេសៈដូច្នេះសម្រាប់ពួកនាង តើរឿងទាំងនេះត្រូវគេប្រាប់ឲ្យដឹងដែរទេ? ។

យុវនារីទាំងនោះដឹងថា ពួកនាងគ្មានសិទ្ធិចោទសួរពីបញ្ហាអស់នេះនៅក្នុងអង្គប្រជុំឡើយ ដែលមានរបៀបវារៈផ្លូវការតែមួយប៉ុណ្ណោះ គឺអំពើគំរាមកំហែងថ្មីៗនេះ ចេញមកពីខាងប្រទេសវៀតណាម តែគេមិនបានបញ្ជាក់ឲ្យច្បាស់លាស់ឡើយ ។ ប៉ុន្តែសេចក្តីព្រួយបារម្ភរបស់ពួកកម្មករទាំងនោះ សុទ្ធតែផ្តែកលើភ័ស្តុតាងជាច្រើន ។ ការធ្វើបដិវត្តន៍ត្រូវតែមានជនរងគ្រោះ ជនដែលចាំតែរងកំហុស គឺពួកអ្នកទាំងនេះហើយ ដែលគេត្រូវទម្លាក់ការទទួលខុសត្រូវ អំពីបញ្ហាទាំងឡាយ ដែលមានពាក់ព័ន្ធទៅនឹងរដ្ឋនោះ ។

គ្មានអ្នកណាម្នាក់រួចផុតពីគ្រោះថ្នាក់ឡើយ ទាំងពួកយុវជនដែលមានឯកសិទ្ធិ ទាំងសមាជិកបក្ស កម្មាភិបាល និងកងទ័ពរាប់ពាន់នាក់ ក៏គេចមិនរួចដែរ ។ គ្រួសារជាច្រើនរបស់មិត្តភក្តិ វណ្ណា នឹងត្រូវគេសម្លាប់ក្នុងកំឡុងនៃការកម្ទេច និងការបោសសម្អាតជាបន្តបន្ទាប់មកទៀត ។ បន្ទាប់ពីបំផ្លិចបំផ្លាញសង្គមចាស់ និងបំបែកប្រជាជនឲ្យរស់នៅឆ្ងាយពីគ្នាមិនអាចទាក់ទងគ្នាបានរួចហើយ ពេលនេះបណ្តាមេដឹកនាំមជ្ឈិមបានចាប់ផ្តើមកាប់សម្លាប់គ្នាឯងម្តង ។



ហួត បុប្ផាណា នៅមន្ទីរស-២១
ថ្ងៃចាប់ខ្លួន ១២-តុលា-១៩៧៦
ថ្ងៃកម្ទេច ១៨-មិនា-១៩៧៧

## ជំពូកទី៧
## «បក្សជាទីគោរព និងជាទីស្នេហា!...»

*«ចំណុចកំពូលរបស់អំពើភេរវកម្ម ដែលឡើងដល់កម្រិតខ្ពស់បំផុត គឺនៅពេលណាដែលប៉ូលិសរបស់រដ្ឋចាប់ផ្តើមសម្លាប់ ប្រជាជនរួមជាតិឯង និងនៅពេលដែលពេជ្ឈឃាតពីម្សិលក្លាយទៅជាអ្នករងគ្រោះនៅថ្ងៃនេះ» ។*

*ហាន់ណាស់ អារេនត៍*

*បក្សជាទីគោរព និងជាទីស្នេហា និងបងៗជាមេដឹកនាំបក្ស ជាទីគោរព និងជាទីស្នេហា ខ្ញុំសូមឲ្យបក្ស និងបណ្តាសមមិត្តជាទីគោរព និងជាទីស្នេហា អាណិតអាសូរខ្ញុំផង ។ គ្មានពេលណាមួយ ដែលខ្ញុំមានបំណងក្បត់បក្សបន្តិចសោះឡើយ.... ។*
*ដោយយល់ពីគំនិតផ្សេងៗរបស់បក្សដែលខ្ញុំធ្លាប់ដឹង ខ្ញុំអាចត្រឹមតែបញ្ជាក់ប្រាប់បក្សដោយស្មោះត្រង់ថា ខ្ញុំខ្លាចប្រភេទនៃសេចក្តីស្លាប់បែបនោះខ្លាំងណាស់[១]... ។*

*សមមិត្ត ផាត់ សរសេរនៅមន្ទីរឃុំឃាំង*
*របស់ផ្នែកសន្តិសុខ ក្រុងភ្នំពេញ ខែមករា ឆ្នាំ១៩៧៨*

គេអាចស្វែងយល់ពីរបបមួយ ដោយធ្វើការសិក្សាស្រាវជ្រាវពីស្ថាប័នផ្សេងៗ ដែលរបបនេះបង្កើតឡើង គឺតាមរយៈមន្ទីរឃុំឃាំងទួលស្លែង[២] ដែលល្មមធ្វើឲ្យគេនឹកឃើញដល់កម្ពុជាប្រជាធិបតេយ្យយ៉ាងពិតប្រាកដ ។ មណ្ឌលសម្រាប់សួរចម្លើយ ធ្វើទារុណកម្ម និងសម្លាប់មនុស្សនេះ បានត្រូវគេរៀបចំឡើងក្នុងកន្លែងមួយ ដែលពីមុនជាសាលាបឋមសិក្សា និងជាវិទ្យាល័យមួយ នៅទីក្រុងភ្នំពេញ (ជាអតីតសាលាទួលស្វាយព្រៃ និងវិទ្យាល័យពញាយ៉ាត) ។ ខ្មែរក្រហមបានបណ្តេញនិស្សិតទាំងអស់ចេញពីរដ្ឋធានី ហើយបញ្ជូនទៅដាក់តាមជំរំពលកម្មជាច្រើន កាលបើពួកគេមិនទាន់ត្រូវសម្លាប់ភ្លាមៗ ។ ខ្មែរក្រហមបានបិទសាលាផ្សេងៗទូទាំងប្រទេស ប៉ុន្តែ អគារទាំងឡាយរបស់សាលាទួលស្វាយព្រៃ ត្រូវបានបក្សប្រគល់ទៅឲ្យផ្នែកសន្តិសុខកាន់កាប់ ។ ដោយបំបាត់កុមារភាព និងការអប់រំ ដោយសម្លាប់អ្នកចេះដឹង និងអ្នកគ្មានទោសពៃរ៍ ក្នុងនាមនៃបដិវត្តន៍ គឺជាចំណែកមួយនៃអ្វីដែលមន្ទីរឃុំឃាំងទួលស្លែងជាតំណាង ។

នេះជាការចំអកបញ្ឈឺចិត្តអាក្រក់ណាស់, ទទួលស្លែងមានន័យថា «ទួលដែលមានដុះដើមឈើពុល» (ស្លែងជាដើមឈើមួយ ដែលផ្លែរបស់វាត្រូវបានប្រើប្រាស់សម្រាប់ត្រាំស្រាធ្វើជាថ្នាំជីក ហើយអាចពុលស្លាប់បើជីក

ច្រើន) ដោយមាន ឌុច ជាអតីតគ្រូបង្រៀនក្រោមឈ្មោះថា កាំង ហ្គិចអៀវ ធ្វើជាប្រធាន ។

អគារទាំងបួនរបស់អតីតសាលានេះ ត្រូវបានបែងចែកជាផ្នែកៗដាច់ដោយឡែកពីគ្នា សម្រាប់ធ្វើជាកន្លែងឃុំឃាំងមនុស្សនិងធ្វើទារុណកម្ម កន្លែងសម្រាប់ពួកអ្នកយាម និងពួកពេជ្ឈឃាតស្នាក់នៅ កន្លែងតម្កល់ឯកសារដ៏ច្រើនសន្ធឹកសន្ធាប់ ។ ពួកសន្តិបាលបានរក្សាទុកសំណុំឯកសារជាច្រើននៅក្នុងនោះ ដែលភាគច្រើនជារបស់អ្នកទោសពីរម៉ឺននាក់ ដែលគេនាំយកមកដាក់គុកនៅមណ្ឌលនេះ ដើម្បីសួរចម្លើយ ។ កន្លែងនេះ ក៏មានប្រមូលផ្តុំចម្លើយសារភាពរាប់រយពាន់ទំព័រ រូបថតអ្នករងគ្រោះរាប់ពាន់សន្លឹក និងសេចក្តីណែនាំឲ្យធ្វើទារុណកម្មទៅលើពួកអ្នកទោស ។ ឯកសារទាំងគំនរនេះ រួមផ្សំបានជាប្រវត្តិសាស្ត្រដ៏កម្រមានមួយ របស់បក្សកុម្មុយនិស្តកម្ពុជា ថ្វីបើវាប្រែប្រួលមិនទៀងក៏ដោយ ។

បន្ទប់រៀនជាច្រើន ត្រូវខ្មែរក្រហមខណ្ឌចែកជាបន្ទប់តូចៗថែមទៀត ដោយរៀបឥដ្ឋជាជញ្ជាំងឡើងរហូតដល់កម្ពស់ពាក់កណ្តាលបន្ទប់រៀននោះ ។ សាលប្រជុំធំៗ សម្រាប់ការប្រជុំកាលពីដើម ត្រូវខ្មែរក្រហមបំពាក់ដោយគ្រឿងសម្ភារសម្រាប់ការធ្វើទារុណកម្មពាសពេញ ដូចជា ខ្សែពួរ ច្រវាក់ ដែលផ្តាក់ស្រួចៗ គ្រែដែកជាច្រើន ដែលនៅលើនោះ អ្នកទោសត្រូវគុកចងសន្ទឹង ដោយមានដាក់ច្រវាក់ដៃជើងទាំងអស់ ។ ក្នុងទីធ្លាសាលា ខ្មែរក្រហមរៀបដាក់ពាងទឹកធំៗ សម្រាប់ចាប់ក្បាលអ្នកទោស ជ្រមុជរហូតទាល់តែថប់ដង្ហើម ។ សៀវភៅសរសេរចាស់ៗរបស់សាលា ត្រូវខ្មែរក្រហមយកមកប្រើប្រាស់សម្រាប់ការកត់ត្រាឯកសារ ក្តារខៀនសម្រាប់បិទបទបញ្ជាផ្ទៃក្នុងរបស់មណ្ឌល ដែលបញ្ជាដាច់ខាត មិនឲ្យអ្នកទោសស្រែកក្នុងពេលគេធ្វើទារុណកម្ម ត្រូវឆ្លើយនឹងសំណួរផ្សេងៗឲ្យចំៗ មិនចាំបាច់គិតវែងឆ្ងាយ ហើយត្រូវតាមវិន័យ ដែលពិបាកទ្រាំជាច្រើនទៀត មុននឹងត្រូវយកទៅប្រហារជីវិត ។

ឌុច បានដឹកនាំជំរំមរណៈមួយដែលមានការរៀបចំយ៉ាងល្អឥតខ្ចោះ ។ ពួកសន្តិបាល បានថតរូបពួកអ្នកទោស នៅពេលដែលគេនាំមកដល់ បន្ទាប់មក ថតក្នុងពេលដែលពួកនេះជិតស្លាប់ ឬមុនស្លាប់បន្តិច ដែលសុទ្ធតែមានបំពង់-ករយៈដោយគេអារ ខ្លួនប្រាណត្រូវគេកាត់អវៈយវៈចេញ ឬត្រូវធ្វើឲ្យចុះស្គមកំព្រឹង ដោយការធ្វើទារុណកម្ម និងការស្រេកឃ្លាន ដែលពុំអាចមើលស្គាល់ ជាអ្នកណាម្នាក់ឡើយ ។ រូបថតទាំងនេះ ជាផ្នែកមួយនៃសំណុំលិខិតផ្សេងៗ ដែលគេបានចងក្រងឡើងជាភស្តុតាង ដើម្បីបង្ហាញឲ្យឃើញថា ពួកសត្រូវរបស់រដ្ឋ ត្រូវបានគេសម្លាប់រួចពិតប្រាកដមែន ។ ឌុច ក៏បានកំណត់ជ្រើសរើសថ្ងៃដោយឡែកតាមពួកសម្រាប់អ្នកទោស ដូចជាថ្ងៃមួយសម្រាប់សម្លាប់ពួកស្ត្រីៗដែល«ជាសត្រូវ» ថ្ងៃមួយទៀតសម្រាប់កុមារ ថ្ងៃមួយផ្សេងទៀតសម្រាប់ពួកកម្មកររោងចក្រជាដើម[៣] ។

សេចក្តីកង្វល់ដ៏ល្អិតល្អន់មួយបែបនោះបានក្លាយទៅជានិមិត្តរូបពិសេសលេខមួយរបស់ ឌុច ក្នុងរយៈពេលនៃការឈានឡើងឋានានុក្រមបក្សរបស់គាត់ ។ ជាអតីតគ្រូបង្រៀននៅខេត្តកំពង់ចាម ដែលទៅជាភូមិភាគបូព៌ា

ផ្ទុយទៅវិញគាត់បានចូលធ្វើការនៅភូមិភាគនិរតី នៅពេលដែលគាត់សម្រេចទៅរួបរួមក្នុងជួរអ្នកបដិវត្ត ហើយនៅទីបំផុត ក៏បានបំពេញមុខងារខាងផ្នែកសន្តិសុខរបស់ភូមិភាគនេះ ។ ក្នុងកំឡុងឆ្នាំដំបូងៗនៃសង្គ្រាម គាត់មានឈ្មោះល្បីជាអ្នកធ្វើឲ្យរបៀបគ្រប់គ្រង ការបោសសម្អាតផ្សេងៗរបស់ខ្មែរក្រហម កាន់តែវិសេសជាងមុន និងស្ទាត់កំប៉ាំងគួរឲ្យកត់សម្គាល់ ក្នុងពេលដែលគាត់ដឹកនាំផ្នែកសន្តិសុខរបស់ភូមិភាគនិរតីនេះ ។

នៅឆ្នាំ១៩៧២ គាត់ត្រូវគេផ្ទេរឲ្យមកធ្វើការនៅភូមិភាគពិសេស ដែលនៅជុំវិញទីក្រុងភ្នំពេញវិញ ក្នុងគោលបំណងឲ្យគាត់រៀបចំសន្តិសុខនៅភូមិភាគនេះ ដែលជាភូមិភាគមួយងាយរងការប៉ះទង្គិច និងទន់ខ្សោយបំផុត ក្នុងចំណោមភូមិភាគនានាពេញរយៈពេលនៃសង្គ្រាម ។ នៅពេលដែលគណៈកម្មការមជ្ឈិមទទួលកាន់កាប់កងទ័ព និងអំណាចផ្នែករដ្ឋបាលជំនួសភូមិភាគពិសេស នៅឆ្នាំ១៩៧៥ ឌុច បានក្លាយទៅជាប្រធានសន្តិសុខសម្រាប់ប្រទេសទាំងមូលយ៉ាងស្រួល អាស្រ័យដោយសិទ្ធិអំណាចរបស់គាត់ពីមុនមកផង ។ ប៉ុន្តែ ផ្នែកសន្តិសុខនេះ ជាអង្គភាពមួយរបស់បក្ស ពុំមែនស្ថិតនៅក្រោមអំណាចរបស់រដ្ឋាភិបាលទេ ហើយ ឌុច ត្រូវផ្ញើរបាយការណ៍ផ្សេងៗទៅឲ្យ ប៉ុល ពត ផ្ទាល់ និងសមាជិកគណៈលេខាមជ្ឈិមបក្ស ពីរ-បីនាក់ប៉ុណ្ណោះ ។ សុន សេន ដែលជារដ្ឋមន្ត្រីក្រសួងការពារប្រទេសផង និងជាអគ្គមេបញ្ជាការកងកម្លាំងប្រដាប់អាវុធផង គឺជាមេកោយផ្ទាល់ -ឬជាគូប្រជែង- របស់ ឌុច ។ ក្នុងប្រទេសមួយដែលដឹកនាំដោយអំពើភេរវកម្ម មនុស្សដែល“វែកមុខ” និងសម្លាប់ខ្មាំងសត្រូវរបស់បដិវត្តន៍ បានក្លាយទៅជាមនុស្សកាន់តែមានអំណាចខ្លាំងឡើង ក្នុងលំដាប់ដែលការភ័យបារម្ភរបស់ពួកមេដឹកនាំបក្ស ការគិតមមៃពីសត្រូវផ្ទៃក្នុង និងក្រៅប្រទេសចេះតែរីកធំឡើងៗ ។

ដូច្នេះ ឌុច បានចូលក្នុងក្រុមមេដឹកនាំសំខាន់ៗរបស់ប្រទេស ដែលមានគ្នាតែ ប្រាំ ឬប្រាំមួយនាក់ប៉ុណ្ណោះ នៅពេលដែលទួលស្លែងក្លាយទៅជាមជ្ឈមណ្ឌល“ខួរក្បាល” នៃប្រព័ន្ធចាត់ចែងអំពើភេរវកម្ម ។ នៅពេលដែលមន្ទីរឃុំឃាំងទួលស្លែងចាប់ផ្តើមដំណើរការនៅឆ្នាំ១៩៧៦ បានបន្តិច ការព្រមព្រៀងគ្នាដែលស្ថិតមានមួយរយៈក្នុងជួរគណៈកម្មាធិការមជ្ឈិមបក្សបានប្រេះស្រាំ ហើយ ប៉ុល ពត បានចាត់តាំងឲ្យ ឌុច តាមដានរកពួកសត្រូវក្នុងផ្ទៃបក្ស ក៏ដូចក្នុងប្រជាជនដែរ ។ មិនត្រឹមតែប៉ុណ្ណោះ ឌុច បានចាប់ឃុំខ្លួនពួកអ្នកដែលត្រូវសង្ស័យជាច្រើននាក់ទៀតតាមការចង្អុលប្រាប់របស់ ប៉ុល ពត ប៉ុន្តែ ឌុច ក៏ជាអ្នកជួយប្រឌិតភស្តុតាងផ្សេងៗ ប្រឆាំងនឹងអ្នកទាំងនោះថែមទៀត ។ ដោយមានអំណាចចាត់ការទៅលើចម្លើយសារភាពផ្សេងៗរបស់ជនរងគ្រោះ ដែលជា“ភស្តុតាង” នៃបទឧក្រិដ្ឋនានា ឌុច បានសម្រេចគោលដៅ“បង្អិល”ពួកមេដឹកនាំបក្សតាមចំណង់របស់គាត់ និងជ្រើសរើសទុកជាមុននូវ“ខ្មាំងសត្រូវ” ដែលគេពុំសង់សង្ស័យថែមទៀត ។

ឌុច និងក្រុមសន្តិបាលរបស់គាត់ បានទទួលសិទ្ធិអំណាចផ្សេងៗ ជាចៅក្រមផង ជាទីប្រឹក្សាតុលាការផង និងជាពេជ្ឈឃាតផង ។ នៅទីបំផុត ទួលស្លែងក៏ក្លាយទៅជាកន្លែងដ៏គួរឲ្យស្បើមមួយ ដែលរួចផុតពីការត្រួតពិនិត្យទាំងអស់ ។

គណៈដឹកនាំបក្ស បានចាប់ផ្ដើមមន្ទិលសង្ស័យកម្មាភិបាល និងអ្នកទទួលខុសត្រូវជាន់ខ្ពស់មួយចំនួនតូច នៅពេលដែលខ្លួនត្រូវបានផ្ដល់ព័ត៌មាន ស្ដីពីការធ្វើមិនបានសម្រេចលទ្ធផលតាមផែនការ នៅតាមជនបទនានា ក្នុងកំឡុងឆមាសទីមួយ ឆ្នាំ១៩៧៦ ។ សេចក្ដីរាយការណ៍របស់ អៀង ធីរិទ្ធ អំពីភូមិភាគពាយ័ព្យ គឺជារបាយការណ៍មួយក្នុងចំណោមសេចក្ដីរាយការណ៍ទាំងឡាយ ដែលធ្វើឲ្យមជ្ឈិមអំពល់គំនិតយ៉ាងខ្លាំង ។ មជ្ឈិមបានបកស្រាយបរាជ័យទាំងនេះថា ជាសក្ខីភាពនៃការមិនចុះសម្រុងគ្នាក្នុងជួររបស់ពួកកុម្មុយនិស្ដហើយ ។ ប៉ុន្តែ បើសិនជាកុំមានកម្មាភិបាលមួយចំនួនតូច មិនប្រតិបត្តិតាមបទបញ្ជាខ្លះៗនោះ ក៏ប្រហែលជាមជ្ឈិមគ្មានដឹងថា ខ្លួនត្រូវគំរាមកំហែងដោយមនុស្សផ្ទាល់របស់ខ្លួនដែរ ។

ភស្ដុតាងជាច្រើនដែលគេប្រមូលបាន បង្ហាញឲ្យឃើញលក្ខណៈផ្ទុយទៅវិញ ។ ប្រធានភូមិភាគទាំងឡាយបានរួមសហការយ៉ាងពេញលេញ ក្នុងការជម្លៀសប្រជាជនចេញពីរដ្ឋធានី គោរពធ្វើតាមបទបញ្ជាផ្សេងៗដោយកែប្រែពួកអ្នកទីក្រុងធ្វើឲ្យក្លាយទៅជាកសិករតែក្នុងមួយថ្ងៃប៉ុណ្ណោះ លុបបំបាត់សិទ្ធិជាបុគ្គលទាំងអស់ រឹបអូសទ្រព្យសម្បត្តិទាំងអស់ក្នុងនាមនៃរដ្ឋ កាប់សម្លាប់បណ្ដាជនជាតិភាគតិច និងប្រើអំពើភេរវកម្ម ដើម្បីតម្រូវឲ្យមានការផ្លាស់ប្ដូរទាំងនេះ ។ វាក៏មានការព្រមព្រៀងគ្នា ស្ដីពីការកំណត់ទិសដៅជាមូលដ្ឋាន និងគោលការណ៍ផ្សេងៗរបស់បដិវត្តន៍ដែរ ជាការព្រមព្រៀងគ្នាដើម្បីរៀបចំដំណើរ "មហាលោតផ្លោះ" មួយពីលើខ្នងប្រជាជនសម្រាប់ជំនាន់ក្រោយ ។

ប៉ុន្តែ វាក៏កើតមានបញ្ហាផ្សេងៗពីរឿងអំណាចដែរ ។ មានការវាយប្រយុទ្ធគ្នាតូចតាចមួយបានកើតឡើងនៅតាមផ្លូវថ្នល់នានា ក្នុងទីក្រុងភ្នំពេញ រវាងកងទ័ព ភូមិភាគបូព៌ា និងកងទ័ពភូមិភាគឧត្ដរ ដើម្បីបោសម្អាតអ្នកមិនល្អចេញ ។ ការរង់ចាំដ៏អន្ទះសាអំពីលទ្ធផលដ៏អស្ចារ្យ ខាងវិស័យសេដ្ឋកិច្ចក្នុងចំណោមពួកមេដឹកនាំជាន់ខ្ពស់ បានប្រែក្លាយទៅជាការរកស្វែងរកខ្មាំងសត្រូវ ដែលជាអ្នកដណ្ដើមជោគជ័យរបស់ខ្លួនទៅវិញ ។ នៅឆ្នាំ១៩៧៦ បន្ទាប់ពីការប្រជុំជាបន្តបន្ទាប់មួយ ដើម្បីវាយតម្លៃពីស្ថានភាពប្រទេស គណៈដឹកនាំបក្ស បានសម្រេចចិត្តដាក់ចេញនូវផែនការសេដ្ឋកិច្ចបួនឆ្នាំមួយ កម្ចាត់បណ្ដាសមាជិកបក្ស ដែលក្លាយទៅជាមនុស្សគួរឲ្យសង្ស័យ ដោយអនុលោមទៅតាមប្រព័ន្ធស៊ើបអង្កេតថ្មីមួយហៅថា "ការស្រាវជ្រាវខ្សែបណ្ដាញ" បន្ទំល្បឿនបដិវត្តសង្គមនិយម និងបញ្ចប់រឿងទាំងនោះ ជាមួយនឹងការសម្របសម្រួលជាប្រវត្តិសាស្ត្រ ស្ដីពីបញ្ហាដើមកំណើតបក្សដែលលំបាកតម្រូវចិត្ត និងទំនាក់ទំនងផ្សេងៗរបស់ខ្លួន ជាមួយប្រទេសវៀតណាម ។

ក្នុងភាសារបស់បក្ស គេលែងនិយាយពាក្យ កម្ចាត់ ឬកែប្រែចរិតវណ្ណៈគហបតីទៀតហើយ ប៉ុន្តែ គេនិយាយថា កម្ចាត់និន្នាការគហបតីក្នុងផ្ទៃបក្សផ្ទាល់ ។ តាមការពិត គណៈដឹកនាំបក្សបានត្រូវធ្វើឲ្យផ្លាស់ប្ដូរជំហរដោយសេចក្ដីបារម្ភអំពីអំពើក្បត់មួយរបស់បណ្ដាមិត្តភក្ដិ និងសម្ព័ន្ធមិត្តរបស់ខ្លួន ។ ដែលចាក់ឫសយ៉ាងជ្រៅតាំងពីមុនមក ដើមដំបូងនៃការបដិវត្ត ពួកកុម្មុយនិស្ដខ្មែរបានទទួលរងការឈឺចាប់បន្តិចបន្តួច ព្រោះតែបណ្ដាសត្រូវ

ក៏ដូចសម្ព័ន្ធមិត្តរបស់ពួកគេ ៖ ពួកវៀតណាមដែលចង់ត្រួតត្រាប្រទេស មេដឹកនាំខ្លួនខ្លះ បានក្លាយទៅជាអ្នកឲ្យការណ៍ទៅសម្ដេច ព្រះនរោត្ដម សីហនុ ពួកចិនបានគាំទ្រសម្ដេច ដោយធ្វើឲ្យខូចប្រយោជន៍ដល់ពួកកុម្មុយនិស្ដខ្មែរ និងពួកវៀតណាម ជាថ្មីក្នុងជម្លោះដែនដីដំបូងៗ បន្ទាប់ពីសម័យសង្គ្រាម ។

ពួកខ្មែរក្រហម បានការពារខ្លួននឹងអំពើក្បត់ថ្មីៗ ដោយមធ្យោបាយការពារពីរដូចគ្នា ៖ ពួកគេបានចងសម្ព័ន្ធភាពដោយឥតអៀនខ្មាស់មួយ ជាមួយនឹងពួកសត្រូវរបស់ពួកគេដោយដឹងថា ពួកគេនឹងបំផ្លាញសម្ព័ន្ធភាពនេះនៅថ្ងៃណាមួយ ហើយពួកគេបានប្រកាន់យកយុទ្ធសាស្ត្រមួយ សំដៅ«កម្ទេច» ឬកម្ចាត់បណ្ដាសត្រូវ ដែលមិនទាន់បេញជាក់ស្ដែងឲ្យអស់មុនពួកនេះមានឱកាសក្បត់នឹងបក្ស ។ សម្ព័ន្ធភាពជាបណ្ដោះអាសន្នក្នុងសម័យសង្គ្រាម ដែលមានទម្រង់ជា«រណសិរ្សរួបរួម»នោះ ទទួលបាននូវជោគជ័យមួយ លើសពីសេចក្ដីសង្ឃឹមទុកទៅទៀត ដោយហេតុតែរណសិរ្សនេះ បានបង្រួបបង្រួមប្រជាជនកម្ពុជាទាំងអស់តាំងពីសម្ដេច ព្រះនរោត្ដម សីហនុ រហូតដល់ព្រះសង្ឃ ប្រជាកសិករ និងបញ្ញវន្ដ ។

ប៉ុន្ដែនៅទីបំផុត អ្វីដែលធ្វើឲ្យរបបនេះវិនាសអន្ដរាយ គឺជំងឺមិនទុកចិត្តគេឯងរបស់ខ្លួននេះឯង ពុំមែនវិនាសដោយពួកសត្រូវរបស់ខ្លួននោះទេ ។ កាលបើគេវិនិច្ឆ័យគួរដល់កាលវេលាហើយ បក្សបានកាត់ផ្ដាច់សម្ព័ន្ធភាព ឬការធ្វើរណសិរ្សនេះភ្លាមដោយរបៀបឃោរឃៅ ។ នៅពេលដែលគេហាមមិនឲ្យមានសាសនា គេមិនលួមចិត្តនឹងបិទវត្តអារាម មិនឲ្យប្រជាជនធ្វើបុណ្យទានប៉ុណ្ណោះទេ គេថែមទាំងសម្លាប់ព្រះសង្ឃ និងប្រែក្លាយវត្តទាំងនោះទៅជាជង្រុកស្រូវថែមទៀត ។ នៅពេលដែលពួកកុម្មុយនិស្ដលែងត្រូវការ សម្ដេច ព្រះនរោត្ដម សីហនុ ពួកគេពុំបានផ្ដល់មុខតំណែងដែលគ្រាន់តែជាកិត្តិយសណាមួយថ្វាយព្រះអង្គឡើយ ពួកគេបានកម្រិតឲ្យព្រះអង្គស្ថិតនៅក្នុងតែព្រះរាជដំណាក់នាព្រះបរមរាជវាំង ដោយចាត់ទុកព្រះអង្គជាអ្នកទោសរបស់គេទៀត ។ បន្ទាប់ពីបានប្រើប្រាស់ពួកខ្មែរដែលត្រឡប់មកពីទីក្រុងហាណូយ ឲ្យជួយបណ្ដុះបណ្ដាលកងទ័ពរបស់ពួកគេរួចមក ពួកខ្មែរក្រហមបានសម្លាប់អ្នកទាំងនោះចោលស្ទើរតែទាំងអស់ ។

ដោយត្រូវប្រឈមមុខនឹងភ័ស្ដុតាងផ្សេងៗ ដែលមិនអាចបដិសេធបានចំពោះបរាជ័យដំបូងៗរបស់ការបដិវត្ត មជ្ឈិមបានទម្លាក់ការទទួលខុសត្រូវទៅលើ កុយ ធួន និងភូមិភាគឧត្ដរ ដែលជាសញ្ញាផ្ដើមធ្វើការបោសសម្អាតថ្នាក់ភូមិភាគ[៤] ជាលើកដំបូង ។ មជ្ឈិមបានបញ្ជាឲ្យកងទ័ពរបស់ភូមិភាគបូព៌ា និងភូមិភាគកណ្ដាលដែលទើបនឹងបង្កើតថ្មី ទៅកម្ទេចពួកកម្មាភិបាលនៅអតីតភូមិភាគឧត្ដរ នៅឆ្នាំ១៩៧៦ ។ កងទ័ពទាំងនោះបានចាប់ខ្លួន និងសម្លាប់កម្មាភិបាលប្រមាណជាដប់នាក់ ហើយដាក់ជំនួសអ្នកទាំងនេះ ដោយមេដឹកនាំ«ស្មោះត្រង់» តាមការណែនាំមជ្ឈិមវិញ ។ វិធីសាស្ត្រនេះមានលក្ខណៈពេញទៅដោយការប៉ិនប្រសប់ ពីព្រោះវារួមបញ្ចូលមេដឹកនាំភូមិភាគបូព៌ា និងភូមិភាគកណ្ដាល ជាមួយគ្នានឹងពួកមេដឹកនាំក្រុងភ្នំពេញដែរ ។ វិធីសាស្ត្រនេះ បានជំរុញឲ្យមានការសង្ស័យក្នុងផ្ទៃបក្សថែមទៀត ។ រឿងនេះ ប្រហែលបកស្រាយឲ្យដឹងពីដើមហេតុដែលលេខាបក្សភូមិភាគ

បូព៌ា បានព្រមព្រៀងរៀបចំអាពាហ៍ពិពាហ៍មួយរវាងកូនស្រីគាត់ និងកូនប្រុសម្នាក់របស់លេខាបក្សភូមិភាគពាយ័ព្យ -នេះជាការជួយគាំពារគ្នាទៅវិញទៅមក ក្នុងករណីដែលភូមិភាគណាមួយ ក្នុងចំណោមភូមិភាគទាំងពីរនឹងត្រូវចាត់តាំងឲ្យធ្វើការបោសសម្អាតភូមិភាគដទៃទៀត (លកខុបាយនេះ គ្មានផលប្រយោជន៍អ្វីទាំងអស់) ។

នៅឆ្នាំ១៩៧៦ ដដែលនោះ បក្សបានប្រកាសឲ្យដឹងពីការជំរុញធ្វើបដិវត្តន៍សង្គមនិយម និងបញ្ជាឲ្យធ្វើការលុបបំបាត់សម្ព័ន្ធភាពវណ្ណៈ -នេះជាការលុបបំបាត់វណ្ណៈផ្សេងៗរបស់ខ្លួនឯងផ្ទាល់ ។ ការបង្គាប់បញ្ជានេះបានទៅជាកម្មវត្ថុនៃការបកស្រាយប្លែកៗពីគ្នា ។ កសិករមានទ្រព្យសម្បត្តិច្រើន ដែលធ្លាប់រួមប្រយុទ្ធតស៊ូជាមួយពួកខ្មែរក្រហមក្នុងរយៈពេលសង្រ្គាម ក៏ត្រូវគេសម្លាប់ចោលដែរ ពីព្រោះជាវណ្ណៈសត្រូវ ។ គេក៏បានសម្លាប់«ពួកអ្នកចាស់» សមាជិកបក្ស និងកងទ័ព ដោយក្រុមគ្រួសារជាមនុស្សដែលត្រូវគេសង្ស័យ ព្រោះតែមានជាប់ពាក់ព័ន្ធនឹងសមាជិកនៃវណ្ណៈមួយដែលផ្តល់គ្រោះថ្នាក់ដល់បដិវត្តន៍ ។ ក្រោយមក អៀង សារី បានរៀបរាប់ពីការតស៊ូវណ្ណៈ ឬ«ការផ្លាស់ប្តូរទ្រង់ទ្រាយសង្គម»នេះថា ជាគ្រោះមហន្តរាយមួយដោយគូសបញ្ជាក់ថា នៅក្នុងតំបន់ខ្លះ ពួកកម្មាភិបាល និង«ពួកអ្នកចាស់» បានប្រព្រឹត្តខុសគន្លងមាគ៌ាដោយធ្វើទុក្ខទោស និងសម្លាប់មនុស្សយ៉ាងច្រើន ដែលគ្មានមិនសមនឹងទទួលទោសដូច្នេះសោះ[៥] ។

ដោយតម្រូវទៅតាមស្ថានការណ៍នោះ បក្សបានបិទទ្វារលែងរើសមនុស្សចូល និងបណ្តេញសមាជិករាប់ពាន់នាក់របស់ខ្លួនចេញថែមទៀត ។ កងទ័ពក៏ត្រូវ«បោសសម្អាត» ជួររបស់ខ្លួនដែរ និងបានសម្លាប់យុទ្ធជនមួយចំនួនតូច ដែលមានវណ្ណៈដើមមិនល្អ ។

ក្នុងសភាពច្របូកច្របល់នេះ កងទ័ពរបស់ភូមិភាគបូព៌ាត្រូវបានបញ្ជូនទៅកាន់តំបន់ព្រំដែន ដើម្បីទប់ទល់នឹងការទន្រ្ទានទីរបស់កងទ័ពវៀតណាម ។ បន្ទាប់ពីការប៉ះទង្គិចគ្នាស្រាលៗជាច្រើនលើក មជ្ឈិមបានស្តីបន្ទោស សោ ភឹម លេខាបក្សភូមិភាគបូព៌ា ដោយចោទប្រកាន់ថា បានវាយពួកវៀតណាមដោយសន្ទុះខ្លាំងក្លាជ្រុលពេក ហើយបានបង្គាប់គាត់ដោយដាច់ខាតថា ត្រូវលែងធ្វើឲ្យល្អក់កករដល់«ស្ថិរភាពដុយស្រួយ» ដែលសម្រេចហើយនៅតាមព្រំដែនឡើយ ។

លទ្ធផលចុងឆ្នាំ បាននាំមកនូវតួលេខស្តីពីការប្រូតកាត់នៅខែធ្នូ និងការប្រមូលផលមិនល្អរបស់ភូមិភាគពាយ័ព្យ ដែលធ្វើឲ្យបក្សខកចិត្តយ៉ាងខ្លាំង ។ នៅពេលដែលមជ្ឈិមសម្រេចថា កំហុសត្រូវធ្លាក់ទៅលើពួកកម្មាភិបាលរបស់ភូមិភាគ ពុំមែនមកពីនយោបាយលោភលន់ហួសហេតុរបស់ក្រុងភ្នំពេញ បក្សបានបញ្ជាឲ្យធ្វើការបោសសម្អាតថ្នាក់ភូមិភាគជាលើកទីពីរទៀត ។ ប៉ុន្តែដំបូងៗ សន្តិសុខបានទម្លាក់កំហុសទៅលើ កុយ ធួន ដើម្បីបញ្ចប់ការបោសសម្អាតលើកទីមួយ[៧] ។ កុយ ធួន ត្រូវបានចាប់ខ្លួនកាលពីមួយរយៈមុន ប៉ុន្តែ ត្រូវដោះលែងមួយវិញ ។ នៅខែមករា ឆ្នាំ១៩៧៧ មជ្ឈិមបានយកគាត់ទៅដាក់គុកនៅទួលស្លែង ដែលមាន ឌុច ជាអ្នកត្រួតត្រាពិនិត្យពីលើការធ្វើទារុណកម្ម និងការសម្លាប់រូបគាត់ដោយផ្ទាល់ ។ កុយ ធួន ត្រូវបានចោទប្រកាន់ និងរកឃើញថា

គាត់ជាភ្នាក់ងារម្នាក់របស់ សេ.អ៊ី.អា. តាំងពីអំឡុងទសវត្សរ៍១៩៦០ពិតមែន ។ គេក៏យកចិត្តទុកដាក់ប្រឆាំងនឹងរូបគាត់ ដោយលើកពីវណ្ណៈភាពដើមរបស់គាត់ជាវណ្ណៈគហបតី ។

គេត្រូវការឲ្យពួកអ្នកមានស្មារតីភក្ដីរបស់បក្សជឿលើភ័ស្ដុតាងដាក់បន្ទុក ចម្លែកខុសគេដែលផ្ដោតប្រឆាំងនឹងមេដឹកនាំម្នាក់ ក្នុងចំណោមមេដឹកនាំសំខាន់ៗរបស់ពួកគេ ហើយពួកគេក៏សម្លាប់អ្នកដែលគេចោទនោះមែន ។ អំពើហិង្សាបានចាក់ឫសយ៉ាងជ្រៅក្នុងលក្ខណៈផ្ទាល់របស់បក្ស រហូតទាល់តែលេខាបក្សភូមិភាគនានា មើលពុំឃើញអ្វីដែលជាភ័ស្ដុតាងដាក់ស្ដែងដូចរឿង កុយ ធួន ឡើយ គឺដឹងត្រឹមតែថា មជ្ឈិមអាចទម្លាក់ទោសកំហុសមកលើអ្នកណាម្នាក់ក៏បានដែរ ក្នុងចំណោមពួកគេទាំងនេះ ។

បន្ទាប់ពីបានរៀបចំការបោសសម្អាតអតីតភូមិភាគឧត្ដរមុនគេជាមួយការសម្លាប់ កុយ ធួន រួចមក មជ្ឈិមបានចាប់ផ្ដើមធ្វើការបោសសម្អាតភូមិភាគមួយទៀត គឺភូមិភាគពាយ័ព្យ ។ ម្ដងនេះ បក្សបានហៅរកកម្មាភិបាលរបស់ភូមិភាគនិរតី ដើម្បីកាច់បំបាក់កិច្ចសន្យាការពារគ្នាក្រៅផ្លូវការមួយ ដែលសម្រេចឡើងដោយមេដឹកនាំភូមិភាគបូព៌ា និងពាយ័ព្យ ។ មជ្ឈិមបានទុកលេខាបក្សភូមិភាគពាយ័ព្យឈ្មោះ រស់ ញឹម ឲ្យនៅកាន់មុខតំណែងមួយរយៈសិន ។

គណៈដឹកនាំរបស់បក្ស បានចាត់ចែងឲ្យមានការស៊ើបអង្កេតមួយផ្សេងទៀត ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យជាហូរហែមួយ អំពីទឹកចិត្តស្មោះត្រង់ទីទៃៗពីគ្នា ។ សញ្ញាដំបូងៗនៃផ្លាស់ប្ដូរនេះ ព្រមទាំងសញ្ញាផ្សេងៗទៀត គេអាចរកឃើញនៅក្នុងសំណុំឯកសារជាច្រើនដែលមាននៅមន្ទីរឃុំឃាំងទួលស្លែង[៨] ។ នៅឆ្នាំ១៩៧៦ មនុស្សដែលគេបានសម្លាប់ទាំងប៉ុន្មាន សុទ្ធតែជាមនុស្សនៅក្នុងរបបចាស់ ៖ កម្មករ១៦៨នាក់ និស្សិត៦១នាក់ សាស្ដ្រាចារ្យ ៣៥ នាក់ គ្រូពេទ្យនិងគិលានុបដ្ឋាក២០ នាក់ វិស្វករ៤៩ នាក់ អ្នករដ្ឋការ៥៥ នាក់ ទាហាន២០៩ នាក់ និងមាន ៤៧នាក់ ជានិស្សិតនិងឥស្សរជនដែលធ្លាប់រស់នៅឯបរទេស[៩] ។ ក្នុងចំនួនអ្នកស្លាប់ ៧៥០នាក់ ដែលមានចុះក្នុង បញ្ជីនៅទួលស្លែងនាឆ្នាំនោះ គេរាប់ឃើញសមាជិកបក្សតែប្រមាណជាងដប់ពីរនាក់ប៉ុណ្ណោះ ។ គឺជាឆ្នាំដែលខ្មែរ បណ្ដាញរបស់ បុប្ផាណា ត្រូវគេធ្វើទារុណកម្ម និងសម្លាប់ចោល ។

ឆ្នាំ១៩៧៧ បានកំណត់នូវការផ្លាស់ប្ដូរមួយ បន្ទាប់ពីបក្សបានដាក់ចេញមតិណែនាំថ្មីៗទៀត ។ ចំនួននៃការប្រហារជីវិតពួកមេដឹកនាំកុម្មុយនិស្ត បានឡើងដល់៤៤នាក់ ហើយចំនួនអ្នកដែលត្រូវចាប់ដាក់គុកមាន ៦១ នាក់ ។ កម្មករចំនួន ១៨២នាក់ ត្រូវបានសម្លាប់ចោល ៖ ពួកកម្មករកំពុងរួមបន្តជាប្រភេទ ដែលត្រូវរងគ្រោះច្រើនជាងគេពីការកាប់សម្លាប់ទាំងនេះ ។ តួលេខទាំងនេះ បានបង្ហាញឲ្យឃើញពីការសម្រេចចិត្តរបស់បក្ស ដើម្បីជំរុញការធ្វើខស្សរាហូបនីយកម្ម និងពិនិត្យពិច័យពីប្រវត្តិដើមរបស់ពួកកម្មករដោយល្អិតល្អន់ ដើម្បីស្ទាបស្ទង់ពី«ភក្ដីភាព»របស់ពួកគេ ។ ការសម្រេចចិត្តនេះ បាននាំទៅដល់ការសម្លាប់វណ្ណៈអធនទៀត ដែលក្នុងនាមនៃវណ្ណៈនេះហើយ ដែលការបដិវត្តត្រូវបានរៀបចំធ្វើឡើងនោះ ។

បន្ទាប់ពីពួកកម្មករ ប្រភេទដែលត្រូវរងការប៉ះពាល់ខ្លាំងជាងគេគឺ ប្រភេទឥស្សរជន និងនិស្សិត ដែលវិលចូលពីបរទេសមកវិញចំនួន ៨២នាក់ -ជាក្រុមចម្រុះដែលធ្លាប់មានសមានចិត្ត នឹងបុព្វហេតុបដិវត្ត និងជាសមាជិកនៃរបបសង្គមចាស់ ។ នៅឆ្នាំ១៩៧៧ សាស្ត្រាចារ្យ៦៤នាក់ផ្សេងទៀត ត្រូវបានសម្លាប់ចោល ។ តមកទៀត ជាវេនពួកមេដឹកនាំកុម្មុយនិស្តចំនួន៦១នាក់ ដែលគេចាប់ដាក់គុកនៅក្នុងឆ្នាំនោះ ។ ក្នុងចំនួនអ្នកដែលត្រូវបានសម្លាប់នៅក្នុងឆ្នាំ១៩៧៧ មិនសូវមានពួក និស្សិត បុគ្គលិករដ្ឋការ វេជ្ជបណ្ឌិត វិស្វករ និងទាហានទេ ។ អ្នកដែលរួចផុតពីការកាប់សម្លាប់ លើកដំបូងសុទ្ធតែចេះសម្របខ្លួនទៅតាមកាលៈទេសៈ ដោយលាក់បាំងអត្តសញ្ញាណរបស់គេជារឿយៗ ។

នៅឆ្នាំ១៩៧៨ មានការប្រែប្រួលថ្មីទៀត ៈ លើកនេះ ប្រភេទពួកមេដឹកនាំកុម្មុយនិស្ត ដែលនាំមុខគេជាមួយនឹងអ្នករងគ្រោះ១០៧នាក់ ។

បញ្ជីរាយឈ្មោះមនុស្ស ដែលត្រូវសម្លាប់នៅមន្ទីរឃុំឃាំងទួលស្លែង បានបើកឱកាសឲ្យគេប្រមាណពីលក្ខណៈលឿនរហ័ស ដែលមិតណែនាំផ្សេងៗរបស់ មជ្ឈិម ត្រូវបានថ្នាក់ក្រោមគោរពយ៉ាងពិតប្រាកដ ។ ពីរ-បីខែបន្ទាប់ពីបក្សសម្រេចចិត្តទម្លាក់កំហុសទៅលើប្រភេទថ្មីមួយ គឺពួកអ្នកដែលគេសង្ស័យ រួចមកគេក៏ឃើញមានអ្នកទាំងនោះ ជាប់នៅក្នុងមជ្ឈមណ្ឌលឃុំឃាំងដែរ ។ ហើយរៀងរាល់លើកដែលបក្សសម្រេចរំលាយសម្ព័ន្ធភាពមួយ ឬបំភ្លេចពាក្យសន្យាមួយ ជនទាំងឡាយដែលការសម្រេចនេះ ធ្វើឲ្យខូតចេញពីតំណែង នៅទីបំផុត បានមកជួបគ្នាជាថ្មី ដោយដៃជើងជាប់ច្រវាក់នៅមន្ទីរឃុំឃាំងទួលស្លែងផង ។

សំណុំឯកសាររបស់មជ្ឈមណ្ឌលនេះ ក៏បង្ហាញឲ្យឃើញពីការស្អប់ខ្ពើមជនបរទេស ដែលគ្មានប្រែប្រួលរបស់ពួកខ្មែរក្រហម ដែលបានសម្លាប់ពួកបរទេសបែបជាប្រព័ន្ធដែលគេស្រាវជ្រាវឃើញ នៅក្នុងប្រទេស ។ ឯកសារផ្សេងៗនៅមន្ទីរឃុំឃាំងទួលស្លែងបង្ហាញឲ្យដឹងថា ជនជាតិថៃជាច្រើនដែលចាប់បាននៅកំពង់ សោម ត្រូវបានសម្លាប់ក្នុងមន្ទីរឃុំឃាំងនេះនៅខែឧសភា ឆ្នាំ១៩៧៦ ។ ប្រហែលជានៅជំនាន់នោះ ពួកអ្នកជំនួញ និងពួកនិស្សិតជាតិឥណ្ឌា និងប៉ាគីស្ថានក៏ត្រូវគេប្រហារជីវិតនៅទីនោះដែរ ។ នៅឆ្នាំ១៩៧៨ ពួកទាហានម៉ារីនអាមេរិកាំង អូស្ត្រាលី អង់គ្លេស និងនូវ៉ែលហ្សេឡង់ ដែលត្រូវចាប់ខ្លួនបាននៅក្នុងឈូងសមុទ្រថៃ ឬនៅតំបន់កោះនានាក្បែរឆ្នេរសមុទ្រ ក៏ត្រូវគេដឹកយកមកដាក់ឃុំនៅទួលស្លែង និងត្រូវសម្លាប់ចោលទាំងអស់ ។

ចំនួនអ្នករងគ្រោះបង្ហាញឲ្យឃើញថា របបនេះបានពឹងផ្អែកលើមន្ទីរឃុំឃាំងទួលស្លែងកាន់តែច្រើនឡើងៗ ថ្វីដ្បិតតែចំនួននេះនៅតែមិនទាន់ពេញលេញក៏ដោយ ។ គេត្រូវការឲ្យ ឌុច និងក្រុមពេជ្ឈឃាតរបស់គាត់បង្ហាញឲ្យឃើញពីមូលហេតុពិតនៃបរាជ័យទាំងឡាយរបស់ការបដិវត្តន៍ ។ នៅឆ្នាំ១៩៧៦ អ្នកទោសប្រហែលពីររយនាក់ បានត្រូវគេនាំទៅដាក់គុកនៅមណ្ឌលឃុំឃាំងនេះ ។ នៅឆ្នាំ១៩៧៧ មនុស្សជាងប្រាំមួយពាន់នាក់ ក៏ត្រូវនាំទៅដាក់គុកនៅទីនោះដែរ ហើយគេវាយតម្លៃថា មានមនុស្សចំនួនដប់ពីរពាន់នាក់ បានត្រូវគេចាប់ដាក់គុកនៅឆ្នាំ

១៩៧៨ ។

បើសិនជាបញ្ជីសម្ងាប់មនុស្សប្រាប់ឲ្យដឹងពីការកើនឡើងមួយនូវចំនួនសមាជិកបក្ស ដែលគេនាំយកទៅដាក់គុកនៅទួលស្លែង មានតែការអានចម្លើយសារភាពទាំងឡាយដែលចម្រាញ់បានពីពួកជនរងគ្រោះមួយមុខប៉ុណ្ណោះ ដែលធ្វើឲ្យគេដឹងពីការគិតមមៃថ្មីៗរបស់បក្ស ។ បន្ទាប់ពីមន្ទីរបក្សចេញបញ្ជាឲ្យធ្វើការផ្លាស់ប្តូរទិសដៅរបស់ការបដិវត្តន៍ក្នុងសម័យប្រជុំផ្សេងៗនៅឆ្នាំ១៩៧៦ ពួកពេជ្ឈឃាតនៅមន្ទីរឃុំឃាំងទួលស្លែង បានចាប់ផ្តើមសួរចម្លើយអ្នកទោសចំពោះឥរិយាបថរបស់គេ ចំពោះប្រទេសវៀតណាមម្តង ។ ពួកមេដឹកនាំខ្ពស់បានជ្រើសរើសបញ្ហា ជាពិសេស នេះដើម្បីវិនិច្ឆ័យពីសេចក្តីស្មោះត្រង់របស់បណ្តាសមាជិកបក្ស និងរែកមុខ“សត្រូវបង្កប់” ចេញពីជួរបក្សផង ។

បក្សបានផ្តើមជជែកអំពីបញ្ហាទាក់ទងនឹងវៀតណាម ស្តីពីថ្ងៃខែនៃការបង្កើតបក្សកុម្មុយនិស្តកម្ពុជាឡើងវិញ ។ នេះពុំមែនជារឿងមួយដែលមិនសូវសំខាន់នោះទេ ។ ក្នុងប្រវត្តិសាស្ត្រផ្លូវការតែមួយគត់របស់បក្ស ដែលបោះពុម្ពផ្សាយក្នុងរយៈពេលសង្គ្រាមឆ្នាំ១៩៧៣ គេបានកំណត់យកថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៥១ ទុកជាថ្ងៃខែបង្កើតបក្ស ។ ថ្ងៃខែនេះ ជាការលាយឡូកឡំមួយរវាងនិន្នាការពីរជាផ្លែផ្កានៃការសម្រុះសម្រួលផ្នែកនយោបាយមួយ សំដៅបង្រួបបង្រួមកម្លាំងទាំងអស់របស់បក្ស ក្នុងកិច្ចប្រឹងប្រែងធ្វើសង្គ្រាម ។

នៅឆ្នាំ១៩៧៦ បក្សបានយកចិត្តទុកដាក់ប្រគល់ឲ្យពួកកុម្មុយនិស្តកម្ពុជា នូវគុណបំណាច់ទាំងអស់នៃជោគជ័យ និងការធ្វើបដិវត្ត ដោយបានបពាប់រឿងនេះ ជាមួយនឹងការស្រុះស្រួលគ្នាមួយអំពីថ្ងៃខែកំណើតបក្សដែលយល់ព្រមឲ្យប្រទេសវៀតណាម នូវតួនាទីដ៏សំខាន់មួយក្នុងការកសាងចលនាកុម្មុយនិស្តនៅកម្ពុជា ។ មជ្ឈិមមានបំណងបដិសេធចោលឧបការគុណ ទាំងអស់របស់ពួកវៀតណាម និងចំណងទាក់ទងទាំងអស់ជាមួយអតីតបក្សកុម្មុយនិស្តឥណ្ឌូចិន ហើយបានសម្រេចចិត្តកាត់ចោលភាគខ្លះ នៃប្រវត្តិសាស្ត្ររបស់ខ្លួន ដោយយកឆ្នាំ១៩៦០ ជាឆ្នាំនៃការបង្កើតបក្ស ដោយធ្វើឲ្យក្រុងហាណូយជាអ្នកធ្វើអំពើល្អទៅជាអ្នកគំរាមកំហែងវិញ ។

ការសម្របសម្រួលគ្នាអំពីថ្ងៃខែកំណើតបក្ស កិច្ចព្រមព្រៀងគ្នាដែលគ្មានចែងច្បាស់លាស់ ស្តីពីប្រភពដើមរបស់បក្ស បានត្រូវបំបាត់បានដោយងាយស្រួលដូចគ្នានឹងសម្ព័ន្ធភាពផ្សេងៗទៀត ដែលបង្កើតឲ្យមានឡើងក្នុងសម័យសង្គ្រាមដែរ នៅពេលណាដែលបក្សត្រូវការកិច្ចគាំទ្រពីនិន្នាការទាំងអស់ និងពីប្រទេសវៀតណាម ។ ដោយប្រទេសមានសន្តិភាព មជ្ឈិម ចង់សាកល្បងធ្វើការបង្កហេតុមួយ (ដោយមើលងាយថា គូប្រឆាំង គ្មានសមត្ថភាពធ្វើអ្វីមួយកើត) ចំពោះពួកវៀតណាម ដើម្បីបង្ហាញឲ្យឃើញពីឧត្តមភាពរបស់បដិវត្តកម្ពុជាជាថ្មី និង “បន្សុទ្ធ” បក្សឲ្យផុតពីសមាសភាពទាំងអស់ ដែលស្និទ្ធនឹងពួកវៀតណាម ។

គឺពុំមែន “ពួកអ្នកថ្មី” ទៀតទេ ដែលពួកមេដឹកនាំកុម្មុយនិស្តផ្តោតការសង្ស័យទៅលើនោះ ហើយប្រជាជនកម្ពុជាដែលធ្លាប់រួមចំណែកជួយកសាងការបដិវត្ត បានក្លាយយ៉ាងឆាប់រហ័សទៅជាអ្នករងគ្រោះវិញ ។ ប្រវត្តិ

សាស្ត្រនៃការបដិវត្តរបស់កម្ពុជា ពីពេលនេះតទៅមានលក្ខណៈដូចប្រវត្តិសាស្ត្ររបស់បក្សមួយ ដែលប្រែត្រឡប់មកប្រឆាំងនឹងសមាជិកផ្ទាល់របស់ខ្លួនវិញ -និងប្រឆាំងនឹងមនុស្សរាប់ពាន់នាក់ផ្សេងទៀត ដែលត្រូវបានសម្លាប់ក្នុងវិបត្តិដូចមនុស្សឆ្កួតលេលានេះ ។

ឌុច បានចាប់ផ្តើមដំណាលគ្នាក្នុងការស្វែងរកដោយខ្វាប់ខ្ជួនទៅ លើជនដែលគេបង្ស័យពីរប្រភេទ គឺពួកបញ្ញវន្តជាសមាជិកបក្ស ឬសាច់សាលោហិត និងប្រជាជនកម្ពុជាដែលត្រូវវិនិច្ឆ័យថា ជំពាក់ចិត្តនឹងពួកកុម្មុយនិស្តវៀតណាមខ្លាំងពេក ។ តាមប្រហែល គេបានកំណត់កាលបរិច្ឆេទដ៏ជាក់លាក់មួយ សម្រាប់ឌុចដើម្បីបង្កើនល្បឿនស្រាវជ្រាវរកពួកកុម្មុយនិស្ត ដែលធ្លាប់ទាក់ទងជាមួយពួកវៀតណាម មុនប្រារព្ធបុណ្យខួបថ្ងៃកំណើតបក្សបន្តិចដែលត្រូវធ្វើនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៦ ។ សម្ព័ន្ធមិត្តដ៏ជិតស្និទ្ធបំផុតរបស់កម្ពុជា គឺប្រទេសចិនបានតឿនបន្ទំឲ្យ ប៉ុល ពត ទម្លាក់របាំងមុខចុះតាំងពីពេលកន្លងមកមិនជាយូរប៉ុន្មាន និងឲ្យទទួលស្គាល់ជាសាធារណៈថាប្រទេសកម្ពុជា គឺដឹកនាំគ្រប់គ្រងដោយបក្សកុម្មុយនិស្តមួយ ។

ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៧៦ ម៉ៅ សេទុង បានទទួលមរណភាព ។ ក្នុងឋានៈខ្លួនជានាយករដ្ឋមន្ត្រីរបស់កម្ពុជាប្រជាធិបតេយ្យ ប៉ុល ពត បានថ្លែងកោតសរសើរចំពោះមេដឹកនាំចិនរូបនេះ តាមវិទ្យុជាតិ នៅថ្ងៃទី១៨ ខែដដែល ។ ការយឺតយូរ ប្រាំបួនថ្ងៃនេះ ពុំមានការពន្យល់បំភ្លឺឲ្យដឹងឡើយ ប៉ុន្តែអត្ថបទនៃសេចក្តី ថ្លែងរបស់ ប៉ុល ពត បានបង្ហាញឲ្យឃើញភ័ស្តុតាងមួយ ៈ ជាលើកដំបូងបំផុត ប៉ុល ពត បានគូសបញ្ជាក់ថា មនោគមវិជ្ជារបស់អង្គការពឹងផ្អែកជាសំអាងលើលទ្ធិម៉ាក្ស-លេនីន ។ ពួកខ្មែរក្រហមមិនដែលដាក់ខ្លួន ទទួលស្គាល់ជាសាធារណៈ អំពីឋានៈជាជនកុម្មុយនិស្តរបស់គេទេ ប៉ុន្តែ ជាសេចក្តីប្រកាសនេះនៅតែពុំទាន់ជាក់លាក់ និងច្បាស់លាស់ ដែលបណ្តាមិត្តភក្តិបរទេសរបស់គាត់ចង់បានពីគាត់ទេ ។

សារសំខាន់នៃការទទួលសារភាពតែពាក់កណ្តាលនេះ ត្រូវបានធ្វើឲ្យលេចឡើងច្បាស់ក្រឡែតតែពីរថ្ងៃក្រោយមកប៉ុណ្ណោះ ដោយព្រឹត្តិការណ៍ពីរ គឺមួយជាព្រឹត្តការណ៍ដែលគេដឹងព្រគ្រប់គ្នា មួយទៀតសម្ងាត់ ។ ប៉ុល ពត បានសុំលាលែងពីមុខតំណែងរបស់គាត់ជានាយករដ្ឋមន្ត្រី សម្រាប់មូលហេតុសុខភាព -តាមគាត់ប្រកាសឲ្យដឹង- ហើយបានចាត់តាំងឲ្យ នួន ជា ឡើងជំនួសគាត់ជាបណ្តោះអាសន្ន ដែលជាមនុស្សគួរឲ្យជឿទុកចិត្តតែម្នាក់គត់ និងជាមនុស្សទីពីររបស់បក្ស ។ នៅពេលនោះ អតីត សាឡុត ស មានសេរីភាពយ៉ាងពេញលេញ ដើម្បីគិតគូរពីព្រឹត្តិការណ៍សំខាន់មួយទៀត គឺការចាប់ខ្លួន កែវ មាស ជាមេដឹកនាំកុម្មុយនិស្ត ជាមេដឹកនាំជាន់ខ្ពស់ម្នាក់ ក្នុងចំណោមមេដឹកនាំកុម្មុយនិស្តជាន់ខ្ពស់ ដែលកំពុងជាប់គុកនៅទួលស្លែង ។ នេះជាគោលដៅវាយប្រហារមួយក្នុងការតាមស្វែងរក និងកម្ទេចបក្សពួកប្រឆាំងខាងនយោបាយ ដែលបក្សចាប់ដំណើរការដើម្បីប្រឆាំងនឹង «បណ្តាសមមិត្ត» របស់វៀតណាម[១០] ។

កែវ មាស ជាអតីតអ្នកប្រយុទ្ធតស៊ូដើងចាស់ម្នាក់ក្នុងសម័យសង្គ្រាមឥណ្ឌូចិនលើកទីមួយ នៅពេលដែលគាត់បានសុំចូលជាសមាជិកបក្សកុម្មុយនិស្តឥណ្ឌូចិន ដែលត្រួតត្រាដោយពួកវៀតណាម ។ គឺរូបគាត់នេះដែរដែលជាអ្នករៀបចំ ចាត់ចែងពួកបុគ្គលិកនៅស្ថានីយរថភ្លើងក្រុងភ្នំពេញ ឲ្យមានដំណើរការឡើង បន្ទាប់ពីសង្គ្រាមនោះផុតរលត់ទៅ ហើយគាត់បានដឹកនាំគណៈកម្មាធិការបក្សប្រចាំរាជធានីទៀត ។ នៅឆ្នាំ១៩៥៨ គាត់បានចាកចេញពីទីក្រុង ដើម្បីភៀសខ្លួននៅទីកន្លែងដែលមានសន្តិសុខគ្រប់គ្រាន់ ហើយមុខតំណែងរបស់គាត់ត្រូវបាន ប៉ុល ពត កាន់ជំនួសវិញ ។ ក្នុងមហាសន្និបាតបក្សឆ្នាំ១៩៦០ កែវ មាស បានជាប់ឈ្មោះចូលក្នុងគណៈកម្មការមជ្ឈិមបក្ស ហើយបើទុកជាគាត់ពុំត្រូវបានជ្រើសរើសឡើងវិញ បន្ទាប់ពីមានការរើរុះនៅឆ្នាំ១៩៦៣ ក៏ដោយក៏គាត់នៅតែជាឥស្សរជនដ៏សំខាន់ម្នាក់របស់បក្សដដែល ។

វាសំខាន់ណាស់ និងថ្លៃថ្នូរណាស់ ដែលគេជឿទុកចិត្តឲ្យគាត់រ៉ាប់រងបន្ទុកតាក់តែងប្រវត្តិសាស្ត្របក្សកុម្មុយនិស្តកម្ពុជាលើកដំបូងមួយ ដែលអាចល្មមទទួលយកបាន ។ ក្នុងមុខងារនេះ គាត់បានប្រមូលសក្ខីភាពទាំងអស់របស់ពួកមេដឹកនាំជាន់ខ្ពស់ រួមទាំង ប៉ុល ពត ផង ហើយបានយល់ច្បាស់ពីផលដែលគេអាចឈានទៅដល់ការស្រុះស្រួលមួយអំពីថ្ងៃខែបង្កើតបក្សថែមទៀត[១១] ។ គឺព្រោះតែមូលហេតុនេះហើយ ដែលគាត់ត្រូវបានចាប់ខ្លួន និងនាំទៅដាក់គុកនៅទួលស្លែងរយៈពេលជាងដប់ពីរឆ្នាំក្រោយមក ៖ ដើម្បីបំភ្លឺពីការស្រុះស្រួលគ្នាក្នុងចម្លើយសារភាពជាបន្តបន្ទាប់មួយ ដើម្បីចោទប្រកាន់ខ្លួនឯងដែលបានចរចាពីរឿងនេះ ដើម្បីនឹងអូសទាញបក្សឲ្យធ្លាក់ក្នុងការឃុបឃិតគ្នាជាសម្ងាត់មួយ សំដៅបិទបាំងអត្ថិភាពនៃបក្សសម្ងាត់ស្របគ្នាមួយ ដែលគ្រប់គ្រងដោយប្រទេសវៀតណាម ។

ការចោទប្រកាន់ទាំងនេះ ត្រូវបានរៀបចំយ៉ាងល្អិតល្អន់ដោយការប្រឌិតហួសប្រមាណមួយ ប៉ុន្តែ ប្រកបដោយគោលដៅជាក់លាក់មួយ ដែលក្លាយទៅជាជាក់ស្តែងក្រោយពីនេះបន្តិច ។ ក្នុងចម្លើយសារភាពដំបូងៗរបស់គាត់ ដែលគាត់សរសេរមុនពេលគេមិនទាន់បង្ខំឲ្យគាត់ទទួលស្គាល់ពិរុទ្ធភាពរបស់ខ្លួន ក្រោមការធ្វើទារុណកម្មកែ មាស នៅតែនិយាយកាន់ជើង ប៉ុល ពត និងក្រុមកុម្មុយនិស្ត ដែលស្ថិតនៅតែក្នុងប្រទេសកម្ពុជាក្រោយឆ្នាំ១៩៥៤ជានិច្ច ។ «មហាសន្និបាតឆ្នាំ១៩៦០នៅក្នុងប្រទេស ត្រូវបានគេសន្មតថា ជាឆ្នាំនៃការបង្កើតបក្ស... ។ បើសិនជាគេពិនិត្យបញ្ហានេះឲ្យដិតដល់ គេកត់សម្គាល់ថា ពីមុនមក ពុំដែលមានបើកធ្វើមហាសន្និបាតទេ ហើយគេអាចចាត់ទុកមហាសន្និបាតឆ្នាំ១៩៦០ ថាជាមហាសន្និបាតបក្សដំបូងគេ ។

ក្នុងចម្លើយសារភាពរបស់គាត់ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៦ កែវ មាស បានបញ្ជាក់យ៉ាងច្បាស់ពីប្រវត្តិ នៃការស្រុះស្រួលគ្នាអំពីកាលបរិច្ឆេទនេះថា «គេបានសម្រេចប្រកាន់យកថ្ងៃទី៣០ ខែកញ្ញា (ជាថ្ងៃតែមួយដែលមហាសន្និបាតឆ្នាំ១៩៦០បើកប្រជុំ) ហើយឆ្នាំ១៩៥១ គឺជាឆ្នាំដែលមានចាត់តាំងបង្កើតគណៈកម្មាធិការ គេណ្ឌប្រមូលកម្លាំងដើម្បីបង្កើតបក្ស» ។

កែវ មាស បានបញ្ជាក់ថា ការសម្របសម្រួលគ្នានេះពុំមានផ្តល់អត្ថប្រយោជន៍ដល់សមាជិកណាម្នាក់ ប្ុចលនាណាមួយរបស់បក្សឡើយ ប៉ុន្តែ ដើម្បីបង្រួបបង្រួម "ពួកឆ្នាំ១៩៥១" និង"ពួកឆ្នាំ១៩៦០"តែប៉ុណ្ណោះ និយាយម្យ៉ាងទៀត គឺពួកអ្នកដែលចេញដំណើរទៅហាណូយ បន្ទាប់ពីមានកិច្ចព្រមព្រៀងក្រុងហ្សឺណែវ និងពួកអ្នកដែលស្ថិតនៅតែក្នុងប្រទេសកម្ពុជា ។ គាត់បានរៀបរាប់តាមលំដាប់លំដោយ អំពីមូលហេតុផ្សេងៗ ដែលថា មហាសន្និបាតឆ្នាំ១៩៥១ ពុំបានបង្កើតបក្សនៅឡើយទេ ប៉ុន្តែ គ្រាន់តែបង្កើតគណៈកម្មាធិការមួយ ប៉ុណ្ណោះ ។ រឿងទាំងអស់នេះ ប្រហែលជាអាចរកឃើញ ដោយការតាមដានយ៉ាងយកចិត្តទុកដាក់របស់ ប៉ុល ពត ប៉ុន្តែ បក្សពុំមែនស្វែងរកការពិតជាប្រវត្តិសាស្ត្រទេ គឺបក្សចង់រកឲ្យឃើញការរួបរួមគំនិតក្បត់មួយ ។

នៅទីបំផុត ដោយត្រូវធ្វើឲ្យឈឺចាប់ក្នុងចិត្ត កែវ មាស បាននិយាយឡើងវិញពីសេចក្តីថ្លែងមុនៗ ហើយបានអះអាងថា ការសម្របសម្រួលគ្នានេះ ពុំមែនជាការប្រឹងប្រែងទៀងត្រង់មួយ ដើម្បីផ្សះផ្សានិន្នាការទាំងពីរនោះទេ ប៉ុន្តែ គឺជាការរួមគំនិតក្បត់មួយ ដើម្បីបំផ្លាញភាពត្រឹមត្រូវតាមច្បាប់ របស់បក្សកុម្មុយនិស្តរបស់កម្ពុជាទៅវិញ ។ ជាមួយនឹងចម្លើយសារភាពរបស់ កែវ មាស ក្នុងដៃស្រាប់ ប៉ុល ពត និងគណៈដឹកនាំបក្សអាចចាត់ចែងឲ្យធ្វើការផ្លាស់ប្តូរកាលបរិច្ឆេទថ្ងៃបង្កើតបក្សជាថ្មី ។ បន្ទាប់មក កែវ មាស បានត្រូវគេយកទៅសម្លាប់ចោល ។

ដើម្បីប្រកាសពីអត្តសញ្ញាណកុម្មុយនិស្តរបស់គេ -ដូចដែលប្រទេសចិនបានស្នើឲ្យគេធ្វើដូច្នេះ- ពួកមេដឹកនាំ បក្ស ត្រូវការវែកមុខ និងកម្ទេចបណ្តាសមាជិកដែលស្ថិតក្នុងការរួមគំនិតក្បត់របស់ កែវ មាស ឲ្យអស់ជាមុនសិន ។ ឯកសារមួយរបស់បក្ស បាននិយាយអំពីការកៀបសង្កត់ជាច្រើនរបស់បក្ស"ជាបងប្អូន"ដែរ នៅពេលប្រកាសជាសាធារណៈពីអត្ថិភាពរបស់បក្ស ។ "នៅខែកញ្ញា និងខែតុលា ឆ្នាំ១៩៧៦ យើងហៀបនឹងសម្រេចចិត្តបញ្ចេញឲ្យគេដឹងពីអត្តសញ្ញាណរបស់យើងទៅហើ ។ ប៉ុន្តែក្រោយមក ឯកសារផ្សេងៗបានបង្ហាញថា ពួកសត្រូវរបស់យើងបានប៉ុនប៉ងវាយប្រហារមកលើយើង ដោយប្រើមធ្យោបាយគ្រប់បែបយ៉ាងទាំងអស់ ដែលពួកគេរៀបបម្រុងជាស្រេច[១៧]" ។

ជាមនុស្សអាថ៌កំបាំងដោយសារចរិតពីកំណើត និង ប៉ុល ពត ប្រហែលជាប្រើប្រាស់ចម្លើយសារភាពទាំងអំបានម៉ានរបស់ កែវ មាស សម្រាប់ធ្វើជាគោលបង្អែកក្នុងការសម្រេចចិត្តលាក់មុខរបស់គាត់ពីក្រោយ "អង្គការ"តទៅទៀតហើយមើលទៅ ។ គេអាចសន្និដ្ឋានថា អតីត សាឡុត ស និងពួកមេដឹកនាំឯទៀតៗ នៃបក្សកុម្មុយនិស្តកម្ពុជាពុំចង់បញ្ចេញមុខឲ្យគេដឹងទេ ហើយចោទប្រកាន់ពីចំណងទាក់ទងរបស់ពួកគេ ជាមួយវៀតណាមឡើងវិញ មុនពេលដែលទុកចិត្តប្រាកដថា ប្រទេសចិនបន្ទាប់ពី ម៉ៅ នឹងនៅបន្តការគាំទ្រប្រទេសកម្ពុជាដដែល ។ ក្នុងកំឡុងរយៈកាលនេះ ពួកអ្នកតំណាងរបស់របបនេះ បានយកចិត្តទុកដាក់ពង្រឹងជំហររបស់កម្ពុជាប្រជាធិបតេយ្យនៅក្នុងពិភពលោកទាំងមូល ។ ខៀវ សំផន ដែលក្លាយទៅជាប្រធានគណៈប្រធានរដ្ឋ បានទៅចូលរួមសន្និសីទកំពូលប្រទេសមិនចូលបក្សសម្ព័ន្ធ នៅទីក្រុងកូឡុំបូ (រដ្ឋធានីប្រទេសស្រីលង្កា) ជាទីដែលគាត់បានប្រកាន់

បុកពាជាអ្នកការទូតរបស់ប្រទេសមួយ ដែលប្រឆាំងដាច់ខាតមិនចូលរួមក្នុងបុកណាមួយឡើយ ។ គាត់ពុំបានរួមដៃគ្នាក្នុងការថ្កោលទោសរបស់ប្រទេសឡាវ និងវៀតណាម ចំពោះសំណើរបស់“អាស៊ាន” [គឺសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍កាលបង្កើតដំបូងមានប្រាំមួយប្រទេសគឺ ថៃ ម៉ាឡេស៊ី សិង្ហបុរី ហ្វីលីពីន ឥណ្ឌូនេស៊ី និងប្រុយណេ - កំណត់របស់អ្នកប្រែសម្រួល] ដើម្បីបង្កើតតំបន់សន្តិភាព សេរីភាព និងអព្យាក្រឹតមួយនៅអាស៊ីអាគ្នេយ៍ឡើយ ។ ហើយគាត់បែរបញ្ឈរក់ដោយប្រុងប្រយ័ត្នពីការគាំទ្ររបស់គាត់ចំពោះ ឯករាជ្យនៃកោះទីម័រ (Timor) ភាគខាងលិច ដែលស្ថិតនៅក្រោមការកាន់កាប់របស់ប្រទេសឥណ្ឌូនេស៊ីទៅវិញ ។

នៅឯមហាសន្និបាតអង្គការសហប្រជាជាតិ អៀង សារី បានថ្លែងនូវការចាប់អារម្មណ៍មួយរបៀបដូចគ្នាដោយប្រកាសថា កម្ពុជាប្រជាធិបតេយ្យជាប្រជាតិមួយដែលមិនចូលបក្សសម្ព័ន្ធដាច់ខាត ។ គាត់បានជំរុញដោយទទូចឲ្យបណ្ដាប្រទេសក្រីក្រភាគច្រើននៅអង្គការសហប្រជាជាតិបញ្ចប់នូវការត្រួតត្រាមួយ ដែលបណ្ដាប្រទេសអ្នកមានភាគតិចប្រព្រឹត្តមកលើអង្គការកំពូលនេះ ។ គណៈប្រតិភូមួយរបស់កម្ពុជា បានទៅធ្វើទស្សនកិច្ចនៅតាមប្រទេសកុម្មុយនិស្តជាច្រើន ដូចជា អាល់បានី កូរ៉េខាងជើង វៀតណាម និងឡាវ ។ ប្រទេសវៀតណាម និងកម្ពុជា បានព្រមព្រៀងគ្នារៀបចំឲ្យមានការទាក់ទងតាមផ្លូវអាកាសជាប្រក្រតី រវាងប្រទេសទាំងពីរ ។ នៅក្នុងកំឡុងឆ្នាំដំបូងនៃការកាន់អំណាចរបស់គេ ពួកខ្មែរក្រហមហាក់ដូចជាចង់កំណត់ដោយច្បាស់លាស់នូវជំហរផ្នែកការទូតផ្ទាល់របស់គេ ដែលជាជំហរឯករាជ្យមិនចំណុះប្រទេសចិន និងវៀតណាម ប៉ុន្តែ ក៏គ្មានប្រឆាំងនឹងប្រទេសណាមួយក្នុងចំណោមប្រទេសទាំងពីរនេះដែរ ។ ប្រហែលជាបក្សការពារខ្លួនជាមុន ទល់នឹងអំពើក្បត់ជាយថាហេតុមួយរបស់ចិន បន្ទាប់ពីមរណភាពរបស់ ម៉ៅ នោះហើយមើលទៅ ។

គ្មានអ្នកណាម្នាក់នឹកឃើញថា ប៉ុល ពត បានដាប់ដៃប្រឡូកក្នុងការតស៊ូមួយដើម្បីដណ្ដើមអំណាច ឬថាបក្សហៀបនឹងបែកបាក់គ្នាអំពីបញ្ហាទំនាក់ទំនងជាមួយនឹងប្រទេសវៀតណាមឡើយ ប៉ុន្តែ គេរកស្មានមិនត្រូវ តើអ្នកណាមួយហ៊ានប្រឆាំងជំទាស់នឹង ប៉ុល ពត នៅក្នុងកាលៈទេសៈនេះ ។ លេខាបក្សភូមិភាគដ៏មានអំណាចបំផុតគឺ សោ ភឹម នៃភូមិភាគបូព៌ា បានរួចសហការយ៉ាងពេញទំហឹង ក្នុងការបោសសម្អាតអតីតភូមិភាគខគ្គរ ដែលសម្រេចដោយមជ្ឈិម ។ តាម៉ុក នៃភូមិភាគនិរតី ដែលជាលេខាបក្សដ៏មានអំណាចសំខាន់ណាស់ដែរ បន្ទាប់ពី សោ ភឹម ក៏ធ្លាប់បានចូលរួមក្នុងការជម្លៀស “ពួកអ្នកថ្មី” យ៉ាងច្រើនចេញពីតំបន់របស់គាត់ទៅកាន់ភូមិភាគពាយ័ព្យដែរ ។ តាមចម្លើយសាក្សីជាច្រើនដែលយកជាការបាន គណៈលេខាមជ្ឈិមបក្ស បានអនុម័តយល់ព្រមមតិណែនាំទាំងអស់របស់ ប៉ុល ពត រហូតមកដល់កាលបរិច្ឆេទនេះ ។ [សមាជិកនៃគណៈលេខានៃគណៈកម្មាធិការមជ្ឈិមបក្សមុនការបោសសម្អាតឆ្នាំ១៩៧៨ រួមមាន ប៉ុល ពត, នួន ជា, តាម៉ុក, សោ ភឹម, អៀង សារី, វ៉ន វ៉េត, សុន សេន និងតាកឹ (នៃបញ្ជាការដ្ឋានកងទ័ពភូមិភាគពាយ័ព្យ) ។ នៅចុងឆ្នាំ១៩៧៨ តាកឹ, វ៉ន វ៉េត និង សោ ភឹម ត្រូវបានសម្លាប់តាមបញ្ជារបស់សមមិត្តខ្លួនក្នុងគណៈលេខាមជ្ឈិម] ។

បើពិនិត្យមើលតាមសភាពខាងក្រៅ ទំនាក់ទំនងផ្សេងៗជាមួយប្រទេសវៀតណាម មានសភាពល្អប្រសើរ ៈ ផ្លូវអាកាសមួយ បានភ្ជាប់ទីក្រុងភ្នំពេញទៅទីក្រុងហូជីមិញ (អតីតក្រុងព្រៃនគរ) ហើយឧប្បត្តិហេតុផ្សេងៗ នៅតាមព្រំដែន ក៏មិនសូវមានញឹកញាប់ដែរ ។ ប្រទេសទាំងពីរ បានចាត់ទុកសហរដ្ឋអាមេរិក ជាសត្រូវសំខាន់បំផុត ហើយ អៀង សារី បានធ្វើសេចក្ដីថ្លែងការណ៍មួយនៅអង្គការសហប្រជាជាតិ ក្នុងន័យនេះដែរ ដោយចោទប្រកាន់សហរដ្ឋអាមេរិកថា នៅតែបន្តនាំមុខធ្វើ«សកម្មភាពឧក្រិដ្ឋ» ផ្សេងៗ ប្រឆាំងនឹងប្រជាជនកម្ពុជាទៀត ។ ពួកវៀតណាមទើបនឹងត្រូវគេទទួលស្គាល់ឲ្យចូលអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ ថ្វីបើមានការប្រឆាំងពីអាមេរិកាំងក៏ដោយ ។

ហេតុនេះ វាពុំមានមូលហេតុសមស្របណាមួយ ដើម្បីចាត់ចែងធ្វើការស្រាវជ្រាវ និងកម្ទេចបក្សពួកប្រឆាំងខាងនយោបាយជាសម្ងាត់នៅក្នុងផ្ទៃបក្សឡើយ ។ ប្រទេសវៀតណាមមិនសម្ដែងឲ្យឃើញលក្ខណៈគំរាមកំហែងខ្លាំងជាងគេទេ ហើយម្យ៉ាងទៀត ក៏ពុំមានការវែកគំនិតដោយចំហក្នុងផ្ទៃបក្សដែរ ។ តាមដំណើរសមជាពិតទាំងអស់ ដំណាក់កាលនេះ គឺជាឧទាហរណ៍មួយទៀត នៃការគិតអំពល់ពីរឿងអំណាច និងការលាក់ការណ៍ ដែលធ្វើឲ្យមជ្ឈិមកើតទុកដោយសារវា ។ បក្សបានសម្លាប់ភាគច្រើននៃ«ពួកកុម្មុយនិស្តឆ្នាំ១៩៥១» នៅពេលដែលពួកនេះវិលត្រឡប់ពីវៀតណាមខាងជើងមកវិញ ក្នុងរយៈពេលសង្គ្រាម ។ ហេតុនេះ ប៉ុល ពត និងក្រុមមេដឹកនាំមួយក្ដាប់តូច គ្មានឃើញមូលហេតុណាមួយ ដើម្បីក្សានូវការសម្របសម្រួលគ្នា (ដែលគេគ្រាន់តែសន្មត) ស្ដីពីការកាលបរិច្ឆេទនៃការបង្កើតបក្សទៀតទេ ។ ហើយដោយផ្លាស់ប្ដូរកាលបរិច្ឆេទនេះ បក្សបានប្រកាសឲ្យដឹងជាសាធារណៈថា មជ្ឈិម បានក្ដោបក្ដាប់អំណាចផ្ដាច់ការរបស់ខ្លួនលើការបដិវត្តន៍យ៉ាងពិតប្រាកដហើយ ។

ឌុច បានប្រើពេលអស់មួយឆ្នាំទៀត តាមរយៈការធ្វើទារុណកម្មដើម្បីទទួលបាន «ភ័ស្ដុតាងផ្សេងៗ» អំពីបក្សសម្ងាត់របស់កម្ពុជាដែលគ្រប់គ្រងដោយពួកវៀតណាមនេះ ។ ឌុច ប្រមូលបានភ័ស្ដុតាងក្នុងចំនួនមួយយ៉ាងគ្រប់គ្រាន់ សម្រាប់ការប្រារព្ធបុណ្យខួបកំណើតបក្សនៅឆ្នាំ១៩៧៧ ដែលក្នុងឱកាសនោះ ប៉ុល ពត បានប្រកាសជាផ្លូវការថា បក្សកុម្មុយនិស្តកម្ពុជា គឺជាអ្នកកាន់អំណាចនៅប្រទេសកម្ពុជា ។

ការដាក់ឲ្យអនុវត្តនូវគម្រោងការដ៏ធំមួយទៀតរបស់ ឌុច –វែកមុខ និងកម្ទេចសមាសភាពគហបតី និងបញ្ញវ័ន ក្នុងជួរបក្ស– បានទទួលជោគជ័យដូចគ្នា ។

ភាគច្រើននៃគំនិត និងសកម្មភាពផ្សេងៗរបស់គណៈដឹកនាំបក្ស ច្រើនតែមិនសមហេតុផល ចម្លែកគួរឲ្យឆ្ងល់ បើគិតតាមលក្ខណៈវិនិច្ឆ័យធម្មតា និងដែលទាក់ទងនឹងមនុស្ស ។ ប៉ុន្តែ ការប្រព្រឹត្តខុសគន្លងនេះ មានរបៀបអនុវត្តម្យ៉ាងដោយឡែករបស់វា ដែលគេរកឃើញក្នុងឯកសារផ្សេងៗនៅមន្ទីរឃុំឃាំងទួលស្លែង និងឯកសារសម្ងាត់របស់បក្ស ។ ប៉ុន្តែ ក្នុងក្របខ័ណ្ឌនៃរបៀបអនុវត្តទៅម្យ៉ាងដោយឡែក ដែលសម្លាប់មនុស្សដោយចេតនា

នេះ ដោយត្រូវការឲ្យជនជាតិកម្ពុជាដែលរស់នៅឯនាយសមុទ្រ វិលត្រឡប់ចូលមកប្រទេសវិញតាមពាក្យសុំរបស់មជ្ឈិមហាក់ដូចជាមិនទំនងទាល់តែសោះ ។

នៅឆ្នាំ១៩៧៥ និង១៩៧៦ ឥស្សរជនជាច្រើនដូចជា ជួន ប្រសិទ្ធិ ជាដើម បានសម្ដែងឲ្យឃើញការប្រឹងប្រែងជាច្រើនក្នុងគោលបំណងធ្វើអ្វីមួយ ដើម្បីបញ្ចុះបញ្ចូលឲ្យជនជាតិកម្ពុជាដែលកំពុងរស់នៅឯបរទេសត្រឡប់ចូលមកប្រទេសវិញ និងរួមចំណែកជួយការបដិវត្តន៍ ។ ពួកបញ្ញវន្ត និងអ្នកមានវិជ្ជាជីវៈសេរី ដែលធ្លាប់គាំទ្រសម្ដេច ព្រះនរោត្តម សីហនុ និងខ្មែរក្រហមក្នុងសម័យសង្គ្រាម បានឆ្លើយតបនឹងការអំពាវនាវនេះ ។ អ្នកខ្លះក្នុងចំណោមនោះ ធ្លាប់បានឮការនិយាយពីការកាប់សម្លាប់មនុស្សដោយព្រាវៗ និងការអត់ឃ្លាន ការដំណាលរបស់ប្រជាជនជាច្រើន ដែលរត់ភៀសខ្លួនទៅប្រទេសថៃដែរ ប៉ុន្តែពួកគេមិនព្រមជឿទេ ដោយចាត់ទុកថាជាការឃោសនាបោកប្រាស់ ។ ភាគច្រើននៃជនជាតិកម្ពុជាទាំងនេះ ពុំមែនជាសមាជិកបក្សទេ ប៉ុន្តែ ជាអ្នកមានសមានចិត្តធម្មតា ដែលមានបំណងថា ការបដិវត្តសង្គមនិយមច្បាស់ជាធ្វើឲ្យប្រទេសគេផ្លាស់សភាពទ្រង់ទ្រាយ និងធ្វើឲ្យជោគវាសនារបស់ខ្លួនបានប្រសើរជាងមុនមិនខាន ។

ពួកគេបានលះបង់មុខរបរ និងគ្រួសាររបស់គេដែលរស់នៅសហរដ្ឋអាមេរិក ប្រទេសបារាំង កាណាដា ឬបណ្ដាប្រទេសអឺរ៉ុបខាងកើត (ពេលនោះជាប្រទេសនៅកាន់លទ្ធិកុម្មុយនិស្តនៅឡើយ ទើបមកដល់ឆ្នាំ១៩៩០ រៀងរហូតមក ទើបប្រទេសទាំងនោះ បានផ្លាស់ប្ដូរប្រព័ន្ធនយោបាយរបស់ខ្លួន ជាប្រទេសកាន់លទ្ធិប្រជាធិបតេយ្យតាមបែបបស្ចិមប្រទេសវិញ) ។ ពួកគេសុខចិត្តបោះបង់មុខតំណែងទូតរបស់គេនៅមជ្ឈឹមបូព៌ា ឬនៅអាស៊ី និងបណ្ដាប្រទេសកុម្មុយនិស្ត និងមិនមែនកុម្មុយនិស្ត ដែលពួកគេធ្លាប់ធ្វើជាតំណាងបុព្វហេតុរណសិរ្សរួបរួមជាតិកម្ពុជាក្នុងសម័យសង្គ្រាម ។ ហើយពួកគេបានវិលត្រឡប់មកក្រុងភ្នំពេញវិញ សម្រាប់តែឲ្យគេចាត់ទុកជាឥស្សរជនដែលគេសង្ស័យ ឬជាមនុស្សក្បត់ប៉ុណ្ណោះ ។

អ្នកការទូតមួយក្រុម ដែលគេហៅឲ្យត្រឡប់មកក្រុងភ្នំពេញវិញនៅឆ្នាំ១៩៧៦ ត្រូវបានគេដឹកពីអាកាសយានដ្ឋានពោចិនតុង ទៅកាន់មន្ទីរឃុំឃាំងទួលស្លែងជាបន្ទាន់ ជាទីដែលអ្នកទាំងនោះត្រូវគេធ្វើទារុណកម្ម និងប្រហារជីវិតចោល ។ ពួកគេត្រូវកាត់ទោសសម្លាប់ចោល ពីព្រោះតែពួកគេធ្លាប់រស់នៅឯបរទេស ដូច្នេះ «គឺនៅដោយឡែកពីចលនាហើយ[១៣]» ពួកគេសុទ្ធតែមានទម្លាប់ផ្ដេសផ្ដាសដោយការសេពគប់ ។ ការស្អប់ជនបរទេសរបស់ខ្មែរក្រហមបានកើនរឹតតែខ្លាំងឡើងគ្មានឈប់ឈរ ។

ពួកបញ្ញវន្ត និងអ្នកមានវិជ្ជាជីវៈសេរី រួមបន្តជាក្រុមជនជាតិកម្ពុជាជាច្រើនជាងគេ ដែលត្រឡប់ពីបរទេសមកមាតុប្រទេសវិញ ហើយបានទទួលការធ្វើបដិសណ្ឋារកិច្ចយ៉ាងប្រសើរមួយនៅពេលមកដល់ដំបូង ។ ក្នុងចំណោមនោះមាន ទ្រី ម៉េងហ៊ួត[១៤] ម្នាក់ដែរ ដែលធ្លាប់បានរួមចំណែកធ្វើសកម្មភាពនយោបាយយ៉ាងសកម្ម ដើម្បីបុព្វហេតុ«សង្គមនិយម» នៅទីក្រុងប៉ារីសក្នុងពេលប្រទេសមានសង្គ្រាម ដោយលះបង់ការសិក្សា និងសុខភាព

របស់គាត់ ដើម្បីការបដិវត្តន៍មួយ ដែលនឹងនាំមកនូវយុត្តិធម៌ និងសេរីភាពសម្រាប់ប្រទេសគាត់ ។ គាត់បានវិលមកក្រុងភ្នំពេញវិញនៅចុងឆ្នាំ១៩៧៥ ព្រោះត្រូវធ្វើឲ្យស្រើបចិត្តខ្លាំងដោយទស្សនវិស័យមួយ ដើម្បីកសាងលទ្ធិសង្គមនិយមនៅប្រទេសកម្ពុជា ។ គាត់យល់ច្បាស់ពីការភាន់ច្រឡំរបស់គាត់ តាំងពេលគាត់មកដល់អាកាសយានដ្ឋានពោធិ៍ចិនតុងម៉្លេះ ។

"ពួកយើងត្រឡប់មកប្រទេសវិញជុំគ្នាទាំងអស់ -ពួកបញ្ញវន្តមកពីប្រទេសបារាំង រូម៉ានី អង់គ្លេស និងអាមេរិក...។ ពួកគេ (ពួកខ្មែរក្រហម) បានអនុញ្ញាតឲ្យគូស្វាមីភរិយាជាតិបរទេសតែម្នាក់គត់ តាមមកជាមួយប្តីរបស់នាង ដោយសារការធ្វើអន្តរាគមន៍របស់សម្តេច ព្រះនរោត្តម សីហនុ ផង (ដែលនៅតែជាមេដឹកនាំរដ្ឋាភិបាលរណសិរ្សមានតែឈ្មោះ ប៉ុន្តែឥតអំណាចនៅឡើយ)" ។

ទីក្រុងភ្នំពេញដែល ហ៊ួត បានឃើញឡើងវិញ បន្ទាប់ពីការរស់នៅប្រាំបួនឆ្នាំនៅបរទេស លែងជាទីក្រុងដែលគាត់ធ្លាប់រក្សាអនុស្សាវរីយ៍ទៀតហើយ ។ "ទីក្រុងមានសភាពប្រែប្រួលខ្លាំងមែនទែន រហូតដល់ធ្វើឲ្យខ្ញុំស្រយុតចិត្តយ៉ាងខ្លាំង ។ តាមខ្ញុំនឹកគិត ទីក្រុងដែលផ្លាស់ប្តូរច្រើនដូច្នេះ ប្រហែលពីព្រោះរបបថ្មីមិនចង់ឲ្យមានភាពខុសគ្នាខ្លាំងពេករវាងពួកអ្នកមាន និងពួកអ្នកក្រហើយមើលទៅ" ។

ហ៊ួត មានអាយុសាមសិបឆ្នាំ ។ តាមពាក្យសម្តីផ្ទាល់របស់គាត់ថា គាត់ជា"សកម្មជន"ម្នាក់ នៃចលនាសង្គមនិយម ជានិស្សិតក្រីក្រម្នាក់ ដែលតស៊ូទប់ទល់នឹងជីវភាពយ៉ាងត្រដាបត្រដួស ដើម្បីបុព្វហេតុបដិវត្តទោះបីជាក្រលំបាកយ៉ាងណាក៏ដោយ ។ រឿងអស់នេះ ដូចជាគ្មានបានផលប្រយោជន៍អ្វីបន្តិចសោះ ក្នុងការសាកល្បងរបស់គាត់កន្លងមក ពេលដែលគាត់ចាប់ផ្តើមនឹកព្រួយបារម្ភតាំងពីការមកដល់របស់គាត់ក្នុងរដ្ឋធានីម៉្លេះ ។

ខៀវ សំផន ត្រូវបានចាត់តាំងឲ្យមកធ្វើការអប់រំខាងនយោបាយមួយ ដល់ពួកបញ្ញវន្តដែលទើបនឹងចុះពីយន្តហោះទាំងនេះ ។ ក្នុងចំណោមមនុស្សទាំងបីរយនាក់ ពួកគេត្រូវបានឲ្យស្នាក់នៅតាមបន្ទប់ផ្សេងៗ នៃអតីតសកលវិទ្យាល័យបច្ចេកទេសមិត្តភាពខ្មែរ-សូវៀត ។ ខៀវ សំផន បាននិយាយទៅកាន់ពួកនេះថា "យើងសុទ្ធតែស្មើភាពគ្នា ។ មនុស្សទាំងអស់ត្រូវតែធ្វើការ ។ ក្នុងប្រទេសពុំមានស្រូវអង្ករច្រើនទេ ។ ការបដិវត្តន៍ ជាកាតព្វកិច្ចរួមគ្នានឹងពួកចិន ។

ខៀវ សំផន ពុំមានលើកនិយាយពីប្រទេសវៀតណាមទេ ។ ការអប់រំនយោបាយបានចប់ត្រឹមនេះ ហើយការងារបានចាប់ផ្តើមភ្លាមដោយគ្មានបង្អែបង្អង់ឡើយ ។ ហ៊ួត បានដំណាលថា "ពួកបញ្ញវន្ត ត្រូវគេដាក់ឲ្យស្នាក់នៅក្នុង"រោងបណ្តោះអាសន្នជាច្រើន ដែលមានមនុស្សពេញណែន ដូចជំរំពួកអ្នកភៀសខ្លួនដែរ" ហើយគេឲ្យអ្នកទាំងនេះធ្វើការដប់ពីរម៉ោងក្នុងមួយថ្ងៃ ដោយដាំស្រូវ និងបន្លែបន្ការផ្សេងៗ ។ ពួកយើងសុទ្ធតែត្រូវគេធ្វើឲ្យខូចទឹកចត្តិទាំងស្រុង ។ យើងទាំងអស់ សុទ្ធតែមានបញ្ហាខាងសុខភាព និងផ្លូវចិត្ត ។ ខ្ញុំមិនដែលនឹកគិតថា រឿងនេះអាចកើតមានចំពោះរូបខ្ញុំសោះ ។ ខ្ញុំគិតថា នឹងធ្វើអ្វីៗគ្រប់បែបយ៉ាង ដើម្បីប្រទេសរបស់ខ្ញុំ ប៉ុន្តែ ពុំមែនដាំស្រូវ

ឬដាំស្ពៃពេញៗមួយឆ្នាំអ៊ីចឹងទេ» ។

ហ៊ួត បានសន្និដ្ឋានថា នៅចុងឆ្នាំ១៩៧៦ មានពួកបញ្ញវន្តពីប្រាំរយទៅប្រាំមួយរយនាក់ នៅធ្វើការ និងរស់នៅជាមួយគ្នា ក្នុងតំបន់ជុំវិញទីក្រុងភ្នំពេញ ដាច់ឡែកពីប្រជាជនទាំងអស់ ។ ហ៊ួត នៅនឹកឃើញថា ពួកអ្នកដែលត្រឡប់ពីសហរដ្ឋអាមេរិកមកវិញ ត្រូវគេយកទៅដាក់ឲ្យរស់រឹតតែឆ្ងាយពីគេពីឯងទៅទៀតនាឆ្នាំដដែលនោះ ។ គឺនៅជំនាន់នោះហើយ ដែល ហ៊ួត និងពួកបញ្ញវន្តដទៃទៀត ត្រូវគេចាត់ឲ្យទៅនៅធ្វើការក្នុងផ្នែកមួយនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រសួងឧស្សាហកម្ម បើតាមគាត់ស្មាន គឺដើម្បីជំនួសកម្មករប្រមាណជាដប់នាក់ដែលត្រូវគេសម្លាប់ក្នុងពេលថ្មីៗនៅមន្ទីរឃុំឃាំងទួលស្លែងនោះហើយ ។ ហ៊ួត នៅធ្វើការក្នុងរោងចក្រស្ពដែកលេខ៧ តាមមាត់ទន្លេបាសាក់ ហើយបានមើលឃើញពីចម្ងាយនូវរបៀបរបបរស់នៅរបស់បណ្ដាសមាជិកនៃវណៈអ្នកមានឯកសិទ្ធិទៀតផង ។

ពួកអ្នកត្រួតការ និងពួកកម្មការសុទ្ធតែជាកម្មាភិបាលខ្មែរក្រហម ។ ហ៊ួត រៀបរាប់ថា «នៅភ្នំពេញពួកគេស្នាក់នៅក្បែរកន្លែងរស់នៅរបស់យើងដែរ ។ ពួកគេធ្វើការជាមួយយើង ប៉ុន្តែ បរិភោគយ៉ាងគ្រប់គ្រាន់នៅពេលដែលយើងហូបតែបបរាវប៉ុណ្ណោះ ។ នេះពុំមែនជាសមភាពទេ ដែលពួកកម្មាភិបាលរស់នៅ និងហូបចុកប្រសើរជាងយើងទៅទៀត ។ រឿងនេះវាមិនសំខាន់ប៉ុន្មានទេកាលបើខ្ញុំមិនដឹងស្លាប់ ឬរស់នោះ ។ តើខ្ញុំអាចអួតខ្លួនបម្រើប្រទេសខ្ញុំដូចម្ដេចទៅ? ។

ទ្រី ម៉េងហ៊ួត និងបញ្ញវន្តដទៃទៀត បានចំណាយពេលវេលាដ៏សំខាន់បំផុតក្នុងជីវិតពេញវ័យរបស់គេដើម្បីសិក្សាពីបញ្ហាផ្សេងៗដែលឥឡូវនេះ ប្រទេសកម្ពុជាកំពុងប្រឈមមុខ - តើត្រូវប្រើប្រាស់ឲ្យអស់លទ្ធភាពនូវប្រភពធនធានដ៏ស្ដួចស្ដើងរបស់ខ្លួន ត្រូវធ្វើទំនើបកម្មកសិកម្ម និងឧស្សាហកម្ម ដោយមិនពឹងផ្អែកសហគ្រាសចម្រុះជាតិ ឬមហាអំណាចបរទេសនានាដោយរបៀបណាទៅ? ។ តើត្រូវប្រើមធ្យោបាយបែបណា ដើម្បីញ៉ាំងឲ្យប្រជាជនជឿថា ការងារ និងការធ្វើពលិកម្មផ្សេងៗ ដែលផ្ដល់ឲ្យក្នុងដំណាក់កាលដំបូងនៃការបដិវត្តន៍ ច្បាស់ជាទទួលបានលទ្ធផលក្នុងការកែលម្អជីវភាពរស់នៅប្រសើរជាងមុនមួយ និងធ្វើឲ្យមានឯករាជ្យពេញលេញដូចម្ដេចទៅ? ។ ប៉ុន្តែ គេបានហាមឃាត់មិនឲ្យប្រើប្រាស់ការចេះដឹងរបស់គេឡើយ ។ ការសិក្សាស្រាវជ្រាវរបស់ពួកគេបានក្លាយទៅជារបស់ដែលគេសង្ស័យទៅវិញ ។ ពួកគេគោងតែលុបលាងទោសដោយទទួលទណ្ឌកម្ម ធ្វើការងារបញ្ញវន្តជាច្រើនឆ្នាំ ដែលពួកគេត្រូវបំពេញដើម្បីពួកខ្មែរក្រហម ។ ហ៊ួត ដែលធ្លាប់ជឿថា អាចក្លាយទៅជាសមាជិកបក្សកាន់អំណាចនោះ នៅពេលនេះទើបដឹងខ្លួនថា ជាទាសកររបស់បក្សទៅវិញសោះ ។ មានតែប្រជាជនកម្ពុជាដែលមានវណ្ណៈភាពដើមត្រឹមត្រូវមួយចំនួនប៉ុណ្ណោះ ដែលគេចាត់ទុកជាមុខសញ្ញាល្អក្នុងការត្រៀមបញ្ចូលក្នុងបក្ស ។ តាមបញ្ជីរបស់គណៈលេខាមជ្ឈិម សុន សេន និង ឌុច បានយកចិត្តទុកដាក់កម្ចាត់សមាសភាពគហបតីចេញពីក្នុងផ្ទៃបក្ស ពុំមែនបង្កើនចំនួនសមាជិកបក្សទេ ។

នៅឆ្នាំ១៩៧៧ ពួកកុម្មុយនិស្តបានចាប់ផ្តើមដាក់គុក និងសម្លាប់ពួកបញ្ញវន្ត ពួកមន្ត្រី ដែលត្រឡប់មកពីបរទេសអស់មួយចំនួន -បញ្ញវន្ត១៤៨នាក់ ដែលមានឈ្មោះក្នុងសំណុំឯកសារនៅមន្ទីរឃុំឃាំងទួលស្លែង និងអ្នកដទៃដែលត្រូវគេសម្លាប់ភ្លាមៗតាំងពីដំបូង ឬដែល“បាត់ខ្លួន” ។

អ្នករងគ្រោះថ្មីៗទាំងនេះ ត្រូវសរសេររៀបរាប់ពី “ខ្សែបណ្តាញ”របស់គេ ដែលជាអ្នកសមគំនិត -នេះជារបៀបចាត់ចែងថ្មី ដើម្បីរកឲ្យឃើញ “សម្បុកចារបុរស” ក្នុងប្រទេសទាំងមូល ហើយតាម សារី ថា បញ្ហានេះត្រូវបានអនុម័តយល់ព្រមតាំងពីឆ្នាំ១៩៧៦ម៉្លេះ ។ ទស្សនៈអំពី“ខ្សែបណ្តាញ”នេះ គឺជារបៀបមួយដែលផ្សេងពីរបៀបចាត់ចែងរបស់ ស្តាលីន ដោយសារថា បណ្តាមិត្តភក្តិ ឪពុកម្តាយ និងសហការីរួមការងារ ដែលមាននិន្នាការដូចគ្នា ត្រូវបានវិនិច្ឆ័យជាអ្នកមានទោស ពីបទសមគំនិតជាមួយនឹងអ្នកជាប់ចោទ ។

របៀបចាត់ចែងរកខ្សែបណ្តាញរួមគំនិតក្បត់ បានទៅជាបញ្ហាស្នូលរបស់មណ្ឌលសន្តិសុខ ដែលរៀបចំឡើងដោយ ឌុច និងបក្ស ដើម្បីចាប់ផ្តើមធ្វើការបោសសម្អាតផ្សេងៗ ទាំងមូល ។ ពួកមេដឹកនាំបក្ស ខិតខំស្រាវជ្រាវរករបៀបចាត់ចែងដ៏ល្អឥតខ្ចោះ ដែលពួកខ្មាំងសត្រូវបិទបាំង ដើម្បីបំផ្លាញឲ្យដល់ឫសគល់នូវកិច្ចប្រឹងប្រែងរបស់ប្រជាជន ហើយនៅទីបំផុត បំផ្លាញការបដិវត្តន៍ថែមទៀត ។ តាមការឲ្យដឹងរបស់ អៀង សារី[១៥] ថាបើសិនជាមនុស្សបីនាក់ចោទប្រកាន់មនុស្សទីបួន ម្នាក់ថាបានរួមគំនិតប្រឆាំងនឹងរបប និងជាសមាជិកនៃ“ខ្សែបណ្តាញ”មួយ ជននេះនឹងត្រូវគេសន្មតថា ជាអ្នកមានទោស ហើយអាចត្រូវចាប់ខ្លួនទៀត ។ សារី បានបញ្ជាក់ថាៈ បើសិនមនុស្សបីនាក់អះអាងថា ម្នាក់ក្នុងចំណោមពួកគេជាភ្នាក់ងារ សេ.អ៊ី.អា. ឬ កា.ហ្សេ.បេ. អ្នកម្នាក់នោះក៏ត្រូវចាប់ខ្លួនដែរ” ។

ឌុច និងក្រុមសន្តិបាលបានគិតគូរពីការរួមគំនិតក្បត់ និងខ្សែបណ្តាញដ៏សាំញ៉ាំជាច្រើន ហើយបង្ហាញជាថ្មីលើបញ្ជីរាយឈ្មោះរឿងផ្សេងៗ ។ ពួកគេពុំហ៊ានបង្ហាញខ្លួន ជាពេជ្ឈឃាតសាមញ្ញ ដែលកំពុងសម្លាប់គូប្រជែង ឬខ្មាំងសត្រូវយ៉ាងគ្មានរំភើបនោះទេ ។ ពួកគេបានចាត់ចែងការសម្លាប់តែម៉្យាងគត់ គឺបន្ទាប់ពីពួកអ្នកទោសទទួល“សារភាព”ថា ខ្លួនជាដើមហេតុនៃបញ្ហាផ្សេងៗ ដែលចោទឡើងចំពោះការបដិវត្តន៍ ។ ការធ្វើទារុណកម្ម និងការសម្លាប់ ត្រូវបានគេចាត់ទុកថា ជាវិធីមួយដែលមានលក្ខណៈចាំបាច់ខានមិនបាន ដើម្បីស្រាវរកខ្សែបណ្តាញផ្សេងៗ ។ មនុស្សភាគច្រើននៃមនុស្សដែលមានរៀបរាប់ក្នុងចំនួនខ្សែបណ្តាញបញ្ញវន្តទាំងនេះ សុទ្ធតែជាបុគ្គលិកធ្វើការនៅក្រសួងការបរទេស ក្នុងនោះមានទាំង ដួន ប្រសិទ្ធិ ផង ។ ក្រសួងនេះ ជាគោលដៅធំមួយ ក្នុងចំណោមគោលដៅសំខាន់ៗនៃរលកបោសសម្អាតជាលើកដំបូង ប្រឆាំងនឹងវណ្ណៈអនុធន ពីព្រោះថា គ្មានក្រសួងណាមួយផ្សេងទៀត មានអតីតបញ្ញវន្តច្រើនដូចក្រសួងនេះទេ ។ ភាគច្រើននៃពួកនិស្សិត និងសាស្ត្រាចារ្យ គ្រូបង្រៀនដែលត្រឡប់មកពីបរទេសក្រោយឆ្នាំ១៩៧៥ សុទ្ធតែស្គាល់រាប់អានមនុស្សដែលធ្វើការនៅក្រសួងការបរទេសជាពិសេស ប្រសិទ្ធិ និង អៀង សារី ហើយអ្នកទាំងនោះ បានរួមធ្វើការជាមួយអ្នកទាំងពីរនាក់នេះទៀតផង ។

ឥស្សរជនបក្សម្នាក់ ក្នុងចំណោមឥស្សរជន ជំបូងៗរបស់បក្ស ដែលគេយកទៅដាក់គុកនៅទួលស្លែង នាខែកុម្ភៈ ឆ្នាំ១៩៧៦ គឺជាមន្ត្រីជាន់ខ្ពស់ម្នាក់នៅក្រសួងនេះ ។

ម្យ៉ាងទៀត ក្រសួងការបរទេស បានត្រូវគេចម្រាញ់យកពួកអ្នកមិនល្អចេញជាប់ជាប្រចាំ ពេញថិរៈវេលា នៃសម័យកាលខ្មែរក្រហម ថ្វីបើ អៀង សារី ជាមេដឹកនាំនៅក្រសួងនេះក៏ដោយ ។ ដោយពិតទៅ អៀង សារី បាន លាក់បំពួនបញ្ញវន្ត ដែលមានចំណេះវិជ្ជាខ្ពស់ៗ ពួកមនុស្សប្រុសស្រី ដែលធ្លាប់ចំណាយពេលវេលាជាច្រើនឆ្នាំ នៅបរទេស ក៏ដូចនៅក្នុងព្រៃភ្នំដែរ ។ សារី បានសម្ដែងឲ្យឃើញថា គាត់គ្មានសមត្ថភាពការពារពួកអ្នកទាំងនោះ បានទេ ហើយក៏ពុំអាចបញ្ជូនពួកនោះទៅបរទេសវិញដែរ ។ នួន ជា បានបដិសេធមិនព្រមផ្ដល់ទិដ្ឋាការឲ្យចេញ សម្រាប់កម្មាភិបាលមួយចំនួន ដែល សារី បានស្នើសុំសម្រាប់មុខតំណែងការទូតមួយនៅបរទេសឡើយ[១៦] ។ ក្នុង របាយការណ៍ដំណាច់ឆ្នាំ១៩៧៦ មេដឹកនាំម្នាក់ បាននិយាយត្អូញត្អែរពីការពុំមានកម្មាភិបាលចេះដឹងគ្រប់គ្រាន់ សម្រាប់បញ្ជូនទៅបរទេសថា ៖ «ការខ្វះខាតតែមួយគត់របស់យើងនៅបរទេស គឺការគ្មានកម្មាភិបាលដែលអាច ធ្វើការក្នុងវិស័យទំនាក់ទំនងនៅក្រៅប្រទេស ។ អ្នកខ្លះដែលវិលពីបរទេស ត្រូវយើងដកចេញពីចលនាបដិវត្ត ។ អ្នកខ្លះទៀត មានប្រវត្តិដើមគួរទទួលយកបាន ប៉ុន្តែ គ្មានគុណសម្បត្តិចាំបាច់ ដែលគេត្រូវការសម្រាប់បម្រើ ចលនាបដិវត្តឡើយ ។ បច្ចុប្បន្ននេះ យើងត្រូវការឯកអគ្គរដ្ឋទូតថ្មីពី បួនទៅដប់នាក់ ហើយយើងសូមឲ្យអ្នកដែល បានចូលរួមក្នុងសម័យប្រជុំនេះ ផ្ដោតការយកចិត្តទុកដាក់ទៅលើបញ្ហានេះផង[១៧]» ។

របបនេះ ត្រូវការឯកអគ្គរដ្ឋទូតថ្មីជាច្រើននាក់ ដោយសារតែក្រុមសន្តិសុខបានចាប់ខ្លួន និងសម្លាប់អ្នក ការទូតចាស់ៗ អស់ទៅហើយ ។

ពួកបញ្ញវន្តនិយមឆ្វេង ពួកមានសមានចិត្តនឹងលទ្ធិកុម្មុយនិស្ត ដែលត្រឡប់ពីបរទេសមកវិញ បានត្រូវ សម្លាប់នៅទួលស្លែង ឬដាក់ឲ្យរស់នៅឆ្ងាយពីគេឯងក្នុង "ជំរំពិសេសៗ សម្រាប់ពួកបញ្ញវន្ត" ដែលនៅតាមច្រក ចេញពីទីក្រុងភ្នំពេញ ។ សារី បានបញ្ចប់ការតស៊ូដែលគ្មានសង្ឃឹមនេះមុនពេលកំណត់ ដើម្បីឲ្យទទួលបានការ អនុញ្ញាតបញ្ជូនអ្នកការទូតដែលមានបទពិសោធន៍ទៅបរទេស ។ ដោយគាត់ពុំអាចបញ្ជូនពួកកសិករបដិវត្ត មិនចេះ អក្សរ ដែលពុំធ្លាប់ផ្ដល់អត្ថប្រយោជន៍បន្តិចសោះឲ្យទៅជំនួសកន្លែងគេ ភាគច្រើននៃមុខតំណែងទូតនៅបរទេស នៅតែទំនេរគ្មានអ្នកណាកាន់កាប់រហូត ។

ប៉ុន្តែ ដោយបណ្ដាលេខាបក្សត្រូវប្រឈមមុខនឹងការបោសសម្អាតភូមិភាគរបស់គេ សារី បានយល់ព្រម ឲ្យអង្គការធ្វើការបោសសម្អាតក្រសួងរបស់គាត់ និងការសម្លាប់បញ្ញវន្តកម្ពុជា ដែលគាត់ជាអ្នកបញ្ចុះបញ្ចូលឲ្យ វិលត្រឡប់មកប្រទេសវិញ ។ ដូចមេដឹកនាំឯទៀតៗ គាត់ក៏ជឿទៅលើរបៀបចាត់ចែងរបស់ក្រុមសន្តិសុខ និង អ្វីៗទាំងអស់ដែលមន្ទីរឃុំឃាំងទួលស្លែងជាតំណាងដែរ ។ គាត់ជឿថា មាន«ខ្មាំងសត្រូវ»បង្កប់ក្នុងជួរប្រជាជន និងបក្សដែលបំផ្លិចបំផ្លាញការបដិវត្តន៍ និងរារាំងជោគជ័យរបស់ខ្លួន ។ គាត់ក៏យល់ព្រមក្នុងការបោសសម្អាត

ជាច្រើនទៀត ដូច្នេះគាត់គ្មានការដោះស្រាយណាផ្សេង ក្រៅពីសុខចិត្តឲ្យគេធ្វើការបោសសម្អាតក្រសួងរបស់គាត់ឡើយ ។

ជោគវាសនារបស់ពួកបញ្ញវន្តកម្ពុជា ត្រូវបានបញ្ចប់នៅថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៧៧ នៅពេលដែល ហ៊ូ នឹម ជាបិសាចម្នាក់ក្នុងចំណោម «បិសាចទាំងបី» ត្រូវចាប់ខ្លួនជាសម្ងាត់នាទីក្រុងភ្នំពេញ ។ ហ៊ូ នឹម ជារដ្ឋមន្ត្រីក្រសួងឃោសនាការ ហើយឈ្មោះរបស់គាត់ធ្លាប់បានលេចឡើងមិនដែលដាច់ពីឈ្មោះ ខៀវ សំផន ដែលជាប្រធានគណៈប្រធានរដ្ឋឡើយ ។ ជាមួយ ខៀវ សំផន និងហ៊ូ យន់ ដែលស្លាប់បាត់ទៅហើយ ហ៊ូ នឹម ក៏ជាអ្នកធ្លាប់ធ្វើសកម្មភាពតំណាងឲ្យបុព្វហេតុរបស់ខ្មែរក្រហម ក្នុងសម័យសង្គ្រាមដែរ ។ កាលពីដើម គាត់គឺជានិមិត្តរូបនៃការប្រឆាំងប្រកបដោយគុណធម៌ និងដែលបេះគិតគូរចំពោះសម្តេច ព្រះនរោត្តម សីហនុ និងអំពើពុករលួយផង ។ ប៉ុន្តែប្រការទាំងអស់នេះ មានសារសំខាន់តិចតួចណាស់នៅឆ្នាំ១៩៧៧ ចំពេលដែលបក្សផ្តើមធ្វើសកម្មភាពកម្ចាត់បណ្តាសមាសភាពអនុធនចេញពីជួរនោះ ។ សេចក្តីភ័យខ្លាច ជំងឺមិនទុកចិត្តគេឯងរបស់ខ្លួនលែងផ្តោតទៅរកជនបទទៀតហើយ ប៉ុន្តែ គឺផ្តោតមកលើទីក្រុងភ្នំពេញវិញម្តង ហើយ ហ៊ូ នឹម មិនដែលសម្តែងឲ្យឃើញថា គាត់ជាមនុស្សមានប្រយោជន៍ដូច ខៀវ សំផន សោះឡើយ ។

ហ៊ូ នឹម ត្រូវបានស្រាល់ជ្រើសជាបញ្ញវន្តនៃរបប ដែលត្រូវគេ «បូជាយញ្ញ» ដោយសារជំងឺមិនទុកចិត្តគេឯងនេះ ។ ប្រពន្ធគាត់ និងរូបគាត់ បានសារភាពក្រោមការធ្វើទារុណកម្មថា គាត់ជាសមាជិកម្នាក់នៃការរួមគំនិតក្បត់មានគ្នាច្រើនមួយ ដែលដឹកនាំដោយពួកសេ.អ៊ី.អា. ។ នៅមន្ទីរឃុំឃាំងទួលស្លែង ហ៊ូ នឹម បានទទួលស្គាល់ថាជាជនក្បត់ម្នាក់ និងជាចារបុរសម្នាក់[១៨] ។ គាត់ត្រូវគេសម្លាប់នៅខែកក្កដា បន្ទាប់ពីការធ្វើទារុណកម្មអស់បីខែ ។

ពុំមានការប្រកាសផ្សាយជាសាធារណៈ អំពីមរណភាពរដ្ឋមន្ត្រីក្រសួងឃោសនាការនេះទេ ។ ជាច្រើនខែក្រោយមក ប្រពន្ធរបស់ សុន សេន ឈ្មោះ យុន យ៉ាត បានឡើងជំនួស ហ៊ូ នឹម ក្នុងអគ្គការលេខនៃរដ្ឋាភិបាល ។ រង្វង់ប្រតិបត្តិការរបស់ក្រុមសន្តិបាននៅពេលនេះ មានទំហំធំសម្បើមមែនទែន ។ នៅខែកក្កដា ឆ្នាំ១៩៧៧ ពួកមេដឹកនាំជាន់ខ្ពស់ឯទៀតៗរបស់បក្ស បានដឹងខ្លួនពីសភាពធ្ងន់ធ្ងរនៃការបោសសម្អាតដែរ ។ ពួកជនបរទេស ដែលយកចិត្តទុកដាក់តាមដាន រឿងនេះ ក៏កត់សម្គាល់ឃើញដូចគ្នា ជាពិសេស អ្នកការទូតចិនម្នាក់[១៩] ដែលធ្វើការនៅក្រុងភ្នំពេញ និងធ្លាប់ជាមិត្តរបស់ ហ៊ូ នឹម ផង ។ អ្នកការទូតនេះ ពុំដែលស្គាល់ភាពរីករាយម្តងណាឡើយ ក្នុងកម្ពុជាប្រជាធិបតេយ្យ ហើយការបាត់ខ្លួនរដ្ឋមន្ត្រីឃោសនាការ គឺជាតំណក់ទឹកចុងក្រោយ ដែលធ្វើឲ្យទឹកហៀរចេញពីកែវ ។

នៅប្រទេសកម្ពុជា គ្មានអ្នកណាម្នាក់មានជីវភាពរស់នៅប្រកបដោយផាសុកជាងគេមួយ ដូចអ្នកការទូតចិនម្នាក់នៅភ្នំពេញឡើយ ។ ស្ថានទូតរបស់ចិន មានសភាពត្រជាក់ល្ហឹម ក្នុងពេលដែលមានចំហាយក្តៅខ្លាំងនៅខាងក្រៅ ។ ក្នុងស្ថានទូតមានអាងហែលទឹកធំមួយ និងវាសនដ្ឋានធំទូលាយជាច្រើនសម្រាប់បុគ្គលិកស្នាក់នៅ ។

ចុងភៅចិនម្នាក់ជាអ្នកធ្វើបាយទឹក ជាមួយនឹងគ្រឿងបរិភោគ ដែលគេដឹកតាមយន្តហោះជារៀងរាល់សប្តាហ៍ពីទីក្រុងប៉េកាំងមក ។ ក្នុងឋានៈជាសម្ព័ន្ធមិត្តគួរឲ្យកត់សម្គាល់របស់កម្ពុជាប្រជាធិបតេយ្យ ពួកចិនទាំងនេះអាចធ្វើការទាក់ទងជាមួយប្រជាជនបាន ហើយអាចធ្វើដំណើរទៅជនបទទៀត ។ ទីប្រឹក្សាចិនរាប់ពាន់នាក់ បានចូលមកជួយប្រទេសកម្ពុជា ដោយស្នាក់អាស្រ័យនៅរយៈពេលខ្លីជាងការស្នាក់នៅរបស់ពួកទាហានអាមេរិកាំង នៅប្រទេសវៀតណាមទៅទៀត ។ ប៉ុន្តែ ពួកចិនប្រហែលជាយល់តាំងពីដើមដំបូងថា រឿងរ៉ាវខ្លះនឹងពុំអាចធ្វើបានសម្រេចជោគជ័យឡើយនៅប្រទេសកម្ពុជា ។

អ្នកការទូតចិនជាន់ខ្ពស់រូបនេះ ដែលពុំប្រាប់ឈ្មោះឲ្យគេដឹងបាននិយាយថា "ប្រាកដណាស់ ខ្ញុំត្រូវធ្វើឲ្យងឿងឆ្ងល់យ៉ាងខ្លាំង នៅពេលមកដល់ក្រុងភ្នំពេញភ្លាម ។ ខ្ញុំទើបនឹងមកពីរដ្ឋធានីមួយរបស់អឺរ៉ុប ប៉ុន្តែខ្ញុំសន្និដ្ឋានថាខ្ញុំច្បាស់ជាទទួលរងការប៉ះទង្គិចផ្លូវចិត្តមួយធំដូចគ្នា បើសិនជាខ្ញុំចេញមកពីទីក្រុងប៉េកាំង ។ ក្នុងទីក្រុងនេះ គ្មានឃើញមនុស្សម្នាក់សោះ ។ មនុស្សណាម្នាក់ដើរលើថ្នល់នានាឡើយ ។ អ្វីដែលធ្វើឲ្យខ្ញុំចាប់អារម្មណ៍ជាងគេគឺស្ថានភាពស្ងាត់ជ្រងំរបស់ទីក្រុង ។ រៀងរាល់ព្រឹកមានក្រុមយុទ្ធជនដើរបោសសម្អាតផ្លូវខ្លះៗ ។ ក្នុងរយៈពេលមួយឆ្នាំកន្លះ ខ្ញុំមិនដែលឃើញប្រជាជនណាម្នាក់ដើរកម្សាន្តទេ ។ កាលដែលខ្ញុំជួបមនុស្សម្នា គឺជួបតែនៅតាមផ្លូវ ឬពួកគេធ្វើដំណើរទៅកន្លែងធ្វើការ ឬនៅធ្វើតាមផ្លូវ ឬយុទ្ធជនដែលកំពុងឈរយាមប៉ុណ្ណោះ" ។

អ្នកការទូតរូបនេះ ធ្លាប់ឮសេចក្តីរាយការណ៍ផ្សេងៗស្តីពីការបដិវត្តន៍របស់កម្ពុជាដែរ ហើយធ្លាប់តម្កើងផ្លូវចិត្តក្នុងសង្គមរឹតត្បិតមួយ ប៉ុន្តែ គាត់មិនដែលនឹកស្មានចំពោះប្រភេទនៃការដាក់ឲ្យនៅតែក្នុងលំនៅដ្ឋានចំពោះបណ្តាអ្នកការទូតនៅទីក្រុងភ្នំពេញ ដោយមានការតាមឃ្លាំមើលរបៀបនេះទេ ។

ជាច្រើនថ្ងៃកន្លងផុតទៅ ដោយគាត់គ្មានមូលហេតុផ្លូវការណាមួយ ដើម្បីបានចេញពីស្ថានទូតទៅក្រៅហើយគាត់នៅតែរស់នៅដូចមនុស្សជាប់ឃុំឃាំងក្នុងបរិវេណស្ថានទូតរបស់គាត់ ដូចដែលគេធ្លាប់ព្រមានគាត់អំពីចិនទៅ ។ ដោយពុំអាចទ្រាំទ្រនឹងបញ្ហានេះ គាត់បានចាប់ផ្តើមធ្វើដំណើរកម្សាន្តផ្សេងៗជាមួយអ្នកការទូតម្នាក់ក្នុងចំណោមអ្នកការទូតចិនប្រមាណដប់ពីរនាក់នៃស្ថានទូតនេះ ។ គាត់បាននិយាយថា "ពួកយើងសុទ្ធតែត្រូវធ្វើឲ្យតប់ប្រមល់ក្នុងចិត្ត និងការអផ្សុក... ។ រដ្ឋាភិបាលកម្ពុជាបានសុំកុំឲ្យយើងចេញដើរកម្សាន្តទៀត ប៉ុន្តែ យើងនៅតែបន្តការចេញដើរលេងដដែល ។ កងទ័ពម្នាក់ ឬពីរនាក់ តែងដើរតាមពីក្រោយយើងជាប់ជានិច្ច ក្នុងចម្ងាយប្រមាណជាហាសិបម៉ែត្រ ។ យើងមិនដែលមានសេចក្តីភ័យខ្លាចសោះឡើយនៅតាមផ្លូវនានា ពីព្រោះមានកងទ័ពប្រដាប់អាវុធដើរយាមល្បាតជាច្រើន" ។

ពីរឬបីដងក្នុងមួយសប្តាហ៍ កម្មាភិបាលមន្ទីរបក្សម្នាក់របស់កម្ពុជាបានមកកាន់ស្ថានទូត ដើម្បីថែរក្សាទំនាក់ទំនងផ្លូវការផ្សេងៗ ឲ្យស្ថិតស្ថេរជាប្រក្រតី ។ ពួកអ្នកការទូតចិនបានទទួលសៀវភៅ ឬអត្ថបទផ្សេងៗ ដែលចេញពីរដ្ឋាភិបាលរបស់កម្ពុជាប្រជាធិបតេយ្យដែរ គឺមានព្រឹត្តិប័ត្រពត៌មានប្រចាំថ្ងៃមួយ ទស្សនាវដ្តី និងកាសែត

ខ្លះៗ ប៉ុន្តែមានចំនួនតិចណាស់ ។ មិនយូរប៉ុន្មានក្រោយមក ពួកចិនបានចាប់ផ្តើមដើរកម្សាន្តសម្រាប់សុខភាព នៅពេលព្រឹក និងពេលល្ងាច បើទុកជាមានការស្តីបន្ទោសធ្ងន់ៗពីរបបនេះក៏ដោយ ។ នៅថ្ងៃគួរឲ្យចងចាំមួយ ពួកចិនបានលើកដៃជាសញ្ញាមិត្តភាព និងអ្នកការទូតអេហ្ស៊ីបម្នាក់ ដែលកំពុងហាត់រត់នៅតាមមហាវិថី ដោយផ្អើននឹងការហាមឃាត់របស់ខ្មែរក្រហមយ៉ាងព្រងើយ ។ ប្រាកដហើយ ការដើរកម្សាន្តទាំងនេះ ក៏ជាមធ្យោបាយមួយ ស្រាវជ្រាវឲ្យដឹងថា តើប្រទេសនេះមានសកម្មភាពដើរទៅមុខដោយរបៀបណាទៅ ។ «ក្នុងឱកាសនៃដំណើរកម្សាន្តនៅពេលល្ងាចៗ យើងបានឃើញកន្លែងសិប្បកម្មតូចៗមួយចំនួន ដែលមានយុវនារីជាច្រើន កំពុងដេរខោអាវក្នុងទីនោះ ប៉ុន្តែ យើងពុំអាចចូលទៅសួរសុខទុក្ខពួកគេបានទេ ។ យើងអាចចូលបានតែក្នុងរោងចក្រ ដែលផ្តល់ទុនដោយផ្ទាល់ តាមរយៈកម្មវិធីជំនួយរបស់យើងប៉ុណ្ណោះ» ។

ការស្អប់ជនបរទេសរបស់កម្ពុជា បានរីករាលដាលដល់សម្ព័ន្ធមិត្តដែលជិតស្និទ្ធបំផុតរបស់ពួកគេថែមទៀត ។ តួនាទីរបស់ពួកចិននៅប្រទេសកម្ពុជា គឺមានសារសំខាន់បំផុត ។ ក្រុមគ្រូពេទ្យចិនជាច្រើន បានចូលមកជួយប្រយុទ្ធប្រឆាំងនឹងជំងឺឆ្លងដ៏សាហាវ ដែលចាប់ផ្តើមលេចឡើងនៅឆ្នាំ១៩៧៦ ។ ក្រុមគ្រូពេទ្យចិនខ្លះទៀត បានបង្រៀនពីចំណុចសំខាន់ៗផ្នែកវេជ្ជសាស្ត្របស្ចិមប្រទេសដល់ពួកគ្រូពេទ្យខ្មែរក្រហម រួមទាំងការវះកាត់ធម្មតា និងបច្ចេកទេសក្នុងការប្រើកាំរស្មីអ៊ិចផង ។ ពួកអ្នកបច្ចេកទេសចិន បានកសាងឡើងវិញនូវរោងចក្រជាច្រើន នៅភ្នំពេញ និងនៅតាមបណ្តាខេត្តខ្លះៗ ។ នៅឆ្នាំ១៩៧៧ កាលបើប្រជាជនកម្ពុជា ត្រូវការទីប្រឹក្សាម្នាក់ខាងវិស័យកសិកម្ម ពួកចិនបានបញ្ជូនអ្នកជំនាញការម្នាក់ ក្នុងចំណោមអ្នកជំនាញដ៏ឆ្នើមបំផុតរបស់ខ្លួនមកឲ្យភ្លាម ។ ការផ្លាស់ប្តូរខាងពាណិជ្ជកម្មដែលមានព្រំដែនរបស់កម្ពុជា បានប្រព្រឹត្តទៅសំខាន់បំផុត តាមរយៈប្រទេសចិន ហើយពួកនិស្សិតខ្មែរមួយចំនួនតូច ដែលគេបញ្ជូនទៅបរទេសបំពេញការសិក្សារបស់គេ នៅទីក្រុងប៉េកាំងដែរ ។

ប៉ុន្តែ តាមការឲ្យដឹងរបស់អ្នកការទូតចិនថា ជំនួយដ៏មានតម្លៃនេះពុំមែនជួយផ្តល់សេរីភាព ដ៏ទូលំទូលាយមួយសម្រាប់រូបគាត់ទេ ។ ការធ្វើដំណើរទាំងឡាយរបស់គាត់ទៅកាន់ខេត្ត ដើម្បីពិនិត្យមើលសមិទ្ធិនានា ដែលផ្តល់ហិរញ្ញវត្ថុដោយប្រទេសចិន បានប្រែទៅជាការធ្វើដំណើរកម្សាន្តរបៀបទេសចរណ៍ទៅវិញ ហើយគាត់កម្រទទួលការអនុញ្ញាត ឲ្យធ្វើដំណើរទៅក្រៅរដ្ឋធានីលើសពីមួយយប់ណាស់ ។ គាត់បានធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយ យ៉ាងហោចជាមួយនឹងឡានហ្ស៊ីបមួយគ្រឿង ឬពីរគ្រឿង ផ្ទុកទៅដោយកងការពារដែលឃ្លាំមើលគាត់ដូចគាត់ជាអ្នកទោសរបស់គេអ៊ីចឹង ។ គាត់បាននិយាយថា «មនុស្សគ្រប់គ្នាគិតថា យើងជាអ្នកដែលត្រូវគេលើកលែង ។ ការមួម៉ៅក្នុងចិត្ត និងការធុញទ្រាន់ គឺសម្រាប់ពួកគេ (ពួកខ្មែរក្រហម) ពុំមែនសម្រាប់ពួកចិនទេ ។ ប៉ុន្តែយើងបានត្រូវខ្មែរក្រហមធ្វើឲ្យលំបាក ដូចអ្នកការទូតដទៃទៀតដែរ ក្នុងការជជែករកខុសត្រូវជាមួយ ភាគច្រើននៃជនកម្ពុជា ។ យើងត្រូវគេដាក់ឲ្យរស់នៅដោយឡែកពីគេឯង ដូចជនបរទេសឯទៀតៗដែរ ។

ប៉ុន្តែ អ្នកការទូតនេះបានបញ្ជាក់ថា ពួកចិនបានសម្រេចចិត្តមិនតវ៉ា និងមិនសម្តែងឲ្យឃើញការមិនយល់

ស្របរបស់គេចំពោះនយោបាយរបស់កម្ពុជាឡើយ ។ តាមគាត់ឲ្យដឹងថា ចាប់ពីឆ្នាំ១៩៧៦ ពួកចិនដឹងថាមានការបោសសម្អាតយ៉ាងធំធេងនៅជនបទ ។ «យើងបានស្ដាប់ពួគេនិយាយពីការកាប់សម្លាប់ ។ ពុំមែនជាការនិយាយដោយជាក់លាក់ទេ ប៉ុន្តែគឺសុទ្ធតែពាក្យចចាមអារ៉ាម ។ យើងទាំងអស់គ្នាសង្ស័យថា ប្រជាជនកម្ពុជាមួយចំនួនធំបានត្រូវសម្លាប់នៅជនបទ ក្រោមការប្រហាររបស់ពួកកម្មាភិបាលនៅនឹងមូលដ្ឋានទាំងនោះ» ។

ប៉ុន្តែ ពួកចិនក៏មានជំនឿចំពោះជោគជ័យផ្នែកសេដ្ឋកិច្ចដែលខ្មែរក្រហមបានអួតក្អេងក្អាង និងចំពោះការឃោសនា ដែលថាប្រទេសជាតិបាន «លោតផ្លោះ» នៅឆ្នាំ១៩៧៧ និងប្រែក្លាយទៅជាប្រទេសដែលខបត្តម្ភខ្លួនដោយខ្លួនឯងបាន ។ អ្នកការទូតរូបនេះបានមានឱកាសជួបនិយាយយ៉ាងយូរជាមួយ ប៉ុល ពត ស្ដីពីបញ្ហាកសិកម្ម ហើយដែលធ្វើឲ្យ ប៉ុល ពត ចាប់អារម្មណ៍អំពីរឿងនោះយ៉ាងខ្លាំង ។ «គាត់ប្រហែលធ្វើដំណើរច្រើនកន្លែងណាស់នៅក្នុងប្រទេស ហើយអាចនិយាយពន្យល់យ៉ាងក្បោះក្បាយអំពីស្ថានភាពកសិកម្មនៅតាមខេត្តនានា... ។ ប៉ុន្តែខ្ញុំគោងតែនិយាយដែរថា ខ្ញុំមិនដែលបានជួបសន្ទនាតែពីរនាក់តតួជាមួយគាត់ទេ ។ ជាទូទៅ គាត់ច្រើនមានអ្នកនៅអមជានិច្ច គឺ អៀង សារី និង ជួន ប្រសិទ្ធិ ។ ប៉ុន្តែ រឿងនិទានពីការរីកលូតលាស់មានទំនងជារឿងពិតប្រាកដ ឆ្នាំដំបូង គឺឆ្នាំ១៩៧៦ ប្រហែលជាឆ្នាំដែលលំបាកបំផុតសម្រាប់ប្រជាជនកម្ពុជា ដែលសុទ្ធតែមានរាងកាយស្គាំងស្គមខ្លាំងណាស់ ។ នៅឆ្នាំ១៩៧៧ ស្ថានភាពមានលក្ខណៈប្រសើរជាងមុន រហូតដល់ពួកគេ អាចនាំស្រូវចេញទៅហុងកុង និងធ្វើជាអំណោយទៅឲ្យប្រទេសឡាវទៀត» ។

ឆ្នាំ១៩៧៧ ក៏ជាឆ្នាំដែលអ្នកការទូតនេះ ត្រូវប្រឈមមុខនឹងប្រភេទនៃការកាប់សម្លាប់នៅទូទាំងប្រទេស ។ មិត្តតែមួយគត់របស់គាត់ក្នុងរដ្ឋាភិបាលរបស់របបនេះ គឺ ហ៊ូ នឹម បានបាត់ខ្លួន ដោយគ្មានការបញ្ជាក់បំភ្លឺច្បាស់លាស់ឡើយ ។ «ហ៊ូ នឹម ជាមិត្តខ្ញុំម្នាក់តាំងពីទសវត្សរ៍ឆ្នាំ១៩៥០ ។ គាត់ជាមនុស្សរាក់ទាក់ និងគួរឲ្យចូលចិត្ត ។ គាត់តែងតែប្រុងប្រយ័ត្នជានិច្ច នៅពេលដែលគាត់និយាយពីស្ថានការណ៍ផ្ទៃក្នុងរបស់កម្ពុជា ជាមួយនឹងខ្ញុំម្ដងៗ ហើយគាត់ចូលចិត្តជជែកពិភាក្សាពីខ្សែភាពយន្ត និងអត្ថបទផ្សេងៗជាង» ។

នៅពេលដែល ហ៊ូ នឹម បាត់ខ្លួន អ្នកការទូតរូបនេះបានសុំឲ្យរដ្ឋាភិបាលគាត់ផ្លាស់គាត់ទៅកន្លែងថ្មីទៀត ដោយមូលហេតុសុខភាព ។ «តាមធម្មតាអ្នកកាន់ទូតម្នាក់ត្រូវការតំណែងនៅប្រទេសមួយក្នុងរយៈបីឆ្នាំ ។ ខ្ញុំចាកចេញពីក្រុងភ្នំពេញ ពីព្រោះខ្ញុំឈឺ ហើយខ្ញុំគ្មានការផ្សារអ៊ីសម្រាប់បំពេញផង...» ។

ជាបញ្ញវន្តពេញលក្ខណៈ គាត់អាចដឹងតទៅទៀតថា សម្ដីនិយាយទាំងប៉ុន្មានរបស់គាត់ មុខជាធ្វើឲ្យ ប៉ុល ពត ត្រិះរិះពិចារណាមិនខាន ។ តាមសម្ដីគាត់ថា រដ្ឋាភិបាលរបស់គាត់បានទម្លាក់ទោសទៅលើ ប៉ុល ពត អំពី«ការប្រព្រឹត្តិខុសចង់ឲ្យមានបដិវត្តន៍គ្រប់កន្លែង» ហើយក៏មិនចាត់ទុកពួកកម្ពុជាជាពួកម៉ៅនិយមសម័យទំនើបដែរ ។ ដូចជនកុម្មុយនិស្តដទៃៗទៀត គាត់កត់សម្គាល់ឃើញក្នុងចំណោមពួកខ្មែរក្រហម នូវការចាប់កំណើតនៃគំនិតមួយចំនួនធំ ដែលមានឈ្មោះជាអ្នកធ្វើបដិវត្ត ក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ។ ពួកខ្មែរក្រហម សុទ្ធតែជាមុស្សចេញមកពី

ចលនាមិនច្បាស់លាស់ដូចគ្នា ដែលហ្វ្រង់ហ្វាណុង *(Frantz Fanon)*[៧០] បានវាយតម្លៃអំពីលក្ខណៈជម្រះសម្អាតក្នុងការធ្វើបដិវត្តខ្លាំងហួសពេក ក្នុងនាមនៃប្រជាជនមួយដែលធ្លាប់ត្រូវជិះជាន់ដោយពួកអាណានិគមស្បែកស ។ ពួកគេបានរងទទួលឥទ្ធិពលពីសម័យជាតិនិយមរើបការតែខ្លាំងមួយ ដែលក្រុមទ័ពព្រៃទាំងឡាយ ទ្រាំមិនបាននឹងគ្រឿងទាក់ចិត្តមិនគួរជឿក្នុងការធ្វើបដិវត្តន៍ដោយប្រើអំពើហិង្សា ។

ភាពខុសគ្នារវាងពួកខ្មែរក្រហម និងពួកអ្នកបដិវត្តន៍ដែលស្រើបចិត្តជំនាន់ស្រករគ្នា គឺថាពួកអ្នកទីមួយពេលយកបានយកជ័យជម្នះ ហើយក៏ដាក់ឲ្យអនុវត្តនូវទស្សនះរបស់គេភ្លាមៗ ។ នៅឆ្នាំ១៩៧៧ វាបានស្តែងឡើងយ៉ាងច្បាស់ សម្រាប់អ្នកការទូតគួរគោរពរបស់ចិន ដែលគាត់គោងតែចាកចេញពីការបដិវត្តន៍មួយពីព្រោះ ធាតុមួយក្នុងចំណោមធាតុដែលមានជាអចិន្ត្រៃយ៍ គឺអំពើភេរវកម្ម ។ អំពើភេរវកម្មនេះហើយ ដែលបានយកមិត្តរបស់ គាត់ឈ្មោះ ហ៊ូ នឹម ធ្វើជាគោលដៅវាយប្រហារ និងអ្វីៗទាំងអស់ដែលគាត់ធ្លាប់ការពារផង ។

## ធនាគារិក និងអ្នកស្រឡាញ់លទ្ធិកុម្មុយនិស្ត

គ្មានអ្នកណាម្នាក់បញ្ចេញឲ្យឃើញវិស្សុតកម្ម អំពីការផ្លាស់ប្តូរទិសដៅ សារសំខាន់នៃជំនឿស៊ប់របស់មជ្ឈិម ដែលគិតថា «ខ្មាំងសត្រូវ»មាននៅពុំមែនក្នុងចំណោម«ពួកអ្នកថ្មី»ទេ ប៉ុន្តែនៅផ្ទៃក្នុងបក្សផ្ទាល់ ជាងធនាគារិក ម៉ី កុម្ពុត *(Mey Kamphot)* និងជនកុម្មុយនិស្តចំណូលថ្មី ឈ្មោះ ផាត់ ជាក្មេងកំព្រាដែលសុំចូលជាសមាជិកចលនាកុម្មុយនិស្តនៅក្រុងភ្នំពេញ បន្ទាប់ពីបានធ្វើការក្នុងកាសែតរបស់ ខៀវ សំផន នោះឡើយ ។ ផាត់ បានឡើងបុណ្យស័ក្តិជាលំដាប់លំដោយ និងជាសហការីម្នាក់របស់ ប៉ុល ពត នៅពេលដែលពួកមេដឹកនាំកុម្មុយនិស្តភៀសខ្លួនចេញពីភ្នំពេញ និងចាប់ផ្តើមការបដិវត្តន៍របស់គេនៅតាមជនបទ ។

កុម្ពុត[៧១] ជាធនាគារិកធ្លាប់គាំទ្រសាធារណរដ្ឋខ្មែរនៅគ្រាដំបូងៗ ប៉ុន្តែ យ៉ាងឆាប់រហ័សទៅជាខ្ពើមអំពើពុករលួយរបស់សាធារណរដ្ឋនេះ ព្រមទាំងការគ្មានសមត្ថភាព ការលោភលន់ទ្រព្យសម្បត្តិ និងជំនឿស៊ប់របស់លន់ នល់ ទៅលើអ្វីៗដែលហួសពីធម្មជាតិពិតទៅវិញ ។ គាត់បន់ឲ្យសង្គ្រាមឆាប់ចប់ និងចង់ឲ្យពួកខ្មែរក្រហមរៀបចំរបបសង្គមនិយមមួយដែលនិយមផ្លូវកណ្តាល និងច្បាស់លាស់ ។ គាត់ក៏ជឿងឆ្ងល់ដូច ប្រជាជនទាំងអស់ដែរ នៅពេលដែលពួកកុម្មុយនិស្តបញ្ជាឲ្យចាកចេញពីរដ្ឋធានីនៅថ្ងៃដែលពួកគេចូលមកដល់រដ្ឋធានី ។ គាត់ត្រូវគេបញ្ជូនទៅដាក់នៅសហករណ៍មួយដូចពួកអ្នកទីក្រុងឯទៀត ដោយបាត់បង់ឯកសិទ្ធិផ្សេងៗរបស់ខ្លួនទាំងអស់ ។ គាត់មានបំណងនឹងធ្វើអត្តឃាតក្រោយពីដឹងច្បាស់នូវអ្វីៗដែលបដិវត្តត្រៀមបម្រុងសម្រាប់រូបគាត់ និងប្រទេសជាតិ ប៉ុន្តែ គាត់បានផ្លាស់ប្តូរគំនិតនេះដោយការស្គាល់ករណីកិច្ចចំពោះពួកអ្នកដែលនៅជុំវិញគាត់ ។

វិធីរបស់គាត់ដើម្បីឲ្យមានជីវិតរស់តទៅទៀត មានលក្ខណៈដូចគ្នានឹងវិធីរបស់ពួកអ្នកមានវិជ្ជាជីវៈសេរី

ជាច្រើនដងទៀតដែរ ។ ពួកខ្មែរក្រហមដឹងថា គាត់ធ្លាប់ធ្វើក្នុងធនាគារមួយ ប៉ុន្តែ ពួកនោះយល់ឃើញថា គាត់គ្រាន់តែជាអ្នកធ្វើការក្រោមបង្គាប់គេប៉ុណ្ណោះ ។ កុម្ហួត បានញុំាងឲ្យពួកនោះលុះក្នុងការយល់ឃើញនេះ ដោយគាត់បានប្រកាន់ឥរិយាបថជា មនុស្សសាមញ្ញម្នាក់ រាងឡប់ៗបន្តិច គាត់បានបំព្រួញឈ្មោះរបស់គាត់ជា ហួត វិញ ដោយជម្រុះចោលរបៀបស្លៀកពាក់ជា អ្នកទីក្រុង ហើយទម្លាប់ខ្លួនស្លៀកខោខ្លីសាច់ក្រណាត់អំបោះមួយទៅវិញ ។ គាត់ចង់បង្ហាញឲ្យឃើញថា បុគពាជាមនុស្សល្ងីល្ងើម្នាក់ ។ ជាមួយបុគពាពិសេសផ្ទាល់ខ្លួននេះ កុម្ហួត ក៏ក្លាយទៅជាមនុស្ស «គ-ថ្លង់» ដើម្បីឲ្យបានរួចផុតពីមហន្តរាយដ៏គួរឲ្យព្រឺខ្លាចនេះ ។

ស្បែករបស់គាត់ដែលស្រអាប់នៅទីក្រុង បានប្រែទៅជាស្ទើរតែខ្មៅនៅជនបទ ។ គាត់បណ្តោយឲ្យសក់ដុះវែងដោយមិនថែទាំឡើយ ។ គាត់ទម្លាប់ខ្លួនមិនប្រកែកតវ៉ា - ធ្វើគ-ថ្លង់ចំពោះមុខការបាត់ខ្លួនសមាជិកសហករណ៍ គាត់ការខ្វះខាតម្ហូបអាហារ និងថ្នាំពេទ្យ ទុក៏តភាពដែលមានជុំវិញគាត់ ។ ហើយគាត់ខំធ្វើការយ៉ាងខ្លាំង, ខ្លាំងមែនទែន ។ ដើមឡើយ សហករណ៍របស់គាត់មានទំហំតូចល្មម ។ ហួត ភរិយាមេម៉ាយ និងកូនៗរបស់បងប្អូនជីដូនមួយគាត់អាចរស់នៅជុំគ្នាជាគ្រួសារមួយ ។ គាត់ត្រូវសរសេរជីវប្រវត្តិផ្ទាល់ខ្លួនជាថ្មី នៅពេលដែលគាត់មកតាំងទីលំនៅក្នុងភូមិ ប៉ុន្តែ គាត់និងបងប្អូនជីដូនមួយទាំងអស់របស់គាត់បានរួចផុតពីគ្រោះថ្នាក់នេះគ្រប់គ្នា ។ នេះគឺពុំមែនជាសម្រាប់អ្នកផ្សេងៗទៀតនោះទេ ។ «មនុស្សជាច្រើនត្រូវបានសម្លាប់ម្តងមួយៗ - ពុំមានការសម្លាប់រង្គាលធំៗទេ ។ ដំបូងគឺមាន «ពួកអ្នកថ្មី» ប្រមាណជាដប់ពីរនាក់ដែលគេសង្ស័យថា ជាទាហានក្នុងកងទ័ពរបស់ លន់ នល់ ត្រូវគេយកទៅសម្លាប់ចោល ។ ក្នុងរយៈពេលពីរឆ្នាំដំបូង «ពួកអ្នកថ្មី» ប្រហែលមួយភាគដប់ ត្រូវបានយកទៅសម្លាប់ម្តងមួយៗ ជាមួយនឹងកូនចៅរបស់គេទាំងអស់ ។ ខ្ញុំពុំបានដឹងពីអ្នកដែលត្រូវស្លាប់មានប៉ុន្មានឡើយ» ។

កុម្ហួត បានមករស់នៅក្នុងអតីតភូមិភាគឧត្តរ ដូច ផាត់ ដែរជាទីដែលគាត់មានមុខពេលមានព្រឹត្តិការណ៍ធ្វើវិស្សុតកម្មជាច្រើនសំដៅប្រឆាំងនឹងកម្មាភិបាលនៅទីនោះ ។ «កុយ ធួន ជាមេដឹកនាំភូមិភាគយើង ត្រូវគេចាប់ខ្លួននាំយកទៅបាត់ ។ គាត់ជាមនុស្សរងគ្រោះពីការធ្វើវិស្សុកម្មនេះ ។ គាត់បានត្រូវគេសម្លាប់ពិតប្រាកដ ប៉ុន្តែ រឿងនេះមិនដែលឮអ្នកណានិយាយសោះ ។ គាត់ត្រូវចោទប្រកាន់ថា ជាភ្នាក់ងារសេ.អ៊ី.អា. ជាមនុស្សមានគុណវិបត្តិមួយ ដែលនាំអន្តរាយដល់បដិវត្តន៍ គឺជាគហបតីម្នាក់ ។ ពួកកម្មាភិបាលថ្មីៗបានទៅដល់ ប៉ុន្តែ បណ្តាអនុប្រធានរបស់ កុយ ធួន នៅតែកាន់អំណាចមួយរយៈពេលខ្លីដែរ ។ ក្រោយមកគេបានចាប់ពួកអ្នកទាំងអស់នេះ ដាក់គុកដោយចោទប្រកាន់ថា ជាភ្នាក់ងាររបស់វៀតណាម» ។

វិទ្យុរបស់ភូមិដែលផ្សាយបន្តពីវិទ្យុរបស់រដ្ឋាភិបាល បានទៅជាប្រភពពត៌មានដ៏សំខាន់មួយដែលអាចឲ្យកុម្ហួត បានយល់ដឹងច្រើនពីការបដិវត្ត ។ កុម្ហួត និយាយថា «យើងបានចូលរួមគ្រប់តែការគ្រប់តែប្រជុំផ្សេងៗដែលគ្មានអ្វី«ប្រាកដប្រជា»ទេ -ពុំមានការពិភាក្សាខាងនយោបាយទេ គឺមានតែការសន្ទនាគ្នាអំពីរបៀបកែលម្អឥរិយាបថការងារ និងរបៀបប្រកាន់បុគពាក្នុងប្រទេសសង្គមនិយមមួយ ឲ្យបានប្រសើរជាងមុនប៉ុណ្ណោះ ។

គេមិនដែលនិយាយពីលទ្ធិម៉ាក្សលេនីនទាល់តែសោះ ។ នៅពេលដំបូង គេក៏មិនដែលនិយាយពាក្យលទ្ធិកុម្មុយនិស្ដដែរ គឺនិយាយតែពីការជឿនលឿនទៅមុខប៉ុណ្ណោះ ។ យើងគោរពតែធ្វើការរួមគ្នា កម្ទេចពួកវណ្ណៈគហបតីទាំងអស់ –អតីតមន្ត្រីបុគ្គលិករបស់រដ្ឋាភិបាលចាស់ និងពួកនាយទុន ។ នេះពុំមែនជាគំនិតធ្វើឲ្យរឹតតែល្អជាងមុនទេ» ។

នៅឆ្នាំ១៩៧៦ កុម្ពុត ត្រូវតែសរសេរជីវប្រវត្តិរបស់ខ្លួនជាថ្មីទៀត ។ គាត់បាននិយាយថា «រៀងរាល់ពេលដែលគេសរសេរជីវប្រវត្តិរបស់ខ្លួន គេតែងព្រួយបារម្ភពីការបាត់ខ្លួនជានិច្ច» ។ ជាថ្មីម្តងទៀត អតីតធនាគារិក និងគ្រួសាររបស់គាត់ បានរស់រានមានជីវិតតមកទៀត ដើម្បីចូលរួមក្នុងការធ្វើបដិវត្តសង្គមនិយមដែលប្រកាសឡើងដោយមជ្ឈិម ។ នោះគឺការបង្កើតឲ្យមានការហូបរួម និងផ្ទះបាយរួម ។ ម្ហូបអាហារបានក្លាយទៅជាម្ហូបដែលគេស្ទើរតែបរិភោគមិនកើត ។ មនុស្សជាច្រើនកើតមានជំងឺរាកមួល ឬទល់លាមក ។ «យើងពុំមានដាំបន្លែបន្ថែមសម្រាប់ឲ្យសហករណ៍ទេ –នៅប្រទេសកម្ពុជាមានបន្លែយ៉ាងច្រើនដែលដុះក្នុងព្រៃ! ។ ប៉ុន្តែ ដោយយើងត្រូវហូបបាយរួម យើងគោរពតែបន្ទុំចិត្តហូបនូវអ្វីដែលគេផ្តល់ឲ្យយើង ។ ជាពិសេស មានតែក្រុមដែលត្រូវចាត់ឲ្យទៅរកបន្លែដែលដុះក្នុងព្រៃ ឬក្តាមខ្យងប៉ុណ្ណោះ បានហូបគ្រាន់បើ ហើយកាលនោះ វាមិនគ្រាប់គ្រាន់សម្រាប់មនុស្សទាំងអស់ទេ ។

ម្យ៉ាងទៀត ពុំមានថ្នាំពេទ្យសម្រាប់ព្យាបាលជំងឺឡើយ ប៉ុន្តែ កុម្ពុតក៏មិនដែលត្អូញត្អែរដែរ ។ «គេគ្មាននិយាយអ្វីទាំងអស់ តាំងពីដំបូង យើងតែងនឹកបារម្ភខ្លាចក្លាយទៅជា«អ្នកបាត់ខ្លួនម្នាក់»ជានិច្ច ។ យើងមិនដែលហ៊ាននិយាយថា មនុស្សទាំងនោះស្លាប់ឬត្រូវគេសម្លាប់ទេ ។ យើងនិយាយបានត្រឹមតែថា រូបកាយរបស់គេបាត់លែងឃើញតែប៉ុណ្ណោះ» ។

កុម្ពុត បាននិយាយរៀបរាប់ថា ប្រហែលនៅពាក់កណ្តាលឆ្នាំ១៩៧៦ «ពួកចាស់»ផ្ទាល់ក៏ព្រមទទួលរបបអាហារកំណត់កាន់តែថយតិចទៅៗសម្រាប់មួយថ្ងៃៗដែរ ដែលនេះជាសញ្ញាមិនល្អមួយសម្រាប់ពួកគេ ។ ការប្រមូលផលស្រូវនៅឆ្នាំ១៩៧៥ ត្រូវបានបែងចែករវាងគ្រួសារទាំងអស់ហើយការប្រមូលផលស្រូវឆ្នាំ១៩៧៦ ជាកម្មសិទ្ធរួម ។ ចំណែកការប្រមូលផលឆ្នាំ១៩៧៧ លែងជាកម្មសិទ្ធរួមទៀតហើយ ៖ ស្រូវមួយភាគធំ ត្រូវគេដឹកជញ្ជូនទៅដាក់ក្នុងជង្រុកនានារបស់រដ្ឋាភិបាល ។ សហករណ៍របស់ កុម្ពុត ដែលពេលឥឡូវមានសមាជិកចំនួនមួយពាន់ប្រាំរយនាក់ចាប់ផ្តើមទទួលបានថ្នាំពេទ្យ និងសម្លៀកបំពាក់ជាច្រើន ប៉ុន្តែ ភាគច្រើន ច្រើនតែបានទៅ«ពួកអ្នកចាស់» ។ គឺនៅខែកក្កដា ឆ្នាំ១៩៧៧ ទើបកើតមានឡើងនូវការសម្លាប់រង្គាលពិតប្រាកដ នៅសហករណ៍របស់ កុម្ពុត ។

«កាលពីមុន គេនាំយកមនុស្សដែលជាប់សង្ស័យពីរឿងអ្វីមួយទៅសម្លាប់តែម្នាក់ៗឯងប៉ុណ្ណោះ ពុំមែននាំយកទៅទាំងគ្រួសារទេ ។ នៅក្នុងកំឡុងការសម្លាប់រង្គាលនេះ «ពួកអ្នកថ្មី»ក៏ដូច«ពួកអ្នកចាស់ ត្រូវគេនាំគ្រួសារទាំងមូលទៅ ទាំងកូនក្មេង ទាំងទារកផង ។ គ្រួសារប្រាំពីរ ឬប្រាំបី ត្រូវគេសម្លាប់ចោលរួមគ្នាតែមួយ លើក ។

យើងមិនដឹងថា បណ្ដាលមកពីមូលហេតុអ្វីទេ» ។

ស្ថានការណ៍បានផ្លាស់ប្ដូរ បក្សចាប់ផ្ដើមកើតមន្ទិលសង្ស័យទៅលើ "ពួកអ្នកចាស់" និងបក្ខជនកុម្មុយនិស្ដមួយចំនួនដែលរួមគំនិតប្រឆាំងនឹងការបដិវត្តន៍ ។ ការបោសសម្អាត "ពួកអ្នកថ្មី" ត្រូវបានបញ្ចប់ការបោសសម្អាត "ពួកអ្នកចាស់" និងពួកអ្នកស្មោះត្រង់នឹងបក្សទើបតែចាប់ផ្ដើមប៉ុណ្ណោះ ។ ការសម្លាប់រង្គាលដំបូង ដែលគេប្រព្រឹត្តក្នុងសហករណ៍របស់កុម្មួតនេះ បានបង្ហាញឲ្យឃើញកាន់តែច្បាស់ចំពោះការពិតមួយ នៃការផ្លាស់ប្ដូរជាទូទៅដ៏គួរឲ្យរន្ធត់ ។ ចាប់ពីថ្ងៃនេះទៅ កុម្មួត លែងមានហេតុផលភ័យខ្លាច ពីការបាត់បង់សម្រាប់ជីវិតរបស់គាត់បន្តិចម្ដងៗដែរ ។ ឥឡូវនេះ មានតែបក្ខជនកុម្មុយនិស្ដដូច ផាត់ ជាដើមប៉ុណ្ណោះ ដែលត្រូវលំបាកចិត្ត[២២] ។

ក្នុងសម័យសង្គ្រាម ផាត់ បានឈានឡើងឋានៈយ៉ាងឆាប់រហ័សព្រោះតែគាត់ក្លាយជាអនុប្រធានតំបន់ ១០៣ ក្នុងខេត្តព្រះវិហារដែលស្ថិតនៅភាគខាងជើងបំផុត ។ គាត់បានរៀបការនៅពេលដែលគាត់ស្ថិតនៅក្នុងភាគខាងប្រទេសនៅឡើយ ហើយ សោ ភឹម ដែលជាលេខាបក្សភូមិភាគបូព៌ាធ្លាប់ធ្វើជាមេបាក្នុងពិធីនេះផង ។ ផាត់ ដែលត្រូវរាប់ចូលក្នុងចំណោមយុទ្ធជនវ័យក្មេង និងពូកែចំណានរបស់កងទ័ព បានបែកចេញពីប្រពន្ធ និងកូនៗរបស់គាត់ ដើម្បីធ្វើដំណើរទៅកាន់តំបន់១០៣ ។ គាត់បានទទួលស្គាល់ថា ក្នុងពេលសង្គ្រាម គាត់បានក្លាយទៅជាពេជ្ឈឃាតម្នាក់ ។ ពួកកុម្មុយនិស្ដខ្មែរទាំងអស់ ដែលវិលពីក្រុងហាណូយមកវិញ ក្រោយឆ្នាំ១៩៧០ ហើយដែលស្ថិតនៅក្នុងតំបន់របស់គាត់ត្រូវបានគេសម្លាប់ចោល ដោយចេតនា ឬប្រើពាក្យថា«ជនគួរឲ្យមើលងាយទាំងអស់ ដែលត្រឡប់ពីទីក្រុងហាណូយមកវិញបានបាត់ខ្លួននៅឆ្នាំ១៩៧៤» ។

ប៉ុន្តែ វាមានដំណើរសៅហ្មងខ្លះដិតដាមលើរយៈពេលបម្រើការងាររបស់ ផាត់ ដែរ ។ នៅដើមឆ្នាំ១៩៧៤ ពួកខ្មែរក្រហមបានផ្ដើមធ្វើការវាយលុកជាទូទៅមួយប្រឆាំងនឹងក្រុងភ្នំពេញ ហើយយុទ្ធជនមួយចំនួនធំរបស់ភូមិភាគឧត្តរ បានត្រូវបញ្ជូនមកភាគខាងត្បូង ដើម្បីជួយធ្វើការហ៊ុំព័ទ្ធរដ្ឋធានី ។ ហេតុដូចនេះ ស្ថាបចំហៀងរបស់ពួកកុម្មុយនិស្ដនៅខេត្តកំពង់ធំត្រូវចំហ ហើយកងទ័ពរបស់សាធារណរដ្ឋខ្មែរ បានឆ្លៀតឱកាសនេះ ចាប់ធ្វើប្រតិបត្តិការវាយទម្លុះមួយ ហើយរំដោះយកប្រជាជនស៊ីវិលបានជិតបីម៉ឺននាក់ ដែលកំពុងរស់នៅក្នុងតំបន់នេះ ។ កាលនោះប្រជាជនទាំងនេះ បានរៀបរាប់ប្រាប់អ្នកសារព័ត៌មានអន្តរជាតិនូវភ័ស្តុតាងដំបូងៗ ស្ដីពីជីវភាពរស់នៅក្នុងតំបន់នានារបស់ខ្មែរក្រហម ហើយការរៀបរាប់របស់ពួកគេ ពុំមែនជារឿងដែលគួរឲ្យរីករាយទាំងស្រុងទេ ។ តំបន់របស់ ផាត់ ត្រូវទទួលការខុសត្រូវមួយផ្នែកដែរ ក្នុងការវាយទម្លុះរបស់ទ័ពបច្ចាមិត្តនេះ ។ មេបញ្ជាការវ័យក្មេង បានបាត់បង់យុទ្ធជនក្នុងការប្រយុទ្ធប្រហែលជាងហាសិបនាក់ដោយមានសែសិបបីនាក់ ត្រូវគេចាប់បានជាឈ្លើយសឹក ។ មេកោយម្នាក់ ក្នុងចំណោមមេកោយរបស់គាត់ បានព្រមានគាត់នៅពេលនោះថា "កំហុសមួយបែបនេះ ពុំអាចលុបលាងត្រឹមតែសម័យប្រជុំស្វ័យទិតៀនមួយបានទេ" ។

និយាយម្យ៉ាងទៀតថា វាមិនត្រឹមតែទេដែលគ្រាន់តែទទួលស្គាល់កំហុសរបស់ខ្លួន និងស្ដាប់ការប្រៀន

ប្រដៅមួយគួរឲ្យធុញទ្រាន់នោះ ។ ប៉ុន្តែ ផាត់ ពុំមែនជាមេដឹកនាំថ្នាក់លើបំផុតក្នុងតំបន់នោះឡើយ ហើយគេមិនចាត់ទុកគាត់ ជាអ្នកទទួលខុសត្រូវដោយផ្ទាល់ពីបញ្ហាចំហមួយរយៈខ្លី ក្នុងការការពាររបស់ខ្មែរក្រហមក្នុងរយៈពេលសង្គ្រាមដែរ ។ កំហុសត្រូវធ្លាក់ទៅលើមេកោយផ្ទាល់ របស់គាត់គឺសមមិត្ត ម៉ន ។ ២-៣ខែក្រោយមក ម៉ន បានស្លាប់ក្នុង«លក្ខណៈអាថ៌កំបាំងបំផុត» គឺថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៨ ដែលមានលំនាំដូចការសម្លាប់មួយដែលបញ្ជាដោយមជ្ឈិមដែរ ។ ផាត់ បានឡើងកាន់តំណែងជំនួស ម៉ន ហើយបានក្លាយទៅជាលេខាបក្សប្រចាំតំបន់ ជាមុខតំណែងដែលគាត់ទៅកាន់ ជាប់រហូតបន្ទាប់ពីមានការរៀបចំភូមិភាគជាច្រើនឡើងវិញ និងការកម្ចាត់ កុយ ធួន ។

ប៉ុន្តែ ការកម្ចាត់រូប កុយ ធួន បានធ្វើឲ្យសេចក្ដីភ័យបារម្ភរបស់ជនកុម្មុយនិស្តវ័យក្មេងនេះចាប់មានឡើងដែរ ។ មជ្ឈិមបានចោទប្រកាន់ កុយ ធួន ជាភ្នាក់ងារសម្ងាត់ម្នាក់របស់សេ.អ៊ី.អា. អាមេរិកាំង ដោយបានបង្ខំឲ្យគាត់ឆ្លើយសារភាពថា ធ្លាប់បានរៀបចំការរួមគំនិតក្បត់យ៉ាងធំមួយ ហើយថា គាត់ជាសមាជិករបស់ក្រុមសេ.អ៊ី.អា. តាំងពីឆ្នាំ១៩៥៨ម្ល៉េះ ហើយបានជ្រៀតចូលបក្សនៅឆ្នាំ១៩៦០ ។ ពិតហើយ កុយ ធួន ជាអ្នកមានធាតុវណ្ណៈ «គហបតី» ជាងបណ្ដាលេខាបក្សភូមិភាគឯទៀតៗ ហើយដែលអាចឲ្យគេជ្រើសរើសជា «ជនក្បត់» មុនគេដែរ ។ ប៉ុន្តែ តាមការវាយតម្លៃម្យ៉ាងទៀតថា បើគេអាចធ្វើឃាតមនុស្សម្នាក់ ដែលគេធ្លាប់ប្រគល់ភារកិច្ចឲ្យគាត់ការពារគណៈកម្មាធិការមជ្ឈិមក្នុងសម័យសង្គ្រាមនោះ តើមានអ្នកណាទៀតអាចគេចរួចពីគ្រោះថ្នាក់បាន?

ក្រោយពេលដែល នួន ជា បើកសាលានយោបាយបក្សនៅក្នុងក្រុងភ្នំពេញនាឆ្នាំ១៩៧៦ បានបន្តិច ផាត់ត្រូវបានថ្នាក់ដឹកនាំរបស់គាត់បញ្ជូនឲ្យទៅរៀននៅទីនោះ ។ មួយថ្ងៃមុនការចាប់ផ្ដើមបង្រៀនឯកសារ គាត់បានជួបធ្វើការសន្ទនាដ៏ចម្លែកមួយ ជាមួយអនុប្រធានសាលាម្នាក់ គឺសមមិត្ត ប៉ង់ ដែលគេចាត់ទុកថា ជាមនុស្សជិតស្និទ្ធបំផុតនឹង ប៉ុល ពត ។ សមមិត្ត ប៉ង់បានដើរមកជួបខ្ញុំ សាកសួរពីសុខទុក្ខពួកយើងគ្រប់គ្នា ពីគ្រួសារខ្ញុំ និងរូបខ្ញុំ បន្ទាប់មក គាត់បាននិយាយមកកាន់ខ្ញុំថា «មានជនក្បត់ជាច្រើន បានបញ្ចូលឈ្មោះឯងទៅក្នុងចង្កោមគេដែរ» ។ «តើអ្នកណាបញ្ចូលឈ្មោះខ្ញុំទៅក្នុងនោះ?» ខ្ញុំសួរទៅវិញយ៉ាងរហ័ស ។ គាត់និយាយថា «ឯងស្មានថា ខ្ញុំជាអ្នកផ្ដល់ឈ្មោះទៅឲ្យពួកអ្នកទាំងនោះឬ?» ។ បន្ទាប់មក គាត់បានបន្ថែមថា «ហេតុអ្វីបានជាឯងអាចទុកចិត្តថា ពួកអស់នោះមិនបានបញ្ចូលឈ្មោះឯង បើឯងធ្លាប់រួមរស់ជាមួយពួកគេដែរនោះ?» ។ ខ្ញុំបានឆ្លើយតប ថា «ខ្ញុំគ្មានខ្លាចអ្វីទាំងអស់ កាលបើខ្ញុំពុំដែលបានប្រព្រឹត្តអំពើក្បត់» ។

របៀបស្រាវជ្រាវរក «ខ្សែបណ្ដាញ» បានត្រូវបក្សបង្កើតឲ្យមានឡើងនៅពេលនេះ ហើយត្រូវបានប្រើប្រាស់ដោយក្រុមសន្តិបាលសម្រាប់ «បញ្ចូល» ឈ្មោះមនុស្សជងទាំងឡាយទៅក្នុងនោះ ដូចរូប ផាត់ ជាដើម ។ ផាត់ យល់ថា គាត់ត្រូវតែបង្ហាញឲ្យឃើញពីសេចក្ដីស្មោះត្រង់របស់គាត់ចំពោះបក្សកុម្មុយនិស្តកម្ពុជាតែមួយប៉ុណ្ណោះ ហើយមិនយល់ថាសេចក្ដីស្មោះត្រង់នេះ មានសារសំខាន់តិចតួចបែបនេះឡើយ ។ គេបានចាត់ចែងឲ្យ

មានការបោសសម្អាតភូមិភាគឧត្តរ ហើយ ផាត់ ដែលធ្លាប់រស់នៅជាមួយមនុស្ស ដែលគេកាត់ទោសជាអ្នកក្បត់ រួចមកហើយនោះ ក៏ត្រូវគេចោទប្រកាន់ជាអ្នកក្បត់ ដូចសមមិត្ត ប៉ង់ បានបញ្ជាក់ប្រាប់គាត់មែនៗ ម្យ៉ាងទៀត "សង្គ្រាមវណ្ណៈ" កំពុងមានភាពពុះកញ្ជ្រោលយ៉ាងខ្លាំង ហើយ ផាត់ ចាប់ផ្ដើមដណ្ដឹងសួរខ្លួនឯងថា តើគេមិនស្ដីបន្ទោសឲ្យគាត់ពីរឿងសមាជិកគ្រួសារគាត់ខ្លះ ដែលប្រព្រឹត្តមិនល្អទេឬ? ។ ដោយឡែក គាត់បានត្រូវធ្វើឲ្យព្រួយចិត្តយ៉ាងខ្លាំង ដោយសាររឿងបងប្រុសរបស់គាត់ម្នាក់ឈ្មោះ ទិត ដែលធ្លាប់គិតគូររកការងារឲ្យគាត់ធ្វើនៅពេលដែលគាត់ទៅដល់ក្រុងភ្នំពេញជាលើកដំបូង ព្រោះ ទិត ធ្លាប់ធ្វើជានាយទាហានម្នាក់ក្នុងកងទ័ពរបស់សម្ដេច ព្រះនរោត្ដម សីហនុ ។

សមាជិកគ្រួសាររបស់គាត់ផ្សេងទៀត ពុំមានបង្កជាគ្រោះថ្នាក់មួយ ដោយការជាប់ពាក់ព័ន្ធពីរឿងវណ្ណៈឡើយ ។ ប៉ុន្ដែ មានស្ដ្រីម្នាក់ទៀត គឺយុវនារីម្នាក់ដែលគាត់ធ្លាប់ស្គាល់កាលនៅខេត្តរតនគិរី ក្នុងពេលដែលគាត់នៅធ្វើការជាមួយ ប៉ុល ពត និងគណៈកម្មាធិការមជ្ឈិម ។ ដោយធ្លាប់មានទំនាក់ទំនងយ៉ាងខ្លីជាមួយនាង ដោយធ្លាប់ដឹកនាំធ្វើការឃោសនាប្រកាន់តាមគោលការណ៍តឹងរ៉ឹងបំផុតនោះ ឥឡូវនេះ គាត់នឹកភ័យខ្លាចថា គេច្បាស់ជារកឃើញថា គាត់"ធ្លាប់បានប្រព្រឹត្តខុសសីលធម៌ជាមួយយុវនារីម្នាក់នោះ" មិនខានឡើយ ។

ផាត់ បានបញ្ចប់ការសិក្សានៅសាលានយោបាយបក្ស ហើយបានវិលត្រឡប់ទៅកាន់ភូមិភាគឧត្តរវិញ ចំពេលដែលអៀង សារី ធ្វើដំណើរទៅរួមប្រជុំបើកសម្ពោធភូមិភាគឧត្តរថ្មីដែរ ។ ដោយមានអារម្មណ៍មិនល្អស្រាប់ យុវបុរសនេះ បានក្លាយទៅជាមនុស្សកើតមានការមិនទុកចិត្តគេឯងទាំងអស់ នៅពេលដែលគេប្រុងតែទម្លាក់កំហុសមកលើរូបគាត់ ។ សារី បានត្រៀមរឿងមួយនេះនៅក្នុងសុន្ទរកថារបស់គាត់រួចជាស្រេច ។ "នៅពេលដែលបងទី២ (គឺ សារី តាមភាសាដោយឡែករបស់ពួកកុម្មុយនិស្ដ) បានលើកយកមកនិយាយពី "រឿងបាត់ខ្សែអាត់ថតសំឡេង" ចំនួនដប់ពាន់ម៉ែត្រ ខ្ញុំនឹកភ័យថា គាត់មុខជាមានកំហឹងមកលើរូបខ្ញុំមិនខាន" ។

តាមប្រហែល គេបានវង្វេងដៃដាក់ខ្សែអាត់ថតសំឡេងមួយដុំក្នុងមន្ទីររបស់ភូមិភាគដែលនៅដំណាក់កាលបដិវត្តនេះ គឺជារឿងដែលគេចាត់ទុកជាកំហុសមួយ ពុំមែនជាការភ័ន្តច្រឡំមួយទេ ។ ប្រហែលជាមានអ្នកណាម្នាក់លួចយកទៅបាត់ ថ្វីបើវាពុំមែនជាផលិតផលដែលគេខំស្វះស្វែងរកដូចស្រូវអង្ករ ឬសាច់ក្រណាត់ក៏ដោយ ។ គេបានចាប់ផ្ដើមអនុវត្ត ទៅលើបណ្ដាសមាជិកបក្ស និង"ពួកអ្នកចាស់" នូវ"គោលការណ៍ផ្សេងៗ"ដែលពួកគេធ្លាប់ប្រើសម្រាប់ដាក់ទោស"ពួកអ្នកថ្មី" និងពួកមនុស្សដែលគេសង្ស័យពីអំពើក្បត់ដែរ ។ តាំងពីថ្ងៃដំបូងៗនៃការបដិវត្តន៍ ពួកខ្មែរក្រហមបានប្រៀនប្រដៅថា "គ្រោះថ្នាក់ទាំងឡាយ" អាចជាកំហុសដែលស្ដែងឲ្យឃើញបំណងប្រព្រឹត្តបទឧក្រិដ្ឋផ្សេងៗ ។ ដូច្នេះ ផាត់ ពិតជាមានមូលហេតុនឹកបារម្ភនូវអំពើសងសឹកមកវិញដែរ ព្រោះរូបគាត់ផ្ទាល់ធ្លាប់បានដាក់ទោសមនុស្សជាច្រើនទៀត ព្រោះតែកាប្រព្រឹត្តបទល្មើសកំប៉ិកកំប៉ុកប៉ុណ្ណោះ ។ គាត់ពុំអាចជៀសវាងមិនកត់សម្គាល់ថា មជ្ឈិមបានបង្រួមការបដិវត្តឲ្យទៅជាបញ្ហាផ្សេងៗ ដូចជាផ្សៀននង្គ័លមួយបាក់ ចំនួន

កម្រិតមួយនៃផលស្រូវដែលធ្វើបាន ឬមិនបាន ខ្សែអាត់មួយដុំបាត់រកមិនឃើញជាដើម ។

ការបាត់ខ្សែអាត់ថតសំឡេងនេះអាចត្រូវគេកាត់យល់ថា ជាការត្រួតពិនិត្យមិនដិតដល់របស់មន្ទីរមួយ ឬតំបន់មួយ ការប្រព្រឹត្តល្មើសចំពោះមជ្ឈិម ការធ្វើឲ្យអន្តរាយដល់សេដ្ឋកិច្ច និងការបដិវត្ត ។ អំពើក្បត់ពុំមែនស្ថិតនៅឯណាឆ្ងាយទេ ។ សមាជិកបក្សមួយចំនួនកាន់តែច្រើនឡើងៗត្រូវបាននាំទៅដាក់នៅមន្ទីរឃុំឃាំងទួលស្លែង ហើយនៅដំណាច់ឆ្នាំ១៩៧៧ គឺជាវេនរបស់ ផាត់ ម្តង ។ មជ្ឈិមបានត្រៀមខ្លួនដាក់ចេញនូវការបោសសម្អាតរបស់ខ្លួនរួច ប្រឆាំងនឹងភូមិភាគបូព៌ាជាស្រេច ដែលបណ្តាលឲ្យមានមនុស្សស្លាប់ច្រើនជាងគេបំផុត ហើយ ផាត់ ធ្លាប់មានទំនាក់ទំនងនឹងភូមិភាគនេះរួមទាំងភូមិភាគផល ។ ឥឡូវនេះ មន្ទីរឃុំឃាំងទួលស្លែងបានកម្ទេចបណ្តាមេដឹកនាំរបស់ការបដិវត្តច្រើនជាងអ្នកដឹកនាំនៃរបបចាស់ ។

នៅពេលចូលឆ្នាំសកល១៩៧៨ និរសារម្នាក់បាននាំយកសំបុត្រមួយមកមន្ទីររបស់ ផាត់ ដើម្បីអញ្ជើញគាត់ឲ្យទៅចូលរួមសម័យប្រជុំគណៈដឹកនាំភូមិភាគមួយ ក្នុងគោលបំណងរៀនចំផែនការប្រចាំឆ្នាំ និងបើកធ្វើមហាសន្និបាតមួយសំដៅថ្កោលទោសពួកវៀតណាម ។ ស្អែកឡើង ផាត់ បានធ្វើដំណើរទៅដល់សៀមរាប នៅពេលរសៀលដែលអមការពារដោយអង្គរក្សពីរនាក់ ហើយការប្រជុំត្រូវចាប់ផ្តើមនៅព្រឹកថ្ងៃបន្ទាប់ ។ នៅពេលព្រលឹមស្រាងៗ រថយន្តមួយបានបើកមកទទួលយក ផាត់ និងមេដឹកនាំម្នាក់ទៀត ហើយអ្នកទាំងពីរបានធ្វើដំណើរទៅជួបលេខាបក្សភូមិភាគ បន្ទាប់មក បានពិនិត្យមើលផែនការប្រចាំឆ្នាំពីស្រុកមួយទៅស្រុកមួយជាបន្តបន្ទាប់ ។ ប្រហែលនៅម៉ោងប្រាំបួនព្រឹក ឡានហ្ស៊ីបមួយគ្រឿងបានបើកមកឈប់នៅពីមុខមន្ទីរ លេខាបក្សក្រឡេកមើលទៅខាងក្រៅហើយប្រាប់ថា «សុទ្ធតែបងប្អូនខាងកងទ័ពអាកាសចរណ៍» ។ មនុស្សទាំងអស់នាំគ្នាក្រោកឈររួមទាំង ផាត់ ផង រួចដើរទៅមុខ ដៃហុចទៅរកអ្នកដែលដើរចូលមក ។

ខ្ញុំនឹកគិតថា ពួកគេសុទ្ធតែជាបងប្អូនរួមជាតិឯង... ហើយពួកគេបានចាប់ឱបរឹតគ្នាទៅវិញទៅមកជាសញ្ញាមិត្តភាព ។ ប៉ុន្តែ ពួកគេបានរឹតបន្តឹងការឱបនេះកាន់តែខ្លាំង ខ្ញុំខំរើបម្រះតែពួកគេបានបញ្ឈរឲ្យខ្ញុំនៅឲ្យស្ងៀមកុំកម្រើក ។ បន្ទាប់មក គេបានដាក់ខ្នោះដៃខ្ញុំ និងចងក្រណាត់មួយបន្ទះពីលើភ្នែកខ្ញុំទៀត... ខ្ញុំនឹកគិតថា នៅទីនេះពិតជាមានសត្រូវមួយចំនួនធំ ដែលរួមបញ្ចូលឈ្មោះខ្ញុំទៅក្នុងចង្កោមពួកគេដែរ...» ។

«បងប្អូនរួមជាតិឯង» ទាំងនេះ ដែលធ្វើអ្វីៗទៅតាមការណែនាំរបស់ ឌុច ដោយមានការយល់ព្រមពីមេកោយផ្ទាល់របស់ ផាត់ ផង បានស្នើរឲ្យអ្នកទោសរបស់គេប្រាប់ឈ្មោះរបស់ខ្លួនឲ្យបានច្បាស់លាស់ ។ គាត់បានធ្វើតាម ហើយបានប្រកាសថា «មុននឹងស្លាប់ឬរស់ខ្ញុំចង់ជួប«អង្គការ»សិន ។ ពួកនោះបានឆ្លើយថា «ពិតជាត្រឹមត្រូវហើយចំពោះអ្វីដែលអ្នកឯងត្រូវទៅជួបអង្គការនោះ» ។

ផាត់ បានឡើងជិះក្នុងរថយន្តហ្ស៊ីប ដើម្បីនាំមកក្រុងភ្នំពេញ និងត្រូវឃុំឃាំងនៅទួលស្លែង នៅថ្ងៃទី៨ ខែមករា ឆ្នាំ១៩៧៨ ។ នៅថ្ងៃបន្ទាប់ គាត់បានសរសេរជីវប្រវត្តិដ៏ច្របូកច្របល់មួយ ពោរពេញទៅដោយ

វិប្បដិសារី ចំពោះបទឧក្រិដ្ឋមួយដែលគាត់ដឹងថា មិនដែលបានប្រព្រឹត្តទាល់តែសោះ ។ គាត់បានសរសេរថា "តាំងពីការចាប់ខ្ញុំដាក់គុក ខ្ញុំមើលឃើញតែផ្លូវមួយគត់ដែលចំហផុងនៅចំពោះមុខខ្ញុំ ។ ខ្ញុំមុខជាស្លាប់ ពីព្រោះខ្ញុំដឹងពីប្រតិកម្មរបស់បក្សចំពោះរូបខ្ញុំ និងការប្រើ "វិធានការចុងក្រោយ" របស់បក្សច្បាស់ណាស់ ។ ខ្ញុំនឹកក្នុងចិត្តថា ខ្ញុំត្រូវតែប្រុងប្រយ័ត្នមិនឲ្យមានអ្វីមកប៉ះពាល់ដល់សុខភាពខ្ញុំនៅតាមផ្លូវឡើយ ក្នុងគោលបំណងដើម្បីឲ្យខ្ញុំអាចរកឃើញបញ្ហាដែលនាំឲ្យមានាការចាប់ខ្លួនខ្ញុំ ពីសំណាក់ពួកសន្តិសុខនេះ..." ។

*បក្សជាទីគោរព និងជាទីស្នេហា! បណ្ដាមេដឹកនាំបក្សជាទីគោរព និងជាទីស្នេហា! ខ្ញុំសូមស្នើឲ្យបក្ស បណ្ដាសមមិត្តជាទីគោរព និងជាទីស្នេហា អាណិតអាសូរចំពោះខ្ញុំផង ។ គ្មានពេលណាមួយដែលខ្ញុំមានបំណងក្បត់នឹងបក្សសោះឡើយ... ។ ដោយហេតុថា ឧត្តមគតិផ្សេងៗរបស់បក្ស ដែលខ្ញុំជឿទុកចិត្តនោះ ខ្ញុំអាចអះអាងចំពោះបក្សយ៉ាងស្មោះអស់ពីដួងចិត្តថា ខ្ញុំមានសេចក្ដីភ័យខ្លាចនឹងប្រភេទនៃការស្លាប់បែបនោះណាស់ ។ ខ្ញុំបារម្ភខ្លាចក្រែងកូន និងចៅរបស់ខ្ញុំ ពុំបានក្លាយទៅជាអ្នកបន្តពូជរបស់បក្ស... ។ ទោះជាមានការធ្វើទារុណកម្មផ្សេងៗ ដែលបក្សអាចដាក់ទោសខ្ញុំក្នុងពេលនេះក៏ដោយ ក៏បក្សពុំអាចយកបានពីខ្ញុំនូវភ័ស្តុតាងណាមួយ ដែលបង្ហាញឲ្យឃើញពីអំពើក្បត់ឡើយ ពីព្រោះខ្ញុំពុំដែលមានចិត្តក្បត់ទាល់តែសោះ ។ ខ្ញុំសូមអង្វរករបក្ស មេត្តាសម្ដែងនូវការអាណិតអាសូរខ្លះ ចំពោះកូនៗរបស់ខ្ញុំ និងទុកជីវិតឲ្យពួកវាបាននៅរស់ផង ពីព្រោះខ្ញុំជាសាច់ជាឈាមរបស់បក្សយ៉ាងពិតប្រាកដ ។*

*ធ្វើនៅមជ្ឈមណ្ឌលឃុំឃាំងរបស់ក្រុមសន្តិសុខ*
*ព្រឹកថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៨*
*ហត្ថលេខា ហង្ស [នាមបដិវត្តរបស់ ផាត់]*

បន្ទាប់ពីការធ្វើទារុណកម្មជាច្រើនសប្ដាហ៍ ផាត់ បានប្រគល់ទៅឲ្យ ឌុច នូវចម្លើយសារភាពសរសេរដៃមួយចំនួនជាងប្រាំបីទំព័រ ស្ដីពី "សកម្មភាពក្បត់របស់គាត់" ។ ក្រោយមក នៅខែកុម្ភៈ គាត់បានទទួលស្គាល់ពីបទល្មើសផ្នែកសីលធម៌ ។ "កំហុសឆ្គងផ្នែកសីលធម៌ជាមួយស្រីៗ" នេះជាចំណងចម្លើយសារភាព ដែលក្នុងនោះគាត់បានរ៉ាយរ៉ាប់ពីស្ត្រីទាំងឡាយ ដែលគាត់ធ្លាប់មានទំនាក់ទំនងខាងផ្លូវភេទនៅមុន និងក្រោយការរៀបអាពាហ៍ពិពាហ៍របស់គាត់ ។ នៅខែមីនា គាត់បានសរសេរឯកសារមួយមាន ហុកសិបបួនទំព័រ ស្ដីពីខ្សែបណ្ដាញឈ្លបយការណ៍មួយ ដែលម្ដងដឹកនាំដោយពួកសេ.អ៊ី.អា.ម្ដង ដោយពួកវៀតណាម ។

ផាត់ ពេជ្ឈឃាតកាលពីពេលថ្មី នៅទីបំផុតបានរកឃើញអាថ៌កំបាំងនៃការរួមគំនិតក្បត់ទាំងអស់ ដែលលាតត្រដាងឲ្យដឹងដោយបក្ស និងពួកក្បត់ដែលបក្សជ្រើសរើសទុកជាមុនសម្រាប់ផ្នែកសន្តិសុខ "ពួកអ្នកថ្មី"

ដែលមានវណ្ណៈគហបតី និងពួកអ្នកទាំងឡាយណាដែលបក្សជឿថា បានចូលរួមយ៉ាងសកម្មក្នុងការឃុបឃិតបម្រុងក្បត់ប្រឆាំងនឹងបុព្វហេតុបដិវត្ត ពីព្រោះបក្ស ឬអង្គការធ្លាប់ប្រកាសថា អ្នកទាំងនោះជាប់ជំពាក់នឹងវណ្ណៈមិនល្អ ឬធ្លាប់ត្រូវវែកមុខរកឃើញដោយការស៊ើបអង្កេតរកខ្សែបណ្ដាញផ្សេងៗ ។ គាត់បានរកឃើញថា នៅពីក្រោយរឿងទាំងនោះ គឺមានតែពាក្យភូតកុហក ដែលគេចម្រាញ់យកបានពីអ្នកទោសទាំងលំបាក ក្រោមការវាយដំ ដើម្បីធ្វើឲ្យការព្រួយបារម្ភរបស់មជ្ឈិម បានស្រាកចុះប៉ុណ្ណោះ ។

នៅពេលដែល ដាត់ សរសេរចម្លើយសារភាពចំនួន ហុកសិបបួនទំព័ររបស់គាត់ចប់ បេសកកម្មរបស់គាត់សម្រាប់បក្សក៏ចប់ត្រឹមនេះដែរ ។ គេបានបិទសំណុំរឿងរបស់គាត់វិញ គេបានកម្ចាត់រូបកាយគាត់ឲ្យបាត់ពីមុខមាត់គេ ។

តើមានអ្វីកើតឡើងក្នុងចិតគំនិតរបស់អ្នកដែលបានធ្វើទារុណកម្ម និងសម្លាប់អ្នករងគ្រោះយ៉ាងច្រើននៅមន្ទីរឃុំឃាំងទួលស្លែង? ហេតុអ្វីបានជាជនបដិវត្តម្នាក់ អាចធ្វើទារុណកម្មទៅលើជនបដិវត្តម្នាក់ទៀត? ហេតុអ្វីបានជាបក្សអាចញុាំងឲ្យពួកកម្មាភិបាលនៅទួលស្លែងជឿជាក់ថា ករណីយកិច្ចរបស់គេ តម្រូវឲ្យពួកគេវាយធ្វើបាប និងធ្វើឲ្យមនុស្សជាច្រើនឈឺចាប់ក្នុងចិត្ត ដែលមុននេះបន្តិចធ្លាប់ត្រូវបានចាត់ទុកជាវីរជននោះ? ។ ចម្លើយអំពីរឿងនេះ គឺមាននៅក្នុងសៀវភៅជាច្រើន ដែលថែរក្សាទុកដោយកម្មាភិបាលម្នាក់ ក្នុងចំណោមកម្មាភិបាលទាំងឡាយនៅមណ្ឌលឃុំឃាំង[៣៣] ។ ជាយុវបុរសមានចំណេះដឹង និងមនសិការម្នាក់ គាត់បានកត់ត្រាទុកដោយលាយលក្ខណ៍អក្សរពីពេលម៉ោងធ្វើការ មតិណែនាំផ្សេងៗរបស់ខ្លួន សម្រាប់ការសួរចម្លើយ និងការធ្វើទារុណកម្ម ព្រមទាំងបណ្ដាមូលហេតុ ផ្នែកនយោបាយដែលពួកអ្នកទោសបកស្រាយបំភ្លឺផង ។ រឿងតែមួយគត់ដែលនៅខ្វះ គឺឈ្មោះរបស់គាត់ ដែលនេះប្រហែលជាសញ្ញានៃការខ្វាចរអែងផ្សេងៗ ឬការដឹងខ្លួនពីពិរុទ្ធភាពមួយហើយមើលទៅ ។

កិច្ចការធ្វើប្រចាំថ្ងៃបានចាប់ផ្ដើមនៅម៉ោង៥និង៣០នាទីព្រឹក ដោយមានបន្ថែម៉ោងក្នុងការសួរចម្លើយដ៏ទៀងទាត់ចំនួន បីពេលទៀត គឺម៉ោង៦និង៤៥នាទី ម៉ោង១៣និង៤៥នាទី និង ម៉ោង១៨និង៤៥នាទី ។ ចាប់ពីការចូលទៅដល់មន្ទីរឃុំឃាំងទួលស្លែងដំបូង ពួកអ្នកទោសបានផ្លាស់ប្ដូរស្ថានភាពផ្ទាល់ខ្លួនទាំងស្រុង ហើយបានទទួលឈ្មោះជា“ខ្មាំង” ឬ“ទណ្ឌិត”(អ្នកត្រូវទទួលទោស) ។ ក្នុងសៀវភៅរបស់គាត់មានសរសេរថា ជាទូទៅកម្មាភិបាលនៅទីនោះ ច្រើនតែចាត់ទុកពួកអ្នកទោសបដិវត្តជា “សត្រូវ” ទាំងអស់ ពីព្រោះ គេចាត់ទុកអ្នកទាំងនោះជាមនុស្សដែលផ្ដល់គ្រោះថ្នាក់ខ្លាំងជាងគេបំផុត ៖ “ពួកគេប្រើប្រាស់លទ្ធិកុម្មុយនិស្ត ដើម្បីបំផ្លាញលទ្ធិកុម្មុយនិស្ត” ។

សៀវភៅទាំងអស់នេះ បានបង្ហាញឲ្យដឹងដោយត្រង់ៗ អំពីដំណើរប្រព្រឹត្តទៅនៃការសួរចម្លើយ និងការធ្វើទារុណកម្ម ៖ “យើងបានចងពួកនោះនឹងច្រវាក់ យើងពិនិត្យបញ្ជាក់ថា មានអ្វីខ្លះជាប់នឹងខ្លួនគេ ហើយនៅពេល

ដែលយើងសួរចម្លើយ យើងមិនទុកវត្ថុណាមួយនៅជិតដៃពួកគេទេ ដោយខ្លាចពួកនោះយកទៅប្រើជាអាវុធ» ។ ឆ្ងាយទៅទៀត កម្មាភិបាលនៅមន្ទីរឃុំឃាំងទួលស្លែងបានសរសេរថា «ជាការសំខាន់ដែលត្រូវធ្វើទារុណកម្មដោយដៃផ្ទាល់» ។ អ្វីដែលគេប្រព្រឹត្តដោយឡែកសម្រាប់ពួកស្ត្រីគឺ «បក្សបានបញ្ជាឲ្យយើងវាយពួកស្ត្រីដែលមានទោសដោយខ្សែតី ជាពិសេស ហាមមិនឲ្យវាយនឹងដៃផ្ទាល់របស់យើងទេ» ។

គេបានព្រមានមិនឲ្យមានការវាយតប់ហួសកំណត់ដែរ ៖ «បើសិនគេវាយ«ខ្មាំង»យូរខ្លាំងពេក ក៏ពួកនោះនៅតែឈឺចាប់ដដែលកាលបើគេលែងវាយតប់ ។ ពួកនោះច្បាស់ជាធ្លាក់ខ្លួនឈឺជាទម្ងន់ ហើយខ្លួនប្រាណនឹងចុះស្គមខ្លាំង ដែលគេលែងអាចវាយដំបាន ។ លទ្ធផលគឺ យើងគ្មានបានទទួលអ្វីជាដុំកំភួនពីពួកនោះឡើយ... ។ ធ្វើឲ្យពួកខ្មាំងឈឺចាប់ខ្លាំងរហូតទាល់តែពួកនោះលែងហើបមាត់និយាយកើត នឹងធ្វើឲ្យបក្សទញ់ទាល់ក្នុងចិត្តជាខ្លាំង» ។

ប៉ុន្តែ ការធ្វើទារុណកម្ម គឺជាការជាប់រវល់ធំបំផុតនៅមន្ទីរឃុំឃាំងទួលស្លែង ហើយទិដ្ឋភាពនៃបច្ចេកទេសរបស់ខ្លួន គឺមាននិយាយឡើងវិញក្នុងកំណត់ហេតុខ្លីរបស់កម្មាភិបាលនោះដែរ ។ «គោលបំណងនៃការធ្វើទារុណកម្ម គឺធ្វើយ៉ាងណាឲ្យបានទទួលចម្លើយ» ។ យើងមិនមែនធ្វើទារុណកម្មសម្រាប់ការសប្បាយទេ... ជួនកាលការក្រេវក្រោធ បានធ្វើឲ្យយើងលែងគិតឃើញខុសត្រូវ យើងក៏បាត់បង់ភាពម្ចាស់ការរបស់យើង ។ ជួនកាលការសួរចម្លើយតម្រូវឲ្យយើងស្រែចំទាលដាក់ត្រចៀកខ្មាំង ហើយនៅពេលដែលវាឆ្លើយក្នុងន័យដែលយើងចង់បាន យើងទាំងអស់គ្នាមានសេចក្ដីត្រេកអរយ៉ាងខ្លាំង យើងនាំគ្នាសើចសប្បាយ ហើយយើងក៏បានឈប់សម្រាកមួយស្របក់ដែរ...» ។

គេបានក្រើនរំឭកប្រាប់ពួកកម្មាភិបាលនៅមន្ទីរឃុំឃាំងទួលស្លែងថា ហេតុអ្វីបានជាត្រូវវាយធ្វើទារុណកម្មពួកអ្នកទោស គឺដើម្បីចម្រាញ់យកចម្លើយសារភាព និង«វត្ថុតាងផ្សេងៗ» ស្ដីពីខ្សែបណ្ដាញ និងការឃុបឃិតគ្នាជាសម្ងាត់ បម្រុងក្បត់ដែលគំរាមកំហែងដល់ការបដិវត្ត ។ គេបាននិយាយប្រាប់គាត់ថា «ការងាររបស់សន្តិសុខគឺជាការងារតស៊ូវណ្ណៈមួយ ដើម្បីការពារបក្ស វណ្ណៈអធន កម្ពុជាប្រជាធិបតេយ្យ មាគ៌ាឯករាជ្យ និងធ្វើម្ចាស់លើជោគវាសនារបស់ខ្លួន ។ ដោយហេតុនេះ យើងនឹងគាស់រំលើងអាថ៌កំបាំងរបស់ខ្មាំង យើងនឹងធ្វើឲ្យខូចគម្រោងការរបស់ពួកវា យើងនឹងកាត់ផ្ដាច់ខ្សែបណ្ដាញ និងផែនការក្បត់របស់ពួកវា ប្រកបដោយប្រសិទ្ធភាពមួយដែលកាន់តែរឹងមាំឡើងៗ» ។

នីតិវិធីដែលធ្វើឲ្យគេដឹងគឺ ត្រូវសម្រេចយកឲ្យបានពត៌មានផ្សេងៗ ធ្វើទុក្ខបុកម្នេញអ្នកទោសជាមួយនឹងការឃោសនានយោបាយ «ដោយដេរប្រមាថដៀលត្មះអ្នកទោស» បន្ទាប់មក ធ្វើទារុណកម្ម ។ «ពិនិត្យមើលម្ដងមួយៗ និងវិភាគអំពីចម្លើយផ្សេងៗរបស់ពួកអ្នកទោស» ដើម្បីដាក់សំណួរផ្សេងទៀត និងឲ្យសំអាងការចោទប្រកាន់ផ្សេងៗ ។ ចៀសវាងកុំធ្វើឲ្យពួកអ្នកទោសស្លាប់ក្នុងពេលសួរចម្លើយ និងស្ដាប់ចម្លើយអ្នកទោសផ្សេងទៀត ហើយជាពិសេស ត្រូវរក្សាការសម្ងាត់ឲ្យបានអំពីសកម្មភាពទាំងឡាយនៅមន្ទីរឃុំឃាំងទួលស្លែង ។ ការធ្វើ

ទារុណកម្មត្រូវតែស្ថិតនៅជាសម្ងាត់ គ្មានអ្នកណាម្នាក់ដឹងថា ពួកអ្នកទោសបានទទួលសារភាពក្រោមការវាយដំប្រំធាក់ឡើយ ។ នៅទីបំផុត ករណីផ្សេងៗរបស់ពួកអ្នកជាប់គុក គោងតែទៅពិភាក្សាជាមួយថ្នាក់លើជាបន្ទាន់ ។ «បើសិនគ្មានការសម្ងាត់ទេ សន្តិសុខក៏គ្មានន័យអ្វីដែរ» នេះគឺជាបទបញ្ញា ។

ចម្លើយសារភាពទាំងឡាយ គឺជាចំណុចសំខាន់បំផុតនៃប្រព័ន្ធសន្តិសុខ ។ គេបានណែនាំឲ្យពួកកម្មាភិបាលនៅទីនោះ បណ្តោយឲ្យពួកអ្នកទោសសរសេរចម្លើយសារភាពដោយដៃផ្ទាល់របស់គេ ហើយចុះហត្ថលេខា និងចុះថ្ងៃខែឲ្យបានច្បាស់លាស់ ។ អ្នកទទួលបន្ទុកបង្ហាប់បញ្ហាម្នាក់បានណែនាំថា «គេគោងតែស្រុះស្រួលគ្នា ដើម្បីនឹងឲ្យពួកអ្នកទោសសរសេរប្រវត្តិនៃសកម្មភាពក្បត់របស់គេ ធ្វើយ៉ាងណាឲ្យទាល់តែរឿងនោះចូលដល់ជម្រៅនៃអាថ៌កំបាំងអត្ថបទត្រូវមានលក្ខណៈច្បាស់លាស់ ជាក់ស្តែង និងបង្ហាញឲ្យដឹងនូវមូលហេតុផ្សេងៗ» ...ដោយបញ្ឈាក់បំភ្លឺពីការធ្វើចារកម្ម និងការជ្រៀតចូលបែបណា ។ «អ្វីដែលប្រសើរជាងគេ គឺធ្វើឲ្យពួកនោះសរសេរចម្លើយសារភាពផ្សេងៗដោយដៃ និងគំនិតផ្ទាល់របស់គេជាមួយពាក្យសម្តីត្រង់ៗ ។ យើងត្រូវចៀសវាងកុំនិយាយឲ្យគេសរសេរតាម ដូច្នេះ នៅពេលដែលពួកគេនិយាយ ឬសរសេរចប់ យើងចាំតែដកស្រង់ចំណុចខ្សោយប៉ុណ្ណោះបានហើយ» ។

ចម្លើយសារភាពដំបូងៗទាំងនេះ ដែលសរសេរជាមួយនឹងពាក្យសម្តីផ្ទាល់របស់ពួកអ្នកជាប់គុក បានរួមបង្កជាឯកសារប្រវត្តិសាស្ត្រដែលមានលក្ខណៈប្លែកពីធម្មតា និងគួរឲ្យរន្ធត់ក្រៃលែង ។

បទបញ្ញាចុងក្រោយមួយ គឺថា«ការសរសេរ និងក្រដាសសរសេរ ត្រូវតែស្អាតល្អ កុំឲ្យមានស្នាមប្រឡាក់ទាំងអស់» ។

មតិណែនាំផ្សេងៗចំពោះពួកកម្មាភិបាលនៅទីនោះ ពុំទុកឲ្យមានសេចក្តីសង្ស័យណាមួយឡើយ ៖ អ្នកទោសទាំងអស់សុទ្ធតែត្រូវសន្មតថា ជាពិរុទ្ធជន និងត្រូវមានទោសប្រហារជីវិត ដោយមិនគិតពីចម្លើយសារភាពដែលពួកនោះបានសរសេរផងទេ ។ គេបានទូន្មានពួកកម្មាភិបាលទាំងនោះថា «ចូរអ្នករាល់គ្នាយកចិត្តទុកដាក់ចំពោះមធ្យោបាយដោះកុន និងល្បិចកលបោកប្រាស់របស់ពួកអ្នកជាប់គុក ក្នុងគោលបំណងបោកបញ្ឆោតយើង អង្វរករយើង និងអះអាងថា ពួកគេសុទ្ធតែជាមនុស្សស្លូតត្រង់ ពុំដែលបានក្បត់នឹងយើងម្តងណាឡើយ... ហើយបន្ទោសថា យើងបានវាយធ្វើបាបពួកគេទាំងអយុត្តិធម៌ ហើយថាពួកគេពុំមែនជាពួកក្បត់ទេ... ឬថា ពួកគេបង្ខំចិត្តឆ្លើយសារភាព ដោយសារការឈឺចាប់ម្យ៉ាងតែប៉ុណ្ណោះ» ។ អ្នកបង្ហាប់បញ្ហាម្នាក់ទៀតបានបន្ថែមថា គេមិនត្រូវបណ្តោយឲ្យពួកអ្នកទោសធ្វើអត្តឃាតទេ ការធ្វើអត្តឃាតក៏ជាល្បិចកលមួយដែរ ។

ពួកអ្នកបង្ហាប់បញ្ហាបានប្រាប់ឲ្យដឹងពីគន្លឹះសម្ងាត់ផ្សេងៗចំពោះពួកកម្មាភិបាលថ្មីៗ ដែលទទួលបន្ទុកសួរចម្លើយ ឲ្យចេះប្រើពាក្យភូតកុហក ដើម្បីជំរុញឲ្យអ្នកទោសទទួលសារភាព ។ ឧទាហរណ៍ គេណែនាំឲ្យចេះសន្យានឹងអ្នកទោសថា បើទទួលសារភាព ពួកគេអាចនឹងត្រូវគេសង្គ្រោះឲ្យរួចជីវិត ព្រមទាំងជីវិតរបស់សមាជិកគ្រួសារគេ

ផង ។ គេបានណែនាំឲ្យពន្យល់ប្រាប់ពួកនោះថា ពួកគេនឹងត្រូវយកទៅដាក់ផ្ញើនៅអគ្គភាពពិសេសមួយរបស់បក្ស ហើយថា បក្ស«មិនបង្ខាតពេលវេលារបស់ខ្លួន ដើម្បីចាប់ និងសម្លាប់មនុស្សទាំងនោះទេ»ថា បក្សចង់ស៊ើបរកតែការពិតប៉ុណ្ណោះ ។

ប៉ុន្តែ របៀបនិយាយ ឬសរសេរដែលប្រើពាក្យសម្ដីមិនសមទំនងក្នុងសៀវភៅទាំងនោះ បានធ្វើឲ្យគេសន្និដ្ឋានថា ពួកកម្មាភិបាលដែលធ្វើការនៅមន្ទីរឃុំឃាំងទួលស្លែងទាំងប៉ុន្មាន ប្រហែលសុទ្ធតែត្រូវធ្វើឲ្យអំពល់ដោយ«មនុស្សខុសគេ» ដែលពួកគេកំពុងតែបង្កើតនោះហើយ ។ ជាមួយនឹងរបៀបគ្រប់គ្រងមួយ ដោយសន្មតជាពិរុទ្ធជននូវពួកអ្នកជាប់គុក និងពួកអ្នករួមគំនិត ឪពុកម្ដាយរបស់គេ និងទំនាក់ទំនងទាំងអស់ នៅទីបំផុត ម៉ាស៊ីនសម្លាប់មនុស្សនៅមន្ទីរឃុំឃាំងទួលស្លែង អាចបញ្ចូលបក្ខជនទាំងមូលរបស់បក្សទៅក្នុងនោះដែរ ។ ភាពជាមនុស្សគ្មានកំហុសពុំមានសារសំខាន់ទេ កម្មាភិបាលទាំងអស់ ត្រូវតែមានសេចក្ដីស្មោះត្រង់ដាច់ខាតមួយនៅក្នុងបក្ស ។ ក៏ប៉ុន្តែ មានតែពួកមេដឹកនាំជាន់ខ្ពស់ ប្រមាណជាសាមសិបនាក់ ក្នុងគណៈកម្មាធិការមជ្ឈិមប៉ុណ្ណោះ ដែលដឹងពីលក្ខណៈពិតប្រាកដ នៃសកម្មភាពទាំងឡាយរបស់ក្រុមសន្តិសុខនៅមន្ទីរឃុំឃាំងទួលស្លែង និងនៅតាមបណ្ដាខេត្តនានា ។ ពួកអ្នកបង្កាប់បញ្ជាបានព្រមានប្រាប់ពួកកម្មាភិបាលនៅមជ្ឈមណ្ឌលឃុំឃាំងថា ការច្រឡូកច្របល់មួយអាចស្ដែងឲ្យឃើញឡើង ៖ «បក្សផ្លាស់ប្ដូរចិត្តឆាប់រហ័ស និងជារឿយៗ ។ បក្សបានដូរផ្លាស់ពួកអ្នកទោស ដែលយើងត្រូវសួរចម្លើយដោយគ្មានកំណត់ពេលវេលាជាក់លាក់... បក្សបានកែប្រែនីតិវិធីចងក្រងឯកសារផង ៗ វិធីសាស្ត្រក្នុងការសួរចម្លើយ ការឃោសនានយោបាយការធ្វើទារុណកម្ម ការចាប់ដាក់គុក និងការផ្ទេរពួកអ្នកទោស- ដែលមានជាញឹកញាប់ និងយ៉ាងរហ័សបំផុត ។

មន្ទីរឃុំឃាំងទួលស្លែងគ្រាន់តែជាកន្លែងកំពូលនៃរឿងអាថ៌កំបាំង ជាទីសេនាធិការរបស់សន្តិបាល និងជាមន្ទីររបស់បក្សប៉ុណ្ណោះ ។ ពួកកម្មាភិបាលរបស់ខ្លួននៅទីនោះ មាននាទីត្រឹមតែទទួលខុសត្រូវមួយចំណែកតូចប៉ុណ្ណោះក្នុងការសម្លាប់មនុស្ស គឺការសម្លាប់អ្នករងគ្រោះដែលកំពុងរស់នៅក្នុងភូមិភាគក្រុងភ្នំពេញ ឬអ្នករងគ្រោះដែលត្រូវវិនិច្ឆ័យជាមនុស្សដែលមានអំណាចគ្រាន់បើដែលមិនអស់នឹងឲ្យ ឃុំ ធ្វើទារុណកម្ម និងសួរចម្លើយ ។

វាក៏មានកន្លែងឃុំឃាំងរបៀប «ទួលស្លែង» ច្រើនរាប់មិនអស់ផ្សេងទៀត ដែលធ្វើឲ្យប្រទេសជាតិប្រឡាក់ទៅដោយឈាមពាលពេញគឺ គុក កន្លែងប្រហារជីវិត រណ្ដៅកប់ខ្មោចរួម ។ ការងារ និងការសម្លាប់មនុស្ស ដោយចេតនា -ជាភាពពិតជាក់ស្ដែងពីររបស់កម្ពុជាប្រជាធិបតេយ្យ ។ អំពើកំណាចឃោរឃៅរបស់បណ្ដាប្រធានភូមិ និងស្រុក មុនដំបូងមានសភាពជាការប្រព្រឹត្តខុសគន្លងសុទ្ធសាធ ប៉ុន្តែ ជាអំពើដែលគេអាចស្មានដឹងមុន សម្រាប់ពលរដ្ឋទាំងអស់នៃរបបនេះ ។ ប្រជាជនទាំងអស់ចេះការពារខ្លួនបែបណាៗជាមុន ប្រឆាំងនឹងការធ្វើទោស ដែលជាក់ស្ដែងបំផុត ពួកគេចេះលាក់ដើមកំណើតរបស់ខ្លួន ប្រសិនបើគេស្ថិតនៅក្នុងត្រកូលអ្នកចេះដឹង ពួកគេចេះធ្វើ

តាមបទបញ្ជាផ្សេងៗ ដោយគ្មានថ្ងូរត្អូញត្អែរឡើយ ។ ប៉ុន្តែ គេនៅមិនដឹងពីមធ្យោបាយ ដើម្បីគេចឲ្យផុតពីកំហឹងក្រេវក្រោធដោយរបៀបណា នៅពេលដែលមជ្ឈិមចេញបញ្ជាឲ្យធ្វើការបោសសម្អាត និងការកាប់សម្លាប់ថ្មីៗទៀត ។ គេមិនដែលធ្វើអ្វីៗដោយចេញមុខទេ លើកលែងតែការឆ្លើយដោះសាពីរឿងផ្សេងៗ ដែលកើតឡើងដោយសារជំងឺមិនទុកចិត្តគេឯងទាំងអស់របស់មជ្ឈិមប៉ុណ្ណោះ ។ ហើយបញ្ហាទាំងនេះ បក្សបានធ្វើឡើងបន្ទាប់ពីបានពិចារណាមុនរួចជាស្រេច ។ ទោះបីជាពួកកម្មាភិបាលរបស់បក្ស ក៏មិនត្រូវគេផ្តល់ពត៌មានឲ្យដឹងពីរឿងនេះដែរ ។ ការបំភិតបំភ័យ ជាមធ្យោបាយដំបូងរបស់មជ្ឈិម ដើម្បីក្តោបក្តាប់ប្រជាជនឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន ។

ប៉ុន្តែ គេអាចបញ្ចេញឲ្យឃើញមាគ៌ាទូទៅមួយក្នុងការសម្លាប់រង្គាលទាំងអស់ ។ ផ្នែកសន្តិសុខរបស់បក្សដែលរៀបចំឲ្យមាននៅមន្ទីរឃុំឃាំងទួលស្លែង បានរួមបន្តជារបៀបគ្រប់គ្រងដ៏រឹងមាំបំផុតមួយ ក្នុងចំណោមរបៀបគ្រប់គ្រងដ៏រឹងមាំបំផុតរបស់កម្ពុជាប្រជាធិបតេយ្យ ។ នៅថ្នាក់ភូមិ ជាកន្លែងសម្រាប់សម្លាប់មនុស្សគ្រាន់តែជាចម្ការសាមញ្ញមួយប៉ុណ្ណោះ ។ បណ្តាកម្មាភិបាលដែលគ្រប់គ្រងដឹកនាំសហករណ៍នានា គោងតែផ្តល់ដំណឹងពីការសម្លាប់មនុស្សទៅឲ្យអ្នកកាន់អំណាចថ្នាក់លើភ្លាមៗ គឺទៅបណ្តាប្រធានឃុំ ។ ភាគច្រើននៃមនុស្សដែលត្រូវសម្លាប់ក្នុងភូមិនានា ត្រូវបានដោះស្រាយសម្រាប់មូលហេតុផ្សេងៗ «ដែលទាក់ទងទៅនឹងវិន័យ» ។ អ្នកដែលស្លាប់ទាំងនោះ សុទ្ធតែជាមនុស្សដែលហ៊ានចោទសួរពីបញ្ហាអំណាចរបស់អង្គការ ជាមនុស្សដែលពុំអាចដើរតាមបដិវត្តន៍ ដែលប្រព្រឹត្តកំហុសឆ្គងជាច្រើន ហើយធ្លាក់ទៅក្នុងប្រភេទជាពលករគ្មានប្រយោជន៍ ជាពពួកមនុស្សដែលគេច្រើនអះអាងថា : «ទុកក៏មិនចំណេញ ដកចេញក៏មិនខាត» ។

ប៉ុន្តែ ការសម្លាប់ទាំងអស់ ពុំដែលត្រូវគេរាយការណ៍ប្រាប់ថ្នាក់លើឲ្យដឹងទេ ហើយទំហំនៃការប្រហារជីវិតឥតអាសូរនេះ ក៏ប្រហែលជាមជ្ឈិមមិនដែលដឹងសោះដែរ ។ ឃុំខ្លះ ស្រុកភាគច្រើន តំបន់ និងភូមិភាគទាំងអស់ សុទ្ធតែមានគុកដាក់មនុស្សតែរៀងៗខ្លួន ។ ជាទូទៅ គេច្រើនយកសាលារៀន វត្ត ឬផ្ទះ ធ្វើជាគុក ដោយមានទីធ្លាមួយសម្រាប់ធ្វើទារុណកម្ម និងរណ្តៅមួយក្បែរនោះសម្រាប់ដាក់ខ្មោច ។ នៅមានជំរំសម្រាប់បង្ខាំងទុកមនុស្សឲ្យនៅតែមួយកន្លែងជាច្រើនទៀត ដែលពួកអ្នកទោសក្នុងនោះ ត្រូវធ្វើការដូចអ្នកស្រែចម្ការដែរ គឺមានសភាពដូចគ្នានឹងជំរំកែប្រែថ្មីបេះបិទ ។ គេអាចសន្និដ្ឋានដោយគ្មានខ្លាចភ័ន្តច្រឡំថា ជាទូទៅគុកទាំងនោះ បានយកមន្ទីរឃុំឃាំងទួលស្លែងធ្វើជាគំរូ ហើយជំរំមរណៈនានានៅតាមជនបទ បានធ្វើទារុណកម្ម និងសម្លាប់ជនទាំងឡាយណា ដែលរបបចាត់ទុកដូចជាខ្មាំងសត្រូវនៅពេលនេះ ហើយថា អ្នកស្លាប់ទាំងនោះ ក៏គេមានទុកឯកសារផ្សេងៗ ដូចនៅមន្ទីរឃុំឃាំងទួលស្លែងដែរ ។

ប៉ុន្តែ កាលបើពេលណាមួយត្រូវធូរស្រាល ការធ្វេសប្រហែសបានបណ្តាលឲ្យកើតវង្វេងពិរុទ្ធភាព និងការសប្បាយ នឹងធ្វើឲ្យអ្នកដទៃឈឺចាប់មួយ ដែលរួចផុតពីការត្រួតត្រាទាំងអស់ ។ ចំណង់សងសឹក ឬសម្លាប់តាម

ធម្មតាត្រូវបានបង្កើនរហូតទាល់តែគេសម្លាប់មនុស្សក្នុងមួយលើកៗ ដោយគ្មានចិត្តស្ទើបរំភើបបន្តិចឡើយ ។ គ្មានអ្វីមួយអាចបន្ធូរការខ្នះខ្នែងរបស់ពួកឃាតករទាំងនោះទេ ដែលនៅទីបំផុតសុទ្ធតែយល់ថ្មុយថា អ្នកណាក៏ដោយ ក៏អាចបែរក្បាលមកប្រឆាំងនឹងពួកគេវិញដែរ -ជាពិសេសបណ្ដាមេដឹកនាំបក្ស- ហើយខំប្រឹងកម្ចាត់សត្រូវផ្ទាល់របស់ខ្លួនចោលទាំងអស់ ។ ពួកគេ បានលាក់ចំនួនមនុស្សដែលគេសម្លាប់ ចំពោះថ្នាក់លើរបស់ពួកគេ ប្រហែលខ្លួនឯងផងក៏មិនដឹង ។

ប៉ុន្តែ គេអាចរាប់ឃើញចំនួនប្រជាជនកម្ពុជា ដែលត្រូវសម្លាប់រង្គាលទាំងអស់ តាមរយៈបណ្ដឹងរបស់សាក្សីម្នាក់ ដែលធ្លាប់រស់នៅភូមិភាគនិរតី[៣៨] ។ គាត់រស់នៅតំបន់១៣ ជាតំបន់មួយ ក្នុងចំណោមតំបន់ទាំងសាមសិបបី របស់ភូមិភាគនេះ ។ ដូចក្នុងទូទាំងភូមិភាគនិរតីដែរ តំបន់នេះត្រូវបាន សម្រាំងទុកដោយមជ្ឈិមសម្រាប់ប្រើប្រាស់ពួកកម្មាភិបាលនៅទីនោះក្នុងការបោសសម្អាតភូមិភាគដទៃៗទៀត ។ ប៉ុន្តែ សាក្សីនោះបាននិយាយថា ប្រជាជនកម្ពុជាប្រហែល៣៨.៤០០នាក់ ត្រូវបានគេសម្លាប់ជាផ្លូវការក្នុងតំបន់របស់គាត់ ចាប់តាំងពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៨ ។ ចំនួននេះប្រហែលជាផ្អែកតាមចិត្តរបស់អ្នកណាម្នាក់ ដូចគ្នានឹងតួលេខនៃការប្រមូលផលទាំងឡាយ ដែលពួកកម្មាភិបាលបានក្លែងបន្លំ សម្រាប់ជាឯកសារសម្រាប់អង្គការកណ្ដាល ប៉ុន្តែក្នុងន័យផ្ទុយគ្នាស្រឡះ ។ ជាទូទៅ ពួកកម្មាភិបាលទាំងនោះ ច្រើនបន្ថយចំនួនពិតនៃអ្នកស្លាប់ឲ្យតិចបំផុតនៅក្នុងរបាយការណ៍ផ្សេងៗរបស់ពួកគេ ពីព្រោះ របបនេះបានប្រកាសថា ចំនួនប្រជាជនគោងតែបង្កើនឲ្យច្រើនថែមទៀត ។ គឺទង្វើនេះហើយ ដែលធ្វើឲ្យឃើញច្បាស់លាស់ពីភាពឆ្កួតលេលារបស់របបនេះ ៖ មជ្ឈិម បានបង្គាប់បញ្ជាឲ្យគេធ្វើការបោសសម្អាតផ្សេងៗ ការសម្លាប់មនុស្ស និងការធ្វើឲ្យប្រជាជនកម្ពុជាស្លាប់ក្នុងពេលធ្វើការងារ ប៉ុន្តែមជ្ឈិម បែរជាសង្ឃឹមចង់ឲ្យប្រជាជនកើនមួយទ្វេជាពីរ ក្នុងរយៈពេលពីរទសវត្សរ៍ខាងមុខទៅវិញ ។

បើគិតឲ្យសព្វៗទៅ បញ្ជីឈ្មោះដ៏វែងនៃអ្នករងគ្រោះនៅមន្ទីរឃុំឃាំងទួលស្លែង ធ្វើឲ្យគេដឹងចំនួនអ្នកស្លាប់តិចជាងចំនួនប្រជាជនដែលគេបានសម្លាប់រៀងរាល់ឆ្នាំក្នុងទូទាំងប្រទេសទៅទៀត ។ គឺមានតែឯកសារ ដែលកម្ររកបានជាចម្លើយសារភាពផ្សេងៗប៉ុណ្ណោះ ដែលបង្ហាញឲ្យគេដឹងពីប្រវត្តិរបស់បណ្ដាសមាជិកបក្សកុម្មុយនិស្តនិងប្រវត្តិមនុស្សធម្មតាមុននិងក្រោយការបដិវត្ត ។ ឯកសារទាំងនោះ បានរៀបរាប់ពីប្រវត្តិនៃការពិភាក្សាផ្នែកនយោបាយ កលល្បិចសម្ងាត់បម្រុងបំផ្លាញគ្នាឯង និងការតស៊ូដើម្បីអំណាចផ្ទៃក្នុងបក្ស ។ ក្នុងរដ្ឋមួយដែលពឹងផ្អែកលើសន្តិសុខជាធំ ដែលបិទទ្វារប្រទេសជាតិឯងទាំងស្រុងនោះ មន្ទីរឃុំឃាំងទួលស្លែងបានក្លាយទៅជាស្ថាប័នតែមួយគត់ ដែលអាចឲ្យដឹងពីបច្ច័យដែលជាដើមហេតុផ្សេងៗ និងគំនិតគួរឲ្យព្រឺខាចបំផុតរបស់ការបដិវត្តនេះ ។

## ជំពូកទី៨
## ខ្លា និងក្រពើ

ពាក្យចចាមអារ៉ាមផ្សេងៗចាប់ផ្ដើមលេចឮនៅពាក់កណ្ដាលឆ្នាំ១៩៧៧ ។ តាមរោងចក្រនានា នៅក្រុងភ្នំពេញ ពួកអ្នកយាមបានប្រាប់កម្មករថា កងទ័ពកម្ពុជាបានត្រូវគេកេណ្ឌ និងបញ្ជូនទៅកាន់ព្រំដែន ដើម្បីវាយប្រានការវាយប្រហាររបស់វៀតណាមដែលគ្រោងទុកជាមុន ។ ក្នុងទីក្រុង យុវនារីដែលកំពុងធ្វើការក្នុងរោងចក្របន្ទុកដ៏រកៅស៊ូ ជាប់នឹងមាត់ទន្លេ បានស្ដាប់ឮគេនិយាយថា ភូមិកំណើតរបស់ពួកនៅភាគខាងកើតកម្ពុជាបានទទួលរងនូវការ វាយលុកពីសំណាក់កងទ័ពវៀតណាម ដែលបានធ្វើទារុណកម្ម និងសម្លាប់ប្រជាកសិករអស់យ៉ាងច្រើន ។ កម្មាភិបាលធ្វើការនៅទីក្រុងម្នាក់បានប្រកាសថា គាត់បានឃើញគេដឹកយុទ្ធជនខ្មែរដែលត្រូវរបួសជាច្រើន មកដាក់នៅអតីតមន្ទីរពេទ្យចិន ។

ពាក្យចចាមអារ៉ាមទាំងនេះ បានរាលដាលចេញពីទីក្រុងភ្នំពេញទៅគ្រប់ទិសទី ហើយក្នុងរវាង ម្ភៃបួនម៉ោង សេចក្ដីភ័យខ្លាចរបស់ប្រជាជនកម្ពុជាបានក៏បង្កើតជាភ្នក់ភ្លើងថ្មីមួយ គឺការឈ្លានពានមួយរបស់កងទ័ពវៀតណាម ។ ក្នុងភូមិភាគនិរតី ដែលបក្សជួយឲ្យរីកលូតលាស់ជាងគេនោះ គេបានដំណាលប្រាប់ប្រជាកសិករថាពួកវៀតណាម បានវាយប្រហារភូមិភាគបូព៌ា ពីព្រោះ ប្រជាជននៅទីនោះអត់ខ្លានរកកលដាច់ពោះស្លាប់ ហើយថា ប្រទេសវៀតណាមចង់ឆក់ប្លន់ស្រូវអង្ករបស់កម្ពុជា ។ ក្នុងភូមិភាគពាយ័ព្យ ដែលរំពើតរំពើងដោយចលាចលផ្សេងៗដំណឹងដែលនិយាយតៗគ្នា បានធ្វើឲ្យប្រជាជនកម្ពុជាដឹងថា “ពួកយួន” ដែលគួរឲ្យព្រឺខ្លាចបំផុតនោះ បានប្រុងប្រៀបខ្លួនវាយប្រហារមកលើប្រទេសកម្ពុជា ហើយរហូតដល់ស្រុកផ្សេងៗដែលនៅដាច់ស្រយាល ដំណឹងនេះបានលេចឮទៅដល់ប្រជាជនដែរ ៖ សត្រូវសួពូជប្រុងនឹងធ្វើការវាយលុកជាស្រេច

បើទោះជាពាក្យចចាមអារ៉ាមស្ដីពីសង្គ្រាម ធ្វើឲ្យភាគផ្សេងៗទៀតនៃប្រទេសភ្ញាក់ផ្អើលក៏ដោយ ក៏ពាក្យចចាមអារ៉ាមទាំងនេះ មិនបង្កឲ្យមានការងឿងឆ្ងល់ទាំងការមិនជឿ នៅក្នុងចំណោមប្រជាជនកម្ពុជា ដែលយល់ឃើញដោយខ្លួនឯង នូវការអះអាងបន្ថែមពីសញ្ញាដែលកើតមានការបារម្ភមួយ ដែលចំពោះរឿងនេះ ពួកគេធ្លាប់មានជីវិតរស់នៅតាំងពីច្រើនជំនាន់មកហើយ ។ នៅពេលដែលព្រឹត្តិការណ៍នេះ ផ្ទះរំលងកំពែងក៏ខ្ពស់នៃព្រះបរមរាជវាំង សម្ដេច ព្រះនរោត្តម សីហនុ បានទទួលស្របដោយចាត់ទុកជារឿងជៀសមិនផុតមួយ ដែលគួរឲ្យភ័យខ្លាច[១] ។ ថ្វីបើព្រះអង្គរស់នៅឆ្ងាយពីប្រជាជន និងត្រូវខ្មែរក្រហមបញ្ញត្តិឲ្យនៅតែក្នុងនិវេសនដ្ឋានក៏ដោយក៏អតីតស្ដេចអង្គនេះ នៅតែបានទទួលដំណឹងផ្សេងៗ និងពាក្យចចាមអារ៉ាមទាំងអស់តាមរយៈកងការពារព្រះអង្គផ្ទាល់ និងតាមការផ្សាយរបស់វិទ្យុបរទេស ដែលគេអនុញ្ញាតឲ្យព្រះអង្គបើកស្ដាប់បានដែរ ។

ត្រូវធ្វើឲ្យទាល់គំនិត ដោយការក្រែងរអែងពីការលុកលុយមួយ និងអ្វីដែលអាចជាសញ្ញាមិនល្អសម្រាប់

ប្រទេសកម្ពុជា សម្តេច ព្រះនរោត្តម សីហនុ បានយាងបោះជំហានទៅមកៗ ពេញព្រះរាជដំណាក់របស់ព្រះអង្គ ។ ម៉្យាង ព្រះអង្គមានព្រះរាជតម្រិះថា ពួកវៀតណាមពិតជាមានសមត្ថភាពផ្តួលរំលំរបបស្រេកឈាមខ្មែរក្រហមបាន ហើយរំដោះប្រជាជនឲ្យផុតពីសុបិន អាក្រក់មួយដែលមានរយៈពេលពីរឆ្នាំមកហើយ មួយផ្នែកទៀត ពួកនោះអាចមិនចាកចេញទៅវិញជារៀងរហូត ហើយប៉ុនប៉ងធ្វើអាណានិគមលើប្រទេសកម្ពុជា ដូចដែលពួកគេធ្លាប់បានធ្វើកាល ពីប៉ុន្មានសតវត្សរ៍មុននេះ ។ ដូចប្រជាជនកម្ពុជាភាគច្រើន សម្តេច ព្រះនរោត្តម សីហនុ មិនជឿថា លទ្ធិកុម្មុយនិស្តអាចទប់បង្អន់ នូវចេតនារបស់វៀតណាម ដែលមានរាល់តែសតវត្សរ៍មកលើប្រទេសកម្ពុជាបានទេ ផ្ទុយទៅវិញលទ្ធិនេះ បានជួយបំពេញនូវការពោលអាងថ្មីៗទៀត ចំពោះបំណងជាក់ស្តែងរបស់ប្រទេសវៀតណាម ដើម្បីក្តោបក្តាប់ប្រទេសកម្ពុជាឲ្យស្ថិតនៅក្រោមការគាំពាររបស់ខ្លួនមិនខាន ។

សម្តេច ព្រះនរោត្តម សីហនុ មានព្រះបន្ទូលថា កាលនោះ ព្រះអង្គនឹកឃើញដល់សម្តីរបស់ព្រះអយ្យកោព្រះអង្គ គឺព្រះមហាក្សត្រនរោត្តម ថា «ពាក្យទំនាញបរមបុរាណមួយ បានទាយទុកជាមុនថា នៅថ្ងៃណាមួយប្រជាជនដ៏អភ័ព្វរបស់យើង នឹងត្រូវគេបង្ខិតបង្ខំឲ្យជ្រើសរើសរវាង តើត្រូវឲ្យសត្វខ្លាខាំហែកស៊ី ឬឲ្យក្រពើលេបត្របាក់[៧] (ចុះទឹកក្រពើ ឡើងលើខ្លា)» ។

ពួកសត្វខ្លាខ្មែរក្រហម បានខាំស៊ីប្រជាជនឯងអស់រាប់លាននាក់រួចមកហើយ រួមទាំងកូនចៅផ្ទាល់របស់សម្តេច ព្រះនរោត្តម សីហនុ ជាច្រើនអង្គផង ។ ពួកសត្វក្រពើវៀតណាម នឹងលេបត្របាក់កម្ពុជា ដូចដែលពួកគេធ្លាប់ធ្វើជាមួយកម្ពុជាក្រោមទៀតឬ? ។ សម្តេច ព្រះនរោត្តម សីហនុ ដែលជាអ្នកទទួលខុសត្រូវចំពោះមហន្តរាយនៅប្រទេសកម្ពុជាមួយចំណែកយ៉ាងធំនោះ ពុំមានចម្លើយទៅនឹងគំនិតនេះទេ ។

សញ្ញាដែលឲ្យកើតមានការបារម្ភពីរឿងវៀតណាម គឺជាការប្រឌិតមួយរបស់ពួកខ្មែរក្រហម ។ ភាពមិនចុះសម្រុងគ្នា ជម្លោះផ្សេងៗដែលមិនទាន់ចេញជាក់ស្តែង មានមិនខ្វះទេរវាងក្រុងភ្នំពេញ និងក្រុងហាណូយ ហើយប្រទេសទាំងពីរ នៅតែត្រូវដោះស្រាយការទាស់ទែងគ្នាពីរឿងព្រំដែនឆ្នាំ១៩៧៥ថែមទៀត ដែលនាំទៅដល់បរាជ័យក្នុងរឿងនាវាម៉ាយ៉ាហ្គេទាំងស្រុង ។ ប្រទេសកម្ពុជាមិនព្រមជជែកពិភាក្សាពីសំណើរបស់វៀតណាម ដើម្បីរៀបចំទំនាក់ទំនងផ្សេងៗ រវាងប្រទេសទាំងពីរទេ ប៉ុន្តែ បញ្ហាទាំងអស់នេះ បានស្ថិតនៅធំក្នុងរយៈពេលច្រើនឆ្នាំតទៅទៀត ដោយមិនធ្លាយចេញទៅរកការប្រឈមមុខមួយឡើយ ។

នៅឆ្នាំ១៩៧៧ របប ប៉ុល ពត ត្រូវការសត្រូវបរទេសមួយ សម្រាប់ទម្លាក់ការទទួលខុសត្រូវ អំពីបញ្ហាធំៗដែលកំពុងធ្វើឲ្យអាប់មុខប្រទេសជាតិ ។ គេត្រូវតែសឹកបញ្ចូលក្នុងការគំរាមកំហែងនេះ នូវធាតុគ្រោះថ្នាក់មួយដែលច្បាស់ជានឹងកើតមានក្នុងពេលឆាប់ៗ ដូចពាក្យចចាមអារ៉ាមស្តីពីការទម្លាក់គ្រាប់បែកមួយរបស់អាមេរិកាំង ដែលពួកខ្មែរក្រហមបានប្រឌិតឡើង និងប្រើប្រាស់យ៉ាងមានប្រសិទ្ធិភាពបំផុត ដើម្បីជម្លៀស

ប្រជាជនចេញពីក្រុងភ្នំពេញនៅថ្ងៃជ័យជម្នះដែរ ។ ហើយគេត្រូវការតែសត្រូវដែលគេអាចជឿមួយ មិនត្រឹមតែសម្រាប់ប្រជាជនកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែ សម្រាប់ពួកមេដឹកនាំមួយចំនួន ។ ក្នុងបំណងធ្វើឲ្យឃើញថា សត្រូវនេះកំពុងគំរាមកំហែងព្រមគ្នាចំពោះបក្សផង និងប្រទេសជាតិផង គេគោងតែជ្រើសយកប្រទេសក្រៅមួយ ដែលធ្លាប់មានទំនាស់នឹងគ្នាជាហូរហែមិនចេះចប់មួយជាមួយនឹងបក្ស ក៏ដូចជាមួយប្រទេសកម្ពុជាផ្ទាល់ ។

ហេតុនេះហើយ ក្នុងកំឡុងខែដំបូងៗនៃឆ្នាំ១៩៧៧ ពួកខ្មែរក្រហមបានប្រកាន់យកនយោបាយឈ្លានពានមួយ ហើយបានវាយកាន់កាប់ទឹកដីជាច្រើនតាមព្រំប្រទល់ថៃ និងវៀតណាម ដែលជាទឹកដីត្រូវជជែករកខុសត្រូវនៅឡើយ ។ ពាក្យចចាមអារ៉ាមស្ដីពីការវាយប្រហារផ្សេងៗ បានលាន់ឮទៅដល់ភូមិភាគបស្ចិម ។ ប្រជាកសិករថៃ ដែលកំពុងរស់នៅលើទឹកដីដែលក្រុងភ្នំពេញចាត់ទុកជារបស់កម្ពុជា ត្រូវបានសម្លាប់រង្គាល ។ ប៉ុន្តែ ប្រទេសថៃពុំបានបង្កជាការគំរាមកំហែងមួយដែលអាចឲ្យគេជឿដូចប្រទេសវៀតណាមទេ ពីព្រោះពីមុនមក ពួកជនជាតិថៃ ពុំដែលចូលជ្រៀតជ្រែកក្នុងរឿងនយោបាយរបស់កុម្មុយនិស្ដកម្ពុជាឡើយ ។

ម្យ៉ាងទៀត ពួកថៃពុំមានទាំងកម្លាំងយោធា ទាំងការប្ដេជ្ញាចិត្តខ្ពស់ដូចពួកវៀតណាមទេ ។ ក្នុងរជ្ជកាលរបស់សម្ដេច ព្រះនរោត្ដម សីហនុ បានឈ្នះប្រទេសថៃឡើងវិញពីរឿងប្រាសាទព្រះវិហារ ដែលតុលាការអន្តរជាតិ ក្រុងឡាអេ (La Haye) សម្រេចវិនិច្ឆ័យថាជាសម្បត្តិវប្បធម៌របស់ប្រជាជនកម្ពុជា ។ ទាំងសម្ដេច ព្រះនរោត្ដម សីហនុ ដែលជាប់ឃុំនៅក្នុងព្រះបរមរាជវាំង ទាំងពួកមេបញ្ជាការខ្មែរក្រហម ដែលកំពុងដើរយាមល្បាតតាមព្រំដែនវៀតណាម ពុំដែលនឹកគិតពីការឈ្លានពានមយរបស់ថៃនៅពេលឆាប់ៗនេះទេ គឺពួកគេគិតតែពីការគំរាមកំហែងរបស់វៀតណាមប៉ុណ្ណោះ ។

ការវាយប្រហាររបស់វៀតណាម គឺសញ្ញាដែលឲ្យកើតមានការបារម្ភមួយក្នុងចំណោមសញ្ញាដែលឲ្យកើតមានការបារម្ភដ៏កម្រនៅឆ្នាំ១៩៧៧ ដែលអាចធ្វើឲ្យរំភើបចិត្តក្នុងចំណោមប្រជាជនកម្ពុជា ដែលមានទុក្ខសោក និងដែលអស់សង្ឃឹម ។ ក្រោយរយៈពេលពីរឆ្នាំ នៃការកាន់អំណាចរបស់ខ្មែរក្រហម និងប្រាំឆ្នាំ នៃសង្គ្រាមដ៏វិនាសហិនហោចយ៉ាងខ្លាំង ដែលមានពីមុនប្រវត្តិសាស្ត្រ និងការពិតបានច្របល់ចូលគ្នាក្នុងភាពមិនច្បាស់លាស់ទាំងស្រុងជាងមុនទៅទៀត ។ ប្រជាជនរស់នៅក្នុងសភាពឯកោ កាត់ផ្ដាច់ពីប្រភពពត៌មានពិតទាំងអស់ ។ ប្រជាជនសឹងតែគ្មានដឹងអ្វីសោះពីបណ្ដាមេដឹកនាំខ្លួន ដែលនៅតែលាក់មុខពីក្រោយរបាំង“អង្គការ”ដដែល ។ វិទ្យុរបស់រដ្ឋាភិបាល ផ្សព្វផ្សាយតែការឃោសនាមិនសមទំនងអំពីប្រទេសជាតិ និងប្រទេសមួយចំនួនតូចនៃពិភពលោកប៉ុណ្ណោះ ។

“អង្គការ” និងបណ្ដាមេដឹកនាំខ្មែរមុនៗ គឺសម្ដេច ព្រះនរោត្ដម សីហនុ និង លន់ នល់ បានបង្កើតមូលហេតុមិនសូវជាក់លាក់មួយក្នុងចិត្តរបស់ប្រជាជនកម្ពុជាដោយរួមបញ្ចូលអតីតសម្ព័ន្ធមិត្ត និងសត្រូវទាំងឡាយរបស់ប្រទេស ។ ក្នុងចំណោមនោះ មានមួយចំនួនតូចអាចនឹកឃើញពី សហរដ្ឋអាមេរិក ប្រទេសចិន ឬ វៀតណាម

ធ្លាប់ធ្វើជា«មិត្ត» ឬជា«សត្រូវ» ក្រោមរបបខុសៗគ្នារបស់កម្ពុជា ។ ក្នុងជំនាន់សព្វថ្ងៃ «ស្លាកឈ្មោះ» ទាំងនេះ បានផ្លាស់ប្ដូរជាញឹកញាប់ សម្រាប់បង្កើតឲ្យមានការមន្ទិលសង្ស័យ និងការចោទសួរផ្សេងៗ ក្នុងចំណោមប្រជាជនកម្ពុជាចេះដឹងភាគច្រើន ដែលធ្លាប់តាមដាននយោបាយរបស់ប្រទេស ។ ប្រជាជនទាំងមូលដែលត្រូវកាត់ផ្ដាច់ពីនយោបាយ នៅនឹកឃើញស្រពេចស្រពិលតែដំណើងខ្លីៗនៃនយោបាយការទូតដ៏ចម្លែករបស់សម្ដេចព្រះនរោត្ដម សីហនុ សង្គ្រាមសាសនា របស់ លន់ នល់ ប្រឆាំងនឹងពួកវៀតណាម និងការថ្កោលទោសខ្មែរក្រហមរបស់សហរដ្ឋអាមេរិក ក្នុងរយៈពេលសង្គ្រាមប៉ុណ្ណោះ ។

ក៏ប៉ុន្តែ មានប្រជាជនកម្ពុជាមួយចំនួនតូច បានភ្លេចគិតពីសេចក្ដីភ័យខ្លាចមានពិបុព្វការីមក និងយ៉ាងជ្រាលជ្រៅចំពោះពួកវៀតណាម ឬការព្រមានមិនចេះចប់ ដែលវាយតម្លៃថា ប្រជាជនខ្មែរជាពូជសាសន៍មួយចៀសមិនផុតពីទុក្ខវេទនា ។ ពួកកុម្មុយនិស្ដកម្ពុជាបានប្រើប្រាស់សេចក្ដីភ័យខ្លាចនេះ ហើយធ្វើឬកពាជាអ្នករងគ្រោះក្នុងពេលជាមួយគ្នា ។ គឺសឹងតែដោយសភាវគតិដែលពួកខ្មែរក្រហម ពួកគេចាប់ផ្ដើមបង្កើតឲ្យមានការគំរាមកំហែងមួយរបស់វៀតណាមនោះ ។ ម្យ៉ាងទៀត លន់ នល់ ធ្លាប់បានរៀបចំស្ថានភាពរួចជាស្រេចក្នុងរយៈពេលសង្គ្រាម ហើយកាលបើបានកាន់អំណាចពួកខ្មែរក្រហមពុំបានធ្វើអ្វីសោះ ដើម្បីលុបបំបាត់រូបភាពសាហាវឃោរឃៅរបស់ពួកវៀតណាមដែលមានពីយូរយារមកហើយ ចេញពីសតិអារម្មណ៍របស់ប្រជាជនខ្មែរ ។ ពួកគេពុំបានលើកទឹកចិត្តឲ្យកម្មាភិបាលផ្ទាល់ខ្លួនសំគាល់ឃើញក្នុងពួកវៀតណាម ជាបណ្ដាសមមិត្តដែលគួរឲ្យជឿទុកចិត្តឡើយ ។ បណ្ដាមេដឹកនាំខ្មែរក្រហម បានយល់ព្រមផ្ដល់នូវគុណសម្បត្តិខ្លះៗចំពោះពួកចិន ប៉ុន្តែ បានដកឃ្លាឆ្ងាយពីពួកវៀតណាមនៅការឃោសនារបស់គេ ចាប់ពីឆ្នាំ១៩៧៥ទៅ ។

ឥឡូវនេះ ដោយស្វែងរកមហាអំណាចបរទេសមួយសម្រាប់ទម្លាក់ការទទួលខុសត្រូវអំពីបញ្ហាផ្សេងៗរបស់ខ្លួន ពួកខ្មែរក្រហមបានប្រើប្រាស់ជាផលប្រយោជន៍របស់គេនូវប្រវត្តិសាហាវយង់ឃ្នងដែល លន់ នល់ ធ្លាប់ផ្សព្វផ្សាយគ្រប់ទិសទី អំពីភាពកំរោលព្រៃផ្សៃរបស់វៀតណាម ព្រមទាំងការភ័យខ្លាច ដែលបក្សផ្ទាល់ សាកពិសោធន៍ចង់ដឹងពីបំណងផ្សេងៗរបស់ប្រទេសវៀតណាមផង ។ ក្នុងពាក់កណ្ដាលទីពីរ នៃឆ្នាំ១៩៧៧ ក្រុងភ្នំពេញបានប្រកាសថា ពួកវៀតណាម បានប្រុងប្រៀបខ្លួនធ្វើសកម្មភាពអ្វីមួយ ដើម្បីសម្រេចមហិច្ឆតា ដែលមានរាប់សតវត្សរ៍មកហើយ ក្នុងការបញ្ចូលប្រទេសកម្ពុជាជាខបសម្ព័ន្ធរបស់គេ ។ ប៉ុន្តែ ខុសប្លែកពីក្រុងហាណូយដែលព្រួយបារម្ភនឹងការគំរាមកំហែងជាប្រពៃណីរបស់ពួកចិនមកលើប្រទេសវៀតណាម ពួកកម្ពុជាបានប្រព្រឹត្តជ្រុលហួសហេតុ ។ មិនត្រឹមតែពួកគេធ្វើឲ្យឈឺចាប់ឡើងវិញនូវការប្រជែងមួយ ដែលមានពីមុនមកប៉ុណ្ណោះទេ ប៉ុន្តែ ពួកគេបានវាយប្រហារទៅលើប្រទេសវៀតណាម និងរករឿងពួកវៀតណាមថា គ្មានសមត្ថភាពឆ្លៀតយកចំណេញពី«ឳកាសជាប្រវត្តិសាស្ត្រ»មួយបែបនេះបានទេ ។

ការរៀបចំប្រុងប្រៀបរបស់ពួកខ្មែរក្រហមសម្រាប់ជម្លោះព្រំដែន បានឡើងដល់ទំហំមួយខុសប្លែកពីសព្

ដង និងមានបដិវាទកម្មជាញឹកញយ ។ ដូចក្នុងករណីដ៏ទៃៗទៀតដែរដម្លោះនេះ បាននាំទៅដល់ការសម្លាប់រង្គាលយ៉ាងហួសប្រមាណមួយ ។ នេះគឺដោយសារ“ការគំរាមកំហែង”របស់វៀតណាម ដែលនៅទីបំផុត ពួកខ្មែរក្រហមបង្ហាញឲ្យឃើញជាចំហ ។ នៅខែកញ្ញា ឆ្នាំ១៩៧៧ ជាបុណ្យខួបកំណើតបក្ស ប៉ុល ពត បានប្រកាសថា ប្រទេសកម្ពុជាត្រូវបានដឹកនាំដោយបក្សកុម្មុយនិស្តកម្ពុជា ដែលមានរូបគាត់ជាមេដឹកនាំ ។ បន្ទាប់មក គាត់បានធ្វើដំណើរទៅកាន់ក្រុងប៉េកាំង និងព្យុងយ៉ាង ដើម្បីបង្ហាញខ្លួនឲ្យពិភពលោកស្គាល់ និងទាក់ទាញការយកចិត្តទុកដាក់ពីព្រឹត្តិការណ៍ផ្សេងៗ ដែលច្បាស់ជាកើតមានក្នុងពេលឆាប់ៗ ។ ឥរិយាបថនេះ បានផ្តល់នូវការពេញចិត្តចំពោះពួកចិនដែលធ្លាប់បានស្នើឲ្យក្រុងភ្នំពេញបញ្ចេញភាពច្បាស់លាស់ និងចាប់ផ្តើមធ្វើឲ្យរូបភាពរបស់ខ្លួនក្នុងពិភពលោកប្រសើរជាងមុនផង ជាពិសេស បើសិនជាពួកខ្មែរក្រហមត្រៀមខ្លួនវាយប្រហារទៅលើពួកវៀតណាមនោះ ។

នៅក្នុងប្រទេស របបនេះបានសម្រេចធ្វើការផ្លាស់ប្តូរទាំងស្រុងមួយ ឬកែប្រែមគិណែនាំផ្សេងៗ កាលពីឆ្នាំមុនដើម្បីល្បងជៀសឲ្យផុតពីមហន្តរាយផ្នែកសេដ្ឋកិច្ច និងលើកទឹកចិត្តប្រជាជនកម្ពុជា សម្រាប់សង្គ្រាមមួយដែលច្បាស់ជានឹងមកដល់ក្នុងពេលឆាប់ៗ ។ មជ្ឈិម បានបង្គាប់ បញ្ជាឲ្យមាន “ការធ្វើឲ្យមានសេរីភាពជាងមុន” មួយ អំពីពេលម៉ោងធ្វើការងារ ការបែងចែកស្បៀងអាហារ អំពីលំដាប់តំណែងរបស់សហករណ៍នានា និងរបៀបគ្រប់គ្រង ដែលអនុញ្ញាតឲ្យចាប់ចងមនុស្សទាំងអស់ ដែលគេសង្ស័យពីអំពើក្បត់ ។ ប៉ុន្តែ ការផ្លាស់ប្តូរទាំងនេះអាចលេចឡើងឲ្យឃើញ“មានសេរីភាព”តែក្នុងសង្គមតឹងរ៉ឹងមួយ ដូចគ្នានឹងកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះ ។

ពីចុងឆ្នាំ១៩៧៧ ដល់ចុងឆ្នាំ១៩៧៨ ដោយមានកំហុសក្នុងការវិនិច្ឆ័យ ឬដោយភាពស្ពឹកស្រពន់ ពួកខ្មែរក្រហមបានធ្វើឲ្យជម្លោះព្រំដែនមានកម្រិតកំណត់ និងមានប្រយោជន៍មួយជាមួយប្រទេសវៀតណាម ទៅជាសង្គ្រាមកម្រិតធំមួយជាពិសេស ដោយប្រកាសថា មានតែសង្គ្រាមទូទៅមួយប៉ុណ្ណោះ ដែលអាចបន្សាត់ការគំរាមកំហែងរបស់វៀតណាមបាន ។ ពួកគេបានធ្វើឲ្យឃើញច្បាស់លាស់នូវអ្វីៗដែលជាការភ័យខ្លាចបំផុត របស់ប្រទេសកម្ពុជា ។ ពួកខ្មែរក្រហម បានបង្កឲ្យមានជម្លោះព្រំដែនមួយ ដើម្បីអាចធ្វើឲ្យប្រទេសវៀតណាមទទួលខុសត្រូវអំពីបញ្ហាផ្សេងៗរបស់ពួកគេ ហើយបង្ហាញខ្លួនឡើងជាអ្នកជាតិនិយមប្តូរផ្តាច់ និងជាអ្នកសង្គ្រោះប្រទេសកម្ពុជា ។ ជាជំនួសប្រការនោះ ពួកគេបង្ហាញខ្លួនឡើងជា មនុស្សដែលបាត់បង់អស់នូវស្មារតីទទួលខុសត្រូវខ្លាំងពេក ដើម្បីគ្រប់គ្រងសង្គ្រាម ហើយលេចឡើងដូចជាពួកក្បត់ជាតិពេញធឹង ដែលជំរុញឲ្យពួកវៀតណាមចូលលុកលុយប្រទេសកម្ពុជា និងវាយដណ្តើមកាន់កាប់ដោយកម្លាំងទ័ពថែមទៀត ។

កាលពីមុន ពួកកុម្មុយនិស្តបានបំផ្លាញសង្គមជាតិឯងក្នុងគោលបំណងស្រោចស្រង់សង្គមឡើងវិញ ពួកគេបានបង្កើតសង្គមជាថ្មី បន្ទាប់មកពួកគេសម្លាប់“សត្រូវ”យ៉ាងរង្គាល ដើម្បីការពារទស្សនៈបដិវត្តរបស់ខ្លួន ។ ឥឡូវនេះ ពួកគេបានប្រលែងលេងជាមួយជោគវាសនារបស់ប្រទេសជាតិទាំងមូល ក្នុងគោលបំណងការពារប្រទេសឡើងវិញទៀត ដែលតាមពិត គឺពួកគេកំពុងរត់ទៅរកគ្រោះមហន្តរាយយ៉ាងធំ ។

បញ្ហាមួយផ្នែកតូចដែលធ្វើឲ្យពួកមេដឹកនាំក្រុងភ្នំពេញខ្វល់ព្រួយ បានរលាយបាត់នៅពាក់កណ្ដាលឆ្នាំ ១៩៧៧ ។ ស្ថិតិផ្សេងៗ[៣]ស្ដីពីការប្រមូលផលស្រូវបានបង្ហាញឲ្យឃើញថា ផលិតផលស្រូវមានសភាពល្អប្រសើរជាងបណ្ដាឆ្នាំមុនៗ -ឆ្នាំ១៩៧៦ ៖ ១.៩០០.០០តោន, ឆ្នាំ១៩៧៧ ៖ ២.៧០០.០០០តោន ដូច្នេះគេត្រូវបង្កើនបរិមាណផលស្រូវឲ្យបានមួយទ្វេជាពីរ ទុកទំនុកបម្រុងសម្រាប់ការបរិភោគ ។ ប៉ុន្តែ គេអាចមិនជឿតួលេខទាំងនេះថាពិតដែរ ។ សហករណ៍នានា ត្រូវតែបញ្ជូនរបាយការណ៍ផ្សេងៗ ទៅថ្នាក់លើរបស់ពួកគេរៀងរាល់ដប់ថ្ងៃម្ដង ហើយបានដឹងយ៉ាងរហ័សថា សហករណ៍ខ្លួនមុខជានឹងត្រូវទទួលកម្ម បើសិនជារបាយការណ៍ទាំងនោះពុំស៊ីគ្នានឹងការគ្រោងទុកជាមុនរបស់មជ្ឈិម ។

ប្រជាជនកម្ពុជាដែលខំប្រឹងប្រែងធ្វើការដូចពួកទាសករ ដើម្បីស្ទូងស្រូវ ពុំបានទទួលលទ្ធផលពីការប្រឹងប្រែងរបស់ខ្លួននេះឡើយ ។ ពិតហើយ មិនត្រឹមតែផលស្រូវមានបរិមាណទាបជាងតួលេខរបស់មជ្ឈិមប៉ុណ្ណោះទេ ប៉ុន្តែ មជ្ឈិមនៅបានប្រមូលយកស្រូវមួយភាគរឹតតែច្រើនឡើងៗគ្មានឈប់ឈរ សម្រាប់ចិញ្ចឹមកងទ័ព ចិញ្ចឹមភូមិភាគដទៃទៀត ដែលកំពុងជួបប្រទះការអត់ឃ្លានយ៉ាងសម្បើម ហើយតាមរដ្ឋាភិបាលឲ្យដឹងថា ស្រូវនោះសម្រាប់នាំចេញទៅប្រទេសចិន សិង្ហបុរី និងអាហ្វ្រិកមួយចំនួន ។ ម្យ៉ាងទៀត ប្រហែលនៅពាក់កណ្ដាលឆ្នាំ ១៩៧៧ ពួកមេដឹកនាំបានផ្ដល់ព័ត៌មានទៅគ្រប់ភូមិភាគថា ត្រូវតែអនុវត្តន៍តាមមគិណែនាំដែលមានពីមុន ដោយតម្រូវឲ្យមានការហូបបាយរួមទាំងអស់ ជាវិធានការដែលកាត់បន្ថយបរិមាណស្បៀងអាហារបម្រុងទុកសម្រាប់ប្រជាជនថែមទៀត ។

ហេតុនេះ ប្រជាជនមានសភាពកាន់តែខ្សោយទៅៗ ឆាប់រងទទួលជំងឺផ្សេងៗ និងកាន់តែត្រូវធ្វើឲ្យខូចទឹកចិត្តខ្លាំងឡើងៗដោយសារការបដិវត្តន៍ នៅពេលដែលមជ្ឈិមបន្ទាប់បញ្ជានៅខែកក្កដា ឆ្នាំ១៩៧៧ ឲ្យពួកគេបញ្ចេញការប្រឹងប្រែងធ្វើការជាថ្មីទៀតនោះ ។ ដោយសំអាងលើតួលេខដែលសរសេរដោយអំណាចចិត្តមនុស្សម្នាក់ និងប្រកបដោយសុទិដ្ឋិយមស្ដីពីផលិតផលកសិកម្មនោះ មជ្ឈិមបានប្រកាសថា ប្រទេសកម្ពុជាមានស្បៀងអាហារអាចខបត្តម្ភខ្លួនដោយខ្លួនឯងបានហើយៗ ត្រៀមខ្លួនសម្រាប់ការអភិវឌ្ឍន៍ដំណាក់កាលទីពីរជាស្រេច គឺការកសាងកសិកម្មទំនើបមួយ ។ ប្រជាជនបានក្លាយទៅជាម្ចាស់លើទឹក ដោយសារការបង្កើតប្រព័ន្ធធារាសាស្ត្រថ្មីៗ ។ មូលដ្ឋានរបស់បដិវត្តត្រូវបានប្រកាសថា មានស្ថិរភាពលើវិស័យសេដ្ឋកិច្ច និងនយោបាយ ដែលជាវិស័យពីរ ដែលមិនអាចបំបែកចេញពីគ្នាបានក្នុងចិត្តគំនិតរបស់ពួកមេដឹកនាំ ។

ផែនការបួនឆ្នាំថ្មី[៤] បានគ្រោងឲ្យសហករណ៍នានាបោះបង់ប្រភពធនធានផ្សេងៗ ដែលនឹងត្រូវបង្កើនមធ្យោបាយផលិតកម្មក្នុងកសិដ្ឋាន និងចម្ការធំៗរបស់រដ្ឋ ហើយដែលផលិតផលនឹងត្រូវទុកសម្រាប់រោងចក្រកែច្នៃម្ហូបអាហារពីកសិផលដែលទើបបង្កើតថ្មី ។ ផែនការនេះ សង្កត់ធ្ងន់ទៅលើរោងចក្រចម្រាញ់ស្ករស, រោងចក្រតម្បាញ, រោងចក្រធ្វើកែវនិងរោងចក្រស៊ីម៉ង់ត៍, រោងចក្រក្រចៅ កៅស៊ូ និងក្ដារបន្ទះ ។ កសិដ្ឋាន និងចម្ការធំៗ

របស់រដ្ឋបានត្រូវរៀបចំឡើងនៅដើមឆ្នាំ១៩៧៦ ដោយប្រើប្រាស់កងចល័តយុវជន ។ ប៉ុន្តែ ផលិតផលនៃឧស្សាហូបនីយកម្មនេះ សម្រាប់តែការនាំចេញប៉ុណ្ណោះ ដែលបំបាត់ចោលជាថ្មីនូវផ្លែផ្កានៃការប្រើងប្រែងរបស់ប្រជាជនទៀត ។ កៅស៊ូ ក្របៅ និងសំឡីក បានក្លាយទៅជាផលិតផលសំខាន់ក្នុងការនាំចេញ ដើម្បីជួយបំពេញហឹបប្រាក់របស់រដ្ឋាភិបាលដែលគ្មានមួយសេនសោះ ។

នេះគឺជាដំណើរប្រែពីល្អទៅអាក្រក់មួយនៃ«ភាពឯករាជ្យម្ចាស់ការ» ដែលពួកខ្មែរក្រហមធ្វើជាគ្រឹះសីលធម៌ និងសេដ្ឋកិច្ចរបស់បដិវត្តគេ ។ ភាពឯករាជ្យម្ចាស់ការនេះ គឺជាពាក្យភូតកុហកមួយ ពីព្រោះ បើគ្មានជំនួយរបស់ចិន ក៏កម្ពុជាប្រជាធិបតេយ្យពុំអាចស្ថិតស្ថេរបានយូរដែរ ។ របបនេះបានប្រើប្រាស់ប្រជាជនផ្ទាល់របស់ខ្លួន ដោយចាត់ទុកជាហត្ថពលករមួយដែលមានតម្លៃឈ្នួលថោក ហើយបានលក់ផលិតផលរបស់ខ្លួនទៅឲ្យពួកចិន ដោយគ្មានផ្ដល់ផលកម្រៃមកវិញសោះ ។ ត្រង់កន្លែងដែលថា រកឲ្យបានពីបរទេសនូវផលិតផល ដែលប្រទេសជាតិត្រូវការ និងប្រមូលផ្ដុំការយកចិត្តទុកដាក់លើផលិតផលក្នុងស្រុក ពួកកុម្មុយនិស្តបានបង្ខំឲ្យប្រជាជនកម្ពុជាធ្វើដោយដៃផ្ទាល់នូវអ្វីដែលមានលក្ខណៈចាំបាច់សម្រាប់គេ ។ បន្ទាប់មក ពួកមេដឹកនាំបានកាត់យកផលិតផលណាដែលល្អលើសគេ ហើយធ្វើការនាំចេញដោយបញ្ចុះតម្លៃទៀត ។ នេះពុំមែនជានយោបាយខ្លួនឧបត្ថម្ភខ្លួនដោយខ្លួនឯងទេ ប៉ុន្តែ គឺជាការបំផ្លាញខ្លួនដោយខ្លួនឯង ។

នៅឆ្នាំ១៩៧៧ រដ្ឋាភិបាលបានដាក់ឲ្យអនុវត្តនូវពេលម៉ោងធ្វើការមួយក្នុងទូទាំងប្រទេស ដោយអះអាងឲ្យឈប់សម្រាកបីថ្ងៃក្នុងមួយខែ ។ សហករណ៍ជាច្រើនពុំយកចិត្តទុកដាក់មតិណែនាំនេះទេ ហើយបានប្រើប្រាស់ថ្ងៃឈប់សម្រាកសម្រាប់ធ្វើការប្រជុំ«រៀនសូត្រនយោបាយ» ដោយផ្ដោតទៅលើកាលវិភាគរដូវច្រូតកាត់ និងភាគរយដែលត្រូវបានទៅវិញ ហើយក្នុងកំឡុងនៃការប្រជុំទាំងនោះ គេចាត់ចែងឲ្យធ្វើការទិតៀន ។ តាមការពិតពេលម៉ោងធ្វើការនៅតែធ្ងន់ធ្ងរ និងតឹងរ៉ឹងដដែល ។

ដោយគ្មាននិយាយរឿងអ្វីក្រៅពីនេះ ពួកខ្មែរក្រហមនៅតែមានបុរេនិច្ឆ័យផ្សេងៗ(ការវិនិច្ឆ័យដោយគ្មានគិតពិចារណា) ចំពោះ«វណ្ណៈគហបតីក្រុង» ដែលពួកគេធ្លាប់មាក់ងាយ ។ ការប្រព្រឹត្តរបស់គេជារបៀបបកស្រាយថ្មីមួយនូវគំនិតចាស់គំរិលរបស់អាណានិគមបារាំង ដែលតាមរយៈនេះប្រជាកសិករកម្ពុជាដែលខ្ជិលច្រអូសអាចសម្រេចឡើងបេះផ្លែផ្កា នៅលើដើមឈើទាំងឡាយដែលគ្រប់គ្រាន់សម្រាប់រស់នៅ ហើយមិនព្រមធ្វើការដោយម៉ឺងម៉ាត់ និងដើរទៅមុខតាមដែលអាចសម្រេចធ្វើបាន ដើម្បីនឹងឲ្យប្រទេសកម្ពុជាទំនើបទាន់សម័យ ។ ពួកកុម្មុយនិស្តបានរិះគន់ប្រព័ន្ធគ្រប់គ្រងចាស់ ពីព្រោះ បានអនុញ្ញាតឲ្យស្រីៗស្ថិតនៅតែក្នុងផ្ទះ និងឲ្យពួកវ័យជំទង់រៀនសូត្រយកចំណេះវិជ្ជា ដោយគ្មានបានអ្វីសម្រាប់ចិញ្ចឹមជីវិតឡើយ ។ ដួន ប្រសិទ្ធិ អ្នកនាំពាក្យនៃក្រសួងការបរទេស បានសង្ខេបការដឹកនាំនេះថា "ក្នុងសង្គមចាស់ ប្រជាកសិករធ្វើស្រែចម្ការក្នុងមួយឆ្នាំ តែបី បួនខែប៉ុណ្ណោះ ជាមួយនឹងក្របី ២ក្បាល ហើយទទួលផលស្រូវបាន ប្រាំតោន ។ ឥឡូវនេះ ជាមួយនឹងសហករណ៍នានា

យើងបានរៀបចំធ្វើយ៉ាងណាឲ្យទាល់តែពួកគេអាចធ្វើការពេញៗមួយឆ្នាំបាន...។ ក្នុងសង្គមចាស់ ស្រីៗស្ថិតនៅតែក្នុងផ្ទះ មានតែប្ដីម្នាក់ប៉ុណ្ណោះដែលធ្វើការ ។ ឥឡូវនេះ មនុស្សទាំងអស់បានចេញទៅធ្វើការគ្រប់ៗគ្នា ជាពិសេស ពួកយុវជនដែលកាលពីដើមគ្មានធ្វើអ្វីក្រៅតែពីដើររាំ និងស៊ីផុះនោះឡើយ[៥]» ។

មានតែអតីតសមាជិកវណ្ណៈអភិជនដូចជាប្រសិទ្ធិម្នាក់ប៉ុណ្ណោះដែលជឿថា ប្រជាកសិករ មិនធ្វើការងារទេក្រោមរបបចាស់ ហើយថាការដែលគាត់ចិញ្ចឹមគ្រួសារមួយ ឃុំគ្រងវង្សត្រកូលមួយ និងចូលរួមធ្វើកិច្ចការច្រើនលើសលប់ក្នុងការរស់នៅជនបទ គឺពុំមែន«ធ្វើការងារ»ទេ ។ ភាគច្រើននៃយុវជន ក៏មិនធ្វើឲ្យបាត់បង់ពេលវេលារបស់គេដោយមិនធ្វើអ្វីសោះដែរ ជាពិសេសនៅស្រុកស្រែចម្ការ ពេលដែលពួកគេបោះបង់សាលាឆាប់ជាងអ្នកឯទៀត ដើម្បីជួយធ្វើការងារស្រែចម្ការរបស់គ្រួសារគេ ។

វាជារឿងឥតន័យទាំងស្រុង ដែលវិនិច្ឆ័យពីការអប់រំទំនើបឥតប្រយោជន៍ ក្នុងដំណើរលោតផ្លោះរបស់ប្រទេសកម្ពុជាឆ្ពោះទៅរកការអភិវឌ្ឍន៍ និងការធ្វើទំនើបកម្ម ។ ទស្សនៈនេះ មានឫសគល់មនោគមវិជ្ជានៅប្រទេសចិន និងបង្កើតរបៀបសម្ដែងចេញរបស់ខ្លួនយ៉ាងពេញលេញក្នុងការតម្កើងភាពអវិជ្ជារបស់ការបដិវត្តន៍វប្បធម៌ ។ ប៉ុន្តែ នៅឆ្នាំ១៩៧៧ របបនេះមានមូលហេតុមួយ ក្នុងការបិទសាលារៀនទាំងអស់ និងបញ្ជូនពួកយុវជនទៅធ្វើការតាមស្រែ កងទ័ព និងមន្ទីរក្រសួងផ្សេងៗ ។ គេលែងសូវទុកចិត្តមនុស្សវ័យកណ្ដាលទៀតហើយ ហើយការបោសសម្អាតទាំងឡាយច្រើនតែសម្លាប់រង្គាលពួកកម្មាភិបាលវ័យចាស់ៗចោល ។ ហេតុនេះហើយ ពួកមេដឹកនាំបានបែរមករកពួកយុវជនកម្ពុជាជានិច្ច ដើម្បីឲ្យក្ដោបក្ដាប់ការបដិវត្តន៍របស់គេ ។ ហើយប្រសិទ្ធិបានអួតខ្លួនថា «អស់លោកអាចកត់សម្គាល់ថា យុទ្ធជនបដិវត្តន៍ទាំងអស់ សុទ្ធតែមានវ័យក្មេង... ការបដិវត្តន៍បង្កើតបានជំនាន់ថ្មីមួយហើយ[៦]» ។

«យុវជនបដិវត្តន៍» មានវ័យកាន់តែក្មេងទៅៗ ។ នៅខែកក្កដា ឆ្នាំ១៩៧៧ ក្រោយពេលដែលរបបនេះប្រកាសជឿទុកចិត្តចំពោះ មូលដ្ឋានបដិវត្តរឹងមាំពិតប្រាកដហើយនោះ បក្សបានចាប់ផ្ដើមជ្រើសរើសមនុស្សថ្មីៗថែមទៀត ដែលសុទ្ធតែមានវ័យជំទង់ស្ទើរតែទាំងអស់ ។

ក្នុងពេលជាមួយគ្នានោះ ពួកមេដឹកនាំបានផ្លាស់ប្ដូរយុទ្ធវិធី និងគោលដៅទាំងឡាយដែលត្រូវវាយប្រហារដែរ ។ មជ្ឈិមខំប្រឹងបញ្ចប់ «ការតស៊ូវណ្ណៈ» ក្នុងផ្នែសហករណ៍នានាដែលនាំមកនូវការច្របូកច្របល់ ការបង្ហូរឈាមជាច្រើន ព្រោះវារបូតផុតពីការគ្រប់គ្រងរបស់របប និងការធ្លាក់ចុះយ៉ាងខ្លាំងមួយផ្នែកផលិតផល ។ ឥឡូវនេះ មជ្ឈិមបានរៀបចំកម្លាំងរបស់ខ្លួនទាំងអស់ពីក្រោយការតាមស្វែងរកនិងការកម្ចាត់បក្សពួកប្រឆាំងផ្នែកនយោបាយដែលមាននៅក្នុងផ្ទៃបក្សផ្ទាល់ និងក្នុងជួរពួកអ្នកធ្វើការតាមមន្ទីរក្រសួងនានា ។ ក្រុងភ្នំពេញដែលរៀបចំខ្លួនក្នុងជម្លោះព្រំដែនមួយជាមួយប្រទេសវៀតណាម ពុំចង់រក្សាទុកមនុស្សក្បត់ណាម្នាក់ឲ្យកាន់តំណែងសំខាន់ៗឡើយ ។ នៅទីបំផុត ក្រុមសន្តិសុខ បានប្រមូលផ្ដុំកិច្ចប្រឹងប្រែងយ៉ាងខ្ជាប់ខ្ជួនរបស់ពួកគេ ទៅលើ

ភូមិភាគបូព៌ា ដែលសង្គ្រាមនឹងប្រព្រឹត្តទៅនៅទីនោះ ហើយដែលពួកក្បត់នឹងទៅជាមនុស្សដែលផ្ដល់មហន្តរាយដាំងគេ ។

គណៈលេខានៃគណៈកម្មាធិការមជ្ឈិមបក្សបានកុហកដោយដឹងខ្លួនចំពោះខ្លួនឯងផ្ទាល់ ឬពន្លិចខ្លួនយ៉ាងជ្រៅទៅក្នុងគំនិតសុទិដ្ឋិនិយមដែលគ្មានមូលដ្ឋានថា បណ្ដាសមាជិករបស់ខ្លួនមានជំនឿចំពោះអ្វី ដែលពួកគេបានអះអាងកាលដែលពួកគេប្រកាសនៅខែកក្កដា ឆ្នាំ១៩៧៧ ថា ការបដិវត្តមានមូលដ្ឋានរឹងមាំពិតប្រាកដនោះ ។ ទុកជាយ៉ាងណាក៏ដោយ មូលដ្ឋានគ្រឹះទាំងនោះបានប្រេះស្រាំអស់ទៅហើយ ។ ពួកខ្មែរក្រហមមានប្រជាជនប្រហែលរវាង ដប់ប្រាំទៅម្ភៃភាគរយប៉ុណ្ណោះ ដែលនៅពីក្រោយពួកគេជាសំខាន់ គឺពួកកសិករក្រ និងពួកយុវជន ។ ប៉ុន្តែនៅពេលនេះ “ពួកអ្នកចាស់” មួយចំនួនធំដែលនឹកស្មានថា អាចទាញយកអត្ថប្រយោជន៍ពីការបដិវត្តក៏អស់សង្ឃឹមដែរ ។ ការប្រើប្រាស់ស្បៀងអាហារបានថយចុះ ។ នៅពេលដែលការបោសសម្អាតថ្នាក់ភូមិភាគ ចាប់ផ្ដើមឆ្លាយពីម្ខាងទៅម្ខាងទៀតនៃប្រទេស “ពួកអ្នកចាស់” បានចាប់ព្រួយបារម្ភពីជីវិតផ្ទាល់របស់គេដែរ ។

ដូចដែលការបោសសម្អាតភូមិភាគពាយ័ព្យបង្ហាញឲ្យឃើញស្រាប់ នៅឆ្នាំ១៩៧៧ “ពួកអ្នកចាស់” បានក្លាយទៅជាអ្នកដែលត្រូវគេសង្ស័យខ្លាំងជាង “ពួកអ្នកថ្មី” ទៅទៀត ។ “ពួកអ្នកចាស់” ត្រូវបានសម្លាប់ ឬបាត់បង់មុខតំណែង និងសិទ្ធិពិសេសៗរបស់ពួកគេក្នុងក្របខ័ណ្ឌនៃការផ្លាស់ប្ដូរជាច្រើនលើក ។ ក្រុមគ្រួសាររបស់អ្នកទាំងនោះ ក៏ក្លាយទៅជាអ្នកដែលត្រូវគេសង្ស័យដូចគ្នា ហើយត្រូវប្រឈមមុខនឹងការសងសឹកទៅថ្ងៃមុខថែមទៀត ។ គឺប្រហែលនៅជំនាន់នេះដែរ ដែលគណៈលេខាមជ្ឈិមបក្សបង្កើតឲ្យមាននយោបាយថ្មីមួយ “ដែលទូលាយជាងមុន” ក្នុងនាទីនៃការប្រហារជីវិតមនុស្ស ។ កាលពីមុន ការចោទប្រកាន់ចំនួន ពីអំពើក្បត់ចំនួនបី ល្មមគ្រប់គ្រាន់ឲ្យគេចាប់បញ្ជូនមនុស្សម្នាក់ទៅដាក់គុក ឬសម្លាប់ ដាក់ជាប្រាកដ ។ អំណឹះតទៅ គេត្រូវការពាក្យចោទប្ដឹងចំនួនប្រាំទើបយកជាការបាន នេះជាវិធានការដែល អៀង សារី យល់ឃើញថា “មានមនុស្សធម៌” ជាងមុន ។

នៅពេលដែលទីដៅវាយប្រហារផ្លាស់ប្ដូរ ការបោសសម្អាតទាំងឡាយ ចេះតែបន្តទៅមុខគ្មានឈប់ឈរ និងកាន់តែឃោរឃៅឡើងៗ ។ នៅខែសីហា ឆ្នាំ១៩៧៧ នៅពេលដែលមជ្ឈិម វិនិច្ឆ័យការរួមគំនិតក្បត់មួយ ដែលមានតាំងពីយូរមកហើយ ហើយដែលដឹកនាំបំផ្លាញការបដិវត្តដោយសម្ងាត់ បក្សបានចាប់ខ្លួនមេដឹកនាំជាន់ខ្ពស់ជាច្រើននាក់ ដែលកាន់កាប់មុខតំណែងផ្សេងៗ ជាមុខតំណែងដែលអនុញ្ញាតឲ្យគេរៀបចំគម្រោងការបែបនោះបាន ។

កាលពីមុន មជ្ឈិមបានកម្ចាត់បណ្ដាមេដឹកនាំជាន់ខ្ពស់ជាបញ្ញវន្ត និងមានប្រភពដើមជាវណ្ណៈគហបតី ដូចជា កុយ ធួន មេដឹកនាំភូមិភាគឧត្ដរ ខែក ប៉ែន កម្មាភិបាលដឹកនាំភូមិភាគពាយ័ព្យ និង ហ៊ូ នឹម រដ្ឋមន្ត្រីឃោសនាការជាដើម ។ អ្នកទាំងអស់នេះ ត្រូវបានចោទប្រកាន់ពីបទធ្វើការឲ្យពួកសេ.អ៊ី.អា. (ក្នុងករណីខ្លះ ការចោទប្រកាន់

ផ្សេងៗ ត្រូវបានកែប្រែជាបន្តបន្ទាប់ដើម្បីដាក់បញ្ចូលរឿងធ្វើចារកម្មបម្រើឲ្យពួកវៀតណាមក៏មាន) ។ ប៉ុន្តែការសម្លាប់ កែវ មាស សមាជិកដ៏មានឥទ្ធិពលរបស់បក្ស ដែលចូលឡូកឡំក្នុងការទាស់ទែងគ្នាពីរឿងកាលបរិច្ឆេទនៃការបង្កើតបក្សនោះ គឺជាសញ្ញាប្រាប់ឲ្យដឹងពីការបោសសម្អាតជាច្រើននៅចុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ ។ ប្រទេសវៀតណាម បានជំនួសសហរដ្ឋអាមេរិក ក្នុងតួនាទីជាមហាអំណាចបរទេសមួយ ដែលគ្រប់គ្រងដឹកនាំខ្សែបណ្ដាញចារកិច្ចជាច្រើន ។

រហូតមកដល់ខែកក្កដា ឆ្នាំ១៩៧៧ ភូមិភាគបូព៌ារបស់ សោ ភឹម ប្រហែលជាភូមិភាគមួយក្នុងចំណោមភូមិភាគពីរ ដែលធ្លាប់ជួយឲ្យប្រទេសជាតិរីកចម្រើនខ្លាំងជាងគេ[៧] ។ ដោយភូមិភាគនិរតីរួចផុតពី "ជំងឺមិនទុកចិត្តគេឯង" របស់ មជ្ឈិម ភូមិភាគបូព៌ា ក៏ខំការពារការជ្រៀតជ្រែកគ្រប់បែបយ៉ាងរបស់ មជ្ឈិម ដែរ ។ ភឹម បានទទួលឯកសិទ្ធិនេះ ដោយគាត់សុខចិត្តធ្វើតាមមតិណែនាំទាំងឡាយផ្នែកនយោបាយ និងការទាមទារផ្សេងៗរបស់មជ្ឈិម - ដោយការទើសទាល់ចិត្ត ឬដោយសេចក្ដីស្រើបចិត្តក៏មិនដឹងប៉ុន្តែគេមិនសូវដឹងរឿងនេះទេ ។ ក៏ប៉ុន្តែអ្វីដែលជាការប្រព្រឹត្តផ្សេងៗរបស់គាត់ បានបង្ហាញប្រាប់យ៉ាងជាក់ច្បាស់ថា គាត់ជាមនុស្សពូកែប្រើល្បិចកលម្នាក់ ដូចម៉ាគីយ៉ាវែល (Machiavel) (អ្នកនយោបាយប្រកបដោយល្បិចកលគ្រប់បែបយ៉ាង ដើម្បីសម្រេចផលប្រយោជន៍ផ្សេងៗ) ដែលអនុញ្ញាតឲ្យគាត់បានរស់រានជីវិតរហូតមកដល់ឆ្នាំ១៩៧៧ ។

កំហុសដែលនាំមកនូវក្ដីវិនាសរបស់គាត់ គឺមកពីគាត់មិនពិនិត្យមើលរឿងជាក់ស្ដែងដែលកើតឡើង ៖ គាត់បានបញ្ចូលខ្លួនទៅក្នុងប្រព័ន្ធគ្រប់គ្រងខ្លាំងពេក ព្រោះតែគាត់នឹកក្នុងចិត្តថា អ្នកណាក៏អាចបែរក្បាលប្រឆាំងនឹងគាត់វិញបានដែរ ឬដើម្បីឲ្យបានដឹងជាមុននូវសញ្ញាផ្សេងៗ ពេលណាដែលមានព្រឹត្តិការណ៍អ្វីមួយកើតឡើងចំពោះរូបគាត់ ។ ជាបក្ខជនដើងចាស់ម្នាក់របស់បក្ស ដែលធ្លាប់មាន បទពិសោធន៍ ជាសមាជិកគណៈលេខាមជ្ឈិមតាំងពីឆ្នាំ១៩៦៣ និងជាលេខាបក្សភូមិភាគបូព៌ា តាំងពីការបង្កើតភូមិភាគ នេះនៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ។

សោ ភឹម ជាអ្នកបង្កើតកងទ័ពដែលល្បីល្បាញបំផុតនៅភូមិភាគបូព៌ាដោយខ្លួនគាត់ផ្ទាល់ ។ គាត់បានសម្រេចចិត្តដឹកនាំធ្វើការតស៊ូដោយអាវុធនៅឆ្នាំ១៩៦៨ ថ្វីបើមានការបដិសេធពីសំណាក់ពួកវៀតណាម មិនព្រមផ្ដល់អាវុធដែលកងទ័ពរបស់គាត់កំពុងត្រូវការយ៉ាងខ្លាំងក៏ដោយ ។ តាមគេនិយាយថា ទោះបីជាគាត់មិនដែលភ្លេចពីការបដិសេធរបៀបទ្រគោះបោះបោករបស់ពួកវៀតណាមសោះក៏ដោយ ក៏គាត់នៅតែថែរក្សាទំនាក់ទំនងផ្សេងៗយ៉ាងល្អជាមួយពួកនោះដដែល ។ នៅឆ្នាំ១៩៦៩ គាត់បានប្រើប្រាស់ទឹកដីរបស់វៀតណាម ដើម្បីលាក់ខ្លួន និងប្រមូលផ្តុំកងទ័ពរបស់គាត់ឡើងវិញ ។ នៅឆ្នាំ១៩៧០ នៅពេលដែលពួកវៀតណាមទន្ទ្រានចូលមកក្នុងទឹកដីកម្ពុជាទាំងហ្វូងៗនោះ សោ ភឹម និងកងទ័ពរបស់គាត់ បានវាយប្រយុទ្ធប្រកៀកស្មា ជាមួយនឹងពួកនោះដែរ ។

ជាមួយពួកវៀតណាម ភឹម បានបង្ហាញឲ្យឃើញថា គាត់ជាអ្នកចរចាដ៏ចំណានម្នាក់ ដោយមិន ដែលយល់

ព្រមតាមសំណើរបស់វៀតណាម ដើម្បីបង្កើតបញ្ជាការដ្ឋានចម្រុះរវាងកងទ័ពវៀតណាម និងខ្មែរទាល់តែសោះ ។ ភឹម បេះឆ្មៀតទាញយកប្រយោជន៍ភ្លាមៗមួយ ពីស្ថានភាពដែលកងទ័ពក្រុងហាណូយ កំពុងធ្វើការប្រយុទ្ធជាគុណប្រយោជន៍សម្រាប់កងទ័ពខ្មែរក្រហម ។ ពួកវៀតណាមបានផ្ដល់អាវុធ ដែលគេវាយយកបានពីសត្រូវទៅឲ្យគាត់ទាំងអស់ ហើយផ្ដល់ឱកាសឲ្យភូមិភាគបូព៌ារៀបចំបង្កើតកងទ័ពផ្ទាល់របស់ខ្លួនទៀតផង ។ ប៉ុន្ដែនៅពេលដែល ប៉ុល ពត បញ្ជាឲ្យគាត់សម្លាប់ពួកកុម្មុយនិស្ដខ្មែរ ដែលវិលត្រឡប់ពីក្រុងហាណូយមកវិញជាមួយកងទ័ពវៀតណាម ភឹម បានធ្វើតាមជាបន្ទាន់ ។

បន្ទាប់ពីជ័យជម្នះ គាត់នៅរក្សាទុកអំណាចបញ្ជាការភូមិភាគបូព៌ាដដែល ហើយនៅឆ្នាំបន្ទាប់ ពេលដែលរដ្ឋាភិបាលត្រូវបង្កើតឡើង គាត់ត្រូវបានតែងតាំងជាអនុប្រធានទីមួយនៃគណៈប្រធានរដ្ឋក្រោម ខៀវ សំផនមួយថ្នាក់ ។ អនុប្រធានរបស់គាត់ម្នាក់ក្នុងចំណោមអនុប្រធានសំខាន់ៗរបស់គាត់ឈ្មោះ ភួង ត្រូវបានចាត់តាំងឲ្យទទួលបន្ទុកក្រសួងចម្ការកៅស៊ូ ហើយត្រូវបានជំនួសតាមបញ្ជារបស់មជ្ឈិមដោយឥស្សរជនម្នាក់ទៀតរបស់ភូមិភាគបូព៌ា គឺឈ្មោះ ចាន់ ដែល ភឹម បានអប់រំណែនាំ ឲ្យប្រកាន់តាមជំហរផ្សេងៗរបស់គាត់បានទាំងស្រុង ។ មជ្ឈិមក៏បានបញ្ជាឲ្យមានការផ្លាស់ប្ដូរមួយចំនួនតូចក្នុងគណៈដឹកនាំភូមិភាគដែរ ប៉ុន្ដែ ដោយបែបផែនទូទៅមួយ មជ្ឈិមមិនជ្រៀតជ្រែកក្នុងកិច្ចការរបស់ ភឹម ទេ ជាពិសេស បើគេប្រៀបធៀបជាមួយនឹងការធ្វើឲ្យមានការប្របូកប្របល់ផ្សេងៗ ដែលតម្រូវទៅលើភូមិភាគផ្សេងៗទៀត ។

មិនត្រឹមតែ ភឹម ប្រតិបត្តិតាមបញ្ជាផ្សេងៗរបស់មជ្ឈិមប៉ុណ្ណោះទេ ប៉ុន្ដែ គាត់ក៏បានរួមចំណែកក្នុងការចេញបទបញ្ជាទាំងនោះដែរ ដោយហេតុថាគាត់ជាសមាជិកគណៈលេខាមជ្ឈិម និងជាសមាជិកគណៈប្រធានរដ្ឋម្នាក់ ។ កងទ័ពរបស់គាត់ធ្លាប់បានចូលរួមក្នុងការជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ ដោយសុទ្ធចិត្ត បន្ទាប់មកការកម្ទេចពួកអ្នកជឿសាសនាផប់ ជាពិសេស ជនជាតិភាគតិចចាមដែលរស់នៅជាប្រពៃណីយូរមកហើយនៅភាគខាងកើត ។ ប៉ុន្ដែភូមិភាគរបស់ ភឹម បានពន្យឺតពេលមិនទាន់ឲ្យមានការហូប បាយរួមភ្លាមៗទេ ហើយក្នុងតំបន់ខ្លះៗ បានកើតមានការតស៊ូមិនព្រមធ្វើតាមបទបញ្ជាឲ្យលុបបំបាត់កម្មសិទ្ធិឯកជនទៀតផង ។ គឺចំពោះមូលហេតុនេះហើយ ដែល ភឹម ត្រូវគេចោទប្រកាន់ជាបន្ទាប់មកទៀតថា ជាអ្នកស្ញើចសរសើរដែលមានចរិតជាអ្នកបម្រើម្នាក់តាមគំរូសហករណ៍បែបចិន ។

ប៉ុន្ដែ ក្នុងអតីតកាលរបស់គាត់គ្មានអ្វីមួយដែលអនុញ្ញាតឲ្យគាត់ធ្វើជាមិត្ដម្នាក់របស់ប្រទេសវៀតណាមទេ ។ ផ្ទុយទៅវិញ គាត់បានសម្ដែងទឹកចិត្ដរីករាយជាខ្លាំងដែលបានបដិសេធមិនស្ថិតនៅក្រោមចំណុះក្រុងហាណូយ ក្នុងពេលសង្គ្រាម ក៏ដូចពេលមានសន្ដិភាពដែរ ។ ម្យ៉ាងទៀត គ្មានអ្វីមួយបន្សល់ទុកឲ្យគេសន្និដ្ឋានថាមានការខ្វែងគំនិតគ្នាខាងនយោបាយក៏ទេដែរ ៖ ភឹម បានកោតសរសើរជាចំហនូវគំរូរបស់កូរ៉េខាងជើង ដែលជាមាគ៌ាដឹកនាំយ៉ាងល្អសម្រាប់កម្ពុជាប្រជាធិបតេយ្យ ។ ទោះជាមានភាពពឹងផ្អែកទាំងស្រុងរបស់កម្ពុជា ចំពោះ

ប្រទេសចិននាសម័យនោះក៏ដោយ ក៏ពួកមេដឹកនាំក្រុងភ្នំពេញចូលចិត្តនិយាយថា ខ្លួនមានចិត្តញ៉ាំងឲ្យចង់ធ្វើការតាមគំរូរបស់កូរ៉េខាងជើងជាង ជាប្រទេសកុម្មុយនិស្តមួយផ្សេងដែលមានទំហំតូច និងមានគោលការណ៍តឹងរ៉ឹងដោយលើកសរសើរពីភាពឯករាជ្យម្ចាស់ការ និងក្តោបក្តាប់ប្រជាជនក្រោមរបបមួយ ដែលប្រើលទ្ធិផ្តាច់ការ ។

ម្យ៉ាងទៀត នៅក្នុងភូមិភាគបូព៌ាមុនឆ្នាំ១៩៧៧ ក៏កើតមានការបោសសម្អាតមួយចំនួនដែរ ដែលអនុវត្តដោយក្រុងសន្តិសុខផ្ទាល់របស់ភូមិភាគនេះ ។ អ្នកជំនាញការម្នាក់បានវាយតម្លៃថា ការបោសសម្អាតនេះ បានប៉ះពាល់ទៅលើកម្មាភិបាលកុម្មុយនិស្ត ពីប្រាំរយទៅមួយពាន់នាក់ នេះជាតួលេខខ្ពស់មួយ សម្រាប់ភូមិភាគបូព៌ាដែលមានកម្មាភិបាលមួយចំនួនធំ រៀនសូត្របេះដឹងប្រសើរច្រើនជាងគេ ។ គេមិនបានដឹងឲ្យប្រាកដថា តើ សោ ភឹម ជាអ្នកបង្គាប់បញ្ជាឲ្យធ្វើការបោសសម្អាតទាំងនេះ ឬថា ការបោសសម្អាតទាំងនេះត្រូវបានធ្វើឡើងទៅតាមការស្នើរបស់មជ្ឈិមឡើយ ។ ទុកជាយ៉ាងណាក៏ដោយ ក៏ ភឹម បានដឹងពីរឿងនេះ និងផ្តល់នូវការយល់ព្រមរបស់គាត់ ដោយប្រហែលជាទទួលស្គាល់“ភ័ស្តុតាង”ផ្សេងៗ ស្តីពីអំពើក្បត់របស់ពួកកម្មាភិបាលទាំងនោះដែរ ។ ដូច ញឹម រស់ លេខាបក្សភូមិភាគពាយ័ព្យ ភឹម បានអនុញ្ញាតឲ្យធ្វើការបោសសម្អាតផ្សេងៗ ជាលើកដំបូងក្នុងភូមិភាគរបស់គាត់ដោយនឹកគិតថា មជ្ឈិម ឬក្រុមសន្តិសុខផ្ទាល់របស់ខ្លួនមានភ័ស្តុតាងផ្សេងៗ សម្រាប់ប្រឆាំងនឹងពួកកម្មាភិបាលដែលគេប៉ងប្រាថ្នាអស់ហើយ ។

ប៉ុន្តែ ក្នុងដំណាក់កាលថ្មីនេះ ពួកអ្នកមានមុខមាត់របស់បក្សបែប សោ ភឹម ជាដើម សុទ្ធតែក្លាយទៅជាមនុស្សដែលអាចត្រូវរងការវាយប្រហារខ្លាំងជាងគេបំផុត ។ គុណសម្បត្តិផ្សេងៗរបស់គាត់ផ្ទាល់ ដែលកាលពីមុនធ្លាប់អនុញ្ញាតឲ្យគាត់ឈានឡើងបុណ្យស័ក្តិជាលំដាប់លំដោយ បានប្រែក្លាយទៅជាលក្ខណៈពិសេសដោយឡែក ដែលត្រូវគេសង្ស័យទៅវិញ ដោយរួមបង្កជាចំណុចសំខាន់ក្នុងការចោទប្រកាន់ចំពោះរូបគាត់ ។ បើ សោ ភឹម យកចិត្តទុកដាក់ខ្លាំងនឹងការបោសសម្អាតផ្សេងៗ នៅភូមិភាគដទៃទៀត និងមូលហេតុទាំងឡាយ ដែលលាក់ខ្លួនពីក្រោយរឿងទាំងនោះ គាត់ច្បាស់ជាមើលឃើញពីការប្រុងប្រៀបខ្លួនធ្វើការបោសសម្អាតភូមិភាគផ្ទាល់របស់គាត់ដែរមិនខាន ។

ភូមិភាគឧត្តរ ត្រូវបានបោសសម្អាតមុនគេបង្អស់ មួយផ្នែកធំ ពីព្រោះ ទីនោះហើយដែលចោទឡើងជាលើកដំបូងនូវបញ្ហាសំខាន់ៗរបស់ការបដិវត្ត ៖ ការគ្មានសមត្ថភាពធានាសន្តិសុខពេញលេញមួយ (គឺនៅភាគខាងជើងដែលកងទ័ពរបស់ លន់ នល់ ធ្វើប្រតិបត្តិការវាយទម្លុះខ្សែក្រវ៉ាត់ការពារចូលយ៉ាងជ្រៅតែម្តងគត់ ក្នុងរយៈពេលសង្គ្រាម គឺឆ្នាំ១៩៧៤) ការគ្មានសមត្ថភាពគ្រប់គ្រងខាងផ្នែកសេដ្ឋកិច្ច ដោយសារតែអនុវត្តកម្មវិធីសង្គមកិច្ចតឹងរ៉ឹងហួសហេតុរបស់ការបដិវត្ត ។ ភូមិភាគពាយ័ព្យ ជាគោលដៅនៃការបោសសម្អាតបន្ទាប់មកទៀតពីព្រោះជាកន្លែងដែលធ្លាប់កើតមានបរាជ័យខ្លាំងជាង គេបំផុត ៖ គម្រោងការប្រកបដោយមហិច្ឆតារបស់មជ្ឈិមដើម្បីបង្កើតភាពរុងរឿងនៅទីនោះដូចសម័យអង្គរឡើងវិញត្រូវបរាជ័យ ហើយផ្ទុយទៅវិញ ភូមិភាគពាយ័ព្យ

បានទទួលរងនូវគ្រោះអត់ឃ្លាន និងការកាប់សម្លាប់មនុស្សមួយចំនួនថែមទៀត ។

បើគិតទៅតាមបែបបទរបស់មជ្ឈិម គោលដៅបន្ទាប់ ប្រហែលជាគោលដៅដែលមជ្ឈិមត្រូវការ ការសម្រេចជោគជ័យប្រសើរមួយ ហើយដែលធ្លាប់ស្គាល់បរាជ័យដូចគ្នា គឺភូមិភាគបូព៌ា ។ មែនហើយ មជ្ឈិមធ្លាប់ផ្ញើសេចក្តីទុកចិត្តលើ ភឹម ដើម្បីទទួលបានជ័យជម្នះមួយក្នុងជម្លោះព្រំដែនជាមួយប្រទេសវៀតណាម ។ សញ្ញាសម្គាល់ដំបូងៗដែលបង្ហាញថា ក្រុងហាណូយមានកងទ័ពមួយប្រសើរលើសគេ យ៉ាងជាក់ស្តែងនោះ បាននាំឲ្យមជ្ឈិមសង្ស័យថា ភឹម មានការឃុបឃិតជាសម្ងាត់ជាមួយប្រទេសវៀតណាម ។ សកម្មភាពពីមុនៗរបស់គាត់ក្នុងបក្ស បានធ្វើឲ្យគាត់ទៅជាតួយ៉ាងបេក្ខជនសម្រាប់ឲ្យគេចោទប្រកាន់ ពីបទដឹកនាំខ្សែបណ្តាញចារកម្មមួយ ដែលរៀបចំឡើងដោយប្រទេសវៀតណាម ក្នុងគោលដៅផ្តួលរំលំបក្ស និងការបដិវត្ត ។

មួយផ្នែកការប្រៀបធៀបរវាង ភឹម និងភូមិភាគបូព៌ា ហើយមួយផ្នែកទៀតរវាង តាម៉ុក និងភូមិភាគនិរតី គឺមានលក្ខណៈធ្វើឲ្យគេដឹងរឿងរ៉ាវយ៉ាងច្រើន ។ នៅខែកក្កដា ឆ្នាំ១៩៧៧ តាម៉ុក និងភូមិភាគរបស់គាត់ បានកាន់កាប់ស្ថានភាពដ៏ប្រសើរមួយ បើនិយាយអំពីផ្នែកនយោបាយ ។ គាត់ទើបនឹងដឹកនាំធ្វើការបោសសម្អាតភូមិភាគពាយ័ព្យ និងភូមិភាគនិរតី ដែលជាតំបន់ក្រីក្រ ដែលមិនដែលមានតួនាទីសំខាន់ណាមួយក្នុងគម្រោងការសេដ្ឋកិច្ចរបស់មជ្ឈិមទាល់តែសោះ ។ ពិតមែនតែភូមិភាគនិរតីមានព្រំដែនរួមមួយជាមួយវៀតណាមក៏ដោយ ក៏ពុំមែនទីនេះទេដែលប្រទេសកម្ពុជា និងវៀតណាមឈ្លោះទាស់ទែងគ្នាពីបញ្ហាទឹកដី និងភូមិមួយចំនួននោះ ដូច្នេះកិត្តិយសអាក្រក់នេះត្រូវធ្លាក់មកលើភូមិភាគបូព៌ាវិញ ។

ម្យ៉ាងទៀត ម៉ុក ពុំមានកាន់មុខតំណែងណាមួយនៅក្នុងរដ្ឋាភិបាលទេ ។ ដើមឡើយ គាត់មានអាជីពជាបញ្ជាការទ័ពម្នាក់ ហើយក្លាយទៅជាលេខាបក្សភូមិភាគរបស់គាត់ ប្រហែលនៅទីបញ្ចប់នៃសង្គ្រាមប៉ុណ្ណោះ ។ ប្រហាក់ប្រហែលជានៅសម័យនោះដែរ គាត់បានឈានចូលក្នុងគណៈលេខាមជ្ឈិម ប៉ុន្តែ ពុំមែនជាសមាជិកដ៏សំខាន់ម្នាក់ដូច សោ ភឹម ទេ ។ ប៉ុន្តែ ចរិតគ្មានអាណិតអាសូរ និងការប៉ិនប្រសប់ផ្នែកយោធារបស់គាត់ បានផ្តល់ឲ្យគាត់នូវសំឡេងដ៏មានឫទ្ធិអំណាចលើសលប់គេឯង (ទឹកមាត់ប្រៃ) ក្នុងផ្ទៃគណៈកម្មាធិការមជ្ឈិមបក្សយ៉ាងឆាប់រហ័ស ។ ម៉ុក ជាគំរូមនុស្សធុន "អ្នកដៃដល់" ដែលការពារភូមិភាគរបស់គាត់ ដោយការផ្គាប់ផ្គុនយកគាប់យកគួរ និងគោរពធ្វើតាមបទបញ្ជាផ្សេងៗរបស់ ប៉ុល ពត គ្មានល្អៀង ដោយជៀសវាងមិនឲ្យកើតមានរឿងរ៉ាវអ្វី ដែលនាំឲ្យមានការលំបាកដល់ខ្លួន និងស្ថិតតែម្នាក់ឯងដោយគ្មានគេស្គាល់ថែមទៀត ។ ដូច្នេះ ប៉ុល ពត មើលពុំឃើញថាគាត់ជាមនុស្សគួរឲ្យព្រួយបារម្ភម្នាក់ទេ ហើយនៅទីបំផុត បានចាត់ទុកគាត់ជាមនុស្សសំខាន់ម្នាក់ក្នុងចំណោមមនុស្សសំខាន់ៗ ដែលអាចឲ្យមជ្ឈិមប្រើប្រាស់សម្រេចបានលទ្ធផលជាច្រើនប្រការ ក្នុងការបោសសម្អាតទាំងឡាយរបស់បក្ស ។

ជាជនសំខាន់ដូចគ្នា ម៉ុក ប្រហែលជាសម្ព័ន្ធមិត្តចាស់ម្នាក់របស់ ឌុច មេគុកទួលស្លែងដែរហើយមើលទៅ ។

ពួកគេ បានធ្វើសកម្មភាពនយោបាយជាមួយគ្នាក្នុងភូមិភាគនិរតី ក្នុងរយៈពេលនៃឆ្នាំដំបូងៗរបស់ការបដិវត្តន៍ ។ ដូច្នេះ ឌុច មានសេចក្តីយកចិត្តទុកដាក់ ការពារពួកកម្មាភិបាលនៅភូមិភាគនិរតីណាស់ ៖ បើសិនជាគាត់បង្កើតឲ្យមានការសង្ស័យពីភក្តីភាពរបស់បណ្តាមេដឹកនាំភូមិភាគនេះ ភក្តីភាពផ្ទាល់របស់គាត់ ក៏អាចត្រូវគេសង្ស័យដែរ ហើយរឿងនេះ វាជាគ្រោះថ្នាក់មួយដែលគាត់ចង់ជៀសវាងឲ្យឆ្ងាយ ។

ដោយមាន ឌុច នៅក្រោយខ្នង ម៉ុក គឺជាមនុស្សដែលមានសន្តិសុខយ៉ាងគ្រប់គ្រាន់ ។ សោ ភឹម និងយុទ្ធជនដើងចាស់ឆ្នើមៗដទៃទៀតរបស់បក្ស នឹងត្រូវចោទប្រកាន់ពីបទក្បត់ជាតិ ដោយរួមគំនិតជាមួយបរទេស ។ ជនដែលស្ថិតនៅក្នុងការគាំពាររបស់ ប៉ុល ពត ផ្ទាល់ឈ្មោះ វ៉ន វ៉េត នឹងត្រូវជាប់ចោទពីបទ ធ្វើវិច្ឆេទកម្មបំផ្លាញបដិវត្តដោយចេតនា ក្រោយពេលបក្សចាប់ផ្តើមធ្វើការវាយប្រហារប្រឆាំងនឹង សោ ភឹម បន្តិច ។ មេដឹកនាំនានា ដែលជាអ្នកស្និទស្នាលនឹង ប៉ុល ពត ឬមានសិទ្ធិអំណាចកាន់តែខ្លាំងកាលណា ពួកគេមុខជានឹងធ្វើឲ្យ ឌុច កម្រើកឡើងនូវការសង្ស័យខ្លាំងឡើងកាលនោះដែរ ។

ប៉ុន្តែ គឺការដួលរលំរបស់ សោ ភឹម និងការបោសសម្អាតភូមិភាគរបស់គាត់ប្រហែលជារួមបន្តជាវគ្គរឿងមួយដែលគួរឲ្យរន្ធត់ញាប់ញ័រ បណ្តាលឲ្យមានការស្លាប់ច្រើន និងដែលបំផ្លាញខ្លាំងជាងគេបំផុត ចំពោះជីវិតយ៉ាងខ្លីរបស់កម្ពុជាប្រជាធិបតេយ្យ ។

## បន្ទុំបញ្ចប់បញ្ហាមួយ

*នៅឆ្នាំ១៩៧៧ ការវាយប្រយុទ្ធគ្នាយ៉ាងសាហាវមួយ បានបណ្តាលឲ្យមានការប្រឈមមុខដាក់គ្នារវាងពួកអ្នកស្នេហាជាតិជាច្រើនដែលអះអាងថា កម្ពុជាត្រូវតែឯករាជ្យមិនចំណុះប្រទេសវៀតណាម និងពួកអ្នកដែលប្រកាសថាត្រូវតែធ្វើ ជាមិត្តដ៏ជិតស្និទ្ធជាមួយប្រទេសវៀតណាម ។ ការវាយប្រហារនេះបានបន្តរហូតមក ដល់ខែកក្កដា ឆ្នាំ១៩៧៨...[៨] ។*

**ជួន មុំ**

ក្នុងសម័យកាលនោះ ជម្លោះព្រំដែនរវាងប្រទេសកម្ពុជានិងប្រទេសវៀតណាម មានក្របខ័ណ្ឌខាងមនោគមន៍វិជ្ជាមួយយ៉ាងច្បាស់[៩] ។ សម្តេច ព្រះនរោត្តម សីហនុ ធ្លាប់មានបញ្ហាយ៉ាងច្រើនជាមួយរបបនានាដែលគាំទ្រដោយសហរដ្ឋអាមេរិក ។ នៅឆ្នាំ១៩៦៧ ពួកកុម្មុយនិស្តវៀតណាមបានទទួលស្គាល់ព្រំដែនរបស់កម្ពុជា ហើយយ៉ាងហោចណាស់ សម្រាប់ពិភពលោកខាងក្រៅពួកកុម្មុយនិស្ត ហាក់ដូចជាត្រៀមបម្រុងដោះស្រាយនូវជម្លោះផ្សេងៗ ដែលចាក់ឫសយ៉ាងជ្រៅរវាងប្រទេសទាំងពីរថែមទៀត ។

គំនិតនេះ លេចឡើងឲ្យឃើញលក្ខណៈដែលមិនពិតដូចភាគច្រើននៃសម្មតិកម្មផ្សេងៗទៀតស្តីពីលក្ខណៈជម្លោះនៃអធិករណ៍ឥណ្ឌូចិនដែរ ។ ក្រោមរបបកុម្មុយនិស្តថ្មីរបស់ពួកគេ ពួកវៀតណាម និងពួកកម្ពុជា បាន

ប្រឈមមុខដាក់គ្នាភ្លាមអំពីបញ្ហាព្រំដែន ។ ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៧ ពួកមេដឹកនាំប្រទេសទាំងពីរបានបើកធ្វើការប្រជុំជាហូរហែមួយ ដើម្បីពិភាក្សាពីរឿងដែនដី និងដែនសមុទ្រដែលជាកម្មវត្ថុក្នុងការជជែកពិភាក្សានៅឡើយ ។ ប៉ុន្តែ ពួកគេពុំបានឈានដល់កិច្ចព្រមព្រៀងណាមួយឡើយ ។ ពួកកុម្មុយនិស្តកម្ពុជាហាក់ដូចជាដឹងខ្លួនថា ពួកវៀតណាមបានសើរើឡើងវិញ នូវកិច្ចព្រមព្រៀងដែលពួកគេបានចុះហត្ថលេខាជាមួយសម្ដេច ព្រះនរោត្តម សីហនុ កាលពីឆ្នាំ១៩៦៧ ។ សម្រាប់ភាគីខ្លួន ពួកកុម្មុយនិស្តខ្មែរបានទទួលស្គាល់ព្រំដែនដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ ។ ប៉ុន្តែ ព្រំដែនដែលគូសឡើងតាំងពីជំនាន់បារាំង ហើយដែលធ្វើឲ្យខូចផលប្រយោជន៍ប្រទេសកម្ពុជានោះ ប្រហែលជាត្រូវបោះបង់ការទាមទារទាំងអស់ក្នុងរឿងទឹកដីកម្ពុជាក្រោម នៅពេលដែលពួកវៀតណាមព្រមគោរពព្រំដែននេះ ។ បោះបង់ទឹកដីខ្មែរមួយចំអាមថែមទៀត នឹងឈានទៅរកគ្រោះមហន្តរាយយ៉ាងធំបើគេជឿលើមេរៀនជាប្រវត្តិសាស្ត្រទាំងឡាយ ។

អ្នកជំនាញការខ្មែរម្នាក់បានកត់សម្គាល់ថា «តាំងពីសម័យសម្ដេច ព្រះនរោត្តម សីហនុ ដែលខំប្រឹងប្រែងយ៉ាងខ្លាំងខាងវិស័យអប់រំសាធារណៈ បានផ្ដោតជាសំខាន់ទៅលើប្រវត្តិសាស្ត្រ និងបញ្ហាព្រំដែនរបស់កម្ពុជា បញ្ហាព្រំដែននៅ តែមានជាប្រចាំសម្រាប់ប្រជាជនកម្ពុជា ប្រៀបដូចជាកែវស្ទង់កម្រិតនៃទំនាក់ទំនងផ្សេងៗរបស់ពួកគេជាមួយនឹងវៀតណាមអ៊ីចឹង ។ ការបន្ធូរបន្ថយដើម្បីសម្របសម្រួលគ្នាចំពោះវិស័យនេះ ច្បាស់ជាតម្រូវឲ្យមានការប្រឈមមុខនឹងការធ្វើពលិកម្មកាន់តែធំ ប្រហែលជាជាងមិត្តភាពជាមួយប្រទេសវៀតណាមទៅទៀត[១០]» ។

លន់ នល់ ធ្លាប់បានប្រកាសសង្គ្រាមសាសនាប្រឆាំងនឹងពួកកុម្មុយនិស្តវៀតណាមដែរ ដោយផ្សាយដំណឹងខ្វះខ្វាវថា ពួកវៀតណាមបានទន្ទ្រានចូលមកក្នុងទឹកដីខ្មែរ ហើយមិនគោរពឯករាជ្យរបស់ប្រទេសកម្ពុជាទៀត ។ តាមអ្វីៗដែលសមជាពិត ពួកវៀតណាមមនមានសង្ស័យពីសេចក្ដីភ័យខ្លាច ដែលពួកគេបង្កើតឲ្យមាននៅក្នុងចំណោមប្រទេសជិតខាងអំពីបញ្ហាព្រំដែនឡើយ ។

នៅពេលដែលជម្លោះព្រំដែនផ្ទុះឡើងជាថ្មី ប៉ុល ពត និង ឌុច ជឿជាក់ថា ច្បាស់ជាប្រមូលបានភស្តុតាងផ្សេងៗ ដែលគេត្រូវការរឹតតែច្រើនថែមទៀត តាមរយៈចម្លើយសារភាពទាំងឡាយរបស់ជនរងគ្រោះនៅមន្ទីរឃុំឃាំងទួលស្លែង ស្ដីពីការជ្រៀតជ្រែករបស់វៀតណាម ក្នុងនយោបាយរបស់បក្សកុម្មុយនិស្តកម្ពុជា ។ ចាប់ពីខែកញ្ញា ឆ្នាំ១៩៧៦ កាសែតរបស់បក្សបានសរសេរថា «ចាប់ពីឥឡូវនេះទៅ យើងត្រូវតែរៀបចំប្រវត្តិសាស្ត្ររបស់បក្សឲ្យបានច្បាស់លាស់ និងពេញលេញ អនុលោមទៅតាមនយោបាយឯករាជ្យរបស់យើង និងធ្វើជាម្ចាស់លើខ្លួនឯងពិតប្រាកដ» ។ ការផ្លាស់ប្ដូរកាលបរិច្ឆេទនៃថ្ងៃកំណើតបក្ស បានក្លាយយ៉ាងរហ័សទៅជាមធ្យោបាយ ដើម្បីទៅដល់គោលដៅមួយរបស់ ប៉ុល ពត និងអ្នកនៅជុំវិញគាត់ ដើម្បីបង្ខំឲ្យបណ្ដា «សម្ព័ន្ធមិត្តរបស់វៀតណាម» សម្ដែងបំណងខ្លួនដោយប្រឆាំងនឹងការផ្លាស់ប្ដូរនេះ ។

ប៉ុល ពត បានបំផ្លាញខ្ទេចខ្ទីនូវសម្ព័ន្ធភាពផ្សេងៗ ដែលបង្កើតជារូបរាងយ៉ាងសម្រាំង ហើយដែលធ្លាប់បង្រួបបង្រួមពួកកុម្មុយនិស្តមកពីប្រភពខុសៗគ្នា ក្នុងរយៈពេលនៃការប្រយុទ្ធដ៏យូរក្នុងការធ្វើសម្ភាពលួចលាក់របស់គេក្នុងសង្គ្រាមប្រឆាំងនឹងសម្ដេច ព្រះនរោត្តម សីហនុ បន្ទាប់មក ប្រឆាំងនឹង លន់ នល់ ។ នេះជាមធ្យោបាយមួយសំដៅឯកោ ពួកបក្ខជនដើងចាស់របស់បក្ស ដែលមានឫសគល់ ចេញពីបក្សកុម្មុយនិស្តឥណ្ឌូចិន គឺបណ្ដាមនុស្សដូច សោ ភឹម លេខាបក្សភូមិភាគបូព៌ាជាដើម ។ ដួច ដួន មុំ បានទទួលស្គាល់រឿងនេះយ៉ាងងាយបំផុតថា «យើងបានលើកថ្ងៃខែ បង្កើតបក្សទៅឆ្នាំ១៩៦០វិញ ក្នុងគោលបំណងផ្ដាច់ខ្លួនឲ្យផុតពីបក្សកុម្មុយនិស្តឥណ្ឌូចិន[១១]» ។

លក្ខណៈពិតប្រាកដនៃការពិនិត្យឡើងវិញជាប្រវត្តិសាស្ត្រនេះ បានប្រហារបក្សដោយភាពកំហែងកំហល់មួយ នៅពេលដែល ប៉ុល ពត និង ឌុច ជួយគាំទ្រដើម្បីថ្លែទម្ងន់ថា ប្រទេសវៀតណាមបានគំរាមកំហែងប្រទេសជាតិ ។ ឌុច បានផ្ដល់នូវចម្លើយសារភាពជាច្រើនរបស់ពួកអ្នកជាប់គុកនៅទួលស្លែង ដែលបង្ហាញឲ្យឃើញថាប្រទេសវៀតណាមបានបង្កើតបក្សស្របគ្នាមួយជាសម្ងាត់នៅប្រទេសកម្ពុជា ដើម្បីបំផ្លាញការបដិវត្ត ហើយនៅទីបំផុតយកប្រទេសកម្ពុជាបញ្ចូលជាខបសម្ព័ន្ធទៀត ។ អ្នកណាក៏ដោយដែលស្គាល់ច្បាស់ជំងឺមិនទុកចិត្តគេឯងទាំងអស់របស់មេគុកទួលស្លែង អាចយល់ធ្លុះដែលការដំណើរបន្ទាប់នឹង នាំទៅដល់ភាពសមហេតុសមផលទាំងស្រុង នៅពេលដែលបណ្ដាមេដឹកនាំបក្ស រួមទាំងមនុស្សមួយចំនួនដូច សោ ភឹម ជាដើម ធ្លាប់បានចូលរួមក្នុងការបោសសម្អាតដំបូងៗ សំដៅប្រឆាំង នឹងពួកកុម្មុយនិស្តកម្ពុជា ដែលត្រឡប់ពីក្រុងហាណូយមកវិញនៅឆ្នាំ១៩៧៤ ពួកគេបានយល់ ស្របតាមការពោលអាងរបស់បក្សដែលថា សមមិត្តទាំងនោះ ជាពួកវិច្ឆេទករធ្វើការបម្រើពួកវៀតណាម ។ ពេលដែលបក្ស កម្ទេចសមាសភាពអនុធនចោលនៅឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៦នោះ ក៏ពួកមេដឹកនាំដដែលនេះ បានយល់ស្របតាមគោលមាគ៌ាដែលថា សមាសភាពអនុធនទាំងនោះ ជាភ្នាក់ងាររបស់ សេ.អ៊ី.អា. ឬកា.ហ្សេ.បេ. ដែលបានជ្រៀតចូលកាលពីច្រើនឆ្នាំមុនដើម្បីបំផ្លាញការបដិវត្តដែរ ។

ហេតុនេះ គ្មានអ្វីឲ្យភ្ញាក់ផ្អើលសោះចំពោះរឿងដែល ឌុច រួមបញ្ចូលឈ្មោះអតីតសមាជិកបក្សកុម្មុយនិស្តឥណ្ឌូចិននៅពេលនេះ ទៅក្នុងការរួមគំនិតក្បត់មួយរបស់វៀតណាម ប្រឆាំងនឹងការបដិវត្តនោះ ។ ការទាស់ទែងគ្នារវាងប្រទេសកម្ពុជា និងវៀតណាមបានផ្ដល់នូវ «ភ័ស្តុតាង» យ៉ាងគ្រប់គ្រាន់ដើម្បីញ៉ាំងឲ្យ ប៉ុល ពត ជឿពីរឿងនេះ ។ នៅក្រុងហាណូយ ពួកវៀតណាមបានបកស្រាយប្រាប់ «អ្នកសង្កេតការណ៍» មួយចំនួនឲ្យដឹងច្បាស់ថាពួកគេនឹងមិនសប្បាយចិត្តទេ បើសិនជា ប៉ុល ពត លែងកាន់អំណាច ។ ពួកវៀតណាម បានតឿនពួកកម្ពុជាឲ្យចុះហត្ថលេខាលើសន្ធិសញ្ញាមិត្តភាពមួយ ដែលនឹងធ្វើឲ្យការត្រួតត្រារបស់វៀតណាមមក លើកុម្មុយនិស្តឥណ្ឌូចិនមានជាស្ថាពរតទៅ ។ ក្រុងហាណូយបដិសេធមិនគោរពកិច្ចព្រមព្រៀង ដែលវៀតណាមខាងជើង និងរដ្ឋាភិបាលបដិវត្តបណ្ដោះអាសន្នភាគខាងត្បូងវៀតណាម បានសម្រេចជាមួយនឹងសម្ដេច ព្រះនរោត្តម សីហនុ ឡើយ ។

ម្យ៉ាងទៀត ពួកខ្មែរក្រហមត្រូវការសញ្ញានៃការគំរាមធ្វើការលុកលុយមួយរបស់វៀតណាមដែរ ដើម្បីបង្វែរការយកចិត្តទុកដាក់របស់ប្រជាជន ចំពោះការធ្វើមិនបានសម្រេចជោគជ័យផ្ទាល់របស់ពួកគេ ។

បណ្ដាមេដឹកនាំបក្សបានត្រូវធ្វើឲ្យជាប់រវល់គិតគូរខ្លាំងមែនទែន ដោយសារតែការប្រែប្រួលភ្លាមៗ របស់របបដែលធ្វើឲ្យពួកគេអាចសម្គាល់ឃើញត្រឹមតែថា ដំណាក់កាលថ្មីនេះនឹងនាំមកនូវការវិនាសផ្ទាល់ខ្លួនរបស់គេប៉ុណ្ណោះ ។ ស្របទៅតាមភ័ស្តុតាងជាក់លាក់ មេដឹកនាំជាច្រើននាក់ ដែលមានរូប សោ ភឹម ដែរ នឹកសង្ស័យមែនទែន ពីការគំរាមកំហែងរបស់វៀតណាមកាលពីពេលថ្មីៗនេះដែលបក្សនិយាយឲ្យដឹងនេះ ។ បណ្ដាមេដឹកនាំខ្លះទៀតដូច វ៉ន វេត ជាដើមបានដណ្ដឹងសួរក្នុងចិត្តថា ហេតុអ្វីបានជាមជ្ឈិមមិនធ្វើប្រតិកម្មចំពោះការគំរាមកំហែងពិតប្រាកដមួយ ដោយប្រើអំពើឃោរឃៅតបទៅវិញ? ប៉ុន្តែ មិនយូរប៉ុន្មាន អ្នកទាំងនេះបង្ហាញគំនិតខ្លួនថា ពួកគេពុំមានការជ្រើសរើសឡើយ ។ សម្រាប់ ប៉ុល ពត និងអ្នកជិតស្និទ្ធរបស់គាត់ពុំមានចំណុចណាមួយដែលត្រូវសួរឡើយ ។ នេះគឺជាបញ្ហាស្លាប់ ឬរស់មួយរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម ។ ហើយក្នុងការប្រយុទ្ធនេះកម្ពុជាអាចស្ថិតនៅគង់វង្សបានទាល់តែ ប៉ុល ពត ទទួលជ័យជម្នះ ។ ប៉ុល ពត បានប្រុងប្រយ័ត្នចំពោះស្ថានភាពរបស់គាត់ និងស្ថានភាពរបស់ប្រទេស គឺត្រូវចងភ្ជាប់គ្នាស្អិតរមួត ។

ការផ្លាស់ប្ដូរឥរិយាបថរបស់មជ្ឈិមចំពោះប្រទេសវៀតណាម បានកើតឡើងឆាប់រហ័សពេកសម្រាប់មេដឹកនាំខ្លះ ដោយហេតុថា គេទើបបានសម្រេចធ្វើការទាក់ទងគ្នាជាអ្នកជិតខាងល្អតែពីរ-បីខែប៉ុណ្ណោះ ចំពោះការគំរាមកំហែងមួយពីសង្គ្រាម ។ នៅខែកក្កដា ឆ្នាំ១៩៧៦ក្នុងឱកាសនៃការចុះហត្ថលេខាលើកិច្ចព្រមព្រៀង ដែលគ្រោងរៀបចំឲ្យមានការទាក់ទងគ្នាតាមផ្លូវអាកាសរវាងរដ្ឋធានីទាំង២ ប្រទេសកម្ពុជា និងវៀតណាម នៅតែយល់ឃើញថា ពួកគេអាចរួមរស់ជាមួយគ្នាបាន ។ នៅសរទរដូវ ចំពោះមុខមហាសន្និបាត អង្គការសហប្រជាជាតិ អៀង សារី បានថ្លែងគាំទ្រដល់ការសុំចូលរបស់ប្រទេសវៀតណាមក្នុងអង្គការអន្តរជាតិនេះ ។ ការសម្រេចផ្លាស់ប្ដូរកាលបរិច្ឆេទ ថ្ងៃខែកំណើតបក្ស និងការកាត់ផ្ដាច់ឫសគល់ ដែលចេញពីបក្សកុម្មុយនិស្តឥណ្ឌូចិន ពុំបានកែប្រែការយល់ឃើញរបស់ខ្លួន ស្ដីពីនយោបាយបរទេសរបស់កម្ពុជាឡើយ ៖ អព្យាក្រឹត សាមគ្គីភាពជាមួយបណ្ដាប្រទេសកុម្មុយនិស្ត និងតតិយលោក ការតស៊ូប្រឆាំងនឹងសហរដ្ឋអាមេរិក និងចក្រពត្តិនិយមអាមេរិកាំង ដែលចាត់ទុកដូចជាសត្រូវសំខាន់បំផុត ។

អៀង សារី ផ្ទាល់ បងធំទី២ក្នុងឋានានុក្រមបក្ស បានអះអាងថាជម្លោះព្រំដែនជាមួយប្រទេសវៀតណាមនឹងមិននាំទៅរកសង្គ្រាមមួយឡើយ ។ ដោយទទួលស្គាល់ជាមួយនឹងសេចក្ដីទុកចិត្តគ្មានពិចារណាមួយពីអត្ថិភាពនៃពួកភ្នាក់ងារវៀតណាមជ្រៀតចូលបក្សដល់ថ្នាក់ខ្ពស់បំផុតនោះ គាត់ពុំដែលប្រការនេះ អាចនាំទៅរកការវិវាទមួយរវាងប្រទេសទាំងពីរផងទេ ។ «យើងបានយល់ព្រមឲ្យវៀតណាម បង្កើតស្ថានទូតមួយមុនពួកចិន ។ យើងបណ្ដោយឲ្យពួកគេ ធ្វើដំណើរទៅកន្លែងផ្សេងៗតាមតែពួកគេចង់ទៅ... ។ ខ្ញុំមិនដែលប្រាថ្នាចង់ឲ្យមានសង្គ្រាម

រវាងវៀតណាម និងកម្ពុជាទាល់តែសោះ... អ្វីដែលខ្ញុំភ័យបារម្ភនោះ គឺរដ្ឋប្រហារមួយក្នុងប្រទេសផ្ទាល់របស់ខ្ញុំ ពុំមែនការឈ្លានពាន មួយមកពីខាងក្រៅនោះទេ...។ ខ្ញុំសូមអះអាងថា បញ្ហានេះជាបញ្ហាផ្ទៃក្នុងសុទ្ធសាធ ដោយសារមានពួកភ្នាក់ងារវៀតណាមជ្រៀតចូល...[១៧]

ប៉ុន្តែ គំនិតស្ដីពីការគំរាមកំហែងមួយរបស់វៀតណាមដែលបណ្ដាលឲ្យគេធុញទ្រាន់នេះ បានធ្វើឲ្យភាពក្រអឺតក្រអោងរបស់ អៀង សារី កើតឡើងថែមទៀត ក្នុងឋានៈគាត់ជារដ្ឋមន្ត្រីការបរទេស ។ ចាប់ពីពេលនេះទៅ ប៉ុល ពត បានត្រៀមបើកទ្វារប្រទេសទទួលពួកឲ្យភ្ញៀវបរទេសជាស្រេច ហើយបង្ហាញឲ្យឃើញថា បក្សកុម្មុយនិស្តកម្ពុជា ជាអ្នកដឹកនាំគ្រប់គ្រងកម្ពុជាប្រជាធិបតេយ្យ ដែលមានគាត់ជាអ្នកកាន់ចង្កូត ។ ក្នុងរយៈពេលមួយភាគធំនៃឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ សារី បានរៀបចំស្ពានភាពជាមួយប្រទេសចិន កូរ៉េខាងជើង និងប្រជាជាតិផ្សេងទៀត ដើម្បីឲ្យជួយនិយាយការពារបុព្វហេតុរបស់កម្ពុជាប្រជាធិបតេយ្យ នៅមុខមតិសាធារណៈអន្តរជាតិ និងទាក់ទាញសមានចិត្តពីពិភពលោកក្នុងការជួយជ្រោមជ្រែងមួយ ប្រឆាំងទល់នឹងប្រទេសវៀតណាម ។

ក្នុងពាក់កណ្ដាលទី១នៃឆ្នាំ១៩៧៧ នៅពេលដែលការរៀបចំប្រុងប្រៀបធ្វើការបោសសម្អាតភូមិភាគពាយ័ព្យកំពុងមានដំណើរទៅមុខលឿនរហ័សនោះ ប៉ុល ពត និង ឌុច ក៏បង្កើនការស្រាវជ្រាវ "ពួកភ្នាក់ងារវៀតណាម" និងការត្រៀមរៀបចំសម្រាប់ជម្លោះព្រំដែនរឹតតែខ្លាំងឡើងដែរ ។

ដែនដីរបស់ សោ ភឹម រួមមានតំបន់ដែលមានព្រំប្រទល់ជាប់ជាមួយខេត្តតាយនិញរបស់វៀតណាម ហើយដែលទាមទារ ដោយប្រទេសទាំងពីរនេះ ។ នៅពេលដែលមជ្ឈិមស្នើឲ្យគាត់បញ្ចេញកម្លាំងទ័ពទៅវាយប្រយុទ្ធ គាត់សុខចិត្តធ្វើតាមភ្លាមមួយរំពេច ថ្វីបើគាត់មិនពេញចិត្តក៏ដោយ នេះបើតាមការរ៉ាយរ៉ាប់របស់មិត្តភក្ដិគាត់ជាច្រើននាក់ ដែលនៅរស់រានមានជីវិត ។ នៅខែមីនា ឆ្នាំ១៩៧៧ គាត់បានបញ្ជាឲ្យកងទ័ពទាំងអស់របស់ភូមិភាគ បញ្ឈប់ការងារតាមស្រែចម្ការ និងការដ្ឋាននានាដើម្បីធ្វើចលនាជាបន្ទាន់ឆ្ពោះទៅកាន់ព្រំដែន ។ ភឹម ជាអ្នកទទួលខុសត្រូវដោយផ្ទាល់ក្នុងកិច្ចការពារផ្លូវជាតិលេខ៧ ជាផ្លូវជាតិដែលសណ្ដូកតាមបណ្ដោយព្រំដែន តាំងពីចម្ការកៅស៊ូស្នួល នៅទិសខាងជើង ហើយដែលឆ្លងកាត់មុខចម្ការកៅស៊ូមេមត់ ធ្លាក់មកដល់ក្រែក ជាចំណុចសំខាន់នៃដែនដីកំពុងមានវិវាទ បន្ទាប់មក តម្រង់មកប្រទេសកម្ពុជា និងឆ្លងកាត់ទន្លេមេគង្គមកក្រុងកំពង់ចាម ។

ផ្លូវជាតិលេខ៧ គឺជាផ្លូវជាតិដែល ខណ្ឌចែកភាគខាងជើងពីអ្វីដែលសន្មតហៅត្រើយខាងលិច ទន្លេមេគង្គ ។ ក្នុងរយៈពេលនៃសង្គ្រាមប្រឆាំង លន់ នល់, ភឹម និងយុទ្ធជនរបស់គាត់បាន វាយប្រយុទ្ធយកឈ្នះចាញ់យ៉ាងននះននៀល ដើម្បីការពារការត្រួតត្រាផ្លូវជាតិនេះ ។ ចុងផ្លូវជាតិលេខ៧ បញ្ចប់នៅត្រង់ផ្លូវខ្វែងជាមួយផ្លូវជាតិលេខ ៦ ជាតំបន់ដែលរងការវិនាសអន្តរាយយ៉ាងខ្លាំង ដោយសារប្រតិបត្តិការចេនឡាទី១ និងទី២ របស់ លន់ នល់ ។ នៅដើមដំបូងនៃសង្គ្រាមព្រំដែនជាមួយវៀតណាម ភឹម ត្រូវបានអង្គការទុកចិត្ត ដោយប្រគល់ឲ្យមើលខុសត្រូវ

ខ្សែការពារមួយ ក្នុងចំណោមខ្សែការពារដ៏សំខាន់បំផុតរបស់កម្ពុជា ។

នៅភាគខាងត្បូងមានតែផ្លូវជាតិលេខ១ប៉ុណ្ណោះ ដែលលាតសន្ធឹងតាមបណ្ដោយព្រំប្រទល់ភាគខាងត្បូងភូមិភាគបូព៌ា និងតភ្ជាប់ទីក្រុងព្រៃនគរមកក្រុងភ្នំពេញ កាត់តាមខេត្តស្វាយរៀង ត្រូវបានគេចាត់ទុកជាផ្លូវ មានសារសំខាន់ដូចគ្នា ។ ផ្លូវជាតិនេះលាតសន្ធឹងឆ្លងកាត់ខេត្តស្វាយរៀង និងតំបន់ដែលគេស្គាល់ក្រោមឈ្មោះថា "ចំពុះសេក" ជាទីលានដែលមានការប្រយុទ្ធបង្ហូរឈាមយ៉ាងខ្លាំងទាំងខាងពួកអាមេរិកាំង ក៏ដូចកងទ័ពវៀតណាម និងកម្ពុជា ។ សុន សេន ដែលមានមុខនាទីជារដ្ឋមន្ត្រីការពារប្រទេស ជាអ្នកទទួលបន្ទុកមើលខុសត្រូវលើផ្លូវជាតិលេខ១នេះ ។ ប្រហែលដើម្បីសង្កត់បញ្ជាក់ពី ខ្សែក្រវាត់ការពាររដ្ឋធានីគឺផ្លូវជាតិទាំងពីរនេះ ស្ថិតនៅក្នុងភូមិភាគបូព៌ាហើយមើលទៅ ទើបបានជា សោ ភឹម ត្រូវបានតែងតាំងជាប្រធាន "គណៈកម្មាធិការសមរភូមិ" នោះ ។

នៅពេលនេះ មជ្ឈិម បានកំណត់ទីទំហំនៃជម្លោះរបស់ខ្លួនជាមួយវៀតណាមរួចជាស្រេច ។ ក្នុងការបកស្រាយចុងក្រោយនេះ ពួកវៀតណាមមិនត្រឹមតែធ្វើឲ្យកម្រើកនូវនិន្នាការមានតាំងពីអតីតកាលមករបស់គេ ក្នុងការបញ្ចូលប្រទេសកម្ពុជាជាខបសម្ព័ន្ធ និងបំផ្លាញប្រជាជននេះឲ្យសាបសូន្យប៉ុណ្ណោះទេ ប៉ុន្តែ ពួកគេបម្រើជាសម្រាប់ពួកសូវៀត ។ ទោះជាដោយដឹងខ្លួន ឬមិនដឹងខ្លួនក៏ដោយ ក៏សង្គ្រាមដែលគេពង្រីកឲ្យធំនេះ ត្រូវសមនឹងបំណងផ្នែកចិត្តសាស្ត្រ និងនយោបាយរបស់កម្ពុជាទាំងស្រុង ។ រឿងនេះមានន័យថា ប៉ុល ពត ចង់ល្បងឫទ្ធិជាថ្មីជាមួយនឹងមហាអំណាចមួយ ក្នុងចំណោមមហាអំណាចធំៗនៃពិភពលោក ។ ដូចពួកគេធ្លាប់បានប្រកាសជ័យជម្នះរបស់គេលើសហរដ្ឋអាមេរិក ក្នុងកំឡុងសង្គ្រាមចុងក្រោយដែរ បក្ស និងមេដឹកនាំរបស់ខ្លួនបានអះអាងនៅពេលនេះថា ត្រូវឡោមព័ទ្ធដោយមហាអំណាចមួយទៀត ។ ប្រការនេះ វាសមស្របនឹងសេចក្ដីត្រូវការផ្នែកចិត្តសាស្ត្ររបស់គេ ដែលស្ថិតនៅក្នុងស្ថានភាពកណ្ដាលការប្រឈមមុខដាក់គ្នាជាសកល ដោយចាត់ទុកប្រទេស និងពួកគេជាចំណីដែលប្រទេសផ្សេងៗទៀត ប៉ងប្រាថ្នាចង់បាន ។

តាមរបៀបមួយដែលឆាប់យល់ការ និងដែលធ្វើឲ្យព្រួយបារម្ភបំផុតនោះ ពួកគេបានបង្កើតល្បែងប្រថុយខាត ឬចំណេញក្នុងសង្គ្រាម ដោយបញ្ជាក់អះអាងថា សង្គ្រាមជាលក្ខណៈដែលស្ដែងចេញឲ្យឃើញការបែកបាក់គ្នារវាងចិន-សូវៀត ។ ត្រង់ចំណុចនេះ ពួកគេប្រហែលជាមិនត្រូវការការលើកទឹកចិត្តរបស់ក្រុងប៉េកាំងប៉ុន្មានទេ ។ ជាទូទៅ ពួកចិនបានព្រមានពិភពលោកជាសាធារណៈ និងដោយឡែកសហរដ្ឋអាមេរិកថា ការដកថយទាំងស្រុងមួយរបស់អាមេរិកាំងចេញពីតំបន់នេះ ក្រោយឆ្នាំ១៩៧៥ នឹងបង្កឲ្យមានការទន្ទ្រានមួយដោយផ្ទាល់ពីរបបវាតទីនិយមសូវៀតមិនខាន ។ ក្នុងពេលមានសន្តិភាព ពួកចិនបានសន្យាផ្ដល់ជំនួយរបស់គេ ទៅឲ្យប្រទេសវៀតណាម បើសិនប្រទេសនេះបរិហារពីអនុត្តរភាពនិយមសូវៀតជាសាធារណៈ ប៉ុន្តែ ពួកវៀតណាមបានច្រានចោល ។ ឥឡូវនេះ ពួកខ្មែរក្រហមបានដុតបញ្ឆេះការវិវាទមួយ ដែលពួកចិនអាចអះអាងថាធ្វើឲ្យមានទម្ងន់ដល់ទស្សនៈរបស់គេ ។

នៅឆ្នាំ១៩៧៧ ក្នុងពេលដែលក្រុងប៉េកាំងយល់ព្រមផ្តល់អាវុធថ្មីៗមកឲ្យពួកកម្ពុជាដែលពួកគេទាមទារ ពួកចិនបានស្នើជាថ្មីឲ្យពួកខ្មែរបង្ហាញខ្លួនជាចំហប្រកាសខ្លួនជាជនកុម្មុយនិស្តបង្ហាញថា ប៉ុល ពត ជាអ្នកដឹកនាំបក្ស និងប្រទេស ហើយចាប់ផ្តើមទប់ទល់នឹងការរៀបរាប់រឿងរ៉ាវដ៏គួរឲ្យរន្ធត់ទាំងឡាយ របស់ពួកអ្នកភៀសខ្លួន ដែលរត់ចេញពីកម្ពុជាប្រជាធិបតេយ្យទៅប្រទេសថៃ ។ ជាថ្នូរនឹងការផ្តល់អាវុធនេះ និងការជួយគាំទ្រផ្នែកការទូតមួយរឹតតែខ្លាំងឡើងរបស់ពួកចិន ប៉ុល ពត បានទទួលយល់ព្រមចេញមុខដឹកនាំក្នុងឋានៈជាមេដឹកនាំរដ្ឋាភិបាលដែលគេបានគ្រោងរួចមកហើយ និងលះបង់ចិត្តគំនិតទ័ពព្រៃរបស់ខ្លួនចោល យ៉ាងហោចណាស់ ក្នុងវិស័យការទូតដែរ ។ ជំហាននេះ ត្រូវបានឆ្លងផុតនៅខែកញ្ញា ឆ្នាំ១៩៧៧ ក្នុងឱកាសធ្វើពិធីបុណ្យខួបនៃការបង្កើតបក្ស ។

ប៉ុន្តែ ប៉ុល ពត បានបញ្ឆេះសង្គ្រាមនៅមុនព្រឹត្តិការណ៍នេះ ។ នៅខែមិថុនា កងទ័ពរបស់ភូមិភាគបូព៌ា បានវាយប្រហារពួកវៀតណាមនៅតាមព្រំដែន ក្នុងតំបន់ផ្លូវជាតិលេខ៧ ដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ សោ ភឹម ។ តាមភស្តុតាងផ្សេងៗ បានឲ្យដឹងថា កងទ័ពបូព៌ាបានវាយប្រហារអាណិកជនវៀតណាម ដែលកំពុងរស់នៅក្នុងដែនដីមួយ ដែលគេកំណត់ឲ្យប្រទេសកម្ពុជាដោយកិច្ចព្រមព្រៀងមួយ ដែលសម្រេចចុះហត្ថលេខានៅឆ្នាំ១៩៦៧ ដោយសម្តេច ព្រះនរោត្តម សីហនុ ក្រុងហាណូយ និងរណសិរ្សជាតិរំដោះភាគខាងត្បូងវៀតណាម ។ នេះជាចំណែកដីមួយរបស់ខេត្តតាយនិញ ដែលវៀតណាមរៀបចំជាតំបន់សេដ្ឋកិច្ចថ្មីនៅទីនោះតាមកម្មវិធីរបស់ក្រុងហាណូយ ទុកសម្រាប់ដាក់ពួកអ្នកទីក្រុងដែលរបបនេះវិនិច្ឆ័យថា គ្មានប្រយោជន៍សម្រាប់សេដ្ឋកិច្ចនៅទីក្រុងព្រៃនគរ ។ ពួកកម្ពុជា បានចាត់ទុកបំណងនេះថា ជារបៀបបកស្រាយមួយរបស់កុម្មុយនិស្តអំពីទម្លាប់ចាស់គំរិលរបស់វៀតណាម ក្នុងការបញ្ជូននិគមជនជាច្រើនឲ្យមករាតត្បាតដណ្តើមទឹកដីបរទេសដោយរៀបចំជាកសិដ្ឋាននៅទីនោះ ។

ការប្រយុទ្ធគ្នាបានបន្តនៅក្នុងតំនប់នេះពេញរយៈពេលនៃខែកក្កដា ។ នៅថ្ងៃទី១៧ កក្កដា ពួកមេបញ្ជាការទ័ពរបស់ភូមិភាគបូព៌ា បានចេញផ្សាយរបាយការណ៍មួយ បន្ទាប់ពីបានបើកធ្វើការប្រជុំមួយ ស្តីពីបញ្ហាជម្លោះព្រំដែន ។ មានសល់តែមួយច្បាប់ប៉ុណ្ណោះ ដែលត្រូវបានរកឃើញឡើងវិញ គឺច្បាប់ដែលបញ្ជូនទៅឲ្យសមមិត្ត រិន មេបញ្ជាការកងពលធំលេខ៤ នៃភូមិភាគបូព៌ា ។ ឈ្មោះពិតរបស់គាត់គឺ ហេង សំរិន ជាមនុស្សម្នាក់ដែលបានសម្តែងតួនាទីមួយយ៉ាងសំខាន់ ក្នុងសង្គ្រាមរយៈពេលមួយឆ្នាំក្រោយមក ។ សម័យប្រជុំនេះ ទំនងជាដឹកនាំដោយ សោ ភឹម ដែលសម្រេចចេញរបាយការណ៍មួយ ដោយផ្សព្វផ្សាយមតិណែនាំទូទៅចំពោះមេបញ្ជាការទ័ពទាំងអស់របស់ភូមិភាគនេះ ។ នេះជាឯកសារសម្ងាត់មួយដែលគេទុកសម្រាប់តែ«មេបញ្ជាការ»ប៉ុណ្ណោះ ។ នេះជាសេចក្តីដកស្រង់មួយ ៖

មតិណែនាំទូទៅទីពីរ ក្នុងនាទីជាកងទ័ព ៖ យើងត្រូវតែបន្តការប្រុងប្រយ័ត្នជាប់ជានិច្ច ត្រៀមធ្វើការប្រយុទ្ធ និងកម្ទេចខ្មាំងសត្រូវគ្រប់ពេលវេលា នៅពេលថ្ងៃក៏ដូចជានៅពេលយប់ ។ យើងមិនត្រូវបើកឱកាសឲ្យសត្រូវ

ជ្រៀតចូលមកក្នុងផ្នែកណាមួយនៃទឹកដីរបស់យើង ហើយប្រព្រឹត្តការឈ្លានពានមួយនៅទីនោះទេ ។ បើសត្រូវធ្វើការឈ្លានពានមួយ យើងត្រូវតែប្រយុទ្ធតបត ដោយបញ្ឈប់ការរុលមកមុខរបស់វា ដោយកម្ទេចវា ហើយយើងមិនត្រូវកំណត់បញ្ឈប់ និងកម្ទេចពួកវានៅលើទឹកដីរបស់យើងទេ យើងត្រូវតែលុកចូលទៅប្រទេសវា ដើម្បីបង្ក្រាបវា និងកម្ទេចវានៅទីនោះវិញ ។ គោលដៅដែលត្រូវស្វែងរក គឺបង្កើនការលំបាករបស់សត្រូវឲ្យរឹតតែខ្លាំង ។ បើសិនជាយើងធ្វើរបៀបនេះ ការភ័យខ្លាចដែលញុំាំឲ្យយើងចង់ធ្វើទៅលើសត្រូវ នឹងកើនកាន់តែធំ ហើយនៅទីបំផុត វានឹងពុំហ៊ានធ្វើការឈ្លានពានរបស់វាជាថ្មីប្រឆាំងនឹងយើងទេ ។ ផ្ទុយទៅវិញ រឿងនេះនឹងធ្លាក់ទៅលើវា ដែលខំប្រឹងបញ្ឈប់ការវាយប្រហាររបស់យើងម្តង ។

របាយការណ៍បានបញ្ជាក់ថា នេះជា«មគិណែនាំទូទៅ»មួយ ពុំមែនជាបទបញ្ជាឲ្យអនុវត្តភ្លាមៗទេ ។ គឺទាល់តែនៅពេលណាដែលយើងត្រូវចេញប្រយុទ្ធ ទើបយើងអនុវត្តតាមមគិណែនាំនេះ... ។ គ្មានកន្លែងណាមួយគ្មានកងឯកភាពទ័ពណាមួយ ត្រូវទទួលការអនុញ្ញាតឲ្យវាយប្រយុទ្ធដាច់ ។ ផ្ទុយទៅវិញ ត្រូវរក្សាឯកភាពរបស់យើងឲ្យបាន» ។

ការចេញផ្សាយរបាយការណ៍នេះ បានជួនគ្នាជាមួយនឹងការប្រកាសជាសាធារណៈថា ប្រទេសឡាវ និងវៀតណាមបានព្រមព្រៀងគ្នាចុះហត្ថលេខាលើសន្ធិសញ្ញាមិត្តភាពមួយ –ដូចសន្ធិសញ្ញា ដែលក្រុងភ្នំពេញមិនព្រមសម្រេចជាមួយក្រុងហាណូយដោយចចេសដែរ ។ ពួកកម្ពុជាវិនិច្ឆ័យក្នុងសន្ធិសញ្ញានេះថា ជាច្រកចេញមួយដែលសម្រេចចំពោះស្ថានភាពផ្ទាល់របស់គេ ។ អៀង សារី បានធ្វើការកត់សម្គាល់ថា «បើសិនជាប្រទេសឡាវមិនព្រមចូលរួមក្នុងសហព័ន្ធឥណ្ឌូចិនទេ ពួកវៀតណាមក៏ពុំអាចរៀបចំបង្កើត បានដែរ ។ ប៉ុន្តែ ពួកកម្មាភិបាលរបស់ឡាវ ត្រូវបានគេបញ្ចូលទៅក្នុងនោះរួចជាស្រេចទៅហើយ ដោយពួកវៀតណាមនៅគ្រប់លំដាប់ថ្នាក់រដ្ឋអំណាចទាំងអស់[១៣]» ។

ក្រុងភ្នំពេញ បានកាត់យល់សន្ធិសញ្ញាមិត្តភាពទាំងឡាយជាមួយប្រទេសវៀតណាមថា ជាការចាក់គ្រឹះរបស់សហព័ន្ធឥណ្ឌូចិនមួយដែលគេប្រោះឲ្យរស់ឡើងវិញ ដែលនឹងត្រូវត្រួតត្រាដោយក្រុងហាណូយ ហើយនឹងឲ្យប្រថ្នុលពីទីបញ្ចប់នៃឯករាជ្យរបស់កម្ពុជាទៀត ។ នៅខែកក្កដា ប៉ុល ពត និងបក្សចាប់ផ្តើមដណ្តឹងសួរក្នុងចិត្តដោយក្តីព្រួយបារម្ភថា តើពួកវៀតណាមមានសមត្ថភាពយកឈ្នះក្នុងជម្លោះព្រំដែនមែនឬ? ។ មជ្ឈិមបានពិនិត្យមើលយ៉ាងល្អិតល្អន់បំផុត ចំពោះកងទ័ព ដែលកំពុងឈរជើងការពារព្រំដែន ដែលអាចត្រូវវាយប្រហាររបស់ភូមិភាគបូព៌ា ។ ប៉ុល ពត និងឌុច បានផ្ញើបញ្ជីរាយឈ្មោះពួកក្បត់ថ្មីមួយទៀតទៅឲ្យ សោ ភឹម ប៉ុន្តែ គាត់បានប្រកែកតវ៉ាថាមនុស្សទាំងនោះ ពុំអាចទៅជាអ្នកក្បត់បានទេ ព្រោះសុទ្ធតែជាអនុប្រធានរបស់គាត់ ជាមេបញ្ជាការដែលគួរឲ្យទុកចិត្តទាំងស្រុង ។ រឿងនេះប្រហែលជាមានការយល់ច្រឡំមួយហើយ ។

តាមការពិនិត្យឃើញរបស់ ឌុច ការយល់ច្រឡំគឺ សោ ភឹមខ្លួនឯង ។ សុន សេន ដែលទទួលខុសត្រូវសមរភូមិផ្លូវជាតិលេខ១ និងជាអគ្គបញ្ជាការកងទ័ពនោះ ក៏ជាមេកោយផ្ទាល់របស់ ឌុច ដែរ ។ ដោយមិនអាចទទួលស្គាល់បញ្ជីឈ្មោះរបស់ ឌុច ភឹម បានចាប់ផ្ដើមស៊ើបអង្កេតរឿងនេះដោយខ្លួនឯង ។ ជាមួយនឹងវត្តមានរបស់ សុន សេន ដែលស្ថិតនៅក្នុងភូមិភាគបូព៌ាស្រាប់ ឌុច និង ប៉ុល ពត អាចរៀបចំធ្វើការបោសសម្អាតភូមិភាគនេះ ដោយមិនចាំបាច់ចំណាយកងទ័ពសម្រាប់ប្រយុទ្ធទៀតឡើយ ។

នៅខែសីហា ភឹម បានចាកចេញពីប្រទេសដើម្បីបន្តព្យាបាលជំងឺមួយនៅក្រុងប៉េកាំង ។ គាត់ស្ថិតនៅឆ្ងាយពីមុខតំណែងរបស់គាត់នៅខែសីហា និងខែកញ្ញា ដែលក្នុងរយៈពេលនោះ ជម្លោះតាមព្រំដែន បានចាប់ផ្ដើមឡើងដោយពិតប្រាកដ មជ្ឈិមក្នុងពេលដែលបញ្ចប់ការរៀបចំប្រុងប្រៀបរបស់ខ្លួន ក្នុងការបោសសម្អាតភូមិភាគបូព៌ាដែរ ។ បើវិនិច្ឆ័យរឿងនេះតាមទិដ្ឋភាពខាងក្រៅ ភឹម ត្រូវបានទទួលធ្វើបដិសណ្ឋារកិច្ច ប្រកបដោយការគោរពជាក់លាក់មួយ ក្នុងរយៈពេលនៃការស្នាក់អាស្រ័យរបស់គាត់នៅប្រទេសចិន ។ គាត់បានទទួលគុណប្រយោជន៍ដូច្នេះ ប្រហែលមកពីការផ្លាស់ប្ដូរមួយកំពុងកើតឡើង ដែលត្រូវសម្រេចតាមរយៈជ័យជម្នះរបស់ពួកអ្នកប្រតិបត្តិនិយម លើពួកម៉ៅនិយមនោះហើយ ។ ដោយមានសុខភាពស្រួលបួលឡើងវិញ ភឹម បានមានមុខនៅក្នុងខ្សែភាពយន្តឃោសនាមួយ ដែលប្រទេសចិនបានផលិតចេញនៅចុងឆ្នាំនោះ ។ ជាមួយនឹងពួកអ្នកប្រតិបត្តិនិយម ផលប្រយោជន៍របស់ក្រុងប៉េកាំងចំពោះប្រទេសកម្ពុជា បានក្លាយទៅជាមានលក្ខណៈខាងយុទ្ធសាស្ត្រច្រើនជាងខាងមនោគមវិជ្ជា ។

នៅខែសីហា ភាពស្ងប់ស្ងាត់បានកើតមានឡើងវិញនៅតាមព្រំដែន ។ វ៉ី ង្វៀងយ៉ាប រដ្ឋមន្ត្រីក្រសួងការពារប្រទេសរបស់វៀតណាមបានធ្វើដំណើរមកត្រួតមើលកងទ័ពរបស់ខ្លួន ហើយមានលេចព្រាពាក្យចចាមអារ៉ាមស្ដីពីបទឈប់បាញ់គ្នាមួយ ។

ប៉ុន្មានសប្ដាហ៍ក្រោយមក ពួកកម្ពុជាបានចាប់ផ្ដើមវាយប្រហារជាថ្មី ។ “មតិណែនាំទូទៅទីពីរ” បានក្លាយទៅជាបទបញ្ជាប្រចាំថ្ងៃ កងទ័ពរបស់ភូមិភាគបូព៌ា បានឆ្លងចូលទៅក្នុងខេត្តតាយនិញ ហើយបើកការវាយលុកទៅលើពួកវៀតណាម ។ តាមបញ្ជារបស់ សុន សេន កងទ័ពខ្មែរក្រហមប្រហែលជាចូលយ៉ាងជ្រៅទៅក្នុងទឹកដីរបស់វៀតណាមព្រមៗគ្នា ដើម្បីស្ទាបស្ទង់ខ្សែការពាររបស់សត្រូវ និងរិះប្រុងប្រយ័ត្នប្រឆាំងនឹងអាកប្បកិរិយាទាមទារទឹកដីរបស់ខ្លួនផង ។ ប៉ុន្តែ កងទ័ពរបស់ភូមិភាគបូព៌ា បានត្រូវពួកវៀតណាមវាយកម្ទេចយ៉ាងធ្ងន់ធ្ងរ ៖ ប្រទេសវៀតណាមមិនព្រមទទួលយក“មេរៀន”របស់ពួកកម្ពុជាទេ ។

ភូមិភាគរបស់ សោ ភឹម ត្រូវទទួលបរាជ័យ កងទ័ពរបស់គាត់ ពុំបានដាក់ទណ្ឌកម្មធ្ងន់ធ្ងរមួយទៅលើទ័ពវៀតណាមដែលមានឧត្ដមភាពជាងខ្លួនឡើយ ។ ឌុច អាចបន្តឲ្យសំអាងដល់នូវការស៊ើបអង្កេតរបស់គាត់ ប្រឆាំងនឹង សោ ភឹម និងកម្មាភិបាលរបស់ភូមិភាគមួយចំនួនធំ ព្រមទាំង“ពួកអ្នកចាស់” រាប់ពាន់នាក់ ដែលត្រូវគេ

សង្ស័យថា បានប្រព្រឹត្តអំពើក្បត់ជង ។ អ្នកទាំងនោះនឹងត្រូវចោទប្រកាន់ថា «ពួកក្បាលយួនខ្លួនខ្មែរ» ។ ភូមិភាគបូព៌ាត្រូវបានជ្រើសរើសសម្រាប់ទម្លាក់ទោសកំហុសទៅលើគ្រប់បែបយ៉ាង ចំពោះបរាជ័យផ្នែកយោធា ដែលប្រទេសកម្ពុជាបានសាកល្បងក្នុងសង្គ្រាមព្រំដែនរបស់ខ្លួនជាមួយនឹងទេសវៀតណាម ។

## ការចេញមុខជាចំហ

នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៧៧ ប៉ុល ពត បាននិយាយទៅកាន់ប្រជាជាតិ និងបង្ហាញខ្លួនជាមេដឹកនាំប្រទេស និងបក្សកុម្មុយនិស្តកម្ពុជា ដែលគេមិនធ្លាប់ស្គាល់សោះរហូតមកដល់ពេលនេះ ។ ភាពអាថ៌កំបាំងត្រូវបានដករបាំងចេញ ។

ក្នុងសុន្ទរកថាមួយដែលមានរយៈពេលប្រាំម៉ោង គាត់បានបញ្ចេញឲ្យដឹងថា «អង្គការ» គឺបក្សកុម្មុយនិស្តជាកម្លាំងដែលលាក់ខ្លួនពីក្រោយឆាកពេញរយៈពេលនៃប្រវត្តិសាស្ត្របច្ចុប្បន្នកាលនេះរបស់ប្រទេសកម្ពុជា ។ គឺបក្សនេះហើយ ដែល ប៉ុល ពត បានលើកគុណសម្បត្តិថា ជាអ្នកជួយតម្រង់ផ្លូវឲ្យសម្ដេច ព្រះនរោត្តម សីហនុ ប្រកាន់ជំហរអព្យាក្រឹត និងមិនចូលបក្សសម្ព័ន្ធក្នុងទសវត្សរ៍ឆ្នាំ១៩៥០ និងឆ្នាំ១៩៦០ ។ បន្ទាប់ពីរដ្ឋប្រហាររបស់ លន់ នល់ ឆ្នាំ១៩៧០ គឺបក្សនេះដែរដែលបានជំរុញឲ្យសម្ដេចធ្វើការសម្រាប់ពួកកុម្មុយនិស្តយ៉ាងប៉ិនប្រសប់ ក្នុងក្របខ័ណ្ឌនៃសម្ព័ន្ធភាពមួយដែលមានលក្ខណៈជាយុទ្ធវិធីសុទ្ធសាធ ។

ប៉ុល ពត បានគូសបញ្ជាក់ថា បក្សបានជ្រើសរើសធ្វើពិធីបុណ្យខួបថ្ងៃបង្កើតបក្សរបស់ខ្លួន ដើម្បី«ប្រកាសជាឱឡារិកចំពោះមុខប្រជាជាតិ និងពិភពលោកនូវអត្ថិភាពរបស់ខ្លួនជាផ្លូវការ[១៤]» ។ គាត់បានសម្ដែងនូវ«ការគោរពដ៏ជ្រាលជ្រៅ» ចំពោះកងទ័ព និងប្រជាកសិករបដិវត្តទាំងអស់ដែលបាន «រក្សាការពារទឹកដីដ៏ពិសិដ្ឋរបស់ជាតិ» កសាងកម្ពុជាថ្មី និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជន ដោយដើរតាមបាវចនា ៖ ធ្វើឲ្យប្រទេសរីកចម្រើន តាមជំហានមហាលោតផ្លោះមហាអស្ចារ្យ!» ។

គោលដៅនៃសុន្ទរកថា របស់ ប៉ុល ពត គឺញ៉ាំងឲ្យមិត្តទាំងអស់ជឿថា ក្រោមការដឹកនាំរបស់គាត់ ពួកកុម្មុយនិស្តនៅប្រទេសកម្ពុជា បានបង្កើតបក្សវណ្ណៈអធនពិតប្រាកដមួយដែលប្រកាន់តាមលទ្ធិម៉ាក់-លេនីន ។ នេះជាសំឡេងប្រមូលរួបរួមមួយ និងជាការអំពាវនាវមួយឲ្យមនុស្សទាំងអស់រួបរួមគ្នាពីក្រោយគាត់ ប្រឆាំងនឹងពួកវៀតណាម និងពួកអ្នកដែលគេសន្មតថា ជាភ្នាក់ងាររបស់វៀតណាមដែលជ្រៀតចូលក្នុងបក្ស ។ ក្នុងរយៈពេលប្រាំម៉ោង គាត់បានបរិហារគំនិតនេះយ៉ាងខ្លាំង ដោយពិនិត្យប្រវត្តិសាស្ត្ររបស់កម្ពុជាមួយម្ដងៗ តាមលំដាប់លំដោយ ស្របទៅតាមទស្សនៈយល់ឃើញរបស់បក្សកុម្មុយនិស្ត ។

គាត់បានទម្លាក់ទោសទៅព្រះពុទ្ធលើសាសនា ៖ ជំនឿចំពោះបរលោក ជោគជតារាសី និងកម្មផលពីអតីត

ជាតិ បាននាំឲ្យប្រជាកសិករយើងយល់ច្រឡំអំពីសារជាតិវណ្ណៈក្នុងការប្រឆាំង ។

គាត់បានបង្ហាញឲ្យឃើញថា តួនាទីរបស់សម្ដេច ព្រះនរោត្តម សីហនុ មានសារសំខាន់តិចតួចបំផុត ហើយបានរិះគន់ស្ថាប័នរាជានិយមថែមទៀត ។ គាត់ពុំទទួលស្គាល់គុណូបការៈរបស់ពួកវៀតណាមដែលបានជួយប្រយុទ្ធក្នុងបណ្ដាឆ្នាំដំបូងៗនៃសង្គ្រាមប្រឆាំងនឹងកងទ័ពរបស់ លន់ នល់ ទេ ហើយក៏មិនសូវសង្កត់បញ្ជាក់ពីតួនាទីរបស់ពួកចិនដែរ ពីព្រោះគាត់គ្មានរៀបរាប់បញ្ចូលប្រទេសណាមួយឡើយ ក្នុងចំណោមប្រទេសទាំងពីរនេះ ។ គាត់និយាយថា ជំនួយរបស់បណ្ដាមិត្តភក្ដិបរទេស វាគ្រាន់តែបន្ទាប់បន្សំប៉ុណ្ណោះ ។

ហើយគាត់បានប្រកាសថា បក្សកុម្មុយនិស្តបានរំដោះប្រទេសកម្ពុជាជាលើកដំបូងបំផុត នៃប្រវត្តិសាស្ត្ររបស់ខ្លួន ៖ ក្នុងរយៈពេលជាងពីរពាន់ឆ្នាំ ប្រជាជនកម្ពុជាបានរស់នៅក្នុងសភាពខ្វះខាតសព្វបែបយ៉ាង និងក្នុងក្ដីអស់សង្ឃឹមយ៉ាងខ្លាំង ។ គាត់បានចោទសួរសំណួរមួយមុននឹងឆ្លើយខ្លួនឯងថា តើថ្ងៃណាដែលជាថ្ងៃលើកកិត្តិយសសម្រាប់ប្រជាជនទាំងនេះ? គឺថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ជាថ្ងៃជ័យជម្នះលើកងទ័ពរបស់ លន់ នល់ ។

បក្សបានរំដោះប្រជាជន រាំងខ្ទប់ការបាត់បង់ទឹកដីរបស់កម្ពុជាជាស្ថាពរ ពីព្រោះរឿងនេះធ្លាប់កើតមានកាលពីមុនរួចមកហើយ នៅពេលដែលប្រទេសជាតិស្ថិតនៅក្រោមការត្រួតត្រារបស់វណ្ណៈកេងប្រវ័ញ្ចផ្សេងៗ ។ គាត់អះអាងថា «ប្រជាជននេះមិនអនុញ្ញាតឲ្យអ្នកណាម្នាក់ប្រព្រឹត្តអំពើរំលោភបំពាន ការឈ្លានពាន ការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងការធ្វើវិទ្ធង្សនា និងការបង្កហេតុ ព្រមទាំងការបង្ខិតព្រំដែនរបស់ខ្លួនជាដាច់ខាត» ។

ប៉ុល ពត បានបញ្ជាក់បំភ្លឺជាថ្មីថា ប្រទេសកម្ពុជាពុំមានចេតនាបង្កហេតុនឹងប្រទេសណាមួយទាល់តែសោះទោះជាប្រទេសណាក៏ដោយហើយ ថាប្រទេសតូច និងទន់ខ្សោយមួយពុំអាចលេបត្របាក់ប្រទេសធំមួយបានទេ ។

នៅថ្ងៃបន្ទាប់ពីការថ្លែងសុន្ទរកថារបស់គាត់ ប៉ុល ពត បានឡើងយន្តហោះឆ្ពោះទៅក្រុងប៉េកាំង ហើយក្រោយមកទៅក្រុងព្យុងយ៉ាងទៀត ។

ដោយត្រូវធ្វើឲ្យសប្បាយរីករាយខ្លាំង ពួកចិនបានត្រៀមបម្រុងនូវការទទួលស្វាគមន៍យ៉ាងកក់ក្ដៅមួយចំពោះជនផ្ដាច់ការនេះ និងអ្នកហែហមរបស់គាត់ដែលរួមមានទាំង អៀង សារី ផង ។ នៅទីក្រុងព្យុងយ៉ាង ប៉ុល ពត បានប្រាប់ឲ្យដឹងជីវប្រវត្តិសង្ខេបមួយនៃជីវិតផ្ទាល់របស់គាត់ ។ ពួកចិន បានជួយឧបត្ថម្ភពួកកម្ពុជា ក្នុងការបោះពុម្ពផ្សាយទស្សនាវដ្ដីខ្នាតធំមួយ រំលេចដោយរូបភាពពណ៌ធម្មជាតិស្ដីអំពីការបដិវត្តន៍របស់ខ្មែរ ដែលមានចំណងជើងថា កម្ពុជាប្រជាធិបតេយ្យបោះជំហានទៅមុខ ។ ខ្សែភាពយន្តរបស់ចិន ដែលធ្វើឲ្យ សោ ភឹម សេចក្ដោឡើង ក៏បានចេញផ្សាយនៅជំនាន់នោះដែរ ។ ដូចគ្នានឹងទស្សនាវដ្ដី ខ្សែភាពយន្តនេះ បានបង្ហាញឲ្យឃើញពីប្រទេសមួយដែលសម្បូរសប្បាយនឹងពួកកសិករ និងកម្មករ ដែលស្រឡាញ់ការងារកំពុងជីកប្រឡាយទឹក ដាំនិងប្រូតស្រូវ ដោយផ្ដល់នូវកម្លាំងចិត្តជាថ្មីដល់រោងចក្រធុនតូច ។ ការឃោសនាអំពីសង្គ្រាម ផ្លាស់ប្ដូររូបភាពប្រទេសកម្ពុជា បានត្រូវបញ្ចេញឲ្យគេដឹងឮ ។

អៀង សារី បានបំពេញមុខងាររបស់គាត់ក្នុងបេសកកម្មនេះដោយយកចិត្តទុកដាក់បំផុត ។ គាត់បានធ្វើដំណើរទៅក្រុងញូវយ៉ក ជាកន្លែងដែលគាត់បានថ្លែងសុន្ទរកថាមួយនៅអង្គការសហប្រជាជាតិ ហើយបានបន្ទុយឲ្យដឹងថា ពួកអ្នកកាសែតខាងលិច និងបណ្ដាមិត្តភក្ដិបរទេសនឹងត្រូវអញ្ជើញឲ្យទៅកាន់ប្រទេសកម្ពុជាក្នុងពេលខាងមុខឆាប់ៗនេះ ។ គាត់បានចែកទស្សនាវដ្ដី បញ្ចាំងខ្សែភាពយន្ត ដោយគ្មានខ្វាយខ្វល់នឹងការនិយាយរឿងដ៏គួរឲ្យព្រឺខ្លាចដែលប្រជាជនកម្ពុជាភៀសខ្លួនទៅប្រទេសថៃ បាននិយាយប្រាប់អ្នកសារពត៌មានផងទេ ។

ប៉ុន្ដែ គេពុំអាចបំផុតចោលនូវភស្ដុតាងទាំងនេះដោយងាយៗនោះឡើយ ។ នៅក្រុងបាងកក ពួកអ្នកនិពន្ធពួកអ្នកកាសែតបានរៀបរាប់តាមសម្ដីនិយាយរបស់អ្នកភៀសខ្លួន ពីអំពើអយុត្តិធម៌ និងការបង្ហូរឈាមផ្សេងៗយ៉ាងស៊ិតស៊្វាយដែលតាមពួកអ្នកភៀសខ្លួនថា នេះជាវាសនារបស់មនុស្សសាមញ្ញក្នុងកម្ពុជាប្រជាធិបតេយ្យ ។ ប្រជាជាតិបស្ចិមប្រទេសជាច្រើន បានរៀបចំសំណុំរឿងដោយសំអាងលើឯកសារបង្ហាញឲ្យឃើញពីភាពរន្ធត់ញាប់ញ័រ ចំពោះអ្វីដែលឥឡូវនេះគេឲ្យឈ្មោះថា របប ប៉ុល ពត ។ ប្រទេសអង់គ្លេស បាននាំមុខគេក្នុងការផ្ដួចផ្ដើមគំនិតមួយ ដើម្បីបង្ខំឲ្យគណៈកម្មាធិការការពារសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ថ្កោលទោសប្រទេសកម្ពុជា ។ មួយឆ្នាំក្រោយមក គណៈកម្មាធិការនេះបានចេញផ្សាយឯកសារមួយ ដោយសន្មតថាពួកខ្មែរក្រហមនឹងឆ្លើយតបចំពោះការចោទប្រកាន់ទាំងអស់ ដែលផ្ដោតប្រឆាំងនឹងពួកគេ ។ ចំនួនប្រជាជនកម្ពុជា ដែលភៀសខ្លួនទៅប្រទេសថៃ បានកើនឡើងយ៉ាងសន្ធឹកសន្ធាប់នៅឆ្នាំ១៩៧៧ បន្ទាប់ពីមានការបោសសម្អាតភូមិភាគពាយ័ព្យ ។ ការបោសសម្អាតនេះ បានផ្ដើតឲ្យមានការច្របូកច្របល់មួយ ដែលល្មមបើកឱកាសឲ្យប្រជាជនកម្ពុជារាប់រយនាក់រត់ភៀសខ្លួនចេញ ហើយការឆ្លើយជាសាក្សីដ៏គួរឲ្យរន្ធត់របស់ពួកគេ បានជំរុញឲ្យប្រជាជនដទៃទៀតនៅលោកខាងលិច ទាមទារយ៉ាងហោចឲ្យមានការស៊ើបអង្កេតមួយនៅប្រទេសកម្ពុជាផ្ទាល់ ។

ពួកវៀតណាម បានឃ្លាំមើលដោយប្រុងប្រយ័ត្ននូវការតទល់គ្នានេះ អំពីរឿងសិទ្ធិមនុស្សនៅប្រទេសកម្ពុជា ហើយមិនបានថ្កោលទោសនយោបាយរបស់ប្រទេសជិតខាងខ្លួន ក្នុងវិស័យនេះឡើយ ។ ហើយទាំង ប៉ុល ពត ក្នុងសុន្ទរកថាជាច្រើនរបស់គាត់ ទាំង អៀង សារី ក្នុងបទសម្ភាសន៍របស់គាត់នៅអង្គការសហប្រជាជាតិ គឺមិនដែលចេញឈ្មោះប្រទេសវៀតណាមម្ដងណាឡើយ ។ ពួកវៀតណាម បានចូលរួម ក្នុងការទទួលធ្វើបដិសណ្ឋារកិច្ច អៀង សារី នៅអង្គការសហប្រជាជាតិ ថ្វីបើ ង្វៀង កូថាច់ *(Nguyen Co Thach)* ដែលកាលណោះជាអនុរដ្ឋមន្ត្រីការបរទេសរបស់ប្រទេសវៀតណាម បានព្រមានអ្នកកាសែតម្នាក់ ដែលគេអញ្ជើញមកចូលរួមក្នុងពិធីនេះ កុំឲ្យប្រើពាក្យ “ឥណ្ឌូចិន” នៅ ចំពោះមុខ សារី ក៏ដោយ ។ ថាច់ និយាយថា “ពួកកម្ពុជាមិនចូលចិត្តពួកគេនិយាយពីពាក្យនេះទេ[១៥] » ។

ការធ្វើដំណើរជាលើកដំបូង និងជាលើកចុងក្រោយរបស់ ប៉ុល ពត ក្នុងឋានៈជាប្រមុខរដ្ឋរបស់កម្ពុជា មានត្រឹមតែប្រទេសចិន និងកូរ៉េខាងជើងប៉ុណ្ណោះ ។ គាត់បានវិលត្រឡប់មកប្រទេសវិញ ដើម្បីត្រៀមរៀបចំធ្វើ

សង្គ្រាម ។

នៅឆ្នាំ១៩៧៧ ប្រហែលជាមានសមរភូមិពីរនៅពេលដំបូង ៖ នៅតាមព្រំដែនជាមួយប្រទេសថៃ និងព្រំដែនជាមួយប្រទេសវៀតណាម ។ នៅឆ្នាំនោះ ប្រទេសថៃបានរាយការណ៍ឲ្យដឹងពីឧប្បត្តិហេតុព្រំដែនប្រមាណមួយរយលើកជាមួយប្រទេសជិតខាងខ្លួន ភាគច្រើនគឺនៅក្នុងតំបន់នានាដែលទាមទារព្រមៗគ្នាដោយពួកថៃផង និងពួកខ្មែរផង ។ ប៉ុន្តែ នៅខែតុលា ឆ្នាំ១៩៧៧ បន្ទាប់ពីបានវិនិច្ឆ័យថា ប្រទេសវៀតណាមជាសត្រូវពិតប្រាកដ ពួកមេដឹកនាំបក្សត្រូវការបញ្ចប់ការប្រយុទ្ធគ្នានៅតាមព្រំដែនថៃមួយអន្លើ ។ គេត្រូវតែរក «ភ្នាក់ងារសម្ងាត់របស់វៀតណាម» ម្នាក់ដើម្បីទម្លាក់កំហុសពីបញ្ហាព្រំដែនជាមួយប្រទេសថៃ ។ តាមការពិត កងទ័ពខ្មែរក្រហមនៅតាមព្រំដែនប្រទេសថៃ បានទទួលបទបញ្ជាផ្សេងៗ ដូចគ្នានឹងកងទ័ពដែលកំពុងឈរជើងការពារតាមព្រំដែនជាមួយប្រទេសវៀតណាមដែរ ៖ «ការពារ» ពោលគឺវាយប្រហារដែនដីទាំងឡាយ ដែលនៅមានការជជែករកខុសត្រូវនៅឡើយ ។

មជ្ឈិមបានបញ្ជូនកងទ័ពរបស់ភូមិភាគនិរតីទៅបោសសម្អាតភូមិភាគពាយ័ព្យរួចហើយ នៅពេលដែលកើតមានឧប្បត្តិហេតុផ្សេងៗនៅតាមព្រំដែនថៃ ។ ពីដំបូង បើពួកមេដឹកនាំបក្សស្តីបន្ទោសឲ្យ រស់ ញឹម លេខាបក្សភូមិភាគពាយ័ព្យ ចំពោះការធ្វើមិនបានសម្រេចលទ្ធផលផ្នែកកសិកម្ម និងប្រព័ន្ធធារាសាស្ត្រ តាមសំណូមពរដែលគេចង់បាននោះ នៅដំណាច់ឆ្នាំ១៩៧៧ ពួកគេបានលើកឡើងនូវការចោទប្រកាន់ថ្មីមួយទៀត គឺការញុះញង់ឲ្យកើតមានបញ្ហាព្រំដែនជាមួយប្រទេសថៃ ។ ហេតុនេះ រស់ ញឹម ត្រូវបានស្តីបន្ទោស មិនត្រឹមតែចំពោះសកម្មភាពបំផ្លិចបំផ្លាញបម្រើឲ្យពួកសេ.អ៊ី.អា. ប៉ុណ្ណោះទេ ប៉ុន្តែ ក៏ត្រូវចោទថាគាត់ជាភ្នាក់ងាររបស់វៀតណាម ។

ពេលនោះ អៀង សារី បានទទួលបំពេញបេសកកម្មកែលម្អទំនាក់ទំនងផ្សេងៗ ជាមួយប្រទេសថៃ ឲ្យបានប្រសើរឡើងវិញ ហើយបានញ៉ាំងឲ្យពួកថៃជឿថា ប្រទេសវៀតណាមរួមបង្កជាការគំរាមកំហែងសំខាន់បំផុតប្រចាំតំបន់ ។ គាត់បានរៀបរាប់ពី «ការរកឃើញ» ទាន់ពេលវេលានូវតួនាទីជាភ្នាក់ងារមុខពីររបស់ រស់ ញឹម ។ «តាម រស់ ញឹម ថា ឧប្បត្តិហេតុនៅតាមព្រំដែនត្រូវបានបង្កឡើងពួកភ្នាក់ងាររបស់«សេ.អ៊ី.អា.[១៦]» ។ (កាលនោះ រស់ ញឹម គ្រាន់តែនិយាយឡើងវិញ នូវការចោទប្រកាន់ផ្សេងៗ ដែលរៀបចំឡើងដោយមជ្ឈិម ដើម្បីស្តីបន្ទោសបណ្តាអនុប្រធានផ្ទាល់របស់គាត់ប៉ុណ្ណោះ) ។ «ប៉ុន្តែ សារី បានបន្ថែមថា យើងបានរកឃើញក្រោយមកថា រស់ ញឹម ក៏ធ្លាប់មានទំនាក់ទំនងផ្សេងៗ ជាមួយពួកវៀតណាមដែរ» ។

ចាប់តាំងពីពេលនោះមក ឧប្បត្តិហេតុជាមួយពួកថៃមិនសូវមានច្រើនប៉ុន្មានឡើយ ទោះបីជាវាមិនទាន់រលាយបាត់ទាំងស្រុងក៏ដោយ ហើយការទាក់ទងរវាងខ្មែរ-ថៃ កាន់តែមានភាពល្អប្រសើរជាងមុនគួរឲ្យកត់សម្គាល់ ។ ប្រទេសកម្ពុជាកំពុងត្រៀមខ្លួនប្រឡងប្ញទ្ធិនឹងប្រទេសវៀតណាមរួចជាស្រេច ។

នៅខែតុលា និងខែវិច្ឆិកា ពួកវៀតណាមមិននៅស្ងៀមដោយឥតគតបត ចំពោះការវាយលុកថ្មីមួយរបស់

កម្ពុជាឡើយ ។ ដោយមើលឃើញឱកាសមួយហុចឲ្យ ពួកគេបានចាប់ផ្តើមជ្រើសរើសពួកកម្ពុជាដែលភៀសខ្លួនទៅក្នុងភាគខាងត្បូងវៀតណាម និងនៅបរទេស ហើយបញ្ចូលអ្នកទាំងនេះ ជាសមាជិក«រណសិរ្សរួបរួម»មួយសំដៅរំដោះប្រទេសកម្ពុជាចេញពីរបប ប៉ុល ពត[១៧] ។ ប្រជាជនកម្ពុជាម្នាក់ ដែលកំពុងរស់នៅតំបន់ជាយក្រុងវ៉ាស៊ីនតោន បានទទួលសំបុត្រមួយ ដែលផ្ញើតាមប្រៃសណីយ៍ក្រុងមូស្គូ ដោយសុំឲ្យគាត់ត្រៀមខ្លួនជួយជនរួមជាតិរបស់ខ្លួន ដែលភៀសខ្លួនទៅរស់នៅភាគខាងត្បូងវៀតណាម ដើម្បី«រំដោះ»ប្រទេសកម្ពុជា[១៨] ។ ប្រជាជនកម្ពុជាដែលត្រូវទទួលឲ្យស្នាក់អាស្រ័យក្នុងជំរំជនភៀសខ្លួននានា នៅភាគ ខាងត្បូងប្រទេសវៀតណាមត្រូវបានរើសឲ្យធ្វើទ័ពទាំងអស់សម្រាប់បុព្វហេតុដូចគ្នា ។ អង្គការអន្តរជាតិជាច្រើនដែលចង់ជួយអ្នកភៀសខ្លួនទាំងនេះ ត្រូវបានអជ្ញាធរបដិសេធមិនឲ្យចូលជំរំនេះទេ ។ ប្រទេសវៀតណាមបានសម្រេចចិត្តថា គេមិនត្រូវការជំនួយអន្តរជាតិសម្រាប់ពួកអ្នកភៀសខ្លួនកម្ពុជាទេ ទោះណាជាគេធ្លាប់បានទាមទារកាលពីមុននូវជំនួយមួយដូចគ្នានឹងជំនួយផ្តល់ឲ្យប្រជាជនខ្មែរដែលភៀសខ្លួនទៅប្រទេសថៃក៏ដោយ ។

នៅខែមិថុនា ក្រុងហាណូយ និងក្រុងភ្នំពេញ បានបញ្ជូនកំណត់ហេតុទូតទៅវិញទៅមកជាច្រើនច្បាប់ស្តីពីបញ្ហាព្រំដែនរបស់គេ ។ ពួកវៀតណាមបានស្នើធ្វើការជួបប្រជុំថ្នាក់ខ្ពស់មួយ ចំណែកពួកកម្ពុជាស្នើថា ភាគីទាំងពីរត្រូវឲ្យកងទ័ពរបស់ខ្លួនដកថយមួយគីឡូម៉ែត្រ ចាប់ពីព្រំដែនដែលនៅមានការជជែកគ្នាចន្លោះខេត្តតាយនិញនិងស្វាយរៀង ។ ប្រទេសវៀតណាមពុំបានដកកងទ័ពរបស់ខ្លួនថយទេ ប្រទេសកម្ពុជា ក៏មិនអាចមិនពិភាក្សាអំពីការជួបប្រជុំមួយរវាងប្រទេសទាំងពីរដែរ ។ គំនិតផ្តួចផ្តើមខាងការទូតដំបូងៗនេះ បានទទួលបរាជ័យ ។

គេកំណត់ឲ្យប្រទេសវៀតណាមទទួលខុសត្រូវអំពីឧប្បត្តិហេតុផ្សេងៗ ដែលកើតមាននៅខែសីហា នៅពេលដែលកងទ័ពរបស់ភូមិភាគបូព៌ា បានបើកការវាយលុកដោយមិនអាចប្រកែកបាននៅខែកញ្ញា ។ នៅខែធ្នូការប្រយុទ្ធគ្នាបានផ្ទុះឡើងជាថ្មី ហើយម្តងនេះបាននាំទៅរកសង្គ្រាមមួយពិតប្រាកដ ។

ពួកវៀតណាមបានដាក់កងទ័ពប្រយុទ្ធលើសចំនួនទ័ពខ្មែរ ពីរដង (៦០.០០០នាក់ ទល់នឹង ២៨.០០០នាក់) និងប្រើប្រាស់ឧទ្ធម្ភាគចក្រប្រដាប់ដោយកាំភ្លើងយន្ត ព្រមទាំងរថក្រោះជាច្រើនគ្រឿង ។ ដោយគ្មានគ្រឿងសព្វាវុធមួយបែបនោះ ពួកកម្ពុជាបានពឹងផ្អែកជាសំអាងលើយុទ្ធវិធីសង្គ្រាមទ័ពព្រៃវិញ ។ ពួកវៀតណាម បានសម្រុកចូលមកក្នុងទឹកដីរបស់កម្ពុជា ដោយឆ្លងកាត់ខេត្តស្វាយរៀងសំដៅមកអ្នកលឿង ដែលជាចំណុចឆ្លងកាត់ទន្លេមេគង្គដ៏សំខាន់ ។ ប៉ុន្តែ ពួកខ្មែរបានវាយប្រយុទ្ធទប់ទល់យ៉ាងសាហាវប្តូរផ្តាច់ ថ្វីបើសត្រូវធ្វើឲ្យខ្លួនរងការខូចខាតធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ។ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ ប្រទេសកម្ពុជា បានផ្តាច់ចំណងទាក់ទងផ្សេងៗរបស់ខ្លួនជាមួយក្រុងហាណូយ ហើយការប្រយុទ្ធគ្នា បានបន្តរហូតមកដល់ពេលដែលពួកវៀតណាមដកថយទៅវិញ នៅខែមករា ឆ្នាំ១៩៧៨ ។ ប៉ុល ពត បានប្រកាសថា ប្រទេសរបស់គាត់ជាអ្នកមានជ័យជម្នះ ពួកវៀតណាមបានចាត់ទុកពួកកម្ពុជាថា ជាមនុស្សព្រៃផ្សៃ គ្មានអារ្យធម៌ ។ សង្គ្រាមពិតប្រាកដបានចាប់ផ្តើមឡើងហើយ ។

វិទ្យុទាំងសងខាងបានផ្សព្វផ្សាយសេចក្ដីរាយការណ៍ អំពីការច្បាំងគ្នាជាច្រើន ដោយដាស់ឲ្យកម្រើកឡើងវិញ នូវបដិបក្ខភាពជាតិសាសន៍ ដែលបាត់ជាយូរមកហើយ ។ ពួកវៀតណាមបានចោទពួកកម្ពុជាថា «រំលោភលើរូបកាយនារីភេទ វះយកទារកចេញពីផ្ទៃម្ដាយ វះពោះ កាត់ក្បាលមនុស្សពេញវ័យ និងទាញយកថ្លើមរបស់គេ សម្លាប់រង្គាលក្មេងៗ ហើយបោះខ្មោចទាំងនោះទៅក្នុងភ្លើង[១៩] » ។

វិទ្យុភ្នំពេញបានបញ្ជាក់ថា ពួកវៀតណាមដែលចូលមកកម្ពុជា គឺដើម្បី«ឆក់ប្លន់ និងនាំយកស្រូវអង្ករ ទៅរាប់ពាន់តោន បាញ់រះទៅលើប្រជាជន ទាំងចាស់ ទាំងក្មេង ដុតផ្ទះ លួចគោ ក្របី មាន់ទា និងទ្រព្យសម្បត្តិរបស់ប្រជាជន ចាប់រំលោភនិងសម្លាប់នារីភេទ របៀបដូចគ្នានឹងកងទ័ពរបស់ ធីវ និង គី ប្រធានាធិបតីនិងអនុប្រធានាធិបតីសាធារណរដ្ឋវៀតណាមខាងត្បូង ក្នុងអំឡុងឆ្នាំ១៩៦៧-៤៩៧៥ -កំណត់របស់អ្នកបកប្រែ) ឬពួកអ្នកស៊ីឈ្នួលច្បាំងជាតិកូរ៉េខាងត្បូងដែរ ឬដោយរបៀបអាក្រក់ជាងនេះទៀត[២០] » ។

ពួកខ្មែរបានបកស្រាយការប្រព្រឹត្តនេះ ដោយនិយាយថា ៖ «ពួកវៀតណាម តែងតែមើលងាយ និងសម្លែងឫកពាក្រអឺតក្រទមជាមួយនឹងប្រជាជនកម្ពុជាជានិច្ច ។ ប្រជាជននិងប្រជាជាតិកម្ពុជាក៏ដូចប្រជាជាតិតូចៗដទៃទៀតដែរ តែងមានកិត្តិយស និងសេចក្ដីថ្លៃថ្នូររបស់ខ្លួន... អ្នកទាំងនោះស្រឡាញ់ពូជសាសន៍របស់គេជ្រាលជ្រៅបំផុត ហើយនឹងមិនបណ្ដោយឲ្យកិត្តិយស និងសេចក្ដីថ្លៃថ្នូរនេះរលត់រលាយឡើយ» ។

នៅពេលដែលវិទ្យុភ្នំពេញប្រកាសថា កងទ័ពរបស់កម្ពុជាបានទទួល«ជ័យជម្នះមួយជាប្រវត្តិសាស្ត្រ» មន្ទីរពេទ្យនានានៅរដ្ឋធានីបានរាយការណ៍ឲ្យដឹងពីរឿងមួយផ្សេងទៅវិញ ។ មន្ទីរពេទ្យទាំងនោះ ពោរពេញទៅដោយអ្នករបួសដែលមួយចំនួនធំបានត្រូវស្លាប់ ពីព្រោះ ពួកកម្មាភិបាលពេទ្យខ្មែរក្រហមដែលគេបណ្ដុះបណ្ដាលជា«វេជ្ជបណ្ឌិតប្រជាជន» នោះ សុទ្ធតែជាមនុស្សគ្មានសមត្ថភាព ។ គេបានអំពាវនាវសុំឲ្យប្រជាជនមកផ្ដល់ឈាមរបស់ខ្លួននៅមន្ទីរពេទ្យ ប៉ុន្តែ គ្រូពេទ្យទាំងនោះក៏គ្មានសមត្ថភាពចាក់យកឈាមដ៏សាមញ្ញមួយដូចតែគ្នា ។

សកម្មភាពទាំងឡាយរបស់បក្ស គ្មានស្របតាមការប្រកាសជាសាធារណៈអំពីជ័យជម្នះនោះឡើយ ។ ការបោសសម្អាតគណៈដឹកនាំ និងប្រជាជនរាប់ពាន់នាក់នៅភូមិភាគបូព៌ាបានចាប់ផ្ដើម ។

## ការបោសសម្អាតនៅទឹកបន្ទើយ

នៅខែមករា និងកុម្ភៈ ក្រោយពេលដែលការប្រយុទ្ធមានភាពធូរស្រាលនៅតាមព្រំដែន មជ្ឈិមបានចាប់ផ្ដើមចាប់ខ្លួនកម្មាភិបាលរបស់ភូមិភាគបូព៌ាជាច្រើននាក់[១៧] ។ សោ ភឹម បានដឹងដោយយឺតពេលទៅហើយថា គាត់ជាកម្មវត្ថុនៃកិច្ចប្រតិបត្តិការនេះ ។ គេបានស្ដីបន្ទោសឲ្យគាត់ចំពោះបរាជ័យ របស់កងទ័ពរបស់កម្ពុជា ដែលពុំបានសម្រេចកម្ចាត់ពួកវៀតណាមឲ្យវិនាសសាបសូន្យ ។ គេបានចោទប្រកាន់ថាគាត់ជាសមាជិកនៃ«បក្សលួចលាក់

របស់វៀតណាម» ដែលគេបញ្ចូលមកក្នុងបក្សកុម្មុយនិស្តកម្ពុជា ។

នៅខែមីនា សោ ភឹម ប្រហែលជាបានបើកធ្វើកិច្ចប្រជុំសម្ងាត់មួយ ជាមួយបណ្តាសហការីដ៏ជិត ស្និទ្ធបំផុតរបស់គាត់ ហើយគាត់បាននិយាយណែនាំឲ្យប្រុងប្រយ័ត្នខ្លួនជាប់ជានិច្ច ៈ បណ្តាកម្មាភិបាលរបស់ភូមិភាគបូព៌ា ដែលមជ្ឈិមបានចាប់ខ្លួននៅពេលថ្មីៗនេះ ពុំមែនជាមនុស្សក្បត់ជាតិទេ ប៉ុន្តែ ជាមិត្តរបស់ ប្រជាជន មាតុភូមិ និងការបដិវត្តន៍ ។ ក្នុងរឿងនេះវាពិតជាមានការភាន់ច្រឡំមួយ ។ ភឹម បានណែនាំគ្នាគាត់មានការប្រុងប្រយ័ត្ន ដ្បិតអីស្ថានការណ៍បានផ្លាស់ប្តូរទាំងស្រុង ហើយមានខ្សែសង្វាក់មួយដែលគាត់រកវាយតម្លៃពុំត្រូវឡើយ ។

ក្នុងរយៈពេលមួយខែ កម្មាភិបាលភូមិភាគបូព៌ាប្រហែលបួនរយនាក់ ត្រូវបានគេចាប់ដាក់គុកនៅទួលស្លែង ។ មេបញ្ជាការនៃកងពលធំចំនួនពីររបស់មជ្ឈិម ដែលបោះប្រចាំការនៅក្នុងភូមិភាគនេះ ត្រូវបានចាប់ខ្លួន និងដាក់ជំនួសដោយមនុស្សដែលគ្មានសេចក្តីស្មោះត្រង់នឹង សោ ភឹម បន្តិចសោះ ។ មជ្ឈិម បានបោសសម្អាតរចនាសម្ព័ន្ធបក្សប្រចាំតំបន់នានា ហើយយកទ័ពដែលកំពុងស្ថិតនៅក្នុងភូមិភាគនេះ មកគ្រប់គ្រងខ្លួនឯង ។ ឌុច នៅភ្នំពេញ និង សុន សេន នៅភូមិភាគបូព៌ាផ្ទាល់ បានគិតគូរធ្វើការបោសសម្អាតមួយ មានតម្លៃស្មើនឹងការវាយប្រហារជាទូទៅមួយប្រឆាំងនឹង សោ ភឹម និងកងទ័ពដែលនៅមានចិត្តស្មោះត្រង់ជាមួយគាត់នៅឡើយ ។

ប៉ុន្តែ ភឹម និងកងទ័ពរបស់គាត់នៅតែជឿមិនអស់មិនហើយថា វាពិតជាមានការភាន់ច្រឡំមួយ ។ អ្នកទាំងនេះយល់ថាពួកគេពុំមែនជាមនុស្សក្បត់ទេ ហើយជឿថា មជ្ឈិមនឹងកែប្រែការសង្ស័យដែលខុសរបស់ខ្លួនឡើងវិញ ក្រោយពេលដែលការពិតនឹងត្រូវគេដឹងច្បាស់ ។ ពួកគេបានបង្ហាញឲ្យឃើញនូវភាព«ឆាប់ងាយជឿ» ដូច«ពួកអ្នកថ្មី»ដែរ នៅដើមដំបូងនៃការបដិវត្តន៍ ។ នៅពេលដែលពួកមេបញ្ជាការទ័ពរបស់ភូមិភាគ ត្រូវកោះហៅទៅចូលរួមការប្រជុំមួយនៅខែឧសភា ពួកគេបានគោរពធ្វើតាមភ្លាម ។ នេះគឺជាអន្ទាក់មួយរបស់មជ្ឈិម ។ នៅចុងខែឧសភា មេបញ្ជាការរបស់ភូមិភាគបូព៌ាប្រមាណជាមួយរយនាក់ បានត្រូវគេកោះហៅទៅចូលរួមក្នុង «ការប្រជុំជាច្រើន»របៀបដូចៗគ្នា ហើយអ្នកទាំងអស់នោះ បានធ្វើដំណើរទៅកាន់កន្លែងប្រជុំ ហាក់ដូចជាហ្វូងចៀម ដើរទៅរកកន្លែងពិឃាតដូច្នោះដែរ ។

នៅទីបំផុត សោ ភឹម ផ្ទាល់ក៏ត្រូវគេហៅទៅចូលរួមការប្រជុំមួយ ដោយអ្នកធ្វើការក្រោមបង្គាប់គាត់ម្នាក់ ដែលគេដឹងច្បាស់ ព្រោះតែភក្តីភាពរបស់គាត់ចំពោះមជ្ឈិម ។ សោ ភឹម បានគេចខ្លួនហើយបានបញ្ជូននិរសារម្នាក់ឲ្យទៅស៊ើបសួរពីកម្មវត្ថុនៃការប្រជុំ ។ និរសាទីមួយពុំឃើញវិលត្រឡប់មកវិញឡើយ ភឹម បានចាត់និរសារទីពីរឲ្យទៅទៀត បន្ទាប់មកនិរសារទីបី ហើយនៅទីបំផុតនិរសារទីបួន ដែលជាសហការីដ៏ជាទីទុកចិត្តបំផុតរបស់គាត់ ។ គ្មានឃើញនិរសារណាមួយវិលត្រឡប់មកវិញសោះ ។ នៅថ្ងៃទី២៥ ខែឧសភា មជ្ឈិម បានបញ្ជាឲ្យធ្វើការវាយលុកទៅលើភូមិភាគបូព៌ាដោយកងពលតូចពីរ ដែលកងពលមួយមានទាំងរថក្រោះ ថលជលិក ផង (ចុះទឹកក៏បាន ឡើងគោកក៏បាន) ហើយឆ្លងកាត់ទន្លេមេគង្គ ដើរចុះតាមផ្លូវជាតិលេខ៧ដើម្បីសម្រុកទៅរក សោ ភឹម ។

សោ ភឹម ដែលជាមនុស្សឆាប់ជឿរហូតដល់ទីបំផុត បានសាកល្បងភ្ជាប់ការទាក់ទងតាមវិទ្យុជាមួយក្រុងភ្នំពេញ ដើម្បីតវ៉ាប្រឆាំងនឹងការវាយលុកនេះ ។ ដោយពុំបានទទួលចម្លើយតបមកវិញ គាត់បានឡើងជិះឡានហ្ស៊ីបមួយធ្វើដំណើរមកកាន់រដ្ឋធានី និងនិយាយប្រាប់ ប៉ុល ពត ដោយខ្លួនគាត់ផ្ទាល់ ។ ក្នុងរឿងនេះប្រហែលជាមានការគិតខុសមួយ ភឹម ពុំអាចនឹកស្មានថា រូបគាត់ផ្ទាល់និងភូមិភាគរបស់គាត់ ត្រូវគេដាក់ឲ្យស្ថិតនៅក្រោមការបោសសម្អាតមួយ សម្រាប់មូលហេតុនៃការប្រព្រឹត្តអំពើក្បត់ បម្រើផលប្រយោជន៍ប្រទេសវៀតណាមឡើយ ។ ផ្ទុយទៅវិញ ពួកគេធ្លាប់ជាខ្សែការពារប្រទេសទីមួយដ៏សំខាន់ ។ ភឹម ជាសមាជិកម្នាក់ក្នុងវង្សដ៏មេដឹកនាំបដិវត្តមួយក្តាប់តូច គាត់ធ្លាប់ទទួលស្របរាល់សកម្មភាពទាំងឡាយដែលប្រើកម្លាំងបាយ និងខបាយកលរបស់បដិវត្ត ហើយគាត់បានគោរពធ្វើតាមបទបញ្ជាទាំងអស់របស់មជ្ឈិម ។ គាត់បានបង្ហាញភស្តុតាងឲ្យឃើញថា ឈាមដែលប្រឡាក់ដៃគាត់ គឺជាឈាមនៃជំនឿមួយចំពោះភាពត្រឹមត្រូវរបស់បក្ស ស្ទើរតែដូចអ្នកមានជំនឿមួយ ចំពោះសាសនាដែរ ។

ភឹម នៅលាក់ខ្លួនសិន ដើម្បីរៀបចំការណាត់ជួបគ្នាមួយជាមួយ ប៉ុល ពត ។ គាត់ជឿជាក់ក្នុងចិត្តថា មេដឹកនាំបក្សនឹងមកកាន់កន្លែងដែលបានណាត់គ្នា ហើយគេទាំងពីរនឹងបកស្រាយបំភ្លឺពីការស្តាប់គ្នាពុំបានថែមទៀត ។ ជំនួសការមកជួបរបស់ ប៉ុល ពត មជ្ឈិម បានបញ្ជូននាវាពីរគ្រឿងផ្ទុកពេញទៅដោយកងទ័ពទៅវិញ ។ ភឹម បានបាញ់សម្លាប់ខ្លួនឯង មុនពេលដែលកងទ័ពទាំងនោះអាចបាញ់ប្រហារគាត់ ។ ប្រពន្ធ និងកូនៗ របស់គាត់ក៏ត្រូវគេបាញ់សម្លាប់ចោលដែរ ក្នុងរយៈពេលដែលអ្នកទាំងនោះ ខំប្រឹងកប់ខ្មោចរបស់គាត់ ។

សហការីមួយចំនួនរបស់ សោ ភឹម បានសម្រេចចិត្តរត់ភៀសខ្លួនទៅរស់នៅក្នុងព្រៃ ជាពិសេស អ៊ុក ប៊ុនឈឿន ដែលជាសមាជិកម្នាក់នៃកងទ័ពតំបន់របស់បក្ស ។ ហេង សំរិន និង ជា ស៊ីម ក៏គេចខ្លួនរួចដូចគ្នាដែរ ។ ពួកគេបានប្រយុទ្ធតស៊ូទៅតាមសមត្ថភាពរៀងៗខ្លួន ប្រឆាំងនឹងកងទ័ពរបស់ មជ្ឈិម ហើយបានលាក់ខ្លួននៅកណ្តាលទ្រូងព្រៃជ្រៅ ។ មិនយូរប៉ុន្មានដោយស្បៀងអាហារ និងគ្រាប់រំសេវកាន់តែរលស់ទៅៗ ពួកគេបានចាប់ផ្តើមធ្វើការទាក់ទងជាមួយពួកវៀតណាមដែលនៅជិតៗទីនោះ និងបានអំពាវនាវសុំឲ្យមកជួយផង ។ ប៉ុន្មានខែក្រោយមក គឺនៅខែតុលា ជា ស៊ីម បានដឹកនាំប្រជាជនរបស់ភូមិភាគបូព៌ាចំនួន បីរយនាក់ ឆ្លងកាត់ព្រំដែនចូលទៅក្នុងប្រទេសវៀតណាម ក្រោយនោះបន្តិច កងទ័ពរបស់វៀតណាមបានលុកលុយចូលមកកម្ពុជា ដើម្បីស្វែងរក ហេង សំរិន និងកងទ័ពរបស់គាត់ ហើយបាននាំយកអ្នកទាំងនេះទៅទុកនៅកន្លែងមួយ ដែលមានសុវត្ថិភាពគ្រប់គ្រាន់ក្នុងប្រទេសវៀតណាម ។ សំរិន និងកងទ័ពរបស់គាត់ ពី ពីរ ទៅបីពាន់ បានឆ្លងកាត់ព្រំដែនដោយទទួលស្គាល់ចំពោះពួកអ្នកដែលពួកគេបានវាយប្រយុទ្ធកាលពីប៉ុន្មានខែមុនប៉ុណ្ណោះ ។

ការបោសសម្អាតភូមិភាគបូព៌ា ជាព្រឹត្តិការណ៍សប្បាយរីករាយមួយដែលកើតឡើងត្រូវពេលវេលាសម្រាប់ប្រទេសវៀតណាម ដែលកំពុងត្រូវការរឿងបែបនេះយ៉ាងខ្លាំង គឺពួកកុម្មុយនិស្តកម្ពុជាមួយក្រុម ដែល

មានសារសំខាន់ និងបទពិសោធន៍គ្រប់គ្រាន់ដើម្បីដឹកនាំ «រណសិរ្ស» មួយប្រឆាំងនឹង ប៉ុល ពត ។ ពួកមនុស្សដែលគេចោទប្រកាន់ទាំងខុសថា «ភ្នាក់ងាររបស់វៀតណាម» ត្រូវតែបន្ទុំចិត្តធ្វើដូច្នេះ ដើម្បីស្រោចស្រង់ជីវិតផ្ទាល់របស់គេ និងបម្រើជា«ផ្នែកខាងមុខ»របស់ក្រុងហាណូយ ។ ដូចវិស័យជាច្រើនដទៃទៀតដែរ ប៉ុល ពត បានធ្វើអ្វីមួយ រហូតទាល់តែការភ័យខ្លាចយ៉ាងអាក្រក់របស់គាត់ លេចចេញជារូបរាងក្លាយទៅជាការពិត ។

វាលែងមាននៅសល់អ្វីទៀត ដើម្បីបញ្ចប់ការបោសសម្អាតភូមិភាគបូព៌ាហើយ ។ អំណើះតទៅមជ្ឈិមក៏លែងត្រូវការលេសសម្រាប់ចោទប្រកាន់ដែរ ។ កងទ័ពរបស់ភូមិភាគដែលកំពុងប្រយុទ្ធតស៊ូដើម្បីរត់គេចពីកងទ័ពរបស់មជ្ឈិមដែលប្រកាសថា ភូមិភាគទាំងមូលជាសម្បុកមួយរបស់ពួកក្បត់ ។ ភូមិទាំងមូលៗត្រូវបានគេបណ្តេញប្រជាជនឲ្យចេញអស់គ្មានសល់ ហើយសម្លាប់ចោលយ៉ាងរង្គាល ។

ហាន់តាវ អ្នកជំនួញជាតិចិននៅក្រុងភ្នំពេញ ដែលត្រូវគេជម្លៀសទៅភូមិភាគបូព៌ាបានចូលរួមមើលក្បួនមនុស្សដើរបន្តបន្ទុយគ្នាដូចគេហែខ្មោចមួយដែរ[២២] ។ នៅឆ្នាំ១៩៧៨ គាត់ត្រូវបានចាត់តាំងឲ្យទៅធ្វើការក្នុងក្រុមមួយ ដែលកំពុងជួសជុលស្ពានធំមួយតភ្ជាប់ភូមិភាគបូព៌ាទៅតំបន់អាគ្នេយ៍ ។ អ្នករងគ្រោះយ៉ាងច្រើន ពីការបោសសម្អាតនេះបានដើរកាន់លើស្ពានសំដៅទៅរកសេចក្តីស្លាប់ ក្រោមព្រះអាទិត្យដ៏កំណាចនៃរដូវក្តៅ ។ តាវ បានរំលឹកថា «កងទ័ពបានមកដល់ជាមួយអ្នកទោស ដែលមានដៃជាប់ចំណងទៅក្រោយ ។ ខ្ញុំបានសួរទៅកម្មករម្នាក់នៅចម្ការកៅស៊ូមួយដែលមកដល់ដោយគាប់ជួនថា គេនាំយកមនុស្សទាំងនោះទៅណា? ហើយកម្មករនោះបានឆ្លើយប្រាប់ខ្ញុំថា អ្នកទាំងនោះនឹងត្រូវគេយកទៅបាញ់ចោលទាំងអស់» ។

កងទ័ព ពួកកម្មាភិបាលរបស់តំបន់អាគ្នេយ៍ ដែលធ្លាប់ចូលរួមក្នុងការបោសសម្អាតផ្សេងៗ និងកម្មាភិបាលរបស់តំបន់នេះ បានផ្សព្វផ្សាយដំណឹងតៗគ្នាថា តំបន់អាគ្នេយ៍ពោរពេញទៅដោយ«ប្រជាជនកម្ពុជាដែលមានក្បាលយួនខ្លួនខ្មែរ»ច្រើនណាស់ ។ កម្មករចម្ការកៅស៊ូដែល តាវ បានជួបនៅលើស្ពាន បាននិយាយប្រាប់គាត់ពីពាក្យចចាមអារ៉ាមទាំងនេះថា មានការប្រយុទ្ធគ្នារវាងកងទ័ពតំបន់អាគ្នេយ៍ និងកងទ័ពមជ្ឈិម ការរត់ភៀសខ្លួនរបស់ពួកកម្មាភិបាលតំបន់ ចូលទៅព្រៃជ្រៅ ជាមួយនឹងកូនចៅមួយចំនួនរបស់ពួកគេ និងការចោទប្រកាន់ពីអំពើក្បត់ដែលគេលើកឡើងប្រឆាំងនឹងរូប សោ ភឹម ផ្ទាល់ ។ តាមពាក្យចចាមអារ៉ាមទាំងនេះថា មជ្ឈិមបានសម្លាប់ ភឹម ហើយដឹកខ្មោចរបស់គាត់ដើរអាក្រាតក្នុងភូមិភាគទាំងមូល ពីសហករណ៍មួយទៅសហករណ៍មួយ ដើម្បីបង្ហាញឲ្យប្រជាជន ឃើញនូវអ្វីដែលកើតមានចំពោះពួកអ្នកដែលក្បត់ប្រទេស និងអង្គការ ។

តាវ ហាក់ដូចជាស្ថិតនៅក្បែរមាត់ភ្នំភ្លើងមួយ ។ ភូមិភាគបូព៌ាបានឈានចូលដំណាក់កាលជិតផ្ទុះហើយ ការសម្លាប់រង្គាលផ្សេងៗបានកើតមានតៗគ្នាដូចទឹករលកបោកបក់ ។ ពួកអ្នកស្រុកទាំងភូមិៗ ត្រូវគេនាំយកទៅវាលស្រែដែលនៅជិតៗនោះ ហើយវាយធ្វើបាបរហូតទាល់តែស្លាប់ ។ គេស្តាប់ឮសំឡេងព្រនង់វៃបំបាក់កញ្ចឹង-ក លាន់ភូងៗ ។ សហករណ៍ខ្លះ បានបណ្តេញសមាជិករបស់ខ្លួនទាំងអស់ ហើយបញ្ជូនឲ្យទៅភូមិភាគ

ពាយ័ព្យ ៖ មជ្ឈិមមិនចង់ទុកពួក មនុស្ស"ដែលឆ្លងរោគ"របស់ភូមិភាគបូព៌ាឲ្យស្ថិតនៅក្បែរព្រំដែនទេ ក្នុងពេលដែលសង្គ្រាមមួយជាមួយវៀតណាមបម្រុងនឹងផ្ទុះឡើងហើយនោះ ។ គេត្រូវតែបោសសម្អាតភូមិភាគទាំងមូលឲ្យអស់ពួក"ក្បាលយួនខ្លួនខ្មែរ" ។

នៅខែកក្កដា ប្រជាជនភូមិភាគបូព៌ាជាងមួយរយពាន់នាក់ បានត្រូវខ្មែរក្រហមសម្លាប់ចោលយ៉ាងរង្គាល[២៣] ។ មុននឹងប្រមូលផ្តុំកម្លាំងប្រជាជនទូទាំងប្រទេសឲ្យស្ថិតនៅពីក្រោយខ្នងគាត់ ដើម្បីប្រឈមមុខទល់នឹងសត្រូវពួកវៀតណាមនោះ ប៉ុល ពត គោងតែបញ្ចប់ការបោសសម្អាតផ្តាច់ព្រ័ត្រនេះ ដោយខ្លួនឯងផ្ទាល់ ដោយពង្រីកឲ្យរាលដាលពាសពេញប្រទេស ។

ក្នុងកំឡុងនៃអំពើឆ្កួតលេលាចុងក្រោយនេះ "ពួកអ្នកចាស់" ពួកកម្មាភិបាលនៅភូមិភាគដទៃទៀត ក៏ត្រូវចាប់ឃុំឃាំង និងសម្លាប់ចោលយ៉ាងច្រើនដែរ ។ គាវ បានរៀបរាប់ថា ពួកកម្មាភិបាល និង"ពួកអ្នកចាស់" នៅសហករណ៍របស់គាត់ ដែលស្ថិតនៅក្នុងភូមិភាគនិរតីក៏មាន"បាត់ខ្លួន" នៅជំនាន់នេះដែរ ។ នៅដំណាក់កាលនៃការបដិវត្តន៍នេះ បក្សមិនត្រឹមតែសម្លាប់មនុស្សដែលត្រូវសង្ស័យថា"ក្បត់"ប៉ុណ្ណោះទេ ប៉ុន្តែ ក៏សម្លាប់គ្រួសារទាំងមូលរបស់ពួកគេដែរ ។

គាវ បានបន្ថែមថា "ពួកគេបានសម្លាប់មនុស្សទាំងគ្រួសារៗ ។ ខ្ញុំធ្លាប់ឮគេនិយាយថា ក្នុងភូមិភាគ និរតី ពួកគេបានសម្លាប់មនុស្សអស់មួយភូមិៗតែម្តង" ។

នេះជាឱកាសដែល មជ្ឈិម ជ្រើសរើស -ទុកណាជាប្រជាជនទូទាំងប្រទេសធ្លាប់ត្រូវបានប្រាប់ឲ្យយកចិត្តទុកដាក់ប្រឆាំងនឹងពួកភ្នាក់ងាររបស់វៀតណាម និងធ្លាប់ឮគេនិយាយពីការបោសសម្អាតដែលបណ្តាលឲ្យមានមនុស្សស្លាប់ច្រើនហួសប្រមាណនៅភូមិភាគបូព៌ា ហើយដែលធ្វើឲ្យគាត់ភ័យខ្លាចពីការជាប់ទាក់ទិនរបស់ខ្លួនក៏ដោយ- ដើម្បីប្រកាសពីជ័យជម្នះរបស់ការបដិវត្តន៍ ។ ឥឡូវនេះវាដល់ពេលដែលត្រូវបង្រួបបង្រួមប្រទេស បង្កើនល្បឿនការធ្វើឧស្សាហូបនីយកម្មពង្រីកការអប់រំ និងពង្រឹងកិច្ចការពារប្រជាជាតិឲ្យរឹតតែរឹងមាំឡើងថែមទៀត ។

## ការរៀបចំធ្វើសង្គ្រាម

ប្រទេសចិន និងវៀតណាមបានប្រឹងប្រែងបន្ការជាមុន នូវការរីករាយដាលនៃស្ថានការណ៍ដែលប្រកបទៅដោយគ្រោះថ្នាក់ នៅតាមព្រំដែន ។ នៅខែមករា ឆ្នាំ១៩៧៨ អនុរដ្ឋមន្ត្រីការបរទេសម្នាក់របស់វៀតណាម បានធ្វើដំណើរទៅក្រុងប៉េកាំងដើម្បីចរចាពីការសម្របសម្រួលគ្នាមួយ ។ បន្ទាប់មក គណៈប្រតិភូមួយរបស់ចិនបានឡើងជិះយន្តហោះមកកាន់ក្រុងភ្នំពេញ ប៉ុន្តែ ការសន្ទនាគ្នាទាំងអម្បាលម៉ាន បានសម្រេចត្រឹមតែការលើក

ឡើងវិញ ពីការគាំទ្ររបស់ចិនចំពោះទស្សនៈរបស់កម្ពុជាបន្តទៅទៀតប៉ុណ្ណោះ ដែលថាប្រទេសវៀតណាមបានសាកល្បងដាក់លក្ខខណ្ឌផ្សេងៗ មកលើបណ្ដាប្រទេសជិតខាងខ្លួន ដើម្បីបង្កើតសហព័ន្ធឥណ្ឌូចិនមួយ ។

នៅខែកុម្ភៈ ពួកវៀតណាមបានអះអាងពីសំណើមួយរួមមានបីចំណុច គឺការឈប់បាញ់គ្នា ការដកថយពីព្រំដែនរៀងខ្លួនចម្ងាយប្រាំគីឡូម៉ែត្រ ការទទួលស្គាល់ព្រំដែនបច្ចុប្បន្ន សន្ធិសញ្ញាផ្លូវការមួយ និងកិច្ចព្រមព្រៀងមួយស្ដីពីការធានាជាអន្តរជាតិ ដែលរ៉ាប់រងឲ្យមានការគោរពសន្ធិសញ្ញានេះ ។ កម្ពុជាបានច្រានចោលសំណើនេះ ដោយចាត់ទុកថា ជារនាំងមួយសម្រាប់ប្រើជាអន្តរជាតិ ដើម្បីបិទបាំងការរៀបចំប្រុងប្រៀបធ្វើសង្គ្រាមរបស់វៀតណាម ។ លើកនេះ ពួកកម្ពុជាពិតជាយល់ឃើញត្រូវមែន ដោយហេតុថា នៅក្នុងកំឡុងសម័យប្រជុំមួយរបស់បក្ស ដែលបានប្រព្រឹត្តទៅនៅខែកុម្ភៈ ក្រុងហាណូយបានសម្រេចចិត្តធ្វើការលុកលុយប្រទេសកម្ពុជា នៅដំណាច់ឆ្នាំ១៩៧៨ជាក់ជាប្រាកដ[៧៤] ។

ភាពចាំបាច់ទាំងឡាយនៃសង្គ្រាម បានបង្ខំឲ្យពួកកុម្មុយនិស្តកម្ពុជាកែប្រែរូបភាពនៃការបដិវត្តន៍ និងប្រទេសរបស់គេជាថ្មី ។ ជាបឋមបក្សបានប្រមូលផ្ដុំកិច្ចប្រឹងប្រែងរបស់ខ្លួនទៅលើប្រទេសក្រៅ បន្ទាប់មក ពួកកម្មាភិបាលបក្ស កងទ័ព ពួកបេសកជនបរទេសនៅក្រុងភ្នំពេញ ហើយនៅទីបំផុតប្រជាជនទាំងមូលមិនដល់ពីរខែផង ។ មុនសង្គ្រាម ប៉ុល ពត បានប្រកាសឲ្យដឹងជាសាធារណៈពីផែនការប្រកបដោយមហិច្ឆតារបស់គាត់ក្នុងការធ្វើឲ្យមានលក្ខណៈជាឧស្សាហកម្ម ព្រមទាំងកម្មវិធីសំខាន់បំផុតរបស់ប្រទេសខាងវិស័យអប់រំផង[៧៥] ។ នៅពេលដែលកងទ័ពទាំងពីរវាយប្រយុទ្ធគ្នានៅចុងឆ្នាំ១៩៧៨ ការយល់ច្រឡំទាំងប៉ុន្មាន បានក្លាយទៅជារឿងគួរឲ្យខ្លាចបំផុតនៅក្នុងប្រទេស ។

តាមការជំរុញរបស់ពួកចិន របបកម្ពុជាប្រជាធិបតេយ្យបានចាប់ផ្ដើមអញ្ជើញគណៈប្រតិភូ បណ្ដាប្រទេសកុម្មុយនិស្តជាមិត្តមកធ្វើទស្សនកិច្ចនៅប្រទេសរបស់ខ្លួន ។ ទស្សនកិច្ចដែលមានភាពល្បីខ្ទរខ្ទារជាងគេ គឺទស្សនកិច្ចរបស់អ្នកកាសែតយូហ្គោស្លាវីមួយក្រុមដែលបានមកដល់ក្រុងភ្នំពេញនៅខែមីនា ឆ្នាំ១៩៧៨[៧៦] ។ ពួកគេជាអ្នកកាសែតដំបូងបង្អស់ ដែលមកស្វែងយល់ពីបដិវត្តន៍នេះ ។ ក្នុងចំណោមនោះមានអ្នកឆ្លើយឆ្លងព័ត៌មានកាសែតពួកអ្នកថតភាពយន្តសម្រាប់ទូរទស្សន៍ ដែលនឹងបង្ហាញឲ្យពិភពលោកឃើញនូវរូបភាពពិតប្រាកដរបស់បដិវត្តជាលើកដំបូងបង្អស់ និងទស្សនៈទូទៅដែលស្ទើរតែគោលដៅស្ដីពីសកម្មភាពនៅកម្ពុជាប្រជាធិបតេយ្យ ។

អត្ថបទផ្សេងៗរបស់សារព័ត៌មានបានបោះបង់ការនិយាយចំអក –ការចំអកតម្រូវឲ្យពួកកុម្មុយនិស្តបញ្ចេញគំនិតយោបល់អំពីពួកកុម្មុយនិស្តដទៃៗទៀត ដែលបានធ្វើឲ្យគេមានសេចក្ដីស្អប់ខ្ពើម ។ អ្នកកាសែតម្នាក់បាននិយាយពីការជួបសន្ទនាគ្នាជាមួយនឹងប្រជាកសិករនៅសហករណ៍មួយដោយពាក្យសម្ដីនេះថា «បរិយាកាសមានលក្ខណៈអឺកធឹកមែនទែន ប្រហែលពីព្រោះយើងសុទ្ធតែជាជនបរទេសដំបូងបង្អស់ ដែលមកដល់កន្លែងនេះ ។ យើងទាំងអស់គ្នាពិបាកបញ្ចុះបញ្ចូលឲ្យស្ត្រីៗសើចញញឹមសម្រាប់ការថតរូបណាស់» ។

ទីក្រុងភ្នំពេញបានលេចឡើងក្នុងអត្ថបទកាសែតទាំងនេះ ហាក់ដូចជាទីក្រុងមួយដែលស្ទើរតែដូចទីក្រុងខ្មោច ។ ពួកអ្នកកាសែតបានគូសបញ្ជាក់ពីការខ្វះភាពទំនើបទាន់សម័យ ចិត្តគំនិតប្រជាកសិករ ជាអ្នកនាំពាក្យបដិវត្តន៍ ដែលពួកគេបានជួបសម្ភាសន៍ ។ កសិករទាំងនោះពុំបាននិយាយពីការសម្លាប់រង្គាលមនុស្សអស់រាប់ពាន់នាក់ទេ- ជាបញ្ហាសំខាន់បំផុតរបស់បដិវត្តន៍ ។ ប្រហែលពួកគេបញ្ចៀសមិននិយាយ ពីព្រោះ ពួកនោះសុទ្ធតែជាពួកកុម្មុយនិស្តដូចគ្នា ។ ប៉ុន្តែ អ្នកឆ្លើយឆ្លងពត៌មានម្នាក់ បានធ្វើការកត់សម្គាល់យ៉ាងប៉ិនប្រសប់នេះថា «យើងទាំងអស់គ្នាបានបាក់ចិត្តជឿមគ្គុទ្ទេសក៍នាំផ្លូវរបស់យើង នៅពេលដែលអ្នកទាំងនោះប្រកាសថា សត្រូវវណ្ណៈត្រូវបានកម្ចាត់ចោលយ៉ាងឆាប់រហ័សនៅប្រទេសកម្ពុជា» ។

សេចក្ដីរាយការណ៍ផ្សេងៗរបស់សារពត៌មានត្រូវបានបកប្រែ និងធ្វើអត្ថាធិប្បាយយ៉ាងទូលំទូលាយ ប៉ុន្តែ គឺខ្សែភាពយន្តរបស់ទូរទស្សន៍ទៅវិញទេ ដែលបង្កឲ្យមានប្រតិកម្មខ្លាំងក្លាបំផុតនោះ ។ នៅសហរដ្ឋអាមេរិក និងនៅអឺរ៉ុប ទូរទស្សនិកជនជាច្រើន បានមើលការយកពត៌មានដ៏អស្ចារ្យមួយ ដែលធ្វើឲ្យអ្នកមើលទន់ចិត្តអាណិតចំពោះអ្វីដែលខ្សែភាពយន្តបង្ហាញឲ្យឃើញយុវជនវ័យក្មេងជាច្រើន ឈរជំទើតលើហិបឈើ ដើម្បីបញ្ជាម៉ាស៊ីននៅក្នុងរោងចក្រមួយ ។ ពួកអ្នកមើលទូរទស្សន៍សម្គាល់ឃើញទឹកមុខរបស់ប្រជាជនកម្ពុជា ដែលត្រូវធ្វើឲ្យភ័យខ្លាច ឬឲ្យបេះអត់ធន់នៅពេលសំដែងឲ្យឃើញការរំជួលចិត្តតិចតួច ។ ពួកគេមើលឃើញឯកសណ្ឋានពណ៌ប្រផេះមួយ ដែលធ្វើឲ្យមានភាពផ្ទុយគ្នាស្រឡះ ជាមួយនឹងអនុស្សាវរីយ៍នៃប្រទេសមួយ ដែលធ្លាប់តែមានសកម្មភាពអ៊ូអរ និងរស់រវើក ។

អ្នកកាសែតបួននាក់នៃបក្សកុម្មុយនិស្ត ម៉ាក្ស-លេនីនតូចមួយនៅសហរដ្ឋអាមេរិក បានធ្វើតាមពួកយូហ្គោស្លាវី ដោយធ្វើដំណើរមកកាន់ក្រុងភ្នំពេញដែរ[២១] ។ ពួកគេបានចំណាយពេលប្រាំបីថ្ងៃនៅប្រទេសកម្ពុជាក្នុងខែមេសា ហើយបានវិលត្រឡប់ទៅវិញជាមួយនឹងទស្សនៈខុសគ្នាមួយ ។ អ្នកនាំពាក្យរបស់ក្រុមគេគឺ ដាន បៀរស្ទេន (Dan Burstein) បានបញ្ចេញនូវការស្ញើចសរសើរជ្រុលហួសហេតុ ចំពោះ«ជោគជ័យ»ទាំងឡាយរបស់ការបដិវត្តន៍ ហើយបានសម្ដែងឲ្យដឹងការជិនឆ្អន់របស់គាត់ ចំពោះពួកអ្នកដែលជឿពីជំរឹការផ្សារ និងការសម្លាប់រង្គាល ដែលអះអាងដោយពួកអ្នកភៀសខ្លួន ។ ដោយផ្ទុយនឹងពួកយូហ្គោស្លាវី ពួកអាមេរិកាំងបាន «រកឃើញមនុស្សដែលមានចិត្តស្មោះត្រង់ ក្នុងរបៀបសម្ដែងទស្សនៈរបស់គេ ទោះជានៅចំពោះមុខបណ្ដាមេដឹកនាំបក្សក៏ដោយ» ។ បៀរស្ទេនបានសួរទៅ អៀង សារី ថា តើ មានការសម្លាប់រង្គាលឬទេ? សារី ឆ្លើយថា : «ពិតជាគ្មានដាច់ខាត» ។ ហើយអ្នកកាសែតនេះបាន បញ្ជាក់អះអាងថា«អំពើប្រល័យពូជសាសន៍ជារឿងមិនពិតមួយ ដែលគេប្រឌិតឡើងទាំងស្រុង» ។

នៅខែសីហា បណ្ដាគណៈប្រតិភូ«ជាមិត្ត»នៃប្រទេសស៊ុយអែត និងបែលហ្សិក បានមកធ្វើទស្សនកិច្ចនៅកម្ពុជា ប៉ុន្តែ ត្រូវបានទទួលរាក់ទាក់ប្រកបដោយភាពមិនសូវហ៊ឹកហ៊ាក់ប៉ុន្មានទេ ទោះជាគណៈប្រតិភូទាំងនោះ បាន

ជួបសន្ទនាជាមួយ ប៉ុល ពត ក៏ដោយ[២៨] ។ មេដឹកនាំកម្ពុជាប្រជាធិបតេយ្យបានលេចមុខលើកញ្ចក់ទូរទស្សន៍របស់ស៊ុយអែត ដែលធ្វើសម្ភាសន៍ដោយ ហ្សង់ មៀរដាល់ *(Jan Myrdal)* ។ ជាកូនប្រុសរបស់ ហ្គុនណា *(Gunna)* និងនាងអាល់វ៉ា *(Alva)* មៀរដាល់ បានចោទសំណួរផ្សេងៗប្រហាក់ប្រហែលសំណួរ ដែលពួកអ្នកកាសែតអាមេរិកាំង បានសួរអៀង សារី ដែរ ប៉ុន្តែចម្លើយរបស់ ប៉ុល ពត បង្ហាញឲ្យឃើញនូវភាពខុសគ្នាមួយគួរឲ្យកត់សម្គាល់ ។ ការផ្តើមធ្វើការទាក់ទងជាសាធារណៈបានរីកចម្រើនជាលំដាប់ ។ សារី ធ្លាប់បានប្រកាសថា សហរដ្ឋអាមេរិកជាអ្នកប្រព្រឹត្តអំពើប្រល័យពូជសាសន៍មួយនៅកម្ពុជាពុំមែនពួកខ្មែរក្រហមទេ ហើយគាត់វាយតម្លៃថា ចំនួនប្រជាជនកម្ពុជាប្រាំបីរយពាន់ត្រូវស្លាប់ដោយពួកអាមេរិកាំងក្នុងកំឡុងសង្រ្គាមប្រាំឆ្នាំ ។ ប៉ុល ពត បានដំឡើងចំនួនប្រជាជនកម្ពុជា ដល់មួយលានបួនសែននាក់ ដែលត្រូវស្លាប់ដោយ «ចក្រពត្តិនិយមអាមេរិកាំង និងបរិវាររបស់វា» ។

ម្យ៉ាងទៀត ប៉ុល ពត បាននិយាយអំពីជោគជ័យយ៉ាងធំធេងក្នុងនាមនៃការបដិវត្តន៍ដែរ ។ ពួកអ្នកកាសែតអាមេរិកាំង បាននាំទៅផ្សព្វផ្សាយត្រឹមតែដំណឹងថា ប្រជាកសិករខ្មែរមានអ៊ីៗហូបគ្រប់គ្រាន់ប៉ុណ្ណោះ ទុកណាជានៅមុនមានការបដិវត្តន៍កសិករទាំងនោះអាចរកម្ហូបអាហារឆ្ងាញ់ៗ ដាក់លើតុរបស់គេក៏ដោយ ។ ប៉ុល ពត បានប្រកាសប្រាប់ពួកស៊ុយអែដ និងពួកបែលហ្ស៊ិក ថាប្រជាជនកម្ពុជាទាំងអស់ បានបរិភោគអាហារតាមការស្រេកឃ្លានរបស់គេ មានស្លៀកមានពាក់ មានជម្រកនៅត្រឹមត្រូវ បានទទួលគុណប្រយោជន៍ពីការថែទាំសុខភាព និងការរៀនសូត្រសមស្របមួយ ។ គាត់បានបញ្ជាក់ថា បដិវត្តន៍បានលុបបំបាត់អនក្ខរភាពទូទាំងប្រទេស ហើយអះអាងទៀតថា ជនរួមជាតិទាំងអស់របស់គាត់អាចលេងកីឡា តន្ត្រី ការច្រៀងរាំ និងទៅមើលភាពយន្តបាន ។

គណៈប្រតិភូទាំងអស់នោះបានត្រូវអមជូនដំណើរដោយមគ្គុទ្ទេសក៍នាំផ្លូវជាច្រើន ដែលនាំបង្ហាញប្រាប់ពួកគេតែតំបន់ និងជួបក្រុមមនុស្សណា ដែលនឹងនិយាយគាំទ្រការភូតកុហក់ទាំងនេះប៉ុណ្ណោះ ។ ដោយអញ្ជើញតែប្រទេសកុម្មុយនិស្ត ឬ«ប្រទេសជាមិត្ត» ដែលបើកផ្លូវឲ្យមុនស្រេចដើម្បីជួយគាំទ្រពួកខ្មែរក្រហម នោះរបបនេះសង្ឃឹមបង្អន់នូវចម្លើយជាសាក្សីរបស់ពួកអ្នកភៀសខ្លួន និងបន្ទោយអ៊ីៗដែលធ្វើប្រឡាក់ប្រឡូសដោយពួកវៀតណាម ហើយដែលមានពាសពេញក្នុងពិភពលោកនូវសេចក្តីរាយការណ៍ផ្សេងៗស្តីពីអំពើសាហាវយង់ឃ្នងរបស់ពួកកុម្មុយនិស្តនៅប្រទេសកម្ពុជាតាំងពីមានជម្លោះព្រំដែនមក ។

នៅខែកុម្ភៈ បន្ទាប់ពីការបញ្ចប់សង្គ្រាមបន្តិចពួកវៀតណាមបានអញ្ជើញពួកអ្នកកាសែតបរទេសល្បីឈ្មោះ ប្រាំនាក់ឲ្យមកធ្វើទស្សនកិច្ចនៅតាមព្រំដែន ដើម្បីឲ្យពួកគេទៅពិនិត្យដោយផ្ទាល់នូវផលវិបាកផ្សេងៗក្នុងជម្លោះនេះ ។ អ្នកយកពត៌មានទាំងនេះ បានថតរូបសាកសពមនុស្សដែលហើមប៉ោង និងដាច់ដៃដាច់ជើង ។ ពួកគេបានសាកសួរកសិករវៀតណាមជាច្រើននាក់ ដែលនិយាយប្រាប់ពួកគេពីការកាប់សម្លាប់យ៉ាងវង្វេល ប្រព្រឹត្តឡើងដោយកងទ័ពកុម្មុយនិស្តខ្មែរ មានអាកប្បកិរិយាហាក់ដូចជាមនុស្សឆ្កួត ។ ប៉ុន្តែ អ្នកកាសែតទាំងនោះសុទ្ធតែជាពួកអ្នកកាសែតជើងចាស់ ដែលធ្លាប់ជួយ«រាំងខ្ទប់»សង្គ្រាមរវាងប្រទេសវៀតណាម និងកម្ពុជា ហើយពួកគេ

បានសរសេររឿងរ៉ាវផ្សេងៗយ៉ាងច្រើន ដែលពួកវៀតណាមមិនចង់បាន ។ ណាយ៉ាន់ ចាន់ដា *(Nayan Chanda)* នៃទស្សនាវដ្ដីសេដ្ឋកិច្ចចុងបូព៌ា *(FAR EASTERN ECONOMIC REVIEW)* បានចុះផ្សាយនូវសេចក្ដីរាយការណ៍ដំបូងរបស់សាក្សីផ្ទាល់ភ្នែកម្នាក់ ស្ដីពីបែបផែនដែលពួកវៀតណាមបានជ្រើសរើស និងហ្វឹកហ្វឺនដល់ពួកអ្នកភៀសខ្លួនកម្ពុជា ដើម្បីបង្កើតកងឯកភាពជួរមុខមួយក្នុងគោលបំណងកុំឲ្យគេនិយាយថា ជាការវាយប្រហារមួយ ដែលគ្រោងរៀបចំដោយប្រទេសវៀតណាម ប្រឆាំងនឹងប្រទេសកម្ពុជា ។ រ៉ូឡង់ ប៉ារាំងហ្គោ *(ROLAND PARINGAUX)* នៃកាសែតឡឺម៉ុងនិងទីហ្សីយ៉ាណូ ទែហ្សានី *(TIZIANO TERZANI)* នៃកាសែតស្ពីហ្គែល *(SPIEGEL)* បានរៀបចំយ៉ាងល្អិតល្អន់ក្នុងអត្ថបទផ្សេងៗរបស់ខ្លួន ដែលមានន័យរបៀបគ្នានេះដែរ ។ បទយកការណ៍ទាំងនេះ បានញ៉ាំងឲ្យរដ្ឋាភិបាលបរទេសជាច្រើននៅ ដែលក្នុងនោះមានរដ្ឋាភិបាលសហរដ្ឋអាមេរិកផង ជឿថាប្រទេសវៀតណាមនិងកម្ពុជា បានណ្ដោយខ្លួនឲ្យធ្លាក់ទៅក្នុងសង្គ្រាម ពិតប្រាកដកម្រិតធំមួយនៅមុនដំណាច់ឆ្នាំ ។

ការពិតនេះបានលេចចេញឲ្យឃើញច្បាប់ពីស្ថានការណ៍ នៅតាមជនបទរបស់កម្ពុជា ។ ខ្យល់បានប្ដូរទិសហើយ ។ កម្មវិធីប្រមូលផ្ដុំកម្លាំងមនុស្សទូទាំងប្រទេស ដើម្បីបង្កើតលទ្ធិសង្គមនិយមពេញលេញមួយបានទទួលបរាជ័យ ។ ការចាប់ហូបបាយរួមឡើងវិញ បានតម្រូវឲ្យគេកាត់បន្ថយបរិមាណស្បៀងពីមនុស្សទាំងអស់ ។ ពលិកម្មថ្មីៗទៀតបានតម្រូវឲ្យពលករធ្វើការកាន់តែខ្លាំង ពេលម៉ោងធ្វើការងារកាន់តែអូសបន្លាយថែមទៀត ហើយការខ្វះថ្នាំពេទ្យបានធ្វើឲ្យសុខភាពរបស់ប្រជាជនចុះថមថយយ៉ាងខ្លាំង ។ ការភ័យខ្លាច ការព្រួយបារម្ភបានញ៉ាំងឲ្យសមាជិកបក្ស ក៏ដូច«ពួកអ្នកថ្មី»មិនអាចធ្វើអ្វីកើតទាំងអស់ ។ ភាគច្រើននៃអ្នករងគ្រោះថ្មីៗ ដោយការបោសសម្អាត និង«ការបាត់ខ្លួន» គឺសុទ្ធតែសមាជិកបក្ស កម្មាភិបាល និង«ពួកអ្នកចាស់» ដែលធ្វើឲ្យការច្របូកច្របល់ និងការភាន់ច្រឡំ រឹតតែធ្ងន់ធ្ងរឡើងៗ ។ មនុស្សម្នាក់ៗលែងដឹងថា អ្នកណាមួយដែលគេអាចជឿទុកចិត្តទៀតហើយ ។

ម្យ៉ាងទៀត ចំនួននៃការសម្លាប់កាន់តែកើនច្រើនកាលណា ការសម្លាត់ក៏រឹតតែពិបាកបិទបាំងកាលនោះដែរ ។ ពេលត្រឡប់ទៅភូមិភាគនិរតីវិញ បន្ទាប់ពីបានចូលរួមក្នុងការជួសជុលស្ពានរួច ហាន់ តាវ បានទៅជាសាក្សីដែលបានឃើញ បានដឹង បានឮ អំពើសាហាវឃោរឃៅជាច្រើនទៀត ។ «មនុស្សជាច្រើនត្រូវគេសម្លាប់ជាមួយនឹងអាវុធគ្រប់ប្រភេទ ។ បន្ទាប់មក គេវះពោះខ្មោចទាំងនោះដើម្បីកុំឲ្យហើម ។ ក៏ប៉ុន្តែ ជួនកាលគេកាត់ខ្មោចមនុស្សជាកង់ៗ ដោយចិត្តខិលខូចតែម្យ៉ាងប៉ុណ្ណោះ ជាពិសេស ជាមួយស្រីៗ[២៩]» ។

គេគោងតែបញ្ចប់ការសម្លាប់មនុស្ស ៖ កងទ័ពកំពុងត្រូវការយុទ្ធជនយ៉ាងច្រើន ហើយបក្សក៏ត្រូវការឲ្យប្រទេសរួបរួមគ្នាតែមួយដែរ ។ ក្នុងកម្ពុជាប្រជាធិបតេយ្យទាំងមូលគេបានបើកធ្វើមិទ្ទីងធំៗ ជាច្រើនកន្លែង ក្នុងគោលបំណងបរិហារពីការគំរាមកំហែងរបស់វៀតណាម និងបំផុសទឹកចិត្តប្រជាជនឡើងវិញ សម្រាប់បុព្វហេតុរបស់ប្រទេសកម្ពុជា ។ ដោយរួមបញ្ចូលនូវមធ្យោបាយសម្រាប់ទាក់ទាញចិត្ត បក្សបានប្រកាសឲ្យដឹងជាសាធារណៈនូវការផ្លាស់ប្ដូរយ៉ាងច្រើន ។ ជាបឋមគឺសេចក្ដីសម្រេចមួយឲ្យលុបបំបាត់«ភាពខុសគ្នា»ទាំងអស់ រវាង«ពួក

អ្នកចាស់» និង«ពួកអ្នកថ្មី» ។ សមាជិកទាំងអស់របស់សហករណ៍នឹងមានសិទ្ធិស្មើគ្នា ទទួលរបបអាហារ «ភាពខុសគ្នា» ដូចគ្នា និងពេលម៉ោងធ្វើការដូចគ្នា ។ បក្សបានសន្យាផ្តល់ស្បៀងអាហារលើសមុនទោះបីជាការសន្យានេះនៅតែជាការសន្យាមួយក្នុងតំបន់ជាច្រើនរបស់ប្រទេសក៏ដោយ ។

តាវ នៅនឹកឃើញពីពេលប្រែប្រួលនេះ ។ «ពួកគេបានផ្លាស់ប្តូរមាគ៌ានយោបាយក្នុងសុន្ទរកថាទាំងឡាយ ដែលផ្សព្វផ្សាយមកពីមេក្រូជាច្រើន ក្នុងមីទ្ទីងផ្សេងៗនៅគ្រប់កន្លែង ។ ពួកខ្មែរក្រហម ចង់ឲ្យប្រជាជនទាំងអស់គាំទ្រពួកគេ ។ ខ្ញុំជឿថា ពួកគេដឹងពីចំណុចណាខ្លះដែលមនុស្សគ្រប់គ្នាត្រូវធ្វើឲ្យវិលខួរ និងភ័យរន្ធត់ហើយ ប៉ុន្តែប្រការនេះ គ្មានន័យសម្រាប់ពួកគេឡើយ ព្រោះថាពួកខ្មែរក្រហមត្រូវការកងទ័ព» ។

កាលបើពួកគេបោះបង់ចោលនូវ«ភាពខុសគ្នា»រវាង«ពួកអ្នកចាស់» និង«ពួកអ្នកថ្មី»កងទ័ពអាចជ្រើសរើសយុវជនក្មេងៗទាំងអស់ឲ្យចូលធ្វើទ័ព ហើយម្យ៉ាងទៀត គឺជ្រើសរើសតែពួកអ្នកដែលស្របនឹងលក្ខណៈវិនិច្ឆ័យខាងនយោបាយក្នុងពេលថ្មីៗប៉ុណ្ណោះ ។ ពួកយុទ្ធជនជ្រើសរើសថ្មីទាំងនេះ ដែលមួយចំនួនធំទើបតែនឹងពេញវ័យ បានទទួលការហ្វឹកហ្វឺនក្នុងរយៈពេលមួយយ៉ាងខ្លី -ជួនកាលមិនលើសពីពីរឬបីថ្ងៃឡើយ- មុនបញ្ជូនទៅសមរភូមិ ។ យូរទៅទៀត កងទ័ពថ្មីរបស់កម្ពុជាប្រជាធិបតេយ្យមានលំនាំដូចកងទ័ពរបស់ លន់ នល់ ដោយសាររយៈការហ្វឹកហ្វឺនច្បោលៗ និងបរិយាកាសវក់វីរបស់ខ្លួន របៀបកងទ័ពខ្មែរក្រហមដែលឈ្នះសង្គ្រាមពីឆ្នាំ ១៩៧០-១៩៧៥ ដែរ ។

នៅរដូវក្តៅ ការវាយប្រយុទ្ធបានបន្តនៅតាមព្រំដែន ជាមួយនឹងការតតាំងទល់មុខគ្នាយ៉ាងសាហាវ នៅខែកក្កដា និងខែសីហា ។ ប្រជាជនទូទៅដូច តាវ ជាដើម ត្រូវបានប្រាប់ឲ្យដឹងពីការវាយប្រយុទ្ធផ្សេងៗ តែតាមរយៈពាក្យចចាមអារ៉ាមផ្សេងៗដែលមកដល់សហករណ៍ ប៉ុណ្ណោះ ពុំមែនតាមរយៈការផ្សាយឃោសនារបស់វិទ្យុផ្លូវការ ដែលផ្សាយបន្តដោយមេក្រូមាននៅគ្រប់ទីកន្លែងទេ ។ តាវ ជឿថា ពួកវៀតណាមបានចូលលុកលុយប្រទេសនៅរដូវប្រាំង ។ គាត់មិនអាចរកការបំភ្លឺណាផ្សេងទៀត ចំពោះការចង់បានដែលកាន់តែកើនធំឡើងៗ ក្នុងការរើសយុទ្ធជនថ្មីដែលកងទ័ពបង្ហាញឲ្យឃើញឡើយ ។

«បន្ទាប់ពីបានជ្រើសរើសពួកអ្នកនៅលីវឲ្យចូលធ្វើទ័ព ពួកគេបានយកពួកយុវជនក្មេងៗ ពួកពេញជំទង់ម្តង ។ បន្ទាប់មក ពួកគេបានហៅរកពួកយុវជនដែលរៀបការរួច ហើយតមកទៀតចាប់ផ្តើមយកមនុស្សវ័យចាស់ឲ្យចូលធ្វើការទ័ពថែមទៀត ។

តាវ និងមិត្តភក្តិជាតិចិនកាត់ខ្មែរជាច្រើនរបស់គាត់បានរួចផុតពីការរើសទ័ពនេះ ពីព្រោះ ពួកកុម្មុយនិស្តមិនសូវជឿទុកចិត្តដើម្បីរើសពួកអ្នកទាំងនេះឲ្យចូលធ្វើទ័ពទេ ។ ថ្វីបើការឃោសនារបស់វៀតណាមដែលថា គឺប្រទេសចិននេះហើយជាអ្នកញុះញង់ពិតប្រាកដឲ្យមានសង្គ្រាម ដែលបានបញ្ជូនកងទ័ពកម្ពុជាឲ្យមកវាយប្រយុទ្ធ ប៉ុន្តែការពិតគឺមានលក្ខណៈខុសគ្នាសម្រាប់ ហាន់ តាវ ៖ «យើងទាំងអស់ដែលជាជនជាតិចិនបានត្រូវគេ

ចាត់ទុកតាមបែបទីទៃៗពីគ្នា ។ ពួកកុម្មុយនិស្តមិនចង់ឲ្យយើងចូលធ្វើទ័ពរបស់គេទេ ។ យើងនៅតែត្រូវគេប្រមាថ កាតទាន និងរើសអើងជាតិសាសន៍ជានិច្ច» ។

ម្យ៉ាងទៀត ទោះបីជា ប៉ុល ពត ប្រកាសដោយខ្លួនឯងនៅទីក្រុងប៉េកាំងពីឥទ្ធិពលរបស់គំនិតម៉ៅ មកលើបដិវត្តន៍របស់កម្ពុជាក៏ដោយ ក៏បក្សនៅតែមានចិត្តសង្ស័យចំពោះបំណងផ្សេងៗរបស់ចិនដដែល ។ ស្ត្រីអ្នករួចរស់ជីវិតម្នាក់គឺ អ្នកស្រី ឡូរ៉ង់ ពិក (Laurence Picq) ដែលធ្វើការនៅក្រសួងការបរទេស បានបញ្ជាក់ថា គេបានទិតៀននាង ចំពោះការកោតស្ញប់ស្ញែងរបស់នាងដែលមានទៅលើប្រទេសចិន ។ ប៉ុន្តែ មេដឹកនាំបក្សម្នាក់គឺ អៀង សារី បានឆ្លើយតបមកនាងថា "ប៉ុន្តែ ប្រទេសចិនពុំមែនជាមិត្តពិតប្រាកដមួយទេ គឺគេចង់យកស្រុកយើងដាក់ជាអាណានិគមរបស់គេ[៣០] » ។

អៀង សារី និងមេដឹកនាំជាន់ខ្ពស់ដទៃទៀតរបស់បក្ស បានបន្តអះអាងនឹងពួកកម្មាភិបាលរបស់គេ នៅពេលប្រជុំជាឯកជន និងក្នុងកម្រិតតិចតួចថា មានតែប្រទេសកម្ពុជាមួយប៉ុណ្ណោះដែលដើរតាមមាគ៌ាបដិវត្តត្រឹមត្រូវ ។ នៅឆ្នាំ១៩៧៨ បន្ទាប់ពីការផ្តួលរំលំ "បនប្អូនទាក់" សារី បានបញ្ជាក់អះអាងថា ប្រទេសចិនបានប្រកាន់យកមាគ៌ាតែមួយដូចគ្នានឹងប្រទេសរុស្ស៊ីសេរីនិយមដែរ[៣១] ។

កងទ័ពបានជ្រើសរើសយុទ្ធជនខ្មែរជាច្រើន និងប្រមូលសម្ភារៈសឹកដើម្បីធ្វើសង្គ្រាម ។ នៅរដូវក្តៅនេះ ក្នុងភូមិភាគពាយ័ព្យ ស៊ីសូផា អតីតអ្នកថែទាំជំងឺស្រីម្នាក់ដែលបានក្លាយទៅជាប្រធានក្រុមការងារមួយបានចាប់ផ្តើមមានសេចក្តីភ័យខ្លាច[៣២] ។ ទោះបីជានាងត្រូវតែងតាំងឲ្យធ្វើការតាមការអនុគ្រោះ ពីពួកកម្មាភិបាលភូមិភាគនិរតី បន្ទាប់ពីពួកគេបានបោសសម្អាតភូមិភាគពាយ័ព្យរួចហើយក៏ដោយ ក៏នាងមិនសូវបានទាញអត្ថប្រយោជន៍ពីមុខងារនេះសម្រាប់ខ្លួននាងនិងគ្រួសារផ្ទាល់របស់នាងដែរ ។ អង្ករបានរលាយបាត់ភ្លាមៗពីតុបាយ ៈ សុន សេន ដែលនាងមិនស្គាល់សោះបានបញ្ជាថា បរិមាណស្រូវអង្ករទាំងអស់ត្រូវដកទុកមួយភាគលើចំណែកដែលត្រូវបែងចែកក្នុងសហករណ៍នានា និងស្តុកទុកសម្រាប់កងទ័ព ។ ដូច្នេះ ក្នុងភូមិភាគទាំងមូលគេបានបង្កើតឃ្លាំងផ្ទុកស្បៀងយ៉ាងច្រើន ហើយគេបានរៀបចំកន្លែងលាក់ទុកមួយចំនួនធំ នៅព្រៃភ្នំខាងជើងទៀត ក្នុងករណីដែលរដ្ឋាភិបាលនឹងត្រូវបង្ខំចិត្តជម្លៀសចេញពីក្រុងភ្នំពេញនៅថ្ងៃណាមួយ ។

ប៉ុល ពត បានប្រកាសថា ឆ្នាំ១៩៧៨ នឹងទៅជាពេលប្រែប្រួលដ៏សំខាន់របស់ការបដិវត្តន៍ ជាឆ្នាំដំបូងដែលមានស្ថិរភាព និងជាឈ្នាន់មួយសម្រាប់ឈានទៅរកជោគជ័យផ្សេងនៅពេលអនាគត ។ សម្រាប់មនុស្សភាគច្រើនយល់ថា ការពិតរឿងគឺខុសគ្នាស្រឡះ ហើយ ស៊ីសូផា បានរៀបរាប់ថា ៈ "នៅរដូវក្តៅនោះយើងត្រូវធ្វើការងាររឹតតែខ្លាំងនិងរឹតតែពិបាកទ្រាំទ្រជាងពេលណាៗទាំងអស់ ហើយយើងបរិភោគតែគ្រាប់សណ្តែក និងពោត ប៉ុណ្ណោះ គ្មានអង្ករហូបទេ» ។

ម្យ៉ាងទៀត ភ្លៀងបានធ្លាក់មកយ៉ាងជោកជាំ ។ ក្នុងឧបទ្វីបទាំងមូល -ប្រទេសឡាវ, ថៃ, កម្ពុជា និងភាគ

ខាងត្បូងប្រទេសវៀតណាម- ខ្យល់រដូវម៉ូសុង បានបង្កឲ្យមានទឹកជំនន់លិចលង់ ។ នៅខែសីហា ទឹកភ្លៀងបានបំផ្លាញផលដំណាំនៅប្រទេសវៀតណាម ឡាវ អស់មួយភាគធំ ហើយបណ្តាលឲ្យខូចខាតស្រែចម្ការនៅប្រទេសថៃ និងកម្ពុជាទៀត ។ គេបានរាយការណ៍ឲ្យដឹងពីមនុស្សស្លាប់ចំនួនពីររយនាក់ ដែលរងគ្រោះដោយសារទឹកជំនន់នេះ ។ ប្រទេសវៀតណាម និងប្រទេសឡាវបានសុំជំនួយស្បៀងអាហារមួយជាបន្ទាន់ពីអន្តរជាតិ ។ រដ្ឋាភិបាលថៃបានប្រកាសថា ទឹកជំនន់នេះ ជាទឹកជំនន់ដែលបំផ្លិចបំផ្លាញខ្លាំងជាងគេនៅរយៈកាលថ្មីៗនេះ ។ ប៉ុន្តែ កម្ពុជាប្រជាធិបតេយ្យបានអះអាងថា ទឹកជំនន់នេះពុំបានប៉ះពាល់ដល់នយោបាយឯករាជ្យម្ចាស់ការខាងវិស័យស្បៀងអាហារទេ ។ «យើងពុំមែនជាអ្នកសុំទានដូចពួកវៀតណាម ដែលសុំស្បៀងអាហារគេរបៀបថៅកទាបនោះទេ» ។ ប៉ុន្តែ វិទ្យុរដ្ឋាភិបាលបានទទួលស្គាល់ថា ទឹកជំនន់នេះ បានធ្វើឲ្យផលដំណាំស្រូវខូចខាតយ៉ាងសម្បើម ។

ប្រជាជនជាច្រើននៅជនបទ ដែលនៅរស់រានមានជីវិតជាងបីឆ្នាំក្នុងបដិវត្ត ដែលដឹកនាំដោយ ប៉ុល ពត និងប្រាំឆ្នាំក្នុងសង្គ្រាមដែលមានពីមុន បានវិនិច្ឆ័យទឹកភ្លៀងនេះថា ជាប្រផ្នូលមួយ ។ តាមការមើលឃើញរបស់ពួកគេ ទឹកជំនន់ និងព្យុះសង្ឃរាឆ្នាំ១៩៧៨ ជាសញ្ញាប្រកាសឲ្យដឹងគ្រោះកំណាចថ្មីៗជាច្រើន ។

ដោយសន្សឹមៗជិតមកដល់ទីបញ្ចប់របស់ខ្លួន ការបដិវត្តន៍បានក្លាយទៅជារឿងដែលប្រជាជនអាចដឹងស្គាល់ច្បាស់លាស់ជាងពីមុន ។ ពិភពដែលខណ្ឌចែក «ពួកអ្នកចាស់» និង«ពួកអ្នកថ្មី» ពួកអ្នកមានឯកសិទ្ធិ និងពួកអ្នកដែលបាត់បង់សេចក្តីអនុគ្រោះបានរលាយខ្សុល ។ ការប្រឹងប្រែងចុងក្រោយ ដើម្បីបង្កើតដោយឆាប់រហ័សនូវ«ប្រជាជាតិថ្មីថ្កើងរុងរឿងមួយ ជាមួយនឹងប្រជាជនប្រកបដោយសុភមង្គលមួយ» បានចាប់ផ្តើមនៅក្រុងភ្នំពេញខែកក្កដា ។ អៀង សារី បានប្រកាសប្រាប់ពួកកម្មាភិបាល អំពីដំណាក់កាលផ្តាច់ព្រ័ត្រនេះក្នុងសុន្ទរកថាមួយ ហើយបានបន្ថែមថា ជាមួយការគំរាមកំហែងរបស់វៀតណាម ដែលគ្របដណ្តប់មកលើប្រទេស និងការកម្ទេចពួកក្បត់ចុងក្រោយ ជាពិសេស សោ ភឹម ប្រទេសកម្ពុជាបានប្តេជ្ញាចិត្តបោះជំហានទៅមុខ ដោយឆ្លាប់រហ័សបំផុត ។ ជាបន្ទាន់នោះ សារី ចង់ឈានដល់ភាពល្អឥតខ្ចោះភ្លាម ។

នៅខែនោះ ពួកបញ្ញវន្តដែលជាប់ឃុំឃាំងក្នុងជំរំមួយនៅមាត់ប្រកចេញពីទីក្រុងភ្នំពេញត្រូវបានគេប្រាប់ឲ្យដឹងថា ការប្រព្រឹត្តមិនល្អមកលើពួកគេ គឺជាការយល់ច្រឡំមួយ[៣៣] ។ ពីពេលនេះតទៅ អៀង សារី ព្រមទាំងក្រសួងការបរទេសនឹងយកចិត្តទុកដាក់ចំពោះសុខុមាលភាពរបស់ពួកគេឡើងវិញ ។ គេបានសន្យាឲ្យធ្វើការក្នុងមួយថ្ងៃតែប្រាំបីម៉ោងប៉ុណ្ណោះ និងថ្ងៃឈប់សម្រាកពិតប្រាកដមួយរៀងរាល់ដប់ថ្ងៃម្តង ។ គេបានបន្ទុយឲ្យដឹងថា ការកាប់សម្លាប់ពួកបញ្ញវន្តត្រូវបានបញ្ចប់ហើយ ។

សម្រាប់ភាគច្រើននៃបញ្ញាវន្តទាំងនេះ ដែលត្រឡប់មកពីបរទេសត្រូវបាន«ជួយឲ្យរួចពីគ្រោះថ្នាក់ដោយពួកអ្នកនោះដែលធ្លាប់ក្បត់ពួកគេដដែល ។ គឺ អៀង សារី នេះឯងដែលបានបញ្ចុះបញ្ចូលបញ្ញវន្តមួយចំនួនធំក្នុងចំណោមពួកគេឲ្យវិលត្រឡប់មកប្រទេសកម្ពុជាវិញ ក្រោយឆ្នាំ១៩៧៥ ។ ជាមួយ ជួន ប្រសិទ្ធ គាត់បានធ្វើ

ដំណើរទៅកាន់ប្រទេសផ្សេងៗ ដើម្បីប្រកាសប្រាប់សហគមន៍ជនជាតិកម្ពុជាថា រដ្ឋអំណាចបដិវត្តន៍ថ្មីរាប់រកបញ្ញវន្តយ៉ាងប្រសើរ ទោះណាជាគាត់ដឹងថា បញ្ញវន្តខ្លះក្នុងចំណោមនោះត្រូវបានគេសម្លាប់បាត់ទៅហើយក៏ដោយ ។ ដូច្នេះ ពួកបញ្ញវន្តទាំងនេះ នៅតែស្អប់ខ្ពើម អៀង សារី ជានិច្ច ។

នៅខណៈនេះ ពួកគេបេះទម្លាប់ខ្លួនទទួលយកការផ្លាស់ប្តូរផ្សេងៗ ដោយមិនបញ្ចេញយោបល់អ្វីទាំងអស់ ។ ដំបូងគេបង្ហាញឲ្យឃើញថា អ្នកណាមួយដែលទទួលខុសត្រូវពីស្ថានភាពរបស់គេពីពេលមុន គេបានបញ្ជូនមកឲ្យបញ្ញវន្តទាំងនោះនូវ “ឯកសារ” ជាច្រើនក្នុងគោលបំណុលបង្ហាញឲ្យឃើញថា កុយ ធួន លេខាបក្សភូមិភាគឧត្តរឃើញថា ជាភ្នាក់ងារម្នាក់របស់សេ.អ៊ី.អា.ហើយថា សោ ភឹម ធ្លាប់ធ្វើការដើម្បីផលប្រយោជន៍ប្រទេសវៀតណាម ។ មនុស្សទាំងពីរនាក់នេះ និងពួកក្បត់ដទៃទៀត ធ្លាប់បានបង្កើតឲ្យមានស្ថានភាពច្របូកច្របល់និងស្រពេចស្រពិលមួយ ដែលជាមូលហេតុធ្វើឲ្យមានព្រឹត្តិការណ៍អាក្រក់ដល់ពួកបញ្ញវន្តផ្សេងៗ ។ ដួន មុំ បាននិយាយប្រាប់អ្នកទាំងនេះ ពីសេចក្ដីស្រឡាញ់របស់របបចំពោះប្រជាជន ។ បើសិនជានយោបាយក្នុងរយៈពេលបីឆ្នាំមុន ធ្វើឲ្យខូចខាតដល់ប្រទេសជាតិក្នុងវិស័យណាមួយនោះ គឺជាកំហុសរបស់ពួកក្បត់ជាតិដែលបានអនុវត្តគោលមាគ៌ារបស់បដិវត្តន៍ ដោយភាន់ច្រឡំក្នុងគោលបំណងផ្តួលរំលំការបដិវត្តន៍នេះ ។

ការដែលពួកគេគាំទ្ររូបគាត់ គឺព្រោះតែគាត់ធ្លាប់ធ្វើជាមេដឹកនាំនិស្សិត ឬជាគ្រូបង្រៀន ឬក្រោយមកនៅពេលដែលគាត់ឈានឡើងដល់ឋានៈជាគណៈដឹកនាំបក្ស ពួកគេបានចាត់គាត់ជាមនុស្សក្បត់នឹងបុព្វហេតុមួយដែលគាត់ធ្លាប់ធ្វើឲ្យមានកិត្តិយស ។ បញ្ញវន្តទាំងនេះ ជាជនជាតិកម្ពុជាទាន់សម័យ ដែលការបន្ទូចរបស់សម្ដេចព្រះនរោត្តម សីហនុ ធ្លាប់ធ្វើឲ្យគ្នាមានការនឿយណាយក្នុងចិត្ត និងជាអ្នកដែលមានបំណងកែលំអ –ពុំមែនបំផ្លាញទេ– របៀបរបបរស់នៅរបស់ខ្មែរឲ្យបានប្រសើរជាងមុន ។

ក្នុងក្រុងភ្នំពេញទាំងមូល នៅជុំវិញពួកបញ្ញវន្តនិងតាមមន្ទីរក្រសួងនានារបស់រដ្ឋាភិបាល មេដឹកនាំជាច្រើនដែលគេស្គាល់ច្បាស់ពីចរិតម៉ឺងម៉ាត់របស់គេ ត្រូវបានផ្លាស់ជំនួសដោយពួកកម្មាភិបាលនិយមនយោបាយកណ្ដាលវិញ ។ អៀង សារី បាននិយាយទៅកាន់ពួកបញ្ញវន្តទាំងនោះ ដើម្បីសម្រួលការប្រែប្រួលផ្សេងៗ ក្រោមទស្សនៈវិស័យត្រឹមត្រូវមួយ ។ “សមមិត្ត យើងទាំងអស់គ្នាស្ថិតនៅលើទូកតែមួយដូចគ្នា” ។ ទូកនេះគឺ ប្រជាជាតិនិងបដិវត្តន៍ ដែលហ៊ុំព័ទ្ធដោយប្រទេសវៀតណាម ។ សារី បានឆ្លើយបដិសេធគំនិតដែលថា បក្សធ្លាប់ស្ថិតនៅពីក្រោយការសម្លាប់រង្គាលពួកបញ្ញវន្តដោយរបៀបម៉្យាង គាត់បានប្រកាសថា “ពាក្យគុកបានត្រូវលុបចេញពីភាសានិយាយរបស់យើងហើយ” ។

នៅខែកញ្ញា ប៉ុល ពត បានថ្លែងសុន្ទរកថាដ៏សំខាន់មួយទៅកាន់មហាសន្និបាតលើកទី៤របស់បក្ស ដែលប្រារព្ធធ្វើនៅទីក្រុងភ្នំពេញ ។ គាត់បានលាតត្រដាងពីគម្រោងការផ្សេងៗរបស់គាត់ ដើម្បីធ្វើឲ្យប្រទេសមានឧស្សាហកម្ម “ឆាប់រហ័ស” ប្រើគ្រឿងយន្តក្នុងវិស័យកសិកម្មនិងរៀបចំប្រព័ន្ធអប់រំបដិវត្តមួយ ។ ក្នុងឱកាសនៃ

សម័យប្រជុំមួយ ដួន មុំ បានឡើងមានមតិដូចមេដឹកនាំបក្សដែរ ដើម្បីពន្យល់អំពីប្រព័ន្ធនេះ ។ មុំ បានត្រូវគេចាត់ឲ្យទទួលបន្ទុកខាងការសិក្សាបច្ចេកទេស ជាភស្តុតាងមួយទៀតនៃឥទ្ធិពលរបស់ អៀង សារី ទៅលើសេរីកម្ម (ការធ្វើឲ្យមានសេរីភាពជាមុន) សម្រាប់របបរបបដែលត្រដាបត្រដួសមួយ ។ មុំ មានបំណងបង្កើតកម្មវិធីមួយ ដែលឆ្ពោះទៅរកការបង្កើតសាលាពាណិជ្ជកម្មមួយនៅក្នុងរដ្ឋធានី ។

នៅខែដដែលនេះ បញ្ញវន្ត និងកម្មាភិបាលជាច្រើននៅភ្នំពេញ ដែលពុំដែលចាកចេញពីទីក្រុងសោះ តាំងតែពីដើមដំបូងនៃការបដិវត្តន៍ បានត្រូវគេនាំទៅធ្វើទស្សនកិច្ចនៅខេត្តបាត់ដំបង ដើម្បីពិនិត្យមើលប្រព័ន្ធធារាសាស្ត្រធំៗ ។ នេះគឺជាសិទ្ធិពិសេសហួសពីការនឹកស្មានមួយ ហើយគេក៏អនុញ្ញាតឲ្យអ្នកខ្លះដឹងថា ប្រជាជននៅជនបទទទួលរងទុក្ខវេទនាជាងពួកគេទៅទៀត ។

នៅមានការសាកល្បងផ្សេងៗទៀតរបស់បក្ស ដើម្បីឲ្យទទួលបានការចូលចិត្តពីពួកបញ្ញវន្តឡើងវិញ ។ នៅខែកញ្ញា គេបានប្រារព្ធពិធីបុណ្យរំឭកខួបកំណើតបក្ស ដោយមានការធ្វើបដិសណ្ឋារកិច្ច និងការរៀបចំភោជនាហារផង ។ មន្ទីរផ្សេងៗនៅក្រសួងការបរទេស បានរៀបចំធ្វើពិធីបុណ្យមួយយ៉ាងធំ បុគ្គលិកធ្វើការ បាននាំគ្នាទៅមើលខ្សែភាពយន្ត ។ ឪពុកមារបស់ ដួន មុំ ត្រូវបានគេបញ្ជូនពីសហករណ៍មួយនៅក្បែរខេត្តកណ្ដាល មកកាន់ជំរំពួកបញ្ញវន្ត ដើម្បីជួយរៀបចំធ្វើពិធីបុណ្យមួយដែរ ។ គាត់ធ្លាប់ដឹកនាំគ្រប់គ្រងអតីតសណ្ឋាគារ «ឡឺរ៉ូយ៉ាល់» នៅភ្នំពេញក្នុងរយៈពេលជាច្រើនឆ្នាំ ហើយនៅថ្ងៃបុណ្យខួបនេះ គេបានអនុញ្ញាតឲ្យ មុំ ហៅពួកអ្នកមានទេពកោសល្យពីមុនមកធ្វើនំមួយ ។ ពួកអ្នកជាប់ឃុំក្នុងជំរំអាចបរិភោគអាហារជាគ្រួសារ បុរសៗលែងត្រូវបំបែកពីពួកនារីៗទៀតហើយ ពួកអ្នកពេញវ័យក៏លែងឃ្លាតឆ្ងាយពីពួកក្មេងៗដែរ ។

នៅខែតុលា ឆ្នាំ១៩៧៨ ជំរំទាំងពីរ (ពួកបញ្ញវន្ត និងពួកអតីតអ្នកការទូត) បានត្រូវគេបញ្ចូលគ្នាជាជំរំតែមួយវិញ ហើយ«ការធ្វើឲ្យមានសេរីភាពជាមុន» បានជឿនលឿនទៅមុខ ។ នៅខែវិច្ឆិកា ភាពខុសប្លែកគ្នាបានចាប់បើកជាថ្មីសម្រាប់ពួកបញ្ញវន្ត និងសម្រាប់ប្រជាជនទាំងអស់ ។ ភ្លាមៗនោះ អ៊ីៗក៏មានហូបដែរ ៈ ត្រីសាច់ បន្លែ និងស៊ុត ដែលជាផលិតផលបាត់មុខតាំងពីដើមដំបូងនៃការបដិវត្តន៍ម្ល៉េះ ។ គេបានចែកសាច់ និងត្រី រៀងរាល់ថ្ងៃឲ្យពួកបញ្ញវន្ត និងអតីតអ្នកការទូត ។ ក្នុងភូមិភាគពាយ័ព្យឆ្ងាយដាច់ស្រយាលរបស់នាង ស៊ីសូផា បានមើលឃើញអ៊ីៗដែលកើតឡើងនេះដូចគ្នា ៈ «អង្ករបានលេចចេញជាថ្មីគួរឲ្យងឿងឆ្ងល់ ដោយមាន សាច់ មាន់ ស៊ុត និងដំឡូងផង ជាមួយនឹងត្រសក់ទុំយ៉ាងច្រើន ។ យើងមិនដឹងស្បៀងអាហារនេះចេញមកពីកន្លែងណាទេ ។ អ្នកខ្លះហូបច្រើនមែនទែន រហូតដល់ស្លាប់» ។

ដូច«ពួកអ្នកថ្មី»របស់ភូមិភាគពាយ័ព្យដែរ ពួកបញ្ញវន្តត្រូវតែបន្ថយការស្រេកឃ្លានរបស់គេឲ្យសម នៅពេលដែលរបបប្រចាំថ្ងៃរបស់គេកើនសាច់និងត្រីភ្លាមៗ ។ មនុស្សប្រុស និងស្រីជាច្រើន មានរាងកាយស្គមកំព្រឹងដូចគ្រោងឆ្អឹង ដោយសារបរិភោគកន្ទក់ និង«កូនជ្រូក» ជាឈ្មោះដែលដាក់ឲ្យសត្វកណ្ដុរ ដែលពួកគេចាប់

បានយកមកធ្វើជាម្ហូប ។ ខ្លួនប្រាណរបស់អ្នកទាំងនោះ ដែលមានស្បែកយុរយារ មើលទៅហាក់ដូចជារូមតូច បន្ទាប់ពីការហូបអាហារមិនគ្រប់គ្រាន់ជាច្រើនឆ្នាំ ។ ពួកគេសុទ្ធតែមានភ្នែកឡើងស្លឹ ។ បើទោះជាពួកគេរួចផុតពីសេចក្តីស្លាប់យ៉ាងប្រផុតប្រដើយក៏ដោយ ក៏ភាគច្រើនយល់ឃើញថា នេះគឺជារឿងចៃដន្យ ពុំមែននយោបាយទេ ដែលជួយពួកគេឲ្យរួចផុតពីគ្រោះថ្នាក់ ។ ដោយមានកម្លាំងកំហែងឡើងវិញ ពួកគេប្រហែលជាមិនបណ្តែតបណ្តោយទៅតាមកំហឹងរបស់គេទៀតទេ ។

អៀង សារី បានផ្តល់ឲ្យពួកបញ្ញវន្តនូវបណ្ណាល័យតូចមួយ ដោយមានសៀវភៅជាភាសាបារាំង សុន្ទរកថាទាំងឡាយរបស់ ប៉ុល ពត ជាភាសាបារាំង និងអង់គ្លេសផង ។ ពួកគេក៏មានសិទ្ធិជ្រើសរើសមេដឹកនាំសម្រាប់ជំរំផ្ទាល់របស់ខ្លួនតាមរបៀបប្រជាធិបតេយ្យដែរ ។ អៀង សារី បានធ្វើជាអធិបតីក្នុងការចាត់តាំង ឈ្មោះបេក្ខជន និងចាត់ចែងការបោះឆ្នោតដោយខ្លួនឯងផ្ទាល់ ។ រឿងនេះហាក់ដូចជាមិនពិត តាមការពិត គឺវាមានមែន ។

សារី ជា“ខួរក្បាល” នៅពីក្រោយភាគច្រើននៃការផ្តួចផ្តើមគំនិតធ្វើ “សេរីកម្ម” (ការធ្វើឲ្យមានសេរីភាពជាងមុន) ក្នុងគោលបំណងញ៉ាំងឲ្យពិភពលោកជឿថា កម្ពុជាប្រជាធិបតេយ្យជាប្រជាជាតិមួយ ដែលមានស្ថិរភាព និងដែលមានការដឹកនាំគ្រប់គ្រងយ៉ាងត្រឹមត្រូវ ។ ដោយគ្មានការសង្ស័យបន្តិច គាត់បានទទួលនូវការគាំទ្រពីពួកចិនយ៉ាងខ្លាំងក្លាក្នុងវិស័យនេះ ។ គាត់បានឆ្លៀតទាញយកអត្ថប្រយោជន៍ពីភារកិច្ចថ្មីនេះ ដើម្បីការពារបណ្តាមិត្តភក្តិរបស់គាត់ ព្រមទាំងពួកបញ្ញវន្ត និងអ្នកការទូត ដែលជាប់ក្នុងជំរំផ្សេងៗនៅក្រុងភ្នំពេញផង ។

នៅខែតុលា សារី បានធ្វើដំណើរទៅក្រុងញូវយ៉ក ដើម្បីចូលរួមមហាសន្និបាតអង្គការសហប្រជាជាតិដើម្បីនឹងបង្ហាញរូបភាពថ្មីរបស់កម្ពុជា និងប្រើប្រាស់វាប្រឆាំងនឹងប្រទេសវៀតណាមថែមទៀត ។ គាត់បានបើកធ្វើសន្និសីទកាសែតមួយចំនួនតូច ដែលក្នុងឱកាសនោះ គាត់បានប្រកាសជាសាធារណៈថា គាត់បានអញ្ជើញលោកឃឹក វ៉ាល់ដែម អគ្គលេខាអង្គការសហប្រជាជាតិ ទៅធ្វើទស្សនកិច្ចនៅកម្ពុជា ដើម្បីស៊ើបអង្កេតអំពីការចោទប្រកាន់រឿងរំលោភសិទ្ធិមនុស្ស ហើយថា បន្តិចទៀត សេចក្តីអញ្ជើញជាច្រើនទៀត នឹងត្រូវផ្ញើឲ្យពួកអ្នកកាសែតបរទេស ។ គាត់បានចែករូបថត សម្តេច ព្រះនរោត្តម សីហនុ និងអ្នកម្នាង ម៉ូនីក ឲ្យពួកអ្នកកាសែតជាច្រើនសន្ធឹក ។ ពិភពលោកនៅតែចាត់ទុកអតីតស្តេចអង្គនេះថា ជាមេដឹកនាំដ៏សំខាន់ម្នាក់នៃប្រទេសតតិយលោកដដែល ហើយរូបថតនេះ គឺមានគោលបំណងឆ្លើយតបទៅនឹងសំណួរជាច្រើន ស្តីពីស្ថានភាពរបស់សម្តេច ព្រះនរោត្តម សីហនុ - តាមពាក្យចចាមអារ៉ាមជាច្រើនថា ព្រះអង្គត្រូវគេសម្លាប់បាត់ទៅហើយ - និងដើម្បីបង្ហាញឲ្យឃើញថា ព្រះអង្គក៏គាំទ្របដិវត្តន៍ដែរ ។ រូបថតទាំងនេះសឲ្យដឹងថា ព្រះអង្គនៅមានព្រះជន្មនៅឡើយ ប៉ុន្តែទឹកព្រះភក្ត្ររបស់ព្រះអង្គធ្វើឲ្យគេយល់ថា ព្រះអង្គគ្មានសុភមង្គលទាល់តែសោះ ។ សម្តេច និងមហេសីរបស់ព្រះអង្គ មានសភាពហាក់ដូចជាមនុស្សរមួរម៉ៅច្រើន នឿយណាយនឹងជីវិតយ៉ាងខ្លាំង ។

សារី បានចែកផ្សាយសៀវភៅខ្មៅរបស់ប្រទេសកម្ពុជា ដែលមានចំណងជើងថា “ហេតុការណ៍ និងភ័ស្តុតាង

នៃអំពើឈ្លានពាន និងការក្អាប់ទឹកដីរបស់វៀតណាមប្រឆាំងនឹងប្រទេសកម្ពុជា» ។ ឯកសារនេះ ជារឿងដ៏សំខាន់ក្នុងបេសកកម្មរបស់ សារី ពីព្រោះគាត់ត្រូវតែបង្ហាញឲ្យគេឃើញថា ប្រទេសវៀតណាមជាអ្នកទទួលខុសត្រូវតែម្នាក់ឯងអំពីការគំរាមកំហែងផ្ញើសង្គ្រាមរវាងប្រទេសទាំងពីរ ។

ការអញ្ជើញលោកវ៉ាល់ដែម បានឆ្លើយតបនឹងការគាបសង្កត់របស់អន្តរជាតិដែលកាន់តែរីកធំឡើងៗ ជាថ្នូរនឹងការបញ្ចប់ការសម្លាប់បំផុតពូជ ។ កាលពីឆ្នាំមុន ប្រទេសអង់គ្លេសបានធ្វើជាអ្នកដឹកមុខចលនាតវ៉ាប្រឆាំងមួយ ហើយសភាទាំងពីររបស់អាមេរិកាំង ក៏ទាមទារឲ្យមានការស៊ើបអង្កេតមួយ ចំពោះរដ្ឋាភិបាលផ្ទាល់របស់ខ្លួនដែរ ។

ការអញ្ជើញនេះបានបណ្ដាលឲ្យមានការប៉ះទង្គិចគ្នាមួយ ។ អង្គការលើកលែងទោស អន្តរជាតិ (Amnesty International) បានអបអរសាទរចំពោះការអញ្ជើញនេះភ្លាម ប៉ុន្តែ វ៉ាល់ដែម បានច្រានចោលដោយប្រកាសថា គាត់អាចធ្វើដំណើរទៅកាន់កម្ពុជាបាន លុះណាតែប្រទេសវៀតណាមធ្វើការអញ្ជើញមួយដូចគ្នានេះ ។ លោកអគ្គលេខា បានទាញហេតុផលថា អង្គការសហប្រជាជាតិ បានគ្រោងប្រើវិធានការផ្សេងៗ ដើម្បីបញ្ឈប់ការវិវាទ ហើយថា ដំណើរទៅកាន់ប្រទេសកម្ពុជាតែមួយអាចនឹងល្បីឈ្មោះថា ជាការលម្អៀងទៅតែម្ខាងៗ ។ ពួកគេដឹកនាំវៀតណាមដែលជាប់រវល់រៀបចំផែនការចូលលុកលុយប្រទេសកម្ពុជាជាសម្ងាត់នោះ បានឆ្លើយតបថា ពួកគេពុំមានគម្រោងអញ្ជើញលោក វ៉ាល់ដែម ទេ ។ ដូច្នេះមធ្យោបាយដើម្បីដោះកុនរបស់ សារី បានទទួលបរាជ័យ ។ ប្រាកដណាស់គាត់ពិតជាជឿថា វត្តមានរបស់លោក វ៉ាល់ដែម នៅកម្ពុជានឹងរាំងរាមិនឲ្យប្រទេសវៀតណាមលុកលុយប្រទេសរបស់គាត់បាន ។

អៀង សារី គ្មានផ្លូវដោះស្រាយណាផ្សេង ក្រៅពីងាកទៅរកសំណើទីពីររបស់គាត់ឡើយ គឺការអញ្ជើញពួកអ្នកតំណាងសារពត៌មានអន្តរជាតិ ដើម្បីទៅអង្កេតអំពីការគោរពសិទ្ធិមនុស្សនៅប្រទេសកម្ពុជា ។ នៅថ្ងៃទី១៧ ខែវិច្ឆិកា ក្រុងភ្នំពេញបានអញ្ជើញអ្នកកាសែតអាមេរិកាំងពីរនាក់ និងសាស្ត្រាចារ្យសាកលវិទ្យាល័យអង់គ្លេសម្នាក់ឲ្យទៅធ្វើទស្សនកិច្ចនៅកម្ពុជាចាប់ពីថ្ងៃទី៩ដល់ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៧៨ ។ អ្នកកាសែតពីរនាក់នោះគឺ រីឆាដ ឌុដម៉ាន (Richard Dudman) នៃកាសែតសាំងល្វីឌីស្ពាត (Saint-Louis Dispatch) និងខ្លួនខ្ញុំផ្ទាល់ (អ្នកនិពន្ធសៀវភៅនេះ) នៃកាសែតវ៉ាស៊ីតោនប៉ុស្តិ៍ (Washington Post) ។ ឌុដម៉ាន និងខ្ញុំ បានទទួលព្រមតាមការអញ្ជើញ ព្រមទាំង ម៉ាល់ខូម ខាដវ៉ែល (Malcolm Caldwell) សាស្ត្រាចារ្យនៃវិទ្យាស្ថានសិក្សាស្រាវជ្រាវពីអាហ្វ្រិក និងអាស៊ីបូព៌ា នៅទីក្រុងឡុង (Londres) ផង ដែលជាអ្នកមានសមានចិត្តម្នាក់ ក្នុងចំណោមអ្នកមានសមានចិត្តដ៏កម្រ នៅបស្ចិមប្រទេសចំពោះរបប ប៉ុល ពត ។

នៅមុនការទៅដល់របស់យើង សារី បាននិយាយថែមថយខ្លះទៀតពីរូបភាពថ្មីរបស់កម្ពុជាបដិវត្ត ។ គាត់បានបញ្ជាឲ្យបុគ្គលិកផ្នែកសារពត៌មានរបស់គាត់ ចាប់ផ្ដើមផ្សព្វផ្សាយកម្មវិធីពត៌មានជាភាសាបរទេស ពិសេសគឺភាសាបារាំង និងអង់គ្លេស តាមវិទ្យុរបស់រដ្ឋាភិបាល ហើយបានផ្ដើមកម្មវិធីនេះនៅថ្ងៃទី១ ខែធ្នូ ឆ្នាំ១៩៧៨ ។ ឌិក សាគុណ បញ្ញវន្តដ៏ល្បីឈ្មោះម្នាក់ ដែលគេផ្សាយដំណឹងពីមរណភាពរបស់គាត់នៅទីក្រុងប៉ារីសនោះ ត្រូវបាន

គេផ្តល់នីតិសម្បទាឡើងវិញ ដើម្បីធ្វើជាអ្នកហែហមអមការពារពួកយើង ក្នុងដំណើរទស្សនកិច្ចនៅប្រទេសនេះ ។ បុគ្គលិកនៃក្រសួងការបរទេស បានចាប់ផ្តើមបោះពុម្ពផ្សាយព្រឹត្តិប័ត្រពត៌មានប្រចាំថ្ងៃមួយ ជាភាសាអង់គ្លេស នៅថ្ងៃទី៣០ ខែវិច្ឆិកា សម្រាប់ដំណើរទៅដល់របស់យើងដែរ ។

នៅពេលដដែលនោះ គេបានឮពាក្យចចាមអារ៉ាមជាច្រើនស្តីពីសង្គ្រាម ។ គេស្នើឲ្យពួកបញ្ញវន្ត រួមបង្កើតជាក្រុមដើរល្បាតក្នុងមួយក្រុមមានគ្នាបីនាក់ ដើម្បីការពារជំរំរបស់គេ ។ នៅខែវិច្ឆិកា គេឃើញមានប្រជាជនខេត្តស្វាយរៀង និងខេត្តតាកែវ នៃភូមិភាគបូព៌ា និងនិរតីចាប់ផ្តើមហូរចូលមកក្នុងរដ្ឋធានីយ៉ាងកុះករ ។ នៅទីបំផុត ពួកបញ្ញវន្តបានដឹងថា ប្រជាជនកម្ពុជានៅតំបន់ព្រំដែនបានសុំចុះចូលនឹងពួកវៀតណាម ហើយថា ពួកខ្មែរក្រហម បានជម្លៀសមនុស្សចេញពីសហករណ៍នានា ដែលការឃោសនា និងកងទ័ពវៀតណាម អាចលាន់ឮនិងមកដល់ភ្លាម ។

វាមានភាពមិនសមស្របគ្នាមួយ រវាងការធ្វើឲ្យមានប្រក្រតីភាពដែលមានតែសម្បកក្រៅ និងការគំរាមកំហែងនៃសង្គ្រាម ។ ក្រសួងការបរទេស បានរៀបចំឲ្យមានដំណើរទស្សនកិច្ចនៅប្រាង្គប្រាសាទអង្គរវត្ត រយៈមួយថ្ងៃ ដោយចេញដំណើរពីទីក្រុងបាងកកមក ដែលនឹងចាប់ផ្តើមនៅខែធ្នូ ឆ្នាំ១៩៧៨ ។ ប៉ុន្តែ នៅពីក្រោយលក្ខណៈមានតែក្រៅ ដែលបង្កើតឡើងដោយ អៀង សារី របបនេះនៅតែបន្តរៀបចំធ្វើសង្គ្រាម ដោយកម្ទេចពួកក្បត់យ៉ាងគ្មានអាណិតអាសូរដដែល ។ ក្នុងភូមិភាគពាយ័ព្យ ពួកកម្មាភិបាលរបស់បក្សបានចាប់ផ្តើមកាប់សម្លាប់ប្រជាជនរបស់ភូមិភាគបូព៌ា ដែលត្រូវជម្លៀសចេញពីសហករណ៍របស់ពួកគេ ប៉ុន្តែ របបនេះនៅតែចាត់ទុកពួកអ្នកទាំងនោះ ជា«ពួកអ្នកដែលត្រូវគេសង្ស័យ»ជានិច្ច ។ ក្នុងចំណោមនោះ ប្រជាជនរាប់រយនាក់ ត្រូវគេបង្ខំឲ្យជីករណ្តៅរួមសម្រាប់កប់ខ្លួនគេផ្ទាល់ ។ ម្តងនេះ គេមិនសូវព្យាយាមរក្សាការសម្ងាត់ទេ ។ ការមានកុះករភ្លាមៗនៃស្បៀងអាហារ ពុំអាចបិទបាំងការព្រួយបារម្ភ ដែលចេះតែរីកធំឡើងៗក្នុងចំណោមពួកមេដឹកនាំបានឡើយ ហើយឥឡូវនេះប្រជាជនដឹងថា សង្គ្រាមច្បាស់ជាកើតមានក្នុងពេលឆាប់ៗនេះមិនខាន ។ ប្រជាជននៅភូមិភាគពាយ័ព្យ បានដឹងរឿងនេះតាមរយៈសំឡេងស្រែករបស់អ្នករងគ្រោះលាន់ឮពីក្នុងព្រៃមក ។ ប្រជាជនជម្លៀសរបស់ភូមិភាគបូព៌ា បានបណ្តោយឲ្យគេសម្លាប់ដោយគ្មានប្រឆាំងតបតឡើយ ពីព្រោះប្រជាជនកម្ពុជានៅតែគ្មានសមត្ថភាពប្រឆាំងតបទៅវិញ ។ ប៉ុន្តែពួកគេដឹងថា អំណឹះតទៅ បដិវត្តន៍ ច្បាស់ជាមានការលំបាកខ្លាំងហើយ ។

ឌុច នៅតែបន្តកម្ចាត់អ្នកដែលគេសង្ស័យតាមសង្វាក់ដដែល ។ បើគាត់មិនយកភូមិភាគផ្សេងមួយទៀតជាគោលដៅកម្ទេច បន្ទាប់ពីការបោសសម្អាតភូមិភាគបូព៌ារួចហើយនោះ គាត់មុខជាទម្លាក់ទោសកំហុសទៅលើអ្នកមានអំណាចសំខាន់ជាងគេម្នាក់នៃរបបនេះជាជំនួសវិញ ។ ជានិច្ចកាល គាត់បានរិះរកទិសដៅដឹកនាំមួយ ក្នុងការគិតមមៃចុងក្រោយរបស់ ប៉ុល ពត គឺការធ្វើខស្សរាហូបនីយកម្មនៅឆ្នាំ១៩៧៨ ។ ក្នុងសុន្ទរកថា ដែលថ្លែងនៅ

ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៧៨ ដើម្បីរំឭកខួបកំណើតបក្ស ប៉ុល ពត បានកំណត់យ៉ាងច្បាស់លាស់នូវ«ទស្សនៈ» ជាមាគ៌ាធំៗរបស់គាត់ ដើម្បីប្រែក្លាយប្រទេសកម្ពុជា ទៅជាប្រទេសឧស្សាហកម្ម និងបដិវត្ត ។ អត្ថបទសុន្ទរកថានេះមានចំណងជើងថា «យើងបន្តជ្រោង ខ្ពស់ទង់ជ័យជម្នះរបស់បក្សកុម្មុយនិស្ត កម្ពុជាដ៏ភ្លឺជាញជ័យដោយម៉ឺងម៉ាត់ ដើម្បីការពារកម្ពុជាប្រជាធិបតេយ្យ បន្តធ្វើបដិវត្តសង្គមនិយម កសាងលទ្ធិសង្គមនិយម» ។

សុន្ទរកថានេះមានលក្ខណៈដែលលំបាកបំពេញ និងមិនសូវបំផុសទឹកចិត្តដូចចំណងជើងរបស់វាទេ ។ រវាងរឿងដទៃៗទៀត ប៉ុល ពត បានបង្អែបង្អង់ស្ដីពីភាពចាំបាច់ ដើម្បីធ្វើឲ្យប្រទេសកម្ពុជាទៅជារដ្ឋកុម្មុយនិស្តមួយដែលប្រកាន់នយោបាយឯករាជ្យម្ចាស់ការ ។ គាត់បានប្រកាសពីសេដ្ឋកិច្ចរបស់ប្រទេសដែលមានស្ថិរភាព និងរឹងមាំ ហើយវិនិច្ឆ័យដោយសេចក្ដីពេញចិត្តពីប្រព័ន្ធធារាសាស្ត្រថ្មី និងផលិតផលកសិកម្មរបស់សហករណ៍នានា ។ សេចក្ដីត្រូវការសំខាន់របស់ប្រជាជន គឺមានគ្រប់គ្រាន់ គាត់វាយតម្លៃថា ពេលវេលាបានមកដល់ហើយ ដើម្បីកសាងប្រទេសលើជោគជ័យទាំងនេះ និងរៀបចំខឿនឧស្សាហកម្មធុនស្រាលផ្សេងៗ ដែលប្រើប្រាស់ផលិតផលកសិកម្មរបស់ប្រទេស ។

ដោយគាត់ត្រូវរៀបចំរឿងនេះជាមុន ឌុចបានចាប់ផ្ដើមស៊ើបអង្កេតទៅលើក្រសួងឧស្សាហកម្ម និងកម្មាភិបាល... អ្នកមិនល្អចេញពីក្រសួងនេះ ។ ភាពបន្តគ្នានៃសកម្មភាពនេះ ត្រូវបានរៀបចំយ៉ាងល្អិតល្អន់ ៖ បើសិនជាការពិតពុំឆ្លើយតបទៅនឹងការចង់បានរបស់ ប៉ុល ពត អ្នកដែលទទួលខុសត្រូវលើ«ការពិត» នេះ នឹងត្រូវចោទប្រកាន់ថា ជាអ្នកធ្វើវិទ្ធ្វំសកម្ម ។ រឿងនេះគេធ្លាប់បានផ្ដើមធ្វើជាមួយ ហ៊ូ យន់ រួចមកហើយនៅពេលដែលគាត់ជំទាស់នឹងការជម្លៀសប្រជាជនចេញពីក្រុងនានា និងទម្រង់នៃជីវពលកម្មនៅតាមសហករណ៍នានា ។ ហើយរឿងនេះបានបន្តមកទៀតជាមួយនឹង កុយ ធួន ដែលគេចាត់ទុកជាអ្នកទទួលខុសត្រូវអំពីបរាជ័យផ្នែកសេដ្ឋកិច្ចនៅពេលដំបូងៗ ជាមួយនឹង រស់ ញឹម ដែលគេបន្ទោសពីការគ្មានសមត្ថភាពរបស់ភូមិភាគពាយ័ព្យ ក្នុងការធ្វើឲ្យបានសម្រេចតាមផែនការដែលតម្រូវដោយមជ្ឈិម ជាមួយនឹង សោ ភឹម ដែលត្រូវចោទប្រកាន់ពីបរាជ័យរបស់កម្ពុជាក្នុងជម្លោះព្រំដែនជាមួយវៀតណាម ។ ហើយឥឡូវនេះ វ៉ន វ៉េត ដែលទទួលខុសត្រូវផ្នែកឧស្សាហកម្មរបស់ប្រទេស ត្រូវគេកម្ចាត់ចោលនៅខែវិច្ឆិកា ពីរឿងមិនចេះជំរុញវិស័យនេះឲ្យលឿនទៅមុខ ស្របទៅតាមសេចក្ដីសង្ឃឹមមិនសមហេតុផលរបស់ ប៉ុល ពត ។

មេដឹកនាំចុងក្រោយក្នុងរដ្ឋាភិបាលដែលត្រូវចាប់ដាក់គុក និងសម្លាប់ចោលនៅមន្ទីរឃុំឃាំងទួលស្លែង សុទ្ធសឹងជាអ្នកធ្វើការនៅក្រសួងឧស្សាហកម្មស្ទើរតែទាំងអស់ ៖ គឺពួកប្រធានៗកន្លែងផលិតស្រា រោងចក្រធ្វើស៊ីម៉ង់ត៍ រោងចក្រផលិតបារី ។ នៅចុងខែវិច្ឆិកា វ៉ន វ៉េត ត្រូវគេចាប់ខ្លួន និងបញ្ជូនទៅមន្ទីរឃុំឃាំងទួលស្លែង ។

ទោះជាគាត់ធ្លាប់មានចិត្តស្មោះត្រង់ចំពោះ ប៉ុល ពត តាំងពីជំនាន់ដែល ប៉ុល ពត រៀបចំគាត់ឲ្យចូលបក្សក៏ដោយ ក៏វាមានសារសំខាន់តិចតួចណាស់ ។ វ៉េត ធ្លាប់ទទួលខុសត្រូវក្នុងការកសាងបក្សនៅក្រុងភ្នំពេញ ក្រោយ

ពេលដែល សាឡុត ស និងមេដឹកនាំបក្សភាគច្រើនផ្សេងទៀត ចាកចេញពីរាជធានី នៅដើមទសវត្សរ៍ឆ្នាំ ១៩៦០ ។ ជាវន្តវាន់លើកទឹកចិត្ត គាត់ត្រូវបានតែងតាំងជាលេខាបក្សភូមិភាគពិសេស ដែលនៅជុំវិញភ្នំពេញ ក្នុងរយៈពេលសង្គ្រាម ។ ក្រោយមក នៅពេលដែលទីក្រុងនេះត្រូវដាក់ឲ្យស្ថិតនៅក្រោមការត្រួតត្រាផ្ទាល់របស់ ប៉ុល ពត និងបក្ស វើត ត្រូវបានទទួលការទុកចិត្តឲ្យកាន់ក្រសួងខស្សរាហកម្ម ។

ក្នុងចម្លើយសារភាពរបស់គាត់ ដែលធ្វើដោយការបង្ខំ វ៉ន វើត គោងតែទទួលស្គាល់ថា គាត់ជាភ្នាក់ងារម្នាក់របស់ពួកវៀតណាម និងសេ.អ៊ី.អា. ដែលត្រូវបានជ្រើសរើសកាលពីដាងដប់ឆ្នាំមុន សម្រាប់ឲ្យបំផ្លាញការបដិវត្តន៍តែម្យ៉ាងប៉ុណ្ណោះ[៣៤] ។ ត្រង់ចំណុចនេះ គេក៏រកឃើញនូវភាពបន្តគ្នានៃសកម្មភាព ដែលគេបានរៀបចំយ៉ាងល្អិតល្អន់ៈ ក្នុងឯកសារទាំងឡាយនៅមន្ទីរឃុំឃាំងទួលស្លែងបង្ហាញឲ្យឃើញថា សេ.អ៊ី.អា. ជាអ្នកទទួលខុសត្រូវអំពីបរាជ័យផ្នែកសេដ្ឋកិច្ច ចំណែកភ្នាក់ងារវៀតណាម ជាមូលហេតុនៃបរាជ័យផ្នែកយោធា និងនយោបាយ ។ ម្យ៉ាងទៀត គេបានបង្ខំឲ្យ វ៉ន វើត សារភាពថា គាត់កោតសរសើរជាមួយនឹងគំនិតថោកទាបអំពីគំរូបដិវត្តរបស់ចិន ។

ក្នុងរឿងនេះវាមានការសង្ស័យមួយរបៀបចំអកបញ្ឈឺចិត្ត ក្នុងការបោសសម្អាតចុងក្រោយនេះ ដោយហេតុផលថា វ៉ន វើត ធ្លាប់ធ្វើជាមេកោយផ្ទាល់របស់ ឌុច ក្នុងរយៈពេលសង្គ្រាម នៅពេលដែល ឌុច រៀបចំបង្កើតផ្នែកសន្តិសុខក្នុងភូមិភាគពិសេស ។ ដូច្នេះ នៅដើមដំបូង វើត ជាបក្សសម្ព័ន្ធម្នាក់ក្នុងចំណោមបក្សសម្ព័ន្ធនៃប្រព័ន្ធសម្លាប់មនុស្ស ដែលឥឡូវនេះវ៉ាប់រងការស្លាប់ផ្ទាល់របស់គាត់ដែរ ។

ដូចពួកកម្មាភិបាលភូមិភាគបូព៌ា ដែលរត់ភៀសខ្លួនទៅប្រទេសវៀតណាម ក្រោយពេលដឹងច្បាស់ថា ពួកគេនឹងត្រូវជំរុញទៅរកការកម្ទេចចោល ពួកអ្នកធ្វើការនៅក្រសួងការបរទេសក៏រត់រកទីកន្លែងលាក់ខ្លួនដែរ ។ ប៉ុន្តែពួកគេពុំមែនស្ថិតនៅក្បែរព្រំដែនឯណា! ហើយគ្មានទាំងការគាំពារពីសំណាក់កងទ័ពវៀតណាម ដូចពួកបូព៌ាទៀតផង ។ ពួកគេបានត្រឹមតែរួបរួមគ្នានិងបំពេញការងារនៅភ្នំពេញរបៀបជា "ក្រុមកម្មការចាំឃ្លាំមើល" មួយដែលគ្មានអាវុធ ដើម្បីសងសឹក ប៉ុល ពត និងបដិវត្តន៍ ។ តាមប្រហែល ពួកគេបានដាក់កន្លែងពួនស្ទាក់ជាច្រើន ដើម្បីចាប់កម្មាភិបាលផ្សេងៗទៀត ដែលពួកគេសម្លាប់ចោលគ្មានសល់ ។ នៅពេលដែល អៀង សារី ប្រកាសខ្លាចក្រែងមានរដ្ឋប្រហារមួយនៅប្រទេសកម្ពុជា គាត់បាននិយាយ ដោយផ្នែកសំដៅទៅរកមនុស្សទាំងនោះ ដោយគ្មានសង្ស័យឡើយ ។

ប៉ុន្តែ ការគំរាមកំហែងពិតប្រាកដ គឺលេចចេញមកពីពួកកម្មាភិបាលភៀសខ្លួនទៅប្រទេសវៀតណាមឯណោះ ហើយដែលក្រុងហាណូយប្រមូលផ្តុំឡើងវិញដើម្បីរៀបចំធ្វើសង្គ្រាម[៣៥] ។ ថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨ មេដឹកនាំភូមិភាគបូព៌ាដែលរត់គេចខ្លួនជាច្រើន បានប្រកាសឲ្យដឹងជាសាធារណៈពីការបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ។ អ្នកដឹកនាំរណសិរ្សនេះរួមមាន ហេង សំរិន ដែលធ្លាប់បញ្ជាកងពលធំលេខ៤ នៃកងទ័ពរបស់ភូមិភាគបូព៌ា ជា ស៊ីម និង ហ៊ុន សែន ដែលដោះខ្លួនចេញពីគណៈកម្មាធិការបក្សមូលដ្ឋាន ។ ដោយបាន

ប្រកាស«រណសិរ្សថ្មី»របស់គេតាមវិទ្យុវៀតណាម ពួកគេបានថ្កោលទោសអ្វីៗទាំងអស់ដែលរបប ប៉ុល ពត បានប្រព្រឹត្តក្នុងរយៈពេលបីឆ្នាំ ដោយពាក្យសម្ដីធ្ងន់ៗ ខ្លាំងជាងសម្ដីពួកអ្នកភៀសខ្លួនខ្មែរទៅប្រទេសថៃទៅទៀត ។ បើទុកជាភាគច្រើនក្នុងចំណោមពួកគេ ធ្លាប់កាន់កាប់តំណែងទទួលខុសត្រូវផ្សេងៗក្នុងរបបនេះកាលពីប៉ុន្មានខែមុនក៏ដោយ ក៏ពួកគេបាននិយាយទម្លាក់កំហុសទៅលើ«បន ប៉ុល ពត, អៀង សារី»ថា «បានសម្លាប់រង្គាលប្រជាជនយ៉ាងសាហាវយង់ឃ្នង អមនុស្សធម៌ ជាងអំពើដែលប្រព្រឹត្តឡើងដោយពួកហ្វាស៊ីសអ៊ីត្លែរទៅទៀត» ហើយបានចាត់ទុកសហករណ៍នានាថា ជា«ជំរំប្រមូលផ្ដុំលាក់លៀម» ។

ដូចដែលគេអាចគិតស្មានជាមុន ពួកគេបានបញ្ជាក់បំភ្លឺពីការបោសសម្អាតភូមិភាគបូព៌ាថា ជាអំពើឧក្រិដ្ឋយ៉ាងធំមួយរបស់កម្ពុជាប្រជាធិបតេយ្យ ។ តាមពិត មានតែភូមិភាគបូព៌ាមួយប៉ុណ្ណោះ ដែលត្រូវគេលើកយកមកនិយាយដោយចេញឈ្មោះ ៖ នេះជាការចាប់ផ្ដើមនូវការប្រឹងប្រែងឃោសនាដ៏សំខាន់មួយ សំដៅពិពណ៌នាពីភូមិភាគបូព៌ាក្នុងឋានៈ ជាភូមិភាគមួយផ្សេងពីភូមិភាគដទៃៗទៀត ជាភូមិភាគដែលរងទុក្ខវេទនាខ្លោចផ្សាខ្លាំងជាងគេ ។ គេបានបង្ហាញការពោលអះអាងទាំងនេះថា ពួកកម្មាភិបាលនៅភូមិភាគបូព៌ា ពុំមានការទទួលខុសត្រូវណាមួយអំពីបទឧក្រិដ្ឋទាំងឡាយ ដែលមាន«លក្ខណៈដូចពួកហ្វាស៊ីសអ៊ីត្លែរ»នោះឡើយ ។

ជាមួយនឹងការប្រកាសលក្ខន្តិកៈរបស់«រណសិរ្ស»នេះ និងការចេញផ្សាយកម្មវិធីនយោបាយរបស់ខ្លួន សង្គ្រាមក៏ត្រូវបានប្រកាសជាផ្លូវការដែរ ។ ពួកវៀតណាមបានរៀបចំស្ថានភាពរួចជាស្រេច ក្នុងគោលបំណងអាចឲ្យខ្លួនអះអាងថា ការចូលលុកលុយប្រទេសកម្ពុជារបស់គេ ជា«ការបះបោរ»ពិតប្រាកដមួយរបស់ពួកកម្មុយនិស្តកម្ពុជាប្រឆាំងនឹងរបបនក្បត់ ដែលដឹកនាំដោយ ប៉ុល ពត ។ ខ្ញុំ(អ្នកនិពន្ធ) បានទៅប្រទេសកម្ពុជាប្រាំមួយថ្ងៃក្រោយមក គឺមុនពេលដែលសង្គ្រាមរវាងខ្វា និងក្រពើផ្ទុះឡើង ។

# ជំពូកទី៩
# ធម្មាប់ផ្សេងៗនៃសង្គ្រាម

ប្រទេសនីមួយៗ សឹងតែមានគូប្រជែងជាប្រពៃណីមួយជានិច្ច ជាទូទៅគឺរដ្ឋជិតខាងមួយ ដែលសម្រាប់ប្រើជាមធ្យោបាយរលាស់ចោលសេចក្តីភ័យខ្លាច និងបុរេនិច្ច័យរបស់ជាតិ ។ មួយសប្តាហ៍នៅប្រទេសក្រៅល្មមគ្រប់គ្រាន់ឲ្យអ្នកទេសចរ ដែលមិនសូវប៉ិនប្រសប់ដូចអ្នកសង្កេតការណ៍ អាចរកឃើញអ្នកណាមួយជាគូប្រជែង ឬជាសត្រូវនេះ តាមរយៈការនិយាយលេងសើចសប្បាយ និងការប្រាប់ពីលក្ខណៈផ្សេងៗ ដែលបញ្ចេញឲ្យដឹងដោយប្រជាពលរដ្ឋនៃប្រទេសនេះ ។ សេចក្តីភ័យខ្លាច និងបុរេនិច្ច័យទាំងនេះ អាចផ្តល់នូវគ្រោះថ្នាក់តែនៅពេលណាដែលវាត្រូវអុជអាលដោយរដ្ឋឬទ្រទ្រង់ដោយសុន្ទរកថា ដែលលាន់ឮរខ្ញាររបស់ពួកអ្នកប្រជាភិថុតិ ប៉ុណ្ណោះ ។

បញ្ហារវាងពួកកម្ពុជា និងពួកវៀតណាម គឺមានលក្ខណៈបែបនេះ ។ ពួកគេមិនបង្ហាញឲ្យឃើញការស្អប់ខ្ពើមនឹងគ្នា ហើយមិនដែលចំណាយពេលវេលាវាយប្រយុទ្ធគ្នាជាដរាបនោះទេ ។ ប៉ុន្តែ ពួកគេជាគូប្រជែងតាំងពីពីរសតវត្សរ៍មកហើយ ហើយវាមានការតូចចិត្ត និងការប្រជែងរវាងរដ្ឋទាំងពីរក្នុងសម័យកាលល្អនឹងគ្នា ។ ប្រជាជនរបស់កម្ពុជា និងវៀតណាម ចេះគោរព និងកោតក្រែងគ្នាទៅវិញទៅមកតាមរយៈរបៀបដោះស្រាយសាមញ្ញៗ ដែលរៀបចំយ៉ាងប្រសើរ ។ ក្នុងសម័យកាលដ៏ខ្មៅងងឹតបំផុត ពួកគេធន់មិនបាននឹងការប្រើអំពើហិង្សា និងការស្អប់ឈ្នានីសគ្នា ក្នុងទំនាក់ទំនងផ្សេងៗរបស់ពួកគេបានឡើយ ជាទូទៅតាមការផ្តើមគំនិតរបស់រដ្ឋាភិបាលរបស់ខ្លួនគេ ។

នៅឆ្នាំ១៩៧៧ ពួកមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ បានអុជអាលឲ្យផុសគំនិតប្រកាន់ពូជសាសន៍ ប្រឆាំងនឹងប្រជាជនវៀតណាម នៅពេលដែលពួកមេដឹកនាំខ្មែរក្រហមយល់ឃើញដោយគ្មានមូលហេតុត្រឹមត្រូវថា ពួកវៀតណាមប៉ុនប៉ងបញ្ចូលប្រទេសកម្ពុជាជាខបសម្ព័ន្ធ ។ ក្នុងការឃោសនារបស់ខ្មែរក្រហម ប្រទេសវៀតណាមមិនត្រឹមតែក្លាយទៅជាប្រទេសសង្គមនិយមជិតខាងមួយប៉ុណ្ណោះទេ ប៉ុន្តែជាសត្រូវ«ស្លូវពូជ» ដែលមិនអាចបោះបង់ចំណង់ជាប្រវត្តិសាស្ត្ររបស់ខ្លួន ដើម្បីដណ្តើមយកប្រទេសកម្ពុជាឡើយ[១] ។

ចំណែកខាងពួកវៀតណាម បានបន្ទោសពួកកម្ពុជាថា ប្រព្រឹត្តអំពើសាហាវយង់ឃ្នង[២] ដែលជាការចោទប្រកាន់តាំងពីមួយសតវត្សរ៍មុន ដោយព្រះចៅអធិរាជមួយអង្គក្នុងចំណោមព្រះចៅអធិរាជទាំងឡាយ របស់ប្រទេសវៀតណាម ហើយដែលនៅដក់ជាប់ក្នុងចំណោមបុរេនិច្ច័យគួរឲ្យភ័យព្រួយរបស់ប្រទេស ។ ប្រទេសទាំងពីរ ចង់បកស្រាយឲ្យឃើញច្បាស់ដោយការប្រកួតមួយ ដែលមានរាល់តែសតវត្សរ៍តាមរយៈសង្គ្រាមជំនាន់ថ្មីមួយទាំងស្រុង (និងដោយបង្កើតសង្គ្រាមមិនធ្លាប់មានពីមុនមួយ) រវាងរដ្ឋកុម្មុយនិស្តផ្សេងៗ ។

បើសិនមិនអាចបដិសេធបានថា បណ្ដាឆ្នាំនៃការប្រជែងគ្នាទាំងនេះដើរតួនាទីមួយ ក្នុងសង្គ្រាមឥណ្ឌូចិនលើកទីបីទេ ក៏ដម្លោះនេះ គ្មានការទាក់ទងនឹង «អនាគតជាក់ស្ដែង» ដែលរដ្ឋាភិបាលទាំងពីរយកទៅធ្វើសំអាងដែរ ។ ប្រទេសកម្ពុជានិងថៃ ដែលជាគូប្រជែងប្រវត្តិសាស្ត្រ តាំងពីរាប់រយឆ្នាំមកហើយ ដូចវៀតណាមដែរនោះ ពុំបន្តឲ្យមានអរិភាពនឹងគ្នានៅឆ្នាំ១៩៧៧ទេ ។ ក្រុងភ្នំពេញ ក៏ពុំចោទប្រកាន់ក្រុងបាងកកថា ចង់ដណ្ដើមយកប្រទេសកម្ពុជាដែរ ទោះបីជានៅពេលនោះពួកកម្ពុជាជឿថា ពួកថៃបានតាំងនៅលើទឹកដីខ្មែរជាច្រើនចំណុចតាមព្រំដែនរួមរបស់គេក៏ដោយ ។

នេះជាលក្ខណៈដោយឡែកនៃទំនាក់ទំនងរវាងខ្មែរ-វៀតណាម និងជាពិសេសបំផុត រវាងរដ្ឋកុម្មុយនិស្តជិតនាន់ថ្មីទាំងពីរ ដែលនាំទៅដល់សង្គ្រាមឥណ្ឌូចិនលើកទីបី ។ នៅឆ្នាំ១៩៧៧ ប្រទេសវៀតណាមកុម្មុយនិស្តបានប្ដេជ្ញាដើរទៅមុខយ៉ាងដាច់ខាត និងតម្រូវឲ្យឆ្លើយតបនឹងសំណួរថា «តើលក្ខណៈនៃទំនាក់ទំនងផ្សេងៗរវាងប្រទេសកម្ពុជា និងវៀតណាម នឹងទៅជាយ៉ាងណានៅពេលនេះ ដែលប្រទេសទាំងពីរសុទ្ធតែកាន់លទ្ធិកុម្មុយនិស្តដូចគ្នា?» ។

ប្រទេសវៀតណាម មានទម្លាប់សម្ដែងតួនាទីកណ្ដាលមួយ ក្នុងឥណ្ឌូចិនសម័យនេះ ។ ការមានជោគជ័យរបស់ខ្លួន បានធ្វើឲ្យប្រទសកម្ពុជាមានទំនងដូចជាត្រូវវាយនឹងរំពាត់ខ្សែតីមួយខ្វាច់ ។ នៅឆ្នាំ១៩៧៧ ការខ្លាចបារម្ភរបស់ពួកខ្មែរក្រហមពុំមែនខ្វះមូលដ្ឋានទាំងស្រុងទេ ។ ដោយពិត ពួកកុម្មុយនិស្តក្រុងហាណូយ បានវិនិច្ឆ័យប្រទេសកម្ពុជាថាជារដ្ឋក្រោមបង្គាប់មួយ ដែលត្រូវតែទទួលស្គាល់អំណាចដែលមានមេត្តា ថែមទាំងការត្រួតត្រាដោយមិនចំពោះរបស់ប្រទេសវៀតណាម ។ គឺឋានៈនេះ ហើយដែលជ័យជម្នះរបស់ខ្មែរក្រហមនៅឆ្នាំ១៩៧៥ជាព្រឹត្តិការណ៍រីករាយមួយផង និងជាគ្រោះកាចមួយផងសម្រាប់ក្រុងហាណូយ ។

បន្ទាប់ពីជ័យជម្នះរបស់ពួកកុម្មុយនិស្តនៅក្រុងភ្នំពេញក្នុងខែមករា ឆ្នាំ១៩៧៦ និងក្រុងព្រៃនគរនៅខែមេសា ឆ្នាំ១៩៧៥ និងទីក្រុងវៀងច័ន្ទ ប្រទេសឡាវនៅខែធ្នូ ប្រទេសទាំងបីនៅអតីតឥណ្ឌូចិន បារាំងបានប្រកាន់យករបបកុម្មុយនិស្តទាំងអស់ ។ ដូច្នេះវាអាចពិតប្រាកដថា ប្រទេសវៀតណាមជាអ្នកចាត់ចែងដឹកនាំប្លុកកុម្មុយ និស្តដ៏ខ្លាំងមួយ ដែលនឹងជួយសម្រួលឲ្យក្រុងហាណូយ មានមុខតំណែងខ្ពស់ជាងគេមួយនៅលើឆាកនយោបាយរបស់អាស៊ី ។ ប៉ុន្តែ ពួកខ្មែរក្រហមមិនទុកចិត្តការឲ្យយោបល់ទាំងអស់របស់ប្រទេសវៀតណាមជាគុណប្រយោជន៍ដល់ការបង្កើតសហពន្ធ័បែបនោះទេ ហើយបានបដិសេធសន្ធិសញ្ញាមិត្តភាព ឬទំនាក់ទំនងពិសេសទាំងអស់ជាមួយក្រុងហាណូយ ។ ម្យ៉ាងទៀត ពួកខ្មែរក្រហមបានខំប្រឹងធ្វើឲ្យគេជឿថា ប្រទេសចិនជាសម្ព័ន្ធមិត្រដ៏មានអានុភាពធំបំផុតរបស់គេ ហើយនៅឆ្នាំ១៩៧៧ ក្រុងប៉េកាំង បានក្លាយទៅជាសត្រូវចម្បងរបស់ប្រទេសវៀតណាម ។ ស្ថានការណ៍ប្រសើរបំផុតមួយ ក្នុងចំណោមស្ថានការណ៍ប្រសើរបំផុតជាច្រើន ដែលក្រុងហាណូយធ្លាប់ស្គាល់ បានរលំដួល ហើយប្រែទៅរកមហន្តរាយវិញ ។

វាច្បាស់ណាស់ថា គឺប្រទេសកម្ពុជាជាអ្នកចាប់ផ្ដើមបង្កជម្លោះព្រំដែនជាមួយប្រទេសវៀតណាម គេមិនសូវសម្គាល់ឃើញ ហេតុអ្វីបានជាក្រុងហាណូយបកស្រាយការបង្កហេតុនេះថា ជាការអញ្ជើញឲ្យចូលលុកលុយ និងកាន់កាប់អ្នកជិតខាងខ្លួនទៅវិញ ។

គឺពុំមែនអំពើសាហាវយង់ឃ្នង ដែលប្រព្រឹត្តដោយពួកខ្មែរក្រហមទេ ដែលញុះញង់ឲ្យពួកវៀតណាមប្រឆាំងនឹងប្រទេសកម្ពុជានោះ ។ សម្រាប់ប្រទេសវៀតណាម នេះជាបញ្ហាមួយទាក់ទងនឹងការត្រួតត្រា អំណាចដែនដី និងការដោះស្រាយឲ្យហើយស្រេចអំពី "បញ្ហា" កម្ពុជា -បញ្ហាដែលគេមិនអាចបោះទ័ពដោយបំពាននៅសម័យកាលកុម្មុយនិស្ត ក៏ដូចនៅសម័យអាណានិគម ឬនៅជំនាន់អង្គរ ។ ប៉ុន្តែ នេះសុទ្ធតែជាបញ្ហាដែលគេអាចដោះស្រាយដោយមិនចាំបាច់ធ្វើសង្គ្រាម និងការកាន់កាប់ប្រទេសទេ ។ នេះជាការពឹងផ្អែកលើសង្គ្រាមសរុបមួយរបស់ពួកវៀតណាម ដែលធ្វើឲ្យកើតមានការប្រៀបធៀបដៀសមិនផុត ជាមួយនឹងបុព្វការីរបស់ពួកគេនៅទន្លេក្រហម (សុងកៃ) ។ ពួកកុម្មុយនិស្តនៅហាណូយបានប្រែក្លាយអ្វីៗដែលស្ទើរតែរលាយបាត់ទៅហើយឲ្យទៅជាឱកាសជាប្រវត្តិសាស្ត្រមួយ ដើម្បីបង្ហើយនូវអ្វីដែលបណ្ដាបុព្វាធិការីរបស់ពួកគេធ្លាប់បានប៉ុនប៉ងកាលពីច្រើនសតវត្សរ៍មុន គឺត្រួតត្រាអាងទន្លេមេគង្គ ។

អនុស្សាវរីយ៍នៃការច្បាំងដណ្ដើមដែនដីសណ្ដទន្លេមេគង្គ ដោយពួកវៀតណាមនៃទន្លេក្រហម គឺជាចំណែកមួយនៃ "បណ្ដាការភ័យខ្លាចជាប្រវត្តិសាស្ត្រ" របស់ពួកខ្មែរ ។ វានឹងទៅជាមួយគ្នាចំពោះគំនិតដែលទទួលដំណែលមិនសមទំនងមួយ ដែលឲ្យឈ្មោះឥណ្ឌូចិនហើយ ដែលគ្រប់គ្រងដោយប្រទេសវៀតណាម ។ ហេតុការណ៍សំខាន់ គឺពុំមានឧទាហរណ៍បញ្ច្រាសគ្នា ក្នុងការភ្ជាប់ទឹកដីរបស់វៀតណាម ដោយប្រទេសកម្ពុជានៅជំនាន់នោះទេ ។ ទោះបីជា មានការអំពាវនាវរបស់ លន់ នល់ ឲ្យដណ្ដើម "កម្ពុជាក្រោម" មកវិញក៏ដោយ ក៏សុន្ទរកថាផ្សេងៗរបស់ខ្មែរមិនបានកត់សម្គាល់ពីរឿងនេះដែរ ។ ការស្អប់ជនបរទេសរបស់ប្រជាជនកម្ពុជាដែលគេដឹងឮគ្រប់គ្នាភាពឆាយចាប់អារម្មណ៍នឹងបញ្ហាព្រំដែនរបស់មេដឹកនាំពួកគេ -ចាប់ពីសម្ដេច ព្រះនរោត្តម សីហនុ រហូតដល់ ប៉ុល ពត- បាបចាប់ឫសយ៉ាងជ្រៅក្នុងសេចក្ដីភ័យខ្លាចអំពីគោលបំណងផ្សេងៗរបស់វៀតណាម និងក្នុងភាពទៃទពីគ្នាផ្នែកវប្បធម៌រវាងប្រជាជាតិទាំងពីរថែមទៀត ។

ព្រំដែនដែលខ័ណ្ឌចែកប្រទេសកម្ពុជាពីប្រទេសវៀតណាម គឺជាខ្សែបន្ទាត់បែងចែកដ៏ធំមួយ ក្នុងចំណោមខ្សែបន្ទាត់បែងចែកធំៗ ខាងផ្នែកវប្បធម៌នៅអាស៊ី ។ ខ្សែបន្ទាត់នេះកំណត់ព្រំដែនរវាងអារ្យធម៌ធំៗពីររបស់ទ្វីប គឺអារ្យធម៌របស់ចិន និងរបស់ឥណ្ឌា ។ ម្ខាងគឺប្រទេសវៀតណាម ជាពាក្យមានន័យថា ភាគខាងត្បូងបំផុតនៃដែនដីមួយ ដែលកាលពីដើមត្រូវគ្រប់គ្រងដោយប្រទេសចិន ។ ម្ខាងទៀត គឺប្រទេសកម្ពុជា ក្នុងចំណោមប្រទេសជាច្រើនដែលត្រូវធ្វើឲ្យជ្រួតជ្រាបនូវវប្បធម៌របស់ឥណ្ឌា ហើយដែលបានសម្រេចផលប្រសើរជាងគេ ។

ដើម្បីធ្វើការប្រៀបធៀបមួយជាមួយទ្វីបអឺរ៉ុប ពួកកម្ពុជានឹងនាំឲ្យស្គាល់វប្បធម៌បែបឡាតាំងផ្នែកសិល្បៈ ហើយពួកវៀតណាមនឹងបង្ហាញឲ្យឃើញចរិតប៊ិនប្រសប់នៅភាគខាងជើង ។ ព្រំដែនរបស់គេ ក៏ដូចព្រំដែនដែលចែកប្រទេសបារាំងនិយមវប្បធម៌ឡាតាំងពីប្រទេសអាល្លឺម៉ង់ជាប់នៅខាងជើងដែរ គឺជាសមរភូមិដែលមានការប្រយុទ្ធគ្នា ខ្លាំងជាងទីណាៗទាំងអស់ ខុសគ្នាពីព្រំដែនទ្វីបអាស៊ី ។ គឺពុំមែនពួកអឺរ៉ុប ទាំងក៏ពុំមែនពួកអាមេរិកាំងដែរ ដែលបាននាំមុខក្នុងការធ្វើសង្គ្រាមដំបូងៗ ដើម្បីត្រួតត្រាអាងទន្លេមេគង្គនោះ ។

ភាពទីទៃពីគ្នាផ្នែកវប្បធម៌ រវាងប្រទេសកម្ពុជា និងវៀតណាម មានលក្ខណៈជាក់ច្បាស់ណាស់ ។ លក្ខណៈទាំងនោះគឺ តម្លៃ គោលបំណង ប្រពៃណី និងសន្តានចិត្តខុសគ្នា ។ ប្រជាជនទាំងពីរនិយាយភាសាដោយឡែកពីគ្នា មិនដូចខ្មែរ និងឡាវ ឬថៃ ដែលនិយាយអម្បូរភាសាដូចគ្នាទេ ។ ហើយក្នុងការស្លៀកពាក់ក៏ខុសគ្នាដែរ ។ តាមប្រពៃណីប្រជាជនខ្មែរ ស្លៀកសារុង-ប្រុសក៏ដូចស្ត្រី ។ ចំណែកប្រុសនិងស្ត្រីវៀតណាម ស្លៀកខោជើងវែងរលុង ។ ពួកខ្មែរបរិភោគអាហារដោយស្លាបព្រាមួយ ឬជាមួយដៃរបស់ពួកគេ, ពួកវៀតណាម បរិភោគអាហារជាមួយចង្កឹះ ។ ប្រជាជនកម្ពុជាសង់ផ្ទះខ្ពស់ផុតពីដី ចំណែកពួកវៀតណាមសង់ផ្ទាល់នឹងដី ។ ក្នុងការបង្កើតអ្វីដែលទាក់ទងនឹងសិល្បៈរបស់គេ ពួកខ្មែរបានប្រើប្រាស់គំនូរដែលមានរូបអង់អាច ពណ៌ភ្លឺថ្លា ពួកវៀតណាមចូលចិត្តប្រើពណ៌ស្រទំជាង ហើយគំនូរច្រើនបង្កប់ទៅដោយអាថ៌កំបាំង ។

គ្មានអ្វីបង្ហាញឲ្យឃើញពីភាពមិនដូចគ្នានេះ ឲ្យបានប្រសើរជាងគំរូខាងផ្នែករបាំឡើយ ។ វប្បធម៌ខ្មែរ គឺជាវប្បធម៌មួយទាក់ទងនឹងរបាំ ។ របាំជួយលើកទឹកចិត្តដល់ដំណើររស់នៅរបស់អ្នកស្រុក របៀបធ្វើបដិសណ្ឋារកិច្ចផ្សេងៗ របស់ពួកអ្នករស់នៅទីក្រុង និងវប្បធម៌បុរាណតាមរយៈក្រុមរបាំព្រះរាជទ្រព្យ ។ ប្រជាជនខ្មែររាំជាជួរដោយប្រើប្រាស់ដៃ និងប្រអប់ដៃ ដូចគ្នានឹងជើងដែរ ។ អ្នករាំ ញាក់ចង្កេះបន្តិចៗ ដោយផ្អៀងក្បាលមកខាងស្តាំ ទឹកមុខញញឹមតិចៗ ។ របៀបសម្តែងឲ្យដឹងពីគំនិត ឬមនោសញ្ចេតនាទាំងអស់ គឺស្ថិតនៅត្រង់ប្រអប់ដៃ ។ ពួកគេរាំដើម្បីកម្សាន្ត និងលំហែកាយ ដើម្បីទាក់ទងស្នេហាគ្នា ឬឲ្យគេសរសើរ ។ ដូចរូបចម្លាក់ដែរ របាំខ្មែរមានលក្ខណៈនាំឲ្យមានសម្រើបតណ្ហា ប៉ុន្តែពុំមែនចំអេសចំអាសទេ ។ សិល្បៈរបស់ប្រជាជនកម្ពុជា គឺស្ថិតក្នុងរបាំរបស់គាត់ដែលពួកគេប្រើប្រាស់ដូចគ្នានៅសម័យមួយ ដើម្បីសាសងជាមួយព្រះអាទិទេពនានា ។

មកពីប្រទេសឥណ្ឌាកាលពីជាងមួយពាន់ឆ្នាំមុន របាំបានស្គាល់នូវភាពកំពូលរបស់ខ្លួននៅសម័យអង្គរ ។ របាំបុរាណនៅជំនាន់នោះ គឺក្រុមល្ខោនព្រះរាជទ្រព្យខ្មែរ ដែលសម្តែងរឿងទេវកថាល្បីៗ ជាពិសេស រឿងរាមាយណៈ ។ មានតែស្ត្រីប៉ុណ្ណោះដែលរាំរបាំ ដោយសម្តែងជាតួអង្គព្រះរាម ក៏ដូចនាងសីតា ជាមហេសីរបស់ព្រះអង្គ ជាតួយក្សក្រុងរាពណ៍ និងស្តេចស្វាហនុមានផង ។ នាងៗរាំដើម្បីបង្កើតឡើងវិញ នូវរឿងនិទានអំពីចម្បាំងរបស់អាទិទេពមួយអង្គនៅលើផែនដី ដើម្បីបញ្ជូនទៅកាន់ឋានសួគ៌ និងនាំមកនូវពរសព្វសាធុការ សម្រាប់ព្រះមហាក្សត្រ និងជីវិតជាអាទិទេពរបស់ព្រះអង្គ ។ នៅពេលដែលក្រុមល្ខោនព្រះរាជទ្រព្យរាំ គេនឹកគិតថា ទីបំផុត

ភាពសុខដុមច្បាស់ជាស្ថិតមាននៅមួយរយៈ រវាងព្រះអាទិទេពទាំងឡាយ និងមនុស្សជាតិមិនខាន ។

ពួកស្ត្រីរបាំសុទ្ធតែត្រូវចាត់ទុកដូចជាអប្សរា ឬទេវតា ជាអ្នកនាំសារដែលបញ្ជូនថ្វាយទៅព្រះអាទិទេព ។ ពួកនាងបញ្ចេញកាយវិការតាមរយៈប្រអប់ដៃ កដៃ និងដៃដ៏ល្អឆើត ដែលពត់ម្រាម និងដើមដៃទៅក្រោយហាក់បីដូចជាពួកនាងគ្មានឆ្អឹងអ៊ីចឹង ។ ដោយបង្កើតផ្នែកមួយដាច់ដោយឡែកពីក្រុមស្ត្រី នៅក្នុងបន្ទប់ស្តេច នាងៗត្រូវបានទំនុកបម្រុង ហើយមានតែទេវរាជា (ស្តេចជាអាទិទេព) មួយអង្គប៉ុណ្ណោះ អាចដាក់ដៃលើទេវតាទាំងនេះបាន ។ យ៉ាងហោចសព្វថ្ងៃនេះ អប្សរា គឺជានិមិត្តរូបនៃប្រទេសកម្ពុជាដែរ បន្ទាប់ពីប្រាសាទអង្គរវត្ត ។

ទេវតាទាំងនេះគ្រងព្រះពស្ត្រធ្វើពីសូត្រភ្លឺផ្លេកៗ និងគ្រឿងអលង្ការផ្សេងៗ ពាក់ក្បាំងល្អប្រណីត ពាក់កងដៃ ខ្សែដៃ និងអ្វីៗដែលមានរាងស្រដៀងកងដៃ ពាក់នឹងភ្នែកគោរ ដែលបានក្លាយទៅជារឿងព្រេង នៅហួសឆ្ងាយពីព្រំដែនប្រទេសកម្ពុជាទៅទៀត ។ នៅពេលដែលប្រទេសសៀមចូលធ្វើការលុកលុយដំបូងៗ របស់ខ្លួននៅក្នុងប្រទេសនេះ សៀមមិនភ្លេចបញ្ចូលក្រុមល្ខោនព្រះរាជទ្រព្យនេះទៅក្នុងអច្ឆិនទ្រព្យ (ទ្រព្យដែលប្រមូលបានពីសត្រូវ) របស់ខ្លួនឡើយ ។ កងទ័ពសៀមដែលឈ្នះ បាននាំយកស្ត្រីរបាំខ្មែរទៅព្រះរាជវាំងសៀម ជាទីដែលពួកនាងបានរួមបង្កើតជាក្រុមរបាំមួយទៀតរបស់សៀម ។

ការធ្លាក់អាប់ឱនរបស់ក្រុងអង្គរ បានបណ្តាលឲ្យមានការធ្លាក់ចុះនៃក្រុមរបាំព្រះរាជទ្រព្យខ្មែរ នៅក្នុងប្រទេសផ្ទាល់របស់ខ្លួន ហើយរបាំដែលនៅគង់វង្សមួយផ្នែកធំ ក៏ដោយសារការការពាររបស់ព្រះរាជវាំងសៀមដែរ ។ នៅពេលដែលពួកអាណានិគមបារាំង ប្រឹងប្រែងធ្វើឲ្យរបាំព្រះរាជទ្រព្យខ្មែរមានជីវិតឡើងវិញ ពួកបារាំងបានបង្គាប់ឲ្យយកក្រុមស្ត្រីរបាំព្រះរាជទ្រព្យរបស់សៀមមកបង្ហាត់ ។ មានតែរបាំប្រជាប្រិយប៉ុណ្ណោះ ដែលបន្តស្ថិតនៅក្នុងសភាពរំដើបរំជួលផ្សេងៗ ដែលរីករាលដាលនៅប្រទេសកម្ពុជា ។ របាំបានក្លាយទៅជាចំណែកទាំងមូលមួយនៃជីវភាពរស់នៅរបស់អ្នកភូមិខ្មែរ នៅពេលដែលរដ្ឋបាលកណ្តាលរបស់ព្រះរាជា បានទម្លាប់ខ្លួននៅដាច់ឆ្ងាយពីប្រជាជន ហើយដែលការឧបត្ថម្ភទាក់ទងនឹងសិល្បៈសម្រាប់ស្តេចបានត្រូវបញ្ឈប់ ។ របាំប្រពៃណីខ្មែរបានផុសគំនិតធ្វើតាមប្រទេសឡាវជិតខាងដែលតាមរឿងព្រេងថា ជាអ្នកបង្រៀនឲ្យចេះ ដោយដូរនឹងពួកកម្ពុជានូវរបាំមួយ ដែលពួកគេហៅរាំឡាវ គឺរបាំរបស់ឡាវ ។

ដូច្នេះជនជាតិខ្មែរ ឡាវ និងសៀមមានសិល្បៈខាងរបាំដូចគ្នា ឬលួចចម្លងពីគ្នាទៅវិញទៅមក ។ ក៏ប៉ុន្តែភាគច្រើននៃប្រជាជនកម្ពុជា និងប្រជាជនវៀតណាមមិនចេះរាំទេ ។ អ្នកខ្លះគិតថា ពួកវៀតណាមមិនអាចយល់ឬស្គាល់ពីរបាំឡើយ ព្រោះពួកគេសុទ្ធតែមិនអាច "កម្រើកដៃជើងរាំ" ដោយចិត្តឯងតាំងពីកំណើត ហើយលក្ខណៈរូបរាងរបស់គេមានសភាពរឹងឆ្អឹត និងសោះកក្រោះខ្លាំងពេក ដែលមិនអនុញ្ញាតឲ្យគេរាំបានទេ ។ នៅពេលដែលពួកវៀតណាមប្រកាន់អាកប្បកិរិយារបៀបនេះ ធ្វើឲ្យពួកកម្ពុជានឹកគិតទៅដល់ពួកអេស្ប៉ាញ៉ុល ដែលរៀននិយាយភាសាអង់គ្លេសដែរ ។

នោះឯង ជាបណ្តាទិដ្ឋភាពជាក់ស្តែងនៃភាពខុសគ្នាដ៏ជ្រាលជ្រៅផ្នែកវប្បធម៌ ដែលមានឫសគល់តាំងពីការចាក់ឫសនៃអារ្យធម៌ពីរ- ដែលមានប្រភពមកពីទីផ្សេងពីគ្នា គឺប្រទេសចិន និងឥណ្ឌា ។ នៅពេលដែលប្រជាជនខ្មែរចូលទៅតាំងនៅយ៉ាងច្រើនក្នុងតំបន់ទន្លេមេគង្គ ហើយឡើងតាមទឹកបន្តិចម្តងៗទៅភាគពាយ័ព្យប្រទេសកម្ពុជា ហើយតាំងរាជធានីរបស់គេនៅអង្គរ ពួកវៀតណាម បានរៀបចំបង្កើតវប្បធម៌របស់គេ ក្នុងដែនដីសណ្តទន្លេក្រហម ត្រង់ព្រំដែនភាគខាងត្បូងប្រទេសចិន ។ វប្បធម៌ទន្លេក្រហមរបស់ពួកវៀតណាម មានសភាពផ្ទុយគ្នាស្រឡះពីវប្បធម៌ ទន្លេមេគង្គរបស់ពួកខ្មែរ ។

ដូចកម្ពុជាដែរ ពួកវៀតណាមទាមទារថា អារ្យធម៌របស់ខ្លួនមានអាយុមួយពាន់ឆ្នាំហើយ ។ បើសិនជាវប្បធម៌របស់វៀតណាម មានឫសគល់ពិតប្រាកដនៅសតវត្សរ៍ទីពីរមុនគ្រិស្តសករាជមែន គឺប្រទេសវៀតណាមមានប្រវត្តិសាស្ត្រខុសគ្នាយ៉ាងខ្លាំងពីប្រវត្តិសាស្ត្ររបស់ពួកខ្មែរហើយ[៣] ។ ពួកវៀតណាម បានរងទទួលការគ្រប់គ្រងដោយផ្ទាល់ពីប្រទេសចិនដ៏ខ្លាំងនៅក្បែរខាង ក្នុងរយៈពេលជាងមួយពាន់ឆ្នាំ ។ អ្វីដែលញែកពួកវៀតណាមឲ្យឃើញខុសពីប្រជាជនដទៃៗទៀត ដែលនៅជិតអាណាចក្រកណ្តាល ដែលឥឡូវនេះគេលែងនឹកនាទៅហើយ គឺការប្តេជ្ញាចិត្តបន្តអត្តិភាពរបស់គេបន្ទាប់ពីការត្រួតត្រារបស់ចិននេះ ។

ក្នុងរយៈពេលមួយពាន់ឆ្នាំ ដែលប្រទេសវៀតណាមធ្លាក់ខ្លួនទៅជាអាណានិគមមួយរបស់ចិន ប្រជាជនវៀតណាមបានត្រូវបង្ខំឲ្យក្លាយទៅជាជនជាតិចិន ក៏ដូចជាអាចទៅជា "ពួកអានារ្យជន" បរទេសដែរ ។ ប្រទេសវៀតណាមត្រូវបានគ្រប់គ្រងរបៀបជារដ្ឋបែបខុងជឺនិយមមួយ ប្រកបដោយរដ្ឋអំណាចកណ្តាលមួយ ដែលគេបង្កើតឡើងអមស្តេច ឬអធិរាជមួយអង្គ ។ ពួកវៀតណាម មានក្រុមជំនុំមន្ត្រីផ្ទាល់របស់គេ ដែលកំពុងផ្តល់ឲ្យប្រទេសជាតិនូវមន្ត្រីរាជការមានចំណេះដឹងយ៉ាងច្រើន ។ ភាសាចិន គឺជាភាសាផ្លូវការ និងជាភាសាអ្នកប្រាជ្ញ ។ ជនជាតិ វៀតណាមទាំងអស់ ដែលលើកទឹកចិត្តដោយចំណង់ហួសកម្រិត ត្រូវតែយកឈ្នះខាងភាសាអក្សរ និងចិត្តគំនិតជាចិន ។ ក្របខ័ណ្ឌនៃវប្បធម៌របស់មន្ត្រីក្នុងស្រុកមានលក្ខណៈជាចិន ៖ តាំងពីសម្លៀកបំពាក់រហូតដល់ចង្កឹះស៊ីបាយ និងសីលធម៌រស់នៅ ដែលសុទ្ធតែដកស្រង់ពីលទ្ធិខុងជឺនិយមទាំងអស់ ។

នៅពេលដែលជនជាតិខ្មែរបង្កើតអារ្យធម៌អង្គរ ដោយយកគំនិតយ៉ាងច្រើនតាមអារ្យធម៌ឥណ្ឌា វប្បធម៌របស់វៀតណាម បានត្រូវរាំងខ្ទប់ក្រោមសង្កត់មួយរបស់ចិន ដែលសម្បូរបែបយ៉ាងខ្លាំង ហើយអាចនៅគង់វង្សតែនៅតាមភូមិនានាប៉ុណ្ណោះ ។ នៅតាមភូមិទាំងនោះ គេនិយាយភាសាវៀតណាម ហើយប្រធានៗភូមិបានចៀសវាងមិនទៅក្បែរទេ ។ ភូមិទាំងឡាយរបស់វៀតណាម បានក្លាយទៅជាកន្លែងរស់នៅតូចៗ ដែលឯកោដោយខ្លួនឯង ហើយបិទមិនឲ្យវប្បធម៌របស់ស្តេចចិន ដែលគ្រប់គ្រងប្រទេសចូលចុះឡើយ ។

ការប្រដែងយកស្មើ និងការបដិសេធដំណាលគ្នារបស់ប្រទេសចិននេះនៅតែមានដដែល ក្នុងសម័យកាលសព្វថ្ងៃនេះ ។ ពួកវៀតណាមនៅតែសរសើរវប្បធម៌របស់ចិនមួយផ្នែកធំនៅឡើយ ។ ប៉ុន្តែ ពួកគេគោងតែបន្ត

បះបោរប្រឆាំង ដើម្បីឲ្យរួចផុតពីការត្រួតត្រាក្នុងឋានៈជាប្រជាជន និងប្រជាជាតិមួយ ។ ក្នុងការស្វែងរកអត្តសញ្ញាណរបស់ខ្លួន នេះពួកវៀតណាមបានក្លាយទៅជា "កូនសិស្ស" ប្រសើរជាងគេរបស់ប្រទេសចិនជាម៉ែ-ទាហាន ឆ្នើមខាងការប្រយុទ្ធ ដូចពួកអ្នកត្រួតត្រារបស់គេដែរ ជាមនុស្សដែលមានជំនឿប្រកបដោយការប្រកាន់ស្អិតចំពោះភាពប្រសើរលើសគេ នៃអារ្យធម៌របស់ខ្លួន និងភាពចាំបាច់ដើម្បីរក្សាឯករាជ្យ ។

ដូច្នេះ ក្នុងពេលដែលវប្បធម៌របស់ខ្មែរឡើងដល់ភាពកំពូលរបស់ខ្លួន ពួកវៀតណាមទើបនឹងរើបម្រះចេញពីនឹមត្រួតត្រារបស់ចិននាសតវត្សរ៍ទី១១ប៉ុណ្ណោះ ។ ប៉ុន្តែទាំងពួកចិន ទាំងពួកម៉ុងហ្គោលជាអ្នកស្នងបន្តមិនលះបង់"អាណានិគមខាងត្បូង"របស់គេដោយស្រួលៗឡើយ ។ នៅសតវត្សរ៍ទី១៣ ពួកវៀតណាមបានតស៊ូប្រឆាំងនឹងការប៉ុនប៉ងមួយរបស់បណ្ដា មេដឹកនាំថ្មីជាជាតិម៉ុងហ្គោល ដែលចង់ច្បាំងដណ្ដើមយកប្រទេសវៀតណាមដាក់ជាចំណុះឡើងវិញ ហើយនៅសតវត្សរ៍ទី១៥ ពួកចិនបានត្រួតត្រាប្រទេសវៀតណាមម្ដងទៀត ក្នុងរយៈពេលមួយយ៉ាងខ្លី ។ ប៉ុន្តែនៅឆ្នាំ១៤២៨ ពួកវៀតណាមបានក្លាយទៅជាម្ចាស់លើចំណែកដែនដីសណ្ដទន្លេក្រហមរបស់គេជាស្ថាពរ ។

ពួកវៀតណាម បានផ្ដើមធ្វើការវាតទឹកដីរបស់គេមកទិសខាងត្បូង តាំងពីពេលនោះមកម្ល៉េះ ដោយបង្ហាញឲ្យឃើញចំណុចខ្លះៗ ដែលពួកគេរៀនចេះតាមមេរៀនរបស់ពួកចិន ដែលជាអ្នកច្បាំងដណ្ដើមទឹកដីដ៏ឆ្នើមផង ។ ពួកវៀតណាមដឹងខ្លួនថា រស់នៅចង្អៀតចង្អល់ក្នុងដែនដីសណ្ដទន្លេក្រហម ជាជ្រលងសម្បូរដីជាតិដ៏ធំទូលាយ ដែលបែរមុខទៅឈូងសមុទ្រតុងកឹង និងព័ទ្ធជុំវិញដោយជួរភ្នំនៅភាគខាងជើង ភាគខាងលិច និងភាគខាងត្បូង ដែលស្ទើរតែបិទជិតទាំងស្រុង ។ បណ្ដាកុលសម្ព័ន្ធភ្នំបានរស់នៅលើខ្ពង់រាបសម្បូរព្រៃ និងងាយរងគ្រោះថ្នាក់ទាំងនេះ ប៉ុន្តែសម្រាប់ដីដាំដំណាំស្រូវដែលត្រូវការទឹក ប្រជាជនវៀតណាមត្រូវការវាលទំនាបដីសណ្ដវិញ ។

ពុំមានផ្លូវចេញរហូតដល់ភាគខាងត្បូង ដែលភ្នំនាំនាបានដែនដីសណ្ដទន្លេមេគង្គដ៏មានដីជាតិ និងធំល្វឹងល្វើយវិញ ។ ពួកវៀតណាមចង់បានទឹកដីនេះ ដើម្បីធ្វើឲ្យសម្រេចនូវការវាតទីរបស់គេបានជោគជ័យ និងការពារវប្បធម៌របស់គេក្នុងពេលជាមួយគ្នា ។ ដែនដីនេះ ដែលប្រជាជនកម្ពុជា នៅតែហៅកម្ពុជាក្រោមរហូតដល់សព្វថ្ងៃនេះ កាលនោះ បានឲ្យជនជាតិចាម និងខ្មែរជ្រកកោនដែរ ។

ការវាតទីទឹកដីរបស់វៀតណាម បានចាប់ផ្ដើមនៅសតវត្សរ៍ទី១១ ជាមួយការក្ដាប់ខេត្តខាងជើងចំនួនបីរបស់ចាមដែលសព្វថ្ងៃគឺភាគកណ្ដាលប្រទេសវៀតណាម ។ ក្នុងរយៈពេលប្រាំពីរសតវត្សរ៍ ដែលមានជាបន្តបន្ទាប់ ពួកវៀតណាម បានរៀបចំសង្គមរបស់គេឡើងវិញ ដើម្បីជួយគាំទ្រកងទ័ព ដោយបង្ហាញឲ្យឃើញឯករាជ្យ (ភាពមិនចំណុះ) របស់ទាំងស្រុងបើប្រៀបធៀបនឹងពួកចិន ។ ពួកគេបានតម្រូវឲ្យពួកអ្នកស្រុកបង់ពន្ធផ្សេងៗ និងបំបែកកម្លាំងទ័ពរបស់ពួកគេទៅជាកងទ័ពជើងគោកនិងជើងទឹក ។ បណ្ដាសន្និវេសរបស់វៀតណាម បានពង្រីង

ខ្លួនរឹតតែខ្លាំង និងបង្ហាញឲ្យឃើញប្រសិទ្ធភាពជាងគេក្នុងការប្រមូលពន្ធដារ និងផ្តល់ឲ្យសង្គមនូវគោលដៅរួមមួយដែលមានលក្ខណៈយោធានិយម ។ ពួកវៀតណាមបានយកប្រទេសចិនជាគំរូ និងជាគោលសម្រាប់វិនិច្ឆ័យ ដើម្បីវាស់ស្ទង់ពីសមិទ្ធកម្មផ្ទាល់ខ្លួនរបស់គេ ដោយសម្លឹងរំពៃឆ្ពោះទៅរកភាគខាងត្បូង និងដែនដីសណ្តទន្លេមេគង្គទៀត ។ គំនិតនេះ នៅមានដដែលរហូតមកដល់សម័យទំនើបនេះ ។ ជាមិត្ត ឬជាសត្រូវ ប្រទេសចិននៅតែជាចំណុចសំខាន់បំផុត នៃការយកចិត្តទុកដាក់របស់វៀតណាម នៅពេលដែលប្រទេសជាច្រើននៃអាងទន្លេមេគង្គ - ចម្ប៉ា, កម្ពុជា ឬឡាវ- សុទ្ធតែត្រូវវៀតណាមចាត់ទុកជាប្រទេសដែលមានអារ្យធម៌ទាបជាង ពុំមែនជាគូប្រជែងពិតប្រាកដទេ ។

ការវាតទីរបស់ប្រទេសវៀតណាមមកទិសខាងត្បូង បង្ហាញឲ្យឃើញថា នាំឲ្យខាតបង់ និងចំណាយសោហ៊ុយយ៉ាងខ្លាំង ដោយហេតុថា វាអាចជំរុញឲ្យមានការច្បាំងដណ្តើមយកប្រទេសឡើងវិញដោយប្រទេសចិន ហើយនៅទីបំផុតនឹងនាំមកនូវសង្គ្រាមស៊ីវិលមួយទៀតផង ។ ពួកចិនបានដាក់ប្រទេសវៀតណាមក្រោមចំណុះខ្លួនជាថ្មី ក្នុងរយៈពេលមួយយ៉ាងខ្លីនៅឆ្នាំ១៤០៧ នៅពេលដែលពួកចាមបានវាយប្រយុទ្ធដើម្បីការពារខ្លួន ដោយធ្វើឲ្យពួកវៀតណាមរងការខូចខាតយ៉ាងធ្ងន់ធ្ងរ ។ ប៉ុន្តែគ្រោះមហន្តរាយនេះបាននាំឲ្យលេចចេញការងើបបះបោរមួយ ដែលដឹកនាំដោយវីរបុរសម្នាក់ក្នុងចំណោមវីរបុរសជាតិគួរជាទីគោរពយ៉ាងជ្រាលជ្រៅបំផុត របស់ប្រទេសវៀតណាម គឺកសិករម្នាក់ឈ្មោះ ឡេ ឡយ (Lê Loi) ដែលបានដឹកនាំការបះបោរប្រឆាំងដ៏មានជោគជ័យមួយក្នុងរយៈពេលម្ភៃឆ្នាំ ប្រឆាំងនឹងប្រទេសចិន និងបានបង្កើតសន្តិវង្សឡេឡើង ។

ជាថ្មីម្តងទៀត ឯករាជ្យត្រូវបានសម្តែងឲ្យឃើញដោយការវាតទឹកដី ។ ក្រោមសន្តិវង្ស ឡេ ពួកវៀតណាមបានទទួលជម្នះធំៗជាច្រើននៅភាគខាងត្បូង ។ ដោយការប្រើអាវុធ និងការចរចា ពួកគេបានធ្វើដំណើរចុះរហូតមកដល់ញ៉ាត្រាង ក្នុងដែនដីសណ្តទន្លេមេគង្គ ប៉ុន្តែការវាតទឹកដីនេះមានសភាពលឿនរហ័ស អង់អាចស្វាហាប់បំផុត ទោះបីជាមានការបែកបាក់គ្នាមួយដែលផ្ទុះឡើងក្នុងផ្ទៃរដ្ឋាភិបាលគ្រប់គ្រងដោយពួកអភិជន និងប្រែក្លាយទៅជាការប្រជែងគ្នាយកស្លាប់រស់ក៏ដោយ ។ គឺពីជម្លោះនេះឯងដែលបណ្តាលឲ្យមានការបែងចែករវាងវៀតណាមខាងត្បូង និងខាងជើងនោះ ។

សមាជិកម្នាក់នៃគ្រួសារត្រកូលង្វៀន ជាអ្នកគ្រប់គ្រងបណ្តាខេត្តថ្មីៗរបស់វៀតណាម ភាគខាងត្បូងបានបង្កើតនៅចុងទសវត្សរ៍ទី១៦ នូវដែនអំណាចដាច់ដោយឡែកមួយ ដើម្បីស្ថិតនៅក្រោមអំណាចរបស់ព្រះរាជវាំង ឡេ ដែលតាំងនៅភាគខាងជើង ។ ជាការសងសឹកពួក អភិជននៅភាគខាងជើងបានកម្ចាត់ពួកត្រកូលង្វៀនពីមុខតំណែងទាំងអស់នៅព្រះរាជវាំង ហើយចោទប្រកាន់ពួកនេះថាបានកេងបន្លំប្រាក់ពន្ធដារ ។ ការប្រយុទ្ធគ្នាបានផ្ទុះឡើងរវាង ភាគខាងជើងនិងខាងត្បូងនៅឆ្នាំ១៦២០ ហើយបានបន្តក្នុងរយៈពេលហាសិបឆ្នាំមកទៀត និងបានបញ្ចប់ដោយការខណ្ឌចែកប្រទេសវៀតណាមជាពីរ ។

ដោយដោះខ្លួនផុតពីអាណាព្យាបាលពួកខាងជើង សន្តិវង្សង្វៀន បានបង្វើយការរុលទៅមុខរបស់ខ្លួនមកខាងត្បូងទៀត ហើយនៅឆ្នាំ១៧៦៥ បានច្បាំងដណ្ដើមយកដែនដីសេសសល់ទាំងអស់ ដែលរួមផ្សំបានជាវៀតណាមភាគខាងត្បូងសព្វថ្ងៃនេះឯង ។ សន្តតិវង្ស ង្វៀន បានភ្ជាប់តំបន់ទាំងនេះ ក្នុងរយៈពេលមួយជាងមួយរយឆ្នាំ និងដោយបែបដែនមួយ ដែលនឹងទៅជាទម្រង់ទីទៃពីគ្នារបស់ខ្លួននៅជំនាន់ថ្មីនេះ ។ ដំបូងត្រកូលង្វៀនបានឆ្លៀតទាញផលប្រយោជន៍ពីការបែកបាក់គ្នាក្នុងផ្ទៃព្រះរាជវាំងខ្មែរ ដើម្បីទទួលបានទឹកដីរបស់ក្សត្រខ្មែរដែលប្រជែងគ្នាឡើងសោយរាជ្យ ។ បន្ទាប់មក ពួកគេបានចូលជ្រៀតជ្រែកដោយចេញមុខក្នុងនយោបាយរបស់បណ្ដាព្រះរាជាខ្មែរ ដែលពួកគេបានដាក់បង្ខំធ្វើតាមឆន្ទៈរបស់គេទាំងអស់ ។ ព្រះរាជាទាំងឡាយរបស់កម្ពុជាដែលចុះដុនដាប និងទន់ខ្សោយ គ្មានធ្វើអ្វីកើតក្រៅតែពីជួយជំរុញឲ្យមានការជ្រៀតជ្រែកទាំងនោះប៉ុណ្ណោះ ។

ពួកង្វៀន បានកាន់កាប់ដែនដីខ្មែរទាំងឡាយ ដែលវាយដណ្ដើមបានថ្មីៗ ដោយរបៀបមួយ ដែលនៅមានគេនៅនិយាយនៅឡើយក្នុងសម័យបច្ចុប្បន្ននេះ ។ មុនដំបូង ពួកគេ បើកឲ្យសមាសភាព ដែលគេមិនត្រូវការ -មនុស្សអនាថា, អ្នករត់ចោលបក្សពួក- និងពពួកមនុស្សដែលត្រូវបណ្ដេញចេញពីស្រុកភូមិរបស់គេ ចូលមករស់នៅលើដែនដីទាំងនោះ ដោយចង់គេចចេញពីភាពម៉ឺងម៉ាត់នៃសង្គមមួយរបស់ត្រកូលង្វៀន ដែលមានការរៀបចំតាមឋានានុក្រមយ៉ាងត្រឹមត្រូវបំផុត ។ បន្ទាប់មក រដ្ឋបានស្រាល់ជ្រើសនិគមជនជាផ្លូវការ ដើម្បីធ្វើស្រែចម្ការ និងបង្កើតភូមិថ្មីៗទៀត ដើម្បីជួយសម្រាលបន្ទុកបណ្ដាលខេត្តក្រីក្រ និងដែលមានប្រជាជនច្រើនហួស ។ នៅទីបំផុត រដ្ឋបានផ្ដល់ឲ្យពួកទាហានរំសាយ ដើម្បីជារង្វាន់ចំពោះការបម្រើជាតិដ៏ស្មោះត្រង់របស់ពួកគេ ។

កាលនោះសន្តតិវង្សនៅខាងជើង បានសម្រេចចិត្តយកដែនដីនៅភាគខាងត្បូង ដែលក្លាយទៅជាទឹកដីដ៏ធំល្វឹងល្វើយ និងចម្រើនលូតលាស់ដាក់ក្រោមអំណាចខ្លួន ហើយបង្រួបបង្រួមវៀតណាមទាំងពីរ សម្រាប់ជាលើកដំបូងបង្អស់ ។ ប៉ុន្តែក្នុងរយៈពេលជាងម្ភៃប្រាំឆ្នាំ នៃសង្គ្រាមភាគខាងត្បូងបានវាយឈ្នះភាគខាងជើង ហើយនៅឆ្នាំ១៨០២ បានទាមទារបង្កើតមហារដ្ឋវៀតណាមមួយ ដែលលាតសន្ធឹងពីដីសណ្ដទន្លេក្រហមរហូត ដល់មាត់ពាមទន្លេមេគង្គ ។ ព្រះចៅអធិរាជថ្មី បានសម្រេចជ្រើសរើសទីក្រុងវ៉េ នៅភាគកណ្ដាលប្រទេសសម្រាប់គង់នៅជាជាងយកក្រុងហាណូយ ឬក្រុងព្រៃនគរ ។ ព្រះអង្គបានស្វះស្វែង និងបានទទួលនូវការប្រគល់អំណាចជាផ្លូវការពីសំណាក់ប្រទេសចិន ដើម្បីបង្កើតភាពពេញច្បាប់របស់ព្រះអង្គ ។

បើនិយាយអំពីផ្នែករដ្ឋបាល ប្រទេសវៀតណាមត្រូវបែងចែកជាបីភូមិភាគ ៖ ខាងជើង គឺតុងកឹង ភាគកណ្ដាល គឺអាណ្ណាម ដោយមានទីក្រុងវ៉េជារាជធានីផង និងខាងត្បូង គឺកូសាំងស៊ីន ។ ភ្លាមនោះ រដ្ឋថ្មីនេះបានចូលមកឡូកឡំក្នុងការរំដើបរំជួល ដែលកំពុងរីករាលដាលនៅប្រទេសកម្ពុជាក្បែរខាងជាថ្មី ។ ព្រះរាជវាំងខ្មែរនៅតែខ្វល់អំពល់ ដោយសារជម្លោះក្នុងរាជវង្សានុវង្សនៅឡើយ ហើយអ្នកចង់ដណ្ដើមរាជបល្ល័ង្កម្នាក់បានហៅកងទ័ពសៀមឲ្យចូលមកជួយ ។ ដើម្បីផ្ដាច់ជើងពួកថៃ ពួកវៀតណាមបានយល់ព្រមផ្ដល់ការគាំទ្ររបស់គេចំពោះស្ដេចដ៏

ទន់ខ្សោយរបស់ខ្មែរ ហើយជួយធ្វើឲ្យព្រះអង្គបានឡើងសោយរាជ្យដូចដើមឡើងវិញ ។ ប៉ុន្តែ នៅឆ្នាំ១៨៣១ ពួកសៀមបានវាយបកមកវិញ និងដណ្តើមបានទឹកដីខ្មែរទាំងអស់ ដែលស្ថិតនៅត្រើយខាងលិចទន្លេមេគង្គ ។ ព្រះចៅអធិរាជវៀតណាមបានបញ្ជូនកងទ័ពចំនួនដប់ប្រាំពាន់នាក់មកជួយច្បាំង ដែលបានវាយឈ្នះលើពួកសៀមផង ហើយនៅឆ្នាំ១៨៣៤ ព្រះចៅអធិរាជបានអភិសេកយុវក្សត្រីខ្មែរមួយអង្គឲ្យឡើងសោយរាជ្យ ដែលសម្រាប់ប្រើជាអាយ៉ងក្នុងពេលដែលប្រទេសវៀតណាមខំប្រឹងភ្ជាប់ទឹកដី ដែលនៅសេសសល់របស់កម្ពុជាទៅក្នុងចក្រភពថ្មីរបស់វៀតណាម ។

ព្រះចៅអធិរាជ មិញ ម៉ាង ដែលជាអ្នកកោតស្ញប់ស្ញែងដ៏ឆ្នើមម្នាក់ ចំពោះវប្បធម៌របស់ចិន បានខំប្រឹងធ្វើឲ្យប្រទេសកម្ពុជាមានលក្ខណៈបែបខុងជឺនិយម ដូចដែលប្រទេសចិនធ្លាប់បានធ្វើទៅលើប្រទេសវៀតណាមក្នុងរយៈពេលជាង មួយពាន់ឆ្នាំដែរ ។ គេបានបង្រៀនភាសាចិន និងវៀតណាម ដល់ប្រជារាស្ត្រខ្មែរ ព្រមទាំងទំនៀមទម្លាប់ផ្សេងៗរបស់វៀតណាមទៀតផង ។ ប្រទេសត្រូវបានបែងចែកជាខេត្តថ្មីៗភ្ជាប់ទៅ កូសាំងស៊ីន ។ ពលរដ្ឋវៀតណាមជាច្រើន បានចូលមកតាំងលំនៅក្នុងប្រទេសកម្ពុជា ដែលតាមការមើលឃើញរបស់ពួកគេ គឺប្រភពអំណាច និងច្បាប់ផ្សេងៗ ពុំមែនចេញមកពីព្រះមហាក្សត្រិយានីរបស់កម្ពុជា ដែលជា«អាយ៉ង»ទេ ប៉ុន្តែចេញពីវៀតណាមឯណោះ ។

ប្រជាជនកម្ពុជាបានទទួលរងនយោបាយទន្ទ្រានកាន់កាប់ និងការលេបទឹកដីនេះ ដែលអុជអាលដោយប្រទេសចិន ក្នុងរយៈពេលប្រាំពីរឆ្នាំ បន្ទាប់មកប្រជាជនកម្ពុជាបានងើបបះបោរឡើងនៅឆ្នាំ១៨៤០ ដោយបានសម្លាប់រង្គាលពួកវៀតណាមកាន់កាប់ទឹកដីរបស់ពួកគេ ។ ពួកគេបានសម្រេចជោគជ័យ ធ្វើឲ្យពួកវៀតណាមទទួលស្គាល់ថា ពួកគេលែងអាចគ្រប់គ្រងដឹកនាំប្រទេសកម្ពុជាដោយផ្ទាល់ទៀតហើយ ប៉ុន្តែមិនអាចដាក់បង្ខំឲ្យមានការដកថយទាំងស្រុងមួយរបស់កងទ័ពវៀតណាមបានឡើយ ។ បន្ទាយរបស់វៀតណាមប្រមាណជាហាសិប បានបោះទីតាំងនៅក្នុងប្រទេស ហើយព្រះចៅអធិរាជមិនដែលសុខចិត្តឲ្យបាត់បង់បន្ទាយទាំងនោះសោះឡើយ ។

ក្នុងរយៈពេលនៃការប្រយុទ្ធគ្នាជាច្រើនលើក មិញ ម៉ាង បាននិយាយថា "ជួនកាល ប្រជាជនកម្ពុជា ជាមនុស្សសុចរិតទៀងត្រង់ ជួនកាល ពួកគេបែរជាក្បត់នឹងយើង ។ យើងបានជួយឧបត្ថម្ភពួកគេ... ជួយយកពួកគេចេញពីភាពថោកទាប ឥឡូវនេះ ពួកគេងើបបះបោរប្រឆាំងនឹងយើង ។ ខ្ញុំខឹងសម្បាខ្លាំងណាស់... គេគោងតែប្រើកាំបិតរាប់រយ ដើម្បីកាប់ចិញ្ច្រាំពួកនេះឲ្យទៅជាដុំតូចៗ[៤]» ។

នៅឆ្នាំ១៨៤៥ គេបានឈានដល់ការស្រុះស្រួលគ្នាមួយដែលតាមរយៈនេះ ប្រទេសកម្ពុជាត្រូវដឹកនាំដោយព្រះមហាក្សត្រថ្មីមួយអង្គដែលស្លូតបូត និងចេះស្តាប់បង្គាប់ជាងមុន ដោយយល់ព្រមឲ្យមានការគាំពាររួមមួយពីសំណាក់ប្រទេសសៀម និងប្រទេសវៀតណាម ។ ប៉ុន្តែការកាន់កាប់របស់កងទ័ពវៀតណាមនៅតែដក់ជាប់ក្នុងការចងចាំរបស់ប្រជាជនកម្ពុជាជានិច្ច ដែលបានចាត់ទុកប្រទេសវៀតណាមជាសត្រូវ«ប្រចាំប្រវត្តិសាស្ត្រ»

ដីធំបំផុតរបស់គេ ។

នៅពេលនោះ ប្រទេសបារាំងបានចូលមកធ្វើអន្តរាគមន៍ និងបានធ្វើឲ្យស្ថិរភាព ដែលបង្កើតឡើងដោយការស្រុះស្រួលគ្នានៅឆ្នាំ១៨៤៥ ភាន់ប្រែអស់ ។ ក្រោមលេសការពារប្រទេសកម្ពុជាទល់នឹងពួកថៃ ពួកបារាំងបានបង្កើតឥណ្ឌូចិន គឺការបញ្ចូលប្រទេសច្រើនជាប្រទេសតែមួយមិនសមទំនងនេះ បានធ្វើឲ្យប្រទេសកម្ពុជាចុះទន់ខ្សោយ និងធ្វើឲ្យកាន់តែអាចងាយរងគ្រោះពីមហិច្ឆតា ផ្សេងៗរបស់វៀតណាមជាងមុនទៅទៀត ។ ពួកបារាំងបានចាប់ផ្ដើមច្បាំងដណ្ដើម យកប្រទេសវៀតណាមនៅឆ្នាំ១៨៦២ ។ នៅចុងសតវត្សរ៍ទី១៩ ពួកបារាំងបានតាំងអាណានិគម ឬកាន់កាប់ ប្រទេសឡាវ កម្ពុជានិងវៀតណាមដោយកម្លាំងទ័ព បង្កើតជាសហព័ន្ធឥណ្ឌូចិនថ្មី ។

ការត្រួតត្រារបស់អាណានិគមបារាំងមានលក្ខណៈកម្រោលព្រៃផ្សៃសម្រាប់ប្រទេសទាំងអស់ ។ ប្រទេសវៀតណាម ត្រូវបែងចែកទៅតាមការកំណត់ព្រំដែនភូមិភាគរដ្ឋបាលទាំងបីរបស់ខ្លួន ៖ កូសាំងស៊ីន ជាមួយនឹងក្រុងព្រៃនគរជារដ្ឋធានីរបស់ខ្លួន បានក្លាយទៅជាអាណានិគមមួយដែលគ្រប់គ្រងដឹកនាំផ្ទាល់ដោយប្រទេសបារាំង«រដ្ឋ»របស់វៀតណាមពីរទៀត ត្រូវបានត្រួតត្រាដោយអគ្គទេសាភិបាលម្នាក់ ។ ការព្រមព្រៀងគ្នាថ្មីរបស់ប្រទេសវៀតណាមបានត្រូវធ្វើឲ្យវិនាស ។ រដ្ឋរបស់វៀតណាមសម័យទំនើបមានរយៈពេលតែជាង ហុកសិបឆ្នាំបន្តិចប៉ុណ្ណោះ ។ ប៉ុន្តែបើគិតឲ្យសព្វៗទៅ ពួកបារាំងបានធ្វើឲ្យពួកវៀតណាមពិនិត្យដោយឡែកនូវសត្រូវរួមមួយ និងគោលដៅមួយដូចគ្នា គឺសេរីភាព ដែលលើកទឹកចិត្តដល់ការរីកលូតលាស់នៃគំនិតជាតិនិយមមួយរបស់វៀតណាមតែម៉្យាងគត់ ។

ដូចដែលយើងធ្លាប់កត់សម្គាល់រួចមកហើយ ពួកបារាំងបានវិនិច្ឆ័យដោយគ្មានរួញរាថា ជនជាតិអណ្ណាម ឬវៀតណាមជាសមាសភាពមនុស្សចូលចិត្តធ្វើការ និងឆ្លាតវាងវៃនៃដែនដីឥណ្ឌូចិនរបស់គេ ជាកន្លែងប្រជុំរបស់អារ្យធម៌បារាំងទាំងមូល ។ ពួកមេដឹកនាំវៀតណាម ដែលតែងតែបង្ហាញឲ្យឃើញនូវការប្រឆាំងរបស់ខ្លួន ចំពោះអំណាចរបស់អាណានិគម នៅពេលក្រោយមកទៀត សុទ្ធតែជាមនុស្ស ប្រុស និងស្ត្រី ដែលធ្លាប់ទទួលការអប់រំមួយនៅប្រទេសបារាំង និងរៀនសូត្រពីពួកបារាំងនូវទស្សនៈមួយចំណែកយ៉ាងធំ ស្ដីពីការរំដោះខ្លួនពីអាណានិគមនិយម ។

ពួកបារាំង បានទូទាត់ទៅឲ្យពួកវៀតណាមវិញ នូវបែបផែនជាច្រើន ។ ពួកគេបានយល់ព្រមឲ្យវៀតណាមមានសិទ្ធិកាន់កាប់ទឹកដីលើប្រទេសកម្ពុជា ព្រមទាំងសិទ្ធិកាន់តំណែងខ្ពស់ៗក្នុងប្រទេសនេះ និងនៅប្រទេសឡាវផង ដែលដូចជាជួយពង្រឹងទឹកចិត្តរបស់ពួកវៀតណាមរឹតតែខ្លាំងឡើង ដែលមាន«វាសនាជាក់ស្ដែង»មួយដូច្នេះ ។ ក្នុងទិដ្ឋភាពស្ទើរតែទាំងអស់របស់ខ្លួន សហភាពឥណ្ឌូចិន បានជួយប្រទេសវៀតណាមឲ្យរីកលូតលាស់ ។ ដំបូងសហភាពនេះធ្វើឲ្យគេទទួលស្គាល់ថា ការបង្កើតនេះត្រឹមត្រូវតាមច្បាប់ ដែលតាមរយៈនេះ គឺប្រទេសទាំងបីបានបង្កើតជាអង្គតែមួយគត់ ដែលគ្រប់គ្រងដឹកនាំដោយមេដឹកនាំតែម្នាក់ ។ នេះជាការយល់ឃើញមួយ ដែលភាន់

ប្រទ្បាំ និងតឹងតែងដូចការបង្កើតសហភាពបារាំង-អាល្លឺម៉ង់មួយធ្លាប់ជួបប្រទះរួចមកហើយ ប៉ុន្តែពួកអ្នកធ្វើអាណានិគមស្គាល់ប្រវត្តិរបស់តំបន់នេះតិចតួចណាស់ ។ ក្រោមខបាយកលនយោបាយរបស់សហភាពឥណ្ឌូចិន គឺពុំមានទាំងវប្បធម៌ទាំងប្រជាជនរបស់«ឥណ្ឌូចិន»ទេ ប៉ុន្តែ មានតែប្រជាជនកម្ពុជា និងប្រជាជនឡាវ និយមប្រពៃណីឥណ្ឌាដែលមានលក្ខណៈខុសគ្នាយ៉ាងខ្លាំងជាមួយនឹងប្រជាជនវៀតណាមនិយមប្រពៃណីចិន ។

នៅពេលដែលពួកបារាំងនិយាយពាក្យឥណ្ឌូចិន ជាទូទៅគឺពួកគេចង់និយាយពី «ប្រជាជនវៀតណាម» ។ ភាសាវៀតណាមបានក្លាយទៅជាភាសាទីពីរបន្ទាប់ពីភាសាបារាំង ដែលគេប្រើនៅទីក្រុងភ្នំពេញ និងវៀងច័ន្ទក៏ដូចនៅទីក្រុងព្រៃនគរ វេ៉ និងហាណូយដែរ ។ ពួកបារាំងបាននិយាយយ៉ាងចេញមុខថា ពួកខ្មែរនិងពួកឡាវជា«ជនជាតិភាគតិច» នៃសហភាពឥណ្ឌូចិន ជាម្ចាស់ស្រុកដែលទន់ខ្សោយយ៉ាងខ្លាំង មិនសូវមានប្រាជ្ញា ជឿអបិយជំនឿ និងខ្ជិលច្រអូស ដែលនៅថ្ងៃណាមួយនឹងត្រូវគ្រប់គ្រងទាំងស្រុងដោយពួកវៀតណាមមិនខាន ។

ដូចដែលគេនឹកសង្ស័យពីរឿងនេះមែន ពួកវៀតណាមបានយល់ព្រមទទួលសញ្ញាណឥណ្ឌូចិន ដោយច្រានចោលទាំងអស់នូវការត្រួតត្រារបស់អាណានិគមបារាំង ។ ពួកគេបានបញ្ចូលពាក្យ និងគំនិតឥណ្ឌូចិនទៅក្នុងភាសារបស់គេ ហើយបកប្រែពាក្យនេះដោយប្រយោគពន្យល់មួយមានន័យថា «ដែនដីនៅខាងកើតសមុទ្រ» ។ ក៏ប៉ុន្តែពួកកម្ពុជា មិនទទួលស្របទាំងគំនិតទាំងឈ្មោះ ។ ពួកគេក៏ពុំមានផ្តល់ន័យណាមួយ ដែលមានតម្លៃដូចគ្នាជាភាសាខ្មែរដែរ ហើយពេញចិត្តប្រើប្រាស់តែពាក្យបារាំងថា«ឥណ្ឌូចិន»ប៉ុណ្ណោះ នៅពេលដែលពួកគេនិយាយភាសាបារាំង ឬខ្មែរ ។

នៅពេលដែលពួកវៀតណាមបង្កើតបក្សកុម្មុយនិស្តមួយ នៅឆ្នាំ១៩៣០ ក្រោមការដឹកនាំរបស់ ហូ ជីមិញ ក្នុងគោលបំណងបញ្ចប់នឹមត្រួតត្រារបស់អាណានិគម និងតាំងឲ្យមានរបបបដិវត្តន៍ដើម្បីកាន់អំណាច គឺពួកគេធ្វើឡើងក្នុងនាមឥណ្ឌូចិនទាំងមូល ។ ការសម្រេចចិត្តនេះ និងការអនុវត្តន៍របស់វា បានបណ្តុះឲ្យមានគ្រាប់ពូជនៃសង្គ្រាម រវាងពួកកុម្មុយនិស្តវៀតណាម និងពួកកុម្មុយនិស្តកម្ពុជា ដែលបានផ្ទុះឡើង សែសិបប្រាំពីរឆ្នាំក្រោយមកទៀត ។

គឺនៅទីក្រុងមូស្គូ ដែលលេចចេញគំនិតបង្កើតបក្សកុម្មុយនិស្តឥណ្ឌូចិនមួយ ប៉ុន្តែគឺដំណើរត្រាច់ចរផ្ទាល់ខ្លួនរបស់ ហូ ជីមិញ ដែលនាំទៅដល់ការបង្កើតបក្សនេះឡើង[៥] ។ ជាកូនមន្ត្រីថ្នាក់ទាបម្នាក់ ហូ ជីមិញ បានបង្កើតចំណងទាក់ទងខាងនយោបាយជាលើកដំបូង និងមាំទាំបំផុតក្នុងផ្ទៃនៃចលនាកុម្មុយនិស្តអន្តរជាតិ ដោយផ្ទុយស្រឡះពីសាឡុត ស ។ ហូ បានចាប់ផ្តើមដំណើរផ្សងព្រេងរបស់គាត់តាំងពីគាត់នៅជាយុវជនវ័យក្មេងបំផុតខ្ចីម្ល៉េះ បន្ទាប់ពី ទទួលការអប់រំតាមគំរូមួយរបស់អាណានិគមបារាំង ក្នុងអណ្តាមជាស្រុកកំណើតរបស់គាត់ ។ នៅទីបំផុតគាត់បានទៅដល់ទីក្រុងប៉ារីសមុន សាឡុត ស ជិតសាមសិបឆ្នាំ ហើយបានក្លាយទៅជាសមាជិកស្ថាបនិកបក្ស

កុម្មុយនិស្តបារាំងនៅឆ្នាំ១៩២០ ។ គាត់គឺជា“ជនឥណ្ឌូចិន” តែម្នាក់គត់ដែលបានចូលរួមមហាសន្និបាតនៅទីក្រុងទួរស៍ (Tours) [នៅឆ្នាំ១៩២០ នាមហាសន្និបាតទីក្រុងទួរស៍ គណបក្សសង្គមនិយមបានបែកចេញ ហើយគណបក្សកុម្មុយនិស្តបារាំងបានចាប់កំណើតឡើង (វចនានុក្រម Larousse ទំព័រ១៦២៥-កំណត់របស់អ្នកបកប្រែ] ។ នៅមហាសន្និបាតនោះ គាត់បានលើកឡើងនូវបញ្ហាស្ដីពីការធ្វើអាណានិគម ហើយចាប់ផ្ដើមអាជីពបែបរឿងព្រេង រហូតដល់គេលើកគាត់ឲ្យកាន់តំណែងជាប្រធានចលនាប្រឆាំងនិគមរបស់វៀតណាម ។

គាត់បានពង្រីកចំណេះដឹងខាងនយោបាយក្នុងផ្ទៃចលនាបារាំងពីយុវជនកុម្មុយនិស្តជាច្រើន និងត្រូវបានឲ្យធ្វើជាសមាជិកប្រតិភូ ទៅចូលរួមមហាសន្និបាតអង្គការកុម្មុយនិស្តអន្តរជាតិ លើកទី៥ នៅទីក្រុងមូស្គូ នៅឆ្នាំ១៩២៥ ។ តមកទៀត គាត់បានក្លាយទៅជាមន្ត្រីរបស់ចលនាកុម្មុយនិស្តអន្តរជាតិ ដែលក្នុងនោះ គាត់បានបញ្ចប់ការអប់រំរបស់គាត់ព្រមជាមួយគ្នា ។ ក្រោយពីការទៅដល់ក្រុងមូស្គូរបស់គាត់បន្តិច អង្គការកុម្មុយនិស្តអន្តរជាតិបានបញ្ជូនគាត់ឲ្យមកជួយពួកអ្នកបដិវត្តន៍ចិនទៀត ។ ក្រោយមក គាត់ត្រូវបានចាត់តាំងឲ្យសម្របសម្រួលចលនាកុម្មុយនិស្ត ក្នុងភូមិភាគអាស៊ីអាគ្នេយ៍ទាំងមូល ដើម្បីជាប្រយោជន៍ដល់អង្គការកុម្មុយនិស្តអន្តរជាតិ ។ នៅពេលដែលគាត់ត្រឡប់មកវៀតណាមវិញ បន្ទាប់ពីឃ្លាតពីស្រុកសាមសិបឆ្នាំ គាត់បានទៅជនកុម្មុយនិស្តអាស៊ីដ៏កម្រម្នាក់ ក្នុងចំណោមជនកុម្មុយនិស្តអាស៊ីដ៏កម្រមានទាំងឡាយ ដែលមានលក្ខណៈ“អន្តរជាតិ” ។ គាត់ធ្លាប់បង្កើតនិងបោះពុម្ពផ្សាយកាសែតមួយនៅទីក្រុងប៉ារីស បង្រៀននៅបណ្ឌិតយោធាដ៏ល្បីល្បាញរបស់ចិន នៅវ៉ាមប៉ាវ (Whampoa) និងធ្លាប់ចាត់ចែងរៀបចំពួកអ្នកបដិវត្តន៍នៅប្រទេសថៃឲ្យមានទម្រង់ត្រឹមត្រូវ ដោយក្លែងខ្លួនជាព្រះសង្ឃ ។

នៅឆ្នាំ១៩៣០ គេបានស្នើឲ្យគាត់ជួយស្រោចស្រង់ចលនាកុម្មុយនិស្តនៅប្រទេសវៀតណាម ។ កាលណោះ ថ្វីបើគេចាត់ទុកគាត់ជាអ្នកស្នេហាជាតិម្នាក់ក៏ដោយ ក៏គាត់ពុំដែលបានចូលរួមក្នុងចលនាកុម្មុយនិស្តវៀតណាម ដែលប្រឡាក់ទៅដោយឈាមនៅពេលចាប់ផ្ដើមធ្វើសកម្មភាពដំបូងៗដែរ ។ គាត់គឺជាជើងចាស់ខាងនយោបាយម្នាក់របស់អង្គការកុម្មុយនិស្តអន្តរជាតិ ពុំមែនជាជើងចាស់នៃសង្គ្រាមប្រឆាំងអាណានិគមក្នុងស្រុកឡើយ ។

ក្នុងមុខនាទីនេះ ហូ ជីមិញ បានបង្ហាញឲ្យឃើញជាអ្នកចរចាដ៏ប៉ិនប្រសប់ម្នាក់ ហើយក្នុងឱកាសនៃការប្រកួតកីឡាបាល់ទាត់មួយនៅក្រុងហុងកុង គាត់បានបញ្ចុះបញ្ចូលពួកកុម្មុយនិស្តវៀតណាមបីក្រុម ដែលនៅដោយឡែកពីគ្នាឲ្យរួមបញ្ចូលជាក្រុមមួយវិញ ។ ប៉ុន្តែអង្គការ កុម្មុយនិស្តអន្តរជាតិបានច្រានចោលការស្រុះស្រួលមូលត្រកូលគ្នានេះ ហើយបានបង្គាប់បញ្ជាឲ្យ ហូ ជីមិញ ប្រែក្លាយបក្សកុម្មុយនិស្តវៀតណាម ទៅជាបក្សកុម្មុយនិស្តឥណ្ឌូចិនវិញ ។ គាត់គោរពធ្វើតាមសេចក្ដីបង្គាប់ផ្សេងៗ ដែលបញ្ជូនមកឲ្យគាត់អនុវត្ត ។ បន្ទាប់មកគាត់បានចាកចេញពីភូមិភាគនេះ ហើយទាល់តែឆ្នាំ១៩៤១ ទើបគាត់ចាប់ផ្ដើមគំនិតគិតគូរពីបដិវត្តន៍របស់វៀតណាមជាថ្មី ។

បក្សថ្មី បានបំពេញករណីយកិច្ចទៅតាមអាណត្តិរបស់ឥណ្ឌូចិនដែលប្រគល់ឲ្យគាត់ខ្លួន ទោះជាពុំទាន់ឈានទៅដល់ការជ្រើសរើសពួកកម្ពុជាបញ្ចូលក្នុងបក្សនេះក៏ដោយ ។ ក្នុង«លិខិតមួយផ្ញើជូនបណ្តាសមមិត្តកម្ពុជា» នៅឆ្នាំ១៩៣៤ បណ្តាមេដឹកនាំបក្សកុម្មុយនិស្តឥណ្ឌូចិន បានប្រកាសដោយសម្តីច្បាស់លាស់ថា គេពុំអនុញ្ញាតឲ្យមានបក្សរបស់កម្ពុជាដាច់ដោយឡែកទេ - ប្រហែលជាការឆ្លើយតបទៅនឹងពាក្យស្នើសុំមួយ ក្នុងន័យនេះ ។ លិខិតបានបញ្ជាក់ថា «នៅឥណ្ឌូចិនមានតែបដិវត្តន៍មួយប៉ុណ្ណោះ ។ ឥណ្ឌូចិនកំពុងស្ថិតនៅក្រោមការត្រួតត្រារបស់រដ្ឋាភិបាលចក្រពត្តិតែមួយគត់ ដូច្នេះកម្លាំងបដិវត្តទាំងអស់ត្រូវតែរួបរួមគ្នាសិន ...ប្រទេសកម្ពុជាពុំមានសិទ្ធិបង្កើតបក្សកុម្មុយនិស្តកម្ពុជាមួយដាច់ដោយឡែកបានទេ[៦]» ។

នៅឆ្នាំ១៩៣៥ ក្នុងមហាសន្និបាតបក្សកុម្មុយនិស្តឥណ្ឌូចិនលើកទីមួយ ពួកវៀតណាម បានរៀបរាប់យ៉ាងល្អិតល្អន់ស្តីពីគោលដៅរបស់គេដើម្បីបង្កើតរដ្ឋាភិបាលទម្រង់សូវៀតមួយ នៅឥណ្ឌូចិន ។ រដ្ឋាភិបាលទម្រង់សូវៀតរបស់ប្រជាជនឥណ្ឌូចិន នឹងមានសមាសភាពភាគច្រើន ជាជនជាតិវៀតណាម និង«ភាគតិច» ជាជនជាតិខ្មែរនិងឡាវ[៧] ។ ជនជាតិទាំងនេះពុំមានបាត់បង់សិទ្ធិអំណាចទាំងអស់លើប្រទេសរបស់គេ ក្នុងផ្ទៃនៃរដ្ឋាភិបាលទម្រង់សូវៀតទេ ប៉ុន្តែ នឹងមានសិទ្ធិ«ដកខ្លួនចេញ និងបង្កើតរដ្ឋឯករាជ្យមួយ» ដោយមានការអនុញ្ញាតរបស់រដ្ឋាភិបាលទម្រង់សូវៀត ដែលគ្រប់គ្រងដោយភាគច្រើនជាជនជាតិវៀតណាមផង ។

ផ្លាស់ប្តូរនឹមត្រួតត្រារបស់បារាំងទល់នឹងការត្រួតត្រារបស់វៀតណាម ក្នុងរដ្ឋកុម្មុយនិស្តមួយមិនសូវធ្វើឲ្យពួកកម្ពុជា ដែលបន្តតស៊ូនឹងការបើកបក្សកុម្មុយនិស្តឥណ្ឌូចិន ចូលចិត្តប៉ុន្មានទេ ។ ម្យ៉ាងទៀត នៅពេលដំបូងពួកឡាវពុំទាន់បានចូលក្នុងបក្សកុម្មុយនិស្តឥណ្ឌូចិនទេ ហើយមានតែអាណិកជនវៀតណាមដែលកំពុងរស់នៅប្រទេសកម្ពុជា និងនៅប្រទេសឡាវប៉ុណ្ណោះ ដែលសុំចូលជាសមាជិកបក្សនេះ ។

គេត្រូវការដំណើរវិលត្រឡប់របស់ ហូ ជីមិញ មកមាតុប្រទេសវិញ ដើម្បីបញ្ចប់ការទទូចរបៀបធ្វើអត្តឃាដ ស្តីពីបក្សមួយក្នុងកម្រិតឥណ្ឌូចិន ។ ហូ យល់ឃើញថា បក្សមួយបែបនោះ នឹងបំផ្លាញបុព្វហេតុរបស់វៀតណាម ដូចគ្នានឹងចលនាកុម្មុយនិស្តរបស់កម្ពុជា និងឡាវ ដែលកំពុង«ត្រដរខ្យល់»ដែរ ។ ដូច្នេះ គាត់បានបង្កើតចលនាវៀតមិញ ដែលជាពាក្យបំព្រួញនៃឃ្លាមួយមានន័យថា សម្ព័ន្ធដើម្បីឯករាជ្យភាពរបស់វៀតណាមជាឡប់ឡែ សំដៅប្រមូលពួកជាតិនិយមវៀតណាមឡើងវិញ កាលពីការប្រយុទ្ធតស៊ូប្រឆាំងនឹងពួកចក្រពត្តិបារាំង ព្រមទាំងពួកចក្រពត្តិជប៉ុន ដែលទើបនឹងកើតឡើងគោកចូលមកប្រទេសវៀតណាម កាលពីពេលថ្មីៗនេះ ។ ប៉ុន្តែបក្សកុម្មុយនិស្តឥណ្ឌូចិន បានរួមបន្តជាស្នូលកណ្តាលមួយនៃចលនាវៀតមិញ និងដឹកនាំការបដិវត្តន៍ ប៉ុន្តែដោយរបៀបលាក់កំបាំង ។ គោលដៅគឺសង្កត់បញ្ជាក់អំពីលទ្ធិជាតិនិយម ។ ដូច្នេះសុន្ទរកថាស្តីពីបដិវត្តន៍កម្រិតឥណ្ឌូចិន បានទៅជារឿងបន្ទាប់ ដែលអនុញ្ញាតឲ្យពួកកុម្មុយនិស្តវៀតណាមឈានជើងចូលទៅប្រទេសឡាវ ជាទីដែលពួកគេគាំទ្រចលនាប៉ាថេឡាវ ពេញដៃពេញជើង និងបង្ហាត់បង្រៀនពួកមេដឹកនាំរបស់ចលនានេះថែម

ទៀត ។ ប៉ុន្តែ នៅប្រទេសកម្ពុជា ពួកវៀតណាមមានសមាជិកបក្សកុម្មុយនិស្តឥណ្ឌូចិន តែប្រមាណសែសិបនាក់ប៉ុណ្ណោះនៅឆ្នាំ១៩៥១[៨] ។ ក្នុងដំណាក់កាលដំបូងនៃការបះបោរប្រឆាំងអាណានិគមនិយម ពួកវៀតណាមបានសម្តែងតួនាទីជាអ្នកបំបែកបំបាក់មួយជារឿយៗ ដោយធ្វើឲ្យពួកកម្ពុជាខូចទឹកចិត្តនឹងរួមកម្លាំងគ្នា លើកលែងតែក្នុងករណី ដែលវាស្ថិតនៅក្រោមការឧបត្ថម្ភរបស់វៀតណាមប៉ុណ្ណោះ ។

ពួកវៀតណាមបានយកចិត្តទុកដាក់ ជាពិសេស ធ្វើម៉េចយកឈ្នះសង្គ្រាមទល់នឹងពួកបារាំងឲ្យបាន ហើយបណ្តាសមមិត្តកម្ពុជារបស់ពួកគេពុំមែនជាកម្លាំងចាំបាច់ខានមិនបានក្នុងការប្រយុទ្ធនេះទេ ។ នៅឆ្នាំ១៩៤៥ បក្សកុម្មុយនិស្តឥណ្ឌូចិន បានក្លាយទៅជាបក្សជ្រុយនឹងច្បាប់ ហើយប្តូរឈ្មោះរបស់ខ្លួនទៅជាបក្សពលករវៀតណាមវិញ ដើម្បីសង្កត់បញ្ជាក់អំពីគំនិតជាតិនិយមដែលចាំបាច់ខានមិនបាន ដើម្បីយកឈ្នះសង្គ្រាម ។ គឺនៅពេលនោះហើយ ដែលពួកវៀតណាមបង្គាប់បញ្ជាឲ្យពួកឡាវ និងពួកខ្មែរបង្កើតបក្ស ឬអង្គការផ្សេងៗផ្ទាល់ខ្លួនរបស់គេ ។ ពួកឡាវបានបង្កើតបក្សរបស់គេនៅឆ្នាំ១៩៥៥ ពួកកម្ពុជាបានបង្កើតសម្ព័ន្ធមួយនៅឆ្នាំ១៩៥១ និងបក្សមួយជាច្រើនឆ្នាំក្រោយមកទៀតគឺឆ្នាំ១៩៦០ ។ ប៉ុន្តែ ពួកវៀតណាមមិនចង់បោះបង់អំណាចទាំងអស់ ដែលមានលើបក្សបែកចេញទាំងនេះទេ ហើយពួកគេបានបញ្ចេញយោបល់នៅខែវិច្ឆិកា ឆ្នាំ១៩៥១ ថា ៖ «បក្សវៀតណាមនៅរក្សាសិទ្ធិត្រួតពិនិត្យពីលើសកម្មភាពផ្សេងៗរបស់បណ្តាបក្ស ជាបងប្អូននៅកម្ពុជា និងនៅឡាវដដែល... ក៏ប៉ុន្តែក្រោយមកទៀត បើសិនជាស្ថានភាពផ្សេងៗ អនុញ្ញាតបក្សបដិវត្ត ទាំងបីនៅវៀតណាម កម្ពុជា និងឡាវអាចរួមគ្នាដើម្បបង្កើតតែបក្សមួយគត់ គឺបក្សរបស់សហព័ន្ធវៀតណាម-ខ្មែរ-ឡាវ[៩] » ។

នៅខណៈនេះ បណ្តាសមមិត្តចិនបានចាប់អារម្មណ៍យ៉ាងខ្លាំងមួយចំពោះសង្គ្រាមរបស់វៀតមិញ ប្រឆាំងនឹងការវិលត្រឡប់របស់ អាណានិគមនិយមបារាំង ។ ជ័យជម្នះរបស់ ម៉ៅ សេទុង នៅឆ្នាំ១៩៤៩ បានផ្តល់ឲ្យពួកវៀតណាមមានមូលដ្ឋានបង្អែក ហើយនៅទីបំផុត ការគាំទ្រខាងសម្ភារៈសឹករបស់ចិន បាននាំឲ្យវៀតណាមទទួលជ័យជម្នះក្នុងសង្គ្រាមឥណ្ឌូចិនលើកទីមួយ ។ នេះជាជំនួយដ៏ថ្លៃថ្លាបំផុតមួយ ដែលបង្ខិតប្រទេសជិតខាងទាំងពីរឲ្យចូលជិតគ្នាថែមទៀត ។ ហូ ជីមិញ និងម៉ៅ សេទុង បានកាត់ផ្តាច់ខ្លួនចេញពី «ដូរ» ប្រទេសនៅអឺរ៉ុបដែលប្រកាន់លទ្ធិកុម្មុយនិស្តបែបសូវៀតទាំងអស់គ្នា ហើយបានបដិសេធមិនធ្វើតាមបទបញ្ជាផ្សេងៗរបស់ ស្តាលីន ឡើយព្រោះស្តាលីនបានកំហិតដាច់ខាតមិនឲ្យផ្តើមសង្គ្រាមទេ បន្ទាប់ពីឆ្នាំ១៩៤៥ ដ្បិតអីគាត់ខ្លាចក្រែងថា ជម្លោះមួយនៅអាស៊ី អាចបណ្តាលឲ្យអន្តរាយដល់សេចក្តីសង្ឃឹមទទួលជោគជ័យរបស់លទ្ធិកុម្មុយនិស្តនៅអឺរ៉ុប ជាពិសេសនៅប្រទេសបារាំង ។ រដ្ឋាភិបាលកុម្មុយនិស្តមួយនៅទីក្រុងប៉ារីស ចាប់អារម្មណ៍នឹង ស្តាលីន ខ្លាំងជាងការបដិវត្តន៍នៅទីក្រុងប៉េកាំង ឬក្រុងហាណូយ ។ ការឡើងកាន់អំណាចរបស់ពួកកុម្មុយនិស្តបារាំងនឹងបង្ហាញឲ្យឃើញនូវគ្រឿងទាក់ចិត្តថា គណបក្សកុម្មុយនិស្តបារាំងកាន់កាប់អំណាចក្នុងរដ្ឋមួយ ដែលមានឧស្សាហកម្មលូតលាស់ទុកណាជាជ័យជម្នះមួយរបស់ចិន ឬវៀតណាមនឹងពង្រឹងការចាប់អារម្មណ៍ជ្រុយទៅវិញក៏ដោយ ៖ លទ្ធិកុម្មុយនិស្ត

ជាមាគ៌ាត្រឹមត្រូវមួយសម្រាប់តែបណ្ដាប្រទេសខនាភិវឌ្ឍ (មិនទាន់ចម្រើនលូតលាស់) ប៉ុណ្ណោះ ។

ថ្វីបើ ស្ដាលីន ម៉ៅ និងហូ ផ្សព្វផ្សាយឲ្យគេស្គាល់សង្គ្រាម«រំដោះជាតិ»របស់ពួកគេ ដោយកែប្រែលក្ខណៈនិងឥទ្ធិពលទាក់ទាញរបស់លទ្ធិកុម្មុយនិស្ដ ដែលកាលពីដើមច្រើនតម្រង់ទៅរកវណ្ណៈកម្មករតែម្យ៉ាងក៏ដោយ ប៉ុន្តែឥឡូវនេះ បានតម្រង់ទៅរកវណ្ណៈកសិករម្ដង ។ ចលនាកុម្មុយនិស្ដរបស់កម្ពុជាអាចរីកធំធាត់ដោយមិនបាច់ធ្វើតាមគំរូដ៏មានឥទ្ធិពលទាំងពីរនេះ ។ ហើយរហូតមកដល់ដើមទសវត្សរ៍១៩៦០ ការបដិវត្តរបស់ចិននិងវៀតណាមហាក់ដូចជាមានគំរូតែមួយ ។ ក្នុងទសវត្សរ៍១៩៥០ ពួកវៀតណាមបានសម្រេចប្រកាន់យកមនោគមវិជ្ជាកុម្មុយនិស្ដ របស់ចិនជាផ្លូវការសម្រាប់រយៈកាលខ្លីមួយ ។ ទំនាក់ទំនងរវាងបក្សទាំងពីរស្ទើរតែដូចទំនាក់ទំនងក្នុងគ្រួសាររបៀបឪពុកមាចាស់ម្នាក់ និងក្មួយវ័យក្មេងម្នាក់ ។

ពួកចិន បានរ៉ាប់រងធ្វើការផ្ដល់គ្រឿងសាស្ត្រាវុធយ៉ាងទៀងទាត់ ទៅឲ្យពួកវៀតមិញតែម្នាក់ឯង ដែលមានចំនួនឡើងដល់ទៅប្រាំមួយពាន់តោនក្នុងមួយខែ ក្នុងឱកាសនៃយុទ្ធនាការវាយផ្ដាច់ព្រ័ត្រនៅ ឌៀនបៀនភូ ក្នុងឆ្នាំ ១៩៥៤ ។ ពួកចិនក៏បានផ្ដល់ទីប្រឹក្សាយោធាមួយក្រុម ដឹកនាំដោយឧត្ដមសេនីយ៍ប្រាំបីនាក់ ។ សហភាពសូវៀតពុំមានផ្ដល់អ្វីទៅឲ្យពួកវៀតណាមសោះឡើយ ។ នៅឆ្នាំ១៩៥០ ស្ដាលីន បានផ្ដល់នូវគាំទ្រខាងផ្លូវចិត្ត និងជំនួយមួយក្នុងវិស័យឃោសនាសម្រាប់ពួកវៀតមិញដែរ ប៉ុន្តែ ពុំមានផ្ដល់អាវុធគ្រឿងសម្ភារៈសឹកប្រភេទណាមួយឡើយ ទោះបីជា ហូ ជីមិញ ក្លាយជាតំណាងជាតិអាស៊ីមួយរូប ក្នុងចំណោមតំណាងជាតិអាស៊ីជាច្រើនដែលត្រូវគេគោរពយ៉ាងជ្រាលជ្រៅរបស់អង្គការកុម្មុយនិស្ដអន្តរជាតិក៏ដោយ ។

តមកទៀត សន្និសីទក្រុងហ្សឺណែវបានបើកប្រជុំ និងការច្របូកច្របល់ក្នុងចលនាកុម្មុយនិស្ដដ៏ក្មេងខ្ចីនៅអាស៊ីដូចដែលមានរៀបរាប់ខាងលើរួចមកហើយ ។ គឺបន្ទាប់ពីសន្និសីទ ហ្សឺណែវនេះហើយ ដែលប្រទេសចិនបានបំបែរការយកចិត្តទុកដាក់របស់ខ្លួនមករកកម្ពុជាវិញ ដែលកាលនោះដឹកនាំដោយសម្ដេច ព្រះនរោត្តម សីហនុ ហើយដែលតំបន់ត្រីកោណកម្ពុជា-វៀតណាម-ចិន បានលេចរូបរាងឡើង ។ ក្រៅពីសន្និសីទ អះអាងបន្ថែមអំពីលំដាប់លំដោយនៃការចឹកស៊ីក្នុងពិភពកុម្មុនិស្ដដ៏រំដើបរំជួលមួយ សន្និសីទក្រុងហ្សឺណែវ បានចង្អុលបង្ហាញពីសញ្ញាដែលឲ្យកើតមានការបារម្ភជាឯកត្តជន ដែលប្រទេសនីមួយៗតោងតែប្រឈមមុខ ។ ប្រទេសចិននៅតែចាត់ទុកសហរដ្ឋអាមេរិកជាសត្រូវសំខាន់បំផុត ហើយដោយការពារគំនិតស្ដីពីការគំរាមកំហែងរបស់អាមេរិកាំងនេះទើបធ្វើប្រទេសចិនងាកមកទាក់ទងនឹងប្រទេសកម្ពុជារបស់សម្ដេច ព្រះនរោត្តម សីហនុ ។

សហរដ្ឋអាមេរិក ធ្លាប់វាយប្រយុទ្ធទល់នឹងកងទ័ពចិនក្នុងសង្គ្រាមនៅប្រទេសកូរ៉េ ។ ពួកអាមេរិកាំងបានផ្ដល់ឲ្យកោះតៃវ៉ាន់នូវលក្ខន្តិកៈជាប្រទេសចិន «ពិតប្រាកដ» ហើយបដិសេធ មិនទទួលស្គាល់សាធារណរដ្ឋប្រជាមានិតចិន ក្នុងរយៈពេលជាច្រើនឆ្នាំ ។ អាមេរិកបានដាក់ទណ្ឌកម្មខាងសេដ្ឋកិច្ច និងយោធាប្រឆាំងនឹងប្រទេសចិនដែលស្ថិតនៅជាធរមានក្នុងរយៈពេលប្រមាណជាដប់ឆ្នាំ ។ រឹតតែអាក្រក់ជាងនេះ ពួកអាមេរិកាំងបាន

លើកទឹកចិត្តឲ្យពួកចិននៅ តែរ៉ាំរ៉ៃវាយយកឈ្នះពួកកុម្មុយនិស្ត និងដណ្ដើមយកប្រទេសចិនដីគោកមកវិញក្នុងគំនិតរវើរវាយរបស់គេថែមទៀត ។ នៅឆ្នាំ១៩៥៤ ពួកអាមេរិកាំងមានលក្ខណៈគំរាមកំហែងចំពោះប្រទេសចិនជាងចំពោះប្រទេសវៀតណាម ។

ការសម្រេចចិត្តវាយប្រយុទ្ធរបស់អាមេរិកាំង ទល់នឹងលទ្ធិកុម្មុយនិស្តនៅប្រទេសវៀតណាម ដើម្បីបំពេញចន្លោះប្រហោង ដែលទុកចោលដោយពួកបារាំងដែលចាញ់សង្គ្រាម បានត្រូវប្រកាន់យកក្នុងក្របខ័ណ្ឌនៃនយោបាយនេះ សំដៅធ្វើឲ្យចុះខ្សោយ ឬយ៉ាងហោចណាស់ ទប់សាធារណរដ្ឋប្រជាមានិតចិន មិនឲ្យធ្វើអ្វីកើតដែរ ។ ស្ថានភាពរបស់លទ្ធិកុម្មុយនិស្តវៀតណាម មានលក្ខណៈជាប់ទាក់ទងយ៉ាងជិតស្និទ្ធ នឹងស្ថានភាពនៃលទ្ធិកុម្មុយនិស្តរបស់ចិនក្រហមដែរ ។ ពួកចិន មានផលប្រយោជន៍ទាំងស្រុងក្នុងការយកចិត្តយកថ្លើមរបបថ្មីរបស់សម្ដេច ព្រះនរោត្ដម សីហនុ ដើម្បីទប់ពួកអាមេរិកាំងឲ្យនៅក្រៅប្រទេសកម្ពុជា ដោយធ្វើឲ្យពួកនេះ ទៅជាអ្នកមិនសូវបង្កការគំរាមកំហែងប៉ុន្មានសម្រាប់ប្រទេសវៀតណាម ក៏ដូចសម្រាប់ប្រទេសចិន ។

ប្រទេសចិនបានចងសម្ព័ន្ធមិត្រជាមួយសម្ដេច ព្រះនរោត្ដម សីហនុ មុនក្រុងហាណូយ ហើយក្នុងសម្ព័ន្ធមេត្រីនេះ ពុំមានការរឹតត្បិតពួកកុម្មុយនិស្តវៀតណាម ដែលទទួលស្វាគមន៍ប្រធានចលនាកុម្មុយនិស្តរបស់កម្ពុជានិងសមាជិកពាក់កណ្ដាលរបស់ខ្លួននៅប្រទេសវៀតណាម ក្រោយឆ្នាំ១៩៥៥ផងទេ ។ម្យ៉ាងទៀតពួកវៀតណាមក៏កំពុងត្រូវធ្វើខ្វាយខ្វល់ដោយព្រឹត្តិការណ៍ផ្សេងៗ ដែលកើតមានក្នុងប្រទេសផ្ទាល់របស់គេដែរ ។ ង៉ោ ឌិញយៀម ដែលក្លាយទៅជាប្រមុខរដ្ឋាភិបាលវៀតណាមខាងត្បូងនៅឆ្នាំ១៩៥៥ បានបដិសេធមិនចូលរួមក្នុងការបោះឆ្នោត ដែលគ្រោងធ្វើនៅឆ្នាំ១៩៥៦ ដើម្បីបង្រួបបង្រួមប្រទេសទេ ព្រោះ យៀម គិតថា ហូ ជីមិញ នឹងឈ្នះគាត់ដោយងាយ ។ នៅជំនាន់នេះ ក្រុងហាណូយពុំទាន់មានបង្ហាញសញ្ញាមិនទុកចិត្តណាមួយចំពោះប្រទេសចិនឡើយ ។ ពួកវៀតណាមខាងជើង បានធ្វើបដិវត្តន៍កសិកម្មនៅឆ្នាំ១៩៥៦ ដោយត្រាប់តាមគំរូរបស់ចិនទាំងផងដីតផងដល់ ហើយបន្ទាប់ពីវាត្រូវបរាជ័យ –កសិករទាំងឡាយ បានកញ្ជ្រោលឡើងប្រឆាំងនឹងវិធានការណ៍ផ្សេងៗ ដែលមានលក្ខណៈបង្ខំរបស់រដ្ឋាភិបាល– ប្រជាជនវៀតណាមបានបន្ទោសពួកអ្នកទ្រឹស្ដីផ្ទាល់របស់ពួកគេ ដែលបង្កើតផែនការនេះ គឺពុំមែនប្រទេសចិនទេ ។

នៅឆ្នាំ១៩៦០ គេបានបង្កើតមាគ៌ាបែងចែកថ្មីមួយក្នុងទំនាក់ទំនងផ្សេងៗ រវាងប្រទេសទាំងបី ។ ពួកកុម្មុយនិស្តកម្ពុជាបានបង្កើតបក្សផ្ទាល់របស់គេ ដែលមិនទទួលស្គាល់បក្សកុម្មុយនិស្តឥណ្ឌូចិនថា ជាអ្នកឲ្យកំណើតតែមួយគត់របស់ខ្លួន ហើយដែលបង្ហាញខ្លួនផ្ទុយទៅវិញ ក្នុងឋានៈជា«ក្រុមជនអ្នកបង្កមួយក្រុមតូច ដែលកកើតក្នុងផ្ទៃបណ្ដាបក្សឥណ្ឌូចិន បារាំង និងថៃ ហើយដោយមានការគាំទ្រពីបក្សកុម្មុយនិស្តរបស់វៀតណាមផង»[១០] ។ ដូច្នេះពួកខ្មែរ បានទទួលស្គាល់ឧបការគុណរបស់វៀតណាម ប៉ុន្តែគ្មានគំនិតចុះញ៉មទេ ។

នៅជំនាន់ដដែលនោះ ដោយវាយតម្លៃចំពោះការប្រយុទ្ធយ៉ាងជូរចត់ទាំងឡាយ ដែលកំពុងប្រព្រឹត្តទៅនៅ

ភាគខាងត្បូង ក្រុងហាណូយបានយល់ព្រមឲ្យដំណើរការសង្គ្រាមទ័ពព្រៃ ដែលដឹកនាំធ្វើក្នុងចំណែករបស់ប្រទេសវៀតណាមនេះ និងការបង្កើតរណសិរ្សរំដោះជាតិមួយនៅពេលក្រោយ ដែលសន្យាធ្វើការ“បង្រួបបង្រួមប្រទេសឡើងវិញជាលំដាប់លំដោយ តាមមធ្យោបាយសន្តិវិធី ដោយឈរលើមូលដ្ឋាននៃការចរចាគ្នា និងការពិភាក្សាគ្នារវាងភូមិភាគទាំងពីរ (ខាងជើង និងខាងត្បូង)...[១១]” ។

រណសិរ្សនេះគឺគ្រប់គ្រងដោយបក្សកុម្មុយនិស្ត “ភាគខាងត្បូង” មួយមានឈ្មោះថា បក្សប្រជាជនបដិវត្ត ដែលតាមការពិត នេះជាលក្ខណៈបញ្ឆោតមួយសម្រាប់សាខាបក្សភាគខាងត្បូង នៃគណៈកម្មាធិការបក្សពលករវៀតណាម សម្រាប់ភាគខាងត្បូងប្រទេស ។ ដើម្បីទាក់ទាញជំនឿផ្នែកនយោបាយឲ្យកាន់តែទូលំទូលាយជាងមុន ភាគខាងជើង បានយល់ព្រមឲ្យមានការបំបែកបក្សមួយជាសាធារណៈ ។ វៀតណាមខាងជើង បានគូសបញ្ជាក់ជាច្រើនលើកច្រើនសាថា “រណសិរ្សរំដោះជាតិភាគខាងត្បូង ជាមូលដ្ឋានសម្រាប់ផ្លាស់ប្តូរជំនួសរបបក្រុងព្រៃនគរ ហើយថាក្រុងហាណូយគ្រាន់ជាសម្ព័ន្ធមិត្តមួយរបស់រណសិរ្សប៉ុណ្ណោះ ។ កម្មវិធីរបស់រណសិរ្សរំដោះជាតិ បានសន្យាផ្តល់សេរីភាពផ្សេងៗស្របទៅតាមលទ្ធិប្រជាធិបតេយ្យ ដែលមិនធ្លាប់មានសោះ នៅភាគខាងជើងដូចជា សេរីភាពក្នុងការបញ្ចេញមតិ ការបង្កើតសមាគម ការដើរហើរសេរី និងសេរីភាពសារព័ត៌មានជាដើម ដែលនឹងចូលជាធរមានបញ្ញត្តិក្រោយពេលបានទទួលជ័យជម្នះ ។

ការកើនឡើងនូវការវាយប្រយុទ្ធជាច្រើនក្នុងប្រទេសវៀតណាមខាងត្បូងជិតខាង បានធ្វើឲ្យ សម្តេច ព្រះនរោត្តម សីហនុ ដែលចុះហត្ថលេខាលើសិទ្ធិសញ្ញាមិត្តភាព និងមិនឈ្លានពានគ្នាមួយជាមួយប្រទេសចិននៅខែធ្នូឆ្នាំ១៩៦០ នឹកព្រួយបារម្ភមួយរំពេច ។ ពួកចិនបានបញ្ជាក់ប្រាប់ប្រជាជនកម្ពុជាជាច្រើនលើកច្រើនសាថា ៈ ពួកគេនឹងគោរពអាព្យាក្រឹតភាពរបស់កម្ពុជា ហើយនៅឆ្នាំ១៩៦៣ ពួកចិនបានផ្តើមកម្មវិធីផ្តល់ជំនួយយោធារបស់គេឲ្យមកសម្តេច ព្រះនរោត្តម សីហនុ ។ នៅពេលដំបូង ក្រុងប៉េកាំងបានធ្វើឲ្យមានការទាក់ទងគ្នាជាមួយក្រុងភ្នំពេញ ដើម្បីរារាំងមិនឲ្យពួកអាមេរិកាំងរំលោភលើទឹកដីកម្ពុជា ក្នុងសង្គ្រាមរបស់គេជាមួយពួកវៀតណាម ។ ប៉ុន្តែ ពួកចិនដឹងយ៉ាងប្រាកដថា អព្យាក្រឹតភាពដ៏ត្រឹមត្រូវរបស់កម្ពុជា គឺសំដៅប្រឆាំងនឹងបំណងផ្សេងៗរបស់ពួកវៀតណាមទាំងកុម្មុយនិស្ត ឬមិនមែនកុម្មុយនិស្ត -ក៏ដូចប្រឆាំងនឹងបំណងរបស់ពួកអាមេរិកាំងដែរ ។ បើប្រទេសចិនសម្គាល់ថា ប្រទេសកម្ពុជា ជាខែលមួយប្រឆាំងនឹងសហរដ្ឋអាមេរិក បើប្រទេសកម្ពុជាចាត់ទុកប្រទេសចិនជាខែលការពារមួយទល់នឹងពួកវៀតណាម និងពួកអាមេរិកាំងនោះ ក្រុងហាណូយក៏ចាប់ផ្តើមពិនិត្យជំហររបស់ខ្លួនឡើងវិញ ចំពោះប្រទេសទាំងពីរនេះដែរ ។

ព្រោះថាឆ្នាំ១៩៦០ ជាឆ្នាំនៃការផ្តាច់ចំណងទាក់ទងការទូតជាសាធារណៈរវាងប្រទេសចិន និងសហភាពសូវៀត ។ សម្រាប់ក្រុងហាណូយ នេះជាពេលវេលាដែលខ្លួនពិបាកសម្រេចចិត្តជាទីបំផុត ។ កាលនោះ វៀតណាមខាងជើង ជាប្រទេសជិតស្និទ្ធជាងគេបំផុតរបស់ប្រទេសចិនដោយឥតប្រកែកបាន ។ ប្រទេសទាំងពីរ

ប្រកាស ធ្វើបដិវត្តន៍កសិករ (ផ្អែកលើវណ្ណៈកសិករជាធំ) ប្រទេសទាំងពីរយល់ថាល្អ «ក្នុងការបញ្ចូលគ្នារវាងអ្វីដែលទាញចិត្តឲ្យរំភើបញាប់ញ័រអំពីជាតិនិយមនិងភាពមោះមុតក្នុងការតស៊ូវណ្ណៈ[១២]» ។ វៀតណាមបានប្រកាន់យកគំនិតម៉ៅនិយមជាគោល ដែលបង្រួបបង្រួមពួកបញ្ញវន្ត ពួកកសិករប្រឆាំងនឹងសត្រូវវណ្ណៈរួមរបស់ពួកគេគឺពួកអ្នករដ្ឋការ អ្នកប្រមូលពន្ធដារ ពួកម្ចាស់ដីធំៗ និងពួកអភិជន ។ នៅពេលនោះ ក្រុងហាណូយបានសង្កត់ធ្ងន់ទៅលើការអភិវឌ្ឍន៍ផ្នែកកសិកម្ម ដែលប្រទេសចិនបានអនុវត្តរួចមកហើយ ដោយផ្ទុយនឹងផែនការសូវៀត ដែលយល់ព្រមឲ្យអាទិភាពទៅលើវិស័យឧស្សាហកម្មធុនធ្ងន់វិញ មិនខុសពីពេលដែលក្រុងហាណូយអបអរសរសើរការជ្រើសរើសរបស់ចិន អំពីសង្គ្រាមទ័ពព្រៃ ជាជាងសង្គ្រាមក្លាស៊ិក ដែលពួកសូវៀតធ្លាប់ជឿទុកចិត្តឡើយ ។

ប៉ុន្តែប្រទេសវៀតណាមកំពុងជាប់ដៃធ្វើសង្គ្រាម ហើយត្រូវការនូវការគាំទ្រជាចាំបាច់ពីប្រទេសចិនផង និងពីសហភាពសូវៀតផង ពីព្រោះសហរដ្ឋអាមេរិកបានយល់ព្រមផ្តល់ទៅឲ្យយៀម (ប្រធានាធិបតីវៀតណាមខាងត្បូងជំនាន់នោះ) ជាពិសេសនូវជំនួយយោធាមួយយ៉ាងសន្ធឹកសន្ធាប់ស្រេចទៅហើយ ។ ដូច្នេះ ហូ ជីមិញ បានជួយគាំទ្រភ្លាម ចំពោះភាពស្រុះស្រួលគ្នារវាងប្រទេសចិន និងសហភាពសូវៀត បើទោះជាគាត់ហាក់បីដូចជានិយាយកាន់ជើងប្រទេសចិនអំពីចំណុចជាក់លាក់នៃការទាស់ទែងគ្នានោះក៏ដោយ ។ ក្រុងហាណូយបាននិយាយបន្ទោសសហភាពសូវៀត នៅពេលដែលប្រទេសនេះផ្តល់ជំនួយយោធារបស់ខ្លួនឲ្យប្រទេសឥណ្ឌា បន្ទាប់ពីមានជម្លោះព្រំដែនចិន-ឥណ្ឌា នៅឆ្នាំ១៩៦៣ ។ នៅឆ្នាំដដែលនោះ ក្រុងហាណូយបានរួបរួមគ្នាជាមួយក្រុងប៉េកាំង ដើម្បីសម្តែងការសោកស្តាយ ដែលក្រុងមូស្គូបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយ ដែលហាមឃាត់ដោយផ្នែកៗ ក្នុងការសាកពិសោធន៍អាវុធនុយក្លេអ៊ែរជាមួយសហរដ្ឋអាមេរិក ។ ពួកវៀតណាមខាងជើងបានព្រមានថា «ប្រៀបធៀបការទាមទារផ្សេងៗរបស់ប្រជាជនទូទាំងពិភពលោក ទៅនឹងជំហរកាលពីមុនរបស់រដ្ឋាភិបាលសូវៀតស្តីពីការហាមឃាត់អាវុធនុយក្លេអ៊ែរ កិច្ចព្រមព្រៀងដែលចុះហត្ថលេខាក្នុងពេលថ្មីៗ គឺជាជំហានថយក្រោយមួយ...។ សំណើផ្សេងៗរបស់រដ្ឋាភិបាលចិនពិតជាត្រឹមត្រូវទាំងស្រុង[១៣]» ។

ក្រុងហាណូយបានស្នើធ្វើជាអាជ្ញាកណ្តាល ដើម្បីសម្រុះសម្រួលការវិវាទរវាងក្រុងប៉េកាំង និងក្រុងមូស្គូ នៅឆ្នាំ១៩៦៣ ប៉ុន្តែគ្មានបានទទួលលទ្ធផលសោះឡើយ ។ ប្រទេសចិនបានឆ្លើយតបចំពោះការគាំទ្រផ្នែកនយោបាយរបស់ប្រទេសវៀតណាម ដោយបានបង្កើនការផ្គត់ផ្គង់គ្រឿងសម្ភារៈសឹករបស់ខ្លួនទៅឲ្យក្រុងហាណូយថែមទៀត ដើម្បីអនុញ្ញាតឲ្យរណសិរ្សរំដោះជាតិបង្កើនសកម្មភាពយោធារបស់ខ្លួនរឹតតែខ្លាំងឡើងៗ បន្ទាប់ពីមានរដ្ឋប្រហារមួយប្រឆាំង យៀម ដែលឲ្យដៃដោយសហរដ្ឋអាមេរិក ។

ដោយជាក់ស្តែង ពួកចិនបានចាត់ទុកថា ប្រទេសវៀតណាមនិងភាគសេសសល់នៃឥណ្ឌូចិន គឺជាចំណែកមួយនៃមណ្ឌលឥទ្ធិពលរបស់គេ ។ នៅពេលនោះ ក្រុងប៉េកាំងបានពង្រីកចំណងទាក់ទងផ្សេងៗរបស់ខ្លួនជាមួយសម្តេច ព្រះនរោត្តម សីហនុ រឹតតែខ្លាំងឡើងទៀត ព្រមទាំងជាមួយមនុស្សនិយមឆ្វេងក្នុងរដ្ឋាភិបាលរបស់

សម្ដេចផង ជាពិសេស ហ៊ូ នឹម ។ នេះពុំមែនជាការពង្រីក របៀបគឃ្លើនមួយទេៈ កងទ័ពរបស់ចិនមិនចូលលុកលុយតំបន់នេះ ដូចដែលកងទ័ពសូវៀតធ្លាប់បានអនុវត្ត ដើម្បីរក្សាឧត្ដមភាពរុស្ស៊ីនៅអឺរ៉ុបខាងកើតឡើយ ។ វានឹងពុំមានបញ្ហាតាំង "មូល ដ្ឋានទ័ព" របស់ចិននៅកម្ពុជាទេ ។ ពួកចិនគ្រាន់តែលើកទឹកចិត្តឲ្យសម្ដេច ព្រះនរោត្ដម សីហនុ ជួយពួកវៀតណាម ដោយអនុញ្ញាតឲ្យពួកនេះ ប្រើប្រាស់កំពង់ផែកំពង់សោម និងយល់ព្រមឲ្យតាំង"ទីជម្រក" នៅភាគខាងកើតប្រទេសប៉ុណ្ណោះ ។

លទ្ធិការណ៍និយម (ដែលទុកតម្លៃនៃការប្រតិបត្តិជាតម្លៃធំបំផុត) ដែលជាប្រភពនយោបាយការបរទេសរបស់របស់ចិនគឺត្រូវសមនឹងចិត្តរបស់ប្រទេសវៀតណាម ។ ពួកចិន និងពួកសូវៀត បានពិភាក្សាគ្នាយ៉ាងតឹងតែងអំពីរបៀបបំផុសសង្គ្រាមរំដោះជាតិលើពិភពលោកទាំងមូល ។ ពួកចិនអះអាងថា គេអាចប្រមូលផ្ដុំឡើងវិញក្នុង"រណសិរ្សរួបរួម" នូវមនុស្សគ្រប់ប្រភេទ រួមទាំង"ស្ដេច ព្រះអង្គម្ចាស់ និងអភិជន[១៨]"ផង ឲ្យតែពួកគេជា"អ្នកស្នេហាជាតិ" និងទទួលស្គាល់អធិកភាព (ភាពលើសលប់) របស់កុម្មុយនិស្តក្នុងរណសិរ្សរួបរួម ប្រឆាំងចក្រពត្តិទាំងនេះ ។ ពួកសូវៀតបានឆ្លើយតបថា ផ្ទុយទៅវិញ គឺ"ព្រះអង្គម្ចាស់ និងស្ដេច"ទាំងនោះ ជាមនុស្សដែលត្រូវពួកចិនឆ្លៀតយកប្រយោជន៍ ហើយពួកសូវៀតនឹកព្រួយបារម្ភជាឯកជនថា វិធីសាស្ត្រផ្សេងៗនៃសង្គ្រាម "រំដោះជាតិ" ច្បាស់ជាជម្រុញឲ្យមានការប្រកាន់ពូជសាសន៍មិនខាន ។ ការភ័យបារម្ភនេះបង្ហាញឲ្យឃើញថាជារឿងដែលមានមូលហេតុត្រឹមត្រូវទាំងស្រុង ។

ស្ដេចមួយអង្គក្នុងចំណោម "ស្ដេចជាច្រើនអង្គ" ដែលពួកចិននឹកដល់នៅពេលពួកគេនិយាយពីអ្នកស្នេហាជាតិដោយព្រមទទួលស្គាល់អធិកភាពរបស់កុម្មុយនិស្តនោះគឺសម្ដេច ព្រះនរោត្ដម សីហនុ ។ ការបែកមតិគ្នារវាង ចិន-សូវៀត ស្ទើរតែគ្មានឥទ្ធិពលមកលើព្រះមហាក្សត្រ ទាំងមកលើពួកកុម្មុយនិស្តកម្ពុជាផងទេ ។ នយោបាយអព្យាក្រឹតរបស់សម្ដេច ព្រះនរោត្ដម សីហនុ មានគោលបំណងស្ថិតនៅឲ្យឆ្ងាយពីសាធារណរដ្ឋសង្គមនិយមសូវៀត និងបក្សកុម្មុយនិស្តរបស់ខ្លួន ក៏ដូចសហរដ្ឋអាមេរិក និងបណ្ដាសម្ព័ន្ធមិត្តរបស់គេដែរ ។ម្យ៉ាងទៀត ពួកកុម្មុយនិស្តរបស់កម្ពុជា ពុំធ្លាប់ដែលត្រូវទទួលស្គាល់ដោយពួកសូវៀតឡើយ ហើយក៏មិនសូវជួយគាំទ្រថែមទៀត ។

បញ្ហាចង់ដឹងថាប្រទេសណាមួយ ប្រទេសចិនឬសហភាពសូវៀត ដែលប្រើឥទ្ធិពលខ្លាំងបំផុតមកលើកម្ពុជាមិនដែលធ្វើឲ្យមានការសង្ស័យបន្តិចសោះឡើយ ។ នៅទីបំផុត ពួកចិនបានក្លាយទៅជាអ្នកការពារស្ដេចរបស់កម្ពុជា និងបណ្ដាសត្រូវរបស់ព្រះអង្គ ដែលជាពួកកុម្មុយនិស្តខ្មែរផង ។ ទោះជាយ៉ាងណាក៏ដោយក្រុមអ្នកកាន់អំណាចនៅក្រុងភ្នំពេញ ប្រទេសចិននឹងជួយគាំទ្រ ហើយនៅឆ្នាំ១៩៦៥ ពួកចិនបានឈានរហូតដល់ ប្រកាសថា ការវាយប្រហារមួយប្រឆាំងនឹងប្រទេសកម្ពុជា នឹងត្រូវចាត់ទុកដូចជាការវាយប្រហារប្រឆាំងនឹងប្រទេសចិនដែរ ។

ប៉ុន្តែ គ្មានស្ថានការណ៍នយោបាយណាមួយនៅស្ថិតស្ថេរយូរអង្វែងទេ ក្នុងអាស៊ីកុម្មុយនិស្ត ក្នុងអំឡុងទស្ស

វត្សរ៍១៩៦០ ។ នៅឆ្នាំ១៩៦៦ ពួកឆ្មាំក្រហមបានគ្រវីកូនសៀវភៅក្រហមរបស់ពួកគេ និងធ្វើឲ្យប្រទេសចិនធ្លាក់ទៅក្នុងសភាពរំដើបរំជួលមួយក្នុងនាមនៃការបដិវត្តន៍វប្បធម៌ ។ ក្រុម«ទាហានម៉ារីន»អាមេរិកាំង បានឡើងគោកនៅប្រទេសវៀតណាមខាងត្បូង ដើម្បីប្រយុទ្ធទល់នឹងលទ្ធិកុម្មុយនិស្ត ។ ការឈានឡើងនៃសង្គ្រាមនៅវៀតណាម មានសភាពលឿនរហ័ស ដែលបណ្តាលឲ្យមានមនុស្សស្លាប់ច្រើន និងកាន់តែឃោរឃៅឡើង ។ នៅពេលដែលក្រុងហាណូយត្រូវការជំនួយច្រើនបំផុត ពីបណ្តាសម្ព័ន្ធមិត្តរបស់ខ្លួន ដំបូងប្រទេសចិនព្រួយបារម្ភនឹងការបដិវត្តន៍ផ្ទៃក្នុង ភាពប្រសើរលើសគេ និងភាពបរិសុទ្ធនៃលទ្ធិម៉ៅនិយមរបស់ខ្លួនដែរ ។ ង្វៀន កូថាច់ បានថ្លែងជាច្រើនឆ្នាំក្រោយមកថា «ពួកឆ្មាំក្រហម ពុំបង្ហាញឲ្យឃើញការគោរពបន្តិចសោះ ចំពោះបណ្តារៀមច្បងនៃគណៈកម្មាធិការមជ្ឈិមបក្សរបស់ពួកគេ ។ នេះដូចជាភាពអនាធិបតេយ្យ និងភាពច្របូកច្របល់របៀបរដ្ឋប្រហារមួយ[១៥]» ។

សម្រាប់ ហូ ជីមិញ យល់ថា បដិវត្តន៍វប្បធម៌បានធ្វើអ្វីៗជ្រុលហួសហេតុពេក ហើយបានយកបុគ្គល ម៉ៅ មកធ្វើលេស រហូតធ្លាក់ទៅក្នុងការស្រឡាញ់ងប់ ។ ចំពោះជនបរទេសម្នាក់ដែលសួរហូថា ហេតុអ្វីបានជាគាត់មិនបោះពុម្ពផ្សាយគំនិតផ្សេងៗរបស់គាត់ដូចដែល ម៉ៅ ធ្លាប់សរសេរក្នុងសៀវភៅក្រហម ហូ ឆ្លើយដោយនិយាយកំប្លែងលេងថា ៈ «បើសិនមានប្រធានបទមួយដែលប្រធាន ម៉ៅ ពុំបានសរសេរសូមប្រាប់ខ្ញុំពីប្រធានបទនោះផងខ្ញុំនឹងសាកល្បងបំពេញកន្លែងចន្លោះនោះ[១៦]» ។

ហូ ជីមិញ បានចំណាយពេលប្រឡូកយ៉ាងយូរក្នុងបណ្តាសង្គ្រាមសម័យទំនើប ហើយគ្មានមហាអំណាចជាសម្ព័ន្ធមិត្ររបស់ខ្លួនណាមួយ -ប្រទេសចិន និងសហភាពសូវៀត- ស្នើឲ្យធ្វើការសងសឹកប្រឆាំងនឹងការលូកដៃដោយផ្ទាល់របស់សហរដ្ឋអាមេរិកឡើយ ។ ប្រទេសចិនហាក់ដូចជាយកចិត្តទុកដាក់ផ្តល់នូវការគាំពារប្រទេសកម្ពុជារបស់សម្តេច ព្រះនរោត្តម សីហនុជាងគេ ហើយមហាអំណាចកុម្មុយនិស្តទាំងពីរ បានចាប់ផ្តើមឈ្លោះប្រកែកគ្នាស្តីពីជំនួយមកឲ្យវៀតណាមខាងជើង ។ ក្រុងមូស្គូ បានឲ្យយោបល់បង្កើតក្រុមការងាររួមមួយ ដោយបញ្ជាក់ថា សំណើនេះចៀសមិនរួចពីការកសាងព្រលានយន្តហោះរបស់សូវៀត ក្នុងភាគខាងត្បូងប្រទេសចិនឡើយ ។ ពួកចិនបានបដិសេធ ហើយបានស្នើធ្វើជាមេដឹកនាំ «រណសិរ្សប្រជាជនពិភពលោក» មួយ ដើម្បីជួយក្រុងហាណូយ ដែលបដិសេធមិនឲ្យសហភាពសូវៀតចូល ។ រណសិរ្សនេះបានក្លាយទៅជាការពិត ហើយសាធារណរដ្ឋសង្គមនិយមសូវៀត ត្រូវតែប្រគល់ជំនួយរបស់ខ្លួនមកឲ្យប្រទេសវៀតណាម ដោយគ្មានការជួយជ្រោមជ្រែងរបស់ប្រទេសចិនឡើយ ។

ព្រឹត្តិការណ៍ដែលធ្វើឲ្យគេព្រួយបារម្ភបំផុត គឺពួកចិនបានណែនាំពួកវៀតណាមឲ្យច្រានចោលជំនួយទាំងអស់របស់សូវៀត ហើយព្រមានពួកវៀតណាមថាការព្រមទទួលយកជំនួយ ការប្រកាន់យកវិធីផ្សេងៗរបស់សូវៀត ដែលនិយមប្រើតាំងពីយូរមកហើយ ដើម្បីវាយប្រយុទ្ធនឹងសហរដ្ឋអាមេរិក គឺដូចពួកគេយល់ព្រមចូល

ក្នុងប្រព័ន្ធរបស់សូវៀត ហើយនឹងក្លាយជារណបមួយរបស់សូវៀតមិនខាន ។ ពួកចិនអះអាងថា ពួកគេទទួលរ៉ាប់រងបន្ទុកសង្គ្រាមទាំងអស់ បើសិនជាក្រុងហាណូយបដិសេធជំនួយរបស់សូវៀត ។ ប៉ុន្តែ ខ្យល់បានផ្លាស់ប្តូរទិសការមិនទុកចិត្តរបស់ពួកវៀតណាម ចំពោះចេតនាផ្សេងៗរបស់ចិនបានចាប់ផ្តើមលេចឡើង ។ មិនត្រឹមតែក្រុងហាណូយព្រមទទួលជំនួយសូវៀត ដោយការដឹងគុណប៉ុណ្ណោះទេ ប៉ុន្តែពួកវៀតណាមបានចាប់ផ្តើមដើរតាមគំរូរបស់រុស្ស៊ីជាងគំរូរបស់ចិនថែមទៀត ។

ពួកវៀតណាមបានប្រែត្រឡប់ខ្លួនទៅខាងសហភាពសូវៀតទាំងស្រុង ជាមួយនឹងប្រតិកម្មរបស់ចិន ចំពោះកិច្ចចរចានៅក្រុងប៉ារីសរវាងវៀតណាម និងសហរដ្ឋអាមេរិកនៅឆ្នាំ១៩៦៨ផង ។ នៅពេលដែលក្រុងហាណូយចរចាជាមួយពួកអាមេរិកាំង អំពីការបញ្ឈប់ការទម្លាក់គ្រាប់បែក ពួកចិនបានប្រឆាំងជំទាស់យ៉ាងខ្លាំងក្លា ។ ក្នុងបទវិចារណកថារបស់ទស្សនាវដ្តីប៉េកាំង លេខចេញផ្សាយខែមេសា ពួកចិនបានប្រកាសថា «បញ្ហាវៀតណាមអាចដោះស្រាយបានតែតាមរយៈកម្ទេចពួកអាមេរិកាំងឈ្លានពានទាំងស្រុង នៅលើសមរភូមិ និងបណ្តេញចេញពីវៀតណាមខាងត្បូងប៉ុណ្ណោះ ។

មិនត្រឹមតែពួកសូវៀតអបអរសរសើរ ការបើកសន្និសីទនៅទីក្រុងប៉ារីសប៉ុណ្ណោះទេ ពួកគេថែមទាំងបង្កើនជំនួយយោធាទៅឲ្យប្រទេសវៀតណាមថែមទៀត ដោយផ្តល់គ្រឿងសាស្ត្រាវុធទំនើបៗ សម្រាប់ការពារខ្លួនទល់នឹងការទម្លាក់គ្រាប់បែករបស់អាមេរិកាំង ។ ពួកចិន បានប្រឆាំងជំទាស់នឹងការផ្តល់អាវុធបែបនោះនេះជាជំហរមួយដែលពួកវៀតណាមលួចពេបជ្រាយតែក្នុងចិត្ត ។ ភាពត្រឹមត្រូវនៃមនោគមវិជ្ជាមានន័យថាពួកចិនបានប្តេជ្ញាចិត្តវាយប្រយុទ្ធទល់នឹងពួកអាមេរិកាំង រហូតដល់ជនវៀតណាមចុងក្រោយបង្អស់ ។

នៅឆ្នាំ១៩៦៨ ពួកសាធារណរដ្ឋនិយមបានទទួលជ័យជម្នះនៅក្នុងការបោះឆ្នោតជ្រើសរើសប្រធានាធិបតីអាមេរិកាំង ហើយបានបញ្ឈប់ការចរចាសន្តិភាពនៅទីក្រុងប៉ារីស ។ សហភាពសូវៀតបានចូលលុកលុយទីក្រុងប្រាក(រដ្ឋធានីប្រទេសឆេកូស្លូវ៉ាគី) ក្រុងហាណូយពុំមានការប្រឆាំងជំទាស់ឡើយ ៖ ពួកវៀតណាមលែងទិតៀន «ពួកអ្នកការពារខ្លួនទៀតហើយ» ។ ដោយប្តេជ្ញាចិត្តយកឈ្នះសង្គ្រាម ពួកវៀតណាមបានប្រកាន់យកមាគ៌ានយោបាយថ្មីមួយ ជាមាគ៌ាដែលនឹងនាំទៅរកការប្រឈមមុខមួយជាមួយពួកចិន ហើយនៅ ទីបំផុតក៏ធ្វើឲ្យប៉ះពាល់ដល់ចំណងទាក់ទងផ្សេងៗរបស់វៀតណាមជាមួយនឹងកម្ពុជាដែរ ។ មិត្តភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗត្រូវបានជំនួសដោយការមន្ទិលសង្ស័យ ដែលមានសភាពរឹតតែធ្ងន់ធ្ងរឡើងៗ ។ ចលាចល ដែលកកូរកកាយនៅភាគខាងត្បូងប្រទេសចិន-ខេត្តយុនណាន ក្វាងស៊ី និងក្វាងទុង -ក្នុងរយៈពេលនៃបដិវត្តន៍វប្បធម៌បានធ្វើឲ្យកើតមានការភ័យបារម្ភនៅប្រទេសវៀតណាម ។ ក្រុងហាណូយ បានចោទសួរតែខ្លួនឯងអំពីការវិនិច្ឆ័យរបស់ពួកចិន និងសេចក្តីទុកចិត្តដែលគេអាចផ្តល់ឲ្យចិនវិញ ។

ទន្ទឹមនឹងនោះ ពួកចិនបានវាយតម្លៃថាប្រទេសវៀតណាមបានចុះកិច្ចសន្យាជាមួយបិសាច -សហភាព

សូវៀត- ដើម្បីបញ្ចៀសវិបត្តិភ័យមួយដែលមិនសូវគួរឲ្យព្រឺខ្លាច គឺចក្រពត្តិនិយមអាមេរិកាំង ។ ប៉ុន្តែប្រជាជនវៀតណាម បានស្លាប់យ៉ាងច្រើនក្រោមគ្រាប់បែករបស់សហរដ្ឋអាមេរិក ហើយកងទ័ពកុម្មុយនិស្តរបស់វៀតណាម បានវាយប្រយុទ្ធប្រឆាំងនឹងកងទ័ពរបស់អាមេរិកាំង ។ ក្នុងកំឡុងសង្គ្រាមឥណ្ឌូចិនលើកទីពីរ សហរដ្ឋអាមេរិក និងសម្ព័ន្ធមិត្តវៀតណាមខាងត្បូងរបស់គេបានទម្លាក់គ្រាប់បែកលើប្រទេសវៀតណាម នូវបរិមាណគ្រាប់បែកមួយមានចំនួនបីដង ច្រើនជាងចំនួនគ្រាប់បែកសរុប ដែលទម្លាក់ក្នុងកំឡុងសង្គ្រាមលោកលើកទីពីរទៅទៀត ។ គ្រាប់បែក និងគ្រឿងផ្ទុះគ្រប់ប្រភេទផ្សេងៗទៀត បានបំផ្លិចបំផ្លាញប្រទេសទាំងខាងជើង ក៏ដូចខាងត្បូង[១៧] ។ គ្មានសហគ្រាសណាមួយក្នុងភាគខាងជើងទោះបីជាតូចតាចក៏ដោយ ក៏គេចមិនផុតពីការទម្លាក់គ្រាប់បែកដែរ ។ សង្គ្រាមអាកាសរបស់អាមេរិកាំងបានបំបែរទៅរកកម្រិតរបស់វា មុនឆ្នាំ១៩៥៨ឡើងវិញ ដោយទម្លាក់បំផ្លាញមូលដ្ឋានឧស្សាហកម្មដែលភាគខាងជើងមាន ។ គ្រាប់បែកនិងគ្រឿងផ្ទុះផ្សេងៗបានធ្វើខូចខាត ឬបំផ្លាញព្រៃឈើចំនួន ប្រាំលានហិកតា ផ្ទៃដីដាំដុះ ចំនួនដប់លានហិកតា ។ នៅភាគខាងត្បូង ភូមិតូចៗជាងពាក់កណ្ដាលបានត្រូវខូចខាត ។ ភាគខាងជើងបានបាត់បង់បណ្ដាញអគ្គិសនីជនបទមួយភាគធំ ក្រោមការទម្លាក់គ្រាប់បែក ។ ស្ថានីយ៍អគ្គិសនីសម្រាប់បូមទឹកបញ្ចូលស្រែ ស្ថិតនៅស្ងៀមគ្មានសកម្មភាពអ្វីទាំងអស់ ហើយកសិករទាំងឡាយគោងតែត្រឡប់មកប្រើស្នាចបាចទឹកដូចពីដើមឡើងវិញ ។ រណ្ដៅគ្រាប់បែកយ៉ាងច្រើន បានរារាំងមិនឲ្យកសិករមួយចំនួនធំ នៅភាគខាងជើងធ្វើស្រែបាន ។

នៅទីបំផុត យ៉ាងហោចណាស់ប្រជាជនវៀតណាមពីរលាននាក់ បានត្រូវស្លាប់ក្នុងកំឡុងសង្គ្រាមទល់នឹងសហរដ្ឋអាមេរិក -សង្គ្រាមទល់នឹងពួកបារាំង បានធ្វើឲ្យមានមនុស្សស្លាប់កន្លះលាននាក់ប៉ុណ្ណោះ ។ ប្រជាជនវៀតណាម ដប់លាននាក់ ក្លាយទៅជាអ្នកភៀសខ្លួនក្នុងប្រទេសផ្ទាល់របស់គេ ។ ភាគច្រើនបំផុតនៃអ្នករងគ្រោះទាំងនេះរស់នៅក្នុងភាគខាងត្បូង ហើយតួលេខពិតប្រាកដ ប្រហែលជាមានច្រើនជាងនេះ ពីព្រោះភាគខាងជើងបដិសេធយ៉ាងចចេស មិន ព្រមផ្ដល់របាយការណ៍លម្អិត ស្ដីពីការខូចខាតដែលកងទ័ពរបស់ខ្លួនបានទទួលរងឡើយ ។

សម្រាប់ពួកវៀតណាមយល់ថា សហរដ្ឋអាមេរិកពុំមែនជាសត្រូវ«បន្ទាប់បន្សំ»មួយទេ ។ គឺជាសត្រូវអាក្រក់ជាងគេបំផុត ដែលពួកវៀតណាមមិនធ្លាប់ដែលប្រឈមមុខតតាំងសោះ ។ គំនុំរបស់ពួកវៀតណាមខាងជើង ចំពោះពួកអាមេរិកាំងមានយ៉ាងជ្រាលជ្រៅ និងស្ថិតស្ថេរយូរអង្វែងជាងការស្អប់ខ្ពើម ជាទូទៅក្នុងចំណែកនេះ នៃពិភពលោក ។

នៅឆ្នាំ១៩៦៨ សហភាពសូវៀតបានផ្ដល់ជំនួយយោធាមួយភាគយ៉ាងធំមកឲ្យប្រទេសវៀតណាម ។ ការគេចវេះមិនផ្ដល់ជំនួយរបស់ក្រុងមូស្គូក្នុងរយៈពេលនៃសង្គ្រាមឥណ្ឌូចិនលើកទីមួយ គឺជាប្រវត្តិសាស្ត្រ ដែលមានពីយូរយារណាស់មកហើយ ។ ដោយបារម្ភពីស្ថានការណ៍នេះ និងសញ្ញានៃការធ្វើឲ្យកាន់តែជាប់ស្អិតឡើងរវាងសម្ព័ន្ធភាពរបស់វៀតណាមជាមួយសហភាពសូវៀត ប្រទេសចិនបានសម្រេចចិត្ត ព្រមព្រៀងគ្នាជាមួយ

សត្រូវនៃសត្រូវរបស់ខ្លួន គឺសហរដ្ឋអាមេរិក ។ នៅឆ្នាំ១៩៦៨ ក្រុងប៉េកាំងបានស្នើបើកធ្វើកិច្ចពិភាក្សាជាមួយអាមេរិកឡើងវិញ ៖ សហភាពសូវៀតបានក្លាយទៅជាសត្រូវសំខាន់បំផុត សហរដ្ឋអាមេរិកក្លាយទៅជារដ្ឋដ៏មានសក្តានុពលមួយ សម្រាប់ប្រឆាំងនឹងការឈ្លានពានមួយរបស់សូវៀត ។

នៅឆ្នាំដដែលនោះ វៀតណាមបានបើកការវាយលុករបស់ខ្លួន ក្នុងឱកាសបុណ្យចូលឆ្នាំចិន-យួន នៅភាគខាងត្បូងវៀតណាម ហើយបានបាត់បង់កម្មាភិបាលរណសិរ្សជាតិរំដោះភាគខាងត្បូងវៀតណាមចំនួនប្រាំម៉ឺននាក់ ។ ពេលនោះ ភាគខាងជើងបានបញ្ជូនកងទ័ពស្រួចមួយចំនួនធំ មកភាគខាងត្បូងទៀត ហើយពឹងផ្អែកជាសំអាង«ទីជម្រក»នានារបស់កម្ពុជា និងការជួយទំនុកបម្រុងរបស់សម្តេច ព្រះនរោត្តម សីហនុ កាន់តែច្រើនថែមទៀត ។ នេះជាឱកាសដែលពួកខ្មែរក្រហមជ្រើសរើស ដើម្បីផ្តើមការបះបោរដោយអាវុធរបស់គេប្រឆាំងនឹងសម្តេច ព្រះនរោត្តម សីហនុ ដែរ ។

ដោយមិនអាចប្រកែកបាន ពួកកម្មុយនិស្តវៀតណាមមិនចូលដៃខាងណាទាំងអស់ ចំពោះអ្វីដែលបណ្តាសមមិត្តកម្ពុជារបស់ពួកគេ វាយប្រយុទ្ធនឹងកម្លាំងរបស់សម្តេច ព្រះនរោត្តម សីហនុ នៅឆ្នាំ១៩៦៨ ។ ក្រុងហាណូយ បានចាត់ទុកការសម្រេចចិត្តរបស់ខ្មែរក្រហមថា មានលក្ខណៈគិតតែខ្លួនឯង និងជំរុញទៅរកបរាជ័យមិនខាន ។ ក្រុងហាណូយបានប្រកាស[១៨] ថា ពួកកម្មុយនិស្តកម្ពុជា គ្រាន់តែជាតំណាងឲ្យ«ភាគតិច»មួយក្នុងចំណោមហ្វូងមហាជនដែលគាំទ្រសម្តេច ព្រះនរោត្តម សីហនុ ប៉ុណ្ណោះ ហើយដូច្នេះពុំមានអ្វីដែលត្រូវប្រយុទ្ធនឹងព្រះអង្គឡើយ ។ ពួកវៀតណាមបានទទួលស្គាល់ថា ទម្រង់ខ្លះរបស់របបសម្តេច ព្រះនរោត្តម សីហនុ មានលក្ខណៈប្រហែលប្រតិកិរិយា និងសក្តិភូមិមែន -ដូចដែលពួកគេបានអះអាងពីរឿងនេះនៅពេលក្រោយមក- ប៉ុន្តែឈមមុខតតាំងនឹងសម្តេច គឺដូចជាបើកទ្វារឲ្យមានការលូកដៃរបស់អាមេរិកាំងនៅកម្ពុជាអ៊ីចឹង- នេះជាបញ្ហាពិតប្រាកដ សម្រាប់ប្រទេសវៀតណាម ។

ប៉ុន្តែ ការបដិវត្តន៍កុម្មុយនិស្តទាំងអស់ បានចាប់ផ្តើមដំបូងជាមួយនឹងភាគតិចមួយ ដូចដែលពួកវៀតណាមបានដឹងពីរឿងនេះយ៉ាងជាក់ច្បាស់ ។ ប៉ុន្តែបញ្ហាពុំមែននៅត្រង់នុ៎ះទេ ទាំងក្នុងពាក្យរិះគន់ផ្សេងៗ ដែលថ្លែងឲ្យដឹងដោយពួកវៀតណាម ៖ ពួកមេដឹកនាំកុម្មុយនិស្ត កម្ពុជា ធ្លាប់ត្រូវចម្លងរោគដោយលទ្ធិត្រុតស្គីនិយម នៅពេលដែលពួកគេសិក្សារៀនសូត្រនៅទីក្រុងប៉ារីស ។ តាមការពិត ពួកកុម្មុយនិស្តខ្មែរ ហើយជាពិសេស សាឡុត ស សុទ្ធតែជាអ្នកនិយមស្តាលីនទាំងស្រុង នៅពេលដែលពួកគេត្រឡប់មកពីប្រទេសបារាំងវិញ ។ តាមការពិត ពួកវៀតណាមគ្រាន់តែវាយតម្លៃថា នៅដំណាក់កាលនេះ សង្គ្រាមរបស់គេមានគេប្រៀបលើអ្វីៗទាំងអស់ប៉ុណ្ណោះ ។ ពួកគេត្រូវការសម្តេច ព្រះនរោត្តម សីហនុ និងការជួយឧបត្ថម្ភរបស់ព្រះអង្គ ពុំមែនត្រូវការសមរភូមិថ្មីមួយ ដែលពួកគេត្រូវតែប្រយុទ្ធនោះទេ ។ ដោយគ្មានទាក់ទងជាមួយការប្រយុទ្ធតស៊ូរបស់ពួកកុម្មុយនិស្តកម្ពុជា ពួកវៀតណាមមិនយល់ថា សម្តេចហៀបនឹងចាកចេញពីឆាកនយោបាយ- និងលឿនរហ័សដូច្នេះសោះ ។

ទំនាក់ទំនងផ្សេងៗរវាងបក្សកុម្មុយនិស្តទាំង២ ប្រែទៅជាតានតឹងយ៉ាងខ្លាំង ។ ពួកកម្ពុជាអះអាងថា ពួកវៀតណាម បានគំរាមកំហែងធ្វើការសងសឹកមកលើពួកគេ បើសិនជាពួកគេមិនព្រមបោះបង់ការប្រយុទ្ធប្រឆាំងនឹងសម្តេច ព្រះនរោត្តម សីហនុ និងបើសិនជាពួកគេធ្វើឲ្យមានគ្រោះថ្នាក់ដល់ផ្លូវចូលរបស់ពួកវៀតណាមមកកាន់ «ទីជម្រក» ទាំងឡាយក្នុងទឹកដីកម្ពុជា និងកំពង់ផែកំពង់សោម ។ មុនរដ្ឋប្រហារ [ឆ្នាំ១៩៧០] អ្វីៗទាំងអស់ដែលបក្សកុម្មុយ និស្តកម្ពុជាដឹកនាំធ្វើត្រូវបានពួកវៀតណាមថ្កោលទោសជានិច្ច ។

រដ្ឋប្រហារទម្លាក់ សម្តេច ព្រះនរោត្តម សីហនុ បានធ្វើឲ្យយុទ្ធសាស្ត្ររបស់បក្សនីមួយៗផ្លាស់ប្តូរ ។ ពួកកុម្មុយនិស្តកម្ពុជា បានប្រកាសដោយអាការៈដែលមានជ័យជម្នះមួយថា ពេលនោះពួកវៀតណាម បានត្រូវបង្ខំចិត្តផ្លាស់ប្តូរយុទ្ធសាស្ត្រភ្លាមៗ ។ «ឥឡូវនេះ អ្វីៗដែលរៀបចំដោយបក្សកុម្មុយនិស្តកម្ពុជា គឺពិតជាត្រឹមត្រូវ ហើយស័ក្តិសមទទួលការកោតសរសើរទៀតផង ។ កាលពីមុន នៅពេលដែល ខៀវ សំផន រត់ចូលព្រៃម៉ាគី ពួកវៀតណាមបានស្តីបន្ទោសបក្សកុម្មុយនិស្តកម្ពុជាថា បានប្រកាន់យកការសម្រេចចិត្តភាន់ច្រឡំមួយ ។ ឥឡូវនេះ ដែលគាត់ក្លាយជាសមាជិកម្នាក់នៃរដ្ឋាភិបាលរួបរួមជាតិ ពួកវៀតណាមបានថ្លែងសរសើរបក្សកុម្មុយនិស្តកម្ពុជាថា បានប្រកាន់យកការសម្រេចចិត្តមួយ ប្រកបដោយសុភនិច្ឆ័យ និងត្រៀមខ្លួនមុនបានល្អប្រសើរ១៩» ។

ក្រោយពីបានស្វែងរកការសម្រុះសម្រួលមួយជាមួយនឹងរបប លន់ នល់ ដើម្បីជួយពួកកុម្មុយនិស្តវៀតណាម ពួកចិនបានបង្កើនការគាំទ្ររបស់ខ្លួនចំពោះសម្តេច ព្រះនរោត្តម សីហនុ និងខ្មែរក្រហមយ៉ាងសម្បើម ។ ចំពោះចំណុចនេះ ពួកចិនបានបង្ហាញឲ្យឃើញលក្ខណៈប្រុងប្រយ័ត្នជាងពួកវៀតណាម ដែលបានពង្រីកសង្គ្រាមរបស់គេនៅប្រទេសកម្ពុជាប្រឆាំងទល់នឹងរបប លន់ នល់ បន្ទាប់ពីមានរដ្ឋប្រហារតែប៉ុន្មានថ្ងៃប៉ុណ្ណោះ ។

ពួកវៀតណាមបានពង្រឹងឥទ្ធិពលរបស់គេនៅប្រទេសឡាវ និងនៅប្រទេសកម្ពុជាកាន់តែខ្លាំងឡើង ដោយជ្រៀតចូលយ៉ាងជ្រៅក្នុងប្រទេសទាំងពីរនេះ ដើម្បីធ្វើសង្គ្រាមជាប្រយោជន៍ដល់លទ្ធិកុម្មុយនិស្ត ។ ទន្ទឹមនឹងនោះ ពួកចិនបានប្រឹងប្រែងពង្រីកទំនាក់ទំនងផ្សេងៗ របស់ពួកគេជាមួយពួកកុម្មុយនិស្តខ្មែរ និងឡាវថែមទៀត ដោយយល់ព្រមផ្តល់ជំនួយ និងការគាំទ្រខាងផ្នែកនយោបាយ ។ ពួកចិនខំប្រឹងបង្ការទុកជាមុននូវការរំលោភរបស់សូវៀត ឬសម្ព័ន្ធមិត្តទាំងឡាយរបស់ខ្លួន មកក្នុងមណ្ឌលឥទ្ធិពលរបស់គេដែរ ។ នៅជំនាន់នោះ ទាហានសូវៀតជិតមួយលាននាក់ បានមកផ្តុំគ្នាយ៉ាងច្រើននៅតាមបណ្តោយព្រំដែនចិន ហើយក្រុងមូស្គូបានឲ្យដំណឹងជារឿយៗថា «នឹងផ្តល់មេរៀនមួយឲ្យពួកចិន[៧០]» ថែមទៀត ។

នៅឆ្នាំ១៩៧០ ប្រទេសចិនបានទទួលធ្វើ «សន្និសីទដើម្បីសាមគ្គីភាពជាមួយប្រជាជនឥណ្ឌូចិន» នៅទីក្រុងកង់តុង ហើយប្រគល់ឲ្យសម្តេច ព្រះនរោត្តម សីហនុ ធ្វើជាអធិបតីភាពសម័យប្រជុំនោះ ។ ក្រោយមក ពួកវៀតណាមបានទាមទារថា ខ្លួនជាអ្នកបង្កើតរណសិរ្សដែលបង្រួបបង្រួមសម្តេច ព្រះនរោត្តម សីហនុ និងពួកខ្មែរក្រហម ប៉ុន្តែភ័ស្តុតាងទាំងអស់ បានដោបញ្ជាក់ឲ្យដឹងថា ការចងសម្ព័ន្ធភាពនេះ គឺពិតជាស្នាដៃរបស់ប្រទេសចិន ។

ហើយនៅសន្និសីទឆ្នាំ១៩៧០នោះ ពួកចិនបានធានាឲ្យពួកវៀតណាមរាប់រកពួកអ្នកបដិវត្តកម្ពុជាដោយស្មើភាពគ្នា ហើយជួយពួកទាំងនេះឲ្យបង្កើតកងទ័ពផ្ទាល់របស់គេផង ។

បើក្រុងហាណូយ ជួយបង្កើតកងទ័ពខ្មែរក្រហមមែន និងជួយវាយប្រយុទ្ធក្នុងចន្លោះពេលនោះ ទល់នឹងកងទ័ព លន់ នល់ ក៏សហប្រតិបត្តិការនេះមានលក្ខណៈតឹងតែងណាស់ ។ មុនដំបូងពួកវៀតណាមបានទាមទារបង្កើតបញ្ជាការដ្ឋានយោធាចម្រុះមួយនៅកម្ពុជា ការធ្វើសកម្មភាពឃោសនារួមគ្នាតែមួយ និងការបើកសាលាយោធាមួយរបស់វៀតណាមក្នុងភាគឦសានប្រទេសកម្ពុជាថែមទៀត[២១] ។ ពួកខ្មែរក្រហមបានបដិសេធការផ្ដល់យោបល់ទាំងនេះ រួមទាំងសំណើផ្សេងទៀតសំដៅរលាយបញ្ចូលកងទ័ព និងរចនាសម្ព័ន្ធកុម្មុយនិស្តទាំងពីរផង ។ ពួកខ្មែរក្រហមខ្លាចក្រែងថាការផ្ដួចផ្ដើមគំនិតមួយបែបនោះ បើគិតឲ្យសព្វៗទៅ គឺជាការចាប់ផ្ដើមដំបូងនៃយុទ្ធនាការមួយ ដើម្បីរួមបញ្ចូលកងទ័ពរបស់គេជាមួយកងទ័ពវៀតណាម ដែលនឹងផ្ដល់ឲ្យក្រុងហាណូយមានអំណាចបញ្ជាពីលើការបដិវត្តរបស់កម្ពុជាមិនខាន ។ ម្យ៉ាងទៀតក្នុងរយៈពេលសង្គ្រាមឥណ្ឌូចិនលើកទីមួយ ពួកវៀតណាមច្បាស់ជាបដិសេធដែរ បើសិនជាប្រទេសចិនស្នើបង្កើតបញ្ជាការដ្ឋានយោធារួមមួយ ជាពិសេស បើសិនជាពួកចិនឲ្យយោបល់ជាមុនថា ប្រទេសវៀតណាមនឹងទៅជាសមាជិកភាគតិចនៃមហាសហភាពមួយរបស់ចិននោះ ។

រឿងទាំងនេះ ជាការប្រឈមមុខចង់អាឃាដគ្នាដដែលៗ ដែលកើតមាននៅឥណ្ឌូចិន បន្ទាប់ពីសង្គ្រាមនៅពេលដែលតួឯកកុម្មុយនិស្តនីមួយៗល្បងការពារតួឯកមួយទៀត ដើម្បីនឹងកំណត់ពីបែបផែនប្រសើរជាងគេ ក្នុងការរក្សាអនុត្តរភាពរបស់ខ្លួន ។ ចំពោះល្បែងនេះ សហភាពសូវៀតបានសម្ដែងឲ្យឃើញលក្ខណៈសោះអង្គើយបំផុត ។ ក្រុងមូស្គូ បានបន្តប្រមូលផ្ដុំការប្រឹងប្រែងរបស់ខ្លួនទៅលើការជួយទំនុកបម្រុងចំពោះក្រុងហាណូយថែមទៀត ហើយចាត់ទុកសង្គ្រាមនៅប្រទេសកម្ពុជា ជាជំពូកចុងក្រោយនៃសង្គ្រាមឥណ្ឌូចិនលើកទីពីរ ។ ពួកសូវៀតបានរក្សាទុកស្ថានទូតរបស់គេនៅក្រុងភ្នំពេញ ពេញរយៈពេលនៃសង្គ្រាម ហើយយល់ព្រមដោយហួសពេលទៅហើយក្នុងការដាក់ឲ្យមានអ្នកតំណាងថ្នាក់ទាបម្នាក់នៅរណសិរ្សរួបរួមជាតិរបស់សម្ដេច ព្រះនរោត្ដម សីហនុ / ខ្មែរក្រហម ។

ប្រទេសចិនបានទាក់ទងកាន់តែជិតស្និទ្ធជាមួយក្រុងវ៉ាស៊ីនតោន ។ នៅឆ្នាំ១៩៧០ ក្រុងប៉េកាំង បានបើកធ្វើការប្រជុំចរចាជាសម្ងាត់ជាមួយរដ្ឋាភិបាលរបស់លោក និចសុន ។ នៅឆ្នាំ១៩៧២ ប្រធានាធិបតីអាមេរិកាំងបានធ្វើដំណើរជាប្រវត្តិសាស្ត្ររបស់គាត់ ទៅទីក្រុងប៉េកាំង ដោយព្រមព្រៀងទទួលស្គាល់ប្រទេសចិនជាផ្លូវការម្ភៃបីឆ្នាំបន្ទាប់ពីជ័យជម្នះរបស់ ម៉ៅ ។ លោក និចសុន បានធ្វើដំណើរទៅសហភាពសូវៀតនៅឆ្នាំនោះដែរ ហើយបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងកម្រិតអាវុធយុទ្ធសាស្ត្រ (SALT) ផង ។ នេះជាសម័យកំពូលនៃយុទ្ធនាការរបស់អាមេរិកាំង ដើម្បីផ្ដាច់សម្បទានផ្សេងៗ ពីក្រុងហាណូយក្នុងការប្រជុំចរចាសន្តិភាព នៅទីក្រុងប៉ារីស ហើយពួកមេដឹកនាំវៀតណាមខាងជើងបានវិនិច្ឆ័យប្រកបដោយការថប់បារម្ភក្នុងចិត្ត ចំពោះបណ្ដាសម្ព័ន្ធមិត្ររបស់

ពួកគេដែលទទួលលោកនិចសុន និងបានសម្រេចធ្វើកិច្ចព្រមព្រៀងថ្មីជាច្រើន ដែលនាំឲ្យខូចប្រយោជន៍ដល់ប្រទេសវៀតណាម ។

ពួកវៀតណាមខាងជើងជឿប្រាកដថា ក្រុងមូស្គូ និងក្រុងប៉េកាំងបានឆ្លៀតទាញយកប្រយោជន៍ពីស្ថានការណ៍នៅប្រទេសវៀតណាម ។ បញ្ហាតែមួយគត់ដែលត្រូវដឹង គឺអ្នកណាមួយដែលជាសត្រូវពិតប្រាកដហើយក្រុងហាណូយបានដឹងចម្លើយរួចស្រេចទៅហើយ ។ ហេតុនេះ ពួកមេដឹកនាំកុម្មុយនិស្តវៀតណាមខាងជើង បានចោទប្រកាន់ពួកចិនតែក្នុងចិត្តថា ជាអ្នកទទួលខុសត្រូវលើបញ្ហាទាំងអស់របស់ពួកគេ ។ ក្រុងប៉េកាំងបានបន្តឡើងវិញជាមួយនឹង«ការកាន់ជើងមាតុភូមិជ្រុលហួសនៃជនជាតិហាន» ជាមួយនឹង«នយោបាយអធិរាជនិយមរបស់ប្រទេសចិនបុរាណ» ជាមួយនឹង«អនុត្តរភាពរបស់ចិនក្នុងអាស៊ីអាគ្នេយ៍ទាំងមូល[២២]» ។ អ្វីដែលអាក្រក់បំផុតនោះគឺ ប្រទេសចិនមានបំណងបំបែកបំបាក់ «សាមគ្គីភាពជាប្រពៃណី[២៣]» រវាងប្រទេសវៀតណាម ឡាវ និងកម្ពុជាថែមទៀត ។

អធិករណ៍របស់វៀតណាមជាមួយប្រទេសចិន បានបំផុស និងរក្សាឲ្យស្ថិតស្ថេរនូវបញ្ហាផ្សេងៗរបស់ប្រទេសវៀតណាមជាមួយនឹងពួកខ្មែរក្រហម និងទៅវិញទៅមក ។ បរិវេណដែលប្រមូលផ្ដុំសេចក្ដីខ្វាចមួយ បានតាំងនៅជាប់នៅមុនពេលដែលសង្គ្រាមត្រូវបញ្ចប់ ។ នៅឆ្នាំ១៩៧៣ ប្រទេសវៀតណាម បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស ដែលបង្កឲ្យមានសង្គ្រាមអាកាសរបស់អាមេរិកាំង ដោយមិនចំពោះប្រឆាំងនឹងប្រទេសកម្ពុជា ហើយដែលធ្វើឲ្យសម្ដេច ព្រះនរោត្តម សីហនុ និងពួកខ្មែរក្រហមព្រួយបារម្ភដូចគ្នា ។ ពួកខ្មែរក្រហមយល់ឃើញថា ខ្លួនជាភាគីដែលត្រូវគេ ធ្វើឲ្យខូចប្រយោជន៍ៈ វៀតណាមខាងជើងបានតឿនបង្ខំឲ្យសម្ដេច ព្រះនរោត្តម សីហនុ ផ្ដើមធ្វើការចរចា និងផ្អាកជំនួយទាំងអស់ សម្រាប់ពួកកុម្មុយនិស្តកម្ពុជា ក្រោយពេលដែលសម្ដេចបដិសេធសំណើនេះ ។

ប៉ុន្តែ ប្រទេសចិនបានតបវិញឲ្យដូចគ្នាចំពោះក្រុងហាណូយ ដោយយល់ព្រមទាំងស្រុង នូវការសម្រេចចិត្តតស៊ូរបស់ខ្មែរក្រហម រហូតដល់ទទួលជ័យជម្នះខាងផ្លូវយោធាមួយ ហើយក្រោយឆ្នាំ១៩៧៣ ចិនបានកាត់បន្ថយការគាំទ្ររបស់ខ្លួនចំពោះវៀតណាមខាងជើងជាលំដាប់លំដោយ ។ ម្យ៉ាងទៀត ប្រទេសចិនពុំបានផ្ដល់នូវការគាំទ្រចំពោះកិច្ចព្រមព្រៀងក្រុងប៉ារីសដោយអស់ពីចិត្តផងទេ ។ ក្រោយមកក្រុងប៉េកាំងបានបញ្ជាក់ថា កាលនោះខ្លួនខ្លាចក្រែងកិច្ចព្រមព្រៀងនេះ អនុញ្ញាតឲ្យភាគខាងជើងដណ្ដើមយកភាគខាងត្បូង បន្ទាប់ពីជ័យជម្នះ ។

នៅឆ្នាំ១៩៧៤ រវាងកងទ័ពកុម្មុយនិស្តទាំងពីររបស់ប្រទេសវៀតណាម និងកម្ពុជា គឺកងទ័ពកុម្មុយនិស្តណាមួយដែលនឹងទទួលជ័យជម្នះមុនគេ ។ កងទ័ពទាំងសងខាងជឿថា កងទ័ពម្ខាងទៀតខំប្រឹងបំបាត់មិនឲ្យម្ខាងមានជោគជ័យមួយឡើយ ។ ពួកខ្មែរក្រហមបានអះអាងដោយមានភ័ស្តុតាងជាបន្ទែកថា ពួកវៀតណាមមិនត្រឹមតែផ្អាកជំនួយរបស់គេប៉ុណ្ណោះទេ ថែមទាំងរារាំងមិនឲ្យជំនួយរបស់ចិនធ្លាក់មកដល់ប្រទេសកម្ពុជាទៀត ។ ត្រូវធ្វើឲ្យ

ព្រួយចិត្តខ្លួនឯង ដោយការបន្ថយជំនួយរបស់ចិន ប្រទេសវៀតណាមបានមើលឃើញនឹងភ្នែក តែរកធ្វើអ្វីមិនកើតចំពោះការវាយដណ្តើមឡើងវិញដោយប្រទេសចិន នូវប្រជុំកោះប៉ារ៉ាសែលរបស់វៀតណាមខាងត្បូង ដែលក្រុងហាណូយធ្លាប់បានទាមទារដែរ ។

នៅពេលដែលជ័យជម្នះមកដល់ គេលែងអាចបញ្ឈប់រឿងហេតុស្មុគស្មាញនៃការមិនទុកចិត្តគ្នាទៀតហើយ ។ ទំនាក់ទំនងផ្សេងៗរវាងសហរដ្ឋអាមេរិក និងប្រទេសចិន បានក្លាយទៅជាគ្រឿង ពិសោធន៍អំពើក្បត់របស់ប្រទេសចិនចំពោះប្រទេសវៀតណាម ហើយចំណងទាក់ទងរបស់ប្រទេសវៀតណាម និងសហភាពសូវៀតបានដើរតួនាទីដូចគ្នាចំពោះក្រុងប៉េកាំងដែរ ។ សេចក្តីភ័យខ្លាច និងការមន្ទិលសង្ស័យ បានបណ្តាលឲ្យមានប្រតិកម្មបន្តកន្ទុយគ្នាមួយនៅក្នុងតំបន់ឥណ្ឌូចិន ក្រោយសម័យសង្គ្រាម ។

សេចក្តីភ័យខ្លាចនេះ ពិតជាមានមូលហេតុត្រឹមត្រូវ ។ ប្រទេសទាំងបី – វៀតណាម កម្ពុជា និងចិន– សុទ្ធតែឈឺចាប់នឹងការរំលោភបំពានរបស់អាមេរិកាំង និងអំពើក្បត់របស់បណ្តាសម្ព័ន្ធ មិត្រជិតស្និទ្ធរបស់ពួកគេដូចគ្នា ។ ពួកគេប្រឈមមុខនឹងបញ្ហាទាំងអស់ដែលស្ទើរតែពុំអាចពុះពារបាននៅក្នុងប្រទេសរបស់ពួកគេ ដែលរដ្ឋាភិបាលធ្លាប់អះអាងឲ្យប្រជាជនរង់ចាំលទ្ធផលដ៏អស្ចារ្យរបស់ការបដិវត្តន៍ ។

ប៉ុន្តែ ត្រីកោណនៃការមិនទុកចិត្តគេឯងនេះ បានបង្ហាញឲ្យឃើញអ្វីៗដែលអាចឲ្យប្រយោជន៍ ៖ ការភ័យខ្លាចរបស់សហភាពសូវៀត អាចបង្ហាញឲ្យឃើញភស្តុតាងតាមរយៈការប្តេជ្ញារបស់ចិន ក្នុងការរក្សាទុកតំបន់ឥណ្ឌូចិនក្នុងវង្វង់ឥទ្ធិពលរបស់ខ្លួន ។ សេចក្តីភ័យខ្លាចរបស់ចិន អាចបង្ហាញភស្តុតាងតាមរយៈរបស់ប្រទេសវៀតណាមមកលើប្រទេសកម្ពុជា ហើយក្រោយមក ការលុកលុយប្រទេសនេះ ។ សេចក្តីភ័យខ្លាចទាំងឡាយ ដែលបំផុសឡើងដោយគោលបំណងចាស់គំរឹលរបស់បក្សកុម្មុយនិស្តឥណ្ឌូចិន និងសេចក្តីភ័យខ្លាច«ជាប្រវត្តិសាស្ត្រ» អំពីការត្រួតត្រាមួយរបស់វៀតណាម អាចប្រើសម្រាប់បង្វែរការយកចិត្តទុកដាក់របស់ប្រជាជនខ្មែរ អំពីភាពក្រីក្រគោកយ៉ាកខាងក្នុងប្រទេស និងធានារក្សានូវការគាំទ្រដោយឥតលក្ខខណ្ឌមួយផ្នែកធំរបស់ប្រទេសចិនផង ។

ប៉ុន្តែ ប្រទេសវៀតណាមបានសម្តែងនូវតួនាទីកណ្តាលមួយក្នុងល្បែងលេងបីនាក់នេះ ហើយគឺប្រទេសវៀតណាមនេះឯង ដែលជំរុញសេចក្តីភ័យខ្លាចទាំងនេះ ដល់កម្រិតខ្ពស់បំផុត ។ នៅទីបំផុត ពួកវៀតណាម បានសម្រេចចោទប្រកាន់ប្រទេសចិនថា ជាសត្រូវ«ស្ទួពូជ»របស់គេ ហើយមានបំណងចូលលុកលុយប្រទេសវៀតណាម ដោយកម្ទេចពូជសាសន៍វៀតណាមឲ្យសាបសូន្យ ។ ម្យ៉ាងទៀត ហើយដោយគ្មានភស្តុតាងបន្តិច ពួកវៀតណាមបានអះអាងថា ប្រទេសកម្ពុជាជាអ្នកសមគំនិតនឹងពួកចិន ហើយបានយល់ព្រមបណ្តោយឲ្យពួកចិនឆ្លងកាត់ដែនដីខ្មែរ ដើម្បីលុកលុយប្រទេសវៀតណាម ។ ដូច្នេះ នេះជាបញ្ហា«ស្លាប់រស់»មួយ សម្រាប់ពួកវៀតណាមដែលអាចបង្ហាញភស្តុតាងថាពួកគេលុកលុយ និងកាន់កាប់ប្រទេសកម្ពុជា ហើយដែលពួកគេបានធ្វើមែន ។

ប្រជាជនវៀតណាមបានរត់ភៀសខ្លួនតាមទូកតូចកញ្ចាស់ៗ ដំបូងមានចំនួនរាប់ពាន់នាក់ បន្ទាប់មកប្រមាណជារាប់ម៉ឺន ដោយពុះពារនឹងពួកចោរប្លន់ និងខ្យល់ព្យុះសង្ឃរានៅសមុទ្រចិនខាងត្បូង ដើម្បីចាកចេញពីប្រទេសវៀតណាម ។ ក្រោយមក គេឲ្យឈ្មោះរួមថា "ជនភៀសខ្លួនតាមទូក" ចំពោះប្រជាជនវៀតណាមទាំងនេះ ដែលត្រូវបង្ខំចិត្តភៀសខ្លួនចេញពីប្រទេសរបស់គេ ឬលែងអាចទ្រាំទ្ររស់នៅទីនេះតទៅទៀត ។

ការចាកចេញទាំងហ្វូងដ៏ធំបានចាប់ផ្តើមនៅឆ្នាំ១៩៧៨ ហើយបានបន្តក្នុងរយៈពេលជាច្រើនឆ្នាំ ។ នេះជាទស្សនីយភាពអាក្រក់មើលណាស់ និងគួរឲ្យភ័យរន្ធត់បំផុត ។ តាមប្រពៃណីប្រជាជនវៀតណាម ជំពាក់ចិត្តនឹងដីធ្លីប្រទេសជាតិ និងទំនៀមទម្លាប់របស់ខ្លួនខ្លាំងណាស់ ។ ពួកគេបានទ្រាំទ្រនឹងសង្គ្រាមចំនួនពីរ ទុរភិក្ស និងជាមួយសតវត្សន៍នៃការតាំងអាណានិគម ព្រោះតែស្ថិតនៅក្នុងមាតុភូមិរបស់គេ ។ ដូចគ្នាដែរ នៅពេលដែលវិបត្តិភ័យទាំងនេះតម្រូវឲ្យរត់ភៀសខ្លួនពីភូមិកំណើតរបស់គេ ពួកគេស្ថិតនៅប្រទេសវៀតណាមដដែល ។

ប៉ុន្តែ នៅពេលដែលសន្តិភាពកើតមានក្នុងទីបំផុត ហើយដែលចាប់ផ្តើមការបដិវត្តន៍ តាមពាក្យសន្យា និងនៅពេលដែលប្រជាជនវៀតណាមត្រូវក្រេបជញ្ជក់ផ្លែផ្កានៃ"សេរីភាព និងឯករាជ្យភាព" ពួកគេបានចាកចេញពីប្រទេសរបស់ខ្លួនទៅវិញ ។ មនុស្សភាគខាងជើង ក៏ដូចភាគខាងត្បូង គ្រប់ស្រទាប់វណ្ណៈសង្គម និងអ្នកមាននាទីខាងនយោបាយទាំងអស់ បានភៀសខ្លួនចេញពីប្រទេសក្នុងចលនាមួយ ដែលមានទំហំជាប្រវត្តិសាស្ត្រ[២៨] ។

ការចាកចេញទៅទាំងហ្វូងដ៏អាថ៌កំបាំងរបស់អ្នកភៀសខ្លួនតាមទូកនេះ គឺជាចំណុចគន្លឹះមួយ សម្រាប់ស្វែងយល់ពីសង្គ្រាមវៀតណាម -កម្ពុជា និងផលវិបាកគួរឲ្យព្រឺខ្លាចផ្សេងៗ នៃការជំពាក់ចាក់ស្រេះក្នុងការវិវាទរវាងប្រទេសកម្ពុជា វៀតណាម និងប្រទេសចិន ដែលបង្កឲ្យមានសង្គ្រាមឥណ្ឌូចិនលើកទីបី ។

តាមការមើលឃើញដំបូង ចំណងទាក់ទងរវាងអ្នកភៀសខ្លួនតាមទូក និងសង្គ្រាមក្នុងនាមនៃប្រទេសកម្ពុជាពុំប្រាកដជាក់ស្តែងទេ ។ នៅពេលដែលពួកអ្នកភៀសខ្លួនតាមទូកបកស្រាយបំភ្លឺ ពីការចាកចេញរបស់គេ ពួកអ្នកភៀសខ្លួនផ្ទាល់បានលើកពីមូលហេតុគ្រប់ប្រភេទទាំងអស់ ប៉ុន្តែ ពុំមានលើកពីប្រទេសកម្ពុជាទេ ៈ ពួកគេភៀសខ្លួនចេញ ពីព្រោះពួកគេជាចំណែកមួយនៃជនជាតិភាគតិចចិនកាត់វៀតណាម ដែលជាប់កុនក្នុងជម្លោះរវាងប្រទេសវៀតណាម និងប្រទេសចិន ឬពីព្រោះក្រុងហាណូយ បានផ្សាយឲ្យដឹងជាសាធារណៈ ពីការកែប្រែផ្នែកសេដ្ឋកិច្ចទាំងស្រុងមួយនៅភាគខាងត្បូង ដែលធ្វើឲ្យពួកគេកាន់តែចុះក្រ ឬពីព្រោះកម្រិតជីវភាពរបស់គេបានធ្លាក់ចុះយ៉ាងខ្លាំង ។ ពួកគេភ័យខ្លាចថា សង្គមលែងត្រូវការពួកគេហើយបញ្ជូនពួកគេទៅដាក់ក្នុងជំរំអប់រំជាថ្មីមួយ ។ ពួកយុវជន ភ័យខ្លាចក្រែងគេបញ្ចូលទៅក្នុងកងទ័ពមួយរបស់វៀតណាម ដែលកំពុងតែរីកលូតលាស់យ៉ាងខ្លាំង ។

ពួកអ្នកភៀសខ្លួនតាមទូក -គឺជាការប្រមូលផ្តុំបណ្តឹងមួយចំពោះក្រុងហាណូយ ។ ទូកតូចៗរបស់អ្នកទាំងនោះ មានចំនួនរាប់ពាន់ ដែលប្រាប់ឲ្យដឹងថាការលំបាកទាំងឡាយ ក្រោយសម័យសង្គ្រាមបានបំផ្លាញប្រទេសវៀតណាម ហើយស្ថានការណ៍នេះ មុខជាជំរុញក្រុងហាណូយឲ្យប្រកាន់ជំហរខ្លាំងបំផុតមិនខាន ។ សេចក្តីភ័យខ្លាច

និងកំហឹង បានកើនឡើងនៅក្នុងប្រទេស -ការភ័យខ្លាចប្រទេសចិន និងកម្ពុជា ការភ័យខ្លាចថា ប្រទេសវៀតណាមដែលរំដោះរួចហើយ នឹងមិនស្គាល់ជោគជ័យណាមួយសោះឡើយ ការភ័យខ្លាចរបស់ ពួកមេដឹកនាំដែលមានវ័យកាន់តែចាស់ ពុំបានមើលឃើញប្រទេសវៀតណាមសង្គមនិយមមួយ ដែលរីកចម្រើន និងស្តារឡើងវិញ ព្រមទាំងបុកកុម្មុយនិស្តឥណ្ឌូចិនមួយ ដែលចាត់ចែងដឹកនាំដោយក្រុងហាណូយ មុនពេលគាត់ស្លាប់ឡើយ ។

ពួកអ្នកកៀសខ្លួនតាមទូក គឺជាអ្នករងគ្រោះដំបូងៗនៃការស្រងាកចិត្តមួយ ដែលស្មុគស្មាញ ដោះស្រាយមិនរួច ទាក់ទងនឹងសង្គ្រាមរវាងប្រទេសវៀតណាមនិងកម្ពុជា ។ ការទាក់ទងនេះ បានក្លាយទៅជាជាក់ស្តែង បើសិនជាគេវាយតម្លៃឥណ្ឌូចិនក្រោយសម័យសង្គ្រាម តាមទស្សនៈយល់ឃើញរបស់ក្រុងហាណូយ ។

កងទ័ពវៀតណាមខាងជើង បានព្រមទទួលការសុំចុះចាញ់របស់របបក្រុងព្រៃនគរ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៥ ។ នេះគឺជាទីបញ្ចប់នៃសាធារណរដ្ឋវៀតណាមខាងត្បូង សេចក្តីសង្ឃឹមផ្សេងៗ របស់អាមេរិកាំងដើម្បីត្រួតត្រាដំណើរប្រវត្តិសាស្ត្ររបស់វៀតណាម ហើយពិសេសជាងនេះទៀត គឺទីបញ្ចប់ភ្លាមៗនៃអត្ថិភាពរបស់រដ្ឋាភិបាលបដិវត្តបណ្តោះអាសន្ន និងរណសិរ្សជាតិរំដោះភាគខាងត្បូង ។ រឿងទាំងអស់នេះ បានលេចឡើងយ៉ាងប្រត្យក្សនៅថ្ងៃជ័យជម្នះ នៅពេលដែលកងពលធំចំនួនបី ស្ថិតនៅក្រោមអំណាចបញ្ជាការរបស់វៀតណាមខាងជើងបានព្រមទទួលការសុំចុះចាញ់របស់ក្រុងព្រៃនគរ ហើយបណ្តោយខ្លួនឲ្យក្រុងហាណូយមកលើប្រទេសទាំងមូល គឺភាគខាងជើង និងភាគខាងត្បូងមានជាស្ថាពរតទៅ ។

កិច្ចព្រមព្រៀងក្រុងប៉ារីស ឆ្នាំ១៩៧៣ ដែលព្រួយបារម្ភយ៉ាងខ្លាំងដោយពួកកម្ពុជា បានរៀបចំស្ថានភាពរួចជាស្រេចសម្រាប់ការច្បាំងដណ្តើមត្រួតត្រានេះ ។ ពួកវៀតណាមខាងជើង បានបញ្ចុះបញ្ចូលឲ្យពួកអាមេរិកាំងឈប់ទាមទារឲ្យមានការដកថយមួយរបស់កងទ័ពក្រុងហាណូយចេញពីវៀតណាមខាងត្បូង ដែលតាមមតិស្ទើរតែជាឯកច្ឆ័ន្ទយល់ឃើញថា នេះជាសម្បទានដែលរួមបន្តជាការបញ្ឈប់សេចក្តីវិនាសមួយ សម្រាប់សម្ព័ន្ធមិត្តរបស់សហរដ្ឋអាមេរិក គឺសាធារណរដ្ឋវៀតណាមខាងត្បូង ។ អ្វីដែលមិនជាក់ស្តែង គឺអានុភាពខាងផ្លូវចិត្ត ដែលការរៀបចំមិនសំខាន់នេះ នឹងមានទៅលើបណ្តាសម្ព័ន្ធមិត្តរបស់ក្រុងហាណូយនៅភាគខាងត្បូង ។

ក្រោយពេលដែលភាគទាំងពីររំលោភបទឈប់បាញ់គ្នា ដែលតម្រូវឲ្យគោរពដោយកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស ក្រុងហាណូយបានចាប់ផ្តើមរៀបចំដណ្តើមយកជ័យជម្នះផ្តាច់ព្រ័ត្រ ។ នៅខែធ្នូ ឆ្នាំ១៩៧៤ ពួកវៀតណាមខាងជើងបានត្រៀមការណ៍ផែនការផ្សេងៗរួចជាស្រេច សម្រាប់ការវាយលុកចុងក្រោយបំផុត[២៥] ។ ក្នុងរយៈពេលម្ភៃពីរថ្ងៃ ការិយាល័យនយោបាយមជ្ឈិមបក្ស បានរួមប្រជុំនៅភាគខាងជើង ដើម្បីសិក្សាដោយល្អិតល្អន់ពីស្ថានការណ៍មួយ ដែលនឹងមិនហុចផលវិបាកមកវិញ ទាំងខាងនយោបាយ និងទាំងខាងយោធា ដើម្បីទាមទារឲ្យមានរដ្ឋាភិបាលចម្រុះមួយ -ជាមួយនឹងអ្នកតំណាងរបបរបស់ លោក ង្វៀង វ៉ាន់ធីវ (ប្រធានាធិបតីវៀតណាមខាងត្បូង) ដែលជាគូសត្រូវរបស់ខ្លួន ឬសម្ព័ន្ធមិត្តផ្ទាល់របស់ខ្លួន គឺរណសិរ្សរំដោះជាតិ ។ ដោយតាំង

ទ័ពនៅភាគខាងត្បូង ពួកវៀតណាមខាងជើង អាចបង្ហាញឲ្យឃើញនូវការគាំទ្រមកពីហែងខាងយោធាមួយរួចជាស្រេច ។ ពួកគេមិនត្រូវការទាំង«រណសិរ្ស»មួយ ទាំង«រដ្ឋាភិបាលបដិវត្ត»មួយ ជារបស់ភាគខាងត្បូងផ្ទាល់ និងរបបអន្តរកាលមួយឡើយ ។ តាំងពីថ្ងៃដំបូង កងទ័ពវៀតណាមខាង ជើងបានសម្រេចប្រើច្បាប់អជ្ញាសឹកក្នុងភាគខាងត្បូង និងក្តោបក្តាប់ការត្រួតត្រាលើកងកម្លាំងស្និទ្ធកុម្មុយនិស្តនៃភាគខាងត្បូង ដែលគេស្គាល់ក្រោមឈ្មោះថា វៀតកុង[២៦] ថែមទៀត ។ ភាគខាងជើងបានប្រកាសថា «គេបានបង្រួបបង្រួមកងទ័ពទាំងពីរឲ្យមានតែមួយ» ៖ តាមពិត គឺគេបានកម្ទេចជាយថាហេតុការប្រឆាំងជិទាស់ដោយ អាវុធទាំងអស់ចំពោះ ផែនការរបស់ខ្លួន ក្នុងការកាន់កាប់ភ្លាមៗ លើប្រទេសទាំងមូលទៅវិញសោះ ។

ការតាំងឲ្យមានឡើងជាបន្ទាន់នូវរដ្ឋអំណាចរបស់ក្រុងហាណូយ បានបំពានទៅលើពាក្យសន្យាច្រើនរាប់មិនអស់ដែលគេធ្វើឡើងជាមួយនឹងប្រជាពលរដ្ឋភាគខាងត្បូង ជាពិសេស ជាមួយរណសិរ្សរំដោះជាតិ ដែលជាសម្ព័ន្ធមិត្តរបស់ខ្លួន ដែលជំរុញទៅរកការភ្ញាក់ខ្លួនរបស់ប្រជាជនវៀតណាមខាងត្បូង និងបរាជ័យ នៃបណ្តាផែនការប្រកបដោយមហិច្ឆតា សម្រាប់ក្រោយសម័យសង្គ្រាមទៀត ។ ក្នុងកម្មវិធីនយោបាយរបស់ខ្លួន រណសិរ្សរំដោះជាតិបានសន្យាធ្វើការបង្រួបបង្រួមភាគខាងជើង និងភាគខាងត្បូងឡើងវិញ តាម«មធ្យោបាយសន្តិវិធី» ជាលំដាប់លំដោយ ។ គេបានសន្យាថា នៅពេលសង្គ្រាមចប់ ភាគខាងត្បូងនឹងទទួលបាន សេរីភាពផ្សេងៗតាមលទ្ធិប្រជាធិបតេយ្យដែលភាគខាងជើងមិនធ្លាប់ដែលស្គាល់សោះ ។ ហើយក្រុងហាណូយ បានអបអរសាទរសើរកម្មវិធីនយោបាយនេះជាច្រើនលើកច្រើនសា ហើយបានប្រកាសដោយការទទូចថា ដំណោះស្រាយក្នុងការផ្លាស់ប្តូររបបក្រុងព្រៃនគរ គឺជាភារកិច្ចរបស់រដ្ឋាភិបាលបដិវត្តបណ្តោះអាសន្ននៅខាងត្បូង ពុំមែនជាភារកិច្ចរបស់រដ្ឋាភិបាលនៅវៀតណាមខាងជើងទេ ។

ប៉ុន្តែទាំងពួកមេដឹកនាំរណសិរ្សជាតិ ទាំងពួកមេដឹកនាំរដ្ឋាភិបាលបិដវត្តបណ្តោះអាសន្ន ពុំដែលបានគ្រប់គ្រងដឹកនាំភាគខាងត្បូងមួយដងណាឡើយ ។ ភាគច្រើនក្នុងចំណោមពួកគេ ត្រូវបានបញ្ជូនទៅក្រៅក្រុងព្រៃនគរ ដើម្បីដើរមើលជនបទ និងរៀនសូត្រ«ឲ្យស្គាល់ជនបទ» កាន់តែប្រសើរជាងមុន ។ ជាបន្ទាន់នោះ រដ្ឋធានីភាគខាងត្បូងត្រូវគេប្រែដាក់ឈ្មោះថា ក្រុងហូជីមិញវិញ ហើយគេបានបង្គាប់បញ្ជាឲ្យពលរដ្ឋនៃទីក្រុងនេះខិតខំបញ្ចេញ ស្នាដៃឲ្យសក្តិសមនឹងឈ្មោះថ្មីនេះ គឺធ្វើឲ្យអតីតទីក្រុងព្រៃនគរ ទៅជាទីក្រុងមួយ «មានសុវត្ថិភាព សុភមង្គល សម្បូរសប្បាយ និងសុទិដ្ឋិនិយមបដិវត្តសក្តិសមនឹងកេរ្តិ៍ឈ្មោះដ៏ឆ្នើមរបស់អ៊ំ ហូ» ។ ក៏ប៉ុន្តែ ទីក្រុងនេះបានបាត់បង់ឋានៈរបស់ខ្លួនជារដ្ឋធានីស្រេច ហើយទីក្រុងហាណូយ បានក្លាយទៅជារដ្ឋធានីសម្រាប់ប្រទេសវៀតណាមកុម្មុយនិស្តថ្មីដែលរួមគ្នាតែមួយ ។ ពួកបារាំង ដែលនៅរក្សាទុកស្ថានទូតរបស់ខ្លួន ទាំងនៅទីក្រុងព្រៃនគរ និងទាំងនៅហាណូយនោះ បានជូនដំណឹងថា មានតែឯកអគ្គរដ្ឋទូតបារាំងប្រចាំក្រុងហាណូយមួយប៉ុណ្ណោះ ដែលជាតំណាងស្របច្បាប់របស់ប្រទេសខ្លួន ហើយទូតដែលប្រចាំនៅក្រុងព្រៃនគរ បានទទួលបញ្ជាឲ្យវិលត្រឡប់ទៅប្រទេសបារាំងវិញ[២៧] ។

ទង់ជាតិ និងបទភ្លេងជាតិរបស់ក្រុងហាណូយ បានក្លាយទៅជាទង់ជាតិ និងបទភ្លេងជាតិសម្រាប់ប្រជាជាតិទាំងមូល ។ ពុំមានការសាកល្បងណាមួយដើម្បីធ្វើឲ្យគេជឿថា ប្រជាពលរដ្ឋភាគខាងត្បូង នឹងត្រូវបានសុំយោបល់ឡើយ ។ ក្នុងចំនួនមេដឹកនាំម្ភៃបួននាក់ជាសមាជិករដ្ឋាភិបាលបដិវត្តន៍បណ្ដោះអាសន្នវៀតណាមខាងត្បូង ក្នុងឱកាសដែលមានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសនោះ គឺមានតែបីនាក់ប៉ុណ្ណោះ ដែលបានទទួលមុខតំណែងមួយក្នុងផ្ទៃរដ្ឋាភិបាល "បង្រួបបង្រួមថ្មី" – ហើយបីនាក់នោះជាបក្ខជនកុម្មុយនិស្តទាំងអស់ ។ ពួកវៀតណាមខាងជើងបានបំបាត់ចោល "រណសិរ្ស" រំដោះជាតិ ដែលជាសម្ព័ន្ធមិត្តរបស់គេយ៉ាងឆាប់រហ័ស ដូចបណ្ដាសមមិត្តកម្ពុជារបស់ពួកគេដែរ ជាមួយនឹងការមិនខ្វាចដូចគ្នាចំពោះការសន្យាផ្សេងៗដែលធ្វើជាមួយពួកអ្នកមានសមានចិត្ត ដែលធ្លាប់វាយប្រយុទ្ធ និងពលីជីវិត ក្នុងគោលបំណងធ្វើឲ្យរបបរបស់ប្រធានាធិបតីធីវបរាជ័យផង ។

មនោសញ្ចេតនាក្បត់ ដែលធ្វើឲ្យគេអត់ទ្រាំតបវិញមិនបាន ត្រូវបានបកស្រាយបំភ្លឺយ៉ាងច្បាស់ដោយទ្រឿង ញូ៉តាង ជាជនមិនមែនកុម្មុយនិស្ត តែជាស្ថាបនិករណសិរ្សជាតិរំដោះវៀតណាមខាងត្បូង និងជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌នៃរដ្ឋាភិបាលបដិវត្តន៍បណ្ដោះអាសន្នថា ៖ "នៅពេលជប់លៀងលាគ្នាយ៉ាងសាមញ្ញ ដែលយើងបានចាត់ចែងឡើងដើម្បីរំលាយរណសិរ្សរំដោះជាតិជាផ្លូវការនៅឆ្នាំ១៩៧៦នោះ គឺបក្ស និងរដ្ឋាភិបាល នៅភាគខាងជើង ពុំមានបញ្ជូនអ្នកតំណាងណាម្នាក់ឲ្យមកចូលរួមឡើយ ។ នេះជាកាយវិការមើលងាយមួយចំពោះគោលការណ៍ជាតិនិយម និងប្រជាធិបតេយ្យ ដែលក្នុងនោះ វៀតកុងបានបង្ហូរឈាមអស់យ៉ាងច្រើន ហើយដែលសហគមន៍អន្តរជាតិដែលស្នេហាសេរីភាពធ្លាប់បានគាំទ្រដោយស្មោះស្ម័គ្របំផុត[២៨]" ។

ពួកមនុស្សភាគខាងជើងបានដឹកនាំប្រទេស ដោយច្បាប់អាជ្ញាសឹក ដោយត្រួតត្រាក្រុងព្រៃនគរដូចផ្លូវត្រឡែងកែងមួយ រវាងអណ្ដូងរ៉ែមាសមួយ និងបនសំដីងមួយ ។ ទីក្រុងព្រៃនគរធ្លាប់បានទទួល និងចាយខ្ជះខ្ជាយលុយជំនួយអាមេរិកាំងរាប់កោដិដុល្លារ, ប្រជាជនទីក្រុងនេះ មានទម្លាប់នឹងកម្រិតជីវភាពមួយបែបលោកខាងលិចទៅហើយ ហើយប្រជាជនវៀតណាមខាងត្បូងសម័យសង្គ្រាម បានផ្ដល់ន័យថ្មីមួយចំពោះពាក្យ "ពុករលួយ" ។ ពួកមេដឹកនាំថ្មី បានចោទប្រកាន់សហរដ្ឋអាមេរិកដោយគួរសមអំពីគុណវិបត្តិទាំងអស់ ដែលកើតមាននៅភាគខាងត្បូង ។ នៅថ្ងៃទី១ ខែឧសភា គណៈកម្មាធិការកងទ័ពដែលកំពុងគ្រប់គ្រងដឹកនាំភាគខាងត្បូង បានចុះហត្ថលេខាលើមតិណែនាំដំបូងរបស់ខ្លួន ដែលបង្គាប់បញ្ជាឲ្យបិទ "បារ, បនសំដីង, រង្គសាល, កន្លែងជក់អាភៀន, ហាងម៉ាស្សា និងទីតាំងទាំងអស់ដែលធ្វើសកម្មភាពតាមគំរូអាមេរិកាំង[២៩]" ។ មតិណែនាំ បានហាមឃាត់មិនឲ្យបោះផ្សាយកាសែត ទស្សនាវដ្ដី ឬសៀវភៅ ដោយគ្មានការអនុញ្ញាតជាផ្លូវការ ពីព្រោះការធ្វើបែបនោះ សុទ្ធតែត្រូវវិនិច្ឆ័យ ជាគំរូ "អាមេរិកាំង" ទាំងអស់ ។ ប្រការទាំងអស់នេះ ត្រូវបានរៀបចំឡើងក្នុងនាមនៃប្រជាជនវៀតណាមទាំងមូល – ទាំងខាងជើង និងខាងត្បូងរួមបញ្ចូលគ្នា ។

ក្រុងហាណូយ មានគោលបំណងបញ្ចប់នូវភាពខុសប្លែកគ្នា ដែលមានរាប់សតវត្សរ៍មកហើយរវាងវប្បធម៌ទន្លេមេគង្គ និងវប្បធម៌ទន្លេក្រហម ។ ឧត្តមសេនីយ៍ ត្រាន់ វ៉ាន់ត្រា ដែលជាអ្នកចុះហត្ថលេខា ទទួលយកការស៊ុំចុះចាញ់ជាផ្លូវការនៃរបបមួយដែលត្រូវបំផ្លាញខ្ទេចខ្ទីនោះបានប្រកាសថា «នៅទីបញ្ចប់នៃការប្រយុទ្ធដ៏យូរលង់ នេះគឺពុំមានអ្នកឈ្នះនិងអ្នកចាញ់ទេ[៣០]» ។ «ប្រជាជនវៀតណាមជាប្រជាជនតែមួយគត់ នៃប្រវត្តិសាស្ត្រទាំងមូលដែលមិនដែលវាយចាញ់ពួកម៉ុងហ្គោលសោះឡើយ ។ នៅឆ្នាំ១៩៤៥ យើងបានវាយឈ្នះពួកជប៉ុន ។ នៅឆ្នាំ ១៩៥៤ យើងបានវាយឈ្នះពួកបារាំងនៅឌៀនបៀនភូ ហើយឥឡូវនេះ គឺឈ្នះសហរដ្ឋអាមេរិក ដែលនឹកស្មានថា ខ្លួនជាប្រទេសមួយខ្លាំងជាងគេបំផុតលើពិភពលោក ។ ជោគជ័យទាំងអស់នេះ គឺទទួលបានមកដោយសារប្រជាជនវៀតណាម» ។

ជ័យជម្នះដ៏ខ្ទរខ្ទារទាំងនេះដែលបំផ្លើសយ៉ាងហួសហេតុ ពុំមែនជារបស់ប្រជាជនវៀតណាមទេ ប៉ុន្តែជារបស់កងទ័ព ហូ ជីមិញ ដែលធ្លាប់វាយបំបាក់កងទ័ពរបស់បារាំង និងអាមេរិកាំងឲ្យបរាជ័យ ។ កងទ័ពសម័យទំនើបតិចតួចប៉ុណ្ណោះ ដែលមានវិន័យត្រឹមត្រូវដូចកងទ័ពរបស់ក្រុងហាណូយ ។ ពុំមានទាំងការលួចប្លន់ ទាំងការសម្លាប់រង្គាលដោយការសងសឹក ទាំងអំពើហិង្សាដែលប្រព្រឹត្តឡើង កងទ័ពវៀតណាមខាងជើងឡើយ ។ កងទ័ពទាំងនេះបានបោះជំរំសមល្មមរបស់ពួកគេ លើទទ្បានសាធារណៈទាំងឡាយរបស់ក្រុង និងសួនច្បារនានា ដែលព័ទ្ធជុំវិញទីក្រុងព្រៃនគរ ដោយចងអង្រឹងរបស់ពួកគេនឹងដើមអម្ពិល ហើយអុជកូនចង្កៀងបំភ្លឺកណ្ដាលវាល ។ យូរទៅទៀតពួកគេមានលក្ខណៈដូចជាក្រុមកាយឫទ្ធិជាងកងទ័ពកាន់កាប់មួយ ។ ក៏ប៉ុន្តែ ក្នុងរយៈពេលនេះ មេបញ្ជាការទាំងឡាយរបស់ពួកគេ បានប្រមូលយកសម្រាប់ខ្លួនឯងផ្ទាល់នូវភូមិគ្រឹះធំៗ អគាររដ្ឋាភិបាលទំនើបៗ សម្រាប់ពួកមេដឹកនាំថ្មី រថយន្តប្រណីតៗរបស់អាមេរិកាំង សម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនរបស់គេ រួមទាំងនិមិត្តរូបផ្សេងៗនៃរបៀបរស់នៅបែបលោកខាងលិច ដែលពួកគេបានថ្កោលទោសក្នុងអត្ថបទផ្សេងៗរបស់គេ ប្រឆាំងនឹងអំពើពុករលួយនៅវៀតណាមខាងត្បូងផង ។

នយោបាយនេះស្ថិតត្រង់ដណ្ដើមយកភាគខាងត្បូង និងបញ្ចូលដោយកម្លាំងក្នុងរបៀបគ្រប់គ្រងមួយដែលបង្កើតឡើងទៅតាមគោលការណ៍របស់ភាគខាងជើង ដែលជំរុញឲ្យមានពួកអ្នកភៀសខ្លួនតាមទូក និងសង្គ្រាមឥណ្ឌូចិនលើកទីបីដោយផ្ទាល់ ។ ក្រុងហាណូយអាចត្រឹមតែអះអាងថា ភាគខាងជើង ភាគកណ្ដាល និងភាគខាងត្បូងប្រទេសវៀតណាម អាចរួបរួមជាមួយគ្នាដោយកម្លាំងនៃការទាក់ចិត្តមួយ ដើម្បីបង្កើតរដ្ឋកុម្មុយនិស្តមួយ ដែលគ្រប់គ្រងដឹកនាំដោយក្រុងហាណូយប៉ុណ្ណោះ ។ ពេញរយៈពេលនៃប្រវត្តិសាស្ត្ររបស់ខ្លួន ប្រទេសវៀតណាម បានរួបរួមគ្នាតែមួយជាងហុកសិបពីរឆ្នាំ ។ ភាគខាងជើង និងភាគខាងត្បូង ធ្លាប់ជាប្រទេស ឬមានវប្បធម៌ ដាច់ឡែកពីគ្នា ក្នុងរយៈពេលមួយពាន់ឆ្នាំមកហើយ ។ ពួកវៀតណាមដែលតាំងលំនៅក្នុងភាគខាងត្បូង ធ្លាប់បានទទួលឥទ្ធិពលនៃវប្បធម៌ទន្លេមេគង្គ ហើយគ្មានវិធីបញ្ចុះបញ្ចូលណាមួយ អាចញុំាងឲ្យប្រជាជននៅទីនោះមិនផ្លាស់ប្ដូរគំនិត

សោះឡើយ ។ ប៉ុន្តែក្រុងហាណូយពុំបានណែនាំឲ្យយោគយល់ដល់សម័យនៃការពិនិត្យឡើងវិញ ឬការពិចារណាមួយ ដើម្បីទទួលប្រជាពលរដ្ឋភាគខាងត្បូងឡើយ ហើយប្រាកដជាពុំមែនសម្រាប់ពួកមិនមែនកុម្មុយនិស្តទេ ។

ពួកវៀតណាមខាងជើងចូលចិត្តមិនស្វែងយល់ពីរឿងប្រវត្តិសាស្ត្រ ដាងដែលនាំឲ្យមានការបែកចេញជាពីរមួយ ដែលស្រពេចស្រពិល និងត្រឡប់ត្រឡិន គឺពួកកុម្មុយនិស្តប្រឆាំងនឹងពួកមិនមែនកុម្មុយនិស្ត ពួកម្ចាស់កសិដ្ឋាន និងពួកអ្នករកស៊ីនៅភាគខាងត្បូង ប្រឆាំងនឹងអ្នកធ្វើការក្នុងការិយាល័យ និងកម្មាភិបាលនៅភាគខាងជើង ប្រជាជនស៊ីវិលប្រឆាំងនឹងពួកយោធា ។ ប៉ុន្តែនៅទីបំផុត ប្រជាជនបានបញ្ចេញឲ្យដឹងគំនិតខ្លួនថា ភាពមិនដូចគ្នាទាំងនេះ ជាការប្រឈមមុខមួយរវាងខាងជើង-ខាងត្បូង ហើយបដិសេធមិនធ្វើសហប្រតិបត្តិការទេ ។ រៀងរាល់លើកដែលភាគខាងជើងដាក់ឲ្យអនុវត្តនយោបាយថ្មីមួយ ភាគខាងត្បូងតែងតែរកឃើញមធ្យោបាយថ្មីដើម្បីជៀសឲ្យផុតពីបញ្ហានោះជានិច្ច ។ នៅពេលដែលភាគខាងជើងប្រើវិធានការកាន់តែម៉ឺងម៉ាត់ឡើង ប្រជាពលរដ្ឋនៅភាគខាងត្បូង បានចាប់ផ្ដើមរត់ភៀសខ្លួនតាមទូកកញ្ចាស់ៗ ចេញពីប្រទេស ។

តាមទិដ្ឋភាពខាងក្រៅ ការរៀបចំថ្មីនេះគឺសមស្របតាមទស្សនៈសង្គមនិយម ដែលក្រុងហាណូយប្រឹងប្រែងធ្វើឲ្យបានសម្រេចនៅភាគខាងជើងដែរ ។ ពួកមេដឹកនាំប្រទេស បានប្រកាសឲ្យដឹងពីបំណងប្រមូលផ្ដុំការប្រឹងប្រែងរបស់ពួកគេ ទៅលើការកសាងប្រទេសឡើងវិញ ដោះស្រាយបញ្ហាស្ដីពីបទខក្រិដ្ឋសង្គ្រាម និងការសំដែងភាតរភាពជាមួយសត្រូវ -របបរបស់ ធីវ និងពួកអាមេរិកាំង- ដោយកម្មវិធីអប់រំជាថ្មីមួយ ប្រកបដោយលក្ខណៈ«មនុស្សធម៌» សម្រាលការខូចខាតផ្សេងៗតាមទីក្រុង ដែលបន្កឡើងដោយសង្គ្រាម ដោយរៀបចំបង្កើត «តំបន់សេដ្ឋកិច្ចថ្មី» នៅជនបទទុកសម្រាប់ពួកអ្នកទីក្រុង ។ ក្នុងគោលបំណងចៀសពីបញ្ហាអត់ការងារធ្វើធ្ងន់ធ្ងរមួយ ពួកមេដឹកនាំវៀតណាម បានសម្រេចចិត្តមិនរំសាយកម្លាំងទ័ពរបស់ពួកគេឡើយ ដែលក្រោយសម័យសង្គ្រាមមានចំនួនដល់ទៅ មួយលាននាក់ ។

តាមការពិត នយោបាយនេះបាននាំឲ្យភាគខាងត្បូងឃ្លាតកាន់តែឆ្ងាយពីភាគខាងជើងថែមទៀត និងនាំទៅរកបរាជ័យមួយក្នុងទូទាំងប្រទេស ជាពិសេសសម្រាប់ការស្ដារប្រទេសឡើងវិញ ។ ក្រុងហាណូយបានប្រកាន់យកពាក្យស្លោក «យកជ័យជម្នះលើសេដ្ឋកិច្ចឲ្យបាន» បន្ទាប់មក បានស្នើឲ្យមិត្តភក្ដិនានារបស់ខ្លួនក្នុងពិភពលោកទាំងមូល ជួយបរិច្ចាកប្រាក់រាប់កោដិដុល្លារ ដើម្បីកសាងប្រទេសមួយឡើងវិញក្នុងចំណោមប្រទេសជាច្រើន ដែលត្រូវបំផ្លិចបំផ្លាញច្រើនជាងគេនៃភពផែនដី ។ ដោយគួរឲ្យស្ដាយ ប្លុកកុម្មុយនិស្តពុំបានដាក់ចេញផែនការ ម៉ារស្ហលមួយសម្រាប់ប្រទេសវៀតណាមទេ ។ ប្រជាជាតិនានាក្នុងប្លុកសូវៀតបានផ្ដល់បីកោដិដុល្លារ សម្រាប់រយៈពេលពីរឆ្នាំដំបូង ប៉ុន្តែជាមួយលក្ខខណ្ឌតឹងរ៉ឹងជាច្រើន ជាពិសេស មួយផ្នែកធំនៃលុយនេះ គឺត្រូវសងវិញជាវត្ថុ ។ ប្រទេសចិនបានបន្ទាបកម្រិតជំនួយដែលផ្ដល់ឲ្យក្នុងរយៈពេលសង្គ្រាម ។ នៅទីបំផុត ពួកវៀតណាមត្រូវបានប្រទេសផ្សេងៗសន្យាផ្ដល់ឲ្យប្រហែលប្រាំមួយកោដិដុល្លារ -នេះជាចំនួនប្រាក់គួរឲ្យរីករាយមួយ ប៉ុន្តែតំណាងឲ្យ

សេចក្តីត្រូវការរបស់ពួកគេតែពាក់កណ្តាលប៉ុណ្ណោះ ។

តមកទៀត ពួកគេបានតែបំបាត់ជំនួយនេះ ក្នុងកម្មវិធីកសាងប្រទេសឡើងវិញមួយ ដែលមិនអាចធ្វើបាន ។ ប្រាក់ស្ទើរតែទាំងអស់ត្រូវបានយកទៅប្រើការភាគច្រើននៅភាគខាងជើង ចំណែកភាគខាងត្បូងតោងតែប្រឹងត្រដររស់ ដោយសារស្តុកផ្សេងៗ ដែលមាននៅសល់អំពីរបបចាស់ និងផលដំណាំដ៏សម្បូររបស់ខ្លួន ។ ម្យ៉ាងទៀត កម្មវិធីជំនួយដែលជ្រើសសម្រាប់ភាគខាងជើង នឹងត្រូវព្រមព្រៀងគ្នានៅក្រុងហុងកុងជាងប្រទេសវៀតណាម ។ ជាជំនួសការស្នើសុំលុយដើម្បីកសាងផ្លូវថ្នល់ រៀបចំបណ្តាញអគ្គិសនីនិងប្រព័ន្ធធារាសាស្ត្រឡើងវិញ... ។ល ។ ប្រទេសវៀតណាម បានទទូចសុំនិងទទួលបានមូលនិធិយ៉ាងច្រើន សម្រាប់ស្ថាបនាកម្មន្តសាលធ្វើក្រដាសមួយ ដែលចំណាយលុយអស់យ៉ាងច្រើនក្នុងភាគខាងជើង និងមន្ទីរពេទ្យទំនើបមួយនៅក្រុងហាណូយ ដែលពួកវៀតណាមមិនអាចទ្រទ្រង់ និងផ្គត់ផ្គង់សម្ភារៈវះកាត់សម្រាប់ មន្ទីរព្យាបាលរោគតាមខេត្ត ដែលមានសម្ភារៈសុទ្ធតែអន់ៗ គឺគ្មានទាំងខណ្ឌមាត្រ (ប្រដាប់ស្ទង់កម្តៅ និងអគ្គិសនីទៀតផង ។ ពួកមេដឹកនាំក្រុងហាណូយមិនព្រមទទួលស្គាល់ថា ប្រទេសខ្លួនជាប្រទេសក្រីក្រមួយក្នុង ចំណោមប្រទេសក្រីក្រជាងគេនៃពិភពតតិយលោកឡើយ ហើយថា គេត្រូវការជំនួយមូលដ្ឋានមួយមុននឹងអាចកសាងហេដ្ឋារចនាសម្ពន្ធខស្សរាហកម្មមួយ ។ ពួកមេដឹកនាំវៀតណាមជឿថា អាចកសាងសង្គមមួយដែលធ្វើឲ្យមានលក្ខណៈជាខស្សរាហកម្ម ទំនើបទាន់សម័យតែមួយជំនាន់មនុស្សប៉ុណ្ណោះ ។ ចំពោះចំណុចនេះ ពួកគេមានការប្រាស់ប្រាល់ដូចពួកកម្ពុជានៅក្បែរខាងពួកគេដែរ : ពួកគេចង់ធ្វើឲ្យសម្រេចលទ្ធផលផ្នែកសេដ្ឋកិច្ចដ៏អស្ចារ្យភ្លាមៗបន្ទាប់ពីសង្គ្រាម ហើយពួកគេមិនព្រមស្តាប់ការណែនាំណាមួយរបស់ពួកអ្នកជំនាញការបរទេស -មួយភាគយ៉ាងធំ ជាអ្នកជំនាញការសូវៀត- ដែលព្រមានថាពួកគេកំពុងអារ-ក ខ្លួនឯងហើយ ។

រូបភាពដែលពួកវៀតណាមមានខ្លួនឯង មិនអនុញ្ញាតឲ្យក្រុងហាណូយធ្វើអ្វីមួយផ្សេងពីនេះឡើយ ។ ពួកគេជាស្តេចដេវីដ *(David)* នៃពិភពតតិយលោក ដែលបានវាយឈ្នះយក្ស ហ្គូលីយ៉ាត *(Goliath)* អាមេរិកាំង ។ ពួកគេបានវាយឈ្នះតែម្នាក់ឯង ដោយគ្មានជំនួយពីកងទ័ពបរទេសណាមួយ និងដោយគ្មានរដ្ឋាភិបាលបរទេសមួយ ដាក់បង្ខំឲ្យធ្វើតាមឆន្ទៈខ្លួនឡើយ ។ ពួកគេជាមនុស្សវិសេសលើសមនុស្សផងទាំងពួង ជារឿងនិទានរស់មួយ ។ ហើយពួកគេគិតថា ប្រទេសវៀតណាមជាប្រទេសខ្ពង់ខ្ពស់ជាងគេមួយក្នុងចំណោមបណ្តាប្រទេសខ្ពង់ខ្ពស់ជាងគេនៃពិភពលោក- ពុំនោះសោត តើត្រូវបកស្រាយពីការសាកល្បងរបៀបធ្វើអត្តឃាដខ្លួនឯង របស់ពួកបារាំង និងពួកអាមេរិកាំង ព្រោះតែមិនទទួលស្គាល់ឯករាជ្យរបស់គេ ក្រោមការវាយប្រហាររបស់ចលនាកុម្មុយនិស្តវៀតណាមដោយរបៀបណាទៅ? ។

អ្នកនាំពាក្យម្នាក់ក្នុងចំណោមអ្នកនាំពាក្យរបស់ប្រទេសវៀតណាម បានប្រកាសជាច្រើនឆ្នាំក្រោយមកថា "មុនដំបូងយើងចង់បង្កើតអ្វីៗ ដែលមានលក្ខណធំខ្លាំងណាស់ ដូចជារោងចក្រ ការដ្ឋានធំៗជាដើម ។ ប៉ុន្តែ វាគ្មាន

បានចេញជាលទ្ធផលអ្វីទាំងអស់ ។ ប្រភពធនធានផ្សេងៗ របស់យើងត្រូវប្រើប្រាស់អស់... ។ យើងមិនដឹងអ្វីខ្លះដែលយើងត្រូវរៀបចំទេ... ។ ក្នុងសម័យសង្គ្រាម យើងមានជីវិតរស់នៅដោយសារជំនួយបរទេសជាសំខាន់ ។ រដ្ឋមិនគ្រប់គ្រងសេដ្ឋកិច្ចឡើយ រដ្ឋគ្រាន់តែចែកផលិតផលផ្សេងៗដែលមកពីបរទេសប៉ុណ្ណោះ -អង្ករ សម្លៀកបំពាក់ ។ល ។ សេចក្តីត្រូវការរបស់យើងនៅលើសមរភូមិមានច្រើនជាងអ្វីៗទាំងអស់ ទោះជាមានតម្លៃថ្លៃយ៉ាងណាក៏ដោយ[៣១] » ។

ពួកអ្នកជំនាញការដែលគ្មានពិសោធន៍នៅភាគខាងជើង ត្រូវបានបញ្ជូនមកភាគខាងត្បូង ដើម្បីបង្កើតរបៀបគ្រប់គ្រងសង្គមនិយមមួយនៅទីនោះ ហើយបញ្ជូនទៅភាគខាងជើងវិញ នូវផលកម្រៃផ្សេងៗ ដែលសម្រេចធ្វើបានដោយវិស័យឧស្សាហកម្ម និងកសិកម្មនៅភាគខាងត្បូង ដែលភាគខាងជើងមានបំណងប្រើប្រាស់សម្រាប់ការស្តារប្រទេសរបស់ខ្លួនឡើងវិញ ។ ប៉ុន្តែមានរឿងមួយ ដែលប្រជាជនវៀតណាមខាងត្បូងចេះយ៉ាងប៉ិនប្រសប់គឺការរកលុយ ។ អ្នកដឹកនាំបារាំងម្នាក់ ដែលបណ្តាជនរួមជាតិរបស់គាត់ជាសាក្សី នៃដំណាក់កាលដំបូង ក្នុងការច្បាំងដណ្តើមភាគខាងត្បូងនេះ បានអះអាងថា ពួកវៀតណាមខាងជើងបាន «បំបែកវៀតណាមខាងត្បូង ក្នុងរយៈពេលមិនដល់មួយឆ្នាំផង[៣២] » ។ បើក្រុងហាណូយមិនធ្វើជាតូបនីយកម្មបណ្តាសហគ្រាសឯកជនទេ ក៏ត្រូវដាក់ឲ្យស្ថិតនៅក្រោមការត្រួតត្រារបស់ខ្លួនដែរ ។ បណ្តាគនេយ្យករនៅភាគខាងជើង ត្រូវបានបញ្ជូនយ៉ាងប្រញាប់ឲ្យមកធ្វើការក្នុងសហគ្រាសឯកជនទាំងអស់ ដែលពួកគេបានបង្គាប់ឲ្យធ្វើតាមអំពីរបៀបប្រើប្រាស់សមត្ថភាពផ្សេងៗ ដែលផ្តល់ផលច្រើន ។ គេបានបង្គាប់ដូច្នេះ ឲ្យចាងហ្វាងរោងចក្ររថយន្តមួយ សញ្ជាតិបារាំងផ្លាស់ពីការផលិតរថយន្តហ្ស៊ីប ទៅផលិតឧបករណ៍តូចៗវិញ ។ ចាងហ្វាងនោះត្រូវតែផ្តើមគំនិត និងធ្វើហិរញ្ញប្បទានដោយខ្លួនឯងផ្ទាល់ នូវការផ្លាស់ប្តូរដែលចៀសមិនរួចនេះ ដោយរក្សាទុកបុគ្គលិកធ្វើការដដែល ភាពអត់ការងារធ្វើមានខ្ពស់ខ្លាំងណាស់ ដែលមិនអាចឲ្យពួកគេទៅធ្វើការផ្សេងពីនេះឡើយ ។ ចាងហ្វាងសញ្ជាតិបារាំងបានបំភ្លឺថា «ពុំមានការដាស់តឿនឲ្យធ្វើការផ្លាស់ប្តូរជាលំដាប់លំដោយ ពីចង្វាក់ផលិតកម្មមួយ ទៅចង្វាក់ផលិតមួយទៀតឡើយ» ។

ក្នុងរយៈមួយឆ្នាំ រោងចក្រធុនស្រាលជាង៧០ភាគរយនៅភាគខាងត្បូងត្រូវបានធ្វើជាតូបនីយកម្ម ហើយផលិតផលសរុបរបស់ភូមិភាគនេះបានបាត់បង់ ៣០ភាគរយ បើប្រៀបធៀបនឹងកម្រិតផលិតរបស់ខ្លួន នៅសម័យសង្គ្រាម ។ ការទទួលខុសត្រូវមួយផ្នែកត្រូវធ្លាក់ ទៅលើសហរដ្ឋអាមេរិក ដែលបានដាក់ទណ្ឌកម្មសេដ្ឋកិច្ចទាំងស្រុងមួយទៅលើប្រទេសវៀតណាម ហើយហាមឃាត់មិនឲ្យបណ្តាក្រុមហ៊ុនអាមេរិកាំង ជួយផ្តល់គ្រឿងបន្លាស់ចាំបាច់ទៅឲ្យពួកវៀតណាម ដើម្បីផ្គត់ផ្គង់រោងចក្រទាំងឡាយ ដែលកសាងក្នុងភាគខាងត្បូងដោយពួកអាមេរិកាំងឡើយ ។

ក្រុងហាណូយ មិនព្រមទទួលស្គាល់ថា គម្រោងការផ្សេងៗរបស់ខ្លួនទទួលបរាជ័យទេ ។ មួយឆ្នាំបន្ទាប់ពី

ជ័យជម្នះ នៅខែមិថុនា ឆ្នាំ១៩៧៦ ឡេយន់ អគ្គលេខាបក្សកុម្មុយនិស្តវៀតណាម បានថ្លែងការណ៍ទៅកាន់រដ្ឋសភាដំបូងរបស់ប្រទេស ដែលបង្រួបបង្រួមឡើងវិញ ។ ប្រជាជនវៀតណាម បានជ្រើសតាំងអ្នកតំណាងរាស្ត្រជាច្រើនរូបក្នុងឱកាសនៃការបោះឆ្នោតយកតែនាមប៉ុណ្ណោះ ហើយក្នុងភាគច្រើនបំផុតនៃប្រទេស មនុស្សខ្លះបានប្រើប្រាស់ប័ណ្ណបើកអង្ករបស់គេយកទៅបោះឆ្នោតទៀតផង ។ បើសិនប័ណ្ណនេះពុំមានបោះត្រារបស់ការិយាល័យបោះឆ្នោតទេ ក៏អ្នកកាន់ប័ណ្ណនេះលែងមានសិទ្ធិទៅបើកអង្ករបានដែរ ។ ឡេយន់ បានប្រកាសចំពោះរដ្ឋសភាជាតិថ្មីនេះថា ៖ «ភារកិច្ចចម្បងរបស់យើងគឺកសាងបណ្តាញឧស្សាហកម្មធុនធ្ងន់មួយ... នៅភាគខាងជើង» ។

នៅចុងបញ្ចប់សុន្ទរកថានេះ គាត់បានប្រកាសឲ្យដឹងជាសាធារណៈនូវផែនការប្រាំឆ្នាំមួយ ហើយបញ្ជាក់ថាគាត់សង្ឃឹមលើភាគខាងត្បូងថានឹងផលិតស្រូវយ៉ាងគ្រប់គ្រាន់ដើម្បីផ្គត់ផ្គង់ប្រទេសវៀតណាមទាំងមូល និងនាំរូបិយប័ណ្ណចូលប្រទេស ដើម្បីនឹងជួយគាំទ្រដល់ការធ្វើឲ្យមានឧស្សាហកម្មនៅភាគខាងជើង ។ គាត់សង្ឃឹម ថាប្រជាជាតិកុម្មុយនិស្តទាំងឡាយនឹងបង្កើនជំនួយរបស់គេ ប៉ុន្តែជំនួយនេះមិនដែលលេចចេញជារូបរាងពិតប្រាកដឡើយ ។ អ្នកការទូតអឺរ៉ុបខាងកើតម្នាក់ ដែលមានមុខតំណែងនៅក្រុងហាណូយ បានប្រាប់ឲ្យដឹងថា ៖ ហេតុអ្វីបានជាពួកគេបន្តសុំជំនួយមិនឈប់ ពីព្រោះពួកគេមិនចេះពីរបៀបរៀបចំទម្រង់សេដ្ឋកិច្ចតាមផែនការមួយ ហើយបើមើលតាមសភាពខាងក្រៅ ពួកគេមិនខ្វីរវល់នឹងផែនការផងទេ ។ គឺពិបាកណាស់សម្រាប់ប្រទេសសង្គមនិយមនានាដែលធ្វើពាណិជ្ជកម្មជាមួយប្រទេសវៀតណាម ជាងជាមួយប្រទេសមូលធននិយមមួយ ដោយសារតែពួកវៀតណាមសុំជំនួយពីយើងមិនឈប់ ហើយសុំកាន់តែច្រើនថែមទៀត និងលក្ខខណ្ឌអនុគ្រោះច្រើនឡើងៗ[៣៣] » ។

តាមការពិត បណ្តាប្រទេសអឺរ៉ុបខាងកើត ជាបណ្តាប្រទេសក្នុងចំណោមប្រទេសដំបូងៗ ដែលយល់ពីចន្លោះចាប់ផ្តាក់បានរបស់វៀតណាម ៖ ពួកវៀតណាមប្រកាន់អាកប្បកិរិយាហំហានណាស់ នៅមុខមហន្តរាយមួយ ប៉ុន្តែបញ្ចេញឲ្យឃើញអសមត្ថភាពដឹកនាំឲ្យល្អប្រសើរ នូវភារកិច្ចដែលគ្មានផល ក្នុងការស្តារសង្គមមួយឡើងវិញសោះ -យ៉ាងហោច ពួកវៀតណាមដែលនិយមកសាងកម្លាំងទ័ពនៅភាគខាងជើង ។ ស្ថានការណ៍មានសភាពរឹតតែធ្ងន់ធ្ងរឡើងនៅឆ្នាំ១៩៧៦ ក្រោយពេលដែល ឡេយន់ ធ្វើសេចក្តីថ្លែងការណ៍អំពីផែនការប្រាំឆ្នាំរបស់គាត់ ។ ប្រទេសចិនបានបញ្ឈប់ការផ្តល់អង្ករដោយឥតគិតថ្លៃ ហើយដែលមានជាមធ្យមចំនួនមួយលានតោនកន្លះក្នុងមួយឆ្នាំ ។ ពួកចិនបានកាត់បន្ថយឬផ្អាកកម្មវិធីជំនួយផ្សេងទៀត ក្នុងការផ្គត់ផ្គង់ឲ្យពួកវៀតណាមជាវត្ថុចាំបាច់ផ្សេងៗ សម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃ ៖ បំពង់ទឹកក្តៅ ចង្កឹះដែកសម្រាប់ផ្សារចង្កៀងប្រេង កាត ឆ្នៀតសម្លៀកបំពាក់ និងប្រដាប់ក្មេងលេង ។ កម្មន្តសាលផលិតគ្រឿងបរិភោគ ដែលកសាងនៅវៀតណាមខាងត្បូងក្នុងកំឡុងសង្គ្រាមដោយពួកអាមេរិកាំង មិនអាចបញ្ចៀសការខ្វះខាតក្នុងពេលមានសន្តិភាពបានទេ មួយផ្នែកធំគឺបណ្តាលមកពីការគ្រប់គ្រងមិនល្អរបស់ពួកអ្នកធ្វើការក្នុងការិយាល័យ ដែលមកពីភាគខាងជើង ។

មិនយូរប៉ុន្មាន ម្ហូបអាហារក៏ខ្វះខាតដូចគ្នា ។ ត្រង់នេះទៀត គេបានលើកហេតុផលខាងនយោបាយច្រើន

ជាងខាងសេដ្ឋកិច្ច ។ នៅឆ្នាំ១៩៧៦ ប្រជាកសិករទាំងឡាយនៅតំបន់ សម្បូរដីធ្វើស្រែនៃដែនដីសណ្ដទន្លេមេគង្គ មិនអាចលក់អង្ករឲ្យរដ្ឋាភិបាលលើសពីប្រាំមួយរយពាន់តោន តាមតម្លៃផ្លូវការដែលកំណត់ក្រោមតម្លៃទីផ្សារឡើយ[៣៤] ។ កសិករជាច្រើនឈប់ធ្វើស្រែ ។ នៅចុងឆ្នាំ១៩៧៦ ប្រទេសវៀតណាមខ្វះស្រូវដល់ទៅមួយលានតោនកន្លះ ។ ម្យ៉ាងទៀត អតិផរណាបានឡើងដល់អត្រាមួយ លើសពីមួយរយភាគរយទៅទៀត ។

ភាពអត់ការងារធ្វើនៅតែជាបញ្ហាមួយ ដោយហេតុថា អ្នកទីក្រុងព្រៃនគរជិតមួយលាននាក់ស្ថិតនៅក្នុងស្ថានភាពគ្មានការងារធ្វើបន្ទាប់ពីសម័យសង្គ្រាម ។ ដើម្បីយកអ្នកគ្មានការងារធ្វើជាប្រជាជនវៀតណាមខាងត្បូងទៅដាក់នៅជនបទ ពួកមេដឹកនាំភាគខាងជើងបានបង្កើត «តំបន់សេដ្ឋកិច្ចថ្មី» នៅក្នុងតំបន់រហោឋានជាច្រើន ស្ថិតក្បែរព្រំដែនរបស់កម្ពុជា ។ កងទ័ពមានករណីកិច្ចកាប់រានដីនៅទីនោះ ដោយស្ថាបនាផ្លូវថ្នល់ជាច្រើន កសាងទីលំនៅឲ្យតែបានៗ និងមជ្ឈមណ្ឌលសម្រាប់សហគមន៍មួយ ដែលប្រើសម្រាប់ធ្វើជាសាលារៀន និងមន្ទីរព្យាបាលរោគ ។

កម្មវិធីនេះ មានភាពជាភយន្តរាយមួយ ។ កងទ័ពពុំបានប្រកាន់តាមការសន្យារបស់រដ្ឋាភិបាលទេ ៈ ព្រៃស្បាត នៅតែជាព្រៃស្បាតដដែល ហើយពួកអ្នកទីក្រុងដែលត្រូវបញ្ជូនទៅទីនោះ បានចាកចេញ និងត្រឡប់មកទីក្រុងព្រៃនគរវិញ ។ ក្រោយមក អ្នកទាំងឡាយដែលគេបញ្ជូនទៅដាក់ម្ដងទៀត ក្នុងតំបន់សេដ្ឋកិច្ចថ្មី បានសម្រេចចិត្តចាកចេញពីប្រទេស ហើយធ្វើឲ្យចំនួនអ្នកភៀសខ្លួនតាមទូកមានកាន់តែច្រើនឡើងៗ ។

បរាជ័យនៃតំបន់សេដ្ឋកិច្ចថ្មី ក៏ជាការបរាជ័យនៃផែនការមួយដែលលោភលន់ហួសកម្រិតដែរ ។ ក្រុងហាណូយធ្លាប់សង្ឃឹមថា ប្រជាពលរដ្ឋភាគខាងត្បូង នឹងទៅកាប់រានស្រែចម្ការ នៅតាមតំបន់ក្បែរប្រទេសកម្ពុជាមិនខាន ។ ការធ្វើដូច្នេះ គឺសម្រាប់ទុកកន្លែងឲ្យអ្នកមកពីភាគខាងជើង ដែលនឹងមកតាំងលំនៅក្នុងភាគខាងត្បូងវិញ ។ ក្រុងហាណូយ បានរៀបចំផែនការ ដោយគ្រោងទុកជាមុនក្នុងការផ្លាស់ប្តូរកន្លែងរស់នៅរបស់ប្រជាជនដប់លាននាក់ ពីភូមិភាគខាងជើង ដែលមានប្រជាជនច្រើនហួស មកភាគខាងត្បូងវិញនៅមុនឆ្នាំ២០០០[៣៥] ។ ចិត្តគំនិតរបស់ពួកវៀតណាមនៃទន្លេក្រហម ពុំមានផ្លាស់ប្តូរទេ ។ ពួកគេមានបំណងបន្តការវាតទីកដី ឆ្ពោះមកទិសខាងត្បូង និងខាងលិចទៀត- ដែលក្នុងទីបំផុត ការដែលពួកគេធ្វើដូច្នេះ ពុំមែនដោយសារតំបន់សេដ្ឋកិច្ចថ្មីទេ ប៉ុន្តែដោយចូលលុកលុយ និងកាន់កាប់ប្រទេសកម្ពុជានៅពីរឆ្នាំក្រោយមក ។

ការស្រងាកចិត្តដ៏ជ្រាលជ្រៅមួយ បានរួបរឹតប្រជាជនវៀតណាមខាងត្បូង នៅពេលដែលពួកគេយល់ច្បាស់ពីកម្មវិធីអប់រំជាថ្មី របស់ភាគខាងជើងមានន័យថាយ៉ាងម៉េចៗ ។ ដើមដំបូង ការអប់រំជាថ្មីបានបញ្ចេញឲ្យឃើញ ជាការបង្រៀនវិជ្ជាពលកម្មធម្មតា ឬការបញ្ចុះបញ្ចូលឲ្យជឿតាមនយោបាយរដ្ឋាភិបាលប៉ុណ្ណោះ ។ ក្រុងហាណូយពុំមានប្រកាសឲ្យដឹងរឿងអ្វីទាំងអស់ ដែលអាចប្រៀបធៀបបាននឹងការកាត់ក្ដីនៅ នុយរ៉ែមបឺក ចំពោះបទឧក្រិដ្ឋសង្គ្រាម ហើយបានប្រកាសផ្ទុយទៅវិញថា រដ្ឋាភិបាលនឹងខំប្រឹងកែលម្អសតិអារម្មណ៍នយោបាយ

មិនត្រឹមត្រូវរបស់បណ្តាអតីតគូសត្រូវរបស់ខ្លួនតែប៉ុណ្ណោះ ។ ការអប់រំជាថ្មី ហាក់ដូចជា រឿងមិនសូវសំខាន់មួយ - ហើយការអប់រំជាថ្មី ត្រូវបានដឹកនាំធ្វើដោយពិតប្រាកដ ក្នុងអំឡុងខែដំបូងៗ ។ គេដឹកនាំធ្វើការអប់រំជាថ្មី តាមរោងចក្រនានា តាមផ្ទះ និងនៅកាច់ជ្រុងផ្លូវទាំងឡាយ នៃទីក្រុងព្រៃនគរ ។

ប៉ុន្តែ នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៧៥ ពួកអ្នកកាន់រដ្ឋអំណាច បានបញ្ជាឲ្យ «ទាហានអាយ៉ង» ទាំងអស់នៅក្រុងព្រៃនគរ ចូលរួមធ្វើកម្មសិក្សារៀនសូត្រមួយ ក្នុងរយៈពេលបីថ្ងៃ ។ ពួកនាយទាហាន ពួកមន្ត្រីជាន់ខ្ពស់ និងអ្នកនយោបាយសំខាន់ៗ នៃរបបចាស់ បានទទួលបញ្ជាឲ្យប្រមូលផ្តុំគ្នា ដោយមានស្បៀងអាហារ សម្លៀកបំពាក់ ។ល ។ផង សម្រាប់រយៈពេលមួយខែ ។

អ្នកទាំងអស់នេះ ពុំមែនចេញដំណើរទៅមួយខែ ដូចដែលពួកគេគិតស្មានជាមុនទេ ប៉ុន្តែ សម្រាប់រយៈពេលមួយដែលគ្មានកំណត់ ។ គេបានបញ្ជូនអ្នកទាំងនោះ ទៅដាក់គុកនៅជនបទ ឬជំរំការងារ ជាទីដែលសម័យប្រជុំរៀនសូត្រមានតិចតួច របបអាហារកាន់តែខ្វះទៅៗ ហើយការព្យាបាលអ្នកជំងឺមិនគ្រប់គ្រាន់ ។ នៅទីក្រុងព្រៃនគរ គ្រួសារអ្នកជាប់ឃុំឃាំងជាច្រើន នឹកតូចចិត្តទ្រាំលែងបាន ហើយបានចាត់ចែងរៀបចំធ្វើបាតុកម្មមួយ ដែលមានមនុស្សចូលរួមជាច្រើនរយនាក់ ដើម្បីសួរឲ្យដឹងយ៉ាងហោចថា កាលណាពួកអ្នកទោសនឹងត្រឡប់មកវិញ ។ ចម្លើយមានលក្ខណៈមិនច្បាស់លាស់សោះ ៖ «ពួកអាយ៉ង» នឹងមិនត្រូវដោះលែងមុនរយៈពេលដាក់លាក់មួយទេ ។

ប្រព័ន្ធតុលាការរបស់ក្រុងហាណូយ បង្ហាញឲ្យឃើញលក្ខណៈ ម៉ៅនិយម ឬស្តាលីននិយមខ្លះៗ ដែលដូចសុទ្ធសាធនឹងលក្ខណៈតុលាការរបស់ពួកកុម្មុយនិស្តកម្ពុជាដែរ ។ ទោសធ្ងន់ធ្ងរជាងគេគឺ បទឧក្រិដ្ឋនយោបាយ ។ ពួកអតីតសត្រូវ ពុំត្រូវបានចោទប្រកាន់ថា ប្រព្រឹត្តល្មើសនឹងច្បាប់សង្គ្រាម សម្លាប់រង្គាលប្រជាជនស៊ីវិល ប្រើប្រាស់ថ្នាំជម្រុះស្លឹកឈើ ឬប្រើឧបាយកលដណ្តើមអំណាចទេ ។ គេបាននិយាយផ្តាច់មិនឲ្យហើបមាត់រួច ដោយប្រជុំមនុស្សច្រើនថា «មនុស្សដែលមានទស្សនៈនយោបាយមិនត្រឹមត្រូវមួយ» ។ ពុំមានទាំងការកាត់ក្តី ចៅក្រមក្រុមប្រឹក្សាតុលាការ និងសាលដីកាឡើយ ។ (តាមការពិត គឺពុំមានរដ្ឋមន្ត្រីក្រសួងយុត្តិធម៌) ។ ប្រព័ន្ធអប់រំ ជាថ្មីលេចឡើងឲ្យឃើញថា ជាវិធីបញ្ឆោតមួយ ដែលនាំទៅដល់ការលុបបំបាត់សិទ្ធិ ដែលខ្លួនមិនយល់ព្រម -ពោលគឺមានការប្រព្រឹត្តនយោបាយមិនត្រឹមត្រូវមួយ ។

ពួកមេដឹកនាំក្រុងហាណូយ បានការពារ«ការអប់រំថ្មី»យ៉ាងម៉ឺងម៉ាត់ ដោយបង្ហាញថា នេះជាដំណោះស្រាយមួយដែលមានលក្ខណៈ«មនុស្សធម៌» ជាតុលាការមួយដូចតុលាការនៅ នុយរ៉ែមប៊ឺក ទៅទៀត ។ ង្វៀន កូថាច់ រដ្ឋមន្ត្រីក្រសួងការបរទេសវៀតណាម បានបំភ្លឺថា «យើងពុំមានការបង្ហូរឈាមនៅក្នុងប្រទេសទេ» ។ វាគ្មានប្រយោជន៍នឹងសម្លាប់មនុស្ស ដូចដែល ប៉ុល ពត ធ្លាប់បានធ្វើឡើយ... ។ នៅពេលដែលគេសម្លាប់មនុស្ស គេច្បាស់ជាបាត់បង់អត្ថន័យគ្រួសារមិនខាន[៣៦] » ។

ពិតហើយ វាពុំមានការបង្ហូរឈាម ដូចដែលគេនឹកគិតមែន ប៉ុន្តែ ប្រជាជនវៀតណាមជាច្រើនត្រូវស្លាប់

ដោយសារជំងឺ ការហូបអាហារមិនគ្រប់គ្រាន់ និងរបួសដែលរងទទួលពីការធ្វើទោស នៅក្នុងជំរំដ៏គួរឲ្យរន្ធត់ទាំងនេះ ។ ម៉្យាងទៀត ការបារម្ភអំពីការអប់រំជាថ្មី បានជំរុញឲ្យអ្នករត់ភៀសខ្លួនតាមទូកជាច្រើនលាននាក់ បោះបង់គ្រួសាររបស់គេ ដើម្បីចេញទៅរស់នៅឯបរទេស ។ ដ្បិតអី ការរក្សាទុកមនុស្សនៅមណ្ឌលអប់រំជាថ្មី សម្រាប់រយៈពេលគ្មានកំណត់មួយ ពុំមានត្រៀមបម្រុងយ៉ាងដាច់មុខ សម្រាប់តែពួកអតីតសត្រូវទេ ។ គេប្រើប្រាស់ជំរំនេះដើម្បីដាក់ទណ្ឌកម្មពួកអ្នកជំទាស់ប្រឆាំងនឹងរបបថ្មី ជាពិសេស បណ្ដាសមាជិក«កម្លាំងទីបី» ដែលជាមនុស្សនិយាយឥតបានការ ដែលធ្លាប់វាយប្រយុទ្ធនឹងប្រធានាធិបតី ធីវ ឬធ្លាប់ជាសមាជិករណសិរ្សរំដោះជាតិ ឬរដ្ឋាភិបាលបដិវត្តន៍បណ្ដោះអាសន្ន ដែលឥតក្លាយខ្លួនទៅជាអ្នកកុម្មុយនិស្ត ។ ចាប់ពីខែមិថុនា ឆ្នាំ១៩៧៥ ពួកអ្នកកាន់អំណាច បានចាប់ដាក់គុកអតីតព្រឹទ្ធបុរសមហាវិទ្យាល័យនីតិសាស្ត្រក្រុងព្រៃនគរ ដែលធ្លាប់ប្រកាន់ឥរិយាបថរិះគន់មួយចំពោះរបបប្រធានាធិបតី ធីវ ក្នុងកំឡុងពេលប្រទេសមានសង្គ្រាម[៣៧] ។ ពួកវៀតណាមខាងជើង មិនសូវចោទប្រកាន់ពី«បទក្បត់ជាតិ» ទេ ។ យុទ្ធិកជនម្នាក់ទៀតដែលមានកិត្តិនាម ត្រូវបានបញ្ជូនទៅដាក់ក្នុងជំរំធ្វើការអប់រំជាថ្មីមួយ គឺអ្នកនិពន្ធជាតិនិយម ហូហ៊ុយតុង ។ ជាមនុស្សមានអាយុចិតសិបឆ្នាំ គាត់ធ្លាប់បានរួចរស់ជីវិតពីគុក របស់ពួកបារាំងនិងគុករបស់ ង៉ោឌិញ យៀម ដែលបញ្ជូនគាត់ទៅដាក់គុក មានឈ្មោះល្បីល្បាញយ៉ាងអាក្រក់នៅលើកោះកុនស៊ឺន *(Con Son)* សម្រាប់រយៈពេលប្រាំឆ្នាំ ។ ប៉ុន្តែ តុង ពុំបានរួចរស់ជីវិតពីជំរំអប់រំជាថ្មីទាំងឡាយ ដែលមានលក្ខណៈ«មនុស្សធម៌» ទេ ហើយគាត់បានស្លាប់នៅក្នុងជំរំមួយក្នុងចំណោមជំរំទាំងនោះ ដោយសារតែរដ្ឋាភិបាលបដិសេធមិនឲ្យគ្រូពេទ្យព្យាបាលគាត់ ។ បញ្ជីរាយឈ្មោះឥស្សរជនជាកម្លាំងទីបី ដែលជាប់ឃុំឃាំងក្នុងជំរំនានាលូតកាន់តែវែងឡើង ។ កម្លាំងទីបីមួយរូបក្នុងចំណោមនោះ គឺអ្នកនិពន្ធម្នាក់ បានត្រូវគេបង្ខំឲ្យសរសេរ«ចម្លើយសារភាព» ជាច្រើន ដែលក្នុងនោះ គាត់បានទទួលស្គាល់ទស្សនៈនយោបាយខុសឆ្គងរបស់គាត់ ហើយរៀបរាប់ថា ពួកអ្នកទោសនៅជំរំគាត់ បានប្រៀបធៀបជាញឹកញយពីជោគវាសនារបស់គេ ទៅនឹងជោគវាសនារបស់អ្នកជាប់គុកនៅក្នុងប្រទេសកម្ពុជាក្បែរខាងដែរ ។ យើងទាំងអស់គ្នាទាមទារថា បើសិនជាយើងសមនឹងស្លាប់ សូមសម្លាប់យើងទៅប្រសើរជាងទុកឲ្យពួកយើងបញ្ចប់ជីវិតនៅក្នុងជំរំនេះ[៣៨]» ។

ប្រជាជនវៀតណាមរាប់សិបពាន់នាក់ បានរស់នៅក្នុងភាពគួរឲ្យអាម៉ាស់ដោយគ្មានកំណត់នៅក្នុងជំរំជាច្រើន នៅពេលដែលក្រុងហាណូយបំភ្លេចពាក្យសន្យារបស់ខ្លួន ដែលថាប្រព័ន្ធអប់រំជាថ្មី នឹងមិនតម្រូវឲ្យធ្វើការវិនិច្ឆ័យលើសពីបីឆ្នាំឡើយ ។

នៅឆ្នាំ១៩៧៦ ប្រជាជនយល់ច្បាស់ថា ទីបញ្ចប់នៃសង្គ្រាមពុំបាននាំមកនូវសន្តិភាពនិងវិបុលភាពទេ ។ បក្សកុម្មុយនិស្តបានសម្រេចធ្វើការសន្និដ្ឋានដដែលៗ ប៉ុន្តែ ដោយចាត់ទុកបញ្ហាប្រទេសតាមទស្សនៈមួយខុសគ្នាទាំងស្រុង ។ សម្រាប់មនុស្សទូទៅនៅភាគខាងត្បូងដ៏គួរឲ្យអាណិត និងប្រជាជននៅភាគខាងជើង ដែលត្រូវធ្វើឲ្យស្រងាកចិត្តយល់ថា នៅទីបំផុតនៃសង្គ្រាមបាននាំមកនូវបញ្ហាថ្មីៗជាច្រើន ។ ការខ្វះម្ហូបអាហារមានភាពរឹតតែ

កើនខ្លាំងឡើង ហើយវិន័យដ៏តឹងរ៉ឹងដែលដាក់បង្ខំឲ្យអនុវត្ត ដោយបក្សកុម្មុយនិស្ត ហាក់ដូចជាគ្មានប្រយោជន៍ផ្សេងទៀត ក្រៅពីគ្រប់គ្រងត្រួតត្រាប្រជាជន និងកាន់កាប់អំណាចឡើយ ។ ការសាកល្បងអ្វីៗឲ្យដឹងល្អឬអាក្រក់ពុំមែនមានតែសម្ភារៈប៉ុណ្ណោះទេ ប៉ុន្តែការស្តីបន្ទោសដែលនាំឲ្យខូចបរិយាកាស ។ អ្នកការទូតម្នាក់ ដែលបំពេញមុខងារនៅក្រុងហាណូយនៅសម័យនោះបានដំណាលថា ៖ «អ្វីៗទាំងអស់ដែលគេនិយាយប្រាប់ខ្ញុំ ស្តីពីប្រទេសវៀតណាមដោយរបៀបដែលធ្វើឲ្យរំភើបចិត្តខ្លាំងមួយ ឃើញថាសុទ្ធតែមិនពិត ។ ពួកវៀតណាម ពុំមែនជាអ្នកយុទ្ធសាស្ត្រចំណាន និងជាអ្នកការទូតប៉ិនប្រសប់ទេ ។ ពួកគេជាមនុស្ស... ចចេស ក្រអឺតក្រអោង ស្មោះត្រង់ និងតស៊ូស៊ូតស៊ូញ ។ មានតែសំដីភ្លីភ្លើរបស់អាមេរិកាំងប៉ុណ្ណោះ ដែលធ្វើឲ្យពួកគេលេចឡើងផ្សេងពីនោះ ។ គំនិតយល់ប្រឡំ ត្រូវរលាយបាត់បង់ជាមួយនឹងការចាកចេញរបស់ពួកអាមេរិកាំង[៣៩] » ។

ចំពោះខ្លួនវិញ បក្សយល់ឃើញថា បញ្ហាទាំងឡាយរបស់ខ្លួនបណ្តាលមកពីវិធានការផ្តល់សេរីភាពឲ្យប្រជាជនលឿនពេក ។ នៅខែវិច្ឆិកា ឆ្នាំ១៩៧៦ របបដឹកនាំប្រទេសបានពិនិត្យផែនការប្រាំឆ្នាំរបស់ខ្លួនឡើងវិញ យ៉ាងម៉ឺងម៉ាត់ ។ លែងមានមូលធនសម្រាប់ឧស្សាហកម្មធុនធ្ងន់ទៀតហើយ មួយចំណែកធំ ដោយសារតែប្លុកសូវៀតមិនគាំទ្រកម្មវិធីមួយបែបនោះ ។ ដូច្នេះ ឧស្សាហកម្មធុនស្រាលបានកាន់កាប់មុខនាទីយ៉ាងប្រសើរមួយក្នុងផែនការថ្មីរបស់រដ្ឋ ប៉ុន្តែគ្មានការធ្វើហិរញ្ញប្បទានច្រើនឡើងសម្រាប់សហគ្រាសទាំងឡាយ ដែលភាគច្រើនស្ថិតក្នុងភាគខាងត្បូងឡើយ ។ តើឧស្សាហកម្មនៅភាគខាងត្បូង អាចរីកលូតលាស់ដោយគ្មានមូលធនគ្រប់គ្រាន់ដូចម្តេចទៅ? ។ បក្សបានឆ្លើយតមនឹងបញ្ហានេះនៅខែបន្ទាប់ ជាពិសេស នៅមហាសន្និបាតលើកទី៤របស់ខ្លួន នៅខែធ្នូ ឆ្នាំ១៩៧៦ ដែលបក្សពលកររបស់វៀតណាម បានផ្លាស់ប្តូរឈ្មោះរបស់ខ្លួនជាផ្លូវការ ទៅជាបក្សកុម្មុយនិស្តវៀតណាមវិញ ។

ពួកមេដឹកនាំបក្សបានប្រកាសឲ្យដឹងជាសាធារណៈថា ភាគខាងត្បូងនឹងបង្កើយ «ដំណើរមួយឆ្ពោះទៅលទ្ធិសង្គមនិយម» បានលឿនរហ័សជាងការគ្រោងទុកជាមុន ។ ការដោះស្រាយបញ្ហាសេដ្ឋកិច្ច គឺមាននៅក្នុងគោលការណ៍ផ្សេងៗដែលមានលក្ខណៈតឹងរ៉ឹងបំផុត ការធ្វើតូបនីយកម្មច្រើនជាងមុន និងការដាក់ទោសកាន់តែម៉ឺងម៉ាត់ឡើងៗ ។ និយាយម្យ៉ាងទៀត ភាគខាងត្បូងនឹងទទួលការធ្វើឲ្យមាន«សន្តិភាព»ទាំងស្រុងមួយ ។ ការអប់រំជាថ្មីពុំគ្រប់គ្រាន់ទេ ការរៀបចំឲ្យមាន «តំបន់សេដ្ឋកិច្ចថ្មី» បានទទួលបរាជ័យ ការសាងល្បងបង្កើតសេដ្ឋកិច្ច«ចម្រុះ» នៅភាគខាងត្បូងពុំបានទទួលលទ្ធផលល្អអស្ចារ្យដែលសង្ឃឹមដោយភាគខាងជើងឡើយ ។ ដូច្នេះ យូរទៅទៀត ភាគខាងត្បូងប្រហែលជាមានសភាព ដូចភាគខាងជើងដែរហើយ ។ ក្នុងខែដែលមានបន្តមកទៀត អ្នកភៀសខ្លួនតាមទូកបានចាប់ផ្តើមចាកចេញពីភាគខាងត្បូងក្នុងចំនួនយ៉ាងសម្បើមមួយ ។

ការកែប្រែទ្រង់ទ្រាយភាគខាងត្បូង មានបញ្ចូលនូវការបង្កើតស្ថាប័នប៉ូលិសមួយ ដែលដាក់ឲ្យដំណើរការរួចមកហើយនៅភាគខាងជើង ។ នៅទីនោះ គ្មានប្រជាជនណាម្នាក់ធ្វើដំណើរទៅណាមកណា ដោយគ្មានការ

អនុញ្ញាតជាផ្លូវការទេ ។ ប្រជាជនឈប់យកការណ៍ពីគ្នាទៅវិញទៅមក ហើយមានទម្លាប់ចង់ឃើញរដ្ឋដឹកនាំ គ្រប់ទិដ្ឋភាពទាំងអស់នៃជីវភាពរស់នៅរបស់គេដោយមធ្យោបាយបែបណាៗ ៈ ការអប់ រំការងារ បរិមាណនៃរបបអាហារ ទ្រព្យសម្បត្តិផ្ទាល់ខ្លួនដែលរដ្ឋអនុញ្ញាតកម្រិតនៃការផលិត ។ ពួកវៀតណាម ដែលឡើងបុណ្យសក្តិក្នុងកាលៈទេសៈនេះ ត្រូវបានបញ្ជូនមកភាគខាងត្បូងដើម្បីមើលខុសត្រូវនូវអ្វីដែលប្រជាពលរដ្ឋខាងត្បូងប្រតិបត្តិតាមបទបញ្ជារបស់ក្រុងហាណូយ ។

នៅពេលដែល "ការធ្វើដំណើរលឿនរហ័ស" ឆ្ពោះទៅកាន់លទ្ធិសង្គមនិយមបរាជ័យ ហើយហ្វូងអ្នកភៀសខ្លួនតាមទូកសម្រុកចេញទៅតាមសមុទ្រចិនខាងត្បូង គឺពួកកម្មាភិបាលក្មេងៗនិងអ្នកធ្វើការក្នុងការិយាល័យរបស់ភាគខាងជើងទាំងនេះហើយ ដែលគេចាត់ទុកជាអ្នកទទួលខុសត្រូវ ។

នៅមហាសន្និបាតនាខែធ្នូ បក្សបានប្រកាសឲ្យដឹងដែរថា "សមាជិកបក្សដែលគ្មានគុណសម្បត្តិគ្រប់គ្រាន់ប្រមាណជាដប់ពាន់នាក់" ត្រូវបានបណ្តេញចេញពីបក្ស ។ នេះជាការបោសសម្អាតក្នុងជួរបក្ស ដូចឆ្នាំមានមកហើយ ដែលបន្តដោយសង្រ្គាមកុម្មុយនិស្តដ៏ជាញជ័យ ។ ពួកវៀតណាមមិនល្មមចិត្តនឹងបណ្តេញចេញពីបក្សនូវបណ្តាសមាជិកដែលមានដើមកំណើតសង្គមជាគហបតី ឬអ្នកជំពាក់ចិត្តនឹងក្រុមគ្រួសារខ្លាំងពេក ។ បក្សបានថ្លែងថា សមាជិកជាច្រើនត្រូវបានបណ្តេញចេញ ដើម្បី "កម្ចាត់ចោលសមាសភាពប្រតិកិរិយា និងសមាជិកនៃកម្លាំងទីប្រាំ" ។

កម្លាំងទីប្រាំនេះ គឺពួកចិនកាត់វៀតណាមដែលធ្លាប់ជាចំណែកមួយរបស់បក្សនៅភាគខាងជើង ។ មិនយូរប៉ុន្មាន ប្រយោគនេះនឹងត្រូវប្រើប្រាស់ប្រឆាំងនឹងជនជាតិចិនទាំងអស់ ដែលរស់នៅក្នុងប្រទេសវៀតណាម –នៅភាគខាងជើងក៏ដូចនៅភាគខាងត្បូង ទាំងបក្ខជនកុម្មុយនិស្ត និងគហបតីដែលរកឃើញថា មានកំហុសពិតមែន ។ ពួកមេដឹកនាំក្រុងហាណូយ បានប្រកាន់យកការសម្រេចចិត្តយ៉ាងតឹងរ៉ឹងជាច្រើន ។ ពួកមេដឹកនាំទាំងនោះគ្មានសមត្ថភាពប្រមូលប្រជាជនដើម្បីកសាងប្រទេសវៀតណាមឡើងវិញទេ យ៉ាងហោចណាស់ ក្នុងកិច្ចសន្យាម៉ឺងម៉ាត់ផ្សេងៗ ដែលពួកគេបានអួតអាង ហើយវាហាក់ដូចជាគួរឲ្យជឿតិចតួចណាស់ ដែលថា មេដឹកនាំមានវ័យចាស់ទាំងនេះ យល់ដឹងពីប្រទេសវៀតណាមសង្គមនិយមមួយពេលគេនៅមានជីវិតនោះ ។ ចំពោះការខកចិត្តយ៉ាងជ្រាលជ្រៅនេះ គេត្រូវតែស្វែងរកអ្នកប្រព្រឹត្តបទល្មើសម្នាក់ជាជាងសត្រូវបរទេសមួយ ។ ដូចប្រទេសកម្ពុជាដែរ ប្រទេសវៀតណាមមានបេក្ខជនម្នាក់ដែលខ្លួនចូលចិត្តទម្លាក់កំហុសទៅលើជាងគេគឺ ប្រទេសចិន ។

ដូច្នេះ ប្រទេសចិននិងពួកចិន បានក្លាយទៅជាអ្នកទទួលខុសត្រូវគ្រប់បញ្ហាទាំងអស់របស់ប្រទេសវៀតណាមទាំងក្នុងនិងក្រៅប្រទេស ។ វៀតណាម បានចោទប្រកាន់ពួកអ្នកជំនួញជាជនជាតិភាគតិចចិននៅទីក្រុងហូជីមិញថា បានធ្វើយុទ្ធសាស្រ្តរបស់ក្រុងហាណូយទទួលបរាជ័យនៅភាគខាងត្បូង ។ គេបានបន្ទោសដូចគ្នា ចំពោះជនកុម្មុយនិស្តចិនកាត់វៀតណាមនៅភាគខាងជើងថា បានជួយបញ្ឆេះឲ្យមានជម្លោះ រវាងប្រទេសវៀតណាម

និងប្រទេសចិន ។ ហើយគេចោទក្រុងប៉េកាំងជាអ្នកទទួលខុសត្រូវ អំពីការគ្មានសមត្ថភាពរបស់ពួកវៀតណាម ដើម្បីអូសទាញប្រទេសកម្ពុជាឲ្យចូលក្នុងប្លុកឥណ្ឌូចិនមួយ ។ តាមពួកមេដឹកនាំថាបញ្ហាទាំងអស់របស់ប្រទេសវៀតណាមតែងមានប្រភពមកពីបណ្ដាមហាអំណាចបរទេសជានិច្ច ហើយប្រទេសចិនត្រូវបានកំណត់ថា ជាការគំរាមកំហែងធ្ងន់ធ្ងរមួយមកលើពូជសាសន៍ និងប្រជាជាតិវៀតណាមទាំងមូល ។

ដូច្នេះប្រទេសវៀតណាមអាចប្រកាន់យកទម្លាប់ផ្សេងៗរបស់សង្គ្រាមឡើងវិញ ។ កងទ័ពដែលមិនដែលត្រូវរំសាយ បានរៀបចំខ្លួនសម្រាប់ការប្រយុទ្ធថ្មីមួយ ។ ខុសប្លែកពីពួកកម្ពុជា ពួកវៀតណាមមានភាពប៉ិនប្រសប់បំផុត ក្នុងការកេណ្ឌប្រមូលប្រជាជនដើម្បីភាពគង់វង្សនៃប្រជាជាតិ ហើយក្រុងហាណូយចេះឆ្លៀតទាញគុណប្រយោជន៍ពីតម្លៃពូជសាសន៍ តែមិនសំដែងឲ្យប្រជាជនដឹងតាមការអំពាវនាវមយយបែបនោះឡើយ ។ ដោយផ្ទុយពីពួកខ្មែរដែលប្រឈមនឹងការគំរាមពីសង្គ្រាមបរទេសមួយ នៅទីបំផុត បានប្រយុទ្ធតែរវាងគ្នាឯង និងស្វែងរកពួកអ្នកគាំពារហួសឆ្ងាយអំពីព្រំដែនរបស់ពួកគេទៅទៀត ចំណែកពួកវៀតណាមបានប្រឹងប្រែងធ្វើឲ្យសម្រេចការបង្រួបបង្រួមប្រទេសរបស់គេដោយសារការធ្វើសង្គ្រាម យ៉ាងហោចណាស់នៅសម័យទំនើបដែរ ។ ង្វៀនកូថាច់ រដ្ឋមន្ត្រីការបរទេសរបស់ប្រទេសវៀតណាមបានបញ្ជាក់ថា «ក្នុងរយៈប៉ុន្មានឆ្នាំនៃសង្គ្រាម លោកអាចមើលឃើញថា យើង[ពួកមេដឹកនាំបក្ស]ទាំងអស់គ្នាបានរួបរួមជាកម្លាំងតែមួយ គឺពុំដូចនៅប្រទេសចិន ឬនៅប្រទេសកម្ពុជាទេ ពីព្រោះយើងតែងតែប្រឈមនឹងការគំរាមកំហែងពីសង្គ្រាមមកខាងក្រៅជានិច្ច[៤០] » ។

ផ្លូវដែលវៀតណាមត្រូវដើរប្រហែលជាបត់បែន ថែមទាំងប្រកបដោយឧបាយកលសម្ងាត់ទៀតផង ប៉ុន្តែ វាបាននាំចេញទៅរកសង្គ្រាម -ជាមួយប្រទេសកម្ពុជាទៅវិញ ។ ការភ្ញាក់ខ្លួននៅខាងក្នុងប្រទេស ដែលបង្កឡើងដោយកម្មវិធីរបស់ក្រុងហាណូយនៅពេលមានសន្តិភាព បាននាំទៅដល់ការប្រកាន់ជំហរផ្សេងៗកាន់តែតឹងរ៉ឹងឡើងគ្មានឈប់ឈរ និងការភ្ញាក់ខ្លួនមួយកាន់តែជ្រាលជ្រៅថែមទៀត ។ ក្រុងហាណូយ បានចោទប្រកាន់ប្រទេសចិន និងពួកចិនកាត់វៀតណាម អំពីបញ្ហាក្នុងប្រទេសទាំងអស់របស់ខ្លួន ហើយទំនាក់ទំនងផ្សេងៗ ដែលគេទ្រទ្រង់ជាមួយពួកកុម្មុយនិស្តកម្ពុជានៅតែពិបាកជានិច្ច ។ បញ្ហាពីរបានចាប់ផ្ដើមតភ្ជាប់គ្នានៅឆ្នាំ១៩៧៧ នៅពេលដែលពួកកុម្មុយនិស្តវៀតណាមផ្ដើមធ្វើការវាយលុករបស់គេ ប្រឆាំងនឹងភាគខាងត្បូង និងជនជាតិភាគតិចចិន ហើយរកឃើញក្របខ័ណ្ឌទូលំទូលាយជាមុនមួយ ដើម្បីបន្តសង្គ្រាមជាមួយប្រទេសកម្ពុជា និងដណ្ដើមយកប្រទេសនេះទៀត ។ នេះហើយជាមូលហេតុនៃការចាប់ផ្ដើមចាកចេញទាំងហ្វូងរបស់អ្នកភៀសខ្លួនតាមទូក ។

ជនជាតិចិននៅក្រុងច្រឹឡឹង ត្រូវបានប្រើប្រាស់ជាអ្នកទទួលរងកំហុសគ្រប់បែបយ៉ាង សម្រាប់ពួកអាជ្ញាធរបដិវត្តន៍នៅប្រទេសវៀតណាម[៤១] ។ ច្រឹឡឹងដែលមានន័យថា «ផ្សារធំ» ត្រូវបានបង្កើតឡើងដោយពួកចិនក្រោយពេលដែលវៀតណាមដណ្ដើមយកដែនដីខ្មែរភាគខាងត្បូងបន្តិច ។ ពួកវៀតណាមខាងជើង បានបញ្ជូនជនជាតិចិនឲ្យមករកស៊ីជួញដូរក្នុងដែនដីថ្មីនេះ ហើយពួកគេបានសម្រេចជោគជ័យប្រាកដមែន ទោះបីជានៅពេល

ប្រទេសត្រូវឆ្លងកាត់សង្គ្រាមជាបន្តបន្ទាប់ក៏ដោយ ។ ជនជាតិចិនទាំងនេះ បានបង្កើតមុខរបរផ្តាច់មុខមួយខាងការលក់ និងចែកចាយផលិតផលស្ទើរតែគ្រប់មុខទាំងអស់ ៖ ស្រូវនៃដីសណ្តទន្លេមេគង្គ រហូតដល់គ្រឿងបន្លាស់រថយន្ត ។ ពួកគេធ្វើជំនួញជាមួយភាគីទាំងអស់ ក្នុងរយៈពេលដែលកើតមានជម្លោះផ្សេងៗ ដោយលក់គ្រឿងសព្វាវុធ និងព័ត៌មានសម្ងាត់ នៅក្នុងតៀមតូចៗរបស់គេ នៅទីក្រុងច្រឹឡឹងខាងលើប៉ាន់តែក្តៅៗ និងគំនរលុយ ។

ពួកគេតែងតែនៅដោយឡែកពីជម្លោះទាំងនេះជានិច្ច និងពីពួកវៀតណាមផ្ទាល់ក្នុងការបេះប្រមាណខ្លាំងមួយ ។ ច្រឹឡឹង បានក្លាយទៅជាតំបន់ជនជាតិភាគតិចមួយ ជាទីដែលពួកចិននិយាយភាសា និងរស់នៅទៅតាមវប្បធម៌ប្រពៃណីរបស់គេ ដោយព្រមទទួលភាពរស់នៅដាច់តែឯង និងបុរេនិច្ឆ័យ ដែលមានជាប់មកពីកំណើតនៅក្នុងតំបន់ជនជាតិតិចនេះ ។ ពិតមែនតែពួកគេជាពលរដ្ឋរបស់សាធារណរដ្ឋវៀតណាមក៏ដោយ ក៏កូនៗរបស់ពួកគេកម្រចូលបម្រើក្នុងកងទ័ពណាស់ ហើយខ្សែរយៈទាក់ទងរបស់ពួកគេមាននៅឯទៃទៀតជាមួយនឹងពួកចិននៅប្រទេសសិង្ហបុរី ហុងកុង តៃវ៉ាន់ ហើយជួនកាលសាធារណរដ្ឋប្រជាមានិតចិនផង ។ សម្រាប់ពួកវៀតណាមយល់ថា ពួកចិននៅ ច្រឹឡឹង សុទ្ធតែជាបុគ្គលពោរពេញទៅដោយការរវក់នឹងគ្រឿងសម្ភារៈតែម្យ៉ាងប៉ុណ្ណោះ និងជាមនុស្សដែលមិនយកចិត្តទុកដាក់ នឹងរឿងសំខាន់ៗ ក្រៅពី«ផ្សារធំ»របស់គេឡើយ ។

ប៉ុន្តែ នៅពេលដែលដំណឹងក្លាយជាប្រត្យក្សថាសង្គ្រាមនឹងត្រូវចប់ ពួកចិននៅក្រុងច្រឹឡឹង នៅតែរស់នៅក្នុងប្រទេសដដែល ៖ ពួកគេ ពុំមែនជាចំណែកមួយនៃហ្វូងមនុស្សដែលច្រឡោតមួរម៉ៅ កំពុងឡោមព័ទ្ធស្ថានទូតសហរដ្ឋអាមេរិកទេ ។ ផ្ទុយទៅវិញ ពួកគេរៀបចំដាក់លក់រូបថតរបស់ ហូ ជីមិញ និងបញ្ចេញប្រាក់ដុង (រូបិយវត្ថុវៀតណាមខាងជើង) ពីកន្លែងលាក់ទុក ។ ពួកគេបានត្រូវញុំាងឲ្យជឿជាក់ថា ពួកមេដឹកនាំថ្មីនឹងត្រូវការពួកចិនក្រុងច្រឹឡឹង ដើម្បីការពារសេដ្ឋកិច្ចឲ្យដើរទៅមុខដូចដើម ។

ក្នុងកំឡុងឆ្នាំដំបូងនៃបដិវត្តន៍ ពួកអ្នកជំនួញនៅក្រុងច្រឹឡឹង បានឆ្លៀតទាញគុណប្រយោជន៍ពីការភាន់ច្រឡំខ្លាំងរបស់ពួកអ្នកកាន់អំណាច ហើយបានប្រមូលទិញស្រូវទាំងអស់ ។ បន្ទាប់មកពួកគេបានបិទសហគ្រាស និងរង់ចាំឲ្យតម្លៃឡើងខ្ពស់ ។ ពួកគេអាចធ្វើឲ្យតម្លៃហាងឆេងផ្លាស់ប្តូរចុះឡើងតាមទំនើងចិត្តរបស់គេ ប៉ុយ៉ាងហោចក៏ធ្វើឲ្យក្រុងហាណូយមានការចាប់អារម្មណ៍ពីរឿងនេះដែរ ។ ហើយនៅពេលដែលរដ្ឋាភិបាលស្វែងរក "អ្នកទទួលថ្ងបាក់"ម្នាក់ ការជ្រើសរើសគឺងាយបំផុត ។ បន្ទាប់ពីមហាសន្និបាតបក្សឆ្នាំ១៩៧៦ "ពួកអ្នកជំនួញជាថៅកែ" ជនជាតិចិននៅទីក្រុងច្រឹឡឹង ត្រូវបានកំណត់ថាអ្នកទទួលខុស ត្រូវទីមួយនៃអតិផរណាដែលឡើងលឿនដូចព្រួញ ការខ្វះម្ហូបអាហារ ការបាត់លំនឹងក្នុងផ្នែកឧបភោគ-បរិភោគ និងការចុះថយនៃឧស្សាហកម្មធុនស្រាល ។

ការវាយប្រហារប្រឆាំងនឹងពួកចិននៅទីក្រុងច្រឹឡឹង មានលក្ខណៈត្រង់ៗ-ដូចដែលពួកអ្នកកាន់អំណាចកុម្មុយនិស្តថ្មីនៅប្រទេសកម្ពុជាធ្លាប់ធ្វើការវាយលុកប្រឆាំងនឹងពួកអ្នកជំនួញចិននៅក្រុងភ្នំពេញដែរ ។ ប៉ុន្តែ នៅប្រទេសវៀតណាមមានសហគមន៍ចិនមួយផ្សេង ដែលពិបាកបណ្តេញពីកន្លែងបំផុត ។ បើសិនការប្រកាន់ពូជ

សាសន៍មានស្ថិតនៅក្នុងការវាយប្រហារប្រឆាំងនឹងពួកចិននៅក្រុងច្រឹឡឹងមែន វាមុខក្លាយទៅជាការប្រឆាំងនឹងពួកចិននៅភាគខាងជើងជាសាធារណៈ ដែលភាគច្រើនធ្លាប់ជួយគាំទ្របដិវត្តន៍កុម្មុយនិស្តដែរ ។

ជនជាតិចិននៅភាគខាងជើងមានតិចជាងនៅភាគខាងត្បូង ៖ ម្ខាងមួយលាននាក់ ម្ខាងទៀតហុកសិបម៉ឺននាក់ ។ ពួកអ្នកមានៗចិននៅភាគខាងជើង បានចាកចេញពីប្រទេស បន្ទាប់ពីកិច្ចព្រមព្រៀងក្រុងហ្សឺណែវឆ្នាំ ១៩៥៤ ។ ពួកចិនដែលស្ថិតនៅក្នុងប្រទេស សុទ្ធតែជាកសិករ, សិប្បករ, បញ្ញាវន្ត, គ្រូបង្រៀន, អ្នករកស៊ីកំប៉ិកកំប៉ុក ។ ដូចពួក ចិននៅភាគខាងត្បូងដែរ ពួកគេរស់នៅក្នុងសង្កាត់ ឬភូមិនានា ដាច់ដោយឡែកពីអ្នកឯទៀតៗ ហើយបំពេញមុខរបរតាមប្រពៃណី ជាអ្នកនេសាទ និងកម្មករដញ្ជូនអីវ៉ាន់ ឡើងចុះកប៉ាល់នៅឆ្នេរសមុទ្រ, កម្មករអណ្តូងរ៉ែនៅតាមភ្នំ ជាអ្នកលក់គ្រឿងចានឆ្នាំង, អ្នកជំនួញ និងអ្នកកាន់កាប់ភោជនីដ្ឋានក្នុងទីក្រុងនានា ។ ខុសប្លែកពីពួកចិននៅភាគខាងត្បូង ពួកចិននៅភាគខាងជើងមានកម្រិតចេះដឹងខ្ពស់មួយ និងយកចិត្តទុកដាក់ក្នុងរឿងនយោបាយ ។ កូនៗរបស់ពួកគេបានចូលបម្រើក្នុងកងទ័ព ហើយក្នុងចំណោមនោះ មានមួយចំនួនបានសុំចូលជាសមាជិកបក្សកុម្មុយនិស្តវៀតណាម ។

ប៉ុន្តែ ពួកមេដឹកនាំក្រុងហាណូយមិនទុកចិត្តថែមទៀត ចំពោះពួកចិននៅភាគខាងជើង ក៏ដូចជាភាគខាងត្បូង ហើយបានទម្លាក់ទោសទៅលើពួកនេះយ៉ាងឆាប់រហ័ស ។ ពួកគេបានក្លាយទៅជាប្រភេទអ្នកលាតត្រដាងឲ្យដឹងរឿងស្ងាត់កំបាំងមួយ អំពីបញ្ហាផ្សេងៗរវាងក្រុងប៉េកាំង និងក្រុងហាណូយ បន្ទាប់មក ក្នុងផ្ទៃនៃត្រីកោណកម្ពុជា-វៀតណាម-ចិន ទៀត ។

រឿងចម្រូងចម្រាសទីមួយ គឺលក្ខណៈជាពលរដ្ឋដែនជាតិចិនកាត់វៀតណាម ។ ទាំងប្រទេសចិន ទាំងប្រទេសវៀតណាម មិនទទួលស្គាល់សញ្ជាតិពីរទេ ហើយប្រទេសទាំងពីរជួយគាំទ្រការរស់នៅបែកខ្ញែកគ្នារបស់ជនជាតិគេ ។ ប្រទេសទាំងពីរ មានក្រុមការងាររៀងៗខ្លួន ដែលធ្វើការសម្រាប់សហគមន៍ជនជាតិគេនៅឯបរទេស ដែលចំពោះអ្នកទាំងនោះ ប្រទេសទាំងពីរបានយល់ព្រមផ្តល់ឲ្យសិទ្ធិពិសេសថែមទៀត ។ ដោយសារហេតុការណ៍នេះ បក្សកុម្មុយនិស្តចិន និងវៀតណាម បានសម្រេចចិត្តធ្វើកិច្ចព្រមព្រៀងរួមមួយនៅឆ្នាំ១៩៥៥ថា សមាជិកជនជាតិភាគតិចចិននៅរដ្ឋកុម្មុយនិស្តថ្មីនៃប្រទេសវៀតណាម នឹងរក្សាសញ្ជាតិចិនរហូតដល់ទីបញ្ចប់នៃសង្គ្រាម ។ ប្រជាជនទាំងនោះនឹងមានសិទ្ធិ និងករណីកិច្ចដូចគ្នា នឹងប្រជាពលរដ្ឋវៀតណាម ហើយនឹងអាចសម្រេចបោះបង់ ឬមិនបោះបង់សញ្ជាតិចិនរបស់គេតាមស្មគ្រ័ចិត្ត ។ នៅប្រទេសវៀតណាមខាងត្បូង ប្រធានាធិបតី យៀម បានប្រកាសជាឯកតោភាគីថា ជនជាតិចិនកាត់វៀតណាមទាំងអស់ សុទ្ធតែជាពលរដ្ឋរបស់សាធារណរដ្ឋវៀតណាម ។

ការពិបាកចិត្តផ្សេងៗ បានចាប់ផ្តើមជាមួយនឹងបដិវត្តន៍វប្បធម៌ នៅពេលពួកយុវជនចិន បានដើរដង្ហែគ្នាជាក្បួន ដោយគ្រវីកូនសៀវភៅក្រហមក្នុងដៃ ។ នៅតាមសាលារៀនចិនទាំងឡាយ ពួកគ្រូៗ បានលើកទឹកចិត្តឲ្យធ្វើ

តាមគំនិតរបស់ ម៉ៅ ។ ដោយខ្លាចបារម្ភក្នុងពេលថ្មីៗនេះ ចំពោះចេតនាផ្សេងៗរបស់ចិន ពួកមេដឹកនាំវៀតណាមខាងជើង បានដាក់សាលារៀនចិនទាំងអស់ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ ហើយផ្លាស់ជំនួសកម្មវិធីសិក្សា ដែលបង្រៀនជាភាសាចិន ដោយមុខវិជ្ជាបង្រៀនជាភាសាវៀតណាមវិញ ។ ចាប់ពីឆ្នាំ១៩៧០ ទៅ កូនៗរបស់ពួកចិនត្រូវបញ្ជូនឲ្យទៅរៀនតាមសាលាវៀតណាមទាំងអស់ ។ ក្រោយនោះបន្តិច ពួកអ្នកកាន់រដ្ឋអំណាច បាននិរទេសជនជាតិចិន មួយចំនួនទៅកាន់ព្រៃភ្នំដែលនៅឆ្ងាយដាច់ស្រយាល និងផុតពីទីក្រុងនានា ។

ភាពបន្តគ្នានៃសកម្មភាពមួយបានផុសចេញឲ្យឃើញ ៈ រៀងរាល់លើក ដែលមានភាពតានតឹង រវាងក្រុងប៉េកាំង និងក្រុងហាណូយ ពួកវៀតណាមបានរករឿងទម្លាក់ទោសទៅលើពួកចិននៅភាគខាងជើងជានិច្ច ។ នៅឆ្នាំ១៩៧៤ គឺមុនជ័យជម្នះរបស់ពួកកុម្មុយនិស្តវៀតណាម ប្រទេសចិន បានវាយកាន់កាប់ប្រជុំកោះប៉ារ៉ាសែល ពីកងទ័ពរបស់ប្រធានាធិបតី យៀម ជាដឹកដីដែលនៅជជែករកខុសត្រូវនៅឡើយ ។ ក្រុងហាណូយពុំមានប្រឆាំងតវ៉ាទេ ប៉ុន្តែ ក្នុងបណ្តាខែដែលមានបន្តពីនោះ អាជ្ញាធរវៀតណាម បានហាមមិនឲ្យប្រជាជនចិនកាត់វៀតណាមនៅភាគខាងជើង បំពេញការងារណាមួយក្នុងបណ្តារោងចក្ររបស់រដ្ឋ ឬផ្នែករោងចក្រដែលមានលក្ខណៈយុទ្ធសាស្ត្រឡើយ ។ ភ្លាមៗបន្ទាប់ពីជ័យជម្នះ បក្សបានប្រកាសឲ្យដឹងថា គ្មានជនបរទេសណាម្នាក់អាចស្ថិតនៅក្នុងជួររបស់ខ្លួនបានទេ ។ អតីតជនកុម្មុយនិស្តម្នាក់ បាននិយាយដើមថា ៈ “តាមយើងដឹង ការសម្រេចនេះ គឺសំដៅប្រឆាំងនឹងពួកចិន ដោយហេតុថា យើងជាជនបរទេសតែឯកឯង ដែលជាចំណែកមួយរបស់បក្ស” ។

ជនជាតិភាគតិចចិន ត្រូវបដិសេធចេញពីការរៀបចំថ្មីនេះ ។ នៅឆ្នាំ១៩៧៧ ច្បាប់ថ្មីៗ បានរារាំងមិនឲ្យសមាជិកជាច្រើនរបស់ខ្លួនជួញដូរអ្វីគ្រាន់នឹងរស់បានទៀតហើយ ។ ពួកកម្មករជញ្ជូនអីវ៉ាន់សញ្ជាតិចិននៅកំពង់ផែហៃហ្វុងសម្គាល់ឃើញបៀរវត្សរ៍របស់គាត់ត្រូវកាត់បន្ថយទាំងបំពាន និងលែងមានសិទ្ធិទទួលប័ណ្ណផ្គត់ផ្គង់ភស្តុភារពីរដ្ឋ ។ ក្នុងពេលជាមួយគ្នានោះ ក្រុមសញ្ជាតិចិនសំខាន់បំផុតក្នុងផ្ទៃរដ្ឋាភិបាលគឺ សមាគមចិនបង្រួបបង្រួមនៅហាណូយ ហៃហ្វុង និងណាមឌិញ ត្រូវបានរំលាយចោល ។ ពួកអ្នកកាន់អំណាចបានប្រកាសឲ្យដឹងថា ៈ “ពួកចិននៅប្រទេស វៀតណាម បានបំពេញបេសកកម្មជាប្រវត្តិរបស់គេរួចហើយ ហើយឥឡូវនេះត្រូវតែបំភ្លេចអតីតកាលចោល[៤២]” ។

និយាយម្យ៉ាងទៀត គឺពួកគេត្រូវតែចាកចេញពីប្រទេស ។ ក្រោយឆ្នាំ១៩៧៥ ទំនាក់ទំនងផ្សេងៗ រវាងចិន-វៀតណាម បានត្រូវគេធ្វើឲ្យក្លាយជាជម្លោះមួយយ៉ាងឆាប់រហ័ស ហើយរដ្ឋាភិបាលក្រុងហាណូយ បានវិនិច្ឆ័យថាអាណិកជនចិននៅក្នុងប្រទេសរបស់ខ្លួន ជាកម្លាំងទី៥មួយ ដែលកំពុងមានអានុភាពអាចត្រូវប្រើប្រាស់ប្រឆាំងនឹងប្រទេសវៀតណាមបាន ក្នុងករណីដែលកើតមានសង្គ្រាម ។ បន្ទាប់ពីឆ្នាំ១៩៧៥ ក្រុងប៉េកាំង បានស្នើឲ្យសហរដ្ឋអាមេរិករក្សាទុកវត្តមានយោធាខ្លួនក្នុងតំបន់នេះ ដើម្បីរារាំងសូវៀតកុំឲ្យចូលមកបំពេញកន្លែងប្រហោងដែលបង្កើតឡើងដោយសារការចាកចេញរបស់សហរដ្ឋអាមេរិក ។ ក្រោយមក ពួកចិនបានសាកល្បងបញ្ចុះបញ្ចូល

ឲ្យប្រទេសវៀតណាមចុះហត្ថលេខាលើកតិកាសញ្ញា“ប្រឆាំងអនុត្តរភាព” សំដៅប្រឆាំងនឹងក្រុងមូស្គូ ។ ទន្ទឹមនឹងនោះ សហភាពសូវៀតពុំទាមទារឲ្យមានកិច្ចព្រមព្រៀងប្រភេទនេះទេ ហើយបានបង្កើនជំនួយរបស់ខ្លួនឲ្យទៅវៀតណាមថែមទៀត ។ ជាមួយនឹងការកម្ចាត់“បនបួននាក់” ទំនាក់ទំនងផ្សេងៗរវាងចិន-វៀតណាម បានស្គាល់នូវភាពប្រសើរមួយរយៈខ្លី ហើយនៅនិទាឃរដូវឆ្នាំ១៩៧៧ ប្រទេសចិនបានអញ្ជើញឧត្តមសេនីយ៍ ផ្មៀងយ៉ាប ឲ្យទៅធ្វើទស្សនកិច្ចបណ្ដាឋានភណ្ឌយោធារបស់ចិនថែមទៀត ។ ក្រុងប៉េកាំងបានធ្វើឲ្យមានសន្ទុះជាថ្មីដល់ គម្រោងកម្មវិធីផ្ដល់ជំនួយទៅឲ្យប្រទេសវៀតណាមជាច្រើន ដែលខ្លួនធ្លាប់បោះបង់ចោលកាលពីមុន ។ ប៉ុន្តែ ប្រហែលជានៅពាក់កណ្ដាលឆ្នាំនោះ ទំនាក់ទំនងរវាងពួកវៀតណាមនិងកម្ពុជាមានសភាពតាន តឹងយ៉ាងខ្លាំង ។ “មធ្យោបាយចាំបាច់”នីមួយៗ ដែលនឹងជំរុញទៅរកសង្គ្រាមឥណ្ឌូចិនលើកទីបីត្រូវបានរៀបចំស្រេចបាត់អស់ហើយ ។

នៅខែកក្កដា ឆ្នាំ១៩៧៧ ប្រទេសឡាវបានសម្រេចចុះហត្ថលេខាលើសន្ធិសញ្ញាមិត្តភាពមួយជាមួយប្រទេសវៀតណាម ដែលបំពេញច្បាប់នូវស្ថានភាពរបស់ខ្លួនដែលស្ទើរតែជារណបមួយរបស់ក្រុងហាណូយ ។ ពួកវៀតណាមបានស្នើឲ្យមានសន្ធិសញ្ញាមួយដូចគ្នា ចំពោះពួកកម្ពុជាដែលបានបដិសេធយ៉ាងចចេស ។ បន្ទាប់មក ប្រទេសវៀតណាមបានស្នើលើកបញ្ហាការចរចាស្ដីពីព្រំដែនខ្មែរ-វៀតណាមជាថ្មី ដែលធ្វើឲ្យគំនិតមិនទុកចិត្តគេឯងទាំងអស់របស់ក្រុងភ្នំពេញចំពោះពួកវៀតណាមឆេះថ្កោលឡើងវិញ ។ ដោយមិនរួញរាក្នុងការបង្កហេតុ ពួកកម្ពុជាបានពង្រីករឿងនេះកាន់តែធំ ហើយចោទប្រកាន់ប្រទេសជិតខាងខ្លួនថា ជាអ្នកទទួលខុសត្រូវចំពោះការខូចខាតទាំងអស់របស់ពួកគេ ទាំងខាងក្នុងនិងខាងក្រៅប្រទេស -ពិតណាស់ គឺដូចពួកវៀតណាមធ្លាប់ចោទប្រកាន់ប្រទេសចិនថា ជាអ្នកទទួលខុសត្រូវអំពីបញ្ហាផ្សេងៗរបស់ពួកគេដែរ ។

ឥឡូវនេះ ក្រុងហាណូយបានចោទប្រកាន់ពួកចិនថា ជាអ្នកទទួលខុសត្រូវអំពីការទាស់ទែងគ្នាជាមួយក្រុងភ្នំពេញទៀត ។ សម្រាប់ពួកវៀតណាមយល់ថា គឺក្រុងប៉េកាំងដែលជាអ្នកអុជអាលឲ្យពួកកម្ពុជាប្រឆាំងនឹងខ្លួននោះ ។ នៅចុងឆ្នាំ១៩៧៧ ពួកខ្មែរបានចាប់ផ្ដើមវាយប្រហារពួកវៀតណាមនៅតាមព្រំដែន ។ ក្នុងបណ្ដាខែដែលមានបន្តមកទៀត ក្រុងហាណូយបានបណ្ដេញអ្នកស្រុកជាជនជាតិភាគតិចចិនដែលត្រូវចោទប្រកាន់ពីបទបម្រើជាកម្លាំងទីប្រាំ ចេញពីប្រទេសវៀតណាមទៅប្រទេសចិនវិញ ។ នៅខែមករា ឆ្នាំ១៩៧៨ ពួកចិនកាត់វៀតណាម នៅភាគខាងជើងគោងតែយល់ព្រមទទួលអត្តសញ្ញាណប័ណ្ណថ្មី ដែលធ្វើឲ្យពួកគេទៅជាអាណិកជនវៀតណាមពុំមែនអាណិកជនចិនទេ ដែលផ្ទុយនឹងកិច្ចព្រមព្រៀងផ្ទាល់មាត់នៅឆ្នាំ១៩៥៥ ។ ម្យ៉ាងទៀត ក្រុងហាណូយបានបញ្ញត្តិឲ្យពួកចិននៅភាគខាងត្បូងប្រកាន់យកសញ្ជាតិវៀតណាមរួចស្រេចទៅហើយ ។ ប៉ុន្តែ បញ្ហាស្ដីពីលក្ខណៈជាពលរដ្ឋនេះ គ្រាន់តែជាភាពដំបូងនៃការផ្ដើមវាយលុកប៉ុណ្ណោះ ។

នៅភាគខាងជើង ប៉ូលិស និងក្រុមអ្នកធ្វើការខាងសន្តិសុខ បានទទួលបញ្ជាឲ្យកម្ចាត់ពួកចិនកាត់វៀតណាមដែលកំពុងរស់នៅតាមជនបទ ជាពិសេសនៅតាមបណ្ដាតំបន់ជាប់ព្រំដែន ។ កសិករជាច្រើនបានឈរមើលការ

កម្ទេចបំផ្លាញផ្ទះសម្បែង និងការលួចប្លន់ទ្រព្យសម្បត្តិរបស់ពួកគេទាំងកុកកួលក្នុងចិត្តដោយឥតមានអំណាចធ្វើអ្វីកើត ។ តាមទីក្រុងនានា ជនជាតិចិនជាច្រើនបានបាត់បង់ការងាររបស់គេ ។ ពួកចិនកាត់វៀតណាម បានចាប់ផ្ដើមលក់អ្វីៗទាំងអស់ដែលពួកគេមាន និងផ្ដល់ប្រាក់សំណូកដើម្បីទទួលបានសំបុត្រអនុញ្ញាតធ្វើដំណើរទៅប្រទេសចិនតាមផ្លូវគោក ។ អ្នកខ្លះទៀត ឡើងជិះកប៉ាល់ដើម្បីប៉ុនប៉ងទៅឲ្យដល់ឆ្នេរសមុទ្រចិន ឬកោះហុងកុង ។ ការចេញទៅទាំងហ្វូងរបស់អ្នកភៀសខ្លួនតាមទូកបានចាប់ផ្ដើម ។

នៅភាគខាងត្បូង បក្សបានអនុវត្តដោយពេញលេញនូវវិធានការតឹងរ៉ឹងផ្សេងៗសំដៅប្រឆាំងនឹងពួកគហបតីនៅខែមីនា ឆ្នាំ១៩៧៨ គឺក្រោយពេលដែលពួកចិននៅភាគខាងជើងចាប់ផ្ដើមភៀសខ្លួនបន្តិច ។ បើជនជាតិភាគតិចនៅភាគខាងជើងត្រូវចោទប្រកាន់ពីសម្ដែងតួនាទីជាកម្លាំងទីប្រាំ ជនជាតិភាគតិចចិននៅភាគខាងត្បូងត្រូវបានចាប់កំហុសដូចគ្នា ពីព្រោះអ្នកទាំងនោះរក្សាទុកលទ្ធិមូលធននិយម ។ រដ្ឋាភិបាលបានធ្វើជាតូបនីយកម្មសហគ្រាសពាណិជ្ជកម្មនៅភាគខាងត្បូង បិទហាងទំនិញទាំងអស់របស់ពួក “អ្នកជំនួញជាគហបតី” ដោយតម្រូវថាប្រាក់សន្សំទុកផ្ទាល់ខ្លួនទាំងអស់ត្រូវយកទៅដាក់ក្នុងធនាគារជាតិនានា ជាមួយនឹងការត្រួតពិនិត្យរបស់រដ្ឋាភិបាលលើការដកប្រាក់ទៅវិញ ។ បើសិនជាវិធានការទាំងនេះត្រូវអនុវត្តទៅលើពួកវៀតណាមក៏ដូចពួកចិន វាមុខជាធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់ពួកចិនកាត់វៀតណាមមិនខាន ។

នៅរដូវសានរដូវ មានជនជាតិចិនកាត់វៀតណាមយ៉ាងហោចហុកសិបពាន់នាក់ បានចាកចេញពីប្រទេសវៀតណាមទៅកាន់ប្រទេសចិន ។ ជនជាតិចិននិងវៀតណាមជាង ដប់ម៉ឺននាក់បានភៀសខ្លួនតាមកាណូតតូចៗដើម្បីទៅកាន់ប្រទេសផ្សេងៗក្នុងអាស៊ីភាគអាគ្នេយ៍ ។ តាមស្ថិតិដែលទើបមានថ្មីៗថា អ្នកទាំងនោះប្រហែលជាត្រូវស្លាប់យ៉ាងច្រើនក្នុងរយៈពេលនៃការធ្វើដំណើរ ។ ប្រទេសចិនបានចោទប្រកាន់ប្រទេសវៀតណាមអំពី “ការធ្វើទុក្ខបុកម្នេញ និងការបណ្ដេញចេញ” ចំពោះជនជាតិភាគតិចចិន ។ នៅខែឧសភា ក្រុងប៉េកាំងបានលុបចោលកម្មវិធីជំនួយសំខាន់ៗដែលផ្ដល់ទៅឲ្យប្រទេសវៀតណាម ហើយហៅទីប្រឹក្សាទាំងឡាយរបស់ខ្លួនត្រឡប់មកស្រុកវិញ ។

សម្រាប់ក្រុងហាណូយយល់ថា ការចោទប្រកាន់ផ្សេងៗរបស់ចិន គឺជាចំណែកមួយនៃការរួមគំនិតក្បត់ដ៏ធំមួយដើម្បីឡោមព័ទ្ធប្រទេសវៀតណាម ។ ក្រោយមានជម្លោះព្រំដែនរវាងខ្មែរ-វៀតណាម នៅខែធ្នូ ឆ្នាំ១៩៧៧ បន្តិច វិទ្យុរបស់វៀតណាម បានផ្សាយសេចក្ដីថ្លែងការណ៍មួយដូចតទៅ “តាំងពីការចាប់ផ្ដើមមានអធិករណ៍រវាងប្រទេសវៀតណាម និងកម្ពុជា ពាក្យចចាមអារ៉ាមផ្សេងៗបានលេចឮពីម្នាក់ទៅម្នាក់ [ក្នុងចំណោមជនជាតិភាគតិចចិន] ថាប្រទេសចិននឹងជួយគាំទ្រប្រទេសកម្ពុជា ហៀបសង្រ្គាមមួយនឹងផ្ទុះឡើង ហើយ [ជនជាតិភាគតិចចិន] នៅប្រទេសវៀតណាមនឹងស្ថិតក្នុងគ្រោះថ្នាក់ ដូច្នេះត្រូវតែចាកចេញពីប្រទេសនេះ ដោយឆាប់រហ័សបំផុត[៤៣]» ។

ការឆ្លើយតបរបស់ក្រុងហាណូយចំពោះដំណើរមានភ្លាមៗនៃអ្នកភៀសខ្លួនតាមទូក គឺស្ថិតនៅត្រង់បន្ទោសប្រទេសចិនដែលផ្សព្វផ្សាយពាក្យចចាមអារ៉ាមអុជអាលឲ្យមនុស្សម្នាគេចចេញពីប្រទេសវៀតណាម ។ នៅខែបន្ទាប់មក ប្រទេសវៀតណាមបានចោទប្រកាន់ពួកចិនថា បានផ្តល់នូវ«ការគាំទ្រទាំងស្រុងមួយចំពោះពួកអ្នកកាន់អំណាចនៅកម្ពុជា ក្នុងការបើកឆាកធ្វើការឈ្លានពានរបស់គេប្រឆាំងនឹងប្រជាជនវៀតណាម» ។

ក្រុងហាណូយបានប្រកាន់ជំហរជាផ្លូវការមួយ ដែលបើកឱកាសឲ្យវៀតណាមប្រកាសពីប្រភេទរដ្ឋមួយស្ថិតក្នុងស្ថានភាពពិសេសមួយដែលកងទ័ពជាអ្នករក្សាសណ្តាប់ធ្នាប់ ។ តាមការយល់ឃើញរបស់ពួកវៀតណាមថា ក្រុងប៉េកាំងបានបើករណសិរ្សពីរប្រឆាំងនឹងប្រទេសរបស់គេ ៖ ដោយធ្វើឲ្យកើតមានការរំជើបរំជួលក្នុងចំណោមជនជាតិភាគតិចចិន និងដោយជួយជំរុញឲ្យពួកកម្ពុជាវាយប្រហារប្រទេសវៀតណាមតាមព្រំដែនភាគខាងត្បូង ហើយប្រទេសចិនបានគំរាមដល់សន្តិសុខ និងអត្ថិភាពរបស់ប្រទេសវៀតណាមថែមទៀត ។ ដូច្នេះឥឡូវនេះ ក្រុងហាណូយអាចផ្តើមធ្វើឲ្យទំនាក់ទំនងផ្សេងៗរបស់ខ្លួន ជាមួយក្រុងមូស្គូទៅជាផ្លូវការដែរ ។

ភាពសំខាន់ខាងជាតិសាសន៍បានចាប់ផ្តើមលេចឡើងនៅពេលធ្វើការវាយលុក ។ តាមការវិនិច្ឆ័យជាមុនដែលមិនគិតដល់ការពិតថា ការមានខ្លួនជាចិនកាត់វៀតណាមគឺជាជនក្បត់ម្នាក់ ។ ប្រទេសចិនផ្ទាល់ត្រូវបានចោទប្រកាន់ពី «គំនិតចង្អៀតចង្អល់និយមនៃជនជាតិហាន» និងមានបំណងដណ្តើមយកប្រទេសវៀតណាមដោយកម្លាំងទ័ព ។ ពួកអ្នកកាន់អំណាចនៅក្រុងហាណូយបានធ្វើឲ្យការរស់នៅរបស់ជនជាតិភាគតិចចិនយ៉ាងច្រើនជួបការលំបាក រួចហើយយល់ព្រមទទួលសំណូកដើម្បីអនុញ្ញាតឲ្យគេរត់ភៀសខ្លួនតាមទូកតូចៗ ដែលមើលទៅគួរឲ្យព្រឺខ្លាចយ៉ាងខ្លាំង បណ្តាលឲ្យអ្នកទាំងនោះស្លាប់អស់យ៉ាងច្រើនដូចគ្នានឹងពួកអ្នកដែលទៅដល់ប្រទេសផ្សេងៗដោយសុវត្ថិភាពដែរ ។

នៅទីបំផុត ប្រទេសវៀតណាមបានប្រុងប្រៀបខ្លួនដើម្បីធ្វើសង្គ្រាមរួចជាស្រេច ។ ឥឡូវនេះកងទ័ពរបស់ខ្លួនបានមានមុខមាត់ក្នុងចំណោមកងទ័ពទាំងប្រាំដែលប្រសើរលើសគេនៃពិភពលោក ។ (កងទ័ពវៀតណាមមានយុទ្ធជនចំនួនមួយលាននាក់ទល់នឹងចំនួនប្រាំបីរយពាន់នាក់ ដែលជាកងទ័ពរបស់បណ្តាប្រទេសមិនមែនកុម្មុយនិស្តក្នុងតំបន់នេះបូកបញ្ចូលគ្នា) ។ ជាមួយនឹងប្រជាជនចំនួនហាសិបលាននាក់ ប្រទេសវៀតណាមគឺជាមហាអំណាចកុម្មុយនិស្តទីពីរនៅអាស៊ី ។

ឥឡូវនេះ ក្រុងហាណូយមានមូលហេតុយ៉ាងប្រសើរមួយគឺសន្តិសុខជាតិរបស់ខ្លួនត្រូវគំរាមកំហែង - ចូលលុកលុយប្រទេសកម្ពុជា ហើយអាចទម្លាក់ការទទួលខុសត្រូវទាំងអស់ទៅលើប្រទេសចិនដែលជាសត្រូវចាស់របស់ខ្លួន ។ ប្រទេសវៀតណាមត្រូវប្រឈមមុខដោះស្រាយបញ្ហាធ្ងន់ធ្ងរជាច្រើននៅក្នុងប្រទេសរបស់ខ្លួនដែលជំរុញរដ្ឋាភិបាលអំពាវនាវឲ្យប្រជាជនប្រមូលផ្តុំកម្លាំងជាថ្មីម្តងទៀត ដើម្បីប្រឈមនឹងការគំរាមកំហែងរបស់មហាអំណាចបរទេសមួយគឺប្រទេសចិន ។ (ប្រទេសកម្ពុជាមិនអាចមានឈ្មោះជាប្រទេសផ្តល់គ្រោះថ្នាក់ពិតប្រាកដ

មួយទេ ក្រុងហាណូយតែងតែកំណត់ប្រទេសចិនជាគោលដៅត្រូវវាយប្រហារជានិច្ច ទោះបីជានៅពេលបំភ្លឺពីការលុកលុយ និងកាន់កាប់ប្រទេសកម្ពុជាក៏ដោយ) ។

ហើយជាពិសេស ពួកកុម្មុយនិស្តកម្ពុជា បានរៀបចំស្ថានភាពជាស្រេចសម្រាប់ការលុកលុយរបស់វៀតណាម ដោយហេតុផ្ទាល់ក៏ស្ថិតនៅក្នុងកាតព្វកិច្ចទម្លាក់ការទទួលខុសត្រូវអំពីអំពើឧក្រិដ្ឋអាក្រក់ហួសប្រមាណក្នុងការធ្វើបដិវត្តន៍របស់គេទៅលើប្រទេសក្រៅមួយដែរ ។ ដូច្នេះសម្រាប់ពិភពលោកទាំងមូលអ្នកកៀសខ្លួនតាមទូកបានទៅជាសញ្ញា ដំបូងមួយដែលប្រមានពីការលូតលាស់ឡើងវិញយ៉ាងឆាប់រហ័សនៃសង្គ្រាមបន្តបន្ទាប់គ្នានៅឥណ្ឌូចិនយ៉ាងមិនគួរឲ្យជឿ ។

# ជំពូកទី១០
# ទីបញ្ចប់ នៃភាពនៅស្ងៀមស្ងាត់

## ការវិលវល់ស្មារតីជារួម

យើងបានទៅដល់ប្រទេសកម្ពុជានៅចំពេលដែលពិភពលោក ជាពិសេស លោកខាងលិច ចាប់នឹកភ្នកដល់សោកនាដកម្មនៅឥណ្ឌូចិន ក្រោយសម័យសង្គ្រាមឡើងវិញ ។ ភ្លាមៗបន្ទាប់ពីសង្គ្រាមចប់ រដ្ឋការអាមេរិកាំង មានបំណងបំភ្លេចចោលប្រយោគ«វៀតណាម ឡាវ និងកម្ពុជា»ទាំងស្រុង ។ ទស្សនីយភាព ដែលបង្ហាញឲ្យឃើញសហរដ្ឋអាមេរិក ដែលបោះបង់ស្ថានទូតរបស់ខ្លួន នៅទីក្រុងព្រៃនគរ មួយថ្ងៃមុនមានការសុំចុះចាញ់របស់វៀតណាមខាងត្បូង គឺជាសញ្ញាចាប់ផ្តើមនូវការពន្យារការជជែកពិភាក្សាគ្នាស្តីពីសង្គ្រាម ដែលប្រកាសឲ្យដឹងពីរ-បីអាទិត្យក្រោយមក ដោយប្រធានាធិបតីជំនាន់នោះ គឺលោក ហ្សេរ៉ាល់ ហ្វ័រដ៍ (Gerald Ford) [ជាអនុប្រធានាធិបតីរបស់ និចសុន ដែលបានបន្តតំណែងនៅពាក់កណ្តាលអាណត្តិពីឆ្នាំ១៩៧៤ ដល់ឆ្នាំ១៩៧៦ -កំណត់របស់អ្នកបកប្រែ] ។ សហរដ្ឋអាមេរិកទើបនឹងស្គាល់នូវការខកចិត្តដ៏ធំជាលើកដំបូងរបស់គេ ហើយថែមទាំងបរាជ័យខាងផ្នែកយោធាដ៏ធំបំផុតជាលើកទីមួយរបស់គេ ហើយគេមិនអាចផ្លាស់ប្តូរការពិតនេះ ដោយបង្កើនការបដិសេធ និងបន្ទោសសភាជាន់ទាបអាមេរិកាំង ដែលកាត់បន្ថយថវិកាជំនួយ ដែលយល់ព្រមផ្តល់ឲ្យក្រុងព្រៃនគរ ក្នុងប៉ុន្មានខែចុងក្រោយនេះ ហើយចោទប្រកាន់ចលនាប្រឆាំងសង្គ្រាមថា បានបំផ្លាញទឹកចិត្តប្រជាជនអាមេរិកាំងឡើយ ។

ការប្រើងប្រែងធ្វើសង្គ្រាមរបស់សហរដ្ឋអាមេរិក បានលេចឡើងឲ្យឃើញគុណវិបត្តិជាសារវន្តមួយ ប៉ុន្តែគ្មានមេដឹកនាំអាមេរិកាំងណាម្នាក់នៅឆ្នាំ១៩៧៥ ព្រមទទួលស្គាល់លក្ខណៈពិរបស់វាសោះឡើយ ។ សម្រែកកងរំពង សម្តែងសេចក្តីក្តៅក្រហាយ ដែលទាមទារឲ្យមានការឆ្លើយតប បានធូរស្រាលមកវិញ ដោយហេតុថាសង្គ្រាមបានឈានដល់ទីបញ្ចប់ហើយ ។ ពីរឆ្នាំបន្ទាប់ពីការដកថយរបស់កងទ័ពអាមេរិកាំង ជ័យជម្នះរបស់ពួកកុម្មុយនិស្ត បានផ្តល់ឲ្យជម្លោះនេះមានប្រេកចេញមិនច្បាប់លាស់មួយ សម្រាប់ចរន្តមតិសាធារណៈអាមេរិកាំងទាំងអស់ ។ សង្គ្រាមត្រូវអូសបន្លាយ ហួសអំពីសម័យកំពូលនៃចលនារបស់អ្នកសន្តិភាពនិយមទៅទៀត ។ ការពិភាក្សាខាងនយោបាយមួយរបស់មនុស្ស ដែលមានភក្តីភាពចំពោះប្រធានាធិបតីនៅសហរដ្ឋអាមេរិកកាលនោះ មិនគួរធ្វើឲ្យពួកវៀតណាមខាងជើង និងពួកខ្មែរក្រហមដើរចូលក្នុងក្រុងព្រៃនគរ និងក្រុងភ្នំពេញបានឡើយ ។

ទាំងពួកអ្នកចូលចិត្តនយោបាយប្រើកម្លាំង ទាំងពួកអ្នកនិយមសន្តិភាព ពុំបានស្វែងរកចម្លើយនៅខាងម្ខាងនៃសង្គ្រាមរបស់អាមេរិកាំងទេ - ដោយពិចារណាជាឧទាហរណ៍ រឿងទាំងមូលនៅឥណ្ឌូចិន, រឿងប្រទេសកម្ពុជា, ប្រទេសវៀតណាម, ប្រទេសចិន និងទំនាក់ទំនងផ្សេងៗរបស់ប្រទេសទាំងនេះ ។ ប្រការនេះ អាចនឹងធ្វើឲ្យមាន

ការចោទប្រកាន់ឡើងវិញអំពីគន្លងមនោគមវិជ្ជា ដែលណែនាំឲ្យប្រព្រឹត្តតាមនៅសហរដ្ឋអាមេរិកក្នុងកំឡុងពេលសង្គ្រាម ។ ដោយហេតុនេះ ចលនាប្រឆាំងសង្គ្រាម បានចាប់ផ្ដើមចុះខ្សោយកាលបើកងទ័ពអាមេរិកាំងបញ្ឈប់ការប្រយុទ្ធ ។ ហើយបន្ទាប់ពីឆ្នាំ១៩៧៥ នៅពេលដែលរដ្ឋាភិបាលសហរដ្ឋអាមេរិក បដិសេធលែងពិនិត្យកិច្ចសន្យារបស់ខ្លួន ដោយក្រសែភ្នែករិះគន់មួយ, លែងទទួលស្គាល់ការទទួលខុសត្រូវដោយថាហេតុនោះគឺអ្វីៗស្ថិតនៅក្នុងភាពមិនអើពើជាទូទៅ ។

នយោបាយជាផ្លូវការរបស់សហរដ្ឋអាមេរិក និងវេទយិតភាព (ភាពឆាប់រំភើប) របស់ពួកអាមេរិកាំងហាក់ដូចជាត្រូវធ្វើឲ្យនៅនឹងថ្កល់ ។ គឺប្រៀបដូចជាប្រទេសទាំងមូលត្រូវធ្វើឲ្យភ្លឹកភ្លាំង, ឲ្យចុះខ្សោយយ៉ាងខ្លាំង, ឲ្យមួម៉ៅមែនទែន នៅពេលផ្លាស់ប្ដូរយោបល់ ឬគិតពិចារណាទៅលើអ្វីដែលកើតមានក្នុងកំឡុងសង្គ្រាមនៅឥណ្ឌូចិន ។ ពួកអ្នកនិយមនយោបាយប្រើកម្លាំងនៅតែជាអ្នកនិយមនយោបាយប្រើកម្លាំង អ្នកនិយមសន្តិភាពនៅតែជាអ្នកនិយមសន្តិភាព ដោយគ្មានពាក្យសម្ដីមួយត្រូវផ្លាស់ប្ដូរឡើយ ។ បុណ្យខួបលើកទីមួយ និងលើកទីពីរនៃការបញ្ចប់សង្គ្រាម បានឆ្លងផុតទៅស្ទើរតែគ្មាននរណាកត់សម្គាល់ ។ ក្នុងចំណោមក្រុមអ្នកតទល់គ្នាខាងនយោបាយទាំងសងខាង មានអ្នករងគ្រោះយ៉ាងច្រើន ទាហានរបួសពិការ ឬចាត់ថាបាត់ខ្លួន, និងខ្មោចច្រើនណាស់ដែលត្រូវបណ្ដេញចេញ ។

ហេតុការណ៍មួយក្នុងចំណោមហេតុការណ៍ជាច្រើននៃការបំពារបំពាន ហួសហេតុមួយ ឬការឡុកឡឺយមួយដែលគេមិនអាចជៀសវាងបាន អាចផ្ដាច់ពួកអាមេរិកាំង ចេញពីការបំភ្លេចប្រទេសវៀតណាម ជារូមរបស់គេ ៈ អតីតយុទ្ធជនម្នាក់ បានលាក់ខ្លួននៅក្នុងផ្ទះរបស់គាត់នៅតំបន់ជាយក្រុងវ៉ាស៊ីនតោន និងបានបាញ់រះដោយកាំភ្លើងយន្តទៅលើគេហដ្ឋានតូចៗក្បែរខាង នាពេលរសៀលថ្ងៃអាទិត្យមួយក្នុងរដូវរងា រហូតទាល់តែប៉ូលិសមូលដ្ឋានទៅដល់ ហើយបានបាញ់សម្លាប់អតីតយុទ្ធជននោះ[1] ។ គេរកឃើញថា ប៉ូលិសព្រៃនគរថៅកទាបម្នាក់បានកាន់«អាហារចម្អិនទាន់ចិត្ត»មួយប្រអប់ នៅក្រោមម្ចប់នៃមន្ទីរបញ្ចកោណ ។

លោក ហង់រី គីស្ស៊ីងហ្គ័រ នៅធ្វើជារដ្ឋមន្ត្រីក្រសួងការបរទេស បម្រើការងារឲ្យលោកប្រធានាធិបតី ហ្វ័ដដែលជាអ្នកលើកទោសឲ្យអតីតប្រធានាធិបតីខូចកេរ្តិ៍ឈ្មោះ និចសុន ចំពោះបទឧក្រិដ្ឋទាំងអស់ដែលគាត់ធ្លាប់បានប្រព្រឹត្ត ទាក់ទងទៅនឹងរឿង វ៉ធឺហ្គេត ។ ជាមួយនឹង គីស្ស៊ីងហ្គ័រ និងហ្វ័រដ៍ បង្ហាញខ្លួនចំពោះមុខចៅក្រម សាលក្រមពន្យារពេលមានន័យថា ការនៅស្ងៀមស្ងាត់ចំពោះពិរុទ្ធភាពទាំងអស់ទាក់ទងនឹងសង្គ្រាម, ការហាមប្រាមមិនឲ្យស៊ុះស៊ើងចង់ដឹងថា ហេតុដូចម្ដេចបានជាសហរដ្ឋអាមេរិកត្រឡប់មកជាប់ពាក់ព័ន្ធក្នុងជម្លោះមួយ ដែលត្រូវចាញ់ទៅហើយ ធ្វើអ្វីថ្មីបើវាធ្វើឲ្យប្រទេសជាតិបង់ខាតយ៉ាងណាក្ដី ។ ពួកអាមេរិកាំងដែលធ្លាប់ទទួលខុសត្រូវចំពោះមហន្តរាយនេះ បានទទួលគុណប្រយោជន៍ពីការលស់លា ដោយភាពនៅស្ងៀមស្ងាត់មួយ ។ ពួកគេបានត្រឡប់ទៅការិយាល័យមេធាវីវិញ ដែលស្ថិតនៅក្នុងរង្វង់ជាន់ខ្ពស់នៃរដ្ឋាភិបាល ឬកាន់កាប់មុខតំណែងខ្ពង់ខ្ពស់នៅទីដទៃ

ទៀត ។ គឺពុំមានការស្តីបន្ទោសជាផ្លូវការ ទាំងពុំមានការពន្យល់ជាសាធារណៈឡើយ គឺមានតែភាពនៅស្ងៀមស្ងាត់ប៉ុណ្ណោះ ។

ក្នុងស្ថានភាពនឹងថ្កល់នេះ ប្រទេសវៀតណាម និងកម្ពុជា នៅតែរក្សារូបភាពជាសត្រូវនឹងគ្នាជានិច្ច ។ ប្រធានាធិបតី ហ្វ័រដ៏ នៅតែប្រកាន់ការរាំងខ្ទប់ផ្នែកសេដ្ឋកិច្ចដែលបានសម្រេចប្រឆាំងនឹងវៀតណាមខាងជើង ក្នុងកំឡុងសង្គ្រាមដដែល ។ អាមេរិកតែម្នាក់ឯងប៉ុណ្ណោះ អាចរារាំងមិនឲ្យប្រទេសវៀតណាមចូលក្នុងអង្គការសហប្រជាជាតិថែមទៀត ។ សហរដ្ឋអាមេរិក ពុំព្រមទទួលយកបរាជ័យដោយស្រួលៗនោះឡើយ ៖ មិនត្រឹមតែក្រុងវ៉ាស៊ីនតោន ប្រានចោលចំណងទាក់ទងផ្សេងៗ ជាមួយក្រុងហាណូយប៉ុណ្ណោះទេ គឺចង់ឲ្យពិភពលោកផ្ចាញ់ផ្ចាលរដ្ឋថ្មីរបស់វៀតណាម ទៅជារដ្ឋក្ររហេមរហាម ។

ការដកថយរបស់អាមេរិកាំងចេញពីអាស៊ីអាគ្នេយ៍ មានសភាពលឿនរហ័សបំផុត ។ មានតែកាសែតធំៗពីរប៉ុណ្ណោះ ដែលរក្សាទុកអ្នកឆ្លើយឆ្លងរបស់ខ្លួន មួយនាក់ប្រចាំនៅទីក្រុងបាងកក គឺកាសែតញូវយ៉កថែមស៍ និងឡូអង់ហ្សឺឡេស ដើម្បី«ចាំស្រង់ពត៌មាន»ក្នុងតំបន់នេះ ពីឆ្នាំ១៩៧៤ ដល់ឆ្នាំ១៩៧៨ ។ ឥណ្ឌូចិន លែងជា«រឿងបច្ចុប្បន្នភាព»សម្រាប់សារពត៌មានទៀតហើយ ហើយតំបន់អាស៊ីអាគ្នេយ៍ទាំងមូល ត្រូវគេ«តាមដាន»ពីទីក្រុងហុងកុងមកវិញ ដែលគេប្រើធ្វើជាកន្លែងសង្កេតការណ៍ ចំពោះប្រទេសចិន ។ បណ្តាប្រទេសដែលធ្លាប់ទទួលការយកចិត្តទុកដាក់របស់អាមេរិកាំង ក្នុងរយៈពេលប្រមាណជាដប់ឆ្នាំ បានរលាយបាត់ឈ្មោះភ្លាមៗពីកាសែត និងកញ្ចក់ទូរទស្សន៍នានា ។

សាកលវិទ្យាល័យអាមេរិកាំង ក៏ឈប់យកចិត្តទុកដាក់នឹងតំបន់នេះដូចគ្នា ។ ការសិក្សាស្រាវជ្រាវពីឥណ្ឌូចិន ក៏លែងឃើញមានក្នុងកម្មវិធីសិក្សារបស់បណ្តាសាកលវិទ្យាល័យអាមេរិកាំងតទៅទៀតដែរ លើកលែងតែសកលវិទ្យាល័យ២-៣ប៉ុណ្ណោះ ។ ជំនួយរបស់រដ្ឋាភិបាលសម្រាប់ផ្នែកនេះ ក៏បាត់លែងឃើញមាន[៧] ។ បណ្តារបបថ្មីនៅឥណ្ឌូចិន បានប្រកាន់យកនយោបាយផ្តល់ទិដ្ឋាការមួយយ៉ាងតឹងរ៉ឹងបំផុត ដោយហាមមិនឲ្យសាស្ត្រាចារ្យសកលវិទ្យាល័យបរទេស ចូលទៅធ្វើការសិក្សាស្រាវជ្រាវនៅក្នុងប្រទេសផ្ទាល់របស់ខ្លួនថែមទៀត ។ សកលវិទ្យាល័យទាំងនោះ បានផ្លាស់ប្តូរកម្មវិធីយ៉ាងឆាប់រហ័ស ឬធ្វើការសម្រាប់ប្រទេសផ្សេងៗ ដែលនៅទាក់ទងនឹងឥណ្ឌូចិននៅឡើយ ជាពិសេស ប្រទេសអូស្ត្រាលី ។

ពួកអ្នកជំនាញការដ៏កម្រឃើញមានដូចជា សាស្ត្រាចារ្យសាកលវិទ្យាល័យ, មន្ត្រី និងអ្នកការសែត ដែលបន្តសរសេរបន្លាញ និងសិក្សាស្រាវជ្រាវអំពីតំបន់នេះ បានត្រូវគេឲ្យឈ្មោះក្រៅថា "អ្នកឃ្លាំមើលឥណ្ឌូចិន" ។ មនុស្ស ទាំងប្រុសទាំងស្រីនេះ ត្រូវបានបង្ខំឲ្យធ្វើតាម"ពួកអ្នកឃ្លាំមើលឥណ្ឌូចិន" នៅក្នុងទសវត្សរ៍១៩៥០ និង ១៩៦០ ជាសម័យកាលដែលប្រជាជាតិយក្សនេះត្រូវកាត់ផ្តាច់ពីពិភពលោក ។ ពួកអ្នកឃ្លាំមើលឥណ្ឌូចិន អាចសង្កេតមើលបណ្តប្រទេសដែលពួកគេយកចិត្តទុកដាក់តែពីចម្ងាយប៉ុណ្ណោះ ។ ពួកគេប្រមូលបានពត៌មានសំខាន់ៗ

មកអំពីប្រភពដ៏កម្រដែលមានបច្ចុប្បន្ន ៖ ការផ្សាយរបស់វិទ្យុ និងកាសែតទាំងឡាយរបស់រដ្ឋាភិបាល ដែលត្រូតពិនិត្យយ៉ាងសម្រិតសម្រាំង, ចម្លើយជាសាក្សីរបស់ពួកអ្នកភៀសខ្លួន ពួកអ្នកការទូតបរទេសដែលបំពេញមុខការនៅប្រទេសឡាវ និងប្រទេសវៀតណាម ។ ប៉ុន្តែ អាស្រ័យដោយដើមកំណើតខាងភូមិសាស្ត្រនិងសង្គម និងទស្សនៈនយោបាយរបស់គាត់ ពួកអ្នកភៀសខ្លួនពុំបានបង្ហាញអ្វីដែលតំណាងឲ្យប្រជាជនទាំងមូលមួយឡើយ ។ ដូចគ្នាដែរ ពួកអ្នកការទូតបរទេស ដែលមកពីក្រុងហាណូយ ឬក្រុងវៀងចន្ទ រដ្ឋធានីប្រទេសឡាវវិញ បានត្រឹមតែផ្ដល់ពត៌មានដែលមានកំណត់មួយអំពីប្រទេសដែលពួកគេបំពេញមុខងាររប៉ុណ្ណោះ ។

សរុបទៅពួកអ្នកឃ្លាំមើលបានត្រឹមតែផ្ដល់ពត៌មានអាវាត់អាវាយមួយ ហើយមិនគ្រប់សព្វទៅទៀត ។ ពួកគេពុំបានប្រាប់ឲ្យដឹងពីរូបភាពទាំងស្រុងមួយរបស់ប្រទេសនីមួយ ៗ ទេ ហើយរឿងនៅឥណ្ឌូចិនរឹតតែតិចទៅទៀត ។ ហើយដោយមានពត៌មានបានពីប្រភពដើមតិចតួចពេក ពួកអ្នកជំនាញការបានសំដែងសេចក្ដីធុញថប់នឹងបញ្ចេញសេចក្ដីសន្និដ្ឋានមុតមាំអំពីរដ្ឋកុម្មុយនិស្តថ្មីៗនៅឥណ្ឌូចិនបំផុត ។ បញ្ហាទៅជាស្មុគស្មាញថែមទៀតអាស្រ័យដោយការលម្អៀងផ្សេងៗ ដែលបណ្ដាលឲ្យមានការលើកមកនិយាយពីប្រទេសវៀតណាម កម្ពុជា និងឡាវ តែមួយប៉ុណ្ណោះ ។ ដំណឹងទាំងអស់ទាក់ទងនឹងឥណ្ឌូចិន បានជំរុញឲ្យមានការពិភាក្សាខាងនយោបាយយ៉ាងគ្រោតគ្រាត ស្ដីពីការប្រឡូករបស់សហរដ្ឋអាមេរិកនៅសម័យសង្គ្រាម ។ ពួកគេពុំអាចរលាស់ចោលភ្លាមនូវទស្សនៈផ្សេងៗ ដែលត្រូវធ្វើឲ្យចាក់ឫសយ៉ាងជ្រៅរួចមកហើយទេ ។ ចំណែកពួកអ្នកឯកទេសក៏អ៊ីចឹងដែរ គេត្រូវការពេលវេលាដើម្បីថយក្រោយ និងវិនិច្ឆ័យឥណ្ឌូចិន ក្នុងឋានៈជាតំបន់ថ្មី ដែលកំពុងតែប្រែប្រួលជាលំដាប់ និងពិនិត្យមើលប្រទេសផ្សេងៗទៀត ក្នុងបរិបទផ្ទាល់របស់គេ គឺពុំមែនតាមរយៈសង្គ្រាមរបស់អាមេរិកាំងទេ ។

បើគិតទាំងអស់ទៅ វាជាលទ្ធផលនៃការបម្រុងខ្លួនជាអ្នកឯកទេស (សម្រាប់ធ្វើការអ្វីមួយឲ្យពិសេស) របស់ពួកអ្នកជំនាញការ និងពួកអ្នកកាសែត ដែលយកចិត្តទុកដាក់ចំពោះឥណ្ឌូចិន ។ ដោយមិនអាចពិពណ៌នាដាក់លាក់ទាំងស្រុងមួយ ពួកអ្នកឃ្លាំមើលបានជញ្ជីងគិតការណ៍វាយរងវិញ ។ នៅទីក្រុងបាងកក ពួកអ្នកកាសែតបានសម្ភាសអ្នកភៀសខ្លួនកម្ពុជាជាច្រើន ប៉ុន្តែ នៅទីក្រុងហុងកុង ពួកគេសរសេរអំពីនយោបាយរបស់រដ្ឋាភិ-បាលខ្មែរ ។ បណ្ដាសាស្ត្រាចារ្យសាកលវិទ្យាល័យ បានបម្រុងខ្លួនជាអ្នកឯកទេសក្នុងវិស័យជាច្រើន ដែលពួកគេអាចទទួលបានឯកសារផ្សេងៗពីក្រសួងការបរទេស, អ្វីៗដែលពួកអ្នកភៀសខ្លួនបានអះអាងជាថ្មី, គម្រោងការរបស់រដ្ឋាភិបាល ។ អ្នកជំនាញការម្នាក់ បានសិក្សាពីការប្រកួតប្រជែងរវាងចិន-វៀតណាម ដោយសំអាងទៅលើការប្រេះឆា រវាងចិន-សូវៀត អ្នកជំនាញការម្នាក់ទៀត សិក្សាពីប្រវត្តិនៃបញ្ហាព្រំដែន រវាងប្រទេសវៀតណាម និងកម្ពុជា ។

ដោយការនៅស្ងាត់ស្ងៀម ការបដិសេធរបស់គេមិនអនុញ្ញាតឲ្យមានការសិក្សាស្រាវជ្រាវ ឬការយក

ពត៌មានអំពីប្រទេសរបស់ពួកគេ ពួកមេដឹកនាំវៀតណាម និងកម្ពុជា ដែលធ្វើឲ្យមានសង្ឃឹមដោយសារការដកថយរបស់អាមេរិកាំង តាមពិត គឺការដកថយរបស់លោកខាងលិចពីភូមិភាគនេះ និងការមិនដឹងព្រមគ្នានូវស្ថានភាពពិតៗមួយចំណែកធំរបស់ប្រទេសទាំងនេះ ។ ទាំងក្រុងហាណូយ ទាំងក្រុងភ្នំពេញ គ្មាននិយាយអ្វីទាំងអស់ ទោះជាអ្វីក៏ដោយ ស្តីពីជម្លោះដែលធ្វើឲ្យព្រួយបារម្ភរបស់គេ មុនពេលដែលវានាំទៅរកជម្លោះព្រំដែនធំសម្បើមមួយនៅចុងឆ្នាំ១៩៧៧ ។ ដូចបណ្តាប្រទេសកុម្មុយនិស្តភាគច្រើនដែរ ប្រទេសវៀតណាម និងកម្ពុជា បានផ្សព្វផ្សាយតែពត៌មានល្អៗប៉ុណ្ណោះ ដោយមិនដែលនិយាយពីបញ្ហាលំបាកស្មុគស្មាញរបស់ខ្លួនទាល់តែសោះ ។ ដោយអានតែកាសែតផ្លូវការរបស់វៀតណាម ឬសេចក្តីចម្លងផ្សេងៗតាមការផ្សព្វផ្សាយរបស់វិទ្យុកម្ពុជា គេហាក់ដូចជាយល់ថា ការបដិវត្តន៍បានធ្វើឲ្យប្រទេសវៀតណាម និងកម្ពុជា ក្លាយទៅរដ្ឋរបស់វណ្ណៈកម្មករ មានសន្តិភាព និងបង្កបង្កើនផល ដោយខិតខំប្រឹងប្រែងអស់ពីសមត្ថភាពរបស់គេ ដើម្បីជួសជុលការខូចខាតយ៉ាងសម្បើម ដែលបណ្តាលឡើងដោយសារសង្គ្រាម ។

ប្រទេសវៀតណាម បានទទួលស្វាគមន៍អ្នកកាសែតបរទេសជាច្រើន, ប្រទេសឡាវទទួលអ្នកកាសែតបរទេសមួយចំនួន, ចំណែកប្រទេសកម្ពុជាគ្មានម្នាក់សោះ ។ ពួកអ្នកកាសែតដែលធ្វើដំណើរទៅប្រទេសវៀតណាម បានបំពេញទស្សនារបៀបជាចរគំរូមួយ ដែលសង្កត់បញ្ជាក់អំពីការបំផ្លិចបំផ្លាញប្រទេស និងបញ្ហាស្តារប្រទេសរបស់ខ្លួនឡើងវិញ ។ តាមធម្មតា កម្មវិធីរួមមានការដើរមើលភូមិនានា និងបណ្តាតំបន់សេដ្ឋកិច្ចថ្មី, មណ្ឌលមួយសម្រាប់ទុកដាក់បណ្តាស្រីពេស្យា ឬអតីតអ្នកជក់ថ្នាំញៀន, រោងចក្រទាំងឡាយដែលកសាងឡើងដោយជំនួយបរទេស ដូចជាកម្មន្តសាល ធ្វើក្រដាសនៅបៃបុង ដែលផ្តល់ប្រាក់ដោយពួកស៊ុយអែដ ។ អ្នកកាសែតទាំងនេះសុទ្ធតែឃ្លាំមើល ហើយត្រូវតែទទួលបានការអនុញ្ញាតជាមុនមួយ សម្រាប់ការសន្ទនារបស់ពួកគេស្ទើរតែទាំងអស់ ជាមួយប្រជាជនវៀតណាមម្នាក់ ដែលប្រព្រឹត្តទៅដោយមានវត្តមាន«មគ្គុទ្ទេសក៍»ម្នាក់ ឬអ្នកបកប្រែម្នាក់ ដែលចេញពីរដ្ឋាភិបាល ។

បើគ្មានពត៌មានទាំងនេះទេ គេមិនអាចរាយការណ៍ពីការពិតនៅឥណ្ឌូចិនក្រោយសម័យសង្គ្រាមឡើយ ។ មានអ្នកជំនាញការតិចតួច ដែលយល់ហើយមិនសូវដឹងថែមទៀត នូវអ្វីដែលចងភ្ជាប់រវាងពួកគេនឹងភាពអាថ៌កំបាំងគួរឲ្យព្រឺរន្ធត់នៃតំបន់នេះ ។ គ្មានអ្នកណាម្នាក់ប្រមាណដឹងជាមុនពីការផ្ទុះសង្គ្រាម នៅឆ្នាំ១៩៧៨ឡើយ ។ តាំងពីសង្គ្រាមចប់ទៅ គេពិបាកដឹងព្រឹត្តិការណ៍ផ្សេងៗ នៅពេលដែលវាកើតមានឡើងក្នុងប្រទេសនីមួយៗ និងពិបាកស្វែងយល់នូវការផ្សាយប្រចាំថ្ងៃរបស់វិទ្យុរដ្ឋាភិបាលប្រទេស ដើម្បីប្រៀបធៀបនឹងចម្លើយជាសាក្សីរបស់ពួកអ្នកភៀសខ្លួន និងបទយកពត៌មានផ្សេងៗរបស់ពួកអ្នកកាសែតដ៏កម្រមាន ដែលធ្លាប់បានទៅទស្សនាតំបន់នេះណាស់ ។ អ្នកឯកទេសម្នាក់ខាងបញ្ហាកម្ពុជា ក៏ពុំសូវមានពេល«តាមដាន»បញ្ហាប្រទេសវៀតណាម ឡាវ និងចិនដែរ ។ នៅពេលដែលសង្គ្រាមឥណ្ឌូចិនលើកទីបីផ្ទុះឡើង ភាគច្រើននៃរដ្ឋាភិបាល និងអ្នកជំនាញការ

ទាំងឡាយ មានការខ្វាយខ្វល់ចិត្តយ៉ាងខ្លាំង ក្នុងការពន្យល់ពីមូលហេតុរបស់វា ឬវិនិច្ឆ័យជាមុននូវផលវិបាកផ្សេងៗ ដែលកើតចេញពីព្រឹត្តិការណ៍ទាំងនោះផង ។

"ការដកថយដែលមានលក្ខណៈរួម" របស់អាមេរិក បានប៉ះពាល់ដល់ភូមិភាគអាស៊ីអាគ្នេយ៍ទាំងមូល ទាំងប្រទេសជាមិត្ត និងអតីតសត្រូវ ។ គ្រោះអាក្រក់ដែលមានទំនងដូចជាការបំអកបញ្ឈឺចិត្តដ៏ជូរចត់នៃស្ថានការណ៍នេះ ពុំរួចផុតពីក្រសែភ្នែករបស់បណ្តាប្រទេសមិនមែនកុម្មុយនិស្តនៅក្នុងតំបន់ គឺប្រទេសថៃ, សិង្ហបុរី, ម៉ាឡេស៊ី, ឥណ្ឌូនេស៊ី និងហ្វីលីពីន ឡើយ ។ បណ្តារដ្ឋជាសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ទាំងនេះបានបញ្ចេញ ប្រតិកម្មជាបន្តបន្ទាប់អំពីគ្រោះថ្នាក់ផ្សេងៗ ដែលគេធ្លាប់និយាយពេញរយៈពេលនៃសង្គ្រាម[៣] ។ គឺប្រទេសទាំងនេះ ហើយដែលសហរដ្ឋអាមេរិក អះអាងការពារពីការគ្រួតគ្រាមួយរបស់ពួកកុម្មុយនិស្តវៀត-ណាម ។ នោះគឺល្បែង ដូមីណូ ដែលនឹងត្រូវដួលរលំ និងទាក់ទាញឲ្យពួកអាមេរិកាំងយកចិត្តទុកដាក់ បើសិនជាពួកកុម្មុយនិស្តទទួលជ័យជម្នះនៅឥណ្ឌូចិន ។

ប៉ុន្តែ ក្រោយឆ្នាំ១៩៧៥ អាមេរិក ហាក់ដូចជាបោះបង់ល្បែងដូមីណូនេះ ព្រមគ្នានឹងឥណ្ឌូចិនដែរ ។ នេះជារយៈកាលព្រួយបារម្ភ និងប្រកបដោយទុទិដ្ឋិនិយមមួយ - ដោយឡែកសម្រាប់ប្រទេសសិង្ហបុរី, ម៉ាឡេស៊ី និងប្រទេសថៃ ។ ប្រទេសថៃ ជាសម្ព័ន្ធមិត្តយោធាមួយរបស់សហរដ្ឋអាមេរិក, ប្រទេសសិង្ហបុរី ជាបក្សសម្ព័ន្ធមោះមុតជាងគេរបស់អាមេរិកនៅអាស៊ី ។ ពួកម៉ាឡេស៊ី និងពួកថៃ បានប្រឈមមុខតតាំងនឹងការបះបោរដ៏ខ្លាំងក្លារបស់ពួកកុម្មុយនិស្ត នៅក្នុងប្រទេសរៀងៗខ្លួន ។ នៅប្រទេសថៃ ពួកកុម្មុយនិស្តដែលទទួលការគាំទ្រដ៏មានតម្លៃមួយពីរបប ឡាវ និងកម្ពុជា ក្បែរខាង បានធ្វើសកម្មភាពខ្លាំងក្លាណាស់ ។ លីគ្វាន់យូ មេដឹកនាំសិង្ហបុរី ដែលធ្លាប់ជាអ្នកការពារដ៏ក្លៀវក្លា នូវ "ទ្រឹស្តីដូមីណូ" និងធ្លាប់បានណែនាំឲ្យប្រធានាធិបតី ចនសុន វាយប្រយុទ្ធនៅប្រទេសវៀតណាមបន្តទៅទៀត ដោយខ្លាចក្រែងថា សង្គ្រាមនឹងរាលដាលមកដល់ប្រទេសថៃ, ម៉ាឡេស៊ី និងសិង្ហបុរី ។

ម៉្យាងទៀត ប្រទេសនានានៃសមាគមអាស៊ាន បានចូលរួមយ៉ាងសកម្មក្នុងជម្លោះ ដោយកាន់ជើងខាងអាមេរិកដែលចាញ់ ។ ប្រទេសថៃ និងហ្វីលីពីន បានផ្តល់កន្លែងឲ្យពួកអាមេរិកាំងកសាងមូលដ្ឋានយោធាជាច្រើន ។ ប្រទេសសិង្ហបុរី, ម៉ាឡេស៊ី និងឥណ្ឌូនេស៊ី បានផ្តល់នូវការគាំទ្រតូចតាចមួយ ក្នុងវិស័យការទូត ឬការបណ្តុះបណ្តាលកម្លាំង ឬសន្តិសុខរបស់វៀតណាមខាងត្បូង ។ ប្រទេសច្រើនក្នុងចំណោមនោះព្រឺខ្លាចណាស់ ពីការសងសឹក ហើយក្នុងបណ្តាឆ្នាំ ដែលមានបន្ទាប់ពីជ័យជម្នះ ក្រុងហាណូយ បានជៀលត្មះបណ្តាប្រទេសនៃសមាគមអាស៊ានមិនឈប់ ចំពោះតួនាទីរបស់គេក្នុងសង្គ្រាម ក្រោមដឹកនាំបញ្ជារបស់សហរដ្ឋអាមេរិក ។

មុនដំបូង ប្រទេសទាំងនេះ បានធ្វើប្រតិកម្មតបតដោយឡែកពីគ្នាជាមួយនឹងកម្រិតនៃការភ័យស្ទន់ស្លោខុសៗគ្នា ។ ប្រទេសថៃ បានស្នើសុំឲ្យពួកអាមេរិកាំងរំសាយមូលដ្ឋានយោធាទាំងអស់របស់ខ្លួន បន្ទាប់មកស្វែងរកការផ្សះផ្សាគ្នាមួយជាមួយប្រទេសចិន ដែលនៅទីបំផុតនឹងនាំដល់ទំនាក់ទំនងខាងយោធាទៀត ។ ប្រាកដ

ណាស់រដ្ឋាភិបាលថៃវិនិច្ឆ័យថា ប្រទេសចិននឹងផ្តល់ឲ្យខ្លួននូវកិច្ចការពារមួយប្រសើរជាងសហរដ្ឋអាមេរិក ។ ប៉ុន្តែស្ថានការណ៍បានវិវត្តលឿនរហ័សពេកសម្រាប់កងទ័ពអភិរក្សមួយ ហើយនៅឆ្នាំ១៩៧៦ រដ្ឋប្រហារបង្ហូរឈាមមួយ បាននាំកងទ័ពឲ្យមកកាន់អំណាចវិញ ។

ប្រទេសម៉ាឡេស៊ី បានស្វែងរកការសន្ទនាជាមួយពួកមេដឹកនាំក្រុងហាណូយ ដែលមានជ័យជម្នះ ។ ប្រទេសឥណ្ឌូនេស៊ី ដែលតែងតែភ័យខ្លាចប្រទេសចិនច្រើនជាងប្រទេសវៀតណាម គឺជាប្រជាជាតិតែមួយគត់ដែលរក្សាការស្ងៀមស្ងាត់របស់ខ្លួន ។ ពួកហ្វីលីពីន កំពុងខ្វល់នឹងចលនាប្រឆាំង និងការបះបោរក្នុងប្រទេសផ្ទាល់របស់គេ ។ លីក្វាន់យូ ជាមេដឹកនាំអង់អាចស្វាហាប់របស់ប្រទេសសិង្ហបុរី បានវាយតម្លៃថា សន្តិសុខនៃរដ្ឋបុរីដ៏តូចរបស់គេទាមទារឲ្យមានកម្មវិធីទូទៅមួយសម្រាប់ប្រទេសទាំងអស់នៃសមាគមអាស៊ាន ក្នុងគោលបំណងចៀសវាងមានបញ្ហាផ្សេងៗ ជាមួយឥណ្ឌូចិនកុម្មុយនិស្ត ។

លី ប្រាថ្នាធ្វើឲ្យគេទុកចិត្តសមាគមនៃប្រជាជាតិអាស៊ីអាគ្នេយ៍ឡើងវិញ និងធ្វើឲ្យទៅកម្លាំងនយោបាយដ៏មានអំណាចមួយផង ។ សមាគមអាស៊ានបានត្រូវបង្កើតឡើងនៅឆ្នាំ១៩៧៦ ក្នុងគោលបំណងបង្កើតសហគមន៍សេដ្ឋកិច្ចមួយ ដូចសហគមន៍សេដ្ឋកិច្ចអឺរ៉ុបនៅក្នុងតំបន់ ។ គោលដៅនេះ បញ្ចេញឲ្យឃើញមិនអាចសម្រេចបានទេ ប៉ុន្តែនៅឆ្នាំ១៩៧៦ សមាគមអាស៊ានមានគោលដៅថ្មីមួយ ដោយបង្ហាញមុខមិនមែនកុម្មុយនិស្តតែមួយប៉ុណ្ណោះ ប្រឈមនឹងប្លុកកុម្មុយនិស្តឥណ្ឌូចិនមួយ ។

ចំនួននៃការប្រជុំរបស់អាស៊ាន បានកើនឡើងយ៉ាងច្រើននៅឆ្នាំ១៩៧៥ និង១៩៧៦ ។ លីក្វាន់យូ បានធ្វើដំណើរទៅមកមិនឈប់ឈរវាងសិង្ហបុរី និងក្រុងបាងកក ដើម្បីរិះរកស្ថានភាពរួមមួយជាមួយប្រទេសថៃ ជាប្រទេសដែលប៉ះពាល់ខ្លាំងជាងគេដោយសារជ័យជម្នះរបស់កុម្មុយនិស្ត ។ នៅចុងឆ្នាំ១៩៧៦ គេបានឈានដល់ការព្រមព្រៀងគ្នាមួយ ។ មិនត្រឹមតែប្រទេសនានានៃសមាគមអាស៊ានទទួលស្គាល់បណ្តារបបថ្មីនៅឥណ្ឌូចិនប៉ុណ្ណោះទេ ប៉ុន្តែពួកគេ បានត្រូវរ៉ូវគ្នាស្តីពីភាពចាំបាច់ក្នុង«ការជួបសន្ទនាគ្នា» ថែមទៀត ទាំងជាមួយពួកវៀតណាមក៏ដូចជាមួយពួកចិន ។ ពួកគេយល់ឃើញថា ពួកគេលែងអាចសំអាងលើពួកអាមេរិកាំងដើម្បីធានាសន្តិសុខរបស់គេទៀតហើយ ហើយថា ប្រទេសថៃ មានការយកចិត្តទុកដាក់ស្វែងរកការធានាបែបនោះពីខាងក្រុងប៉េកាំងវិញ ។ ជាមួយគ្នានោះ ពួកគេយល់ឃើញថា គេមិនចាំបាច់ឱនលំទោននៅមុខក្រុងហាណូយ និងក្រុងប៉េកាំងទេ ហើយថា ដោយរួមគ្នាជាប្លុកតែមួយ ពួកគេអាចក្លាយទៅជាគ្រឿងការពារដ៏ប្រសើរទល់នឹងស្ថានភាពធ្លាក់ចុះផ្នែកនយោបាយ និងសេដ្ឋកិច្ចរបស់គេ ។

ប្រាកដហើយ ប្រទេសទាំងនោះកើតមានការព្រួយបារម្ភមែនពីរឿងសេដ្ឋកិច្ចរបស់គេ បន្ទាប់ពីឆ្នាំ១៩៧៥ ។ បើសិនជាពួកអ្នកវិនិយោគបរទេស មិនបោះបង់ប្រទេសនានានៃសមាគមអាស៊ានទេ គេពិបាកស្វែងរកអ្នកវិនិយោគជាថ្មីណាស់ ។ ពិភពអ្នករកស៊ីមុខជារួញរាមិនដាក់ទុនឡើងវិញក្នុងតំបន់ដែលប្រទេសបីទើប

នឹងក្លាយជារដ្ឋកុម្មុយនិស្តទេ ។ គឺពិតជាធ្វើឲ្យអំពល់យ៉ាងចម្លែក សម្រាប់បណ្ដាប្រទេសនៃសមាគមអាស៊ានដែលជាអ្នកដើរតាមលទ្ធិមូលធននិយមយ៉ាងម៉ឺងម៉ាត់ ហើយដែលធ្លាប់ពឹងផ្អែកលើការវិនិយោគរបស់បរទេស ដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់គេ ។ នៅពេលនោះឯង ដែលពួកគេសម្រេចចិត្តប្រែក្លាយខ្លួនជាអ្នកលក់ និងអ្នកការពារដោយផ្ទាល់, ពង្រីកហេដ្ឋារចនាសម្ព័ន្ធ និងទាក់ទាញពួកអ្នកវិនិយោគិនបរទេសដោយខ្លួនឯង ហើយលែងសំអាងលើការជួយគាំទ្រ របស់សហរដ្ឋអាមេរិកតទៅទៀត ។

ស្ថានភាពផ្សេងៗបានតម្រូវឲ្យ«ប្រទេសរងគ្រោះ»ពីជ័យជម្នះមួយរបស់កុម្មុយនិស្ត ដែលមិនទាន់ចេញជាក់ស្ដែងទាំងនេះ ក្លាយទៅជាអ្នកទទួលផលប្រយោជន៍យ៉ាងធំនៃស្ថានភាពនេះ –មួយចំណែកធំដោយសារការប្រឹងប្រែងផ្ទាល់របស់គេ ដើម្បីរារាំងមិនឲ្យទ្រឹស្ដីដូមីណូលេចជារូបរាងពិតប្រាកដ ។ នៅឆ្នាំ១៩៧៨ នៅពេលដែលពិភពលោក ពុំមានជម្រើសណាផ្សេងទៀតក្រៅពីយកចិត្តទុកដាក់ជាថ្មីចំពោះភូមិភាគអាស៊ីអាគ្នេយ៍នោះ បណ្ដាប្រទេសនៃសមាគមអាស៊ាន បានបំពេញនូវអ្វីដែលពួកអ្នកជំនាញការអឺរ៉ុបចាត់ទុកជា «អព្ភូតហេតុសេដ្ឋកិច្ច» ។ ទោះបីជាប្រទេសកំពុងអភិវឌ្ឍន៍ក៏ដោយ ក៏ប្រទេសអាស៊ានទាំងអស់ បានស្គាល់នូវការលូតលាស់មួយខ្ពស់ជាងការលូតលាស់ជាមធ្យមនៃពិភពលោក សម្រាប់បណ្ដាប្រទេសដែលប្រាក់ចំណូលជាមធ្យម ។ ព្រឹត្តិការណ៍ដែលមានសារសំខាន់ដែរ គឺប្រទេសទាំងនោះ បានសម្រេចផលល្អ ដោយរួមកម្លាំងគ្នាប្រឈមនឹងការគំរាមកំហែងមួយរបស់បរទេស ដោះស្រាយបញ្ហាផ្សេងៗរវាងពួកគេ ដែលនៅជំតាំងពីយូមកហើយ ។

អាស៊ាន បានក្លាយទៅជាសមាគមមានប្រសិទ្ធភាពប្លែកពីគេមួយ នៃពិភពលោកដែលកំពុងរីកលូតលាស់ ហើយអាចប្រៀបធៀបនឹងសមាគមដូចគ្នាផ្សេងៗនៅក្នុងពិភពលោកដែលមានខស្សរាហកម្មលូតលាស់ ។ ប៉ុន្តែពួកអាមេរិកាំងត្រូវការពេលវេលាដ៏ដាក់លាក់មួយ ដើម្បីស្វែងយល់ពីការពិតនេះ និងមូលហេតុផ្សេងៗ ដែលខ្លួនធ្លាប់ធ្វើឲ្យលេចឡើង ។ សាកលវិទ្យាល័យនានា នៅសហរដ្ឋអាមេរិក មិនត្រឹមតែឈប់យកចិត្តទុកដាក់នឹងឥណ្ឌូចិនប៉ុណ្ណោះទេ ប៉ុន្តែ គឺភូមិភាគអាស៊ីអាគ្នេយ៍ទាំងមូល ។ ក្រោយឆ្នាំ១៩៧៥ បណ្ដាមជ្ឈមណ្ឌលស្រាវជ្រាវអំពីភូមិភាគអាស៊ីអាគ្នេយ៍ បានរលាយបាត់ពីសកលវិទ្យាល័យកូឡុំបៀ, យែល និងសាកលវិទ្យាល័យផ្សេងៗទៀត ។ កាសែតនិងទស្សនាវដ្ដីទាំងឡាយ កម្របោះពុម្ពផ្សាយដំណឹងផ្សេងៗស្ដីពីបណ្ដាប្រទេសនៃសមាគមអាស៊ានណាស់ ។

ជាថ្មីម្ដងទៀត សហរដ្ឋអាមេរិកបានយកចិត្តទុកដាក់នឹងបណ្ដានៃសមាគមអាស៊ាន គឺនៅពេលដែលឥណ្ឌូចិនស្គាល់នូវហេតុការណ៍សំខាន់ប្រកបដោយទុក្ខសោកជាច្រើន គឺការចាកចេញតាមទូកទាំងហ្វូងៗរបស់ប្រជាជនដែលភៀសខ្លួនចេញពីប្រទេសវៀតណាមឆ្នាំ១៩៧៨ ហើយទៅឡើងគោកនៅតាមឆ្នេះសមុទ្រប្រទេសនានានៃសមាគមអាស៊ាន ។

នៅទីបំផុត សង្គ្រាមឥណ្ឌូចិនលើកទីបី បង្ហាញឲ្យឃើញថា អ្នករងគ្រោះសំខាន់បំផុតនៃជ័យជម្នះរបស់

កុម្មុយនិស្តនៅឥណ្ឌូចិន គឺពិភពកុម្មុយនិស្តខ្លួនឯងតែម្តុ ។ នៅពេលដែលពួកគេឈ្នះសង្គ្រាមពួកកុម្មុយនិស្តឥណ្ឌូចិន បានលុបបំបាត់មូលដ្ឋានសហប្រតិបត្តិការដែលមានតែមួយរវាងប្រទេសចិន និងសហភាពសូវៀត បើទោះជាវា គ្រាន់តែជានិមិត្តរូបក៏ដោយ គឺបំណងរួមរបស់គេដើម្បីយកឈ្នះអាមេរិក និងបណ្តាសម្ព័ន្ធមិត្តរបស់ ។ ក្រោយឆ្នាំ ១៩៧៥ ពិភពកុម្មុយនិស្តបានស្គាល់នូវការបែកបាក់របស់ខ្លួនយ៉ាងជ្រាលជ្រៅ និងស្រួចស្រាល់បំផុត តាំងពីការ ប្រេះឆាររវាងចិន-សហភាពសូវៀត នៅឆ្នាំ១៩៦៣ ជាមួយនឹងផលវិបាកប្រកបដោយមហន្តរាយថែមទៀត ។

ជម្លោះជាប្រវត្តិសាស្ត្រខាងផ្នែកមនោគមវិជ្ជា និងទឹកដីរវាងប្រទេសវៀតណាម, កម្ពុជា និងចិន ដែល រីករាលដាលប្រកបដោយកល្បិច បានត្រូវចាត់ថាជារឿងបន្ទាប់បន្សំ ដោយសង្គ្រាមប្រឆាំងចក្រពត្តិនិយម អាមេរិកាំង ធ្វើឲ្យកម្រើកឡើងវិញរឹតតែខ្លាំងឡើង ។ មិនត្រឹមតែវានាំទៅរកសង្គ្រាមមួយរវាងប្រទេសទាំងនេះទេ ប៉ុន្តែវាបានធ្វើឲ្យប្រទេសចិនទាក់ទងគ្នាជាមួយប្រទេសលោកខាងលិចថែមទៀត ជាពិសេស សហរដ្ឋអាមេរិក ។

ប្រទេសចិន និងសហភាពសូវៀត បានប្រឈមមុខដាក់គ្នាជាចំហ ដើម្បីប្រទាញឥណ្ឌូចិនកុម្មុយនិស្តឲ្យធ្លាក់ ក្នុងវង់ឥទ្ធិពលរបស់គេ ហើយបង្ខំឲ្យពិភពកុម្មុយនិស្តជ្រើសរើសក្រុមបក្សរបស់ខ្លួន ។ ដោយស្វែងរកការគាំទ្រ មួយនៅទីដទៃទៀត នៅទីបំផុត ប្រទេសកម្ពុជា និងវៀតណាម ក៏បែរមករកបណ្តាប្រទេសមិនមែនកុម្មុយនិស្តនៅ ក្បែរខាងវិញ គឺសមាគមអាស៊ាន ។

នៅឆ្នាំ១៩៧៨ ពួកកុម្មុយនិស្តបានបំផ្លាញការរួមសម្បាច់នឹងគ្នាដែលពួកគេបានសម្រេចក្នុងរយៈពេលនៃ សង្គ្រាម ។ នៅឆ្នាំ១៩៧៥ ការបះបោររបស់កុម្មុយនិស្ត ហាក់ដូចជាទឹករលកដែលបោកបក់ទៅរកអនាគត ។ នៅឆ្នាំ១៩៧៨ ពួកកុម្មុយនិស្តផ្ទាល់ បានបោះបង់ចោលសេចក្តីសង្ឃឹមនេះ ដោយវាយប្រយុទ្ធតែរវាងគ្នានិងគ្នា ដោយក្បត់គ្នាទៅវិញទៅមក ដោយដឹកនាំប្រទេសរបស់ពួកគេតាមរបៀបដ៏គួរឲ្យព្រឺខ្លាចមួយ ដែលពួកគេបានបន្ត ឲ្យមានការស្រងាកចិត្តនៅក្នុងពិភពលោកទាំងមូល ។

រូបភាពប្រទេសវៀតណាម គឺជារូបភាពមួយក្នុងចំណោមរូបភាពដំបូងគេ ដែលផ្លាស់ប្តូរ ។ ក្នុងរយៈពេល សង្គ្រាម គេបានពិពណ៌នាដោយយុត្តិធម៌ថា ប្រទេសវៀតណាមខាងជើងដូចជាស្តេចដេវីដ *(David)* តូចមួយកំពុង ប្រឈមមុខនឹងយក្ស ហ្គូលីយ៉ាត *(Goliath)* នៃម៉ាស៊ីនសង្គ្រាមរបស់អាមេរិកាំង ។ បន្ទាប់ពីសង្គ្រាម នៅពេលនេះ ពួកកុម្មុយនិស្តវៀតណាម បានរក្សាទុករូបភាពនេះក្នុងពិភពតតិយលោក និងប្រទេសសង្គមនិយមផ្សេងៗ ។ គេបានអបអរសរសើរពួកកុម្មុយនិស្តវៀតណាម ដែលបានប្រយុទ្ធទល់នឹងការត្រួតត្រារបស់បរទេស ទោះបីជា មានសេចក្តីសង្ឃឹមទទួលជ័យជម្នះតិចណាស់ និងត្រូវវាយប្រហារក្នុងរយៈពេលបីទសវត្សរ៍ ដើម្បីដណ្តើម ឯករាជ្យរបស់ខ្លួនក៏ដោយ ។

ប៉ុន្តែ ឋានៈរបស់ប្រទេសវៀតណាមនៅក្នុងពិភពលោកបានផ្លាស់ប្តូរយ៉ាងសម្បើម ។ ជាមួយប្រជាជន ហាសិបលាននាក់ ប្រទេសវៀតណាម ដែលបង្រួបបង្រួមតែមួយ គឺជាមហាអំណាចកុម្មុយនិស្តទីពីរនៅអាស៊ី ។

ជោគជ័យផ្នែកយោធារបស់ខ្លួនជាជោគជ័យដែលធ្វើឲ្យគេស្រឡាំងកាំង ។ ជាមួយនឹងសន្តិភាព ក្រុងហាណូយពុំបានរំសាយកងទ័ពរបស់ខ្លួនទេ ប៉ុន្តែផ្ទុយទៅវិញ បានបង្កើនចំនួនពិតនៃកងទ័ពរបស់ខ្លួនដល់មួយលាននាក់ ដែលធ្វើកងទ័ពវៀតណាម មានឋានៈទីបីក្នុងពិភពលោក ។ ប្រទេសវៀតណាមក៏មានមុខក្នុងចំណោមមហាអំណាចយោធាសំខាន់បំផុតទាំងប្រាំនៃភពផែនដីដែរ ។ សង្គ្រាមសាមសិបឆ្នាំ បានធ្វើឲ្យវៀតណាម ខាងជើងទៅជាសង្គមមួយដែលបណ្តុះចិត្តប្រជាជនឲ្យមានទម្លាប់ជាទាហានយ៉ាងជ្រាលជ្រៅ ហើយកងទ័ពវៀតណាមខាងជើងបានក្លាយទៅជា ហ្គូលីយ៉ាត នៅអាស៊ីភាគអាគ្នេយ៍ ។

អនុភាពនេះ បានបំភ្លឺឲ្យដឹងដោយផ្អែកពីគំនិតផ្តួចផ្តើមរបស់សមាគមអាស៊ាន ដើម្បីបង្កើតយ៉ាងហោចនូវកម្លាំងទប់ផ្នែកនយោបាយមួយ ប្រឈមនឹងឥណ្ឌូចិនថ្មី ដែលសុទ្ធតែជាប្រទេសកុម្មុយនិស្ត ។

ភាគច្រើននៃបណ្តាប្រទេសលោកខាងលិច បានធ្វើប្រតិកម្មយ៉ាងខ្លាំងនឹងសភាពមិនអាចប្រកែកបានមួយទៀតនៃប្រទេសវៀតណាមក្រោយសម័យសង្គ្រាម ៈ វិនាសកម្មយ៉ាងសម្បើមរបស់ប្រទេស ។ ប្រទេសមួយភាគយ៉ាងធំ ចង់ជួយប្រទេសវៀតណាម ។ ក្នុងរវាងមួយឆ្នាំ ពួកវៀតណាម បានបង្កើតឲ្យមានទំនាក់ទំនងការទូតជាមួយប្រទេសចំនួនកៅសិបប្រាំពីរ និងចូលជាសមាជិកអង្គការអន្តរជាតិចំនួនម្ភៃពីរ ដូចជា ធនាគារពិភពលោកអង្គការយូបិយវត្ថុអន្តរជាតិ និងធនាគារអភិវឌ្ឍន៍អាស៊ីជាដើម ។ ក្នុងរយៈពេលពីរ-បីឆ្នាំ ប្រទេសក្រៅជាច្រើនបានយល់ព្រមផ្តល់ជំនួយ ជាងប្រាំមួយកោដិដុល្លារឲ្យប្រទេសវៀតណាម សម្រាប់ការស្តាបនាប្រទេសឡើងវិញ ។

ប៉ុន្តែ ពួកវៀតណាមបានចាត់ចែងដោយមិនប្រសប់នូវកម្មវិធីស្តារប្រទេសឡើងវិញរបស់ពួកគេ ហើយក្រុងហាណូយបានរួសរាន់ផ្តល់អាទិភាព ចំពោះបញ្ហាយោធាជាថ្មី ។ ការស្តារប្រទេសឡើងវិញ បានកន្លងផុតទៅបន្ទាប់ពីការត្រួតត្រាតំបន់ដែលចាត់ទុកដូចជាគោលដៅមានអាទិភាព ។ ប្រទេសឡាវ[៤] បានក្លាយយ៉ាងឆាប់រហ័សទៅជារដ្ឋអាណាព្យាបាលមួយរបស់ក្រុងហាណូយ ដែលជាជំហានដំបូងឆ្ពោះទៅរកគោលដៅនេះ ។

ពួកកុម្មុយនិស្តរបស់ឡាវ -ប៉ាថេតឡាវ- បានឡើងកាន់អំណាចតាមរយៈជ័យជម្នះតូចតាចជាបន្តបន្ទាប់មួយ ៈ បទឈប់បាញ់គ្នានៅឆ្នាំ១៩៧៣ ការបង្កើតរដ្ឋាភិបាលចម្រុះនៅខែមេសា ឆ្នាំ១៩៧៤ ការស្រុតចុះរបស់ក្រុមនិយមស្តាំនៅខែឧសភា ឆ្នាំ១៩៧៥ និងការប្រកាសបង្កើតសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវនៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៥ ។ គឺពុំមានការឡោមព័ទ្ធរដ្ឋធានីនៅទីកន្លែងដាច់ព្រ័ត្រ ដែលធ្វើឲ្យមានមនុស្សស្លាប់ព្រាត់ប្រាស់ ដូចនៅប្រទេសវៀតណាម និងកម្ពុជា ទាំងពុំមានការរត់គេចខ្លួនរបស់ពួកអាមេរិកាំងឡើយ ។ កងទ័ពរបស់ប៉ាថេតឡាវ បានដើរចូលក្នុងរដ្ឋធានីវៀងច័ន្ទ របៀបជាក្បួនព្យុហយាត្រា ដោយមានយុទ្ធជនកាន់អាវុធតុបតែងដោយផ្កាភ្លីផង ។ ក្នុងចំណោមមនុស្សជាច្រើន គេសង្កេតឃើញពួកអ្នកការទូតអាមេរិកាំង ហើយស្ថានទូតរបស់គេនៅតែបើកទ្វារដដែល ។

ការកែប្រែប្រទេសឡាវ ធ្វើឲ្យទៅជារណបរបស់ប្រទេសវៀតណាម បានប្រព្រឹត្តទៅយ៉ាងស្ងប់ស្ងៀម ។

នៅទីបំផុត កងទ័ពវៀតណាមប្រហែលបួនម៉ឺននាក់ បានបោះទីតាំងសំចតនៅក្នុងប្រទេសនេះ ដែលរួមបង្កជាកង-ទ័ពបរទេសមួយមានចំនួនច្រើនជាងកងទ័ពរបស់ឡាវទៅទៀត ។ កម្មាភិបាលវៀតណាមជាច្រើន បានណែនាំឲ្យពួកអ្នកទទួលខុសត្រូវសំខាន់ៗក្នុងរដ្ឋាភិបាល ធ្វើតាមគំរូរបស់ខ្លួន ហើយគំរូវៀតណាម បានក្លាយទៅជាមូលដ្ឋាននយោបាយរបស់ឡាវ ។

ពួកឡាវ មិនសូវមានលទ្ធភាព ឬបំណងធ្វើអ្វីមួយផ្សេងពីនេះឡើយ ។ ប្រទេសរបស់គេដែលមានប្រជាជនតិចជាងបីលាននាក់គឺជាប្រទេសសម្បូរភ្នំដែលមានប្រទេសឯទៀតព័ទ្ធជុំវិញដូចជាប្រទេសចិន, ភូមា, ថៃ, កម្ពុជា, វៀតណាម និងឡាវ តែងតែស្វែងរកការគាំពារពីរដ្ឋមួយដែលមានអនុភាពជាងគេជានិច្ច ។

ពួកវៀតណាម បានបង្កើតចលនាកុម្មុយនិស្តឡាវតាមរយៈបក្សកុម្មុយនិស្តឥណ្ឌូចិន ហើយបានគាំទ្រចលនា នេះយ៉ាងពេញទំហឹងរហូតដល់ណ្តើមបានជ័យជម្នះជាស្ថាពរ ។ ក្រោយឆ្នាំ១៩៧៥ ប្រទេសឡាវមានអត្ថប្រយោជន៍បន្តិចបន្តួច ដែលខ្លួនត្រូវស្ថិតនៅក្រោមម្លប់របស់វៀតណាម ។ ប្រទេសឡាវ ពុំគំរាមកំហែងដល់ប្រទេសណាមួយឡើយ ហើយមានសេរីភាពយ៉ាងធំមួយ ក្នុងវិស័យកិច្ចការបរទេស ក៏ដូចក្នុងការថែរក្សាវប្បធម៌ឡាវ ជាពិសេស ជំនឿរបស់អ្នកកាន់ពុទ្ធសាសនាផង ។ ប៉ុន្តែតឡាវ បានតម្រូវឲ្យប្រទេសជាតិ អនុវត្តប្រព័ន្ធកុម្មុយនិស្តមួយតាមគំរូវៀតណាម រួមទាំងបង្កើតជំរំអប់រំកែប្រែថ្មីផង ប៉ុន្តែ ក្រោមទម្រង់មួយទន់ភ្លន់ជាង និងមិនសូវឃោរឃៅប៉ុន្មានទេ ។ ថ្វីបើការចាប់ផ្តើមដំបូងៗមានការលំបាកក៏ដោយ ក៏សេដ្ឋកិច្ចរបស់ឡាវអាចធ្វើឲ្យសម្រេច នូវការលាយបញ្ចូលគ្នាមួយរវាងសហគ្រាសសេរី និងការធ្វើជាតូបនីយកម្ម ដែលនៅទីបំផុតបានធ្វើឲ្យកម្រិតជីវភាពរស់នៅមួយភាគធំរបស់សង្គមប្រសើរលើសមុនដែរ -នេះជាលទ្ធផលដែលទាំងប្រទេសវៀតណាម ទាំងប្រទេសកម្ពុជា មិនអាចអួតក្អេងក្អាងបានទេ ។

ប្រទេសឡាវ បានរក្សាចំណងទាក់ទងជាមួយបណ្តាប្រទេសកុម្មុយនិស្ត ឬមិនមែនកុម្មុយនិស្តជាច្រើន រួមទាំងសហរដ្ឋអាមេរិក ។ រដ្ឋធានីវៀងចន្ទ បានក្លាយទៅជាបង្អួចមួយសម្រាប់ឲ្យពិភពលោកខាងក្រៅពិនិត្យមើលលទ្ធផលនៃការផ្លាស់ប្តូរផ្សេងៗ នៃការបដិវត្តន៍នៅឥណ្ឌូចិន ។

ប៉ុន្តែ តម្លៃនៃជ័យជម្នះទាំងនេះមានលក្ខណៈថ្លៃថ្នូរណាស់ដោយហេតុថា នេះជាឯករាជ្យរបស់ប្រទេស ។ រដ្ឋាភិបាលរបស់ឡាវ តោងតែយល់ព្រមទទួលយកមធ្យោបាយបត់បែនទាំងអស់ ដែលបង្គាប់បញ្ជារដោយប្រទេសវៀតណាម ទាំងក្នុងប្រទេសក៏ដូចក្រៅប្រទេស ។ ជាច្រើនលើកច្រើនសា ពួកឡាវបានធ្វើអ្វីមួយដោយគ្មានទាក់ទងជាមួយក្រុងហាណូយទេ ទោះបីជាខ្លួនត្រូវក្រើនរំឭកដោយពួកវៀតណាមក៏ដោយ ។ ប៉ុន្តែ ដោយឡាវព្រមទទួលការត្រួតត្រារបស់វៀតណាម ប្រទេសឡាវក៏បានគេចផុតពីសមុទ្រឈាមនៃសង្គ្រាមឥណ្ឌូចិនលើកទីបីដែរ ។

នៅពេលដែលក្រុងវៀងចន្ទចុះហត្ថលេខាលើសន្ធិសញ្ញាមិត្តភាពជាមួយក្រុងហាណូយនៅឆ្នាំ១៩៧៧ ពួកកុម្មុយនិស្តកម្ពុជាដឹងថា ត្រូវគេវាយអន្ទាក់ដាក់ហើយ ។ ពួកវៀតណាម បានបង្ហាញឲ្យឃើញទំនាក់ទំនងផ្សេងៗ

របស់គេជាមួយប្រទេសឡាវ ទុកដូចជាគំរូដែលពួកគេសង្ឃឹមថា នឹងទទួលបានពីក្រុងភ្នំពេញដែរ ។ អំណើះតទៅ ពួកកម្ពុជា លែងទុកចិត្តប្រទេសឡាវទៀតហើយ ។ ប្រទេសវៀតណាមបានរៀបចំការលុកលុយរបស់ខ្លួនមកលើប្រទេសកម្ពុជាដោយរួមជាមួយពួកឡាវ ៖ កងទ័ពក្រុងហាណូយ ដែលសំចតនៅប្រទេសឡាវ បានវាយប្រហារចេញពីមូលដ្ឋានរបស់ខ្លួននៅក្នុងទឹកដីឡាវ ហើយពួកអ្នកភៀសខ្លួនខ្មែរនៅប្រទេសឡាវ ត្រូវបានបំពាក់អាវុធឲ្យដើម្បីវាយប្រយុទ្ធប្រកៀកស្មាជាមួយពួកវៀតណាម ប្រឆាំងនឹងកងទ័ពរបស់ ប៉ុល ពត ថែមទៀត ។

និមិត្តរូបរបស់ប្រទេសវៀតណាម ធ្លាប់ស្គាល់នូវការក្លែងបន្លំផ្សេងៗយ៉ាងប្រសប់បំផុត ។ ពួកវៀតណាមដែលធ្វើជាសមាជិកនៃបណ្តាចលនាមិនមែនកុម្មុយនិស្ត ដែលធ្លាប់ជួយគាំទ្ររណសិរ្សរំដោះជាតិ(វៀតកុង) និងក្រោយមក រដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្ន ។ នៅពេលដែលមនុស្សទាំងនេះ ត្រូវបណ្តេញចេញពីតំណែងសំខាន់ៗ ក្នុងរដ្ឋាភិបាលក្រោយសម័យសង្គ្រាមលទ្ធផលបានកើតមានភ្លាមៗ ។ ពួកកុម្មុយនិស្តក្រុងហាណូយដែលការពារដោយផ្ទាល់នូវបុព្វហេតុរបស់គេ មិនសូវដូចពួកវៀតណាមនៅភាគខាងត្បូង ដែលធ្លាប់បង្ហាញឲ្យឃើញការប៉ិននិយាយខ្លាំងណាស់ ។

ប៉ុន្តែ ក្រុងហាណូយមិនយល់ពីចំណុចណាខ្លះដែលពួកអ្នកប្រឆាំងនឹងរបបរបស់ ធីវ មានឥទ្ធិពលទៅលើមតិសាធារណៈអាមេរិកាំង, របៀបយ៉ាងម៉េចបានជាសតិសម្បជញ្ញៈរបស់ពួកអាមេរិកាំង ត្រូវធ្វើឲ្យកម្រើកឡើងដោយបណ្តាព្រះសង្ឃពុទ្ធសាសនា ដែលធ្វើពលិកម្មដោយដុតខ្លួននៅឆ្នាំ១៩៦៣ ដើម្បីតវ៉ាប្រឆាំងនឹងរបបផ្តាច់ការនៅក្រុងព្រៃនគរផងទេ ហើយពុំមែនដោយសេចក្តីថ្លែងការណ៍ផ្សេងៗ ដែលក្រុងហាណូយសំអាងលើកេរ្តិ៍ឈ្មោះរបស់ ហូ ជីមិញ ឡើយ ។ ម្យ៉ាងទៀត ក្រុងហាណូយក៏មិនយល់ពី«ឱកាស»នៃការឃោសនា ដែលបានសម្រេចផលល្អ ដោយពួកវៀតណាមខាងត្បូង ដែលធ្វើការនៅទីក្រុងប៉ារីស ឬវ៉ាស៊ីនតោន ជាមួយពួកយុទ្ធិកជនសន្តិភាពនិយមបារាំង និងអាមេរិកាំង ។

អ្នកប្រឆាំងវៀតណាមខាងត្បូងទាំងនេះ យល់ច្បាស់ពីគូសត្រូវរបស់គេ ។ ការចេះដឹងរបស់គេអំពីប្រព័ន្ធនយោបាយរបស់សហរដ្ឋអាមេរិក គឺប្រសើរជាងការចេះដឹងរបស់ប្រជាជនអាមេរិកាំងសាមញ្ញទៅទៀត ។ សមាជិកម្នាក់នៃចលនាប្រឆាំងសង្គ្រាមនៅចាំបានថា ដោយធ្វើដំណើរទៅកាន់ផ្ទះអ្នកតំណាងម្នាក់នៃរណសិរ្សរំដោះជាតិ នៅទីក្រុងប៉ារីសកាលពីទសវត្សរ៍១៩៦០ គាត់បានត្រូវធ្វើឲ្យភ្ញាក់ផ្អើល ដែលមើលឃើញផែនទីមួយដាក់តាំងពេញជញ្ជាំងមួយនៅពេលគាត់ឈានចូលក្នុងបន្ទប់ទទួលភ្ញៀវដ៏តូច ។ នោះគឺផែនទីមួយនៃសភារបស់សហរដ្ឋអាមេរិក ដែលមានបិទទង់ក្រហម ឬខៀវតូចៗ សម្រាប់សំគាល់ដែនខាងពួកប្រជាធិបតេយ្យ ពីដែនខាងពួកសាធារណរដ្ឋនិយម ។ ដោយចុចនឹងម្ជុលនៅលើផែនទី មានបញ្ជីវែងមួយ ដែលរៀបរាប់ល្អិតល្អន់ពីប្រភពធនធានផ្នែសេដ្ឋកិច្ចរបស់មណ្ឌលនីមួយៗថែមទៀត ។

គឺមនុស្សទាំងនោះហើយដែលពាំនាំដំណឹងផ្សេងៗពីរណសិរ្ស ហើយបញ្ចេញឲ្យដឹងគំនិតដោយទាញហេតុ

ផលផ្សេងៗ ដែលធ្វើឲ្យស្រឡាំងកាំងប្រឆាំងនឹងសង្គ្រាមដែលប្រើវិធីកាន់តែខ្លាំងរបស់អាមេរិកាំង ។ គឺពួកអ្នកទាំងនោះហើយ ដែលក្រុងហាណូយរលាស់ចោល ដើម្បីដណ្ដើមយកអំណាចភ្លាមៗបន្ទាប់ពីជ័យជម្នះ ។ លទ្ធផលគឺប្រទេសវៀតណាម ត្រូវបានគេដឹងឮកាន់តែតិចទៅៗថាជាប្រជាជាតិខ្លាំងពូកែមួយ ហើយត្រូវគេស្គាល់កាន់តែច្រើនឡើងៗថា ជារដ្ឋមួយពឹងផ្អែកលើប៉ូលិស ដែលប្រើវិធីឃោរឃៅផ្សេងៗ ។

ពួកវៀតណាម ដែលនឹងអាចផ្ដល់ដល់ក្រុងហាណូយនូវរូបភាពប្រសើរជាងមុនមួយ សុទ្ធតែត្រូវបំបែកចេញឲ្យរស់នៅឯបរទេស (គេមិនត្រូវការការបម្រើការងាររបស់ពួកនោះទេ) ឬធ្វើការដោយមានបៀវត្សពាក់កណ្ដាលនៅទីក្រុងព្រៃនគរ ឬត្រូវជាប់ឃុំក្នុងជំរំអប់រំកែប្រែជាថ្មីមួយ ហើយក្រោយមកស្ថិតក្នុងចំណោមអ្នកអស់សង្ឃឹមរាប់ពាន់នាក់ ដែលភៀសខ្លួនតាមទូកចេញទៅនៅប្រទេសក្រៅ ។

ប៉ុន្តែ បន្ទាប់ពីជ័យជម្នះ ប្រការនេះមិនបានធ្វើឲ្យក្រុងហាណូយខ្វាយខ្វល់ឡើយ ដោយគិតថាខ្លួនឯងស៊ើរតែមិនដែលចាញ់ឡើយ ។ ពួកមេដឹកនាំវៀតណាម បានឈ្នះសង្គ្រាមមួយ ដែលបានធ្វើឲ្យកាសែតនានាក្នុងពិភពលោកទាំងមូល ចុះផ្សាយលើទំព័រទីមួយក្នុងរយៈពេលជាច្រើនឆ្នាំ ។ ពួកគេមានគំនិតកាន់កាប់ប៉ែកខាងមុខឆាកជាស្ថាពរ ក្នុងឋានៈជាវីរបុរសនៃពិភពតតិយលោក ជានិមិត្តរូបនៃសមត្ថភាពរបស់ពួកអ្នកត្រូវគេសង្កត់សង្កិន ដែលបំផ្លាញការធ្វើអន្តរាគមន៍របស់បរទេស ។ ជាជំនួសប្រការនេះ ពួកគេបានបំបាត់ឱកាសជាឯតទគ្គៈមួយ នូវកំណប់ចិត្តដែលពួកគេប្រមូលបាន ។

«ពួកវៀតណាម មានសុទ្ធរកថារៀបចំរួចស្រេចជាច្រើន ដែលពួកគេសូត្រគ្មានឈប់ស្ដីពីការឈឺចាប់ទាំងឡាយដែលពួកគេធ្លាប់ស្គាល់... ។ ពួកគេចាត់ទុកខ្លួនឯងនៅពីលើការបន្ទោសទាំងអស់ ហើយមិនស្ដាប់ការរិះគន់ណាមួយឡើយ ជាពិសេស ស្ដីពីការបង្រួបបង្រួមប្រទេសដោយបង្ខំ ។ ពួកគេបានបាត់បង់មិត្តភក្ដិទាំងឡាយយ៉ាងឆាប់រហ័ស»[៥] ។ នេះជាសម្ដីដែលអ្នកការទូតកុម្មុយនិស្តអឺរ៉ុបម្នាក់បានអះអាង ។

នៅពេលដែលសង្គ្រាមឥណ្ឌូចិនលើកទីបីផ្ទុះឡើង ប្រទេសវៀតណាម អាចត្រឹមតែសង្ឃឹមថា មតិសាធារណៈពិភពលោក នឹងគាំទ្រក្រុងហាណូយប្រឆាំងនឹងក្រុងភ្នំពេញប៉ុណ្ណោះ ។ នេះជាការភាន់ច្រឡំមួយដែលនាំឲ្យវិនាសក្នុងការគន់គូររបស់ពួកវៀតណាម ជាពិសេស ដោយសេចក្ដីសម្រេចផលរបស់ខ្លួនលើសហរដ្ឋអាមេរិក ។

ក្រុមនិយមឆ្វេងរបស់អាមេរិកាំង ដែលរីកឡើងយ៉ាងខ្លាំងក្នុងចលនាប្រឆាំងសង្គ្រាម បានចុះខ្សោយយ៉ាងឆាប់រហ័ស បន្ទាប់ពីឆ្នាំ១៩៧៥ និងទីបញ្ចប់នៃជម្លោះ[៦]-ម្យ៉ាងទៀត នេះជាហេតុផលមួយក្នុងចំណោមហេតុផលជាច្រើន ដែលធ្វើឲ្យសហរដ្ឋអាមេរិកអាចបំភ្លេចប្រទេសវៀតណាម ឡាវ និងកម្ពុជា ។ ចលនាមហាជនដែលធ្លាប់ប្រឆាំងចំពោះការធ្វើអន្តរាគមន៍របស់ក្រុងវ៉ាស៊ីនតោននៅឥណ្ឌូចិន បានរលាយបាត់បន្ទាប់ពីការដកថយរបស់កងទ័ពអាមេរិកាំងនៅឆ្នាំ១៩៧៣ ។ ភាគច្រើននៃយុទ្ធិកជននិយមសន្តិភាព ដែលបន្តសកម្មភាពរបស់គេរហូតដល់

ទីបញ្ចប់នៃសង្គ្រាម បានបោះបង់ចោលវិស័យនយោបាយនៅឆ្នាំ១៩៧៥ ដោយបកស្រាយថា ពួកគេត្រូវធ្វើឲ្យអស់កម្លាំងខ្លាំងណាស់ ។ ពួកអ្នកដែលរួចខ្លួនខ្លះ បានសម្រេចចិត្តបន្តប្រើឥទ្ធិពលមួយលើនយោបាយជាតិដល់ទីបំផុតសម្រាប់សមាជិកភាគច្រើននៃគណបក្សប្រជាធិបតេយ្យដែលធ្លាប់លាតត្រដាងពីរឿងសង្គ្រាម-ថមហៃដិន និងសាមប្រោន ជាគំរូដ៏ល្បីល្បាញពីរនាក់ ។ ពួកមេដឹកនាំនៃបណ្តាក្រុមដោយឡែកពីគ្នា ដែលផ្គត់ផ្គង់ក្រុមមនុស្សឲ្យចលនាប្រឆាំងសង្គ្រាម -ចលនាស្ត្រីនិយម, សិទ្ធិពលរដ្ឋ, សិទ្ធិពួកអ្នកស្រឡាញ់ភេទដូចគ្នា ជាពិសេស -បានបំបែរសមានចិត្តរបស់ពួកគេឆ្ពោះទៅរកសកម្មភាពផ្សេងៗ ដែលមានលក្ខណៈប្រពៃណីបំផុតក្នុងផ្ទៃនៃប្រព័ន្ធនយោបាយដែលតាំងឲ្យមានឡើង ។

ពួកយុទ្ធិកជននិយមឆ្វេងជ្រុលមួយចំនួនតូច បានប្រកាន់យកមធ្យោបាយប្រឆាំងដែលបណ្តាលឲ្យមានបាតុភូតមិនបានប្រុងទុកតូចមួយ ៈ ក្នុងរវាងពីរឆ្នាំ ពួកគេបានបង្កើតយ៉ាងហោចគណបក្សថ្មីចំនួនបួន និងអង្គការកុម្មុយនិស្តពីរ ។ នោះគឺជាក្រុមនយោបាយតូចៗ ដែលអួតអំពីការផ្លាស់ប្តូរបដិវត្តន៍មួយនៅសហរដ្ឋអាមេរិកទៅតាមខ្សែបន្ទាត់ នៃបដិវត្តន៍វប្បធម៌របស់ម៉ៅ ឬប្រទេសចិនដែលទុកតម្លៃនៃការអនុវត្តន៍ជាធំរបស់ តេងស៊ាវពីង ឬប្រទេសអាល់បានី ថែមទៀត ។ គណបក្សថ្មីទាំងនេះ បានប្រកាសឲ្យដឹងជាសាធារណៈ ពីភាពនៅតែឯកឯងនៃក្រុមអ្នកបដិវត្តន៍និយមឆ្វេង ក៏ដូចការពង្រីកចលនានិយមឆ្វេងថ្មីមួយនៅសហរដ្ឋអាមេរិកដែរ ។ ម្យ៉ាងទៀត ភាគច្រើនក្នុងចំណោមនោះ បានរលត់រលាយ ហើយមានតែមួយប៉ុណ្ណោះ ដែលនៅរស់រានមានជីវិត គឺគណបក្សកុម្មុយនិស្តបដិវត្តន៍ និងគណបក្សពលករកុម្មុយនិស្ត ដែលស្ថិតនៅជាក្រុមនយោបាយតូចៗ ។ ប៉ុន្តែពួកគេមានលក្ខណៈពិសេសជា គណបក្សនយោបាយថ្មីតែមួយគត់ ដែលកើតចេញពីចលនាប្រឆាំងសង្គ្រាម ។

នៅពេលដែលពួកវៀតណាម និងកម្ពុជា ត្រូវការពួកអ្នកមានសមានចិត្តពីសហរដ្ឋអាមេរិក នៅពេលចាប់ផ្តើមដំបូងនៃសង្គ្រាមរបស់គេ គឺមិនសូវមានលទ្ធផលទេ ។ មានតែការ«ឡប់ប៊ី» តិចតួចមួយរបស់វៀតណាមប៉ុណ្ណោះ ដែលបន្តធ្វើឲ្យមានការយកចិត្តទុកដាក់ដល់ឥណ្ឌូចិនក្រោមសម័យសង្គ្រាម ។ ម្យ៉ាទៀត ពាក្យ «ឡប់ប៊ី» មានន័យថា ជាការចាត់ចែងប្រកបដោយរចនាសម្ព័ន្ធត្រឹមត្រូវមួយ ដែលក្រុមអតីតយុទ្ធិកជននេះ រួមមានមិនត្រឹមតែបណ្តាឥស្សរជនល្បីល្បាញលេចធ្លោ ដែលធ្លាប់ធ្វើជានិមិត្តរូបចលនាប៉ុណ្ណោះទេ ប៉ុន្តែក៏មានក្រុមមនុស្សជាសមាជិកនៃចលនាអ្នកកាន់សាសនាប្រូតេស្តង់, ក្រុម *mennonites*, ពួកគ្រូបង្រៀន និងបព្វជិត ដែលធ្លាប់ជាក្រុមចេញលាក់ការសម្ងាត់ និងស៊ូប្តូរជាមួយ ។ មនុស្សជាច្រើនក្នុងចំណោមនោះ ធ្លាប់រស់នៅប្រទេស វៀតណាម, ឡាវ ឬកម្ពុជា ហើយមិនអាចបំភ្លេចប្រទេសទាំងនោះបានទេ ។ ពួកគេធ្វើការជាថ្នូរនឹងប្រាក់បៀវត្សរ៍ ស្តួចស្តើងក្នុងបណ្តាអង្គការតូចៗ ដែលមានគោលដៅមិនរកកម្រៃក្រៅ ដូចជា អង្គការគណៈកម្មការសេវាកម្មមិត្តភាពអាមេរិកាំង និងមជ្ឈមណ្ឌលធនធានឥណ្ឌូចិន នៅក្រុងវ៉ាស៊ីនតោនជាដើម ។ ការចាប់អារម្មណ៍របស់គេ លែងជាមតិរបស់អាមេរិកាំងទៀតហើយ ប៉ុន្តែ អ្នកស្រាវជ្រាវ, សាស្ត្រាចារ្យសាកលវិទ្យាល័យ និងអ្នកកាសែតមួយ

ចំនួនតូច នៅតែចាប់អារម្មណ៍នឹងឥណ្ឌូចិន ហើយពួកអ្នកធ្វើការ និងអ្នកនយោបាយ ក៏សរសេរ ឬអត្ថាធិប្បាយពីផ្នែកផ្សេងៗទាក់ទងនឹងឥណ្ឌូចិនដែរ ។ យុទ្ធវិធីរបស់គេក៏ដូចយុទ្ធវិធីរបស់ក្រុមក្បៀសផ្អត់តូចៗដទៃទៀតដែរ គឺផ្តល់ពត៌មានផ្សេងៗ ដើម្បីការពារបុព្វហេតុ ។

ប៉ុន្តែ ពួកគេទាំងនោះ មិនសូវបានគិតអំពីសោកនាដកម្ម និងជម្លោះ ដែលរីករាលដាលយ៉ាងឆាប់រហ័សក្នុងឥណ្ឌូចិនក្រោយឆ្នាំ១៩៧៥ឡើយ ។ ពួកគេល្បងចង់ដឹងពីស្ថានការណ៍ផ្សេងៗ នៅក្នុងប្រទេសទាំងបី ប៉ុន្តែ ដោយកំណត់ត្រឹមតែពីរ-បីចំណុចប៉ុណ្ណោះ ៖ សម្រួលការធ្វើឲ្យមានប្រក្រតីភាពនូវទំនាក់ទំនងផ្សេងៗ រវាងប្រទេសវៀតណាម និងសហរដ្ឋអាមេរិក បញ្ចុះបញ្ចូលសហរដ្ឋអាមេរិកឲ្យផ្តល់វិភាគទានជាពិសេសដល់ការកសាងប្រទេសទាំងបីឡើងវិញ ។ ដើម្បីឈានឲ្យដល់គោលដៅទាំងនោះ ពួកគេគោងតែកែប្រែរូបភាពអវិជ្ជមានរបស់ពួកវៀតណាមខាងជើង និងខ្មែរក្រហមសិន ហើយរៀបចំការពិភាក្សាខាងនយោបាយស្តីពីប្រទេសទាំងនេះ ក្នុងបរិបទនៃការប្រឈមមុខ រវាងសហរដ្ឋអាមេរិកមួយ ដែលសម្បូរសប្បាយ ដែលធ្វើឲ្យគេវិនាស និងប្រទេសក្រីក្រ ពីរ ដែលត្រូវបំផ្លិចបំផ្លាញខ្ទេចខ្ទាំ ។ ចំពោះគោលបំណងនេះ ពួកគេបានច្រានចោល ឬបន្លាញថា មិនសូវសំខាន់ៗនូវចម្លើយជាសាក្សីដ៏គួរឲ្យព្រឺរន្ធត់របស់ពួកអ្នកភៀសខ្លួនកម្ពុជា និងបញ្ចៀសបញ្ហាស្តីពីសិទ្ធមនុស្ស ដែលមានក្នុងប្រទេសវៀតណាម ក្រោយសម័យសង្គ្រាមថែមទៀត ។

ឥរិយាបថនេះ បានបង្កឲ្យមានសេចក្តីវិនាសដល់ការ «ឡប់ប៊ី» របស់វៀតណាម និងការប៉ុនប៉ងទាំងឡាយរបស់ខ្លួនជាគុណប្រយោជន៍ដល់ការខិតចូលជិតគ្នាមួយរវាងក្រុងវ៉ាស៊ីនតោន និងក្រុងហាណូយ ឬក្រុងវ៉ាស៊ីន-តោន និងក្រុងភ្នំពេញ ។ ពួកវៀតណាម និងពួកខ្មែរក្រហម បានបន្តនយោបាយរបស់គេ ដែលធ្វើឲ្យចំនួនភស្តុតាងផ្សេងៗ ស្តីពីរឿងរ៉ាវអាក្រក់ៗ ដែលកើតមានក្នុងប្រទេសទាំងពីរកើនឡើង ។ នាទីរបស់ពួកអ្នកដែលមានអំពល់នៅឡើយពីជោគវាសនារបស់ឥណ្ឌូចិន បានបាក់បែកចេញពីគ្នា ហើយបណ្តាលឲ្យជនអភិរក្សនិយម ដែលកំពុងមានឥទ្ធិពលទៅលើមតិសាធារណៈ អាចបំផ្លាញគ្រឹះនៃ«ឡប់ប៊ី»របស់វៀតណាមបាន ។

ពួកអ្នកអភិរក្សនិយម បានប្រើប្រាស់ការបរិយាយរឿងផ្សេងៗរបស់ពួកអ្នកភៀសខ្លួនកម្ពុជា ដើម្បីជាសំអាងដល់មតិរបស់គេ ដែលថាអំពើគួរឲ្យរន្ធត់ទាំងឡាយបន្ទាប់ពីសង្គ្រាម សឲ្យឃើញពីភាពថ្លៃថ្នូរនៃការជាប់ដៃប្រយុទ្ធរបស់អាមេរិកាំងក្នុងសង្គ្រាមឥណ្ឌូចិនលើកទីពីរ ។ តាមរបៀបយល់ឃើញសមហេតុសមផលមួយនេះគឺជា មធ្យោបាយបញ្ឆោតសត្រូវមួយដែលមិនទំនង និងដែលគ្មានអាងលើហេតុការណ៍ផ្សេងៗទេ ជាពិសេសក្នុងករណីប្រទេសកម្ពុជា ប៉ុន្តែវាបង្កើតបានការទុកចិត្តដរាបណាក្រុមនិយមឆ្វេងបដិសេធថា វាពុំមានអ្វីពិតប្រាកដទេក្នុងចម្លើយជាសាក្សីរបស់អ្នកភៀសខ្លួនទាំងនោះ ។

ក្នុងក្រុមទាំងសងខាង គេធ្វើកិច្ចការអ្វីមួយក្នុងនាមនៃផលប្រយោជន៍ផ្ទាល់ខ្លួនម្នាក់ៗ ។ របៀបដែលឥណ្ឌូចិនក្រោយសម័យសង្គ្រាម ត្រូវបានស្គាល់ដឹងនៅសហរដ្ឋអាមេរិក ទៅជាមានសារសំខាន់ជាងគេ ទោះបីជា

មានការយល់ដឹងច្បាស់ពីការផ្លាស់ប្តូរប្រកបដោយគ្រោះថ្នាក់ ប៉ះពាល់ដល់តំបន់នេះក៏ដោយ ។ មនុស្សច្រើនបំផុត នៅក្នុងផ្ទៃ ឬនៅក្រៅរដ្ឋាភិបាល ធ្លាប់បានប្រឌិតកេរ្តិ៍ឈ្មោះ, អាជីព និងសេចក្តីរាប់អានផ្ទាល់របស់គេ ដោយប្រកាន់ជំហរដដែលក្នុងរយៈពេលនៃសង្គ្រាម ។ ក្រុមនីមួយៗពោលអះអាងថា សម័យក្រោយសង្គ្រាមជាចំណែកមួយនៃស្ថានភាពមុនៗទាំងនេះ ហើយបង្ហាញភស្តុតាងពីមូលកភាព (ភាពសមហេតុសមផល) របស់គេផង ។ ដំណឹងផ្សេងៗរបស់តំបន់នេះ ពុំត្រូវបានចាត់ទុកជាពត៌មានស្តីពីតណ្ហចិនមួយ ដែលដឹកនាំដោយពួកវៀតណាម និងកម្ពុជាទេ ប៉ុន្តែ ចាត់ទុកដូចជារបោយពត៌មានមិនទាន់ចេញជាក់ស្តែងប្រឆាំងទល់នឹងបណ្តាគូប្រឆាំងចាស់ៗរបស់អាមេរិកាំង និងជាភស្តុតាងនៃពិរុទ្ធភាព ឬភាពថ្លៃថ្នូររបស់អាមេរិក ។

គូប្រឆាំងមួយចំនួនតូចចំពោះការជាប់ដៃប្រយុទ្ធរបស់សហរដ្ឋអាមេរិកនៅប្រទេសវៀតណាម និងកម្ពុជា បានក្លាយជាអ្នករិះគន់ដំបូងៗ ដល់បណ្តារបបកុម្មុយនិស្តថ្មីនៃប្រទេសទាំងនេះ ហើយបានទៅជាមនុស្សដ៏កម្រក្នុងចំណោមមនុស្សដ៏កម្រជាច្រើន ដែលបានប្រកាសឲ្យដឹងជាសាធារណៈពីសោកនាដកម្មគួរឲ្យព្រឺខ្លាចមួយថែមទៀតក្នុងបណ្តាខែ និងឆ្នាំ ជាបន្តបន្ទាប់មកទៀត ។ ពួកគេបានត្រូវបរិហារយ៉ាងខ្លាំងក្លា ដោយបណ្តាអតីតសម្ព័ន្ធមិត្តក្នុងផ្ទៃនៃក្រុមនិយមឆ្វេង ដែលធ្វើខូចប្រយោជន៍ដល់គោលដៅដូចគ្នាដែលក្រុមនិយមឆ្វេងកំពុងបន្តធ្វើ គឺដោះស្រាយការវិវាទរវាងប្រទេសវៀតណាម និងសហរដ្ឋអាមេរិក ។

គឺចម្លើយជាសាក្សីស្តីពីប្រទេសកម្ពុជាទាំងនេះហើយ ដែលបំបាត់ភាពនៅស្ងៀមស្ងាត់នេះ ។ តាំងពីខែមិថុនា ឆ្នាំ១៩៧៥ កាសែតវ៉ាស៊ីនតោនប៉ុស្តិ៍ បានជួយផ្សាយអត្ថបទមួយដោយដកស្រង់តាមសេចក្តីថ្លែងរបស់យុវជនខ្មែរម្នាក់ឡើងវិញថា ៖ «លើកលែងតែពួកចាស់ៗ និងក្មេងៗចេញ មនុស្សទាំងអស់ត្រូវទៅធ្វើការនៅតាមវាលស្រែ យើងបានឈប់សម្រាកតែនៅពេលហូបបាយ និងពេលដេកពួនប៉ុណ្ណោះ» ។ យុវជននោះ បានបន្ថែមថា ពុំសូវមានអាហារបរិភោគគ្រប់គ្រាន់ទេ, ឱសថព្យាបាលជំងឺស្ទើរតែគ្មានសោះ និងបានវាយស្មានជាមុនថាមនុស្សជាច្រើននឹងត្រូវស្លាប់ ។ ក្នុងអត្ថបទដដែលអ្នកភៀសខ្លួនខ្មែរម្នាក់ទៀត បានរៀបរាប់ថា ពុំមានឧបករណ៍ប្រើប្រាស់ទេ ហើយថា មានមនុស្សមួយក្រុមបានអូសនង្គ័លភ្ជួរស្រែ "ដូចសត្វគោ-ក្របី" ។

ពិភពលោកបានត្រូវធ្វើឲ្យស្រឡាំងកាំង នៅពេលដែលកាសែតនានាបានចុះផ្សាយអត្ថបទផ្សេងៗស្តីពីការជម្លៀសប្រជាជនភ្លាមៗចេញពីទីក្រុងភ្នំពេញ, ការធ្វើដំណើររបស់ប្រជាជនទៅកាន់ជនបទ ភាគច្រើនទៅរស់នៅលើដីមិនសូវមានជីជាតិ, ពេលម៉ោងធ្វើការច្រើនហួសប្រមាណ, ការលុបបំបាត់សេរីភាពផ្សេងៗ និងជីវិតឯកជន, ការភ័យខ្លាចនឹងការសម្លាប់មនុស្សច្រើនឥតគណនា ។ អ្នកកាសែតនិយមឆ្វេងមួយក្រុមតូចបានចំអកឲ្យអត្ថបទទាំងនោះ ដោយបកស្រាយថា ភស្តុតាងទាំងនោះមិនគ្រប់គ្រាន់ទេ ហើយថាពួកអ្នកនិពន្ធអត្ថបទទាំងនេះជាចំណែកមួយនៃសមាសភាពមនុស្សមួយក្រុម "ដែលចូលចិត្តបញ្ឆោតលេងជាល្បែង" សំដៅធ្វើឲ្យឃើញថាការប្រឹងប្រែងធ្វើសង្គ្រាមរបស់អាមេរិកាំង ដែលបរាជ័យទៅហើយនោះ ពិតជាត្រឹមត្រូវមែន ។ និយាយ

ម៉្យាងទៀត គឺហេតុការណ៍ធម្មតាដែលនិយមអំពីស្ថានការណ៍ថ្មីដ៏គួរឲ្យព្រឺរន្ធត់នៅកម្ពុជា មានការទាក់ទងនឹងការឃុបឃិតថែមទៀត ។

ដើម្បីកុំឲ្យបំពានទៅលើពួកខាងឆ្វេងរបស់ខ្លួន ក្រុមនិយមស្តាំបំផុតបានផ្តើមធ្វើការវាយប្រហារដូចគ្នាប្រឆាំងនឹងសារពត៌មាន ដោយចោទប្រកាន់ថា មិនបាននិយាយឲ្យគ្រប់គ្រាន់ពីសោកនាដកម្មរបស់កម្ពុជា ហើយសមគំនិតក្នុងការគិតក្បត់មួយ នឹងក្រុមសេរីនិយមដ៏មានអំណាច ដើម្បីបង្កប់ចោលពត៌មានផ្សេងៗ ដែលបញ្ចេញឲ្យដឹងពីរបបកុម្មុយនិស្ត ក្រោមទិដ្ឋភាពដែលបង្ហាញការមិនចូលចិត្តមួយ ។

ការពិភាក្សា (ខាងនយោបាយ) ដូចគ្នាមួយ បានមត់គ្នានិយាយអំពីបញ្ហាសិទ្ធិមនុស្សនៅប្រទេសវៀតណាម ។ រឿងនោះ បានចាប់ផ្តើមដោយការពិភាក្សាគ្នាមួយរវាងយុទ្ធិកជនពីររូប ដែលប្រឆាំងនឹងការដាក់ទាហានឲ្យចូលប្រយុទ្ធរបស់អាមេរិកាំង ហើយដែលនៅទីបំផុតក៏បំផ្លាញកុងសង់ស៊ីស (Consensus) នៅក្រោយសម័យសង្គ្រាម ។ ស្ត្រីយុទ្ធិកជនម្នាក់ក្នុងចំណោមនោះ គឺនាង ខូរ៉ា វើស (Cora Weiss)[៧] ដែលជាអ្នកទទួលមរតកយ៉ាងសម្បើមមួយ បានក្លាយទៅជាអ្វីដែលនាងឲ្យឈ្មោះថា មេអណ្តើក "សមហេតុផល" រវាងពួកអាមេរិកាំង និងពួកវៀតណាម ដែលមានជ័យជម្នះក្រោយឆ្នាំ១៩៧៥ ។ ក្នុងកំឡុងសង្គ្រាម នាងបានជំរុញឲ្យមានការជជែកវែកញែករកខុសត្រូវមួយ ដោយធានាការទាក់ទងរវាងក្រុងហាណូយ និងសហរដ្ឋអាមេរិក, ដោយដឹកនាំអង្គការតូចមួយជាអង្គការតែមួយគត់ ដែលពួកវៀតណាមខាងជើងអនុញ្ញាតឲ្យដឹកនាំសំបុត្ររវាងពួកឈ្លើយសឹកអាមេរិកាំង និងគ្រួសាររបស់ពួកគេ ។ វើស បានធ្វើដំណើរចុះឡើងរវាងក្រុងហាណូយ និងសហរដ្ឋអាមេរិក ដើម្បីនាំយោបល់របស់វៀតណាមខាងជើង មកប្រាប់មតិសាធារណៈអាមេរិកាំង ។

ក្រោយសម័យសង្គ្រាម នាងបានប្រើប្រាស់មរតករបស់នាង ដើម្បីគាំទ្រគំនិតផ្តួចផ្តើមទាំងឡាយ ដែលលើកទឹកចិត្តដល់ការស្តារប្រទេសវៀតណាមឡើងវិញ ការធ្វើឲ្យទំនាក់ទំនងអាមេរិក-វៀតណាម បានប្រសើរជាងមុន និងការជួយរបស់សហរដ្ឋចំពោះប្រទេសវៀតណាម ។ កាលពីដំបូងៗ នាងបានជួយលើកតម្កើងរបបខ្មែរក្រហម ។ ខូរ៉ា វើស គ្មាននិយាយទិតៀនប្រឆាំងនឹងប្រទេសវៀតណាមមួយម៉ាត់សោះ ៖ "វាមានមនុស្សច្រើនគ្រប់គ្រាន់រួចមកហើយ ដែលជៀលត្មះពួកវៀតណាម ។ អ្វីដែលពួកគេរៀបចំនៅក្នុងប្រទេស គឺពួកគេគិតណាស់ទើបធ្វើ" ។

ឥរិយាបថនេះ ប្រឆាំងទៅនឹងឥរិយាបថរបស់ ជូអេន បាអេ (Joan Baez) ដែលជាមិត្តស្រីម្នាក់ក្នុងចំណោមអតីតមិត្តស្រីរបស់នាង និងជាស្ត្រីម្នាក់ក្នុងចំណោមឥស្សរជនល្បីល្បាញជាច្រើននៃចលនាប្រឆាំងសង្គ្រាម ។ ការវិវាទរបស់ស្ត្រីទាំងពីរ ឆ្លុះបញ្ចាំងឲ្យឃើញនូវការបែកបាក់គ្នា ក្នុងផ្ទៃនៃក្រុមនិយមឆ្វេងរបស់អាមេរិកាំង និងជាសញ្ញាឲ្យដឹងមុនពីការមិនទទួលស្គាល់ពួកវៀតណាម ដោយមតិសាធារណៈអន្តរជាតិនៅពីរ-បីឆ្នាំក្រោយមក ។ បាអេ ជាតំណាងចលនាដើម្បីសិទ្ធមនុស្ស ។ នាងបានអួតអំពីអហិង្សា និងជាមិត្តរបស់លោក ម៉ានតាំង

លុយធ័រឃើង ។ នៅឆ្នាំ១៩៧៦ នៅពេលដែលគេស្នើឲ្យនាងចុះហត្ថលេខាលើលិខិតមួយ ប្រឆាំងនឹងការរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្តដោយរដ្ឋាភិបាលក្រុងហាណូយ នាងបានយល់ព្រម បន្ទាប់ពីបានពិនិត្យមើលភស្តុតាងផ្សេងៗដែលអាចយកជាការបាន ។

នៅពេលនោះ ទូរស័ព្ទរបស់នាងបានរោទិ៍ឡើង ។ ហ្សូអេន បាអេ[៨] បានដំណាលថា "គឺពុំមែនជាការហៅនិយាយតាមទូរស័ព្ទរបស់ ខូវ៉ា [វើស] តែប៉ុណ្ណោះទេ គឺជាបញ្ជាដាច់ខាតមួយឲ្យដកឈ្មោះ របស់ខ្ញុំចេញពីបញ្ជីនេះ" ។

លិខិតដែលគាំទ្រដោយសម្ព័ន្ធសិទ្ធិមនុស្សអន្តរជាតិ ត្រូវបានបោះពុម្ពផ្សាយនៅខែធ្នូ ឆ្នាំ១៩៧៦ ។ ជាធម្មតា គឺឈ្មោះ ហ្សូអេន បាអេ ដែលបង្កឲ្យមានការយកចិត្តទុកដាក់ជាងគេនៅក្នុងអត្ថបទផ្សេងៗដោយទាញសម្បជញ្ញៈអតីតឥស្សរជនទាំងឡាយនៃចលនាប្រឆាំងសង្គ្រាម ដែលចោទប្រកាន់រដ្ឋាភិបាលវៀតណាមពីបទ "រំលោភបំពានទាំងកម្រោល" លើសេរីភាពផ្សេងៗ ជាពិសេស ការចាប់ដាក់គុកដោយអំណាចផ្ដាច់ការ នូវមនុស្សទាំងឡាយ ដែលមានទស្សនៈនយោបាយ និងជំនឿសាសនា ផ្ទុយនឹងរដ្ឋាភិបាល ។ បាអេ បានបន្ទោសខ្លួនឯងដែលមិនបានត្រិះ រិះពិចារណាចំពោះអ្វីដែលតែងតែកើតមានឡើងនៅប្រទេសវៀតណាម និងកម្ពុជា ក្រោយសម័យប្រឆាំងនឹងសហរដ្ឋអាមេរិកទេ ។

"ខ្ញុំគិតថា នេះជាកំហុសរបស់ខ្ញុំ ។ ខ្ញុំមិនសូវពិចារណាចំពោះនយោបាយទៅតាមរបៀបគ្រប់គ្រងទេ ។ ខ្ញុំនឹកគិតដល់ម្ដាយ, ក្មេងៗ និងគ្រាប់ណាប៉ាល់ប៉ុណ្ណោះ... ។ ខ្ញុំនឹកឃើញថា ធ្លាប់បានជួបបុរសម្នាក់នៅវៀតណាមខាងជើង ដែលប្រើពេលប្រយុទ្ធពេញមួយជីវិតរបស់គាត់ ដើម្បីបណ្ដេញអ្នកឈ្លានពានចេញពីប្រទេស ហើយខ្ញុំបានសួរគាត់ថា ក្នុងពេលណាមួយអ្វីដែលគាត់នឹងត្រូវធ្វើ បើសិនជាយើង [ពួកអាមេរិកាំង] ចាកចេញ ហើយបើសិនជាគាត់ស្គាល់ឱកាសសន្តិភាពមួយ ។ ទឹកមុខរបស់គាត់រីកថ្លា ហើយគាត់ឆ្លើយថា ៖ "អូហ៎! ខ្ញុំនឹងជិះទូកតូចនេះ ដើម្បីធ្វើដំណើរជុំវិញកោះនានារបស់ប្រទេសវៀតណាម" ។ គាត់ក៏គ្មាននិយាយពាក្យពេចន៍ណាមួយទាក់ទងនឹងនយោបាយដែរ ។ ក្នុងចំណោមយើងគ្មានអ្នកណាម្នាក់និយាយដូចគាត់ទេ នៅពេលដែលយើងនឹកគិតចំពោះអ្វីដែលយើងនឹងត្រូវធ្វើនៅពេលដែលសង្គ្រាមនឹងត្រូវបញ្ចប់ ។

ការទាស់ទែងគ្នា និងការពិនិត្យឡើងវិញ នូវការវិនិច្ឆ័យក្នុងផ្ទៃនៃអតីតចលនាប្រឆាំងសង្គ្រាមបានដកយកពួកអ្នកមានសមានចិត្តដ៏ល្បីល្បាញចេញពីគាត់ទាំងអស់ ។ នៅឆ្នាំ១៩៧៨ ដោយត្រូវប្រឈមនឹងសង្គ្រាមមួយជាមួយប្រទេសកម្ពុជា ពួកវៀតណាមបានមកសហរដ្ឋអាមេរិក ដើម្បីស្វែងរកការអនុគ្រោះពីរដ្ឋាភិបាល និងសាធារណៈមតិ ប៉ុន្តែ បង្ហាញការ "ឡប់ប៊ី" មួយរបស់វៀតណាមដែលគ្មានអានុភាព, គ្មានសមត្ថភាពធ្វើឲ្យចលនាមហាជនមួយ សម្រាប់ប្រទេសវៀតណាម មានសន្ទុះជាថ្មី និងរដ្ឋាភិបាលមួយដែលធុញទ្រាន់ចំពោះយុទ្ធសាស្ត្រវៀចវេររបស់ក្រុងហាណូយ ។

ប៉ុន្តែពួកវៀតណាមប្រហែលជាសម្រេចជោគជ័យដោយងាយស្រួល ដើម្បីឲ្យមានការគាំទ្រដល់បុព្វហេតុរបស់គេតទល់នឹងពួកខ្មែរក្រហម ដែលធ្លាប់ត្រូវថ្កោលទោសគ្រន់ៗដោយរដ្ឋាភិបាលអាមេរិកាំង បើពុំដូច្នោះទេដោយក្រុមនិយមឆ្វេងថែមទៀត ។ ប៉ុន្តែ អាស្រ័យដោយការប្រព្រឹត្តផ្ទាល់របស់គេ ពួកគេត្រឡប់ទៅជាគ្មានអ្នករាប់រកនៅសហរដ្ឋអាមេរិកទៅវិញ ។ ហើយពួកវៀតណាមត្រូវប្រឈមមុខតទល់នឹងពួកកម្ពុជា ដោយគ្មានការជួយគាំទ្រជាក់លាក់ពីមជ្ឈដ្ឋានមួយចំនួនតូច ទោះជានៅសហរដ្ឋអាមេរិកក៏ដោយ ។

## លួចលោមអង្វរក្រុងវ៉ាស៊ីនតោន

ជីមមី ខាធ័រ អតីតអភិបាលរដ្ឋហ្សេអ័រហ្ស៊ី ដ៏វ៉ាងវៃ បានមើលឃើញនូវបរិយាកាសប្រកបដោយគ្រោះថ្នាក់ និងមិនសុខស្រួលរបស់ប្រទេសបន្ទាប់ពីទីបញ្ចប់នៃសង្គ្រាមនៅប្រទេសវៀតណាម និងរឿងវ៉ាវ វ៉ធឺហ្គេត ដែលបណ្តាលឲ្យប្រធានាធិបតី និចសុន ធ្លាក់ពីតំណែង ។ គាត់បានឈ្នះការបោះឆ្នោតជ្រើសរើសប្រធានាធិបតីអាមេរិកាំង នៅឆ្នាំ១៩៧៦ ជាមួយនឹងកម្មវិធីមួយសំដៅផ្សះមុខរបួសទាំងអស់របស់ប្រទេស ដែលកើតឡើងដោយសារសង្គ្រាម ឬអ្វីៗដែលទាក់ទាញការយកចិត្តទុកដាក់របស់សេតវិមានមួយ ដែលឥតអៀនខ្មាស និងដែលប្រទាញទៅតែខាងផ្លូវអាក្រក់ ។

ពួកវៀតណាម អាចចង់បានប្រធានាធិបតី ដែលបង្ហាញសេចក្តីអនុគ្រោះដាងគេ ចំពោះបុព្វហេតុរបស់គេ ដោយហេតុថា ខាធ័រ ធ្លាប់ឃោសនាក្នុងពេលបោះឆ្នោត ដោយសន្យាខំប្រឹងបង្កើតឲ្យមានទំនាក់ទំនងជាប្រក្រតីជាមួយក្រុងហាណូយ ។ ហើយក្នុងរយៈពេលប្រាំបួនខែដំបូងនៃអាណត្តិរបស់គាត់ ប្រធានាធិបតី ខាធ័រ ប្រាថ្នាធ្វើឲ្យពិភពលោកភ្ញាក់ផ្អើល ដោយអះអាងពីទិសដៅថ្មីមួយនៃនយោបាយការបរទេសអាមេរិកាំង ក៏ដូចការបញ្ចូលរបៀបថ្មីដូចនៅបណ្តាឆ្នាំដែលមានបន្តពីសង្គ្រាមលោកទីពីរដែរ ។ ក្នុងក្របខ័ណ្ឌនេះ គំនិតផ្តួចផ្តើមដំបូងមួយ ក្នុងចំណោមគំនិតផ្តួចផ្តើមដំបូងៗរបស់គាត់ គឺបញ្ជូនទៅក្រុងហាណូយនូវគណៈបេសកម្មមួយ ដែលមានគោលដៅប្រកាសឲ្យដឹងពីគោលបំណង ជួយសម្រួលការរៀបចំស្ថិតិចំនួនទាហានអាមេរិកាំង ដែលបាត់ខ្លួនក្នុងការប្រយុទ្ធឲ្យហើយជាស្ថាពរ ។ គណៈបេសកម្មនេះ ក៏មានគោលដៅមួយសំខាន់ណាស់ដែរ គឺបញ្ចុះបញ្ចូលប្រទេសវៀតណាម ធ្វើឲ្យមានប្រក្រតីភាពនូវទំនាក់ទំនងផ្សេងៗ ក្នុងលក្ខខណ្ឌអាចទទួលយកបានសម្រាប់មជ្ឈដ្ឋានអាមេរិកាំងភាគច្រើន ។

ប៉ុន្តែ ប្រវត្តិនៃការចរចាទាំងឡាយរបស់អាមេរិកាំងជាមួយពួកកុម្មុយនិស្តវៀតណាម នឹងត្រូវជំរុញឲ្យមានការប្រុងប្រយ័ត្នថែមទៀត ។ ស៊ីរុសវ៉ាន់ស៍ រដ្ឋមន្ត្រីការបរទេសថ្មីរបស់ ខាធ័រ ស្គាល់យ៉ាងច្បាស់នូវសុំណុំរឿងនេះ ដោយហេតថាគាត់ធ្លាប់ចូលរួមក្នុងការប្រជុំចរចានៅឆ្នាំ១៩៦៨ ដែលរកកលតែនឹងបិទទៅហើយស្តីពី

បញ្ហាទ្រទ្រង់ទ្រាយតុសម្រាប់ចរចា ។ ប៉ុន្តែ យុទ្ធកោសល្យរបស់ ខាធ័រ ពឹងផ្អែកដោយផ្អែកលើលក្ខណៈ ដែលធ្វើឲ្យគេស្រឡាំងកាំងនៃការសម្រេចចិត្តរបស់គាត់ ។ គាត់បានបញ្ជូនគណៈបេសកកម្មទៅក្រុងហាណូយស្ទើរតែមិនដល់ពីរខែផង បន្ទាប់ពីគាត់ចូលកាន់តំណែងជាផ្លូវការ និងបានជ្រើសរើសជាពិសេសនូវពួកអ្នកសេរីនិយម ដែលសម្ដែងមតិប្រឆាំងសង្គ្រាមឲ្យធ្វើជាសមាជិករដ្ឋាភិបាលរបស់គាត់ ។ ការជ្រើសរើសពេលវេលា និងសមាសភាពរបស់គណៈប្រតិភូ ទំនងជាធ្វើឲ្យពួកវៀតណាមចាប់អារម្មណ៍ ដូចលោកប្រធានាធិបតីធ្វើឲ្យពួកអាមេរិកាំង ធ្លើងធ្លល់ស្រឡាំងកាំង និងសប្បាយរីករាយខ្លាំង ដោយលោកបដិសេធមិនជិះរថយន្តលីមូហ្ស៊ីនពាសគ្រោះមួយគ្រឿង ហើយសុខចិត្តដើរតាមវិថីភេនស៊ីវ៉ានៀ នៅថ្ងៃនៃការចូលកាន់មុខតំណែងរបស់គាត់ដែរ ទោះបីជាមានខ្យល់ត្រជាក់ស្រេប និងបក់បោកយ៉ាងខ្លាំងក៏ដោយ ។ ខាធ័រ នឹកក្នុងចិត្តថា ពួកវៀតណាមនឹងត្រូវធ្វើឲ្យចាប់អារម្មណ៍ខាងផ្លូវចិត្តចំពោះនិមិត្តរូបនៃការចាប់ចេញដំណើរជាថ្មីនេះ ។

គណៈប្រតិភូ គឺដឹកនាំដោយលោក ឡេអូណាដ៍ វូដខូក ជាមេដឹកនាំសហជីពបង្រួបបង្រួមកម្មកររថយន្ត ដែលធ្លាប់ធ្វើឲ្យមួយផ្នែកធំនៃចលនាសហជីព ផ្ទៀងទៅខាង ខាធ័រ ដំបូងសម្រាប់ការបោះឆ្នោតជ្រើសតាំងបេក្ខជនឈរឈ្មោះជាប្រធានាធិបតីខាងគណបក្សប្រជាធិបតេយ្យ បន្ទាប់មក ក្នុងការបោះឆ្នោតសកលតទល់នឹងប្រធានាធិបតី ជេរ៉ាល់ហ្វ័រដ៏ ។ វូដខូដ ត្រូវបានអមដំណើរដោយអ្នកតំណាងរាស្ត្រប្រជាធិបតេយ្យសេរីនិយម បីរូប និងដោយអ្នកតំណាង *G.V. (Sonny) Montgomery* ដែលត្រូវជ្រើសតាំងជាតំណាងរាស្ត្រខាងគណបក្សប្រជាធិបតេយ្យប្រចាំរដ្ឋ មីស្ស៊ីស៊ីពី ហើយដែលធ្លាប់គាំទ្រការប្រយុទ្ធរបស់អាមេរិកាំងនៅប្រទេសវៀតណាម និងជាប្រធានគណៈកម្មការអង្កេតរបស់សភាស្ដីពីទាហានអាមេរិកាំងបាត់ខ្លួនក្នុងការប្រយុទ្ធ ។

គណៈកម្មាធិការនេះ បានផ្សាយនៅចុងឆ្នាំ១៩៧៦ នូវរបាយការណ៍មួយដោយប្រកាសថា គ្មានទាហានអាមេរិកាំងបាត់ខ្លួនណាម្នាក់អាចនៅមានជីវិតរស់នៅក្នុងឥណ្ឌូចិនឡើយ ។ សេចក្ដីសន្និដ្ឋាននេះ បានបំបាត់បញ្ហាមួយកំភួសធំសម្រាប់ ខាធ័រ ។ ក្នុងកំឡុងពេលឃោសនាបោះឆ្នោត ប្រធានាធិបតី ហ្វរដ៏ បានការពារជំហររបស់គាត់ប្រឆាំងនឹងការធ្វើឲ្យមានប្រក្រតីភាព នូវទំនាក់ទំនងផ្សេងៗជាមួយប្រទេសវៀតណាម ដោយពោលអះអាងថា វារួមបង្កជាមធ្យោបាយតែមួយគត់ ដែលបន្ទំឲ្យក្រុងហាណូយរាយការណ៍ពីទាហានអាមេរិកាំងដែលបាត់ខ្លួនក្នុងការប្រយុទ្ធ ។ ក្នុងសម័យក្រោយសង្គ្រាម បញ្ហាទាហានបាត់ខ្លួនក្នុងការប្រយុទ្ធ ជាបញ្ហាមួយក្នុងចំណោមបញ្ហាដែលកម្រសូវមានជាច្រើន ដែលបន្តធ្វើឲ្យពួកអាមេរិកាំងខ្វល់អំពល់មិនចេះចប់ ។ ឪពុកម្ដាយរបស់ទាហានដែលចាត់ទុកថាបាត់ខ្លួនចំនួន ២.៥៤៥នាក់ បានបង្កើតជាក្រុមដ៏មានអានុភាពមួយ ដោយមេដឹកនាំជាច្រើនរូបរបស់រដ្ឋាភិបាល ជាពិសេស នៅមន្ទីរប៉ង់តាហ្គោន ។ ម្យ៉ាងទៀត នេះជាបញ្ហាតែមួយគត់ដែលសម្រេចបាននូវមតិជាឯកច្ឆន្ទៈ ក្រៅពីមតិនយោបាយរបស់ពួកគេ ពួកអាមេរិកាំង បានបញ្ចេញឲ្យឃើញការទទួលខុសត្រូវចំពោះពួកអ្នកដែលធ្លាប់វាយឈ្នះខ្លួន ។

ខាង៉រ បានសន្យាធ្វើឲ្យសម្រេចដូចប្រាថ្នា នូវពត៌មានពេញលេញគ្រប់គ្រាន់ ស្តីពីទាហានបាត់ខ្លួនក្នុងការប្រយុទ្ធ មុននឹងចរចាពីការធ្វើឲ្យមានប្រក្រតីភាព នូវទំនាក់ទំនងផ្សេងៗជាមួយប្រទេសវៀតណាម ហើយរបាយការណ៍របស់ ម៉ុងហ្គោមេរី គ្មាននរណារវល់យកចិត្តទុកដាក់ ៖ «រដ្ឋភិបាលនានានៅឥណ្ឌូចិន មិនអាចរាយការណ៍ពី [ចំនួនទាហានបាត់ខ្លួន ក្នុងការប្រយុទ្ធទាំងអស់បានទេ] ដូច្នេះ វាគ្មានប្រយោជន៍នឹងរង់ចាំរឿងបែបនោះឡើយ», នេះជាសេចក្តីសន្និដ្ឋានរបស់របាយការណ៍ មុននឹងផ្តាំផ្ញើសហរដ្ឋអាមេរិកធ្វើឲ្យទំនាក់ទំនងរបស់ខ្លួនមានប្រក្រតីភាពជាមួយប្រទេសវៀតណាម ។

រដ្ឋាភិបាលក្រុងហាណូយ សម្គាល់ឃើញក្នុងបេសកកម្មរបស់ វូដខូក តែការផ្តើមគំនិតស្វែងរកសន្តិភាពប៉ុណ្ណោះ ។ ប៉ុន្តែ នៅពេលមកដល់ប្រទេសវៀតណាម បណ្តាសមាជិកនៃគណៈបេសកកម្មបានរកឃើញភ្លាមថា ពួកវៀតណាម ពុំបានបោះបង់ការទាមទារដែលមានពីមុនរបស់គេឡើយ ៖ ក្នុងកិច្ចព្រមព្រៀងធ្វើឲ្យមានប្រក្រតីភាពទាំងអស់ សហរដ្ឋអាមេរិកត្រូវតែសន្យាជួយក្នុងការកសាងប្រទេសវៀតណាមឡើងវិញ ។ សមាជិកគណៈប្រតិភូ ស្ទើរតែដាក់អីវ៉ាន់របស់ពួកគេនៅសណ្ឋាគារធុនល្មមរបស់រដ្ឋាភិបាលមិនទាន់ស្រួលបួលផង ពួកគេបានត្រូវអញ្ជើញទៅចូលរួមសម័យប្រជុំមិនបានគិតទុកជាមុនមួយ ជាមួយ រដ្ឋមន្ត្រីការបរទេសរបស់វៀតណាម ដែលរាយការណ៍ប្រាប់ពួកគេនូវអ្វីដែលក្រោយមក វូដខូក បានហៅថា «ខ្សែបន្ទាត់ស្តង់ដារ[៧]» ៖ សហរដ្ឋអាមេរិកមានកាតព្វកិច្ចតាមច្បាប់ក្នុងការបរិច្ចាគប្រាក់ចំនួន ៣,២៥ កោដិដុល្លារ ជាជំនួយដល់ការកសាងប្រទេសវៀតណាមឡើងវិញ ដែលសន្យាដោយប្រធានាធិបតី និចសុន ក្នុងសំបុត្រមួយផ្ញើឲ្យនាយករដ្ឋមន្ត្រី ផាំវ៉ាន់ដុង ដែលការលនោះជារឿងសម្ងាត់ ។

ពួកវៀតណាម ពិតជាឈ្នះសង្គ្រាម ប៉ុន្តែ ទ្រព្យរបស់ដែលប្រមូលបានពីសត្រូវ គឺមិនគ្រប់គ្រាន់សម្រាប់កសាងប្រទេសមួយដែលវិនាសហិនហោចឡើងវិញបានឡើយ ។ ខាងផ្នែកសម្ភារៈទ័ព របស់របរដែលប្រមូលបានមានកាំភ្លើងវែង ១,៦លានដើម, គ្រាប់រំសេវ ១៣០.០០០តោន, អាវុធប្រឆាំងរថក្រោះ ៦៣.០០០ដើម រួមទាំងយន្តហោះ មួយចំនួនធំផង ជាពិសេសយន្តហោះប្រដេញប្រតិកម្ម និងនាវាចម្បាំងប្រហែល ១.០០០គ្រឿង - តើប្រទេសវៀតណាម ដែលជាមហាអំណាចយោធាដ៏បូងមួយ ក្នុងចំណោមមហាអំណាចយោធាដ៏បូងៗនៃពិភពលោកធ្វើយ៉ាងម៉េចទៅជាមួយរបស់របរទាំងនោះ ។

ប៉ុន្តែ ពួកវៀតណាមពុំមានអ្វីគ្រប់គ្រាន់សម្រាប់ចិញ្ចឹមប្រជាជនទេ ។ សហគ្រាសទាំងឡាយនៅភាគខាងត្បូង ប្រែទៅជាផលិតផលចុះមិនដូចមុនមួយផ្នែកគឺដោយសារបណ្តាកម្មវិធីសេដ្ឋកិច្ចថ្មីរបស់ក្រុងហាណូយ ប៉ុន្តែក៏ដោយសារការរាំងខ្ទប់ខាងពាណិជ្ជកម្មរបស់លោកប្រធានាធិបតី ហ្វ័រដ៏ ដែលហាមឃាត់មិនឲ្យលក់វត្ថុធាតុដើម និងគ្រឿងបន្លាស់ផ្សេងៗទៅឲ្យប្រទេសវៀតណាមដែរ ។ ពួកមេដឹកនាំវៀតណាមយល់ឃើញថា ក្រុងវ៉ាស៊ីនតោនបានបំបាត់ផ្លែផ្កានៃជ័យជម្នះរបស់ប្រទេសគេ ដោយការរាំងខ្ទប់ផ្នែកពាណិជ្ជកម្មនេះ និងដោយការបដិសេធមិន

ព្រមផ្តល់ជំនួយរបស់ខ្លួនចំនួន ៣,២៥ កោដិដុល្លារ សម្រាប់ការស្តារប្រទេសឡើង ។

នៅខែមេសា ឆ្នាំ១៩៧៦ ក្រុងហាណូយ បានបោះពុម្ពផ្សាយនូវសេចក្តីដកស្រង់ខ្លះៗនៃលិខិតសម្ងាត់របស់លោក និចសុន ក្នុងកាសែតញិនហ្សិន ជារបស់រដ្ឋាភិបាល ដើម្បីធ្វើជាសំអាងដល់ការទាមទាររបស់ខ្លួន ៖ «រដ្ឋាភិបាលសហរដ្ឋអាមេរិក នឹងផ្តល់វិភាគទានបន្ទាប់ពីសង្គ្រាម ជួយដល់ការស្ថាបនាវៀតណាមខាងជើងឡើងវិញ ដោយគ្មានដាក់លក្ខខណ្ឌនយោបាយណាមួយឡើយ ។ តាមការសិក្សាដំបូងៗរបស់អាមេរិកាំង បង្ហាញឲ្យឃើញថា កម្មវិធីផ្សេងៗ ដែលមានលក្ខណៈសមហេតុសមផលសម្រាប់ការជួយជ្រោមជ្រែងរបស់អាមេរិកាំងក្នុងការស្ថាបនាប្រទេសឡើងវិញ ដូចដែលរៀបរាប់ខាងលើ និងមានចំនួនប្រហែល ៣,២៥ កោដិដុល្លារ ជាជំនួយឥតសំណង...» ។

ប៉ុន្តែ លោក និចសុន បានសរសេរលិខិតនេះ ដោយគ្មានសុំយោបល់ពីសភាទេ ហើយគាត់បានដាក់ជូនសំណើក្នុងការផ្តល់ឲ្យ ៣,២៥ កោដិដុល្លារ ដើម្បីឲ្យសភាអាមេរិកាំងពិនិត្យយល់ព្រម ។

បើទោះជាលោក វ៉ូដខូក ជាអ្នកចរចាវៃឆ្លាតម្នាក់នៃសហជីពក៏ដោយ ក៏គាត់មិនស្គាល់ពួកវៀតណាម និងការប្តេជ្ញាចិត្តរបស់គេដែរ ។ មុនការចេញដំណើររបស់គាត់ គេបានបង្ហាញលិខិតរបស់ និចសុន ឲ្យគាត់មើលក្នុងសម័យប្រជុំធ្វើការចាត់ចែងផ្សេងៗដែលត្រូវធ្វើបន្ទាន់ ហើយគេបានប្រាប់គាត់ថា សភានឹងមិនយល់ព្រមផ្តល់ជំនួយដល់ប្រទេសវៀតណាមតាមកិច្ចសន្យាបែបនោះឡើយ ។ ថ្ងៃបន្ទាប់ពីការទៅដល់របស់គណៈប្រតិភូ[១០] លោក វ៉ូដខូក បានជួបសមភាគីវៀតណាមរបស់គាត់ ជាអនុរដ្ឋមន្ត្រីការបរទេសឈ្មោះ ផាន់ហៀន ដែលនៅពេលនោះកំពុងឡើងបុណ្យសក្តិស្រឹតៗ ។ ជាមនុស្សមាននិស្ស័យគួរឲ្យស្រឡាញ់ចូលចិត្ត រួសរាយរាក់ទាក់ក្នុងការនិយាយស្តីរបស់ខ្លួន ផាន់ហៀន ធ្លាប់បានចូលរួមក្នុងការចរចានៅទីក្រុងប៉ារីសក្នុងឆ្នាំ១៩៦៨ និងធ្លាប់ធ្វើឲ្យគេនឹកឃើញពីមនុស្សម្នាក់ ដែលប្រកាន់ស្អិតចំពោះខ្សែបន្ទាត់នយោបាយរបស់រដ្ឋាភិបាល ដោយមិនធ្វើឲ្យបណ្តាគូសន្ទនារបស់គាត់អាក់អន់ចិត្តឡើយ ។ គាត់និយាយពីការទាមទារឡើងវិញ ដែលលោក វ៉ូដខូក ធ្លាប់ឮពីមុនមកហើយ ។

ដោយគាត់បានទទួលសេចក្តីបង្គាប់បញ្ជារួចហើយ លោក វ៉ូដខូក បានសង្កត់ថា លិខិតរបស់លោក និចសុន ដែលដូចលិខិតបន្ថែមក្នុងកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសនៅឆ្នាំ១៩៧៣ គឺគ្មានតម្លៃ និងមិនបានការ(មោឃៈ) ពីព្រោះប្រទេសវៀតណាម បានរំលោភលើខសំខាន់ជាច្រើនរបស់កិច្ចព្រមព្រៀងនេះ ជាពិសេស តាំងពីពេលដែលកងទ័ពវៀតណាមខាងជើង បានទទួលជ័យជម្នះផ្តាច់ព្រ័ត្រ ។ ផាន់ហៀន ឆ្លើយថា បើសហរដ្ឋអាមេរិកប្រកាន់យកជំហរនេះ ការសន្យាដែលធ្វើឡើងដោយប្រទេសវៀតណាម ត្រង់កថាខ័ណ្ឌទី៨ នៃកិច្ចព្រមព្រៀងស្តីពីការស្វែងរកដោយសេចក្តីរៀសរវៃនូវទាហានអាមេរិកាំងបាត់ខ្លួនក្នុងការប្រយុទ្ធ នឹងត្រូវចាត់ទុកថា គ្មានតម្លៃ និងគ្មានបានការដូចគ្នាដែរ ។ គ្មាន«រឿងថ្មី»ណាមួយត្រូវបានដោះស្រាយឡើយ ។ លោក វ៉ូដខូក ត្រូវវៀតណាម

ចាត់ទុកជាអ្នកទទួលមរតកពីគីស្សីងហ្គ័រ ពុំមែនជាមនុស្សដែលប្រើប្រាស់ការផាត់ទូតខុសគ្នាទេ ។ នៅពេលនោះ ប្រធានគណៈប្រតិភូអាមេរិកាំង បានស្នើ ដាន់ហៀន ឲ្យមានការប្រជុំមួយតែពីរនាក់គត់ ។

វ៉ូដខូក បានប្រកាសប្រាប់សមាជិកផ្សេងៗទៀតរបស់គណៈប្រតិភូ មុននឹងបែកចេញពី ដាន់ហៀន និងអ្នកបកប្រែម្នាក់ថា ៖ «បើសិនទេនេះជាកូដកម្មមួយដែលគេចរចា ខ្ញុំហ៊ានទាយទុកជាមុនថាប្រាំមួយខែយ៉ាងយូរ យើងនឹងជួបភាពទ័លច្រក» ។

លោក វ៉ូដខូក បានប្រព្រឹត្តកន្លងសេចក្តីបង្គាប់បញ្ជាផ្សេងៗ ដែលលោកប្រធានាធិបតីបានកំណត់ឲ្យគាត់ ។ ដោយពិត លោក ខាធ័រ បានសុំលោក វ៉ូដខូក កុំឲ្យចរចាតាមការនិយាយណែនាំមិនត្រូវគ្នាជាមួយមេដឹកនាំនៃសហជីព ដោយគ្រាន់តែឲ្យស្តាប់សម្តីគេនិយាយប៉ុណ្ណោះ ។ វ៉ូដខូក បានដំណាលថា ៖ «ការប្រជុំមានរយៈពេលប្រមាណជា ម្ភៃនាទី មិនលើសពីនេះទេ ។ ខ្ញុំបានរាយការណ៍ប្រាប់គាត់ដោយពាក្យសម្តីច្បាស់លាស់ និងសាមញ្ញថា គឺមិនអាចចរចាតទៅទៀតទេ បើសិនជាលោកនៅតែរក្សាការទាមទាររបស់ខ្លួនដូច្នេះ ។

គាត់បានប្រកាសប្រាប់អ្នកចរចារបស់វៀតណាមថា ៖ «លោកបានអះអាងថានឹងប្រគល់សាកសពទាហានបាត់ខ្លួនរបស់យើងមកឲ្យយើងជាថ្នូរនឹងជំនួយសេដ្ឋកិច្ចមួយ ។ គ្មានប្រធានាធិបតីអាមេរិកាំងណាម្នាក់ នឹងអាចអនុម័តយល់ព្រមចំពោះកិច្ចសន្យាបែបនេះបានទេ ហើយសភារឹតតែមិនអាចទៅទៀត ។ បើសិនជាលោកចង់ធ្វើឲ្យទំនាក់ទំនងផ្សេងៗជាមួយសហរដ្ឋ ល្អប្រសើរជាងមុន លោកត្រូវតែបោះបង់ចោលការទាមទារនេះ បើមិនដូច្នោះទេ ថ្ងៃនៃការធ្វើឲ្យមានប្រក្រតីភាព នឹងត្រូវរុញទៅមុខជាច្រើនឆ្នាំទៀត ។ វាទំនងជាគួរឲ្យជឿតិចតួចណាស់ថា គណៈប្រតិភូដែលយោគយល់បំផុតមួយ មកកាន់ទីនេះ មុនពេលជាច្រើនឆ្នាំ ។ ជំហរដែលយើងមានអំពីសង្គ្រាមមានលក្ខណៈច្បាស់លាស់ណាស់ ។ ចូរយើងញែកបញ្ហាទាំងអស់នេះចេញពីគ្នា ដោយទទួលស្គាល់ក្នុងពេលជាមួយគ្នានោះនូវការប្រឹងប្រែងថ្មីៗ ដែលនឹងត្រូវរៀបចំនៅពេលក្រោយទៀត បន្ទាប់ពីការធ្វើឲ្យមានប្រក្រតីភាព ដើម្បីស្វែងរកមធ្យោបាយផ្សេងៗ ដើម្បីជួយប្រទេសវៀតណាម ។ លោកមិនអាចមិនទទួលសំណូមពររបស់យើងដោយការឆ្លើយបដិសេធដូច្នេះទេ» ។

ដាន់ហៀន គ្មានឆ្លើយតបទាល់តែសោះ ហើយលោក វ៉ូដខូក បានត្រឡប់ទៅជួបសមាជិកឯទៀតរបស់គណៈប្រតិភូគាត់វិញ ។ ប្រតិកម្មរបស់ពួកវៀតណាម បានធ្វើឡើងខុសពីការដែលគេសង្ឃឹមទុក ៖ ការជួបប្រជុំដើម្បីចរចា បានចាប់បើកឡើងវិញជាសម័យប្រជុំពេញអង្គ ជាមួយនឹងសេចក្តីថ្លែងការណ៍ចាប់ផ្តើមមួយ របស់ដាន់ហៀន ដែលគូសបញ្ជាក់ថា ការធ្វើឲ្យមានប្រក្រតីភាពនូវទំនាក់ទំនងផ្សេងៗ ការស្វែងរកទាហានអាមេរិកបាត់ខ្លួនក្នុងការប្រយុទ្ធ និងការផ្តល់ជំនួយសេដ្ឋកិច្ច គឺជាបញ្ហាដោយឡែកពីគ្នា បើទោះជាវាទាក់ទងរវាងគ្នានឹងគ្នាក៏ដោយ ។ ពួកវៀតណាមបានផ្លាស់ប្តូរជំហរបន្តិច ហើយការចរចាបានបន្តទៅទៀត ។

សមាជិកបួនរូបនៃគណៈប្រតិភូ គឺមានអមទៅដោយអ្នកជំនាញការអាមេរិកាំងស្តីពីទាហានបាត់ខ្លួនក្នុងការ

ប្រយុទ្ធ ដែលត្រូវជួបប្រជុំដោយឡែកជាមួយសមភាគីវៀតណាមរបស់ពួកគេ ។ សមាជិកជាច្រើនក្នុងចំណោមនេះ ធ្លាប់បានធ្វើការពិភាក្សាក្នុងរយៈពេលជាច្រើនឆ្នាំ ជាមួយពួកវៀតណាម ដែលឥតបានការជាញឹកញយ ស្ដីពីទាហានបាត់ខ្លួនក្នុងការប្រយុទ្ធ ហើយមានបំណងឆ្លៀតទាញយកប្រយោជន៍ពីការចាប់ផ្ដើមចរចានៅក្រុង-ហាណូយនេះឲ្យបាន ។ ក្នុងឱកាសនៃការប្រជុំមួយរបស់ពួកអ្នកជំនាញការ ពួកវៀតណាមបានស្នើឲ្យបង្កើតការិយាល័យដោយឡែកមួយ ក្នុងផ្ទៃរដ្ឋាភិបាលរបស់គេ ដែលមានភារៈទទួលឯកសារផ្សេងៗរបស់អាមេរិកាំងស្ដីពីទាហានបាត់ខ្លួនក្នុងការប្រយុទ្ធ និងពត៌មានទាំងអស់មកពីខាងវៀតណាម ស្ដីពីទីកន្លែងដែលទាហានបាត់ខ្លួនទាំងនេះត្រូវគេកប់ ។ ក្រុមអ្នកជំនាញការអាមេរិកាំង ដែលនាំមកជាមួយនូវឯកសារលម្អិតស្ដីពីករណីមួយចំនួនមានបំណងប្រគល់សំណុំឯកសារទាំងនេះឲ្យពួកវៀតណាមភ្លាមៗ[១១] ។ វូដខូក បានជំទាស់ ពីព្រោះប្រការនេះនឹងធ្វើឲ្យមាន«ការឆ្លើយបដិសេធ»មួយ ។

វូដខូក បានទទួលស្គាល់ថា «ខ្ញុំរំឭកប្រាប់ [ពួកអ្នកជំនាញការ] ឲ្យសំដែងភាពវិជ្ជមានបំផុត... ។ ខ្ញុំជាមនុស្សម្នាក់ដែលមានលក្ខណៈតឹងរ៉ឹងបន្តិច» ។

ពួកអ្នកជំនាញការបានបញ្ចប់ការប្រជុំរបស់ពួកគេទាំងខកចិត្ត ដែលបានបណ្ដោយឲ្យឱកាសមាសមួយកន្លងផុតទៅសម្រាប់អត្ថប្រយោជន៍នយោបាយមួយ ដែលមិនបានសម្រេចអ្វីសោះ ។ វូដខូក បានលើកហេតុផលថា សហរដ្ឋអាមេរិក បានព្រមទទួលសំណើរបស់វៀតណាមហើយ ហើយថា សំណុំឯកសារផ្សេងៗអាចនឹងបញ្ជូនទៅជាក្រោយក៏បាន ។ ពួកអ្នកជំនាញការបានឆ្លើយតបថា កាលពីមុន ការសន្យាប្រភេទនេះកម្រមានអ្នកណាប្រកាន់ណាស់ ។ នៅទីបញ្ចប់នៃការស្នាក់អាស្រ័យរបស់គេ សមាជិកទាំងឡាយរបស់គណៈប្រតិភូ បានទទួលប្រអប់តូចពណ៌ខ្មៅចំនួនដប់ពីរ មានអដ្ឋិធាតុទាហានអាមេរិកាំងបាត់ខ្លួននៅក្នុងនោះ ។ ការប្រមូលសំណល់ទាហានបាត់ខ្លួនទាំងនេះត្រឡប់ប្រទេសវិញ គឺជាគោលដៅមួយក្នុងចំណោមគោលដៅជាច្រើននៃដំណើរនេះ ។

គណៈប្រតិភូបានចាកចេញពីក្រុងហាណូយដើម្បីធ្វើទស្សនកិច្ចខ្លីមួយនៅប្រទេសឡាវ ក្នុងគោលបំណងពិភាក្សាពីបញ្ហាទាហានបាត់ខ្លួនក្នុងការប្រយុទ្ធនៅក្នុងប្រទេសនេះ ។ ពួកអាមេរិកាំងប្រាថ្នាធ្វើដំណើរទៅកាន់ប្រទេសកម្ពុជា ប៉ុន្តែ ពួកអ្នកអំណាចក្រុងភ្នំពេញ មិនអនុញ្ញាតឲ្យយន្តហោះចុះចតឡើយ ។ វូដខូក ជាមនុស្សមានបទពិសោធន៍មិនគ្រប់គ្រាន់នៅពេលយល់ថា បេសកកម្មរបស់គាត់នៅប្រទេសវៀតណាម បានទទួលលទ្ធផលមិនប្រាកដប្រជា ហើយគាត់បានបដិសេធថាជាបរាជ័យ ឬជោគជ័យទេ នៅពេលដែលពួកអ្នកកាសែតបានទៅទទួលគាត់នៅមូលដ្ឋានអាកាសអេនឌ្រូ ក្បែរទីក្រុងវ៉ាស៊ីនតោន ។ ការវាយតម្លៃនេះគឺជាការសម្រេចខាងនយោបាយមួយរបស់លោកប្រធានាធិបតី ខាធ័រ ។

ដោយធ្វើឲ្យសមាជិកគណៈប្រតិភូជាច្រើននាក់ងឿងឆ្ងល់ លោក ខាធ័រ បានប្រកាសថា បេសកកម្មបានទទួល«ជោគជ័យមួយយ៉ាងត្រចះត្រចង់» ។ ប៉ុន្តែ ហេតុការណ៍ផ្សេងៗ បានជំរុញឲ្យមានរបៀបនិយាយមួយក្នុង

លក្ខណៈសមហេតុបំផុតៈ វូដខូក បានត្រឡប់មកវិញជាមួយការសន្យាបង្កើតការិយាល័យវៀតណាមថ្មីមួយទទួលចាត់ចែងពីរឿងទាហានបាត់ខ្លួនក្នុងការប្រយុទ្ធ រួមទាំងការព្រមព្រៀងដោយពាក្យសម្ដីមួយ ស្ដីពីការបំបែកបញ្ហាទាហានបាត់ខ្លួនក្នុងការប្រយុទ្ធ, ការធ្វើឲ្យទំនាក់ទំនងផ្សេងៗមានប្រក្រតីភាព និងជំនួយសេដ្ឋកិច្ចក្នុងការចរចាអាមេរិក-វៀតណាម លើកក្រោយៗទៀត ។

លោក វូដខូក បានពាំនាំលិខិតមួយរបស់នាយករដ្ឋមន្ត្រី ផាំ វ៉ាន់ដុង មកជូនប្រធានាធិបតី ខាធ័រ ដែលក្នុងនោះ មេដឹកនាំវៀតណាមបានស្នើធ្វើការចរចាថែមទៀត ដើម្បីធ្វើឲ្យមានប្រក្រតីភាពនូវទំនាក់ទំនងផ្សេងៗ ។ សំណើនេះ បានធ្វើជញ្ជីងផ្អៀងមកខាងគាត់ ហើយលោក ខាធ័រ បានយល់ព្រមដោយសប្បាយរីករាយយ៉ាងខ្លាំងក្នុងការជួបគ្នាមួយនៅទីក្រុងប៉ារីសនៅខែឧសភា គឺមិនដល់បួនខែផង ក្រោយការចូលកាន់មុខតំណែងជាផ្លូវការរបស់គាត់ ។ ក្រុមចរចារបស់ប្រទេសទាំងពីរ បានរៀបចំតាក់តែងយ៉ាងយូរ នូវអ្វីដែលនឹងទៅជាសេចក្ដីសម្រេចផ្ដាច់ព្រ័ត្រ ។ តាមការពិត លោក ខាធ័រ បានអះអាងពីវិរកម្មរបស់វៀតណាមថា ជាការបកស្រាយមួយដែលគាត់ចង់បាន ហើយបានឲ្យដំណឹងដល់សារពត៌មាន និងមតិសាធារណៈថា ទំនាក់ទំនងជាមួយប្រទេសវៀតណាមនឹងអាចមានភាពប្រសើរជាងមុន ។

សំណើទូទៅមួយរបស់អ្នកនៅក្រុងវ៉ាស៊ីនតោន បានផ្ដាំផ្ញើរដ្ឋាភិបាលថ្មីឲ្យប្រុងប្រយ័ត្នមែនទែននៅឆ្នាំដំបូង ដើម្បីនឹងទុកឲ្យពួកអ្នកបោះឆ្នោតនូវពេលវេលាគ្រប់គ្រាន់មួយ ដើម្បីបំភ្លេចបរាជ័យដែលកើតមានជាយថាហេតុមុនការបោះឆ្នោតនៅពេលខាងមុខឆាប់ៗ ។ ការធ្វើឲ្យមានទំនាក់ទំនងផ្សេងៗមានប្រក្រតីភាពជាមួយប្រទេសវៀតណាម ដែលជាសត្រូវកាលពីមុនអាចធ្វើឲ្យកើតមានប្រតិឃាតយ៉ាងសម្បើមនៅសហរដ្ឋអាមេរិក ហើយលោក ខាធ័រ បានវៀសវៃ ធ្វើអ្វីមួយភ្លាមមុនពេលដែលគូប្រឆាំងទាំងឡាយរបស់គាត់ អាចរាំងខ្ទប់គំនិតផ្ដួចផ្ដើមរបស់គាត់ ។

ប្រធានាធិបតីអាមេរិកាំងបានបង្ហាញគំនិតខ្លួនថា គាត់ពុំមានបញ្ហានៅអាមេរិកទេ ប៉ុន្តែគឺនៅក្រុងហាណូយ ហើយការចរចានៅទីក្រុងប៉ារីសលេចឡើងឲ្យឃើញថា ជាភាន់ច្រឡំធំមួយ ក្នុងចំណោមការភាន់ច្រឡំធំៗរបស់ប្រទេសវៀតណាម-ជាការភាន់ច្រឡំមួយដែលមានផលប្រកបដោយក្ដីវិនាស ព្រោះតែសង្គ្រាមដែលផ្ទុះឡើងជាមួយប្រទេសកម្ពុជានៅឆ្នាំបន្ទាប់ ។

អ្នកចរចារបស់លោក ខាធ័រ នៅទីក្រុងប៉ារីស គឺលោក រីឆាដហូលប្រ៊ុក ជាអនុរដ្ឋលេខាធិការទទួលបន្ទុកកិច្ចការអាស៊ីខាងកើត និងប៉ាស៊ីហ្វិក ។ ក្នុងអាយុសាមសិបប្រាំឆ្នាំ គាត់ធ្លាប់បានធ្វើជាអ្នកការទូតនៅប្រទេសវៀតណាម និងមានឈ្មោះជាអ្នកនៅក្នុងការឧបត្ថម្ភគាំពាររបស់ វ៉ាន់ស៍ រដ្ឋមន្ត្រីក្រសួងការបរទេស ។ ហូលប្រ៊ុក ប្រាថ្នាឈានឲ្យដល់កិច្ចព្រមព្រៀងមួយជាមួយប្រទេសវៀតណាម ពីព្រោះ វ៉ាន់ស៍ វាយតម្លៃថា គឺជារឿងចាំបាច់ ដើម្បីធានាភាពសុខសាន្ត និងស្ថិរភាពក្នុងភូមិភាគអាស៊ីអាគ្នេយ៍ ។ ចំពោះការធ្វើឲ្យមានប្រក្រតីភាព គឺពុំមានការ

សន្យាខាងផ្លូវចិត្ត ដែលលោក ខាធ័រ សំដែងឲ្យដឹងនេះទេ នៅពេលដែលគាត់និយាយអំពីការផ្សះមុខរបួសសង្គ្រាមនោះ[១៧] ។

វ៉ាន់ស៍ ប្រាថ្នាចង់ឲ្យលោក ខាធ័រ ទៅជាប្រធានាធិបតីម្នាក់ដែលនិយមសន្តិភាព ហើយតួនាទីរបស់ ហូលប្រ៊ូក ស្ថិតនៅត្រង់បញ្ចៀសការគំរាមកំហែងទាំងអស់ ដែលពួកវៀតណាមអាចនឹងសង្កត់មកលើសន្តិភាពនេះ ។ រដ្ឋមន្ត្រីការបរទេសអាមេរិកាំង បានវាយតម្លៃថា កាលណាគេបន្តចាត់ទុកប្រទេសវៀតណាមជាប្រទេសក្រីក្រគ្មានអ្នកណារាប់រកកាន់តែច្រើនឡើងៗ មុខរបួសចាស់ៗមុខជានឹងឆ្លងមេរោគ និងបណ្តាលឲ្យមានបញ្ហាថ្មីៗកាន់តែច្រើនកាលនោះដែរ ថែមទាំងមានសង្គ្រាមជាថ្មីទៀតផង ។

ហូលប្រ៊ូក បានទៅដល់ទីក្រុងប៉ារីសនៅខែឧសភា ឆ្នាំ១៩៧៧ ដោយមានអំណាចដ៏ដាក់លាក់ក្នុងការសម្រេចកិច្ចព្រមព្រៀងជាមួយពួកវៀតណាមថែមទៀត ។ គាត់មានដៃគូចរចាវៀតណាមម្នាក់គឺ ផាន់ហៀន ជាអនុមន្ត្រីការបរទេស ដែលធ្លាប់ចរចាជាមួយ វូដខូក កាលពីពីរខែមុន ។ អ្នកចរចាអាមេរិកស្គាល់ ផាន់ហៀនច្បាស់ ដែលគាត់ធ្លាប់បានជួបក្នុងឱកាសនៃការប្រជុំចរចាពីមុននៅទីក្រុងប៉ារីស នៅពេលដែលអ្នកទាំងពីរជាឧបការីវ័យក្មេងក្នុងការចរចានៅឆ្នាំ១៩៦៨ ។ ហូលប្រ៊ូក បានត្រូវធ្វើឲ្យសប្បាយរីករាយខ្លាំង ដែលមានគូប្រឆាំងធ្លាប់ស្គាល់ម្នាក់ ។ គាត់គ្មានដឹងថា ផាន់ហៀន ដែលធ្លាប់បញ្ជូនដោយក្រុងហាណូយឲ្យមកចរចា ពុំមែនធ្វើឲ្យសម្រេចបានកិច្ចព្រមព្រៀងមួយទេ ប៉ុន្តែ ដើម្បីធ្វើឲ្យទទួលបាននូវអ្វីដែលពួកកុម្មុយនិស្តវៀតណាមនឹងចាត់ទុកដូចជាដំណោះស្រាយប្រកបដោយកិត្តិយសមួយ ដើម្បីទាញយកលុយ ៣,២៥កោដិដុល្លារ ដែលសន្យាឲ្យដោយលោក និចសុន ។

ការជួបទាក់ទងគ្នាដំបូងៗ មានលក្ខណៈរាក់ទាក់ផុសចេញពីដួងចិត្ត ហើយការពិភាក្សាប្រាកដប្រជាបានចាប់ផ្តើមនៅសម័យប្រជុំលើកទីពីរ ។ ហូលប្រ៊ូក បានសន្និដ្ឋានដោយឡែកនូវកិច្ចព្រមព្រៀងដែលមានតែក្នុងគំនិតដោយហេតុថា លោក ខាធ័រ បានអនុញ្ញាតឲ្យគាត់ស្នើប្រទេសវៀតណាម ដើម្បីធ្វើឲ្យទំនាក់ទំនងផ្សេងៗមានប្រក្រតីភាព ដោយគ្មានលក្ខខណ្ឌជាមុន ។ ការសន្យារបស់វៀតណាម ក្នុងការបង្កើតការិយាល័យមួយសម្រាប់កិច្ចការទាហានបាត់ខ្លួនក្នុងការប្រយុទ្ធ គឺគ្រប់គ្រាន់ធ្វើឲ្យប្រធានាធិបតី ខាធ័រ លែងដាក់បញ្ហាទាហានអាមេរិកាំងដែលបាត់ខ្លួនក្នុងការប្រយុទ្ធ សម្រាប់ការចរចាទៀតហើយ ។ ឯកសារទាំងអស់ត្រូវបានបកប្រែជាភាសាវៀតណាម អមទៅដោយផែនទីរបស់វៀតណាមជាច្រើន ហើយបញ្ជូលទៅប្រទេសវៀតណាម ដូចដែលក្រុង-ហាណូយធ្លាប់បានស្នើគាត់ ។ ជាសាធារណៈ លោក ខាធ័រ បានតម្លើងវីរកម្មរបស់ក្រុងហាណូយក្នុងការបន្ធូរបន្ថយផ្សេងៗ ដើម្បីសម្របសម្រួលគ្នា ។ ជាថ្នូរទៅវិញ លោកប្រធានាធិបតី បានផ្ដុកផ្ដាក់ឲ្យលោក ហូលប្រ៊ូកប្រកាសថា សហរដ្ឋអាមេរិកមានបំណងយល់ព្រមចំពោះការសុំចូលជាសមាជិកអង្គការសហប្រជាជាតិរបស់ប្រទេសវៀតណាម ទោះបីជាលទ្ធផលសម្រេចនៃការប្រជុំចរចាមានលក្ខណៈយ៉ាងណាក៏ដោយ ។

ហ្វូលប្រ៊ិក យល់ឃើញការស្នើដ៏គួរឲ្យទាក់ចិត្តនេះថា លោកប្រធានាធិបតី បានបោះបង់អ្វីៗដែលមានខាង ដើមទាំងអស់ ហើយផ្ទុយទៅវិញ បានចាប់ផ្ដើមធ្វើការអំពាវនាវដោយផ្ទាល់មួយ ។ ហ្វូលប្រ៊ិក បានបន្ទន់ខ្លួនពីលើ តុចរចា ហើយនិយាយថា ៖ «យើងអាចចេញពីសាលប្រជុំនៅពេលរសៀលនេះ ដើម្បីប្រកាសជាសាធារណៈពី ការធ្វើឲ្យមានប្រក្រតីភាពបានទេ? សហរដ្ឋអាមេរិក ពុំមានដាក់លក្ខខណ្ឌណាមួយជាមុនទេ ។ បន្ទាប់ពីការបង្កើត ស្ថានទូតរៀងខ្លួន យើងនឹងដកការរាំងខ្ទប់ផ្នែកពាណិជ្ជកម្មចេញ[១៣] ។

ផាន់ហៀន បានឆ្លើយដោយត្រង់ៗថា ៖ «ទេ បើគ្មានជំនួយ គឺអ្វីៗមិនអាចប្រព្រឹត្តទៅបានទេ» ។

ភាពស្ងៀមស្ងាត់បានកើតមានឡើង ។ លោក ខេនណេតឃ្វីន សមាជិកអ្នកការទូតដែលចេះនិយាយភាសា វៀតណាមយ៉ាងស្ទាត់ និងធ្លាប់អមដំណើរជាមួយគណៈបេសកកម្ម វូដខូក ចូលរួមក្នុងការប្រជុំ បានរំឭកដោយ ច្បាស់លាស់ពីពេលនោះថា ៖ «ខ្ញុំដឹងខ្លួនថា គ្មានអ្វីផ្លាស់ប្ដូរទាំងអស់ ។ ពួកវៀតណាមពិតជា«បំបែក» ចេញពីគ្នានូវ បញ្ហាផ្សេងៗជាថ្នូរនឹង វូដខូក មែន ប៉ុន្តែ ពួកគេនៅបន្តទាមទារជំនួយមួយដដែល ។ ខ្ញុំគិតថា វាគួរឲ្យសោកសៅ ណាស់ ដែលពួកវៀតណាមមិនឆក់យកឱកាសនេះ ហើយខ្ញុំនឹកក្នុងចិត្តទៀតថា ម្ដងនេះ ពួកគេនឹងពុំអាចទម្លាក់ការ ទទួលខុសត្រូវមកលើយើងបានទេ[១៤] ។

ហ្វូលប្រ៊ិក ពុំបានបដិសេធឡើយ ។ គាត់បានបញ្ចប់ការចរចាយ៉ាងរហ័ស ដោយគ្មានស្ដីតបទៅវិញសោះ ។ ប៉ុន្តែ បរាជ័យទាំងស្រុងកែលែងកើត មិនត្រូវឲ្យនៅក្នុងសាលប្រជុំដដែលទេ ។ ភ្លាមៗនោះ លោក ផាន់ហៀន បានចេញពីបន្ទប់ប្រជុំ ដើម្បីមកជួបពួកអ្នកកាសែតនៃសាពត៌មានអន្តរជាតិ ដែលយ៉ាងច្រើនរង់ចាំស្ដាប់សេចក្ដី ថ្លែងការណ៍ដ៏សំខាន់មួយ ហើយគាត់បានអានអត្ថបទមួយដែលលាតត្រដាងឲ្យដឹងល្អិតល្អន់នៃលិខិតសម្ងាត់របស់ លោក និចសុន ឆ្នាំ១៩៧៣ ដែលសន្យាផ្ដល់ជំនួយ ៣,២៥ កោដិដុល្លារ ។ នេះជាការសន្យាដែលត្រូវតែប្រកាន់ យក មុនប្រទេសវៀតណាមយល់ព្រមបង្កើតទំនាក់ទំនងការទូតពេញលេញជាមួយសហរដ្ឋអាមេរិក ។ ពុំមែនមាន តែមួយលើកទេ ដែល ផាន់ហៀន និយាយអំពីលិខិតនេះប្រាប់ ហ្វូលប្រ៊ិក ក្នុងរយៈពេលនៃការចរចាគ្នា ។

ដោយត្រូវធ្វើឲ្យខុសបំណងខ្លាំងដើម្បីបង្ហាញខ្លួននៅមុខអ្នកសារពត៌មាន ហ្វូលប្រ៊ិក បានចាត់ឲ្យអ្នកនាំពាក្យ ម្នាក់ប្រកាសយ៉ាងខ្លីថា សហរដ្ឋអាមេរិកមិនដាក់លក្ខខណ្ឌជាមុនក្នុងការធ្វើឲ្យមានប្រក្រតីភាពទេ ហើយថា ជាសញ្ញានៃសុច្ឆន្ទៈ សហរដ្ឋអាមេរិកនឹងដកឆ្នោតវេតូរបស់ខ្លួន ក្នុងការសុំចូលជាសមាជិកអង្គការសហប្រជាជាតិ របស់ប្រទេសវៀតណាមថែមទៀត ។ ក្រោយមកនៅក្នុងថ្ងៃនោះ ហ្វូលប្រ៊ិក បានទូរស័ព្ទទៅផាន់ហៀន ដោយបាន រំឭកគាត់ថា ប្រទេសវៀតណាមបានប្រព្រឹត្ត«ការភាន់ច្រឡំមួយយ៉ាងធំ» ហើយបានស្នើធ្វើការប្រជុំចរចាជាថ្មី ជាមួយសេចក្ដីសង្ឃឹមថា ពួកវៀតណាម នឹងផ្លាស់ប្ដូរយោបល់មិនខាន ។

គឺនៅពេលនោះហើយដែលសភាអាមេរិកាំងចូលអន្តរាគមន៍ ។ នៅពេលដែលសេចក្ដីថ្លែងការណ៍ទាំង ឡាយរបស់ ផាន់ហៀន លេចទៅដល់ទីក្រុងវ៉ាស៊ីនតោន រដ្ឋសភាបានអនុម័តច្បាប់មួយជាបន្ទាន់ ដោយហាមមន្ត្រី

ផ្លូវការអាមេរិកាំងទាំងអស់ មិនឲ្យដដែកពិភាក្សាពីជំនួយមួយសម្រាប់ប្រទេសវៀតណាមឡើយ ។ បណ្តាសមាជិកនៃអនុគណៈកម្មការពិសេសដែលរដ្ឋសភាបង្កើតឡើងសម្រាប់ពិនិត្យរឿងនេះ បានអញ្ជើញលោកគីស្ស៊ីងហ្គ័រ និងលោក និចសុន ជាថ្មីឲ្យមកបង្ហាញខ្លួននៅមុខអនុគណៈកម្មការ ដើម្បីផ្តល់នូវការបកស្រាយបំភ្លឺអំពីលិខិតសម្ងាត់នេះ ។ ក្រសួងការបរទេសបានផ្សាយអត្ថបទទាំងស្រុងនៃលិខិតនេះឲ្យដឹងជាសាធារណៈ និងសេចក្តីបន្ថែមរបស់លិខិតដែលសន្យាពីទឹកលុយ ៣,២៥ កោដដុល្លារមែន ប៉ុន្តែ ក្រោមលក្ខខណ្ឌត្រូវមានការយល់ព្រមពីសភាសិន ។ នេះជាការសន្យាមួយ ដែលលោក និចសុន មិនត្រូវធ្វើដោយមិនឲ្យសភាដឹងទេ ហើយដែលលេចចេញឡើងជាទិដ្ឋភាពមួយ ក្នុងចំណោមទិដ្ឋភាពដែលនាំមកនូវគ្រោះថ្នាក់បំផុតដល់ «សន្តិភាពប្រកបដោយកិត្តិយស» ដែលផ្ទេរមកឲ្យដោយលោក និចសុន និងលោក គីស្ស៊ីងហ្គ័រ ។

ការចាប់ផ្តើមដំបូងៗដែលចង់បានដោយលោក ខាធ័រ បានដួលរលំ ។ ពួកវៀតណាមមិនត្រឹមតែប្រានចោលការស្នើរបស់គាត់ប៉ុណ្ណោះទេ ប៉ុន្តែ ដោយលាតត្រដាងជាចំហ និងធ្វើឲ្យផ្អកផ្អើលខ្លាំងនូវខ្លឹមសារនៃលិខិតសម្ងាត់ ពួកគេបានស្កាត់មុនប្រធានាធិបតី លែងឲ្យធ្វើអ្វីកើត ។ ពួកវៀតណាម ពុំបានប្រកាន់យកវិធានការផ្សេងៗ នៅពេលមានការផ្លាស់ប្តូរនយោបាយដ៏សំខាន់ ដែលកើតមានដោយចៃដន្យនៅសហរដ្ឋអាមេរិក តាំងពីឆ្នាំ១៩៧៥មក ។ សភាលែងជាអង្គការសេរីមួយដែលប្រយុទ្ធទល់នឹងប្រធានាធិបតីអភិរក្សនិយមទៀតហើយ ៖ តាំងពីការបោះឆ្នោតរើសលោក ខាធ័រ ជាប្រធានាធិបតីនៅឆ្នាំ១៩៧៦ គឺវាជួយគ្នា ។ ទីពីរ ការស្នើធ្វើកិច្ចចរចាដែលនិយាយឲ្យសាធារណៈមតិអាមេរិកាំងដឹងឮ តាមរយៈការប្រាប់ឲ្យដឹងរឿងអាថ៌កំបាំងផ្សេងៗ ដូចដែលលោក ផាន់ហៀន និយាយនៅក្រុងប៉ារីស គឺមានប្រសិទ្ធភាពក្នុងរយៈពេលសង្គ្រាម នៅពេលដែលជីវិតរបស់ជនជាតិអាមេរិកាំងកំពុងស្ថិតក្នុងគ្រោះថ្នាក់ ហើយដែលយុវជនរាប់ពាន់ប្រាថ្នាឲ្យការប្រយុទ្ធផុតរលត់ មុនពេលដែលពួកគេត្រូវបញ្ចូលទៅក្នុងជួរកងទ័ព ។ ប៉ុន្តែ ក្រុមអ្នកស្តាប់នេះ បានរលាយបាត់នៅទីបំផុតនៃសង្គ្រាមព្រមគ្នានឹងចលនាសន្តិភាពនិយមដ៏សំខាន់ ដែលធ្លាប់ធ្វើឲ្យគេដឹងពីជម្រៅនៃលិខិតផង ។ ប្រទេសវៀតណាម លែងជាមូលហេតុមួយដែលត្រូវការពារទៀតហើយ ប៉ុន្តែ ជាអនុស្សាវរីយ៍ឈឺចាប់មួយ ។ ហើយបន្ទាប់ពីរឿងអាស្រូវវ៉ធឺហ្គេត ពួកអាមេរិកាំងមិនសូវទោរទន់ទៅរកការទទួលខុសត្រូវតាមការសន្យាមួយដែលប្រកាន់យកដោយមនុស្សម្នាក់ ដែលបាត់បង់អំណាចឡើយ ។

ការចរចានៅដំណាក់កាលបន្ទាប់ ត្រូវបានកំណត់នៅខែមិថុនា ដែលធ្វើឲ្យក្រុងហាណូយមានពេលពិចារណាពីជំហររបស់ខ្លួនឡើងវិញ ។ សម្រាប់មនុស្សសាមញ្ញម្នាក់យល់ថា ពួកវៀតណាមហាក់ដូចជាបាត់បង់ការប៉ិនប្រសប់របស់គេខាងការឃោសនា ។ ពួកគេមានលក្ខណៈដូចពួកកុម្មុយនិស្តដែលប្រកាន់លទ្ធិខាប់ខ្ជាំងឡើងៗ និងមិនសូវទន់ភ្លន់ទេ ក្នុងបណ្តាឆ្នាំនៃសង្គ្រាម ហើយមានសមត្ថភាពយល់ពីរបៀបកាច់តម្រង់សហរដ្ឋអាមេរិក ឬមតិសាធារណៈអាមេរិកាំង តាមមធ្យោបាយបែបណាៗ ក៏កាន់តែខ្សោយទៅៗដែរ ។ ការផ្លាស់ប្តូរទង្វើតាមដែលគេ

មើលឃើញនេះ គឺមានលក្ខណៈបន្ទំដោយផ្នែក ហើយបើគិតឲ្យមែនទែនទៅ ដោយសារតែពួកកុម្មុយនិស្តភាគខាងជើង បានចូលជំនួសពួកសកម្មជនភាគខាងត្បូង ដែលធ្លាប់ធ្វើបានសម្រេច"ជោគជ័យ"យ៉ាងសម្បើមក្នុងការឃោសនាមុនៗ ។

ក្នុងឱកាសនៃការចរចា"ទឹកទី២"នេះ ហូលប្រ៊ូក បានខំប្រឹងលាតត្រដាងយ៉ាងជាក់លាក់ពីស្ថានភាពដែលលោក ខាធ័រ ត្រូវប្រឈមមុខនៅទីក្រុងវ៉ាស៊ីនតោន និងការផ្លាស់ប្តូរទិដ្ឋភាពនយោបាយរួមរបស់អាមេរិកាំង ។ ចលនាប្រឆាំងនឹងសង្គ្រាមលែងមានសកម្មភាពទៅហើយ ។ គាត់បានរំឭកពួកវៀតណាមថា ជប់ប្រាំពីរឆ្នាំបានកន្លងផុតទៅមុនសហរដ្ឋអាមេរិកទទួលស្គាល់សហភាពសូវៀត ហើយថា អាមេរិកត្រូវតែរៀបចំឲ្យមានទំនាក់ទំនងធម្មតាជាមួយសាធារណរដ្ឋប្រជាមានិតចិនថែមទៀត ។ គាត់បានឲ្យពួកវៀតណាមសង្កេតថា មួយផ្នែកធំនៅសហរដ្ឋអាមេរិកនៅតែចាត់ទុកក្រុងហាណូយជាសត្រូវមួយជានិច្ច ។

ក្នុងរយៈពេលនៃការសម្រាកហូបកាហ្វេ ផាន់ហៀន បានប្រកាសថា ប្រទេសវៀតណាមអាចនឹងព្រមទទួលការស្នើរបស់ ហូលប្រ៊ូក បើសិនសហរដ្ឋអាមេរិកសន្យាបង់ប្រាក់ ៣,២៥ កោដិដុល្លារជាសម្ងាត់ ដោយមិនបាច់ទទួលស្គាល់រឿងនេះជាសាធារណៈឡើយ ។

អ្នកការទូតអាមេរិកាំងបានឆ្លើយថា ការសន្យាជាសម្ងាត់បែបនេះ គឺមិនអាចធ្វើបានទេ ប៉ុន្តែ ផាន់ហៀន មិនបានបង្ហាញគាត់នូវឯកសាររៀបរាប់ល្អិតល្អន់មួយ ស្តីពីបែបផែនដែលប្រាក់ដុល្លារទាំងនេះ នឹងត្រូវប្រើប្រាស់យ៉ាងណាៗទេ ។ អ្នកចរចាវៀតណាមបានបន្ថែមថា គាត់មានការណែនាំក្នុងការទទួលលុយនេះ-ទាំងជាសធារណៈ ឬជាសម្ងាត់ ។ ការប្រជុំដើម្បីចរចាត្រូវចប់ ។

លោក ខាធ័រ នៅប្រកាន់ពាក្យសម្តីគាត់ ហើយនៅសរទរដូវ សហរដ្ឋអាមេរិក បានបោះឆ្នោតឲ្យប្រទេសវៀតណាមចូលក្នុងអង្គការសហប្រជាជាតិ ។ ការសាកល្បងធ្វើការផ្សះផ្សាយ៉ាងស្មោះរបស់គាត់ ថ្វីបើធ្វើដោយគ្មានពិចារណាក៏ដោយ បានប៉ះទង្គិចនឹងការចចេស ដែលពួកវៀតណាមតម្រូវឲ្យសហរដ្ឋអាមេរិកជួសជុលការខូចខាតដោយសារសង្គ្រាម ទោះបីជាពាក្យពេចន៍នេះ មិនធ្លាប់ដែលប្រើប្រាស់សោះក៏ដោយ ។ ពួកវៀតណាមបាន បង្ហាញខ្លួនឡើងជាអ្នករងគ្រោះពីរឿងកន្លងយូរមកហើយមួយ ដូចពួកអាមេរិកាំងដែរ ។ ពួកគេជឿថា មតិសាធារណៈអាមេរិកាំង ធ្លាប់បានបន្ទោសការធ្វើសង្គ្រាមសម្រាប់មូលហេតុផ្សេងៗខាងសីលធម៌ ហើយអបអរសរសើរការ សងសំណងសង្គ្រាម ដោយមនោសញ្ចេតនាជាអ្នកមានពិរុទ្ធភាព ។ វៀតណាមនៅតែយល់ថា បើសិនយោបល់តែមួយស្តីពីសង្គ្រាម ធ្វើឲ្យមានភាពឯកច្ឆ័ន្ទក្នុងចំណោមពួកអាមេរិកាំង គឺយោបល់ថា សហរដ្ឋមិនដែលចូលប្រឡូកក្នុងសង្គ្រាមដ៏បង្ហូរឈាមមួយ ដែលនាំឲ្យចំណាយលុយច្រើន និងជំរុញទៅរកបរាជ័យដូច្នេះទេ ។

ដូចដែលគេបានរំពឹងទុក ពួកវៀតណាមដែលមានជ័យជម្នះ បានខាំក្រាញនឹងទស្សនៈដែលកាន់ប្រឡំរបស់គេដដែល និងមិនកែប្រែឥរិយាបថរបស់គេចំពោះសហរដ្ឋអាមេរិកទេ មុនដែលព្រឹត្តិការណ៍ផ្សេងៗកើតមាន

ឡើងដោយចៃដន្យនៅក្នុងប្រទេសផ្ទាល់របស់ខ្លួន ដែលបង្ខំឲ្យពួកគេវាយតម្លៃជាថ្មីនូវអ្វីដែលមានលក្ខណៈ ចាំបាច់ពិតប្រាកដរបស់គេ ៈ លុយ ឬទំនាក់ទំនងល្អជាមួយក្រុងវ៉ាស៊ីតោន ។ ប៉ុន្តែលក្ខខណ្ឌប្រកបដោយសុច្ចន្ទៈរបស់ប្រធានាធិបតី ខាធ័រ នៅពេលនោះបានចាប់ផ្តើមថមថយចុះយ៉ាងខ្លាំង ។ ពួកវៀតណាមបានធ្វើឲ្យលោកប្រធានាធិបតីបាក់មុខ ដោយប្រានចោលការស្នើរបស់គាត់ ។ នយោបាយរបស់ វ៉ាន់ស៍ និងហូលប្រ៊ុក បានត្រូវបរាជ័យ ហើយឥឡូវនេះ លោក ខាធ័រ បានស្តាប់ដោយយកចិត្តទុកដាក់បំផុត នូវយោបល់លោក ប៊ីកញូប្រ៊ីហ្សីនស្គី ជាទីប្រឹក្សាសន្តិសុខជាតិរបស់គាត់វិញម្តង ដែលអួតពីនយោបាយខុសគ្នាមួយ ដែលមានលក្ខណៈអនុគ្រោះ ជាងចំពោះអនាគត់សត្រូវ គឺប្រទេសវៀតណាម និងប្រទេសចិន ។

នៅឆ្នាំ១៩៧៧ សហរដ្ឋអាមេរិក បានបំបាត់នូវភាពនៅស្ងៀមស្ងាត់របស់ខ្លួនស្តីពីប្រទេសកម្ពុជា ៈ ពុំមែនដោយការអំពាវនាវនៃរដ្ឋាភិបាលរបស់ខ្លួនទេ ប៉ុន្តែ ដោយសភាអាមេរិកាំង ។ អ្នកតំណាងរាស្ត្រ ស្តេហ្វិន សូឡា *(Stephen Solarz)* ខាងគណបក្សប្រជាធិបតេយ្យប្រចាំទីក្រុងញូវយ៉ក បានចាប់ផ្តើមធ្វើការអង្កេតរកការពិតសំខាន់បំផុតជាផ្លូវការ អំពីអំពើសាហាវយង់ឃ្នងរបស់ពួកខ្មែរក្រហម ។ សូឡា បេក្ខជនប្រឆាំងនឹងសង្គ្រាម ដែលត្រូវជ្រើសតាំងនៅឆ្នាំ១៩៧៤ បានរួមចំណែកវាំងខ្ទប់ឥណទានថ្មីៗរបស់អាមេរិកាំង មិនផ្តល់ទៅឲ្យរបបក្រុងព្រៃនគរ និងក្រុងភ្នំពេញឡើយ ។ ប៉ុន្តែ ប្លែកអំពីអ្នកនយោបាយភាគច្រើនដទៃទៀត គាត់នៅតែយកចិត្តទុកដាក់ចំពោះភូមិភាគនេះជាប់ជានិច្ច បន្ទាប់ពីពួកកុម្មុយនិស្តបានទទួលជ័យជម្នះ ។

គាត់បានដឹងពីរឿងរ៉ាវផ្សេងៗតាមរយៈចម្លើយជាសាក្សីដំបូងស្តីពីពួកអ្នកភៀសខ្លួនកម្ពុជា នៅពេលដែលគាត់ធ្វើជាគណៈកម្មាធិការទទួលកិច្ចការទំនាក់ទំនងអន្តរជាតិ របស់រដ្ឋសភាអាមេរិកាំង[១៥] ។ នៅចុងឆ្នាំ១៩៧៦ គាត់បានដឹកនាំ គណៈប្រតិភូមួយក្រុមធ្វើដំណើរមកកាន់ទីក្រុងបាងកក ហើយបានឮគេនិយាយប្រាប់ពីរឿងរ៉ាវរបស់ពួកអ្នកភៀសខ្លួន ខ្មែរទៀតផង ។ ពត៌មាននេះបានត្រូវផ្តល់ឲ្យគាត់ដឹងដោយលោក ស្ហាលថ្វៃ នីង *(Charles Twining)* ជាអ្នកជំនាញការខាងបញ្ហាកម្ពុជាប្រចាំស្ថានទូតអាមេរិកាំងនៅក្រុងបាងកក ។ អ្វីដែលធ្វើឲ្យសមាជិកសភារូបនេះ មានការយកចិត្តទុកដាក់ជាពិសេសនោះ គឺការជម្លៀសប្រជាជនជាលើកទីពីរ ដែលក្នុងរយៈពេលនោះ “ពួកអ្នកថ្មី” បានត្រូវគេបញ្ជូនពីភូមិភាគនិរតីទៅភូមិភាគពាយ័ព្យ ។ សម្រាប់គាត់ រឿងនេះ បានបង្ហាញឲ្យឃើញគួឲ្យភ័យរន្ធត់ស្រដៀងគ្នាមួយ ជាមួយនឹងការជម្លៀសជនជាតិជីហ្វទាំងហ្វូងៗ នៅក្នុងអំឡុងពេលដែលគេយកមនុស្សទៅសម្លាប់ដែរ ។ មណ្ឌលបោះឆ្នោតញូវយ៉ក របស់ សូឡា មានប្រជាជនជីហ្វ ដែលរត់រួចពីជំរំទាំងនោះ រស់នៅយ៉ាងច្រើនជាងមណ្ឌលបោះឆ្នោតរបស់អាមេរិកាំងឯទៀតៗ ហើយសមាជិកសភារូបនេះ បានជួបប្រជុំគ្នាដោះស្រាយពីបញ្ហាពួកអ្នកភៀសខ្លួនកម្ពុជាម្តង ។

នៅក្រុងវ៉ាស៊ីនតោន សូឡា បានបើកទ្វារការិយាល័យរបស់គាត់សម្រាប់ប្រជាជនកម្ពុជាទាំងឡាយ ដែលកំពុងស្វែងរកអ្នកនយោបាយនានា ដែលចាត់ចែងលើកយកបញ្ហាស្ថានការណ៍នៅកម្ពុជាទៅពិភាក្សាគ្នា ។ ក្រោយ

ការធ្វើដំណើររបស់គាត់ទៅទីក្រុងបាងកក គាត់មានអារម្មណ៍ថា សភាអាមេរិកាំង ត្រូវតែបើកសម័យប្រជុំជាសាធារណៈស្តីពីបញ្ហានេះ ។ គាត់យល់ថា សហរដ្ឋអាមេរិកប្រហែលជានឹងគ្មានអានុភាពបញ្ឈប់អំពើសាហាវយង់ឃ្នងទាំងនោះទេ ប៉ុន្តែ យ៉ាងហោចណាស់ រដ្ឋាភិបាលអាចថ្កោលទោសរបបខ្មែរក្រហមបាន ។ ម្យ៉ាងទៀត គាត់សង្ឃឹមទទួលបានការជួយគាំទ្រមួយយ៉ាងគ្រប់គ្រាន់ ដើម្បីផ្លាស់ប្តូរការធ្វើច្បាប់ និងអនុញ្ញាតឲ្យប្រជាជនកម្ពុជា ដែលរស់នៅក្នុងជំរំនានាតាមព្រំដែនថៃ អាចធ្វើដំណើរមកកាន់សហរដ្ឋអាមេរិក ដោយត្រង់ ។ លោក សូឡា បារម្ភថា ក្នុងទីបំផុត មនុស្សទាំងនេះនឹងមិនត្រូវគេរករឿងដូចពួកជីហ្វនៅអឺរ៉ុបទេ ។

សេចក្តីយកចិត្តទុកដាក់ដំបូងៗ បានកើតមាននៅខែឧសភា ឆ្នាំ១៩៧៧ ។ វាបានទាក់ទាញការយកចិត្តទុកដាក់ពីសាធារណជនជាច្រើនមកលើប្រទេសកម្ពុជា ហើយជំរុញឲ្យក្រសួងការបរទេសអាមេរិកាំង ធ្វើសេចក្តីថ្លែងការណ៍ផ្សេងៗ ដោយម៉ឺងមាត់បំផុត ស្តីពីអំពើសាហាវយង់ឃ្នង ដែលប្រព្រឹត្តឡើងនៅក្នុងប្រទេសនេះ ។ លោកប្រធានាធិបតី ខាទ័រ បានបង្កើតគណៈកម្មាធិការសិទ្ធិមនុស្សមួយក្នុងផ្ទៃក្រសួងការបរទេស ប៉ុន្តែ អង្គការថ្មីនេះ ពុំដែលចេញផ្សាយរបាយការណ៍ណាមួយ ស្តីពីបទឧក្រិដ្ឋផ្សេងៗរបស់ពួកខ្មែរក្រហមឡើយ ។ សមាជិកទាំងឡាយរបស់ខ្លួនបានទាញហេតុផលថា មុខនាទីរបស់គេ គឺធ្វើអង្កេតតែលើប្រទេសណាដែលកំពុងទទួលជំនួយរបស់សហរដ្ឋអាមេរិកប៉ុណ្ណោះ ហើយថា ប្រទេសកម្ពុជាពុំមានចូលក្នុងប្រភេទនេះទេ ។ ហូលប្រ៊ូក បានចូលរួមក្នុងរឿងនេះ ហើយដោយសារការប្រឹងប្រែងរបស់ពួកអ្នកជំនាញការខាងបញ្ហាកម្ពុជារបស់គាត់ រដ្ឋាភិបាលបានថ្លែងពីបំណងខ្លួនប្រឆាំងនឹងការរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្តឡើងដោយរបបក្រុងភ្នំពេញ ។

ក្នុងចន្លោះពេលនោះ ព្រឹទ្ធសមាជិក រ៉ូបឺត ដូល (Robert Dole) ខាងគណបក្សសាធារណរដ្ឋប្រចាំរដ្ឋខេនសាស (Kansas) បានចាប់ផ្តើមយកចិត្តទុកដាក់ចំពោះស្ថានភាពរបស់ពួកអ្នកភៀសខ្លួនកម្ពុជា ។ ដោយធ្លាប់ឮចម្លើយជាសាក្សីនៃអ្នកភៀសខ្លួនខ្មែរម្នាក់ឈ្មោះ ឆាំង សុង គាត់បានសម្រេចចិត្តទៅចូលរួមក្នុងកិច្ចប្រឹងប្រែងផ្សេងៗរបស់អ្នកតំណាងរាស្ត្រ សូឡា ដែរ ក្នុងការផ្តួចផ្តើមគំនិតទ្វេភាគីមួយ ដើម្បីផ្លាស់ប្តូរការធ្វើច្បាប់ស្តីពីជនភៀសខ្លួន ហើយអនុញ្ញាតឲ្យជនជាតិកម្ពុជាដប់ប្រាំពាន់នាក់ ចូលទៅរស់នៅក្នុងសហរដ្ឋអាមេរិកក្នុងឋានៈជាក្រុម ដោយមិនចាំបាច់បំពេញសំណុំបែបបទផ្ទាល់ខ្លួនម្នាក់ៗ ដែលនាំឲ្យខាតបង់ពេលវេលាឡើយ ។

នៅដំណាច់ឆ្នាំ១៩៧៧ សហរដ្ឋអាមេរិក បានរួបរួមជាមួយប្រទេសដទៃទៀត ដើម្បីរៀបចំសំណុំឯកសារស្តីពីការរំលោភសិទ្ធិមនុស្សនៅកម្ពុជា ។ ឥណ្ឌូចិន ត្រឡប់មកស្ថិតនៅក្រោមការយកចិត្តទុកដាក់ពីសាធារណជនឡើងវិញ ។ ប្រទេសកម្ពុជា មានបញ្ហាសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរមួយ ប្រទេសវៀតណាម គឺមានបញ្ហាការទូតដ៏ចម្រូងចម្រាសមួយ ។ ការពន្យារពេលស្តីពី“ប្រទេសវៀតណាម” –សង្គ្រាមអាមេរិកាំងនៅឥណ្ឌូចិន– រកខុសត្រូវ បានក្លាយទៅជារឿងត្រូវជជែកវែកញែកគ្នា នៅពេលដែលរដ្ឋាភិបាលរបស់លោក ខាទ័រ ល្បងបញ្ឈប់ស្ថានការណ៍កំពុងប្រែប្រួលនៅភូមិភាគអាស៊ីអាគ្នេយ៍ ។

នៅពេលដែលជម្លោះព្រំដែនផ្ទុះឡើងនៅចុងឆ្នាំ១៩៧៧ ប៊ីកញ្ញូ ប្រ៊ីហ្សឹនស្គី *(Zbigniew Brzezinski)* បានចូលរួមក្នុងការពិភាក្សាខាងនយោបាយស្តីពីឥណ្ឌូចិននេះដែរ[១៦] ។ កាលពីមុន គាត់បានបង្ហាញឲ្យឃើញនូវការយកចិត្តទុកដាក់តិចតួចចំពោះប្រទេសវៀតណាម និងកម្ពុជា ដោយគាត់ខ្វាយខ្វល់តែបញ្ហាផ្សេងៗ ដែលគាត់វិនិច្ឆ័យថាជាបញ្ហាមានលក្ខណៈជាសាកល និងជ្រៅជ្រះជាងប៉ុណ្ណោះ ។ ប៉ុន្តែតាមគាត់យល់ ជម្លោះព្រំដែននេះ មានលក្ខណៈពិសេសៗ ជាការប្រឈមមុខមួយ រវាងមហាអំណាចផ្សេងៗ ។ ដូច គីស្ស៊ីងហ្គ័រ ជាបុព្វាធិការីសាធារណរដ្ឋនិយមរបស់គាត់ ប្រ៊ីហ្សឹនស្គី មានទំនោរចាត់ទុកជម្លោះផ្សេងៗ ក្នុងបរិបទទូលំទូលាយមួយ ហើយជាទូទៅដែលធ្វើឲ្យព្រួយបារម្ភបំផុត ដូចបណ្តាសហការីគាត់នៅក្រសួងការបរទេសដែរ ។ តាមប្រពៃណី ពួកអ្នកជំនាញការនៃក្រសួងនេះ បាននិយាយណែនាំឲ្យដាក់ជម្លោះទាំងឡាយក្នុងក្របខណ្ឌដដែលវិញ ។ ផ្ទុយទៅវិញ ប្រ៊ីហ្សឹនស្គី ដែលជាទីប្រឹក្សាម្នាក់របស់«មហាអំណាចធំៗ» បានទាញជម្លោះផ្សេងៗចេញពីបរិបទ មានព្រំដែនរបស់គេ ហើយប្រែក្លាយជម្លោះទាំងនោះ ទៅជាការប្រឈមមុខរវាងលោកខាងកើត- ខាងលិចវិញ ។

ក្នុងសេចក្តីថ្លែងការណ៍លើកដំបូងរបស់គាត់ស្តីពីជម្លោះព្រំដែន ប្រ៊ីហ្សឹនស្គី បានអះអាងថា សហភាពសូវៀត និងប្រទេសចិន បានប្រឈមមុខដាក់គ្នាតាមរយៈ«ម៉ូយ»របស់ខ្លួន ដែលគេដាក់នៅចន្លោះកណ្តាល ។ គាត់រំពុកថា នេះគឺជា«សង្គ្រាមតាមការប្រគល់សិទ្ធិ» លើកដំបូងរវាងប្រទេសកុម្មុយនិស្តនានា ។ ម៉្យាងវិញទៀត ទីប្រឹក្សានេះ យល់ឃើញថា ប្រទេសវៀតណាម ជាអ្នកឈ្លានពានគេតាមការញុះញង់របស់ពួកសូវៀត ។

សម្តីនេះ បានបណ្តាលឲ្យអ្នកជំនាញការជាច្រើននៃក្រសួងការបរទេសអាមេរិកាំង មានកំហឹងយ៉ាងខ្លាំងចំពោះ ប្រ៊ីហ្សឹនស្គី ដែលគាត់បានរៀបរាប់តាមតែចិត្តនឹកឃើញ ដោយគ្មានពត៌មានផ្សេងៗ ដើម្បីជាសំអាងដល់សម្តីបង្កូរឿងរបស់គាត់ឡើយ ។ តាមសេចក្តីរាយការណ៍របស់ពួកអ្នកជំនាញការគាត់ វ៉ាន់ស៍ និងហូលប្រ៊ុក ដឹងថាសង្គ្រាមនេះ មានមូលហេតុផ្សេងៗផ្អែកមនោគមវិជ្ជា ដែលមានភាពទាក់ទងគ្នាតិចឬច្រើនទៅនឹងសាច់រឿងនៃការវិវាទរវាងចិន-សូវៀតដែរ ប៉ុន្តែ ពួកគេនៅតែញាំងឲ្យជឿថា មុនអ្វីៗទាំងអស់ សង្គ្រាមមានប្រភពដើមរបស់វាក្នុងការប្រកួតប្រជែងផ្ទាល់រវាងប្រទេសវៀតណាម និងកម្ពុជា ។ ដោយផ្ទុយពី ប្រ៊ីហ្សឹនស្គី ពួកគេភ័យបារម្ភថា ប្រទេសទាំងពីរ មុខជាប្រទាញសហភាពសូវៀត និងប្រទេសចិន ឲ្យធ្លាក់ទៅក្នុងសង្គ្រាមកាន់តែធំធេងមួយ- និងមិនផ្ទុយមកវិញទេ ។

ដោយយកចិត្តទុកដាក់រារាំងអគ្គិភ័យកុំឲ្យរាលដាលទៅទៀត វ៉ាន់ស៍ បានជំរុញឲ្យ ប្រ៊ីហ្សឹនស្គី បដិសេធសេចក្តីថ្លែងការណ៍របស់គាត់ជាបន្ទាន់ ។ ទីប្រឹក្សារូបនេះ បានគោរពធ្វើតាម ប៉ុន្តែ មិនផ្លាប់ប្តូរទស្សនះរបស់គាត់ឡើយ គាត់នឹកបារម្ភថា ឧត្តមភាពរបស់វៀតណាមនៅឥណ្ឌូចិន មុខជាធ្វើឲ្យជំហររបស់អាមេរិកាំងក្នុងពិភពលោកចុះទន់ខ្សោយ និងថាប្រទេសវៀតណាម ជាសេះទីក្រុងត្រ័រ *(Troie)* [ជាសេះឈើយ៉ាងធំ ដែលពួកទាហានក្រិចបោះបង់ចោលនៅមុខទីក្រុងត្រ័រ ។ នៅពេលយប់ស្ងាត់ ទាហានដែលបង្កប់ខ្លួននៅក្នុងពោះសេះនោះ បានចុះចេញ

មកក្រៅដើម្បីវាយប្រហារសត្រូវរបស់ខ្លួន ។ យុទ្ធសាស្ត្រនេះ បានបើកឱកាសឲ្យពួកក្រិច វាយដណ្ដើមយកទីក្រុងត្រ័រ បាន-កំណត់ហេតុអ្នកបកប្រែ] នៃការវាតទីរបស់សូវៀតនៅអាស៊ីអាគ្នេយ៍ ។

ការមិនចុះសម្រុងតាំងពីដើមទីរវាងវ៉ាន់ស៍ និងប្រ៊ីហ្សីនស្គី បានប្រែក្លាយទៅជាជម្លោះពិតប្រាកដស្ដីពីនយោបាយរបស់អាមេរិកាំងនៅអាស៊ី ។ ជាអកុសល បញ្ហាស្ដីពីឥរិយាបថដែលត្រូវប្រកាន់យកនៅចំពោះមុខសង្គ្រាមខ្មែរ-វៀតណាមនោះ ត្រូវបានចាត់ទុកជារឿងបន្ទាប់បន្សំទៅវិញ ដោយសារកិត្យានុភាពរបស់មហាអំណាចមួយដែលចេះតែកើនឡើងៗ គឺប្រទេសចិន ។

ការវាលុកផ្នែកការទូតរបស់លោក ខាធ័រ នៅឆ្នាំ១៩៧៧ ដែលមានលក្ខណៈធ្វើឲ្យខុសបំណងជាច្រើនចំណុចជាពិសេស វាពុំមានលទ្ធផលស្ដីពីការកែលម្អទំនាក់ទំនងផ្សេងៗ ជាមួយប្រទេសចិនប្រសើរលើសមុនឡើយ ។ នៅខែសីហា វ៉ាន់ស៍ បានធ្វើដំណើរទៅក្រុងប៉េកាំង ។ មុនការធ្វើដំណើររបស់គាត់ គាត់បានត្រៀមរួចជាស្រេច ដើម្បីធ្វើសេចក្ដីថ្លែងការណ៍ដ៏សំខាន់មួយ ដើម្បីបន្ថយការបារម្ភផ្សេងៗរបស់សូវៀតថា ការព្រមព្រៀងមួយរវាងចិន-អាមេរិកាំង ពុំមែនសំដៅប្រឆាំងនឹងសហភាពសូវៀតទេ[១៧] ។ លោករដ្ឋមន្ត្រីការបរទេស វ៉ាន់ស៍ បានបញ្ជាក់អះអាងថា ការធ្វើឲ្យទំនាក់ទំនងផ្សេងៗជាមួយក្រុងប៉េកាំង ប្រសើរជាងមុននឹងពុំគំរាមកំហែងប្រទេសណាមួយទេ ហើយបម្រើតែផលប្រយោជន៍សន្តិភាពប៉ុណ្ណោះ ។ ក្រុងមូស្គូ បានត្រូវធ្វើឲ្យពេញចិត្ត ប៉ុន្តែ នៅពេលទៅដល់ប្រទេសចិន វ៉ាន់ស៍ បានរកឃើញថា ពួកចិនសុទ្ធតែត្រូវធ្វើឲ្យខកចិត្ត ។ "បនប្អូននាក់" ដែលជាស្នងតំណែងបន្ត បានទទួលជាដំណែលនូវជំងឺមិនទុកចិត្តរបស់ ម៉ៅ ចំពោះចេតនាផ្សេងៗរបស់សូវៀត ។ ពួកគេពិនិត្យឃើញក្នុងរយៈពេលក្រោយសង្គ្រាមនូវអត្ថប្រយោជន៍មួយ សម្រាប់ពួកសូវៀតនៅអាស៊ី ហើយបានប្រកាសជាសាធារណៈ ពីរឿងនេះ នៅពេលដែលពួកគេស្នើឲ្យពួកអាមេរិកាំងរក្សាទុកមូលដ្ឋាន ទ័ពរបស់ពួកគេនៅអាស៊ីអាគ្នេយ៍ដដែល ។

ពួកចិន បានធ្វើឲ្យគេយល់យ៉ាងច្បាស់ថា ពួកគេត្រូវការការព្រមព្រៀងគ្នាមួយជាមួយសហរដ្ឋអាមេរិក ដើម្បីបញ្ចប់នូវអ្វីដែលពួកចិនចាត់ទុកជាការជឿនទៅមុខមួយរបស់សូវៀត បន្ទាប់ពីការដកថយរបស់អាមេរិកាំងក្នុងពិភពលោកទាំងមូល ។ ពួកគេបានថ្កោលទោសនូវពាក្យសន្យាពីមុនៗរបស់លោក ខាធ័រ ដែលថាបង្ការជាមុននូវការរីកដាលប្រកបដោយគ្រោះថ្នាក់ និងកាត់បន្ថយការប្រឈមមុខសូវៀត-អាមេរិកាំង ដោយសារការចរចាកាត់បន្ថយអាវុធយុទ្ធសាស្ត្រ សូល ២ (SALT II) ។ ជំហររបស់ចិន គឺស្មើរតែដូចការវិភាគរបស់អាមេរិកាំងក្នុងរយៈពេលមានសង្គ្រាមត្រជាក់អ៊ីចឹង ។ ហើយនៅពេលដែល វ៉ាន់ស៍ បញ្ជាក់ថែមទៀតអំពីនយោបាយរបស់ ខាធ័រ នៅទីក្រុងប៉េកាំង ពួកចិនសម្គាល់ឃើញការបន្កហេតុមួយនៅទីនោះ ។ ឧបនាយករដ្ឋមន្ត្រីចិន តេង ស៊ាវពីង បានប្រកាសថា ទស្សនវិស័យ នៃទំនាក់ទំនងជាប្រក្រតីជាមួយ ខាធ័រ មានលក្ខណៈអាប់អួ ជាងប្រធានាធិបតីហ្វរដ៏ ទៅទៀត ។

បន្ទាប់មក ពួកចិនបានចាប់ផ្ដើមធ្វើយុទ្ធនាការមួយដើម្បីក្រើនរំឭកក្រុងវ៉ាស៊ីនតោនជារឿយៗថា ពួកគេ

បានត្រូវធ្វើឲ្យតូចចិត្តយ៉ាងខ្លាំង ដោយដំណើរលំអៀងរបស់អាមេរិកាំងទៅរកសូវៀត ។ អត្ថបទមួយរបស់ទស្សនាវដ្ដីប៉េកាំង បានសន្និដ្ឋានថា ៖ «គ្មានអ្នកណាម្នាក់អាចដឹងច្បាស់ប្រាកដនូវអ្វី ដែលនឹងក្លាយជាប្រតិកម្មរបស់សហរដ្ឋអាមេរិកឡើយ បើសិនជាសហភាពសូវៀតរុញទម្លាក់អឺរ៉ុបខាងលិច ឲ្យធ្លាក់ទៅក្នុងសង្គ្រាមផ្ទៃកបន្ទោរមួយនោះ» ។ លើសពីនេះទៅទៀត ទិនានុប្បវត្តិប្រជាជនរបស់ចិន បានចោទប្រកាន់ពី «ពួកមេអណ្ដើកក្នុងការធ្វើឲ្យមានភាពធូរស្រាល» ថា បានខំប្រឹង «បំបែរសហភាពសូវៀតឲ្យងាកមកខាងកើត (ប្រទេសចិន) ដើម្បីដោះខ្លួនឲ្យផុតពីគ្រោះថ្នាក់របស់សូវៀត ដោយនាំឲ្យអន្តរាយដល់សន្តិសុខនៃប្រជាជាតិដទៃៗ ទៀត» ។

ការខិតចូលជិតគ្នាជាប្រវត្តិសាស្ត្ររបស់ប្រទេសចិនជាមួយសហរដ្ឋអាមេរិក នៅឆ្នាំ១៩៧២ គឺផ្អែកលើគំនិតថា សហភាពសូវៀតរួមបង្កជាការគំរាមកំហែងធំជាងគេបំផុតចំពោះក្រុងប៉េកាំង ។ ពួកចិន ធ្លាប់ធ្វើអន្តរាគមន៍ នៅចំពោះមុខក្រសែភ្នែករបស់ប្រទេសកុម្មុយនិស្ត និងតតិយលោកជាច្រើន ជាពិសេស ប្រទេសវៀតណាម ពីព្រោះពួកចិនយល់ថា គេត្រូវការនូវការគាំពាររបស់អាមេ រិកាំងប្រឈមនឹងក្រុងមូស្គូ ។ ជាមួយ ខាធ័រ ពួកអាមេរិកាំងប្រព្រឹត្តហាក់ដូចជាពួកគេភ្លេចគិតពីការគំរាមកំហែងរបស់សូវៀត យ៉ាងហោច ក្រុងប៉េកាំងមានការចាប់អារម្មណ៍យ៉ាងដូច្នេះ ។

នៅឆ្នាំ១៩៧៨ ប្រ៊ីហ្សីនស្គី បានការពារនូវសេចក្ដីសំអាងផ្សេងៗរបស់ពួកចិនដែលមានន័យសំដៅទៅរកជំហរតែមួយដែលគាត់ធ្លាប់គាំទ្រតាំងពីយូរមកហើយ ៖ សហភាពសូវៀត គឺជាមហាអំណាចវាតទីនិយមមួយដែលការច្បាំងដណ្ដើមទឹកដីប្រទេសផ្សេងៗ បានគំរាមកំហែងដល់ផលប្រយោជន៍នានារបស់អាមេរិកាំង ហើយដោយហេតុនេះ យើងត្រូវតែវាយប្រយុទ្ធ ។ យ៉ាងហោចទីប្រឹក្សារូបនេះបានបង្ហាញឲ្យឃើញកន្លង ដោយការគំរាមកំហែងរបស់សូវៀតដូចគ្នានឹងលោក គីស្ស៊ីងហ្គ័រ (រដ្ឋមន្ត្រីការបរទេសរបស់ប្រធានាធិបតី និចសុន) ដែរ ។ ប៉ុន្តែ នៅពេលដែល គីស្ស៊ីងហ្គ័រ ធ្លាប់ធ្វើឲ្យត្រីកោណ សូវៀត-ចិន-សហរដ្ឋអាមេរិកវិនាសបន្តិចម្ដងៗ ដើម្បីទាញយកសម្បទាផ្សេៗពីមហាអំណាចកុម្មុយនិស្តទាំងពីរ លោក ប្រ៊ីហ្សីនស្គី ចង់ប្រែក្លាយត្រីកោណនេះឲ្យទៅជាការព្រមព្រៀងគ្នាមួយ រវាងចិន-អាមេរិកាំង ប្រឆាំងនឹងសូវៀតវិញ ។

ទីប្រឹក្សារបស់លោក ខាធ័រ បានទៅជាមេអណ្ដើកឲ្យប្រទេសចិននៅពេលដែល វ៉ាន់ស៍ ចាប់ផ្ដើមបាត់បង់សេចក្ដីសង្ឃឹមខុសរបស់គាត់លើប្រទេសវៀតណាមដែរ ។ ខុសប្លែកពីពួកវៀតណាម ពួកចិនបានលើកសរសើរប្រ៊ីហ្សីនស្គី ចំពោះការយកចិត្តទុកដាក់របស់គាត់មកលើប្រទេសចិន ដោយផ្ដល់ឲ្យគាត់ទទួលបានជោគជ័យខាងផ្នែកការទូត ដែលក្រុងហាណូយបានបដិសេធចំពោះទីប្រឹក្សារូបនេះ ។ ដោយបំបាក់មុខ ខាធ័រ ជាសាធារណៈដែលស្វែងរកការធ្វើឲ្យមានប្រក្រតីភាពមួយ ពួកវៀតណាមបានបំផុសឲ្យមានការមិនទុកចិត្តល្មមបង្គួរ ក្នុងចំណោមប្រជាជនអាមេរិកាំង ដើម្បីបើកឱកាសឲ្យប្រទេសចិន ប្រឆាំងនឹងក្រុងវ៉ាស៊ីនតោន ក្នុងសង្គ្រាមដែលហៀបនឹងផ្ទុះឡើង នៅពេលខាងមុខ ។ ហើយក្នុងបណ្ដាខែជាបន្តបន្ទាប់ពីជម្លោះនេះ ក្រុងប៉េកាំងបានជំរុញសហរដ្ឋអាមេរិក

ឲ្យប្រកាន់ជំហរជាសត្រូវមួយចំពោះវៀតណាមយ៉ាងប៉ិនប្រសប់ ។

ចរន្តបានប្រែត្រឡប់នៅខែឧសភា ឆ្នាំ១៩៧៨ នៅពេលដែល ប្រ៊ីហ្សីនស្គី ធ្វើដំណើរទៅទស្សនកិច្ចជាផ្លូវការនៅប្រទេសចិន ។ គាត់បានចោលសំដីធ្វើការព្រមានខ្លាំងៗរបស់អាមេរិក អំពីជម្លោះដ៏ជូរចត់របស់ប្រទេសនៅអាស៊ី ដែលសម្រេចចិត្តចូលទៅខាងប្រទេសចិនរាល់លើក ។

សម្រាប់អាស៊ីទាំងមូល ឆ្នាំ១៩៧៨ គឺជាឆ្នាំដែលព្រឹត្តិការណ៍ផ្សេងៗប្រែប្រួលយ៉ាងខ្លាំង ។ វិបត្តិជាហូរហែមួយ ដែលប្រហែលជាគ្មានទាក់ទងរវាងគ្នានិងគ្នា បានបណ្តាលឲ្យមានការប្រឈមមុខខាងនយោបាយយ៉ាងតឹងតែង ហាក់ដូចជាស្នាមប្រេះជាសញ្ញាឲ្យដឹងមុនពីការរញ្ជួយដីមួយដែរ ។ នៅខែឧសភា រដ្ឋាភិបាលអាមេរិកាំងបានដឹងថា ប្រទេសវៀតណាម មានគម្រោងការចូលលុយប្រទេសកម្ពុជា ។ កាលពីខែមុន ស្ថានទូតសហរដ្ឋ-អាមេរិកនៅក្រុងបាងកកបានបញ្ជូនទូរលេខជាបន្ទាន់មួយទៅទីក្រុងវ៉ាស៊ីនតោន ៖ តាមប្រភពពត៌មានមួយរបស់វៀតណាមជាមិត្ត បានឲ្យដឹងថា ក្រុងហាណូយបានវាយតម្លៃថា ពួកកុម្មុយនិស្តកម្ពុជា “បានប្រកាន់យកមាគ៌ាភាន់ច្រឡំមួយ ដែលពួកគេដើរទៅរកផ្លូវអាក្រក់... ហើយថា នេះជារឿងដែលយើងមិនអាចទទួលយកបានដាច់ខាត” ។ ពត៌មាននេះ និងពត៌មានផ្សេងៗទៀត ជាពិសេស អំពីការធ្វើទុក្ខបុកម្នេញទៅលើជនជាតិភាគតិចចិនបាននាំឲ្យ“ពួកអ្នកចាំឃ្លាំមើលឥណ្ឌូចិន” នៅស្ថានទូតសន្និដានថា សង្គ្រាមនឹងផ្ទុះឡើងនៅមុនដំណាច់ឆ្នាំនេះ ។ ស្ថានទូតអាមេរិក ចង់ដឹងថាពួកចិននឹងធ្វើប្រតិកម្ម ដោយមធ្យោបាយយ៉ាងម៉េចខ្លះ ៖ ពួកគេនឹងការពារប្រទេសកម្ពុជារបស់ ប៉ុល ពត ដោយម៉ឺម៉ាត់មែនឬ? ។

ប្រ៊ីហ្សីនស្គី ពុំបានលើកយករឿងវៀតណាមមកនិយាយទេ ក្នុងរយៈពេលនៃដំណើរទស្សនកិច្ចរបស់គាត់នៅប្រទេសចិន ពីព្រោះពួកចិនបាននិយាយការពារបុព្វហេតុរបស់ខ្លួនយ៉ាងច្រើន ក្នុងការវិវាទដែលនាំឲ្យពួកគេប្រឆាំងនឹងក្រុងហាណូយនោះ ។ (រឿងដែលមានគោលបំណង គឺក្រុងប៉េកាំងពុំបានពិភាក្សាពីគុណសម្បត្តិនៃរបប ប៉ុល ពត នៅកម្ពុជាឡើយ) ។ ប្រ៊ីហ្សីនស្គី បានធ្វើឲ្យចិនរំភើបចិត្ត តាមពាក្យសម្តីថា “ប្រាកដមែនហើយខ្ញុំដឹងថាទំនាក់ទំនងផ្សេងៗរវាងប្រទេសចិន និងវៀតណាមមានសភាពអាក្រក់យ៉ាងខ្លាំង ប៉ុន្តែខ្ញុំមិនយល់ពីរឿងដែលពួកចិនកត់សម្គាល់ថា ពួកវៀតណាមជាអ្នកគំរាមកំហែងមកលើខ្លួននោះឡើយ ។ ប្រទេសវៀតណាមបានក្លាយទៅជាប៉ុស្តិ៍ជួរមុខមួយរបស់ក្រុងមូស្គូ នៅព្រំដែនភាគខាងត្បូងរបស់ប្រទេសចិន” ។

នៅខែឧសភា ឆ្នាំ១៩៧៨ សម្តីទាំងនេះបានទៅជាសម្តីបំផ្លើសហួសហេតុ ប៉ុន្តែវាបានផ្តល់នូវតម្លៃដល់និក្ខេបបទរបស់ ប្រ៊ីហ្សីនស្គី អំពីការប្រឈមមុខមួយ“តាមការប្រគល់សិទ្ធិ” ។ វាបានបង្ហាញ នូវមូលដ្ឋានដែលពួកចិនពឹងផ្អែកជាសំអាង ដើម្បីទាមទារឲ្យពួកអាមេរិកាំង បោះបង់ចោលបំណងធ្វើឲ្យមានប្រក្រតីភាពនូវទំនាក់ទំនងផ្សេងៗរបស់គេជាមួយក្រុងហាណូយ ។ ម៉ៃខិល អូសេនបឹក អ្នកឯកទេសខាងបញ្ហាប្រទេសចិននៅក្រុមប្រឹក្សាសន្តិសុខជាតិ បានដំណាលថា ៖ “យើងដឹងថា ទំនាក់ទំនងផ្សេងៗរបស់ប្រទេសចិនជាមួយពួកវៀត-

ណាម បានប្រែទៅជាល្បីងដូរចត់យ៉ាងជាក់ច្បាស់ ប៉ុន្តែ គឺពិតជាធ្ងន់ធ្ងរខ្លាំងជាងយើងនឹកគិតទៅទៀត ។ ដំបូង នៅពេលដែលយើងឲ្យដំណឹងពួកចិនថា យើងមានបំណងនឹងធ្វើឲ្យមានប្រក្រតីភាពនូវទំនាក់ទំនងរបស់យើងជាមួយប្រទេសវៀតណាម ពួកគេបានឆ្លើយដោយសម្ដីថ្ងាស ៗ មកយើងថា ៖ គឺជាកិច្ចការរបស់អ្នកឯង ។ លើកនេះ ពួកគេបានប្រើសម្ដីខ្លាំង ៗ ប្រឆាំងនឹងពួកវៀតណាម និងការធ្វើឲ្យមានប្រក្រតីភាពទៅវិញ ។

ប្រ៊ីហ្សីនស្គី បានប្រញាប់យល់ព្រមចំពោះដំហររបស់ចិនភ្លាម ។ គាត់បានឆ្លងផុតដោយរីករាយនូវព្រំដែនទាំងឡាយ ដែលរៀបចំឲ្យមានទំនាក់ទំនងចិន-អាមេរិកាំង និងរួបរួមជាពួកម្ចាស់ផ្ទះរបស់គាត់ដើម្បីថ្កោលទោសសហភាពសូវៀត និងប្រទេសវៀតណាម ។ ប្រ៊ីហ្សីនស្គី ជាអ្នកទេសចរបានឡើងកាំជណ្ដើរថ្មមហាកំពែងដោយជំហានលោតផ្លោះ និងគ្មានព្រួសំឡេង ហើយបញ្ចេញយ៉ាងខ្លាំងនូវពាក្យប្រទេចផ្ដាសាប្រឆាំងនឹងសូវៀត ជា «ខ្លាឃ្មុំទិសខាងជើង» ។ ក្នុងពិធីលៀងសាយភោជន៍ជាផ្លូវការ និងដែលមានសម្ដីដាក់ផ្ដែផ្កា ប្រ៊ីហ្សីនស្គី អ្នកតំណាងសំខាន់របស់សហរដ្ឋអាមេរិកបានប្រកាសថា ក្រុងវ៉ាស៊ីតោន សូមចូលរួមជាមួយ «ការប្ដេជ្ញាចិត្តរបស់ប្រទេសចិន ដែលមិនចុះចាញ់ការប្រឹងប្រែងរបស់ប្រជាជាតិទាំងអស់ ដែលកំពុងស្វះស្វែងបង្កើតអនុត្តរភាពមួយលើពិភពលោក ឬភូមិភាគ» ។ គាត់អាងលើពាក្យនិយាយពង្វាងរបស់ចិន សម្រាប់សម្គាល់សហភាពសូវៀត និងវៀតណាម ហើយហាក់ដូចជាដាក់ទម្ងន់លើសហរដ្ឋអាមេរិក ពីក្រោយការព្រមានដែលប្រទេសចិនបញ្ចេញឲ្យប្រទេសទាំងពីរដឹងជាសាធារណៈ ។

ប៉ុន្តែ អាមេរិកអាចនឹងស្ថិតនៅដោយឡែកពីជម្លោះទាំងនេះ ជាពិសេស នៅពេលដែលវាប្រឈមមុខតែជាមួយប្រទេសកុម្មុយនិស្តនានាប៉ុណ្ណោះ ។ គេមិនអាចប្រមាណពីលទ្ធផលភ្លាម ៗ ដែលសេចក្ដីថ្លែងការណ៍របស់ប្រ៊ីហ្សីនស្គី មានទៅលើប្រទេសវៀតណាមទេ ។ ក្រុងហាណូយ បានសម្រេចចិត្តធ្វើសង្គ្រាមនៅប្រទេសកម្ពុជារួចស្រេចទៅហើយ ។ ប៉ុន្តែ វាប្រាកដថា ការធ្វើដំណើរទៅប្រទេសចិនផ្ដើមយុទ្ធនាការមួយរបស់ ប្រ៊ីហ្សីនស្គី ដើម្បីរៀបចំ និងភ្ជាប់អាមេរិកទៅខាងពួកចិនសម្រាប់ដំណាក់កាលសង្គ្រាមឥណ្ឌូចិនបន្ទាប់ខាងមុខ ហើយថាប្រការនេះប្រហែលជាធ្វើឲ្យមានឥទ្ធិពលជ្រាលជ្រៅមួយទៅលើនយោបាយអាមេរិកាំង ក្នុងឆ្នាំបន្ទាប់ ៗ ទៀត ។

ដោយប្រឆាំងតបតភ្លាម ៗ បន្ទាប់ពីការចាកចេញរបស់អាមេរិកាំង ក្រុងប៉េកាំងបានរិះគន់ជាសាធារណៈសម្រាប់ជាលើកដំបូងអំពីការធ្វើបាបដោយក្រុងហាណូយ ចំពោះអាណិកជនចិននៅប្រទេសវៀតណាម ។ ការចោរប្រកាន់ និងការប្រឆាំងនឹងការចោទប្រកាន់ បានមានឡើងបន្តគ្នា ហើយជនជាតិចិនកាត់វៀតណាម ១៧០.០០០នាក់ បានភៀសខ្លួនទៅប្រទេសចិនមុនក្រុងប៉េកាំងបិទព្រំដែននៅនិទាឃរដូវ ។ ប្រទេសចិនបានផ្អាកកម្មវិធីជំនួយរបស់ខ្លួនទៅឲ្យប្រទេសវៀតណាម ក្រុងហាណូយបានចូលជាសមាជិកអង្គការកូមេកុង (COMECON) ដែលជាសហគមន៍សេដ្ឋកិច្ចរបស់ប្លុកសូវៀត ។ នៅខែកក្កដា ប្រទេសវៀតណាម បានប្រមូលផ្ដុំទ័ព ១៥០.០០០នាក់ តាមព្រំដែនចិន ជាមួយគ្រឿងសព្វាវុធ និងគ្រាប់រំសេវគ្រប់គ្រាន់សម្រាប់ការប្រយុទ្ធគ្នាដ៏យូរមួយនៅតាម

ព្រំដែន ។

ដំណើររបស់ ប្រ៊ីហ្សីនស្គី ក៏បង្កឲ្យមានព្រឹត្តិការណ៍អាក្រក់មកដល់ក្រុងវ៉ាស៊ីនតោនភ្លាមៗដែរ ។ វ៉ាន់ស៍ បានត្រូវធ្វើឲ្យខឹងខ្លាំងណាស់ ប៉ុន្តែ ចៀសវាងការប្រឈមមុខដោយផ្ទាល់មួយ ជាមួយទីប្រឹក្សាសន្តិសុខជាតិ ដែលពោរពេញទៅដោយភាពរហ័សរហួន ហើយពេញចិត្តនឹង«ជជែករកខុសត្រូវ» អំពីចំណុចខ្វែងយោបល់គ្នាតែប៉ុណ្ណោះ ។ លោករដ្ឋមន្ត្រីការបរទេស ជាមនុស្សស្ថិតក្នុងជំហរពិបាកដោះស្រាយមួយ ៖ ទស្សនកិច្ចរបស់ ប្រ៊ីហ្សីនស្គី បានទទួលជោគជ័យមួយ នៅពេលដែលដំណើររបស់ វ៉ាន់ស៍ ទៅទីក្រុងប៉េកាំង និងការចរចារបស់ ហូលប្រ៊ុក ជាមួយប្រទេសវៀតណាម បែរជាទទួលបរាជ័យ ។ ក្នុងជម្លោះដែលកើតមានរវាងបណ្ដាគូប្រឆាំងក្នុងប្រទេស ប្រ៊ីហ្សីនស្គី គឺជាអ្នកប្រសើរជាងគេ ហើយគាត់មានពួកចិននៅខាងគាត់ទៀត ដែលនេះប្រហែលជាធ្វើឲ្យគាត់មានអំណាចទៀតផង ។ ប្រទេសវៀតណាម នៅតែទាមទារឲ្យអាមេរិកាំងផ្ដល់ជំនួយមួយជានិច្ច ដើម្បីធ្វើឲ្យទំនាក់ទំនងរបស់ខ្លួនជាមួយក្រុង វ៉ាស៊ីនតោន មានប្រក្រតីភាព ហើយម៉្យាងទៀត រឿងរ៉ាវ ដេវីដ ទ្រឿង (David Troung) ក៏ផ្ទុះឡើងដែរ[១៩] ។

ទ្រឿង ដែលជាឥស្សរជននៃចលនាប្រឆាំងសង្គ្រាមនៅសហរដ្ឋអាមេរិក បានត្រូវចាប់ខ្លួននៅថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៧៨ និងត្រូវចោទពីបទធ្វើចារកិច្ច រដ្ឋាភិបាលអាមេរិកាំងដើម្បីប្រទេសវៀតណាម នៅក្នុងរយៈពេលចរចាឆ្នាំ១៩៧៨ ស្ដីពីប្រក្រតីភាពនៃទំនាក់ទំនងផ្សេងៗរវាងប្រទេសទាំងពីរ ។ កើតនៅប្រទេសវៀតណាម ទ្រឿង ជាកូនប្រុសរបស់សមាជិកឆ្នើមម្នាក់នៃកម្លាំងទីបីនៅវៀតណាមខាងត្បូង ដែលពុំមែនជាអ្នកកុម្មុយនិស្តទាំងក៏មិនមែនជាអ្នកប្រឆាំងកុម្មុយនិស្តដែរ ។ ដោយមកសិក្សានៅសហរដ្ឋអាមេរិក នៅទីបំផុត ទ្រឿង បានមក តាំងទីលំនៅនៅក្រុងវ៉ាស៊ីនតោន ជាកន្លែងដែលគាត់បានក្លាយទៅជាអ្នកនាំពាក្យរបស់កម្លាំងទីបីសម្រាប់ប្រទេសវៀតណាម ។

ទ្រឿង និង រ៉ូណាល់ ហ៊ុមហ្វ្រី ជាអ្នកជាប់ចោទជាមួយគ្នាក្នុងរឿងរ៉ាវនេះ បានត្រូវចោទប្រកាន់ពីបទផ្ដល់ឲ្យពួកវៀតណាម នូវទូរលេខសម្ងាត់ទាក់ទងនឹងបញ្ហានយោបាយជាហូរហែមួយ ដែលមានសារសំខាន់សម្រាប់ក្រុងហាណូយ គឺសេចក្ដីសង្ខេបមួយមានចំណងជើងថា ការទាក់ទងអាមេរិកាំង-វៀតណាម ៖ បេសកកម្ម វូដខុក ដែលរៀបចំឡើងដោយស្ថានទូតអាមេរិកាំងប្រចាំប្រទេសម៉ាឡេស៊ីនៅខែមេសា ឆ្នាំ១៩៧៧ ព្រមទាំងការវិភាគមួយក្រោមចំណងជើងថា ៖ ទំនាក់ទំនងក្រៅប្រទេសរបស់វៀតណាម ដែលសរសេរដោយកុងស៊ុលអាមេរិកាំងប្រចាំទីក្រុងហុងកុង នៅខែឧសភា ឆ្នាំ១៩៧៧ ។ ភាគច្រើននៃទូរលេខសុទ្ធតែមានចារបញ្ជាក់ថា «ការសម្ងាត់» តែត្រូវទទួលការចាត់ជាថ្នាក់ក្រោមបំផុតខាងវិស័យសន្តិសុខ ហើយពួកមេធាវីរបស់អ្នកទាំងពីរមិនជឿថា ឯកសារទាំងនេះ មានលក្ខណៈសំខាន់ សម្រាប់សន្តិសុខជាតិរបស់សហរដ្ឋអាមេរិកទេ ។ ប៉ុន្តែ ទ្រឿង និង ហ៊ុមហ្វ្រី ត្រូវបានកាត់ទោស ហើយរដ្ឋាភិបាលរបស់វៀតណាមត្រូវរួមបញ្ចូលក្នុងរឿងរ៉ាវនេះដែរ ។ ឯកអគ្គរដ្ឋទូតដំបូងរបស់

វៀតណាមប្រចាំអង្គការសហប្រជាជាតិ ត្រូវត្រឡប់មកប្រទេសវៀតណាមវិញ ។ ក្រុងហាណូយ បាននិយាយអំពី«ឱកាសបង្កើតរឿងជាក់ស្តែង» ដើម្បីបង្ហាញគេឯងឲ្យដឹង ថាបើសហរដ្ឋអាមេរិកនៅរក្សា«អរិភាពចំពោះសាធារណរដ្ឋសង្គមនិយមវៀតណាមក៏ដោយ» ។

ផលវិបាកសម្រាប់នយោបាយរបស់អាមេរិកាំងនៅឥណ្ឌូចិន គឺការពិភាក្សាជាមួយប្រទេសវៀតណាម ដើម្បីធ្វើឲ្យទំនាក់ទំនងផ្សេងៗមានប្រក្រតីភាព បានត្រូវពន្យារពេលរហូតដល់ការដោះស្រាយបញ្ចប់រឿងរ៉ាវរបស់ ទ្រៀង ។ ផែនការរបស់ វ៉ាន់ស៍ បានក្លាយទៅជាអសារឥតការ ។ ប្រទេសវៀតណាម នឹងមិនធ្វើសហប្រតិបត្តិការតទៅទៀតទេ ហើយប្រទេសចិនបានប្រើប្រាស់ ប្រ៊ីហ្សីនស្គី ដើម្បីបំបាត់យោបល់ទាំងអស់ ដែលឲ្យអាមេរិកនៅក្រោសង្គ្រាមដែលប្រុងប្រៀបនឹងផ្ទុះឡើងនៅឥណ្ឌូចិន ។

អ្វីៗដែលអាក្រក់បំផុតគឺ ប្រ៊ីហ្សីនស្គី បានចាប់បន្តនយោបាយធ្វើឲ្យមានប្រក្រតីភាពជាមួយប្រទេសចិនឡើងវិញ ដែលនេះជាគំនិត វ៉ាន់ស៍ តាំងតែពីដើមដំបូង ដើម្បីធ្វើឲ្យក្លាយទៅជានយោបាយប្រឆាំងប្រទេសវៀតណាមវិញ ។ ដំបូង លោករដ្ឋមន្ត្រីការបរទេស បានជជែកតវ៉ាដើម្បីធ្វើឲ្យមានប្រក្រតីភាពទាំងស្រុងមួយ ជាមួយក្រុងប៉េកាំង ប៉ុន្តែ ពុំមែនធ្វើឲ្យខូចស្ថិរភាពនៅទ្វីបអាស៊ីទេ ។ នៅឆ្នាំ១៩៧៨ វ៉ាន់ស៍ ប្រាថ្នាបន្តចរចាជាមួយប្រទេសវៀតណាម ដើម្បីមានកម្លាំងទប់ទល់នឹងឥទ្ធិពលរបស់សូវៀតមកលើក្រុងហាណូយ ដែលចេះតែកើនខ្លាំងឡើងៗ ។ ប៉ុន្តែ ប្រ៊ីហ្សីនស្គី បានពោលអះអាងថា ប្រទេសវៀតណាម ស្ថិតនៅក្នុងបុកខាងសត្រូវរួចស្រេចទៅហើយ ហើយមានបំណងផ្អាកការចរចាទាំងអស់ជាមួយក្រុងហាណូយរហូតដល់ការធ្វើឲ្យមានប្រក្រតីភាពទាំងស្រុងជាមួយក្រុងប៉េកាំងដូចប្រាថ្នា ។

វ៉ាន់ស៍ រកធ្វើអ្វីមិនកើតទាំងអស់ (ដូចគេចងដៃជាប់) ដោយសារព្រឹត្តិការណ៍ផ្សេងៗ កំពុងកើតមានបន្តគ្នានៅក្នុងឥណ្ឌូចិន ក៏ដូចការប្រើមធ្យោបាយផ្សេងៗ ដើម្បីទៅដល់គោលដៅអ្វីមួយរបស់ ប្រ៊ីហ្សីនស្គី ដែរ ។ នៅឆ្នាំ១៩៧៨ អារម្មណ៍របសល់លោក ខាធ័រ បានផ្លាស់ប្តូរ ។ ប្រ៊ីហ្សីនស្គី បានតាំងខ្លួនជាអ្នកមានគុណសម្បត្តិ ដែលបានធ្វើឲ្យជឿនលឿនទៅមុខ នូវការធ្វើឲ្យមានប្រក្រតីភាពជាមួយប្រទេសចិន ហើយបានក្លែងរឿងភូតដើម្បីធ្វើឲ្យគេជឿថា ការធ្វើឲ្យមានប្រក្រតីភាពជាមួយប្រទេសវៀតណាម គឺជាគំនមួយដែលរៀបចំយ៉ាងល្អិតល្អន់ ដោយពួកសេរីនិយមនៅក្រសួងការបរទេស ហើយពុំមែនជានយោបាយរបស់ ខាធ័រ ទេ[៧០] ។ លោកប្រធានាធិបតី ពុំបានបដិសេធសម្តីនេះឡើយ ។ គាត់ត្រូវការជោគជ័យ ហើយ ប្រ៊ីហ្សីនស្គី អួតខ្លួនថា អាចយកប្រទេសចិនដាក់លើថាសមួយមកជូនគាត់ ។

ប៉ុន្តែ លោក ខាធ័រ បានលៃការដាក់កំហិតរបស់គាត់ឲ្យស្មើគ្នា ហើយពុំដែលបញ្ជាឲ្យ វ៉ាន់ស៍ បញ្ឈប់ការចរចាជាមួយពួកវៀតណាមឡើយ ។ នៅពេលដែលរឿងរ៉ាវចារកម្មរបស់ ទ្រៀង ត្រូវបានដោះស្រាយចប់សព្វគ្រប់ លោករដ្ឋមន្ត្រីការបរទេស វ៉ាន់ស៍ បានអញ្ជើញពួកអ្នកជំនាញការវៀតណាមមកធ្វើទស្សនកិច្ច នៅមន្ទីរពិសោធន៍

រកអត្តសញ្ញាណសាកសពនៅក្រុងហូណូលូលូ ។ គណៈប្រតិភូវៀតណាម បានមកដល់រដ្ឋហាវៃ នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៧៨ និងបានទៅទស្សនាបណ្ដាថបនភណ្ឌយោធារបស់ទីក្រុង ជាមួយលោក ហ្វ្រេដ ក្រេជ្រាន ដែលជាបុគ្គលិកក្រសួងការបរទេស ។ គឺនៅពេលនោះហើយដែលសមាជិកគណៈប្រតិភូសម្រេចចិត្តប្រគល់ឲ្យ ក្រេជ្រាន នូវសារពិសេសមួយ ៖ ប្រទេសវៀតណាមយល់ព្រមលះបង់ការទាមទារជំនួយសេដ្ឋកិច្ចរបស់ខ្លួន ៖ ការធ្វើឲ្យមានប្រក្រតីភាពអាចចាប់ផ្ដើមបាន ។

ការបញ្ចេញឲ្យដឹងនេះត្រូវបានធ្វើឲ្យគេជឿថា ប្រាកដប្រជា ហើយពីរសប្ដាហ៍ក្រោយមក វ៉ាន់ស៍ បានស្នើពួកវៀតណាមតាមរយៈគណៈបេសកកម្មរបស់វៀតណាម នៅក្រុងប៉ារីសឲ្យចាប់ផ្ដើមធ្វើការចរចាជាថ្មី ។ ដោយស្របទៅតាមកិច្ចព្រមព្រៀងមួយ ហូលប្រ៊ុក នឹងជួប ង្វៀន កូថាច់ (អនុរដ្ឋមន្ត្រីការបរទេសម្នាក់ទៀត របស់វៀតណាម) នៅពេលបើកមហាសន្និបាតអង្គការសហប្រជាជាតិនៅខែកញ្ញា នាទីក្រុងញូវយ៉ក ។

ទោះបីជាទើបតែមួយឆ្នាំកន្លងផុតទៅតាំងពីបរាជ័យនៃការចរចារវាង ផាន់ហៀន និងហូលប្រ៊ុក ក៏ដោយ ក៏ ថាច់ ត្រូវធ្វើដំណើរទៅកាន់ក្រុងញូវយ៉ក ជាមួយសេចក្ដីបង្គាប់បញ្ជាផ្សេងៗដែលបណ្ដាលឲ្យមានស្ថានភាពមួយខុសគ្នាដែរ[២១] ។ បេសកម្មរបស់ ថាច់ ស្ថិតនៅត្រង់បញ្ឈាក់ពីអព្យាក្រឹតភាព (ការនៅជាកណ្ដាល) របស់សហរដ្ឋ-អាមេរិក និងធ្វើឲ្យទំនាក់ទំនងផ្សេងៗរបស់ចិនជាមួយក្រុងវ៉ាស៊ីនតោន មានលក្ខណៈស្មុគស្មាញ ។ ប៉ុន្តែពួកអាមេរិកបានដឹងពីការរៀបចំប្រុងប្រៀបធ្វើសង្គ្រាមរបស់ក្រុងហាណូយជាស្រេច ។ ការឆ្លើយបំភ្លឺរបស់ហូលប្រ៊ុក ក៏ដូចនៅខែឧសភា ឆ្នាំ១៩៧៨ដែរ ជាមួយបដិញ្ញា (ខ ដែលមានចែងក្នុងកិច្ចសន្យា) បន្ថែមថា គាត់ត្រូវតែធ្វើសេចក្ដីរាយការណ៍ប្រាប់ វ៉ាន់ស៍ ដែលនឹងជជែកគ្នាបន្ទាប់ជាមួយ ខាធ័រ អំពីមូលកភាព (ភាពសមហេតុសមផល) នៃដើមហេតុនេះ ។ ហូលប្រ៊ុក នឹងជជីកសួរប្រទេសវៀតណាមអំពីការប្រុងប្រៀបចំធ្វើសង្គ្រាម និងអំពីអ្នកភៀសខ្លួនតាមទូករាប់រយពាន់នាក់ ដែលកំពុងរត់គេចចេញពីប្រទេស ។

អ្នកភៀសខ្លួនតាមទូកទាំងនេះ ធ្លាប់បានបង្កឲ្យមានការរំជួលចិត្តយ៉ាងសម្បើមនៅសហរដ្ឋអាមេរិក ។ កាលពីឆ្នាំមុន វ៉ាន់ស៍ បានលើករឿងនេះមកជជែកពិភាក្សាដែរ ហើយបានចាត់ឲ្យបណ្ដាសមាជិកនៃក្រុមអ្នកធ្វើការខាងការទូត ដែលបំពេញមុខងារក្នុងភូមិភាគផ្ដល់មកឲ្យគាត់នូវសេចក្ដីរាយការណ៍លម្អិតស្ដីពីបាតុភូតដ៏ខ្លោចផ្សានេះ ។ ពួកអ្នកភៀសខ្លួនបានទៅឡើងគោកនៅប្រទេសថៃ ប្រទេសម៉ាឡេស៊ី និងនៅប្រទេសឥណ្ឌូនេស៊ី ឬប្រទេសហ្វីលីពីនថែមទៀត ។ បណ្ដាប្រទេសនៃសមាគមអាស៊ាន បានបង្ខំឲ្យពួកអាមេរិកាំងធ្វើឲ្យទំនាក់ទំនងផ្សេងៗ មានប្រក្រតីភាពជាមួយប្រទេសវៀតណាម ក្នុងក្ដីសង្ឃឹមថា ប្រការនេះនឹងធ្វើឲ្យពួកវៀតណាមរសាយចិត្ត ហើយនឹងទប់ស្កាត់ការហូរជន់ជោររបស់ពួកអ្នកភៀសខ្លួន ។ សមាគមអាស៊ាន ក៏សង្ឃឹមថា ការធ្វើឲ្យមានប្រក្រតីភាពនឹងកាត់បន្ថយគ្រោះថ្នាក់ផ្សេងៗពីសង្គ្រាមមួយរវាងវៀតណាម និងកម្ពុជា ។ ប៉ុន្តែ នៅពេលនោះសមាគមអាស៊ានមិនសូវមានឥទ្ធិពល ទៅលើក្រុងវ៉ាស៊ីនតោន ក៏ដូចប្រទេសចិនប៉ុន្មានទេ ហើយតាម

ប្រ៊ីហ្សីនស្គី ថា នៅពេលនោះ ក្រុងប៉េកាំង បានស្នើសហរដ្ឋអាមេរិក ដោយទទូចកុំឲ្យសម្រេចធ្វើកិច្ចព្រមព្រៀងមួយជាមួយក្រុងហាណូយ ។

ហូលប្រ៊ុកត្រូវបានប្រាប់ឲ្យដឹងដែរថា សហរដ្ឋអាមេរិកប្រហែលជាអាចបោះជំហានយ៉ាងធំមួយទៅរកប្រទេសវៀតណាមមុនការបោះឆ្នោតនៅសភាអាមេរិកាំងនៅខែវិច្ឆិកា ឆ្នាំ១៩៧៨ ។

អ្នកការទូតអាមេរិកាំងរូបនេះ បានជួប ថាច់ ក្នុងល្វែងបន្ទប់របស់គណៈប្រតិភូវៀតណាមនៅអង្គការសហប្រជាជាតិ តាមមាត់ទន្លេ *Riverside Plaza* ជាសណ្ឋាគារធ្វើពីបេតុងពណ៌ប្រផេះដែលអមដោយទន្លេ *East River* ។ ហូលប្រ៊ុក ដំណាលថា គាត់បានចូលចរចាទាំងមិនប្រាកដក្នុងចិត្ត ។ ដោយមិនចង់ឲ្យមានបរាជ័យជាសាធារណៈថ្មីមួយ គាត់ពុំបានធ្វើការប្រកាសណាមួយស្ដីពីការជួបគ្នានេះទេ ។ ពួកអ្នកជំនាញការរបស់គាត់នៅការិយាល័យសម្រាប់កិច្ចការអាស៊ីខាងកើតធ្លាប់បានទាយទុកជាមុនថា ប្រទេសវៀតណាមនឹងត្រៀមវាយប្រហារប្រទេសកម្ពុជានៅចុងឆ្នាំ១៩៧៨ ។ ពួកគេដឹងមុនថា ពួកវៀតណាមមុខជាធ្វើការវាយលុករហូតដល់ត្រើយខាងកើតទន្លេមេគង្គ ដែលនឹងអនុញ្ញាតិឲ្យក្រុងហាណូយដណ្ដើមបានដែនដីធំបន្តួរ ដើម្បីបង្កើតរដ្ឋាភិបាលកុម្មុយនិស្តកម្ពុជាមួយដែលរៀបចំឡើងសម្រាប់ផ្លាស់ជំនួស ។

ថាច់ បានចាប់ផ្ដើមការពិភាក្សាដោយបញ្ហាមួយស្ដីពីចំនួនទឹកប្រាក់ជំនួយដែលសហរដ្ឋអាមេរិកយល់ព្រមផ្ដល់ឲ្យប្រទេសវៀតណាម ។ ហូលប្រ៊ុក ដែលមានបំណងចោទសួរ ថាច់ នូវសំណួរមួយស្ដីពីចេតនាផ្សេងៗ របស់ប្រទេសវៀតណាមចំពោះប្រទេសចិននិងប្រទេសកម្ពុជា បានត្រូវធ្វើឲ្យភ្ញាក់ផ្អើលដោយមិនបានដឹងខ្លួនជាមុន ។ គាត់គោងតែរំពឹកប្រាប់ ថាច់ ថា ការជួបគ្នាដែលកើតមាននៅពេលនេះ គឺដោយសារតែប្រទេសវៀតណាម បានឲ្យដឹងតាមរយៈសារលិខិតមួយនៅក្រុងហូណូលូលូថា ខ្លួនបោះបង់លែងទាមទារជំនួយមួយទៀតហើយ ។ ថាច់ សើចញញឹមៗ ប៉ុន្តែ នៅតែប្រកាន់លើចំណុចនេះដដែល ។

ក្នុងអំឡុងសម័យប្រជុំលើកទីពីរ និងលើកចុងក្រោយ អ្នកចរចាវៀតណាមបានបន្តទាមទារលុយមិនឈប់ហើយ ហូលប្រ៊ុកបានឆ្លើយថា វាគ្មានប្រយោជន៍បន្តការចរចាតទៅទៀតទេ ។

ថាច់ សើចផ្អៀងក្បាល ហើយសូមឲ្យអាមេរិកាំងត្រឡប់មកកាន់តុចរចាម្ដងទៀត ។ កាលបើអ្នកចរចាទាំងពីរដាក់បន្ទុយលើកៅអីពូកជាថ្មី ថាច់ បានប្រកាសដោយសំឡេងលះថា «យើងយល់ព្រមតាមឥរិយាបថរបស់អាមេរិកាំង ។ យើងពុំមានដាក់លក្ខខណ្ឌណាមួយគេ ។ យើងអាចចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយឥឡូវនេះ» ។

គឺដល់វេនដែលលោក ហូលប្រ៊ុក ត្រូវធ្វើឲ្យជួបការពិបាកម្ដង ។ គាត់បានសង្កត់បញ្ជាក់ថា «ខ្ញុំពុំត្រូវបានអនុញ្ញាតឲ្យចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយទេ ទោះជាកិច្ចព្រមព្រៀងអ្វីក៏ដោយ» ។ ម៉ាស៊ីនថតសំឡេងដែលពួកវៀតណាមបានដាក់នៅលើតុបានបន្លឺសូរងឺតៗក្នុងរយៈពេលស្ងប់ស្ងាត់យ៉ាងយូរ ។ ហូលប្រ៊ុក បញ្ជាក់ប្រាប់ ថាច់ ថា រដ្ឋមន្ត្រីការបរទេសអាមេរិកាំងនឹងត្រូវធ្វើឲ្យសប្បាយរីករាយយ៉ាងខ្លាំង ដែលឥឡូវនេះជំហររបស់

ប្រទេសទាំងពីរ ហាក់ដូចជាខិតចូលជិតគ្នាខ្លាំងមែនទែន ។ អាស្រ័យដោយការសម្រេចតាំងពីដំបូង គាត់បានប្រកាសថា តាមខ្ញុំយល់ប្រទេសទាំងពីរហាក់ដូចជាបោះជំហានទៅមុខហើយ ប៉ុន្តែដំបូងគេគោងតែពិគ្រោះនឹង វ៉ាន់ស៍ សិន ដែល«បរិបទជុំវិញ» មានលក្ខណៈប្រែប្រួលខ្លាំងបំផុត ដើម្បីនឹងឲ្យគាត់អាចផ្តល់ចម្លើយភ្លាមៗមួយ ។ សម្រាប់សហរដ្ឋអាមេរិក លទ្ធភាពធ្វើឲ្យទំនាក់ទំនងផ្សេងៗ របស់ខ្លួនមានប្រក្រតីភាពជាក្រុងហាណូយ នឹងសម្រេចនៅត្រង់ទំនាក់ទំនងរបស់ប្រទេសវៀតណាម ជាមួយនឹងប្រជាជាតិផ្សេងៗទៀត ។ ថាច់ ចង់បានការចុះហត្ថលេខារបស់ ហូលប្រ៊ុក សម្រាប់កិច្ចព្រមព្រៀងជាគោលការណ៍មួយ ប៉ុន្តែ ហូលប្រ៊ុក បានបដិសេធហើយឆ្លើយថា ខ្ញុំនឹងទាក់ទងជាមួយគាត់តទៅទៀត ។

វ៉ាន់ស៍ បានបង្ហាញឲ្យឃើញថា គាត់ជាមនុស្សគិតគូរមធ្យ័ត ។ នៅថ្ងៃទី២៨ ខែកញ្ញា គាត់បានសរសេរក្នុងអនុសាសន៍របស់គាត់ផ្ញើជូនលោកប្រធានាធិបតីថា សហរដ្ឋអាមេរិកគួរតែព្រមទទួលការស្នើរបស់វៀតណាម និងធ្វើឲ្យទំនាក់ទំនងផ្សេងមានប្រក្រតីភាព ប៉ុន្តែគឺបន្ទាប់ពីការបោះឆ្នោតនៅខែវិច្ឆិកា ដែលមានរយៈពេលជាងមួយខែទៀតប៉ុណ្ណោះ ។ រយៈពេលនេះគឺវែងល្មមគ្រប់គ្រាន់ហើយ ដើម្បីអនុញ្ញាតិឲ្យយើងវិនិច្ឆ័យនូវអ្វីដែលប្រទេសវៀតណាម គ្រោងការចំពោះប្រទេសកម្ពុជា ហើយវាចាំបាច់ដើម្បីជៀសវាងការលើកបញ្ហាសំខាន់មួយមកពិភាក្សាទៅមុនការបោះឆ្នោត ។ ដោយដើរក្នុងទិសតែមួយដូច វ៉ាន់ស៍ ដែរ ប្រ៊ីហ្សីនស្គី បាននិយាយណែនាំកុំឲ្យធ្វើអ្វីសោះមុនការចរចាជាមួយប្រទេសចិន ដែលមានសារសំខាន់ជាងត្រូវបានចាត់ចែងរួចរាល់ហើយ មានន័យថា មុនខែធ្នូ ជាកាលបរិច្ឆេទដែលគ្រោងទុកជាមុន សម្រាប់សេចក្តីសម្រេចរបស់គាត់ ។ លោកប្រធានាធិបតី ខាធ័រ បានអនុញ្ញាតឲ្យធ្វើការបង្កើតនៅក្រុងញូវយ៉កនូវក្រុមសិក្សាអាមេរិក -វៀតណាមមួយដែលនឹងចាត់ចែង ការណ៍រាយរងទាំងអស់នៃការធ្វើឲ្យមានប្រក្រតីភាព ដែលបានដាក់ឲ្យពិនិត្យ- ទំហំបុគ្គលិកនៃអនាគតស្ថានទូតទាំងពីរ ដោយប្រៀបធៀបនឹងស្ថានភាពអគារផង ។

ការប្រុងប្រយ័ត្នរបស់ វ៉ាន់ស៍ បានធ្វើឲ្យ ង្វៀនកូថាច់ អ្នកចរចារបស់វៀតណាមក្តៅក្រហាយ ដែលរង់ចាំចម្លើយស្តាពរមួយជិតមួយខែមកហើយនៅទីក្រុងញូវយ៉ក ។ នៅខែតុលា គាត់បានចាកចេញដោយត្រូវញ៉ាំងឲ្យជឿថា ពាក្យសម្អាងពីការបោះឆ្នោតនៅសភា គ្រាន់តែជាឧបាយកលមួយប៉ុណ្ណោះ ។ ថាច់ បានបញ្ជាក់ថា ហូលប្រ៊ុក ធ្លាប់អះអាងនឹងគាត់ថា វានឹងមានការធ្វើឲ្យមានប្រក្រតីភាព ហើយនៅសល់តែបញ្ហាមួយប៉ុណ្ណោះគឺការណ៍រាយរងមួយចំនួនតូចដែលត្រូវដោះស្រាយ ។ ថាច់ បានដំណាលថា «ប៉ុន្តែក្រោយពីការប្រជុំ ហូលប្រ៊ុក បានប្រាប់ខ្ញុំមិនឈប់ថា គាត់ជាប់រវល់ណាស់គ្មានពេលនឹងជួបខ្ញុំទៀតទេ ។ គាត់បង្ហាញខ្ញុំឲ្យឃើញថា សហរដ្ឋ-អាមេរិកពុំបានប្រុងប្រៀបជាស្រេចទេ» ។

ថាច់ និងហូលប្រ៊ុក មិនមែនមិនព្រមព្រៀងគ្នាទៅលើអ្វីដែលធ្លាប់បានអះអាងទេ ប៉ុន្តែគឺគ្រាន់តែឲ្យមានការបញ្ជាក់ទៅលើចំណុចខ្លះៗប៉ុណ្ណោះ ។ តាមការពិត មនុស្សទាំងពីរជាតំណាងប្រទេសដែលយល់ឃើញដំណើរនៃ

ការចរចាខុសគ្នាទាំងស្រុង ។ បើវ៉ាន់ស៍ ពិតជាជាប់រវល់ដោយការបោះឆ្នោតនៅសភា, ថាច់ ដែលដឹងថាបើរង់ចាំរហូតដល់ពាក់កណ្តាលខែវិច្ឆិកា គឺមិនអាចដាច់ខាតសម្រាប់ប្រទេសវៀតណាម ។ ប្រទេសរបស់គាត់កំពុងរៀបចំធ្វើសង្គ្រាម ហើយត្រូវតែស្វែងរកដោយឆាប់រហ័សនូវការគាំទ្រដ៏ជាក់លាក់មួយ ។ ថាច់ បានឡើងយន្តហោះសំដៅទៅកាន់ក្រុងមូស្គូជាទីដែលគាត់ត្រូវជួប ឡេ យន់ ដោយផ្ទាល់ ដែលស្ថិតនៅសហភាពសូវៀតរួចមកហើយ ។

នៅថ្ងៃទី៣ ខែវិច្ឆិកា គឺបួនថ្ងៃមុនការបោះឆ្នោតនៅសភា ប្រទេសវៀតណាមបានចុះហត្ថលេខាលើសន្ធិសញ្ញាមិត្តភាពមួយជាមួយសហភាពសូវៀត ។ ចាប់ពីថ្ងៃនេះទៅ គេលែងអាចពន្យារពេលទៀតហើយ ។ សន្ធិសញ្ញានេះរួមមានខសំខាន់ស្តីពីការសង្គ្រោះគ្នាទៅវិញទៅមក ក្នុងករណីដែលប្រទេសណាមួយត្រូវគេវាយប្រហារនៅពេលខាងមុខ ។ តាមការយល់ឃើញរបស់ប្រទេសភាគច្រើន ការសន្យានេះមានន័យស្មើនឹងសម្ព័ន្ធភាពយោធាថ្មីមួយ ។ សន្ធិសញ្ញានេះ ដូចសន្ធិសញ្ញាដែលពួកឥណ្ឌាធ្លាប់បានចុះហត្ថលេខាជាមួយក្រុងមូស្គូណាស់ នៅមុនសង្គ្រាមរបស់គេប្រឆាំងប្រទេសប៉ាគីស្ថានបន្តិច ។

រ៉ូប៊ឺត អូកលី (Robert Oakley) ជំនួយការរបស់ លោក ហូល ប្រ៊ូក បានចាត់ចែងរៀបចំនូវការជួបគ្នាលើកចុងក្រោយជាមួយពួកវៀតណាមជាបន្ទាន់បន្ទាប់ពីការបោះឆ្នោតនៅថ្ងៃទី៧ ខែវិច្ឆិកា ដូចដែលបានសន្យាពីមុន[២២] ។ នៅខណៈនេះ សហរដ្ឋអាមេរិក បានទទួលពីក្រុមភ្នាក់ងារស៊ើបការណ៍នូវរបាយការណ៍គួរឲ្យទុកចិត្តជាច្រើន ដែលអះអាងបន្ថែមពីពាក្យចចាមអារ៉ាមផ្សេងៗថា រដ្ឋាភិបាលវៀតណាម ស្ថិតនៅពីក្រោយការចាកចេញទាំងហ្វូងរបស់ពួកអ្នកភៀសខ្លួនតាមទូក ហើយសមាជិកខ្លះនៃជនជាតិភាគតិចចិន មិនត្រឹមតែត្រូវបង្ខំឲ្យចាកចេញពីប្រទេសប៉ុណ្ណោះទេ ប៉ុន្តែ ក៏ត្រូវបង់ថ្លៃជាមាសសម្រាប់សិទ្ធិឡើងជិះទូកដែរ ។ វ៉ាន់ស៍ បានអោយពត៌មានដល់ អូកលី ថា ការចរចាស្តីពីការធ្វើឲ្យមានប្រក្រតីភាពគឺត្រូវលុបចោល ហើយគោងតែនិយាយប្រាប់ពួកវៀតណាមថា សន្ធិសញ្ញាជាមួយសហភាពសូវៀត បង្ហាញអោយឃើញយ៉ាងច្បាស់ថា គោលបំណងរបស់ក្រុងហាណូយពុំមែនស្រលាញ់សន្តិភាពទេ ។

នៅសម័យប្រជុំផ្តាច់ព្រ័ត្រ អូកលី បានបញ្ជូនសារទៅឲ្យលោក វ៉ាន់ស៍ ថា ៖ «ខ្ញុំបានប្រាប់គេថា លោកមិនយល់នូវអ្វីដែលនឹងកើតឡើងទេ ឬបើសិនជាលោកលុកលុយប្រទេសកម្ពុជា? នេះពុំមែនជាមធ្យោបាយផ្តល់សន្តិភាពក្នុងភូមិភាគទេ ។ តើយើងអាចល្បងធ្វើតាមការទទូចសុំមួយរបស់អង្គការសហប្រជាជាតិ ដោយប្រើប្រាស់អង្គការនេះ ក្រោមទម្រង់ណាមួយបានទេ? ។ ពួកវៀតណាមបានឆ្លើយប្រាប់ខ្ញុំថា ពួកគេត្រូវតែធ្វើនូវអ្វីដែលពួកគេត្រូវធ្វើ, ពួកគេគ្មានមធ្យោបាយណាផ្សេងក្រៅពីនេះទេ ។ នេះជាពេលលំបាកចិត្តបំផុតសម្រាប់ខ្ញុំ ។ ខ្ញុំបានលុបចោលការចរចាផ្សេងៗជាផ្លូវការ» ។

យ៉ាងហោចណាស់ នេះគឺជាអ្វីដែល អូកលី សន្និដ្ឋាន ។ វ៉ាន់ស៍ យល់ឃើញផ្ទុយទៅវិញថា លោក ខាធ័រ

និងរូបគាត់ផ្ទាល់ បានលុបចោលការធ្វើឲ្យមានប្រក្រតីភាព ដោយសារតែ«ការកើនឡើងនូវកត្តាជាច្រើន ៖ អ្នកភៀសខ្លួនតាមទូក, ប្រទេសកម្ពុជា, ការចុះសន្ធិសញ្ញាជាមួយក្រុងមូស្គូ» ។ តាមលោករដ្ឋមន្ត្រីការបរទេសថា ប្រទេសចិនពុំមានជាប់ពាក់ព័ន្ធក្នុងការសម្រេចនេះទេ ៖ «ប្រទេសចិនបានដើរតួនាទីតូចតាចមួយក្នុងកិច្ចការនៃការធ្វើឲ្យមានប្រក្រតីភាពជាមួយប្រទេសវៀតណាម ។ គឺព្រឹត្តិការណ៍ផ្សេងៗ ដែលនាំទៅរកលទ្ធផលចុងក្រោយ» ។

ប៉ុន្តែ លោក ខាឆ័រ និង ប្រ៊ីហ្សីនស្គី បញ្ជាក់ថា វ៉ាន់ស៍ យល់ច្រឡំខ្លួនឯង ៖ គឺសេចក្តីសំអាងផ្សេងៗរបស់ប្រ៊ីហ្សីនស្គី ដែលញុាំងឲ្យលោក ខាឆ័រ ជឿតាម ពុំមែនអ្នកភៀសខ្លួនតាមទូក ឬសន្ធិសញ្ញាសូវៀតនោះទេ ។ ខាឆ័រ បញ្ជាក់ថា គាត់ប្រឆាំងនឹងការធ្វើឲ្យមានប្រក្រតីភាពជាមួយប្រទេសវៀតណាម ពីព្រោះសហរដ្ឋអាមេរិកចង់ «គិតគូរពីប្រទេសចិនដំបូងគេ»[១៣] ។

បើសិនជាអ៊ីចឹងមែនគឺលោកប្រធានាធិបតី បានប្រថុយនឹងល្បែងប្រកបដោយគ្រោះថ្នាក់មួយ ដែលអាចកើតមានទៅថ្ងៃមុខ ដោយប្រើប្រាស់នយោបាយការទូតមួយតាមមធ្យោបាយពីរ ដែលទោះជាយ៉ាងណាក៏ដោយក៏គេថាបោកបញ្ឆោតដែរ ។ ព្រឹត្តិការណ៍ផ្សេងៗបានធ្វើឲ្យលោក ប្រ៊ីហ្សីនស្គី មានប្រៀបជាង ។ នៅថ្ងៃទី១៥ ខែធ្នូ សហរដ្ឋអាមេរិក និងសាធារណរដ្ឋប្រជាមានិតចិន បានប្រកាសឲ្យដឹងជាសាធារណៈក្នុងពេលដំណាលគ្នាថាពួកគេព្រមព្រៀងគ្នា បង្កើតទំនាក់ទំនងការទូតជាធម្មតាឡើងវិញ ។

លោក ខាឆ័រ និងវ៉ាន់ស៍ ប្រហែលជាមិនយល់ស្របអំពីមូលហេតុដែលសហរដ្ឋអាមេរិកពុំទាន់សម្រេចធ្វើឲ្យទំនាក់ទំនងផ្សេងៗ មានប្រក្រតីភាពជាមួយប្រទេសវៀតណាមទេ ។ (ហើយ វ៉ាន់ស៍ ទំនងជាមានជោគជ័យដែលអះអាងថា ប្រទេសវៀតណាមគឺជាអ្នកទទួលខុសត្រូវមួយផ្នែកធំ) ។ ប៉ុន្តែ អ្វីដែលមានសារសំខាន់ក្នុងបណ្តាសប្តាហ៍ជាបន្តបន្ទាប់មកទៀត គឺមនោសញ្ចេតនារបស់លោក ខាឆ័រ ដែលចូលចិត្តធ្វើឲ្យមានទំនាក់ទំនងជាមួយប្រទេសចិន ស្របគ្នានឹងការធ្វើឲ្យមានទំនាក់ទំនងជាមួយប្រទេសវៀតណាមជាង ។ នៅពេលដែលក្រុងហាណូយចូលលុកលុយប្រទេសកម្ពុជានៅថ្ងៃបុណ្យណូអែលឆ្នាំ១៩៧៨ សហរដ្ឋអាមេរិកបានប្រុងប្រៀបទទួលព្រមធ្វើតាមប្រតិកម្មរបស់គេទាំងងងឹតងងល់ជាស្រេច អំពីប្រតិកម្មរបស់ចិនចំពោះសង្គ្រាមឥណ្ឌូចិនលើកទីបី ។

នៅឆ្នាំ១៩៧៨ ប្រទេសវៀតណាមបានរាកទៅចូលខាងសូវៀតពេញទីង ។ ដោយគ្មានជំនួយរបស់សហភាពសូវៀត ក្រុងហាណូយនឹងពុំអាចធ្វើសង្គ្រាមទាំងពុំអាចរស់រានតទៅទៀតឡើយ ។ ប្រទេសវៀតណាម បានក្លាយទៅជាសម្ព័ន្ធមិត្តគួរឲ្យទុកចិត្តជាងគេមួយក្នុងចំណោមសម្ព័ន្ធមិត្តដ៏គួរឲ្យទុកចិត្តជាងគេរបស់ក្រុងមូស្គូ ដោយបានបោះឆ្នោតជាប់ជាប្រចាំជាមួយសហភាពសូវៀតក្នុងអង្គការអន្តរជាតិទាំងអស់ និងព្រមអនុញ្ញាតឲ្យមានវត្តមានយោធា និងសេដ្ឋកិច្ចមួយ ដែលលេចធ្លោជាងគេរបស់ក្រុងមូស្គូ នៅក្នុងប្រទេសទៀតផង ។ អាស៊ីត្រូវបែងចែកជាពីរយ៉ាងច្បាស់ ដែលមិនធ្លាប់មានសោះ តាំងពីមុនមក ។ ហើយពិភពលោក បានមានមុខនៅក្នុងសង្គ្រាមកុម្មុយនិស្តប្រភេទថ្មីមួយ ដែលធ្វើឲ្យកើតមានឡើងវិញនូវបដិបក្ខភាពជាតិសាសន៍ និងចំណង់ហួស

ព្រំដែនក្នុងការធ្វើសញ្ញ័យជាជាងស្មារតី «រំដោះជាតិ» ។

ពួកអ្នកទទួលផលប្រយោជន៍ដោយផ្ទាល់ពីស្ថានការណ៍ថ្មីនេះ គឺបណ្ដាប្រទេសនៃសមាគមអាស៊ានឯណោះទេ ។ នៅឆ្នាំ១៩៧៨ ប្រទេសទាំងនេះបានត្រូវបញ្ជោររកផលប្រយោជន៍ដោយក្រុងហាណូយ ក្រុងភ្នំពេញ និងក្រុងប៉េកាំង ដែលតឿនបង្ខំឲ្យជ្រើសរើសចូលខាងបក្សពួកគេក្នុងសង្គ្រាមកុម្មុយនិស្ដ ដែលច្បាស់ជាមកដល់ក្នុងពេលឆាប់ៗ ។ សមាគមអាស៊ាន បានស្ថិតនៅជាអព្យាក្រឹត ហើយបានទទួលការបន្ទូបន្ទាយយ៉ាងសម្បើមទាំងពីខាងកម្ពុជាក៏ដូចវៀតណាម ។

ដំណើរទស្សនកិច្ចបន្តកន្ទុយគ្នា នៃបណ្ដាបេសកជនកុម្មុយនិស្ដ បានចាប់ផ្ដើមនៅខែមករា ឆ្នាំ១៩៧៨ ដោយការធ្វើទស្សនកិច្ចរបស់ ង្វៀនឌុយទ្រិញ រដ្ឋមន្ត្រីការបរទេសរបស់វៀតណាមនៅក្នុងប្រទេសបួននៃសមាគមអាស៊ាន[២៤] ។ គាត់បានសម្រេចធ្វើកិច្ចព្រមព្រៀងមួយជាមួយប្រទេសហ្វីលីពីន ដែលក្នុងនោះជម្លោះទាំងអស់ នៅពេលអនាគតនឹងត្រូវចរចា និងសម្រេចក្នុងស្មារតី «សម្រុះសម្រួល និងមិត្តភាព» មួយ ។ នៅប្រទេសថៃ អ្នកតំណាងរបស់វៀតណាម បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មមួយ ។

ដំណើរផ្ទួនៗគ្នានៃទស្សនកិច្ចទាំងនោះ បានថយចុះជាបណ្ដោះអាសន្ន នៅពេលដែលប្រទេសវៀតណាម និងកម្ពុជា ពិភាក្សាអំពីសំណើសន្តិភាពផ្សេងៗ ។ បន្ទាប់មក ក្រុងភ្នំពេញបានច្រានចោលផែនការសន្តិភាព ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ១៩៧៨ របស់វៀតណាម ហើយក្រោយមកមិនយូរប៉ុន្មាន គណៈកម្មាធិការមជ្ឈិមបក្សវៀតណាមបានរួមប្រជុំគ្នា និងបានធ្វើការសម្រេចចិត្តចូលលុកលុយប្រទេសកម្ពុជាជាសម្ងាត់ ។

ក្រុងភ្នំពេញបានបន្តធ្វើការវាយប្រហាររបស់ខ្លួន តាមព្រំដែនប្រទេសទាំងពីរ គឺប្រឆាំងនឹងប្រទេសថៃផង ប្រទេសវៀតណាមផង ។ ប្រការនេះបានជំរុញឲ្យពួកថៃ ស្នើដាក់បញ្ចូលប្រទេសឥណ្ឌូចិន ទាំងអស់ក្នុងតំបន់សន្តិភាពមួយ ដែលនឹងរួមបញ្ចូលទាំងប្រទេសអាស៊ាន ។ ទាំងកម្ពុជា ទាំងវៀតណាម គ្មានរំភើបរីករាយនឹងគំនិតនេះទេ ។

ចលនានៃការចរចាទៅវិញទៅមកផ្នែកការទូតចេះតែបន្តទៅមុខទៀត ។ នៅខែឧសភា ក្រុងភ្នំពេញបានសម្រេចធ្វើកិច្ចព្រមព្រៀងមួយជាមួយសិង្ហបុរី ដើម្បីធ្វើការផ្លាស់ប្ដូរខាងពាណិជ្ជកម្ម និងការរៀបចំផ្នែកទូរគមនាគមន៍រវាងប្រទេសទាំងពីរឡើងវិញ ។ ប៉ុន្តែ អាស៊ាននៅតែមិនកាន់ជើងខាងណាជានិច្ច ។

នៅខែមិថុនា ឆ្នាំ១៩៧៨ ពួកកម្ពុជាបានដាក់ឲ្យពួកវៀតណាមពិនិត្យនូវសំណើសន្តិភាពរបស់គេម្ដង ៖ វានឹងមានការជួបប្រជុំពិភាក្សាគ្នា ក្នុងគោលបំណងរិះរកដំណោះស្រាយមួយតាមការចរចានៅដំណាច់ឆ្នាំ បើសិនជាវៀតណាមសន្យាជៀសវាង «អំពើអរិភាពទាំងអស់» ចាប់ពីពេលនេះទៅ ។ ពួកវៀតណាមបានចាត់ទុកការស្នើនេះ ជារឿង «គួរឲ្យអស់សំណើច» ហើយបានលើកសំណើប្រឆាំងមួយទៅវិញ គឺការឈប់បាញ់គ្នាជាបន្ទាន់មួយ និងការបង្កើតតំបន់គ្មានកងទ័ពមួយ នៅតាមបណ្ដោយព្រំដែនរួម ។ ប្រទេសកម្ពុជាបានឆ្លើយតបថា នេះគ្រាន់តែ

ជា «រនាំងផ្សែង» ថ្មីមួយទៀតប៉ុណ្ណោះ ហើយបានចោទប្រកាន់ក្រុងហាណូយថា បានបញ្ជូនពួកវិច្ឆេទករមកក្រុងភ្នំពេញ ដើម្បីរៀបចំរដ្ឋប្រហារមួយជាសម្ងាត់ ។

នៅខែដដែលនេះ ពួកអ្នកភៀសខ្លួនតាម ទូក ចាប់ផ្តើមចាកចេញពីប្រទេសទាំងហ្វូងៗ ។ បណ្តាប្រទេសនៃសមាគមអាស៊ាន បានចាប់ផ្តើមធ្វើការអំពាវនាវមួយចំពោះប្រទេសរីកចម្រើននានា ដោយស្នើសុំឲ្យបញ្ជាក់ច្បាស់លាស់ ពីចំនួនពួកអ្នកភៀសខ្លួនឥណ្ឌូចិនដែលពួកគេទទួលឲ្យស្នាក់នៅមានប៉ុន្មាន ។ សេចក្តីអំពាវនាវនេះប្រៀបដូចការកៀបសង្កត់ផ្លូវចិត្តមួយយ៉ាងខ្លាំង ។ ក្រោយមកប្រទេសខ្លះនៃសមាគមអាស៊ានបានរុញច្រានឲ្យពួកអ្នកភៀសខ្លួនទៅវិញដោយគ្មានអាណិតអាសូរ -ទូកអ្នកភៀសខ្លួនជាច្រើន ត្រូវបានបញ្ជាឲ្យបើកទៅសមុទ្រវិញ ហើយពួកអ្នកភៀសខ្លួនកម្ពុជា បញ្ជូនទៅចម្ការមីននៅតាមព្រំដែន- ពីព្រោះបណ្តាប្រទេសដែលមានឧស្សាហកម្មលូតលាស់បានបដិសេធមិនទទួលពួកគេទេ ។

អគ្គស្នងការទទួលបន្ទុកជនភៀសខ្លួនរបស់អង្គការសហប្រជាជាតិ បានប្រកាសនៅក្រុងហ្សឺណែវថា មនុស្សមួយលាននាក់បានភៀសខ្លួនចេញពីប្រទេសវៀតណាម និងកម្ពុជាក្នុងពេលថ្មីៗនេះ- ប៉ុន្តែ ជាពិសេសប្រទេសវៀតណាម ។

ក្នុងសប្តាហ៍ដែលមានជាបន្តបន្ទាប់មកទៀត ក្រុងហាណូយ បានបញ្ជូនអនុរដ្ឋមន្ត្រីការបរទេស ផាន់ហៀន ក្នុងដំណើរទស្សនកិច្ចជាហូរហែថ្មីមួយនៅតាមប្រទេសជាច្រើន នៃសមាគមអាស៊ាន ដើម្បីបង្វែរការយកចិត្តទុកដាក់ពីបញ្ហាជនភៀសខ្លួនតាមទូក និងប្រទេសកម្ពុជា ។ គាត់បានប្រកាសថា គាត់មកពិភាក្សាពីសំណើ«តំបន់សន្តិភាព» និងបង្ហាញនូវការយល់ព្រម របស់ប្រទេសគាត់ចំពោះគំនិតបង្កើតប្លុកអាស៊ានមួយ ។ផាន់ហៀន ប្រាថ្នាបំបាត់ការភ័យ បារម្ភដែលឃើញប្រទេសវៀតណាម ចូលលុកលុយប្រទេសកម្ពុជា ឬក្លាយទៅសម្ពន្ធមិត្រដ៏ជិតស្និទ្ធមួយរបស់សហភាពសូវៀត ។

ក្រោយមកមិនយូរប៉ុន្មាន ពួកអ្នកភៀសខ្លួនកម្ពុជា បានចូលជំនួសរឿងរបស់គាត់ម្តង ។ ពួកអ្នកភៀសខ្លួនប្រមាណជាមួយរយនាក់បានសម្រេចឆ្លងកាត់ព្រំដែនទៅដល់ប្រទេសថៃ ដោយជោគជ័យ និងបានផ្តល់នូវភស្តុតាងថ្មីៗជាច្រើន ស្តីពីលទ្ធផលនៃការប្រែប្រួលដ៏អាថ៌កំបាំង ដែលកំពុងកើតមានដោយចៃដន្យនៅកម្ពុជាប្រជាធិបតេយ្យ ។ ប្រហែលនៅជំនាន់នោះដែរ សមាគមមួយដើម្បីសិទ្ធិមនុស្ស បានបើកធ្វើសន្និសីទកាសែតមួយ ដោយរៀបរាប់ពីការបង្រ្កាប និងការភ័យរន្ធត់ដែលមានជាទូទៅនៅកម្ពុជា ។

នៅខែកញ្ញា ក្រុងភ្នំពេញបានប្រជែងនឹងក្រុងហាណូយយ៉ាងចេញមុខ ដើម្បីទទួលបានការគាំទ្រពីរដ្ឋមិនមែនកុម្មុយនិស្តនានានៅអាស៊ី ។ ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំក្រុងប៉េកាំង ត្រូវធ្វើឲ្យភ្ញាក់ផ្អើលស្រឡាំងកាំង នៅពេលដែលសមភាគីកម្ពុជារបស់គាត់ប្រកាសថា រដ្ឋាភិបាលរបស់ខ្លួនចង់ធ្វើឲ្យមានទំនាក់ទំនងជាធម្មតាជាមួយក្រុងកង់បែរ៉ា ។ នៅទីបំផុត ប្រទេសកម្ពុជា និងប្រទេសវៀតណាមបានផ្តល់ទៅឲ្យបណ្តាប្រទេសអាស៊ាន នូវអ្វីដែល

ប្រទេសទាំងនោះប្រាថ្នាចង់បាន គឺការសន្យាយ៉ាងឱឡារិកបញ្ឈប់ការគាំទ្រទាំងអស់ ចំពោះការបះបោរនៃពួកកុម្មុយនិស្ត ដែលកំពុងកើតមាននៅខាងក្រៅព្រំដែនប្រទេសរបស់ពួកគេទាំងពីរ ។

ផាំ វ៉ាន់ដុង រដ្ឋមន្ត្រីទី១របស់វៀតណាមដ៏មានឈ្មោះល្បីម្នាក់ បានត្រូវអញ្ជើញឲ្យទៅធ្វើទស្សនកិច្ចនៅប្រទេសប្រាំនៃសមាគមអាស៊ាន [ក្រោយមក មាន៦ប្រទេសគឺថែមប្រទេសប្រ៊ុយណេ មួយទៀត] ។ នៅទីនោះគាត់បានផ្សព្វផ្សាយនូវរបៀបបកស្រាយរបស់វៀតណាមស្តីពីសង្គ្រាម និងអ្នកភៀសខ្លួនតាមទូក ហើយសន្យាថាប្រទេសវៀតណាមនឹងឈប់គាំទ្រចលនាកុម្មុយនិស្តទាំងអស់ ដែលបះបោរប្រឆាំងនៅក្នុងបណ្តាប្រទេសទាំងនេះ ។ ការសន្យារបស់ ផាំ វ៉ាន់ដុង នេះបានត្រូវបានសង្កត់បញ្ជាក់ជាសាធារណៈ និងធ្វើឲ្យគេចាប់អារម្មណ៍យ៉ាងខ្លាំង ក្នុងឱកាសនៃដំណើររបស់គាត់នៅប្រទេសម៉ាឡេស៊ី ព្រោះថា គាត់បានដាក់កម្រងផ្កាមួយ នៅវិមានរំឭកវិញ្ញាណក្ខន្ធទាហានដែលស្លាប់ដោយការប្រយុទ្ធទល់នឹងពួកឧទ្ទាមកុម្មុយនិស្តរបស់ប្រទេសម៉ាឡេស៊ី ក្នុងអំឡុងទសវត្សរ៍ ១៩៦០ ។ ការលះបង់ដែលធ្វើឲ្យស្រឡាំងកាំងនូវមនុស្សដែលសន្មតថាជាបងប្អូនរួមអាវុធរបស់ខ្លួននេះ បង្ហាញឲ្យឃើញនូវអ្វីដែលប្រទេសវៀតណាមប្រុងប្រៀបធ្វើពលិកម្មជាស្រេចដើម្បីយកឈ្នះប្រទេសកម្ពុជា ។

នៅខែតុលា ឆ្នាំ១៩៧៨ អៀង សារី ក៏បានទៅធ្វើទស្សនកិច្ចនៅបណ្តាប្រទេសអាស៊ានទាំងនោះ ។ កន្លែងឈប់សំចតសំខាន់បំផុតរបស់គាត់ គឺក្រុងបាងកក ជាទីដែលគាត់បានសន្យានឹងពួកថៃថា នឹងលែងមានបញ្ហានៅតាមបណ្តោយព្រំដែនរួមរបស់គេទៀតហើយ ។ គាត់ក៏បានសន្យាដូចគ្នាថា កម្ពុជាលែងគាំទ្រពួកឧទ្ទាមកុម្មុយនិស្តថៃដែរ ។ ទំនាក់ទំនងរដ្ឋ និងរដ្ឋពិតជាមានទម្ងន់ធ្ងន់ជាងការទាក់ទងរវាងបក្ស និងបក្ស ហើយប្រទេសថៃធ្លាប់មានកិត្យានុភាពសំខាន់មួយចំពោះពួកកុម្មុយនិស្តកម្ពុជា ៈ បើក្រុងបាងកកមិនគាំទ្រពួកខ្មែរក្រហមទេ យ៉ាងហោចប្រទេសថៃត្រូវនៅជាអព្យាក្រឹតដែរ ។ ប៉ុន្តែ ពួកមិត្តចិននៅកម្ពុជាបានយកចិត្តទុកដាក់ធ្វើអ្វីមួយស្រេចទៅហើយ ដើម្បីទទួលបានការគាំទ្ររបស់ពួកថៃ ។

ដូច្នេះ តេងស៊ាវពីង បានរួមជាមួយមន្ត្រីកុម្មុយនិស្តខ្លះក្នុងដំណើរបន្តៗគ្នាដើម្បីទៅបញ្ចោរយកផលប្រយោជន៍នៅប្រទេសនានានៃសមាគមអាស៊ានដែរ ។ ប្រទេសចិនសង្ឃឹមលើកយកបុព្វហេតុខ្មែរក្រហមមកនិយាយ ដោយធ្វើឲ្យរំដើបរំជួលពីស្រមោលវាតទីនិយមរបស់សូវៀតនៅក្នុងតំបន់ ។ នៅខណៈនេះពួកចិនបានចាត់ទុកប្រទេសវៀតណាមថា ជាខ្ញុំបម្រើរបស់សូវៀតដោយចេញមុខ ។ ពួកកម្ពុជាបានយកតម្រាប់តាមពួកចិនដែរ ហើយនៅក្នុងអំឡុងទស្សនកិច្ចរបស់គាត់នៅប្រទេស ហ្វីលីពីននៅខែតុលា អៀង សារី បានអះអាងថា ពួកខ្មែរក្រហមបានសម្លាប់ទីប្រឹក្សាសូវៀតពីរនាក់នៅក្នុងសង្គ្រាមប្រឆាំងនឹងប្រទេសវៀតណាម ។

វាយឺតពេលណាស់ទៅហើយដើម្បីត្រឡប់មកក្រោយវិញ ។ តំបន់នេះបានឈានចូលទៅក្នុងភ្នក់ភ្លើងសង្គ្រាមជាស្រេច ហើយប្រទេសទាំងអស់តែងនឹកគិតពីផលប្រយោជន៍ផ្ទាល់របស់ពួកគេជាធម្មតា ។ បណ្តាប្រទេសនៃសមាគមអាស៊ានបាន សម្រេចចិត្តស្ថិតនៅ“អព្យាក្រឹត” ក្នុងការប្រឈមមុខតតាំងរវាងកម្ពុជា និង

វៀតណាម ។

ការអំពាវនាវទាំងនេះ ដែលរៀបចំឡើងក្នុងគោលបំណងជួយគាំទ្រប្រទេសអាស៊ាន បានទទួលលទ្ធផលដូចដែលគេសង្ឃឹមទុកមែន ៖ ការរក្សាស្ថានភាពដូចមុនដដែល ។ សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍យល់ឃើញថា គ្មានហេតុផលណាមួយដែលត្រូវបោះបង់អព្យាក្រឹតភាពរបស់ខ្លួន ដើម្បីពួកខ្មែរក្រហម ឬពួកវៀតណាមឡើយ ។ ដូច្នេះហើយបានជាអាស៊ានពុំតវ៉ា ឬប្រឆាំងនឹងការរំលោភសិទ្ធិមនុស្សនៅកម្ពុជាប្រជាធិបតេយ្យ ហើយមិនប្រឆាំងនឹងឥរិយាបថរបស់វៀតណាមចំពោះពួកអ្នកភៀសខ្លួនតាមទូកនោះ ។ សមាគមអាស៊ានយកចិត្តទុកដាក់នឹងរឿងផ្សេងជាជាងបញ្ចុះបញ្ចូលឲ្យបស្ចិមប្រទេសទទួលយកពួកអ្នកភៀសខ្លួនឥណ្ឌូចិន ដែលទៅពីប្រទេសវៀតណាម-ឡាវ-កម្ពុជា និងសម្រាលបន្ទុកយ៉ាងធ្ងន់ធ្ងរមួយផង ។

ការចេញទៅទាំងហ្វូងភ្លាមៗ និងប្រកបដោយទុក្ខភ័យបានធ្វើឲ្យតំបន់ជិតឆ្នេរ និងឆ្នេរសមុទ្ររបស់ប្រទេសទាំងអស់នៃសមាគមអាស៊ានប្រែទៅជាខុសពីសភាពដើម ។ ប្រទេសម៉ាឡេស៊ី បានប្រើកោះទាំងមូលមួយសម្រាប់ឲ្យពួកភៀសខ្លួនស្នាក់នៅ ។ ពួកចោរប្លន់បានចេញប្លន់តាមសមុទ្រ និងរំលោភស្ត្រីភេទ ហើយសម្លាប់ជនជាតិវៀតណាមទន់ខ្សោយជាច្រើន មុនដែលទូករបស់ពួកគេចូលទៅដល់ច្រាំង ។ ឆ្នេរសមុទ្រពណ៌មាសរបស់តំបន់បានត្រូវចូលលុកពាសពេញដោយពួកអ្នកភៀសខ្លួន ដែលស្រេកឃ្លានដាច់ដាច និងរាយដេរដាសទៅដោយកម្ទេចកម្ទីទូក ។ ពួកសិល្បករម៉ាឡេស៊ី ដែលប្រើប្រាស់ក្រណាត់បាទិក សម្រាប់គូរគំនូរ បានរកឃើញប្រធានបទថ្មីមួយក្នុងហ្វូងអ្នកភៀសខ្លួនតាមទូកដែលឃំសស្រាក់ទាំងនេះសម្រាប់បង្ហាញក្នុងគំនូរដ៏វិចិត្ររបស់ពួកគេ ។

បណ្ដាលរដ្ឋទាំងអស់បានធ្វើសកម្មភាពអ្វីមួយដូចគ្រោងទុកជាមុន ៖ សមាគមអាស៊ាននៅតែប្រកាន់ជំហរអព្យាក្រឹត ។ រដ្ឋកុម្មុយនិស្តនានាបានចូលខាងបក្សពួកមួយ ឬមួយទៀតនៅក្នុងជម្លោះដើម្បីប្រទេសកម្ពុជា ។ បស្ចិមប្រទេសបង្ហាញឲ្យឃើញថា ខ្លួនត្រូវធ្វើឲ្យខ្វល់អំពល់ដូចគ្នា ដោយបញ្ហាជនភៀសខ្លួនក៏ដូចជាបញ្ហាសង្គ្រាមដែលច្បាស់ជាមកដល់ក្នុងពេលឆាប់ៗ ។ ការរៀបចំផ្សេងៗ ត្រូវបានគេរៀបចំដាក់ស្ទើរតែរួចរាល់អស់ហើយ ។ ទោះជាបញ្ហាភស្តុតាងនៃរឿងរំលោភសិទ្ធិមនុស្សក៏ត្រូវបញ្ចប់ដោយ អៀង សារី រួចអស់ហើយដែរ ក្នុងឱកាសនៃដំណើររបស់គាត់ទៅអង្គការសហប្រជាជាតិនៅខែតុលា រួចរាល់ហើយដែរ នៅពេលដែលគាត់បានអញ្ជើញយើងឲ្យទៅធ្វើទស្សនកិច្ចនៅប្រទេសរបស់គាត់ ។

នៅខែកញ្ញា ពួកអ្នកកាសែតក្រុងហុងកុងបានទៅធ្វើទស្សនកិច្ចនៅកម្ពុជា ហើយនៅដើមខែវិច្ឆិកា គណៈប្រតិភូជាន់ខ្ពស់មួយក្រុមរបស់ចិន ក៏បានទៅដល់ភ្នំពេញដែរ ។ គណៈប្រតិភូនោះ រួមមានជាពិសេសអ្នកទទួលខុសត្រូវផ្នែកសន្តិសុខផ្ទៃក្នុងរបស់បក្សកុម្មុយនិស្តចិនផង - ជាមនុស្សម្នាក់ដែលធ្លាប់ដឹកនាំការធ្វើវិសុទ្ធកម្មជាច្រើនក្នុងប្រទេសផ្ទាល់របស់ខ្លួន ។ ចាប់ពីថ្ងៃនេះទៅ ប្រទេសជាតិត្រូវប្រកាសដាក់ក្នុងភាពមានអាសន្ន ។ របបខ្មែរក្រហម បានបញ្ជូនទូរលេខទៅឲ្យ រីឆាដ ឌុដម៉ាន់ និងខ្ញុំ(អ្នកនិពន្ធ) ដោយប្រាប់ដំណឹងថា ដំណើរមកកម្ពុជារបស់អស់

លោក នឹងចាប់ផ្តើមនៅថ្ងៃសៅរ៍ ទី៩ ខែធ្នូ ឆ្នាំ១៩៧៨ ។ កាលពីមួយសប្តាហ៍មុនដំណើរទៅដល់របស់យើង ពួកវៀតណាមបានប្រកាសពីការបង្កើតរណសិរ្សកម្ពុជារបស់គេជាសាធារណៈ គឺរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលកម្មវិធីគ្មានអ្វីក្រៅពី «ផ្តួលរំលំបនប្រតិកិរិយា ប៉ុល ពត, អៀង សារី» ឡើយ ។ រណសិរ្សនេះមាន ហេង សំរិន ជាប្រធានដឹកនាំ ។ គាត់ជាសមាជិកគណៈកម្មាធិការប្រតិបត្តិបក្ស នៅភូមិភាគបូព៌ា និងជាមេបញ្ជាការកងពលធំលេខ៤ ប្រចាំភូមិភាគនេះ ដែលធ្លាប់ភៀសខ្លួនទៅប្រទេសវៀតណាម នៅខែកញ្ញា បន្ទាប់ពីការធ្វើវិសុទ្ធកម្មដែលបញ្ជាដោយមជ្ឈិម ។

ចាប់ពីថ្ងៃនេះទៅ «កូនអុក» ទាំងអស់ ត្រូវបានគេរៀបចំដាក់តាមទីកន្លែងរួចជាស្រេច ។ សង្គ្រាមក្នុងនាមនៃប្រទេសកម្ពុជាអាចចាប់ផ្តើមបានហើយ ។

# ជំពូកទី១១
# ការវិលត្រឡប់ទៅក្រុងភ្នំពេញម្តងទៀត

*“ពាក្យខ្ញុំក្នុងអត្ថបទនេះសម្គាល់អ្នកនិពន្ធ គឺអ្នកស្រី អេលីហ្សាបែត បេ៊កខ័រ”*

គ្រាន់តែយន្តហោះចិនរបស់យើងចុះដល់ចំណតអាកាសយានដ្ឋានពោចិនតុងភ្លាម ខ្ញុំហាក់ដូចជាមានអារម្មណ៍ថា នឹងបានជួបក្នុងគំនិតរវើរវាយរបស់ខ្ញុំ នូវមនុស្សម្នាក់ក្រោយពីឃាតក្នុងយ៉ាងយូរ[១] ។ ខ្ញុំធ្លាប់ស្គាល់ប្រទេសកម្ពុជាដែរ ក្នុងរយៈពេលនៃសង្គ្រាម ព្រោះខ្ញុំធ្លាប់រស់នៅទីក្រុងភ្នំពេញ ពីរឆ្នាំ ក្នុងឋានៈជាបេសកជនពិសេសរបស់កាសែតវ៉ាស៊ីនតោនប៉ុស្តិ៍ ។ ក្រោយមក នៅពេលដែលខ្ញុំស្ថិតនៅទីក្រុងវ៉ាស៊ីនតោន ដើម្បីសរសេរអត្ថបទឲ្យកាសែត ខ្ញុំនៅតែយកចិត្តទុកដាក់ចំពោះប្រទេសនេះជានិច្ច ហើយក្នុងអាយុសាមសិបមួយឆ្នាំ ខ្ញុំមានឈ្មោះល្បីល្បាញជាប្រទេសអ្នកដើងចាស់ ឬជាអ្នកឯកទេសខាងបញ្ហាកម្ពុជាទៅហើយ ។ ប៉ុន្តែ អ្វីដែលខ្ញុំមើលឃើញក្រោមក្រសែភ្នែកខ្ញុំនៅពលនេះ គឺពុំមែនប្រទេសកម្ពុជា ដែលខ្ញុំធ្លាប់ស្គាល់ក្នុងរយៈពេលសង្គ្រាមទេ គឺជាប្រទេសមួយដែលរត់គេចចេញពីខ្ញុំ ។ ផ្លូវថ្នល់ទាំងឡាយស្ងាត់ជ្រងំ គ្មានអ្វីមួយកម្រើកសោះ ។ គ្មានអ្នកណាម្នាក់និយាយមករកយើងឡើយ លើកលែងតែអ្នកនោះបានទទួលបញ្ជាពីអ្នកកាន់អំណាចពីអង្គការ ។ គ្មានការធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយទាល់តែសោះ បើអ្នកណាមួយមិនត្រូវបានអនុញ្ញាតដោយអង្គការ ។

យើងបានទៅដល់ប្រទេសកម្ពុជាពីទីក្រុងប៉េកាំងតាមជើងយន្តហោះ មានពីដងក្នុងមួយសប្តាហ៍ ដែលកាលនោះជាផ្លូវទាក់ទងផ្នែកពាណិជ្ជកម្មតែមួយគាត់រវាងប្រទេសកម្ពុជា និងពិភពខាងក្រៅ ។ គេបានបង្គាប់ឲ្យយើងនៅអង្គុយស្ងៀមសិន រហូតទាល់តែគេហៅឈ្មោះយើងតាមក្រុមៗ ។ ក្រុមដំបូងបំផុត ដែលចុះពីយន្តហោះ សុទ្ធតែពួកអ្នកជំនាញការចិន មានចំនួនប្រមាណជាដប់ពីរនាក់ ដែលតំណាងប្រហែលបីភាគបួន នៃអ្នកដំណើរទាំងអស់ ។ បន្ទាប់មក គឺពួកអឺរ៉ុបផាត់ៗ ដុះក្បាលពោះ មួយក្រុមតូច និងគណៈប្រតិភូមួយនៃគណបក្សពលករជប៉ុន ។ នៅទីបំផុត គេបានហៅឈ្មោះយើង ហើយយើងបានចុះពីយន្តហោះ ដើម្បីឡើងជិះក្នុងឡានម៉ែសឺដេស ពីរគ្រឿងដែលចតនៅជើងជណ្តើរនោះ ។ នេះគឺ ជាការចាប់ផ្តើមដំណើរទស្សនកិច្ច “ដែលមានក្របខ័ណ្ឌ” របស់យើងចំពោះការបដិវត្តន៍ខ្មែរក្រហម ។ យើងស្ថិតក្នុងដុំមូលមួយ ដែលរមៀលនៅមុខមនុស្សម្នា និងទីកន្លែងផ្សេងៗដែលគេអាចធ្វើឲ្យផុះ បែកបានដោយខំប្រឹងបង្ខិតដកខ្លួនឲ្យផុតពីអំណាចរបស់បក្ស ។

ប្រទេសដែលគេអាចឈោងដៃដល់ បានបង្ហាញខ្លួនឡើងជាប្រទេសដែលមានរឿងអាថ៌កំបាំង ធ្វើមិនឲ្យគេយល់បាន ។ ក្រុងភ្នំពេញដែលខ្ញុំមើលឃើញពីចម្ងាយ មានសម្រស់យ៉ាងសោះកក្រោះ របៀបជាប្រាង្គតម្កល់សពមួយ ។ ខ្សែលួសបន្លាប្រែះចាប់ដែលគេដាក់ព័ទ្ធជុំវិញសួនច្បារ មហាវិថី និងគ្រឹះស្ថាននានា របស់រដ្ឋាភិបាលក្នុងពេលសង្គ្រាមត្រូវរលាយបាត់អស់មិនដឹងទៅណាៗ ។ របាំងទាំងឡាយ នៅតាមផ្លូវត្រូវបានជំនួសដោយដើង

ដើមផ្កាក្រដាស និងដើមចម្ប៉ា ។ គ្រឹះស្ថានសាធារណៈជាច្រើនត្រូវបានលាបពណ៌ថ្មីឡើងវិញ -ស្ថានីយរថភ្លើង គេលាបពណ៌សស្រអាប់ ដូចផ្កាថ្ម អតីតទីស្តីការរដ្ឋមន្ត្រីក្រសួងឃោសនាការ គេលាបពណ៌លឿងភ្លាវ ។ សួនច្បារសាធារណៈទាំងឡាយ មានសភាពល្អស្អាតឥតហ្មង កម្រាលស្មៅត្រូវគេកាត់តម្រឹមឡើងរាបស្មើ ។ គ្មានអ្វីមួយនៅរាយពាសពេញលើវិថីនានាឡើយ គ្មានភាពក្រខ្វក់ គ្មានកាកសំរាម ។ ប៉ុន្តែទីនេះក៏គ្មានមនុស្សនៅដែរ គ្មានទាំងកង់ទាំងរថយន្តធំដឹកអ្នកដំណើរក្នុងក្រុង ហើយមានរថយន្តតិចតួចណាស់ ។

ដោយឆ្លងកាត់ទីក្រុងពីម្ខាងទៅម្ខាង ខ្ញុំក្រឡេកឃើញកងទ័ពមួយក្រុមតូចកំពុងដើរយាមល្បាត ប៉ុន្តែអ្នកទាំងនោះហាក់ដូចជាគ្មានស្ថានភាពការពារឲ្យប្រាកដប្រជាឡើយ ។ តួបសម្រាប់កងទ័ពយាម សុទ្ធតែលាបពណ៌បៃតង និងទឹកមាសឡើងរលើបរលោង ។ ខ្ញុំពុំឃើញមានលេណដ្ឋានធំៗ រថក្រោះ និងកាំភ្លើង ដ.ស.អា ឡើយ ។ បើទោះជាប្រទេសស្ថិតក្នុងស្ថានភាពប្រុងជើងការក៏ដោយ ក៏រដ្ឋធានីនេះ គ្មានបង្ហាញឲ្យឃើញសញ្ញាណាមួយក្នុងការរៀបចំធ្វើសង្គ្រាមឡើយ ។

ពីចំណតអាកាសយាន គេបាននាំយើងដោយត្រង់ឆ្ពោះទៅកាន់លំនៅដ្ឋានផ្លូវការរបស់យើង ដែលស្ថិតនៅតាមផ្លូវធំជាងគេនៃទីក្រុង គឺមហាវិថីមុនីវង្ស ក្នុងផ្នែកមួយនៃទីក្រុងដែលខ្ញុំធ្លាប់ស្គាល់យ៉ាងច្បាស់ ។ គឺជាគ្រឹះស្ថានឯកជនបុរាណមួយ ដែលសង់ឡើងប្រមាណជាងដប់ម៉ែត្រប៉ុណ្ណោះ ពីមាត់ច្រកចូលខាងក្រោយវិមានរដ្ឋចម្ការមន ។ វិមានដ៏ទំនើបនេះ ត្រូវបានកសាងឡើងដើមដំបូងសម្រាប់សម្តេច ព្រះនរោត្តម សីហនុ កណ្តាលខទ្យានដ៏ធំមួយ ។

ធាតុអាកាសត្រជាក់ល្មមនៅខែធ្នូ ដែលត្រូវនឹងចិត្តរបស់យើងទាំងស្រុង ក៏ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយក៏គេបើកម៉ាស៊ីនត្រជាក់ដំណើរការតាមបំណងរបស់យើងជានិច្ច ។ ខ្ញុំត្រូវគេនាំទៅកាន់បន្ទប់មួយនៅជាន់ទីមួយ ។ ក្នុងទូនៃបន្ទប់ងូតទឹកមានឃើញថ្នាំលាបក្រចកបារាំងពីរដប ក្រែមលាបបបូរមាត់ប្រាំបំពង់ ម្សៅមួយប្រអប់ ប៉ុន្តែគ្មានឃើញសាប៊ូទេ ។ មនុស្សប្រុសៗ ត្រូវគេនាំទៅសម្រាកនៅជាន់ទីពីរ ដោយដាក់ឲ្យសម្រាកក្នុងបន្ទប់ដេកមួយម្នាក់ ក្បែរបានីយដ្ឋានមួយ ដែលមានលាក់ទុកដប ស្រាវីស្គី ស្រាហ្ស៊ីន *(Gin)* និងស្រាកូញាក់យ៉ាងច្រើន ។ កញ្ចប់បារីរបស់កម្ពុជា ត្រូវបានគេដាក់ស្ទើរនៅគ្រប់កន្លែងក្នុងផ្ទះនេះ ។ យើងជាអ្នកកាសែតបស្ចិមប្រទេសដំបូងបង្អស់ដែលត្រូវបានអនុញ្ញាតឲ្យចូលប្រទេសនេះ ហើយការទទួលបដិសណ្ឋារកិច្ចដែលគេបានធ្វើចំពោះពួកយើងបង្ហាញឲ្យឃើញថា ពួកខ្មែរក្រហមចេះដឹងពីរបៀបរបបរស់នៅប្រចាំថ្ងៃរបស់យើងដែរ ។

ថ្ងៃទីមួយ ពួកម្ចាស់ផ្ទះរបស់យើង បានទុកទ្វារចំហ ហើយកាលបើពួកអ្នកការពាររបស់យើងចេញផុតភ្លាម យើងបានចេញធ្វើដំណើរកំសាន្តមួយយ៉ាងយូរក្នុងតំបន់ជិតៗនោះ ។ ថ្វីបើខ្ញុំធ្លាប់ស្គាល់ទីក្រុងនេះបន្តិចក៏ដោយ ក៏ខ្ញុំត្រូវវង្វេងវង្វាន់ដែរ ដោយខ្ញុំរកចំណុចចំណាំទិសពីមុនមិនឃើញ ។ ក្នុងរយៈពេលសង្គ្រាម ហាងកាត់ដេរសម្លៀកបំពាក់ស្ត្រី ពួកអ្នកលក់ផ្លែឈើត្រាំតាមរទេះរុញ ផ្លូវរថយន្តនៅពីមុខស្ថានីយចាក់សាំងធ្លាប់បានជួយខ្ញុំឲ្យស្គាល់

ឈ្មោះ វិថីជាច្រើន ។ ប្រការនេះ បានរលាយបាត់អស់ទៅហើយ ហើយមហាវិថីមុនីវង្សមានសភាព ហាក់ដូចជាជ្រលងភ្នំដ៏សែនស្ងាត់មួយ ។ យើងបានធ្វើដំណើរចំពាក់កណ្តាលទ្រូវផ្លូវ ដោយគ្មានរថយន្តណាមួយបើកបរសោះឡើយ ។

យើងបានចាកចេញពីមហាវិថីនេះ ដើរតម្រង់ទៅមាត់ទន្លេរហូតដល់មហាវិថីព្រះនរោត្តម និងវនៅមានឯករាជ្យ ហើយពីទីនេះទៅទិសខាងត្បូង គឺស្ថានទូតរបស់អាមេរិកាំង ។ កាលពីមុន ឌុចម៉ាន់ និង ខាដវ៉ែល ធ្លាប់ស្នាក់នៅទីក្រុងភ្នំពេញមួយរយៈខ្លីដែរ ប៉ុន្តែ គ្មានអ្នកណាម្នាក់ ធ្លាប់បានរស់នៅក្នុងប្រទេសនេះទេ ។ ខ្ញុំត្រូវតែធ្វើខ្លួនទៅជាមគ្គុទ្ទេសក៍នាំផ្លូវដ៏មានសមត្ថភាពម្នាក់ ប៉ុន្តែ ខ្ញុំដឹងខ្លួនថា ខ្ញុំមានលក្ខណៈជាអ្នកទេសចរណ៍ម្នាក់ដូចពួកអ្នកទាំងពីរដែរ ។ ម៉្យាងវិញទៀត យើងទើបនឹងស្គាល់គ្នាក្នុងពេលថ្មីៗ ហើយយើងមិនទាន់ទុកចិត្តគ្នាទាំងស្រុង នៅឡើយទេ ។ នៅពេលធម្មតា រឿងនេះពុំមានសារសំខាន់ឡើយ ប៉ុន្តែ ចំពោះដំណើរនេះ យើងទាំងអស់គ្នាសុទ្ធតែដឹងពីមុខនាទីរបស់យើងដែលជា«កសិណសាក្សី» ដ៏មានឯកសិទ្ធិរបស់ការបដិវត្តន៍ ហើយប្រហែលជាសាក្សីនៃសង្គ្រាមដែលពិភពលោកទាំងមូល បាននិយាយទុកជាមុនដែរ ។

តាមសំបកខាងក្រៅ យើងទាំងអស់គ្នាសុទ្ធតែជាអ្នកមានសម្ថភាព និងបទពិសោធន៍បន្ថែមមួយ ។ ខាដវ៉ែលជាសាស្ត្រាចារ្យសាកលវិទ្យាល័យម្នាក់ មានឯកទេសខាងបញ្ហាអាស៊ីអាគ្នេយ៍ ។ គាត់ធ្លាប់ធ្វើដំណើរមកប្រទេសកម្ពុជាគត់ នៅចុងទសវត្សឆ្នាំ១៩៦០ ដើម្បីធ្វើអង្កេតលើការចោទប្រកាន់ផ្សេងៗ អំពីការរំលោភអព្យាក្រឹតរបស់កម្ពុជាពីសំណាក់សហរដ្ឋអាមេរិក ។ គាត់ជាសហនិពន្ធសៀវភៅមួយ ស្តីពីសង្គ្រាមនៅកម្ពុជា និងការពារបុព្វហេតុបដិវត្តខ្មែរក្រហមតាំងពីថ្ងៃជ័យជម្នះ នៅឆ្នាំ១៩៧៥ ។ ខាដវ៉ែល ធ្លាប់បានទៅធ្វើទស្សនកិច្ចនៅប្រទេសចិនកុម្មុយនិស្ត និងកូរ៉េខាងជើងផង ។ គាត់ត្រូវបានអញ្ជើញឲ្យមកក្រុងភ្នំពេញក្នុងឋានៈជា«មិត្ត» នៅពេលដែល ឌុដម៉ាន់ និងខ្ញុំ ក្នុងឋានៈជាអ្នកកាសែតដដែល ។ នេះជាភាពខុសគ្នា ដែលពួកខ្មែរក្រហមវិនិច្ឆ័យថាជារឿងសំខាន់ ។

ឌុដម៉ាន់ ជាអ្នកយកពត៌មានល្បីឆ្នើមម្នាក់ ពោរពេញទៅដោយបទពិសោធន៍ ។ គាត់បានធ្វើដំណើរទៅប្រទេសវៀតណាមជាញឹកញាប់ក្នុងរយៈពេលសង្គ្រាម ហើយដណ្តើមបានភាពល្បីល្បាញយ៉ាងសម្បើម ជាមួយនឹងអត្ថបទរិះគន់របស់គាត់ស្តីពីការប្រឹងប្រែងធ្វើសង្គ្រាមរបស់អាមេរិកាំងនៅក្នុងប្រទេសនេះ ។ ត្រូវចាប់ខ្លួននៅដើមដំបូងនៃសង្គ្រាមនៅប្រទេសកម្ពុជា នៅឆ្នាំ១៩៧០ គាត់ធ្លាប់ត្រូវពួកកុម្មុយនិស្តវៀតណាមឃុំខ្លួនអស់រយៈពេល សែសិបថ្ងៃ នៅក្នុងទឹកដីរបស់កម្ពុជា ។ គាត់ធ្លាប់បាននិយាយប្រកបដោយសមានចិត្តក្នុងកាសែតរបស់គាត់ អំពីចលនាកុម្មុយនិស្តដែលកំពុងវិវឌ្ឍន៍ឈានឡើង ដែលគាត់បានសង្កេតឃើញក្នុងរយៈពេលនៃការជាប់ឃុំរបស់គាត់ ។ បន្ទាប់ពីសង្គ្រាម ឌុដម៉ាន់ គឺជាអ្នកកាសែតអាមេរិកាំងដំបូងបង្អស់ ដែលត្រូវគេអញ្ជើញឲ្យត្រឡប់មកប្រទេសវៀតណាមជាថ្មី ហើយបានដើរធ្វើទស្សនកិច្ចនៅពាសពេញប្រទេសនោះ ។ ឥឡូវនេះ គាត់ជិតដល់ពេល

ចូលរ៉ឺត្រែតទៅហើយ ហើយការអញ្ជើញនេះ បានធ្វើឲ្យគាត់ទៅជាអ្នកកាសែតដំបូងគេម្នាក់ក្នុងចំណោមអ្នកកាសែតដំបូងៗ ដែលបានទៅមើលការបដិវត្តន៍របស់កម្ពុជា ។ គាត់គឺជាប្រធានផ្នែកកិច្ចការនយោបាយបរទេសរបស់កាសែត ហើយប្រាកដណាស់ គាត់ជាមនុស្សដែលមានបទពិសោធន៍យ៉ាងច្រើនក្នុងចំណោមយើងទាំងបីនាក់ ។ រវាងពួកយើង គាត់គឺជាមនុស្សតែម្នាក់គត់ ដែលមិនធ្លាប់បានសរសេរពីរឿងខ្មែរក្រហមទាល់តែសោះបន្ទាប់ពីឆ្នាំ១៩៧៥ ហើយគាត់ត្រូវតែបញ្ចេញទស្សនៈមួយស្ដីពីការបដិវត្តន៍របស់ខ្មែរក្រហម ។ ខាដវែល ត្រូវគេដាក់សម្មិតនាមក្លាមៗថា ជា អេដហ្គា ស្នូវ (Edgar Snow) របស់ប្រទេសកម្ពុជា ។

ការយកពត៌មានផ្សេងៗរបស់ខ្ញុំនៅបរទេសកំពុង កំណត់ព្រំដែននៅប្រទេសកម្ពុជា ខ្ញុំដឹងខ្លួនថា ខ្ញុំមានចិត្តជាប់ជំពាក់នឹងប្រវត្តិសាស្ត្រប្រទេសនេះយ៉ាងខ្លាំង ។ ខ្ញុំជាចំណែកមួយនៃក្រុមអ្នកកាសែតលោកខាងលិចមួយក្ដាប់តូច ដែលធ្លាប់ចាប់ផ្ដើមធ្វើការដោយ "ជួយបំបិទបំបាំង" សង្គ្រាម ។ គឺនៅប្រទេសកម្ពុជា ដែលយើងទាំងអស់គ្នាបានក្លាយទៅជាអ្នកចាស់ចិត្តចាស់គំនិតក្នុងវិជ្ជាជីវៈកាសែត ។ យើងបានបាត់បង់មិត្តភាពជាច្រើនក្នុងសង្គ្រាម ហើយបានមានមុខមើលឃើញនូវការចាប់ផ្ដើមសោកនាដកម្មមួយក្នុងចំណោមសោកនាដកម្មធំៗ នៃសតវត្សនេះ ដោយគ្មានបានដឹងពីរឿងនេះឡើយ ។ បន្ទាប់ពីសង្គ្រាម ភាគច្រើនក្នុងចំណោមពួកយើង មិនព្រមជឿការរ៉ាយរ៉ាប់ពីរឿង ដ៏គួរឲ្យព្រឺខ្លាចរបស់ពួកអ្នកភៀសខ្លួនឡើយ ដោយខ្លាចក្រែងប្រការនេះបានត្រឹមតែមានន័យថា ប្រជាជនកម្ពុជាជាច្រើនដែលយើងទាំងអស់គ្នា បានចងមិត្តភាពអាចត្រូវរងគ្រោះថ្នាក់នៅពេលនេះ ។ យើងបានគិតពីអ្វីៗដែលអាក្រក់បំផុតក្នុងរយៈពេលសង្គ្រាម ៖ ការទម្លាក់គ្រាប់បែក ការបំផ្លិចបំផ្លាញ ការធ្លាក់ចុះយ៉ាងរហ័សរបស់ប្រទេស –ប្លែកអំពីអ្វីដែលកើតឡើងនៅប្រទេសវៀតណាម ។ ពិតមែនតែខ្ញុំធ្លាប់បានសរសេរនៅឆ្នាំ១៩៧៣ នូវអត្ថបទអង្កេតមួយ ក្នុងចំណោមអត្ថបទអង្កេតដ៏កម្របំផុត ស្ដីពីពួកខ្មែរក្រហមក្នុងរយៈពេលសង្គ្រាមក៏ដោយ (អត្ថបទស៊ីជម្រៅមួយរបស់កាសែតវ៉ាស៊ីនតោនប៉ុស្ដិ៍ ដែលពិពណ៌នា "ឆន្ទៈដែកថែប" និងស្មារតីមោះមុត ដែលនាំខ្មែរក្រហមទៅរកជ័យជម្នះ ជាមួយនឹងការបង្ហាញឲ្យដឹងពីប្រវត្តិសាស្ត្រ និងបណ្ដាមេដឹកនាំដែលបញ្ជាពួកគេរួមទាំង សាឡុត ស ផង) ក៏ខ្ញុំមានការងឿងឆ្ងល់ដូចអ្នកឯទៀតដែរ ដោយការជម្លៀសប្រជាជន និងការបំផ្លិចបំផ្លាញសង្គមខ្មែរ ដែលមានជាបន្តបន្ទាប់មកទៀត ។ ខ្ញុំនឹកក្នុងចិត្តតែខ្លួនឯងថា ខ្ញុំត្រូវតែត្រឡប់ទៅប្រទេសកម្ពុជាម្ដងទៀត ដើម្បីពិនិត្យមើលការបដិវត្តន៍ដោយផ្ទាល់ភ្នែករបស់ខ្ញុំ ។ ថ្វីបើត្រូវកំហិតឲ្យស្ថិតនៅតែទីក្រុងវ៉ាស៊ីនតោន ដោយមុខនាទីថ្មីៗរបស់ខ្ញុំក៏ដោយ ក៏ខ្ញុំខំស្វះស្វែងរកបានពត៌មានដ៏កម្រផ្សេងៗស្ដីពីប្រទេសកម្ពុជា ដែលអាចយកជាការបាន ហើយខ្ញុំខំប្រឹងប្រែងធ្វើឲ្យទទួលបានទិដ្ឋាការមួយ ។ រាល់ពេលដែល អៀង សារី ធ្វើដំណើរមកកាន់អង្គការសហប្រជាជាតិ ខ្ញុំតែងសាកល្បងរកជួបគាត់ជានិច្ច ហើយនៅទីបំផុត ខ្ញុំបានញ៉ាំងឲ្យគាត់ជឿថា ខ្ញុំជាអ្នកកាសែតស្រីម្នាក់ដែលគាត់ត្រូវតែអញ្ជើញឲ្យទៅប្រទេសកម្ពុជាម្ដងទៀត ។

ក្នុងពេលជាមួយគ្នានោះ ខ្ញុំបានសរសេរអត្ថបទសំខាន់ៗជាច្រើន ស្ដីពីការបដិវត្តន៍ ដើម្បីធ្វើជាលេស

ជាពិសេស អត្ថបទរិះគន់ដ៏វែងមួយក្នុងសៀវភៅពីរក្បាល ដោយផ្ដោតទៅលើប្រធានបទនេះ ហើយក្នុងនោះខ្ញុំបានសរសេរថា ភស្ដុតាងផ្សេងៗដែលផ្ដល់ឲ្យដោយពួកអ្នកភៀសខ្លួន មានយ៉ាងច្រើនលើសលុបហើយថា ការបដិវត្តន៍ជាព្រឹត្តិការណ៍គួរឲ្យខ្លាចមួយ ។ ប៉ុន្តែ ខ្ញុំបានទទួលទិដ្ឋាការមួយ ប្រហែលពីព្រោះពួកកម្ពុជានឹកឃើញជាពិសេសនូវអត្ថបទពត៌មានរបស់ខ្ញុំ ដែលកំពុងរិះគន់តួនាទីរបស់សហរដ្ឋអាមេរិក ក្នុងសង្គ្រាមនោះហើយមើលទៅ ។ ម្យ៉ាងទៀត ខ្ញុំធ្លាប់ជាអ្នកតំណាងឲ្យការសែតវ៉ាស៊ីនតោនប៉ុស្ដិ៍ ដែលជាកាសែតមួយដ៏សំខាន់ បើសិនជាពួកខ្មែរក្រហម ចង់ធ្វើឲ្យរដ្ឋាភិបាលអាមេរិកាំងយល់ច្បាស់ពីខ្លួន ពិតប្រាកដ ។

យើងទាំងបី បានទៅដល់ប្រទេសកម្ពុជាប្រកបដោយទស្សនៈប្លែកៗពីគ្នាចំពោះការបដិវត្តន៍ ។ ខាដវែលសង្ឃឹមលើភាពប៉ិនប្រសប់របស់គាត់ខាងផ្នែកនយោបាយ ។ ខ្ញុំបានផ្ដើមធ្វើសកម្មភាពតាំងពីយូរមកហើយ ដើម្បីបង្ហាញឲ្យឃើញអត្ថន័យនៃការបដិវត្តន៍ តាមគម្រោងផ្ទាល់របស់ខ្លួន និងតាមមុខវិជ្ជាជីវៈ ចំណែកឯ ឌុដម៉ាន់ វិញ គាត់បានបង្ហាញស្ដីពីបញ្ហានៃភាពព្រងើយកន្តើយមិនអើពើគួរឲ្យចង់បានមួយ ។ យើងបានរកឃើញដោយឆាប់រហ័ស នូវអ្វីដែលប្រទេសកម្ពុជាផ្ដល់ឲ្យយើងម្នាក់ៗដឹង ។ អ្វីដែលយើងមិនបានដឹងមុនដំណើរទៅដល់របស់យើង គឺមរណភាពរបស់គ្នាយើងម្នាក់ ដែលគេបានរៀបចំគម្រោងការមុនរួចជាស្រេច ។

ការលួចវេះនៅថ្ងៃដំបូងរបស់យើង បានត្រូវបញ្ចប់ មុនពេលដែលយើងសម្រេចចិត្តវិលត្រឡប់មកកន្លែងស្នាក់នៅវិញ ។ មគ្គុទ្ទេសក៍នាំផ្លូវម្នាក់ ក្នុងចំណោមមគ្គុទ្ទេសក៍នាំផ្លូវជាច្រើន បានបញ្ឈប់ឡានម៉ែស៊ីដេសមួយគ្រឿងក្បែរពួកយើង ហើយបានធ្វើសញ្ញាឲ្យពួកយើងឡើងជិះលើរថយន្ត ។ គេបាននាំយើងមកកាន់និវេសនដ្ឋានវិញ ដោយបានបង្គាប់បញ្ជាឲ្យយើងស្ថិតនៅតែក្នុងផ្ទះដាច់ខាត រហូតដល់មានបទបញ្ជាថ្មី ៖ យើងលែងបានចេញទៅខាងក្រៅតែឯកឯងទៀតហើយ គឺវាមានគ្រោះថ្នាក់ខ្លាំងណាស់ ។ គេមិនដឹងមុនពីអ្វីដែលសត្រូវ (គេមិនដែលចង្អុលឈ្មោះប្រាប់សោះ) អាចធ្វើសកម្មភាពឡើយ ។ យើងត្រូវគេកំណត់ឲ្យនៅតែក្នុងផ្ទះ យ៉ាងដាច់ខាត ។

ឌុដម៉ាន់ និងខ្ញុំ ធ្លាប់បានទទួលពត៌មានស្ដីពីស្ថានការណ៍ប្រកបដោយគ្រោះថ្នាក់នៅកម្ពុជា មុនដំណើរទៅដល់របស់យើងម្ល៉េះ ។ ខ្ញុំបានជជែកពិភាក្សាជាមួយបណ្ដាអ្នកជំនាញការនៃក្រសួងការពារប្រទេស និងនាយកដ្ឋានសេ.អ៊ី.អា. នៅក្រុងវ៉ាស៊ីនតោនដែរ ។ នៅក្រុងបាងកក និងក្រុងប៉េកាំង ខ្ញុំធ្លាប់បានជួបនឹងពួកអ្នកឯកទេសខាងនយោបាយ និងយោធាអាមេរិកាំង បារាំង កាណាដា អូស្ត្រាលី និងចិនថែមទៀត ។ គ្មានអ្នកណាម្នាក់និយាយប្រាប់ខ្ញុំឲ្យដឹងមុនអំពីសង្គ្រាមកម្រិតធំមួយ រវាងប្រទេសវៀតណាម និងកម្ពុជាឡើយ ។ តាមទស្សនៈអ្នកទាំងនោះថា យ៉ាងច្រើនណាស់ ពួកវៀតណាមនឹងរុលដំណើររហូតដល់ទន្លេមេគង្គ ហើយនឹងឈប់នៅត្រឹមនោះ ដោយពេញចិត្តកាន់កាប់ត្រួតត្រាត្រើយខាងកើតទន្លេ មុននឹងបន្តដំណើរឆ្ពោះទៅរដ្ឋធានីទៀត ក្នុងកំឡុងពេលនៃការវាយលុកនៅពេលក្រោយមួយ ។ អ្នកជំនាញការអាមេរិកាំងដ៏ឆ្នើមម្នាក់ ក្នុងចំណោមអ្នកជំនាញការឆ្នើមៗដែលជាមិត្តចាស់ម្នាក់ បានអះអាងប្រាប់ខ្ញុំនៅក្រុងបាងកកថា សេចក្ដីភ័យខ្លាចរបស់ខ្ញុំពីរឿងពាក្យចចាមអារ៉ាមទាំងឡាយ

និងពីសន្តិសុខផ្ទាល់របស់ខ្ញុំ សុទ្ធតែជារឿងគ្មានមូលដ្ឋាន ។ គាត់បានបង្ហើយថា "វានឹងទៅជារឿងងាយស្រួលបំផុត" ។

ពិតណាស់ នៅពេលដែលអ្នកការពារយើងព្រមានប្រាប់យើងថា របបរបស់គេមិនធានា សន្តិសុខឲ្យយើងបានទេ បើសិនជាយើងចេញដើរតែម្នាក់ឯង គឺដើម្បីរារាំងយើងមិនឲ្យមើលឃើញអ្វីដែលគេហាមឃាត់ ។ ប៉ុន្តែភាពស្ងប់ស្ងាត់ដែលធ្វើឲ្យព្រួយបារម្ភ និងផ្លូវថ្នល់ទាំងឡាយដែលមានសភាពស្ងាត់ជ្រងំការមានអារម្មណ៍ដើរកំសាន្តក្នុងពិភពចម្លែកមួយ បានធ្វើឲ្យពួកយើងដណ្តឹងសួរក្នុងចិត្តថា បើសិននៅទីនេះ ពុំមាន"សត្រូវ" -ពួកវៀតណាម ឬពួកផ្សេងទៀត តើអ្នកណាមួយដែលចូលចិត្តឃើញយើងស្លាប់ជាងសត្រូវទាំងនោះ ។ ពត៌មានផ្សេងៗដែលគេបញ្ជូនមកឲ្យយើងមុនការមកដល់របស់យើង ឥឡូវនេះហាក់ដូចជាមិនសូវសំខាន់ទៅវិញ ។ តែប៉ុន្មានថ្ងៃប៉ុណ្ណោះ យើងទាំងបីបានត្រូវធ្វើឲ្យជឿប្រាកដក្នុងចិត្តថា ស្ថានការណ៍ក្នុងប្រទេសនេះ មានសភាពគួរឲ្យខ្វាចរន្ធត់ជាងពិភពលោកខាងក្រៅគិតឃើញទៅទៀត ។

ក្នុងការប៉ុនប៉ងថ្មីមួយដើម្បីស្វែងយល់ប្រទេសកម្ពុជាជាថ្មី ដែលខ្ញុំធ្លាប់ស្គាល់ច្បាស់ នៅព្រឹកថ្ងៃបន្ទាប់ ខ្ញុំបានភ្ញាក់ពីដំណេកលឿនជាងសព្វដង ហើយខ្ញុំបានចេញទៅក្រៅមុនការមកដល់នៃក្រុមការពារពួកយើង ។ ទ្វារចម្រឹងដែកពុំមានចាក់សោទេ ។ ព្រះអាទិត្យរះខ្ពស់ណាស់ទៅហើយ ដោយបញ្ចេញរស្មីមកលើទ្រូងផ្លូវភ្លឺឆ្វះដូចប្រដាប់បញ្ចាំងពន្លឺមួយ ។ លើកនេះខ្ញុំបានជួបពួកកម្មករ ដែលឈរនៅលើចិញ្ចើមថ្នល់ជាក្រុមតូចៗ ដើម្បីរង់ចាំរថយន្ត ដែលត្រូវដឹកយកពួកគេទៅកាន់ស្រែចម្ការ ឬរោងចក្រនានា ។ ក្រៅពីពួកអ្នកទាំងនោះ គឺគ្មានឃើញមនុស្សណាម្នាក់សោះនៅតាមផ្លូវ ។

ខ្ញុំដើរក្បែរចិញ្ចើមថ្នល់ក្រោមដើមឈើទាំងឡាយ ដោយគេចលាក់ខ្លួនម្តងៗផង នៅពេលដែលខ្ញុំឮសំឡេងឡានមួយគ្រឿងបើកមក ។ ម្តងនេះ ខ្ញុំអាចដើរគ្មានគោលដៅទៅតាម ចំណង់ចិត្តរបស់ខ្ញុំ ដោយអាចរកឃើញនូវអ្វីដែលយើងពុំអាចមើលឃើញពេលធ្វើដំណើរពីពោចិនតុងមក ឬក្នុងរយៈពេលនៃការដើរកំសាន្តដ៏ខ្លីរបស់យើងកាលពីមួយថ្ងៃមុន ។ ហួសពីមហាវិថីព្រះមុនីវង្សទៅ ទីក្រុងហាក់ដូចជាត្រូវបោះបង់ចោលទាំងស្រុង ។ តាមផ្លូវជាច្រើនដែលនៅចំហៀងមហាវិថី គេហដ្ឋានដែលមានសួនច្បារល្អៗ ភោជនាគារ និងហាងលក់ទំនិញ សុទ្ធតែរាតត្បាតដោយស្មៅចង្រៃ ។ សួនដាំដើមឈើសម្រាប់មនុស្សដើរកំសាន្តត្រូវបានកែប្រែឲ្យក្លាយទៅជាកន្លែងចាក់សំរាមវិញ ។ នៅក្នុងនោះ គេរៀបគរទុកគ្រឿងសង្ហារិមផ្សេងៗ ឬគ្រឿងយន្តគ្រប់ប្រភេទ ។

ឆ្ងាយបន្តិចទៅមុខទៀត គឺអតីតផ្សារថ្មី ដែលមានដាំដើមចេកពាសពេញ ហើយស្លឹករបស់វាហាក់ដូចជាផ្តិតធ្លាក់សំយ៉ាកពីរានលក់ទំនិញ ។ ទីនេះ ក៏គ្មានឃើញមនុស្សណាម្នាក់រស់នៅដែរ ។ ដោយបន្តដំណើរឆ្ពោះទៅទិសខាងជើងតាមផ្លូវមុនីវង្ស ខ្ញុំបានដើរកាត់ពីមុខអតីតធនាគារពាណិជ្ជកម្មខ្មែរ (បេ កា សេ) ហើយខ្ញុំនឹកទៅដល់មិត្តរបស់ម្នាក់ឈ្មោះ មី កុម្ភត ដែលធ្លាប់ធ្វើការនៅទីនេះ ។ ខ្ញុំដឹងថាគាត់ស្ថិត នៅក្នុងប្រទេសកម្ពុជានៅឡើយ ។

មកដល់កន្លែងនេះ ខ្ញុំនឹកតែក្នុងចិត្តថា ខ្ញុំអាចជួបប្រទះដោយចៃដន្យនូវអតីតធនាគារិកនេះ ឬមិត្តភក្តិផ្សេងទៀតដែលខ្ញុំធ្លាប់ស្គាល់ ។ ខ្ញុំបានពិនិត្យឃើញមនុស្សពីរនាក់ កំពុងដើរចេញពីអតីតវិទ្យាល័យ ដេកាត ដើម្បីមកសែងពាងជាច្រើន ដែលស្ថិតនៅផ្លូវម្ខាងទៀត ។ ដោយស្លៀកពាក់ឯកសណ្ឋានខ្មែរក្រហមពណ៌ខ្មៅ ពួកគេបានឈប់នៅស្ងៀមមួយកន្លែងហើយសម្លឹងមើលមកខ្ញុំគ្មានដាក់ភ្នែក ។ ខ្ញុំបានគោរពអ្នកទាំងពីរតាមរបៀបខ្មែរ ។

ឥឡូវនេះ ខ្ញុំអាចមើលឃើញសណ្ឋាគាររ៉ូយ៉ាល់ ឬសណ្ឋាគារឡឺភ្នំដែលបន្ទប់លេខ២៧ ធ្លាប់ជាការិយាល័យធ្វើការ និងជាកន្លែងដេករបស់ខ្ញុំ ។ មុននឹងដើរឆ្លងកាត់ផ្លូវ ខ្ញុំបានក្រឡេកមើលខាងឆ្វេងដែរ ឃើញគោញីពីរក្បាល កំពុងស៊ីស្មៅក្នុងទីធ្លាធំទូលាយមួយ ដែលកាលពីមុនជាកន្លែងវិហារកាតូលិករបស់បារាំង ។ គេបាននិយាយប្រាប់ខ្ញុំថា វិហារនេះ ត្រូវខ្មែរក្រហមបំផ្លាញខ្ទេចខ្ទីដូចធនាគារជាតិកម្ពុជាដែរ ប៉ុន្តែ ខ្ញុំមិននឹកស្មានថាអ៊ីចឹងគេបានកម្ទេចវា ដោយគ្មានឃើញសល់ថ្មមួយដុំឡើយ ។ ខ្ញុំបានប្រញាប់ប្រញាល់ចាកចេញទៅវិញភ្លាម ។

នៅពេលក្រឡេកឃើញដំបូង សណ្ឋាគារនេះ ហាក់ដូចជាបានទទួលការថែទាំល្អប្រសើរ ដូចក្នុងរយៈពេលសង្គ្រាមដែរ ប៉ុន្តែ កាលបើមកឈរក្នុងសាលធំ ខ្ញុំសម្គាល់ឃើញថា វាមានរូបភាពដូចអ៊ីៗនៅក្នុងទីក្រុងដែរ ៈ យ៉ខាងក្រៅនៅល្អឥតខ្ចោះ ផ្នែកខាងក្នុងមានសភាពទ្រុឌទ្រោម ។ ដោយគ្មានគិត ខ្ញុំបានដើរចូលទៅជិតបន្ទប់ទទួលភ្ញៀវ ។ ពុំឃើញមានកូនសោរបន្ទប់និមួយៗព្យួរនៅប្រអប់ឈើឡើយ ។ ភ្លាមនោះស្រាប់តែមានបនុស្សប្រុសម្នាក់លេចចេញមក ហើយនិយាយភាសាខ្មែរមករកខ្ញុំ ។ ដោយខ្ញុំស្តាប់មិនបានគាត់បានបណ្តេញខ្ញុំចេញដោយលើកដៃជាសញ្ញា ។ ម្តងនេះខ្ញុំដើរតម្រង់មកវត្តព្រះពុទ្ធសាសនានៅវត្តភ្នំ ដែលខ្ញុំត្រូវបានទទួលរាក់ទាក់ដោយយុវជនបដិវត្តន៍ពីរនាក់ ដែលសើចញឹមៗដាក់ខ្ញុំ ។ ខ្ញុំបានថតរូបពួកគេ ប៉ុន្តែ ការកំសាន្តនេះមានរយៈយ៉ាងខ្លី ហើយពួកគេ ក៏បានប្រាប់ខ្ញុំតាមកាយវិការថា កុំឲ្យខ្ញុំប្រថុយដើរឆ្ងាយហួសពីទីនេះទៅទៀត ។

ខ្ញុំបែរត្រឡប់ក្រោយចាកចេញពីទីនោះមកផ្ទះវិញទាំងហត់នឿយ ទាំងមួរហ្មង និងពោរពេញដោយការច្របូកច្របល់ក្នុងចិត្ត ។ ពេលខ្ញុំខំប្រឹងស្វែងយល់ពីអតីតប្រទេសកម្ពុជាពេលណា វាកាន់រហូតផុតពីខ្ញុំកាលនោះដែរ ។ កម្មាភិបាលក្មេងម្នាក់ទៀតដែលជិះម៉ូតូបានបើកមកឈប់ជិតខ្ញុំ ខ្ញុំបានលើកមេដៃជាសញ្ញាទៅរកគាត់ ។ គាត់បញ្ឈប់ម៉ូតូ ខ្ញុំបានឡើងជិះពីក្រោយគាត់ ហើយបង្ហាញផ្លូវដែលត្រូវត្រឡប់ទៅផ្ទះខ្ញុំវិញ ។ នេះជាការសាកល្បងដើរកំសាន្តតាមត្រង់របស់ខ្ញុំជាលើកចុងក្រោយ ដើម្បីបង្កើតទីក្រុងដែលខ្ញុំធ្លាប់ស្គាល់ឡើងវិញ ជាកន្លែង ដែលខ្ញុំអាចសួររកមនុស្សដែលខ្ញុំមិនធ្លាប់ស្គាល់សោះ ឲ្យជូនខ្ញុំត្រឡប់មកវិញ ដោយមានសេចក្តីទុកចិត្តទាំងស្រុង ។

កម្មាភិបាលក្មេងនេះប្រហែលយល់ព្រមជូនដំណើរ ខ្ញុំត្រឡប់មកវិញ ប៉ុន្តែ គាត់ត្រូវធ្វើឲ្យអាក់ខាន ដោយការមកដល់នៃក្រុមអ្នកការពាររបស់ខ្ញុំ ។ ខ្ញុំធ្លាប់ត្រូវអវត្តមាននៅពេលគេហៅរកនៅពេលព្រឹក ។ គេបានបញ្ជាខ្ញុំឲ្យចុះពីម៉ូតូ ហើយឡើងជិះក្នុងរថយន្តម៉ែសឺដេសវិញ ។ គេបាននាំខ្ញុំយ៉ាងលឿនមកកាន់និវេសនដ្ឋានវិញ ដែល

ចាប់ពីថ្ងៃនេះទៅ ទ្វារដែកត្រូវបានគេចាក់សោគ្រប់ពេលម៉ោង ។

ឥឡូវនេះ ខ្ញុំលែងអាចបានជួបទៀតក្នុងទីក្រុងភ្នំពេញថ្មី ដែលខ្ញុំធ្លាប់ស្គាល់នូវសម្រាប់ការទទួលឲ្យស្នាក់អាស្រ័យដោយការគួរសម និងរាក់ទាក់ ជាមួយនឹងការទាក់ចិត្តដោយឡែក ជាទីក្រុងមួយនៃអ្នកកាន់ព្រះពុទ្ធសាសនានៃទ្វីបអាស៊ីនេះ ដែលមិនអាចក្លាយទៅជាទីក្រុងទំនើប ឬបែបបស្ចិមប្រទេសឡើយ ។ រដ្ឋធានីទទួលរងគ្រោះកាចជាច្រើន ៖ អំពើពុករលួយការលោភលន់ទ្រព្យសម្បត្តិគអំពើហិង្សបិទមុខ និងភាពមិនអើពើចំពោះទុគ៌ភាពរបស់អ្នកដទៃ ។ ទិដ្ឋភាពទាំងពីរនេះ បានកើតមានព្រមគ្នាក្នុងអតីតក្រុងភ្នំពេញ ដូចក្នុងចំណោមប្រជាជនខ្មែរទាំងមូលដែរ ។ អ្នកខ្លះដូចរូបខ្ញុំជាដើមធ្លាប់ស្រឡាញ់ចូលចិត្តប្រទេសនេះ និងអាថ៌កំបាំងរបស់ខ្លួន ។ អ្នកខ្លះទៀត ធ្លាប់បានរកឃើញទាំងអស់សង្ឃឹមនូវភាពចុះដុនដាប និងជំនឿក្រៅសាសនា ។ ប៉ុន្តែ សម្រាប់ទាំងអស់គ្នាប្រទេសកម្ពុជាជាប្រទេសមួយដែលមិនអាចភ្លេចបាន ។ ពេលត្រឡប់មកដល់លំនៅដ្ឋានវិញ ខ្ញុំបានសន្យាធ្វើតាមច្បាប់វិន័យទាំងអស់ ៖ ខ្ញុំបានធ្វើឲ្យអ្នកដទៃស្ថិតក្នុងគ្រោះថ្នាក់ដូចខ្ញុំដែរ ។ យើងបានស្រស់ស្រូបអាហារពេលព្រឹកក្នុងបន្ទប់ទទួលទានបាយ ជាកន្លែងដែលយើងបរិភោគបាយរួមគ្នាគ្រប់តែពេល ។ ម្ហូបអាហារត្រូវគេនាំយកមកពីផ្ទះបាយមួយនៅជិតៗនោះ ដោយអ្នកជិះម៉ូតូម្នាក់ដែលយកមកដាក់នៅមាត់ទ្វារផ្ទះខាងក្រោយ ។ យើងត្រូវបានបម្រើដោយបុគ្គលិកមួយ ក្រុមមានខ្មែរបីនាក់ ៖ អ្នកបម្រើវ័យក្មេងម្នាក់ និងយុវនារីធ្វើកិច្ចការផ្ទះពីរនាក់ ។ យើងក៏មានអ្នកបើកឡានម្នាក់ និងអ្នកការពារមួយក្រុម ។

នៅទីបំផុត ជួន ប្រសិទ្ធិ បានមកដល់ ដើម្បីចាប់ផ្តើមណែនាំយើងឲ្យស្គាល់ពីរបៀបរបបនៅទីនេះ ។ ឌុដម៉ាន់ និងខ្ញុំ ធ្លាប់បានជួបគាត់ដែរ នៅពេលដែលគាត់អមដំណើរ អៀង សារី ទៅក្រុងញូវយ៉ក ប៉ុន្តែ យើងទាំងពីរគ្មានអ្នកណាមួយដឹងថា គាត់ជាមិត្តដ៏ជិតស្និទ្ធបំផុតរបស់រដ្ឋមន្ត្រីការបរទេស និងជាមិត្តរបស់ ប៉ុល ពត ផ្ទាល់ ក្នុងសម័យនៅជានិស្សិតរៀននៅទីក្រុងប៉ារីសនោះទេ ។ នេះគឺជាមនុស្សទីមួយដែលយើងស្គាល់ច្បាស់ ហើយដែលគេបញ្ជូនមកឲ្យយើង ឃើញចាប់តាំងពីការមកដល់របស់យើង ។

ប្រសិទ្ធិ មានមាឌធំ និងមានពណ៌សម្បុរភ្លឺថ្លាជាងពួកខ្មែរភាគច្រើន ។ គាត់មានឫកពារសន្ធាស្ទើរតែដូចស្ដេចផែនដី បើប្រៀបធៀបនឹងពួកអ្នកបដិវត្ត ផ្សេងទៀតដែលយើងបានជួប ។ ក្នុងចំណែកនៅសល់នៃការស្នាក់អាស្រ័យ គាត់គឺជាខ្សែចំណងរបស់យើងជាមួយប្រទេសនេះ ជាមគ្គុទ្ទេសក៍នាំផ្លូវ និងជាអ្នកបកប្រែភាសារបស់យើង ។ គាត់ជាមនុស្សដែលត្រូវថ្នាក់លើចាត់តាំងឲ្យមកបង្ហាញនិមិត្តរូបប្រសើរៗបំផុត របស់ប្រទេសកម្ពុជាដល់ពួកអ្នកកាសែតបរទេស ។ ការណ៍ដែលគេប្រគល់ឲ្យគាត់មើលខុសត្រូវលើពួកយើង គឺជាសញ្ញាដ៏មានសារសំខាន់ដំបូងបំផុត ដែលគេផ្តល់ឲ្យចំពោះទស្សនកិច្ចរបស់យើង ។

គាត់បានចាប់ផ្តើមនិយាយដោយការធ្វើសេចក្តីរាយការណ៍មួយ ។ ក្នុងបន្ទប់បាយ យើងអង្គុយនៅជុំវិញតុចាំកត់ត្រាដោយយកចិត្តនូវតួលេខផ្សេងៗ ដែលគាត់ប្រាប់ឲ្យដឹងពីលទ្ធផលដ៏អស្ចារ្យខាងផ្នែកសេដ្ឋកិច្ច សេចក្តី

ប្រកាសផ្សេងៗស្តីពីប្រវត្តិនៃជម្លោះជាមួយប្រទេសវៀតណាម ទ្រឹស្តីផ្សេងៗដែលគាត់អះអាងពីទិសដៅរបស់ការបដិបវត្តន៍កម្ពុជា ។ ប៉ុន្តែ គាត់តែងតែវិលមក និយាយពីបញ្ហាពួកក្បត់វៀតណាមជានិច្ច ហើយម្យ៉ាងទៀត ដោយយើងបានយកជាប់ជាមួយនូវសៀវភៅខ្មៅរបស់របបនេះ ស្តីពីអំពើឈ្លានពានរបស់វៀតណាមផងនោះ គាត់បានផ្តែផ្តាំឲ្យយើងអាននៅពេលយប់ៗផង ។ នៅទីបញ្ចប់ យើងបានលើកយកបញ្ហាសិទ្ធិមនុស្សមកនិយាយ ហើយគាត់បានឆ្លើយមកវិញដោយសើចញឹមៗថា «ពួកអស់លោកនឹងបានឃើញមិនខាន គឺពុំមានបញ្ហាស្តីពីសិទ្ធិមនុស្សទេ ។ អស់លោកខ្វាយខ្វល់តែនឹងពួកក្បត់របស់បន លន់ នល់ ខ្លាំងពេក ហើយពុំបានយកចិត្តទុកដាក់នឹងប្រជាជនកម្ពុជាចំនួន៩០ភាគរយ ដែលរស់នៅប្រកបដោយជីវភាពល្អប្រសើរជាងមុន ដោយសារតែការបដិវត្តន៍ផងទេ» ។

ពេលម៉ោងដែលនៅសល់ក្នុងថ្ងៃនោះ និងថ្ងៃបន្ទាប់បានត្រូវយើងប្រើប្រាស់មួយភាគធំ សម្រាប់ការធ្វើទេសចរណ៍ ។ យើងមានសិទ្ធិទទួលបានកម្មវិធីដូច«បណ្តាគណៈប្រតិភូជាមិត្ត»នៃប្រទេសស៊ុយអែដ យូហ្គោស្លាវី និងប៊ែលហ្ស៊ិក ដែលមកកាលពីថ្ងៃមុនដែរ ។ ក៏ប៉ុន្តែ គ្រប់តែការដើរមើលរបស់យើង តែងតែមាននិរសារម្នាក់តាមដានយើងជាប់ជានិច្ច ។ គេបាននាំយើងទៅមើលព្រះបរមរាជវាំង និងព្រះវិហារព្រះកែវមរកត ដែល ប្រសិទ្ធិ បានធ្វើសេចក្តីរាយការណ៍ថ្មីមួយ ស្តីពីការគ្របដណ្តប់ផ្នែកវប្បធម៌របស់បារាំង ជាប្រធានបទដែលគាត់ហាក់ដូចជាចាំជាប់ក្នុងចិត្ត ។ គាត់បានចោទប្រកាន់ពួកបារាំងថា បានប្រមូលយករបស់របរមានតម្លៃ លួចប្លន់រូបបដិមាករ និងរតនវត្ថុរបស់ប្រទេសអស់ជាច្រើន ។ គាត់បានអះអាងថា ពួកប្រវត្តិវិទូបារាំង បានសរសេរប្រវត្តិសាស្ត្រកម្ពុជាឡើងវិញ លំអៀងទៅរកជោគជ័យផ្ទុសល់របស់ខ្លួន ឬរបស់វៀតណាម ។ គាត់គ្មាននិយាយមួយម៉ាត់សោះពីពួកអាមេរិកាំង ប្រហែលមកពីមូលហេតុខាងនយោបាយថ្មីៗ ហើយមើលទៅដោយគាត់ចូលចិត្តត្រៀមទុកការស្អប់ខ្ពើមរបស់គាត់ ប្រឆាំងនឹងអាណានិគមបារាំង ដែលគាត់ធ្លាប់ស្គាល់យ៉ាងច្បាស់ជាង ។

ចេញពីព្រះបរមរាជវាំង យើបានធ្វើដំណើរទៅកាន់សារមន្ទីជាតិ ដែលស្ថាបនាឡើងដោយពួកបារាំងដែរ ក្នុងរចនាប័ទ្មខ្មែរ និងដែលស្ថិតនៅផ្លូវម្ខាងក្បែរនោះ ។ ប្រសិទ្ធ បានណែនាំយើងឲ្យកត់សម្គាល់ថា សារមន្ទីរនេះត្រូវបានទទួលការថែទាំយ៉ាងប្រសើរ ហើយថា ការបដិវត្តន៍បានចាត់ទុកប្រកបដោយសេចក្តីពេញចិត្តពីអតីតកាលរបស់ប្រទេស ។ ប្រសិទ្ធិ បានរៀបរាប់ថា វត្ថុមួយចំនួនបានបាត់រកមិនឃើញ បណ្តាលមកពីការលួចប្លន់ ដែលកើតមានឡើងនៅទីបញ្ចប់នៃសង្គ្រាម ប៉ុន្តែ វត្ថុសិល្បៈភាគច្រើនដែលមានតម្លៃកាត់ថ្លៃមិនបាននោះ គឺស្ថិតនៅតាមកន្លែងដើមរបស់វាដដែល ។ ប៉ុន្តែវត្ថុទាំងនោះគ្មានអ្នកណាការពារ និងថែទាំឡើយ ៈ សត្វប្រចៀវជាច្រើនបានបញ្ចេញសំឡេងគ្រលួច ក្រោមមេដំបូល ធូលី និងសម្បុកពីងពាង រុំព័ទ្ធពីលើព្រះកេសរូបចម្លាក់ បណ្តាព្រះរាជាក្រុងអង្គរ អាចម៍សត្វផ្សេងៗ បានធ្វើឲ្យភក្ត្ររូបដិមាប្រឡាក់សសំព្រុះ ។

នៅពេលព្រលប់ បន្ទាប់ពីបរិភោគបាយល្ងាចរួច គេបាននាំយើងទៅទស្សនាខ្សែភាពយន្ត សម្រាប់

ឃោសនា ។ ការបញ្ចាំងបានចាប់ផ្ដើមនៅម៉ោងដប់យប់ ហើយរថយន្តរបស់យើងបានបើកបរនៅតាមផ្លូវនានាដែលងងឹតស្លុប និងស្ងាត់ជ្រងំ ។ ចង្កៀងដងគោមត្រូវគេបំភ្លឺតែក្នុងសង្កាត់ខ្លះនៃទីក្រុងប៉ុណ្ណោះ ។ យើងបានឆ្លងកាត់ពីមុខផ្ទះជាច្រើន ដែលមានពួកស្រីៗឱនឈ្ងោកពីលើម៉ាស៊ីនដេរធាក់ដោយជើង និងប្រមូលខោអាវពណ៌ខៀវរៀបចំទុកដាក់ ។ គ្មានសញ្ញាណាមួយបង្ហាញឲ្យឃើញជីវភាពផ្សេងក្រៅពីនេះឡើយ ។ រហូតមកដល់ពេលនេះយើងពុំដែលបានឮសំឡេងកុមារា-កុមារីទេ យើងឃើញតែពួកកម្មាភិបាលក្មេងៗ និងពួកកម្មករប៉ុណ្ណោះ ។ នៅទីនេះ គ្មានឃើញរានលក់ទំនិញ គ្មានក្រុមគ្រួសារ គ្មានយុវជនលេងកីឡា ឬកំសាន្តនៅលើ ចិញ្ចើមថ្នល់ឡើយ-នៅតាមផ្លូវ គ្មានឃើញមនុស្សម្នាក់សោះ គ្មានទាំងសត្វឆ្កែ ឬឆ្មាដើររកចំណីថែមទៀត ។

នៅថ្ងៃបន្ទាប់មក គេបាននាំយើងធ្វើដំណើរប្រាស់ទឹកទន្លេសាបតាមកាណូតកំសាន្តកញ្ចាស់មួយគ្រឿងដែលនៅមានវាំងននជីបជ្រួញៗ និងខ្នើយកើយជាច្រើននៅឡើយ ។ ការណូតបើកអែបតាមបណ្ដោយមាត់ច្រាំងទន្លេដែលពោរពេញទៅដោយចម្ការបន្លែផ្សេងៗ យើងបានឆ្លងកាត់ពីមុខស្ថានីយស្តុកប្រេងឫស្សីកែវ រោងចក្របង្កក់ជ័រកៅស៊ូ និងចម្ការចេកនានា ។ ខ្យល់រំភើយពេលព្រឹកព្រលឹម នៅតែមានធាតុត្រជាក់ស្រេងនៅឡើយក្នុងពេលដែលយើងបានមកដល់គោលដៅរបស់យើង គឺ«សហករណ៍នេសាទ» មួយដែលមានលក្ខណៈជាហ្វូងទូកមួយក្រុម ។ ប្រសិទ្ធិ បានបកប្រែនៅពេលដែលពួកអ្នកនេសាទនិយាយប្រាប់យើងពីសត្រូវដែលមានសម្បូរហូរហៀរពីការបែងចែកផលនេសាទស្មើៗគ្នា ពីការខុបត្ថម្ភផ្សេងៗរបស់ការបដិវត្ត ។

តមកទៀត យើងត្រូវគេនាំទៅកាន់អតីតអគ្គសេនាធិការកងទ័ព លន់ នល់ ដែលគេបានប្រែក្លាយឲ្យទៅជាសារមន្ទីរតាំងសម្ភារៈសង្គ្រាមវិញ ។ យុទ្ធជនក្មេងម្នាក់នៃភូមិភាគនិរតី បាននិយាយប្រាប់យើងពីការប្រយុទ្ធគ្នានៅកន្លែងធ្វើការចាស់របស់លោក សូស្ទេន ហ្វែណង់ដេស (អតីតមេបញ្ជាការកងទ័ព លន់ នល់) ហើយបានប្រើប្រាស់ផែនទីរបស់អតីតនាយអគ្គសេនាធិការរូបនេះ ដើម្បីពន្យល់ប្រាប់យើងពីលក្ខណៈងាយស្រួល ដែលពួកខ្មែរក្រហមបានវាយឈ្នះសាធារណរដ្ឋខ្មែររបស់ លន់ នល់ ទៀតផង ។ អ្វីដែលទាក់ទាញភ្នែក យើងជាងគេក្នុងទស្សនកិច្ចនេះ គឺសម្ភារសឹកដែលដណ្ដើមបានពីពួកវៀតណាមក្នុងពេលថ្មីៗ ៖ រថក្រោះរបាំងមុខការពារខស្ម័ន ដែលប្រើប្រាស់ដោយពួកវៀតណាម ដើម្បីការពារខ្លួនពីផ្សែងពុលអាថ៌កំបាំងមួយដែលតាមពួកខ្មែរក្រហមនិយាយ គឺខស្ម័នដែលពួកនោះប្រើប្រឆាំងនឹងកងទ័ពកម្ពុជា ។

យើងនៅមានការណាត់ជួបគ្នាមួយ ដែលបានគ្រោងទុកជាមុននៅទីក្រុងភ្នំពេញ មុននឹងយើងចេញដំណើរទៅជនបទនៅថ្ងៃស្អែក ។ យើងបានទៅទស្សនានៅវិទ្យាស្ថានសម្រាប់ការបណ្ដុះបណ្ដាល និងការផ្ដល់ពត៌មានផ្នែកវិទ្យាសាស្ត្រ ដែលជាស្នាដៃរបស់ ដួន មុំ បងប្រុសដ៏ល្បីល្បាញរបស់ ដួន ប្រសិទ្ធិ ។

នៅមាត់ទ្វារចូល យើងត្រូវបានទទួលស្វាគមន៍ដោយយុវបុរសម្នាក់ ដែលបានប្រាប់ឈ្មោះបដិវត្តតែមួយម៉ាត់របស់ខ្លួនថា គុន ។ គេបានណែនាំប្រាប់យើងថា គាត់ជាប្រធានវិទ្យាស្ថាននេះ អាយុម្ភៃប្រាំបីឆ្នាំ ហើយនេះ

ពុំមែនជារឿងអាថ៌កំបាំងទេ ។ ក្នុងកម្ពុជាប្រជាធិបតេយ្យ យើងតែងបានជួបប្រទះនឹងបាតុភូតរបៀបនេះ ជារឿយៗ ។ គឺសុទ្ធតែជាពួកកម្មាភិបាលដែលគេប្រគល់ភារកិច្ចឲ្យដឹកនាំស្ថាប័នមួយរបស់រដ្ឋមួយ ព្រោះគេអាចជឿទុកចិត្តខាងផ្នែកនយោបាយ ជាទូទៅ ច្រើនតែជាអតីតយុទ្ធជនក្នុងកងទ័ព ។ ពួកបញ្ញវន្តត្រូវធ្លាក់ទៅជួរទីពីរ ព្រោះពួកគេពុំមែនតំណាងប្រជាជន ។ ប៉ុន្មាននាទីក្រោយមក យើងបានជួបនឹង ជួន មុំ ដែលជាអ្នកនៅក្រោមបង្គាប់ គុនៈ ក្នុងឋានានុក្រម មុំ គ្រាន់តែជានាយកវិទ្យាស្ថានប៉ុណ្ណោះ ។ តាមការពិត យើងគ្មានដឹងថា មុំ ធ្លាប់អង្គុយក្បែរ ប៉ុល ពត ផ្ទាល់ ក្នុងឱកាសមហាសន្និបាតចុងក្រោយបំផុតកាលពីប៉ុន្មានខែមុន ហើយជាអ្នករៀបរាប់ប្រាប់ពួកមេដឹកនាំកុម្មុយនិស្ត ពីប្រព័ន្ធអប់រំថ្មីនេះឡើយ ។ ប៉ុន្តែ ក្នុងក្របខ័ណ្ឌនៃវិទ្យាស្ថាន នៅមុខពួកអ្នកកាសែតបរទេស គាត់គឺជាមនុស្សដ៏សំខាន់ដែលប្រជាជន ដែលតំណាងដោយ គុន បានសន្មតឲ្យគាត់មានឋានៈទីមួយនេះ ។

ការលាក់ពុតបានបន្តទៅទៀត ៖ ប្រសិទ្ធិ និងមុំ មិនសម្តែងការគួរសមនឹងគ្នា ដូចបណ្តាសមមិត្តឯទៀតៗទេ ។ គុន បានស្នើឲ្យ មុំ ផ្តល់ព័ត៌មានប្រាប់យើងស្តីពីវិទ្យាស្ថាន និងមុខនាទីរបស់គាត់ក្នុងប្រទេសកម្ពុជាបដិវត្តន៍ ។ មុំ បានអនុវត្តតាមដោយប្រកាសថា វិទ្យាស្ថាននេះបង្កើតឡើងនៅឆ្នាំ១៩៧៧ ដោយទទួលយកកូនៗរបស់ប្រជាជនឲ្យចូលរៀន ។ នៅទីនេះ មានរោងជាងជាច្រើនសម្រាប់ដាក់ម៉ាស៊ីន និងសម្ភារៈបរិក្ខារអគ្គិសនី ឡរំលាយដែកមួយ ក្រុមរៀបចំតម្លើងបំពង់សម្រាប់បាញ់ថ្នាំសម្លាប់សត្វល្អិត ។ មុំ បានរៀបរាប់ពីកិច្ចការប្រចាំថ្ងៃរបស់កូនសិស្សម្នាក់ៗ មេរៀនផ្សេងៗដែលពួកគេត្រូវរៀនឲ្យចេះចាំ “ដំណាំយុទ្ធសាស្ត្រ” ដែលពួកគេត្រូវដាំ (ដំឡូងជ្វា បន្លែ និងព្រលិត) វិស្សមកាលដែលគេអនុញ្ញាតឲ្យឈប់ ។ គាត់និយាយជាភាសាខ្មែរ បន្ទាប់មក ប្អូនប្រុសរបស់គាត់ គឺប្រសិទ្ធិ ជាអ្នកបកប្រែមកជាភាសាអង់គ្លេស ។

នៅទីបញ្ចប់ ខ្ញុំបាននិយាយកាត់ ប្រសិទ្ធិ ដើម្បីសួរគាត់ថា ហេតុអ្វីបានជាបងប្រុសរបស់គាត់ និងគាត់ប្រកាន់អាកប្បកិរិយាដូចជាអ្នកក្រៅដូច្នេះ ។ លោកទាំងពីរអាចពន្យល់ប្រាប់ខ្ញុំពីរបៀបយ៉ាងដូចម្តេចបានជាអស់លោកដែលសុទ្ធតែជាអ្នកទទួលមរតកពីគ្រួសារអភិជនមួយ អាចក្លាយទៅជាសមាជិកនៃក្រុមវរជនរបស់ប្រទេសកម្ពុជាបដិវត្តន៍ ។ ជាមួយបុកពាខ្ពស់យ៉ាងម៉ឺងម៉ាត់មួយ មុំ បានឆ្លើយថា “ជាធម្មតា ជនបដិវត្តម្នាក់មិនចូលចិត្តតាំងសម្ញែងសញ្ញាប័ត្រផ្សេងៗរបស់ខ្លួន... និងជដែករកខុសត្រូវពីដើមកំណើតរបស់ខ្លួនឡើយ” ។

គាត់ទទួលស្គាល់ថា គាត់ជាអ្នកមានសញ្ញាប័ត្រពីសាលាពហុបច្ចេកទេសក្រុងប៉ារីស ហើយក្រៅពីនេះ គាត់គ្មាននិយាយអ្វីទាំងអស់ ។ ជាមួយការសើចញញឹមយ៉ាងស្រស់មួយ គាត់បាននាំពួកយើងជាបន្តទៀត ទៅជួបពួកកូនសិស្សរបស់គាត់ ។ ភ្លាមនោះ យើងសម្គាល់ឃើញថា កូនសិស្សគំរូទាំងនេះសុទ្ធតែជាយុវជនក្មេងៗ ធ្វើការក្នុងរោងចក្រមួយ ដែលយើងធ្លាប់បានឃើញក្នុងខ្សែភាពយន្តរបស់ពួកអ្នកកាសែត យូហ្គោស្លាវី ថតកាលពីមួយឆ្នាំមុន ជាក្មេងដែលឈរជិតទើតលើហិបឈើ ដើម្បីឈោងដៃមួលខ្ចៅ ឬក្បាលម៉ាស៊ីន ។ ក្នុង“បន្ទប់រៀន” ទាំងនេះ ក៏ដូចលើកញ្ចក់ទូរទស្សន៍ ពួកគេមានសភាពដូចក្មេងប្រុសៗដែលត្រូវគេបោះបង់ចោលរបៀបក្នុង

ប្រលោមលោកមួយរបស់លោក ឌីក កេន (អ្នកនិពន្ធជាតិអង់គ្លេស ១៨១២-១៨៧០) ដែរ ដែលមានអាយុប្រាំពីរ ឬប្រាំបីឆ្នាំប៉ុណ្ណោះ ហើយបើគិតឲ្យសព្វៗទៅ ពួកគេត្រូវបំបាក់ឲ្យនៅក្រោមការឆ្លៀតទាញយកប្រយោជន៍ពីការងារមួយរបស់ក្មេងៗ ។

ផ្ទុយទៅវិញ តាមការមើលឃើញរបស់ មុំ ក្មេងៗទាំងនេះជាមនុស្សឈានមុខនៃបទពិសោធន៍មួយដែលថ្មីទាំងស្រុងក្នុងការសិក្សាផ្នែកបច្ចេកទេស ។ បន្ទប់សិក្សាមានតុបតែងលម្អដោយបដាពាក្យស្លោកផ្សេងៗ ដែលមានសេចក្តីថា "បក្សកុម្មុយនិស្តដ៏ភ្លឺស្វាង និងដ៏ត្រឹមត្រូវ" "ត្រូវប្តេជ្ញាចិត្តខិតខំបំពេញការងារឲ្យឆាប់រហ័ស និងជំរុញទៅមុខដោយជំហានលោតផ្លោះជានិច្ច" ។ មុំ បានប្រកាសយ៉ាងខែងរ៉ែងថា យុវជនទាំងនេះ មានសមត្ថភាពខ្ពស់ជាងបណ្តាវិស្វករនៅអឺរ៉ុបទៅទៀត ៖ "នៅអឺរ៉ុបមានវិស្វករច្រើនទាក់ណាស់ ដែលមិនចេះតខ្សែភ្លើងតូចភ្ជាប់នឹងខ្សែភ្លើងធំឌីណាម៉ូមួយផង" ។

គាត់បានបន្ថែមថា បដិវត្តន៍មិនទទួលយកពួកវិស្វករ និងអ្នកបច្ចេកទេសរបស់សង្គមចាស់មកប្រើទេ ពីព្រោះពួកនេះ "គ្មានមនសិការកសាងប្រទេស ដើម្បីសេចក្តីត្រូវការផ្សេងៗរបស់ប្រជាជនឡើយ...។ អ្វីដែលពួកគេត្រូវការគឺកម្រិតជីវភាពខ្ពស់មួយ...។ ដូច្នោះ យើងគោងតែបន្តធ្វើតាមមធ្យោបាយមួយផ្សេងទៀត" ។

មធ្យោបាយមួយផ្សេងទៀតគឺ បន្ទប់សិក្សារបស់ក្មេងៗ ដែលមានជើងទទេកំពុងសាកល្បងជួសជុលទាំងញ័រដៃជើងនូវគ្រឿងម៉ាស៊ីនចាស់ៗ និងចងចាំពីរបៀបតខ្សែភ្លើងឌីណាម៉ូមួយ ។ តាមការរៀបរាប់របស់ មុំ ថា វិធីសាស្ត្រក្នុងការបង្ហាត់បង្រៀនជំនាន់មុនមានរយៈពេលយូរពេក ហើយចំណាយអស់លុយកាក់ច្រើនណាស់ ។ គាត់បានអួតថា បន្ទាប់ពីការសិក្សាប្រាំមួយខែ ក្មេងៗទាំងនេះ ដែលស្ទើរមិនចេះអក្សរសោះ នឹងមានកម្រិតយល់ដឹងខាងផ្នែកវិទ្យាសាស្ត្រមួយ ដូចកូនសិស្សបារាំងថ្នាក់ទី៨ដែរ ។ គឺលើមូលដ្ឋានរវើរវាយដោយច្បាស់លាស់ទាំងនេះហើយ ដែល មុំ បង្កើតវណ្ណៈអ្នកបច្ចេកាធិបតេយ្យរបស់បដិវត្តន៍ ។

ប្រាំមួយខែសម្រាប់ការបណ្តុះបណ្តាល ប្រាំមួយខែសម្រាប់ការអនុវត្តក្នុងសហករណ៍មួយ ធ្វើការប្រាំមួយខែក្នុងរោងចក្រមួយ បន្ទាប់មក ត្រូវត្រឡប់មកវិទ្យាស្ថានរបស់ មុំ វិញ ដើម្បីរៀនសូត្រមេរៀនផ្នែក "ទ្រឹស្តី" ចំនួនដប់ប្រាំបីខែទៀត ជាពិសេស មុខវិជ្ជាប្រវត្តិសាស្ត្រ ភូមិសាស្ត្រ និងគណិតសាស្ត្រ ។ នៅចុងបញ្ចប់នៃវគ្គសិក្សានេះ កូនសិស្សត្រូវបានប្រកាស ជាអ្នកបច្ចេកទេសដែលមានសមត្ថភាពគ្រប់គ្រាន់ ហើយត្រូវបញ្ជូនឲ្យទៅធ្វើការនៅក្នុងរោងចក្ររយៈពេលមួយឆ្នាំ ។ បន្ទាប់មក ពួកគេត្រូវវិលមកវិទ្យាស្ថានជាថ្មីម្តងទៀត សម្រាប់ការរៀនសូត្រចំនួន ដប់ប្រាំបីខែទៀត ដើម្បីបញ្ចប់កម្មសិក្សារបស់ខ្លួន ។

ផែនការនេះពុំមានអ្វីទាក់ទងជាមួយនឹងការពិតរបស់កម្ពុជាប្រជាធិបតេយ្យសោះ ដូចដែលយើងត្រូវការរកឲ្យឃើញរឿងនេះនៅពេលក្រោយ ។ គាត់ធ្លាប់យល់ក្រៅពីពិភពលោក ពីការបដិវត្តន៍ដែលផ្លាស់ប្តូរគ្មានឈប់ឈរ ដែលកម្មាភិបាលជាច្រើនបានទទួលរងគ្រោះពីការបោសសម្អាតផ្សេងៗ ដែលមាគ៌ាបក្សបានផ្លាស់ប្តូរ

ជាញឹកញាយ ហើយមានពួកមេដឹកនាំកំពូលៗតែប៉ុន្មាននាក់ប៉ុណ្ណោះ ដែលយល់ពីទិសដៅដែលប្រកាន់យកដោយរដ្ឋ ។ ប៉ុន្តែ គេបានចាត់តាំងឲ្យ មុំ បង្ហាញមូលដ្ឋានខាងទ្រឹស្តីឲ្យយើងដឹង ដែលអនុញ្ញាតឲ្យយើងក្តាប់បានយ៉ាងល្អនូវអ្វីដែលយើងនឹងឃើញក្នុងរយៈពេលនៃការធ្វើដំណើររបស់យើងទៅកាន់ជនបទ ។ គឺនៅទីបញ្ចប់នេះហើយដែលគាត់ផ្តល់ឲ្យយើងនូវការនិយាយរៀបរាប់ខ្លីមួយស្តីពីអារ្យធម៌របស់ខ្មែរ និងការបដិវត្តកម្ពុជា ។ «អារ្យធម៌របស់យើងមានអាយុ ៨.៨០០ឆ្នាំ -ដូចអារ្យធម៌ រ៉ូម ដែរ ។ ដូច្នេះ យើងមានប្រពៃណី ដ៏យូរលង់មួយអំពីឯករាជ្យភាព អធិបតេយ្យភាព និងខ្លួនទីពឹងខ្លួន ។ យើងគ្មានគ្រាប់ចម្លងធ្វើតាមប្រទេសណាមួយឡើយ... ការបដិវត្តរបស់យើង គឺអនុលោមតាមស្ថានភាពជាក់ស្តែងរបស់ប្រទេស គឺពុំមែនជាការគ្រាប់តាមបដិវត្តមួយផ្សេងទៀតទេ ។ យើងធ្លាប់វាយឈ្នះសហរដ្ឋអាមេរិក យើងនឹងដណ្តើមជ័យជម្នះលើពួកវៀតណាមដែលគាំទ្រដោយសហភាពសូវៀតទៀត...។ ជាមួយនឹងការបដិវត្តនេះ យើងមានលទ្ធភាពបង្ហាញឲ្យឃើញវប្បធម៌របស់កម្ពុជា សម្រាប់ជាលើកដំបូងបង្អស់» ។

គេនឹងមិននិយាយបំផ្លើសពីការច្របូកច្របល់ និងការមិនយល់ ដែលជារបស់យើងក្នុងរយៈពេលនៃដំណើរទស្សនកិច្ចរបស់យើងនៅកម្ពុជាឡើយ ។ យើងប្រៀបដូចជាមនុស្សខ្វាក់ បីនាក់ក្នុងរឿងល្បើកមួយ ដែលខំប្រឹងនឹកគិតក្នុងចិត្តពីរូបរាងដំរីមួយក្បាល ។ នៅជំនាន់នេះ គ្មានអ្នកណាម្នាក់ដឹងពីការប្រព្រឹត្តទៅនៃកិច្ចចាត់ចែងការងារផ្ទៃក្នុងរបស់របបនេះទេ ៖ តើភូមិភាគនានាធ្វើសកម្មភាពយ៉ាងដូចម្តេចខ្លះ តើបក្សគ្រប់គ្រងដឹកនាំប្រទេសដោយរបៀបណា តើក្រុមសន្តិសុខធ្វើប្រតិបត្តិការបែបណា? ។ គ្មានអ្នកណាម្នាក់ដឹងពីអត្ថិភាពនៃមណ្ឌលសម្រាប់ធ្វើទារុណកម្ម និងសម្លាប់មន្ទីរឃុំឃាំងទួលស្លែង ជម្រៅនៃភាពក្រីក្រគោកយ៉ាក និងការឈឺចាប់ខ្លោចផ្សារបស់ប្រជាជនឡើយ ។ ក្នុងពេលដែលមនុស្សភាគច្រើនខំប្រឹងតាមដានព្រឹត្តិការណ៍ផ្សេងៗនៅកម្ពុជា យើងមានសេចក្តីលំបាកនឹងពន្យល់ពីសៀវភៅខ្មៅ ស្វែងយល់ពីការផ្តន្ទាទោសដែលមានក្នុងសៀវភៅ និងវិនិច្ឆ័យពីសុពលភាពក្នុងការចោទប្រកាន់ផ្សេងៗ ដែលផ្តោតប្រឆាំងនឹងពួកវៀតណាមណាស់ ។

ចម្លើយជាសាក្សីរបស់ពួកអ្នកភៀសខ្លួនខ្មែរ ដែលគេស្រង់យកទៅចុះផ្សាយឡើងវិញក្នុងកាសែតនានា និងសៀវភៅខ្លះ បានត្រូវថ្កោលទោសដោយមនុស្សមួយចំនួន ជាពិសេស ខាងវែល ។ ក្នុងរយៈពេលនៃការធ្វើដំណើររបស់យើង ពួកមគ្គុទេសក៍នាំផ្លូវបានសម្រេចចិត្តយ៉ាងមុតមាំ មិនឲ្យយើងអាចមើលឃើញនូវអ្វីដែលអាចអះអាងបន្ថែមលើការរៀបរាប់ផ្សេងៗ របស់ពួកអ្នកភៀសខ្លួនទាំងនោះ ។ ការដោះស្រាយរឿងនេះ ស្ថិតនៅត្រង់គេឲ្យកម្មាភិបាលជាច្រើននាក់ តាមអមដំណើរយើងជាប់ជានិច្ច គេដាក់ឲ្យយើងស្ថិតនៅតែក្នុងលំនៅដ្ឋានឬរថយន្ត ដែលយើងអាចមើលឃើញការបដិវត្តដោយស្រពេចស្រពិលប៉ុណ្ណោះ ។

នៅព្រឹកនៃការចេញដំណើររបស់យើងទៅជនបទ វិទ្យុបរទេសនានាបានសង្កត់បញ្ជាក់អំពីដំណឹងផ្សេងៗ

ដែលមានប្រភពពីទីក្រុងភ្នំពេញ ៖ ប៉ុល ពត បានប្រកាសថា ក្នុងករណីចាំបាច់ គាត់នឹងបោះបង់រដ្ឋធានី ក្នុងសង្គ្រាមដែលគាត់ត្រូវដឹកនាំធ្វើក្នុងពេលណាមួយ ។

ពត៌មាននេះ បានកម្ចាត់អស់នូវការចាប់អារម្មណ៍ពិភពឥតមន្ទិល ដែលផ្តល់ឲ្យដោយម្ចាស់ផ្ទះរបស់យើង ។ ដោយភ័យខ្លាចមិនបានត្រឡប់មកភ្នំពេញ យើងបានរៀបចំអីវ៉ាន់យកទៅតាមខ្លួនទាំងអស់ ។ ប្រសិទ្ធិ បានធានាអះអាងថា វាគ្មានរឿងអ្វីកើតឡើងទេ ប៉ុន្តែ យើងនៅតែមិនព្រមស្តាប់ ហើយយើងក៏លើកវ៉ាលិសដ៏ធ្ងន់របស់យើងដាក់ក្នុងក្តិតឡានម៉ែសឺដេស ។

យើងឡើងជិះកាណូតមួយគ្រឿង ដែលបើកឡើងតាមទន្លេមេគង្គ រហូតដល់ខេត្តកំពង់ចាមក្នុងភូមិភាគបូព៌ា ។ ប៉ុន្តែយើងដឹងមុនថា តំបន់នេះធ្លាប់កើតមានការទាស់ទែងគ្នាខ្លាំងក៏ដោយ ក៏យើងគ្មានដឹងដូចអ្នកដទៃទៀតដែរថា ការបោសសម្អាតនៅភូមិភាគបូព៌ា បានបញ្ចូលឲ្យមនុស្សស្លាប់យ៉ាងច្រើន ហើយបានបង្ខំឲ្យមនុស្សជាច្រើន និរទេសខ្លួនចេញពីស្រុកភូមិ ដែលពួកវៀតណាមបង្ហាញឲ្យដឹងនៅពេលឥឡូវនេះ ក្នុងឋានៈជាមេដឹកនាំ "រណសិរ្ស" មួយរបស់កម្ពុជា ទុកសម្រាប់បិទបាំងការឈ្លានពានរបស់វៀតណាម ។

យើងជិះកាណូតឡើងតាមទឹកទន្លេជាមួយ ប្រសិទ្ធិ និងសហសេវិកថ្មីម្នាក់ទៀតឈ្មោះ ឳក សាគុណ ជាបញ្ញវន្តដែលគេស្គាល់ច្បាស់ក្នុងមជ្ឈដ្ឋានអឺរ៉ុបខ្លះ ហើយដែលបណ្តាមិត្តភក្តិក្រុងប៉ារីសរបស់គាត់ជឿថា ស្លាប់បាត់ទៅហើយ ។ ដោយណែនាំ សាគុណ ឲ្យយើងស្គាល់ ប្រសិទ្ធិ បានប្រកាសថា គាត់នេះ គឺប្រាកដជា "បិសាច" ម្នាក់មែន ដោយហេតុថា កាសែតបារាំងជាច្រើនបានផ្សព្វផ្សាយជាសាធារណៈថា គាត់ត្រូវគេសម្លាប់ -តាមយោបល់គាត់ថា នេះជាតឹកតាងនៃការឃោសនាភូតកុហក ដែលរបបរបស់គាត់ត្រូវរងទទួល ។

បើទុកជា ឳក សាគុណ ពុំមែនជាបិសាចម្នាក់ក៏ដោយ ក៏គាត់មានរូបរាងស្គមដូចគ្រោងឆ្អឹងមួយ តែស្បែកដណ្តប់ឆ្អឹងជាមួយនឹងភ្នែករូងជ្រៅ ខ្លួនប្រាណស្តើងរញ៉េរ បង្ហាញឲ្យឃើញថា គាត់ឈឺដោយសារបរិភោគអាហារមិនគ្រប់គ្រាន់ ។ គាត់ត្រូវគេអនុញ្ញាតឲ្យនិយាយជាមួយយើងបានលុះណាតែមានវត្តមានអ្នកបកប្រែភាសាម្នាក់ជាទូទៅគឺ ប្រសិទ្ធិ ហើយគាត់សម្តែងឲ្យឃើញការចាប់ចិត្តខ្លាំងនឹងម៉ាស៊ីនថតរូបរបស់យើង ជាងពួកយើងទៅទៀត ។ មានមួយដងគត់ ដែលខ្ញុំបាននៅតែម្នាក់ឯងជាមួយរូបគាត់ ហើយគាត់បាននិយាយជាមួយខ្ញុំតែពីរឿងបុប្ផា មួយមុខគត់ ដោយគូសបញ្ជាក់ពីចំណុចខ្លះដែលមនុស្សប្រុសម្នាក់អាចខ្វះផ្កាបាន ។ នៅពេលនោះ ខ្ញុំត្រូវធ្វើឲ្យឆ្ងល់យ៉ាងខ្លាំង ដោយពាក្យសម្តីទាំងប៉ុន្មានរបស់គាត់ ប៉ុន្តែឥឡូវនេះ ខ្ញុំគិតថា គាត់បានធ្វើអ្វីៗដោយប្រុងប្រយ័ត្នបំផុត បន្ទាប់ពីការដោះលែងរូបគាត់ពីជំរំពលកម្មមួយ ។

ខ្ញុំធ្លាប់បានធ្វើដំណើរជាលើកចុងក្រោយទៅកាន់តំបន់នៃប្រទេសកម្ពុជានេះ នៅឆ្នាំ១៩៧៣ ពេលដែលមានការប្រយុទ្ធគ្នាយ៉ាងខ្លាំងដើម្បីកាន់កាប់ទីក្រុងកំពង់ចាម ។ នៅពេលនោះ តាមដងទន្លេមេគង្គមានទាហានទាំងពីរពួកច្រើនឥតគណនា ហើយវាមានគ្រោះថ្នាក់ខ្លាំងណាស់បើគេប្រថុយដើរតាមត្រើយទាំងសងខាង ។

អ្នកថតរូបរបស់ខ្ញុំ និងខ្ញុំ បានពើបប្រទះនឹងការបាញ់កាំភ្លើងត្បាល់ធ្លាក់ដូចគ្រាប់ព្រិល នៅពេលដែលខទូម្ភាគចក្ររបស់យើងសាកល្បងចុះចតនៅក្បែរក្រុងកំពង់ចាម ហើយយើងមានភ័ព្វសំណាងណាស់ ដែលយើងរួចផុតពីស្ថានភាពដ៏អាក្រក់នេះ ដោយគ្មានខូចខាតអ្វីសោះ ។

លើកនេះ កម្ពុជាប្រជាធិបតេយ្យ គ្រោះថ្នាក់មានលក្ខណៈបិទបាំងមិនឲ្យឃើញ ។ ដំណើររបស់យើងបានប្រព្រឹត្តទៅយ៉ាងស្ងប់ស្ងៀមដូចនៅក្រុងភ្នំពេញដែរ យើងពុំឃើញមានសញ្ញានៃការរស់នៅចាធម្មតាណាមួយឡើយ ៖ ពុំមានស្ត្រីៗបោកខោអាវរបស់គេតាមមាត់ទន្លេ ពុំមានអ្នកនេសាទបង់សំណាញ់ ពុំមានក្មេងៗបាចភក់ដាក់គ្នាក្នុងទឹកដូចកាលពីមុនទេ ។ ដោយមានខិតទៅជិតដល់ក្រុងកំពង់ចាម ទស្សនីយភាពបានប្រែប្រួលមួយរំពេច ហើយជាលើកដំបូង យើងបានឃើញពីចម្ងាយនូវក្មេងប្រុសៗកំពុងលេងនៅឯទីឆ្ងាយ ដោយលោតដាំក្បាលចុះពីលើទូក ដែលចងជាប់នឹងដៃ ហើយស្រែកហ៊ោរកញ្ជ្រៀវនៅក្នុងទឹក ។ រូបភាពដែលយើងមើលឃើញនេះ ប្រហែលជារៀបចំដើម្បីបម្រើបម្រើគោលបំណងរបស់យើងហើយមើលទៅ ។

បន្ទាប់ពីការចូលចតដៃ ការដឹងដោយវិញ្ញាណពីភាពសោះកក្រោះបានកើតមានឡើងវិញ ។ យើងត្រូវគេដាក់ឲ្យស្នាក់នៅក្នុងអគារមួយដែលកងទ័ព លន់ នល់ ធ្លាប់យកធ្វើជាទីសេនាធិការរបស់គាត់ក្នុងរយៈពេលសង្គ្រាម ។ នៅទីនេះ ក៏មិនឃើញមានមនុស្សណាម្នាក់ដើរនៅតាមផ្លូវថ្នល់ គ្មានឃើញអ្នកជំនួញណាម្នាក់នៅទីផ្សារ និងគ្មានចរាចរទាល់តែសោះនៅតាមផ្លូវ ។ ដូចនៅក្រុងភ្នំពេញដែរ យើងបានទៅទស្សនាសមិទ្ធិផលបដិវត្តជាច្រើនកន្លែង ដោយមានអ្នកអមការពារជាច្រើន ៖ ការដ្ឋានសាងសង់នាវា វិទ្យាស្ថានវេជ្ជសាស្ត្រដោយប្រើរុក្ខជាតិសម្រាប់ផ្សំឱសថបុរាណ និងកន្លែងផលិតឱសថសម័យមួយ ។ នៅពេលយប់ គេបានបន្ទំាងយើងក្នុងនិវេសនដ្ឋានដោយផ្ដាំផ្ញើឲ្យយើងសម្រាកបានលក់ស្រួល ៖ ថ្ងៃស្អែកយើងត្រូវធ្វើដំណើរទៅសមរភូមិទៀត ។

យើងបានចេញដំណើរនៅមុនពេលព្រះអាទិត្យរះ ក្រោមផ្ទៃមេឃប្រកបទៅដោយការស្មៅពណ៌មាស និងពពកសៗដេរដាស ។ ក្បួនដំណើររបស់យើងមានលក្ខណៈធំដុំណាស់ ៖ រថយន្តប៊ីហ្សូពីរគ្រឿង ឡានម៉ែសឺដេសរបស់ យើង និងឡានហ្ស៊ីបពីរ សម្រាប់ដឹកយុទ្ធជនប្រាំនាក់ ជាអ្នកកាន់កាំភ្លើងស្វ័យប្រវត្តិ បុគ្គលិកក្រសួងការបរទេសបួននាក់ និងសមាជិកគណៈកម្មាធិការភូមិភាគបូព៌ាប្រាំពីរនាក់ ។ យើងបើកឡានតាមបណ្ដោយត្រើយខាងស្ដាំទន្លេមេគង្គ ជាតំបន់ដែលគេពុំអាចដឹងរបស់ «ក្រុមម្នាងទៀត» និងជាតំបន់ដែលត្រួតត្រាដោយពួកខ្មែរក្រហម ។ យូរៗម្ដង យើងមើលឃើញក្មេងកំព្រឹងម្នាក់ពីចម្ងាយ ប៉ុន្តែជាទូទៅ ផ្លូវថ្នល់នៅតែមានសភាពស្ងាត់ជ្រងឹងដដែល ។ ប្រសិទ្ធ បានធ្វើការឆ្លើយដោះសារមួយដែលត្រៀមទុកជាមុនជាស្រេចថា «ពេលនេះពួកកសិករបានចេញទៅធ្វើការនៅតាមស្រែចម្ការឲ្យហើយ» ។

យើងបានឆ្លងកាត់ពីមុខឃ្លាំងធ្វើពីបេតុងមួយដែលទើបស្ថាបនាក្នុងពេលថ្មីៗ បន្ទាប់មក ក្មេងជាច្រើនទៀតដែលស្គមឃើញតែឆ្អឹង ពោះឡើងកំប៉ោង បានបង្ហាញខ្លួនឡើងចំពោះភ្នែករបស់យើង ។ តមកទៀត ពីលើ

រថយន្ត យើងបានឃើញទស្សនីយភាពមួយរបស់អ្នកស្រុក និងពួកកសិករ ដែលប្រឹងប្រែងធ្វើការរស់រវើក ហាក់ដូចជាបានស៊ីចុកគ្រប់គ្រាន់ ប៉ុន្តែ យើងពុំអាចឈប់រថយន្តបានទេ ។ យើងបានបន្តដំណើររហូតទៅដល់អគ្គបញ្ជាការដ្ឋានការពារផ្លូវជាតិលេខ៧ ដោយគ្មានដឹងថាទីនេះជាកន្លែងដែល សោ ភឹម និងបក្សសម្ព័ន្ធរបស់គាត់ធ្លាប់ត្រូវគេផ្ដាញ់ផ្ដាលរកគបតមិនកើត ហើយដែលមជ្ឈមប៉ុនប៉ងកម្ទេចចោលមេបញ្ជាការភាគច្រើន របស់ភូមិភាគបូព៌ាដែលគេសង្ស័យថាក្បត់ឡើយ ។

គេឲ្យយើងចុះពីរថយន្តហើយ គេនាំយើងទៅជួបអ្នកនាំផ្លូវម្នាក់ទៀតសម្រាប់ជូនយើងដើរមើលសមរភូមិប្រយុទ្ធ គឺសមមិត្ត ពិន ជាអ្នកនៅរស់រានជីវិតម្នាក់របស់ការបដិវត្តខ្មែរ ។ ក្រោយមកទៀត ខ្ញុំបានដឹងយ៉ាងច្រើនថា ពីន បានរក្សាទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយផ្នែកសន្តិសុខ ដែលមានមន្ទីរឃុំឃាំងទួលស្លែងជាទីតាំង ។ ក្នុងសម័យសង្គ្រាមគាត់បានបញ្ជាកងពលតូចមួយ ក្នុងចំណោមកងពលតូចជាច្រើន ដែលកំពុងវាយប្រយុទ្ធនៅជុំវិញក្រុងភ្នំពេញ ។ ក្រោយមក មនុស្សរបស់គាត់មួយចំនួនធំ បានត្រូវគេផ្ទេរឲ្យទៅធ្វើការនៅផ្នែកសន្តិសុខវិញ ហើយរូប ពិន ផ្ទាល់ ជាអ្នកជ្រើសរើសទុកជាមុនចំពោះ «ពួកក្បត់» ដែលត្រូវសម្លាប់ ឬ«ធ្វើឲ្យអាប់មុខ» តាមភាសាដោយឡែកក្នុងបក្ស ។

ប៉ុន្តែ វេលាព្រឹកខែធ្នូនេះ ពីន បានបង្ហាញខ្លួនឡើងក្នុងឋានៈជាមេបញ្ជាការទ័ពម្នាក់ពោរពេញទៅដោយការចេះប្រមាណ និងការឡកឡឺយ ដែលប្រាថ្នាបម្រើប្រជាជនគ្រប់ពេលវេលា ។ គាត់ចាប់ផ្ដើមនិយាយប្រាប់យើងពីការធ្វើសង្គ្រាមរបស់ប្រទេសវៀតណាម ។ តាមគាត់និយាយថា ពួកវៀតណាមបានចាប់បង្កសង្គ្រាមនៅខែកក្កដា ហើយបន្តការវាយប្រយុទ្ធរហូតមកដល់ខែសីហា ។ ដូច្នេះ ពួកគេគឺជាពួកឈ្លានពាន ។ ពីន បានបន្តថា នៅខែកញ្ញា ពួកគេបានឆ្លងកាត់ព្រំដែនហើយរុលចូលចម្ងាយបួនគីឡូម៉ែត្រមកក្នុងចម្ការកៅស៊ូនៅជិតមេមត់ មុនពេលយុទ្ធជនរបស់យើងសម្រេចដេញកម្ចាត់ទៅវិញ ។ នៅខែតុលា និងខែវិច្ឆិកា ពួកវៀតណាមបានធ្វើការវាយប្រហារជាច្រើនលើក តែមានទំហំតូចជាងមុន ដោយមានការគាំទ្រពីរថក្រោះ និងយន្តហោះទម្លាក់គ្រាប់បែកជាគ្រឿងផង ។

ពិន បានប្រកាសដោយភាពក្រអឺតក្រអោងថា «យើងបានដឹកនាំធ្វើសង្គ្រាមឆ្នក់មួយ ។ យើងពឹងផ្អែកជាសំអាងលើប្រជាជន ។ ពួកវៀតណាមបានដឹកនាំធ្វើសង្គ្រាម តាមរបៀបធម្មតាមួយ ជាមួយនឹងយន្តហោះគ្រាប់បែក និងរថក្រោះជាច្រើន» ។

ការឃោសនាដែលប្រើប្រាស់ដោយពួកកុម្មុយនិស្តវៀតណាម និងកម្ពុជាក្នុងរយៈពេលសង្គ្រាមបញ្ជាក់ឲ្យដឹងថា ពួកអាមេរិកាំង និងពួកសម្ព័ន្ធរបស់គេ សុទ្ធតែយល់ខុសទាំងផ្នែកនយោបាយ ទាំងខាងផ្លូវចិត្ត ពីព្រោះពួកគេអាងលើសាស្ត្រាវុធរបស់គេ ដើម្បីដណ្ដើមយកជ័យជម្នះ ។ ដោយបន្តគំនិតនេះរហូតដល់អ្វីដែលឥតន័យហួសហេតុមួយ ពួកកម្ពុជាយល់ឃើញថា វាជារឿងធម្មតាទៅហើយ ដែលគេប្រើប្រាស់យន្តហោះ និងគ្រាប់បែក

យ៉ាងច្រើនវាយបំបាក់កងទ័ពមួយ ឲ្យបរាជ័យលើសមរភូមិនៅទីកបង្កើយនោះ ។ម្យ៉ាងទៀត ពួកកម្ពុជាចូលចិត្ត សន្និដ្ឋានបញ្ជាក់ថា ពួកកុម្មុយនិស្តវៀតណាម ធ្លាប់បានថ្កោលទោសការទម្លាក់គ្រាប់បែករបស់ពួកអាមេរិកាំង ប៉ុន្តែ ក្នុងសង្គ្រាមរបស់ខ្លួនប្រឆាំងនឹងកម្ពុជា ក្រុងហាណូយមិនរួញរានឹងទម្លាក់ គ្រាប់បែកលើជនបទរបស់កម្ពុជាឡើយ ដើម្បីធានាជ័យជម្នះរបស់ខ្លួន ។

បន្ទាប់ពីការបញ្ជាក់បំភ្លឺទាំងនេះ យើងបានចេញដំណើរឆ្ពោះទៅកាន់សមរភូមិមែនទែន ។ យើងជា អ្នកកាសែតបរទេសដំបូង និងចុងក្រោយបំផុត ដែលបានទៅពិនិត្យមើលកងទ័ពកម្ពុជា ត្រៀមរៀបចំធ្វើសង្គ្រាម នៅប្រទេសវៀតណាម ។ ទីដៅដែលយើងត្រូវទៅគឺ ក្រែក ដែលតាមពួកអ្នកជំនាញការផ្នែកយោធាបរទេសខ្លះ ថា បានធ្លាក់ទៅក្នុងកណ្តាប់ដៃពួកវៀតណាមស្រេចទៅហើយ ។ យើងបានដើរឆ្លងកាត់ព្រៃចម្ការកៅស៊ូជប់ ពណ៌បៃតងស្រងាត់ ហើយបានទៅដល់ក្រែកនៅពេលជិតថ្ងៃត្រង់ ។

មុនពេលយើងអាចចុះពីរថយន្ត ពីន បានរាយទ័ពព័ទ្ធជុំវិញយើង ដែលមានជំហរត្រៀមប្រយុទ្ធជាស្រេចៈ គ្មានបញ្ហាធ្វើឲ្យបាត់បង់អ្នកកាសែតបរទេសម្នាក់ ក្នុងចំណោមអ្នកកាសែតបរទេសជាច្រើន ដែលគេប្រគល់ឲ្យ គាត់ទទួលខុសត្រូវឡើយ ។

លើសមរភូមិមានសភាពស្ងាត់ឈឹង ជាពិសេសបើគេនឹកគិតគិតទៅដល់របាយការណ៍ផ្សេងៗ របស់ផ្នែក ស៊ើបការណ៍អាមេរិកាំងដែលថា ពួកវៀតណាមបានវាយដណ្តើមកាន់កាប់ក្រែកបាត់ទៅហើយ ។ គេឮសូរសន្ទឹក សំឡេងកាណុងលាន់ក្តិលៗ នៅឯនាយឆ្ងាយ ។ នៅខាងទិសព្រំដែន គេឃើញផ្សែងហុយទ្រលោមឡើងទៅលើ មេឃ នោះគឺជាបាញ់កាំភ្លើងធំឆ្លើយឆ្លងគ្នា ។ យើងបានស្ថិតនៅ“សមរភូមិ”តែកន្លះម៉ោងប៉ុណ្ណោះ ក្បែរផ្ទាំង ប៉ាណូមួយ ដែលប្រាប់ឲ្យគេដឹងថា យើងកំពុងស្ថិតនៅក្រែក ។

ក្នុងពេលដែលយើងថតរូប ពីន បានធ្វើការប្រៀបធៀបសង្គ្រាមនេះ និងសង្គ្រាមពេលមុនដែលមាន ជិតរវេលាប្រាំឆ្នាំប្រាប់យើងថា “ការទម្លាក់គ្រាប់បែបរបស់អាមេរិកាំងគ្មានប្រសិទ្ធិភាពទេ” ។ ពួកវៀតណាម ក៏ ដឹងទីដៅសំខាន់ដែលត្រូវវាយប្រហារដែរ ។ “នៅពេលមានការទម្លាក់គ្រាប់បែកខ្លាំងក្លាអស្ចារ្យរបស់អាមេរិកាំង យើងបានខិតចូលទៅកៀកនឹងកងទ័ពបច្ចាមិត្រ ។ កាលណាពួកគេទម្លាក់គ្រាប់បែកកាន់តែខ្លាំង យើងក៏កាន់តែខិត ចូលកៀកកាលនោះដែរ ។ មានតែប្រជាជនប៉ុណ្ណោះ ដែលទទួលរងការឈឺចាប់ ហើយនៅទីបំផុតអ្នកទាំងនោះបាន ចងគំនុំពួកអាមេរិកាំងយ៉ាងខ្លាំង” ។

ការវិភាគរបស់ ពីន បានលាន់ឮរំពងដូចការវិភាគរបស់ឧត្តមសេនិយឆ្នើមៗមួយចំនួនរបស់ លន់ នល់ ដែរ ដែលបន្ទោសពីរបៀបដែលពួកអាមេរិកាំងជួយគាំទ្រពួកគេ ។

ខ្ញុំបានសួរគាត់ថា លោកអាចនិយាយប្រាប់ពួក យើងបានទេ ពីអតីតនាយទាហាន លន់ នល់ តើពួកគេក្លាយ ទៅជាយ៉ាងណាទៅហើយ បើពួកអ្នកភៀសខ្លួនពោល អះអាងថា អ្នកទាំងនោះត្រូវគេសម្លាប់ចោលទាំងអស់

នៅពេលសង្គ្រាមចប់បន្តិច? ពីន បានឆ្លើយថា គាត់គ្មាន យោបល់ណាមួយអំពីរឿងនេះទេ ក៏ប៉ុន្តែ ជំនួសសំណួរនេះ គាត់បែរជាផ្ដល់ព័ត៌មានស្ដីពីដោគវាសនា «ពួកក្បាត់ជាតិ» វៀតណាម ដែលជ្រៀតចូលក្នុងជួរកងទ័ពរបស់ភូមិភាគបូព៌ាទៅវិញ ។ គាត់និយាយថា «យើងបានកម្ទេចពួកនោះអស់ហើយ» ។

បីសប្ដាហ៍បន្ទាប់ពីទស្សនកិច្ចរបស់យើង ពួកវៀតណាមបានវាយលុកចូលរហូតមកដល់ក្រែក ។

យើងបានវិលត្រឡប់មកកំពង់ចាមវិញទៅតាមការកំណត់ ដើម្បីស្រស់ស្រូបអាហារថ្ងៃត្រង់ និងរៀបចំប្រដាប់ប្រដាររបស់យើងសម្រាប់ការធ្វើដំណើរវគ្គទីពីរទៀត គឺការធ្វើទស្សនកិច្ចនៅចម្ការកៅស៊ូមួយឈ្មោះចម្ការអណ្ដូង ។ យើងបានទៅដល់ទីនោះមុនពេលថ្ងៃលិច ។ ប៉ុន្មានគីឡូម៉ែត្រពីទីនេះ មិត្តរបស់ខ្ញុំឈ្មោះ ម៉ឺ កុម្ភួត ជាអតីតធនាគារិក បានស្ដាប់ព្រវិទ្យុរដ្ឋាភិបាលផ្សាយបន្តនៅក្នុងសហករណ៍របស់គាត់ថា ខ្ញុំកំពុងស្ថិតនៅក្នុងប្រទេសកម្ពុជា ។ គាត់គ្មានជឿពីរឿងនេះមួយម៉ាត់ឡើយ ៖ គាត់គិតថា របបនេះមិនអនុញ្ញាតឲ្យខ្ញុំត្រឡប់មកកម្ពុជាម្ដងទៀតទេ ហើយថារឿងភរនេះ វាគ្រាន់តែជាការឃោសនាធ្វើឲ្យយើងភ្លេចគិតពីការគំរាមកំហែងរបស់វៀតណាមប៉ុណ្ណោះ ។

គេបានរៀបចំឲ្យយើងសម្រាកនៅក្នុងផ្ទះធំមួយរបស់កម្មករចម្ការកៅស៊ូ ដែលបន្ទប់ទទួលភ្ញៀវមួយក្នុងចំណោមបន្ទប់ទទួលភ្ញៀវជាច្រើន ត្រូវគេកែប្រែឲ្យទៅជាបន្ទប់ដេកវិញ ។ ជួរគ្រែធ្វើពីឈើដែលមានចងមុងភ្ជាប់នឹងពិតានបានធ្វើឲ្យបន្ទប់នេះពេញណែន ។ ខ្ញុំបានត្រូវគេឲ្យដេកនៅជ្រុងមួយ ហើយពួកប្រុសៗនៅជ្រុងម្ខាងទៀតនៃបន្ទប់ ។ អតីតម្ចាស់គេហដ្ឋាននេះ បានដាំដើមឈើហូបផ្លែនៅជុំវិញផ្ទះ ដែលធ្វើឲ្យខ្យល់អាកាសក្នុងពេលរាត្រីមានក្លិនក្រអូបប្រហើរ ។ យើងបានបរិភោគបាយពេលល្ងាច ហើយយើងបានចូលនិទ្រាតាំងពីក្បាលព្រលប់ ។

នៅយប់នោះ សេចក្ដីភ័យខ្លាច និងការមិនទុកចិត្ត ដែលខ្ញុំខំប្រឹងធ្វើមិនដឹងមិនឮការមិនចុះសម្រុងជាក់ស្ដែងចំពោះអ្វីៗទាំងអស់ ដែលខ្ញុំពុំបានពិនិត្យរហូតដល់ពេលនៃការធ្វើដំណើរនេះ បានលេចចេញភ្លាមៗមកក្នុងគំនិតរវើរវាយរបស់ខ្ញុំ ។ ខ្ញុំបានយល់សប្ដិអាក្រក់គួរឲ្យរន្ធត់ ដែលបញ្ចប់ទៅនៅពេលដែលខ្ញុំមមើមមាយឃើញពួកក្បាត់ជាតិកូរ៉េខាងជើងកំសៀកខ្លួនចូលមកក្នុងផ្ទះធំនេះ ដើម្បីសម្លាប់ពួកយើង ។ សំឡេងថ្ងូរ និងសម្រែករបស់ខ្ញុំបានធ្វើឲ្យ ឌុដម៉ាន់ និងខាដវើល ភ្ញាក់ដឹងខ្លួន ដែលដំបូងសន្និដ្ឋានថា សំឡេងនេះមកពីខាងក្រៅ ។ ព្រឹកឡើង យើងទាំងអស់គ្នា នឹកអស់សំណើចនឹងការយល់សប្ដិផ្ដេសផ្ដាស់របស់ខ្ញុំនេះ ហើយដោយខ្ញុំជាស្ត្រីតែម្នាក់ឯង ខ្ញុំបានធ្វើការកត់សម្គាល់ពីលក្ខណៈរំជើបរំជួលក្នុងចិត្តរបស់ភេទទន់ខ្សោយដោយត្រឹមត្រូវ ។

ប៉ុន្តែ ព័ត៌មានផ្សេងៗដែលផ្សាយតាមវិទ្យុនៅពេលព្រឹកនេះ បានបង្កើននូវការព្រួយបារម្ភរបស់យើងថែមទៀត ។ តាមដំណឹងផ្សេងៗដែលមានប្រភពមកពីក្រុងភ្នំពេញ បានឲ្យដឹងថា ប៉ុល ពត និងបក្ស បានប្រុងប្រៀប

ខ្លួនទប់ទល់ការលុកលុយមួយ ដែលច្បាស់ជាមកដល់ក្នុងពេលឆាប់ៗ ។ ប្រសិទ្ធិ បាននិយាយប្រាប់ឲ្យយើងស្ថិតនៅស្ងៀមកុំជ្រួលច្របល់ ហើយប្រាប់ដំណឹងថា យើងត្រូវធ្វើដំណើរទៅធ្វើទស្សនកិច្ចនៅចម្ការកៅស៊ូមួយ រួចហើយសហករណ៍កសិកម្មទីមួយរបស់យើងឈ្មោះ ភូមិព្រះមាស ។

ចម្ការកៅស៊ូ ត្រូវបានទទួលការផ្គត់ផ្គង់យ៉ាងល្អ កម្មករទាំងបុរសទាំងនារី សុទ្ធតែមានសុខភាពមាំទាំ ។ មុនគេនាំយើងទៅមើលទីតាំងដែលធ្វើឲ្យតែបានៗសម្រាប់បង្អកជ័រកៅស៊ូ គេបានធ្វើសេចក្ដីរាយការណ៍មួយស្ដីពីការងាររបស់ពួកកម្មករ បន្ទាប់មក យើងមានសិទ្ធទទួលទានភេសជ្ជៈ និងទទួលការបញ្ជាក់បំភ្លឺថ្មីៗទៀត ។ អ្នកដឹកនាំចម្ការកៅស៊ូនេះ មានគ្នាបីនាក់ សុទ្ធតែជាអតីតយុទ្ធជន ដែលមានម្នាក់ដាច់បាត់ស្លឹកត្រចៀកម្ខាង ។ ម្នាក់នេះមិនសូវបានសម្ដីទេ ចំណែកខាងអ្នកទទួលខុសត្រូវធំជាងគេ បាននិយាយប្រាប់យើងអំពីលទ្ធផលដែលចម្ការកៅស៊ូ និងរោងចក្រសម្រេចធ្វើបានកន្លងមក ។

កម្មករម្ភៃប្រាំពាន់នាក់ របស់អង្គភាពនេះ ពុំមានបទពិសោធន៍បន្តិចសោះក្នុងការចៀរជ័រកៅស៊ូមុននឹងចាត់តាំងឲ្យមកទទួលមុខការថ្មីដោយអំណាច ។ ប្រធានដឹកនាំអង្គភាពបានប្រកាសដោយភាពក្រអឺតថា «ក្នុងចំណោមពួកនេះ ភាគច្រើនលើសលុប គឺមានប្រភពដើមជាប្រជាកសិករសុទ្ធសាធ ហើយមិនទាំងស្គាល់ «ដើមកៅស៊ូ» យ៉ាងម៉េចផង ។ ពួកគេចេះចៀរដើមកៅស៊ូបង្ហូរជ័រ ចេះថែទាំ ចេះធ្វើឲ្យរោងចក្រដំណើរការបាន... ក្រោមរបបចាស់ ភាគច្រើននៃពួកកម្មកររោងចក្រកៅស៊ូសុទ្ធតែជាវៀតណាម ។ ពួកគេបានវិលទៅស្រុកវិញនៅឆ្នាំ១៩៧៣ អស់ហើយ» ។

អ្នកដែលបាត់ស្លឹកត្រចៀកម្ខាងបានបន្ថែមថា «ពួកបារាំងពុំបានបង្រៀនជនជាតិខ្មែរពីរបៀប ដាំ ថែទាំ និងចៀរជ័រកៅស៊ូឡើយ ពួកគេបង្រៀនតែជនជាតិវៀតណាមប៉ុណ្ណោះ» ។

ពួកយើងមានសិទ្ធិចោទសួរសំណួរមួយចំនួនតូច ហើយនៅពេលដល់វេនរបស់ខ្ញុំ ខ្ញុំបានសួរទៅពួកអ្នកដឹកនាំពីដើមកំណើតរបស់ពួកគេ ដែលសុទ្ធតែជាសមាជិកបក្ស ឬអ្នកធ្លាប់ប្រយុទ្ធតស៊ូក្នុងរយៈពេលសង្គ្រាម ។ បន្ទាប់ពីសំណួរស្ដីពីការចូលជាសមាជិកបក្ស កើតមានការស្ងប់ស្ងៀមមួយ បន្ទាប់មក មនុស្សដែលមានតែត្រចៀកម្ខាងបានឆ្លើយថា «បាទ គាត់ជាសមាជិកបក្សមែន និងជាអតីតយុទ្ធជននភូមិភាគបូព៌ា ។ ពេលនោះ អ្នកដឹកនាំពីរនាក់ទៀតក៏ចាប់និយាយដែរ ហើយពេលវេលាដែលគេអនុញ្ញាតឲ្យចោទសួរ បានបញ្ចប់ទៅយ៉ាងឆាប់រហ័ស ។ ដោយសើចផង ប្រសិទ្ធិ បានសម្លឹងមើលមកខ្ញុំ ហើយនិយាយថា សំណួរទាំងប៉ុន្មានរបស់ខ្ញុំ មិនខ្វះការកំប្លែងស្អួត ដើម្បីបញ្ឈឺចិត្តឡើយ ។

យើងបានវិលត្រឡប់មករថយន្តវិញ ហើយបានចេញដំណើរឆ្ពោះទៅសហករណ៍កសិកម្មទៀត ។ ការយល់សប្តិអាក្រក់របស់ខ្ញុំ ថ្ងៃមុនប្រហែលពីព្រោះអ្វីៗដែលគេបង្ហាញឲ្យយើងឃើញដូចការពិតនោះ គឺសុទ្ធតែក្លែងបន្លំយ៉ាងជាក់ស្ដែង ។ ខ្ញុំសង្ឃឹមថា ទិដ្ឋភាពពិតប្រាកដមួយរបស់ប្រទេសកម្ពុជា មុខជារកឃើញទំនាស់ដែល

វុំព័ទ្ធជុំវិញយើងព្រមនឹងការកាប់សម្លាប់ផង ។ សហករណ៍ដែលគុបតែងពិតៗ សម្រាប់ការថតភាពយន្ត វាមិនស្របគ្នានឹងការពិពណ៌នាដោយពួកអ្នកភៀសខ្លួន ពីទីកន្លែងផ្សេងៗដែលពួកគេបានរត់គេចមកទាល់តែសោះ ។ ប្រធានភូមិបានបញ្ជាក់ប្រាប់យើងថា ក្នុងក្រុមផ្ទះឈើល្អៗសង់ខ្ពស់ពីដីទាំងនេះ មនុស្សទាំងអស់បានទទួលទានបាយបីដងក្នុងមួយថ្ងៃ ហើយនៅថ្ងៃបុណ្យមានបន្ថែមថែមទៀត ។ កសិករមានសិទ្ធិឈប់សម្រាក ៣ថ្ងៃក្នុងមួយខែ គឺថ្ងៃទី១០ ទី២០ និងទី៣០ ។ ពួកមេដឹកនាំសហករណ៍ បានបង្ហាញប្រាប់យើងពីពួកស្ត្រីៗដែលជាប់រវល់ត្បាញ ពួកប្រុសៗ កំពុងជួសជុលឧបករណ៍ផ្សេងៗ និងផ្ទះបាយដ៏ធំល្វឹងល្វើយមួយ ដែលអ្នកភូមិទាំងអស់ត្រូវទៅបរិភោគរួមគ្នានៅទីនោះ ។ ប្រធានភូមិ បានសង្កត់បញ្ជាក់ថា ខ្លួនគាត់ផ្ទាល់ និងកម្មាភិបាលដទៃទៀត សុទ្ធតែជាអ្នកបម្រើប្រជាជន ដែលជ្រើសរើសឡើងដោយមហាជន ចំពោះគុណសម្បត្តិរបស់ពួកគេក្នុងការគ្រប់គ្រងភូមិ ។ តាមការពិត ក្រោយមកខ្ញុំរកឃើញថា ពួកគេសុទ្ធតែជាមេដឹកនាំជាន់ខ្ពស់របស់បក្ស ។

ប៉ុន្តែ គឺនៅទីនោះហើយ ដែល ប្រសិទ្ធ បាននាំយើងឲ្យស្គាល់សាក្សីម្នាក់ក្នុងចំណោមសាក្សីជាច្រើន ដែលខ្ញុំស្នើសុំជួបតាំងពីថ្ងៃដំបូងម្ល៉េះ ៖ ជនណាម្នាក់ក៏ដោយ ដែលធ្លាប់រស់នៅទីក្រុងភ្នំពេញមុនការជម្លៀស ។ មនុស្សនោះ គឺជនជាតិចិនកាត់ខ្មែរម្នាក់ ។ ដោយចាំស្តាប់សំណួរផ្សេងៗរបស់ខ្ញុំ គាត់បានឆ្លើយថា គាត់ជាអ្នកធ្លាប់រស់នៅទីក្រុងភ្នំពេញមែន ប៉ុន្តែមើលទៅ គាត់របៀបដូចជាមនុស្សខូចសរសៃប្រសាទយ៉ាងខ្លាំង ។ ខ្ញុំបានចោទសួរគាត់នូវសំណួរមិនសូវសំខាន់ជាច្រើន ដោយបណ្តោលឲ្យគាត់និយាយប្រាប់ខ្ញុំនូវអ្វីដែលគាត់ចង់និយាយ ។ គាត់និយាយប្រាប់ខ្ញុំថា គាត់ធ្លាប់បំពេញការងារជាបន្តបន្ទាប់មួយ ដោយបានទទួលផលកម្រៃទាប ក្នុងរយៈពេលសង្គ្រាម ជានិយោជិតក្នុងហាងលក់គ្រឿងសង្ហារិមមួយ រហូតដល់ក្លាយទៅជាលក់ស្រា-ស នៅតាមចិញ្ចើមថ្នល់ ។ គាត់បានបញ្ចប់ថា «អង្គការបានអនុញ្ញាតឲ្យខ្ញុំរស់នៅទីនេះ បន្ទាប់ពីការជម្លៀសចេញពីភ្នំពេញ» ។ គាត់ពុំមែនជាសមាជិកបក្សកុម្មុយនិស្តទេ ប៉ុន្តែ ជា«ពលរដ្ឋសាមញ្ញ»ម្នាក់ដែលគិតថា មានអ្នកជម្លៀសពីក្រុងភ្នំពេញជាច្រើននាក់ទៀត កំពុងរស់នៅក្នុងភូមិនេះដែរ ប៉ុន្តែ គាត់ក៏ដឹងមិនច្បាស់ដែរ ។ ប៉ុន្តែគាត់ទាយថា មនុស្សខ្លះមកពីរដ្ឋធានីតាមរបៀបដែលពួកគេធ្វើការក្នុងវាលស្រែ ប៉ុន្តែ គាត់មិនដែលនិយាយពីពួកគេសោះ ។

ដោយជាក់ស្តែង ការពិនិត្យមើលឲ្យប្រាកដប្រជាអំពីបញ្ហាសិទ្ធិមនុស្ស ត្រូវតែចាប់ផ្តើមពីស្រទាប់ប្រជាជន ដែលរងគ្រោះដោយការវាយដំយ៉ាងឃោរឃៅ និងរំលោភបំពានខ្លាំងបំផុត គឺ«ប្រជាជនធ្លាប់រស់នៅទីក្រុងនានា មន្ត្រីរដ្ឋការ និងនាយទាហាននៃរបបចាស់» ។ ប្រសិទ្ធិ ពុំបានយល់ស្របតាមទស្សនៈយល់ឃើញរបស់ខ្ញុំទេ ហើយបញ្ជាក់ថា ខ្ញុំមានគំនិតខុសគេ ៖ ខ្ញុំគោងតែមើលឲ្យឃើញពីមធ្យោបាយដែលប្រជាកសិករ រស់នៅផង -៩០ភាគរយនៃប្រជាជនទាំងអស់- ហើយឲ្យខ្ញុំឈប់ខ្វាយខ្វល់ពីពួកឧក្រិដ្ឋជននៃរបបចាស់ទៀតទៅ ។ ដោយហេតុថា ប្រជាជនកម្ពុជាជិតពីរលាននាក់ ក្នុងចំនួនប្រជាជនសរុប ប្រាំមួយ ឬប្រាំពីរលាននាក់ ដែលធ្លាប់រស់នៅតាមទីក្រុងនានា ក្នុងពេលដែលខ្មែរក្រហមទទួលជ័យជម្នះនោះ តាមយោបល់ខ្ញុំថា គេអាចរកជួបអ្នកតំណាង

ពួកនេះចំនួន មួយភាគបី ឬមួយភាគបួន បានដោយងាយស្រួល បើប្រៀបធៀបនឹងចំនួនទាំងអស់ ។ ប្រសិទ្ធិ គ្រវីក្បាល ។

ប្រសិទ្ធិ បានរៀបរាប់ប្រាប់យើងពីទិដ្ឋភាពមួយនៃការបដិវត្តន៍របស់កម្ពុជា ដែលហាក់ដូចជាសមស្រប នឹងកន្លែងដែលយើងទៅទស្សនាដែរ ។ នៅសហករណ៍ គាត់បានលាតត្រដាងអំពីការគ្រប់គ្រងប្រទេស ការបែង ចែកប្រទេសទៅជាសហករណ៍ សង្កាត់ ស្រុក តំបន់ និងភូមិភាគ ។ សហករណ៍កសិកម្មទាំងឡាយ ត្រូវទទួលមតិ ណែនាំផ្សេងៗពីរដ្ឋអំណាចស្រុក ឬសង្កាត់ ។ ក៏ប៉ុន្តែ ចម្ការកៅស៊ូទាំងអស់ គឺស្ថិតនៅក្រោមអំណាចត្រួតត្រា របស់ក្រសួងពាណិជ្ជកម្មដោយផ្ទាល់ ដែលកាន់កាប់លើផលិតផលជ័រកៅស៊ូ ។

ប្រសិទ្ធិ ប្រាថ្នាធ្វើឲ្យយើងចាប់អារម្មណ៍ថារបបរបស់គាត់ គឺជារបបដែលប្រកបដោយវិចារណញ្ញាណ និងមានប្រសិទ្ធភាព ។ សម្រាប់រឿងនីមួយៗ គឺមានចម្លើយមួយ ។ ប្រទេសកម្ពុជារបស់ប្រសិទ្ធិមិនដែលស្គាល់ គ្រោះអត់ឃ្លាន ពន្ធនាគារឡើយ ហើយបន្ទប់ធ្វើទារុណកម្ម និងដំរំពលកម្មអមនុស្សធម៌រឹតតែគ្មានទៅទៀត ។ នៅទីនោះគេបែងចែកអ្វីៗស្មើគ្នាទាំងអស់ គេធ្វើការងារក្នុងស្មារតីសហប្រតិបត្តិការ និងជឿទុកចិត្តដោយរង់ចាំ សម័យរីកចម្រើនបំផុតមួយ ដែលការងារដ៏នឿយលំបាករបស់គេនឹងហុចផ្លែផ្កាឲ្យ ។

ហើយប្រទេសកម្ពុជាដែលមានតែមួយ ដែលគេអនុញ្ញាតឲ្យយើងដើរមើលក្នុងរយៈពេលនៃការធ្វើដំណើរ នេះ គឺកម្ពុជាប្រជាធិបតេយ្យ ដូចដែល ប្រសិទ្ធិ ដឹងក្នុងគំនិតដែរ ។ យើងពុំ អាចទៅជួបមនុស្សណាម្នាក់បានឡើយ យើងទទួលទានបាយដោយឡែកពីគេ យើងស្នាក់នៅតែឯង ឆ្ងាយពីប្រជាជនទាំងពួង ។ មនុស្សខ្លះ ដែលគេ អនុញ្ញាតឲ្យយើងនិយាយរកបាន សុទ្ធតែជាមនុស្សដែលអង្គការជ្រើសរើសសម្រាប់ជាតំណាងប្រទេសកម្ពុជា ហើយ ប្រសិទ្ធិ ជាអ្នកបកប្រែនៅរៀងរាល់លើកដែលប្រជាជនទាំងនោះនិយាយ ។ យើងជិះរថយន្តជាច្រើន ម៉ោង ដើម្បីទៅធ្វើការសន្ទនាមួយរយៈពេលដប់នាទី ជាមួយនឹងប្រធានសហករណ៍ម្នាក់ បន្ទាប់មក យើងចាប់ធ្វើ ដំណើរជាថ្មីអស់រាប់ម៉ោងទៀត ដើម្បីបរិភោគអាហារនៅតាមចិញ្ចើមផ្លូវ រួចហើយចាកចេញឆ្ពោះទៅគោលដៅថ្មី បន្ទាប់ទៀត ។ ការបរិភោគអាហារថ្ងៃត្រង់ តម្រូវឲ្យមានការរៀបចំរយៈពេលមួយម៉ោងជាចាំបាច់ ។ (ខ្ញុំសង្ស័យ លើ ប្រសិទ្ធិ ដែលធ្លាប់រៀបចំម្ហូបអាហារក្នុងឱកាសរៀបអាពាហ៍ពិពាហ៍ អៀង សារី នៅក្រុងប៉ារីស កាលពី ម្ភៃប្រាំឆ្នាំមុនថា ច្បាស់ជាត្រួតពិនិត្យមើលមុខម្ហូបនីមួយៗ ដែលគេបានរៀបចំជូនយើងមិនខាន) ។ បន្ទាប់មក គេបានឲ្យយើងសម្រាកពេលថ្ងៃចំនួន មួយម៉ោង ហើយជាទូទៅ នៅពេលយប់គេតែងបណ្ដេញយើងឲ្យចូលដេក ជានិច្ច បើទុកជាយើងមិនទាន់ងងុយក៏ដោយ ។

ដោយចាកចេញពីសហករណ៍នោះ យើងបានធ្វើដំណើរតម្រង់ទៅទីក្រុងសៀមរាបទៀត ដែលស្ថិតនៅ ជិតប្រាសាទអង្គរវត្ត និងជារមណីយដ្ឋានដែលមានប្រាសាទល្បីៗ ។ នៅតាមផ្លូវ យើងបានឈប់សំចតនៅក្រុង កំពង់ធំ ដើម្បីទទួលទានអាហារថ្ងៃត្រង់នៅលើផ្ទះទឹកមួយ តាមដងស្ទឹងសែន ។ បន្ទាប់មក យើងបានបន្តដំណើរទៅ

មុខទៀត ហើយអ្នកបើកឡានរបស់យើង បានបញ្ឈប់រថយន្ត «ដោយឥតអ្នកណាប្រាប់» ដើម្បីអនុញ្ញាតឲ្យយើងសម្លឹងមើលប្រជាកសិករមួយក្រុមពីចម្ងាយ ដែលកំពុងធ្វើការផ្សារ និងច្រៀងបដិវត្តក្នុងស្រែមួយក្រោមទង់ពណ៌ក្រហមដែលកំពុងបក់រវិចៗតាមកម្លាំងខ្យល់បក់ ។ ឌុដម៉ាន់ និងខ្ញុំ បានថតរូបជាច្រើនប៉ុស្តិ៍ ខាងវើល «មិត្ត» របស់របបនេះ គឺជាមនុស្សតែម្នាក់គត់ ក្នុងចំណោមពួកយើងដែលធ្លាប់មានបទពិសោធន៍ក្នុងការធ្វើដំណើរក្នុងប្រទេសសង្គមនិយមផ្សេងៗ បានធ្វើជាបន្ទាល់ចំពោះភាពឥតអៀនខ្មាសនេះ ។ គាត់ចូលចិត្តស្ថិតនៅក្នុងរថយន្តជាង ហើយមិនរវល់ថតយករូបភាពមួយ ដែលគេបានរៀបចំយ៉ាងឆ្គងសម្រាប់ពួកយើងឡើយ ។

ស្អែកឡើង យើងបានទៅទស្សនាប្រាសាទជាច្រើន ។ អ្វីដែលត្រូវទៅជាឱកាសមួយធ្វើឲ្យយើងកោតស្ញប់ស្ញែងចំពោះស្នាដៃទាំងនោះ បានត្រូវបំផ្លាញដោយសារវត្តមាននៃម្ចាស់ផ្ទះរបស់យើង គឺពួកខ្មែរក្រហម ជាពិសេស ប្រសិទ្ធិ ដែលឆ្លៀតយក«ភាពត្រូវកាលៈទេសៈ»នេះ ដើម្បីបង្ហាញថា គាត់មិនសូវចេះចាំប្រវត្តិសាស្ត្រប្រទេសគាត់ប៉ុន្មានទេ ហើយគាត់មានតែសំដីមាក់ងាយ ចំពោះពួកបារាំងដែលធ្លាប់ជួសជុលប្រាសាទទាំងនេះឡើងវិញប៉ុណ្ណោះ ។

ដូចសារមន្ទីរនៅភ្នំពេញដែរ ប្រាសាទទាំងអស់នេះ ពុំមានអ្នកណាម្នាក់យកចិត្តទុកដាក់ថែរក្សាឡើយ ។ ពួកអភិរក្សខ្មែរ ដែលបណ្ដុះបណ្ដាលដោយពួកបារាំង កំពុងធ្វើការក្នុងទីក្រុងសៀមរាប នៅពេលដែលខ្មែរក្រហមទទួលជ័យជម្នះ ។ ខ្ញុំបានសួរទៅ ប្រសិទ្ធិ ថា តើអ្នកទាំងនោះ ក្លាយទៅជាយ៉ាងណាហើយ ។ គាត់ឆ្លើយប្រាប់ខ្ញុំថា ពួកបញ្ញវន្តពុំត្រូវបានយកមកប្រើប្រាស់តាមមុខជំនាញរបស់ខ្លួនទេ លើកលែងតែអ្នកទាំងនោះ បង្ហាញឲ្យឃើញពីការយកចិត្តទុកដាក់របស់គេ ចំពោះទិសដៅផ្សេងៗរបស់បដិវត្តសិន ។ តាមប្រហែល គ្មានអភិរក្សអង្គរណាមួយ បានសម្រេចជោគជ័យតាម «ការសាកពិសោធន៍» នេះទេ ។ នៅជុំវិញទីនោះ យើងឃើញមានតែកងទ័ព និងប្រជាកសិករខ្លះៗ កំពុងរាស់សម្អាតកម្រាលស្មៅ ដែលលាតសន្ធឹងនៅខាងមុខប្រាសាទប៉ុណ្ណោះ ។ ប្រាង្គប្រាសាទផ្ទាល់ ត្រូវគេបោះបង់ចោលគ្មានការថែទាំឡើយ ។

ប៉ុន្តែ ប្រាសាទទាំងនោះ បានទទួលអត្ថប្រយោជន៍ពីគាំពារផ្នែកនយោបាយមួយ ដោយហេតុថា វាស្ថិតនៅក្នុងស្ថានភាពម៉្យាងដែលពួកខ្មែរក្រហម -ហើយមុនពួកគេ គឺបណ្ដាមេដឹកនាំកម្ពុជាជំនាន់បច្ចុប្បន្ន- ចាត់ទុកថា ជាវប្បធម៌របស់ប្រទេសកម្ពុជា ។ ក្នុងប្រទេសកម្ពុជាបដិវត្តន៍ ផ្ទាំងគំនូរប្រាសាទអង្គរវត្ត នៅមានព្យួរក្នុងអគារ និងនិវេសដ្ឋានផ្លូវការនានាដែលយើងទៅទស្សនានៅឡើយ ។ ពុំមានរូបថត ប៉ុល ពត ឬមេដឹកនាំផ្សេងៗទៀតឡើយ ហើយពុំមានរូបថត ម៉ាក្ស លេនីន ឬស្តាលីន ដូចនៅប្រទេសវៀតណាមទេ ។ មានតែរូបអង្គរវត្តមួយប៉ុណ្ណោះ ដែលក្លាយទៅជានិមិត្តរូបរបស់ប្រទេសកម្ពុជាបដិវត្ត ។ ប៉ុល ពត បានកាន់កាប់តំណែងមិនទាន់ជាក់លាក់មួយ នៅឡើយ សម្រាប់ឲ្យគេព្យួររូបថតគាត់នៅតាមមន្ទីរក្រសួងទូទាំងប្រទេសនោះ ។ (បើទុកជាគាត់បានបញ្ជាឲ្យគេធ្វើរូបដិមាផ្ទាល់របស់គាត់រួចមកហើយក៏ដោយ ក៏យើងគ្មានឃើញរូបសំណាកណាមួយនៅតាមទីកន្លែងសាធារណៈ

ផ្សេងៗ  ក្នុងរយៈពេលនៃការស្នាក់អាស្រ័យរបស់យើងដែរ) ។

យើងបានស្នាក់នៅអង្គរចំនួន ពីរយប់ ។ នៅពេលរៀបចំចេញដំណើរត្រឡប់មកវិញ គឺកើតមានការយឺតយូរមួយ ដែលយើងមិនបាននឹកគិតជាមុន ។ ដំបូង គេបាននិយាយប្រាប់យើងថា ផ្លូវថ្នល់ត្រូវលិចទឹកអស់ហើយ ប៉ុន្តែ បុគ្គលិកផ្នែកសន្តិសុខ បានមករាយការណ៍ប្រាប់ ប្រសិទ្ធិ ជារឿយៗ ។ ដោយភ័យបារម្ភផង យើងបានអង្គុយរង់ចាំជាច្រើនម៉ោងដោយស្តាប់វិទ្យុកំសាន្តផង ៈ សហរដ្ឋអាមេរិក និងប្រទេសចិន បានព្រមព្រៀងគ្នាធ្វើឲ្យទំនាក់ទំនងផ្សេងៗរបស់គេមានជាប្រក្រតិវិញ ។ ប្រសិទ្ធិ បានប្រកាសថា កិច្ចព្រមព្រៀងនេះ បានកើតឡើងត្រូវឱកាសល្អណាស់សម្រាប់កម្ពុជាប្រជាធិបតេយ្យ ។

នៅទីបញ្ចប់ យើងបានចេញដំណើរឆ្ពោះទៅទីក្រុងបាត់ដំបង ស្ថិតនៅក្នុងភូមិភាគពាយ័ព្យ ។ គឺទីនោះហើយ ដែលប្រជាជនទីក្រុងភ្នំពេញមួយចំនួនធំរស់នៅបន្ទាប់ពីការបណ្តេញចេញ ។ ថ្វីបើនៅជំនាន់នេះ មិនសូវមានអ្នកណាម្នាក់ដឹងពីសកម្មភាពប្រព្រឹត្តទៅនៃប្រទេសកម្ពុជាបដិវត្តក៏ដោយ ក៏យើងបានទទួលពត៌មានមួយចំនួន ស្តីពីភូមិភាគពាយ័ព្យនេះដែរ ពីព្រោះភូមិភាគនេះមានព្រំដែនជាប់នឹងប្រទេសថៃ ហើយមានពួកអ្នកភៀសខ្លួនរត់ចេញពីប្រទេសយ៉ាងច្រើនតាំងពីឆ្នាំ១៩៧៥ ។ តាមបណ្តាស្រុកខ្លះ ការសម្លាប់មនុស្ស និងការអត់ឃ្លាន បានប្រល័យជីវិតប្រជាជនទាំងស្រុក ទាំងភូមិ ។ គឺទីនោះហើយ ដែលខ្ញុំសង្ឃឹមបានជួបអ្នកណាម្នាក់ ដែលខ្ញុំធ្លាប់ស្គាល់ និងនៅទីនោះដែរ ដែលខ្ញុំអាចពិនិត្យមើលដោយល្អិតល្អន់ពីស្ថានភាពរស់នៅរបស់ប្រជាជនដែលគេចាត់ទុកថា ជាអ្នកងាយរងគ្រោះជាងគេក្រោមរបបខ្មែរក្រហមដ៏តឹងរ៉ឹង ។

យើងត្រូវចំណាយពេលមួយថ្ងៃ ដើម្បីបានទៅដល់ក្រុងបាត់ដំបង ។ យើងឈប់នៅក្បែរស៊ីសុផុន ដើម្បីទទួលអាហារថ្ងៃត្រង់ និងទស្សនាមជ្ឈមណ្ឌលស្រាវជ្រាវកេរ្តិ៍ត្រសាស្ត្រមួយ ។ ប្រសិទ្ធិ ក្នុងបែបបទពុំអាចគ្រាប់តាមរបស់គាត់ បានខំប្រឹងធ្វើឲ្យយើងជឿថា ដីដ៏មានជីជាតិរបស់ភូមិភាគពាយ័ព្យ ត្រូវប្រជាជនបង្កបង្កើនផលបានល្អប្រសើរ សម្រាប់ជាលើកដំបូងបង្អស់ក្នុងប្រវត្តិសាស្ត្ររបស់កម្ពុជា ។ ពួកខ្មែរក្រហមបានសាកល្បងឲ្យគេស្ទូងពូជស្រូវថ្មីប្លែកៗគ្នា តាមគំរូដ៏ផ្សេងៗ ដែលមិនទាមទារឲ្យមានការដាក់ជីគីមី ដ៏មានតម្លៃថ្លៃនោះឡើយ ។ ពូជស្រូវទាំងនោះ ត្រូវបានបែងចែកឲ្យប្រជាជនក្នុងទូទាំងភូមិភាគពាយ័ព្យ ហើយរួមផ្សំនឹងប្រព័ន្ធធារាសាស្ត្រផងបានផ្តល់ផលស្រូវយ៉ាងច្រើនលើសលុប ។

នៅពេលយប់ គេបានណែនាំឲ្យយើងរៀបចំសំណួរផ្សេងៗទុកជាមុន ក្នុងករណីដែល ប៉ុល ពត យល់ព្រមឲ្យយើងចូលជួបមុនការបញ្ចប់នៃដំណើរទស្សនកិច្ចនេះ ។

នៅព្រឹកថ្ងៃបន្ទាប់ មានការរឿងឆ្ងល់មួយកើតឡើង ។ ប្រសិទ្ធិ បានប្រាប់ឲ្យយើងដឹងថា យើងអាចទៅទស្សនាតែសហករណ៍មួយគត់របស់ភូមិភាគនេះ គឺអ៊ីៗត្រូវហាមឃាត់ទាំងអស់ ។ គាត់អះអាងថា មេដឹកនាំទាំងអស់ទៅធ្វើស្រែអស់ហើយ ។ ជំនួសរឿងនេះ យើងបែរទៅមើលសំណង់ទំនប់ទឹកជាច្រើនកន្លែងដែលកសាង

ឡើងដោយពួកអ្នកជម្លៀសវិញ ។

ដោយគ្មានគិតគូរវែងឆ្ងាយ ខ្ញុំចាប់ផ្ដើមជជែកជាមួយ ប្រសិទ្ធិ ថា យើងត្រូវតែទៅទស្សនាសហករណ៍នានារបស់ភូមិភាគពាយ័ព្យ បើមិនដូច្នោះទេ ដំណើររបស់យើងនឹងក្លាយទៅជាគ្មានផលប្រយោជន៍ ហើយលេសទាំងឡាយរបស់លោក មិនមែននៅដដែលៗដូច្នេះទេ ។ គាត់បានសង្សម្លឹមកខ្ញុំភ្លាមៗថា ខ្ញុំនេះគ្មានដឹងសម្ដីខ្លួនឯងដែលបាននិយាយផងទេ ហើយគាត់បានបន្ថែមថា "អ្នកឯងនឹងមិនយល់ច្បាស់ពីប្រទេសនេះជារហូត" ។

ការជជែកគ្នាបានបន្តទៅទៀត ហើយខ្ញុំបានរំឭកថា អៀង សារី បានសន្យាថា យើងអាចនឹងទៅទស្សនាសហករណ៍នានា របស់ភូមិភាគពាយ័ព្យ ដើម្បីបដិសេធដោយជាក់លាក់នូវការពោលអាងផ្សេងៗ អំពីការរំលោភសិទ្ធិមនុស្សយ៉ាងច្រើន ដោយផ្ទុយនឹងការលើកឡើងរបស់ពួកអ្នកធ្លាប់រស់នៅទីក្រុងភ្នំពេញ ។ ប៉ុន្តែ គឺឥតបានការទាំងអស់ ៖ ប្រសិទ្ធិ ជាមន្ត្រីបដិវត្តន៍ម្នាក់ដែលត្រូវចាត់ឲ្យមកភូតកុហកយើង ។ ត្រូវជំរុញទៅក្នុងជំហរការពារខ្លួនរបស់គាត់ គាត់គ្មានការជ្រើសរើសណាក្រៅពីបង្កើនការភូតភរឡើយ ។

កំហឹងរបស់ខ្ញុំកើតឡើងដោយសារយោបល់មិនអាចជៀសរួចមួយផ្នែកធំនៃការហាមឃាត់នេះ ។ តើគាត់ទទួលស្គាល់សេចក្ដីទុកចិត្តដែលខ្ញុំមានទៅលើពួកមគ្គុទ្ទេសក៍នាំផ្លូវ បានចាប់ផ្ដើមរលាយខ្សុល ។ ក្នុងរយៈពេលសេសសល់នៃថ្ងៃនោះ ប្រសិទ្ធិ និងខ្ញុំ បាននិយាយរកគ្នាតិចតួចណាស់ ហើយការធ្វើដំណើរជាបន្តបន្ទាប់មកទៀតខ្ញុំហាក់ដូចជាក្លាយទៅជាអ្នក ប្រកែកប្រណាំងជាងគេ ដោយខ្ញុំប្រកែកមិនត្រឹមតែជាមួយម្ចាស់ផ្ទះរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែ ជាមួយ ឌុដម៉ាន់ និង ខាដវើល ។

នៅពេលរសៀល យើងបានដើរទៅមើលទំនប់ទឹកមួយ ហើយយើងនិយាយគ្នាពីភាគសេសសល់នៃដំណើររបស់យើងបន្តទៀត ។ ខាដវើល និង ឌុដម៉ាន់ បានចោទសួរពីសំណង់នេះ ដែលគេបានជួសជុលឡើងវិញបន្ទាប់ពីទទួលការខូចខាតដោយសារទឹកជំនន់ដ៏សាហាវកាលពីរដូវវស្សាមុន ។ យុវបុរសនេះឈ្មោះ វ៉ុន មានអាយុម្ភៃប្រាំឆ្នាំ គឺជាអតីតយុទ្ធជនម្នាក់ ដែលរំសាយចេញពីកងទ័ព និងត្រូវបានតែងតាំងជាប្រធានគណៈកម្មាធិការ ទទួលបន្ទុកក្នុងការកសាងទំនប់ទឹក ។ (យើងធ្លាប់បានទទួលស្ថិតិតាមឯកសារ និងដែលមិនអាចផ្ទៀងពិនិត្យដឹងខុសត្រូវបានស្ដីពីទំនប់នេះ និងសំណង់ផ្សេងៗទៀតដែលកសាងក្នុងភូមិភាគពាយ័ព្យ ។ ម្យ៉ាងទៀត សំណង់ទាំងនេះធ្លាប់ត្រូវវិទ្យុផ្សាយកាលពីប៉ុន្មានខែមុនផង) ។ សន្ទះទប់ទឹកបានបាក់ខ្ទេចខ្ទី ពីព្រោះទំនប់ពុំបានទទួលការត្រួតពិនិត្យត្រឹមត្រូវតាមបទដ្ឋានក្នុងរយៈពេលនៃការសាងសង់ទេ ។ នៅពេលដល់វេនរបស់ខ្ញុំ ខ្ញុំបានសាកសួរយុវជនទទួលខុសត្រូវកន្លែងនេះ ពុំមែនសួរពីប្រព័ន្ធធារាសាស្ត្រ ដែលគេអួតអាងខ្លាំងណាស់នោះទេ គឺសួរពីបញ្ហាសង្គ្រាម ។

វ៉ុន បានប្រែក្លាយការសម្ភាសន៍ទៅជាល្បែងការពិភាក្សាតទល់មួយ ។ ដោយត្រូវឆ្លើយនឹងសំណួរផ្សេងៗរបស់ខ្ញុំ គាត់បែរជាប្រគោងឡើងទៅលើសំណង់បេតុងទៅវិញ ដោយតម្រូវឲ្យ ប្រសិទ្ធិ និងខ្ញុំ ឡើងទៅតាមគាត់ដែរ ។ ខ្ញុំបានសួរគាត់ពីការទម្លាក់គ្រាប់បែករបស់អាមេរិកាំងក្នុងអំឡុងពេលសង្គ្រាម ពីស្ថានភាពរស់នៅរបស់

គាត់ និងកងទ័ពថ្មីរដើងផ្សេងៗទៀត ។ នៅទីបញ្ចប់នៃកិច្ចសម្ភាសន៍នេះ ខ្ញុំបានវិលទៅជួបសហសេវិកទាំងពីររបស់ខ្ញុំវិញ ហើយ ខាដវែល បាននិយាយពីអាកប្បកិរិយារបស់ខ្ញុំ ដែលធ្វើឲ្យគាត់ភ្ញាក់ផ្អើលថា «អ្នកឯងជាស្រីអាមេរិកាំង ហេតុអ្វីបានជាអ្នកឯងចោទសួរសំណួរផ្សេងៗដូច្នេះ ចំពោះជនជាតិកម្ពុជាម្នាក់? គឺវាប្រកបដោយគ្រោះថ្នាក់ដូចគ្នា បើសិនជាអ្នកយកពត៌មានជាតិអាល្លឺម៉ង់ម្នាក់ ធ្វើដំណើរទៅដល់ទីក្រុងឡុង (Londres) បន្ទាប់ពីសង្គ្រាមចប់ (សង្គ្រាមអាល្លឺម៉ង់ និងអង់គ្លេស) ដើម្បីសួរទាហានអង់គ្លេសម្នាក់ថា តើអ្នកឯងវាយប្រយុទ្ធជាមួយពួកណាហ្ស៊ីដូចម្តេចខ្លះទៅ?» ។

ក្រោយពីខ្ញុំពន្យល់គាត់ថា ខ្ញុំមកទីនេះដើម្បីទទួលបានពត៌មានផ្សេងៗ ពុំមែនមកដើម្បីធ្វើទេសចរណ៍ទេ ហើយយើងក៏លែងមានអ្វីនិយាយតទៅទៀតដែរ ។

នៅថ្ងៃបន្ទាប់ ប្រសិទ្ធិ បាននាំពួកយើងត្រឡប់មកក្រុងភ្នំពេញវិញ ហើយបានបោះបង់តួនាទីជាមគ្គុទ្ទេសក៏របស់គាត់ ។ ក្នុងរាត្រីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៧៨ យើងបានចូលរួមទទួលទានបាយល្ងាចជាមួយ អៀង សារី នៅវិមានរដ្ឋចម្ការមន ។ ប្រសិទ្ធិ ជាអ្នកបកប្រែភាសាឲ្យ អៀង សារី ហើយហាក់ដូចជាបំភ្លេចនូវចរិតមិនល្អរបស់គាត់អស់ ។ គាត់បានប្រាប់ឲ្យដឹងថា ថ្ងៃស្អែកមានកម្មាភិបាលម្នាក់ទៀត នឹងជូនយើងទៅភាគខាងត្បូង គឺទៅកំពង់សោម ចំណែកឯគាត់នឹងស្ថិតនៅក្នុងរដ្ឋធានី ដើម្បីធ្វើកិច្ចការបន្ទាន់ផ្សេងៗ ។ បន្ទាប់ពីបានសាកសួរពីសុខភាពរបស់យើង សារី បានសម្តែងនូវការសប្បាយរីករាយយ៉ាងខ្លាំង ដែលពួកយើងបានធ្វើដំណើរចម្ងាយជាងមួយពាន់គីឡូម៉ែត្រ ហើយថាឥឡូវនេះយើងអាចធ្វើជាកសិណសាក្សី ចំពោះស្ថានភាពរស់នៅដ៏ប្រសើររបស់ប្រជាជនយើង ។ គាត់តុបតែងខ្លួនស្អាតបាត ក្នុងសម្លៀកបំពាក់ពណ៌ខ្មៅគដូច ម៉ៅ សេទុង ដែលកាត់ដេរយ៉ាងផ្ចិតផ្ចង់ ។ សារី មានទឹកមុខមួយដូចសត្វជ្រូក ដែលអាចសម្តែងចេញនូវទឹកមុខក្រញូវដោយងាយ ។ ប៉ុន្តែ គាត់ក៏អាចបង្ហាញទឹកមុខស្រស់ស្រាយ ធ្វើឲ្យគេចូលចិត្តខ្លាំង ហើយដោយឡែក ក្នុងមជ្ឈដ្ឋានអ្នកបដិវត្តគាត់ពុំដែលល្បីឈ្មោះថា ជាមនុស្សមិនចេះអាណិតអាសូរនោះទេ ។

ប្រសិទ្ធិ ជាអ្នកបកប្រែភាសាក្នុងការសន្ទនាទាំងអស់ ។ «ល្ងាចនេះ ខ្ញុំមានឱកាសបានពិសាភោជនាហារពេលល្ងាចជាមួយអស់លោក ដោយមិនចាំបាច់មានពិធីការ... ។ ខ្ញុំធ្លាប់ស្គាល់លោក ឌុដម៉ាន់ និងនាងកញ្ញាអេលីហ្សាបែត បេ៊កឌ័រ រួចមកហើយ ។ គឺជាលើកដំបូងបង្អស់ ដែលខ្ញុំបានជួបលោកសាស្ត្រាចារ្យ ខាដវែល... តើមានបញ្ហា ឬសំណួរអ្វីខ្លះ ដែលអស់លោកចង់ដាក់ឲ្យខ្ញុំពិនិត្យ?» ។

ឌុដម៉ាន់ ជាអ្នកទទួលភារៈសួរសំណួរផ្សេងៗយ៉ាងប៉ិនប្រសប់ គឺជាអ្នកជំនាញខាងការទាក់ទងនៃក្រុមរបស់យើង ។ ក៏ប៉ុន្តែ សារី បានសម្រេចចិត្តមិនឆ្លើយនឹងសំណួរទាំងនេះទេ ហើយបានស្នើឲ្យយើងរង់ចាំទទួលចម្លើយនេះ នៅក្នុងការជួបសន្ទនាជាមួយ ប៉ុល ពត វិញ ដែលត្រូវមានការយល់ព្រមថែមទៀត ។ ជំនួសការធ្វើសុន្ទរកថាមួយស្តីពីលក្ខណៈដែលជៀសមិនរួចនៃសង្គ្រាម ជាមួយប្រទេសវៀតណាមគាត់បានសុំឲ្យយើងអនុគ្រោះឲ្យ

គាត់ផង ។

«ប្រទេសវៀតណាម ចង់បង្ខំឲ្យកម្ពុជាចូលជាចំណែកមួយនៃសហព័ន្ធឥណ្ឌូចិនរបស់ខ្លួន... ។ យើងបានដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរ ចំពោះពួកឈ្លានពានវៀតណាម... ។ ពួកគេនឹងត្រូវប្រឡូកក្នុងសង្គ្រាមយូរអង្វែងមួយ... ។ ឆ្នាំមុន ពួកគេត្រូវស្ថិតនៅក្នុងភាពឯកោឡើងវិញលើឆាកអន្តរជាតិ ដោយសារតែរឿង«អ្នករត់ភៀសខ្លួនតាមទូក» ។ ពួកវៀតណាមលែងអាចបំភ័ន្តមតិសាធារណៈពិភពលោកបានទៀតហើយ ។ ឥឡូវនេះ ពិភពលោកដឹងថា ប្រទេសវៀតណាមជាកូនអុកមួយរបស់សហភាពសូវៀត» ។

សង្គ្រាមច្បាស់ជាកើតមានក្នុងពេលឆាប់ៗ សំណួររបស់យើងស្ដីពីបញ្ហាសិទ្ធិមនុស្ស និងស្ថានភាពរស់នៅរបស់ប្រជាជន សុទ្ធតែនៅក្រៅសាច់រឿង ។ ប្រសិទ្ធ និង សារី បានបញ្ជាក់អះអាងទាំងពីរនាក់ថា ពុំមានពន្ធនាគារនៅក្នុងប្រទេសទេ យុត្តិធម៌ត្រូវបានផ្ដល់ឲ្យក្នុងសហករណ៍នានា ដោយតុលាការប្រជាជន ហើយចម្លើយ គឺមានតែប៉ុណ្ណឹង ចំពោះសំណួរទាំងប៉ុន្មានរបស់យើង ។ សង្គ្រាមវាមានសារសំខាន់ជាងពួកយើង ។ ប៉ុន្តែ សារី បានប្រកាសប្រាប់យើងថា ពុំមានរឿងអ្វីធ្វើឲ្យអស់លោកព្រួយបារម្ភទេ អស់លោកធ្លាប់ឃើញកិច្ចការពាររបស់កងទ័ពកម្ពុជានៅក្រែករួចហើយ ។ (តាមការពិត យើងធ្លាប់ឃើញតែឡាន ហ្ស៊ីមួយចំនួន ផ្ទុកពេញទៅដោយកងទ័ពប៉ុណ្ណោះ) ។ គាត់បានបន្ថែមថា ទីភ្នាក់ងារព័ត៌មានទាំងឡាយនៅក្រុងបាងកក បានបដិសេធមិនជឿថា យើងបានធ្វើដំណើរទៅកាន់កាប់ក្រែកទេ ហើយបានសរសេរថា យើងបានទៅត្រឹមតែទន្លេបិទនៅត្រើយម្ខាងទន្លេមុខក្រុងកំពង់ចាមប៉ុណ្ណោះ ។ នៅទីបញ្ចប់ សារី បានសួរពីការចាប់អារម្មណ៍របស់យើង ហើយ ឌុដម៉ាន់ បានធ្វើការឆ្លើយតបគួរឲ្យស្ងើចសរសើរថា «យើងនឹងបន្តសង្កេតពិនិត្យ និងចោទសួរនូវសំណួរផ្សេងៗតទៅទៀត» ។

សម្រាប់ពួកអ្នកការសែត គឺវាគ្រប់គ្រាន់ណាស់ទៅហើយ ប៉ុន្តែ សារី ចង់ឲ្យ ខាដវែល មិត្តរបស់ប្រទេសកម្ពុជា ធ្វើការចាប់អារម្មណ៍ ហើយគាត់បានតៀនបង្ខំឲ្យ ខាដវែល បញ្ចេញនូវទស្សនៈផ្ទាល់របស់គាត់ ។ សារី បាននិយាយទៅកាន់សាស្ត្រាចារ្យអង់គ្លេសថា «យើងគ្មានអ្វីលាក់បាំងសោះឡើយ» ។ ប៉ុន្តែ ខាដវែល បានធ្វើឲ្យសារី ងឿងឆ្ងល់ស្រឡាំងកាំង៖ «ជំនួសការពិភាក្សាពីផ្ទៃផ្ការបស់បដិវត្តសាស្ត្រាចារ្យរូបនេះ បែរជាសួររដ្ឋមន្ត្រីការបរទេសអំពីសង្គ្រាមជាមួយប្រទេសវៀតណាមទៅវិញ ដោយថា វានឹងមានតម្លៃដូចម្ដេចខ្លះទៅសម្រាប់ចំពោះបណ្ដាចលនាកុម្មុយនិស្តផ្សេងៗទៀត នៅក្នុងភូមិភាគនេះ ជាពិសេស ចំពោះបក្សកុម្មុយនិស្តថៃ ។ ខាដវែល បានចាត់ទុកខ្លួនគាត់ថា ជាមិត្តរបស់អ្នកបដិវត្តទាំងអស់ –ពួកអ្នកបដិវត្តវៀតណាម ពួកថៃ និងពួកកម្ពុជា ហើយបានបង្ហាញឲ្យឃើញនូវការព្រួយបារម្ភយ៉ាងខ្លាំង ចំពោះទស្សនវិស័យផ្សេងៗនៃសង្គ្រាម រវាងប្រទេសកម្ពុជា និងវៀតណាមទៀតផង ។ សារី បានឆ្លើយតបដូចដែលគាត់ធ្លាប់និយាយកាលពីមុនដែរថា ពួកកុម្មុយនិស្តកម្ពុជាបានឈ្នះសង្គ្រាមរបស់ខ្លួន ដោយគ្មានការជួយឧបត្ថម្ភពីអ្នកណាម្នាក់ឡើយ ហើយថា ពួកថៃ អាចដឹកនាំធ្វើដូចគ្នាដែរ ។ គាត់បានបន្ថែមទៀតថា កម្ពុជាត្រូវការថែរក្សាទំនាក់ទំនង ដ៏ល្អប្រសើរជាមួយប្រទេសថៃ នៅពេលនេះ ។

គឺវាជាបញ្ហាស្លាប់រស់មួយសម្រាប់ប្រទេសកម្ពុជា ។

ខាដវ៉ើល ពុំទូចសួរអ្វីទៀតទេ ហើយបានចំណាយពេលវេលាសេសសល់ក្នុងយប់នោះ អង្គុយសម្លឹងមើលចានបាយគាត់ទៅវិញ ។ ដូចដែលយើងទាំងអស់គ្នានឹកស្មឹម ម្ហូបអាហារសុទ្ធតែមានរសជាតិឆ្ងាញ់ និងពោរពេញទៅដោយស្រាល្អៗ ។ ប៉ុន្តែ មានតែពួកយើងប៉ុណ្ណោះ ដែលផឹកស្រា ពួកកម្ពុជាគ្រាន់តែលើកកែវផ្ទឹបនឹងបបូរមាត់របស់ខ្លួន ជាកិច្ចគួរសមប៉ុណ្ណោះ ។ យើងបានក្រោកចេញពីតុឆាប់រហ័សមុនគេ ៈ សារី មានកិច្ចការជាច្រើនដែលមិនទាន់ធ្វើ ។ ខាដវ៉ើល នៅតែអង្គុយស្ងៀមគ្មាននិយាយស្តី ។ គាត់ធ្លាប់ជាមនុស្សដែលនិយាយច្រើន និងរួសរាយជាងគេ ក្នុងរយៈពេលនៃការធ្វើដំណើរ អារម្មណ៍មួហ្មងរបស់គាត់ បានសាចចេញមកលើយើងដែរ ។ គាត់យល់ថា បំណងដ៏ខ្ជាប់ខ្ជួនអំពីសហប្រតិបត្តិការបដិវត្តរបស់គាត់ ដែលមានពីយូរមកហើយ បានត្រូវរលាយបាត់បង់អស់នៅមុខកែវភ្នែកទាំងគូរបស់គាត់ ហើយធ្វើឲ្យគាត់ភ័យស្លុតក្នុងចិត្តយ៉ាងខ្លាំង ។

ស្អែកឡើង យើងបានចេញដំណើរឆ្ពោះទៅភាគខាងត្បូង ហើយយើងទៅដល់កំពុងផែកំពង់សោម នៅពេលរសៀល បន្ទាប់ពីបានប្រើខបាយកលមួយដើម្បីសម្ភាសពួកអ្នកភៀសខ្លួនខ្មែរក្រោម ដែលរត់មកពីវៀតណាមខាងត្បូង ។ អ្នកទាំងនេះបានថ្លែងប្រាប់យើងថា ពួកគេបានរត់ចេញពីប្រទេសវៀតណាម ពីព្រោះ រដ្ឋអំណាចនៅទីនោះ សុទ្ធតែប្រឆាំងនឹងរបបមូលធននិយម ហើយថា ពួកគេមកប្រទេសកម្ពុជា ដើម្បីស្វែងរកប្រាក់កាស ។ យើងពុំបានធ្វើឲ្យអ្នកទាំងនោះអស់សង្ឃឹមឡើយ ។ ដោយគ្មាន ប្រសិទ្ធិ យើងទាំងបីនាក់ បានយល់ចិត្តថ្លើមគ្នាប្រសើរជាងមុន ។ ប្រាកដហើយ យើងបានបង្កើតក្រុមមួយមានគ្នា បីនាក់ ដែលចូលចិត្តចង់ដឹងរឿងសម្ងាត់របស់គេ ។ ឌុដម៉ាន់ មានក្បាលទំពែក និងមានទឹកមុខមួយជាអ្នកសប្បាយរីករាយរបៀប “អ៊ំចាស់” ចិត្តល្អម្នាក់ ។ ខាដវ៉ើល ជាជនជាតិអេកូសម្នាក់ មានមាឌមាំ ពោរពេញដោយកម្លាំងក្លៀវក្លា រហ័សរហួន មានសំណុំសក់វែងដែលរលាស់រវិច ដូចសក់ស្រី បិទបាំងមិនឲ្យគេដឹងអាយុពិតប្រាកដរបស់គាត់ ។ ខ្ញុំបន្ថែមលក្ខណៈប្លែកៗរបស់ក្រុមតែប៉ុណ្ណឹង ពីព្រោះខ្ញុំជាស្ត្រីម្នាក់ ។

នៅកំពង់សោម យើងបានស្នាក់នៅក្នុងគេហដ្ឋានដ៏ល្អមួយ លើកូនភ្នំមួយ ដែលលយចេញទៅរកសមុទ្រតាមគេនិយាយប្រាប់យើងថា ផ្ទះនេះជាកម្មសិទ្ធិរបស់ព្រះមហាក្សត្រិយានី កុសមៈ (ព្រះមាតា សម្តេចព្រះនរោត្តម សីហនុ) ។ នៅព្រឹកថ្ងៃបន្ទាប់ ផ្ទៃមេឃភ្លឺស្រឡះល្អណាស់ ហើយយើងសង្ឃឹមចំណាយពេលវេលាពេញមួយថ្ងៃនៅកំពង់ផែ ។ មុនដំបូង គេនាំយើងដើរតាមផ្លូវជាប់មាត់សមុទ្រ ដែលយើងអាចមើលឃើញនាវាមួយគ្រឿងកំពុងបើកមកពីសិង្ហបុរី មួយទៀត មកពីប្រទេសចិន កាណូតសណ្តោងមួយដែលតុបតែងលម្អមើលទៅគួរឲ្យសប្បាយរីករាយ ព្រមទាំងឃ្លាំងផ្ទុកទំនិញធំទូលាយមួយ ពោរពេញដោយសំឡីក និងជ័រកៅស៊ូសម្រាប់ការនាំចេញ ។ មេដឹកនាំម្នាក់នៃគណៈកម្មាធិការកំពង់ផែ បានអនុញ្ញាតឲ្យយើងជួបសម្ភាសន៍រយៈពេលកន្លះម៉ោងបន្ទាប់មក គេបានប្រាប់យើងឲ្យដឹងជាមុនថា ដល់ពេលដែលយើងត្រូវវិលត្រឡប់ទៅវិញហើយ គឺវិល

ត្រឡប់មកក្រុងភ្នំពេញ ។ យើងដឹងបន្តិចបន្តួចនូវអ្វីដែលយើងជំទាស់ការកែប្រែ«កម្មវិធី» ហើយយើងទម្លាប់ខ្លួនចំពោះអ្វីដែលយើងមើលឃើញពីចម្ងាយតាមកញ្ចក់ឡានប៉ុណ្ណោះ ។

យើងឃើញឡានកាមីញ៉ុងពណ៌ខៀវ ដែលធ្វើនៅប្រទេសចិនចំនួន ហាសិបប្រាំគ្រឿង គ្មានដឹកអ្វីសោះបានបើកចេញពីយានដ្ឋានមួយ ដោយរោទិ៍ម៉ាស៊ីនឡើងរំពង ។ ក្បួនរថយន្ត បានបើកដែងយើងហួសទៅមុន និងបើកឆិតៗ ស្ត្រីៗ ដែលកំពុងបោកស្រូវលើផ្លូវជាតិលេខ៤ ។ អ្វីដែលយើងមើលឃើញ គឺការប្រមូលផលស្រូវឆ្នាំនេះទទួលបានផលយ៉ាងបរិបូរណ៍ ៈ ស្ត្រីទាំងនោះ បានប្រើប្រាស់ទ្រូងថ្មល់រាប់គីឡូម៉ែត្រ ដើម្បីបោកស្រូវ និងបញ្ចប់ជាមួយនឹងទិដ្ឋភាពផ្សេងៗ ក្នុងរដូវចម្រូតមុនថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៩ ។ គោលដៅនេះ ត្រូវបានប្រកាសផ្សាយដោយផ្ទួនៗ តាមវិទ្យុរដ្ឋាភិបាល ហើយយើងដណ្ដឹងសួរក្នុងចិត្តថា តើពួកមេដឹកនាំកម្ពុជាគិតថា សង្គ្រាមនឹងមិនផ្ទុះឡើងមុនកាលបរិច្ឆេទនេះ ឬមួយយ៉ាងណា? ។ ក្នុងថិរវេលានៃការធ្វើដំណើររបស់យើង យើងបានក្រឡេកឃើញស្រមោលស្គមៗរបស់កសិករកំពុង ដើរនៅឯនាយឆ្ងាយឆ្ពោះទៅកាន់ស្រែ ដើម្បីប្រញាប់ប្រមូលផលឲ្យទាន់ផែនការដែលពួកអ្នកកាន់អំណាចដាក់ឲ្យគាត់បំពេញ ។ នៅពេលដែលយើងជួបប្រទះក្មេងមួយក្រុមនៅតាមផ្លូវតូចមួយ ដោយកាន់ដំបងម្នាក់មួយ គេបានពន្យល់ប្រាប់យើងថា ពួកនេះជាផ្នែកមួយនៃ«កងចល័តយុវជន» ដែលជួយធ្វើការសហករណ៍មួយ ដើម្បីធ្វើឲ្យសម្រេចតាម«ផែនការ»របស់ខ្លួន ។

រៀងរាល់ថ្ងៃ យើងបានឃើញកសិករទាំងឡាយក្រោកពីដេកមុនព្រះអាទិត្យរះ ដើម្បីធ្វើដំណើរទៅកាន់ស្រែ ។ យើងពុំអាចនិយាយជាមួយពួកគេបានទេ ប៉ុន្តែ យើងកត់សម្គាល់ថា ពួកនោះកម្របានឈប់សម្រាកណាស់ ។ ជួនកាល យើងមើលពីចម្ងាយឃើញមនុស្សចាស់ម្នាក់ឈរច្រត់ដៃលើដងចបកាប់របស់គាត់ ឬក្មេងតូចៗកំពុងស្ទូចត្រីក្នុងប្រឡាយមួយ ប៉ុន្តែ យើងមិនដែលឃើញក្រុមពលករលេងកំសាន្ត និយាយលេងសើច ឬសម្រាកលំហែខ្លួននៅពេលបាយថ្ងៃត្រង់សោះឡើយ ។ ប្រការនេះ ប្រហែលជាមានខ្លះៗដែរ ប៉ុន្តែ យើងមិនដែលបានឃើញសោះ ។

វិទ្យុរបស់កម្ពុជាប្រជាធិបតេយ្យ បានផ្សាយឲ្យយើងដោយទៀតទាត់ នូវរបាយការណ៍ផ្សេងៗ ស្ដីពីជោគជ័យនៃការប្រមូលផលក្នុងព្រឹត្តិប័ត្រ«ពត៌មានក្នុងប្រទេស»របស់ខ្លួន ។ «បច្ចុប្បន្ន ការប្រមូលផលស្រូវនៅរដូវភ្លៀង បានប្រព្រឹត្តទៅនៅតាមស្រុក និងសហករណ៍ទាំងអស់ ក្រោមបរិយាកាសមហាសាមគ្គី និងសុទិដ្ឋិនិយមបដិវត្តមួយជាអចិន្ត្រៃយ៍» ។ និយាយម្យ៉ាងទៀត របបកម្ពុជាប្រជាធិបតេយ្យប្រាថ្នាថាការប្រមូលផលស្រូវត្រូវបញ្ចប់មុនការចូលលុកលុយរបស់វៀតណាម ។

ដោយបើកតម្រង់មកក្រុងភ្នំពេញវិញ យើងមើលឃើញកម្មករជាច្រើនកំពុងរៀបចំដាក់ផ្លូវដែកថ្មីមួយដែលភ្ជាប់ទីក្រុងភ្នំពេញទៅកំពង់ផែកំពង់សោម ។ រឿងនេះហាក់ដូចជាចម្លែកគួរឲ្យឆ្ងល់ ដោយហេតុថា ផ្លូវជាតិលេខ៤មួយ អាចរ៉ាប់រងខាងការដឹកជញ្ជូនស្រេចទៅហើយ ហើយហាក់ដូចជាមិនសូវប្រើញឹកញាប់ផង ។ គេអាច

នឹងត្រូវការគំនិតផ្តួចផ្តើមមួយបែបនេះពីពួកអាណានិគមបារាំងនៅដើមសតវត្សរ៍ ប៉ុន្តែ ពុំមែនពួកអ្នកបដិវត្តន៍របស់កម្ពុជាទេ ។ ម្យ៉ាងទៀត នេះគឺជាកិច្ចការចាំបាច់មួយធំធេងណាស់ ដោយតម្រូវឲ្យជីកផ្លូវរូងក្រោមភ្នំជាច្រើនដែលអាចវាងបាន ។

ការឈប់ជាលើកចុងក្រោយរបស់យើងមុនត្រឡប់មកក្រុងភ្នំពេញវិញ បានប្រព្រឹត្តទៅក្នុងសហករណ៍គំរូមួយ របស់ប្រទេសឈ្មោះ ឡាយ បូរ ក្នុងខេត្តតាកែវ ។ បណ្តាគណៈប្រតិភូជាមិត្ត របស់បរទេសជាច្រើន ធ្លាប់បានមកធ្វើទស្សនកិច្ចនៅទីនេះដែរ ហើយទស្សនកិច្ចផ្ទាល់របស់យើងបានប្រព្រឹត្តទៅតាំងពីដើមដល់ចុងបញ្ចប់ដោយគ្មានឧប្បត្តិហេតុអ្វីឡើយ ។ គ្រួសារនីមួយៗ មានលំនៅដ្ឋានសង់ខ្ពស់ពីដី បំពាក់ទៅដោយសម្ភារៈផ្សេងៗ ដូចជាកន្ទេលថ្មីៗខ្វល់ខ្វើយ និងតុទូតាំងមួយចំនួន ។ ប្រជាជនរស់នៅជាគ្រួសារដែលផ្ទុយនឹងការពោលអាងរបស់ពួកអ្នកភៀសខ្លួន ។

យើងត្រូវបានគេនាំទៅកាន់ផ្ទះខ្ទមមួយក្នុងចំណោមផ្ទះខ្ទមជាច្រើន ហើយណែនាំម្តាយម្នាក់ និងកូនប្រុសរបស់គាត់ឲ្យស្គាល់យើង ។ ដោយស្លៀកសារុងមួយ និងពាក់អាវពណ៌ខ្មៅគាត់នៅអង្គុយលើកន្ទេលមួយ ពេញរយៈពេលនៃការទៅលេងផ្ទះរបស់គាត់ ហើយសម្លឹងពួកយើងជាមួយទឹកមុខខ្វាយខ្វល់ ដោយមិនដែលរើខ្លួនសោះ ។ នេះគឺជាទឹកមុខមួយក្នុងចំណោមទឹកមុខជាច្រើន ដែលពួកអ្នកកាសែតយូហ្គោស្លាវីធ្លាប់បានកត់សម្គាល់ និងជាទឹកមុខមួយដែលលែងអាចសើចញញឹមទៀតហើយ ។ យើងទាំងអស់គ្នាបានប្រញាប់ចាកចេញពីផ្ទះខ្ទមមកវិញ ដោយខ្លាចក្រែងធ្វើឲ្យស្រ្តីនេះខ្វល់អំពល់ថែមទៀត ឬធ្វើឲ្យគាត់អាចមានគ្រោះថ្នាក់ដោយប្រការផ្សេងៗ ។

ខាងក្រោយផ្ទះបាយរួមរបស់សហករណ៍មានឡរំលាយដែកមួយ សម្រាប់ផលិតឧបករណ៍ផ្សេងៗ គេបានផ្តល់ឲ្យយើងនូវកូនពូថៅដៃ ធ្វើពីសំបកគ្រាប់កាំភ្លើងអាមេរិកាំងមួយម្នាក់ ទុកជាអនុស្សាវរីយ៍ ។ ហើយគេបាននិយាយប្រាប់យើងជាថ្មីម្តងទៀត ពីភាពឯករាជ្យម្ចាស់ការរបស់ការបដិវត្ត និងសមិទ្ធផលយ៉ាងធំបំផុតរបស់ប្រទេសកម្ពុជា ។ ប្រធានសហករណ៍បានរំឭកពីលទ្ធផលផ្សេងៗ នៃនយោបាយឯករាជ្យម្ចាស់ការនេះថា "ប្រជាជនបានក្លាយទៅជាម្ចាស់ដីធ្លី ម្ចាស់ទឹក ម្ចាស់ក្នុងការការពារប្រទេសជាតិ ។ ប្រជាជនកម្ពុជាទាំងអស់ ត្រូវបានធានាតាមរយៈរដ្ឋនូវសេចក្តីត្រូវការផ្សេងៗ របស់ពួកគេផ្នែកស្បៀងអាហារ សម្លៀកបំពាក់ គ្រឿងឧបករណ៍កសិកម្ម និងគ្រឿងប្រើប្រាស់ចាំបាច់ផ្សេងៗទៀតសម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃ ។ លុយកាក់ពុំមែនជារបស់ចាំបាច់ទេ ដោយហេតុថា រដ្ឋជួយផ្គត់ផ្គង់សព្វបែបយ៉ាងហើយ ។ ប្រទេសកម្ពុជាត្រូវតែពឹងផ្អែកលើប្រភពធនធានផ្ទាល់របស់ខ្លួន ។ នេះគឺជាអ្វីដែលយើងគោងតែប្រកាសឲ្យពួកអាមេរិកាំង និងពិភពលោកដឹងជាសាធារណៈ ។

នៅមិនឆ្ងាយពីផ្ទះបាយរួម មានវត្តជាច្រើនដែលត្រូវប្រែក្លាយទៅជាជង្រុកដាក់ស្រូវវិញ ។ ដោយជាក់ស្តែង ព្រះពុទ្ធសាសនាត្រូវបានលុបបំបាត់ចោលទាំងស្រុង ។ ប្រសិទ្ធិ បានគូសបញ្ជាក់ថា គឺជា "សាសនាប្រតិកិរិយាមួយ" ដែលប្រជាជនលែងគោរពបូជាទៀតហើយ ។ ប្រធានសហករណ៍បានយក "រូបមន្ត" នេះមក

និយាយឡើងវិញដែរ ។ ដូចពួកមេដឹកនាំដទៃទៀតដែលយើងធ្លាប់បានជួប គាត់គឺជាអតីតយុទ្ធជនខ្មែរក្រហមម្នាក់ ។ គាត់មានពាក់នាឡិកាដៃមួយ ហើយបញ្ចេញអាការៈឲ្យគេឃើញថាគាត់ជាសមាជិកមួយរូបនៃក្រុមអ្នកដែលចំណានលើសគេនៅក្នុងភូមិ ។ នៅពេលដែលខ្ញុំសុំជួបមនុស្សណាម្នាក់ដែលធ្លាប់រស់នៅទីក្រុងភ្នំពេញ គាត់បាននាំខ្ញុំឲ្យជួបមនុស្សប្រុសម្នាក់ ដែលប្រកាសថា គាត់បានទទួលការទំនុកបម្រុងយ៉ាងប្រសើរពីបដិវត្តន៍ ។

គេបានអនុញ្ញាតឲ្យយើង ពីរម៉ោងពេញ ដើម្បីដើរមើលសហករណ៍ និងពិភាក្សាពីសម័យប្រជុំរៀនសូត្រនយោបាយ -តាមការឲ្យដឹងរបស់ពួកមេដឹកនាំ ថាការប្រជុំមួយផ្នែកត្រូវបានអនុញ្ញាតសម្រាប់និយាយពីបញ្ហាការរស់នៅប្រចាំថ្ងៃ ៈ ការប្រមូលផល និងតារាងពេលវេលាសម្រាប់ការច្រូតកាត់ ។ សហករណ៍នេះ គឺជាកញ្ចក់របស់របបដែលតាមចំណុចទាំងអស់នៃមូលដ្ឋានគ្រឹះផ្នែកមនោគវិជ្ជា ដែលថ្លែងដោយ ប្រសិទ្ធិ ។ ឥឡូវនេះវាច្បាស់ណាស់ថា ភាគច្រើននៃអ្វីៗដែលយើងបានឃើញក្នុងរយៈពេលនៃការធ្វើដំណើររបស់យើង សុទ្ធតែត្រូវបានរៀបចំជាកិត្តិយសសម្រាប់យើង ។ ប៉ុន្តែ ទោះជាយ៉ាងនេះក៏ដោយ ក៏គោងតែសង្កេតពិនិត្យនូវការចាប់អារម្មណ៍របស់យើងដែរ ដើម្បីរកឃើញនៅក្នុងនោះនូវភស្តុតាងដែលប្រាប់ឲ្យដឹងរឿងស្ងាត់កំបាំងផ្សេងៗ ។ ឧទាហរណ៍ ប្រទេសកម្ពុជាបានប្រើប្រាស់ហត្ថពលករសុទ្ធតែមានវ័យក្មេងៗ ដោយមិនអាចប្រកែកបាន ។ យ៉ាងហោច ការធ្វើពលិកម្មរបស់ជំនាន់មួយ ហាក់ដូចជាចាំបាច់ខានមិនបាន ដើម្បីឈានឲ្យដល់គោលដៅដ៏ពិសិដ្ឋបំផុតនៃនយោបាយឯករាជ្យម្ចាស់ការ ។ ម្យ៉ាងទៀត គ្មានពលិកម្មណាមួយលេចឡើងឲ្យឃើញជុំកំភួន ដើម្បីធានាស្វ័យភាពរបស់ប្រទេស ដើម្បីដាក់ប្រទេសកម្ពុជាឲ្យផុតពីការធ្វើអ្វីៗតាមតែក្បាលចិត្ត និងការឃុបឃិតរបស់បណ្តារដ្ឋមានទ្រព្យធន និងក្រុមហ៊ុនចម្រុះជាតិផ្សេងៗឡើយ ។ ដូចសម្តេច ព្រះនរោត្តម សីហនុមុនពួកគេដែរ ពួកខ្មែរក្រហមបានការពារប្រជាជន ដោយដាក់ប្រជាជនឲ្យនៅឆ្ងាយពីការពិតទាំងឡាយ ដែលស្ថិតមាននៅខាងក្រៅឆ្ងាយពីព្រំដែនប្រទេស -គឺយ៉ាងហោច របបបន្តបន្ទាប់គ្នាជាច្រើនបានធ្វើដូច្នេះ ។ កម្ពុជា គឺជាប្រទេសដែលរងគ្រោះដោយសារនយោបាយរបស់មហាអំណាចនានាថែមទៀត និងរងគ្រោះពីការសាកល្បងខ្លាំងហួសហេតុរបស់បណ្តាដឹកនាំរបស់ខ្លួន ដើម្បីនាំប្រទេសឲ្យចាកផុតពីឥទ្ធិពលរបស់មហាអំណាចទាំងនោះ ។

ស្អែកឡើងថ្ងៃសុក្រ ទី២២ ខែធ្នូ ឆ្នាំ១៩៧៨ ជាថ្ងៃចុងក្រោយរបស់យើងនៅក្នុងប្រទេសនេះ ។ យើងបានធ្វើដំណើរទៅទស្សនារោងចក្រតម្បាញមួយ ដែលកសាងឡើងនៅតាមបណ្តោយផ្លូវទៅអាកាសយានដ្ឋានពោចិនតុង ដោយជំនួយរបស់ប្រទេសចិនតាំងជំនាន់សម្តេច ព្រះនរោត្តម សីហនុ ។ នៅពេលដែលយើងដើរឆ្លងកាត់គ្រឹះស្ថាននេះ យើងបានថតរូបបុគ្គលិកធ្វើការមួយក្រុម ដែលមានស្រីភាគច្រើនបំផុត ។ យើងបាននិយាយលេងជាមួយនារីបីនាក់ ជាគណៈកម្មាធិការដឹកនាំរោងចក្រ -ជាអតីតយុទ្ធនារី- បន្ទាប់មក យើងដើរទៅមើលកន្លែងស្នាក់នៅរបស់គេ ដែលស្ថិតនៅខាងផ្លូវម្ខាងទៀត ដោយគេបានអញ្ជើញយើងឲ្យទៅមើលកន្លែងដាំបាយមួយភ្លែតទៀតផង ។ នៅទីនោះគេរៀបចំម្ហូបអាហារដាំបាយនិងបបរលាយត្រកួន ។ យើងសើចញឹមៗ អំណើះ

តទៅ  យើងមានទម្លាប់នឹងរបៀបចាត់ការនេះហើយ ។

គេនៅមិនទាន់និយាយប្រាប់យើងពីការជួបសន្ទនាជាមួយ  ប៉ុល  ពត  ដដែល  ហើយយើងបានវិលត្រឡប់មកនិវេសនដ្ឋាននៅក្រុងភ្នំពេញវិញ  ដើម្បីរៀបចំប្រដាប់ប្រដារបស់យើង ។ បន្ទាប់ពីស្រស់ស្រូបអាហារថ្ងៃត្រង់រួច  ប្រុសៗបានដកខ្លួនទៅកាន់បន្ទប់របស់គេម្នាក់ៗ  ដើម្បីពិនិត្យមើលកំណត់ខ្លីៗរបស់ខ្លួនឡើងវិញ  ឬសម្រាកកាយ ។ ខ្ញុំនៅរង់ចាំឲ្យពួកអង្គរក្សការពារចេញទៅដេកថ្ងៃសិន  ដើម្បីចេញដើរលេងក្រៅ ។ ទ្វារដែកពុំមានអ្នកណាចាក់សោឡើយ ។ ខ្ញុំលបចេញមកក្រៅ  ដែលខ្ញុំសន្មតថា  ជាការដើរកំសាន្តលើកចុងក្រោយបង្អស់របស់ខ្ញុំក្នុងក្រុងភ្នំពេញ ។  ខ្ញុំបានដើរកាត់ខាងមុខអតីតមន្ទីរពេទ្យចិន  នៅតាមមហាវិថីព្រះមុនីវង្ស  ហើយភ្នែកដៀងសម្លឹងមើលទៅខាងក្នុងនោះ ។  កងទ័ពកម្ពុជាជាច្រើន  ទំនងជាត្រូវរបួសក្នុងពេលប្រយុទ្ធគ្នា  ដេកស្តូកស្តឹងនៅលើគ្រែរង់ចាំទទួលការព្យាបាល ។  ខ្ញុំបន្តដំណើរឆ្ពោះទៅមាត់ទន្លេ  នៅពេលដែលរថយន្តម៉ែស៊ីដេសមួយគ្រឿង  បានបើកមកឈប់ក្បែរក្នុងសំឡេងកង់រថយន្តស្អៀតនឹងថ្នល់កៅស៊ូ ។

សួន  អ្នកបម្រើដ៏រាក់ទាក់របស់យើង  បានចុះពីរថយន្តប្រកបដោយកំហឹងយ៉ាងខ្លាំង  គាត់ប្រាប់ខ្ញុំឲ្យចូលទៅក្នុងរថយន្ត  ហើយនាំខ្ញុំមកកាន់កន្លែងស្នាក់នៅវិញយ៉ាងលឿន  ព្រោះ  ប៉ុល  ពត  បានយល់ព្រមទទួលជួបពួកយើងក្នុងរវាង១ម៉ោងទៀត   ហើយ   សួន   បារម្ភថា   ខ្ញុំវង្វេងផ្លូវ ។

ដោយគ្មានឲ្យខាតពេល  ខ្ញុំងូតទឹកប្រញិបប្រញាប់  រួចស្លៀកពាក់  និងខំប្រឹងរកនឹកឡើងវិញនូវសំណួរដែលឌុដម៉ាន់  និងខ្ញុំ  បានរៀបចំរួចជាស្រេចសម្រាប់សួរ  ប៉ុល  ពត ។  យើងនឹងត្រូវគេទទួលជួបរួមគ្នា  ចំណែក  ខាដវែលបានទទួលសិទ្ធិឲ្យធ្វើការសន្ទនាមួយដាច់ឡែក   ដោយសារគាត់ជា“មិត្ត”របស់របបនេះ ។

ការកាច់ឫកកាច់រាងទាំងនេះ  មានតម្លៃស្មើនឹងការបានជួបសន្ទនាគ្នាមួយ  ជាមួយនឹងមេដឹកនាំដ៏អាថ៌កំបាំងម្នាក់ដែរ ។  ពួកយើងជាអ្នកកាសែតអាមេរិកាំងដំបូងបង្អស់  ដែលត្រូវធ្វើសម្ភាសន៍ជាមួយគាត់ ។  ឡានម៉ែស៊ីដេសធំមួយ   ដែលយើងមិនធ្លាប់ដែលឃើញកាលពីមុន   ត្រូវមកទទួលយកពួកយើងដើម្បីនាំទៅកាន់អតីតវិមានរដ្ឋាភិបាល   ដែលកសាងដោយពួកបារាំង ។  គឺជាគ្រឹះស្ថានមួយពណ៌ប្រផេះស្រអាប់មួយ   សង់នៅក្បែរមាត់ទន្លេខាងកើតវត្តភ្នំ ។

រថយន្ត  បានបើកឡើងតាមផ្លូវរាងកោងដូចធ្នូ  មួយហើយដាក់យើងចុះចំពីមុខទ្វារ ។  មន្ត្រីរបស់រដ្ឋាភិបាលពីរនាក់   ដែលនៅរង់ចាំការទៅដល់របស់យើង   បានអមជូនដំណើរយើងរហូតដល់បន្ទប់ទទួលភ្ញៀវដ៏ធំសម្បើមមួយ ។  វាំងននពណ៌សនៅតាមបង្អួចទាំងអស់  កម្រើកតិចៗតាមកម្លាំងខ្យល់បក់នៃកង្ហារអគ្គិសនីជាច្រើន  ដែលគេរៀបចំដាក់ជុំវិញបន្ទប់នោះ ។  ពីចម្ងាយ  ខ្ញុំមើលឃើញ  ប្រសិទ្ធិ  មុនគេ  ដែលនៅឈរខាងស្តាំដៃជាមួយអ្នកបកប្រែភាសាម្នាក់ទៀត   និងសហការីម្នាក់ ។

អៀង  សារី  នៅឈរក្នុងជម្រៅនៃបន្ទប់ ។  នៅក្បែរគាត់  គឺតួអង្គ  ប៉ុល  ពត  ផ្ទាល់តែម្តងនៅអង្គុយដូចជា

ស្ដេចមួយអង្គ ។ យើងដើរតម្រង់ទៅរកនាយករដ្ឋមន្ត្រី ជាអគ្គលេខាបក្សកុម្មុយនិស្ដកម្ពុជា និងជាមនុស្សដែលត្រូវចោទប្រកាន់ថា បានប្រព្រឹត្តអំពើឧក្រិដ្ឋយ៉ាងសាហាវយង់ឃ្នងមួយចំនួន ក្នុងប្រវត្តិសាស្ត្រសម័យបច្ចុប្បន្ន ។ គាត់ពុំមែនជាមនុស្សដែលខ្ញុំធ្លាប់ស្រមៃឃើញនោះទេ ហើយខ្ញុំត្រូវការពេលវេលាជាច្រើននាទី ដើម្បីប្រមូលការរំជួលក្នុងចិត្តរបស់ខ្ញុំឡើងវិញ និងសង្កេតមើលគាត់យ៉ាងល្អិតល្អន់ ។ តាមការពិត គឺជាមនុស្សម្នាក់ដែលមានលក្ខណៈស្រស់សង្ហា ប្រកបដោយទឹកមុខគួរឲ្យចូលចិត្តមួយមិនល្អទេ តែជាមុខដែលទាក់ទាញចិត្ត ។ គាត់មានលក្ខណៈម៉ឺងម៉ាត់ និងការសើចញញឹមមួយ ដែលស្ទើរតែញ៉ាំងឲ្យមានសមានចិត្ត ។ គេបានអនុញ្ញាតឲ្យ ឌុដម៉ាន់ និងខ្ញុំ ថតរូបជាច្រើនប៉ុស្ដិ ហើយក្រោយមក រូបថតដែលជារបស់ខ្ញុំបង្ហាញឲ្យឃើញថា ល្អលើពីការពិតទៅទៀត ។

ថ្វីបើខ្ញុំធ្លាប់ឮគេនិយាយពីអំណាចជាមេដឹកនាំម្នាក់របស់ ប៉ុល ពត ក៏ដោយ ក៏ខ្ញុំមិនជឿថាពិតដែរ ដោយខ្ញុំសំអាងលើរូបថតរបស់គាត់ ដែលគេថតយ៉ាងរហ័សចុះផ្សាយក្នុងកាសែតនានា ។ ប៉ុន្ដែ តាមពិត គាត់មានរូបសម្រស់មួយ មិនអាចប្រកែកបានឡើយ ។ របៀបនិយាយស្ដីរបស់គាត់មានលក្ខណៈល្អិតល្អន់ គ្មានភាពគ្រោតគ្រាត គ្មានលេចចេញជាបុកក្រអឺតក្រទមឡើយ ។ ចំពោះរូបរាងកាយវិញ គាត់មានមាឌធំមាំ លក្ខណៈរឹងប៉ឹងមានរបៀបធ្វើការគ្មានទាស់ឆ្គង ។ គាត់សើចញញឹម ហើយងក់ក្បាល ដោយនិយាយកំប្លែងលេងផង នៅពេលដែលយើងផឹកទឹក ផ្លែក្រូចពោធិសាត់ស្រស់ ដែលគេដាក់នៅខាងមុខយើង ។ បន្ទាប់មក អារម្មណ៍មួយហ្វូង និងមនុស្សបានប្រែប្រួល ។

យើងអង្គុយនៅខាងស្ដាំដៃឆ្ងាយពីគាត់ជាច្រើនម៉ែត្រ ពួកអ្នកបកប្រែភាសារបស់គាត់ស្ថិតនៅចំពីមុខយើងខាងឆ្វេងដៃគាត់ ។ ក្រោយខ្នងគាត់ គឺ អៀង សារី នៅឈរផ្ទឹង ។ ជាក់ស្ដែង វាមានការប្រែប្រួលឆាប់រហ័សណាស់ដែលគេយល់ព្រម គេឲ្យយើងជួបធ្វើសវនាការមួយទៅវិញ ពុំមែនជួបធ្វើសម្ភាសន៍មួយទេ ហើយថាមនុស្សដែលព្រមទទួលជួបយើងក៏និយាយរបៀបស្រមើស្រមៃហួសហេតុដែរ ។

ក្នុងរយៈពេលជាងមួយម៉ោង ប៉ុល ពត បានធ្វើសុន្ទរកថាស្ដីពីពួកវៀតណាម ។ ដោយនិយាយមិនចាំបាច់មានកំណត់ខ្ទីៗ និងប្រយ័ត្នប្រយែង គាត់បានថ្លែងថ្កោលទោសប្រឆាំង នឹងប្រទេសវៀតណាមយ៉ាងធ្ងន់ធ្ងរ និងបាននិយាយទុកជាមុនពីសង្គ្រាមមួយដែលច្បាស់ជានឹងផ្ទុះឡើងក្នុងពេលឆាប់ៗ ហើយបានបញ្ចប់ដោយ សេណារីយ៉ូ មិនសមហេតុផលមួយ ដោយរៀបចំកងទ័ពរបស់បក្សសម្ព័ន្ធកតិកាសញ្ញាវ៉ាសូវី ឲ្យប្រយុទ្ធនឹងកងទ័ពរបស់អង្គការ អូតង់ នៅលើសមរភូមិរបស់កម្ពុជា ។

គាត់មានសំឡេងទន់ភ្លន់ ដែលធ្វើឲ្យគេទុកចិត្តមួយ ៖ «យើងចង់បានតែសន្តិភាពប៉ុណ្ណោះ ដើម្បីកសាងប្រទេសយើង... ។ សាធារណៈមតិពិភពលោក បានជួយជ្រោមជ្រែងផ្ដល់នូវការយកចិត្តទុកដាក់ខ្លាំងមួយ ចំពោះការគំរាមកំហែងផ្សេងៗ ដែលកំពុងគ្របដណ្ដប់មកលើកម្ពុជាប្រជាធិបតេយ្យ ។ គេភ័យខ្លាចថា កម្ពុជាពុំអាចទប់ទល់នឹងពួកវៀតណាមបានទេ ។ រឿងនេះ អាចធ្វើឲ្យខូចខាតដល់ផលប្រយោជន៍ផ្សេងៗរបស់ប្រទេសនានា

នៅអាស៊ីអាគ្នេយ៍ និងប្រទេសទាំងអស់ក្នុងពិភពលោក ។ យើងពេញចិត្តផ្តល់ព័ត៌មានឲ្យអស់លោកដឹងពីស្ថានការណ៍នេះ...» ។

មនុស្សដែលអួតខ្លួនថា ចូលចិត្ត «រស់នៅក្នុងសភាពស្ងប់ស្ងាត់» នេះ បានបញ្ជាឲ្យគេសម្លាប់ប្រជាជនកម្ពុជាអស់រាប់រយពាន់នាក់ ដោយពិភពលោកមិនដែលបានស្គាល់រូបគាត់នៅឡើយ ។ គាត់បានដឹកនាំបក្សមួយដែលមានសមាជិកជាច្រើន បានរួមចំណែកក្នុងការសម្លាប់រង្គាលជនរួមជាតិឯង យ៉ាងហោចចំនួនមួយលាននាក់ដែរ ។ ជាមនុស្សម្នាក់ដែលអាចបំផ្លិចបំផ្លាញប្រទេសរបស់ខ្លួន ដោយទឹកចិត្តស្ងប់ស្ងាត់ជាទីបំផុត ដើម្បីអនាគតដ៏ប្រសើរថ្ងៃថ្លាមួយ ដែលមានតែបក្សប៉ុណ្ណោះ អាចប្រមាណបាន ។ ពុំមែនមានតែមួយដងទេ នៅពេលដែលគាត់បរិហារិះគន់ប្រទេសវៀតណាម និងសហភាពសូវៀតយ៉ាងខ្លាំងនោះ គាត់មិនដំឡើងសំឡេង ឬយកដៃទះលើក្ដារក់ដៃកៅអីបង្អែករបស់គាត់ឡើយ ។ យ៉ាងច្រើនណាស់ គាត់គ្រាន់តែផ្អៀងក្បាលតិចៗ ឬគ្រវីដៃរបស់គាត់ ដើម្បីសង្កត់បញ្ជាក់នូវការអះអាងរបស់គាត់ប៉ុណ្ណោះ ។

គាត់និយាយតែរឿងដដែលៗជារឿយៗ ។ ប្រទេសវៀតណាមចង់ភ្ជាប់ប្រទេសកម្ពុជាជា រណបរបស់ខ្លួនក្នុងផ្ទៃសហព័ន្ធឥណ្ឌូចិន ដែលគ្រប់គ្រងត្រួតត្រាដោយពួកវៀតណាម ។ គាត់និយាយថា ទីបំផុត ប្រទេសវៀតណាមផ្ទាល់មុខជាក្លាយទៅជារណបមួយរបស់សហភាពសូវៀតមិនខាន ។ «ប្រទេសវៀតណាម បានទៅឱនថើបចុងជើងសហភាពសូវៀត ហើយបានសម្រេចចងសម្ព័ន្ធភាពផ្នែកយោធាជាមួយគ្នាទៀត» ។ សម្រាប់ ប៉ុល ពត នេះគឺជាភស្តុតាងដែលក្រុងហាណូយចង់«ធ្វើអន្តរជាតូបនីយកម្ម» នូវអធិករណ៍រវាងប្រទេសយើងទាំងពីរ ។

គាត់បានបន្តថា ដោយធ្វើឲ្យសង្គ្រាមមានលក្ខណៈទៅជាអន្តរជាតិ ប្រទេសវៀតណាមអាចនឹងប្រើប្រាស់កងទ័ពសូវៀត កងទ័ពរបស់បណ្ដាប្រទេសបក្សសម្ព័ន្ធ វ៉ាសូវី ដើម្បីចូលលុកលុយ និងកាន់កាប់ប្រទេសកម្ពុជាផងដែរ ។

គាត់បានអះអាងទៀតថា «ប្រទេសវៀតណាមចង់ពឹងផ្អែកជាសំអាងលើលទ្ធិវាតទីនិយមអន្តរជាតិរបស់សហភាពសូវៀត និងបក្សសម្ព័ន្ធវ៉ាសូវី ។ ប៉ុន្តែ ដើម្បីលុកលុយប្រទេសកម្ពុជា ប្រទេសទាំងនោះ នឹងត្រូវបញ្ជូនកងទ័ពរបស់ពួកគេពីឆ្ងាយមក និងដឹកជញ្ជូនអ្វីៗគ្រប់បែបយ៉ាងដែលកងទ័ពនេះត្រូវការពីទីនោះមក ព្រោះនៅប្រទេសវៀតណាមគ្មានអ្វីទាំងអស់» ។

ប៉ុល ពត នៅតែទទូចដោះស្រាយសេណារីយ៉ូ ប្រកបដោយមហន្តរាយរបស់គាត់ដដែល ។ នៅពេលដែលបណ្ដាប្រទេសនៃបក្សសម្ព័ន្ធវ៉ាសូវី បញ្ជូនកងទ័ពមកឥណ្ឌូចិន ពួកគេនឹងត្រូវខ្វាយខ្វល់នឹងប្រតិកម្មប្រឆាំងនៅអឺរ៉ុបដែរ ។ «បើសិនជាពួកគេចង់ដកកងទ័ពខ្លះចេញពីសមរភូមិអាស៊ីអាគ្នេយ៍ ពួកគេនឹងត្រូវធ្វើដោយប្រុងប្រយ័ត្នបំផុត...។ ប្រទេសកម្ពុជា ប្រទេសនានានៅអាស៊ីអាគ្នេយ៍ និងពិភពលោកទាំងមូលនឹងមិនយល់ព្រមឲ្យសហភាពសូវៀត និងប្រទេសផ្សេងៗនៃបក្សសម្ព័ន្ធ វ៉ាសូវី ដណ្ដើមយកប្រទេសកម្ពុជា និងអាស៊ីអាគ្នេយ៍

ដោយកម្លាំងទ័ពឡើយ» ។

គំនិតដែលធ្លាប់បង្កើតជារូបរាងនៅមន្ទីរឃុំឃាំងទួលស្លែង និងកន្លែងធ្វើទារុណកម្មផ្សេងៗទៀត នូវទ្រឹស្តីអំពីការរួមគំនិតក្បត់មួយ បានបណ្តាលឲ្យកើតមានគំនិតរវើរវាយប្លែកខុសគេនេះដែលថា រថក្រោះរបស់ប៉ូឡូញជាច្រើនគ្រឿង និងកងទ័ពថ្មើរជើងរបស់ឆេកូ (ប្រទេសឆេកូស្លូវ៉ាគី) កំពុងតែដើរឆ្លងកាត់វាលស្រែនៅភាគខាងកើតកម្ពុជាសំដៅមកក្រុងភ្នំពេញ និងទៅហួសពីនេះទៅទៀត ។ ដ្បិតអី ប៉ុល ពត បាននិយាយទុកជាមុនហើយថា បណ្តាប្រទេសនៃបក្សសម្ព័ន្ធវ៉ាសូវី ពុំមែនចង់បានតែត្រឹមនោះទេ ៖ ពីភ្នំពេញទៅកងទ័ពទាំងនោះនឹងដើរសំដៅទៅក្រុងបាងកក ហើយចុះមកប្រទេសម៉ាឡេស៊ី និងសិង្ហបុរីទៀត ។

នេះជារបៀបបកស្រាយថ្មីមួយនូវទ្រឹស្តីនៃល្បែងដូមីណូ (រឿងដែលគេគិតក្នុងចិត្តផ្សេង ប៉ុន្តែ សម្តីនិយាយផ្សេង) ហើយប្រហែលជាការប៉ុនប៉ងបំភិតបំភ័យសាមញ្ញមួយ ។ ប៉ុល ពត បញ្ជាក់ថា «បក្សសម្ព័ន្ធវ៉ាសូវីត្រូវប្រឈមមុខនឹងអង្គការអូតង់» ហើយថាគាត់មានបំណងចងភ្ជាប់ភាពគង់វង្សរបស់ខ្លួននឹងបណ្តាប្រទេសអាស៊ាន និងបណ្តាប្រទេសនៃអង្គការអូតង់ យ៉ាងគួរឲ្យឆ្ងល់ ។ ហេតុការណ៍ដែលរឹតតែគួរឲ្យចាប់អារម្មណ៍ ជាទីបំផុតនោះគឺ ប្រទេសចិនត្រូវបានគាត់រៀបរាប់បញ្ចូលក្នុងល្បែងសង្គ្រាមនេះតែមួយម៉ាត់គត់ ។ ប៉ុល ពត និយាយតែពីអាស៊ាន និងអូតង់ ប៉ុណ្ណោះ ហាក់ដូចជាប្រទេសក្នុងអង្គការទាំង២នេះ ជាអ្នកការពារប្រទេសកម្ពុជាអីចឹង ។ ប្រទេសចិន និងគ្រឿងសព្វាវុធដែលខ្លួនផ្តល់មកឲ្យ ពុំមានពុទ្ធិយាយក្នុងគម្រោងនៃការជួបសម្ភាសន៍នេះទេ ។

អៀង សារី ដែលដើរចុះដើរឡើងពីក្រោយខ្នង ប៉ុល ពត បានទប់ដំហានជំក់ ចិញ្ចើមឡើងជ្រួញ ដៃទាំងពីរក្រពាត់ទៅក្រោយ ។

ពួកអ្នកបកប្រែភាសា បានស្នើឲ្យមានការបញ្ជាក់បំភ្លឺច្បាស់លាស់ ។

ឌុដម៉ាន់ និងរូបខ្ញុំ ផ្ទាល់បានបែរមើលមុខគ្នាទៅវិញទៅមក ដើម្បីបញ្ជាក់ឲ្យដឹងថា យើងស្តាប់ពាក្យដែលគាត់និយាយដូចគ្នាដែរទេ -កតិកាសញ្ញាវ៉ាសូវី បាទ ។

ប៉ុល ពត បានបន្តដោយបកស្រាយបំភ្លឺថា ហេតុអ្វីបានជាប្រទេសវៀតណាមពុំអាចយកឈ្នះប្រទេសកម្ពុជាតែម្នាក់ឯងបាន? គាត់បញ្ជាក់ថា ពួកវៀតណាម «ពុំអាចសម្រេចជោគជ័យវាយដណ្តើមយកកម្ពុជាដោយកម្លាំងទ័ពដាច់ខាត... ។ ពួកគេពុំអាចក្តាប់ភូមិសាស្ត្រទឹកដីរបស់កម្ពុជា ហើយពុំមានជនកម្ពុជាចូលរួមជាមួយដើម្បីជួយពួកគេ និងពុំអាចដឹកជញ្ជូនគ្រឿងសម្ភារៈបរិក្ខាររបស់ខ្លួនចូលមកក្នុងប្រទេសយើងបានឡើយ ។ យើងបានធ្វើឲ្យពួកវៀតណាមទទួលរងបរាជ័យជាបន្តបន្ទាប់... ។ ហេតុដូច្នេះ ពួកគេត្រូវតែបើកការវាយប្រហារយ៉ាងធំប្រឆាំងនឹងយើង» ។

ការចូលជួបសវនាការបានចប់សព្វគ្រប់ យើងឡើងវិលខួរក្បាលអស់ ។ ប៉ុន្មានខែក្រោយមក យើងនៅតែត្រូវធ្វើឲ្យភ័យព្រួយនៅឡើយ នៅពេលដែលលេចឮថា ប៊ីកញ្ញូ ប្រ៊ីហ្សីនស្គី ទីប្រឹក្សាសន្តិសុខជាតិរបស់ប្រធានា

ធិបតីអាមេរិកាំង មានទស្សនៈយល់ស្របតាមការវិភាគមួយផ្នែកធំរបស់ ប៉ុល ពត ដែរ ។

គេបាននាំយើងមកកាន់និវេសនដ្ឋានវិញ ហើយ ខាដវែល ត្រូវគេជូនទៅវិមានរដ្ឋាភិបាលតាមរថយន្តដដែលនេះ ។ គាត់ត្រឡប់មកវិញដោយមានចិត្តសប្បាយរីករាយយ៉ាងខ្លាំង ចំពោះការជួបសន្ទនារបស់គាត់ជាមួយមេដឹកនាំកម្ពុជា ។ អ្នកទាំងពីរនាក់នេះ បានចំណាយពេលមួយភាគធំក្នុងការជួបគ្នាដើម្បីជជែកពិភាក្សាអំពីទ្រឹស្តីផ្នែកសេដ្ឋកិច្ចបដិវត្ត ជាប្រធានបទមួយដែល ខាដវែល ចូលចិត្តនិយាយច្រើនជាងគេក្នុងកំឡុងពេលនៃដំណើរនេះ ។ ប៉ុល ពត បានអញ្ជើញគាត់ដោយខ្លួនឯងឲ្យត្រឡប់មកវិញនៅឆ្នាំបន្ទាប់ ដើម្បីវាយតម្លៃពីការរីកលូតលាស់របស់ការបដិវត្ត ។

យើងបានពិនិត្យប្រៀបធៀបកំណត់ត្រាខ្លីៗរបស់យើង បន្ទាប់មក យើងបានរៀបចំពិធីជួបជុំសប្បាយដោយ ស៊ីដឹក និងរាំលេង ។ រយៈ២សប្តាហ៍ដែលយើងស្ថិតនៅក្នុងប្រទេសនេះហាក់ដូចជាមានរយៈពេលយូរដូចពីរឆ្នាំអ៊ីចឹង ។ ពេលវេលាបានរសាត់ទៅយឺតៗ ដោយសារភាពធុញទ្រាន់ក្នុងការរង់ចាំម្ចាស់ផ្ទះមករកពួកយើងដែលមានរយៈពេលយូររាប់ម៉ោង ដោយសារការជិះឡានដាច់គ្នានចុះដី ដើម្បីដើរមើលប្រទេស ដូចដែលយើងប៉ងប្រាថ្នាពីនាយមក និងដោយសារភាពអសកម្មដែលប្រជាជនកម្ពុជាធ្វើឲ្យយើងខ្វាចរអែង ។ ប៉ុន្តែ យើងបានសម្រេចជោគជ័យក្នុងការជួបជាមួយ ប៉ុល ពត ដែរ ។

បន្ទាប់ពីបរិភោគបាយល្ងាចរួច ឌុដម៉ាន់ បានដើរទៅកាន់បន្ទប់របស់គាត់ ដើម្បីចម្លងកំណត់ខ្លីៗដោយម៉ាស៊ីនអង្គុលីលេខ ខាដវែល និងខ្ញុំ នៅអង្គុយកន្លែងតុបាយដដែល ដើម្បីពិភាក្សាគ្នាជាលើកចុងក្រោយមួយអំពីប្រទេសកម្ពុជា ។ ដោយប្រកាន់ជាប់នូវអ្វីដែលគាត់ចាត់ទុកជាទស្សនៈមានតម្លៃយូរអង្វែងនោះ ខាដវែល បានបញ្ចេញនូវការវិនិច្ឆ័យវិជ្ជមានមួយចំពោះការបដិវត្ត ។ ចំណែកខ្ញុំ ខ្ញុំជឿអំពីលក្ខណៈពិតប្រាកដនៃការឆ្លើយជាសាក្សីរបស់ពួកអ្នកភៀសខ្លួនច្រើនជាង -ហើយក្រោយមកខ្ញុំបានសរសេររឿងនេះថែមទៀត ។ យប់នោះ ខាដវែល បានសាកល្បងជាថ្មីម្តងទៀតដើម្បីធ្វើឲ្យខ្ញុំដូរយោបល់ ។ ដោយប្រៀបធៀបប្រទេសកម្ពុជាជាមួយប្រទេសអេកូស- គាត់ជាអ្នកជាតិនិយមអេកូសម្នាក់-គាត់បានប្រកាសថា ប្រទេសកម្ពុជាខ្លាចញញើតប្រទេសវៀតណាម ដូចពួកអេកូសខ្លាចពួកអង់គ្លេសដែរ ។ ខ្ញុំពុំឃើញមានភាពសមហេតុសមផលសោះក្នុងការប្រៀបធៀបរបស់គាត់ ហើយគាត់បានដកខ្លួនចេញទៅកាន់បន្ទប់របស់គាត់ ដោយបាននិយាយទុកជាមុនថា អេកូសនឹងបានទទួលឯករាជ្យពីប្រទេសអង់គ្លេស នៅមុនពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៨០ ។

ខ្ញុំបានដកខ្លួនចេញពីតុបាយហើយចូលដេកប្រមាណជាម៉ោង ដប់មួយយប់ ។ វ៉ាលិសទាំងប៉ុន្មានរបស់ខ្ញុំត្រូវបានរៀបចំរួចជាស្រេច ហើយទុកដាក់វាក្បែរមាត់ទ្វារបន្ទប់ខ្ញុំនៅជាន់ទីមួយ ។ ប៉ុន្មានម៉ោងក្រោយមកខ្ញុំភ្ញាក់ពីដំណេកទាំងមមិងមមាំង ហ្វូងឆ្កែទំនងជាផ្ទុលធុងសម្រាមជាច្រើននៅខាងក្រោមលំនៅដ្ឋានខ្ញុំ... ។ ប៉ុន្តែខ្ញុំពុំមែនស្ថិតនៅទីក្រុងវ៉ាស៊ីនតោនឯណា គឺខ្ញុំកំពុងស្ថិតនៅក្រុងភ្នំពេញទាំងកណ្តាលអធ្រាត្រ ។ សំឡេង

ដែលខ្ញុំឮអម្បាញ់មិញ ពុំមែនបណ្ដាលមកពីផុងសម្រាមដែលផ្អែផ្ញើឲ្យដួលរលំនោះទេ ព្រោះខ្ញុំមិនដែលឃើញផ្អែមួយក្បាលសោះក្នុងទីក្រុង ។ ខ្ញុំទម្លាក់ខ្លួនពីលើគ្រែមកក្រោម ហើយខ្ញុំឮសូរសំឡេងថ្មីមួយទៀតដែលធ្វើឲ្យខ្ញុំដឹតពោះប៉ង្អក គឺសំឡេងគ្រាប់កាំភ្លើងមួយជិតបង្កើយ ដែលខ្ញុំអាចផ្ទុំក្លិនរំសេវឡើងឈ្ងៀម ។ ខ្ញុំស៊ីកអាវហ្សង់ (គឺជាអាវសម្រាប់ពាក់ពីក្រៅអាវរាត្រី ពេលដែលគេចេញពីបន្ទប់ដេក) មួយហើយដើរសំដៅទៅកាន់បន្ទប់បាយ ។

ខ្ញុំឮសំឡេងថ្ងូរមួយ ខ្ញុំបើកទ្វារ ហើយដើរចូលទៅក្នុងបន្ទប់មួយទៀតចំពេលដែលយុវជនម្នាក់ លេចមុខចូលមកដល់ទីនេះតាមទ្វារខាងក្នុងដែរ ។ យើងសម្លឹងសម្លក់រកគ្នា ។ គឺជាជនជាតិខ្មែរម្នាក់ស្លៀកពាក់ខុសប្លែកពីគេពាក់មួយមួយដូចមួកកីឡាករបាសបល់ (Base-Ball) ដែរ (ល្បែងកីឡាមួយ៉ាង ដែលគេនិយមចូលចិត្តនៅសហរដ្ឋអាមេរិក) ។ ជននេះមានពាក់កាទូសៀ ពីរខ្វែងខ្វែងគ្នានៅលើដើមទ្រូង កាន់កាំភ្លើងកាវ៉ាប៊ីនស្វ័យប្រវត្តិមួយដើមពាក់នៅនឹងស្មា ហើយកាន់កាំភ្លើងខ្លីមួយដើមទៀត ដោយភ្ជង់តម្រង់មករកខ្ញុំ ។ ជននោះមើលទៅមានសភាពដូចជាភ័យរន្ធត់ជាងខ្ញុំទៅទៀត ក៏ប៉ុន្តែ ខ្ញុំមានអារម្មណ៍ថា ខ្លួនប្រាណខ្ញុំប្រុងនឹងផ្ទុះធ្លាយដោយការភ័យខ្លាចនេះដែរ ។

"ទេ! កុំបាញ់" ខ្ញុំស្រែកឡើងយ៉ាងខ្លាំង ។ ខ្ញុំដោះខ្លួនរត់ចូលទៅក្នុងបន្ទប់របស់ខ្ញុំ ទាញទ្វារបិទ ឮសូរគ្រាំងប៉ុន្តែភ្លេចចាក់សោ ។ ខ្ញុំបោលសំដៅទៅរកបន្ទប់ទឹកដែលនៅជាប់គ្នា ហើយលោតចូលក្នុងអាងងូតទឹក ដោយដេកសណ្ដូកខ្លួនផ្កាប់មុខ ។ ខ្ញុំគ្មាននឹកឃើញអ្វីទាំងអស់ ខ្ញុំធ្វើប្រតិកម្មតាមតែសភាវគតិប៉ុណ្ណោះ ។ មួយផ្នែកនៃចិត្តខ្ញុំ នឹកឃើញដំបូន្មានមួយដែលធ្លាប់ឮគេនិយាយក្នុងរយៈពេលសង្គ្រាមថា អាងងូតទឹកមួយ ជាគ្រឿងការពារដ៏ប្រសើរបំផុត ដូចគេហដ្ឋានមួយដែលអាចឲ្យយើងទប់ទល់នឹងគ្រាប់កាំភ្លើងផ្សេងៗ ដែលរត់ខុសគោលដៅរបស់វាដែរ ។

យុវបុរសនោះ ពុំបានដេញតាមខ្ញុំទេ ។

អាងងូតទឹកនេះស្ថិតនៅក្រោមបន្ទប់ជណ្ដើរ ខ្ញុំឮសូរសំឡេងជើងដើរឡើងកាំជណ្ដើរយ៉ាងប្រញាប់ ដោយមានឮសំឡេងអាវុធ និងគ្រាប់រំសេវរបស់ពួកគេទង្គិចគ្នាផង ។ អំពូលអគ្គិសនីត្រូវគេពន្លត់ទាំងអស់ ដែលធ្វើឲ្យក្នុងផ្ទះឡើងងងឹតឈឹង ។ ខ្ញុំឮសូរសំឡេងគ្រាប់កាំភ្លើងជាច្រើនគ្រាប់ទៀត ប៉ុន្តែខ្ញុំពុំអាចរាប់ចំនួនបានទេ ។ ប្រហែលជាប្រាំមួយគ្រាប់ ឬច្រើនជាងនេះក៏មិនដឹង ។ បន្ទាប់មក សំឡេងមួយដូចមនុស្សកំពុងដើរចុះជណ្ដើរ និងភាពស្ងប់ស្ងាត់ដូចវាលខ្មោច ក្នុងរយៈពេលមួយម៉ោងកន្លះ ។

តើគេបាញ់ទៅលើអ្នកណា? មានអ្នកណាម្នាក់ត្រូវរបួសទេ? ហេតុអ្វីបានជាគ្មានមនុស្សម្នាក់ចុះមកក្រោយសោះ? តើពួកអ្នកការពារយើងនៅឯណា? ។ ក្នុងប្រទេសនេះ ពុំមានទូរស័ព្ទសម្រាប់និយាយទាក់ទងគ្នាទេ គ្មានទាំងលេខសម្រាប់ហៅរកអ្នកសង្គ្រោះទៀតផង ។ ការវ៉ាយវ៉ាប់ទាំងប៉ុន្មានរបស់ពួកអ្នកភៀសខ្លួន បានលេចឡើងក្នុងសតិអារម្មណ៍ខ្ញុំសាជាថ្មី ។ ខ្ញុំសាកល្បងងើបឈរឡើងវិញ ៖ នៅខាងលើប្រហែលជាមានអ្នកណាម្នាក់ត្រូវការជំនួយរបស់ខ្ញុំ ។ ខ្ញុំពុំអាចងើបឈរបានឡើយ ។ ប៉ុន្តែខ្ញុំសម្រេចចិត្តចេញពីអាងងូតទឹកឲ្យទាល់តែបានដោយប្រឹងតោងជញ្ជាំងក្បែរមាត់ទ្វារ ។ ខ្ញុំមើលឃើញពន្លឺព្រះចន្ទតាមបង្អួច ។ តើជារដ្ឋប្រហារមួយឬ? តើពួក

អ្នកការពារយើងនៅឯណា? តើពួកគេត្រឡប់មកសម្លាប់ខ្ញុំវិញទេ? ។

ខ្ញុំឈប់គិតពីប្រទេសកម្ពុជាទៀត ដោយខ្លាចក្រែងក្លាយទៅជាមនុស្សឡប់សតិ ។ ក្នុងរយៈពេលប្រមាណជា ហុកសិបនាទី ខ្ញុំបានដោះខ្លួនដោយការត្រិះរិះ ហើយនឹកទៅដល់មនុស្សផ្សេងទៀត ។ ខ្ញុំមិនអាចនឹកគិតក្នុងចិត្តនូវអ្វីដែលបានកើតឡើងឡើយ ។

ខ្ញុំឮសូរសំឡេងទ្រហឹងមួយយ៉ាងខ្លាំង បន្ដដោយសំឡេងលាន់ប្រើបៗមួយ ។ សំឡេងកែវបែកមួយ ជំហានដើរឡើងជញ្ជាំងលាន់ខ្ទរក្នុងបន្ទប់ដែលយើងស្នាក់អាស្រ័យនៅខាងមុខ ដោយធ្វើឲ្យឮសូរសំឡេងគ្គងគ្គាំងក្នុងបន្ទប់ខ្ញុំ ។ ស្នូរជំហានដើរមកជិតទ្វារបន្ទប់ងូតទឹក ខ្ញុំឃើញដៃក្រង៉ុករបស់សោទ្វារធ្លាក់ចុះ គឺមិត្ត ឡា ជាមនុស្សម្នាក់ក្នុងចំណោមមនុស្សជាច្រើនដែលខ្ញុំស្គាល់ច្បាស់ និងជាអ្នកបម្រើក្នុងផ្ទះដែលមិនចេះនិយាយភាសាបរទេសណាមួយឡើយ ។ ខ្ញុំនៅលុតជង្គង់នៅឡើយ ។ ឡា ក្រឡេកមើលខ្ញុំមួយភ្លែត ដើម្បីមើលថាតើខ្ញុំមានត្រូវរបួសឬទេ ហើយគាត់បែរក្រោយត្រឡប់ទៅវិញបាត់ ។ ខ្ញុំបានឈោងទៅចាប់ដៃគាត់ សួរគាត់ដោយនិយាយខ្មែរប៉ៃឡាំថា តើជនជាតិអាមេរិកាំង និងអង់គ្លេស គឺ ឌុដម៉ាន់ និង ខាដវែល នោះបានសុខសប្បាយជាទេ? គាត់ឆ្លើយថា "មិនអីទេ! មិនអីទេ!" ។ ខ្ញុំគោងគាត់ជាប់អង្វរសុំឲ្យគាត់នៅទីនេះសិន ។ គាត់បើកភ្លើងឡើងវិញ ដោយប្រាប់ឲ្យខ្ញុំនៅស្ងៀមកុំដើររវេតរវូត ហើយគាត់ក៏ចាកចេញទៅ ។ ខ្ញុំស្ថិតនៅតែម្នាក់ឯងជាថ្មីក្នុងសំឡេងទ្រហឹងនៃម៉ាស៊ីនត្រជាក់ដោយគ្មានដឹងពីអ្វី ដែលបានកើតឡើងបន្តិចសោះឡើយ ។

ខ្ញុំអាចត្រឡប់ទៅបន្ទប់ដេកវិញបាន ប៉ុន្តែ ខ្ញុំនៅតែអង្គុយច្រហោងក្នុងបន្ទប់ទឹកដដែល ។ តើប្រជាជនងើបបះបោរប្រឆាំងឬ? តើខ្ញុំត្រូវគេចាត់ទុកជាសត្រូវម្នាក់មែនទេ? តើពួកវៀតណាមវាយប្រហារប្រទេសកម្ពុជាឬ? តើខ្ញុំត្រូវជាប់អន្ទាក់ក្នុងប្រទេសមួយដែលត្រូវគេលុកលុយ ដូចដែលខ្ញុំធ្លាប់នឹកព្រឺខ្លាចតាំងតែពីដំបូងនោះមែនឬ? ទេ! គឺជារឿងមិនទំនងសោះ ។ បើបែរជាគេនឹកស្មានថាពួកយើងជា... ទៅវិញ? ទេ! យើងសុទ្ធតែពួកស្បែកស គេមិនអាចច្រឡំយើងជាមួយនឹងពួកអ្នកដឹកនាំខ្មែរក្រហមបានឡើយ ។ យកល្អ! ខ្ញុំត្រូវឈប់គិតជាថ្មី ។ ក្នុងកំឡុងដប់ប្រាំនាទី ខ្ញុំបានឮសំឡេងមួយដែលខ្ញុំស្គាល់យ៉ាងច្បាស់ ។ ប្រសិទ្ធិ ជាមួយនឹងបែបបទជាមន្រ្តីរបស់គាត់បានគោះទ្វារបន្ទប់របស់ខ្ញុំ ហើយហៅឈ្មោះខ្ញុំ ។ ខ្ញុំក៏ចេញទៅទាំងញ័រចំប្រប់នៅឡើយ ហើយខ្ញុំបានស៊ើបសួរពីជោគវាសនារបស់អ្នកឯទៀត ដែលរួមដំណើរមកជាមួយខ្ញុំ ។

ឌុដម៉ាន់ បានសុខសប្បាយជាទេ ។ ខាដវែល ត្រូវស្លាប់ដោយសារត្រូវគ្រាប់ ។

ក្នុងទីក្រុង គ្មានរឿងអ្វីផ្សេងទៀតកើតឡើងឡើយ លើកលែងតែឃាតកម្មលើរូប ម៉ាល់ខូម ខាដវែល ។ គ្មានការបះបោរប្រឆាំងដោយអាវុធ គ្មានរដ្ឋប្រហារ គ្មានទាំងការឈ្លានពានរបស់វៀតណាមឡើយ ។

ពួកគេបាននាំ ឌុដម៉ាន់ ចុះមកក្រោម ដើម្បីឲ្យខ្ញុំអាចឃើញរូបគាត់ បន្ទាប់មក គេបានស្នើឲ្យយើងឡើងនៅខាងលើវិញ ដើម្បីបង្ហាញឲ្យយើងឃើញរូប ខាដវែល ដែលដេកស្តូកលើឥដ្ឋការ៉ូក្នុងខោអាវពីហ្សាម៉ា

មានឈាមនៅកកលើដើមទ្រូង សក់វែងពណ៌ខ្មៅគរបស់គាត់ឡើងរាត់រាយលើផ្ទៃមុខរបស់គាត់ ភ្នែកបិទជិតឈឹង ។ នៅមាត់ទ្វារបន្ទប់របស់គាត់ មានសាកសពម្នាក់ទៀតនៅស្ដូកស្ដឹងគ្មានកម្រើក ជាយុវបុរសម្នាក់ស្លៀកពាក់ខ្មៅ ដូចមនុស្សដែលកាន់កាំភ្លើងតម្រង់ដាក់ខ្ញុំដែរ ។ តើគាត់ មកធ្វើអ្វីនៅទីនេះ? មករកស្លាប់? ដៃទាំងពីរខ្វែងគ្នានៅលើដើមទ្រូងដូច្នេះ? ។

តើ ប្រសិទ្ធិ និងពួកអ្នកការពារយើងធ្វើអ្វីខ្លះនៅក្នុងរយៈពេលនោះ? គ្មានចម្លើយ ។ ប្រសិទ្ធិ និយាយថា សូមអភ័យទោស សូមរៀបចំអីវ៉ាន់ផ្ទាល់ខ្លួនរបស់អស់លោក ហើយសូមចាកចេញពីទីនេះជាបន្ទាន់ ។ យុវនារីម្នាក់បាននៅរង់ចាំក្នុងបន្ទប់ខ្ញុំ ហើយដោយសារជំនួយរបស់នាង ខ្ញុំបានរៀបចំទុកដាក់ក្រដាសឯកសារផ្សេងៗដែលខ្ញុំពុំទាន់បានប្រមូលទុកស្រួលបួលនោះ ដាក់ក្នុងវ៉ាលិសមួយ ។ ខ្ញុំបានទុកចោលដោយចេតនានូវកូនពូថៅដៃដែលគេបានជូនខ្ញុំពីថ្ងៃមុននៅសហករណ៍មួយ ។ ខ្ញុំមិនចង់បានពូថៅ មួយរបស់កម្ពុជាប្រជាធិបតេយ្យទេ ។ គ្មានសេចក្ដីត្រូវការចាំបាច់ណាសោះ ដែលគេជំរុញឲ្យខ្ញុំចាកចេញជាបន្ទាន់នោះ ។ រថយន្តមួយគ្រឿងបានចតចាំនៅលើផ្លូវសួន ហើយគេបាននាំយើងទៅកាន់ផ្ទះមួយ ដែលនៅក្បែរនោះតាមផ្លូវដដែល ។

នៅពេលដែលយើងចុះពីរថយន្ត ឌុដម៉ាន់ និងខ្ញុំ ត្រូវបានគេអញ្ជើញឲ្យទៅបង្ហាញខ្លួនភ្លាមៗ នៅមុខប្រធានសន្តិសុខម្នាក់ដែលមានភារកិច្ចសាកសួរពួកយើងពីរឿងនេះ ។ យើងទាំងពីរបានធ្វើសេចក្ដីរាយការណ៍ម្ដងម្នាក់ ។ ឌុដម៉ាន់ បានរាយការណ៍ថា គាត់ត្រូវដាស់ឲ្យភ្ញាក់ពីដំណេកនៅម៉ោងមួយខ្វះប្រាំនាទី ដោយស្នូរសំឡេងបាញ់កាំភ្លើងជាច្រើនគ្រាប់ ។ តាមបង្អួច គាត់បានឃើញមនុស្សមួយជួរកំពុងរត់លើផ្លូវថ្នល់ -ប្រហែលប្រាំមួយនាក់ ។ ពួកនោះបានបំបែកគ្នាចូលទៅច្រកផ្លូវតូចៗដែលខណ្ឌចែកគេហដ្ឋាននានា ។ គាត់បានចេញមកឈរនៅរានហាលខាងមុខ ហើយបានឃើញមនុស្សប្រុសជាច្រើនទៀតកំពុងរត់តាមផ្លូវដែរ ។ គាត់បានទៅគោះបន្ទប់របស់ខាដវែល ដើម្បីដាស់ឲ្យគាត់ភ្ញាក់ ។ ជនជាតិអេកូសរូបនេះបានចេញមកជួបគាត់ ហើយបានផ្លាស់ប្ដូរយោបល់គ្នាពីរ-បីម៉ាត់ គាត់បានឮសំឡេងផ្ទុះផ្សេងទៀតជាច្រើន ។ ឌុដម៉ាន់ លែងនឹកឃើញពីអ្វីដែល ខាដវែល បានធ្វើមកទៀតឡើយ -គាត់មានការភ័យខ្លាចយ៉ាងខ្លាំង ។ ដោយបែរត្រឡប់ក្រោយវិលមកបន្ទប់របស់គាត់វិញ គាត់បានឃើញមនុស្សប្រុសម្នាក់ មានពាក់អាវុធស្រោចខ្លួនដើរតម្រង់មករកគាត់ ។ មនុស្សនោះបានបាញ់ផ្ទុចដីមួយគ្រាប់ ហើយ ឌុដម៉ាន់ ក៏រត់សម្រុកទៅក្នុងបន្ទប់របស់គាត់វិញ ទាញទ្វារបិទឮសូរគ្រាំង ហើយផ្អួលខ្លួនពួននៅកន្លៀតជញ្ជាំង ។ មនុស្សនោះបានបាញ់សំដៅទ្វារពីរគ្រាប់ ឌុដម៉ាន់ លូនក្រាបផ្ទាល់ដី ហើយបានឮសំឡេងកាំភ្លើងជាច្រើនគ្រាប់ផ្សេងទៀត យ៉ាងហោចណាស់ក៏គាត់ស្រមៃឃើញចំនួនគ្រាប់កាំភ្លើងទាំងនោះដែរ ។ ដល់វេនដែលខ្ញុំត្រូវរៀបរាប់ពីហេតុការណ៍ដែលខ្ញុំបានដឹងម្ដង ហើយភាគល្អិតល្អន់នៃសាច់រឿងបានលេចឡើងក្នុងអារម្មណ៍ខ្ញុំជាថ្មី ៈ សំឡេងមនុស្សជាច្រើនកំពុងរត់ជុំវិញផ្ទះ បន្ទាប់ពីមានឃាតកម្មដែលបានគ្រោងទុកជាមុន ក្នុងរយៈពេលនៃការរង់ចាំរបស់យើងអស់រយៈពេលយ៉ាងយូរនោះ ។ ខ្ញុំឮសូរពួកគេនិយាយគ្នាជាភាសាខ្មែរដោយសំឡេងតិចៗ

ប្រហែលកំពុងខ្សឹបប្រាប់ពីបទបញ្ជាផ្សេងៗ ។

បន្ទាប់ពីការសាកសួរចម្លើយរបស់យើង យើងបានចោទសួរសំណួរជាច្រើនទៅ ប្រសិទ្ធិ វិញម្តង ។ តើហេតុការណ៍មានយ៉ាងដូចម្តេចខ្លះ? តើមានអ្វីកើតឡើង? គាត់ឆ្លើយថា "អ្នកដែលវាយប្រហារយើង" ទំនងជានៅមានសេរីភាពនៅឡើយ ។ ក្រៅពីពួកអ្នកដែលត្រូវសម្លាប់រួចហើយ ពីរនាក់ទៀត បានត្រូវពួកយើងចាប់ខ្លួនបាននៅក្នុងសួនច្បារ គាត់បានបញ្ជាក់ថា មនុស្សបីនាក់ ប្រដាប់ដោយអាវុធបានឈរយាមការពារផ្ទះនេះនៅពេលដែលយើងត្រូវវាយប្រហារ ។ បន្ទាប់មក ប្រសិទ្ធិ បានទុកចោលពួកយើងឲ្យនៅតែឯងក្នុងផ្ទះមួយទៀតដោយធានាអះអាងថា យើងត្រូវបានការពារល្អស្រួលបួលហើយ ។ ឌុដម៉ាន់ និងខ្ញុំបានឆ្លងកាត់រាត្រីនោះ ដោយនិយាយគ្នារហូត ។ នៅពេលព្រឹក គេបាននាំយកអាហារពេលព្រឹកមកឲ្យយើងស្រស់ស្រូប ហើយគេអញ្ជើញយើងឡើងជិះរថយន្តម៉ែសឺដេសមួយគ្រឿង ។ អៀង សារី បានរៀបចំពិធីបុណ្យមួយសម្រាប់ ខាដវើល ដែរបន្ទាប់មក យើងត្រូវឡើងជិះយន្តហោះធ្វើដំណើរឆ្ពោះទៅក្រុងប៉េកាំងវិញ ។

ពិធីបុណ្យបានប្រព្រឹត្តទៅនៅក្នុងនិវេសនដ្ឋានចាស់របស់យើង ដែលជាកន្លែងឃាតកម្ម ។ សាកសពរបស់ ខាដវើល បានត្រូវគេដាក់ក្នុងក្តារមឈូសឈើយ៉ាងសាមញ្ញមួយ ព័ទ្ធជុំវិញដោយបាច់ផ្កាជាច្រើន ។ ពួកគេបានបើកគម្របក្តារមឈូស ដើម្បីឲ្យយើងអាចមើលមុខរបស់គាត់ដែលស្លេកស្លាំង និងស្ងប់ស្ងាត់ជាលើកចុងក្រោយ ។ យើងទាំងអស់បានឱនគោរពសពដោយស្ងៀមស្ងាត់ ហើយមានមនុស្សជាច្រើនក្នុងចំណោមពួកយើងបានយំ ។ យើងមានគ្នាតែ ៤នាក់ប៉ុណ្ណោះ គឺ អៀង សារី, ជួន ប្រសិទ្ធិ, ឌីដ ឌុដម៉ាន់ និងខ្ញុំ ។ លើសពីនេះ មានពួកអ្នកការពារ និងពួកអ្នកបម្រើជាច្រើននាក់ ។ ក្នុងសេចក្តីថ្លែងមរណទុក្ខយ៉ាងខ្លីមួយ សារី បានចោទប្រកាន់ពួកវៀតណាម ហើយបានសម្តែងមនោសញ្ចេតនាសោកស្តាយដ៏ជ្រាលជ្រៅរបស់ប្រទេសគាត់ចំពោះមរណភាពរបស់ ខាដវើល នេះ ។ ក្រោយមក គេរកឃើញថា បណ្តាសមាជិកខាងផ្នែកសន្តិសុខខ្មែរក្រហមជាអ្នកធ្វើប្រតិបត្តិការដើម្បីសម្លាប់ ខាដវើល ដោយចេតនា ។

ចម្លើយសារភាពចុងក្រោយជាច្រើន ដែលគេចម្រាញ់យកបានដោយការធ្វើទារុណកម្មលើពួកអ្នកទោសនៅមន្ទីរឃុំឃាំងទួលស្លែង ក៏មានទាក់ទងនឹងឃាតកម្មរបស់ ខាដវើល ដែរ ។ កម្មាភិបាលខ្មែរក្រហមពីរនាក់ត្រូវគេបង្ខំឲ្យទទួលសារភាពថា ពួកគេបានទទួលបញ្ជាឲ្យសម្លាប់ជនជាតិអេកូសនេះ ពុំមែន ឌុដម៉ាន់ និងខ្ញុំ ទេ ក្នុងក្របខ័ណ្ឌនៃការរួមគំនិតក្បត់មួយ សំដៅធ្វើឲ្យរបបនេះធ្លាក់ទៅក្នុងស្ថានការណ៍លំបាកមួយ នៅពេលហៀបមានសង្រ្គាមជាមួយប្រទេសវៀតណាម ។ ភស្តុតាងប្រយោលទាំងឡាយ ដែលមាននៅក្នុងចម្លើយសារភាពទាំងនេះ បានបំផុសឲ្យ មានយោបល់មួយថា ខាដវើល ត្រូវគេជ្រើសរើសធ្វើគោលដៅក្នុងការសម្លាប់នេះ ពីព្រោះគាត់ជា«មិត្ត»របស់របបខ្មែរក្រហម ហើយប្រហែលជាដើម្បីបង្កើតជាឧបសគ្គ និងធ្វើឲ្យគម្រោងការ«សេរីកម្ម» របស់ អៀង សារី ទទួលបរាជ័យ ។ អ្វីដែលជាក់ច្បាស់គ្មានសង្ស័យ គឺថាសមាជិកម្នាក់នៃក្រុមមេដឹកនាំបក្ស

មួយក្តាប់តូច បានបន្តាប់បញ្ជាឲ្យធ្វើឃាតកម្ម ខាដវើល -មនុស្សម្នាក់ដែលជាអ្នកដឹងពីរបៀបជៀសវាងពួកអ្នកយាម ដែលកំពុងការពារផ្ទះ មនុស្សម្នាក់ដែលជាអ្នកប្រាកដក្នុងចិត្តខ្លួនឯងដើម្បីតម្រូវឲ្យសម្លាប់តែ ខាដវើល ម្នាក់ប៉ុណ្ណោះ ដោយគ្រាប់កាំភ្លើងមួយគ្រាប់ ពុំមែនដោយគ្រាប់បែកដៃមួយដែលគេអាចគ្រវែងចូលទៅក្នុងផ្ទះដោយងាយស្រួលឡើយ ។ អ្នកដែលបានបញ្ជាឲ្យធ្វើឃាតកម្ម ទោះជាអ្នកណាក៏ដោយ គឺចង់ទុកឲ្យពួកអ្នកកាសែតអាមេរិកាំងនៅរស់ជីវិត ដើម្បីអាចនិយាយរ៉ាយរ៉ាប់ប្រាប់ពិភពលោកពីមរណភាពរបស់ ខាដវើល ។

យើងសម្លឹងមើលពួកកម្ពុជាលើកក្តារមឈូសដាក់ក្នុងរថយន្តមួយ បន្ទាប់មក ក្បួនរថយន្តដ៏ក្រៀមក្រំរបស់យើងបានចេញដំណើរឆ្ពោះទៅអាកាសយានដ្ឋាន ។ ប្រសិទ្ធិ បានជូនដំណើរយើងទៅក្រុងប៉េកាំងដែរ ជាមួយនឹងសព ខាដវើល ។ នៅពេលនោះ គ្មានអ្នកណាម្នាក់បានដឹងពីមរណភាពរបស់ ខាដវើល ទេ លើកលែងតែពួកយើងផ្ទាល់ និងមេដឹកនាំជាន់ខ្ពស់របស់របប ប៉ុល ពត ប៉ុណ្ណោះ ។ នៅពេលទៅដល់ក្រុងប៉េកាំង ឌុដម៉ាន់ និងខ្ញុំបានទាមទារធ្វើ ដំណើរទៅស្ថានកុងស៊ុលសហរដ្ឋអាមេរិកដោយផ្ទាល់ ដែលយើងអាចនិយាយទៅកាន់ប្រធានគណៈបេសកកម្មរបស់យើងបានគឺលោក ឡេអូណា វូដខុក ។ យើងបានសំណូមពរឲ្យពួកកម្ពុជា បញ្ជូនទូរលេខប្រាប់ដំណឹងទៅកាសែតរបស់យើងស្តីពីរឿងដែលបានកើតឡើងនេះ ប៉ុន្តែ ពួកគេបានបោះសារទូរលេខរបស់យើងទៅក្នុង កន្ត្រកដាក់ឯកសាររបស់យើងវិញ ។ វូដខុក បានប្រាប់ឲ្យពួកអ្នកការទូតអង់គ្លេសប្រចាំនៅក្រុងប៉េកាំងដឹងពីរឿងនេះ តមកទៀត ពួកអង់គ្លេសបានបញ្ជូនទូរលេខមួយទៅក្រុងឡុងដ៍ និងប្រាប់ឲ្យគ្រួសាររបស់ ខាដវើល ដឹងជាមុនផង ។ យើងទាំងអស់គ្នាបានទៅដល់រដ្ឋធានីចិននៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៧៨ ជាមួយសាកសព ខាដវើល ។ ពីរថ្ងៃក្រោយមក គឺថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៧៨ ពួកវៀតណាមបានចូលលុកលុយប្រទេសកម្ពុជា ។ ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ពួកគេបានវាយដណ្តើមកាន់កាប់ទីក្រុងភ្នំពេញបាន ។

# ជំពូកទី១២
# សង្គ្រាមក្នុងនាមនៃប្រទេសកម្ពុជា

នេះជាការលុកលុយមួយដូចធ្លាប់មានតាំងពីមុនមក ។ ពួកវៀតណាមបានបញ្ជូនកងទ័ពចំនួនដប់បួនកងពលធំ ដោយមានរថក្រោះយ៉ាងច្រើន និងបានចាត់ចែងធ្វើការទម្លាក់គ្រាប់បែកតាមផ្លូវអាកាសផង ។ ការវាយលុកនេះ ត្រូវបានដឹកនាំដោយឧត្តមសេនីយ៍វៀតណាមម្នាក់ឈ្មោះ វ៉ាន់ ទៀងយុង ជានាយអគ្គសេនាធិការកងទ័ព ដែលធ្លាប់បានផ្ដើមធ្វើការវាយលុកផ្ដាច់ព្រ័ត្រប្រឆាំងនឹងសាធារណរដ្ឋវៀតណាមខាងត្បូង នៅឆ្នាំ១៩៧៥ ។ គាត់បានអនុវត្តនូវអ្វីដែលគាត់ហៅថា យុទ្ធសាស្ត្រ “ផ្កាឈូករីក” ដែលត្រូវគេប្រើប្រាស់ជាលើកដំបូង ក្នុងការវាយលុកនៅឆ្នាំ១៩៧៥ នោះ ។

មុនការចូលលុកលុយជាទូទៅ នៅថ្ងៃបុណ្យណូអែលពួកវៀតណាមបានចាប់វាយប្រហារនៅថ្ងៃទី២១ ខែធ្នូ ក្នុងតំបន់សម្បូរទៅដោយព្រៃភ្នំនៅភាគឦសាន តម្រង់មកស្ទឹងត្រែង ដែលនៅជាប់មាត់ទន្លេមេគង្គ ។ ថ្ងៃទី២៥ ខែធ្នូ កងទ័ព មួយភាគយ៉ាងធំ បានបើកធ្វើការវាយសម្រុកចេញពីមូលដ្ឋានពីរ ដែលស្ថិតនៅខាងក្នុងភាគខាងត្បូងវៀតណាម ។ ពីតាយនិញ ពួកវៀតណាមបានសម្រុកឡើងទៅខេត្តក្រចេះ ឆ្លងមកភាគពាយ័ព្យខេត្តកំពង់ចាម និងខាងលិចក្រុងភ្នំពេញ ។ ពីកំពង់ផែសមុទ្រហាទៀង ពួកនេះបានវាយឡើងមកភាគខាងកើតរួចសំដៅទៅរកកំពង់ផែកំពង់សោមរបស់កម្ពុជា និងឡើងទៅទិសខាងជើងហួសពីខេត្តតាកែវទៅទៀត ទើបតម្រង់មកក្រុងភ្នំពេញ ។

យុទ្ធសាស្ត្ររបស់វៀតណាម ស្ថិតនៅត្រង់ពន្លាងកិច្ចការពាររបស់ខ្មែរក្រហម ដើម្បីឈានទៅវាយទីតាំងយោធាសំខាន់ៗដោយចំៗ ជាពិសេសក្រុងភ្នំពេញ ។ ពីទីតាំងយោធាសំខាន់ៗទាំងនេះ កងទ័ពរបស់វៀតណាម និងពង្រាយទ័ពចេញបន្តទៀតប្រៀបដូចជាផ្កាឈូករីកមួយ ហើយវាយខ្សែការពាររបស់បច្ចាមិត្តពីក្រោយខ្នងវិញ ។ កងទ័ពរបស់ក្រុងហាណូយ បានរុលទៅមុខក្រោមកិច្ចគាំពារតាមផ្លូវអាកាសមួយ ដែលរ៉ាប់រងដោយយន្តហោះអាមេរិកាំង ដែលគេរឹបអូសបាន និងយន្តហោះមិច-២១ ដែលផ្ដល់ដោយពួកសូវៀត ។

កងទ័ពខ្មែរក្រហម បានតស៊ូទប់ទល់យ៉ាងននះននៀលណាស់ដែរ ប៉ុន្តែ ត្រូវពួកវៀតណាម ធ្វើឲ្យស្រឡាំងកាំងបាត់ម្ចាស់ការទាំងស្រុង និងស្ទើរតែគ្មានការគាំទ្រពីប្រជាជនផង ។ យុទ្ធសាស្ត្រ“ផ្កាឈូករីក” បានបំបែកប្រជាជនកម្ពុជាឲ្យស្ថិតនៅដាច់ពីមួយទៅមួយមិនអាចទាក់ទងគ្នាបានឡើយ ហើយបើកឱកាសឲ្យពួកវៀតណាមបង្វែងដានកងវរសេនាធំទាំងមូលជាច្រើនរបស់ខ្មែរក្រហម ក្នុងដំណើររុលរបស់គេសំដៅមកក្រុងភ្នំពេញ ។

ប៉ុន្តែក្រុងហាណូយបានបដិសេធគ្មានឈប់ឈរថា ពុំបានឲ្យកងទ័ពរបស់ខ្លួនចូលប្រយុទ្ធទេ ។ វៀតណាមអះអាងថា គឺរណសិរ្សសង្គ្រោះជាតិកម្ពុជាដែលជាអ្នករ៉ាប់រងការវាយប្រយុទ្ធទាំងអស់ ហើយគេបានលើកសរ

សេរីរណសិរ្សក្នុងការវាយយកបានទីក្រុងភ្នំពេញទៀតផង ។ ពួកវៀតណាមបានទ្រទ្រង់ពាក្យភូតកុហកនេះ រហូតដល់ខែកុម្ភៈ ជាកាលបរិច្ឆេទដែលរបបថ្មីត្រូវការឲ្យមានវត្តមានកងទ័ពរបស់វៀតណាមនៅប្រទេសកម្ពុជាជាផ្លូវការ ។ បណ្ដាអតីតមិត្តភក្ដិពីមុនៗរបស់ប្រទេសវៀតណាម ដូចជារដ្ឋមន្ត្រីទីមួយប្រទេសស៊ុយអែដ គឺលោកអូឡាស្វ ប៉ាល់ (Olaf Plame) ជាដើម សុទ្ធតែត្រូវទទួលរងនូវការប្រានចោលដោយគំរោះគំរើយមួយ នៅពេលដែលពួកគេសាកល្បងជំរុញឲ្យពួកវៀតណាមទទួលស្គាល់ថា ពួកគេបានចូលលុកលុយប្រទេសកម្ពុជាមែននោះ ។

ប៉ុល ពត ត្រូវបានធ្វើឲ្យភ្ញាក់ផ្អើលផ្សើងឆ្ងល់ទាំងស្រុង ៖ ប្រទេសវៀតណាម ដែលគ្មានជំនួយពីបណ្ដាប្រទេសនៃគតិកាសញ្ញាវ៉ាសូវី បានផ្ដើមធ្វើការវាយលុកមួយលឿនស្ទេវដូចផ្លេកបន្ទោរ ហើយសម្រុកចូលដូចទឹកបាក់ទំនប់ឆ្លងកាត់ភាគខាងកើតប្រទេសកម្ពុជារួមជាមួយអតីតមេខ្មែរក្រហមធំៗ ដើម្បីឲ្យធ្វើអ្នកដឹកនាំក្នុងការវាយលុកនេះ ។

អៀង ធីរិទ្ធ ប្រពន្ធរបស់ អៀង សារី បានពិពណ៌នាពីភាពស្ងន់ស្ងោរបស់ពួកមេដឹកនាំប្រទេសថា “ពួកយើងអាចនាំយកទៅជាមួយខ្លួនតែសម្លៀកបំពាក់ខ្លះៗប៉ុណ្ណោះ ។ យើងបានទុកចោលឯកសារជាច្រើន កិច្ចការធ្វើមិនទាន់ហើយស្ថិតនៅក្រុងភ្នំពេញទាំងអស់ ពីព្រោះយើងគិតថា នឹងបានវិលត្រឡប់មកវិញក្នុងពេលឆាប់ៗ ។ ពួកយើងជឿថា នេះគ្រាន់តែជាការចេញបណ្ដោះអាសន្នប៉ុណ្ណោះ[១]” ។

ពួកវៀតណាមបានរៀបចំរដ្ឋាភិបាលអាយ៉ងមួយ ដឹកនាំដោយ ហេង សំរិន មេបញ្ជាការកងទ័ព របស់ភូមិភាគបូព៌ា ដែលបានភៀសខ្លួនទៅវៀតណាមនៅខែកញ្ញា ឆ្នាំ១៩៧៨ ដើម្បីគេចពីការកាប់សម្លាប់របស់ ប៉ុល ពត ។ ប្រទេសត្រូវបានដាក់ឈ្មោះថា សាធារណរដ្ឋប្រជាមានិតកម្ពុជា ហើយរដ្ឋាភិបាលមួយបានត្រូវបង្កើតឡើង មានសមាសភាពសុទ្ធតែអតីតខ្មែរក្រហម ដែលបានគេចខ្លួនរួចពីកណ្ដាប់ដៃពួកសន្តិសុខរបស់ ប៉ុល ពត ក្នុងកំឡុងពេលនៃការបោសសម្អាតជាច្រើន ។

ពួកវៀតណាមបានប្រើប្រាស់សំណុំឯកសារទាំងឡាយដែលទុកចោលដោយ អៀង ធីរិទ្ធ និងសមាជិកដទៃទៀតរបស់របបនេះដើម្បីរៀបចំធ្វើការកាត់ទោស ប៉ុល ពត និងបនរបស់គាត់ ។ បន្តិចម្ដងៗ ពួកគេបានផ្សព្ផ្សាយឲ្យសាធារណជនឃើញរូបថតជាច្រើន ដែលបង្ហាញឲ្យឃើញនូវសាកសពមនុស្ស ដែលត្រូវសម្លាប់នៅមន្ទីរឃុំឃាំងទួលស្លែង រណ្ដៅកប់ខ្មោចរួមរបស់សហករណ៍នានា ដែលគេបានសម្លាប់មនុស្សចោលដោយព្រាវៗស្ទើរតែទាំងអស់ ។

ពីរថ្ងៃមុនពេលដែលពួកវៀតណាមមិនទាន់វាយយកទីក្រុងភ្នំពេញបាន សម្ដេច ព្រះនរោត្តម សីហនុ ត្រូវបានដោះលែង ពីការឃុំឃាំងដែលគេដាក់ឲ្យស្ថិតនៅតែក្នុងនិវេសនដ្ឋានរបស់ព្រះអង្គ ប្រហែលជាតាមការទទូចសុំរបស់ពួកចិនក៏មិនដឹង ។ ជាបឋម សម្ដេច និងព្រះជាយា គឺអ្នកម្នាង ម៉ូនីក ព្រមទាំងអ្នកដែលនៅសេសសល់ជាព្រះរាជវង្សានុវង្ស និងមិត្តភក្ដិខ្លះរបស់ព្រះអង្គ ត្រូវបានគេនាំទៅជួប ប៉ុល ពត សិន ដែលបាននិយាយទៅកាន់

អតីតរាជាអង្គនេះថា ៖ “ដល់ពេលដែលសម្ដេច និងអ្នករាល់គ្នាជួយយើងខ្ញុំផ្នែកការទូតម្ដងទៀតហើយ ។ យើងកំពុងជួបការលំបាកខ្លាំងណាស់” ។

សម្ដេច ព្រះនរោត្តម សីហនុ បានទទួលយល់ព្រមដោយគ្មានរួញរា ហើយបានធ្វើដំណើរទៅកាន់ក្រុងប៉េកាំង ជាទីដែលព្រះអង្គបានធ្វើសន្និសីទកាសែតមួយជាឯតទគ្គៈ មានរយៈពេលប្រាំមួយម៉ោង ។ ព្រះអង្គមានព្រះបន្ទូលពីការជាប់ឃុំនៅតែក្នុងព្រះរាជដំណាក់បីឆ្នាំ ដែលក្នុងរយៈពេលនោះ ព្រះអង្គថ្មីបានតែបីម៉ោងប៉ុណ្ណោះក្នុងមួយយប់ ។ ព្រះអង្គយាងដោះជិហានវែងទៅមកៗក្នុងបន្ទប់នានានៃអគារដ៏តូច ដែលគេរៀបចំឲ្យព្រះអង្គគង់នៅក្នុងព្រះបរមរាជវាំង ព្រះអង្គរៀបចំធ្វើបាយទឹកដោយផ្ទាល់ និងស្ដាប់វិទ្យុបរទេសផ្សេងៗ ។ ក្នុងរយៈពេលពីរឆ្នាំដំបូង សម្ដេច ព្រះនរោត្តម សីហនុ និងអ្នកនៅជុំវិញរបស់ព្រះអង្គ មិនដែលឃើញមនុស្សណាម្នាក់ក្រៅពីខៀវ សំផន ឡើយ ។ ឆ្នាំចុងក្រោយ គឺឆ្នាំ១៩៧៨ សម្ដេចត្រូវគេនាំដើរកំសាន្តទៅជនបទនានាជារៀងរាល់ខែដើម្បីលើកទឹកចិត្តប្រជាជនឡើងវិញ ដោយមានការសន្និដ្ឋានទុកជាមុនអំពីការឈ្លានពានរបស់វៀតណាម ។ ម៉ូនីក ដែលអមដំណើរជាមួយព្រះអង្គដែរ បានបញ្ជាក់ថា “ព្រះអង្គមានប្រជាប្រិយភាពច្រើនជាងមុនពេលមុនមានរដ្ឋប្រហារឆ្នាំ១៩៧០ ទៅទៀត ។ ប្រជានុរាស្ត្រស្រែកអបអរសាទរ ស្ទើរៗយំ...[២]” ។

ចេញពីទីក្រុងប៉េកាំង សម្ដេច ព្រះនរោត្តម សីហនុ បានយាងទៅកាន់ក្រុងញូវយ៉ក ដែលព្រះអង្គត្រូវតំណាងឲ្យកម្ពុជាប្រជាធិបតេយ្យ ក្នុងរយៈពេលនៃការពិភាក្សាផ្នែកនយោបាយ នៅអង្គការសហប្រជាជាតិ ស្ដីពីការលុកលុយរបស់វៀតណាម ។ ប៉ុន្ដែការពិភាក្សានោះពុំមានលក្ខណៈសមស្របនឹងស្ថានការណ៍ជាក់ស្ដែងឡើយ ។ ពួកវៀតណាមបានបញ្ជាក់ថា គ្មានទាហានរបស់ខ្លួនណាម្នាក់បានចូលរួមក្នុងការវាយលុកនេះទេ ។ សម្ដេច ព្រះនរោត្តម សីហនុ សម្រេចទទួលបាននូវការបោះឆ្នោតអនុគ្រោះមួយ ចំពោះកម្ពុជាប្រជាធិបតេយ្យជាប្រទេសដែលទើបតែទទួលការផ្ដន្ទាទោសមួយរបស់គណៈកម្មាធិការអង្គការសហប្រជាជាតិ ទទួលបន្ទុកបញ្ហាសិទ្ធិមនុស្សកាលពីប៉ុន្មានខែមុនប៉ុណ្ណោះ ។ ម្យ៉ាងទៀត នេះពុំមែនជាលក្ខណៈចំអកបញ្ឈឺចិត្តមួយ ក្នុងចំណោមលក្ខណៈចំអកបញ្ឈឺចិត្តជាច្រើន និងអាកប្បកិរិយាលាក់ពុត ដែលចេញមកពីការលុកលុយ និងស្ថានភាពថ្មីនៅអាស៊ីទេ ។

នៅទីបញ្ចប់ វិធានការនិងមធ្យោបាយទាំងអស់បានស្ថិតនៅតាមទីកន្លែងរួចជាស្រេច ។ ប្រទេសវៀតណាមបានធ្វើខ្លួនឲ្យទៅជាល្បីល្បាញ ដោយពោលអះអាងថា ៖ “គ្មានអ្វីប្រសើរថ្លៃថ្លាជាងសេរីភាព និងឯករាជ្យភាព” ទេ ដែលបានកាន់កាប់នៅពេលនេះ នូវប្រទេសដែលគេប៉ងចង់បានតាំងពីរាប់ទសវត្សរ៍មកហើយ ។ ជាមួយការចុះហត្ថលេខាលើសន្ធិសញ្ញាសន្ដិភាព និងមិត្តភាពមួយ ដែលមានរយៈពេលម្ភៃប្រាំឆ្នាំ រវាងក្រុងហាណូយ និងរដ្ឋាភិបាលដែលខ្លួនលើកបន្តុបនៅប្រទេសកម្ពុជា គឺពួកវៀតណាមមានអំណាចត្រួតត្រាលើឥណ្ឌូចិនទាំងមូល ។

ពាក្យព្យាករណ៍ដែលក្នុងនោះថា ប្រទេសកម្ពុជានឹងធ្លាក់ទៅក្រោមចំណុះប្រទេសជិតខាងមួយទាំងស្រុងគឺមួយផ្នែកធំបណ្ដាលមកពី ប៉ុល ពត និងបក្សកុម្មុយនិស្តកម្ពុជា ដែលមានរូបគាត់ដឹកនាំ ។ ដើម្បីស្ថាបនាប្រទេសកម្ពុជាមួយដែលខ្លាំងពូកែ ឯករាជ្យ មិនចំណុះរបៀបរបបសេដ្ឋកិច្ចពិភពលោក និងជាប្រទេសដែលមិនអាចវិនាសពីបណ្ដាប្រទេសជិតខាងនោះ បក្សកុម្មុយនិស្តកម្ពុជាមិនត្រឹមតែកាប់សម្លាប់ប្រជាជនឯងអស់ទាំងស្រុកទាំងភូមិ និងបំផ្លាញអង្គការចាត់តាំងរបស់ខ្លួនស្ទើរតែខ្ទេចខ្ទីប៉ុណ្ណោះទេ ថែមទាំងបានអុជអាលឲ្យប្រទេសវៀតណាមលុកលុយចូលមកប្រទេសកម្ពុជាថែមទៀត ។

ដោយការសងសឹកតាមការប្រើកម្លាំង ប្រទេសចិនបានចូលលុកលុយប្រទេសវៀតណាមនៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ១៩៧៩វិញ ជាមួយនឹងកងទ័ពពីរយហាសិបពាន់នាក់ ដែលបានវាយប្រយុទ្ធក្នុងរយៈពេលពីរសប្ដាហ៍ លើសមរភូមិមួយប្រវែងប្រាំបីរយគីឡូម៉ែត្រ ។ ពួកចិនបានដកកងទ័ពរបស់ខ្លួនថយទៅវិញនៅខែមីនា ដោយបានប្រកាសថា ពួកគេបាន«ផ្ដល់មេរៀនមួយ»ឲ្យវៀតណាមរួចហើយ ដើម្បីឆ្លើយតបទៅនឹងការកាន់កាប់ប្រទេសកម្ពុជារបស់វៀតណាម ។ ក៏ប៉ុន្តែនេះជាការបង្ហាញឡើងឲ្យឃើញនូវការគាំទ្រយ៉ាងគួរឲ្យឆ្ងល់មួយ ចំពោះបណ្ដាសមមិត្តកម្ពុជារបស់ពួកគេ ។

ដោយពិត ពួកចិនបានរង់ចាំក្នុងរយៈពេលពីរខែ ក្រោយពីមានការលុកលុយប្រទេសកម្ពុជា ដើម្បីធ្វើការសងសឹកទៅលើប្រទេសវៀតណាម ។ ប្រាកដណាស់ ការចូលលុកលុយភាគខាងជើងប្រទេសវៀតណាម ដោយពួកចិនអាចឲ្យគេវិនិច្ឆ័យថា នេះជាប្រតិកម្មនយោបាយមួយ ពុំមែនជាការសាកល្បងខាងយោធាមួយ ដើម្បីជួយពួកកម្ពុជានោះទេ ។ម្យ៉ាងទៀត ការចូលលុកលុយនេះ មានអានុភាពទូទៅមួយខុសគ្នាទាំងស្រុង ដោយហេតុថា ប្រទេសចិនបានភ្ជាប់ជម្លោះដ៏យូរលង់របស់ខ្លួនជាមួយប្រទេសវៀតណាម ទៅនឹងភាពជំពាក់ចាក់ស្រេះនៃសង្គ្រាម ក្នុងនាមនៃប្រទេសកម្ពុជាដែរ ។

ក្រុងប៉េកាំង ឆ្លៀតទាញយកប្រយោជន៍ពីឱកាសនេះ ដើម្បីសង្កត់បញ្ជាក់ពីល្បែងសម្ព័ន្ធថ្មី ដែលរៀបចំឡើងថែមលើអ្វីៗដែលគួររន្ធត់នៃសង្គ្រាមឥណ្ឌូចិនលើកទីបីទៀត ។ សហរដ្ឋអាមេរិក បានយល់ព្រមដោយគ្មានរារែក នូវពាក្យពោលអាងរបស់ចិន ដែលបង្ហាញភស្តុតាងពីការសងសឹកនឹងប្រទេសវៀតណាម ទោះបីជា ប្រជាជាតិជាច្រើនភ័យខ្លាចថា ការលុកលុយរបស់ចិនអាចធ្វើឲ្យមានការតតាំងគ្នាក្នុងទំហំធំមួយ រវាងចិន និងសូវៀតក៏ដោយ ។

ការចូលលុកលុយរបស់ចិន បានធ្វើឲ្យគេដឹងឮជាសាធារណៈ នូវការរួមគ្នាសំដៅគោលបំណងតែមួយក្នុងផលប្រយោជន៍របស់ចិន-អាមេរិកាំង ហើយអះអាងថា ប្រទេសចិននឹងនៅបន្តឃ្លាំមើលបញ្ហាផ្សេងៗរបស់ឥណ្ឌូចិនតទៅទៀត ប៉ុន្តែម្ដងនេះ គឺស្ថិតក្នុងបុកលោកខាងលិចម្ដង ។ ប្រ៊ីហ្សីនស្គី បានរួមវិភាគទានជួយក្នុងរឿងនេះយ៉ាងខ្លាំង ។ គាត់បាននិយាយដោយផ្ទាល់ថា គាត់មានគំនិតបញ្ចុះបញ្ចូលប្រទេសថៃ ឲ្យរួមសហការយ៉ាង

ពេញលេញក្នុងការប្រើងប្រែងផ្សេងៗរបស់ចិន ដើម្បីរៀបចំកងទ័ពខ្មែរក្រហមឡើងវិញ ។ នៅនិទាឃរដូវឆ្នាំ ១៩៧៩ ទីប្រឹក្សាសន្តិសុខជាតិអាមេរិកាំងរូបនេះ បានឆ្លៀតឱកាសនៃដំណើរទស្សនកិច្ចរបស់រដ្ឋមន្ត្រីការបរទេសថៃ ដើម្បីធ្វើឲ្យផែនការផ្សេងៗរបស់គាត់បានលឿនទៅមុខមួយកម្រិត ។

ប្រ៊ីហ្សីនស្គី បានប្រកាសថា ៖ «ខ្ញុំបានលើកទឹកចិត្តពួកចិនឲ្យជួយគាំទ្រ ប៉ុល ពត ។ ខ្ញុំបានជំរុញពួកថៃឲ្យជួយកម្ពុជាប្រជាធិបតេយ្យ ។ បញ្ហាស្ថិតនៅត្រង់ថា តើយើងត្រូវជួយ ប្រជាជនកម្ពុជាដោយរបៀបណា? ប៉ុល ពត ជាមនុស្សអាក្រក់បំផុតម្នាក់ យើងពុំអាចគាំទ្រគាត់ទេ ប៉ុន្តែ ប្រទេសចិនអាចអប់រំគាត់បាន[៣]» ។

រឿងនេះ វាចេញមកអំពីនយោបាយមួយដែលសហរដ្ឋអាមេរិកនៅបន្តអនុវត្តក្រោមរដ្ឋាភិបាលរបស់គណបក្សសាធារណរដ្ឋនិយមដែលកាន់អំណាចបន្តមកទៀត ។ សហរដ្ឋអាមេរិក បាន«មិចភ្នែកឲ្យជាសញ្ញាខ្លះៗជាសាធារណៈ» -ដើម្បីបន្តការទាក់ទងរបស់ ប្រ៊ីហ្សីនស្គី ឡើងវិញ- ដោយជំរុញឲ្យប្រទេសចិន និងថៃ ផ្តល់ជំនួយដោយផ្ទាល់មួយទៅឲ្យពួកខ្មែរក្រហម ដើម្បីប្រយុទ្ធនឹងការកាន់កាប់វៀតណាម ។

ហើយការអត់ឃ្លានបានកើតមានបន្តពីសង្គ្រាមឥណ្ឌូចិនលើកទីបីនេះ ។ នៅពេលដែលនៅក្នុងរដ្ឋធានីជាច្រើននៃពិភពលោកទាំងមូល អ្នកនយោបាយនានា បានខំប្រឹងការពារល្បែងធ្វើសម្ព័ន្ធភាពដ៏ចម្លែក ដែលកំពុងមានរូបរាងនេះ ប្រជាជននៅប្រទេសកម្ពុជាត្រូវរស់នៅឆ្លងកាត់ទុក្ខវេទនាថ្មីៗជាច្រើន ៖ ជំងឺឆ្លង និងការអត់ឃ្លាន ។ ដំបូង ការចូលលុកលុយរបស់វៀតណាម ត្រូវបានទទួលស្វាគមន៍ទុកដូចជាការរំដោះមួយពីពួកខ្មែរក្រហម ។ ប្រជាជនកម្ពុជាយ៉ាងច្រើន បានរុលចូលទៅក្នុងជង្រុកស្រូវទាំងឡាយដែលបោះបង់ចោលដោយកងទ័ពរបស់ ប៉ុល ពត ហើយជួបជុំគ្នាផឹកស៊ីយ៉ាងសប្បាយ ។ កងទ័ពវៀតណាមក៏យកអង្ករពីកន្លែងស្តុកផ្សេងៗ ដើម្បីចិញ្ចឹមទ័ពខ្លួន ។ ការវាយប្រយុទ្ធបានបន្តក្នុងរយៈពេលជាច្រើនខែ មុនពេលដែលក្រុងហាណូយអាចអះអាងថា បានធ្វើប្រទេសមាន«សន្តិភាព» ហើយសន្តិភាពនេះ មានត្រឹមតែរយៈពេលខ្លីប៉ុណ្ណោះ ។

ប្រទេសចិន ប្រទេសថៃ និងអង្គការមនុស្សធម៌ផ្សេងៗបានជួយជ្រោមជ្រែងខ្មែរក្រហមឲ្យបានរឹងជំហរឡើងវិញដោយមិនចំពោះ ។ ការប្រយុទ្ធទាំងឡាយបានចាប់ផ្តើមឡើងវិញក្រោមទម្រង់ថ្មីមួយ ។ ពួកខ្មាំង ពួកអ្នកតស៊ូ ដែលតាំងនៅតាមព្រំដែនរវាងប្រទេសកម្ពុជា និងប្រទេសថៃ បានចាប់ផ្តើមវាយប្រហារពួកវៀតណាម ។ បណាអង្គការមនុស្សធម៌បស្ចិមប្រទេស និងអន្តរជាតិ ដែលប្រឹងប្រែងជួយបក្សពួកទាំងពីរ ក៏យល់ឃើញខ្លួនឯងថាជាប់កុនក្នុងការប្រយុទ្ធគ្នាទាំងនេះដែរ ។ គេត្រូវរង់ចាំដល់ខែវិច្ឆិកា ឆ្នាំ១៩៧៩ ដើម្បីនឹងឲ្យអង្គការទាំងនេះ សម្រេចកិច្ចព្រមព្រៀងមួយជាមួយរបបក្រុងភ្នំពេញនៅទីបំផុត ដែលធានាឲ្យមានការដឹកជំនួយទៅកាន់គោលដៅណាមួយក្នុងប្រទេស ។ ជំនួយនេះ មួយភាគធំបានធ្លាក់ទៅក្នុងដៃពួកអតីតខ្មែរក្រហម ដែលឥឡូវនេះបានគ្រប់គ្រងប្រទេសកម្ពុជាក្នុងនាមនៃពួកវៀតណាម ។

ប៉ុន្តែ រដ្ឋាភិបាលក្រុងភ្នំពេញ បានទាក់ទាញប្រទេសមិនមែនកុម្មុយនិស្តសំខាន់ៗមួយចំនួនធំ ដែលយល់

ឃើញថា ពួកវៀតណាមជាទ័ពដែលគួរឲ្យចូលចិត្តជាងពួកខ្មែរក្រហម ហើយដែលបានជួយឲ្យប្រទេសនេះងើបឡើងវិញ ប៉ុន្តែ តែមួយយ៉ាងខ្លីប៉ុណ្ណោះ ។ នៅតាមបណ្តោយព្រំដែន ពួកមិនមែនកុម្មុយនិស្តផ្សេងៗទៀត បានចាប់ផ្តើមការតស៊ូចំពោះការកាន់កាប់របស់វៀតណាម ក្រោមការដឹកនាំរបស់អ្នកនយោបាយវ័យចាស់ម្នាក់ឈ្មោះ សឺន សាន ។ ជាអតីតនាយករដ្ឋមន្ត្រីរបស់សម្តេច ព្រះនរោត្តម សីហនុ គាត់ធ្លាប់ជាអ្នកដឹកនាំដំបូងម្នាក់ក្នុងចំណោមអ្នកដឹកនាំដំបូងៗនៃចលនាប្រជាធិបតេយ្យ ដែលបញ្ចេញឲ្យគេស្គាល់នៅដំណាច់ទសវត្សរ៍ឆ្នាំ១៩៤០ ។ ក្នុងរយៈពេលសង្គ្រាមពីឆ្នាំ១៩៧០-១៩៧៥ គាត់បដិសេធមិនគាំទ្រខាងក្រុមណាមួយឡើយ ដោយគាត់វិនិច្ឆ័យថា លន់ នល់ ជាមនុស្សគ្មានសមត្ថភាព ពុករលួយ ជៀសមិនផុតពីបរាជ័យឡើយ និងវិនិច្ឆ័យថា ពួកខ្មែរក្រហម ជាពួកដែលមិនគួរឲ្យទុកចិត្ត កាចឃោរឃៅ គ្មានចិត្តអាណិតអាសូរ ហើយប្រាកដជាឈ្នះ ។ គាត់បានអំពាវនាវឲ្យសម្តេច ព្រះនរោត្តម សីហនុ បោះបង់ពួកខ្មែរក្រហម ដើម្បីបង្កើត«កម្លាំងទីបី»មួយ ។ ពីទីក្រុងប៉េកាំងមក ព្រះអង្គបានឆ្លើយតបថា ទ្រង់នឹងឲ្យគេព្យួរក សឺន សាន ។ បន្ទាប់ពីឆ្នាំ១៩៧៥ សឺន សាន បានបង្កើតបណ្តាញភ្នាក់ងារមួយក្រុម ដើម្បីផ្តល់ព័ត៌មានឲ្យពិភពលោកដឹងពីភាពសាហាវឃោរឃៅរបស់ពួកខ្មែរក្រហម ហើយនៅឆ្នាំ១៩៧៨ ពួកវៀតណាមបានស្នើគាត់ឲ្យចូលរួមក្នុងរណសិរ្សមួយដែលពួកគេកំពុងរៀបចំបង្កើតឡើង ប៉ុន្តែ សឺន សាន បានបដិសេធ ។

បន្ទាប់ពីការចូលលុកលុយរបស់វៀតណាម សឺន សាន បានចាកចេញពីលំនៅដ្ឋានរបស់គាត់នៅទីក្រុងប៉ារីស ដើម្បីមករៀបចំទីតាំងនៅតាមព្រំដែនថៃ ហើយក្នុងអាយុជិត ចិតសិបឆ្នាំ គាត់បានប្រមូលផ្តុំ«កម្លាំងទីបី»មួយដើម្បីប្រយុទ្ធប្រឆាំងនឹងការកាន់កាប់របស់វៀតណាម ។ គួរឲ្យស្តាយ ក្រុមរបស់គាត់គឺ រណសិរ្សរំដោះប្រជាពលរដ្ឋខ្មែរ មានការយឺតមួយឆ្នាំទៅហើយ ។ សហរដ្ឋអាមេរិក ពុំឃើញមានផលប្រយោជន៍ក្នុងការផ្តល់ជំនួយយោធាទៅឲ្យគាត់ ដែលគាត់ត្រូវការជាចាំបាច់សម្រាប់ពង្រឹងរណសិរ្សឲ្យទៅជាកម្លាំងសំខាន់មួយឡើយ ។ បើទុកជាកងទ័ពរបស់គាត់កើនចំនួនពី បីពាន់ ដល់ ដប់ប្រាំពាន់ នាក់ ក៏ដោយ ក៏កងទ័ពនេះមិនអាចយកទៅប្រៀបផ្ទឹមនឹងកងទ័ពរបស់ពួកខ្មែរក្រហម ដែលបានទទួលជំនួយយោធាដ៏សប្បុរសមួយពីប្រទេសចិនជាដរាប ។ នៅទីបំផុត សឺន សាន ក៏ងាកទៅពឹងផ្អែក លើប្រទេសចិនដែរ ប៉ុន្តែ ក្រុងប៉េកាំងបានយល់ព្រមផ្តល់ឲ្យគាត់តែអាវុធសំណល់ពីគេប៉ុណ្ណោះ ហើយនៅតែជួយពួកខ្មែរក្រហមឲ្យបានទទួលអាវុធច្រើនជាងគេជានិច្ច ក្នុងចំណោមចលនាតស៊ូទាំងអស់របស់ខ្មែរ ។ ប្រជាជនកម្ពុជានៅតែប្រឈមមុខនឹងការជ្រើសរើសគួរឲ្យព្រឺខ្លាចរវាងសត្រូវខ្លា និងសត្រូវក្រពើតទៅទៀតមិនចេះចប់ ។

នៅឆ្នាំ១៩៨០ នៅទីក្រុងភ្នំពេញពួកវៀតណាមបានរៀបចំបង្កើតរដ្ឋាភិបាលមួយ ដែលដឹកនាំដោយបក្សកុម្មុយនិស្តកម្ពុជាមួយ ដែលប្រោះឲ្យរស់ឡើងវិញ ដោយទទួលស្គាល់អំណាចត្រួតត្រារបស់ក្រុងហាណូយ លើឥណ្ឌូចិន និងការកាន់កាប់ប្រទេសដោយកងទ័ពវៀតណាម មួយរយហាសិបពាន់នាក់ ។ នៅក្រុងហាណូយ ផ្ទៀង

កូថាច់ រដ្ឋមន្ត្រីការបរទេសវៀតណាមបាននិយាយជាច្រើនលើកច្រើនសាថា ស្ថានការណ៍នៅកម្ពុជា “មិនអាចប្រែក្រឡាស់” បានឡើយ ហើយមិនអាចចរចាគ្នាបានទៀត ។ នៅភ្នំពេញ ការពោលអាងសំខាន់ជាងគេរបស់រដ្ឋាភិបាលដើម្បីបង្ហាញពីភាពត្រឹមត្រូវតាមច្បាប់របស់ខ្លួនគឺថា ពួកអ្នកឧបត្ថម្ភគាំពាររបស់ខ្លួន -ពួកវៀតណាម- បានជួយរំដោះប្រទេសចេញពីនឹមត្រួតត្រារបស់ខ្មែរក្រហម ។ ប៉ុន្តែ រដ្ឋាភិបាលនេះមានសមាសភាពភាគច្រើនជាអតីតខ្មែរក្រហម ជាពួកមនុស្សដែលធ្លាប់ដើរតាម ប៉ុល ពត និងបក្ស យ៉ាងស្មោះត្រង់បំផុត រហូតមកដល់ពេលដែលជីវិតរបស់គេត្រូវមានគ្រោះថ្នាក់ ។

រូប ប៉ុល ពត ផ្ទាល់នៅតែមានជីវិត និងបានដឹកនាំកងទ័ពគាត់ប្រឆាំងនឹងវៀតណាមទៀត ។ គាត់បានកាយទៅជាយុទ្ធជនទ័ពព្រៃម្នាក់ជាថ្មី ។ សេដ្ឋកិច្ចរបស់វៀតណាមបានស្រុតចុះ ហើយនៅចុងឆ្នាំ១៩៧៩ របបនេះបានត្រូវបង្ខំចិត្តធ្វើកែទម្រង់សេដ្ឋកិច្ចឲ្យមានលក្ខណៈសេរី ដោយបំបាត់ចោលទាំងស្រុង នូវដំណើរឆ្ពោះទៅសង្គមនិយមដែលតម្រូវឲ្យធ្វើនៅនិទាឃរដូវឆ្នាំ១៩៧៨ ដើម្បីរៀបចំធ្វើសង្គ្រាម ។ កូនចៅរបស់វៀតណាមជាច្រើនបានទៅជួបជុំគ្នានៅក្នុងជួរកងទ័ពមួយ ដែលគោកយ៉ាកជាងគេនៃពិភពលោក ប្រកបដោយអត្រាក្នុងការផ្គត់ផ្គង់អាហារមិនគ្រប់គ្រាន់ និងជំងឺគួរឲ្យភ័យព្រួយ ។

ប៉ុន្តែ ប្រទេសវៀតណាមទទួលរងទុក្ខលំបាកកាន់តែខ្លាំងកាលណា ពួកមេដឹកនាំរបស់ខ្លួនកាន់តែត្រូវញ៉ាំងឲ្យជឿថា ប្រទេសកម្ពុជាត្រូវតែស្ថិតនៅក្រោមចំណុះគេកាលនោះដែរ ទោះជាអស់ប៉ុន្មានក៏ដោយ ។ ការធ្វើពលិកម្មគឺមានធំធេងរួចមកហើយ ដើម្បីនឹងឲ្យពួកវៀតណាមគ្រោងគិតពីការដកថយត្រឡប់ទៅវិញ ។

ហើយសង្គ្រាមក្នុងនាមនៃប្រទេសកម្ពុជា បានបន្តមកទៀត ដោយគ្មានអ្នកណាម្នាក់អាចអះអាងនូវអ្វីដែលប្រទេសនេះនឹងក្លាយទៅជាយ៉ាងណាទេ នៅពេលដែលការប្រយុទ្ធនឹងត្រូវចប់ ។

# ជំពូកទី១៣
# សន្តិភាពអសារបង់

*(ចំណាយកម្លាំងធំធេង ប៉ុន្តែទទួលបានផលតិច)*

*នារដូវរំហើយដែល ហ៊ុន សែន កំពុងជួបជាមួយ អ៊ីហ្គ័រ រ៉ូហ្កាឆូវ សម្ដេច ព្រះនរោត្តម សីហនុ កំពុងតែធ្វើយុទ្ធនាការមួយនៅក្រៅប្រទេស ។ នាពិធីជប់លៀងដែលពោរពេញដោយរុយនោះ រ៉ូហ្កាឆូវ បានពន្យល់ប្រាប់ ហ៊ុន សែន ថា សម្ដេច ព្រះនរោត្តម សីហនុ គឺជាតួឯកដែលទទួលខុសត្រូវក្នុង បញ្ហាស្មុគស្មាញនៅលើឆាកអន្តរជាតិ ។ បន្ទាប់ពីបានគេចចេញពីកម្ពុជា ដោយការជូនពររបស់ខ្មែរក្រហមមក សម្ដេច ព្រះនរោត្តម សីហនុ មានជោគជ័យយ៉ាងខ្លាំង នៅក្នុងការថ្លែងសន្ទរកថាមួយថ្កោលទោសវៀតណាមហើយគាំទ្រចិន ។ ហើយទ្រង់ក៏ព្យាយាមបង្វែងដានមិនឲ្យគេគិតថា ទ្រង់ជាតួឯកក្នុងការលើកស្ទួយខ្មែរក្រហមដែរ ។ សម្ដេច ព្រះនរោត្តម សីហនុ បានថ្កោលទោស ការកាន់កាប់របស់វៀតណាមនៅកម្ពុជាថា “ជាគ្រោះថ្នាក់មួយ ដែលមិនមែនត្រឹមតែជាគ្រោះថ្នាក់របស់ប្រទេសនានានៅអាស៊ីប៉ុណ្ណោះទេ តែក៏ជាគ្រោះថ្នាក់ចំពោះពិភពលោកទាំងមូលដែរ” ។ ចូលមកដល់ការនិយាយអំពីរឿងខ្មែរក្រហម សម្ដេច ព្រះនរោត្តម សីហនុ មានបន្ទូលប្រាប់ “សហរដ្ឋអាមេរិកថា នេះគឺជាពេលវេលាដែលយើង ត្រូវទុករឿងសិទ្ធិមនុស្សដោយឡែកសិន ព្រោះថា មានរឿង ចំពោះមុខជាច្រើន ដែលត្រូវតែដោះស្រាយជាបន្ទាន់ គឺសន្តិភាព និងតុល្យភាព នៃប្រទេសមហាអំណាច” ។*

*នៅក្នុងដំណាក់កាលដំបូងនៃការលេងល្បែងនោះ លក្ខខ័ណ្ឌក៏បានត្រូវកំណត់ឡើងរួចជាស្រេច ។ សហរដ្ឋអាមេរិក និងប្រទេសទាំងឡាយនៅអាស៊ីអាគ្នេយ៍ ព្រមទាំងប្រទេសភាគច្រើននៅអឺរ៉ុប បានព្រមព្រៀងគ្នាចំពោះការទាមទារឲ្យដាក់បញ្ហាអំណាចនយោបាយ ធំជាងរឿងសិទ្ធិមនុស្សនៅកម្ពុជា ។ សំណួរគ្រប់យ៉ាងព័ទ្ធជុំវិញតែបញ្ហាថា តើធ្វើយ៉ាងណាដើម្បីបញ្ចប់ការគ្រប់គ្រងរបស់វៀតណាមនៅកម្ពុជា ។ បញ្ហាផ្សេងទៀត ត្រូវបានហាមមិនឲ្យយកមកនិយាយពិភាក្សាឡើយ ។ អ្វីដែលហាមជាពិសេសនោះគឺ ការទទួលដឹងពីអំពើប្រល័យពូជសាសន៍របស់ខ្មែរក្រហមថា តើអំពើទាំងនោះ ត្រូវបានវៀតណាមបញ្ចប់បានដោយរបៀបណា ហើយក៏មិនឲ្យនិយាយអំពីថា តើខ្មែរក្រហមគួរទទួលទោសបែបណា ចំពោះអំពើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលពួកគេបានប្រព្រឹត្តនោះដែរ ។ ទាំងនេះ បានធ្វើឲ្យមានភាពខ្វះការជឿទុកចិត្ត ជាពិសេស នៅពេលដែលនៅអង្គការសហប្រជាជាតិ ឈ្មោះរបស់ អ៊ីគ្លែរ ត្រូវបានគេលើកឡើងជារឿយៗ ដើម្បីបង្ហាញអំពីភាពពុះពារក្នុងការការពារអំពើប្រល័យពូជសាសន៍មិនឲ្យកើតមានឡើងម្ដងទៀត ។*

*ប៉ុន្តែ បញ្ហារវាងវៀតណាម និងកម្ពុជា ត្រូវបានចិនដាក់លើគេក្នុងបញ្ជីដែលជាបញ្ហារបស់ចិន ។ ចិនបានប្រើឥទ្ធិពលរបស់ខ្លួន ជាពិសេស ជាមួយសហរដ្ឋអាមេរិក និងអាស៊ីអាគ្នេយ៍ ដើម្បីគ្រប់គ្រងមតិអន្តរជាតិជុំវិញ*

បញ្ហានោះ ។ ការជជែកវែកញែកអំពីបញ្ហាកម្ពុជា នៅឆ្នាំ១៩៧៩ នៅអង្គការសហប្រជាជាតិ គឺជាការចារទុកជាលើកដំបូង ដែលចិនដាក់ដំណោះស្រាយនៅចំពោះមុខគណកម្មាធិការសន្តិសុខ នៃអង្គការសហប្រជាជាតិ ។ ចិនបានស្នើសុំឲ្យថ្កោលទោសចំពោះវៀតណាម ហើយឲ្យកាត់ផ្ដាច់ជំនួយពីវៀតណាម និងបន្តទទួលស្គាល់ខ្មែរក្រហមជាតំណាងស្របច្បាប់នៃកម្ពុជាប្រចាំនៅអង្គការសហប្រជាជាតិ ។ នៅក្នុងការប្រកែកចុងក្រោយចំពោះចិនជាមួយសូវៀតចំពោះរឿងនោះ នៅអង្គការសហប្រជាជាតិ សហរដ្ឋអាមេរិក ជាអ្នកគាំទ្រធំជាងគេរបស់ចិន ។ ចិនបានឈ្នះនូវអ្វីគ្រប់យ៉ាងដែលគេបានស្នើសុំនោះ ។ ខ្មែរក្រហមនៅតែអាចរក្សាកៅអីរបស់គេនៅអង្គការសហប្រជាជាតិដដែល ។ នៅរដូវស្លឹកឈើជ្រុះនាឆ្នាំនោះ មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័តឲ្យខ្មែរក្រហម រក្សាកៅអីនៅអង្គការសហប្រជាជាតិដដែល ដោយមាន ៧១ប្រទេសបោះឆ្នោតគាំទ្រ ៣៥ប្រទេសជំទាស់ និង៤៣ប្រទេសអនុបវាទ ។ ការសម្របតាមផ្លូវច្បាប់ ដោយរក្សាទុកអាសនៈកម្ពុជានៅអង្គការសហប្រជាជាតិឲ្យនៅទំនេរ គឺពុំមាននរណាលើកយកមកពិភាក្សា ដើម្បីបោះឆ្នោតសម្រេចឡើយ ។

ភ្លាមនោះ ការរិះគន់ក៏កើតមានឡើង ។ ស្ថាប័នច្បាប់នាំមុខមួយរបស់អឺរ៉ុប បានសរសេរថា «ដោយផ្ដល់កៅអីឲ្យរដ្ឋាភិបាលដែលគេបានផ្ដួលរំលំ មហាសន្និបាតសហប្រជាជាតិបានធ្វើការសម្រេចចិត្តមួយ ដែលផ្ទុយអំពីករណីនៃការប្រើទ័ពឈ្លានពាន ដើម្បីលើកតាំងរដ្ឋាភិបាល» ។

ប៉ុន្មានខែក្រោយមក ប្រវត្តិសាស្ត្របានបញ្ជាក់ឲ្យឃើញអំពីចំណុចនោះមែន ។ នៅថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៩ រដ្ឋាភិបាល អ៊ីឌីអាមីន នៃប្រទេសអ៊ូហ្គង់ដា ដែលត្រូវបានគេស្អប់ខ្ពើម បានត្រូវកងទ័ពនៃប្រទេសតង់ហ្សានី ដែលជាប្រទេសជិតខាងផ្ដួលរំលំ ។ អង្គការសហប្រជាជាតិ ក៏បានទទួលយកដោយស្វ័យប្រវត្តិ នូវរដ្ឋាភិបាលដែលបានលើកតាំងដោយប្រទេសតង់ហ្សានី ដោយមិនបានទាំងគិតថា តើគួរទទួលស្គាល់ រដ្ឋាភិបាល អ៊ីឌីអាមីន ដែលដាក់ឲ្យនៅក្រៅប្រទេសនោះផង ។ មិនដូចជាប្រទេសកម្ពុជា និងវៀតណាម ដែលជាប្រទេសរក្សាតំណែងជាទីលានប្រយុទ្ធដ៏សំខាន់ នៃសង្គ្រាមត្រជាក់នៅអាស៊ី ប្រទេសអ៊ូហ្គង់ដា និងប្រទេសតង់ហ្សានី ជាប្រទេសដែលស្ថិតនៅក្រៅសារសំខាន់នៃការចាត់តាំងអំណាចនយោបាយ, ហេតុដូច្នេះហើយ ទើបសុភនិច្ឆ័យ និងក្រឹត្យក្រមច្បាប់ ត្រូវបានគេយកមកអនុវត្ត ។

សម្ដេច ព្រះនរោត្ដម សីហនុ បានបញ្ចប់ជ័យជម្នះរបស់ទ្រង់នៅអង្គការសហប្រជាជាតិ ដោយការរសាប់រសល់របស់ទ្រង់លើការផ្លាស់ប្ដូរ បត់បែន ទៅជារឿងមិនល្អដែលទ្រង់គិតថា បម្រុងនឹងកើតឡើងនោះ ។ នៅក្នុងពិធីជប់លៀងដ៏ធំ និងខ្ជះខ្ជាយមួយ សម្ដេច ព្រះនរោត្ដម សីហនុ បានរអ៊ូថា «ជីវិតរបស់ខ្ញុំជារឿងចំអកឡកឡឺយមួយ ហើយដែលមិនគួរជាទីពេញចិត្តសោះ» ទ្រង់ហាក់បីដូចជាចង់បង្ហាញឲ្យឃើញថា ទ្រង់ជឿថាទ្រង់នឹងរួចផុតពីខ្មែរក្រហម ហើយក៏បន្តមានបន្ទូលទៀតថា «ពួកគេនិយាយថា ពួកគេខ្លាំងក្លាជាងពេលណាៗទាំងអស់ ។ ពួកគេនិយាយទៀតថា ពួកគេនឹងប្រយុទ្ធដល់ទីបំផុត ហើយនឹងប្រាកដជាឈ្នះពុំខាន ។ ប៉ុន្តែពួកគេ គឺរស់នៅក្នុងការ

ស្រមើស្រមៃទាំងស្រុង ប្រៀបដូចជា ហ្គូអ៊ីបែល នៅក្នុងខែចុងក្រោយនៃរដ្ឋាភិបាលអ៊ីត្លែរអ៊ីចឹង» មហេសីរបស់ទ្រង់ អ្នកម្នាង ម៉ូនីក គ្រាន់តែ មានបន្ទូលថា ទ្រង់នឹងមិនត្រឡប់ចូលកម្ពុជាវិញឡើយ ។

នៅព្រឹកថ្ងៃបន្ទាប់ពីទ្រង់ភ្ញាក់ពីបន្ទំ ទ្រង់បានស្ងន់ស្ងោចំពោះច្រវាក់ការទូតអន្តរជាតិ ដែលបានដាក់នៅជុំវិញព្រះកាយរបស់ទ្រង់ ។ ពេលនោះ ទ្រង់ក៏បានបញ្ជូនសារមួយទាំងឆ្កួងឲ្យទៅអគ្គរដ្ឋទូតអាមេរិក ប្រចាំនៅអង្គការសហប្រជាជាតិអេនឌ្រូ យ៉ង់ សំណើសុំនូវសិទ្ធិជ្រកកោនខាងផ្នែកនយោបាយ ។ ភ្លាមនោះ លោកអគ្គរដ្ឋទូត យ៉ង់ ក៏បានពិភាក្សាពីរឿងនេះជាមួយថ្នាក់លើរបស់គាត់ នៅក្រសួងការបរទេសឯទីក្រុងវ៉ាស៊ីនតោន ។ ក្រោមបញ្ជាពីថ្នាក់លើរបស់គាត់ គាត់ក៏បានដាក់ឲ្យទ្រង់ចូលសម្រាកពេទ្យ នៅមន្ទីរពេទ្យ ឡេណុកហៀល ។ នៅទីនោះ លោក យ៉ង់ បានទូលទ្រង់ថា ការជ្រើសរើសយកការនិរទេសខ្លួន គឺជាការសម្រេចចិត្តខុសមួយ ។ រីឆាដ ហូលប្រុក ដែលជាជំនួយការរបស់លោករដ្ឋលេខាធិការប្រចាំអាស៊ីប៉ូពាំ៌បាននិយាយថា «ពួកយើងបានទូលទ្រង់ថា ការជ្រើសរើសយកការនិរទេសខ្លួនរបស់ទ្រង់ ទៅសហរដ្ឋអាមេរិក នឹងធ្វើឲ្យទ្រង់បាត់បង់នូវភាពជាអ្នកដឹកនាំឯករាជ្យរបស់ទ្រង់ នៅពេលនេះ សហរដ្ឋអាមេរិកនឹងមិនដាក់សេះរបស់ខ្លួនចូលទៅក្នុងការប្រណាំងឡើយ ។ វ៉ាស៊ីនតោន នឹងធ្វើការប្រឆាំងនឹងវៀតណាម ប៉ុន្តែ នឹងមានឈរពីក្រោយមេដឹកនាំរបស់កម្ពុជាណាមួយឡើយ» ។

សម្តេច ព្រះនរោត្តម សីហនុ ក៏បានយល់អំពីសម្តីនោះ ។ ចិននៅគ្រប់គ្រងទ្រង់នៅឡើយ ហើយក៏មិនចង់ឲ្យទ្រង់យាងទៅនៅសហរដ្ឋអាមេរិកដែរ ។ សូម្បីតែប្រទេសបារាំង ដែលជាទីស្រឡាញ់របស់ទ្រង់នោះ ក៏បានធ្វើឲ្យទ្រង់អស់សង្ឃឹមដូចគ្នា ។ បារាំង បានឲ្យទ្រង់បោះបង់ចោលនៅរាល់សកម្មភាពនយោបាយគ្រប់យ៉ាង ប្រសិនបើទ្រង់ចង់បានសិទ្ធិស្នាក់នៅឯប្រទេសបារាំង ។ ទ្រង់ក៏បានចាកចេញពីមន្ទីរពេទ្យ ហើយរើទៅដំណាក់របស់ទ្រង់នៅឯក្រុងប៉េកាំង ។ នៅក្នុងកំណត់ហេតុរបស់ទ្រង់ដែលបានធ្វើឡើងនៅឆ្នាំ១៩៨១ ទ្រង់មិនបានរៀបរាប់ពីរឿងនេះទេ តែមានបន្ទូលថា ទ្រង់រើទៅប៉េកាំងព្រោះបញ្ហាថវិកា ។ ទ្រង់បានមានបន្ទូលថា «នៅខែមករា ឆ្នាំ១៩៧៩ ខ្ញុំបានធ្លាក់ខ្លួនក្រ ។ ខ្ញុំមិនធ្លាប់មានសម្បត្តិផ្ទាល់ខ្លួនអ្វីនោះទេ ។ ខ្ញុំធ្លាប់គិតថាចង់ចូលនិវត្តន៍នៅប្រទេសបារាំងជាមួយមហេសីរបស់ខ្ញុំឯ មូហ្សាំង នៅអាល់ម៉ារូទីម ប៉ុន្តែ...» ។

ក្នុងព្រះជន្ម ៥៧ព្រះវស្សា សម្តេច ព្រះនរោត្តម សីហនុ អាចនឹងត្រូវបានគេលើកលែងឲ្យ ប្រសិនបើទ្រង់ព្រមចូលនិវត្តន៍ ហើយទុកឲ្យក្មេងៗជំនាន់ក្រោយ បង្កើតសង្គ្រាមនៅកម្ពុជាជំនួសទ្រង់ ។ ប៉ុន្តែ បើទ្រង់សម្រេចព្រះទ័យដូច្នោះ ទ្រង់នឹងបណ្តោយឲ្យអ្នកដទៃដណ្តើមស្នាដៃជាអ្នកសង្គ្រោះជាតិរបស់ទ្រង់ ជារឿងមួយដែលទ្រង់មិនជ្រើសយកជាដាច់ខាត លទ្ធផលនៃការសម្រេចចិត្តនោះ បាននាំឲ្យមានសង្គ្រាមមួយដែលយូរជាងគេ ហើយព្រៃផ្សៃជាងគេក្នុងចំណោមសង្គ្រាមទាំងឡាយនៅកម្ពុជា ។

ចំណុចសំខាន់ៗទាំងឡាយ ត្រូវបានគេគូសវាសតាំងតែពីឆ្នាំដំបូងមកម្ល៉េះ ។ ប្រតិយាគនៃការសេចក្តីសម្រេចចិត្តរបស់អន្តរជាតិ ដើម្បីដាក់វៀតណាមឲ្យនៅក្រៅច្បាប់ ហើយគ្រប់គ្រងកម្ពុជាត្រូវបានសុសសាយ

ពេញដំណើរជីវិតរបស់ប្រទេសទាំងនោះ ។

ចំណុចសំខាន់នៃសង្គ្រាមនោះគឺ ថាតើពួកគេឈរនៅខាងណា នរណាត្រូវបានដាក់ពិន័យ ហើយនរណាត្រូវជូនរង្វាន់? ការសម្រេចចិត្តរបស់អន្តរជាតិ គឺមិនរវល់ខ្វាយខ្វល់នូវរាល់ការចោទប្រកាន់ស្ដីពីបទឧក្រិដ្ឋកម្មប្រឆាំង និងការរំលោភសិទ្ធិមនុស្សរបស់ខ្មែរក្រហមឡើយ ។ អង្គការសហប្រជាជាតិ ក៏បានបញ្ឈប់ការស៊ើបអង្កេតរបស់ពួកគេលើរឿងក្ដី នៃការរំលោភបំពានសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងររបស់ខ្មែរក្រហម ។ រឿងក្ដីដែលកំពុងមានដំណើរការនៅទីក្រុងហ្សឺណែវ ត្រូវបានគេទុកចោលដោយឡែក ដោយយកហេតុផលដ៏សាមញ្ញថា អធិបតេយ្យភាពរបស់កម្ពុជា គឺសំខាន់ជាងបញ្ហាសិទ្ធិមនុស្ស ។ ពួកគេបានបិទបាំងជិតនូវការពិតដែលថា ប៉ុល ពត និងខ្មែរក្រហម ត្រូវបានចោទពីបទឧក្រិដ្ឋកម្មដ៏ព្រៃផ្សៃបំផុតនៅសតវត្សទី២០ ។ ការវិភាគបែបទ័ព ស្ដីអំពីទំហំនៃបញ្ហារបស់សហគមន៍អន្តរជាតិ មិនត្រូវបានគេលើកឡើងមកពិភាក្សាទេ ។ មានទ័ពរបស់ខ្មែរក្រហម ត្រូវបានគេសម្រេចថា ជាការចាំបាច់ក្នុងការដេញវៀតណាមឲ្យចាកចេញ និងជំរុញឲ្យមានការចរចារសន្និសញ្ញាសន្តិភាពនៅកម្ពុជា ។ គេឲ្យហេតុផលថា ប្រសិនបើមិនឲ្យកងទ័ពខ្មែរក្រហមធ្វើសកម្មភាព ហើយយកពួកគេឲ្យឡើងតុលាការអន្តរជាតិនោះ វៀតណាមនឹងមិនព្រមចាកចេញពីទឹកដីកម្ពុជាឡើយ ។ ករណីក្រៅពីនេះ ជាពិសេស ការចង់ឲ្យមានតុលាការកាត់ទោសខ្មែរក្រហម ដើម្បីបង្កើតឲ្យមានយុត្តិធម៌ និងជំនឿទុកចិត្តខ្លួនឯងរបស់ប្រជាជនកម្ពុជាត្រូវបានគេទាត់ចោល ។ បើចង់ផ្លាស់ប្ដូរគំនិតដែលគិតថាការមានតុលាការ គឺនាំឲ្យតែមានអូសបន្លាយការប្រយុទ្ធឲ្យកាន់តែយូរនោះ ត្រូវការពេលប្រហែលជា ១៥ឆ្នាំទៀត ដើម្បីប្ដូរចេញ ។ តុលាការនៅអតីតយូហ្គោស្លាវី ទើបកើតមានឡើងនៅឆ្នាំ១៩៩៤ មួយឆ្នាំក្រោយពេលសន្ធិសញ្ញាសន្តិភាពនៅបូស្នៀ ។ ហើយត្រូវបានចុះហត្ថលេខានៅដៃតុន រដ្ឋអូហៃយូ សហរដ្ឋអាមេរិក ។

នៅទសវត្សរ៍ឆ្នាំ៨០ ក្រសួងការបរទេសអាមេរិក មិនព្រមប្រើពាក្យប្រល័យពូជសាសន៍ ដើម្បីអធិប្បាយពីរបប ប៉ុល ពត នោះទេ ។ ការសាកល្បងរបស់រដ្ឋាភិបាលប្រទេសអូស្ត្រាលី ក្នុងបំណងលើកអំពីតុលាការនៅទសវត្សរ៍ឆ្នាំ៨០ ត្រូវបានសហរដ្ឋអាមេរិក ចិន និងប្រទេសអាស៊ានទាំងឡាយបង្អាក់ ។ គេយល់ថា ការយល់ដឹងអំពីការប្រព្រឹត្តអំពើប្រល័យពូជសាសន៍របស់ខ្មែរក្រហម ដែលនាំឲ្យវៀតណាមចូលមកផ្ដួលរំលំពួកគេនោះ នឹងផ្ដល់គុណសម្បត្តិដល់ការឈ្លានពានរបស់វៀតណាម ។ ហើយនឹងនាំឲ្យមានការបង្ខំឲ្យធ្វើការចរចាមួយជាមួយហាណូយ ។ សហរដ្ឋអាមេរិក ចង់ឲ្យនិយាយតែពីគ្រោះថ្នាក់នៃការឈ្លានពានរបស់វៀតណាមប៉ុណ្ណោះ ។ អាមេរិកចង់បញ្ចុះបញ្ចូលឲ្យសហគមន៍អន្តរជាតិគិតដូចខ្លួនដែរ ។ អ្នកការទូតរបស់អាមេរិកត្រូវហាមមិនឲ្យចាប់ដៃជាមួយមន្ត្រីខ្មែរក្រហមឡើយ ។ សុន្ទរកថាភាគច្រើន បានត្រូវដាក់បញ្ចូលនូវរឿងរ៉ាវអាក្រក់ពីអតីតកាល ប៉ុន្តែ ចំណែករឿងសង្គ្រាមវិញ ពុំឃើញមានដាក់បញ្ចូលទាល់តែសោះ ។

ចំណុចដំបូងបំផុតរបស់ពួកគេ គឺនិយាយថា ការគ្រប់គ្រងរបស់វៀតណាមនៅកម្ពុជា ត្រូវតែទទួលការដាក់

ពិន័យ ។ ដោយមានការជំរុញរបស់សហរដ្ឋអាមេរិក និងចិន ការដាក់ទណ្ឌកម្មធ្ងន់ធ្ងរបំផុតរបស់អន្តរជាតិ មកលើវៀតណាមក៏កើតមាន ហើយមូលហេតុនៃការពិន័យនោះ គឺដោយសារការគ្រប់គ្រងរបស់វៀតណាម នៅប្រទេសកម្ពុជា ។ នៅរដូវក្តៅឆ្នាំ១៩៧៩ រដ្ឋាភិបាលរបស់ប្រធានាធិបតី កាធ័រ បានចាប់ផ្តើមធ្វើការបញ្ចុះបញ្ចូលដ៏មានប្រសិទ្ធភាពមួយ ឲ្យប្រទេសដទៃទៀត ក៏ដូចជាសហគមន៍ជំនួយនានា និងអង្គការជំនួយអន្តរជាតិ ដូចជាអង្គការរូបិយវត្ថុអន្តរជាតិ និងធនាគារពិភពលោកជាដើម ឲ្យផ្តាច់ជំនួយដែលផ្តល់ឲ្យវៀតណាម និងកម្ពុជា ។ ហូលប្រូក និងអនុប្រធានរបស់គាត់ ជាអ្នកដឹកនាំយុទ្ធនាការនោះ ។ ពួកគេប្រើការពោលអាងថា រាល់ជំនួយទាំងអស់ គួរបញ្ឈប់ដោយសំអាងលើការគ្រប់គ្រងរបស់វៀតណាមនៅកម្ពុជា ។ ស្ថាប័នដំបូងបង្អស់ដែលអាមេរិកធ្វើការបញ្ចុះបញ្ចូលនោះ គឺធនាគារពិភពលោក ។ ធនាគារពិភពលោកជាស្ថាប័នមួយដែលសហរដ្ឋអាមេរិកមានសំឡេង និងចំណែកច្រើននៅក្នុងនោះ ។ អ្នកតំណាងធនាគារឈ្មោះ អូគ្លី បាននិយាយថា ពួកគាត់ត្រូវបានគេបញ្ជាឲ្យប្រយ័ត្នប្រយែងបំផុត ពេលពិចារណាឲ្យវៀតណាមខ្ចីប្រាក់ ។

ទិសដៅរបស់ពួកគេ គឺចង់លុបបំបាត់កម្មវិធីមិនមែនកុម្មុយនិស្ត ដែលមានទឹកប្រាក់ចំនួន ១,៧កោដិដុល្លារសហរដ្ឋអាមេរិក មានតម្លៃប្រហែល១ភាគ៣នៃតម្លៃជំនួយអន្តរជាតិទាំងអស់ ដែលជួយប្រទេសវៀតណាម ។ ហូលប្រូក បាននិយាយថា គ្មានផ្លូវណាដែលអាចជំរុញឲ្យសហគមន៍អន្តរជាតិ ជួយចេញលើចំណាយវៀតណាមក្នុងពេលនេះទេ ។ ខ្ញុំដឹងថា នេះជារឿងមួយដែលពិបាកពន្យល់ឲ្យយល់ពីហេតុផលណាស់ ។ បើសិនជាយើងវាយក្បាលវៀតណាមខ្លាំង គឺហាក់ដូចជាជំរុញឲ្យវៀតណាម ខិតទៅរកសូវៀតកាន់តែខ្លាំង ។ ប៉ុន្តែ បើប្រើធម៌ត្រជាក់ចំពោះវៀតណាម គឺមិនមានប្រសិទ្ធភាពទេ ប្រសិនបើសិនវៀតណាមនៅតែធ្វើអ្វីដូចដែលគេកំពុងធ្វើសព្វថ្ងៃនេះ ។

នេះគឺជារឿងមួយដែលលើសពីការប្រយ័ត្នប្រយែង ចំពោះវៀតណាម តែជាវិធានការដ៏ជោគជ័យរបស់អាមេរិក ក្នុងការទប់ស្កាត់ឥទ្ធិពលរបស់វៀតណាមកុំឲ្យកាន់តែរីកធំធាត់ទៀត ។ ពេលនិយាយដល់របបស្តាលីន នៅវៀតណាម និងការគ្រប់គ្រងរបស់វៀតណាមនៅកម្ពុជា គោលការណ៍នេះ ត្រូវបានក្លាយជាការដាក់ទណ្ឌកម្មដ៏សកម្មមួយ ។

លទ្ធផលនៃគោលការណ៍នោះ គឺការពន្យារការខ្ទប់ដង្ហើមសេដ្ឋកិច្ចរបស់វៀតណាមឲ្យបានយូរ និងការអូសបន្លាយការប្រវាងើបចេញរបស់កម្ពុជា ក្រោយពេលឲ្យផុតពីការខ្ទេចខ្ទាំ បណ្តាលមកពីរបបខ្មែរក្រហម ឲ្យកាន់តែវែង ។ ដរាបណាវៀតណាមនៅគ្រប់គ្រងប្រទេសកម្ពុជា ដរាបនោះ គ្មានការងើបរស់ឡើងរបស់សេដ្ឋកិច្ចនៅភ្នំពេញទេ ។ ប្រទេសដែលឆ្លើយតបនឹងការទាមទាររបស់សហរដ្ឋអាមេរិក ឲ្យកាត់ផ្តាច់ជំនួយដល់កម្ពុជា គឺជប៉ុនអូស្ត្រាលី កាណាដា និងម៉ាឡេស៊ី ព្រមទាំងសហគមន៍សេដ្ឋកិច្ចអឺរ៉ុប និងធនាគារពិភពលោក ។ ក្រៅពីប្លុកសូវៀត គឺមានតែប្រទេសស៊ុយអែត បារាំង និងឥណ្ឌា ប៉ុណ្ណោះ ដែលនៅបន្តផ្តល់ជំនួយដល់វៀតណាម ។ គួបផ្សំជាមួយ

ការដឹកនាំថយក្រោយរបស់របបសាធារណរដ្ឋនៅវៀតណាម ក្នុងរយៈពេលតែ២ឆ្នាំប៉ុណ្ណោះ គ្រោះទុរភិក្ស ក៏បាន កើតមានចំពោះកុមារវៀតណាមរួចបាត់ទៅហើយ ។ សូម្បីតែសូវៀត ក៏ទប់ទល់មិនរួចក្នុងការចិញ្ចឹមប្រជាជន វៀតណាម ដែលចេះតែមានចំនួនកើនឡើងមិនឈប់នោះដែរ ។ នៅឆ្នាំ១៩៧៩ សូវៀតបានឲ្យស្បៀងដល់វៀត ណាមចំនួន ១,២លានតោន ប៉ុន្តែក្នុងរយៈតែ ២ឆ្នាំប៉ុណ្ណោះ បរិមាណម្ហូបផ្លាក់ចុះសល់ត្រឹមតែ ៧០០.០០០តោន ប៉ុណ្ណោះ ។

ពេលនោះ វៀតណាមបានចាប់ផ្តើមមើលឃើញពីលទ្ធផល ដែលខ្លួនធ្វើការគ្រប់គ្រងលើទឹកដីកម្ពុជា ។ ក្រោយមក ក៏ចាប់ផ្តើមបើកទ្វារឲ្យសហរដ្ឋអាមេរិក បង្ហាញពីកំហុសរបស់គេជាចំហ និងបង្ហាញពីការឈឺចុកចាប់ របស់គេ ដែលបានចាញ់សង្គ្រាមនៅវៀតណាម និងបណ្តាលឲ្យបាត់បង់ទាហានអាមេរិក ចំនួនជាង ៥០.០០០ នាក់នោះ ។

នៅរដូវក្តៅឆ្នាំ១៩៧៩ វៀតណាម ត្រូវបានគេថ្កោលទោសពីរឿងមួយទៀត ។ អគ្គលេខាអង្គការ សហប្រជាជាតិបាន ដឹកនាំបើកការប្រជុំវិសាមញ្ញមួយនៅទីក្រុងហ្សឺណែវ ដែលចូលរួមប្រជុំដោយសហគណៈ កម្មការជាន់ខ្ពស់ជនភៀសខ្លួន ដើម្បីសម្រេចពីដោតវាសនារបស់អ្នកភៀសខ្លួនតាមទូក ចេញពីវៀតណាម ។ មកទល់ត្រឹមខែកក្កដា ឆ្នាំ១៩៧៩ មានជនជាតិវៀតណាមចំនួន ២០០០០០នាក់ នៅក្នុងជំរុំជនភៀសខ្លួន នៅអាស៊ី ហើយមានវៀតណាមចំនួនជិត ១០០០០០នាក់ទៀត ដែលបានរកឃើញទីជម្រកអចិន្ត្រៃយ៍ នៅប្រទេសនានាជុំវិញពិភពលោក ។ ការប្រយុទ្ធរបស់វៀតណាមនៅសមុទ្រខាងលើហាក់បីដូចជាគ្មានទីបញ្ចប់ ហើយការជជែកវែកញែកនៅក្នុងកិច្ចពិភាក្សានោះ មានពោរពេញទៅដោយភាពវិនាសដ៏ធ្ងន់ធ្ងរ ។ សកម្មភាព របស់ពួកគេគឺជាប្រចាំ មិនដូចជនជាតិជ្វីហ្វ បានជួបប្រទះនៅពេលដែលរត់គេចពីការគ្រប់គ្រងរបស់ពួកហ្វាស៊ីស នៅអឺរ៉ុបនោះទេ ។ ទោះបីជាជនភៀសខ្លួនតាមទូករបស់វៀតណាមបានជួបប្រទះនូវវិនាសកម្ម និងការលំបាកនៅ វៀតណាមក៏ដោយ ក៏ការទាំងនេះ មិនស្មើនឹងអ្វីដែលប្រជាជនកម្ពុជាបានជួបប្រទះក្រោមគោលការណ៍សម្លាប់ ផ្តាច់ពូជរបស់ខ្មែរក្រហមដែរ ។

លោកអនុប្រធានាធិបតី វាល់ទ័រ ម៉ុនដែល បានមានប្រសាសន៍ក្នុងសុន្ទរកថារបស់គាត់ថា "ចូរយើងនាំគ្នា ធ្វើអ្វីមួយដែលមានន័យជ្រៅជ្រះ ដើម្បីបញ្ឈប់នូវសោកនាដកម្មនេះ ។ ពេលជួបនូវបញ្ហាពិភពលោក ចូរយើង ទាំងអស់ស្រុះគ្នារកដំណោះស្រាយពិភពលោកមួយ ។ ប្រវត្តិសាស្ត្រ នឹងមិនលើកលែងឲ្យយើងទេ ប្រសិន បើយើងបរាជ័យ ហើយប្រវត្តិសាស្ត្រក៏មិនអាចបំភ្លេចយើងដែរ ប្រសិនបើយើងទទួលជោគជ័យ" ។

ក្រោមការសន្និដ្ឋានដ៏ទូលំទូលាយដែលមិនបានគិតឲ្យដិតដល់នោះ ដំណោះស្រាយដ៏ទូលំទូលាយ ដែលមិន បានគិតឲ្យដិតដល់មួយក៏កើតមានឡើង ។ សន្និសីទបានប្រកាសថា ជនភៀសខ្លួនតាមទូករបស់វៀតណាម និងត្រូវ ទទួលសិទ្ធិជ្រកកោនដោយស្វ័យប្រវត្តិ ដោយមិនបាច់ឆ្លងកាត់ការពិនិត្យជ្រើសរើស និងមិនបាច់មានការកំណត់ពី

មូលហេតុនៃការភៀសខ្លួនថាដោយហេតុផលនយោបាយ ឬហេតុផលសាសនា ឬក៏ហេតុផលជនជាតិអ្វីដែរ ។

ជាការស្រាល់ជ្រើសពិសេស ដែលពួកគេត្រូវបានផ្តល់ឲ្យនូវសិទ្ធទី២ មួយទៀត ។ សិទ្ធទី២ គឺជាសិទ្ធជ្រកកោនដែលពុំធ្លាប់មានពីមុនមក ដែលអនុញ្ញាតឲ្យទៅរស់នៅប្រទេសអភិវឌ្ឍន៍ ជាជាងសិទ្ធិរស់នៅទាំងហូងទាំងហ្វាយត្រឹមប្រទេសជិតខាង ។

ខុសពីប្រទេសនានានៅអាហ្វ្រិក និងអឺរ៉ុបខាងលិច ដែលទទួលយកជនភៀសខ្លួនរាប់ពាន់នាក់ ពីប្រទេសជិតខាងរបស់ខ្លួននោះ ប្រទេសថៃ ប្រទេសសិង្ហបូរី ប្រទេសម៉ាឡេស៊ី និងប្រទេសឥណ្ឌូនេស៊ី បដិសេធមិនព្រមទទួលយកជនភៀសខ្លួនពីវៀតណាមឡើយ ។ ពួកគេឲ្យហេតុផលថា ខ្លាចមានបញ្ហាមិនចេះចប់ ទាក់ទងនឹងបញ្ហានយោបាយ និងបញ្ហាជនជាតិកើតមាន ។ បន្ទាប់ពីបានបង្ហាញឲ្យឃើញថា ពួកគេនឹងបញ្ជូនជនភៀសខ្លួនតាមទូកឲ្យត្រឡប់ទៅស្លាប់វិញដោយមិនព្រមផ្តល់ជម្រកដល់ពួកគេនោះ សហគមន៍អន្តរជាតិក៏ទទួលយល់ព្រមវិញ ។ ការស្រុះស្រួលគ្នាមួយក៏កើតមានឡើងនៅទីក្រុងហ្សឺណែវ ដោយថា ប្រទេសនៅអាស៊ីអាគ្នេយ៍ យល់ព្រមផ្តល់ជម្រកបណ្តោះអាសន្នដល់ជនភៀសខ្លួន ប្រសិនបើប្រទេសអភិវឌ្ឍន៍ទាំងឡាយ ដូចជាប្រទេសអូស្ត្រាលី អាមេរិកខាងជើង និងអឺរ៉ុប ព្រមផ្តល់ជម្រកអចិន្ត្រៃយ៍ដល់ជនភៀសខ្លួនទាំងនោះ ។

ការអាណិតអាសូរពេលនោះមានភាពជ្រាលជ្រៅណាស់ ដែលសូម្បីតែការយល់ព្រមដ៏លំបាក និងស្មុគស្មាញមួយក៏ត្រូវបានសម្រេចឡើង ។ ជនភៀសខ្លួនតាមទូកវៀតណាមចំនួន ៩០០០០០នាក់ ត្រូវបានគេផ្តល់ជម្រកឲ្យ ។ ក្នុងអំឡុងឆ្នាំ៨០ ប្រទេសអភិវឌ្ឍន៍ទាំងនោះ ក៏បានរក្សាពាក្យសន្យារបស់ពួកគេ ។

ជនភៀសខ្លួនកម្ពុជាត្រូវបានផ្តល់នូវការស្វាគមន៍ខុសប្លែកពីនោះ ។ ពួកគេបានមកតាមផ្លូវដី ដើរអស់រាប់គីឡូម៉ែត្រឆ្លងមកព្រំដែនថៃ ។ ពួកគេភាគច្រើនមិនបានត្រូវគេផ្តល់សិទ្ធជាជនភៀសខ្លួនឲ្យទេ ហើយក៏មិនបានផ្តល់ឲ្យនូវសិទ្ធិភៀសខ្លួបណ្តោះអាសន្ន ដើម្បីទៅនៅប្រទេសទីបីនៅលោកខាងលិចដែរ ។ រដ្ឋអំណាចថៃព្រមឲ្យពួកគេនៅជាជនភៀសខ្លួនមិនស្របច្បាប់ ។ មានតែចំនួន១០ភាគរយនៃជនជាតិខ្មែរប៉ុណ្ណោះ ដែលត្រូវបានទទួលសិទ្ធិភៀសខ្លួន និងទទួលផលប្រយោជន៍ នៃការការពារអន្តរជាតិដោយគណៈកម្មាធិការជាន់ខ្ពស់របស់អង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ។ ភាគច្រើនក្នុងចំណោមជនជាតិខ្មែរចំនួន៣ ០០០០០នាក់ ត្រូវបានគេដាក់ឲ្យនៅជំរំភៀសខ្លួនរបស់អង្គការសហប្រជាជាតិ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទាហានខ្មែរ ដែលកំពុងតស៊ូប្រឆាំង និងការគ្រប់គ្រងរបស់វៀតណាម ដែលក្នុងនោះរួមមានទាំងកងទ័ពខ្មែរក្រហម ។

ការរៀបចំបែបនោះគឺមាននៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ៨០ ។ ជនភៀសខ្លួនខ្មែរត្រូវបានគេរៀបចំឲ្យនៅជំរំជនភៀសខ្លួននៅតាមព្រំដែនខ្មែរថៃ ហើយធ្វើទ័ព ដើម្បីជួយវាយប្រឆាំងនឹងការគ្រប់គ្រងរបស់វៀតណាមនៅកម្ពុជា ក្រោមការជួយរបស់សហគមន៍អន្តរជាតិ ។ ឯជនភៀសខ្លួនតាមទូករបស់វៀតណាម ត្រូវបានគេរៀបចំឲ្យទៅរស់នៅប្រទេសទី៣ឆ្ងាយពីប្រទេសរបស់ខ្លួន ។

នៅទីបំផុត សហគមន៍អន្តរជាតិបដិសេធមិនព្រមផ្តល់ជំនួយអភិវឌ្ឍន៍ ហើយដាច់ខាតមិនព្រមផ្តល់ជំនួយគ្រាអាសន្នដល់ប្រជាជនកម្ពុជា ដែលនៅក្នុងស្រុកឡើយ ។

ខ្មែរក្រហម ត្រូវអន្តរជាតិអនុញ្ញាតឲ្យរួបរួម និងកសាងកម្លាំងទ័ពសារជាថ្មីឡើងវិញនៅតាមព្រំប្រទល់កម្ពុជា-ថៃ ក្រោមការជួយឧបត្ថម្ភរបស់ជំនួយបរទេស ជាពិសេស ពីចិន ។ ក្រុមចលនាតស៊ូមិនមែនកុម្មុយនិស្តក្រោមការដឹកនាំរបស់ សឺន សាន, ក្រុមចលនាតស៊ូមិនមែនកុម្មុយនិស្ត ដែលមកពីប្រទេសបារាំងនៅតាមព្រំប្រទល់ ព្រមទាំងក្រុមចលនាតស៊ូដែលស្មោះស្ម័គ្រនឹងសម្តេច ព្រះនរោត្តម សីហនុ បាននាំគ្នាមកបោះទីតាំង នៅតាមព្រំប្រទល់ថៃ ហើយរើសទ័ព និងដើរកៀងប្រមូលអ្នកគាំទ្រ ។ សកម្មភាពនោះត្រូវបានទទួលការគាំទ្រ អំពីសំណាក់អង្គការសហប្រជាជាតិ និងជំនួយឯកជនដទៃទៀតនៅជុំវិញពិភពលោក ។ ប្រជាជននៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ត្រូវបានរស់ក្រោមជំនួយពីប្រទេសសូវៀត ដែលស្មានទៅមានចំនួនប្រមាន៨០លានដុល្លារក្នុងមួយឆ្នាំ និង ជំនួយរបស់ប្រទេសកុម្មុយនិស្តដទៃទៀតមកពីអឺរ៉ុបខាងកើត ព្រមទាំងជំនួយ២០លានដុល្លាទៀត ពីវៀតណាម ។ ជំនួយអភិវឌ្ឍន៍ទាំងឡាយពីលោកខាងលិចត្រូវបានគេហាមឃាត់ ។ មានតែអង្គការអន្តរជាតិមួយចំនួនដូចជា យូនីសេហ្វ និងកម្មវិធីជួយជនភៀសខ្លួនរបស់អង្គការសហប្រជាជាតិទេ ដែលត្រូវគេយល់ព្រមឲ្យជួយ ។ នៅទីបំផុត កម្ពុជានៅតែស្ថិតកប់នៅក្រោមបាតដដែល ។ មានអត្រាកុមារម្នាក់ក្នុងចំណោមកុមារ៧នាក់ បានស្លាប់មុនពេលដែលពួកគេមានអាយុមួយឆ្នាំ ហើយមានតែកុមារម្នាក់ក្នុងចំណោមកុមារ៥នាក់ប៉ុណ្ណោះ ដែលរស់ដល់អាយុ ៥ឆ្នាំ ។ មានប្រជាជនកម្ពុជាចំនួនតែមួយភាគរយប៉ុណ្ណោះ ដែលមានទឹកស្អាតប្រើប្រាស់ ។

នៅពេលដែលសម្តេច ព្រះនរោត្តម សីហនុ រើទៅនៅប៉េកាំង ទ្រង់ក៏បានដឹងដែរថា ទ្រង់មានជម្រើសតិចតួចណាស់ ប្រសិនបើទ្រង់ចង់មានការរស់នៅសុខសាន្ត ក្រោមការទទួលរាក់ទាក់របស់ចិន ហើយបើទ្រង់ចង់នៅរក្សាការគ្រប់គ្រងលើចលនាតស៊ូរបស់កម្ពុជានោះ ។ ទ្រង់បានមានបន្ទូលជាមួយអ្នកមកទស្សនកិច្ចដោយត្រង់ៗថា ទ្រង់មិនប្រកាន់ចំពោះការរស់នៅដ៏ល្អក្នុងវិមាននៅប៉េកាំង ក្រោមការឃ្លាំមើលរបស់គេនោះទេ ។ ទ្រង់នឹងរង់ចាំឱកាសដើម្បីត្រឡប់ទៅធ្វើជាមេដឹកនាំរបស់កម្ពុជាវិញ ។

ទ្រង់បានមានបន្ទូលថា "ខ្ញុំតែងមានសុបិនដដែលៗថា ខ្ញុំកំពុងដើលេងតាមមហាវិថីនៅ កូដដាហ្សេរ៍ *(Côte d'Azur)* ឱនក្បាលដើរដោយគ្មានទិសដៅសម្លឹងមើលមុខជនចម្លែកៗ ហើយរំពេចនោះឃើញមនុស្សម្នាក់ដែលខ្ញុំស្គាល់ ហើយម្នាក់នោះគឺ បាវដាយ" ។ ទ្រង់បានសំដៅទៅរកអធិរាជវៀតណាមមួយអង្គ ដែលបានទទួលយកនូវការនិរទេសខ្លួន ហើយទៅរស់នៅប្រទេសបារាំង ដោយបានទទួលការគោរព និងត្រូវបានប្រវត្តិសាស្ត្របំភ្លេចចោល ។ ទ្រង់បានមានបន្ទូលបន្តថា "ខ្ញុំក៏ភ្ញាក់ហើយស្រែកថាទេ រឿងនេះមិនអាចកើតឡើងទេ ខ្ញុំនឹងមិនរលាយបាត់ខ្លួននោះទេ" ។

នៅក្នុងស្ថានភាពនោះទ្រង់បានជួបជាមួយអ្នកការទូតបារាំងមួយឈ្មោះ ក្លូដ ម៉ាតាំង ដែលបានប្តេជ្ញាចិត្ត

ជួយរកផ្លូវទៅមុខឲ្យទ្រង់ និងប្រទេសកម្ពុជា ។

នៅក្នុងវ័យទើបតែ៣៥ឆ្នាំ លោក ក្លូដ ម៉ាតាំង ជាអ្នកការទូតទីពីរនៅប្រចាំនៅស្ថានទូតបារាំង គាត់ស្ថិតនៅក្រោមតែបញ្ជារបស់លោកអគ្គរដ្ឋទូតម្នាក់ប៉ុណ្ណោះ ។ ដែលចម្លែកជាងនេះទៅទៀតនោះគឺ លើកនេះជាលើកដំបូងហើយ ដែលគាត់ត្រូវបានគេបញ្ជូនឲ្យមកធ្វើការនៅក្រៅស្រុក ។ ប៉ុន្តែ ម៉ាតាំង ជាមនុស្សដែលមានសមត្ថភាពមួយរូប ហើយជាបុគ្គលដែលចំណានពីរឿងរ៉ាវទាក់ទងនឹងចិន ។ នៅពេលរៀននៅមហាវិទ្យាល័យ លោកបានយកជំនាញពីរមុខ ។ មួយគឺ វិទ្យាសាស្ត្រនយោបាយ ដើម្បីក្លាយជាអ្នកការទូត ហើយមួយទៀតគឺជំនាញខាងភាសារបស់ប្រទេសបូព៌ា ។ គាត់បានជ្រើសយកជំនាញខាងភាសាចិន និងភាសារុស្ស៊ី ។ នៅឆ្នាំ ១៩៦៤ ពេលដែលគាត់ត្រូវបានតម្រូវឲ្យបម្រើការងារទ័ពពីរឆ្នាំ ក្រោយពេលបញ្ចប់មហាវិទ្យាល័យនោះ គាត់ត្រូវបានរដ្ឋាភិបាលបារាំង បញ្ជូនគាត់ឲ្យមកប្រចាំការនៅស្ថានទូតឯទីក្រុងប៉េកាំង ដែលទើបនឹងបើកថ្មី ដោយមានតំណែងជាអនុព័ន្ធផ្នែកវប្បធម៌ ។ ធាក់កង់នៅក្នុងទីក្រុងនោះអស់រយៈពេល២ឆ្នាំ នៅក្នុងពេលដែលចលនាបដិវត្តន៍វប្បធម៌ចិនកំពុងតែពុះកញ្ជ្រោលនោះ ម៉ាតាំង ចាប់ផ្តើមមានមនោសញ្ចេតនាចាក់ជ្រៅចំពោះប្រទេសចិន ហើយព្រមពេលជាមួយគ្នានោះក៏ស្អប់បដិវត្តន៍ចិន ។ គាត់បានចាកចេញពីប្រទេសចិននៅឆ្នាំ ១៩៦៦ ហើយធ្វើដំណើរត្រឡប់ទៅប្រទេសរបស់គាត់វិញ កាត់តាមប្រទេសកម្ពុជា ។ នៅពេលនោះ សម្តេច ព្រះនរោត្តម សីហនុ ជាប្រមុខរដ្ឋហើយជនជាតិបារាំង នៅមានការស្វាគមន៍នៅកម្ពុជានៅឡើយ ។ ម៉ាតាំង បានធ្វើទស្សនកិច្ចនៅអង្គរ ហើយភ្ញាក់ផ្អើលយ៉ាងខ្លាំង ចំពោះការមោះមុតសកម្មរបស់កម្ពុជា ក្នុងការការពារនម្មានិកដ៏អស្ចារ្យរបស់ខ្លួន ដែលផ្ទុយពីចិន គឺកំពុងតែខំប្រឹងបំផ្លាញខ្លួនឯងទៅវិញ ។ នៅពេលត្រឡប់មកប៉ារីសវិញ ដើម្បីការហ្វឹកហាត់ការទូត ម៉ាតាំង បានសម្រេចថា នឹងបន្តរៀនភាសា និងអក្សរសាស្ត្រចិនបន្តទៀត សម្រាប់ជីវិតឯកជន និងចំណង់ចំណូលចិត្តរបស់គាត់ ។

ក្រោយពេលត្រឡប់មកវិញ ម៉ាតាំង បានចូលធ្វើការនៅក្រសួងការបរទេសទទួលបន្ទុកផ្នែកអឺរ៉ុប ។

ហេលី ដឺណូអាយ ដែលជាមិត្តរបស់ ម៉ាតាំង ហើយធ្លាប់បានធ្វើដំណើរការទូតជាមួយគាត់ទៅប្រទេសភូមានោះ បាននិយាយថា ម៉ាតាំង មានការប្រយ័ត្នប្រយែងណាស់ ហើយមិនឲ្យខ្លួនឯងធ្លាក់ខ្លួនជាជនរងគ្រោះនៃភាពប្លែកៗរបស់អាស៊ីនោះទេ ។ មានអ្នកជំនាញអាស៊ីជាច្រើននៅក្រសួងការបរទេស ដែលលែងជាបារាំងទៀត ប៉ុន្តែ ម៉ាតាំង ខុសប្លែកពីពួកនោះ គឺគាត់មិនមែនជាប្រភេទដែលស្លៀកសារុង ហើយផឹកតែបៃតងនោះទេ ។

ក្រោយពីពេលបញ្ចប់ការងារបួនឆ្នាំនៅការិយាល័យប្រធានាធិបតីបារាំង ដែលគាត់បានធ្វើការ ៨០ ម៉ោងក្នុងមួយអាទិត្យ ហើយនិងបានក្លាយជាអ្នកដើងឯកការិយាធិបតេយ្យ និងជាអ្នកយុទ្ធសាស្ត្រស៊ីសងដែរនោះ គាត់ក៏បានទទួលតំណែងទៅនៅប៉េកាំងវិញ ។ នៅទីនោះគាត់បានជួបសម្តេច ព្រះនរោត្តម សីហនុ ។ ភ្លាមនោះជនជាតិបារាំងម្នាក់នោះ ក៏បានជាប់ចិត្តនឹងប្រជាប្រិយភាព និងភាពវ័យឆ្លាតរបស់សម្តេច ព្រះនរោត្តម សីហនុ

ទៅហើយ ។ រាល់មនោសញ្ចេតនាទាំងឡាយ រវាងអាស៊ី និងបារាំង ដែលគាត់បានលាក់ទុកក្នុងចិត្តជាយូរមកហើយ រួមទាំងកំណាព្យរបស់រាជវង្សម៉េង ដែលគាត់អានពេលរាត្រីនោះក៏ផុសចេញមក ។ ពេលនោះ គាត់ក៏ស្វាគមន៍នូវការប្រឹងប្រែង ដើម្បីស្ដាបនាឡើងវិញ នូវតួនាទីរបស់បារាំងនៅប្រទេសកម្ពុជា និងសង្គ្រោះឲ្យផុតពីខ្មែរក្រហម តាមរយៈសម្ដេច ព្រះនរោត្តម សីហនុ ។ សភាពរញ៉េរញ៉ៃរបស់កម្ពុជារឹតតែធ្វើឲ្យ ម៉ាតាំង ចង់សម្រេចកិច្ចការនោះឲ្យបាន ។ សម្ដេចក៏កំពុងតែប្រឹងប្រែងរកវិធីសាស្ត្រថ្មីដែរ ។ ទ្រង់ធ្វើដំណើរចេញចូលប្រទេសបារាំង និងសហរដ្ឋអាមេរិក ជម្នះការចាកចេញពីប្រទេសខ្មែររបស់ទ្រង់ ។ ទ្រង់ធ្វើជាប្រឆាំងទាំងខ្មែរក្រហម និងវៀតណាម ហើយបានមានបន្ទូលនៅពេលមួយថា «យើងជាជនភៀសខ្លួនខ្មែរទាំងអស់នៅជុំវិញពិភពលោក នឹងមិនចូលខ្មែរក្រហមជាដាច់ខាត» ។

ទាំងនោះសុទ្ធតែជាការកុហក ។ តាមការពិតទៅ ទ្រង់មិនបានចាកចេញពីខ្មែរក្រហមឡើយ ទោះបីជាទ្រង់មិនមែនជាសមាជិករបស់បក្ស ឬរដ្ឋាភិបាលខ្មែរក្រហមក៏ដោយ ។ ហើយនោះក៏ជាហេតុផលមួយដែលរដ្ឋាភិបាលបារាំងបានប្រាប់លោកម៉ាតាំងដោយចំហកុំឲ្យទាក់ទងជាមួយទ្រង់ ។ ជាផ្លូវការជំហររបស់បារាំងចំពោះកម្ពុជា គឺមិនឈរខាងណាឡើយ ។ ប៉ុន្តែក្រៅផ្លូវការ លោកប្រធានាធិបតី វ៉ាឡេរី ហ្ស៊ីស្កាដ ដេសស្តាំងមានការសង្ស័យចំពោះសម្ដេច ព្រះនរោត្តម សីហនុ យ៉ាងខ្លាំង ។ បើតាមលោក ម៉ាតាំង គឺដល់ថ្នាក់ស្អប់ទ្រង់ទៀតផង ហើយគិតថានៅក្នុងរឿងនេះ វៀតណាមត្រូវបានគេចោទដោយអយុត្តិធម៌ថាជាជនអាក្រក់ ។ បារាំងមិនបានបោះឆ្នោតដើម្បីផ្ដល់កៅអីកម្ពុជាដល់ខ្មែរក្រហមនៅអង្គការសហប្រជាជាតិទេ ដោយអះអាងថា ធ្វើយ៉ាងនោះ គឺបានន័យថាបារាំងទទួលស្គាល់ខ្មែរក្រហម ដែលជារឿងមួយក្រៅពីការគិតរបស់គេ ។ ព្រមពេលជាមួយគ្នានោះ បារាំងក៏មិនព្រមបោះឆ្នោត ដើម្បីផ្ដល់កៅអីកម្ពុជាឲ្យទៅរដ្ឋាភិបាល ដែលបន្តុបដោយវៀតណាមដែរ ។ សេចក្ដីប្រកាសជាផ្លូវការរបស់បារាំងបានបដិសេធជម្រើសទាំងពីរនោះ ដោយសង្ឃឹមថា និងឈរនៅកណ្ដាល ។ នៅក្នុងសេចក្ដីថ្លែងការណ៍មួយ បារាំងនិយាយថា បើនិយាយពីផ្នែកមនុស្សធម៌បារាំងបានមកជួយសង្គ្រោះប្រជាជនស៊ីវិលរបស់កម្ពុជារួចទៅហើយ បើនិយាយពីផ្នែកនយោបាយវិញ ទោះក្នុងកាលៈទេសៈណាក៏ដោយ ក៏បារាំងមិនអាចទទួលស្គាល់ការឈ្លានពានបូរណភាពដែនដីនៃរដ្ឋ ដែលបណ្ដាលឲ្យមានការគ្រប់គ្រងពីសំណាក់ទាហានបរទេសនោះដែរ ។

ម៉ាតាំង យល់ស្របនឹងការប្រកាន់ជំហររបស់រដ្ឋាភិបាលគាត់ តែមិនយល់ស្របចំពោះការវិនិច្ឆ័យលើសម្ដេច ព្រះនរោត្តម សីហនុ ទេ ។ គាត់បានជួបដោយសម្ងាត់ជាមួយសម្ដេច ព្រះនរោត្តម សីហនុ ស្ដាប់ពីរឿងនិងគំនិតទាំងឡាយរបស់ទ្រង់ ដោយមិនបានរាយការណ៍ឲ្យទីក្រុងប៉ារីសដឹងឡើយ ។ គាត់ក៏បានក្លាយជាអ្នកជំនាញដែលយល់ពីទម្លាប់របស់សម្ដេច ព្រះនរោត្តម សីហនុ ។ បន្តិចម្ដងៗ គាត់ជម្នះលើកពីគំនិតរបស់គាត់ដែលយល់ថាបារាំងអាចជួយឲ្យសម្ដេច ព្រះនរោត្តម សីហនុ យកកន្លែងប្រមុខរដ្ឋនៃកម្ពុជាវិញ ។ ដោយថា ម៉ាតាំង ដែលមិនមែនជាអ្នកការទូតបារាំង ហើយក៏មិនមែនរដ្ឋាភិបាលបារាំងនោះ នៅពេលដែលសម្ដេចលើកទឹកចិត្តឲ្យ ម៉ាតាំង

ស្វែងរកផ្លូវមួយដែលអំណោយផលដល់ទ្រង់ ទ្រង់មិនបានពឹងផ្អែកទាំងស្រុងលើ ម៉ាតាំង ទេ ។

ប៉ុន្តែក្នុងរយៈពេលប្រាំឆ្នាំនៅស្ថានទូតបារាំងប្រចាំនៅប្រទេសចិន ម៉ាតាំង នៅតែមានការចាប់អារម្មណ៍ចំពោះរឿងនោះ ។ នៅឆ្នាំ១៩៨១ លោក ហ្វ្រង់ស្វ័រ មីតេរ៉ង់ ត្រូវបានប្រជាជនបារាំងបោះឆ្នោតឲ្យធ្វើជាប្រធានាធិបតី ហើយ ម៉ាតាំង ក៏បារៀបចំឲ្យសម្តេច ព្រះនរោត្តម សីហនុ ជួបជាមួយនឹងគាត់នៅឆ្នាំ១៩៨៣ ។ តាមរយៈសម្តីរបស់ ម៉ាតាំង បានឲ្យដឹងថា មីតេរ៉ង និងរដ្ឋាភិបាលរបស់គាត់ បើកចំហជាងរដ្ឋាភិបាលមុនចំពោះការគាំទ្រសម្តេច ព្រះនរោត្តម សីហនុ តែមិនមែនក្នុងភាពជាមេដឹកនាំរបស់គណបក្សតស៊ូទាំងបីរបស់សម្តេច ព្រះនរោត្តម សីហនុ ទេ ប៉ុន្តែ ក្នុងភាពជា បុគ្គលមួយរូប ដែលពោរពេញទៅដោយការជឿជាក់លើសេរីភាព និងឯករាជ្យជាតិរបស់កម្ពុជា ។

ទាំងនោះគឺជាការគិតរបស់ម៉ាតាំង ។ សម្តេច ព្រះនរោត្តម សីហនុ ជាបុគ្គលដែលមានទេពកោសល្យ ហើយជាមេដឹកនាំមួយរូប ដែលគេទម្លាក់ចេញពីតំណែង និងត្រូវបានគេកាត់ផ្តាច់ពីប្រជាជនអស់ប្រាំបួនឆ្នាំហើយ ។ ម៉ាតាំង គឺហាក់ដូចជាអ្នកលេងល្បែងភ្នាល់សេះម្នាក់ ដែលចាក់លើអ្នកបំបោលសេះមួយរូបដោយទាំងមិនស្គាល់ថា តើអ្នកបំបោលសេះនោះនឹងជិះសេះណានៅឡើយផង ។ នៅពេលនោះ សម្តេច ព្រះនរោត្តម សីហនុ គ្មានជម្រើសអ្វីក្រៅពីជិះសេះចិនទេ ។ ទាំងនោះ ជាការកំណត់មួយ ប៉ុន្តែយ៉ាងហោចណាស់នៅក្នុងចិត្តរបស់ ម៉ាតាំង សម្ព័ន្ធភាពមួយរវាងទ្រង់ និងគាត់ត្រូវបានបង្កើត ។ ប៉ុន្តែ មុននឹងអ្នកការទូតមួយរូបនេះ អាចជម្នះការទាមទាររបស់គាត់បាននោះ គាត់ត្រូវគេបញ្ជូនឲ្យទៅធ្វើការនៅទីក្រុងប្រ៊ុចសែល ចំនួនពីរឆ្នាំឯសហគមន៍សេដ្ឋកិច្ចអឺរ៉ុប ទទួលខុសត្រូវខាងផ្នែកកសិកម្ម ។ ម៉ាតាំង បាននិយាយថា «នៅទីនោះមួយយប់ៗគាត់ចំណាយពេលពិភាក្សាតែអំពីតម្លៃប៊ឺន» ។

នៅឆ្នាំ១៩៦៨គាត់ត្រូវបានគេផ្លាស់ឲ្យមកវិញ ដើម្បីដឹកនាំផ្នែកអាស៊ីនៅក្រសួងការបរទេសបារាំង ។

នៅក្នុងរយៈពេលដំបូងនៃសង្គ្រាមកម្ពុជាថ្មីក្នុងអំឡុងឆ្នាំ១៩៨០ ដល់ឆ្នាំ១៩៨៥ សម្តេច ព្រះនរោត្តម សីហនុ បានសម្របតាមសឹងតែគ្រប់គោលការណ៍ទាំងអស់ ដែលចិនបានគូសទុកឲ្យទ្រង់ ។ ក្រុមនិរទេសជនខ្មែរមួយក្រុមកំពុងតែបង្កើតក្រុមតស៊ូមួយដែលមានឈ្មោះរបស់ទ្រង់ ហើយក្រោយមកត្រូវបានគេស្គាល់ថាជាហ៊្វុនស៊ិនប៉ិចដែលជាអក្សរកាត់បារាំងមួយឃ្លា (FUNCIPEC) មានសម្រាយថា រណសិរ្សបង្រួបបង្រួមជាតិដើម្បីកម្ពុជាមួយឯករាជ អព្យាក្រឹត សន្តិភាព និងសហប្រតិបត្តិ ។ ក្រុមនោះប្រមូលបានអ្នកគាំទ្រជាច្រើនទាំងស៊ីវិល និងទាហាននៅតាមព្រំដែន និងតំណាងនយោបាយបណ្តោះអាសន្ននានាតាំងពីក្រុងបាងកក រហូតដល់ទៅក្រុងវ៉ាស៊ីនតោន ។ ដំបូងឡើយ ក្រុមនេះគ្រាន់តែជាក្រុមអ្នកតស៊ូតូចជាងគេ ដែលនៅក្រោយខ្មែរក្រហម និងរណសិរ្សរំដោះប្រជាពលរដ្ឋខ្មែរដឹកនាំដោយ សឺន សាន ប៉ុណ្ណោះ ។ ជារឿងមួយដែលជៀសមិនផុត គឺមនុស្សរបស់សម្តេច ព្រះនរោត្តម សីហនុ ប្រណាំងប្រជែងជាមួយក្រុមរបស់ សឺន សាន ក្នុងការជ្រើសរើសជនភៀសខ្លួន

មកធ្វើជាទ័ព និងដើម្បីជំនួយអន្តរជាតិ ។

យុគសម័យនោះគឺជាចំណុចកកដ៏ខ្លាំងបំផុតនៃសង្គ្រាមត្រជាក់ ។ នៅឆ្នាំ ១៩៨០ រ៉ូណាល់រីហ្គេន បានជាប់ឆ្នោតជាប្រធានាធិបតីទី៤០របស់សហរដ្ឋអាមេរិក ហើយភ្លាមនោះ ក៏ផ្តោតទៅលើការបង្កើនទ័ពរបស់សូវៀត ដែលជាការគំរាមកំហែងដល់សន្តិភាពពិភពលោក ។ កាលនោះ ឡេអូនីត ប្រេសណេវ នៅជាប្រធានាធិបតីរបស់សូវៀតនៅឡើយ ។ ដោយសារអសមត្ថភាព និងការជឿលើលទ្ធិស្តាលីនដ៏ងងឹតងងល់របស់គាត់ បានធ្វើឲ្យ រីហ្គេន ដាក់ងាររចំពោះទង្វើរបស់គាត់ថា ជាទង្វើដែលលាបសូវៀតឲ្យក្លាយជា«ចក្រភពបិសាច» ។ នៅពេលប្រហាក់ប្រហែលគ្នា ដែលជនភៀសខ្លួនកម្ពុជាកំពុងត្រដាបត្រដួសភៀសខ្លួនពីប្រទេសកម្ពុជាទៅប្រទេសថៃ ស្គមស្គាំងឈឺរីងរៃ និងពោរពេញដោយការខ្វះខាតនោះ ចក្រភពសូវៀតត្រូវបានទទួលការវាយប្រហារពីខាងក្នុង ។ ការវាយប្រហារនោះចាប់ផ្តើមពីកូដកម្មនៃរោងចក្រកប៉ាល់ *Gdansk* ក្រោមការដឹកនាំរបស់ លេច វ៉ាលេសា ។ ការគ្រប់គ្រងរបស់សូវៀតនៅអាហ្គានីស្ថានកាន់តែព្រៃផ្សៃឡើង ។ នោះបន្ថែមន័យថា ការគ្រប់គ្រងរបស់វៀតណាមគ្រាន់តែជាផ្នែកតូចមួយនៃការគ្រប់គ្រងរបស់សូវៀតប៉ុណ្ណោះ ។ នាវាដើងទឹករបស់សូវៀតបានចាប់ផ្តើមប្រើផែកាំរ៉ាញ់ របស់វៀតណាមនៅខែមីនា ឆ្នាំ១៩៧៩ ។ សូវៀត ជាប្រទេសមួយក្នុងចំនោណាមប្រទេស មួយចំនួនតូច ដែលគាំទ្រការគ្រប់គ្រងរបស់វៀតណាមនៅកម្ពុជា ។

នៅពេលដែលប្រទេសទាំងឡាយនៅអាស៊ីអាគ្នេយ៍ កំពុងជំរុញឲ្យមានការទទួលខុសត្រូវលើជនភៀសខ្លួនតាមទូករបស់វៀតណាមឲ្យទៅប្រទេសនានានោះ ប្រទេសថៃ កំពុងជួបប្រទះនូវការហូរចូលនូវជនភៀសខ្លួនខ្មែររាប់ម៉ឺននាក់ដែរ ។ នៅដំណាក់កាលនៃឆ្នាំដំបូងសភាពការណ៍គឺច្របូកច្របល់ណាស់ ។ ក្នុងចន្លោះខែមីនា និងមេសា ឆ្នាំ១៩៧៩ ថៃបានបិទព្រំដែនរបស់គេ ។ ប៉ុន្តែ ក្រោយមកក៏បើកឡើងវិញ បន្ទាប់ពីវៀតណាមសម្រេចចិត្តបង្អត់អាហារខ្មែរក្រហមបាក់ទ័ព និងប្រជាជនស៊ីវិលក្រោមការគ្រប់គ្រងរបស់គេ ។ សភាពការណ៍បានធ្លាក់ចុះដុនដាបរហូតដល់ជនទាំងនោះ មានសភាពដូចជាគ្រោងឆ្អឹងចេះដើរដូច្នោះដែរ ។ បន្ទាប់មក វៀតណាមបានចាប់ផ្តើមបោសសំអាតទីក្រុងភ្នំពេញដោយកម្ចាត់ចោលអ្នកស្នាក់នៅដែលគេមិនចង់បាន ជាពិសេស គឺខ្មែរកាត់ចិន ។ សកម្មភាពនោះ បណ្តាលឲ្យប្រជាជនដែលត្រូវគេជម្លៀសចេញពីភ្នំពេញនៅឆ្នាំ១៩៧៥ ហើយព្យាយាមត្រឡប់មកភ្នំពេញវិញ ភៀសខ្លួនទៅកាន់ព្រំដែន ដែលជាហេតុធ្វើឲ្យចំនួនជនភៀសខ្លួននៅព្រំដែនកាន់តែមានចំនួនច្រើនឡើង ។ ពួកគេខ្លាចថា វៀតណាមនឹងធ្វើការជម្លៀសប្រជាជនចេញពីទីក្រុង ដូចដែលខ្មែរក្រហមបានធ្វើដែរ ។ ដំបូង ថៃបានឲ្យពួកគេចូលទាំងអស់ ប៉ុន្តែក្រោយមក នៅខែមិថុនា ក៏បានបញ្ជូនពួកគេចំនួន ៤២.៩៨៦នាក់ឲ្យមកប្រទេសកម្ពុជាវិញតាមជម្រាលខេត្តព្រះវិហារដែលពោរពេញដោយមីន ។ ហេតុការណ៍នោះ បានបណ្តាលឲ្យប្រជាជនចំនួន ១០.០០០នាក់ស្លាប់ ។

ហើយចំពោះជនភៀសខ្លួនតាមទូកវិញ ត្រូវបានសហគមន៍អន្តរជាតិឆ្លើយតបដោយភាពសប្បុរសបំផុត ។

រូបថតដ៏ស្ពាំងស្គមរបស់ជនភៀសខ្លួនកម្ពុជាដែលឃើញតែឆ្អឹងដូចខ្មោចនោះ បានជំរុញឲ្យអង្គការជំនួយមកបោះទីតាំងនៅព្រំដែន ។ អ្នកស្ម័គ្រចិត្តបរទេសបានមកធ្វើការផ្ទាល់ ជួយបោះតង់ ជីកបង្គន់អនាម័យ ហើយបញ្ចុះបញ្ចូលអ្នកការទូត និងអ្នកកាសែត ឲ្យមកព្រំដែនខាងកើតរបស់ថៃ ដើម្បីធ្វើជាសាក្សីចំពោះការឈ្លានពានលើមនុស្សលោកនេះ ។ រឿងរ៉ាវឃើញថា មានភាពស្មុគស្មាញជាងអ្វីដែលជនបទេសទាំងឡាយនឹងគិតទៅទៀត ។ ក្នុងចំណោមអ្នកដែលទទួលជំនួយទាំងនោះ មានទាំងខ្មែរក្រហម និងចំណាប់ខ្មាំងរបស់ពួកគេដែលភ្ជង់យកមកពីព្រំដែន ។ អ្នកធ្វើការក្នុងអង្គការជំនួយមួយ បានប្រៀបធៀបការភ្ជង់កៀងគរឲ្យដើរតាមខ្មែរក្រហមនោះជា “បន្ទាយឃុំឃាំងចល័ត” ។ ប៉ុន្តែ នៅពិភពខាងក្រៅ រឿងរ៉ាវនេះត្រូវបានគេដឹងថាជាការរត់ភៀសខ្លួនរបស់ប្រជាជនពីសង្គ្រាម ខ្មែរក្រហម និងវៀតណាម ។ ពួកគេបានជួបនូវសភាពអត់ឃ្លាន ជំងឺអាសន្នរោគ គ្រុនចាញ់ និងជំងឺរបេង ដែលធ្វើឲ្យអត្រាមនុស្សស្លាប់ក្នុងមួយថ្ងៃគឺ ៥០នាក់ ។ ទាំងនោះតំណាងឲ្យសោកនាដកម្មដ៏ខ្លោចផ្សា ដែលមានលក្ខណៈរួមមួយដូចគ្នា ។ នៅឆ្នាំដំបូង គេបានទទួលនូវការអាណិតអាសូរ និងប្រាក់ពីអន្តរជាតិនោះ ជាលទ្ធផលនៃការយល់ស្របមតិជាទូទៅមួយនៅអង្គការសហប្រជាជាតិ ដែលថ្កោលទោសវៀតណាម ។

ដល់ឆ្នាំ១៩៨១ ជំរំបានផ្តល់នូវលទ្ធផលដ៏ជោគជ័យមួយក្នុងប្រវត្តិសាស្ត្រទំនើបនៃជំនួយ ដោយបានកាត់បន្ថយអត្រាជំងឺបណ្តាលមកពីកង្វះអាហារ ក្នុងចំណោមកុមារពី ៥០ភាគរយ ចុះមកត្រឹម ២.៥ភាគរយ ត្រឹមរយៈពេលតែមួយឆ្នាំប៉ុណ្ណោះ ។ ហើយនោះក៏ជាប្រតិបត្តិការជំនួយដ៏ថ្លៃមួយ ដែលចំណាយអស់ទឹកប្រាក់ចំនួន៧/១៥០០ដុល្លាក្នុងមួយថ្ងៃ នៅជំរំខៅអ៊ីដាង ទៅលើអាហារ សេវាពេទ្យ ការហ្វឹកហ្វឺន និងការអប់រំដ៏ល្អ ដែលសឹងតែល្អជាងនៅតាមភូមិនានានៅប្រទេសថៃទៅទៀត ។ CNM ដែលជាអ្នកសម្របសម្រួលរបស់អង្គការសហប្រជាជាតិបាននិយាយថា “ដោយមិនចាំបាច់ឆ្លល់ថាហេតុអ្វី បានជាទីនេះ មានការចំណាយលើសពីធម្មតាទេ ។ ឃើញថាយើងមិនអាចធ្វើអ្វីច្រើនចំពោះរឿងនោះបានទេ ។ ដោយសារទំនាក់ទំនងចាស់របស់អាមេរិកប្រជាជនមើលឃើញសូវៀតជាពួកវាតទីនិយម ហើយមានការចាប់អារម្មណ៍យ៉ាងច្រើននៅទីនេះ ដែលជាចំណាប់អារម្មណ៍មួយដែលគ្មាននៅកន្លែងដូចជាអាហ្វ្រិកអីជាដើម” ។

នៅក្នុងប្រទេសកម្ពុជាស្ថានភាពជំនួយមានលក្ខណៈផ្ទុយទាំងស្រុង ចំពោះអ្វីដែលកើតមាននៅតាមជំរំ ។ ប្រជាជនដែលចាកចោលស្រុកភៀសខ្លួនទៅប្រទេសថៃត្រូវបានគេជួយឧបត្ថម្ភ ឯចំណែកអ្នកនៅក្នុងស្រុកត្រូវបានគេព្រងើយកន្តើយ ។ ប្រភពដើមនៃបញ្ហានេះ គឺការគិតគូរខុសរបស់វៀតណាម ។ មានតែកាសែតជម្រើសមួយចំនួនប៉ុណ្ណោះ ដែលបានត្រូវអនុញ្ញាតឲ្យចូលមកក្នុងប្រទេសកម្ពុជា ។ ជំនួយពីខាងក្រៅប្រទេសត្រូវបានគេហាមប្រាម បណ្តាលឲ្យម្ចាស់ជំនួយមានការលំបាកក្នុងការស្វែងយល់ ដើម្បីដឹងថាតើជំនួយទាំងនោះត្រូវបានយកទៅជួយប្រជាជន ឬក៏យកទៅជួយទ័ព ។ បេសកម្មរួមគ្នាមួយរបស់ យូនីសេហ្វ និងគណៈកម្មាការកាកបាទក្រហមអន្តរជាតិ ត្រូវបានគេស្វាគមន៍ដោយភាពសោះអង្គើយ ។ រដ្ឋាភិបាលកម្ពុជា ក៏បានទទួលស្គាល់

ដោយសោះកក្រោះថា រដ្ឋាភិបាលមិនទាន់បានរៀបចំខ្លួនរួចរាល់ ដើម្បីទទួលយកជំនួយទាំងនេះទេ ។ បន្ទាប់ពីរបបខ្មែរក្រហម ប្រទេសទាំងមូល គ្មានប្រព័ន្ធភស្តុភារ គ្មានឡានដឹកទំនិញ គ្មានគ្រឿងបន្លាស់ គ្មានស្ថានីយប្រេងឥន្ធនៈ គ្មានឡានលើកដាក់ទំនិញ គ្មានផ្លូវសម្រាប់នាវាអាកាសល្អ គ្មានផ្លូវល្អ ឬឃ្លាំងផ្ទុកទំនិញនោះឡើយ ។ ជៀសជាងទទួលយកការពិតនេះ វៀតណាមចង់ធ្វើឲ្យគេយល់ថា ស្ថានភាពនៅកម្ពុជាមិនអាក្រក់ដល់កម្រិតនោះឡើយ ។ នៅពេល គូឌីនបា ដែលជាកុងស៊ុលរបស់វៀតណាមនៅអង្គការសហប្រជាជាតិ ត្រូវបានគេសួរថា ហេតុអ្វីបានជាកម្ពុជាមិនទទួលយកអាហារ ដើម្បីជួយគ្រោះទុរភិក្សនៅក្នុងប្រទេសរបស់ខ្លួន គាត់បានឆ្លើយថា «គ្រោះទុរភិក្សទាំងនេះ ជាអន្ទាក់របស់ចិន ជាល្បែងដែលលោកខាងលិចលេងដើម្បីជួយអាហារ និងគ្រឿងផ្ទុះដល់ទ័ពខ្មែរក្រហម» ។

នៅឯភ្នំពេញ រដ្ឋាភិបាលបានប្រកាសថា ទាំងនោះគ្រាន់តែជាការខ្វះខាតអាហាររមួយរយៈប៉ុណ្ណោះ ហើយបញ្ហានោះ នឹងត្រូវដោះស្រាយបានបន្ទាប់ពីការប្រមូលកាត់ប្រមូលផលល្អមួយ ។ ចំណាយនៃការភូតកុហកនោះ ត្រូវធ្លាក់ជាបន្ទុករបស់សូវៀត ។ សូវៀត បានចំណាយអស់ ៨៥លានដុល្លារ រួមជាមួយនឹងពោតក្រហមចំនួន ៨ម៉ឺនតោន ដើម្បីផ្តល់ជំនួយបន្ទាន់សម្រាប់សង្គ្រោះប្រជាជនកម្ពុជានាឆ្នាំដំបូងនោះ ។ ប្រជាជនកម្ពុជាដែលត្រូវការអង្ករយ៉ាងខ្លាំង ព្រោះថាមានការលំបាកបំផុតក្នុងការបរិភោគពោតក្រហមទាំងនោះ ។ ក្រោយពេលដែល អង្គការសហប្រជាជាតិបានបោះឆ្នោតទទួលស្គាល់របប ប៉ុល ពត សាធារណរដ្ឋប្រជាមានិតកម្ពុជា និងអ្នកគ្រប់គ្រងវៀតណាមរបស់គេយល់ថា ជំនួយអន្តរជាតិ គឺមានបំណងចង់ឆ្លុះឲ្យពិភពលោកឃើញពីភាពទន់ខ្សោយរបស់ពួកគេ និងជាការគាំទ្រនូវការវិលត្រឡប់មកវិញរបស់ខ្មែរក្រហម ។ យូនីសេហ្វ និងកាកបាទក្រហមអន្តរជាតិ បានរួមគ្នាជូនជំនួយដល់កម្ពុជា ប៉ុន្តែ ត្រូវអង្វរករនៅភ្នំពេញ ពន្យាររហូតដល់ទៅមួយឆ្នាំ ទើបអនុញ្ញាតឲ្យជំនួយទាំងនោះ ចែកចាយសព្វពេញប្រទេស ។ ពេលដែលនិយាយយកការពិតថា រដ្ឋាភិបាលកម្ពុជាគ្មានសម្ភារៈគ្រប់គ្រាន់ដើម្បីដឹកជញ្ជូនអំណោយនោះ តាមពិតពីក្រោយការពិតនោះ គឺរដ្ឋាភិបាលកម្ពុជា និងវៀតណាម មានការសង្ស័យចំពោះអ្នកធ្វើការជំនួយឲ្យអង្គការអន្តរជាតិទាំងនោះ ដែលមកពីប្រភពប្រទេស និងអង្គការដែលពួកគេធ្វើការឲ្យ ។

នៅពេលនោះរដ្ឋាភិបាលបានបង្កើតនូវប្រព័ន្ធមួយ ដែលប្រើប្រាស់អំណោយទាំងនោះ ដើម្បីបង់ជាប្រាក់បៀវត្សដល់អ្នកធ្វើការរដ្ឋ ។ ប្រជាជនសាមញ្ញបានរអ៊ូថា ពួកគាត់បានទទួលតែមួយចំណែក នៃចំណែកដែលគួរតែជារបស់គាត់ប៉ុណ្ណោះ ។ ដើម្បីបង្ក្រាប់តម្រូវការនោះ ពួកគេបាននាំគ្នាទៅផ្តុំនៅតាមព្រំដែន ។ នៅទីនោះ ពួកគេអាចទទួលយកនូវអាហារ និងគ្រាប់ធញ្ញជាតិត្រឡប់យកមកចម្ការ និងភូមិរបស់ពួកគេវិញ ។ ប៉ុន្តែ នៅពេលដែលទៅព្រំដែន ពួកគេក៏ត្រូវបានគេរើសឲ្យចូលជាក្រុមប្រឆាំងនឹងវៀតណាម ។ គ្រប់គ្នាបានប្រើប្រាស់អាហារជាអាវុធនយោបាយ ។

នៅក្នុងទស្សនកិច្ចដំបូង និងបន្ទាប់នោះ អ៊ីហ៊្គ័រ រ៉ូហ្កាឆូវ បាននិយាយថា ហ៊ុន សែន បានរាយការណ៍ឲ្យគាត់នូវបញ្ហាដ៏ធំដែលកម្ពុជាកំពុងមាន ហើយគាត់ក៏រាយការណ៍បន្តទៅមូស្គូទៀត ។ គាត់មិនដឹងច្បាស់ថាតើមូស្គូប្រាប់វៀតណាមយ៉ាងណានោះទេ ជាពិសេស នៅពេលខ្លួនឯងកំពុងតែវិវត់ជុំវិញរឿងរបស់អាហ្កានីស្ថានផងនោះ ។ វៀតណាមបានព្រងើយកន្តើយចំពោះយោបល់របស់សូវៀត ដែលឲ្យទទួលស្គាល់បញ្ហារបស់កម្ពុជាដែលកំពុងជួបក្នុងពេលនោះ ។ រ៉ូហ្កាឆូវ បានទទួលស្គាល់ថា «នោះជាកំហុសពីខាងយើងដែលយើងសាកល្បងបង្កើតជារូបភាពដែលថាកម្ពុជាគ្មានបញ្ហានោះ» ។

ពីរឆ្នាំក្រោយមកនៅឆ្នាំ១៩៨១ អង្គការសហប្រជាជាតិបានប្រារព្ធបើកសន្និបាតមួយស្តីពីកម្ពុជា ។ នៅក្នុងសតិអារម្មណ៍កោតសសើរចំពោះខ្លួនឯងមួយ របៀបវារៈនៃសន្និបាត ពោរពេញដោយប្រទេសទាំងឡាយដែលប្រឆាំងនឹងវៀតណាម ។ អ្នកការទូតរបស់ពួកគេបានចូលរួមសន្និបាតបួនថ្ងៃ នៅក្នុងអាកាសធាតុក្តៅនៃសប្តាហ៍ខែកក្កដានោះ ។ ពួកគេបានដឹកនាំគណៈប្រតិភូក្តាប់យកឱកាសដំបូង ដើម្បីពន្យល់ពីជំហរអន្តរជាតិក្នុងវិធានការដើម្បីបញ្ចប់ការគ្រប់គ្រងរបស់វៀតណាមនៅកម្ពុជា ។ នៅពេលនោះហើយដែលវៀតណាម និងសូវៀត បានចាប់ផ្តើមយល់ពីជម្រៅនៃកំហុសក្នុងការរៀបចំរបស់ពួកគេ ។ ពួកគេប្រកែកមិនព្រមចូលរួមក្នុងសន្និបាត ដើម្បីដោះស្រាយទំនាស់នៅកម្ពុជា ព្រោះមានតែខ្មែរក្រហមប៉ុណ្ណោះ ដែលត្រូវបានអញ្ជើញជាតំណាងកម្ពុជា ។

អត្ថបទចំនួន១១ទំព័រត្រូវបានព្រមព្រៀងយកមកអនុវត្ត ។ មានប្រទេសចំនួន ៧៩ បានមកចូលរួម ។ រដ្ឋមន្ត្រីក្រសួងការបរទេសរបស់អូទ្រីស ត្រូវបានគេជ្រើសតាំងជាប្រធាននៃសន្និបាត ហើយអ្នកការទូតពីប្រទេសហុងឌុយរ៉ា និងសេនេហ្កាល់ ត្រូវបានគេជ្រើសរើសជាអនុប្រធាននៃសន្និបាតស្តីពីកម្ពុជា ។ ក្នុងចំណោមប្រទេសដែលមកចូលរួមសន្និបាត មានគណៈប្រតិភូពីប្រទេសមួយចំនួនតូចប៉ុណ្ណោះ ដែលធ្លាប់មកទស្សនកិច្ចនៅកម្ពុជា ហើយអ្នកដែលដឹងពីស្ថានភាពពិតប្រាកដបច្ចុប្បន្នរបស់កម្ពុជា រឹតតែមានចំនួនតិចជាងនោះទៅទៀត ។ ពួកគេ បានបោះឆ្នោតអនុញ្ញាតឲ្យសម្ព័ន្ធមិត្តមិនមែនកុម្មុយនិស្តរបស់ខ្មែរក្រហម ជាអ្នកត្រួតពិនិត្យភាពស្មៀមស្ងាត់របស់សន្និបាត ប៉ុន្តែ មិនយល់ព្រមឲ្យប្រតិភូរបស់កម្ពុជា ដែលនៅក្នុងស្រុកចូលរួមក្នុងសន្និបាតឡើយ ។

អង្គសន្និបាត បានព្រមព្រៀងយកនូវពាក្យស្លោកមួយ ដែលជាប់នៅពេញទសវត្សរ៍នោះ ។ «អង្គសន្និបាតបាននិយាយថា ស្ថានភាពបច្ចុប្បន្ននៅកម្ពុជា ជាលទ្ធផលនៃការល្មើសចំពោះគោលការណ៍នៃការគោរពអធិតេយ្យភាព ឯករាជ្យ បូរណភាពដែនដី ការមិនលូកដៃក្នុងរឿងផ្ទៃក្នុងរបស់រដ្ឋ និងការហាមផ្តាច់ចំពោះការគំរាម ឬប្រើប្រាស់ទ័ពក្នុងទំនាក់ទំនងអន្តរជាតិ» ។

(សញ្ញាចំពោះសិទ្ធមនុស្សនៅក្នុងសុន្ទរកថាបិទសន្និបាត របស់ប្រធានសន្និបាតជនជាតិអូទ្រីសលោកវីលីបាតជា មានប្រសាសន៍ថា «ការប្រកាសដែលយើងទើបបានព្រមព្រៀងនេះ គឺជាការត្រួសត្រាយផ្លូវមួយ

ដើម្បីឆ្ពោះទៅរកការបង្កើតឡើងវិញនូវរដ្ឋាភិបាលមួយ ដែលប្រកបដោយឯករាជ្យនយោបាយ និងបូរណភាពដែនដីរបស់កម្ពុជា ដែលជ្រើសរើសឡើងក្រោមការបោះឆ្នោតដោយសេរី ។ ជារដ្ឋាភិបាលដែលគោរពសិទ្ធិមនុស្ស និងគ្រឹះសេរីភាពរបស់ប្រជាជនកម្ពុជា» ។

គាត់ក៏បានជំរុញឲ្យប្រទេសទាំងឡាយ ដែលពេលនោះជ្រើសរើសយកភាពអវត្តមាន ក្នុងអង្គសន្និបាតឲ្យប្តូរគំនិតហើយចូលរួមក្នុងការរំដោះកម្ពុជាផង ។ សេចក្តីសម្រេចនោះត្រូវបានវៀតណាម និងសាធារណរដ្ឋប្រជាមានិតកម្ពុជា ព្រមទាំងសូវៀតដែលសម្រេចចិត្តមិនចូលរួមក្នុងអង្គសន្និបាតនោះ ចាត់ទុកជាការមាក់ងាយមួយ ។ ពួកគេបដិសេធមិនយល់ព្រមថា ការគ្រប់គ្រងរបស់វៀតណាមជាបញ្ហាតែមួយនៅកម្ពុជានោះទេ ។ ហើយពួកគេក៏មិនព្រមព្រងើយកន្តើយ ចំពោះអំពើប្រល័យពូជសាសន៍របស់ខ្មែរក្រហមនោះដែរ ។

ផ្ទុយទៅវិញ វៀតណាមបានផ្តោតលើការឃោសនាអំពីភស្តុតាងទាំងស្រុង ដែលគេ និងរដ្ឋាភិបាលថ្មីរបស់កម្ពុជា កំពុងគាស់បង្ហាញពីវិធីដែលខ្មែរក្រហមបំផ្លាញប្រទេសជាតិ ដែលបណ្តាលឲ្យមានប្រជាជនខ្មែរស្លាប់អស់ចំនួនជាងមួយលាននាក់ ។ បន្តបន្ទាប់មក អ្នកកាសែត និងអ្នកជំនួយអន្តរជាតិនៃអង្គការក្រៅរដ្ឋាភិបាល ត្រូវបានអនុញ្ញាតឲ្យចូលមកក្នុងប្រទេស ។ មិនយូរក្រោយមក មានសមាគមនៃអ្នកធ្វើការរបស់អង្គការក្រៅរដ្ឋាភិបាលមួយទាមទារថា ប្រជាជននៅក្នុងស្រុក គួរត្រូវទទួលបានការចាប់អារម្មណ៍ដូចជនភៀសខ្លួននៅតាមព្រំដែនដែរ ។ ប៉ុន្តែគុណសម្បត្តិពួកគេនោះ ត្រូវបានគេសង្ស័យពីព្រោះថា ពួកគេបានក្លាយជាពាក់ព័ន្ធនឹងរដ្ឋាភិបាលភ្នំពេញ ហើយក៏ព្រោះតែពួកគេជម្នះថា សាធារណរដ្ឋប្រជាមានិតកម្ពុជាមិនមានការពាក់ព័ន្ធចំពោះបញ្ហាដែលប្រជាជនកម្ពុជាកំពុងមានសព្វថ្ងៃនោះទេ ។ ដំណោះស្រាយរបស់ពួកគេដែលចង់ឲ្យទទួលស្គាល់សាធារណរដ្ឋកម្ពុជានោះ ត្រូវបានពិភពលោក និងប្រជាជនកម្ពុជាដែលចង់ឲ្យវៀតណាមដកទ័ព និងចង់បានការបោះឆ្នោតរើសរដ្ឋាភិបាលថ្មីនោះមិនពេញចិត្ត ។ រូបភាពថ្មីរបស់កម្ពុជាបានលេចឡើងនៅតាមកាសែត ទូរទស្សន៍ វិទ្យុ និងក្នុងយុទ្ធការបក្សព័ន្ធ ។ កម្ពុជាមិនត្រឹមតែជាមហន្តរាយនៃប្រទេសក្រីក្រ ឬត្រឹមតែជាប្រទេសតូចមួយដែលត្រូវបានគេញាក់ និងត្រូវគេបោះបង់ចោលក្នុងអំឡុងសង្គ្រាមត្រជាក់ប៉ុណ្ណោះទេ តែជាប្រទេសមួយក្នុងចំណោមប្រទេសគួរឲ្យរន្ធត់ជាងគេនៅលើពិភពលោក ។ ហើយចំណែកឯ ប៉ុល ពត និងខ្មែរក្រហមត្រូវបានពិភពលោកដឹងបណ្តើរៗថា ជាអ្នក«ប្រល័យពូជសាសន៍ឯង» និងបានប្រព្រឹត្តការរំលោភសិទ្ធមនុស្សខ្លាំងជាងគេបំផុតនៅសតវត្សទី២០ ។ ប៉ុន្តែ បញ្ហាវៀតណាមគ្រប់គ្រងកម្ពុជានៅតែជាបញ្ហាក្តៅគគុកក្នុងនយោបាយអន្តរជាតិ និងជាបញ្ហាដែលប្រជាជនខ្មែរទទួលរងគ្រោះយ៉ាងយូរដដែល ។ ការយល់ដឹងរបស់សាធារណជនត្រូវបានលើកកម្ពស់ដោយផ្អែកលើភស្តុតាងនៃការរំលោភសិទ្ធមនុស្សរបស់ខ្មែរក្រហម ។ ប៉ុន្តែ ទន្ទឹមនឹងនោះ គំនិតសាធារណជនក៏ត្រូវបាននាំទៅដល់ការតស៊ូ ដែលដឹកនាំដោយខ្មែរក្រហមដែរ ។

ពេញទសវត្សរ៍ឆ្នាំ៨០ កម្ពុជាត្រូវបានជាប់ជាចំណាប់ខ្មាំងនៃគំនិត ដែលមិនអាចបំបែកបានពីរនោះ ។

ទោះបីជាវៀតណាម និងរដ្ឋាភិបាលភ្នំពេញ ខិតខំប្រឹងប្រែងឲ្យគេអាណិតអាសូរ ចំពោះជំហរប្រឆាំងនឹងខ្មែរក្រហមក៏ដោយ ក៏នៅតែចាញ់កលយុទ្ធរបស់ក្រុមតស៊ូដដែល ។ ឃើញថាការយល់ដឹងពីទុក្ខវេទនារបស់ប្រជាជនខ្មែរក្រោមរបបខ្មែរក្រហមកាន់តែកើនឡើង ហើយទន្ទឹមនោះ ការប្រឈមមុខរបស់វៀតណាម និងរដ្ឋាភិបាលភ្នំពេញចំពោះក្រុមតស៊ូរួមទាំងខ្មែរក្រហមនោះក៏កាន់តែពិបាកឡើងដែរ ។

គឺពួកគេត្រូវប្រឈមមុខនឹងល្បែងមួយ ដែលដឹកនាំរឿងដោយចិន និងសម្តែងដោយសម្តេច ព្រះនរោត្តម សីហនុ ។ ក្រុមមិនមែនកុម្មុយនិស្ត និងក្រុមប្រឆាំងវៀតណាមក្រោមការដឹកនាំរបស់សម្តេច ព្រះនរោត្តម សីហនុ និង សឺន សាន បានសង្ឃឹមថា សហរដ្ឋអាមេរិកនឹងផ្តល់ជំនួយទ័ពដល់ពួកគេដើម្បីរំដោះកម្ពុជា ។ ប៉ុន្តែ អាមេរិកបានប្រាប់ពួកគេឲ្យទៅរកចិនទៅវិញ ។ ចិនជំរុញឲ្យពួកគេបង្កើតសម្ព័ន្ធភាពដ៏វិការមួយជាមួយខ្មែរក្រហម ដើម្បីប្តូរយកកាំភ្លើង និងគ្រាប់រំសេវ ។ នៅឆ្នាំ១៩៨២ សម្តេច ព្រះនរោត្តម សីហនុ បានយល់ព្រមនឹងការរៀបចំនោះ ហើយបានសន្យាថានឹងមិនធ្វើម្តងទៀតទេ ។ ទ្រង់បានសង្គ្រោះខ្មែរក្រហម និងសហគមន៍អន្តរជាតិ ដោយយល់ព្រមដឹកនាំសម្ព័ន្ធភាពមួយ ដែលរួមមានខ្មែរក្រហម និងចលនាតស៊ូមិនមែនកុម្មុយនិស្ត ។ ចំណែករណសិរ្សរំដោះប្រជាពលរដ្ឋខ្មែរត្រូវបានដឹកនាំដោយ សឺន សាន ។ រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ត្រូវបានសម្ពោធនៅទីក្រុងកូឡាឡាំពួរ នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៩៨២ ដោយ នរិជ្ជរិទ្ធ ។ នោះគឺជាដំណោះស្រាយនយោបាយដ៏ឥតខ្ចោះមួយ ។ ជៀសជាងដណ្តើមគ្នាធ្វើជាអ្នកតំណាងកម្ពុជា ក្រុមចលនាតស៊ូបានរួបរួមគ្នាប្រឆាំងនឹងការគ្រប់គ្រងរបស់វៀតណាម ។ ដោយទុកឈ្មោះកម្ពុជាប្រជាធិតេយ្យ និងគ្រាន់តែថែមខាងមុខថា ជារដ្ឋាភិបាលចម្រុះក្រុមថ្មីនោះ ត្រូវបានទទួលស្គាល់ដោយអង្គការសហប្រជាជាតិដោយពេញច្បាប់អន្តរជាតិ ។ គឺពួកគេលែងស្ថិតក្រោមការដឹកនាំរបស់ ប៉ុល ពត ទៀតហើយ តែស្ថិតក្រោមការដឹកនាំរបស់សម្តេច ព្រះនរោត្តម សីហនុ វិញ ។ ដូចបានយល់ព្រមនៅក្នុងអំឡុងសង្គ្រាម ឆ្នាំ៧០ សម្តេច ព្រះនរោត្តម សីហនុ បានអនុញ្ញាតឲ្យខ្មែរក្រហមពួនពីក្រោយឈ្មោះរដ្ឋាភិបាលនេះ និងកិត្តិស័ព្ទរបស់ទ្រង់ ។

ជាងនេះទៅទៀត គឺរដ្ឋាភិបាលចម្រុះអាចនិយាយបានថា គ្រោះថ្នាក់ដែលបណ្តាលពីខ្មែរក្រហម គឺជារឿងពីអតីតកាល ។ សព្វថ្ងៃ ពួកគេបានរួបរួមគ្នាជារដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ។ ហើយគ្រោះថ្នាក់ចំពោះមុខនៅពេលនោះ គឺការគ្រប់គ្រងរបស់វៀតណាមទៅវិញទេ ។

សម្ព័ន្ធភាពថ្មីនោះ គឺគ្រាន់តែឈ្មោះខាងក្រៅប៉ុណ្ណោះ ចំណែកការពិតពួកគេនៅតែជាក្រុមឈានមុខខ្មែរក្រហមដដែល ។ ក្រុមតស៊ូទាំងបី គឺនៅតែជាអង្គការបីដាច់ខ្នាដដែល ។ ទោះបីថា សម្តេច ព្រះនរោត្តម សីហនុ ជាប្រមុខរដ្ឋ ហើយ សឺន សាន ជានាយករដ្ឋមន្ត្រីក៏ដោយ ក៏អំណាចទ័ពនៅតែស្ថិតលើដៃខ្មែរក្រហមដូចមុន ។ ពួកគេថែមទាំងឈ្នះបានសិទ្ធិទុកអ្នកការទូតខ្មែរក្រហមនៅក្នុងតំណែងអន្តរជាតិទាំងអស់ តាំងពីតំណាងអចិន្ត្រៃយ៍របស់កម្ពុជា នៅអង្គការសហប្រជាជាតិ រហូតដល់អគ្គរដ្ឋទូតកម្ពុជាប្រចាំនៅយូនីស្កូ នៅទីក្រុងប៉ារីសទៀតផង ។

អ្នកដែលតវ៉ាខ្លាំងជាងគេគឺ សឺន សាន ដែលធ្លាប់តែជាជនឯករាជ្យពីយូរមកហើយ ។ ប៉ុន្តែ គាត់នៅតែស្ថិតក្រោមការគាបសង្កត់របស់ម្ចាស់ជំនួយគាត់គឺ សហរដ្ឋអាមេរិក និងប្រទេសនានានៅអាស៊ីអាគ្នេយ៍ ជាពិសេសគឺប្រទេសសិង្ហបុរី ។ ដូចពាក្យសន្យា ក្រុមទាំងបីនេះ បានទទួលជំនួយច្រើនជាងមុន ទាំងខាងអាវុធ និងជំនួយមនុស្សធម៌ ដើម្បីឲ្យពួកគេរក្សាជំរំរបស់ពួកគេនៅលើដីថៃ និងរំដោះកម្ពុជា ។ ដីនៅតាមព្រំប្រទល់ផុតពីខ្សែកាណុងរបស់វៀតណាម ។

សហរដ្ឋអាមេរិកបានផ្តល់ជំនួយដល់ក្រុមតស៊ូមិនមែនកុម្មុយនិស្តរបស់សម្តេច ព្រះនរោត្តម សីហនុ និងសឺន សាន ។ ទឹកប្រាក់ចំនួន ១៥លានដុល្លារក្នុងមួយឆ្នាំ ត្រូវបានផ្តល់ឲ្យតាមរយៈអង្គការអន្តរជាតិនានា ដូចជាប្រតិបត្តិការជួយតាមព្រំដែនរបស់អង្គការសហប្រជាជាតិ សមាគមកាកបាទក្រហមអន្តរជាតិ និងកម្មវិធីស្បៀងអាហារពិភពលោករបស់អង្គការសហប្រជាជាតិជាដើម ។ ប្រទេសអាស៊ានទាំងឡាយ បានផ្តល់នូវជំនួយខាងទ័ពក៏ដូចជាជំនួយមនុស្សធម៌ដែរ ហើយចិនក៏បន្តមើលការខុសត្រូវចំពោះតម្រូវការផ្នែកយោធារបស់ខ្មែរក្រហមបន្តទៀត ។

នៅរដូវក្តៅបន្ទាប់ ចាប់តាំងពីខែមករារហូតដល់ខែមេសា វៀតណាមបានឆ្លើយតបដោយការប្រឆាំងដ៏ខ្លាំងក្លាមួយ ។ ពួកគេបានកម្ទេចចោលនូវជំរំរបស់ក្រុមតស៊ូមិនមែនកុម្មុយនិស្តទាំងឡាយនៅ ណងចាន់ និងរិទ្ធិសែន បង្ខំឲ្យខ្មែរចំនួន៦០០០០នាក់ គេចខ្លួនទៅព្រំប្រទល់ថៃ ។ វៀតណាម ក៏បានការពារខ្សែត្រៀមរបស់ពួកគេនៅទិសខាងលិច ហើយព្រមទាំងវាយលុកដល់តំបន់តស៊ូនៅក្នុងប្រទេសថៃ ។ បន្ទាប់មក ទីក្រុងបាងកកលោកខាងលិច និងចិន បានធ្វើការព្រមាន និងតវ៉ាយ៉ាងខ្លាំងថា ពួកគេនឹងមិនឈរឡិបដៃមើលការវាតទីរបស់វៀតណាមឡើយ ។ ប៉ុន្តែវៀតណាម បានបញ្ជាក់ច្បាស់ពីទិសដៅរបស់គេថា "រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យថ្មីនេះ អាចឈ្នះសង្គ្រាមលើឆាកនយោបាយអន្តរជាតិបាន ប៉ុន្តែ ពួកគេនៅតែមិនអាចទទួលបានកម្ពុជាជារង្វាន់របស់គេជាដាច់ខាត ។

ក្នុងអំឡុងពេលជាមួយគ្នានោះ ចិនបានធ្វើការលុកលុយតូចមួយ ចូលក្នុងតំបន់ខាងជើងរបស់វៀតណាម ។ សកម្មភាពនោះ ធ្វើឡើងដើម្បីគ្រាន់តែចង់ឲ្យវៀតណាមដឹងថា នរណាជាអ្នកគាំទ្រក្រុមតស៊ូរបស់កម្ពុជាប៉ុណ្ណោះ ។

កិត្តិស័ព្ទរបស់រដ្ឋាភិបាលចម្រុះថ្មីនោះ បានគ្របដណ្តប់ការទូតគ្រប់ទីកន្លែង ។ ប្រទេសកម្ពុជា ជាចំណុចក្តៅគគុកនៃការពិភាក្សារបស់អង្គការសហប្រជាជាតិក្នុងអំឡុងទសវត្សរ៍ឆ្នាំ៨០ ។ លោកអគ្គរដ្ឋទូតរបស់សិង្ហបុរីគឺសូរី ម៉ាបូបានី ហៅកម្ពុជាថាជា រ៉ូលរ៉យ នៃកិច្ចការទូត ។ ប្រទេសអាស៊ានទាំងឡាយ បានក្លាយជាប្លុកសំខាន់ថ្មីមួយ ដែលឈរនៅលើទីតាំងសំខាន់មួយជុំវិញបញ្ហាសំខាន់ៗនៃសង្គ្រាមត្រជាក់ ។ ពួកគេបានប្រកាសថា ការគ្រប់គ្រងរបស់វៀតណាមនៅកម្ពុជា ជាការគំរាមកំហែងផ្ទាល់ដល់ប្រទេសជិតខាងដូចពួកគេជាដើម ។ ការផ្តើមគំនិតដើម្បីដោះស្រាយបញ្ហាកម្ពុជា មិនមែនត្រូវធ្វើឡើងដោយអង្គការសហប្រជាជាតិ ដែលរៀបចំសន្និបាត

ប្រចាំឆ្នាំស្តីពីកម្ពុជាប៉ុណ្ណោះទេ ។

សូម្បីតែប្រទេសអូស្ត្រាលី ជប៉ុន និងអ្នកនយោបាយមួយចំនួន ដូចជាសមាជិសភាអាមេរិកមួយរូបរបស់គណបក្សប្រជាធិបតេយ្យពីទីក្រុងញូវយ៉ក ឈ្មោះ ស្តេហ្វិន សូឡា ក៏ចូលរួមផ្តួចផ្តើមដែរ ។ មានការប្រជុំជាច្រើនបានកើតមានឡើង ហើយពត៌មានទាក់ទងនឹងកម្ពុជាក៏ចេញលើទំព័រកាសែតជាច្រើនដែរ ។ ប៉ុន្តែសកម្មភាពទាំងឡាយនោះ មានការផ្លាស់ប្តូរតែបន្តិចបន្តួចប៉ុណ្ណោះ ។

នៅក្នុងប្រទេសកម្ពុជាវិញ ការវិវឌ្ឍន៍មានទំហំតិចតួចបំផុត ។ វៀតណាមនៅតែបន្តការគ្រប់គ្រងលើរដ្ឋាភិបាលតាមរយៈជំនួយការរបស់គេ ។ វៀតណាមទទួលការខុសត្រូវដោយផ្ទាល់លើយោធា ដោយដាក់ទ័ពរបស់វៀតណាមធ្វើជាខ្សែការពារ ។ ចំណែកជំនួយខាងសេដ្ឋកិច្ចវិញវៀតណាម និងសម្ព័ន្ធមិត្តរបស់គេ មានតិចតួចណាស់ដែលអាចផ្តល់ឲ្យកម្ពុជា ។ ការបិទទ្វារសេដ្ឋកិច្ចបានផ្តាច់ដង្ហើមក្នុងការខំប្រឹងជួសជុល និងសង្គ្រោះប្រទេសឡើងវិញ ។ នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៨០ កម្ពុជាបានត្រូវគេទុកចោលពីក្រោយ ហើយអត្រារីកចម្រើនរបស់កម្ពុជាគឺមានត្រឹមតែពីរខ្ទង់ប៉ុណ្ណោះ ។ នៅពេលដែលប្រទេសថៃ សិង្ហបុរី ឥណ្ឌូណេស៊ី និងម៉ាឡេស៊ី កំពុងពង្រីក និងអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ពួកគេជាមួយនឹងបច្ចេកវិទ្យាទំនើប ហើយប្រព័ន្ធអប់រំរបស់ប្រទេសទាំងនោះកាន់តែប្រសើរឡើង ប្រទេសកម្ពុជាកំពុងស្ថិតនៅក្នុងយុគសម័យថ្មីនៅឡើយ ។ កម្ពុជារវល់ស្វះស្វែងរកគ្រាប់ធញ្ញជាតិឲ្យបានគ្រប់គ្រាន់ ដើម្បីចិញ្ចឹមប្រជាជនខ្លួនដែលភាគច្រើនជាស្ត្រីមេម៉ាយ និងកុមារ ។ សហគ្រាសចម្បងរបស់កម្ពុជា គឺការជីកអណ្តូង ធ្វើប្រព័ន្ធស្រែ និងបើកទីផ្សារ សាលា និងផ្ទះឲ្យមានដំណើរការដូចប្រក្រតីឡើងវិញ ។

រឿងរ៉ាវរបស់ខ្មែរក្រហម បានចាប់ផ្តើមជ្រាបចូលក្នុងសតិសាធារណជននៅឆ្នាំ១៩៨៤ នៅពេលដែលរឿង «វាលពិឃាត» បានចេញផ្សាយ ។ នោះជារឿងមួយដែលនិយាយអំពីសង្គ្រាមនៅកម្ពុជា និងបដិវត្តន៍ខ្មែរក្រហមតាមរយៈជីវិតរបស់អ្នកកាសែតខ្មែរម្នាក់ឈ្មោះ ឌិត ប្រន និងមិត្តភាពរបស់គាត់ជាមួយ អ្នករាយការណ៍ពត៌មានរបស់កាសែតញូវយ៉កថែមឈ្មោះ ស៊ីតនី ស្តាន់បឺក ។ ជាមួយការស្មោះត្រង់ចំពោះរឿងពិតមួយដែលគួរឲ្យកោតសសើរ, អ្នកផលិតកុន ដេវីដ ផុតមេន និង រូឡង់ ស្សូហ្វេ បានបកស្រាយនូវរឿងរ៉ាវដ៏ស្មុគស្មាញមួយ ដាក់ទៅក្នុងសោនាដកម្មរបស់បុគ្គលម្នាក់ ដើម្បីឲ្យងាយស្រួលយល់ ។ ក្នុងអំឡុងពេលតែប៉ុន្មានខែប៉ុណ្ណោះ រឿងវាលពិឃាត បានបោះកម្ពុជាពីសង្គ្រាមត្រជាក់ទៅក្នុងវប្បធម៌សាធារណៈមួយ ។ ខ្មែរក្រហមអាវខ្មៅ បានចូលជាមួយ ហ្វាស៊ីស អាវប្រផេះហើយត្រូវបានគេស្គាល់ថាជាតួអង្គអាក្រក់នៅសតវត្សទី២០នោះ ។ ពាក្យថា វាលពិឃាត បានក្លាយជាចំណែកមួយនៃពាក្យអាមេរិក ។

ក្រុមរិះគន់នយោបាយអាមេរិក មួយចំនួនតូចបានសង្ឃឹមថា ការទទួលស្គាល់រឿងរ៉ាវកាប់សម្លាប់របស់ខ្មែរក្រហមនឹងបង្ខំឲ្យរដ្ឋាភិបាលអាមេរិក កាត់ឈ្មោះខ្មែរក្រហមចេញពីបញ្ជីក្រុមតស៊ូសម្ព័ន្ធមិត្តរបស់អាមេរិក ។

ចំណែកមតិសាធារណៈ មិនបានយកចិត្តទុកដាក់នឹងនយោបាយដ៏ជ្រៅ និងស្មុគស្មាញពិបាកយល់នោះទេ ។ នៅឯសហរដ្ឋអាមេរិកវិញ ការស្អប់ខ្ពើមចំពោះអំពើព្រៃផ្សៃរបស់ខ្មែរក្រហម បានធ្វើឲ្យជនភៀសខ្លួនខ្មែរក្លាយជាករណីមួយដែលគេចាប់អារម្មណ៍ ។ ក្រុមសប្បុរសធម៌ បានរកចំណូលបានរាប់លានដើម្បីជួយពួកគេ ។ ចំណែកឯក្រុមអ្នកធ្វើច្បាប់វិញ បានយករឿងនោះដើម្បីជំរុញឲ្យវៀតណាមចេញពីកម្ពុជា ។

ស្តេហ្វេន សូឡា ដែលជាប្រធានអនុគណៈកម្មការការងារអាស៊ីប៉ាស៊ីហ្វិក បានទុករឿងកម្ពុជា ជារឿងផ្ទាល់ខ្លួនរបស់គាត់ ។ ក្នុងរបបខ្មែរក្រហមគាត់បានទាញការប្រៀបធៀបរវាងខ្មែរក្រហម និងរបបណាហ្ស៊ី ហើយបានជំរុញឲ្យមានការចូលធ្វើអន្តរាគមន៍ពេលនោះ ។ សម្តេច ព្រះនរោត្តម សីហនុ បានយល់ដឹងអំពីការចាប់អារម្មណ៍របស់ ស្តេហ្វេន លើបញ្ហាកម្ពុជា និងស្គាល់អំពីឥទ្ធិពលរបស់គាត់នៅវ៉ាស៊ីនតោន, ដូច្នេះក្រោយពីពេលទ្រង់ត្រូវបានដោះលែងនៅឆ្នាំ១៩៧៩ ទ្រង់ក៏បានបង្កើតចំណងមិត្តភាពជាមួយ សូឡា ។ ទ្រង់បានអញ្ជើញប្រុកគ្លីន ដេម៉ូក្រាត ទទួលទានអាហារពេលយប់ នៅឯអគ្គការសហប្រជាជាតិ ហើយក្រោយពេលមកទៀត ក៏បានរៀបចំពិធីខួបកំណើតឲ្យ នីណា ដែលជាភរិយារបស់ សូឡា នៅពេលដែលពួកគេទៅទស្សនកិច្ចនៅប៉េកាំង ។ ពេញចិត្តចំពោះការចាប់អារម្មណ៍ និងភាពប៉ិនប្រសប់ការទូតរបស់សម្តេច ព្រះនរោត្តម សីហនុ សូឡាក៏បានក្លាយជាដើងឯករបស់ទ្រង់ប្រចាំនៅវ៉ាស៊ីនតោន ។

នៅឆ្នាំ១៩៨៥ ដោយឡែកពីការជំរុញដែលមិនចាំបាច់របស់រដ្ឋាភិបាល រីហ្គេន សូឡា តែងបានជំរុញឲ្យមានជំនួយផ្នែកយោធាដោយចំហដល់ក្រុមតស៊ូមិនមែនកុម្មុយនិស្ត ។ នៅក្នុងការផ្តល់ចម្លើយនៅចំពោះមុខអនុគណៈកម្មការរបស់ សូឡា ប៉ូល ឌី វុលហ្វូវិត ដែលជាជំនួយការរដ្ឋលេខាធិការ ផ្នែកអាស៊ីបូព៌ាបាននិយាយថា ក្រុមអ្នកតស៊ូមិនមែនកុម្មុយនិស្ត មិនត្រូវការអាវុធបន្ថែមទៀតទេ "ដូចដែលយើងដឹងស្រាប់ថា ពួកគេអាចរកជំនួយបាន ហើយយើងក៏មិនចាប់បាច់ជំរុញពួកគេដែរ" ។

និយាយឲ្យស្រួលយល់គឺថា ប្រទេសអាស៊ាន និងចិនបានផ្តល់ដល់ក្រុមទាំងនោះ នូវអាវុធគ្រប់គ្រាន់ដែលពួកគេត្រូវការ ។ អ្វីដែលពួកគេខ្វះនោះ គឺភាពប៉ិនប្រសប់ក្នុងការប្រើអាវុធ និងការហ្វឹកហាត់ទ័ព ។ ពួកគេបានបាត់បង់នូវជំរំប៉ែកខាងលិចរបស់ពួកគេ ក្រោមការវាយលុករបស់វៀតណាម ហើយត្រូវជាប់មួងទៀតនៅត្រឹមតែតាមព្រំដែនថៃប៉ុណ្ណោះ ។ មូលហេតុធំនៃការបាត់បង់នោះ គឺមកពីការខ្វះជំនាញរបស់ពួកគេ ។ ដោយប្រឆាំងនឹងការជួយផ្នែកយោធា រដ្ឋាភិបាលរីហ្គេន បានមកដល់ការសន្និដ្ឋានមួយដូចពួកអ្នករិះគន់ផ្នែកមនុស្សធម៌ដែរ គឺថា សហរដ្ឋអាមេរិកគួរតែជំរុញឲ្យមានដំណោះស្រាយនយោបាយចំពោះរឿងនោះ ហើយមិនគួរចាក់សាំងលើភ្លើង ដែលកំពុងឆេះសន្ធោសន្ធៅ នៃការប្រយុទ្ធដោយអាវុធទេ ។

នៅទីបញ្ចប់ សូឡា បានឈ្នះដោយការសម្រុះសម្រួលមួយ ដោយបញ្ជូនជំនួយសង្គ្រោះដល់ក្រុមអ្នកតស៊ូ ។ កម្មវិធីនោះមានតម្លៃ ៣.៥លានដុល្លារដែលរួមបញ្ចូលទាំងឯកសណ្ឋាន និងភស្តុភា ។ សូឡា បាន

ឈ្នះលើរដ្ឋាភិបាល ហើយក្រោយមកលើសភាទៀត ដោយសំអាងលើការអះអាងថា មានក្រុមចលនាតស៊ូមិនមែនកុម្មុយនិស្តដ៏រឹងមាំមួយ ក៏ជាការធានារ៉ាប់រងមួយ ការពារមិនឲ្យមានការវិលត្រឡប់របស់ខ្មែរក្រហមដែរ ។ ការអះអាងនោះ ត្រូវបានចាញ់នៅសភាចំពោះមុខអ្នកជំនាញរបស់គណបក្សប្រជាធិបតេយ្យ និងលោក រីឆាដ៍ ហុលប្រ៊ូក អតីតជំនួយការរដ្ឋលេខាធិការ ។ លោក ហុលប្រ៊ូក បានអធិប្បាយចំពោះកម្មវិធីរបស់ សូឡា ថា «បើនិយាយចំពោះជនដែលជាប់ពាក់ព័ន្ធកម្មវិធីនេះ ឃើញថា ជាកម្មវិធីដែលមិនមានការទទួលខុសត្រូវទាល់តែសោះ ។ ហើយនៅក្នុងចិត្តរបស់ខ្ញុំទំនាក់ទំនងជាមួយខ្មែរក្រហម ជាសំណួរសម្បជញ្ញៈមួយដែលចាក់ជ្រៅបំផុត» ។

តែសម្ដីនោះមិនបានកែប្រែអ្វីសោះ ព្រោះថា នយោបាយផ្លូវការ នៅតែឈរពីក្រោយការគាំទ្រក្រុមតស៊ូសម្ព័ន្ធមិត្ត ដែលរួមមានទាំងខ្មែរក្រហមដដែល ។ សហរដ្ឋអាមេរិកនៅតែបន្តរារាំងនូវរាល់ការព្យាយាម ដើម្បីបង្កើតឲ្យមានតុលាការអន្តរជាតិមួយ ដើម្បីស៊ើបអង្កេត និងកាត់ទោសខ្មែរក្រហម ចំពោះឧក្រិដ្ឋកម្មសង្គ្រាមរបស់ពួកគេ ។ ហើយក៏ទប់ស្កាត់កុំឲ្យមានការប្រើពាក្យប្រល័យពូជសាសន៍ ដើម្បីពណ៌នាអំពីឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមដែរ ព្រោះថាសហរដ្ឋអាមេរិកខ្លាចថា រឿងទាំងនោះនឹងនាំទៅដល់ការដាក់ខ្មែរក្រហមឲ្យនៅក្រៅក្រុមសម្ព័ន្ធមិត្ត ។

ទីបំផុត កម្ពុជាត្រូវបានចងជាប់ឲ្យពាក់ព័ន្ធនឹងបញ្ហាស្មុគស្មាញ នៃរឿងទាហានអាមេរិកបាត់ខ្លួនក្នុងសង្គ្រាមវៀតណាម ។ បញ្ហារឿងអ្នកទោសសង្គ្រាមនិងទាហានបាត់ខ្លួនក្នុងបេសកកម្ម ដែលបានបង្អាក់ការផ្សះផ្សាទំនាក់ទំនងជាមួយវៀតណាម ក្នុងពេលប្រធានាធិបតី កាធ័រ កាន់តំណែងជាប្រធានាធិបតីនោះ ឥឡូវងើបឡើងវិញ ក្នុងពេលប្រធានាធិបតីរីហ្គេននៅក្នុងរដ្ឋាភិបាល ។

ដោយឡែក សាធារណជនអាមេរិក បានយល់អំពីរឿងរ៉ាវសង្គ្រាមនៅវៀតណាម តាមរយៈផ្លូវផ្សេងមួយ ។ នៅថ្ងៃបុណ្យយុទ្ធជនជើងចាស់នាឆ្នាំ១៩៨២ បូជនីយដ្ឋានសង្គ្រាមវៀតណាមមួយបានខិតសឡើង ដែលដឹកនាំដោយយុទ្ធជនជើងចាស់ជិះលើកៅអីរុញ ។ គ្មានវត្តមានរបស់ប្រធានាធិបតី រីហ្គេន នៅក្នុងពិធីនោះទេ ។ នោះគឺជាការចាប់ផ្ដើមទទួលស្គាល់នូវសេវារបស់ទាហានជើងចាស់ នៅវៀតណាមទាំងនោះ បន្ទាប់ពីត្រូវបានគេព្រងើយអស់រយៈពេលដ៏យូរ ។ ពីរឆ្នាំមុននេះ ទាហានជើងចាស់ពីសង្គ្រាមវៀតណាម បានមើលឃើញដោយរំភើប នូវការប្រារព្ធរបស់សាធារណជនអាមេរិក នូវការត្រឡប់វិញរបស់ចំណាប់ខ្មាំងជនជាតិ អាមេរិកចំនួន ៥២នាក់ ដែលត្រូវបានគេដោះលែងពីស្ថានទូតអាមេរិកប្រចាំនៅ តេអេរ៉ង់ ។ ដើម្បីអបអរចំពោះការត្រឡប់វិញនេះ នៅថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៨១ ទីក្រុងឈីកាហ្គោបានលែងប៉េងប៉ោងលឿងចំនួន ១០.០០០ ទៅលើអាកាស ។ នៅញូវយ៉ក មានការរៀបចំឡើងនូវពិធីដង្ហែដែលមានបដា និងការបោះក្រដាស ដើម្បីអបអរ ។ ឯនៅទីក្រុងឡូអង់ហ្សឺឡេស មានប្រារព្ធការអុជភ្លើងឡើងវិញ នៅស្តាតអូឡាំពិករបស់គេ ។ នៅពេលមួយសប្តាហ៍ក្រោយមក ដោយខឹងថាពួកគេមិនត្រូវបានគេផ្ដល់កិត្តិយស ដោយការដើរដង្ហែបែបជាតិ ដើម្បីទទួល

ស្វាគមន៍នោះ ពួកអ្នកទាហានជើងចាស់ពីសង្គ្រាមវៀតណាម ក៏បានរៀបចំដើរជាក្រុមមួយដោយខ្លួនឯង នៅអ៊ីនឌីយ៉ាណាផូលីស ហើយចលនាមួយក៏បានចាប់ផ្តើម ។ មានការបរិច្ចាគយ៉ាងច្រើនជូនដល់ក្រុមគេ ។ បូបី មៀលី នៃក្រុមទាហានវៀតណាមជើងចាស់របស់អាមេរិកបានមានប្រសាសន៍ថា «នេះគឺជាលើកទីមួយហើយដែលអាមេរិកផ្តល់ឱកាសដ៏រំភើបមួយ ដើម្បីចាត់ចែងចំពោះរឿងវៀតណាម» ។

នៅក្នុងការទទួលយកនូវបរិយាកាសថ្មីនេះ មូលនិធិដើម្បីបូជនីយដ្ឋានទាហានជើងចាស់វៀតណាមមួយក៏បានចាប់ផ្តើមកើតឡើងដោយ ជេនស្ក្រាក់ ដែលជាទាហានជើងចាស់មួយរូបដែលបានផ្តើមគំនិត ដើម្បីសង់បូជនីយដ្ឋានដោយចាប់ផ្តើមពីទឹកប្រាក់ចំនួន ២,៥០០ ដែលគាត់បានមកពីការលក់ដីផ្ទាល់ខ្លួនរបស់គាត់ នៅម៉ែរីលែន ។

បូជនីយដ្ឋាននេះ មានភាពអស្ចារ្យណាស់ គឺធ្វើឡើងពីជញ្ជាំងថ្មម៉ាបខ្មៅទាបពីរផ្ទាំងយ៉ាងសាមញ្ញ ដែលចាប់ផ្តើមដោយរាងអក្សរ «វ» ហើយបន្តអែបទៅក្នុងដីជាស្រមោលនៃបូជនីយដ្ឋានលីនកុន ។ ឈ្មោះទាហានដែលបានស្លាប់ ឬបាត់ខ្លួននៅក្នុងសង្គ្រាមវៀតណាមជាង ៥៧.០០០នាក់ បានត្រូវគេចារឆ្លាក់ទុកក្នុងថ្មម៉ាបដែលចាំងក្នុងផ្ទៃខ្មៅនោះ ។ ទាហានជើងចាស់ចំនួនជាង ១៥០.០០នាក់ បានជួបជុំគ្នានៅទីក្រុងវ៉ាស៊ីនតោននៅខែវិច្ឆិកា ឆ្នាំ១៩៨២ ដើម្បីធ្វើពិធីរំឭកដល់ជនដែលស្លាប់និងបាត់ខ្លួនទាំងនោះ ។ នៅពេលនោះមានមនុស្សស្រក់ទឹកភ្នែកយំដោយឃើញជញ្ជាំងនេះ ហើយក៏យកដៃស្ទាបឈ្មោះអ្នករួមអាវុធរបស់ខ្លួន ដែលចារនៅលើនោះ ។ បន្ទាប់ពីពេលនោះមក ជញ្ជាំងបូជនីយដ្ឋាន ដែលប្រជាជនអាមេរិកគោរពសក្ការៈនោះ បានក្លាយជាកន្លែងដែលមានអ្នកមកទស្សនកិច្ចច្រើនជាងគេនៅក្នុងទីក្រុងវ៉ាស៊ីនតោន ។ ផ្កា ការបងចាំ និងរូបថតរបស់ជនពលី ត្រូវបានគេទុកនៅតាមជើងជញ្ជាំង ។ មានអ្នកទស្សនាខ្លះបានធ្វើគំនូរនៃឈ្មោះចារឹកនោះ ដើម្បីទុកតាំងនៅផ្ទះរបស់ពួកគេទៀតផង ។

ក្រុមអ្នករិះគន់អភិរក្សមិនចូលចិត្តជញ្ជាំងនោះទេ ។ យុទ្ធជនជើងចាស់ដ៏មានកិត្តិនាមម្នាក់ឈ្មោះ ចេមវេប ជូញ៉័រ ដែលជាអ្នកនិពន្ធនៃប្រលោមលោកដ៏មានប្រជាប្រិយភាពមួយមានចំណងជើងថា «វាលភ្លើង» (Field of Fire) ហើយដែលលាចេញពីតំណែងគណៈកម្មការមូលនិធិនោះបានទាយថា បូជនីយដ្ឋាននេះ នឹងក្លាយជា«ជញ្ជាំងសំណាកមួយដើម្បីការធ្វើកូដកម្មប្រឆាំងនឹងសង្គ្រាម» ហើយឃើញថា គាត់មិនអាចមិនត្រូវជាងនេះទេ ព្រោះថាជាជាងដែលបូជនីយដ្ឋានបម្រើចំពោះគោលបំណងប្រឆាំងនឹងសង្គ្រាម បូជនីយដ្ឋាននោះ បានក្លាយជាទីតាំងរបស់ក្រុមអ្នកតវ៉ាដើម្បីអ្នកឈ្លើយសឹក និងជនបាត់ខ្លួនក្នុងសង្គ្រាម ដ៏មានឥទ្ធិពលមួយទៅវិញ ។ ចំណែកឯអ្នកសេរីនិយមម្នាក់ ដែលជាយុទ្ធជនជើងចាស់ក្នុងសង្គ្រាមវៀតណាមឈ្មោះ មូល័រ ដែលខំជំរុញឲ្យមានការសម្របសម្រួលទំនាក់ទំនងជាមួយវៀតណាម និងទុករឿងសង្គ្រាមក្នុងអតីតកាលនោះ បែរជាមិនអាចធ្វើអ្វីចេញទៅវិញ ។ ការប្រែប្រួលចំពោះការយល់ឃើញ ចំពោះយុទ្ធជនជើងចាស់ បានផ្តល់ប្រយោជន៍ដល់ក្រុមអ្នកតវ៉ា

ដើម្បីឈ្លើយសឹក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាមដាងគេ ។ ទង់ជ័យពណ៌ខ្មៅរបស់ពួកគេផ្សំជាមួយនឹងប្រវត្តិរបស់ក្រុមយុទ្ធជនជើងចាស់ បានចាប់ផ្តើមបក់រវិចនៅលើរដ្ឋធានីវ៉ាស៊ីនតោន ។ អ្នកនិពន្ធតាមតំបន់ ទាមទារឲ្យបង្កើនការទទួលខុសត្រូវចំពោះយុទ្ធជន ដែលបាត់ខ្លួនក្នុងសង្គ្រាម ។ សូម្បីតែខ្សែភាពយន្តក៏ជួយលើករឿងនេះដែរ ក្នុងនោះមានរឿងរ៉ាំបូជាដើម ។ រឿងនោះសម្តែងដោយ ស៊ីលវេសស្ទឺ ស្តាឡូន ដើរតួជាវីរបុរសជួយសង្គ្រោះអ្នកទោសជនជាតិអាមេរិកដែលនៅរស់ តែត្រូវគេបោះបង់ចោលនៅវៀតណាម ។ តួឯកស្រីមួយឈ្មោះថា ចេនហ្វុនដា ដែលបានធ្វើដំណើរទៅទីក្រុងហាណូយ ហើយផ្សាយដោយចំហពីការប្រឆាំងនឹងទ័ពរបស់ប្រទេសខ្លួនឯងនោះ បានបែរមកសុំអភ័យទោសពីសំណាក់យុទ្ធជនជើងចាស់អាមេរិកវិញ ។

អាមេរិកក្រោមការដឹកនាំរបស់ រីហ្គេន ក្រុមសីលធម៌ថ្មីមួយបានមកជំនួសអារម្មណ៍ចាស់ ដែលប្រឆាំងនឹងសង្គ្រាម ។ ដោយមិនបានវិភាគវែកញែកអំពីគុណសម្បត្តិនៃសង្គ្រាម សាធារណជនរបស់អាមេរិក បានស្ទុងយល់ថា សង្គ្រាមនោះ គឺជាកំហុសមួយ ។ ការស្លាប់ និងការបាត់ខ្លួនក្នុងសង្គ្រាម វៀតណាមត្រូវបានគេកែប្រែឲ្យទៅជាមូលហេតុនៃការល្បីល្បាញទៅវិញ ។ ជាប់នឹងសភាវគតិពីសម័យដើម សាធារណជនទទួលយកការលើកតម្កើងបញ្ហាឈ្លើយសឹក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម ជាឱកាសមួយដើម្បី ស្វែងរកកិត្តិយសពីប្រទេសរបស់ខ្លួន ដែលមាន សង្គ្រាមដ៏យូរអង្វែង និងការបរាជ័យក្រោមដៃជនបរទេសដ៏អាម៉ាស់នោះ ។

រដ្ឋាភិបាលរបស់រីហ្គេន បានសម្រេចថា វីរជនដែលទទួលមរណភាពទាំងនោះ ត្រូវតែទទួលបានការតំណាងនៅក្នុងអគ្គប្រជុំនយោបាយ ។ ដល់ឆ្នាំ១៩៨៣ ការជំរុញចំពោះឈ្លើយសឹក និងជនបាត់ខ្លួនក្នុងសង្គ្រាមបានក្លាយជាបញ្ហាចម្បងក្នុងយុទ្ធសាស្ត្រនៅឥណ្ឌូចិន ។ អានមៀល គ្រីហ្វីត នាយកក្រុមជាតិ នៃគ្រួសាររបស់ឈ្លើយសឹក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម បានត្រូវគេផ្តល់ឲ្យនូវការចាត់តាំងដោយសម្ងាត់បំផុតមួយ និងបានក្លាយទៅជាផ្នែកមួយនៃអ្នកជំនួការផ្ទៃក្នុងរបស់ក្រសួងការបរទេស និងមហាផ្ទៃ ព្រមទាំងក្រុមប្រឹក្សាសន្តិសុខជាតិ ដែលជាអ្នកកំណត់អំពីនយោបាយរបស់អាមេរិកចំពោះប្រទេសវៀតណាម និងកម្ពុជាផង ។ លោកស្រី គ្រីហ្វិន បានមានប្រសាសន៍ថា «យើងបាននិយាយច្បាស់ហើយថា នឹងមិនមានទំនាក់ទំនងជាន់ខ្ពស់រវាងអាមេរិក និងវៀតណាមទេ ប្រសិនបើគ្មានការយល់ព្រមពីគ្រួសាររបស់ឈ្លើយសឹក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម ។

សមត្ថភាពក្នុងការឆ្លើយតបរបស់វៀតណាម ចំពោះការទាមទាររបស់អាមេរិកនូវការទទួលខុសត្រូវចំពោះទាហានអាមេរិកបាត់ខ្លួន ត្រូវបានគេចងភ្ជាប់ទៅនឹងឥរិយាបថរបស់អាមេរិកមកលើវៀតណាម ចំពោះបញ្ហាគ្រប់គ្រងរបស់វៀតណាមនៅកម្ពុជា ។ សហរដ្ឋអាមេរិក បដិសេធមិនព្រមនិយាយរឿងរបស់កម្ពុជាជាមួយវៀតណាមទេ ទាល់តែវៀតណាមអាចបង្ហាញនូវការទទួលខុសត្រូវ ចំពោះរឿងទាហានអាមេរិកបាត់ខ្លួន ។ នោះគឺជាឱកាសមួយដែលពុំធ្លាប់មានពីមុនមក ដែលជនស៊ីវិលមួយក្រុមតូច អាចជះឥទ្ធិពលលើនយោបាយនៃសង្គ្រាមត្រជាក់ ។ ចំពោះរដ្ឋមន្ត្រីការបរទេសរបស់វៀតណាម ង្វៀន កូថាច់ នយោបាយរបស់អាមេរិក ជានយោបាយ

គំរាមកំហែងផ្នែកសតិអារម្មណ៍មួយ ហើយក៏ជាវិធីសាស្ត្រដ៏អាត្មានិយមមួយ ដើម្បីគេចវេះមិនផ្សះផ្សាទំនាក់ទំនងជាមួយវៀតណាម ។ វាក៏ជាវិធីដើម្បីបង្ខំឲ្យវៀតណាមចេញពីកម្ពុជា ដោយមិនទាំងសន្យាថានឹងការពារកម្ពុជាមិនឲ្យខ្មែរក្រហមចូលកម្ពុជាវិញផងទេ ។

ប៉ុន្តែទោះជាយ៉ាងនោះក៏ដោយ ក៏ ថាច់ នៅតែជួបជាមួយ គ្រីសហ៊ីន នៅអង្គការសហប្រជាជាតិនៅឆ្នាំ ១៩៨៣ ។ គាត់បានសាកល្បងពន្យល់ដល់ គ្រីសហ៊ីន ថា ជារឿងសឹងតែមិនអាចធ្វើបានមួយបើចង់ឲ្យរដ្ឋាភិបាលរបស់គាត់រកឃើញនូវសាកសព និងចំណុចល្អិតល្អន់អំពីសាកសពទាហានបាត់ខ្លួនរបស់អាមេរិកទាំងអស់ ។ វៀតណាម ដែលកំពុងតែមានវិបត្តិសេដ្ឋកិច្ចតាំងតែពីសង្គ្រាមចប់នោះ គ្មានលុយ ហើយក៏គ្មានជំនាញក្នុងការធ្វើប្រតិបត្តិការបែបនោះដែរ ។ អាមេរិកបានស្ម័គ្រចិត្តរ៉ាប់រងនូវបញ្ហាទាំងពីរនេះ ប៉ុន្តែ ថាច់ បានបកវិញថា ឋិតក្នុងជំហររបស់អាមេរិកក្នុងពេលនោះចំពោះបញ្ហាកម្ពុជា វៀតណាមមានការបារម្ភក្នុងការអនុញ្ញាតឲ្យអាមេរិកចូលក្នុងវៀតណាមដោយសេរីនោះ ។ សំណូមពររបស់ ថាច់ ដែលទាមទារក្នុងជំហរសហការ ដើម្បីផ្សះផ្សាទំនាក់ទំនងជាមួយគ្នាវិញនោះ មិនត្រូវបានគេយកមកស្ដាប់ទេ ។ ថាច់ ដែលជារដ្ឋបុរសកុម្មុយនិស្តដ៏ឈានមុខម្នាក់តាំងពីសម័យ ដូ អេនឡាយ បានភ្នាល់កិត្តិស័ព្ទរបស់គាត់ រវាងការផ្សះផ្សាទំនាក់ទំនងជាមួយអាមេរិក ជាងចិននោះ សឹងតែមិនជឿថា អាមេរិកនឹងបោះបង់ឱកាសនេះទេ ។

ផ្ទុយទៅវិញគ្រីហ៊ីនបាននិយាយនៅមុខសភានាឆ្នាំនោះថា អង្គការដើម្បីឈ្លើយសឹកនិងយុទ្ធជនបាត់ខ្លួន «មិនគិតថាអាមេរិកគួរធ្វើដំណើរឈានទៅមុខ ដើម្បីពង្រឹកនយោបាយ ដែលទាក់ទងដូចជាការផ្សះផ្សាទំនាក់ទំនងជាមួយនឹងវៀតណាមនោះទេ លើកលែងតែមានដំណោះស្រាយគួរជាទីពេញចិត្តមួយ ចំពោះបញ្ហាមនុស្សជាតិមួយកើតឡើង» ។

រហូតមកដល់ឆ្នាំ១៩៨៥ ប្រទេសមហាអំណាចនៅតែរឹងរូសមិនព្រមដើរចេញពីជម្លោះស្ដីពីបញ្ហាកម្ពុជា ដែលមិនអាចឈ្នះចាញ់ទេ ។ ចិន សហរដ្ឋអាមេរិក និងប្រទេសអាស៊ានទាំងឡាយ មិនព្រមទទួលស្គាល់ថា មានបញ្ហាអ្វីក្រៅពីការគ្រប់គ្រងរបស់វៀតណាមនៅកម្ពុជានោះឡើយ ។ សកម្មជន បានបន្តតវ៉ានៅវ៉ាស៊ីនតោន ទីក្រុងឡុងដ៍ និងទីក្រុងប៉ារីស ឲ្យមានដំណោះស្រាយកណ្ដាលមួយ ដែលអាចឲ្យមានការដកទ័ពវៀតណាមចេញពីកម្ពុជា និងឲ្យមានការកាត់ទោសខ្មែរក្រហម ប៉ុន្តែនៅតែពុំមានជោគជ័យសោះ ។ នៅទីបំផុត ការវិវឌ្ឍដ៏ធំមួយ មិនបានចេញមកពីប្រទេសលោកខាងលិចទេ តែបែរជាចេញមកពីខាងប្រទេសលោកខាងកើតទៅវិញ ។ នោះគឺការបោះឆ្នោតឲ្យ មីខាអ៊ីល ហ្គោបាឆូវ ជាប្រធានបក្សកុម្មុយនិស្តសូវៀត និងជាមេដឹកនាំថ្មីរបស់សហភាពសូវៀត ។

ពេលដែល ហ្គោបាឆូវ (Gorbachev) ទទួលយកអំណាចនៃបក្សកុម្មុយនិស្ត ប្រទេសសូវៀតទើបតែធ្លាក់ចូលក្នុងមហន្តរាយនយោបាយដ៏ធ្ងន់ធ្ងរមួយ ។ សូវៀតបានឈ្លានពានប្រទេសអាហ្គានីស្ថាន នៅឆ្នាំ១៩៧៩ ហើយបានចាប់ផ្ដើម ការគ្រប់គ្រងមួយរបស់សូវៀត ដែលត្រូវបានគេពិពណ៌នាថាជាសង្គ្រាមវៀតណាមរបស់សូវៀត ។

ប្រទេសក្រោមការគ្រប់គ្រងរបស់សូវៀតទាំងឡាយនៅអឺរ៉ុបខាងកើត បានចាប់ផ្តើមការប្រឆាំងនឹងសហភាពសូវៀត ។ ការប្រឆាំងដំបូងបង្អស់គឺចាប់ផ្តើមនៅឆ្នាំ១៩៨០ នៅរោងចក្រផលិតកប៉ាល់មួយឈ្មោះ Gdansk នៅប្រទេសប៉ូឡូញ ដឹកនាំដោយ ឡេច វ៉ាឡេសា ។ នៅឆ្នាំ១៩៨៣ ទ័ពជើងអាកាសរបស់សូវៀត បានបាញ់ទម្លាក់យន្តហោះ របស់កូរ៉េ-០០៧ មួយនៅពីលើកោះសាខាលីន ដែលសម្លាប់អស់ជនស៊ីវិលចំនួន២៦៩នាក់ ។ ជាងនោះទៅទៀត គឺសូវៀតមើលងាយចំពោះការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល រីហ្គេន ក្នុងការប្រណាំងប្រជែងខាងសព្វាវុធ ហើយបានធ្វើឲ្យសេដ្ឋកិច្ចសូវៀតរីងរៀខ្សោះអស់ ។ ដោយសារការចំណាយលើយោធាហួសហេតុ សេដ្ឋកិច្ចរបស់សូវៀតប្រហែលក្នុងអំឡុងឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨៥ មិនមានការលូតលាស់សោះ ។

ទើបតែអាយុ៥៤ឆ្នាំនៅពេលចូលកាន់អំណាច ហ្គោបាឆូវ បានធ្វើការវាយសម្រុកមកលើនយោបាយប្រទេសរបស់គាត់ ដោយបង្កើតនូវពាក្យស្លោកទាំងឡាយដែលសន្យានូវការកែប្រែនយោបាយរួមមាន (Glasnost) ការបើកចំហ (Perestroika) ការកែប្រែរចនាសម្ព័ន្ធ (Democratization) ប្រជាធិបតេយ្យភាព (New thinking) គំនិតថ្មីដែលផ្តល់សេរីភាពពេញលេញ ដើម្បីធ្វើឲ្យនយោបាយបរទេសរបស់សូវៀតបានរស់ឡើងវិញ ។

កិត្យានុភាពរបស់សូវៀតបានធ្លាក់ចុះបំផុត ជាពិសេស គឺទំនាក់ទំនងជាមួយចិននិងសហរដ្ឋអាមេរិក ។ នៅឆ្នាំ១៩៨៤ ទីភ្នាក់ងារពត៌មាន Tass បានផ្សាយថា ទំនាក់ទំនងរវាងសូវៀត និងសហរដ្ឋអាមេរិក បានធ្លាក់ចុះដល់កម្រិតមួយ ដែលមិនធ្លាប់មានពីមុនមកក្នុងប្រវត្តិសាស្ត្រសូវៀត ។ ចំណែកទំនាក់ទំនងជាមួយចិន គឺមានកម្រិតទាបដូចគ្នា ។ ជម្លោះពីបញ្ហាកម្ពុជាបានឆ្លុះបញ្ចាំងឲ្យឃើញពីការប្រយុទ្ធគ្នាជាបន្តបន្ទាប់ដោយផ្ទាល់ និងចំហអស់កាលជាង២០ឆ្នាំកន្លងមក ។

ហ្គោបាឆូវ បានកែប្រែសភាពការណ៍នោះយ៉ាងឆាប់រហ័ស ។ នៅឆ្នាំ១៩៨៩ គាត់បានបញ្ជូនគណៈប្រតិភូខាងពាណិជ្ជកម្មឲ្យទៅប្រទេសចិន ។ នោះជាសកម្មភាពដំបូង បន្ទាប់ពីពេលជាង២០ឆ្នាំកន្លងមក ។ នៅខែវិច្ឆិកានាឆ្នាំនោះ ការប្រជុំកំពូលមួយជាមួយលោកប្រធានាធិបតី រីហ្គេន នៅទីក្រុងហ្សឺណែវក៏បានបើកឡើង ។

ហ្គោបាឆូវ បានបែរទៅរកមិត្តរបស់គាត់ឲ្យជួយ ហើយបានតែងតាំងមិត្តរបស់គាត់ជារដ្ឋមន្ត្រីក្រសួងការបរទេស ទោះបីជាមិត្តគាត់ពុំធ្លាប់មានបទពិសោធន៍ខាងផ្នែកនេះក៏ដោយ ។ ជាបន្តមិត្តរបស់គាត់បានពឹង រ៉ូហ្កាឆូវ បន្តទៀត ដោយតែងតាំង រ៉ូហ្កាឆូវ ឲ្យទទួលបន្ទុកផ្នែកអាស៊ី ។ រឿងរ៉ាវក៏ចាប់ផ្តើមមានភាពប្រក្រតីវិញ ។ រ៉ូហ្កាឆូវ ឥឡូវទទួលខុសត្រូវការងារនៅអាស៊ី និងធ្វើការជាមួយរដ្ឋមន្ត្រីការបរទេស ។ ពួកគេដាក់ការពង្រឹងទំនាក់ទំនងនៅអាស៊ីជាចំណុចចម្បងនៃរបៀបវារៈរបស់សូវៀត ។

រ៉ូហ្កាឆូវ មិនដែលមើលត្រឡប់មកក្រោយវិញឡើយ ។

នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៨៦ រ៉ូហ្កាឆូវ បានធ្វើដំណើរទៅទីក្រុងកំពង់ផែរបស់សូវៀត នៅតាមជាយសមុទ្រប៉ាស៊ីហ្វិកឈ្មោះ វ្ល៉ាឌីវ៉ូស្តុក ដើម្បីរៀបចំគ្រោងពីយុទ្ធសាស្ត្ររបស់សូវៀតនៅអាស៊ី ។ គាត់បាននិយាយ

អំពីគ្រប់ចំណុចទាំងបីដែលចិនដាបញ្ហា ។ ដំបូងគាត់ថា សូវៀតនឹងសហការជាមួយចិន ដើម្បីកំណត់ឡើងវិញនូវព្រំប្រទល់របស់ពួកគេនៅតាមផ្លូវកប៉ាល់នៃទន្លេអាមួ ។ គាត់បានប្រកាសពីការដកកងវរសេនាធំចំនួនប្រាំចេញពីប្រទេសអាហ្គានីស្ថាន និងដកទ័ពចេញពីម៉ុងហ្គោលី ។ គាត់បានសន្យាដោះស្រាយរឿងនៅតំបន់អាស៊ីប៉ាស៊ីហ្វិក «ដោយផ្អែកលើការទទួលស្គាល់ និងយល់ដឹងអំពីការពិតជាក់ស្តែងដែលមានហើយ» ។

ចំពោះរឿងដ៏ស្មុគស្មាញជាងគេនៅកម្ពុជា គាត់បាននិយាយថានឹងពង្រឹងមិត្តភាពជាមួយ ប្រទេសទាំងអស់នៅអាស៊ីអាគ្នេយ៍ គឺមិនមែនត្រឹមតែជាមួយប្រទេសនៅឥណ្ឌូចិននិងប្រទេសចិនប៉ុណ្ណោះទេ ។ គាត់បាននិយាយពីការបាត់បង់ដ៏ធំធេងរបស់កម្ពុជា ហើយបន្តថា បញ្ហារបស់កម្ពុជាមិនអាចដោះស្រាយបាន «នៅទីក្រុងឆ្ងាយៗ ឬនៅអង្គការសហប្រជាជាតិឡើយ» ។

គាត់បាននិយាយថា «បញ្ហានៅទីនេះ ក៏ដូចជាបញ្ហាទាំងឡាយនៅអាស៊ីអាគ្នេយ៍ ដំណោះស្រាយភាគច្រើនគឺពឹងលផ្អែកលើការផ្សះផ្សាទំនាក់ទំនងចិន និងវៀតណាម» ។

ទោះបីជាសម្តីទាំងនោះ ប្រហែលជាគ្មានន័យចំពោះត្រចៀកអ្នកដទៃក៏ដោយ ប៉ុន្តែចំពោះត្រចៀកគាត់វិញវាជាកំណាព្យមួយ ។

រ៉ូហ្គាឆូវ បាននិយាយថា «យើងបានចម្លើយភ្លាមៗ និងវិជ្ជមានពីចិន ។ គេបានបង្ហាញឲ្យឃើញពីការរួសរាន់ក្នុងការជជែកអំពីបញ្ហាព្រំដែន» ។

ចំពោះ រ៉ូហ្គាឆូវ សុន្ទរកថានៅ វ្ល៉ាឌីវូស្តុក គឺជារូបភាពក្នុងកញ្ចក់មួយនៃការបើកទ្វាររបស់ និចសុន ឲ្យចិនកាលពីឆ្នាំ១៩៧២ ។ ដោយឥឡូវចិនស្ថិតនៅលើគេក្នុងបញ្ជីនោះដែរ រ៉ូហ្គាឆូវ គួរតែនៅតាំងពីយូរមកហើយ សេវ៉ាដណាដហ្សេ បានផ្តោតលើសំណួរជុំវិញអាហ្គានីស្ថាន និងកម្ពុជា ។

នៅខែតុលា រ៉ូហ្គាឆូវ បានទៅប៉េកាំងដើម្បីពិភាក្សាជាមួយចិន ។ ហើយនោះជាលើកទីមួយហើយដែលការពិភាក្សាមានភ្ជាប់ជាមួយនូវបញ្ហាកម្ពុជា ។

នៅរដូវផ្ការីកនាឆ្នាំបន្ទាប់ គាត់បានធ្វើដំណើរជាមួយរដ្ឋមន្ត្រីក្រសួងការបរទេសសេវ៉ាដណាដហ្សេ ទៅអាស៊ីអាគ្នេយ៍ដើម្បីបណ្តុះគ្រាប់នៃវិធានការថ្មីសន្ទាងរបស់ពួកគេ ដើម្បីដោះស្រាយបញ្ហាអាស៊ី ។ សេវ៉ាដណាដហ្សេ ជារដ្ឋមន្ត្រីការបរទេសទីមួយដែលបានធ្វើដំណើរទៅប្រទេសថៃ ដើម្បីពិភាក្សាអំពីរឿងកម្ពុជា ។ គាត់ក៏បន្តដំណើរ ទៅទីក្រុងកង់បែរ៉ា និងហ្សាកាតា ថែមទៀត ។

នៅថ្ងៃទី១០ និងទី១១ ខែមីនា រដ្ឋមន្ត្រីការបរទេសសូវៀតបានធ្វើដំណើរទៅក្រុងភ្នំពេញ ។ នៅទីនោះគាត់បានជួបជាមួយ ហ៊ុន សែន ។ ហ៊ុន សែន បានក្លាយជានាយករដ្ឋមន្ត្រី នៅថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៨៥ ហើយព្រមពេលជាមួយគ្នានោះ គាត់នៅកាន់តំណែងជារដ្ឋមន្ត្រីក្រសួងការបរទេសដដែល ។

រ៉ូហ្គាឆូវ បានចាក់ភ្ជាល់ចំសេះត្រូវ ។ ការទទួលខុសត្រូវចម្បងរបស់ ហ៊ុន សែន ដែលគាត់គ្មានបទពិសោធន៍

អ៊ីក្រៅពីនយោបាយស្លាប់រស់ និងរដិបរដុបរបស់បដិវត្តន៍កុម្មុយនិស្តកម្ពុជា បានក្លាយជាចំណុចខ្លាំងរបស់គាត់ ។ មានប្រជាជនកម្ពុជាតិចតួចណាស់ ដែលយល់ពីការពិតនៃនយោបាយរបស់ប្រទេសកម្ពុជា ឬមានទេពកោសល្យ និងការប្តេជ្ញាចិត្តគ្រប់គ្រាន់ដូច ហ៊ុន សែន នោះ ។ ដោយសារគាត់ចាប់ផ្តើមប្រឡូកក្នុងសង្គ្រាមបដិវត្តន៍ខ្មែរក្រហមតាំងពីវ័យក្មេង គាត់ពុំមានបញ្ហារឿងសុជីវធម៌ចំពោះមនុស្សដែលមានវ័យចំណាស់ជាងគាត់ឡើយ ។

អ៊ីដែលសំខាន់ជាងនោះទៅទៀត គឺពេលដែលគាត់គ្រប់គ្រងប្រទេសដែលពោរពេញដោយអ្នករួចផុតពីសេចក្តីស្លាប់ និងមនុស្សដែលធ្លាប់បានឆ្លងកាត់នូវសុបិនដ៏អាក្រក់ ហើយរួចចេញមកពោរពេញដោយស្លាកស្នាមដ៏ជូរចត់នោះ ហ៊ុន សែន មិនបានមើលខ្លួនឯងជាជនរងគ្រោះម្នាក់ឡើយ ។ គាត់ស្ថិតនៅខាងក្រុមអ្នកឈ្នះសង្គ្រាម ។ ហើយនៅពេលដែលមេដឹកនាំខ្មែរក្រហមដេញចាប់កម្មាភិបាល គាត់នៅភូមិភាគបូព៌ា គាត់បានគេចទៅវៀតណាម ។ ភាពមានជំនឿទុកចិត្តចំពោះខ្លួនឯងរបស់គាត់ មានទំហំធំធេងណាស់ ដែលធ្វើឲ្យគាត់មានគូប្រជែងតិច ។ នៅពេលដែល ហ៊ុន សែន ចង់បានអ្វីមួយគាត់ធ្វើឲ្យបានដោយគ្មានការអៀនប្រៀន ហើយជាទូទៅ គឺប្រកបដោយភាពមោះមុតក្នុងភាពជាយុវវ័យរបស់គាត់ ។

គាត់មានភាពប៉ិនប្រសប់ក្នុងការលាក់ទុកនូវមហិច្ឆតារបស់គាត់ ដោយប្រើមន្តស្នេហ៍ និងការដាក់ខ្លួនរបស់គាត់ ។ គាត់បាននិយាយពន្យល់ពីការលូតលាស់ដ៏ឆាប់រហ័សរបស់គាត់ នៅក្នុងការសម្ភាសន៍មួយថា "ខ្ញុំរៀនរហូត ហើយប្រសិនបើខ្ញុំគិតខ្ពស់ពេកចំពោះខ្លួនឯង ខ្ញុំប្រហែលជាធ្វើខុសច្រើនជាងនេះ ។ដូច្នេះខ្ញុំក៏រឹតតែខំប្រឹងឡើង" ។

ក្នុងការប្រជុំនៅខែមីនានោះ សេវ៉ាដណាដហ្សេ បានប្រាប់ ហ៊ុន សែន ថា សហភាពសូវៀតសង្ឃឹមថា នឹងអាចរៀបចំការប្រជុំមួយរវាង ហ៊ុន សែន និង សម្តេច ព្រះនរោត្តម សីហនុ ដើម្បីដោះស្រាយនូវជម្លោះដ៏រ៉ាំរ៉ៃរបស់កម្ពុជា ហើយនឹងធ្វើឲ្យមានការជួបដោយផ្ទាល់រវាងបុរសទាំងពីររូបនោះ ។ ហ៊ុន សែន មានការត្រេកអរយ៉ាងខ្លាំង ដោយការប្រជុំនោះ ដែលដាក់គាត់ឲ្យស្មើគ្នាជាមួយសម្តេច ព្រះនរោត្តម សីហនុ ។

ក្រោយមក រ៉ូហ្គាឆូវ បាននិយាយថា "យើងបានពន្យល់ដោយផ្អែកលើការផ្សះផ្សាជាតិ ដើម្បីដោះស្រាយបញ្ហាតំបន់ដែលមួយផ្នែកជាទ្រឹស្តី និងមួយផ្នែកទៀតជាការអនុវត្ត ។ ចំពោះកម្ពុជា នោះគឺជាការផ្សះផ្សារជាតិរវាងរដ្ឋាភិបាលភ្នំពេញ និង សម្តេច ព្រះនរោត្តម សីហនុ ។ ខ្មែរក្រហម គឺនៅឆ្ងាយពីភ្នំពេញពេកដើម្បីធ្វើការផ្សះផ្សា ហើយម៉្យាងទៀត យើងស្គាល់សម្តេច ព្រះនរោត្តម សីហនុ ច្បាស់ជាង" ។

នៅក្នុងសេចក្តីថ្លែងការណ៍រួមមួយបន្ទាប់ពីការប្រជុំ ភាគីទាំងពីរបានគាំទ្រការប្រឹងប្រែងចរចាជាមួយក្រុមកម្ពុជាប្រឆាំងនឹងក្រុមតស៊ូផ្តាច់ខ្លួនមិនមែនកុម្មុយនិស្តពីរក្រុម ។ ឆាកទីមួយនៃយុទ្ធនាការនោះ បានទទួល ជោគជ័យជាស្ថាពរ ។

ទិសដៅបន្ទាប់របស់ សេវ៉ាដណាដហ្សេ គឺហាណូយ ។ វៀតណាមរឹតតែបង្ហាញឲ្យឃើញពីការបើកចំហចំពោះការកែប្រែជាងកម្ពុជាទៅទៀត ។ បីខែមុននៅពាក់កណ្តាលខែធ្នូ បក្សកុម្មុយនិស្តវៀតណាមបានបញ្ឈប់

មេដឹកនាំបក្សជាន់ខ្ពស់បីរូប និងសមាជិកគណៈកម្មាធិការជាន់ខ្ពស់កុម្មុយនិស្តបីរូបទៀត ដែលជាក្រុមដឹកនាំនៅត្រាំត្រែងអស់ពេល៤០ឆ្នាំ ហើយបើកផ្លូវឲ្យអ្នកជំនាន់ក្រោយឡើងកាន់តំណែងម្តង ។ គេបានបង្វែរការចាប់អារម្មណ៍ទាំងស្រុង មកផ្តោតលើការកំណែទម្រង់សេដ្ឋកិច្ចវិញ ។ ង្វៀន វ៉ាន់ លិញ (Nguyen Van Linh) បានត្រូវគេឲ្យធ្វើជាមេដឹកនាំបក្សថ្មី ហើយគាត់ក៏បានដាក់នូវកម្មវិធីមួយឈ្មោះថ ដូម៉ឹយ ។ កម្មវិធីនោះជាការជួសជុលសេដ្ឋកិច្ចដែលរួមមានការជំនួសផែនការមជ្ឈិម ដោយសហគ្រាសឯកជនថ្មី និងទីផ្សារសេរី នឹងរំលាយចោលនូវកសិកម្មជាសហគមន៍ ។

នៅក្នុងសុន្ទរកថារបស់គាត់ក្នុងសភាព្រឹទ្ធាចារ្យរបស់គាត់ ទ្រឿងជិញ បានមានប្រសាសន៍ ទទួលស្គាល់ថា វៀតណាមបានធ្លាក់នៅក្នុងវិបត្តិសេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរមួយ ដែលត្រូវរាំងស្ទះដោយលទ្ធិកុម្មុយនិស្ត ។ គាត់បាននិយាយថា «យើងវិភាគដោយស្មោះ និងទទួលស្គាល់ដោយភាពក្លាហាននូវកំហុសធ្ងន់ធ្ងរ រ៉ាំរ៉ៃ ដែលកើតចេញមកពីគណៈកម្មាធិការមជ្ឈិមបក្ស ការិយាល័យនយោបាយ លេខាធិការបក្ស និងទីស្តីការរដ្ឋមន្ត្រី» ។

តាមការពិតទៅ ជីវភាពរបស់ប្រជាជន បានធ្លាក់ដល់កម្រិតក្រោមស្តង់ដារមុនពេលសង្គ្រាមទៅទៀត ។ ចំពោះសូវៀតវិញ ផែនការ ដូម៉ុយ ដែលអនុវត្តដើម្បីងើបចេញពីវិបត្តិសេដ្ឋកិច្ចនោះ គឺដូចគ្នានឹងផែនការ *Perestroika* របស់សូវៀតដែរ ។ ប៉ុន្តែដោយឡែកពីសូវៀត វៀតណាមមិនស្របនឹង *Glasnost* ដែលបើកចំហដល់សិទ្ធក្នុងការនិយាយស្តីដោយសេរី គំនិតសេរី និងការបង្កើតសមាគមឡើយ ។ ប៉ុន្តែវៀតណាមយកគំរូប្រហាក់ប្រហែលនឹងរូបនីយកម្មទាំងបួនរបស់ចិន ។ ប៉ុន្តែដរាបណាវៀតណាម នៅតែទទួលរងនូវការគាបសង្កត់ពីសំណាក់អន្តរជាតិដរាបនោះ គេមិនអាចទទួលបាននូវការវិនិយោគ និងចំណេះដឹងពីបរទេសដែលគេត្រូវការទេ ។

ចិនមានប្រភពទឹកប្រាក់ ហើយបើត្រូវការចាំបាច់មាននៅ ហុង កុង និងពីសំណាក់អណិកជនចិននៅបរទេស និងនៅអាស៊ីអាគ្នេយ៍ ។ ចំណែកវៀតណាមត្រូវស្វែងរកធនធាននៅកន្លែងផ្សេង ហើយដើម្បីធ្វើដូច្នោះ វៀតណាមត្រូវដោះស្រាយបញ្ហាកម្ពុជាសិន ។ ទោះបីមានការពង្រឹងទំនាក់ទំនងជាមួយលោកខាងលិច និងជាមួយចិនក៏ដោយ ក៏គេអាចងើបចេញឲ្យផុតពីវិបត្តិសេដ្ឋកិច្ច ដែលគេដឹកកប់ខ្លួនឯងបាន លុះត្រាតែគេអាចដោះស្រាយបញ្ហាចាកចេញពីកម្ពុជាសិនដែរ ។

នៅឆ្នាំ១៩៨៧ ការគ្រប់គ្រងរបស់វៀតណាមនៅកម្ពុជា ត្រូវបកប្រែជាសមយុទ្ធដើម្បីកម្ពុជា ។ សេវ៉ាដណាដហ្សេ មិនទុកឲ្យឱកាសនោះកន្លងទៅដោយឥតប្រយោជន៍ទេ ។

ក្នុងអំឡុងពេលទស្សនកិច្ចរបស់គាត់ សេវ៉ាដណាដហ្សេ បានបញ្ជាក់ឲ្យឃើញច្បាស់ថា សូវៀតចង់ឲ្យវៀតណាមបំបែករឿងកម្ពុជា ។ រ៉ូហ្គាឆូវ បាននិយាយថា «សេវ៉ាដណាដហ្សេ ធ្វើដំណើរទៅអាស៊ីអាគ្នេយ៍ភ្លាម បន្ទាប់ពីគាត់បញ្ចប់ទស្សនកិច្ចនៅអាហ្គានីស្ថាន» ។ រ៉ូហ្គាឆូវ ក៏បានរៀបរាប់ពីការប្រៀបធៀបរបស់ សេវ៉ាដណាដហ្សេ អំពីបទពិសោធន៍របស់សូវៀតនៅអាហ្គានីស្ថាន ទៅនឹងវៀតណាមនៅកម្ពុជា ។ សូវៀតបានដកចេញពីអាហ្គានី-

ស្ថាន និងបង្កើតឱកាសដល់ការផ្សះផ្សាជាតិដោយទ្រង់ទ្រាយធំ ។ សេវ៉ាដណាដហ្សេ បាននិយាយប្រាប់វៀតណាមដោយគាត់សង្ឃឹមថា វៀតណាមនឹងយល់ថា នោះជា"ទ្រឹស្តីលាយនឹងការអនុវត្តន៍"នៃលទ្ធិកុម្មុយនិស្ត ។

ផ្នែកចុងក្រោយជាផ្នែកមួយ ដែលវៀតណាមយល់ច្បាស់ ។ ទ័ពរបស់ពួកគេមិនអាចនៅកម្ពុជាតទៅទៀតបានទេ ។ សំណូមពររបស់ សេវ៉ាដណាដហ្សេ ដើម្បីរៀបចំការជួបប្រជុំរវាង សម្តេច ព្រះនរោត្តម សីហនុ និង ហ៊ុន សែន ជាដំបូង ត្រូវបានយល់ព្រមព្រោះតែការគួរសមប៉ុណ្ណោះ ។ នៅក្នុងពិធីជប់លៀងនៅថ្ងៃទី១២ ខែមីនា ដែលធ្វើឡើង ដើម្បីជាកិត្តិយសដល់ សេវ៉ាដណាដហ្សេ រដ្ឋមន្ត្រីក្រសួងការបរទេស ង្វៀង កូថាច់ បាននិយាយថាប្រទេសនៅឥណ្ឌូចិនទាំងបី ចង់ជួបជាមួយចិន និងប្រទេសអាស៊ានទាំងឡាយ ដើម្បីដោះស្រាយពីបញ្ហាកម្ពុជា ។

នៅផ្ទាល់ជាមួយសូវៀត វៀតណាមបាននិយាយថា គេមិនសូវចង់ឲ្យ ហ៊ុន សែន ជួបជាមួយសម្តេច ព្រះនរោត្តម សីហនុ ប៉ុន្មានទេ ដោយហេតុថា ខ្លាច ហ៊ុន សែន ទប់ទល់នឹងសម្តេច ព្រះនរោត្តម សីហនុ មិនបាន ។ រ៉ូហ្គាឆូវ ទទួលខុសត្រូវពន្យល់ឲ្យ វៀតណាមយល់ថា ហ៊ុន សែន អាចទប់ទល់បាន ។ រ៉ូហ្គាឆូវ បាននិយាយថា "ខ្ញុំទៅហាណូយ ហើយវៀតណាមមកម៉ូស្គូ ប៉ុន្តែ ការពន្យល់ឲ្យវៀតណាមយល់ព្រមឲ្យ ហ៊ុន សែន ទៅជួបប្រជុំជាមួយសម្តេច ព្រះនរោត្តម សីហនុ នោះ គឺជាការមួយលំបាកជាទីបំផុត ។ ទស្សនកិច្ចរបស់សេវ៉ាដណាដហ្សេ ជាចំណុចចាប់ផ្តើមនៃការខំប្រឹងប្រែងនេះ ។

ជាងនោះទៅទៀត ទស្សនកិច្ចរបស់ សេវ៉ាដណាដហ្សេ បានជួយឲ្យវៀតណាមផ្លាស់ប្តូរឥរិយាបថចំពោះកម្ពុជា ។ គ្រាន់តែ៩ថ្ងៃបន្ទាប់ពីសូវៀតបញ្ចប់ទស្សនកិច្ច នាយករដ្ឋមន្ត្រីវៀតណាមបានប្រកាសថា វៀតណាមនឹងដកទ័ពចេញទាំងស្រុងពីកម្ពុជានៅឆ្នាំ១៩៩០ ទោះបីជាកម្ពុជាមានសន្តិភាព ឬមិនមានក៏ដោយ ។ ការប្រែប្រួលទាំងស្រុងរបស់វៀតណាម បានធ្វើឲ្យសហរដ្ឋអាមេរិក និងចិន មានការសង្ស័យចំពោះភាពស្មោះត្រង់របស់វៀតណាម ។

រង្វាន់ទីមួយរបស់វៀតណាមគឺការអញ្ជើញមេដឹកនាំបក្សថ្មី ង្វៀន វ៉ាន់លិញ និងរដ្ឋមន្ត្រីការបរទេស ថាច់ ទៅទស្សនកិច្ចនៅម៉ូស្គូនៅដើមខែឧសភា ដើម្បីចរចាជាមួយ ហ្គោបាឆូវ ។ ហើយរឿងត្រូវបានបញ្ចប់ដោយការបើកសេដ្ឋកិច្ច និងការទូតថ្មី ។ ពួកគេបានចុះហត្ថលេខាលើកិច្ចព្រមព្រៀង ១៣ឆ្នាំ ដោយសូវៀតយល់ព្រមផ្តល់ជំនួយដល់វៀតណាម ក្នុងការផលិតសម្ភារៈឧស្សាហកម្មធុនស្រាល ។ កិច្ចព្រមព្រៀងនោះបាននាំទៅដល់ការនិយាយរបស់ លិញ ថា "យើងច្បាស់ថា ទំនាក់ទំនងរវាងវៀតណាម និងសូវៀត នឹងធ្វើជាគំរូដល់ទំនាក់ទំនងរវាងប្រទេសអភិវឌ្ឍន៍ផ្នែកឧស្សាហកម្ម និងប្រទេសដែលមានសេដ្ឋកិច្ចអន់ថយ" ។

ដើម្បីបញ្ជាក់ឲ្យឃើញច្បាស់អំពីភាពជាក់លាក់នៃជំហររបស់វៀតណាមថ្មី ចំពោះរឿងរបស់កម្ពុជា ហ្គោបាឆូវ ប្រកាសថា រឿងខ្មែរក្រហមអាចដាក់បញ្ចូលក្នុងការចរចាស្តីពីរឿងកម្ពុជា ។ ឥរិយាបថនោះ ជាវិធីមួយដើម្បីយកចិត្តចិន និងបើកផ្លូវដើម្បីសម្របសម្រួលទំនាក់ទំនងរវាងសូវៀតជាមួយចិន ដែលជាបំណងចម្បង

របស់ ហ្គោបាឆូវ ។

ហ៊ុន សែន បានត្រៀមខ្លួនរួចជាស្រេចចំពោះការស្នើសុំរបស់ សេវ៉ាដណាដហ្សេ ។ គាត់បានទទួលសញ្ញាជាមុនពីទូតដែលគាត់ចាត់តាំងទៅសូវៀត ស្តីពីការផ្លាស់ប្តូរនៃគំនិតរបស់សូវៀតចំពោះកម្ពុជា ។ នៅឆ្នាំ១៩៨២ ហ៊ុន សែន បានបញ្ជូន ហោ ណាំហុង ដែលជាអ្នកការទូតដ៏ប្រសប់សល់ពីជំនាន់សម្តេច ព្រះនរោត្តម សីហនុ ឲ្យទៅធ្វើជាឯកអគ្គរដ្ឋទូតនៅមូស្គូ ដែលជាកន្លែងដ៏សំខាន់មួយរបស់កម្ពុជាក្រៅពីហាណូយ ។ ពេលទៅដល់ភ្លាម ហោ ណាំហុង ត្រូវបាន រ៉ូហ្គាឆូវ ជួយយកអាសារ និងមើលខុសត្រូវ ។ ហោ ណាំហុង បាននិយាយថា "រ៉ូហ្គាឆូវជាមនុស្សសំខាន់បំផុតសម្រាប់ខ្ញុំ ។ ច្បាស់ហើយ ខ្ញុំនឹងមិននិយាយជាមួយគាត់ពីរឿងវៀតណាមគ្រប់គ្រងទេ ។ ដោយសារការទៅដល់ដោយផ្ទាល់របស់ រ៉ូហ្គាឆូវ និងការគាំទ្ររបស់គាត់ចំពោះខ្ញុំ បានប្រាប់ភ្នំពេញដោយផ្ទាល់មាត់ថា ឲ្យត្រៀមខ្លួនចំពោះការប្រែប្រួល ហើយការប្រែប្រួលនោះ នឹងមានទំហំធំដោយសារការគិតថ្មីរបស់ហ្គោបាឆូវ ។ នេះជារឿងដែលត្រូវនិយាយ ហើយ ហ៊ុន សែន ក៏គាត់ស្តាប់ ។ ខ្ញុំបានប្រាប់គាត់ថា ខ្ញុំបានសង្កេតឃើញពីការប្រែប្រួលរវាងទំនាក់ទំនងរវាងសូវៀត និងអឺរ៉ុបខាងកើត ហើយខ្ញុំដឹងថា ដោយសារតែយើងមិនសូវសំខាន់នោះ ខ្ញុំគិតថា យើងនឹងមានការប្រែប្រួលដែរ" ។

ដោយសារការគាំទ្រខ្លាំងពីសូវៀត ហ៊ុន សែន ក៏អាចបញ្ចុះបញ្ចូលឲ្យវៀតណាម និងរដ្ឋាភិបាលភ្នំពេញថា រដ្ឋាភិបាលទាំងពីរគួរយល់ព្រមឲ្យគាត់ជួបជាមួយសម្តេច ព្រះនរោត្តម សីហនុ ។ នៅថ្ងៃទី២២ ខែមេសា ដោយមានការអបអរ ខ្លះ ហ៊ុន សែន បានយាងអញ្ជើញសម្តេច ព្រះនរោត្តម សីហនុ ឲ្យជួបគាត់នៅទីក្រុងប៉ារីស, ស្តុកខូម ឬក៏ កង់ប៊ែរ៉ា ។

សម្តេច ព្រះនរោត្តម សីហនុ បានឆ្លើយថា ទេ! ។

ពីរបីសប្តាហ៍ក្រោយមក នៅថ្ងៃទី៧ ខែឧសភា សម្តេច ព្រះនរោត្តម សីហនុ បានលាលែងពីតំណែងជាប្រធានរដ្ឋាភិបាលចម្រុះ ដែលប្រឆាំងនឹងរដ្ឋាភិបាលភ្នំពេញអស់រយៈពេល១ឆ្នាំ ។ ពីប៉េកាំងមក ទ្រង់បានមានបន្ទូលថា ទ្រង់ធុញទ្រាន់នឹង "អំណាចផ្តាច់ការរបស់ខ្មែរក្រហម ដែលនៅតែប្រកាន់ខ្ជាប់នូវមាគ៌ាបែបអ៊ីត្លែរ និងស្តាលីន របស់លោក ប៉ុល ពត" ។ នៅពីក្រោយការបំផ្លើសនេះ គឺជាការតវ៉ាដ៏ស្របច្បាប់មួយថា ខ្មែរក្រហមវាយប្រយុទ្ធជាមួយក្រុមអ្នកគាំទ្ររបស់ទ្រង់នៅតាមព្រំដែនកម្ពុជាថៃ ។ នោះគឺមិនមែនជាលើកទីមួយទេ ប៉ុន្តែជាពេលដ៏ល្អមួយសម្រាប់ទ្រង់ ដើម្បីទ្រង់អាចផ្តាច់ខ្លួនពីរដ្ឋាភិបាលចម្រុះ ដើម្បីជួបជាមួយ ហ៊ុន សែន" ។

នៅមូស្គូវិញ រ៉ូហ្គាឆូវ បានចាប់ផ្តើមហៅឲ្យឯកអគ្គរដ្ឋទូតខ្មែរ ហោ ណាំហុង ចាប់ផ្តើមរៀបចំការប្រជុំដោយបានបញ្ជូនឲ្យគាត់ទៅប៉ារីស ។ ហោ ណាំហុង បាននិយាយថា ជាលទ្ធផលនៃការពិភាក្សារវាង រ៉ូហ្គាឆូវ និងក្លូដ ម៉ាតាំង "ខ្ញុំត្រូវបានបញ្ជូនទៅប៉ារីសដើម្បីរៀបចំការប្រជុំ" ។

អ្នកការទូតទាំងពីរបានជួបគ្នានៅមូស្គូ បន្ទាប់ពី រ៉ូហ្គាឆូវ ត្រឡប់ទៅពីភ្នំពេញវិញ ។ នៅតាមផ្លូវធ្វើដំណើរទៅ

គាល់សម្តេច ព្រះនរោត្តម សីហនុ , ម៉ាតាំង បានឈប់នៅមូស្គូ ដើម្បីជួបជាមួយ រ៉ូហ្កាឆូវ ហើយបានជជែកគ្នាយ៉ាងយូរ នៅក្នុងការិយាល័យរបស់ រ៉ូហ្កាឆូវ ។ «យើងជជែកពីទំនាក់ទំនងរវាងសម្តេច ព្រះនរោត្តម សីហនុ និងរដ្ឋាភិបាលភ្នំពេញ ។ ក្នុង ម៉ាតាំង បានប្រាប់ខ្ញុំពីសម្តេច ព្រះនរោត្តម សីហនុ យ៉ាងច្រើន ហើយខ្ញុំក៏បានប្រាប់គាត់ពីសារជាតិនៃរដ្ឋាភិបាលនៅភ្នំពេញ» ។

រ៉ូហ្កាឆូវ បាននិយាយថា «ប្រាកដហើយយើងបានរិះគន់ពីមិត្តរៀងៗខ្លួន ។ ប៉ុន្តែ យើងបានគិតពីការសន្ទនាដែលនឹងកើតមានរវាងសម្តេច ព្រះនរោត្តម សីហនុ និង ហ៊ុន សែន ដែរ» ។

ពេលនោះគឺជាចំណុចចាប់ផ្តើមនៃការចងសម្ព័ន្ធដោយប្រយោលមួយរវាង រ៉ូហ្កាឆូវ និង ម៉ាតាំង ។ ពួកគេមានចំណុចដូចគ្នាច្រើន ដូចជាចំណង់ចំណូលចិត្តចំពោះចិន ការប៉ងប្រាថ្នាចង់ឲ្យមានសន្តិភាពនៅប្រទេសកម្ពុជា និងវេទយិតភាពការទូតពីប្រទេសដែលជាប់ពាក់ព័ន្ធ ។ បន្តបន្ទាប់មក រ៉ូហ្កាឆូវ ក៏ហៅ ម៉ាតាំង ថាជាមិត្ត ឬក៏អាចជាមិត្តជិតស្និទ្ធផង ។

ចំណែកម៉ាតាំងវិញគាត់និយាយថា សម្តេច ព្រះនរោត្តម សីហនុ ចង់ជួបសន្ទនាជាមួយ ហ៊ុន សែន នៅរដូវស្លឹកឈើជ្រុះនាឆ្នាំ១៩៨៦ ។ ម៉ាតាំង បានត្រឡប់មកប៉ារីសវិញ ។ នៅប៉ារីសក្នុងតំណែងជាប្រធានខាងផ្នែកអាស៊ី នៃក្រសួងការបរទេស គាត់បានជួបជាមួយអគ្គរដ្ឋទូតសូវៀតនិងវៀតណាមដើម្បីពិភាក្សា ពីទស្សនៈរបស់ពួកគេ ។ បន្ទាប់មក គាត់បានជួយសម្តេច ព្រះនរោត្តម សីហនុ ដើម្បីរៀបចំទស្សនកិច្ចនៅប៉ារីសនាចុងឆ្នាំ ១៩៨៦ ប៉ុន្តែត្រូវបរាជ័យ ។

ម៉ាតាំង បាននិយាយថា «ខ្ញុំបានរៀបចំឲ្យទ្រង់ បានជួបអាហារពេលរាត្រីមួយជាមួយរដ្ឋមន្ត្រីការបរទេស ប៉ុន្តែបរិយាកាសមិនអំណោយផលចំពោះទ្រង់សោះ ។ ទ្រង់ចង់បោះទីតាំងនៅបារាំងហើយសួរថា តើបារាំងអាចជួយអ្វីទ្រង់បានខ្លះ?

យើញថាបារាំងជួយបានមិនច្រើនទេ ។ ទាល់តែនៅឆ្នាំបន្ទាប់ទៀតពេលដែលសូវៀតលូកដៃនោះ ម៉ាតាំង បានជួយបញ្ចុះបញ្ចូលឲ្យរដ្ឋាភិបាលបារាំង យល់ព្រមឲ្យសម្តេច ព្រះនរោត្តម សីហនុ តាំងនៅប៉ារីស ដើម្បីឲ្យទ្រង់អាចអញ្ជើញ ហ៊ុន សែនមកជួបនឹងទ្រង់នៅពេលទទួលទានអាហារថ្ងៃត្រង់ ។

កម្ពុជាបានត្រៀមខ្លួនរួចជាស្រេច ដើម្បីយកផលប្រយោជន៍នេះ ។ ប្រទេសនោះបានមានជីវិតឡើងវិញ ។ ការវាយលុករបស់វៀតណាមទៅលើខ្មែរក្រហមនៅតាមព្រំប្រទល់ថៃ បានបង្អាក់ការប្រយុទ្ធគ្នានៅតាមតំបន់ខាងលិចប្រទេសកម្ពុជា ។ ទោះបីជាអសន្តិសុខ និងការអាប់អួបានទាញឲ្យប្រទេសកម្ពុជាឋិតក្នុងភាពក្រីក្រក៏ដោយ ក៏រដ្ឋនាយទុន ភាពពុករលួយបានចាប់ផ្តើមចាក់ឫសនៅឯទីក្រុង ។ ពាណិជ្ជកម្មឯកជនរវាងវៀតណាម និងកម្ពុជាបានរីកលូតលាស់ ។ អ្នកពាណិជ្ជកម្មមកពីប្រទេសសិង្ហបុរី និងថៃ បានមើលរំលងនយោបាយពហិការរបស់ប្រទេសខ្លួន ហើយនាំចូលឥវ៉ាន់មកលក់នៅប្រទេសកម្ពុជា ។ មនុស្សម្នាចាប់ផ្តើមទទួល

មានឡើងវិញ ។ ភូមិគ្រឹះ និងអគារពាណិជ្ជកម្មនៅភ្នំពេញ ត្រូវបានចាប់ផ្ដើមជួសជុលជាថ្មី ។ រដ្ឋធានី បានចាប់ផ្ដើមមានសម្រស់បន្តិចម្ដងៗឡើងវិញ ។

ការអប់រំចាប់ផ្ដើមរស់រានមានជីវិតឡើងវិញក្រោមការជួយឧបត្ថម្ភរបស់សូវៀត និងអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិទាំងឡាយ ដែលបានជួយបំពេញនូវចន្លោះ ដែលប្រទេសពួកគេបានផ្ញើមកលើកម្ពុជា ។ អង្គការក្រៅរដ្ឋាភិបាលទាំងនោះ ដើរតួរនាទីដូចជាស្ថានទូតខ្នាតតូច ដោយផ្សាយនូវព័ត៌មានតាមពេលវេលា ធ្វើការជំរុញដល់រដ្ឋាភិបាលរបស់ខ្លួន និងផ្ដល់ជំនួយក៏ដូចជាជំនួយផ្នែកបច្ចេកទេស ក្នុងអំឡុងរយៈពេលឯកោក្នុងទសវត្សរ៍ឆ្នាំ៨០ ។

ទន្ទឹមនឹងនោះ ក៏មានអ្នកជួរផារ ដែលបានទ្រព្យពីទីផ្សារងងឹត ហើយមានរថយន្ត និងម៉ូតូល្អៗ ។ ភោជនីយដ្ឋាន ពោរពេញទៅដោយអ្នកជំនួញស្រីប្រុសធាត់ៗ ដែលទទួលទានឆ្ងាញ់ និងស្លៀកពាក់ស្អាតបាត ផ្ទុយស្រឡះពីប្រជាជនកម្ពុជាភាគច្រើន ។ នៅតាមជនបទ ការលូតលាស់មានល្បឿនយឺត បើមើលលើចំនួនផ្ទះ ដែលប្រក់ដំបូលថ្មី ឬប្រក់ស័ង្កសីថ្មី ដោយមិនគិតពីជំនួញថ្មី ឬក៏ការច្រូតកាត់ ដែលប្រសើរឡើងជាមុនឡើយ ។ នៅតាមភូមិខ្លះ អាចជីកអណ្ដូងបាន ហើយកសិករបានចិញ្ចឹមជ្រូកបន្ថែមលើសត្វចិញ្ចឹមរបស់គាត់ ដូចជា មាន់ ជាដើម ។ ជំនួនដ៏ល្អមួយ គឺការបង្កើតច្បាប់ថ្មី ដែលអនុញ្ញាតឲ្យគ្រួសារមានកម្មសិទ្ធិលើចម្ការរបស់ខ្លួន ហើយអាចយកចំណូលដែលបានមកពីពលកម្ម និងអ្វីៗដែលវិនិយោគទៅលើដីរបស់ខ្លួន ដើម្បីបង្កើនគុណភាពដីនោះ ។ ក្នុងឆ្នាំដដែល ហ៊ុន សែន បាននិយាយហើយនិយាយទៀតថា "ជាលើកទីមួយអស់រយៈពេល១០ឆ្នាំ ដែលយើងដាំដើមត្នោតឡើងវិញលើភ្លឺស្រែ" ។

នៅឆ្នាំ១៩៨៦ ប្រជាជនខ្មែរដែលរត់ភៀសខ្លួនចេញពីស្រុកនៅឆ្នាំ១៩៧៥ បានចាប់ផ្ដើមត្រឡប់មកលេងស្រុកវិញ ហើយរន្ធត់ចំពោះភាពក្រីក្រនៃប្រទេសរបស់ខ្លួន ។ គ្រួសារកសិករដែលនៅប្រទេសផ្សេងទៀតជាវណ្ណៈកណ្ដាលនោះ នៅទីនេះរស់នៅដោយពឹងផ្អែកមិនត្រឹមតែលើការប្រមូលផលពីស្រែស្រូវប៉ុណ្ណោះទេ ប៉ុន្តែបានយកទឹកត្នោតធ្វើស្ករ ដាំម្រេច និងល្ង ត្បាញក្រណាត់ពីអំបោះ និងសូត្រ ធ្វើធ្យូង រហូតដល់ធាក់ស៊ីក្លូនៅទីក្រុង ដើម្បីចិញ្ចឹមជីវភាពថែមទៀត ។

ជាងគេបំផុតនោះ គឺប្រទេសនេះហាក់ដូចជាផូស៊ីលនៅក្នុងត្បូងអាំប័រ ដែលរលាយបាត់ហើយ ព្រមពេលជាមួយនោះ គួរជាទីចាប់អារម្មណ៍ និងអាថ៌កំបាំង ដោយសារតែខ្វះភាពជឿនលឿន ។ ដោយការឃោសនាបំប៉ាកបែបកុម្មុយនិស្ត ដែលប្លែកចំពោះជនដែលនៅក្រៅពិភពនយោបាយ ឃើញថា ប្រទេសនេះ អាចប្រកបជីវភាពបានដោយផ្អែកលើកសិកម្ម ជាងដែលមានជីវភាពបែបទីក្រុងហើយដែលរវល់ ប្រញិបប្រញាប់ ដូចជានៅថៃ ម៉ាឡេស៊ី ឬសិង្ហបុរីដែរ ។ កំពង់ផែភ្នំពេញនៅតែពេញដោយទូកតូចៗ និងទូកនេសាទ ហើយគ្មានសណ្ឋាគារស៊ីម៉ងត៍ទំនើបឡើយ ។ ផ្លូវនៅក្នុងស្រុកពោរពេញទៅដោយរទេះគោ ហើយអគារដែលខ្ពស់ជាងគេ គឺវត្ត ។

ដោយរដ្ឋាភិបាលសព្វថ្ងៃអនុញ្ញាតឲ្យពុទ្ធសាសនារស់ឡើងវិញ វត្តភាគច្រើនកំពុងស្ថិតក្នុងការជួសជុល ។

ហ៊ុន សែន ជាអ្នកត្រួតពិនិត្យមើលលើការផ្លាស់ប្តូរទាំងអស់ ដែលធ្វើឲ្យគេគិតថាគាត់ជាមេដឹកនាំរបស់កម្ពុជា ។ នៅពេលដែលកម្ពុជាកំពុងតែជាទីចាប់អារម្មណ៍របស់អន្តរជាតិ អ្នកការទូតភាគច្រើន មើលរំលងប្រធានក្រុមប្រឹក្សារដ្ឋ ហេង សំរិន ដែលជាមេដឹកនាំតាមផ្លូវការ ហើយដែលធ្លាប់ជាថ្នាក់លើរបស់ ហ៊ុន សែន នៅភូមិភាគបូព៌ា កាលពីសម័យខ្មែរក្រហម ។ ហ៊ុន សែន មានសំណាងល្អក្នុងការប្រជែង ។ បើប្រៀបទៅនឹង ហេង សំរិន, ហ៊ុន សែន ជាអ្នកនយោបាយសកម្មនិងទាន់សម័យម្នាក់ ។ គាត់មិនបញ្ឈប់នូវទម្លាប់គ្រប់គ្រងដ៏ល្អិតល្អន់ និងតឹងរ៉ឹងដែលចាក់ឫសដ៏ជ្រៅរបស់គាត់ទេ ។ ហើយទម្លាប់នេះ ជាទម្លាប់ដែលជាលទ្ធផលនៃអាយុ និងដោយលទ្ធិកុម្មុយនិស្តរបស់គាត់ ។ ប៉ុន្តែខុសគ្នាត្រង់ថា ការយល់ឃើញរបស់គាត់ មិនសូវជាខុសការយល់ឃើញរបស់អ្នក ដែលមិនគិតពីភ័ស្តុតាង ឬហេតុផល ឬក៏គំនិតអ្នកដទៃសោះពេកឡើយ ។ ប្រសិនបើមាននរណាម្នាក់អាចជួយគាត់ឲ្យពង្រឹងអំណាចបាន គាត់នឹងឲ្យអ្នកនោះចូលក្រុមជាមួយ ដោយមិនប្រកាន់ថា ជននោះជាព្រះអង្គម្ចាស់ ជាកសិករ ជាអ្នកជំនួញ ឬក៏ជាទាហានឡើយ ។ ដូចអ្នកនយោបាយក្នុងស្រុកដទៃទៀតដែរ គាត់ចូលចិត្តធ្វើដំណើរជុំវិញប្រទេសដដែកលេងជាមួយកសិករ និងសម្ពោធទីលំនៅថ្មី ។ ទោះបីជាគាត់លាក់បាំងពីសញ្ញាដំបូងនៃអំពើពុករលួយ ដែលទទួលប្រាក់សំណូក និងអំណោយ ដើម្បីឲ្យរដ្ឋាភិបាលអនុញ្ញាត គាត់មិនដែលលាក់នូវការស្រឡាញ់ចូលចិត្តចំពោះជីវិតដែលប្រសើរឡើងនោះទេ ។ គាត់ជំរុញឲ្យប្រជាជនខ្មែររស់នៅបានប្រសើរ ហើយចេះទាញប្រយោជន៍ពីការបើកទ្វារប្រទេសឡើងវិញ ។

នៅលើឆាកអន្តរជាតិ ហ៊ុន សែន មានប្រៀបមួយទៀត ។ ខុសពីសម្តេច ព្រះនរោត្តម សីហនុ គាត់បានផ្តាច់ខ្លួនចេញពីខ្មែរក្រហមតាំងពីយូរមកហើយ ហើយខុសពីសម្តេច ព្រះនរោត្តម សីហនុ គាត់មិនដែលជាបុគ្គលសំខាន់នៅក្នុងបក្សរបស់ ប៉ុល ពត ឬក៏ក្នុងជួរទាហាន ឬរដ្ឋាភិបាលឡើយ ។ ប្រហែលជាគ្មានមេដឹកនាំខ្មែរក្រហមណាមួយធ្លាប់ឮឈ្មោះ ស្គាល់ ហ៊ុន សែន មុនពេលដែលគាត់ឡើងកាន់អំណាច ពេលដែលវៀតណាមចូលស្រុកផងទេ ។ ដោយហេតុនោះ គាត់អាចទាមទារចរចាតែជាមួយសម្តេច ព្រះនរោត្តម សីហនុ តែម្នាក់ប៉ុណ្ណោះ ។ គាត់បានឲ្យហេតុផលថា គាត់លះបង់អស់យ៉ាងច្រើន ទើបអាចការពារមិនឲ្យខ្មែរក្រហមត្រឡប់មកវិញ ដូច្នេះគាត់មិនចាំបាច់ជួបចរចាជាមួយពួកខ្មែរក្រហមទេ ។ វ៉ូហ្កានូវ បានសន្យាថា ខ្មែរក្រហមគង់តែនឹងត្រូវដាក់បញ្ចូលក្នុងការចរចាទេ ។ ប៉ុន្តែ ហ៊ុន សែន ចង់ឲ្យពួកគេ គ្មានវត្តមានសោះក្នុងការជួបពិភាក្សារវាងគាត់ និង សម្តេច ព្រះនរោត្តម សីហនុ ព្រោះថាខ្លាចពួកនោះឆ្លៀតឱកាសត្រឡប់មក កាន់អំណាចវិញ "ក្រោមសំពត់របស់សម្តេច ព្រះនរោត្តម សីហនុ" ។

ដើម្បីឲ្យពិភពលោកយល់ច្បាស់ពីជំហររបស់គាត់នៅកម្ពុជា ហ្គោបាឆូវ បានអញ្ជើញអ្នកកាសែតនាំមុខឥណ្ឌូនេស៊ីម្នាក់ឲ្យមកធ្វើកិច្ចសម្ភាសន៍ដ៏កម្រមួយនៅមូស្គូ នៅថ្ងៃទី២១ ខែកក្កដា ។ បន្ទាប់ពីបាននិយាយម្តងទៀត

នូវជំហររបស់គាត់ក្នុងការដកទ័ពពីអាហ្គានីស្ថាន ក្នុងរយៈពេលដ៏ខ្លី ហើយគាត់បានបន្តអធិប្បាយអំពីសញ្ញាដ៏ជាក់លាក់មួយនៃដំណោះស្រាយនៅកម្ពុជា ។

គាត់បាននិយាយថា «ថ្ងៃខែជាក់លាក់ក្នុងការដកទ័ពវៀតណាមចេញពីកម្ពុជាត្រូវបានកំណត់ ហើយយើងច្បាស់ថាការកំណត់នោះនឹងត្រូវគេគោរពនិងធ្វើតាម ។ ហើយសំខាន់ជាងនេះទៀតគឺ ទោះបីជាការផ្សះផ្សាជាតិមានដំណើរយឺតក៏ដោយ ប៉ុន្តែ ប្រាកដជានឹងកើតមានឡើង» ។

សន្ទុះនៃសង្គ្រាមត្រជាក់ត្រូវបានបំបែក ។ ឥឡូវគឺការប្រជែងថាតើប្រទេសណាដែលអាចធ្វើឲ្យ សម្តេច ព្រះនរោត្តម សីហនុ និង ហ៊ុន សែន នៅជាមួយគ្នាបាន ។ អ្នកការទូតធ្វើដំណើរជុំវិញពិភពលោក ដើម្បីចូលរួមចំណែកក្នុងព្រឹទ្ធការណ៍ប្រជុំជាប្រវត្តិសាស្ត្ររវាងសម្តេច ព្រះនរោត្តម សីហនុ និងនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលនឹងដោះស្រាយនូវអំពើហិង្សាជុំវិញបញ្ហាកម្ពុជា ។ អ្នកការទូត សេណោហ្គាល់ ដែលបានដឹកនាំអង្គសន្និបាតអន្តរជាតិអចិន្ត្រៃយ៍នៃអង្គការសហប្រជាជាតិស្តីពីកម្ពុជា បានធ្វើដំណើរទៅទីក្រុងបាងកក ដើម្បីរៀបចំការប្រជុំ ។ ពេលដែលបានជួបសម្តេច ព្រះនរោត្តម សីហនុ នៅទីនោះ អ្នកការទូតឥណ្ឌូនេស៊ី ក៏មានបំណងដូច សេណោហ្គាល់ ដែរ ។ អ្នកការទូតអូទ្រីសក៏បានធ្វើដំណើរទៅទីក្រុងព្យុងយ៉ាង ដើម្បីបញ្ចុះបញ្ចូលឲ្យសម្តេច ព្រះនរោត្តម សីហនុ ចូលរួមក្នុងកិច្ចសន្ទនាចតុភាគីជាមួយគ្រប់ក្រុមខ្មែរទាំងអស់ ។ ខាងឥណ្ឌូនេស៊ី ចង់ឲ្យព្រឹត្តិការណ៍នោះកើតមានឡើងនៅទីក្រុងហ្សាកាតា ហើយខាងអូទ្រីសគិតថា គួរតែជាទីក្រុងវៀតណាមវិញ ។

អ្នកការទូតជប៉ុនបានទៅហាណូយ ដើម្បីរៀបចំកិច្ចប្រជុំរវាងកម្ពុជា ក្រោមការឧបត្ថម្ភរបស់ជប៉ុន ។ ហើយនៅឯអង្គការសហប្រជាជាតិវិញ មេដឹកនាំក្រុមចលនាតស៊ូមិនមែនកុម្មុយនិស្ត សឺន សាន បានសាកល្បងបន្ទាក់កិច្ចប្រជុំរវាង ហ៊ុន សែន និង សម្តេច ព្រះនរោត្តម សីហនុ ដោយព្រមឲ្យរដ្ឋាភិបាលនៅភ្នំពេញ ក្លាយជាផ្នែកមួយនៃរដ្ឋាភិបាលចម្រុះ ។ នេះជាជំនួនមួយដ៏ចម្លែក ដែលមិនដែលបានទទួលនូវការឆ្លើយតបទាល់តែសោះ ។

នៅក្នុងការប្រណាំងប្រជែងនេះ អ្នកការទូត និងអ្នកនយោបាយទាំងខាងកើត និងខាងលិច បានមកដល់ការសន្និដ្ឋានរួមមួយគឺ «នោះជាឱកាសដ៏កម្រមួយដែលនៅចំពោះមុខពួកគេ» ។ ជំនាន់ដែលរស់នៅក្នុងសង្គ្រាមត្រជាក់ ឥឡូវអាចមើលឃើញឱកាសដើម្បីបញ្ចប់វា ។ នៅអាស៊ីសង្គ្រាមត្រជាក់ ត្រូវបានបង្រួមត្រឹមការសម្រុះសម្រួលសូវៀត និងចិនឲ្យស្រុះស្រួលគ្នា ដែលជាគន្លឹះអនុញ្ញាតឲ្យប្រទេសទាំងឡាយបើកទ្វារទំនាក់ទំនង និងនាំមកនូវទំនាក់ទំនងល្អរវាងប្រទេសនិងប្រទេស ហើយនាំទៅរកការឈានដល់ការបើកព្រំដែនលើកទី១ អស់ពេលដ៏យូរ ក្រោយពីពេលរបបអាណានិគមត្រូវបានបញ្ចប់ ។ ដើម្បីសម្រុះសម្រួលចិន និងសូវៀត ទ័ពវៀតណាម ត្រូវតែដកចេញពីប្រទេសកម្ពុជា និងការបញ្ចុះបញ្ចូលឲ្យខ្មែរឈប់វាយក្នុងចំណោមគ្នាឯង ដែលបានក្លាយជាកត្តាចម្បងនៃនយោបាយសង្គ្រាមត្រជាក់ ហើយគ្រប់គ្នាចង់មានចំណែកក្នុងនោះ ។

នៅក្នុងកិច្ចការទូតដែលមានលក្ខណៈដូចភ្លៀងបើកថ្ងៃនោះ អាមេរិក និងចិន សឹងតែគ្មានលូកដៃចូល

សោះ ។ ប្រទេសពីរដែលជាអ្នកកំណត់វិន័យសង្គ្រាមត្រជាក់កាលពី៨ឆ្នាំមុន ឥឡូវកំពុងនៅចាំត្រៀមខ្លួនរួចជាស្រេច ដើម្បីចេញប្រតិបត្តិការ ។ សហរដ្ឋអាមេរិកនិយាយថា គេដើរតាមប្រទេសទាំងឡាយនៅអាស៊ីអាគ្នេយ៍ បើនិយាយឲ្យចំ គឺគេមិនព្រមលូកដៃក្នុងរឿងនោះទេ ។ ឯចិនវិញកំពុងតថ្លៃចុះបន្ថែមពីវៀតណាម ។

បន្ទាប់ពីការប្រជុំពីរបីដងនៅវៀតណាមនិងបាងកក ប្រទេសទាំងឡាយនៅតំបន់ឥណ្ឌូចិន និងប្រទេសអាស៊ានបានសម្រេចថា ដល់ពេលវេលាដែលត្រូវពិភាក្សារឿងកម្ពុជាមិនមែនផ្លូវការ ដែលពួកគេនឹងហៅថា ជាការប្រជុំក្រៅផ្លូវការមួយ ឬហៅ JIM (Jakarta Informal Meeting) ។ នៅខែកញ្ញា រដ្ឋមន្ត្រីការបរទេសចិន បានជួបជាមួយ សេវ៉ាដណាដហេ្ស ពីរឿងកម្ពុជា ហើយក្នុងអំឡុងពេលតែមួយខែប៉ុណ្ណោះរដ្ឋទូតចិនប្រចាំនៅប្រទេសថៃបានប្រកាសថាប្រទេសរបស់គាត់បានយល់ព្រមចំពោះការជួបប្រជុំរវាងសម្តេច ព្រះនរោត្តម សីហនុ និង ហ៊ុន សែន ។

ការចរចាពិតប្រាកដត្រូវបានធ្វើឡើងនៅក្រៅការចំណាយការទូតជាសាធារណៈដ៏ថ្លៃ ។ ទោះបីនៅក្រោយឆាកក៏មានការចរចាពីរដំណាក់កាលដែរ ។ ដំណាក់កាលទីមួយគឺជាផ្លូវការទូតដ៏ចាំបាច់ ។ សម្តេច ព្រះនរោត្តម សីហនុ ធ្វើការជាមួយ ម៉ាតាំង និងពួកបារាំង ។ ហើយ ហ៊ុន សែន ធ្វើការតាមរយៈ រ៉ូហ្កាឆូវ និងសូវៀត ។ សម្តេច ព្រះនរោត្តម សីហនុ បានសម្រេចហើយថា កិច្ចប្រជុំនឹងធ្វើឡើងនៅប្រទេសបារាំង ហើយសង្ឃឹមថា ម៉ាតាំង នឹងរ៉ាប់រងខាងភស្តុភា និងទំនាក់ទំនងជាមួយសូវៀត និងវៀតណាម ។ ម៉ាតាំង បាននិយាយថា “នៅពេលដំបូង ដែល រ៉ូហ្កាឆូវ បានមកជួបយើង ដើម្បីពិភាក្សាពីសម្តេច ព្រះនរោត្តម សីហនុ ខ្ញុំបានប្រាប់គាត់ថា ខ្ញុំចង់ឲ្យសម្តេច ព្រះនរោត្តម សីហនុ ចេញពីចិន និងពីក្រោមស្រមោលរបស់ចិន មកប្រទេសដែលអត់មានចិន និងពីក្រោមស្រមោលរបស់ចិន មកប្រទេសដែលមានអព្យាក្រឹតភាព ដូចជាប្រទេសបារាំង ។

ចំណែកឯ រ៉ូហ្កាឆូវ វិញ មានសុទិដ្ឋិនិយមថា មិនមែនត្រឹមតែ ហ៊ុន សែន ប៉ុណ្ណោះទេ ដែលព្រមតាមសំណើរបស់គាត់ដោយឈរលើជំហរសាធារណៈ ដើម្បីផ្សះផ្សាជាតិ សូម្បីតែវៀតណាមក៏ព្រមសម្រុះសម្រួលជាមួយសម្តេច ព្រះនរោត្តម សីហនុ ដែរ ។ នោះគឺជាផ្លាស់ប្តូរមួយយ៉ាងខ្លាំងបន្ទាប់ពីប៉ុន្មានអាទិត្យមុន ដែល ហ៊ុន សែន និងវៀតណាម បានរិះគន់សម្តេច ព្រះនរោត្តម សីហនុ យ៉ាងខ្លាំង ហើយមិនជឿថា អាចមានដំណោះស្រាយសន្តិភាព ។

ហ៊ុន សែន បានស្នើឲ្យសូវៀតរៀបចំឲ្យគាត់ទៅប៉ារីស ។ ហើយនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៨៧ គាត់បានប្រកាសថា គាត់នឹងទៅជួបជាមួយសម្តេច ព្រះនរោត្តម សីហនុ នៅខែក្រោយ ដែលទុកពេលតិចជាងមួយខែដល់ថ្ងៃប្រជុំនៅថ្ងៃទី២ ខែធ្នូ ដើម្បីរៀបចំការប្រជុំនៅវិមានសណ្ឋាគារមួយនៅខេត្តនៃស្រាសំប៉ាញរបស់បារាំង នៅ ហ្វែរ អង់ តាឌឺន័រ (Fere-en-Tardenois) ។ រ៉ូហ្កាឆូវ បាននិយាយថា “យើងឲ្យយន្តហោះមួយដល់គាត់ ហើយបារាំងរ៉ាប់រងចំណាយគ្រប់យ៉ាងផ្សេងទៀត ដែលដូចជាការសហការមួយជាមួយបារាំងដែរ ។

ម៉ាតាំង នៅចាំបានថា សូវៀតធ្លាប់មានការព្រួយបារម្ភចំពោះព្រះទ័យឯករេរបស់សម្តេច ព្រះនរោត្តម

សីហនុ ហើយ រ៉ូហ្កានូវ បានបញ្ជូនអ្នកជំនួយការជាន់ខ្ពស់របស់គាត់ឲ្យទៅឃ្លាំមើលការជជែកនោះ ។ តាំងពីពេលនោះមក ម៉ាតាំង បាននិយាយថា «ទំនាក់ទំនងរបស់ខ្ញុំជាមួយសូវៀត មានសារសំខាន់ជាងទំនាក់ទំនងជាមួយវៀតណាមខ្លាំងណាស់» ។

ដោយសារថា គ្មានខ្សែច្បាស់គួរផ្ដាច់រវាងការផ្ទុយគ្នាពីទំនាក់ទំនងការទូត ក្រៅពីទំនាក់ទំនងក្រៅផ្លូវការសម្ដេច ព្រះនរោត្តម សីហនុ និង ហ៊ុន សែន ក៏មានទំនាក់ទំនងផ្ទាល់ខ្លួនដែរ ។ ដើម្បីធ្វើឲ្យឃើញថាអ្នកទាំងពីររៀបចំទាក់ទងគ្នាតាមផ្លូវការទូត ពួកគាត់បានសរសេរទាក់ទងគ្នាតាមរយៈទូរសារខ្លីៗ ហើយផ្ញើទៅផ្ទះរបស់ ហ្សង់ហ្សាក់ ហ្គាឡាប្រ៊ូ ។ ហ្សង់ហ្សាក់ ហ្គាឡាប្រ៊ូ ជាអតីតអ្នកការទូតបារាំង មានភរិយាខ្មែរ ឈ្មោះថា ខែក ដែលមានឪពុកមានទំនាក់ទំនង យូរអង្វែងជាមួយរាជវង្សខ្មែរ និងសម្ដេច ព្រះនរោត្តម សីហនុ ។

គ្រួសារហ្គាឡាប្រូ ជាជម្រើសពីកំណើតសម្រាប់ធ្វើការងារនេះ ។ លោកស្រី ហ្គាឡាប្រ៊ូ បានស្គាល់សម្ដេច ព្រះនរោត្តម សីហនុ ស្ទើរតែមួយជីវិតទៅហើយ ។ ឪពុករបស់គាត់ ប៉ុង ប៉េងចេង បានធ្វើការជាមួយសម្ដេច ព្រះនរោត្តម សីហនុ ដល់ឆ្នាំ ១៩៨២ ហើយផ្ដាច់ខ្លួនចេញ ព្រោះសម្ដេច ព្រះនរោត្តម សីហនុ ចូលរួមសម្ព័ន្ធជាមួយខ្មែរក្រហម ។ ខែក បានជួបជាមួយ ហ៊ុន សែន មួយឆ្នាំ ក្រោយពីនោះនៅពេលកិច្ចប្រជុំកំពូលនៃប្រទេសតតិយលោកនៅ អង់ហ្គោឡា នៅពេលដែលស្វាមីរបស់គាត់ធ្វើទូតនៅទីនោះ ។ ហ៊ុន សែន បានទៅរកគាត់ ហើយបានប្រាប់ពីរឿងរបស់ខ្លួន ដល់គាត់ និងស្វាមីរបស់គាត់ នៅក្នុងពេលជួបទទួលទានអាហារពេលយប់ដ៏វែងមួយ ។ ហ៊ុន សែន បានពន្យល់ឲ្យប្ដីប្រពន្ធគាត់ជឿថា «ហ៊ុន សែន មិនមែនជាអាយ៉ងរបស់វៀតណាមទេ ។ គាត់ជាអ្នកស្នេហាជាតិ ។ ខ្ញុំបានប្រាប់គាត់អ៊ីចឹងដែរ ហើយនិយាយមុនពេលមានការយល់ច្រឡំ» ។

ដល់ពេល សម្ដេច ព្រះនរោត្តម សីហនុ និង ហ៊ុន សែន បានសម្រេចចិត្តជួបគ្នា ហើយត្រូវការអ្នកទំនាក់ទំនងនៅប៉ារីសនោះ ខែក និងប្ដីរបស់គាត់បានទទួលសេចក្ដីទុកចិត្តពីបុរសទាំងពីរ ដើម្បីនាំសារទៅមករវាងបន្ទាយទាំងពីរ ។

ការផ្លាស់ប្ដូរសារមានលក្ខណៈគួរសម និងមានប្រសិទ្ធភាព ។ នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៨៧ មានសារមួយបានមកដល់ភូមិគ្រឹះរបស់ក្រុមគ្រួសារហ្គាឡាប្រូ ដែលនៅលេខ១៧៣ ផ្លូវហ្សង់ហ្ស ផ្ញើថ្វាយសម្ដេច ព្រះនរោត្តម សីហនុ ។ គឺជាសារមកពី ហ៊ុន សែន ទូលទ្រង់ថា គាត់ចង់ចូលគាល់ទ្រង់នៅពេលដែលទ្រង់សព្វព្រះទ័យ ។ ពីរថ្ងៃក្រោយមក សម្ដេច ព្រះនរោត្តម សីហនុ បានផ្ញើសារទៅ ហ៊ុន សែន នៅអាសយដ្ឋានដូចគ្នានោះ ដែលក្នុងសារមានអត្ថន័យថា «ដោយឆ្លើយតបទៅនឹងសាររបស់លោក ខ្ញុំមានកិត្តិយស អនុញ្ញាតឲ្យលោកចូលជួបខ្ញុំ នៅឯសណ្ឋាគាររបស់ខ្ញុំ នៅហ្វែរអង់តាឌឺន័រ នៅថ្ងៃដែលលោកអាចមកបាន ។ ដោយសេចក្ដីរាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។ សម្ដេច ព្រះនរោត្តម សីហនុ នៃកម្ពុជា ។

បន្ទាប់ពីការផ្លាស់ប្ដូរសារម្ដងទៀត ដោយការជួយនាំសាររបស់ហ្គាឡាប្រ៊ូ ថ្ងៃខែជួបមួយត្រូវបានកំណត់

ឡើង "ខ្ញុំមានកិត្តិយសសូមគោរពអញ្ជើញលោកមកចូលរួមការទទួលទានអាហារពេលព្រឹក ជាលក្ខណៈការងារមួយ នៅម៉ោង១០ ថ្ងៃពុធ ទី២ ខែធ្នូ ឆ្នាំ១៩៨៧ ឯសណ្ឋាគាររបស់ខ្ញុំ ឈ្មោះ "*the Hôltellerie du Château Fère-en-Tardenois*" ។ សូមអរគុណចំពោះការយល់ព្រមឲ្យថតទុកនូវការសន្ទនារបស់យើង ដើម្បីផ្សាយទាំងស្រុងជាសាធារណៈ ។ ពីសម្តេច ព្រះនរោត្តម សីហនុ នៃកម្ពុជា ។

មុនដល់ពេលអាហារពេលព្រឹក សណ្ឋាគារមានពោរពេញទៅដោយអ្នកកាសែត និងអ្នកការទូត ។ នៅឯកន្លែងទទួលភ្ញៀវរបស់សណ្ឋាគារ អ្នកកាន់កាមេរ៉ា បានប្រជ្រៀតគ្នាថតដោយដងមីក្រូហ្វូន ចាក់ប៉ះចង្កៀងត្រីស្តាល់ ។ ដោយសារការកក់ទុកមួយឆ្នាំមុននៃពិធីអាពាហ៍ពិពាហ៍មួយ ការជួបប្រជុំរបស់បុរសទាំងពីរ ត្រូវបានលើកពេល ។ ប៉ុន្តែទាំងនោះមិនបានធ្វើឲ្យ ហ៊ុន សែន មានការរំខានចិត្តក្នុងដំណើរដំបូងរបស់គាត់ទៅអឺរ៉ុប និងការជួបគាល់លើកទីមួយជាមួយសម្តេច ព្រះនរោត្តម សីហនុ ឡើយ ។ ស្នាមញញឹមរបស់គាត់ គឺរីកប្រិមប្រិយប្រហែលនឹងស្នាមញញឹមរបស់កូនកម្លោះកូនក្រមុំដែលរៀបអាពាហ៍ពិពាហ៍នៅពេលនោះដែរ ។

នៅថ្ងៃដំបូងបុរសទាំងពីរបានជួបប្រជុំអស់ជិត៧ម៉ោង ហើយបានឈានដល់គម្រោងសន្តិភាពមួយគឺ "ដំណោះស្រាយនយោបាយជាតម្រូវការមួយ រាល់គណបក្សនយោបាយកម្ពុជាទាំងអស់ ត្រូវចូលរួមក្នុងការចរចា ហើយនៅពេលដែលកម្ពុជាឈានដល់សន្ធិសញ្ញាមួយ សន្ធិសញ្ញានោះត្រូវតែអនុម័តនៅក្នុងសន្និបាតអន្តរជាតិមួយ ដែលធានានូវឯករាជ្យភាពនៃកម្ពុជា ។ មេដឹកនាំទាំងពីរបានសន្យាជួបគ្នាជាលើកទីពីរនៅខែមករា នាកន្លែងដដែល និងលើកទីបីនៅក្រុងរ៉េខាងជើង ។

នៅថ្ងៃទីពីរពួកគេបានជួបចរចាអស់រយៈពេលបីម៉ោង ជជែកអំពីជនភៀសខ្លួន ការជួសជុលប្រាសាទអង្គរ និងបញ្ហាសិទ្ធិមនុស្ស ។ នៅថ្ងៃទីបីពួកគេបានចុះហត្ថលេខា និងធ្វើការកំណត់សម្គាល់ដ៏ទូលាយមួយ ។ បន្ទាប់ពីបានប្រកាសថា "ទ្វារសន្តិភាពត្រូវបានបើកហើយនោះ" សម្តេច ព្រះនរោត្តម សីហនុ បានលើកយករឿង ដែលទុកឲ្យគ្រប់គ្នាគិតដោយខ្លួនឯងថា ខ្មែរអាចរកសន្តិភាពរវាងគ្នានឹងគ្នា ។ គាត់បានស្នើឲ្យចិន សហភាពសូវៀត និងវៀតណាមឈប់ឈ្លោះគ្នាពីក្រោយកម្ពុជា ហើយទ្រង់បានសន្យាថា នឹងត្រឡប់ទៅភ្នំពេញវិញ ដើម្បីដឹកនាំរដ្ឋាភិបាលទាំងបួនបក្សក្នុង"រដ្ឋកម្ពុជាថ្មីដែលមានរដ្ឋសភាបែបបារាំង និងមានឯករាជ្យភាព១០០ភាគរយ" ។

តាមរយៈអ្នកបកប្រែ ហ៊ុន សែន ហាក់ដូចជាប្រយ័ត្នប្រយែងនិងបារម្ភ ។ នៅថ្ងៃដំបូង គាត់បានទទួលថាគាត់ចាត់ទុក សម្តេច ព្រះនរោត្តម សីហនុ ដូចជា "គ្រូអាចារ្យនិងឪពុកម្នាក់" ហើយអធិប្បាយពីការជួបប្រទះរបស់ពួកគេជា "ទស្សនកិច្ចជាមិត្តភាពរវាងជនរួមជាតិ ដែលអាចនាំទៅដល់ដំណោះស្រាយដ៏ពិតប្រាកដមួយ" ។

ហ៊ុន សែន និយាយនៅពេលបញ្ចប់ថា "យើងបានធ្វើការហើយចេញជាលទ្ធផល" ។ រូបថតអធិប្បាយពីអារម្មណ៍នៅពេលនោះ ច្បាស់ជាងសេចក្តីបញ្ចប់របស់គាត់ ។ សម្តេច ព្រះនរោត្តម សីហនុ សក់ពណ៌ស ស្បែកភ្លឺថ្លា ក្នុងសម្លៀកបំពាក់សមសួនបានចាប់ដៃជាមួយ ហ៊ុន សែន ដែលមានស្បែកស្រអែមជាងព្រះអង្គច្រើន និងសក់

លាបប៉ូម៉ាត និងក្នុងសម្លៀកបំពាក់អាវធំភ្លឺចាំង ។ សម្តេច ព្រះនរោត្តម សីហនុ មានស្នាមញញឹមបែបក្សត្រ ហើយ ហ៊ុន សែន សើចបែបយុវជន ។

ទាំងនោះបានប្រព្រឹត្តឡើងនៅក្នុងសណ្ឋាគារផ្កាយបួន ដែលសង់នៅជាប់ប្រាសាទទ្រុឌទ្រោមបុរាណមួយ ។ សារត្រូវបានអានដោយអ្នកដូវការសំខាន់ៗ រួមមានរដ្ឋមន្ត្រីការបរទេសអាមេរិក ហ្សុកស៊ូល ដែលបង្ហាញពីក្តីសង្ឃឹមចំពោះការជជែកនោះ ។ ម៉ាតាំង នៅគ្រប់ទីកន្លែងត្រួតពិនិត្យពីលើការលម្អិតគ្រប់យ៉ាងទាំងអស់ ចាប់តាំងពីការរៀបចំឲ្យមានការថតសំឡេង ដែលសម្តេច ព្រះនរោត្តម សីហនុ ទាមទារ និងចំណាយលើគ្រប់វិក្កយប័ត្ររបស់សម្តេច ព្រះនរោត្តម សីហនុ និង ហ៊ុន សែន ។ "ប្រាកដណាស់ បារាំងនឹងចំណាយលើគ្រប់ទាំងអស់" ។

សារពត៌មានអន្តរជាតិបានប្រកាសពីជោគជ័យ ។ សូម្បីតែទ្រង់ រណឫទ្ធិ ជាបុត្រា សម្តេច ព្រះនរោត្តម សីហនុ ដែលមិន សប្បាយចិត្តជាមួយ ហ៊ុន សែន ក៏ទទួលស្គាល់ថាមានការព្រមព្រៀងរវាងទ័ពនៅភ្នំពេញ និងទ័ពតស៊ូដើម្បីឈានទៅរកការដាក់អាវុធ ។

រឿងរាវល្អរហូតដល់ថ្នាក់មិនចង់ជឿ ។

ដូចបានគិតទុកមុនក្នុងរយៈពេលតែប៉ុន្មានថ្ងៃប៉ុណ្ណោះ សម្តេច ព្រះនរោត្តម សីហនុ បានប្រែចិត្តហើយ លុបចោលនូវការ ជួបក្រោយទៀត ហើយក៏លើកទៅជួបនៅថ្ងៃទី២០ ខែមករា នៅឯសាំងហ្សែម៉ាំងដឺឡេ (St. Gemain-de-Laye) នៅជិតប៉ារីស ។ លើកនេះ សម្តេច ព្រះនរោត្តម សីហនុ គង់នៅសណ្ឋាគារដ៏ប្រណីតមួយឈ្មោះ ប៉ាវីយុង ហេនរី ទី៤ (Pavillion Henri IV) ដែលជាកន្លែងប្រជុំ ។ ទ្រង់ទាមទារឲ្យ ហ៊ុន សែន នៅកន្លែងផ្សេងទៀត ។ សម្តេច ព្រះនរោត្តម សីហនុ ចាប់ផ្តើមមិនសប្បាយ ព្រះទ័យចំពោះជោគជ័យរបស់ ហ៊ុន សែន ។ បន្ទាប់ពីរយៈពេលពីរថ្ងៃនៃការប្រជុំ ហ៊ុន សែន មានសុទិដ្ឋិនិយមថា "យើងមានការឈានទៅមុខយ៉ាងច្រើន" ។

មេដឹកនាំទាំងពីររូប បានយល់ស្របជាគោលការណ៍ចំពោះការដកទ័ពវៀតណាមទាំងស្រុង ចេញពីកម្ពុជា ការបង្កើតរដ្ឋាភិបាលចម្រុះ និងការបោះឆ្នោតក្រោមការគ្រប់គ្រងរបស់អន្តរជាតិ ។ ប៉ុន្តែ ពួកគេនៅមិនទាន់ស្រុះស្រួលគ្នាចំពោះចំណុចលម្អិតនៃគម្រោងទាំងនោះ និងមិនទាន់ចេញសេចក្តីថ្លែងការណ៍នៅឡើយ ។

ចំពោះការជជែកគ្នារឿងនេះ រណរិទ្ធ ដែលមានចរិតដូចបិតា និងមានរូបរាងដូចបិតារបស់ទ្រង់បេះបិទនោះ បានចេញមុខជជែកច្រើនអំពីរឿងនោះ ។ ទ្រង់នឹងឈររៀបឬកនៅតាមផ្លូវដណ្តើរធំ ដើម្បីផ្តល់បទសម្ភាសន៍ជាមួយអ្នកកាសែត អំពីការជជែកដ៏តានតឹងរវាងបិតារបស់ទ្រង់ និង ហ៊ុន សែន ។ ទ្រង់បានប្រឈមជាមួយអ្នកកាសែតដោយប្រើទាំងភាសាអង់គ្លេស និងបារាំង និងប្រកបដោយលក្ខណៈច្រឡោត ដែលទ្រង់បានស្នង ឬចម្លងចេញពីបិតារបស់ទ្រង់មក ។

កាន់តែខំប្រឹងធ្វើឲ្យដូចបិតារបស់ទ្រង់ ចំណុចខុសគ្នារវាងទ្រង់ និងបិតាក៏កាន់តែមើលឃើញច្បាស់ឡើងដែរ ។ រណឫទ្ធិ ចេញពីប្រទេសនៅពេលដែលទ្រង់មានព្រះជន្មាយុប្រហែល ម្ភៃព្រះវស្សា ហើយបានក្លាយជា

សាស្ត្រាចារ្យមួយរូបនៅប្រទេសបារាំង ដោយគ្មានបទពិសោធន៍នយោបាយ ក្នុងស្រុករបស់ទ្រង់ទាល់តែសោះ ។ ទ្រង់ក៏បាននៅក្រៅប្រទេសតាំងពីពេលនោះមក ។ ដាងនេះទៅទៀត សម្តេច ព្រះនរោត្តម សីហនុ បានទុកមាតារបស់ទ្រង់ចោល ហើយបែរមករកអ្នកម្នាង ម៉ូនីក វិញ ។ អ្នកម្នាង ម៉ូនីក មានការសង្ស័យលើរូបទ្រង់ ហើយចង់ឲ្យបុត្របង្កើតរបស់ទ្រង់ដែលជាអ្នករាំរបាំឡើងស្នងរាជ្យជំនួសសម្តេច ព្រះនរោត្តម សីហនុជាង ។

នៅពេលដែល ហ៊ុន សែន ហៅសម្តេច ព្រះនរោត្តម សីហនុថា ជាបិតារបស់គាត់នោះក៏មិនខុសដែរ ព្រោះថាគាត់ជាកូនក្នុងនយោបាយរបស់ទ្រង់ ដោយមានលក្ខណៈដូចគ្នាត្រង់ថាមានមហិច្ឆតាធំធេង ប្រកបដោយស្នេហ៍មុខ និងមានសមត្ថភាពមោះមុត ។ ចំណែកឯ រណឫទ្ធិ វិញ ជាកូនក្នុងរាជវង្សរបស់ទ្រង់ ។ នៅក្នុងការប្រណាំងប្រជែង រណឫទ្ធិ ចាប់ផ្តើមធ្វើឲ្យគេធុញទ្រាន់នឹងទ្រង់ ។ សូម្បីតែម៉ាតាំងដែលជាសម្ព័ន្ធមិត្តរបស់ រណឫទ្ធិ នោះ ក៏ព្រួគាត់រអ៊ូថា «រណឫទ្ធិ ចូលចិត្ត ធ្វើឲ្យរឿងស្មុគស្មាញ ។ មានពេលមួយ ទ្រង់បានមករកខ្ញុំ ហើយនិយាយថា បិតារបស់ទ្រង់ ទន់ជ្រាយណាស់ ហើយទ្រង់សន្យាថា នឹងធ្វើខ្លួនឲ្យរឹងមាំជាងបិតារបស់ទ្រង់ ។

តាមការស៊ើបអង្កេត ម៉ាតាំង ឃើញថាភាពរឹងមាំ ដែល រណឫទ្ធិ សំដៅដល់នោះ គឺការចងសម្ព័ន្ធមិត្តជាមួយខ្មែរក្រហម ។ ហើយនោះជារឿងមួយដែលបារាំងមិនចង់ឲ្យមាន ។

ម៉ាតាំង បាននិយាយថា «ល្បែងរបស់យើង គឺបញ្ចុះបញ្ចូលឲ្យ សម្តេច ព្រះនរោត្តម សីហនុ ឈរលើជំហរអព្យាក្រឹតភាព ដោយឈរនៅកណ្តាលហើយគ្មានទំនាក់ទំនងជាមួយក្រុមចលនាតស៊ូ ។ ទ្រង់មិនអាចនៅក្នុងចលនាតស៊ូទេ ប្រសិនបើទ្រង់ធ្វើជាបិតាជាតិ ។

ប៉ុន្តែ រណឫទ្ធិ ប្រកែកជំទាស់គ្នាពីគំនិតនោះ ។ ហើយនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៨៨ សម្តេច ព្រះនរោត្តម សីហនុ បានត្រឡប់មកធ្វើជាប្រធាននៃក្រុមតស៊ូវិញ ។ ម៉ាតាំង បាននិយាយដោយចាញ់ការប្រកែកថា «បន្តិចម្តងៗ រណឫទ្ធិ បញ្ចុះបញ្ចូលទ្រង់បាន» ។ សម្តេច ព្រះនរោត្តម សីហនុ បានចាកចេញពីប្រទេសបារាំង ហើយត្រឡប់ទៅប្រទេសចិនវិញ ។

រដ្ឋមន្ត្រីការបរទេសចិនថ្មី គៀន គីចេន ហាក់ដូចជាមានការពេញចិត្តយ៉ាងខ្លាំង ដែលសម្តេច ព្រះនរោត្តម សីហនុ ត្រឡប់មករស់នៅដំណាក់ដ៏ធំនៅប៉េកាំងវិញ ។ តាមការពិតទៅ គៀន គីចេន បានព្រមានសហភាពសូវៀតឲ្យ «ឈប់គាំទ្រវៀតណាមក្នុងការឈ្លានពានកម្ពុជា ហើយជំរុញឲ្យវៀតណាមដកទ័ពទាំងអស់ចេញពីកម្ពុជា» ។ ដែលជាការតវ៉ាមួយហួសហេតុ បន្ទាប់ពីវៀតណាម និងសូវៀត បានចុះសន្ធិសញ្ញាមិត្តភាពក្នុងពេលថ្មីៗនេះ ។

ចំពោះ វ៉ូហ្គាឆ្វូវ វិញ ការតវ៉ានោះជាការឃើញថា ចិនហាក់បីដូចជាត្រូវតែធ្វើគ្រប់ផ្នែកទាំងអស់ ដើម្បីធ្វើឲ្យក្រុមចលនាតស៊ូពេញចិត្តដែលក្នុងនោះរួមមានទាំងខ្មែរក្រហមផង ។ បន្ទាប់ពីការជួបជជែកគ្នាពីរដងនៅប៉ារីស វ៉ូហ្គាឆ្វូវ បាននិយាយថា «ហ៊ុន សែន មានការរីករាយ ហើយមានសុទិដ្ឋិនិយមយ៉ាងខ្លាំងថា សន្តិភាពនឹងអាចកើតមានព្រោះតែ ហ៊ុន សែន និងសម្តេច ព្រះនរោត្តម សីហនុ មានការចូលចិត្តគ្នាទៅវិញទៅមក» ។

ការពន្យល់ទាំងនោះជាតួនាទីរបស់ រ៉ូហ្កាឆូវ ព្រោះថា សម្ដេច ព្រះនរោត្តម សីហនុ គ្រាន់តែជាផ្នែកម្ខាងនៃក្រុមតស៊ូ ។ ពួកគេត្រូវតែរកឲ្យឃើញនូវវិធីមួយ ដើម្បីដោះស្រាយជាមួយក្រុមមិនមែនកុម្មុយនិស្ដ ដូចជា សឺន សាន និងខ្មែរក្រហមជាដើម ។ ចំណែកឯសូវៀត នឹងចាប់ផ្ដើមដោះស្រាយជាមួយសហរដ្ឋអាមេរិក» ។

នៅខែមេសា រ៉ូហ្កាឆូវ បានជួបជាមួយហ្គាសតុន ជេ ស៊ីហ្គឺ ជំនួយការរដ្ឋលេខាធិការនៃផ្នែកការងារទាក់ទងនឹងអាស៊ីបូព៌ារបស់លោកប្រធានាធិបតី រីហ្គេន ដើម្បីការជជែកទុកមុនអំពីសន្និបាតកំពូល ហ្គោបាឆូវ-រីហ្គេន ។ ប៉ុន្តែ ជំហររបស់អាមេរិកក្នុងការគាំទ្រចំពោះអាស៊ាន ពុំមានការកែប្រែឡើយ ។ «លោកស៊ីហ្គឺបាននិយាយថា អាមេរិកមានមិត្តច្រើននៅអាស៊ាន ហើយអ្វីដែលពួកគេចង់បានពីអាមេរិកនោះ គឺការគាំទ្ររបស់អាមេរិក» ។

នៅខែមិថុនា វៀតណាមដកមេបញ្ជាការទ័ពជាន់ខ្ពស់របស់ពួកគេចេញពីកម្ពុជា ហើយបានសន្យាថា នឹងដកទ័ពចំនួន ៥០.០០០នាក់ទៀតនៅចុងឆ្នាំនោះ» ។

ពត៌មាននេះសឹងតែមិនចេញសោះនៅអាមេរិក គឺមានតែសមាជិកព្រឹទ្ធសភាពីរបីនាក់ និងអគ្គការក្រៅរដ្ឋាភិបាលអាមេរិកប៉ុណ្ណោះ ដែលតាមដានរឿងទាំងនេះ ។ រដ្ឋាភិបាល រីហ្គេន នៅតែបន្តមើលឃើញថា វាជាបញ្ហារបស់វៀតណាម ដែលតម្រូវឲ្យមានទណ្ឌកម្មទាំងស្រុងចំពោះវៀតណាម ។ ហើយព្រឹទ្ធសភានៅតែបន្តទទួលឥទ្ធិពលពីអ្នកតំណាងសាស្រ្ដ សូឡា ហើយមើលឃើញរឿងនោះ ដូចជាការគាំទ្រសមាជិកតស៊ូដែលមិនមែនកុម្មុយនិស្ដ ។

សូឡា បែបនោះ បានក្លាយជាមុខព្រួញរបស់អគ្គការក្រៅរដ្ឋាភិបាលដើម្បីទាមទារនៅ កាពីតូល ហៀល ។ ពួកគេបានប្រកែកថាដើម្បីជំនួយមនុស្សជាតិ ដើម្បីប្រជាជនកម្ពុជានៅក្នុងសាធារណរដ្ឋកម្ពុជា មិនមែនត្រឹមតែពួកតស៊ូប៉ុណ្ណោះទេ ប៉ុន្តែ ពួកគេបានសាកល្បងបញ្ចុះបញ្ចូល សូឡា និងសមាជិកព្រឹទ្ធសភាឲ្យយល់ថា ការផ្ដោតទៅលើតែក្រុមតស៊ូមិនមែនកុម្មុយនិស្ដជាឧបសគ្គមួយ ដែលរាំងស្ទះដល់ដំណោះស្រាយផ្នែកនយោបាយ ។ ការប្រកែករបស់ពួកគេត្រូវបានរលាយបាត់នៅត្រឹមវ៉ាស៊ីនតោន ប៉ុន្តែចំណែកនៅកម្ពុជាវិញការប្រកែកនោះក៏ដូចជាប្រធានបទផ្សេងៗទៀត មានលក្ខណៈខុសពីនៅប៉ារីស មូស្គូ ឬបាងកក ។

សម្ដីរបស់រដ្ឋាភិបាលរីហ្គេន និងសមាជិកព្រឹទ្ធសភាភាគច្រើន សម្ដែងឡើងឲ្យឃើញហាក់បីដូចជានយោបាយសហរដ្ឋអាមេរិកធ្ងើឡើង តែជុំវិញការថ្កោលទោសដ៏រឹងមាំចំពោះខ្មែរក្រហម ស៊ីហ្គឺ បាននិយាយនៅចំពោះមុខព្រឹទ្ធសភានៅខែកក្កដា ឆ្នាំ១៩៨៨ថា «ខ្ញុំចង់បញ្ជាក់ឲ្យឃើញច្បាស់ថា សហរដ្ឋអាមេរិក នៅតែប្រកាន់ជំហរប្រឆាំងនឹងខ្មែរក្រហម ។ ពួកយើងមានការភ្ញាក់រន្ធត់យ៉ាងខ្លាំង ចំពោះអំពើព្រៃផ្សៃ និងគ្មានសីលធម៌របស់ពួកគេ ។ ហើយពួកខ្ញុំប្ដេជ្ញាថា របបបែបនោះ នឹងកើតមានឡើង ដែលធ្វើឲ្យប្រជាជនកម្ពុជាធ្លាក់ក្នុងសភាពរន្ធត់ ដែលធ្លាប់កើតមកម្ដងទៀតឡើយ» ។

គាត់ក៏ដូចជាមន្ត្រីរដ្ឋបាលទាំងឡាយ ជាញឹកញាប់ តែងតែប្រកែកមិនទទួលស្គាល់ថា ជំនួយរបស់អាមេរិក

ចំពោះរដ្ឋាភិបាលចម្រុះ ដែលក្នុងនោះរួមមានខ្មែរក្រហមដែរនោះ គឺដូចជាការជួយដល់ផ្នែកម្ខាងទៀតនៃសង្គ្រាម និងការប្រឆាំងដោយដាច់ណាត់ ។ ស៊ីហ្គឺ បាននិយាយប្រាប់ រ៉ូហ្កាឆូវ ថា សហរដ្ឋអាមេរិកមិនមានគម្រោងផ្លាស់ប្តូរនយោបាយរបស់គេ តាមការនាំមុខរបស់ប្រទេសអាស៊ាន ឬក៏ពួនពីក្រោយដូចគេរិះគន់ឡើយ ។

ចំណែក ម៉ាតាំង វិញ មិនបានបោះបង់ចោលនូវគំនិតដែលថា បារាំងនឹងរៀបចំសន្និសីទសន្តិភាពនោះឡើយ ។ គាត់បានបញ្ចុះបញ្ចូលលោកនាយករដ្ឋមន្ត្រី ហ្សាក់ ស៊ីរ៉ាក់ ថ្វាយជូន សម្តេច ព្រះនរោត្តម សីហនុ នូវអតីតស្ថានទូតខ្មែរ នៅប៉ារីស ដើម្បីជាអំណោយបុណ្យណូអែល ។ ម៉ាតាំង បានចំណាយពេលយ៉ាងច្រើននៅក្នុងរដូវផ្ការីកដើម្បីត្រួតមើល និងរៀបចំស្ថានទូតនោះឡើងវិញ ហើយថែមទាំងដើរទិញតាមហាងទំនិញនៅប៉ារីស នូវវាំងនន ស្រោមពូក ភួយ ដែលគាត់ដឹងថា សម្តេច ព្រះនរោត្តម សីហនុ សព្វព្រះទ័យទៅគុបតែងអគារបូរាណដ៏ប្រណីតនោះ ។

នៅខែមិថុនា បន្ទាប់ពីការបោះឆ្នោតនៅប្រទេសបារាំង ដែលផ្តល់ឲ្យគណបក្សសង្គមនិយមរបស់ មីតេរ៉ង់ នូវការគ្រប់គ្រងរដ្ឋាភិបាល ម៉ាតាំង បានធ្វើដំណើរទៅហាណូយ ដើម្បីពិភាក្សាជាមួយរដ្ឋមន្ត្រីការបរទេស ង្វៀន កូថាច់ ។ រដ្ឋមន្ត្រីការបរទេសថ្មីរបស់បារាំង រូឡង់ ឌុយម៉ាស បានសសេរទៅ ថាច់ សំណូមពរឲ្យមានការពង្រឹងមិត្តភាពឡើងវិញ រវាងវៀតណាម និងបារាំង និងធ្វើការរួមគ្នាឆ្ពោះទៅរកដំណោះស្រាយបញ្ហាកម្ពុជា ។ ម៉ាតាំង បានជូនសំបុត្រនោះដល់ ថាច់ ។ ថាច់ បានឆ្លើយតបដោយពាក្យល្អច្រើន ។ គាត់និយាយថា សម្តេច ព្រះនរោត្តម សីហនុ មានមិត្តច្រើននៅហាណូយ" ។ នៅពេលដែលគាត់រុញឲ្យ ថាច់ អញ្ជើញ សម្តេច ព្រះនរោត្តម សីហនុ ទៅហាណូយ ថាច់ បានបដិសេធថា "យើងមានមិត្តដែលបារម្ភនៅភ្នំពេញ ហ៊ុន សែន" ។

ដូច្នេះ ម៉ាតាំង បានពន្យារការសន្ទនាជាមួយ ថាច់ ហើយទៅជួប សម្តេច ព្រះនរោត្តម សីហនុ នៅឯប្រទេសថៃ ។ នៅពេលនោះ សម្តេច ព្រះនរោត្តម សីហនុ កំពុងខ្វាល់ ។ ម៉ាតាំង និយាយថា "សម្តេច ព្រះនរោត្តម សីហនុ ខ្លាចថាថៃបំពុលទ្រង់ ឬក៏អ្នកផ្សេងបំពុលទ្រង់ ។ ទ្រង់ខ្លាចគ្រប់ពេលទាំងអស់" អ្នកការទូតបារាំងរូបនេះបាននិយាយអំពីការបារម្ភរបស់សម្តេច ព្រះនរោត្តម សីហនុ ដោយក្តីអំណត់ ។ គាត់បានក្លាយទៅជាអ្នកជំនាញយល់ពីចិត្តសាស្ត្ររបស់សម្តេច ព្រះនរោត្តម សីហនុថា ទ្រង់បដិសេធ មិនព្រមទទួលទូរស័ព្ទ ហើយឲ្យអ្នកផ្សេងនិយាយដោយចាំស្តាប់ពីការសន្ទនានោះ ពីការមិនព្រមសោយអាហារ ដោយខ្លាចថានឹងនាំឲ្យកើតភាពដែលទ្រង់ផ្ទឹពុំបាន ។

ម៉ាតាំង បាននិយាយថា "ខ្ញុំមិនបានតឿនឲ្យទ្រង់ផ្តាច់ចេញពីខ្មែរក្រហមទេ ខ្ញុំគ្រាន់តែតឿនឲ្យទ្រង់បន្តការជជែកគ្នាជាមួយ ហ៊ុន សែន ដើម្បីរៀបចំការចែកអំណាចគ្នាមួយ នៅកម្ពុជាជាមួយ ហ៊ុន សែន ។ ខ្ញុំប្រាកដក្នុងចិត្តថា បើទ្រង់ធ្វើយ៉ាងនេះ ខ្មែរក្រហម និងត្រូវតែយល់ស្រប" ។

មកទល់ពេលនេះ អាស៊ានកំពុងតែប្រឹងនាំមុខ ។ ការជួបគ្នាមិនផ្លូវការមួយរវាងភាគីទាំងបួន ត្រូវបានគេ

រៀបចំ ដើម្បីឲ្យជួបនៅបូហ្គ័ប្រទេសឥណ្ឌូនេស៊ី ។ ប្រទេសវៀតណាម ឡាវ និងប្រទេសអាស៊ានទាំងឡាយ នឹងជួបគ្នានៅថ្ងៃមួយផ្សេងទៀត ។

ម៉ាតាំងបានបញ្ចុះបញ្ចូលឲ្យ សម្ដេច ព្រះនរោត្តម សីហនុ ទៅទស្សនកិច្ចនៅប្រទេសបារាំង មុននឹងទ្រង់ទៅប្រទេសឥណ្ឌូនេស៊ី ។ នៅប៉ារីសទ្រង់ត្រូវបានគេទទួលក្នុងនាមជាប្រមុខរដ្ឋ ។ នាយករដ្ឋមន្ត្រីថ្មីរបស់បារាំង លោក មីសែល រ៉ូកាដ់ បានសន្យាថា ប្រទេសបារាំងនឹងប្រើប្រាស់ឥទ្ធិពលដែលខ្លួនមាន ដើម្បីស្វែងរកដំណោះស្រាយមួយ ដោយដាក់សម្ដេច ព្រះនរោត្តម សីហនុ នៅខាងមុខ ។ បន្ទាប់នោះ សម្ដេច ព្រះនរោត្តម សីហនុ ក៏លាលែងម្ដងទៀត ពីមុខតំណែងជាប្រធានរដ្ឋាភិបាលចម្រុះនៅថ្ងៃទី១០ ខែកក្កដា ។ ប៉ុន្តែលើកនេះ ទ្រង់បានយកហេតុផលនៃការលាលែងនោះថា ទ្រង់ខ្លាចខ្មែរក្រហមនឹងចាប់ផ្ដើម“ប្រល័យពូជសាសន៍”ម្ដងទៀត ។ នៅក្នុងបទសម្ភាសដ៏វែងមួយ ទ្រង់បានមានបន្ទូលថា ទ្រង់ជ្រាបថា វៀតណាមកំពុងតែដកទ័ពចេញពីកម្ពុជា ហើយឥឡូវទ្រង់ជឿថា អំពើប្រល័យពូជសាសន៍របស់ ខ្មែរក្រហមមួយទៀត “កំពុងតែក្លាយជារឿងមួយជៀសមិនរួច” ។

ទ្រង់បានឡាយព្រះហស្ដលេខានៅក្នុងសារជាផ្លូវការបំផុតមួយរបស់ទ្រង់ថា “នៅពេលបច្ចុប្បន្ន គ្រោះថ្នាក់នៃវៀតណាម បានចាប់ផ្ដើមរលប់បន្តិចម្ដងៗ ហើយមហាគ្រោះថ្នាក់នៃខ្មែរក្រហម បានចាប់ផ្ដើមលេចរូបរាងឡើង ហើយបានបង្ហាញខ្លួននៅចំពោះប្រជាជនខ្មែរ ដោយគ្មានកេរ្ដិ៍ខ្មាស់” ។ ប្រទេសទាំងឡាយណា ដែលនៅតែបន្តគាំទ្រក្រុមសម្ព័ន្ធដែលមានខ្មែរក្រហមនៅក្នុងនោះ “ត្រូវទទួលខុសត្រូវទាំងស្រុង ចំពោះអំពើប្រល័យពូជសាសន៍ថ្មី មកលើប្រជាជនកម្ពុជា” ។

បន្ទាប់មក សម្ដេច ព្រះនរោត្តម សីហនុ បានយាងទៅកាន់ប្រទេសឥណ្ឌូនេស៊ី ដែលនៅទីនោះ ទ្រង់ត្រូវបានស៊ូហាតូ ស្វាគមន៍ជាភ្ញៀវផ្ទាល់ខ្លួនរបស់គាត់ ។

សឹងតែគ្រប់គណៈប្រតិភូទាំងអស់ បាននាំមកនូវសំណើប្រាំមួយ ឬប្រាំពីរចំណុច ដែលមានការយល់ព្រមទូលំទូលាយចំពោះចំណុចទូទៅមួយចំនួន ។ ហ៊ុន សែន បាននិយាយថា “នោះជាដំណើរការមួយ ជាជាងប្រកែកគ្នា ហើយបែរជាមកអង្គុយទល់មុខគ្នាផ្លាស់ប្ដូរគំនិតយោបល់ និងគោលជំហររបស់គ្នាទៅវិញទៅមក” ។ សេចក្ដីកំណត់ដែលមានលក្ខណៈសម្រួលចិត្តនោះ បែរជាបាត់ទៅវិញ នៅពេលដែលគាត់និយាយដោយខឹងចំពោះការមិនយល់ព្រមរបស់គូបដិបក្សរបស់គាត់ ចំពោះការទាមទារលើសពីកាលវិភាគ ដែលគាត់ស្នើថ្វាយចំពោះការដកទ័ពវៀតណាមទាំងស្រុងចេញពីកម្ពុជា ។ “តើនោះមានន័យយ៉ាងម៉េចទៅវិញ ប្រសិនបើអ្នកទាមទារឲ្យទ័ពវៀតណាមដកចេញ ហើយបែរជាផ្ដល់ឱកាសដល់អំពើប្រល័យពូជសាសន៍របស់ខ្មែរក្រហម កើតមានមកលើប្រជាជនខ្មែរជាថ្មីវិញនោះ?”

សម្ដេច ព្រះនរោត្តម សីហនុ បានមានបន្ទូលដូចជាប្រជាពលរដ្ឋសាមញ្ញម្នាក់ ឬក៏លម្អិតជាងនោះទៀត គឺទ្រង់មានបន្ទូល ក្នុងនាមជាបិតាជាតិកម្ពុជា ។ បន្ទាប់ពីទុកឲ្យប្រជាជនគ្រប់រូបបញ្ចេញយោបល់អស់ហើយ

ទ្រង់បានបញ្ចេញនូវ សំណើសុំដ៏លម្អិតសម្រាប់ការផ្សះផ្សាជាតិ តាមរយៈសន្និសីទអន្តរជាតិមួយស្តីពីកម្ពុជា ។ សំណើសុំនោះរួមមានបញ្ជីរាយនាមអ្នកខបត្ថម្ភអង្គសន្និសីទ ក៏ដូចជាលក្ខណៈទង់ជាតិកម្ពុជាថ្មី និងអត្ថន័យនៃបទចម្រៀងជាតិ ។ នៅក្នុងពេលនោះមានតែខ្មែរក្រហមមួយគត់ដែលជំទាស់នឹងសំណើសុំរបស់ទ្រង់ ។

តាំងពីឆ្នាំ១៩៧៩មក នេះគឺជាលើកទីមួយហើយដែលខ្មែរក្រហមនៅឯកោតែឯង ។ ដោយមិនបាច់មានសំបុត្រហត្ថលេខាទំនាក់ទំនងអ្វី សម្តេច ព្រះនរោត្តម សីហនុ និង ហ៊ុន សែន បានយល់ព្រមជួបគ្នាម្តងទៀតនៅឆ្នាំដដែល នៅឯប្រទេសបារាំង ។

គួដ ម៉ាតាំង និង អ៊ីហ្គ័រ រ៉ូហ្កាឆូវ ពេញចិត្តយ៉ាងខ្លាំង ។

ប្រកបដោយភាពជាសាសនទូតដ៏មោះមុត បុរសទាំងពីរ បានប្រឹងប្រែងធ្វើឲ្យខ្មែរក្រហមទន់ខ្សោយ ដើម្បីឆ្លងកាត់ឲ្យផុតនូវឧបសគ្គបន្ទាប់នៃការចរចាដើម្បីសន្តិភាពនៅកម្ពុជា ។ ឥឡូវ រ៉ូហ្កាឆូវ អាចចរចានូវសំណើសុំមួយថ្មីទៀតជាមួយចិន ។ ដូច្នេះគាត់ក៏បានធ្វើដំណើរទៅប៉េកាំងនៅថ្ងៃទី២៨ ខែសីហា ក្នុងរយៈពេលពីរបីថ្ងៃ ដើម្បីចរចាជាមួយភាគីម្ខាងទៀតរបស់គាត់ ឡៀន ជិនបេយ ។ វគ្គយុទ្ធសាស្ត្រមួយត្រូវចំណាយពេលអស់ ១៦ម៉ោង ។ រ៉ូហ្កាឆូវ បាននិយាយថា «វាជាកំហុសពីខាងពួកយើងដែលទំធ្វើឲ្យឃើញថា គ្មានបញ្ហាអ្វីសោះនៅកម្ពុជា ។ វិន័យរបស់ពួកយើងគឺត្រូវតែនិយាយជានិច្ចថា ទេនោះមិនមែនជាបញ្ហាទេ ប្រសិនបើចិនលើកថា នោះជាបញ្ហា ។ ឥឡូវយើងសម្រេចចិត្តនឹងនិយាយជាមួយចិនដោយចំហ ។ យើងសម្រេចចិត្តថា នឹងដាក់ជូននូវទិសដៅមួយថា «នឹងពង្រីកទំហំនៃការស្រុះស្រួលរបស់យើង ហើយបង្រួមភាពមិនស្រុះស្រួលរបស់យើង» ។

រ៉ូហ្កាឆូវបានបន្តថា «វៀតណាមបានចាប់ផ្តើមនិយាយពីរឿង ការដកទ័ពចេញពីកម្ពុជាតាំងពីយូរមកហើយ ។ យើងលើកយករឿងនោះមកស្នើចំពោះចិន ព្រោះថាគ្មានផ្លូវផ្ទាល់លើកមកដល់ចិនចំពោះបញ្ហានេះទេ ។ ខាងចិនបានកំណត់ថ្ងៃដើម្បីឲ្យវៀតណាមដកទ័ពចេញ ។ យើងក៏បានលើកពីសំណើសុំរបស់អាមេរិក នូវថ្ងៃខែពិតប្រាកដ ។ ប៉ុន្តែវៀតណាម បានធ្វើការសម្រេចចិត្តពីថ្ងៃខែដើម្បីដកទ័ពរួចទៅហើយ ។ មិនអាចទៅរួចឡើយថាពួកគេមិនព្រមទទួលយកមកពិចារណា នូវសំណូមពររបស់មហាអំណាចដទៃទៀតនោះ ។ នៅទីបញ្ចប់ថ្ងៃខែនៃការដកទ័ពរបស់ពួកគេ ក៏ត្រូវថ្ងៃគ្នាជាមួយការលើកឡើងរបស់ចិន» ។

ដំណាក់កាលឥឡូវនោះ គឺឆ្ពោះទៅរកការស្រុះស្រួលគ្នារវាងចិន និងសូវៀត ។ រ៉ូហ្កាឆូវ កំពុងតែខិតទៅជិតដល់ទិសដៅរបស់គាត់ ។

ម៉ាតាំងក៏ដូច្នោះដែរ ។ នៅខែដដែលនៅថ្ងៃទី២៤ ខែកញ្ញា ប្រធានាធិបតីបារាំង មីតេរ៉ង់ បានជួបជាមួយសម្តេច ព្រះនរោត្តម សីហនុ នៅទីក្រុងប៉ារីស ។ មេដឹកនាំទាំងពីរបានជួបពិភាក្សាគ្នាអស់រយៈពេល ៤៥នាទីហើយយល់ព្រមថា បារាំងនឹងរៀបចំឲ្យមានការប្រជុំសន្និសីទបែបអន្តរជាតិលើបញ្ហាកម្ពុជា ។ នៅរាត្រីថ្ងៃដដែលរដ្ឋមន្ត្រីការបរទេស ឌុយម៉ាស បានរៀបចំលៀងអាហារពេលរាត្រីបែបការងារមួយ ជាមួយសម្តេច ព្រះនរោត្តម

សីហនុ ដើម្បីពិភាក្សាពីចំណុចលម្អិតរបស់សន្និសីទ ។ ម៉ាតាំង ក៏បានស្បើយចិត្តច្រើន ។ ប្រទេសបារាំងនឹងធ្វើជាម្ចាស់ផ្ទះនៃការប្រជុំសន្និសីទ ដើម្បីសន្តិភាពសម្រាប់អតីតប្រទេសក្រោមអាណានិគមរបស់ខ្លួន ហើយរក្សានូវឥទ្ធិពលរបស់ខ្លួននៅអាស៊ីអាគ្នេយ៍ និងមិនឲ្យធ្លាក់ពីតំណែងមហាអំណាចដែលបារាំងដាក់ឲ្យខ្លួនឯងទេ ។

នាឆ្នាំនោះ គ្រប់យ៉ាងហាក់បីដូចជាមានដំណើរការទៅបានល្អ ។ នៅឯមហាសន្និបាតអង្គការសហប្រជាជាតិ នារដូវស្លឹកឈើជ្រុះឆ្នាំនោះ កៅអីរបស់កម្ពុជានៅអង្គការសហប្រជាជាតិ ត្រូវបានគេអធិប្បាយថា ជារបស់រដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់សម្ដេច ព្រះនរោត្តម សីហនុ ។ នៅតាមផ្លូវទៅទីក្រុង ប៉ារីស ហ៊ុន សែន បានចូលជួបជាមួយ អេឌូអាត សេវ៉ាដណាដហ្សេ នៅទីក្រុងម៉ូស្គូ ។ នៅទីនោះគាត់បានជួបជាមួយ សឺន សាន និងសម្ដេច ព្រះនរោត្តម សីហនុ នៅស្ថានទូតខ្មែរដែលទើបជួសជុលរួច ។ នៅខែវិច្ឆិកា នាយករដ្ឋមន្ត្រីចិនបានប្រកាសថា គ្រប់ជំនួយបរទេសទាំងអស់ ដល់ក្រុមផ្ដាច់ខ្លួនរបស់កម្ពុជានឹងត្រូវបញ្ឈប់ បន្ទាប់ពីការដកទ័ពវៀតណាមចេញពីកម្ពុជា ។ នៅខែធ្នូ ទ័ពវៀតណាមចំនួន ៥០០០០នាក់ បានដកចេញពីកម្ពុជា ។

ហើយនៅខែធ្នូដដែល រដ្ឋមន្ត្រីការបរទេសចិន គៀន គីចេន បានធ្វើដំណើរទៅទីក្រុងម៉ូស្គូ ដើម្បីជួបជាមួយ សេវ៉ាដណាដហ្សេ ពិភាក្សាផ្ដោតលើបញ្ហាកម្ពុជា ។ គៀន គីចេន ក្រោយមកបានជួបនិយាយជាមួយ ហ្គោបាឆូវ ហើយពួកគាត់ក៏បានព្រមព្រៀងធ្វើសន្និសីទកំពូល ចិន-សូវៀត នៅដើមឆ្នាំ១៩៨៩ ។

ឆ្នាំ១៩៨៩ ជាឆ្នាំដែលសន្យានូវជោគជ័យ ។

នៅដើមឆ្នាំ ហ៊ុន សែន បានប្រកាសថា ថ្ងៃខែនៃការដកកងទ័ពវៀតណាមទាំងស្រុង នឹងអាចខិតមកលឿនជាងមុន ។ វៀតណាមនឹងចេញអស់នៅខែកញ្ញា ប្រសិនបើសន្ធិសញ្ញាសន្តិភាពអាចកើតមានឡើង នៅរដូវក្ដៅឆ្នាំនោះ ។ ទោះបីជាសន្ធិសញ្ញាសន្តិភាព មិនអាចកើតមានក៏ដោយ ក៏ទ័ពវៀតណាម នៅតែដកចេញអស់ យ៉ាងយូរបំផុតនៅចុងខែធ្នូ ។ ការប្រកាសរបស់ ហ៊ុន សែន ធ្វើឡើងនៅរដូវរំហើយនាខែមករា គឺធ្វើឡើងជាការប្រជែងមិនមែនជាការបន្ធូរបន្ថយទេ ។ គាត់កំពុងបញ្ចេញខ្លួនគាត់នៅលើឆាកនយោបាយអន្តរជាតិ ដោយបង្ហាញនូវមោទនភាពដ៏មានះរបស់គាត់ ដែលគ្រប់គ្នានៅក្នុងប្រទេសបានដឹងរួចមកហើយ ។ ឥឡូវនេះ គឺសម្រេចលើទ័ព និងប្រទេសទាំងឡាយនៃភាគីម្ខាងទៀត ដូចជារដ្ឋាភិបាលចម្រុះរបស់សម្ដេច ព្រះនរោត្តម សីហនុ និងខ្មែរក្រហម ព្រមទាំង សហរដ្ឋអាមេរិក ប្រទេសអាស៊ាន ចិន និងជប៉ុន ថាតើអាចដើរដល់ចំណុចសន្តិភាពដែលពួកគេចោទថា គាត់នឹង វៀតណាមកំពុងរារាំងដែរទេ ។

ស្រាប់តែមួយរំពេចនោះ ប្រទេសថៃក៏បានឆ្លើយតបនឹង ហ៊ុន សែន ។ ចាប់តាំងពីពេលឡើងកាន់តំណែងមក លោកនាយករដ្ឋមន្ត្រីថ្មី ឆាទីឆៃ ឈុនហាវ៉ាន និងក្រុមទីប្រឹក្សាក្មេងៗរបស់គាត់ បានឲ្យគម្រុយជាច្រើនពីរឿងនេះ ។ ពួកគេចង់បំបែករូបភាពទោរទន់ទៅរកសហរដ្ឋអាមេរិករបស់ពួកគេ ។ មានតែមនុស្សពីរបីនាក់ប៉ុណ្ណោះដែលទុកសម្ដីនោះជាការពិត ។ ឆាទីឆៃ ប្រហែលជាឈ្នះការបោះឆ្នោត ដែលមានលក្ខណៈប្រជាធិបតេយ្យជាង

គេមួយ ប៉ុន្តែគ្មាននរណាម្នាក់គិតថា នាយករដ្ឋមន្ត្រីរូបនេះ នឹងកែប្រែជំហររបស់ប្រទេសថៃនៅលើពិភពលោកឡើយ ។ម្យ៉ាងទៀត ឆាទីឆៃ ផ្ទាល់ ជាបុគ្គលដែលមានទំនុកចិត្តលើខ្លួនឯង និងគួរជាទីចាប់អារម្មណ៍ ប៉ុន្តែ មិនមែនជាបុគ្គលដែលមានលក្ខណៈបដិវត្តន៍នោះទេ ។ ធ្លាប់ជាអតីតរាជទូត ជាអ្នកជំនួញ ដែលមានប្រាក់រាប់លាន និងជាអ្នកនយោបាយជាន់ខ្ពស់មួយរូប ដែលធ្លាប់ជាមេទាហានដ៏ពូកែម្នាក់ គាត់គួរតែយល់ថា នៅពេលដែលមេដឹកនាំម្នាក់ឈានជើងចេញឆ្ងាយពីព្រំដែនពេក មេទ័ពនឹងធ្វើរដ្ឋប្រហារទម្លាក់គេមិនខាន ។ ទោះបីជា ឆាទីឆៃ មានកេរ្តិ៍ឈ្មោះថា ជាអ្នកពូកែប្រថុយប្រថាន និងល្បីខាងអំពើពុករលួយ ដើម្បីទប់ទល់នឹងជីវភាពដ៏ខ្ពង់ខ្ពស់របស់គាត់ក៏ដោយ ក៏គាត់មិនត្រូវបានគេគិតថា ជាអ្នកធ្វើឲ្យមានការរំដើបរំជួលនោះទេ ។

តម្រុយដំបូងដែលបញ្ជាក់ផ្ទុយពីគំនិតខាងលើគឺក្រុមទីប្រឹក្សារបស់គាត់ ។ ពួកគេសុទ្ធតែក្មេងៗ ហើយប្រសិនបើពួកគេមិនស៊ើរើទាំងស្រុងនោះទើបជារឿងមួយដែលចម្លែក ។ អ្នកជាស្នូលក្រុមគឺកូនប្រុសរបស់គាត់ ក្រៃសាក់ ឈុនហាវ៉ាន ។ អ្នកទទួលខុសត្រូវខាងនយោបាយបរទេសរបស់គាត់គឺ ផាន់សាក់ វិញយ៉ារ៉ាត់ ដែលជាអ្នកជំនាញខាងវិទ្យាសាស្ត្រនយោបាយពីប្រទេសអាមេរិក ហើយក៏បានធ្លាប់ជាប់គុក ដោយសារគំនិតបែកធ្លេងរបស់គាត់ ក្នុងការធ្វើរដ្ឋប្រហារនៅឆ្នាំ១៩៧៦ដែរ ។ គាត់បាននិរទេសខ្លួនទៅនៅសហរដ្ឋអាមេរិក ហើយត្រឡប់ចូលស្រុកវិញនៅឆ្នាំ១៩៨០ ដោយនាំមកជាមួយនូវការយល់ដឹងដ៏ជ្រាលជ្រៅពីនយោបាយអាមេរិក និងបញ្ជីឈ្មោះដ៏ក្រាស់នៃក្រុមអ្នកកាសែត និងអ្នកនយោបាយនៅសហរដ្ឋអាមេរិក និងអឺរ៉ុបផង ។

ផាន់សាក់បាយ និយាយថា ឆាទីឆៃ បានប្រាប់ទីប្រឹក្សារបស់គាត់ទាំងពីររូបនោះថាគាត់ចង់ "ចូលក្នុងប្រទេសកម្ពុជាក្នុងរយៈពេលមួយឆ្នាំខាងមុខនេះ" ។ ហេតុផលនៅពីក្រោយនោះ គឺចង់ដាក់បាងកកទៅក្នុងចំណុចសំខាន់នៃអាស៊ីអាគ្នេយ៍ និងប្រាប់ដល់ប្រទេសសិង្ហបុរីថា ពួកគេចង់ជំនួសតំណែងសិង្ហបុរីជាចំណុចស្នូលនៃសេដ្ឋកិច្ចប្រចាំតំបន់វិញ ។ នៅទសវត្សរ៍ឆ្នាំ៨០ ជាពេលដែលប្រទេសទាំងឡាយរួចផុតពីក្រញាំកុម្មុយនិស្ត មានការលូតលាស់សេដ្ឋកិច្ចយ៉ាងសម្បើម ហើយប្រទេសសិង្ហបុរី ជាប្រទេសមួយដែលការរីកលូតលាស់ មានភាពលេចធ្លោជាងគេបង្អស់ ។ មកដល់ត្រឹមឆ្នាំ១៩៨៩ សិង្ហបុរី បានរីកលូតលាស់លឿនជាងប្រទេសនានានៅអឺរ៉ុប ក្នុងវិស័យមួយចំនួន ។ ចំណូលក្នុងបុគ្គលម្នាក់ៗនៅប្រទេសសិង្ហបុរី មានកម្រិតខ្ពស់ជាងចក្រភពអង់គ្លេស ដែលធ្លាប់ជាប្រទេសដាក់អាណានិគមនៅសិង្ហបុរីដល់ឆ្នាំ១៩៥៧ទៅទៀត ។ ជាងនេះទៅទៀត អត្រាស្លាប់របស់កុមារនៅប្រទេសសិង្ហបុរីមានចំនួនតិចជាងអត្រានៅសហរដ្ឋអាមេរិក ។ រដ្ឋដែលមានទំហំត្រឹមតែជាទីក្រុងប្រទេសសិង្ហបុរីត្រូវបានប្រទេសនានា នៅក្នុងតំបន់មានការស្ញប់ស្ញែងយ៉ាងខ្លាំង ។ តាមរយៈអត្រាភាគច្រើននៃជនជាតិចិននៅក្នុងប្រទេស សិង្ហបុរីជាប្រទេសទីមួយ ដែលទាញយកផលប្រយោជន៍ចេញពីការបើកទីផ្សាររបស់ចិននៅឆ្នាំ១៩៨៥ ដោយដាក់ឲ្យមានការវិនិយោគទុនយ៉ាងធំនៅប្រទេសចិន ។ ខុសពីក្រុមអ្នកជំនួញចិននៅក្រៅស្រុកមួយចំនួន ចិន សិង្ហបុរីនាសម័យទំនើប មិនស្រវាយកតែចិន ហើយបោះវិនិយោគទុនជាមួយប្រទេសខាងលិចចោល

ឡើយ ។ នៅឆ្នាំ១៩៨៩ សិង្ហបុរី បាននាំទំនិញទៅកាន់សហរដ្ឋអាមេរិក ក្នុងទឹកប្រាក់ចំនួន ៩ កោដិដុល្លារ សហរដ្ឋអាមេរិក ប្រៀបទៅនឹងប្រទេសថៃដែលនាំរបស់ទៅកាន់សហរដ្ឋអាមេរិកក្នុងទឹកប្រាក់ចំនួន ៨,៤ កោដិដុល្លារ សហរដ្ឋអាមេរិក ។ ចំណុចនោះធ្វើឲ្យ ឆាទីឆៃ មានការខឹង ហើយគិតថា ផ្លូវមួយដែលលើកតម្កើងតំណែងរបស់ថៃ គឺការបង្កើនទំនាក់ទំនងទៅក្នុងប្រទេសនៅឥណ្ឌូចិន ហើយនាំវៀតណាម និងកម្ពុជាឲ្យចូលក្នុងក្រុមវិញ ។ ដើម្បីនឹងធ្វើទៅបានលុះត្រាតែសង្គ្រាមនៅកម្ពុជាបញ្ចប់ ។

ឆាទីឆៃ បានថ្លែងសុន្ទរកថានៅក្នុងពិធីចូលកាន់តំណែងរបស់គាត់ថា គាត់ចង់កែប្រែឥណ្ឌូចិន «ពីទីលានប្រយុទ្ធឲ្យក្លាយទៅជាទីផ្សារជំនួញវិញ» ។ ប្រសាសន៍នោះមានលក្ខណៈបដិវត្តន៍យ៉ាងខ្លាំង ។ ប្រទេសថៃ ធ្លាប់ជាកន្លែងសម្រាប់ប្រយុទ្ធ ហើយនាយករដ្ឋមន្ត្រីថ្មី មិនអាចចេះតែចង់ផ្លាស់ប្តូរខាង ក៏ប្តូរខាង យ៉ាងដូច្នេះបានឡើយ ។ នៅពេលដែលការប្រឆាំងមានភាពស្ងប់ស្ងាត់បន្តិច គាត់ក៏និយាយថា គាត់គ្រាន់តែចង់សង្កត់ធ្ងន់ថា សេដ្ឋកិច្ចកាន់តែមានសារសំខាន់ខ្លាំងឡើងពីមួយថ្ងៃទៅមួយថ្ងៃ ហើយគាត់ចង់ឲ្យប្រទេសថៃក្លាយជាចំណុចលូតលាស់ជាងគេនៅអាស៊ីអាគ្នេយ៍ ។ គាត់ក៏បានលុបចោលទិសដៅ«ពីទីលានប្រយុទ្ធកជាទីផ្សារ» ចេញពីសុន្ទរកថារបស់គាត់នៅសភា ។

បន្ទាប់មកគាត់ក៏ដើរផ្លូវក្រោមម្តង ។ គាត់បានផ្លាស់ប្តូរនយោបាយថៃដោយសម្ងាត់ សំដៅមកខាងវៀតណាម និងកម្ពុជាវិញ ។ នៅខែធ្នូគាត់បានបញ្ជូនឧត្តមសេនិយបញ្ជាការរបស់គាត់ទៅប្រទេសឡាវដោយសម្ងាត់ ដែលជាប្រទេសមួយ ដែលប្រទេសថៃតែងតែមានទំនាក់ទំនងការទូតជាមួយល្អជាធម្មតា ។ នៅទីនោះលោកឧត្តមមេបញ្ជាការ ក៏បានជួបគ្នាក្រៅផ្លូវការជាមួយសម្តេច ហ៊ុន សែន ។ ក្រោយមកនៅខែមករា ឆាទីឆៃ បានចាប់ផ្តើមអនុវត្តវិធានការចំពោះឥណ្ឌូចិនដ៏ភ្ញាក់ផ្អើលរបស់គាត់ ។ គាត់បានបញ្ជូនរដ្ឋមន្ត្រីការបរទេសរបស់គាត់លោក ស៊ីធី សាវេត ស៊ីឡា រួមជាមួយក្រុមអ្នកអមដំណើរចំនួន៧០នាក់ឲ្យទៅហាណូយ ដើម្បីបញ្ឈប់ការប្រេះឆាវវាងគ្នានឹងគ្នាអស់រយៈពេលរាប់ទសវត្សរ៍មកហើយ ។ តាំងពីឆ្នាំ១៩៦០ ថៃបាននៅពីក្រោយសត្រូវរបស់វៀតណាម ។ ថៃបានអនុញ្ញាតឲ្យសហរដ្ឋអាមេរិកបោះជំរំនៅលើទឹកដីរបស់ខ្លួន ដើម្បីទម្លាក់គ្រាប់បែកនៅវៀតណាម ។ ហើយឥឡូវ បានផ្តល់ដល់ខ្មែរក្រហម និងក្រុមចលនាតស៊ូខ្មែរឯទៀតនូវជំរំទ័ព និងសិទ្ធិធ្វើប្រតិបត្តិការផ្សេងៗនៅក្នុង និងក្រៅប្រទេសថៃ ។ ប្រសិនបើគ្មានការស្មុគស្មាញរបស់ថៃ ការប្រឆាំងនឹងការគ្រប់គ្រងរបស់ទ័ពវៀតណាមនៅលើដីកម្ពុជា ក៏ប្រហែលជាគ្មានដែរ ។ ការធ្វើទស្សនកិច្ចរបស់ ស៊ីធី ទៅហាណូយ បានធ្វើឲ្យមានការកែប្រែវិន័យខ្លះ នៃល្បែងនៅកម្ពុជា ។

ក្រោយមកនៅចុងខែនោះ ឆាទីឆៃ បានអញ្ជើញឲ្យ ហ៊ុន សែន ទៅទីក្រុងបាងកកជាភ្ញៀវផ្ទាល់ខ្លួនរបស់នាយករដ្ឋមន្ត្រីថៃ ។ ការដើរក្រឡាពីរបីនេះ បានធ្វើឲ្យមានការរំជើបរំជួលនៅក្នុងចំណោមក្រុមតស៊ូ និងអ្នកគាំទ្ររបស់ពួកគេ ។ ចំណងជើងធំៗនៅក្នុងទំព័រកាសែតសសេរថា «ហ៊ុន សែន ទៅជួប ឆាទីឆៃ នៅថ្ងៃនេះ» «ថៃមិនថយ

ក្រោយចំពោះបញ្ហាកម្ពុជាឡើយ» «កម្ពុជាបានឈ្នះមួយគ្រាប់នៅទឹកចុងក្រោយ» «ចូលនាំគ្នាធ្វើការជជែកវែកញែកជាសាធារណៈមួយស្តីពីបញ្ហាកម្ពុជា» និង«ហ៊ុន សែន ទៅជួបការបែងចែក» ។

ថៃជាប្រទេសសំខាន់មួយនៃអាស៊ាន ដែលសហរដ្ឋអាមេរិកគិតថានឹងដើរតាមនោះ បែរជាដកជើងចេញពីក្រុមទៅវិញ ។ ឆាទីឆៃ កំពុងលៀងអាហាររាត្រីជាមួយសត្រូវ ។ ហ៊ុន សែន និងអ្នកអមដំណើររបស់គាត់ បានដើរថតរូបពេញទីក្រុង ដូចជាភ្ញៀវទេសចរនៅឯវិហារព្រះកែវមរកត និងថតរូបជាភ្ញៀវកិត្តិយសជាមួយនាយករដ្ឋមន្ត្រីថៃ ។ ទីប្រឹក្សាម្នាក់របស់ ឆាទីឆៃ លោក ភានសាក់ និយាយថា «នេះជាលើកដំបូងហើយ ដែលនយោបាយរបស់ថៃមានសច្ចៈធម៌ និងជាក់ស្តែង ។ យើងចង់ធ្វើជាកាតាលីករដើម្បីបញ្ឈប់អំពើហិង្សា» ។

ហ៊ុន សែន បានមានប្រសាសន៍ដដែលៗថា «ខ្ញុំចង់បញ្ជាក់ឲ្យច្បាស់ថា ចំណុចសំខាន់នៃការជួបជជែករវាងយើង គឺដើម្បីបញ្ចប់ការកាប់សម្លាប់គ្នា និងដើម្បីបញ្ចប់សង្គ្រាមនៅកម្ពុជា» ។

កម្ពុជាបានធ្វើការព្រមព្រៀងពាណិជ្ជកម្មមួយចំនួនជាមួយថៃ ។ ភ្លាមបន្ទាប់នោះ ថៃក៏បានបញ្ជូនក្រុមមិនមែនជាផ្លូវការមួយមកប្រទេសកម្ពុជា ដើម្បីវិភាគមើលឱកាសសម្រាប់ពាណិជ្ជកម្ម និងវិនិយោគទុន ។ ឆាទីឆៃ ដែលជាពាណិជ្ជករដែរនោះ បានមើលឃើញនូវឱកាសដ៏ធំធេង សម្រាប់ឲ្យពាណិជ្ជកម្មថៃ មកស្វែងរករ៉ែត្បូងនៅក្នុងព្រៃ និងបឹង ដែលសម្បូរទៅដោយត្រីរបស់កម្ពុជា ។ អ្នកតំណាងរបស់គាត់ លីឃីត ហុងឡាដារុម បានអធិប្បាយពន្យល់គំនិតរបស់គាត់ខាងលើនោះឲ្យពិរោះស្តាប់ថា «នាយករដ្ឋមន្ត្រីរបស់ពួកយើងខ្ញុំ គឺចង់មានប្រសាសន៍ថា សត្រូវពិតប្រាកដរបស់កម្ពុជា គឺភាពក្រីក្រ» ។

ថៃដែលនៅពេលនោះកំពុងតែបូមយកប្រាក់ពីជំនួញខុសច្បាប់ នៅតាមព្រំដែនរួចមកហើយនោះ គឺនឹងមានឱកាសមុនគេ ដើម្បីបូមយកប្រាក់ស្របច្បាប់ ដែលនឹងរកបានពេលសង្គ្រាមត្រូវបញ្ចប់ ។ ទីប្រឹក្សារបស់ ឆាទីឆៃ ត្រូវបានគេរិះគន់ថា ធ្វើចរិតដូចនិស្សិតរៀនចប់មិនព្រមចាស់គំនិត ។ ចំណែកឯគាត់វិញត្រូវបានគេរិះគន់ថា រស់នៅហ៊ឺហា មានស្រីរាំតាំងពីក្នុងពេលអាហារថ្ងៃត្រង់ ។ ប៉ុន្តែនៅក្នុងរបាំងមុខនោះ គាត់ជាមនុស្សដែលមានភាពហ្មត់ចត់ណាស់ ។ គាត់ចង់ឲ្យសេដ្ឋកិច្ចរបស់ថៃ លូតលាស់ក្នុងអត្រាពីរខ្ទង់ដូចប្រទេសសិង្ហបុរីដែរ ហើយក្រោយមក ក្រោមការដឹកនាំរបស់គាត់ ការលូតលាស់របស់សេដ្ឋកិច្ចថៃក៏ឡើងដល់ ១៣ភាគរយ ។ គាត់ចង់បញ្ឈប់ការគាំទ្រ របស់ថៃដល់សង្គ្រាមនៅកម្ពុជា ជាពិសេសគឺ ប៉ុល ពត ដែលគាត់ពិពណ៌នាថា ជាមនុស្សផប់ផល់នឹងលទ្ធិកាល់ម៉ាក្ស ។

អ្នកស៊ើបការណ៍ទ័ពថៃបានរាយការណ៍ប្រាប់ ឆាទីឆៃ ថា ទោះបីជាមានការភ័យខ្លាច និងការប្រឹងពាក់មុខសិង្ហរបស់ខ្មែរក្រហមក៏ដោយ ក៏ខ្មែរក្រហមមិនអាចយកកម្ពុជាវិញបានដែរ ។ ប៉ុន្តែទ័ពរបស់ ហ៊ុន សែន ក៏មិនពូកែដល់កម្រិតលុបបំបាត់ទ័ពដែលប្រឆាំងឲ្យអស់ និងទប់ស្កាត់ការបង្អាក់ដំណើរស្រុកទេសរបស់ពួកនោះដូចគ្នា ។ ការវាយប្រយុទ្ធគ្នា មិនមែនជាដំណោះស្រាយឡើយ ។ ឆាទីឆៃ ដឹងច្បាស់ថា «ក្នុងស្ថានភាពអាក្រក់បំផុត ដែលខ្មែរ

ក្រហមធ្វើការគំរាមកំហែងចំពោះភ្នំពេញនោះ គ្មានប្រទេសណាមួយ ហ៊ានប្រថុយដាក់ទ័ពជើងទឹករបស់ពួកគេឲ្យចូលមកប្រទេសកម្ពុជាទេ ទោះបីជាសហរដ្ឋអាមេរិកក្តី ឬចិនក្តី» ។

ដោយសារហេតុដូច្នេះ ប្រទេសថៃនៅតែជាទីតាំងមួយ សម្រាប់មហាអំណាចទាំងឡាយ ក្នុងការបង្កបាតុភូតនានា ។

ដូច្នេះ ឆាទីឆៃ ក៏បញ្ចុះបញ្ចូលប្រទេសមហាអំណាចមួយចំនួន ជាពិសេស សហរដ្ឋអាមេរិក «កុំឲ្យគិតប្រទេសនៅអាស៊ីអាគ្នេយ៍ និងឥណ្ឌូចិន ក្នុងន័យទ័ព ប៉ុន្តែគិតក្នុងន័យសេដ្ឋកិច្ចនយោបាយវិញ ។ ហើយយើងត្រូវការដោះស្រាយបញ្ហារបស់កម្ពុជា ក្នុងពេលឆាប់ៗខាងមុខ» ។

បន្ទាប់ពីដំណើរទស្សនកិច្ចរបស់ ហ៊ុន សែន នាយករដ្ឋមន្ត្រីថៃបានបន្តយុទ្ធនាការរបស់គាត់ ហើយធ្វើដំណើរទៅប៉េកាំងដើម្បីជួបជាមួយ តេង ស៊ាវពីង និងជួបពិភាក្សាជាមួយមហាអំណាច ដែលនៅពីក្រោយក្រុមតស៊ូប្រឆាំង ។ តាមសម្តីរបស់ ផាន់សាក់ មេដឹកនាំចិនបានខឹងយ៉ាងខ្លាំង ហើយក៏ប្រដៅ ឆាទីឆៃ ។ ប៉ុន្តែឆាទីឆៃ បានកាត់ការប្រដៅរបស់គាត់ នៅត្រង់កន្លែងដែលគាត់និយាយអំពីការឈ្លានពានរបស់សូវៀត ហើយនិយាយថា «នោះជារឿងអតីតកាល ។ ពួកយើងធ្លាប់បានសាកល្បងសង្កត់ប្រទេសវៀតណាម និងកម្ពុជា អស់រយៈពេល១១ឆ្នាំមកហើយ ឃើញថា មិនមានបានការអ្វីទាំងអស់ ។ នេះមិនមែនជាវិធីមួយក្នុងទំនាក់ទំនងនៅតាមតំបន់នោះទេ» ។

ក្រោយមក ឆាទីឆៃ បាននិយាយបន្តថា «ចិនប្រហែលជាអាចចាំបាន ១០ឆ្នាំទៀត តែយើងមិនអាចចាំបានទេ» ។ ទោះបីជាខឹងនឹង ឆាទីឆៃ ក៏ដោយ តេង បានចាប់ផ្តើមរៀបចំវិធានការដើម្បីដើរទៅជាមួយឥណ្ឌូចិនទៅហើយ ។ មុនពេល ហ៊ុន សែន ទៅបាងកក ចិនបានអញ្ជើញឧបនាយករដ្ឋមន្ត្រីវៀតណាមមកប្រទេសចិន ដើម្បីជួបពិភាក្សាជាលើកទីមួយ រវាងប្រទេសទាំងពីរក្រោយរយៈពេលលែងទាក់ទងគ្នាមួយទសវត្សរ៍ ។

ពីរបីសប្តាហ៍ក្រោយមក នៅថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ១៩៨៩ សេវ៉ាដណាដហ្សេ បានមកដល់ប៉េកាំង ដើម្បីចូលរួមធ្វើការប្រជុំពិភាក្សាជាមួយចិន ដែលនាំទៅដល់ការអញ្ជើញជាផ្លូវការមួយចំពោះ ហ្គោបាឆូវ ឲ្យមកទស្សនកិច្ចនៅប្រទេសចិន និងទទួលស្គាល់ជាផ្លូវការមួយថា ទ័ពវៀតណាមនឹងដកចេញនៅឆ្នាំ១៩៨៩ ។

ក្រុមបដិបក្ខកម្ពុជា បានជួបប្រជុំពិភាក្សាគ្នាម្តងទៀត នៅទីក្រុងហ្សាកាតា ។ ប៉ុន្តែ តិចតួចណាស់ ដែលបានលទ្ធផល ព្រោះថាគ្រប់ភាគី សុទ្ធតែដឹងថា ប្រទេសមហាអំណាចទាំងឡាយ ដែលនឹងចូលប្រជុំសន្និសីទសន្តិភាពនាវដូវក្តៅ នឹងជួយទាមទារឲ្យពួកគេ ។ ពេលនោះ មានការផ្លាស់ប្តូរដ៏ធំមួយ ដែលជាជោគជ័យរបស់ ហ៊ុន សែន គឺគាត់អាចធ្វើឲ្យក្រុមទាំងឡាយ ទទួលយល់ព្រម«ការការពារដើម្បីកុំឲ្យកើតមានឡើងម្តងទៀត នូវនយោបាយប្រល័យពូជសាសន៍ និងការអនុវត្តន៍នៃរបប ប៉ុល ពត» ។

ក្រោយមក នៅថ្ងៃទី៥ ខែមេសា វៀតណាមបានប្រកាសដកទ័ពចេញពីកម្ពុជា ដោយគ្មានលក្ខខណ្ឌ នៅថ្ងៃទី៣០ ខែកញ្ញា ។ ប៉ុន្តែពត៌មានរបស់វៀតណាម ត្រូវបានបាំងជាស្រមោល ដោយពត៌មានធំមួយទៀត ដែល

នាំឲ្យមានការប្រែប្រួលយ៉ាងខ្លាំងដែរ ហើយជាពត៌មានដែលកាន់តែធំឡើង ទៅតាមការវិវត្តនៃពេលវេលាដែលក្រោយមក ក្លាយជាការចារឹកទុកក្នុងប្រវត្តិសាស្ត្រនយោបាយ ។

មានការផ្លាស់ប្តូររដ្ឋាភិបាលនៅឯសហរដ្ឋអាមេរិក ដោយ ចចប៊ូស ត្រូវបានប្រជាជនអាមេរិកបោះឆ្នោតឲ្យធ្វើជាប្រធានាធិបតី នៅខែវិច្ឆិកា ឆ្នាំ១៩៨៨ ហើយរៀបពិធីឡើងកាន់តំណែងនៅខែមករា ឆ្នាំ១៩៨៩ ។ នៅថ្ងៃទី១៥ ខែកុម្ភៈ សូវៀតបានដកទ័ពលើកចុងក្រោយរបស់គេចេញពីប្រទេសអាហ្គានីស្ថាន ។ នៅពេលរដ្ឋមន្ត្រីការបរទេសថ្មី ជេម បេកឺ របស់ ប៊ូស បានជួបជាមួយ សេវ៉ាដណាដហ្សេ នៅទីក្រុងវៀតណាមជាលើកទីមួយនៅខែមីនា នោះ ប្រទេសទាំងឡាយនៅអឺរ៉ុបខាងកើតមានការប្រែប្រួលយ៉ាងខ្លាំង ។ នៅថ្ងៃទី២ ខែមីនា ទាហានហុងគ្រី បានចាប់ផ្តើមផ្តួលរំលំជញ្ជាំងលួស តាមព្រំប្រទល់ជាមួយប្រទេសអូទ្រីស ។ នោះជាលើកទីមួយ នៃការបំបែករនាំងដែកដោយពិតប្រាកដ ។

គឺផ្នែកខាងនេះ នៃសង្គ្រាមត្រជាក់ ដែលបានស្ថិតនៅក្នុងចិត្តរបស់ បេកឺ នៅពេលដែលគាត់ធ្វើដំណើរទៅទីក្រុងមូស្គូ រយៈពេលពីរបីថ្ងៃនៅថ្ងៃទី១០ ខែឧសភា ដើម្បីជួបប្រជុំជាមួយ សេវ៉ាដណាដហ្សេ និងមេដឹកនាំសូវៀត ហ្គោបាឆូវ ។ ចំណែកនៅអាស៊ីវិញ មិនបានស្ថិតនៅក្នុងចិត្ត និងគម្រោងរបស់គាត់ទេ ។ ទោះបីជាពេលនោះ នៅក្បែរពេលដែល ហ្គោបាឆូវ បម្រុងនឹងទៅប៉េកាំងដើម្បីសម្រុះសម្រួលទំនាក់ទំនងចិន-សូវៀតក៏ដោយក៏ចំណុចបីរបស់ បេកឺ នៅក្នុងពេលប្រជុំ គឺការសម្រួលទំនាក់ទំនងជាទូទៅរវាងសូវៀត និងសហរដ្ឋអាមេរិកការនាំចូលអាវុធទៅអាមេរិកកណ្តាល និងការប្រជុំ ដែលបម្រុងនឹងកើតមានរវាងមេដឹកនាំនៃប្រទេសទាំងពីរ ។ ពួកគេក៏បាន និយាយពីការដកអាវុធនុយក្លេអែរពីអឺរ៉ុបខាងកើត ការគ្រប់គ្រងអាវុធផ្សេងទៀត និងការប្រជុំ NATO ។ បន្ទាប់ពីការជួបប្រជុំជាមួយ ហ្គោបាឆូវ មក បេកឺ បារម្ភថា “ដរាបណាយើងអាចធ្វើបាននូវគម្រោងដែលមានលក្ខណៈស្រមើស្រមៃ បែបនយោបាយសម្រាប់ការប្រជុំ ណាតូ ដែលនឹងកើតឡើងនៅពេលជិតមួយខែទៅមុខទៀតនោះ យើងនឹងត្រូវសូវៀតបាំងមុខបាត់ ខាងផ្នែកការទូតដោយសារ ហ្គោបាឆូវ” ។

ឃើញថា ហ្គោបាឆូវ ត្រូវគេបាំងបាត់ទៅវិញ តែមិនមែនដោយសារតែមេដឹកនាំសំខាន់ៗ នៅលើពិភពលោកទេ គឺដោយសារតែមានការធ្វើបាតុកម្មដែលធ្វើឡើងដោយក្រុមប្រឆាំងនឹងរដ្ឋាភិបាលចិន រាប់ពាន់នាក់នៅទីលានធៀនអានម៉េន ។

ប្រជាជនអាមេរិកភាគច្រើន មិនសូវយល់ច្បាស់អំពីបញ្ហាសង្គ្រាមត្រជាក់នៅអាស៊ី ។ ពួកគេយល់ច្បាស់ជាងអំពីសង្គ្រាមត្រជាក់លើទីវ៉ានអឺរ៉ុប ។ ភាពមិនចុះសម្រុងគ្នារវាងសូវៀត និងសហរដ្ឋអាមេរិក នៅអឺរ៉ុបជារឿងមួយដែលស្រួលវិភាគយល់ជាង ។ ម្ខាងជាផ្នែកលោកខាងលិច ដែលប្រកាន់លទ្ធិប្រជាធិបតេយ្យ ហើយប្រព័ន្ធមូលធននិយម បានចងភ្ជាប់អឺរ៉ុបខាងលិចជាមួយសហរដ្ឋអាមេរិកនៅក្នុងសម្ព័ន្ធទ័ព ណាតូ ។ ឯម្ខាងទៀតជាផ្នែកលោកខាងកើត ។ រដ្ឋនានានៅអឺរ៉ុបខាងកើត ត្រូវបានបង្ខំឲ្យចូលក្នុងប្រព័ន្ធរដ្ឋអំណាចកុម្មុយនិស្តជាមួយនឹង

សហភាពសូវៀត និងសម្ព័ន្ធទ័ពនៃកតិកាសញ្ញាសង្គ្រាម ។ ជញ្ជាំងមួយត្រូវបានដាក់វ័ណ្ឌទីក្រុងប៊ែរឡាំង ។ រហូតដល់ត្រឹមឆ្នាំ១៩៨៩ ឃើញច្បាស់ថាប្រព័ន្ធទីផ្សារមូលធននិយមមានជោគជ័យជាង ហើយប្រជាជននៅលោកខាងកើត គាំទ្រការផ្លាស់ប្តូរបែបប្រជាធិបតេយ្យ ។ ការសម្រុះសម្រួលគ្នានៃសង្គ្រាមត្រជាក់ ឃើញកើតមាននៅដូចប្រទេសហុងគ្រីជាដើម ។ ទាហានហុងគ្រី បានវាយទម្លាយជញ្ជាំងលួសចូលទៅក្នុងប្រទេសអូទ្រីស ។

ឯនៅអាស៊ីវិញ មានភាពស្មុគស្មាញជាងនោះ ។

ដល់ឆ្នាំ១៩៨៩ សង្គ្រាមត្រជាក់នៅអាស៊ីដើរលើសពីការមិនចុះសម្រុងគ្នារវាងប្រទេសមូលធននិយម និងប្រទេសកុម្មុយនិស្ត ហើយបានធ្លាក់ដល់ជម្លោះរវាងប្រទេសកុម្មុយនិស្តពីរ ចិន និងសូវៀត ។ នៅឆ្នាំ១៩៧៩ ក្រោយពេលដែលប្រធានាធិបតីជីមមី កាធ័របានផ្សះផ្សាទំនាក់ទំនងជាមួយចិន សហរដ្ឋអាមេរិកបានគាំទ្រចិន ។ ពេលដែលសហរដ្ឋអាមេរិកចូលជាមួយចិន ប្រទេសជប៉ុន និងប្រទេសនានានៅអាស៊ីអាគ្នេយ៍ ក៏ធ្វើតាម ។ បញ្ហាចាប់ផ្តើមដំបូង គឺបញ្ហាដណ្តើមអំណាចនយោបាយ ដូចជាការភ័យខ្លាចចំពោះការឈ្លានពានរបស់សូវៀតនៅអាហ្គានីស្ថាន និងការឈ្លានពានរបស់វៀតណាមនៅកម្ពុជាជាដើម ។ ក្រោយមកទៀត ការដណ្តើមអំណាចបានបន្ធូរមកត្រឹមការលេងល្បៀតនយោបាយវិញ ។ នេះមិនមែនជាបញ្ហាខុសគ្នារវាងកុម្មុយនិស្ត និងមូលធននិយមទេ ។ ចំពោះសហភាពសូវៀតវិញ ទីផ្សារសេរីចាប់ផ្តើមចាក់គ្រឹះនៅអាស៊ី ។ ដូចជានៅសហភាពសូវៀតមូលធន ទីផ្សារសេរី បានចាប់ផ្តើមកើតមាននៅប្រទេសកុម្មុយនិស្តនានា នៅអាស៊ី ។ នៅឯប្រទេសចិន និងវៀតណាម ក៏មានការប្រែប្រួលផ្នែកសេដ្ឋកិច្ច ទោះប្រព័ន្ធនយោបាយរបស់ពួកគេ នៅដដែលក៏ដោយ ។ ការធ្វើដំណើរទៅមកនៅប្រទេសកុម្មុយនិស្ត ក៏ចាប់ផ្តើមបើកចំហ ។ ហុងកុង លែងជាកន្លែងនៃលោកសេរីនៅក្រៅប៉ុស្តិ៍ចិនតែមួយទៀតហើយ ប៉ុន្តែនៅតែជាច្រកផ្លូវសេដ្ឋកិច្ច ជាធនាគារនៃប្រភពវិនិយោគទុនអន្តរជាតិ ដែលហូរចូលប្រទេសចិនជាងពាក់កណ្តាលដដែល ។ ការប្រជែងប្រឈមមុខគ្នាទៅវិញទៅមករវាងប្រទេសទាំងឡាយនៅអាស៊ី ការប្រយុទ្ធនៃសង្គ្រាមត្រជាក់ដ៏សាហាវបំផុតនៅឥណ្ឌូចិន និងកូរ៉េ មិនទាន់ចប់ពិតប្រាកដនៅឡើយទេ ។ លទ្ធិកុម្មុយនិស្តដែលស្ថិតនៅក្នុងរូបភាពថ្មី បានចាក់ឫសយ៉ាងរឹងមាំនៅចិន វៀតណាម និងកូរ៉េខាងជើង ។ អ្វីដែលបានសម្រេច គឺប្រទេសទាំងឡាយមិនថាប្រទេសនេះកាន់នយោបាយបែបណាទេ គឺបានត្រៀមខ្លួនរួចជាស្រេចដើម្បីបើកផ្លូវគ្នាទៅវិញទៅមក ហើយធ្វើគ្រាប់តាមនយោបាយរបស់ ឆាទីឆៃ ទាំងអស់ ដែលថា កែប្រែទីបទាំងអស់ពីកន្លែងសមរភូមិទៅជាទីផ្សារវិញ ។

ការបង្វែទិសនៃសង្គ្រាមត្រជាក់បែបអាស៊ីគឺ ប្រទេសមហាអំណាចកុម្មុយនិស្តទាំងពីរ ត្រូវសម្រុះសម្រួលគ្នាមុននឹង វាំងននឫស្សីធ្លាក់មកលើពួកគេ ។ ហើយនោះគឺជាគោលបំណងនៃដំណើររបស់ ហ្គោបាឆូវ មកប៉េកាំងនៅខែឧសភា ឆ្នាំ១៩៨៩ ។

មីខាអ៊ីល ហ្គោបាឆូវ បានមកដល់ប៉េកាំងនៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៨៩ ។ ពេលនោះសំណួរទីមួយ

ដែលគ្រប់គ្នាចោទសួរក្នុងចិត្តនោះគឺ «ហេតុអ្វីបានជាកិច្ចប្រជុំនោះមិនត្រូវបានគេលើកថ្ងៃ?» ។

នៅចំពេលនោះ មានក្រុមបាតុករកូនសិស្សរាប់ម៉ឺននាក់ បានមកនៅពាសពេញវាលធៀនអានម៉េន ជាកន្លែងដែលនឹងត្រូវគេទទួលស្វាគមន៍ ហ្គោបាឆូវ ជាផ្លូវការ ។ ពួកក្រុមនិស្សិតចិនបានលើកថ្ងៃអបអរសាទរទិវាយុវជន មកធ្វើការកាន់ទុក្ខការស្លាប់ភ្លាមៗរបស់ ហូ យ៉ាវបាង ដែលជាមេដឹកនាំមួយរូបរបស់ពួកគេ ។ នៅតាមផ្លូវសន្តិភាពសួគ៌ាទៅវាលធៀនអាម៉េន ពួកគេបានស្រែកបន្តថា «លទ្ធិប្រជាធិបតេយ្យ យើងចង់បានលទ្ធិប្រជាធិបតេយ្យ» ។ ពួកគេបានទទួលការគាំទ្រពីសំណាក់ប្រជាជនគ្រប់ស្រទាប់ ចាប់តាំងពីកម្មកររហូតដល់អ្នកជំនាញ ដោយពួកគេបានផ្តល់ដល់ក្រុមបាតុករនូវទឹក និងម្ហូបអាហារ ឬក៏ចូលរួមដើរជាមួយពួកគេនៅក្នុងទីលាននោះ ។ ភ្លាមនោះ បាតុកម្មនេះបានក្លាយជាបាតុកម្មស៊ីវិលមួយដ៏ធំជាងគេបង្អស់ នៅក្នុងប្រវត្តិសាស្ត្រកុម្មុយនិស្តចិន ។ ពួកគេ បានទាមទារឲ្យដាក់បញ្ចូលលទ្ធិប្រជាធិបតេយ្យទៅក្នុងមហិច្ឆតារបស់ចិន ក្នុងកម្មវិធីអភិវឌ្ឍន៍ទំនើបរបស់ចិន ។

ហ្គោបាឆូវ បានធ្វើដូចអ្វីដែលក្រុមនិស្សិតនោះ ទាមទារដោយបានបញ្ចូល ប៉េរ៉េស្ត្រូយកា ចូលទៅក្នុងផែនការ អភិវឌ្ឍន៍ទំនើបរបស់ប្រទេសគាត់ ដែលបានមកដល់ចំពេលអាក្រក់បំផុតដែលអាចទៅរួច ។ ក្រុមប្រឆាំងរដ្ឋាភិបាលចិនចាត់ទុកគាត់ជាវីរជន ។ ចំណែកឯម្ចាស់ផ្ទះរបស់គាត់ ដែលនឹងទទួលការជួបប្រជុំជាមួយគាត់ បែរជាគិតថា គំនិតរបស់គាត់ស្តីពីលទ្ធិប្រជាធិបតេយ្យនៅក្នុងលទ្ធិកុម្មុយនិស្ត ជាគំនិតដ៏គ្រោះថ្នាក់មួយ ។ បដានៅតាមទីលានធៀនអាម៉េន ប្រហែលជានិយាយពីគាត់ដូចជា «អគ្គរដ្ឋទូតប្រជាធិបតេយ្យ» ប៉ុន្តែគាត់មិនត្រូវបានគេអនុញ្ញាតឲ្យឃើញបដា ការធ្វើកូដកម្មដោយអត់អាហារ និងតង់បោះនៅតាមទីលាននោះទេ ។ ផ្ទុយទៅវិញ គេបានប្តូរទីតាំងទទួលគាត់ទៅឯវាលយន្តហោះ ដែលគ្មានទាំងព្រំក្រហមផង ។

ពេលវេលាដ៏វិសេសនៃជ័យជម្នះផ្នែកកិច្ចការទូតរបស់ តេង ដែលនឹងត្រូវធ្វើឡើងក្នុងថ្ងៃទីពីរនៃដំណើរទស្សនកិច្ចបីថ្ងៃរបស់ ហ្គោបាឆូវ នឹងត្រូវធ្វើនៅមហាសាលប្រជាជន ។ តែកន្លែងនោះត្រូវនិស្សិតយកធ្វើចំណាប់ខ្មាំង ។ ពេលដ៏វិសេសនោះ គឺការជួបគ្នារវាង តេង និងហ្គោបាឆូវ ដើម្បីសម្របសម្រួលទំនាក់ទំនងរវាងប្រទេសទាំងពីរ បន្ទាប់ពីមានការប្រេះឆារអស់រយៈពេលសាមសិបឆ្នាំមកហើយ ។ នៅនាទីចុងក្រោយ មេដឹកនាំសូវៀត ត្រូវបានរុញទៅទ្វារចំហៀងនៃទីលាន ដើម្បីឲ្យជួបនឹង តេង ។ ហ្គោបាឆូវ បានចុះហត្ថលេខាជាមួយ តេង នូវចំណុចទាំង១៨ ដោយមានដាក់បញ្ហាកម្ពុជាជាចំណុចចម្បង នៅក្នុងបញ្ជីដែលគម្រោងនឹងក្នុងពេលបន្តិចទៀតសម្រេច ។ មេដឹកនាំចិនត្រូវបានអញ្ជើញឲ្យទៅទស្សនកិច្ចនៅសូវៀត ។

នៅថ្ងៃបន្ទាប់ ដែលជាថ្ងៃចុងក្រោយនៃដំណើរទស្សនកិច្ច ហ្គោបាឆូវ ត្រូវជួបនិយាយជាមួយអ្នកសារព័ត៌មានអន្តរជាតិដែលជួបជុំគ្នាជាប្រវត្តិសាស្ត្រ ។ ប៉ុន្តែសន្និសីទកាសែតនេះ ស្ទើរតែនឹងត្រូវលុបចោលទៅហើយ ដោយសារតែក្រុមឡានរបស់ ហ្គោបាឆូវ ត្រូវបាំងស្ទះដោយបាតុករនៅតាមផ្លូវមកកាន់មហាសាល

ប្រជាជន ។ នៅពេលដែលបាតុករដឹងថាក្រុមឡានគណៈប្រតិភូនោះជានរណា ពួកគេក៏បើកផ្លូវឲ្យគាត់ទៅ ។ ពេលមកដល់គាត់ត្រូវបានទទួលការហ៊ោកញ្ជ្រៀវដោយក្រុមនិសិ្សត ប៉ុន្តែត្រូវប្រយ័ត្នធ្វើឲ្យម្ចាស់ផ្ទះគាត់ទាស់ចិត្ត ។ នៅពេលគាត់ទៅដល់ខាងក្នុង ហ្គោបាឆូវ និយាយថា ពួកក្រុមបាតុករធ្វើទៅលឿនពេក ។ គាត់និយាយថា "ពួកយើង ក៏មានក្រុមពួកឈាមក្តៅ ដែលចង់កែប្រែរបបសង្គមនិយមក្នុងរយៈពេលដ៏ខ្លីដែរ ប៉ុន្តែនៅក្នុងជីវិតពិត រឿងរ៉ាវវាមិនអាចធ្វើទៅបានលឿនដូចចង់បានទេ ។ ហើយអ្វីដែលអាចធ្វើទៅឲ្យលឿនបាន គឺមានតែក្នុងរឿងនិទានប៉ុណ្ណោះ" ។

ក្រោយមកមេដឹកនាំសូវៀតបានធ្វើដំណើរត្រឡប់ទៅប្រទេសវិញ ដូច្នេះមេដឹកនាំចិនក៏បណ្តោយឲ្យការរិះគន់ទាំងឡាយបន្តទៅ ។

បាតុកម្មដើម្បីលទ្ធិប្រជាធិបតេយ្យ បានកើតឡើងនៅតាមខេត្តក្រុងជុំវិញប្រទេសចិន ហើយក្រុមអ្នកសារព័ត៌មានជាច្រើននៅចាំធ្វើការផ្សព្វផ្សាយព័ត៌មាន ។ ការផ្សាយបន្តផ្ទាល់តាមរយៈវិទ្យុ និងទូរទស្សន៍បានធ្វើចេញពីទីលានធៀនអានម៉េន ។ មានមនុស្សជាងមួយលាននាក់ បានចេញមកគាំទ្រការធ្វើកូដកម្មអត់អាហារនេះ ។ មិនបានពីរថ្ងៃក្រោយមកផង នៅថ្ងៃទី២០ ខែឧសភា គេង បានចាប់ធ្វើប្រតិបត្តិការ ។ រដ្ឋាភិបាលបានប្រើច្បាប់អាជ្ញាសឹកនៅកន្លែងខ្លះនៃរដ្ឋធានី ហើយបានបញ្ជាទ័ពឲ្យចូលទៅក្រុងប៉េកាំង ដើម្បីរក្សាសណ្តាប់ធ្នាប់ ។ នៅសប្តាហ៍ដ៏តឹងតែងក្រោយមក ពួកនិសិ្សតបានរង់ចាំនូវការវាយលុក ដែលគេមិនបានគិតទុកជាមុន ។ ចំនួនក្រុមបាតុករក៏ចាប់ផ្តើមថយចុះ នៅពេលដែលហេតុការណ៍នៅទីលានធៀនអានម៉េន ចាប់ផ្តើមអាក្រក់ ហើយបាតុករមួយចំនួនចាប់ផ្តើមចុះចាញ់ចំពោះជំងឺផ្សេងៗ ។ ក្រោយមកភ្លាមៗនោះនៅថ្ងៃទី៣ ខែមិថុនា គេង បានបញ្ជាទ័ពឲ្យវាយលុក ។ ពួកគេត្រូវសម្រុកចូលតាមហ្វូងមនុស្សនៅតាមផ្លូវនៃក្រុងប៉េកាំង ហើយទទួលរងនៅការចំអកឡកឡឺយ ពីសំណាក់ប្រជាជននៅតាមផ្លូវថា ពួកគេជា "ទ័ពប្រជាជន" ដែលកង់ឡានរបស់ពួកគេត្រូវប្រជាជនចាក់ឲ្យធូរខ្យល់អស់ ។ ដល់ពេលថ្ងៃត្រង់យុទ្ធនាការដ៏គ្រោះថ្នាក់ និងពេញធឹងមួយ ដើម្បីបំបែកក្រុមចលនាប្រឆាំងបានចាប់ដំណើរការ ។ ការប្រយុទ្ធចាប់ផ្តើមផ្ទុះឡើងនៅតាមកន្លែងមួយចំនួននៅក្នុងទីក្រុង ។ ក្រុមទ័ពបានប្រើឧស្ម័នបង្ហូរទឹកភ្នែក និងវាយក្រុមបាតុករ ។ គេនិយាយថា មានទ័ពប្រមានជាង ៣០០,០០០នាក់ បានដាក់ពង្រាយនៅក្នុង និងជុំវិញប៉េកាំង ។ ដល់ម៉ោង៦កន្លះល្ងាច រដ្ឋាភិបាលបញ្ជាឲ្យគ្រប់គ្នាចេញឲ្យអស់ពីលើផ្លូវ ។

ការសម្លាប់បានចាប់ផ្តើមនៅម៉ោង១០យប់ ដោយទ័ពដែលចូលមកពីទិសខាងលិច ។ រនាំងរថយន្តក្រុង និងឡាន ឆេះទាំងដួល មិនអាចបញ្ឈប់ពួកគេឲ្យសម្រុកចូលក្នុងទីលានធៀនអានម៉េនបានទេ ។ ក្រោយមកឃើញពួកគេចេញមកពីទិសផ្សេងៗគ្នា ។ ទ័ពបានបាញ់សម្រុកលើក្រុមបាតុករ និងប្រជាជន ដែលមិនស្តាប់បង្គាប់រដ្ឋាភិបាលដែលឲ្យនៅតែក្នុងផ្ទះ ។ ផ្លូវពោរពេញទៅដោយឈាម ដោយទ័ពប្រើកាំភ្លើងអាកា ៤៧របស់ពួកគេបាញ់ និងបោះគ្រាប់បែក និងបាញ់ផ្សែងបង្ហូរទឹកភ្នែក ដើម្បីវែកផ្លូវចូលទៅក្នុងទីលានធៀនអានម៉េមន ។ កូនសិស្ស

ម្នាក់ បានស្រែកទៅទាហានថា «មើលទៅថាឯងបានធ្វើអ្វីខ្លះមកលើបងប្អូនរបស់ឯង» ។ ការវាយកម្ទេចរបស់រដ្ឋាភិបាលមកលើប្រជាជនដែលគ្មានអាវុធ ត្រូវបានផ្សព្វផ្សាយជាពត៌មានជុំវិញពិភពលោក ។

អ្នកបាញ់អាវុធក្នុងជួរទ័ព បានបាញ់រើសយកអ្នកនៅជួរមុខនៃក្បួនបាតុករ ហើយក្រុមអាវក្រោះ និងរថក្រោះសម្រុកចូល ហើយកិនអ្វីៗទាំងអស់ ដែលនៅពាំងមុខពួកគេ ។ ទ័ពប្រជាជនចិនបានធ្វើឃាដប្រជាជានរាប់ពាន់នាក់ដោយគ្មានស្តាយក្រោយអ្វីបន្តិចសោះ ។ ដល់ម៉ោង៦ព្រឹកថ្ងៃទី៤ សាកសពមាននៅពាសពេញទីលានធៀនអានម៉េន និងពេញតាមផ្លូវក្បែរៗនោះ ។ ផ្សែងខ្មៅទ្រុបចេញពីការឆេះគំនររថយន្តក្រុង និងរថក្រោះ ។ អត្រាស្លាប់របស់ប្រជាជនស៊ីវិល គឺប្រហាក់ប្រហែលមាននៅចន្លោះពី២០០០ ទៅ៦០០០នាក់ ហើយទ័ពប្រហែលជា១០០០នាក់ ។ ទាហានបានប្រកាសជ័យជម្នះលើ«ទម្រង់នៃសង្គម» ។ លោកខាងក្រៅហៅហេតុការណ៍នោះថា ជាការសម្លាប់រង្គាលនៅទីលានធៀនអានម៉េន ។ នៅតាមបែបរបស់ខ្លួនឯងនោះធៀនអានម៉េនជាសញ្ញាស្រពេចស្រពិលនៃទីបញ្ចប់សង្គ្រាមត្រជាក់ ។

នៅពេលកំពុងមានការរញ្ជួយផ្នែកនយោបាយ កូដ ម៉ាតាំង បានធ្វើដំណើរមកដល់ប៉េកាំង ហើយនៅថ្ងៃទី៣ ខែមិថុនា គាត់បានជិះយន្តហោះតូចមួយទៅឈីងដាវ ដែលនៅទីនោះ សម្តេច ព្រះនរោត្តម សីហនុ ត្រូវបានគេការពារដោយសុវត្ថិភាព ។ គាត់និយាយថា «ការងាររបស់គាត់ គឺយកសំបុត្រអញ្ជើញទៅចូលរួមអង្គសន្និសីទអន្តរជាតិស្តីពីកម្ពុជា ទៅថ្វាយដល់ទ្រង់ដោយផ្ទាល់ដៃ» ។ ហើយគាត់ក៏អាចមើលឃើញសម្រាប់វិភាគដឹងថាតើបញ្ហានៅចិនពេលនោះ មានផលប៉ះពាល់យ៉ាងណាចំពោះសន្តិភាពរបស់កម្ពុជាក្នុងពេលអនាគត ។ នៅពេលនោះ ចិនកំពុងតែខឹងចំពោះការជះឥទ្ធិពលរបស់អន្តរជាតិ ហើយគេឃើញជាពិសេសថា អាមេរិកជាអ្នកញុះញង់ឲ្យមានចលនា ដើម្បីលទ្ធិប្រជាធិបតេយ្យ ។ ចិនជាកូនសោដែលចាក់ដោះគ្រប់បក្សខ្មែរទាំងឡាយ ឲ្យស្រុះស្រួលគ្នា តែក្នុងពេលនោះ ចិនគ្មានអារម្មណ៍សម្រុះសម្រួលទេ» ។

នៅពេលដែលម៉ាតាំងចូលគាល់សម្តេច ព្រះនរោត្តម សីហនុ គាត់បានទូលទ្រង់ថា «សូមទ្រង់ទតមើលរឿងដែលកើតឡើងនៅចិនចុះ ។ ប្រទេសចិនគួរតែធ្វើតាមទ្រង់ ។ សូមទ្រង់ធ្វើអ្វីដែលទ្រង់គិតថាឆ្លាត ។ សព្វថ្ងៃ ចិនកំពុងតែច្របូកច្របល់» ។

សម្តេច ព្រះនរោត្តម សីហនុ បានឆ្លើយមកគាត់វិញថា «ចិនពូកែរក្សាទឹកមុខប្រឈមនឹងលោកខាងក្រៅណាស់» ។ នៅពេលដែលទ្រង់ចេញពីចិនទៅចូលរួមសន្និសីទទ្រង់មានបន្ទូលថា ទ្រង់យាងទៅព្រោះតែបារាំងប៉ុណ្ណោះ ។

សហរដ្ឋអាមេរិករំពេចនោះក៏ដាក់ទណ្ឌកម្មសេដ្ឋកិច្ចដល់ចិន ។ តែអ្វីដែលម៉ាតាំងមិនដឹង គឺសហរដ្ឋអាមេរិកបានបញ្ជូនតំណាងជាន់ខ្ពស់របស់គេពីររូប មកទីក្រុងប៉េកាំងប្រទេសចិន ដើម្បីប្រាប់ថា ទោះបីជាសហរដ្ឋអាមេរិកថ្កោលទោសចំពោះការសម្លាប់រង្គាលនោះក៏ដោយ ក៏អាមេរិក នៅចង់រក្សាទំនាក់ទំនងការទូតជាមួយចិនដដែល ។

លោករដ្ឋមន្ត្រីការបរទេស បេកឺ ជាឥស្សរជនចុងក្រោយគេ ដែលបានទទួលលិខិតអញ្ជើញឲ្យទៅចូលរួមអង្គសន្និសីទ ។ គាត់បានឲ្យជំនួយការរបស់គាត់ខាងផ្នែកអាស៊ីបូព៌ា រីឆាដ៍ សូឡូម៉ុង ធ្វើការរៀបចំទាំងអស់ ។ សូឡូម៉ុង ជាអ្នកជំនាញខាងចិនដូចជា ម៉ាតាំង និងវ៉ូហ្កាឆ្វូវ ដែរ ។ នៅតាមគេហបថក្នុងក្រសួងការបរទេសអាមេរិក បេកឺ បានឲ្យឈ្មោះថ្មីដល់ជំនួយការរបស់គាត់ថា ជាជំនួយការរដ្ឋមន្ត្រីរបស់កម្ពុជា ព្រោះថា បញ្ហារបស់កម្ពុជា សឹងតែស្រូបពេលរបស់ សូឡូម៉ុង ទាំងអស់ទៅហើយ ។

បេកឺ និងក្រុមការងាររបស់ ប៊ូស ទាំងអស់ បានផ្តោតការងាររបស់ពួកគេលើចលនាដ៏គួរឲ្យចាប់អារម្មណ៍នៅអឺរ៉ុប ។ នៅថ្ងៃទី៦ ខែមិថុនា នាយករដ្ឋមន្ត្រីកុម្មុយនិស្តរបស់ប៉ូឡូញ បានលាលែងចេញពីតំណែង បើកឲ្យមានការទាមទារអំណាច ។ នៅខែកក្កដាប្រធានាធិបតី ប៊ូស បានមកធ្វើទស្សនកិច្ចនៅប្រទេសហុងហ្គ្រី ។ នៅទីនោះ គេបានឲ្យគាត់នូវរូបវាំងននដែកក្នុងកែវមួយ ដើម្បីឲ្យជាសញ្ញាថា ប្រទេសនោះចង់ផ្តួលជញ្ជាំងនោះចោល ឲ្យជនភៀសខ្លួនរាប់ពាន់នាក់មកពី ប្រទេសអាល្លឺម៉ង់ខាងកើតចូលមក ។ នៅក្នុងខែដដែលនោះ ហ្គោបាឆូវ បានមកធ្វើទស្សនកិច្ចនៅសភាសហគមន៍អឺរ៉ុបនៅស្ត្រាសបួរក៏ ។ គាត់បានប្រកាសថា សង្គ្រាមត្រជាក់នឹង«ក្លាយជារឿងបំភ្លេចចោលមួយ» ។

នៅក្នុងបរិយាកាសលាយឡំដោយការរីងទទឹងរបស់ចិន និងសុទិដ្ឋិនិយមរបស់ប្រទេសនៅអឺរ៉ុប សន្និសីទដើម្បីសន្តិភាពនៅកម្ពុជា បានធ្វើឡើងនៅប៉ារីសនៅចុងខែ ក្រោមការទទួល និងរៀបចំរួមគ្នាមួយ រវាងរដ្ឋមន្ត្រីការបរទេសបារាំង និងរដ្ឋមន្ត្រីការបរទេសឥណ្ឌូនេស៊ីអាលីអាឡាតាស ។ សន្និសីទនោះ ឆ្លុះបញ្ចាំងដោយលើកឡើងពីការប្រជុំរវាង ហ្គោបាឆូវ និងតេង ព្រោះថាសន្និសីទនោះ អាចជោគជ័យទៅបានលើកលែងតែប្រទេសកុម្មុយនិស្តដែលជាសត្រូវនឹងគ្នាព្រមឈប់ប្រយុទ្ធគ្នា ។ ចិនគាំទ្រខ្មែរក្រហមរបស់ ប៉ុល ពត ហើយសាធារណរដ្ឋប្រជាមានិតកម្ពុជា ត្រូវបានគាំទ្រដោយសហភាពសូវៀត ។ ប្រទេសមហាអំណាចពីរត្រូវគេហៅឲ្យមកជុំគ្នា ដើម្បីដោះស្រាយបញ្ហារបស់ប្រទេសដ៏តូចតាច និងទន់ខ្សោយជាងគេមួយ ។ សម្តេច ព្រះនរោត្តម សីហនុ តំណាងឲ្យការប្រែប្រួលឆ្នោតដ៏សំខាន់មួយនៃប្រទេស ដែលមិនមែនកុម្មុយនិស្តទាំងឡាយរួមទាំងអាមេរិក ។ ទោះបីជា ហ៊ុន សែន មិនសូវបានទទួលការគាំទ្រពីអន្តរជាតិដូចគូប្រឆាំងរបស់គាត់ក៏ដោយ ក៏គាត់មានរបស់មួយ៉ាងដែលគ្រប់បក្សខ្មែរទាំងអស់ចង់បានគ្រប់គ្នា នោះគឺការគ្រប់គ្រងលើប្រទេសកម្ពុជា ។

កម្ពុជាបានមកដល់មុនគេដើម្បីការរៀបចំប្រជុំនៅវិមាន ឡាសែល សាំងក្លូដ នៅឯជាយក្រុងប៉ារីស ។ ឌុយម៉ាស បានស្វាគមន៍ ហ៊ុន សែន, សម្តេច ព្រះនរោត្តម សីហនុ , សឺន សាន, និង ខៀវ សំផន ។ គាត់បាននិយាយថា គាត់សង្ឃឹមថា សន្តិភាពនឹងកើតមាននៅកម្ពុជា បន្ទាប់ពីសង្គ្រាមដែលអូសបន្លាយអស់រយៈពេលជាង២០ឆ្នាំ «នៃអំពើប្រល័យពូជសាសន៍ផ្តាច់ការ និងដោយការឈ្លានពានរបស់ទ័ពបរទេស» ។ ហ៊ុន សែន បានប្រកាសថ្ងៃខែពិតប្រាកដ នៃការដកទ័ពវៀតណាម គឺពីថ្ងៃទី២១ ខែកញ្ញា ដល់ថ្ងៃទី២៦ ខែកញ្ញា ។ ការជជែកគ្នាពេលនោះ

បង្រួញមកត្រឹមថា តើក្រុមទាំងនោះនឹងត្រូវប្រជុំជាកៅអីបែបណា ជាគណបក្សបួននៃប្រទេសមួយ ឬក៏ជាគូបដិបក្ខពីរ ។ ជម្រើសជាប្រទេសមួយត្រូវបានគេសម្រេច ។ សន្និសីទបានធ្វើឡើងនៅថ្ងៃទី៣០ ខែកក្កដា នៅមជ្ឈមណ្ឌលក្លេប៊ែរដ៏ស្អាតមួយនៅប៉ារីស ។

មានប្រទេសចំនួនម្ភៃដែលបានបញ្ជូនរដ្ឋមន្ត្រីការបរទេសរបស់ពួកគេឲ្យមកចូលរួម ហើយក្នុងនោះ ក៏មានរដ្ឋមន្ត្រីការបរទេសចិន គៀន គីចេន ចេញមុខលើឆាកអន្តរជាតិជាលើកទីមួយ បន្ទាប់ពីការសម្លាប់រង្គាលនៅទីលានធៀនអានម៉េន ។ ប្រទេសធំៗទាំងឡាយ បានឡើងថ្លែងសុន្ទរកថាអស់រយៈពេលពីរថ្ងៃ លើកឡើងពីគម្រោងនៃកិច្ចព្រមព្រៀង ។ សេចក្តីថ្លែងការណ៍របស់ បេកឺ មានលក្ខណៈខ្លាំងជាងជំហររបស់អាមេរិកពីមុនៗមក ។ គាត់និយាយថា «ខ្មែរក្រហមមិនគួរមានចំណែកនៅក្នុងកម្ពុជាឡើយ» ។ នោះធ្វើឲ្យបរិយាកាសកាន់តែតឹងតែង ។ អ្វីដែលគួរឲ្យភ្ញាក់ផ្អើលគឺ គៀន គីចេន មិនបាននិយាយដល់ខ្មែរក្រហមចំៗឈ្មោះ ហើយក៏មិនបានធ្វើការទាមទារថា ខ្មែរក្រហមត្រូវមានចំណែកធំនៅក្នុងរដ្ឋាភិបាលនោះដែរ ។

នៅក្នុងសុន្ទរកថារបស់គាត់ហាក់ដូចជានិយាយពីអ្វីដែលរដ្ឋមន្ត្រីការបរទេសសូវៀត សេវ៉ាដណាដហ្សេបាននិយាយថា សន្និសីទគួរដោះស្រាយបញ្ហាក្នុងអំណាចរបស់គេ ។ នោះគឺការបញ្ឈប់ការលូកដៃ និងជំនួយពីបរទេសដល់គណបក្សទាហាន និងបង្កើតឡើងនូវក្រុមរក្សាសន្តិសុខអន្តរជាតិនៅកម្ពុជា ដើម្បីធ្វើការរៀបចំបោះឆ្នោតជាទូទៅមួយ ។ នៅពីក្រោយឆាកចិនក៏បានជួយដែរ ។ ដោយមានសំណូមពរម្តងហើយម្តងទៀតរបស់ឌុយម៉ាស ចិនបានធ្វើពិធីលៀងអាហារពេលល្ងាចមួយដល់ខ្មែរក្រហម និងមេដឹកនាំក្រុមប្រឆាំងទាំងឡាយនៅស្ថានទូតរបស់ពួកគេ ។ ចិនបានប្រាប់ខ្មែរក្រហមឲ្យបញ្ឈប់គំនិតទាមទារឲ្យថ្កោលទោសលើការឈ្លានពានរបស់វៀតណាម ។ ពួកគេក៏យល់ព្រម ។

បេកឺបានផ្តល់រង្វាន់ដល់ គៀន គីចេន ក្រោយពីពេលដែលគាត់ជួបនិយាយជាមួយខ្មែរក្រហម និងការជំរុញដែកដើម្បីសន្តិភាពរបស់គាត់ ។ រដ្ឋមន្ត្រីការបរទេសរបស់អាមេរិក បានជួបជាមួយរដ្ឋមន្ត្រីការបរទេសចិននៅឯសន្និសីទ ដែលជាការជួបជាសាធារណៈជាលើកទីមួយក្រោយពីហេតុការណ៍នៅទីលានធៀនអានម៉េន ។

តែម្នាក់ដែលចម្លែកនោះគឺ សម្តេច ព្រះនរោត្តម សីហនុ ។ ដោយរង្វង់នៅជុំវិញភ្នែក និងសម្តីដ៏ទន់របស់ព្រះអង្គ ទ្រង់បានជំរុញការពារខ្មែរក្រហមយ៉ាងខ្លាំង ។ ទ្រង់មានបន្ទូលថា នៅកម្ពុជាមានតែបញ្ហាមួយគត់ ហើយនោះគឺ ការគ្រប់គ្រងរបស់វៀតណាមនៅកម្ពុជា កម្ពុជាពុំធ្លាប់មាន ហើយពុំមានសង្គ្រាមស៊ីវិលនៅកម្ពុជាឡើយ ។ ក្រោយមក ព្រះអង្គក៏ក្រឡាស់បន្ទូលរបស់ទ្រង់ ដែលប្រៀបធៀបខ្មែរក្រហមទៅនឹងអំពើប្រល័យពូជសាសន៍របស់អ៊ីត្លែរ ហើយប្រៀបធៀបវៀតណាមទៅនឹងពួកហ្វាស៊ីសទៅវិញ» ។

«បើធ្វើពើថានៅកម្ពុជាមានសង្គ្រាមស៊ីវិល គឺហាក់បីដូចជាថាសង្គ្រាម ដែលធ្វើដោយកងទ័ពបារាំងសេរីនៅនៅក្នុងសង្គ្រាមលោកលើកទីពីរ មិនមែនប្រឆាំងនឹងអាល្លឺម៉ង់ អ៊ីត្លែរ ប៉ុន្តែបែជាប្រឆាំងនឹងសហគមន៍

បារាំងទៅវិញ ។

ក្រោយមកបន្ទាប់ពីប្រកាសខ្លួនទ្រង់ថា ជាបិតាឯករាជ្យជាតិរួចមក សម្តេច ព្រះនរោត្តម សីហនុ បានទាមទារឲ្យដាក់ខ្មែរក្រហមចូលក្នុងរដ្ឋាភិបាលចតុភាគី ដោយឲ្យរដ្ឋាភិបាលរបស់ ហ៊ុន សែន តែមួយគៅអីប៉ុណ្ណោះ ។ បើគំនិតនោះ ត្រូវបានគេបដិសេធចោល នោះវៀតណាមនឹងបន្តការ «ទទួលខុសត្រូវទាំងស្រុងនូវរាល់ការបន្តសង្គ្រាម និងការលំបាកទាំងឡាយនៅកម្ពុជា» បន្តទៀត ។

មកដល់សប្តាហ៍ទីមួយនៃខែសីហា សន្និសីទបានយល់ព្រមនូវការរៀបចំគម្រោងសន្ធិសញ្ញាសន្តិភាពអន្តរជាតិមួយ ប៉ុន្តែកម្ពុជាមិនព្រមទទួលយក ។ អ្នកម្ចាស់ជំនួយធំរបស់ពួកគេក៏ចាកចេញពីប៉ារីសភ្លាម ។ នៅក្នុងអង្គប្រជុំមិនឈប់ឈរ ពួកគេបានប្រកែកអស់រយៈពេលបីសប្តាហ៍ រួមមានទាំងរឿងស្តីពីបេសកកម្មរកការពិតរបស់អង្គការសហប្រជាជាតិនៅកម្ពុជាផង ។

ម៉ាតាំង បានទទួលស្គាល់ថា «កិច្ចប្រជុំនៅសប្តាហ៍ទីមួយមានដំណើរការទៅល្អ ប៉ុន្តែនៅសប្តាហ៍ទីពីរ គ្រប់យ៉ាងមិនដំណើរការទៅបានល្អទេ» សម្តេច ព្រះនរោត្តម សីហនុបដិសេធមិនព្រមកម្រើកទៅមុខ វាយបករាល់ការលើកនិយាយពីខ្មែរក្រហមពីអំពើប្រល័យពូជសាសន៍ ហើយមិនព្រមទទួលស្គាល់ថា ពួកខ្មែរក្រហម និងអំពើប្រល័យពូជសាសន៍របស់ពួកគេជាហេតុផល ដែលបណ្តាលឲ្យមានបញ្ហានៅកម្ពុជាឡើយ ។ គ្រប់យ៉ាងសុទ្ធតែជាកំហុសរបស់វៀតណាម និងរដ្ឋាភិបាលរបស់ ហ៊ុន សែន ។

ម៉ាតាំង បានទៅលេងសម្តេច ព្រះនរោត្តម សីហនុ រាល់ថ្ងៃនៅសណ្ឋាគារហ្វូលីដេអ៊ីនជិតព្រលានយន្តហោះជាកន្លែង ដែលទ្រង់ចបេសទារស្នាក់នៅទីនោះ ។ «ទ្រង់ថា ទ្រង់មិនចង់ចូលរួមក្នុងសន្និសីទ ដែលមានសុទ្ធតែពួករដ្ឋមន្ត្រីការបរទេសធុនទាបទេ ។ ទ្រង់ទាមទារការមើលសកម្មភាពបន្តផ្ទាល់តាមទូរទស្សន៍វិញ» ។

នៅថ្ងៃទី១៨ ខែសីហា ឌុយម៉ាស បានយាងសម្តេច ព្រះនរោត្តម សីហនុ លៀងអាហារថ្ងៃត្រង់ជាមួយម៉ាតាំង ។ ឌុយម៉ាស ទូលទ្រង់ថា បារាំងដាក់ឲ្យមានសន្និសីទនេះ ព្រោះចង់ផ្តល់ឱកាសថ្វាយទ្រង់ ។ ពេលនោះសម្តេច ព្រះនរោត្តម សីហនុក៏សួរវិញថា តើអាចមានផ្លូវឲ្យកម្ពុជាស្រុះស្រួលគ្នាទេ? តាមរយៈសម្តីរបស់ម៉ាតាំង «ឌុយម៉ាស និងខ្ញុំ បានថ្វាយ យោបល់ថា ក្រុមប្រឹក្សាជាតិចតុភាគី ដែលមានគណបក្សពីរក្នុងរដ្ឋាភិបាល» ។ ក្រោយមកពួកគេក៏ស្នើឲ្យទ្រង់ទុក រឿងដែល ពួកគេនិយាយនេះជាសម្ងាត់សិន ហើយសម្តេច ព្រះនរោត្តម សីហនុក៏យល់ព្រម ។ ក្នុងរយៈពេលតែប៉ុន្មានម៉ោង ប៉ុណ្ណោះ ពួកក្រុមតស៊ូបានប្រកាសថា នោះគឺជាការដាក់មកពីប្រទេសបារាំងដែលពួកគេមិនអាចទទួលយកបាន ។ ហើយពួកគេក៏ទទួលបានការគាំទ្រពីម្ចាស់ជំនួយរបស់ពួកគេ ។ នៅទីបញ្ចប់នៃអង្គសន្និសីទ អ្នកគាំទ្ររបស់សម្តេច ព្រះនរោត្តម សីហនុ នៅតែគាំទ្រទ្រង់ ។ ប្រទេសសិង្ហបុរីជាឧទាហរណ៍ បាននិយាយគាំទ្រសម្តេច ព្រះនរោត្តម សីហនុ យ៉ាងខ្លាំង ហើយប្រឆាំងនឹង ហ៊ុន សែន បានលុបចោលការផ្លាស់ប្តូរជំហររបស់ប្រទេសអាស៊ាន ដែលនាយករដ្ឋមន្ត្រីថៃ ឆាទីឆៃ បានចាប់ផ្តើមនោះ ។ នៅក្នុងគំនិត

របស់សិង្ហបុរីដោយតាមរយៈឯកអគ្គរដ្ឋទូតរបស់គេ ធុមមី ធី បីកុ សន្និសីទនេះ «និយាយអំពីការឈ្លានពានរបស់វៀតណាមមកលើទឹកដីរបស់កម្ពុជា និងថាតើធ្វើយ៉ាងណា ដើម្បីបញ្ចប់នូវការគ្រប់គ្រងរបស់វៀតណាម ហើយទុកឲ្យកម្ពុជារស់នៅដោយសន្តិភាព» ។ ហើយនៅពេលត្រូវបានគេសួរអំពីការទទួលខុសត្រូវរបស់ខ្មែរក្រហម គាត់បានឆ្លើយដូចជាប្រទេសរបស់គាត់អ៊ីចឹងដែរ «ខ្ញុំមិនចង់ត្រឡប់ដើរទៅរកអតីតកាលវិញទេ ខ្ញុំចង់មើលទៅអនាគតជាង» ។

នៅយប់ជជែកគ្នាថ្ងៃចុងក្រោយនោះ សម្តេច ព្រះនរោត្តម សីហនុ បានឡើងនិយាយដោយភ្នែកស្រវាំង ហើយស្រែកខ្លាំងៗថា «ខ្ញុំគាំទ្រអំពើប្រល័យពូជសាសន៍ ខ្ញុំគាំទ្រអំពើប្រល័យពូជសាសន៍» ។ ក្រោយមកដោយដឹងថា ទ្រង់មិនគួរមានបន្ទូល ដូច្នោះនោះ ព្រះអង្គក៏ប្រែសម្តីថា ទ្រង់ប្រាកដជាប្រឆាំងនឹងអំពើប្រល័យពូជសាសន៍ដែលប្រព្រឹត្តដោយខ្មែរក្រហម ហើយបន្ថែមថា «ខ្ញុំសុំទោស ខ្ញុំមិនបានផ្ទំអស់៤៨ម៉ោងហើយ» ។

ម៉ាតាំងនៅតែស្មោះស្ម័គ្រនឹងទ្រង់ហើយនិយាយថា «សម្តេច ព្រះនរោត្តម សីហនុ មានបន្ទូលថា ទ្រង់បានត្រៀមខ្លួនរួចជាស្រេច ដើម្បីប្រយុទ្ធ ហើយព្រះអង្គមានក្តីរំភើបចំពោះការគាំទ្ររបស់ចិន អាស៊ាន និងសហរដ្ឋអាមេរិកចំពោះទ្រង់ ។ ប៉ុន្តែនៅចុងខែព្រះអង្គមានការខ្វាយខ្វល់យ៉ាងខ្លាំងថា ទ្រង់នឹងត្រូវគេបន្ទោសបើដើរអស់ក្រឡាអុក ។ ទ្រង់មិនបានផ្ទំអស់ជិតមួយសប្តាហ៍ ។ ទ្រង់មានភាពស្មុគស្មាញ និងធុញថប់យ៉ាងខ្លាំង» ។

ដល់ពេលនោះព្រះអង្គក៏បានបោះបង់ចោលនូវទម្លាប់ផ្ទំពេលថ្ងៃរបស់ទ្រង់ ហើយធ្វើការ ដោយមិនសោយក្រយាពេលយប់របស់ទ្រង់ ។ «នៅក្នុងសប្តាហ៍នោះ ទ្រង់មានភ្ញៀវមិនឈប់ឈរ នៅរហូតដល់ពេលកណ្តាលអធ្រាត្រ និងម៉ោងមួយភ្លឺ ហើយទ្រង់ផាយហត់ណាស់» ។

បន្ទាប់ពីការជជែកប្រកែកគ្នាដោយមិនសម្រេចអស់ពេលមួយខែមក ឌុយម៉ាស បានលើកសន្និសីទ ដែលគម្រោងធ្វើនៅថ្ងៃទី៣០ ខែមេសា ។ គាត់និយាយថា «ប្រហែលជាយើងគួរទៅឲ្យជ្រៅ ហើយចំណេញពេល និងជៀសវាងការរងទុក្ខវេទនា និងស្លាប់ជីវិតកាន់តែច្រើនទៀត» ។

សម្តេច ព្រះនរោត្តម សីហនុ ខាតច្រើនជាងគេ ជាពិសេសជាមួយរដ្ឋាភិបាលបារាំងដែលគេថា សម្តេច ព្រះនរោត្តម សីហនុ ឥឡូវ លែងមានជោគជ័យច្រើនទៀតហើយ ។ មានការជជែករវាងក្រុមគណៈប្រតិភូផ្សេងទៀតដែលខាតពេលអស់មួយខែ ហើយប្រាក់អស់១៥លានហ្វ្រង់ តែសម្តេច ព្រះនរោត្តម សីហនុ បែរជាដើរចេញពីការជជែកទៅវិញ ។

ហ៊ុន សែន ចាកចេញពីប៉ារីសដោយប្រកាសថា គាត់ត្រូវ«សម្តេច ព្រះនរោត្តម សីហនុ បោកប្រាស់» ។ រដ្ឋមន្ត្រីការ បរទេសវៀតណាម ង្វៀន កូថាច់ បាននិយាយថាទ័ពវៀតណាមនឹងចេញពីកម្ពុជាក្នុងរយៈពេលមួយខែ ហើយថា សហរដ្ឋអាមេរិកត្រូវគោរពពាក្យសន្យារបស់ខ្លួន បើចង់ផ្សះផ្សារទំនាក់ទំនងជាមួយហាណូយ ។ នៅក្នុងការជួបគ្នា ក្រៅផ្លូវការមួយ រីឆាដ់ សូឡូម៉ុង បានប្រាប់ ថាច់ ថា ក្រៅពីការដកទ័ពចេញពីកម្ពុជារបស់វៀតណាម

សហរដ្ឋអាមេរិក មិនទាន់ត្រៀមខ្លួនក្នុងការផ្សះផ្សាទំនាក់ទំនងជាមួយហាណូយទេ ។

ជាងនោះទៅទៀត គាត់បាននិយាយពីគំនិតផ្ទាល់ខ្លួនរបស់គាត់ថា ប្រទេសជាច្រើនខ្លាច សម្ដេច ព្រះនរោត្ដម សីហនុ និងខ្មែរក្រហម បង្អាក់ដំណើរការសន្តិភាព ព្រោះពួកគេដឹងថា ទ័ពវៀតណាមនឹងដកថយ ដែលធ្វើឲ្យពួកគេគិតថា គេនឹងឈ្នះប្រទេសមកវិញដោយប្រើកម្លាំងទ័ព ។ “ពួកគេឆ្លៀតយកប្រយោជន៍ពីការដកទ័ពរបស់ពួកយើង ដើម្បីសាកល្បងមើលលើកចុងក្រោយ” ថាច់ និយាយ ។

ហើយគាត់ព្រមានថា ប្រសិនបើខ្មែរក្រហមខិតមកជិតដែលអាចគំរាមកំហែងក្រុងភ្នំពេញបាន វៀតណាមនឹងមិនត្រឡប់មកជួយ ហ៊ុន សែន វិញទេ “ទាំងនោះ នឹងក្លាយជាការទទួលខុសត្រូវរបស់សហគមន៍ពិភពលោកជាពិសេស ប្រទេសទាំងឡាយណា ដែលទាមទារឲ្យមានការដកទ័ពចេញ” ។

នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៨៩ វៀតណាមបានដកទ័ពលើកចុងក្រោយចេញពីកម្ពុជា ។ ពួកគេបានប្រកាសពីចំនួនស្លាប់របស់គ្នាគេ ចាប់តាំងពីពេលចូលមកប្រទេសកម្ពុជានៅឆ្នាំ១៩៧៨ ។ ពួកគេបាននិយាយថាមានទាហានវៀតណាមស្លាប់ពេលនោះមានចំនួន៥៥៣០០ ។ ចំនួននេះ មានលេខប្រហាក់ប្រហែលនឹងចំនួនទាហានអាមេរិកស្លាប់នៅក្នុងសង្គ្រាមវៀតណាមដែរ ។ ក្រុមតន្ត្រីកាងទ័ពកម្ពុជា បានប្រគុំកំដរដំណើរចាកចេញនារីកម្ពុជាក្នុងសំពត់ហូល ផាមួង ដ៏ល្អប្រណីតបានយកផ្កាមកឲ្យពួកគេ ហើយនៅតាមផ្លូវជូនដំណើរ មានអ្នកខ្លះបង្ហូរទឹកភ្នែក នៅពេលដែលទ័ពធ្វើដំណើរកាត់ ។ នៅទូទាំងប្រទេស អារម្មណ៍ចំពោះការចាកចេញនោះ មានលក្ខណៈលាយឡំគ្នា ។ រដ្ឋាភិបាលរបស់កម្ពុជា បានសម្ដែងនូវការដឹងគុណចំពោះវៀតណាម ដែលបានជួយសង្គ្រោះពួកគេចេញពីរបបខ្មែរក្រហម នៅពេលមួយទសវត្សរ៍មុន ។ ចំណែកឯប្រជាជនខ្លះ បារម្ភខ្លាចថា ពេលវៀតណាមមិននៅខ្មែរក្រហមនឹងត្រឡប់មកវិញ ។ ក្រុមអ្នកសង្កេតការណ៍មិនផ្លូវការលើកាលបរិច្ឆេទ នៃការដកទ័ពវៀតណាមចេញ បានសម្គាល់ថា ទ័ពវៀតណាមចុងក្រោយបង្អស់ បានដកចេញពីកម្ពុជានៅថ្ងៃទី២៩ ខែកញ្ញា ។

គ្មាននរណាម្នាក់គិតថា មានជំនាញការវៀតណាមរាប់រយនាក់នៅប្រទេសកម្ពុជា ក្នុងរូបភាពផ្សេងទៀតនៅឡើយទេ ។ របបភ្នំពេញនៅដោយខ្លួនឯងឯករាជ្យ ។ ហ៊ុន សែន បានគូសវាសទុកថ្ងៃបែបនោះ ជាយូរមកហើយ ។ សញ្ញាណវៀតណាម ដូចជារូបភាពរបស់ ហូ ជីមិញ និងការឃោសនាតាមវិទ្យុ ដែលរំពុកគ្រប់គ្នាពីរបបខ្មែរក្រហម បានរលាយបាត់អស់ ។ គាត់បានជំនួសការឃោសនា ដោយការទេសនាធម៌ ហើយក៏ដកចេញនូវការហាមប្រាមចំពោះជំនឿសាសនា ។ គាត់ក៏ឲ្យមានឡើងវិញនូវទ្រព្យសម្បត្តិផ្ទាល់ខ្លួន និងចាប់ផ្ដើមឲ្យមានមូលធនិយមវិញ ។ ប៉ុន្តែអំណាចនៃរដ្ឋបាលនៅតែនៅក្នុងដៃរបស់គណបក្សរបស់គាត់ដដែល ។ រដ្ឋាភិបាលក៏បង្កើតឡើងនូវរដ្ឋធម្មនុញ្ញថ្មីមួយដែលផ្អែកភាគច្រើនលើច្បាប់ក្រោមសម័យ លន់ នល់ ដែលមិនសង្កត់ធ្ងន់លើការផ្ដល់នូវសេចក្ដីធានា នូវសេរីភាពផ្ទាល់ខ្លួនដូចជាសេរីភាពក្នុងការបញ្ចេញយោបល់ សិទ្ធិបង្កើតសមាគមសេរី សារព័ត៌មាន

សេរី និងប្រព័ន្ធពហុបក្ស ។

ខុសពីសម្តេចព្រះនរោត្តម សីហនុ ដែលបន្ទាប់ពីសន្និសីទនៅប៉ារីស បានរំពឹងលើអ្នកជំនួយបរទេសកាន់តែខ្លាំងឡើងនោះ ហ៊ុន សែន បានយកស្មៀតអ្នកកីឡាប្រដាល់ដ៏រឹងមាំមួយ ហើយនិយាយថា ទ័ពរបស់គាត់អាចទប់ទល់ និងខ្មែរក្រហមបាន ។ គាត់បានធ្វើដំណើរជុំវិញប្រទេសហើយរាយការណ៍ថា ទ័ពរបស់គាត់កំពុងប្រយុទ្ធជាមួយទ័ពខ្មែរក្រហមនៅតាមព្រំដែនថៃ ។ ហ៊ុន សែន បាននិយាយនៅក្នុងសន្និសីទកាសែតថា «អ្នកឮថាខ្មែរក្រហមបម្រុងនឹងវាយយកភ្នំពេញ? តើពួកគេអាចនឹងវាយយកភ្នំពេញយ៉ាងដូចម្តេច បើគេពុំអាចទាំងទប់ទល់នៅតាមព្រំដែនផង?» ។

ប៉ុន្តែ ហ៊ុន សែន ក៏បានដឹងថា គាត់បានបាត់បង់ការគាំទ្ររបស់សូវៀតដែរ ។ រ៉ូហ្កាឆូវ បានប្រាប់គាត់ទុកជាមុនថា សូវៀតមិនអាចបន្តជួយបានរហូតនោះទេ ។ ក្រោយការដកទ័ពចេញរបស់វៀតណាម រដ្ឋាភិបាលកម្ពុជាមានឯករាជ្យភាព ពីការការពាររបស់បរទេស ជាងពេលណាៗទាំងអស់ តាំងពីឆ្នាំ១៩៧៩មក ។

ប្រទេសនានាមិនសូវមានការទុកចិត្តចំពោះសមត្ថភាពរបស់រដ្ឋាភិបាលភ្នំពេញ ក្នុងការទប់ទល់ជាមួយការវាយសម្រុករបស់ខ្មែរក្រហមទេ ។ នៅខែដដែលនៅឯការប្រជុំរបស់អង្គការសហប្រជាជាតិ រដ្ឋលេខាធិការ ជេម បេកឺ នៅថ្ងៃទី២៩ ខែកញ្ញា បានជួបបរិភោគអាហារពេលព្រឹកមួយ ជាមួយរដ្ឋមន្ត្រីការបរទេសនៃប្រទេសអាស៊ាននានា ហើយសួរយោបល់របស់ពួកគេ ពីបញ្ហាប្រទេសមហាអំណាចនានា ដើម្បីរកដំណោះស្រាយឲ្យកម្ពុជា ។ នៅឯវ៉ាស៊ីនតោនវិញ រដ្ឋាភិបាលរបស់ ប៊ូស បានទទួលរងសម្ពាធឲ្យឆ្លើយនឹងនយោបាយរបស់ពួកគេលើបញ្ហាខ្មែរក្រហម ។ នៅរដូវស្លឹកឈើជ្រុះឆ្នាំនោះ កាសែតបានចោទសួរថា តើហេតុអ្វីបានជារដ្ឋាភិបាលគាត់ទុកឲ្យខ្មែរក្រហមនៅសេរី បើឥឡូវទ័ពវៀតណាមដកអស់ចេញពីកម្ពុជារួចទៅហើយ? ។ ការចោទសួរនោះ បាននាំឲ្យអនុរដ្ឋលេខាធិការរបស់ បេកឺ លោករូបឺត គីមមីត លើកបញ្ហានោះនៅក្នុងអង្គប្រជុំជាន់ខ្ពស់ ។ តាមរយៈអ្នកចូលរួមប្រជុំម្នាក់បានថា គីមមីត និយាយថា «យើងត្រូវជៀសពីកាសែតលើបញ្ហានេះ ហើយបែរមកផ្តោតលើថា តើអង្គការសហប្រជាជាតិអាចធ្វើអ្វីបានខ្លះ» ។

រដ្ឋាភិបាលរបស់ប៊ូស មិនជឿថា ទ័ពរបស់វៀតណាមដកចេញអស់ពីកម្ពុជាទេ ។ ពួកគេបានបញ្ជូនដោយសម្ងាត់ នូវទាហានអាវុធធុនស្រាលរបស់ពួកគេ ឲ្យមកជួយក្រុមតស៊ូរបស់កម្ពុជា ដែលមិនមែនកុម្មុយនិស្ត ដើម្បីបម្រុងក្រែងមានការប្រយុទ្ធគ្នាម្តងទៀត ។

សំណួរដែលចោទសួរខាងលើនេះ បានឆ្លើយដោយការវាយប្រយុទ្ធរបស់ខ្មែរក្រហមថ្មីមួយ ។ បន្ទាប់ពីការប្រយុទ្ធគ្នាអស់ពីរបីសប្តាហ៍ ទ័ពរបស់ ប៉ុល ពត បានប្រកាសថា ពួកគេវាយបានទីក្រុងប៉ៃលិនភាគខាងលិច ដែលជាតំបន់រ៉ែត្បូងហើយ ។ ក្រោយមកខ្មែរក្រហមបានបែរមកប៉ងយកបាត់ដំបង ដែលជាចំណុចសំខាន់ក្នុងភូមិភាគពាយ័ព្យទាំងមូល ។ ឆ្លើយតបនឹងការបាត់បង់ក្រុងប៉ៃលិននេះ រដ្ឋាភិបាលរបស់ ហ៊ុន សែន បានប្រកាស

បោសសម្អាតឲ្យអស់ខ្មែរក្រហមនៅចុងខែ ។ ការប្រកាសនោះរួមនឹងចលនារបស់ទ័ព ប៉ុល ពត មកដល់ទំនាបកណ្ដាលខាងលិចរបស់ប្រទេស មានការបារម្ភធំមួយថា រឿងរ៉ាវអាក្រក់បំផុតនោះនឹងកើតមានឡើង ។

ម្ដងនេះគឺស្រេចលើ រ៉ូហ្កាឆូវ ទៀតហើយថា នឹងបន្ធូរបន្ថយការភ័យខ្លាចនៅភ្នំពេញ និងហាណូយយ៉ាងដូម្ដេចនៅពេលដែលសន្និសីទនៅប៉ារីសបរាជ័យហើយនោះ ។ គាត់បានធ្វើទស្សនកិច្ចទៅទីក្រុងទាំងពីរ ហើយជំរុញឲ្យពួកគេមានការជឿទុកចិត្តលើដំណោះស្រាយរបស់អង្គការសហប្រជាជាតិ ដោយមិនបាច់គិតពីអត្តចរិតរបស់វ៉ាស៊ីនតោន និងប៉េកាំងចំពោះការដកទ័ពវៀតណាមចេញទេ ។ គាត់បានទទួលការជំទាស់ជាច្រើន ។ គាត់និយាយថា “ជាសាធារណៈ យើងគាំទ្រមតិរបស់កម្ពុជានិងវៀតណាមដែលថា អង្គការសហប្រជាជាតិមិនអព្យាក្រឹតទេ” ។ គាត់និយាយនោះសំដៅទៅលើការបន្តផ្ដល់កៅអីនៅអង្គការសហប្រជាជាតិឲ្យខ្មែរក្រហមកាន់ និងការបដិសេធមិនព្រមទទួលស្គាល់ថា វៀតណាមបានដកទ័ពអស់ពីកម្ពុជាទេ ។ គាត់បន្តទៀតថា “ប៉ុន្តែ នៅខាងក្រៅវិញពួកយើងបន្តនិយាយពន្យល់ដល់ កម្ពុជា និងវៀតណាមថា អង្គការសហប្រជាជាតិជាស្ថាប័នដ៏ល្អបំផុតមួយ ក្នុងការដោះស្រាយបញ្ហានេះ ។ ប៉ុន្តែខ្ញុំក៏យល់ដែរថា ពួកគេមានហេតុផលសមរម្យរបស់ពួកគេ ដែលមិនទុកចិត្តលើអង្គការសហប្រជាជាតិ” ។

វៀតណាម រឹតតែឈឺចាប់ជាងនោះទៅទៀត ។ នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៨៩ ឧត្ដមសេនីយ៍ ចន វេសស៊ី បេសកជនពិសេសរបស់អាមេរិក ទាក់ទងនឹងអ្នកទោសសង្គ្រាម និងយុទ្ធជនបាត់ខ្លួនក្នុងពេលបំពេញបេសកម្ម បានមកជួប ង្វៀន កូថាច់ នៅហាណូយ ។ តាមសម្ដីរបស់បុរសទាំងពីរ ពួកគាត់ បានបង្កើតឡើងនូវទំនាក់ទំនងការងារដ៏ល្អមួយ ហើយ ថាច់ រង់ចាំទទួលពត៌មានពីវ៉ាស៊ីនតោនរហូតមក ។ ពីរឆ្នាំកន្លងមក គាត់បានសម្រួលការស្នើសុំរបស់វេសស៊ី ដោយបង្កើនសហប្រត្តិការរបស់វៀតណាម ក្នុងការស្វែងរកពត៌មាន និងអដ្ឋិធាតុរបស់កងទ័ពវៀតណាមដែលស្លាប់ និងបាត់ខ្លួននៅក្នុងពេលសង្គ្រាមវៀតណាម ។ ប៉ុន្តែ វេសស៊ី បានប្រាប់គាត់ថា “ផ្នែកខ្លះយើងជាមិត្ត ប៉ុន្តែ យើងមិនអាចទៅលើសអ្វីដែលយើងមានកាលពីយើងជួបគ្នាលើកមុននោះឡើយ” ។ ពុំហើយ ថាច់ ក៏ប្ដូរចិត្ត ហើយរដ្ឋាភិបាលរបស់គាត់ក៏បណ្ដោយឲ្យអាមេរិក ធ្វើការរុករកដោយខ្លួនឯង ។

ប៉ុន្តែពេលដែល ថាច់ ត្រូវការជំនួយបំផុតពីវេសស៊ី គាត់បែរជាព្រងើយទៅវិញ ។ ដូចសព្វដង គាត់បានមកជាមួយ អាន មៀល គ្រីហ្វិត ដែលតាមសម្ដីរបស់វេសស៊ីថា អាន ជាមនុស្សគួរឲ្យធុញទ្រាន់ម្នាក់ ។ ពួកគេបានបង្ខំឲ្យ ថាច់ ផ្ដល់ពត៌មានបន្ថែមពីអដ្ឋិធាតុនោះ ។ ចំណែកខាងគាត់វិញ វេសស៊ី បាននិយាយថា ឥឡូវដែលវៀតណាមដកទ័ពចេញពីកម្ពុជាអស់ហើយ អាមេរិកមិនបានត្រៀមខ្លួន ដើម្បីផ្សះផ្សាទំនាក់ទំនងជាមួយ វៀតណាមនៅឡើយ ។

ថាច់ បានស្នើសុំជួបជាមួយ វេសស៊ី ក្រៅផ្លូវការ ។ វេសស៊ី បាននិយាយថា “ថាច់បានរំឭកខ្ញុំពីដំណើរទស្សនកិច្ចលើកទីមួយរបស់ខ្ញុំទៅហាណូយ ហើយដែលពេលនោះខ្ញុំបញ្ជាក់ច្បាស់ថា វៀតណាមត្រូវតែដកទ័ព

ចេញពីកម្ពុជា ។ ឥឡូវ ថាច់ ក៏និយាយថា អាមេរិកកាន់តែដំឡើងតម្រូវការរបស់គេ ។ ខ្ញុំគ្រាន់តែអាចនិយាយបានថា «រឿងនោះគឺវាអ៊ីចឹងឯង» ។

ពុំហើយ ថាច់ ក៏សម្លឹងមើលចំភ្នែករបស់ វេសស៊ី ហើយនិយាយថា «អ្នកឯងធ្វើឲ្យខ្ញុំអស់ចិត្តដល់ហើយ» ។

ថាច់ បានរៀបចំគណៈកម្មាការមួយ ដើម្បីសម្រះសម្រួលទំនាក់ទំនងជាមួយអាមេរិក ហើយក៏បានបើកស្ថានទូតនានា ។ តែឥឡូវគាត់ត្រូវប្រាប់រដ្ឋាភិបាលគាត់វិញថា ទាំងនោះត្រូវឆាបោលទាំងអស់ ។

វេសស៊ីក៏ចាកចេញទៅដោយការខកចិត្ត ព្រោះថា គាត់នៅឆ្ងាយនៅឡើយក្នុងការពង្រឹងទំនាក់ទំនងជាមួយវៀតណាម ។ ការសម្រួលទំនាក់ទំនងជាមួយវៀតណាម ជាបំណងចម្បងរបស់គាត់ ជាពិសេស ចំពោះគាត់ យុទ្ធជនដើងចាស់នៃសង្គ្រាមវៀតណាម ។ គាត់និយាយថា «នេះជាឆាកមិនល្អមួយ» ។

ចំណែកឯ មៀល ហ្គ្រីហ្វីត វិញ មានការពេញចិត្តចំពោះឆាកនោះ ។ ក្រោយមកគាត់បាននិយាយពន្យល់ថា «ខ្ញុំមានចំណាប់អារម្មណ៍ផ្ទាល់ខ្លួន ក្នុងការមិនឲ្យបាត់បង់បញ្ហារឿងអ្នកទោសសង្គ្រាម និងយុទ្ធជនបាត់ខ្លួននៅក្នុងពេលបំពេញបេសកម្ម នោះក៏ព្រោះតែអ្វីដែលវៀតណាមធ្វើនៅកម្ពុជា» ។

នៅពេលដែល រ៉ូហ្គានូវ បានដឹងអំពីការសម្រេចចិត្តរបស់អាមេរិក គាត់ក៏រាយការណ៍ទៅដល់មូស្គូ ។ «យើងបានគិតថា ការពង្រឹងទំនាក់ទំនងរវាងវៀតណាមជាមួយនឹងអាមេរិក ជាផ្លូវកាត់មួយដែលនាំទៅដល់សន្តិភាពនៅកម្ពុជា ។ ប៉ុន្តែឃើញថា រឿងនោះមិនមែនដូច្នោះទៅវិញ ។ ក្រោយមកខ្ញុំបាននិយាយទៅកាន់អាមេរិកវិញថា វៀតណាមបានធ្វើតាមលក្ខខណ្ឌអស់ហើយ ប៉ុន្តែអាមេរិកនៅតែមិនប្រែប្រួល ។ ការប្រឈមមុខរបស់ពួកគេមានលក្ខណៈមនោគមវិជ្ជាជាងគេទាំងអស់» ។

នៅឯអឺរ៉ុប បញ្ហាកម្ពុជាជាបញ្ហាមួយដែលជជែកវែកញែកជាសាធារណៈជាងនៅអាមេរិក ។ នៅតាមកាសែតមានសរសេរជាអត្ថបទដែលមានចំណងជើងដូចជា «វៀតណាមបានទុកនូវវាលមីន... ការប្រចប្រូកប្រចបល់មាននៅខាងមុខ» ។ «ត្រុំប៉ែតសម្រាប់កម្ពុជាឯកោ» «វៀតណាមចាកចេញពីកម្ពុជាដោយមិនបាននិយាយឈ្នះការសន្ទនាជាមួយចិនឬអាមេរិក» «កម្ពុជា ៖ កំណើតថ្មីរបស់លីបង់» ។ មួយឆ្នាំមុននោះ មានអ្នកបានវង្វេនណូបែលសន្តិភាពពីរបីនាក់ដូចជាដេសមុន ទូទូនៃអាហ្វ្រិកខាងត្បូង និង អេលី វីសែល បានសូមឲ្យមានការទទួលស្គាល់រដ្ឋាភិបាល ហ៊ុន សែន ដើម្បីជាផ្លូវមួយការពារកុំឲ្យខ្មែរក្រហមត្រឡប់មកវិញ» ។

រាជរដ្ឋាភិបាលអង់គ្លេសជាប្រទេសដំបូងដែលចាប់ផ្តើម ។ នៅថ្ងៃទី៨ ខែវិច្ឆិកា រដ្ឋមន្ត្រីក្រសួងការបរទេស ឌូហ្គាស ហឺត បាននិយាយប្រាប់ទៅអង្គសភាថា គាត់ជឿថាវៀតណាមបានដកទ័ពហើយ ។ ហើយនេះគួរតែជាពេលដែលអង់គ្លេសចាប់ផ្តើម ជួយជំនួយមនុស្សធម៌ដល់កម្ពុជា ។ រដ្ឋាភិបាល បានឧបត្ថម្ភលុយចំនួន ៣៥ម៉ឺនដល់យូនីសេហ្វសម្រាប់ភ្នំពេញ ហើយក៏បានបញ្ជូនអ្នកការទូតទៅរដ្ឋធានីប្រទេសកម្ពុជា ដើម្បីធ្វើទស្សនកិច្ចជាលើកទីមួយចាប់តាំងពីឆ្នាំ១៩៧៥ ។

នៅខែដដែលនាយករដ្ឋមន្ត្រីថៃ ឆាទីឆៃ បាននាំមកនូវគំនិតឲ្យមានសន្និសីទថ្មីមួយទៀត ។ ទីប្រឹក្សារបស់គាត់ ផាន់សាក់ បានធ្វើដំណើរជុំវិញតំបន់ និងទៅអឺរ៉ុប ដើម្បីទទួលការគាំទ្រនូវគំនិតនៃការដាក់អាវុធចុះនៅកម្ពុជា ។ គាត់បាននិយាយថា «ការគាំទ្រសង្គ្រាមរបស់ ប៉ុល ពត ជារឿងអសីលធម៌មួយ ។ គំនិតខុសគ្នានៅក្នុងរដ្ឋាភិបាលរបស់យើង រវាងនាយករដ្ឋមន្ត្រី និងក្រុមលេខានុការ របស់លោករដ្ឋមន្ត្រីក្រសួងការបរទេស ស្តីពីបញ្ហាកម្ពុជា ត្រូវបានពិភាក្សាជាសាធារណៈនៅលើទំព័រកាសែត ។ ក្រុមលេខានុការថា ពួកគេឈប់ខ្វាយខ្វល់ពីរឿងរ៉ាវនៅកម្ពុជាទៀតហើយ» ។

បារាំងមានការបារម្ភចំពោះរឿងនោះ ប្រហាក់ប្រហែលនឹងថៃដែរ ។ រដ្ឋមន្ត្រីការបរទេសបារាំង បាននិយាយពីដំណោះស្រាយរបស់អង្គការសហប្រជាជាតិ ជាមួយសមភាគីសូវៀតសេវ៉ាដណាដហ្សេ ។ ក្រោយមកក៏បញ្ជូន ក្លូដ ម៉ាតាំង ឲ្យទៅតាមតំបន់ ។ ដំបូង គឺទៅទស្សនកិច្ចចាប់ផ្តើមនៅវៀតណាម ហើយក្រោយមកទៅថៃ សិង្ហបុរី និងឥណ្ឌូនេស៊ី ។ នៅហ្សាការតា រដ្ឋមន្ត្រីការបរទេស អាឡាតាស ចង់បង្កើតឲ្យមានការប្រជុំជាអន្តរជាតិរួមមួយនៅតាមតំបន់ ។ ប៉ុន្តែម៉ាតាំងនិយាយថា បារាំងគិតថា ការប្រជុំនឹងមិននាំមកនូវផលសម្រេចនោះទេ ។ ហើយប្រទេសមហាអំណាចគួរតែ ជួយដោះស្រាយពីបញ្ហានេះ «ខ្ញុំនិយាយយ៉ាងច្បាស់ថា ចិនកំពុងរាំងស្ទះនូវដំណោះស្រាយដ៏ធំមួយ ។ ក្រោយមកម៉ាតាំងបានទៅជួប រ៉ូហ្កាឆូវ នៅមូស្គូ ហើយក៏បន្តទៅវ៉ាស៊ីនតោន ដើម្បីជួបជាមួយ រីឆាដ៍ សូឡូម៉ុង ។ នៅក្នុងការប្រជុំ សូឡូម៉ុង បានប្រាប់ ម៉ាតាំង ពីគំនិតរបស់ បេកឺ ក្នុងការប្រជុំរវាងសមាជិកអចិន្ត្រៃយ៍ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ ហើយលុបចោលសន្និសីទនៅប៉ារីស ។ «ខ្ញុំនិយាយថា លុបចោលសន្និសីទនៅប៉ារីសមិនបានទេ ។ ប៉ុន្តែ ការប្រជុំសមាជិកអចិន្ត្រៃយ៍ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិគួរតែធ្វើ ។ ពួកយើងបានត្រៀមខ្លួនរួចជាស្រេច ហើយសូវៀតក៏ដូច្នោះដែរ» ។

នៅពេលនោះមានប្រទេសមួយក៏លូកដៃចូលក្នុងរឿងនេះដែរ ។ នៅថ្ងៃទី២៤ ខែវិច្ឆិកា រដ្ឋមន្ត្រីការបរទេសរបស់ប្រទេសអូស្ត្រាលី ហ្គារេត អេវ៉ាន បានប្រកាសពីគំនិតថ្មីមួយរបស់អូស្ត្រាលី ដែលចូលរួមដោយរដ្ឋមន្ត្រីការបរទេសរបស់ប្រទេសអាស៊ានមួយចំនួន និងសមាជិកសភារបស់អាមេរិក ស្តេហ្វេន សូឡា ។ គំនិតនោះគឺការដាក់ឲ្យមានរដ្ឋបាលកម្ពុជាបណ្តោះអាសន្នមួយ ដែលស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់ របស់អង្គការសហប្រជាជាតិ ។ នោះមានន័យថា «រហូតដល់មានការបោះឆ្នោតដោយសេរី និងយុត្តិធម៌មួយ គ្មានគណបក្សរបស់កម្ពុជាណាមួយ មានសិទ្ធិសម្រេចពីអនាគតរបស់កម្ពុជាទេ» ។ យោបល់នោះ ក៏បានទទួលការគាំទ្រពី ហ៊ុន សែន និងសម្តេច ព្រះនរោត្តម សីហនុ ភ្លាម ។ ពួកគេនិយាយថា «គំនិតនោះគួរត្រូវយកមកពិចារណាឲ្យបានដិតដល់» ។

អូស្ត្រាលីក៏បញ្ជូនអ្នកការទូតរបស់គេម៉ាយកូល កុសស្តេលូ ឲ្យទៅប៉េកាំង ហាណូយ និងភ្នំពេញ ក៏ដូចជាបាងកកដែរ ដើម្បីទទួលការគាំទ្រចំពោះយោបល់នេះ ដែលគេហៅថា គម្រោង អេវ៉ាន ។

កិច្ចការទូតស្មើភាពគ្នានៅកម្ពុជា បានចេញជាពត៌មានអេឡេចត្រូនិចនៅអឺរ៉ុប ។ នៅយប់ថ្ងៃទី៩ ខែវិច្ឆិកា

ជញ្ជាំងបែរឡាំងត្រូវបានផ្តួលចោល ។ មុននោះមានប្រជាជនអាល្លឺម៉ង់ខាងលិចរាប់ម៉ឺននាក់ បានរត់គេចមកអាល្លឺម៉ង់ខាងលិចតាមច្រកបើកថ្មី តាមរយៈប្រទេសហុងគ្រី និងឆេកូស្លូវ៉ាគី ។ ពួកគេជាច្រើន បានទៅបោះជំរំនៅខាងមុខស្ថានទូតអាល្លឺម៉ង់ខាងលិច ។ ភាគច្រើនទៀត ជុំគ្នាធ្វើបាតុកម្មប្រចាំថ្ងៃគាំទ្រលទ្ធិប្រជាធិបតេយ្យ ដែលបង្កើតជាការក្រុមដើរដង្ហែក្បួន មានគ្នា៥សែននាក់ នៅតាមបែរឡាំងខាងកើតនៅថ្ងៃទី៤ ខែវិច្ឆិកា ។ ក្រោយមកនៅក្នុងសន្និសីទកាសែត ថ្ងៃទី៩ ខែវិច្ឆិកា អ្នកតំណាងឲ្យរដ្ឋាភិបាលបានប្រកាសថា ចាប់តាំងពីពេលនោះទៅប្រជាជននៅអាល្លឺម៉ង់ខាងលិចទាំងអស់ អាចសុំធ្វើដំណើរទៅបរទេសដោយមិនបាច់មានលក្ខខ័ណ្ឌជាមុនទេ ។

ក្នុងរយៈពេលតែមួយម៉ោងប៉ុណ្ណោះ អ្នកនៅបែរឡាំងខាងកើតរាប់ពាន់អ្នកបានដើរឆ្ពោះទៅជញ្ជាំង ។ ដល់ពេលកណ្តាលអធ្រាត្រអ្នកយាមតាមព្រំដែនក៏ត្រូវបង្ខំឲ្យបើករបាំងចេញ ។ អ្នកនៅបែឡាំងខាងលិច បានឡើងទៅខាងលើហើយរាំនៅខាងលើនោះ ។ ដល់ម៉ោង១លើសអធ្រាត្រ អ្នកនៅបែឡាំងទាំងសងខាង ក៏ច្រៀងរាំនិងអបអរសាទរជាមួយគ្នា ។ រឿងបែបនេះបានកើតឡើងជាបន្តគ្នា ។ ប្រទេសប៉ូឡូញ និងហុងគ្រី បានចាប់ផ្តើមដំណើរចាកចេញពីរបបកុម្មុយនិស្តទៅហើយ ។ នៅយប់ថ្ងៃ២៨ ខែវិច្ឆិកា ស្រាសំប៉ាញ ក៏បានបើកបង្ហូរនៅទីក្រុងប្រាក នៃប្រទេសឆេកូស្លូវ៉ាគី ដើម្បីអបអរពីជ័យជម្នះនៃបដិវត្តិសន្តិភាព និងបញ្ចប់លទ្ធិកុម្មុយនិស្ត ។ ហើយនៅខែធ្នូ អំណាចផ្តាច់ការកុម្មុយនិស្តនៅប៊ុយការ៉េស ប្រទេសរ៉ូមានី ក៏រលត់រលាយ ។

នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៩០ បេកឺបានផ្ញើសំបុត្រទៅភាគី ចិន សូវៀត បារាំង និងអង់គ្លេស សូមឲ្យពួកគេប្រញាប់រួបរួមគ្នា ក្នុងនាមជាសមាជិកអចិន្ត្រៃយ៍ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ ដើម្បីដោះស្រាយបញ្ហាកម្ពុជា ។ លើកលែងតែចិនមួយ ដែលឆ្លើចម្លើយយ៉ាងគ្រោតគ្រាតគ្រប់គ្នាឆ្លើយតបយ៉ាងសកម្ម ។ ទោះបីយ៉ាងនោះក៏ចិននៅតែព្រមចូលប្រជុំដដែល ។ បេកឺ ឲ្យហេតុផលថា បើសង្គ្រាមត្រជាក់អាចបញ្ចប់បាននៅប្រទេសនានានៅអឺរ៉ុប គាត់មិនជឿថា មិនអាចបញ្ចប់បាននៅប្រទេសដ៏តូចមួយ ដូចកម្ពុជាទេ ។

ការប្រមូលផ្តុំនូវសមាជិកអចិន្ត្រៃយ៍ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិទាំងប្រាំ មិនមែនជាគំនិតមួយថ្មីនោះទេ ។ នៅឯអង្គការសហប្រជាជាតិ រដ្ឋទូតនៃប្រទេសទាំងប្រាំ បានបង្កើតជាទម្លាប់មួយជួបជុំគ្នាដើម្បីដោះស្រាយនូវបញ្ហាពិបាកនានា ។ ដំបូងឡើយ ពួកគេជួបគ្នាដើម្បីស្វែងរកដំណោះស្រាយរបស់សង្គ្រាមនៅអ៊ីរ៉ាក់-អ៊ីរ៉ង់ ហើយក្រោយមក រកដំណោះស្រាយឲ្យណាមីប៊ី ។ បញ្ហារបស់កម្ពុជា បានក្លាយជាចំណុចពិភាក្សារបស់គេតាំងពីឆ្នាំ១៩៨៨ម៉្លេះ ហើយពួកគេក៏បានរៀបចំនូវឯកសារជាច្រើន ដែលមានជំហររួមមួយសម្រាប់សន្និសីទនៅប៉ារីសដែរ ។

អ្វីដែលខុសគ្នា គឺរូបភាពជាសាធារណៈរបស់មហាអំណាចទាំងប្រាំ ក្នុងការដាក់ចេញនូវដំណោះស្រាយដោយមិនមានប្រទេសដទៃទៀតចូលរួម ។ ក្លូដ ម៉ាតាំង បានឈ្នះលើការជជែករបស់គាត់ ហើយក៏អាចសម្រេចបាននូវការប្រជុំ៥ភាគី ដែលស្ថិតនៅក្រោមការណែនាំនៃសន្និសីទ ដើម្បីសន្តិភាពនៅប៉ារីស ។ វគ្គដំបូងនៃសន្និសីទ

គឺធ្វើឡើងនៅប៉ារីស ។ បន្ទាប់មកទៀត គឺធ្វើនៅប៉ារីសដដែល ឬក៏នៅអង្គការសហប្រជាជាតិឯញូវយក ។

អ្នកជំនាញរបស់ក្រសួងការបរទេសអាមេរិក បានចំណាយពេលនៃសប្តាហ៍ក្រោយមកទៀត ដើម្បីពិភាក្សាថា តើដំហរថ្មីរបស់ពួកគេស្ថិតនៅត្រង់ណា ។ ទីប្រឹក្សាសន្តិសុខ ប្រេនស្កូក្រោស ដែលជាដៃគូដ៏យូរអង្វែងរបស់ គីស្សីងហ្គ័រ ជាអ្នកដែលគាំទ្រខ្លាំងក្លាចំពោះការគាំទ្រចិន ហើយប្រឆាំងនឹងវៀតណាម និង ហ៊ុន សែន ។ គាត់ជាមន្ត្រីដែល ប៊ូស បញ្ជូនទៅចិន បន្ទាប់ពីពេលមានបញ្ហានៅទីលានធៀនអានម៉េន ។ គាត់ក៏ជាមន្ត្រីមួយរូបដែលធ្លាប់ឆ្លងកាត់ការបរាជ័យនៃសង្គ្រាមវៀតណាម ជាមួយ គីស្សីងហ្គ័រ និងក៏ជាអ្នកធ្លាប់ឆ្លងកាត់ជោគជ័យជាមួយ គីស្សីងហ្គ័រ ក្នុងការបើកទំនាក់ទំនងជាថ្មីជាមួយចិន ។ រីឆាដ៍ សូឡូម៉ុង ក៏ធ្លាប់ជាសមាជិកក្មេងមួយរូបនៃក្រុមរបស់ គីស្សីងហ្គ័រ ក្នុងបញ្ហាទាក់ទងនឹងចិនដែរ ប៉ុន្តែមិនធ្លាប់ដែលដោះស្រាយបញ្ហាជាមួយវៀតណាម នៅឡើយទេ ។ ការធ្វើទស្សនកិច្ចលើកដំបូងរបស់គាត់ទៅប្រទេសចិន គឺជាប់នឹងជំនួយរបស់ គីស្សីងហ្គ័រ នៅឆ្នាំ ១៩៧២ ។ នៅពេលនោះ ចំថ្ងៃខួបកំណើត៣៥ឆ្នាំរបស់គាត់ ។ ហើយក្នុងទស្សនកិច្ចនេះ គាត់ក៏បានជួបនឹង ជូអេងឡាយ ។ ប៉ុន្មានឆ្នាំក្រោយមក គាត់និយាយថា នោះជារឿងគួរឲ្យរំភើប និងលើកទឹកចិត្តណាស់ ។ សូឡូម៉ុង មិនដែលបាត់បង់នូវការចាត់ទុកចិន ជាអ្នកនយោបាយពិភពលោកម្តងណាទេ ។ ដោយមិនទាំងដឹងពីកម្ពុជាផង គាត់បានប្រកែកក្នុងនាមក្រសួងការបរទេសអាមេរិកថា អង្គការសហប្រជាជាតិ ត្រូវតែមើលខុសត្រូវលើកម្ពុជា ហើយអនុញ្ញាតឲ្យអាមេរិកដកដៃចេញ ។ បេកឺ បានប្រាប់ជំនួយការរបស់គាត់ថា គាត់មិនចង់ឲ្យកម្ពុជាក្លាយទៅជាបញ្ហាមួយរបស់អាមេរិកឡើយ ។

អ៊ីហ្គ័រ រ៉ូហ្គាឆូវ បានធ្វើដំណើរទៅប៉េកាំងដើម្បីចរចាជាមួយចិន ហើយកុំឲ្យចិនចុះចាញ់ខ្មែរក្រហម ។ គាត់បានជួបនិយាយជាមួយមេដឹកនាំក្រុងភ្នំពេញ និងហាណូយ ហើយពន្យល់ឲ្យយល់ថា នោះជាដំណោះស្រាយត្រូវមួយ ។ វៀតណាម និងកម្ពុជា បានទទួលយល់ព្រមនឹងគំនិតរបស់ប្រទេសទាំងប្រាំ ព្រោះពួកគេយល់ថា ជាគំនិតរបស់អូស្ត្រាលី ។ រ៉ូហ្គាឆូវ និយាយថា នោះជារឿងចៃដន្យមួយ ប៉ុន្តែក៏ល្អដែរ ព្រោះថា ពួកគេទុកចិត្តលើអេវ៉ាន់ ។ រ៉ូហ្គាឆូវ បន្ថែមថា «អ្នកគួរឃើញមុខពួកគេ នៅពេលដែលពួកគេដឹងពីអត្តសញ្ញា របស់អ្នកតំណាងប្រទេសទាំងនោះ ។ ពួកគេតវ៉ាថា អ្នកទាំងនោះសុទ្ធតែជាបញ្ញវន្តសិក្សាពីចិន» ។

បញ្ញវន្តទាំងនោះដែលជំនាញពីបញ្ហាចិនគឺ រីឆាដ៍ សូឡូម៉ុង នៃសហរដ្ឋអាមេរិក ក្លូដ ម៉ាតាំង ពីបារាំង អ៊ីហ្គ័រ រ៉ូហ្គាឆូវ នៃសូវៀត និង ស៊ូដុងស៊ីន នៃចិន ។ ពួកគេបានជួបជុំគ្នាជាមួយ ដេវីដ ហ្គីលម័រ នៃអង់គ្លេស ។ ហ្គីលម័រ ជាបុគ្គលតែម្នាក់គត់ ដែលមិនមែនអ្នកជំនាញខាងបញ្ហាចិន ។ នោះជាការជួបប្រជុំលើកទីមួយរបស់ពួកគេ ហើយការប្រជុំនេះ ធ្វើឡើងនៅថ្ងៃទី១៥ ខែមករា ឯមណ្ឌលកេ្លប៊ែរ ។ ម៉ាតាំង ជាអ្នកដឹកនាំការប្រជុំ ។ មិនយូរប៉ុន្មាន ការចុះស្រុងគ្នាក៏ចាប់ផ្តើម ។ សូឡូម៉ុង និងចនបុលតុន ដែលជាជំនួយការរដ្ឋលេខាធិការនៃអង្គការអន្តរជាតិ បាននាំមកនូវយោបល់នៃការកែសម្រួលរដ្ឋបាលជាលំដាប់មួយ និងការរៀបចំឲ្យមានការបោះឆ្នោត ។ ក្នុងនោះ

នឹងមានក្រុម ប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជា ដែលមានក្រុមអ្នកតស៊ូ នៅក្នុងនោះមានន័យថា រដ្ឋាភិបាលភ្នំពេញនឹងស្ថិតនៅក្រោមការឃ្លាំមើលរបស់អង្គការសហប្រជាជាតិ ។ វ៉ូហ្គាឆ្វូវ បានតវ៉ាថា គួរទុកឲ្យមានរដ្ឋាភិបាលកម្ពុជាពីរដដែល ។ បន្ទាប់ពីអាហារថ្ងៃត្រង់ហើយ ម៉ាតាំង បានលើកគំនិតកណ្តាលមួយថា ស្ថាប័នបច្ចេកទេសរបស់រដ្ឋាភិបាលភ្នំពេញ គួរទុកនៅដដែល ហើយប្រគល់ក្រសួងធំៗ ឲ្យទៅអង្គការសហប្រជាជាតិ ។ ចិនបានយល់ព្រមហើយការប្រជុំពេលល្ងាចក៏បានបញ្ចប់ ។

ប៉ុន្តែនៅប្រហែលម៉ោង៩យប់ ម៉ាតាំង និង ហ្សៀលម័រ បានមកដល់ស្ថានទូតអាមេរិក ដើម្បីពិនិត្យលើ ១៥ ចំណុច ជាមួយអាមេរិក ។ ពួកគេក៏ពិនិត្យចប់នៅមុនពេលកណ្តាលអធ្រាត្រ ។ នោះគឺជាចំណុចចាប់ផ្តើមនៃការបែកកិច្ចការគ្នាជាកង់ៗ ។ ខាងអាមេរិកក្រៅក្រុមដែលមាន សូឡូម៉ុង ម៉ាតាំង និង ហ្សៀលម័រ ថាជា«ពួកសេរីទាំងបី» ។ ក្រុមនោះបានបង្កើតនូវកម្មវិធីរួមមួយ មុននឹងគេចូលជាមួយក្រុម«កុម្មុយនិស្តទាំងពីរ» ដែលសំដៅលើ វ៉ូហ្គាឆ្វូវ និង ស៊ូ ហើយដែលមិនសូវចុះគ្នាទៀត ។

ក្រុមទាំងប្រាំ បានជួបគ្នានៅថ្ងៃបន្ទាប់ ។ ស៊ូ និង វ៉ូហ្គាឆ្វូវ បានយល់ព្រមចុះហត្ថលេខាលើចំណុចទាំង១៥ មុនម៉ោង១១សៀល ដោយគ្រាន់តែសួរសំណួរតិចតួចប៉ុណ្ណោះ ។ ក្រោយមកនៅយប់នោះ ឯសន្និសីទកាសែតនៅឯស្ថានទូតអាមេរិក សូឡូម៉ុង ក៏អាចប្រកាសនូវជ័យជម្នះមួយ ។ ចលនាដើម្បីសន្តិភាពនៅកម្ពុជា បានចាប់ផ្តើមយ៉ាងរឹងមាំ ដោយទាំងមិនមានវត្តមានរបស់កម្ពុជាផង ។ លើសនោះទៅទៀតគឺរឿងនោះ ត្រូវបានសម្រេចដោយមនុស្សមួយក្រុម ដែលគ្មានទំនាក់ទំនងយល់ពីកម្ពុជាដោយផ្ទាល់ លើកលែងតែ វ៉ូហ្គាឆ្វូវ ដែលធ្លាប់មកទស្សនកិច្ចនៅកម្ពុជា និង ម៉ាតាំង ដែលមកកំសាន្តកាលពីនៅក្មេងនាឆ្នាំ១៩៦០ ។

នោះបញ្ជាក់ឲ្យឃើញពីការវិលវល់របស់ប្រទេស ដែលត្រូវគេយកមកពិភាក្សា ។ វៀតណាមបានដកទ័ពចេញពីកម្ពុជា ហើយក៏បានយកទៅជាមួយនូវហេតុផល ដែលនាំឲ្យគេមានទំនាក់ទំនងជាមួយកម្ពុជា ។ ឥឡូវរដ្ឋមន្ត្រីបរទេសទាំងអស់ ត្រូវរៀបចំផ្លូវមួយ ដើម្បីដកខ្លួនចេញ ដោយធ្វើយ៉ាងណាមិនឲ្យប៉ះពាល់ខូចខាតដល់កម្ពុជា ។ ម៉ាតាំងបានស៊ាំនឹងការឲ្យតម្លៃ សម្តេច ព្រះនរោត្តម សីហនុ និងប្រទេសបារាំងដោយប្រើយុទ្ធសាស្ត្រដូចគ្នា ។ គាត់មានជោគជ័យក្នុងការការពារតំណែងដែលសម្តេច ព្រះនរោត្តម សីហនុ ចូលចិត្ត ។ នោះជាតំណែងព្រះបិតាជាតិ ជាមេដឹកនាំរបស់កម្ពុជា និងជាអ្នកមានគុណចំពោះប្រទេសជាតិក្នុងន័យថា អនុញ្ញាតឲ្យប្រជាជនមានសិទ្ធិបោះឆ្នោតដោយសេរីមួយ ។ ការងាររបស់ វ៉ូហ្គាឆ្វូវ ក៏បានជោគជ័យនៅមុនការប្រជុំលើកទីមួយដែរ ។ គាត់មានជោគជ័យដោយញ៉ាំងឲ្យវៀតណាមចេញពីកម្ពុជា ហើយទុក ហ៊ុន សែន ឲ្យនៅគ្រប់គ្រងភ្នំពេញដដែល ។ អ្នកធ្វើការជាមួយគាត់ មានការស្ញប់ស្ញែងយ៉ាងខ្លាំង ចំពោះឥរិយាបថរបស់គាត់នៅក្នុងពេលពិភាក្សានោះ ។ គាត់និយាយត្រូវ ហើយម៉ឺងម៉ាត់ចំពោះ ស៊ូ ។ ពេលខ្លះទាំងពីរនាក់នេះនិយាយគ្នាជាភាសាចិន ហើយ ស៊ូ ក៏និយាយភាសាចិនជាមួយ ម៉ាតាំង និង សូឡូម៉ុង ដែរ ។ ជាងនោះទៅទៀត វ៉ូហ្គាឆ្វូវ មិនដែលចូលចិត្តធ្វើជាអ្នកនាំនិយាយ

ទេ ។ គាត់ហាក់បីដូចជាចូលចិត្តអង្គុយស្តាប់ ហើយទុកឲ្យជំនួយការរបស់គាត់និយាយប្រកែក ហើយគាត់លូកដៃចូលតែក្នុងការពិភាក្សាចម្បងៗប៉ុណ្ណោះ ។

មិនយូរប៉ុន្មាន គ្រប់គ្នាក៏យល់ឃើញថា អាមេរិក និងចិន ជាប្រទេសពីរដែលមានចំណែកសំខាន់ក្នុងរឿងរបស់កម្ពុជា ។ ពួកគេជាប្រទេសដែលទទួលខុសត្រូវច្រើនជាងគេបំផុត ក្នុងការអូសបន្លាយសង្គ្រាម ហើយក៏បង្ហាញឲ្យឃើញយ៉ាងច្បាស់ថា គេទាំងពីរមិនចុះសម្រុងគ្នា ក្នុងការធ្វើយ៉ាងណាដើម្បីដកខ្លួនចេញដែរ ។ ការពិតដែលថា ខ្មែរក្រហមនៅតែអាចធ្វើសង្គ្រាមស៊ីវិលបាន នៅតែអាចកាន់អាសនៈរបស់កម្ពុជា នៅឯអង្គការសហប្រជាជាតិបាន នៅតែរស់នៅសេរី ដោយមិនចាំបាច់ភ័យពីការចាប់ខ្លួន ឬកាត់ទោសពីអំពើប្រល័យពូជសាសន៍របស់ពួកគេនោះ បានបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់ពីការគាំទ្ររបស់អ្នកជំនួយបរទេស និងសហព័ន្ធរបស់ពួកគេ ។ នៅពេលអ្នកជំនួយបរទេស និងសហព័ន្ធរបស់ពួកគេទាំងនោះ ឲ្យខ្មែរក្រហមហោះទៅហោះមកពីប៉ារីស ទៅញូវយ៉ក ទៅបាងកកនោះ អ្នកទាំងនោះ បានផ្តាច់ប្រទេសកម្ពុជាឲ្យដាច់ចេញឆ្ងាយពីគេ ហើយដាក់ទណ្ឌកម្មដ៏ធ្ងន់បំផុតដល់កម្ពុជា ទោះបីជាក្រោយពេលដែលវៀតណាមដកទ័ពចេញអស់ពីកម្ពុជាក៏ដោយ ។

នៅក្នុងការប្រជុំលើកទីពីរនៅខែកុម្ភៈឯទីក្រុងញូវយ៉ក ប្រទេសទាំងប្រាំ បានចាប់ផ្តើមចរចាពីការដាក់អាវុធចុះ ហើយរំសាយទ័ពកម្ពុជាទាំងអស់ ទោះបីជាខ្មែរក្រហមនៅធ្វើការការពារនាវដូវប្រាំងក៏ដោយ ។ សូវៀត និងចិន បានប្រកែកគ្នាអំពីអំណាចនៃរដ្ឋាភិបាលបណ្តោះអាសន្នរបស់កម្ពុជា ។ ដូចសព្វដង ចិនចង់ឲ្យមានកៅអី បួនដែលមានសិទ្ធស្មើគ្នាសម្រាប់ខ្មែរក្រហម សម្តេច ព្រះនរោត្តម សីហនុ ក្រុម សឺន សាន និង ហ៊ុន សែន ។ សូវៀតយល់ថា សំណូមពរនោះ ជារឿងមិនសមហេតុសមផល ហើយយល់ថាគួរមានពីរក្រុម ។ ក្រុមមួយជាក្រុមរបស់រដ្ឋាភិបាល ហើយមួយទៀតជាក្រុមអ្នកតស៊ូ ដូច្នេះ ក្រុមទាំងពីរគួរមានតួនាទីស្មើគ្នា ។ ក្រោយមកចិនប្រកែកថា បើមិនដូច្នោះទេ អង្គការសហប្រជាជាតិ គួរមានអំណាចផ្តាច់មុខតែឯង ហើយរដ្ឋាភិបាលគ្មាន ។ សូវៀតក៏តបថា «ចុះធ្វើយ៉ាងម៉េចវិញប្រសិនបើសមាជិករដ្ឋាភិបាលអាមេរិកទាំងអស់ ឈប់សម្រាកវិស្សមកាល ? » អ្នកតំណាងពីអាមេរិកគាំទ្រគំនិតនេះ ។

ឥឡូវដល់ពេលដែលកម្ពុជាជជែកគ្នាក្នុងចំណោមកម្ពុជាគ្នាឯងម្តងហើយ ។ នាយករដ្ឋមន្ត្រីថៃ ឆាទីឆៃ បានអញ្ជើញ ហ៊ុន សែន និង សម្តេច ព្រះនរោត្តម សីហនុ ឲ្យមកចូលរួមការប្រជុំនៅបាងកកនាខែកុម្ភៈ ។ ពួកគេក៏បានយល់ព្រមនឹងដំណោះស្រាយមួយ ដែលមានលក្ខណៈប្រហាក់ប្រហែលនឹង ការចរចាទាំង៥បក្សដែរ ។ សម្តេច ព្រះនរោត្តម សីហនុ បាននិយាយជាមួយបារាំងដោយចំៗថា ទ្រង់លែងចង់ទៅប៉ារីសទៀតហើយ ហើយទ្រង់បន្តថា «ពួកអ្នកលែងសួរយោបល់ខ្ញុំទៀតហើយ ។ តើប្រទេសធំៗទាំងប្រាំនោះ គិតថាពួកគេហ្នឹងជានរណា ? » ។

នៅចុងខែកុម្ភៈ ឌុយម៉ាស និង អាឡាតាស ដែលជាសហប្រធានទាំងពីរនៃសន្និសីទនៅប៉ារីស បានជួបគ្នា

នៅហូរ៉ាការតា ។ ក្នុងរយៈពេល៨ថ្ងៃនៃការប្រជុំ ពួកគេក៏ព្រមបោះត្រាយល់ព្រម ចំពោះការប្រជុំភាគីទាំង៥ ។ ឥណ្ឌូនេស៊ី បានអញ្ជើញរដ្ឋមន្ត្រីក្រសួងការបរទេសអូស្ត្រាលី ហ្គារ៉េត អេវ៉ាន ដើម្បីចូលរួមក្នុងការពិភាក្សា ដើម្បីផ្តល់ជាកិត្តិយសដល់ កួដ ម៉ាតាំង ។ ម៉ាតាំង បាននិយាយថា "ពួកគេបាននាំយកសៀវភៅក្រហមរបស់ពួកគេ ដែលខ្ញុំគិតថា ភាគច្រើនជាឯកសារមកពីសន្ធិសីទនៅប៉ារីស ។ "នៅវគ្គជួបជាមួយអ្នកកាសែតចុងក្រោយ ខ្ញុំបាននិយាយថា អូស្ត្រាលីបានដើរតួនាទីសំខាន់ក្នុងរឿងនេះ អេវ៉ាន ក៏តបមកខ្ញុំវិញថា "អរគុណចំពោះសម្តីដ៏ល្អរបស់លោក" ខ្ញុំក៏ឆ្លើយថា"នោះជាសម្តីដែលចេញពីបេះដូងរបស់ខ្ញុំ" ហើយ អេវ៉ាន ក៏តបទៀតថា "លោកមានបេះដូងដែរ? " ។

ដល់ខែមីនា មហាអំណាចទាំងប្រាំ បានវិវត្តន៍ដល់កម្រិតមួយថ្មីទៀត ។ ពួកគេអាចបកមុខរដ្ឋអាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិនៅកម្ពុជា *(UNTAC)* ថា ជាបិសាចលើឆាកអន្តរជាតិ ដែលផ្តល់សិទ្ធអំណាចដល់អង្គការសហប្រជាជាតិ លើសអង្គការរក្សាសន្តិភាពនានា ។ នៅក្នុងអង្គប្រជុំនាខែមីនានោះ រ៉ាហ្វីឌីន អាម៉េដ ដែលជាតំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ មានការបារម្ភចំពោះតម្លៃនៃបិសាចនោះ ដែលត្រូវបានគេវាយតម្លៃថាអស់១,៥កោដិដុល្លារ ។ នៅក្នុងការប្រជុំដោយឡែកមួយ គាត់បានផ្តល់យោបល់ដល់ពួកសេរីទាំងបីថា មិនគួរដោះស្រាយភាពខុសគ្នារវាងពួកគេជាមួយចិន និងសូវៀត ដោយបន្ថែមការទទួលខុសត្រូវរបស់ អង្គការសហប្រជាជាតិមួយស្រទាប់ទៀតទេ ។ វានឹងចំណាយអស់ប្រាក់ច្រើនពេក ។

នៅទីបញ្ចប់ទាំងនោះមិនចាំបាច់ទេ ។ មហាអំណាចទាំងប្រាំ បានយល់ទទួលយកគម្រោងនៃការធ្វើមាតុភូមិនិវត្តនៃជនភៀសខ្លួន និងការកសាងឡើងវិញ ដែលមានសសេរនៅក្នុងសន្ធិសីទប៉ារីសនៅរដូវក្តៅឆ្នាំមុន ។ រ៉ូហ្កាឆូវ មិនបាន ឈ្នះក្នុងការទាមទារឲ្យដាក់ការចោទទោស អំពើប្រល័យពូជសាសន៍ខ្មែរក្រហម ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នៅផ្នែកមួយនៃចំពូកសិទ្ធមនុស្សក្នុងគម្រោងច្បាប់នេះទេ ។ គាត់ត្រូវបានអាមេរិក បារាំង អង់គ្លេស និងចិន បោះឆ្នោតប្រឆាំង ។ អ្នកការទូតអាមេរិកឈ្មោះ ចន បុលតុន បានឲ្យយោបល់ថា យ៉ាងហោចណាស់ដាក់ជាសម្មិតកម្មអំពើប្រល័យពូជសាសន៍បានហើយ ។ ប៉ុន្តែការផ្តល់យោបល់នេះ មិនត្រូវបានគេយកមកគិតឡើយ ។ ពួកគេបានយល់ព្រមលើទម្រង់នៃការបោះឆ្នោត និងលក្ខខ័ណ្ឌចំពោះជនភៀសខ្លួន ដែលត្រូវត្រឡប់ទៅប្រទេសវិញ ដើម្បីអាចមានសិទ្ធបោះឆ្នោតបាន ។ អ្នកការទូតរបស់អង់គ្លេសឈ្មោះ ហ្គៀលម័រ បានធ្វើឲ្យមានការយល់ព្រមសម្រួលចំពោះតួនាទីរបស់ក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជា ឬ *SNC* ។ ក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជានឹង"រក្សានូវបូរណភាពរបស់រដ្ឋាភិបាល" ជាជាងមានតួនាទីដូចជារដ្ឋាភិបាលដែលចិនចង់បាន ឬក៏គ្មានបូរណភាពសោះ ដូចសូវៀតទាមទារ ។ ម៉ាតាំង ប្រកាសថា នោះជា"ដំណោះស្រាយដ៏ស្អាតមួយ របស់បុរសម្នាក់ដែលប្រកបដោយវប្បធម៌រុងរឿង និងញាន ដែលប្រកបដោយមជ្ឈិមបដិបទា" ។ គ្រប់គ្នាក៏យល់ព្រម ហើយដើរចេញទៅជួបអ្នកកាសែត ។ ពួកគេមានការខកចិត្តយ៉ាងខ្លាំង ដែលមានតែអ្នកកាសែតមួយចំនួនប៉ុណ្ណោះ មកស្តាប់ពី

ការវិវឌ្ឍន៍ដ៏សំខាន់នេះ ។

ប៉ុន្តែនៅពីក្រោយសកម្មភាពការទូតដ៏ចង្អៀតនេះ ការប្រកែកគ្នាដ៏ធំមួយបានកើតឡើងនៅក្នុងសភារបស់អាមេរិកប្រឆាំងនឹងនយោបាយរបស់រដ្ឋាភិបាល ប៊ូស ចំពោះកម្ពុជា ។ នៅក្នុងសភាតំណាងរាស្ត្រ សមាជិកសភា ឆេសស៊ី អាត់ឃីន នៃគណបក្សប្រជាធិបតេយ្យពីរដ្ឋម៉ាសាឈូសេត ជាអ្នកជំទាស់ខ្លាំងជាងគេនៅក្នុងសភា ។ ព្រមពេលជាមួយនោះ ក្រុមភាគច្រើនដែលដឹកនាំដោយ ចត មីតឆែល ខាងគណបក្សប្រជាធិបតេយ្យ ពីរដ្ឋម៉េន បានបង្កនូវបញ្ហាយ៉ាងខ្លាំងចំពោះរដ្ឋភិបាលរបស់ប៊ូស ។ ម្តងនោះ អាតឃីន ធ្លាប់ធ្វើការជាមួយ សូឡា ដើម្បីផ្តល់ជំនួយដល់ជនភៀសខ្លួនកម្ពុជានៅតាមព្រំដែនថៃ ។ ជនភៀសខ្លួនទាំងនោះ ឥឡូវភាគច្រើនរស់នៅម្តុំទីក្រុងឡូវែល រដ្ឋម៉ាសាឈូសេត ។ ប៉ុន្តែក្រោយមក គាត់ក៏បែកចេញពី សូឡា ព្រោះគាត់មិនពេញចិត្តចំពោះការគាំទ្ររដ្ឋាភិបាលចម្រុះ សម្តេច ព្រះនរោត្តម សីហនុ ខ្មែរក្រហម និង សឺន សាន ពីព្រោះមានខ្មែរក្រហមនៅក្នុងនោះ ។ ឥឡូវពេលដែល ទ័ពរបស់វៀតណាមដកចេញពីកម្ពុជា គាត់ជឿយ៉ាងខ្លាំងថា នយោបាយរបស់អាមេរិក ដែលបន្តគាំទ្រចំពោះរដ្ឋាភិបាលចម្រុះ ជាអំពើអសីលធម៌មួយ ។ ទីបំផុត គាត់ក៏បញ្ចេញនូវគំនិតរបស់គាត់ ចំពោះទស្សនិកជនទូទាំងប្រទេសតាមរយៈកម្មវិធីពត៌មានពិសេស របស់ ពីទី ចេននីង នៃទូរទស្សន៍ អេ ប៊ី ស៊ី ដែលបានចាក់ផ្សាយនៅថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩០ ។

ដោយឆ្លើយនូវសំណួររបស់ ចេននីង ដែលមានទំនោរទៅលើគាត់នោះ គាត់ក៏បញ្ចេញឲ្យដឹងពីភាពមិនពេញចិត្តរបស់គាត់ចំពោះរដ្ឋាភិបាល របស់ប៊ូស ដែលបន្តជួយខបត្តម្ភជាទឹកប្រាក់ដល់ជំរំជនភៀសខ្លួនខ្មែរក្រហម ដែលស្ថិតនៅក្រោមការដឹកនាំរបស់ ប៉ុល ពត ។ ហើយគាត់ក៏និយាយដល់ការបន្តទទួលស្គាល់ខ្មែរក្រហម នៅឯអង្គការសហប្រជាជាតិ ការផ្អប់មិនឲ្យមានជំនួយមនុស្សធម៌ដល់ប្រជាជនកម្ពុជាថែមទៀត ។ ទង្វើទាំងនេះ គឺសំអាងលើតែហេតុផលថា ជាការប្រឆាំងនឹងការគ្រប់គ្រងរបស់វៀតណាមលើទឹកដីកម្ពុជា សូម្បីតែឥឡូវនេះវៀតណាមដកទ័ពអស់ពីកម្ពុជាក៏ដោយ ។

នៅពេលដែល ចេននីង សួរពីមូលហេតុ គាត់បានឆ្លើយថា នយោបាយអាមេរិក ជា«នយោបាយនៃការគុំសួប» ។

«យើងបានធ្វើសង្គ្រាមជាមួយវៀតណាម ហើយឥឡូវនេះ នៅផ្នែកចុងក្រោយនៃសង្គ្រាមនោះ បើយើងប្រើខ្មែរក្រហមជាចំណាប់ខ្មាំងនោះយើងនឹងប្រើពួកគេ ។ យើងមិនដឹង យើងឥឡូវមិនមែនប្រើប្រាស់ខ្មែរក្រហមនោះទេ» ។

នៅពីមុខរូបភាពព្រៃខៀវស្រងាត់តាមព្រំដែន ចេននីង បានសម្ភាសន៍ជាមួយទាហាន ដែលនិយាយថា ការធ្វើសហប្រតិបត្តិការរវាងកងទ័ពខ្មែរក្រហមជាមួយទ័ពរបស់សម្តេច ព្រះនរោត្តម សីហនុ និង សឺន សាន មានដំណើរទៅយ៉ាងល្អ ។ អាមេរិកបានហាម ទាំងពីរក្រុមថា នោះមិនមែនជាជំនួយរបស់អាមេរិកទេ ។ ចេននីង

បានបង្ហាញពីសភាពដែលជនភៀសខ្លួន ត្រូវបានមេទាហានបង្ខំឲ្យនៅក្នុងជំរំអស់រយៈពេល១០ឆ្នាំ ដោយសំឡុតគំរាមពីលទ្ធផលធ្ងន់ធ្ងរ ដែលគេនឹងទទួល បើមិនធ្វើតាមបញ្ជា ។ មកដល់ពេលនេះ ព្រំប្រទល់ថៃ-ខ្មែរ បានក្លាយជាវាលដែលមានមីនច្រើនជាងគេក្នុងលោក ។

ចេននីង បានចោទសួរ សូឡូម៉ុងដូចជាសួរចម្លើយអ្នកទោសអ៊ីចឹង ។ គាត់បានបង្ខំឲ្យ សូឡូម៉ុង ទទួលស្គាល់ថា អាមេរិកបដិសេធមិនព្រមចាប់ខ្លួន ប៉ុល ពត ឬក៏ខ្មែរក្រហម ដែលទទួលខុសត្រូវក្នុងការប្រល័យពូជសាសន៍ទេ ។ សូឡូម៉ុង បានធ្វើតាមគោលការណ៍របស់អាមេរិក ហើយប្រកែកមិនព្រមប្រើពាក្យប្រល័យពូជសាសន៍ ហើយប្រើពាក្យ «អំពើហិង្សាដែលខ្មែរក្រហមបានប្រព្រឹត្ត»ជំនួសវិញ ។

ចេននីង បានបើកកម្មវិធីរបស់គាត់ដោយនិយាយថា សហរដ្ឋអាមេរិកទទួលខ្មែរក្រហម ហើយបញ្ចប់កម្មវិធីរបស់គាត់ដោយនិយាយថា ខ្មែរក្រហមនឹងអាចត្រឡប់មកម្តងទៀត ដោយថា ឥឡូវទ័ពវៀតណាម បានដកចេញពីកម្ពុជាទៅហើយ» ។ ការនិយាយបែបនោះ បានទុកឲ្យ«អាមេរិកមានគ្រោះថ្នាក់ដោយឈរនៅខាងខុសក្នុងប្រវត្តិសាស្ត្រ» ។

ប្រតិកម្មបានកើតមាននៅ កាពីតូលហៀល និងនៅតាមសារពត៌មាន ។ គំនិតរបស់ អាត់ឃីន ត្រូវទទួលបានការគោរពដោយកាសែតញូវយកថេម និងវ៉ាស៊ីនតោនប៉ុស្តិ៍ ។ កម្ពុជាបានក្លាយជាប្រធានបទនៃការវិភាគរិះគន់ម្តងទៀត ។ ហើយលើកនេះ ខុសប្លែកពីមុនដោយថា ពិភពលោកបានលើកកម្ពស់ចំពោះការជជែកនោះ ។ នៅខែឧសភា ចិន និងវៀតណាម បានចាប់ផ្តើមនិយាយពីការសម្រុះសម្រួល ទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរឡើងវិញ ។ ហើយនៅចុងខែ ប្រទេសទាំងប្រាំ បានជួបគ្នាម្តងទៀត ដើម្បីជជែកពីកម្ពុជា ហើយបានដាក់ជាលាយលក្ខណ៍អក្សរ នូវអ្វីដែលគេបានយល់ព្រមជាមួយគ្នាពីមុនមក ។ តែពួកគេមិនអាចធ្វើឲ្យចិនប្តូរគំនិត ដែលចង់ដករដ្ឋាភិបាល ហ៊ុន សែន ចេញទេ ។ ជប៉ុនក៏លូកដៃចេញចំណាយសម្រាប់សន្និសីទ ដើម្បីសន្តិភាពនៅកម្ពុជា ។ ប៉ុន្តែខ្មែរក្រហមប្រកែកមិនព្រមចូលរួម ហើយទុកឲ្យតែ ហ៊ុន សែន និង សម្តេច ព្រះនរោត្តម សីហនុ ចុះហត្ថលេខា លើលិខិតដោយឡែកពីគ្នា ។

ឆ្លៀតក្នុងឱកាសអំណោយផលនេះ នៅខែមិថុនា អាត់ឃីន បានលើកយកមកជជែកនៅក្នុងសភា ដើម្បីកាត់ផ្តាច់ជំនួយដល់ក្រុមតស៊ូ ហើយបង្កើនថវិកាចំនួន១០លានដុល្លារ ដើម្បីជ្រោមជ្រែងការពិភាក្សា ដើម្បីសន្តិភាពវិញម្តង ។ ហេតុការណ៍នេះ នាំទៅដល់ការវាយបកលើ សូឡា ដែលជាដៃគូចាស់របស់គាត់ ដែលប្រកែកឲ្យបន្តការគាំទ្រផ្តល់ជំនួយដល់ក្រុមមិនមែនកុម្មុយនិស្ត ។ សូឡា និយាយថា គ្មានភស្តុតាងអ្វី ដែលបញ្ជាក់ថា ជំនួយរបស់អាមេរិក បាន«ធ្លាក់ដល់ដៃខ្មែរក្រហមទេ ។ ប្រសិនបើដូច្នោះមែន ខ្ញុំប្រាកដជាតវ៉ាឲ្យផ្តាច់ជំនួយដល់ក្រុមមិនមែនកុម្មុយនិស្តនោះបាត់ទៅហើយ» ។

សូឡា បានសួរបកវិញថា «តើធ្វើដូចម្តេចនឹងអាចឲ្យយើងជួយតែក្រុមមិនមែនកុម្មុយនិស្តសុទ្ធសាធនោះ

បើខ្មែរក្រហមក៏អង្គុយនៅក្នុងក្រុមប្រឹក្សាសង្គ្រាមជាមួយពួកមិនមែនកុម្មុយនិស្តដែរ? គ្មានអ្វីដែលអាចបាំងជិតនោះទេ មេដឹកនាំរបស់ក្រុមមិនមែនកុម្មុយនិស្ត បានចែកកៅអីជាមួយខ្មែរក្រហមអង្គុយ នៅឯអង្គការសហប្រជាជាតិ» ។

ទោះបីជាការពិតឈរនៅខាង អាត់ឃីន ក៏ដោយ ក៏សូឡា នៅតែឈ្នះឆ្នោត ២៨០ លើ ១៦៣ដដែល ។

ប៉ុន្តែ ការប្រយុទ្ធទើបតែចាប់ផ្តើមប៉ុណ្ណោះ ។ ដល់ត្រឹមខែកក្កដា ខាងព្រឹទ្ធសភា បានលូកដៃចូលក្នុងរឿងនោះ ដោយពេញទំហឹង ។ សមាជិកព្រឹទ្ធសភា មីតឆែល និងចនស៊ី ដាន់ហ្វត នៃគណបក្សសាធារណរដ្ឋ មកពីរដ្ឋមីសួរី បានដើរចែកចាយសំបុត្រទាមទារឲ្យបដិសេធអាសនៈរដ្ឋាភិបាលចម្រុះនៅអង្គការសហប្រជាជាតិ ។ ហើយពួកគេទាមទារឲ្យចាប់ផ្តើមផ្តល់ជំនួយមនុស្សធម៌ដល់កម្ពុជា ហើយឲ្យបើកទំនាក់ទំនងដោយផ្ទាល់ ជាមួយរដ្ឋាភិបាល ហ៊ុន សែន ។ ពួកគេក៏ទាមទារ ឲ្យបញ្ជាក់ច្បាស់ថា ខ្មែរក្រហមគ្មានចំណែកក្នុងអនាគតរបស់កម្ពុជា ឡើយ ។ នៅពេលដែលមហាអំណាចជួបប្រជុំគ្នានៅលើកនេះនៅប៉ារីស សមាជិកព្រឹទ្ធសភាទាំងពីររូបនោះ ប្រមូលបានហត្ថលេខាចំនួនជាង៦០ ។

ឥឡូវរដ្ឋាភិបាលរបស់ប៊ូស ត្រូវតែរើសថា យកមួយណា ។ ទីប្រឹក្សាសន្តិសុខជាតិ ស្កូក្រូហ្វ បានដឹកនាំក្រុមប្រឆាំងនឹងការដើរឈានទៅរកវៀតណាម ឬរដ្ឋាភិបាល ហ៊ុន សែន ។ ជំនួយការរបស់ បេកឺ បានរុញគាត់ឲ្យដើរទៅផ្លូវបញ្ច្រាសពីនោះវិញ ។ អនុរបស់គាត់ រូបឺត គីមីត បានទទួលស្គាល់ថា “មានមនុស្សមួយក្រុម នៅក្នុងរដ្ឋាភិបាលយល់ថា ផ្លូវដើរដែលល្អបំផុតក្នុងរឿងវៀតណាម គឺឈរឲ្យនឹង ។ ពួកគេជឿថា វិធីមួយដែលអាចធ្វើឲ្យវៀតណាមទោរទន់បាន គឺមានតែយើងមិនទោរទន់ខ្លួនឯង» ។ គីមីត ត្រូវបាន បេកឺ ដាក់ឲ្យទទួលខុសត្រូវរកវិធានការនយោបាយថ្មីមួយ ដើម្បីតទល់នឹងវៀតណាម និងរដ្ឋាភិបាល ហ៊ុន សែន ។ បន្ទាប់ពីបានជួបជជែកជាមួយមន្ត្រីពីរបីនាក់មក គីមីត និយាយថា គាត់បានដាក់យោបល់របស់ពួកគេបញ្ចូលគ្នា ឲ្យចេញជាកញ្ចប់គំនិតមួយ ដែលអាចឲ្យអ្នកនៅសេតវិមាន ដែលជំទាស់នឹងគំនិតនេះបែរទៅរកវៀតណាម និង ហ៊ុន សែន អាចទទួលយកបាន ។ តែរឿងនេះ យើងត្រូវតែធ្វើដោយស្ងាត់ៗ ។

សមាជិកផ្សេងទៀតនៃរដ្ឋាភិបាល បានរំលឹកពីកំហុសរបស់ បេកឺ ដែលបរាជ័យក្នុងសន្និសីទប៉ារីស នៅឆ្នាំ ១៩៨៩ គឺនៅពេលដែលគាត់សុំឲ្យ គីមីត មើលជាពិសេសលើបញ្ហាអាស៊ី ។ ជំនួយការលេខាធិការនៃអង្គការអន្តរជាតិ ចន បុលតុន បាននិយាយថា បេកឺ គិតថា ជារឿងមួយចំឡែក ដែលសហរដ្ឋអាមេរិកមិនព្រមជួបដោះស្រាយជាមួយវៀតណាម និង ហ៊ុន សែន នៅពេលដែលវៀតណាម បានដកទ័ពចេញពីកម្ពុជាអស់ហើយនោះ ។ បុលតុន និយាយថា«កម្មវិធីរបស់ ពីទ័រ ចេននីង បានធ្វើឲ្យព្រឹទ្ធសភាខឹងយ៉ាងខ្លាំង ។ ផ្នែកមួយនៃការធូរស្បើយនោះ ហើយដែលបាននាំយកកម្ពុជាមកដាក់នៅខាងមុខវិញ» ។

សូឡូម៉ុង បានចេញទៅប៉ារីសដោយទាំងមិនដឹងថា តើការចុះសម្រុងនោះជាអ្វីផងទេ ។ នៅពេលដែលគាត់

ទៅដល់ប៉ារីស គាត់បានទៅជួបជាមួយអ្នកការទូតចិន ស៊ូ ដុងស៊ុន ។ គាត់បានបង្ហាញសំបុត្ររបស់សមាជិកព្រឹទ្ធសភា មីតឆែល ទៅ ដុងស៊ុន "ខ្ញុំបាននិយាយប្រាប់គាត់ថា "លោកត្រូវតែយល់ថា រដ្ឋាភិបាលយើងស្ថិតនៅក្រោមសម្ពាធមួយ ។ ប្រសិនបើយើងមិនអាចបញ្ចេញនូវសកម្មភាពមួយ គ្រប់គ្នា និងបែរមកគាំទ្រ ហ៊ុន សែន ។ ហើយលោកនឹងត្រូវគេទុកឲ្យទទួលបន្ទុកឈាមរបស់ខ្មែរក្រហម" ។

មិនយូរប៉ុន្មាន សូឡូម៉ុង ក៏បានទទួលដំណោះស្រាយ ក្នុងការចុះសម្រុង ដែល បេកឺ រកឲ្យគាត់បាន ។ នៅថ្ងៃបន្ទាប់ ប្រទេសទាំងប្រាំ ក៏បានជួបពិភាក្សាពីកម្ពុជាម្តងទៀត ។ រដ្ឋមន្ត្រីការបរទេសបានមកដល់ប៉ារីស ដើម្បីជួបជាមួយ សេវ៉ាដណាដហ្សេ នៅឯគេហដ្ឋានឯកអគ្គរដ្ឋទូតអាមេរិក ។ បន្ទាប់ពីការសហការគ្នាដ៏លំបាក ដើម្បីឈានទៅដល់ការរំដោះនៃអឺរ៉ុបខាងកើត បេកឺ ឥឡូវចាត់ទុក សេវ៉ាដណាដហ្សេ ជាមិត្តដោយចំហ ។ ដូច្នេះគ្មានអ្វីចម្លែកទេ ដែលគាត់ធ្វើការប្រកាសពីកម្ពុជា ដោយឈរជិត សេវ៉ាដណាដហ្សេ ។ ឆ្លើយទៅនឹងសំណួរដំបូងបំផុត នៅសន្និសីទកាសែត បេកឺ បានប្រកាសថា សហរដ្ឋអាមេរិក ទទួលស្គាល់ការដកទ័ពរបស់វៀតណាម ហើយគេនឹងធ្វើវិធានការដើម្បីការពារមិនឲ្យខ្មែរក្រហមត្រឡប់មកវិញបាន ។ បេកឺ និយាយថា "ដើម្បីអាចធ្វើទៅបានយើងនឹងជួបពិភាក្សាជាមួយវៀតណាមស្តីពីកម្ពុជា ។ យើងនឹងពង្រីងជំនួយមនុស្សធម៌ដល់កម្ពុជា ។ ហើយយើងនឹងរៀបចំ និងប្តូរនយោបាយរបស់យើង ស្តីពីអាសនៈរបស់កម្ពុជានៅអង្គការសហប្រជាជាតិ ដែលពេលនោះជារបស់រដ្ឋាភិបាលចម្រុះ ដែលរួមមានទាំងខ្មែរក្រហមផង" ។

បេកឺ ក្រោយមកក៏ទទួលស្គាល់ថា សហរដ្ឋអាមេរិក មានការបារម្ភថា ខ្មែរក្រហមអាចឈ្នះក្នុងការប្រយុទ្ធគ្នា ។ "ជាច្រើនឆ្នាំមកហើយ ដែលយើងសាកល្បងដដែកនយោបាយ តាមរយៈសន្និសីទ ស្តីពីកម្ពុជានៅប៉ារីសប៉ុន្មានឆ្នាំមុន ។ ខ្មែរក្រហមបានទទួលជោគជ័យក្នុងការបំបែរការសន្ទនានោះ ទៅនិយាយពីសមរភូមិមុខវិញ" ។

គាត់និយាយថា "គោលបំណងរបស់យើង គឺការពារមិនឲ្យខ្មែរក្រហមត្រឡប់មកកាន់អំណាចវិញ" ។

ព្រមពេលដែលគាត់និយាយនៅក្រុងប៉ារីស នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៩០ គាត់បានផ្ញើសំបុត្រទៅមីដឆែល នៅឯវ៉ាស៊ីនតោន ។ នៅក្នុងសំបុត្រនោះ គាត់ប្រាប់ដល់ មីដឆែល ពីនយោបាយថ្មីរបស់រដ្ឋាភិបាលដែលចាប់ផ្តើមជជែកដោយផ្ទាល់ជាមួយវៀតណាម និងភ្នំពេញ បោះឆ្នោតប្រឆាំងនឹងរដ្ឋាភិបាលចម្រុះខ្មែរក្រហមនៅអង្គការសហប្រជាជាតិ អនុញ្ញាតឲ្យមានការបង្កើនជំនួយមនុស្សធម៌ដល់វៀតណាម និងកម្ពុជា នឹងបង្កើតកម្មវិធីថ្មីមួយ ដើម្បីជួយកម្ពុជា និងជនរងគ្រោះដោយសារសង្គ្រាម ។

ការប្រែប្រួលដ៏ខ្លាំងនៃនយោបាយរបស់អាមេរិក បានបញ្ចប់ការចរចា ។ ចិនក៏បន្ថយការទាមទាររបស់គេដែលឲ្យរំសាយរដ្ឋាភិបាល ហ៊ុន សែន ដែរ ។ តាមពិតទៅ រដ្ឋាភិបាលភ្នំពេញ បានទទួលស្មើគ្នាជាមួយក្រុមតស៊ូ ដូចដែល រ៉ូហ្កាឆូវ បានស្នើសុំឲ្យ ។ រណឫទ្ធិ បានរអ៊ូទាំងខឹងថា ការប្រែប្រួលលើកនោះ ហាក់បីដូចជា "សម្ងាប់មិត្តរបស់ខ្លួនឯងអឺចឹង ។ ដំណោះស្រាយនោះ គឺបន្ថយកម្លាំងខ្មែរក្រហមនៅពេលក្រោយ មិនមែននៅពេលនេះទេ" ។

ម៉ាតាំង ជំទាស់ថា «ខ្ញុំមិនទម្លាក់តម្លៃនៃតួនាទីរបស់បារាំងនៅកម្ពុជាទេ ប៉ុន្តែ ចិនយល់ច្បាស់ថា អាមេរិកប្រឆាំងនឹងចិនកាន់តែចំហ ហើយពួកគេយល់ថា គេនឹងត្រូវបានដាក់ដោយឡែកឲ្យនៅជាមួយខ្មែរក្រហម បើគេមិនប្រយ័ត្ន ។ ចិនតែងតែបន្ទូរបន្ថយ ចំពោះរឿងទំនាក់ទំនងអន្តរជាតិ ដើម្បីជៀសវាងមិនបន្ទូរបន្ថយរឿងផ្ទៃក្នុង ជាពិសេស ជុំវិញរឿងសិទ្ធិមនុស្ស» ។

ការឆ្លើយតបរបស់ រ៉ូហ្កាឆូវ រឹតតែចំថែមទៀត ។ គាត់ថា «សុន្ទរកថារបស់ បេកឹ ជះឥទ្ធិពលយ៉ាងខ្លាំងចំពោះប្រទេសអាស៊ាន ។ ពួកគេដឹងថា ភ្នំពេញជាកម្លាំងពិតប្រាកដ ។ ហើយចប់» ។

នៅខែបន្ទាប់ គឺខែសីហា កិច្ចព្រមព្រៀងដំបូង បានដល់ដំណោះស្រាយនៅកម្ពុជា ។ ក្រុមតស៊ូរបស់កម្ពុជាបានជួបគ្នានៅប៉េកាំង ហើយក៏ទទួលយល់ព្រម ។ នៅចុងខែ ប្រទេសទាំងប្រាំ ក៏បានបង្កើតឡើងនូវគម្រោងពេញលេញមួយ ។ នៅថ្ងៃទី៩ ខែកញ្ញា ហ៊ុន សែន បានព្រមទទួលយកនូវគម្រោង នៅពេលប្រជុំនៅហ្សាការតា ។ ថ្ងៃបន្ទាប់មក ក្រុមរបស់កម្ពុជាទាំងអស់ ក៏ចុះហត្ថលេខាយល់ព្រម ។

មកដល់ត្រឹមនោះកម្ពុជាត្រូវបានគេបំភ្លេចចោល ។ អ៊ីរ៉ាក់ បានចូលឈ្លានពានគុយវ៉ែត នៅដើមខែ ហើយបានបញ្ឆេះទំនាស់អន្តរជាតិ ដែលបន្តរហូតដល់ចុងឆ្នាំហើយបន្តទៅឆ្នាំបន្ទាប់ទៀត ។

នៅរដូវសឹកឈើជ្រុះឆ្នាំនោះ អង្គការសហប្រជាជាតិ បានបោះឆ្នោតឲ្យក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជាដែលជាលទ្ធផលនៃការចរចាសន្តិភាពឲ្យកាន់កាន់អសនៈនៅទីនោះ ។ ទីបំផុត អាមេរិក ក៏អញ្ជើញរដ្ឋមន្ត្រីការបរទេសរបស់វៀតណាមទៅវ៉ាស៊ីនតោន ។ នោះជារឿងមួយដែលគួរធ្វើយូរមកហើយ ព្រោះមន្ត្រីវៀតណាមរូបនេះ បានខំពង្រឹងទំនាក់ទំនងវៀតណាមជាមួយអាមេរិក តាំងពីមុនជាមួយចិនម៉្លេះ ។ គាត់ត្រូវចាញ់ ហើយក្នុងឆ្នាំនោះ បក្សបានដកគាត់ចេញពីតំណែង ។

ដោយមិនដឹងខ្លួនអ៊ីរ៉ាក់បានជំរុញដល់អ្នកចរចាទាំងឡាយ ជាពិសេស ខ្មែរក្រហម និងបក្សពួកមិនមែនកុម្មុយនិស្តរបស់គេ ។ នៅចុងឆ្នាំ ឌុយម៉ាស បានហៅឲ្យភាគីខ្មែរទាំងអស់ឲ្យមកបញ្ចប់ការចរចារបស់ពួកគេជាបន្ទាន់ ។ «ខ្ញុំសូមប្រាប់ឲ្យដឹងថា ពិភពលោកសព្វថ្ងៃ បានប្រែប្រួល មានបញ្ហាផ្សេងទៀតត្រូវការឲ្យយើងយកចិត្តទុកដាក់ ។ សហគមន៍អន្តរជាតិ មិនអាចបន្តដោះស្រាយបញ្ហាកម្ពុជារហូតទេ ប្រសិនបើកម្ពុជាខ្លួនឯងមិនបង្ហាញឲ្យឃើញពីបំណងនយោបាយ ដើម្បីរកដំណោះស្រាយនោះ» ។

ការព្រមាននេះទទួលបានជោគជ័យ ។នៅថ្ងៃទី២២ ខែធ្នូ ភាគីកម្ពុជាទាំងអស់ បានយល់ព្រមជាលាយលក្ខណ៍អក្សរថា គេ«ទទួលយកនូវគម្រោងរបស់សមាជិកអចិន្ត្រៃយ៍ ក្រុមប្រឹក្សាសន្តិសុខទាំងប្រាំ ដើម្បីដោះស្រាយជម្លោះនៅកម្ពុជា» ។

ក្នុងរយៈពេលប៉ុន្មានខែនេះ លើកនេះ ជាលើកចុងក្រោយហើយ ដែលអន្តរជាតិផ្តោតការយកចិត្តទុកដាក់លើបញ្ហាកម្ពុជា ។ រដ្ឋាភិបាលជុំវិញពិភពលោក បានខ្វាយខ្វល់ពីការការពារកុំឲ្យសង្គ្រាមរវាងអាមេរិក និងអ៊ីរ៉ាក់

ផ្ទុះចេញឡើង ។ ប៉ុន្តែបន្ទាប់ពីការចរចាជាច្រើនលើក ដោយឲ្យអ៊ីរ៉ាក់ដកចេញពីគុយវ៉ែត មិនបានសម្រេច អាមេរិក និងទ័ពសម្ព័ន្ធមិត្តរបស់គេ ក៏វាយទ័ពរបស់អ៊ីរ៉ាក់នៅគុយវ៉ែតនាខែកុម្ភៈ ។

ឆ្លៀតឱកាសច្របូកច្របល់ដែលអារម្មណ៍ផ្តោតលើអ៊ីរ៉ាក់នោះ មេទ័ពបានធ្វើរដ្ឋប្រហារ ដើម្បីទម្លាក់នាយករដ្ឋមន្ត្រី ឆាទីឆៃ ។ មេទ័ពទាំងនោះ អាចទ្រាំនឹងនយោបាយរបស់ ឆាទីឆៃ លើបញ្ហាពិភពលោកបាន តែមិនអាចទ្រាំនឹងការប្រកាសផ្លាស់ប្តូរមេទាហានបានទេ ។ ពួកគេក៏យកបញ្ហាអំពើពុករលួយ មកធ្វើជាហេតុផលក្នុងការធ្វើរដ្ឋប្រហារនេះ ។

នៅក្នុងអំឡុងរដូវផ្ការីក និងរដូវក្តៅនោះ កម្ពុជាបាន ឈានដល់កិច្ចព្រមព្រៀងមួយទៀត ដោយលើកឲ្យសម្តេច ព្រះនរោត្តម សីហនុ ជាប្រធាន ហើយ ហ៊ុន សែន ជាអនុប្រធានក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ។ នៅអង្គប្រជុំនៅខែកក្កដា ភាគីកម្ពុជាទាំងអស់ និងអ្នកតំណាងរៀបចំសន្និសីទនៅប៉ារីស និងអង្គការសហប្រជាជាតិ បានទទួលស្គាល់រួមមួយថា «សម្តេច ព្រះនរោត្តម សីហនុ ជាបុគ្គលតែមួយគត់ដែលអាចផ្សះផ្សាបង្រួបបង្រួមកម្ពុជាបាន» ។ នៅខែសីហា ការចរចាលើកម្រោងបានបញ្ចប់នៅប៉ាតាយ៉ា ។ ផ្នែកទីពីរនៃសន្និសីទប៉ារីសបានត្រូវគេកំណត់បើកនៅចុងខែតុលា ។

ប្រតិបត្តិការ UNTAC ជាប្រតិបត្តិការដ៏ធំមួយ និងថ្លៃបំផុត ដែលអង្គការសហប្រជាជាតិមិនធ្លាប់ធ្វើ ។ គឺមានតម្លៃ ពីរកោដិដុល្លារ ក្នុងរយៈពេល២ឆ្នាំ ។ គ្មានក្រុម ឬប្រទេសណា ជាពិសេសខ្មែរក្រហមអាចមកបង្អាក់សន្ធិសញ្ញាសន្តិភាពនេះបានឡើយ ។ ការជួបជុំគ្នាលើកនេះ មានការហ្មត់ចត់ជាងពីរឆ្នាំមុនឆ្ងាយណាស់ ។ ប៉ុន្តែមានតួអង្គសំខាន់មួយចំនួនបានអវត្តមាន ។ រ៉ូហ្កាឆូវ មានវត្តមាន ប៉ុន្តែ សេវ៉ាដណាដហ្សេ បានលាលែងដើម្បីប្រឆាំងនឹងការដោះស្រាយរបស់ ហ្គោបាឆូវ ដែលក្រោយមកក្លាយជាដំណោះស្រាយបរាជ័យរបស់សូវៀត ។ ឌុយម៉ាស មានវត្តមាន ប៉ុន្តែ ម៉ាតាំង អវត្តមាន ។ គាត់ត្រូវបានគេលើកឲ្យធ្វើជាឯកអគ្គរដ្ឋទូត ហើយត្រូវបញ្ជូនទៅប៉េកាំង ។ វៀតណាមមានរដ្ឋមន្ត្រីការបរទេសថ្មី ។ ង្វៀន កូថាច់ ត្រូវបានគេដាត់ឲ្យនៅដោយឡែកជាការចំណាយសម្រាប់ដោះស្រាយទំនាក់ទំនងជាមួយចិន ។

រ៉ូឡង់ ឌុយម៉ាស បានស្វាគមន៍គណៈប្រតិភូត្រឡប់មកវិញ បន្ទាប់ពីរយៈពេល២ឆ្នាំ២ខែនិងប្រាំថ្ងៃ តាំងពីការប្រជុំលើកដំបូង ។ គាត់បានអរគុណចំពោះសហប្រធានរបស់គាត់ អាលីអាឡាតាស ថា ជាមិត្តល្អជាងមុន ហើយក៏អរគុណសមាជិកអចិន្ត្រៃយ៍ក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិដែលឲ្យឱកាសសន្តិភាពដកដង្ហើមជាលើកទីពីរ ។ នៅពេលដែលត្រូវអរគុណចំពោះកម្ពុជា គាត់ដូចជាមេដឹកនាំដទៃទៀតនាពេលនោះបានអរគុណសម្តេច ព្រះនរោត្តម សីហនុ ដែលធ្វើជាអ្នកសម្រុះសម្រួល ។ ក្រោយមកគាត់ក៏បើកសន្និសីទមួយក្នុងរយៈពេល១ថ្ងៃ ប្រកាសថា «កម្ពុជាបានត្រឡប់មកក្នុងសហគមន៍អន្តរជាតិវិញ» ។

នៅថ្ងៃបន្ទាប់ក្នុងសម្លៀកបំពាក់អាវទប់ខ្យល់ និងខោគគីរបស់គាត់ គាត់បាននិយាយថា «មិត្តរបស់យើង

នៅភ្នំពេញតែងគិតថា វានឹងប្រើពេលវេលាច្រើនដើម្បីអាចឈានដល់ការផ្សះផ្សាជាតិ ។ ហើយខ្ញុំក៏មិនច្បាស់ថាពួកគេធ្លាប់គិតថា បើមានខ្មែរក្រហម ការផ្សះផ្សានោះនឹងអាចធ្វើឡើងដោយសន្តិវិធីដែរឬទេ» ។

បំណែងចម្បងត្រូវបានសម្រេចមុនពេលដែលទ័ពរបស់អង្គការសហប្រជាជាតិបានមកដល់ម្ល៉េះ ។ នោះគឺការបញ្ចប់ជំនួយរបស់បរទេសក្នុងការគាំទ្រសង្គ្រាម ។ «គ្មានសង្គ្រាមទៀតឡើយ ព្រោះគ្មានប្រទេសណាគាំទ្រសង្គ្រាមទៀតទេ ។ ទោះបីជាខ្មែរធ្វើអីចំពោះខ្មែរក៏ដោយ ក៏យើងនៅតែអាចហោះផ្ទាល់ពីបាងកកមកភ្នំពេញដែរ ។ ចប់ត្រឹមនោះឯង» ។

# អវសានកថា

ប្រាំពីរឆ្នាំបន្ទាប់ពីការលុកលុយរបស់វៀតណាម គេមិនអាចសម្តែងចេញនូវសេចក្តីសង្ឃឹមថា ដំណោះស្រាយមួយត្រូវបានគេគិតគូរឡើយ ។ ប្រជាជនកម្ពុជាប្រាំពីរលាននាក់នៅក្នុងប្រទេសនៅត្រូវរត់គេចខ្លួនរវាងសត្វខ្លា និងក្រពើនៅឡើយ ។ សង្គ្រាមចេះតែបន្តទៅតាមសង្វាក់នៃរដូវកាល ៖ កងទ័ពរបស់វៀតណាម គឺជាម្ចាស់សមរភូមិនៅរដូវប្រាំង ទ័ពព្រៃខ្មែរក្រហមបានវាតត្បាតប្រទេសនៅរដូវភ្លៀងធ្លាក់ ។

សង្គ្រាមបាននាំឲ្យគេដឹងរឿងហេតុសំខាន់ៗជាច្រើន ប៉ុន្តែ វាពុំបាននាំមកនូវការប្រែប្រួលធំដុំឡើយ ។ កងទ័ពនៃរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ បានពង្រឹងខ្លួនហើយចេញមុខស្នើធ្វើការដោះស្រាយមិនមែនកុម្មុយនិស្ត ដែលគួរឲ្យទុកចិត្តមួយរហូតដល់ថ្ងៃដែលពួកវៀតណាមវាយកម្ទេចមូលដ្ឋាននានារបស់ខ្លួន ក្នុងទឹកដីប្រទេសកម្ពុជានៅឆ្នាំ១៩៨៥ ខ្ទេចខ្ទីអស់ និងពេលដែលពួកមេដឹកនាំរណសិរ្សនេះ បានបំផ្លាញចលនាផ្ទាល់របស់ខ្លួនដោយសារជម្លោះផ្ទៃក្នុងដែលកើតមានមិនចេះចប់ ។ ប្រទេសជាច្រើនដូចជា ប្រទេសបារាំង និងអូស្ត្រាលីជាដើម បានសាកល្បងផ្តួចផ្តើមគំនិតផ្នែកការទូតផ្សេងៗដែរ តែត្រូវបរាជ័យមុនពេលចាប់ផ្តើមទៅទៀត ។

បើគិតឲ្យសព្វៗទៅ សេចក្តីរាយការណ៍អំពីកម្លាំងទ័ពមិនសូវមានការប្រែប្រួលទេ ។ កងទ័ពរបស់វៀតណាមមួយរយហាសិបពាន់នាក់ ដែលកាន់កាប់ប្រទេសកម្ពុជាមានចំនួនច្រើនជាងកងទ័ពរបស់រដ្ឋាភិបាលភ្នំពេញ ៣ដងដែលគ្មានសមត្ថភាពការពារប្រទេសប្រឆាំងនឹងពួកទ័ពព្រៃខ្មែរក្រហមឡើយ ។ ថ្វីបើបានប្រកាស "ចូលនិវត្តន៍" ជាផ្លូវការក៏ដោយ ក៏ ប៉ុល ពត នៅតែបន្តដឹកនាំបញ្ជាលើកងទ័ពរបស់គាត់ និងទទួលបានជំនួយយ៉ាងស្ទុកស្ទម្ភមួយពីពួកចិនដដែល ក្នុងការសាកល្បងរបស់គាត់ដើម្បីដណ្តើមយកប្រទេសកម្ពុជាជាថ្មី ។

សង្គ្រាមក្នុងនាមនៃប្រទេសកម្ពុជានៅតែជាសង្គ្រាមកុម្មុយនិស្តមួយ ។ បណ្តាប្រទេសនៃសមាគមអាស៊ានបានស្វែងរកដំណោះស្រាយសម្រាប់ធ្វើឲ្យស្ថានការណ៍ប្រែប្រួលដែរ ដោយជៀសមិនរួចពីវិលទៅរកសម្តេចព្រះនរោត្តម សីហនុ វិញឡើយ ។ នៅខែមិថុនា ឆ្នាំ១៩៨២ សម្តេច ព្រះនរោត្តម សីហនុ, សឺន សាន និងពួកខ្មែរក្រហម បានរៀបចំបង្កើតរដ្ឋាភិបាលកម្ពុជាចម្រុះមួយ តែមិនសូវបានសម្រេចជោគជ័យប៉ុន្មាន ទេ គឺបានត្រឹមតែធ្វើស្ថានភាពទ័លច្រកអូសបន្លាយទៅទៀតប៉ុណ្ណោះ ។ ទោះជារដ្ឋាភិបាលនេះនៅរក្សាទុកឈ្មោះរបបឧក្រិដ្ឋរបស់ ប៉ុល ពត ក៏ដោយ ក៏ត្រូវបានទទួលស្គាល់ជារដ្ឋាភិបាលផ្លូវការរបស់ប្រទេសកម្ពុជា នៅអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិនានាដែរ ។ មួយចំណែកធំ គឺដើម្បីរាំងរាមិនឲ្យការកាន់កាប់របស់វៀតណាមលើប្រទេសកម្ពុជា ប្រែក្លាយទៅជាព្រឹត្តិការណ៍មួយពេញលក្ខណៈច្បាប់ ។ ត្រង់ចំណុចនេះ អាស៊ានបានទទួលជោគជ័យលើសមរភូមិការទូតមួយ ប៉ុន្តែនៅឥណ្ឌូចិន នយោបាយផ្នែកការទូតកម្រដោះស្រាយបានជម្លោះផ្សេងៗខាងនយោបាយ ឬខាងយោធាណាស់ ។ នយោបាយរបស់ក្រុងហាណូយក៏ដូចនយោបាយរបស់ពួកខ្មែរ

ក្រហម និងក្រុងប៉េកាំងដែរ បញ្ចេញឲ្យឃើញផ្លូវតែមួយប៉ុណ្ណោះសម្រាប់ដោះស្រាយបញ្ហា គឺផ្លូវហិង្សាឆ្ពោះទៅរកការប្រើកម្លាំងបាយ ។

អ្វីដែលនាំឲ្យវិនាសអន្តរាយនោះ គឺបក្សពួកនីមួយៗអួតខ្លួនថា ខ្លួនមានបទពិសោធន៍ច្រើនជាងពេលណាៗទាំងអស់ ។ ជាមួយការបែកខ្ញែកនៃបណ្តាក្រុមអ្នកជាតិនិយមមិនមែនកុម្មុយនិស្តទៅជាពួកជាក្រុមបះបោរ ដែលប្រឈ្លោះតែគ្នាឯង ពួកខ្មែរក្រហមបានធ្វើឲ្យគេទទួលស្គាល់ថា ជាកម្លាំងសំខាន់បំផុត ដែលប្រយុទ្ធតស៊ូនឹងការកាន់កាប់របស់វៀតណាម ។ ពួកគេសុទ្ធតែជាមនុស្សឃោរឃៅ ដែលបានទទួលអត្ថប្រយោជន៍យ៉ាងច្រើនពីការមិនសប្បាយចិត្ត ដែលកាន់តែរីកធំឡើងៗនៅប្រទេសកម្ពុជាចំពោះនយោបាយកាន់កាប់ទឹកដីរបស់ពួកវៀតណាម ។ គឺកងទ័ពរបស់គេដែលជ្រើសរើសពីក្នុងចំណោមប្រជាជនកម្ពុជា ដែលធុញទ្រាន់នឹងការត្រួតត្រាស៊ើរតែដូចអាណានិគមដែលក្រុងហាណូយធ្វើទុក្ខទោសលើពួកគេ ។

ទោះបីជាប្រទេសកម្ពុជាផលិតស្រូវពុំបានគ្រប់គ្រាន់សម្រាប់ចិញ្ចឹមប្រជាពលរដ្ឋខ្លួនក៏ដោយ ក៏គេត្រូវបញ្ជូនស្រូវទៅប្រទេសវៀតណាមដែរ ។ ភាសាវៀតណាម បានក្លាយទៅជាភាសាទីពីរ តែត្រូវបានប្រើប្រាស់នៅក្នុងការិយាល័យផ្សេងៗរបស់រដ្ឋាភិបាល ។ ចំនួននៃនិគមជនវៀតណាមថ្មីៗបានរីកធំឡើង ជារៀងរាល់ឆ្នាំទៅតាមដំណើរមួយដែលមានតាំងពីរាប់រយឆ្នាំមកហើយ នៅពេលដែលពួកវៀតណាមបានទន្ទ្រានកាន់កាប់ទឹកដីដែលឥឡូវនេះ ជាភាគខាងត្បូងប្រទេសវៀតណាម ។ ដំបូង គឺពួកឈ្មួញតូចតាចវៀតណាមបានចូលមកតាំងនៅ (ដែលឥឡូវនេះ មានរស់នៅស៊ើរតែគ្រប់សង្កាត់ក្នុងក្រុងភ្នំពេញ) បន្ទាប់មក គឺកសិករ និងពួកអ្នកនេសាទត្រី ។ ពួកកសិករបានចូលមករស់នៅលើដែនដីទាំងឡាយ ដែលកំពុងមានវិវាទនៅតាមព្រំដែនវៀតណាម -កម្ពុជាដែលធ្វើឲ្យរឹងតែមិនច្បាស់លាស់ថែមទៀតដល់ការកម្រិតព្រំដែនរវាងប្រទេសទាំងពីរ ។ ពួកអ្នកនេសាទបានឡើងតាមផ្លូវទឹកពីក្រោមមក ហើយជម្រុលទៅដល់ភាគខាងលិចទន្លេសាបទៀត ។ បើសិនជាដំណើរនេះមានសកម្មភាពបន្តទៅទៀត និគមជនដែលត្រូវមកដល់នៅពេលខាងមុខគឺជាក្រុមកងទ័ពវៀតណាមរំសាយចេញពីជួរ ដែលនឹងទទួលបានដីធ្លីជាថ្នូរនឹងការធ្វើឲ្យប្រទេសកម្ពុជាមានសន្តិភាព ។

ពួកវៀតណាមក៏បានរើសប្រជាជនកម្ពុជារាប់រយពាន់នាក់ ដើម្បីស្ថាបនាទំនប់ការពារ(ផែនការ ក-៥) ប្រឆាំងនឹងសង្គ្រាមទ័ពព្រៃខ្មែរក្រហមក្នុងភាគខាងលិចប្រទេស ។ ពួកអ្នកធ្វើការក្នុងការិយាល័យ និងពួកមេដឹកនាំនយោបាយខ្មែរនៃរបបក្រុងភ្នំពេញ គោងតែទៅចូលរួម “ការរៀនសូត្រ” ដែលរ៉ាប់រងការបង្រៀនទ្រឹស្តី នៅប្រទេសវៀតណាមដោយទៀងទាត់ ។ តាមច្បាប់ក្បួននយោបាយ នេះជារឿងចាំបាច់ដើម្បីប្រែក្លាយប្រទេសកម្ពុជាទៅជារណបមួយរបស់វៀតណាម ដែលងាយស្រួលដឹកនាំមុនការកសាងប្រទេសឡើងវិញ ។

ក្រុងហាណូយមិនអាចអះអាងថា កងទ័ពរបស់ខ្លួនបានរួមបង្កជាដំណោះស្រាយសម្រាប់ផ្លាស់ប្តូរពួកខ្មែរក្រហមដែលមានតិចតួចក៏ទេដែរ ។ ការស្រាវជ្រាវមួយនៅឆ្នាំ១៩៨៥ ស្តីពីការរំលោភសិទ្ធិមនុស្សនៅប្រទេស

កម្ពុជា បានបង្ហាញឲ្យឃើញចំនួនដ៏គួរឲ្យភ្ញាក់ផ្អើលមួយនៃការចាប់ខ្លួនដោយបំពាន ការធ្វើទារុណកម្ម ការដាក់គុកចំពោះបទល្មើសបញ្ចេញទស្សនៈ ការវាយធ្វើបាបនៅក្នុងគុកនានារបស់របបក្រុងភ្នំពេញ ដែលរឿងទាំងអស់នេះស្ថិតនៅក្រោមការត្រួតត្រាដោយផ្ទាល់របស់ពួកវៀតណាម ។

ប៉ុន្តែ តើអ្នកណាមួយដែលនឹងបញ្ចេះឲ្យប្រជាជនកម្ពុជាប្រើប្រាស់អំពើហិង្សា ដើម្បីបណ្តេញកងទ័ពវៀតណាមចេញពីប្រទេស បើសិនប្រការនេះបណ្តាលឲ្យមានការវិលត្រឡប់របស់ពួកខ្មែរក្រហម?

ស្ថានការណ៍រឹតតែធ្វើឲ្យគេទុញទ័លគំនិតថែមទៀត បើសិនជាគេចាត់ទុកអ្នកកំពុងដឹកនាំប្រទេសកម្ពុជាថាស្ថិតក្រោមអំណាចវៀតណាម ៖ ពួកអតីតយុទ្ធជនរបស់ ប៉ុល ពត ។ តាមទស្សនៈដ៏ជាក់លាក់មួយ គេអាចសំគាល់ឃើញសង្គ្រាមក្នុងនាមនៃប្រទេសកម្ពុជាជាការតស៊ូផ្ទៃក្នុងបក្សមួយ ។ ពួកកុម្មុយនិស្តកម្ពុជាមួយក្រុមដែលដឹកនាំដោយអតីតកម្មាភិបាលម្នាក់របស់ភូមិភាគបូព៌ា និងបណ្តាសមាជិកនៃជាតិសាសន៍ភាគតិចមួយ បានបន្តបង្កើតបក្សឡើងវិញក្រោមឈ្មោះថា បក្សប្រជាជនបដិវត្ត ហើយបានអះអាងថា នេះជាបក្សពិតប្រាកដដែលបង្កើតឡើងកាលពីឆ្នាំ១៩៥១ ។ ប៉ុល ពត បានពិពណ៌នាទុកដូចជាការក័ន្តប្រឡូមួយ ដែលអំពើឧក្រិដ្ឋផ្សេងៗមានឫសគល់តាំងពីឆ្នាំ១៩៧៥ ។

ក្នុងសកម្មភាពដែលមានគ្រោងទុកជាមុននេះ អំពើឧក្រិដ្ឋធំបំផុតរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យគឺការទម្លាក់ទោសកំហុសទៅលើសមាជិកមួយចំនួនរបស់បក្ស ដូចជាលោក ហ៊ុន សែន រដ្ឋមន្ត្រីការបរទេសជាដើមដែលបានប្រកាសប្រាប់ខ្ញុំ នៅភ្នំពេញកាលពីឆ្នាំ១៩៨៣ (ឥឡូវនេះគាត់ជានាយករដ្ឋមន្ត្រី) ។ ហេតុដូច្នេះហើយបានជាគ្មានការលុបបំបាត់លក្ខណៈដាច់ការនៃលទ្ធិ«ស្តាលីននិយម» និង«លទ្ធិណាហ្ស៊ីនិយម» នៅប្រទេសកម្ពុជាតាំងពីការលុកលុយរបស់វៀតណាមមក ។ សាធារណរដ្ឋប្រជាមានិតកម្ពុជាយល់ឃើញថា ឧក្រិដ្ឋជន ពីរនាក់ជាអ្នកទទួលខុសត្រូវយ៉ាងសំខាន់ចំពោះការកាប់សម្លាប់ប្រជាជនឯងនេះ គឺ ប៉ុល ពត និង អៀង សារី ។ បក្សកុម្មុយនិស្តដែលអ្នកទាំងពីរដឹកនាំ ត្រូវបានបង្ហាញថាជាអ្នករងគ្រោះម្នាក់ ពុំមែនជាពេជ្ឈឃាតសម្លាប់ប្រជាជនឯងទេ ។

ទន្ទឹមនឹងនោះ ពួកកុម្មុយនិស្តដែលកំពុងប្រយុទ្ធតស៊ូក្រោមបញ្ជារបស់ ប៉ុល ពត បានរក្សាភាពមិនច្បាស់លាស់ឲ្យនៅស្ថិតស្ថេរជាបន្តទៀត ដោយបានប្រកាសជាសាធារណៈនៅឆ្នាំ១៩៨១ ពីការរំលាយបក្សកុម្មុយនិស្តកម្ពុជា«ពិតប្រាកដ»ចោល ។ ដូចក្នុងរយៈពេលសង្គ្រាមឆ្នាំ១៩៧០-១៩៧៥ដែរ ប៉ុល ពត ចូលចិត្តលាក់ទង់ក្រហមរបស់គាត់ជាង ។

គេពិបាកប៉ាន់ស្មានពីមនោសញ្ចេតនារបស់ប្រជាជនកម្ពុជា ដែលកំពុងរស់នៅក្នុងប្រទេសណាស់ ។ ខ្ញុំអាចសន្និដ្ឋានថា ពួកគេមិនចង់ឲ្យពួកខ្មែរក្រហមវិលត្រឡប់មកទេ ។ ម្យ៉ាងទៀត ខ្ញុំក៏យល់ថាការបន្តការកាន់កាប់របស់វៀតណាម នឹងធ្វើឲ្យប្រជាជនទាំងនោះរីករាយវិញក៏ទេដែរ ប៉ុន្តែខ្ញុំនឹងមិនប្រាថ្នាដឹងពីមតិរបស់គេហួសអំពីការ

ពោលអះអាងច្បាស់លាស់ទាំងពីរនេះទេ ។

ខ្ញុំមិនត្រូវការមនុស្សដែលនិយាយទុកជាមុនឡើយ ។ ទោះបីជាមានបញ្ហាផ្សេងៗ ទោះជាប្រវត្តិសាស្រ្តរបស់ខ្លួនប្រកបដោយការស្លាប់ព្រាត់ប្រាសអន្តរាយយ៉ាងណាក៏ដោយ ក៏ប្រទេសកម្ពុជា នៅតែជាប្រទេសនៃសោភ័ណភាព និងការតស៊ូមិនចំណុះអ្នកណាដដែល ។ ហើយសេចក្ដីបញ្ចប់ដែលមានលក្ខណៈសមស្របជាងគេ គឺប្រហែលជាសេចក្ដីសង្ខេបមួយ នៃរឿងរ៉ាវរបស់មនុស្សខ្លះក្នុងចំណោមមនុស្សជាច្រើន ដែលខ្ញុំបានលើកឡើងនៅក្នុងសៀវភៅនេះ ។

## ធនាគារិក ម៉ី កុម្ភត

កុម្ភត បានក្លាយទៅជាមនុស្សម្នាក់ក្នុងចំណោមប្រជាជនចំនួន ប្រាំរយពាន់នាក់ ដែលរត់ភៀសខ្លួនចេញពីប្រទេសរបស់គេ ហើយបែកខ្ញែកទៅរស់នៅប្រទេសផ្សេងៗពាសពេញពិភពលោក ។ នៅដំណាច់ឆ្នាំ១៩៨៥ ក្នុងចំនួនអ្នកភៀសខ្លួនទាំងអស់នេះ មានមនុស្សប្រហែល ពីររយពាន់នាក់ បានចេញទៅតាំងលំនៅនៅបរទេស ៈ មួយរយសាមសិបពាន់នាក់នៅអាមេរិកខាងជើង ចិតសិបពាន់នាក់នៅអឺរ៉ុប ។ ម្ភៃពាន់នាក់ទៀតរស់នៅតាមជំរំផ្សេងៗរបស់អង្គការសហប្រជាជាតិក្បែរព្រំដែនថៃ ។ ចំនួនប្រជាជនកម្ពុជាក្នុងបរិមាណខ្ពស់បំផុត -ពីររយសាមសិបប្រាំពាន់នាក់ បានរស់នៅតាមបណ្ដោយព្រំដែនថៃ-កម្ពុជា ដោយគ្មានការគាំពារពីអង្គការសហប្រជាជាតិឡើយ គ្មានទាំងលក្ខន្តិកៈជាជនភៀសខ្លួនថែមទៀត ហើយស្ថិតនៅប្រឡោះកណ្ដាលរវាងពួកអ្នកតស៊ូកម្ពុជា និងកងទ័ពរបស់ថៃ ។

កុម្ភត ជាមនុស្សមានភ័ព្វសំណាងម្នាក់ក្នុងចំណោមអ្នកទាំងនោះ ។ គាត់បានចាកចេញពីប្រទេសកម្ពុជាចំពេលដែលមានការចូលលុកលុយរបស់វៀតណាម ហើយបានឆ្លងកាត់ព្រំដែនថៃនៅខែឧសភា ឆ្នាំ១៩៧៩ បន្ទាប់ពីបានដើរឆ្លងកាត់ប្រទេសអស់រយៈពេលបួនខែ ។ គាត់និយាយថា ៈ «ការយល់ច្រឡំរបស់ខ្ញុំ គឺមកពីខ្ញុំជឿថា គេច្បាស់ជាទទួលរាក់ទាក់ខ្ញុំ ដោយរាក់ទាក់មិនខាន ។ ខ្ញុំគិតថា ពិភពលោកខាងក្រៅ នឹងបង្ហាញសមានចិត្តរបស់គេចំពោះយើង» ។

ដោយភ័ព្វល្អ ស្ថានទូតប្រទេសកាណាដា បានយល់ព្រមទទួលស្គាល់ខ្ញុំជាជនភៀសខ្លួនពេញច្បាប់ ហើយក៏មិនត្រូវគេរុញច្រានទៅព្រំដែនម្ដងទៀតដែរ ។ (នៅខែមិថុនា ឆ្នាំ១៩៧៩ កងទ័ពរបស់ថៃបានបង្ខិតបង្ខំប្រជាជនកម្ពុជា សែសិបពាន់នាក់ ឲ្យឆ្លងព្រំដែនទៅកាន់កន្លែងមួយដែលប្រកបដោយគ្រោះថ្នាក់យ៉ាងខ្លាំង ។ មនុស្សជាច្រើននាក់ត្រូវស្លាប់ ។ មិនយូរប៉ុន្មានក្រោយមក សហគមន៍អន្តរជាតិ បានបញ្ចុះបញ្ចូលឲ្យពួកថៃប្រកាន់នវិយាបថមនុស្សធម៌ជាមុនមួយ ចំពោះអ្នកភៀសខ្លួនកម្ពុជាទាំងអស់) ។

ដោយនៅរង់ចាំដើម្បីចាកចេញពីជំរំ កុម្ហួត បានស្នើបានសុំបម្រើការជាអ្នកបកប្រែភាសាឲ្យប្រជាជនកម្ពុជា ដែលស្នើសុំចូលទៅរស់នៅសហរដ្ឋអាមេរិក ។ នៅដំណាច់ឆ្នាំ១៩៧៦ គាត់បានចាកចេញដំណើរទៅកាន់ប្រទេសកាណាដា ដែលចាប់ពីពេលនោះមក គាត់បានចូលធ្វើការជាធនាគារិក មានឯកទេសខាងសេដ្ឋកិច្ចអន្តរជាតិ ។ គាត់បានជួយគ្រួសារខាងបងប្អូនជីដូនមួយរបស់គាត់ឲ្យបានទៅរស់នៅទីក្រុងឡូអង់ហ្សឺឡេស ដែរ ។ គាត់បានទទួលសញ្ជាតិជាកាណាដាបីឆ្នាំមកហើយ ។

## គូជីវិតស្នេហ៍ស្មោះស្ម័គ្រ បុប្ផាណា និង ដែត

គូរស្នេហាទាំងពីរ បានក្លាយទៅជានិមិត្តរូបនៃជនរងគ្រោះជាច្រើននៅក្នុងរបបខ្មែរក្រហម ។ មុនពេលដែល បុប្ផាណា ត្រូវបានសម្លាប់នៅមន្ទីរឃុំឃាំង ស-២១ នាងបានសរសេរជាសំបុត្រជាច្រើនទៅកាន់ប្តីសម្លាញ់របស់ខ្លួន (ដែត) ហើយនាងបានបន្តធ្វើយ៉ាងនេះរហូតដល់ទីបញ្ចប់ ពីព្រោះនាងចង់ឃើញការពិតនៃអ្វីដែលស និងអ្វីដែលខ្មៅ នៃរឿងរ៉ាវទាំងនេះ និងអំពីការបញ្ចប់រឿងនេះដោយរបៀបណា ។ សេចក្តីប្រាថ្នារបស់នាងត្រូវបានផ្តល់ឲ្យដោយលោក រិទ្ធី ប៉ាន់ ដែលជាជនភៀសខ្លួនខ្មែរម្នាក់រស់នៅស្រុកបារាំង ហើយដែលបានក្លាយទៅជាអ្នកថតខ្សែភាពយន្តល្បីល្បាញម្នាក់ ។ លោកបានយកសៀវភៅរបស់ខ្ញុំជាភាសាបារាំងធ្វើជាខ្សែភាពយន្តមួយ ដែលនិយាយអំពីរឿងរ៉ាវជីវិតរបស់ បុប្ផាណា ។ ខ្សែភាពយន្តល្បីល្បាញមួយចំនួនទៀតរបស់លោក រិទ្ធី ប៉ាន់ រួមមាន អ្នកស្រែ ដែលបានទទួលរង្វាន់ខ្សែភាពយន្តនៅទីក្រុងកាន ប្រទេសអ៊ីតាលី ។ លោក រិទ្ធី ប៉ាន់ បានទាក់ទងខ្ញុំ ហើយខ្ញុំបានផ្តល់សិទ្ធឲ្យលោកដោយទូលំទូលាយ ក្នុងការប្រើប្រាស់ឯកសារសៀវភៅរបស់ខ្ញុំ សម្រាប់ថតជាខ្សែភាពយន្តអំពីរឿងរ៉ាវជីវិតរបស់ បុប្ផាណា ។ ជាលទ្ធផល ខ្សែភាពយន្តមួយត្រូវបានផលិតឡើងជាភាសាខ្មែរជាលើកដំបូងទាក់ទងទៅនឹងអំពើប្រល័យពូជសាសន៍ ដែលមានឈ្មោះថា បុប្ផាណា ៖ សោកនាដកម្មកម្ពុជា ។ ខ្សែភាពយន្តនេះត្រូវបានបញ្ចាំងនៅមហោស្រពភាពយន្តទីក្រុង វ៉េនីស ហើយបានទទួលរង្វាន់ខ្ពស់បំផុត នៅឆ្នាំ ១៩៩៦ នៅឯមហោស្រពភាពយន្តអន្តរជាតិ ទីក្រុងម៉ាកស៊ី ។

## បញ្ញវន្ត ធ្រី ម៉េងហ៊ួត

ហ៊ួត ជាបញ្ញវន្តដែលទទួលការអប់រំនៅប្រទេសបារាំងបានត្រឡប់មកប្រទេសកម្ពុជាវិញ បន្ទាប់ពីជ័យជម្នះរបស់ខ្មែរក្រហម ។ គាត់ជាបញ្ញវន្តម្នាក់ក្នុងចំណោមបញ្ញវន្តជាច្រើនដែលបានចាកចេញពីប្រទេស បន្ទាប់ពីមានការលុកលុយរបស់បរទេស ។ ដូចកុម្ហួតដែរ គាត់បានតាំងចិត្តជួយពួកអ្នកភៀសខ្លួនដទៃទៀត ហើយបាន

ក្លាយទៅជាប្រធានដំរំក្រៅផ្លូវការ និងជាអ្នកបកប្រែភាសា ។ ប្រទេសបារាំងជាអ្នកផ្តល់សិទ្ធិជ្រកកោនដល់រូបគាត់ ។

នៅទីក្រុងប៉ារីស គាត់បានរៀបអាពាហ៍ពិពាហ៍ជាមួយស្ត្រីម្នាក់ ហើយរកបានការងារមួយខាងផ្នែកគីមី ។ ប៉ុន្តែក្នុងសៀវភៅមួយដែលបោះពុម្ពផ្សាយនៅប្រទេសបារាំងដោយជនរួមជាតិម្នាក់ ហ៊ួត ត្រូវបានរៀបរាប់ទាំងខុសថា គាត់ជាសមាជិកម្នាក់របស់បក្សកុម្មុយនិស្តកម្ពុជាដែលធ្លាប់បោះបង់បញ្ជាវន្តដទៃៗទៀត ។

ខាងលើនេះប្រហែលជាមូលហេតុមួយក្នុងចំណោមមូលហេតុជាច្រើន ដែលគាត់ត្រូវបានគេលួចធ្វើឃាដ ។ នៅខែមីនា ឆ្នាំ១៩៨៥ ហ៊ួត ប្រពន្ធគាត់និងស្វាមីភរិយាមួយគូទៀត ត្រូវគេសម្លាប់នៅក្នុងល្វែងបន្ទប់នៃអគារស្នាក់នៅរបស់គាត់នៅទីក្រុងប៉ារីស ។ នៅលើទ្វារបន្ទប់ គេបានសរសេរអក្សរក្រវេមក្រវាមថា ៈ "ពួកអ្នកនៅរស់ពីអំពើប្រល័យពូជសាសន៍របស់កម្ពុជា!" ។ តាមការសន្និដ្ឋានថា ហ៊ួត ជាជនជាតិខ្មែរដំបូងគេដែលត្រូវធ្វើឃាត ដើម្បីធ្វើទោសប្រដៅចំពោះបទឧក្រិដ្ឋផ្សេងៗខ្មែរក្រហម ។

## ពួកមនុស្សដែលត្រូវចោទប្រកាន់ពីបទមនុស្សឃាតដោយចេតនាលើរូបលោក ខាដវ៉ែល

យ៉ាងហោចណាស់មនុស្សពីរនាក់ បានឆ្លើយសារភាពក្រោមការធ្វើទារុណកម្មនៅមន្ទីរឃុំឃាំងទួលស្លែងថា ពួកគេបានចូលរួមក្នុងការរួមគំនិតក្បត់មួយ ដើម្បីសម្លាប់ភ្ញៀវម្នាក់ក្នុងចំណោមភ្ញៀវបរទេសបីនាក់ ។ មនុស្សទាំងពីរនាក់ នោះមានឈ្មោះ ឆន និងពឿន ពួកគេបានប្រកាសក្នុងចម្លើយសារភាពរបស់ខ្លួនថា ការរួមគំនិតក្បត់នេះមានគោលដៅបន្ទុចកិត្យានុភាពរបស់បក្ស ដែលត្រូវដឹកនាំជាសម្ងាត់ដោយ សុន សេន រដ្ឋមន្ត្រីការពារប្រទេសរបស់កម្ពុជាប្រជាធិបតេយ្យ ។

ចម្លើយសារភាពរបស់ ឆន ខ្វីជាងគេទាំងអស់ យ៉ាងហោច បំណែកដែលខ្ញុំបានទទួល ដែលបកប្រែដោយស្តេហ្វេន ហេដ័រ ។ ឆន និយាយថា ក្រុមឃុបឃិតរបស់គាត់ បានសម្រេចសម្លាប់ភ្ញៀវជនជាតិអង់គ្លេស ដើម្បី "បំផ្លាញ"នយោបាយរបស់បក្ស និង "រាំងរាបក្សមិនឲ្យមានមិត្តភក្តិច្រើនក្នុងពិភពលោក" ។ ខាដវែល អ្នកជាតិនិយមជាតិអេកូស ដែលគេកំណត់ទុកជាមុនក្រោមពាក្យថា "ភ្ញៀវជាតិអង់គ្លេស" នៅក្នុងឯកសារនោះ ត្រូវបានជ្រើសរើសជាមុខសញ្ញាដែលគេត្រូវសម្លាប់ ពីព្រោះគាត់ជាមិត្តម្នាក់របស់របបនេះ ដែលផ្សេងគ្នាពីភ្ញៀវជាតិអាមេរិក ។ មរណភាពរបស់គាត់នឹងបង្ហាញឲ្យឃើញថា បដិវត្តន៍គ្មានសមត្ថភាពយាមការពារបណ្តាមិត្តភក្តិរបស់ខ្លួន ដែលជំរុញឲ្យមានការច្របូកច្របល់ថែមទៀតឡើយ ។ ជនជាតិអាមេរិកាំងទាំងពីរត្រូវគេទុកឲ្យនៅរស់ជីវិតដើម្បីអាចពន្យល់ពីឃាតកម្មនេះ ។

គេបានធ្វើឲ្យ ឆន និងពឿន សារភាពដូចគ្នាថា អ្នកបម្រើក្នុងផ្ទះ ឆ្មាំការពារ អ្នកបើកឡាន ជាច្រើននាក់ ក៏

សមគំនិតក្នុងរឿងនេះដែរ ។ អ្នកទាំងពីរបានប្រកាសថា អ្នកសម្លាប់មានឈ្មោះថា វ៉ុធ ហើយអ្នករួមគំនិតទាំងអស់បានសម្រេចចិត្តប្រហារជីវិត វ៉ុធ ទៀត ក្រោយពីវាបានសម្លាប់ ខាដវែល រួច ។

ពឿន ក៏ត្រូវបង្ខិតបង្ខំឲ្យឆ្លើយសារភាពថា គាត់ជាសមាសភាពម្នាក់ក្នុងការរួមគំនិតក្បត់មួយ ដែលដឹកនាំដោយ វ៉ន វ៉េត ដែលត្រូវបានកម្ទេចនៅមន្ទីរឃុំឃាំងទួលស្លែងរួចមកហើយ មុនការទៅដល់ក្រុងភ្នំពេញរបស់ពួកយើង ។ ពឿន គោងតែប្រកាសថា វ៉ន វ៉េត ធ្លាប់មានសមានចិត្តចំពោះប្រទេសវៀតណាម ហើយថាគាត់បានប៉ុនប៉ងសម្លាប់ ប៉ុល ពត នៅឆ្នាំ១៩៧៧ ។

ពឿន និង ឆន បាន«ឆ្លើយសារភាព»ទាំងពីរនាក់ថា ការធ្វើឃាតភ្ញៀវបរទេស ត្រូវបានរៀបចំឡើងដោយសមមិត្ត កន ដែលជាប្រធានខាងពិធីការរបស់កម្ពុជាប្រជាធិបតេយ្យ ។ កន គឺជាអ្នកដែលទៅទទួលពួកយើងនៅអាកាសយានដ្ឋាន និងបានជូនតាមដំណើរយើងជាច្រើនលើក ។

ប៉ុន្តែ ពឿន បានថ្លែងឲ្យដឹងថា អត្តសញ្ញាណរបស់ភ្ញៀវដែលត្រូវសម្លាប់ មិនសូវជាមានភាពសំខាន់ប៉ុន្មានទេ ។ ចម្លើយសារភាពរបស់អ្នកទាំងពីរ មានចុះកាលបរិច្ឆេទថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៩ ។ មនុស្សមួយចំនួនដែល ឆន និងពឿន រៀបរាប់បញ្ចូលក្នុង«ចម្លើយសារភាព»របស់ពួកគេស្ថិតនៅក្បែរៗ ប៉ុល ពត ជានិច្ច ក្រោយពីមានការចូលលុកលុយរបស់វៀតណាម ហើយបានបន្តប្រយុទ្ធតស៊ូក្រោមបទបញ្ជាផ្សេងៗរបស់ ប៉ុល ពត ដដែល ។ សុន សេន នៅតែជាមេដឹកនាំកងទ័ពដ៏សំខាន់ម្នាក់ កន នៅតែទទួលខុសត្រូវខាងពិធីការដូចកាលពីមុន ហើយមេបញ្ជាការ ពីន ដែលយើងធ្លាប់បានជួបនៅសមរភូមិភាគខាងកើត ហើយដែលមានជាប់ឈ្មោះក្នុងចម្លើយសារភាពរបស់អ្នកទាំងពីរនាក់នេះដែរនោះ បានស្ថិតនៅជាមួយ ប៉ុល ពត ដដែល ។

បើសិនជាចម្លើយសារភាពទាំងនេះ ត្រូវគេប្រឌិតឡើងដើម្បីបង្កឲ្យមានការរលំដួលរបស់ សុន សេន មែននោះ គឺជារឿងយ៉ាងឥតប្រយោជន៍ស្មោះ ។ ប្រហែល ប៉ុល ពត បដិសេធ មិនជឿ«ភ័ស្តុតាង»ផ្សេងៗ ដែល ឌុច ផ្តល់មកឲ្យទេ ពីព្រោះផែនការយោធារបស់ សុន សេន បានបញ្ចៀសមិនឲ្យមេផ្តាច់ការ និងបនរបស់គាត់ត្រូវចាប់ជាឈ្លើយសឹកដោយកងទ័ពវៀតណាម ដែលកំពុងសម្រុកចូលទប់មិនឈ្នះមកក្នុងប្រទេសកម្ពុជាឡើយ ។

## ស៊ីស្វផា និងគ្រួសារម៉ែ

ស៊ីសូផា ស្រីជំនួយព្យាបាលជំងឺ បានរកឃើញប្អូនស្រីពីរនាក់ និងប្អូនប្រុសម្នាក់ ដែលរួចផុតពីសេចក្តីស្លាប់ឡើងវិញ ។ ពួកគេបានភៀសខ្លួនទៅប្រទេសថៃ ហើយនៅខែឧសភា ឆ្នាំ១៩៨០ អ្នកទាំងនេះបានធ្វើការទាក់ទងជាមួយខ្ញុំ (អ្នកនិពន្ធ) តាមរយៈអ្នកកវីនិពន្ធម្នាក់ ឈ្មោះ ហេរ្យម ហ៊ុងតុន ជាមិត្តម្នាក់ ដែលបាន«ផ្តល់ពត៌មាន»យ៉ាងពេញលេញស្តីពីសង្គ្រាមនៅកម្ពុជាដូចជារូបខ្ញុំដែរ ។ សូម៉េត ប្អូនប្រុសរបស់នាង បានធ្វើការជាអ្នកបកប្រែ

ភាសាសម្រាប់កាសែតវ៉ាស៊ីនតោនប៉ុស្ដិ៍ ក្នុងរយៈពេលសង្គ្រាម ។ ប្រធានផ្នែកនយោបាយបរទេសរបស់កាសែត បានបញ្ជូនទូរលេខមួយច្បាប់ទៅឲ្យអាជ្ញាធរមានសមត្ថកិច្ចនានា ដើម្បីសុំអនុញ្ញាតឲ្យគ្រួសារម៉ៃ បានចេញទៅរស់នៅសហរដ្ឋអាមេរិក ។ នៅទីក្រុងវ៉ាស៊ីនតោន គ្រួសារខ្ញុំជាអ្នកធានាខុសត្រូវចំពោះបងប្អូនម៉ៃទាំងនេះ ។

បុប្ផា ប្អូនស្រីម្នាក់ក្នុងចំណោមប្អូនស្រីទាំងពីរ បានរៀបការជាមួយ រាម ថាញ់ ហើយនាងប្រសូត្របានកូនស្រីម្នាក់នៅទីក្រុងវ៉ាស៊ីនតោន ដែលនាងបានដាក់ឈ្មោះថា ថាវី ។ ឃុន បងប្អូនរបស់ ថាញ់ បានរួមដំណើរមកអាមេរិកជាមួយពួកនេះដែរ ហើយពីថ្ងៃនេះទៅ សមាជិកគ្រួសារនេះមានមនុស្សពេញវ័យប្រាំនាក់ ជីទួតម្នាក់ និងទារកម្នាក់ ។

សូម៉ែត ធ្វើការនៅកាសែតវ៉ាស៊ីនតោនប៉ុស្ដិ៍ ក្នុងបណ្ដាឆ្នាំដំបូងៗដែលពួកគេរស់នៅសហរដ្ឋអាមេរិកបន្ទាប់មក គាត់បានតាំងលំនៅនៅប្រទេសអង់គ្លេសវិញ ដោយគាត់ទៅរស់នៅជាមួយ ហុងតុន ហើយបានសរសេរ“ការចងចាំរបស់គាត់” នៅទីនោះ ។

សមាជិកដទៃទៀតនៃគ្រួសារនេះស្ថិតនៅសហរដ្ឋអាមេរិក ។ ដោយធ្វើការជាច្រើនម៉ោង ដោយសន្សំប្រាក់កាសលើការជួលលំនៅដ្ឋាន ដោយរស់នៅក្នុងបន្ទប់តូចមួយទាំងអស់គ្នា ពួកគេបានធ្វើឲ្យសម្រេចនូវបំណងខ្ជាប់ខ្ជួនមួយក្នុងចំណោមបំណងខ្ជាប់ខ្ជួនទាំងឡាយដែលមានតាំងពីយូរមកហើយ ។ ឆ្នាំមុន ពួកគេបានទិញផ្ទះថ្មដ៏ធំល្វឹងល្វើយមួយខ្នងនៅជាយក្រុងវ៉ាស៊ីនតោន ដែលមានប្រាំបន្ទប់ និងសួនច្បារធំមួយ ដែលពួកគេប្រែឲ្យទៅជាសួនដាំបន្លែ និងផ្កាផ្សេងៗទៅវិញ ។ ព្រះសង្ឃពុទ្ធសាសនា ជាច្រើនអង្គតែងនិមន្តមកបិណ្ឌបាត្រដល់គេហដ្ឋានរបស់ពួកគេ ។ ក្នុងចន្លោះពេលនោះ ស៊ីសូផា បានរៀបការជាមួយអ្នកភៀសខ្លួនម្នាក់ទៀតពីសង្គ្រាមមួយផ្សេងទៀតដែរ ឈ្មោះ ហ្វ្រង់ស៊ីស្កូ ឆាវេ ដែលមកពីប្រទេសសាលវ៉ាឌ័រ ។ ពីរខែបន្ទាប់ពីការមករស់នៅក្នុងគេហដ្ឋានថ្មី ស៊ីសូផា បង្កើតបានកូនប្រុសម្នាក់ដែលនាងដាក់បកតិនាមថា សុត្រា មានន័យថា គតិបណ្ឌិត ។

## អ្នកការទូត ក្លូត ម៉ាទីន និង អ៊ីហ្គ័រ រ៉ូហ្គាឆូវ

ម៉ាទីន និង រ៉ូហ្គាឆូវ បន្តការងារកិច្ចការបរទេសរបស់ខ្លួន ។ ម៉ាទីន គឺជាឯកអគ្គរដ្ឋទូតបារាំងប្រចាំនៅប្រទេសចិនរហូតដល់ទីបញ្ចប់នៃបេសកម្មសន្តិភាពអង្គការសហប្រជាជាតិ និងការបោះឆ្នោតនៅកម្ពុជា ។ រ៉ូហ្គាឆូវក្រោយមក បានបំពេញការងារបរទេសនៅទីក្រុងប៉េកាំង ជាមួយ ម៉ាទីន ដែរ ក្នុងឋានៈជាឯកអគ្គរដ្ឋទូតរ៉ូស៊ី ប្រចាំនៅប្រទេសចិន ក្រោយពេលការបែកបាក់នៃសហភាពសូវៀត ។ ម៉ាទីន បានត្រឡប់មកទីក្រុងបារីសវិញ ដែលបច្ចុប្បន្ននេះ គាត់គឺជាមន្ត្រីជាន់ខ្ពស់លំដាប់ទី៣ នៅឯក្រសួងការបរទេសបារាំង ដែលមានការទទួលខុសត្រូវពិសេសចំពោះកិច្ចការអ៊ឺរ៉ុប នឹងគោលនយោបាយសេដ្ឋកិច្ច ។ រ៉ូហ្គាឆូវ នៅប្រទេសចិននៅឡើយ សព្វថ្ងៃនេះ ។

# កំណត់ចំណាំខ្លីៗ

## ជំពូកទី១

[១] សេចក្តីដកស្រង់ពី *"In a Notebook", in The Memory of War: Poems 1968-1982 (Edimbourg, Salamander Press, 1982)* ។

[២] ការសម្ភាសន៍ដែលធ្វើឡើងដោយអ្នកនិពន្ធ ។

[៣] សង្គ្រាមលើកទីមួយបានប្រព្រឹត្តទៅពីឆ្នាំ១៩៤៦ ដល់ឆ្នាំ១៩៥៤ រវាងវៀតមិញ និងពួកបារាំងដែលល្បងដណ្តើមការត្រួតត្រាលើបណ្តាអាណានិគមរបស់ពួកគេនៅឥណ្ឌូចិនឡើងវិញ បន្ទាប់ពីសង្គ្រាមលោកលើកទីពីរ ។

[៤] គេប្រហែលជាមិនដឹងពីចំនួនអ្នករងគ្រោះ ដែលចូលរួមធ្វើបដិវត្តន៍នៅកម្ពុជា ដោយការសម្លាប់, ជំងឺ, ការបរិភោគអាហារមិនគ្រប់គ្រាន់ ពិតប្រាកដសោះឡើយ ។ សាស្ត្រាចារ្យសាកលវិទ្យាល័យ លោក *Stephen Heder* និងលោក *Ben Kiernan* បានអះអាងថា មានចំនួនមួយលាននាក់ ។ លោក *David Hawk* អ្នកទទួលខុសត្រូវលើការអង្កេតមួយស្តីពីអំពើសាហាវយង់ឃ្នងរបស់បដិវត្តន៍កម្ពុជា បានវាយតម្លៃថា ចំនួនពីរលាននាក់ គឺកៀកបំផុតនឹង ចំនួនពិតប្រាកដ ហើយគឺគាត់នេះឯងដែលខ្ញុំធ្លាប់ស្តីបន្ទោស ហើយវាពុំមានការស្រុះស្រួលគ្នាស្តីពីចំនួនប្រជាពលរដ្ឋនៅឆ្នាំ១៩៧៥ ដែលមានពីប្រាំមួយលានទៅជាងប្រាំពីរលាននាក់ក៏ទេដែរ ។

[៥] ប្រវត្តិរបស់ធនាគារិក គឺសំអាងលើការទាក់ទងគ្នា ដែលអ្នកនិពន្ធបានសម្ភាសន៍ជាមួយគាត់នៅក្នុងអំឡុងពេលសង្គ្រាម និងការសម្ភាសន៍នៅពេលក្រោយៗមកទៀត ដែលធ្វើឡើងដោយអ្នកនិពន្ធនៅឆ្នាំ១៩៨២ និងនៅឆ្នាំ១៩៨៣ ។

[៦] ធនាគារអន្តរជាតិដើម្បីការស្តាបនាឡើងវិញ និងការអភិវឌ្ឍន៍ *(BIRD)* និងសមាគមអន្តរជាតិដើម្បីការអភិវឌ្ឍន៍, របាយការណ៍របស់គណៈបេសកកម្មសេដ្ឋកិច្ចនៅប្រទេសកម្ពុជា, ឆ្នាំ១៩៦៩, ឯកសារសម្ងាត់មានបីក្បាល, ថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៧០, ទំព័រ៤៥ ។

[៧] *Ibid.,* ទំព័រ៤៥-៤៦ ។

[៨] លោក ស៊ែក ស៊្បុង, "ទស្សនៈរបស់កម្ពុជាអំពីបដិវត្តន៍" *, in Revolution and Its Aftermath in Kampuche:a Eight Essays,* ក្រោមការចាត់ចែងដឹកនាំរបស់លោក ដេវីដ ឆេនល័រ និងលោក បេន ឃៀនិន *(New Haven, Yale University Southeast Asia Studies, 1983)* ។

[៩] របាយការណ៍របស់គណៈបេសកកម្មសេដ្ឋកិច្ច, *op. cit.,* ទំព័រ៤៦-៤៧ ។

[១០] សូមអាន *Cambodi:a The Search for Security,* របស់លោក *Michael Leifer (New York, Praeger, 1968)* សម្រាប់ការវិភាគពេញលេញមួយ ។

[១១] សម្តេច ព្រះនរោត្តម សីហនុ ដែលទាញហេតុសំអាងក្នុងសារទូរលេខរបស់ស្ថានទូតសហរដ្ឋអាមេរិកនៅក្រុង

ភ្នំពេញ បញ្ជូនទៅឲ្យក្រសួងការបរទេសអាមេរិកាំង, ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៦៣ ។ រកឃើញជាថ្មីដោយសារច្បាប់ស្តីពីសេរីភាពសារពត៌មាន ។

១២ ការពិពណ៌នា ផ្អែលើការយកពត៌មានដែលធ្វើឡើងដោយអ្នកនិពន្ធនៅជំនាន់នោះ ។

១៣ តាមរបាយការណ៍សម្ងាត់មួយរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ, ការវិវត្តន៍ផ្នែកសេដ្ឋកិច្ចថ្មីៗរបស់សាធារណរដ្ឋខ្មែរ, ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៧៤ ។

១៤ លោក ហ្វ្រង់ស័រ ប៉ុងស្វូ, "កម្ពុជាឆ្នាំសូន្យ" (*Paris, Julliard,* ឆ្នាំ១៩៧៧) ។

## ជំពូកទី២

១ ទស្សនាវដ្តី "ទង់បដិវត្តន៍" លេខ៨ ខែសីហា ឆ្នាំ១៩៧៥ ។ ការពោលសរសើរអំពីគុណសម្បត្តិកង់ទ័ពទាំងអស់ដែលមានតទៅទៀតនៃសុន្ទរកថា គឺចេញពីប្រភពតែមួយ ។

២ ផ្នែកស្តីពីប្រវត្តិសាស្ត្របុរាណនេះ គឺសំអាងជាសំខាន់លើសៀវភៅផ្សេងៗដូចតទៅ ៖

- "បណ្តាប្រជាជននៅឧបទ្វីបឥណ្ឌូចិន" របស់លោក ហ្សក សឺដេស, *Paris, Dunod, 1962* ។
- "បណ្តារដ្ឋដែលនិយមសាសនាហិណ្ឌូ (ព្រហ្មញ្ញសាសនា) នៅឥណ្ឌូចិន និងឥណ្ឌូនេស៊ី", *Paris, De Boccard, 1964* ។
- អង្គរ : *An Introduction, Hong Kong, Oxford University Press, 1963* ។

  "អង្គរ, មនុស្ស និងថ្ម" របស់លោក ប៊ែណារដ៍-ហ្វីលីព គ្រូសលីយេ, *Paris, B. Arthaut, 1965* ។

  *"A History of South-East"* របស់លោក *D.G.E. Hall, New York, Sain Martin's Press, 1980* ។

៣ ហ្សក សឺដេស

៤ *Georges Coedès, Angkor: An Introduction (Hong Kong, Oxford University Press, 1963),* ទំព័រ៨៥ ។

៥ *Ibid.*

៦ រ៉េស៊ីដង់ ជាន់ខ្ពស់នៅ *Champeaux* ក្នុងរបាយការណ៍ទីពីរប្រចាំត្រីមាសរបស់គាត់នៅឆ្នាំ១៨៨៨ នៅភ្នំពេញ ដែលស្រង់មកនិយាយជាសំអាងដោយលោក *Milton Edgeworth Osborne, Rule and Response: Interaction in Cambodia and Cochinchina (1859-1905)* (និក្ខេបបទថ្នាក់បណ្ឌិត, *Cornell University, Ithaca, N.Y., 1968*) ទំព័រ៣៥៨ ។

៧ *Ibid.,* ទំព័រ៣៦៣ ដែលដកស្រង់តាមលោក *E. Aymonier* ជាអតីតអ្នកតំណាងប្រទេសបារាំងនៅក្រុងភ្នំពេញ ។

៨ ប្រវត្តិរបស់នាង ស៊ុយហ្សាន កាប៊ុឡេស គឺដកស្រង់ពី *French Indochina* របស់អ្នកនិពន្ធ *Virginia Thompsom (New York, Octagon Books, 1968,* សៀវភៅបោះពុម្ពតាមច្បាប់ដើម, ១៩៣៧) និងការសន្ទនាមួយរបស់អ្នកនិពន្ធ ជាមួយលោក ប៊ែណារដ៍ ហ្វីលីព គ្រូសលីយេ ។

៩ *Virginia Thompson, op. cit.,* ទំព័រ៣៥៨ ។

[១០] លោក *V.M. Reddi, A History of the Cambodian Independance Movement 1863-1935 (Tirupati, Inde, Sri Venkateswara University Press, 1970)* ទំព័រ៣៣ ។

[១១] ប្រវត្តិរបស់ សឺងង៉ុកថាញ់ និងការធ្វើបាតុកម្មនៅក្រុងភ្នំពេញ គឺពឹងផ្អែកជាសំអាងលើសៀវភៅរបស់លោក *V.M. Reddy* និង *V. Thompson* ព្រមទាំងនិក្ខេបបទថ្នាក់បណ្ឌិតរបស់លោក បេនឃៀរនិន ក្រោមចំណងជើងថា "តើ ប៉ុល ពត ចូលកាន់អំណាចបែបណា? : ប្រវត្តិនៃលទ្ធិកុម្មុយនិស្តនៅកម្ពុជា, ១៩៣០-១៩៧៥ *(Monash University, Victoria, Australia, 1983)* ។

[១២] *V.M. Reddi, op. cit.,* ទំព័រ៨៤ ។

[១៣] និក្ខេបបទរបស់ បេន ឃៀរនិន, *op. cit.,* ទំព័រ៦០ ។

[១៤] *V.M. Reddi, op. cit.,* ទំព័រ៨៥ ។

[១៥] *V.M. Reddi, op. cit.,* ទំព័រ១០០ ។

[១៦] "បទសម្ភាសន៍របស់សមមិត្ត ប៉ុល ពត... ចំពោះគណៈប្រតិភូអ្នកសារពត៌មាន យូហ្គោស្លាវី", ក្រុងភ្នំពេញ, ខែមីនា ឆ្នាំ១៩៧៨ ។ ជីវប្រវត្តរបស់យុវជន សាឡុត ស គឺសំអាងលើការធ្វើសម្ភាសន៍នេះ, លើសៀវភៅ សិក្ខាគារិក ជំនាន់អាណានិគមបារាំង និងការធ្វើសម្ភាសន៍ ឡុត សួង ជាប្អូនប្រុសរបស់ ស ដោយលោក ស្ទេហ្វេន ហេដ័រ ។

[១៧] *V.M. Reddi, op. cit.,* ទំព័រ១២៥ ។

[១៨] ការធ្វើសម្ភាសន៍ អៀង ធីរិទ្ធ ជាប្រពន្ធរបស់ សារី ដោយអ្នកនិពន្ធ ។

[១៩] និក្ខេបបទរបស់លោក *Milton Osborne, op. cit.* ។

[២០] សៀវភៅ "អនុស្សាវរីយ៍ផ្អែមល្ហែម និងជូរចត់" របស់សម្តេច ព្រះនរោត្តម សីហនុ *(Paris, Hachette, 1981)* ។ ប្រវត្តិរបស់គ្រួសារ ជួន គឺត្រូវបានបំពេញបន្ថែមដោយការធ្វើសម្ភាសន៍ មិត្តរួមវិទ្យាល័យម្នាក់ឈ្មោះ គិរីទិត និងការធ្វើសម្ភាសន៍ ជួន ម៉ុម និង ជួន ប្រសិទ្ធ ដោយអ្នកនិពន្ធ ។

[២១] ការវិភាគអំពីនយោបាយរបស់បារាំងនៅសម័យនោះ គឺសំអាងលើសៀវភៅផ្សេងៗដូចតទៅ :

- *"Communism and the French Intellectuals"* របស់លោក *David Caute, New York, Macmillan, 1964* ។
- *"Les communistes français dans leur premier demi-siècle (1920-1970),* របស់លោក *Annie Kriegel, Paris, Le seuil, nouvelle édition 1985* ។
- សមាជនៅទីក្រុងទួរស៍ *(Tours),* ការចាប់កំណើតរបស់បក្សកុម្មុយនិស្តបារាំង, *Paris, R. Julliard, 1964* ។
- *"French Communism 1920-1972"* របស់អ្នកនិពន្ធ *Ronald Tiersky, New York, Colombia University Press, 1974* ។

[២២] សម្ភាសន៍ដែលសម្រេចធ្វើឡើងដោយអ្នកនិពន្ធ ។

២៣ ប្រវត្តិនៃការរស់នៅរបស់ សារី និង ធីរិទ្ធ នៅទីក្រុងប៉ារីស គឺសំអាងលើការធ្វើសម្ភាសន៍មួយជាមួយ ធីរិទ្ធ ដោយអ្នកនិពន្ធផ្ទាល់ ។

២៤ សៀវភៅ *Communism and the Frends Intellectuals* របស់អ្នកនិពន្ធ *David Caute, (New York, Macmillan, 1964)*, ទំព័រ១៧៩ ។

២៥ *Ibid.*, ទំព័រ១៩៥ ។

២៦ សៀវភៅមានចំណងជើងថា "ខ្មែរក្រហម!" របស់លោក ស៊ែកស្ប៉ុង និង បេនឃៀនិន *(Paris, J.E. Hallier-Albin Michel, 1981)*, ទំព័រ៣៥៧-៣៦១ ។

## ជំពូកទី៣

១ *Im et Sivone Prom, Khmer Folk Tales* (អត្ថបទវាយអង្គុលីលេខ, ១៩៧៦) ។

២ សៀវភៅ"បណ្ដារដ្ឋដែលនិយមសាសនាហិណ្ឌូនៅឥណ្ឌូចិន និងឥណ្ឌូនេស៊ី" របស់លោក ហ្សក់ សឺដេស, *Paris, De Boccard, 1964* ។

៣ *Ibid.*

៤ សៀវភៅ *The Great Chinese Travelers: An Anthology* របស់លោក *Jeannette Mirsky, (New York, Pantheon, 1964)*, ទំព័រ២១៨-២១៩ ។

៥ និក្ខេបបទរបស់លោក បេនឃៀនិន "តើ ប៉ុល ពត ចូលកាន់អំណាចបែបណា?៖ ប្រវត្តិនៃលទ្ធិកុម្មុយនិស្ត នៅកម្ពុជា ១៩៣០-១៩៧៣, *(Monash University, Victoria, Australie, 1983)* ។

៦ "ចលនាតស៊ូប្រដាប់អាវុធខ្មែរ", សៀវភៅស្ដើងរបស់គណៈកម្មាធិការសន្តិភាពខ្មែរ, ខែតុលា ឆ្នាំ១៩៥២ ។

៧ និក្ខេបបទរបស់លោក បេន ឃៀនិន, *opt. cit.* ។

៨ *Ibid.*

៩ ឯកសារស៊ើបអង្កេតបានពីសត្រូវ "ការណែនាំស្ដីពីលក្ខខណ្ឌនៃការចូលជាសមាជិកបក្សរបស់ជនជាតិចិន", ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៥២ ។ ទូរលេខជាផ្លូវការរបស់អាមេរិកាំងលេខ ៧៤៩ ដែលគេអាចរកពត៌មាននៅ *Wasson-Echols Collection, Cornell University* ។

១០ ការសម្ភាសន៍ដែលធ្វើឡើងដោយលោក ស្ទេហ្វេន ហេដ័រ ។

១១ ការសម្ភាសន៍ដែលធ្វើឡើងដោយអ្នកនិពន្ធ ។

១២ និក្ខេបបទរបស់លោក បេន ឃៀនិន, *opt. cit.* ។

១៣ សេចក្ដីថ្លែងសារភាពរបស់ វ៉ន វ៉េត ដែលលើកមកនិយាយជាសំអាងក្នុងនិក្ខេបបទរបស់លោក បេន ឃៀនិន, *op. cit.* ។

១៤ ប្រវត្តិរបស់ អៀង លីម និងការរៀបរាប់ពីរឿងរ៉ាវទាំងអស់របស់គាត់ គឺស្រង់ចេញពី«ការសន្ទនាជាមួយ អៀង លីម ជាខ្មែរក្រហមចុះចូល» , ទូរលេខនៃស្ថានទូតអាមេរិកាំងនៅក្រុងភ្នំពេញបញ្ជូនទៅឲ្យក្រសួងការបរទេសនៅក្រុងវ៉ាស៊ីនតោន, ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៧១ ។

១៥ និក្ខេបបទរបស់លោក បេន យៀនិន, *opt. cit.* ។

១៦ សេចក្តីសង្ខេបនៃប្រវត្តិសាស្ត្របក្សដែលមានឲ្យយោបល់ពីលើ ជាឯកសារដែលរឹបអូសបានពីផ្នែកទទួលបន្ទុកនយោបាយកងទ័ពរបស់ភូមិភាគបូព៌ា ។

១៧ ទូរលេខនៃស្ថានទូតអាមេរិកាំងនៅក្រុងភ្នំពេញផ្ញើជូនក្រសួងការបរទេស, ថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៥៥ ។

១៨ ចំនួនដែលដកស្រង់ពីឯកសារប្រវត្តិសាស្ត្របក្ស ។

១៩ ឯកសារដែលបញ្ជូនដោយស្ថានទូតអាមេរិកាំងនៅក្រុងភ្នំពេញ ទៅក្រសួងការបរទេស នៅថ្ងៃទី៨ ខែតុលា ឆ្នាំ១៩៥៦ ។

២០ *Ibid.*

២១ ឯកសារដែលបញ្ជូនដោយស្ថានទូតអាមេរិកាំងនៅក្រុងភ្នំពេញ ទៅក្រសួងការបរទេសនៅឆ្នាំ១៩៥៧ ។

២២ ពីស្ថានទូតអាមេរិកាំងនៅក្រុងភ្នំពេញទៅក្រសួងការបរទេស, ថ្ងៃទី៩ ខែមិថុនា ឆ្នាំ១៩៥៦ ។

២៣ *Ibid.*

២៤ ឯកសារដែលបញ្ជូនដោយស្ថានទូតអាមេរិកាំងនៅក្រុងភ្នំពេញទៅឲ្យក្រសួងការបរទេស, ថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៦៩ ។

២៥ *Laura Summers,* ការនាំឲ្យស្គាល់ ខៀវ សំផន ។

២៦ *Ibid.*

២៧ *Ibid.*

២៨ កន្លែងអត្ថបទម្ដុំនេះ និងការពោលសរសើរ សំអាងទៅលើការសម្ភាសន៍មួយដែលធ្វើឡើងដោយអ្នកនិពន្ធ ។

២៩ ប្រវត្តិសាស្ត្របក្សពលករវៀតណាម, ១៩៣០-១៩៧៥ (ហាណូយ, សៀវភៅដែលបោះពុម្ពផ្សាយជាភាសាបរទេស, ១៩៧៧), ទំព័រ១០៥ ។

៣០ ប្រវត្តិរបស់ ប៉ូផាត ពឹងផ្អែកជាសំអាងលើឯកសារផ្សេងៗនៅសារមន្ទីរទួលស្លែង ។ គេនឹងរកឃើញសេចក្តីរៀបរាប់ពិស្តារមួយនូវឯកសារ និងសេចក្តីពន្យល់ផ្សេងៗស្តីពីមណ្ឌលឃុំឃាំងអ្នកទោស ក្នុងកំណត់ហេតុពិសេស អំពីឯកសារទាំងឡាយនៅសារមន្ទីរទួលស្លែង ដែលមានបន្តពីសេចក្តីកត់ហេតុទាំងនេះ ។

៣១ ការវាយតម្លៃដែលស្រង់ចេញពីការធ្វើជំរឿនឆ្នាំ១៩៦២ ។

៣២ ការពិពណ៌នាអំពីមហាសន្និបាត និងការលើករៀបរាប់ពីឯកសារបង្កើតបក្សត្រូវបានដកស្រង់ពីសុន្ទរកថា

របស់ ប៉ុល ពត : “មហាជោគជ័យរបស់បដិវត្តន៍...”, ខែកញ្ញា ឆ្នាំ១៩៧៧ ។

៣៣ *Stephen Hedter, The Historial Basis of the Kampuchea-Vietnam Conflict: The Development of the Kampuchea Communist Movement and Its Relations with Vietnamese Communism, 1930-1970* (អត្ថបទវាយអង្គលីលេខ, *Cornell University, 1978*¦ ។

៣៤ អ្វីៗដែលមានបន្តពីប្រវត្តិរបស់ ប៊ូផាត គឺសំអាងលើចម្លើយសារភាពរបស់គាត់ ។

៣៥ ឯកសារដែលបញ្ជូនដោយស្ថានទូតអាមេរិកាំងទៅក្រសួងការបរទេស, ថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៦៣ ។

៣៦ ប្រវត្តិសាស្ត្របក្ស ។

៣៧ ប្រវត្តិនៃការបះបោរតាមអត្ថបទរបស់លោក បេនឃៀនិន, *The Samlaut Rebellion and Its Aftermath: 1967-1970, The Origins of Cambodia's Liberation Movement (Melbourne, Monash University Center of Southeast Asian Studies, 1976)* ។

៣៨ *Stephen Heder, The Historial Basis... (op. cit.)* ។

៣៩ អៀង ធីរិទ្ធ ដែលធ្វើសម្ភាសន៍ដោយអ្នកនិពន្ធ ។

៤០ *Stephen Heder, The Historial Basis... (op. cit.)* ។

៤១ ប៉ុល ពត, “មហាជោគជ័យរបស់បដិវត្តន៍...”, សុន្ទរកថា, ខែកញ្ញា ឆ្នាំ១៩៧៧ ។

៤២ សៀវភៅ “កំណត់ហេតុស្តីពីដំណើរក្នុងកន្លែងសំខាន់ៗនៅប្រទេសសៀម, កម្ពុជា និងប្រទេសឡាវ, ១៨៥៨-១៨៦១” របស់លោក ហង់រី មូហូត ។

៤៣ និក្ខេបបទរបស់លោក *M.E. Osborne, Rule and Response: Interaction In Cambodia and Cochinchina (1859-1905) (Cornell University, Ithaca, N.Y., 1968)* ។

៤៤ ប៉ុល ពត, “យើងបន្តជ្រោងខ្ពស់ទង់ជ័យជម្នះរបស់បក្សកុម្មុយនិស្តកម្ពុជាដ៏ជាញជ័យ ដើម្បីកម្ពុជាប្រជាធិបតេយ្យ, បន្តធ្វើបដិវត្តន៍សង្គមនិយម និងកសាងលទ្ធិសង្គមនិយមថែមទៀត”, សុន្ទរកថា, ភ្នំពេញ, ខែកញ្ញា ឆ្នាំ១៩៧៨ ។

៤៥ ប៉ុល ពត, “មហាជោគជ័យរបស់បដិវត្តន៍...”, សុន្ទរកថា, ខែកញ្ញា ឆ្នាំ១៩៧៧ ។

៤៦ *Ibid.*

៤៧ *Stephen Heder, The Historial Basis... (op. cit.)* ។

៤៨ ចម្លើយសារភាពរបស់ ប៊ូផាត ។

៤៩ *Ibid.*

៥០ *Stephen Heder, The Historial Basis... (op. cit.)* ។

៥១ *Ben Kiernan, The Samlaut Rebellion... (op. cit.)* ។

៥២ ប៉ុល ពត, “យើងបន្ត...”, សុន្ទរកថា, ខែកញ្ញា ឆ្នាំ១៩៧៨ ។

## ជំពូកទី៤

១ ការរៀបរាប់ពីរដ្ឋប្រហារឆ្នាំ១៩៧០ តាមពត៌មានដែលចុះផ្សាយក្នុងកាសែតនៅជំនាន់នោះ និងសៀវភៅផ្សេងៗដូចតទៅ ៖

- *Anatomy of a coup* របស់លោក *T.D. Allman* ។
- *Cambodi:a The Widening War In Indochina* របស់លោក *Jonathan Grant, Laurence Moss et Jonathan Unger (New York, Washington Square Press, 1971)* ។
- *The Khmer Republic at War and The Final Collapse,* របស់លោក សាក់ស៊ុត សាខន *(Washington, U.S. Army Center for Milatary History, 1980)* ។

២ សាក់ស៊ុត សាខន, *op. cit.* ។

៣ តាមលោក *William Harben, The Antropological Lon Nol,* ទូរលេខផ្ទាល់ខ្លួនរបស់ស្ថានទូតអាមេរិកាំងនៅក្រុងភ្នំពេញផ្ញើរទៅឲ្យក្រសួងការបរទេស, ថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧២ ។

៤ *Ibid.*

៥ ការឲ្យអត្ថន័យរបស់ *Merriam-Webster Dictionary (New York, Simon and Schuster, 1974)* ។

៦ *William Harben, The Antropological Lon Nol,* ទូរលេខដែលរៀបរាប់រួចមកហើយ ។

៧ សាក់ស៊ុត សាខន, *op. cit.* ។

៨ *William Harben, The Antropological Lon Nol,* ទូរលេខដែលរៀបរាប់រួចមកហើយ ។

៩ ការពិពណ៌នាពីចលនាបំបាត់ជាតិជីហ្វ ដោយលោក *Jonathan Grand et al. (op. cit.)* ព្រមទាំងលោក *William Shawcross, Sideshow: Kissinger, Nixon, and The Destruction of Cambodia* (សោកនាដកម្មមួយដែលគ្មាន សារសំខាន់, *Paris, Balland, 1979)* ។

១០ ម៉ៃ ស៊ីសុផា ដែលសម្ភាសន៍ដោយអ្នកនិពន្ធ ។

១១ ទូរលេខរបស់ស្ថានទូតអាមេរិកាំងនៅក្រុងភ្នំពេញ ផ្ញើទៅឲ្យក្រសួងការបរទេស, ថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៧០ ។

១២ *Ibid.*

១៣ *William Harben, The Antropological Lon Nol,* ទូរលេខដែលរៀបរាប់រួចមកហើយ ។

១៤ សៀវភៅ “នវខេមរនិយម” របស់ លន់ នល់ (ភ្នំពេញ, សាធារណរដ្ឋខ្មែរ, ១៩៧៤) ។

១៥ នៅមានការដាប់ដៃប្រយុទ្ធពេញទំហឹង មានទាហានអាមេរិកាំង ពីរម៉ឺនប្រាំពាន់នាក់នៅកម្ពុជា នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧០ ។

[១៦] សូមអានសៀវភៅរបស់លោក Showcross (op. cit.) សម្រាប់ការវិភាគពេញលេញមួយអំពីនយោបាយរបស់អាមេរិកាំងក្នុងការទម្លាក់គ្រាប់បែកនៅប្រទេសកម្ពុជា ។

[១៧] សាក់ស៊ុត សាខន, op. cit. ។

[១៨] ទូរលេខរបស់ស្ថានទូតអាមេរិកាំងនៅក្រុងភ្នំពេញ ដែលចុះហត្ថលេខាដោយលោកឯកអគ្គរដ្ឋទូត អេម៉ូរី ស្វាំង នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៧១ ហើយបញ្ជូនទៅឲ្យក្រសួងការបរទេស ។

[១៩] ការលើកកិត្តិយសនេះ និងការរៀបរាប់ពីការពិភាក្សាក្នុងផ្នែកផ្ទៃពអំពីរឿងប្រតិបត្តិការសឹកចេនឡាទី២ គឺស្រង់តាមសៀវភៅរបស់លោក សាក់ស៊ុត សាខន, op. cit. ។

[២០] ការសន្ទនាជាសម្ងាត់របស់លោក អ៊ិន តាំ ជាមួយឯកអគ្គរដ្ឋទូតអាមេរិកាំង តាមទូរលេខមួយរបស់ស្ថានទូតអាមេរិកាំងផ្ញើទៅក្រសួងការបរទេស, ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ១៩៧២ ។

[២១] អត្ថបទវាយអង្គុលីលេខរបស់លោក Timothy Carney: The Unexpected Victory ។

[២២] ទឹកប្រាក់មួយកោដិដុល្លារជាជំនួយទៅឲ្យប្រទេសវៀតណាម ត្រូវបានឲ្យដំណឹងមកអ្នកនិពន្ធដោយអ្នកនាំពាក្យម្នាក់របស់រដ្ឋាភិបាលក្រុងហាណូយ និងបោះពុម្ពផ្សាយក្នុងកាសែតវ៉ាស៊ីនតោនប៉ុស្ដិ៍ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ១៩៨៣ ។ ចំនួនទឹកប្រាក់សរុបនៃជំនួយអាមេរិកាំងផ្ដល់ទៅឲ្យសាធារណរដ្ឋខ្មែរ គឺស្រង់តាមលោក Tim Carney ។

[២៣] ការចុះយកពត៌មានដោយអ្នកពិន្ធនៅឆ្នាំ១៩៧៣ សម្រាប់កាសែតវ៉ាស៊ីនតោនប៉ុស្ដិ៍ ។

[២៤] ចំនួន គឺដកស្រង់ពីរបាយការណ៍សម្ងាត់មួយរបស់អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ ។

[២៥] សៀវភៅខ្មៅ ៈ ហេតុការណ៍ និងកស្តុតាងនៃអំពើឈ្លានពាន និងការក្ដាប់ដែនដីរបស់ប្រទេសវៀតណាមប្រឆាំងនឹងកម្ពុជាប្រជាធិបតេយ្យ, ភ្នំពេញ, ខែកញ្ញា ឆ្នាំ១៩៧៨ ។

[២៦] តាមសៀវភៅរបស់លោក Tim Carney, The Unexpected Victory (op. cit.) និងរបស់លោក Richard Dudman, Forty Days with the Ennemy (New York, Liveright, 1971) ។

[២៧] សៀវភៅខ្មៅ ៈ (op. cit.) ទំព័រ៥៦ ។

[២៨] ហែម សាមិន ដែលសម្ភាសដោយលោក ស្ដេហ្វេន ហេដ័រ ។

[២៩] Ibid.

[៣០] ទូរលេខរបស់ស្ថានទូតអាមេរិកាំង ដែលស្រង់ចេញពីប្រវត្តិសាស្ត្រដែលមានតមកទៀត និងការពោលសរសើរទាំងអស់ ។

[៣១] សន្ដាត់អត្ថបទមុំនេះ ពឹងផ្អែកជាសំអាងលើសៀវភៅ "Backward Toward Revolution : The Chines Revolutionary Party" របស់លោក Edward Friedman (Berkeley, University of California Presse, 1974), ជាពិសេសនៅត្រង់ទំព័រ២១៣-២១៥ ។

៣២ តាមសៀវភៅ *Cambodia in the Southeast Asian War* របស់លោក *Malcolm Caldwell et Lek Hor Tan (New York, Monthly Review Press, 1975)* ។

៣៣ បញ្ជីឈ្មោះបណ្ដាលសមាជិកនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងរណសិរ្សរួបរួមជាតិកម្ពុជា ដោយយកតាមបញ្ជីរបស់លោក *Malcolm Caldwell* ។

៣៤ ជា សុទ្ធ ដែលសម្ភាសដោយលោក ស្ដេហ្វេន ហេដ័រ នៅខែមិថុនា ឆ្នាំ១៩៨១ ។

៣៥ ការពិពណ៌នា និងការលើកនិយាយសំអាងទាំងនេះ គឺសំអាងលើសេចក្ដីបកប្រែចំនួនពីរ ពីសៀវភៅ "ស្រណោះព្រលឹងខ្មែរ" របស់ អ៊ិត សារិន ។ សេចក្ដីបកប្រែមួយដែលវាយអង្គុលីលេខ ត្រូវបានស្នើដោយអ្នកនិពន្ធ និងលោក អ៊ីស៊ីយ៉ាម៉ា កូគី ។ សេចក្ដីដកស្រង់ខ្លះត្រូវបានបោះពុម្ពផ្សាយក្នុងអត្ថបទ "តើខ្មែរក្រហមជាអ្នកណា" ដោយអ្នកនិពន្ធ នៅក្នុងកាសែតអាស៊ីគោនប៉ុស្ដិ៍នាខែមីនា ឆ្នាំ១៩៧៤ ។ សេចក្ដីបកប្រែទីពីរដែលមានលក្ខណៈពេញលេញជាង ត្រូវបានបោះពុម្ពផ្សាយដោយលោក *Timothy Carney* ក្នុងសៀវភៅ *Communist Party Power in Kampuchea (Ithaca, Cornell University, 1977)* ។ ការលើកនិយាយទាំងប៉ុន្មានតាមសៀវភៅ "ស្រណោះព្រលឹងខ្មែរ" គឺបានមកពីការបកប្រែរបស់លោក *Carney* ឬលោក *Koki* ។

៣៦ ឃ្លា ឬអត្ថបទម្ដុំៗ និងការពិពណ៌នាដែលមានតទៅទៀត សុទ្ធតែសំអាងលើប្រវត្តិសាស្ត្របក្ស ។

៣៧ ចម្លើយសារភាពរបស់ កែវ មាស, "ចម្លើយរបស់ X", ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៦, នៅសារមន្ទីរទួលស្លែង ។ អត្ថបទបកប្រែរបស់លោក ស្ដេហ្វេន ហេដ័រ ។

៣៨ ពួកមេដឹកនាំនៃចលនាតស៊ូខ្មែរ និងសមាជិករាជរដ្ឋាភិបាលរួបរួមជាតិ នៅខាងក្នុងប្រទេសកម្ពុជា ។

៣៩ សៀវភៅខ្មៅ *(op. cit.)* ។

៤០ ការរៀបរាប់អំពីសហករណ៍ទាំងឡាយ គឺយកគំនិតតាមអត្ថបទ "កម្មាភិបាល, បណ្ដាសមាជិក, ប្រជាជននិងកងទ័ពបដិវត្តន៍ត្រូវមូលមតិតែមួយ", ក្នុងទស្សនាវដ្ដីទង់បដិវត្តន៍ ខែសីហា ឆ្នាំ១៩៧៥ និងតាមអត្ថបទ *The Khmer Krahom Program to create a Communist Society in Southern Cambodia* របស់លោក *Kenneth Quinn,* ទូរលេខផ្ញើទៅក្រសួងការបរទេសនៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៧៤ ។

៤១ សុន្ទរកថារបស់ ប៉ុល ពត "យើងបន្តជ្រោងខ្ពស់...", ខែកញ្ញា ឆ្នាំ១៩៧៨ ។

៤២ ដួន ប្រសិទ្ធិ ដែលធ្វើសម្ភាសដោយអ្នកនិពន្ធ ។

៤៣ សៀវភៅ *"Aftermath: The Struggle of Cambodia and Vietnam"* របស់លោក *John Pilger* និង *Anthong Barnett (Londres, New Statesman, 1982),* ទំព័រ៥២ ។

៤៤ តាមទូរលេខរបស់លោក *Kenneth Quinn* ដែលមានរៀបរាប់រួចមកហើយ ព្រមទាំងការលើករៀបរាប់ទាំងអស់ដែលមានជាបន្តមកទៀត ។

៤៥ ការពិពណ៌នាអំពីទីក្រុងភ្នំពេញក្នុងរយៈពេលសង្គ្រាម គឺសំអាងលើការយកពត៌មានផ្សេងៗដែលសម្រេចធ្វើឡើងនៅជំនាន់នោះ ដោយអ្នកនិពន្ធផ្ទាល់ រួមទាំងរបាយការណ៍ប្រចាំថ្ងៃរបស់ស្ថានទូតអាមេរិកាំងពេញអំឡុងពេលនៃសង្គ្រាម ។

៤៦ តាមសៀវភៅ *The Political Thought of Mao Tse-tung* របស់លោក *Stuart Schram (New York, Frederick A. Praeger, 1963)* ។

៤៧ ប៉ុល ពត, ក្នុងទស្សនាវដ្ដីទង់បដិវត្ដន៍ ។

៤៨ *Ibid.*

៤៩ *John Pilger et Anthony Barnett, op. cit.*

៥០ ការធ្វើសម្ភាសន៍របស់អ្នកនិពន្ធ ។

៥១ សាក់ស៊ុត សាខន, *op. cit.* ។

៥២ ទូរលេខរបស់ស្ថានទូតអាមេរិកាំងនៅក្រុងភ្នំពេញ ផ្ញើទៅឲ្យក្រសួងការបរទេស, ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ ១៩៧៣ ។

៥៣ ហែម សាមិន ដែលធ្វើសម្ភាសដោយលោក ស្ដេហ្វេន ហេដ័រ ។

៥៤ ប៉ុល ពត, ក្នុងទស្សនាវដ្ដីទង់បដិវត្ដន៍ ។

៥៥ ទូរលេខរបស់ស្ថានទូតអាមេរិកាំងនៅក្រុងភ្នំពេញផ្ញើជូនក្រសួងការបរទេស, ថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៧៤ ។

៥៦ ការពិពណ៌នាពីការប្រយុទ្ធផ្ដាច់ព្រ័ត្រ តាមការរៀបរាប់របស់លោក សាក់ស៊ុត សាខន, *op. cit.*, និងរបាយការណ៍ផ្សេងៗប្រចាំថ្ងៃរបស់ស្ថានទូតអាមេរិកាំង ។

៥៧ ទូរលេខរបស់ស្ថានទូតអាមេរិកាំងនៅទីក្រុងភ្នំពេញ ផ្ញើទៅឲ្យក្រសួងការបរទេស, ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៥ ។

៥៨ សាក់ស៊ុត សាខន, *op. cit.* ។

## ជំពូកទី៥

១ ប៉ុល ពត, ក្នុងទស្សនាវដ្ដីទង់បដិវត្ដន៍ ។

២ សៀវភៅ *Staline (Staline: A Political Biography)* របស់លោក *Isaac Deutscher*, បកប្រែពីសៀវភៅជាភាសាបារាំងរបស់លោក *J.P. Herbert (Paris, Julliard, 1953)* ។

៣ *Franz Schurmann* និង *Orville Schell*, អ្នកទទួលខុសត្រូវលើសៀវភៅរួមមានចំណងថា *Communist China Revolutionary Reconstruction and International Confrontation (New York, Vintage, 1967)* ។

៤ ការធ្វើសម្ភាសន៍ អៀង សារី ដោយអ្នកនិពន្ធ ដែលក្នុងនោះគឺពឹងផ្អែកជាសំអាងលើសេចក្តីរាយការណ៍ដែលធ្វើឡើងដោយ សារី នៅថ្ងៃដំបូងៗនៃជ័យជម្នះ ។

៥ អត្ថបទវាយអង្គុលីលេខ *The Unexpected Vicotry* របស់លោក *Tim Carney* ។

៦ ការរៀបរាប់ពីការផ្គត់ផ្គង់ភស្តុភារទីក្រុងព្រៃនគរ តាម *With Firm Steps: Southern Vietnam Since Liberation 1975-1977* (ហាណូយ, ការបោះពុម្ពផ្សាយជាភាសាបរទេស, ឆ្នាំ១៩៧៨) ។

៧ កាសែតញូវយ៉កថែមស៍, ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៧៥ ។

៨ ការវាយតម្លៃអំពីការខូចខាតទាំងអស់ តាមសុន្ទរកថារបស់ អៀង សារី នៅមហាសន្និបាតអង្គការសហប្រជាជាតិ នាខែតុលា ឆ្នាំ១៩៧៦ និងតាមរបាយការណ៍សម្ងាត់របស់អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ ។

៩ គំរូនៅ រាម និងកំពង់សោម គឺដកស្រង់ពីការចុះយកពត៌មានមួយដែលធ្វើឡើងដោយអ្នកនិពន្ធនៅឆ្នាំ១៩៧៨ ។

១០ ការពិពណ៌នាតាមការធ្វើសម្ភាសន៍ ធីរិទ្ធ ដោយអ្នកនិពន្ធ និងសៀវភៅ«ការវិលត្រឡប់ទៅក្រុងភ្នំពេញ» របស់លោក អ៊ី ផាន់ដារា *(Paris, A.M. Métaillé, 1982)* ។

១១ ប៉ុល ពត, ក្នុងទស្សនាវដ្តីទង់បដិវត្តន៍ ។

១២ ការវាយតម្លៃទាំងនេះ សំអាងលើការប្រៀបធៀបមួយនូវចំនួនតួលេខរបស់លោក បេន ឃៀនិន និង លោកស្ទេហ្វេន ហ៊ីឌ័រ ។ ខ្ញុំធ្លាប់សន្និដ្ឋានថា អតីតភូមិភាគឧត្តរបានផ្តល់ទ័ពបីកងពលធំទៅឲ្យមជ្ឈិម ។ ពីរកងពលធំស្ថិតនៅភ្នំពេញ, កងពលធំទីបី ត្រូវបញ្ជូនទៅព្រំដែនភាគឦសាន ។ ភូមិភាគបូព៌ា ផ្តល់ទៅឲ្យក្រុងភ្នំពេញតែមួយកងពលធំប៉ុណ្ណោះ (ដែលស្ថិតនៅក្នុងកងទ័ពមជ្ឈិម) និងរក្សាទុកពីរកងពលធំ ។ ភូមិភាគពិសេស បានក្លាយទៅជាភូមិភាគរបស់មជ្ឈិម និងបានប្រគល់កងទ័ពរបស់ខ្លួនទៅឲ្យក្រុងភ្នំពេញទាំងអស់ ។ កងពលធំតែមួយគត់របស់ភូមិភាគពាយ័ព្យ ដែលមានចំនួនទ័ពមិនគ្រប់គ្រាន់ ត្រូវបានអនុញ្ញាតឲ្យនៅនឹងកន្លែង ។ ភូមិភាគនិរតី បានផ្តល់ទ័ពឲ្យក្រុងភ្នំពេញមួយកងពលធំ (ប៉ុន្តែត្រូវដាក់ឲ្យប្រចាំការនៅកំពង់សោម ក្នុងភូមិភាគរបស់ខ្លួនដដែល) ហើយបានរក្សាកងទ័ពរបស់ខ្លួនពីរកងពលធំទៀត ។

១៣ ប្រវត្តិរបស់ភូមិភាគនិរតី គឺសំអាងលើអត្ថបទ “ពី ប៉ុល ពត ដល់ប៉ែនសុវណ្ណ...” របស់លោក ស្ទេហ្វេន ហេដ័រ ដែលគាត់បានថ្លែងនៅក្នុងសន្និសីទអន្តរជាតិស្តីពីឥណ្ឌូចិន និងបញ្ហាសន្តិសុខ និងស្ថិរភាពនៅអាស៊ីភាគអាគ្នេយ៍ (សាកលវិទ្យាល័យជូឡាឡុងកន, បាងកក, ឆ្នាំ១៩៨០) ។

១៤ ជីវប្រវត្តិរបស់ តាម៉ុក យកតាមចម្លើយសារភាពរបស់ នង សួន ដែលសរសេរនៅសារមន្ទីរទួលស្លែង នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ។

១៥ ជីវប្រវត្តិរបស់ សោ ភឹម យកតាមចម្លើយសារភាពរបស់ វ៉ន វ៉េត នៅសារមន្ទីរទួលស្លែង, អត្ថបទបកប្រែ

របស់លោក ស្ទេហ្វេន ហេដ័រ និងតាមនិក្ខេបបទថ្នាក់បណ្ឌិតរបស់ បេន យៀនិនៈ តើប៉ុល ពត ចូលកាន់អំណាចបែបណា, ប្រវត្តិនៃលទ្ធិកុម្មុយនិស្តនៅកម្ពុជា ១៩៣០-១៩៧០ (អត្ថបទវាយអង្គុលីលេខ, សាកលវិទ្យាល័យ វ័រណែល, ឆ្នាំ១៩៧៨) ។

១៦ ហែម សាមិន ត្រូវបានសម្ភាសន៍ដោយលោក ស្ទេហ្វេន ហេដ័រ ។

១៧ សំឡូត ជាការសម្រេចចិត្តដើមដំបូងរបស់កុម្មុយនិស្ត ក្នុងការចាប់ផ្តើមការតស៊ូដោយអាវុធ ហើយថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៦៨ បានក្លាយទៅជាថ្ងៃខែនៃការបង្កើតកងទ័ពបដិវត្តន៍ ។ ជួន ប្រសិទ្ធិ ដែលធ្វើសម្ភាសដោយអ្នកនិពន្ធ ។

១៨ ប៉ុល ពត, ក្នុងទស្សនាវដ្តីទង់បដិវត្តន៍ ។

១៩ ក្នុងអត្ថបទ "សម្រួចសតិអារម្មណ៍វណ្ណៈអធន...", ទស្សនាវដ្តីទង់បដិវត្តន៍ប្រចាំខែកញ្ញា-តុលា ឆ្នាំ១៩៧៦ ដែលអត្ថបទនេះត្រូវបានបកប្រែដោយលោក គីម សុស និង ធីម៉ូធី ខារនី ។

២០ សៀវភៅ "ត្រុតស្គី, ព្យាការីប្រដាប់ដោយអាវុធ" របស់លោក *Isaac Deutscher "The Prophet Armed: Trotsky 1879-1921)*, ការបកប្រែពីសៀវភៅជាភាសាបារាំងរបស់លោក ប៉េ ប៉េហ្ស៊ុយ *(Paris, Julliard, 1962)* ។

២១ ប៉ុល ពត, "យើងបន្ត...", សុន្ទរកថានៅខែកញ្ញា ឆ្នាំ១៩៧៨ ។

២២ *Ibid.*

២៣ *Ibid.*

២៤ សៀវភៅ "ស្តាលីន" របស់លោក *Isaac Deutscher (op. cit.)* ។

២៥ *Ibid.*

២៦ សៀវភៅ *"A History of Russia"* របស់លោក *Sir Bernard Pares (New York, Alfred A. Knopf, 1947)*, ទំព័រ៥០៧ ។

២៧ *Franz Schurmann et Orville Schell (op. cit.)*, ទំព័រ៤០៩-៤១០ ។

២៨ *Ibid.*, ទំព័រ២១១ ។ (បដិវត្តន៍ទីពីររបស់ស្តាលីន និងនយោបាយមហាលោតផ្លោះរបស់ចិន បានសម្រេចជំរុញផ្នែកសេដ្ឋកិច្ចទៅរកខស្សរាហូបនីយកម្ម និងកែប្រែការប្រព្រឹត្តិផ្សេងៗ ដើម្បីនឹងធ្វើឲ្យប្រជាជនក្នុងប្រទេសជឿថា គេឈានចូលសម័យទំនើបហើយ ។ ពួកខ្មែរក្រហមមិនស្គាល់ពីជោគជ័យ ដែលមានកំណត់នេះផងទេ) ។

២៩ លោក ហាណាហ៍ អារ៉េន បាននិយាយព្យាករថា ៖ "កាលណាព្រះរាជាកាន់តែផ្តាច់ការ បដិវត្តន៍ដែលនឹងមកជំនួសកន្លែងរបស់ព្រះអង្គកាន់តែផ្តាច់ការជាងព្រះអង្គទៅទៀត", ក្នុងការនិពន្ធល្បងស្តីពីការបដិវត្តន៍ *(Gallimard, 1985)* ។ ទេវរាជានៃប្រទេសកម្ពុជា គឺជាព្រះរាជាកាន់អំណាចផ្តាច់ការជាងគេមួយអង្គក្នុងចំណោមព្រះរាជា ដែលកាន់អំណាចផ្តាច់ការជាងគេ ហើយពួកខ្មែរក្រហមជាអ្នកបដិវត្តន៍ប្រើអំណាចផ្តាច់ការជាងគេ

ក្នុងចំណោមអ្នកបដិវត្តន៍ ដែលប្រើអំណាចផ្តាច់ការជាងគេ ។

៣០ D.G.E. Hall, *A History of South-East Asia* (New York, St. Martin's Press, 1970).

៣១ សៀវភៅមានចំណងជើងថា "អង្គរ" របស់លោក ហ្ស៊ក សឺដេស ។

៣២ វិទ្យុក្រុងភ្នំពេញ, ថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៧៥ ក្នុងព្រឹត្តិបត្រពត៌មានរបស់ខ្លួនជាភាសាបរទេស ។

៣៣ សៀវភៅ "អង្គរ" របស់លោក ហ្ស៊ក សឺដេស ដែលស្រង់ម៉ុំៗមាននិយាយជាសំអាងដោយលោក លុីស៍ ហ្វីណូត ។

៣៤ សម្ភាសន៍របស់មេដឹកនាំចំពោះពួកអ្នកកាសែតយូហ្គោស្លាវី ។ *Edward Conze dans Buddhism, Its Essence and Development* (New York, Harper Torchbooks, 1959) ដែលគូសបញ្ជាក់ថា គោលដៅរបស់ព្រះពុទ្ធសាសនាគឺ "ធ្វើឲ្យមនុស្សមានចិត្តស្ងប់ស្ងាត់" ។

៣៥ អ្នកការទូតចិន ដែលសម្ភាសន៍ដោយអ្នកនិពន្ធ និងមានបំណងឲ្យរក្សាអនាមិកភាព ។

៣៦ សៀវភៅ "គំនិតហួសវិស័យដែលបណ្តាលឲ្យមានមនុស្សស្លាប់អស់ជាច្រើន" របស់ ពិន យ៉ាថៃ, អ្នករួចពីគ្រោះថ្នាក់នៃអំពើប្រល័យពូជសាសន៍កម្ពុជាម្នាក់ និយាយបង្ហាញឲ្យឃើញរឿងនោះ (Paris, R. Laffont, 1979), ទំព័រ៩៧-៩៨ ។

៣៧ A.L. Bashman, *The Wonder That Was India* (New York, Grove Press, 1954) ។

៣៨ ពិន យ៉ាថៃ, *op. cit.*, ទំព័រ៣៥ ។

៣៩ ដួន ប្រសិទ្ធិ ដែលធ្វើសម្ភាសដោយអ្នកនិពន្ធ ។

៤០ កាសែតវ៉ាស៊ីនតោនប៉ុស្តិ៍ ចេញថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៧៥ ។

៤១ សៀវភៅ "Origins of the conflict" របស់លោក ស្តេហ្វេន ហេដ័រ, *Southeast Asia Chronicle*, ខែកញ្ញា-តុលា ឆ្នាំ១៩៧៨ ។

៤២ ការដំណាលឡើងវិញអំពីវិបត្តិនាវា ម៉ៃយ៉ាហ្គេ គឺពឹងផ្អែកជាសំអាងលើ "ការចាប់នាវា ម៉ៃយ៉ាហ្គេ", សវនាការរបស់សភាអាមេរិកាំងនៅឆ្នាំ១៩៧៥ និងសេចក្តីកត់ទុកខ្លីៗដែលសរសេរដោយអ្នកនិពន្ធក្នុងឱកាសនៃសន្និសីទកាសែតដែលធ្វើឡើងដោយ អៀង សារី ស្តីពីរឿងនេះ នៅទីក្រុងញូវយ៉កនាថ្ងៃទី៦ ខែកញ្ញា ឆ្នាំ១៩៧៥ ។

៤៣ សេចក្តីកត់ទុកខ្លីៗរបស់អ្នកនិពន្ធ និងអត្ថបទក្នុងកាសែតវ៉ាស៊ីនតោនប៉ុស្តិ៍ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ១៩៧៥ ។

៤៤ ទស្សនាវដ្តីថៃម ថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៧៥ ។

៤៥ សៀវភៅស្តើងស្តីពីវិមានរំឭកវិញ្ញាណក្ខន្ធអតីតយុទ្ធជននៅប្រទេសវៀតណាម, ក្រុងវ៉ាស៊ីនតោន, D.C. ។

៤៦ ទូរលេខរបស់ស្ថានទូតអាមេរិកាំងនៅក្រុងបាងកក ផ្ញើទៅឲ្យក្រសួងការបរទេស, ថ្ងៃទី៩ ខែឧសភា ឆ្នាំ១៩៧៥ ។

[៤៧] សុន សេន បានប្រកាសថា គាត់ធ្លាប់បានសិក្សាពីសង្គ្រាមទាំងឡាយរបស់អឺរ៉ុប ក្នុងការធ្វើសម្ភាសន៍មួយដែលផ្តល់ដល់លោក ស្តេហ្វេន ហេដ័រ នៅឆ្នាំ១៩៧៩ ។

[៤៨] ការរៀបរាប់អំពីការិយាធិបតេយ្យ (អំណាច, ទម្លាប់, របៀបចាត់ចែងកិច្ចការរដ្ឋ) និងការប្រព្រឹត្តទៅរបស់របបនេះ គឺយកតាមការធ្វើដំណើររបស់អ្នកនិពន្ធទៅកាន់កម្ពុជាប្រជាធិបតេយ្យ នៅឆ្នាំ១៩៧៨ និងការសម្ភាសន៍ជាច្រើន ដែលបានធ្វើនៅជំនាន់នោះ ។

[៤៩] ផ្នែកសំខាន់ៗនៃជីវប្រវត្តិទាក់ទងនឹង នួន ជា គឺយកតាមនិក្ខេបបទរបស់លោក បេន ឃៀនិន, *op. cit.* ។

[៥០] នៅខណៈនេះ កងទ័ពបានទទួលបញ្ជាឲ្យបញ្ចប់មុខការផ្សេងៗរបស់ខ្លួនជាសន្តិសុខ ដែលរួមមានការសម្លាប់មនុស្សផង ។ លោកឡូរ៉ា សាមម័រ និងបេន ឃៀនិន បានបកស្រាយរឿងនេះថាដូចជាបញ្ជាមួយឲ្យបញ្ឈប់ការសម្លាប់ទាំងអស់ ។ ប៉ុន្តែ វាហាក់ដូចជាថា ពុំមានការផ្អាកជាបណ្តោះអាសន្នក្នុងការសម្លាប់មនុស្សទេ ប៉ុន្តែថាកិច្ចការចាំបាច់នេះ ត្រូវបានប្រគល់ឲ្យផ្នែកសន្តិសុខនៅមន្ទីរឃុំឃាំងទួលស្លែងដែលដឹកនាំដោយ ឌុច វិញ ។ តាមពិត គឺក្រោយមានបញ្ជានេះបន្តិច ដែលមន្ទីរឃុំឃាំងទួលស្លែងចាប់ផ្តើមដំណើរការ ។

## ជំពូកទី៦

[១] សំបុត្រនេះ ជាចំណែកមួយនៃឯកសាររបស់ ហួត បុប្ផាណា នៅសារមន្ទីរទួលស្លែង ដែលរកឃើញដោយអ្នកនិពន្ធនៅមជ្ឈមណ្ឌលនេះ ហើយបកប្រែនៅនឹងកន្លែងដោយ ជុំ បូរី ជាមគ្គុទ្ទេសក៍របស់រដ្ឋាភិបាល ។ ក្នុងឯកសារនេះមានម្តេមួយជុំ ៖ សេចក្តីប្រកាសរបស់នាងនៅថ្ងៃដែលសន្តិសុខនាំខ្លួនមកដាក់គុក, ជីវប្រវត្តិរបស់នាង, ការលាតត្រដាងពីឈ្មោះសមាជិកដែលគេអះអាងថា ជាខ្សែបណ្តាញរបស់នាងចំនួន ១៥ច្បាប់ ចម្លើយសារភាពអំពីសំបុត្រជាច្រើន ដែលនាងសរសេរផ្ញើឲ្យស្វាមីរបស់នាង, ជីវប្រវត្តិមួយរបស់ប្តីនាង និងមតិណែនាំយ៉ាងវែងរបស់ ឌុច ផ្ញើទៅឲ្យកម្មាភិបាលដែលទទួលបន្ទុកសួរចម្លើយ ។ ពួកអ្នកថែរក្សាសារមន្ទីរទួលស្លែងបាននិយាយប្រាប់ខ្ញុំថា នេះជាឯកសារក្រាស់ជាងគេក្នុងចំណោមឯកសារនៅទីនោះ ។

[២] ទ្រី ម៉េងហួត និង ប៊ុន ណាល់ ដែលធ្វើសម្ភាសដោយអ្នកនិពន្ធ ។

[៣] តាមច្បាប់រដ្ឋធម្មនុញ្ញ ដែលបោះពុម្ពផ្សាយ និងវិភាគដោយ មៀន សង់គីម ក្នុង *Southeast Asian Affairs*, ឆ្នាំ១៩៧៧ ។

[៤] បទភ្លេងជាតិត្រូវបានបោះពុម្ពផ្សាយ ក្នុងទស្សនាវដ្តី “កម្ពុជាប្រជាធិបតេយ្យបោះជំហានទៅមុខ” ដែលជាទស្សនាវដ្តីផ្លូវការមួយរបស់របបនេះ ។

[៥] សម្ភាសន៍ដែលធ្វើឡើងដោយអ្នកនិពន្ធ ។

[៦] *Hannah Arendt, On Violence (New York, Harcourt, Brace & World, 1969)*, ទំព័រ៥៣ ។ “ពីការភូតកុហក ទៅអំពើហិង្សា

*(Paris, Calmann - Lévy, 1972)* ។

៧ *Ibid., p. 55* ។

៨ *Ibid., p. 55* ។

៩ ប្រវត្តិរបស់ បុប្ផាណា និង ដែត គឺសំអាងលើឯកសាររបស់នាងនៅសារមន្ទីរទួលស្លែង ។ ការប្រើប្រាស់ឯកសារនេះ និងឯកសារផ្សេងៗទៀត ដែលប្រើសម្រាប់បញ្ជាក់អំពីសម័យនេះ គឺត្រូវបានញុំាងឲ្យផុសគំនិតដោយលោក *Jonathan Spence, The Death of Woman Wang (New York, Penguin, 1982)* ។

១០ សៀវភៅ *"The Khmer Republic at War and the Final Collapse"* របស់ សាក់ស៊ុត សាខន *(Washington, U.S. Army Center for Military History, 1980)* ។

១១ ការយកពត៌មានដែលធ្វើឡើងដោយអ្នកនិពន្ធនៅសម័យនោះ ។

១២ សូមអានរឿង "រាមាយណៈ" (រាមកេរ្តិ៍) ដើម្បីដឹងពីរឿងយុទ្ធកថាទាំងមូល ។

១៣ ការពិពណ៌នាអំពីមន្ទីរឃុំឃាំងទួលស្លែងតាមការធ្វើទស្សនកិច្ចរបស់អ្នកនិពន្ធនៅឆ្នាំ១៩៨៣ ។ លក្ខណៈពិតនៃចម្លើយសារភាពជាច្រើននៅសារមន្ទីរទួលស្លែង គឺត្រូវបានអះអាងបន្ថែមដោយ អៀង សារី ក្នុងការធ្វើសម្ភាសន៍មួយដែលយល់ព្រមនឹងអ្នកនិពន្ធ ហើយត្រូវបោះពុម្ពផ្សាយក្នុងអត្ថបទ "បន្ទប់មរណៈរបស់ពួកខ្មែរក្រហម" របស់កាសែតវ៉ាស៊ីនតោនប៉ុស្តិ៍ ថ្ងៃទី២ ខែសីហា ឆ្នាំ១៩៨១ ។

១៤ បទសម្ភាសន៍ទាំងឡាយរបស់អ្នកនិពន្ធនៅសារមន្ទីរទួលស្លែង និងការពិភាក្សាជាមួយ ដេវីដ ហក ។

១៥ បទសម្ភាសន៍ដែលយល់ព្រមធ្វើជាមួយអ្នកនិពន្ធ ដោយពួកអ្នកភៀសខ្លួនដែលចូលចិត្តលាក់អនាមិកភាព ។

១៦ អៀង សារី ដែលធ្វើសម្ភាសដោយអ្នកនិពន្ធ ។

១៧ បណ្តាមេដឹកនាំសហករណ៍របស់ភូមិភាគនិរតី ដែលធ្វើសម្ភាសដោយអ្នកនិពន្ធនៅខែធ្នូ ឆ្នាំ១៩៧៨ ។

១៨ សូមអានអត្ថបទវាយអង្គុលីលេខ "សហករណ៍ទាំងឡាយក្នុងកម្ពុជាប្រជាធិបតេយ្យ" របស់លោក ឡូវ៉ា សាមម័រ, ខែសីហា ឆ្នាំ១៩៨១ និងការធ្វើសម្ភាសន៍ អៀង សារី ដោយអ្នកនិពន្ធ ។

១៩ តាមអត្ថបទរបស់លោក ឡូវ៉ា សាមម័រ, *op. cit.* ។

២០ ប្រវត្តិរបស់គ្រួសារម៉ៃ គឺស្រង់ចេញពីការធ្វើសម្ភាសន៍ដែលអនុញ្ញាតផ្តល់ដល់អ្នកនិពន្ធដោយសមាជិកគ្រួសារដែលរស់រានមានជីវិតចំនួន៤រូបគឺ ស៊ីសុផា, បូផា, សូម៉េត និង ឱភា ។

២១ សម្ភាសន៍ដែលធ្វើឡើងដោយអ្នកនិពន្ធ ។

២២ សម្ភាសន៍ដែលធ្វើឡើងដោយអ្នកនិពន្ធ ។

២៣ *Ibid.*

២៤ សម្ភាសន៍ដែលធ្វើឡើងដោយអ្នកនិពន្ធ ។

[២៥] ការរៀបល្បិតល្អន់ស្តីពីការផ្លាស់ប្តូរខាងពាណិជ្ជកម្មរបស់ពួកខ្មែរក្រហម និងក្រុមហ៊ុន រ៉េនហ្វុង *(Ren Fung, Co.)* ក្នុងទស្សនាវដ្តីសេដ្ឋកិច្ចចុងបូព៌ា *(FEER)* ថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៧ ។

[២៦] របាយការណ៍ដំណាច់ឆ្នាំ របស់រដ្ឋាភិបាល គឺលើកមកនិយាយជាសំអាងក្នុងសៀវភៅរបស់លោក *David Chandler, A Revolution in Full Spate: Communist Party Policy in Democratic Kampuchea, December 1976* (បទអន្តរាគមន៍នៅសន្និសីទព្រីនស៍តុន ស្តីពីប្រទេសកម្ពុជា, ខែវិច្ឆិកា ឆ្នាំ១៩៨២) ។

[២៧] *Chandler, op. cit.* ។

[២៨] ការធ្វើសម្ភាសន៍ និងទស្សនកិច្ចនៅកម្ពុជាប្រជាធិបតេយ្យរបស់អ្នកនិពន្ធនៅឆ្នាំ១៩៧៨ ។

[២៩] ការធ្វើសម្ភាសន៍ដែលផ្តល់ដល់អ្នកនិពន្ធដោយវិស្សុករ រ៉ូដុលហ្វូ ហ្សុយអារ៉េ ដែលជួសជុលប្រព័ន្ធធារាសាស្ត្ររបស់ប្រទេសនេះពីខែសីហា ឆ្នាំ១៩៨០ ដល់ខែកក្កដា ឆ្នាំ១៩៨២ ។

[៣០] សម្ភាសន៍ដែលសម្រេចធ្វើឡើងដោយអ្នកនិពន្ធ ។

[៣១] ការពិភាក្សាជាមួយសាស្ត្រាចារ្យ ហ្វ្រង់ អុហ្វម៉ាន ដែលបានបំភ្លឺខ្ញុំអំពីចំណុចនេះ ។

[៣២] លើកមកនិយាយជាសំអាងក្នុងសៀវភៅ *"The Norms and Standards International Human Rights and Khmer Rouge Rule in Democratic Kampuchea 1975-1979"* របស់លោក ដេវីដ ហក ដែលជិតចេញផ្សាយ ។

[៣៣] ប្រវត្តិរបស់ ហាន តាវ សំអាងលើបទសម្ភាសន៍មួយដែលយល់ព្រមផ្តល់ឲ្យអ្នកនិពន្ធនៅឆ្នាំ១៩៧៩ និងត្រូវបានបំពេញបន្ថែម ដោយការធ្វើសម្ភាសន៍ជនជាតិចិនកាត់ខ្មែរ ប្រាំមួយនាក់ផ្សេងទៀត ។

[៣៤] សុន្ទរកថារបស់ ប៉ុល ពត "យើងបន្តជ្រោងខ្ពស់...", ខែកញ្ញា ឆ្នាំ១៩៧៨ ។

[៣៥] ការរៀបរាប់ពីការបោសសម្អាតថ្មីៗ គឺយកតាមបញ្ជីឈ្មោះជនរងគ្រោះដែលជាប់គុក និងត្រូវសម្លាប់នៅមន្ទីរឃុំឃាំង ស-២១ ក្រោមរបប ប៉ុល ពត, អៀង សារី ។ មន្ទីរនេះស្ថិតនៅក្នុងអតីតវិទ្យាល័យទួលស្វាយព្រៃ ក្រុងភ្នំពេញ (ឯកសារវាយអង្គុលីលេខ, សារមន្ទីរទួលស្លែង, ពុំមានចុះកាលបរិច្ឆេទទេ) ។

[៣៦] សម្ភាសន៍ដែលធ្វើឡើងដោយលោក ស្តេហ្វេន ហេដ័រ ។

[៣៧] *David Hawk, op. cit.* ។

[៣៨] បទសម្ភាសន៍ដែលយល់ព្រមផ្តល់ឲ្យអ្នកនិពន្ធ ដោយលោក ឆាំង សុង, អតីតរដ្ឋមន្ត្រីក្រសួងពត៌មានរបស់សាធារណរដ្ឋខ្មែរ ។

[៣៩] "ពីការភូតកុហកទៅអំពើហិង្សា" របស់លោក អារ៉េនដ៍ ។

[៤០] *David Hawk, op. cit.* ។

[៤១] ឃ្លា ឬអត្ថបទម្តុំៗ គឺដកស្រង់ចេញពីទស្សនាវដ្តីយុវជនបដិវត្តន៍ តាមសៀវភៅ *"Communist Party Power in Kampuchea (Cambodia): Documents and Discussion"* របស់លោក *Timothy Carney, Conell University Southeast Asia Program,*

*Data Paper No 106, Ithaca, 1977)* ។

៤២ អត្ថបទ “អ្នកណាខ្លះជាពួកខ្មែរក្រហម?” របស់អ្នកស្រី អេលីហ្សាបែត បេិកខ័រ ចុះផ្សាយក្នុងកាសែតវ៉ាស៊ីនតោនប៉ុស្ដិ៍ ខែមីនា ឆ្នាំ១៩៧៤ ។

៤៣ វ៉ុន ដែលធ្វើសម្ភាសដោយអ្នកនិពន្ធនៅឆ្នាំ១៩៧៨ ។

៤៤ មេបញ្ជាការ ពីន ដែលសម្ភាសដោយអ្នកនិពន្ធ ។

៤៥ ការកត់សម្គាល់របស់អ្នកនិពន្ធក្នុងរយៈពេលនៃការធ្វើដំណើរនៅឆ្នាំ១៩៧៨ ។

៤៦ ការសម្ភាសន៍ដែលសម្រេចធ្វើដោយអ្នកនិពន្ធនៅឆ្នាំ១៩៧៩ ។

## ជំពូកទី៧

១ តាមចម្លើយសារភាពរបស់ ប៊ូ ផាត (សុំណុំឯកសារនៅសារមន្ទីរទួលស្លែង) ។

២ ការរៀបរាប់ពីមន្ទីរឃុំឃាំងទួលស្លែង និងសម្ភារៈធ្វើទារុណកម្ម តាមការធ្វើទស្សនកិច្ចដែលធ្វើឡើងដោយអ្នកនិពន្ធនៅឆ្នាំ១៩៨៣ ។

៣ ដេវីដ ហក, “មន្ទីរសម្លាប់មនុស្សទួលស្លែង *Index on Censorship, Londres,* ខែមករា ឆ្នាំ១៩៨៦ ។

៤ ការរៀបរាប់អំពីការបោសសម្អាតនៅភូមិភាគខត្តរ និងពាយ័ព្យ គឺយកតាមឯកសារផ្សេងៗរបស់លោក *Timothy Carney, The Organization of Power in Democratic Kampuchea,* (ឯកសារវាយអង្គុលីលេខដែលពិនិត្យឡើងវិញនៅខែសីហា ឆ្នាំ១៩៨២) ។

៥ សម្ភាសន៍ដែលសម្រេចធ្វើឡើងដោយអ្នកនិពន្ធ ។

៦ *Timothy Carney, The Organization of Power..., (op. cit.)* ។

៧ ការចាប់ខ្លួន និងការសម្លាប់ កុយ ធួន គឺយកតាមសៀវភៅខ្មៅ, ហេតុការណ៍ និងភស្តុតាងផ្សេងៗនៃអំពើឈ្លានពាន និងការក្ជាប់ទឹកដីរបស់ប្រទេសវៀតណាម ប្រឆាំងនឹងកម្ពុជា (ភ្នំពេញ, ១៩៧៨) និងបញ្ជីជនរងគ្រោះ ដែលជាប់គុក និងសម្លាប់នៅមន្ទីរស-២១ ក្នុងរបប ប៉ុល ពត / អៀង សារី, អតីតវិទ្យាល័យទួលស្វាយព្រៃនៅក្រុងភ្នំពេញ (អត្ថបទវាយអង្គុលីលេខ, សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅទួលស្លែង, ភ្នំពេញ, គ្មានកាលបរិច្ឆេទ ។

៨ តាមបញ្ជីជនរងគ្រោះ... *(op. cit.)* ។

៩ ការវាយតម្លៃតាមបញ្ជីជនរងគ្រោះ... *(op. cit.)* និងការស្រាវជ្រាវរបស់លោក ស្ដេហ្វេន ហេដ័រ និងលោក ដេវីដ ហក ។

១០ ឯកសារចុះកាលបរិច្ឆេទថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៦, មានចំណងជើងថា “ចម្លើយរបស់ X ។ លើកទី មួយ :

ការសន្ទនាជាចំហអំពីបដិវាទកម្មនឹងក្រុងហាណូយ ស្ដីពីការជ្រើសរើសថ្ងៃខែឆ្នាំនៃការបង្កើតបក្ស, ១៩៥១ ឬ ១៩៦០ (ឯកសារនៅសារមន្ទីរទួលស្លែង), អត្ថបទបកប្រែរបស់លោក ស្ដេហ្វេន ហេដ័រ ។ ការរៀបរាប់ទាំងអស់ ដែលមានជាបន្ត គឺបានមកពីចម្លើយសារភាពទាំងនេះ ។

១១ បញ្ហានៃថ្ងៃខួបកំណើត គឺយកតាមលោក *David Chandler, "Revising the Past in Democratic Kampuche:a When Was the Birthday of the Party?", Pacific Affairs,* រដូវក្ដៅ ឆ្នាំ១៩៨៣ ។

១២ *David Chandler, A Revolution in Full Spate: Communist Party Policy in Democratic Kampuchea, December, 1976,* (អត្ថបទវាយអង្គុលីលេខ ដែលបង្ហាញជូននៅសន្និសីទព្រីនស៍តុន ស្ដីពីប្រទេសកម្ពុជា, ខែវិច្ឆិកា ឆ្នាំ១៩៨២) ។

១៣ *Ibid.*

១៤ ប្រវត្តិរបស់ ទ្រី ម៉េងហួត តាមការសម្ភាសន៍ដែលយល់ព្រមធ្វើជាមួយអ្នកនិពន្ធ ។

១៥ សម្ភាសន៍ដែលផ្ដល់ដល់អ្នកនិពន្ធ ។

១៦ *Ibid.*

១៧ *David Chandler, A Revolution in Full Spate (op. cit.)* ។

១៨ សេចក្ដីដកស្រង់ពីចម្លើយសារភាពរបស់ ហ៊ូ នឹម ដែលបោះពុម្ពផ្សាយក្នុងសៀវភៅ *"The Bureaucracy of Death: Documents from Inside Pol Pot's Torture Machine"* របស់លោក *Anthony Barnett, Ben Kierman, Chantou Boua, New Statement (Londres),* ថ្ងៃទី២ ខែឧសភា ឆ្នាំ១៩៨០ ។

១៩ តាមបទសម្ភាសន៍ដែលសម្រេចធ្វើឡើងដោយអ្នកនិពន្ធនៅខែកក្កដា ឆ្នាំ១៩៨១ ។

២០ លោក ហ្វ្រង់ ហ្វាណុង, គ្រូពេទ្យខាងចិត្តវិទ្យា កើតនៅកោះម៉ាទីនិក ដែលធ្វើការនៅប្រទេសអាល់ហ្សេរី និងបានក្លាយទៅជាបក្សព័ន្ធនៃការបដិវត្តន៍នៅទីនោះ ។ សៀវភៅ "ពួកអ្នករងទុក្ខខ្លាំងនៅលើផែនដី" របស់គាត់ ដែលអួតអំពីកសិករ និងការបដិវត្តន៍តាមរយៈការប្រើកម្លាំង បានជះឥទ្ធិពលទៅលើមនុស្សនិយមឆ្វេង និងអ្នកបដិវត្តន៍ជាច្រើន ក្នុងទសវត្សរ៍ ១៩៦០ ជាពិសេសនៅអាហ្វ្រិក និងអាមេរិកខាងត្បូង ។

២១ អ្វីៗដែលមានបន្តពីប្រវត្តិរបស់ កុម្មួត គឺយកតាមការជួបសម្ភាសជាច្រើនលើកដែលធ្វើឡើងដោយអ្នកនិពន្ធ ។

២២ អ្វីៗដែលមានបន្តពីប្រវត្តិរបស់ ផាត គឺយកតាមចម្លើយសារភាពរបស់គាត់ ។

២៣ សៀវភៅដែលរកឃើញនៅសារមន្ទីរទួលស្លែងដោយលោក ដេវីដ ហក និងបកប្រែដោយលោក ស្ដេហ្វេន ហេដ័រ ។

២៤ អ្នកបានឃើញ-បានដឹង-បានឮ នៅភូមិភាគនិរតី ដែលសម្ភាសដោយលោក ដេវីដ ហក និងអ្នកនិពន្ធ ។

## ជំពូកទី៨

១ សម្ភាសន៍ដែលព្រមផ្តល់ឲ្យអ្នកនិពន្ធនៅខែមករា ឆ្នាំ១៩៧៩ ។

២ សៀវភៅ "សាវតារនៃសង្គ្រាម... និងសេចក្តីសង្ឃឹម" របស់សម្តេច ព្រះនរោត្តម សីហនុ (Paris, Hachette - Stock, 1979) ។

៣ ចំនួនតួលេខ គឺយកតាមចម្លើយជាលាយលក្ខណ៍អក្សររបស់ ប៉ុល ពត ចំពោះសំណួរផ្សេងៗដែលចោទសួរដោយអ្នកនិពន្ធ និងលោក រីឆាដ ឌុដម៉ាន នៅទីក្រុងភ្នំពេញ នាខែធ្នូ ឆ្នាំ១៩៧៨ ។

៤ ការរៀបរាប់ពីផែនការ ៤ឆ្នាំ តាមសុន្ទរកថារបស់ ប៉ុល ពត, "យើងបន្តលើកជ្រោង...", ភ្នំពេញខែកញ្ញា ឆ្នាំ១៩៧៨ ។

៥ បទសម្ភាសន៍ដែលផ្តល់ឲ្យអ្នកនិពន្ធ, កម្ពុជាប្រជាធិបតេយ្យ, នៅខែធ្នូ ឆ្នាំ១៩៧៨ ។

៦ *Ibid.*

៧ ការវិភាគអំពីភូមិភាគបូព៌ា គឺយកតាម :

- សេចក្តីសង្ខេបនៃការកាត់ទោស (ដោយកំបាំងមុខ) ប៉ុល ពត និង អៀង សារី នៅខែសីហា ឆ្នាំ១៩៧៩ នៅភ្នំពេញ ដែលមានផ្សាយតាមវិទ្យុជាផ្លូវការ ។
- សៀវភៅ *"Wild Chickens, Farm Chickens and Cormorans"* របស់លោក Ben Kiernan, ក្នុងសៀវភៅ *"Revolution and Its Aftermath in Kampuche:a Eight Essays* របស់លោក David Chandler និង Ben Kiernan (New Haven, Yale University Southeast Asia Chronicle, No 64 (ខែកញ្ញា - ខែតុលា ឆ្នាំ១៩៧៨) ។
- ការសម្ភាសន៍នឹង ហែម សាមិន ដែលធ្វើឡើងដោយលោក ស្តេហ្វេន ហេដ័រ នៅខែកក្កដា ឆ្នាំ១៩៨១ ។
- ការម្ភាសន៍ជាមួយ ហ៊ុន សែន និង អ៊ុក ប៊ុនឈឿន ដែលធ្វើឡើងដោយអ្នកនិពន្ធនៅភ្នំពេញ, ឆ្នាំ១៩៨៣ ។
- ប្រវត្តិសាស្ត្របក្ស ។

៨ សម្ភាសន៍ដែលធ្វើឡើងដោយលោក ស្តេហ្វេន ហេដ័រ នៅខែសីហា ឆ្នាំ១៩៨០ ។

៩ ការវិភាគអំពីឥរិយាបថរបស់កម្ពុជាចំពោះប្រទេសវៀតណាម គឺយកតាមសៀវភៅដូចខាងក្រោម :

- *Cambodi:a The Search for Security* របស់លោក Michael Leifer (New York, Praeger, 1967) ។
- *Document on Border Issue* (ហាណូយ, ក្រសួងការបរទេសវៀតណាម, ថ្ងៃទី៧ ខែមេសា ឆ្នាំ១៩៧៨) ។
- *"Origins of the conflict"* របស់លោក ស្តេហ្វេន ហេដ័រ (op. cit.) ។

១០ *Stephen Heder, ibid.* ។

១១ សម្ភាសន៍ដែលធ្វើឡើងដោយលោក ស្តេហ្វេន ហេដ័រ ។

១២ សម្ភាសន៍ដែលអនុញ្ញាតឲ្យអ្នកនិពន្ធ ។

១៣ សម្ភាសន៍ដែលផ្តល់ឲ្យអ្នកនិពន្ធ ។

១៤ ការលើកសរសើរនេះ និងអ៊ីៗដែលមានបន្តមកទៀត គឺដកស្រង់ចេញពីសុន្ទរកថារបស់ ប៉ុល ពត «មហាជ័យជម្នះរបស់បដិវត្តន៍...», ខែកញ្ញា ឆ្នាំ១៩៧៧ ។

១៥ ការសម្ភាសន៍ដែលផ្តល់ឲ្យអ្នកនិពន្ធ ។

១៦ សម្ភាសន៍ដែលផ្តល់ឲ្យអ្នកនិពន្ធ ។

១៧ លោក ណាយ៉ាន់ ចាន់ដា ក្នុងទស្សនាវដ្តីសេដ្ឋកិច្ចចុងបូព៌ា (FEER) ខែកុម្ភៈ ឆ្នាំ១៩៧៨ ។

១៨ សម្ភាសន៍ដែលផ្តល់ឲ្យអ្នកនិពន្ធនៅខែវិច្ឆិកា ឆ្នាំ១៩៧៧ ។

១៩ តាមទីភ្នាក់ងារពត៌មានវៀតណាមថ្មី ។

២០ តាមវិទ្យុកម្ពុជាប្រជាធិបតេយ្យ ។

២១ ការរៀបរាប់អំពីការបោសសម្អាត និងការសម្លាប់ សោ ភឹម គឺយកតាមសៀវភៅ *"Wild Chicken..." (op. cit.)* របស់លោក *Ben Kiernan* ។

២២ ការសម្ភាសន៍ដែលផ្តល់ឲ្យអ្នកនិពន្ធនៅខែកក្កដា ឆ្នាំ១៩៧៩ ។

២៣ ចំនួនដែលអះអាងដោយលោក បេន ឃៀនិន, *op. cit.* ។

២៤ លោក ណាយ៉ាន់ ចាន់ដា ក្នុងទស្សនាវដ្តីសេដ្ឋកិច្ចចុងបូព៌ា, ឆ្នាំ១៩៧៩ ។

២៥ សុន្ទរកថា ប៉ុល ពត «យើងបន្ត...», ខែកញ្ញា ឆ្នាំ១៩៧៨ ។

២៦ សេចក្តីដកស្រង់ពីលិខិតផ្លូវការរបស់ពួកអ្នកកាសែតក្នុង *"Seven Days"*, ថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៧៨ ។

២៧ របាយការណ៍ពេញលេញនៃដំណើរនេះមានក្នុង *Robert Brown, The New Face of Kampuchea (Chicago, Liberator Press, 1979)* ។

២៨ ការកត់សម្គាល់ផ្សេងៗរបស់ ប៉ុល ពត ចំពោះលោក មៀវដាល់ និងគណៈប្រតិភូបែលហ្សិក គឺយកតាមការសម្ភាសន៍ដែលយល់ព្រមដោយ ប៉ុល ពត ចំពោះលោក ហ្សង់ មៀវដាល់ និង ប៉ុល ពត សន្ទនាជាមួយគណៈប្រតិភូសមាគមបែលហ្សិក-កម្ពុជា, ភ្នំពេញ, ខែសីហា ឆ្នាំ១៩៧៨ ។

២៩ តាមការសម្ភាសន៍ដែលផ្តល់ឲ្យអ្នកនិពន្ធ ដូចការលើកអ៊ីៗមកនិយាយជាសំអាងរបស់ ហាន តាវ ដែរ ។

៣០ សៀវភៅ «ឆ្ងាយហួសជើងមេឃ, ប្រាំឆ្នាំជាមួយពួកខ្មែរក្រហម» របស់អ្នកស្រី ឡូរ៉ង់ពិច *(Paris, Barrautt, 1984)* ។

៣១ *Ibid.*

៣២ រឿងដែលមានបន្តពីប្រវត្តិរបស់ ស៊ីសុផា គឺយកតាមការសម្ភាសន៍ដែលផ្តល់ឲ្យអ្នកនិពន្ធ ។

៣៣ សៀវភៅ «ការត្រឡប់មកភ្នំពេញវិញ, ប្រទេសកម្ពុជា : ពីអំពើប្រល័យពូជសាសន៍ទៅការតាំងជាអាណានិគម» របស់លោក អ៊ី ផាន់ដារា ។ ការធ្វើជាសាក្សី (អារម្ភកថា ដោយលោក *Jean Lacouture, Paris, A : M. Métailié,*

1982) ។ ការអះអាងបន្ថែមពីការផ្លាស់ប្តូររបៀបចាត់ចែងការងារដោយ ឡូវ៉ង់ពិច (op. cit.) និង ទ្រី ម៉េងហួត (សម្ភាសន៍ដែលផ្តល់ឲ្យអ្នកនិពន្ធនៅខែកក្កដា ឆ្នាំ១៩៧៩) ។

៣៨ ចម្លើយសារភាពរបស់ វ៉ន វ៉េត ដែលបកប្រែទៅជាភាសាអង់គ្លេស ដោយលោក ស្តេហ្វេន ហេដ័រ (ឯកសារនៅសារមន្ទីរទួលស្លែង) ។ តាមកម្មវិធីរបស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា, ឆ្នាំ១៩៧៨ ។

## ជំពូកទី៩

១ សូមអានសៀវភៅ : ហេតុការណ៍ផ្សេងៗ និងភស្តុតាងនៃអំពើឈ្លានពាន និងការក្តាប់ទឹកដីរបស់ប្រទេសវៀតណាម ប្រឆាំងនឹងកម្ពុជា (ភ្នំពេញ, ឆ្នាំ១៩៧៨) ដើម្បីឲ្យដឹងភាគល្អិតល្អន់ថែមទៀត ។

២ *Timothy Carney, Background to Cambodia - Vietnamese Relations* (ឯកសារវាយអង្គុលីលេខ, ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៧៨) ។

៣ ប្រវត្តិសាស្ត្ររបស់វៀតណាម គឺយកតាមសៀវភៅទាំងឡាយដូចខាងក្រោម :

- *Vietnam: A Dragon Embattled, Vol. 1 : From Colonialism to the Viet-Minh* របស់លោក *Joseph Buttinger (New York, Praeger, 1967)* ។
- បណ្តាប្រជាជននៅឧបទ្វីបឥណ្ឌូចិនរបស់លោក ហ្សង់ឈីណេស, *Paris, Dunod,* ឆ្នាំ១៩៦២ ។
- *A History of South-East Asia* របស់លោក *D.G.E. Hall (New York, St. Martin's Press,* ឆ្នាំ១៩៧០ ។

៤ *Timothy Carney, Background to Cambodia - Vietnamese Relations (op. cit)* ។

៥ ប្រវត្តិរបស់ ហូ ជីមិញ, លទ្ធិជាតិនិយម និងកុម្មុយនិស្តនិយមរបស់វៀតណាម គឺយកតាមសៀវភៅដូចខាងក្រោម :

- "ហូ ជីមិញ" របស់លោក ហ្សង់ ឡាគូទៀរ, ប៉ារីស, ឆ្នាំ១៩៦៨ ។
- *"Vietnamese Anticolonialism"* របស់លោក *David Marc (Berkely, University of California Press, 1971)* ។
- "លទ្ធិកុម្មុយនិស្តនិយម និងជាតិនិយមរបស់វៀតណាម" របស់លោក ព្យែរ រូសេត (ប៉ារីស, *Galilée,* ឆ្នាំ១៩៧៨) ។

៦ ព្យែរ រូសេត, *op. cit.,* ទំព័រ២០០-២០២ ។

៧ *Ibid.*

៨ ប្រវត្តិសាស្ត្របក្ស ។

៩ ទូរលេខជាផ្លូវការចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៥២ របស់គណៈកម្មការកិច្ចការបរទេស ។ *Echols Collection, Cornell University, Ithaca, New York* ។

១០ ប្រវត្តិសាស្ត្របក្សកុម្មុយនិស្តកម្ពុជា, *op. cit.* ។

១១ កម្មវិធីនយោបាយរបស់រណសិរ្សជាតិរំដោះវៀតណាមខាងត្បូង (ឆេកូស្លូវ៉ាគី, ឆ្នាំ១៩៦៧) ។

១២ សៀវភៅ *Chinese foreign Policy in an Age of Transition: The Diplomacy of Cultural Despair* របស់លោក *Ishwer C. Ojha (Boston, Beacon Press, 1971)* ។

១៣ *Elizabeth Becker, "The Chinese Invasion of Vietnam: Changing Alliances", Indochina Issues, No. 1,* ខែមីនា ឆ្នាំ១៩៧៩ ។

១៤ *Ishwer Ojha, op. cit.* ។

១៥ ការសម្ភាសន៍ដែលផ្ដល់ឲ្យអ្នកនិពន្ធនៅក្រុងហាណូយ, ឆ្នាំ១៩៧៩ ។

១៦ ហ្សង់ ឡាគូទៀរ, *op. cit.* ។

១៧ ចំនួនតួលេខ និងការរៀបរាប់ពីការខូចខាត គឺយកតាម ៖

- *The Endless War: Fifty Years of Struggle in Vietnam* របស់ *James Harrison (New York, Free Press, 1982).*
- *With Firm Steps: Southern Vietnam Since Liberation 1975-1977* (ហាណូយ, ការបោះពុម្ពផ្សាយជា ភាសាបរទេស, ឆ្នាំ១៩៧៩ ។
- *Alexandro Casella, "Dateline Vietnam: Managing the Peace", Foreign Policy,* និទាឃរដូវ ឆ្នាំ១៩៧៨ ។

១៨ ជម្លោះរវាងវៀតណាម-កម្ពុជា (ហាណូយ, ការបោះពុម្ពផ្សាយជាភាសាបរទេស, ឆ្នាំ១៩៧៩) ។

១៩ សៀវភៅខ្មៅ *(op. cit.)* ។

២០ *Harrison Salisbury, War between Russia and China (New York, W.W. Norton, 1969)* ។

២១ សៀវភៅខ្មៅ *(op. cit.)* ។

២២ ជម្លោះរវាងវៀតណាម-កម្ពុជា *(op. cit.)* ។

២៣ *Ibid.*

២៤ ប្រជាជនវៀតណាម ៩២៩.៦០០នាក់ បានភៀសខ្លួនទៅបរទេសនៅឆ្នាំ១៩៨៤ តាមការឲ្យដឹងរបស់អគ្គស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកជនភៀសខ្លួន ។ ពីររយហាសិបពាន់នាក់ទៀត ទំនងជាស្លាប់ក្នុងសមុទ្រ ។

២៥ *Van Tien Dugn, Our Great Spring Victory,* ការបកប្រែជាភាសាអាមេរិកាំងរបស់លោក *John Spragens Jr. (New York, Monthly Review Press, 1977)* ។

២៦ ការពិពណ៌នាពីទីក្រុងព្រៃនគរ ក្រោយសម័យសង្គ្រាម គឺយកតាមសៀវភៅផ្សេងៗដូចខាងក្រោម ៖

- *"The Fall of Saigon"* របស់លោក *James Fenton, Granta (Londres) No 15, 1985* ។
- *"Giai Phong : The Fall and Liberation of Saigon"* របស់លោក *Tiziano Terzani (New York, St. Martin's Press, 1976)* ។

- *With Firm Steps (op. cit.)* ។
- *Van Tien Dung, op. cit* ។ ។
- *"The Myth of a Liberation"* របស់ *Truong Nhu Tang, New York Review of Books,* ថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៨២ ។

២៧ សន្ទាត់អត្ថបទម្តុំនេះ និងអ្វីៗទាំងអស់ដែលមានតទៅទៀត ដែលផ្តោតទៅលើឥរិយាបថរបស់ប្រទេសវៀតណាម ក្រោយសម័យសង្គ្រាម គឺសំអាងលើការសម្ភាសន៍ដែលយល់ព្រមផ្តល់ដល់អ្នកនិពន្ធ ដោយមន្ត្រីជួរការបារាំងម្នាក់ដែលប្រាថ្នាលាក់អនាមិកភាពរបស់ខ្លួន ។

២៨ *Troung Nhu Tang, op. cit.* ។

២៩ *Tiziano Terzani, op. cit.* ។

៣០ *Ibid.*

៣១ *Hoang Nguyen* ដែលធ្វើសម្ភាសដោយអ្នកនិពន្ធនៅក្រុងហាណូយ ឆ្នាំ១៩៨៣ ។

៣២ ការសម្ភាសន៍ដែលផ្តល់ឲ្យអ្នកនិពន្ធ ។

៣៣ សម្ភាសន៍ដែលយល់ព្រមនឹងអ្នកនិពន្ធ នៅក្រុងហាណូយ ឆ្នាំ១៩៧៩ ។

៣៤ ចំនួនតួលេខនៃផលិតផលស្រូវ, អតិផរណា និងការខ្វះខាតស្រូវ គឺស្រង់ចេញពីអត្ថបទ : "ប្រទេសវៀតណាមប្រឹងប្រែងបន្តការអភិវឌ្ឍន៍ : ការសន្យាធ្វើសង្គមនិយម, វិបត្តិភ័យពីគ្រោះធម្មជាតិ និងការហាត់រៀនជាអចិន្ត្រៃយ៍", វប្បធម៌ និងការអភិវឌ្ឍន៍ (សាកលវិទ្យាល័យកាតូលិកលូវ៉ាំង, បែលហ្ស៊ិក, ឆ្នាំ១៩៧៩) ។

៣៥ *Vietnam: A Socialist Economy in Transition,* របាយការណ៍សម្ងាត់របស់ធនាគារពិភពលោក, ថ្ងៃទី៥ ខែមីនា ឆ្នាំ១៩៨០, ភាគទី១, ទំព័រ១៥ ។

៣៦ ការសម្ភាសន៍ដែលផ្តល់ដល់អ្នកនិពន្ធនៅក្រុងហាណូយ នៅឆ្នាំ១៩៧៩ ។

៣៧ សេចក្តីរាយការណ៍អំពីរបសកម្មនៅសាធារណរដ្ឋសង្គមនិយមវៀតណាម, អង្គការលើកលែងទោសអន្តរជាតិ, ទីក្រុងឡុងដ៍, ឆ្នាំ១៩៨១ ។

៣៨ *Duyen Anh* ដែលធ្វើសម្ភាស៍ដោយ ឡិក ហោតាន់ ក្នុង *Index on Censorship,* ទីក្រុងឡុងដ៍, ខែមីនា ឆ្នាំ ១៩៨៤ ។

៣៩ ការសម្ភាសន៍ដែលផ្តល់ដល់អ្នកនិពន្ធ នៅក្រុងហាណូយ នៅឆ្នាំ១៩៧៩ ។

៤០ ការសម្ភាសន៍ដែលផ្តល់ដល់អ្នកនិពន្ធ នៅក្រុងហាណូយ នៅឆ្នាំ១៩៧៩ ។

៤១ ការវិភាគអំពីបញ្ហាជនជាតិភាគតិចចិន និងការស្រាវជ្រាវករណីនេះ គឺយកតាម :

- ឯកសារវាយអង្គលីលេខ *The Chinese Community in North Vietnam : Comrades in Confrontation (1979)* របស់លោក *Alexandro Casella* និង *Paul Quinn-Judge,* ការធ្វើសម្ភាសន៍អ្នកភៀសខ្លួនជាបន្តបន្ទាប់នៅទីក្រុងហុងកុង ពីថ្ងៃទី៤ ដល់ថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៧៩, ក្នុងនាមនៃអង្គការ *American Friends Service Committee* (ឯកសារវាយ

អន្តុលីលេខ) ។ ការសិក្សាពីករណីនេះ គឺមួយផ្នែកធំដកស្រង់ចេញពីអត្ថបទរបស់លោក *Casella* ។

៤២ *Alexandro Casella, The Chinese community in North Vietnam (op. cit.)* ។

៤៣ *Elizabeth Baker, "The Chinese Invasion of Vietnam" (op. cit.)* ។

## ជំពូកទី១០

១ អេលីហ្សាបែត បើកខ័រ, កាសែតវ៉ាស៊ីនតោនប៉ុស្ត៍, ឆ្នាំ១៩៧៥ ។

២ ពីមុន, អាហារូបករណ៍ជាច្រើនរបស់ក្រសួងការពារប្រទេស បានជំរុញឲ្យមានការសិក្សាស្រាវជ្រាវពីឥណ្ឌូចិន ។ សូមអានអត្ថបទ *"Cambodian Tragedy", Problems of Communism* របស់អ្នកស្រី អេលីហ្សាបែត បើកខ័រ, ខែឧសភា-មិថុនា ឆ្នាំ១៩៨៤ ។

៣ អត្ថបទមុំៗស្តីពីសមាគមអាស៊ាន គឺយកតាមការធ្វើសម្ភាសន៍អ្នកការទូតជាច្រើនរបស់ប្រទេសទាំងនេះ និងការយកពត៌មានផ្សេងៗនៅជំនាន់នោះ ។

៤ ផ្នែកស្តីពីប្រទេសឡាវ គឺដកស្រង់តាមអត្ថបទ *"Laos : The Widening Indochina Conflict"* របស់អ្នកស្រី អេលីហ្សាបែត បើកខ័រ, *Indochina Issues, No 2* (ខែមិថុនា ឆ្នាំ១៩៧៩) ។

៥ សម្ភាសន៍ដែលយល់ព្រមផ្តល់ឲ្យអ្នកនិពន្ធ ។

៦ ការរៀបរាប់អំពីចលនាសន្តិភាពនិយមក្រោយឆ្នាំ១៩៧៥ គឺធ្វើតាមការកត់សម្គាល់ផ្សេងៗរបស់អ្នកនិពន្ធ និងការសន្ទនាជាមួយសកម្មជនជាច្រើននាក់ ។

៧ ការលើករៀបរាប់ទាំងអស់របស់ ខូវ៉ា វើស សុទ្ធតែដកស្រង់ចេញពីការធ្វើសម្ភាសន៍ដែលយល់ព្រមផ្តល់ដល់អ្នកនិពន្ធ នៅខែកក្កដា ឆ្នាំ១៩៨៣ ។

៨ ការលើករៀបរាប់ទាំងអស់របស់ ហ្វូអេនបាអេ គឺស្រង់ចេញពីការធ្វើសម្ភាសន៍ដែលព្រមផ្តល់ដល់អ្នកនិពន្ធ នៅខែតុលា ឆ្នាំ១៩៨២ ។

៩ ការរៀបរាប់ទាំងអស់របស់ ឡេអូណារដ៍ វូដខូក គឺដកស្រង់ពីបទសម្ភាសន៍ ដែលផ្តល់ដល់អ្នកនិពន្ធ នៅខែធ្នូ ឆ្នាំ១៩៨១ ។

១០ ការបកស្រាយរបស់ ដាន់ ហៀន អំពីការចរចា គឺយកតាមបទសម្ភាសន៍ដែលផ្តល់ដល់អ្នកនិពន្ធ នៅក្រុងហាណូយ នៅឆ្នាំ១៩៨៣ ។ ការបកស្រាយរបស់ ឡេអូណារដ៍ វូដខូក តាមការធ្វើសម្ភាសន៍ ដែលយល់ព្រមផ្តល់ឲ្យអ្នកនិពន្ធ ។

១១ ការសម្ភាសន៍សមាជិកម្នាក់នៃក្រុមការងារ ដែលប្រាថ្នាឲ្យលាក់អនាមិកភាព ។

១២ ការយល់ឃើញ និងការរៀបរាប់ទាំងឡាយរបស់ ហូលប្រ៊ុក គឺដកស្រង់ពីការសម្ភាសន៍ដែលធ្វើឡើងជាមួយ

អ្នកនិពន្ធនៅខែធ្នូ ឆ្នាំ១៩៨៣ ។

១៣ ហូលប្រ៊ុក និង ផាន់ ហៀន បានអះអាងបន្ថែមទៅវិញ ទៅមកនូវការបកស្រាយពីការចរចាររបស់គេ នៅទីក្រុងប៉ារីស ក្នុងការធ្វើសម្ភាសន៍ជាមួយអ្នកនិពន្ធដាច់ដោយឡែកពីគ្នា ។

១៤ សម្ភាសន៍ដែលយល់ព្រមធ្វើជាមួយអ្នកនិពន្ធ ។

១៥ ការបរិយាយរឿងរបស់ ស្តេហ្វេន សូឡា និងការរៀបរាប់ទាំងឡាយ គឺយកតាមបទ សម្ភាសន៍ដែលយល់ព្រមធ្វើជាមួយអ្នកនិពន្ធ នៅខែសីហា ឆ្នាំ១៩៨២ ។

១៦ ការពិភាក្សាតទល់រវាង ប្រ៊ីហ្សីនស្គី - ស៊ីរុសវ៉ាន់ស៍ ស្តីពីនយោបាយអាមេរិកាំងនៅអាស៊ី គឺពឹងផ្អែកជាសំអាងលើពត៌មានផ្សេងៗដែលផ្សាយចេញនៅជំនាន់នោះ ព្រមទាំងលើការធ្វើសម្ភាសន៍ដែលព្រមផ្តល់ឲ្យអ្នកនិពន្ធ ដោយមនុស្សពីរនាក់ (ម្នាក់នៅខែកក្កដា និងម្នាក់ទៀត នៅខែវិច្ឆិកា ឆ្នាំ១៩៨១) និងដោយបណ្តាសហការីរបស់គាត់ រីឆាដ ហូលប្រ៊ុក (នៅខែមេសា ឆ្នាំ១៩៨១ និងខែវិច្ឆិកា ឆ្នាំ១៩៨៣), ម៉ៃខឹល អូកសេនបឹក (នៅខែវិច្ឆិកា ឆ្នាំ១៩៨១) និង រ៉ូប៊ឺតអូកលី (នៅខែធ្នូ ឆ្នាំ១៩៨១) ផង ។ ការរៀបរាប់ទាំងអស់ - លើកលែងតែពត៌មានផ្ទុយ- សុទ្ធតែដកស្រង់ចេញពីការធ្វើសម្ភាសន៍ទាំងនេះ ។

១៧ បទអន្តរាគមន៍របស់ ស៊ីរុសវ៉ាន់ស៍ នៅ *Asia Society* នៅក្រុងញូវយ៉ក, ឆ្នាំ១៩៧៧ ។

១៨ ទូរលេខដែលអ្នកនិពន្ធមានមធ្យោបាយយកបាន ដោយសារប្រភពពត៌មានផ្សេងៗ ដែលចេញពីរដ្ឋាភិបាល ។

១៩ ការយកពត៌មានដែលបំពេញដោយអ្នកនិពន្ធនៅជំនាន់នោះ ហើយដែលមួយផ្នែកបានចេញផ្សាយក្នុងកាសែតវ៉ាស៊ីនតោនប៉ុស្តិ៍ នៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ១៩៧៨ ។

២០ សូមអានសារណារបស់លោក ខាធ័រ និង ប្រ៊ីហ្សីនស្គី :

- “អនុស្សាវរីយ៍របស់ប្រធានាធិបតីម្នាក់” របស់លោក ជីមមីខាធ័រ, *Paris, Plon,* ឆ្នាំ១៩៨៤ ។
- *“Power and Principe : Memoirs of the National Security Advisor 1977-1981”* របស់លោក ប៊ីកញូ ប្រ៊ីហ្សីនស្គី *(New York, Farrar, Straus & Giroux, 1983)* ។

២១ ការរៀបរាប់ពីការចរចាតាមការធ្វើសម្ភាសន៍នានា ដែលព្រមផ្តល់ដល់អ្នកនិពន្ធដោយ វៀន កូថាប់, រីឆាដ ហូលប្រ៊ុក និង ម៉ៃខឹល អូកសេនបឹក ។

២២ ការម្ភាសន៍ដែលធ្វើឡើងដោយអ្នកនិពន្ធនៅខែធ្នូ ឆ្នាំ១៩៨១ ។

២៣ តាមចម្លើយជាលាយលក្ខណ៍អក្សររបស់លោក ជីមមី ខាធ័រ តបនឹងលិខិតសួររបស់អ្នកនិពន្ធដែលធ្វើឲ្យពិស្តារក្នុងសារណា នៃអតីតប្រធានាធិបតី *(op. cit.)* ។

២៤ កាលប្បវត្តិនេះ គឺសំអាងលើអត្ថបទផ្សេងៗដែលចេញផ្សាយនៅសម័យនោះ ជាពិសេសក្នុងទស្សនាវដ្តីសេដ្ឋកិច្ចចុងបូព៌ា *(Far Eastern Economic Review)* ។

## ជំពូកទី១១

១ ជំពូកដែលមានបន្តមកទៀត គឺផ្អែកលើកំណត់ខ្លីៗ និងរូបថតជាច្រើនដែលថតដោយអ្នកនិពន្ធ នៅក្នុងរយៈពេលនៃដំណើរពីរសប្តាហ៍របស់ខ្លួននៅកម្ពុជាប្រជាធិបតេយ្យ នាខែធ្នូ ឆ្នាំ១៩៧៨ ។

## ជំពូកទី១២

១ សម្ភាសន៍ដែលយល់ព្រមផ្តល់ឲ្យអ្នកនិពន្ធ នៅខែតុលា ឆ្នាំ១៩៨០ ។

២ សម្ភាសន៍ដែលយល់ព្រមផ្តល់ឲ្យអ្នកនិពន្ធ នៅខែមករា ឆ្នាំ១៩៧៩ ។

៣ សម្ភាសន៍ដែលយល់ព្រមផ្តល់ឲ្យអ្នកនិពន្ធ នៅខែកក្កដា ឆ្នាំ១៩៨១ ។

## ជំពូកទី១៣

១ ក្រសួងការបរទេសរបស់សហភាពសូវៀតបានសួរសំណួរទៅ អ៊ីហ៊ុីរ រ៉ូហ្កាឆូវ... នេះ និងឯកសាររបស់ រ៉ូហ្កាឆូវ ទាំងអស់ និងពាក្យសម្តីដកស្រង់ផ្ទាល់ទាំងអស់គឺផ្អែកលើបទសម្ភាសរបស់អ្នកនិពន្ធជាមួយ រ៉ូហ្កាឆូវ នៅទីក្រុងប៉ារីស នៅថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩១ និងនៅទីក្រុងញូយ៉ក នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩២ ។

២ ភាសាចិនដែលគាត់និយាយគឺ "ពិសេសមែនទែន ហើយនិងពិរោះមែនទែន" ។ បទសម្ភាសនៅទីក្រុងវ៉ាស៊ីនតោន ឌី.ស៊ី. ជាមួយ Yassen N. Zassoursky ដែលជាព្រឹទ្ធបុរសរបស់មហាវិទ្យាល័យសារពត៌មានវិទ្យានៅសាកលវិទ្យាល័យម៉ូស្គូ ។

៣ វ៉យ មានអារម្មណ៍ថាងាយស្រួលធ្វើទំនាក់ទំនងជាមួយ រ៉ូហ្កាឆូវ ណាស់... បទសម្ភាសរបស់អ្នកនិពន្ធជាមួយស្តេបភ្លីលថុន វ៉យ នៅទីក្រុងវ៉ាស៊ីនតោនឌីស៊ី នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ១៩៩១ ។

៤ "គាត់ត្រូវបានកត់សម្គាល់ដោយសារការគិតបែបមិនទាក់ទងទៅនឹងសាសនា និងដោយសារភាពទន់ភ្លន់...." ។ បទសម្ភាសរបស់អ្នកនិពន្ធជាមួយ Yevgniy V. Afansyev នៅថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ១៩៩១ ។

៥ ចាប់តាំងពីអាយុ១៦ឆ្នាំ នៅពេលដែលគាត់បោះបង់ការរៀនសូត្រនៅថ្នាក់វិទ្យាល័យ... លុះត្រាណាតែនិយាយម្យ៉ាងទៀត រាល់ពាក្យសម្តីដកស្រង់ផ្ទាល់ និងឯកសារប្រវត្តិរូបរបស់ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ទាំងអស់ គឺសម្អាងទៅលើបទសម្ភាសរបស់អ្នកនិពន្ធនៅ ទីក្រុងភ្នំពេញនៅថ្ងៃទី០៨ ខែមករា ឆ្នាំ១៩៨៣, នៅទីក្រុងស័សសុងរបស់ប្រទេសបារាំង នៅថ្ងៃទី១០ ខែវិច្ឆិការ ឆ្នាំ១៩៨៨, នៅទីក្រុងភ្នំពេញ នៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៨៩, នៅទីក្រុងប៉ារីស នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៨៩ និងថ្ងៃទី៣០ ខែសីហា ឆ្នាំ១៩៨៩, នៅទីក្រុងភ្នំពេញ នៅថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៩២ ។

៦ គាត់បាននិយាយថា "ខ្ញុំមានសំណាង" ។ បទសម្ភាសរបស់អ្នកនិពន្ធ នៅឆ្នាំ១៩៨៣ ។

៧ ដូច្នេះ គាត់បានឡើងជិះយន្តហោះនៅវត្តនាគវ័ន្ត... បទសម្ភាសរបស់អ្នកនិពន្ធ នៅខែមីនា ឆ្នាំ១៩៨៩ ។

៨ "...គ្រោះថ្នាក់មិនមែនត្រឹមតែនៅក្នុងទ្វីបអាស៊ីទេ ប៉ុន្តែពីទ្វីបអាស៊ីទៅកាន់ពិភពលោក" ។ សម្តេច ព្រះនរោត្តម សីហនុ, អ្នកនិពន្ធ, "Sihanouk Center Stage," *Washington Post* ថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៧៩ ។

៩ "ឆាកជីវិតរបស់ខ្ញុំគឺជារឿងដ៏យស្រឡះ..." នៅក្នុងអត្ថបទខាងលើដដែល ។

១០ នៅក្នុងកាយវិការផ្ទុយខុសពីធម្មតា... Nayan Chanda, *Brother Enemy: The War After the War* (San Diego: Harcourt, Brace, Jovanovich, 1986), p. 365 ។

១១ "យើងបានប្រាប់គាត់" ។ អ្នកនិពន្ធសម្ភាសជាមួយ រីឆាដ ហូលប្រុក នៅឆ្នាំ១៩៨៣ ។

១២ "នៅខែមករា ឆ្នាំ១៩៩៧ ក្នុងទីក្រុងញូយ៉ក ខ្ញុំទទួលស្គាល់ថាខ្លួនខ្ញុំគួរឲ្យអាណិតដូច Job ដែរ ..." *Souvenirs doux et amers* ។

១៣ "បើពិនិត្យមើលអំពីការគ្រប់គ្រងជាមុនរបស់រដ្ឋាភិបាលវៀតណាមជាមួយបញ្ហាសុវត្ថិភាព..." ។ បទសម្ភាសរបស់អ្នកនិពន្ធជាមួយ Robert B. Oakley នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៧៩ ។

១៤ "គ្មានផ្លូវដែលលោកអាចទទួលបាន..." ។ អ្នកនិពន្ធសម្ភាសជាមួយ រីឆាដ ហូលប្រុក នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៣ ។

១៥ ប្រទេសកម្ពុជានៅតែនៅបាតតារាងដដែល... ។ សូមមើល Eva Mysliwiec, *Punishing the Poor: The International Isolation of Kampuchea* (Oxford: Oxfam Publishers, 1988), p. 77 ។

១៦ "ខ្ញុំមានយល់សប្តិអាក្រក់មួយ..." ។ អ្នកនិពន្ធសម្ភាសជាមួយសម្តេច ព្រះនរោត្តម សីហនុ, *Washington Post* ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ១៩៨០ ។

១៧ នៅអាយុ៣៥ឆ្នាំ កួត ម៉ាទីន នៅក្មេង... ។ នេះ និងរាល់ពាក្យសម្តីដកស្រង់និងពត៌មានទាំងអស់ដែលពាក់ព័ន្ធនឹង កួត ម៉ាទីនគឺផ្អែកលើបទសម្ភាសរបស់អ្នកនិពន្ធដែលធ្វើនៅទីក្រុង ប៉ារីស នៅខែវិច្ឆិកា ឆ្នាំ១៩៨៩ នៅខែកក្កដា ឆ្នាំ១៩៩០ និងនៅខែធ្នូ ឆ្នាំ១៩៩១ ហើយនិងផ្អែកលើលិខិត និងការសន្ទនាតាមទូរសព្ទពីទីក្រុងប៉េកាំង នៅខែវិច្ឆិកា ឆ្នាំ១៩៩០ និងខែកក្កដា ឆ្នាំ១៩៩២ និងពីទីក្រុងហុងកុង នៅខែឧសភា ឆ្នាំ១៩៩១ ។

១៨ ផ្អែកលើឯកសារជាសារពត៌មាន និងបទសម្ភាសរបស់អ្នកនិពន្ធនៅតាមព្រំដែន ។

១៩ "នៅទីនេះ មានការចំណាយជ្រុល ដោយគ្មានការសង្ស័យឡើយ" ។ បទសម្ភាសរបស់ អ្នកនិពន្ធ *Washington Post* នៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ១៩៨១ ។

២០ ការពិពណ៌នាអំពីទីក្រុងភ្នំពេញ ដោយផ្អែកលើ William Shawcross, *The Quality of Mercy: Cambodia, Holocaust and Modern Conscience* (New York: Simon & Schuster, 1984) ។

២១ សូមមើល Report of the International Conference on Kampuchea, New York: United Nations, July 13-17, 1981 ។

២២ “ការទូតបែប ស្តេចភ្លីលថុន រ៉យ” ។ បទសម្ភាសរបស់អ្នកនិពន្ធ នៅខែតុលា ឆ្នាំ១៩៨៤ ។

២៣ សម្តេច ព្រះនរោត្តម សីហនុ បានអញ្ជើញអ្នកប្រជាធិបតេយ្យមកពីទីក្រុងប្រូកគ្លីន... អ្នកនិពន្ធសម្ភាសជាមួយ Stephen Solarz នៅខែកក្កដា ឆ្នាំ១៩៩១ ។

២៤ លោកស្រី Griffith បាននិយាយថា “យើងបាននិយាយច្បាស់ហើយ” ។ អ្នកនិពន្ធសម្ភាស ជាមួយ Ann Mills Griffith នៅខែឧសភា ១៩៩១ ។

២៥ នៅពេលដែល ហ្គោបាឆូវ កាន់អំណាច... ឯកសារនេះពឹងផ្អែកទាំងស្រុងលើ Michael Dobbs, *Down with Big Brother, The Fall of the Soviet Empire (New York: Alfred A. Knopf, 1997)* ។

២៦ មីខាអ៊ីល ហ្គោបាឆូវ ធ្វើដំណើរទៅកាន់ទីក្រុងកំពង់ផែ Vladivostok... *Vital Speeches of the Day, pp. 706-11* ។

២៧ កាលប្បវត្តិដែលផ្អែកលើឯកសារជាសារពត៌មានពី *New York Times, Washington Post, Bangkok Post,* and Patrick Raszelenberg and Peter Schier, *The Cambodia Conflict: Search for a Settlement, 1979-1991, an Analytical Chronology* (Hamburg: Mitteilungen des Instituts für Asienkunde, 1995) ។

២៨ “យើងវិភាគដោយស្មោះត្រង់ និងទទួលស្គាល់យ៉ាងក្លាហាន...” Asia 1988 Yearbook, *Far Eastern Economic Review,* p.252 ។

២៩ “លោករ៉ូហ្គាឆូវ គឺសំខាន់បំផុតសម្រាប់ខ្ញុំ...” ។ នេះ និងពាក្យសម្តីដកស្រង់បន្តបន្ទាប់គឺ ពឹងផ្អែកលើបទសម្ភាសរបស់អ្នកនិពន្ធនៅទីក្រុងប៉ារីស នៅឆ្នាំ១៩៨៩ និង១៩៩១, នៅទីក្រុងភ្នំពេញ នៅឆ្នាំ១៩៨៩ និងឆ្នាំ១៩៩១ និងនៅទីក្រុងវ៉ាស៊ីនតោន នៅឆ្នាំ១៩៩១ ។

៣០ មានខ្សែទំនាក់ទំនងផ្ទាល់ខ្លួនផងដែរ... ហេតុការណ៍នៃរឿងនេះគឺពឹងផ្អែកលើបទសម្ភាសរបស់អ្នកនិពន្ធជាមួយ Jean-Jacques និង Khek Galabru នៅទីក្រុងប៉ារីស ក្នុងឆ្នាំ១៩៨៩ និង១៩៩០ និងឯកសារចម្លងរបស់ទូរលេខចំនួន១៨ រវាងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងសម្តេច ព្រះនរោត្តម សីហនុ ។

៣១ ផ្អែកលើការយកពត៌មានរបស់អ្នកនិពន្ធជុំវិញកិច្ចប្រជុំពីររវាងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងសម្តេច ព្រះនរោត្តម សីហនុ ។

៣២ នៅក្នុងបទសម្ភាសសរសេរដ៏វែងមួយ... ។ បទសម្ភាសរបស់អ្នកនិពន្ធ នៅខែកក្កដា ឆ្នាំ១៩៨៨ ។

៣៣ លោក ឆាទីឆៃ ឈុនហាវ៉ាន បានប្រាប់ទីប្រឹក្សាក្មេងទាំងពីនេះ... ។ អ្នកនិពន្ធសម្ភាសជាមួយលោក ឆាទីឆៃ ឈុនហាវ៉ាន, Kraisak Choonhaven, និង Pansak Vinyaratn, នៅទីក្រុងបាងកក នៅឆ្នាំ១៩៩០, ហើយពាក្យសម្តីដកស្រង់ផ្សេងទៀតពី Pansak គឺពឹងផ្អែកលើបទសម្ភាសរបស់អ្នកនិពន្ធនៅក្នុងទីក្រុងប៉ារីស នៅឆ្នាំ១៩៨៩ នៅក្នុងទីក្រុងបាងកក និងទីក្រុងវ៉ាស៊ីនតោន នៅឆ្នាំ១៩៩១ ។

៣៤ ដំណើរទស្សនះកិច្ចរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ផ្អែកលើសេចក្តីរាយការណ៍ តាមសារពត៌មានពី

*Bangkok Post* និង *The Nation (Bangkok)* ។

៣៥ ឯកសារពី James A. Baker III, *The Politics of Diplomacy, Revolution, War and Peace 1989-1992* (New York: G. P. Putnam's Sons, 1995), pp. 72-83 ។

៣៦ ឯកសារជាសារពត៌មាន និង Dobbs, *Down with Big Brother* ។

៣៧ ឯកសារជាសារពត៌មាន និង Donald Morrison, ed., *Massacre in Beijing: China's Struggle for Democracy* (New York: Times, Inc., 1989) ។

៣៨ ផ្អែកលើការយកសារពត៌មានរបស់អ្នកនិពន្ធនៅក្នុងព្រឹត្តិការណ៍ និងឯកសារដូវការរបស់សន្និសីទនៅទីក្រុងបារីស ។

៣៩ កិច្ចប្រជុំជាមួយ Nguyen Co Thach និង General John W. Vessey, Jr. ដែលផ្អែកលើ បទសម្ភាសរបស់អ្នកនិពន្ធជាមួយ Vessey នៅទីក្រុងវ៉ាស៊ីនតោនឌីស៊ី នៅឆ្នាំ១៩៩១ ។

៤០ នៅឯកិច្ចប្រជុំ សូឡូម៉ូន បានប្រាប់ ក្វូត ម៉ាទីន អំពីផែនការរបស់ បេកគ័រ... រាល់ពាក្យសម្ដីដកស្រង់ទាំងអស់ពីរីឆាត សូឡូម៉ូន និងរបាយការណ៍អំពីកិច្ចប្រជុំការទូតរបស់គាត់ដែលផ្អែកលើបទសម្ភាសរបស់អ្នកនិពន្ធ នៅឆ្នាំ១៩៩១ និងឆ្នាំ១៩៩២ ។

៤១ នៅថ្ងៃទី២ ខែមករា ឆ្នាំ១៩៩០ រដ្ឋមន្ត្រីក្រសួងការបរទេស James Baker បានផ្ញើរលិខិតមួយ... ។ ដោយផ្អែកលើកំណត់ហេតុឯកជនរបស់មន្ត្រីអាមេរិកជាន់ខ្ពស់ម្នាក់ដែលបានចូលរួមនៅក្នុងកិច្ចចចារទាំងនេះ ។

៤២ គំនិតក្នុងការកោះប្រជុំសមាជិកអចិន្ត្រៃយ៍របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ។ បទសម្ភាសជាមួយ សូឡូម៉ូន និង ចន បូលតុន ។

៤៣ ការរៀបរាប់អំពីកិចប្រជុំរបស់សមាជិកអចិន្ត្រៃយ៍ទាំង៥ របស់អង្គការសហប្រជាជាតិ ដែលផ្អែកលើបទសម្ភាសជាមួយ សូឡូម៉ូន, រ៉ូហ្កាឆូវ, ម៉ាទីន, បូលតុន និងកំណត់ហេតុរបស់មន្ត្រីម្នាក់ដែលមិនស្គាល់ឈ្មោះ ។

៤៤ "មានមនុស្សមួយក្រុមនៅក្នុងជួររដ្ឋបាល..." ។ បទសម្ភាសរបស់អ្នកនិពន្ធជាមួយ Robert Kimmit, នៅទីក្រុងវ៉ាស៊ីនតោន ឌី.ស៊ី. នៅខែធ្នូ ឆ្នាំ១៩៩០ ។

## ឧបសម្ព័ន្ធស្តីពីឯកសារផ្សេងៗនៅសារមន្ទីរទួលស្លែង (អតីតមន្ទីរស-២១)

*ក្នុងជំពូកទីបី ខ្ញុំបានរៀបរាប់ពីប្រវត្តិរបស់ ប៊ូ ផាត់ ដែលគេស្គាល់ក្រោមឈ្មោះថា ផាត់ ហៅ ហង្ស ដោយដកស្រង់ចេញពីឯកសារទាំងមូលរបស់គាត់ ដែលមាននៅសារមន្ទីរទួលស្លែង ។ កន្លែងនេះ បានក្លាយទៅជាសារមន្ទីរមួយ និងជាបណ្ណាល័យមួយ ដែលមានតម្កល់សំណុំឯកសារអតីតអ្នកទោស ចំនួនដប់ពាន់នាក់ ដូចជា ប៊ូ ផាត់ ជាដើម ព្រមទាំងឯកសារប្រវត្តិសាស្ត្រផ្សេងៗទៀតស្តីពីរបបខ្មែរក្រហម ។*

*សំណុំឯកសារទាំងនោះ រួមផ្សំបានជាប្រភពពត៌មានមួយ ដែលមិនអាចកាត់ថ្លៃបាន ស្តីពីប្រវត្តិសាស្ត្ររបស់ខ្មែរក្រហម ។ ឯកសារទាំងអស់នេះ មានចំណុចសំខាន់ៗជាច្រើនសម្រាប់ផ្សំផ្គុំឡើងវិញ នូវការជម្លោះទាំងឡាយ ដែលមានលក្ខណៈបត់បែនស្មុគស្មាញ និងអាថ៌កំបាំងនៅផ្ទៃក្នុងបក្ស មុននិងក្រោយការឈានឡើងកាន់អំណាចរបស់ខ្មែរក្រហម ដើម្បីយល់ដឹងពីប្រការដែលបក្សបានកាន់កាប់អំណាចនេះតាមមធ្យោបាយណា និងវែកញែកពីការបំផ្លិចបំផ្លាញប្រទេសផង ។*

*ប៉ុន្តែសំណុំរឿងសម្រាប់ផ្គុំឡើងនេះ ត្រូវបានរាយការណ៍ដោយប្រុងប្រយ័ត្ន និងប្រៀបធៀបទៅនឹងឯកសារប្រវត្តិសាស្ត្រដទៃៗទៀត ។ សំណុំរឿងរបស់អ្នកទោសម្នាក់ គឺមានផ្នែកខុស និងផ្នែកត្រូវផង ។ ជីវប្រវត្តិដំបូងដែលសរសេរដោយអ្នកទោសម្នាក់ ជាទូទៅ គឺច្រើនតែនិយាយត្រង់អស់ពីដួងចិត្ត ព្រោះនៅពេលនោះ អ្នកទោសនៅតែជឿថា ខ្លួនអាចមានភ័ព្វសំណាងត្រូវគេដោះលែងឲ្យមានសេរីភាពវិញ ។ ហើយនៅពេលដែលគេនិយាយរៀបរាប់ពីជីវិតផ្ទាល់របស់គាត់ ដូចដែលគេសួរនាំនោះ គាត់ខំប្រឹងបង្ហាញឲ្យឃើញពីភាពគ្មានទោសពៃរ៍របស់គាត់ជានិច្ច ហើយបដិសេធចោលការចោទប្រកាន់ផ្សេងៗ ដែលពួកអ្នកត្រួតត្រាគុកបានចោទទម្លាក់មកលើគាត់ទៀតផង ។ ក្រោយមក បន្ទាប់ពីការធ្វើទារុណកម្ម ការគំរាមកំហែង ប្រឆាំងនឹងគ្រួសារ និងបណ្តាមិត្តភក្តិរបស់គាត់ អ្នកទោសក៏ព្រមចុះចាញ់ ហើយសារភាពពីអំពើឧក្រិដ្ឋផ្សេងៗ ដែលគាត់ពុំដែលបានប្រព្រឹត្តទាល់តែសោះ ។*

*ចម្លើយសារភាពទាំងអស់សុទ្ធតែសរសេរជាភាសាខ្មែរ លើកលែងតែចម្លើយសារភាពរបស់អ្នកទោសបរទេសមួយចំនួនចេញ ដែលមិនសូវមានផលប្រយោជន៍ខាងប្រវត្តិសាស្ត្រប៉ុន្មានឡើយ ។ ភាសាដែលអ្នកទាំងនោះប្រើប្រាស់ មានលក្ខណៈពិបាកយល់ណាស់សម្រាប់ប្រជាជនកម្ពុជាធុនមធ្យម ពីព្រោះវាទាមទារនូវការចេះដឹងមួយខាងផ្នែកវាក្យស័ព្ទ ដែលបញ្ចូលដោយពួកខ្មែរក្រហម នូវឈ្មោះមនុស្ស ពាក្យ និងឃ្លាប្រយោគពិសេសៗ ដែលពួកគេប្រើប្រាស់សម្រាប់តែគ្នាគេប៉ុណ្ណោះ ។ ដូច្នេះ ការបកប្រែឯកសារទាំងនេះ ស្ទើរតែមិនអាចធ្វើបានឡើយសម្រាប់ប្រជាជនកម្ពុជាភាគច្រើន ។ ខ្ញុំបានហៅរកអ្នកស្រាវជ្រាវជាតិអាមេរិកាំងម្នាក់ឈ្មោះ ស្ទេហ្វេន ហេដ័រ ដើម្បីជួយបកប្រែឯកសារមួយភាគច្រើននៅសារមន្ទីរទួលស្លែង ។ ដែលមានប្រយោជន៍ដល់ខ្លួនខ្ញុំ ហើយខ្ញុំត្រូវតែដឹងគុណគាត់ជារៀងរហូត ។ បន្ថែមពីលើអ្នកបកប្រែម្នាក់ ខ្ញុំបានរកមគ្គុទ្ទេសក៍ម្នាក់ទៀត ដែលបានពុះ*

ទម្លាយភាពស្មុគស្មាញនៃការចោទប្រកាន់ផ្សេងៗ និងអក្សរសម្ងាត់របស់ពួកខ្មែរក្រហម ។

ម្យ៉ាងទៀត គាត់មានទឹកចិត្តទូលំទូលាយបំផុត ដែលផ្តល់ឲ្យខ្ញុំនូវឯកសារផ្សេងៗ ដែលរកឃើញនៅសារមន្ទីរទួលស្លែង ។ ហេដ័រ ផ្សាល់ និង ដេវីដ ហក ដែលបានស៊ើបអង្កេតពីបញ្ហាសិទ្ធិមនុស្ស បានដាក់ឲ្យខ្ញុំប្រើប្រាស់នូវព័ត៌មាន និងឯកសារជាច្រើនដែលគាត់ប្រមូលបាននៅទួលស្លែង ហើយដែលអនុញ្ញាតឲ្យខ្ញុំបានសរសេរសៀវភៅនេះឡើង ។ ខ្ញុំសូមថ្លែងសេចក្តីដឹងគុណចំពោះលោក ធីម៉ូធី ខាណី ជាអ្នកឯកទេសអាមេរិកាំងម្នាក់ ទៀតខាងបញ្ហាកម្ពុជានិងជាសមាជិកផ្នែកកិច្ចការទូត ដែលបង្ហាញឲ្យឃើញនូវទឹកចិត្តទូលាយ ដោយបានផ្តល់ឯកសារជាប្រវត្តិសាស្ត្រយ៉ាងច្រើនមកឲ្យខ្ញុំ ដែលមានមួយចំនួនធំ គឺគាត់ប្រមូលបានមកពីគុកទួលស្លែងដែរ ។ ខាណី ក៏ជាមនុស្សដ៏កម្រម្នាក់ក្នុងចំណោមមនុស្សដ៏កម្រជាច្រើននាក់ ដែលមានសមត្ថភាពបកប្រែពីភាសាអង់គ្លេសទៅជាភាសាខ្មែរ ដែលអាចឲ្យគេយល់សេចក្តីបានពីរឿងពួកកុម្មុយនិស្តកម្ពុជា ។

ជំនួយរបស់ ហេដ័រ, ហក និងខាណី មានលក្ខណៈកំណត់សម្រេចពីរឿងនេះ ពីព្រោះគេបានរារាំងខ្ញុំជាច្រើនលើកច្រើនសា មិនឲ្យខ្ញុំធ្វើដំណើរទៅប្រទេសកម្ពុជា និងទាញយកគុណប្រយោជន៍ពីឯកសារផ្សេងនៅសារមន្ទីរទួលស្លែង ដោយខ្លួនខ្ញុំផ្ទាល់ទេ ។ របបរបស់លោក ហេង សំរិន បានត្រួតត្រាយ៉ាងប្រយ័ត្នប្រយែង មិនឲ្យអ្នកណាម្នាក់ចូលទៅរកឯកសារទាំងនោះឡើយ ។ សម្រាប់បញ្ហាទាំងនេះ គេត្រូវតែទទួលបានការអនុញ្ញាតពិសេសមួយ ។ អ្នកអភិរក្សសារមន្ទីរទួលស្លែង បាននិយាយប្រាប់ខ្ញុំជាសម្ងាត់នៅឆ្នាំ១៩៨៣ថា ជាទូទៅប្រជាជនកម្ពុជាពុំដែលបានទទួលការអនុញ្ញាតឲ្យចូលមើលឯកសារទាំងនោះទេ ហើយថា មានតែជនបរទេសមួយចំនួនប៉ុណ្ណោះ ដែលគេអនុញ្ញាតឲ្យថតចម្លងឯកសារទាំងនោះបាន ។ ម្យ៉ាងទៀត ការចូលទៅស្រាវជ្រាវឯកសារ គឺត្រូវបានកម្រិតព្រំដែនដោយសារភាពកម្រចេញទិដ្ឋការ ដែលគេយល់ព្រមផ្តល់ឲ្យពួកបរទេសដើម្បីទស្សនាប្រទេសកម្ពុជាតិចតួចពេក ។

ក្រោយពីការដាក់ពាក្យសុំចូលរបស់ខ្ញុំ ២ឆ្នាំ ខ្ញុំបានទទួលទិដ្ឋាការមួយ នៅដំណាច់ឆ្នាំ១៩៨០ ប៉ុន្តែរដ្ឋាភិបាលរបស់វៀតណាមបានរារាំងការធ្វើដំណើររបស់ខ្ញុំទៀត ដោយបដិសេធមិនព្រមឲ្យខ្ញុំឆ្លងកាត់តាមប្រទេសវៀតណាមឡើយ ដែលនៅពេលនោះវាជាផ្លូវតែមួយគត់ដែលអាចទៅដល់ប្រទេសកម្ពុជាបាន ។ បន្ទាប់ពីបានសើរើពាក្យសុំរបស់ខ្ញុំឡើងវិញ ខ្ញុំបានទទួលការអនុញ្ញាតទៅកាន់ប្រទេសទាំងពីរ នៅឆ្នាំ១៩៨៣ ប៉ុន្តែតាំងពីពេលនោះមកទិដ្ឋាការផ្សេងៗបានត្រូវគេច្រានចោលជានិច្ច ។ ប៉ុន្តែ ឯកសារជាច្រើនដែលខ្ញុំប្រមូលបាននៅឆ្នាំ១៩៨៣ បានអនុញ្ញាតឲ្យខ្ញុំបញ្ចប់សៀវភៅរបស់ខ្ញុំចប់សព្វគ្រប់ ។

លក្ខខណ្ឌជាក់លាក់នៃឯកសារទាំងឡាយនៅសារមន្ទីរទួលស្លែង គឺគ្មានអ្វីធ្វើឲ្យគេងឿងឆ្ងល់ឡើយ ។ បណ្តាអ្នកឯកទេសល្បីៗ -ហេដ័រ និងខាណី- ក៏បានបញ្ជាក់អះអាងពីភាពទាក់ទងគ្នាយ៉ាងជិតស្និទ្ធជាប្រវត្តិសាស្ត្ររបស់វាដែរ ។ ហើយក្នុងបទសម្ភាសន៍មួយ ដែលគាត់បានអនុញ្ញាតឲ្យខ្ញុំជួបនៅឆ្នាំ១៩៨១ អៀង សារី មនុស្សទីពីររបស់បក្ស បានបញ្ជាក់បំភ្លឺពីលក្ខណៈពិតនៃចម្លើយសារភាពជាច្រើន ដែលខ្ញុំបានដាក់ជូនគាត់ពិនិត្យ ជាឧទាហរណ៍

និងការទទួលខុសត្រូវរបស់ពួកខ្មែរក្រហមក្នុងការប្រព្រឹត្តអំពើសាហាវយង់ឃ្នង នៅទួលស្លែងដើម្បីឲ្យរឹតតែច្បាស់លាស់ថែមទៀត ។ (ខ្ញុំបានបោះពុម្ពផ្សាយសេចក្តីបញ្ជាក់បំភ្លឺនេះ ក្នុងអត្ថបទមួយក្រោមចំណងជើងថា ៖ "បន្ទប់មរណៈ របស់ពួកខ្មែរក្រហម" ក្នុងកាសែតវ៉ាស៊ីនតោនប៉ុស្តិ៍ ចេញនៅថ្ងៃទី២ ខែសីហា ឆ្នាំ១៩៨១) ។

សំណុំរឿងរបស់ ប៊ូ ផាត ជាតួយ៉ាងគំរូមួយ រួមមាន ៨ ចំណែកវែងៗ ដែលមានជីវប្រវត្តិខុសៗគ្នាបួន និងឯកសារបួនផ្សេងៗទៀត ស្តីពីស្ថានការណ៍នៅភាគឥសានប្រទេសកម្ពុជាមុនសម័យសង្គ្រាម "កំហុសខាងសីលធម៌" របស់ ផាត់ ជាមួយស្រីៗ ការធ្វើឃាតមេដឹកនាំបក្សម្នាក់នៅភូមិភាគឧត្តរ ក្នុងរយៈពេលសង្គ្រាម និងសេចក្តីសង្ខេបមួយនៃចម្លើយរបស់ ផាត់ ចំពោះសំណួរផ្សេងៗ ដែលគេសួរបន្តគ្នាមិនចេះចប់ ដោយអ្នកសួរចម្លើយអនាមិកម្នាក់ ។

ហេង៍រ បានប្រទះឃើញឯកសារនេះនៅសារមន្ទីរទួលស្លែងក្នុងឆ្នាំ១៩៨១ ហើយគាត់បានបកប្រែសម្រាប់ខ្ញុំ នៅឆ្នាំ១៩៨២ ។ ខ្ញុំបានជ្រើសរើសយកឯកសារនេះ ពីព្រោះប្រវត្តិរបស់ ផាត់ ការងាររបស់គាត់ក្នុងផ្ទៃបក្ស បានផ្តល់នូវរូបភាពមួយ ដែលសឹងតែសព្វគ្រប់ស្តីពីសមាជិកបក្សថ្នាក់មធ្យមម្នាក់ ពីព្រោះមុខងារដែលគាត់បានបំពេញជាបន្តបន្ទាប់ សុទ្ធតែមានជាប់ទាក់ទងជាមួយនឹងពួកមេដឹកនាំជាន់ខ្ពស់មួយចំនួនដូចជា ខៀវ សំផន, អៀង សារី និង ប៉ុល ពត ផ្ទាល់ ។ ម្យ៉ាងទៀត អនាគតរបស់គាត់ក៏ឆ្លុះបញ្ចាំងឲ្យឃើញពីអនាគតរបស់ចលនាខ្មែរក្រហមដែរ ។ ជាកូនកំព្រាដែលមានមុខរបរកំប៉ិកកំប៉ុក គាត់បានក្លាយទៅជាមេដឹកនាំតំបន់ដ៏សំខាន់ម្នាក់ បន្ទាប់មកបានអន្តរាយជីវិត នៅក្នុងការបោសសម្អាតដ៏ធំមួយក្នុងចំណោមការបោសសម្អាតធំៗរបស់បក្ស ។

ដើម្បីរៀបចំឡើងវិញនូវប្រវត្តិរបស់ ផាត់ ខ្ញុំបានប្រើប្រាស់ព័ត៌មានជាច្រើនដែលមាននៅក្នុងសំណុំឯកសាររបស់គាត់ ហើយខ្ញុំបានយកព័ត៌មាននេះទៅប្រៀបធៀបនឹងឯកសារផ្សេងៗទៀត គឺព័ត៌មានដែលគេរកឃើញក្នុងសំណុំរឿងផ្សេងៗទៀតនៅសារមន្ទីរទួលស្លែង ឬមកពីប្រភពជាច្រើនមិនមែនកុម្មុយនិស្ត ក្នុងជំនាន់ សម្តេចព្រះនរោត្តម សីហនុ និង លន់ នល់ ។ ក្នុងសំណុំរឿងផ្ទាល់របស់គាត់ ជីវប្រវត្តិដំបូងដែលសរសេរដោយដៃរបស់ផាត់គឺជាប្រវត្តិមួយមានសារសំខាន់ជាទីបំផុត ។ ហើយខាងក្រោមនេះ គឺជាការបកប្រែមួយ ដែលផ្តល់ចំពោះមិត្តអ្នកអាននូវគំរូមួយ នៃបណ្តាជីវប្រវត្តិ និងចម្លើយសារភាពជាច្រើន ដែលយកបានមកពីទួលស្លែង ។ នេះគឺជាការបកប្រែបង្រួញមួយ អត្ថបទពេញទាំងស្រុងមានសេចក្តីវែងពេក ពុំអាចចុះក្នុងសៀវភៅនេះបានឡើយ ។

## ជីវប្រវត្តិមួយ

ឈ្មោះដើម ៖ ប៊ូ ផាត់, ឈ្មោះបដិវត្ត ៖ ហង្ស អាយុសែសិបឆ្នាំ កើតនៅភូមិរមេញ ស្រុកកោះអណ្តែត ខេត្តតាកែវ ។

ឈ្មោះឪពុក ៖ ប៊ូ ភោគ, ឈ្មោះម្តាយ ៖ នព្វ កូវ ។ អ្នកទាំងពីររកស៊ីចិញ្ចឹមជីវិតដោយធ្វើស្រែចម្ការ ។

គាត់ទាំងពីរបានស្លាប់តាំងពីខ្ញុំនៅក្មេងនៅឡើយ ។ ខ្ញុំមិនដែលនឹកស្រមៃឃើញពីមុខមាត់រាងរៅរបស់គាត់យ៉ាងដូចម្ដេចទេ ។

ខ្ញុំមានបងប្អូនប្រុសស្រីប្រាំពីរនាក់ បងស្រីបង្អស់ឈ្មោះ ថេង ឥឡូវនេះគាត់ប្រហែលជាមានអាយុ ៦០ ឆ្នាំ ហើយ(គិតត្រឹមឆ្នាំ១៩៧៨) ខ្ញុំជាកូនពៅគេបង្អស់...។

បន្ទាប់ពីបាត់បង់ឪពុកម្ដាយ យើងបានរកស៊ីចិញ្ចឹមជីវិតដោយធ្វើស្រែដដែល...។

ពីឆ្នាំ១៩៥០ ដល់ឆ្នាំ១៩៥៣ ខ្ញុំបានរៀនសូត្រនៅក្នុងសាលាមួយនៅកោះអណ្ដែត ។ នៅឆ្នាំ១៩៥៤ ខ្ញុំចូលរៀននៅសាលាវត្តគឺ វត្តមេព្រៃមេលង...។ ខ្ញុំបានសិក្សានៅទីនោះរហូតដល់ថ្នាក់អាទិកដ្ឋាន ។ កាលនោះខ្ញុំរស់នៅក្នុងវត្តជាមួយព្រះសង្ឃជាច្រើនអង្គ ។ នៅឆ្នាំ១៩៥៥ និងឆ្នាំ១៩៥៦ ខ្ញុំបានមកបន្តការសិក្សា (ថ្នាក់អាទិកដ្ឋានទី២) នៅសាលាពោធិចិនតុង ស្រុកភ្នំពេញ ។ នៅពេលនោះ ខ្ញុំបានរស់នៅក្រោមអាណាព្យាបាល របស់បងប្រុសខ្ញុំឈ្មោះ ប៉ូ ទិត ជានាយទាហានពាក់សក្ដិមួយនៃកងទ័ពឆ័ត្រយោងប្រចាំបន្ទាយពោធិចិនតុង ។ ពីឆ្នាំ ១៩៥៦ ដល់ឆ្នាំ១៩៥៩ ខ្ញុំបានសិក្សានៅវិទ្យាល័យឯកជនកម្ពុជបុត្រក្រុងភ្នំពេញ...។ ខ្ញុំសូមជម្រាបថា ការបំពាក់បំប៉នអំពីបដិវត្តរបស់ខ្ញុំ បានចាប់ផ្ដើមតាំងពីឆ្នាំ១៩៥៧មក នៅវិទ្យាល័យឯកជនកម្ពុជបុត្រ ។ ខ្ញុំធ្លាប់បានចូលរួមក្នុងសកម្មភាពឃោសនាផ្សេងៗ ដើម្បីពង្រីកឥទ្ធិពលកាសែត“ប្រជាជន” ក្នុងចំណោមកូនសិស្សវិទ្យាល័យជាច្រើន ។

ខ្ញុំធ្លាប់ទៅកន្លែងការិយាល័យរបស់កាសែតនោះជារឿយៗ ។ គេអាចអះអាងថា ខ្ញុំមិនដែលធ្វើការទាក់ទងជាមួយមជ្ឈដ្ឋានអ្នកចម្រើននិយមរបស់កាសែតទាល់តែសោះ...។

នៅចុងឆ្នាំ១៩៥៩ ខ្ញុំបានរត់ចេញពីផ្ទះបងប្រុសរបស់ខ្ញុំ ប៉ូ ទិត ទាំងកណ្ដាលអធ្រាត្រ ដើម្បីទៅរស់នៅក្នុងការិយាល័យរបស់កាសែត “អ្នកសង្កេតការណ៍” ដែលក្នុងនោះ ខ្ញុំបានធ្វើការខាងកំណែអត្ថបទកាសែត ដែលគេបោះពុម្ពសាកល្បងដំបូង និងការងារខាងចែកកាសែត...។ មិនយូរប៉ុន្មានក្រោយមក ខ្ញុំបានចូលធ្វើការជាមួយបងហែម (ឈ្មោះបដិវត្ត ខៀវ សំផន) ។ ខ្ញុំត្រូវគេចាប់ខ្លួន និងដាក់គុក ដំណាលគ្នានឹងអ្នកធ្វើការនៅកាសែត បួននាក់ផ្សេងទៀត ដោយរដ្ឋាភិបាលជំនាន់នោះ ។ ពេលខ្ញុំចេញពីគុកនៅដើមឆ្នាំ១៩៦០ ខ្ញុំបានទៅនៅវត្តស្វាយពពែមួយរយៈខ្លី ដោយនៅតែធ្វើការទាក់ទងជាមួយ បងហែម ជានិច្ច ដែលនៅតែជាមេកោយរបស់ខ្ញុំដដែល...។

ខ្ញុំបានក្លាយទៅជាកម្មករសង់ផ្ទះថ្ម.... ប៉ុន្តែ គិញបានតាមដានខ្ញុំយ៉ាងប្រកិត... ខ្ញុំបានគេចខ្លួនទៅនៅជាមួយនឹងព្រះសង្ឃ ហើយបានចូលរួមក្នុងការសរសេរសៀវភៅ... ការវិភាគខាងអក្សរសិល្ប៍ជាមួយ “មិត្តម្នាក់” ទៀត ។ យើងបានលក់សិទ្ធិនិពន្ធក្នុងសៀវភៅមួយក្បាលចំនួន បីពាន់រៀល បន្ទាប់មក យើងបែងចែកលុយគ្នា និងចាយវាយទៅលើរបស់ប្រើប្រាស់ផ្សេងៗ ។

[ការស្រាវជ្រាវរបស់ប៉ូលិសសម្ងាត់បានបង្ខំឲ្យគាត់ផ្លាស់ប្ដូរទីលំនៅ និងមុខរបរជាថ្មីម្ដងទៀត] ។ ខ្ញុំបាន

ដួលខ្ទមស្លឹកមួយនៅក្បែរឃ្លាំងផ្ទុកស្បៀងអាហារ និងគ្រាប់រំសេវរបស់កងទ័ពខេមរភូមិន្ទ ។ ខ្ញុំត្រូវគេនាំចូលឲ្យធ្វើការជាជាងសង់ផ្ទះឈើ... ។ នៅឆ្នាំ១៩៦២ កាសែតប្រជាជនបានចេញផ្សាយឡើងវិញ ហើយខ្ញុំបានទៅធ្វើការជាអ្នកកែអត្ថបទនៅទីនោះម្តងទៀត ។ នៅឱកាសមហាសន្និបាតពិសេសរបស់បក្សកុម្មុយនិស្ត អ្នកនិពន្ធនាយករបស់ កាសែតបានត្រូវគេចាប់ដាក់គុក ។ បន្ទាប់ពីចេញផ្សាយបានតែមួយលេខ "អង្គការ" បានផ្តល់បទបញ្ជាឲ្យយើងបញ្ឈប់ការចេញផ្សាយ និងចាប់ធ្វើសកម្មភាពដោយលួចលាក់វិញ ។

ថ្ងៃមួយដែលខ្ញុំកំពុងស្ថិតនៅក្នុងទីលាក់ខ្លួនមួយ... ជឹម បានមករកជួបខ្ញុំ ហើយសួរខ្ញុំថា "សមមិត្ត អ្នកចង់ចូល បក្សឬទេ?"... ។ នៅជំនាន់នោះ ខ្ញុំគ្មានដឹងថាមានបក្សមួយនៅឡើយទេ... ។ តា ជឹម បានពន្យល់ប្រាប់ខ្ញុំពីអត្ថន័យនៃបក្សជាអ្វីទៅ ហើយបានស្នើឲ្យខ្ញុំសុំចូល ។ តមកទៀត ខ្ញុំបានសរសេរប្រវត្តិរូបពិស្តារមួយ ដើម្បីយកទៅជូនថ្នាក់លើពិនិត្យ ។ ថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៦២ ខ្ញុំបានត្រូវគេធ្វើពិធីបញ្ចូលបក្សនៅក្នុងផ្ទះមួយ ស្ថិតនៅខាងក្រោយមន្ទីរពេទ្យព្រះសង្ឃ ជាមួយមនុស្សដែលគួរឲ្យមើលងាយ គឺសមមិត្ត យ៉ា និងវី ដែលជាអ្នកស្នើបេក្ខភាពរបស់ខ្ញុំ និងអ្នកធានាខ្ញុំម្នាក់ទៀតគឺសមមិត្ត កែវ មាស ។ ["មនុស្សដែលគួរឲ្យមើលងាយ" ជាពាក្យដែលបំពាក់លើឈ្មោះបណ្តាសមមិត្តដែលជឿជាក់ក្នុងខ្លួនពីអំពើក្បត់ ។ នៅឆ្នាំ១៩៧៨ យ៉ា និង កែវ មាស បានក្លាយទៅជាអ្នករងគ្រោះពីការបោសសម្អាតមួយ ហើយបានត្រូវគេសម្លាប់ចោលទាំងអស់] ។

នៅពាក់កណ្តាលឆ្នាំ១៩៦២ សមមិត្ត ប៉ាំង ដែលមានបុណ្យសក្តិធំ បាននាំខ្ញុំទៅរៀនទ្រឹស្តីជាបន្តទៀត ក្នុងផ្ទះដែលស្ថិតនៅខាងក្រោយពេទ្យព្រះសង្ឃដដែល ដោយមានបងទីមួយ (ប៉ុល ពត) ជាគ្រូខន្ទេសនាម ។ អ្វីដែលខ្ញុំនៅតែនឹកឃើញកាលណោះ គឺមានកូនសិស្សតែប៉ុន្មាននាក់ប៉ុណ្ណោះ.... ។

[ការរស់នៅក្នុងទីលាក់ខ្លួនមួយផ្សេងទៀត] ។ សមមិត្តយ៉ា បានមកជួបខ្ញុំជាញឹកញាប់ដើម្បីលើកកម្ពស់ជីហាវណ្ណៈរបស់ខ្ញុំ ក្នុងគោលបំណងធ្វើកុំឲ្យខ្ញុំនឿយណាយក្នុងការរស់នៅរបៀប "លាក់ខ្លួន" នេះ គាត់បាននិយាយប្រាប់ខ្ញុំថា ខ្ញុំនឹងត្រូវចាកចេញទៅកាន់ព្រៃម៉ាគីក្នុងពេលឆាប់ៗនេះហើយ... ។ បន្ទាប់ពីស្ថិតក្នុងសភាពលួចលាក់ចំនួនដប់ខែ យប់មួយ អង្គការបានយកចេញពីទីនោះនៅចុងឆ្នាំ១៩៦២ ។ សមមិត្ត យ៉ា បានប្រាប់ខ្ញុំឲ្យនៅរង់ចាំឡានមួយ ដែលមានលេខសម្គាល់មួយខុសគេនៅខាងជើងវត្តទួលទំពូងតាមពេលម៉ោងកំណត់ទុក ។ រំពេចនោះ ឡានបានមកដល់ភ្លាម ដោយមិនដឹងលេចចេញពីខាងណា ។ ខ្ញុំបើកទ្វាររថយន្ត ហើយបានឃើញបងទីមួយ (ប៉ុល ពត) អង្គុយនៅក្នុងនោះដែរ ។ ដោយបើកបរវិលវង់ក្នុងក្រុងភ្នំពេញបណ្តើរ គាត់សួរខ្ញុំបណ្តើរថា តើអ្នកឯងប្រាកដជាចង់ចាកចេញដាច់ខាតមែនឬ ។

បន្ទាប់មក គាត់បានបើកតម្រង់ទៅស្តាតចាស់ ហើយបត់ទៅកាន់កន្លែងមួយដែលមានសុទ្ធតែគំនរក្រួសល្អិត (ក្រួសអាចម៍ផ្កាយ) ហើយយើងបានជួបបងទពីរ (អៀង សារី ឬ នួន ជា) នៅទីនោះដែរ ។ បងទីពីរបានពង្រឹងការសម្រេចចិត្តរបស់ខ្ញុំ ហើយនាំខ្ញុំចាកចេញទៅជាមួយនិរសារយួនម្នាក់... ។ នៅពេលព្រឹក ខ្ញុំបាន

ឡើងជិះឡានមួយ ហើយធ្វើដំណើរទៅកាន់ទីក្រុងស្វាយរៀងជាមួយមីងម្នាក់ ។ បន្ទាប់មក ខ្ញុំបានចាកចេញពីស្វាយរៀង តាមរទេះគោមួយគ្រឿង និងឆ្លងចូលទៅក្នុងប្រទេសវៀតណាមខាងត្បូង ។ ខ្ញុំបានធ្វើដំណើរទៅកាន់ទីស្នាក់ការផ្នែកឃោសនារបស់វៀតកុងទៀត ។

ខ្ញុំបានស្ថិតនៅជាមួយពួកវៀតកុងក្នុងរយៈពេលប្រហែលប្រាំមួយខែ ហើយជួយធ្វើការពួកនោះសម្រាប់វិទ្យុផ្សាយជាភាសាខ្មែរ ។ បន្ទាប់មក ប្រហែលជានៅខែកក្កដា ឆ្នាំ១៩៦៣ ខ្ញុំបានជួបបងទីមួយ និងបងទីពីរ ដែលមកយកខ្ញុំចេញពីពួកយួន ហើយខ្ញុំបានធ្វើដំណើរទៅរស់នៅជាមួយ“អង្គការ”យើង ដែលនៅពេលនោះរួមមានសមាសភាពៈ បងទីមួយ បងវ៉ាន់ (អៀង សារី) និងបងខៀវ (សុន សេន) ។ នៅឆ្នាំ១៩៦៤ ខ្ញុំបានរៀបការប្រពន្ធជាកូនស្រីរបស់សមមិត្ត សាក់គី នៅចំពោះមុខបង ភីម (សោ ភីម មេដឹកនាំភូមិភាគបូព៌ា...) ។ នៅឆ្នាំ១៩៦៦ បក្សបានចាកចេញពីតំបន់វាលរាបទៅតាំងនៅខេត្តរតនគិរីវិញ ។ បងវ៉ាន់ បានចេញដំណើរទៅមុនគេ... ប្រពន្ធរបស់ខ្ញុំដែលមានកូនមួយទៅហើយ បានទទួលបញ្ជាឲ្យស្ថិតនៅជាមួយឪពុកនាងក្នុងទីស្នាក់ការចាស់ដែលតាំងនៅក្បែរព្រំដែនសិន ។

នៅខែកក្កដា ឬខែសីហា ឆ្នាំ១៩៦៧ ខ្ញុំបានចាកចេញពីតំបន់វាលរាបឆ្ពោះទៅរតនគិរីជាមួយបងទីមួយ និងសមមិត្តមួយចំនួនធំផ្សេងទៀត... ។ ខ្ញុំជាអនុប្រធានមន្ទីរទទួលបន្ទុកខាងអក្សរសម្ងាត់ និងរោងពុម្ព... ។ ប្រហែលនៅខែកុម្ភៈ ឆ្នាំ១៩៦៨ បងទីមួយ បានរៀបចំកម្មវិធីធ្វើការហ្វឹកហាត់ក្បួនយោធាជាលើកដំបូងបង្អស់... ។ គាត់ទើបតែបង្ហាញជូនពីកម្មវិធីសិក្សាស្រាប់តែកងទ័ពរបស់ លន់ នល់ (ពេលនោះជាមេបញ្ជាការកងទ័ពរបស់សម្ដេច ព្រះនរោត្តម សីហនុ) បានចាប់ធ្វើសកម្មភាពវាយឆ្មក់មួយ ប្រឆាំងនឹងយើងក្នុងចំណោមការវាយឆ្មក់ជាច្រើនរបស់ពួកគេ ។

[ក្នុងចម្លើយសារភាព និងជីវប្រវត្តិនៅសារមន្ទីរទួលស្លែងទាំងអស់ សម្ដេច ព្រះនរោត្តម សីហនុ ត្រូវបានញែកដាច់មិននិយាយដល់ឡើយ... ។ គឺ លន់ នល់ ជានិច្ច ដែលគេសន្មតថា ជាអ្នកធ្វើការប្រយុទ្ធប្រឆាំងនឹងពួកអ្នកបដិវត្តពុំមែនសម្ដេចទេ ។

ក្រោយមក បងទីមួយ បានបញ្ជូនខ្ញុំទៅវាយប្រយុទ្ធជាមួយសត្រូវនៅវ៉ឺនសៃជាមួយនឹង បងខៀវ (សុន សេន ដែលនឹងក្លាយទៅជាមេបញ្ជាការកងទ័ពខ្មែរក្រហម) ។ ពីឆ្នាំ១៩៦៩ រហូតមកដល់ពេលមានរដ្ឋប្រហារ ខ្ញុំស្ថិតនៅក្នុងស្រុកវ៉ឺនសៃ ដដែល (ខេត្តរតនគិរីភាគខាងលិច) ។ បន្ទាប់ពីរដ្ឋប្រហារ (ឆ្នាំ១៩៧០) បក្សបានចាត់តាំងឲ្យខ្ញុំទទួលបញ្ជាយោធា ក្នុងឋានៈជាស្នងការនយោបាយកងអនុសេនាធំមួយ ដែលកំពុងវាយប្រយុទ្ធនឹងសត្រូវនៅស្រុកបានលុង ខេត្តរតនគិរី... ។ ប្រហែលជានៅខែសីហា ឆ្នាំ១៩៧០ បក្សបានតែងតាំងខ្ញុំជាសមាជិកគណៈកម្មាធិការតំបន់១០៣ (ក្នុងភូមិភាគឧត្តរ) ។ នៅថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៤ បន្ទាប់ពី បងម៉ន ទទួលមរណភាព បក្សបានប្រគល់តំបន់របស់គាត់ (១០៣) មកឲ្យខ្ញុំទទួលខុសត្រូវរហូតមកដល់ចុងឆ្នាំ បន្ទាប់មក

បក្សបានបញ្ជូនប្រធានគណៈកម្មាធិការតំបន់ថ្មីម្នាក់ទៀត ដោយមានខ្ញុំធ្វើជាលេខា...។

[មរណភាពរបស់ បងម៉ន ត្រូវគេស្តីបន្ទោសឲ្យ ផាត់ នៅពេលក្រោយមកទៀត ។ អ្វីដែលមកបន្ទាប់ចម្លើយសារភាពដំបូងទាំងនេះ បានឆ្លងពីជីវប្រវត្តិពិតប្រាកដមួយ ទៅនឹងការស៊ើបអង្កេតមួយស្តីពីកំហុសជាយថាហេតុផ្សេងៗ ការប្រព្រឹត្តខុសគន្លងមាគ៌ា និងអំពើឧក្រិដ្ឋផ្ទាល់របស់ ផាត់ ។

យប់ម្សិល សមមិត្ត ឌុច ខាងផ្នែកសន្តិសុខពិសេសបានប្រកាសថា ពួកយុវជន និងពួកចាស់ៗ ប្រជាជនគ្រប់ភូមិភាគទាំងអស់ បានបញ្ចូលឈ្មោះខ្ញុំទៅក្នុង (ចម្លើយសារភាពរបស់ពួកគេដែរ) ។

បក្សជាទីគោរព និងជាទីស្នេហា ។ មុននឹងខ្លួនត្រូវជាប់គុក ខ្ញុំគ្មានភ័យខ្លាចថាបក្សចាប់ខ្ញុំ ដោយសារមានទាក់ទងជាមួយនឹងអំពើក្បត់របស់ក្រុមផ្សេងៗដែលជាខ្សែរយៈ យួន, សេ.អ៊ី.អា. ឬ កា.ហ្សេ.បេ. ឡើយ ពីព្រោះខ្ញុំមិនដែលមានគោលបំណងក្បត់នឹងបក្សបន្តិចបន្តួចសោះឡើយ ខ្ញុំសូមស្បថ ។ មនុស្សក្បត់ទាំងអស់ ដែលខ្ញុំធ្លាប់ស្គាល់ ហើយជាមួយអ្នកទាំងនោះដែលខ្ញុំធ្លាប់ធ្វើការទាក់ទង ក៏មិនដែលនិយាយប្រាប់ខ្ញុំពីអំពើក្បត់ដែរ...។

ដំបូង នៅពេលដែលមិត្តភក្តិរបស់យើងចូលមករកខ្ញុំ ខ្ញុំមិនដែលនឹកគិតថា គេមករកចាប់រូបខ្ញុំទេ ។ ខ្ញុំជឿថា គឺពួកគេសុទ្ធតែជាបងប្អូនរួមជាតិឯង ជាមនុស្សដែលខ្ញុំធ្លាប់ស្គាល់ប៉ុណ្ណោះ ហើយពួកគេបានចាប់ក្រសោបខ្ញុំដើម្បីឱបរឹត ប៉ុន្តែ នៅពេលដែលពួកគេរឹតបន្តឹងការឱបរបស់គេ ហើយនៅពេលដែលខ្ញុំចាប់ផ្តើមរើបម្រះ មិត្តយើងបាននិយាយប្រាប់ខ្ញុំឲ្យនៅស្ងៀមកុំកម្រើក ពួកគេយកខ្នោះមកដាក់ដៃខ្ញុំ ហើយគ្របភ្នែកខ្ញុំដោយក្រណាត់មួយបន្ទះទៀត ។ ខ្ញុំមានសេចក្តីភ័យខ្លាចដូចជាស្លាប់ស្រេចទៅហើយ...។

តាំងតែពីការចាប់ខ្ញុំដាក់ឃុំឃាំង ខ្ញុំមើលឃើញច្រកតែមួយគត់សម្រាប់ខ្ញុំ ។ ខ្ញុំច្បាស់ជាស្លាប់ ពីព្រោះខ្ញុំធ្លាប់ដឹងពីប្រតិកម្មរបស់បក្សចំពោះរូបខ្ញុំ ដឹងពីការពឹងលើវិធានការចុងក្រោយផ្សេងៗជាស្រេច ។ ខ្ញុំទូន្មានខ្លួនឯងថា ខ្ញុំត្រូវតែថែរក្សាសុខភាពមិនឲ្យមានអ្វីមកប៉ះពាល់ឡើយ ដើម្បីខ្ញុំអាចស្រាវជ្រាវរកឲ្យឃើញពីបញ្ហាដែលនាំឲ្យមានការចាប់ខ្លួនខ្ញុំដោយផ្នែកសន្តិសុខនេះ ។ បក្សជាទីគោរព និងជាទីស្នេហា បណ្តាមេដឹកនាំបក្សជាទីគោរព និងជាទីស្នេហា ខ្ញុំសូមសំណូមពរឲ្យបក្ស បណ្តាសមមិត្តជាទីគោរព និងជាទីស្នេហាមានសេចក្តីអាណិតអាសូរចំពោះរូបខ្ញុំផង...។

ខ្ញុំសូមទទួចអង្វរបក្ស មេត្តាបង្ហាញនូវសេចក្តីអាណិតប្រណីចំពោះកូនៗរបស់ខ្ញុំ និងទុកជីវិតពួកវាឲ្យរស់នៅផង ។ ពីព្រោះខ្ញុំជាសាច់ជាឈាមពិតប្រាកដរបស់បក្ស ។

ធ្វើនៅមជ្ឈមណ្ឌលឃុំឃាំងរបស់ផ្នែកសន្តិសុខ
ព្រឹកថ្ងៃទី៥ ខែមករា ១៩៧៩
ហត្ថលេខា : ហង្ស

ជាកូនអតីតនាយកផ្នែកការសិក្សាចិន នៃសកលវិទ្យាល័យមូស្គូ អ៊ីហ្គ័រ រ៉ូហ្កាឆូវ បានត្រូវបណ្តុះបណ្តាលចិញ្ចឹមជាកូនដ៏វិសេសមួយ ក្នុងភ្នែកប្រជាជនសូវៀតភាគច្រើន ។ គ្រួសាររបស់គាត់ ជាគ្រួសារមួយដែលមានអភ័យឯកសិទ្ធិ ជាងប្រជាជនសូវៀតធម្មតា ។ តាមរយៈឪពុករបស់គាត់ គាត់បានត្រូវចិញ្ចឹមបីបាច់ឲ្យមានការស្រឡាញ់ និងស្ញប់ស្ញែងចំពោះវប្បធម៌ចិន និងអាស៊ី ដែលធ្វើឲ្យគាត់មានលក្ខណៈប្លែកពីអ្នកធ្វើការជាមួយគាត់ក៏ដូចជាជនជាតិសូវៀតភាគច្រើន ដែលមានការស្រឡាញ់ និងស្ញប់ស្ញែង តែចំពោះវប្បធម៌អឺរ៉ុបនោះ ។ អភ័យឯកសិទ្ធិមួយទៀត ដែលគាត់មានជាប់ជាមួយត្រកូលរបស់គាត់គឺ តំណែងមួយនៅក្នុងក្រសួងការបរទេស ដែលនឹងធានាដល់គាត់ នូវជីវិតប្រកបដោយការធ្វើដំណើរដ៏ប្រសើរមួយ ហើយពិភពរបស់គាត់ នឹងពុំមានដែនកំណត់ឡើយ ។ គ្រាន់តែចាប់ផ្តើមបម្រើការងារទូតភ្លាម ជំនាញភាសារបស់គាត់ត្រូវបានគេស្ញប់ស្ញែងយ៉ាងខ្លាំងរួចទៅហើយ ។ អ្នកធ្វើការជាមួយគាត់បានអធិប្បាយថា គាត់និយាយភាសាចិនពូកែ ហើយមានខ្យល់បញ្ចេញសំឡេងភាសាចិនពិរោះ ត្រូវខ្លាប់ខ្លួនណាស់ គុណសម្បត្តិផ្នែកភាសារបស់គាត់ បានធ្វើឲ្យគាត់ក្លាយជាអ្នកបកប្រែសំណព្វនិងជំនិតរបស់មេដឹកនាំចិន និងសូវៀតមួយចំនួន ។ ជាងនេះទៅទៀតសមត្ថភាពនៃការយល់ និងវិភាគវិនិច្ឆ័យរបស់គាត់ ក្នុងការយល់ និងផ្នត់គំនិតដូចអាស៊ី បានផ្តល់ដល់គាត់នូវតំណែងដ៏សំខាន់មួយ ។

តំណែងដំបូងរបស់គាត់ គឺទៅប៉េកាំង ក្នុងអំឡុងពីឆ្នាំ១៩៥៦ ដល់ឆ្នាំ១៩៦១ គឺមុនពេលដែលទំនាក់ទំនងរវាងសូវៀត និងចិន ត្រូវបានកាត់ផ្តាច់ ។ ក្រោយមកទៀត គាត់បានចំណាយពេលបួនឆ្នាំ នៅវ៉ាស៊ីនតោនដើម្បីសិក្សាតាមដានអំពីចំណងមិត្តភាពរវាងសហរដ្ឋអាមេរិក និងចិន ដែលនៅពេលនោះ កំពុងតែប្រសើរឡើង ។ ក្រោយមក គាត់ក៏បានយល់ជ្រួតជ្រាបអំពីសម្ព័ន្ធភាពរវាងចិន និងសហរដ្ឋអាមេរិក ។ គាត់បានមានប្រសាសន៍ថា ខ្ញុំមានមោទនភាពយ៉ាងខ្លាំង ដោយបានក្លាយជាជនជាតិសូវៀតដំបូងបង្អស់ ដែលត្រូវចាត់តាំងឲ្យទៅសិក្សាពីចិននៅក្រុងវ៉ាស៊ីនតោន ។ ពេលនោះ គឺជាពេលដែលអាមេរិក កំពុងតែចែចង់ចិន ហើយអ្នកខ្លះហៅនយោបាយនោះថា ជានយោបាយការទូត ពីង ប៉ុង ស្អីគេនោះ ។

គាត់មានការចម្លែកក្នុងចិត្ត ក្នុងន័យរីករាយចំពោះចំនួនមិត្តភក្តិដ៏ច្រើន និងមិត្តភាពដែលគាត់បានបង្កើតនៅក្នុងអំឡុងពេលគាត់នៅធ្វើការនាទីក្រុងវ៉ាស៊ីនតោន ។ ក្នុងនោះរួមមាន ស្តេបភ្លិលថុន រ៉យ (Stapleton Roy) ។ ក្រោយមក រ៉យ (Roy) បានក្លាយជាឯកអគ្គរដ្ឋទូតអាមេរិកឈានមុខមួយប្រចាំនៅអាស៊ី ។ គាត់បាននិយាយថា រ៉យ ជាមិត្តភក្តិដ៏ជិតស្និទ្ធម្នាក់របស់គាត់ ។ គាត់ក៏បានទៅចូលរួមពិធីអាពាហ៍ពិពាហ៍របស់ រ៉យ ។ ចំណែក រ៉យវិញគិតថា រ៉ូហ្កាឆូវ (Rogachev) ជាមនុស្សម្នាក់ស្រួលរាប់អានជាងអ្នកការទូតបរទេសដទៃទៀត រួមទាំងអឺរ៉ុបក៏ដូចជាសូវៀតដែរ មិនថាកុម្មុយនិស្ត ឬមិនមែនកុម្មុយនិស្តទេ ។ រ៉យ បាននិយាយបន្តថា "ជារឿងមួយគួរឲ្យអស់សំណើចណាស់ ដែលឲ្យខ្ញុំស្គាល់ និងយល់ពីគាត់ រហូតដល់ខ្ញុំអាចទាយបានថា តើគាត់នឹងគិតពីអ្វី ។ ហើយអ្វីដែលខ្ញុំទាយច្រើនតែត្រូវ ។ គាត់ជាមនុស្សម្នាក់ ដែលបើកចំហក្នុងរូបភាពដ៏ស្ញប់ស្ញាត់របស់គាត់ ។

ភាពជឿចិត្តចំពោះខ្លួនឯងរបស់គាត់នេះ បានជួយឲ្យគាត់អាចកែប្រែសភាពការណ៍ស្មុគស្មាញ នាទសវត្សរ៍ឆ្នាំ៧០ បាន ។ ធ្វើជាអ្នកជំនាញផ្នែកការទូតចិនរបស់សូវៀតនាពេលនោះ គឺមានការធុញថប់ ប្រហាក់ប្រហែលគ្នានឹងធ្វើការឲ្យក្រសួងការបរទេសអាមេរិក នាទសវត្សរ៍ឆ្នាំ៥០ដែរ ។ គឺថា តំណែងទាំងពីរនេះ ត្រូវបានចិនចាត់ទុកជាសត្រូវ ។ បញ្ញវន្តដែលយល់អំពីស្ថានភាពរបស់ចិន ហើយនិយាយពន្យល់អំពីសារសំខាន់នោះ នឹងត្រូវប្រយ័ត្នចំពោះការត្រូវយល់ច្រឡំថា កាន់ជើងចិន ហើយប្រឆាំងនឹងរដ្ឋាភិបាលខ្លួនឯង ។ ប៉ុន្តែ អ្នកធ្វើការជាមួយបានឲ្យដឹងថា រ៉ូហ្កាឆូវ មិនបានសម្តែងឲ្យឃើញថាគាត់ត្រូវទេ ហើយការគិតនោះ នាំមកនូវការរាំងស្ទះដំណើរការសម្របសម្រួលទំនាក់ទំនងជាមួយចិនរបស់គាត់ថែមទៀត ។ ផ្ទុយទៅវិញ គាត់ហាក់ដូចជាបង្ហាញឲ្យឃើញថា គាត់មានពេលពេញមួយជីវិត សម្រាប់ជម្នះនូវការរិះគន់នេះទៅវិញ ។ Yevgeniy V Afansyev អតីតកុងស៊ុលសូវៀតប្រចាំនៅវ៉ាស៊ីនតោន បានអធិប្បាយពីគាត់ថា គាត់ត្រូវបានគេចាប់អារម្មណ៍ស្គាល់ ដោយសារការគិតប្លែកៗរបស់គាត់ និងដោយសារភាពរួសរាយបែបការទូតរបស់គាត់ ។

ក្រោមបញ្ជាររបស់ម៉ូស្គូ រ៉ូហ្កាឆូវ បានជិះឧទ្ធម្ភាគចក្រពីក្រុងព្រៃនគរមកភ្នំពេញ ដោយឲ្យឧទ្ធម្ភាគចក្រហោះខ្ពស់ផុតចុងឈើទៅទៀត ព្រោះបារម្ភខ្លាចថា ខ្មែរក្រហមបាញ់ ។ ជិះផុតព្រំដែនវៀតណាមមិនបានប៉ុន្មានផង គាត់ក៏ចាប់មានការបារម្ភទៅហើយ ព្រោះថា ស្ថានភាពដីនៅអាស៊ី ដែលគាត់ធ្លាប់ស្គាល់តាមរយៈការធ្វើដំណើរពីមុនរបស់គាត់ទៅប្រទេសចិន និងប្រទេសនៅអាស៊ីទាំងឡាយ ដែលមានវាលស្រែ ក្របី និងភូមិស្រុកនោះ គឺមិនបានឃើញនៅប្រទេសកម្ពុជាពេលនោះឡើយ ។ ផ្ទុយទៅវិញ ទីនោះបែរហាក់ដូចជាពីភពព្រះច័ន្ទទៅវិញ ។

«ពីលើឧទ្ធម្ភាគចក្រ ខ្ញុំមើលមិនឃើញមនុស្សប្រុសត្រីពាហនៈសោះ ។ ភូមិគ្មានជីវិតរស់នៅ គ្មានផ្សែងចេញពីភូមិដូចនៅប្រទេសអាស៊ីដទៃទៀតឡើយ ។ គឺឃើញពោរពេញដោយរណ្តៅគ្រប់ទិសទីទាំងអស់ ។

នាអាកាសយានដ្ឋានពោធិចិនតុងឧទ្ធម្ភាគចក្រចុះ គាត់ស្រាប់តែមានអារម្មណ៍មិនស្រួលភ្លាម នៅវិនាទីដំបូង ដែលបានជាន់ទឹកដីកម្ពុជា ។ ក្រៅអំពីវៀតណាម គាត់គឺជាជនជាតិបរទេសដំបូងបំផុត ដែលបានមកដល់ទឹកដីកម្ពុជា បន្ទាប់ពីការបរាជ័យរបស់ខ្មែរក្រហម ។ ហើយក៏ជាជនបរទេសដំបូង ដែលមកមើលឃើញនូវអ្វីដែលការកៀបសង្កត់ជិះជាន់ក្នុងអំឡុងបួនឆ្នាំ បាននាំមកដល់កម្ពុជា ។ គាត់ក៏បានត្រូវគេនិយាយប្រាប់អំពីរបបខ្មែរក្រហម ។ ក្រោយមកប្រទេសរបស់គាត់ ក៏បានរៀបសំណុំរឿងប្តឹង ប៉ុល ពត ចោទអំពីបទឧក្រិដ្ឋកម្មដ៏ព្រៃផ្សៃ ។ ប៉ុន្តែ ពិភពលោកនៅមិនទាន់បានជ្រួតជ្រាបអំពីអ្វីដែលខ្មែរក្រហមបានធ្វើដល់ប្រជាជន និងប្រទេសកម្ពុជានៅឡើយ ។ គាត់ក៏មិនអាចត្រៀមចិត្តបាននៅឡើយ ដើម្បីទទួលមើលឃើញនូវការខ្ទេចខ្ទាំ និងសោកនាដកម្ម ដែលគាត់បានឃើញនោះដែរ ។

ដំបូងឡើយ វៀតណាមបានគ្រប់គ្រងប្រទេសកម្ពុជាដោយចំហ ។ គឺជាការត្រួតត្រាមួយដោយពេញទំហឹង ។ តាមការធ្វើដំណើរពីអាកាសយានដ្ឋានចូលមកក្នុងទីក្រុង គាត់យល់ថា ភ្នំពេញ មានរូបភាពជាកន្លែង

ចម្បាំងដាច់ដូចទីក្រុង ។ សញ្ញាណនៃសង្គ្រាមមាននៅគ្រប់ទីកន្លែង ទីក្រុងពោរពេញទៅដោយលេណដ្ឋាន និងធូលីដែលនាំមកជាមួយពីការច្របូកច្របល់នៃសង្គ្រាម និងការស្លាប់ ។ ឃើញថា គ្មានអ្វីនៅក្នុងទីក្រុងដែលមានដំណើរការនោះទេ ។ គាត់បាននិយាយនឹងខ្លួនឯងថា "កន្លែងនេះជាកន្លែងអ្វីហ្នឹង? មិនដូចជាប្រទេសនៅអាស៊ីអាគ្នេយ៍ដែលខ្ញុំធ្លាប់ស្គាល់នោះឡើយ មិនមែនជាទីក្រុងបាងកក ហើយក៏មិនដូចក្រុងព្រៃនគរដែរ" ។

វៀតណាមបាននាំគាត់ទៅស្នាក់នៅសណ្ឋាគារមួយ ដែលមានដំណើរការជាសណ្ឋាគាររួយ៉ាល់ចាស់ ប្ញភ្នំដែលសព្វថ្ងៃហៅថា សាមគ្គី ។ កំពុងស្ថិតនៅក្នុងសភាពរន្ធត់បន្តិចបន្តួចនៅឡើយនោះ គាត់ក៏បានបំពេញសំណុំបែបបទដ៏ចម្លែក ដើម្បីចូលស្នាក់នៅសណ្ឋាគារដ៏ទ្រុឌទ្រោមនេះ ក្រោយមក គាត់ក៏សម្រេចចិត្តចាប់ផ្តើមធ្វើការងារតូចៗខ្លះ ។ ក្រសួងការបរទេសសូវៀត បានឲ្យគាត់ទៅត្រួតពិនិត្យមើលស្ថានទូតរបស់សូវៀត ដែលបានបិទទ្វារកាលពីបួនឆ្នាំមុន ។ គេឲ្យគាត់ប៉ាន់ស្មានថា តើនឹងត្រូវការការងារជួសជុលប៉ុន្មាន ដើម្បីអាចឲ្យស្ថានទូតនោះអាចផ្តើមបើកឡើងវិញបាន ។ គាត់មិនបានដឹងថា ខ្មែរក្រហមបានប្រើកន្លែងនោះធ្វើជាទីតាំងធំ នៃបក្សកុម្មុយនិស្តទេ ។ ការដើររកស្ថានទូតនោះពុំមានការលំបាកឡើយ ព្រោះថា អ្នកការពារគាត់ស្គាល់ផ្លូវ ។ ប៉ុន្តែ គាត់ពុំបានត្រៀមចិត្តចំពោះអ្វីដែលគាត់បម្រុងនឹងឃើញនោះទេ ។ គាត់បានអធិប្បាយក្រោយមកថា "ស្ថានទូតរបស់យើងគឺស្ថិតក្នុងសភាពរញ៉េរញ៉ៃបំផុត បង្ហូចគ្មានកញ្ចក់ គ្រប់យ៉ាងនៅរប៉ាត់រប៉ាយគ្រប់ទីកន្លែងទាំងអស់ ។ នៅក្នុងបន្ទប់ធ្វើការមួយ មានស្នាមថ្កុកឈាមក្រៀមកកមួយយ៉ាងធំ ហើយក៏មានស្នាមនៅជាប់ជញ្ជាំង គឺមានមនុស្សត្រូវបានគេបាញ់សម្លាប់នៅទីនេះ" ។

គាត់ក៏បានគេចពីសភាពនៃការសម្លាប់ប្រល័យនោះហើយចេញទៅក្រៅឯសួនច្បាររបស់ស្ថានទូត ។ ប៉ុន្តែនៅទីនោះ គាត់បានជួបសភាពការណ៍រឹតតែរន្ធត់ជាងមុនទៅទៀត គឺវាលកប់ខ្មោច ដែលទើបនឹងកប់ហើយថ្មីៗមួយ ។ "គួរឲ្យព្រៃផ្សៃណាស់ ទីនោះមានក្លិនអាក្រក់រហូតដល់យើងត្រូវខ្ទប់ច្រមុះ ។ យើងឃើញមានសាកសពមួយចំនួន ដែលកប់ដីមិនជិត ។ គ្មាននរណាដឹងថា សាកសពទាំងនោះជានរណាទេ" ។

មន្ត្រីទូតសូវៀតរូបនោះ បានជាន់ចំកន្លែងសម្លាប់មួយ នៅក្នុងចំណោមកន្លែងសម្លាប់រាប់រយ ដែលមានជុំវិញប្រទេស ។ នៅក្នុងអំឡុងប៉ុន្មានខែចុងក្រោយ ក្រោមការគ្រប់គ្រងរបស់ ប៉ុល ពត ស្ថានទូតចាស់របស់សូវៀតត្រូវបានគេប្រើប្រាស់ជាកន្លែងធ្វើទារុណកម្ម និងសម្លាប់ជនណាដែលខ្មែរក្រហមថ្កោលទោសឲ្យស្លាប់ ។ ក្រោយមកទៀត សូវៀត គឺជាជនជាតិមួយក្នុងចំណោមជនបរទេសដំបូង ដែលបានឃើញសាលារៀន វត្តអារាម និងវាលដែលធ្លាប់ប្រើប្រាស់សម្រាប់ពិឃាតប្រជាជនខ្មែរ ។ ប៉ុន្តែនារសៀលខែកុម្ភៈនោះ មានរឿងរ៉ាវតិចតួចណាស់ ដែលនិយាយអំពីកន្លែងសម្លាប់ទាំងនោះ ដូច្នេះ រ៉ូហ្កាឆូវ ពេលនោះក៏ស្ទុះចេញពីស្ថានទូតដោយភាពរន្ធត់ ។

នាពេលយប់ថ្ងៃនោះ មានការរៀបចំអាហារពេលល្ងាចមួយ ដើម្បីជាកិត្តិយសដល់ភ្ញៀវសូវៀត ។ ពិធីលាងអាហារពេលល្ងាចនោះ បានត្រូវរៀបចំឡើងនៅក្នុងសួនច្បារនៃសណ្ឋាគារ ។ តុត្រូវបានគេដាក់រៀបចំនៅ

ក្រោមដើមឈើ ។ ក្រោយពីបានឃើញនូវស្ថានភាពស្រុកទេស ដែលប្រកបដោយគ្រោះទុរភិក្ស និងជំងឺមក គាត់ពុំបានសង្ឃឹមថា នឹងមានការជប់លៀងទទួលគាត់ឡើយ ។ ប៉ុន្តែម្ចាស់ផ្ទះ ពុំបានធ្វើឲ្យគាត់អស់សង្ឃឹមទេ ។ ក្រឡេកទៅឃើញមាន ចាន កែវ ដែលឆែបមាត់ដាក់ទទួលគាត់ ។ មានរុយរាប់ពាន់ហើរទុំលើម្ហូប ។ នៅឯចុងតុជាម្ចាស់កម្មវិធី គឺរដ្ឋមន្ត្រីការបរទេស ហ៊ុន សែន ។ រ៉ូហ្កាន្ធូវ បានចាប់ដៃស្វាគមន៍ជាមួយបុរសដ៏ក្មេងនោះ ។ រ៉ូហ្កាន្ធូវ បានដឹងជាមុនអំពីពូជពង្សរបស់សមភាគីនយោបាយមួយនេះ រួចទៅហើយ ។ ហ៊ុន សែន បានអះអាងខ្លួនគាត់ថា ជាអតីតមេបញ្ជាការខ្មែរក្រហមថ្នាក់កណ្តាល ដែលបានគេចទៅវៀតណាមនៅឆ្នាំ១៩៧៧ ព្រោះមិនពេញចិត្តចំពោះការចុះទ្រុឌទ្រោមនៃប្រទេស ដែលបណ្តាមកពីការបំផ្លិចបំផ្លាញក្រោមការដឹកនាំរបស់ ប៉ុល ពត ហើយក៏ដោយសារការភ័យខ្លាចថា គាត់ និងក្រុមរបស់គាត់នៅភូមិភាគបូព៌ា ត្រូវគេដាក់ចូលក្នុងបញ្ជីយកទៅសម្លាប់ចាល ។ បុរសទាំងប្រាំ មានទីតាំងនៅជិតព្រំដែន ដែលបង្កលក្ខណៈងាយស្រួលដល់ការរត់គេចអំពីការដេញចាប់របស់ខ្មែរក្រហម ។ ហ៊ុន សែន បានប្រាប់ទាហានវៀតណាមថា គាត់ និងគ្នារបស់គាត់ គឺជាក្រុមប្រឆាំងនឹងខ្មែរក្រហម ។ នៅឆ្នាំ១៩៧៧ គាត់ និងខ្មែរក្រហមផ្តាច់ខ្លួនមួយចំនួនទៀត ដូចជា ហេង សំរិន និង ជា ស៊ីម បានក្លាយជាក្រុមប្រឆាំងនឹងខ្មែរក្រហម ។ តាមរយៈក្រុមនេះ វៀតណាមបានបង្កើតឡើងនូវក្រុមសមរភូមិមុខមួយហៅថា ក្រុមរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ។ នៅពេលនោះ ក្រុមនេះកំពុងគ្រប់គ្រងប្រទេសកម្ពុជា ។ ក្រុមនេះ គឺជាអ្នកមានគុណសម្បត្តិចំពោះប្រទេសជាតិផង និងក៏ជាអាយ៉ងដែលត្រូវបានគេប្រើសម្រាប់ការផ្លាស់ប្តូរអនាគតកម្ពុជា ។

ក្នុងចំណោមក្រុមអ្នកផ្តាច់ខ្លួនទាំងនោះ វៀតណាមបានជ្រើសរើសតែងតាំងឲ្យ ហ៊ុន សែន ធ្វើជារដ្ឋមន្ត្រីក្រសួងការបរទេស ។ នៅពេលនោះ បុរសយុទ្ធជនកុម្មុយនិស្តអាយុ២៨ឆ្នាំរូបនោះ ពុំទាន់មានគុណសម្បត្តិគ្រប់គ្រាន់សម្រាប់មុខតំណែងនេះនៅឡើយ ។ គាត់ស្លៀកពាក់ឯកសណ្ឋានកងទ័ពសឹងតែមួយជីវិតយុវវ័យរបស់គាត់ទៅហើយ ។ គាត់បានឈប់រៀននៅវិទ្យាល័យឯទីក្រុងភ្នំពេញ ហើយចូលរួមចលនាខ្មែរក្រហម តាំងតែពីគាត់អាយុទើប ១៦ឆ្នាំប៉ុណ្ណោះ ។ ហ៊ុន សែន បានចូលរួមក្នុងការប្រយុទ្ធមួយហើយមួយទៀត ។ គាត់ធ្លាប់មានរបួសធ្ងន់ធ្ងរដល់ទៅប្រាំលើក ក្នុងបដិវត្តន៍ដ៏ច្របូកច្របល់ និងពេញលេញដោយការបង្ហូរឈាម ។ គាត់មិនត្រឹមតែធំឡើងធ្លាប់ប្រឈមមុខក្នុងការប្រយុទ្ធធំៗប៉ុណ្ណោះទេ គាត់ថែមទាំងធ្លាប់នាំមុខចលនាបដិវត្តន៍ ដើម្បីផ្តួលរំលំអ្នកនយោបាយខ្មែរក្រហមសំខាន់ៗ ។ គាត់បានបាត់បង់ភ្នែកម្ខាងរបស់គាត់ ក្នុងការវាយប្រយុទ្ធដណ្តើមកាន់កាប់ក្រុងភ្នំពេញ ។ ក្នុងពេលជម្លៀសប្រជាជនចេញពីភ្នំពេញដ៏វន្ទត់នោះ គាត់ត្រូវបានគេដាក់ឲ្យនៅសម្រាកក្រៅការងារ ។ នោះជាឱកាសមួយ ដែលគេទុកឲ្យគាត់ឈប់សម្រាកព្យាបាលជំងឺ ។ ពេលនោះ គាត់បានចងចំណងមិត្តភាពជាមួយគិលានុបដ្ឋាយិកាខ្មែរក្រហមម្នាក់ ហើយក្រោយមកគាត់ក៏បានសុំនារីនោះរៀបការជាមួយ ។ ដោយសារគាត់ជាទាហានពិការមានគុណសម្បត្តិ ខ្មែរក្រហមក៏អនុញ្ញាតឲ្យគាត់រៀបការនៅពេលនោះ ។ គាត់ជាគូទី១៣នៃការរៀបអាពាហ៍ពិពាហ៍ជាក្រុមរបស់ខ្មែរក្រហម ។ ហ៊ុន សែន បាននិយាយថា “ខ្ញុំមានសំណាងណាស់ ដែលគេ

ព្រមឲ្យរៀបការ ព្រោះថាជាធម្មតា គឺមានតែបុរសអាយុលើសពី៣០ឆ្នាំ ឬពិការទេ ទើបគេព្រមឲ្យរៀបការ» ។

ទាំងពីរអ្នកបានរួមរស់នៅជាមួយគ្នា ហើយក្រោយមកប្រពន្ធគាត់ បានបង្កើតកូនមួយឲ្យគាត់ ។ នៅឆ្នាំ ១៩៧៧ ប៉ុន្មានថ្ងៃមុនគេបម្រុងយកគាត់ទៅសម្លាប់ គាត់ក៏បានរត់គេច ។ គាត់បានជួបជុំជាមួយប្រពន្ធរបស់គាត់វិញ ក្រោយពេលវៀតណាមចូលស្រុក ។ នៅពេលនោះ គាត់បានដឹងថា កូនដំបូងរបស់គាត់ត្រូវស្លាប់ នៅពេលដែលគាត់មិននៅ ។

រ៉ូហ្កានូវ បានកត់សម្គាល់អំពីសភាពបញ្ហារូបរាងរបស់ ហ៊ុន សែន ។ ការរងរបួសជាច្រើនដង និងការហូបអាហារមិនគ្រប់គ្រាន់របស់គាត់ ធ្វើឲ្យគាត់មានរូបរាងស្គាំងស្គម ហើយភ្នែកសិប្បនិម្មិតរបស់គាត់ ហាក់ដូចជាដាក់មិនស៊ីបស្រួលសម្រាប់គាត់សោះ ។ ប៉ុន្តែ បន្ទាប់ពីបានជជែកគ្នាមួយសន្ទុះមក ជនជាតិរុស្សីម្នាក់នោះ ក៏បានភ្លេចអំពីរូបរាងខាងក្រៅទាំងនេះរបស់គាត់អស់ ហើយក៏បែរមកផ្តោតអារម្មណ៍លើគំនិត និងឆន្ទៈរបស់គាត់ទៅវិញ ។ គាត់ជាមនុស្សមានគំនិតបញ្ញា ហើយមានគម្រោងការ និងមហិច្ឆតាធំ ចំពោះខ្លួនឯង និងប្រទេសរបស់គាត់ ។ ផ្ទុយអំពីភាពពិតដែលគាត់ធ្លាប់មានជីវិតឆ្លងកាត់អំពើព្រៃផ្សៃ និងការស្រេកឃ្លានខ្វះខាត អស់រយៈពេលយូរឆ្នាំមកនោះ គាត់គួរតែជាមនុស្សដែលមិនយល់អ្វីសោះ សូម្បីតែការសន្ទនាធម្មតា ។ ផ្ទុយទៅវិញ ហ៊ុន សែន បែរជាមនុស្សម្នាក់គួរឲ្យចង់និយាយជាមួយទៅវិញ ។ គាត់ជាបុគ្គលដែលមានសុទិដ្ឋិនិយមចំពោះឱកាសនៅចំពោះមុខគាត់យ៉ាងខ្លាំង ។ រ៉ូហ្កានូវ បាននិយាយថា "ខ្ញុំចាប់អារម្មណ៍ និងចូលចិត្តគាត់ភ្លាមមួយរំពេច" ។

បុរសទាំងពីរនោះ ក៏បានជជែកគ្នាអំពី ថាតើសូវៀតអាចជួយកម្ពុជាបានអ្វីខ្លះ? ដោយគ្មានការធុញទ្រាន់ចំពោះគ្នាទៅវិញទៅមក ហ៊ុន សែន បានចោទសួរនូវសំណួរជាច្រើន ដើម្បីជួយឲ្យគាត់ដឹងថា តើនឹងត្រូវធ្វើយ៉ាងម៉េចទៀតនៅថ្ងៃមុខ ។ ក្រៅពីការស្នាក់នៅដ៏ខ្លីនៅប្រទេសវៀតណាមពេលនោះ ហ៊ុន សែន មិនធ្លាប់បានធ្វើដំណើរចេញទៅក្រៅប្រទេសទេ ។ គាត់សឹងតែមិនស្គាល់ឈ្មោះប្រទេសភាគច្រើននៅលើពិភពលោកផង កុំថាឡើយពីទីតាំងរបស់ប្រទេសទាំងនោះ ។ ការយល់ឃើញអំពីប្រទេសទាំងនោះ គឺរឹតតែនៅឆ្ងាយទៅទៀត ។ ទាំងនេះ គឺបណ្តាលមកពីប្រវត្តិនៃការធំលូតលាស់នៅស្រុកស្រែចម្ការ និងជីវិតជាកងទ័ព ក្នុងដំណើរបដិវត្តន៍កម្ពុជារបស់គាត់ ។ គាត់បានរួចផុតជីវិតពីការប្រយុទ្ធនៅខ្សែត្រៀមជួរមុខនៃសង្គ្រាមដែលគ្មានព្រំដែន, រួចជីវិតពីការទម្លាប់គ្រាប់បែក បេ-៥២, ហើយក្រោយមកទៀត រួចជីវិតពីគ្រោងការសម្លាប់របស់មិត្តរួមអាវុធរបស់គាត់ ។ គាត់ផ្តោតអារម្មណ៍ទាំងស្រុង ទៅលើការងារចំពោះមុខ ដោយមិនភ្ញាក់ផ្អើលរន្ធត់ពីការប្រព្រឹត្តផ្ទុយពីឧត្តមគតិឡើយ ។

ហ៊ុនសែនបានស្តាប់ រ៉ូហ្កានូវ និយាយពន្យល់ដោយយកចិត្តទុកដាក់ ។ រ៉ូហ្កានូវ បានអធិប្បាយពី ហ៊ុន សែន ថា "ខ្ញុំឃើញដោយផ្ទាល់ភ្នែកខ្លួនឯងថា ហ៊ុន សែន ជាកូនសិស្សដ៏ល្អ និងឆាប់ចេះចាំម្នាក់" ។

ហ៊ុន សែន ខំប្រឹងស្វែងយល់អំពីអ្វីដែលពិបាក ដើម្បីបំពេញនូវចន្លោះនៃការខ្វះខាតរបស់គាត់ ។ តាមពិត

ទៅ ប្រវត្តិជាអ្នកស្រែចម្ការរបស់គាត់ បានផ្តល់ផលល្អច្រើនដល់គាត់ទៅវិញ ។ គាត់បានធំដឹងក្តីឡើងនៅកំពង់ចាម ជាខេត្តតែមួយដែលគាត់ត្រូវខ្មែរក្រហមឲ្យនៅប្រចាំការ ។ គាត់កើតនៅឆ្នាំ១៩៥១ ហើយជាកូនប្រុសប្អូនដ៏សំណព្វម្នាក់ នៅក្នុងគ្រួសារមួយដែលមានសមាជិកច្រើន ។ ដោយមានមោទនភាពចំពោះខ្លួនគាត់ ហ៊ុន សែន ត្រូវបានបញ្ជូនឲ្យទៅរៀនវិទ្យាល័យនៅភ្នំពេញ ។ ដោយសារថាឪពុកម្តាយរបស់គាត់មានលុយកាក់តិចតួច គាត់បានសុំស្នាក់នៅវត្តនាគវ័ន ក្បែរសាលាឥន្ទ្រទេវី ដែលគាត់រៀន ។ នូវ គៀន ដែលជាបងប្អូនសាច់ឆ្ងាយរបស់គាត់ បានចុះឈ្មោះឲ្យគាត់ចូលខ្មែរក្រហម ។ ដំបូងឡើយ គាត់ធ្វើជាអ្នករត់សំបុត្រចែកពីភ្នំពេញទៅតាមខេត្ត ។ ប៉ុន្តែបងប្អូនរបស់គាត់ត្រូវបានគេចាប់ខ្លួន ហើយហេតុការណ៍នោះ ធ្វើឲ្យ ហ៊ុន សែន ភ័យយ៉ាងខ្លាំង ។ គាត់បាននិយាយថា "ខ្ញុំត្រូវតែរត់គេចចេញពីភ្នំពេញ ហើយរកឲ្យឃើញទីតាំងបដិវត្តន៍" ។ ក្រោយមក គាត់បានចូលបក្ស និងបដិវត្តន៍នៅឆ្នាំ១៩៧០ ។

រដ្ឋមន្ត្រីក្រសួងការបរទេសដ៏ក្មេងខ្ចី និងប្រហែលជាក្មេងជាងគេ និងមានបទពិសោធន៍តិចជាងគេនោះ បានអង្គុយស្តាប់ រ៉ូហ្គាឆូវ ហើយស្រង់យកពត៌មានដ៏មានតម្លៃដែល រ៉ូហ្គាឆូវ ផ្តល់ឲ្យគាត់ ។ គាត់យកគំនិតនោះមកវិភាគ ដើម្បីអាចយកយោបល់នោះមកប្រើបាននៅក្នុងស្ថានភាពកម្ពុជា ។ ហ៊ុន សែន ចោទសួរសំណួរជាច្រើនរហូតដល់គាត់អាចយល់អំពីទំនាក់ទំនងរវាងវៀតណាម និងសូវៀត និងយល់ថា តើទំនាក់ទំនងនោះ ជះឥទ្ធិពលយ៉ាងណាខ្លះដល់ប្រទេសកម្ពុជា ។ តាមរយៈនៃការរៀនសូត្រនេះ រ៉ូហ្គាឆូវ អាចមើលឃើញអំពីការប៉ិនប្រសប់របស់អ្នករួចពីស្លាប់ម្នាក់នេះថា គាត់ពិតជាមនុស្សមានទេពកោសល្យជាងគេម្នាក់មែន ។

ពេលនោះ គឺជាចំណុចចាប់ផ្តើមដំបូងមួយ នៃជំនួយរបស់បរទេសមួយចំនួន ហើយក៏បានសសេរប្រវត្តិសាស្ត្រកម្ពុជាឡើងវិញ ។ រ៉ូហ្គាឆូវ បានក្លាយជាអ្នកគាំទ្រ ហ៊ុន សែន ដំបូងគេ ។ ទោះបីការបង្ហាញឲ្យឃើញពីទេពកោសល្យរបស់ ហ៊ុន សែន គឺជាការលំបាកមួយក៏ដោយ ក៏រ៉ូហ្គាឆូវ នៅតែជឿជាក់ចំពោះការបង្ហាញនោះជានិច្ច ។ គាត់បានបញ្ចូលការធ្វើដំណើរមកមើលខុសត្រូវ ហ៊ុន សែន ពីរ ឬបីដង ក្នុងមួយឆ្នាំ ជាភារកិច្ចចាំបាច់របស់គាត់ ។ ហើយគ្រប់ពេលដែលគាត់មក គឺគាត់តែងតែមានការពេញចិត្តចំពោះការវិវត្តិន៍របស់ ហ៊ុន សែន ជានិច្ច ។ "ខ្ញុំបានមើលឃើញនូវការរីកចម្រើនគំនិតរបស់គាត់ ទាំងការងារក្រៅប្រទេស និងការងារក្នុងប្រទេស ហើយគាត់បានក្លាយជាអ្នកនយោបាយដ៏ពូកែមួយរូប" ។

នៅទសវត្សរ៍ក្រោយៗមកទៀត ហ៊ុន សែន បានពឹងផ្អែកយ៉ាងខ្លាំង ទៅលើអ្នកជំនួយការសូវៀតរបស់គាត់រូបនោះ ។ នៅវគ្គចុងក្រោយនៃសង្គ្រាមត្រជាក់ កម្ពុជាបានក្លាយទៅជាការចាប់អារម្មណ៍មួយ របស់អន្តរជាតិ ។ ក្នុងពេលសង្គ្រាមវៀតណាម កម្ពុជាគ្រាន់តែជាអ្នកបន្ទាប់បន្សំក្រៅឆាកប៉ុណ្ណោះ ។

ការគ្រប់គ្រងរបស់វៀតណាមនៅលើទឹកដីកម្ពុជា ត្រូវបានប្រទេសនានាដាក់ធ្វើជាចំណុចសំខាន់ នៃបញ្ជីបញ្ហាពិភពលោករបស់ពួកគេ ។ បញ្ហាកម្ពុជា ក៏ជាបញ្ហាមួយក្នុងចំណោមបញ្ហាទាំងបី ដែលកាត់ផ្តាច់សម្ព័ន្ធភាព

រវាងចិន និងសូវៀតដែរ ។ បញ្ហាពីរទៀតគឺបញ្ហាព្រំដែន និងការគ្រប់គ្រងរបស់សូវៀតលើប្រទេសអាហ្គានីស្ថាន ។ រឿងកម្ពុជាក៏ត្រូវបានដាក់នៅក្នុងនីតិកាលសំខាន់នៅអង្គការសហប្រជាជាតិ ។ បញ្ហាកម្ពុជា ក៏បានជួយពង្រឹងសាមគ្គីភាពរវាងចិន និងសហរដ្ឋអាមេរិក និងប្រទេសនានា នៅអាស៊ានដែរ ។ រឿងនោះ ក៏ជាហេតុផលចម្បង ដែលសហរដ្ឋអាមេរិមិនព្រមមានទំនាក់ទំនងធម្មតាវិញជាមួយវៀតណាមដែរ ។ អ្វីៗនឹងមិនទៅមុខទេ ប្រសិនបើរឿងរបស់កម្ពុជាមិនអាចដោះស្រាយបាន ។

# កាលប្បវត្តិសង្ខេប

សតវត្សរ៍ទី៩ ដល់ទី១៤ : សម័យអង្គរ (ចក្រភពខ្មែរ) ។

សតវត្សរ៍ទី១៤ ដល់ទី១៩ : ការចុះអាប់ឱននៃរាជាណាចក្រអង្គរ ។

១៨៦៣-១៨៦៤ : ព្រះមហាក្សត្រនរោត្តម ឡាយព្រះហស្តលេខាលើសន្ធិសញ្ញាឲ្យមានអាណាព្យាបាលមួយរបស់បារាំង ដែលមានថិរវេលារហូតដល់ឆ្នាំ១៩៥៣ ។

១៩៣០ : ស្ត្រីជាតិបារាំង ស៊ុយហ្សន ការ៉ុឡេស បង្កើតពុទ្ធសាសនបណ្ឌិត្យដែលនឹងបម្រើជាមជ្ឈដ្ឋានជួយដល់ការរីកលូតលាស់របស់ចលនាទាមទារឯករាជ្យមួយរបស់កម្ពុជា និងជាមូលដ្ឋានមួយរបស់ សឺង ង៉ុកថាញ់ ធ្វើសកម្មភាពដែរ ។

◆ ហូ ជីមិញ បង្កើតបក្សកុម្មុយនិស្តឥណ្ឌូចិន ដែលផ្សាយឥទ្ធិពលមកលើប្រទេសវៀតណាម កម្ពុជា និងឡាវ ។

១៩៤១ : ពួកទាហានជប៉ុនចូលក្រុងភ្នំពេញ ។

◆ សម្តេច ព្រះនរោត្តម សីហនុ ត្រូវបានអភិសេកជាព្រះមហាក្សត្រដោយរដ្ឋាភិបាលក្រុងវីឈី ។

១៩៤២ : សឺង ង៉ុកថាញ់ រៀបចំបាតុកម្មដំបូងៗប្រឆាំងបារាំងនៅក្រុងភ្នំពេញ ដើម្បីគាំទ្រគំនិតជាតិនិយមរបស់ព្រះសង្ឃទាំងឡាយ ។

◆ នៅទីក្រុងបាងកក ពួកកម្ពុជាបានបង្កើតគណៈកម្មាធិការឥស្សរៈ (សេរីភាព) ដើម្បីតស៊ូប្រឆាំងនឹងពួកបារាំង ។

១៩៤៥ : ពួកទាហានជប៉ុន បានកម្ចាត់ក្រុមអ្នកតំណាងរដ្ឋាភិបាល វីឈី ចេញពីអំណាចដោយការធ្វើពលប្រហារមួយហើយយល់ព្រមផ្តល់ "ឯករាជ្យ" ឲ្យប្រទេសកម្ពុជាដោយមានសម្តេច ព្រះនរោត្តម សីហនុ ជាព្រះមហាក្សត្រផង ។

◆ សង្គ្រាមផុតរលត់ សម្តេច ព្រះនរោត្តម សីហនុ ចង់បានការវិលត្រឡប់របស់ពួកបារាំងមកវិញ ។

◆ នៅទីក្រុងហាណូយ ហូ ជីមិញ ប្រកាសឯករាជ្យសម្រាប់ប្រទេសវៀតណាម ។

១៩៤៦ : សង្គ្រាមឥណ្ឌូចិនលើកទីមួយ បានផ្ទុះឡើងរវាងកងទ័ពវៀតមិញរបស់ ហូ ជីមិញ និងពួកបារាំង ។

១៩៤៩ : សាឡុត ស (អនាគត ប៉ុល ពត) បានធ្វើដំណើរទៅកាន់ទីក្រុងប៉ារីស ដើម្បីរៀនសូត្រ ហើយបានស្ថិតនៅទីនោះរហូតដល់ឆ្នាំ១៩៥៣ ។ នៅពេលគាត់ត្រឡប់មកប្រទេសកម្ពុជាវិញ គឺគាត់បានក្លាយទៅជាជនកុម្មុយនិស្តរួចទៅហើយ ។

១៩៥១ : ការបង្កើតបក្សប្រជាជនបដិវត្តន៍ខ្មែរ ចេញពីបក្សកុម្មុយនិស្តឥណ្ឌូចិន ។

១៩៥៣ : សម្តេច ព្រះនរោត្តម សីហនុ បានទទួលពីប្រទេសបារាំងនូវឯករាជ្យដែលមានកំណត់មួយ ។

១៩៥៤ : កងទ័ព ហូ ជីមិញ វាយប្រហារពួកបារាំងនៅ ឌៀនបៀនភូ ។

◆ សន្និសីទក្រុងហ្សឺណែវ ដើម្បីដោះស្រាយជម្លោះរបស់កូរ៉េ និងឥណ្ឌូចិន ។

◆ សម្តេច ព្រះនរោត្តម សីហនុ ទទួលកាន់កាប់អំណាចទាំងស្រុងមួយលើប្រទេសកម្ពុជាមួយ ដែលមានឯករាជ្យ ។

◆ មេដឹកនាំកុម្មុយនិស្តខ្មែរ សឺង ង៉ុកមិញ និងចលនាកុម្មុយនិស្តខ្មែរប្រហែលពាក់កណ្តាល បានចាកចេញពីប្រទេសទៅវៀតណាមខាងជើង ។

១៩៥៥ : ការបោះឆ្នោតនៅប្រទេសកម្ពុជា ។ សម្តេច ព្រះនរោត្តម សីហនុ បានដាក់រាជ្យជាគុណប្រយោជន៍ដល់ព្រះបិតាព្រះអង្គ ។ សម្តេចបានបង្កើតគណបក្សជារបស់ព្រះអង្គផ្ទាល់ ហើយបានទទួលជ័យជម្នះភ្លូកទឹកភ្លូកដីមួយ ។

១៩៥៥-១៩៦០ : ពួកកុម្មុយនិស្តបានសាកល្បងជ្រៀតជ្រែកតាំងនៅក្នុងក្រុងភ្នំពេញក៏ដូចនៅជនបទ ។

១៩៥៩ : និពន្ធនាយកកាសែតមួយក្នុងចំណោមកាសែតពួកកុម្មុយនិស្តបានត្រូវធ្វើឃាដ ។

◆ ស៊ីវហេង មេដឹកនាំកុម្មុយនិស្តសម្រាប់ផ្នែកខាងក្នុងប្រទេសស៊ីវហេង បានចុះចូលខាងសម្តេច ព្រះនរោត្តម សីហនុ ជាសាធារណៈ ។

១៩៦០ : ក្នុងឱកាសនៃមហាសន្និបាតមួយដែលបើកធ្វើនៅក្រុងភ្នំពេញ ពួកកុម្មុយនិស្តបានបង្កើតបក្សម៉ាក្ស-លេនីន មួយរបស់កម្ពុជា គឺបក្សពលករកម្ពុជា (ដែលនឹងត្រូវប្រសិទ្ធនាមថា បក្សកុម្មុយនិស្តកម្ពុជានៅឆ្នាំ១៩៦៦) ។

១៩៦៣ : នៅមហាសន្និបាតលើកទី២ សាឡុត ស បានក្លាយទៅជាអគ្គលេខាធិការបក្ស ។

◆ ភាគច្រើននៃមេដឹកនាំបក្ស បានចាកចេញពីក្រុងភ្នំពេញ ដើម្បីបង្កើតចលនារបស់គេក្នុងព្រៃម៉ាគី ។

១៩៦៥ : សហរដ្ឋអាមេរិក ផ្តើមដាក់កងទ័ពប្រយុទ្ធជាលើកដំបូងបង្អស់នៅប្រទេសវៀតណាម ។

◆ សម្តេច ព្រះនរោត្តម សីហនុ កាត់ផ្តាច់ទំនាក់ទំនងទាំងអស់ជាមួយសហរដ្ឋអាមេរិក ។

១៩៦៦ : សម្តេច ព្រះនរោត្តម សីហនុ អនុញ្ញាតឲ្យពួកកុម្មុយនិស្តវៀតណាមប្រើប្រាស់តំបន់នានា នៅតាមព្រំដែន និងកំពង់ផែសមុទ្ររបស់ព្រះអង្គ ។

១៩៦៧ : ការបះបោររបស់ប្រជាកសិករប្រឆាំងនឹងការប្រមូលស្រូវនៅសំឡូត ក្នុងភាគពាយ័ព្យប្រទេស ។ ការងើបបះបោរនេះ បាននាំឲ្យពួកកុម្មុយនិស្តសម្រេចចិត្តផ្តើមការតស៊ូដោយអាវុធប្រឆាំងនឹងសម្តេច ព្រះនរោត្តម សីហនុ ។

១៩៦៧-១៩៨០ : សម្តេច ព្រះនរោត្តម សីហនុ បានរ៉ាប់រងដោយការប្រយុទ្ធនឹងចលនាខ្មែរក្រហម

ដ៏តូចដែលមានកម្លាំងឡើងដល់ ៥.០០០នាក់ - ប្រឈមនឹងកងទ័ពជាតិ ៣៥.០០០នាក់ ។

១៩៦៩ : ការទម្លាក់គ្រាប់បែករបស់អាមេរិកាំងជាសម្ងាត់ និងដោយខុសច្បាប់លើគោលដៅនានារបស់វៀតណាម ដែលស្ថិតនៅក្នុងទឹកដីខ្មែរ ។

១៩៧០ : ថ្ងៃទី១៨ ខែមីនា : សម្តេច ព្រះនរោត្តម សីហនុ បានត្រូវទម្លាក់ពីអំណាចដោយ លន់ នល់, សិរិមតៈ និង ចេង ហេង ។

- ថ្ងៃទី២៣ ខែមីនា : សម្តេច ព្រះនរោត្តម សីហនុ ប្រកាសពីការបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា ដែលរួមមានពួកខ្មែរក្រហមផង ។
- ថ្ងៃទី៩ ខែតុលា : សាធារណរដ្ឋខ្មែរ បានត្រូវប្រកាសឡើងនៅក្នុងភ្នំពេញ ។

១៩៧១ : កងទ័ពវៀតណាមខាងជើង បន្តការវាយប្រយុទ្ធទល់នឹងកងទ័ព លន់ នល់ ក្នុងពេលដែលពួកខ្មែរក្រហមបង្កើតកងទ័ពរបស់ខ្លួន ។ នៅខែធ្នូ កងទ័ពក្រុងភ្នំពេញ បានផ្តើមធ្វើប្រតិបត្តិការសឹកចេនឡាទី២ ហើយបានត្រូវរងការវាយប្រហារយ៉ាងខ្លាំងដោយកងទ័ពវៀតណាមខាងជើង ។ ប្រតិបត្តិការសឹកនេះ មិនដែលចាប់ផ្តើមជាថ្មីសោះឡើយ ។

១៩៧២ : លន់ នល់ ត្រូវបានបោះឆ្នោតជាប់ជាប្រធានាធិបតី របស់សាធារណរដ្ឋខ្មែរ ។

១៩៧៣ : ថ្ងៃទី២៧ ខែមករា : ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្រុងប៉ារីសស្តីពីការបញ្ចប់សង្គ្រាមនៅវៀតណាម ។ ពួកកុម្មុយនិស្តកម្ពុជាបានបដិសេធមិនចរចា ។

- ពួកខ្មែរក្រហម រ៉ាប់រងការវាយប្រយុទ្ធភាគច្រើនបំផុតនៅកម្ពុជា នៅពេលដែលពួកកុម្មុយនិស្តវៀតណាម ដកថយទៅបណ្តាតំបន់ជាប់ព្រំដែន ។
- សហរដ្ឋអាមេរិក បានចាប់ផ្តើមទម្លាប់គ្រាប់បែកលើប្រទេសកម្ពុជាឡើងវិញ ។
- ពួកខ្មែរក្រហមបញ្ជាឲ្យបង្កើតសហករណ៍ក្នុងតំបន់ទាំងអស់ដែលពួកគេកាន់កាប់ ។
- សមាជអាមេរិកាំងបានតម្រូវឲ្យបញ្ឈប់ការទម្លាក់គ្រាប់បែកនៅថ្ងៃទី១៥ ខែសីហា ។

១៩៧៤ : ជាឆ្នាំចុងក្រោយដែលពោរពេញដោយសង្គ្រាមនៅប្រទេសកម្ពុជា ។ ពួកខ្មែរក្រហមដណ្តើមយកការគ្រប់គ្រងចលនាបះបោរដោយកម្ចាត់ពួកកុម្មុយនិស្ត ដែលត្រឡប់មកពីវៀតណាមខាងជើង បណ្តាសមាជិកនៃជនជាតិភាគតិចវៀតណាម និងពួកសម្តេច ព្រះនរោត្តម សីហនុ និយម ។

១៩៧៥ : ការវាយលុកផ្តាច់ព្រ័ត្ររបស់ខ្មែរក្រហម បានចាប់ផ្តើមនៅថ្ងៃចូលឆ្នាំសកល (០១-០១-១៩៧៥) ។

- ថ្ងៃទី១៧ ខែមេសា : ពួកខ្មែរក្រហមដើរចូលក្នុងក្រុងភ្នំពេញ និងបញ្ជាឲ្យជម្លៀសប្រជាជនចេញពីរដ្ឋធានីភ្លាមមួយរំពេច ។

◆ ថ្ងៃទី៣០ ខែមេសា ៖ ពួកកុម្មុយនិស្តវៀតណាមឈ្នះសង្គ្រាម និងដណ្ដើមកាន់កាប់ទីក្រុងព្រៃនគរ ។
◆ ថ្ងៃទី១២ ខែឧសភា ៖ ការចាប់នាវាដឹកទំនិញអាមេរិកាំងឈ្មោះ ម៉ៃយ៉ាហ្គេ ដោយកងទ័ពជើងទឹកខ្មែរក្រហម ដែលនាំឲ្យមានការទម្លាក់គ្រាប់បែករបស់អាមេរិកាំង និងឧប្បត្តិហេតុធ្ងន់ធ្ងរមួយ ។

បដិវត្តន៍ខ្មែរក្រហមប្រើវិធីប្រែងរៀបចំប្រជាជនទាំងអស់ឲ្យរស់នៅក្នុងសហករណ៍នានា តាមជនបទ ។ នៅខែកក្កដា ពួកកុម្មុយនិស្តបានចាប់ផ្ដើមដាក់មន្ទីរផ្សេងៗរបស់បក្ស និងរដ្ឋាភិបាលនៅក្រុងភ្នំពេញ ។ នៅចុងឆ្នាំ ពួកកុម្មុយនិស្ត បានបញ្ជាឲ្យធ្វើការជម្លៀសពួកអ្នកទីក្រុងជាលើកទីពីរពីភូមិភាគនិរតីទៅភូមិភាគពាយ័ព្យ និងភូមិភាគផ្សេងៗទៀត ដែលនៅភាគខាងជើង ។

១៩៧៦ ៖ នៅមហាសន្និបាតបក្ស, ពួកមេដឹកនាំបានសម្រេចបង្កើនល្បឿនបដិវត្តន៍ និងពង្រីកស្រែចម្ការថែមទៀត ។

◆ ការប្រកាសឲ្យប្រើរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ។
◆ សម្ដេច ព្រះនរោត្ដម សីហនុ សុំលាលែងពីមុខងារទាំងអស់របស់ព្រះអង្គជាព្រះប្រមុខរដ្ឋ ។
◆ ការប្រកាសជាផ្លូវការនូវរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យដោយមាន "ប៉ុល ពត" ជានាយករដ្ឋមន្ត្រី ។
◆ មរណភាពរបស់ ម៉ៅ សេទុង ។ ប៉ុល ពត ចាកចេញពីមុខតំណែងរបស់គាត់ជាបណ្ដោះអាសន្ន ។
◆ ការផ្ដើមធ្វើការសម្លាប់ពួកមេដឹកនាំបក្សក្នុងក្របខណ្ឌនៃបញ្ហាមានទំនាក់ទំនងជាមួយប្រទេសវៀតណាម ។
◆ ពួកកុម្មុយនិស្តបញ្ចប់ការបោសសម្អាតភូមិភាគឧត្តរ ។

១៩៧៧ ៖ បក្សបានបញ្ចប់ការកម្ចាត់ចោលបណ្ដាមេដឹកនាំនៃរបបចាស់ស្ទើរតែទាំងស្រុង និងបង្កើនការធ្វើវិសុទ្ធកម្មក្នុងជួររបស់ខ្លួនផ្ទាល់ ។

◆ ប្រទេសកម្ពុជា បង្កឧប្បត្តិហេតុផ្សេងៗតាមព្រំដែនជាមួយប្រទេសថៃ និងវៀតណាម ។ គឺជាមួយប្រទេសវៀតណាមនេះឯងដែលការវិវាទមានលក្ខណៈធ្ងន់ធ្ងរបំផុត ។
◆ ការផ្ដើមធ្វើការបោសសម្អាតភូមិភាគពាយ័ព្យ ។
◆ ខែកក្កដា ៖ ប្រទេសវៀតណាម និងប្រទេសឡាវ ចុះហត្ថលេខាលើសន្ធិសញ្ញាមិត្តភាពមួយ ដែលពួកកុម្មុយ និស្តកម្ពុជា ចាត់ទុកជាគម្រុយសំខាន់មួយឆ្ពោះទៅរកគោលដៅរបស់វៀតណាម ក្នុងការបង្កើតសហព័ន្ធឥណ្ឌូចិនមួយ ។
◆ ខែកញ្ញា ៖ ប៉ុល ពត នៅទីបំផុតក៏ប្រកាសជាសាធារណៈថា ប្រទេសរបស់គាត់ជាប្រទេសកាន់លទ្ធិកុម្មុយនិស្ត ។ គាត់បានធ្វើដំណើរទៅប្រទេសចិន និងកូរ៉េខាងជើង ដោយលាតត្រដាងឲ្យដឹង

អាចកំបាំងថា គាត់ជា សាឡុត ស ។

- សង្គ្រាមតាមព្រំដែនជាមួយប្រទេសវៀតណាមបានចាប់ផ្តើម ។
- ថ្ងៃទី៣១ ខែធ្នូ ៖ ប្រទេសកម្ពុជាកាត់ផ្តាច់ទំនាក់ទំនងការទូតរបស់ខ្លួនជាមួយប្រទេសវៀតណាម ។

១៩៧៨ ៖ ពួកវៀតណាម ដកថយកងទ័ពរបស់គេ ពីក្នុងប្រទេសកម្ពុជា, ពួកខ្មែរក្រហមស្រែកប្រកាសពីជោគជ័យ ។

- ក្នុងឱកាសនៃការប្រជុំជាសម្ងាត់មួយនៅនិទាឃរដូវ ពួកមេដឹកនាំវៀតណាម បានសម្រេចចិត្តចូលលុកលុយប្រទេសកម្ពុជា និងផ្តួលរំលំរដ្ឋាភិបាល ប៉ុល ពត ។
- ការបោសសម្អាតភូមិភាគបូព៌ា ។
- ដោយរួមប្រជុំជាមហាសន្និបាត បក្សកម្ពុជាបានបង្ហាញផែនការខស្សវាហូបនីយកម្មរបស់ខ្លួន ។
- ខែធ្នូ ៖ វិទ្យុរបស់វៀតណាមបានប្រកាសឲ្យដឹងជាសាធារណៈ ពីការបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដើម្បីប្រឆាំងនឹងរដ្ឋាភិបាល ប៉ុល ពត ។
- ម៉ាល់ខូម ខាដវែល ត្រូវបានធ្វើឃាដនៅក្រុងភ្នំពេញ ។
- ថ្ងៃទី២២ ខែធ្នូ ៖ ប្រទេសវៀតណាមចាប់ផ្តើមការវាយលុករបស់ខ្លួន ។

១៩៧៩ ៖ ថ្ងៃទី៧ ខែមករា ៖ កងទ័ពវៀតណាមដណ្តើមបានទីក្រុងភ្នំពេញ ។

- ថ្ងៃទី៨ ខែមករា ៖ ពួកវៀតណាមប្រកាសជាសាធារណៈពីការបង្កើតក្រុមប្រឹក្សាប្រជាជនបដិវត្តន៍មួយ ដោយមាន ហេង សំរិន អតីតប្រធានកងពលធំលេខ៤ ជាអ្នកដឹកនាំ ។
- ថ្ងៃទី១៦ ខែកុម្ភៈ ៖ រដ្ឋាភិបាល ហេង សំរិន ចុះហត្ថលេខាលើសន្ធិសញ្ញាមិត្តភាពមួយជាមួយប្រទេសវៀតណាម ។
- ប៉ុល ពត និងពួកកុម្មុយនិស្តកម្ពុជា ដែលនៅតែស្មោះត្រង់នឹងគាត់បានប្រមូលផ្តុំគ្នាឡើងវិញនៅតាមបណ្តោយព្រំដែនរវាងប្រទេសថៃ និងកម្ពុជា ។ ដោយមានការគាំទ្រពីប្រទេសចិន ពួកខ្មែរក្រហមបានផ្តើមធ្វើសង្គ្រាមទ័ពព្រៃមួយប្រឆាំងនឹងកងទ័ពកាន់កាប់វៀតណាម ។
- គ្រោះទុរ្ភិក្សគំរាមកំហែងប្រទេសកម្ពុជា ដែលនឹងប៉ះពាល់ដល់មនុស្សពីរលាននាក់, នេះបើតាមការឲ្យដឹងរបស់ពួកមេដឹកនាំថ្មីនៅក្រុងភ្នំពេញ ។ ការធ្វើយុទ្ធនាការផ្តល់ជំនួយជាអន្តរជាតិដ៏សម្បើមមកឲ្យប្រជាជនកម្ពុជា ។
- ការបង្កើត "រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ" ដោយអតីតនាយករដ្ឋមន្ត្រី សឺន សាន ដែលជាចលនាតស៊ូមិនមែនកុម្មុយនិស្តប្រឆាំងនឹងពួកវៀតណាម ។
- ការដាក់ទណ្ឌកម្មសេដ្ឋកិច្ចរបស់អាមេរិកាំងប្រឆាំងនឹងប្រទេសវៀតណាម ។

◆ ការកាត់ទោស ប៉ុល ពត និង អៀង សារី ដោយកំបាំងមុខ នៅក្រុងភ្នំពេញពីបទប្រល័យពូជសាសន៍ ។

១៩៨០ ៖ គ្រោះទុរ្ភិក្សធំមួយត្រូវបានបញ្ចៀស ។

◆ សម្ដេច ព្រះនរោត្ដម សីហនុ រៀបចំបង្កើតចលនាតស៊ូផ្ទាល់ព្រះអង្គ ។

◆ ការប្រឹងប្រែងដំបូងៗក្នុងការស្ដារបនាប្រទេសឡើងវិញ ៖ ការបញ្ចូលក្រដាសប្រាក់ជាថ្មី, ការបើកមហាវិទ្យាល័យវេជ្ជសាស្ត្រ និងការរៀបចំឲ្យមានប្រព័ន្ធអប់រំឡើងវិញ ។

◆ ការលេចធ្លោឡើងនូវមនោសញ្ចេតនាប្រឆាំងវៀតណាម ។

១៩៨១ ៖ ការបញ្ចប់នូវជំនួយស្បៀងអាហារ ។

◆ របបក្រុងភ្នំពេញប្រកាសពីការបង្កើតបក្សម៉ាក្ស-លេនីន ថ្មីមួយ គឺបក្សប្រជាជនបដិវត្តន៍កម្ពុជា ។

◆ ការបោះឆ្នោតសភា ។ មានតែគណបក្សកាន់អំណាចមួយប៉ុណ្ណោះ អាចដាក់បេក្ខជនរបស់ខ្លួនឲ្យឈរឈ្មោះបោះឆ្នោត ។

◆ ចលនាតស៊ូទាំងបី -ខ្មែរក្រហម, សម្ដេច ព្រះនរោត្ដម សីហនុ និង សឺន សាន- គ្រោងបង្កើតរដ្ឋាភិបាលចម្រុះមួយ ។ សមាគមអាស៊ានជាអ្នកផ្ដល់អាវុធ និងលុយកាក់ទៅឲ្យចលនាតស៊ូមិនមែនកុម្មុយនិស្ដ ។

◆ នៅក្រុងញូវយ៉ក, សន្និសីទអន្តរជាតិស្ដីពីប្រទេសកម្ពុជាដែលតំណាងតែចលនាតស៊ូ និងសម្ព័ន្ធមិត្តរបស់ខ្លួនប៉ុណ្ណោះ ។

១៩៨២ ៖ ការវាយប្រយុទ្ធនៅតាមព្រំដែនថៃ-កម្ពុជា ប្រឆាំងនឹងកងទ័ពខ្មែរក្រហម ។ ការវាយលុករបស់វៀតណាម ជាលើកដំបូងប្រឆាំងនឹងចលនាតស៊ូ ។

◆ នៅខែមិថុនា, ចលនាតស៊ូរួមគ្នាបង្កើតរដ្ឋាភិបាលចម្រុះមួយជាផ្លូវការ ។

◆ ការដកកងទ័ពរបស់វៀតណាមជាលើកដំបូង ។ ប៉ែន សុវណ្ណ ជាជនទី២របស់របបក្រុងភ្នំពេញ ត្រូវបានកម្ចាត់ចេញ (ដោយខុបាយ) ពីអំណាច ។

១៩៨៣ ៖ ការវាយលុកកាន់តែកើនឡើង, ពួកវៀតណាមបានវាយប្រហារជំរំជនភៀសខ្លួននានា របស់ចលនាតស៊ូ ហើយដេញតាមទាហានបះបោររហូតដល់ទឹកដីថៃ ។

◆ នៅប្រទេសវៀតណាម មានបើកសន្និសីទកំពូលរបស់ឥណ្ឌូចិនលើកទីមួយ តាំងពីឆ្នាំ១៩៧០ ដែលឲ្យសច្ចាប័នដល់ការត្រួតត្រារបស់វៀតណាមលើប្រទេសឡាវ និងប្រទេសកម្ពុជា ។

◆ និគមជនវៀតណាមជាច្រើនបានចូលមកតាំងនៅប្រទេសកម្ពុជា ។ តាមការឲ្យដឹងរបស់ក្រុងព្រៃនគរថា ចំនួនរបស់និគមជនទាំងនោះ មានមិនលើសពីចំនួនសហគមន៍វៀតណាម ដែលធ្លាប់រស់នៅក្នុងប្រទេសកម្ពុជាពីមុនទេ ។

១៩៨៤ ៈ នៅខែកក្កដា, រដ្ឋាភិបាលក្រុងភ្នំពេញទទួលស្គាល់ថា សង្គ្រាមតាមព្រំដែនបានរាលដាលមកក្នុងប្រទេសហើយថា ស្ថានការណ៍មានសភាព "តានតឹង" ។

១៩៨៥ ៈ ពីខែធ្នូ ឆ្នាំ១៩៨៤ ដល់ខែមីនា ឆ្នាំ១៩៨៥, ការវាយលុកជាទូទៅរបស់វៀតណាម នៅតាមបណ្ដោយព្រំដែនថៃ-កម្ពុជា ប្រឆាំងនឹងមូលដ្ឋានទាំងឡាយរបស់ចលនាតស៊ូ ។

- ការច្របូកច្របល់ក្នុងផ្ទៃចលនាតស៊ូ ។ ការឈ្លោះទាស់ទែងផ្ទៃក្នុងជុំវិញខ្លួន សឺន សាន ។ សម្ដេច ព្រះនរោត្ដម សីហនុ ប្រកាសថា ព្រះអង្គមិនប្រាកដក្នុងព្រះទ័យរកឃើញដំណោះស្រាយមួយ នៅពេលព្រះអង្គ នៅមានព្រះជន្មនៅឡើយទេ ។
- ហ៊ុន សែន បានក្លាយទៅជានាយករដ្ឋមន្ត្រីនៅពេលគាត់មានអាយុ ៣៤ឆ្នាំ ។
- អង្គការអាមេរិកាំងមួយ បានចោទប្រកាន់រដ្ឋាភិបាលក្រុងភ្នំពេញពីបទរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ។

១៩៨៦ ៈ ជោគជ័យរបស់ចលនាតស៊ូក្នុងសង្គ្រាមឆ្មក់របស់ខ្លួន ។ ដំណើរលំបាករ៉ាប់រងរបស់ពួកវៀតណាម ។

- នៅទីក្រុងប៉េកាំង រដ្ឋាភិបាលចម្រុះរបស់ចលនាតស៊ូប្រកាសពីសំណើសន្តិភាពថ្មីៗ ។
- នៅទីក្រុងភ្នំពេញ ការផ្លាស់ប្ដូរក្នុងផ្ទៃរដ្ឋាភិបាលដែលត្រូវចោទប្រកាន់ថា ពុករលួយ ។

១៩៨៧ ៈ ក្រុងមូស្គូ ស្វែងរកដំណោះស្រាយសន្តិភាពមួយសម្រាប់ប្រទេសកម្ពុជា ដោយរួមបញ្ចូលភាគីទាំងអស់នៅក្នុងការចរចា ។

- ជ័យជម្នះថ្មីៗរបស់ពួកខ្មែរក្រហម និងពួកសម្ដេច ព្រះនរោត្ដម សីហនុ និយមនៅប្រទេសកម្ពុជា ។
- នៅខែឧសភា សម្ដេច ព្រះនរោត្ដម សីហនុ បោះបង់មុខតំណែងជាផ្លូវការរបស់ព្រះអង្គ ។
- ប្រទេសថៃ បិទដំរំដេនគៀសខ្លួនចុងក្រោយ ក្រោមការឧបត្ថម្ភរបស់អង្គសហប្រជាជាតិ គឺ ខាវអ៊ីដាង ។
- ការជួបគ្នាជាឯកជននៅប្រទេសបារាំងរវាង សម្ដេច ព្រះនរោត្ដម សីហនុ និង ហ៊ុន សែន ដែលព្រមព្រៀងគ្នាស្ដីពីគោលដៅ ដែលត្រូវឈានឲ្យដល់ ៈ ឯករាជ្យប្រទេសកម្ពុជា ដែលធានាដោយសន្និសីទអន្តរជាតិមួយ ។ តាម ហ៊ុន សែន ថា ពួកវៀតណាមនឹងចាកចេញពីប្រទេសនៅឆ្នាំ១៩៩០ ។

១៩៨៨ ៈ ការជួបសន្ទនាលើកទីពីរ រវាង សម្ដេច ព្រះនរោត្ដម សីហនុ និង ហ៊ុន សែន នៅតំបន់ជាយក្រុងប៉ារីស ។ ការបង្កើតរដ្ឋាភិបាលរួបរួមជាតិមួយត្រូវបានគ្រោងគិត ។

- ការវាយប្រយុទ្ធបានថយចុះនៅប្រទេសកម្ពុជា ដែលភាគីទាំងអស់រង់ចាំការរីកចម្រើននៃការចរចាជាថ្មី ។
- សម្ដេច ព្រះនរោត្ដម សីហនុ បានស្នើឲ្យមានការជួបប្រជុំដើម្បីចរចាដោយផ្ទាល់ជាមួយពួកវៀតណាមស្ដីពីការដកទ័ព ថយចេញពីកម្ពុជា ។

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំសូមសំដែងនូវការដឹងគុណរបស់ខ្ញុំចំពោះអ្នកទាំងឡាយណា ដែលបានជួយជ្រោមជ្រែងខ្ញុំឲ្យធ្វើការស្រាវជ្រាវ និងនិពន្ធសៀវភៅនេះឡើងតាមមធ្យោបាយផ្សេងៗ ៖ អ្នកបោះពុម្ពផ្សាយសៀវភៅរបស់ខ្ញុំ *Alice Mayhew* ដែលមានសទ្ធាចំពោះសៀវភៅនេះ និងទទួលស្គាល់ភាពបត់បែនទាំងអស់តាមផ្លូវដែលគាត់ត្រូវតែដើរតាម ។ ចំពោះ ម៉ី កុម្ភួត និង ឆាំង សុង ដែលធ្វើឲ្យខ្ញុំស្គាល់ប្រទេសរបស់គេក្នុងរយៈពេលនៃសង្គ្រាម និងជួយខ្ញុំឲ្យយល់ច្បាស់ពីសោកនាដកម្មរបស់ខ្លួននៅពេលនោះ និងក្រោយមកទៀត ។ ចំពោះអ្នកឯកទេសនយោបាយ *Stephen R. Heder* ដែលបានបកប្រែឯកសារជាច្រើន និងឆ្លើយតបដោយអត់ធ្មត់ចំពោះសំណួរផ្សេងៗរបស់ខ្ញុំ ស្តីពីនយោបាយខ្មែរក្រហម និងជួយអានសំណៅដើមរបស់ខ្ញុំ និងចំពោះអ្នកការទូត និងប្រវត្តវិទូ *Tim Carney* ដែលជួយខ្ញុំដោយចិត្តសប្បុរសក្នុងការស្វែងរកឯកសារផ្សេងៗរបស់ខ្ញុំ និងជាអ្នកអានសំណៅព្រាងរបស់ខ្ញុំមួយផ្នែកដែរ ។ ចំពោះគ្រួសារម៉ៃ និង រាម -ស៊ីសូផា, បុប្ផា, ថាញ់, យុន, ថាវី, សូម៉េត និង ឱភា- ចំពោះមិត្តភាព និងការស្គាល់រាប់អានរបស់គេ ព្រមទាំង *James Fenton* ដែលបានរៀបចំឲ្យយើងបានជួបគ្នាផង ។ ចំពោះលោកសាស្ត្រាចារ្យ *Edward Friedman* សម្រាប់ការណែនាំទាំងឡាយរបស់គាត់ស្តីពីបណ្តាការបដិវត្តន៍នៅអាស៊ី ។ ចំពោះលោក *Peter Pringle Etel Adnan* ដែលជួយផ្តល់ឲ្យខ្ញុំនូវទម្រង់ផ្តើមនៃសៀវភៅនេះ ។ ចំពោះលោក *Ben Kiernan* ដែលបានបញ្ជូននិក្ខេបបទថ្នាក់បណ្ឌិតរបស់គាត់មកឲ្យខ្ញុំ ។ ចំពោះកាសែតវ៉ាស៊ីនតោនប៉ុស្តិ៍ ដែលខ្ញុំធ្លាប់ធ្វើការជាមួយសម្រាប់មួយផ្នែកធំនៃការស្រាវជ្រាវរបស់ខ្ញុំ ហើយជាពិសេស ចំពោះបណ្តាអតីតសហការីរបស់ខ្ញុំ *H.D.S. Greenway* និង *Laurence Stern* សម្រាប់ការលើកទឹកចិត្តរបស់គេនៅគ្រាដំបូង, ចំពោះ *Lynn Darling* និង *John Burgess* ។ ចំពោះសហការីទាំងអស់របស់កាសែត និងបណ្តាសមាជិកនៃអង្គទូត ដែលបានជួប និងលើកកម្លាំងចិត្តខ្ញុំ ដោយគ្មានសំចៃ ជាពិសេសលោក *Sathiah, Kishore Mahbubani, Alexandro Casella, Betsy Kenedy, Neil Davis, Dominique Gerard, Desaix Anderson, David Hawk, Christopher Hitchens* និង *Nayan Chanda* ។ *William Goodfellow* និងមជ្ឈមណ្ឌលនយោបាយអន្តរជាតិ ដែលបានយល់ព្រមផ្តល់អាហារូបករណ៍មួយឲ្យខ្ញុំសម្រាប់រយៈពេលមួយឆ្នាំ ។ *Bob Borosage* និងវិទ្យាស្ថានស្រាវជ្រាវនយោបាយ ដែលបានផ្តល់ការិយាល័យធ្វើការមួយឲ្យខ្ញុំ ។ *Carol* និង *Ping Ferry* ដែលបានផ្តល់អាហារូបករណ៍មួយសម្រាប់ការធ្វើដំណើររបស់ខ្ញុំ ។ *J.R. Reeder* ដែលបានសរសេរសំណើសុំឲ្យពិនិត្យឯកសារផ្សេងៗទៅតាម ច្បាប់ស្តីពីសេរីភាពក្នុងការផ្តល់ព័ត៌មាន ។ ចំពោះបណ្ឌិត *Marianne Faure* និង *Wendy Law-Yone* សម្រាប់ការស្រឡាញ់យកចិត្តទុកដាក់របស់គាត់ ។ ចំពោះលោក *Steve Mendelson* សម្រាប់គំនូររបស់គាត់ ។ នៅទីបញ្ចប់ ខ្ញុំសូមបញ្ជូននូវការថ្លែងអំណរគុណដ៏កក់ក្តៅចំពោះប្រជាជនកម្ពុជាជាច្រើន ដែលខ្ញុំបានធ្វើសម្ភាសន៍នៅក្នុងប្រទេសរបស់គេ ឬនៅបរទេស ហើយដែលបានរៀបរាប់ប្រាប់ខ្ញុំដោយក្លាហាននូវរឿងរ៉ាវរបស់គាត់ ដែលជាញឹកញយស្ថិតក្នុងកាលៈទេសៈមិនគួរឲ្យជឿទៅទៀត ។ ទីបំផុត គឺអ្នកទាំងនេះហើយដែលផ្តល់ជាមធ្យោបាយឲ្យខ្ញុំសរសេរសៀវភៅនេះឡើង ៕

# អំពីអ្នកនិពន្ធ

*អេលីហ្សាបែត បេ៊កខ័រ គឺជាអ្នកឆ្លើយឆ្លងសារព័ត៌មានរបស់សារព័ត៌មាន វ៉ាស៊ីនតោនប៉ុស្តិ៍ដែលក្រោយមក បានទទួលតំណែងជានិពន្ធនាយកបរទេសជាន់ខ្ពស់របស់វិទ្យុជាតិ ហើយថ្មីៗនេះ ជាជំនួយការនិពន្ធនាយករបស់ សារព័ត៌មានញ៉ូវយ៉កថៃមស៍ ទទួលបន្ទុកសារព័ត៌មានបរទេស និងសារព័ត៌មានហិរញ្ញវត្ថុ ។ គាត់បានរាយការណ៍ និងសរសេរព័ត៌មានពីប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ១៩៧៣ ឲ្យទៅញ៉ូវយ៉កថៃមស៍,* The London Review of Books, *ទស្សនាវដ្តីសេដកិច្ចចុងបូព៌ា និង* Die Tageszeitung *។ សៀវភៅ នៅពេលដែលសង្គ្រាមរលត់ទៅទទួលបានរង្វាន់សៀវភៅរបស់* Robert F. Kennedy *និងត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការថតខ្សែភាពយន្តឯកសាររបស់ រិទ្ធី ប៉ាន់ ដែលមានចំណងជើងថា បុប្ផាណា ។ គាត់ក៏ជាអ្នកនិពន្ធសៀវភៅប្រវត្តិសាស្ត្រ សង្គ្រាមវៀតណាមរបស់សហរដ្ឋអាមេរិក ។ គាត់ទទួលបានសញ្ញាប័ត្រផ្នែក ការសិក្សាពីអាស៊ីខាងត្បូង ពីសាកលវិទ្យាល័យ ទីក្រុងវ៉ាស៊ីនតោន ហើយសព្វថ្ងៃ កំពុងរស់នៅជាមួយកូនពីរនាក់របស់គាត់នៅទីក្រុងវ៉ាស៊ីនតោនឌីស៊ី ។*